# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Oct-2020, 10:50
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន (សំណុំរឿង ០០២/០២)

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Dounia HATTABI

កញ្ញា Marine BOUDJEMAA

កញ្ញា អ៊ុច ស្រីផាត់

លោក តាន់ ឆាយរ័ត្ន

ចៅក្រម Florence Ndepele Mwachande MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Mareen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# សារាងមាតិកា

សេចក្ដីផ្ដើម ....................................................................................................................28

ជាលក្ខណៈចម្បង ..............................................................................................................37

១. អសុពលភាពនៃសាលក្រមដែលបានប្រកាសដោយខុសច្បាប់ទាំងស្រុង...............................................37

១.១. នៅ អ.វ.ត.ក សាលក្រមត្រូវតែមានសំអាងហេតុ និងត្រូវចេញជាលាយលក្ខណ៍អក្សរ នៅថ្ងៃប្រកាសសាលក្រមតែម្ដង ..................................................................................................................38

១.២. នៅ អ.វ.ត.ក ក៏ដូចនៅកន្លែងផ្សេងទៀតដែរ ចៅក្រមត្រូវគោរព និងអនុវត្តច្បាប់.............................41

១.៣. ការផ្ដន្ទាទោសខុសច្បាប់ និងតាមទំនើងចិត្ត លើរូប ខៀវ សំផន ................................................46

២. វិការៈមិនអាចលុបលាងបានដោយការចេញសំអាងហេតុនៅពេលក្រោយ ..........................................47

២.១. សំអាងហេតុចេញនៅពេលក្រោយ មិនអាចធ្វើឱ្យសាលក្រមដែលប្រកាសបែបប្រតិសកម្មមានសុពលភាពឡើយ ...........................................................................................................................47

២.២. សំអាងហេតុចេញនៅពេលក្រោយ គ្មានសុពលភាពទាល់តែសោះ.................................................51

២.៣. ភាពមន្ទិលសង្ស័យចំពោះសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ...............................54

ជាលក្ខណៈបន្ទាប់បន្សំ.........................................................................................................57

សេចក្ដីផ្ដើម ....................................................................................................................57

ភាគទី ១. កំហុសប្រព្រឹត្តដោយរំលោភបំពានលើវិធានមូលដ្ឋានអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌..........60

មាតិកាទី ១. ច្បាប់ជាធរមាន...........................................................................................64

មាតិកាទី ២. វិធីសាស្ត្រលម្អៀងនៃគោលការណ៍នាំមុខក្នុងការជំនុំជម្រះក្ដីព្រហ្មទណ្ឌ..................................64

ជំពូកទី ១. ទស្សនាទានខុសឆ្គង និងរើសអើងអំពីនីតិព្រហ្មទណ្ឌ ..................................................64

ជំពូកទី ២. ទស្សនាទានមិនត្រឹមត្រូវ និងរើសអើងអំពីនីតិវិធីព្រហ្មទណ្ឌ ...........................................66

ផ្នែកទី ១. ការជំនុំជម្រះដ៏វែងអន្លាយក្នុងព្រំដែនដែលអាចរំកិលបាន............................................66

ផ្នែកទី ២. ការជំនុំជម្រះសម្រាប់ប្រវត្តិសាស្ត្រ.........................................................................71

១. អង្គហេតុ“ក្រៅបរិបទ” តែ “ពាក់ព័ន្ធ” ..........................................................................71

២. សេចក្ដីសង្កេតដោយចៃដន្យ និងបន្ទាប់បន្សំ *(Obiter Dicta)*................................................73

ជំពូកទី ៣. វិធីសាស្ត្រមិនត្រឹមត្រូវ និងរើសអើង ក្នុងសំណុំរឿង ០០២/០២ ក្រោយការជំនុំជម្រះលើសំណុំរឿង

០០២/០១......74

ផ្នែកទី ១. ចៅក្រមជិតដាមដោយភាពលម្អៀង......74

ផ្នែកទី ២. ចៅក្រមដែលមានទស្សនាទានឯកតោភាគីអំពីការជំនុំជម្រះ......77

១. ការលាតត្រដាងតាមទស្សនះច្បាប់......77

១.១. ការជំនុំជម្រះពីរដងចំពោះអង្គហេតុដដែល (Bis in idem)......77

១.២. ការកំណត់បទចោទសាជាថ្មីដោយខុសច្បាប់......78

២. ការលាតត្រដាងដោយផ្អែកលើភស្តុតាង......86

មាតិកាទី ៣. វិធីសាស្ត្រលម្អៀងក្នុងការគ្រប់គ្រងភស្តុតាង......94

ជំពូកទី ១. កំហុសក្នុងការគ្រប់គ្រងភស្តុតាងក្នុងអំឡុងពេលសវនាការ......94

ផ្នែកទី ១. សេចក្តីសម្រេចលើការកោះហៅឱ្យចូលមកបង្ហាញខ្លួនបណ្តើរៗ......94

ផ្នែកទី ២. ភាពធ្វេសប្រហែសចំពោះលក្ខណៈពិសេសនៃវិធាន ៨៧(៤)......98

ផ្នែកទី ៣. ធាតុផ្សំនៃភស្តុតាងមកពីសំណុំរឿង ០០៣ និង ០០៤......107

ផ្នែកទី ៤. ធាតុផ្សំភស្តុតាងចេញមកពីប្រវត្តិវិទូដែលមិនបានចូលមកបង្ហាញខ្លួន......118

១. ការទទួលយកឯកសាររបស់លោកសាស្ត្រាចារ្យ GOSCHA......119

១.១. កង្វះសំអាងហេតុ និងកង្វះតម្លាភាពក្នុងការទទួលបានឯកសារទាំងនេះ......119

១.២. កំហុសពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារទាំងនេះ......120

១.៣. កំហុសលើការប្រើប្រាស់ឯកសារទាំងនេះសម្រាប់គាំទ្រដល់ភស្តុតាងដទៃទៀត......123

២. ការទទួលយកបញ្ជីពណ៌ទឹកក្រូចនៃមន្ទីរ ស-២១......124

ជំពូកទី ២. កំហុសលើការសិក្សាអំពីភស្តុតាងទូទៅ......125

ផ្នែកទី ១. ជំនឿឥស្សរចិត្ត និងជំនឿហួសពីវិមតិសង្ស័យ......125

ផ្នែកទី ២. ការបំភ្លៃ ឬការបំប្លែងភស្តុតាង......127

ផ្នែកទី ៣. ស្តង់ដាពីរ រវាងការដាក់បន្ទុក និងការដោះបន្ទុក......129

ផ្នែកទី ៤. ការបំភ្លេចចោលនូវភស្តុតាងដោះបន្ទុក......129

ផ្នែកទី ៥. បន្ទុកភស្តុតាង......130

ផ្នែកទី ៦. អនុមានវិធី/ភស្តុតាងទេសកាល......131

ផ្នែកទី ៧. ការសន្និដ្ឋានពង្រីក/ការសន្និដ្ឋានទូទៅ......132

ផ្នែកទី ៨. ចំនួនភស្តុតាង និងតម្លៃជាភស្តុតាង......133

ផ្នែកទី ៩. ភាពស៊ីចង្វាក់គ្នា......134

ផ្នែកទី ១០. ភាពផ្ទុយគ្នា......135
ផ្នែកទី ១១. ចម្លើយពីមុនៗ/ចម្លើយពេលក្រោយៗមកទៀត......136
១. ការទទួលយកជាភស្តុតាង......136
២. ការអានឡើងវិញមុនពេលចូលបង្ហាញខ្លួន......138
ផ្នែកទី ១២. សំអាងហេតុនៃការនិយាយកុហក......143
ផ្នែកទី ១៣. បុរេវិនិច្ឆ័យវប្បធម៌......144
ជំពូកទី ៣. កំហុសលើប្រភេទភស្តុតាងមួយចំនួនជាពិសេស......146
ផ្នែកទី ១. ចម្លើយ/សៀវភៅរបស់ ខៀវ សំផន......146
ផ្នែកទី ២. ធាតុផ្សំភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម......147
១. ភស្តុតាងបានមកដោយខុសច្បាប់......148
២. អញ្ញត្រកម្មនៃវិធានបដិសេធភស្តុតាង......155
២.១. សារបាននៃអនុសញ្ញា......158
២.២. គោលបំណង និងកម្មវត្ថុនៃអនុសញ្ញា......160
២.២. គោលបំណង និងកម្មវត្ថុនៃអនុសញ្ញា......164
ផ្នែកទី ៣. ឃោសនាការ......165
ផ្នែកទី ៤. សក្ខីកម្មជាលាយលក្ខណ៍អក្សរ......167
១. តម្លៃជាភស្តុតាង......167
២. អំពើ និងការប្រព្រឹត្តិ......168
២.១. ការបង្ហាញអំពីក្របខ័ណ្ឌច្បាប់មិនត្រឹមត្រូវដែលដាក់ចេញដោយអង្គជំនុំជម្រះ......168
២.២. ការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់......172
២.៣. កំហុសច្រំដែលរបស់អង្គជំនុំជម្រះ នៅក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ និង ០០២/០២..173
ផ្នែកទី ៥. ចម្លើយក្រៅប្រព័ន្ធតុលាការ......175
ផ្នែកទី ៦. ពាក្យចចាមអារ៉ាម......179
ផ្នែកទី ៧. ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី......180
១. ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី......180
២. ការវាយតម្លៃលើចម្លើយ......182
ផ្នែកទី ៨. ឯកសារដែលទទួលបានសច្ចធារណ៍ថាអាចទទួលយកបាន......183
ផ្នែកទី ៩. ភស្តុតាងជាឯកសារ និងយថាភាព......185

១. ក្របខ័ណ្ឌវាយតម្លៃភ័ស្តុតាងជាឯកសារ និងឯកសារនៅសម័យអង្គហេតុ ....185
១.១. . ភាពអាចចូលពិគ្រោះបាននៃឯកសារសម័យអង្គហេតុ ....185
១.២. ការវាយតម្លៃលើតម្លៃជាភ័ស្តុតាង ....186
២. ឧទាហរណ៍បញ្ជាក់ពីកំហុសនៃការវាយតម្លៃលើភ័ស្តុតាងជាឯកសារ ....186
២.១. លក្ខន្តិកៈរបស់ ប.ក.ក ....186
២.២. កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ....188
ផ្នែកទី ១០. អ្នកជំនាញ ....191
មាតិកាទី ៤. សេចក្តីសន្និដ្ឋាន - ឥទ្ធិពលត្រួតគ្នានៃការរំលោភបំពាន ....192
ភាគទី ២. កំហុសពាក់ព័ន្ធនឹងវិសាលភាពនៃបណ្តឹង ....193
មាតិកាទី ១. ការអនុវត្តហួសពីវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យជំនុំជម្រះ ....193
ជំពូកទី ១. អង្គច្បាប់ ....193
ផ្នែកទី ១. ភាពអាចទទួលយកបាន ....194
១. ការភាន់ច្រឡំនៃការកំណត់ថាជាអញ្ញត្រកម្ម ....194
២. ឱកាសនិយមនៃការកំណត់ថាជាអញ្ញត្រកម្ម ....198
៣. យុត្តិនិសេធ ....200
ផ្នែកទី ២. ច្បាប់ជាធរមានសម្រាប់ការពិនិត្យពិចារណាលើអង្គសេចក្តី ....201
ជំពូកទី ២. កំហុស និងផលប៉ះពាល់ដោយសារទីតាំងឧក្រិដ្ឋកម្ម ....208
ផ្នែកទី ១. ត្រាំកក់ ....208
១. គ្មានបណ្តឹងពីទីតាំងភូមិសាស្ត្រលើសពីប្រាំបីឃុំនៃស្រុកត្រាំកក់ ....208
១.១. ការរំលោភបំពានលើបណ្តឹងជាក់ស្តែងអំពីសំណាក់សហថៅក្រមស៊ើបអង្កេត ....209
១.២. ការផ្តន្ទាទោសចំពោះអង្គហេតុដែលបានកើតឡើងនៅក្នុងឃុំក្រៅវិសាលភាពភូមិសាស្ត្រ ....209
២. គ្មានបណ្តឹងអំពីការស្លាប់ដោយមូលហេតុផ្សេងក្រៅពីការអត់ឃ្លាន ....217
៣. ការនិរទេស ....219
ផ្នែកទី ២. ទំនប់ត្រពាំងថ្ម ....223
ផ្នែកទី ៣. ទំនប់១មករា ....224
១. គ្មានបណ្តឹងអំពីការសម្លាប់មនុស្សនៅវត្តបារាយណ៍ជាន់ដែក ....224
២. គ្មានបណ្តឹងអំពីការស្លាប់ដោយគ្រោះថ្នាក់ ....227
៣. គ្មានបណ្តឹងអំពីអង្គហេតុនៃ “ការរើសអើង” ដោយមូលហេតុនយោបាយចំពោះប្រជាជនថ្មី....228

៤. គ្មានបណ្តឹងអំពីអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុសាសនា ....229

៥. គ្មានអំបណ្តឹងពីអង្គហេតុនៃការបាត់ខ្លួន ....230

ផ្នែកទី ៤. ភ្នំក្រោល ....232

១. ការធ្វើឱ្យក្លាយជាទាសករ ....232

២. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្ស ....233

៣. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ....235

ផ្នែកទី ៥. ក្រាំងតាចាន់ ....236

១. គ្មានបណ្តឹងអំពីអង្គហេតុនៃការស្លាប់ដោយសារលក្ខខ័ណ្ឌឃុំឃាំង ....236

២. គ្មានបណ្តឹងអំពីអង្គហេតុនៃការធ្វើឱ្យក្លាយជាទាសករ ....239

៣. គ្មានបណ្តឹងអំពីអង្គហេតុនៃអំពើទារុណកម្ម ....240

៤. គ្មានបណ្តឹងអំពីអង្គហេតុនៃការធ្វើបាប ....242

៥. គ្មានបណ្តឹងអំពីអង្គហេតុនៃការបាត់ខ្លួន ....243

ផ្នែកទី ៦. អូរកន្សែង ....245

១. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ ....245

២. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ....246

ផ្នែកទី ៧. ការបោសសម្អាត ....247

១. ការរំលោភបំពានលើបណ្តឹងជាក់ស្តែងពីសំណាក់សហចៅក្រមស៊ើបអង្កេត ....247

២. ការផ្តន្ទាទោសដែលផ្អែកទាំងស្រុងលើអង្គហេតុ "បោសសម្អាត" ក្រៅវិសាលភាព ....248

២.១. ការផ្តន្ទាទោសដែលផ្អែកទាំងស្រុងលើការដឹងឮអំពីអង្គហេតុ "បោសសម្អាត"ក្រៅវិសាលភាព. 248

២.២. ការផ្តន្ទាទោសដែលផ្អែកទាំងស្រុងលើអង្គហេតុ "បោសសម្អាត" ក្រៅវិសាលភាព ....249

ជំពូកទី ៣. កំហុស និងផលប៉ះពាល់លើក្រុមជាក់លាក់ ....249

ផ្នែកទី ១. ពុទ្ធសាសនិក ....249

១. គ្មានបណ្តឹងអំពីអង្គហេតុប្រឆាំងនឹងពុទ្ធសាសនិក នៅត្រាំកក់ ....249

២. ការផ្តន្ទាទោសចំពោះអង្គហេតុនៃ "ការរើសអើង" ចំពោះពុទ្ធសាសនិក ....254

ផ្នែកទី ២. ជនជាតិវៀតណាម ....255

មាតិកាទី ២. បទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ ....259

ជំពូកទី ១. អង្គច្បាប់ ....259

ជំពូកទី ២. កំហុស និងផលប៉ះពាល់ នៅត្រាំកក់ ....261

១. ការចេញក្រៅវិសាលភាពនៃឧក្រិដ្ឋកម្ម ....................261
១.១. គ្មានបណ្តឹងអំពីការស្លាប់ដោយសារភាពអត់ឃ្លាន នៅក្នុងឃុំនៃស្រុកត្រាំកក់ ....................261
១.២. គ្មានបណ្តឹងអំពី "ការប្រព្រឹត្តិរើសអើង" លើប្រជាជនថ្មី ....................263
២. គ្មានបណ្តឹងអំពីអង្គហេតុនៃការឃ្លាំមើល និងការបាត់ខ្លួនអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ....................266
២.១. គ្មានភ័ស្តុតាងគាំទ្រការចោទប្រកាន់ពីការឃ្លាំមើលអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងកថាខណ្ឌ ៣១៩ ....................267
២.២. គ្មានភ័ស្តុតាងគាំទ្រអង្គហេតុនៃការបាត់ខ្លួនរបស់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ក្នុងកថាខណ្ឌ ៤៩៨ ....................268
២.៣. ការផ្តន្ទាទោសចំពោះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្រៅបណ្តឹង ....................270
មាតិកាទី ៣. កំហុសអង្គហេតុសំខាន់ៗមួយចំនួនដែលត្រូវបានកំណត់ជាបទចោទ ....................271
ជំពូកទី ១. អង្គច្បាប់ ....................271
ជំពូកទី ២. កំហុស និងផលវិបាកសម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗ ....................274
ផ្នែកទី ១. ត្រាំកក់ ....................274
១. គ្មានបណ្តឹងពីការស្លាប់បណ្តាលមកពីបញ្ហាសុខភាព និងល័ក្ខខ័ណ្ឌរស់នៅ ....................274
១.១. គ្មានការស្លាប់ណាមួយបណ្តាលមកពីល័ក្ខខ័ណ្ឌរស់នៅជាទូទៅ ក្រៅពីការស្លាប់បណ្តាលមកពីការអត់អាហារ នៅត្រាំកក់ ....................274
១.២. ការផ្តន្ទាទោសចំពោះការស្លាប់បណ្តាលមកពីល័ក្ខខ័ណ្ឌរស់នៅ ដោយរំលោភលើបណ្តឹងជាក់ស្តែង ....................277
២. គ្មានបណ្តឹងពីការស្លាប់បណ្តាលមកពីការអត់ឃ្លាន នៅក្រៅឃុំសំរោង និងឃុំតាភេម ....................278
២.១. ការបង្ហាញតែមួយគត់អំពីការស្លាប់បណ្តាលមកពីការអត់អាហារ ដែលបានកើតឡើងក្នុងឃុំសំរោង និងឃុំតាភេម ត្រង់កថាខណ្ឌ ៣១២ នៃដីកាដំណោះស្រាយ ....................278
២.២. ការផ្តន្ទាទោសចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ នៅកន្លែងផ្សេង ដោយរំលោភលើបណ្តឹងជាក់ស្តែង ....................279
៣. គ្មានបណ្តឹងពីអង្គហេតុ "ការរើសអើង" ចំពោះប្រជាជនថ្មី ក្រៅពីការកម្រិតនូវការអនុវត្ត "សិទ្ធិនយោបាយ" មួយចំនួន ....................280

៣.១. កាលុបបំបាត់ "សិទ្ធិ" នយោបាយ គឺជាអំពើរើសអើងតែមួយគត់ចំពោះប្រជាជនថ្មី នៅក្នុងដីកាដំណោះស្រាយ ..... 281

៣.២. ការផ្ដន្ទាទោសចំពោះអង្គហេតុ "ការរើសអើង" លើប្រជាជនថ្មី នៅក្រៅបណ្ដឹង ..... 282

ផ្នែកទី២. ទំនប់ត្រពាំងថ្ម ..... 283

ផ្នែកទី ៣. ទំនប់១មករា ..... 285

១. គ្មានបណ្ដឹងពីការស្លាប់នៅក្រៅទំនប់១មករា ..... 285

២. គ្មានបណ្ដឹងពីការស្លាប់បណ្ដាលមកពីគ្រោះថ្នាក់ផ្សេងៗ ..... 286

៣. គ្មានបណ្ដឹងពីអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ..... 287

ផ្នែកទី ៤. ព្រលានយន្តហោះកំពង់ឆ្នាំង ..... 289

ផ្នែកទី ៥. ក្រាំងតាចាន់ ..... 290

១. គ្មានបណ្ដឹងពីអង្គហេតុនៃ "ការរើសអើង" ចំពោះប្រជាជនថ្មី ..... 290

១. គ្មានបណ្ដឹងពីអង្គហេតុនៃ "ការរើសអើង" ចំពោះប្រជាជនថ្មី ..... 291

១.២. ការផ្ដន្ទាទោសចំពោះអង្គហេតុ "ការរើសអើង" លើប្រជាជនថ្មី នៅក្រៅបណ្ដឹង ..... 292

២. គ្មានបណ្ដឹងពីអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ..... 293

២.១. គ្មានអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងចំណោមអង្គហេតុទាំងឡាយ ក្នុងកថាខណ្ឌ ៤៨៩-៥១៤ នៃដីកាដំណោះស្រាយ ..... 293

២.២. ការផ្ដន្ទាទោសចំពោះអង្គហេតុ "ការរើសអើង" លើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រៅវិសាលភាពនៃការជំនុំជម្រះ ..... 295

៣. បណ្ដឹងកម្រិតត្រឹមក្រុមចំនួនបី នៅក្នុងផ្នែកកំណត់ប្រភេទបទល្មើសនៃដីកាដំណោះស្រាយ ..... 296

៣.១. ក្រុមចំនួនបីគត់ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងដីកាដំណោះស្រាយ ..... 296

៣.២. ការផ្ដន្ទាទោសចំពោះ "ការរើសអើង" ចំពោះ "ក្រុម" ខ្នាំងពិតប្រាកដ ឬសន្មត នៅក្រៅបណ្ដឹង..... 298

ផ្នែកទី ៦. អូរកន្សែង ..... 298

ផ្នែកទី ៧. ភ្នំក្រោល ..... 300

ជំពូកទី ៣. កំហុស និងផលវិបាក ពាក់ព័ន្ធនឹងក្រុមជាក់លាក់ ..... 302

ផ្នែកទី ១. ជនជាតិចាម ..... 302

១. គ្មានបណ្ដឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ នៅភូមិទ្រា ..... 302

២. គ្មានបណ្តឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្រោមបទសហក្រិដ្ឋកម្មរួម303

ផ្នែកទី ២. ជនជាតិវៀតណាម ......303

ផ្នែកទី ៣. អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ......305

១. ការរំលោភលើបណ្តឹងជាក់ស្តែងដោយអង្គជំនុំជម្រះ ......305

១.១. គ្មានការបង្ហាញពីអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងចំណោមក្រុមជាក់លាក់ នៅក្នុងដីកាដំណោះស្រាយ ......306

១.២. ការពង្រីកវិសាលភាពនៃបណ្តឹងជាក់ស្តែង នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី......306

១.៣. កំហុសជាក់ស្តែងក្នុងការវិនិច្ឆ័យលើវិសាលភាពនៃការជំនុំជម្រះ......308

២. ការផ្តន្ទាទោសក្រោមបទសហឧក្រិដ្ឋកម្មរួមចំពោះឧក្រិដ្ឋកម្មនៅក្រៅបណ្តឹង......309

មាតិកាទី ៤. ការដកអង្គហេតុចេញ តាមរយៈការបំបែកកិច្ចដំណើរការនីតិវិធី......310

ជំពូកទី ១. អង្គច្បាប់......310

ជំពូកទី ២. កំហុស និងផលវិបាកពាក់ព័ន្ធនឹងក្រុមជាក់លាក់ ......312

ផ្នែកទី ១. ជនជាតិចាម ......312

១. គ្មានបណ្តឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត/ការជម្លៀសដោយបង្ខំ......312

១.១. បណ្តឹងពីការជម្លៀសប្រជាជន ដំណាក់កាលទីពីរ តែនៅក្នុងក្របខ័ណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា......313

១.២. ការផ្តន្ទាទោសចំពោះអង្គហេតុនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ នៅក្រៅវិសាលភាពនៃបណ្តឹង......314

២. គ្មានបណ្តឹងពីអង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងៗទៀត/ការជម្លៀសដោយបង្ខំ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ ......316

២.១. គោលការណ៍អាជ្ញាអស់ជំនុំ ......316

២.២. ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ......318

ផ្នែកទី ២. ជនជាតិវៀតណាម ......319

ភាគទី ៣. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ......321

មាតិកាទី ១. ការមិនគោរពគោលការណ៍នីត្យានុកូលភាព......321

ជំពូកទី ១. កំហុសពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព......321

ផ្នែកទី ១. ការបំបែរកម្មវត្ថុនៃគោលការណ៍អាជ្ញាអស់ជំនុំ តាមបែបឱកាសនិយម......322

ផ្នែកទី ២. ការវិនិច្ឆ័យទៅតាមការប្រព្រឹត្តិរបស់ជនជាប់ចោទ .....327

ផ្នែកទី ៣. ការពិនិត្យច្បោលៗ មិនសមរម្យ លើល័ក្ខខ័ណ្ឌតម្រូវនៃគោលការណ៍ .....332

ជំពូកទី ២. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត .....337

ផ្នែកទី ១. អង្គច្បាប់៖ គ្មានការបញ្ចូលចេតនាប្រយោលទៅក្នុងធាតុផ្សំអត្តនោម័តិ .....337

១. គ្មានមូលដ្ឋានគតិយុត្តិដែលមានសុពលភាព .....337

១.១. ការយល់ច្រឡំ និងការច្របល់បញ្ចូលគ្នាពុំត្រឹមត្រូវ រវាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ .....338

១.២. អវត្តមាននៃចេតនាប្រយោលនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឆ្នាំ១៩៧៥ .....339

១.៣. ការយោងគ្មានសុពលភាពទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីបន្ទាបចេតនាដែលជា ល័ក្ខខ័ណ្ឌតម្រូវ .....348

១.៤. នត្ថិភាពនៃគោលការណ៍ទូទៅនៃច្បាប់ដែលបន្ទាបធាតុផ្សំអត្តនោម័តិមកត្រឹមចេតនាប្រយោល .361

២. ភាពមិនអាចដឹងបាន និងភាពមិនអាចគ្រោងទុកមុនបាន នាឆ្នាំ១៩៧៥ នូវកម្រិតនៃចេតនាដែលបានកំណត់ .....366

ផ្នែកទី ២. កំហុស និងផលវិបាកតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗ .....367

១. អំពីការដ្ឋានការងារត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង .....367

២. នៅក្នុងមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល .....368

ជំពូកទី ៣. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ .....369

ផ្នែកទី ១. អង្គច្បាប់ .....369

១. ការវិភាគសើៗពុំត្រឹមត្រូវលើសាលដីកាសំណុំរឿង ឌុច ដែលអង្គជំនុំជម្រះអនុវត្តតាម .....370

២. ល័ក្ខខ័ណ្ឌតម្រូវឱ្យបង្ហាញថាមានគោលបំណងដកចេញដោយសារ "ការរើសអើង" ជាក់ស្តែង .....371

២.១. ល័ក្ខខ័ណ្ឌមួយដែលមានការព្រមព្រៀងគ្នាពីដំបូង ត្រូវបំភ្លេចដោយអង្គជំនុំជម្រះ .....371

២.២. ការដកចេញ៖ ធាតុផ្សំសំខាន់នៃការធ្វើទុក្ខបុកម្នេញនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាម .....376

ផ្នែកទី ២. កំហុស និងផលវិបាកនៅតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗ .....380

១. គ្មានចេតនារើសអើងចំពោះពុទ្ធសាសនិក និងព្រះសង្ឃ .....380

២. គ្មានចេតនារើសអើងចំពោះជនជាតិចាម .....380

ជំពូកទី ៤. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមអំពើអមនុស្សធម៌ផ្សេងៗទៀត .....381

ផ្នែកទី ១. ការវាយតម្លៃពុំត្រឹមត្រូវលើនីត្យានុកូលភាពនៃឧក្រិដ្ឋកម្មដែលជាអំពើអមនុស្សធម៌ ផ្សេងៗទៀត .381

ផ្នែកទី ២. ការរំឭកបែបបំប្រួញនៃល័ក្ខខ័ណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការ ................................385
មាតិកាទី ៣. កំហុសពាក់ព័ន្ធនឹងការប្រមូលធាតុផ្សំ.....................................................................................388
ជំពូកទី ១. សហករណ៍ និងការដ្ឋានការងារ ........................................................................................388
ផ្នែកទី ១. ត្រាំកក់.....................................................................................................................388
១. គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល ...........................................................................388
១.១. កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអំពើអកម្ម “នាំឱ្យមានពិរុទ្ធ” ..............................................389
១.២. កំហុសអង្គច្បាប់ពាក់ព័ន្ធនឹង “ចេតនាប្រយោល” .................................................................391
១.៣. លក្ខណៈមិនសមហេតុផលនៃការកត់សម្គាល់ឃើញអំពីអង្គហេតុ ..........................................392
២. កំហុសដោយបានសន្និដ្ឋានថាមានការនិរទេសជនជាតិវៀតណាម ..........................................396
២.១. កំហុសដោយបានសន្និដ្ឋានថាជនរងគ្រោះពិតជាបានឆ្លងព្រំដែនប្រទេស.................................397
២.២. កំហុសពាក់ព័ន្ធនឹងចេតនាជម្លៀសជនរងគ្រោះដោយបង្ខំ ឱ្យទៅម្ខាងទៀតនៃព្រំដែនជាតិ.......411
៣. គ្មានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ...........................................................412
៣.១. គ្មានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ..............................................................................................................412
៣.២. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជនថ្មី.................................417
៤. អវត្តមាននៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា.......................................................427
៤.១. ការប្រព្រឹត្តិស្មើភាព មិនផ្សំបានជាការប្រព្រឹត្តិបែបរើសអើង.....................................................428
៤.២. គ្មានភ័ស្តុតាងអំពីផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តរបស់ពុទ្ធសាសនិក............................429
៥. កំហុសដោយបានសន្និដ្ឋានថាមានការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ចំពោះជនជាតិវៀតណាម......................................................................................................................................430
៥.១. កំហុសដោយបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីធាតុផ្សំសត្យានុម័តិ ......................430
៥.២. កំហុសដោយបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីធាតុផ្សំអត្តនោម័តិ ......................431
៦. កំហុសដោយបានសន្និដ្ឋានថាមានការបាត់ខ្លួនដោយបង្ខំចំពោះជនជាតិវៀតណាម ......................433
៧. កំហុសដោយបានសន្និដ្ឋានថាមានការបាត់ខ្លួនខ្មែរក្រោមដោយបង្ខំ..........................................434
ផ្នែកទី ២. ទំនប់ត្រពាំងថ្ម.....................................................................................................434
១. គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល ...........................................................................434
២. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ .........................................................................437
ផ្នែកទី ៣. ទំនប់១មករា..........................................................................................................439

១. គ្មានអំពើមនុស្សឃាត ដោយចេតនាប្រយោល ....................................439
១.១. កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអំពើអកម្ម "នាំឱ្យមានពិរុទ្ធ" ....................................440
១.២. ភាពមិនសមហេតុផលនៃការកត់សម្គាល់ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាត ដោយចេតនាប្រយោល....................................441
១.៣. គ្មានភស្តុតាងអំពីចេតនាប្រយោល ចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និង ល័ក្ខខ័ណ្ឌរស់នៅ....................................448
២. គ្មានការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ ....................................450
២.១. ការប្រព្រឹត្តិលើប្រជាជនថ្មី....................................450
២.២. ការប្រព្រឹត្តិចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ....................................456
៣. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ....................................460
៣.១. គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាម....................................460
៣.២. ការប្រព្រឹត្តិស្មើភាពគ្នា មិនមែនជាធាតុផ្សំនៃការប្រព្រឹត្តិរើសអើង ....................................464
ផ្នែកទី ៤. ព្រលានយន្តហោះកំពង់ឆ្នាំង....................................464
ជំពូកទី ២. មន្ទីរសន្តិសុខ ....................................468
ផ្នែកទី ១. មន្ទីរ ស-២១ ....................................468
១. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ....................................468
១.១. កំហុសពាក់ព័ន្ធនឹងក្រុម "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមសន្មត" ដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់....................................468
១.២. កំហុសពាក់ព័ន្ធនឹងការរើសអើងជាក់ស្តែង....................................469
២. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ....................................470
២.១. គ្មានការពិចារណាអំពីបញ្ហាពូជសាសន៍នៅមន្ទីរ ស-២១ ....................................471
២.២. គ្មានការឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តី ....................................473
ផ្នែកទី ២. ក្រាំងតាចាន់ ....................................475
ផ្នែកទី ៣. អូរកន្សែង....................................477
១. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាមប្រាំមួយនាក់....................................478
២. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....................................480
២.១. កំហុសពាក់ព័ន្ធនឹងក្រុម "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" ដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់....................................480

២.២. កំហុសពាក់ព័ន្ធនឹងការរើសអើងជាក់ស្តែង ....................482
៣. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ....................485
ផ្នែកទី ៤. មន្ទីរសន្តិសុខភ្នំក្រោល ....................487
១. ការធ្វើមនុស្សឃាត ....................487
១.១. កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាលើ ហ៊ើស ....................487
១.២. កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាប្រយោលលើ ទូច ....................491
១.៣. កំហុសទូទៅដោយមិនបានពិចារណាលើភ័ស្តុតាងដោះបន្ទុក ....................494
២. ការធ្វើឱ្យក្លាយជាទាសករ ....................496
២.១. បណ្តឹងខុសច្បាប់ពីអង្គហេតុរងការចោទប្រកាន់ ....................496
២.២. កង្វះភ័ស្តុតាងសម្រាប់សន្និដ្ឋានថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ....................497
៣. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....................498
៤. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ....................499
ជំពូកទី ៣. ក្រុមជាក់លាក់នានា ....................502
ផ្នែកទី ១. ជនជាតិចាម ....................502
១. កង្វះភ័ស្តុតាងអំពីបទមនុស្សឃាតនៅភូមិទ្រា និងវត្តអូរត្រកួន ....................503
១.១. ភាពមិនច្បាស់លាស់ និងភាពជាទូទៅ ទាក់ទងនឹងការសម្លាប់នៅមន្ទីរសន្តិសុខភូមិទ្រា ....................503
១.២. កង្វះភ័ស្តុតាងចំពោះការចោទប្រកាន់ពីបទមនុស្សឃាត នៅវត្តអូរត្រកួន ....................506
២. ការសម្លាប់រង្គាល ....................512
២.១. សេចក្តីសន្និដ្ឋានមិនសមហេតុផលអំពីតួលេខនៃការសម្លាប់ដែលបានបង្ហាញ ....................512
២.២. សេចក្តីសន្និដ្ឋានមិនសមហេតុផលអំពីចេតនាសម្លាប់ជនជាតិចាមក្នុងទ្រង់ទ្រាយធំ ....................513
៣. ការធ្វើទារុណកម្ម ....................518
៤. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ....................519
៤.១. គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាម ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ ....................519
៤.២. កំហុសពាក់ព័ន្ធនឹងគោលបំណងចម្បងនៃការជម្លៀសប្រជាជន ....................520
៤.៣. ការបង្ហាញដោយខុសច្បាប់ពីការចាប់ខ្លួនក្រៅវិសាលភាពនៃការជំនុំជម្រះ ដើម្បីប៉ុនប៉ងបង្ហាញឱ្យឃើញពីកម្រិតនៃភាពធ្ងន់ធ្ងរដែលជាល័ក្ខខ័ណ្ឌតម្រូវ ....................522
៥. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ....................523

៥.១. គ្មានភស្តុតាងអំពីការរើសអើងជាក់ស្តែងចំពោះជនជាតិចាម.......................................523

៥.២. គ្មានចេតនារើសអើង ចំពោះការប្រតិបត្តិសាសនា/វប្បធម៌........................................539

៥.៣. ការរំលោភលើសិទ្ធិជាមូលដ្ឋាន .................................................................................541

៥.៤. កម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើដែលកំណត់ការរើសអើងជាក់ស្តែង..................................542

៦. ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ ..........................................................................543

៦.១. ការរំឮកពីការគ្មានការចរិតរើសអើងនៃការជម្លៀសដោយបង្ខំ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ..........................................................................................543

៦.២. ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ ....................................................................544

ផ្នែកទី ២. ជនជាតិវៀតណាម .........................................................................................545

១. ការនិរទេស .................................................................................................................545

១.១. ការសន្និដ្ឋានពង្រីកមិនសមហេតុផលរបស់អង្គជំនុំជម្រះ ...........................................545

១.២. អលទ្ធភាពក្នុងការបង្ហាញករណីប្រមូល និងបណ្តេញជនជាតិវៀតណាម.........................546

១.៣. កំហុសក្នុងការពិចារណាលើលក្ខណៈបង្ខំនៃការបណ្តេញចេញ.....................................551

១.៤. កំហុសក្នុងការមិនបានបង្ហាញពីចេតនានៃការនិរទេសជនជាតិវៀតណាមក្នុងខេត្តព្រៃវែង.......553

២. ការសម្លាប់ជនជាតិវៀតណាម .......................................................................................554

២.១. កំហុសក្នុងការសន្និដ្ឋានលើការសម្លាប់ជនជាតិវៀតណាមបួនគ្រួសារនៅខេត្តស្វាយរៀង........554

២.២. កំហុសក្នុងការសន្និដ្ឋានលើការសម្លាប់ជនជាតិវៀតណាមនៅតាមសមុទ្រ.......................557

២.៣. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅក្នុងភូមិភាគបស្ចិម...561

២.៤. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅវត្តខ្សាច់...............563

២.៥. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅក្នុងតំបន់ ៥០៥ (ក្រចេះ) ...............................................................................................................................567

៣. ការសម្លាប់រង្គាលជនជាតិវៀតណាម ...............................................................................569

៣.១. ការសន្និដ្ឋានរួមខុសទៅលើហេតុការណ៍ផ្សេងៗគ្នា ....................................................569

៣.២. ការសន្និដ្ឋានពង្រីកអំពីចំនួនជនរងគ្រោះ..................................................................572

៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ...............................................................573

៤.១. កំហុសអំពីប្រជាជនវៀតណាមក្នុងឋានៈជាក្រុមពូជសាសន៍មួយដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់..........................................................................................................573

៤.២. កំហុសក្នុងការពិចារណាពីការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម ដោយការនិរទេស ការចាប់ខ្លួន និងមនុស្សឃាត ....................575

៤.៣. កំហុសក្នុងការពិចារណាថាអំពើដែលបានរៀបរាប់ ជាការរើសអើងជាក់ស្តែង ....................576

៤.៤. កំហុសក្នុងការសន្និដ្ឋានពីការកំណត់គោលដៅដោយចេតនាលើប្រជាជនវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង....................578

៥. អំពើប្រល័យពូជសាសន៍....................582

៥.១. កំហុសអំពីធាតុផ្សំសត្យានុម័តិ....................583

៥.២. កំហុសអំពីធាតុផ្សំអត្តនោម័តិ....................586

ជំពូកទី ៤. ការរៀបអាពាហ៍ពិពាហ៍ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍....................609

ផ្នែកទី ១. ការរៀបអាពាហ៍ពិពាហ៍ ....................609

១. កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ....................609

១.១. ការវិភាគខុសលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពផ្លូវការ ....................609

១.២. គ្មានតំណភ្ជាប់រវាងសិទ្ធិ និងបម្រាម នៅសម័យនោះ ....................613

១.៣. ភាពមិនអាចផ្តន្ទាទោស ខៀវ សំផន បាន ....................617

២. កំហុសក្នុងការពិនិត្យលើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ....................618

២.១. កំហុសក្នុងការពិនិត្យលក្ខណៈវិនិច្ឆ័យនៃប្រភេទ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សធម៌ផ្សេងទៀតដូចបានរៀបរាប់ ....................619

២.២. កំហុសក្នុងការពិនិត្យលើការឈឺចាប់ដែលទទួលរង ក្នុងការរៀបអាពាហ៍ពិពាហ៍....................639

២.៣. កំហុសពាក់ព័ន្ធនឹងបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តបទបញ្ញា....................663

ផ្នែកទី ២. ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ....................736

១. កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការរំលោភសេពសន្ថវៈដែលប្រព្រឹត្ត ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩....................736

១.១. គ្មានការវិភាគទៅលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ....................736

១.២. គ្មានការចែងអំពីការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ក្នុងលិខិតុបករណ៍អន្តរជាតិនៅសម័យនោះ ....................738

១.៣. ភាពមិនអាចផ្តន្ទាទោស ខៀវ សំផន ....................739

២. កំហុសពាក់ព័ន្ធនឹងការពិនិត្យធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ......740

២.១. កំហុសពាក់ព័ន្ធនឹងការពិនិត្យលើល័ក្ខខ័ណ្ឌតម្រូវនៃលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែល ..740

២.២. កំហុសពាក់ព័ន្ធនឹងការពិនិត្យលើការទទួលរងការឈឺចាប់ ក្នុងបរិបទនៃទំនាក់ទំនងផ្លូវភេទ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ......747

២.៣. កំហុសពាក់ព័ន្ធនឹងការតាមដានការរួមដំណេក ......768

ភាគទី ៤. កំហុសពាក់ព័ន្ធនឹងគោលបំណងរួម ......798

មាតិកាទី ១. កំហុសពាក់ព័ន្ធនឹងផែនការបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក ......798

ជំពូកទី ១. កំហុសអង្គច្បាប់ ......800

ជំពូកទី ២. កំហុសអង្គហេតុ ......803

ផ្នែកទី ១. ទំនាក់ទំនងនយោបាយជាមួយវៀតណាម នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ......803

ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងខ្លឹមសារនៃ "បដិវត្តន៍សង្គមនិយម" ......807

១. ឆន្ទៈចង់បានឯករាជ្យ ដែលស្តែងឡើងតាមរយៈបរិបទឆ្នាំ១៩៧៥ ......807

២. "មហាលោតផ្លោះ មហាអស្ចារ្យ" និងភាពធ្ងន់ធ្ងរនៃសភាពការណ៍ជាតិក្រោយជម្លោះ ......809

ផ្នែកទី ៣. ការផ្សព្វផ្សាយផែនការនយោបាយនៃ "បដិវត្តន៍សង្គមនិយម" ......814

១. កំហុសពាក់ព័ន្ធនឹងមធ្យោបាយផ្សព្វផ្សាយគោលនយោបាយ ......814

១.១. កំហុសពាក់ព័ន្ធនឹងតម្លៃជាភ័ស្តុតាងនៃឯកសារដែលបានប្រើប្រាស់ ......814

១.២. ភាពលម្អៀងក្នុងតម្លៃប្រែប្រួលដែលបានផ្តល់ទៅលើភ័ស្តុតាង ......816

២. កំហុសពាក់ព័ន្ធនឹងវិសាលភាពនៃការផ្សព្វផ្សាយ ......818

មាតិកាទី ២. កំហុសពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំនៃគោលបំណងរួម និងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយទាំងនោះ ......820

សេចក្តីផ្តើម. ដំណើរការខុសឆ្គងនៃការពិនិត្យលើគោលនយោបាយ ......820

ជំពូកទី ១. កំហុសពាក់ព័ន្ធនឹងការយល់ឃើញអំពីខ្មាំងរបស់ ប.ក.ក ......823

ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងទិដ្ឋភាពទូទៅនៃកាលប្បវត្តិនៃសញ្ញាណខ្មាំង ......824

១. កំហុសពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ នៅមុនឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៥ ......825

២. កំហុសពាក់ព័ន្ធនឹងរយៈពេល ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ ......828

២.១. សម្រាប់ឆ្នាំ១៩៧៦ ......828

២.២. សម្រាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ......831

ផ្នែកទី ២. កំហុសតមកទៀតក្នុងការវិភាគអង្គហេតុ ....................................................835
១. ការបំភ្លៃទស្សនៈម៉ាក្សនិយមអំពីខ្សាំងវណ្ណៈ..........................................................835
១.១. សារៈសំខាន់នៃមនោគមន៍វិជ្ជាម៉ាក្សនិយម ក្នុងភាសារបស់ ប.ក.ក ............................835
១.២. ភាពខុសគ្នារវាងការតស៊ូមនោគមន៍វិជ្ជា និងការតស៊ូពិតប្រាកដ ................................837
២. ការភាន់ច្រឡំរវាងខ្សាំងនយោបាយ និងខ្សាំងយោធា ..................................................839
២.១. កំហុសពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យ “យួន”.........................................................839
២.២. កំហុសបណ្តាលមកពីការលាក់បាំងជម្លោះប្រដាប់អាវុធ..............................................841
ជំពូកទី ២. “គោលនយោបាយ” ជម្លៀសប្រជាជន សហករណ៍ និងការដ្ឋាន ...................................843
ផ្នែកទី ១. អត្ថិភាពនៃគោលនយោបាយជម្លៀសប្រជាជន ......................................................843
ផ្នែកទី ២. គោលដៅរបស់សហករណ៍ .....................................................................................844
១. សេចក្តីសន្និដ្ឋានខុសអំពីគោលនយោបាយរបស់ បក.ក.......................................................845
១.១. សេចក្តីតម្រង់ទិសនយោបាយដែលត្រូវបានកំណត់ចរិតលក្ខណៈខុស ..................................846
១.២. សេចក្តីណែនាំស្តីពីសហករណ៍ ដែលត្រូវបានលាក់បាំង ...............................................849
១.៣. កំហុសពាក់ព័ន្ធនឹងការនាំចេញអង្ករ .........................................................................851
២. កំហុសអំពីតួនាទីរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងសហករណ៍ ..............................................854
២.១. កំហុសពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន...............................................854
២.២. កំហុសពាក់ព័ន្ធនឹងការចូលរួមចំណែករបស់ ខៀវ សំផន ..............................................856
៣. កំហុសពាក់ព័ន្ធនឹងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយ ......................................................858
ជំពូកទី ៣. “គោលនយោបាយ” មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ......................................860
ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ.........................................................................860
១. កំហុសពាក់ព័ន្ធនឹងដើមកំណើតនៃមន្ទីរសន្តិសុខ ...........................................................860
១.១. ភាពហិង្សានៃចលនាបដិវត្តរបស់ ប.ក.ក .......................................................................860
១.២. ការបង្កើតមន្ទីរសន្តិសុខ ...........................................................................................862
២. ការបំភ្លៃឯកសារ និងសុន្ទរកថាផ្លូវការ..............................................................................863
២.១. អត្ថបទ និងសុន្ទរកថា ...............................................................................................863
២.២. ការដឹងឮពីការម្ទេចខ្សាំង ..........................................................................................871
ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងគោលនយោបាយ ....................................................................872
ជំពូកទី ៤. “គោលនយោបាយ” ចំពោះក្រុមពិសេស ...............................................................876

ផ្នែកទី ១. គោលនយោបាយចំពោះជនជាតិវៀតណាម ....876

ផ្នែកទី ២. គោលនយោបាយចំពោះជនជាតិចាម ....882

១. គ្មានឯកសារផ្លូវការស្តីពីគោលនយោបាយជាតិប្រឆាំងនឹងជនជាតិចាម....885

២. គ្មានគោលនយោបាយជាតិ ដែលបញ្ជាក់ដោយសាក្សី ....887

២.១. កម្មាភិបាលជាន់ខ្ពស់ ....887

២.២. អ្នកជំនាញ ....888

៣. ការកំណត់គោលដៅលើជនជាតិចាម ដោយគ្មានភស្តុតាងបង្ហាញ....890

ផ្នែកទី ៣. គោលនយោបាយប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ....891

ផ្នែកទី ៤. គោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិក....895

ជំពូកទី ៥. ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍....897

ជំពូកទី ៦. កំហុសពាក់ព័ន្ធនឹងគោលបំណងរួមដែលបានចោទប្រកាន់ ....897

ផ្នែកទី ១. គោលបំណងរួមខុសពីគោលនយោបាយ "ឧក្រិដ្ឋ"....898

ផ្នែកទី ២. ការចូលរួមខុសពីចេតនាឧក្រិដ្ឋ ....900

ភាគទី ៥. កំហុសពាក់ព័ន្ធនឹងការទទួលខុសត្រូវ ....902

មាតិកាទី ១. ការរំលោភលើគោលការណ៍នៃការទទួលខុសត្រូវជាឯកត្តជន ....902

ជំពូកទី ១. គ្មានទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងទីតាំងឧក្រិដ្ឋកម្ម....902

ផ្នែកទី ១. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅសហករណ៍ត្រាំកក់ ....902

ផ្នែកទី ២. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅទំនប់ត្រពាំងថ្ម ....903

ផ្នែកទី ៣. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅទំនប់១មករា....904

ផ្នែកទី ៤. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅព្រលានយន្តហោះកំពង់ឆ្នាំង....904

ផ្នែកទី ៥. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខ ស-២១ ....905

ផ្នែកទី ៦. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខក្រាំងតាចាន់....907

ផ្នែកទី ៧. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខអូរកន្សែង....907

ផ្នែកទី ៨. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខភ្នំក្រោល ....907

ជំពូកទី ២. មធ្យោបាយសិប្បនិម្មិត ដើម្បីប៉ះប៉ូវការគ្មានទំនាក់ទំនង និងសម្ភូហភាវូបនីយកម្មនៃការទទួលខុសត្រូវ ....908

ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យក្តោបរួម....909

១. "មជ្ឈិមបក្ស"....909

១.១. "មជ្ឈិមបក្ស" មិនត្រូវបានកំណត់ក្រៅបរិបទ.....909
១.២. កំហុសពាក់ព័ន្ធនឹងការទំនាក់ទំនង (ផ្នែកទី ៦ នៃសំអាងហេតុសាលក្រម).....910
១.៣. កំហុសពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាន នៅក្នុងផ្នែកទី ១៦. គោលបំណងរួម.....914
១.៤. កំហុសពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននៅក្នុងផ្នែកទី ១៨. ការទទួលខុសត្រូវព្រហ្មទណ្ឌ.....916
២. អង្គការ.....918
២.១. កំហុសពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននៅក្នុងផ្នែកទី ១៦. គោលបំណងរួម.....918
២.២. កំហុសពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននៅក្នុងផ្នែកទី ១៨. ការទទួលខុសត្រូវព្រហ្មទណ្ឌ.....919
៣. "៨៧០".....920
ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងមធ្យោបាយទំនាក់ទំនង.....923
១. ទស្សនាវដ្តី "ទង់បដិវត្ត" "យុវជន និងយុវនារីបដិវត្ត".....923
២. រចនាសម្ព័ន្ធ និងការទំនាក់ទំនងរបស់កងទ័ព.....926
ផ្នែកទី ៣. គោលការណ៍រក្សាការសម្ងាត់.....932
មាតិកាទី ២. កំហុសទូទៅពាក់ព័ន្ធនឹងតួនាទីរបស់ ខៀវ សំផន.....935
ជំពូកទី ១. កំហុសពាក់ព័ន្ធនឹងសម័យកាលមុនរបបកម្ពុជាប្រជាធិបតេយ្យ.....935
ផ្នែកទី ១. កុមារភាព យុវវ័យ និងអាជីព.....935
១. កំហុសពាក់ព័ន្ធនឹងនិក្ខេបបទបណ្ឌិត.....935
២. កំហុសពាក់ព័ន្ធនឹងសកម្មភាព និងការសេពគប់.....936
ផ្នែកទី ២. សមាជិក ប.ក.ក.....940
ផ្នែកទី ៣. ពីឆ្នាំ១៩៧០ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥.....941
១. ការគាំទ្រដល់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា.....942
២. ការឃោសនា សុន្ទរកថា និងសេចក្តីអំពាវនាវឱ្យតស៊ូដោយហិង្សា.....943
ផ្នែកទី ៤. ការចូលរួមក្នុងកិច្ចប្រជុំគណៈមជ្ឈិម នៅខែមិថុនា ឆ្នាំ១៩៧៤ និងខែមេសា ឆ្នាំ១៩៧៥.....944
១. ការងាកត្រឡប់មករកកិច្ចប្រជុំ ខែមិថុនា ឆ្នាំ១៩៧៤.....945
២. កិច្ចប្រជុំ ខែមេសា ឆ្នាំ១៩៧៥ នៅមន្ទីរ ប-៥.....947
២.១. ភាពផ្ទុយគ្នា និងកង្វះភាពអាចជឿជាក់បានរបស់ ភី ភួន ដែលត្រូវបានធ្វើមិនដឹងមិនឮ.....947
២.២. សេចក្តីលម្អិតនៃភាពផ្ទុយគ្នាជាមួយភស្តុតាងទាំងអស់អំពីមន្ទីរ ប-៥.....948
២.៣. ភស្តុតាងផ្សេងទៀតដែលមិនត្រូវបានយកចិត្តទុកដាក់.....951
ជំពូកទី ២. កំហុសពាក់ព័ន្ធនឹងកន្លែងស្នាក់នៅ កន្លែងធ្វើការ និងការធ្វើដំណើរ.....952

ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងការនៅកៀកនឹងមេដឹកនាំ ប.ក.ក......952

ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងការចុះទស្សនកិច្ចនៅតាមការដ្ឋាន......954

ជំពូកទី ៣. កំហុសពាក់ព័ន្ធនឹងតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ......955

ផ្នែកទី ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា 955

ផ្នែកទី ២. ប្រធានគណៈប្រធានរដ្ឋ......957

១. កំហុសពាក់ព័ន្ធនឹងការចាត់តាំង......958

២. កំហុសពាក់ព័ន្ធនឹងមុខងារ និងការទទួលខុសត្រូវ......958

៣. កំហុសពាក់ព័ន្ធនឹងសុន្ទរកថា......960

៣.១. សុន្ទរកថាដែលត្រូវបានសន្មតខុសថា ខៀវ សំផន ជាអ្នកថ្លែង......960

៣.២. សុន្ទរកថាផ្សេងទៀត......961

ផ្នែកទី ៣. "សមាជិក" គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍......962

១. សមាជិកភាពក្នុងគណៈមជ្ឈិម......963

១.១. កំហុសពាក់ព័ន្ធនឹងវិសាលភាពនៃមុខងារ និងសិទ្ធិអំណាចរបស់គណៈមជ្ឈិម......963

១.២. កំហុសពាក់ព័ន្ធនឹងការសន្មតសេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថាជារបស់គណៈមជ្ឈិម......966

១.៣. កំហុសពាក់ព័ន្ធនឹងកាលបរិច្ឆេទចូលជាសមាជិកពេញសិទ្ធិ......969

១.៤. កំហុសពាក់ព័ន្ធនឹងវត្តមានក្នុងមហាសន្និបាត......971

២. វត្តមានក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈអចិន្ត្រៃយ៍......974

២.១. កំហុសពាក់ព័ន្ធនឹងភស្តុតាងអំពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ......975

២.២. កំហុសពាក់ព័ន្ធនឹង "ការចូលរួម" របស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍......976

២.៣. កំហុសពាក់ព័ន្ធនឹង "តួនាទីពិសេស" របស់ ខៀវ សំផន......980

៣. ប្រជាធិបតេយ្យប្រមូលផ្ដុំ......981

ផ្នែកទី ៤. មុខងារបន្ទាប់បន្សំ......984

១. វគ្គរៀនសូត្រ......984

១.១. កំហុសពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់សាក្សីដាក់បន្ទុក......984

១.២. កំហុសពាក់ព័ន្ធនឹងខ្លឹមសារនៃវគ្គរៀនសូត្រនយោបាយ......988

២. សមាជិកមន្ទីរ ៨៧០......990

២.១. កំហុសពាក់ព័ន្ធនឹងសមាជិកភាពនៃមន្ទីរ ៨៧០ នៅខែតុលា ឆ្នាំ១៩៧៥......991

២.២. កំហុសពាក់ព័ន្ធនឹងការកំណត់ថា ខឿន ជា "អ្នកកាន់តំណែងមុន" ខៀវ សំផន......993

៣. ការត្រួតពិនិត្យលើគណៈកម្មាធិការពាណិជ្ជកម្ម....994
៣.១. កំហុសពាក់ព័ន្ធនឹងមុខងារ និងវិសាលភាពនៃមុខងារ នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម......995
៣.២. ការសន្និដ្ឋានពង្រីកចេញពីរបាយការណ៍ផ្ញើជូន ខៀវ សំផន ....1004
៣.៣. កំហុសពាក់ព័ន្ធនឹងការពិនិត្យ និងវគ្គរៀនសូត្រ ....1007
៤. អ្នកទទួលខុសត្រូវក្រសួងការបរទេស....1011
មាតិកាទី ៣. កំហុសពាក់ព័ន្ធនឹងការដឹងរបស់ ខៀវ សំផន....1013
ជំពូកទី ១. ការប្រែប្រួលកម្រិតនៃការដឹង ទៅតាមពេលវេលា....1013
ជំពូកទី ២. ការដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត ....1014
ជំពូកទី ៣. ការដឹងអំពីឧក្រិដ្ឋកម្ម ក្នុងពេលប្រព្រឹត្ត ....1020
ផ្នែកទី ១. សហករណ៍ និងការដ្ឋាន ....1020
១. កំហុសរួមចំពោះការដ្ឋានទាំងអស់....1020
១.១. ការបំភ្លៃចម្លើយរបស់ ខៀវ សំផន ក្នុងពេលសម្ភាសន៍....1020
១.២. កំហុសពាក់ព័ន្ធនឹងការដឹងអំពីល័ក្ខខ័ណ្ឌរស់នៅក្នុងខេត្តព្រះវិហារ ....1027
១.៣. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការប្រព្រឹត្តិរើសអើងចំពោះប្រជាជនថ្មី ....1030
១.៤. គ្មានភ័ស្តុតាងពីការដឹងឮអំពីឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋានការងារ នៅសម័យអង្គហេតុ ....1032
២. សហករណ៍ត្រាំកក់ ....1033
៣. ទំនប់ត្រពាំងថ្ម ....1033
៣.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង ....1033
៣.២. កំហុសរបស់អង្គជំនុំជម្រះក្នុងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន ....1034
៤. ទំនប់១មករា....1036
៥. ព្រលានយន្តហោះកំពង់ឆ្នាំង ....1036
ផ្នែកទី ២. មន្ទីរសន្តិសុខនានា....1038
១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង ....1039
១.១. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១....1039
១.២. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខក្រាំងតាចាន់....1040
១.៣. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខអូរកន្សែង....1041
១.៤. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខភ្នំក្រោល....1041

២. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងពេលនៃការបោសសម្អាត............ 1042
២.១. កំហុសដោយបានសំអាងលើចម្លើយក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្ហាញឱ្យឃើញពីការដឹងឮ............ 1042
២.២. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការបោសសម្អាតកម្មាភិបាលជាន់ខ្ពស់មួយចំនួននៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ............ 1044
២.៣. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការបោសសម្អាតថ្នាក់ក្រោម ............ 1052
ផ្នែកទី ៣. ក្រុមជាក់លាក់នានា............ 1055
១. ជនជាតិចាម ............ 1055
១.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង............ 1055
១.២. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន ............ 1056
២. ជនជាតិវៀតណាម ............ 1058
២.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង ............ 1059
២.២. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន ............ 1060
៣. ពុទ្ធសាសនិក ............ 1075
៣.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង ............ 1076
៣.២. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន ............ 1076
៤. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ............ 1080
៤.១. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន ............ 1081
៤.២. ការដឹងឮអំពីឧក្រិដ្ឋកម្មជាក់លាក់............ 1083
ផ្នែកទី ៤. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីឧក្រិដ្ឋកម្មនៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍............ 1084
ជំពូកទី ៤. ការដឹងពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម............ 1086
មាតិកាទី ៤. កំហុសពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ............ 1090
ជំពូកទី ១. សហឧក្រិដ្ឋកម្មរួមតាមផ្លូវច្បាប់ ............ 1090
ផ្នែកទី ១. ចរិតឧក្រិដ្ឋនៃគោលបំណង ស្ថិតត្រង់ធាតុផ្សំសត្យានុម័តិ............ 1090
១. គោលបំណងរួមមានចរិតឧក្រិដ្ឋ............ 1090
១.១. ការរំឭកពីអង្គច្បាប់បានយ៉ាងត្រឹមត្រូវ ប៉ុន្តែមិនពេញលេញ និងពិបាកយល់ ............ 1091
១.២. ការពង្រីកវិសាលភាពនៃគោលបំណងឧក្រិដ្ឋរួមទៅតាមពេលវេលា ............ 1098
២. ការចូលរួមចំណែកសំខាន់ចាំបាច់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់............ 1099

២.១. ការចូលរួមក្នុងគោលបំណងរួមតាមរយៈអំពើអកម្មមានពិរុទ្ធ ....... 1099

២.២. ការចូលរួមក្នុងគោលបំណងឧក្រិដ្ឋរួម ....... 1101

ផ្នែកទី ២. ធាតុផ្សំអត្តនោម័តិ៖ ចេតនាប្រព្រឹត្តបទឧក្រិដ្ឋរួម នៅចំស្នូលនៃគោលបំណងរួម ....... 1103

ជំពូកទី ២. ការប្រព្រឹត្តិកំហុសដើម្បីគេចចេញពីធាតុផ្សំសត្យានុម័តិ ....... 1105

ផ្នែកទី ១. ការវិវត្តកាលប្បវត្តិនៃសហឧក្រិដ្ឋកម្មរួម និងការកំណត់និយមន័យនៃគោលបំណងរួម....... 1105

១. ការប៉ុនប៉ងម្តងហើយម្តងទៀត ដើម្បីពង្រីករចនាសម្ព័ន្ធនៃគោលបំណងរួមក្នុងច្បាប់ ដើម្បីបញ្ចូលឧក្រិដ្ឋកម្មនៅក្រៅគោលបំណងនេះ ....... 1106

១.១. ទស្សនៈភាន់ច្រឡំក្នុងដីកាដំណោះស្រាយ និងក្នុងសាលក្រមសំណុំរឿ ០០២/០១៖ គោលបំណងមានលក្ខណៈឧក្រិដ្ឋ ប្រសិនបើឧក្រិដ្ឋកម្មកើតចេញពីគោលបំណងនេះ ....... 1106

១.២. ទស្សនៈភាន់ច្រឡំនៅក្នុងសាលដីកាសំណុំរឿង ០០២/០១៖ គោលបំណងមានលក្ខណៈឧក្រិដ្ឋ ប្រសិនបើមានភវនីយភាពនៃការប្រព្រឹត្តិបទឧក្រិដ្ឋដែលចារីមិនចង់ប្រព្រឹត្ត ឬមិនចាំបាច់ប្រព្រឹត្ត..... 1108

២. ការវិវត្តជាប់ជានិច្ចនៃគោលបំណង "ឧក្រិដ្ឋ" ដោយមិនគោរពច្បាប់ ....... 1109

២.១. គោលបំណងរួមទូលាយ និងប្រែប្រួលពេញមួយរយៈពេលនៃកិច្ចដំណើរការនីតិវិធី ....... 1110

២.២. គោលបំណងឧក្រិដ្ឋ តាមរយៈ "គោលនយោបាយ" ....... 1113

ផ្នែកទី ២. ការភាន់ច្រឡំលើការចូលរួមចំណែករបស់ ខៀវ សំផន ....... 1123

១. កំហុសទូទៅ ....... 1127

២. ការគាំទ្រ ....... 1128

៣. ការលើកកម្ពស់ ....... 1132

៤. ការជំរុញ ការញុះញង់ ការផ្តល់ភាពស្របច្បាប់ ....... 1133

៥. ការណែនាំរងការចោទប្រកាន់ ....... 1136

៦. ការសម្រួល និងការត្រួតពិនិត្យ ....... 1139

ជំពូក ៣. កំហុសលើធាតុផ្សំអត្តនោម័តិ ....... 1141

ផ្នែកទី ១. កំហុសទូទៅលើធាតុផ្សំនៃចេតនាប្រព្រឹត្តបទល្មើស ....... 1141

១. ការរំឮកអំពីកំហុសលើចេតនាចូលរួមក្នុងគោលបំណងឧក្រិដ្ឋរួម ....... 1141

២. វិចារណកិច្ចមិនត្រឹមត្រូវក្នុងការទាញការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋ ....... 1142

២.១. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងគោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋចំតួ....... 1142

២.២. ល័ក្ខខ័ណ្ឌតម្រូវឱ្យមានចេតនាចាំបាច់ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ តែមិនមែនចំពោះ "ឧក្រិដ្ឋកម្ម" ជាទូទៅ....... 1144

ផ្នែកទី ២. សហករណ៍ និងការដ្ឋាន ........ 1144
១. គ្មានការបង្ហាញចេតនាឧក្រិដ្ឋ ........ 1145
១.១. គ្មានទំនាក់ទំនងជាមួយចេតនាឧក្រិដ្ឋ ........ 1145
១.២. ការមិនបានដឹងឮអំពីល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌរស់នៅដែលបានកំណត់ ........ 1147
១.៣. គ្មានភ័ស្តុតាងពាក់ព័ន្ធនឹងការជំរុញឱ្យមានការប្រព្រឹត្តិការរើសអើងទៅលើប្រជាជនថ្មី ........ 1148
១.៤. គ្មានចេតនារួមតែមួយ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ........ 1148
១.៥. គ្មានធាតុផ្សំភ័ស្តុតាងដែលបង្ហាញអំពីចេតនាចង់ឱ្យដោះស្រាយ "ជោគវាសនារបស់ខ្មាំងជាសម្ងាត់" ........ 1149
២. គ្មានសំអាងហេតុអំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ ........ 1149
ផ្នែកទី ៣. មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស និងការបោសសម្អាត ........ 1151
ផ្នែកទី ៤. ក្រុមជាក់លាក់ ........ 1155
១. ជនជាតិចាម ........ 1155
១.១. គ្មានចេតនាឧក្រិដ្ឋដែលត្រូវបានបង្ហាញ ........ 1155
១.២. គ្មានសំអាងហេតុទាល់តែសោះ ទាក់ទងនឹងចេតនាប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ ........ 1158
២. ជនជាតិវៀតណាម ........ 1160
២.១. គ្មានចេតនានិរទេស ........ 1160
២.២. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត និងការសម្លាប់រង្គាល ........ 1161
២.៣. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ........ 1164
២.៤. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយអំពើមនុស្សឃាត ........ 1166
២.៥. គ្មានចេតនាប្រព្រឹត្តអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ........ 1167
៣. ពុទ្ធសាសនិក ........ 1168
៣.១. គ្មានចេតនាឧក្រិដ្ឋដែលត្រូវបានបង្ហាញ ........ 1168
៣.២. ការសន្និដ្ឋានសមហេតុផលមានតែមួយគត់ គឺគ្មានចេតនាឧក្រិដ្ឋ ........ 1170
៤. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ........ 1171
៤.១. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ. 1171
៤.២. គ្មានភ័ស្តុតាងបង្ហាញពីចេតនាប្រព្រឹត្តបទល្មើសជាអំពើមនុស្សឃាត ........ 1174
ផ្នែកទី ៥. ការរៀបអាពាហ៍ពិពាហ៍ ........ 1177

មាតិកាទី ៥. ការយល់ច្រឡំលើការជួយ និងការជំរុញ ........ 1179
ជំពូក ១. ការជួយជ្រោមជ្រែង និងការជំរុញ តាមផ្លូវច្បាប់ ........ 1180
ជំពូកទី ២. កំហុសពាក់ព័ន្ធនឹងធាតុផ្សំភ័ស្តុតាងសត្យានុម័តិ ........ 1181
១.ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាត ដោយចេតនាប្រយោល នៅត្រាំកក់ ........ 1182_Toc45094473
១.១. ការគាំទ្រផ្នែកសីលធម៌ និងការលើកទឹកចិត្តដោយតុល្លីភាពដល់ស្ថាប័នមានសិទ្ធិអំណាចចេញសេចក្តីសម្រេច ........ 1182
១.២. ការគាំទ្រខាងសីលធម៌ អ្នកធានាខាងសីលធម៌ និងការលើកទឹកចិត្តយ៉ាងសកម្មដល់កម្មាភិបាល ប.ក.ក ........ 1183
១.៣. គ្មានសំអាងហេតុពីផលប៉ះពាល់ខ្លាំងទៅលើការស្លាប់របស់កម្មករដែលធ្វើការនៅក្នុងសហករណ៍ 1185
២. គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតនៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល........ 1185
២.១. ជំនួយជាក់ស្តែងដល់មជ្ឈិមបក្ស ........ 1186
២.២. ការគាំទ្រខាងសីលធម៌ដល់មជ្ឈិមបក្ស ........ 1187
២.៣. គ្មានសំអាងហេតុពីការជះឥទ្ធិពលខ្លាំងទៅលើការប្រព្រឹត្តិអំពើមនុស្សឃាតដោយចេតនាប្រយោល ........ 1187
ជំពូកទី ៣. កំហុសពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិ ........ 1188
១. គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាប្រយោល នៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង........ 1188
២. គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាប្រយោល នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល ........ 1189
ជាសំណើបន្ទាប់បន្សំបំផុត........ 1191
១. ការបង្ហាញអំពីភាពលម្អៀងទាក់ទងនឹងគោលដៅនៃការដាក់ទោស ........ 1191
២. កំហុសលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត........ 1193
២.១. កំហុសចេញពីការពិចារណាអំពីភ័ស្តុតាងនៅក្រៅវិសាលភាព ........ 1193
២.២. កំហុសលើតួនាទីរបស់ ខៀវ សំផន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ........ 1195
៣. កំហុសពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស ........ 1198
៣.១. កំហុសចំពោះការរំលោភបំពានមុខតំណែងមានអំណាច និងឥទ្ធិពល........ 1198
៣.២. កំហុសចេញពីការគិតពីកម្រិតវប្បធម៌ ........ 1200

៤. កំហុសពាក់ព័ន្ធនឹងស្ថានសម្រាលទោស ........ 1202

៤.១. កំហុសពាក់ព័ន្ធនឹងការសហការរបស់ខៀវ សំផន ជាមួយ អ.វ.ត.ក ........ 1202

៤.២. កំហុសដោយមិនគិតពីវ័យ និងស្ថានភាពសុខភាព ........ 1204

៤.៣. កំហុសស្តីពីសីលធម៌ល្អ ........ 1208

អាស្រ័យហេតុនេះ........ 1212

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

## សេចក្ដីផ្ដើម

## ប្រវត្តិសង្ខេបនៃនីតិវិធី

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ បន្ទាប់ពីការបើកកិច្ចស៊ើបសួរដោយសហព្រះរាជអាជ្ញា នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧[1] ខៀវ សំផន ក្រោយពីបានជាប់ឃុំបណ្ដោះអាសន្នអស់រយៈពេល៣ឆ្នាំ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មជាច្រើន[2] មុននឹងត្រូវបានបញ្ជូនខ្លួនទៅជំនុំជម្រះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នៅក្នុងសំណុំរឿង ០០២[3]។

២. ក្រោយទទួលបានសំណុំរឿង អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានបំបែកបទចោទជាច្រើនដង មុននឹងបំព្រួញបទចោទទាំងនោះ។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ជាបឋម អង្គជំនុំជម្រះបានកំណត់វិសាលភាពនៃការជំនុំជម្រះសំណុំរឿងវគ្គទី១ គឺសំណុំរឿង ០០២/០១[4]។ បន្ទាប់មក នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ក្រោយបញ្ចប់សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានកំណត់វិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០២[5]។ ជាចុងក្រោយ នៅថ្ងៃទី២៧ ខែ

---

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨-០៧-២០០៧ ឯកសារ **D3**។

[2] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ **D427** ។

[3] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/4/14** ។ ឯកសារយោងពេញលេញនៃសេចក្ដីសម្រេច សេចក្ដីសន្និដ្ឋាន និងឯកសារច្បាប់ដទៃទៀត ត្រូវបានផ្ដល់ជូន នៅក្នុងឧបសម្ព័ន្ធនៃសារណាបណ្ដឹងសាទុក្ខនេះ។ ប្រសិនបើជាសេចក្ដីសម្រេចគ្មានសេចក្ដីបញ្ជាក់ជាក់លាក់ដែលបានចេញសេចក្ដីសម្រេចនោះពីតុលាការទេ មានន័យថាជាសេចក្ដីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង។ ប្រសិនបើជាយុត្តិសាស្ត្រគ្មានសេចក្ដីបញ្ជាក់ជាក់លាក់ពីតុលាការដែលបានចេញសេចក្ដីសម្រេចនោះទេ មានន័យថាជាគឺជាយុត្តិសាស្ត្រនៃ អ.វ.ត.ក។

[4] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E124** ជាមួយនឹងឧបសម្ព័ន្ធនៃសំណុំរឿង ០០២/០១ (បានធ្វើវិសោធនកម្មរួច) ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ ឯកសារ **E124/7.3**។ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ **E284**។

[5] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E301/9/1** ជាមួយនឹងឧបសម្ព័ន្ធនៃសំណុំរឿង ០០២/០២ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E301/9/1.1**។

កុម្ភៈ ឆ្នាំ២០១៧ បន្ទាប់ពីបញ្ចប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានបំព្រួញបទចោទ ដោយបិទបញ្ចប់រាល់បទចោទដែលមិននៅក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២[6]។

៣. នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានប្រកាសថា ខៀវ សំផន ជាប់ពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានផ្តន្ទាទោសគាត់ឱ្យជាប់ពន្ធនាគារអស់មួយជីវិត[7]។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅចុងបញ្ចប់នៃសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") បានតម្កល់សេចក្តីសម្រេចលើពិរុទ្ធភាពមួយចំនួន និងធ្វើមោឃភាពសេចក្តីសម្រេចលើពិរុទ្ធភាពផ្សេងទៀត តែតម្កល់ការផ្តន្ទាទោស[8]។

៤. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានប្រកាសថា ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ (លើជនជាតិវៀតណាម) បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ហើយបានផ្តន្ទាទោសគាត់ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ("សាលសក្រម")[9]។ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួននឹងចេញសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ "ក្នុងពេលសមស្រប"[10]។

៥. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រុមមេធាវីការពារក្តី ខៀវ សំផន ("មេធាវីការពារក្តី" និង/ឬហៅថា "ម្ចាស់បណ្តឹងសាទុក្ខ") បានស្នើសុំតុលាការកំពូលឱ្យធ្វើមោឃភាពសាលក្រម (ផ្នែកសម្រេចសេចក្តីនៃ

---

[6] សេចក្តីសម្រេច ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E439/5**។

[7] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E313** ("សាលក្រមសំណុំរឿង០០២/០១")។

[8] សាលដីកាសំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** ("សាលដីកាសំណុំរឿង០០២/០១")។

[9] ប្រតិចារឹកសវនាការលើអង្គសេចក្តីនៃសំណុំរឿង០០២០២/ ("ប្រតិចារឹក") ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/5** ថ្ងៃទី២៩ ខែមករា ទំព័រ ៦៤-៦៨ ចន្លោះម៉ោង 11.28.58 និងម៉ោង 11.37.34 ("សាលក្រម")។

[10] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/5** ថ្ងៃទី២៩ ខែមករា មុនម៉ោង 09.35.46. សូមមើលផងដែរ៖ ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង០០២០២/ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **E462** ទំព័រ ២។

សាលក្រម) ដោយមូលហេតុវិការៈទម្រង់ និងកង្វះសំអាងហេតុ[11]។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការកំពូលបានសម្រេចបដិសេធបណ្តឹងសាទុក្ខនេះ[12]។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំឱ្យបដិសេធសេចក្តីសម្រេចរបស់តុលាការកំពូល ដោយសារតែសមាសភាពមិនប្រក្រតីនៃក្រុមប្រឹក្សាជំនុំជម្រះនៅពេលនោះ[13]។ សំណើសុំនេះ ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩[14] ត្រូវបានតុលាការកំពូលវិនិច្ឆ័យថាគ្មានមូលដ្ឋាន នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩[15]។

៦. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ភាគីទទួលបានការជូនដំណឹងពីសេចក្តីពេញលេញនៃសំអាងហេតុសាលក្រមជាលាយលក្ខណ៍អក្សរ ចុះកាលបរិច្ឆេទចាស់ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (“សេចក្តីសំអាងហេតុសាលក្រម”)[16] កម្រាស់ ៤១០១ ទំព័រ ជាភាសាខ្មែរ ២៨២៨ ទំព័រ ជាភាសាបារាំង និង ២៣៨៧ ទំព័រ ជាភាសាអង់គ្លេស (“កំណត់សម្គាល់ជើងទំព័រ)។

៧. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំពេលប្រាំបីខែ និងចំនួន ១០០ ទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន ជាពីរភាសា ដោយគូសបញ្ជាក់ពីចេតនាដាក់ឱ្យបានលឿនតាមដែលអាចធ្វើទៅបាន បន្ទាប់ពីការដាក់បណ្តឹងជិតចិត្តប្រឆាំងចៅក្រមនៃតុលាការកំពូល[17]។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ តុលាការកំពូលបានផ្តល់រយៈពេលបីខែ និង ៦០ ទំព័រ ដល់គ្រប់ភាគី[18]។ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំឱ្យពិនិត្យសេចក្តីសម្រេចនេះ

---

[11] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1**។

[12] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **E463/1/3**។

[13] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ឯកសារឯកសារ **E463/1/4**។

[14] សំណើដែលបានដាក់នៅ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ នៅម៉ោង 11:52 ត្រូវបានជូនដំណឹងបីខែក្រោយមកប៉ុណ្ណោះ គឺនៅ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ នៅម៉ោង 10:28។

[15] សេចក្តីសម្រេចលើរបស់តុលាការកំពូល ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ **E465/1/5**។

[16] សាលក្រមសំណុំរឿង ០០២០២/ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** (“សំអាងហេតុសាលក្រម”)។

[17] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F39/1.1**។

[18] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ **F43**។

ឡើងវិញ[19]។ រយៈពេលមួយខែក្រោយមក នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ តុលាការកំពូលបាន បដិសេធសំណើរបស់មេធាវីការពារក្តី[20]។

៨. នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ របស់ខ្លួន[21]។

៩. នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន ដោយអះអាងជាថ្មីពីចេតនាដាក់បណ្តឹងជិតចិត្តឱ្យបានលឿនតាមដែលអាចធ្វើទៅបាន[22]។

១០. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំរយៈពេលដប់ខែកន្លះ និង ៩៥០ទំព័រ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខតែមួយភាសា ក្នុងដំណាក់កាលដំបូង។ ជាមួយគ្នានេះដែរ មេធាវី ការពារក្តីបានស្នើសុំអនុញ្ញាតដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ ក្នុងអំឡុងពេល ៥០ ថ្ងៃ បន្ទាប់ពីបានដាក់សារណារបស់ខ្លួនផ្ទាល់[23]។

១១. នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[24]។

១២. នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ តុលាការកំពូលបានបង្គាប់ឱ្យមេធាវីការពារក្តីដាក់សារណាបណ្តឹង សាទុក្ខមិនលើសពី ៧៥០ ទំព័រ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ជាមួយភាសា នៅជំហានដំបូង និង

---

[19] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ឯកសារ F44។

[20] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ F44/1។

[21] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ E465/2/1។

[22] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ របស់លោក ខៀវ សំផន ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ E465/4/1។

[23] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី10 ខែកក្កដា ឆ្នាំ២០១៩ ឯកសារ F45។

[24] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ របស់លោក ខៀវ សំផន ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ឯកសារ F50 (បកប្រែជាភាសា បារាំង និងបានជូនដំណឹង ននៅ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩)។

ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីពេលជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការកំពូល[25]។

១៣. នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ មេធាវីការពារក្តីបានឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[26]។

១៤. នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ក្រុមមេធាវីការពារក្តីបានដាក់សំណើសុំឱ្យទទួលយកភ័ស្តុតាងបន្ថែម[27] ហើយតុលាការកំពូលបានអនុញ្ញាតតាមសំណើ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០[28]។

១៥. នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំប្តឹងជំទាស់ចៅក្រមប្រាំមួយរូប (ក្នុងចំណោមប្រាំពីររូប) នៃតុលាការកំពូល ដែលបានសម្រេចសេចក្តីក្នុងសំណុំរឿង ០០២/០២ ដោយអះអាងពីអគតិភាពរបស់ចៅក្រមទាំងនេះ ដែលបានវិនិច្ឆ័យរឿងក្តីស្រដៀងគ្នាទៅនឹងរឿងក្តីក្នុងសំណុំរឿង ០០២/០២[29]។ តុលាការកំពូលមិនទាន់បានចេញសេចក្តីសេចក្តីសម្រេចលើបណ្តឹងនេះនៅឡើយ។

១៦. មេធាវីការពារក្តីសូមដាក់សារណាបណ្តឹងសាទុក្ខជាលាយលក្ខណ៍អក្សររបស់ខ្លួនដូចខាងក្រោម។

## ការបរិយាយពីសារណា

១៧. សារណានេះមិនត្រូវបានតាក់តែងឡើង តាមរបៀបដូចសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខឡើយ។ ចំពោះសេចក្តីជូនដំណឹង មេធាវីការពារក្តីគ្រាន់តែបានអនុវត្តតាមគម្រោងនៃសំអាងហេតុសាលក្រម ដោយសារខ្វះពេលវេលា។ ទោះយ៉ាងណាក្តី វាងាយស្រួលណាស់ក្នុងការភ្ជាប់ឯកសារទាំងពីរ ព្រោះ

---

[25] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F49។

[26] ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ F50/1។

[27] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ F51។

[28] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ F51/3។

[29] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ឯកសារ F53 (ឬ 1)។

មេធាវីការពារក្តីបានរក្សាទុកការបង់លេខដដែលលើកំហុសផ្សេងៗ ក្នុងប្រអប់សង្ខេបអំណះអំណាង។ ដូចដែលបានប្រកាសនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ កំហុសជាច្រើន នៅកន្លែងផ្សេងៗគ្នា ក្នុងសំអាងហេតុសាលក្រម មានលក្ខណៈត្រួតគ្នា ហើយដោយហេតុផលនេះ កំហុសត្រូវបានប្រមូលដាក់ក្រោមផ្នែកសំអាងហេតុនៃបណ្តឹងសាទុក្ខរួម[30]។

១៨. ដោយកង្វល់ពីប្រវែងសារណា មេធាវីការពារក្តីបានដាក់ពាក្យបំព្រួញជាច្រើន នៅក្នុងបញ្ជីនៅដើមសារណានេះ។ ជួនកាល មេធាវីការពារក្តីបានយោងទៅសេចក្តីសន្និដ្ឋានរបស់ខ្លួនកន្លងមក ដើម្បីចៀសវាងការច្រំដែល[31] ដូចជាសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ (“សារណាបណ្តឹងសាទុក្ខ ០០២/០១) និងសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ (“សារណាបណ្តឹងសាទុក្ខ ០០២/០២)[32]។ ជួនកាល ការបកប្រែសេចក្តីសន្និដ្ឋានទាំងនេះជាភាសាអង់គ្លេសមានកំហុស ដែលចាំបាច់ត្រូវផ្ទៀងផ្ទាត់ជាប្រចាំជាមួយឯកសារដើមជាភាសាបារាំង។

## លក្ខណៈវិនិច្ឆ័យសម្រាប់ពិនិត្យបណ្តឹងសាទុក្ខ

១៩. យោងតាមវិធាន ១០៤ នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីសូមលើកឡើងអំពីប្រភេទផ្សេងៗនៃកំហុសរបស់អង្គជំនុំជម្រះ។

[30] សេចក្តីសង្ខេបនៃសំអាងហេតុបណ្តឹងជិតចិត្តមាននៅក្នុងឧបសម្ព័ន្ធ ក និង មានចំណុចលម្អិតពាក់ព័ន្ធនឹងការជូនដំណឹងបណ្តឹងសាទុក្ខ។ កំហុសដែលមិនមាននៅក្នុងស៊ុមត្រូវបានបោះបង់ចោល នៅក្នុងពេលសរសេរសារណាបណ្តឹងសាទុក្ខ ដោយសារវាជាន់គ្នានឹងកំហុសដទៃទៀត ឬដោយសារតែចុងបញ្ចប់វាមិនបង្កឱ្យមានផលប៉ះពាល់ ឬយើងវិនិច្ឆ័យទៅឃើញថាវាបន្ទាប់បន្សំដោយសារតែខ្វះពេលវេលា និង/ឬខ្វះកន្លែងសរសេរ។

[31] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ ឯកសារ **F23/1** កថាខណ្ឌ ៩ (“ទាក់ទងនឹង [...] ការបញ្ចូលដោយយោងទៅលើឯកសារផ្សេងៗដូចជាសារណាពីមុនៗនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ក្នុងការចៀសវាងនូវភាពច្រំដែល”)។

[32] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **F17** (“សារណាបណ្តឹងសាទុក្ខ០០២/០១”)។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០២/០០២) ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ឯកសារ ធ្វើវិសោធកម្មនៅ ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ ឯកសារ **E457/6/4/1** (“សេចក្តីសន្និដ្ឋានបញ្ចប់ ០០២/០២”)។

## កំហុសអង្គច្បាប់ដែលធ្វើឱ្យសាលក្រម ឬសេចក្ដីសម្រេចគ្មានសុពលភាព

២០. កំហុសអង្គច្បាប់កើតចេញមកពីការអនុវត្តលក្ខណៈវិនិច្ឆ័យគតិយុត្តិដែលមានកំហុស ដោយអង្គជំនុំជម្រះ[33]។ សាលក្រមមួយត្រូវអស់សុពលភាពដោយកំហុសអង្គច្បាប់។ ក្នុងករណីគ្មានកំហុស ការជំនុំជម្រះក្ដីនឹងត្រូវបញ្ចប់ដោយការចេញសាលក្រមមួយខុសគ្នាពីសាលក្រមបច្ចុប្បន្នទាំងស្រុង ឬដោយផ្នែក[34]។

២១. ដើម្បីបង្ហាញអំពីការប្រព្រឹត្តិកំហុសបែបនេះ ម្ចាស់បណ្ដឹងសាទុក្ខអាចលើកឡើង ជាអាទិ៍ នូវទឡ្ហីករណ៍ដែលបានបង្ហាញរួចមកហើយដល់អង្គបុរេជំនុំជម្រះ និង/ឬអង្គជំនុំជម្រះ[35]។ ក្នុងករណីនេះ បន្ទុកភស្តុតាងក្នុងបណ្ដឹងសាទុក្ខមិនដាច់ខាតឡើយ។ ទោះបីជាទឡ្ហីករណ៍ដែលបានលើកឡើង មិនអាចឱ្យបង្ហាញពីកំហុសអង្គច្បាប់ដូចការចោទប្រកាន់ក៏ដោយ ក៏តុលាការកំពូលអាចរកសំអាងហេតុផ្សេងទៀត និងអាចបង្ហាញហេតុផលដល់ម្ចាស់បណ្ដឹងសាទុក្ខបានដែរ។ ដើម្បីសម្រេចលើរឿងក្ដីដែលបានប្ដឹងមក តុលាការកំពូលត្រូវពិនិត្យផងដែរ នូវរាល់សេចក្ដីសន្និដ្ឋានតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះដែលជាមូលដ្ឋាននៃសេចក្ដីសម្រេចរងបណ្ដឹង[36]។

## កំហុសអង្គហេតុបណ្ដាលឱ្យមានយុត្តិនិសេធ

២២. កំហុសអង្គហេតុកើតចេញមកពីសេចក្ដីសន្និដ្ឋានមួយ ដែលគ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចធ្វើកើតឡើយ ពីព្រោះចៅក្រមនោះនឹងមិនទទួលយកធាតុផ្សំភស្តុតាងដែលអង្គជំនុំជម្រះយកមកធ្វើជាសំអាង ឬដោយហេតុថា ការវាយតម្លៃលើធាតុផ្សំទាំងនេះមានកំហុសទាំងស្រុង[37]។

[33] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៦។

[34] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៩។ សាលដីកា *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៦។

[35] សាលដីកា *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៦៤។

[36] សាលដីកាឌុច ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៥ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៥។

[37] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៨-៨៩។

សាលក្រមមួយមានមោឃភាពដោយកំហុសអង្គហេតុ នៅពេលកំហុសនេះបង្កឱ្យមានយុត្តិនិសេធ (ជាលទ្ធផលនៃភាពអយុត្តិធម៌ជាក់ស្តែងនៃនីតិវិធីផ្លូវច្បាប់)។ ក្នុងការវិនិច្ឆ័យ កំហុសប្រាកដជាមានទម្ងន់ខ្លាំងនៅក្នុងការសម្រេចសេចក្តី[38]។

២៣. ការពិនិត្យកំហុសអង្គហេតុរងការចោទប្រកាន់ មានជាប់ទាក់ទងនឹងការកំណត់ថា តើអង្គជំនុំជម្រះនីតិវិធីដែលសមហេតុផល និងត្រឹមត្រូវ អាចជឿជាក់លើសពីវិមតិសង្ស័យលើការសន្និដ្ឋានពាក់ព័ន្ធ ដោយផ្អែកលើធាតុផ្សំនៃភស្តុតាងក្នុងដៃ ដោយរក្សាបទដ្ឋានជាធរមាននៃការគ្រប់គ្រងភស្តុតាង ដែ ឬទេ[39]។

២៤. ពេលស្នើសុំឱ្យវាយតម្លៃលក្ខណៈសមហេតុផលនៃការសន្និដ្ឋានពីអង្គហេតុរបស់អង្គជំនុំជម្រះ តុលាការកំពូលចាប់ផ្តើមផ្អែកលើវិចារណកិច្ចផ្តល់ដោយអង្គជំនុំជម្រះ ដើម្បីគាំទ្រដល់ការវិភាគអង្គហេតុដោយផ្អែកលើធាតុផ្សំនៃភស្តុតាងពាក់ព័ន្ធ។ ជាពិសេសក្នុងករណីមានធាតុផ្សំនៃភស្តុតាងផ្ទុយ ឬធាតុផ្សំមានតម្លៃជាភស្តុតាងស្តួចស្តើង (ដូចជាចម្លើយក្រៅប្រព័ន្ធតុលាការ ឬភស្តុតាងបានមកពីការនិយាយតៗគ្នា) ការពន្យល់របស់អង្គជំនុំជម្រះអំពីរបៀបទាញសេចក្តីសន្និដ្ឋានលើអង្គហេតុដែលបានផ្តល់ជូន ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងពាក់ព័ន្ធ ទំនងជាមានសារៈសំខាន់ធំធេង ក្នុងការកំណត់ថាតើការសន្និដ្ឋាននេះសមហេតុផល ឬអត់។ តាមវិធានទូទៅ នៅពេលភស្តុតាងសម្រាប់គាំទ្រដល់ការសន្និដ្ឋានពីអង្គហេតុ បង្ហាញអាការៈដំបូងមិនគួរឱ្យជឿជាក់ វិចារណកិច្ចគួរតែរឹងមាំជាងពេលដែលការសន្និដ្ឋាននោះផ្អែកលើភស្តុតាងរឹងមាំមួយ[40]។

២៥. ជាចុងក្រោយ តុលាការកំពូលត្រូវជឿជាក់ថា សេចក្តីសន្និដ្ឋានលើអង្គហេតុដែលធ្វើឡើងហួសពីវិមតិសង្ស័យ ត្រូវតែច្បាស់លាស់ និងមិនអាចប្រកែកបាន ទាំងភស្តុតាង ទាំងវិចារណកិច្ច។ ដូច្នេះប្រសិនបើតុលាការកំពូលអាចកំណត់ការសន្និដ្ឋានលើសពីវិមតិសង្ស័យ តុលាការកំពូលត្រូវតែលុបចោលសេចក្តីសន្និដ្ឋាននោះ។ វាមិនមែនជារឿងរបស់តុលាការកំពូលដែលត្រូវចេញសេចក្តីសន្និដ្ឋាន

---

[38] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៩។

[39] សាលដីកា *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៤២។

[40] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩០។

ផ្ទាល់ខ្លួនជំនួសអង្គជំនុំជម្រះនោះទេ។ តុលាការកំពូលគ្រាន់តែត្រូវអនុវត្តបទដ្ឋាននៃការគ្រប់គ្រងភ័ស្តុតាងប៉ុណ្ណោះ[41]។

២៦. ដើម្បីបង្ហាញពីការប្រព្រឹត្តិកំហុសអង្គហេតុ ម្ចាស់បណ្តឹងសាទុក្ខត្រូវពន្យល់ ជាអាទិ៍ ពីភាពមិនសមហេតុផលនៃសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។ ម្ចាស់បណ្តឹងសាទុក្ខមិនអាចត្រឹមតែថាតាមទឡ្ហីករណ៍ ដែលបានបង្ហាញនៅក្នុងការជំនុំជម្រះអំពីរបៀបវាយតម្លៃភ័ស្តុតាង ក្នុងករណីដែលទឡ្ហីករណ៍ទាំងនេះគ្រាន់តែលើកឡើងពីការបកស្រាយផ្សេងគ្នាអំពីភ័ស្តុតាង[42]។

២៧. ផ្ទុយទៅវិញ វាជាកាតព្វកិច្ចរបស់តុលាការកំពូលក្នុងការវាយតម្លៃ ថាតើអង្គជំនុំជម្រះបានអនុវត្តបទដ្ឋាននៃការគ្រប់គ្រងភ័ស្តុតាងបានត្រឹមត្រូវដែរឬទេ។ ជនជាប់ចោទគ្មានអ្វីត្រូវទៅបង្ហាញថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុនោះឡើយ។ គាត់គ្រាន់តែត្រូវកំណត់ប្រភពមន្ទិលសង្ស័យចំពោះភាពត្រឹមត្រូវនៃសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដើម្បីជំរុញតុលាការកំពូលឱ្យធ្វើការពិនិត្យដោយឯករាជ្យលើវិចារណកិច្ចរបស់អង្គជំនុំជម្រះ ផ្អែកលើភ័ស្តុតាងក្នុងដៃអង្គជំនុំជម្រះ។ ក្នុងករណីអង្គជំនុំជម្រះមិនមានវិចារណកិច្ចច្បាស់លាស់គ្រប់គ្រាន់សម្រាប់គាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួន ក្នុងការបង្ហាញច្បាស់ឥតស្រពិចស្រពិលទាំងភ័ស្តុតាងគាំទ្រសេចក្តីសន្និដ្ឋាន ទាំងការវិភាគលើភ័ស្តុតាងទាំងនេះ តុលាការកំពូលគ្មានជម្រើសអ្វីក្រៅពីបដិសេធសេចក្តីសន្និដ្ឋានពាក់ព័ន្ធ ដោយហេតុថា ការខ្វះសំអាងហេតុត្រឹមត្រូវមិនអាចឱ្យគេពិនិត្យការសន្និដ្ឋាននៃបណ្តឹងសាទុក្ខបានឡើយ ហើយការណ៍នេះបង្កឱ្យមានវិការៈនីតិវិធីធ្ងន់ធ្ងរ។ អ្វីដែលសំខាន់ដែរនោះ គឺថាកាតព្វកិច្ចពន្យល់ពីកំហុសនៅក្នុងដីកាសម្រេចលើពិរុទ្ធភាព នឹងមិននាំទៅដល់ការបដិសេធបន្ទុកភ័ស្តុតាងឡើយ[43]។

## <u>បណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចតាមនីតិវិធី</u>

---

[41] សាលដីកា *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៤៥-៤៦ (បន្ទាប់ពីបានយោងទៅកថាខណ្ឌ ៤៣-៤៤ ក្នុងសាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩០)។

[42] សាលដីកា *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៦៥។

[43] សាលដីកា *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៦៦។

២៨. ថ្វីបើ ជាញឹកញយ អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិលើបញ្ហានីតិវិធី ប៉ុន្តែ អង្គជំនុំជម្រះត្រូវអនុវត្តអំណាចនេះឱ្យបានសមស្រប។ តុលាការកំពូលអាចធ្វើអន្តរាគមន៍កែតម្រូវការអនុវត្តអំណាចឆន្ទានុសិទ្ធិក្នុងករណីដូចតទៅ៖ i) ការអនុវត្តផ្អែកលើការបកស្រាយច្បាប់មិនត្រឹមត្រូវ។ ii) ការអនុវត្តផ្អែកលើការសន្និដ្ឋានខុសជាក់ស្តែង។ ឬ iii) សេចក្តីសម្រេចធ្វើឡើងដោយរំលោភបំពានអំណាចនេះ[44]។

២៩. **នៅក្នុងសារណានេះ** មេធាវីការពារក្តីសូមជម្រាប**ជាលក្ខណៈចម្បង**ថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលធ្វើឱ្យសាលក្រមគ្មានសុពលភាព ដោយសារមិនបានគោរពតាមវិធានគតិយុត្តិដែលតម្រូវឱ្យអង្គជំនុំជម្រះផ្តល់សំអាងហេតុជាលាយលក្ខណ៍អក្សរ នៅថ្ងៃប្រកាសសាលក្រមតែម្តង។ **ជាលក្ខណៈបន្ទាប់បន្សំ** ដោយសារ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើនសន្ធឹកសន្ធាប់ ជាហេតុនាំឱ្យការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោស ត្រូវទុកជាមោឃៈ។ **ជាលក្ខណៈបន្ទាប់បន្សំបំផុត** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងការកំណត់ទោស។

## ជាលក្ខណៈចម្បង

៣០. ដោយមិនបានផ្តល់សំអាងហេតុសាលក្រមនៅថ្ងៃប្រកាសតែម្តង[45] អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ធ្ងន់ធ្ងរ ជាហេតុធ្វើឱ្យសាលក្រមដែលបានប្រកាសដោយខុសច្បាប់គ្មានសុពលភាព (១)។ វិការៈនេះមិនអាចត្រូវបានលាងជម្រះដោយការចេញសំអាងហេតុនៅពេលក្រោយបានឡើយ (២)។

### ១. អសុពលភាពនៃសាលក្រមដែលបានប្រកាសដោយខុសច្បាប់នាំឱ្យតែម្តង

[44] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៧។ សាលដីកា *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៤៨។

[45] ប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/5** ថ្ងៃទី២៩ ខែ1 ទំព័រ ៦៤-៦៨ ចន្លោះម៉ោង 11.28.58 និងម៉ោង 11.37.34)។ សេចក្តីសំអាងហេតុបានដាក់នៅ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ (ឯកសារ **E465**)។

៣១. នៅ អ.វ.ត.ក ដាច់ខាត សាលក្រមត្រូវតែមានសំអាងហេតុ និងត្រូវចេញជាលាយលក្ខណ៍អក្សរ នៅថ្ងៃប្រកាសសាលក្រមតែម្តង (១.១) ហើយចៅក្រមត្រូវតែគោរពបញ្ញត្តិច្បាប់តម្រូវ (១.២)។ បើមិនដូច្នោះទេ សាលក្រមគឺខុសច្បាប់ និងបំពានច្បាប់ (១.៣)។

## ១.១. នៅ អ.វ.ត.ក សាលក្រមត្រូវតែមានសំអាងហេតុ និងត្រូវចេញជាលាយលក្ខណ៍អក្សរ នៅថ្ងៃប្រកាសសាលក្រមតែម្តង

### ១.១.១. កាតព្វកិច្ចស្របច្បាប់ត្រូវបានកំណត់យ៉ាងច្បាស់ដោយវិធានផ្ទៃក្នុង

៣២. វិធានផ្ទៃក្នុងចែងច្បាស់ណាស់ថា នៅ អ.វ.ត.ក សាលក្រមត្រូវតែបានតាក់តែងមុនពេលប្រកាស[46]។ អង្គជំនុំជម្រះមានកាតព្វកិច្ចចេញសាលក្រមជាលាយលក្ខណ៍អក្សរ មានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រម និងក្រឡាបញ្ជី "យ៉ាងយូរបំផុត" នៅត្រឹមថ្ងៃប្រកាសតែម្តង។ នៅថ្ងៃនោះ ច្បាប់ថតចម្លងសាលក្រមត្រូវតែផ្តល់ជូនភាគី និងផ្សព្វផ្សាយ[47]។ បើជនជាប់ចោទមានវត្តមាន រយៈពេលបណ្តឹងសាទុក្ខចាប់ផ្តើមរាប់ចាប់ពីថ្ងៃនោះ។ ដូចនៅក្នុងច្បាប់កម្ពុជាដែរ[48] មានតែក្នុងករណីដែលជនជាប់ចោទអវត្តមានប៉ុណ្ណោះ ដែលរយៈពេលបណ្តឹងសាទុក្ខចាប់ផ្តើមគិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រម។

[46] វិធានផ្ទៃក្នុង វិធាន ១០១, ១០២ និង ១០៧។

[47] កាតព្វកិច្ចទាំងនេះត្រូវបានស្តែងឡើងដោយការប្រើកិរិយាស័ព្ទ « *shall* » នៅក្នុងអត្ថបទសរសេរជាភាសាអង់គ្លេសនៃវិធានផ្ទៃក្នុង។

[48] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក៏មានចែងច្បាស់លាស់ពីចំណុចចាប់ផ្តើមនៃរយៈពេលប្តឹងឧទ្ធរណ៍នេះដែរ។ តាមមាត្រា ៣៨១ រយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា "ផ្តើមគិតពីពេលប្រកាសសាលក្រម"។ បើតាមមាត្រា៣៨២ ប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជនត្រូវតែធ្វើក្នុងរយៈពេល១ខែ។ កាលណាសាលក្រមនោះចាត់ទុកថាជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម។ កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឱ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ"។ នៅផ្នែកខាងចុងនៃក្រមព្រហ្មទណ្ឌដដែលនេះ សាលក្រមមួយជាសាលក្រមចំពោះមុខ "ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ" (មាត្រា៣៦០ វាក្យខណ្ឌ ១)។ "ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ" សាលក្រមត្រូវចាត់ទុកថាជាសីលក្រោមចំពោះមុខជនជាប់ចោទ (មាត្រា៣៦១ វាក្យខណ្ឌ ១)។

៣៣. កាតព្វកិច្ចទាំងនេះដែលកំណត់ដោយវិធានផ្ទៃក្នុង មិនមែនគ្រាន់តែជាបែបបទសាមញ្ញដែលអង្គជំនុំជម្រះអាចគេចវេសបានឡើយ។ កាតព្វកិច្ចទាំងនេះឆ្លុះបញ្ចាំងអំពីលក្ខណៈពិសេស និងសារៈសំខាន់នៃសាលក្រម ហើយកាតព្វកិច្ចទាំងនេះបង្កលក្ខណៈប្រសើរដល់ការគោរពសិទ្ធិជាមូលដ្ឋាន។

### ១.១.២. កាតព្វកិច្ចស្របច្បាប់ត្រូវបានកំណត់ ដោយសារសារៈសំខាន់នៃសាលក្រម

៣៤. សាលក្រមខុសគ្នាពីសេចក្តីសម្រេចផ្សេងៗទៀត ព្រោះវាជាសេចក្តីសម្រេចចុងក្រោយរបស់តុលាការជំនុំជម្រះទៅលើពិរុទ្ធភាព ឬអពិរុទ្ធភាពរបស់ជនជាប់ចោទ។ អានុភាពរបស់វាមានលក្ខណៈពិសេស និងសំខាន់ណាស់ ព្រោះវាពាក់ព័ន្ធនឹងការដាក់/ការបន្តឃុំឃាំង ឬការដោះលែង/"ការបន្ត" ឱ្យមានសេរីភាព។ ដើម្បីឱ្យមានភាពស្របច្បាប់ និងធម្មនុញ្ញភាព សេចក្តីសម្រេចលើគុណសម្បត្តិនៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌមួយ ត្រូវធ្វើឡើងជាសាធារណៈដោយតុលាការដែលបានបង្កើតឡើងដោយច្បាប់ ហើយត្រូវតែអាចពិនិត្យបានដោយតុលាការជាន់ខ្ពស់[49]។

៣៥. ដោយមូលហេតុនេះ វិធានផ្ទៃក្នុងចែងជាក់លាក់ពីបែបបទទាំងអស់នេះសម្រាប់តែសាលក្រមប៉ុណ្ណោះ តែមិនមែនសម្រាប់សេចក្តីសម្រេចផ្សេងៗទៀតឡើយ។ តុលាការកំពូលក៏បានរំឭកផងដែរថា ខុសពីសេចក្តីសម្រេចផ្សេងទៀត ការមិនចេញសាលក្រមជាលាយលក្ខណ៍អក្សរ គឺជាដើមចមនៃមោឃភាព[50]។

៣៦. បន្ទាប់មក តុលាការកំពូលក៏បានរំឭកពី "ការអនុវត្តជាប្រចាំនៅចំពោះមុខ អ.វ.ត.ក ថា សេចក្តីសម្រេចបើកផ្លូវតវ៉ាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ" ជាពិសេស ដោយសារភាពស្មុគស្មាញនៃបញ្ហាដែល អ.វ.ត.ក ត្រូវដោះស្រាយ៖

---

[49] មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[50] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E176/2/1/4** កំណត់សម្គាល់ជើងទំព័រលេខ ៧៨ (នៃកថាខណ្ឌ ២៥)៖ "តាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក សេចក្តីសម្រេចដែលមានកង្វះទម្រង់ជាលាយលក្ខណ៍អក្សរ លើកលែងតែសាលក្រម ពុំបានបណ្តាលអោយមានមោឃភាពឡើយ"។

"ការអនុវត្តនេះ ទោះបីជាមិនបានកំណត់ដោយច្បាប់ក៏ដោយ ក៏រួមចំណែកផងដែរដល់សច្ចភាពគតិយុត្តិ និងតម្លាភាពនៃនីតិវិធី ស្របតាមបទប្បញ្ញត្តិនៃវិធាន ២១ របស់វិធានផ្ទៃក្នុង ក៏ដូចជាអនុញ្ញាតឱ្យធ្វើបណ្ដឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងសេចក្ដីសម្រេច។ លើសពីនេះទៀត ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានថ្លែងនៅក្នុងឱកាសផ្សេងមួយទៀត កាតព្វកិច្ចផ្ដល់សំអាងហេតុគ្រប់គ្រាន់សម្រាប់រាល់សេចក្ដីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ប្រសូត្រចេញពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ តាមពិត សិទ្ធិទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុ គឺជាសិទ្ធិរបស់បុគ្គលពាក់ព័ន្ធក្នុងការឱ្យគេដឹងពីបុព្វហេតុរបស់គាត់"[51]។

៣៧. ហេតុផលមួយទៀត គឺអានុភាពនៃសាលក្រមទៅលើសេរីភាព ឬការជាប់ឃុំរបស់ជនជាប់ចោទ (វិធាន៩៩ នៃវិធានផ្ទៃក្នុង) ហើយដោយសារតែសាលក្រមបើកផ្លូវប្ដឹងសាទុក្ខភ្លាមៗ (វិធាន ១០៧(៤) និង ១០២(១) នៃវិធានផ្ទៃក្នុង) ទើបសាលក្រមមិនត្រូវបានចេញជាពីរដំណាក់កាល ដូចសេចក្ដីសម្រេចផ្សេងទៀត (វិធាន ១០១ នៃវិធានផ្ទៃក្នុង)។

៣៨. គឺនៅក្នុងកាលៈទេសៈខុសគ្នាខ្លាំងបែបនេះដែលអង្គជំនុំជម្រះនីមួយៗ នៃ អ.វ.ត.ក បានផ្ដល់ផ្នែកសម្រេចសេចក្ដីនៃដីកាសម្រេចមួយចំនួនរួចហើយ នៅដំណាក់កាលដំបូង (ដោយមាន ឬគ្មានសេចក្ដីសង្ខេបនៃសំអាងហេតុ) មុននឹងផ្ដល់សេចក្ដីពេញលេញនៃសំអាងហេតុ នៅដំណាក់កាលបន្ទាប់។ រាល់លើក វាជាសេចក្ដីសម្រេចដែលជះឥទ្ធិពលដោយផ្ទាល់លើកិច្ចដំណើរការនីតិវិធី (ផ្នែកសម្រេចសេចក្ដីដែលមានអាជ្ញាអស់ជំនុំ និងដែលបង្កព្យសនកម្មផ្នែកច្បាប់ ខុសពីសំអាងហេតុ) និងបិទផ្លូវប្ដឹងសាទុក្ខភ្លាមៗ ឬបិទផ្លូវប្ដឹងសាទុក្ខទាំងស្រុង[52]។ ដូច្នេះ ដើម្បីបកស្រាយសាលក្រមរបស់តុលាការកំពូល ការលើកពេលចេញសំអាងហេតុមិនបានប៉ះពាល់ដល់សិទ្ធិរបស់ភាគីទេ ពីព្រោះចំណាត់ការនីតិវិធីនីមួយៗ

---

[51] សេចក្ដីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E176/2/1/4** កថាខណ្ឌ ២៥ និងកំណត់សម្គាល់ជើងទំព័រលេខ ៧៨។

[52] សូមមើលឧទាហរណ៍លម្អិត និងឯកសារយោងនៅក្នុងបណ្ដឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1** កថាខណ្ឌ ៤០-៤៣។ សូមមើលផងដែរចំណុចទាក់ទងនឹងនិយមន័យ និងអានុភាពនៃផ្នែកសម្រេចសេចក្ដីការឆ្លើយតបរបស់លោក ខៀវ សំផន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E463/1/2/1** កថាខណ្ឌ ១៨-២២។

ដែលត្រូវធ្វើ មិនអាស្រ័យទៅលើការជូនដំណឹងភ្លាមៗពីសំអាងហេតុឡើយ ដោយឈរលើមូលដ្ឋានច្បាប់[53]។

៣៩. ដូច្នេះ ប្រាកដណាស់ វាមិនមែនជាករណីនៃសាលក្រម ឬដីកាដំណោះស្រាយ ដែលបញ្ចប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ហើយអាចប្តឹងឧទ្ធរណ៍បានភ្លាមៗនោះទេ[54]។ ជាក់ស្តែង អង្គបុរេជំនុំជម្រះបានរំឭក នៅក្នុងសំណុំរឿង ០០៤/១ ដោយប្រកាសជាអត្តនោម័តិថា ការចេញសំអាងហេតុនៅពេលក្រោយ គឺជា “នីតិវិធីដែលមិនអាចប្រើសម្រាប់ដីកាដំណោះស្រាយ” ជា “ដំណើរការនីតិវិធីដែលបញ្ចប់ការស៊ើបអង្កេតជាផ្លូវការ”។ អង្គបុរេបានរំឭកផងដែរថា សហចៅក្រមស៊ើបអង្កេតបានដកខ្លួនភ្លាមៗពីសំណុំរឿងនេះ បន្ទាប់ពីបានចេញផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយរបស់ខ្លួន[55]។

៤០. ដូច្នេះ សារៈសំខាន់នៃសេចក្តីសម្រេចលើពិរុទ្ធភាព ឬអពិរុទ្ធភាពរបស់ជនជាប់ចោទ គឺស្ថិតត្រង់ថាចៅក្រមមិនអាចគេចវេសបានឡើយពីបែបបទ ដែលត្រូវបានអនុម័តជាពិសេសដោយអ្នកធ្វើច្បាប់។

### ១.២. នៅ អ.វ.ត.ក ក៏ដូចនៅកន្លែងផ្សេងទៀតដែរ ចៅក្រមត្រូវគោរព និងអនុវត្តច្បាប់

៤១. មាត្រា ១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បញ្ញត្តថា៖

---

[53] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **F2/10/3** ទំព័រ ៤ កំណែចុងក្រោយ។ សំណៅដើមជាភាសាអង់គ្លេសមានភាពច្បាស់លាស់ជាងការបកប្រែជាភាសាបារាំង (សូមមើលទំព័រ ៣ កំណែចុងក្រោយ)។

[54] វិធាន៦៧(៥) នៃវិធានផ្ទៃក្នុង៖ “សហព្រះរាជអាជ្ញា ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានជូនដំណឹងជាបន្ទាន់អំពីការចេញដីកាដំណោះស្រាយនេះ និងទទួលបានច្បាប់ចម្លងនៃដីកានេះនៅពេលបន្ទាប់។ ដីកាដំណោះស្រាយនេះបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤”។

[55] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ សំណុំរឿង ០០៤/០១ ឯកសារ **D308/3/1/20** កថាខណ្ឌ ៣៣។

"ការជម្រះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្ដី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។"

៤២. ច្បាប់ស្ដីពី អ.វ.ត.ក ចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៣៣ ថ្មី ថា៖

"អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី [...]។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៤៣. អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវតែគោរពនីតិវិធី និងបែបបទនានាដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង "ក្នុងគោលបំណងសង្ខេបនីតិវិធីកម្ពុជាដែលអនុវត្តចំពោះការជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក" ក៏ដូចជាមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[56]។

៤៤. តាមបទប្បញ្ញត្តិនៃមាត្រា ១៤-១ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តុលាការទទួលបន្ទុកវិនិច្ឆ័យលើគុណសម្បត្តិនៃបទចោទព្រហ្មទណ្ឌ ត្រូវ "បង្កើតឡើងដោយច្បាប់"។ តុលាការសិទ្ធិមនុស្សអឺរ៉ុបរំឭកថា ពាក្យពេចន៍នេះដែលមានចែងផងដែរក្នុងមាត្រា ៦-១ នៃអនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន រំលេចអំពីគោលការណ៍នីតិរដ្ឋ[57]។ យោង

---

[56] វិធានផ្ទៃក្នុង បុព្វកថា ទំព័រ ៦ វិសោធនកម្មលើកទី ៥ និង វិសោធនកម្មចុងក្រោយ។

[57] សាលដីកា *Kontalexis ទល់នឹងប្រទេសក្រិក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ កថាខណ្ឌ ៣៨។ សាលដីកា *Pandjikidzé និងអ្នកផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ១០៣។ សាលដីកា *Gorguiladzé ទល់នឹងប្រទេសហ្សកហ្ស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩

តាមកតិកាសញ្ញាដដែល ឃ្លាដែល "បង្កើតឡើងដោយច្បាប់" មិនត្រឹមតែទាក់ទងនឹងមូលដ្ឋានច្បាប់នៃអត្ថិភាពរបស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែក៏មានទាក់ទងផងដែរនឹងការគោរពរបស់តុលាការចំពោះវិធានជាក់លាក់ដែលគ្រប់គ្រងតុលាការនោះផងដែរ[58]។

៤៥. ដោយវិធានទាំងនេះអាចមានលក្ខណៈខុសគ្នាពីតុលាការមួយទៅតុលាការមួយទៀត ចៅក្រមត្រូវគោរពវិធានរបស់តុលាការណាដែលខ្លួនកំពុងបំពេញមុខងារ។

៤៦. ពាក់ព័ន្ធនឹងទម្រង់នៃសាលក្រម បទប្បញ្ញត្តិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិខ្លះ អនុញ្ញាតឱ្យចៅក្រមសាលាដំបូងផ្តល់សំអាងហេតុសាលក្រមរបស់ខ្លួននៅដំណាក់កាលទីពីរ ខណៈដែលតុលាការផ្សេងទៀតមិនអនុញ្ញាតបែបនេះទេ។ បើក្នុងករណីដូចនេះ ក៏ដូចជានៅចំពោះមុខយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ បទប្បញ្ញត្តិចែងថា ចំណុចចាប់ផ្តើមនៃរយៈពេលបណ្តឹងសាទុក្ខចាប់ផ្តើមគិតពីថ្ងៃដាក់សំអាងហេតុជាលាយលក្ខណ៍អក្សរ[59]។ ផ្ទុយទៅវិញ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ និងនៅ

---

កថាខណ្ឌ ៦៧។ សាលដីកា *Lavents ទល់នឹងប្រទេសឡេតតូនី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១១៤។

[58] សាលដីកា *Pandjikidzé និងអ្នកផ្សេងទៀត ទល់នឹងប្រទេសហ្សកហ្ស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ១០៥។ សាលដីកា *Gorguilazé ទល់នឹងប្រទេសហ្សកហ្ស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ៦៩។ សាលដីកា *Sokurenko* និង *Strygun ទល់នឹងប្រទេសអ៊ុយក្រែន* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ២៤។ ជាឧទាហរណ៍ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានវិនិច្ឆ័យថា មានការរំលោភលើសិទ្ធិអ្នកប្តឹង នៅក្នុងតុលាការដែលត្រូវបានបង្កើតឡើងតាមច្បាប់ ដោយសារតែមានភាពខ្វះខាតជាក់ស្តែង នៅក្នុងបទបញ្ញត្តិជាតិសមស្របដែលទាមទារឱ្យកំណត់ហេតុសវនាការកំណត់ពីហេតុផលដែលចៅក្រមមិនអាចចូលជំនុំជម្រះបាន និងត្រូវបានជំនួសដោយចៅក្រមជំនួស នៅថ្ងៃបើកសវនាការ។ តុលាការក៏បានលើកឡើងផងដែរថាការមិនមានសេចក្តីចង្អុលបង្ហាញលម្អិតនៅក្នុងហេតុផលអវត្តមាន វាគ្រប់គ្រាន់ក្នុងការបង្កើតជាការសង្ស័យលើតម្លាភាពនៃនីតិវិធីក្នុងការជំនួសចៅក្រម និងភាពពិតជាក់ស្តែងនៃហេតុផលរបស់ខ្លួន៖ សាលដីកា *Kontalexis ទល់នឹងប្រទេសក្រិក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ កថាខណ្ឌ ៤២-៤៤។

[59] វិធាននីតិវិធី និងភស្តុតាងតុលាការនៃយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា ១២២.គ ("សាលក្រមត្រូវបានអនុម័តដោយសម្លេងភាគច្រើន និងមានសំអាងហេតុជាលាយលក្សណ៍អក្សរ នៅក្នុងចិរវេលាដ៏ឆាប់បំផុតតាមតែអាចធ្វើទៅបាន")។ មាត្រា ១៣៣ ("ភាគីណាមួយដែលមានបំណងដាក់ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រម ក្នុងរយៈពេលសាមសិបថ្ងៃក្រោយពេលដាក់សាលក្រមជាលាយលក្សណ៍អក្សរ ត្រូវដាក់លិខិតបណ្តឹងឧទ្ធរណ៍, គឺជាឯកសារដែលបង្ហាញពីមធ្យោបាយនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

អ.វ.ត.ក បទប្បញ្ញត្តិមិនផ្តល់ឆន្ទានុសិទ្ធិដល់ចៅក្រមសាលាដំបូងដែលត្រូវបង្ហាញសំអាងហេតុជាលាយលក្ខណ៍អក្សរ ស្របពេលគ្នាជាមួយនឹងសេចក្តីសម្រេច[60] នោះទេ។ បទប្បញ្ញត្តិរបស់តុលាការពិសេសរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសលីបង់ ត្រូវបានធ្វើវិសោធនកម្មក្នុងន័យនេះ[61] កាលពីពេលថ្មីៗកន្លងទៅ។

៤៧. អ្នកតាក់តែងច្បាប់ជាអ្នកចាប់យកជម្រើសនេះ តែមិនមែនចៅក្រមទេ។ ប្រសិនបើអ្នកតាក់តែងច្បាប់របស់ អ.វ.ត.ក ចង់យកគំរូតាមតុលាការតាមអាណត្តិនៅពេលអនុម័តវិធានផ្ទៃក្នុង ឬដោយធ្វើវិសោធនកម្មវិធានផ្ទៃក្នុងនៅពេលក្រោយមក គាត់គួរណាបានធ្វើវានៅពេលនោះ[62]។ ខណៈពេលដែលគាត់បានធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ដើម្បីអនុញ្ញាតឱ្យតុលាការកំពូលចេញសេចក្តីជូនដំណឹងពេញ

---

[60] លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា ៧៤.៥ (“សេចក្តីសម្រេចត្រូវសរសេរជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចត្រូវមានបទបង្ហាញពេញលេញ និងមានសំអាងហេតុនៃសេចក្សីសង្កេតនៃអង្គជំនុំជម្រះសាលាដំបូងស្តីអំពីភ័ស្តុតាង និងសេចក្តីសន្និដ្ឋាន។ សេចក្តីសម្រេចត្រូវចេញប្រកាសតែមួយលើកគត់។ បើមិនមានការយល់ព្រមជាឯកច្ឆ័ន្ទទេ សេចក្តីសម្រេចនោះត្រូវមានឆ្លងការពិនិត្យពីសម្លេងភាគច្រើន និង សម្លេងភាគតិច។ អំណាននៃសេចក្តីសម្រេច ឬសេចក្តីសង្ខេបនៃសេចក្តីសម្រេចត្រូវអានជាសាធារណៈ”។)។ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក វិធាន ១០១។

[61] វិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃតុលាការពិសេសសម្រាប់លីបង់ ធ្វើវិសោធនកម្មនៅ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ មាត្រា ១៦៨.កៈ “សាលក្រមត្រូវអនុម័តដោយសម្លេងភាគច្រើននៃចៅក្រម។ សាលក្រមនោះមានអមទៅដោយសំអាងហេតុជាលាយលក្ខណ៍អក្សរ។ រាល់ការផ្តល់យោបល់ដោយឡែក ឬយោបល់ជំទាស់ ត្រូវដាក់ភ្ជាប់ជាមួយនឹងសំអាងហេតុនោះ”។ កំណែលើកមុននៃមាត្រានេះ មានដូចតទៅៈ “សាលក្រមត្រូវអនុម័តដោយសម្លេងភាគច្រើននៃចៅក្រម។សាលក្រមនោះមានអម ឬភ្ជាប់តាមក្រោយដោយសំអាងហេតុជាលាយលក្ខណ៍អក្សរ ដែលត្រូវតាក់តែងឡើងយ៉ាងឆាប់បំផុតតាមតែអាចធ្វើទៅបាន។ រាល់ការផ្តល់យោបល់ដោយឡែក ឬយោបល់ជំទាស់ ត្រូវដាក់ភ្ជាប់ជាមួយនឹងសំអាងហេតុនោះផងដែរ”។

[62] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក ត្រូវបានអនុម័ត នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ខណៈដែលវិធានផ្ទៃក្នុងដែលបានអនុម័តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិមានតាំងពីឆ្នាំ១៩៩៥មកម៉្លេះៈ <u>វិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី</u> មាត្រា៩៨ ស្ទួនពីរ (ក) និង (គ) បញ្ចូលក្នុងនាមនៃមាត្រា ៨៨ (ក) និង (គ) ដែលបានធ្វើវិសោធនកម្មនៅ ថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៥។ <u>វិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា</u> មាត្រា៩៨ ស្ទួនពីរ (ក) និង (គ) បានបង្ហាញកំណែទី១នៅ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៥។ <u>វិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ</u> មាត្រា ១២២ (ក) និង (គ) មានចាប់ពីក្នុងកំណែទី១ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២។ <u>វិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់តុលាការពិសេសសម្រាប់លីបង់</u> មាត្រា ១៦៨ (ក) និង (ខ) មានវត្តមានតាំងពីកំណែចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ រហូតដល់វិសោធនកម្មចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩។

លេញពីសំអាងហេតុនៅពេលក្រោយ ក្នុងករណីបណ្តឹងសាទុក្ខភ្លាមៗ[63] ក៏ប៉ុន្តែ គាត់បែរជាមិនបានធ្វើបែបនេះ ចំពោះសាលក្រម។ ខណៈពេលដែលគាត់បានធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ដើម្បីផ្តល់សិទ្ធិឱ្យអង្គជំនុំជម្រះបង្រួម ឬបំបែកកិច្ចដំណើរការនីតិវិធី[64] តែគាត់មិនដែលអនុញ្ញាតឱ្យបង្រួម ឬបំបែកសាលក្រមឡើយ។

៤៨. ផ្ទុយទៅវិញ រហូតមកទល់ពេលនេះ អ្នកតាក់តែងច្បាប់របស់ អ.វ.ត.ក បានសម្រេចបង្គាប់អង្គជំនុំជម្រះឱ្យចេញសាលក្រមដែលមានសំអាងហេតុជាលាយលក្ខណ៍អក្សរ "យ៉ាងយូរបំផុត" នៅថ្ងៃប្រកាសសាលក្រម និងចាប់ផ្តើមកំណត់ពេលវេលាសម្រាប់បណ្តឹងសាទុក្ខរហូតដល់ពេលប្រកាសសាលក្រម ក្នុងករណីជនជាប់ចោទវត្តមាន។

៤៩. កាលពីពេលថ្មីៗនេះ តុលាការកំពូលបានលើកយកសុភាសិតឡាតាំងពីរ ដែលបានតាក់តែងឡើងក្នុងគោលបំណងធ្វើសេចក្តីព្រាងច្បាប់ ព្រមទាំងបកស្រាយច្បាប់ និងសកម្មភាពនានា៖

> "Expressio unis is exclusio alteus"៖ ការបញ្ចេញមតិរបស់បុគ្គលម្នាក់ គឺជាការបដិសេធការបញ្ចេញមតិរបស់បុគ្គលផ្សេងទៀត ឬការលើកឡើងពីអ្វីមួយជាក់លាក់ គឺជាការទាត់ចោលនូវអ្វីដែលមិនបានលើកឡើង។ "Expressum facit cessare tacitum"៖ អ្វីដែលពោលចេញញ៉ាំងឱ្យអ្វីដែលមិនពោលចេញនៅស្ងាត់ស្ងៀម ឬអ្វីដែលពោលចេញច្បាស់លាស់ទាត់ចោលអ្វីដែលពោលមិនចំៗ[65]។

---

[63] វិធាន ១០៨(៤) ស្ទួន នៃវិធានផ្ទៃក្នុង ដែលបានធ្វើវិសោធនកម្មក្នុងន័យនេះ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ ២០១១។

[64] វិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង (ការបំបែកកិច្ចដំណើរការនីតិវិធី) អនុម័តនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១។ វិធាន៨៩ ស្ទួនបី នៃវិធានផ្ទៃក្នុង (ការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ) អនុម័តនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[65] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ **F46/2/4/2** កំណត់សម្គាល់ជើងទំព័រលេខ ៧៣ (នៃកថាខណ្ឌ ៣៧)។

៥០. យោងតាមគោលការណ៍នៃការបែងចែកអំណាច អង្គជំនុំជម្រះត្រូវតែគោរពជម្រើសជាផ្លូវការ និង ច្បាស់លាស់របស់អ្នកតាក់តែងច្បាប់នៃ អ.វ.ត.ក។ អង្គជំនុំជម្រះមាន ជម្រើសស្របច្បាប់តែមួយគត់ គឺស្នើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ស្របតាមការអនុញ្ញាតរបស់វិធាន ៣[66]។

## ១.៣. ការផ្តន្ទាទោសខុសច្បាប់ និងតាមទំនើងចិត្ត លើរូប ខៀវ សំផន

៥១. យោងតាមច្បាប់ជាធរមាន អង្គជំនុំជម្រះមានកាតព្វកិច្ចចេញសាលក្រមជាលាយលក្ខណ៍អក្សរ នៅថ្ងៃ ប្រកាសសាលក្រមតែម្តង។ សាលក្រមនេះ ត្រូវមានសំអាងហេតុ និងចុះហត្ថលេខា "យ៉ាងយូរបំផុត ត្រឹម" ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ ច្បាប់ចម្លងនៃសាលក្រមត្រូវប្រគល់ជូនភាគី និងផ្សព្វផ្សាយ នៅ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

៥២. អង្គជំនុំជម្រះមិនមានអំណាចឆន្ទានុសិទ្ធិ ឬអំណាចជាប់ខ្លួនណាមួយ ដើម្បីរំលោភវិធានផ្ទៃក្នុងឡើយ។ តាមរយៈទង្វើផ្ទុយពីឆន្ទៈរបស់អ្នកតាក់តែងច្បាប់របស់ អ.វ.ត.ក អង្គជំនុំជម្រះបានប្រព្រឹត្តខុសច្បាប់ និងហួសដែនអំណាចរបស់ខ្លួន។ សាលក្រមរបស់អង្គជំនុំជម្រះគ្មានមូលដ្ឋានច្បាប់។ ដូច្នេះ សាលក្រម នេះគ្មានតម្លៃគតិយុត្តិឡើយ។ វាគ្រាន់តែជាសាលក្រមដែលគ្មានសុពលភាព និងគ្មានសារៈសំខាន់។ ពិរុទ្ធ ភាពរបស់ ខៀវ សំផន មិនត្រូវបានរកឃើញដោយស្របច្បាប់ទេ។

៥៣. លើសពីនេះទៀត អង្គជំនុំជម្រះមិនធ្លាប់បានព្យាយាមពន្យល់ និងបង្ហាញអំពីភាពត្រឹមត្រូវនៃវិធីសាស្ត្រ របស់ខ្លួនឡើយ។ សេចក្តីសម្រេចលើកលែងការចោទប្រកាន់ប្រហែលជាអាចពន្យល់ពីរឿងនេះ (និង ច្រើនជាងនេះទៀត) ប៉ុន្តែវាមិនមានការពន្យល់អ្វីឡើយ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានប្រព្រឹត្ត តាមទំនើងចិត្តទាំងស្រុង។

---

[66] វិធាន ៣(១) នៃវិធានផ្ទៃក្នុង៖ "សំណើសុំធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងនេះ អាចត្រូវដាក់ជូនគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃ ក្នុងដោយសហព្រះរាជអាជ្ញាណាម្នាក់ សហចៅក្រមស៊ើបអង្កេតណាម្នាក់ [...]"។

៥៤. អង្គជំនុំជម្រះបានបំផ្លាញទំនុកចិត្តបុគ្គលក្នុងរឿងក្តី និងសាធារណជន ដែលអាចមានចំពោះខ្លួន ក៏ដូចជាស្ថាប័ន អ.វ.ត.ក ទាំងមូល។ ជាក់ស្តែង វិធីសាស្ត្ររបស់អង្គជំនុំជម្រះបង្ហាញឱ្យឃើញថា ចៅក្រមដែលអាចគេចវេសពីវិធាននីតិវិធីមូលដ្ឋាន ទទួលបានទំនុកចិត្តមុតមាំថាមានសមត្ថភាពគេចវេសពីវិធានច្បាប់ និងវិធានគ្រប់គ្រងភ័ស្តុតាង ហើយចៅក្រមអាចធ្វើអ្វីគ្រប់យ៉ាងបាននៅ អ.វ.ត.ក ដែលគេសន្មតថាជាទីអធ្ឍរិយៈនៃច្បាប់។

៥៥. បន្ថែមពីលើការធ្វើឱ្យខូចដល់ធម្មនុញ្ញភាពរបស់ អ.វ.ត.ក ការប្រព្រឹត្តិកំហុសរបស់អង្គជំនុំជម្រះ បានធ្វើឱ្យប៉ះពាល់ដល់សុពលភាពរបស់សាលក្រម និងបានរំលោភសិទ្ធិទទួលបានតុលាការមួយដែលបង្កើតឡើងដោយច្បាប់ សច្ចភាពគតិយុត្តិ និងនីតិវិធី តម្លាភាពនៃនីតិវិធី រួមទាំង សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ។

៥៦. ការចេញសំអាងហេតុសាលក្រមនៅពេលក្រោយ មិនសម្រាលកំហុសនេះទេ។ ផ្ទុយទៅវិញ វាកាន់តែធ្វើឱ្យកំហុសកាន់តែធ្ងន់ធ្ងរថែមទៀត។

**២. វិការៈមិនអាចលុបលាងបានដោយការចេញសំអាងហេតុនៅពេលក្រោយ**

**២.១. សំអាងហេតុចេញនៅពេលក្រោយ មិនអាចធ្វើឱ្យសាលក្រមដែលប្រកាសបែបប្រតិសកម្មមានសុពលភាពឡើយ**

៥៧. ការចេញសំអាងហេតុនៅពេលក្រោយសម្រាប់គាំទ្រដល់សាលក្រម មិនអាចផ្តល់សុពលភាពដល់ដីកាសម្រេចដែលមានមោឃភាពផ្ទាល់បានទេ។ សំអាងហេតុនេះកាន់តែជួយពង្រឹងការរំលោភបទប្បញ្ញត្តិច្បាប់ផ្លូវការនៃវិធានផ្ទៃក្នុងថែមទៀតតែប៉ុណ្ណោះ។

៥៨. លើសពីនេះទៀត ទោះបីបាន ឬមិនបានផ្តល់ក្នុងពេលតែមួយជាមួយផ្នែកសម្រេចសេចក្តីក៏ដោយ ក៏សំអាងហេតុនៃសេចក្តីសម្រេចមួយមិនមានអានុភាពលើសេចក្តីសម្រេចនេះដែរ[67]។ តាមពិត អានុភាពនៃសេចក្តីសម្រេចស្ថិតនៅលើផ្នែកសម្រេចសេចក្តីតែមួយគត់ ដែលចងភ្ជាប់ជាមួយអាជ្ញាអស់ជំនុំ តែមិនស្ថិតនៅលើផ្នែកសំអាងហេតុ ដែលជាការបង្ហាញហេតុផលសម្រាប់ឱ្យចៅក្រមសម្រេចចិត្តក្នុងន័យមួយ ឬន័យផ្សេងទៀតនោះទេ។

៥៩. លើសពីនេះទៀត ផ្នែកសំអាងហេតុមិនអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់អតីតកាល ឬលុបចោលរយៈពេលបន្ទាប់ពីការប្រកាសសាលក្រមឡើយ។ ក្នុងអំឡុងពេលនោះ ដែលនៅតែមិនទាន់បានកំណត់រហូតដល់ថ្ងៃជូនដំណឹងពីសំអាងហេតុដែលបានផ្តល់រយៈពេលបួនខែកន្លះ (១៣២ ថ្ងៃ) ក្រោយមក វាជាដំណាក់កាលដែលគ្របដណ្តប់ទៅដោយអសច្ចភាពគតិយុត្តិ (ឬនត្ថិភាពគតិយុត្តិ) ធ្ងន់ធ្ងរបំផុត។

៦០. ក្នុងកំឡុងពេលនោះ កាលបរិច្ឆេទនៃការចេញសំអាងហេតុ (ដែលត្រូវផ្តល់ "ក្នុងពេលសមស្រប")[68] មិនទាន់ត្រូវបានកំណត់ សាលក្រមមិនទាន់ត្រូវបានផ្តល់យុត្តិកម្ម ហើយការប្តឹងឧបាស្រ័យមិនអាចធ្វើបានប្រឆាំងនឹងការប្រកាសជាសាធារណៈពីពិរុទ្ធភាព និងការផ្តន្ទាទោស។

៦១. ពេលតុលាការកំពូលសម្រេចបដិសេធបណ្តឹងសាទុក្ខបន្ទាន់របស់មេធាវីការពារក្តី ចំពោះបញ្ហាខាងលើ សេចក្តីសម្រេចរបស់តុលាការកំពូលបានចោទជាសំណួរច្រើនជាងចម្លើយ។ ដំបូង តុលាការកំពូលបានលើកឡើងថា នេះជាបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសង្ខេបនៃសំអាងហេតុដែលបានអាននៅឯសវនាការ (ដែលត្រូវបានបញ្ជាក់តាមរយៈការរំឭកពីនីតិវិធីនៃសេចក្តីសម្រេចថ្មីៗរបស់ខ្លួន)[69] ខណៈដែលវា

---

[67] វចនានុក្រមវាក្យស័ព្ទច្បាប់ ដឹកនាំតាក់តែងដោយលោក Rémy CABRILLAC គ្រឹះស្ថានរៀបរៀង LexisNexis Litec បោះពុម្ពលើកទី៣ (ឆ្នាំ២០០៨) ទំព័រ ១៤៩ ឯកសារ **E463/1/2/1.1.4**។ រាល់សេចក្តីសម្រេចដែលបានធ្វើឡើងជាពីរដំណាក់កាល នៅ អ.វ.ត.ក បានបញ្ចេញឥទ្ធិពលរបស់ខ្លួនចាប់តាំងពីផ្នែកសម្រេចសេចក្តីម្ល៉េះ៖ សូមមើលខាងលើ កថាខណ្ឌ ៣៨។

[68] ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង០០២/០២ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **E462** ទំព័រ ២។ ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/5** ថ្ងៃទី២៩ ខែមករា មុនម៉ោង 09.35.46។

[69] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **E463/1/3** ចំណងជើង និងកថាខណ្ឌ ៦, ១២, ១៨ ។ សូមមើលផងដែរ សូមមើលផងដែរ៖ សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ **F46/2/4/2**

ជាបណ្តឹងសាទុក្ខយ៉ាងច្បាស់ក្រឡែតប្រឆាំងនឹងផ្នែកសម្រេចសេចក្តីដែលបានប្រកាស[70]។ បន្ទាប់មក តុលាការកំពូលបានថ្លែងយ៉ាងសាមញ្ញថា អង្គជំនុំជម្រះបានបញ្ជាក់ថា សំអាងហេតុពេញលេញនឹងត្រូវជូនដំណឹងនៅក្នុងពេលវេលាសមស្រប ហើយថា ពេលវេលាសម្រាប់ការប្តឹងសាទុក្ខនឹងចាប់ផ្តើមពីការជូនដំណឹងនោះ[71]។ តុលាការកំពូលមិនបាននិយាយអ្វីទាំងអស់ពីការអានវិធានផ្ទៃក្នុងខុសដោយអង្គជំនុំជម្រះ ដែលវិធាននេះតម្រូវឱ្យអង្គជំនុំជម្រះចេញសេចក្តីពេញលេញនៃសំអាងហេតុ "យ៉ាងយូរត្រឹម" ថ្ងៃប្រកាស ហើយដែលកំណត់ចំណុចចាប់ផ្តើមនៃកាលកំណត់នៅថ្ងៃនោះ នៅពេលជនជាប់ចោទវត្តមាន និងនៅថ្ងៃជូនដំណឹងដល់ជនជាប់ចោទ នៅពេលគាត់អវត្តមាន[72]។ តុលាការកំពូលក៏មិនបានថ្លែងអ្វីទាំងអស់អំពីការដែលអង្គជំនុំជម្រះមិនមានយុត្តាធិការ ក្នុងការពន្យារពេលការចាប់ផ្តើមនៃរយៈពេលបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចណាមួយដែរ[73]។ តុលាការកំពូលតែមួយគត់អាចធ្វើរឿងនេះបាន តែតុលាការកំពូលមិនបានធ្វើអ្វីសោះ[74]។

---

កថាខណ្ឌ ២ (នៅក្នុងនោះមេធាវី ការពារក្តីប្រហែលជាបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យ "ធ្វើមោឃភាពលើសេចក្តីសង្ខេបដែលបានដាក់នៅថ្ងៃទី១៦ ខែវិច្ឆិកា ដោយសារតែមានវិការៈទម្រង់")។ សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៦ ខែមករា ឆ្នាំ ២០២០ ឯកសារ **F51/3** កថាខណ្ឌ ៣ (នៅក្នុងនោះមេធាវី ការពារក្តីប្រហែលជាបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យ "លុបចោលសេចក្តីសង្ខេបនៃសាលក្រម ដែលបានប្រកាស នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយសារតែមានវិការៈទម្រង់")។

[70] ជាពិសេស៖ បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1** កថាខណ្ឌ ២-៣ (និងកំណត់សម្គាល់ជើងទំព័រលេខ ២ ដែលយោងតែទៅលើផ្នែកសម្រេចសេចក្តីប៉ុណ្ណោះ) កថាខណ្ឌ ១១, ៣៧។ ចម្លើយតបរបស់លោកខៀវ សំផន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E463/1/2/1** កថាខណ្ឌ ១៧-២២។ ខណៈពេលទាំងពីរលើកដែលក្រុមមេធាវីបានរំឭកដល់សេចក្តីសង្ខេប។ ក្រុមមេធាវីបានរំឭកថាសេចក្តីសង្ខេបនោះ មិនមានតម្លៃគតិយុត្តិទេ ដោយហេតុថាវាមិនបង្ហាញពីការពិត វាមិនមានអានុភាពឡើយ (បណ្តឹងសាទុក្ខភ្លាមៗ ឯកសារ **E463/1** កថាខណ្ឌ ៦១។ ចម្លើយតប ឯកសារ **E463/1/2/1** កថាខណ្ឌ ៥២)។

[71] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **E463/1/3** កថាខណ្ឌ ១១-១២, ១៤-១៥, ១៨។

[72] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1** កថាខណ្ឌ ៦-៧, ១៥-១៦, ៤៩។ ចម្លើយតបរបស់លោក ខៀវ សំផន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E463/1/2/1** កថាខណ្ឌ ១២។

[73] ចម្លើយតបរបស់លោក ខៀវ សំផន ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E463/1/2/1** កថាខណ្ឌ ៤០-៤៨។ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F39/1.1** កថាខណ្ឌ ១៣ និង កំណត់សម្គាល់ជើងទំព័រលេខ១៨។

[74] តុលាការកំពូលមិនបានប្រតិកម្មអ្វីសោះឡើយចំពោះសំណើស្តីពីការលើកពេលចាប់ផ្តើមនៃការកំណត់ថិរវេលាបណ្តឹងសាទុក្ខ ដោយសុំរាប់ចាប់ពីពេលជូនដំណឹងសំអាងហេតុដែលក្រុមមេធាវីការពារក្តីបានដាក់ជូន៖ បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ចុះ

៦២. ដូច្នេះ វាហាក់ដូចជាតុលាការកំពូលបានពិចារណាថា រាល់ភាពអនាធិបតេយ្យនៃនីតិវិធីនេះ គឺជារឿងធម្មតា ហើយផ្នែកសម្រេចសេចក្តីដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ពុំមានតម្លៃ ឬអានុភាពផ្លូវច្បាប់សោះឡើយ ក្នុងករណីគ្មានសំអាងហេតុជាលាយលក្ខណ៍អក្សរ។ វាហាក់ដូចជាអ្វីដែលបានកើតឡើងនៅថ្ងៃនោះ មិនត្រូវបានយកជាបានការ។

៦៣. យ៉ាងណាក៏ដោយ ប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនទាំងអស់យល់ថា ខៀវ សំផន ត្រូវបានប្រកាសថាជាប់ពិរុទ្ធ និងត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ទោះបីគ្មានសេចក្តីពេញលេញនៃសំអាងហេតុជាលាយលក្ខណ៍អក្សរនៅថ្ងៃនោះក៏ដោយ[75]។

---

ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1** កថាខណ្ឌ ៧០-៧១ និង ៧៣។ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F39/1.1**, កថាខណ្ឌ ១១-១៥ និង ៥៥។

[75] គឺជាអ្វីដែលលោកខៀវ សំផនបានដាក់ពាក្យបណ្តឹង តែមិនមែនធ្វើបែបនោះតែម្នាក់ឯងឡើយ។ឧទាហរណ៍ សូមមើល៖ ការជំនុំជម្រះមួយទៀត៖ ការពិនិត្យទៅលើសំណុំរឿង ០០២/០២៖ ការជំនុំជម្រះលើកទីពីរចំពោះលោក នួន ជា និង លោក ខៀវ សំផន នៅ [អ.វ.ត.ក] ដោយ Caitlin McCaffrie និង Daniel Mattes សំណៅកែសម្រួល បោះពុម្ពផ្សាយនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ របាយការណ៍សម្រាប់ មជ្ឈមណ្ឌល WSD HANDA ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស និងយុត្តិធម៌ផ្ទៃក្នុង នៅ សាកលវិទ្យាល័យ Stanford និង មជ្ឈមណ្ឌល East-West (ទំព័រ ១៖ "ជារឿងគួរឱ្យខកចិត្តដែលថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចេញតែសាលក្រមសង្ខេបនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ អ.វ.ត.ក ត្រូវបានបង្កើតឡើងជាផ្នែកនៃស្ថាប័នមួយដែលដើរតួនាទីជាគំរូដល់ស្ថាប័នតុលាការកម្ពុជាដែលទន់ខ្សោយ ដែលជារឿយៗចេញតែសាលក្រមសង្ខេបដោយគ្មានសំអាងហេតុពេញលេញ។ [...] ឱកាសរបស់សាលាក្តីនេះ ក្នុងការបង្កើតជាកេរតំណែលពិតប្រាកដត្រូវរងភាពអាប់ឱន ដោយសារសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបែបនេះ"។ ទំព័រ ៣០៖ "នាពេលនេះ នៅចុងឆ្នាំ២០១៨ ទៅហើយ យើងនៅតែរង់ចាំសាលក្រមដែលមានសំអាងហេតុពេញលេញទៀត។ ជិតបួនឆ្នាំហើយ ក្រោយពេលចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ ការដែលចេញបានត្រឹមតែសាលក្រមសង្ខេបធ្វើឱ្យមនុស្សជាច្រើនមានការខកចិត្ត។ អ.វ.ត.ក ត្រូវបានបង្កើតឡើងនៅកម្ពុជា មួយផ្នែកគឺដើម្បីបង្កើនសមត្ថភាពតុលាការជាតិ ដែលនៅតែមានលំដាប់ទាបនៅក្នុងមាត្រដ្ឋានឯករាជភាពសាកល ហើយដែលល្បីឈ្មោះខាងចេញសាលក្រមសង្ខេប ដោយគ្មានសំអាងហេតុពេញលេញ។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវចេញសាលក្រមដែលមានសំអាងហេតុពេញលេញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ប្រជាជនកម្ពុជាស័ក្តិសមនឹងដឹងឮអំពីសំអាងហេតុពេញលេញចំពោះការផ្តន្ទាទោសនានា។ ពួកគេបានរង់ចាំជាយូរឆ្នាំណាស់មកហើយ")។

៦៤. ក្នុងរយៈពេល១៣២ថ្ងៃក្រោយមក ខៀវ សំផន រងទម្ងន់នៃការផ្តន្ទាទោសលើរូបគាត់ ដោយមិនដឹងមូលហេតុ ដោយមិនអាចពិនិត្យ និងមិនបានដាក់ឱ្យតុលាការជាន់ខ្ពស់ណាមួយពិនិត្យឱ្យបានស៊ីជម្រៅលើការផ្តន្ទាទោសនោះ[76]។ សូម្បីតែបណ្តឹងសាទុក្ខបន្ទាន់របស់គាត់លើទិដ្ឋភាពផ្លូវការ និងនីតិវិធី ក៏មិនអាចត្រូវបានពិនិត្យឱ្យបានស៊ីជម្រៅដែរ ដែលបង្កការរំលោភយ៉ាងពិតប្រាកដលើសិទ្ធិរបស់គាត់ក្នុងការឱ្យគេទទួលដឹងឮពីរឿងក្តីរបស់គាត់ និងសិទ្ធិរបស់គាត់ក្នុងការការពារក្តីប្រកបដោយប្រសិទ្ធភាព។

៦៥. ការជូនដំណឹងអំពីសំអាងហេតុដែលគ្មានអានុភាពប្រតិសកម្ម មិនផ្លាស់ប្តូរអ្វីទាំងអស់សម្រាប់រយៈពេល១៣២ថ្ងៃ នៃអសច្ចភាព ឬនត្ថិភាពគតិយុត្តិ ដែលជាការបន្ថែមភាពយឺតយ៉ាវមិនសមហេតុផលក្នុងរយៈពេលនៃនីតិវិធី។ ថ្វីបើឥឡូវនេះ តុលាការកំពូលកំពុងអន្តរាគមន តុលាការកំពូលហាក់ដូចជាត្រៀមខ្លួនដើម្បីស្តាប់ ខៀវ សំផន ក៏ប៉ុន្តែ ជាក់ស្តែង ការច្របូកច្របល់នីតិវិធី និងច្បាប់ដែលបានបង្កឡើងដោយអង្គជំនុំជម្រះ នៅតែមិនទាន់ត្រូវបានដោះស្រាយ។ ការច្របូកច្របល់នេះកាន់តែធ្ងន់ធ្ងរថែមទៀតដោយសារសំអាងហេតុផ្ទាល់តែម្តង។

## ២.២. សំអាងហេតុចេញនៅពេលក្រោយ គ្មានសុពលភាពទាល់តែសោះ

---

[76] ដោយអនុលោមទៅតាមគណៈកម្មាធិការសិទ្ធិមនុស្ស សិទ្ធិក្នុងការទទួលបានបណ្តឹងឧទ្ធរណ៍ ត្រូវបានកំណត់ នៅក្នុងមាត្រា ១៤.៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាសិទ្ធិ "ក្នុងការពិនិត្យមើលអង្គសេចក្តីនៃការដាក់ពិរុទ្ធភាព ឬការប្រកាសទោស ដោយផ្ទៀងផ្ទាត់មើលថាតើធាតុផ្សំភ័ស្តុតាងគ្រប់គ្រាន់ដែរឬទេ ហើយតើវាស្របទៅតាមបទបញ្ញត្តិនីតិបញ្ញត្តិតាមការអនុវត្តដែរឬទេ" (*Bandajevsky ទល់នឹងប្រទេសបេឡារុស* ទំនាក់ទំនងលេខ 1100/2002 សេចក្តីសង្កេតអនុម័តដោយ គណៈកម្មាធិការសិទ្ធិមនុស្ស ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ១០.១៣)។ "ដើម្បីប្រតិបត្តិច្បាប់នេះ សាមីជនត្រូវមានក្នុងដៃនូវសាលក្រមជាលាយលក្ខណ៍អក្សរ ជាមួយនឹងសំអាងហេតុ នៃតុលាការដែលបានប្រកាសសាលក្រម" *(រឿងក្តី Van Hulst ទល់នឹងប្រទេសហុឡង់* ទំនាក់ទំនង លេខ 903/1999 សេចក្តីសង្កេតអនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ ៦.៤)។ គឺជាការពិនិត្យឡើងវិញដែល "ទាក់ទងនឹងនឹងទម្រង់ ឬទិដ្ឋភាពច្បាប់នៃសាលក្រមដែលមិនស្របទៅតាមការទាមទារចង់បាន នៅកថាខណ្ឌ ៥ នៃមាត្រា ១៤ នៃ[កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ]" *(រឿងក្តី Gómez Vázquez តទល់នឹងប្រទេសអេស្ប៉ាញ* ទំនាក់ទំនង n°701/1996 សេចក្តីសង្កេតដែលអនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០ កថាខណ្ឌ ១១.១)។

៦៦. មូលហេតុទីមួយ សំអាងហេតុសាលក្រមជាលាយលក្ខណ៍អក្សរដែលបានផ្តល់ក្រោយការប្រកាសសាលក្រម មិនមានចែងនៅក្នុងវិធានផ្ទៃក្នុងទេ។ ដូច្នេះ សំអាងហេតុនោះ មិនមែនជាកម្មវត្ថុនៃណ្តឹងឧបាស្រ័យណាមួយឡើយ ដែលខុសពីសាលក្រមអមដោយសំអាងហេតុជាលាយលក្ខណ៍អក្សរ និងហត្ថលេខា ដែលបានប្រកាសនៅថ្ងៃដដែល[77]។ ឯកសារបែបនេះដែលមិនស្របច្បាប់ នៅក្នុងក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក គ្មានសុពលភាពសោះឡើយ ជាពិសេស នៅពេលដែលអ្នកតាក់តែងច្បាប់ នៃ អ.វ.ត.ក បានបង្ហាញបំណងប្រាថ្នារបស់ខ្លួនយ៉ាងច្បាស់ និងជាក់ស្តែងថា បញ្ហាបែបនេះមិនគួរកើតមានឡើយ។

៦៧. ទីពីរ សំអាងហេតុបានមកពីការរំលោភអំណាចរបស់អង្គជំនុំជម្រះ ដែលលែងមានយុត្តាធិការក្នុងការតាក់តែង និងចេញសំអាងហេតុ ក្រោយថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០១៨។ ជាក់ស្តែង នៅថ្ងៃនោះ អង្គជំនុំជម្រះបានផ្តល់ផ្នែកសម្រេចសេចក្តីនៃសាលក្រមរបស់ខ្លួន និងសាលក្រមផ្ទាល់តែម្តង។ អង្គជំនុំជម្រះបានសម្រេចលើវិវាទចម្បងក្នុងចំណាត់ការរបស់ខ្លួន ហើយ តាមរបៀបនេះ អង្គជំនុំជម្រះបានធ្វើឱ្យអំណាចយុត្តាធិការរបស់ខ្លួនចុះខ្សោយ។ ផលប៉ះពាល់នៃការដកខ្លួនចេញរបស់ចៅក្រមពាក់ព័ន្ធនឹងសាលក្រម អាចបញ្ជាក់បានតាមរយៈសុភាសិតឡាតាំងថា៖ ក្រោយបញ្ចប់ភារកិច្ចជម្រះក្តីរបស់ខ្លួន ចៅក្រមលែងជាចៅក្រមទៀតហើយ។ គាត់បានដកខ្លួនពីសំណុំរឿងទាំងស្រុង (adage lata sententia, judex desinit esse judex)។

[77] សូមមើលខាងលើ កថាខណ្ឌ ៣២។ ចំណុចផ្តើមនៃថិរវេលាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម "ដែលបានប្រកាស" នៅក្នុងពេលជូនដំណឹងសាលក្រម នៅពេលដែលជនជាប់ចោទអវត្តមាន មិនមានផ្លាស់ប្តូរអ្វីឡើយ ពីព្រោះថាសាលក្រមត្រូវតែដាក់ជាមួយនឹងឯកសារលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា "យ៉ាងយូរបំផុត" នៅថ្ងៃប្រកាសសាលក្រម។ ម្យ៉ាងវិញទៀត នៅក្នុងវិធានផ្ទៃក្នុង គឺមិនសំដៅលើសាលក្រម "លាយលក្ខណ៍អក្សរ" ដូចនៅក្នុងយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនោះឡើយ៖ វិធាននីតិវិធី និងភ័ស្តុតាងតុលាការនៃយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា ១២២-គ ("សាលក្រមត្រូវបានអនុម័តដោយសម្លេងភាគច្រើន និងមានសំអាងហេតុជាលាយលក្ខណ៍អក្សរ ឱ្យបានមុនថិរវេលាកំណត់ តាមតែអាចធ្វើទៅបាន")។ មាត្រា ១៣៣ ("ភាគីណាមួយដែលមានបំណងដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ត្រូវដាក់លិខិតជូនដំណឹងបណ្តឹងសាទុក្ខ ៣០ថ្ងៃបន្ទាប់ពីបានដាក់សាលក្រមលាយលក្ខណ៍អក្សរ ដោយមានបង្ហាញពីមធ្យោបាយក្នុងបណ្តឹងសាទុក្ខ" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៦៨. ដោយតម្រូវឱ្យចៅក្រមជំនុំជម្រះចេញសាលក្រមជាលាយលក្ខណ៍អក្សរនៅថ្ងៃប្រកាសតែម្តង និងដោយកំណត់ដំណើរការរយៈពេលបណ្តឹងសាទុក្ខចាប់ពីថ្ងៃដដែលនោះ អ្នកតាក់តែងច្បាប់របស់ អ.វ.ត.ក មិនបានផ្តល់ការលើកលែងចំពោះគោលការណ៍ជាមូលដ្ឋាននេះទេ (ដូចនៅ យន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ)។ ម៉្យាងវិញទៀត គោលការណ៍នេះត្រូវបានរំឭកឡើងវិញដោយអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/១ ដោយអង្គបុរេជំនុំជម្រះបានប្រកាសថា សហចៅក្រមស៊ើបអង្កេត ត្រូវបានដកចេញពីសំណុំរឿងភ្លាមៗ បន្ទាប់ពីបានចេញដីកាសម្រេចសេចក្តីនៃដីកាដំណោះស្រាយរបស់ខ្លួន[78]។

៦៩. ទីបី ទោះបីទើបបានចេញកាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ សំអាងហេតុសាលក្រមមានចុះកាលបរិច្ឆេទតាំងពីយូរមកហើយ គឺថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០១៨[79]។ ការដាក់កាលបរិច្ឆេទផ្លូវការមុនកាលបរិច្ឆេទជាក់ស្តែងនៃការតាក់តែង និងចុះហត្ថលេខា គឺជាការបំភ្លៃតថភាពជាក់ស្តែង ព្រោះថា រហូតដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ វាច្បាស់ណាស់ថាសំអាងហេតុទាំងនេះ មិនទាន់បានបញ្ចប់ និងមិនទាន់បានចុះហត្ថលេខានៅឡើយ បើមិនដូច្នេះទេ អង្គជំនុំជម្រះនឹងមិនមានការលំបាកក្នុងការចេញសំអាងហេតុនោះ ក្នុងពេលតែមួយជាមួយផ្នែកសម្រេចសេចក្តី នោះឡើយ។ នេះជារឿងគួរឱ្យភ្ញាក់ផ្អើល មិនអាចពន្យល់បាន និងមិនអាចយល់បាន ហើយមិនធ្លាប់មានពីមុនមកនៅ អ.វ.ត.ក[80]។

[78] សេចក្តីសង្កេតនៃអង្គបុរេជំនុំជម្រះ ចុះ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ **004/1-D308/3/1/20** កថាខណ្ឌ ៣៣។

[79] សេចក្តីបញ្ជាក់មុនពេលចុះហត្ថលេខា "ដែលធ្វើឡើងជាភាសាខ្មែរ អង់គ្លេស និងភាសាបារាំង។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីក្រុងភ្នំពេញ (ប្រទេសកម្ពុជា)"៖ សំអាងហេតុសាលក្រម កថាខណ្ឌ ទំព័រ ២៦៥៧ ជាភាសាបារាំង ទំព័រ ៣៦១២-៣៦១៣ ជាភាសាខ្មែរ ("ធ្វើឡើងជាភាសាខ្មែរ អង់គ្លេស និងបារាំង ធ្វើនៅ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា") និង ទំព័រ ២២៣២ ជាភាសាអង់គ្លេស (*« Done in Khmer, English and French. Dated this 16th day of November 2018 At Phnom Penh Cambodia »*)។ កាលបរិច្ឆេទនេះក៏ មានចុះនៅត្រង់ទំព័រដើម ព្រមទាំងនៅជើងទំព័រនីមួយៗនៃសំអាងហេតុនៅក្នុងអត្ថបទគ្រប់ភាសាផងដែរ។

[80] ក្រុមមេធាវីការពារក្តីមិនឃើញមានបទបង្ហាញណាមួយសោះឡើយនៃសំអាងហេតុដែលផ្តល់ជូននៅពេលក្រោយដាក់ផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចដែលបានចេញបែបនោះដោយអង្គតុលាការនីមួយៗនៃអ.វ.ត.ក ហើយដែលចុះកាលបរិច្ឆេទមុនពេលវេលាជាក់ស្តែងបើប្រៀបធៀបទៅនឹងថ្ងៃចេញផ្នែកសម្រេចសេចក្តី។ សំអាងហេតុទាំងអស់សុទ្ធតែបានចុះកាលបរិច្ឆេទ នៅថ្ងៃប្រគល់ឯកសារនោះ។

៧០. អាស្រ័យហេតុនេះ សំអាងហេតុដែលមិនត្រឹមតែគ្មានតម្លៃគតិយុត្តិ ឬតម្លៃយុត្តាធិការ ប៉ុន្តែថែមទាំងមានចុះកាលបរិច្ឆេទហួសសម័យ គឺមានវិការៈយ៉ាងជ្រាលជ្រៅ។ អត្ថិភាព និងរបៀបចេញសំអាងហេតុ បង្កភាពមន្ទិលសង្ស័យចំពោះសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ។

## ២.៣. ភាពមន្ទិលសង្ស័យចំពោះសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ

៧១. ជាគោលការណ៍ និងជាតក្កៈ វិចារណកិច្ចនាំទៅដល់ការធ្វើសេចក្តីសម្រេច។ ដោយតម្រូវឱ្យចៅក្រមចេញសាលក្រមដែលមានសំអាងហេតុជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខា "យ៉ាងយូរត្រឹម" ថ្ងៃប្រកាសសាលក្រម អ្នកតាក់តែងច្បាប់របស់ អ.វ.ត.ក មានគោលបំណងធានាថា វិចារណកិច្ច ដែលនាំទៅដល់ការធ្វើសេចក្តីសម្រេចលើធម្មនុញ្ញភាពនៃបទចោទព្រហ្មទណ្ឌ និងការកំណត់ទោសប្រសិនបើមាន ត្រូវបានបង្ហើយ បញ្ចប់ និងប្រមើលឃើញបែបណាមួយហ្នឹង នៅថ្ងៃប្រកាសសាលក្រម។

៧២. ការចុះកាលបរិច្ឆេទថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ លើសំអាងហេតុសាលក្រម អាចធ្វើឱ្យមនុស្សនៅខាងក្រៅនីតិវិធីជឿថា នេះជាករណីអនុវត្តនៅទីនេះ។ តែវាមិនពិតទេ ដោយហេតុថា បើវិចារណកិច្ចត្រូវបានបញ្ចប់មុនកាលបរិច្ឆេទនេះ សំអាងហេតុគួរតែត្រូវបានផ្តល់ជូនភាគី និងសាធារណជន នៅថ្ងៃនោះហើយ មិនមែននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ពោលគឺ ៤.៥ ខែ ឬ ១៣២ ថ្ងៃ ក្រោយមក នោះទេ។

៧៣. ដូចគ្នានេះដែរ ការអានសេចក្តីសង្ខេបដ៏វែងអន្លាយដោយប្រធានអង្គជំនុំជម្រះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មុនពេលប្រកាសផ្នែកសម្រេចសេចក្តី អាចផ្តល់នូវចំណាប់អារម្មណ៍ថា ការពិភាក្សាត្រូវបានបញ្ចប់ដាច់ស្រេច ហើយវិចារណកិច្ចត្រូវបានបញ្ចប់មុនកាលបរិច្ឆេទនោះ។ មានន័យថា សេចក្តីសង្ខេបនេះមានភាពមិនច្បាស់លាស់ខ្លាំងណាស់។ សេចក្តីសង្ខេបមិនមានការចង្អុលបង្ហាញណាមួយអំពីធាតុផ្សំនៃអង្គហេតុ និងអង្គច្បាប់ ដែលជាមូលដ្ឋាននៃសេចក្តីសម្រេចឡើយ។ សេចក្តីសង្ខេបក៏មិនបានបញ្ជាក់ច្បាស់អំពីអ្វីដែលឈ្មោះ ខៀវ សំផន ត្រូវបាន ឬមិនត្រូវបានផ្តន្ទាទោសចំពោះទីតាំងឧក្រិដ្ឋកម្ម

នីមួយៗនោះដែរ[81]។ ជាពិសេស អង្គជំនុំជម្រះបានបញ្ជាក់ថា សេចក្ដីសង្ខេបនេះមិនមានភាពត្រឹមត្រូវទេ មិនដូចអត្ថបទទាំងមូលនៃសាលក្រមដែលនឹងមកដល់ក្នុងពេលសមស្រប[82]។ ទោះបីជាអង្គជំនុំជម្រះបានចែកចាយសេចក្ដីសង្ខេបជាលាយលក្ខណ៍អក្សរនេះ បន្ទាប់ពីសវនាការក៏ដោយ ក៏អង្គជំនុំមិនបានចុះហត្ថលេខាលើវាដែរ[83]។ ដូច្នេះ សេចក្ដីសង្ខេបនៃវិចារណកិច្ចមិនទាន់ដាច់ស្រេចទាល់តែសោះ។

៧៤. វិចារណកិច្ចអាចមានភាពវិវត្តកាន់តែខ្លាំង ដោយសារអង្គជំនុំជម្រះមិនបានផ្ដល់យុត្តិកម្មដល់ការពន្យារពេលចេញសេចក្ដីពេញលេញនៃសំអាងហេតុជាលាយលក្ខណ៍អក្សរ និងមិនបានផ្ដល់កាលបរិច្ឆេទសម្រាប់ការចេញសេចក្ដីពន្យល់នោះដែរ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើចៅក្រមបានបញ្ចប់ការវិភាគទាំងអស់របស់ខ្លួនលើអង្គហេតុ ភ័ស្ដុតាង និងអង្គច្បាប់ ចៅក្រមត្រូវតែអាចចេញសេចក្ដីសម្រេចដោយមានសំអាងហេតុពេញលេញ ឬយ៉ាងហោចណាស់ អាចបញ្ជាក់ពីពេលវេលាកំណត់ដ៏តឹងរ៉ឹងដែលចៅក្រមនឹងចេញសំអាងហេតុនៃសេចក្ដីសម្រេច និងផ្ដល់យុត្តិកម្មដល់កាលកំណត់នោះ។

៧៥. ការទុកបញ្ហាចោល ដោយគ្មានការពន្យល់ ក៏ដូចជាកាលកំណត់ដ៏វែងដែលបានកន្លងផុតទៅ ធ្វើឱ្យគេអាចសន្និដ្ឋានបានថា វាមិនមែនជាបញ្ហាសាមញ្ញនៃការកែសម្រួលដែលគួរទាមទារពេលតិចជាង ១៣២ ថ្ងៃ ឡើយ។ វាក៏មិនមែនជាបញ្ហាពេលវេលាសម្រាប់ការបកប្រែនោះដែរ ព្រោះថា សំអាងហេតុត្រូវបានចេញជាភាសាដើម ជាបីភាសាការងាររបស់ អ.វ.ត.ក។ ប្រសិនបើវាជាបញ្ហានៃការផ្ទៀងផ្ទាត់ ឬការបន្សុីគ្នារវាងសំណៅទាំងបីភាសា វានឹងចំណាយពេលតិចជាង ហើយក្នុងករណីណាក៏ដោយ វាគួរតែត្រូវបានធ្វើឡើងក្នុងកំឡុងពេលពិភាក្សាសម្រេច។ ជាក់ស្ដែង ការរកឃើញភាពខុសគ្នានៅក្នុងសំណៅភាសាផ្សេងគ្នាអំពីធាតុផ្សំនៃភ័ស្ដុតាងសម្រាប់គាំទ្រដល់វិចារណកិច្ច អាចនាំឱ្យពិចារណាឡើងវិញលើវិចារណកិច្ចនេះ និងសេចក្ដីសម្រេចផងដែរ។ ដូចតុលាការកំពូលបានថ្លែងថា៖

---

[81] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **529.1** ចន្លោះម៉ោង 09.35.46 និងម៉ោង 11.25.55។

[82] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **529.1** មុនម៉ោង 09.35.46។

[83] បន្ទាប់មក សេចក្ដីសង្ខេបនោះត្រូវបានផ្សព្វផ្សាយនៅលើវែបសាយនៃ អ.វ.ត.ក និងជាកម្មវត្ថុនៃការអានឡើងវិញ (https://www.eccc.gov.kh/fr/document/public-affair/resume-du-jugement-de-la-chambre-de-premiere-instance-rendu-dans-le-deuxieme)។

"លទ្ធភាពនៃការផ្តន្ទាទោសអាចប្រែប្រួលទៅតាមវត្ថុតាងនីមួយៗ ដែលបានបង្ហាញ។ ដូច្នេះ កម្រិតនៃភ័ស្តុតាងនៅពេលជំនុំជម្រះ អាចត្រូវបានបង្ហាញក្រោមទម្រង់ជារូបភាព ដូចជាខ្សែកោងឡើងចុះ"[84]។

៧៦. លើសពីនេះទៀត សមាសភាពនៃចៅក្រមជំនុំជម្រះ ពេលប្រកាសសាលក្រម និងពេលចេញសំអាងហេតុ បង្កការភាន់ច្រឡំ និងចោទជាបញ្ហាផ្សេងៗ។ ទោះបីជាចៅក្រម Lavergne បានត្រឡប់ទៅបំពេញមុខងារតុលាការរបស់គាត់នៅប្រទេសបារាំង បន្ទាប់ពីបានបម្រើការនៅ អ.វ.ត.ក រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨[85] ក្តី តែចៅក្រមរូបនេះបែរជាបានលាឈប់ពីមុខតំណែងចៅក្រម "ពេញម៉ោង" នៅ អ.វ.ត.ក នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ឯណោះទៅវិញ[86]។

៧៧. ទោះក្នុងករណីណាក៏ដោយ ដោយសារកង្វះតម្លាភាពរបស់អង្គជំនុំជម្រះលើវិធីសាស្ត្ររបស់ខ្លួន និងភាពស្រពិចស្រពិលទាំងឡាយជុំវិញពេលវេលា និងរយៈពេលនៃការពិភាក្សាសម្រេច គេនឹងមិនដឹងថាមានអ្វីបានកើតឡើងពិតប្រាកដ និងថាតើសាលក្រមដែលបានប្រកាសពិតជាប្រសូត្រចេញពីវិចារណកិច្ចកាលពីមុនរបស់ចៅក្រម ឬអត់។

៧៨. តុលាការកំពូលអាចដោះស្រាយបញ្ហានេះបាន ប្រសិនបើខ្លួនបានទទួលស្គាល់តម្លៃគតិយុត្តិនៃផ្នែកសម្រេចសេចក្តីនៃសាលក្រម និងបានប្រកាសទទួលយកបណ្តឹងសាទុក្ខបន្ទាន់របស់មេធាវីការពារក្តី។ តុលាការកំពូលអាចធ្វើមោឃភាពសាលក្រមដែលបានប្រកាស និងអាចបង្គាប់ឱ្យអង្គជំនុំជម្រះចេញដីកាសម្រេចថ្មី ដោយអនុលោមតាមវិធានផ្ទៃក្នុង។ ប៉ុន្តែ តុលាការកំពូលមិនបានធ្វើបែបនេះទេ ហើយពេលនេះ វាជារឿងដែលមិនអាចត្រឡប់ថយក្រោយវិញបានឡើយ។

---

[84] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ឯកសារ **E275/2/3** កំណត់សម្គាល់ជើងទំព័រលេខ៧១ (នៃកថាខណ្ឌ ៣៥)។

[85] ព្រះរាជក្រិត្យចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ ដែលលើកឡើងពីការបន្តនៅក្រៅតំណែង (អង្គចៅក្រម) របស់លោកចៅក្រម LAVERGNE (Jean-Marc), JORF n°0158 ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ អត្ថបទលេខ ៦០។ (https://www.legifrance.gouv.fr/affichTexte.do?cidTexte=JORFTEXT000037172176&categorieLien=id)។

[86] ដីកាចាត់តាំងចៅក្រមបម្រុង ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ **E466**។

៧៩. ជាសេចក្តីសន្និដ្ឋាន ដោយមិនគោរពតាមឆន្ទៈរបស់អ្នកតាក់តែងច្បាប់របស់ អ.វ.ត.ក ដែលបានសម្តែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលធ្វើឱ្យអសុពលភាពដល់ការប្រកាសអំពីពិរុទ្ធភាព និងការផ្តន្ទាទោស។ តុលាការកំពូលត្រូវសម្រេចលើមោឃភាពនៃសាលក្រមលើអសុពលភាពនៃសំអាងហេតុ និងលើការរំលោភលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានតុលាការដែលបង្កើតឡើងដោយច្បាប់ សច្ចភាពគតិយុត្តិ និងនីតិវិធី តម្លាភាពនៃនីតិវិធី សំអាងហេតុនៃសេចក្តីសម្រេច ការដឹងឮពីបុព្វហេតុរបស់គាត់ ការការពារខ្លួនដ៏មានប្រសិទ្ធភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយមិនយឺតយ៉ាវហួសហេតុ។

**ជាលក្ខណៈបន្ទាប់បន្សំ**

**សេចក្តីផ្តើម**

៨០. ពេញមួយសំណុំរឿង ០០២ (សវនាការលើសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២) មេធាវីការពារក្តីតែងតែព្យាយាមរំឭកឡើងវិញនូវវិធាននានាដែលត្រូវយកចិត្តទុកដាក់ខ្ពស់ នៅពេលពិនិត្យអង្គហេតុ និងអង្គច្បាប់ ស្របតាមការជំនុំជម្រះក្តីដោយយុត្តិធម៌។ សារណានេះមិនប្រាសចាកពីវិធានច្បាប់ទេ ទោះបីវាត្រូវបានតាក់តែងឡើងក្នុងក្របខ័ណ្ឌនីតិវិធីវិសាមញ្ញក៏ដោយ។ ជាក់ស្តែង ដោយសារតែការបំបែកសំណុំរឿងមិនធ្លាប់មាននៃសំណុំរឿង ០០២ ខៀវ សំផន បង្ហាញទឡ្ហីករណ៍របស់ខ្លួននៅចំពោះមុខតុលាការកំពូល ដែលតុលាការនេះត្រូវដឹង និងវិនិច្ឆ័យមួយផ្នែកធំនៃអង្គហេតុ ដែលគាត់ត្រូវបានផ្តន្ទាទោសដោយអង្គជំនុំជម្រះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[87]។

៨១. បន្ទាប់ពីការវិនិច្ឆ័យពីរលើកដំបូងដោយអង្គជំនុំជម្រះដែលមានសមាសភាពដដែល ក្រោយការផ្តន្ទាទោសពីរលើកឱ្យជាប់ពន្ធនាគារអស់មួយជីវិត ក្នុងនោះការផ្តន្ទាទោសមួយត្រូវបានតម្កល់ដោយតុលាការកំពូល ម្ចាស់បណ្តឹងសាទុក្ខចាំបាច់ត្រូវដាក់សារណា ដោយពិចារណាលើលក្ខណៈពិសេសនៃ

[87] គឺជាអ្វីដែលតុលាការកំពូលបានពិនិត្យសម្រេចរួចមកហើយ សូមមើលឧបសម្ព័ន្ធនៃបណ្តឹងដីតចិត្ត ពីឯកសារ **F53.2** ដល់ឯកសារ **F53.17** (ឬពីឯកសារ **1.2** ដល់ **1.17**)។

ដំណើរការនៃសំណុំរឿងវិសាមញ្ញនេះ។ បណ្តឹងជិតចិត្តដែលត្រូវបានដាក់ដោយម្ចាស់បណ្តឹងសាទុក្ខ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ មិនទាន់ទទួលបានការសម្រេចនៅឡើយ នៅពេលដាក់សារណានេះ[88]។ ទោះយ៉ាងណាក៏ដោយ សារណាត្រូវបានតាក់តែងឡើង ដើម្បីដាក់ជូនថៅក្រុមដែលគ្មានបុរេវិនិច្ឆ័យចំពោះម្ចាស់បណ្តឹងសាទុក្ខ ធ្វើការពិចារណា។

៨២. បុរេវិនិច្ឆ័យដំបូងដែលត្រូវច្រានចោល គឺការចាត់ទុកថាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ពិតជាកើតចេញមកពីគោលនយោបាយមួយ។ ក៏ប៉ុន្តែ វាជាការសន្និដ្ឋានដំបូងបង្អស់របស់អង្គជំនុំជម្រះ ដែលគាំទ្ររបៀបពន្យល់ និងអនុវត្តច្បាប់ ក៏ដូចជារបៀបពិនិត្យអង្គហេតុ។

៨៣. ជម្លោះប្រដាប់អាវុធ ដែលជាកម្មវត្ថុនៃអង្គហេតុរងការចោទប្រកាន់ និងជាបរិបទចាំបាច់សម្រាប់ស្វែងរកអង្គហេតុ និងឥរិយាបទរបស់តួអង្គ ក្នុងសម័យកាលប្រវត្តិសាស្ត្រកម្ពុជា មិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ បរិបទនៃសង្គ្រាមត្រជាក់ និងការតស៊ូមនោគមន៍វិជ្ជាដែលកំពុងកើតឡើងនៅគ្រានោះ ត្រូវបានគេមើលឃើញ តែតាមរយៈការបកស្រាយបែបបំព្រួញ និងសាមញ្ញ នូវអ្វីដែលអាចជាឧត្តមគតិនៃប្រជាជាតិមួយនៅជំនាន់នៃទឹកដីអតីតអាណានិគម ដែលចង់ផ្លាស់ប្តូរប្រទេសរបស់ពួកគេ ដូចករណីនៅប្រទេសកម្ពុជាដែរ។

៨៤. ជាងសែសិបឆ្នាំក្រោយព្រឹត្តិការណ៍ វាមិនងាយស្រួលទេក្នុងការពិនិត្យមើលដោយមិនលម្អៀង នូវរយៈពេលដ៏ឈឺចាប់ និងស្មុគស្មាញនៃប្រវត្តិសាស្ត្រកម្ពុជាមួយនេះ។ ហើយវាក៏មិនងាយស្រួលដែរ ក្នុងការធ្វើកិច្ចការចាំបាច់ក្នុងការវិលទៅរកសម័យកាលនៃអង្គហេតុ ដើម្បីពិនិត្យមើលអង្គច្បាប់ជាធរមាន។ ទាំងនេះគឺជាឧបសគ្គពីរ ដែលអង្គជំនុំជម្រះមិនអាចជម្នះបាននៅក្នុងសំអាងហេតុសាលក្រមរបស់ខ្លួន។

៨៥. ខណៈពេលដែលយើងកំពុងតែឈានដល់ទីបញ្ចប់នៃសំណុំរឿងដ៏វែងអន្លាយ និងវិសាមញ្ញ ទាំងប្រភេទ និងចំនួននៃអង្គហេតុរងការចោទប្រកាន់ ទាំងធាតុផ្សំនៃភ័ស្តុតាងដ៏ក្រាស់ក្រែលក្រោមទម្រង់ជាសក្ខីកម្ម និងឯកសារ ការសន្និដ្ឋានរបស់មេធាវីការពារក្តីនៅតែដដែល ដូចបានរៀបរាប់ នៅក្នុងសារណាបណ្តឹង

[88] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ឯកសារ F53 (ឬឯកសារ ១)។

សាទុក្ខរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១៖ "ផ្ទុយពីអ្វីដែលចៅក្រមប្រកបដោយវិចារណញ្ញាណ និង យុត្តិធម៌ត្រូវធ្វើ អង្គជំនុំជម្រះបានចាប់ផ្តើមពីការដាក់ពិរុទ្ធភាពលើ ខៀវ សំផន បន្ទាប់មក បានទាញ យក និងបង្ខូចទ្រង់ទ្រាយភស្តុតាង ដើម្បីតម្កល់ដីកាដែលបានសម្រេចទុកជាមុនរបស់ខ្លួន[89]។

៨៦. ដើម្បីឈានដល់ការប្រកាសពិរុទ្ធភាព និងផ្តន្ទាទោស បែបបទនៃរបៀបប្រតិបត្តិការរបស់អង្គជំនុំជម្រះ គឺដូចគ្នានឹងសាលក្រម ០០២/០១ ដែរ ដែលជាការបំពានជាប្រព័ន្ធលើគោលការណ៍នីត្យានុកូលភាព ដោយមិនអើពើនឹងច្បាប់ជាធរមាននៅសម័យកាលនៃអង្គហេតុ និងគោលការណ៍នៃភាពអាចដឹងជាមុន បានថាជាបទល្មើស ជាអាទិ៍ ចំពោះនិយមន័យនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ការអនុវត្តខុសច្បាប់ និងនីតិវិធី បើទោះបីអង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវពីគោលការណ៍ និងការបកស្រាយដាក់បន្ទុក ជានិច្ចជាកាលនូវអង្គហេតុទាំងឡាយ ដែលផ្ទុយនឹងកាតព្វកិច្ចប្រកាន់យកភាពមិនលម្អៀងរបស់ខ្លួន។

៨៧. កំហុសអង្គច្បាប់របស់អង្គជំនុំជម្រះក្នុងការគាំទ្រដល់សេចក្តីសម្រេចផ្តន្ទាទោសរបស់ខ្លួន មានទំនោរ ពង្រីកនិយមន័យនៃឧក្រិដ្ឋកម្ម ជាពិសេស តាមរយៈធាតុផ្សំសត្យានុម័តិដែលនាំទៅដល់ការបន្សាបធាតុ ផ្សំអត្តនោម័តិ។ ក្នុងន័យដូចគ្នា ទម្រង់នៃទំនួលខុសត្រូវនៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលជាការបន្សាប ទំនួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលតែម្តង ក៏ត្រូវបានពង្រីកដោយផែនការរួមដែលបានកំណត់ ទាំងស្រពិចស្រពិល និងការបកស្រាយពន្លាត។ ការដាក់ទណ្ឌកម្មលើផែនការនយោបាយរបស់បក្ស កុម្មុយនីស្តកម្ពុជា (ប.ក.ក) ដែលទោះបីជាផែនការនេះគ្មានលក្ខណៈឧក្រិដ្ឋផ្ទាល់ក៏ដោយ ក៏គឺជា មធ្យោបាយតែមួយគត់សម្រាប់កំណត់ការទទួលខុសត្រូវរបស់ ខៀវ សំផន។

៨៨. វាបង្ហាញយ៉ាងច្បាស់ចេញពីការអានសំអាងហេតុសាលក្រមថា ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្ម គឺមិន ជាប់ពាក់ព័ន្ធនឹង ខៀវ សំផន ទេ ហើយថា អង្គជំនុំជម្រះបានភ្ជាប់ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្មទៅ នឹងរូបគាត់ និង/ឬផ្អែកលើភស្តុតាងដែលគ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចវិនិច្ឆ័ យថាគួរឱ្យជឿជាក់បាន ឬគ្រប់គ្រាន់ ដោយផ្អែកតែលើការសន្មតនោះ។

[89] សារណាបណ្តឹងសាទុក្ខ០០២/០១ កថាខណ្ឌ ៥។

៨៩. សារណានេះមានគោលបំណងវិភាគវិចារណកិច្ចដែលនាំទៅដល់ការផ្តន្ទាទោស ខៀវ សំផន និងបង្ហាញពីដំណាក់កាលផ្សេងៗដែលអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ។ ប្រឈមមុខនឹងសាលក្រមអមដោយផ្អែកសំអាងហេតុដ៏ក្រាស់ឃ្មឹក និងស្មុគស្មាញ គេត្រូវធ្វើការជ្រើសរើសដោយផ្អែកលើកំហុសសំខាន់ៗដែលបានរកឃើញ។ វិធីសាស្ត្ររបស់មេធាវីការពារក្តី គឺការជ្រើសរើសយកកំហុសដើមសំខាន់ៗ ដែលនាំឱ្យមានកំហុសផ្គួនសន្ទឹកសន្ទាប់នាពេលបន្ទាប់ ទាំងក្នុងការអនុវត្តច្បាប់ ទាំងក្នុងការពិនិត្យអង្គហេតុ។

៩០. ហេតុដូច្នេះ សារណាបណ្តឹងសាទុក្ខនេះត្រូវបានរៀបចំឡើង ដើម្បីបង្ហាញតាមលំដាប់លំដោយអំពីការរំលោភផ្សេងៗលើអង្គច្បាប់ ដែលបណ្តាលឱ្យមានក្របខ័ណ្ឌច្បាប់មិនត្រឹមត្រូវសម្រាប់ការពិនិត្យអង្គហេតុ។ បន្ទាប់មកទៀត កំហុសរបស់អង្គជំនុំជម្រះក្នុងការពិនិត្យអង្គហេតុដែលជំទាស់ដោយ ខៀវ សំផន (គួររំឭកថាម្ចាស់បណ្តឹងមិនបានជំទាស់គ្រប់បញ្ហាទាំងអស់នេះទេ) នឹងត្រូវបានលើកឡើងផងដែរដោយសង្កត់ធ្ងន់ទៅលើវិធីជ្រើសរើសធាតុផ្សំនៃភ័ស្តុតាងនៅក្នុងសំណុំរឿង។

៩១. ដូច្នេះ បន្ទាប់ពីផ្អែកពាក់ព័ន្ធនឹងការរំលោភបំពានលើវិធាននៃការជំនុំជម្រះដោយយុត្តិធម៌ (ភាគទី ១) សារណានឹងបង្ហាញកំហុសរបស់អង្គជំនុំជម្រះលើចំណាត់ការលើបណ្តឹង (ភាគទី ២) ឧក្រិដ្ឋកម្ម (ភាគទី ៣) ផែនការបដិវត្តន៍សង្គមនិយម (ភាគទី ៤) និងការទទួលខុសត្រូវរបស់ ខៀវ សំផន (ភាគទី៥)។

## ភាគទី ១. កំហុសប្រព្រឹត្តដោយរំលោភបំពានលើវិធានមូលដ្ឋានអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

៩២. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីស្របតាមច្បាប់កម្ពុជា ចំពោះចារីនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត នៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ចែងក្នុងមាត្រា ១២-២ ថា៖ "អង្គជំនុំជម្រះវិសាមញ្ញអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានអន្តរជាតិនៃយុត្តិធម៌ សមធម៌ និងការគោរពចំពោះនីតិវិធីត្រឹមត្រូវ"។ មាត្រា ១៣-១ បញ្ជាក់ថា សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទត្រូវតែបានគោរព "ពេញមួយអំឡុងពេលនៃការ

ជំនុំជម្រះ"។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែគោរពសិទ្ធិជាមូលដ្ឋាន ទាំងក្នុងដំណាក់កាលជំនុំជម្រះ ទាំងក្នុងដំណាក់កាលបណ្ដឹងសាទុក្ខ។

៩៣. អាស្រ័យហេតុនេះ តុលាការកំពូលមានកាតព្វកិច្ចគោរពសិទ្ធិទាំងនោះ ហើយមិនត្រូវផ្ដើមចេញពីទស្សនៈបុរេវិនិច្ឆ័យដែលថា អង្គជំនុំជម្រះទំនងជាបាន "អនុវត្តពេញលេញ" សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះឡើយ[90]។ ក្នុងឋានៈជាស្ថាប័នឧទ្ធរណ៍ តុលាការកំពូលត្រូវតែពិនិត្យលើការជំទាស់របស់ម្ចាស់បណ្ដឹងសាទុក្ខចំពោះការរំលោភបំពានសិទ្ធិរបស់គាត់ (ដូចសំណុំរឿង ០០២/០១)[91] ប្រកបដោយភាពសត្យានុម័តិពេញលេញ។

៩៤. ក្នុងសំណុំរឿង ០០៤/១ សហចៅក្រមស៊ើបអង្កេត Michael BOHLANDER និង យូ ប៊ុនឡេង បានសង្កត់ធ្ងន់លើលក្ខណៈសំខាន់នៃការអនុវត្តគោលការណ៍ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនសង្ស័យ និងគោលការណ៍បកស្រាយតឹងរ៉ឹងនៃច្បាប់ព្រហ្មទណ្ឌនៅ អ.វ.ត.ក ដែលនៅទីនោះ ច្បាប់មិនទាន់ត្រូវបានកំណត់ទាំងស្រុងនៅឡើយ[92]។ សហចៅក្រមស៊ើបអង្កេតបានពិពណ៌នាអំពីចំណុចខ្វះខាតដែលត្រូវចៀសវាងក្នុងករណីពិសេសនៃតុលាការវិសាមញ្ញនេះ រួមមាន យុត្តាធិការពេលវេលា យុត្តាធិការបុគ្គល និងយុត្តាធិការរឿងក្ដី ដែលបានបង្កើតឡើងតាមកាលៈទេសៈជាក់ស្ដែង បន្ទាប់ពីការចរចាដ៏ចម្រូងចម្រាស និងបានចាប់ផ្ដើមសកម្មភាពរបស់ខ្លួនក្នុងរយៈពេល ៣០ ឆ្នាំ ក្រោយអង្គហេតុ[93]។ សហចៅក្រមបានកត់សម្គាល់ថា ការចោទប្រកាន់ និងធាតុផ្សំគតិយុត្តិ ជាញឹកញាប់ មានទម្រង់ដូច "គោល

---

[90] សេចក្ដីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ **F46/2/4/2** កថាខណ្ឌ ៣៧ នៅទីនេះតុលាការកំពូលបានប្រកាសថា បន្ទាប់ពីម្ចាស់បណ្ដឹងសាទុក្ខម្នាក់បានទទួលមរណភាពមុនពេលចេញសាលដីកា "ការមោឃភាពកំណត់ត្រាការជំនុំជម្រះទាំងមូល និងការយល់ឃើញ <u>បន្ទាប់ពីការអនុវត្តយ៉ាងពេញលេញស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងយុត្តិធម៌ចំពោះជនជាប់ចោទ</u> គឺជាការមិនអើពើទាល់តែសោះទៅលើអត្ថប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[91] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០៩។

[92] ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ២៦-២៧។

[93] ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ២៧។

ដោយរោ”[94]។ ពួកគេបានពណ៌នាករណីរបស់ អ.វ.ត.ក ថាជាឧទាហរណ៍ដ៏ល្អឥតខ្ចោះនៃភាពចាំបាច់ក្នុងការបង្ហាញភាពអត់ធ្មត់ចំពោះការបកស្រាយរបស់តុលាការ[95] មុននឹងបន្ថែមថា៖

> “នេះជាការពិត ជាពិសេស ដោយសារមានសម្ពាធពីការរំពឹងរបស់សាធារណជន ពីសារព័ត៌មាន ដែលព្រួយបារម្ភជុំវិញទស្សនៈនិទណ្ឌភាពចំពោះអំពើឃោរឃៅជាទ្រង់ទ្រាយធំ របៀបវារៈនយោបាយ ព្រមទាំងការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រទៅលើព្រឹត្តិការណ៍សំខាន់នេះកន្លងមក។ និយាយម៉្យាងទៀត ជាញឹកញយ នៅក្នុងសេណារីយ៉ូរបៀបនេះ ពិរុទ្ធភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ ហាក់ដូចជាមិនចាំបាច់ពិភាក្សាដេញដោល *តាំងពីដំបូង* (ab initio)។ ទោះបីជាយ៉ាងនេះក្តី កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការពុំមែនគ្រាន់តែជាការយល់ស្រប និងការបញ្ជាក់ជាផ្លូវការគាំទ្រចំពោះទស្សនៈយល់ឃើញជាទូទៅដែលមានស្រាប់ប៉ុណ្ណោះទេ”[96]។

៩៥. សហចៅក្រមស៊ើបអង្កេតបានរំឭកផងផងដែរពីគោលការណ៍គ្រឹះ ដែលមិនតម្រូវឱ្យគេចូលទៅក្នុងនីតិវិធីច្បាប់ត្រឹមត្រូវ ដរាបណាគេមិនទាន់ត្រៀមខ្លួនដើម្បីឃើញជនជាប់ចោទត្រូវបានដោះលែង ក្នុងករណីរកមិនឃើញពិរុទ្ធភាព[97]។ សហចៅក្រមស៊ើបអង្កេតបានហៅថាជាទស្សនៈមួយ “ដ៏សាហាវ” ក្នុងការគិតថា ក្នុងករណីឥរិយាបទព្រហ្មទណ្ឌធ្ងន់ធ្ងរបំផុត គេអាចទៅហួសព្រំដែនកំណត់ដោយច្បាប់ ដោយសារតែហេតុផលទំហំសម្បើមនៃឧក្រិដ្ឋកម្ម[98]។

---

[94] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ២៧។

[95] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ២៧។

[96] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ២៨។

[97] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ២៩។

[98] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ៣០។

៩៦. យោងតាមសហចៅក្រមស៊ើបអង្កេត ពិតមែនតែ អ.វ.ត.ក ផ្តល់យុត្តិធម៌មានជម្រើស ក្នុងន័យសត្យានុម័តិ[99] តែចំណុចនេះនឹងមិនអាចនាំឱ្យមានការសន្មតថា មនុស្សមួយចំនួនដែលសហព្រះរាជអាជ្ញាបានបញ្ជូនខ្លួនមកចំពោះមុខតុលាការ មានទោសនោះទេ[100]។ សហចៅក្រមបានថ្លែងថា៖

"សច្ចធារណ៍បែបនេះ ប្រសិនបើសន្មតមែននោះ ត្រូវធ្វើឡើងក្នុងលក្ខណៈផ្សេងពីនេះ។ ក្រោយរយៈពេលកន្លងហួសដ៏យូរ ភ័ស្តុតាងសំខាន់ខ្លះតាមរយៈសាក្សី ឬប្រភពផ្សេងទៀត អាចបាត់បង់ រហូតដល់កម្រិតមួយដែលពិបាករកព័ត៌មានលម្អិតអាចទុកចិត្តបាន ហើយតាមពិតសាក្សីអាចនឹងពិបាកមកផ្តល់សក្ខីកម្ម។ ករណីនេះគឺពុំមែនជាការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវឱ្យមេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេ ឬនាំឱ្យក្លាយជាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬការផ្តន្ទាទោសនោះឡើយ។ មេធាវីការពារក្តីមានសិទ្ធិទទួលបាននូវការវាយតម្លៃឱ្យបានសមហេតុផលលើភ័ស្តុតាង និងការបកស្រាយច្បាប់នៅក្នុងឋានានុក្រមតុលាការនៃ អ.វ.ត.ក គ្រប់ជាន់ថ្នាក់ដោយចាប់ផ្តើមពី ក.ស.ច.ស"[101]។

៩៧. ក្នុងរឿងក្តីនេះ គួរកត់សម្គាល់ថា អង្គជំនុំជម្រះមិនចេះរំដោះខ្លួនឱ្យចេញផុតពីភាពបរាជ័យដែលត្រូវបានពិពណ៌នាយ៉ាងត្រឹមត្រូវដោយសហចៅក្រមស៊ើបអង្កេតឡើយ។ សិទ្ធិជាមូលដ្ឋានរបស់ ខៀវ សំផន ដូចត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក (មាតិកាទី ១) មិនត្រូវបានគោរពទេ ដោយសារតែវិធីសាស្ត្រលម្អៀងរបស់គាត់ចំពោះគោលការណ៍នាំមុខនៃការជំនុំជម្រះក្តីព្រហ្មទណ្ឌ (មាតិកាទី ២) និងការគ្រប់គ្រងភ័ស្តុតាង (មាតិកាទី ៣)។ អានុភាពត្រួតគ្នានៃការរំលោភបំពានរងការចោទប្រកាន់បានធ្វើឱ្យការជំនុំជម្រះផ្ទាល់មានភាពអយុត្តិធម៌ (មាតិកាទី ៤)។

[99] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ៣១, ៣៥។

[100] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ៣៥។

[101] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ៣៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

**មាតិកាទី ១. ច្បាប់ជាធរមាន**

៩៨. ក្របខ័ណ្ឌច្បាប់ជាធរមាននៅ អ.វ.ត.ក តម្រូវឱ្យមានការគោរពសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ[102] ជាពិសេស សិទ្ធិទទួលបានការជំនុំជម្រះដោយមិនយឺតយ៉ាវហួសហេតុ តុលាការដែលចាត់ការតាមបណ្តឹងជាក់ស្តែង និងដែលបង្កើតដោយច្បាប់ ការជូនដំណឹងពីប្រភេទ និងសំអាងហេតុនៃការចោទប្រកាន់ សច្ចភាពគតិយុត្តិ និងនីតិវិធី តុលាការឯករាជ្យ និងមិនលម្អៀង សច្ចធារណ៍និរទោស ពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់ការរៀបចំការពារក្តី សវនាការចំពោះមុខ ការដឹងឮពីរឿងក្តីរបស់គាត់ ការការពារក្តីដ៏មានប្រសិទ្ធភាព តម្លាភាពនៃនីតិវិធី សំអាងហេតុនៃដីកានានា និងសាលក្រម និងសិទ្ធិទទួលបានសមភាពនៃការតទល់ក្តី ក៏ដូចជាសិទ្ធិមិនទទួលបានការកាត់ទោស ឬដាក់ទណ្ឌកម្ម ដោយសារតែបទល្មើសដែលគាត់ត្រូវបានលើកលែងទោស ឬផ្តន្ទាទោសរួចហើយ។

៩៩. ក្របខ័ណ្ឌគតិយុត្តិមានគោលបំណង "ការពារសិទ្ធិដែលមិនមែនជាទ្រឹស្តី ឬការបំភាន់ឡើយ ប៉ុន្តែជាសិទ្ធិជាក់ស្តែង និងមានប្រសិទ្ធភាព[103]។

**មាតិកាទី ២. វិធីសាស្ត្រលម្អៀងនៃគោលការណ៍នាំមុខក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ**

**ជំពូកទី ១. ទស្សនាទានខុសឆ្គង និងរើសអើងអំពីនីតិព្រហ្មទណ្ឌ**

១០០. ជាជាងអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តវិធាននីតិព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង និងមិនលម្អៀង អង្គជំនុំជម្រះបានចាកចេញពីតួនាទីរបស់ខ្លួនជាចៅក្រម។ ប្រឈមមុខនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវជំនុំ

[102] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ វិធានផ្ទៃក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ដោយសារកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មានបទប្បញ្ញត្តិស្រដៀងគ្នានឹងអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលកតិកាសញ្ញានោះបានដកស្រង់ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបក៏មានភាពពាក់ព័ន្ធដែរ។

[103] សាលដីកា *Airey ទល់នឹងប្រទេសអៀរឡង់* (អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន) ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៩ កថាខណ្ឌ ២៤។

ជម្រះ អង្គជំនុំជម្រះបានងាកទៅរកកំហុស ដោយចូលទៅក្នុងការងារគោលនយោបាយឧក្រិដ្ឋ និងចូលទៅក្នុងការប្រយុទ្ធប្រឆាំងនិទណ្ឌភាព។

១០១. កំហុសអង្គច្បាប់ ដែលអង្គជំនុំជម្រះបានប្រព្រឹត្តទាក់ទងនឹងគោលការណ៍នីត្យានុកូលភាព និងការកំណត់ទោសដែលនឹងលើកឡើងដូចខាងក្រោម នឹងបង្ហាញឲ្យឃើញពីរឿងនេះ។

១០២. ជាក់ស្ដែង អង្គជំនុំជម្រះបានប្រែក្លាយតម្រូវការនៃគោលការណ៍អាចដឹងជាមុនបានថាជាបទល្មើស និងគោលការណ៍អាចដឹងជាមុនបានថាមានច្បាប់ចែង ដែលជាលក្ខខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព ឲ្យទៅជាអស់ន័យ ដោយផ្ដល់ទម្ងន់ដល់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មជាងលក្ខណៈវិនិច្ឆ័យសត្យានុម័តិនៃគុណភាពច្បាប់ និងការកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ[104]។ លើសពីនេះ អង្គជំនុំជម្រះបានអនុវត្តច្បាប់ដែលគ្មាននៅសម័យអង្គហេតុ ដែលអង្គជំនុំជម្រះបានបង្កើតឡើងសម្រាប់តែការផ្ដន្ទាទោស[105]។

១០៣. អង្គជំនុំជម្រះបានកំណត់ទោសផងដែរ ដោយគិតថា ក្នុងការទទួលខុសត្រូវចំពោះការជំនុំជម្រះក្ដីនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងវិសាលភាពដ៏សម្បើម កាតព្វកិច្ចចម្បងរបស់អង្គជំនុំជម្រះ គឺដាក់ទោសឲ្យធ្ងន់ដើម្បីបង្ហាញដល់ជនរងគ្រោះ និងសាធារណជនទូទៅ[106]។

១០៤. ក្នុងការអនុវត្តបែបនេះ អង្គជំនុំជម្រះមិនត្រឹមតែបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលធ្វើឱ្យសេចក្ដីសម្រេចរបស់ខ្លួនអស់សុពលភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញពីអសមត្ថភាពរបស់ខ្លួនក្នុងការកាត់សេចក្ដី ខៀវ សំផន ដោយមិនលម្អៀង។

---

[104]សូមមើលខាងក្រោម កថាខណ្ឌ ៥៥០-៥៧៤។

[105] សូមមើលខាងក្រោម កថាខណ្ឌ ៥៧៥-៦៣៦, ៦៤២-៦៥៥, ៦៥៨-៦៧១, ១៩៣៨-១៩៦៥, ២១២០-២១២៣។

[106] សូមមើលខាងក្រោម កថាខណ្ឌ ២១៤៤-២១៤៧។

## ជំពូកទី ២. ទស្សនាទានមិនត្រឹមត្រូវ និងរើសអើងអំពីនីតិវិធីព្រហ្មទណ្ឌ

១០៥. ជាជាងបំពេញកាតព្វកិច្ចរបស់ខ្លួនដោយម៉ឺងម៉ាត់ ក្នុងការសម្រេចលើការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលដែលជាកម្មវត្ថុនៃបណ្តឹងមកកាន់ខ្លួន អង្គជំនុំជម្រះបានដើរទៅរកភាពបរាជ័យក្នុងការវិនិច្ឆ័យពីប្រវត្តិសាស្ត្រនយោបាយកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបាននាំការជំនុំជម្រះក្តីដ៏វែងអន្លាយទៅក្នុងព្រំដែនដែលអាចរំកិលបាន (ផ្នែកទី ១) ដើម្បីធ្វើការជំនុំជម្រះក្តីជាប្រវត្តិសាស្ត្រ (ផ្នែកទី ២)។

### ផ្នែកទី ១. ការជំនុំជម្រះដ៏វែងអន្លាយក្នុងព្រំដែនដែលអាចរំកិលបាន

១០៦. ប្រឈមនឹង "ប្រវែង និងភាពស្មុគស្មាញ" នៃដីកាដំណោះស្រាយ[107] អង្គជំនុំជម្រះបានបំបែកបទចោទក្នុងសំណុំរឿង ០០២ មុននឹងបង្រួម និងបិទបញ្ចប់បទចោទមួយចំនួន[108]។ នៅក្នុងការអនុវត្ត វិធីសាស្ត្ររបស់អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យអង្គជំនុំជម្រះផ្តោតលើបទចោទជាក់លាក់ទេ ប៉ុន្តែ បានបង្កើតភាពច្របូកច្របល់ដែលអនុញ្ញាតឱ្យមានការទទួលយកដោយចំហានូវអង្គហេតុដែលមិនពាក់ព័ន្ធ។

១០៧. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តិកំហុសអង្គច្បាប់ ដោយមិនផ្តល់ការយកចិត្តទុកដាក់ "ខ្ពស់ខ្លាំង"[109] និងការបញ្ជាក់ចាំបាច់លើការកំណត់វិសាលភាពនៃបទចោទនៅក្នុងបណ្តឹង និងដោយបើកទ្វារចំហាទទួលអង្គហេតុជានិច្ច ដែលប៉ះពាល់ជាពិសេសដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹង "ឱ្យបានឆាប់បំផុត" និង "លម្អិត" អំពីប្រភេទ និងបុព្វហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់[110]។

---

[107] សំអាងហេតុសាលក្រម កថាខណ្ឌ ៤។

[108] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣។ សេចក្តីសម្រេច ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ សេចក្តីសម្រេច ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E439/5**។

[109] សាលដីកា *Pélissier និង Sassi ទល់នឹងប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការកំពូល) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ ៥១។ សាលដីកា *Mattoccia ទល់នឹងប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ៥៩។

[110] មាត្រា ១៤.៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

១០៨. អង្គជំនុំជម្រះមិនទាន់បានកំណត់វិសាលភាពឱ្យបានត្រឹមត្រូវនៅឡើយសម្រាប់ការជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ ដែលកំពុងដំណើរការ ខណៈដែលការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០១ មិនទាន់ត្រូវបានបញ្ចប់ជាស្ថាពរ និងដោយគ្មានព័ត៌មានអំពីជោគវាសនានៃបទចោទដែលមិននៅក្នុងការជំនុំជម្រះទាំងពីរនេះ។ ចំពោះមុខ អង្គជំនុំជម្រះគួរតែផ្តល់ភាពច្បាស់លាស់បន្ថែម និងបង្ហាញភាពច្បាស់លាស់បំផុត នៅក្នុងស្ថានភាពស្មុគស្មាញ និងមិនធ្លាប់មានពីមុនមក។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបែរជាមិនបានកំណត់វិសាលភាពច្បាស់លាស់ពីបទចោទដែលបាន ឬមិនបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០២ ហើយថែមទាំងទទួលបានបានបទចោទដែលបានប្តឹងមកខ្លួននៅក្នុងដីកាដំណោះស្រាយកាន់តែកើនច្រើនឡើងទៀតផង។

១០៩. **ទីមួយ** វិសាលភាពនៃសំណុំរឿង ០០២/០២ មិនត្រូវបានកំណត់នៅក្នុងរបៀបមួយដែលអាចយល់បានគ្រប់គ្រាន់ សម្រាប់មេធាវីការពារក្តី ហើយក៏ប្រហែលជាសម្រាប់អង្គជំនុំជម្រះផ្ទាល់ផងដែរ។

១១០. នៅពេលនោះ មេធាវីការពារក្តីហាក់ដូចជាយល់ច្បាស់ថា អង្គជំនុំជម្រះនឹងមិនពិនិត្យលើអង្គហេតុក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងការជម្លៀសប្រជាជន ដែលបានជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ទេ។ ក៏ប៉ុន្តែ នៅពេលអានសំអាងហេតុសាលក្រម ក្រុមមេធាវីការពារក្តីបានរកឃើញថា អង្គជំនុំជម្រះមិនអនុវត្តបែបនេះឡើយ។ អង្គជំនុំជម្រះបានពិចារណានៅក្នុងផ្នែកសំអាងហេតុថា វាមានលក្ខណៈ "ពាក់ព័ន្ធក្នុងការពិនិត្យរួមគ្នាលើ<u>ការជម្លៀសប្រជាជន</u> លើការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ ដោយផ្អែកលើភាពត្រួតស៊ីគ្នានៃគោលបំណងនយោបាយ និងមនោគមន៍វិជ្ជានៃការជម្លៀសប្រជាជន"[111]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញទឡ្ហីករណ៍ទាក់ទងនឹងគោលនយោបាយជម្លៀសប្រជាជន[112] ហើយបន្ទាប់មក បានពិនិត្យគោលនយោបាយនេះយ៉ាងយូរគួរសម[113]។

---

[111] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[112] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៩-៣៨៧១។

[113] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៧៧-៣៨៨៣, ៣៨៩២, ៣៩០៣, ៣៩០៨, ៣៩១៥-៣៩១៦, ៣៩១៨។

១១១. ទោះយ៉ាងណា អង្គជំនុំជម្រះបានប្រកាសនៅក្នុងដីកាបំបែកបទចោទរបស់ខ្លួនថា អង្គជំនុំជម្រះបានដាក់បញ្ចូលគោលនយោបាយជម្លៀសប្រជាជននៅក្នុងសំណុំរឿង ០០២/០២ "នៅក្នុងករណីដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះអះអាងថា ដីកានេះត្រូវបានអនុវត្តនៅក្នុងបរិបទនៃការជម្លៀសជនជាតិភាគតិចចាម តែប៉ុណ្ណោះ"[114]។ ឧបសម្ព័ន្ធនៃដីកានេះចែងថា៖ "ការពិនិត្យនឹងត្រូវបានកម្រិតត្រឹមវិធានការនានាដែលធ្វើឡើងប្រឆាំងនឹងជនជាតិភាគតិចចាម ក្នុងបរិបទនៃការអនុវត្តគោលនយោបាយនេះ (ដំណាក់កាលទី ២)"[115]។ មេធាវីការពារក្តីកាន់តែយល់ច្បាស់ថា អង្គជំនុំជម្រះនឹងមិនពិនិត្យលើអង្គហេតុផ្សេងក្រៅពីអង្គហេតុពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម នៅក្នុងការជម្លៀសប្រជាជនដំណាក់កាលទី២ និងថា នៅក្នុងសវនាការ អង្គជំនុំជម្រះ បានបញ្ឈប់ភ្លាមៗចំពោះភាគីណាដែលចោទសួរអំពីដំណាក់កាលទី១ នៃការជម្លៀសប្រជាជន[116]។ ក្នុងល័ក្ខខ័ណ្ឌទាំងនេះ វាមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេ ដែលមេធាវីការពារក្តីមិនបានបង្ហាញចទឡ្ហីករណ៍លើគោលនយោបាយជម្លៀសប្រជាជនដែលមេធាវីការពារក្តីគួរនឹងធ្វើ ប្រសិនបើបានដឹងថាអង្គជំនុំជម្រះនឹងពិនិត្យមើលទឡ្ហីករណ៍របស់ខ្លួន។

១១២. លើសពីនេះទៀត មេធាវីការពារក្តីមិនមាន (និងនៅតែមិនមាន) ការយល់ដូចគ្នានឹងអង្គជំនុំជម្រះ អំពីការកំណត់បទចោទទាក់ទងនឹងជនជាតិចាមក្នុ ងអំឡុងពេលជម្លៀសប្រជាជន ដំណាក់កាលទី ២[117]។

[114] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E301/9/1** កថាខណ្ឌ ៤៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[115] ឧបសម្ព័ន្ធនៃសំណុំរឿង០០២/០២ ឯកសារ **E301/9/1.1** ទំព័រ ១។ សូមមើលផងដែរ ទំព័រ ២៖ "៣. អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម - ការផ្លាស់ទីលំនៅប្រជាជន - ១) ដំណាក់កាលទី២ (កថាខណ្ឌ ២៦៦, ២៦៨ និង ២៨១) (កម្រិតត្រឹមតែការប្រព្រឹត្តិលើជនជាតិចាម)"។

[116] ជាឧទាហរណ៍៖ ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/387.1** ចន្លោះម៉ោង 10.55.17 និងម៉ោង 10.56.58 (ប្រធានអង្គប្រជុំ៖ "អង្គជំនុំជម្រះរំឭកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី [...] អង្គហេតុដែលសួរនេះទំនងជានៅក្នុង០០២/០១ យើងធ្វើសវនាការរួចហើយ")។

[117] សូមមើលខាងក្រោម កថាខណ្ឌ ៥៣៨-៥៤៦។

១១៣. លើសពីនេះទៀត កង្វះវិរភាពរបស់អង្គជំនុំជម្រះក្នុងការកំណត់បទចោទឱ្យបានច្បាស់ និងជាក់លាក់ គឺបង្ហាញពីភាពមិនប្រក្រតីនៃឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង ០០២/០២ ជាពិសេស ទាក់ទងទៅនឹងបទចោទជាក់លាក់ពាក់ព័ន្ធនឹងជនជាតិវៀតណាម។

១១៤. ទោះបីជាការប្រព្រឹត្តិលើជនជាតិវៀតណាមត្រូវដាក់ឱ្យពិនិត្យក្នុងសំណុំរឿង ០០២/០២ និងត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយថា ការបាត់ខ្លួនដោយបង្ខំត្រូវបានរកឃើញនៅក្នុងបរិបទនេះ[118] អង្គជំនុំជម្រះមិនបានចុះបញ្ជីបទចោទទាំងនេះ ទៅក្នុងឧបសម្ព័ន្ធកំណត់វិសាលភាពសំណុំរឿង០០២/០២ ឡើយ[119]។ ប្រសិនបើមិនបានយល់ពីមូលហេតុ មេធាវីការពារក្តីប្រាកដជានឹងមិនប្តឹងតវ៉ា ហើយគ្រាន់តែស្នើសុំឱ្យដកធាតុផ្សំដែលទទួលបាន និងបានស្តាប់ ស្តីពីអង្គហេតុទាំងនេះ[120]។ ទោះបីប្រព្រឹត្តកំហុសបែបនេះក្តី អង្គជំនុំជម្រះនៅតែបានព្យាយាមគ្រប់យ៉ាងកែខៃកំហុស ដោយដាក់បញ្ចូលឡើងវិញដោយខុសច្បាប់នូវអង្គហេតុទាំងនេះ ទៅក្នុងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មរងការចោទប្រកាន់[121]។

១១៥. មេធាវីការពារក្តីក៏មិនយល់ដែរថា ហេតុអ្វីបទចោទអំពីការនិរទេសខ្លួនទៅត្រាំកក់ មិនមាននៅក្នុងឧបសម្ព័ន្ធកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២[122]។ រហូតដល់ការរៀបចំចម្លើយតបរបស់ខ្លួនទៅនឹងសារណារបស់ភាគីផ្សេងទៀតសម្រាប់ការជជែកពិភាក្សាផ្ទាល់មាត់ ទើបក្រុមមេធាវីការពារក្តីយល់ថា ពុំមានបទចោទនេះជាភាសាបារាំងនៅក្នុងឧបសម្ព័ន្ធទេ លើកលែងតែភាសាអង់គ្លេស និងភាសាខ្មែរ។ មេធាវីការពារក្តីបានយកចិត្តទុកដាក់លើកឡើងពីបញ្ហានេះ នៅក្នុងសវនាការ[123]។ នៅក្នុងសំអាងហេតុសាលក្រម[124] អង្គជំនុំជម្រះមិនបានពិចារណា ទាំងលើសេចក្តីថ្លែងការណ៍របស់មេធាវីការពារក្តីនៅក្នុងអំឡុងពេលពិភាក្សាផ្ទាល់មាត់ ទាំងលើដីកាបបំបែកបទចោទ និងឧបសម្ព័ន្ធ ដែលត្រូវ

---

[118] ដីកាដំណោះស្រាយ កថាខណ្ឌ១៤៧០។

[119] ឧបសម្ព័ន្ធនៃសំណុំរឿង០០២/០២ ឯកសារ **E301/9/1.1** ទំព័រ ៥។

[120] សេចក្តីសន្និដ្ឋានបញ្ចប់ ០០២/០២ កថាខណ្ឌ ១៩៣០-១៩៣១។

[121] សូមមើលខាងក្រោម កថាខណ្ឌ៥៤៧-៥៤៩។

[122] សេចក្តីសន្និដ្ឋានបញ្ចប់ ០០២/០២ កថាខណ្ឌ ២២៨ និង ៩៦៥។

[123] ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ **E1/525.1** ចន្លោះម៉ោង 10.42.03 និងម៉ោង 10.11.59។

[124] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩។

បានចេញជាបីភាសាដើម[125]។ ដូច្នេះ ភាសាបារាំង គឺត្រូវតែជាភាសាដើមដូចគ្នានឹងភាសាអង់គ្លេស និងខ្មែរដែរ[126]។ ប្រាកដណាស់ មេធាវីការពារក្តីគួរតែអាចបានដឹងអំពីភាពខុសគ្នានេះ ប៉ុន្តែ វាជាកាតព្វកិច្ចចម្បងរបស់អង្គជំនុំជម្រះក្នុងការយកចិត្តទុកដាក់ខ្ពស់លើព័ត៌មានស្តីពីការកំណត់ដែននីតិវិធីដែលខ្លួនបានសម្រេច។

១១៦. អង្គជំនុំជម្រះក៏មិនបានយកចិត្តទុកដាក់ផងដែរ ក្នុងការបញ្ចៀសការភាន់ច្រឡំជុំវិញបទចោទអំពីការនិរទេសខ្លួនជនស៊ីវិលដោយខុសច្បាប់ ដែលមិនគួរមានក្នុងឧបសម្ព័ន្ធកំណត់ដែនសំណុំរឿង ០០២/០២ និងនៅក្នុងសំអាងហេតុសាលក្រមឡើយ[127]។ ជាក់ស្តែង អង្គជំនុំជម្រះបានសម្រេចមិនដាក់បញ្ចូលអង្គហេតុនៃការប្រព្រឹត្តិរបស់កងទ័ពបដិវត្តកម្ពុជាលើទឹកដីវៀតណាម ដែលជាអង្គហេតុតែមួយគត់ដែលអាចជាធាតុផ្សំនៃបទចោទបែបនេះ[128]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានចំណាយពេលវេលាដើម្បីលើកឡើងពីច្បាប់ជាធរមាន មុនពេលប្រកាសថាខ្លួនអាចពិនិត្យធាតុផ្សំនៃភ័ស្តុតាងពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ ដែលបានដកចេញពីសំណុំរឿង ០០២/០២ ក្នុងករណីធាតុផ្សំនោះមានជាប់ពាក់ព័ន្ធទៅនឹងបទចោទផ្សេងទៀត[129]។ អង្គជំនុំជម្រះបានប្រើវិធីដោយភាន់ច្រឡំ និងប្រើប្រភពមិនច្បាស់លាស់ ជាច្រើនលើកច្រើនសា[130]។ ប្រសិនបើអង្គជំនុំជម្រះបានច្បាស់តាំងពីដំបូង អង្គជំនុំជម្រះនឹងបានបញ្ចៀសរាល់ការភាន់ច្រឡំ និងចំណេញពេលវេលា។

១១៧. **ទីពីរ** ក្រៅពីការចង់ធ្វើសេចក្តីសម្រេចតែលើបទចោទដែលប្តឹងមកខ្លួនដោយហ្មត់ចត់ និងស្របច្បាប់ អង្គជំនុំជម្រះបានប្រើវិធីសាស្ត្រពង្រីកវិសាលភាពនៃបទចោទនៅក្នុងដីកាដំណោះស្រាយ។ ដូចយើង

---

[125] សូមមើលទំព័រផ្តើមនៃសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E301/9/1**។

[126] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កំណត់សម្គាល់ជើងទំព័រលេខ("ជើងទំព័រ") ៩៣៧ (នៃកថាខណ្ឌ ៣៨០)។

[127] ជាឧទាហរណ៍៖ សំអាងហេតុសាលក្រម កថាខណ្ឌ ១៦, ៣២៤, ៣២៦, ៧៧៤-៧៧៨, ២០៧៣។

[128] សេចក្តីសន្និដ្ឋានបញ្ចប់ ០០២/០២ កថាខណ្ឌ ១១៧៧ និង ២០៤-២១២។

[129] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៧៨។

[130] សូមមើលខាងក្រោម ផ្នែកបន្ទាប់។

នឹងបង្ហាញតាមរយៈការពិភាក្សានៅផ្នែកខាងក្រោម អង្គជំនុំជម្រះថែមទាំងបានពង្រីកវិសាលភាពនៃបទចោទរហូតដល់អង្គហេតុដែលមានលើកឡើងនៅក្នុងធាតុផ្សំនៃភស្តុតាង នៅក្នុងផ្នែកជើងទំព័រ តែមិននៅក្នុងបទចោទផ្ទាល់តែម្តងទេ។ នៅទីបំផុត អង្គជំនុំជម្រះបានផ្តន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋដែលគាត់មិនត្រូវបានគេចោទប្រកាន់ស្របច្បាប់ឡើយ[131]។ សូម្បីតែនៅពេលអង្គជំនុំជម្រះមិនបានផ្តន្ទាទោសគាត់ ក៏អង្គជំនុំជម្រះបានចំណាយពេលវេលាឥតប្រយោជន៍ ដើម្បីពិនិត្យអង្គហេតុទាំងនេះ[132]។

១១៨. **ទីបី** ដូចដែលនឹងពិភាក្សាខាងក្រោម អង្គជំនុំជម្រះបានរក្សា និងបន្ថែមភាពច្របូកច្របល់ជុំវិញការយល់ដឹងអំពីបណ្តឹងមកកាន់ខ្លួន និងបទចោទ ដោយការទទួលយក និងការស្តាប់ភស្តុតាងមិនពាក់ព័ន្ធ នៅពេញមួយអំឡុងពេលនៃសវនាការ[133] ដោយធ្វើការជំនុំជម្រះ (ដ៏យូរ) សម្រាប់ប្រវត្តិសាស្ត្រ។

## ផ្នែកទី ២. ការជំនុំជម្រះសម្រាប់ប្រវត្តិសាស្ត្រ

១១៩. វិធីសាស្ត្រមានលក្ខណៈប្រវត្តិសាស្ត្រច្រើនជាងគតិយុត្តិរបស់អង្គជំនុំជម្រះ បង្កឱ្យមាននីតិវិធីប្រតិបត្តិការច្រំដែល។ សូម្បីតែនៅពេលអង្គជំនុំជម្រះបានទទួលស្គាល់ថា ខ្លួនមិនបានទទួលបណ្តឹងពីអង្គហេតុដែលជនជាប់ចោទមិនត្រូវបានកាត់ទោសក៏ដោយ ក៏អង្គជំនុំជម្រះបានចាត់ទុកថា ធាតុផ្សំនៃភស្តុតាងលើអង្គហេតុទាំងនេះ មានភាពពាក់ព័ន្ធ (១) ហើយសូម្បីតែនៅពេលដែលអង្គជំនុំជម្រះបានរកឃើញថា គ្មានភស្តុតាងគ្រប់គ្រាន់លើអង្គហេតុមួយចំនួនក៏ដោយ ក៏អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋាន "ដោយចៃដន្យ" ដែលមិនចាំបាច់ទាល់តែសោះ (២)។

### ១. អង្គហេតុ"ក្រៅបរិបទ" តែ "ពាក់ព័ន្ធ"

131 សូមមើលខាងក្រោម កថាខណ្ឌ ៣៣៤-៥៣០។

132 ជាឧទាហរណ៍៖ កថាខណ្ឌ ១១៦១-១១៦៣។ កថាខណ្ឌ ៨០៩ និង ១១៦៧។ កថាខណ្ឌ ១១៣៩, និង ១១៤៦។ កថាខណ្ឌ ១៧៩៤-១៧៩៨។ កថាខណ្ឌ ១៥៩-១៦១ និង ៣០១៧-៣០១៨។ កថាខណ្ឌ ៣១៣២-៣១៣៥។

133 សូមមើលខាងក្រោម ចំណុចបន្ទាប់ និងកថាខណ្ឌ ១៧៥-២២៦។

១២០. រាល់ពេលដែលអង្គជំនុំជម្រះទទួលស្គាល់ថា ខ្លួនមិនបានទទួលបណ្ដឹងពីអង្គហេតុជាក់លាក់មួយចំនួន អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយពិចារណាថា ភ័ស្តុតាងលើអង្គហេតុទាំងនោះពាក់ព័ន្ធនឹងអ្វីផ្សេងទៀត[134]។

១២១. វិធីសាស្ត្រនេះមិនស្របគ្នានឹងតួនាទីរបស់អង្គជំនុំជម្រះ និងគោលបំណងនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានរំឭកដោយវិធានផ្ទៃក្នុងថា អង្គជំនុំជម្រះត្រូវតែពិនិត្យថាតើអង្គហេតុចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ដែលជាកម្មវត្ថុនៃការបញ្ជូនខ្លួនគាត់ទៅនុំជម្រះ ជាធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទេ ហើយថាតើគាត់អាចត្រូវដាក់ឱ្យទទួលខុសត្រូវ ឬអត់ចំពោះអង្គហេតុនោះ។ អង្គជំនុំជម្រះអាច និងត្រូវធ្វើសេចក្ដីសម្រេចតែលើអង្គហេតុទាំងនេះ (វិធាន ៩៨)។ ជនជាប់ចោទត្រូវតែការពារខ្លួនតែចំពោះអង្គហេតុទាំងនេះ។

១២២. ទន្ទឹមនឹងនេះ ពេញមួយអំឡុងពេលនៃការជំនុំជម្រះ និងជំនួសឱ្យការផ្ដោតលើអង្គហេតុក្នុងបណ្ដឹង អង្គជំនុំជម្រះបានទទួលយក និងស្ដាប់ធាតុផ្សំនៃភ័ស្តុតាង “ក្រៅបរិបទ តែពាក់ព័ន្ធ”។ ក្រុមមេធាវីការពារក្ដីបានបន្តបរិហារ និងប្រឆាំងនឹងការភាន់ច្រឡំនេះ។ មេធាវីការពារក្ដីបានពិពណ៌នាដ៏វែងនៅក្នុងសារណាចុងក្រោយរបស់ខ្លួន ដើម្បីរំឭកអំពីគោលការណ៍ និងវិសាលភាពនៃបណ្ដឹងបញ្ជូនមកចៅក្រមជំនុំជម្រះដែលជាអ្នកកំណត់ព័ត៌មានអំពីការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ[135]។

១២៣. ទោះបីជាមានបញ្ហានេះក៏ដោយ អង្គជំនុំជម្រះនៅតែបន្តប្រើប្រាស់ប្រភពមិនច្បាស់លាស់ និងបញ្ចប់ដោយប្រើប្រាស់ធាតុផ្សំទាំងនេះលើអង្គហេតុដែលមិនបានប្ដឹងមកខ្លួន ដើម្បីដាក់បន្ទុក ខៀវ សំផន ខណៈដែលគាត់មិនចាំបាច់ត្រូវធ្វើការការពារខ្លួនឡើយ។ ដោយរំលោភលើគោលការណ៍ដឹកនាំ និងគោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌ អង្គជំនុំជម្រះបានប្រើប្រភពទាំងនោះ ដើម្បីបង្កើតធាតុផ្សំឧក្រិដ្ឋ

---

[134] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០, ១៧៧-១៧៨, ១៨១-១៨៥, ១៨៦-១៨៨, ១៨៩-១៩០។ សូមមើលផងដែរផ្នែកបន្ទាប់នៃសារណានេះ។

[135] សារណាបណ្ដឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៥៩-២៩៩។

កម្មដទៃទៀត និងទម្រង់នៃការទទួលខុសត្រូវ ព្រមទាំងបានប្រើប្រាស់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដើម្បីកំណត់ទោស[136]។

១២៤. ដូច្នេះ អង្គជំនុំជម្រះបានធ្វើឱ្យអត្ថិភាព និងហេតុផលគ្រឹះនៃបទចោទ និងការបំបែកដំណើរការនីតិវិធីអស់ន័យ។ ខៀវ សំផន មិនចាំបាច់ និងមិនអាចការពារខ្លួន ចំពោះអ្វីៗទាំងឡាយដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

១២៥. អង្គជំនុំជម្រះបានប្រព្រឹត្តខុសអង្គច្បាប់ និងរំលោភសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជូនដំណឹងអំពីប្រភេទ និងមូលដ្ឋាននៃបទចោទប្រឆាំងនឹងរូបគាត់ ពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់ការរៀបចំការការពារក្តីរបស់គាត់ក្នុងតុលាការ តុលាការដែលចាត់ការតាមបណ្តឹងជាក់ស្តែង/បង្កើតឡើងដោយច្បាប់ សច្ចភាពគតិយុត្តិ និងនីតិវិធី តុលាការមិនលម្អៀង និងសិទ្ធិទទួលបានការជំនុំជម្រះដោយមិនយឺតយ៉ាវហួសហេតុ។

## ២. សេចក្តីសង្កេតដោយចៃដន្យ និងបន្ទាប់បន្សំ *(Obiter Dicta)*

១២៦. នៅពេលអង្គជំនុំជម្រះបានទទួលស្គាល់ថា គ្មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបង្កើតអង្គហេតុមួយចំនួនយ៉ាងណាក្តី ក៏អង្គជំនុំជម្រះបានប្រើពេលវេលាដើម្បីទាញសេចក្តីសន្និដ្ឋានឥតប្រយោជន៍សម្រាប់ដោះស្រាយវិវាទ[137]។ សេចក្តីសង្កេតដោយចៃដន្យ និងបន្ទាប់បន្សំទាំងនេះ[138] មិនគួរកើតមានឡើយ ជាពិសេស នៅក្នុងបរិបទមួយដែលជនជាប់ចោទត្រូវបានឃុំខ្លួនចាប់តាំងពីឆ្នាំ២០០៧ សវនាការលើអង្គសេចក្តីបាន

---

[136] សូមមើលខាងក្រោម កថាខណ្ឌ ៧៥៧, ១២៦២-១២៦៣, ២១៤៨-២១៥០។

[137] ជាឧទាហរណ៍៖ កថាខណ្ឌ ១១៣៧ កំណត់សម្គាល់ជើងទំព័រលេខ៤២៨៩ (នៃកថាខណ្ឌ ១២៥៦), ២១៧៣។

[138] វាក្យស័ព្ទច្បាប់ G. CORNU គ្រឹះស្ថានរៀបរៀង PUF បោះពុម្ពលើកទី៨ ឆ្នាំ២០០៧ « *Obiter dictum* »៖ ជាកម្រងពាក្យភាសាឡាតាំង [...] ប្រើសម្រាប់បង្ហាញ នៅក្នុងការជំនុំជម្រះ អំពីយោបល់ដែលចៅក្រមផ្តល់ជូន នៅក្នុងពេលកំពុងជំនុំជម្រះទុកជាឧទាហរណ៍ ឬជាការកត់សម្គាល់យូរៗម្តង។ ខុសពីសំអាងហេតុ ទោះបីជាសម្បូរបែបយ៉ាងណាក្តី វាមិនមានទំនោរទៅរកការផ្តល់ហេតុផលចំពោះសេចក្តីសម្រេចដែលមាន ប៉ុន្តែគ្រាន់តែដើម្បីធ្វើឱ្យដឹងជាមុន ក្នុងករណីចាំបាច់ ពីសញ្ចេតនារបស់ចៅក្រមទៅលើបញ្ហាផ្សេងៗទៀតខុសពីដំណោះស្រាយជម្លោះ ដែលតម្រូវឱ្យលោកសម្រេច"។

ប្រើពេលជាងពីរឆ្នាំ ការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ចុងក្រោយបានប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០១៧ ហើយដែលសាលក្រមត្រូវបានចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយគ្មានសំអាងហេតុ (ដែលបានចេញត្រឹមតែរយៈពេល ៤ ខែកន្លះ ក្រោយមក)។ ដូច្នេះ អង្គជំនុំជម្រះបានរំលោភសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ និងបង្ហាញពីភាពលម្អៀងរបស់អង្គជំនុំជម្រះ។

## ជំពូកទី ៣. វិធីសាស្ត្រមិនត្រឹមត្រូវ និងរើសអើង ក្នុងសំណុំរឿង ០០២/០២ ក្រោយការជំនុំជម្រះលើសំណុំរឿង ០០២/០១

### ផ្នែកទី ១. ចៅក្រមជិតជាមដោយភាពលម្អៀង

១២៧. អង្គជំនុំជម្រះបានប្រព្រឹត្តខុសអង្គច្បាប់ ដោយមិនបានឆ្លើយតប ឬឆ្លើយតបមិនបានគ្រប់គ្រាន់ ចំពោះការចោទប្រកាន់ពីអគតិភាព ដោយសារតែខ្លួនធ្លាប់បានជំនុំជម្រះរឿងក្តី ០០២/០១ រួចមកហើយ[139]។ អង្គជំនុំជម្រះគួរតែឆ្លើយតបរឿងនេះ និងទទួលស្គាល់ថា បន្ទាប់ពីបានវិនិច្ឆ័យសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនកាត់ផ្តាច់ទាំងស្រុងពីភាពលម្អៀង ក្នុងការកាត់សេចក្តីលើសំណុំរឿង ០០២/០២ ឡើយ។ ជាក់ស្តែង វាមិនអាចទៅរួចទេក្នុងនាមយុត្តិធម៌ ក្នុងការមិនគោរពតាមសេចក្តីសន្និដ្ឋានអង្គហេតុ និងអង្គច្បាប់ ដែលអង្គជំនុំជម្រះបានធ្វើក្នុងសំណុំរឿង ០០២/០១ ដែលជះឥទ្ធិពលលើសំណុំរឿង ០០២/០២ នោះឡើយ។ អង្គជំនុំជម្រះបានរំលោភបំពានសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានសំអាងហេតុនៃដីកា និងសាលក្រម សិទ្ធិទទួលបានសច្ចាធារណ៍និរទោស និងសិទ្ធិទទួលបានតុលាការមិនលម្អៀង។

[139] សំអាងហេតុសាលក្រម កថាខណ្ឌ១១៣-១១៥។ អង្គជំនុំជម្រះមិនបានរំឭក ហើយក៏មិនបានយោងទៅទឡ្ហីករណ៍ដែលបានផ្តល់ជូនដោយមេធាវីការពារក្តីនៅក្នុងសារណាបណ្តឹងសាទុក្ខ០០២/០២ សោះឡើយ កថាខណ្ឌ ៦៥១-៦៥៨។ អង្គជំនុំជម្រះបានត្រឹមតែច្រានចោលទឡ្ហីករណ៍ខ្លះ ដោយក្រុមចៅក្រមពិសេសដែលបានពិនិត្យសម្រេចលើបណ្តឹងជំទាស់ (កថាខណ្ឌ ១១៥)។

១២៨. មេធាវីការពារក្ដីសូមយោងទៅលើសេចក្ដីសន្និដ្ឋានពីមុនរបស់ខ្លួនលើប្រធានបទនេះ[140] និងយោងលើច្បាប់ជាធរមាន ដែលបានបង្ហាញនៅក្នុងបណ្ដឹងជំទាស់របស់ខ្លួនប្រឆាំងនឹងចៅក្រមនៃតុលាការកំពូល ដែលបានធ្វើសេចក្ដីសម្រេចនៅក្នុងសំណុំរឿង ០០២/០១[141]។

១២៩. ការអានសំអាងហេតុសាលក្រមកាន់តែពង្រឹងទឡ្ហីករណ៍បន្ថែមទៀតថា បណ្ដឹងជំទាស់របស់មេធាវីការពារក្ដីចំពោះចៅក្រមនៃអង្គជំនុំជម្រះ គួរតែត្រូវបានទទួលយកមុនពេលចាប់ផ្ដើមសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះមិនត្រឹមតែបានជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ តាមរបៀបដូចគ្នានឹងបញ្ហាដែលអង្គជំនុំជម្រះបានសម្រេចក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះទេ[142] ក៏ប៉ុន្តែ អង្គជំនុំជម្រះពិតជាបានអនុវត្តតាមសេចក្ដីសន្និដ្ឋានដែលខ្លួនបានទាញទុកជាមុនសម្រាប់សំណុំរឿង ០០២/០២[143]។ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានសម្រេចថា សេចក្ដីសន្និដ្ឋាននោះមានតម្លៃផ្ដាច់មុខ ហើយដោយសារតម្លៃផ្ដាច់មុខនេះ សេចក្ដីសន្និដ្ឋានមិនអាចត្រូវបានត្រួតពិនិត្យឡើងវិញក្នុងបណ្ដឹងសាទុក្ខឡើយ[144]។ វាច្បាស់ណាស់ថា នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះមិនបានឃ្លាតឆ្ងាយពីអារម្មណ៍ជិតដាមនឹងបញ្ហាមួយចំនួននៃសំណុំរឿង០០២/០២ ដែលខ្លួនបានធ្វើឱ្យគេដឹងជាមុននោះទេ។

១៣០. សេចក្ដីសន្និដ្ឋានទាញចេញពីក្នុងសំណុំរឿង ០០២/០១ ស្ដីពីអត្ថិភាពនៃគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ ប.ក.ក[145] បន្ទាប់ពីបានរកឃើញធាតុផ្សំនៃភ័ស្ដុតាងនៅក្នុងទិសដៅនេះ និង

---

[140] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ E314/1។ បណ្ដឹងជំទាស់សាជាថ្មី ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ ឯកសារ E314/8។ សារណាបណ្ដឹងសាទុក្ខ០០២/០១ កថាខណ្ឌ ១២, ៤៧ និងកំណត់សម្គាល់ជើងទំព័រលេខ ១១៦, ១៩៧, ៥៨១-៥៨២។ សារណាបណ្ដឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៦៥០-៦៥៨។

[141] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ឯកសារ F53 កថាខណ្ឌ ២៥-៣៩។

[142] ជាពិសេសចំពោះសំណួរទាក់ទងនឹងល័ក្ខខ័ណ្ឌទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះគម្រោងរួមនៃសហឧក្រិដ្ឋកម្មរួម ការជម្លៀសប្រជាជន តួនាទីរបស់លោក ខៀវ សំផន និងក្នុងការចូលរួមគម្រោងបដិវត្តន៍សង្គមនិយម នៃ ប.ក.ក។

[143] ជាពិសេសចំពោះសំណួរទាក់ទងនឹងគម្រោងសហឧក្រិដ្ឋកម្មរួម ទៅនឹងសហករណ៍ និងការដ្ឋានធ្វើការងារ ការរៀបអាពាហ៍ពិពាហ៍ និងតួនាទីរបស់លោក ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងស្រុង។

[144] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២២៩។

[145] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៣០។

ធាតុផ្សំផ្សេងទៀតក្នុងទិសដៅផ្ទុយពីនេះ[146] គឺជាឧទាហរណ៍មួយគ្រប់គ្រាន់។ ដូច្នេះ មុននឹងពិនិត្យមើល ធាតុផ្សំនៃភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានសម្រេចរួចហើយក្នុងទិសដៅមួយដែល ខ្លួនចង់បាន។ វាច្បាស់ណាស់ថា អង្គជំនុំជម្រះនឹងសម្រេចក្នុងទិសដៅតែមួយដូចគ្នាក្នុងសំណុំរឿង ០០២/០២[147]។ ដូច្នេះ តើអង្គជំនុំជម្រះអាចធ្វើអ្វីបានខុសពីនេះ ក្នុងនាមយុត្តិធម៌?

១៣១. ការប្រាសចាកពីការសន្និដ្ឋានសំខាន់ៗបែបនេះ មិនមែនមិនអាចទៅរួចទេក្នុងនាមយុត្តិធម៌ ជាពិសេស ចៅក្រមដែលបានបំបែកកិច្ចដំណើរការនីតិវិធី និងបានជំនុំជម្រះក្តីលើសំណុំរឿង ០០២/០១ (និងចូល ដល់សំណុំរឿង ០០២/០២) ក្នុងការពិចារណាថា សំណុំរឿង ០០២/០១ នឹងត្រូវប្រើជា "មូលដ្ឋាន ទូទៅ" សម្រាប់ការជំនុំជម្រះផ្សេងទៀតជាយថាហេតុ[148] ដែលសម្រាប់ចៅក្រមទាំងនោះ គ្រាន់តែជា "កិច្ចការបន្ត" មកពីការជំនុំជម្រះដំបូង តែមិនមែនជាការជំនុំជម្រះដាច់ដោយឡែកឡើយ[149]។ ជាក់ស្តែង ចៅក្រមបានប្រកាសតាំងពីឆ្នាំ២០១១ ថា៖

> "អង្គជំនុំជម្រះរំពឹងថាសវនាការដំណាក់កាលដំបូងនេះ នឹងផ្តល់ជាមូលដ្ឋានទូទៅមួយ សម្រាប់ ការពិនិត្យមើលអង្គហេតុទាំងអស់ដែលចោទប្រកាន់ជនជាប់ចោទ រួមទាំងបទចោទនានាដែល អង្គជំនុំជម្រះនឹងលើកយកទៅពិនិត្យក្នុងសវនាការដំណាក់កាលបន្ទាប់"[150]។

---

[146] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១២៨-១២៩។

[147] សំអាងហេតុសាលក្រម កថាខណ្ឌ ចំណុច ៣.៥ និង ១៤។

[148] សេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ឯកសារ **E124/7** កថាខណ្ឌ ១០។ សេចក្តីសម្រេច ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១៣ ឯកសារ **E284** កថាខណ្ឌ ១៥។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៤ កថាខណ្ឌ ៥។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E301/9/1** កថាខណ្ឌ ២៣។

[149] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ **E302/5** កថាខណ្ឌ ៥ និង ៧ (សម្រង់សម្តី ទាញចេញពីកថាខណ្ឌ ៧)។

[150] ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ឯកសារ **E131** កថាខណ្ឌ ៣។

១៣២. ក្នុងរឿងនេះ វាជាការលំបាកក្នុងការមើលឃើញអ្វីផ្សេងទៀត ក្រៅពីចេតនាមិនងាកវេររបស់អង្គជំនុំជម្រះក្នុងការដាក់មូលដ្ឋានទូទៅនៃមតិយោបល់របស់ខ្លួនទៅលើអង្គហេតុដែលបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ក្នុងសំណុំរឿង ០០២/០១ និងក្រៅពីការគិតថា សំណុំរឿង ០០២/០២ គ្រាន់តែជាការកិច្ចការបន្តរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះ។

១៣៣. ក្នុងឆ្នាំ២០១៤ ជាពិសេស តុលាការកំពូល បានទាក់ទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះទៅលើបញ្ហា "នៃការបង្កើតវិធីសាស្ត្រមិនត្រឹមត្រូវដែលចាត់ទុកសេចក្ដីសន្និដ្ឋានទាញចេញនៅក្នុងការជំនុំជម្រះមួយ ថាជា "មូលដ្ឋាន" សម្រាប់ការជំនុំជម្រះមួយផ្សេងទៀត"[151]។ ថ្វីបើអង្គជំនុំជម្រះបានប្រកាសថានឹងពិចារណាលើបញ្ហានេះ[152] ក៏ប៉ុន្តែ សំអាងហេតុសាលក្រមបង្ហាញថា អង្គជំនុំជម្រះមិនដែលឃ្លាតឆ្ងាយពីទស្សនាទានឯកតោភាគីមិនងាកវេររបស់ខ្លួន អំពីការជំនុំជម្រះឡើយ។

## ផ្នែកទី ២. ចៅក្រមដែលមានទស្សនាទានឯកតោភាគីអំពីការជំនុំជម្រះ

### ១. ការលោតរំលងតាមទស្សនៈច្បាប់

#### ១.១. ការជំនុំជម្រះពីរដងចំពោះអង្គហេតុដដែល *(Bis in idem)*

---

[151] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២២៨៖ "ទាក់ទងទៅនឹងភាពស្មុគស្មាញជាសក្ដានុពល ដែលបណ្ដាលមកពីភាពត្រួតគ្នានៃការយល់ឃើញផ្នែកអង្គហេតុនៅក្នុងស្ថានភាព ដែលមានជនជាប់ចោទដដែលកំពុងត្រូវបានជំនុំជម្រះម្ដងទៀតដោយក្រុមប្រឹក្សាដដែលសម្រាប់បទឧក្រិដ្ឋដែលកើតចេញពីមូលដ្ឋាននៃអង្គហេតុរួមតែមួយ និងទាក់ទងទៅនឹងភាពពុំសមស្របក្នុងការចាត់ទុកការយល់ឃើញក្នុងរឿងក្ដីមួយធ្វើជា"មូលដ្ឋាន"សម្រាប់រឿងក្ដីមួយផ្សេងទៀត អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បញ្ហានេះម្ដងហើយម្ដងទៀត និងរំឭកអំពីការយល់ឃើញរបស់ខ្លួននៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធី។ ទោះជាយ៉ាងណាក្ដី បញ្ហានេះពុំមានឥទ្ធិពលលើរឿងក្ដីបច្ចុប្បន្នឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញមានភាពចាំបាច់ក្នុងការវាយតម្លៃលើបញ្ហានេះបន្តទៀតឡើយ"។ តុលាការកំពូលបានយោងទៅកំណត់សម្គាល់ជើងទំព័រ ៥៦០ នៅក្នុងសេចក្ដីសម្រេចជាច្រើនរបស់ខ្លួន ក្នុងនោះមានសេចក្ដីសម្រេច ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E301/9/1/1/3** (មានការពង្រីកសេចក្ដីច្រើនជាងពេលមុន លើប្រធានបទនេះ ប៉ុន្តែបានសម្រេចមួយសប្ដាហ៍មុនចេញ សាលក្រម សំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ ដូច្នេះមិនមានអានុភាពលើសាលក្រមនេះឡើយ)។ នៅក្នុងសេចក្ដីសម្រេចទាំងនោះ តុលាការកំពូលបានអះអាងថាបានបង្កើតអង្គចៅក្រមថ្មី សម្រាប់សំណុំរឿង ០០២/០២។

[152] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦ និងកំណត់សម្គាល់ជើងទំព័រលេខ ៨៣។

១៣៤. ដូចដែលនឹងត្រូវបរិយាយខាងក្រោម[153] ទោះបីជាមានការបំបែបកបទចោទ អង្គជំនុំជម្រះបានកាត់ទោស ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ ចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវបានផ្តន្ទាទោសរួចហើយក្នុងសំណុំរឿង ០០២/០១ ដោយរំលោភគោលការណ៍ "គ្មានការជំនុំជម្រះពីរដងសម្រាប់អង្គហេតុដដែល" (non bis in idem)។ តុលាការកំពូលត្រូវតែបដិសេធការផ្តន្ទាទោសថ្មីទាំងនេះ ហើយប្រកាសថា ការជំនុំជម្រះក្តី ខៀវ សំផន គឺអយុត្តិធម៌។

## ១.២. ការកំណត់បទចោទសាជាថ្មីដោយខុសច្បាប់

១៣៥. អង្គជំនុំជម្រះបានពិចារណាថា ដោយមិនប៉ះពាល់ដល់សមភាពនៃការជំនុំជម្រះ ខ្លួនអាចកំណត់បទចោទសាជាថ្មីចំពោះអង្គហេតុ "សម្លាប់រង្គាល" នៅក្នុងដីកាដំណោះស្រាយ ដែលជាធាតុផ្សំនៃអំពើឃាតកម្មដោយចេតនាប្រយោល។ អង្គជំនុំជម្រះបានអនុវត្តបែបនេះ ជាច្រើនលើក[154] នៅពេលបន្ទាប់មក។ ក្នុងការអនុវត្តដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដែលធ្វើឱ្យសេចក្តីសម្រេចរបស់ខ្លួនអស់សុពលភាព។

១៣៦. ប្រាកដណាស់ អង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវអំពីវិធានជាធរមានពាក់ព័ន្ធនឹងការកំណត់បទចោទ តែអង្គជំនុំជម្រះមិនបានអនុវត្តវិធានទាំងនេះឱ្យបានត្រឹមត្រូវទេ។ អង្គជំនុំជម្រះពិតជាបានរំឭកពីវិធាន ៩៨ (២) នៃវិធានផ្ទៃក្នុង ដែលផ្អែកលើវិធាននេះ អង្គជំនុំជម្រះអាចកំណត់បទចោទសាជាថ្មី "ក្នុងករណីមិនដាក់បញ្ចូលធាតុផ្សំថ្មីណាមួយ"។ អង្គជំនុំជម្រះក៏បានរំឭកផងដែរ អំពីវិធានសមធម៌ ដែលជនជាប់ចោទត្រូវទទួលបានការជូនដំណឹងអំពីលទ្ធភាពនៃការផ្លាស់ប្តូរបទចោទ[155]។ អង្គជំនុំជម្រះបានរំឭកថា ការកំណត់បទចោទនៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធតែនឹងអង្គហេតុនៃការសម្លាប់រង្គាលប៉ុណ្ណោះ និងថា ការណត់បទចោទសាជាថ្មីចំពោះអង្គហេតុឃាតកម្មដោយចេទនាប្រយោល "នឹងមានលក្ខណៈត្រឹមត្រូវ តែក្នុងករណីដែលវាមិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំ

[153] សូមមើលខាងក្រោម ផ្នែកទី ១ មាតិកាទី ៤ ជំពូក៣ កថាខណ្ឌ ៥៣៨-៥៤៦។

[154] សំអាងហេតុសាលក្រម កថាខណ្ឌ ១៥៣-១៥៧។ សូមមើលខាងក្រោម ផ្នែកទី ១។

[155] សំអាងហេតុសាលក្រម កថាខណ្ឌ ១៥៣។

ជម្រះក្តីដោយយុត្តិធម៌”[156]។ ប៉ុន្តែ អង្គជំនុំជម្រះបានពិចារណាខុសថា ដោយសារតុលាការកំពូលបានអនុវត្តការកំណត់បទចោទសាជាថ្មីបែបនេះនៅក្នុងសាលដីកា ០០២/០១ ជនជាប់ចោទត្រូវបានជូនដំណឹង “យ៉ាងត្រឹមត្រូវ” អំពីលទ្ធភាពនៃការកំណត់បទចោទសាជាថ្មី នៅក្នុងសំណុំរឿង ០០២/០២ (១.២.១)។ អង្គជំនុំជម្រះមិនបាននិយាយអ្វីទាំងអស់អំពីការបញ្ចូលធាតុផ្សំថ្មីមួយ ដែលអង្គជំនុំជម្រះបានធ្វើ (១.២.២)។

## ១.២.១. កង្វះព័ត៌មានអំពីការកំណត់បទចោទសាជាថ្មី តាមការគ្រោងទុក

១៣៧. អង្គជំនុំជម្រះបានពិចារណាថា សាលដីកា ០០២/០១ ផ្តល់ការកត់សម្គាល់ដ៏មានសារៈសំខាន់ស្តីពីការកំណត់បទចោទសាជាថ្មីនៅក្នុងសំណុំរឿង ០០២/០២ ដោយហេតុថា សំណុំរឿង ០០២/០១ និង ០០២/០២ “ចេញមកពីដីកាបញ្ជូនរឿងទៅជំនុំជម្រះតែមួយ” ហើយ “សំណុំរឿង” ព្រមទាំងភាគី និងអ្នកតំណាងរបស់ពួកគេ មិនមានការផ្លាស់ប្តូរទេនៅក្នុងការការជំនុំជម្រះនានា និងដោយសារ “ចំណងពិសេសដែលចងភ្ជាប់ការជំនុំជម្រះទាំងពីរ និងភាពស្រដៀងគ្នានៃស្ថានភាពអង្គហេតុជាក់ស្តែងដែលត្រូវយកមកពិចារណា”[157]។

១៣៨. វិចារណកិច្ចនេះមិនបានពិចារណាពីភាពខុសគ្នាជាមូលដ្ឋាន រវាងសំណុំរឿង ០០២/០១ និង ០០២/០២ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធី ដែលនឹងនាំទៅដល់ការបំបែកបទចោទប្រឆាំនឹងជនជាប់ចោទ ហើយដែលពួកគេត្រូវការពារខ្លួន។ ការកំណត់បទចោទសាជាថ្មីដែលធ្វើឡើងក្នុងករណីមួយទៀត ដោយយុត្តាធិការផ្សេងទៀត មិនអាចលើកលែងអង្គជំនុំជម្រះឱ្យរួចផុតពីកាតព្វកិច្ចក្នុងការជូនដំណឹងដល់ជនជាប់ចោទអំពីចេតនាជាយថាហេតុរបស់អង្គជំនុំជម្រះក្នុងការផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់នៅក្នុងសំណុំរឿង ០០២/០២ ដែលជាចំណាត់ការរបស់អង្គជំនុំជម្រះ និងដែលមានបទចោទខុសគ្នាឡើយ។

---

[156] សំអាងហេតុសាលក្រម កថាខណ្ឌ ១៥៤។

[157] សំអាងហេតុសាលក្រម កថាខណ្ឌ ១៥៥-១៥៧ (សម្រង់សេចក្តីទាញចេញពីកថាខណ្ឌ ១៥៦ និង ១៥៧)។

១៣៩. ដូច្នេះ អង្គជំនុំជម្រះត្រូវជូនដំណឹងក្នុងសំណុំរឿង ០០២/០២ អំពីការផ្លាស់ប្តូរបទចោទដែលអាចកើតមានក្នុងសំណុំរឿង ដើម្បីឱ្យជនជាប់ចោទអាចការពារខ្លួននៅក្នុងសំណុំរឿង ០០២/០២។

១៤០. អង្គជំនុំជម្រះមិនបានធ្វើដូច្នោះទេ ដោយរំលោភលើវិធានសមធម៌ និង"ភាពចំបាច់នៃវិរភាពខ្ពស់បំផុតក្នុងការជូនដំណឹងអំពី "បទចោទ" ដល់បុគ្គលពាក់ព័ន្ធ"[158]។ ជនជាប់ចោទត្រូវតែទទួលបានការជូនដំណឹង "ឱ្យបានលឿនបំផុត" និង "ដោយលម្អិត" អំពីបទចោទប្រឆាំងនឹងរូបគាត់[159]។ ដូច្នេះ "ព័ត៌មានច្បាស់លាស់ និងពេញលេញអំពីបទចោទប្រឆាំងនឹងជនជាប់ចោទ រួមទាំងការកំណត់បទចោទដែលតុលាការនឹងអាចអនុម័តប្រឆាំងនឹងរូបគាត់ គឺជាលក្ខខ័ណ្ឌចាំបាច់នៃសមភាពនីតិវិធី"[160]។ ក្នុងករណី "ផ្លាស់ប្តូរបទចោទ រួមទាំងការកែប្រែទាំងឡាយដែលប៉ះពាល់ដល់ "បុព្វហេតុ" របស់គាត់ ជនជាប់ចោទត្រូវតែទទួលបានការជូនដំណឹងត្រឹមត្រូវ និងពេញលេញ និងត្រូវតែមានពេលវេលា និងសម្ភារៈចាំបាច់សម្រាប់ប្រតិកម្មតប និងរៀបចំការពារខ្លួនដោយផ្អែកលើរាល់ព័ត៌មាន ឬការចោទប្រកាន់ថ្មីៗ"[161]។

១៤១. ហេតុដូច្នេះ តុលាការត្រូវតែផ្តល់លទ្ធភាពដល់ជនជាប់ចោទក្នុងការរៀបចំការការពារខ្លួន ទាក់ទងនឹងការកំណត់បទចោទថ្មី "ដោយជាក់ស្តែង និងមានប្រសិទ្ធភាព ហើយជាពិសេស ក្នុងពេលវេលាសមស្រប"។ ព័ត៌មានអំពីលទ្ធភាពនៃការកំណត់បទចោទសាជាថ្មីតែមួយមុខ គឺមិនគ្រប់គ្រាន់ទេ សម្រាប់

---

158 សាលដីកា *Pélissier និង Sassi ទល់នឹងប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការវិសាមញ្ញ) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សាលដីកា *Mattoccia ទល់នឹងប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ៥៩។

159 មាត្រា ១៤.៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៦.៣.ក នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

160 សាលដីកា *Pélissier និង Sassi ទល់នឹងប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការវិសាមញ្ញ) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥១-៥៤ (សម្រង់សម្តីទាញចេញពីកថាខណ្ឌ ៥២ យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

161 សាលដីកា *Mattoccia ទល់នឹងប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ៦១។

ជនជាប់ចោទ។ គាត់ក៏ត្រូវទទួលបានឱកាស ដើម្បីជជែកតវ៉ាចំពោះមុខ និងការពារខ្លួនផងដែរ ពាក់ព័ន្ធនឹងការកំណត់បទចោទសាជាថ្មីនេះ[162]។

១៤២. ក្នុងករណីបច្ចុប្បន្ន អង្គជំនុំជម្រះមិនដែលជូនដំណឹងដល់មេធាវីការពារក្តី ពីលទ្ធភាពកំណត់បទចោទសាជាថ្មី ពីអង្គហេតុសម្លាប់រង្គាលទៅជាអង្គហេតុឃាតកម្មដោយចេតនាប្រយោល និងមិនដែលបានអញ្ជើញមេធាវីការពារក្តីឱ្យមកជជែកដេញដោលចំពោះមុខអំពីបញ្ហានេះ ដើម្បីឱ្យក្រុមមេធាវីអាចការពារខ្លួនបាន។

---

[162] សាលដីកា *Pélissier និង Sassi ទល់នឹងប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការវិសាមញ្ញ) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៦២ (“ដូច្នេះ តុលាការពិចារណាថាសាលាឧទ្ធរណ៍នៅ Aix-en-Provence ដោយបានប្រើប្រាស់សិទ្ធិ របស់ខ្លួនក្នុងការកំណត់ឡើងវិញឡើងវិញនូវអង្គហេតុដែលរងការចោទប្រកាន់ជារឿយៗនោះ ត្រូវ ផ្តល់លទ្ធភាពដល់អ្នកដាក់ពាក្យប្តឹង នូវសិទ្ធិក្នុងការប្រើប្រាស់ទទួលបានការការពារ របស់ខ្លួន ត្រង់ចំណុចនេះ ប្រកបដោយជាក់ស្តែង និង ប្រសិទ្ធភាពហើយជាពិសេស នៅក្នុងពេលវេលាមួយសមស្រប។ ក្នុងករណីនេះ អង្គជំនុំជម្រះ មិនបានលើកឡើងនូវភ័ស្តុតាងដែលអាចពន្យល់បាន ដូចជាការដែលមិនបានបញ្ជូនរឿងក្តីនេះទៅបើកកិច្ចពិភាក្សាដេញដោលថ្មី ឬក្នុងករណីចាំបាច់ មិនមានផ្ញើការស្នើសុំរបស់ម្ចាស់បណ្តឹង ដើម្បីទទួលបាននូវសេចក្តីសង្កេតជាលាយលក្សណ៍អក្សរពីអ្នកប្តឹងនោះ នៅក្នុងពេលកំពុងពិនិត្យសម្រេចសេចក្តីឡើយ។ ផ្ទុយទៅវិញ អ្វីដែលចេញពីសំណុំរឿងនោះ គឺថាម្ចាស់បណ្តឹងមិនមានឱកាសរៀបចំការការពារក្តីរបស់ខ្លួន ចំពោះមុខការកំណត់បទចោទថ្មី ពីព្រោះថាមានតែសាលដីកានៃសាលាឧទ្ធរណ៍តែមួយគត់ដែលអាចឱ្យពួកគេដឹងអំពីការផ្លាស់ប្តូរបទចោទ តែដល់ពេលនោះ វាហួសពេលទៅហើយ”)។ តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ លេខ ០៩-៨៧.៨៥៣ (“ដោយហេតុថា ទោះបីជាចៅក្រមនៃតុលាការព្រហ្មទណ្ឌជាអ្នកចាត់ចែងឡើងវិញនូវអង្គហេតុដែលចៅក្រមជាអ្នកទទួលពាក្យបណ្តឹងលើបទចោទក៏ពិតមែន តែជនជាប់ចោទត្រូវមានល័ក្ខខ័ណ្ឌសមស្របដើម្បីការពារខ្លួន ចំពោះបទចោទថ្មីដែលបានកំណត់។ (...) ទោះបីជានៅក្នុងសាលដីកាមានចែងថា អយ្យការ “បានស្នើសុំឱ្យអង្គជំនុំជម្រះកំណត់បទចោទឡើងវិញ លើអង្គហេតុហិង្សាដែលបានប្រព្រឹត្តចំពោះអ្នកទទួលបន្ទុកបំពេញបេសកកម្មសាធារណៈ”ក៏ដោយ ហើយទោះបីជា “លទ្ធភាពក្នុងការកំណត់បទចោទឡើងវិញត្រូវបានជូនដំណឹងដល់ជនជាប់ចោទ” យ៉ាងណាក្តី ប៉ុន្តែមិនមានទាំងសេចក្តីបញ្ជាក់នៅក្នុងសាលដីកា ក៏ដូចជានៅក្នុងវត្ថុតាងនៃដំណើរការនីតិវិធី ថាលោក X... ត្រូវបានស្នើឱ្យការពារខ្លួនចំពោះមុខការកំណត់បទចោទឡើងវិញនោះឡើយ។ ដូច្នេះ ការដែលសាលាឧទ្ធរណ៍បានប្រកាសដូចដែលខ្លួនបានធ្វើ គឺថាសាលាឧទ្ធរណ៍មិនបានដឹងពីអត្ថបទច្បាប់ដែលបញ្ជាក់ជូនខាងលើ និង គោលការណ៍ដែលបានរំឭកខាងលើ។ ដូច្នេះ ការបដិសេធត្រូវបានអនុវត្ត”)។ សូមមើលផងដែរ៖ សាលដីកា *Drassich ទល់នឹងប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ២០០៧ កថាខណ្ឌ ៣៤ និង ៣៦។

១៤៣. ដំបូង អង្គជំនុំជម្រះគួរតែអាចធ្វើបាន នៅពេលចាប់ផ្តើមការជំនុំជម្រះ នៅពេលដែលខ្លួនបានស្នើសុំឱ្យភាគីបញ្ជាក់នៅក្នុងសវនាការបឋម ថាតើពួកគេមានបំណង "ស្នើសុំធ្វើការកំណត់បទចោទសាជាថ្មីចំពោះអង្គហេតុមួយចំនួន និងទម្រង់នៃការចូលរួម ដែលបានយោងនៅក្នុងផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលពាក់ព័ន្ធក្នុងក្របខ័ណ្ឌនៃ [ការជំនុំជម្រះក្តី ០០២/០២]ដែរឬទេ"[163]។ អង្គជំនុំជម្រះមិនបានថ្លែងអ្វីទាំងអស់ពីបញ្ហានេះនៅឯសវនាការ ហើយមានតែសហព្រះរាជអាជ្ញាប៉ុណ្ណោះ ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាពីសហឧក្រិដ្ឋកម្មរួម-ទម្រង់៣ ថាជាទម្រង់នៃការទទួលខុសត្រូវ[164]។ នៅពេលនោះ មេធាវីការពារក្តីបានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងករណីកំណត់បទចោទសាជាថ្មីតាមការគ្រោងទុក ខ្លួនចង់ទទួលបានលទ្ធភាពឆ្លើយតបជាលាយលក្ខណ៍អក្សរ ទាំងអង្គច្បាប់ និងទាំងអង្គហេតុ[165]។

១៤៤. បន្ទាប់មក អង្គជំនុំជម្រះគួរតែអាចធ្វើដូច្នេះបានក្នុងសវនាការ ជាពិសេស បន្ទាប់ពីបានដឹងអំពីសាលដីកា ០០២/០១ នៅចុងបញ្ចប់នៃសវនាការលើអង្គសេចក្តី ខណៈដែលអង្គជំនុំជម្រះស្នើសុំឱ្យភាគីធ្វើសេចក្តីសង្កេតអំពីផលវិបាកជាយថាហេតុនៃសាលក្រម ០០២/០១ ដែលអាចពាក់ព័ន្ធភ្លាមៗនឹងការពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២[166]។ ប្រសិនបើអង្គជំនុំជម្រះបានវាយតម្លៃថា មេធាវីការពារក្តីគួរតែអាចប្រមើលឃើញជាមុនពីការកំណត់បទចោទសាជាថ្មីដែលបានគ្រោងទុកនៅពេលនោះ អង្គជំនុំជម្រះនឹងអាចគ្រោងទុកជាមុននូវលទ្ធភាពនេះ និងអាចជូនដំណឹងយ៉ាងត្រឹមត្រូវដល់មេធាវីការពារក្តី ទៅតាមអ្វីដែលត្រូវធ្វើ (ហើយបើយើងស្របតាមវិចារណកិច្ចរបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះក៏មានវត្តមាននៅក្នុងសំណុំរឿង ០០២/០១ ដែរ)។ ក៏ប៉ុន្តែ ទាំងអង្គជំនុំជម្រះ ទាំងសហព្រះរាជអាជ្ញាមិនបានលើកឡើងពីការកំណត់បទចោទសាជាថ្មីណាមួយទាលតែសោះ នៅពេលនោះ។

---

[163] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E311/1** កថាខណ្ឌ ៩។

[164] ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E1/240.1** ចន្លោះម៉ោង 10.11.34 និងម៉ោង 10.19.02។

[165] ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E1/240.1** បន្ទាប់ពីម៉ោង 10.17.18 (លោកស្រី GUISSÉ៖ "ចំពោះក្រុមមេធាវីខៀវសំផន គឺថាមិនមែនខាងជនជាប់ចោទទេដែលត្រូវសុំធ្វើការកំណត់បទចោទឡើងវិញនេះ។ ក៏ប៉ុន្តែយើងត្រូវសួរថាតើមានការកែប្រែបទចោទយ៉ាងដូចម្តេចទេ គឺថានៅមុខតុលាការអន្តរជាតិផ្សេងទៀតដើម្បីឆ្លើយតបជាលាយលក្ខណ៍អក្សរ តាមផ្លូវច្បាប់ ហើយផ្តល់ការគាំទ្រថ្មីៗទៀតដើម្បីគាំទ្រដល់ការកែប្រែបទចោទទាំងអស់នោះ")។

[166] សំអាងហេតុសាលក្រម កថាខណ្ឌ១៥៧។

១៤៥. ជាចុងក្រោយ អង្គជំនុំជម្រះគួរតែអាចធ្វើរឿងនេះទៅបានក្នុងកំឡុងពេលពិភាក្សាសម្រេច[167] ដោយបើកដំណើរការនីតិវិធីពិភាក្សាឡើងវិញ និងស្នើសុំឱ្យភាគីទាំងអស់ធ្វើការសន្និដ្ឋានលើប្រធានបទនេះ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានធ្វើអ្វីសោះ។

១៤៦. ដូច្នេះ រហូតទាល់តែថ្ងៃប្រកាសសាលក្រម ទើបមេធាវីការពារក្តីបានដឹងអំពីការផ្លាស់ប្តូរបទចោទពីអង្គហេតុសម្លាប់រង្គាលមួយចំនួនទៅជាអំពើឃាតកម្មដោយចេតនាប្រយោល[168] ខណៈដែលទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះ មិនធ្លាប់បានលើកឡើងពីលទ្ធភាពបែបនេះនៅដំណាក់កាលដំបូង ហើយមេធាវីការពារក្តីមិនត្រូវបានអញ្ជើញឱ្យពិភាក្សាពីរឿងនេះឡើយ[169]។

១៤៧. ប្រសិនបើមេធាវីការពារក្តីបានអញ្ជើញឱ្យចូលរួមពិភាក្សា មេធាវីការពារក្តីនឹងមិនការពារតែបទចោទសម្លាប់រង្គាលមួយប៉ុណ្ណោះទេ (បទចោទតែមួយគត់ដែលត្រូវបញ្ជាក់ក្នុងដីកាបញ្ជូនទៅជំនុំជម្រះ ចំពោះអង្គហេតុទាំងនេះ) ដូចអ្វីដែលមេធាវីការពារក្តីបានធ្វើ[170]។ មេធាវីការពារក្តីនឹងបង្ហាញមធ្យោបាយការពារផ្សេង ជាពិសេស ដោយសារការដាក់បញ្ចូលធាតុផ្សំថ្មីមួយដែលវិធានផ្ទៃក្នុងហាមឃាត់។

### ១.២.២. ការដាក់បញ្ចូលធាតុផ្សំថ្មី

---

[167] វិធាន ៩៦.២ នៃវិធានផ្ទៃក្នុង៖ "អំឡុងពេលពិភាក្សាសម្រេច ចៅក្រមអាចបើកនីតិវិធីឡើងវិញបាន"។

[168] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/5.29.1** ម៉ោង 11.29.52។

[169] ដូចក្នុងសាលដីកា *Drassich ទល់នឹងប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ ៣៦ ("អំណើះតទៅ តុលាការបានសង្កេតឃើញថាការកំណត់បទចោទនៃជម្លោះបានប្រព្រឹត្តទៅនៅក្នុងពេលដែលសាលាឧក្រិដ្ឋធ្វើការពិភាក្សាសម្រេចសេចក្តី។ លើសពីនោះ អយ្យការ ឬចៅក្រមមួយរូបដែលជាសមាសភាពនៃអង្គចៅក្រមនៃតុលាការកំពូល ហាក់ដូចជាបានរំឭកពីកាលានុវត្តភាពក្នុងការកំណត់បទចោទនៃអង្គហេតុឡើងវិញ តាំងពីមូលហេតុ រហូតដល់ដំណាក់កាលមុនដំណើរការនីតិវិធី។ នៅក្នុងល័ក្ខខ័ណ្ឌនេះ មិនមានការកំណត់ទេថាម្ចាស់បណ្តឹងត្រូវទទួលបានការជូនដំណឹងអំពីការដែលអាចកំណត់បទចោទជាថ្មីប្រឆាំងនឹងរូបគាត់ ហើយគាត់រឹតតែមិនមានឱកាសពិភាក្សាដេញដោលលើបទចោទថ្មី"។ (មិនមានឯកសារយោង)។

[170] ជាឧទាហរណ៍៖ សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៩៩៤-៩៩៧, ១០៣៨-១០៤៥, ១០៨២-១០៨៧, ១១៣៩-១១៤៦។

១៤៨. ដូចដែលអង្គជំនុំជម្រះផ្ទាល់បានបញ្ជាក់ថា៖

"បើយោងតាមវិធាន ៩៨ (២) នៃវិធានផ្ទៃក្នុង ថ្វីបើអង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទដែលបានប្រើក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងករណីមិនដាក់បញ្ចូលធាតុផ្សំថ្មីណាមួយ (វិធាន ៩៨ (២) នៃវិធានផ្ទៃក្នុងក៏ដោយ តែអង្គជំនុំជម្រះមិនមានសមត្ថកិច្ចដាក់បញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នូវអង្គហេតុថ្មីៗ ឬបទចោទ ដែល [ស.ច.ស] បានសម្រេចថាមិនត្រូវបញ្ជូនទៅជំនុំជម្រះទេ និងជាពិសេស សេចក្តីសម្រេចនោះមិនត្រូវបានកែប្រែដោយអង្គបុរេជំនុំជម្រះឡើយ"[171]។

១៤៩. ការកំណត់បទចោទសាជាថ្មីចំពោះអង្គហេតុដែលជាធាតុផ្សំនៃការសម្លាប់រង្គាល ទៅជាអង្គហេតុឃាតកម្មដោយចេតនាប្រយោល គឺការដាក់បញ្ចូលធាតុផ្សំថ្មីទៅក្នុងនោះ។ ជាក់ស្តែង បទចោទទាំងពីរនេះខុសពីគ្នាស្រឡះដោយសារធាតុផ្សំរបស់វា និងទាមទារតម្រូវការផ្សេងៗគ្នា។ ដូចដែលតុលាការកំពូលបានរំឭកថា៖ ""អំពើឃាតកម្ម" និង "ការសម្លាប់រង្គាល" គឺជាឧក្រិដ្ឋកម្មដាច់ដោយឡែកពីគ្នា ហើយនិយមន័យនីមួយៗត្រូវតែកំណត់ដោយឯករាជ្យពីគ្នាទៅវិញទៅមក"[172]។

១៥០. ពិតមែនតែបទឃាតកម្ម និងការសម្លាប់រង្គាល មានចំណុចរួមត្រង់ការផ្តាច់ផ្តិលជីវិតមនុស្សទូទៅក៏ដោយ ក៏បទទាំងពីរទាក់ទងនឹងចរិតឧក្រិដ្ឋពីរខុសគ្នាស្រឡះ។ ការសម្លាប់រង្គាលខុសគ្នាពីឃាតកម្មត្រង់ថា ការសម្លាប់រង្គាលផ្តោតលើក្រុមបុគ្គល ឬប្រជាជនមួយ។ គោលបំណងគឺដើម្បីកម្ចាត់ចោលបុគ្គលដែលជាសមាជិកនៃក្រុមមួយ ដែល "មិនត្រូវគ្នានឹងសញ្ញាណនៃចេតនាប្រយោល"[173]។

---

[171] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ៣ ដែលបានស្រង់សម្តីនៅក្នុងកថាខណ្ឌ ១៨៧ សំអាងហេតុនៃសាលក្រម (អក្សរទ្រេតនៅក្នុងច្បាប់ដើម យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[172] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥១៦។

[173] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥១៩-៥២១។

១៥១. ដូច្នេះ ខុសពីបទឃាតកម្ម ធាតុផ្សំសត្យានុម័តិនៃនៃការសម្លាប់រង្គាល កើតចេញពីការសម្លាប់មនុស្សមួយចំនួនធំ[174]។ ទាក់ទងនឹងធាតុអត្តនោម័តិ មេគំនិតក្នុងការសម្លាប់ច្បាស់ជាមានចេតនាផ្ទាល់ ក្នុងការសម្លាប់មនុស្សមួយចំនួនធំ ឬក្នុងការដាក់ពួកគេឱ្យរស់នៅក្នុងស្ថានភាពរស់នៅដែលគេបានគិតរួចហើយថានឹងបណ្តាលឱ្យបាត់បង់ជីវិត[175]។

១៥២. តាមពិត ការកែប្រែបទចោទដំបូងពីការសម្លាប់រង្គាលទៅជាអំពើឃាតកម្មដោយចេតនាប្រយោល ពាក់ព័ន្ធនឹងការដាក់បញ្ចូលបទចោទថ្មី ជាមួយធាតុផ្សំថ្មី គឺចេតនាប្រយោល ដែលជាធាតុផ្សំមិននៅក្នុងបទចោទដំបូង តែជាធាតុផ្សំចម្លែក និងនៅក្រៅបទចោទ។

១៥៣. ប្រឈមនឹងបទចោទនៃការសម្លាប់រង្គាល មេធាវីការពារក្តីប្រឆាំងតែមួយគត់នឹងការខ្វះចេតនាប្រយោលក្នុងការសម្លាប់មនុស្សមួយចំនួនធំ[176]។ មេធាវីការពារក្តីមិនការពារខ្លួនពីចេតនាកម្រិតទាបជាង ដែលមិនមាននៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្ម ហើយថែមទាំងផ្ទុយពីនិយមន័យទៀតផង នោះទេ។

១៥៤. ដូច្នេះ ប្រឈមមុខនឹងបទចោទឃាតកម្មដោយចេតនាប្រយោល ខៀវ សំផន ប្រហែលជានឹងបង្ហាញមធ្យោបាយការពារខ្លួនផ្សេងពីនេះឆ្ងាយ ជាពិសេស ដើម្បីការពារខ្លួនពីតថភាពនៃចេតនាប្រយោលក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

១៥៥. ខៀវ សំផន មិនត្រឹមតែមិនទទួលបានការជូនដំណឹង និងមិនអាចដដែកដេញដោលពីការកំណត់បទចោទសាជាថ្មីដែលបានគ្រោងដោយអង្គជំនុំជម្រះប៉ុណ្ណោះទេ តែថែមទាំងត្រូវបានផ្តន្ទាទោសពីបទរំលោភលើវិធានផ្ទៃក្នុង ចំពោះបទចោទនានាដែលមិននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់អង្គជំនុំជម្រះ។ ការផ្តន្ទាទោសទាំងនេះ ត្រូវតែទុកជាមោឃៈ[177]។

---

[174] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥១៧។

[175] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥១៧-៥២២។

[176] ជាឧទាហរណ៍៖ សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៩៩៤-៩៩៧, ១០៣៨-១០៤៥, ១០៨២-១០៨៧, ១១៣៩-១១៤៦។

[177] សូមមើលខាងក្រោម ភាគទី ៣, មាតិកាទី ១ ជំពូកទី ៣ ផ្នែកទី ២, និងមាតិកាទី ២ ស្តីពីសហករណ៍ត្រាំកក់, ទំនប់ត្រពាំងថ្ម, ទំនប់១មករា, ព្រលានយន្តហោះកំពង់ឆ្នាំង, មន្ទីរសន្តិសុខ ស-២១, មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។

១៥៦. ម្ចាស់បណ្ដឹងសាទុក្ខលើកឡើងបន្ថែមទៀតថា ដូចតុលាការកំពូលក្នុងសំណុំរឿង០០២/០១[178] ដែរ អង្គជំនុំជម្រះបានកំណត់បទចោទសាជាថ្មី ក្នុងអំឡុងពេលពិភាក្សាសម្រេច ដោយមិនបានជូនដំណឹងដល់នរណាម្នាក់សោះ ដោយសារតែកង្វះភ័ស្តុតាងនៃចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សទ្រង់ទ្រាយធំ ហើយដោយសារខ្វះភ័ស្តុតាងនេះ គេពុំមានហេតុផលណាមួយដើម្បីឈានដល់ការផ្ដន្ទាទោសឡើយ។ វិធីបែបនេះសរបង្ហាញពីការខ្វះភាពមិនលម្អៀងរបស់អង្គជំនុំជម្រះ និងតុលាការកំពូល។

១៥៧. ដូច្នេះ អង្គជំនុំជម្រះបានរំលោភសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជូនដំណឹងអំពីប្រភេទ និងសំអាងហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់ការរៀបចំការការពារក្ដីរបស់គាត់ សវនាការចំពោះមុខ សច្ចភាពគតិយុត្តិ និងនីតិវិធី តម្លាភាពនៃនីតិវិធី ព្រមទាំងសិទ្ធិទទួលបានតុលាការមិនលម្អៀង។

## ២. ការលាតត្រដាងដោយផ្អែកលើភ័ស្តុតាង

១៥៨. នៅកថាខណ្ឌ ៣៦ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានប្រកាសថា សេចក្ដីសន្និដ្ឋានទាក់ទងនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទ និងការវិភាគអង្គហេតុដែលមានពិពណ៌នានៅក្នុងសាលក្រម ០០២/០១ "នឹងមិនអាចត្រូវបានដាក់ចូល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវិនិច្ឆ័យនេះទេ"។ អង្គជំនុំជម្រះបានយកចិត្តទុកដាក់ក្នុងការបញ្ជាក់ថា តើក្នុងករណីណាដែលខ្លួនប្រើ "ពាក្យពេចន៍ស្រដៀង ឬដូចគ្នា" ទៅនឹងវិធីដែលបានប្រើនៅក្នុងសាលក្រម ០០២/០១។ "ចំណុចនេះបង្ហាញយ៉ាងសាមញ្ញថា នៅចុងបញ្ចប់នៃការវិភាគភ័ស្តុតាងដែលអង្គជំនុំជម្រះបានអនុវត្តម្ដងទៀត ក្នុងសំណុំរឿង [០០២/០២] អង្គជំនុំជម្រះបានឈានដល់ការសន្និដ្ឋានដូចគ្នានឹងអ្វីដែលបានរកឃើញក្នុងសំណុំរឿង [០០២/០១]" ដែរ[179]។ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា នៅពេលដែលអង្គជំនុំជម្រះបានវិភាគភ័ស្តុតាងនៃសំណុំ

[178] សូមមើលការពង្រីកសេចក្ដីនៃក្រុមមេធាវីការពារក្ដីលើចំណុចនេះ នៅក្នុងបណ្ដឹងជំទាស់ ចំពោះមុខចៅក្រមតុលាការកំពូល ដែលបានធ្វើការពិនិត្យសម្រេចនៅក្នុងសំណុំរឿង ០០២/០១៖ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ឯកសារ F53 កថាខណ្ឌ ៩៣-១០៩។

[179] សំអាងហេតុសាលក្រម កថាខណ្ឌ កំណត់សម្គាល់ជើងទំព័រលេខ៨៣ (នៃកថាខណ្ឌ ៣៦)។

រឿង ០០២/០១ ដោយផ្អែកលើបញ្ហានៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះ "ធានាថាសិទ្ធិទទួលបានសវនាការចំពោះមុខត្រូវបានគោរពយ៉ាងពេញលេញ"។ អង្គជំនុំជម្រះបានបដិសេធ "ទឡ្ហីករណ៍របស់មេធាវីការពារក្តី ដោយចាត់ទុកថាគ្មានមូលដ្ឋានត្រឹមត្រូវ។ ទឡ្ហីករណ៍នោះបញ្ជាក់ថា ប្រតិចារឹកសវនាការនៃសំណុំរឿង ០០២/០១ គឺជាសក្ខីកម្មជាលាយលក្ខណ៍អក្សរនៅក្នុងសំណុំរឿង ០០២/០២"។ ទោះយ៉ាងនេះក្តី អង្គជំនុំជម្រះមិនបានអនុវត្តគោលការណ៍ដែលបានប្រកាសជាលក្ខណៈប្រព័ន្ធទេ។

១៥៩. ទីមួយ ការប្រើពាក្យពេចន៍មួយចំនួន "ដូចគ្នា ឬស្រដៀងគ្នា" ទៅនឹងពាក្យពេចន៍ដែលបានប្រើ នៅក្នុងសាលក្រម ០០២/០១ មិនត្រូវបានប្រើឡើយ បន្ទាប់ពីធ្វើការវិភាគឡើងវិញនូវភស្តុតាងក្នុងសំណុំរឿង ០០២/០២។ ចំណុចនេះត្រូវបានបញ្ជាក់ដោយអង្គហេតុសាមញ្ញថា អង្គជំនុំជម្រះបានបន្តសន្មតថា ខៀវ សំផន ជាអ្នកថ្លែងសុន្ទរកថាបើកសម្ពោធរបស់កងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦ ដោយផ្អែកលើឯកសារមួយ ដែលការសន្និដ្ឋាននេះមិនអាចទៅរួច និងត្រូវបានទាត់ចោលដោយតុលាការកំពូល[180]។

១៦០. ទីពីរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយហេតុថា ជានិច្ចជាកាល អង្គជំនុំជម្រះមិនដែលបានធានាថា ដំណើរការដេញដោលចំពោះមុខ ត្រូវបានគោរព "ពេញលេញ" ក្នុងការវិភាគធាតុផ្សំនៃសំណុំរឿង ០០២/០១ យោងតាមបញ្ហាដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២។

១៦១. ជាបឋម អង្គជំនុំជម្រះបានបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តីស្តីពីតម្លៃនៃការប្រើប្រតិចារឹកសវនាការនៃសំណុំរឿង ០០២/០១ នៅក្នុងសំណុំរឿង ០០២/០២ ដោយកាត់ឱ្យខ្លីៗ។ ជាក់ស្តែង ទោះបីជាមេធាវីការពារក្តីបានបញ្ជាក់ថា "ប្រតិចារឹកមកពីសវនាការលើសំណុំរឿង ០០២/០១ [គឺជា] សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅក្នុងសវនាការ ០០២/០២" តែអង្គជំនុំជម្រះបានបន្ថែមភ្លាមៗថា៖

"ដោយមានអញ្ញត្រកម្មពីរ៖

[180] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៩៨៥។ សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០២៣។ សំអាងហេតុសាលក្រម កថាខណ្ឌ ៥៩៨ និង ៣៧៣៩។

- នៅពេលដែលបុគ្គលដែលបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២/០១ បានត្រឡប់មកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ២០០២/០២។
- នៅពេលដែលបុគ្គលដែលបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២/០១ បានផ្តល់សក្ខីកម្មលើប្រធានបទស្តីពីការពិនិត្យលើសំណុំរឿង ០០២/០២ ហើយអាចត្រូវបានសួរដេញដោលលើបញ្ហាទាំងនេះ”[181]។

១៦២. អវត្តមាននៃការតទល់ចំពោះមុខ វាច្បាស់ណាស់ថា សក្ខីកម្មរបស់សាក្សីដែលមិនអាចត្រូវបានសួរដេញដោលដោយមេធាវីការពារក្តី មានតម្លៃជាសក្ខីម្មជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[182]។

១៦៣. បន្ទាប់មក ទោះបីជាអង្គជំនុំជម្រះបានប្រកាសច្បាស់ៗថា ខ្លួននឹងពិនិត្យមើល ថាតើភាគីត្រូវបានរារាំងមិនឱ្យសាកសួរអ្នកដែលបានផ្តល់សក្ខីកម្ម ក្នុងសំណុំរឿង ០០២/០១ លើបញ្ហានៃសំណុំរឿង ០០២/០២ សំដៅធានានូវការគោរពនីតិវិធីដេញដោលចំពោះមុខឱ្យបានពេញលេញ[183] ដែរឬទេ អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់បុគ្គលដែលបានស្តាប់ចម្លើយតែនៅក្នុងសំណុំរឿង ០០២/០១ លើអង្គហេតុដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ ខណៈដែលមេធាវីការពារក្តីមិនអាចសាកសួរពួកគេអំពីបញ្ហានេះបាន។ ជាឧទាហរណ៍ ករណីនៃផ្នែកខ្លះនៃសក្ខីកម្មរបស់ ឆោម សែ ស្តីពីអូរកន្សែង[184] ឬករណីរបស់ ឯម អឿន ស្តីពីអាពាហ៍ពិពាហ៍ និងពុទ្ធសាសនិក[185]។

១៦៤. គួរឱ្យកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះបានប្រើប្រាស់ផ្នែកជាច្រើននៃសក្ខីកម្មរបស់បុគ្គលដែលបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០២/០១ ដែលហាក់ដូចជាពួកគេត្រូវបានគេស្តាប់នៅក្នុងសំណុំរឿង

---

[181] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៥៥២។ សូមមើលផងដែរ ការពង្រីកន័យសេចក្តីបន្ទាប់ពីកថាខណ្ឌ ៥៥៣-៥៥៦។

[182] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៨-៧០។ សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២២៦។

[183] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦។

[184] សូមមើលខាងក្រោម កថាខណ្ឌ ៨៤២-៨៤៧។

[185] សូមមើលខាងក្រោម កថាខណ្ឌ ១១៦៨, ១១៧២, ១១៨៥, ១៣៣៥ (ការរៀបអាពាហ៍ពិពាហ៍) និង សំអាងហេតុសាលក្រម កថាខណ្ឌ ៤០១៥ (កំណត់សម្គាល់ជើងទំព័រលេខ១៣៣០១, ១៣៣១០), កថាខណ្ឌ ៤០១៦ (ពុទ្ធសាសនិក)។

០០២/០២ ដែរ ដើម្បីធ្វើការសន្និដ្ឋាននៅក្នុងសំណុំរឿង ០០២/០២ ពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិកជន ក្នុងពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[186] ខណៈដែលបុគ្គលទាំងនេះត្រូវបានគេសន្មតថាបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ស្តីពីព្រះពុទ្ធសាសនាតែនៅក្នុងបរិបទប្រវត្តិសាស្ត្រ ពោលគឺមុនសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ ពេលនោះ មេធាវីការពារក្តីត្រូវផ្តោតលើអង្គហេតុដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១ ហើយច្បាស់ណាស់ នឹងមិនបានខ្ជះខ្ជាយពេលវេលាសាកសួរបុគ្គលដែលត្រូវបានបម្រុងទុកដើម្បីសាកសួរពីព្រះពុទ្ធសាសនាបន្ទាប់ពីឆ្នាំ១៩៧៥ ដែលមិនមែនជាកម្មវត្ថុនៃការជំនុំជម្រះកំពុងដំណើរការ។ នេះជាករណីជាក់ស្តែងជាទូទៅសម្រាប់ការចូលមកបង្ហាញខ្លួនស្តីពីបញ្ហាទាំងអស់ដែលមិនមែនជាកម្មវត្ថុនៃសំណុំរឿង ០០២/០១...។

១៦៥. នេះជារឿងប្រពៃណាស់ ព្រោះថា នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនអាចសាកសួរបុគ្គលមួយចំនួនដែលអាចផ្តល់សក្ខីកម្មលើបញ្ហាជាច្រើននៅពេលពិនិត្យសំណុំរឿង ០០២/០២ ទៅតាមការស្នើសុំរបស់មេធាវីការពារក្តីឱ្យមានការកោះហៅជាថ្មីនៅក្នុងសំណុំរឿង ០០២/០២។

១៦៦. ដូច្នេះ មុនពេលចាប់ផ្តើមការជំនុំជម្រះ មេធាវីការពារក្តីបានដាក់បញ្ជីដ៏ខ្លីមួយនៃឈ្មោះបុគ្គលប្រាំពីរនាក់ដែលខ្លួនស្នើសុំឱ្យចូលមកបង្ហាញខ្លួននៅក្នុងសំណុំរឿង ០០២/០២[187]។ ក្នុងចំណោមបុគ្គលទាំងនោះ បុគ្គលបួននាក់ត្រូវបានស្តាប់ចម្លើយ និងវាយតម្លៃថាគួរឱ្យជឿជាក់នៅក្នុងសំណុំរឿង ០០២/០១ និងមានភាពពាក់ព័ន្ធខ្លាំងសម្រាប់សំណុំរឿង ០០២/០២ រួមមាន ជួន ធី, Stephen HEDER, François

[186] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០១៥-៤០១៧, កំណត់សម្គាល់ជើងទំព័រលេខ ១៣៣០០ ដល់ ១៣៣១៤។ ក្រៅពី អែម អឿន មាន៖ ពាន ឃាន, យុន គីម, ខៀវ អេន, ហ៊ុន ឈុនលី, ពិន យ៉ាថៃ, នូ ម៉ៅ, ស៊ឹម ហោ, អុង ថុងហឿង, ក្លាន វិត, គឹម វ៉ាន់ឌី, សូផាន់ សុវណ្ណី។ មេធាវីការពារក្តីលើកឡើងថាអង្គជំនុំជម្រះបានរៀបចំបញ្ជីប្រតិចារឹកសវនាការតាមលំដាប់ពេលវេលា មុនសេចក្តីប្រកាសជាលាយលក្សណ៍អក្សរ (កំណត់ហេតុស្តាប់ចម្លើយសាក្សី)។ ដូច្នេះ អង្គជំនុំជម្រះបានដាក់សក្ខីកម្មនៃសំណុំរឿង ០០២/០១ ក្នុងចំណាត់ថ្នាក់ស្មើនឹងសំណុំរឿង ០០២/០២ ធ្វើហាក់ដូចជាសេចក្តីប្រកាសទាំងពីរមានតម្លៃគួរឱ្យជឿជាក់បានដូចៗគ្នាដូច្នោះដែរ គឺមានតម្លៃខ្ពស់ជាងសក្ខីកម្មជាលាយលក្សណ៍អក្សរ (ហើយហាក់បីដូចជាសំណុំរឿង ០០២/០១ និង ០០២/០២ ជាការជំនុំជម្រះតែមួយគត់)។

[187] សាក្សី និងអ្នកជំនាញស្នើឡើងដោយលោក ខៀវ សំផន នៅ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E305/5** និង ឧបសម្ព័ន្ធ ឯកសារ **E305/5.2** (សង្ខេប)។

PONCHAUD និង Philip SHORT។ បើទោះបីជាអង្គជំនុំជម្រះបានសម្រេចកោះហៅ ជួន ធី តែអង្គជំនុំជម្រះបែរជាបានបដិសេធមិនកោះហៅបុគ្គលបីនាក់ផ្សេងទៀតជាថ្មី ដោយហេតុផលថា ពួកគេបានបង្ហាញខ្លួនរួចហើយនៅក្នុងសំណុំរឿង ០០២/០១។

១៦៧. ក្នុងអំឡុងពេលនៃដំណើរការជំនុំជម្រះ ដោយហេតុថាអង្គជំនុំជម្រះគ្រាន់តែផ្សព្វផ្សាយបន្តិចម្តងៗ និងដោយគ្មានមូលហេតុ នូវសេចក្តីសម្រេចរបស់ខ្លួនលើការស្នើសុំការបង្ហាញខ្លួន ដោយយល់ព្រមតាមសំណើសុំកោះឱ្យចូលមកបង្ហាញខ្លួនជាថ្មីពីភាគីផ្សេងទៀតក្នុងអំឡុងពេលជំនុំជម្រះ[188] ក្រុមមេធាវីការពារក្តីបានបញ្ជាក់ម្តងហើយម្តងទៀត ពីសារៈសំខាន់នៃការចូលមកបង្ហាញខ្លួនរបស់សាក្សីតាមការស្នើសុំរបស់ខ្លួន ជាពិសេស គឺ François PONCHAUD និង Stephen HEDER[189]។ នៅចុងបញ្ចប់នៃសវនាការលើអង្គសេចក្តី អង្គជំនុំជម្រះបានបដិសេធសំណើសុំកោះហៅពួកគាត់ឱ្យចូលមកបង្ហាញខ្លួន "ដោយសារតែប្រធានបទនោះត្រូវបានលើកឡើងរួចហើយ ក្នុងអំឡុងពេលពួកគេមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ (រួមមាន "បញ្ហាផ្សេងៗពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២") និងថា សក្ខីកម្មរបស់ពួកគេក្នុងសំណុំរឿង ០០២/០២ "អាចច្រំដែល"។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "ការស្តាប់ចម្លើយពួកគេជាថ្មីទៀតនឹងពន្យារពេលកិច្ចដំណើការនីតិវិធីដោយមិនសមហេតុផល"[190]។

---

[188] សូមមើលខាងក្រោម កថាខណ្ឌ ១៧៥-២១៥។

[189] ជាឧទាហរណ៍៖ ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E366/1** កថាខណ្ឌ ២៦-២៨។ ប្រតិចារឹក ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/371.1** ចន្លោះម៉ោង 09.45.40 និងម៉ោង 09.49.13 (លោក គង់ សំអុន)។ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ E4**08/6**។ ប្រតិចារឹក ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/458.1** ចន្លោះម៉ោង 10.25.32 និងម៉ោង 10.31.40 (លោកស្រី GUISSÉ) សំណើ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E408/6/1**។

[190] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E408/6/2** កថាខណ្ឌ ៦។ អង្គជំនុំជម្រះបានបន្ថែមថាខ្លួនបានជ្រើសរើស និងស្តាប់អ្នកជំនាញ Stephen MORRIS ដែលបានផ្តល់សក្ខីកម្មស្តីពីជម្លោះប្រដាប់អាវុធ។ ក៏ប៉ុន្តែអង្គជំនុំជម្រះមិនធ្លាប់បានពន្យល់សោះថាហេតុអ្វីបានជាខ្លួនសម្រេចជ្រើសរើសយក HEDER ជាជាងជ្រើសយកអ្នកជំនាញខាងលើ (ដែលអាចផ្តល់សក្ខីកម្មស្តីពីជម្លោះប្រដាប់អាវុធ និងអាចលើកឡើងពីប្រធានបទផ្សេងៗទៀតនៅក្នុងសំណុំរឿង ០០២/០២ ខុសប្លែកពីលោក MORRIS) ដែលការស្នើសុំត្រូវបានគាំទ្រដោយក្រុមមេធាវីការពារក្តីលោក នួន ជា និង ព្រមទាំងគាំទ្រដោយសហព្រះរាជអាជ្ញាផងដែរ (អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ E408/6/2 កថាខណ្ឌ ១)។ នៅក្នុងសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួន ស្តីពីការចូលមកផ្តល់សក្ខីកម្មរបស់លោក MORRIS អង្គជំនុំជម្រះគ្រាន់តែបានប្រកាសថា

១៦៨. ពិតមែនតែអង្គជំនុំជម្រះបានទទួលស្គាល់នូវភាពពាក់ព័ន្ធដ៏ធំធេងនៃសក្ខីកម្មទាំងនេះ សម្រាប់សំណុំរឿង ០០២/០២ តែអង្គជំនុំជម្រះមិនបានពិចារណាទាល់តែសោះថា មេធាវីការពារក្តីមិនអាចសាកសួរពួកគេនៅក្នុងសំណុំរឿង ០០២/០១ លើអង្គហេតុនៃសំណុំរឿង ០០២/០២ ទេ។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះបានថ្លែងមុនពេលជំនុំជម្រះ ដោយផ្តល់ការបញ្ជាក់ព័ត៌មានអំពីក្របខ័ណ្ឌនីតិវិធីសម្រាប់ការកោះហៅសាក្សីឡើងវិញ ដោយសារតែការបំបែកកិច្ចដំណើរការនីតិវិធី៖

> "អង្គជំនុំជម្រះនឹងពិចារណាថា តើភាគីត្រូវបានរារាំង ឬមិនអាចមានលទ្ធភាពចោទសួរឱ្យបានលម្អិតបុគ្គលណាម្នាក់ ដែលខ្លួនបានស្នើសុំឱ្យចូលមកបង្ហាញខ្លួនជាថ្មីនៅសវនាការ ដោយសារវិសាលភាពចង្អៀតនៃ [ការជំនុំជម្រះលើសំណុំរឿង ០០២/០១]"[191]។

១៦៩. ការបដិសេធកោះហៅលោក HEDER និងលោក PONCHAUD ឱ្យមកផ្តល់សក្ខីកម្មម្តងលើបញ្ហាជាច្រើនដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ ដោយសារតែអ្វីមួយដែលគេហៅថាជាការយឺតយ៉ាវនៃកិច្ចដំណើរការនីតិវិធី គឺមានយុត្តិកម្មតិចជាងមុន ជាហេតុធ្វើឱ្យអង្គជំនុំជម្រះបានសម្រេចតាមទំនើងចិត្ត ឱ្យកោះហៅម្តងទៀតសាក្សីដែលបានស្តាប់ចម្លើយក្នុងសំណុំរឿង ០០២/០១ ដូចជា ផន វ៉ាន់ និង សៅ សារុន[192] ដែលបុគ្គលចុងក្រោយនេះស្ថិតក្នុងចំណោមមនុស្សកម្របំផុតដែលត្រូវបានស្តាប់

---

បានដឹងថាលោក Nayan CHANDA និងលោក Michael VICKERY មិនមានពេលទំនេរ (សេចក្តីសម្រេច ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ E445)។

[191] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ **E302/5** កថាខណ្ឌ ៨។សូមមើលផងដែរla សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E301/9/1** កថាខណ្ឌ ៤២ និង កំណត់សម្គាល់ជើងទំព័រលេខ៩១ នៅក្នុងទីនេះអង្គជំនុំជម្រះបានអះអាងថាបញ្ហាខ្លះមិនអាចយកមកពិនិត្យពេញលេញបានទេ នៅក្នុងសំណុំរឿង០០២/០១ ហើយក៏អាចមានភាពពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/០២ និងបានរំឭកថា "អង្គជំនុំជម្រះនឹងផ្តល់នូវការពិចារណាលើអង្គហេតុពិស្តារក្នុងសវនាការលើកដំបូង ចំពោះបទចោទទាំងនោះដែលត្រូវបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១"។

[192] សេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **E459** កថាខណ្ឌ ៩៥ និងកំណត់សម្គាល់ជើងទំព័រលេខ ២៤២-២៤៣ (ដែលយោងទៅលិខិតចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦)។

ចម្លើយនៅក្នុងសំណុំរឿង ០០២/០១ ដែលអាចត្រូវបានសាកសួរលើអង្គហេតុទាំងអស់នៅក្នុងសំណុំរឿង ០០២ ដើម្បីចៀសវាងការកោះហៅពួកគេជាថ្មីម្តងទៀត[193]។

១៧០. លើសពីនេះទៅទៀត គឺផ្អែកលើសំអាងហេតុ (ដែលបានផ្តល់ជូន បន្ទាប់ពីការបញ្ចប់សវនាការលើអង្គសេចក្តី) ដែលភាគីនៅក្នុងសំណុំរឿង ០០២/០១ នឹងត្រូវបានអនុញ្ញាតឱ្យចោទសួរលោក Philip SHORT "កាន់តែទូលំទូលាយលើបញ្ហាទាំងអស់ដែលជាវិស័យជំនាញរបស់គាត់ ដើម្បីចៀសវាងការកោះហៅគាត់មកកាន់សវនាការវិញ ដែលអង្គជំនុំជម្រះបានសម្រេចមិនកោះហៅជាថ្មី នៅក្នុងសំណុំរឿង ០០២/០២"[194]។ ទោះយ៉ាងណា អង្គជំនុំជម្រះបានដកហូតការអនុញ្ញាតនេះ ដើម្បីធានាបាននូវដំណើរការនីតិវិធីឆាប់រហ័ស[195]។ លើសពីនេះទៀត អង្គជំនុំជម្រះបានបដិសេធមិនទទួលយកឯកសារស្តីពីបទប្រល័យពូជសាសន៍ សម្រាប់ការបង្ហាញខ្លួនរបស់គាត់ ដោយផ្អែកលើហេតុផលថាអំពើប្រល័យពូជសាសន៍មិនស្ថិតនៅក្នុងបទចោទនៅចំពោះមុខអង្គជំនុំជម្រះទេ[196]។ អង្គជំនុំជម្រះក៏បាន

---

[193] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E194** (TCW-604)។

[194] សេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **E459** កថាខណ្ឌ ១៩៣ (និងកំណត់សម្គាល់ជើងទំព័រលេខ ៥៣៦ ដែលយោងទៅ សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E215** កថាខណ្ឌ ៤)។ អង្គជំនុំជម្រះបានបន្ថែមថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថាការស្តាប់សក្ខីកម្មរបស់លោក SHORT ជាលើកទីពីរ ទំនងជាមានភាព "ច្រំដែល" យ៉ាងច្រើនទៅនឹងភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង ០០២/០១ ដែលក្នុងនោះរួមមានទាំងសក្ខីកម្មរបស់ PONCHAUD, HEDER និង CHANDLER។

[195] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E215** កថាខណ្ឌ ៤៖ "ដោយសារភាគីបានស្នើសុំឱ្យស្តាប់សក្ខីកម្មបុគ្គលទាំងនេះ មុនពេលបំបែកនីតិវិធីនៃសំណុំរឿង ០០២ ទៅជាសវនាការមួយចំនួន និងដើម្បីបញ្ចៀសការហៅសាក្សីឬអ្នកជំនាញទាំងនេះមកធ្វើសក្ខីកម្មឡើងវិញ ដោយមិនចាំបាច់នោះ អង្គជំនុំជម្រះធ្លាប់បានសម្រេចរួចមកហើយថា អ្នកទាំងនោះអាចនឹងត្រូវសាកសួររាល់បញ្ហានានា ទៅតាមការយល់ដឹងឬជំនាញរបស់ខ្លួន ដែលពាក់ព័ន្ធនឹងដីកាដំណោះស្រាយទាំងមូលក្នុងសំណុំរឿង ០០២។ ក្នុងគោលបំណងដើម្បីធានាឱ្យមានសវនាការឆាប់រហ័ស និង ដោយសារការអនុញ្ញាតឱ្យសួរសំណួរហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលជាញឹកញយ នាំឱ្យមានការសួរដេញដោលវែងឆ្ងាយនោះ អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ការសួរដេញដោលរបស់ខ្លួនគួរតែផ្តោតជាសំខាន់ត្រឹមតែបញ្ហាសាច់រឿងក្នុងសំណុំរឿង ០០២/០១ បានហើយ។ ការសាកសួរបញ្ហានានាដែលហួសពីវិសាលភាពនេះគួរតែត្រូវកំហិតត្រឹមតែចំណុចណាដែលភាគីយល់ថាអ្នកជំនាញ ឬសាក្សីនោះមានគុណវុឌ្ឍិដោយឡែកក្នុងការឆ្លើយតបលើចំណុចនោះតែប៉ុណ្ណោះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[196] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ឯកសារ **E260** កថាខណ្ឌ ៧-៨។

វិំខានដោយផ្ទាល់នូវសក្ខីកម្មរបស់អ្នកជំនាញ ដែលបានលើកឡើងពីបញ្ហានេះ ដោយថ្លែងថា "យើងមិនកំពុងពិនិត្យមើលអង្គហេតុទាំងនេះ នៅក្នុងក្របខ័ណ្ឌនៃផ្នែកសវនាការនេះទេ"[197]។

១៧១. ដូច្នេះ វាជាហេតុផលមិនត្រឹមត្រូវ ដែលអង្គជំនុំជម្រះបានបដិសេធការកោះហៅម្តងទៀតលោក PONCHAUD, HEDER និង SHORT ដែលតាមពិតទៅមានសារៈសំខាន់ខ្លាំងណាស់សម្រាប់មេធាវីការពារក្តី។

១៧២. នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន អង្គជំនុំជម្រះបានអះអាងថា ក្នុងចំណោមបុគ្គលសរុបចំនួន ១៨៦ នាក់ ដែលបានស្តាប់ចម្លើយ នៅក្នុងសំណុំរឿង ០០២/០២ គឺមានតែពីរនាក់ប៉ុណ្ណោះដែលត្រូវបានស្នើឡើងដោយអង្គជំនុំជម្រះ (ឬត្រូវជា ១,០៧%) និងជាពិសេស សម្រាប់ការចូលមកបង្ហាញខ្លួនដាក់បន្ទុក[198]។ អង្គជំនុំជម្រះបានឆ្លើយតបថា ខ្លួនមិនបានពិចារណាថា មេធាវីការពារក្តីបានបង្ហាញពីការរំលោភលើសមភាពនៃគូភាគីនោះទេ ពីព្រោះអង្គជំនុំជម្រះបានអនុវត្តចំពោះរាល់សំណើសុំឱ្យចូលមកបង្ហាញខ្លួនទាំងអស់ នូវ "លក្ខណៈវិនិច្ឆ័យតែមួយគត់ និងដូចគ្នា ពោលគឺលក្ខណៈវិនិច្ឆ័យនៃភាពពាក់ព័ន្ធនៃសក្ខីកម្មដែលបានគ្រោងទុក"[199]។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើអង្គជំនុំជម្រះបានអនុវត្តលក្ខណៈវិនិច្ឆ័យនេះយ៉ាងពិប្រាកដ អង្គជំនុំជម្រះនឹងកោះហៅសាជាថ្មី PONCHAUD, HEDER និង SHORT ដែលអង្គជំនុំជម្រះបានទទួលស្គាល់ថាមានភាពពាក់ព័ន្ធ ដើម្បីផ្តល់សក្ខីកម្មម្នាក់ម្តងៗអំពីបញ្ហាជាច្រើននៃសំណុំរឿង ០០២/០២។

១៧៣. ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រើប្រាស់អំណាចឆន្ទានុសិទ្ធរបស់ខ្លួនដោយអយុត្តិធម៌ ដោយធ្វើការជ្រើសរើសតាមទំនើងចិត្ត ឬតាមសំណើរបស់សហព្រះរាជអាជ្ញា នៅពេញមួយអំឡុងពេលនៃការជំនុំជម្រះ នូវធាតុផ្សំភ័ស្តុតាងថ្មីសម្រាប់ដាក់បន្ទុក ក្រោមទម្រង់ជាសក្ខីកម្ម ឬឯកសារ ដែលជាញឹកញយ

---

[197] ប្រតិចារឹក ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** មុនម៉ោង 11.53.37 (លោកស្រីចៅក្រម CARTWRIGHT)។

[198] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៦៦៣-៦៦៥។

[199] សំអាងហេតុសាលក្រម កថាខណ្ឌ ១២៦-១២៧ (សម្រង់សម្តី ទាញចេញពីកថាខណ្ឌ ១២៧)។

គ្មានភាពពាក់ព័ន្ធ និងគ្មានតម្លៃជាភ័ស្តុតាង និងដែលពន្យារកិច្ចដំណើរការនីតិវិធីដោយអយុត្តិធម៌ ជំនួសឱ្យការទទួលស្គាល់ និងស្តាប់សក្ខីកម្ម[200]។

១៧៤. ជាសរុប អង្គជំនុំជម្រះបានរំលោភបំពានសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានសវនាការចំពោះមុខ សំអាងហេតុនៃដីកាសម្រេច និងសាលក្រម ការជំនុំជម្រះដើម្បីឱ្យរឿងក្តីរបស់គាត់ត្រូវបានគេដឹងឮ សមភាពនៃការតទល់ក្តី តុលាការមិនលម្អៀង និងសិទ្ធិទទួលបានការជំនុំជម្រះដោយមិនយឺតយ៉ាវហួសហេតុ។

**មាតិកាទី ៣. វិធីសាស្ត្រលម្អៀងក្នុងការគ្រប់គ្រងភ័ស្តុតាង**

**ជំពូកទី ១. កំហុសក្នុងការគ្រប់គ្រងភ័ស្តុតាងក្នុងអំឡុងពេលសវនាការ**

**ផ្នែកទី ១. សេចក្តីសម្រេចលើការកោះហៅឱ្យចូលមកបង្ហាញខ្លួនបណ្តើរៗ**

១៧៥. នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ក្នុងការកំណត់របៀបវារៈសម្រាប់ការពិនិត្យលើអង្គហេតុដែលជាកម្មវត្ថុនៃការជំនុំជម្រះលើសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានបញ្ជាក់ថា៖

> "អង្គជំនុំជម្រះនឹងចេញដីកាកំណត់របៀបវារៈ សម្រាប់ការចូលមកបង្ហាញខ្លួនរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីស្តាប់ចម្លើយលើប្រធានបទនីមួយៗ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះនឹងចេញដីកាកំណត់កាលបរិច្ឆេទ និងកាលវិភាគនៃការចាប់ផ្តើមសវនាការ ក្នុងពេលឆាប់ៗ"[201]។

១៧៦. ទោះជាអង្គជំនុំជម្រះបានចេញដីកាកំណត់កាលបរិច្ឆេទ និងកាលវិភាគសម្រាប់ការចាប់ផ្តើមការជំនុំជម្រះក្តី ប៉ុន្តែអង្គជំនុំជម្រះមិនបានចេញដីកាបង្គាប់ឱ្យចូលមកបង្ហាញខ្លួន នូវបុគ្គលដែលបានស្នើសុំនោះទេ។ តាមពិត អង្គជំនុំជម្រះបានផ្សព្វផ្សាយតាមរយៈអ៊ីម៉ែលជាច្រើនអំពីផ្នែកសម្រេចសេចក្តីនៃដីកា

[200] សូមមើលខាងក្រោម កថាខណ្ឌ ១៨២-២២៦។

[201] សេចក្តីសម្រេច ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E315 កថាខណ្ឌ ១២។

សម្រេចរបស់ខ្លួនលើការកោះហៅឱ្យចូលមកបង្ហាញខ្លួនមុនពេលជំនុំជម្រះ នៅពេញមួយអំឡុងពេលនៃការជំនុំជម្រះ ហើយអង្គជំនុំជម្រះទើបតែបានផ្តល់សំអាងហេតុ បន្ទាប់ពីសវនាការលើអង្គសេចក្តីបានបញ្ចប់[202]។ ក្នុងការអនុវត្តបែបនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធរបស់ខ្លួនយ៉ាងជាក់ស្តែង ដែលបង្កព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ។

១៧៧. ជាក់ស្តែង ដោយបរិហារការខ្វះតម្លាភាពរបស់អង្គជំនុំជម្រះក្នុងពេលជំនុំជម្រះ និងដោយស្នើសុំម្តងហើយម្តងទៀតនូវបញ្ជីឈ្មោះសាក្សីសរុបដែលត្រូវចូលមកបង្ហាញខ្លួន[203] មេធាវីការពារក្តីបានពន្យល់ពី

[202] ផ្នែកសម្រេចសេចក្តី៖ លិខិតចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ នៅម៉ោង 14:06, ចុះថ្ងៃទី10 ខែតុលា ឆ្នាំ២០១៤ នៅម៉ោង 14:35, ចុះថ្ងៃទី10 ខែធ្នូ ឆ្នាំ២០១៤ នៅម៉ោង 9:00, ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ នៅម៉ោង 12:37, ចុះថ្ងៃទី២0 ខែមករា ឆ្នាំ២០១៥ នៅម៉ោង 11:59, ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ នៅម៉ោង 10:02, ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ នៅម៉ោង 11:45, ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥ នៅម៉ោង 15:25, ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ នៅម៉ោង 10:58, ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥ នៅម៉ោង 14:01, ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ នៅម៉ោង 16:29, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ នៅម៉ោង 15:34 ឯកសារ **E366/1.2**, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ នៅម៉ោង 10:39 ឯកសារ **E381.1.1** ចុះថ្ងៃទី២0 ខែតុលា ឆ្នាំ២០១៥ នៅម៉ោង 14:36, ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅម៉ោង 11:33 ឯកសារ **E381.1.3**, ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ នៅម៉ោង 10:05 ឯកសារ **E364/1.1**, ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ នៅម៉ោង 13:34 ឯកសារ **E380/2.2**, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នៅម៉ោង 14:23, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ នៅម៉ោង 15:15, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នៅម៉ោង 14:03, ចុះថ្ងៃទី0៥ ខែកុម្ភៈ ឆ្នាំ២០១៦ នៅម៉ោង 13:33 ឯកសារ **E390/1.1.1**, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ នៅម៉ោង 12:45 ឯកសារ **E405.1.1**, ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦ នៅម៉ោង 16:25 ឯកសារ E3**92.1.1**, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦ នៅម៉ោង 10:44 ឯកសារ **E408/6.1**, ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ នៅម៉ោង 13:51 ឯកសារ E4**31/2.2**, ចុះថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២០១៦ នៅម៉ោង 14:01 ឯកសារ **E434.1.2**, ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦ នៅម៉ោង 8:54, ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ នៅម៉ោង 14:06 ឯកសារ **E448.1.1**, ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ នៅម៉ោង 16:15 ឯកសារ **E453/1.2**, ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៦ នៅម៉ោង 15:13។ សំអាងហេតុនៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **E459**។ លិខិតដែលគ្មានចុះលេខកូដត្រូវបានដាក់ភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

[203] ឧទាហរណ៍ សូមមើល៖ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ **E363** កថាខណ្ឌ ៤៨។ សេចក្តីជំទាស់របស់មេធាវីការពារក្តី លោក ខៀវ សំផន ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E364** កថាខណ្ឌ ១១។ ចម្លើយ និង សំណើបន្ទាប់បន្សំរបស់លោក ខៀវ សំផន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ **E366/1**។ សំណើ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E374** កថាខណ្ឌ ១៧។ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E421/2**។ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ E408/6។ ប្រតិចារឹក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/471.1** ចន្លោះម៉ោង 11.23.27 និងម៉ោង 11.27.06។ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E408/6/1**។ មេធាវីការពារក្តីក៏បានយោងទៅនឹងការពង្រីកសេចក្តីនៅក្នុងសារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៦៦០-៦៦៥។

ការលំបាកដែលបណ្តាលមកពីកង្វះភាពប្រមើលមើលឃើញក្នុងរយៈពេលខ្លី និងវែងសម្រាប់ការត្រៀមខ្លួន។ ដោយសារជនជាប់ចោទអាចផ្តល់សក្ខីកម្មលើប្រធានបទណាមួយនៃសំណុំរឿង ០០២/០២ ដែលពួកគេអាចដឹង ហើយបើមេធាវីការពារក្តីមានបញ្ជីសរុបនោះ មេធាវីការពារក្តីអាចត្រៀមខ្លួន និងអាចសាកសួរពួកគេ ដោយផ្អែកលើវត្តមាន ឬអវត្តមានរបស់អ្នកដែលនឹងចូលមកបង្ហាញខ្លួន (ករណីនេះទាក់ទងនឹងការបង្ហាញសក្ខីកម្មរបស់បុគ្គលផ្សេងទៀត ឬឯកសារ ជាដើម)។ គ្រប់ភាគីទាំងអស់អាចស្នើសុំឱ្យទទួលយកឯកសារពាក់ព័ន្ធសម្រាប់ចោទសួរនៅពេលចាប់ផ្តើមជំនុំជម្រះ តែមិនពេញមួយអំឡុងពេលនៃការជំនុំជម្រះឡើយ និងភ្លាមៗមុនពេលចូលមកបង្ហាញខ្លួន[204]។ សំណើសុំឱ្យចូលមកបង្ហាញខ្លួនរាប់មិនអស់របស់ភាគីនានា បានបំពុលដំណើរការនីតិវិធីនៃកិច្ចពិភាក្សាលើអង្គសេចក្តី និងចំណាយពេលវេលាសន្ធឹកសន្ធាប់ឥតប្រយោជន៍។

១៧៨. វិធីសាស្ត្ររបស់អង្គជំនុំជម្រះក៏បើកឱកាសដល់ការប្រព្រឹត្តិខុសគន្លងជាច្រើន។ ជាពិសេស អង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើសំណើសុំឱ្យចូលមកបង្ហាញខ្លួនថ្មី ដោយផ្អែកលើភ័ស្តុតាងដែលបានស្តាប់មកទល់ពេលនោះ នៅពេលដែលសហព្រះរាជអាជ្ញាមិនពេញចិត្ត[205]។ ទំនោររបស់សហ

---

[204] ឧទាហរណ៍ សូមមើល សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ១៣ និង ១៥ នៅទីនេះ គេសង្កេតឃើញថាព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញពីការជួបការលំបាកទាក់ទងនឹងការផ្តល់ព័ត៌មានស្តីពីឯកសារនៃសំណុំរឿង ០០៣ និង ០០៤៖ "សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថានៅ ពេលសាក្សីត្រូវបានជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង ពីរសប្តាហ៍ឬជួនកាលប៉ុន្មានថ្ងៃមុនចូលសវនាការ គឺមិនអាចឱ្យសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំផ្តល់ឯកសារឱ្យបានរៀបរយល្អនោះទេ"។ (កថាខណ្ឌ ១៥)។

[205] ជាឧទាហរណ៍ ទាក់ទងនឹង<u>ជនជាតិចាម</u>៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E366** (ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E366/1**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E372** (ផ្នែកសម្រេចសេចក្តី) សេចក្តីសម្រេច ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ E366/3 (សំអាងហេតុ))។ <u>ទាក់ទងនឹងជនជាតិវៀតណាម</u>៖ សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E381** និង សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E382** (ចម្លើយផ្ទាល់មាត់របស់ លោក ខៀវ សំផន ប្រតិចារឹក ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ឯកសារឯកសារ **E1/371.1** ចន្លោះម៉ោង 09.17.08 និងម៉ោង 09.49.13។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ E3**80/1** (ផ្នែកសម្រេចសេចក្តី)។ សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ E3**80/2** (សំអាងហេតុ)។ ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍៖ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសាក្សី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E425** (ចម្លើយតបរបស់មេធាវីការពារក្តីលោក

ព្រះរាជអាជ្ញាក្នុងការចង់មានសាក្សីច្រើនតាមដែលអាចធ្វើទៅបាន ដរាបណាសហព្រះរាជអាជ្ញាមិនទាន់បានទទួលការបញ្ជាក់គាំទ្រនិក្ខេបបទរបស់ខ្លួន នៅសវនាការ គឺមានភាពជាក់ស្តែងតាំងពីការចាប់ផ្តើមជំនុំជម្រះ ហើយត្រូវបានកត់សម្គាល់ដោយមេធាវីការពារក្តី[206]។ អង្គជំនុំជម្រះមិនត្រឹមតែបណ្តោយឱ្យរឿងនេះកើតឡើងប៉ុណ្ណោះទេ ប៉ុន្តែអង្គជំនុំជម្រះផ្ទាល់ក៏ឆ្លៀតយកឱកាស ដើម្បីកោះហៅភ្លាមៗបុគ្គលដែលសក្ខីកម្មរបស់ពួកគេ (ត្រូវបានប្រមូលនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលកំពុងស្ថិតក្រោមការស៊ើបអង្កេត) ត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយខុសច្បាប់ ដោយសហព្រះរាជអាជ្ញាពេញមួយសវនាការ[207]។

១៧៩. លើសពីនេះទៀត ដោយមិនផ្តល់សំអាងហេតុជាបន្តបន្ទាប់ អង្គជំនុំជម្រះបានរក្សាភាពមិនច្បាស់លាស់ជុំវិញវិសាលភាពនៃការជំនុំជម្រះក្តី ០០២/០២ ជាពិសេស លើបញ្ហានៃ "ការបោសសម្អាតផ្ទៃក្នុង" ដែលជាប្រធានបទថ្មីមួយដែលបានលេចចេញក្នុងពេលជំនុំជម្រះ[208]។

១៨០. ក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី ផ្នែកសម្រេចសេចក្តីនៃដីកាសម្រេចរបស់អង្គជំនុំជម្រះ អាចធ្វើឱ្យគេយល់ថា អង្គជំនុំជម្រះបានពិចារណាលើសក្ខីកម្មពាក់ព័ន្ធនឹងប្រធានបទជាក់លាក់មួយ។ បន្ទាប់

---

ខៀវ សំផន ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ឯកសារ E425/1។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E425/2)។

[206] សេចក្តីជំទាស់របស់ លោក ខៀវ សំផន ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ ឯកសារ E305/9 កថាខណ្ឌ ៣៤ ដែលយោងទៅបញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ E305/6 កថាខណ្ឌ ១១ (នៅទីនេះ សហព្រះរាជអាជ្ញាជូនព័ត៌មានដល់អង្គជំនុំជម្រះថាខ្លួនមិនច្រានចោលនូវការស្នើស្តាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញ "បម្រុង" វិញ ក្នុងករណីដែលបុគ្គលដែលបានស្នើឡើងមិនអាចមកបង្ហាញខ្លួននៅតុលាការដោយសារមូលហេតុណាមួយ ឬ "មិនអាចបង្ហាញអង្គហេតុដូចនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី") និង កថាខណ្ឌ ១៣ ("និយាយក្នុងលក្ខណៈទូទៅជាងនេះ នៅពេលសវនាការ ដំណើរការទៅមុខ ប្រសិនបើសហព្រះរាជអាជ្ញាជឿថាចាំបាច់ត្រូវការកោះហៅសាក្សីបន្ថែមលើបញ្ហាជាក់លាក់ណាមួយដើម្បីបំពេញបន្ទុកភស្តុតាងរបស់ខ្លួន នោះសហព្រះរាជអាជ្ញារក្សាសិទ្ធិស្នើសាក្សីបន្ថែមជូនអង្គជំនុំជម្រះសាលាដំបូងនៅក្នុងពេលនោះតែម្តង")។

[207] សូមមើលខាងក្រោម កថាខណ្ឌ ១៩៨-២១៥។

[208] សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E420។ សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ២៧៧-២៩៣។

ពីសវនាការលើអង្គសេចក្តី សំអាងហេតុនៃដីកាសម្រេចរបស់អង្គជំនុំជម្រះ មិនអនុញ្ញាតឱ្យយើងដឹងលើសពីហ្នឹងទៀតទេ លើកលែងតែអង្គជំនុំជម្រះបានបង្គាប់ឱ្យកោះហៅបុគ្គល "ដែលសក្ខីកម្មរបស់គាត់នឹងរួមចំណែកច្រើនបំផុតដល់ការស្វែងរកការពិត"[209]។ លើសពីនេះ អង្គជំនុំជម្រះគ្រាន់តែបានផ្តល់មូលហេតុដែលខ្លួនមិនបានជ្រើសរើសបុគ្គលផ្សេងទៀតដែលស្នើឡើងដោយភាគី ហើយហេតុផលចម្បងគឺសក្ខីកម្មរបស់ពួកគេអាចនឹងមានភាពច្រំដែលច្រើន បើប្រៀបធៀបនឹងសក្ខីកម្មរបស់បុគ្គលដែលបានស្តាប់ចម្លើយរួចហើយ[210]។ ដូច្នេះ អង្គជំនុំជម្រះមិនដែលពន្យល់ទេ ថាហេតុអ្វីបានជា កាលពីដំបូង អង្គជំនុំជម្រះបានជ្រើសរើសបុគ្គលនេះ ឬបុគ្គលនោះ ដែលនៅទីបំផុត ទង្វើនេះមើលទៅហាក់ដូចជាការបង្ហាញពីចំណូលចិត្តរបស់ខ្លួនចំពោះការផ្តល់សក្ខីកម្មដាក់បន្ទុក ដោយមិនចាំបាច់និយាយឱ្យចំនៅពេលអង្គជំនុំជម្រះបានធ្វើការជ្រើសរើស ក្នុងសវនាការ។

១៨១. កំហុសរបស់អង្គជំនុំជម្រះបាននាំឱ្យមានការរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានពេលវេលា និងសម្ភារចាំបាច់សម្រាប់ការរៀបចំការការពារក្តីរបស់គាត់ តម្លាភាពនីតិវិធី សំអាងហេតុនៃសេចក្តីសម្រេច ការជូនដំណឹងអំពីប្រភេទ និងមូលដ្ឋាននៃការចោទប្រកាន់ប្រឆាំងនឹងគាត់ សច្ចភាពគតិយុត្ត និងនីតិវិធី ការជំនុំជម្រះដោយគ្មានការពន្យារពេលហួសប្រមាណ និងសិទ្ធិទទួលបានតុលាការមិនលម្អៀង។

### ផ្នែកទី ២. ភាពខុសប្រហែសចំពោះលក្ខណៈពិសេសនៃវិធាន ៨៧(៤)

១៨២. នៅក្នុងសំអាងហេតុសាលក្រម បន្ទាប់ពីបានរំឭកថាការទទួលយកភ័ស្តុតាងក្នុងអំឡុងពេលសវនាការបានគោរពតាមរបបពិសេសនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[211] អង្គជំនុំជម្រះបានបញ្ជាក់ថា ធាតុផ្សំនៃភ័ស្តុតាង "មួយចំនួន" ត្រូវបានទទួលយកដោយផ្អែកលើមូលដ្ឋាននេះ នៅក្នុងការជំនុំជម្រះក្តី ០០២/

[209] សេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ E459 កថាខណ្ឌ ២០។

[210] សេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ E459 កថាខណ្ឌ ២២-១៩៤។

[211] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣។

០២[212]។ តាមពិត សាក្សី និងឯកសារថ្មីៗមួយចំនួនធំ ត្រូវបានទទួលយកគ្រប់ពេលទាំងអស់ នៅពេញមួយអំឡុងពេលជំនុំជម្រះ។

១៨៣. ទោះបីជាដំណាក់កាលស៊ើបអង្កេតដ៏វែង និងដំណាក់កាលត្រៀមសម្រាប់ការជំនុំជម្រះក្តី ក្នុងកំឡុងពេលដែលមានធាតុផ្សំភ័ស្តុតាងរាប់ពាន់ត្រូវបានបញ្ចូលក្នុងសំណុំរឿងរួចហើយ អង្គជំនុំជម្រះបានផ្តល់តម្លៃដល់បរិមាណច្រើនជាងគុណភាព និងល្បឿន។ អង្គជំនុំជម្រះបានងាកចេញពីយុត្តិសាស្ត្រមុនរបស់ខ្លួន ដោយទទួលស្គាល់លក្ខណៈពិសេសនៃការដាក់បញ្ចូលធាតុផ្សំភ័ស្តុតាងក្នុងអំឡុងពេលជំនុំជម្រះ ដើម្បីប្រែក្លាយវាឱ្យទៅជាវិធាន តែមិនមែនជាអញ្ញត្រកម្មទេ។ តាមរបៀបដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងកំហុសជាក់ស្តែងនៃការប្រើឆន្ទានុសិទ្ធិ ដែលបង្កព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ។

១៨៤. យោងតាមវិធានផ្ទៃក្នុង ការទទួលយកភ័ស្តុតាងត្រូវបានគ្រប់គ្រងតាមរបៀបខុសគ្នា អាស្រ័យលើដំណាក់កាលនៃការជំនុំជម្រះ៖ ការទទួលយកក្នុងអំឡុងពេលជំនុំជម្រះ (វិធាន ៨៧(៤)) គឺជាការលើកលែងចំពោះវិធានដែលចែងថា ភ័ស្តុតាងត្រូវបានបង្ហាញនៅក្នុងដំណាក់កាលត្រៀមជំនុំជម្រះ (វិធាន ៨០ និង ៨៧(៣))។

១៨៥. ជាក់ស្តែង នៅ អ.វ.ត.ក បន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅស៊ើបសួររបស់សហព្រះរាជអាជ្ញា ភ័ស្តុតាងត្រូវបានប្រមូលដោយសហចៅក្រមស៊ើបអង្កេត[213]។ ដោយផ្អែកលើមូលដ្ឋាននៃសំណុំរឿងស៊ើបអង្កេត ភាគី និងអង្គជំនុំជម្រះត្រៀមរៀបចំ សម្រាប់ការជំនុំជម្រះ[214]។ ក្នុងដំណាក់កាលត្រៀមនេះ ភាគីផ្តល់បញ្ជីភ័ស្តុតាងដែលពួកគេស្នើសុំ ទាំងភ័ស្តុតាងនៅក្នុងសំណុំរឿងស៊ើបអង្កេត ទាំងភ័ស្តុតាងថ្មី។ បញ្ជីទាំងនេះត្រូវតែរួមបញ្ចូលនូវសេចក្តីសង្ខេបអំពីខ្លឹមសារនៃភ័ស្តុតាងដែលបានស្នើសុំ និងចំណុចពាក់ព័ន្ធ

[212] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៦។

[213] វិធាន ៥៣ និង ៥៥ នៃវិធានផ្ទៃក្នុង។

[214] វិធាន ៥៥-១១, ៦៧, ៦៩, ៧៩.១ និង ៨០ នៃវិធានផ្ទៃក្នុង។

នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[215]។ អង្គជំនុំជម្រះចេញសេចក្តីសម្រេចដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង (ភាពពាក់ព័ន្ធ លក្ខណៈមិនច្រំដែល។ ល។)[216]។

១៨៦. នៅពេលបើកសវនាការ ប្រសិនបើភាគីទាំងអស់នៅតែអាចស្នើសុំភស្តុតាងថ្មី ពេលនោះ គេត្រូវអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ យោងតាមវិធាននេះ ភាគីស្នើសុំត្រូវតែផ្តល់សំអាងហេតុនៃសំណើរបស់ខ្លួន ដើម្បីបញ្ចុះបញ្ចូលអង្គជំនុំជម្រះថា ភស្តុតាងដែលស្នើសុំមិនមានទេ មុនពេលបើកសវនាការ ហើយភស្តុតាងនោះមានប្រយោជន៍សម្រាប់ស្វែងរកការពិត។ ការស្នើសុំភស្តុតាងត្រូវតែអនុលោមតាមវិធាន ៨៧(៣) [217]។

១៨៧. ហេតុផលចម្បងនៃលក្ខណៈពិសេសនៃវិធាន ៨៧(៤) និងនៃតម្រូវការបន្ថែមរបស់វិធាននេះក្នុងពេលជំនុំជម្រះ គឺមានលក្ខណៈសាមញ្ញ៖ បន្ទាប់ពីការស៊ើបអង្កេតដ៏វែង និងការត្រៀមរៀបចំសវនាការដ៏យូរ ភាគីលែងអាចត្រៀមរៀបចំសម្រាប់ការជំនុំជម្រះ ក្នុងអំឡុងពេលជំនុំជម្រះក្តីទៀតហើយ ជាពិសេស ខណៈដែល "ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប" [218]។

១៨៨. ពេលចាប់ផ្តើមសវនាការសំណុំរឿង ០០២/០១ និងក្នុងដំណាក់កាលត្រៀមរៀបចំសវនាការ សំណុំរឿង ០០២/០២ យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ គឺស្របនឹងបទប្បញ្ញត្តិ និងស្មារតីនៃវិធាន ៨៧(៤)។ នៅ

[215] វិធាន ៨០ នៃវិធានផ្ទៃក្នុង។

[216] "អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖ ក- មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា ខ- មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ- មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ឃ- ច្បាប់មិនអនុញ្ញាត ឬ ង- មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។

[217] "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំ ជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុ នៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាម ខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះ ជឿជាក់ថា សក្ខីកម្ម ឬភស្តុតាង ដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"។

[218] វិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

ពេលនោះ អង្គជំនុំជម្រះសន្និដ្ឋានថា ភាគីស្នើសុំត្រូវតែបំពេញតាម "លក្ខណៈវិនិច្ឆ័យខ្ពស់បំផុត" ដែលត្រូវបង្ហាញថា គេមិនអាចរកបានឯកសារនោះកាលពីពេលមុន ហើយការទទួលយក"យឺតយ៉ាវ" នូវឯកសារទាំងនោះ គឺ "មានសារៈសំខាន់" ឬ "មានប្រយោជន៍" សម្រាប់យុត្តិធម៌[219]។ អង្គជំនុំជម្រះពន្យល់ថា "លក្ខណៈវិនិច្ឆ័យកាន់តែតឹងរ៉ឹងដែលមានចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង មានគោលបំណងជួយសម្រួលដល់ប្រសិទ្ធភាពនៃនីតិវិធី"[220]។

១៨៩. ទោះយ៉ាងណា ចាប់ពីការចាប់ផ្តើមនៃការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានងាកចេញយ៉ាងខ្លាំងពីយុត្តិសាស្ត្រនេះ និងពីភាពចាំបាច់ក្នុងការធានាប្រសិទ្ធភាព និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី។ នៅក្នុងសវនាការ ពេលសហព្រះរាជអាជ្ញាអន្តរជាតិបានចាប់ផ្តើមស្នើសុំឱ្យទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរជាច្រើនពីសំណុំរឿងផ្សេងទៀត (ដែលគាត់មិនបានធ្វើនៅក្នុងសំណុំរឿង ០០២/០១)[221] អង្គជំនុំជម្រះទាមទារត្រឹមតែសំអាងហេតុមួយដែលកម្រិតត្រឹមភាពពាក់ព័ន្ធតែមួយគត់ (ដែលអាចដេញដោលបាន) នៃឯកសារទាំងនេះ។ អង្គជំនុំជម្រះបានទទួលយកឯកសារដ៏ក្រាស់ក្រែលទាំងនោះដោយស្វ័យប្រវត្តិ ទោះបីជាវាមានតម្លៃជាភ័ស្តុតាងតិចក៏ដោយ ដោយផ្អែកលើហេតុផលថាវាពាក់ព័ន្ធ ហើយដូច្នេះ វាមានប្រយោជន៍សម្រាប់ស្វែងរកការពិត[222]។ ដោយភ្ជាប់ភាព

---

[219] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ ឯកសារ **E131/1** ទំព័រ ៤ កថាខណ្ឌមុនចុងក្រោយ។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ **E118/4** ទំព័រ ៣ កថាខណ្ឌមុនចុងក្រោយ។ អត្ថបទជាភាសាអង់គ្លេសនៃអនុស្សរណៈទាំងពីរនេះមានអត្ថន័យដូចគ្នា៖ « *(...) the extremely high threshold of showing that these documents could have been disclosed within the applicable deadlines with the exercise of due diligence, and that their late admission is vital in the interests of justice* »។

[220] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ **E307/1** កថាខណ្ឌ ៣។ សូមមើលផងដែរអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ ឯកសារ **E307/1/2** កថាខណ្ឌ ១១៖ "វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងថ្លឹងថ្លែងអំពីភាពចាំបាច់ក្នុងការធានាថាភ័ស្តុតាងពាក់ព័ន្ធ និងអាចជឿទុកចិត្តបានទាំងអស់ត្រូវបានដាក់បញ្ចូលក្នុងការពិភាក្សាដេញដោល ក្នុងគោលបំណងដើម្បីជូនដំណឹងឱ្យបានទាន់ពេលអំពីភ័ស្តុតាងបែបនេះ ដោយធានាឱ្យមានការជំនុំជម្រះមួយឆាប់រហ័ស និងប្រកបដោយយុត្តិធម៌ និងដើម្បីឱ្យការគ្រប់គ្រងការជំនុំជម្រះប្រកបដោយប្រសិទ្ធភាពរហូតដល់ទីបញ្ចប់"។

[221] សូមមើលខាងក្រោម ក្នុងផ្នែកបន្ទាប់ស្តីពីធាតុផ្សំភ័ស្តុតាងនៅក្នុងសំណុំរឿង ០០៣ និង ០០៤។

[222] ឧទាហរណ៍ សូមមើល៖ សេចក្តីសម្រេច ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ **E319/7** កថាខណ្ឌ ១០។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E319/17/1** កថាខណ្ឌ ៤។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E319/22/1** កថាខណ្ឌ ៥។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨

ពាក់ព័ន្ធទៅនឹងប្រយោជន៍នៃការស្វែងរកការពិត និងដោយអនុវត្តតែលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) ក្នុងពេលជំនុំជម្រះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ហើយបើកឱកាសឱ្យសហព្រះរាជអាជ្ញាដាក់បញ្ចូលធាតុផ្សំថ្មីរាប់រយក្នុងពេលជំនុំជម្រះ។

១៩០. សំណើទាំងនេះរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺជាចំណុចចាប់ផ្តើមនៃការស្នើសុំជាច្រើនឱ្យទទួលយកភ័ស្តុតាងថ្មី នៅក្នុងអំឡុងពេលជំនុំជម្រះ។ ពិតមែនតែសំណើទាំងនេះមួយចំនួនត្រូវបានធ្វើឡើងសម្រាប់ការចូលមកបង្ហាញខ្លួន និងត្រូវបានផ្តល់យុត្តិកម្ម ដោយហេតុថា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនលើការបង្ហាញខ្លួនរបស់សាក្សី បន្តិចម្តងៗ ក្នុងអំឡុងពេលជំនុំជម្រះក្តី[223] តែសំណើភាគច្រើនមិនចាំបាច់ដាច់ខាតនោះទេ។ ដោយពិចារណាលើភ័ស្តុតាងរាប់ពាន់ដែលត្រូវបានទទួលយករួចហើយនៅក្នុងសំណុំរឿង ០០២/០២ ការទទួលយកភ័ស្តុតាងថ្មីក្នុងអំឡុងពេលជំនុំជម្រះ តាមការស្នើសុំ គឺភាគច្រើនមិនមាន "ប្រយោជន៍" ឬ "សារៈសំខាន់" នៅក្នុងផលប្រយោជន៍យុត្តិធម៌ទេ។ ការទទួលយកនេះត្រូវបានធ្វើឡើង ដោយមិនពិចារណាដល់ការចូលមកបង្ហាញខ្លួនរបស់សាក្សីសំខាន់ៗមួយចំនួន ដែលត្រូវបានស្នើដោយមេធាវីការពារក្តី នៅមុនពេលជំនុំជម្រះ[224]។

១៩១. រហូតមកដល់ចុងខែមិថុនា ឆ្នាំ២០១៦ ទើបអង្គជំនុំជម្រះហាក់ដូចជាវិលត្រឡប់ទៅរកស្មារតី និងបទប្បញ្ញត្តិ នៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ នៅក្នុងអនុស្សរណៈស្តីពីដំណាក់កាលចុងក្រោយនៃការជំនុំជម្រះក្តី ០០២/០២ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគី អំពីការកំណត់កាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ សម្រាប់ការដាក់ពាក្យស្នើឱ្យទទួលយក ដោយផ្អែកលើមូលដ្ឋាននេះ[225]។ អង្គជំនុំជម្រះក៏បានចាប់ផ្តើមបដិសេធឯកសារមួយចំនួន ដែលស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ

ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E319/32/1** កថាខណ្ឌ ១០។ សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E319/36/2** កថាខណ្ឌ ២១-២២, ២៦-២៧, ៣០, ៤០-៤១។

[223] សូមមើលខាងលើ ផ្នែកមុន។

[224] សារណាបណ្តឹងសាទុក្ខ ០០២/០២កថាខណ្ឌ ៦៦៣-៦៦៥។ សូមមើលខាងលើ កថាខណ្ឌ ១៦៥-១៧៣។

[225] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E421** កថាខណ្ឌ ៣។ សូមមើលផងដែរ៖ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E421/3** (ផ្នែកសម្រេចសេចក្តី) និង សេចក្តីសម្រេច ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E421/4** (អង្គហេតុ) កថាខណ្ឌ ១៣-១៨។

ដោយផ្អែកលើហេតុផលថាសហព្រះរាជអាជ្ញាអន្តរជាតិខ្វះវិរភាព និងប្រកាសថា ដោយសារកិច្ច ពិភាក្សាជិតឈានដល់ទីបញ្ចប់ អង្គជំនុំជម្រះនឹងដាក់សំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មីទៅពិនិត្យ "ប្រយ័ត្នប្រយែងជាងនេះ"[226]។

១៩២. ការពិនិត្យ "ប្រយ័ត្នប្រយែងជាងនេះ" ដែលគួរតែត្រូវបានធ្វើឡើងតាំងពីពេលចាប់ផ្តើម តែមិនមែននៅចុងបញ្ចប់នៃការជំនុំជម្រះក្តី មិនបានរារាំងអង្គជំនុំជម្រះមិនឱ្យបន្តទទួលយកសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមានតម្លៃជាភ័ស្តុតាងជាក់ស្តែងទាប (និងមានភាពពាក់ព័ន្ធមានកម្រិត) នៅចុងបញ្ចប់នៃការជំនុំជម្រះ[227]។ អង្គជំនុំជម្រះក៏មិនស្ទាក់ស្ទើរក្នុងការទទួលយកឯកសារដែលមានតម្លៃជាភ័ស្តុតាងទាប នៅចុងបញ្ចប់នៃការជំនុំជម្រះ ពីបុគ្គលដែលមិនបានចូលមកបង្ហាញខ្លួន[228]។

១៩៣. អង្គជំនុំជម្រះគួរតែអនុវត្តតាមយុត្តិសាស្ត្រអន្តរជាតិ និងអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន "ដោយថ្លឹងថ្លែងតម្លៃជាភ័ស្តុតាងនៃឯកសារ និងភាពអយុត្តិធម៌ដែលអាចបង្កចំពោះជនជាប់ចោទ ដោយការទទួលយកនៅដំណាក់កាលយឺតយ៉ាវបែបនេះ" ហើយអង្គជំនុំជម្រះគួរតែ "ដកចេញនូវរាល់ធាតុផ្សំដែលមានតម្លៃជាភ័ស្តុតាងដែលមិនអាចទូទាត់បានជាមួយការចង់បានការជំនុំជម្រះក្តីមួយយុត្តិធម៌"[229]។

១៩៤. ការប្រកាសអំពីការត្រួតពិនិត្យ "ប្រយ័ត្នប្រយែងជាងនេះ" ក៏មិនបានរារាំងដល់អង្គជំនុំជម្រះក្នុងការទទួលយកសៀវភៅទាំងក្បាលៗដោយយឺតយ៉ាវ នៅចុងបញ្ចប់នៃការជំនុំជម្រះ ទោះបីមានការជំទាស់

[226] សេចក្តីសម្រេច ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E319/47/3** កថាខណ្ឌ ២៣។ សូមមើលផងដែរសេចក្តីសម្រេច ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E319/52/4** កថាខណ្ឌ ១២៖ "អង្គជំនុំជម្រះសូមរំឮកថាសំណើសុំឱ្យទទួលយកភ័ស្តុតាង នៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីត្រូវធ្វើការពិនិត្យដល់តឹងរ៉ឹង"។

[227] ជាឧទាហរណ៍៖ សេចក្តីសម្រេច ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E319/47/3** កថាខណ្ឌ ២៤-២៧។

[228] ជាពិសេស សូមមើលខាងក្រោម កថាខណ្ឌ ២១៦-២២៦។

[229] សូមមើលឧទាហរណ៍៖ សាលដីកា *Kordic* និង *Cerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់យូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ២២១-២២២។

ពីមេធាវីការពារក្តី[230] ខណៈដែលអង្គជំនុំជម្រះបានបង្គាប់ដល់ភាគីទាំងអស់ឱ្យជ្រើសរើស ផ្នែកដែលគិតថាពាក់ព័ន្ធ នៅពេលចាប់ផ្តើមជំនុំជម្រះ[231]។

១៩៥. ការប្រកាសនេះ និងកាលបរិច្ឆេទផុតកំណត់នៃសំណើសុំថ្មីៗ ក៏មិនបានរារាំងអង្គជំនុំជម្រះមិនឱ្យសម្រេចតាមទំនើងចិត្តលើការចូលមកបង្ហាញខ្លួនរបស់បុគ្គលថ្មីទាំងអស់[232] ឬបើកឱកាសដល់ការស្នើសុំឱ្យចូមកបង្ហាញខ្លួនថ្មី នៅចុងបំផុតនៃការជំនុំជម្រះក្តី។ បន្ទាប់ពីការស្នើសុំការបញ្ជាក់ពីមេធាវីការពារក្តីទាក់ទងនឹងសក្ខីម្មជាលាយលក្ខណ៍អក្សរដែលបានទទួលយកដោយផ្អែកលើភាពពាក់ព័ន្ធរបស់វា ជាពិសេស ភាពពាក់ព័ន្ធនឹងសកម្មភាព និងការប្រព្រឹត្តិរបស់ជនជាប់ចោទ[233] អង្គជំនុំជម្រះបានបញ្ជាក់ថា "បានទាញចំណាប់អារម្មណ៍របស់ភាគី អំពីភាពពាក់ព័ន្ធបន្ថែមដែលអាចកើតមាន ក្នុងករណីភាគីចង់ដាក់សំណើសុំឱ្យសាក្សីទាំងនេះចូលមកបង្ហាញខ្លួន"[234]។ សហព្រះរាជអាជ្ញាបានដើរលើផ្លូវនេះ ហើយបានចោទសួរភ្លាមៗអំពីតួនាទីរបស់ជនជាប់ចោទ បន្ទាប់ពីការចូលមកបង្ហាញខ្លួនរបស់សាក្សីថ្មីៗ។ ទោះបីជាអង្គជំនុំជម្រះបានបដិសេធសំណើនេះក៏ដោយ[235] ក៏អង្គជំនុំជម្រះបានចំណាយពេលពីរបីថ្ងៃ

[230] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E431/4** (ផ្នែកសម្រេចសេចក្តី) និងសេចក្តីសម្រេច ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E431/5** (សំអាងហេតុ) កថាខណ្ឌ ២៧ (សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់លោក ខៀវ សំផន ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 09.31.08-09.36.53)។ សេចក្តីសម្រេចផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/480.1** ចន្លោះម៉ោង 11.07.00 និងម៉ោង 11.11.50 (ផ្នែកសម្រេចសេចក្តី) និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E433/4** (សំអាងហេតុ) កថាខណ្ឌ ២ និង ៥។

[231] សេចក្តីសម្រេចផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/285.1** ចន្លោះម៉ោង 10.03.12 និងម៉ោង 10.05.13 និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E342/3** កថាខណ្ឌ ៥-៦ (នៅទីនេះ អង្គជំនុំជម្រះសង្កត់ធ្ងន់លើភាពពាក់ព័ន្ធ និងលើកឡើងថាកិច្ចការនោះបង្កភាពងាយស្រួលដល់ការងារបកប្រែឯកសារភ័ស្តុតាងទាក់ទងនឹងសំណុំរឿង ០០២/០២)។

[232] សូមមើលខាងក្រោម ផ្នែកបន្ទាប់ កថាខណ្ឌ ២១២-២១៣។

[233] សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E319/52/4/1** ដែលយោងទៅសេចក្តីសម្រេច ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E319/52/4** កថាខណ្ឌ ១៥-ឃ។

[234] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១០១៦ ឯកសារ **E319/52/5** កថាខណ្ឌ ៣។

[235] សេចក្តីសម្រេចដោយផ្ទាល់មាត់៖ ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E1/514.1** ចន្លោះម៉ោង 15.44.18 និងម៉ោង 15.46.55 (ផ្នែកសម្រេចសេចក្តី) និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ឯកសារ **E452/1** (សំអាងហេតុ)។

ទៀត បន្ទាប់ពីបញ្ចប់សវនាការលើអង្គសេចក្តី បន្ថែមពីលើពេលវេលាបន្ថែមសម្រាប់ការជំនុំជម្រះលើសំណើសុំភ័ស្តុតាងថ្មី។

១៩៦. នៅក្នុងពេលជំនុំជម្រះក្តី ដោយប៉ះពាល់ដល់ការត្រៀមរៀបចំសវនាការលើអង្គសេចក្តីរបស់ខ្លួន ក្រុមមេធាវីការពារក្តីបានចំណាយពេលជាច្រើន ដើម្បីជំទាស់នឹងសំណើសុំឱ្យទទួលយកធាតុផ្សំថ្មីដែលបានបង្កើតដោយភាគីផ្សេងទៀត ឬជំទាស់ទៅនឹងការទទួលយកធាតុផ្សំទាំងនោះដោយអត្តនោម័តិពីសំណាក់អង្គជំនុំជម្រះ[236] ជាពិសេស ដោយសារតែការទទួលយកធាតុផ្សំទាំងនេះដែលនឹងត្រូវពិនិត្យនៅទីបញ្ចប់ដោយផ្អែកលើធាតុផ្សំទាំងអស់ នឹងពន្យារដំណើរការនីតិវិធី[237]។ ក្នុងសារណាចុងក្រោយរបស់ខ្លួន មេធាវីការពារក្តីបានពន្យល់ពីព្យសនកម្មទទួលរង ដោយត្រូវរៀបចំការជំនុំជម្រះក្នុងអំឡុងពេលសវនាការ និងពីផលប៉ះពាល់អវិជ្ជមានទៅលើល្បឿននីតិវិធីនៃការទទួលយកធាតុផ្សំថ្មីៗក្នុងបរិមាណច្រើន[238]។ បើអង្គជំនុំជម្រះមិនបានឆ្លើយតបនឹងបញ្ហានេះនៅក្នុងសំអាងហេតុសាលក្រម[239] វាហាក់ដូចជាថា អង្គជំនុំជម្រះបានដឹងអំពីផលប៉ះពាល់របស់វាលើពេលវេលានៃការពិភាក្សាសម្រេច។ ជាក់ស្តែង ក្នុងអំឡុងពេលពិភាក្សាសម្រេច អង្គជំនុំជម្រះបានចង្អុលបង្ហាញពីរដង ក្នុងឯកសាររដ្ឋបាលបណ្តោះអាសន្នប្រចាំត្រីមាស (ផែនការបញ្ចប់) ថា បាន *"ប៉ាន់ស្មានពីពេលវេលាចាំបាច់សម្រាប់វាយ*

[236] ក្រៅពីឯកសារដែលមានយោងនៅក្នុងផ្នែកនេះ សូមមើលសេចក្តីសន្និដ្ឋានជាលាយលក្សណ៍អក្សរ និងផ្ទាល់មាត់ជាច្រើន ដែលត្រូវបានរៀបចំក្នុងបញ្ជីនៅក្នុងផ្នែកបន្ទាប់នៃឯកសារនេះ ទាក់ទងទៅនឹងភ័ស្តុតាងនៅក្នុងសំណុំរឿង ០០៣ និង ០០៤ កំណត់សម្គាល់ជើងទំព័រនៃកថាខណ្ឌ ១៩៩)។ សូមមើលផងដែរ៖ សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E327/**4/6។ ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E434/1/1**។ ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E393/3/1**។

[237] ជាឧទាហរណ៍៖ ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/56/2** កថាខណ្ឌ ២៥-២៨។

[238] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៦៦០-៦៦៥។

[239] សំអាងហេតុសាលក្រម កថាខណ្ឌ១១៣-១១៥ (នៅទីនេះ អង្គជំនុំជម្រះឆ្លើយយ៉ាងខ្លីបំផុត ហើយចម្លើយនោះស្ថិតនៅតែក្នុងផ្នែកចោទប្រកាន់ដែលមានភាពលម្អៀង) និង កថាខណ្ឌ ១៣៩-១៤៨ (នៅទីនេះ អង្គជំនុំជម្រះមិនឆ្លើយសោះតែម្តង ចំពោះទឡ្ហីករណ៍ដែលលើកឡើងដោយមេធាវីការពារក្តីទាក់ទងនឹងភាពយឺតយ៉ាវ ដែលបានរំឮកនៅក្នុង កថាខណ្ឌ ១៣៩)។

*តម្លៃ និងពិចារណាសម្រេចលើភស្តុតាងដ៏ច្រើនក្រាស់ក្រែល នៅក្នុងករណីដ៏ស្មុគស្មាញនេះ"*[240]។ លើសពីនេះទៀត ឯកសារថ្មីៗមួយចំនួនធំដែលត្រូវបានទទួលយកក្នុងពេលជំនុំជម្រះ មិនទាន់បានប្រើក្នុងសំអាងហេតុនៅឡើយផង ដែលជាការបញ្ជាក់ថា ការទទួលយកភស្តុតាងទាំងនោះដោយយឺតយ៉ាវ គឺកាន់តែគ្មានសារៈសំខាន់ ឬចាំបាច់ សម្រាប់ផលប្រយោជន៍យុត្តិធម៌[241]។ ការទទួលយកបែបនេះ គឺជាការអាសាបង់ និងពន្យារពេលការជំនុំជម្រះឥតប្រយោជន៍។

១៩៧. ប្រសិនបើអង្គជំនុំជម្រះបានពិនិត្យសំណើនីមួយៗ សម្រាប់ការទទួលយកភស្តុតាងថ្មីតាំងពីដំបូង ក្នុងលក្ខណៈយកចិត្តទុកដាក់ពិតប្រាកដ ដោយមិនព្រងើយកន្តើយនឹងចរិតពិសេសនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និងដោយអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនអោយបានត្រឹមត្រូវ នោះអង្គជំនុំជម្រះនឹងអាចគ្រប់គ្រងកិច្ចដំណើរការនីតិវិធីបានល្អប្រសើរ ហើយបានចេញសាលក្រមរបស់ខ្លួនលឿនជាងនេះ (ប្រហែលជាក្នុងពេលជាមួយគ្នានឹងសំអាងហេតុ នៅថ្ងៃប្រកាសផ្ទាល់)។ ដោយខកខានមិនបានធ្វើដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ហើយតាមរបៀបនេះ បានរំលោភបំពានសិទ្ធិរបស់

---

[240] ផែនការបញ្ចប់ កំណែប្រែទី ១៧ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣១។ ផែនការបញ្ចប់ កំណែប្រែទី ១៨ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៣២។ អាចចូលអានបាននៅក្នុងគេហទំព័រនៃ អ.វ.ត.ក ដោយចុចលើតំណភ្ជាប់ដូចខាងក្រោម៖ https://www.eccc.gov.kh/en/about-eccc/finances។

[241] ជាឧទាហរណ៍៖ ឯកសារដែលបានទទួលយក នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E345**។ ការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី នៅក្នុងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ដែលត្រូវបានយល់ព្រមនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E356/2** (ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E356/1**)។ ឯកសារដែលបានទទួលយក អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E388/1**។ ឯកសារដែលបានទទួលយក អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ **E437/2** (សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សំផន ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E437/1** និង ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E437/1/1**)។ ដូចគ្នាដែរ ប្រសិនបើការគណនារបស់មេធាវីការពារក្តីត្រឹមត្រូវ អង្គជំនុំជម្រះប្រើប្រាស់សេចក្តីអះអាងជាលាយលក្ខណ៍អក្សរតែចំនួន ៨៧ប៉ុណ្ណោះ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ដែលបានពីសំណុំរឿង ០០៣ និង ០០៤ ក្នុងចំណោមឯកសារ២៥០ ដែល មេធាវីការពារក្តីបានរាប់ឃើញ។ មេធាវីការពារក្តីក៏បានកត់សម្គាល់ផងដែរថាការប្រើប្រាស់សេចក្តីអះអាងមួយចំនួន បង្ហាញថាគេមិនចាំបាច់ទទួលយកឯកសារទាំងនោះឡើយ។ ឧទាហរណ៍ សូមមើលការប្រើប្រាស់ឯកសារ **E3/9498** ក្នុងកំណត់សម្គាល់ជើងទំព័រលេខ ១៣០៨៦ (នៃកថាខណ្ឌ ៣៩១៧) នៃសំអាងហេតុសាលក្រម នៃឯកសារ **E3/9656** ក្នុងកំណត់សម្គាល់ជើងទំព័រលេខ ១១២២០ (នៃកថាខណ្ឌ ៣៣០៣) នៃឯកសារ **E3/9528** ក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៤៤៥២ (នៃកថាខណ្ឌ ១៣០១) ឬនៃឯកសារ **E3/9785** ក្នុងកំណត់សម្គាល់ជើងទំព័រលេខ ១២១៦១ (នៃកថាខណ្ឌ ៣៦៣៦)។

ខៀវ សំផន ផងដែរ ក្នុងការទទួលបានពេលវេលា និងសម្ភារៈចាំបាច់សម្រាប់ការរៀបចំការការពារក្ដីរបស់គាត់ សច្ចភាពគតិយុត្តិ និងនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះដោយមិនយឺតយ៉ាវហួសហេតុ។

## ផ្នែកទី ៣. ធាតុផ្សំនៃភ័ស្តុតាងមកពីសំណុំរឿង ០០៣ និង ០០៤

១៩៨. ក្នុងកំឡុងពេលជំនុំជម្រះ និងនៅក្នុងសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានពិចារណាថា ការដាក់បង្ហាញធាតុផ្សំនៃភ័ស្តុតាងមកពីសំណុំរឿង ០០៣ និង ០០៤ ដោយអយ្យការ មិនបានបង្កផលប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការរៀបចំការពារក្ដីប្រកបដោយប្រសិទ្ធភាព និងដល់សមភាពនៃគូភាគីនោះឡើយ ដោយហេតុថាអង្គជំនុំជម្រះបានចាត់វិធានការចំពោះបញ្ហានេះរួចហើយ[242]។ ក៏ប៉ុន្តែ សភាពយឺតយ៉ាវ និងខ្វះខាតខ្លាំងនៃវិធានការទាំងនេះ ក្រៅតែបានសម្រាលបន្តិចបន្តួចដល់ការរំលោភសិទ្ធិខាងលើ បានពានសិទ្ធិរបស់ ខៀវ សំផន កាន់តែធ្ងន់ធ្ងរថែមទៀត ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលជ្រុលហួសហេតុ។ ប្រសិនបើអង្គជំនុំជម្រះបានអនុវត្តលក្ខណៈវិនិច្ឆ័យគតិយុត្តិត្រឹមត្រូវចំពោះកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់បង្ហាញធាតុផ្សំភ័ស្តុតាងដោះបន្ទុកជាសក្តានុពលម្ល៉េះសមសំណុំរឿង ០០២/០២ ប្រហែលជាមិនត្រូវបានបំបែងទៅជាការស៊ើបអង្កេតដាក់បន្ទុកក្នុងដំណាក់កាលជំនុំជម្រះ ហើយសាលក្រមក៏ត្រូវបានចេញឆាប់ជាងនេះដែរ។

១៩៩. ដើម្បីចំណេញទំព័រ និងចៀសវាងការច្រំដែល មេធាវីការពារក្ដីសូមយោងទៅលើទឡ្ហីករណ៍ដែលបានអធិប្បាយនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនស្ដីពីកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់បង្ហាញភ័ស្តុតាង។ មេធាវីការពារក្ដីសូមរក្សាទឡ្ហីករណ៍របស់ខ្លួនដដែល[243]។

---

[242] សំអាងហេតុសាលក្រម កថាខណ្ឌ១៣៩-១៤៨។

[243] សេចក្ដីសន្និដ្ឋានរបស់លោក ខៀវ សំផន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E363**។ ការឆ្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផនថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E363/2**។ សារណាបណ្ដឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៦៦០-៦៦៦។ មេធាវីការពារក្ដីក៏បានយោងទាំងស្រុងផងដែរទៅនឹងសេចក្ដីសន្និដ្ឋានជាលាយលក្សណ៍អក្សរ និងផ្ទាល់មាត់ ដែលតាមរយៈឯកសារទាំងនោះ មេធាវីការពារក្ដីប្រឆាំងជាពិសេសទៅនឹងការទទួលយកសេចក្ដីថ្លែងការណ៍ធ្វើជាភ័ស្តុតាង ព្រមទាំងប្រឆាំងទៅនឹងការអនុញ្ញាតឱ្យសាក្សីផ្តល់សក្ខីកម្មដោយផ្អែកទៅលើឯកសារបែបនោះ៖ សេចក្ដីជំទាស់របស់មេធាវីការពារក្ដី លោក ខៀវ សំផន ចុះថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E364** និង ប្រតិចារឹក ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/341.1** ម៉ោង 15.38.51-15.48.15

២០០. ជាក់ស្តែង អង្គជំនុំជម្រះបានបិទភ្នែកចំពោះការប្រព្រឹត្តិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ខុសពីការប្រព្រឹត្តិក្នុងសំណុំរឿង ០០២/០១) ដែលមិនបានគោរពឱ្យបានត្រឹមត្រូវតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញភ័ស្តុតាងដោះបន្ទុក។ នៅក្នុងសំណុំរឿង ០០២/០១ សហព្រះរាជអាជ្ញាបានត្រឹមតែបង្ហាញភ័ស្តុតាងដោះបន្ទុកបន្តិចបន្តួចតែប៉ុណ្ណោះ ដោយហេតុថាចម្លើយពីមុនៗរបស់សាក្សីដែលអាចចូលខ្លួនមកផ្តល់សក្ខីកម្ម ឬការស្តាប់យកចម្លើយសាក្សីដែលមានព័ត៌មានទាក់ទងនឹងជនដែលបានផ្តល់សក្ខីកម្មកន្លងមក សុទ្ធតែស្ថិតក្នុងដៃរបស់សហព្រះរាជអាជ្ញាទាំងអស់[244]។ ពេលនោះ សម្រាប់ចម្លើយសាក្សីនីមួយៗដែលគាត់បានបញ្ជូនមក គាត់ថែមទាំងបានបញ្ជាក់មូលហេតុជាក់លាក់នៃការបញ្ជូន (ជួនកាលជា "[ឈ្មោះសាក្សី] ដែលបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ជួនកាល "មានផ្ទុកនូវធាតុផ្សំដោះបន្ទុក" ជួនកាល "ទាក់ទងនឹង [ឈ្មោះសាក្សី] ដែលបានផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿង ០០២/០១")[245]។ ប៉ុន្តែចាប់តាំងពីពេលចាប់ផ្តើមសំណុំរឿង ០០២/០២ សហព្រះរាជអាជ្ញាបានចាប់ផ្តើមដាក់

---

ម៉ោង 15.52.06-15.54.55។ ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោង 09.25.48-09.28.51 ម៉ោង 09.35.01-09.40.51 និងចម្លើយ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E**366/1**។ ប្រតិចារឹក ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/360.1** ម៉ោង 09.37.04-09.43.28 ម៉ោង 09.44.35 ម៉ោង 13.39.12-13.55.25 ម៉ោង 14.05.04-14.06.58 និងប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/374.1** ម៉ោង 11.31.02-11.38.42។ ចម្លើយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E319/36/1**។ ប្រតិចារឹក ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/371.1** ម៉ោង 09.17.08-09.49.13។ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/405.1** ម៉ោង 09.23.15-09.33.51 ម៉ោង 09.39.44-09.41.21។ ប្រតិចារឹក ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/429.1** ថ្ងៃទី២៩ ខែមករា ម៉ោង 10.13.24-10.34.31។ ចម្លើយ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E319/51/1**។ ចម្លើយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E425/1**។ ចម្លើយ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E319/52/3**។ ប្រតិចារឹក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/471.1** ម៉ោង 10.52.58-11.08.42។ ប្រតិចារឹក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/471.1** ម៉ោង 11.33.47-11.36.00។ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/472.1** ម៉ោង 09.17.29-09.19.51។ ប្រតិចារឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/474.1** ម៉ោង 14.00.08-14.15.39 ម៉ោង 14.26.15-14.26.49។ ចម្លើយ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/56/2**។ ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E1/514.1** ម៉ោង 09.23.35-09.43.27 ម៉ោង 09.57.33-09.59.21។

[244] ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១ ឯកសារ **E127** កថាខណ្ឌ ១។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **E127/5** កថាខណ្ឌ ១។ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ឯកសារ E1**27/7** កថាខណ្ឌ ៤។

[245] ឧបសម្ព័ន្ធសម្ងាត់ ឯកសារ **E127/7.1** នៃការបង្ហាញ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ឯកសារ **E127/7**។

បង្ហាញយ៉ាងច្រើនសន្ធឹកសន្ធាប់នូវភ័ស្តុតាងពាក់ព័ន្ធសាមញ្ញៗសម្រាប់ការជំនុំជម្រះ ទាំងភ័ស្តុតាងដាក់បន្ទុក ទាំងភ័ស្តុតាងដោះបន្ទុក ដោយមិនបានបញ្ជាក់ថាភ័ស្តុតាងណាមួយជាភ័ស្តុតាងដោះបន្ទុកឡើយ។

២០១. ទោះបីជាអង្គជំនុំជម្រះបានទទួលស្គាល់ថា អយ្យការបានធ្វើការការបកស្រាយ "ទូលំទូលាយពេក" លើវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង ដែលចែងអំពីកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញភ័ស្តុតាងក៏ដោយ[246] ក៏អង្គជំនុំជម្រះមិនបានបង្គាប់ឱ្យឈប់ដាក់ភ័ស្តុតាងដោះបន្ទុកជាសក្ខីនុពល នាពេលអនាគតនោះដែរ។ អង្គជំនុំជម្រះក៏មិនបានដកចេញពីសំណុំរឿងនូវឯកសារដែលត្រូវបានបញ្ចូលដោយខុសច្បាប់ដែរ។ អង្គជំនុំជម្រះបានចាត់ទុកថា ការដាក់បង្ហាញវត្ថុតាងបន្ថែម ទោះបីក្នុងបរិមាណច្រើនក៏ដោយ ក៏មិនមែនជាការបំពានសិទ្ធិរបស់ជនជាប់ចោទឡើយ ដរាបណាមានការចាត់វិធានការផ្សេងៗហើយនោះ[247]។

២០២. ក៏ប៉ុន្តែ បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេល ៣ ឆ្នាំ ក្នុងខណៈដែល ខៀវ សំផន ជាប់ឃុំខ្លួនបណ្ដោះអាសន្ន ៨ ឆ្នាំហើយ ចំពោះអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ដោយមានធាតុផ្សំនៃភ័ស្តុតាងរាប់ពាន់ដែលបានទទួលយករួចហើយ នៅក្នុងដំណាក់កាលត្រៀមសវនាការជំនុំជម្រះ អង្គជំនុំជម្រះគួរតែជួយលើកកម្ពស់សិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ ជាជាងការចាត់វិធានការដែលពន្យារពេលជំនុំជម្រះ ដោយសារការដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវចម្លើយជាលាយលក្ខណ៍អក្សររាប់ពាន់ ហើយដែលក្នុងនោះមានឯកសារដែលមានតម្លៃជាភ័ស្តុតាងស្ទើរតែស្មើសូន្យ។

២០៣. ផ្ទុយទៅវិញ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាបង្កើតឃ្លាំងស្តុកភ័ស្តុតាងដាក់បន្ទុកដ៏ធំមួយ ដែលក្នុងអំឡុងពេលជំនុំជម្រះ សហព្រះរាជអាជ្ញាអាចទទួលយកភ័ស្តុតាងរាប់រយឯកសារ និងសាក្សីថ្មីៗដែលមិនធ្លាប់ត្រូវបានស្ដាប់ចម្លើយសោះនៅក្នុងសំណុំរឿង ០០២[248] ដោយមើលរំលងសាក្សី

---

[246] សេចក្តីសម្រេច ចុះថ្ងៃទី ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ **E363/3** កថាខណ្ឌ ៣១។

[247] សេចក្តីសម្រេច ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ **E363/3** កថាខណ្ឌ ៣១។

[248] សេចក្តីសម្រេច ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E319/7**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E319/11/1**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ

ដែលមេធាវីការពារក្តីបានស្នើតាំងពីពេលចាប់ផ្តើមការជំនុំជម្រះ[249]។ ដូច្នេះ ទោះបីជាមានវិធានការរបស់អង្គជំនុំជម្រះក៏ដោយ ក៏មេធាវីការពារក្តីត្រូវរវល់ត្រៀមខ្លួនបន្ថែមសម្រាប់ការជំនុំជម្រះក្នុងអំឡុងពេលដែលការជំនុំជម្រះកំពុងដំណើរការ ហើយការជំនុំជម្រះនេះទៀតសោតមានការផ្លាស់ប្តូរកាលវិភាគនៅនាទីចុងក្រោយមិនចេះចប់មិនចេះហើយ ដោយសារតែសាក្សីមិនទំនេរ (វាជាការលំបាកដែលអង្គជំនុំជម្រះដឹងយ៉ាងច្បាស់)។

២០៤. ដូចដែលមេធាវីការពារក្តីតែងតែលើកឡើង[250] លទ្ធភាពនៃការទទួលយកភស្តុតាងថ្មីៗក្នុងអំឡុងពេលជំនុំជម្រះ អាចជាការចាំបាច់។ ប៉ុន្តែ ក្នុងរឿងក្តីនេះ បញ្ហាចោទស្ថិតនៅត្រង់បរិមាណឯកសាររាប់ពាន់ទំព័រដែលត្រូវពិនិត្យ និងធាតុផ្សំភស្តុតាងថ្មីរាប់រយដែលត្រូវបានទទួលយក។ ទាំងនេះ យើងមិនទាន់

---

**E319/17/1**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E319/22/1**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E372** (ផ្នែកសម្រេចសេចក្តី) និង សេចក្តីសម្រេច ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E366/3** (សំអាងហេតុ)។ លិខិតចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ឯកសារ **E380/2.2** និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E380/1** (ផ្នែកសម្រេចសេចក្តី) និង សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E380/2** (សំអាងហេតុ)។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E319/32/1**។ លិខិត ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ ឯកសារ **E364.2** និង លិខិតចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E364/1.1** (ផ្នែកសម្រេចសេចក្តី) និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E364/1** (សំអាងហេតុ)។ សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E319/36/2**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E319/47/3**។ សេចក្តីសម្រេចផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/408.1** ចន្លោះម៉ោង 09.07.33 និងម៉ោង 09.10.21 (ផ្នែកសម្រេចសេចក្តីមួយផ្នែក) និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E390/3** (សំអាងហេតុ)។ លិខិតចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ 11:32 (ភ្ជាប់ក្នុងឧបសម្ព័ន្ធ) និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E425/2**។ លិខិត ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14:06 ឯកសារ **E448.1.1** (ឬឯកសារ **E444.1.2**) និងសេចក្តីសម្រេចផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/479.1** ចន្លោះម៉ោង 09.05.55 និងម៉ោង 09.07.55។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E436/1**។ សេចក្តីសម្រេចផ្ទាល់មាត់មួយផ្នែក ប្រតិចារឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/483.1** ម៉ោង 13:33-38 និង ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ម៉ោង 13:35-38 និង សេចក្តីសម្រេច ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E319/56/3** (សំអាងហេតុ)។

[249] សារណាបណ្តឹងសាទុក្ខ 00២/0២ កថាខណ្ឌ ៦៦៣-៦៦៥។សូមមើលខាងលើ កថាខណ្ឌ ១៦៥-១៧៣។

[250] ជាឧទាហរណ៍៖ ចម្លើយតបរបស់លោក ខៀវ សំផន ចុះថ្ងៃទី ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ **E363/2** កថាខណ្ឌ ១៧-២០។

ទាំងគិតពីពេលវេលាដែលចំណាយទៅលើសំណើ ការឆ្លើយតប សំណើសុំពេលវេលា និងពេលវេលាសវនការសម្រាប់និយាយអំពីបញ្ហាទាំងនេះផង...។

២០៥. ទោះបីបរិមាណដ៏ច្រើននៃធាតុផ្សំថ្មីទាំងអស់នេះ ដែលសហព្រះរាជអាជ្ញាបានដឹងមុនមេធាវីការពារក្តី និងទោះបីសហព្រះរាជអាជ្ញាមានកាតព្វកិច្ច ក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់មេធាវីការពារក្តីទៅលើធាតុផ្សំភ័ស្តុតាងដោះបន្ទុក[251]ក៏ដោយ ក៏អង្គជំនុំជម្រះតែងតែបដិសេធមិនបង្គាប់ឱ្យសហព្រះរាជអាជ្ញាបញ្ជាក់ថា តើអ្វីខ្លះជាធាតុផ្សំដោះបន្ទុក។ អង្គជំនុំជម្រះបានពិចារណា តាមរបៀបមួយមិនអាចយល់ និងមិនអាចពន្យល់បានថា "ជាភវនីយភាព វិធីសាស្ត្រនេះមិនបានលទ្ធផលអ្វីក្រៅពីបន្ថែមបន្ទុកការងាររបស់មេធាវីការពារក្តី និងភាគីផ្សេងៗទៀតប៉ុណ្ណោះ"[252]។ នៅពេលកំណត់កាលកំណត់សម្រាប់ការដាក់បង្ហាញភ័ស្តុតាងទាំងអស់ត្រឹមថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ លើកលែងតែវត្ថុតាងដោះបន្ទុក ដោយហេតុថាសវនាការលើអង្គសេចក្តីជិតឈានចូលដល់ទីបញ្ចប់ អង្គជំនុំជម្រះបានបដិសេធម្តងទៀតមិនបង្គាប់ឱ្យសហព្រះរាជអាជ្ញាផ្តល់សេចក្តីបញ្ជាក់ពីភ័ស្តុតាងដោះបន្ទុកជាអាទិ៍ ដោយយល់ឃើញថាមេធាវីការពារក្តីស្ថិត "ក្នុងស្ថានភាពល្អបំផុត" ក្នុងការសម្រេចថា តើឯកសារណាដែលខ្លួនគិតថាមានផ្ទុកភ័ស្តុតាងដោះបន្ទុក[253]។

២០៦. ដូចបានកត់សម្គាល់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ BOHLANDER អង្គជំនុំជម្រះមិនមានបំណងចូលរួមក្នុងដំណើរការនេះទេ[254]។ ជាក់ស្តែង ដោយនឿយណាយនឹងសំណើសុំបង្ហាញភ័ស្តុតាង

---

[251] សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សំផន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E363** កថាខណ្ឌ ១៣ និង ២០-២១។

[252] សេចក្តីសម្រេច ចុះថ្ងៃទី ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E363/3** កថាខណ្ឌ ៣៥។

[253] សេចក្តីសម្រេច ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E421/4** (សំអាងហេតុនៃសេចក្តីសម្រេចនៅក្នុង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E421/3**) កថាខណ្ឌ ១០។

[254] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ២៦។ សូមមើលផងដែរប្រតិចារឹក ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/454/1.1** (សវនាការអសាធារណៈ) ចន្លោះម៉ោង 13.59.52 និងម៉ោង 14.00.34 (ចៅក្រម LAVERGNE៖ "ខ្ញុំមិនគិតថាអង្គជំនុំជម្រះត្រូវពិនិត្យមើលថាតើពិតជា... តើអ្វីដែលបានបង្ហាញជូន ពិតជាភ័ស្តុតាងដកបន្ទុក ឬដាក់បន្ទុកឡើយ។ យើងមានកិច្ចការច្រើនត្រូវបំពេញទៅហើយ ខ្ញុំមិនយល់ថាយើងត្រូវតែធ្វើរឿងនោះទេ")។

ជាច្រើន និងផលប៉ះពាល់នៃសំណើទាំងនេះលើការិយាល័យរបស់ខ្លួន[255] សហចៅក្រមស៊ើបអង្កេតបានសម្រេចបញ្ចូលអង្គជំនុំជម្រះ "ដែលជាអង្គភាពបង្កើតឱ្យមានភាពអាសន្ននេះ"[256] ជាអង្គភាពពាក់ព័ន្ធដោយហេតុថា "ទំនួលខុសត្រូវតែមួយគត់របស់អង្គជំនុំជម្រះ"[257] គឺការទទួលយកជាភ័ស្តុតាងនូវរាល់វត្ថុតាងដែលបានដាក់បង្ហាញចំពោះមុខខ្លួន។ ចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា សំណើថ្មីបំផុតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានដាក់បន្ទាប់ពីថ្ងៃផុតកំណត់ថ្ងៃទី០១ ខែកញ្ញាឆ្នាំ ២០១៦ មិនមែនជាបណ្តាប្រភេទឯកសារភ័ស្តុតាងដោះបន្ទុកទេ បើផ្អែកលើសេចក្តីពិពណ៌នានៃឯកសារទាំងនេះ[258]។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបសួរបានសម្រេច"[ជួយអង្គជំនុំជម្រះ] និង<u>មេធាវីការពារក្តីក្នុងសំណុំរឿង [០០២/០២]</u> ក្នុងការវាយតម្លៃភាពពាក់ព័ន្ធនៃឯកសារដែលត្រូវបានស្នើសុំបញ្ចូល ដោយតម្រូវឱ្យសហព្រះរាជអាជ្ញាបំពេញល័ក្ខខ័ណ្ឌតម្រូវនៃភាពជាក់លាក់ក្នុងកម្រិតខ្ពស់ជាងនេះ នៅក្នុងសំណើសុំដាក់បង្ហាញភ័ស្តុតាងដោះបន្ទុករបស់ខ្លួន"[259]។

២០៧. ចៅក្រម BOHLANDER ក៏បានបង្កើតរបៀបរបបថ្មីមួយនៃការបញ្ជាក់លើភ័ស្តុតាងដោយអង្គជំនុំជម្រះ ដើម្បីជួយដល់អង្គជំនុំជម្រះ និងមេធាវីការពារក្តីក្នុងការវាយតម្លៃថា តើឯកសារដែលស្នើសុំ

---

[255] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ២៤ ("ហេតុនេះ ខ្ញុំត្រូវបានស្នើឱ្យគាំទ្រដល់ការងាររបស់អង្គជំនុំជម្រះសាលាដំបូងដោយសម្រេចទៅលើសំណើសុំដាក់បង្ហាញឯកសារជាច្រើនសន្ធឹកសន្ធាប់ដែលនៅទីបញ្ចប់ ឯកសារទាំងនោះភាគច្រើនអាចមិនត្រូវបានទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងការជំនុំជម្រះ។ ដូចខ្ញុំបានលើកឡើងពីមុន ការងារនេះតម្រូវឱ្យបុគ្គលិករបស់ខ្ញុំត្រូវចំណាយពេលយ៉ាងច្រើនហួសប្រមាណដែលមិនអាចឱ្យពួកគេមានពេលវេលាសម្រាប់បន្តការស៊ើបអង្កេតទៀតបាន")។

[256] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ២៨។

[257] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ២៩។

[258] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ២៧ (លោកចៅក្រមស៊ើបសួរបានអះអាងថាបានទទួលយកសំណើនោះ ដោយសារសំណើនោះមានលក្ខណៈបន្ទាន់ ដោយពុំបានដឹងពីសំអាងហេតុនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះឡើយ)។

[259] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ២៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

បញ្ចូលក្នុងសំណុំរឿងបំពេញល័ក្ខខ័ណ្ឌតម្រូវដែរឬទេ។ ចៅក្រមដដែលក៏បានបង្គាប់សហព្រះរាជអាជ្ញាឱ្យដាក់បញ្ចូល "ព័ត៌មានលម្អិតទាក់ទងនឹងផ្នែកនៃឯកសារដែលខ្លួនយល់ថាវាអាចជាភ័ស្តុតាងដោះបន្ទុក" "ក្នុងបំណងដដែល គឺជួយដល់អង្គជំនុំជម្រះ និងមេធាវីការពារក្តីក្នុងការពិនិត្យឯកសារទាំងនេះ"[260]។

២០៨. បន្ទាប់ពីការសម្រេចនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យអង្គជំនុំជម្រះបញ្ជាក់លើឯកសារចំនួន ២១[261]។ មេធាវីការពារក្តីបានជំទាស់នឹងការបញ្ជាក់ឯកសារចំនួន ១២ ក្នុងចំណោមឯកសារទាំងនេះ[262]។ ដោយបកស្រាយខុសលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបសួរ អង្គជំនុំជម្រះបានពិចារណាថា គ្មានបទប្បញ្ញត្តិណាមួយផ្តល់លទ្ធភាពដល់មេធាវីការពារក្តីក្នុងសំណុំរឿង ០០២/០២ ក្នុងការដាក់ចម្លើយតបទៅនឹងសំណើបែបនេះរបស់សហព្រះរាជអាជ្ញា ហើយមេធាវីការពារក្តីពុំមានគុណសម្បត្តិដើម្បីជំទាស់នឹងសំណើនេះទេ[263]។ ពីរបីថ្ងៃបន្ទាប់ពីការស្នើសុំរបស់សហព្រះរាជអាជ្ញា និងជាច្រើនថ្ងៃមុនពេលការឆ្លើយតបរបស់មេធាវីការពារក្តី អង្គជំនុំជម្រះបានជូនដំណឹងដល់សហចៅក្រមស៊ើបសួរថាខ្លួនបានយល់ព្រមលើសំណើនេះ[264]។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើសំណើសុំបញ្ជាក់លើឯកសារផ្សេងៗទៀត ដែលមេធាវីការពារក្តីមិនបានឆ្លើយតប ដោយហេតុថាអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចថា មេធាវីការពារក្តីមិនមានគុណសម្បត្តិដើម្បីឆ្លើយតប។ បន្ទាប់មកអង្គជំនុំជម្រះបានទទួលយកជាភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ នូវឯកសារទាំងអស់ដែលបានស្នើសុំបញ្ជាក់ ដោយបញ្ជាក់ថាពុំមានភាគីណាមួយបានបង្ហាញទទ្បីករណ៍ក្នុងការឆ្លើយតបទៅនឹង

---

[260] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E319/62** (ឬឯកសារ **D193/102**) កថាខណ្ឌ ៣០។

[261] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E319/63**។

[262] ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E319/63/1**។

[263] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E319/63/2** កថាខណ្ឌ ៣។

[264] សេចក្តីសម្រេចនៃចៅក្រមស៊ើបសួរអន្តរជាតិ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E319/64** (ឬឯកសារ **D100/41**) កថាខណ្ឌ ១៣ ដែលបានសង្ខេបសារលិខិតរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦)។

សំណើរបស់អយ្យការទេ[265] ទោះបីជាអង្គជំនុំជម្រះបានដកហូតពីមេធាវីការពារក្តីនូវសិទ្ធិជជែកតតាំងលើបញ្ហានេះ និងសិទ្ធិឱ្យគេដឹងឮពីបុព្វហេតុរបស់ខ្លួន។

២០៩. មុនពេលអនុវត្តប្រព័ន្ធដាក់បង្ហាញភស្តុតាងថ្មី អង្គជំនុំជម្រះបានស្តីបន្ទោសមេធាវីការពារក្តីដែលមិនបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យដាក់បញ្ចូលឯកសារក្នុងសំណុំរឿង[266]។ ក៏ប៉ុន្តែមេធាវីការពារក្តីបានពន្យល់ថា ខ្លួនគិតថាមិនអាចធ្វើបានទេ ដោយហេតុថា ក្នុងគ្រប់ករណី រាល់ឯកសារភ្ជាប់ទៅនឹងសំណើទាំងនេះ សុទ្ធតែត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដោយស្វ័យប្រវត្តិ[267]។ ក្រោយមកទៀត នៅពេលមេធាវីការពារក្តីបាននិយាយថា ខ្លួនត្រូវការពេលវេលាដើម្បីឆ្លើយតបទៅនឹងសំណើសុំឱ្យដាក់បញ្ចូលឯកសារក្នុងសំណុំរឿង ក្នុងករណីមិនមែនជាឯកសារដោះបន្ទុក អង្គជំនុំជម្រះបានប្រកាសថា ពុំមានផលប្រយោជន៍ណាមួយដែលត្រូវផ្តល់សិទ្ធិឱ្យមេធាវីការពាក្តីធ្វើអន្តរាគមន៍ នៅពេលមានការដាក់បង្ហាញភស្តុតាងនោះទេ[268]។

២១០. អាកប្បកិរិយាផ្ទុយគ្នារបស់អង្គជំនុំជម្រះ បណ្តាលមកពីការមិនគោរពតាមការអះអាងរបស់ខ្លួន និងល័ក្ខខ័ណ្ឌតម្រូវនៃវិធានផ្ទៃក្នុង។ បន្ទាប់ពីយល់ឃើញថា ទោះបីជាការដាក់បង្ហាញវត្ថុតាងបន្ថែមក្នុងបរិមាណច្រើនយ៉ាងណាក៏ដោយ ក៏វាមិនបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទដែរ ដរាបណាមានការចាត់វិធានការផ្សេងៗហើយ អង្គជំនុំជម្រះបានបន្ថែមថា៖

---

[265] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ឯកសារ **E319/67**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ឯកសារ **E319/68/1**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ឯកសារ **E319/69**។

[266] សេចក្តីសម្រេច ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ **E363/3** កថាខណ្ឌ ១៨។

[267] ចម្លើយតបរបស់លោក ខៀវ សំផន ចុះថ្ងៃទី ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ **E363/2** កថាខណ្ឌ ៣០។

[268] ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/454/1.1** ចន្លោះម៉ោង 13.58.28 និងម៉ោង 14.13.09 (នៅក្នុងទំនាក់ទំនងរវាងលោកស្រីមេធាវី GUISSÉ និងលោកចៅក្រម LAVERGNE និងលោកស្រីចៅក្រម FENZ គឺមានលើកឡើងមិនត្រឹមត្រូវអំពីឃ្លាំងផ្ទុកឯកសាររួម តែតាមពិតនិយាយពី *Zylab* ទៅវិញទេ ដែលអាចឱ្យគេចូលអានឯកសារដែលបានដាក់បញ្ចូលក្នុងសំណុំរឿង)។

"ត្រង់ចំណុចនេះ អង្គជំនុំជម្រះរំឭកថា ឯកសារដែលបានដាក់បង្ហាញមិនត្រូវបានចាត់ទុកថាអាចទទួលយកបានឡើយ ដោយគ្រាន់តែសំអាងថាភាគីផ្សេងៗអាចចូលពិគ្រោះវាបាននោះ។ អង្គជំនុំជម្រះអាចផ្អែកលើឯកសារទាំងនេះ ដើម្បីធ្វើសេចក្តីសម្រេច ឬប្រកាសសាលក្រម តែក្រោយពេលដែលឯកសារត្រូវបានចាត់ទុកថាអាចទទួលយកបាន និងត្រូវបានដាក់ឱ្យពិភាក្សាដេញដោលត្រឹមត្រូវតាមនីតិវិធីនៅក្នុងសវនាការ ដូចដែលបានតម្រូវដោយវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ ល័ក្ខខ័ណ្ឌតម្រូវបែបនេះកាត់បន្ថយយ៉ាងសម្បើមនូវព្យសនកម្មដែលចោទប្រកាន់ដោយមេធាវីការពារក្តី ខៀវ សំផន"[269]។

២១១. អង្គជំនុំជម្រះបានសំអាងលើវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងស្តីពីការទទួលយកភ័ស្តុតាងថ្មីក្នុងអំឡុងពេលជំនុំជម្រះ[270] ដែលយើងបាននិយាយនៅក្នុងផ្នែកមុននេះថា អង្គជំនុំជម្រះមិនបានអនុវត្តវិធាននេះដោយត្រឹមត្រូវនោះទេ ជាពិសេសក្នុងការទទួលយកចម្លើយជាលាយលក្ខណ៍អក្សររាប់រយ ដោយគ្រាន់តែផ្អែកលើភាពពាក់ព័ន្ធរបស់វា (ដែលជាញឹកញយ មានភាពចម្រូងចម្រាស) និងបើទោះបីជាវាមានតម្លៃជាភ័ស្តុតាងតិចតួចក្តី។ អង្គជំនុំជម្រះក៏យល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យសាក្សីចូលបង្ហាញខ្លួន ដោយផ្អែកលើឯកសារជាច្រើនដែលត្រូវបានបង្ហាញ[271] ហើយតាមរយៈនេះ អង្គជំនុំ

[269] សេចក្តីសម្រេច ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E363/3** កថាខណ្ឌ ៣២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[270] សេចក្តីសម្រេច ចុះថ្ងៃទី ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ **E363/3** កំណត់សម្គាល់ជើងទំព័រលេខ ៦៧ (នៃកថាខណ្ឌ ៣២) ដែលអង្គជំនុំជម្រះយោងទៅវិធាន ៨៧(២) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។

[271] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E319/17/1**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E372** (ផ្នែកសម្រេចសេចក្តី) និងសេចក្តីសម្រេច ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E366/3** (សំអាងហេតុ)។ លិខិតចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ឯកសារ **E380/2.2** និង អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E380/1** (ផ្នែកសម្រេចសេចក្តី) និងសេចក្តីសម្រេចចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E380/2** (សំអាងហេតុ)។ សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E319/36/2**។ សេចក្តីសម្រេចផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/408.1** ចន្លោះម៉ោង 09.07.33 និងម៉ោង 09.10.21 (ផ្នែកសម្រេចសេចក្តីមួយផ្នែក) និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E390/3** (សំអាងហេតុ)។ លិខិត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 11:32 (មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E425/2**។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E436/1**។

ជម្រះក៏បានអនុញ្ញាត នៅក្នុងពេលកំពុងពេញជំនុំជម្រះ ឱ្យមានការបង្ហាញខ្លួនបុគ្គលមួយចំនួនដែលមេធាវីការពារក្តីមិនដែលស្គាល់តែសោះ និងមានពាក់ព័ន្ធគួរឱ្យសង្ស័យ ឧទាហរណ៍ ដូចជាដើមបណ្តឹងរដ្ឋប្បវេណី សុន វុត (សាក្សីដាក់បន្ទុក)[272]។

២១២. លើសពីនេះទៀត អង្គជំនុំជម្រះមិនដែលប្រឹងប្រែងផ្តល់សំអាងហេតុគាំទ្រដល់សេចក្តីសម្រេចដោយចិត្តឯងក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីថ្មីថែសឈ្មោះ ព្រាប សុខឿន (សាក្សីដាក់បន្ទុក)[273] ដែលសេចក្តីសម្រេចនេះបានធ្វើឡើង បន្ទាប់ពីថ្ងៃផុតកំណត់ដែលបានកំណត់ត្រឹមថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០១៦ សម្រាប់ការដាក់សំណើសុំឱ្យទទួលយកភស្តុតាងថ្មី ដោយសារតែការខិតមកដល់ទីបញ្ចប់នៃសវនាការលើអង្គសេចក្តី និងដោយសារតែសារៈសំខាន់ចាំបាច់នៃសច្ចភាពគតិយុត្តិសម្រាប់ភាគី[274]។

---

[272] សេចក្តីសម្រេចផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/408.1** ចន្លោះម៉ោង 09.07.33 និងម៉ោង 09.10.21 (ផ្នែកសម្រេចសេចក្តី) និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E390/3** (សំអាងហេតុ)។ សូមមើលសេចក្តីជំទាស់ផ្ទាល់មាត់របស់លោក ខៀវ សំផន ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/405.1** ចន្លោះម៉ោង 09.23.15 និងម៉ោង 09.33.51 បន្ទាប់មក ចន្លោះម៉ោង 09.39.44 និងម៉ោង 09.41.21 និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៦៣ កំណត់សម្គាល់ជើងទំព័រលេខ ៦២៧ និងកថាខណ្ឌ ១៤១៩-១៤៣៨។ សូមមើលផងដែរ៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៣០២០, ៣០៦៦-៣០៧៥ (នៅក្នុងទីនេះ អង្គជំនុំជម្រះទទួលស្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានគេឃុំខ្លួននៅភ្នំក្រោលនោះទេ នោះជាហេតុផលដែលគេកោះហៅរូបគាត់ឱ្យមកសវនាការ)។

[273] ប្រតិចារឹក ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/471.1** មុនម៉ោង 09.04.02 (សេចក្តីប្រកាសអំពីចេតនាចង់ស្រង់សេចក្តីអំពីការចូលផ្តល់សក្ខីកម្មរបស់ ព្រាប សុខឿន បន្ទាប់ពីសវនាការស្តីពីឯកសារគន្លឹះ) និងបន្ទាប់ពីម៉ោង 11.34.54 (នៅទីនេះ លោកប្រធានអង្គជំនុំជម្រះបញ្ជាក់ថាអង្គជំនុំជម្រះ "នឹងចេញសេចក្តីសម្រេចក្នុងពេលឆាប់ៗខាងមុខ")។ លិខិតចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10:34 (មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) នៅទីនេះមានរហស្សនាមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងប្រក្រតិទិនលើកក្រោយ ហើយនៅទីនេះដែរ មានតែការបញ្ជាក់ថាមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីនឹងចាប់ផ្តើមការសាកសួររបស់ខ្លួន។ អង្គជំនុំជម្រះក៏មានលើកឡើងអ្វីលើសពីនោះដែរ នៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **E459** កំណត់សម្គាល់ជើងទំព័រលេខ ៤១៨ (នៃកថាខណ្ឌ ១៤៨)។ សូមមើលផងដែរ៖ សេចក្តីយោងទៅសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ - សេចក្តីសង្កេតផ្ទាល់មាត់របស់លោក ខៀវ សំផន ប្រតិចារឹក ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/471.1** ចន្លោះម៉ោង 11.33.47 និងម៉ោង 11.36.00។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៦៤។

[274] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E421** កថាខណ្ឌ ៣។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E421/3** (ផ្នែកសម្រេចសេចក្តី) និង សេចក្តីសម្រេច ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E421/4** (សំអាងហេតុ) កថាខណ្ឌ ១៣-១៨។

កាលនោះ សម្រង់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានប្រមូលនៅក្នុងសំណុំរឿង ០០៤ ទើបតែត្រូវបានអានដោយសហព្រះរាជអាជ្ញាក្នុងអំឡុងពេលសវនាការលើឯកសារគន្លឹះ។ ទោះបីជាការបង្ហាញខ្លួននេះមានផលប្រយោជន៍យ៉ាងច្បាស់ដល់សហព្រះរាជអាជ្ញាក៏ដោយ ក៏អង្គជំនុំជម្រះមិនដែលពន្យល់ថា ហេតុអ្វីបានជាការបង្ហាញខ្លួនយ៉ាងថ្មីស្រឡាងនៅចុងបញ្ចប់នៃការជំនុំជម្រះនេះ អនុលោមតាមបទប្បញ្ញត្តិតឹងរ៉ឹងស្តីពីការទទួលយកភស្តុតាងថ្មីក្នុងអំឡុងពេលជំនុំជម្រះ និងមានភាពចាំបាច់ ទោះជាវាមានលក្ខណៈយឺតយ៉ាវខ្លាំង និងបង្កព្យសនកម្មថ្មីដល់មេធាវីការពារក្តីយ៉ាងណាក្តី។

២១៣. លើសពីនេះទៀត ផ្ទុយទាំងស្រុងនឹងអ្វីដែលបានលើកឡើងអំពីល័ក្ខខ័ណ្ឌតម្រូវដើម្បីសម្រាលព្យសនកម្មលើមេធាវីការពារក្តី ពាក់ព័ន្ធនឹងការដាក់បង្ហាញភស្តុតាង អង្គជំនុំជម្រះបែរជាបានធ្វើសេចក្តីសម្រេចមួយចំនួន ដោយគ្រាន់តែផ្អែកលើឯកសារដែលបានបង្ហាញ ខណៈដែលឯកសារទាំងនេះមិនទាន់ត្រូវបានទទួលយក។ អង្គជំនុំជម្រះបានអនុវត្តបែបនេះ រយៈពេលពីរបីសប្តាហ៍មុនការប្រកាសសម្រេចដោយអត្តនោម័តិរបស់ខ្លួន អំពីការចូលមកបង្ហាញខ្លួនរបស់សាក្សី មុយ វាន់នី (សាក្សីដាក់បន្ទុក) ដែលចម្លើយពីមុនៗរបស់គាត់ត្រូវបានដាក់បង្ហាញ ប៉ុន្តែមិនដែលធ្លាប់ជាកម្មវត្ថុនៃការស្នើសុំឱ្យទទួលយកនោះទេ[275]។ ឆ្នាំបន្ទាប់មកទៀត អង្គជំនុំជម្រះបានអនុវត្តបែបនេះម្តងទៀតជាមួយសាក្សី ឡុង សាត (សាក្សីដាក់បន្ទុក)[276] ទោះបីជាកាលកំណត់ត្រឹមថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ សម្រាប់ដាក់សំណើសុំឱ្យទទួលយកភស្តុតាងថ្មី និងសច្ចភាពគតិយុត្តិសម្រាប់ភាគី បានកន្លងផុតទៅហើយក្តី។

---

[275] លិខិត ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E364.2** និងលិខិត ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E364/1.1** និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E364/1**។ សូមមើលសេចក្តីជំទាស់របស់លោក ខៀវ សំផន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E364** និង សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់លោក ខៀវ សំផន ប្រតិចារឹក ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/341.1** ចន្លោះម៉ោង 15.38.51 និងម៉ោង 15.48.15 បន្ទាប់មក ចន្លោះម៉ោង 15.52.06 និងម៉ោង 15.54.55។ លុះបន្ទាប់ពីការចេញសេចក្តីសម្រេចឱ្យចូលសវនាការ ទើបមានការស្នើឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី (សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E319/32**) ហើយកំណត់ហេតុទាំងនោះក៏ទទួលបានការយល់ព្រម (អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E319/32/1**)។

[276] លិខិតចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14:06 ឯកសារ **E448.1.1** (ឬឯកសារ **E444.1.2**) និង សេចក្តីសម្រេចផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/479.1** ចន្លោះម៉ោង 09.05.55 និងម៉ោង 09.07.55 (សេចក្តីសម្រេចបង្គាប់ឱ្យចូលផ្តល់សក្ខីកម្ម និងការយល់ព្រមទទួលកំណត់ហេតុស្តាប់ចម្លើយសាក្សី។ សូមមើលសេចក្តី សន្និដ្ឋានផ្ទាល់មាត់របស់លោក ខៀវ សំផន ប្រតិចារឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/474.1** ចន្លោះម៉ោង 14.00.08 និងម៉ោង 14.15.39 បន្ទាប់មក ចន្លោះ

២១៤. សេចក្តីសម្រេចទាំងនេះបង្ហាញច្បាស់ពីអសុទ្ធចិត្តរបស់អង្គជំនុំជម្រះ និងឆន្ទៈ ក្នុងការទាញយកអត្ថប្រយោជន៍ពីការបញ្ចូលភស្តុតាងថ្មីដែលជាភស្តុតាងដាក់បន្ទុក ច្រើនជាងដោះបន្ទុក ដើម្បីធ្វើការស៊ើបអង្កេតក្នុងដំណាក់កាលកាត់សេចក្តី ដោយមិនពិចារណាជាក់ស្តែងអំពីព្យសនកម្មដែលអាចមានទៅលើមេធាវីការពារក្តី ដែលអង្គជំនុំជម្រះបានរឹតត្បិតសិទ្ធិរហូតដល់ធ្វើអ្វីលែងកើតទៅហើយ។ អង្គជំនុំជម្រះមានភស្តុតាងគ្រប់គ្រាន់នៅក្នុងសំណុំរឿង ០០២/០២ ដើម្បីសម្រេចលើការទទួលខុសត្រូវរបស់ជនជាប់ចោទ ដោយមិនបង្កភាពស្មុគស្មាញ និងអូសបន្លាយការជំនុំជម្រះក្តី ដោយឥតប្រយោជន៍។ គេអាចព្យាករណ៍បានថា ការដាក់បញ្ចូលភស្តុតាងថ្មីទាំងអស់នេះ ក្នុងអំឡុងពេលជំនុំជម្រះ នឹងមានផលប៉ះពាល់លើថេរវេលានៃការពិភាក្សាសម្រេច។

២១៥. ដូច្នេះ កំហុសអង្គច្បាប់ និងកំហុសជាក់ស្តែងនៃការវាយតម្លៃរបស់អង្គជំនុំជម្រះទាក់ទងនឹងការដាក់បញ្ចូល និងការទទួលយកធាតុផ្សំភស្តុតាងថ្មី មកពីសំណុំរឿង ០០៣ និង ០០៤ ក្នុងអំឡុងពេលជំនុំជម្រះ បានបង្កការរំលោភលើសិទ្ធិ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ ការជូនដំណឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់លើរូបគាត់ សច្ចភាពគតិយុត្តិ និងនីតិវិធី តុល្យការមិនលម្អៀង ពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់ការរៀបចំការការពារក្តីរបស់ខ្លួន សវនាការចំពោះមុខ ការដឹងឮពីបុព្វហេតុរបស់ខ្លួន ការការពារក្តីដ៏មានប្រសិទ្ធភាព សំអាងហេតុនៃសេចក្តីសម្រេច និងសមភាពនៃគូភាគី។

## ផ្នែកទី ៤. ធាតុផ្សំភស្តុតាងចេញមកពីប្រវត្តិវិទូដែលមិនបានចូលមកបង្ហាញខ្លួន

២១៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានទទួលយកភស្តុតាងចេញមកពីអ្នកស្រាវជ្រាវ ឬប្រវត្តិវិទូដែលមិនបានមកបង្ហាញខ្លួន ហើយឯកសារដែលពួកគាត់ប្រើមិនអាចត្រូវបានផ្ទៀងផ្ទាត់ពីយថាភាព និងភាពអាចជឿជាក់បាន។ ជាពិសេស គឺឯកសារវៀតណាមចំនួន ១៣ ដែលបានមកពី

ម៉ោង 14.26.15 និងម៉ោង 14.26.49។ កំណត់ហេតុស្តាប់ចម្លើយសាក្សីមិនបានត្រូវគេលើកជាសំណួរស្តីពីមូលដ្ឋានគ្រឹះនៃវិធាន ៨៧ (៤) សោះឡើយ។

សាស្ត្រាចារ្យ GOSCHA (១) និងបញ្ជីពណ៌ទឹកក្រូចនៃមន្ទីរ ស-២១ ដែលត្រូវបានទទួលយកនៅចុងបញ្ចប់នៃការជំនុំជម្រះ (២)។ របៀបគ្រប់គ្រងការទទួលយក និងការវាយតម្លៃលើឯកសារទាំងនេះ គឺជាការបង្ហាញដ៏ល្អឥតខ្ចោះអំពីអគតិភាពរបស់របស់អង្គជំនុំជម្រះ ក្នុងការពិចារណាលើភ័ស្តុតាងនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២។

## ១. ការទទួលយកឯកសាររបស់លោកសាស្ត្រាចារ្យ GOSCHA

២១៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសលើការវាយយ៉ាងជាក់ស្តែង ដោយបានទទួលយកឯកសារវៀតណាមចំនួន ១៣ ដែលបានមកពីសាស្ត្រាចារ្យ GOSCHA ក្នុងដំណាក់កាលជំនុំជម្រះ[277]។ ជាក់ស្តែង អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុគាំទ្រសេចក្តីសម្រេចរបស់ខ្លួនទាក់ទងនឹងវិធីដែលបានអនុវត្ត ដើម្បីទទួលបានឯកសារទាំងអស់នេះ ស្របតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង (១.១)។ លើសពីនេះទៀត កង្វះយ៉ាងជាក់ស្តែងនៃភាពអាចជឿជាក់បាននៃឯកសារទាំងនេះ មិនបានបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃភាពអាចទទួលយកបាននៃភ័ស្តុតាងដែលមានចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ (១.២)។

### ១.១. កង្វះសំអាងហេតុ និងកង្វះតម្លាភាពក្នុងការទទួលបានឯកសារទាំងនេះ

២១៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាក់ស្តែងលើការវាយតម្លៃ ដោយយល់ឃើញថាវិធីដែលខ្លួនបានអនុវត្ត ដើម្បីទទួលបាន និងទទួលយកឯកសារទាំងនេះ បានគោរព "រាល់សិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវដែលបានផ្តល់ជូនជនជាប់ចោទ"[278]។ តាមពិត ការស៊ើបរករបស់អង្គជំនុំជម្រះដើម្បីទទួលបានឯកសាររបស់សាស្ត្រាចារ្យ GOSCHA បានទៅហួសឆ្ងាយពីសំណើរបស់សហព្រះរាជអាជ្ញាដែលគ្រាន់តែសុំឱ្យស្វែងរកសម្រង់នៃកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ និង ប.ក.ក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ ១៩៧៧ ("កំណត់ហេតុ")[279]។ មេធាវីការពារក្តីសូមយោងទៅសារណាជាលាយលក្ខណ៍អក្សរពីមុនៗ

[277] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7**។

[278] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ១៩។

[279] សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E327/4**។

របស់ខ្លួនដែលបង្ហាញពីកង្វះតម្លាភាព និងសំអាងហេតុរបស់អង្គជំនុំជម្រះ ក្នុងការទទួលបានឯកសាររបស់លោក GOSCHA [280]។

២១៩. ក៏ប៉ុន្តែ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើការទទួលយកឯកសាររបស់សាស្ត្រាចារ្យ GOSCHA នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានបង្ហាញអសុទ្ធចិត្ត ដោយអះអាងថា មេធាវីការពារក្តីមិនបានជំទាស់ឡើយទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យស្វែងរកសម្រង់នៃកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងបក្សកុម្មុយនីស្តកម្ពុជាចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ("កំណត់ហេតុកិច្ចប្រជុំ")[281]។ ជាក់ស្តែង ដោយត្រូវបានគេទុកមិនឱ្យដឹងអ្វីទាំងអស់ មេធាវីការពារក្តីមិនបានស្ថិតក្នុងស្ថានភាពមួយដែលអាចជំទាស់នឹងការស៊ើបរកផ្សេងៗទៀតរបស់សាស្ត្រាចារ្យ GOSCHA ឡើយ។ អង្គជំនុំជម្រះគ្មានជំរើសអ្វីក្រៅពីទទួលស្គាល់នៅក្នុងកថាខណ្ឌបន្ទាប់ថា ខ្លួនមិនបានប្រកាសប្រាប់ដល់ភាគីអំពីវិធីរបស់ខ្លួនក្នុងការស្វែងរកឯកសារផ្សេងៗទៀតនៃសម័យកម្ពុជាប្រជាធិបតេយ្យ[282]។

២២០. អង្គជំនុំជម្រះបានចាត់ទុកថា ភាគីមានឱកាសបង្ហាញសេចក្តីសង្កេតរបស់ខ្លួន ហើយសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវរបស់ជនជាប់ចោទ ត្រូវបានគោរព[283]។ ក៏ប៉ុន្តែ វាមិនគ្រប់គ្រាន់ទេ។ ដោយមិនផ្តល់មូលហេតុនៃការស៊ើបអង្កេតដែលបានធ្វើឡើងដោយអត្តនោម័តិ អង្គជំនុំជម្រះមិនបានគោរពសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវរបស់ជនជាប់ចោទ ព្រមទាំងបង្ហាញពីអគតិភាពរបស់ខ្លួន។ ដោយសម្រេចទទួលយកឯកសារទាំង ១៣ ដោយអត្តនោម័តិ អង្គជំនុំជម្រះបានធ្វើហួសពីសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឱ្យទទួលយកតែប្រាំមួយឯកសារប៉ុណ្ណោះក្នុងចំណោមឯកសារទាំងនេះ[284]។

## ១.២. កំហុសពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឯកសារទាំងនេះ

---

[280] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E327/4/6** កថាខណ្ឌ ៩-១៦។

[281] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ១៨។

[282] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ១៩។

[283] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ១៩។

[284] សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E3**27/4/5/1**។

២២១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាក់ស្តែងក្នុងការវាយតម្លៃ ដោយពិចារណាថា ឯកសារទាំង ១៣ ដែលបានមកពីសាស្ត្រាចារ្យ GOSCHA គឺជា "ឯកសារដែលអាចទុកចិត្តបាន និងមានយថាភាព[285] នៅពេលឃើញភ្លាមពីដំបូង"។ ខ្សែចង្វាក់នៃការរក្សាទុក និងការបញ្ជូនឯកសារទាំងនេះ មិនអាចរកឃើញបានទេ។ លោកសាស្ត្រាចារ្យ GOSCHA មិនដែលបានឃើញឯកសារច្បាប់ដើមជាភាសាខ្មែរទេ ពីព្រោះថា គាត់បានពិគ្រោះតែ "សំណៅបកប្រែ" នៃឯកសារទាំងនេះជាភាសាវៀតណាមតែប៉ុណ្ណោះ ហើយគេក៏មិនដឹងថាតើឯកសារត្រូវបានតាក់តែងដោយនរណា និងតាមរបៀបណានោះដែរ[286]។ ដូច្នេះ អង្គជំនុំជម្រះគួរតែយកចិត្តទុកដាក់ខ្លាំងជាងនេះ ទៅលើការមន្ទិលសង្ស័យអំពីភាពអាចទុកចិត្តបាននៃការបកប្រែឯកសារដែលកាន់កាប់ដោយអាជ្ញាធរនៃប្រទេសមួយ ដែលមានភាពលម្អៀងក្នុងជម្លោះដែលប្រើឯកសារនោះប្រឆាំងនឹងរបបខ្មែរក្រហម។ ការប្រុងប្រយ័ត្នកាន់តែមានភាពចាំបាច់ទៅទៀត ក្នុងខណៈដែលរដ្ឋវៀតណាមតែងតែបដិសេធមិនសហការជាមួយ អ.វ.ត.ក ក្នុងក្របខ័ណ្ឌតុលាការ។ លើសពីនេះទៀត ឯកសារទាំងនេះហាក់ដូចជាបានមកពីទស្សនាវដ្តី ចេញឆ្នាំ១៩៨០ ឈ្មោះ ទស្សនាវដ្តីកុម្មុយនីស្ត ឬកាសែតកុម្មុយនីស្ត ជាឧបករណ៍ឃោសនារបស់សាធារណរដ្ឋសង្គមនិយមវៀតណាម។ ប្រការនេះគួរតែនាំឱ្យអង្គជំនុំជម្រះមានការប្រុងប្រយ័ត្នខ្លាំងជាងនេះ[287]។

២២២. លោកសាស្ត្រាចារ្យ GOSCHA ក៏បានពន្យល់ផងដែរថា គាត់មិនត្រូវបានអនុញ្ញាតឱ្យថតចម្លងឯកសារទាំងនេះទេ។ គាត់ក៏បានកត់ចម្លងឯកសារដោយដៃ។ ផ្ទុយពីការអះអាងរបស់អង្គជំនុំជម្រះ លោកសាស្ត្រាចារ្យមិនបាននិយាយថាគាត់បាន "ចម្លងទាំងស្រុង" នូវឯកសារទាំងនេះនោះទេ[288]។ លោកបានពន្យល់កាន់តែច្បាស់ថា៖ *"ខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យថតចម្លងអ្វីច្រើនទេ។ ខ្ញុំបានកត់ត្រាដោយដៃ ប៉ុន្តែខ្ញុំ*

---

[285] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ២៦។

[286] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4**/7 កថាខណ្ឌ ២៦។ សូមមើលផងដែរ អនុស្សរណៈ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E327/4/5** កថាខណ្ឌ ១ "សាស្ត្រាចារ្យ Goscha បានបញ្ជាក់ថាគាត់មើលតែសំណៅបកប្រែជាភាសាវៀតណាមប៉ុណ្ណោះនៅក្នុងការស្រាវជ្រាវរបស់គាត់នោះ ហើយគាត់បានលើកឡើងថាកងទ័ពប្រាកដជាមានឯកសារដើមជាភាសាខ្មែរប៉ុន្តែគាត់បានបញ្ជាក់ថាគាត់មិនដែលបានឃើញឯកសារទាំងនោះទេ"។

[287] សូមមើលឯកសារ **E3/10688** ឯកសារ **E3/10689** ឯកសារ **E3/10690** ឯកសារ **E3/1069**1 ឯកសារ **E3/10692** និងឯកសារ **E3/10694**។

[288] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ២៥។

*តែងតែកត់ចម្លងឯកសារស្ទើរតែទាំងស្រុង*"[289]។ ភាពខុសគ្នាផ្សេងៗអាចកើតចេញមកពី "ការចម្លង" ដោយដៃ ដែលជួនពេលខ្លះមិនបានពេញលេញ ជាភាសាមួយដែលយើងមិនដឹងថាតើលោកសាស្ត្រាចារ្យចេះភាសានេះច្បាស់លាស់ឬអត់។ អង្គជំនុំជម្រះខ្លួនឯងបានកត់សម្គាល់អំពី "ភាពខុសគ្នាមួយចំនួនអំពីកាលបរិច្ឆេទនៃឯកសារចម្លងមួយចំនួន"[290]។ មេធាវីការពារក្តីក៏បានលើកឡើងពីឯកសារមួយចំនួនដែលអានមិនដាច់ ដែលធ្វើឱ្យមានមន្ទិលសង្ស័យលើភាពពេញលេញនៃសំណៅបកប្រែជាភាសាអង់គ្លេស[291]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនលើយថាភាព និងភាពអាចជឿជាក់បាននៃឯកសារទាំងនេះ ដោយបានពិចារណាខុសថា "ឯកសារជាច្រើនក្នុងចំណោមឯកសារទាំងនោះ មានដាក់ឈ្មោះអ្នកបកប្រែ និងកាលបរិច្ឆេទនៃការបកប្រែ ដែលអាចឱ្យយល់បានថាឯកសារទាំងនេះត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រត្រឹមត្រូវ"[292]។ ក្នុងចំណោមឯកសារទាំង ១៣ ដែលត្រូវបានទទួលយក មានតែឯកសារ ២ ប៉ុណ្ណោះ ដែលមានដាក់ឈ្មោះអ្នកបកប្រែ ឬទីភ្នាក់ងារបកប្រែ ហើយមានតែឯកសារមួយគត់ដែលមានចុះកាលបរិច្ឆេទនៃការបកប្រែ[293]។

២២៣. អាស្រ័យហេតុនេះ ច្បាស់ណាស់ថា ពុំមានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចចាត់ទុកឯកសារទាំងនេះថា "អាចជឿទុកចិត្តបាន និងមានយថាភាព នៅពេលឃើញភ្លាមពីដំបូងនោះទេ"[294] ដូច្នេះ គឺមិនគួរទទួលយកឯកសារទាំងនេះជាភស្តុតាងឡើយ។

---

[289] ទំនាក់ទំនងតាមសារអេឡិចត្រូនិករវាងក្រឡាបញ្ជីនៃអង្គជំនុំជម្រះ និងលោកសាស្ត្រាចារ្យ Goscha ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០១៦ ឯកសារ **E327/4/3.7**។

[290] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ២៦។

[291] សំណើ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E327/4/6** កថាខណ្ឌ ២៥។

[292] សេចក្តីសម្រេច ចុះចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ២៥។

[293] ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E327/4/6** កថាខណ្ឌ ២២ កំណត់សម្គាល់ជើងទំព័រលេខ២៤ ដែលទាក់ទងនឹងឯកសារ **E3/10693** "បកប្រែដោយ Le Dinh Thao" និងឯកសារ **E3/10695** "ឯកសារនេះត្រូវបានបកប្រែដោយការិយាល័យនយោបាយទូទៅ នៅ ថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៨"។

[294] សេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E327/4/7** កថាខណ្ឌ ២៦។

## ១.៣. កំហុសលើការប្រើប្រាស់ឯកសារនាំងនេះសម្រាប់គាំទ្រដល់ភស្តុតាងដទៃទៀត

២២៤. យោងតាមហេតុផលដែលបានលើកឡើងខាងលើ គេមិនចាំបាច់បង្ហាញថាឯកសារទាំងនេះគ្មានតម្លៃជាភស្តុតាងទាល់តែសោះនោះទេ ជាពិសេស ដោយសារភាគីមិនអាចសួរដេញដោលសាស្ត្រាចារ្យ GOSCHA។ ទោះយ៉ាងនេះក្តី អង្គជំនុំជម្រះបានពិចារណាថា ខ្លួនអាចប្រើឯកសារទាំងនេះ "សម្រាប់គាំទ្រភស្តុតាងផ្សេងៗទៀត"[295]។ យោងទៅតាមអង្គជំនុំជម្រះ ឯកសារមួយរបស់សាស្ត្រាចារ្យ GOSCHA ទំនងជាមានយថាភាពពិតមែន ពីព្រោះថា ទាហានវៀតណាមចំនួន ២៩.០០០ នាក់ ដែលត្រូវបានសម្លាប់ ស៊ីគ្នានឹងអ្វីដែលបានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ចុះខែកុម្ភៈ ឆ្នាំ១៩៧៨[296]។ ចំពោះភាពស៊ីគ្នាតែមួយចំណុចនោះ ការវិភាគសើៗអំពីយថាភាពនៃឯកសារ ដោយអង្គជំនុំជម្រះ មានការភាន់ច្រឡំខ្លាំងណាស់។

២២៥. វាកាន់តែបង្កឱ្យមានការភាន់ច្រឡំទៅទៀត ដោយហេតុតែអង្គជំនុំជម្រះបានបំភ្លៃភស្តុតាង ដោយព្យាយាមបន្សុំឯកសារ GOSCHA E3/10693 ជាមួយនឹងឯកសារមួយផ្សេងទៀតនៅក្នុងសំណុំរឿង គឺឯកសារ E3/7328 ដែលមានប្រតិចារឹកនៃសម្រង់កំណត់ហេតុនៃកិច្ចប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧។ ក៏ប៉ុន្តែ សម្រង់ទាំងពីរនេះមិនត្រឹមតែខុសគ្នាទាំងស្រុងប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះទៀត គេត្រូវកត់សម្គាល់ថា អង្គជំនុំជម្រះបានព្យាយាមបន្សុីខ្លឹមសារនៃឯកសារទាំងពីរនេះ ថាជាការប្រជុំតែមួយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ក្នុងខណៈដែល តាមការពិត មិនមែនត្រឹមតែ "ឃ្លាឃ្លោងនោះដែលមិនដូចគ្នាទាំងស្រុង"[297] សូម្បីតែកាលបរិច្ឆេទនៃកិច្ចប្រជុំក៏ខុសគ្នាដែរ...។ ជាក់ស្តែង សម្រង់ដកស្រង់ចេញពីឯកសារ GOSCHA E3/10693 ទំនងជាមានប្រភពមកពីសម្រង់មួយនៃកិច្ចប្រជុំនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៧ គឺមិនមែនថ្ងៃទី១១ ខែមេសា នោះទេ[298]។ ដូច្នេះ

---

[295] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥២-៣៥៤។

[296] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥២។

[297] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥២ កំណត់សម្គាល់ជើងទំព័រលេខ៩៨៣។

[298] កំណត់ហេតុអង្គប្រជុំនៃគណៈអចិន្ត្រៃយ៍ និងកំណត់ហេតុអង្គប្រជុំនៃលេខា និងអនុលេខាកងពល និងកងអនុសេនាធំ ចុះថ្ងៃទី១០ ទី១១ និងទី១៣ ខែមេសា ឆ្នាំ១៩៧៧ (ចម្លងឡើងវិញដោយលោក C.E. Goscha) ឯកសារ **E3/10693** ERN 01338229-30៖ "ថ្ងៃទី

ដោយមិនអាចបង្ហាញទឡ្ហីករណ៍ដែលមានសុពលភាពគាំទ្រដល់យថាភាព និងភាពអាចជឿជាក់បាននៃឯកសារទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ខ្លួនអាចប្រើវាសម្រាប់គាំទ្រឯកសារផ្សេងៗទៀត។ រាល់ការសន្និដ្ឋានលើអង្គហេតុទាំងអស់ដោយផ្អែកលើឯកសារទាំងនេះ ត្រូវទុកជាមោឃៈ[299]។

## ២. ការទទួលយកបញ្ជីពណ៌ទឹកក្រូចនៃមន្ទីរ ស-២១

២២៦. យើងគួរនិយាយយ៉ាងខ្លីអំពីបញ្ជីពណ៌ទឹកក្រូចនៃមន្ទីរ ស-២១ (ហៅកាត់ថា "បញ្ជី") ដែលត្រូវបានទទួលយកនៅថ្ងៃចុងក្រោយនៃការជំនុំជម្រះ[300]។ ជាក់ស្តែង អង្គជំនុំជម្រះមិនបានពិចារណាលើការកត់សម្គាល់របស់មេធាវីការពារក្តីចំពោះចន្លោះប្រហោងក្នុងការទទួលយកបញ្ជីនេះជាភ័ស្តុតាង និងចំពោះតម្លៃជាភ័ស្តុតាងដ៏ទាបរបស់វា[301]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានសម្រេចពឹងផ្អែកលើបញ្ជីនេះយ៉ាងច្រើន នៅក្នុងសំអាងហេតុសាលក្រម[302]។ ដូច្នេះ មេធាវីការពារក្តីសូមយោងទៅលើទឡ្ហីករណ៍ ដូចមានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សររបស់ខ្លួន។ សេចក្តីសន្និដ្ឋានអំពីអង្គហេតុផ្អែកលើបញ្ជីនេះ ត្រូវតែបដិសេធចោល[303]។

---

១៣ ខែមេសា ឆ្នាំ១៩៧៧ [...] ការបន្តប្រយុទ្ធប្រឆាំងនឹងពួកប្រតិកិរិយា និងស្វែងរកពួកប្រតិកិរិយានៅក្នុងនាយកដ្ឋានរបស់យើង និងនៅតាមមូលដ្ឋានដើម្បីលើកកម្ពស់ និងជំរុញបេសកកម្មក្នុងឆ្នាំ ឆ្នាំ១៩៧៧" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[299] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៤, ៣៥៧, ៣៦៤, ៣៧៧, ៤១៥, ៤២១, ៤២៧, ៥០៤, ៥៤៣, ៥៥៤-៥៥៦, ១៤៥៩, ១៧២៣, ១៧៦៣, ២០០៦, ២០១០, ២០១៦, ៣៣៩៧, ៣៧៤០, ៣៨០៥, ៣៨១៤ និង ៤១២៦។ សូមមើលខាងក្រោម ជាឧទាហរណ៍ កថាខណ្ឌ ១៤៦៣។

[300] របាយការណ៍ប្រចាំថ្ងៃ - បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ ឯកសារ **E3/10770** អនុម័តដោយអង្គជំនុំជម្រះ នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E443/3**។

[301] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១១៨៥-១១៩៣។

[302] សំអាងហេតុសាលក្រម កថាខណ្ឌ ៤១៩, ១៤៦៧, ២១១៥, ២១១៦, ២១២២, ២១២៣, ២២៨៩, ២២៩០, ២២៩៧, ២២៩៩, ២៣៦៩, ២៣៩៧, ២៤៣៦, ២៤៤៣, ២៥០៥, ២៥៤៩-២៥៥១, ២៨៨៦, ៣០៥៤ និង ៣០៥៨។

[303] សំអាងហេតុសាលក្រម កថាខណ្ឌ ៤១៩, ១៤៦៧, ២១១៥, ២១១៦, ២១២២, ២១២៣, ២២៨៩, ២២៩០, ២២៩៧, ២២៩៩, ២៣៦៩, ២៣៩៧, ២៤៣៦, ២៤៤៣, ២៥០៥, ២៥៤៩-២៥៥១, ២៨៨៦, ៣០៥៤ និង ៣០៥៨។

## ជំពូកទី ២. កំហុសលើការសិក្សាអំពីភស្តុតាងទូទៅ
## ផ្នែកទី ១. ជំនឿឥតស្សេរចិត្ត និងជំនឿហួសពីវិមតិសង្ស័យ

២២៧. ដូចនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានថ្លែងថា៖

> "ដើម្បីដោះស្រាយរាល់ការខ្វែងគំនិតគ្នា ដែលអាចកើតចេញពីរបៀបផ្សេងគ្នានៃការរៀបរាប់អំពីលក្ខណៈវិនិច្ឆ័យដែលជាមូលដ្ឋាននៃការផ្តន្ទាទោស ហើយដែលការផ្តន្ទាទោសនេះអាចធ្វើឡើងជាបីភាសាស្របតាមវិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង ឧទាហរណ៍ដូចជាផ្អែកលើសញ្ញាណ "ជំនឿឥតស្សេរចិត្ត" បានមកពីប្រព័ន្ធច្បាប់ *civil law* ឬប្រពៃណីរ៉ូម៉ាំង-អាល្លឺម៉ង់ និងផ្អែកលើជំនឿ "លើសពីវិមតិសង្ស័យ" បានមកពីប្រព័ន្ធច្បាប់ *common law* អង្គជំនុំជម្រះបានអនុម័តវិធីសាស្រ្តរួមមួយដែលនាំឱ្យមានការកំណត់ ចំពោះគ្រប់ករណី ថាតើមានភស្តុតាងគ្រប់គ្រាន់ដែរឬទេដើម្បីផ្តន្ទាទោសជនជាប់ចោទ។ អាស្រ័យហេតុនេះ ផ្អែកលើការវិភាគភស្តុតាងដែលមានហេតុផល អង្គជំនុំជម្រះបានបកស្រាយការសង្ស័យណាមួយទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ ដើម្បីជប្រយោជន៍របស់ជនជាប់ចោទ"[304]។

២២៨. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ម្តងទៀត ដោយបានពិចារណាថា វាចាំបាច់ត្រូវអនុម័តវិធីសាស្រ្តរួមមួយដែលអាចដោះស្រាយការខ្វែងគំនិតគ្នាយ៉ាងខ្លាំងរវាងសញ្ញាណទាំងពីរនេះ ដោយតាមពិតទៅ គ្មានការខ្វែងគំនិតនេះនោះទេ[305]។ ជាក់ស្តែង នៅក្នុងបរិបទ អ.វ.ត.ក ជំនឿឥតស្សេរះចិត្តមិនអាចត្រូវបានបកស្រាយថាជាអ្វីផ្សេងទៀតក្រៅពីជំនឿហួសពីវិមតិសង្ស័យ ដែលជាសញ្ញាណតែមួយគត់ដែលត្រូវយកមកអនុវត្ត។ មេធាវីការពារក្តីសូមយោងទៅលើទឡ្ហីករណ៍ពីមុនៗរបស់ខ្លួនលើចំណុចនេះ[306]។

---

[304] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨ (យើងគូសបន្ទាត់ពីក្រោម) ។ សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២២។

[305] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨-៣៩។

[306] សារណាបណ្តឹងសាទុក្ខ០០២/០១ កថាខណ្ឌ ១០៩-១១០។ សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៣៦៧-៦៤៨។

២២៩. ទោះបីជាអង្គជំនុំជម្រះបានរំឭកឡើងវិញយ៉ាងត្រឹមត្រូវថា ភ័ស្តុតាងនៃអង្គហេតុចាំបាច់ទាំងអស់សម្រាប់ការប្រកាសពិរុទ្ធភាព ត្រូវតែត្រូវបានបង្ហាញឱ្យលើសពីវិមិតិសង្ស័យក៏ដោយ[307] ក៏ខ្លួនមិនបានអនុវត្តគោលការណ៍នេះឱ្យបានជាប់លាប់នោះដែរ។ ដូចដែលនឹងបង្ហាញខាងក្រោមនៅក្នុងសារណានេះត្រង់ផ្នែកពិនិត្យកំហុសអង្គហេតុ អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋានមិនសមហេតុផល ដែលជាញឹកញយ គ្មានសំអាងហេតុ ឬគ្មានសំអាងហេតុគ្រប់គ្រាន់ និង/ឬផ្អែកលើភ័ស្តុតាងដែលមិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីទាញការសន្និដ្ឋានឱ្យលើសពីវិមតិសង្ស័យ។ ជារឿយៗ អង្គជំនុំជម្រះបានសន្និដ្ឋានព្រាវៗ និងទាញសេចក្តីសន្និដ្ឋានតាមបែបអនុមានដែលមិននាំទៅដល់ការសន្និដ្ឋានសមហេតុផលតែមួយគត់បាន។ អង្គជំនុំជម្រះមិនត្រឹមតែមិនអាចទាញការសន្និដ្ឋានសមហេតុផលតែមួយគត់បានប៉ុណ្ណោះទេ គឺថែមទាំងបានជ្រើសរើសភាគច្រើនយកការសន្និដ្ឋានដែលមិនសមហេតុផលបំផុត ពីព្រោះវាជាការសន្និដ្ឋានចោទប្រកាន់។

២៣០. ដូច្នេះ អង្គជំនុំជម្រះបានប្រើប្រាស់បទដ្ឋានទាបជាងបទដ្ឋាននៃជំនឿលើសពីវិមតិសង្ស័យ ស្របតាមស្មារតី និងខ្លឹមសារនៃការរិះគន់របស់ចៅក្រម VAN DEN WYNGAERT នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងមតិជំទាស់របស់គាត់ដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសាលក្រម *Katanga*៖

> “ក្តីកង្វល់ចម្បងមួយរបស់ខ្ញុំទាក់ទងនឹងសាលក្រមនេះ គឺថាសេចក្តីសម្រេចទាំងមូលខ្វះខាតយ៉ាងសម្បើមនូវអង្គហេតុជាក់លាក់ និងជាក់ស្តែង តែគ្របដណ្តប់ទៅដោយ “សេចក្តីសន្និដ្ឋាន” ការនិយាយបង្វើរ និងបញ្ចិតបញ្ចៀងស្រពិចស្រពិលមិនច្បាស់លាស់។ ទោះជាសហភាគាររបស់ខ្ញុំមានជំនឿឥស្សរចិត្តក៏ដោយ ក៏ខ្ញុំខ្លាចតែជំនឿនេះមិនអាចទប់ទល់នឹងនិយាមស្តីពីការគ្រប់គ្រងភ័ស្តុតាងជាធរមាន និងភាពតឹងរ៉ឹងឥតមនោសញ្ចេតនាដែលតម្រូវដោយនិយាមនេះ។ ច្បាស់ជាងនេះទៅទៀត សំណុំរឿងមានចំណុចខ្សោយច្រើន និងបង្ហាញរូបភាពមិនពេញលេញមួយយ៉ាងខ្លាំងរហូតដល់ខ្ញុំគិតថា គេមិនអាចទាញសេចក្តីសន្និដ្ឋានលើចំណុចជាច្រើនឱ្យលើសពីវិមតិសង្ស័យ។ លើសពីនេះទៀត ភ័ស្តុតាងភាគច្រើនមិនគោរពនិយាមនៃភាពគួរឱ្យជឿជាក់បាន ដែលខ្ញុំធ្លាប់អនុវត្តនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោ

[307] សំអាងហេតុសាលក្រម កថាខណ្ឌ ៥០។

ស្ថានីយ៍។ តាមទស្សនៈរបស់ខ្ញុំ វាមិនអាចទៅរួចទេក្នុងការផ្អែកលើភ័ស្តុតាងខ្សោយបែបនេះដើម្បីប្រកាសពិរុទ្ធភាព។ មូលហេតុដ៏សាមញ្ញមួយ គឺថានិយាមស្តីពីការគ្រប់គ្រងភ័ស្តុតាងដែលត្រូវតែអនុវត្តដូចគ្នាសម្រាប់មនុស្សគ្រប់រូប ដោយមិនគិតពីការលំបាកដែលសហព្រះរាជអាជ្ញាអាចជួបប្រទះ មិនអនុញ្ញាតឱ្យប្រកាសពិរុទ្ធភាពបានឡើយ”[308]។

២៣១. ប្រសិនបើអង្គជំនុំជម្រះបានអនុវត្តលក្ខណៈវិនិច្ឆ័យគតិយុត្តិនៃជំនឿហួសពីវិមតិសង្ស័យ ឱ្យបានត្រឹមត្រូវ អង្គជំនុំជម្រះនឹងមិនអាចជឿជាក់លើពិរុទ្ធភាពរបស់ ខៀវ សំផន នោះទេ។ តុលាការកំពូលត្រូវធ្វើមោឃភាពការផ្តន្ទាទោស និងស្ថានទម្ងន់ទោសដែលអង្គជំនុំជម្រះបានសម្រេច[309]។ លើសពីនេះទៅទៀត តុលាការកំពូលត្រូវកត់សម្គាល់ផងដែរអំពីការរំលោភសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានសច្ចធារណ៍នៃនិរទោស សំអាងហេតុសាលក្រម និងតុលាការអនាគតិ។

## ផ្នែកទី ២. ការបំភ្លៃ ឬការបំប្លែងភ័ស្តុតាង

២៣២. ទាក់ទងទៅនឹងជំនឿឥស្សរចិត្តរបស់ចៅក្រមជំនុំជម្រះអង្គសេចក្តី អង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការសម្រេចលើតម្លៃជាភ័ស្តុតាង និងភាពអាចជឿជាក់បាននៃភ័ស្តុតាង។ អង្គជំនុំជម្រះមិនអាចបំភ្លៃ ឬបំប្លែងភ័ស្តុតាងបានទេ ដោយហេតុថាចៅក្រមមានកាតព្វកិច្ចបង្ហាញការពិតជាក់ស្តែង ដែលចេញពីភ័ស្តុតាងតែម្តង។ ការបំប្លែងធាតុផ្សំណាមួយនៃភ័ស្តុតាង គឺជាការកែប្រែធាតុផ្សំណាមួយ ដោយបកស្រាយវា ឬដោយបំភ្លៃខ្លឹមសាររបស់វា។ ការបំភ្លៃធាតុផ្សំភ័ស្តុតាងគឺជាមូលហេតុនៃបណ្តឹងសាទុក្ខទាំងក្នុងច្បាប់បារាំង ទាំងក្នុងច្បាប់កម្ពុជា។ យោងតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការបំភ្លៃអង្គហេតុមានចែងយ៉ាងច្បាស់ ថាជាមូលហេតុមួយក្នុងចំណោមមូលហេតុដទៃទៀតនៃបណ្តឹងសាទុក្ខ[310]។ ម៉្យាងវិញទៀត តាមច្បាប់បារាំង ការបំភ្លៃភ័ស្តុតាងមានគុណវុឌ្ឍិមួយទៀត។ កាលណាអង្គហេតុដែលបញ្ជាក់ដោយសាលដីកា ផ្ទុយនឹងអង្គហេតុដែលមានបញ្ជាក់នៅក្នុងធាតុផ្សំភ័ស្តុតាង

---

[308] មតិផាគតិចដែលបង្ហាញដោយលោកស្រីចៅក្រម Christine Van den Wyngaert, ICC-01/04-01/07-3436-AnxI ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ កថាខណ្ឌ ១៧២ (គូសបន្ទាត់ពីក្រោមនៅក្នុងច្បាប់ដើម)។

[309] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៦-៤២៣៨, ៤៤០០, ៤៤០២។

[310] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤១៩។

តុលាការព្រហ្មទណ្ឌនៃតុលាការវិនិច្ឆ័យចាត់ទុកសាលដីកានេះជាមោឃៈ ដោយមូលហេតុភាពផ្ទុយគ្នានៃសំអាងហេតុ និងកង្វះមូលដ្ឋានច្បាប់[311]។

២៣៣. នៅក្នុងសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានបំភ្លៃ និងបំប្លែងធាតុផ្សំភ័ស្តុតាងដែលបានបង្ហាញក្នុងអំឡុងពេលដំណើរការនីតិវិធីជាច្រើនដង[312]។ ជាឧទាហរណ៍ នៅក្នុងការព្យាយាមផ្តន្ទាទោសយ៉ាងចចេសរបស់ខ្លួន អង្គជំនុំជម្រះបានចោទ ខៀវ សំផន ថាជាអ្នកថ្លែងសុន្ទរកថាបើកសម័យប្រជុំសភា នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦ ក្នុងខណៈដែលការប្រកាន់គោលជំហរនេះត្រូវបានតុលាការកំពូលថ្កោលទោសរួចមកហើយ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១[313]។ លើសពីនេះទៅទៀត តុលាការកំពូលបានពិចារណាម្តងហើយម្តងទៀតថា អង្គជំនុំជម្រះអនុវត្តមិនសមហេតុផលក្នុងការវាយតម្លៃភ័ស្តុតាងនៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ជាពិសេស ដោយបាន "ដកស្រង់មិនត្រឹមត្រូវ" នូវសាច់រឿងមួយ[314] ឬដោយបំភ្លៃចម្លើយមួយចំនួន[315]។ នៅក្នុងសំណុំរឿង ០០២/០២ ដោយបន្តអនុវត្តដដែលៗនូវវិធីសាស្ត្រអគតិទូទៅមួយស្តីពីភ័ស្តុតាង តាមរយៈការបំភ្លៃ និងការបំប្លែងភ័ស្តុតាង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដែលមិនត្រឹមតែធ្វើឱ្យសេចក្តីសន្និដ្ឋានជាច្រើនរបស់ខ្លួនអស់សុពលភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំឱ្យការជំនុំជម្រះក្តី ខៀវ សំផន ពុំមានភាពយុត្តិធម៌ ហើយដែលតុលាការកំពូលត្រូវតែកត់សម្គាល់លើចំណុចនេះ។

---

[311] Dalloz action ការធ្វើមោឃភាពព្រហមទណ្ឌ ជំពូកទី ៨៥ ការបំប្លែងសំណេរ ផ្នែកទី២ ការបំប្លែងឯកសារភ័ស្តុតាង ៨៥.២១ ភាពផ្ទុយគ្នានៃសំអាងហេតុ។ Jacques និង Louis BORÉ ឆ្នាំ២០១៨/២០១៩។

[312] សូមមើលខាងក្រោម កថាខណ្ឌ ២៥៧។

[313] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៩។ សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០២៣៖ "ផ្ទុយទៅវិញ ទាក់ទងទៅនឹងសុន្ទរកថាបើកសម័យប្រជុំនៅ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៦ ជាការត្រឹមត្រូវដែលខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្មតថាជាសុន្ទរកថារបស់គាត់។ [...] ពុំមានការបញ្ជាក់នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះថា ខៀវ សំផន បានបំពេញតួនាទីជា"ប្រធានគណៈអធិបតី" និងថ្លែងសុន្ទរកថាបើកសម័យប្រជុំនោះឡើយ"។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៤២០-១៤២៧។

[314] សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៤៤០, ៤៤២។

[315] សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០០៩។

## ផ្នែកទី ៣. ស្តង់ដាពីរ រវាងការដាក់បន្ទុក និងការដោះបន្ទុក

២៣៤. នៅក្នុងការវាយតម្លៃភ័ស្តុតាង និងបទដ្ឋានគតិយុត្តិដែលបានកំណត់ អង្គជំនុំជម្រះបានអនុវត្តស្តង់ដាពីរជាច្រើនលើកច្រើនសា រវាងការដាក់បន្ទុក និងការដោះបន្ទុក ដែលរុញច្រានម្ចាស់បណ្តឹងសាទុក្ខឱ្យធ្លាក់ក្នុងស្ថានភាពនៃអសច្ចភាពគតិយុត្តិ និងបង្កព្យសនកម្មទាំងស្រុងដល់សិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវរបស់គាត់។ ជាឧទាហរណ៍ នៅក្នុងការវាយតម្លៃលើបន្ទុកភ័ស្តុតាង មូលហេតុនៃការនិយាយកុហក ការសំអាងឯកសារ ឬការគិតពិចារណាអំពីចម្លើយ និងសំណេរនានារបស់ម្ចាស់បណ្តឹងសាទុក្ខ ឬរបស់អ្នកជំនាញ ឬចម្លើយជាលាយលក្ខណ៍អក្សរទាំងអស់ អង្គជំនុំជម្រះបានអនុវត្តការវាតយតម្លៃដោយប្រើឧបករណ៍វាស់វែងអថេរ ដែលរំលោភលើគ្រប់បទដ្ឋាន និងគោលការណ៍ស្តីអំពីភ័ស្តុតាងដែលខ្លួនបានតាក់តែងឡើងដោយផ្ទាល់[316]។

## ផ្នែកទី ៤. ការបំភ្លេចចោលនូវភ័ស្តុតាងដោះបន្ទុក

២៣៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយលើកឡើងជាន់កែងឯងនៅក្នុងសំអាងហេតុរបស់ខ្លួន និងដោយមិនបានអនុវត្តគោលការណ៍នៃភ័ស្តុតាងដោះបន្ទុក ដែលខ្លួនបានកំណត់។ យោងតាមខ្លឹមសារនៃសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះ "[ត្រូវ] ចោទសួរខ្លួនឯងថា តើ [មាន] ការបកស្រាយសមហេតុផលផ្សេងទៀតដែរឬទេ រួមទាំងការបកស្រាយខ្លះទៀតដែលអាចជាការបកស្រាយដោះបន្ទុក" និងត្រូវ "ស្រង់ និង [...] ពិនិត្យទាំងធាតុផ្សំនៃភ័ស្តុតាងដាក់បន្ទុកជាសក្តានុពលលើចំណុចណាមួយ ទាំងភ័ស្តុតាងដែលអាចប្រើសម្រាប់ដោះបន្ទុកជនជាប់ចោទ"[317]។

២៣៦. តុលាការកំពូលបានយល់ស្របនឹងការបកស្រាយនេះ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ និងបានពិចារណាថា៖ "តាមពិត ចៅក្រមជំនុំជម្រះសេចក្តីត្រូវតែជឿជាក់ឱ្យហួសពីវិមតិសង្ស័យ ដោយផ្អែក

[316] សូមមើលខាងក្រោម កថាខណ្ឌ ២៤១-២៤២, ២៩៣-៣០៥, ៣១២-៣១៣, ៣១៤-៣១៩, ៣២៩-៣៣០។ សូមមើលផងដែរឧទាហរណ៍នៃអង្គហេតុខាងក្រោម៖ កថាខណ្ឌ ៨៩១, ៩២២, ៩៩៩,១១៩៥,១២៣៥, ១៣៨៣, ១៥២៩, ១៧៥២ (កំណត់សម្គាល់ជើងទំព័រលេខ៣៤០០)។

[317] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥។

លើមូលដ្ឋាននៃភ័ស្តុតាងទាំងអស់ ថារាល់អង្គហេតុទាំងអស់ដែលបង្កើតបានជាធាតុផ្សំនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការចូលរួម ក៏ដូចជារាល់អង្គហេតុចាំបាច់សម្រាប់ការផ្តន្ទាទោស ត្រូវបានរកឃើញ"[318]។ តុលាការកំពូលបានផ្អែកជាពិសេសទៅលើយុត្តិសាស្ត្រនៃសាលដីកា *Ntagerura* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ដែលបានណែនាំវិចារណកិច្ចមួយជាច្រើនដំណាក់កាល ដើម្បីវាយតម្លៃភាពជឿជាក់បាននៃភ័ស្តុតាងពាក់ព័ន្ធដែលបានដាក់បង្ហាញ[319]។ ទោះបីជាគោលការណ៍ដែលបានបង្កើតឡើងមានភាពច្បាស់លាស់ក៏ដោយ ក៏អង្គជំនុំជម្រះមិនបានជឿថាវាជាការល្អ ដែលត្រូវអនុវត្តគោលការណ៍នេះនៅក្នុងផ្នែកសំអាងហេតុរបស់ខ្លួនដែរ។ ជាឧទាហរណ៍ នៅផ្នែកស្តីអំពីទោសរបស់ ខៀវ សំផន និងក្នុងការវាយតម្លៃលើលក្ខណៈវិនិច្ឆ័យនៃសីលធម៌ អង្គជំនុំជម្រះបានមើលរំលងទាំងស្រុង នូវសាក្សីអំពីបុគ្គលិកលក្ខណៈរបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយនិយាយថាខ្លួនមិនដែលបានស្តាប់សក្ខីកម្មរបស់ពួកគេណាម្នាក់ឡើយ[320]។ ការសន្និដ្ឋាននេះគឺមិនពិតទេ ពីព្រោះអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សីអំពីបុគ្គលិកលក្ខណៈក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ ហើយក៏បដិសេធយ៉ាងរំភើយមិនព្រមស្តាប់សក្ខីកម្មរបស់ពួកគេម្តងទៀត នៅក្នុងការជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ដោយពន្យល់ដល់មេធាវីការពារក្តីថា សក្ខីកម្មរបស់សាក្សីស្តីពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទទាំងអស់នេះ នឹងត្រូវបានយកពិចារណាក្នុងការពិភាក្សាសម្រេចនៅក្នុងការជំនុំជម្រះក្តីវគ្គពីរ[321]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានថ្លែងផ្ទុយពីផ្នែកសំអាងហេតុរបស់ខ្លួន និងដោយមិនបានអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ដែលខ្លួនបានបង្កើតឡើង[322]។

## ផ្នែកទី ៥. បន្ទុកភ័ស្តុតាង

២៣៧. យោងលើខ្លឹមសារនៃសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ៖ "ជនជាប់ចោទត្រូវបានសន្មតថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់ពួកគាត់មិនត្រូវបានរកឃើញ។ បន្ទុកនៃការបង្ហាញអំពីពិរុទ្ធភាព

[318] សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៤១៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[319] សាលដីកា *Ntagerura* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា) ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ១៧៤។

[320] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩៩។

[321] សូមមើលខាងក្រោម កថាខណ្ឌ ២១៧៧-២១៨៣។

[322] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម៖ កថាខណ្ឌ ៧៥៦, ១២៧៩-១២៨០។

របស់ជនជាប់ចោទ ជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា"[323]។ ការសន្និដ្ឋានទាំងនេះគឺជាការរំឭកអំពីវិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាមានបន្ទុកបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ វិធាននេះផ្អែកលើគោលការណ៍សច្ចធារណ៍នៃនិរទោស ដែលចែងថា "រាល់បុគ្គលរងការចោទប្រកាន់ពីបទល្មើសណាមួយ ត្រូវតែបានសន្មតទុកជាមុនថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គាត់ពុំត្រូវបានរកឃើញក្នុងសាលក្រមបិទផ្លូវតវ៉ាណាមួយ។ គោលការណ៍នេះមានគោលបំណងការពារបុគ្គលប្រឆាំងនឹងអំណាចសាធារណៈ"[324]។ ដូចតុលាកាជាន់ខ្ពស់បារាំងធ្លាប់បានរំឭក ដោយផ្អែកលើគោលការណ៍នេះ ភាគីដើមចោទជាអ្នករ៉ាប់រងបន្ទុកភស្តុតាង[325]។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានប្រកាន់យកគោលជំហរបែបនេះ គឺថា "បន្ទុកភស្តុតាងជាកាតព្វកិច្ចរបស់រដ្ឋអាជ្ញា ហើយការសង្ស័យត្រូវតែជាប្រយោជន៍ដល់ជនជាប់ចោទ"។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបញ្ជាក់ថា អយ្យការត្រូវផ្តល់ "ភស្តុតាងគ្រប់គ្រាន់" ដើម្បីជាមូលដ្ឋាននៃការប្រកាសពិរុទ្ធភាព[326]។ យុត្តិសាស្ត្រតុលាការនេះក៏បានយល់ផងដែរថា គោលការណ៍សច្ចធារណ៍នៃនិរទោសនឹងត្រូវបានរំលោភបំពាន កាលណាបន្ទុកភស្តុតាងបញ្ជាក់អំពីពិរុទ្ធភាពត្រូវបានផ្ទេរបញ្ច្រាសទិសពីអយ្យការទៅមេធាវីការពារក្តី[327]។ ទោះបីជាគ្មាននរណាម្នាក់សង្ស័យអំពីភាពច្បាស់លាស់របស់គោលការណ៍នេះក៏ដោយ ក៏អង្គជំនុំជម្រះបាននិយាយជាន់កែងខ្លួនឯងនៅក្នុងសំអាងហេតុរបស់ខ្លួន ដោយមិនអនុវត្តគោលការណ៍នេះឱ្យបានខ្ជាប់ខ្ជួនឡើយ[328]។

## ផ្នែកទី ៦. អនុមានវិធី/ភស្តុតាងទេសកាល

---

[323] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨។

[324] ឃ្លាំងឯកសារច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ, ភស្តុតាង, មាត្រា ១ សច្ចធារណ៍និរទោស កថាខណ្ឌ ៩ Jacques BUISSON ខែតុលា ឆ្នាំ ២០១៣។

[325] ទស្សនាវដ្តី Crim. ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ លេខ n° 11-83.816។

[326] សាលដីកា *Barbera, Messegue* និង *Jabardo ទល់នឹងប្រទេសអេស្ប៉ាញ* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៨៨ កថាខណ្ឌ ៧៧។

[327] សាលដីកា *Telfner ទល់នឹងប្រទេសអូទ្រីស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ កថាខណ្ឌ ១៥។

[328] ជាឧទាហរណ៍ សូមមើលខាងក្រោម កថាខណ្ឌ ១៤២១។

២៣៨. ផ្អែកលើខ្លឹមសារនៃសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ៖ "ដើម្បីដាក់ទោសជនជាប់ចោទបាន លុះត្រាតែការសន្និដ្ឋានបែបនេះជាការសន្និដ្ឋានសមហេតុផលតែមួយគត់ ដែលទាញចេញពីភ័ស្តុតាង ដែលបានដាក់បង្ហាញនៅក្នុងសវនាការ"[329]។ អង្គជំនុំជម្រះបានរំឭកគោលការណ៍ដែលកំណត់ដោយ តុលាការកំពូល ក្នុងសាលដីកាសំណុំរឿង ០០២/០១[330]។ អង្គជំនុំជម្រះបានលើកឡើងបន្តថា ខ្លួន [អាច] ប្រើសក្ខីកម្មរបស់សាក្សីមួយចំនួនតូចដើម្បីទាញសន្និដ្ឋានជាទូទៅ តែក្នុងករណីដែលការទាញ សន្និដ្ឋានទូទៅនេះ ត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ"[331]។ ក្នុងវិធីសាស្ត្រនេះ អង្គជំនុំជម្រះត្រូវ ពិចារណាថា តើមានការបកស្រាយសមហេតុផលផ្សេងៗទៀត រួមទាំងការបកស្រាយមួយចំនួនដែល អាចដោះបន្ទុកដែរឬទេ[332]។ ទោះបីវិធានច្បាប់ស្តីពីភ័ស្តុតាងទាក់ទងនឹងអនុមានវិធី និងភ័ស្តុតាង ទេសកាលដែលត្រូវបានកំណត់ដោយត្រឹមត្រូវដោយអង្គជំនុំជម្រះក៏ដោយ ក៏ខ្លួនបានលើកឡើងជាន់ កែងខ្លួនឯង ក្នុងសំអាងហេតុរបស់ខ្លួន ដោយមិនបានអនុវត្តវិធានច្បាប់ទាំងនេះទេ។ រាល់ការសន្និដ្ឋាន បែបនេះត្រូវទុកជាមោឃៈ ហើយតុលាការកំពូលត្រូវតែកត់សម្គាល់អំពីភាពអយុត្តិធម៌នៃការជំនុំជម្រះ ក្តី ខៀវ សំផន[333]។

## ផ្នែកទី ៧. ការសន្និដ្ឋានពង្រីក/ការសន្និដ្ឋានទូទៅ

២៣៩. ដូចដែលបានបញ្ជាក់ខាងលើ[334] យោងតាមខ្លឹមសារនៃសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខ៖ "ដើម្បីដាក់ទោសជនជាប់ចោទបាន លុះត្រាតែការសន្និដ្ឋានបែបនេះជាការសន្និដ្ឋានសមហេតុផលតែ

---

329 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៤។

330 សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៩៨៖ "នៅក្នុងរឿងក្តីពាក់ព័ន្ធទៅនឹងបទល្មើសធំធេង ការកោះហៅសាក្សីទាំងអស់មកផ្តល់សក្ខីកម្មអំពីព្រឹត្តិការណ៍ជាច្រើនដែលចោទជាបញ្ហានេះ គឺពុំអាចធ្វើទៅបានឡើយ។ ក្នុងស្ថានភាពបែបនេះ តុលាការអង្គហេតុអាចតម្រូវឱ្យទាញយកសេចក្តីសន្និដ្ឋានចេញពីភ័ស្តុតាងទាក់ទងទៅនឹងបទពិសោធន៍យ៉ាងទូលំទូលាយនោះ"។ សំអាងហេតុសាលក្រម កថាខណ្ឌ ៦៤។

331 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៤។

332 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥។

333 សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម កថាខណ្ឌ ៦៩៥, ៩១០, ១៦១១, ១៨៨១។

334 សូមមើលខាងលើ កថាខណ្ឌ ២៣៨។

មួយគត់ដែលទាញចេញពីភ័ស្តុតាងដែលបានដាក់បង្ហាញនៅក្នុងសវនាការ"[335]។ ដូច្នេះ គោលការណ៍នេះហាមឃាត់មិនឱ្យទាញសន្និដ្ឋានពង្រីក ដើម្បីឈានទៅដល់សេចក្ដីសន្និដ្ឋានដែលត្រូវតែធ្វើឡើងឱ្យហួសវិមតិសង្ស័យ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះអនុវត្តផ្ទុយពីគោលការណ៍ខ្លួនឯង ក្នុងសំអាងហេតុសាលក្រមរងបណ្ដឹងសាទុក្ខនេះ ដោយទាញសេចក្ដីសន្និដ្ឋានផ្អែកលើការការសន្និដ្ឋានពង្រីក និងការសន្និដ្ឋានជាទូទៅ ដែលមិនត្រូវមានឡើយនៅក្នុងការជំនុំជម្រះក្ដីព្រហ្មទណ្ឌ[336]។ តាមរយៈទង្វើនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ជាច្រើន ដែលត្រូវទុកជាមោឃៈ។

## ផ្នែកទី ៨. ចំនួនភ័ស្តុតាង និងតម្លៃជាភ័ស្តុតាង

២៤០. មេធាវីការពារក្ដីគោរពតាមគោលការណ៍របស់អង្គជំនុំជម្រះទាក់ទងនឹងចំនួនភ័ស្តុតាង និងការវាយតម្លៃភ័ស្តុតាងទាំងនេះ[337]។ ចៅក្រមត្រូវវាយតម្លៃភ័ស្តុតាងទាំងមូលដែលបានដាក់បង្ហាញក្នុងសវនាការ ដោយមិនវាយតម្លៃភ័ស្តុតាងទាំងនេះជាកំណាត់តូចៗ ឬបន្ថែមវាដើម្បីបំពេញខគ្គខណ្ឌបន្ទុកនៃភ័ស្តុតាង។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តិកំហុសអង្គច្បាប់ ដោយលើកឡើងផ្ទុយពីសំអាងហេតុសាលក្រមរង

---

[335] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៤។

[336] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម៖ កថាខណ្ឌ ១៨២៩-១៨៣៥ សេចក្ដីសន្និដ្ឋានស្ដីពីការដឹងឮអំពីសហករណ៍៖ ការដឹងឮពីសហករណ៍ព្រះវិហារដោយម្ចាស់បណ្ដឹងសាទុក្ខ គឺមានន័យថាដឹងឮអំពីស្ថានភាពគ្រប់ទីកន្លែងក្នុងកម្ពុជាប្រជាធិបតេយ្យ។

[337] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៖ "អង្គហេតុទាំងអស់ដែលបញ្ជាក់អំពីធាតុផ្សំនៃបទឧក្រិដ្ឋឬទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ព្រមទាំងអង្គហេតុទាំងអស់ដែលមិនអាចខ្វះបានសម្រាប់ការសម្រេចលើការផ្ដន្ទាទោស ជាពិសេសអង្គហេតុទាំងឡាយដែលបង្កើតជាធាតុផ្សំនៃបទឧក្រិដ្ឋ (...)។ នេះត្រូវមានការគាំទ្រដោយមតិដែលមានសំអាងហេតុ ដោយផ្អែកលើភ័ស្តុតាងទាំងស្រុងដោយពុំចាំបាច់អនុវត្តបទដ្ឋាននៃការបង្ហាញភ័ស្តុតាងឱ្យហួសពីវិមតិសង្ស័យជាផ្នែកផ្នែកនោះទេ។ ជាក់ស្ដែង ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានសម្រេច ករណីនេះពុំមានន័យថា "ភ័ស្តុតាង ផ្សេងៗជាច្រើនអាចបូកបញ្ចូលគ្នាដើម្បីបំពេញលក្ខខណ្ឌនៃការបង្ហាញឱ្យហួសពីវិមតិសង្ស័យ ដោយពុំគិតពីទម្ងន់នៃភ័ស្តុតាងនីមួយៗដែរ"។ អង្គជំនុំជម្រះបញ្ជាក់ដូចខាងក្រោមអំពីផលប៉ះពាល់នៃបទដ្ឋាន ក្នុងការបង្ហាញភ័ស្តុតាងឱ្យហួសពីវិមតិសង្ស័យទៅលើការវាយតម្លៃលើតម្លៃនៃភ័ស្តុតាង ដែលត្រូវបានដាក់នៅចំពោះមុខខ្លួន (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើល កំណត់សម្គាល់ជើងទំព័រលេខ ៩០-៩៩។

បណ្តឹងសាទុក្ខនេះ និងដោយមិនអនុវត្តតាមគោលការណ៍ដែលបានកំណត់ឱ្យបានខ្ជាប់ខ្ជួន[338]។ រាល់ការសន្និដ្ឋានបែបនេះ ត្រូវទុកជាមោឃៈ។

### ផ្នែកទី ៩. ភាពស៊ីចង្វាក់គ្នា

២៤១. យោងតាមខ្លឹមសារនៃសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានកំណត់ក្របខ័ណ្ឌសម្រាប់វាយតម្លៃលើភាពស៊ីចង្វាក់គ្នា។ អង្គជំនុំជម្រះបានថ្លែងថា ខ្លួនបានពិនិត្យ៖ “ដោយផ្អែកតាមករណីនីមួយៗ លើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ យោងតាមភាពជឿជាក់បាននៃចម្លើយរបស់ពួកគេ និងយោងទៅតាមកត្តាដទៃទៀត ដូចជាឥរិយាបទ អវត្តមាន ឬវត្តមាននៃអសង្គតភាពទាក់ទងនឹងអង្គហេតុសំខាន់ៗ នៅក្នុងសក្ខីកម្មរបស់ពួកគេ”[339]។

២៤២. ការស្វែងរកភាពស៊ីចង្វាក់គ្នាមានគោលបំណងពង្រឹងភ័ស្តុតាង និងរកបង្អែកសមហេតុផល។ វាក្យស័ព្ទ CORNU កំណត់សកម្មភាពនេះដូចតទៅ៖ “ដើម្បីធ្វើជាមធ្យោបាយបង្ហាញភ័ស្តុតាង គេត្រូវធ្វើសកម្មភាពពង្រឹងភ័ស្តុតាងមួយទៀតដែលមានន័យស្របគ្នា និងសកម្មភាពបង្កើនតម្លៃជាភ័ស្តុតាងរបស់វាដោយភាពស៊ីចង្វាក់គ្នា ជួនកាលរហូតដល់ផ្តល់ឱ្យវានូវតម្លៃពិសេសមួយ ឬធ្វើឱ្យគេមិនអាចជំទាស់បានទៅនឹងអ្វីដែលកើតចេញពីភាពស៊ីចង្វាក់គ្នានៃភ័ស្តុតាង”[340]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានផ្តល់និយមន័យច្បាស់លាស់មួយ នៅក្នុងសាល

---

[338] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម៖ កថាខណ្ឌ ២០២៦ និង សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧១ កំណត់ជើងទំព័រ ១៣៩៣៨ ដែលយោងទៅកថាខណ្ឌ ៣៣៩០, កថាខណ្ឌ ៤២៧១, កំណត់សម្គាល់ជើងទំព័រលេខ១៣៩៣៩ ដែលយោងទៅ កថាខណ្ឌ ៣៥១៧ ដែលយោងទៅកថាខណ្ឌ ៣៣៨៥, ៣៣៩០, ៣៣៩១ និង ៣៣៩៦។ សម្រង់សម្តីរបស់អង្គជំនុំជម្រះ នៅកថាខណ្ឌ ៤២៧១ ដែលទាញចេញពីកថាខណ្ឌ ៣៣៩១ ដែលយោងទៅកំណត់សម្គាល់ជើងទំព័រលេខ១១៤៣៦ ដែលស្រង់ធាតុផ្សំភ័ស្តុតាងជាច្រើនស្តីពីសុន្ទរកថាថ្នាក់ដឹកនាំ។ ចំពោះសុន្ទរកថារបស់លោក ខៀវ សំផន ប្រភពតែមួយគត់ គឺបានមកពីសាក្សី ឯក ហេន។

[339] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៩ សូមមើលផងដែរសំអាងហេតុសាលក្រម កថាខណ្ឌ ៥៣៖ “ដោយផ្អែកលើភាពអាចជឿជាក់បាននៃសក្ខីកម្ម និងដោយការពិចារណាផ្អែកលើកត្តាមួយចំនួនដូចជាអត្តចរិតរបស់បុគ្គលដែលផ្តល់សក្ខីកម្ម ភាពស៊ីចង្វាក់គ្នា និងភាពមិនស៊ីចង្វាក់គ្នាទាក់ទងនឹងអង្គហេតុសំខាន់ៗ ការជំរុញពីខាងក្រៅដែលអាចមានការអះអាងបញ្ជាក់ និងកាលៈទេសៈទាំងអស់នៃរឿងក្តីនេះ”។

[340] និយមន័យនៅក្នុងវាក្យស័ព្ទច្បាប់ ដោយលោក Gérard CORNU, *Corroborer* បោះពុម្ពលើកទី១២ ទំព័រ ២៧៨។

ដីការឿងក្តី *Nahimana* ដែលគួរត្រូវបានដកស្រង់ទៅដូចតទៅ៖ “មានភាពស៊ីចង្វាក់គ្នារវាងសក្ខីកម្មនានា លុះត្រាតែសក្ខីកម្មមួយដែលអាចជឿទុកចិត្តបានពេលឃើញពីដំបូងភ្លាម ស៊ីគ្នាជាមួយនឹងសក្ខីកម្មមួយទៀតដែលអាចជឿទុកចិត្តបាន ដោយគ្រាន់តែឃើញពីដំបូងភ្លាម ចំពោះអង្គហេតុមួយដូចគ្នា ឬដំណើរនៃអង្គហេតុដែលមានទំនាក់ទំនងរវាងគ្នា”។ សកម្មភាពស្វែងរកភាពស៊ីចង្វាក់គ្នានេះ ត្រូវបានបញ្ជាក់កាន់តែច្បាស់ថែមទៀតដោយគោលការណ៍នាំមុខផ្សេងទៀតនៃច្បាប់ស្តីពីភ័ស្តុតាង និងការជំនុំជម្រះក្តីព្រហ្មទណ្ឌ។ ជាក់ស្តែង សកម្មភាពនេះអនុញ្ញាតឱ្យមានការពិភាក្សាចំពោះមុខអំពីភ័ស្តុតាង និងហាមឃាត់ចៅក្រមមិនឱ្យជ្រើសរើសយកអនុមានវិធីដោយផ្អែកលើពាក្យចចាមអារ៉ាម[341]។ ការជំនុំជម្រះនេះទាមទាឱ្យមានភាពម៉ត់ចត់ពិសេស។ ដោយសារហេតុការណ៍បានកើតឡើងកាលពីជាង ៤០ ឆ្នាំមុន ភ័ស្តុតាងដែលបានបង្ហាញមានលក្ខណៈចន្លោះប្រហោងច្រើនណាស់។ អាស្រ័យហេតុនេះ គេត្រូវអនុវត្តការស្វែងរកភាពស៊ីចង្វាក់គ្នាឱ្យបានខ្ជាប់ខ្ជួន ដើម្បីផ្តល់តម្លៃជាភ័ស្តុតាង។ ទោះបីជាគោលការណ៍ដែលបានកំណត់មានភាពច្បាស់លាស់ក៏ដោយ ក៏អង្គជំនុំជម្រះបានលើកឡើងជាន់កែងខ្លួនឯងក្នុងផ្នែកសំអាងហេតុរបស់ខ្លួន ដោយមិនអនុវត្តគោលការណ៍នេះឱ្យបានខ្ជាប់ខ្ជួន[342]។

## ផ្នែកទី ១០. ភាពផ្ទុយគ្នា

២៤៣. អង្គជំនុំជម្រះបានកំណត់ក្របខ័ណ្ឌវាយតម្លៃភ័ស្តុតាង ក្នុងករណីមានភាពផ្ទុយគ្នានៅក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ[343]។ ដូច្នេះ អង្គជំនុំជម្រះបានថ្លែងថា ខ្លួនបានពិនិត្យមើលចំណុចទាំងនេះ ដោយពិចារណាលើ “អវត្តមាន ឬវត្តមាននៃភាពមិនស៊ីចង្វាក់គ្នាទាក់ទងនឹងអង្គហេតុសំខាន់ៗ នៅក្នុងសក្ខីកម្មរបស់ពួកគេ”[344]។ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានពិចារណាថា ខ្លួនអាចពិចារណាលើតម្លៃជាភ័ស្តុតាងបាន ដោយផ្អែកលើធាតុពាក់ព័ន្ធជាច្រើនដែលត្រូវបានចោទប្រកាន់ថា មានភាពផ្ទុយគ្នា ឬមានកង្វះខាត ដោយផ្អែកលើការវិភាគគួរអោយ

---

[341] សូមមើលខាងលើ កថាខណ្ឌ ២៣៨ និងខាងក្រោម កថាខណ្ឌ ៣១២-៣១៣។

[342] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម កថាខណ្ឌ ៧៨១, ៨៦៦។

[343] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៩-៥៤។

[344] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៩ កំណត់សម្គាល់ជើងទំព័រលេខ ១៣១៖ សេចក្តីសម្រេច ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E96/7** កថាខណ្ឌ ៦, ២៦។ សេចក្តីសម្រេច **E299**។ សេចក្តីសម្រេច **E305/17**។

ទុកចិត្តបានខ្លាំង[345]។ បន្ទាប់មក អង្គជំនុំជម្រះបានបន្ថែមទៀតថា ភាពអាចជឿទុកចិត្តបាននៃសក្ខីកម្មមួយ ត្រូវវាយតម្លៃដោយផ្អែកលើកត្តាមួយចំនួន "ដូចជាអវត្តមាន ឬវត្តមាននៅក្នុងចម្លើយ នូវភាពមិនស៊ីចង្វាក់គ្នាទាក់ទងនឹងអង្គហេតុសំខាន់ៗ អត្ថិភាពនៃធាតុផ្សំគាំទ្រសក្ខីកម្មនេះ និងគ្រប់កាលៈទេសៈនៃករណីនេះ"[346]។ ទោះបីជាមេធាវីការពារក្ដីគោរពតាមក្របខ័ណ្ឌគតិយុត្តិនេះ និងគោរពតាមគោលការណ៍ដែលបានចែងដោយអង្គជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានលើកឡើងផ្ទុយពីអ្វីដែលខ្លួនបានអះអាង នៅក្នុងសំអាងហេតុសាលក្រមរងបណ្ដឹងសាទុក្ខនេះ និងដោយមិនអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវការណែនាំដែលខ្លួនបានចេញ[347]។

## ផ្នែកទី ១១. ចម្លើយពីមុនៗ/ចម្លើយពេលក្រោយៗមកទៀត

### ១. ការទទួលយកជាភ័ស្តុតាង

២៤៤. យោងតាមសំអាងហេតុសាលក្រមរងបណ្ដឹងសាទុក្ខនេះ អង្គជំនុំជម្រះ "បានប្រកាស ដើម្បីផលប្រយោជន៍យុត្តិធម៌ [...] ទទួលយកជាភ័ស្តុតាងរាល់ចម្លើយពីមុនៗរបស់សាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានប្រមូលក្នុងដំណាក់កាលសាកសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ក្នុងខណៈដែលពួកគេត្រូវតែមកមកផ្ដល់សក្ខីកម្មក្នុងសវនាការ ដើម្បីឱ្យដឹងថាតើចម្លើយរបស់ពួកគេអាចត្រូវបានទទួលយកជាភ័ស្តុតាង ឬយ៉ាងណា"[348]។ នេះមិនមែនជាគោលជំហរថ្មីនោះទេ។ ជាឧទាហរណ៍ ក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចផ្សេងៗ ដែលនៅក្នុងសេចក្ដីសម្រេចទាំងនោះ ខ្លួនយល់ឃើញថាត្រូវតែអនុវត្តបែបនេះ "ដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះ

---

[345] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១ សូមមើលផងដែរ កថាខណ្ឌ ៥១៖ "អង្គជំនុំជម្រះបានទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងប្រតិចារឹក ស្ដីពីកិច្ចដំណើរការនីតិវិធីមុនៗ រួមទាំង ឬជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ដើម្បីផ្ដល់ឱកាសឱ្យភាគីសួរតទល់ជាមួយនឹងបុគ្គលដែលរងការចោទប្រកាន់ថាមានភាពមិនស៊ីចង្វាក់គ្នា រវាងភ័ស្តុតាងផ្ទាល់មាត់ និងកំណត់ហេតុនៃការស្ដាប់ចម្លើយមុនៗរបស់ពួកគាត់នៅក្នុងសវនាការ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[346] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៣។

[347] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោមស្ដីពីការនិយាយផ្ទុយគ្នារបស់សាក្សី ឯម ហឿន កថាខណ្ឌ ១៧៥៧-១៧៥៨។

[348] សំអាងហេតុសាលក្រម កថាខណ្ឌ ៥១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

និងភាគីអាចវាយតម្លៃឱ្យបានពេញលេញ លើភាពជឿជាក់បាន ទៅតាមកម្រិតសង្គតភាពនៃចម្លើយរបស់សាក្សី" "ដើម្បីជាផលប្រយោជន៍ដល់ការស្វែងរកការពិត"[349]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយមិនបើកកិច្ចដំណើរការនីតិវិធីសួរដេញដោលឡើងវិញ ទោះបីដឹងថាឯកសារទាំងនេះបានមកពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញខ្លួននៅចំពោះមុខខ្លួនក៏ដោយ[350]។

២៤៥. ជាក់ស្តែង នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ ខណៈពេលដែលអង្គជំនុំជម្រះកំពុងពិភាក្សាសម្រេចអស់រយៈពេលជាងមួយឆ្នាំមកហើយនោះ ឯកសារមួយចំនួនត្រូវបានដាក់បង្ហាញ ក្នុងនោះរួមមាន កំណត់ហេតុស្តាប់ចម្លើយ ឯក ហេន ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ និងកំណត់ហេតុស្តាប់ចម្លើយ ជួន ធី ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧។ មេធាវីការពារក្តីបានស្នើសុំភ័ស្តុតាងបន្ថែមចំពោះកំណត់ហេតុទាំងពីរនៅចំពោះមុខតុលាការកំពូល[351]។ ដូចដែលមេធាវីការពារក្តីបានចង្អុលបង្ហាញរួចហើយនៅក្នុងសំណើរបស់ខ្លួន៖

> "ដោយជាន់ឈ្លីយុត្តិសាស្ត្ររបស់ខ្លួន អង្គជំនុំជម្រះបានត្រឹមតែស្នើសុំការអនុញ្ញាតផ្សព្វផ្សាយឯកសារទាំងនេះពីសហចៅក្រមស៊ើបអង្កេត ដើម្បីឱ្យភាគីអាចចូលពិគ្រោះបាន ទាំងដឹងថាភាគីនឹងមិនអាចពិភាក្សាសួរដេញដោលអំពីឯកសារទាំងនេះ។ តាមពិត ស្របតាមវិធាន ៩៦(២) នៃវិធានផ្ទៃក្នុង ភាគីមិនអាចដាក់សេចក្តីសន្និដ្ឋាន ក្នុងអំឡុងពេលដែលអង្គជំនុំជម្រះកំពុងពិភាក្សាសម្រេចបានទេ ដោយហេតុថាមានតែអង្គជំនុំជម្រះប៉ុណ្ណោះដែលមានសិទ្ធិអំណាចបើកកិច្ចដំណើរការនីតិវិធីឡើងវិញ។ អាស្រ័យហេតុនេះ ដោយគេចវេសមិនព្រមបើកកិច្ច

[349] អនុស្សរណៈ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ឯកសារ **E319/68/1** កថាខណ្ឌ ២។ អនុស្សរណៈ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ឯកសារ **E319/69** កថាខណ្ឌ ២។ អនុស្សរណៈ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ឯកសារ **E319/67** កថាខណ្ឌ ២ និង ៤។ សូមមើលផងដែរ សេចក្តីសម្រេច ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E363/3** កថាខណ្ឌ ២៥។

[350] អនុស្សរណៈ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ ឯកសារ **E319/71/1**។ *International co-prosecutor's proposed disclosure of documents from cases 003 and 004* ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **E319/71**។

[351] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7**។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4**។

ដំណើរការនីតិវិធីឡើងវិញ អង្គជំនុំជម្រះបានរារាំងមេធាវីការពារក្តីមិនឱ្យមានលទ្ធភាពជជែកដេញដោលចំពោះមុខខ្លួន អំពីខ្លឹមសារនៃចម្លើយដោះបន្ទុក ឬអំពីភាពជឿជាក់បាននៃចម្លើយរបស់សាក្សីមួយចំនួនដែលត្រូវបានប្រើសម្រាប់ដាក់បន្ទុកលើ ខៀវ សំផន"[352]។

២៤៦. ចម្លើយរបស់ ឯក ហេន និង ជួន ធី[353] បង្កផលប៉ះពាល់យ៉ាងខ្លាំងទៅលើការវាយតម្លៃភាពជឿជាក់បាន និងភាពទុកចិត្តបាននៃសក្ខីកម្មរបស់ពួកគេ ហើយគួរតែទទួលយក នៅក្រោយការបើកកិច្ចដំណើរការនីតិវិធីឡើងវិញ។ ពិតណាស់ តុលាការកំពូលបានទទួលយកចម្លើយទាំងនេះ ក្នុងបណ្តឹងសាទុក្ខ ប៉ុន្តែវាមានការបាត់បង់ឱកាសដើម្បីបង្ហាញទឡ្ហីករណ៍បញ្ជាក់អំពីភាពផ្ទុយគ្នាថ្មីៗទៀតរបស់ ឯក ហេន និងបញ្ជាក់ពីសក្ខីកម្មដោះបន្ទុករបស់ ជួន ធី។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងកំហុសជាក់ស្តែងក្នុងការវាយតម្លៃ ដែលបានបង្កព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ ដែលបានបាត់បង់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយកម្រិត[354] ចំពោះអង្គហេតុទាំងនេះ។

## ២. ការអានឡើងវិញមុនពេលចូលបង្ហាញខ្លួន

២៤៧. ចាប់តាំងពីសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបង្កើតទម្លាប់ឱ្យសាក្សីអានកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួនពីមុនៗឡើងវិញ មុនពេលពួកគេចូលបង្ហាញខ្លួននៅចំពោះមុខអង្គសវនាការ។ អង្គជំនុំជម្រះបានរំឭកអំពីក្របខ័ណ្ឌដែលខ្លួនបានបង្កើតឡើងកន្លងមក ក្នុងសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ៖

"ជាទៀងទាត់ លោកប្រធានបានចាប់ផ្តើមការសួរចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗដែលបានកោះហៅមកបង្ហាញខ្លួន ដោយសួរពួកគាត់ថា តើពួកគាត់បញ្ជាក់ថា កំណត់

---

[352] សំណើរបស់លោក ខៀវ សំផន សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ ឯកសារ F51 កថាខណ្ឌ ១៣។

[353] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ E319/71.2.7។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ E319/71.2.4។

[354] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម ដែលលើកឡើងពី ឯក ហេន៖ កថាខណ្ឌ ១០៧៥, ១៤២៤, ១៧៥៥, ១៧៥៩, ១៨៩៣-១៨០៤, ១៩០០, ២០១៦, ២៩៧៥ និងអំពី ជួន ធី៖ កថាខណ្ឌ ១២០៧, ១២២០, ១២២៦។

ហេតុស្តាប់ចម្លើយដែលត្រូវបានរៀបចំឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ទុះបញ្ចាំងពីខ្លឹមសារនៃចម្លើយរបស់ពួកគាត់ត្រឹមត្រូវដែរឬទេ។ បើពួកគាត់ឆ្លើយថាត្រឹមត្រូវ ភាគីទាំងអស់ត្រូវបានអញ្ជើញឱ្យសួរសំណួរបន្ថែមទាក់ទងនឹងខ្លឹមសារនៃចម្លើយទាំងនេះ លុះត្រាតែសំណួរទាំងនេះមានគោលបំណងបំភ្លឺលើចំណុចពាក់ព័ន្ធ ដែលសហចៅក្រមស៊ើបអង្កេតមិនបានសួរដេញដោលគ្រប់គ្រាន់ ឬមិនបានសួរនៅពេលស្តាប់ចម្លើយ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា ការអនុវត្តនេះមិនបង្កព្យសនកម្មដល់សិទ្ធិរបស់ភាគីក្នុងការពិនិត្យលើភាពអាចជឿទុកចិត្តបានរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងចំណុចនានាក្នុងចម្លើយមុនៗរបស់ពួកគេ ឬបញ្ហានានាដែលមិនត្រូវលើកយកមកពិភាក្សាក្នុងចម្លើយទាំងនេះ"[355]។

២៤៨. បន្ទាប់មក អង្គជំនុំជម្រះបានរំឭកថា ការវាយតម្លៃលើភាពអាចទុកចិត្តបាននៃសក្ខីកម្ម ត្រូវធ្វើឡើងទៅតាមករណីនីមួយៗ៖

"ដោយពិចារណាលើកត្តាមួយចំនួន ដូចជាអត្ថិភាព ឬនត្ថិភាពនៃសង្គតភាពនៃអង្គហេតុសំខាន់ៗ អត្ថិភាពនៃធាតុផ្សំសម្រាប់គាំទ្រសក្ខីកម្ម និងកាលៈទេសៈនានានៃរឿងក្តី។ នៅពេលវាយតម្លៃភាពអាចជឿជាក់បាន និងភាពគួរឱ្យទុកចិត្តបាននៃសក្ខីកម្មមួយ អង្គជំនុំជម្រះក៏នឹងគិតអំពីការប្រើប្រាស់សំណួរនាំមុខជាយថាហេតុ ដូចជាការចោទសំណួរដែលផ្អែកលើចម្លើយពីមុនៗរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរំឭកការចងចាំរបស់គាត់"[356]។

២៤៩. អង្គជំនុំជម្រះបានលើកឡើងជាន់កែងខ្លួនឯង ភ្លាមៗក្រោយពេលខ្លួនបានកំណត់ក្របខ័ណ្ឌវាយតម្លៃលើភាពអាចទុកចិត្តបានរបស់សាក្សី៖ "អង្គជំនុំជម្រះពិចារណាថា ភាពអាចទុកចិត្តបានរបស់សាក្សីអាស្រ័យលើសមត្ថភាពរបស់បុគ្គលពាក់ព័ន្ធក្នុង<u>ការក្តាប់បានព្រឹត្តិការណ៍នានា សមត្ថភាពចងចាំ</u>

355 សំអាងហេតុសាលក្រម កថាខណ្ឌ ៥២។ សេចក្តីសម្រេច ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E96/7 កថាខណ្ឌ ៣១។

356 សំអាងហេតុសាលក្រម កថាខណ្ឌ ៥៣។

ព្រឹត្តិការណ៍ទាំងនេះក្រោយហេតុការណ៍បានកន្លងផុតទៅ និងសមត្ថភាពនិទានវាឡើងវិញដោយត្រឹមត្រូវដូចដើម”[357]។

២៥០. ដូច្នេះ យើងពិបាកនឹងយល់ពីការអនុវត្តរបស់អង្គជំនុំជម្រះ ក្នុងការអានសក្ខីកម្មពីមុនៗឱ្យសាក្សីស្ដាប់ ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី និង ដើម្បីវាយតម្លៃលើភាពអាចទុកចិត្តបានរបស់សាក្សី។ អង្គជំនុំជម្រះបានផ្អែកលើសមត្ថភាពរបស់សាក្សីក្នុងការក្ដាប់បាន ឬការនឹកឃើញឡើងវិញអំពីព្រឹត្តិការណ៍នានា។ ការសន្និដ្ឋានទាំងនេះមានលក្ខណៈផ្ទុយគ្នា ដោយហេតុថា ការអនុញ្ញាតឱ្យសាក្សីអានចម្លើយពីមុនៗរបស់គាត់ បណ្ដាលឱ្យការវាយតម្លៃលើសមត្ថភាពក្ដាប់បាន ឬនឹកឃើញឡើងវិញអំពីព្រឹត្តិការណ៍មានលក្ខណៈសិប្បនិម្មិត។ ចាប់តាំងពីឆ្នាំ២០១២ និងការចាប់ផ្ដើមសំណុំរឿង ០០២/០១ អ.វ.ត.ក បានអនុញ្ញាតឱ្យមានការអានឱ្យសាក្សីស្ដាប់ឡើងវិញនូវចម្លើយពីមុនៗរបស់ពួកគាត់។ តុលាការកំពូលបានផ្ដល់សុពលភាពដល់ការអនុវត្តនេះ ក្នុងសាលដីកានៃណុំរឿង ០០២/០១[358]។ តុលាការកំពូលបានទទួលស្គាល់ថា ទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទាំងវិធានផ្ទៃក្នុង ពុំមានចែងអំពីការផ្ដល់លទ្ធភាពដល់សាក្សី ដើម្បីពិគ្រោះចម្លើយពីមុនៗរបស់គាត់ ឬឯកសារណាមួយផ្សេងទៀត មុនពេលផ្ដល់សក្ខីកម្មក្នុងសវនាការឡើយ[359]។ ទោះជាយ៉ាងនេះក្ដី តុលាការកំពូលមិនគួរផ្ដល់សុពលភាពដល់វិធីសាស្ត្របែបនេះ ដែលប៉ះពាល់ដល់គោលការណ៍សួរដេញដោលផ្ទាល់មាត់។ ក៏ប៉ុន្តែ នីតិវិធីដេញដោលផ្ទាល់មាត់ត្រូវតែអនុញ្ញាតឱ្យមានសយម្ភូតភាពនៃសវនាការព្រហ្មទណ្ឌ។ ទោះបីជាល្បឿននៃកិច្ចដំណើរការនីតិវិធីមានសារៈសំខាន់ក៏ដោយ ក៏យើងពុំគួរណាគិតគូរខ្លាំងដល់ល្បឿននេះ រហូតដល់ធ្វើឱ្យប៉ះពាល់ដល់ការសួរឆ្លងឆ្លើយដែលនាំទៅដល់ការស្វែងរកការពិតនោះឡើយ។ ដោយកង្វល់ពីល្បឿននៃការជំនុំជម្រះក្ដី ចាប់តាំងពីការធ្វើកំណែទម្រង់មួយ ក្នុងឆ្នាំ២០១១ នីតិព្រហ្មទណ្ឌរបស់ប្រទេសស្វីសបានអនុញ្ញាតឱ្យប្រធានអង្គជំនុំជម្រះអានចម្លើយមុនៗរបស់សាក្សីឱ្យគាត់ស្ដាប់ ហើយសុំឱ្យគាត់បញ្ជាក់ថាតើចម្លើយទាំងនោះពិតជាត្រឹមត្រូវដែរឬទេ។ ប៉ុន្តែ កំណែទម្រង់នេះក៏បានបញ្ចូលគោលការណ៍ថ្មីមួយទៅក្នុងនីតិព្រហ្មទណ្ឌស្វីស ហៅថា “គោលការណ៍ដេញដោលផ្ទាល់មាត់មានកម្រិត”។ កំណែទម្រង់នេះ

---

[357] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[358] អនុស្សរណៈ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ **E141/1**។ សូមមើលផងដែរ អនុស្សរណៈ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ២០១១ ឯកសារ **E141**។

[359] សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ២០១៦ កថាខណ្ឌ ២៦២។

រងការរិះគន់ជាច្រើន ហើយការអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះនេះ ក៏អាចរងការរិះគន់ទាំងនេះដូចគ្នា[360]។

២៥១ នៅក្នុងនីតិព្រហ្មទណ្ឌបារាំងដែលជាប្រភពនៃច្បាប់កម្ពុជា គោលការណ៍ដេញដោលផ្ទាល់មាត់ដែលជាគោលការណ៍នាំមុខក្នុងការជំនុំជម្រះក្ដី ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង។ វាតម្រូវឱ្យមានការពិភាក្សាលើភ័ស្តុតាងទាំងអស់នៅចំពោះមុខតុលាការ។ គោលការណ៍នេះបង្កើតឱ្យមានគោលការណ៍ចំពោះមុខដែលតម្រូវឱ្យ មានការពិភាក្សាដេញដោលចំពោះមុខលើរាល់ធាតុផ្សំភ័ស្តុតាង ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី[361]។ ដូច្នេះ សក្ខីកម្មរបស់សាក្សី និងអ្នកជំនាញ ត្រូវតែធ្វើឡើងដោយផ្ទាល់មាត់។ រាល់បុគ្គលដែលមកផ្ដល់សក្ខីកម្មត្រូវតែថ្លែងដោយផ្ទាល់មាត់ និងត្រូវបានហាមឃាត់មិនឱ្យអានសក្ខីកម្មដែលបានរៀបចំទុកជាមុន។ ក្នុងអំឡុងពេលសាក្សីផ្ដល់សក្ខីកម្ម គេមិនអាចអានចម្លើយពីមុនៗរបស់គាត់ឡើយ សូម្បីតែផ្នែកខ្លះ ឬពីរបីបន្ទាត់ក៏ដោយ។ អាស្រ័យហេតុនេះ វាមិនអាចទៅរួចនោះទេក្នុងការអានសក្ខីកម្មមួយ ហើយសួរសាក្សីឱ្យបញ្ជាក់ថាគាត់ពិតជាបាននិយាយអញ្ចឹងដែរឬទេ ឬក៏រំឭកគាត់ជាមុនអំពីពាក្យពេចន៍ដែលគាត់បាននិយាយក្នុងចម្លើយរបស់គាត់ ឬក៏កាត់សំដីគាត់ពេលគាត់កំពុងផ្ដល់សក្ខីកម្មក្នុងសវនាការ ដើម្បីអានផ្នែកខ្លះនៃចម្លើយពីមុនៗរបស់គាត់[362]។ នេះជាយុត្តិសាស្ត្រតាំងពី

---

360 អត្ថបទសរសេរដោយលោកស្រី Christiane BESNIER *សាលាឧក្រិដ្ឋនៅសតវត្សទី២១ - II) យុត្តិធម៌នៃបទព្រហ្មទណ្ឌនៅអឺរ៉ុបអនាគតនៃការជំនុំជម្រះក្ដីបទឧក្រិដ្ឋ៖ ប្រទេសបារាំង បែលហ្ស៊ិក ស្វីស* ឆ្នាំ២០១៧ (យើងគូសបន្ទាត់ពីក្រោម) សូមមើលផងដែរទំព័រ ៦៤៦។ "ការកាត់បន្ថយរយៈពេលនៅក្នុងការជំនុំជម្រះធ្វើឱ្យប្រភេទនៃការពិភាក្សាដេញដោលមានការប្រែប្រួល ហើយតាមរយៈការកាត់បន្ថយនោះក៏ធ្វើឱ្យការកាត់សេចក្ដីត្រូវគេមើលឃើញថាមានភាពចុះខ្សោយ។ រយៈពេលកំណត់សម្រាប់ការពិភាក្សាដេញដោល តាមរយៈការកោះហៅសាក្សី និងការចោទសួរដេញដោលដោយភាគី សុទ្ធតែជាភ័ស្តុតាងដែលចូលរួមក្នុងដំណើរការផ្ដល់ភាពជឿជាក់ដល់ចៅក្រម"។

361 អត្ថបទសរសេរដោយលោក Michel REDON *តុលាការឧក្រិដ្ឋកម្ម មាត្រា ២ គោលការណ៍នៃកិច្ចពិភាក្សាដេញដោលផ្ទាល់មាត់* ឃ្លាំងឯកសារក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីព្រហ្មទណ្ឌ Dalloz ឆ្នាំ២០១៧។

362 អត្ថបទសរសេរដោយលោក Michel REDON *សាលាឧក្រិដ្ឋ គោលការណ៍គ្រឹះនៃកិច្ចពិភាក្សាដេញដោល នៅក្នុងរឿងក្ដីឧក្រិដ្ឋកម្មកថាខណ្ឌ ៤ - សាក្សី និង អ្នកជំនាញដែលទទួលការអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចពិភាក្សាដេញដោល* ឃ្លាំងឯកសារក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ Dalloz ឆ្នាំ២០១៨។

បុរាណដែលគេអនុវត្តរហូតដល់សព្វថ្ងៃ[363]។ ក៏ប៉ុន្តែ គោលការណ៍សួរដេញដោលផ្ទាល់មាត់នេះ មិនរារាំងប្រធានអង្គជំនុំជម្រះមិនឱ្យអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការរៀបរាប់អំពីចម្លើយពីមុនៗរបស់សាក្សី ដើម្បីធ្វើការប្រៀបធៀប **បន្ទាប់ពីសាក្សីបានផ្ដល់សក្ខីកម្មចប់ហើយ**[364]។ ដូចគ្នានេះដែរ ដូចអង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងរឿងក្តី *Lubanga* បានរំឭករួចមកហើយ លទ្ធិដែលអនុញ្ញាត ឬហាមឃាត់ការអានឡើងវិញនូវចម្លើយពីមុនៗ ប្រសូត្រចេញមកពីបដិទស្សនៈគតិយុត្តិរវាងប្រទេសដែលប្រើច្បាប់ Common Law និងប្រទេសប្រើច្បាប់ Civil Law[365]។ ដោយសារគ្មានអត្ថបទច្បាប់កម្ពុជាណាមួយលើកឡើងពីចំណុចនេះ ការស្រាវជ្រាវស្វែងរកយុត្តិសាស្ត្របង្អែកមួយប្រហែលជានឹងអាចបំភ្លឺដល់អង្គជំនុំជម្រះ អំពីអនុលោមភាពនៃការអនុវត្តបែបនេះទៅនឹងច្បាប់ជាតិ។ អង្គជំនុំជម្រះ និងតុលាការកំពូល មិនអាចបង្កើតការអនុវត្តនូវការអានសក្ខីកម្មពីមុនៗរបស់សាក្សីឡើងវិញ ដោយមិនធ្វើឱ្យខូចខាតដល់ប្រពៃណីច្បាប់ស៊ីវិល ដែលជាប្រភពនៃច្បាប់កម្ពុជានោះទេ។

២៥២. តាមព្រឹត្តន័យ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ហើយក្របខ័ណ្ឌច្បាប់នេះ ក៏ដូចជាការសន្និដ្ឋានទាំងអស់ដែលទាញចេញពីវា ត្រូវតែទុកជាមោឃៈ។ លើសពីនេះទៀត កំហុសរបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃលើភាពផ្ទុយគ្នានៃសក្ខីកម្មដាក់បន្ទុក កាន់តែធ្ងន់ធ្ងរទៅទៀត ពីព្រោះខ្លួនមិនបានពិចារណាលើការដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញខ្លួននៅចំពោះមុខ មានឱកាសអានចម្លើយពីមុនៗរបស់ពួកគេឡើងវិញ ដើម្បីរំឭកការចងចាំ។ នៅក្នុងការពិនិត្យរបស់ខ្លួន តុលាការកំពូលត្រូវតែគិតអំពីកំហុសអង្គហេតុដែលកំណត់ដោយមេធាវីការពារក្តី។

---

[363] តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩០ លេខ ៨៩-៨៧១៧០។ តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩២ លេខ ៩១-៨៣១៦៥។ តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៩ លេខ ៨៨-៨៣៨៦០។

[364] តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៣៤ ព្រឹត្តិប័ត្រព្រហ្មទណ្ឌលេខ ១៧៩។ តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥១ ព្រឹត្តិប័ត្រព្រហ្មទណ្ឌលេខ ២៨ - តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៥៧ ព្រឹត្តិប័ត្រព្រហ្មទណ្ឌលេខ ២៨៥។ អត្ថបទសរសេរដោយលោក Michel REDON, *សាលាឧក្រិដ្ឋ គោលការណ៍គ្រឹះនៃកិច្ចពិភាក្សាដេញដោលនៅក្នុងរឿងក្តីព្រហ្មទណ្ឌ* កថាខណ្ឌ ៤ - *សាក្សី និងអ្នកជំនាញដែលទទួលការអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចពិភាក្សាដេញដោល* ក*ម្រងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ Dalloz ឆ្នាំ២០១៨*។

[365] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Lubanga* សំណុំរឿងលេខ ICC-01/04-01/06 (សេចក្តីសម្រេចទាក់ទងនឹងការប្រតិបត្តិសម្រាប់ត្រៀមរៀបចំ និងជួយសម្រួលដល់សាក្សីមុនពេលឡើងផ្តល់សក្ខីកម្មក្នុងពេលជំនុំជម្រះ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ៤១។

## ផ្នែកទី ១២. សំអាងហេតុនៃការនិយាយកុហក

២៥៣. ក្នុងការបញ្ជាក់ពីក្របខ័ណ្ឌរបស់ខ្លួន សម្រាប់ពិនិត្យពិចារណាលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ អង្គជំនុំជម្រះបានពន្យល់ថា ខ្លួននឹងគិតអំពី "អត្ថិភាពជាយថាហេតុនៃចេតនាលាក់កំបាំងរបស់បុគ្គលពាក់ព័ន្ធ"[366] និងអំពី "អត្ថិភាពនៃធាតុផ្សំសម្រាប់គាំទ្រសក្ខីកម្ម និងកាលៈទេសៈនានានៃរឿងក្តី"[367]។ នៅក្នុងការវាយតម្លៃរបស់ខ្លួនអំពីភាពអាចទុកចិត្តបាននៃសក្ខីកម្មរបស់សាក្សីជាបន្ទាប់មកទៀត អង្គជំនុំជម្រះបានលើកឡើងថា ខ្លួននឹងព្យាយាមស្វែងយល់ថា "តើមានបណ្ដឹងតវ៉ាពាក់ព័ន្ធនឹងភាពលម្អៀងជាយថាហេតុរបស់ម្ចាស់សក្ខីកម្ម ឬប្រភព ឬបុព្វហេតុរបស់ម្ចាស់សក្ខីកម្មដែរឬទេ[368] ក៏ដូចជា "អត្ថិភាពនៃភាពលម្អៀងដែលកើតចេញបំណងមិនចង់និយាយដាក់បន្ទុកខ្លួនឯង មិនចង់ដាក់ខ្លួនឯងនៅក្នុងស្ថានភាពអាម៉ាស់ ឬចង់ការពារមនុស្សទីបី"[369]។ លើសពីនេះទៀត អង្គជំនុំជម្រះបានរំឭកថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់សក្ខីកម្មនៅក្នុងសវនាការ មិនតម្រូវឱ្យស្បថនោះទេ[370] និងថា សាក្សីត្រូវបានគេជូនដំណឹងអំពីសិទ្ធិរបស់ពួកគេក្នុងការបដិសេធផ្ដល់សក្ខីកម្មដែលអាចដាក់បន្ទុកលើខ្លួនឯង ហើយពួកគេបានទទួលជំនួយពីមេធាវី ក្នុងករណីចាំបាច់[371]។ ការសន្និដ្ឋានទាំងនេះបង្ហាញថា ក្នុងកាលៈទេសៈខ្លះ សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចនិយាយកុហកនៅក្នុងសវនាការ ដោយសារហេតុផលផ្ទាល់ខ្លួន។ យើងអាចពិចារណាថាវាជាអនុសាធមួយនៃសិទ្ធិមិននិយាយដាក់បន្ទុកខ្លួនឯង ដែលត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ[372]។ ដោយយល់ឃើញថាវិធានការទាំងនេះមិនគ្រប់គ្រាន់ដើម្បីស្វែងរកការពិតបាន តុលាការ និងការិយាល័យសហព្រះរាជអាជ្ញា បានបង្កើតលិខិតបញ្ជាក់ធានាមិនចោទប្រកាន់សាក្សី

---

[366] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៩។

[367] សំអាងហេតុសាលក្រម កថាខណ្ឌ៥៣។

[368] សំអាងហេតុសាលក្រម កថាខណ្ឌ៦១។

[369] សំអាងហេតុសាលក្រម កថាខណ្ឌ៦២។

[370] សំអាងហេតុសាលក្រម កថាខណ្ឌ៤៩។

[371] សំអាងហេតុសាលក្រម កថាខណ្ឌ៥០។

[372] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤.២ ឆ។

តាំងពីសំណុំរឿង ០០២/០១[373]។ ទោះយ៉ាងនេះក្តី ជាច្រើនលើកច្រើនសា អង្គជំនុំជម្រះបានប្រើស្តង់ដាពីរចំពោះសំអាងហេតុនៃការនិយាយកុហក អាស្រ័យតាមសក្ខីកម្មដាក់បន្ទុក ឬដោះបន្ទុករបស់សក្សី[374] ។ ពុំមានការផ្តល់យុត្តិកម្មណាមួយឡើយទៅលើការអនុវត្តស្តង់ដារពីរនេះ ដោយសារមានការធានារឹងមាំពីសំណាក់តុលាការ តាមរយៈវិញ្ញាបនប័ត្រធានាមិនចោទប្រកាន់សាក្សី។ ដូច្នេះ រាល់ការសន្និដ្ឋានដែលអនុវត្តស្តង់ដាពីរសម្រាប់សំអាងហេតុនៃការនិយាយកុហក ត្រូវទុកជាមោឃៈ។

## ផ្នែកទី ១៣. បុរេវិនិច្ឆ័យវប្បធម៌

២៥៤. អង្គជំនុំជម្រះបានបញ្ជាក់ថា នៅពេលវាយតម្លៃភាពអាចជឿជាក់បានរបស់សាក្សី ខ្លួន "នឹងស្របតាមការសម្រេចរបស់ចៅក្រមខ្មែរដែលជាសមាជិក ដើម្បីចៀសវាងការបកស្រាយខុសដោយមូលហេតុបុរេវិនិច្ឆ័យវប្បធម៌"[375]។ មេធាវីការពារក្តីយល់ស្របខ្លះៗជាមួយវិធីសាស្ត្រនេះ ព្រោះវាជារឿងធម្មតាដែលចៅក្រមត្រូវតែមានកាតព្វកិច្ចនេះ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ ក៏ប៉ុន្តែ មេធាវីការពារក្តីសូមកត់សម្គាល់ថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយអនុវត្តក្របខ័ណ្ឌនេះ តែដើម្បីវាយតម្លៃភាពជឿជាក់របស់សាក្សីប៉ុណ្ណោះ។ ជាក់ស្តែង ក្នុងផ្នែកសំអាងហេតុទាំងមូលនៃសាលក្រម អង្គជំនុំជម្រះបានលើកឡើងយ៉ាងវែងអំពីអំពីបរិបទដែលខ្លួនគិតថាចាំបាច់បំផុតដើម្បីក្តាប់បានអំពីអង្គហេតុ និងបានប្រើបរិបទនោះ ដើម្បីកំណត់ប្រភេទបទល្មើសចំពោះឧក្រិដ្ឋកម្ម។

២៥៥. យើងគួរកត់សម្គាល់ថា ចៅក្រមជិតដាមទៅដោយបុរេវិនិច្ឆ័យវប្បធម៌ ព្រោះថា នៅពេលនិយាយអំពីជីវភាពរស់នៅ និងអំពីអនាម័យនៅទីតាំងការដ្ឋានទំនប់ត្រពាំងថ្ម ចៅក្រមបានកំណត់ថា "តែងតែមានរុយជាច្រើនរោមម្ហូបអាហារ"[376]។ ក៏ប៉ុន្តែ តាមពិតទៅ មិនថានៅទីក្រុង ឬទីជនបទទេ នេះជាតថភាព

---

[373] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ និងសេចក្តីបំភ្លឺរបស់កម្មាភិបាលដែលត្រូវគេផាត់ចេញទាំងទទឹងទិស ដោយហេតុថាកម្មាភិបាលទាំងនោះ "មាននិន្នាការបន្ថយការទទួលខុសត្រូវរបស់ខ្លួន" កថាខណ្ឌ ១១៩៤-១១៩៥ និងកំណត់សម្គាល់ជើងទំព័រលេខ២២៣៣ ជាមួយនឹងឧទាហរណ៍នឹងការធានាមិនចោទប្រកាន់លើកម្មាភិបាលមួយចំនួន។

[374] សូមមើលខាងក្រោម កថាខណ្ឌ ១១៩៤-១១៩៥, ១២៣៣-១២៤២។

[375] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២។

[376] សំអាងហេតុសាលក្រម កថាខណ្ឌ ១២៩៨ កំណត់សម្គាល់ជើងទំព័រលេខ៤៦៤៨។

ធម្មតាមួយនៅក្នុងប្រទេសកម្ពុជា អាស្រ័យទៅតាមរដូវកាល និងអាកាសធាតុ។ លើសពីនេះទៅទៀត លក្ខណៈខុសគេនៃសាលាក្តីនេះ ក្រៅពីលក្ខណៈកូនកាត់ គឺស្ថិតនៅត្រង់យុត្តាធិការនៃពេលវេលាដ៏យូរលង់ដែលអង្គជំនុំជម្រះត្រូវជំនុំជម្រះ។ ចៅក្រមត្រូវវិនិច្ឆ័យអង្គហេតុដែលបានកើតឡើងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ នេះគឺជាការលំបាកសម្រាប់ចៅក្រមជាតិក៏ដូចជាសម្រាប់ចៅក្រមអន្តរជាតិ។ យើងបានកត់សម្គាត់ការលំបាកនេះពាក់ព័ន្ធនឹងបញ្ហានីត្យានុកូលភាព។ ដូច្នេះ ទោះបីចៅក្រមអន្តរជាតិបានប្រគល់បញ្ហានេះទៅឱ្យចៅក្រមជាតិដើម្បីចៀសវាងការបកស្រាយខុសដោយហេតុផលបុរេវិនិច្ឆ័យវប្បធម៌ក៏ដោយ ក៏ទាល់តែចៅក្រមជាតិវាយតម្លៃអង្គហេតុទាំងនេះ ដោយផ្អែកលើវប្បធម៌ខ្មែរ នៅសម័យអង្គហេតុ។ ចៅក្រមអន្តរជាតិណាម្នាក់ដែលទទួលយកបេសកកម្មដូច ក្នុងរឿងក្តីនេះ មានកាតព្វកិច្ចជំនះលើបុរេវិនិច្ឆ័យវប្បធម៌ បុគ្គល ឬសញ្ជាតិ និងត្រូវរៀនបើកស្មារតីទូលាយដើម្បីទទួលវិធីសាស្ត្រមួយចំនួនដែលខុសប្លែកខ្លាំងពីការគិតរបស់គាត់[377]។ កាតព្វកិច្ចជម្នះលើបុរេវិនិច្ឆ័យវប្បធម៌នេះមិនមានតែចំពោះ អ.វ.ត.ក និងតុលាការយុត្តិធម៌អន្តរជាតិនោះទេ។ វាក៏ជាកាតព្វកិច្ចរបស់ចៅក្រមជាតិផងដែរ នៅពេលដែលគាត់បំពេញមុខងាររបស់ខ្លួនក្នុងក្របខ័ណ្ឌតុលាការជាតិ។ ក្រមសីលធម៌វិជ្ជាជីវៈរបស់ចៅក្រមបារាំងក៏មានចែងអំពីកាតព្វកិច្ចនេះ ដោយផ្សារភ្ជាប់វាជាមួយឯករាជ្យភាពរបស់ចៅក្រម។ ចំណុច ក.៣ នៃក្រម នេះចែងដូចតទៅ៖ "ចៅក្រមត្រូវតែដឹងជ្រួតជ្រាបអំពីផលប៉ះពាល់នៃបុរេវិនិច្ឆ័យ វប្បធម៌ និងសង្គមរបស់គាត់ ក៏ដូចជាជំនឿនយោបាយ ទស្សនវិជ្ជា ឬជំនឿសាសនារបស់គាត់ ទៅលើការយល់ដឹងអំពីអង្គហេតុដែលខ្លួនបានទទួល និងលើការបកស្រាយវិធានច្បាប់របស់គាត់"[378]។ ដូច្នេះ ចៅក្រមអន្តរជាតិត្រូវពឹងផ្អែកលើចៅក្រមជាតិដើម្បីស្វែងយល់ និងចៀសវាងការបកស្រាយខុស ដោយសារបុរេវិនិច្ឆ័យវប្បធម៌ ដើម្បីវាយតម្លៃភាពជឿជាក់របស់សាក្សី និងវាយតម្លៃលើបរិបទដែល ជះឥទ្ធិពលលើវិចារណកិច្ចរបស់អង្គជំនុំជម្រះទៅលើការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ។ ដូច្នេះ ការវាយតម្លៃរបស់ចៅក្រមជាតិដើម្បីចៀសវាងការបកស្រាយ ខុសដោយហេតុផលបុរេវិនិច្ឆ័យវប្បធម៌ មិនត្រូវអនុវត្តតែចំពោះការវាយតម្លៃភាពជឿជាក់របស់សាក្សីប៉ុណ្ណោះទេ តែត្រូវអនុវត្តផងដែរចំពោះការយល់ដឹងអំពីអង្គហេតុ អំពីបរិបទប្រទេសកម្ពុជានៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩

---

[377] អត្ថបទសរសេរដោយលោក Régis DE GOUTTES *ជំនុំជម្រះនៅទីផ្សេង ជំនុំជម្រះរបៀបផ្សេង - ចៅក្រមជាតិ និងច្បាប់អន្តរជាតិ ។ សក្ខីកម្មនៃចៅក្រមបារាំងមួយរូប* កម្រងសៀវភៅ Les cahiers de la Justice ឆ្នាំ២០១៧ ទំព័រ ៤៩៧។

[378] កម្រងកាតព្វកិច្ចនៃក្រមសីលធម៌វិជ្ជាជីវៈនៃចៅក្រមបារាំង។ អាចចូលអានបានក្នុងវែបសាយ៖ http://www.conseil-superieur-magistrature.fr/publications/recueil-des-obligations-deontologiques/lindependance

ដែលអាចនាំទៅដល់ ការបកស្រាយអំពីវិធានច្បាប់សមស្រប ដោយមិនផ្អែកលើចក្ខុវិស័យសហសម័យលម្អៀង។

២៥៦. យើងគួរគប្បីកត់សម្គាល់ថា គោលការណ៍ទាំងនេះមិនត្រូវបានអនុវត្តនៅក្នុងសំអាងហេតុសាលក្រមឡើយ។ ប្រាកដណាស់ គេអាចរកឃើញឧទាហរណ៍ជាក់ស្តែងបំផុត នៅក្នុងសេចក្តីសន្និដ្ឋានស្តីពីអាពាហ៍ពិពាហ៍ ដែលអង្គជំនុំជម្រះមិនត្រឹមតែរំលោភគោលការណ៍នីត្យានុកូលភាពប៉ុណ្ណោះទេ តែថែមទាំងបានបិទបាំងបរិបទសង្គមវប្បធម៌ ទាំងថៅក្រមអន្តរជាតិ ទាំងថៅក្រមជាតិ[379]។

### ជំពូកទី ៣. កំហុសលើប្រភេទភ័ស្តុតាងមួយចំនួនជាពិសេស

### ផ្នែកទី ១. ចម្លើយ/សៀវភៅរបស់ ខៀវ សំផន

២៥៧. ទាក់ទងទៅនឹងចម្លើយ និងសំណេររបស់ ខៀវ សំផន អង្គជំនុំជម្រះបានកំណត់ ក្របខ័ណ្ឌវាយតម្លៃផ្សេងៗ។ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្ម សៀវភៅ ឬឯកសារចេញពីជនជាប់ចោទទាំងមូលដែលត្រូវយកមកគិតជាមួយ "ស្នាដៃស្រាវជ្រាវ" របស់សាក្សីជាអ្នកជំនាញ បង្កើតបានជាតារាង លម្អិតមួយសម្រាប់អំឡុងពេលមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[380]។ ទាក់ទងនឹង "សក្ខីកម្ម" របស់ ខៀវ សំផន អង្គជំនុំជម្រះយល់ឃើញថា គាត់បាន "ផ្តល់ការបំភ្លឺមួយដ៏មានប្រយោជន៍អំពីអង្គហេតុនានាដែលបានកើតឡើងមុនសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបានគិតពិចារណាលើការបំភ្លឺនេះ ដោយភាពប្រុងប្រយ័ត្នចាំបាច់ និងដោយធានាឱ្យប្រាកដថាសំដី ខៀវ សំផន ពិតជាត្រូវបានបញ្ជាក់គាំទ្រដោយភ័ស្តុតាងផ្សេងៗទៀត"[381]។ បន្ទាប់មកទៀត ទាក់ទងនឹងសៀវភៅរបស់ម្ចាស់បណ្តឹងសាទុក្ខដែលមានចំណងជើងថា *"ការពិចារណាលើប្រវត្តិសាស្ត្រកម្ពុជាចាប់ពីដំណាក់កាលដំបូងៗ រហូតមកដល់សម័យកម្ពុជាប្រជាធិបតេយ្យ"* អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនផ្អែកលើសៀវភៅនេះ "តែក្នុងកម្រិតតិចតួចប៉ុណ្ណោះ" ដោយកត់សម្គាល់ថា សៀវភៅនេះយោងជាច្រើនទៅសំណេររបស់លោក Philip SHORT និងអ្នកនិពន្ធដទៃ

---

[379] សូមមើលខាងក្រោម កថាខណ្ឌ ១១៤០-១១៤៤, ១១៥៧-១១៦២។

[380] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩២។

[381] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៤។

ទៀត[382]។ នៅចុងបញ្ចប់ អង្គជំនុំជម្រះបានបញ្ជាក់ថា ដើម្បីវាយតម្លៃភាពជឿជាក់ទូទៅនៃរឿងរ៉ាវប្រវត្តិសាស្ត្រ ខ្លួនបានស្វះស្វែងរកឱ្យឃើញថា “តើអត្ថបទទាំងនេះមានការបញ្ជាក់គាំទ្រដោយឯកសារសហសម័យ និងភ័ស្តុតាងផ្សេងៗទៀតដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដែរឬទេ”[383]។ អង្គជំនុំជម្រះបានបន្ថែមថា ខ្លួន “បានផ្តល់តម្លៃខ្លាំងជាពិសេសដល់ចម្លើយក្នុងសវនាការ និងឯកសារបានពីអ្នកនិពន្ធដែលត្រូវបានសាកសួរលើចំណុចប្រវត្តិសាស្ត្រពាក់ព័ន្ធក្នុងអំឡុងពេលជំនុំជម្រះ ឬដល់សៀវភៅរបស់ពួកគាត់ដែលត្រូវបានយកមកពិភាក្សាសួរដេញដោលក្នុងសវនាការដោយភាគីនានា”[384]។ ទោះយ៉ាងនេះក្តី អង្គជំនុំជម្រះបាននិយាយជាន់កែងខ្លួនឯង នៅក្នុងផ្នែកសំអាងហេតុរបស់ខ្លួន និងបានបំភ្លៃបំប្លែងចម្លើយ ឬឯកសាររបស់ ខៀវ សំផន ឬប្រើប្រាស់វាសម្រាប់តែដាក់បន្ទុក[385]។

### ផ្នែកទី ២. ធាតុផ្សំភ័ស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម

២៥៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ក្នុងការវាយតម្លៃអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម ស្តីពីការប្រើប្រាស់ភ័ស្តុតាងបានមកពីការធ្វើទារុណកម្ម ជាពិសេសភ័ស្តុតាងបានមកដោយខុសច្បាប់ (១) អញ្ញត្រកម្មនៃ វិធានស្តីពីការហាមឃាត់ ស្របតាមមាត្រា ១៥ (២) និងការប្រើប្រាស់កំណត់ត្រាសួរចម្លើយ និងបញ្ជីរបស់អ្នកសួរចម្លើយនៃមន្ទីរសន្តិសុខ (៣)។ ទោះបីកំហុសអង្គច្បាប់នេះបានត្រឹមតែធ្វើមោឃភាពសេចក្តីសន្និដ្ឋានមួយចំនួនក្នុងសំអាងហេតុសាលក្រមក៏ដោយ ក៏ចំណាប់អារម្មណ៍ទូទៅលើបញ្ហាអង្គច្បាប់សម្រាប់ជាយុត្តិសាស្ត្ររបស់ អ.វ.ត.ក តម្រូវដាច់ខាតឱ្យតុលាការកំពូលសម្រេចលើបញ្ហាអង្គច្បាប់នេះដែរ[386]។ ជាការពិត ការហាមឃាត់អំពើទារុណកម្មចំណុះឱ្យនិយាមអន្តរជាតិដាច់

[382] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៤។

[383] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៥។

[384] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៥។

[385] សូមមើលខាងក្រោម កថាខណ្ឌ ១២៤៤, ១៣៩៥-១៣៩៨, ១៥២៦-១៥៤០។

[386] សាលដីកា *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ២២។ សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២៤៧។

ខាត ហៅថា jus cogens។ ក៏ប៉ុន្តែ យុត្តិសាស្ត្រមិនដាច់ខាតដែលអង្គជំនុំជម្រះជ្រើសរើសយក បង្កការប៉ះពាល់ខ្លាំងដល់បម្រាមនេះ។

## ១. ភស្តុតាងបានមកដោយខុសច្បាប់

២៥៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋានថា "ភស្តុតាងដែលត្រូវបានរកឃើញចេញពីព័ត៌មានទទួលបានដោយការធ្វើទារុណកម្ម អាចអនុញ្ញាតឱ្យប្រើបាន ដរាបណាការប្រើនេះមិនបណ្តាលឱ្យមានការបញ្ចៀសការហាមឃាត់មិនឱ្យប្រើចម្លើយសារភាពបានមកពីការធ្វើទារុណកម្ម ដើម្បីបង្ហាញថាព័ត៌មានក្នុងចម្លើយសារភាពនេះជាការពិត"[387]។ ជំហារនេះដើរផ្ទុយពីបម្រាមដាច់ខាតមិនឱ្យប្រើប្រាស់ភស្តុតាងបានមកពីការធ្វើទារុណកម្ម។ យោងតាមតុលាការកំពូល ផ្នែកដំបូងនៃមាត្រា ១៥ គឺច្បាស់លាស់គ្រប់គ្រាន់ និង "មិនមានចែងពីបម្រាមណាមួយមិនឱ្យប្រើប្រាស់រាល់ព័ត៌មានបានមកពីការធ្វើទារុណកម្ម"[388]។ បម្រាមនេះមិនមែនតែចំពោះចម្លើយសារភាពប៉ុណ្ណោះទេ គឺចំពោះព័ត៌មានផ្សេងៗទៀត ដែលទទួលបានមកពីការធ្វើទារុណកម្មផងដែរ។ តុលាការកំពូលបានពន្យល់ថា បម្រាមនេះធ្វើឡើងដោយផ្អែកលើហេតុផលជាក់ស្តែង ព្រោះថាព័ត៌មានទាំងនេះមិនគួរទុកចិត្តបានទាល់តែសោះ ខណៈដែលអ្នករងទារុណកម្មបានត្រៀមខ្លួននិយាយអ្វីៗទាំងអស់ ដើម្បីកុំឱ្យទទួលរងការឈឺចាប់តទៅទៀត។ ដូច្នេះ ការវិភាគនេះបង្ហាញថាទាំងចម្លើយ ទាំងព័ត៌មានដែលទទួលបានមកពីការធ្វើទារុណកម្មត្រូវតែបានហាមឃាត់៖

> "ទទ្បីករណ៍អំពីភាពមិនគួរឱ្យទុកចិត្តបាននៃភស្តុតាង ដែលទទួលបានមកពីការធ្វើទារុណកម្ម មិនត្រឹមតែអនុវត្តចំពោះចម្លើយសារភាពដែលបានផ្តល់ក្រោមការបង្ខិតបង្ខំប៉ុណ្ណោះទេ គឺថែមទាំងចំពោះរាល់ព័ត៌មានដែលទទួលបានពីបុគ្គលរងការធ្វើទារុណកម្ម បើទោះបីជាបុគ្គលនោះមិនមែនជាភាគីនៃនីតិវិធីដែលត្រូវប្រើព័ត៌មាននោះក៏ដោយ"[389]។

[387] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៥។

[388] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **F26/12** កថាខណ្ឌ ៤០។

[389] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **F26/12** កថាខណ្ឌ ៤២។

២៦១. អង្គជំនុំជម្រះលើកទឡ្ហីករណ៍ថា មាត្រា ១៥ អនុវត្តតែចំពោះចម្លើយដែលទទួលបានដោយការធ្វើទារុណកម្មប៉ុណ្ណោះ។ ហេតុនេះហើយបានជាមាត្រានេះមិនមានចែងអ្វីទាំងអស់អំពីភ័ស្តុតាងចេញមកពីព័ត៌មានដែលទទួលបានដោយការធ្វើទារុណកម្ម។ ទឡ្ហីករណ៍នេះមិនមានមូលដ្ឋានទេ។ ដូចតុលាការព្រហ្មទណ្ឌអន្តរជាតិបានរំឭក នៅក្នុងរឿងក្តី *Lubanga* "[ការដែលអត្ថបទគតិយុត្តិមួយមិនបានចែងអំពីការអនុវត្តណាមួយ]" មិនប្រាកដជាមានន័យថា ការអនុវត្តនេះត្រូវបានអនុញ្ញាតនោះទេ"[390]។

២៦១. អង្គជំនុំជម្រះបានគិតថា វាមានប្រយោជន៍ក្នុងការយោងទៅការងារពង្រាងអនុសញ្ញា។ សំណៅដែលបង្ហាញដោយសមាគមនីតិព្រហ្មទណ្ឌអន្តរជាតិ បានបញ្ចូលបន្ថែមលើចម្លើយសារភាព នូវ "រាល់ធាតុផ្សំភ័ស្តុតាងផ្សេងទៀត ដែលទទួលបានពីព័ត៌មាននៅក្នុងការងារពពង្រាងនេះ"[391]។ សំណៅនេះមិនត្រូវបានអនុម័តយកទេ។ ប្រការនេះគួរតែបង្ហាញឱ្យអង្គជំនុំជម្រះយល់ថា អ្នកតាក់តែងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនមានបំណងបញ្ចូលភ័ស្តុតាងមិនស្របច្បាប់ទាំងនេះទៅក្នុងវិធានបដិសេធភ័ស្តុតាងឡើយ។ ទន្ទឹមនឹងនោះ យោងតាមតុលាការយុត្តិធម៌អន្តរជាតិ៖ "ការដែលអត្ថបទគតិយុត្តិណាមួយមិនត្រូវបានអនុម័តដោយស្ថាប័នអន្តរជាតិ មិនមែនប្រាកដជាមានន័យថា មានសេចក្តីសម្រេចរួមផ្ទុយពីនេះនោះទេ។ ការបដិសេធ ឬការមិនឯកភាពនឹងសំណើណាមួយ តម្រូវឱ្យមានសំអាងហេតុជាច្រើន"[392]។

២៦២. លើសពីនេះទៅទៀត ការយល់ឃើញរបស់អង្គជំនុំជម្រះទំនងជាផ្ទុយពីកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញា។ ដូចដែលបានលើកឡើងដោយតុលាការកំពូល៖

> "រាល់ការបកស្រាយណាមួយអំពីអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ឬផ្នែកសំខាន់ៗនៃអនុសញ្ញានេះ រួមទាំងមាត្រា ១៥ ដែលធ្វើឱ្យចុះខ្សោយដល់ការហាមឃាត់ និងការការពារ

[390] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Lubanga* សំណុំរឿងលេខ ICC-01/04-01/06 (សេចក្តីសម្រេចទាក់ទងនឹងការប្រតិបត្តិសម្រាប់ត្រៀមរៀបចំ និងជួយសម្រួលដល់សាក្សីមុនពេលឡើងផ្តល់សក្ខីកម្មក្នុងពេលជំនុំជម្រះ) ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ៣៦។

[391] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៦៥។

[392] តុលាការយុត្តិធម៌អន្តរជាតិ យោបល់ Namibie, Rec. 1971 ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧១ កថាខណ្ឌ ៦៩។

ប្រឆាំងនឹងការធ្វើទារុណកម្ម គួរតែត្រូវបដិសេធចោល។ លើសពីនេះទៀត ទាក់ទងនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញា គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម បានសង្កត់ធ្ងន់ថា កាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការចាត់វិធានការបង្ការប្រកបដោយប្រសិទ្ធភាព ត្រូវអនុវត្តឱ្យហួសពីអ្វីដែលមានចែងច្បាស់លាស់នៅក្នុងអនុសញ្ញានេះ។ ក្នុងករណីនេះ កម្មវត្ថុ និងគោលបំណងចម្បងនៃមាត្រា ១៥ គឺដើម្បីទប់ស្កាត់ការអនុវត្តទារុណកម្ម ដោយបញ្ចៀសលទ្ធភាពនៃការជំរុញឱ្យប្រើប្រាស់ទារុណកម្ម ដើម្បីទទួលបានព័ត៌មានដែលអាចយកប្រើបាននៅក្នុងនីតិវិធីផ្លូវការណាមួយ”[393]។

២៦៣. អង្គជំនុំជម្រះក៏មិនបានពិចារណាលើសេចក្តីសង្កេតរបស់គណៈកម្មាធិការ ប្រឆាំងនឹងការធ្វើទារុណកម្ម ដែល “ផ្តល់អនុសាសន៍ថា រាល់ចម្លើយដែលទទួលបានដោយផ្ទាល់ ឬដោយប្រយោលតាមរយៈការធ្វើទារុណកម្ម ត្រូវតែបដិសេធមិនឱ្យប្រើជាភ័ស្តុតាងនៅចំពោះមុខតុលាការឡើយ”[394]។ ដូច្នេះ អង្គជំនុំជម្រះគួរតែផ្តល់សារៈសំខាន់ណាមួយដល់សេចក្តីសង្កេត និងរបាយការណ៍របស់គណៈកម្មាធិការនេះ ដែលត្រូវបានទទួលស្គាល់ថាជា “អាជ្ញាគតិ” យោងទៅតាមការយល់ឃើញរបស់តុលាការកំពូល[395]។ ជាការគាំទ្រដល់សំអាងហេតុរបស់ខ្លួនដែល អង្គជំនុំជម្រះយល់ឃើញថា គោលការណ៍ដាក់ភ័ស្តុតាងដោយសេរីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ជាមូលដ្ឋានគាំទ្រដល់ទស្សនៈរបស់ខ្លួន។ ជាក់ស្តែង បើទោះជាគោលការណ៍នេះចែងថាអាចទទួលយកភ័ស្តុតាងដែលបានដោយមធ្យោបាយមិនទៀងត្រង់ ឬមិនស្របច្បាប់ ដូចក្នុងករណីរឿងក្តីនេះក៏ដោយចុះ ក៏គោលការណ៍នេះមិនអនុញ្ញាតឱ្យអង្គជំនុំជម្រះផ្អែកលើគោលការណ៍នេះដើម្បីវិនិច្ឆ័យក្តីដែរ។ លើសពីនេះទៀត អង្គជំនុំជម្រះបានយោងទៅលើ “ប្រភពច្បាប់ផ្សេងៗដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ” ដែលប្រភពទាំងនេះមិន “អាចបង្កើតឱ្យមានឯក

[393] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **F26/12** កថាខណ្ឌ ៤០។

[394] *OHCHR Summary Record of the Public Part of the 279th Meeting Georgia Poland Recommendations*, 21.03.1997, CAT/SR/279 កថាខណ្ឌ ១៥។ *OHCHR Summary Record of the Public Part of the 250th Meeting Finland Recommendations* ខែឧសភា ឆ្នាំ១៩៩៦ CAT/SR/250 កថាខណ្ឌ ១៨។ សូមមើលផងដែរ*OHCHR Report of the Committee Against Torture Annual Sessional Report CAT*, 16.09.1998, 53/44 ‘1998 CAT Report’ 27 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[395] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **F26/12** កថាខណ្ឌ ៣៩។

ភាពគ្នាជាផ្លូងមួយលើសំណួរសួរថា តើវិសាលភាពនៃវិធានបដិសេធភ័ស្តុតាងបានដោយការធ្វើទារុណកម្មនេះ គ្របដណ្តប់ដល់ភ័ស្តុតាងមួយចំនួននៅក្នុងព័ត៌មានដែលទទួលបានដោយការធ្វើទារុណកម្មដែរឬទេ និងមិនអាចកំណត់លក្ខខណ្ឌបានថា តើករណីលើកលែងនេះ អាចត្រូវយកមកអនុវត្តបាន ក្នុងកាលៈទេសៈណាខ្លះ"[396]។ ទោះយ៉ាងណាក្តី ក្នុងរឿងក្តីទាំងបួនដែលលើកឡើងដោយអង្គជំនុំជម្រះគោលជំហររបស់ចៅក្រមទាំងអស់ សុទ្ធតែប្រឆាំងការប្រើភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។

២៦៤. ក្នុងរឿងក្តី *Gäfgen ទល់នឹងរដ្ឋអាល្លឺម៉ង់* តុលាការជាន់ខ្ពស់បានពិចារណាថា ការប្រើប្រាស់ភ័ស្តុតាងនៅក្នុងព័ត៌មានដែលប្រមូលបានដោយការប្រព្រឹត្តអំពើអមនុស្សធម៌ ប៉ះពាល់ដល់សមធម៌នៃនីតិវិធី ប្រសិនបើការប្រើប្រាស់នេះជះឥទ្ធិពលលើការផ្តន្ទាទោស ឬការដាក់ទោស[397]។ លើសពីនេះទៀត ភ័ស្តុតាងដែលទទួលបានពីការធ្វើបាបទាំងនេះ ត្រូវតែទទួលបានពីប្រភពផ្សេងៗទៀត ដើម្បីឱ្យនីតិវិធីមានភាពយុត្តិធម៌។ យុត្តិសាស្ត្រនេះមិនគាំទ្រការប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មនោះទេ។ លើសពីនេះទៀត នៅក្នុងរឿងក្តីយើងនេះ វាជាការប្រព្រឹត្តអំពើអមនុស្សធម៌។ ក៏ប៉ុន្តែ សាលដីកាមួយទៀតរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបលើកឡើងថា ការប្រើប្រាស់ភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម ឬភ័ស្តុតាងខុសច្បាប់ ប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌។ រីឯចំពោះការប្រព្រឹត្តផ្សេងទៀតក្រៅពីការធ្វើទារុណកម្ម គប្បីត្រូវតែបង្ហាញថាការប្រើប្រាស់ភ័ស្តុតាងបានមកពីការប្រព្រឹត្តទាំងនេះ ជះឥទ្ធិពលទៅលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធី ពោលគឺវាជះឥទ្ធិពលទៅលើសាលក្រមផ្តន្ទាទោស ឬការដាក់ទោសដែលបណ្តាលឱ្យការជំនុំជម្រះមិនប្រកបដោយយុត្តិធម៌[398]។

២៦៥. តុលាការកំពូលក៏បានធ្វើការវិភាគផងដែរលើយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ក្នុងនោះរួមមានសាលដីកា *Gäfgen ទល់នឹង រដ្ឋអាល្លឺម៉ង់* ដោយផ្តល់ការពន្យល់ថា ការប្រើប្រាស់ភ័ស្តុតាងបានពីការធ្វើទារុណកម្ម ធ្វើឱ្យនីតិវិធីទាំងមូលមិនយុត្តិធម៌ ទោះបីវាសំខាន់ចាំបាច់ ឬមិនចាំបាច់ដល់ការ ចេញ

---

[396] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៦៥-៦៨ ដែលយោងទៅរឿងក្តី *Gäfgen ទល់នឹងប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) *Jalloh ទល់នឹងប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) *Cabrera Garcia និង Montiel Flores ទល់នឹងប្រទេសម៉ិកស៊ិក* (CIDH) និង *Mthembu ទល់នឹងរដ្ឋ* (តុលាការកំពូលអាហ្វ្រិកខាងត្បូង)។

[397] សេចក្តីសម្រេច ចុះថ្ងៃទី៥ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៦៦។

[398] សាលដីកា *El Haski ទល់នឹងប្រទេសបែលហ្ស៊ិក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ៨៥។

សាលក្រមផ្តន្ទាទោសប្រឆាំងនឹងជនជាប់ចោទក្តី[399]។ ជាក់ស្តែង សាលដីកា *Gäfgen* មានខ្លឹមសារច្បាស់លាស់ បើយើងអានវាទាំងស្រុង។ ក្នុងរឿងក្តីនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានដាក់ចេញនូវគោលការណ៍បដិសេធរាល់ភស្តុតាងដែលទទួលបានដោយការធ្វើបាប៖

> "ការប្រើប្រាស់ភស្តុតាងដែលទទួលបាន តាមរយៈការរំលោភលើសិទ្ធិមួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានដែលជាស្នូលនៃអនុសញ្ញានេះ រមែងបង្កភាពមន្ទិលសង្ស័យយ៉ាងខ្លាំងអំពីភាពត្រឹមត្រូវនៃនីតិវិធី បើទោះបីការទទួលយកវាជាភស្តុតាងមិនចំបាច់ដាច់ខាតសម្រាប់ ការផ្តន្ទាទោសជនសង្ស័យក៏ដោយ"។ អាស្រ័យហេតុនេះ តុលាការបានសន្និដ្ឋានអំពីចម្លើយសារភាពបែបនេះថា ការទទួលយកអង្គហេតុពាក់ព័ន្ធជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ចេញមកពីចម្លើយដែលទទួលបានដោយអំពើទារុណកម្ម [...] ឬការធ្វើបាបដទៃទៀតដែលហាមឃាត់ដោយមាត្រា ៣ [...] បណ្តាលឱ្យនីតិវិធីទាំងមូលមិនមានយុត្តិធម៌។ តុលាការនេះបានបន្ថែមទៀតថា វាប៉ះពាល់ដល់ភាពយុត្តិធម៌នៃនីតិវិធី ដោយមិនអាស្រ័យលើតម្លៃជាភស្តុតាងនៃចម្លើយ ឬលើភាពចាំបាច់ក្នុងការទទួលយកវាជាភស្តុតាងសម្រាប់សម្រេចផ្តន្ទាទោស ដែលប៉ះពាល់ដល់ម្ចាស់បណ្តឹងសាទុក្ខនោះឡើយ (ibidem)។ ទាក់ទងទៅនឹងការប្រើប្រាស់ក្នុងការជំនុំជម្រះនូវភស្តុតាងជាក់ស្តែង ដែលប្រមូលបានតាមរយៈការរំលោភបំពានដោយផ្ទាល់លើមាត្រា ៣ តុលាការបានពិចារណាថា ភស្តុតាងដាក់បន្ទុកជាក់ស្តែងដែលប្រមូលបានដោយប្រើអំពើហិង្សា ឬអំពើទាំងឡាយណាដែលអាចចាត់ទុកថាជាការធ្វើទារុណកម្ម ត្រូវតែហាមឃាត់មិនឱ្យប្រើដើម្បីបង្ហាញពីពិរុទ្ធភាពរបស់ជនរងគ្រោះនៃអំពើនេះ ទោះបីជាវាមានតម្លៃជាភស្តុតាងប៉ុនណាក៏ដោយ។ សេចក្តីសន្និដ្ឋានណាមួយផ្សេងទៀតបានត្រឹមតែផ្តល់ភាពស្របច្បាប់ដោយប្រយោល ទៅដល់ការប្រព្រឹត្តិប្រាសចាកពីសីលធម៌ដែលអ្នកតាក់តែងមាត្រា ៣ នៃអនុសញ្ញាបានព្យាយាមហាមឃាត់ ឬនិយាយម្យ៉ាងទៀត គឺបានត្រឹមតែ "ផ្តល់រូបភាពស្របច្បាប់ទៅដល់ភាពសាហាវឃោរឃៅប៉ុណ្ណោះ [...]។ ក៏ប៉ុន្តែ តុលាការពិចារណាថា នៅក្នុងនីតិវិធីព្រហ្ម

[399] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **F26/12** កថាខណ្ឌ ៤៣ ដែលដកស្រង់ពីសាលដីកាផ្សេងៗនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប៖ សាលដីកា *Gäfgen ទល់នឹងប្រទេសអាល្លឺម៉ង់* កថាខណ្ឌ ១៦៥-១៦៦ សាលដីកា *Desde ទល់នឹងប្រទេសទួរគី* កថាខណ្ឌ ១២៥-១២៦ សាលដីកា *Othman ទល់នឹងចក្រភពអង់គ្លេស* កថាខណ្ឌ ២៦៣-២៦៧។

ទណ្ឌ ការប្រើប្រាស់ចម្លើយដែលទទួលបានតាមរយៈការរំលោភលើមាត្រា ៣ - ទោះការបំពាននេះជាការធ្វើទារុណកម្មក្តី ឬជាអំពើអមនុស្សធម៌ ឬអំពើប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្សក្តី - ក៏ដូចជាការប្រើប្រាស់ភស្តុតាងជាក់ស្តែងដែលប្រមូលបានដោយផ្ទាល់ពីការធ្វើទារុណកម្ម -ធ្វើឱ្យដំណើរការនីតិវិធីទាំងមូលបាត់បង់យុត្តិធម៌ និងរំលោភលើមាត្រា ៦ (ibidem)”[400]។

២៦៦. តុលាការគូសបញ្ជាក់ពីហានិភ័យនៃការលើកទឹកចិត្តដល់រដ្ឋនានាឱ្យប្រើវិធីសាស្ត្រស៊ើបអង្កេតបែបនេះ ដែលរំលោភលើមាត្រា ៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (បម្រាមអំពើទារុណកម្ម) ប្រសិនបើភស្តុតាងនេះត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់៖

“តុលាការនេះមិនអាចគ្រាន់តែធានាការការពារអាយុជីវិតមនុស្ស ឬការផ្តន្ទាទោសព្រហ្មទណ្ឌ ដោយធ្វើឱ្យអន្តរាយដល់ការការពារសិទ្ធិដាច់ខាតមិនឱ្យគេធ្វើបាប ស្របតាមបម្រាមនៃមាត្រា ៣។ បើមិនដូច្នោះទេ យើងនឹងលះបង់គុណតម្លៃទាំងនេះ និងធ្វើឱ្យបាត់បង់ទំនុកចិត្តលើរដ្ឋបាលយុត្តិធម៌”[401]។

២៦៧. អង្គជំនុំជម្រះក៏បានដកស្រង់រឿងក្តី *Jalloh ទល់នឹងរដ្ឋអាល្លឺម៉ង់*[402]។ ក៏ប៉ុន្តែ រឿងក្តីនេះក៏ជំទាស់ផងដែរនឹងការប្រើប្រាស់ភស្តុតាងបានមកដោយខុសច្បាប់។ ជាក់ស្តែង មានការវិនិច្ឆ័យថា “ការប្រើប្រាស់ជាភស្តុតាងនូវគ្រឿងញៀនដែលប្រមូលបានតាមរយៈការចាប់បញ្ចូកថ្នាំក្អួតទៅលើម្ចាស់បណ្តឹង បានធ្វើឱ្យការជំនុំជម្រះទាំងមូលរបស់គាត់បាត់បង់យុត្តិធម៌”[403]។ ទោះបីជាអង្គជំនុំជម្រះបានពិចារណាថាវាគ្រាន់តែជាការកត់សម្គាល់ចៃដន្យ និងបន្ទាប់បន្សំរបស់ចៅក្រម ក្នុងរឿងក្តី *Cabrera Garcia និង Montiel Flores ទល់នឹងប្រទេសម៉ិកស៊ិក* ក៏ដោយ ក៏ចៅក្រមគណៈកម្មាធិការសិទ្ធិមនុស្សអន្តរអាមេរិក

---

[400] សាលដីកា *Gäfgen ទល់នឹងប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ១៦៥-១៦៧ និង ១៧៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[401] សាលដីកា *Gäfgen ទល់នឹងប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ១៧៧។

[402] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៦៦ កំណត់សម្គាល់ជើងទំព័រលេខ ១៣១។

[403] សាលដីកា *Jalloh ទល់នឹងប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ១០៨។

បានបញ្ជាក់ជំហរយ៉ាងច្បាស់ថា ខ្លួនមិនអនុញ្ញាតឱ្យប្រើប្រាស់ភ័ស្តុតាងបានមកពីការធ្វើទារុណកម្មឡើយ[404]។ ជំហរនេះគឺស្របនឹងគោលជំហររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប។ ដូច្នេះ យើងមិនយល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះងាកចេញពីគោលជំហរនេះ។

២៦៨. នៅក្នុងរឿងក្តី *Mthembu ទល់នឹងរដ្ឋ* តុលាការកំពូលអាហ្វ្រិកខាងត្បូងក៏បានវិនិច្ឆ័យផងដែរថា វិធានស្តីពីការបដិសេធភ័ស្តុតាងដែលមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គ្របដណ្តប់លើរាល់ភ័ស្តុតាងបានមកដោយខុសច្បាប់។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះយល់ឃើញថា ចៅក្រមមិនបដិសេធភ័ស្តុតាងបែបនេះទាំងស្រុងទេ "ប្រសិនបើវាអាចត្រូវទទួលបានពីប្រភពមួយដែលមិនមានទំនាក់ទំនងជាមួយនឹងការអនុវត្តអំពើទារុណកម្ម ឬប្រសិនបើវាអាចត្រូវបានរកឃើញដោយចៀសមិនផុតដដែល"[405]។ ដូច្នេះ គោលជំហរតុលាការកំពូលអាហ្វ្រិកខាងត្បូង គាំទ្រស្មារតីមាត្រា ១៥ ដែលមិនអនុញ្ញាតឱ្យប្រើភ័ស្តុតាងបានមកដោយខុសច្បាប់។

២៦៩. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋានថាយុត្តិសាស្ត្រអន្តរជាតិពុំមានលក្ខណៈដូចគ្នា និងពុំមានវិធាននៃច្បាប់ទម្លាប់អន្តរជាតិណាមួយអនុញ្ញាតឱ្យពង្រីកវិសាលភាពនៃមាត្រា ១៥ រហូតដល់ភ័ស្តុតាងបានមកដោយខុសច្បាប់ នោះឡើយ។ យុត្តិសាស្ត្រមួយចំនួនតូចដែលខ្លួនបានលើកឡើងគាំទ្រការហាមឃាត់មិនឱ្យប្រើប្រាស់ភ័ស្តុតាងទាំងនេះទៅវិញទេ ហើយវាសមហេតុផល ពីព្រោះថាមាត្រា ១៥ ដាក់បម្រាមយ៉ាងច្បាស់មិនឱ្យប្រើប្រាស់ចម្លើយដែលទទួលបានពីការធ្វើទារុណកម្ម។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះគួរតែចោទសួរខ្លួនឯងថា តើមាននិយាមច្បាប់ទំនៀមទំលាប់អន្តរជាតិណាមួយដែលអនុញ្ញាតឱ្យប្រើភ័ស្តុតាងបានមកដោយមធ្យោបាយខុសច្បាប់ដែរឬទេ ហើយមិនត្រូវសួរថាតើនិយាមនេះហាមឃាត់ខ្លួនមិនឱ្យប្រើវាដែរឬទេ នោះទេ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះអសមត្ថភាពក្នុងការដកស្រង់ប្រភពច្បាប់អន្តរជាតិណាមួយ ដែលអនុញ្ញាតជាក់ស្តែងឱ្យប្រើប្រាស់ភ័ស្តុតាងទាំងនេះ។

---

[404] សេចក្តីសម្រេច ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៦៧។

[405] សេចក្តីសម្រេច ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៦៨។

២៧០. ដូច្នេះ ការសម្រេចរបស់អង្គជំនុំជម្រះក្នុងការប្រើភស្តុតាងបានមកដោយមធ្យោបាយខុសច្បាប់ មានន័យថាបានមកពីព័ត៌មានផ្ទាល់ទទួលបានមកពីអំពើទារុណកម្ម ដើរផ្ទុយពីគោលបំណង និងកម្មវត្ថុនៃអនុសញ្ញា អនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម ព្រមទាំងផ្ទុយពីសេចក្តីសម្រេចរបស់តុលាការកំពូល យុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប យុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអន្តរអាមេរិក និងតុលាការកំពូលនៃអាហ្វ្រិកខាងត្បូង។ ប្រសិនបើមានការសង្ស័យដ៏តូចណាមួយទាក់ទងនឹងការបកស្រាយវិធានច្បាប់នេះ អង្គជំនុំជម្រះគួរតែអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវតែជាប្រយោជន៍របស់ជនចោទ[406]។

## ២. អញ្ញត្រកម្មនៃវិធានបដិសេធភស្តុតាង

២៧១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយពិចារណាថា "ព័ត៌មានក្នុងចម្លើយមួយបានមកពីការធ្វើទារុណកម្ម អាចប្រើប្រាស់បានដើម្បីគោលបំណងមួយផ្សេងទៀត ក្រៅពីគោលបំណងបង្ហាញពីការពិតនៃព័ត៌មាននៅក្នុងចម្លើយនោះ។ ទោះយ៉ាងណាក្តី គេត្រូវប្រើព័ត៌មានទាំងនោះដើម្បីសម្រេចគោលបំណងតែមួយគត់ គឺបង្ហាញពីសកម្មភាពទាំងឡាយដែលបានកើតឡើងបន្ទាប់ពីចម្លើយត្រូវបានធ្វើរួច"[407]។ ការបកស្រាយនេះគឺជាការរំលោភលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ដែលចែងថា៖

> "រដ្ឋភាគីនីមួយៗត្រូវធានាថា រាល់ចម្លើយណាមួយដែលទទួលបានពីការធ្វើទារុណកម្ម មិនអាចយកមកប្រើជាភស្តុតាងនៅក្នុងដំណើរការនីតិវិធីបានទេ លើកលែងតែក្នុងករណីប្រើប្រាស់វាប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម ដើម្បីបង្ហាញថាចម្លើយមួយត្រូវបានធ្វើឡើង"[408]។

---

[406] សំអាងហេតុសាលក្រម កថាខណ្ឌ ២១។

[407] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៧។

[408] អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ មាត្រា១៥។

២៧២. ដូច្នេះ អញ្ញត្រកម្មតែមួយគត់ចំពោះបម្រាមដាច់ខាតមិនឱ្យប្រើប្រាស់ភ័ស្តុតាងដែលទទួលបាពីការធ្វើទារុណកម្ម គឺការបង្ហាញថាចម្លើយមួយត្រូវបានធ្វើឡើង។ អង្គជំនុំជម្រះបានរំឭកចំណុចនេះខ្លួនឯងផ្ទាល់ នៅក្នុងសេចក្តីសម្រេចមួយរបស់ខ្លួនទាក់ទងនឹងភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម៖

> "ពាក្យពេចន៍មានខ្លឹមសារច្បាស់លាស់នៃមាត្រា ១៥ ស្តីពីអញ្ញត្រកម្ម បង្ហាញថា បទប្បញ្ញត្តិទាំងនេះត្រូវតែបកស្រាយយ៉ាងតឹងរ៉ឹង។ ជាក់ស្តែង បទប្បញ្ញត្តិនេះចែងថា ចម្លើយនេះអាចប្រើប្រាស់បានតែក្នុងករណីមួយគត់ គឺដើម្បីបង្ហាញថា "ចម្លើយមួយត្រូវបានធ្វើឡើង"[409]។

២៧៣. ដូច្នេះ អង្គជំនុំជម្រះគួរចញ្ចប់ការវិភាគរបស់ខ្លួនត្រង់នេះ។ កាលណាខ្លឹមសារនៃសន្ធិសញ្ញាមួយមានភាពច្បាស់លាស់ និងមិនផ្ទុយពីកម្មវត្ថុ និងគោលបំណងរបស់វាទេ គេមិនចាំបាច់ស្វែងរកការបកស្រាយផ្សេងទៀតនោះទេ។ ជាក់ស្តែង យោងតាមតុលាការយុត្តិធម៌អន្តរជាតិ៖

> "កាតព្វកិច្ចចម្បងបំផុតរបស់តុលាការដែលត្រូវបានស្នើសុំឱ្យបកស្រាយ និងអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញាមួយ គឺត្រូវព្យាយាមអនុវត្តវាឱ្យមានប្រសិទ្ធភាព យោងទៅតាមអត្ថន័យធម្មជាតិ និងធម្មតានៃបទប្បញ្ញត្តិទាំងនេះ នៅក្នុងបរិបទរបស់វា។ នៅពេលផ្តល់អត្ថន័យធម្មជាតិ និងធម្មតាទៅដល់ពាក្យពាក់ព័ន្ធ ប្រសិនបើពាក្យទាំងនេះមានអត្ថន័យនៅក្នុងបរិបទរបស់វា ការពិនិត្យបកស្រាយត្រូវតែបញ្ចប់ត្រឹមនេះ"[410]។

២៧៤. ប៉ុន្តែ ដើម្បីអាចឱ្យខ្លួនបកស្រាយអត្ថបទគតិយុត្តិនេះ អង្គជំនុំជម្រះបានបង្កើតភាពស្រពិចស្រពិលមួយ។ អង្គជំនុំជម្រះបានយល់ឃើញថា "មាត្រានេះមិនបានបញ្ជាក់ថា តើចម្លើយមួយអាចត្រូវបានប្រើប្រាស់តាមរបៀបណា និងក្នុងគោលបំណងអ្វីឡើយ" ហើយដូច្នេះ វាចាំបាច់ត្រូវយោងទៅ "គោលបំណងនៃ

---

[409] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៧២។

[410] យុត្តាធិការនៃមហាសន្និបាតក្នុងការអនុម័តរដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ មតិពិគ្រោះយោបល់ (តុលាការយុត្តិធម៌អន្តរជាតិ) ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥០ ទំព័រ ៨។ សូមមើលផងដែរ ការកំណត់ព្រំប្រទល់សមុទ្រ និងបញ្ហាទឹកដី សាលដីកា (តុលាការយុត្តិធម៌អន្តរជាតិ) ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ទំព័រ ១៩។

មាត្រា ១៥ ទាំងមូល និងសារបាននៃការតាក់តែងមាត្រានេះ"[411]។ ក៏ប៉ុន្តែ ដូចដែលតុលាការកំពូលបាន កត់សម្គាល់ មិនមានភាពស្រពិចស្រពិលណាមួយនៅក្នុងអត្ថបទគតិយុត្តិនេះទេ៖

> "អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខ្លឹមសារនៃមាត្រា ១៥ មានលក្ខណៈច្បាស់លាស់ គ្រប់គ្រាន់ដើម្បីអាចអនុវត្តបទប្បញ្ញត្តិនេះបាន ដោយមិនចាំបាច់ឆ្លងច្បាប់ផ្តល់សម្បទា"[412]។

២៧៥. អញ្ញត្រកម្មនេះចែងអំពីលទ្ធភាពលើកយកចម្លើយមួយ មកប្រើជាភស្តុតាងប្រឆាំងនឹងបុគ្គលម្នាក់ដែល ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើទារុណកម្ម តែដើម្បីបញ្ជាក់ថាចម្លើយបែបនេះត្រូវបានធ្វើឡើង។ នេះគឺជាអ្វីដែលលោកស្រីចៅក្រម Fenz បានចង្អុលបង្ហាញនៅក្នុងមតិជំទាស់របស់គាត់៖

> "ពាក្យពេចន៍មានភាពច្បាស់លាស់ ទាំងលើប្រភេទមនុស្ស ពោលគឺអ្នកដែលត្រូវបានចោទ ប្រកាន់ថាបានធ្វើទារុណកម្ម និងការប្រើប្រាស់ (គោលបំណង) ជាភស្តុតាងបញ្ជាក់ថាចម្លើយ នោះត្រូវបានធ្វើឡើង។ និយាយម៉្យាងទៀត ការប្រើប្រាស់ចម្លើយបែបនេះត្រូវបានអនុញ្ញាត តែ ដើម្បីបញ្ជាក់ពីអត្ថិភាពរបស់វា (ឬដើម្បីបញ្ជាក់ថាចម្លើយនោះត្រូវបានធ្វើឡើងក្រោមការធ្វើ ទារុណកម្ម)"[413]។

២៧៦. អង្គជំនុំជម្រះថែមទាំងបានដើរផ្ទុយពីយុត្តិសាស្ត្ររបស់តុលាការកំពូល ដោយបានពិចារណាខុសថា នៅ ក្នុងសេចក្តីសម្រេច F26/12 របស់ខ្លួន តុលាការកំពូលមិនបានបកស្រាយអញ្ញត្រកម្មនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាទេ[414]។ ផ្ទុយទៅវិញ ប្រឈមមុខនឹងទឡ្ហីករណ៍ស្រដៀងគ្នារបស់សហព្រះរាជអាជ្ញាអំពី ការពង្រីកការប្រើប្រាស់ចម្លើយដែលទទួលបានពីការធ្វើទារុណកម្ម ក្នុងគោលបំណងចោទប្រកាន់ជា ចាំបាច់ តុលាការកំពូលបានឆ្លើយតបថា៖

---

[411] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៧២។

[412] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **F26/12** កថាខណ្ឌ ៣៥។

[413] មតិជំទាស់ដោយផ្នែករបស់ចៅក្រម Fenz ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E350/8.1** កថាខណ្ឌ ១៥។

[414] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៣។

"វិធានបដិសេធភ័ស្តុតាងមិនគាំទ្រការបកស្រាយរបស់សហព្រះរាជអាជ្ញានោះទេ។ កម្មវត្ថុ និង គោលបំណងនៃមាត្រា ១៥ ចែងអំពីការបដិសេធជាទូទៅនៃរាល់ព័ត៌មានបានមកពីការធ្វើទារុណកម្ម ដោយហេតុថាអញ្ញត្រកម្មនៃវិធាននេះ ត្រូវតែបកស្រាយក្នុងន័យចង្អៀត។ អ្វីដែលពិសេសជាងនេះទៅទៀត គឺអង្គជំនុំជម្រះតុលាការកំពូលបានគោរពតាមយុត្តិសាស្ត្រខាងលើដែលចែងថា ភាពចាំបាច់នៃការចោទប្រកាន់មិនមែនជាសំអាងហេតុត្រឹមត្រូវនៃការប្រើប្រាស់ចម្លើយដែលទទួលបានពីការធ្វើទារុណកម្មនោះទេ ទោះក្នុងករណីដែលភាគីស្នើសុំការប្រើប្រាស់នេះ មិនមែនជាអ្នកទទួលខុសត្រូវលើទារុណកម្មក៏ដោយ"[415]។

២៧៧. អង្គជំនុំជម្រះបានងាកចេញពីគោលជំហររបស់តុលាការកំពូល ដោយបកស្រាយមាត្រា ១៥ ស្របតាមអនុសាសន៍របស់សហព្រះរាជអាជ្ញា។ ការបកស្រាយនេះមិនអាចមានមូលដ្ឋានគាំទ្រឡើយ តាមរយៈការសិក្សាលើសារបាននៃការតាក់តែងអនុសញ្ញានេះ (២.១) ឬលើគោលបំណង និងកម្មវត្ថុរបស់វា (២.២)[416]។

## ២.១. សារបាននៃអនុសញ្ញា

២៧៨. អង្គជំនុំជម្រះគ្រាន់តែបានបញ្ជាក់ថា សំណៅដំបូងនៃមាត្រា ១៥ មិនអនុញ្ញាតឱ្យមានអញ្ញត្រកម្មណាមួយ ចំពោះបម្រាមមិនឱ្យប្រើប្រាស់ចម្លើយបានមកពីការធ្វើទារុណកម្មនោះទេ ប៉ុន្តែថា បទប្បញ្ញត្តិមួយត្រូវបានបន្ថែម ក្នុងអំឡុងពេលតាក់តែងអត្ថបទច្បាប់ដែលអនុញ្ញាតឱ្យប្រើប្រាស់ភ័ស្តុតាងបែបនេះដើម្បីចោទប្រកាន់លើជនជាប់ចោទ[417]។ ពិតមែនតែអង្គជំនុំជម្រះបញ្ជាក់ថា បទប្បញ្ញត្តិនេះអនុញ្ញាតឱ្យមានការបកស្រាយ "យ៉ាងទូលំទូលាយ" ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានវិភាគឱ្យស៊ីជម្រៅលើសារបាននៃការតាក់តែងអនុសញ្ញាឡើយ។ ទោះយ៉ាងនេះក្តី យើងដឹងថាសារបាននេះផ្តល់ព័ត៌មានច្រើនជាងនេះបន្តិចទៀត។ វាប្រាកដណាស់ថា ក្នុងមាត្រាដែលបានធ្វើវិសោធនកម្ម មានបន្ថែមនូវបទប្បញ្ញត្តិមួយ

[415] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ F26/12 កថាខណ្ឌ ៦៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[416] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៧២។

[417] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៧៣។

ដែលបើកឱ្យប្រើភស្តុតាងនេះក្នុងគោលបំណងចោទប្រកាន់លើអ្នកធ្វើទារុណកម្មតាមការសន្មត ប៉ុន្តែបទប្បញ្ញត្តិនេះត្រូវបានបដិសេធចោលដោយត្រឹមត្រូវ ដើម្បីរឹតត្បិតការប្រើប្រាស់ភស្តុតាងទាំងនេះមកត្រឹមតែអញ្ញត្រកម្មដែលយើងរាល់គ្នាដឹង[418]។ បទប្បញ្ញត្តិទូលំទូលាយ ដែលអនុញ្ញាតឱ្យប្រើប្រាស់ដោយគ្មានការរឹតត្បិត នូវភស្តុតាងទាំងនេះប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ថាជាអ្នកធ្វើទារុណកម្ម ដូចអង្គជំនុំជម្រះបានលើកឡើង មានចែងដូចតទៅ៖ *"រដ្ឋភាគីនីមួយៗត្រូវធានាថា ចម្លើយណាមួយដែលត្រូវបានរកឃើញថាកើតចេញពីការធ្វើទារុណកម្ម មិនត្រូវបានអនុញ្ញាតឱ្យយកមកប្រើជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែក្នុងករណីប្រើប្រឆាំងអ្នកដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម ដើម្បីទទួលចម្លើយនេះ"*។

២៧៩. ប៉ុន្តែនៅទីបញ្ចប់ មាត្រា ១៥ ត្រូវបានអនុម័តដូចតទៅ៖ *"រដ្ឋភាគីនីមួយៗត្រូវធានាថា រាល់ចម្លើយណាដែលត្រូវបានរកឃើញថាជាលទ្ធផលនៃការធ្វើទារុណកម្ម មិនត្រូវបានអនុញ្ញាឱ្យយកមកធ្វើជាភស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែក្នុងករណីប្រើដើម្បីប្រឆាំងនឹងបុគ្គលម្នាក់ដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម និងដើម្បីបញ្ជាក់ថាចម្លើយនេះត្រូវបានធ្វើឡើង"*។

២៨០. ដូច្នេះ អ្នកតាក់តែងអនុសញ្ញានេះ បានពិចារណាលើលទ្ធភាពនៃការប្រើប្រាស់ដោយគ្មានដែនកំណត់ នូវរាល់ភស្តុតាងទទួលបានពីការធ្វើទារុណកម្ម ដើម្បីប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម។ ប៉ុន្តែ នៅទីបំផុត លទ្ធភាពនេះមិនត្រូវបានអនុម័តយកទេ។ ដូច្នេះ ឆន្ទៈចង់រឹតត្បិតការប្រើចម្លើយបានមកពីការធ្វើទារុណកម្មមកត្រឹមករណីតែមួយគត់ ត្រូវបានពិចារណាយ៉ាងប្រុងប្រយ័ត្ន[419]។ នេះគឺជាអ្វីដែលអង្គជំនុំជម្រះគួរតែគោរព ជាជាងបង្កើតការបកស្រាយថ្មីមួយផ្ទុយពីខ្លឹមសារ និងស្មារតីនៃអត្ថបទស្តីពីការពង្រីកលទ្ធភាពនៃការប្រើប្រាស់ភស្តុតាងបានមកពីការធ្វើទារុណកម្ម។

---

[418] *Report of Working Group on Draft Convention Against Torture and Other Cruel Inhuman or Degrading Treatment or Punishment* ឯកសារ E/CN.4/1367 ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៨០ កថាខណ្ឌ ៨២-៨៤។

[419] *Application of Amnesty international, the international commission of jurists and the redress trust to present an* amicus curiae *submission pursuant to internal rule 33* ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D130/9/15.4 កថាខណ្ឌ ៣១-៣៤។

## ២.២. គោលបំណង និងកម្មវត្ថុនៃអនុសញ្ញា

២៨១. បន្ទាប់មក អង្គជំនុំជម្រះបានយោងលើគោលបំណង និងកម្មវត្ថុនៃអនុសញ្ញានេះ ដោយពិចារណាថា គោលបំណងនៃបម្រាមការប្រើប្រាស់ភ័ស្តុតាងបានមកពីការធ្វើទារុណកម្ម គឺ ដើម្បី "រារាំងមិនឱ្យផ្អែកលើភ័ស្តុតាងទាំងនោះ ដើម្បីទាញយកអត្ថប្រយោជន៍ណាមួយ ដោយហេតុថាគោលបំណងចុងក្រោយបំផុត គឺទប់ស្កាត់ការប្រើប្រាស់អំពើទារុណកម្ម"[420]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វានឹងធ្វើឱ្យ "គោលបំណងនេះបរាជ័យ ប្រសិនបើក្នុងអំឡុងពេលចោទប្រកាន់លើអ្នកទទួលខុសត្រូវចំពោះអំពើទារុណកម្ម ភ័ស្តុតាងបែបនេះត្រូវបានហាមឃាត់មិនឱ្យប្រើ ព្រោះថា ទង្វើនេះនឹងផ្តល់ភាពអនុគ្រោះដល់បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនេះ"។ ការកត់សម្គាល់នេះមិនត្រឹមត្រូវទាល់តែសោះ។ អង្គជំនុំជម្រះបានយល់ជ្រួតជ្រាបច្បាស់ណាស់ថា "ការប្រើប្រាស់ភ័ស្តុតាងបែបនេះ" មិនត្រូវបានហាមឃាត់ទាំងស្រុងនោះទេ។ អ្នកតាក់តែងអនុសញ្ញាបានគិតយ៉ាងល្អិតល្អន់អំពីក្តីកង្វល់របស់ខ្លួន។ ហេតុដូច្នេះហើយបានជាពួកគាត់ដាក់បញ្ចូលក្នុងផ្នែកទី ២ នៃមាត្រា ១៥ នូវលទ្ធភាពផ្អែកលើ "ភ័ស្តុតាងបែបនេះ" ប្រឆាំងនឹងអ្នកដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម។ ទន្ទឹមនឹងនោះ អ្នកតាក់តែងបានដាក់ដែនកំណត់មួយលើការប្រើប្រាស់នេះ គឺថា ចម្លើយមួយអាចត្រូវបានអនុញ្ញាតឱ្យប្រើប្រឆាំងនឹងបុគ្គលនេះ តែក្នុងបំណងបញ្ជាក់ថាចម្លើយមួយត្រូវបានធ្វើឡើង។ ដូច្នេះ ខ្លឹមសារនៃមាត្រា ១៥ ពិតជាគោរពតាមគោលបំណង និងកម្មវត្ថុនៃអនុសញ្ញា ដោយហេតុថា អញ្ញត្រកម្មនៃមាត្រានេះអនុញ្ញាតឱ្យទប់ស្កាត់ការប្រើប្រាស់ទារុណកម្ម។ អង្គជំនុំជម្រះគួរតែមានភាពប្រាកដក្នុងចិត្តថា ការអនុវត្តយ៉ាងតឹងរ៉ឹងនៃមាត្រា ១៥ មិនអនុញ្ញាតឱ្យអ្នកទទួលខុសត្រូវចំពោះអំពើទារុណកម្ម អាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។

២៨២. អង្គជំនុំជម្រះក៏បានពិចារណាផងដែរថា មាត្រា ១៥ មានគោលបំណង "ការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ជាពិសេសតាមរយៈបម្រាមមិនឱ្យប្រើប្រាស់ភ័ស្តុតាងដែលមិនអាចជឿទុកចិត្តបាន"។ មេធាវីការពារក្តីមិនជំទាស់នឹងចំណុចនេះទេ។ ប៉ុន្តែ បើទោះជាវាច្បាស់ណាស់ថា ខ្លឹមសារនៃភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្មមិនគួរទុកចិត្តបានក៏ដោយ ក៏វាមិនមែនជាហេតុផល

[420] សេចក្តីសម្រេច ចុះថ្ងៃទី ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៧៥។

តែមួយគត់ ដែលថាគេមិនអាចយកវាមកប្រើក្នុងកិច្ចដំណើការនីតិវិធីនោះដែរ។ ដូច្នេះ វាជាការត្រឹមត្រូវក្នុងការពិចារណាថា បម្រាមការប្រើប្រាស់ភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម រារាំងមិនឱ្យភាគីព្យាយាមបង្ហាញថាខ្លឹមសាររបស់វាជាការពិត។ ម្យ៉ាងទៀត វាមិនមានន័យថា ខ្លឹមសារនៃភ័ស្តុតាងទាំងនេះ អាចត្រូវបានប្រើក្នុងគោលបំណងផ្សេងទៀត ដូចដែលអង្គជំនុំជម្រះចង់ឱ្យគេជឿនោះទេ[421]។ ជាថ្មីម្តងទៀត មាត្រា ១៥ ចែងពីអញ្ញត្រកម្មតែមួយគត់ប៉ុណ្ណោះ គឺបង្ហាឱ្យឃើញថាចម្លើយមួយត្រូវបានធ្វើឡើង។ ពុំមានចែងអំពីការប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតនោះទេ។

២៨៣. អង្គជំនុំជម្រះចង់ប្រើខ្លឹមសារនៃចម្លើយទាំងនេះដើម្បី "បញ្ជាក់អំពីសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងការតាក់តែងឡើងនូវចម្លើយផ្ទុកព័ត៌មានទាំងនេះ"។ ដូច្នេះ អង្គជំនុំជម្រះមានបំណងប្រើប្រាស់ខ្លឹមសារនៃចម្លើយទាំងនេះ ដើម្បីបង្ហាញអំពី "ការចាប់ខ្លួន គោលនយោបាយ ឬដំណើរការនៃការបោសសម្អាត"[422]។ តាមរយៈទង្វើនេះ អង្គជំនុំជម្រះលែងគោរពតាមខ្លឹមសារនៃមាត្រា ១៥ ដែលអនុញ្ញាតឱ្យមានអញ្ញត្រកម្មចំពោះការប្រើប្រាស់ភ័ស្តុតាងទាំងនេះប្រឆាំងនឹងជនទាំងឡាយ ដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម ក្នុងគោលបំណងធានាថាជនទាំងនោះមិនអាចគេចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ក៏ប៉ុន្តែ ដោយមានបំណងបង្ហាញពីអត្ថិភាពនៃការចាប់ខ្លួន គោលនយោបាយ ឬដំណើរការនៃការបោសសម្អាត យើងងាកចេញពីដែនអញ្ញត្រកម្មនេះ ដើម្បីកាត់សេចក្តីជនដែលត្រូវបានចោទប្រកាន់ពីអង្គហេតុផ្សេងៗទៀត។

២៨៤. សូមឱ្យយើងច្បាស់លាស់ទាំងអស់គ្នាថា តាមរយៈការបន្ថែមលទ្ធភាពប្រើប្រាស់ភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម មាត្រា ១៥ លែងមានអញ្ញត្រកម្មតែមួយទៀតហើយ គឺមានអញ្ញត្រកម្មមួយចំនួន។ នេះជាការជាក់ស្តែង ប្រសិនបើយើងប្រៀបធៀបអញ្ញត្រកម្មទៅនឹងវិធានបដិសេធភ័ស្តុតាង (មាត្រា ១៥ នៃអនុសញ្ញា)៖

[421] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៧៥។

[422] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៧៥។

**- ចម្លើយមួយដែលទទួលបានពីការធ្វើទារុណកម្ម អាចត្រូវប្រើជាមូលដ្ឋានប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម ដើម្បីបញ្ជាក់ថាចម្លើយមួយត្រូវបានធ្វើឡើង។**

២៨៥. ចំណែកអ្វីដែលអង្គជំនុំជម្រះគិតថាខ្លួនត្រូវបានអនុញ្ញាតឱ្យធ្វើ៖

**- ចម្លើយមួយដែលទទួលបានពីការធ្វើទារុណកម្ម អាចត្រូវបានប្រើជាមូលដ្ឋានប្រឆាំងនឹងអ្នកដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម ប្រសិនបើវាមានគោលបំណងផ្សេងក្រៅពីការបញ្ជាក់ពីភាពពិតនៃព័ត៌មានដែលមានក្នុងចម្លើយនេះ ក្នុងគោលបំណងតែមួយគត់គឺបញ្ជាក់ពីសកម្មភាពនៃការតាក់តែងឡើងនូវចម្លើយដែលផ្ទុកមានព័ត៌មានទាំងនេះ។**

២៨៦. អង្គជំនុំជម្រះបានចាកចេញពីតួនាទីរបស់ខ្លួន។ អង្គជំនុំជម្រះមិនបានបកស្រាយទេ ប៉ុន្តែបានបង្កើតច្បាប់។ ក្នុងហេតុផលនេះហើយបានជាមេធាវីក្រុម Fenz បានជំទាស់យ៉ាងត្រឹមត្រូវនឹងការបកស្រាយរបស់ថៅក្រុមភាគច្រើននេះ[423]។ នៅចុងបញ្ចប់ អង្គជំនុំជម្រះបានអះអាងថា "វិធានបដិសេធភ័ស្តុតាងនេះមានគោលបំណងថែរក្សាសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធីផងដែរ ដោយរារាំងអង្គជំនុំជម្រះមិនឱ្យផ្តល់ភាពស្របច្បាប់ណាមួយទៅដល់ការប្រើអំពើដ៏សាហាវដើម្បីទទួលបានចម្លើយទាំងនេះ"[424]។ ដូច្នេះអង្គជំនុំជម្រះយល់ឃើញថា របៀបដែលខ្លួនចង់ប្រើភ័ស្តុតាងទាំងនេះ គោរពសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងអនុញ្ញាតឱ្យ "វាយតម្លៃបានពេញលេញលើចរិតឧក្រិដ្ឋរងការចោទប្រកាន់"។ ចរិតឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងមាត្រា ១៥ គឺពាក់ព័ន្ធនឹងអំពើទារុណកម្ម។ ក៏ប៉ុន្តែ បើផ្អែកលើកថាខណ្ឌមុន អង្គជំនុំជម្រះក៏ចង់បង្ហាញអំពីចរិតឧក្រិដ្ឋផ្សេងៗទៀតដែរ។ ដើម្បីបង្ហាញអំពីអង្គហេតុនៃការធ្វើទារុណកម្ម ខ្លឹមសារនៃចម្លើយមិនមានប្រយោជន៍សម្រាប់អង្គជំនុំជម្រះទេ។ ការទទួលយក និងការប្រើភ័ស្តុតាងទាំងនេះជាមូលដ្ឋាន ជាការគ្រប់គ្រាន់ ក្នុងការបញ្ជាក់បានថាចម្លើយមួយត្រូវបានធ្វើឡើងក្រោមការធ្វើទារុណកម្ម។

---

[423] មតិជំទាស់ដោយផ្នែករបស់ថៅក្រុម ១១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E350/8.1** កថាខណ្ឌ ៣-១១។

[424] សេចក្តីសម្រេច ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៧៦។

២៨៧. **សេចក្ដីសន្និដ្ឋាន៖** អង្គជំនុំជម្រះបានផ្ដល់យុត្តិកម្មពីភាពត្រឹមត្រូវនៃការប្រើប្រាស់ខ្លឹមសារនៃភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម ដើម្បីគោលបំណងស្របច្បាប់។ ស្របពេលដែលអង្គជំនុំជម្រះសំអាងលើចេតនាមួយដ៏គួរឱ្យស្ងើចសរសើរ (គឺអនុញ្ញាតឱ្យមានកាត់ទោសអ្នកធ្វើទារុណកម្ម) យើងមិនអាចធ្វើអ្វីក្រៅពីលើកឡើងពីក្ដីកង្វល់របស់ Lord Bingham នៅចំពោះមុខសភាជាន់ខ្ពស់ថា៖

> "ការប្រើប្រាស់ភស្តុតាងទាំងនេះដែលទទួលបានពីការធ្វើទារុណកម្ម រំលោភលើសិទ្ធិរបស់ភាគី និងប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដើរផ្ទុយពីមនសិការតុលាការ បំពាន និងបំផ្លាញវិធាននីតិវិធី ព្រមទាំងរុញច្រានរដ្ឋឱ្យធ្លាក់ទៅក្នុងសភាពស្មោកគ្រោកខាងសីលធម៌"[425]។

២៨៨. បន្ថែមលើការធានាឱ្យមានយុត្តិធម៌ និងការផ្សះផ្សាជាតិ អ.វ.ត.ក មានតួនាទីផ្ដល់គំរូដល់ប្រព័ន្ធយុត្តិធម៌កម្ពុជា ក៏ដូចជាផ្ទេរជំនាញដល់បុគ្គលិកកម្ពុជា[426]។ អ្វីដែលសំខាន់ប្រាកដនោះ គឺកេរ្តិ៍ដំណែលដែលបន្សល់ទុកដោយយុត្តិសាស្ត្រនៃ អ.វ.ត.ក ពាក់ព័ន្ធនឹងការបកស្រាយអនុសញ្ញាអន្តរជាតិដ៏មានសារៈសំខាន់មួយ ដូចជាអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ដែលប្រទេសកម្ពុជាជាភាគីហត្ថលេខី[427]។ ការបកស្រាយធូរលុងអំពីការប្រើប្រាស់ភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម អាចបើកឱកាសឱ្យអាជ្ញាធរកម្ពុជាប្រើភស្តុតាងបែបនេះ នៅក្នុងតុលាការជាតិដើម្បីគោលបំណងផ្សេងៗទៀត។ សង្គមស៊ីវិលកម្ពុជា និងអន្តរជាតិ បានលើកឡើងពីហានិភ័យនេះ៖ សំណើសុំដាក់សារណារបស់មិត្តតុលាការលើបញ្ហាកេរដំណែល ត្រូវបានដាក់ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងសំណើមួយទៀតត្រូវបានដាក់ដោយគណៈកម្មការអ្នកច្បាប់អន្តរជាតិ នៃអង្គការលើកលែងទោសអន្តរជាតិ និងអង្គការមនុស្សធម៌ *REDRESS Trust*[428]។ បើទោះជាការក្ដីកង្វល់ទាំងនេះត្រូវបានលើកឡើងបន្ទាប់ពីមានសេចក្ដីសម្រេច

---

[425] *A* និងអ្នកផ្សេងទៀត ព្រឹទ្ធសភាចក្រភពអង់គ្លេស ឆ្នាំ២០០៥ UKHL 71, Lord Bingham កថាខណ្ឌ ៣៩។

[426] របាយការណ៍របស់អគ្គលេខាធិកាស្ដីពីការជំនុំជម្រះរឿងក្ដីខ្មែរក្រហម ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤ ឯកសារ អ.ស.ប លេខ A/59/432 កថាខណ្ឌ ២៧។

[427] ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។

[428] *Application of Amnesty International, the International Commission of Jurists and the REDRESS Trust to present an* amicus curiae *submission pursuant to internal rule 33* ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **D130/9/15.4**,

មួយរបស់សហចៅក្រមស៊ើបសួរក៏ដោយ[429] ក៏ក្តីកង្វល់នេះកាន់តែបន្តពុះកញ្ជ្រោលថែមទៀត ដោយសារភ័ស្តុតាងទាំងនេះត្រូវបានប្រើជាក់ស្តែងនៅក្នុងការជំនុំជម្រះក្តី។ ដូច្នេះ តុលាការកំពូលត្រូវតែកែតម្រូវកំហុសអង្គច្បាប់នេះ ហើយច្រោលទោស និងចាត់ទុកជាមោឃៈរាល់ការប្រើប្រាស់ចម្លើយសារភាពដើម្បីគោលបំណងផ្សេងទៀតក្រៅពីបញ្ជាក់ថាចម្លើយមួយត្រូវបានធ្វើឡើង[430]។

## ៣. សៀវភៅកត់ត្រា និងបញ្ជីដែលបានមកពីមន្ទីរសន្តិសុខ

២៨៩. អង្គជំនុំជម្រះបានពិចារណាថា "យើងអាចប្រើឯកសារបែបនេះ [សៀវភៅកត់ត្រា ឬបញ្ជី] ជាមូលដ្ឋានដោយហេតុថាវាមានផ្ទុកព័ត៌មានទាក់ទងនឹងការពិចារណា និងប្រតិកម្មរបស់អ្នកធ្វើទារុណកម្ម គឺអាចប្រើវាបានដរាបណាយើងមិនបានបង្ហាញវាទៅសាក្សី ដើម្បីបញ្ជាក់អំពីការពិតនៃចម្លើយរបស់អ្នករងទារុណកម្ម"[431]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានបញ្ជាក់អំពីករណី "ប្រតិកម្ម" ឬ "ការពិចារណា" របស់អ្នកធ្វើទារុណកម្មទាក់ទងនឹងចម្លើយសារភាពរបស់អ្នករងការសួរចម្លើយឡើយ។ ដោយហេតុថានៅតាមមន្ទីរសន្តិសុខ មនុស្សភាគច្រើនត្រូវបានគេសាកសួរអំពីទំនាក់ទំនង "ជាសន្មត" របស់ពួកគេជាមួយសត្រូវ វាមានភាពទំនងច្រើន ដែលថាអ្នកសួរចម្លើយកត់ត្រាព័ត៌មានអំពីខ្មាំងដែលបានពីចម្លើយសារភាពទាំងនេះ នៅក្នុងសៀវភៅកត់ត្រារបស់ពួកគេ ដោយគ្មានបញ្ជាក់ច្បាស់លាស់ពី អ្នកនិពន្ធនោះទេ។ ចំពោះមុខហានិភ័យនេះ អង្គជំនុំជម្រះគួរតែពិចារណាថា វាមិនគួរឱ្យទុកចិត្តបានឡើយ ក្នុងការ

---

*Application of the CCHR to present an* amicus curiae *submission pursuant to internal rule 33* ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **D/130/9/15.3**។

[429] ដីកាសម្រេចលើការប្រើប្រាស់ភ័ស្តុតាងដែលបានមក ឬដែលអាចបានមកដោយ ការធ្វើទារុណកម្ម ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ **D130/8**។

[430] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៨, ៣៧៥, ១១១៥, ១៣៥៨, ២២៧៤, ២២៧៦, ២២៧៧, ២២៧៩, ២២៨៥-២២៨៦, ២៣០០-២៣០២, ២៣១៣, ២៣២០, ២៣២២, ២៣២៧, ២៥៧៨, ២៦៧០, ២៧១៧, ២៧២០, ២៧២៤, ២៧២៥, ២៧២៩, ២៧៨៨-២៧៩០, ៤២២៨។ ជាពិសេស សូមមើលខាងក្រោម កថាខណ្ឌ ៦៨៦-៧១៨, ១៨៦៧-១៨៦៨។

[430] សេចក្តីសម្រេច ចុះថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៨៧។

[431] សេចក្តីសម្រេច ចុះថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៨៧។

ផ្អែកលើឯកសារបែបនេះ ដែលខ្លឹមសារត្រូវបានបន្ថែមបន្ថយដោយពួកអ្នកសួរចម្លើយ ដែលសួរចម្លើយអ្នកទោសពេញក្នុងរយៈពេលយូរ។

២៩០. ករណីសៀវភៅកត់ត្រានៃមន្ទីរសន្តិសុខក្រាំងតាចាន់ ឆ្លុះបញ្ចាំងពីបញ្ហានេះ។ អង្គជំនុំជម្រះបានប្រើភ័ស្តុតាងសៀវភៅកត់ត្រាម្តងរួចមកហើយ ដើម្បីគាំទ្រអង្គហេតុនៃការជម្លៀសជនជាតិវៀតណាម[432]។ នៅក្នុងសម្រង់ដែលអង្គជំនុំជម្រះបានប្រើ គ្មានអ្វីបញ្ជាក់ជាក់លាក់ណាមួយថា កំណត់ត្រាទាំងឡាយក្នុងសៀវភៅកត់ត្រានេះបានមកពីចម្លើយសារភាពនោះទេ។ ក៏ប៉ុន្តែ វាគ្រាន់តែជាការពិពណ៌នាអំពីសកម្មភាពរបស់មនុស្សជាច្រើន ដែលទំនងជាត្រូវបានឃុំខ្លួននៅក្រាំងតាចាន់។ ដូច្នេះ វាមានហានិភ័យខ្ពស់ដែលថា វាគឺជាព័ត៌មានដែលបានមកពីអ្នកទទួលរងការសួរចម្លើយនៅក្រាំងតាចាន់ ដូច្នេះ វាគឺជាព័ត៌មានទទួលបានការធ្វើទារុណកម្ម។ ម្យ៉ាងវិញទៀត មានការលើកឡើងញឹកញាប់នៅក្នុងកំណត់ត្រាទាំងនេះថា មនុស្សទាំងនេះត្រូវបានគេ "សួរចម្លើយ" ឬបាន "សារភាព"[433]។ ការប្រើប្រាស់ឯកសារទាំងនេះត្រូវតែច្រានចោល ហើយសេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះទាក់ទងនឹងឯកសារទាំងនេះ ត្រូវទុកជាមោឃៈ[434]។

## ផ្នែកទី ៣. ឃោសនាការ

[432] សំអាងហេតុសាលក្រម កថាខណ្ឌ១១១៥។

[433] ប្រវត្តិរូបជនរងគ្រោះនៅក្រាំងតាចាន់ មិនមានចុះកាលបរិច្ឆេទ ឯកសារ E3/5827 ERN 00270855 ("លុះសួរទៅ")។ ERN 00270857 ("សារភាព") ("ពីរដង")។ ERN 00270876 ("អាក្បត់នេះវាបានសារភាពថា៖ អំពើក្បត់វាមានដូចខាងក្រោមនេះ"។ ERN 00270879 ("សារភាព ជាសកម្មភាពក្បត់មានគ្នាបីនាក់")។ ERN 00270880 ("សារភាពថា")។ ERN 00270883 ("យើងបានចាប់មកហើយៗបានសួរចម្លើយវា។ ថាបានត្រូវរ៉ូវជាមួយអាកែវ")។ ERN 00270887 ("អានេះវាសារភាពថា ខ្ជិលធ្វើការណាស់")។ ERN 00270892 ("តាមចម្លើយអាទាំងពីរនាក់ខាងលើ") ("តាមការសួរបញ្ជាក់នូវចម្លើយ អាសេង ពីបញ្ហាឈ្មោះឈៀង")។ ERN 00270895 ("តាមការសាកសួរសាចុះឡើង អាខ្សែរយៈតើដឹងពីណា")។ ERN 00270896 ("សារភាព")។

[434] សូមមើលផងដែរ សំអាងហេតុសាលក្រម កថាខណ្ឌ ២២៧៤ ដែលផ្អែកលើសៀវភៅកំណត់ហេតុរបស់លោក ពៅ ផល្លី នៅមន្ទីរស-២១ ឯកសារ **E3/8368**។

២៩១ យោងតាមសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានកំណត់តម្លៃដែលត្រូវផ្តល់ដល់ភស្តុតាងកើតចេញពីឯកសារឃោសនា។ ដូចតុលាការកំពូលបានកត់សម្គាល់រួចហើយនៅក្នុងសាលដីកាសំណុំរឿង ០០២/០១[435] តុលាការកំពូលបានពិចារណាថា "សក្ខីកម្មដែលធ្វើឡើងក្នុងគោលបំណងឃោសនា អាចទទួលភាពទុកចិត្តបានតិចតួចប៉ុណ្ណោះ"[436]។

២៩២. ដូច្នេះ ឯកសារទាំងនេះត្រូវតែបានវាយតម្លៃដោយប្រយ័ត្នប្រយែងបំផុត ពីព្រោះឯកសារទាំងនេះកើតចេញពីបរិបទសង្គមនយោបាយពិសេសមួយ។ គោលគំនិតឃោសនាគឺផ្អែកលើវោហារសាស្ត្រជាក់លាក់មួយ។ គោលគំនិតឃោសនាអាចឱ្យគេបញ្ចុះបញ្ចូលប្រជាជន បង្រួបបង្រួមពួកគេក្នុងបរិបទសង្គមនយោបាយច្បាស់លាស់មួយ ហើយដែលជារឿយៗ គោលគំនិតឃោសនានេះច្រើនតែប្រាសចាកឆ្ងាយដោយចេតនាពីតថភាព។ វចនានុក្រម LAROUSSE កំណត់និយាមន័យពាក្យ "ឃោសនា" ថាជា "សកម្មភាពជាប្រព័ន្ធដែលជះឥទ្ធិពលទៅលើមតិសាធារណៈ ដើម្បីធ្វើឱ្យទទួលយកគំនិត ឬលទ្ធិមួយចំនួន ជាពិសេសក្នុងវិស័យនយោបាយ ឬសង្គម"[437]។ ដូច្នេះ ការឃោសនាអាចផ្អែកតែទៅលើភាពជាតំណាង ឬចក្ខុវិស័យខុសពីតថភាព ដោយហេតុថាគោលបំណងតែមួយគត់របស់វា គឺដើម្បីបញ្ចុះបញ្ចូល និងបង្រួបបង្រួមក្រុមមួយ ឱ្យដើរតាមលទ្ធិនយោបាយមួយ ដោយមិនអាស្រ័យលើកត្តាសត្យានុម័តិដែលអាចមាននោះទេ។ ដូច្នេះ អ្នកនិពន្ធឯកសារឃោសនាមិនរាយការណ៍អំពីហេតុការណ៍ តាមរបៀបមួយដែលអាចទុកចិត្តបាន និងដោយសត្យានុម័តិឡើយ។ នៅត្រង់នេះ គ្មានអង្គជំនុំជម្រះណាមួយអាចផ្តន្ទាទោសឱ្យលើសពីវិមតិសង្ស័យ ដោយផ្អែកលើឯកសារប្រភេទនេះឡើយ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបាននិយាយជាន់កែងឯង នៅក្នុងសំអាងហេតុរបស់ខ្លួន ដោយខកខានមិនបានអនុវត្តការផ្តល់ភាពគួរឱ្យទុកចិត្តបានតិចតួចចំពោះឯកសារឃោសនា តែបែរជាផ្តល់ន័យត្រង់តាមពាក្យពេចន៍ទៅដល់សុន្ទរកថាឃោសនា នៅពេលដែលត្រូវទាញយកផលប៉ះពាល់អវិជ្ជមានពីពាក្យពេចន៍ដែលប្រើក្នុងសុន្ទរកថាទាំងនេះ។ ករណីសុន្ទរកថារបស់ ខៀវ សំផន អំពីជនជាតិវៀតណាម នៅក្នុងឱកាសប្រារព្ធ

[435] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៨៣។

[436] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥។ សូមមើលផងដែរកថាខណ្ឌ ៤៧២, ៤៧៩។

[437] និយមន័យ នៅក្នុងវចនានុក្រមអនឡាញ LAROUSSE ដែលអាចចូលមើលបានក្នុងវេបសាយ៖ https://www.larousse.fr/dictionnaires/francais/propagande/64344

ពិធីរំឭកខួប ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជាភ័ស្តុតាងជាក់ស្តែង[438]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានច្រានចោលវិធានស្តីពីការស្ម័គ្រចិត្តរៀបការរបស់ស្វាមីភរិយា នៅក្នុងទស្សនាវដីទង់បដិវត្ត ដោយអះអាងថាវាជាការឃោសនានៅក្នុងក្របខ័ណ្ឌនៃទស្សនាវដីបដិវត្ត ក្នុងខណៈដែលវិធាននេះស្ថិតក្នុងចំណោមគោលការណ៍សីលធម៌ទាំង១២ប្រការ ដែលសមាជិកនៃ ប.ក.ក គ្រប់រូបត្រូវតែគោរព[439]។ អង្គជំនុំជម្រះផ្អែកតែលើឯកសារឃោសនាដើម្បីផ្តន្ទាទោស។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ជាច្រើន ហើយការសន្និដ្ឋានបែបនេះត្រូវទុកជាមោឃៈ។

## ផ្នែកទី ៤. សក្ខីកម្មជាលាយលក្ខណ៍អក្សរ

### ១. តម្លៃជាភ័ស្តុតាង

២៩៣. ពាក់ព័ន្ធនឹងតម្លៃជាភ័ស្តុតាងនៃសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលអ្នកនិពន្ធមិនអាចចូលមកផ្តល់បាននៅសវនាការ អង្គជំនុំជម្រះបានបញ្ជាក់ថា "ការគ្មានលទ្ធភាពសួរដេញដោលអ្នកនិពន្ធអំពីភ័ស្តុតាង ឬពិនិត្យមើលប្រភពភ័ស្តុតាង គឺជាការកាត់បន្ថយទម្ងន់នៃភ័ស្តុតាងនោះ"[440]។ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានកំណត់ក្របខ័ណ្ឌបែបនេះរួចហើយ ដោយបានរំឭកជាច្រើនដងថា "ការគ្មានលទ្ធភាពសួរដេញដោលអ្នកនិពន្ធអំពីភ័ស្តុតាង ឬពិនិត្យប្រភពភ័ស្តុតាង គឺជាការបញ្ជាក់ថា គេផ្តល់តម្លៃជាភ័ស្តុតាង និងទម្ងន់តិចតួចដល់ភ័ស្តុតាងនេះ"[441]។

២៩៤. តុលាការកំពូលបានបញ្ជាក់ពីការវិភាគនេះ ដោយចង្អុលបង្ហាញនៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ថា សក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមិនត្រូវបានដាក់ឱ្យសួរដេញដោលចំពោះមុខ ក្នុងសវនាការមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ដូច្នេះ តុលាការកំពូលបានកំណត់ក្របខ័ណ្ឌច្បាស់លាស់ជាងអង្គ

---

438 សូមមើលខាងក្រោម កថាខណ្ឌ ១៥៥១-១៥៦០។

439 សូមមើលខាងក្រោម កថាខណ្ឌ ១១៩៣។

440 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៩។

441 សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៣៤។ សេចក្តីសម្រេច ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E96/7** កថាខណ្ឌ ២១-២២, ២៤-២៥, ២៧, ២៩, ៣៤។ សេចក្តីសម្រេច ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ឯកសារ **E299** កថាខណ្ឌ ១៩។

ជំនុំជម្រះ ដោយប្រកាសថា "សក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សីដែលមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងដែលមិនត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ត្រូវតែទទួលបានតម្លៃជាភ័ស្តុតាងទាបជាងសក្ខីកម្មរបស់សាក្សីដែលបានបង្ហាញខ្លួននៅក្នុងសវនាការ"[442]។ តុលាការកំពូលក៏បានកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះ "មិនបានពន្យល់ក្នុងសាលក្រមសំណុំរឿង ០០២/០១ ថាហេតុអ្វីបានជា ទោះដឹងថាវាមានតម្លៃជាភ័ស្តុតាងតិចតួចបំផុតក៏ដោយ ក៏អង្គជំនុំជម្រះនៅតែអាចប្រើវាជាមូលដ្ឋាននៃការសន្និដ្ឋានហួសពីវិមតិសង្ស័យ ទាក់ទងនឹងហេតុការណ៍ដាច់ដោយឡែកនីមួយៗនៃការសម្លាប់មនុស្ស"[443]។

២៩៥. យោងតាមខ្លឹមសារនៃសាលក្រមរងបណ្តឹងសាទុក្ខនេះ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានត្រឹមតែចង្អុលបង្ហាញសើរៗ ដោយប្រើពាក្យពេចន៍ទូលំទូលាយខ្លាំង អំពីក្របខ័ណ្ឌច្បាប់នេះដែលប៉ះពាល់ដល់គោលការណ៍ចំពោះមុខ។ ជាច្រើនលើកច្រើនសា អង្គជំនុំជម្រះផ្អែកការសន្និដ្ឋានផ្តន្ទាទោសតែទៅលើចម្លើយជាលាយលក្ខណ៍អក្សរដោយមិនយកចិត្តទុកដាក់ក្នុងការផ្តល់សំអាងហេតុឱ្យបានម៉ត់ចត់ ហើយពេលខ្លះដោយមិនបានបញ្ជាក់ថាសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមិនបានមកផ្តល់សក្ខីកម្មក្នុងសវនាការ។ ដូច្នេះ ការសន្និដ្ឋានបែបនេះត្រូវទុកជាមោឃៈ[444]។

## ២. អំពើ និងការប្រព្រឹត្ត

### ២.១. ការបង្ហាញអំពីក្របខ័ណ្ឌច្បាប់មិនត្រឹមត្រូវដែលដាក់ចេញដោយអង្គជំនុំជម្រះ

[442] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៩៦។

[443] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៤៣០៖ "ភ័ស្តុតាងនេះមានតម្លៃទាប ដែលជាការពិតអង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែទទួលស្គាល់ជាទូទៅ ប៉ុន្តែពុំអាចយកប្រើប្រាស់ជាក់ស្តែងបានឡើយ។ ទាក់ទងទៅនឹងភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះសាលាដំបូងពិតជាពុំបានពន្យល់ពីមូលហេតុដែលខ្លួនពិចារណាឃើញថា បើទោះបីជាមានតម្លៃជាភ័ស្តុតាងកម្រិតទាបក៏ដោយ ក៏ខ្លួននៅតែផ្តល់ការយល់ឃើញដោយផ្អែកលើមូលដ្ឋាននេះហួសពីវិមតិសង្ស័យទាក់ទងទៅនឹងហេតុការណ៍មួយៗនៃការសម្លាប់"។

[444] សូមមើលខាងក្រោម កថាខណ្ឌ ៨៦៣-៨៧៣, ៨៩២-៨៩៧, ១០៥៥។

២៩៦. យោងទៅតាមខ្លឹមសារនៃសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានយល់ឃើញថា ខ្លួនអាចប្រកាសទទួលយកបាននូវចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងប្រតិចារឹកសវនាការបានមកពីការជំនុំជម្រះមុនៗកន្លងមក បន្ថែមពីលើសក្ខីកម្មផ្ទាល់មាត់ ឬដើម្បីជំនួសសក្ខីកម្មផ្ទាល់មាត់ទាំងនេះ[445]។ ទាក់ទងនឹងការគ្មានការសួរដេញដោលចំពោះមុខអំពីការប្រើសក្ខីកម្មជាលាយលក្ខណ៍អក្សរជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ អង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួនបានទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ៖ “កាលណាពេលឃើញពីដំបូងភ្លាម ឯកសារទាំងនេះបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពពាក់ព័ន្ធ និងភាពគួរឱ្យទុកចិត្តបាន (រួមបញ្ចូលទាំងយថាភាពរបស់វាផង) និងកាលណាមានសំណើសុំដាក់វាបញ្ចូលទៅក្នុងកិច្ចពិភាក្សា ដើម្បីអាចប្រើវាជាភ័ស្តុតាង <u>លើបញ្ហាដែលមិនទាក់ទងទៅនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ</u>”[446]។

២៩៧. អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា ខ្លួនទទួលយកចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីដែលបានទទួលមរណភាព ឬសាក្សីដែលមិនអាចផ្តល់សក្ខីកម្មនៅក្នុងសវនាការបាន រួមទាំងចម្លើយពាក់ព័ន្ធនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទផងដែរ។ អង្គជំនុំជម្រះបានយល់ស្របថានឹងផ្តល់តម្លៃជាភ័ស្តុតាងតិចតួចបំផុតចំពោះចម្លើយទាំងនេះ ហើយបានលើកឡើងថា “ការផ្តន្ទាទោសមិនអាចផ្អែកទាំងស្រុង ឬដាច់ខាតលើចម្លើយបែបនេះនោះទេ”[447]។ ប៉ុន្តែអ្វីដែលមិនសមហេតុផលនោះ គឺថាបើទោះជាចម្លើយទាំងនេះមានតម្លៃជាភ័ស្តុតាងតិចតួចក្តី “ក៏វានៅតែជាមូលដ្ឋានភ័ស្តុតាងដ៏សំខាន់ដែរ ជាពិសេសនៅក្នុងករណីដែលវាត្រូវបានប្រមូលចងក្រងនៅក្នុងក្របខ័ណ្ឌនៃនីតិវិធីតុលាការ”[448]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានគិតពីតម្លៃទាបបំផុតនៃចម្លើយប្រភេទនេះ តាមរយៈការចេញសេចក្តីសន្និដ្ឋានដែលរំលោភលើគោលការណ៍សួរដេញដោលផ្ទាល់មាត់ និងដែលធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ចំពោះមុខ។ ចៅក្រមបានបញ្ជាក់អំពីមូលហេតុនៃអញ្ញត្រកម្មនេះចំពោះ “វិធាន និងការអនុវត្តពាក់ព័ន្ធជាធរមាន នៅកម្រិតអន្តរជាតិ ដែលអនុញ្ញាតឱ្យចៅក្រមផ្អែកលើចម្លើយ” របស់សាក្សីបី

---

445 សំអាងហេតុសាលក្រម កថាខណ្ឌ ៥១។

446 សំអាងហេតុសាលក្រម កថាខណ្ឌ ៧០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

447 សំអាងហេតុសាលក្រម កថាខណ្ឌ ៧១-៧២។

448 សំអាងហេតុសាលក្រម កថាខណ្ឌ ៧១-៧២។

ប្រភេទ[449]៖ (i) សាក្សីដែលបានទទួលមរណភាព (ii) សាក្សីដែលមិនអាចត្រូវបានរកឃើញ ទោះបីជាមានការប្រឹងប្រែងស្វែងរកក៏ដោយ (iii) សាក្សីដែលអសមត្ថភាពផ្តល់សក្ខីកម្មផ្ទាល់មាត់ ដោយសារតែស្ថានភាពសុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់គាត់[450]។

២៩៨. អង្គជំនុំជម្រះបានពិចារណាថា ខ្លួនអាចផ្អែកលើចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីទាំងបីប្រភេទនេះ ពេលខ្លួនមានជំនឿជឿជាក់ថា "សាក្សីនេះពិតជាមិនទំនេរមែន ហើយភ័ស្តុតាងដែលគ្រោងចង់បាននោះអាចទុកចិត្តបាន លើកលែងតែអង្គជំនុំជម្រះយល់ឃើញថា តម្លៃជាភ័ស្តុតាងនៃភ័ស្តុតាងនេះ ទាបជាងកម្រិតតម្រូវចាំបាច់ឆ្ងាយ ដើម្បីធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌"[451]។ ជាចុងក្រោយ អង្គជំនុំជម្រះបានបញ្ជាក់ថា៖ "ភាពពាក់ព័ន្ធនៃភ័ស្តុតាងនេះជាមួយនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ដូចដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ មិនមែនជាឧបសគ្គផ្ទាល់តែម្តងនោះទេ ប៉ុន្តែវានឹងជះឥទ្ធិពលលើការកំណត់តម្លៃភ័ស្តុតាងនេះ"[452]។ តុលាការកំពូលបានយល់ស្របនឹងការវិភាគនេះ ហើយបានរំឭកក្របខ័ណ្ឌសម្រាប់អនុវត្តអញ្ញត្រកម្មទាំងនេះនៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ដែលមានខ្លឹមសារដូចតទៅនេះ៖

> "ទីមួយ ដោយសារអង្គជំនុំជម្រះសាលាដំបូងអាចមិនមានឱកាសវាយតម្លៃអត្តចរិតរបស់បុគ្គលក្នុងអំឡុងពេលផ្តល់សក្ខីកម្ម និងសួរដេញឱ្យបំភ្លឺលើបញ្ហានានាឡើយ។ ទីពីរ យោងតាមយុត្តិសាស្ត្រដែលគួរអោយជឿជាក់បានរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ការផ្តន្ទាទោសមិនអាចផ្អែកទាំងស្រុង ឬស្ទើរតែទាំងស្រុង ទៅលើចម្លើយរបស់បុគ្គលម្នាក់ ដែលមេធាវីការពារក្តីពុំមានឱកាសសួរដេញដោលឡើយ លើកលែងតែជនជាប់ចោទត្រូវបានផ្តល់លទ្ធភាពគ្រប់គ្រាន់ដើម្បីជំទាស់ប្រកបដោយប្រសិទ្ធភាពទៅនឹងចម្លើយប្រឆាំងនឹងគាត់"[453]។

[449] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២។

[450] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២។

[451] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២។

[452] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២។

[453] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៩៦។

២៩៩. ទោះយ៉ាងណា ការអនុវត្តអន្តរជាតិដែលអង្គជំនុំជម្រះបានយកជាមូលដ្ឋានបង្អែក តែងតែរំឭកពីភាពជាទីសក្ការៈនៃគោលការណ៍សួរដេញដោលផ្ទាល់មាត់ និងភាពចាំបាច់នៃការការពារសិទ្ធិរបស់ជនជាប់ចោទ ដោយធានាឱ្យបាននូវការគោរពគោលការណ៍ចំពោះមុខ។ សេចក្តីសម្រេចថ្មីៗមួយចំនួនផ្ទុះបញ្ចាំងពីគោលជំហរនេះ។ ក្នុងរឿងក្តី Bemba អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានរំឭកអំពីសារៈសំខាន់នៃការសួរដេញដោលផ្ទាល់មាត់ក្នុងកិច្ចដំណើរការនីតិវិធី ដោយកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងដើរផ្ទុយពីបទប្បញ្ញត្តិនៃមាត្រា ៦៩-២ នៃលក្ខន្តិកៈទីក្រុងរ៉ូម[454] ដោយបានទទួលយក និងប្រើប្រាស់ជាភ័ស្តុតាងនូវចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី ដែលមិនបានចូលមកផ្តល់សក្ខីកម្មផ្ទាល់មាត់នៅក្នុងសវនាការ និងដែលមិនត្រូវបានពិនិត្យជាមុន តាមករណីនីមួយៗ[455]។ តុលាការកំពូលរំឭកផងដែរថា កាលណាអង្គជំនុំជម្រះសាលាដំបូងងាកចេញពីវិធានសួរដេញដោលដោយផ្ទាល់មាត់ អង្គជំនុំជម្រះសាលាដំបូងត្រូវតែបញ្ជាក់ឱ្យច្បាស់ថា វិធីសាស្ត្ររបស់ខ្លួនមិនបង្កព្យសនកម្ម ឬមិនរំលោភសិទ្ធិការពារក្តី និងល័ក្ខខ័ណ្ឌតម្រូវនៃការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌ និងមិនលម្អៀង"[456]។ ដូចគ្នាផងដែរ ថ្មីៗនេះ ក្នុងរឿងក្តី *Karadzic* តុលាការកំពូលបានរំឭកថា៖ *"សេចក្តីសម្រេចទទួលយកភ័ស្តុតាង ដោយពុំមានការសួរដេញដោលផ្ទាល់មាត់ គឺជាសេចក្តី*

[454] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៦៩.២៖ "សក្ខីកម្មរបស់សាក្សីក្នុងពេលជំនុំជម្រះត្រូវផ្តល់ដោយបុគ្គលផ្ទាល់ខ្លួន លើកលែងតែស្ថិតក្នុងកម្រិតវិសាលភាពដែលមានចែងក្នុងវិធានការដែលបានកំណត់ក្នុងមាត្រា ៦៨ ឬក្នុងវិធាននៃនីតិវិធី និងភ័ស្តុតាង។ តុលាការអាចអនុញ្ញាតផងដែរឱ្យផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ឬសក្ខីកម្មដែលបានថតទុករបស់សាក្សីណាម្នាក់ តាមមធ្យោបាយបច្ចេកវិទ្យាវីដេអូ ឬខ្សែអាត់ព្រមទាំងការណែនាំបង្ហាញពីឯកសារ ឬលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរដែលជាកម្មវត្ថុនៃច្បាប់លក្ខន្តិកៈនេះ និងស្របតាមវិធាននៃនីតិវិធី និងភ័ស្តុតាង។ វិធានការទាំងនេះមិនត្រូវមានលក្ខណៈអគតិធម៌ចំពោះ ឬមិនត្រូវមានលក្ខណៈមិនសមស្របជាមួយសិទ្ធិរបស់ជនជាប់ចោទឡើយ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[455] សាលដីកានៅក្នុងរឿងក្តី *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក Jean-Pierre Bemba Gombo និងរដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងការព្រមទទួលយកធ្វើជាភ័ស្តុតាងនូវឯកសារដែលមាននៅក្នុងបញ្ជីភស្តុតាងរបស់រដ្ឋអាជ្ញា ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងទី៣ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ កថាខណ្ឌ ៧៤-៨១។

[456] សាលដីកានៅក្នុងរឿងក្តី *Bemba* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក Jean-Pierre Bemba Gombo និង និងរដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងការព្រមទទួលយកធ្វើជាភ័ស្តុតាងនូវឯកសារដែលមាននៅក្នុងបញ្ជីភស្តុតាងរបស់រដ្ឋអាជ្ញា ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងទី៣ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១ កថាខណ្ឌ ៧៨។

*សម្រេចមួយដែលតម្រូវឱ្យសាលាដំបូងពិចារណាអំពីផលប៉ះពាល់លើសិទ្ធិជនជាប់ចោទ ដោយប្រយ័ត្ន ប្រយែងជាមុនសិន"*[457]។

៣០០. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបង្កើតក្របខ័ណ្ឌបែបនេះ សម្រាប់វាយតម្លៃចម្លើយជាលាយលក្ខណ៍អក្សរ ដោយមិនថ្លឹងថ្លែងវាឱ្យស្របតាមគោលការណ៍ចំពោះមុខ។ ការអនុវត្តបែបនេះរំលោភលើសិទ្ធិនីតិវិធីរបស់ ខៀវ សំផន ហើយ តុលាការកំពូលត្រូវតែសន្និដ្ឋានថាមានភាពអយុត្តិធម៌ដែលកើតចេញពីក្របខ័ណ្ឌនេះ។

## ២.២. ការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់

៣០១. តុលាការអឺរ៉ុបស្តីពីសិទ្ធិបានលើកឡើងជាច្រើនដងថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានរំលោភបំពាន កាលណាការផ្តន្ទាទោសជនជាប់ចោទផ្អែកទៅលើសក្ខីកម្មមួយដែលគាត់មិនត្រូវបានអនុញ្ញាតឱ្យពិភាក្សា ឬតទល់ជាមួយសាក្សីម្តងណាសោះ[458]។ តុលាការនេះបានទទួលយកអញ្ញត្រកម្មមួយចំនួនចំពោះគោលការណ៍នេះ ដោយថ្លែងថា៖

> "ជាគោលការណ៍ ភស្តុតាងត្រូវតែបង្ហាញដល់ជនជាប់ចោទក្នុងសវនាការជាសាធារណៈ ក្នុងគោលបំណងពិភាក្សាដេញដោលចំពោះមុខ។ ទោះយ៉ាងនេះក្តី វាមិនមានន័យថាសក្ខីកម្មរបស់សាក្សីត្រូវតែធ្វើឡើងជាប្រចាំ នៅក្នុងសវនាការជាសាធារណៈ ដើម្បីអាចប្រើវាជាភស្តុតាងនោះទេ ពីព្រោះថាការប្រើប្រាស់សក្ខីកម្មដែលបានធ្វើឡើងនៅដំណាក់កាលស៊ើបអង្កេតបឋមមិនផ្ទុយពីបទប្បញ្ញត្តិនៃកថាខណ្ឌ ៣**(ឃ)** និងកថាខណ្ឌ ១ នៃមាត្រា ៦ (មាត្រា ៦(៣)**(ឃ)** មាត្រា ៦(១)) នោះទេ <u>ប្រសិនការប្រើប្រាស់នេះគោរពសិទ្ធិរបស់មេធាវីការពារក្តី។ តាមច្បាប់</u>

---

457 សាលក្រម *Karadzic* (យន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ) ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ កថាខណ្ឌ ១៦២។

458 ជាពិសេស សូមមើល សាលដីកា *Unterpertinger ទល់នឹងប្រទេសអូទ្រីស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៨៦ កថាខណ្ឌ ៣១។ សាលដីកា *Saïdi ទល់នឹងប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣ កថាខណ្ឌ ៤៣-៤៤។ សាលដីកា *Barberà, Messegué* និង *Jabardo ទល់នឹងប្រទេសអេស្ប៉ាញ* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៨៨ កថាខណ្ឌ ៧៨។

សិទ្ធិទាំងនេះតម្រូវឱ្យផ្ដល់ដល់ជនជាប់ចោទនូវឱកាសសមស្រប និងគ្រប់គ្រាន់ដើម្បីធ្វើការជំទាស់សក្ខីកម្មដាក់បន្ទុក និងសួរដេញដោលម្ចាស់សក្ខីកម្មនេះ នៅពេលផ្ដល់សក្ខីកម្ម ឬនៅពេលក្រោយ"[459]។

៣០២. ដូច្នេះ សេចក្ដីសម្រេចមួយមិនអាចផ្អែកលើភ័ស្ដុតាងដែលមិនបានដាក់ឆ្លងការពិភាក្សាចំពោះមុខដោយភាគីបានទេ។ គោលការណ៍ចំពោះមុខ ប្រសូត្រចេញពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមិនអាចបរិហារបាន។ តុលាការព្រហ្មទណ្ឌនៃតុលាការកំពូលបារាំង បានប្រកាន់យកវិចារណកិច្ចស្រដៀងគ្នា។ យោងតាមវាក្យខណ្ឌ ២ មាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ "ចៅក្រមអាចផ្អែកសេចក្ដីសម្រេចរបស់ខ្លួនតែលើភ័ស្ដុតាងដែលត្រូវបានដាក់ឱ្យពិភាក្សា ក្នុងអំឡុងពេលដំណើរការនីតិវិធី និងសួរដេញដោលចំពោះមុខខ្លួន"។ អាស្រ័យហេតុនេះ រាល់សេចក្ដីសម្រេចដែលផ្អែកលើភ័ស្ដុតាងដែលមិនបានដាក់ឆ្លងការពិភាក្សាដេញដោលរបស់ភាគី ត្រូវទុកជាមោឃៈ ពីព្រោះថាការចាត់ទុកសេចក្ដីសម្រេចបែបនេះជាមោឃៈមានច្រើនណាស់[460]។ វាជាការរំលោភលើសំអាងហេតុរបស់ខ្លួនឯងផ្ទាល់ និងយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ដែលអង្គជំនុំជម្រះបានផ្ដន្ទាទោស ខៀវ សំផន ដោយផ្អែកទាំងស្រុងលើចម្លើយជាលាយលក្ខណ៍អក្សរ[461]។

## ២.៣. កំហុសច្រំដែលរបស់អង្គជំនុំជម្រះ នៅក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ និង ០០២/០២

៣០៣. ក្នុងអំឡុងពេលនៃការជំនុំជម្រះក្ដីសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបង្កើតក្របខ័ណ្ឌច្បាប់នេះរួចហើយ[462]។ ក្នុងអំឡុងពេលជំនុំជម្រះក្ដីសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានជ្រើសរើសបញ្ចូល

---

[459] សាលដីកា *Kostovski ទល់នឹងប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ កថាខណ្ឌ ៤១ (យើងគូសបន្ទាត់ពីក្រោម)។

[460] កម្រងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ Dalloz មាត្រា ៣ - ការមិនដឹងពីគោលការណ៍ចំពោះមុខ កថាខណ្ឌ ២៧៨-២៧៩។

[461] សូមមើលខាងក្រោម កថាខណ្ឌ ៨៤២-៨៤៧, ១០៥៥។

[462] សេចក្ដីសម្រេច ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ឯកសារ **E299** កថាខណ្ឌ ១៩, ២៣។ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៣១។ សារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៣០-៥៣៦។

ចម្លើយជាលាយលក្ខណ៍អក្សរជាអតិបរិមាទៅក្នុងសំណុំរឿង ដោយមិនបានកោះហៅម្ចាស់ចម្លើយទាំងនេះមកផ្តល់សក្ខីកម្មក្នុងសវនាការ។ ចម្លើយជាលាយលក្ខណ៍អក្សរជាច្រើនទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខ[463] ឬត្រូវបានប្រើដើម្បីបញ្ជាក់អំពីឧក្រិដ្ឋកម្ម[464]។

៣០៤. យោងតាមសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានប្រើប្រាស់តែចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព ដើម្បីកំណត់ប្រភេទបទល្មើស និងផ្តន្ទាទោស ខៀវ សំផន។ ឧទាហរណ៍ជាក់ស្តែង អង្គជំនុំជម្រះផ្អែកតែលើដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ ដែលបានទទួលមរណភាព និងមិនដែលបានមកបង្ហាញខ្លួននៅក្នុងសវនាការ ដើម្បីសម្រេចថាមានធាតុផ្សំភ័ស្តុតាងគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត នៅភ្នំក្រោល[465]។ នៅក្នុងក្របខ័ណ្ឌនៃការពិនិត្យពិចារណារបស់ខ្លួនអំពីបទបញ្ញាស្តីពីអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះបានសន្និដ្ឋានថា ខៀវ សំផន មានទំនួលខុសត្រូវ ដោយវិនិច្ឆ័យថា តួនាទីរបស់គាត់ "ក្នុងការអនុវត្តគោលនយោបាយនេះ ត្រូវបានបញ្ជាក់គាំទ្រដោយសម្តេចសីហនុ ដែលព្រះអង្គបានចងចាំថាបានឮ ខៀវ សំផន និយាយអំពីស្ត្រីក្មេងៗថាជាអ្នកស្នេហាជាតិដ៏ក្លៀវក្លា ដែលរៀបការជាមួយយុទ្ធជនពិការ និងលះបង់ខ្លួនដើម្បីសង្គ្រោះជាតិ"[466] [467]។ ក៏ប៉ុន្តែ សម្តេច សីហនុ ជាសាក្សីដែលមេធាវីការពារក្តីបានទទូចស្នើសុំឱ្យចូលមកបង្ហាញខ្លួន ក្នុងកំឡុងពេលព្រះអង្គនៅមានព្រះជន្មនៅឡើយ ពីព្រោះថាព្រះអង្គបានធ្វើសេចក្តីថ្លែងការផ្ទុយគ្នាជាច្រើន ហើយវាចាំបាច់ណាស់ដែលយើងត្រូវមានឱកាសសាកសួរព្រះអង្គ។ លើសពីនេះទៅទៀត ដើម្បីសន្និដ្ឋានថាជនជាតិវៀតណាមមកពីភូមិអន្លង់ទ្រា ត្រូវបានចាប់បញ្ជូនទៅប្រទេសវៀតណាម អង្គជំនុំជម្រះផ្អែកទាំងស្រុងតែទៅលើចម្លើយ

[463] សារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៤១-៥៥១។

[464] សូមមើលខាងក្រោម កថាខណ្ឌ ៨៤២-៨៤៧, ៨៦៣-៨៧៣, ៨៩៩-៩១០, ១០៥៥។

[465] សូមមើលខាងក្រោម កថាខណ្ឌ ៨៦៣-៨៧៣។

[466] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៨ កំណត់សម្គាល់ជើងទំព័រលេខ១៣៨៦៤ (ដែលយោងទៅកថាខណ្ឌ ៣៥៨៥)។

[467] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៨ កំណត់សម្គាល់ជើងទំព័រលេខ១៣៨៦៤ (ដែលយោងទៅកថាខណ្ឌ ៣៥៨៥)។

ជាលាយលក្ខណ៍អក្សរចំនួនពីរប៉ុណ្ណោះ[468]។ មិនមានធាតុផ្សំណាមួយដើម្បីបញ្ជាក់គាំទ្រចម្លើយទាំងនេះ ហើយដែលចម្លើយទាំងនេះផ្អែកលើការនិយាយតៗគ្នា[469]។

៣០៥. អង្គជំនុំជម្រះដទៃៗទៀតទទួលយកចម្លើយជាលាយលក្ខណ៍អក្សរជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ដែរ ប៉ុន្តែយកចិត្តទុកដាក់ក្នុងការរំឭកថា ការពិចារណាលើភស្តុតាងបែបនេះ ត្រូវតែបានវាយតម្លៃដោយប្រយ័ត្នប្រយែង[470]។ ទោះយ៉ាងណាក្តី អង្គជំនុំជម្រះមិនបានគោរពក្របខ័ណ្ឌគតិយុត្តិដែលខ្លួនឯងបានបង្កើតផ្ទាល់។ ប្រការនេះរំលោភបំពានវិធានច្បាប់ស្តីពីភស្តុតាង និងសិទ្ធិទទួលបាននីតិវិធីយុត្តិធម៌ត្រឹមត្រូវរបស់ ខៀវ សំផន។

## ផ្នែកទី ៥. ចម្លើយក្រៅប្រព័ន្ធតុលាការ

៣០៦. យោងតាមសំអាងហេតុសាលក្រមនេះ អង្គជំនុំជម្រះបានរំឭកថា តម្លៃជាភស្តុតាងនៃភស្តុតាងត្រូវតែត្រូវបានវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានបញ្ជាក់ថា "ក្នុងករណីភស្តុតាងជាឯកសារ ទាំងឯកសារច្បាប់ដើម ទាំងច្បាប់ចម្លងដែលត្រូវបានទទួលយកមកពិភាក្សាក្នុងដំណើរការនីតិវិធី គឺត្រូវគិតពីភាពអាចអានដាច់នៃឯកសារទាំងនេះ អត្ថិភាពនៃភាពខុសគ្នារវាងសំណៅដែលបានដាក់ពិភាក្សានៅក្នុងកិច្ចដំណើរការនីតិវិធី និងសំណៅផ្សេងៗទៀតនៃភស្តុតាងដដែល អត្ថិភាពនៃភាពផ្ទុយគ្នាដែលត្រូវបានចោទប្រកាន់ ឬអត្ថិភាពនៃកំហុស

[468] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣០។

[469] សូមមើលខាងក្រោម កថាខណ្ឌ ៦៨៦-៧១៨។

[470] សាលក្រម *Prlic និងអ្នកដទៃទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ៣៨៨៖ "អង្គជំនុំជម្រះបានយកចិត្តទុកដាក់ជាពិសេសទៅនឹងការដែលថាសក្ខីកម្មជាលាយលក្សណ៍អក្សរត្រូវបានទទួលយក ដោយគ្មានឱកាសក្នុងការសួរដេញដោលគ្នាចំពោះអ្នកដែលបានផ្តល់សក្ខីកម្មនោះ"។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* សំណុំរឿងលេខ ICC-01/04-01/07 សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភស្តុតាង ដែលខ្លួនចង់ដាក់ឱ្យពិភាក្សាដេញដោយដោយផ្ទាល់ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ កថាខណ្ឌ ៤២៖ "សិទ្ធិរបស់ជនជាប់ចោទក្នុងការចោទសួរ ឬឱ្យគេចោទសួរសាក្សីបដិបក្ខ គឺមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីមានភាពយុត្តិធម៌នៅក្នុងដំណើរការនីតិវិធី។ គ្មានសាលក្រមណាមួយដែលត្រូវចេញបានត្រឹមត្រូវឡើយ ប្រសិនបើសាលក្រមនោះផ្អែកតែទៅលើភស្តុតាងដែលរៀបចំដោយភាគីតែម្ខាង ប៉ុន្តែ គូបដិបក្ខមិនបានចោទសួរ ឬផ្ទៀងផ្ទាត់"។

ដែលត្រូវបានរកឃើញតាមរយៈការវិភាគមួយដែលអាចជឿទុកចិត្តបាន លទ្ធភាពរបស់សាក្សីក្នុងការជំទាស់នឹងភស្តុតាង និងវត្ថុមានតម្រុយនានានៃភាពគួរឱ្យទុកចិត្តបាន ដូចជាព័ត៌មានអំពីខ្សែចង្វាក់បញ្ជូន និងថែរក្សាឯកសារភស្តុតាងនេះ"[471]។ បន្ទាប់មក អង្គជំនុំជម្រះបានបញ្ជាក់ថា រាល់ភស្តុតាងដែលប្រមូលបាននៅក្រៅក្របខ័ណ្ឌតុលាការ "មានតម្លៃជាភស្តុតាងតិចតួចបំផុត" និងថា នៅពេលអង្គជំនុំជម្រះយកភស្តុតាងបែបនេះជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន "អង្គជំនុំជម្រះត្រូវជាប់កាតព្វកិច្ចពន្យល់ឱ្យបានច្បាស់លាស់អំពីវិចារណកិច្ចរបស់ខ្លួន ជាពិសេស ក្នុងករណីដែលការផ្តន្ទាទោសផ្អែកទាំងស្រុង ឬដាច់ខាត លើចម្លើយទាំងនេះ"[472]។

៣០៧. យោងតាមសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះយល់ឃើញថា ខ្លួនអាចផ្តន្ទាទោស ដោយផ្អែកលើមូលដ្ឋាននៃចម្លើយក្រៅផ្លូវតុលាការ ដែលមានតម្លៃជាភស្តុតាងតិចតួចបំផុត តាំងពីពេលអង្គជំនុំជម្រះបង្ហាញវិចារណកិច្ចរបស់ខ្លួនយ៉ាងច្បាស់លាស់ភ្លាមមកម្ល៉េះ។ ក្របខ័ណ្ឌច្បាប់បែបនេះរំលោភបំពានលើសិទ្ធិទទួលបាននីតិវិធីប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងសាទុក្ខ។ តាមស្មារតីច្បាប់ គេមិនអាចទទួលយកការសន្និដ្ឋានហួសពីវិមតិសង្ស័យ ដោយផ្អែកលើភស្តុតាងដែលត្រូវបានគេវិនិច្ឆ័យថាមានតម្លៃជាភស្តុតាងតិចតួចបំផុតនោះ។ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបញ្ជាក់ថា "រាល់ចម្លើយ ឬឯកសារផ្សេងៗទៀតដែលធ្វើឡើងនៅក្រៅស្ថាប័ន ដូចជា ដោយអង្គការអន្តរការី ឬអង្គភាពផ្សេងៗទៀតដែលមិនចំណុះឱ្យ អ.វ.ត.ក" មិនអាចត្រូវបានសន្មតថាអាចគួរឱ្យទុកចិត្តបាននោះទេ លើកលែងតែកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលត្រូវបានបង្កើតឡើង នៅក្នុងក្របខ័ណ្ឌតុលាការ[473]។ ដូច្នេះ ចៅក្រមបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការរំលោភលើសិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយជីកកប់គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

៣០៨. នៅក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម សហចៅក្រមស៊ើបអង្កេតបានពន្យល់ពីមូលហេតុដែលធ្វើឱ្យចម្លើយក្រៅប្រព័ន្ធតុលាការមានតម្លៃតិចតួចបំផុត។ ជាបឋម ពួកគាត់បានរំឭកថា កំណត់

[471] សំអាងហេតុសាលក្រម កថាខណ្ឌ៦១។

[472] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៩។

[473] សេចក្តីសម្រេច ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E96/7** កថាខណ្ឌ ២៩។ សារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៥៥៧។

ហេតុស្តាប់ចម្លើយត្រូវបានធ្វើនៅក្នុងក្របខ័ណ្ឌតុលាការ ដូច្នេះទទួលបានការធានាតាមផ្លូវច្បាប់ និងនីតិវិធី ហើយទទួលបានការសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចទុកចិត្តបាន[474] គឺផ្ទុយពីចម្លើយក្រៅប្រព័ន្ធតុលាការ[475]។ ផ្ទុយពីអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតបានពិចារណាថា បទសម្ភាសន៍ចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមិនត្រូវបានធ្វើឡើងក្នុងបំណងជំនុំជម្រះក្តីព្រហ្មទណ្ឌ មិនទទួលបានការធានាតាមផ្លូវតុលាការ ដូចកំណត់ហេតុស្តាប់ចម្លើយឡើយ និងមានតម្លៃជាភ័ស្តុតាងតិចតួចណាស់[476]។ ពួកគាត់ក៏បានពិចារណាផងដែរថា បទសម្ភាសន៍ធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញាក្នុងគោលបំណង និងក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តី មិនត្រូវបានធ្វើឡើងក្រោមសម្បថ ហើយត្រូវបានដឹកនាំយដោយភាគីមួយដែលមានផលប្រយោជន៍ពីលទ្ធផលនៃរឿងក្តី[477]។ នៅទីបញ្ចប់ យោងតាមសហចៅក្រមស៊ើបអង្កេត ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានសន្មតជាមុនថាគួរឱ្យទុកចិត្តបានទេ។ លើសពីនេះទៀត ខ្លឹមសារនៃពាក្យសុំត្រូវបានតាក់តែងឡើងដោយប្រើពាក្យពេចន៍ទូទៅ (បែបពិពណ៌នាទូទៅ)។ ដូច្នេះ ពាក្យសុំទាំងនេះមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់បង្ហាញអំពីអង្គហេតុពាក់ព័ន្ធបានឡើយ[478]។

៣០៩. នៅក្នុងរឿងក្តី *Katanga* អង្គជំនុំជម្រះសាលាដំបូងបានផ្តល់លក្ខណៈវិនិច្ឆ័យមិនពិស្តារសម្រាប់វាយតម្លៃលើភាពគួរឱ្យទុកចិត្តនៃភ័ស្តុតាង។ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងនេះ រួមមាន៖ “ក) ប្រភព៖ តើអង្គភាពដែលផ្តល់ភ័ស្តុតាងនេះមានទំនាក់ទំនងនឹងភាគីណាមួយ ឬមានផលប្រយោជន៍ផ្ទាល់ខ្លួនចំពោះលទ្ធផលនៃរឿងក្តីនេះដែរឬទេ? ឬតើមានសូចនាករផ្សេងៗទៀតបង្ហាញពីភាពលម្អៀងក្នុងកម្រិតណាមួយដែរឬទេ? [...] ឃ) គោលបំណង៖ ឯកសារនេះត្រូវបានបង្កើតឡើងជាពិសេសសម្រាប់នីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខតុលាការ ឬសម្រាប់ហេតុផលផ្សេងទៀត? ង) មធ្យោបាយ

---

[474] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ១០៣។

[475] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ១០៤-១០៨។

[476] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ១០៤-១០៦។

[477] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ១០៥។

[478] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ១០៧។

វាយតម្លៃត្រឹមត្រូវ៖ តើព័ត៌មាន និងវិធីទទួលព័ត៌មាននេះអាចផ្ទៀងផ្ទាត់ ឬយកមកសាកពិសោធន៍ដោយមធ្យោបាយឯករាជ្យបានដែរឬទេ?[479]"។

៣១០. ចំពោះការប្រើប្រាស់ភ័ស្តុតាងប្រភេទនេះ តុលាការកំពូលបានរំឭកនៅក្នុងសាលដីកា ០០២/០១ អំពីតម្លៃជាភ័ស្តុតាងដ៏តិចតួចរបស់វា ហើយបានបញ្ជាក់ថា ក្នុងករណីនេះ ប្រសិនបើចម្លើយក្រៅប្រព័ន្ធតុលាការត្រូវបានប្រើជាមូលដ្ឋាននៃការសន្និដ្ឋានពីអង្គហេតុណាមួយ "វិចារណកិច្ចត្រូវតែមានលក្ខណៈពិស្តារ" ជាងពេលដែលការសន្និដ្ឋានផ្អែកលើភ័ស្តុតាងរឹងមាំ[480]។

៣១១. ដោយគ្មានភាពម៉ត់ចត់ផ្នែកច្បាប់ និងការពិនិត្យលម្អិត អង្គជំនុំជម្រះបានធ្វើសេចក្ដីសន្និដ្ឋានពីពិរុទ្ធភាពផ្អែកលើចម្លើយក្រៅប្រព័ន្ធតុលាការ[481]។ អង្គជំនុំជម្រះមិនជឿថាវាមានប្រយោជន៍ក្នុងការបញ្ជាក់លម្អិតអំពីប្រភព ឬក្នុងការបង្ហាញពីភាពពាក់ព័ន្ធ និងភាពអាចទុកចិត្តបាន នៃឯកសារទាំងនេះ។ អង្គជំនុំជម្រះបានបន្តប្រតិបត្តិដូចក្នុងសំណុំរឿង ០០២/០១ ក្នុងខណៈដែលតុលាការកំពូលបានណែនាំឱ្យខ្លួនកែប្រែកំហុសឆ្គងនេះរួចម្តងហើយ[482]។ អាស្រ័យហេតុនេះ តុលាការកំពូលត្រូវតែធ្វើមោឃភាព

---

[479] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Katanga និង Ngudjolo Chui* សំណុំរឿងលេខ ICC-01/04-01/07 សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភ័ស្តុតាង ដែលខ្លួនចង់ដាក់ឱ្យពិភាក្សាដេញដោយដោយផ្ទាល់ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ កថាខណ្ឌ ២៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[480] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩០។

[481] សូមមើលខាងក្រោម ឧទាហរណ៍អង្គហេតុ កថាខណ្ឌ ៧៣១, ១០៤៤-១០៤៥, ១៤២៩-១៤៣០, ១៥២៥។

[482] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៥៥០៖ "អង្គជំនុំជម្រះសាលាដំបូង ពុំបានធ្វើការពិចារណាច្បាស់លាស់ណាមួយអំពីតម្លៃជាភ័ស្តុតាងចំពោះភ័ស្តុតាងដែលខ្លួនបានសំអាង ឬលើហេតុការណ៍ណាមួយអំពីការស្លាប់ដែលត្រូវមានភ័ស្តុតាងគាំទ្រជាច្រើននោះ។ ដូចបានកត់សម្គាល់ខាងលើ ជាពិសេសនៅពេលដែលតម្លៃជាភ័ស្តុតាងដែលការយល់ឃើញផ្អែកទៅលើ មានមូលដ្ឋានខ្សោយ (ដូចជាករណីនៃចម្លើយក្រៅតុលាការរបស់សាក្សី និងរបស់ដើមបណ្តឹងរដ្ឋប្បវេណី) ការពន្យល់របស់អង្គជំនុំជម្រះសាលាដំបូងពីមូលហេតុក្នុងការជឿជាក់ថា ការយល់ឃើញហួសពីវិមតិសង្ស័យអាចផ្អែកលើភ័ស្តុតាងនេះបាន មានសារៈសំខាន់ជាក់លាក់ នៅពេលកំណត់ ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងសមហេតុផល ដែរ ឬយ៉ាងណា។ ដោយសារពុំមានការពន្យល់ណាមួយនោះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការយល់ឃើញទាក់ទងទៅនឹងការស្លាប់ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរដោយផ្អែកលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពាក្យបណ្តឹងរបស់ជនរងគ្រោះ និងការរៀបរាប់របស់ជនភៀសខ្លួន ពុំអាចនិយាយបានថា ធ្វើឡើងដោយសមហេតុផលឡើយ"។ (យើងខ្ញុំជា

សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលផ្អែកទាំងស្រុងទៅលើចម្លើយក្រៅប្រព័ន្ធតុលាការ និងកត់សម្គាល់ថា ការជំនុំជម្រះក្តី ខៀវ សំផន មានភាពអយុត្តិធម៌។

## ផ្នែកទី ៦. ពាក្យចចាមអារ៉ាម

៣១២. យោងទៅតាមសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានពិចារណាថា ក្នុងការវាយតម្លៃភ័ស្តុតាងចេញពីពាក្យចចាមអារ៉ាម ខ្លួនត្រូវតែពិចារណាអំពី "ការមិនអាចកោះហៅបុគ្គលដែលបង្កើតពាក្យចចាមអារ៉ាម មកសួរដេញដោលតតាំងចំពោះមុខ ព្រមទាំង កាលៈទេសៈប្រែប្រួលខ្លាំងជុំវិញការផ្តល់សក្ខីកម្ម [ទាក់ទងនឹងអង្គហេតុបានមកពីពាក្យចចាមអារ៉ាម]"។ ដូច្នេះ ភ័ស្តុតាងចេញពីពាក្យចចាមអារ៉ាម ត្រូវតែយកមកពិចារណាដោយប្រយ័ត្នប្រយែង"[483]។ មេធាវីការពារក្តីយល់ស្របនឹងការវាយតម្លៃភ័ស្តុតាងនេះ។ ទោះយ៉ាងនេះក្តី តាមការសង្កេតជាក់ស្តែង អង្គជំនុំជម្រះបានលើកឡើងជាន់កែងខ្លួនឯងក្នុងសំអាងហេតុសាលក្រមរបស់ខ្លួន ដោយមិនអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ដែលបានដាក់ចេញ[484]។ ដោយមើលឃើញអាការៈប្លែកនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ មេធាវីការពារក្តីបានព្យាយាមពញ្ញាក់ស្មារតីអង្គជំនុំជម្រះអំពីសារៈសំខាន់នៃការយកចិត្តទុកដាក់លើភ័ស្តុតាងប្រភេទនេះ[485]។ ជាក់ស្តែង ក្នុងអំឡុងពេលនៃការជំនុំជម្រះក្តី ទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះ មិនបានចាប់អារម្មណ៍លើប្រភពនៃចម្លើយចេញពីពាក្យចចាមអារ៉ាមដែលបានផ្តល់ក្នុងសវនាការឡើយ សំដៅធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះមានកាតព្វកិច្ចយកវាមកពិចារណាក្នុងពេលពិភាក្សាសម្រេច។

---

អ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ កថាខណ្ឌ ៩៧០៖ "សរុបសេចក្តីមក ភ័ស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើ មានកម្រិតខ្សោយ ពុំមានភាពច្បាស់លាស់ និងមានតម្លៃទាប និងចោទជាបញ្ហាដោយសារភ័ស្តុតាងដទៃទៀត"។

[483] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣។ សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣០២ (ដែលយោងទៅយុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ)។

[484] ជាពិសេស សូមមើលខាងក្រោម ឧទាហរណ៍អង្គហេតុ កថាខណ្ឌ ៧០៣, ៧១០, ៧៥០, ៧៧៤, ៧៨០-៧៨១, ៧៩៩, ៨០០, ៨០២, ៨៧៨, ៨៨៨-៨៨៩, ៩០០-៩០១, ៩០៨, ៩១៩, ៩២១, ៩៧១, ៩៧៥, ៩៨៧, ៩៩១-៩៩២, ១០០៤-១០០៥, ១០០៧, ១០១១, ១០១៣-១០១៤, ១០៤៤, ១០៩៥, ១២៦៦, ១៧៦២, ១៨៦៨។

[485] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៥៦៧-៥៦៩។

៣១៣. ជាឧទាហរណ៍ អង្គជំនុំជម្រះបានលើកឡើងជាន់កែងខ្លួនឯងក្នុងផ្នែកសំអាងហេតុរបស់ខ្លួន ដោយសន្និដ្ឋានថា ជនជាតិវៀតណាមមកពីភូមិពោធិ៍ចិន្តាំ ត្រូវបានបញ្ជូនខ្លួនទៅប្រទេសវៀតណាម[486]។ ការសន្និដ្ឋាននេះផ្អែកលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន តែម្នាក់ប៉ុណ្ណោះ[487]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបែរជាចង្អុលបង្ហាញថា បើតាមសក្ខីកម្មរបស់ ដួង អឿន ព័ត៌មានដែលថាជនជាតិវៀតណាមនៅក្នុងតំបន់គាត់ ដូចជា តាគី យាយមីន និងកូនៗរបស់ពួកគេត្រូវវិលត្រឡប់ទៅប្រទេសវៀតណាមវិញ គឺជាព័ត៌មានចចាមអារ៉ាម[488]។ តុលាការកំពូលត្រូវតែទុកជាមោឃៈរាល់សេចក្ដីសន្និដ្ឋានដែលបានធ្វើឡើងដោយរំលោភលើក្របខ័ណ្ឌច្បាប់ដែលខ្លួនឯងផ្ទាល់បានដាក់ឱ្យអនុវត្ត និងកត់សម្គាល់ពីភាពអយុត្តិធម៌នៃការជំនុំជម្រះក្ដីម្ដាស់បណ្ដឹងសាទុក្ខ។

## ផ្នែកទី ៧. ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

## ១. ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

៣១៤. យោងតាមសាលក្រមរងបណ្ដឹងសាទុក្ខ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានតាក់តែងឡើងដោយស្ថាប័នតុលាការ មិនទទួលបាន "ការសន្មតជាមុនថាអាចទុកចិត្តបាន" ឡើយ[489]។ ដូច្នេះ វាមានតម្លៃជាភ័ស្តុតាងតិចតួច[490]។ អង្គជំនុំជម្រះបានប្រកាន់យកគោលជំហរស្រដៀងគ្នានេះរួចមកហើយ នៅក្នុងសំណុំរឿង ០០២/០១[491]។

---

[486] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥05-៣៥០៧។

[487] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣១។

[488] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣១ សូមមើលខាងក្រោម កថាខណ្ឌ ៩៧៧។

[489] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៣។

[490] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៣។

[491] សេចក្ដីសម្រេច ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E96/7 កថាខណ្ឌ ២៩៖ "នៅពេលគ្មានព័ត៌មានពាក់ព័ន្ធនឹងកាលៈទេសៈនានាដែលគេបានធ្វើកំណត់ហេតុ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី(ដែលជាញឹកញាប់ត្រូវបានអង្គការអន្តរការីផ្សេងៗរៀបចំឡើង ក្នុងនាមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី) ក៏អាចត្រូវបានស្នើឱ្យបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះផងដែរ ប៉ុន្តែ នៅទីបំផុតអាចត្រូវបានផ្ដល់ឱ្យនូវទម្ងន់ជាភ័ស្តុតាងតិចតួចប៉ុណ្ណោះប្រសិនបើមាន" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៣១៥. ដូចគ្នាដែរ ក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង ០០២/០២ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងសន្ធឹកសន្ធាប់ ដែលផ្ទេរចេញពីសំណុំរឿង ០០៣ និង ០០៤ អង្គជំនុំជម្រះបានរំឭកថា ឯកសារទាំងនេះមានតម្លៃជាភ័ស្តុតាង "តិចជាង" កំណត់ហេតុស្តាប់ចម្លើយសាក្សី[492]។ សហចៅក្រមស៊ើបអង្កេត[493] និងតុលាការកំពូល[494] យល់ស្រប នឹងគោលជំហរនេះ។ ទោះបីជាខ្លួនទទួលស្គាល់ថាវាមានតម្លៃជាភ័ស្តុតាងដ៏តិចតួចក៏ដោយ ក៏អង្គជំនុំជម្រះមិនញញើតនឹងប្រើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឧបសម្ព័ន្ធដ៏សាមញ្ញ ធ្វើជាមូលដ្ឋានដើម្បីប្រកាសពិរុទ្ធភាពដែរ។

៣១៦. ជាឧទាហរណ៍ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយផ្អែកលើឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសន្និដ្ឋានពីការបណ្តេញជនជាតិវៀតណាមចេញពីភូមិអង្គរយស[495]។ ពីដំបូង អង្គជំនុំជម្រះបានអះអាងថា ខ្លួនផ្អែកលើឧបសម្ព័ន្ធនេះគ្រាន់តែដើម្បី "បញ្ជាក់គាំទ្រដល់អត្ថិភាពនៃការផ្លាស់ទីលំនៅទាំងស្រុងរបស់ជនជាតិវៀតណាមនៅខេត្តព្រៃវែង ក្នុងឆ្នាំ១៩៧៥"[496]។ ក៏ប៉ុន្តែ នៅពេលកំណត់ប្រភេទបទល្មើសនៃអង្គហេតុ អង្គជំនុំជម្រះបានពិចារណាថា "ករណីជាក់លាក់ [មួយចំនួន] នៃក្រុមគ្រួសារដែលត្រូវបានគេប្រមូលផ្តុំ ជម្លៀស និងត្រូវបានគេឃើញចាកចេញពីកន្លែងកើតហេតុដោយជិះកាណូត ត្រូវបានរកឃើញថាពិតជាបានកើតឡើង នៅ [តាមបណ្តា] ភូមិ [...] អង្គរយស" ដោយផ្អែកលើឧបសម្ព័ន្ធមួយនេះតែប៉ុណ្ណោះ[497]។ ដូច្នេះ ការរកឃើញដែលបណ្តាលឱ្យមានការផ្តន្ទាទោស ខៀវ សំផន នេះ ត្រូវបានធ្វើឡើងដោយរំលោភលើច្បាប់ស្តីពីភ័ស្តុតាងជាធរមាន[498]។ តុលាការកំពូលត្រូវតែធ្វើមោឃភាពលើសេចក្តីសន្និដ្ឋានទាំងនេះ និងកត់សម្គាល់អំពីភាពអយុត្តិធម៌នៃការជំនុំជម្រះក្តី។

---

[492] អនុស្សរណៈ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ឯកសារ E319/14/2 កថាខណ្ឌ ៩។

[493] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ១០៧។

[494] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៥០។

[495] សូមមើលខាងក្រោម កថាខណ្ឌ ៩៧៨-៩៨០។

[496] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣២។

[497] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៥។

[498] សូមមើលខាងក្រោម កថាខណ្ឌ ៩៧៨-៩៨០។

## ២. ការវាយតម្លៃលើចម្លើយ

៣១៧. អង្គជំនុំជម្រះក៏ដូចជាតុលាការកំពូលបានពិចារណាថា ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានតម្លៃស្មើគ្នានឹងចម្លើយរបស់សាក្សីដែរ។ អាស្រ័យហេតុនេះ តុលាការកំពូលបានផ្តល់សុពលភាពដល់សេចក្តីសន្និដ្ឋានពាក់ព័ន្ធចំណុចនេះទាំងអស់របស់អង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ដោយផ្អែកលើវិធាន ៩១(១) នៃវិធានផ្ទៃ[499]។

៣១៨. តុលាការកំពូលក៏បានផ្តល់សុពលភាពដល់ការវាយតម្លៃរបស់អង្គជំនុំជម្រះលើករណីនីមួយៗ ជាអាទិ៍លើអត្តចរិតរបស់បុគ្គលដែលផ្តល់សក្ខីកម្ម ភាពស៊ីចង្វាក់គ្នានៃការនិទានឡើងវិញពីអង្គហេតុសំខាន់ៗ ឬភាពផ្ទុយគ្នានៃអង្គហេតុទាំងនេះ គោលដៅលាក់បាំងដែលគាត់ចង់សម្រេចឱ្យបាន ការអះអាងបញ្ជាក់ និងកាលៈទេសៈនានានៃរឿងក្តី[500]។ នៅក្នុងសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានបន្តប្រកាន់យកគោលជំហរនេះដដែល[501]។ ខុសពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្បថទេ ហើយក្នុងឋានៈជាភាគី ពួកគាត់ថែមទាំងមានផលប្រយោជន៍ពីកិច្ចដំណើរការនីតិវិធីទៀតផង។ អាស្រ័យហេតុនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចផ្តល់ការធានាអំពីអនាគតិភាពដូចគ្នានឹងសាក្សីឡើយ។ ប្រសិនបើអង្គជំនុំជម្រះសម្រេចផ្តល់តម្លៃដល់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្មើនឹងចម្លើយរបស់សាក្សី ខ្លួនជាប់កាតព្វកិច្ចផ្ទៀងផ្ទាត់អំពីភាពគួរជឿជាក់បាន និងភាពគួរឱ្យទុកចិត្តបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយយោងទៅតាមកាលៈទេសៈនានានៃរឿងក្តីនេះ។

---

[499] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣១៣៖ "ដូចនេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានលើកយកមកនិយាយ ព្រមគ្នាជាមួយនឹងសាក្សី និងអ្នកជំនាញថាជាមធ្យោបាយសម្រាប់បង្ហាញការពិតទាក់ទងទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងអាចសំអាងលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់អំពីពិរុទ្ធភាព ដូចគ្នាទៅនឹងការដែលអង្គជំនុំជម្រះសំអាងលើសក្ខីកម្មរបស់ជនជាប់ចោទផងដែរ ប្រសិនបើជនជាប់ចោទសម្រេចចិត្តផ្តល់សក្ខីកម្ម។ ដោយហេតុថាឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចជាប់ពាក់ព័ន្ធទៅនឹងតម្លៃជាភ័ស្តុតាង និង/ឬភាពអាចជឿជាក់បាននៃសក្ខីកម្ម ពុំមានហេតុផលអ្វីត្រូវបដិសេធសក្ខីកម្មនេះឡើយ"។

[500] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣១៤។

[501] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៧។

៣១៩. ក៏ប៉ុន្តែ តាមការសង្កេតជាក់ស្តែង ទោះបីជាដើម្បីបណ្តឹងរដ្ឋប្បវេណីណាម្នាក់មិនគួរឱ្យទុកចិត្ត និងជឿជាក់បានក៏ដោយ ក៏អង្គជំនុំជម្រះនៅតែផ្អែកលើសក្ខីកម្មរបស់គាត់ ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីពិរុទ្ធភាពដែរ[502]។ សក្ខីកម្មរបស់ អែម អឿន ដែលត្រូវបានទទួលយកដើម្បីដាក់បន្ទុក ពាក់ព័ន្ធនឹងសម្តីដែលគាត់ថាជារបស់ ខៀវ សំផន នៅក្នុងវគ្គរៀនសូត្រមួយ គឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយបញ្ជាក់អំពីរបៀបដែលអង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការវាយតម្លៃលើភាពអាចជឿបានរបស់ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូប[503]។ គេសង្កេតឃើញការអនុវត្តដូចគ្នាចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ស្តីពីខ្លឹមសារនៃសុន្ទរកថាដែលសន្មតថាជារបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងអាពាហ៍ពិពាហ៍[504]។ ការសន្និដ្ឋានបែបនេះត្រូវទុកជាមោឃៈ។

## ផ្នែកទី ៨. ឯកសារដែលទទួលបានសច្ចធារណ៍ថាអាចទទួលយកបាន

៣២០. ដូចបានរំឮកនៅក្នុងអំឡុងពេលសវនាការលើសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបាន "ពិចារណាថាឯកសារ [ខ្លះ] ត្រូវបានផ្តល់សច្ចធារណ៍ដែលអាចជំទាស់បាន ដោយយោងទៅតាមភាពពាក់ព័ន្ធ និងភាពអាចទុកចិត្តបាន (រាប់បញ្ចូលទាំងយថាភាពដែរ)"[505]។ អង្គជំនុំជម្រះក៏បានដកស្រង់ផងដែរនូវយុត្តិសាស្ត្ររបស់តុលាការកំពូល ដែលបានពិចារណាថា "ចំពោះឯកសារបានទទួលសច្ចធារណ៍ដែលអាចជំទាស់បាន ក្នុងករណីមានការជំទាស់អំពីយថាភាព គឺភាគីជំទាស់ត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃឯកសារនេះ"[506]។ នៅទីបញ្ចប់ ក្នុងករណីបដិសេធសច្ចធារណ៍នេះ អង្គជំនុំជម្រះបានពិចារណាថា "គឺភាគីជំទាស់លើភាពទុកចិត្តបាន ឬយថាភាពនៃភស្តុតាង ជាអ្នកកំណត់ភស្តុតាងនោះ និងត្រូវផ្តល់សំអាងហេតុគាំទ្រការបដិសេធសច្ចធារណ៍។ ក្នុងករណីកើតមានបញ្ហាបែបនេះ អង្គជំនុំ

---

[502] សូមមើលខាងក្រោម ឧទាហរណ៍អង្គហេតុ ជាពិសេសនៅក្នុងកថាខណ្ឌ ៩៧៨-៩៨០, ១០១៤-១០១៦, ១២៣៣-១២៤២។

[503] សូមមើលខាងក្រោម កថាខណ្ឌ ១៧៥៤-១៧៦២។

[504] សូមមើលខាងក្រោម កថាខណ្ឌ ១២៣៣-១២៤២។

[505] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦។ សាលក្រម សំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ កថាខណ្ឌ ៣៤។

[506] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ កថាខណ្ឌ ៣៧៥។

ជម្រះពិនិត្យមើលករណីជាក់ស្ដែងនីមួយៗ ហើយប្រសិនបើពុំមានផ្ដល់យុត្តិកម្មណាមួយទេ សច្ចធារណ៍នៃភាពអាចទុកចិត្តបាន (រួមទាំងយថាភាពផង) ត្រូវតម្កល់ដដែល”[507]។

៣២១. វិធីសាស្រ្តនេះមិនបានផ្ដល់ការធានាគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងបទដ្ឋាននៃភ័ស្តុតាងនៅក្នុងនីតិព្រហ្មទណ្ឌឡើយ។ ជាពិសេស ក្នុងរឿងក្ដីនេះតែម្ដង គេត្រូវតែគោរពវិធានទាំងនេះ ឱ្យកាន់តែខ្លាំងថែមទៀត ដោយហេតុថាទាំងភ័ស្តុតាងជាក់បង្ហាញ ទាំងការចងចាំហេតុការណ៍ដែលបានកើតឡើងកាលពី៤០ឆ្នាំមុន សុទ្ធតែមានចន្លោះប្រហោងទាំងអស់។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែដាក់ចេញនូវក្របខ័ណ្ឌវាយតម្លៃដ៏តឹងរ៉ឹងមួយ ហើយត្រូវវាយតម្លៃតាមករណីជាក់ស្ដែង។

៣២២. ក្នុងរឿងក្ដី *Prlić* សាលាឧទ្ធរណ៍នៃយន្តការអន្តរជាតិទទួលបន្ទុកបំពេញមុខងារសេសសល់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានបង្កើតក្របខ័ណ្ឌវាយតម្លៃយថាភាពនៃឯកសារហួតចត់ជាងនេះ ដើម្បីធានាបទដ្ឋាននៃភ័ស្តុតាង៖ “*(១) ទាល់តែមានអង្គជំនុំជម្រះសាលាដំបូងមួយផ្សេងទៀតបានទទួលស្គាល់ឯកសារទាំងនេះជាភ័ស្តុតាង (២) ទាល់តែមានសាក្សីម្នាក់ថ្លែងថាគាត់ចំណាំអក្សរសរសេរដោយដៃរបស់លោក Mladic ក្នុងសៀវភៅកត់ត្រាប្រចាំថ្ងៃផ្ទាល់ខ្លួនគាត់ (៣) ទាល់តែមានចម្លើយសាក្សីណាមួយទាក់ទងទៅនឹងខ្សែចង្វាក់នៃការថែរក្សាសៀវភៅនេះ និង (៤) ទាល់តែមានឯកសារភ័ស្តុតាងបញ្ជាក់គាំទ្រដល់អង្គហេតុមួយចំនួនដែលមានរៀបរាប់នៅក្នុងសៀវភៅនេះ*[508]។ ផ្ទុយពីសំអាងហេតុសាលក្រមរងបណ្ដឹងសាទុក្ខនេះ សាលាឧទ្ធរណ៍នេះបានចាត់ទុកថាវាមិនគ្រប់គ្រាន់ទេក្នុងការទទួលយកយថាភាពនៃភ័ស្តុតាងមួយ ដោយគ្រាន់តែផ្អែកលើសច្ចធារណ៍ដែលអាចជំទាស់បានដោយពុំមានលក្ខណៈវិនិច្ឆ័យសត្យានុម័តិណាមួយ។ ប៉ុន្តែ សាលាឧទ្ធរណ៍នេះបានបង្កើតវិធីវាយតម្លៃដោយផ្អែកលើកត្តាចង្អុលបង្ហាញច្បាស់លាស់ជាច្រើន។ ការរកឃើញនេះរបស់អង្គជំនុំជម្រះ កាន់តែទទួលរងការរិះគន់ខ្លាំងថែមទៀត ដោយហេតុថាក្នុងអំឡុងពេលជំនុំជម្រះក្ដី មេធាវីការពារក្ដីបានដាក់សារណាជាច្រើន ដើម្បីជំទាស់នឹងយថាភាពនៃភ័ស្តុតាងមួយចំនួន ដោយពុំបានទទួលចម្លើយមាន

---

[507] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦។

[508] សាលដីកា *Prlić* និងអ្នកដទៃទៀត (យន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ ១២១។

សំអាងហេតុណាមួយឡើយ[509]។ ផ្អែកលើអសច្ចភាពតគិយុត្តិ ដែលកើតចេញពីក្របខ័ណ្ឌសម្រាប់វាយតម្លៃយថាភាពនៃភ័ស្តុតាងមួយចំនួន សេចក្តីសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ[510]។

## ផ្នែកទី ៩. ភ័ស្តុតាងជាឯកសារ និងយថាភាព

### ១. ក្របខ័ណ្ឌវាយតម្លៃភ័ស្តុតាងជាឯកសារ និងឯកសារនៅសម័យអន្តហេតុ

### ១.១. ភាពអាចចូលពិគ្រោះបាននៃឯកសារសម័យអន្តហេតុ .

៣២៣. អង្គជំនុំជម្រះបានរំឭកថា "ឯកសារនានាដែលត្រូវបានធ្វើឡើងនៅសម័យអង្គហេតុ ស្ថិតក្នុងចំណោមប្រភពភ័ស្តុតាងសំខាន់ៗបំផុត"[511]។ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា "ឯកសារទាំងអស់ [ខ្លះ] ដែលត្រូវបានដាក់បង្ហាញនៅចំពោះមុខខ្លួន រួមមានកំណត់ហេតុប្រជុំ ឬការប្រស្រ័យទាកទងនានា ហើយថាខ្លួនពុំបានស្តាប់សក្ខីកម្មផ្ទាល់ណាមួយស្តីពីឯកសារទាំងនេះទេ"[512]។ ជាចុងក្រោយ អង្គជំនុំជម្រះបានបន្ថែមថា "ឯកសារភាគច្រើនលើសលប់ [មួយចំនួនធំ] នៃឯកសារសម័យអង្គហេតុដែលបានបញ្ចូលទៅក្នុងសំណុំរឿង អាចចូលពិគ្រោះបានតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងខណៈដែលច្បាប់ដើមមាននៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរទួលស្លែង បណ្ណសារជាតិនៃកម្ពុជា ឬមជ្ឈមណ្ឌលបុប្ផាណា"[513]។ ប្រសិនបើឯកសារសម័យអង្គហេតុនៅក្នុងសំណុំរឿង អាចពិគ្រោះបានតាមប្រព័ន្ធប្រព័ន្ធអេឡិចត្រូនិច ដូចដែលអង្គជំនុំជម្រះបានចង្អុលបង្ហាញនោះ គឺឯកសារទាំងនេះគ្រាន់តែជាឯកសារថតចម្លងចេញពីឯកសារដែលប្រមូលបានដោយស្ថាប័នមិនមែនតុលាការ ដែលភាគច្រើនប្រមូលបានក្នុងល័ក្ខខ័ណ្ឌអាថ៌កំបាំង។ តាមពិត សាលាក្តីមានឯកសារដើមតែពីរប៉ុណ្ណោះ គឺឯកសារដែលផ្តល់ជូនដោយ Stephen HEDER កាលពីខែកក្កដា ឆ្នាំ២០១៣[514]។ លើសពីនេះទៀត ដូចដែលនឹងបាន

[509] សូមមើលខាងលើ កថាខណ្ឌ ២១៧-២២៥, ២២៦។

[510] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦។

[511] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧។

[512] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧។

[513] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧។

[514] អនុស្សរណៈ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E297** (គឺជាទស្សនាវដ្តី*យុវជន និងយុវនារីបដិវត្ត* មួយលេខ និងទស្សនា វដ្តី*ទង់បដិវត្ត* មួយលេខ)។

ឃើញខាងក្រោម អង្គជំនុំជម្រះបានយល់ច្រឡំ ដោយនិយាយថាមានច្បាប់ដើម[515]។ ដូច្នេះ ភ័ស្តុតាងប្រភេទនេះ គួរតែត្រូវបានពិនិត្យពិចារណា ដោយប្រុងប្រយ័ត្ន និងម៉ត់ចត់បំផុត។

### ១.២. ការវាយតម្លៃលើតម្លៃជាភ័ស្តុតាង

៣២៤. អង្គជំនុំជម្រះបានកំណត់ក្របខ័ណ្ឌទូទៅមួយសម្រាប់ការវាយតម្លៃលើតម្លៃជាភ័ស្តុតាង ដោយពិចារណាថា "ខ្លួនផ្អែកសេចក្តីសម្រេចរបស់ខ្លួនតែលើភ័ស្តុតាងណាដែលត្រូវបានដាក់បង្ហាញចំពោះមុខខ្លួនក្នុងអំឡុងពេលជំនុំជម្រះ និងដែលត្រូវបានសួរដេញដោលតតាំងគ្នាចំពោះមុខ"[516]។ បន្ទាប់មក អង្គជំនុំជម្រះបានបញ្ជាក់អំពីក្របខ័ណ្ឌនេះដោយប្រើវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង[517]។ ទោះជាក្របខ័ណ្ឌនៃការវាយតម្លៃភ័ស្តុតាងនេះមើលទៅហាក់ដូចជាគួរជាទីពេញចិត្ត ពេលឃើញពីដំបូងភ្លាមក៏ដោយ ក៏ប៉ុន្តែ អ្នកណាក៏កត់សម្គាល់ឃើញដែរថាអង្គជំនុំជម្រះនិយាយជាន់កែងខ្លួនឯង ដោយមិនបានអនុវត្តគោលការណ៍ដែលខ្លួនបានកំណត់ឱ្យបានខ្ជាប់ខ្ជួន[518]។

### ២. ឧទាហរណ៍បញ្ជាក់ពីកំហុសនៃការវាយតម្លៃលើភ័ស្តុតាងជាឯកសារ

### ២.១. លក្ខន្តិកៈរបស់ ប.ក.ក

---

[515] សូមមើលខាងក្រោម កថាខណ្ឌ ៣២៧-៣២៨។

[516] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១។

[517] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១ "កត្តាមួយចំនួនគឺមានភាពពាក់ព័ន្ធទៅនឹងតម្លៃនៃភ័ស្តុតាង ដែលកត្តាទាំងអស់នោះរួមមានលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧.៣ នៃផ្ទៃក្នុង កាលៈទេសៈជុំវិញ ការបង្កើត ឬកត់ត្រាភ័ស្តុតាង តើឯកសារដែលត្រូវបានទទួលយកនោះជាឯកសារដើម ឬឯកសារថតចម្លង លទ្ធភាពអានបាន ភាពមិនស៊ីចង្វាក់ខ្លះៗទៅនឹងសំណៅដទៃទៀត ភាពខ្វះចន្លោះដែលអាចចោទប្រកាន់ បានថាតើភាគីមានឱកាសសួរដេញដោលភ័ស្តុតាង និងសញ្ញាណផ្សេងៗទៀតនៃភាពអាចទុកចិត្តបាន រួមទាំងដំណើរការនៃការរក្សាភ័ស្តុតាង និងប្រភពភ័ស្តុតាង។ អង្គជំនុំជម្រះក៏ពិចារណាផងដែរទៅលើការកំណត់អត្តសញ្ញាណ ការពិនិត្យលើភ័ស្តុតាង ភាពលម្អៀង ប្រភព និងបុព្វហេតុរបស់បុគ្គលដែលជាម្ចាស់ភ័ស្តុតាងនោះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[518] សូមមើលឧទាហរណ៍អង្គហេតុខាងលើ កថាខណ្ឌ ២១៧-២២, ២២៦។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៦០៤, ១៨១៩-១៨២៨, ១៨៧៥។

៣២៥. ទាក់ទងនឹងលក្ខន្តិកៈរបស់ ប.ក.ក ឆ្នាំ១៩៧១ និងឆ្នាំ១៩៧៦ អង្គជំនុំជម្រះបានកត់សម្គាល់ថា "លក្ខន្តិកៈ [មិនពេញលេញ] ឆ្នាំ១៩៧៦ដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ជាសំណៅអក្សរពុម្ពពេញលេញនៃឯកសារស្ថាបនិករបស់ ប.ក.ក ហើយត្រូវបានបញ្ជាក់អំពីយថាភាពដោយសាក្សីជាច្រើន រួមមាន ឌុច និង នួន ជា"[519]។ ការអះអាងរបស់អង្គជំនុំជម្រះនេះ មិនត្រឹមត្រូវទេ។ នួន ជា មិនដែលបានបញ្ជាក់ជាផ្លូវការអំពីអត្តសញ្ញាណលក្ខន្តិកៈឆ្នាំ១៩៧៦ទេ។ ក្នុងអំឡុងពេលជំនុំជម្រះក្តីសំណុំរឿង ០០២/០១ គាត់បានឆ្លើយសំណួរមួយរបស់ចៅក្រម Cartwright ដែលសុំឱ្យគាត់កំណត់អត្តសញ្ញាណលក្ខន្តិកៈ ប.ក.ក។ គាត់មិនដែលបានអះអាងថាឯកសារដែលបានបង្ហាញជូនគាត់នោះ ជាលក្ខន្តិកៈ ប.ក.ក ឆ្នាំ១៩៧៦ ឡើយ។ លើសពីនេះទៅទៀត ឯកសារនេះមិនមានកាលបរិច្ឆេទទេ។ ដូច្នេះ អង្គជំនុំជម្រះក៏មិនអាចអះអាងបានដែរថា វាជាលក្ខន្តិកៈឆ្នាំ១៩៧៦[520]។ មួយវិញទៀត អង្គជំនុំជម្រះក៏បានធ្វើការប្រៀបធៀបលក្ខន្តិកៈបក្សឆ្នាំ១៩៦០ ១៩៧១ និង ១៩៧៦ ផងដែរ[521]។ ការប្រៀបធៀបនេះនាំឱ្យមានការវាយតម្លៃជាចាំបាច់លើតម្លៃជាភ័ស្តុតាងនៃឯកសារសម័យអង្គហេតុទាំងនេះ ដូចដែលអង្គជំនុំជម្រះធ្លាប់បានបង្ហាញនៅក្នុងសំអាងហេតុរបស់ខ្លួន[522]។ ក៏ប៉ុន្តែ បើតាមការសង្កេតជាក់ស្តែង អង្គជំនុំជម្រះបាននិយាយជាន់កែងខ្លួនឯងម្តងទៀត ដោយមិនអនុវត្តគោលការណ៍ដែលបានបង្កើតឡើងឱ្យបានខ្ជាប់ខ្ជួន។ ជាក់ស្តែង ក្នុងសំណុំរឿង ពុំមានដានណាមួយនៃលក្ខន្តិកៈឆ្នាំ១៩៦០ទេ។ ដូច្នេះ យើងមិនដឹងថាតើអង្គជំនុំជម្រះមានមូលដ្ឋានអ្វី ដើម្បីធ្វើការប្រៀបធៀបបែបនេះឡើយ។ ដោយហេតុថា ទាំងចៅក្រម ទាំង

---

[519] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥។

[520] <u>នួន ជា</u}៖ ប្រតិចារិក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ម៉ោង 10.09.26៖ "ឆ. ខ្ញុំសូមជម្រាបលោកចៅក្រម តាមខ្ញុំចាំ លក្ខន្តិកៈនេះមាន ៨ ជំពូក ហើយមាន៣០មាត្រា។ ប៉ុន្តែក្នុងនេះ ឃើញមានតែ ២៩មាត្រា ប៉ុន្តែតាមខ្ញុំចាំមាន ៣០ មាត្រា ៨ជំពូក។ ស. ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា នៅក្នុងអត្ថបទភាសាខ្មែរដែលលោកនួនជាកំពុងតែមាននោះ គឺមិនពេញទាំងស្រុងទេ ពីព្រោះអត្ថបទភាសាអង់គ្លេសនោះ តាមពិតគឺមាន ៨ ជំពូក ហើយមាន ៣០ មាត្រា។ សូមលោកចូលទៅដល់ចំណុចខាងក្រោយដែលបង្ហាញថា នៅក្នុងអេក្រង់របស់តុលាការនេះ តើមានទំព័រផ្សេងទៀតទេ ដូចដែលយើងឃើញនៅលើអេក្រង់នេះ។ សូមអញ្ជើញបើកមីក្រូហ្វូនពីលោក នួន ជា។ លោក នួន ជា នៅពេលដែលលោកបញ្ជាក់ ពេលនោះមីក្រូហ្វូនបានបិទទេ អ៊ីចឹងសូមលោកបញ្ជាក់ម្តងទៀត។ ឆ. ខ្ញុំមើលមិនឃើញទេ។ មើលអេក្រង់នេះមិនឃើញ។ លោកស្រីចៅក្រម CARTWRIGHT៖ មន្ត្រីតុលាការសូមពិនិត្យមើលអត្ថបទជាមួយលោក នួន ជា ដើម្បីមើលថាតើគាត់មានទំព័រដូចដែលយើងបានបញ្ជាក់ដែរឬទេ ? អ៊ីចឹងសូមជួយ។ នួន ជា៖ មានមាត្រា ៣០ នៅក្នុងជំពូកទី ៨។ លោកស្រីចៅក្រម CARTWRIGHT៖ សូមអរគុណ"។

[521] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨។

[522] សំអាងហេតុសាលក្រម កថាខណ្ឌ៦១។

ភាគី សុទ្ធតែពុំមានឯកសារនេះក្នុងដៃ យើងមិនដឹងថាអង្គជំនុំជម្រះអាចផ្អែកលើអ្វីនោះទេ។ ដោយអនុលោមតាមបទដ្ឋាននៃភស្តុតាង អង្គជំនុំជម្រះបានផ្តល់តម្លៃខ្ពស់ដល់ការស្មាន ដោយទាញការសន្និដ្ឋានទូទៅចេញពីឯកសារដែលខ្លួនមិនមានក្នុងដៃ។ ការសន្និដ្ឋានដោយផ្អែកលើភស្តុតាង ដែលមិនអាចត្រូវបានផ្ទៀងផ្ទាត់អំពីយថាភាព ត្រូវតែទុកជាមោឃៈ[523]។

## ២.២. កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

៣២៦. អង្គជំនុំជម្រះបានប្រើការវិភាគរបស់ខ្លួនក្នុងសាលក្រម ០០២/០១ ឡើងវិញ ទាក់ទងនឹងយថាភាព និងតម្លៃជាភស្តុតាងនៃកំណត់ហេតុកិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ២៣។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានរំឭកថា "[ខ្លួន] បានពិចារណារួចហើយថាមានការរកឃើញថា ខ្លឹមសារនៃកំណត់ហេតុប្រជុំទាំង ២៦ របស់គណៈកម្មាធិការអចិន្ត្រៃយ៍ អាចទទួលសច្ចធារណ៍ថាគួរជាទីទុកចិត្តបាន (រាប់បញ្ចូលទាំងយថាភាពនៃឯកសារទាំងនេះផង) ដោយផ្អែកលើវិធីសាស្ត្រដែលប្រើដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីវាយតម្លៃ និងរក្សាទុកឯកសារ និង/ឬដោយហេតុថា ឯកសារទាំងនេះត្រូវបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ"[524]។ ក៏ប៉ុន្តែ ទោះជាអង្គជំនុំជម្រះហាក់ដូចជាទុកចិត្តផ្កាប់មុខលើវិធីសាស្ត្រដែលប្រើដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដោយ ក៏មេធាវីការពារក្តីនៅតែមិនជឿជាក់ថា អង្គជំនុំជម្រះផ្តល់នូវការធានាផ្នែកតុលាការ និងនីតិវិធីគ្រប់គ្រាន់ដែរ។ ជាក់ស្តែង យើងមិនច្បាស់ទេថា តើអង្គជំនុំជម្រះយោងទៅវិធីសាស្ត្រណា។ អង្គជំនុំជម្រះមិនបានប្រាប់ថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំលក្ខណៈយ៉ាងដូចម្តេចក្នុងការវិភាគភស្តុតាងទាំងនេះ ហើយបានល្អប៉ុនណា រហូតដល់គ្មានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពណាមួយត្រូវបានធ្វើឡើង។ ហេតុដូចនេះ អង្គជំនុំជម្រះបានពិចារណាថា៖

> "នៅពេលដែល ខ្លួនសម្រេចលើភាពអាចទទួលយកបាននៃឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឱ្យជាទម្រង់ឌីជីថល អង្គជំនុំជម្រះបានសម្រេចថា [ខ្លួន] ជឿជាក់ថា នីតិវិធី

---

[523] *ជាពិសេស* កថាខណ្ឌ ៣៩៤, ៣៩៨។

[524] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧។

ដែលប្រើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា [ក្នុងការប្រមូល និងថែរក្សាឯកសារ] មិនបង្កឱ្យមានការបារម្ភមិនសមហេតុផលណាមួយដែលថា ឯកសារបានមកពីប្រភពនេះអាចត្រូវបានក្លែងបន្លំ ឬក្លែងក្លាយឡើយ"។ អង្គជំនុំជម្រះបានកត់សម្គាល់ថា នៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានឯកសារច្បាប់ដើមមួយចំនួននៃកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍។ ប្រសិនបើមានកូនចិត្តព្រួយបារម្ភទាក់ទងនឹងភាពត្រឹមត្រូវនៃឯកសារថតចម្លងដែលបានបញ្ចូលក្នុងសំណុំរឿង ឬប្រភពភ័ស្តុតាង ឬភាពទុកចិត្តបាននៃឯកសារមួយចំនួនភាគីអាចពិគ្រោះច្បាប់ដើមដែលមានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដោយហេតុថាពុំមានភ័ស្តុតាងថ្មី ឬទឡ្ហីករណ៍ថ្មីណាមួយទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះចាត់ទុកថាការវិភាគពីមុនរបស់ខ្លួននៅតែមានសុពលភាព និងប្រកាន់យកសំអាងហេតុដដែលមកប្រើទាក់ទងនឹងភាពអាចជឿជាក់បាននៃឯកសារភ័ស្តុតាងទាំងនេះ"[525]។

៣២៧. នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៩៣៤ នៃកថាខណ្ឌ ៣៤៨ នៃសំអាងហេតុសាលក្រមនេះ អង្គជំនុំជម្រះផ្អែកលើចម្លើយរបស់ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលថាស្ថាប័នគាត់ "នឹងឆ្លើយតបទៅនឹងរាល់សំណើសុំឯកសារដែលដាក់ដោយមេធាវីការពារក្តី"[526]។ ក៏ប៉ុន្តែ យើងគួររំឭកថាជាក់ស្តែង អង្គជំនុំជម្រះមានឯកសារច្បាប់ដើមតែពីរប៉ុណ្ណោះ ដែលបានផ្តល់ដោយ Stephen HEDER កាលពីខែកក្កដា ឆ្នាំ២០១៣[527]។ ម្យ៉ាងវិញទៀត បើទោះជាមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារដែលខ្លួនចាត់ទុកថាជាច្បាប់ដើមក៏ដោយ (ហើយឯកសារទាំងនេះមិនដែលត្រូវបានផ្ទៀងផ្ទាត់ដោយអង្គជំនុំជម្រះឡើយ) ក៏ លោកនាយក ឆាង យុ មិនចង់ប្រាប់ក្នុងសវនការសំណុំរឿង០០២/០១ ថា ឯកសារ

[525] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨។

[526] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨។ កថាខណ្ឌ ៣៤៨។ កំណត់សម្គាល់ជើងទំព័រលេខ៩៦៤ "ប្រតិចារឹក ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២ (ឆាំង យុ) ឯកសារលេខ **E1/37.1** ទំព័រ ១០៣ និង ១០៤ (នៅក្នុងទីនេះ សាក្សីពន្យល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្លើយតបទៅរាល់ការស្នើសុំឯកសារដែលស្នើដោយមេធាវីការពារក្តី) ទំព័រ១០២ ដល់១០៤ (នៅទីនេះ សាក្សីបង្ហាញឯកសារផ្សេងៗដែលក្រុមមេធាវីការពារក្តីបានពិគ្រោះនៅមជ្ឈមណ្ឌលឯកសារកម្ពុជា) និងនៅទំព័រ ១០៥ (នៅទីនេះ សាក្សីនិយាយថាគ្មានភាគីណាមួយដែលត្រូវបានអនុញ្ញាតឱ្យអានឯកសារច្បាប់ដើមឡើយ)"។

[527] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E297** (គឺជាទស្សនាវដ្តី*យុវជន និងយុវនារីបដិវត្ត* មួយលេខ និង ទស្សនាវដ្តី*ទង់បដិវត្ត*មួយលេខ)។ សូមមើលខាងលើផងដែរ កថាខណ្ឌ ២២៦។

ទាំងនេះស្ថិតនៅទីណានោះដែរ ហើយដែលប្រការនេះហាក់ដូចជាមិនចោទជាបញ្ហាអ្វីទាំងអស់ដល់អង្គជំនុំជម្រះ ដោយប្រធានអង្គជំនុំជម្រះបានថ្លែងថា៖

> "លោកសាក្សីមិនចាំបាច់ឆ្លើយសំណួរដែលសួរដោយមេធាវីការពារក្តីទេ ពីព្រោះវាពាក់ព័ន្ធនឹងហេតុផលសុវត្ថិភាពទាក់ទងនឹងច្បាប់ដើម។ មិនចាំបាច់បង្ហាញពីទីតាំងនៃឯកសារច្បាប់ដើមទាំងនេះទេ។ ភាគីខ្លះបានស្នើសុំបើកសវនាការអសាធារណៈ។ ប៉ុន្តែ ចំពោះអង្គជំនុំជម្រះ វាហាក់ដូចជាមិនបានប្រយោជន៍អីទេ។ លោកអាចបន្តផ្តល់សក្ខីកម្មទៀតបាន ប៉ុន្តែដូចដែលខ្ញុំបានបង្គាប់អញ្ជើង គឺមិនត្រូវបង្ហាញទីតាំងថែរក្សាឯកសារច្បាប់ដើមទាំងនេះទេ។ បញ្ហាចម្បងគឺផ្តោតលើឯកសារថតចម្លង"[528]។

៣២៨. ដូច្នេះ យើងមិនដឹងថាតើច្បាប់ដើមទាំងនេះរក្សាទុកនៅឯណា ដោយសារមូលហេតុសុវត្ថិភាពបែបសន្ទុត ហើយមូលហេតុទាំងនេះក៏មិនបានពន្យល់ដល់ភាគីដែរ។ "ច្បាប់ដើម" ទាំងនេះមិនដែលត្រូវបានផ្ទៀងផ្ទាត់ដោយអង្គជំនុំជម្រះ ឬអ្នកជំនាញដែលត្រូវបានចាត់តាំងឡើយ។ អង្គជំនុំជម្រះគ្រាន់តែបណ្តោយខ្លួនតាមអារម្មណ៍ទុកចិត្តគួរឱ្យភ្ញាក់ផ្អើល ក្នុងរឿងក្តីដ៏ធំធេងនេះ។ ទង្វើនេះមិនមានសំអាងហេតុគាំទ្រក្នុងច្បាប់សោះឡើយ ហើយវាក៏មិនផ្តល់ការធានាផ្នែកនីតិវិធីណាមួយដែរ។ អង្គជំនុំជម្រះចង់ផ្តោតការយកចិត្តទុកដាក់លើ "ការចម្លងឯកសារ" ដោយបំភ្លេចរឿងសំខាន់បំផុត គឺការផ្ទៀងផ្ទាត់យថាភាពនៃច្បាប់ដើម ដើម្បីឱ្យដឹងថាតើឯកសារចម្លងទាំងនោះអាចត្រឹមត្រូវទុកចិត្តបាន ឬទេ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាភាគីនៃរឿងក្តី។ អ្នកតំណាងអង្គការនេះមិនធ្វើសច្ចាប្រណិធានចំពោះមុខសាលាក្តី។ ពួកគេបំពេញបេសកកម្មសេវាសាធារណៈសម្រាប់ប្រទេសកម្ពុជា ដោយមានទស្សនៈលម្អៀង ប៉ុន្តែវាជាសិទ្ធិរបស់ពួកគេ។ ក៏ប៉ុន្តែ គោលជំហរនេះមិនឆ្លើយតបនឹងការធានាផ្នែកច្បាប់ និងនីតិវិធីនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌទេ។ ក្នុងចំណោមមូលហេតុជាច្រើនទៀត គឺដោយសារគោលជំហរលម្អៀងនេះហើយទើបបទសម្ភាសន៍ដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា មិនទទួលបានសច្ចធារណ៍ថាអាចជឿជាក់បាន[529]។ តើយើងអាចនិយាយបានថាកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍

[528] ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **E1/38.1** ទំព័រ ១២ ម៉ោង 09.28.13 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[529] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ១០៤-១០៨។

ដែលទទួលបាន និងថែរក្សាដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានផ្ទៀងផ្ទាត់ដែរឬទេ។ ទេ! ដូច ដែលបានចង្អុលបង្ហាញអញ្ចើង គ្មានភ័ស្តុតាងណាមួយដែលថា អង្គជំនុំជម្រះពិតជាបានផ្ទៀងផ្ទាត់យថាភាពនៃឯកសារទាំងនេះឡើយ។ តើមជ្ឈមណ្ឌលឯកសារកម្ពុជាជាស្ថាប័នមួយដែលមើលទៅទំនងជាស្ថាប័នឯករាជ្យដែរឬទេ? អង្គជំនុំជម្រះគួរតែបង្ហាញចំណុចទាំងនេះ ប៉ុន្តែខ្លួនមិនដែលបំពេញកិច្ចការនេះសោះ។ ក្នុងល័ក្ខខ័ណ្ឌនេះ ការសន្និដ្ឋានខាងលើត្រូវទុកជាមោឃៈ[530]។

## ផ្នែកទី ១០. អ្នកជំនាញ

៣២៩. ក្នុងអំឡុងពេលជំនុំជម្រះក្តីសំណុំរឿង ០០២/០២ អ្នកជំនាញដូចតទៅនេះ ត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសវនាការ៖ Elizabeth BECKER, Henri LOCARD, អ៊ីសា ឧស្មាន, វឿន វុទ្ធី, Peg LEVINE, Kasumi NAKAGAWA, Alexander HINTON និង Stephen MORRIS។ អង្គជំនុំជម្រះបានថ្លែងថាបានវាយតម្លៃយ៉ាងល្អិតល្អន់លើប្រភពដែលជាមូលដ្ឋាននៃការសន្និដ្ឋានរបស់អ្នកជំនាញ[531]។

៣៣០. នៅក្នុងសំអាងហេតុសាលក្រមទាក់ទងនឹងបរិការណ៍ប្រវត្តិសាស្ត្រ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា ហេតុការណ៍ដែលបានកើតឡើងក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវតែបានស្វែងយល់តាមរយៈព្រឹត្តិការណ៍ដែលបានកើតឡើងមុនពេលបង្កើតរបបនេះ[532]។ ដូច្នេះ អង្គជំនុំជម្រះបានបញ្ជាក់ថា ក្នុងការធ្វើបទបង្ហាញអំពីការបង្កើត និងការងើបឡើងនៃ ប.ក.ក ខ្លួនបានផ្អែកជាពិសេសទៅលើសក្ខីកម្មស្នាដៃ និងឯកសាររបស់ជនជាប់ចោទ និងអ្នកជំនាញ[533]។ ចំពោះការវាយតម្លៃលើធាតុផ្សំភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនបានផ្តល់ទម្ងន់ធ្ងន់ដល់សក្ខីកម្មដែលបានធ្វើឡើងក្នុងសវនាការ

---

[530] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧, ៦១, ៣៤៤។ ៣៤៧-៣៥១, ៣៩៨។

[531] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៦។ សូមមើលផងដែរ៖ "អង្គជំនុំជម្រះត្រូវតែពិនិត្យ ពិចារណាដោយប្រុងប្រយ័ត្នទៅលើប្រភពនានាដែលអ្នកជំនាញបានប្រើជាសំអាងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ពួកគាត់។ ក្នុងករណីដែលការសម្រេចផ្អែកអង្គហេតុដោយផ្អែកទៅលើស្នាដៃនិពន្ធរបស់អ្នកជំនាញណាម្នាក់ ត្រូវតែមានការចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីប្រភពជាក់លាក់ និងអាចផ្ទៀងផ្ទាត់បាន ដែលជាមូលដ្ឋាននៃមតិយោបល់របស់អ្នកជំនាញរូបនោះ។

[532] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩១-១៩៥។

[533] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩២។

និងដល់ឯកសារដែលបានមកពីអ្នកនិពន្ធដែលត្រូវបានសាកសួរ ក្នុងអំឡុងពេលជំនុំជម្រះលើចំណុច ប្រវត្តិសាស្ត្រពាក់ព័ន្ធ និងដែលស្នាដៃរបស់ពួកគេត្រូវបានសួរដេញដោលដោយភាគី[534]។ បើទោះជា មេធាវីការពារក្តីយល់ស្របនឹងការវិភាគនេះក៏ដោយ ក៏យើងយល់ឃើញថា អង្គជំនុំជម្រះលើកឡើង ជាន់កែងខ្លួនឯងនៅក្នុងផ្នែកសំអាងហេតុរបស់ខ្លួន ដោយមិនបានអនុវត្តក្របខ័ណ្ឌវាយតម្លៃភ័ស្តុតាង ដែលបង្ហាញដោយអ្នកជំនាញ ជាពិសេស ដោយបដិសេធតាមទំនើងចិត្តនូវភ័ស្តុតាងពាក់ព័ន្ធ កាលណា វាជាភ័ស្តុតាងដោះបន្ទុកសម្រាប់ម្ចាស់បណ្តឹងសាទុក្ខ[535]។ តុលាការកំពូលត្រូវធ្វើមោឃភាពការ សន្និដ្ឋានបែបនេះ និងកត់សម្គាល់ពីភាពអយុត្តិធម៌នៃការជំនុំជម្រះក្តី ខៀវ សំផន។

## មាតិកាទី ៤. សេចក្តីសន្និដ្ឋាន - ឥទ្ធិពលត្រួតគ្នានៃការរំលោភបំពាន

៣៣១. យោងទៅតាមយុត្តិសាស្ត្រអន្តរជាតិ និងយុត្តិសាស្ត្រនៃសិទ្ធិមនុស្ស វាជាកាតព្វកិច្ចរបស់តុលាការកំពូល ក្នុងការពិនិត្យមើលថា តើការរំលោភលើសិទ្ធិជាមូលដ្ឋានមិនមានអានុភាពត្រួតគ្នាដែលបណ្តាលឱ្យការ កាត់ក្តីមិនមានភាពយុត្តិធម៌ដែរឬទេ[536]។

---

[534] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៥។

[535] សូមមើលឧទាហរណ៍អង្គហេតុខាងក្រោម ជាពិសេស នៅក្នុងកថាខណ្ឌ ១២០៩-១២១០។ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៣១ (LEVINE) កថាខណ្ឌ ៣៥៣៣ (NAKAGAWA)។

[536] សាលដីកា *Ntagerura* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ១១៤ ("ទោះបីជាទឡ្ហីករណ៍របស់រដ្ឋអាជ្ញាដែលថាបទចោទត្រូវបានជម្រះវិការៈ បានចម្រើនទៅមុខតាមករណីនីមួយៗ ហើយទោះបីជាយ៉ាងណា តុលាការកំពូលត្រូវមានកណើយកិច្ចពិនិត្យមើលថាតើទំហំនៃវិការៈដែលរកឃើញទាំងនោះបានធ្វើឱ្យការជំនុំជម្រះបាត់បង់ភាពយុត្តិធម៌ដែរឬទេ"។ សាលដីកា *Mirilachvili ទល់នឹងប្រទេសរុស្ស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ១៦៥-១៦៦ ("ក្នុងរឿងក្តី *Barberà, Messegué* និង *Jabardo ទល់នឹងប្រទេសអេស្ប៉ាញ* (សាលដីកាចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៨៨ ស៊េរី A លេខ ១៤៦ កថាខណ្ឌ ៨៩) អង្គជំនុំជម្រះបានវិនិច្ឆ័យថាឥទ្ធិពលត្រួតគ្នានៃការមិនគោរពវិធានបញ្ញត្តិជាច្រើនបានបង្កឱ្យដំណើរការនីតិវិធីផ្ទៃក្នុងមានភាពអយុត្តិធម៌។ បើពិនិត្យដាច់ដោយឡែកពីគ្នា វិការៈនីមួយៗមិននាំឱ្យអង្គជំនុំជម្រះចេញសេចក្តីសន្និដ្ឋានបែបនេះឡើយ។ តែការផ្តុំវិការៈទាំងអស់បញ្ចូលគ្នាបាននាំឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានថាមានការរំលោភលើមាត្រា ៦។ និយាយរួម ដើម្បីកំណត់ថាតើមានការរំលោភលើមាត្រា ៦ កថាខណ្ឌ ១ និង ៣ អង្គជំនុំជម្រះត្រូវបានជំរុញឱ្យវិភាគដាច់ដោយឡែកពីគ្នានូវមូលដ្ឋាននីមួយៗរបស់ម្ចាស់បណ្តឹង មុននឹងធ្វើការវាយតម្លៃរួម (សូមមើលករណីស្រដៀងទៅនឹងរឿងក្តី *Goddi ទល់នឹងប្រទេសអ៊ីតាលី* ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៨៤ កថាខណ្ឌ ២៨ ស៊េរី A លេខ ៧៦)"។

៣៣២. ក្នុងរឿងក្ដីនេះ ដូចដែលបានបង្ហាញជាច្រើនលើកច្រើនសាមកហើយ នៅក្នុងផ្នែកនេះ និងនៅក្នុងបណ្ដឹងសាទុក្ខទាំងមូលតែម្ដង អំពីការរំលោភបំពានលើសិទ្ធិរបស់ ខៀវ សំផន រួមមាន សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ ការកាត់សេចក្ដីដោយតុលាការមួយដែលជំនុំជម្រះតែលើបណ្ដឹងជាក់ស្ដែង ឬដោយតុលាការដែលបង្កើតឡើងដោយច្បាប់ ការជូនដំណឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ សច្ចភាពគតិយុត្តិ និងនីតិវិធី ការកាត់សេចក្ដីដោយតុលាការឯករាជ្យ និងមិនលម្អៀង សច្ចធារណ៍និរទោស ពេលវេលា និងមធ្យោបាយចាំបាច់សម្រាប់ការរៀបចំការពារក្ដី សវនាការចំពោះមុខ សិទ្ធិឱ្យគេដឹងឮពីបុព្វហេតុរបស់គាត់ ការការពារក្ដីប្រកបដោយប្រសិទ្ធភាព តម្លាភាពនៃនីតិវិធី សំអាងហេតុនៃដីកា និងសាលក្រម សមភាពនៃគូភាគី ព្រមទាំងសិទ្ធិមិនត្រូវបានចោទប្រកាន់ ឬដាក់ទណ្ឌកម្ម ចំពោះបទល្មើសដែលគាត់ត្រូវបានលើកលែងទោស ឬផ្ដន្ទាទោសរួចហើយ។

៣៣៣. អានុភាពត្រួតគ្នានៃការរំលោភបំពានទាំងនេះ បានធ្វើឱ្យការជំនុំជម្រះក្ដីលើ ខៀវ សំផន មិនយុត្តិធម៌តែម្ដង។ ការសម្រេចលើពិរុទ្ធភាព និងការផ្ដន្ទាទោសគាត់ ត្រូវតែទុកជាមោឃៈ។

## ភាគទី ២. កំហុសពាក់ព័ន្ធនឹងវិសាលភាពនៃបណ្ដឹង

### មាតិកាទី ១. ការអនុវត្តហួសពីវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យជំនុំជម្រះ

#### ជំពូកទី ១. អង្គច្បាប់

៣៣៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានពិចារណាថា សំណើរបស់មេធាវីការពារក្ដីសុំឱ្យពិនិត្យភាពមិនត្រឹមត្រូវតាមច្បាប់នៃចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបានស៊ើបសួរលើអង្គហេតុនៅក្រៅវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គួរតែត្រូវបានលើកឡើងដោយអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[537]។ ដោយផ្អែកលើច្បាប់ជាធរមាន អង្គជំនុំជម្រះមិនអាចចាត់ទុកថា សំណើសុំធ្វើអញ្ញត្រកម្មទាំងនេះមិនអាចទទួលយកបាន ដោយសារធ្វើឡើងយឺតយ៉ាវ

[537] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៨-១៦៥។

នោះទេ (ផ្នែកទី ១)។ អង្គជំនុំជម្រះគួរតែពិនិត្យ និងយល់ស្របតាមសំណើទាំងនេះ (ផ្នែកទី ២ និងជំពូកបន្ទាប់)។

## ផ្នែកទី ១. ភាពអាចទទួលយកបាន

៣៣៥. ការចាត់ទុកថាសំណើទាំងនេះជាការសុំធ្វើអញ្ញត្រកម្មមិនត្រឹមតែខុសប៉ុណ្ណោះទេ (១) វាជាការធ្វើឡើងបែបឱកាសនិយមទៀតផង (២)។ ដោយខកខានមិនបានពិនិត្យសំណើទាំងនេះឱ្យបានស៊ីជម្រៅ អង្គជំនុំជម្រះបានប្រព្រឹត្តិយុត្តិនិសេធ (៣)។

### ១. ការភាន់ច្រឡំនៃការកំណត់ថាជាអញ្ញត្រកម្ម

៣៣៦. អង្គជំនុំជម្រះបានយល់ឃើញថា ការបដិសេធមិនទទួលស្គាល់យុត្តាធិការរបស់ខ្លួន "លើការសម្រេចលើអង្គហេតុមួយចំនួន" ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ជាអញ្ញត្រកម្មដែលមានចែងនៅវិធាន ៨៩ នៃវិធានផ្ទៃក្នុង "ដែលមានប្រយោជន៍សម្រាប់កំណត់ឱ្យច្បាស់លាស់អំពីវិសាលភាពនៃការជំនុំ មុនពេលបើកសវនាការពិនិត្យភ័ស្តុតាង"[538]។ ក៏ប៉ុន្តែ បើទោះជាវិធាន ៨៩ ចែងថាត្រូវដាក់អញ្ញត្រកម្មទាក់ទងនឹង "យុត្តាធិការ" (វិធាន ៨៩(១)(ក)) ក្នុង រយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដែលដីកាដំណោះស្រាយបានចូលជាស្ថាពរក៏ដោយ ក៏វាមិនមែនជាយុត្តាធិការលើអង្គហេតុឡើយ តែជាយុត្តាធិការគតិយុត្តិ *(ឬដែនសមត្ថកិច្ច)* របស់ អ.វ.ត.ក ដែលកំណត់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៣៣៧. ស្របតាមវិធាន ៨៩(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចចេញសេចក្តីសម្រេចរបស់ខ្លួនលើអញ្ញត្រកម្ម "ភ្លាមៗ ឬក្នុងពេលចេញសាលក្រម"។ ដូច្នេះ គេត្រូវអានវិធាន ៨៩(១)(ក) ដោយភ្ជាប់ជាមួយនឹងវិធាន ៩៨ ("សាលក្រម") ដែលចែងពីយុត្តាធិការនៅក្នុងន័យច្បាប់ (ឬដែនសមត្ថកិច្ច) នៃពាក្យអញ្ញត្រកម្មនេះ៖

[538] សំអាងហេតុសាលក្រម កថាខណ្ឌ១៦១-១៦២, ១៦៥។

"៣) អង្គជំនុំជម្រះពិនិត្យមើលថា តើអំពើនោះជាបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ខ្លួន និងថា តើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ? [...]

៦) ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា អំពើដែលមានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះមិនមានភស្តុតាងពិតប្រាកដ ឬយល់ថាជនជាប់ចោទមិនមានពិរុទ្ធភាពចំពោះអំពើទាំងនោះ ជនជាប់ចោទត្រូវតែរួចផុតពីការចោទប្រកាន់។

៧) ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា បទឧក្រិដ្ឋដែលកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនទៅជំនុំជម្រះ មិនស្ថិតក្នុងយុត្តាធិការរបស់ខ្លួន អង្គជំនុំជម្រះត្រូវប្រកាសសម្រេចថា ខ្លួនគ្មានសមត្ថកិច្ចក្នុងរឿងក្តីនេះទេ"។

៣៣៨. អាស្រ័យហេតុនេះ អញ្ញត្រកម្មនៃវិធាន ៨៩(១)(ក) ស្តីអំពីយុត្តាធិការ ពាក់ព័ន្ធតែនឹងយុត្តាធិការក្នុងន័យច្បាប់ និងក្នុងន័យគោរពគោលការណ៍នៃនីត្យានុកូលតែប៉ុណ្ណោះ។ សំណៅជាភាសាខ្មែរ និងអង់គ្លេសនៃវិធាន ៩៨ មិនបង្កឱ្យមានមន្ទិលសង្ស័យឡើយទាក់ទងនឹងប្រធានបទនេះ ដោយហេតុថាវាមានចែងយ៉ាងច្បាស់ពី "យុត្តាធិការរបស់ អ.វ.ត.ក"[539] ជាទូទៅ (ក៏ដូចជាវិធាន ៧៤(៣)(ក) ដែលចែងអំពីសេចក្តីសម្រេចបើកផ្លូវឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ)។

៣៣៩. រហូតដល់ពេលចេញសំអាងហេតុសាលក្រម ពុំមានភាគីណានៅ អ.វ.ត.ក បានបកស្រាយផ្សេងពីនេះអំពីយុត្តាធិការដូចមបានចែងក្នុងវិធាន ៨៩(១)(ក) ក៏ដូចជាវិធាន ៩៨។ ជាការពិត ដោយផ្អែកលើមូលដ្ឋាននេះ មេធាវីការពារក្តី ដែលមានវត្តមានពេលដាក់អញ្ញត្រកម្ម បានលើកឡើងតែអញ្ញត្រកម្មទាក់ទង

---

[539] វិធាន ៩៨៖ « 3. *The Chamber shall examine whether the acts amount to <u>a crime falling within the jurisdiction of the ECCC</u>, and whether the Accused has committed those acts*. (…) 7. *Where the Chamber considers that <u>the crimes</u> set out in the Indictment <u>do not fall within the jurisdiction of the ECCC</u>, it shall decide that it does not have jurisdiction in the case.*»។ "៣. អង្គជំនុំជម្រះត្រូវពិនិត្យថា តើអំពើនោះជាបទឧក្រិដ្ឋដែល<u>ស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា</u> និងថា តើជនជាប់ចោទបានប្រព្រឹត្តអំពើនោះដែរឬទេ។ ៧. នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែលកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ<u>មិនស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា</u> នោះអង្គជំនុំជម្រះត្រូវសម្រេចថា គ្មានសមត្ថកិច្ចទៅលើករណីនោះទេ"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

នឹងយុត្តាធិការដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[540]។ សហព្រះរាជអាជ្ញាបានអះអាងថា វិធាន ៨៩ ពាក់ព័ន្ធនឹង"យុត្តាធិការរបស់ អ.វ.ត.ក ដូចមានកំណត់ក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលនេះជាចំណុចយោងដ៏ពាក់ព័ន្ធបំផុត"[541]។ យោងតាមវិធាន ៩៨(៣) អង្គជំនុំជម្រះបានបញ្ជាក់ថា "វាជាកាតព្វកិច្ចរបស់ខ្លួនក្នុងការពិនិត្យមើលថាតើអំពើដែលបានប្រព្រឹត្តដោយជនជាប់ចោទបង្កើតបានជាបទឧក្រិដ្ឋ ក្នុងន័យច្បាប់ដែរឬទេ"[542]។

៣៤០. ក្នុងសំណុំរឿង ០០៣ ក្នុងដំណាក់កាលស៊ើបអង្កេត អង្គបុរេជំនុំជម្រះបានបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា ខ្លួនពុំមានផ្លូវឧបាស្រ័យពិតប្រាកដ នៅក្នុងការជំនុំជម្រះទាក់ទងទៅនឹងអង្គហេតុនៅក្រៅបណ្តឹងទៅកាន់សហចៅក្រមស៊ើបសួរ។ ដើម្បីបដិសេធ អង្គបុរេជំនុំជម្រះមិនបានផ្អែកលើវិធាន ៨៩ នៃវិធានផ្ទៃក្នុងទេ តែផ្អែកលើសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូងដែល "បានពិចារណាថា វាជាការសមហេតុផលដែលត្រូវពិនិត្យ "សំណើសុំធ្វើមោឃភាពជាក់លាក់ និងមានសំអាងហេតុពាក់ព័ន្ធនឹងភាពមិនត្រឹមត្រូវតាមច្បាប់ដែលបានកើតឡើង ក្នុងដំណាក់កាលមុនការជំនុំជម្រះ""[543]។ ដូច្នេះ អង្គបុរេជំនុំជម្រះក៏មិនបានបកស្រាយវិធាន ៨៩ ថាជាមធ្យោបាយមួយសម្រាប់ដោះស្រាយបញ្ហាជំទាស់បែបនេះដែរ។

[540] អញ្ញត្រកម្មរបស់លោក នួន ជា ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E36 (ដែលបន្ទាប់មក ត្រូវបានជំនួសដោយឯកសារ E42)។ អញ្ញត្រកម្មរបស់ អៀង ធីរិទ្ធិ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E44។ អញ្ញត្រកម្មរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E46។ អញ្ញត្រកម្មរបស់លោក អៀង សារី ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ E48 កថាខណ្ឌ ១៣។

[541] សំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ កំណត់សម្គាល់ជើងទំព័រលេខ១២ (នៃកថាខណ្ឌ ១០)។ សូមមើលផងដែរ៖ សំណើរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E99 កំណត់សម្គាល់ជើងទំព័រលេខ ១៣ (នៃកថាខណ្ឌ ១១)។

[542] សេចក្តីសម្រេច ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ ឯកសារ E95/8 កថាខណ្ឌ ៩ និង កំណត់សម្គាល់ជើងទំព័រលេខ៣១។

[543] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ឯកសារ D158/1 កថាខណ្ឌ ២០ និងកំណត់សម្គាល់ជើងទំព័រលេខ ៤៤ ដែលយោងទៅសេចក្តីសម្រេច ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E306/5 កថាខណ្ឌ ៦-១០ ដែលយោងទៅសេចក្តីសម្រេច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ឯកសារ E142/3 កថាខណ្ឌ ៧ (ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សី)។

៣៤១. នៅក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា បណ្តឹងឧទ្ធរណ៍ដែលលើកឡើងអំពីវិការៈនៃដីកាដំណោះស្រាយរងការចោទប្រកាន់ "មិនមែនចំជាអញ្ញត្រកម្មចំពោះភាពគ្មានយុត្តាធិការ" ស្របតាម "ខ្លឹមសារធម្មតានៃវិធាន ៧៤ (៣) (ក) នៃវិធានផ្ទៃក្នុង និងតាមជំពូក២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលចែងពីចំណុចសំខាន់ៗនៃយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការបទល្មើសរបស់អង្គជំនុំជម្រះវិសាមញ្ញ" មុននឹងបន្ថែមដូចតទៅនេះ៖

> "ពុំមានមាត្រាណាមួយនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬវិធានណាមួយនៃ [វិធានផ្ទៃក្នុង] អាចនាំឱ្យសន្និដ្ឋានថា វិការៈទម្រង់ ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការ នោះទេ។ អាស្រ័យហេតុនេះ មូលដ្ឋានបណ្តឹងក្នុងន័យនេះ អាចលើកឡើងចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីពិនិត្យ ក្នុងពេលសវនាការលើអង្គសេចក្តី ដោយសារតែមូលដ្ឋានទាំងនេះមិនមែនលើកឡើងដើម្បីធ្វើអញ្ញត្រកម្មចំពោះយុត្តាធិការរបស់ អ.វ.ត.ក នោះឡើយ"[544]។

៣៤២. ជាការសន្និដ្ឋាន អង្គជំនុំជម្រះមិនអាចបកស្រាយថា វិធាន ៨៩ អនុញ្ញាតឱ្យដាក់សំណើសុំឱ្យកត់សម្គាល់អំពីភាពមិនត្រឹមត្រូវនៃវិសាលភាពបណ្តឹងមកកាន់ខ្លួន ចំពោះអង្គហេតុមួយចំនួន នៅក្នុងដីកាដំណោះស្រាយ។

[544] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ **D427/3/15** កថាខណ្ឌ ៦៣ (យើងគូសបន្ទាត់ពីក្រោម)។ នៅក្នុងកថាខណ្ឌ ៦០ អង្គបុរេជំនុំជម្រះបានរំឭកថា មានតែការជំទាស់ផ្នែកយុត្តាធិការប៉ុណ្ណោះដែលអាចលើកឡើងស្របតាមវិធាននោះបាន។ ក្នុងការសម្រេចអំពីអ្វីដែលបង្កើតជាការជំទាស់ផ្នែកយុត្តាធិការត្រឹមត្រូវ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា អ.វ.ត.ក "ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានឹងតុលាការមិន*អចិន្ត្រៃយ៍* នានា" ផ្ទុយទៅនឹងប្រព័ន្ធច្បាប់ស៊ីវិលជាតិ នៅពេលដែលលក្ខខណ្ឌនៃច្បាប់លក្ខន្តិកៈពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ និងការទទួលខុសត្រូវដែលអាចត្រូវបានចោទប្រកាន់ មានលក្ខណៈទូលំទូលាយ នៅពេលដែលច្បាប់ជាធរមានគ្មានការកំណត់ច្បាស់លាស់ និងនៅពេលដែលគោលការណ៍នីត្យានុកូលភាព (ដែលយោងទៅសេចក្តីសម្រេចមុន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១០ ឯកសារ **D97/14/15** កថាខណ្ឌ ២១ និង ២៣-២៤)។ សូមមើលផងដែរ៖ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ **D427/1/30** កថាខណ្ឌ ៤៧ (និងកថាខណ្ឌ ៤៥)។

## ២. ឱកាសនិយមនៃការកំណត់ថាជាអញ្ញត្រកម្ម

៣៤៣. មេធាវីការពារក្តីត្រូវតែគូសបញ្ជាក់ថា អង្គជំនុំជម្រះកំណត់ថាជាអញ្ញត្រកម្មក្តី ឬមិនមែនជាអញ្ញត្រកម្មក្តី ទៅតាមការចង់បានរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះ។

៣៤៤. នៅក្នុងសំណុំរឿង ០០២/០១ ក្នុងដំណាក់កាលសវនការលើអង្គសេចក្តី អង្គជំនុំជម្រះបានពិនិត្យសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យ "កំណត់បទចោទឡើងវិញ" ស្របតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ដោយបដិសេធការទាមទាររបស់មេធាវីការពារក្តីដែលបានជំទាស់ទៅនឹងសំណើទាំងនេះ ដោយមូលហេតុថា តាមពិតវាជាអញ្ញត្រកម្មយឺតយ៉ាវ[545]។ ក្នុងសំណុំរឿង ០០២/០២ នៅទីបំផុត អង្គជំនុំជម្រះបានទទួលស្គាល់ថា វាជាសំណើសុំធ្វើអញ្ញត្រកម្ម ដោយចុះសំណើទាំងនេះទៅក្នុងបញ្ជីនៃសំណើធ្វើអញ្ញត្រកម្មដែលខ្លួនបានសម្រេចរួចហើយក្នុងសំណុំរឿង ០០២/០១[546]។

៣៤៥. នៅក្នុងសំអាងហេតុសាក្រមនេះ អង្គជំនុំជម្រះបានកំណត់ថាជាអញ្ញត្រកម្មនូវសំណើដែលបានលើកឡើងជាដំបូងដោយ អៀង សារី ហើយដែលក្រោយមក មេធាវីការពារក្តីលើកឡើងបន្ត ទាក់ទងនឹងអង្គហេតុនៃការនិរទេស[547]។ ដោយសារបានកំណត់ថាជាអញ្ញត្រកម្ម និងដោយសារវាត្រូវបានលើកឡើង "ក្នុងពេលវេលាសមស្រប"[548] អង្គជំនុំជម្រះអាចផ្តល់យុត្តិកម្មថា ខ្លួននឹងសម្រេចតែលើសំណើនេះតែប៉ុណ្ណោះក្នុងសវនាការលើអង្គសេចក្តី តែនឹងមិនសម្រេចលើសំណើដទៃទៀតទេ[549]។ ក៏ប៉ុន្តែ សំណើនេះ

---

[545] សេចក្តីសម្រេច ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ **E100/6** (កថាខណ្ឌ ១១-១២ និង ២៣-២៥ ស្តីពីភាពអាចទទួលយកបាន)។ សេចក្តីសម្រេច ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ ឯកសារ **E95/8** (កថាខណ្ឌ ៣-៥ និង ៩ ស្តីពីភាពអាចទទួលយកបាន)។

[546] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E306** កថាខណ្ឌ ១៖ "មុនពេលចាប់ផ្តើមសវនាការសំណុំរឿង ០០២ ភាគីបានដាក់អញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង។ នៅពេលនោះ អង្គជំនុំជម្រះបានដោះស្រាយទៅលើអញ្ញត្រកម្មទាំងឡាយណាដែលខ្លួនយល់ឃើញថាមានភាពពាក់ព័ន្ធ និងចាំបាច់ដែលត្រូវសម្រេចជាមុន មុនពេលដំណើរការនីតិវិធីដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ (ឧទាហរណ៍សូមមើលឯកសារ **E51/14**, **E116**, **E100/6**, **E122**, **E95/8** និង **E51/15**)"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[547] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៣-១៦៤។

[548] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៤។

[549] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៥។

មិនមែនផ្អែកលើវិធាន ៨៩ នៃវិធានផ្ទៃក្នុងនោះទេ។ វាជាផ្នែកមួយនៃសំណើសុំធ្វើមោឃភាពលើវិការៈជាច្រើននៃដីកាដំណោះស្រាយ ដែលភាពអាចទទួលយកបាននៃដីកានេះផ្អែកលើយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលបានបញ្ជូនបញ្ហាទាំងនេះទៅឱ្យអង្គជំនុំជម្រះសាលាដំបូងដោះស្រាយវិញ។ លើសពីនេះទៀត សំណើនេះត្រូវបានដាក់ដាច់ដោយឡែកពីការដាក់អញ្ញត្រកម្ម បន្ទាប់ពីរយៈពេលកំណត់សម្រាប់ការដាក់អញ្ញត្រកម្មបានផុតកំណត់[550]។

៣៤៦. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបែងចែកដាច់ពីគ្នារវាងអញ្ញត្រកម្ម និងសំណើដែលខ្លួនបានកំណត់យ៉ាងច្បាស់ថាជា “សំណើសុំធ្វើមោឃភាពផ្នែកជាច្រើននៃ [ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ] អាស្រ័យទៅតាមវិការៈដែលធ្វើឱ្យខូចខាតដល់ដីកានេះ”[551]។ លើសពីនេះទៅទៀត ប្រការនេះបានអនុញ្ញាតឱ្យអង្គជំនុំជម្រះមិនពិនិត្យបញ្ហារសើបនៃការរលត់បណ្ដឹងអាជ្ញាក្នុងច្បាប់ជាតិ ក្នុងសវនាការលើអង្គសេចក្ដី។ ទាក់ទងនឹងភាពអាចទទួលយកបាននៃសំណើនេះ កាលនោះ អង្គជំនុំជម្រះបានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា “តាមធម្មតា ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក មិនអនុញ្ញាតឱ្យដាក់” សំណើបែបនេះ នៅដំណាក់កាលជំនុំជម្រះទេ[552]។ ទោះយ៉ាងនេះក្ដី អង្គជំនុំជម្រះបានពិនិត្យសំណើនេះ ដើម្បីគោរព “សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌”[553]។

---

[550] ញាតិរបស់ អៀង សារី ចុះថ្ងៃទី២៤ [ខែកុម្ភៈ] ឆ្នាំ២០១១ ឯកសារ E58 (ថ្វីត្បិតតែចុះកាលបរិច្ឆេទ នៅថ្ងៃទី២៤ “ខែមករា”ក៏ពិតមែន តែសំណើនេះបានដាក់នៅថ្ងៃទី២៤ ខែកុម្ភៈ ដូចមានត្រាដែលបានបោះនៅលើទំព័រដើមនៃឯកសារដើមជាភាសាអង់គ្លេសជាតឹកតាំង) កថាខណ្ឌ ១ (មុនពេលយោងទៅកថាខណ្ឌ ៦៣ នៃសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/3/15 មេធាវីការពារក្ដី អៀង សារី បានអះអាងថា៖ “ច្បាប់កម្ពុជា និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មិនបាននិយាយពីការកំណត់ពេលវេលា និងនីតិវិធីសម្រាប់ការស្នើសុំឱ្យលុបចោល ឬធ្វើការកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារការមិនគោរពតាមវិធានបញ្ញត្តិនោះ”។ អញ្ញត្រកម្មប្រហែលជាបានដាក់នៅ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ (អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ **E35** ទំព័រ ២)។

[551] សេចក្ដីសម្រេច ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E122** កថាខណ្ឌ ១-២។

[552] សេចក្ដីសម្រេច ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E122** កថាខណ្ឌ ១៦។ សហព្រះរាជអាជ្ញាបានលើកឡើងថា វិធានផ្ទៃក្នុងមិនអនុញ្ញាតឱ្យមានការស្នើបែបនោះឡើយ នៅពេលដែលដីកាដំណោះស្រាយចូលជាធរមានស្ថាពរ និងថាគេធ្វើការបែងចែកភាពខុសគ្នារវាងសំណើ និងអញ្ញត្តកម្ម (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ ឯកសារ **E58/1** កថាខណ្ឌ ៣-៤)។

[553] សេចក្ដីសម្រេច ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E122** កថាខណ្ឌ ១៦។

នេះជាអ្វីដែលអង្គជំនុំជម្រះគួរតែបានធ្វើចំពោះរាល់សំណើរបស់មេធាវីការពារក្ដី ទោះជាសំណើទាំងនោះត្រូវបានកំណត់ថាជាអញ្ញត្រកម្ម ឬមិនមែនអញ្ញត្រកម្មក៏ដោយ។

## ៣. យុត្តិនិសេធ

៣៤៧. អង្គជំនុំជម្រះបានប្រព្រឹត្តយុត្តិនីសេធ ដោយយល់ឃើញថាមេធាវីការពារក្ដីមិនបានប្រើប្រាស់មធ្យោបាយនីតិវិធី ដែលតាមពិតមិនត្រូវបានផ្ដល់ជូនមេធាវីការពារក្ដីនោះទេ តែបានត្រឹមតែទទួលស្គាល់ថា បញ្ហាដែលបានលើកឡើង មានសារៈសំខាន់ខ្លាំងដែលអង្គជំនុំជម្រះចាំបាច់ត្រូវពិនិត្យលើបញ្ហាទាំងនេះ។

៣៤៨. នៅចំពោះមុខតុលាការមិនអចិន្ត្រៃយ៍ គេអាចលើកអំពីអញ្ញត្រកម្មចំពោះយុត្តាធិការ នៅពេលចាប់ផ្ដើមជំនុំជម្រះដែលរួមបញ្ចូលយ៉ាងច្បាស់នូវ "ការជំទាស់ទៅនឹងយុត្តាធិការ" និង "ការជំទាស់ផ្អែកលើវិការៈទម្រង់ណាមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[554]។

៣៤៩. មានការយល់ឃើញថា ដោយផ្អែកលើសារៈសំខាន់របស់វាពាក់ព័ន្ធនឹងសមធម៌ និងការធានាភាពត្រឹមត្រូវនៃនីតិវិធី អញ្ញត្រកម្មត្រូវតែបានពិនិត្យពិចារណា បើទោះបីជាវាត្រូវបានដាក់ក្រោយពេលកំណត់ក៏ដោយ[555]។ លើសពីនេះទៀត ដោយគិតអំពីសារៈសំខាន់នៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាន

[554] មាត្រា ៧២.ក នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង វិធាននីតិវិធី និងភស្តុតាងនៃ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា មាត្រា ៧៩.៤ វិធាននីតិវិធី និងភស្តុតាងនៃយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។

[555] ជាឧទាហរណ៍៖ រឿងក្ដីរវាង *រដ្ឋអាជ្ញា ទល់នឹង Turinabo និងអ្នកដទៃទៀត* MICT-18-116-PT សេចក្ដីសម្រេចទាក់ទងនឹងការស្នើសុំពន្យារពេលដាក់អញ្ញត្រកម្ម ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ទំព័រ ២៖ "ក៏ប៉ុន្តែ **ដោយហេតុថា** អញ្ញត្រកម្មដែលមានចែងនៅក្នុងមាត្រា ៧៩.ក នៃវិធានផ្ទៃក្នុង ស្ដីពីភាពយុត្តិធម៌ និង ការធានាបាននូវដំណើរការនីតិវិធី និងដោយហេតុថាអញ្ញត្រកម្មបែបនោះនឹងត្រូវយកទៅពិនិត្យ ទោះបីជាត្រូវបានដាក់ហួសថិរវេលាកំណត់ក៏ដោយ"។ សូមមើលផងដែរ វិធាន ៣៩.៤.ខ នៃវិធានផ្ទៃក្នុង៖ "សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច៖ [...] ទទួលស្គាល់ថាមានសុពលភាព ចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល"។

ការជូនដំណឹងអំពីការចោទប្រកាន់ប្រឆាំងនឹងគាត់ គេមិនត្រូវដកហូតសិទ្ធិពីគាត់ ក្នុងការលើកឡើងពីវិការៈនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយទោះបីទើបតែលើកឡើងជាលើកដំបូង នៅក្នុងបណ្តឹងឧទ្ធរណ៍ក៏ដោយ[556]។

៣៥០. ហេតុដូច្នេះ អង្គជំនុំជម្រះគួរតែបានពិនិត្យរាល់ការជំទាស់របស់មេធាវីការពារក្តី ដោយមិនចាំបាច់គិតពីចរិតលក្ខណៈ និងខណៈពេលលើកឡើងនៃការជំទាស់ឡើយ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនទទួលយកសំណើជំទាស់ទាំងអស់ ត្រូវតែទុកជាមោឃៈ។ ប្រសិនបើអង្គជំនុំជម្រះបានពិនិត្យការតវ៉ាទាំងអស់ ក្នុងសវនាការលើអង្គសេចក្តី ដោយអនុវត្តលក្ខណៈវិនិច្ឆ័យត្រឹមត្រូវសម្រាប់ការពិនិត្យវិញនោះ អង្គជំនុំជម្រះនឹងមិនអាចផ្តន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុដែលអង្គជំនុំជម្រះមិនបានទទួលត្រឹមត្រូវតាមច្បាប់នោះទេ។

## ផ្នែកទី ២. ច្បាប់ជាធរមានសម្រាប់ការពិនិត្យពិចារណាលើអង្គសេចក្តី

៣៥១. នៅពេលពិចារណាលើវិសាលភាពនៃបណ្តឹងមកកាន់សហចៅក្រមស៊ើបអង្កេត ស្តីពីការនិរទេសខ្លួន (ពិភាក្សាលម្អិតខាងក្រោម)[557] អង្គជំនុំជម្រះមិនបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យច្បាប់ត្រឹមត្រូវឡើយ។ អង្គជំនុំជម្រះបានកត់សម្គាល់ដំបូងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយខុសពីគ្នា "ត្រង់កម្រិតព័ត៌មានលម្អិតដែលតម្រូវឱ្យរៀបរាប់ អង្គហេតុដែលត្រូវស៊ើបសួរ ឬអង្គហេតុដែលត្រូវជំនុំជម្រះ"[558]។ បន្ទាប់មក "ដើម្បីយល់ពីវិសាលភាពជាក់លាក់នៃអង្គហេតុដែលសហព្រះរាជអាជ្ញាមានបំណងបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត" អង្គជំនុំជម្រះបានសម្រេចពិនិត្យមើលដីកា

---

[556] សាលដីកា *Šainović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ២២៤។ សាលដីកា *Simić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦។ សាលដីកា *Niyitegeka* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា) ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤។ សូមមើលផងដែរសារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៤៨ និង ឯកសារយោងសម្រង់សម្តី។

[557] សូមមើលខាងក្រោម កថាខណ្ឌ ៣៨០-៣៨៥។

[558] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ "ដោយផ្អែកលើឯកសារគាំទ្រទាំងអស់ដែលត្រូវបានដកស្រង់ដាក់លាក់ដើម្បីគាំទ្រដីកានេះ"[559]។ វិធារណកិច្ចបែបនេះគឺខុសទាំងស្រុង។

៣៥២. ទោះក្នុងករណីណាក៏ដោយ "កម្រិតលម្អិត" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយ មិនអាចផ្តល់យុត្តិកម្មដល់ការព្យាយាមកំណត់វិសាលភាពនៃបណ្តឹង នៅក្នុងភស្តុតាងគាំទ្រដីកាទាំងពីរនេះឡើយ។ ជាក់ស្តែង អង្គហេតុដែលបានបញ្ជូនមកកាន់សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង គឺជាអង្គហេតុដែលអ្នកកាន់តំណែងនេះពីមុនៗបានកំណត់ថាជាបទចោទ ដោយមិនអាស្រ័យលើភស្តុតាងឡើយ។ គឺតាមរយៈប្រតិបត្តិការកំណត់ប្រភេទបទល្មើសនេះហើយដែលសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតជូនដំណឹងអំពីអង្គហេតុដែលខ្លួនមានបំណងបញ្ជូនទៅជំនុំជម្រះចំពោះមុខសាលាដំបូង។

៣៥៣. បន្ទាប់ពីបញ្ចប់កិច្ចស៊ើបសួរ (វិធាន ៥០ នៃវិធានផ្ទៃក្នុង) ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានកើតមានពិតមែន ខ្លួនត្រូវបើកការស៊ើបអង្កេតដោយ បញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង) ទៅសហចៅក្រមស៊ើបអង្កេត។ បន្ទាប់ពីបានស៊ើបអង្កេតដាក់បន្ទុក និងដោះបន្ទុក (វិធាន ៥៥(៥)) តែលើអង្គហេតុណាដែលសហព្រះរាជអាជ្ញាបានបញ្ជូនឱ្យតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្នុងករណីមានអង្គហេតុថ្មីៗផ្សេងទៀតលេចឡើង (វិធាន ៥៥(២) និង ៥៥(៣)) សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើខ្លួនយល់ឃើញថាអំពើទាំងនេះជាបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និងថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ (វិធាន ៦៧(៣))។ បន្ទាប់ពីជំនុំជម្រះចប់ហើយ អង្គជំនុំជម្រះអាចសម្រេចតែលើអង្គហេតុដែលមានបញ្ជាក់ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ (វិធាន ៩៨(២))។ អង្គជំនុំជម្រះពិនិត្យមើលថា តើអង្គហេតុទាំងនោះជាបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ និងថាតើជនជាប់ចោទបានប្រព្រឹត្តអំពើដែលបានចោទប្រកាន់លើរូបគាត់ដែរឬទេ (វិធាន ៩៨(៣))។ សេចក្តីសម្រេចនេះត្រូវតែផ្អែកលើភស្តុតាងណាដែលត្រូវបានដាក់

[559] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧។

បង្ហាញក្នុងកំឡុងពេលសវនាការ និងដែលត្រូវបានដាក់ឱ្យភាគីពិភាក្សាតតាំងចំពោះមុខ (វិធាន ៨៧ (២))។

៣៥៤. ទាំងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាំងដីកាដំណោះស្រាយ ត្រូវតែមានសេចក្តីពេញលេញនៃអង្គហេតុ និងការកំណត់ប្រភេទបទល្មើស (វិធាន ៥៣(១) និង ៦៧(២)) បើពុំដូចនេះទេ ដីកាទាំងនេះត្រូវទុកជាមោឃៈ (វិធាន ៥៣(៣) និង ៦៧(២))។ នេះមិនមែនជារឿងភ័ស្តុតាងសម្រាប់គាំទ្រការចោទប្រកាន់អំពីអង្គហេតុទាំងនេះ នោះទេ។

៣៥៥. ការគ្មានសេចក្តីពេញនៃអង្គហេតុ និងការកំណត់ប្រភេទបទល្មើស ស្របតាមទម្រង់បែបបទ បង្កមោឃភាពដល់ដីកាទាំងនេះ ដោយហេតុថា មានតែអង្គហេតុដែលរាប់បញ្ចូលបណ្តោះអាសន្នជាបទឧក្រិដ្ឋទាំងនេះប៉ុណ្ណោះដែលកំណត់វិសាលភាពនៃបណ្តឹង តាមរយៈការជូនដំណឹងអំពីបទចោទប្រឆាំងនឹងជនសង្ស័យ ឬជនរងការចោទប្រកាន់ ហើយការសម្រេចត្រូវតែផ្អែកលើបទចោទទាំងនេះ។ អង្គបុរេជំនុំជម្រះបានយល់អំពីបញ្ហានេះ ក្រោយបានអានវិធាន ៥៥ ភ្ជាប់ជាមួយនឹងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះបានប្រកាសថា៖

> "នៅពេលកំណត់វិសាលភាពនៃបណ្តឹងមកកាន់ខ្លួន សហចៅក្រមស៊ើបអង្កេតបានយកតាមការកំណត់ប្រភេទបទល្មើសដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា"[560]។

៣៥៦. កាលនោះ អង្គបុរេជំនុំជម្រះបានរំឭកផងដែរថា យោងតាមវិធាន ២១(១)(ឃ) និង ៥១(១) នៃវិធានផ្ទៃក្នុង សិទ្ធិទទួលបានការជូនដំណឹងអំពីបទល្មើសដែលចោទប្រកាន់ប្រឆាំងនឹងខ្លួន ត្រូវអនុវត្តក្នុងដំណាក់កាលស៊ើបអង្កេតចាប់ពីពេលចាប់ខ្លួន៖

> "វិធានស្តីពីការដឹកនាំការស៊ើបអង្កេតនៅចំពោះមុខ អ.វ.ត.ក ដូចមានចែងក្នុងវិធានផ្ទៃក្នុងមានគោលបំណងធានាឱ្យបាននូវនីតិវិធីត្រឹមត្រូវដល់ជនត្រូវចោទ ដោយធ្វើយ៉ាងណាឱ្យគាត់

[560] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ **D99/3/42** កថាខណ្ឌ ៣៥។

បានទទួលការជូនដំណឹងអំពីខ្លឹមសារជាក់លាក់ និងវិសាលភាពនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបអង្កេត ហើយដែលជនត្រូវចោទអាចនឹងត្រូវទទួលខុសត្រូវចំពោះមុខតុលាការ”[561]។

៣៥៧. វិចារណកិច្ចរបស់អង្គបុរេជំនុំជម្រះ មិនត្រឹមតែស្របនឹងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ប៉ុណ្ណោះទេ តែថែមទាំងស្របគ្នាទៅនឹងយុត្តិសាស្ត្រនៃសិទ្ធិមនុស្ស និងតុលាការចំពោះកិច្ចផងដែរ។

៣៥៨. យោងទៅតាមយុត្តាធិការរបស់គណៈកម្មាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សិទ្ធិនេះត្រូវបានកំណត់ថាជាសិទ្ធិទទួលបានការជូនដំណឹង “អំពីមូលហេតុនៃការចោទប្រកាន់ ពោលគឺអំពីអង្គហេតុជាក់ស្តែងដែលគាំទ្រការចោទប្រកាន់ និងដែលជាដើមចមនៃការចោទប្រកាន់រូបគាត់ និងជូនដំណឹងអំពីប្រភេទ នៃការចោទប្រកាន់នោះ ពោលគឺអំពីការកំណត់ប្រភេទបទល្មើសនៃអង្គហេតុជាក់ស្តែង”[562]។ ការជូនដំណឹងនេះ “ត្រូវតែមានព័ត៌មានចាំបាច់ដើម្បីឱ្យជនជាប់ចោទអាចរៀបចំការការពារក្តីរបស់ខ្លួនបាន ដោយមិនចាំបាច់បញ្ជាក់អំពីភ័ស្តុតាងដែលជាមូលដ្ឋាននៃការចោទប្រកាន់នេះ”[563]។ តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស “ពិចារណាថា នៅក្នុងរឿងព្រហ្មទណ្ឌ ព័ត៌មានច្បាស់លាស់ និងពេញលេញនៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ពោលគឺការកំណត់ប្រភេទបទល្មើសដែលអាចយកមកអនុវត្តឆាំងនឹងគាត់ គឺជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ភាពយុត្តិធម៌នៃនីតិវិធី”[564]។

---

[561] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ **D99/3/42** កថាខណ្ឌ ១៣៨-១៤០។

[562] រឿងក្តី *X. ទល់នឹងប្រទេសបែលហ្ស៊ិក* (គណៈកម្មការការសិទ្ធិមនុស្សអឺរ៉ុប) សេចក្តីសម្រេចលើភាពអាចទទួលយកសំណើបាន (ឯកសារលេខ n°7628/76) ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៧ កថាខណ្ឌ ១ (មិនមានឯកសារយោង មានគូសបន្ទាត់ពីក្រោមនៅក្នុងច្បាប់ដើម)។ សូមមើលផងដែរ រឿងក្តី *Colozza និង Rubinat ទល់នឹងប្រទេសអ៊ីតាលី* (គណៈកម្មការការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) របាយការណ៍នៃគណៈកម្មការ (សំណើលេខ n°9024/80 និង 9317/81) ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៨៣ កថាខណ្ឌ ១១៤។

[563] រឿងក្តី *X. ទល់នឹងប្រទេសបែលហ្ស៊ិក* (គណៈកម្មការការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) សេចក្តីសម្រេចលើភាពអាចទទួលយកសំណើបាន (ឯកសារលេខ 7628/76) ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៧ កថាខណ្ឌ ១ (មិនមានឯកសារយោង យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ៖ រឿងក្តី *Colozza* និង *Rubinat ទល់នឹងប្រទេសអ៊ីតាលី* (គណៈកម្មការការសិទ្ធិមនុស្សនៃសហភាពអឺរ៉ុប) របាយការណ៍នៃគណៈកម្មការ (សំណើលេខ n°9024/80 និង 9317/81) ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៨៣ កថាខណ្ឌ ១១៤។

[564] សាលដីកា *Pélissier* និង *Sassi ទល់នឹងប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការកំពូល) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ កថាខណ្ឌ ៥១-៥២ (មិនមានឯកសារយោង សម្រង់សម្តីទាញចេញពីកថាខណ្ឌ ៥២ យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៣៥៩. ដូចគ្នានេះដែរ នៅចំពោះមុខតុលាការចំពោះកិច្ច យោងទៅតាមអត្ថបទគតិយុត្តិជាធរមាន រដ្ឋអាជ្ញាត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ដែលក្នុងនោះមានបង្ហាញដោយសង្ខេប នូវអង្គហេតុ និងឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលត្រូវបានចោទប្រកាន់លើគាត់"[565]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែបង្ហាញ "ទំនាក់ទំនងខ្លីហើយខ្លឹមរវាងអង្គហេតុនៃរឿងក្តី និងការកំណត់បទល្មើសនៃអង្គហេតុទាំងអស់នេះ"[566]។ យោងតាមយុត្តិសាស្ត្រអចិន្ត្រៃយ៍របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការនេះ រដ្ឋអាជ្ញាត្រូវតែបង្ហាញពីការចោទប្រកាន់ និងអង្គហេតុសំខាន់ៗជាមូលដ្ឋាន ឱ្យបានច្បាស់លាស់គ្រប់គ្រាន់ "ប៉ុន្តែមិនចាំបាច់បង្ហាញភ័ស្តុតាងដើម្បីបញ្ជាក់ថាហេតុការណ៍ទាំងនោះពិតជាបានកើតឡើងមែននោះទេ"[567]។

៣៦០. ដូច្នេះ យោងតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក យុត្តិសាស្ត្រសិទ្ធិមនុស្ស និងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ការជូនដំណឹងអំពីការចោទប្រកាន់ (ពោលគឺអំពីវិសាលភាពនៃបណ្តឹង) ពាក់ព័ន្ធតែនឹងអង្គហេតុដែលត្រូវបានកំណត់ប្រភេទបទល្មើសប៉ុណ្ណោះ តែមិនពាក់ព័ន្ធនឹងភ័ស្តុតាងសម្រាប់គាំ

---

[565] មាត្រា ១៨.៤ នៃលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មាត្រា ១៧.៤ នៃលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា មាត្រា ១៦.៤ នៃលក្ខន្តិកៈនៃយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម ដោយកត់សម្គាល់ភាពស្របគ្នាទៅនឹងលក្ខណៈ "សង្ខេបខ្លីៗ"នៃបទបង្ហាញអង្គហេតុ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៥៣.១.ក នៃវិធានផ្ទៃក្នុង)។

[566] មាត្រា ៤៧.គ នៃ RPP នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងនៃ RPP នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា, មាត្រា ៤៨.គ នៃយន្តការសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ សូមមើលដែរ បទដ្ឋាន ៥២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលចែងថាឯកសារដែលចង្អុលបង្ហាញពីបន្ទុក មាន៖ "ខ) ការបង្ហាញពីអង្គហេតុ ដែលបង្ហាញជាពិសេសថានៅ ពេលណា និងនៅទីណាដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ដោយផ្តល់ជូននូវមូលដ្ឋាននៃអង្គច្បាប់ និងអង្គហេតុគ្រប់គ្រាន់ ក្នុងការនាំបុគ្គលម្នាក់ ឬច្រើននាក់ទៅកាត់ទោស ហើយត្រូវមានអង្គហេតុពាក់ព័ន្ធស្របតាមយុត្តាធិការនៃអង្គជំនុំជម្រះ។ គ) ការកំណត់បទចោទប្រកាន់នៃអង្គហេតុទាំងឡាយដែលពាក់ព័ន្ធទៅនឹងបទល្មើស [...] ក៏ដូចជាទម្រង់ជាក់លាក់នៃការចូលរួមក្នុងបទ ល្មើសនោះ"។

[567] សាលដីកា *Kanyarukiga* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ្វ៉ាន់ដា) ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៧៣។ សាលដីកា *Sainović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ២១៣។ សាលដីកា *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ៨៨។

ទ្រអង្គហេតុនោះទេ។ កាតាព្វកិច្ចនេះត្រូវតែបំពេញចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក៏ដូចជាចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះដែរ។

៣៦១. សហព្រះរាជអាជ្ញាមិនមែនយល់អំពីការជូនដំណឹងក្នុងន័យផ្សេងពីនេះនោះទេ នៅពេលដែលខ្លួនតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលដីកានេះ បង្ហាញឱ្យឃើញយ៉ាងច្បាស់ថា សហព្រះរាជអាជ្ញាមិនមានចេតនាបញ្ជូន ទៅសហចៅក្រមស៊ើបអង្កេត នូវអង្គហេតុដែលមានបញ្ជាក់ក្នុងភស្តុតាងសម្រាប់គាំទ្រការចោទប្រកាន់របស់ពួកគេឡើយ។

៣៦២. បន្ទាប់ពីបានបង្ហាញអង្គហេតុ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួនមាន "ហេតុផលដើម្បីជឿថា នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ, និង ឌុច បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលមានពិពណ៌នាយ៉ាងច្បាស់នៅក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបទឧក្រិដ្ឋទាំងនេះស្ថិតក្រោមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក"[568]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានដោយសម្រេច "បើកការស៊ើបអង្កេតតាមផ្លូវតុលាការ" ប្រឆាំងនឹងបុគ្គលខាងលើ "ចំពោះអង្គហេតុដែលមានរៀបរាប់ក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ ទាក់ទងនឹងបទចោទដូចតទៅ៖ (...)"[569]។ សម្រាប់បទចោទនីមួយៗដែលបានស្នើឡើង សហព្រះរាជអាជ្ញាបានភ្ជាប់ទៅនឹងអង្គហេតុពាក់ព័ន្ធ ដោយបញ្ជាក់ថា៖ "លេខក្នុងវង់ក្រចកនៅខាងក្រោយបទឧក្រិដ្ឋ យោងទៅកថាខណ្ឌនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលមានរៀបរាប់អំពីភស្តុតាងជាមូលដ្ឋាននៃការចោទប្រកាន់"[570]។

[568] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ៧៣ (យើងគូសបន្ទាត់ពីក្រោម) និង កថាខណ្ឌ ១១៤។

[569] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ១២២។

[570] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ១២២ និងកំណត់សម្គាល់ជើងទំព័រលេខ ៥៧១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ នៅក្នុងច្បាប់ដើមជាភាសាអង់គ្លេស៖ « *The bracketed numbers following each crime type indicate the paragraphs in the Introductory Submission that provide the core basis for that allegation.* » (យើងគូសបន្ទាត់ពីក្រោម)។

៣៦៣. បន្ទាប់ពីពេលនោះមកទេទើបសហព្រះរាជអាជ្ញាបានដាក់សំណុំរឿងព្រហ្មទណ្ឌ និងឯកសារសំអាងនានាដែលត្រូវបានដកស្រង់ដើម្បីគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុងឋានៈជា "វត្ថុតាងដែលមានតម្លៃជាភស្តុតាងខ្ពស់"[571]។ សហព្រះរាជអាជ្ញាបានផ្តល់ឯកសារទាំងនេះគ្រាន់តែដើម្បីបញ្ជាក់ថា ខ្លួនមាន "ហេតុផលត្រឹមត្រូវក្នុងការជឿ" ថាជនសង្ស័យបានប្រព្រឹត្ត "ឧក្រិដ្ឋកម្មមួយ ឬឧក្រិដ្ឋកម្មទាំងឡាយដែលមានពិពណ៌នានៅក្នុងដីកានេះ" ដោយហេតុថា ឯកសារទាំងនេះ "នាំឱ្យគេគិតយ៉ាងទំនងថា ជនសង្ស័យដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នឹងត្រូវកាត់ក្តីឱ្យមានទោសពីបទឧក្រិដ្ឋដែលមានរៀបរាប់ក្នុងដីកានេះ ហើយត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក"[572]។

៣៦៤. អាស្រ័យហេតុនេះ បើពិនិត្យទៅតាមច្បាប់ជាធរមាន និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អង្គជំនុំជម្រះមិនអាចចាត់ទុកថា សហចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងពីអង្គហេតុទាំង ឡាយដែលមានបញ្ជាក់នៅក្នុងភស្តុតាងគាំទ្រដីកានេះឡើយ។

៣៦៥. វិចារណកិច្ចបែបនេះជាការបដិសេធមិនទទួលស្គាល់ខ្លឹមសារនៃវិធាន ៥៣ នៃវិធានផ្ទៃក្នុង ដែលតម្រូវឱ្យសង្ខេបអង្គហេតុចោទប្រកាន់ រួមជាមួយនឹងការកំណត់ប្រភេទបទល្មើសនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បើពុំនោះសោត ដីកានេះត្រូវទុកជាមោឃៈ។ បើតាមអង្គជំនុំជម្រះ សហព្រះរាជអាជ្ញាគ្រាន់តែបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត នូវភស្តុតាងដែលពួកគេបានប្រមូលក្នុងអំឡុងពេលសាកសួរបឋម វាជាការគ្រប់គ្រាន់ហើយ។ ការយល់ឃើញបែបនេះកាន់តែលែងមានន័យទៅទៀត បើ

[571] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ១២២ (នៅក្នុងច្បាប់ដើមជាភាសាអង់គ្លេស « *material of evidentiary value* ») និង កំណត់សម្គាល់ជើងទំព័រលេខ៥៧២។

[572] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ១១៨-ក។ នៅក្នុងច្បាប់ដើមជាភាសាអង់គ្លេស៖ « *the Introductory Submission provides well founded reasons to believe that these suspects have committed the crime or crimes specified herein. The evidence collected during the Co-Prosecutors' preliminary investigation, including witness* ឯកសារ *Expert and documentary evidence supports the likelihood that the suspects named in this Introductory Submission will be convicted of the crimes specified herein and punished according the ECCC law.* »។

យោងទៅលើប្រភេទ និងទំហំនៃរឿងក្តីដែលបានដាក់ចំពោះមុខ អ.វ.ត.ក ជាមួយភស្តុតាងរាប់ពាន់ទំព័រដែលត្រូវពិនិត្យ[573]។

៣៦៦. ជាការសន្និដ្ឋាន ការកំណត់វិសាលភាពនៃបណ្តឹង ពោលគឺបទចោទនានាប្រឆាំងនឹង ខៀវ សំផន មិនអាច និងមិនត្រូវយកតាមការកំណត់ប្រភេទបទល្មើសលើអង្គហេតុដាក់បន្ទុកដោយសហព្រះរាជអាជ្ញាឡើយ។ ការកំណត់ប្រភេទបទល្មើសនេះស្ថិតនៅកថាខណ្ឌ ១២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលសហព្រះរាជអាជ្ញាបានបង្កើតទំនាក់ទំនងយ៉ាងច្បាស់រវាងអង្គហេតុ និងការកំណត់ប្រភេទបទល្មើស ដោយបញ្ជាក់យ៉ាងជាក់លាក់សម្រាប់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នីមួយៗ នូវកថាខណ្ឌពាក់ព័ន្ធដែលមានចាប់ពី ៣៧ ដល់ ៧២ ក្នុងការពិពណ៌នាអំពីអង្គហេតុរបស់ខ្លួន។

## ជំពូកទី ២. កំហុស និងផលប៉ះពាល់ដោយសារទីតាំងឧក្រិដ្ឋកម្ម

### ផ្នែកទី ១. ត្រាំកក់

### ១. គ្មានបណ្តឹងពីទីតាំងភូមិសាស្ត្រលើសពីច្រាំបីឃុំនៃស្រុកត្រាំកក់

៣៦៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋានថា បណ្តឹងពីទីតាំងភូមិសាស្ត្រមកកាន់ខ្លួនលាតសន្ធឹងដល់គ្រប់សហករណ៍ទាំងអស់ នៅក្នុងស្រុកត្រាំកក់ទាំងមូល ដោយយោងទៅតាមខ្លឹមសារទូទៅរបស់ដីកាដំណោះស្រាយ[574]។ អង្គជំនុំជម្រះគួរតែគិតពីការរំលោភបំពានអំពីសំណាក់សហចៅក្រមស៊ើបអង្កេត លើវិសាលភាពនៃបណ្តឹងជាក់ស្តែង (១.១) និងកត់សម្គាល់ថាខ្លួនមិនអាចផ្តន្ទាទោសលើសពីវិសាលភាពនៃបណ្តឹងនេះទេ (១.២)។

---

[573] មេធាវីការពារក្តីសូមកត់សម្គាល់ថា នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៣៦៥ (នៃកថាខណ្ឌ ១៦៧) នៃសាលដីកាហេតុសាលក្រម អង្គជំនុំជម្រះបានកត់សម្គាល់សេចក្តីសម្រេចពីរនៃអង្គជំនុំជម្រះបទឧក្រិដ្ឋនៃសាលាឧក្រិដ្ឋបារាំង។ សេចក្តីសម្រេចទាំងពីរនោះ មិនមានភាពពាក់ព័ន្ធគ្នាឡើយ ពីព្រោះថានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មិនមានបទបញ្ញត្តិណាមួយ ដែលដូចគ្នានឹងវិធាន ៥៣ នៃវិធានផ្ទៃក្នុងឡើយ ហើយវត្ថុតាងដែលភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបារាំង មិនមានលក្ខណៈដូចគ្នា និងមិនមានទំហំដូចគ្នា បើប្រៀបធៀបទៅនឹងធាតុផ្សំភស្តុតាងដែលគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា នៅ អ.វ.ត.ក ឡើយ។

[574] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ៨០៩។

## ១.១. ការរំលោភបំពានលើបណ្តឹងជាក់ស្តែងអំពីសំណាក់សហចៅក្រមស៊ើបអង្កេត

៣៦៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយដាក់បញ្ចូលក្នុងវិសាលភាពនៃការជំនុំជម្រះ នូវឃុំមួយចំនួនដែលមិនមែនជាឃុំមានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ មានតែកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយតែប៉ុណ្ណោះ ដែលឆ្លុះបញ្ចាំងត្រឹមត្រូវអំពីវិសាលនៃអង្គហេតុ ដែលសហព្រះរាជអាជ្ញាបានបញ្ជូនមកសហចៅក្រមស៊ើបអង្កេត ដែលកម្រិតត្រឹមប្រាំបីឃុំ ដូចមានបញ្ជាក់នៅកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ អាស្រ័យហេតុនេះ មានតែឃុំ ១) គូស ២) សំរោង ៣) ត្រពាំងធំខាងត្បូង ៤) ត្រាំកក់ ៥) ត្រពាំងធំខាងជើង ៦) ញ៉ែង ញ៉ង ៧) ស្រែរនោង ៨) តាភេម ប៉ុណ្ណោះ ដែលស្ថិតក្នុងវិសាលភាពនៃបណ្តឹងមកកាន់សហចៅក្រមស៊ើបអង្កេត។ ការផ្លាស់ប្តូរន័យពីពាក្យ "ឃុំ" នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅពាក្យ "អនុស្រុក" នៅក្នុងដីកាដំណោះស្រាយ មិនជះឥទ្ធិពលលើវិសាលភាពនៃបណ្តឹងមកកាន់សហចៅក្រមស៊ើបសង្កេតឡើយ គឺនៅតែកម្រិតត្រឹមប្រាំបី "ឃុំ" ឬ "អនុស្រុក" ដូចដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ក៏ប៉ុន្តែ នៅកថាខ័ណ្ឌ ៣០៣ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានទាញការសន្និដ្ឋានលើអនុស្រុកទាំងអស់នៃស្រុកត្រាំកក់ ដោយរំលោភបំពានលើបណ្តឹងជាក់ស្តែង។ អង្គជំនុំជម្រះដែលជាអ្នកធានាឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ មិនគួរណាបន្តដើរតាមការរំលោភបំពាននេះឡើយ។

## ១.២. ការផ្តន្ទាទោសចំពោះអង្គហេតុដែលបានកើតឡើងនៅក្នុងឃុំក្រៅវិសាលភាពភូមិសាស្ត្រ

៣៦៩. ការអនុវត្តច្បាប់មិនត្រឹមត្រូវនេះ បណ្តាលឱ្យមានការពង្រីកដោយខុសច្បាប់នូវដែនសមត្ថកិច្ចរបស់ខ្លួន។ វាជះឥទ្ធិពលផ្ទាល់ទៅលើការរកឃើញរបស់អង្គជំនុំជម្រះ ដោយផ្អែកលើភ័ស្តុតាងដែលទាក់ទងទៅនឹងអង្គហេតុនៅខាងក្រៅឃុំទាំងប្រាំបី។ អង្គហេតុទាំងនេះមិនមែនជាការចោទប្រកាន់ដែល ខៀវ សំផន ត្រូវទទួលខុសត្រូវឡើយ។ អង្គជំនុំជម្រះមិនត្រូវបានប្តឹងដោយត្រឹមត្រូវតាមច្បាប់ អំពីអង្គហេតុដែលបានកើតឡើងនៅក្នុងឃុំផ្សេងៗទៀតក្រៅពីឃុំដែលត្រូវបានបញ្ជាក់ក្នុងកថាខណ្ឌ ៣០២ នៃដីកាដំណោះស្រាយឡើយ។ រាល់ភ័ស្តុតាងទាក់ទងនឹងអង្គហេតុទាំងនេះ សុទ្ធតែនៅក្រៅវិសាលភាពនៃរឿង

ក្តី។ ការផ្តន្ទាទោសចំពោះការស្លាប់ដែលបានកើតឡើងនៅខាងក្រៅឃុំទាំងប្រាំបីនេះ ត្រូវទុកជាមោឃៈ (១.២.១)។ វាដូចគ្នាដែរ ចំពោះការផ្តន្ទាទោសពីបទធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (១.២.២) និងលើប្រជាជនថ្មី (១.២.៣)។

## ១.២.១. ការផ្តន្ទាទោសចំពោះការស្លាប់ដោយសារលក្ខខណ្ឌរស់នៅ នៅក្រៅឃុំទាំងប្រាំបី

៣៧០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានថា ការបាត់បង់ជីវិតបណ្តាលមកពីកង្វះស្បៀងអាហារដ៏ស្រួចស្រាវ ដោយផ្អែកលើភស្តុតាងក្រៅវិសាលភាពដែលមានរៀបរាប់ក្នុងកថាខណ្ឌ ១០១១ ដល់ ១០១៦[575]។ ការសន្និដ្ឋាននេះត្រូវតែទុកជាមោឃៈ។ ជាក់ស្តែង នៅក្នុងកថាខណ្ឌ ១០១១-១០១២ សក្ខីកម្មរបស់ ឯក ហឿន ទាក់ទងនឹងកង្វះស្បៀងអាហារនៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៦ នៅឃុំលាយបូរ ស្ថិតនៅក្រៅវិសាលភាព។ ហេតុដូចនេះ វាមិនអាចយកទៅប្រើជាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់អំពើមនុស្សឃាតបានឡើយ[576]។ ដូចគ្នាដែរចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡាន ស្តីពីការស្លាប់កូនរបស់គាត់ ដែលបានកើតឡើងនៅក្នុងឃុំតែមួយ[577]។ ភស្តុតាងដាក់បន្ទុកនៅកថាខណ្ឌ ១០១៣ សុទ្ធតែស្ថិតនៅក្រៅវិសាលភាពភូមិសាស្ត្រនៃការជំនុំជម្រះក្តី[578]។ ដូច្នេះ វាមិនអាចធ្វើជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានថាមានធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាតឡើយ។

---

[575] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២ កំណត់សម្គាល់ជើងទំព័រលេខ៣៨៨០ ដែលយោងទៅកថាខណ្ឌ ១០១១-១០១៦។

[576] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១១។ ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/298.1** ចន្លោះម៉ោង 15.49.55 និងម៉ោង 15.51.56។

[577] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១១ កំណត់សម្គាល់ជើងទំព័រលេខ ៣២១៨។ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ចន្លោះម៉ោង 11.28.13 និងម៉ោង 11.29.04។

[578] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៣។ អ្វីដែលនៅក្រៅវិសាលភាពគឺ៖ របាយការណ៍ដែលធ្វោះឡើងដោយឃុំខ្ពបត្របែក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ (កំណត់សម្គាល់ជើងទំព័រលេខ ៣២២៥ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/4108** ERN 00271040)។ របាយការណ៍ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ នៃភូមិភាគនិរតីដែលលើកឡើងពីស្ថានភាពទូទៅនៃតំបន់តាកែវ (កំណត់សម្គាល់ជើងទំព័រលេខ ៣២២៦។ សេចក្តីរាយការណ៍នៃភូមិភាគនិរតី សូមរាយណ៍ជូនអង្គការជាទីគោរពស្នេហា ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារ **E3/853** ERN 00052825)។ សក្ខីកម្មរបស់ នាង អ៊ូច ស្តីពីការខ្វះខាតម្ហូបអាហារនៅក្នុងឃុំលាយបូរ ដែលជាកន្លែងគាត់រស់នៅចាប់ពីខែមិថុនា ឆ្នាំ១៩៧៧ (កំណត់សម្គាល់ជើងទំព័រលេខ៣២២៩។ ប្រតិចារឹក ថ្ងៃទី

៣៧១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា មនុស្សបានស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ ការងារហួសកម្លាំង និងជំងឺ ដោយផ្អែកលើធាតុផ្សំភ័ស្តុតាងនៅក្រៅវិសាលភាពនៃការជំនុំជម្រះ[579]។ ធាតុផ្សំភ័ស្តុតាងដែលអង្គជំនុំជម្រះប្រើជាមូលដ្ឋានសុទ្ធតែលើកឡើងពីទីតាំងភូមិសាស្រ្តនៅក្រៅវិសាលភាពនៃបណ្តឹង[580]។ ដូច្នេះ វាក៏ជាការភាន់ច្រឡំមួយដែរ ដែលខ្លួនសន្និដ្ឋានថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រៅវិសាលភាពនៃការជំនុំជម្រះ ដែលបានលើកឡើងពីមរណភាពនៅឃុំលាយបូរ "ស៊ីចង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងភ័ស្តុតាងផ្សេងទៀត [...] ដែលបង្ហាញថាមានមនុស្សស្លាប់ជាច្រើននៅស្រុកត្រាំកក់ ដោយសារតែល័ក្ខខ័ណ្ឌដាក់កំហិតទៅលើប្រជាជន"[581]។ អាស្រ័យហេតុនេះ

១០ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/274.1** ចន្លោះម៉ោង 09.32.48 និងម៉ោង 09.34.57 ម៉ោង 10.04.25)។ ភ័ស្តុតាងឯកសារដែលជាពាក្យបណ្តឹងអំពីស្ថានភាពអាហារនៅអង្គតាសោម លាយបូរ និងខ្ពបត្រប៉ែក (កំណត់សម្គាល់ជើងទំព័រលេខ ៣២២៨។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ ឯកសារ **E3/2044** ERN 00079148។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/8422** ERN 00270726។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/4108** ERN 00271040។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៧៧ ឯកសារ **E3/4111** ERN 00079149។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៧ ឯកសារ **E3/8424** ERN 00270967។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/2784** ERN 00079113។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៧៨ ឯកសារ **E3/2448** ERN 00079102)។ សូមមើលផងដែរសំអាងហេតុសាលក្រម កថាខណ្ឌ ១០១៥។ ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ក៏ទាក់ទងផងដែរនឹងឃុំលាយបូរ ហើយសក្ខីកម្មនោះស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ម៉ោង 15.14.53។

[579] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២ កំណត់សម្គាល់ជើងទំព័រលេខ៣៨៨២ ដែលយោងទៅកថាខណ្ឌ ១០១៦, ១០២០, ១០៣៧។

[580] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០ សក្ខីកម្មរបស់ ឯក ហឿន ដែលថាប្រជាជនស្លាប់នៅក្នុងការដ្ឋាននៅក្នុងស្រុកត្រាំកក់ស្ថិតនៅក្រៅវិសាលភាព (កំណត់សម្គាល់ជើងទំព័រលេខ ៣២៨១)។ តាមពិតទៅ សម្រង់ពាក្យពេចន៍យោងនោះគឺនិយាយពីការស្លាប់នៅក្នុងការដ្ឋានខ្ពបត្រប៉ែក ដែលជាឃុំស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ (ឯក ហឿន៖ ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/298.1** ម៉ោង 15.55.56)។

[581] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០ កំណត់សម្គាល់ជើងទំព័រលេខ៣២៨២។ ការស្លាប់នៃកូនរបស់ ជួ គឹមឡន ត្រូវបានលើកឡើងរួចហើយនៅក្នុងកថាខណ្ឌ ១០១៥ ក្នុងឃុំលាយបូរ ក៏ស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះដែរ សំអាងហេតុសាលក្រម កថាខណ្ឌ ១០៣៧ កំណត់សម្គាល់ជើងទំព័រលេខ៣៣៧០ "ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ (ជួ គឹមឡន) ឯកសារ **E1/253.1** ទំព័រ ២៧ ដល់ ២៩ (នៅក្នុងទីនេះ គាត់បានលើកឡើងថាកូនស្រីទីមួយកើតរោគកញ្រ្ជឹល ហើយក៏ជ្រុះសក់អស់ ហើយគាត់

អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានវិនិច្ឆ័យថា មានធាតុផ្សំសត្យានុម័តិគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត ដោយផ្អែកលើអង្គហេតុក្រៅវិសាលភាពភូមិសាស្ត្រនៃការជំនុំជម្រះក្តីទាំងនេះ[582]។ ទន្ទឹមនឹងនេះ រាល់ការសន្និដ្ឋានក្នុងន័យនេះ រួមទាំងការផ្តន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ដោយចេតនាប្រយោលផងដែរ ត្រូវតែទុកជាមោឃៈ[583]។

### ១.២.២. ការផ្តន្ទាទោសពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្រៅឃុំទាំងប្រាំបី

៣៧២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា ចាប់ពីខែមេសា និងឧសភា ឆ្នាំ ១៩៧៧ អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេកំណត់គោលដៅចាប់ខ្លួន និងសម្លាប់ ដោយផ្អែកទៅលើភស្តុតាងនៅក្រៅវិសាលភាពនៃការជំនុំជម្រះ ដែលមានរៀបរាប់ក្នុងកថាខណ្ឌ ១០៦២, ១០៦៣, ១០៨០, ១០៨១, និង ២៨១៣[584]។ ក្នុងកថាខណ្ឌ ១០៦២ សហចៅក្រមស៊ើបអង្កេតបានផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ទាក់ទងនឹងវគ្គរៀនសូត្រនយោបាយខ្លីមួយដែលបានប្រព្រឹត្តទៅនៅក្នុងកងវរសេនាតូចរបស់គាត់ នៅថ្ងៃមួយ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ការពិនិត្យមើលដោយប្រុងប្រយ័ត្នលើសក្ខីកម្មរបស់គាត់បង្ហាញថា កិច្ចប្រជុំនេះមិនបាន "ប្រព្រឹត្តទៅនៅក្នុងភូមិ ឬក្នុងឃុំទេ" គឺនៅក្នុងកងវរសេនាតូចរបស់គាត់ដែលមានទីតាំងនៅ "ក្នុងស្រុកកោះអណ្តែតជិតព្រំដែនវៀតណាម"[585]។ នៅក្នុងកថាខណ្ឌ ១០៦៣ អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ ខឹម បឿន និងលើរបាយការណ៍ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ដែលចេញពីឃុំ

---

ក៏ត្រូវគេអនុញ្ញាតឱ្យចូលមន្ទីរពេទ្យ ប៉ុន្តែមិនមានថ្នាំសង្កូវ។ ក៏ប៉ុន្តែមូលហេតុនៃការស្លាប់នោះគឺនាងមិនមានអ្វីហូប ដូច្នេះក៏រើសរបស់ហូបនៅលើដី)"។

[582] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤។

[583] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥ កថាខណ្ឌ ៤៣១៨-៤៣២៨, ៤៤០០, ៤៤០២។

[584] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៥ កំណត់សម្គាល់ជើងទំព័រលេខ ៣៩៩៤ ដែលយោងទៅកថាខណ្ឌ ១០៦២, ១០៦៣, ១០៨០, ១០៨១ និង ផ្នែក ១២.៣៖ មន្ទីរសន្តិសុខក្រាំងតាចាន់ កថាខណ្ឌ ២៨១៣។

[585] ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 10.59.36។

ជាងទង ដើម្បីគាំទ្រសក្តីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ពោលគឺវាជាធាតុភ្ស័ស្តុតាងពីរនៅក្រៅវិសាលភាពភូមិសាស្ត្រនៃការជំនុំជម្រះ[586]។ នៅកថាខណ្ឌ១០៨០ អង្គជំនុំជម្រះក៏បានផ្អែកលើភស្តុតាងឯកសារក្រៅវិសាលភាពនៃការជំនុំជម្រះដើម្បីអះអាងថាអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ អាចត្រូវបានចាប់ខ្លួន ដោយសារទស្សនៈ ការនិយាយស្តី ឬអំពើរបស់ពួកគេ ដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងបដិវត្តន៍ និងអះអាងថាមានប្រតិបត្តិការដ៏ប្រល័យមួយចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដែលនៅក្នុងប្រតិបត្តិការនោះ អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ "ជាច្រើន" និងក្រុមគ្រួសាររបស់ពួកគេត្រូវបានសម្លាប់នៅត្រាំកក់[587]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានវិនិច្ឆ័យថាមានធាតុផ្សំសត្យានុម័តិគ្រប់គ្រាន់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញចំពោះអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រោមមូលហេតុនយោបាយ ដោយផ្អែកលើអង្គហេតុក្រៅវិសាលភាពភូមិសាស្ត្រនៃការជំនុំជម្រះទាំងនេះ[588]។

---

[586] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៦ ពាកំណត់សម្គាល់ជើងទំព័រលេខ ៣៥២៥-៣៥២៦។ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/296.1** ម៉ោង 11.23.46។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/2048** ERN 00079088។

[587] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៨០។ ចំណុចនៅ ក្រៅវិសាលភាពនៃការជំនុំជម្រះ៖ សេចក្តីរាយការណ៍ ចុះថ្ងៃទី១១ ខែមេសា នៃឃុំពពេល (កំណត់សម្គាល់ជើងទំព័រលេខ៣៥៨៩ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី១១ ខែមេសា [ឆ្នាំ១៩៧៧] ឯកសារ **E3/4629** ERN 00143476)។ សេចក្តីរាយការណ៍ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៧ ដែលបញ្ជូនដោយឃុំខ្ពបត្របែក (កំណត់សម្គាល់ជើងទំព័រលេខ ៣៥៩២ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2050** ERN 00079111។ របាយការណ៍ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ ស្តីពីឃុំពពេល (កំណត់សម្គាល់ជើងទំព័រលេខ៣៥៨៩ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2048** ERN 00079087)។ សំអាងហេតុសាលក្រម កថាខណ្ឌ ១០៨១។ បញ្ជីនៃសេចក្តីរាយការណ៍ដែលនៅក្រៅវិសាលភាពនៃការជំនុំជម្រះដែលមកពីឃុំអង្គតាសោម (កំណត់សម្គាល់ជើងទំព័រលេខ ៣៥៩៥៖ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧៧ ឯកសារ **E3/2440**។ កំណត់សម្គាល់ជើងទំព័រលេខ ៣៥៩៨៖ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/2784**។ បណ្ណសារនៃស្រុកត្រាំកក់ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/2785** ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៨)។

[588] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៥។

៣៧៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានធ្វើការវិនិច្ឆ័យដោយផ្អែកលើអង្គហេតុទាំងអស់នេះ ហើយប្រការនេះបង្កមោឃភាពដល់សេចក្តីសន្និដ្ឋានទាំងអស់របស់ខ្លួនលើធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[589]។ ដូច្នេះ អង្គជំនុំជម្រះក៏មិនអាចបញ្ចូលអង្គហេតុទាំងនេះក្នុងគោលនយោបាយដែលត្រូវបានកំណត់ថា "មានចរិតឧក្រិដ្ឋបានដែរ[590]។ អាស្រ័យហេតុនេះ រាល់ការសន្និដ្ឋានក្នុងន័យនេះ រួមទាំងការផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅត្រាំកក់ ដោយមូលហេតុនយោបាយ ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម ត្រូវទុកជាមោឃៈ[591]។

### ១.២.៣. ការផ្តន្ទាទោសចំពោះការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយទៅលើប្រជាជន ថ្មីនៅក្រៅឃុំទាំងប្រាំបី

៣៧៤. **<u>អំពីការផ្គត់ផ្គង់ស្បៀងអាហារខុសគ្នា</u>៖** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ប្រជាជនថ្មីទទួលបានរបបអាហារតិចជាងប្រជាជនមូលដ្ឋាន ផ្អែកលើកថាខណ្ឌ ១០១៦ ដែលរៀបរាប់ភ័ស្តុតាងក្រៅវិសាលភាពភូមិសាស្ត្រនៃការជំនុំជម្រះក្តី[592]។

---

[589] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥។

[590] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៥៨, ៤០៦០-៤០៦១។

[591] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[592] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ ៤០០៣ ដលយោងទៅកថាខណ្ឌ ១០១៦។ អ្វីដែលនៅក្រៅវិសាលភាពនៃការជំនុំជម្រះគឺ៖ ការរៀបរាប់នៃដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន (ឃុំលាយបូរ) ដែលជាទីតាំងភូមិសាស្ត្រក្រៅវិសាលភាពនៃការ ជំនុំជម្រះ (កំណត់សម្គាល់ជើងទំព័រលេខ ៣២៥៨៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ម៉ោង 11.53.40)។ ការរៀបរាប់របស់ ពេជ្រ ជីម ដែលថាគាត់បានឃើញប្រជាជនមូលដ្ឋានទទួលបានអង្ករច្រើនជាងប្រជាជនថ្មីពីព្រោះអ្វីបញ្ជាក់ពីទីកន្លែងនៅក្នុងស្រុកត្រាំកក់ ដែលនៅទីនោះគាត់បានសង្កេតឃើញរឿងនោះ (កំណត់សម្គាល់ជើងទំព័រលេខ ៣២៥១៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** ម៉ោង 14.01.10)។

៣៧៥. **អំពីល័ក្ខខ័ណ្ឌការងារខុសគ្នា៖** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ប្រជាជនថ្មីមានល័ក្ខខ័ណ្ឌការងារធ្ងន់ធ្ងរជាងប្រជាជនមូលដ្ឋាន ដោយផ្អែកលើភ័ស្តុតាងជាច្រើននៅក្រៅពីវិសាលភាពភូមិសាស្ត្រនៃការជំនុំជម្រះក្តី[593]។

៣៧៦. **អំពីការប្រព្រឹត្តិ "ជំរន្ធត់"៖** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ប្រជាជនថ្មីបានទទួលរងការប្រព្រឹត្តិជំរន្ធត់ ដោយផ្អែកលើសក្ខីកម្មរបស់ រី ពៅ[594]។ គាត់បានលើកឡើងពីកន្លែងជាច្រើនដែលគាត់ធ្លាប់រស់នៅ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីគាត់បានត្រឡប់មកពីប្រទេសវៀតណាមវិញ ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦៖ នៅក្នុងភូមិត្នោតជ្រុំ ឃុំខ្ពបត្របែក ស្រុកត្រាំកក់ មុនពេលត្រូវបានបញ្ជូនទៅកងចល័តមួយនៅក្បាលពូ "នៅខាងត្បូងខេត្តតាកែវ"[595]។ ទោះបីជាមានការលំបាកក្នុងការដឹងថាតើគាត់បានផ្លាស់ទីលំនៅនៅពេលណាក៏ដោយ ក៏គាត់បាននិយាយដែរថា គាត់បានចេញ "ពីភូមិស្ទឹង ឃុំខ្ពបត្របែកទៅកាន់ឃុំសំរោង" ហើយក្នុងពេលជាមួយគ្នា គាត់បានបន្ថែមថាគាត់ត្រូវ "ភ្ជួរស្រែ និងជីកប្រឡាយនៅក្នុងភូមិពងទឹក"[596]។ ទីបំផុត នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គាត់បាននិយាយថា គាត់បានឆ្លងកាត់ "ភូមិព្រៃតាខាប ឃុំសំរោង"[597]។ ដោយហេតុ រី ពៅ ពុំបានផ្តល់មានព័ត៌ចង្អុលបង្ហាញអំពីការប្រព្រឹត្តិជំរន្ធត់នេះ ក្នុងពេលគាត់ផ្តល់សក្ខីកម្មនៅក្នុងសវនាការ

---

[593] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៨។ ស្ថិតក្រៅវិសាលភាព៖ សក្ខីកម្មរបស់ គាក សាន់ ទាក់ទងទៅនឹងការរៀបរាប់របស់គាត់អំពីល័ក្ខខ័ណ្ឌការងារនៅការដ្ឋានទំនប់គោកគ្រួស ដែលមិនស្ថិតក្នុងវិសាលភាពភូមិសាស្ត្រនៃការជំនុំជម្រះក្តីនេះឡើយ (កំណត់សម្គាល់ជើងទំព័រលេខ ៣២៦៤៖ ប្រតិចារឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1**), សក្ខីកម្មរបស់ អៀម យេន ដែលលើកឡើងអំពីការដ្ឋានទំនប់ទួលគ្រួស (កំណត់សម្គាល់ជើងទំព័រលេខ៣២៦៧៖ ប្រតិចារឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1**)។ សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៩។ ស្ថិតក្រៅវិសាលភាព៖ សក្ខីកម្មដាក់បន្ទុករបស់ ឯម កឿង ពីព្រោះគាត់មិនបានបញ្ជាក់ថាគាត់ធ្វើការនៅទីណាទេ (កំណត់សម្គាល់ជើងទំព័រលេខ ៣២៧០៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/263.1** ទំព័រ ៨០)។ សក្ខីកម្មដាក់បន្ទុករបស់ មាស សុខា (ឃុំជាងទង) ស្ថិតក្រៅវិសាលភាពភូមិសាស្ត្រ និងមិនអាចប្រើប្រាស់ជាធាតុផ្សំភ័ស្តុតាង (កំណត់សម្គាល់ជើងទំព័រលេខ ៣២៧៣៖ ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/250.1** ទំព័រ ២៩-៣០)។

[594] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ៤០០៧ ដែលយោងទៅកថាខណ្ឌ ១០២៧។

[595] ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ម៉ោង 10.42.55។

[596] ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ម៉ោង 11.22.04។

[597] កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី រី ពៅ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E3/9604** សំណួរ-ចម្លើយ ២៤។

គេមិនអាចកំណត់ថាតើទីតាំងនោះនៅឯណាទេ។ ក្នុងក្តីមន្ទិលសង្ស័យដូចនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា វាជាឃុំមួយដែលស្ថិតក្នុងវិសាលភាពនៃបណ្តឹងមកកាន់ខ្លួននោះទេ។

៣៧៧. **អំពីការឃ្លាំមើល និងការចាប់ខ្លួន**៖ ការសន្និដ្ឋានលើអង្គហេតុចុងក្រោយថាមានការប្រព្រឹត្តិដោយរើសអើង ចំពោះប្រជាជនថ្មី និងអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងមនុស្សផ្សេងទៀតដែលត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់ ប.ក.ក ហើយដែលអង្គជំនុំជម្រះបានយល់ឃើញថាពួកគេ "អាចត្រូវបានចាប់ខ្លួន ដោយសារតែទស្សនៈ ការនិយាយស្តី និងអកប្បកិរិយារបស់ពួកគេ"[598]។ ទោះយ៉ាងនេះក្តី ភ័ស្តុតាងទាក់ទងនឹងការឃ្លាំមើលមនុស្ស ស្ថិតនៅក្រៅវិសាលភាពភូមិសាស្ត្រនៃបណ្តឹងមកកាន់អង្គជំនុំជម្រះ[599]។ ភ័ស្តុតាងនៅក្នុងកថាខណ្ឌ ១០៨០ ដែលអង្គជំនុំជម្រះបានផ្អែកលើដើម្បីសន្និដ្ឋានថា សមាជិកប្រជាជនថ្មីអាចត្រូវបានចាប់ខ្លួន ក៏ស្ថិតនៅក្រៅវិសាលភាពភូមិសាស្ត្រផងដែរ[600]។ អាស្រ័យហេតុនេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលរាប់បញ្ចូលអង្គហេតុទាំងនេះថាជាផ្នែកមួយនៃគោលនយោបាយ"ឧក្រិដ្ឋ" ត្រូវទុកជាមោឃៈ[601]។ ការផ្តន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូល

[598] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ ៤០១០ ដែលយោងទៅកថាខណ្ឌ ១០៥៥ និង ១០៨០។

[599] អ្វីដែលនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី គឺសក្ខីកម្មរបស់ ឯក ហឿន សំអាងហេតុសាលក្រម កថាខណ្ឌ១០៥៥ កំណត់សម្គាល់ជើងទំព័រលេខ៣៤៧០។ ការផ្តល់សក្ខីកម្មរបស់ ថាន់ ធីម (ផូមិត្រពាំងត្រាវ ឃុំត្រពាំងធំខាងជើង)។ សំអាងហេតុនៃសាលក្រម កថាខណ្ឌ ១០៦៦ (កំណត់សម្គាល់ជើងទំព័រលេខ ៣៤៧៣៖ ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/289.1** ចន្លោះម៉ោង 10.33.09 និងម៉ោង 10.36.02)។ ការផ្តល់សក្ខីកម្មរបស់ វង សារុន (ភូមិចាន់ទាប) សំអាងហេតុសាលក្រម កថាខណ្ឌ ១០៥៥ (កំណត់សម្គាល់ជើងទំព័រលេខ ៣៤៧៦៖ ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/300.1** ទំព័រ ៦៩-៧០)។ សេចក្តីរាយការណ៍នៃឃុំជាងទង ក៏ដូចគ្នានេះដែរ សំអាងហេតុនៃសាលក្រម កថាខណ្ឌ១០៥៥ កំណត់សម្គាល់ជើងទំព័រលេខ ៣៤៧១។ បណ្ណសារនៃឃុំត្រាំកក់ ឯកសារ **E3/8428** ERN 00271051។ និង សេចក្តីរាយការណ៍ឃុំពពេល និងឃុំសើន សំអាងហេតុសាលក្រម កថាខណ្ឌ១០៥៥ កំណត់សម្គាល់ជើងទំព័រលេខ៣៤៨០ និង ៣៤៨១។

[600] សូមមើលខាងលើ នៅកថាខណ្ឌ ៣៧២ ទាក់ទងនឹងឃុំពពេល។ លើសពីនោះ សេចក្តីរាយការណ៍ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៧ នៃឃុំពពេទាក់ទងនឹងអង្គហេតុក្រៅវិសាលភាពនៃការជំនុំជម្រះ។ បណ្ណសារនៃឃុំត្រាំកក់ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2048** ERN 00079087។

[601] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២៤-៣៩២៥, ៣៩២៨។

ហេតុយោបាយទៅលើប្រជាជនថ្មីនៅត្រាំកក់ ចំពោះអង្គហេតុទាំងនេះ ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម ត្រូវទុកជាមោឃៈ[602]។

## ២. គ្មានបណ្ដឹងអំពីការស្លាប់ដោយមូលហេតុផ្សេងក្រៅពីការអត់ឃ្លាន

៣៧៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា វិសាលភាពនៃបណ្ដឹងជាក់ស្ដែងមកកាន់ខ្លួន លាតសន្ធឹងដល់ការស្លាប់ដោយមូលហេតុផ្សេងទៀតក្រៅពីការស្លាប់ដោយអត់ឃ្លាន[603]។ អង្គជំនុំជម្រះគួរពិចារណាពីការរំលោភបំពានលើវិសាលភាពនៃបណ្ដឹងជាក់ស្ដែងពីសំណាក់សហចៅក្រមស៊ើបអង្កេត និងកត់សម្គាល់ថា ខ្លួនមិនអាចវិនិច្ឆ័យ និងផ្ដន្ទាទោសលើសពីវិសាលភាពនៃបណ្ដឹងមកកាន់ខ្លួនឡើយ។

៣៧៩. ទាក់ទងទៅនឹងបទចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋានថា ខ្លួនបានទទួលបានបណ្ដឹងអំពីបទចោទ ក្រៅពីការស្លាប់ដោយសារការអត់ឃ្លាន ដើម្បីអាចបញ្ចូលអង្គហេតុនៃល័ក្ខខ័ណ្ឌរស់នៅមិនសមរម្យ កង្វះអនាម័យ និងជំនួយវេជ្ជសាស្ត្រ ព្រមទាំងបញ្ចូលកត្តាបន្ថែមពាក់ព័ន្ធនឹងការបង្ខំជនរងគ្រោះឱ្យធ្វើការក្នុងល័ក្ខខ័ណ្ឌលំបាកលំបិនខ្លាំង"[604]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបកស្រាយថា កថាខណ្ឌ ១៣៨៧ នៃដីកាដំណោះស្រាយ[605] ផ្ដល់មូលដ្ឋានត្រឹមត្រូវតាមច្បាប់ដល់បណ្ដឹងមកកាន់ខ្លួន ដើម្បីកាត់សេចក្ដីលើបទសម្លាប់រង្គាល ចំពោះអង្គហេតុទាក់ទងនឹងស្ថានភាពរស់នៅជាទូទៅ បន្ថែមពីលើការមិន

[602] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[603] សំអាងហេតុសាលក្រម កថាខណ្ឌ ៨០៨, ៨០៩។

[604] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១។

[605] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៧៖ "ដោយឡែក ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកស្ដីពី "ទង្វើអមនុស្សធម៌ផ្សេងៗទៀត" និង "ការធ្វើទុក្ខបុកម្នេញ" មានមនុស្សជាច្រើននាក់បានស្លាប់ ដោយសារស្ថានភាពរស់នៅមានការលំបាកវេទនា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនលើកទី១ និងទី២ និងនៅតាមមន្ទីរសន្តិសុខទាំងនោះ។ មនុស្សទាំងនោះទទួលបានរបបអាហារមិនគ្រប់គ្រាន់ គ្មានជម្រក គ្មានការថែទាំវេជ្ជសាស្ត្រ និងអនាម័យ។ ដូចគ្នានេះដែរ ចំពោះអ្នកដែលធ្វើការនៅការដ្ឋានធ្វើការងារដោយបង្ខំ ពួកគេស្ថិតក្នុងស្ថានភាពរស់នៅ ដូចគ្នា មិនតែប៉ុណ្ណោះ ពួកគេត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ថែមទៀតផង" (យើងគូសបន្ទាត់ពីក្រោម)។

ផ្តល់អាហារគ្រប់គ្រាន់[606]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយផ្អែកលើការសន្និដ្ឋានមួយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានធ្វើឡើងហួសដែនសមត្ថកិច្ចរបស់ខ្លួន ដោយរំលោភបំពានលើវិសាលភាពនៃបណ្តឹងជាក់ស្តែង[607]។ ជាក់ស្តែង សហព្រះរាជអាជ្ញាមិនដែលបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត នូវអង្គហេតុនៃការស្លាប់ណាផ្សេងក្រៅពីការស្លាប់ដោយសារកង្វះអាហារឡើយ[608]។ ដោយមូលហេតុពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ការសន្និដ្ឋានខាងលើរបស់សហចៅក្រមស៊ើបអង្កេត បានរំលោភលើវិសាលភាពនៃបណ្តឹងជាក់ស្តែង ដែលកម្រិតត្រឹមតែការស្លាប់ដោយសារកង្វះអាហារតែប៉ុណ្ណោះ។ ដោយបានទទួលអង្គហេតុទាំងនេះដោយមិនត្រឹមត្រូវតាមច្បាប់ អង្គជំនុំជម្រះគួរណាទាញផលវិបាកពីរឿងនេះ ហើយគួរណាកត់សម្គាល់ថា ខៀវ សំផន មិនចាំបាច់ឆ្លើយតបនឹងបញ្ហាទាំងនេះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកាត់សេចក្តីលើអង្គហេតុដែលខ្លួនមិនបានទទួលត្រឹមត្រូវតាមច្បាប់។ ការអនុវត្តច្បាប់ដោយមិនត្រឹមត្រូវនេះ នាំឱ្យអង្គជំនុំជម្រះពង្រីកវិសាលភាពនៃការជំនុំជម្រះដោយខុសច្បាប់។ កំហុសនេះជះឥទ្ធិពលដោយផ្ទាល់ទៅលើការសន្និដ្ឋាននានារបស់ខ្លួន ដោយផ្អែកលើភ័ស្តុតាងទាក់ទងនឹងអង្គហេតុក្រៅពីការស្លាប់ដោយទុរ្ភិក្ស ដែលម្ចាស់បណ្តឹងសាទុក្ខត្រូវទទួលខុសត្រូវឡើយ។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា "មនុស្សជាច្រើនបានស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ ការងារហួសកម្លាំង និងជំងឺ រាប់បញ្ចូលទាំងក្នុងរយៈពេលក្រោយៗមកទៀត ហើយប្រជាជនថ្មីទទួលរងផលប៉ះពាល់យ៉ាងខ្លាំង" ត្រូវទុកជាមោឃៈ[609]។ ដូចគ្នាដែរ ការសន្និដ្ឋានថា "មានមនុស្សស្លាប់ជាពិសេសនៅមន្ទីរពេទ្យស្រុក ដោយសារតែការថែទាំវេជ្ជសាស្ត្រមានកម្រិតទាបបំផុត កង្វះអាហារូបត្ថម្ភ និងការងារហួសកម្រិត ត្រូវទុកជាមោឃៈ"[610]។ ដូច្នេះ ផ្អែកលើការសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយកំណត់អង្គហេតុទាំងនេះថាជាបទមនុស្សឃាត ដែលតាមពិតទៅ អង្គ

---

[606] សំអាងហេតុសាលក្រម កថាខណ្ឌ៨១១។

[607] សំអាងហេតុសាលក្រម កថាខណ្ឌ៨១១, ៨១៣។

[608] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៣៖ "មនុស្សរាប់ពាន់នាក់ស្លាប់ដោយសារស្រេកឃ្លាននៅក្នុងសហករណ៍ទាំងនេះ [...]"។

[609] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២, ១០១៦, ១០២០ និង ១០៣៧។

[610] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២, ១០៤៧។

ហេតុទាំងនេះទាក់ទងនឹងការស្លាប់ដោយសារល័ក្ខខ័ណ្ឌការងារ និងកត្តាជីវភាព[611]។ ផ្ទុយទៅវិញ តុលាការកំពូលត្រូវតែប្រកាសសម្រេចថា អង្គជំនុំជម្រះគ្មានយុត្តាធិការក្នុងការវិនិច្ឆ័យអង្គហេតុទាំងនេះ និងធ្វើមោឃភាពការសន្និដ្ឋានថាអង្គហេតុទាំងនេះជាធាតុផ្សំសត្យានុម័តិនៃបទមនុស្សឃាត[612]។ ការផ្ដន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់អំពើមនុស្សឃាតដោយចេតនាប្រយោល ចំពោះការស្លាប់ផ្សេងទៀតក្រៅពីការស្លាប់ដោយសារភាពអត់ឃ្លាន ក៏ត្រូវទុកជាមោឃៈដែរ[613]។

## ៣. ការនិរទេស

៣៨០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយពិចារណាថា "ការចោទប្រកាន់លើអង្គហេតុនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យទៅស៊ើបសួរ បានធ្វើឱ្យជនជាប់ចោទដឹងថា សហចៅក្រមស៊ើបអង្កេតនឹងស៊ើបសួរលើហេតុការណ៍ដែលកើតចេញពីការអនុវត្តគោលនយោបាយរបស់ ប.ក.ក ក្នុងការចាត់វិធានការរើសអើងប្រឆាំងជនជាតិវៀតណាម រួមទាំងការផ្លាស់ទីលំនៅពួកគេដោយបង្ខំ ឬការនិរទេសពួកគេចេញពីប្រទេសកម្ពុជាដោយបង្ខំ"[614]។ ដើម្បីគាំទ្រដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះមិនបានគោរពតាមវិធានស្ដីពីការស៊ើបអង្កេតព្រហ្មទណ្ឌ ដោយបន្ថែមអង្គហេតុថ្មីៗនៅក្នុងដីកានេះ។ អង្គជំនុំជម្រះវិភាគផ្នែកខ្លះនៃដីកា ដោយដកស្រង់តែផ្នែកមួយនៃកថាខណ្ឌ ១២ ដែលបរិយាយថាការប្រព្រឹត្តិឧក្រិដ្ឋកម្មលើជនជាតិវៀតណាម ជាគោលនយោបាយរើសអើង និងឃាតកម្ម[615]។ ការអានអត់ក្បាលអត់កន្ទុយនេះធ្វើឱ្យគេយល់ថា ដីកានេះមិនច្បាស់លាស់ ហើយចាំបាច់ត្រូវវិភាគវាដោយយោងទៅលើឯកសារផ្សេងៗទៀត។ ក៏ប៉ុន្តែ ផ្នែកក្រោយមកទៀត នៃកថាខណ្ឌ ១២ ពន្យល់ពីអង្គហេតុចោទប្រកាន់ដោយសហព្រះរាជអាជ្ញា ពោលគឺ អង្គហេតុនៃគោលនយោបាយកម្ទេចបុគ្គលដែលត្រូវបានគេ

---

[611] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៩៤-១១៩៥។

[612] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៩៤-១១៩៥។

[613] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៨-៤៣២៨ កថាខណ្ឌ ៤៤០០, ៤៤០២។

[614] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៨។

[615] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៨។

ចាត់ទុកថាជាជនជាតិវៀតណាម។ សហព្រះរាជអាជ្ញាពុំបានបញ្ជូនអង្គហេតុណាមួយសោះទាក់ទងនឹងការនិរទេសឡើយ[616]។

៣៨១. ពេលវិភាគដីកានេះមកខាងក្រោយទៀត អង្គជំនុំជម្រះបានបញ្ជាក់ថា សហព្រះរាជអាជ្ញាផ្អែកលើឯកសារចំនួនពីរ ដើម្បី "បញ្ជាក់ពីអង្គហេតុចោទរងការចោទប្រកាន់ដែលត្រូវស៊ើបអង្កេត" នោះគឺសៀវភៅខ្មៅ និងសៀវភៅមួយក្បាលរបស់ Ben KIERNAN[617]។ ដើម្បីឱ្យយល់កាន់តែច្បាស់ ថាតើឯកសារទាំងពីរនេះ "បញ្ជាក់គាំទ្រ" អង្គហេតុណាខ្លះ អង្គជំនុំជម្រះបានយោងទៅកំណត់សម្គាល់ជើងទំព័រលេខ ៣៧ និង ២៩១ នៃដីកានេះ[618] សម្រាប់សៀវភៅខ្មៅ។ ប៉ុន្តែ សម្រាប់សៀវភៅ Ben KIERNAN អង្គជំនុំជម្រះមិនបានយោងទៅចំណុចណាមួយនៃដីកានេះឡើយ ដែលរារាំងមិនឱ្យដឹងថាតើឯកសារនេះ "បញ្ជាក់គាំទ្រ" ដល់អង្គហេតុណាខ្លះឡើយ។ ទាក់ទងនឹងសៀវភៅខ្មៅ កំណត់សម្គាល់ជើងទំព័រលេខ ៣៧ និង ២៩១ បញ្ជាក់គាំទ្រដល់ទឡ្ហីករណ៍ពីរដូចតទៅនេះ៖ (i) "ដោយហេតុទំនាក់ទំនងរបស់ ប.ក.ក ជាមួយវៀតណាមកាន់តែធ្លាក់ដុនដាបទៅ វៀតណាមកាន់តែត្រូវបានចាត់ទុកជាខ្មាំង"[619] និង (ii) "យុទ្ធជននៃកងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានញុះញង់ឱ្យស្អប់ជនជាតិវៀតណាម និងទទួលបន្ទុកសម្លាប់រាល់ជនជាតិវៀតណាមដែលពួកគេជួបប្រទះ[620]។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាមិនបានបញ្ជូនអង្គហេតុណាមួយទាក់ទងនឹងការនិរទេសជនជាតិវៀតណាមមកកាន់សហចៅក្រម

---

[616] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ១២-ច៖ "បក្សកុម្មុយនីស្តកម្ពុជាបានបន្តធ្វើនយោបាយរើសអើង ប្រឆាំង និងសម្លាប់ជនជាតិភាគតិចវៀតណាម។ ពីដំបូង បក្សកុម្មុយនីស្តកម្ពុជាបានអនុម័តនូវនយោបាយមួយ ក្នុងការបោសសម្អាតជនទាំងនោះដែលត្រូវបានគេចាត់ទុកថាជាជនជាតិវៀតណាម ឬអ្នកដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម។ យ៉ាងណាមិញ ទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជា ជាមួយប្រទេសវៀតណាមបានចុះដុនដាបជាលំដាប់ហើយមានទស្សនៈដែលចេះតែកើនឡើងថា ប្រទេសវៀតណាមគឺជាខ្មាំង។ ទស្សនៈនេះវាស៊ីគ្នាទៅនឹងជំនឿដែលថា គិញវៀតណាមកំពុងព្យាយាមវិលំបក្សកុម្មុយនីស្តកម្ពុជា។ មកដល់ពាក់កណ្តាល និងចុងឆ្នាំ១៩៧៧ គោលនយោបាយបានវិវត្តទៅជាគោលនយោបាយមួយដែលលុបបំបាត់ប្រជាជនទាំងអស់ ដែលមានទំនាក់ទំនងជាមួយប្រទេសវៀតណាម"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[617] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៨។

[618] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៨ កំណត់សម្គាល់ជើងទំព័រលេខ៣៦៦។

[619] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ១២-ច។

[620] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 កថាខណ្ឌ ៧០។

ស៊ើបអង្កេតដើម្បីស៊ើបសួរឡើយ។ អាស្រ័យហេតុនេះហើយបានជានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពុំមានលើកឡើងអំពីអង្គហេតុនៃការជម្លៀសជនជាតិវៀតណាមទាល់តែសោះ។

៣៨២. ប៉ុន្តែអង្គជំនុំជម្រះមិនបានបញ្ឈប់នៅត្រឹមហ្នឹងទេ។ អង្គជំនុំជម្រះថែមទាំងប្រឹងស្វែងរកក្នុងតារាងពន្យល់ចំនួន ២៣០ ទំព័រ និងឧបសម្ព័ន្ធ (គ) ១៣៨ ទំព័រ ដែលភ្ជាប់ជាមួយដីកានេះ ដើម្បីរកឱ្យបានចំណុចយោងមួយទៅនឹងសម្រង់ចេញពីសៀវភៅខ្មៅ ដែលសម្រង់នេះលើកឡើងអំពីកិច្ចព្រមព្រៀងមួយដើម្បីឱ្យជនជាតិវៀតណាមចាកចេញពីប្រទេសកម្ពុជាក្រោយថ្ងៃរំដោះ[621] និងឱ្យបានចំណុចយោងមួយទៅសៀវភៅរបស់ Ben KIERNAN ដែល "អាចបញ្ជាក់" ថាពិតជាមាន "ការជម្លៀសជនជាតិវៀតណាមសុទ្ធដោយបង្ខំមែន"[622]។ ពិតមែនតែអង្គជំនុំជម្រះបានបញ្ជាក់ថា ដីកានេះត្រូវតែវិភាគដោយ "យោងទៅតាមឯកសារគាំទ្រភ័ស្តុតាងទាំងអស់ដែលត្រូវបានដកស្រង់ជាក់លាក់ដើម្បីគាំទ្រដីកានេះ"[623] ក៏ប៉ុន្តែ នេះមិនមែនករណីនៃឯកសារដែលអង្គជំនុំជម្រះបានដកស្រង់នោះទេ។ ជាក់ស្តែង វាជាករណីនៃអង្គហេតុថ្មីដែលមានតែនៅក្នុងឧបសម្ព័ន្ធប៉ុណ្ណោះ។ ទោះយ៉ាងណា សហចៅក្រមស៊ើបអង្កេតត្រូវតែស៊ើបអង្កេតតែលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ"[624]។ បន្ថែមលើនេះ "ប្រសិនបើពេលស៊ើបអង្កេត ក្នុងករណីទទួលបានអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងអំពីអង្គហេតុថ្មីដល់សហព្រះរាជអាជ្ញា [...]។ ក្នុងករណីពុំបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សហចៅក្រមស៊ើបសួរមិនមានសិទ្ធិអំណាចស៊ើបអង្កេតលើអង្គហេតុថ្មីៗទេ"[625]។ ដូច្នេះ ដោយពិចារណាថាសហចៅក្រមស៊ើបអង្កេតអាចស៊ើបសួរ ដោយមិនរំលោភវិសាលភាពនៃបណ្តឹងអំពីអង្គហេតុនៃការនិរទេសជនជាតិវៀតណាមដោយផ្អែកតែលើភ័ស្តុតាងដែលមាននៅក្នុងឧបសម្ព័ន្ធ ហើយដែលមិនមានបញ្ជាក់ច្បាស់លាស់

[621] តារាងបញ្ជីឯកសារ ១០៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ **D3/I** ERN 00194238។

[622] ឧបសម្ព័ន្ធ គ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ **D3/IV** ERN 00271584។

[623] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦។

[624] វិធានផ្ទៃក្នុង វិធាន ៥៥.២។

[625] វិធានផ្ទៃក្នុង វិធាន ៥៥.៣។

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អង្គជំនុំជម្រះមិនបានគោរពតាមវិធានស្តីពីការស៊ើបអង្កេតព្រហ្មទណ្ឌឡើយ។

៣៨៣. លើសពីនេះទៅទៀត ការប្រកាន់យកវិចារណកិច្ចបែបនេះរបស់អង្គជំនុំជម្រះ ធ្វើឱ្យអស់ខ្លឹមសារចំពោះអត្ថប្រយោជន៍នៃនីតិវិធីចាំបាច់របស់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវតែមាន "សេចក្តីសង្ខេបអង្គហេតុ" និង "ការកំណត់ប្រភេទបទល្មើស"[626]។ អង្គជំនុំជម្រះពិចារណាថា វាជាការឡូហ្សិកក្នុងការសន្និដ្ឋានថា អង្គហេតុទាំងអស់ដែលមានរៀបរាប់នៅក្នុងភ័ស្តុតាងដែលភ្ជាប់ជាឧបសម្ព័ន្ធនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សុទ្ធតែជាអង្គហេតុដែលត្រូវស៊ើបអង្កេត។ ក៏ប៉ុន្តែ វាមិនសមហេតុផលទេក្នុងការពិចារណាថា អង្គហេតុទាំងអស់ដែលបានរៀបរាប់នៅក្នុងសៀវភៅ Ben KIERNAN ឬនៅក្នុងសៀវភៅខ្មៅ សុទ្ធតែអាចជាកម្មវត្ថុនៃការស៊ើបអង្កេត។ នៅក្នុងល័ក្ខខ័ណ្ឌនេះ និងក្នុងសំណុំរឿងមួយដ៏សម្បើមបែបនេះ ម្ចាស់បណ្តឹងសាទុក្ខពុំមានលទ្ធភាពដឹង ថាតើសហចៅក្រមស៊ើបអង្កេតត្រូវបានអនុញ្ញាតឱ្យស៊ើបអង្កេតលើអង្គហេតុណាខ្លះ។ នេះជាការប្រមាថមាក់ងាយគោលការណ៍ធានាឱ្យមានសច្ចភាពគតិយុត្តិ។

៣៨៤. ជាទីបញ្ចប់ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយអះអាងថា ដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរ "បញ្ជាក់យ៉ាងច្បាស់ពី "ការនិរទេស" ក្នុងចំណោមឧក្រិដ្ឋកម្ម ដែលត្រូវស៊ើបសួរ"[627]។ ដូចដែលបានរំឭករួចហើយ សហចៅក្រមស៊ើបអង្កេតត្រូវបាន អនុញ្ញាតឱ្យស៊ើបអង្កេត "តែលើអង្គហេតុណាដែលត្រូវបានកំណត់ដោយដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"[628]។ ដូច្នេះ អង្គជំនុំជម្រះ បានរំលោភលើវិធានស្តីពីការស៊ើបអង្កេតព្រហ្មទណ្ឌ ដោយពិចារណាថា សហចៅក្រម ស៊ើបអង្កេតអាចស៊ើបសួរលើ "ឧក្រិដ្ឋកម្ម" ណាមួយ[629]។ លើសពីនេះ

[626] វិធានផ្ទៃក្នុង វិធាន ៥៣.១ក និង ៥៣.១ខ។

[627] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨។

[628] វិធានផ្ទៃក្នុង វិធាន ៥៥.២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[629] តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧២ លេខ ៧១-៩៣៦២២ ("ចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹងលើអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលខុសពីប្រភេទនៃបទល្មើសនៃអង្គហេតុ

ទៀត ក្នុងផ្នែក កំណត់ប្រភេទបទល្មើស ដីកានេះពុំបានសំដៅទាល់តែសោះទៅលើអង្គហេតុទាក់ទង នឹងជនជាតិវៀតណាម តែគ្រាន់តែសំដៅទៅលើដំណាក់កាលទាំងបីនៃការជម្លៀស ប្រជាជនទាំងអស់ ដោយបង្ខំ ហើយអង្គហេតុទាំងនេះមិនទាក់ទងនឹងការបញ្ជូន ប្រជាជនទៅប្រទេសវៀតណាមទេ[630]។

៣៨៥. យោងលើធាតុផ្សំភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះបានពង្រីកទាំងខុសច្បាប់ នូវវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅដល់អង្គហេតុថ្មីៗទៀត។ ទាំងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាំងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពុំមានការកំណត់ឱ្យស៊ើបអង្កេតណាមួយលើអង្គហេតុនិរទេសឡើយ។ រាល់ការសន្និដ្ឋានផ្លូវច្បាប់ដែលទាក់ទងនឹងអង្គហេតុទាំងអស់នេះ ត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែបានលើកលែងទោស ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការនិរទេស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុរើសអើងពូជសាសន៍ នៅត្រាំកក់ និងព្រៃវែង ចំពោះអំពើនិរទេស[631]។

**ផ្នែកទី ២. ទំនប់ត្រពាំងថ្ម**

៣៨៦. **<u>អំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ៖</u>** អង្គជំនុំជម្រះបាន ប្រកាសថា ខ្លួនបានទទួលអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានទំនប់ត្រពាំង ថ្ម[632] ខណៈពេលដែលមេធាវីការពារក្តីបានជំទាស់នឹងការចោទប្រកាន់លើអង្គហេតុ ទាំងនេះ ដោយហេតុថាអង្គជំនុំជម្រះផ្អែកលើចំ

ដោយអយ្យការ")។ តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩២ លេខ ៩១-៨៦០៦៦ (ចៅក្រមស៊ើបសួរ "មិនពាក់ព័ន្ធនឹងការកំណត់បទល្មើសបណ្តោះអាសន្ននៃអង្គហេតុដោយរដ្ឋអាជ្ញា")។

[630] កថាខណ្ឌ ៣៧ ដល់ ៤២ កំណត់ដោយប្រភេទនៃបទល្មើសទាក់ទងនឹងការជម្លៀសប្រជាជនមានជាប់ទាក់ទងនឹងអង្គហេតុជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញ និង ទីក្រុងផ្សេងៗទៀតទៅកាន់ស្រុកជនបទ បន្ទាប់ពីរំដោះប្រទេស អង្គហេតុនៃការជម្លៀសប្រជាជនរាប់ពាន់នាក់ពីផ្នែកកណ្តាល និងផ្នែកនីរតីនៃប្រទេស ឱ្យទៅនៅភូមិភាគឧត្តរ និងពាយ័ព្យ (ក្នុងនោះមានជនជាតិភាគតិចចាម) និងអង្គហេតុជម្លៀសប្រជាជនរាប់ម៉ឺននាក់ដោយបង្ខំពីភូមិភាគបូព៌ា ទៅកាន់ភូមិភាគកណ្តាល បស្ចឹម និងពាយ័ព្យ។

[631] សំអាងហេតុសាលក្រម កថាខណ្ឌ១០៦៨, ១១១០-១១២៥, ១១៥៦-១១៥៩, ៣៤២៩-៣៤៣៩, ៣៥០២-៣៥០៩, ៣៥១២, ៣៥១៣, ៤០០៤, ៤០១២, ៤២៣៧, ៤២៩២ និង ៤៣០៦។

[632] សំអាងហេតុសាលក្រម កថាខណ្ឌ ១២០៦។

ណាត់ការរបស់ចៅក្រមស៊ើបអង្កេត ដែលរំលោភបំពានលើវិសាលនៃបណ្តឹង[633]។ ជាក់ស្តែង ចៅក្រមស៊ើបអង្កេតបានទទួល បណ្តឹងពីការដ្ឋានទំនប់ត្រពាំងថ្ម តែតាមរយៈកថាខណ្ឌ ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះ។ កថាខណ្ឌនេះ មិនមានលើកឡើងទាល់តែសោះពីបញ្ហានៃការបាត់ខ្លួនរបស់កម្មករ។ ដូច្នេះ ការចោទប្រកាន់នេះត្រូវបានធ្វើឡើងដោយខុសច្បាប់ប្រឆាំងនឹង ខៀវ សំផន[634]។

៣៨៧. អង្គជំនុំជម្រះបានច្រានចោលទឡ្ហីករណ៍របស់មេធាវីការពារក្តី ដោយមិនផ្តល់សំអាងហេតុ។ អង្គជំនុំជម្រះបានថ្លែងយ៉ាងសាមញ្ញថា បណ្តឹងតវ៉ានេះមិនត្រូវបានលើកឡើងជាលក្ខណៈអញ្ញត្រកម្មឡើយ ដូច្នេះ បណ្តឹងតវ៉ានេះត្រូវបានដាក់យឺតពេល អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[635]។ ដូចដែលបានបង្ហាញខាងលើ ការសន្និដ្ឋាននេះមានកំហុសអង្គច្បាប់[636]។ ដូច្នេះ អង្គជំនុំជម្រះផ្អែកលើការសន្និដ្ឋានខុសច្បាប់នៃដីកាដំណោះស្រាយ ដើម្បីពិចារណាថាមានភ័ស្តុតាងគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ដទៃទៀត នៅការដ្ឋានត្រពាំងថ្ម[637] ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។ ការសន្និដ្ឋានទាំងនេះដែលផ្អែកលើបណ្តឹងខុសច្បាប់ ត្រូវតែទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែទទួលបានការលើកលែងទោស ចំពោះអង្គហេតុរងការចោទប្រកាន់[638]។

**ផ្នែកទី ៣. ទំនប់១មករា**

**១. គ្មានបណ្តឹងអំពីការសម្លាប់មនុស្សនៅវត្តបារាយណ៍ជាន់ដែក**

៣៨៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុសម្លាប់មនុស្សដែលបានកើតឡើងនៅវត្តបារាយណ៍ជាន់

[633] ដីកាដំណោះស្រាយ ៣៣៦, ៣៤៦, ៣៤៨, ១៤៧០។ សូមមើលផងដែរសារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១០១៨-១០២១។

[634] វិធានផ្ទៃក្នុង កថាខណ្ឌ ៤៦។

[635] សំអាងហេតុសាលក្រម កថាខណ្ឌ ១២០៦។

[636] សូមមើលខាងលើ កថាខណ្ឌ ៣៣៦-៣៥០។

[637] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤២២-១៤២៩។

[638] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤២៤-១៤២៩។

ដែក[639]។ អង្គជំនុំជម្រះគួរណាគិតពីការរំលោភបំពាន ពីសំណាក់សហចៅក្រមស៊ើបអង្កេតលើវិសាលភាពនៃបណ្ដឹងដាក់ស្ដែង ហើយគួរណាកត់សម្គាល់ថា ខ្លួនមិនអាចជំនុំជម្រះ ឬផ្ដន្ទាទោសចំពោះអង្គហេតុនៅក្រៅបណ្ដឹងឡើយ។ សេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលអង្គជំនុំជម្រះយកជាមូលដ្ឋាន ដើម្បីប្រកាសថាខ្លួនមានយុត្តាធិការលើអង្គហេតុនៃការសម្លាប់មនុស្សនៅវត្តបារាយណ៍ រំលោភបំពានលើវិសាលភាពនៃបណ្ដឹងដាក់ស្ដែង[640]។ អាស្រ័យហេតុនេះ ម្ចាស់បណ្ដឹងសាទុក្ខមិនចាំបាច់ឆ្លើយតបនឹងអង្គហេតុទាំងនេះទេ ពីព្រោះអង្គជំនុំជម្រះមិនបានទទួលអង្គហេតុទាំងនេះដោយត្រឹមត្រូវតាមច្បាប់ឡើយ។ នៅកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា មានភ័ស្តុតាងគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់អំពើមនុស្សឃាតនៅទីតាំងឧក្រិដ្ឋកម្មជាច្រើន រួមមាន ទំនប់១មករា។ មានតែការស្លាប់ដោយការប្រហារជីវិតប៉ុណ្ណោះ ដែលត្រូវកំណត់ប្រភេទជាអំពើមនុស្សឃាតនៅទំនប់១មករា[641]។ កថាខណ្ឌ ១៣៧៧ បញ្ជាក់ថា ទាក់ទងនឹងទំនប់១មករា ប្រជាជនត្រូវបាន "ចាប់យក ទៅសម្លាប់នៅក្បែរៗនោះ"។ ការប្រហារជីវិតទាំងនេះត្រូវបានពិពណ៌នានៅក្នុងកថាខណ្ឌ ៣៦៦ និងកថាខណ្ឌ ៣៦៧ នៃដីកាដំណោះស្រាយ។ នៅក្នុងកថាខណ្ឌ ៣៦៦ មានការលើកឡើងថា ប្រហែលជាមានប្រើឧបករណ៍រំពងសំឡេងដើម្បីបិទបាំងសំឡេងស្រែកយំក្នុងអំឡុងពេលសម្លាប់ ក្នុងខណៈដែលកថាខណ្ឌ ៣៦៧ លើកឡើងថា "សាក្សីមួយចំនួនបានឃើញការចាប់ខ្លួន សាក្សីខ្លះទៀតទៀតបានឮពីការសម្លាប់ [...]។ សាក្សីម្នាក់បានឃើញមនុស្សម្នាក់ត្រូវគេសម្លាប់។ កន្លែងមួយនៅក្បែរវត្តបារាយណ៍ជាន់ដែក ត្រូវបានគេស្គាល់ថាជាទីតាំងសម្លាប់មនុស្ស ក្រៅពីនេះ ទីតាំងសម្លាប់មនុស្សក៏មាន នៅកន្លែងផ្សេងៗទៀតដែរ"។

៣៨៩. ទោះជាយ៉ាងណាក្ដី សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្ដីសន្និដ្ឋានទាំងអស់នេះហួសពីដែនសមត្ថកិច្ចរបស់ខ្លួន។ កថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលជាកថាខណ្ឌតែមួយគត់នៃបណ្ដឹងអំពីទំបន់១មករា មិនមានលើកឡើងទាល់តែសោះ ពីអត្ថិភាពនៃទីតាំងសម្លាប់មនុស្សនៅខាង

---

[639] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥, ១៤៣៤, ១៦៦៥។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/304.1** ម៉ោង 15:24-31 ម៉ោង 15:37-47។ ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/326.1** ម៉ោង 13:20-23។

[640] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤៣៤, ១៦៦៥។

[641] សូមមើលខាងលើ កថាខណ្ឌ ១០០១-១០០៣។ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៧។

ក្រៅបរិវេណនៃការដ្ឋាន។ ផ្ទុយទៅវិញ កថាខណ្ឌនេះ លើកឡើងតែពីការបាត់បង់ជីវិត "នៅការដ្ឋាននេះ" ដោយមិនមានលើកឡើងពី "ការយកមនុស្សទៅសម្លាប់" និង "ការសម្លាប់មនុស្សនៅក្បែរនោះ" ទេ។ វត្តបារាយណ៍ជាន់ដែកត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ៩៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីបញ្ជាក់ពីវត្តមាននៃរណ្តៅកប់សាកសពជនរងគ្រោះ។ មិនដែលមានការលើកឡើងអំពីកន្លែងណាមួយដែល "គេស្គាល់ថាជា" កន្លែងសម្លាប់មនុស្ស ដូចការអះអាងខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេតឡើយ។ ការប្រៀបធៀបជាមួយអង្គហេតុដែលមានពិពណ៌នាអំពីមន្ទីរ ស-២១ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបង្ហាញថា សហចៅក្រមស៊ើបអង្កេតមិនទទួលបានបណ្តឹងពីទីតាំងនេះឡើយ។ ផ្ទុយទៅវិញ កថាខណ្ឌ ៥៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបង្ហាញយ៉ាងច្បាស់ថា ទីតាំងជើងឯកជាកន្លែងសម្លាប់អ្នកទោសមកពីមន្ទីរ ស-២១។ វាខុសពីករណីវត្តបារាយណ៍ជាន់ដែក ដែលមានតែវត្តមាននៃរណ្តៅសាកសពប៉ុណ្ណោះដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដោយហេតុពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ខៀវ សំផន មិនត្រូវទទួលខុសត្រូវចំពោះការស្លាប់ដែលបានកើតឡើងនៅវត្តនេះឡើយ។

៣៩០. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយកាត់ក្តីគាត់ចំពោះអង្គហេតុទាំងនេះ និងដោយសន្និដ្ឋានថា វត្តបារាយណ៍ជាន់ដែក គឺជាកន្លែងឃុំឃាំង និងកន្លែងសម្លាប់មនុស្ស[642] និងដោយបានទាញការសន្និដ្ឋានថា មានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត[643]។ ការសន្និដ្ឋានទាំងអស់នេះ ត្រូវទុកជាមោឃៈ។ ការសន្និដ្ឋានរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយដែលត្រូវបានកំណត់ថាមានលក្ខណៈ "ឧក្រិដ្ឋ"[644] និងការផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត[645] ក៏ត្រូវទុកជាមោឃៈដែរ។

[642] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦៦ ដែលយោងទៅកថាខណ្ឌ ១៥៦៧-១៥៨០។

[643] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦៦។

[644] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២០, ៣៩២៨។

[645] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨២, ៤៣០៦។

## ២. គ្មានបណ្តឹងអំពីការស្លាប់ដោយគ្រោះថ្នាក់

៣៩១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលអង្គហេតុដោយត្រឹមត្រូវតាមច្បាប់ និងមានយុត្តាធិការវិនិច្ឆ័យអំពីការស្លាប់ដោយសារគ្រោះថ្នាក់នៅទំនប់១មករា[646]។ អង្គជំនុំជម្រះគួរណាគិតអំពីការរំលោភបំពានលើបណ្តឹងពីសំណាក់សហចៅក្រមស៊ើបអង្កេត និងគួរណាកត់សម្គាល់ថា ខ្លួនមិនអាចជំនុំជម្រះ ឬផ្តន្ទាទោសហួសពីបណ្តឹងឡើយ។ កថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លើកឡើងថា "មនុស្ស ២០.០០០ នាក់ [...] បានស្លាប់ដោយមូលហេតុផ្ទាល់នៃការអត់ឃ្លាន ការងារហួសកម្លាំង និងការសម្លាប់"។ អាស្រ័យហេតុនេះ ដោយសារគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតមិនមានសិទ្ធិអំណាចស៊ើបអង្កេតលើមរណភាពបណ្តាលមកពីគ្រោះថ្នាក់នៅនឹងទីតាំងនោះឡើយ។ សេចក្តីសន្និដ្ឋាននៃដីកាដំណោះស្រាយ ក្នុងកថាខណ្ឌ ៣៦៣ ដែលថា "មនុស្សដទៃផ្សេងទៀតត្រូវបានសម្លាប់ដោយគ្រោះថ្នាក់ ដូចជាការបាក់ថ្ម ឬដី" ធ្វើឡើងដោយរំលោភលើបណ្តឹងពីសំណាក់សហចៅក្រមស៊ើបអង្កេត ដែលកំណត់ដោយកថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដូច្នេះ បណ្តឹងមកកាន់អង្គជំនុំជម្រះពីអង្គហេតុទាំងនេះ មិនត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ។

៣៩២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានជំនុំជម្រះអំពីការស្លាប់ដោយសារគ្រោះថ្នាក់នៅទំនប់១មករា ដែល ខៀវ សំផន មិនត្រូវបានចោទប្រកាន់ត្រឹមត្រូវតាមច្បាប់ចំពោះអង្គហេតុទាំងនេះឡើយ[647]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដែលរកឃើញថាគ្រោះថ្នាក់ជាច្រើនបានបណ្តាលឱ្យកម្មករមួយចំនួនស្លាប់ ត្រូវទុកជាមោឃៈ[648]។ ការសន្និដ្ឋាននេះមិនអាចយកមកធ្វើជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានកែប្រែប្រភេទបទល្មើសមកជាការសម្លាប់រង្គាល ក្រោមទម្រង់អំពើមនុស្សឃាតបានឡើយ[649]។ អាស្រ័យហេតុនេះ ការផ្តន្ទាទោស ខៀវ

[646] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦៨។

[647] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦៨។

[648] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧១ ដែលយោងទៅកថាខណ្ឌ ១៥៣៥។

[649] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧២-១៦៧៣។

សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់អំពើមនុស្សឃាតដោយប្រយោលនៅទំនប់ ១មករា ចំពោះអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ[650]។

## ៣. គ្មានបណ្តឹងអំពីអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុនយោបាយចំពោះប្រជាជនថ្មី

៣៩៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយប្រកាសថា ខ្លួនបានទទួលបណ្តឹងដោយត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ចវិនិច្ឆ័យអង្គហេតុនៃ "ការរើសអើង" ប្រឆាំងនឹងប្រជាជនថ្មី ដែលបានកើតឡើងនៅទំនប់១មករា[651]។ អង្គជំនុំជម្រះគួរណាគិតពីការរំលោភបំពានអំពីសំណាក់សហចៅក្រមស៊ើបអង្កេត លើវិសាលភាពនៃបណ្តឹងជាក់ស្តែង និងគួរកត់សម្គាល់ថា ខ្លួនពុំមានសិទ្ធិអំណាចជំនុំជម្រះ ឬផ្តន្ទាទោសហួសពីវិសាលភាពនៃបណ្តឹងឡើយ។ នៅក្នុងកថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយ មានការចោទប្រកាន់ថា នៅតាមការដ្ឋាន សមាជិកនៃក្រុមទាំងនេះទទួលរងល័ក្ខខ័ណ្ឌរស់នៅលំបាកជាងហើយត្រូវបានចាប់ខ្លួនជាច្រើន។ ការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនេះ ផ្អែកលើកថាខណ្ឌ ៣៦០ នៃដីកាដំណោះស្រាយ ដែលមានរៀបរាប់ជាអាទិ៍ថា "ពលករទទួលរងការប្រព្រឹត្តិខុសគ្នា អាស្រ័យតាមអង្គភាពរបស់ពួកគេ ឬអាស្រ័យថាតើពួកគេជាប្រជាជនថ្មីដែរឬទេ"។ ការសន្និដ្ឋានទាំងអស់របស់សហចៅក្រមស៊ើបអង្កេត សុទ្ធតែធ្វើឡើងនៅក្រៅវិសាលភាពនៃបណ្តឹង។ កថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនបានលើកឡើងទាល់តែសោះអំពីព័ត៌មានពាក់ព័ន្ធនឹងការរើសអើង ឬអំពីការបែងចែកប្រភេទអ្នកធ្វើការឡើយ។ កថាខណ្ឌនេះគ្រាន់តែបញ្ជាក់ថា "អ្នកធ្វើការរាប់ពាន់នាក់នៅក្នុងតំបន់ ៤១, ៤២, និង ៤៣ ត្រូវបានបង្ខំឱ្យធ្វើការសាងសង់ទំនប់នេះ"។ ផ្ទុយទៅវិញ នៅពេលដែលសហព្រះរាជអាជ្ញាចង់បញ្ជូនអង្គហេតុពាក់ព័ន្ធនឹងការរើសអើងប្រឆាំងនឹងក្រុមណាមួយទៅសហចៅក្រមស៊ើបអង្កេត ពួកគាត់បានបញ្ជាក់យ៉ាងច្បាស់។ ឧទាហរណ៍ ទាក់ទងនឹងសហករណ៍ត្រាំកក់ សហព្រះរាជអាជ្ញាបានចែងនៅក្នុងកថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថា "អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទទួលរងវិធានការរើសអើង"។ ដូច្នេះ ខៀវ សំផន មិនចាំបាច់ឆ្លើយតបនឹងអង្គហេតុគាំទ្រការចោទប្រកាន់ទាំងនេះទេ ហើយអង្គជំនុំ

---

[650] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២០, ៣៨២៨, ៤២៨២, ៤៣០៦។

[651] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ១៤៣៥, ១៦៨៥។

ជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយប្រកាសថាខ្លួនមានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុទាំងនេះ[652]។

៣៩៤. អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយកាត់សេចក្ដីហួសពីដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះអង្គហេតុនៃ "ការរើសអើង" ចំពោះប្រជាជនថ្មី។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថាមានការប្រព្រឹត្តិការរើសអើង[653]លើប្រជាជនថ្មីនៅទំនប់១មករា ហើយថាជាផលវិបាក គឺមានភ័ស្តុតាងគ្រប់គ្រាន់[654]ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយប្រឆាំងនឹងប្រជាជនថ្មី ត្រូវទុកជាមោឃៈ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយរាប់បញ្ចូលអង្គហេតុទាំងនេះដែលត្រូវបានកំណត់ប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញខាងនយោបាយ ហើយដែលគោលនយោបាយនេះត្រូវបានកំណត់ថាមានចរិត"ឧក្រិដ្ឋ"[655]។ ការសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ។ ដូចគ្នាដែរ ការផ្ដន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុទាំងនេះ អនុលោមតាមសហឧក្រិដ្ឋកម្មរួម ត្រូវទុកជាមោឃៈ[656]។

## ៤. គ្មានបណ្ដឹងអំពីអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុសាសនា

៣៩៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយប្រកាសថា ខ្លួនបានទទួលបណ្ដឹងត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ច ក្នុងការវិនិច្ឆ័យលើអង្គហេតុ នៃ"ការរើសអើង" ដោយមូលហេតុសាសនាប្រឆាំងនឹងចាម នៅទំនប់១មករា[657]។ អង្គជំនុំជម្រះគួរគិតពីការរំលោភបំពានរបស់សហចៅក្រមស៊ើបអង្កេត លើបណ្ដឹងជាក់ស្ដែង និងគួរកត់សម្គាល់ថា ខ្លួនពុំមានសិទ្ធិអំណាចជំនុំជម្រះ ឬផ្ដន្ទាទោសហួសពីបណ្ដឹងជាក់ស្ដែងឡើយ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៤២០ នៃដីកាដំណោះស្រាយ

---

[652] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ១៤៣៥, ១៦៨៥។

[653] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៨-១៦៨៩ ដែលយោងទៅកថាខណ្ឌ ១៦៤១-១៦៥៣។

[654] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩១-១៦៩២។

[655] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៩, ៣៩២៤-៣៩២៥។

[656] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៧, ៤៣០៦។

[657] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ១៤៣៥, ១៦៩៣។

ថា មានភ័ស្តុតាងគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាទៅលើជនជាតិចាម នៅទំនប់១មករា។ ដូចគ្នានឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយដែលបានលើកឡើងខាងលើ ការចោទប្រកាន់នេះផ្អែកលើ កថាខណ្ឌ ៣៦០ ផង និងលើ កថាខណ្ឌ ៣៦៦ នៃដីកាដំណោះស្រាយផង ដែលបញ្ជាក់ថា "មួយចំនួនធំនៃអ្នកដែលបានបាត់ខ្លួនគឺ [...] ជនជាតិចាម"។ ដូចគ្នានឹងមូលហេតុដែលមេធាវីការពារក្តីបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងប្រធានបទនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ សបាចៅក្រមស៊ើបអង្កេតចេញសេក្តីសន្និដ្ឋានទាំងអស់នេះ ដោយរំលោភលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន។ ដូច្នេះ ខៀវ សំផន មិនចាំបាច់ឆ្លើយតបចំពោះអង្គហេតុទាំងនេះទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យអង្គហេតុ នៃ"ការរើសអើង" ដោយមូលហេតុសាសនា និងដោយបានសន្និដ្ឋានថាជនជាតិចាមដែលធ្វើការនៅទំនប់១មករា ទទួលរងអំពើរើសអើងជាក់ស្តែង ដោយចេតនា ដោយសារតែការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ[658]។ ការសន្និដ្ឋានថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ប្រឆាំងនឹងជនជាតិចាមនៅទំនប់១មករា ត្រូវទុកជាមោឃៈ[659]។ ដូចគ្នាដែរ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយ ដែលត្រូវបានពិពណ៌នាថាមានចរិត "ឧក្រិដ្ឋ"[660] ត្រូវទុកជាមោឃៈ។ អាស្រ័យហេតុនេះ ការផ្តន្ទាទោស ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាប្រឆាំងនឹងជនជាតិចាម នៅទំនប់១មករា ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម ចំពោះអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ[661]។

## ៥. គ្មានអំបណ្តឹងពីអង្គហេតុនៃការបាត់ខ្លួន

[658] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩៥។

[659] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩៥-១៦៩៧។

[660] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩៨។

[661] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៧០, ៤០៧៣-៤០៧៤, ៤៣០៦។

៣៩៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ចវិនិច្ឆ័យលើអង្គហេតុនៃការបាត់ខ្លួនដែលបានកើតឡើងនៅទំនប់១មករា[662]។ អង្គជំនុំជម្រះគួរគិតពីការរំលោភបំពាន អំពីសំណាក់សហចៅក្រមស៊ើបអង្កេតលើវិសាលភាពនៃបណ្តឹងជាក់ស្តែង និង គួរកត់សម្គាល់ថា ខ្លួនមិនមានសិទ្ធិអំណាចជំនុំជម្រះ ឬផ្តន្ទាទោសហួសពីវិសាលភាពនៃបណ្តឹងឡើយ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយថា ការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ) ត្រូវបានរកឃើញនៅទំនប់១មករា។ ការចោទប្រកាន់នេះផ្អែកលើអង្គហេតុនៃការបាត់ខ្លួនដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ៣៦៦ ដែលបញ្ជាក់ថាមានមនុស្ស "បាត់ខ្លួនពីការដ្ឋាននៃទំនប់នេះ"។ សហចៅក្រមស៊ើបអង្កេតបានទាញការសន្និដ្ឋាននេះ ដោយរំលោភលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន ដោយហេតុថា កថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពុំមានលើកឡើងអំពីអង្គហេតុនៃការបាត់ខ្លួនទាល់តែសោះ។ ក៏ប៉ុន្តែ នៅកន្លែងខ្លះនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាបានបញ្ជូនយ៉ាងច្បាស់លាស់នូវអង្គហេតុនៃការបាត់ខ្លួនទៅកាន់សហចៅក្រមស៊ើបអង្កេត។ គឺមិនមានអ្វីពាក់ព័ន្ធជាមួយអង្គហេតុដែលមានពិពណ៌នានៅក្នុងកថាខណ្ឌ ៤៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរស្តីពីការដ្ឋានទំនប់១មករា ដែលមានតែការលើកឡើងអំពីការសម្លាប់មនុស្ស ឬការស្លាប់ ដោយសារល័ក្ខខ័ណ្ឌរស់នៅតែប៉ុណ្ណោះ។ ដោយសារគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតមិនមានសិទ្ធិអំណាចស៊ើបអង្កេតលើអង្គហេតុទាំងនេះឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានជំនុំជម្រះអង្គហេតុនៃការបាត់ខ្លួននៅទំនប់១មករា[663] និងដោយបានសន្និដ្ឋានថា មានធាតុផ្សំភ័ស្តុតាងគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមរូបភាពនៃការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈអង្គហេតុដែលត្រូវបានកំណត់ប្រភេទថាជាការបាត់ខ្លួនដោយបង្ខំ[664]។ ការសន្និដ្ឋានទាំងនេះ ដែលធ្វើឡើងដោយផ្អែកលើបណ្តឹងមិនត្រឹមត្រូវតាមច្បាប់ ត្រូវទុកជាមោឃៈ។ ដូចគ្នាដែរចំពោះការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយដែលពិពណ៌នាថាមានចរិត"ឧក្រិដ្ឋ"[665]។ ដូច្នេះ ការផ្តន្ទាទោស ខៀវ សំផន ពីបទ

---

[662] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ១៤៣៥, ១៧០៨។

[663] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧១០-១៧១២។

[664] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧១២, ៣៩២៧។

[665] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២៧-៣៩២៨។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈអង្គហេតុដែលត្រូវបានកំណត់ប្រភេទថាជាការបាត់ខ្លួនដោយបង្ខំពីទំនប់១មករា ក្នុងរូបភាពសហឧក្រិដ្ឋកម្មរួម ត្រូវទុកជាមោឃៈ[666]។

## ផ្នែកទី ៤. ភ្នំក្រោល

### ១. ការធ្វើឱ្យក្លាយជាទាសករ

៣៩៧. នៅក្នុងសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានរំឮកថា យោងតាមដីកាដំណោះស្រាយ ខ្លួនបានទទួលបណ្តឹងពីអង្គហេតុឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើឱ្យក្លាយជាទាសករ[667]។ ក្នុងឋានៈនេះ អង្គជមនុំជម្រះបានកំណត់ប្រភេទបទល្មើសលើអង្គហេតុទាំងនេះ ហើយបានសន្និដ្ឋានថា មានភ័ស្តុតាងគ្រប់គ្រាន់ទាក់ទងនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខភ្នំក្រោល[668]។ មេធាវីការពារក្តីបានបង្ហាញរួចហើយថា អង្គជំនុំជម្រះបានទទួលតែអង្គហេតុក្នុងដែនទីតាំងភូមិសាស្រ្តមន្ទីរ ក-១១ ប៉ុណ្ណោះ[669]។ ជាក់ស្តែង យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតបានទទួលតែអង្គហេតុនៃការធ្វើការងារដោយបង្ខំរបស់អ្នកទោសនៅ ក-១១ ដោយមិនរាប់បញ្ចូលអង្គហេតុទាក់ទងនឹងអ្នកទោសនៅទីតាំង ក-១៧ និងភ្នំក្រោល[670]។

៣៩៨. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយថា មានភ័ស្តុតាងគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនៃការដាក់ឱ្យក្លាយជាទាសករនៅភ្នំក្រោល តាមរយៈការគ្រប់គ្រងជាប្រចាំលើពួកអ្នកជាប់ឃុំ និងការដាក់ឱ្យពួកគេធ្វើការដោយបង្ខំ ដោយមិនមានប្រាក់កម្រៃ[671]។ ការសន្និដ្ឋាននេះផ្អែកលើអង្គហេតុដែលមានរៀបរាប់នៅកថាខណ្ឌ ៦៣៦ ដល់ ៦៣៨ នៃដីកាដំណោះស្រាយ។ តាម

---

[666] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[667] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០១៩, ៣០២៤។

[668] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៩-៣១២៦។

[669] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៣៧២-១៣៧៩។

[670] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **D202** កថាខណ្ឌ ៨។

[671] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩២-១៣៩៤។

ការអានកថាខណ្ឌទាំងនេះ យើងអាចឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រើសក្ខីកម្មមួយចំនួន ដែលស្ទើរតែមិនមានព័ត៌មានបញ្ជាក់អំពីទីតាំងភូមិសាស្ត្រ[672]។ មានការកត់សម្គាល់អំពីអង្គហេតុតែមួយប៉ុណ្ណោះដែលត្រូវបានធ្វើឡើងក្នុងវិសាលភាពនៃបណ្តឹង និងដែលមានលើកឡើងអំពីអង្គហេតុនៃការងារដោយបង្ខំនៅទីតាំង ក-១១[673]។ ដោយហេតុថាបណ្តឹងទៅកាន់សហចៅក្រមស៊ើបអង្កេតកម្រិតត្រឹមតែនៅទីតាំង ក-១១ ខៀវ សំផន គ្រាន់តែទទួលខុសត្រូវចំពោះអង្គហេតុដែលត្រូវបានចោទប្រកាន់នៅទីតាំងនេះជាការគ្រប់គ្រាន់ ពោលគឺ ចំពោះអង្គហេតុដែលមានរៀបរាប់នៅក្នុង កថាខណ្ឌ ៦៣៦ នៃដីកាដំណោះស្រាយ។ ដោយបកស្រាយវិធាន ៨៩ នៃវិធានផ្ទៃក្នុងខុស អង្គជំនុំជម្រះបានច្រានចោលទឡ្ហីករណ៍នេះ នៅក្នុងផ្នែកជំទាស់បឋមរបស់ខ្លួន[674]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដូចដែលបានពន្យល់ខាងលើ[675]។ ដោយមូលហេតុផ្តន្ទាទោស ខៀវ សំផន ដោយផ្អែកលើអង្គហេតុដែលត្រូវបានប្រព្រឹត្តទៅនៅ ក-១១, ក-១៧ និងនៅគុកភ្នំក្រោល[676] ក្នុងខណៈដែលខ្លួនមិនបានទទួលអង្គហេតុដែលបានកើតឡើងលើទីតាំងពីរកន្លែងចុងក្រោយនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលនាំទៅដល់ការបំពានសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ។ អាស្រ័យហេតុនេះ ការសន្និដ្ឋានទាក់ទងនឹងទីតាំង ក-១៧ និងភ្នំក្រោល ត្រូវទុកជាមោឃៈ[677]។

## ២. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់ភាពថ្លៃថ្នូរបស់មនុស្ស

៣៩៩. នៅក្នុងសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានរំឭកថា តាមខ្លឹមសារនៃដីកាដំណោះស្រាយ ខ្លួនបានទទួលអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់ភាពថ្លៃថ្នូររបស់មនុស្ស[678]។ ដូច្នេះ អង្គជំនុំ

[672] ដីកាដំណោះស្រាយ កថាខណ្ឌ ៦៣៦, ៦៣៨។

[673] ដីកាដំណោះស្រាយ កថាខណ្ឌ ៦៣៦។

[674] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦០-១៦៥។

[675] សូមមើលខាងលើ កថាខណ្ឌ ៣៣៦-៣៥០។

[676] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១២១-៣១២៥។

[677] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១២១-៣១២៦។

[678] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០១៩, ៣០២៤។

ជម្រះបានកំណត់ប្រភេទបទល្មើសលើអង្គហេតុ ហើយបានសន្និដ្ឋានថាមានភស្តុតាងគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មនេះ នៅមន្ទីរសន្តិសុខភ្នំក្រោល[679]។ ដើម្បីជាមូលដ្ឋាននៃការផ្តន្ទាទោស អង្គជំនុំជម្រះបានផ្អែកជាពិសេសលើអង្គហេតុនៃការធ្វើទារុណកម្ម ក្នុងខណៈដែលអង្គហេតុទាំងនេះមិនមែនជាកម្មវត្ថុនៃបណ្តឹង[680]។ មេធាវីការពារក្តីបានលើកឡើងអំពីការអនុវត្តហួសបណ្តឹងនេះ នៅក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន ក្នុងសំណុំរឿង ០០២/០២[681]។

៤០០. សម្រាប់កំណត់ត្រា រាល់ការសន្និដ្ឋានទាំងអស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការធ្វើទារុណកម្ម សុទ្ធតែត្រូវបានធ្វើឡើង ដោយរំលោភបំពានលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន ដោយហេតុថាទាំងកថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាំងកថាខណ្ឌ ៨ ដល់ ១១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សុទ្ធតែមិនបានលើកឡើងពីអង្គហេតុនៃការសួរចម្លើយ ឬការធ្វើទារុណកម្មលើរាងកាយ ឬលើផ្លូវចិត្ត[682]។ បើទោះជាក្រោមល័ក្ខខ័ណ្ឌនៃ កថាខណ្ឌ ១៤៣៨ នៃដីកាដំណោះស្រាយ ខៀវ សំផន ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សនៅភ្នំក្រោលក៏ដោយចុះ ក៏ប៉ុន្តែ រាល់ការសន្និដ្ឋានទាក់ទងនឹងការធ្វើទារុណកម្មដែលសហចៅក្រមស៊ើបអង្កេតមិនបានទទួល ត្រូវតែចាត់ទុកថាខុសច្បាប់។ ដូច្នេះ អង្គជំនុំជម្រះក៏មិនបានទទួលដោយត្រឹមត្រូវតាមច្បាប់នូវអង្គហេតុនៃការធ្វើទារុណកម្មនៅភ្នំក្រោលនេះដែរ។ អង្គជំនុំជម្រះថែមទាំងបានពិចារណា នៅក្នុងសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះថា រកមិនឃើញថាមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាការធ្វើទារុណកម្មនោះទេ ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់[683]។ ផ្អែកលើមូលដ្ឋាននៃការអនុវត្តហួសបណ្តឹងនេះ ខៀវ សំផន មិនអាចត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាអំពើអមនុស្សធម៌

[679] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៥២-៣១៥៩។

[680] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៥២ កំណត់សម្គាល់ជើងទំព័រលេខ ១០៦០៧។

[681] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៣៩០-១៣៩៣។

[682] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៣៨២-១៣៨៦, ១៣៩០-១៣៩៣។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៤។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **D202** កថាខណ្ឌ ៨ ដល់ ១១។

[683] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៣៣៥។

ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ទាក់ទងនឹងអង្គហេតុនៃការធ្វើទារុណកម្ម នៅទីតាំងភ្នំក្រោលនោះទេ[684]។

## ៣. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ

៤០១. នៅក្នុងសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះបានរំឭកថា ខ្លួនបានទទួលអង្គហេតុនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ស្របតាមដីកាដំណោះស្រាយ[685]។ ដូច្នេះ អង្គជំនុំជម្រះបានកំណត់ប្រភេទបទល្មើសលើអង្គហេតុទាំងនេះ ហើយបានសន្និដ្ឋានថាបានរកឃើញថាមានឧក្រិដ្ឋកម្មនេះ ទាក់ទងនឹងអង្គហេតុដែលបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល[686]។ ក៏ប៉ុន្តែ នៅក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល មេធាវីការពារក្តីបានបង្ហាញយ៉ាងច្បាស់ថា បណ្តឹងត្រូវបានធ្វើឡើងដោយរំលោភលើវិធាននីតិវិធី[687]។ ជាក់ស្តែង អនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបានទទួលអង្គហេតុនៃការបាត់ខ្លួន <u>តែ</u>នៅទីតាំង ក-១៧ <u>ប៉ុណ្ណោះ</u>[688]។

៤០២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សំដៅទៅមន្ទីរសន្តិសុខភ្នំក្រោល[689]។ ដូចដែលមានពន្យល់នៅក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ការពិពណ៌នាអំពីទីតាំងនេះ តាមពិតទៅ គឺត្រូវនឹងទីតាំងរបស់ ក-១៧[690]។ ដោយបញ្ជូន ខៀវ សំផន ទៅជំនុំជម្រះ ចំពោះអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំនៅលើទីតាំង ក-១១ ក-១៧ និងនៅក្នុងគុកភ្នំក្រោល <u>សហចៅក្រមស៊ើបអង្កេត</u>

---

684 សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៥២-៣១៥៩។

685 សំអាងហេតុសាលក្រម កថាខណ្ឌ ៣០១៩, ៣០២៤។

686 សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៦០-៣១៦៦។

687 សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៣៩៤-១៣៩៩។

688 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៤។

689 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៤។

690 សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៣៥៩។

បានចេញក្រៅវិសាលភាពភូមិសាស្ត្រនៃបណ្តឹងមកកាន់ខ្លួន ដែលជាការរំលោភបំពានវិធាននីតិវិធី[691]។ ដោយបកស្រាយវិធាន ៨៩ នៃវិធានផ្ទៃក្នុងខុស អង្គជំនុំជម្រះបានបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តីស្តីពីការអនុវត្តហួសបណ្តឹងនេះ។ អង្គជំនុំជម្រះបានរកឃើញថា ខៀវ សំផន មានទោសដោយផ្អែកលើការរំលោភលើវិសាលភាពភូមិសាស្ត្រនៃបណ្តឹង។

៤០៣. អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា ហេតុការណ៍បាត់ខ្លួនដោយបង្ខំបានកើតឡើងនៅទីតាំង ក-១៧, ក-១១ និងនៅគុកភ្នំក្រោលបានឡើយ។ កំហុសអង្គច្បាប់នេះធ្វើឱ្យការសន្និដ្ឋានរបស់អង្គជំនុំជម្រះក្លាយជាមោឃៈ[692]។ ខៀវ សំផន មិនអាចត្រូវបានផ្តន្ទាទោសពីបទអំពើអមនុស្សធម៌ផ្សេងៗទៀត ឬពីបទបាត់ខ្លួនដោយបង្ខំ ដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុដែលបានកើតឡើងនៅ ក-១១ និងនៅគុកភ្នំក្រោលឡើយ។ ដូច្នេះ គាត់ត្រូវទទួលបានលើកលែងការចោទប្រកាន់ ចំពោះអង្គហេតុទាំងនេះ។

## ផ្នែកទី ៥. ក្រាំងតាចាន់

### ១. គ្មានបណ្តឹងអំពីអង្គហេតុនៃការស្លាប់ដោយសារល័ក្ខខ័ណ្ឌឃុំឃាំង

៤០៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយប្រកាសខ្លួនថាបានទទួលត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុនៃការស្លាប់ដែលបណ្តាលមកពីល័ក្ខខ័ណ្ឌឃុំឃាំងនៅក្រាំងតាចាន់[693]។ អង្គជំនុំជម្រះគួរណាគិតពីការរំលោភបំពានលើបណ្តឹងជាក់ស្តែងអំពីសំណាក់សហចៅក្រមស៊ើបអង្កេត និងគួរកត់សម្គាល់ថា ខ្លួនមិនអាចវិនិច្ឆ័យ និងផ្តន្ទាទោស លើសពីវិសាលភាពនៃបណ្តឹងនោះទេ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅក្នុងកថាខណ្ឌ ១៣៧៣ នៃដីកាដំណោះស្រាយថាបានរកឃើញការប្រព្រឹត្តិឧក្រិដ្ឋកម្មតាមរយៈ អំពើមនុស្សឃាតទៅលើ "មនុស្សដែលត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខនានា" ក្នុងនោះមានមន្ទីរក្រាំងតាចាន់។ ពួកគាត់បន្ថែមនៅកថាខណ្ឌ ១៣៧៤ ថា "ការស្លាប់របស់ជនរងគ្រោះកើតចេញពីអំពើសកម្ម ឬអកម្មរបស់ចារី ដែលជាមូលហេតុចម្បងនៃការស្លាប់របស់ជនរង

---

[691] សូមមើលខាងលើ កថាខណ្ឌ ៣៣៦-៣៥០។

[692] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៦០-៣១៦៦។

[693] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ២៦៣៨។

គ្រោះ"។ យោងទៅតាមកថាខណ្ឌ ១៣៧៦ សហចៅក្រមស៊ើបអង្កេតបានផ្តល់ព័ត៌មានលម្អិតអំពីការស្លាប់ដែលបានកើតឡើងនៅគ្រប់មន្ទីរសន្តិសុខទាំងអស់ ដែលមានកំណត់នៅកថាខណ្ឌ ១៣៧៣[694]។

៤០៥. ការរៀបរាប់ពីហេតុការណ៍ដែលបានកើតឡើងនៅក្រាំងតាចាន់ ពីកថាខណ្ឌ ៤៨៩ ដល់ កថាខណ្ឌ ៥១៤ នៃដីកាដំណោះស្រាយ អាចធ្វើឱ្យគេមានលទ្ធភាពកំណត់ ថាតើអង្គហេតុណាខ្លះត្រូវបានកំណត់ប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ស្របតាមបទប្បញ្ញត្តិដែលបានរៀបរាប់ខាងលើ។ នៅកន្លែងជាច្រើន សហចៅក្រមស៊ើបអង្កេតបានរៀបរាប់ថា ការស្លាប់ដែលកើតឡើងនៅក្រាំងតាចាន់ បណ្តាលមកពីការប្រហារជីវិត (កថាខណ្ឌ ៥០០ និង ពី ៥១០ ដល់ ៥១៤ ក្រោមចំណងជើងថា "ការបាត់ខ្លួន និងការប្រហារជីវិត") បណ្តាលមកពីជំងឺ (កថាខណ្ឌ ៥០០ ៥០២ និង ៥០៨) បណ្តាលមកពីទុរ្ភិក្ស (៥០២ និង ៥០៨) បណ្តាលមកពីថែសង្កើចខាំ (កថាខណ្ឌ ៥០២) ឬបណ្តាលមកពីស្នាមរបួសដែលបានកើតឡើងក្នុងកំឡុងពេលសួរចម្លើយ (កថាខណ្ឌ ៥០៨)។ ការសន្និដ្ឋានមួយចំនួនក្នុងចំណោមការសន្និដ្ឋានទាំងអស់នេះ ត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ដោយរំលោភលើវិសាលភាពនៃបណ្តឹងដែលកំណត់ដោយកថាខណ្ឌ ៤៣ និង ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ យោងតាមកថាខណ្ឌ ៤៣ ស្តីពីសហករណ៍ត្រាំកក់ សហចៅក្រមស៊ើបអង្កេតបានទទួលសិទ្ធិអំណាចក្នុងការស៊ើបអង្កេតលើការប្រហារជីវិតប្រជាជនថ្មី ដែលត្រូវបានបញ្ជូនទៅក្រាំងតាចាន់។ យោងទៅតាមកថាខណ្ឌ ៦០ ដែលពាក់ព័ន្ធផ្ទាល់នឹងមន្ទីរសន្តិសុខក្រាំងតាចាន់ សហចៅក្រមស៊ើបអង្កេតត្រូវបានផ្តល់សិទ្ធិអំណាចឱ្យ <u>ស៊ើបអង្កេតតែលើការប្រហារជីវិតអ្នកជាប់ឃុំដោយគ្មានការបែងចែកពីការជាប់ពាក់ព័ន្ធរបស់ពួកគេជាមួយក្រុមណាមួយឡើយ</u>[695]។

---

[694] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៦៖ "ទាក់ទងដល់**មន្ទីរសន្តិសុខ**នានានៅក្នុងរបបនោះ បុគ្គលិកមន្ទីរសន្តិសុខគឺជាអ្នកដែលបានបង្កដោយផ្ទាល់ឬដោយប្រយោលឱ្យមានការស្លាប់បាត់បង់ជីវិតដល់ជនជាប់ឃុំឃាំងយ៉ាងច្រើនសន្ធឹកសន្ធាប់។ ជាទូទៅ អ្នកទោសត្រូវបានគេសម្លាប់ដោយចេតនា តាមរយៈមធ្យោបាយច្រើនយ៉ាង ជាពិសេស ការសម្លាប់ភ្លាមៗនៅក្នុងមន្ទីរសន្តិសុខតែម្តង ឬក៏នៅក្បែរៗនោះ។ ក៏ប៉ុន្តែមានអ្នកទោសជាច្រើនបានស្លាប់ដោយសារការធ្វើទារុណកម្ម និងការធ្វើបាបផ្សេងៗដែលប្រព្រឹត្តមកលើពួកគេ"។ (អក្សរដិត នៅក្នុងច្បាប់ដើម)។

[695] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦០៖ "ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជាបានសម្លាប់មនុស្សប្រហែលជា <u>១២ ០០០ នាក់</u> នៅកន្លែងសន្តិសុខ និងឃុំឃាំង នៅក្រាំងតាចាន់ ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ភូមិភាគនីរតី។ អ្នកជាប់ឃុំរួមមាន ប្រជាជនថ្មី គ្រួសារអតីត<u>ទាហាន</u> និងប្រជាជនផ្សេងៗក្នុងខេត្តតាកែវ។ ពួកអ្នកជាប់ឃុំ

៤០៦. ដូច្នេះ សហចៅក្រមស៊ើបអង្កេត បានទទួលយកមកស៊ើបសួរតែអង្គហេតុពាក់ព័ន្ធការស្លាប់របស់ប្រជាជន ដែលត្រូវបានសម្លាប់នៅក្រាំងតាចាន់តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ សហចៅក្រមមិនត្រូវបានផ្ដល់សិទ្ធិអំណាចឱ្យធ្វើការស៊ើបអង្កេតលើការស្លាប់មនុស្ស ដោយសារតែស្ថានភាពរស់នៅ ក្នុងមន្ទីរសន្តិសុខ (អាហារ សុខភាព អនាម័យ) ឬលើការស្លាប់ដោយសារការធ្វើទារុណកម្មឡើយ។ ដោយសារគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ការចោទប្រកាន់ទាំងឡាយរបស់ចៅក្រមស៊ើបអង្កេតដែលផ្អែកលើព្រឹត្តិការណ៍បែបនេះគឺសុទ្ធតែខុសច្បាប់។ ម្ចាស់បណ្ដឹងសាទុក្ខមិនចាំបាច់ឆ្លើយតបទេ។ ការគ្មានបណ្ដឹងឱ្យស៊ើបសួរកាន់តែលេចឡើងច្បាស់ទៅទៀត ដោយហេតុថានៅពេលដែលសហព្រះរាជអាជ្ញាចង់ឱ្យចៅក្រមស៊ើបអង្កេតស៊ើបសួរអំពីការស្លាប់ដែលកើតឡើងនៅទីតាំងផ្សេងៗទៀតដោយសារស្ថានភាពរស់នៅ ឬផលវិបាកនៃអំពើទារុណកម្ម សហព្រះរាជអាជ្ញាបានបញ្ជាក់អំពីបំណងរបស់ខ្លួនយ៉ាងច្បាស់[696]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនបានទទួលអង្គហេតុពាក់ព័ន្ធនឹងការស្លាប់ដោយសារល័ក្ខខ័ណ្ឌឃុំឃាំងនៅក្រាំងតាចាន់ ដោយត្រឹមត្រូវតាមច្បាប់ ដើម្បីយកមកជំនុំជម្រះទេ។

៤០៧. ដូច្នេះ ម្ចាស់បណ្ដឹងសាទុក្ខមិនតម្រូវឱ្យទទួលខុសត្រូវចំពោះអង្គហេតុដែលអ្នកទោសបានស្លាប់នៅក្នុងមន្ទីរឃុំឃាំង ដោយទទួលរងការប្រព្រឹត្តិលើ និងចំពោះការដែលអង្គហេតុទាំងនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាតដោយចេតនាប្រយោល នោះឡើយ[697]។

---

ត្រូវបានដាក់ខ្នោះ គ្រប់ពេលវេលា និង<u>សម្លាប់តាមកាលកំណត់ជាទៀងទាត់</u>ក្នុងនោះរួមមានការវាយរហូតដល់ស្លាប់ផង។ មុនការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យបន្តិច ក្នុងឆ្នាំ ១៩៧៨ <u>ពួកអ្នកទោសនៅសល់ទាំងអស់ត្រូវសម្លាប់</u>។ ការគាស់ផ្នូរក្រោយឆ្នាំ ១៩៧៩ សំណល់សាកសពអ្នកទោសប្រមាណ ២០០០ នាក់ត្រូវបានរកឃើញនៅទីនោះ ឬក្បែរនោះ។ សំណល់សាកសពមនុស្សជាង ១០០០០ នាក់ទៀតអាចស្ថិតនៅក្នុងរណ្ដៅសាកសពរួម នៅក្នុងតំបន់នេះ"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[696] សូមមើលកថាខណ្ឌ ៥៥ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាស្ដីពីអង្គហេតុដែលកើតឡើង នៅមន្ទីរស-២១។ សហព្រះរាជអាជ្ញាបានចង្អុលថា "ពួកអ្នកជាប់ឃុំខ្លះបានស្លាប់ក្នុងពេលទទួលរងទារុណកម្ម ឬដោយសារបរិភោគមិនគ្រប់គ្រាន់ ដោយជំងឺ ឬលក្ខណៈរស់នៅអមនុស្សធម៌"។ ដូចគ្នានេះដែរ កថាខណ្ឌ ៥៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ស្ដីពីមន្ទីរសន្តិសុខកោះខ្លុង សហព្រះរាជអាជ្ញាបានបញ្ជាក់ថា "មានអ្នកទោសស្លាប់ ៥ ឬ ៦ នាក់ ដោយសារជំងឺ អត់ឃ្លាន ឬការបង្ខំសួរចម្លើយ"។

[697] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨១៥ ដែលយោងទៅកថាខណ្ឌ ២៦៧៤, ២៦៧៦ និង ២៧៤៤-២៧៤៧។

ដូច្នេះ ការសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែបានលើកលែងការចោទប្រកាន់ចំពោះអង្គហេតុទាំងនេះ[698]។

## ២. គ្មានបណ្តឹងអំពីអង្គហេតុនៃការធ្វើឱ្យក្លាយជាទាសករ

៤០៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលយកមកជំនុំជម្រះដោយត្រឹមត្រូវតាមច្បាប់ និងថា ខ្លួនមានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុនៃការដាក់ឱ្យក្លាយជាទាសករ ដែលបានកើតឡើងនៅក្រាំងតាចាន់[699]។ អង្គជំនុំជម្រះគួរគិតពីការរំលោភបំពានលើបណ្តឹងជាក់ស្តែងអំពីសំណាក់សហចៅក្រមស៊ើបអង្កេត ហើយគួរកត់សម្គាល់ថា ខ្លួនមិនមានសិទ្ធិអំណាចជំនុំជម្រះ ឬផ្តន្ទាទោសហួសពីបណ្តឹងបានឡើយ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៣៩១ នៃដីកាដំណោះស្រាយថា បានរកឃើញការប្រព្រឹត្តិឧក្រិដ្ឋកម្ម តាមរយៈការដាក់ឱ្យក្លាយជាទាសករ នៅក្រាំងតាចាន់។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅ កថាខណ្ឌ ១៣៩២ និង ១៣៩៤ ថា បទឧក្រិដ្ឋនេះមានធាតុផ្សំពីរបូកបញ្ចូលគ្នា គឺការគ្រប់គ្រងជាអចិន្ត្រៃយ៍លើអ្នកជាប់ឃុំ និងការបង្ខំឱ្យធ្វើការដោយមិនបង់ប្រាក់កម្រៃ។ ភាពប្រាកដប្រជាថាពិតជាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មមែន ផ្អែកលើការសន្និដ្ឋានពីអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត ដែលមានរៀបរាប់ពីកថាខណ្ឌ ៤៩៧ ទៅដល់ ៥០៥ នៃដីកាដំណោះស្រាយ ក្រោមចំណងជើងថា "ការចាប់ខ្លួន និងការឃុំខ្លួន"។ កថាខណ្ឌ ៥០៣ រៀបរាប់បានល្អបំផុតអំពីល័ក្ខខ័ណ្ឌការងារនៅក្រាំងតាចាន់៖

> "អ្នកទោសខ្លះនិយាយថា ពួកគេត្រូវបានបង្ខំឱ្យធ្វើការច្រើនមុខនៅក្នុងបរិវេណ គុក។ អ្នកដែលធ្វើការបានទទួលអាហារច្រើនជាងអ្នកដែលនៅជាប់ខ្នោះក្នុង អគារ។ អ្នកដែលធ្វើការនៅវាលស្រែមិនត្រូវបានដាក់ខ្នោះទេ ប៉ុន្តែស្ថិតនៅ ក្រោមការឃាមកាម។ អ្នកខ្លះដែលបានត្រឡប់មកធ្វើការវិញ ត្រូវបានដាក់ក្នុង បន្ទប់ឃុំឃាំងពេលយប់"[700]។

[698] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៧-៤៣១៨។

[699] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ២៦៣៨, ២៦៤០។

[700] សូមមើលផងដែរដីកាដំណោះស្រាយ កថាខណ្ឌ ៥០១ ដែលនៅទីនេះដីកាដំណោះស្រាយលើកឡើងយ៉ាងខ្លីថា "គេបញ្ជូនមនុស្សទៅធ្វើការ"។

៤០៩. ការសន្និដ្ឋានពាក់ព័ន្ធនឹងការងារអ្នកទោសនៅក្រាំងតាចាន់របស់សហចៅក្រមស៊ើបអង្កេត ខុសច្បាប់ទាំងស្រុង ពីព្រោះនៅកថាខណ្ឌ ៤៣ និង ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមាននិយាយអំពីការបង្ខំអ្នកទោសឱ្យធ្វើការងារអ្វីឡើយ។ សហចៅក្រមស៊ើបអង្កេតបានបញ្ចូលអង្គហេតុថ្មីៗទៀត ដើម្បីសន្និដ្ឋានថាពិតជាមានការប្រព្រឹត្តិបទឧក្រិដ្ឋ ដោយមិនបានទទួលដីកាសន្និដ្ឋានឱ្យស៊ើបសួរបន្ថែម។ អាស្រ័យហេតុនេះ ខៀវ សំផន មិនចាំបាច់ទទួលខុសត្រូវចំពោះអង្គហេតុគាំទ្រការចោទប្រកាន់នេះទេ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋាន ថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការដាក់ឱ្យក្លាយជាទាសករ នៅក្រាំងតាចាន់ ដោយរំលោភវិសាលភាពនៃបណ្ដឹងជាក់ស្ដែង[701]។ ការសន្និដ្ឋានទាំងនេះ ត្រូវទុកជាមោឃៈ។ ដូចគ្នាដែរ ចំពោះការសន្និដ្ឋានរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយ ដែលកំណត់ថាមានចរិត "ឧក្រិដ្ឋ"[702]។ អាស្រ័យហេតុនេះ ការផ្ដន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការដាក់ឱ្យក្លាយជាទាសករ នៅក្រាំងតាចាន់ ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម ចំពោះអង្គហេតុទាំងនេះត្រូវទុកជាមោឃៈ[703]។

## ៣. គ្មានបណ្ដឹងអំពីអង្គហេតុនៃអំពើទារុណកម្ម

៤១០. អង្គជំនុំជម្រះបានប្រព្រឹត្តិកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្ដឹងដោយត្រឹមត្រូវតាមច្បាប់ និងថា ខ្លួនមានសមត្ថកិច្ចក្នុងការជំនុំជម្រះអំពីអង្គហេតុទារុណកម្ម ដែលបានកើតឡើងនៅក្រាំងតាចាន់[704]។ អង្គជំនុំជម្រះគួរណាគិតពីការរំលោភបំពានលើបណ្ដឹងជាក់ស្ដែងអំពីសំណាក់សហចៅក្រមស៊ើបអង្កេត និងគួរណាកត់សម្គាល់ថា ខ្លួនមិនអាចវិនិច្ឆ័យ ឬផ្ដន្ទាទោស ហួសពីបណ្ដឹងជាក់ស្ដែងឡើយ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៤០៨ នៃដីកាដំណោះស្រាយ ថាបានរកឃើញការប្រព្រឹត្តិឧក្រិដ្ឋកម្ម តាមរយៈការធ្វើទារុណកម្ម នៅក្រាំងតាចាន់។ អង្គហេតុនៃការធ្វើ

[701] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨២២-២៨២៣, ៣៩៧៩។

[702] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧៩, ៣៩៨៧។

[703] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[704] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ២៦៣៨, ២៨២៨។

ទារុណកម្មដែលបានរៀបរាប់ពីកថាខណ្ឌ៥០៧ ដល់ ៥០៩ នៃដីកាដំណោះស្រាយ បង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់ក្នុងកថាខណ្ឌ ១៤០៨។ ការសន្និដ្ឋានទាំងអស់នេះ ត្រូវបានធ្វើឡើងដោយរំលោភលើបណ្តឹងពីសំណាក់សហចៅក្រមស៊ើបអង្កេត។ កថាខណ្ឌ ៤៣ និង ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពុំលើកឡើងពីអង្គហេតុពាក់ព័ន្ធនឹងការសួរចម្លើយ ឬការធ្វើទារុណកម្មលើរូបរាងកាយ ឬផ្លូវចិត្តណាមួយឡើយ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនបានទទួលសិទ្ធិអំណាចដើម្បីស៊ើបអង្កេតលើអង្គហេតុទាំងនេះទេ។ ជាថ្មីម្តងទៀត ត្រង់នេះដូចគ្នាដែរ នៅពេលដែលសហព្រះរាជអាជ្ញាចង់ឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងការធ្វើទារុណកម្ម សហព្រះរាជអាជ្ញាបានបញ្ជាក់អំពីបំណងនេះយ៉ាងច្បាស់បំផុត[705]។ ទាក់ទងនឹងក្រាំងតាចាន់ ក្នុងកថាខណ្ឌ ៤៣ និង ៦០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមានការយោងណាមួយទៅ អង្គហេតុបែបនេះឡើយ។ ហេតុដូចនេះ ដោយអង្គជំនុំជម្រះមិនបានទទួលបណ្តឹងដោយត្រឹមត្រូវតាមច្បាប់ពីអង្គហេតុនៃការធ្វើទារុណកម្មនៅក្រាំងតាចាន់ ខៀវ សំផន មិនចាំបាច់ឆ្លើយតបឡើយ។

៤១១. អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋានថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទារុណកម្មនៅក្រាំងតាចាន់ ដោយរំលោភបណ្តឹងជាក់ស្តែងមកកាន់ខ្លួន[706]។ ការសន្និដ្ឋានទាំងនេះ ត្រូវទុកជាមោឃៈ។ ដូចគ្នាដែរចំពោះការសន្និដ្ឋានរាប់បញ្ចូលអង្គហេតុទាំងនេះក្នុងគោលនយោបាយដែលកំណត់ថាមានចរិត "ឧក្រិដ្ឋ"[707]។ ការផ្តន្ទាទោស ខៀវ សំផន

---

[705] សូមមើលកថាខណ្ឌ ៥២ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ស្តីពីមន្ទីរ ស-២១ ដែលលើកឡើងថា "ពួកអ្នកជាប់ឃុំភាគច្រើនលើសលប់ត្រូវទទួលរងទារុណកម្មដើម្បីបង្ខំទាញយកចម្លើយសារភាព"។ ដូចគ្នានេះដែរ នៅកថាខណ្ឌ ៥៩ ស្តីពីស្តីពីមន្ទីរសន្តិសុខកោះខ្លូង សហព្រះរាជអាជ្ញាបានចោទប្រកាន់ថា "មានអ្នកទោសរាប់ពាន់នាក់ត្រូវបានដាក់ឃុំ ធ្វើទារុណកម្ម ហើយ បន្ទាប់មក សម្លាប់ចោល"។ កថាខណ្ឌ ៦៣ ស្តីពីស្តីពីមន្ទីរសន្តិសុខកោះខ្លូង សហព្រះរាជអាជ្ញាបានអះអាងទៀតថា "ពួកអ្នកទោសត្រូវដាក់ខ្នោះ គ្រប់ពេលវេលា និងទទួលរងទារុណកម្មជាប្រចាំ"។ សូមមើលផងដែរ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៩, ៥០, ៥៣ និង ៥៥ ស្តីពីមន្ទីរ ស-២១។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **D202** កថាខណ្ឌ ៧ ស្តីពីស្តីពីមន្ទីរសន្តិសុខក្បាលឈើពុក ("ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោស បានធ្វើឡើងជាទៀងទាត់ នៅឯមណ្ឌលសន្តិសុខមួយនេះ")។

[706] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨២៩-២៨៣២, ៣៩៨១។

[707] សំអាងហេតុសាលក្រម កថាខណ្ឌកថាខណ្ឌ ៣៩៧៩, ៣៩៨៧។

ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទារុណកម្ម នៅក្រាំងតាចាន់ ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម ត្រូវទុកជាមោឃៈ[708]។

## ៤. គ្មានបណ្តឹងអំពីអង្គហេតុនៃការធ្វើបាប

៤១២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងដោយត្រឹមត្រូវតាមច្បាប់ និងថា ខ្លួនមានសមត្ថកិច្ចវិនិច្ឆ័យលើអង្គហេតុនៃការធ្វើបាបពីសំណាក់អ្នកយាមគុក និងអ្នកសួរចម្លើយនៅក្រាំងតាចាន់[709]។ អង្គជំនុំជម្រះគួរណាពិចារណាពីការរំលោភបំពានលើបណ្តឹងជាក់ស្តែងអំពីសំណាក់សហចៅក្រមស៊ើបអង្កេត និងគួរណាកត់សម្គាល់ថា ខ្លួនមិនមានសិទ្ធិអំណាចវិនិច្ឆ័យ ឬផ្តន្ទាទោសហួសពីបណ្តឹងឡើយ។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ១៤៣៤ នៃដីកាដំណោះស្រាយថា មានការប្រព្រឹត្តិឧក្រិដ្ឋកម្ម តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៅក្រាំងតាចាន់។ នៅក្នុងកថាខណ្ឌ ១៤៣៨ សហចៅក្រមស៊ើបអង្កេតបានរៀបរាប់លម្អិតអំពីធាតុផ្សំភ័ស្តុតាងនានា ដែលត្រូវបានយកជាមូលដ្ឋានដើម្បីពិចារណាថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្រាំងតាចាន់ (អាហារមិនគ្រប់គ្រាន់សម្រាប់អ្នកទោស ល័ក្ខខ័ណ្ឌដ៏អាក្រក់នៃការឃុំឃាំង កង្វះអនាម័យ ...)។ ធាតុផ្សំភ័ស្តុតាងទាំងនេះត្រូវបានពិពណ៌នានៅកថាខណ្ឌ ៤៩៧ ដល់ ៥០៥ នៃដីកាដំណោះស្រាយ ស្តីពីល័ក្ខខ័ណ្ឌនៃការឃុំខ្លួន។ មានការលើកឡើងផងដែរនៅកថាខណ្ឌ ១៤៣៨ អំពី “ការធ្វើបាបពីសំណាក់ឆ្មាំ និងអ្នកសួរចម្លើយ”។ កថាខណ្ឌនេះយោងទៅកថាខណ្ឌ ៥០៦ ដល់ ៥០៩ ដែលរៀបរាប់ពី “ការសួរចម្លើយ”។ ដូចដែលបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងប្រធានបទនៃការធ្វើទារុណកម្ម រាល់ការសន្និដ្ឋានលើប្រធានបទនេះដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត សុទ្ធតែខុសច្បាប់ ពីព្រោះពួកគាត់មិនដែលបានទទួលអង្គហេតុទាំងនេះដោយត្រឹមត្រូវតាមច្បាប់ពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ[710] ហើយក៏មិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែរ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនបានទទួលអង្គហេតុទាំងនេះ

[708] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[709] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ២៦៣៨, ២៨៤៨។

[710] សូមមើលខាងលើ កថាខណ្ឌ ៤១០។

មកជំនុំជម្រះដោយត្រឹមត្រូវតាមច្បាប់ទេ។ ដូច្នេះ ខៀវ សំផន មិនចាំបាច់ទទួលខុសត្រូវចំពោះអង្គហេតុទាំងនេះឡើយ។

៤១៣. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋានមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្រាំងតាចាន់ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ឬការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស តាមរយៈការធ្វើបាបអំពីសំណាក់ឆ្មាំ និងអ្នកសួរចម្លើយ ដោយរំលោភបំពានបណ្ដឹងជាក់ស្ដែងមកកាន់ខ្លួន[711]។ ការសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ រួមទាំងការសន្និដ្ឋានដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយដែលកំណត់ថាមានចរិត "ឧក្រិដ្ឋ" ផងដែរ[712]។ អាស្រ័យហេតុនេះ ការផ្ដន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ឬការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សនៅក្រាំងតាចាន់ចំពោះអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ[713]។

## ៥. គ្មានបណ្ដឹងអំពីអង្គហេតុនៃការបាត់ខ្លួន

៤១៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនទទួលបានបណ្ដឹងដោយស្របច្បាប់ និងមានសមត្ថកិច្ចវិនិច្ឆ័យលើអង្គហេតុនៃការធ្វើបាបពីសំណាក់ឆ្មាំ និងអ្នកសួរចម្លើយ នៅក្រាំងតាចាន់[714]។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន នៅកថាខណ្ឌ ១៤៧០ នៃដីកាដំណោះស្រាយ ថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្រោមទម្រង់អំពើអមនុស្សធម៌ផ្សេងៗទៀត (ឬការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស) នៅក្រាំងតាចាន់។ ធាតុផ្សំរ៉ស្តុតាងដែលបង្កើតបានជាឧក្រិដ្ឋកម្មនេះ ត្រូវបានពិពណ៌នានៅកថាខណ្ឌ ១៤៧១ ស្ដីពីការដកហូតមនុស្សចេញពីការការពារដោយច្បាប់ និង "ការបដិសេធមិនផ្ដល់ឱ្យជនរងគ្រោះនូវព័ត៌មានទាក់ទងនឹងជោគវាសនា ឬកន្លែងឃុំឃាំង" នៃសាច់ញាតិ

[711] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៤៩-២៨៥១, ៣៩៨៥។

[712] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៥។

[713] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[714] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ២៦៣៨, ២៨៤៨។

របស់ពួកគេ[715]។ កថាខណ្ឌ ១៤៧២ លើកឡើងពីការដាក់ចេញនូវ"វិធានការលាក់បាំងជោគវាសនារបស់បុគ្គលដែលបាត់ខ្លួន ដោយធានាថាគ្មានសាក្សីណាម្នាក់អាចដឹងព័ត៌មានអំពីពួកគេឡើយ"។ ការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត ផ្អែកលើធាតុផ្សំភ័ស្តុតាងមួយចំនួនដែលមានរៀបរាប់នៅកថាខណ្ឌ ៥១០ ដល់ ៥១៤ នៃដីកាដំណោះស្រាយ ក្រោមចំណងជើងថា "ការបាត់ខ្លួន និងការសម្លាប់"។ ការសន្និដ្ឋានទាំងអស់លើអង្គហេតុនៃការបាត់ខ្លួន គឺសុទ្ធតែខុសច្បាប់។ សហចៅក្រមស៊ើបអង្កេតមិនបានទទួលបណ្តឹងអំពីអង្គហេតុនៃការបាត់ខ្លួន តាមរយៈផ្នែកពាក់ព័ន្ធនៃកថាខណ្ឌ ៤៣ ស្តីអំពីសហករណ៍ត្រាំកក់ ឬតាមរយៈកថាខណ្ឌ ៦០ ស្តីពីក្រាំងតាចាន់ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នោះឡើយ។

៤១៥. នៅកថាខណ្ឌ ៦០ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា "រហូតដល់ទៅ ១២.០០០ នាក់" ត្រូវបានគេសម្លាប់នៅក្រាំងតាចាន់ គឺមានន័យថាស្មើនឹងចំនួនអ្នកទោសទាំងអស់នៅទីតាំងនេះ បើតាមការគណនាគំនរឆ្អឹងដែលត្រូវបានធ្វើឡើងនៅពេលក្រោយមក[716]។ យោងតាមសហចៅក្រមស៊ើបអង្កេត ការសន្និដ្ឋាននេះហាក់ដូចជាជ្រុលបន្តិច ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមិនមានតួនាទីជួយជួសជុលចន្លោះប្រហោងរបស់សហព្រះរាជអាជ្ញាឡើយ។ ជាថ្មីម្តងទៀត ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានឧទាហរណ៍ដែលសហព្រះរាជអាជ្ញាបានបញ្ជូនអង្គហេតុនៃការបាត់ខ្លួន យ៉ាងច្បាស់លាស់ទៅកាន់សហចៅក្រមស៊ើបអង្កេត[717]។ ប៉ុន្តែ វាមិនមែនជាករណីនៃអង្គហេតុដែលបានកើតឡើងនៅក្រាំងតាចាន់ទេ។ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម អង្គជំនុំជម្រះមិនបានទទួលអង្គហេតុទាំងនេះដោយត្រឹមត្រូវតាមច្បាប់ ហើយក៏មិនមានសិទ្ធិអំណាចសម្រេចសេចក្តីលើអង្គហេតុទាំងនេះ។ ខៀវ សំផន ក៏មិនត្រូវទទួលខុសត្រូវចំពោះអង្គហេតុទាំងនេះដែរ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានរំលោភលើបណ្តឹងជាក់ស្តែង ហើយបានសន្និដ្ឋានថាបានរកឃើញការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ឬការបាត់ខ្លួនដោយបង្ខំ នៅ

[715] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧១។

[716] នៅកថាខណ្ឌ ៦០ សហព្រះរាជអាជ្ញាបានអះអាងថា សំណល់សាកសពអ្នកទោសប្រមាណ ២០០០ នាក់ត្រូវបានរកឃើញនៅទីនោះ ឬក្បែរនោះ។ សំណល់សាកសពមនុស្សជាង ១០០០០ នាក់ទៀតអាចស្ថិតនៅក្នុងរណ្តៅសាកសពរួម នៅក្នុងតំបន់នេះ។

[717] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៧ ចំពោះព្រលានយន្តហោះកំពង់ឆ្នាំង ("ប្រជាជនដែលបាត់ខ្លួនត្រូវបានជំនួសជាប្រចាំដោយអ្នកជាប់ឃុំថ្មី") និង កថាខណ្ឌ ៦៤ ចំពោះមន្ទីរសន្តិសុខភ្នំក្រោល ("មនុស្សទាំងនោះបាត់ខ្លួន ហើយប្រហែលជាត្រូវគេសម្លាប់")។

ក្រាំងតាចាន់[718]។ ការសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ ដូចគ្នានេះដែរចំពោះការសន្និដ្ឋានដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយដែលកំណត់ថាមានចរិត "ឧក្រិដ្ឋ"[719]។ អាស្រ័យហេតុនេះ ការផ្តន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ឬការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស នៅក្រាំងតាចាន់ ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម ចំពោះអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ[720]។

## ផ្នែកទី ៦. អូរកន្សែង

### ១. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍

៤១៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានចាត់ទុកថា ខ្លួនបានទទួលបណ្តឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម នៅអូរកន្សែង[721]។ ជាក់ស្តែង អង្គជំនុំជម្រះបានផ្អែកលើកថាខណ្ឌ ៦២២ នៃដីកាដំណោះស្រាយ ស្តីពីការចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាម ៦ នាក់[722]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមិនមានអាណត្តិស៊ើបអង្កេតលើអង្គហេតុទាំងនេះ នោះទេ។ យោងតាមកថាខណ្ឌតែមួយគត់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលនិយាយអំពីអូរកន្សែង គឺសហព្រះរាជអាជ្ញាមិនបានបញ្ជាក់អំពីអង្គហេតុនៃការរើសអើងជាតិសាសន៍ប្រឆាំងនឹងជនជាតិវៀតណាមនោះទេ[723]។

៤១៧. បើទោះជាសហចៅក្រមស៊ើបអង្កេតមានអាណត្តិស៊ើបអង្កេតការសម្លាប់មនុស្សនៅអូរកន្សែង ហើយបានរកឃើញថា ជនជាតិវៀតណាមស្ថិតក្នុងចំណោមអ្នកដែលត្រូវបានគេសម្លាប់ក៏ដោយចុះ ក៏មិនមែនមានន័យថាពួកគាត់ត្រូវបានផ្តល់សិទ្ធិអំណាច ដើម្បីស៊ើបអង្កេតលើការរើសអើងលើជនជាតិវៀត

[718] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៥៣-២៨៥៨, ៣៩៨៦។

[719] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៦។

[720] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[721] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៥។

[722] ដីកាដំណោះស្រាយ កថាខណ្ឌ ៦២២។

[723] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៧។

ណាមទាំងនេះ នោះដែរ[724]។ ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ការសន្និដ្ឋានទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍លើប្រជាជនវៀតណាម នៅអូរកន្សែង សុទ្ធតែត្រូវបានធ្វើឡើងដោយរំលោភបំពានបណ្តឹងជាក់ស្តែង។ ដូច្នេះ អង្គជំនុំជម្រះមិនត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលអង្គហេតុទាំងនោះទេ[725]។ ដូច្នេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវបានរួចផុតពីបទឧក្រិដ្ឋនេះ[726]។

## ២. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស

៩១៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានពិចារណាថា ខ្លួនបានទទួលបណ្តឹងអំពីអង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស នៅអូរកន្សែង ដោយសារតែហេតុផល "គ្មានការថែទាំវេជ្ជសាស្ត្រ" និង "ការធ្វើទារុណកម្មផ្លូវកាយ និផ្លូវចិត្តលើអ្នកទោស"[727]។ អង្គជំនុំជម្រះបានផ្អែកលើកថាខណ្ឌ ១៤៣៤ និង ១៤៣៨ នៃដីកាដំណោះស្រាយដែលរៀបរាប់លម្អិតអំពីអង្គហេតុដែលត្រូវយកមកពិចារណាដើម្បីកំណត់ប្រភេទបទល្មើសនេះ។

៩១៩. ក៏ប៉ុន្តែ ការសន្និដ្ឋានលើអង្គហេតុនៃការគ្មានការថែទាំវេជ្ជសាស្ត្រ និងការធ្វើបាបពីសំណាក់ពួកឆ្មាំ និងអ្នកសួរចម្លើយ ត្រូវបានធ្វើឡើងដោយរំលោភលើបណ្តឹងជាក់ស្តែងពីសំណាក់សហចៅក្រមស៊ើបអង្កេត[728]។ ជាក់ស្តែង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនដែលលើកឡើងពីអង្គហេតុទាំងនេះទេ[729]។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចពិនិត្យអង្គហេតុទាំងនេះ ដោយស្របច្បាប់បានឡើយ[730]។ ការសន្និដ្ឋានថាមានធាតុផ្សំភ័ស្តុតាងគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើ

---

[724] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៣២៦-១៣២៩។

[725] សូមមើលខាងលើ កថាខណ្ឌ ៣៥១-៣៦៦។

[726] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៤-២៩៩៩ និង កថាខណ្ឌ ៤៣០៦។

[727] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០០៣។

[728] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៣៣០-១៣៣៣។

[729] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៧។

[730] សូមមើលខាងលើ កថាខណ្ឌ ៣៥១-៣៦៦។

អមនុស្សធម៌ផ្សេងៗទៀត ដោយ ធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស តាមរយៈការធ្វើបាបពីសំណាក់ឆ្មាំ និងអ្នកសួរចម្លើយ និងគ្មានការថែទាំវេជ្ជសាស្ត្រ ត្រូវទុកជាមោឃៈ[731]។ ដូច្នេះ ការផ្តន្ទាទោស ខៀវ សំផន ដោយផ្អែកលើមូលដ្ឋានច្បាស់លាស់នេះ ក៏ត្រូវទុកជាមោឃៈដែរ។

## ផ្នែកទី ៧. ការបោសសម្អាត

៤២០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយកាត់សេចក្តីអង្គហេតុនៃការបោសសម្អាតហួសពីអ្វីដែលបានកើតឡើងនៅក្នុងភូមិភាគឧត្តរ ក្នុងឆ្នាំ១៩៧៦ និងភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨[732]។ អង្គជំនុំជម្រះគួរពិចារណាពីការរំលោភបំពានលើបណ្តឹងអង្គហេតុអំពីសំណាក់សហចៅក្រមស៊ើបអង្កេត (១) និងគួរកត់សម្គាល់ថា ខ្លួនមិនមានសិទ្ធិអំណាចជំនុំជម្រះ ឬផ្តន្ទាទោសហួសពីបណ្តឹងជាក់ស្តែងឡើយ (២)។

### ១. ការរំលោភបំពានលើបណ្តឹងជាក់ស្តែងពីសំណាក់សហចៅក្រមស៊ើបអង្កេត

៤២១. យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបានទទួលតែបណ្តឹងពីអង្គហេតុដែលបានកើតឡើងនៅភូមិភាគឧត្តរចាស់ ក្នុងឆ្នាំ១៩៧៦ និងនៅភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨[733]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានពង្រីកវិសាលភាពនៃការស៊ើបអង្កេតដោយចិត្តឯង ទៅដល់អង្គហេតុ "បោសសម្អាត" ផ្សេងទៀត ក្រៅពីអង្គហេតុដែលមានបញ្ជាក់នៅក្នុងបណ្តឹង ក្នុងខណៈដែលពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយឡើយ។

៤២២. នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ មេធាវីការពារក្តីបានដាក់សំណើបន្ទាន់ទៅអង្គជំនុំជម្រះ សុំការបញ្ជាក់អំពីបណ្តឹងមកកាន់អង្គជំនុំជម្រះអំពី "ការបោសសម្អាតផ្ទៃក្នុង"[734]។ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ

[731] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០០៤, ៣០០៦ និង ៣០០៨។

[732] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ២៦៣៨, ២៦៤០។

[733] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤២, ៧១។

[734] សំណើបន្ទាន់របស់លោក ខៀវ សំផន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E420។

២០១៦ អង្គជំនុំជម្រះបានឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី តាមរយៈអនុស្សារណៈខ្លីមួយ (E420/1)[735]។ នៅក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះមិនដែលបានឆ្លើយទៅបញ្ហាដែលលើកឡើងដោយ ខៀវ សំផន ទេ។ វាមិនមែនជាបញ្ហាទំនាក់ទំនងរវាងគោលនយោបាយដែលបានចោទប្រកាន់ និងឧក្រិដ្ឋកម្មពាក់ព័ន្ធនោះទេ ប៉ុន្តែវាជាបញ្ហានៃវិសាលភាពនៃបណ្តឹងទៅកាន់សហចៅក្រមស៊ើបអង្កេត និងបន្ទាប់មក បណ្តឹងទៅកាន់អង្គជំនុំជម្រះ ដែលមួយភាគធំមិនជាក់ស្តែង។ តាមពិត អង្គជំនុំជម្រះមិនអាចសម្រេចលើអង្គហេតុ "បោសសម្អាត" ដែលខ្លួនមិនបានទទួលដោយត្រឹមត្រូវតាមច្បាប់នោះទេ។

## ២. ការផ្តន្ទាទោសដែលផ្អែកទាំងស្រុងលើអង្គហេតុ "បោសសម្អាត" ក្រៅវិសាលភាព

### ២.១. ការផ្តន្ទាទោសដែលផ្អែកទាំងស្រុងលើការដឹងឮអំពីអង្គហេតុ "បោសសម្អាត"ក្រៅវិសាលភាព

៤២៣. អង្គជំនុំជម្រះបានរកឃើញថា ខៀវ សំផន ដឹងឮអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលបោសសម្អាតផ្ទៃក្នុង នៅក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុនៅក្រៅបណ្តឹងជាក់ស្តែង។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានពិចារណាថា ខៀវ សំផន បានដឹងឮអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងរយៈពេលបោសសម្អាតផ្ទៃក្នុង ដែលបានធ្វើឡើងក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកលើមូលដ្ឋាននេះ[736]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយសន្និដ្ឋានថា ខៀវ សំផន ដឹងឮអំពីការចាប់ខ្លួន និងជោគវាសនារបស់កម្មាភិបាលមួយចំនួនបៃរបបកម្ពុជាប្រជាធិបតេយ្យ[737]។ ជាទូទៅ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយពិចារណាថា ខៀវ សំផន "បានដឹងឮអំពីការបោសសម្អាត និងការសម្លាប់ជាទូទៅទៅលើប្រជាជនទូទាំងប្រទេស" ដោយផ្អែកលើភស្តុតាងជាច្រើន ដែលមិនទាក់ទងនឹងការបោសសម្អាតនៅភូមិភាគឧត្តរ នៅឆ្នាំ១៩៧៦ និងភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨[738]។ ការសន្និដ្ឋានទាំងអស់នេះ ដែលត្រូវបានធ្វើឡើងដោយរំលោភលើបណ្តឹងជាក់ស្តែងមកកាន់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

---

[735] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E420/1**។

[736] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៥។

[737] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៥-៤២៣០។

[738] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣១។

៤២៤. អង្គជំនុំជម្រះមិនអាចយកការដឹងឮដោយសន្មតនេះ ដើម្បីទាញការសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនៅតាមមន្ទីរសន្តិសុខ (កថាខណ្ឌ ៤២៨៣-៤២៨៧)។ អង្គជំនុំជម្រះមិនអាចស្វែងរកភស្តុតាងដែលខ្លួនមិនមាន ពាក់ព័ន្ធនឹងអង្គហេតុ និងទីតាំងផ្សេងៗ ដើម្បីបង្ហាញថាពិតជាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅតាមទីតាំង និងក្នុងរយៈពេល ដែលជាកម្មវត្ថុនៃបណ្តឹងជាក់ស្តែងឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋាន តាមរបៀបនេះថា ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យក្លាយជាទាសករ ការឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអង្គហេតុដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ[739]។

## ២.២. ការផ្តន្ទាទោសដែលផ្អែកទាំងស្រុងលើអង្គហេតុ "បោសសម្អាត" ក្រៅវិសាលភាព

៤២៥. ជាក់ស្តែង មេធាវីការពារក្តីនឹងបង្ហាញខាងក្រោមថា ការអះអាងថា ខៀវ សំផន បាន ចូលរួមចំណែកក្នុងការបោសសម្អាតនៅទូទាំងប្រទេស[740] ជាការភាន់ច្រឡំ។

## ជំពូកទី ៣. កំហុស និងផលប៉ះពាល់លើក្រុមជាក់លាក់

## ផ្នែកទី ១. ពុទ្ធសាសនិក

### ១. គ្មានបណ្តឹងអំពីអង្គហេតុប្រឆាំងនឹងពុទ្ធសាសនិក នៅត្រាំកក់

៤២៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសម្រេចជាអត្តនោម័តិ បដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តីស្តីពីការកម្រិតវិសាលភាពនៃការជំនុំជម្រះមកត្រឹមអង្គហេតុ នៅក្នុងបណ្តឹងជាក់ស្តែង

---

[739] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៧។

[740] សូមមើលខាងក្រោម, កថាខណ្ឌ ១៨៤៩-១៨៧៨។

មកកាន់សហចៅក្រមស៊ើបអង្កេត[741]។ សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលអង្គជំនុំជម្រះយកជាមូលដ្ឋាន ដើម្បីប្រកាសថាខ្លួនមានសមត្ថកិច្ចជំនុំជម្រះអង្គហេតុប្រឆាំងនឹងពុទ្ធសាសនិក ដែលបានកើតឡើងនៅក្នុងសហករណ៍ត្រាំកក់ រំលោភបំពានលើបណ្តឹងជាក់ស្តែងទៅកាន់សហចៅក្រមស៊ើបអង្កេត[742]។ ខៀវ សំផន មិនចាំបាច់ទទួលខុសត្រូវចំពោះអង្គហេតុទាំងនេះឡើយ។ អង្គហេតុដែលម្ចាស់បណ្តឹងសាទុក្ខត្រូវទទួលខុសត្រូវ ត្រូវបានកំណត់ប្រភេទដោយសហចៅក្រមស៊ើបអង្កេតថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅកថាខណ្ឌ ១៤២១ នៃដីកាដំណោះស្រាយ និងអង្គហេតុគាំទ្រការចោទប្រកាន់នេះ មានរៀបរាប់លម្អិតនៅកថាខណ្ឌ ៣២១ នៃដីកាដំណោះស្រាយ ដោយរំលោភបំពានលើបណ្តឹងជាក់ស្តែង។

៤២៧. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមានការចោទប្រកាន់ណាមួយទាក់ទងនឹងជោគវាសនារបស់ពុទ្ធសាសនិក នៅត្រាំកក់ទេ។ កថាខណ្ឌ ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើសហករណ៍ត្រាំកក់ មិនបានធ្វើការចោទប្រកាន់ពាក់ព័ន្ធនឹងពុទ្ធសាសនិកឡើយ។ យោងតាមកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើការប្រព្រឹត្តិចំពោះពុទ្ធសាសនិក ពុំមានការចោទប្រកាន់ណាមួយពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ឡើយ។ ការបកស្រាយត្រឹមត្រូវតែមួយគត់នៃកថាខណ្ឌ ៧២ នេះ គឺជាការបកស្រាយដែលបែងចែកព្រឹត្តិការណ៍ពីរឈុតខុសគ្នា៖ (i) បម្រាមមិនឱ្យប្រតិបត្តិសាសនាចំពោះ "ពុទ្ធសាសនិកជន" រួមមានទាំងពុទ្ធបរិស័ទ និងបុព្វជិត និង (ii) ការបង្កព្យសនកម្មទៅលើព្រះសង្ឃ និងទីសក្ការៈបូជា ដែលបានកើតឡើងក្នុងវត្តចំនួនប្រាំពីរ នៃខេត្តចំនួនប្រាំមួយ។ ដោយឡែកចំណងជើងអង្គហេតុទាំងអស់ដែលមានពិពណ៌នានៅកថាខណ្ឌ ៧២ នាំឱ្យយល់ថា វិសាលភាពនៃបណ្តឹងកម្រិតមកត្រឹមតែអង្គហេតុដែលកើតឡើងនៅក្នុងខេត្តចំនួនប្រាំតែប៉ុណ្ណោះ គឺ កណ្តាល ក្រចេះ កំពត ស្ទឹងត្រែង និងបាត់ដំបង។ ក៏ប៉ុន្តែ សហករណ៍ស្រុកត្រាំកក់ស្ថិតក្នុងខេត្តតាកែវ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតពុំមានសមត្ថកិច្ចស៊ើបសួរក្នុងស្រុកត្រាំកក់ លើអង្គហេតុរងការចោទប្រកាន់ នៅដើមកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ។ អាស្រ័យហេតុនេះ ខុសពីការចោទប្រកាន់នៅកថាខណ្ឌ ២០៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតមិនដែលបានទទួលអង្គ

---

[741] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥, ៨០៩, ៨១៥, ១១៨០។

[742] សំអាងហេតុសាលក្រម កថាខណ្ឌ១១៨០ ដែលយោងទៅដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤២១ និង ៣២១។

ហេតុ "ប្រឆាំងនឹងពុទ្ធសាសនិកនៅទូទាំងប្រទេស" ឡើយ តែបានទទួលអង្គហេតុនៅទីតាំងមួយចំនួន នៃទឹកដីកម្ពុជា ស្របតាមខ្លឹមសារនៃកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនបានកត់សម្គាល់ពីការអនុវត្តហួសបណ្តឹងពីសំណាក់សហចៅក្រមស៊ើបអង្កេត។ កំហុសនេះនាំឱ្យអង្គជំនុំជម្រះប្រកាសថា ខ្លួនមានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុទាក់ទងនឹងជោគវាសនារបស់ពុទ្ធសាសនិកនៅត្រាំកក់[743]។

៤២៨. ទាក់ទងនឹងការបង្កព្យសនកម្មលើ "ព្រះសង្ឃ" និងទីសក្ការៈបូជា សហចៅក្រមស៊ើបអង្កេតផ្អែកលើឃ្លា *"គោលនយោបាយនេះត្រូវបានអនុវត្តទូទាំងប្រទេស នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ"* រួមបញ្ចូលទាំងកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មុនពេលបង្កើតបញ្ជីវត្តទាំងប្រាំពីរ ដែលឆ្លុះបញ្ចាំងពីពាក្យពេចន៍របស់សហចៅក្រមស៊ើបអង្កេត។ វិសាលភាពនៃបណ្តឹងទៅកាន់សហចៅក្រមស៊ើបអង្កេត ផ្តោតតែទៅលើអង្គហេតុដែលបានកើតឡើងនៅក្នុងវត្តទាំងនេះប៉ុណ្ណោះ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនអាចអះអាងថា យោងតាមកថាខណ្ឌ ២០៦ ខ្លួនបានទទួលបណ្តឹងពីអង្គហេតុ "ទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ" បានឡើយ។

៤២៩. គោលបំណងរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺដើម្បីបង្ហាញអង្គហេតុដែលបានកើតឡើងនៅកន្លែងផ្សេងៗនៃប្រទេសកម្ពុជា ដើម្បីគាំទ្រទស្សនៈដែលថា ប.ក.ក មានគោលនយោបាយនេះតាំងពីមុនមកហើយ ទើបបណ្តាលឱ្យមានការប្រព្រឹត្តិអំពើហ្នឹង។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាបានពិពណ៌នាវត្តចំនួនប្រាំពីរដែលស្ថិតនៅក្នុងខេត្តចំនួនប្រាំមួយផ្សេងគ្នា។ ខេត្តទាំងប្រាំមួយនេះ ដែលមានទីតាំងស្ថិតនៅក្នុងប្រាំភូមិភាគ ក្នុងចំណោមភូមិភាគទាំងប្រាំពីរ ដែលបង្កើតដោយខ្មែរក្រហមក្រោយថ្ងៃរំដោះ បង្ហាញពីទ្រឹស្តីដែលថាមានការផ្សព្វផ្សាយទូទាំងប្រទេស នូវគោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិកដែលរងការចោទប្រកាន់[744]។ ដូច្នេះ បំណងរបស់សហ

[743] សំអាងហេតុសាលក្រម កថាខណ្ឌ១១៨០។

[744] នៅកថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាគ្រាន់តែបានបញ្ជាក់ពីឈ្មោះខេត្តដែលវត្តទាំងនោះស្ថិតនៅ។ ចៅក្រមស៊ើបសួរ បើតាមកថាខណ្ឌ ៧៤៣ នៃដីកាដំណោះស្រាយ បានជូនព័ត៌មានអំពីភូមិភាគនានាដែលខេត្តទាំងនោះស្ថិតនៅ។ ដូច្នេះ ភមិភាគនិរតី ពាយ័ព្យបូព៌ា ឦសាន និងតំបន់ ៥០៥ ត្រូវបានបង្ហាញនៅក្នុងកថាខណ្ឌ ៧២ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា។ មានតែភូមិភាគឧត្តរ និងបស្ចឹមប៉ុណ្ណោះដែលមិនត្រូវបានលើកយកមកបង្ហាញ។

ព្រះរាជអាជ្ញាមិនមែនបញ្ជូនអង្គហេតុដែលបានកើតឡើងនៅគ្រប់វត្តអារាម ក្នុងទូទាំងប្រទេសកម្ពុជានោះទេ គឺចង់បញ្ជូនតែអង្គហេតុដែលបានកើតឡើងនៅតាមវត្តអារាមមួយចំនួន ដែលត្រូវបានចាត់ទុកថាជាសំណាកគំរូក្នុងការគាំទ្រទ្រឹស្តីរបស់ពួកគាត់តែប៉ុណ្ណោះ។

៤៣០. បន្ទាប់មក នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម សហព្រះរាជអាជ្ញាបានលើកឡើងប្លុនដង ពីអត្ថិភាពនៃវត្តដទៃទៀត ដោយមិនដែលនិយាយអំពីជោគវាសនារបស់ពុទ្ធសាសនិកនៅទីតាំងទាំងនេះទាល់តែសោះ[745]។ ការសង្កេតនេះមានភាពទាក់ទាញជាពិសេសសម្រាប់ទីតាំងចំនួនបី រួមមាន វត្តធ្លក វត្តគិរីរម្យ និងវត្តអូរត្រកួន[746]។ ដោយហេតុថាវត្តទាំងនេះបានក្លាយជាមន្ទីរឃុំឃាំងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ សហចៅក្រមស៊ើបអង្កេតបានទទួលយកមកស៊ើបសួរអំពីអង្គហេតុដែលបានកើតឡើងនៅទីនោះ[747]។ សហព្រះរាជអាជ្ញាប្រាកដជាបានសង្កេតឃើញថា កន្លែងទាំងនេះជាអាស្រមរបស់ព្រះសង្ឃមុនពេលខ្មែរក្រហមមកដល់ ហើយថាទីតាំងទាំងនេះត្រូវបានវាយឱ្យបែកបាក់ដើម្បីយកវាធ្វើគុក។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាមិនបាននិយាយអំពីរឿងទាំងនេះ ឬអ្វីផ្សេងទៀតទាក់ទងនឹងការលុបបំបាត់សាសនានៅទីតាំងទាំងនេះទេ[748]។

៤៣១. សហព្រះរាជអាជ្ញាបានជ្រើសរើសមិនបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតនូវអង្គហេតុទាក់ទងនឹងពុទ្ធសាសនិកនៅវត្តដែលបានរៀបរាប់ខាងលើ ដូចដែលខ្លួនជ្រើសរើសមិននិយាយអំពីជោគវាសនារបស់ពុទ្ធសាសនិកនៅក្នុងសហករណ៍នានាក្នុងស្រុកត្រាំកក់ដែរ។ ដូច្នេះ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតមិនបានទទួលអង្គហេតុពាក់ព័ន្ធនឹងជោគវាសនារបស់ពុទ្ធសាសនិកនៅតាមវត្តដទៃទៀត ដែលត្រូវបានបញ្ជាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ វាមិនអាចទៅរួចទេក្នុងការនិយាយថា

---

[745] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៥ (វត្តបារាយណ៍ជើងដែក ដែលពីដំបូងស្ថិតនៅក្នុងខេត្តកំពង់ធំ) កថាខណ្ឌ ៦៦ (វត្តធ្លក ស្ថិតនៅក្នុងខេត្តស្វាយរៀង) និង កថាខណ្ឌ ៦៨ (វត្តគិរីរម្យ ស្ថិតនៅក្នុងខេត្តបាត់ដំបង)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ **D196** កថាខណ្ឌ ៨-១២ (វត្តអូរត្រកួន ស្ថិតនៅក្នុងខេត្តកំពង់ចាម)។

[746] ដីកាដំណោះស្រាយ កថាខណ្ឌ ៧៧៦-៧៨៣។

[747] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៦ (វត្តធ្លក) និង កថាខណ្ឌ ៦៨ (វត្តគិរីរម្យ)។

[748] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៦ (វត្តធ្លក) និង កថាខណ្ឌ ៦៨ (វត្តគិរីរម្យ)។

សហព្រះរាជអាជ្ញាចង់បញ្ជូនឱ្យសហចៅក្រមស៊ើបអង្កេតនូវអង្គហេតុដែលបានកើតឡើង នៅតាមវត្ត ដែលមិនត្រូវបានលើកឡើងម្តងណាសោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទាំងអស់។

៤៣២. ទីបំផុត សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅកថាខណ្ឌ ៧៤៣ នៃដីកាដំណោះស្រាយថា មាន "ការកម្ទេចវត្តអារាម" និង "ការប្រើប្រាស់វាសម្រាប់មុខងារផ្សេងទៀត [...] នៅគ្រប់ខេត្តទាំងអស់នៃប្រទេសកម្ពុជា ក្រោមរបប "កម្ពុជាប្រជាធិបតេយ្យ"។ បន្ទាប់មក ពួកគាត់បានចុះបញ្ជីភូមិភាគទាំងអស់នៃកម្ពុជាប្រជាធិបតេយ្យថាជាទីតាំងនៃការវាយប្រហារទាំងនេះ និងសំអាងលើកំណត់ហេតុស្តាប់ចម្លើយសាក្សីជាច្រើននៅក្នុងកំណត់ត្រាឯកសាពិគ្រោះនៅចុងបញ្ចប់ដីកានេះ។ ទោះបីជាមានការកត់សម្គាល់យ៉ាងច្បាស់លើអង្គហេតុដែលបានកើតឡើងនៅលើទីតាំងផ្សេងៗទៀត ដែលមិនមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតបានកំណត់ថាជាបទល្មើសធ្វើទុក្ខបុកម្នេញនៅក្នុងកថាខណ្ឌ ១៤២១ នៃដីកាដំណោះស្រាយ តែចំពោះអង្គហេតុដែលបានកើតឡើងនៅក្នុងវត្តមានរាយឈ្មោះនៅកថាខណ្ឌ ៧២ និងតែចំពោះអង្គហេតុដែលបានកើតឡើងនៅវត្តធ្លក វត្តគិរីរម្យ និងនៅសហករណ៍នានាក្នុងស្រុកត្រាំកក់ ពោលគឺចំពោះទីតាំងដែលត្រូវបានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៤៣៣. ដូច្នេះ នៅពេលកំណត់ប្រភេទបទល្មើសលើអង្គហេតុ សហចៅក្រមស៊ើបអង្កេតបានបង្ហាញថា ខ្លួនដឹងអំពីវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន។ ប្រសិនបើពួកគាត់ពិតជាគិតថាខ្លួនបានទទួលអង្គហេតុ នៅទូទាំងប្រទេសកម្ពុជាវិញ ម្ល៉េះសមពួកគាត់កំណត់ថាជាបទល្មើសធ្វើទុក្ខបុកម្នេញចំពោះអង្គហេតុដទៃទៀតក្រៅពីអ្វីដែលបានកើតឡើងនៅទីតាំងដែលមានបញ្ជាក់ស្រាប់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបាត់ទៅហើយ ហើយដែលចំពោះអង្គហេតុទាំងនេះ ម្ល៉េះសមពួកគាត់និយាយនៅកថាខណ្ឌ ៧៤៣ ថាខ្លួនបានរកឃើញភ័ស្តុតាងដាក់បន្ទុកបាត់ទៅហើយ។ ទាំងនេះជាទឡ្ហីករណ៍កាន់តែគួរឱ្យជឿជាក់ទៅទៀត ចំពោះអង្គហេតុដែលបានកើតឡើងនៅក្នុងភូមិភាគដែលមិនត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយហេតុថាវាជួយពង្រឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអំពីការផ្សព្វផ្សាយថ្នាក់ជាតិនៃគោលនយោបាយរបស់ ប.ក.ក។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនបានកត់សម្គាល់ពីការអនុវត្តហួសបណ្តឹងពីសំណាក់សហ

ចៅក្រមស៊ើបអង្កេត។ កំហុសនេះនាំឱ្យអង្គជំនុំជម្រះសម្រេចដោយមិនត្រឹមត្រូវថា ខ្លួនមានសមត្ថកិច្ចវិនិច្ឆ័យលើអង្គហេតុទាក់ទងនឹងជោគវាសនារបស់ព្រះសង្ឃពុទ្ធសាសនា នៅត្រាំកក់[749]។

## ២. ការផ្តន្ទាទោសចំពោះអង្គហេតុនៃ "ការរើសអើង" ចំពោះពុទ្ធសាសនិក

៤៣៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសម្រេចបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តីទាក់ទងនឹងការកម្រិតការជំនុំជម្រះមកត្រឹមអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយ ហើយដែលសហចៅក្រមស៊ើបអង្កេតបានទទួលដោយត្រឹមត្រូវតាមច្បាប់។ សេចក្តីសន្និដ្ឋានរបស់ សហចៅក្រមស៊ើបអង្កេតដែលអង្គជំនុំជម្រះប្រើជាមូលដ្ឋានបង្អែកដើម្បីសម្រេចថា ខ្លួនមានសមត្ថកិច្ចជំនុំជម្រះលើអង្គហេតុពាក់ព័ន្ធនឹងការរើសអើងដោយមូលហេតុសាសនាចំពោះពុទ្ធសាសនិក និងព្រះសង្ឃ រំលោភបំពានលើបណ្តឹងជាក់ស្តែងមកកាន់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ ខៀវ សំផន មិនចាំបាច់ទទួលខុសត្រូវចំពោះអង្គហេតុទាំងនេះទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានជម្នុះវិនិច្ឆ័យលើអង្គហេតុទាំងនេះ និងដោយបានសន្និដ្ឋានថាបានរកឃើញការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាចំពោះអង្គហេតុនៃ "ការរើសអើង" ប្រឆាំងនឹងពុទ្ធសាសនិក និងព្រះសង្ឃក្នុងសហករណ៍នានានៃស្រុកត្រាំកក់[750]។ ជាផលវិបាក អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ផងដែរ ដោយបានរាប់បញ្ចូលអង្គហេតុដែលត្រូវបានកំណត់ប្រភេទថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទៅក្នុងគោលនយោបាយដែលខ្លួនចាត់ទុកថាមានចរិត "ឧក្រិដ្ឋ"[751]។ ការសន្និដ្ឋានទាំងនេះ រួមទាំងការផ្តន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុទាំងនេះ ក្រោមទម្រង់សហឧក្រិដ្ឋកម្មរួម ត្រូវទុកជាមោឃៈ[752]។

[749] សំអាងហេតុសាលក្រម កថាខណ្ឌ១១៨០។

[750] សំអាងហេតុសាលក្រម កថាខណ្ឌ១១៨៣-១១៨៧។

[751] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០១៩, ៤០២១-៤០២២, ៤២៩៦, ៤២៩៨។

[752] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

## ផ្នែកទី ២. ជនជាតិវៀតណាម

៤៣៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានពិចារណាថា ការចោទប្រកាន់ពីអំពើមនុស្សឃាតលើជនជាតិវៀតណាម គ្របដណ្តប់លើទឹកដីកម្ពុជាទាំងមូល[753]។ អង្គជំនុំជម្រះបានធ្វើយុត្តិកម្មសម្រាប់ខ្លួនឯង ដោយពន្យល់ថាផ្នែកមួយនៃដីកាដំណោះស្រាយ ផ្តោតយ៉ាងជាក់លាក់ទៅលើ ការសម្លាប់មនុស្សនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង[754]។ ក៏ប៉ុន្តែ ផ្នែកនេះត្រូវបានធ្វើឡើងដោយរំលោភបំពានលើបណ្តឹងមកកាន់សហចៅក្រមស៊ើបអង្កេត។ ជាក់ស្តែង យោងទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាបានសម្រេចបើកការស៊ើបអង្កេតប្រឆាំងនឹង ខៀវ សំផន លើអង្គហេតុទាក់ទងទៅនឹងវិធានការប្រឆាំងនឹងជនជាតិវៀតណាមរស់នៅខេត្តព្រៃវែង ស្វាយរៀង និងកំឡុងពេលលុកលុយចូលក្នុងទឹកដីវៀតណាម[755]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានទទួលតែអង្គហេតុទាំងនេះប៉ុណ្ណោះ ដូចដែលពួកគាត់បានគូសបញ្ជាក់នៅក្នុងដីកាដំណោះស្រាយដែរថា៖ "សហចៅក្រមស៊ើបអង្កេតបានទទួលដោយត្រឹមត្រូវតាមច្បាប់នូវអង្គហេតុទាក់ទងទៅនឹងវិធានការ [...] ប្រឆាំងនឹងជនជាតិវៀតណាមរស់នៅខេត្តព្រៃវែង ស្វាយរៀង (ភូមិភាគបូព៌ា) និងកំឡុងពេលលុកលុយចូលក្នុងទឹកដីវៀតណាម[756]។

៤៣៦. គោលជំហរនេះត្រូវបានរំឭកក្នុងដីការបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ តាមរយៈការច្រានចោលសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងខ្មែរក្រោម និងជនជាតិវៀតណាម នៅក្រៅខេត្តព្រៃវែង និងស្វាយរៀង ព្រោះថាឧក្រិដ្ឋកម្មទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃបណ្តឹងជាក់ស្តែងទៅកាន់សហចៅក្រមស៊ើបអង្កេត[757]។ ដូច្នេះ ភាពផ្ទុយគ្នាដែលលើកឡើងដោយអង្គជំនុំជម្រះ មិនមែន

---

753 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥៨ និង ៣៣៦០។

754 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥៨ ដែលយោងទៅកថាខណ្ឌ ៨០២ និង ៨០៣ នៃដីកាដំណោះស្រាយ។

755 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៩-៧០។

756 ដីកាដំណោះស្រាយ កថាខណ្ឌ ២០៦។

757 ដីការបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ឯកសារ **D250/3/3** កថាខណ្ឌ ៧-៩៖ "ប្រសិនបើគេយោងទៅកថាខណ្ឌ ៦៩ និង ៧០ នៃដីកាបញ្ជូនរឿងទៅស៊ើបសួររបស់ចៅក្រមស៊ើបសួរបានទទួលពាក្យបណ្តឹងស្តីពីការប្រព្រឹត្តិចំពោះប្រជា

បណ្ដាលមកពីមេធាវីការពារក្ដីទេ គឺមកពីសហចៅក្រមស៊ើបអង្កេត[758]។ មេធាវីការពារក្ដីដឹងច្បាស់ណាស់ថា ផ្នែកមួយនៃដីកាដំណោះស្រាយ ផ្ដោតទៅលើវិធានការប្រឆាំងនឹងជនជាតិវៀតណាមនៅក្រៅខេត្តទាំងពីរនេះ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតធ្វើហាក់ដូចជាយល់ជ្រួតជ្រាបច្បាស់ណាស់ថា វិសាលភាពនៃបណ្ដឹងមកកាន់ខ្លួន កម្រិតត្រឹមតែខេត្តព្រៃវែង និងស្វាយរៀងប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាក៏ជ្រួតជ្រាបពីវិសាលភាពនៃបណ្ដឹងនេះដែរ៖

> "សហចៅក្រមស៊ើបអង្កេតបានពិចារណាថា ខ្លួនបានទទួលបណ្ដឹងទាក់ទងនឹងអង្គហេតុនៃការប្រព្រឹត្តិលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងស្វាយរៀង ក្នុងភូមិភាគបូព៌ា និងអំឡុងពេលលុកលុយចូលក្នុងប្រទេសវៀតណាម។ នៅពេល បំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានដកចេញពីវិសាលភាពនៃការជំនុំជម្រះវគ្គ ២ នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្នុងអំឡុងពេលលុកលុយចូលប្រទេសវៀតណាម។ <u>ដោយមូលហេតុនេះ ការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ដែលជនជាតិវៀតណាមជាជនរងគ្រោះ ទាក់ទងតែនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងខេត្តព្រៃវែង និងស្វាយរៀងតែប៉ុណ្ណោះ</u>។ បទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត ដែលទាក់ទងជាក់លាក់នឹងការប្រព្រឹត្តិលើជនជាតិវៀតណាម ត្រូវបានផ្ដោតជាចម្បងតែនៅក្នុងតំបន់ទាំងពីរនេះដែរ"[759]។

---

ជនវៀតណាមនៅក្នុង ខេត្តព្រៃវែង និងស្វាយរៀង និងចំពោះប្រជាជនវៀតណាម នៅក្នុងពេលវាយលុកចូលក្នុងប្រទេសវៀតណាម [...]។ ទាក់ទងទៅនឹងទិដ្ឋភាពទីមួយនៃសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី (ស្នើសុំឱ្យមានការពិចារណាលើភស្តុតាងថ្មី ទាក់ទងនឹងឧក្រិដ្ឋកម្មប្រព្រឹត្តលើក្រុមខ្មែរក្រោម នៅក្នុងខេត្តពោធិសាត់ និងខេត្តតាកែវ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា វាបានលើកឡើងនូវបញ្ហាដែលដូចគ្នាទៅនឹងសំណើសុំរបស់ ក.ស.ព ជាក់ស្ដែង អំពីការស៊ើបអង្កេតទាក់ទងនឹងប្រព្រឹត្តកម្មលើខ្មែរក្រោម និងជនជាតិវៀតណាមនៅតាមតំបន់ភូមិសាស្ត្រដែលមិនស្ថិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធចំពោះការលើកឡើងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីបញ្ហានេះ ក្នុងហេតុផល ដូចការបដិសេធសំណើសុំរបស់ ក.ស.ព"។

[758] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥៦។

[759] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E381** កថាខណ្ឌ ៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/371.1** ក្រោយម៉ោង 09.52.57 "វាមិនមែនមានតែអំពើប្រល័យពូជសាសន៍ទេ។ ចេតនាក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍មានការទាមទារច្រើន ហើយពិបាកនឹងបង្ហាញភស្តុតាង

៩៣៧. សូម្បីតែអង្គជំនុំជម្រះក៏ធ្វើហាក់ដូចជាដឹងជ្រួតជ្រាបអំពីវិសាលភាពនៃបណ្ដឹងនេះ ក្នុងមួយរយៈពេលកន្លងមកដែរ[760]។ ក៏ប៉ុន្តែ នៅក្នុងសំអាងហេតុសាលក្រមរងបណ្ដឹងសាទុក្ខនេះ អង្គជំនុំជម្រះមិនបានពន្យល់ពីមូលហេតុ និងមូលដ្ឋានដែលនាំឱ្យខ្លួនអាចពិចារណាថា វិសាលភាពនៃបណ្ដឹងជាក់ស្ដែង ត្រូវបានពង្រីកដល់អង្គហេតុដែលជាធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ ក្រោមទម្រង់ជាអំពើមនុស្សឃាតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល និងមនុស្សឃាតនៅខាងក្រៅខេត្តទាំងពីរនេះ[761]។ ចន្លោះប្រហោងនៃកម្រិតភ័ស្ដុតាងស្ដីពីអំពើមនុស្សឃាតលើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងស្វាយរៀង ប្រាកដជាដើមចមដែលនាំឱ្យអង្គជំនុំជម្រះចង់ពិនិត្យអំពើមនុស្សឃាតនៅទូទាំងប្រទេស ជាពិសេសក្នុងបំណងបង្ហាញថាពិតជាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[762]។ ទោះយ៉ាងណាក្ដី អង្គជំនុំជម្រះបានជ្រើសរើសយកការបកស្រាយមិនត្រឹមត្រូវលើដីកាដំណោះស្រាយ[763]។ អង្គជំនុំជម្រះមិនមានសិទ្ធិអំណាចពិនិត្យអង្គហេតុទាំងនេះ ដោយរំលោភបំពានលើវិសាលភាពនៃបណ្ដឹង

---

ប៉ុន្តែពេលនេះ យើងនិយាយអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តទៅ នៅព្រៃវែង និងស្វាយរៀងដែលជាការអនុវត្តតាមគោលនយោបាយជាតិមួយ។ ហេតុនេះហើយបានជាយើងឃើញមានសាក្សីជាច្រើនបានមកផ្ដល់សក្ខីកម្ម នៅតំបន់ផ្សេងទៀតក្រៅពីស្វាយរៀង និងព្រៃវែង"។ ក្រោយម៉ោង 09.55.57 "យើងបានស្នើនូវសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦ រូបដាក់ជូនទៅអង្គជំនុំជម្រះ ជាពិសេសពាក់ព័ន្ធទៅនឹងព្រៃវែង និងស្វាយរៀង ហើយខ្ញុំចង់សង្កត់ធ្ងន់ផងដែរថា <u>មកទល់នឹងពេលនេះ យើងទើបតែបានស្ដាប់សាក្សីឬដើមបណ្ដឹងរដ្ឋប្បវេណីបួនរូបតែប៉ុណ្ណោះពាក់ព័ន្ធទៅនឹងខេត្តទាំងពីរនេះ"</u> (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[760] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E380/2** កថាខណ្ឌ ២៧៖ "ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះសូមរំឭកថាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ទាក់ទងទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាម ពឹងផ្អែកមួយចំណែកធំទៅលើឧក្រិដ្ឋកម្មជាមូលដ្ឋានដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង"។

[761] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥៨ និង ៣៣៦០។

[762] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៤២-៣៤៥៥ ដែលនៅទីនេះអង្គជំនុំជម្រះបានតែត្រឹមធ្វើសេចក្ដីសន្និដ្ឋានលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើប្រជាជនវៀតណាមបួនគ្រួសារនៅខេត្តស្វាយរៀងតែប៉ុណ្ណោះ។ សេចក្ដីសន្និដ្ឋាននេះក៏មានការជំទាស់ផងដែរ សូមមើលនៅខាងក្រោម កថាខណ្ឌ ៩៨៧-៩៩២។

[763] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥៨ សូមមើលផងដែរ កំណត់សម្គាល់ជើងទំព័រលេខ ១១៣១៧។

មកកាន់សហចៅក្រមស៊ើបអង្កេតឡើយ ដើម្បីកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់អំពើមនុស្សឃាត ការសម្លាប់រង្គាល និងបទប្រល័យពូជសាសន៍តាមរយៈអំពើមនុស្សឃាតនោះទេ[764]។

៤៣៨. ទោះបីជាអង្គហេតុទាំងនេះត្រូវបានយកមកជំនុំជម្រះដោយរំលោភបំពានលើបណ្ដឹងក៏ដោយ ក៏វាស្ដែងចេញពីដីកាដំណោះស្រាយយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតបានរៀបរាប់អនុផ្នែកនេះពាក់ព័ន្ធនឹងការសម្លាប់រង្គាលលើជនជាតិវៀតណាម នៅខាងក្រៅខេត្តព្រៃវែង និងស្វាយរៀង ដើម្បីបង្ហាញថាមាន "គោលនយោបាយជាតិ"[765]។ ដោយឥតសង្ស័យ នេះជាមូលហេតុដែលសហព្រះរាជអាជ្ញាបានពិចារណាថា ភ័ស្តុតាងដែលបានប្រមូល នៅខាងក្រៅខេត្តព្រៃវែង និងស្វាយរៀង អាចមានប្រយោជន៍ដែរ ដើម្បីបង្ហាញឱ្យឃើញថាមានគោលនយោបាយជាតិ និងដើម្បីទាញការសន្និដ្ឋានលើចេតនាប្រល័យពូជសាសន៍[766]។ មូលហេតុនេះមិនត្រឹមត្រូវទេទាក់ទងទៅនឹងចេតនា ពីព្រោះចេតនាត្រូវបានពិចារណាវិភាគដាច់ដោយឡែកនៅក្នុងដីកាដំណោះស្រាយ[767]។ ទោះយ៉ាងណាក្ដី គោលនយោបាយជាតិមិនសមមូលនឹងការកំណត់ប្រភេទបទល្មើសនោះទេ។ ដូច្នេះគួរគប្បីធ្វើការបែងចែកជាមួយអង្គហេតុដែលបានលើកឡើងដើម្បីគាំទ្រដល់ការចោទប្រកាន់ជាក់លាក់ប្រឆាំងនឹងជនជាប់ចោទ។ ដូច្នេះ អង្គជំនុំជម្រះមិនមានសិទ្ធិអំណាចពង្រីកវិសាលភាពនៃបណ្ដឹងជាក់ស្ដែង ទៅដល់អង្គហេតុដែលបង្កើតបានជាបទប្រល័យពូជសាសន៍ ក្រោមទម្រង់ជាអំពើមនុស្សឃាត បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់

---

[764] សូមមើលខាងលើ កថាខណ្ឌ ៣៥១-៣៦៦។

[765] ដីកាដំណោះស្រាយ កថាខណ្ឌ ៨០២ "ការសម្លាប់ប្រជាជនវៀតណាម មិនមែនកើតឡើងត្រឹមតែនៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ប៉ុណ្ណោះទេ ដែលនេះបង្ហាញឱ្យឃើញថា ជាការរៀបចំឡើងនៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិ"។ (យើងគូសបន្ទាត់ពីក្រោម)។

[766] ប្រតិចារឹក ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/371.1** ក្រោយម៉ោង 09.52.57 "វាមិនមែនមានតែអំពើប្រល័យពូជសាសន៍នោះទេ។ ចេតនានៅក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍មានការទាមទារច្រើន ហើយពិបាកនឹងបង្ហាញភ័ស្តុតាង ប៉ុន្តែពេលនេះយើងនិយាយអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តទៅ នៅព្រៃវែង នៅស្វាយរៀង ដែលជាការអនុវត្តតាមគោលនយោបាយជាតិមួយ។ ហេតុនេះហើយបានជាយើងឃើញមានសាក្សីជាច្រើនបានមកផ្ដល់សក្ខីកម្ម នៅតំបន់ផ្សេងទៀត ក្រៅពីស្វាយរៀង និងព្រៃវែង"។

[767] នៅក្នុងដីកាដំណោះស្រាយ ការសម្លាប់នៅក្រៅខេត្តព្រៃវែង និងស្វាយរៀង ដែលជាការបង្ហាញពីនយោបាយជាតិនោះ ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ៨០២-៨០៤ ខណៈដែលចេតនានៃការកំចាត់ក្រុមគោលដៅ ត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ៨១៤-៨១៨។

ជាការសម្លាប់រង្គាល និងការសម្លាប់ជនជាតិវៀតណាមនៅក្រៅខេត្តព្រៃវែង និងស្វាយរៀង ដោយយកលេសថាជាការបរិយាយទាក់ទងនឹងគោលនយោបាយជាតិ។ ដូច្នេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែបានរួចផុតពីបទឧក្រិដ្ឋទាំងនេះ[768]។

## មាតិកាទី ២. បទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ

៤៣៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនអើពើនឹងទឡ្ហីករណ៍របស់មេធាវីការពារក្ដីអំពីបទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះ (ជំពូកទី ១) និងអំពីអង្គហេតុនៅត្រាំកក់ (ជំពូកទី ២)។

### ជំពូកទី ១. អង្គច្បាប់

៤៤០. បន្ទាប់ពីសង្ខេបទឡ្ហីករណ៍របស់មេធាវីការពារក្ដីទាក់ទងនឹងភាពមិនត្រឹមត្រូវតាមច្បាប់នៃបណ្ដឹង ដែលខ្លួនបានទទួល ដោយមូលហេតុបទចោទមិនគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅជំនុំជម្រះ អង្គជំនុំជម្រះបានបដិសេធចោលទាំងស្រុង ដោយផ្តល់សំអាងហេតុថា ដោយហេតុពុំមានសូចនាករច្បាស់លាស់ វាពិបាកនឹងកំណត់ថាតើដីកាដំណោះស្រាយមានវិការៈអ្វីខ្លះ ហើយក៏ពិបាកនឹងដឹងថាតើអង្គបុរេជំនុំជម្រះបានទទួលបណ្តឹងអំពីវិការៈនេះហើយ ឬនៅ[769]។

៤៤១. ក៏ប៉ុន្តែ ការសន្និដ្ឋានរបស់មេធាវីការពារក្ដីមានភាពច្បាស់លាស់ និងជាក់លាក់គ្រប់គ្រាន់ល្មមនឹងឱ្យអង្គជំនុំជម្រះគោរពកាតព្វកិច្ចរបស់ខ្លួនក្នុងការឆ្លើយតបនឹងការសន្និដ្ឋានទាំងនេះ អនុលោមតាមវិធាន ១០១ (៤) នៃវិធានផ្ទៃក្នុង[770]។

---

[768] សំអាងហេតុសាលក្រម កថាខណ្ឌ៣៤៥៦-៣៤៨៨, ៣៤៩០, ៣៤៩២-៣៤៩៧, ៣៤៩៨-៣៥០២ និង ៣៥១៤-៣៥១៩។

[769] សំអាងហេតុសាលក្រម កថាខណ្ឌ១៦៨-១៦៩។

[770] វិធាន ១០១.៤ នៃវិធានផ្ទៃក្នុង៖ "ផ្នែកសំអាងហេតុនៅក្នុងសាលក្រម ត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរដែលបានធ្វើឡើងដោយភាគីទាំងអស់"។ សូមមើលផងដែរមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលរៀបរាប់ពីហេតុផលដែលអាចនាំឱ្យតុលាការកំពូលបដិសេធសេចក្តីសម្រេច ដូចជាការខកខានមិនបានសម្រេចលើពាក្យប្តឹងសុំនៃភាគីណាមួយ នៅពេលដែលពាក្យប្តឹងសុំធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់។

៤៤២. ជាបឋម មេធាវីការពារក្តីបានពន្យល់យ៉ាងច្បាស់អំពីមូលហេតុដែលមិនអាចទៅរួច តាមផ្លូវច្បាប់ ក្នុងការលើកឡើងអំពីវិការៈដែលធ្វើឱ្យដីកាដំណោះស្រាយក្លាយជាមោឃៈ ចំពោះមុខអង្គបុរេជំនុំជម្រះ និងមូលហេតុដែលតម្រូវឱ្យអង្គជំនុំជម្រះពិនិត្យវិការៈទាំងនេះ[771]។ បន្ទាប់មក មេធាវីការពារក្តីបានបញ្ជាក់ថា ខ្លួននឹងរៀបរាប់លម្អិតអំពីការតវ៉ារបស់ខ្លួន ចំពោះទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធ[772] ហើយដែលខ្លួនបានធ្វើកិច្ចការនេះយ៉ាងច្បាស់សម្រាប់ទីតាំងនីមួយៗ ដោយចង្អុលបង្ហាញកថាខណ្ឌពាក់ព័ន្ធនៃដីកាដំណោះស្រាយ និងដោយពន្យល់ថាតើហេតុអ្វីបានជាភ័ស្តុតាងគាំទ្រ ឬអវត្តមាននៃភ័ស្តុតាង មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះ[773]។

៤៤៣. ហេតុដូចនេះ អង្គជំនុំជម្រះពុំមានលេសគេចវេសមិនពិនិត្យទឡ្ហីករណ៍ទាំងនេះទេ។ ជាពិសេស គឺដោយហេតុថាទឡ្ហីករណ៍ទាំងនេះមានហេតុផលគាំទ្រគ្រប់ជ្រុងជ្រោយ យ៉ាងហោចណាស់ ក៏គ្រប់ជ្រុងជ្រោយស្របតាមច្បាប់ដែលសហចៅក្រមស៊ើបអង្កេតបានប្រកាសថាខ្លួននឹងអនុវត្តនោះដែរ[774]។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា សញ្ញាណនៃបន្ទុក គ្រប់គ្រាន់នៃភ័ស្តុតាង គឺសំដៅលើធាតុផ្សំភ័ស្តុតាងដែល "មានទម្ងន់គ្រប់គ្រាន់ និងស៊ីចង្វាក់គ្នា ដើម្បីបង្ហាញទម្ងន់ជាភ័ស្តុតាងមួយចំនួន" ឬ "ធាតុផ្សំភ័ស្តុតាងដែលអាចទុកចិត្តបាន សម្រាប់ប្រើជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់"[775]។

---

[771] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៧០, ២១៣-២១៦, ២៤៤-២៥៥, ២៩៤-២៩៩។

[772] សារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ១៥៤-១៥៥, ២៩៨ និងកំណត់សម្គាល់ជើងទំព័រលេខ ២៧០។

[773] សារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ សហករណ៍ត្រាំកក់៖ កថាខណ្ឌ ៩២៤-៩៣១, ៩៤២-៩៤៨, ៩៦៨-៩៦៩។ ទំនប់ត្រពាំងថ្ម៖ កថាខណ្ឌ ១០២២-១០២៨។ ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង៖ កថាខណ្ឌ ១០៩៦-១១០៥។ ក្រាំងតាចាន់៖ កថាខណ្ឌ ១២៥៤-១២៧១។ អតីតទាហាន និងមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ៖ កថាខណ្ឌ ២២៦៤-២២៦៧, ២២៨៣-២២៨៧, ២២៨៨-២២៩៨, ២៣០៦។

[774] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២០-១៣២៦។

[775] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣-១៣២៦ (សម្រង់សម្តីទាញចេញពីកថាខណ្ឌ ១៣២៣ និង ១៣២៥)។

៤៤៤. សហចៅក្រមស៊ើបអង្កេតបានបញ្ជូន ខៀវ សំផន ទៅជំនុំជម្រះចំពោះអង្គហេតុដែលភ័ស្តុតាងគាំទ្រមិនដល់កម្រិតស្តង់ដារអប្បបរមា។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងដោយត្រឹមត្រូវតាមច្បាប់ទេ ហើយក៏មិនមានសិទ្ធិអំណាចសម្រេចលើអង្គហេតុទាំងនេះដែរ។ ការផ្តន្ទាទោសចំពោះអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ។

**ជំពូកទី ២. កំហុស និងផលប៉ះពាល់ នៅត្រាំកក់**

**១. ការចេញក្រៅវិសាលភាពនៃឧក្រិដ្ឋកម្ម**

**១.១. គ្មានបណ្តឹងអំពីការស្លាប់ដោយសារភាពអត់ឃ្លាន នៅក្នុងឃុំនៃស្រុកត្រាំកក់**

៤៤៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយសន្និដ្ឋានថា ខ្លួនបានទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ចជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការសម្លាប់រង្គាល ចំពោះការស្លាប់ដោយសារភាពអត់ឃ្លានដែលបានកើតឡើងនៅសហករណ៍នានានៃស្រុកត្រាំកក់[776]។ ដោយអត្តនោម័តិ និងមិនត្រឹមត្រូវ ដោយគ្រាន់តែលើកឡើងថា "ពុំមានសូចនាករច្បាស់លាស់" អង្គជំនុំជម្រះបានបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលយល់ឃើញថា ភ័ស្តុតាងដាក់បន្ទុកខ្សោយខ្លាំងពេកមិនអាចជាមូលដ្ឋាននៃការបញ្ជូនទៅជំនុំជម្រះចំពោះអង្គហេតុ នៅឃុំនានានៃស្រុកត្រាំកក់ ដែលជាផ្នែកមួយនៃវិសាលភាពភូមិសាស្ត្រនៃបណ្តឹងមកកាន់សហចៅក្រមស៊ើបអង្កេត[777]។ អង្គជំនុំជម្រះគួរពិចារណាពីការលើកឡើងពីកង្វះភ័ស្តុតាង ដើម្បីគាំទ្រការបញ្ជូនទៅជំនុំជម្រះ (១.១.១) ហើយគួរសម្រេចថា ខ្លួនមិនមានសិទ្ធិអំណាចផ្តន្ទាទោសហួសពីបណ្តឹងជាក់ស្តែងមកកាន់ខ្លួនឡើយ (១.១.២)។

**១.១.១. កង្វះភ័ស្តុតាងដាក់បន្ទុកពាក់ព័ន្ធ នៅសំរោង និងតាភេម**

---

[776] សំអាងហេតុសាលក្រម កថាខណ្ឌ ៨០៨, ៨០៩, ១១៤១។

[777] សំអាងហេតុសាលក្រម កថាខណ្ឌ១៨០, ៨១១។ សូមមើលសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៣០-៩៣១។

៤៤៦. ពីដំបូង វិសាលភាពនៃភ័ស្តុតាងដាក់បន្ទុកពាក់ព័ន្ធដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ដើម្បីគាំទ្រដល់ការបញ្ជូនទៅជំនុំជម្រះក្តីចំពោះការស្លាប់ដោយសារភាពអត់ឃ្លាន ក្នុងស្រុកត្រាំកក់ កម្រិតត្រឹមតែអង្គហេតុដែលបានកើតឡើងនៅក្នុងឃុំសំរោង និងតាភេមប៉ុណ្ណោះ[778]។ នេះជាវិសាលភាពនៃបណ្តឹងដែលសហចៅក្រមស៊ើបអង្កេតបានទទួល។ នៅឃុំទាំងពីរនេះ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថាមានមនុស្សស្លាប់បួននាក់[779]៖ ម្នាក់មិនមានដាក់ឈ្មោះ ស្លាប់នៅក្នុងភូមិប៉ែនមាស ឃុំសំរោង[780] និងមនុស្សបី នាក់ទៀត មានឈ្មោះប៊ិន តាម៉ាក និងយាយតង ស្លាប់នៅភូមិតាស្វ ឃុំតាភេម ដែលមានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយ[781]។ ដូច្នេះ ភ័ស្តុតាងដ៏ស្តួចស្តើងនេះមិនអាចគាំទ្រដល់ការចោទប្រកាន់អំពី "ទុរភិក្សទ្រង់ទ្រាយធំ" និងអំពីការស្លាប់ "មនុស្សរាប់ពាន់នាក់" ដោយការអត់ឃ្លាននោះឡើយ[782]។ លើសពីនេះទៀត ទម្ងន់នៃភ័ស្តុតាងដាក់បន្ទុកនេះធ្លាក់មកស្មើសូន្យ បើប្រៀបធៀបវាទៅនឹងភ័ស្តុតាងដោះបន្ទុក ដែលមានចំនួនច្រើនប្រហាក់ប្រហែលគ្នា ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបានបដិសេធវាចោលដោយមិនផ្តល់សំអាងហេតុ[783]។ ដូច្នេះ អង្គហេតុទាំងនេះច្បាស់ជាមិនអាចគាំទ្រដល់ការបញ្ជូន ខៀវ សំផន ទៅជំនុំជម្រះក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោម

---

[778] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២ ចុងទំព័រ ១២៨៣ ដែលដើម្បីភ័ស្តុតាងដាក់បន្ទុក បានស្រង់សម្តីពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី សុក សុត ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៧ ឯកសារ **E3/5835** (D25/32) ERN 00163525-00163526 កំណត់ហេតុស្តាប់ចម្លើយសាក្សី សឹម ឃៀង **E3/7980** (D40/16) ទំព័រ ៣-៤ និងកំណត់ហេតុស្តាប់ចម្លើយសាក្សី សុក ស៊ឹម ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/5519** (D232/67) ERN 00408333-00408334។ ចុងទំព័រ ១២៨៤ ដែលដើម្បីភ័ស្តុតាងដាក់បន្ទុក បានស្រង់សម្តីពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី តុប ដេ ឯកសារ **E3/7982** (D40/19) ទំព័រ ២-៣ និង កំណត់ហេតុស្តាប់ចម្លើយសាក្សី នុត នូវ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ **E3/5521** (D232/70) ERN 00408300-00408302។

[779] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២។

[780] កំណត់ហេតុស្តាប់ចម្លើយសាក្សី សឹម ឃៀង ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ **E3/7980** ERN 00165301-02។

[781] កំណត់ហេតុស្តាប់ចម្លើយសាក្សី សុក ស៊ឹម ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/5519** ស/ឆ ៥ និង ៤៣។

[782] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៣។

[783] កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប ដេ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ **E3/7982** ERN 00165322-24។ (មនុស្សទី១ ជាសមាជិកសហករណ៍នៅក្នុងភូមិព្រៃក្តី ឃុំត្រពាំងធំត្បូង បាននិយាយថាមិនបានឃើញ "ប្រជាជនស្លាប់ដោយការអត់ឃ្លានទេ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី នុត នូវ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ **E3/5521** ស/ឆ ៣២, ៣៦ និង ១០០។ (មនុស្សទី២ ជាកម្មាភិបាលខ្មែរក្រហម បានរស់នៅក្នុងឃុំញ៉ែងញ៉ង រហូតដល់ឆ្នាំ១៩៧៧ បន្ទាប់មកក៏ត្រូវបានចាត់តាំងជាប្រធានឃុំស្រែរនោង។ គាត់និយាយថាមិនមានអ្នកណាស្លាប់ដោយសារអត់ឃ្លាននៅទីនោះទេ។

ទម្រង់ជាការសម្លាប់រង្គាល ហើយក៏មិនអាចជាការចោទប្រកាន់ដែល ខៀវ សំផន ត្រូវទទួលខុសត្រូវនោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងជាក់ស្តែងអំពីអង្គហេតុទាំងនេះទេ។

### ១.១.២. ការផ្តន្ទាទោសចំពោះការស្លាប់ដោយសារភាពអត់ឃ្លាន ក្នុងឃុំនៃស្រុកត្រាំកក់ នៅក្រៅបណ្តឹង

៤៤៧. អង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យអង្គហេតុនៅក្រៅបណ្តឹងជាក់ស្តែង និងពង្រីកវិសាលភាពនៃការជំនុំជម្រះដោយខុសច្បាប់ ដើម្បីបញ្ចូលការស្លាប់ដោយសារភាពអត់ឃ្លាន និងជាលក្ខណៈទូលាយ ដើម្បីបញ្ចូលអង្គហេតុដែលត្រូវបានកំណត់ប្រភេទថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការសម្លាប់រង្គាល[784]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនគួរសម្រេចថាខ្លួនមានសមត្ថកិច្ចវិនិច្ឆ័យអំពីការស្លាប់ដោយសារភាពអត់ឃ្លានដែលបានកើតឡើង នៅក្នុងសហករណ៍ទាំងអស់នៃស្រុកត្រាំកក់ឡើយ។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះលើអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ[785]។ ដោយផ្អែកលើមូលដ្ឋានខុសនេះហើយទើបអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយកែប្រែអង្គហេតុទាំងនេះទៅជាអំពើមនុស្សឃាតដោយចេតនាប្រយោលចំពោះការស្លាប់ដោយសារស្ថានភាពរស់នៅ និងការងារ[786]។ អាស្រ័យហេតុនេះ តុលាការកំពូលត្រូវតែសម្រេចថា អង្គជំនុំជម្រះមិនមានយុត្តាធិការក្នុងការជំនុំជម្រះអង្គហេតុទាំងនេះ និងបដិសេធសេចក្តីសន្និដ្ឋានរបស់សាលាដំបូង ដែលបានចាត់ទុកអង្គហេតុទាំងនេះជាធាតុផ្សំសត្យានុម័តិនៃបទឧក្រិដ្ឋមនុស្សឃាត[787] ក៏ដូចជាបដិសេធការសម្រេចពីពិរុទ្ធភាព និងការផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខ[788]។

### ១.២. គ្មានបណ្តឹងអំពី "ការប្រព្រឹត្តិរើសអើង" លើប្រជាជនថ្មី

[784] សំអាងហេតុសាលក្រម កថាខណ្ឌ ៨០៨-៨០៩, ៨១១, ១១៤១។

[785] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២-១១៤៦។

[786] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥។

[787] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥។

[788] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៨-៤៣២៨, ៤៤០០, ៤៤០២។

៤៤៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យអង្គហេតុទាក់ទងទៅនឹង "ការប្រព្រឹត្តិរើសអើង" ប្រឆាំងនឹងប្រជាជននៅក្នុងសហករណ៍នានា ក្នុងស្រុកត្រាំកក់[789]។ អង្គជំនុំជម្រះបានបដិសេធ ដោយអត្តនោម័តិ និងមិនត្រឹមត្រូវ ដោយគ្រាន់តែលើកឡើងពី"ការគ្មានសូចនាករច្បាស់លាស់" នូវទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលយល់ឃើញថា ភ័ស្តុតាងដាក់បន្ទុកខ្សោយខ្លាំងពេក មិនអាចជាមូលដ្ឋាននៃការបញ្ជូនទៅជំនុំជម្រះ ចំពោះអង្គហេតុហេតុនៃការលុបបំបាត់ "សិទ្ធិនយោបាយ" របស់ប្រជាជនថ្មី ដែលត្រូវបានកំណត់ប្រភេទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[790]។ អង្គជំនុំជម្រះគួរពិចារណាពីការលើកឡើងពីកង្វះភ័ស្តុតាង ដើម្បីគាំទ្រការបញ្ជូនរឿងទៅជំនុំជម្រះ (១) ហើយគួរកត់សម្គាល់ថា ខ្លួនមិនមានសិទ្ធិអំណាចផ្តន្ទាទោសហួសពីបណ្តឹងជាក់ស្តែងនោះទេ (២)។

### ១.២.១. គ្មានភ័ស្តុតាងគាំទ្រអង្គហេតុនៃការដកហូត "សិទ្ធិនយោបាយ" ពីប្រជាជនថ្មី

៤៤៩. ការបកស្រាយពីវិសាលភាពនៃបណ្តឹងនៅក្នុងដីកាដំណោះស្រាយ ដែលកម្រិតមកត្រឹមការចោទប្រកាន់ពាក់ព័ន្ធនឹងការដកហូត "សិទ្ធិនយោបាយ" ពីប្រជាជនថ្មី ដែលមានចែងនៅកថាខណ្ឌ ៣០៥ មិនមានសុពលភាពទេ។ ជាក់ស្តែង ភ័ស្តុតាងដែលគាំទ្រដល់ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត មិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីគាំទ្រការចោទប្រកាន់នេះឡើយ។ ជាក់ស្តែង សម្រង់ដកចេញពីកំណត់ហេតុសម្ភាប់ចម្លើយរបស់ ភ្លៅ យ៉ាវ និង ពិល យាង ដែលជាប្រជាជនមូលដ្ឋាននៅឃុំសំរោង មិនគាំទ្រដល់ការសន្និដ្ឋាននៅកថាខណ្ឌ ៣០៥ របស់សហចៅក្រមស៊ើបអង្កេតឡើយ។ ភ្លៅ យ៉ាវ មិនបាននិយាយអ្វីទាំងអស់ អំពីការហាមឃាត់ប្រជាជនថ្មីមិនឱ្យដាក់ពាក្យសុំធ្វើជាប្រធានកងនៅតាមសហករណ៍[791]។ មានតែ ពិល យាង តែប៉ុណ្ណោះ ដែលបាននិយាយថាប្រជាជនថ្មី "មិនមានសិទ្ធិក្លាយជាប្រធានកង ឬប្រធានភូមិ"[792]។ ភ័ស្តុតាងនេះឯកោ ហើយខ្សោយដោយមិនអាចប្រកែកបាន។ ដូច្នេះ

---

[789] សំអាងហេតុសាលក្រម កថាខណ្ឌ១៨០, ៨១៣, ១១៦៩, ១១៧១។

[790] សំអាងហេតុសាលក្រម កថាខណ្ឌ១៨០, ៨១៣។ សូមមើលសារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ៩៤២-៩៤៨។

[791] កំណត់ហេតុស្តាប់ចម្លើយសាក្សី ភ្លៅ យ៉ាវ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E3/5515 ស/ឆ ១៣។

[792] កំណត់ហេតុស្តាប់ចម្លើយសាក្សី ពិល យៀង ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ E3/5135 ERN 00165295-96។

ការសន្និដ្ឋាននៅកថាខណ្ឌ ៣០៥ ត្រូវបានគាំទ្រដោយភស្តុតាងដាក់បន្ទុកតែមួយគត់ ហើយដែលកម្រិតមកត្រឹមតែឃុំមួយនៃស្រុកត្រាំកក់ប៉ុណ្ណោះ។ ភស្តុតាងនេះមិនគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងប្រជាជនថ្មី នៅត្រាំកក់នោះទេ[793]។ ដោយឈរតែលើមូលដ្ឋាននេះ ម្ចាស់បណ្តឹងសាទុក្ខមិនចាំបាច់ទទួលខុសត្រូវចំពោះអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុនយោបាយទាំងនេះទេ។

### ១.២.២. ការផ្តន្ទាទោសចំពោះ "ការប្រព្រឹត្តិរើសអើង" លើប្រជាជនថ្មី នៅក្រៅបណ្តឹង

៩៥០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងដោយត្រឹមត្រូវតាមច្បាប់ ទោះបីជាមានភស្តុតាងចាំបាច់មិនគ្រប់គ្រាន់យ៉ាងជាក់ស្តែង ដើម្បីបញ្ជូនរឿងទៅជំនុំជម្រះឱ្យត្រឹមត្រូវតាមច្បាប់ក៏ដោយ[794]។ កំហុសនេះបាននាំឱ្យអង្គជំនុំជម្រះកាត់ក្តី ខៀវ សំផន ចំពោះអង្គហេតុដែលត្រូវបានកំណត់ប្រភេទថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ លើប្រជាជនថ្មីដែល ខៀវ សំផន មិនចាំបាច់ទទួលខុសត្រូវឡើយ[795]។ ដូច្នេះ តុលាការកំពូលត្រូវធ្វើមោឃភាពចំពោះការសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដែលថា "កម្មាភិបាលខ្លះត្រូវបានជ្រើសរើសចេញពីចំណោមប្រជាជនមូលដ្ឋានទាំងស្រុង" និងថាការរើសអើងប្រឆាំងនឹងប្រជាជនថ្មីជាបញ្ហាសិទ្ធិនយោបាយ ឬបញ្ហាលទ្ធភាពរបស់ប្រជាជនថ្មីក្នុងការចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេច នៅក្នុងសហករណ៍ ឬអង្គភាពការងារ" នៅក្នុងចំណោមបញ្ហាដទៃៗទៀត[796]។ ដូចគ្នាដែរ តុលាការកំពូលត្រូវធ្វើមោឃភាពចំពោះការសន្និដ្ឋានថា អំពើទាំងនេះដែលត្រូវយកមកពិចារណាក្នុងបរិបទ និងភ្ជាប់ជាមួយអំពើដទៃទៀតដែលបង្កើតបានជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ឱ្យក្លាយជាទាសករ និងជាអំពើអមនុស្សធម៌ផ្សេងៗទៀត និងសក្ខីកម្មពាក់ព័ន្ធនឹងការចាប់ខ្លួន និងអំពើមនុស្សឃាត បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅលើ

[793] ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥ និងកំណត់ចុងទំព័រ ១២៩៥ ដែលស្រង់ស្តីពីក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ភ្មៅ យ៉ារ ឯកសារ **E3/5515** (D232/62) ERN 00402457-58 និង ពិល ឃៀង ឯកសារ **E3/5135** (D40/15) ទំព័រ ៣-៩។

[794] សំអាងហេតុសាលក្រម កថាខណ្ឌ១៨០, ៨១៣, ១១៦៩, ១១៧១។

[795] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៦-១១៧៩, ៣៩២៥។

[796] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧។

ប្រជាជនថ្មី[797]។ អាស្រ័យហេតុនេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយដែលកំណត់ថាមានចរិត "ឧក្រិដ្ឋ" ត្រូវតែបដិសេធចោល[798] រួមទាំងការផ្តន្ទាទោស ខៀវ សំផន ក្រោមសហឧក្រិដ្ឋកម្មរួម ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅលើប្រជាជនថ្មីនៅត្រាំកក់[799]។

## ២. គ្មានបណ្តឹងអំពីអង្គហេតុនៃការឃ្លាំមើល និងការបាត់ខ្លួនអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៤៥១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់ និងមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យអង្គហេតុទាក់ទងទៅនឹង "ការប្រព្រឹត្តិរើសអើង"ប្រឆាំងនឹងអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលបានកើតឡើងនៅក្នុងសហករណ៍នៃស្រុកត្រាំកក់[800]។ អង្គជំនុំជម្រះបានបដិសេធ ដោយអត្តនោម័តិមិនត្រឹមត្រូវ ដោយគ្រាន់តែលើកឡើងថា "ពុំមានសូចនាករច្បាស់លាស់" ចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលយល់ឃើញថាភ័ស្តុតាងដាក់បន្ទុកខ្សោយខ្លាំងពេក មិនអាចជាមូលដ្ឋាននៃការបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះអង្គហេតុនៃការឃ្លាំមើលអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវបានកំណត់ប្រភេទថាជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ[801]។ ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មទាំងអស់ដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ ដែលជាកថាខណ្ឌរួមស្តីពីការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទីតាំងនានាដែលឧក្រិដ្ឋកម្មប្រហែលជាត្រូវបានប្រព្រឹត្តប្រឆាំងនឹងអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មិនត្រូវបានបែងចែកឱ្យដាច់ពីទីតាំងដែលកំណត់ជាគោលដៅនូវក្រុមជាក់លាក់មួយ

---

[797] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៨-១១៧៩។

[798] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២៤-៣៩២៥, ៣៩២៨។

[799] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[800] សំអាងហេតុសាលក្រម កថាខណ្ឌ១៨០, ៨១២, ១១៧២។

[801] សំអាងហេតុសាលក្រម កថាខណ្ឌ១៨០, ៨១២, ១១៧២។ សូមមើលសារណាបណ្តឹងសាទុក្ខ ០០២/០២ កថាខណ្ឌ ២២៦៥, ២២៦៧, ២២៨៣-២២៨៧។

ក្នុងចំណោមក្រុមផ្សេងៗទៀតដែលមានរៀបរាប់នៅកថាខណ្ឌ ១៤១៧។ អង្គហេតុទាក់ទងនឹងអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានរៀបរាប់ក្នុងឃ្លាចំនួនបីនៃកថាខណ្ឌ ៣១៩ នៃដីកាដំណោះស្រាយ ("សហករណ៍ត្រាំកក់") និងនៅក្នុងការរៀបរាប់លម្អិតនៅកថាខណ្ឌ ៤៩៨ ("មន្ទីរសន្តិសុខក្រាំងតាចាន់")។ អង្គជំនុំជម្រះគួរពិចារណាពីកង្វះភ័ស្តុតាង ដើម្បីគាំទ្រការបញ្ជូនទៅជំនុំជម្រះ (២.១) និងកត់សម្គាល់ថាខ្លួនមិនមានសិទ្ធិអំណាចផ្តន្ទាទោសហួសពីបណ្តឹងជាក់ស្តែងនោះទេ (២.២)។ ដូច្នេះ ការផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវទុកជាមោឃៈ (២.៣)។

### ២.១. គ្មានភ័ស្តុតាងគាំទ្រការចោទប្រកាន់ពីការឃ្លាំមើលអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងកថាខណ្ឌ ៣១៩

៤៥២. អង្គជំនុំជម្រះបានច្រានចោលដោយមិនត្រឹមត្រូវ នូវទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា ការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតនៅកថាខណ្ឌ ៣១៩ នៃដីកាដំណោះស្រាយ ដែលថា អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបាន "ឃ្លាំមើលយ៉ាងតឹងរ៉ឹង" មិនមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជូន ខៀវ សំផន ទៅជំនុំជម្រះ ចំពោះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[802]។ ជាក់ស្តែងនៅកថាខណ្ឌ ៣១៩ នៃដីកាដំណោះស្រាយ មានរៀបរាប់ដូចតទៅនេះ៖

> "អតីតទាហាន និងប៉ូលីសនៃរបប លន់ នល់ ជាពិសេសអ្នកមានតំណែងជាមន្ត្រីត្រូវបានគេពិនិត្យមើលយ៉ាងតឹងតែង"។ បញ្ជីឈ្មោះអតីតទាហាន លន់ នល់ ដែលបានមកដល់ឃុំ ត្រូវបានគេរៀបចំ និងបញ្ជូនទៅស្រុក។ ឧទាហរណ៍ ឯកសារផ្ញើរចេញពីស្រុក ១០៥ ទៅឃុំញ៉ែងញ៉ង បានកត់ត្រាឈ្មោះអតីតទាហាន ១១ រូប ដែលត្រូវបានបញ្ជូនទៅឃុំនេះ"។

[802] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧២។

៥៥៣. ក៏ប៉ុន្តែ ភស្តុតាងគាំទ្រដល់កថាខណ្ឌ ៣១៩ ស្តីពីការប្រព្រឹត្តិលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានលក្ខណៈខ្សោយមិនដល់កម្រិតតម្រូវ ដើម្បីផ្តល់យុត្តិកម្មដល់ការបញ្ជូនទៅជំនុំជម្រះ។ ជាបឋម ការឃ្លាំមើលតាមសន្មតទៅលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មិនត្រូវបានគាំទ្រដោយភស្តុតាងណាមួយឡើយ។ លើសពីនេះទៀត សេចក្តីសន្និដ្ឋានថាមានការធ្វើបញ្ជីឈ្មោះមន្ត្រី លន់ នល់ នៅតាមឃុំ បន្ទាប់មកបញ្ជូនទៅកាន់ស្រុកនេះ បានលើកភស្តុតាងគាំទ្រតែមួយប៉ុណ្ណោះ ដែលជាឧទាហរណ៍គំរូមួយនៃការអនុវត្តទាំងនេះ។ ពិតមែនតែរបាយការណ៍ចុះបញ្ជីឈ្មោះមានសរសេរឈ្មោះមន្ត្រី និងឃុំដែលគាត់ស្នាក់នៅ ក៏ប៉ុន្តែ របាយការណ៍នេះមិនបង្ហាញអ្វីទាំងអស់អំពីអ្នកទទួលព័ត៌មាននេះ។ ក្នុងល័ក្ខខ័ណ្ឌនេះ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងជាក់ស្តែងអំពីអង្គហេតុដែលត្រូវបានកំណត់ប្រភេទថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ឡើយ។

## ២.២. គ្មានភស្តុតាងគាំទ្រអង្គហេតុនៃការបាត់ខ្លួនរបស់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ក្នុងកថាខណ្ឌ ៤៩៨

៥៥៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងអំពីអង្គហេតុនៃការបាត់ខ្លួនរបស់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[803]។ យោងតាមការបកស្រាយលំៗនៃកថាខណ្ឌ ៤៩៨ នៃដីកាដំណោះស្រាយ ខៀវ សំផន ត្រូវទទួលខុសត្រូវចំពោះអង្គហេតុនៃការបាត់ខ្លួនដែលត្រូវបានចោទប្រកាន់ទាំងនេះ។ ក៏ប៉ុន្តែ ភស្តុតាងគាំទ្រការចោទប្រកាន់នេះ មានភាពមិនស្របច្បាប់ជាច្រើន ហើយមិនអាចអនុញ្ញាតឱ្យបញ្ជូនទៅជំនុំជម្រះចំពោះអង្គហេតុនៃការបាត់ខ្លួនរបស់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ បានឡើយ។ អង្គហេតុដែលបានលើកឡើងមិនត្រូវបានគាំទ្រដោយភស្តុតាងណាមួយទាល់តែសោះ ពីព្រោះសហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ប្រភពព័ត៌មាន

[803] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧២។

ណាមួយឡើយ[804]។ ម្ចាស់បណ្តឹងសាទុក្ខមិនចាំបាច់ទទួលខុសត្រូវចំពោះការចោទប្រកាន់គ្មានមូលដ្ឋាននេះឡើយ។

៤៥៥. ផ្ទុយពីអ្វីដែលត្រូវបានប្រកាសនៅពេលក្រោយ[805] ការចោទប្រកាន់នេះត្រូវបានបញ្ជាក់ដោយមនុស្សតែម្នាក់គត់ គឺ អៀប ឌុច ដែលត្រូវបានស្តាប់យកចម្លើយដោយអ្នកស៊ើបអង្កេត ក្នុងអំឡុងពេលនៃការស៊ើបអង្កេត និងមិនដែលបានអះអាងថាមនុស្សបានបាត់ខ្លួននោះទេ តែគាត់គ្រាន់តែបាននិយាយថា "ច្បាស់ជាបាត់ខ្លួន" ដោយហេតុមិនទាន់មានការស្វែងរកណាមួយទៅតាមតាមសក្ខីកម្មរបស់គាត់នៅឡើយ[806]។ ដូចគ្នានេះដែរ សេចក្តីសន្និដ្ឋានបន្ទាប់របស់សហចៅក្រមស៊ើបអង្កេតលើការបាត់ខ្លួនជាសន្ទុតរបស់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[807] មិនត្រូវបានគាំទ្រដោយ ប៊ុន ធៀន ទេ ដោយហេតុថាគាត់មិនដែលរស់នៅស្រុកត្រាំកក់ ប៉ុន្តែនៅក្នុងស្រុកទ្រាំង[808]។ ការសន្និដ្ឋានបន្ទាប់ទៀតរបស់សហចៅក្រមស៊ើបអង្កេតដែលថា "បញ្ជីអ្នកទោសក្រាំងតាចាន់ ក៏ដូចជាកំណើននៃចំនួនអ្នកជាប់ឃុំបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ បង្ហាញថា អ្នកបាត់ខ្លួនមួយចំនួនធំត្រូវបានបញ្ជូនទៅក្រាំងតាចាន់" មានសារៈសំខាន់ណាស់ ពីព្រោះវាមិនផ្អែកលើបញ្ជីឈ្មោះអ្នកទោសណាមួយទាល់តែសោះ ប៉ុន្តែបែរជា

---

[804] ពីព្រោះថា បើតាមឃ្លាទាំងពីរនៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨៖ "អ្នករស់នៅស្រុកត្រាំកក់បានបំភ្លឺថា មុនពេលដែលអ្នកត្រូវបានជម្លៀសមកពីភ្នំពេញមកដល់ក្នុងតំបន់នេះ លេខាស្រុក និងឃុំ បានចូលរួមអង្គប្រជុំ ដោយពួកគេត្រូវបានណែនាំថា នឹងមានការសម្រិតសម្រាំងក្នុងចំណោម អ្នកដែលត្រូវបានគេជម្លៀស។ ជនណាមួយធ្លាប់ជាពលបាលទោ ឬខ្ពស់ជាងនេះ ក្នុងរបបលន់ នល់ ហើយអ្នកណាធ្លាប់បម្រើឱ្យរដ្ឋការលន់ នល់ ក្នុងឋានៈជាអនុប្រធានទីមួយ ឬខ្ពស់ជាងនេះ នឹងត្រូវបានសម្រិតសម្រាំង"។

[805] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨៖ "ហេតុការណ៍នេះត្រូវបានបញ្ជាក់បន្ថែមដោយសាក្សីបីរូប រួមទាំងអតីតប្រធានយុវជនស្រុកថា នៅពេលដែល"ប្រជាជនថ្មី"មកដល់ត្រាំកក់ ពួកគេត្រូវបានបង្ខំឱ្យធ្វើប្រវត្តិរូបហើយថា អ្នកដែលប្រាប់ថាខ្លួនជាទាហាននឹងត្រូវបានបាត់ខ្លួនបន្ទាប់មក"។

[806] កំណត់ហេតុស្តាប់ចម្លើយសាក្សី អៀប ឌុច ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ឯកសារ **E3/4627** ERN 00163493-94។

[807] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨៖ "សមាជិកគណៈកម្មាធិការឃុំម្នាក់ក្នុងឃុំត្រាំកក់បញ្ជាក់ថា លេខាឃុំ បានបញ្ជាឱ្យប្រមូលអ្នកជម្លៀសទាំងអស់ដែលមានឋានៈពីស័ក្តិមួយឡើងទៅ។ នៅពេលប្រមូលផ្តុំរួច ថ្នាក់លើបានបញ្ជូនឡានមកដឹកចេញទៅ។ ប្រជាជនទាំងនោះបាត់ខ្លួនជារៀងរហូត"។ គួរកត់សម្គាល់ផងដែរថា ឃ្លាមួយទៀតនៅក្នុងកថាខណ្ឌ ៤៩៨ នេះមិនមានបទចោទលើការរើសអើងឡើយ។

[808] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ **E3/5498** ERN 00368598-00368600 និង 00368605។

ផ្អែកលើពាក្យសម្ដីរបស់ ពេជ្រ ជឹម និង ផាន ឆេន ដែលមិនបាននិយាយអ្វីទាំងអស់អំពីការអះអាងរបស់សហចៅក្រមស៊ើបអង្កេត[809]។

៤៥៦. បន្ទាប់មកទៀត សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា "របាយការណ៍ជាច្រើន ពីឃុំទៅស្រុកក្នុងឆ្នាំ១៩៧៧បង្ហាញថា ការបោសសម្អាតអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅតែបន្តក្រោយឆ្នាំ១៩៧៥"[810]។ បើទោះជាការសន្និដ្ឋាននេះហាក់ដូចជាគាំទ្រដោយភស្តុតាងមួយចំនួនដែលស៊ីចង្វាក់គ្នាទៅនឹងការអះអាងរបស់ខ្លួនក៏ដោយ ក៏ប៉ុន្តែភស្តុតាងទាំងនេះពាក់ព័ន្ធនឹងព្រឹត្តិការណ៍ជាច្រើនដែលបានកើតឡើងនៅឃុំនៃស្រុកត្រាំកក់ ដែលសហចៅក្រមស៊ើបអង្កេតមិនបានទទួលបន្ទុលឱ្យស៊ើបទេ[811]។ ដូច្នេះ អង្គជំនុំជម្រះមិនបានទទួលបណ្ដឹងដោយត្រឹមត្រូវតាមច្បាប់ ហើយ ខៀវ សំផន មិនចាំបាច់ទទួលខុសត្រូវចំពោះអង្គហេតុទាំងនេះឡើយ។

## ២.៣. ការផ្ដន្ទាទោសចំពោះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្រៅបណ្ដឹង

៤៥៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យទៅលើអង្គហេតុនៃការឃ្លាំមើល និងការបាត់ខ្លួនទៅលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រោមបទចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលជាអង្គហេតុនៅក្រៅបណ្ដឹងជាក់ស្ដែង[812]។ អង្គជំនុំជម្រះពុំមានយុត្តាធិការ ដើម្បីកំណត់ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[813]។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវតែទុកជាមោឃៈ។ ដូច្នេះ សេចក្ដី

---

[809] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨ កំណត់ចុងទំព័រ ២១៥៩។

[810] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨។

[811] ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨ កំណត់ចុងទំព័រ ២១៦០។ ជាឧទាហរណ៍ សូមមើលឯកសារ **E3/2048** (RI18.33) ERN 00079087 (របាយការណ៍ឃុំពពេល)។ ERN 00079088 (របាយការណ៍ឃុំជាងទង)។ ERN 00079089 (របាយការណ៍ឃុំពពេល)។

[812] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៥, ១១៧៧-១១៧៩។

[813] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៥, ១១៧៧-១១៧៩, ៣៩២៤-៣៩២៥។

សន្និដ្ឋានរបស់អង្គជំនុំជម្រះដែលបញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយ "ឧក្រិដ្ឋ" ត្រូវតែទុកជាមោឃៈ[814] ដូចជា ការផ្តន្ទាទោសម្ចាស់បណ្តឹងពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ក្រោមបទសហឧក្រិដ្ឋកម្មរួម[815]។

## មាតិកាទី ៣. កំហុសអង្គហេតុសំខាន់ៗមួយចំនួនដែលត្រូវបានកំណត់ជាបទចោទ

៤៥៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមិនអើពើចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលលើកឡើងថា អង្គជំនុំជម្រះមិនអាចវិនិច្ឆ័យអង្គហេតុ ដែលមិនត្រូវបានជ្រើសរើស និងដែលមិនត្រូវបានកំណត់ជាបទចោទ ដោយសហចៅក្រមស៊ើបអង្កេតឡើយ (ជំពូកទី ១)។ កំហុសនេះបាននាំឱ្យអង្គជំនុំជម្រះបំពានលើវិសាលភាពនៃបណ្តឹងមកកាន់ខ្លួន ពាក់ព័ន្ធនឹងអង្គហេតុជាច្រើន (ជំពូកទី ២)។

### ជំពូកទី ១. អង្គច្បាប់

៤៥៩. យោងតាមវិធានផ្ទៃក្នុង ដីកាដំណោះស្រាយបង្ហាញពីអត្តសញ្ញាណរបស់ជនជាប់ចោទ អង្គហេតុរងការចោទប្រកាន់ និងការកំណត់បទចោទដោយសហចៅក្រមស៊ើបអង្កេត រួមទាំងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ (វិធាន ៦៧(២))។ ដីកាដំណោះស្រាយត្រូវមានសំអាងហេតុ ហើយអាចជាការបញ្ជូនទៅជំនុំជម្រះសម្រាប់អង្គហេតុមួយចំនួន ឬអាចជាការលើកលែងការចោទប្រកាន់ចំពោះអង្គហេតុផ្សេងទៀត (វិធាន ៦៧(៤))។

៤៦០. ដូចដែលមេធាវីការពារក្តីបានលើកឡើង នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ និងពីខាងលើរួចមកហើយ[816] ការកំណត់អំពីវិសាលភាពនៃការ

[814] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២៤-៣៩២៥, ៣៩២៨។

[815] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[816] ដើម្បីចៀសវាងលើកឡើងដដែលៗ មេធាវីការពារក្តីសូមយោងចំណុចនេះទៅ៖ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៦, ៦៨, ៧៧-៩៧, ខាងលើ កថាខណ្ឌ ៣៥១-៣៦៦។

ចោទប្រកាន់ (អង្គហេតុសត្យានុម័តិដែលចោទប្រកាន់ លើជនជាប់ចោទជាមួយនឹងការកំណត់ប្រភេទបទល្មើសចំពោះអង្គហេតុទាំងនោះ) ពោលគឺការជំនុំជម្រះផ្ទាល់តែម្តង មិនអាច និងមិនត្រូវដឹកមុខតែមួយមុខដោយការកំណត់ប្រភេទបទល្មើសលើអង្គហេតុដែលត្រូវបានចោទប្រកាន់ឡើយ។ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យវិនិច្ឆ័យតែលើអង្គហេតុ ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតជ្រើសរើសតែប៉ុណ្ណោះ និងដែលអាចដាក់ជនជាប់ចោទឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ។ អង្គជំនុំជម្រះមិនត្រូវបានស្នើសុំឱ្យវិនិច្ឆ័យលើអង្គហេតុផ្សេងទៀត ដែលបានលើកឡើងក្នុងដីកាដំណោះស្រាយ ឬលើការកំណត់បទចោទដែលគ្មានទំនាក់ទំនងជាមួយអង្គហេតុ។ អង្គជំនុំជម្រះក៏មិនត្រូវបានស្នើឱ្យពិនិត្យលើអង្គហេតុដែលត្រូវបានបង្ហាញនៅក្នុងភស្តុតាងគាំទ្រដីកាដំណោះស្រាយនោះដែរ[817]។

៤៦១. ដូច្នេះ គេមិនត្រូវពិនិត្យដីកាដំណោះស្រាយ "ទាំងមូល" ដ៏ក្រាស់ឃ្មឹកនោះជាដាច់ខាត[818] ព្រោះថាសហចៅក្រមស៊ើបអង្កេតបានដាក់បញ្ចូលក្នុងដីកាដំណោះស្រាយនូវខ្លឹមសារថា៖

> "ប្រហែលជាមិនចាំបាច់នោះទេ តែវាទំនងជាសំខាន់ ក្នុងករណីដែលដីកាដំណោះស្រាយនឹងស្ថិតនៅជាដានតែមួយគត់ដែលបន្សល់ទុកដោយតុលាការមួយនេះ ទាក់ទងនឹងអ្វីដែលបានកើតឡើងនៅកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"[819]។

៤៦២. ម្យ៉ាងទៀត ក្នុងឋានៈជាឧបករណ៍ចោទប្រកាន់ ដីកាដំណោះស្រាយត្រូវបង្ហាញ "ឱ្យបានពិស្តារនូវអង្គហេតុចោទប្រកាន់សំខាន់ៗ ដែលជាមូលដ្ឋាននៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ដើម្បីឱ្យគេអាចដឹងបានច្បាស់នូវអ្វីដែលខ្លួនគេត្រូវបានចោទប្រកាន់ ហើយដើម្បីឱ្យគេអាចការពារខ្លួនបានប្រកប

---

817 ទាក់ទងនឹងចំណុចចុងក្រោយនេះ សូមមើលផងដែរ៖ សាលដីកា *Đorđevic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ៣៣១៖ "ដូច្នេះ វាគួរតែចែកឱ្យដាច់ពីគ្នារវាងអង្គហេតុសំខាន់ៗដែលរដ្ឋអាជ្ញាយកធ្វើជាមូលដ្ឋាន ហើយដែលគួរត្រូវបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាមួយនឹងភស្តុតាងទាំងឡាយដែលបានបង្ហាញដើម្បីគាំទ្រ"។

818 សំអាងហេតុសាលក្រម កថាខណ្ឌ ១៧៣។

819 សេចក្តីដកស្រង់ចេញពីសៀវភៅលោក Marcel LEMONDE មានចំណងជើងថា "*Un juge face aux Khmers Rouges*" បោះផ្សាយក្នុងខែមករា ឆ្នាំ ២០១៣ ទំព័រ ២០២ [ភាសាបារាំង] ឯកសារ **E280.12**។

ដោយប្រសិទ្ធភាព"[820]។ បើមិនដូច្នោះទេ ដីកាដំណោះស្រាយនោះនឹងមាន "កំហុសធ្ងន់ធ្ងរ"[821]។ អង្គហេតុមួយសំខាន់មួយដែលត្រូវពិពណ៌នាឱ្យបានជាក់លាក់គ្រប់គ្រាន់ដើម្បីជូនដំណឹងដល់ជនជាប់ចោទ គឺជាអង្គហេតុដែលសេចក្តីសម្រេចចុងក្រោយ "ត្រូវសំអាងលើយ៉ាងស្និតរមួត"[822]។

៤៦៣. បទចោទទាំងឡាយដែលមានលក្ខណៈទូលំទូលាយ (ដូចជាបទចោទពីការធ្វើទុក្ខបុកម្នេញជាដើម) មិនអាចត្រូវបានប្រើប្រាស់ធ្វើជាបទចោទ "ទទើសទទែង" បាននោះទេ។ យោងតាមគោលការណ៍បឋមសម្រាប់គ្រប់គ្រងការរៀបរាប់ពីបទចោទ គឺវាមិនគ្រប់គ្រាន់ទេ ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះពិពណ៌នាពីឧក្រិដ្ឋកម្មមួយក្នុងពាក្យពេចន៍បែបទូទៅនោះ។ វាត្រូវតែមានសេចក្តីលម្អិត និងបញ្ជាក់ឱ្យ

---

[820] សេចក្តីសម្រេចចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E122** កថាខណ្ឌ ១៨ យោងទៅសាលដីកា *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ៨៨។ សូមមើលផងដែរ៖ សាលដីកា *Kanyarukiga* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៧៣ ("ការចោទប្រកាន់ និងអង្គហេតុសំខាន់ៗដែលជាមូលដ្ឋាន ត្រូវតែបង្ហាញឱ្យបានច្បាស់លាស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជនជាប់ចោទត្រូវបានជូនដំណឹងពីបទចោទប្រកាន់ប្រឆាំងនឹងរូបគេ")។

[821] សេចក្តីសម្រេចចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E122** កថាខណ្ឌ ១៩ យោងទៅរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Pavković *និងអ្នកផ្សេងទៀត* សំណុំរឿង IT-03-70-PT សេចក្តីសម្រេចលើអញ្ញត្រកម្មលើកឡើងដោយ Vladimir Lazarević ដោយសារមានកំហុសផ្នែកទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ ៦។ សូមមើលផងដែរ៖ សាលដីកា *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ១១៤ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាឧបករណ៍ចោទប្រកាន់យ៉ាងសំខាន់ ត្រូវតែបង្ហាញឱ្យបានលម្អិតអំពីចំណុចសំខាន់ៗនៃទឡ្ហីករណ៍របស់រដ្ឋអាជ្ញា ហើយបើមិនដូច្នោះទេ ដីកានោះនឹងមានកំហុសធ្ងន់ធ្ងរ។ ក្នុងកាលៈទេសៈខ្លះ គ្រាន់តែដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយដែលមានកំហុស គឺវាគ្រប់គ្រាន់ធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើមោឃៈភាពលើសេចក្តីប្រកាសស្តីពីពិរុទ្ធភាពបាន"), សាលដីកា *Kanyarukiga* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌ ៧៣ ("កំហុសកើតមានលើរាល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះណាដែលមិនបានរៀបរាប់ឱ្យបានត្រឹមត្រូវនូវអង្គហេតុសំខាន់ៗដែលជាមូលដ្ឋាននៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ")។

[822] សាលដីកា *Haradinaj និងអ្នកផ្សេងទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣១២ ដែលយោងទៅ សាលដីកា *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ៩៩ និងកថាខណ្ឌ ១០៥។

បានច្បាស់អំពីទិដ្ឋភាពសំខាន់ៗនៃចរិតឧក្រិដ្ឋ ហើយបើមិនដូច្នោះទេ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងមិនមានភាពច្បាស់លាស់ដែលអាចទទួលយកបានឡើយ[823]។

៤៦៤. ប្រសិនបើអង្គជំនុំជម្រះអនុវត្តបានយ៉ាងត្រឹមត្រូវ នូវគោលការណ៍គតិយុត្តិទាំងអស់នេះ អង្គជំនុំជម្រះនឹងមិនសម្រេចសេចក្ដីលើអង្គហេតុនៅក្រៅបណ្ដឹងជាក់ស្ដែងនោះទេ ហើយអង្គជំនុំជម្រះនឹងកត់សម្គាល់ថា ដីកាដំណោះស្រាយមានកំហុសធ្ងន់ធ្ងរជាច្រើន ដែលនឹងរារាំងអង្គជំនុំជម្រះមិនឱ្យផ្ដន្ទាទោស ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មមួយចំនួន។

**ជំពូកទី ២. កំហុស និងផលវិបាកសម្រាប់ទីតាំងឧក្រិដ្ឋកម្មនីមួយៗ**

**ផ្នែកទី ១. ត្រាំកក់**

**១. គ្មានបណ្ដឹងពីការស្លាប់បណ្ដាលមកពីបញ្ហាសុខភាព និងលក្ខខណ្ឌរស់នៅ**

៤៦៥. ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមរូបភាពសម្លាប់រង្គាល ចំពោះអង្គហេតុដែលកើតឡើងនៅសហករណ៍ត្រាំកក់ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា ខ្លួនទទួលបានបណ្ដឹងជាក់ស្ដែងអំពីការស្លាប់មនុស្ស ក្រៅពីការស្លាប់ដោយសារការអត់អាហារ ដើម្បីបញ្ចូលអង្គហេតុទាក់ទងនឹង "លក្ខខណ្ឌអាក្រក់នៃការស្នាក់នៅ និងអនាម័យ កង្វះសេវាថែទាំវេជ្ជសាស្ត្រ រួមទាំងកត្តាផ្សេងទៀតដែលជនរងគ្រោះត្រូវបានតម្រូវឱ្យធ្វើការងារយ៉ាងលំបាក"[824]។

**១.១. គ្មានការស្លាប់ណាមួយបណ្ដាលមកពីលក្ខខណ្ឌរស់នៅជាទូទៅ ក្រៅពីការស្លាប់បណ្ដាលមកពីការអត់អាហារ នៅត្រាំកក់**

[823] សាលដីកា *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ កថាខណ្ឌ ៩៨។

[824] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១, ១១៣៨-១១៣៩, ១១៤១។

៤៦៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ នៅក្នុងការបកស្រាយលើកថាខណ្ឌ ១៣៨៧ នៃដីកាដំណោះស្រាយ ដោយបានចាត់ទុកកថាខណ្ឌនេះ ថាជាមូលដ្ឋានមួយមានសុពលភាពសម្រាប់ការពិនិត្យលើបណ្តឹងមកកាន់ខ្លួន ចំពោះការចោទប្រកាន់ពីបទសម្លាប់រង្គាល ទាក់ទងនឹងអង្គហេតុមួយចំនួនក្រៅពីការបង្អត់អាហារ និងជាមូលដ្ឋានមួយគ្រប់គ្រាន់ដើម្បីបញ្ចូលទៅក្នុងនោះ នូវល័ក្ខខ័ណ្ឌរស់នៅ[825]។ កថាខណ្ឌ ១៣៨១ និង ១៣៨៧ នៃដីកាដំណោះស្រាយ បានកំណត់បទចោទប្រកាន់ចំពោះអង្គហេតុលម្អិតនៅក្នុងផ្នែក "ការពិពណ៌នាអំពីអង្គហេតុ" ដែលពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ ត្រង់កថាខណ្ឌ ៣០២-៣២១។ អង្គជំនុំជម្រះមិនអាចគេចវេសមិនពិនិត្យកថាខណ្ឌទាំងអស់នេះ ដើម្បីកំណត់វិសាលភាពនៃអង្គហេតុទាំងឡាយដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាលបានឡើយ[826]។

៤៦៧. ក៏ប៉ុន្តែ ពុំមានការបង្ហាញណាមួយអំពីការស្លាប់ដែលបណ្តាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅជាទូទៅ ត្រង់កថាខណ្ឌ ៣០១-៣២១ និងបណ្តាលមកពីបញ្ហាសុខភាព ត្រង់កថាខណ្ឌ ៣១៣ នោះទេ។ កថាខណ្ឌតែបីប៉ុណ្ណោះ ដែលលើកឡើងពីការស្លាប់មនុស្ស ហើយក៏ពុំមានកថាខណ្ឌណាមួយនិយាយអំពីការស្លាប់ ក្រៅតែបណ្តាលមកពីការអត់ឃ្លាននោះដែរ។ កថាខណ្ឌ ៣១២ និយាយពីការស្លាប់ដោយសារការអត់អាហារ។ កថាខណ្ឌ ៣១៣ រៀបរាប់ពីការពុំមានពិធីបុណ្យសព ខណៈដែលកថាខណ្ឌ ៣២០ លើកឡើងពីការសម្លាប់ជនជាតិវៀតណាម។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ នៅត្រង់កថាខណ្ឌ ១១៣៩ នៃសំអាងហេតុសាលក្រម ដោយបានសង្ខេបទឡ្ហីករណ៍របស់មេធាវីការពារក្តី ប្រាសចាកពីន័យដើមទាំងស្រុង។ ជាក់ស្តែង ផ្ទុយពីការលើកឡើងរបស់អង្គជំនុំជម្រះ មេធាវីការពារក្តីអះអាងថា បទចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការសម្លាប់រង្គាល បានដកចេញនូវការស្លាប់ដែលបណ្តាលមកពីបញ្ហាសុខភាព និងត្រូវបានកម្រិតនៅត្រឹមការស្លាប់បណ្តាលមកពីការអត់អាហារ[827]។

---

825 សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១។

826 សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១។

827 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៣៩៖ "មេធាវីការពារក្តី ខៀវ សំផន បានអះអាងថា ការចោទប្រកាន់លើការសម្លាប់រង្គាលត្រូវបានកំណត់ត្រឹមតែការស្លាប់ពីការអត់អាហារ បញ្ហាសុខភាព និងការសម្លាប់ប្រជាជនវៀតណាមប៉ុណ្ណោះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើល *ផ្ទុយពីនេះ* សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៨៥៨-៨៦៣។។

៩៦៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្តោតលើករណីនៃការស្លាប់បណ្តាលមកពីការថែទាំវេជ្ជសាស្ត្រមិនបានត្រឹមត្រូវ ដូចបង្ហាញនៅកថាខណ្ឌ ៣១៣[828]។ នៅក្នុងកំណត់សម្គាល់ជើងទំព័រ អង្គជំនុំជម្រះបានលើកឡើងផងដែរថា កថាខណ្ឌ ៣១៣ នៃដីកាដំណោះស្រាយ "ពាក់ព័ន្ធនឹងបញ្ហាសុខភាព ជាពិសេសក្នុងចំណោមប្រជាជនថ្មី ហើយប្រជាជនដែលស្លាប់ដោយគ្មានការជូនដំណឹងដល់គ្រួសារ"[829] និង "ពាក់ព័ន្ធនឹងបញ្ហាកង្វះការថែទាំវេជ្ជសាស្ត្រ" រួចបន្តថា "នៅពេលមានមនុស្សស្លាប់ ពួកគេត្រូវកប់ដោយគ្មានការជូនដំណឹងដល់គ្រួសារឡើយ"[830]។ ការវិភាគរបស់អង្គជំនុំជម្រះលើកថាខណ្ឌ ៣១៣ នៃដីកាដំណោះស្រាយ គឺមិនត្រឹមត្រូវទេ ព្រោះថាសហចៅក្រមស៊ើបអង្កេតព្យាយាមបង្ហាញពីការស្លាប់មនុស្សនៅចុងកថាខណ្ឌ ដោយពុំបានភ្ជាប់ទំនាក់ទំនងណាមួយរវាងការស្លាប់មនុស្ស ជាមួយនឹងបញ្ហាសុខភាព ឬភាពទន់ខ្សោយនៃប្រព័ន្ធសុខាភិបាលដែលអាចចោទប្រកាន់ចំពោះគោលនយោបាយ ប.ក.ក[831]។ ការប្រើប្រាស់សន្ធានសព្ទ "ហើយ" បង្ហាញឱ្យឃើញច្បាស់ពីភាពពុំទាក់ទងគ្នារវាងជំងឺ និងការស្លាប់។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយប្រកាសថា ខ្លួនទទួលបានបណ្តឹងជាក់ស្តែងអំពីអង្គហេតុមួយចំនួន ក្រៅពីការស្លាប់បណ្តាលមកពីការអត់អាហារ[832]។

---

[828] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ២៥១៣ យោងទៅកថាខណ្ឌ ៣១៣ នៃដីកាដំណោះស្រាយ និងកថាខណ្ឌ ១១៤១។

[829] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ២៥១៣ យោងទៅកថាខណ្ឌ ៣១៣ នៃដីកាដំណោះស្រាយ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[830] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤១ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ៣៨៧៥ យោងទៅកថាខណ្ឌ ៣១៩ នៃដីកាដំណោះស្រាយ។

[831] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៣ "មនុស្សជាច្រើនរស់នៅក្នុងសហករណ៍ មានបញ្ហាសុខភាព ជាពិសេសអ្នកដែលត្រូវបានគេជម្លៀសដែលមិនស៊ាំនឹងការរស់នៅតាមទីជនបទ។ អ្នកមានជំងឺត្រូវបានព្យាបាលដោយពេទ្យឃុំ។ ក៏ប៉ុន្តែ ការព្យាបាលធ្វើឡើងតាមបែបបុរាណ និងថ្នាំដែលត្រូវផលិតនៅក្នុងស្រុក។ អ្នកជំងឺត្រូវបានផ្តល់ថ្នាំដែលធ្វើពីឫសឈើ និងថ្នាំអាចម៍ទន្សាយ។ អ្នកជំងឺត្រូវបានផ្តល់ថ្នាំចាក់ជាប្រភេទប៉េនីសេលីន លាយជាមួយទឹកដូង។ គ្រូពេទ្យគឺជាកម្មាភិបាលនារីរបស់ ប.ក.ក ដែលមិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការឡើយ។ ពួកគេភាគច្រើនមានអាយុចន្លោះពី ១២ ទៅ ១៣ ឆ្នាំ។ នៅពេលមានមនុស្សស្លាប់ សាកសពត្រូវកប់ និងគ្មានការជូនដំណឹងដល់គ្រួសារទេ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[832] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១, ១១៤០-១១៤១។

## ១.២. ការផ្តន្ទាទោសចំពោះការស្លាប់បណ្តាលមកពីល័ក្ខខ័ណ្ឌរស់នៅ ដោយរំលោភលើបណ្តឹងជាក់ស្តែង

៤៦៩. កំហុសនេះបាននាំឱ្យអង្គជំនុំជម្រះប្រកាសថា ខ្លួនមានយុត្តាធិការវិនិច្ឆ័យការចោទប្រកាន់អំពីការស្លាប់បណ្តាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅជាទូទៅ និងនាំទៅដល់ការសន្និដ្ឋានថា "មនុស្សជាច្រើនបានស្លាប់ដោយសារកង្វះអាហាររូបត្ថម្ភ ការងារហួសកម្រិត និងជំងឺ រួមទាំងក្នុងរយៈពេលក្រោយៗមកទៀត ហើយប្រជាជនថ្មីទទួលរងផលប៉ះពាល់យ៉ាងខ្លាំង"[833]។ អង្គជំនុំជម្រះបានអះអាងដែរថា "ប្រជាជនបានស្លាប់នៅក្នុងមន្ទីរពេទ្យស្រុក [...] ដោយសារតែកង្វះការថែទាំវេជ្ជសាស្ត្រ កង្វះអាហាររូបត្ថម្ភ និងការងារហួសកម្រិត"[834]។ ផ្អែកលើសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់បទចោទប្រកាន់ឡើងវិញចំពោះអង្គហេតុទាំងនេះ ពីការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាត ដោយអង្គជំនុំជម្រះបានសន្និដ្ឋានថា ធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាតត្រូវបំពេញដោយមាន "ទំនាក់ទំនងទៅនឹងការស្លាប់មនុស្សដែលបណ្តាលមកពីល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌនៃការរស់នៅ ដូចដែលបានរៀបរាប់ខាងលើ"[835]។

៤៧០. ផ្ទុយទៅវិញ អង្គជំនុំជម្រះគួរតែប្រកាសថា ខ្លួនគ្មានយុត្តាធិការវិនិច្ឆ័យអង្គហេតុទាំងអស់នេះ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា ការស្លាប់បណ្តាលមកពីលក្ខខណ្ឌនៃការរស់នៅ ក្រៅពីការស្លាប់បណ្តាលមកពីការអត់អាហារ ហើយដែលត្រូវបានកំណត់បទចោទប្រកាន់ឡើងវិញ គឺជាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មមនុស្សឃាត ត្រូវតែទុកជាមោឃៈ។ ហេតុដូច្នេះ ការផ្តន្ទាទោស ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ក៏ត្រូវតែទុកជាមោឃៈដែរ[836]។

---

[833] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២ កំណត់សម្គាល់ជើងទំព័រលេខ៣៨៨២ យោងទៅកថាខណ្ឌ ១០១៦, ១០២០, ១០៣៧។

[834] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២ កំណត់សម្គាល់ជើងទំព័រលេខ៣៨៨៤ យោងទៅកថាខណ្ឌ ១០៤៧។

[835] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤, ១១៤៥។

[836] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥, ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

## ២. គ្មានបណ្តឹងពីការស្លាប់បណ្តាលមកពីការអត់ឃ្លាន នៅក្រៅឃុំសំរោង និងឃុំតាភេម

៤៧១. ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការសម្លាប់រង្គាល ចំពោះអង្គហេតុកើតឡើងនៅក្នុងសហករណ៍ត្រាំកក់ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបដិសេធចោលទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលលើកឡើងថា ក្នុងសំណុំរឿង ០០២/០២ ខៀវ សំផន ត្រូវឆ្លើយតបតែទៅនឹងអង្គហេតុកើតឡើងនៅក្នុងឃុំសំរោង និងឃុំតាភេម ប៉ុណ្ណោះ[837]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា ខ្លួនទទួលបានបណ្តឹងជាក់ស្តែងអំពីការស្លាប់បណ្តាលមកពីការអត់អាហារ ដែលកើតឡើងនៅក្រៅឃុំទាំងពីរនេះ[838]។

៤៧២. អង្គជំនុំជម្រះគួរតែពិនិត្យកថាខណ្ឌពាក់ព័ន្ធនានាដែលបង្ហាញថា គ្មានអង្គហេតុណាមួយដែលត្រូវបានកំណត់ថាជាការសម្លាប់រង្គាល នៅក្នុងការរៀបរាប់អំពីអង្គហេតុ ក្រៅតែពីការស្លាប់បណ្តាលមកពីការអត់ឃ្លាន កើតឡើងក្នុងឃុំសំរោង និងឃុំតាភេម ត្រង់កថាខណ្ឌ ៣១២ នៃដីកាដំណោះស្រាយ (២.១) នោះទេ ហើយអង្គជំនុំជម្រះគួរតែកត់សម្គាល់ថា ខ្លួនមិនអាចផ្តន្ទាទោសហួសពីបណ្តឹងឡើយ (២.២)។

### ២.១. ការបង្ហាញតែមួយគត់អំពីការស្លាប់បណ្តាលមកពីការអត់អាហារ ដែលបានកើតឡើងក្នុងឃុំសំរោង និងឃុំតាភេម ត្រង់កថាខណ្ឌ ៣១២ នៃដីកាដំណោះស្រាយ

៤៧៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបកស្រាយដីកាដំណោះស្រាយមិនបានស៊ីជម្រៅ ដោយបានសម្រេចលើវិសាលភាពអង្គហេតុនៃការស្លាប់បណ្តាលមកពីការអត់អាហារ ដែលត្រូវបានបង្ហាញត្រង់កថាខណ្ឌ ៣១២ នៃដីកាដំណោះស្រាយ ហើយដែលត្រូវបានកំណត់ជាប្រភេទបទល្មើស នៅក្នុងកថាខណ្ឌ ១៣៨១ និង ១៣៨៧ ដោយពុំបានវាយតម្លៃអំពីវិសាលភាពភូមិសាស្ត្រនៃការអត់អា

[837] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១, ១១៤០-១១៤១។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៩២៤-៩៣១។

[838] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១, ១១៣៨ កំណត់សម្គាល់ជើងទំព័រលេខ៣៨៧០ យោងទៅកថាខណ្ឌ ៣១២ នៃដីកាដំណោះស្រាយ។ សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៩៣០-៩៣១។

ហារ។ អង្គហេតុទាំងឡាយ ដែលត្រូវបានពណ៌នានៅកថាខណ្ឌ ៣១២ បានផ្អែកលើភ័ស្តុតាងមួយចំនួន។ អង្គហេតុទាំងអស់នេះ ដែលមានទីតាំងភូមិសាស្ត្រច្បាស់លាស់ គឺជាវិសាលភាពនៃអង្គហេតុទាំងឡាយដែលត្រូវបានកំណត់បទចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងផ្នែកកំណត់ប្រភេទបទល្មើស។ ក៏ប៉ុន្តែ ក្នុងករណីជាក់ស្តែងនេះ ភ័ស្តុតាងដាក់បន្ទុកដែលពាក់ព័ន្ធ ហើយដែលត្រូវបានយោងដោយសហចៅក្រមស៊ើបអង្កេត បានសង្ខេបមកត្រឹមអង្គហេតុមួយចំនួនដែលបានកើតឡើងនៅក្នុងឃុំពីរប៉ុណ្ណោះ ដែលជាកម្មវត្ថុនៃបណ្តឹង នោះគឺឃុំសំរោង និងឃុំតាភេម[839]។ ដូច្នេះ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះត្រូវបានប្តឹងជាក់ស្តែង តែអំពីការស្លាប់បណ្តាលមកពីការអត់ឃ្លានដែលបានកើតឡើងនៅក្នុងឃុំទាំងពីរនេះប៉ុណ្ណោះ ហើយអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនត្រូវបានស្នើឱ្យជំនុំជម្រះការស្លាប់បណ្តាលមកពីការអត់អាហារនៅកន្លែងផ្សេង[840]។

## ២.២. ការផ្តន្ទាទោសចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ នៅកន្លែងផ្សេង ដោយរំលោភលើបណ្តឹងជាក់ស្តែង

៤៧៤. ការអនុវត្តច្បាប់មិនត្រឹមត្រូវបែបនេះ បាននាំឱ្យអង្គជំនុំជម្រះពង្រីកវិសាលភាពនៃការជំនុំជម្រះដោយខុសច្បាប់។ កំហុសអង្គច្បាប់មួយនេះ មានផលវិបាកផ្ទាល់ទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលត្រូវបានធ្វើឡើងដោយផ្អែកលើភ័ស្តុតាងនៃការស្លាប់បណ្តាលមកពីការអត់អាហារ ក្រៅពីការស្លាប់ដែលបានកើតឡើងនៅក្នុងឃុំសំរោង និងឃុំតាភេម[841]។ អង្គហេតុទាំងនេះ ពុំមែនជាការចោទ

[839] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១២ កំណត់សម្គាល់ជើងទំព័រលេខ១២៨៣ យោងទៅភ័ស្តុតាងដាក់បន្ទុក មានកំណត់ហេតុនៃការស្តាប់ចម្លើយ សុក សុត ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៧ ឯកសារ **E3/5835** (D25/32) ERN 00163525-00163526 កំណត់ហេតុនៃការស្តាប់ចម្លើយ សឹម ឈៀង ឯកសារ **E3/7980** (D40/16) ទំព័រ ៤-៥ និងកំណត់ហេតុនៃការស្តាប់ចម្លើយ សុក ស៊ីម ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/5519** (D232/67) ERN 00408334-00408335, កំណត់សម្គាល់ជើងទំព័រលេខ១២៨៤ យោងទៅលើភ័ស្តុតាងដោះបន្ទុក មានកំណត់ហេតុនៃការស្តាប់ចម្លើយ តុប ដេ ឯកសារ **E3/7982** (D40/19) ទំព័រ ២-៣ និងកំណត់ហេតុនៃការស្តាប់ចម្លើយ <u>នុត នូវ</u> ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ **E3/5521** (D232/70) ERN 00408300-00408302។ លើសពីនេះទៀត ចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ផងដែរអំពីការស្លាប់មនុស្សនៅក្នុងឃុំជាងទង ដែលពុំស្ថិតក្នុងកិច្ចស៊ើបសួរ។

[840] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១១, ១១៤០-១១៤១។

[841] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២-១១៤៥។

ប្រកាន់ដែល ខៀវ សំផន ត្រូវឆ្លើយតបនោះទេ ហើយសេចក្តីសន្និដ្ឋានទាក់ទងនឹងការស្លាប់បណ្តាលមកពីការអត់អាហារ ដែលបានកើតមាននៅក្រៅឃុំទាំងពីរនេះ ត្រូវទុកជាមោឃៈ។ ផ្អែកលើសេចក្តីសន្និដ្ឋានហួសពីសមត្ថកិច្ចរបស់ខ្លួននេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់បទចោទប្រកាន់ឡើងវិញចំពោះអង្គហេតុទាំងនេះ ពីការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាត ហើយដោយបានសន្និដ្ឋានថា ធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាតត្រូវបានបង្ហាញ "ទាក់ទងនឹងការស្លាប់មនុស្សដែលបណ្តាលមកពីល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌនៃការរស់នៅ ដូចដែលបានរៀបរាប់ខាងលើ"[842]។ ដូច្នេះ ការផ្តន្ទាទោសលើរូប ខៀវ សំផន ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ពាក់ព័ន្ធនឹងការស្លាប់បណ្តាលមកពីការអត់អាហារដែលបានកើតឡើងនៅក្រៅឃុំសំរោង និងឃុំតាភេម ត្រូវតែទុកជាមោឃៈ[843]។

## ៣. គ្មានបណ្តឹងពីអង្គហេតុ "ការរើសអើង" ចំពោះប្រជាជនថ្មី ក្រៅពីការកម្រិតនូវការអនុវត្ត "សិទ្ធិនយោបាយ" មួយចំនួន

៤៧៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនទទួលបានបណ្តឹងជាក់ស្តែងអំពីអង្គហេតុ "ការរើសអើង" ចំពោះប្រជាជនថ្មី ដែលហួសពីការកម្រិតនូវការអនុវត្ត "សិទ្ធិនយោបាយ" មួយចំនួន[844]។ អង្គជំនុំជម្រះគួរពិនិត្យកថាខណ្ឌពាក់ព័ន្ធនានានៃដីកាដំណោះស្រាយដែលបង្ហាញថាគ្មានអង្គហេតុណាមួយដែលត្រូវបានកំណត់ប្រភេទបទល្មើសថាជាការសម្លាប់រង្គាល នៅក្នុងការរៀបរាប់អំពីអង្គហេតុ ក្រៅតែពីការចោទប្រកាន់ចំពោះការលុបបំបាត់ "សិទ្ធិ" នយោបាយ ដែលកើតមាននៅត្រាំកក់នោះទេ (៣.១) ហើយអង្គជំនុំជម្រះគួរកត់សម្គាល់ថា ខ្លួនពុំអាចធ្វើការផ្តន្ទាទោសហួសពីបណ្តឹងនេះដែរ (៣.២)។

---

[842] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤, ១១៤៥។

[843] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥, ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

[844] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១៣, ១១៧០-១១៧១។

## ៣.១. ការលុបបំបាត់ "សិទ្ធិ" នយោបាយ គឺជាអំពើរើសអើងតែមួយគត់ចំពោះប្រជាជនថ្មី នៅក្នុងដីកាដំណោះស្រាយ

៤៧៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយោងទៅលើកថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយ ដើម្បីលើកឡើងថា "ប្រជាជនថ្មីបានទទួលរងការធ្វើបាបយ៉ាងឃោរឃៅជាងប្រជាជនចាស់ក្នុងគោលបំណងលត់ដំពួកគេ/ឬកំណត់អត្តសញ្ញាណខ្មាំងនៅក្នុងចំណោមពួកគេ"[845]។ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋាននៅត្រង់ចំណុចនេះថា៖

> "**នៅតាមសហករណ៍ និងនៅតាមការដ្ឋានធ្វើការដោយបង្ខំ** ដូចនៅពេល**ផ្លាស់ទីលំនៅប្រជាជន**ដែរ ខ្មាំងពិត ឬតាមការសន្មតរបស់ ប.ក.ក ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខ័ណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនោះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅកសាងឡើងវិញ ឬទៅកម្ទេចចោលនៅតាម**មន្ទីរសន្តិសុខ និងទីពិឃាតមនុស្ស**"[846]។

៤៧៧. ពាក់ព័ន្ធនឹងប្រជាជនថ្មី អង្គហេតុដែលត្រូវបានកំណត់ប្រភេទបទល្មើសជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រង់កថាខណ្ឌ ១៤១៨ គឺជាអង្គហេតុដែលត្រូវបានអធិប្បាយនៅក្នុងផ្នែកពិពណ៌នាអំពីអង្គហេតុនៃដីកាដំណោះស្រាយ។ ការពិនិត្យឱ្យបានច្បាស់លាស់លើរាល់កថាខណ្ឌនានានៅក្នុងផ្នែក "ការកំណត់ប្រភេទបទល្មើស" អាចឱ្យគេកំណត់បានថា កថាខណ្ឌ ៣០៤-៣០៦ និង ៣១៩ គឺបង្ហាញពីការប្រព្រឹត្តិលើប្រជាជនថ្មី។ យោងលើមូលដ្ឋាននៃអង្គហេតុទាំងនេះ សេចក្តីសន្និដ្ឋានក្នុងកថាខណ្ឌ ១៤១៨ គឺផ្អែកលើការយោងចំនួនបីទៅរកការប្រព្រឹត្ត "បែបរើសអើង" ចំពោះប្រជាជនថ្មី៖ (១) ពេលខ្លះ ក្រោយពេលទៅដល់សហករណ៍ត្រាំកក់ អ្នកជម្លៀសពីទីក្រុង "ត្រូវបានផ្លាស់ពីទីកន្លែងមួយទៅកន្លែងមួយ នៅក្នុងស្រុកទាំងមូល"[847] (២) ពួកគេ "មិនមានសិទ្ធិនយោបាយដែលអាច

[845] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧០។

[846] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៨ (ដាក់ជាអក្សរដិតនៅក្នុងអត្ថបទដើម)។ សូមមើលផងដែរ កថាខណ្ឌ ៣០២-៣២១។

[847] ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៤។

ឱ្យអ្នកទាំងនោះធ្វើជាប្រធានកងនៅក្នុងសហករណ៍ទេ”[848] ហើយ (៣) ពួកគេ “ត្រូវបានឃ្លាំមើល [...] យ៉ាងជិតដល់”[849]។

៤៧៨. ប៉ុន្តែ ចរិតរើសអើងនៃអង្គហេតុទាំងនេះ ត្រូវបានបដិសេធចោលដោយសេចក្តីសន្និដ្ឋានផ្សេងៗទៀត ដែលបង្ហាញពីការប្រព្រឹត្តិមួយដែលគ្មានការរើសអើង។ បើយោងតាមសហចៅក្រមស៊ើបអង្កេត ការប្រព្រឹត្តិលើប្រជាជនថ្មី ពុំមានអ្វីជាពិសេសនោះឡើយ ពោលគឺការផ្លាស់ទីលំនៅប្រជាជនបានប៉ះពាល់ទាំងប្រជាជនចាស់ និងប្រជាជនថ្មី[850] ហើយប្រជាជនគ្រប់ប្រភេទនៅតាមសហករណ៍ ដោយពុំមានការបែងចែកវណ្ណៈ ត្រូវបានចាប់ខ្លួនយកទៅ[851]។ លើសពីនេះទៀត បើយោងតាមសហចៅក្រមស៊ើបអង្កេត “ការនិយាយអ្វីផ្ទុយពីអង្គការ” ឬ “ការត្អូញត្អែរនឹងលក្ខខ័ណ្ឌការងារ និងការរស់នៅ” អាចនាំឱ្យមានការចាប់ខ្លួន ទាំងចំពោះប្រជាជនថ្មី និងប្រជាជនទាំងអស់នៅតាមសហករណ៍។ គេអាចនិយាយតាមបែបម្យ៉ាងទៀតថា ការប្រព្រឹត្តិចំពោះពួកគេ គឺដូចគ្នាទាំងអស់។

៤៧៩. ដូច្នេះ រាល់អំពើរើសអើងជាក់លាក់ទាំងអស់ ដែលត្រូវបានលើកឡើងយ៉ាងច្បាស់នៅក្នុងដីកាដំណោះស្រាយ គឺត្រូវសង្ខេបមកត្រឹមការចោទប្រកាន់ពីការលុបបំបាត់ “សិទ្ធិនយោបាយ” ចំពោះប្រជាជនថ្មី ដែលពួកគេមិនអាចធ្វើជាមេកងបាន។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអះអាងថាខ្លួនត្រូវបានស្នើឱ្យពិនិត្យយ៉ាងទូលាយលើ “ការប្រព្រឹត្តិខុសគ្នា”[852]។

### ៣.២. ការផ្តន្ទាទោសចំពោះអង្គហេតុ “ការរើសអើង” លើប្រជាជនថ្មី នៅក្រៅបណ្តឹង

៤៨០. ក្រៅពីការចោទប្រកាន់ចំពោះការលុបបំបាត់ “សិទ្ធិនយោបាយ” គឺគ្មានអង្គហេតុណាមួយទាក់ទងនឹងការប្រព្រឹត្តិលើប្រជាជនថ្មីនៅក្នុងសហករណ៍ត្រាំកក់ ជាការចោទប្រកាន់ដែល ខៀវ សំផន មិនត្រូវ

[848] ដីកាដំណោះស្រាយ កថាខណ្ឌ ៣០៥។

[849] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៩។

[850] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១០។

[851] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១១-៣១២ និង ៣១៥-៣១៨។

[852] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧០-១១៧១។

ឆ្លើយតបនោះទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងអំពើ "រើសអើង" ដែលសំដៅចំពោះប្រជាជនថ្មីជាទូទៅ គឺត្រូវបានធ្វើឡើងដោយរំលោភបណ្តឹង[853]។ ផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើប្រជាជនថ្មី និងបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មនេះត្រូវបានបង្ហាញពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ[854]។ អង្គជំនុំជម្រះបានពិចារណាខុសថា ក្នុងបរិបទរបស់វា និងពិចារណាជាមួយនឹងអង្គហេតុនៃការចាប់ខ្លួន និងការធ្វើមនុស្សឃាត អង្គហេតុទាំងនេះ តាមរយៈអានុភាពត្រួតគ្នារបស់វា បានឈានដល់កម្រិតធ្ងន់ធ្ងរដែលជាល័ក្ខខ័ណ្ឌតម្រូវនៃធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មី ដោយមូលហេតុនយោបាយ[855]។

៤៨១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានបញ្ចូលអង្គហេតុទាំងអស់នេះ ដែលត្រូវបានកំណត់ប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅក្នុងគោលនយោបាយមួយដែលអង្គជំនុំជម្រះកំណត់ថាមានលក្ខណៈ "ឧក្រិដ្ឋ"[856]។ សេចក្តីសន្និដ្ឋានទាំងនេះត្រូវតែទុកជាមោឃៈ ហើយដូចគ្នាចំពោះសេចក្តីប្រកាសពិរុទ្ធភាព ខៀវ សំផន សម្រាប់អង្គហេតុទាំងនេះ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម[857]។

## ផ្នែកទី២. ទំនប់ត្រពាំងថ្ម

៤៨២. **<u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ</u>**៖ យោងតាមសំអាងហេតុសាលក្រម អង្គជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវបានស្នើសុំឱ្យជំនុំជម្រះលើឧក្រិដ្ឋកម្មនៃការធ្វើទុក្ខ បុកម្នេញដោយមូលហេតុនយោបាយ នៅការដ្ឋានទំនប់ត្រពាំងថ្ម ពាក់ព័ន្ធនឹង "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក"

---

853 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៥-១១៧៧។

854 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៨-១១៧៩។

855 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៨-១១៧៩។

856 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៨-១១៧៩, ៣៣១៩, ៣៣២៤-៣៣២៥, ៣៩២៨-៣៩២៩។

857 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

ដែលត្រូវបានគេ "ធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខ័ណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត"[858]។ ដូចដែលបាន បញ្ជាក់ពីខាងដើម[859] គឺមានតែក្រុមចំនួនបីប៉ុណ្ណោះ ដែលត្រូវបានកំណត់អត្តសញ្ញាណដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយ។ យោងតាមខ្លឹមសារនៃកថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ បុគ្គលដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ រួមមាន អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេសវិញ[860]។ គ្រប់ផ្នែកទាំងអស់នៃដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្ម គឺយោងតែទៅលើអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយប្រឆាំងនឹងប្រជាជនថ្មីប៉ុណ្ណោះ[861]។ នៅត្រង់កថាខណ្ឌ ៣៤៣ នៃដីកាដំណោះស្រាយ មានការបង្ហាញថា ប្រជាជនថ្មី "បានទទួលរងនូវលក្ខខ័ណ្ឌការងារធ្ងន់ធ្ងរជាង ដូចជាម្នាក់ៗត្រូវធ្វើការងារច្រើនជាងអ្នកដទៃ ឬទទួលរងនូវការដាក់ទណ្ឌកម្មមិនសមហេតុផល"[862]។

៤៨៣. សហចៅក្រមស៊ើបអង្កេត ពុំបានធ្វើសេចក្តីសន្និដ្ឋានណាមួយទាក់ទងនឹងលក្ខខ័ណ្ឌការងារ និងលក្ខខ័ណ្ឌនៃការរស់នៅរបស់អតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ និងរបស់ប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេសនោះទេ។ ដូច្នេះ វាបានបង្ហាញឱ្យឃើញតាមរយៈនេះថា អង្គជំនុំជម្រះទទួលបានបណ្តឹងតែពីអង្គហេតុទាំងនេះប៉ុណ្ណោះ ពាក់ព័ន្ធនឹងប្រជាជនថ្មី។ អង្គជំនុំជម្រះបានបដិសេធចោលទឡ្ហីករណ៍មួយនេះរបស់មេធាវីការពារក្តី ដោយផ្តល់នូវការបកស្រាយមួយមិនត្រឹមត្រូវលើដីកាដំណោះស្រាយ[863]។ អង្គជំនុំជម្រះយល់ឃើញថា ក្រុមទាំងបីដែលត្រូវបានកំណត់នេះ គឺពុំត្រូវបានលើកយកមកឱ្យអស់នោះទេ ហើយវាអាចវិវត្តទៅតាមពេលវេលា[864]។ ការបកស្រាយបែបពង្រីកដូច្នេះ គឺជា

[858] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤០៥ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៨។

[859] សូមមើលខាងលើ កថាខណ្ឌ ៣៥៩-៤៦៤។

[860] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៧។

[861] ដីកាដំណោះស្រាយ កថាខណ្ឌ ៣២៣-៣៤៩។

[862] ដីកាដំណោះស្រាយ កថាខណ្ឌ ៣៤៣។

[863] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧០, ១៤០៥។

[864] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧០។

កំហុសអង្គច្បាប់[865]។ ហេតុដូច្នេះ អង្គជំនុំជម្រះអាចគិតថា ខ្លួនត្រូវបានស្នើសុំឱ្យជំនុំជម្រះលើអង្គហេតុទាំងនេះ ដោយកម្រិតត្រឹមតែលើប្រជាជាជនថ្មីប៉ុណ្ណោះ។ ដូច្នេះ រាល់សេចក្តីសន្និដ្ឋានទាំងអស់ ដែលស្ថិតក្រៅក្របខ័ណ្ឌនេះ ត្រូវទុកជាមោឃៈ[866]។

### ផ្នែកទី ៣. ទំនប់១មករា

### ១. គ្មានបណ្តឹងពីការស្លាប់នៅក្រៅទំនប់១មករា

៤៨៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានពង្រីកវិសាលភាពភូមិសាស្ត្រនៃរឿងក្តី ដោយបានវិនិច្ឆ័យលើការស្លាប់នៅក្រៅទំនប់១មករា ដើម្បីបញ្ចូលក្នុងការជំនុំជម្រះ នូវការស្លាប់ដែលកើតមាននៅតាមភូមិ និងតាមរោងព្យាបាលនៅក្នុងមូលដ្ឋាន[867]។ អង្គជំនុំជម្រះគួរណាពិចារណាពីវិសាលភាពភូមិសាស្ត្រនៃបណ្តឹង និងគួរកត់សម្គាល់ថា ខ្លួនមិនអាចផ្តន្ទាទោសហួសពីបណ្តឹងឡើយ។

៤៨៥. យុត្តាធិការទឹកន្លែងរបស់អង្គជំនុំជម្រះ គឺកម្រិតត្រឹមការស្លាប់ដែលកើតមាននៅទំនប់១មករា។ ដូចដែលអង្គជំនុំជម្រះបានរំឭកថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានកម្រិតយុត្តាធិការរបស់អង្គជំនុំជម្រះ នៅត្រឹមការស្លាប់ដែលកើតមាននៅទីតាំងទំនប់១មករា[868]។ ដូច្នេះ ខៀវ សំផន ពុំចាំបាច់ឆ្លើយតបទៅនឹងអង្គហេតុទាំងនេះទេ។

៤៨៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យលើការស្លាប់ដែលកើតមាននៅតាមភូមិ និងតាមរោងព្យាបាលនៅមូលដ្ឋាន ដែលពុំត្រូវបានចោទប្រកាន់លើរូប ខៀវ សំផន[869]។ សេចក្តីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ[870]។ សេចក្តីសន្និដ្ឋាននេះ ពុំអាចយកធ្វើជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័ត

---

[865] សូមមើលខាងលើ កថាខណ្ឌ ៣៥៩-៤៦៤។

[866] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤០៥-១៤២៩។

[867] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦២៩។

[868] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦៨។

[869] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦២៩។

[870] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧១ យោងទៅកថាខណ្ឌ ១៥៣៥។

សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានកំណត់បទចោទឡើងវិញ ពីការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាត[871]។ ហេតុដូច្នេះ ការផ្តន្ទាទោស ខៀវ សំផន ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយចេតនាប្រយោល នៅទំនប់១មករា ពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ[872]។

## ២. គ្មានបណ្តឹងពីការស្លាប់បណ្តាលមកពីគ្រោះថ្នាក់ផ្សេងៗ

៤៨៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនទទួលបានបណ្តឹងជាក់ស្តែង និងមានយុត្តាធិការកាត់សេចក្តីលើការស្លាប់បណ្តាលមកពីគ្រោះថ្នាក់ផ្សេងៗនៅទំនប់១មករា[873]។ ការស្លាប់ទាំងនោះពុំស្ថិតនៅក្នុងអង្គហេតុ ដែលត្រូវបានកំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ហើយដូច្នេះ ខៀវ សំផន ពុំចាំបាច់ឆ្លើយតបទៅនឹងអង្គហេតុទាំងអស់នេះឡើយ។ អង្គជំនុំជម្រះគួរណាពិចារណាពីវិសាលភាពជាក់ស្តែងនៃបណ្តឹង និងគួរកត់សម្គាល់ថា ខ្លួនមិនអាចផ្តន្ទាទោសហួសពីបណ្តឹងឡើយ។

៤៨៨. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅត្រង់កថាខណ្ឌ ១៣៨១ នៃដីកាដំណោះស្រាយ ថា ឧក្រិដ្ឋកម្មសម្លាប់រង្គាលត្រូវបានបង្ហាញ ជាពិសេសចំពោះ "ជនដែលត្រូវបានសម្លាប់ ឬជនដែលបានស្លាប់ក្នុងទ្រង់ទ្រាយធំ" នៅតាមទីតាំងឧក្រិដ្ឋកម្មជាច្រើន ក្នុងនោះមានទំនប់១មករា ផងដែរ។ ធាតុផ្សំទូទៅដែលត្រូវយកមកពិចារណាសម្រាប់ទីតាំងទាំងអស់នេះ ដែលត្រូវបានចោទប្រកាន់ថាមានការសម្លាប់រង្គាល គឺត្រូវបានបង្ហាញនៅកថាខណ្ឌ ១៣៨២ និង ១៣៨៣ ក្នុងដីកាដំណោះស្រាយ។ នៅត្រង់នោះ មានការបង្ហាញផងដែរពី "ធាតុផ្សំពាក់ព័ន្ធផ្សេងទៀត" ដែលត្រូវពិចារណាសម្រាប់ទីតាំងនីមួយៗ ដែលត្រូវបានបង្ហាញថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ធាតុផ្សំទាំងអស់នោះត្រូវបានផ្តល់ឱ្យនៅត្រង់កថាខណ្ឌ ១៣៨៧ សម្រាប់គ្រប់ការដ្ឋានការងារដោយបង្ខំ៖

---

[871] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧២-១៦៧៣។

[872] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២០, ៣៩២៨, ៤២៨២, ៤៣០៦។

[873] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦៨។

"ដោយឡែក [...] មានមនុស្សជាច្រើននាក់បានស្លាប់ ដោយសារស្ថានភាពរស់នៅលំបាកវេទនា [...]។ មនុស្សទាំងនោះទទួលបានរបបអាហារមិនគ្រប់គ្រាន់ គ្មានជម្រក គ្មានការថែទាំវេជ្ជសាស្ត្រ និងអនាម័យ។ ដូចគ្នានេះដែរ ចំពោះអ្នកដែលធ្វើការនៅការដ្ឋានធ្វើការងារដោយបង្ខំ ពួកគេស្ថិតក្នុងស្ថានភាពរស់នៅដូចគ្នា មិនតែប៉ុណ្ណោះ ពួកគេត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ថែមទៀតផង"។

៤៨៩. សេចក្ដីសន្និដ្ឋានត្រង់កថាខណ្ឌ ៣៦៣ ដែលនិយាយថា "មានអ្នកផ្សេងទៀតស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗ ដូចជា រលំថ្មសង្កត់ ឬបាក់ដីលើ" ពុំត្រូវបានលើកឡើងវិញនៅក្នុងការកំណត់ប្រភេទបទល្មើសនោះទេ។ ដូច្នេះ ខៀវ សំផន ពុំចាំបាច់ត្រូវឆ្លើយតបទៅនឹងអង្គហេតុទាំងនេះឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យលើការស្លាប់បណ្ដាលមកពីគ្រោះថ្នាក់ផ្សេងៗនៅទំនប់១មករា ហើយដែល ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ចំពោះអង្គហេតុទាំងអស់នេះ[874]។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះពីអត្ថិភាពនៃគ្រោះថ្នាក់ជាច្រើនដែលបានបង្កឱ្យមានការបាត់បង់អាយុជីវិតរបស់កម្មករនោះ ត្រូវទុកជាមោឃៈ[875]។ សេចក្ដីសន្និដ្ឋានមួយនេះ មិនអាចយកមកធ្វើជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានកំណត់បទចោទឡើងវិញ ពីការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាតបានឡើយ[876]។ ដូច្នេះ ការផ្ដន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយមានចេតនាដោយប្រយោលនៅទំនប់១មករា ពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ ត្រូវតែទុកជាមោឃៈ[877]។

## ៣. គ្មានបណ្ដឹងពីអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរ

---

[874] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦៨។

[875] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧១ យោងទៅកថាខណ្ឌ ១៥៣៥។

[876] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧២-១៦៧៣។

[877] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២០, ៣៩២៨, ៤២៨២, ៤៣០៦។

៩៩០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកាត់សេចក្តី ខៀវ សំផន ចំពោះអំពើ "រើសអើង" លើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅទំនប់១មករា[878]។ អង្គជំនុំជម្រះគួរតែពិនិត្យលើកថាខណ្ឌពាក់ព័ន្ធនានានៃដីកាដំណោះស្រាយ ដែលបង្ហាញឱ្យឃើញថា គ្មានអំពើ "រើសអើង" ណាមួយចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរនោះទេ ហើយអង្គជំនុំជម្រះគួរណាកត់សម្គាល់ថា ខ្លួនមិនអាចផ្តន្ទាទោសបហួសពីបណ្តឹងឡើយ។ នៅត្រង់កថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា នៅតាមការដ្ឋានការងារ ក្រុមមនុស្សដែលត្រូវបានកំណត់ជាគោលដៅនៅក្នុងកថាខណ្ឌ ១៤១៧ "ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនោះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅកសាងឡើងវិញ ឬទៅកម្ទេចចោលនៅតាម**មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស**" (សរសេរជាអក្សរដិតនៅក្នុងអត្ថបទដើម)។ ក៏ប៉ុន្តែ នៅក្នុងផ្នែក "ការពិពណ៌នាអំពីអង្គហេតុ" ពាក់ព័ន្ធនឹងទំនប់១មករា សហចៅក្រមស៊ើបអង្កេតពុំបានធ្វើការបង្ហាញឱ្យឃើញពីអង្គហេតុនៃការរើសអើង ទាក់ទងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនោះទេ។

៩៩១. គឺមានតែកថាខណ្ឌ ៣៦៦ នៃដីកាដំណោះស្រាយប៉ុណ្ណោះ ដែលទំនងជាមូលដ្ឋាននៃការចោទប្រកាន់មួយនេះ ដោយកថាខណ្ឌនេះបានបង្ហាញពីការបាត់ខ្លួនអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរក្នុងចំនួនមួយដ៏ច្រើន។ យ៉ាងណាមិញ កថាខណ្ឌនេះបានបង្ហាញពីលក្ខណៈមិនរើសអើងក្នុងការចាប់ខ្លួន ព្រោះថាអ្នកធ្វើការនៅការដ្ឋានទាំងអស់អាចត្រូវចាប់ខ្លួនគ្រប់គ្នា ដោយពុំមានការបែងចែកថាពួកគេស្ថិតក្នុងក្រុមណាមួយជាក់លាក់នោះឡើយ។ ដូច្នេះ ការពិនិត្យលើអង្គហេតុដែលត្រូវបានពិពណ៌នានៅក្នុងកថាខណ្ឌ ៣៥១-៣៦៧ បានស្តែងឱ្យឃើញនូវកំហុសអង្គហេតុទាក់ទងនឹងការ "រើសអើង"។ ហេតុដូច្នេះហើយបានជាសហចៅក្រមស៊ើបអង្កេតពុំអាចកំណត់ប្រភេទបទល្មើសចំពោះអង្គហេតុដែលពុំមានជាក់ស្តែងបានឡើយ។ គ្មានអង្គហេតុនៃ "ការរើសអើង" ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ នៅទំនប់១មករា បង្កើតបានជាការចោទប្រកាន់ដែល ខៀវ សំផន ត្រូវឆ្លើយតបនោះទេ។

---

[878] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦១, ១៤៣៥, ១៦៨៥។

៤៩២. អង្គជំនុំជម្រះមិនទទួលបានបណ្តឹងជាក់ស្តែងអំពី "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទេ។ អង្គជំនុំជម្រះគ្មានយុត្តាធិការកាត់សេចក្តីលើអង្គហេតុ ដែលត្រូវបានកំណត់ថាជាការប្រព្រឹត្តិបែបរើសអើងលើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរបានឡើយ ហើយសេចក្តីសន្និដ្ឋានទាំងអស់នេះ ត្រូវទុកជាមោឃៈ[879]។ ផ្អែកលើសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងអង្គហេតុកើតឡើងនៅទំនប់១មករា[880]។ ហេតុដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបញ្ចូលអង្គហេតុទាំងនេះ ដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅក្នុងគោលនយោបាយមួយដែលខ្លួនកំណត់ថាមានលក្ខណៈ"ឧក្រិដ្ឋ"[881]។ សេចក្តីសន្និដ្ឋានទាំងអស់នេះ ត្រូវទុកជាមោឃៈ ហើយដូចគ្នាសម្រាប់ការប្រកាសពិរុទ្ធភាព ខៀវ សំផន សម្រាប់អង្គហេតុទាំងនេះ ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម[882]។

## ផ្នែកទី ៤. ព្រលានយន្តហោះកំពង់ឆ្នាំង

៤៩៣. **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** អង្គជំនុំជម្រះយល់ថា ខ្លួនត្រូវទទួលបានបណ្តឹងជាក់ស្តែងអំពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[883] ដោយផ្អែកលើបណ្តឹងខុសច្បាប់។ បើទោះបីជាសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាននៅត្រង់កថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញឱ្យឃើញនៅព្រលានយន្តហោះកំពង់ឆ្នាំងក៏ដោយ ក៏អង្គហេតុទាំងឡាយដែលត្រូវបានពណ៌នាទាក់ទងនឹងឧក្រិដ្ឋកម្មនេះ ពុំបានយោងទៅក្រុមណាមួយក្នុងចំណោមក្រុមទាំងបី

---

[879] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦០-១៦៦៣, ១៦៩០-១៦៩២។

[880] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩១-១៦៩២។

[881] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២៤-៣៩២៥, ៤០៤៩-៤០៥០, ៤០៥៨-៤០៦១។

[882] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៦, ៤២៩៩-៤៣០០, ៤៣០៦។

[883] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨១៨-១៨២០។

ដែលត្រូវបានកំណត់នៅត្រង់កថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយនេះដែរ[884]។ ហេតុដូចនេះ ដោយសារពុំមានការកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ណាមួយនោះ ការចោទប្រកាន់លើរូប ខៀវ សំផន គឺខុសច្បាប់[885]។

៤៩៤. អង្គជំនុំជម្រះបានបដិសេធចោលទឡ្ហីករណ៍មួយនេះ តាមរយៈការអានដោយពុំត្រឹមត្រូវនូវដីកាដំណោះស្រាយ និងវិធានច្បាប់មួយចំនួន ដោយអង្គជំនុំជម្រះយល់ឃើញជាអាទិ៍ថា ក្រុមទាំងបីដែលត្រូវបានកំណត់ ពុំត្រូវបានកំណត់ឱ្យអស់នោះទេ ហើយថា ក្រុមទាំងបីនេះអាចវិវត្តទៅតាមពេលវេលា[886]។ សេចក្ដីសន្និដ្ឋានទាំងនេះ គឺមានកំហុសអង្គច្បាប់ ហើយដូច្នេះ ត្រូវទុកជាមោឃៈ ដូចគ្នាដែរសម្រាប់ការផ្តន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុដែលត្រូវបានចោទប្រកាន់[887]។

**ផ្នែកទី ៥. ក្រាំងតាចាន់**

**១. គ្មានបណ្ដឹងពីអង្គហេតុនៃ "ការរើសអើង" ចំពោះប្រជាជនថ្មី**

៤៩៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថាខ្លួនបានទទួលបណ្ដឹងជាក់ស្ដែង និងមានយុត្តាធិការវិនិច្ឆ័យអង្គហេតុ "ការរើសអើង" ចំពោះប្រជាជនថ្មី ដោយមូលហេតុនយោបាយ នៅក្រាំងតាចាន់[888]។ អង្គជំនុំជម្រះគួរតែពិនិត្យកថាខណ្ឌពាក់ព័ន្ធនានាដែលបង្ហាញឱ្យឃើញថាគ្មាន"ការរើសអើង" ចំពោះប្រជាជនថ្មី (១.១) និងត្រូវកត់សម្គាល់ថា ខ្លួនមិនអាចផ្តន្ទាទោសហួសពីបណ្តឹងឡើយ (១.២)។

---

[884] ដីកាដំណោះស្រាយ កថាខណ្ឌ ៣៨៣-៣៨៤, ១៤១៦-១៤១៧ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១១២០-១១២៣។

[885] សូមមើលខាងលើ កថាខណ្ឌ ៣៥៩-៤៦៤។

[886] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧០។

[887] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨១៤-១៨២៤។

[888] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៣៥-២៨៣៦។

**១.១. គ្មានអង្គហេតុរើសអើងណាមួយចំពោះប្រជាជនថ្មី នៅក្នុងផ្នែកពិពណ៌នាអំពីអង្គហេតុ នៅកថាខណ្ឌ ៤៨៩-៥១៤ នៃដីកាដំណោះស្រាយ**

៤៩៦. នៅកថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបញ្ជាក់ពីរបៀបនៃការអនុវត្តការធ្វើទុក្ខបុកម្នេញ នៅតាមទីតាំងឧក្រិដ្ឋកម្មផ្សេងៗ៖

> "**នៅតាមសហករណ៍ និងនៅតាមការដ្ឋានធ្វើការដោយបង្ខំ** ដូចនៅពេល**ផ្លាស់ទីលំនៅប្រជាជន**ដែរ ខ្មាំងពិត ឬតាមការសន្មតរបស់ ប.ក.ក ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងល័ក្ខខ័ណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនោះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅកសាងឡើងវិញ ឬកម្ទេចចោលនៅតាម**មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស**" (សរសេរជាអក្សរដិតនៅក្នុងអត្ថបទដើម)។

៤៩៧. មានតែអង្គហេតុនៃការចាប់ខ្លួន ការលត់ដំ និងការកម្ទេចមនុស្សប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងក្រាំងតាចាន់ និងបង្ហាញពីការរើសអើងដែលទទួលរង។ អ្នកជាប់ឃុំគ្រប់គ្នា រស់នៅ និងធ្វើការក្នុងល័ក្ខខ័ណ្ឌដូចៗគ្នា។ ពុំមានការបង្ហាញថា នៅក្រាំងតាចាន់ សមាជិកក្រុមដែលត្រូវបានកំណត់អត្តសញ្ញាណដោយសហចៅក្រមស៊ើបអង្កេត ត្រង់កថាខណ្ឌ ១៤១៧ ត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពរស់នៅលំបាកធ្ងន់ធ្ងរជាងអ្នកផ្សេងទៀតនោះទេ។ ពាក់ព័ន្ធនឹងប្រជាជនថ្មី មានការលើកឡើងពីរដងនៅក្នុងការអធិប្បាយអំពីអង្គហេតុនៅក្នុងដីកាដំណោះស្រាយ ទាក់ទងនឹងក្រាំងតាចាន់ ដែលសហចៅក្រមស៊ើបអង្កេតបានយោងសម្រាប់កំណត់បទចោទ។ នៅត្រង់កថាខណ្ឌ ៤៩៨ មានការលើកឡើងថា ពេលទៅដល់ត្រាំកក់ "ប្រជាជនថ្មី" បានសរសេរប្រវត្តិរូបខ្លួន។ បន្ទាប់មក នៅកថាខណ្ឌ ៥០០ ពាក់ព័ន្ធនឹងសមាសភាពអ្នកជាប់ឃុំ សហចៅក្រមស៊ើបអង្កេតបញ្ជាក់ថា៖

> "បុរស ស្ត្រី និងកុមារ រួមទាំងគ្រួសារ ត្រូវបានឃុំខ្លួននៅក្រាំងតាចាន់។ មានសាក្សីប្រាំបីនាក់ជាអតីតអ្នកជាប់ឃុំឃាំង។ សាក្សីបានឱ្យដឹងថា ភាគច្រើននៃអ្នកជាប់ឃុំឃាំងជាប្រជាជនថ្មី

មកពីភ្នំពេញ។ ប៉ុន្តែ ក៏មានប្រជាជនមូលដ្ឋាន អតីតទាហាន លន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ចិន វៀតណាម និងចាម ស្ថិតនៅក្នុងចំណោមអ្នកជាប់ឃុំឃាំងដែរ"។

៤៩៨. សេចក្តីសន្និដ្ឋាននេះបដិសេធចោលនូវអត្ថិភាពនៃការរើសអើង ព្រោះថាមនុស្សគ្រប់គ្នា ដោយពុំមានការបែងចែកអាយុ ភេទ សញ្ជាតិ ឬមុខងារ សុទ្ធតែត្រូវរងគ្រោះដោយការចាប់ខ្លួន។ សហចៅក្រមស៊ើបអង្កេតអាចនឹងចង់និយាយថា ប្រជាជនថ្មីត្រូវបានចាប់ខ្លួនញឹកញាប់ជាងជនរួមជាតិរបស់ពួកគេ តែក៏គ្មានព័ត៌មានណាមួយទាក់ទងនឹងចំណុចមួយនេះដែរ។ នៅត្រង់កថាខណ្ឌ ៥០១ នៃដីកាដំណោះស្រាយ មានការលើកឡើងថា "ភ័ស្តុតាងបានបង្ហាញថា អ្នកទោសត្រូវបានបែងចែកជាពីរប្រភេទ មានអ្នកទោសកម្រិតស្រាល និងធ្ងន់"។ ក្នុងកថាខណ្ឌនេះ គ្មានកន្លែងណាមួយដែលនិយាយទៅដល់ក្រុមណាមួយដែលត្រូវបានលើកឡើងត្រង់កថាខណ្ឌ ៥០០ នោះទេ។ ហេតុដូច្នេះ គេមិនអាចនិយាយបានថា ដោយសារតែជាប្រជាជនថ្មី មនុស្សម្នាក់អាចប្រឈមខ្លាំងនឹងការត្រូវបានចាត់បញ្ចូលក្នុងចំណោមអ្នកទោសធ្ងន់។ ក៏ប៉ុន្តែ សេចក្តីសន្និដ្ឋានតែមួយគត់នេះ ទំនងជាអាចបង្ហាញឱ្យឃើញពីការរើសអើង ដែលអាចកំណត់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ជាចុងក្រោយ ចន្លោះពីកថាខណ្ឌ ៥១០ ដល់កថាខណ្ឌ ៥១៤ ក្រោមចំណងជើងថា "ការបាត់ខ្លួន និងការសម្លាប់" គឺពុំមានការលើកឡើងអំពីប្រជាជនថ្មីទាល់តែសោះ។ ផ្ទុយពីអ្វីដែលត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌ ១៤១៨ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតពុំបានយោងលើការរៀបរាប់នេះ ដើម្បីគាំទ្រការលើកឡើងថាមានការរើសអើងចំពោះប្រជាជនថ្មី។ ដូច្នេះ គ្មានអង្គហេតុណាមួយ ជាមូលដ្ឋាននៃការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ត្រង់កថាខណ្ឌ ១៤១៨ នោះទេ។ ដូច្នេះ គ្មានអង្គហេតុណាមួយ ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើប្រជាជនថ្មីនៅក្រាំងតាចាន់ បង្កើតបានជាការចោទប្រកាន់ដែល ខៀវ សំផន ត្រូវឆ្លើយតបឡើយ។

## ១.២. ការផ្តន្ទាទោសចំពោះអង្គហេតុ "ការរើសអើង" លើប្រជាជនថ្មី នៅក្រៅបណ្តឹង

៤៩៩. ដោយហេតុតែ ខៀវ សំផន មិនត្រូវបានចោទប្រកាន់ដោយត្រឹមត្រូវចំពោះអង្គហេតុដែលត្រូវបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងប្រជាជនថ្មី នៅក្រាំងតាចាន់ ដូច្នេះសេចក្តីសន្និដ្ឋានលើអង្គហេតុនានារបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងអំពើ "រើសអើង" ចំពោះប្រជាជនថ្មី គឺហួសពីសមត្ថកិច្ច

របស់អង្គជំនុំជម្រះ[889]។ ផ្អែកលើសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសម្រេចថា ធាតុផ្សំសត្យានុម័តិ និងអត្ថនោម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជនថ្មី ត្រូវបានបំពេញ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបញ្ចូលអង្គហេតុទាំងនេះ ដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជនថ្មី ទៅក្នុងគោលនយោបាយមួយ ដែលអង្គជំនុំជម្រះកំណត់ថាមានលក្ខណៈ "ឧក្រិដ្ឋ"[890]។ សេចក្តីសន្និដ្ឋានទាំងនេះ ត្រូវទុកជាមោឃៈ ហើយដូចគ្នាសម្រាប់ការប្រកាសពីពិរុទ្ធភាព ខៀវ សំផន សម្រាប់អង្គហេតុទាំងនេះ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម[891]។

## ២. គ្មានបណ្តឹងពីអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៥០០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនបានទទួលបណ្តឹងជាក់ស្តែង និងមានយុត្តាធិការវិនិច្ឆ័យលើអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយមូលហេតុនយោបាយ នៅក្រាំងតាចាន់[892]។ អង្គជំនុំជម្រះគួរតែពិនិត្យកថាខណ្ឌពាក់ព័ន្ធនានានៃដីកាដំណោះស្រាយ ដែលបង្ហាញឱ្យឃើញថាគ្មានអង្គហេតុ "ការរើសអើង" ណាមួយចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ (២.១) ហើយគួរកត់សម្គាល់ថាខ្លួនមិនអាចផ្តន្ទាទោសហួសពីបណ្តឹងឡើយ (២.២)។

### ២.១. គ្មានអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងចំណោមអង្គហេតុនានាឡាយ ក្នុងកថាខណ្ឌ ៨៤៩-៩១៤ នៃដីកាដំណោះស្រាយ

[889] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៣៩-២៨៤១។

[890] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៣, ៣៩៨៧។

[891] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[892] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៣៥-២៨៣៧។

៥០១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យទោស ខៀវ សំផន ចំពោះអង្គហេតុនៃការរើសអើងចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្រាំងតាចាន់[893]។ ដូចបានលើកឡើងខាងលើ ពាក់ព័ន្ធនឹង "ការរើសអើង" ចំពោះប្រជាជនថ្មី នៅក្រាំងតាចាន់ ត្រង់កថាខណ្ឌ ១៤១៨ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីរបៀបនៃការប្រព្រឹត្តិអំពើធ្វើទុក្ខបុកម្នេញ នៅតាមទីតាំងឧក្រិដ្ឋកម្មផ្សេងៗ៖

> "**នៅតាមសហករណ៍ និងនៅតាមការដ្ឋានធ្វើការដោយបង្ខំ** ដូចនៅពេល**ផ្លាស់ទីលំនៅប្រជាជន**ដែរ ខ្លាំងពិត ឬតាមការសន្មតរបស់ ប.ក.ក ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងល័ក្ខខ័ណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនោះក៏ត្រូវបានគេចាប់ខ្លួនជាក្រុមៗផងដែរ ដើម្បីយកទៅកសាងឡើងវិញ ឬទៅកម្ទេចចោលនៅតាម**មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស**" (សរសេរជាអក្សរដិតនៅក្នុងអត្ថបទដើម)។

៥០២. មានតែអង្គហេតុនៃការចាប់ខ្លួន ការលត់ដំ និងការកម្ទេចមនុស្សប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងក្រាំងតាចាន់ និងបង្ហាញពីការរើសអើងដែលទទួលរង។ ត្រង់កថាខណ្ឌ ៤៩៨ នៃដីកាដំណោះស្រាយ ក្នុងការពិនិត្យលើអង្គហេតុទាក់ទងនឹងក្រាំងតាចាន់ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានលើជោគវាសនារបស់អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្រាំងតាចាន់។ ពាក់ព័ន្ធនឹងអង្គហេតុកើតឡើងក្នុងបរិវេណក្រាំងតាចាន់ផ្ទាល់ គឺមានការលើកឡើងពីអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ តែនៅត្រង់កថាខណ្ឌ ៥០០ ប៉ុណ្ណោះ ដោយមានន័យសេចក្តីជាអាទិ៍ថា "[...] ក៏មានប្រជាជនមូលដ្ឋាន អតីតទាហាន លន់ នល់ កម្មាភិបាល ប.ក.ក ចិន វៀតណាម និងចាម ស្ថិតនៅក្នុងចំណោមអ្នកជាប់ឃុំឃាំងដែរ"។ សេចក្តីសន្និដ្ឋាននេះបដិសេធចោលការចោទប្រកាន់ថាមានការរើសអើង ព្រោះថាមនុស្សគ្រប់គ្នា ដោយពុំមានការបែងចែកអាយុ ភេទ សញ្ជាតិ ឬមុខងារ សុទ្ធតែត្រូវរងគ្រោះដោយការចាប់ខ្លួន។

---

[893] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៣៥-២៨៣៦។

៥០៣. សហចៅក្រមស៊ើបអង្កេតពុំបានរាយការណ៍ពីភស្តុតាងបង្ហាញពីអត្ថិភាពនៃការរើសអើង ដែលត្រូវបានប្រព្រឹត្តចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងបរិវេណក្រាំងតាចាន់ផ្ទាល់នោះទេ។ ដូច្នេះ គ្មានអង្គហេតុណាមួយជាសំអាងនៃសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ត្រង់កថាខណ្ឌ ១៤១៨។ ហេតុដូច្នេះ គ្មានអង្គហេតុណាមួយពាក់ព័ន្ធនឹងការប្រព្រឹត្តិលើអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ នៅក្រាំងតាចាន់ បង្កើតបានជាការចោទប្រកាន់ដែល ខៀវ សំផន ត្រូវឆ្លើយតប។

## ២.២. ការផ្តន្ទាទោសចំពោះអង្គហេតុ "ការរើសអើង" លើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្រៅវិសាលភាពនៃការជំនុំជម្រះ

៥០៤. អង្គជំនុំជម្រះគ្មានយុត្តាធិការវិនិច្ឆ័យលើអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្រាំងតាចាន់។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះលើអង្គហេតុ "ការរើសអើង" ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានធ្វើឡើងដោយរំលោភលើបណ្តឹងជាក់ស្តែង ហើយសេចក្តីសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ[894]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានបង្ហាញ[895]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានបញ្ចូលអង្គហេតុទាំងនេះ ដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទៅក្នុងគោលនយោបាយដែលខ្លួនកំណត់ថាមានលក្ខណៈ "ឧក្រិដ្ឋ"[896]។ សេចក្តីសន្និដ្ឋានទាំងនេះ ត្រូវទុកជាមោឃៈ ហើយដូចគ្នាសម្រាប់ការប្រកាសពិរុទ្ធភាព ខៀវ សំផន សម្រាប់អង្គហេតុទាំងនេះ ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម[897]។

[894] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៣៩, ២៨៤១-២៨៤៣។

[895] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៤៣, ៤០៥៨។

[896] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៥៨-៤០៦១។

[897] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៦, ៤២៩៩-៤៣០០, ៤៣០៦។

## ៣. បណ្តឹងតម្រិតត្រឹមក្រុមចំនួនបី នៅក្នុងផ្នែកកំណត់ប្រភេទបទល្មើសនៃដីកាដំណោះស្រាយ

៥០៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា បណ្តឹងមកកាន់ខ្លួនអំពី អង្គហេតុនៅក្រាំងតាចាន់ ពង្រីកទៅហួសពីក្រុមខ្មាំងទាំងបីដែលត្រូវបានកំណត់នៅក្នុងផ្នែក "ការកំណត់ប្រភេទបទល្មើស" ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[898]។ អង្គជំនុំជម្រះគួរពិចារណាថាមានក្រុមតែបីប៉ុណ្ណោះដែលត្រូវបានកំណត់ក្នុងដីកាដំណោះស្រាយ (៣.១) និងគួរកត់សម្គាល់ថា ខ្លួនមិនអាចផ្តន្ទាទោសហួសពីបណ្តឹង ដែលត្រូវបានកំណត់យ៉ាងតឹងរ៉ឹងបានទេ (៣.២)។

### ៣.១. ក្រុមចំនួនបីគត់ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងដីកាដំណោះស្រាយ

៥០៦. នៅត្រង់កថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានជ្រើសយកឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅតាមទីតាំងឧក្រិដ្ឋកម្មជាច្រើន ក្នុងនោះមានក្រាំងតាចាន់ផងដែរ។ ជាបឋម កថាខណ្ឌ ១៤១៧ បានផ្តល់ព័ត៌មានទូទៅមួយចំនួនទាក់ទងនឹងការស្វែងយល់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅតាមទីតាំងឧក្រិដ្ឋកម្មទាំងអស់[899]។

---

[898] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៣៤ យោងទៅកថាខណ្ឌ ១៧០ និង ២៨៣៧។

[899] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៦៖ "អាជ្ញាធរនៃប.ក.កបានកំណត់អត្តសញ្ញាណ "ខ្មាំង" ជាច្រើនក្រុម ដោយសារមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬសន្មតរបស់ក្រុមមនុស្សទាំងនោះ ឬដោយសារមូលហេតុនៃការប្រឆាំងរបស់ពួកគេទៅនឹងអ្នកកាន់អំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ មនុស្សប្រភេទខ្លះនៃក្រុមមនុស្សទាំងនេះ ដូចជាអតីតថ្នាក់ដឹកនាំស៊ីវិល និងយោធានៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានរាប់បញ្ចូលក្នុងផែនការរួមនៃការកសាងលទ្ធិសង្គមនិយម។ ចំណែកឯភ្នាក់ងារតូចតាចនៃរបបចាស់ អ្នកខ្លះត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាដណ្តើមបានអំណាច ដោយសារការគាំទ្ររបស់ខ្លួនដល់រដ្ឋា- ភិបាលចាស់ ហើយជាញឹកញាប់ ពួកគេត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខ ដូចជាមន្ទីរ ស-២១ ឬទួលពោធិ៍ជ្រៃ។ ប្រជាជនទាំងអស់ដែលស្ថិតនៅតាមទីប្រជុំជន នៅពេលដែលប.ក.កដណ្តើមបានអំណាច ត្រូវបានចាត់ទុកជា "ប្រជាជនថ្មី" ឬ "ប្រជាជន១៧ មេសា" និងបានស្ថិតនៅក្រោមការប្រព្រឹត្តិតឹងរ៉ឹងជាងប្រជាជនចាស់ ក្នុងគោលបំណងលត់ដំ ឬកំណត់អត្តសញ្ញាណ "ខ្មាំង" នៅក្នុងចំណោមពួកគេ។ បញ្ញវន្ត និស្សិត និងអ្នកការទូតដែលរស់នៅបរទេស ត្រូវបានហៅឱ្យត្រឡប់ចូលស្រុកវិញ ហើយនៅពេលមកដល់ ពួកគាត់ត្រូវបានបញ្ជូនទៅជំរំលត់ដំ ឬទៅមន្ទីរ ស-២១" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ អង្គហេតុពាក់ព័ន្ធនឹង ស-២១ និងព្រៃស ត្រូវបានលើកឡើងនៅផ្នែកខាងក្រោម កថាខណ្ឌ ១១៧៥ និងកថាខណ្ឌបន្តបន្ទាប់។

៥០៧. ដូច្នេះ សហចៅក្រមស៊ើបអង្កេតលើកឡើងថា ក្រុមចំនួនបីត្រូវបានចាត់ប្រភេទថាជា "ខ្មាំង" ក្នុងនោះមានអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស។ កថាខណ្ឌដែលពុំមានផ្ដល់ព័ត៌មានបន្ថែមណាមួយ ទាក់ទងនឹងការកំណត់អត្តសញ្ញាណ "ប្រភេទ"ខ្មាំង"" ផ្សេងទាំងនេះ នោះទេ។ ឃ្លាចុងក្រោយរបស់កថាខណ្ឌ ១៤១៧ មានភាពស្រពេចស្រពិល។ គេមិនអាចដឹងបានថា សហចៅក្រមស៊ើបអង្កេតចង់និយាយពីអ្វីឡើយ។ សហចៅក្រមស៊ើបអង្កេតបង្ហាញធាតុផ្សំមួយ គឺ "ការកម្ចាត់ចោលបុគ្គលទាំងឡាយណា ដែលមិនយល់ស្របនឹងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា" ដែលឃ្លានេះទំនងជាទៅហួសពីនិយមន័យក្រុម ដែលកំណត់នៅក្នុងកថាខណ្ឌ ១៤១៧។ ដូច្នេះ បុគ្គលគ្រប់រូបអាចក្លាយជាជនរងគ្រោះនៃការធ្វើទុក្ខបុកម្នេញ ទោះជាគេមិនស្ថិតនៅក្នុងក្រុមណាមួយក៏ដោយ។ អ្វីដែលគេភ្លេចនោះគឺថា ការធ្វើទុក្ខបុកម្នេញសន្មតថាក្រុមមួយត្រូវបានកំណត់អត្តសញ្ញាណដោយអាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជា[900]។

៥០៨. ដោយសារថាលែងមានក្រុមដែលត្រូវបានកំណត់អត្តសញ្ញាណច្បាស់លាស់ហើយនោះ ដូច្នេះ ក៏លែងមានឧក្រិដ្ឋកម្មទៀតដែរ។ ក្នុងន័យនេះ ជំហររបស់អង្គជំនុំជម្រះតុលាការកំពូលចំពោះការកើនឡើងនៃអំពើឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានភាពច្បាស់លាស់ខ្លាំងណាស់៖

> "បន្តិចម្តងៗ ខណៈពេលដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងកម្ទេចដោយមិនរើសមុខ និងដោយគ្មានការផ្តល់យុត្តិកម្មសមហេតុផល ដោយមូលហេតុនយោបាយឡើយ។ <u>សកម្មភាពបែបនេះ មិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែ ជាការសាបព្រួសបរិយាកាសភ័យខ្លាច ដែលជនរងគ្រោះលែងត្រូវបានគេកំណត់គោលដៅ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលអាចយល់បានទៀតហើយ</u>"[901]។

[900] ធាតុផ្សំមួយនេះដែលផ្តល់ដោយសហចៅក្រមស៊ើបអង្កេត គឺជាការចាប់ដាក់ទៅក្នុងអង្គហេតុនូវសមាសភាគនៃនិយមន័យគតិយុត្តិរបស់អំពើឧក្រិដ្ឋកម្មដែលតម្រូវថា ការកំណត់និយមន័យក្រុមដោយចារីនៃអំពើឧក្រិដ្ឋកម្មត្រូវធ្វើឡើងដោយ "ផ្អែកលើមូលដ្ឋាននៃ លក្ខណៈវិនិច្ឆ័យជាក់លាក់មួយចំនួន" ហើយថាក្រុមនោះត្រូវតែ"អាចកំណត់អត្តសញ្ញាណបាន"។ សូមមើលខាងក្រោម កថាខណ្ឌ ១២១២-១២១៣។

[901] សាលដីកា *ឌុច* ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៨៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៥០៩. ដូច្នេះ ខៀវ សំផន ត្រូវឆ្លើយតបតែទៅនឹងការចោទប្រកាន់ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញទៅលើក្រុមទាំងបី ដែលត្រូវបានកំណត់យ៉ាងច្បាស់នៅត្រង់កថាខណ្ឌ ១៤១៧ ប៉ុណ្ណោះ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនទទួលបានបណ្តឹងជាក់ស្តែងលើអង្គហេតុ "ការរើសអើង" ចំពោះក្រុមមួយចំនួនដែល ខៀវ សំផន មិនទាំងស្គាល់សមាសភាព និងឈ្មោះផង។

## ៣.២. ការផ្តន្ទាទោសចំពោះ "ការរើសអើង" ចំពោះ "ក្រុម" ខ្មាំងពិតប្រាកដ ឬសន្មត នៅក្រៅបណ្តឹង

៥១០. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងអំពើ "រើសអើង" ចំពោះ "ក្រុម" ខ្មាំងពិតប្រាកដ ឬសន្មត ត្រូវបានធ្វើឡើង ដោយរំលោភលើបណ្តឹងជាក់ស្តែង[902]។ ផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងអង្គហេតុនៃ "ក្រុម" ខ្មាំងពិតប្រាកដ ឬសន្មត[903]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានបញ្ចូលអង្គហេតុទាំងអស់នេះ ដែលត្រូវបានកំណត់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើ "ក្រុម" ខ្មាំងពិតប្រាកដ ឬសន្មត ទៅក្នុងគោលនយោបាយមួយដែលអង្គជំនុំជម្រះកំណត់ថាមានលក្ខណៈ "ឧក្រិដ្ឋ"[904]។ សេចក្តីសន្និដ្ឋានទាំងនេះ ត្រូវទុកជាមោឃៈ ហើយដូចគ្នាដែរសម្រាប់ការប្រកាសពិរុទ្ធភាព ខៀវ សំផន សម្រាប់អង្គហេតុទាំងនេះ ក្រោមបទសហឧក្រិដ្ឋកម្មរួម[905]។

## ផ្នែកទី ៦. អូរកន្សែង

[902] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៣៩។

[903] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៤៣។

[904] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧៣, ៣៩៨៣, ៣៩៨៧។

[905] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

៥១១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយល់ឃើញថា ខ្លួនទទួលបានបណ្តឹងជាក់ស្តែង អំពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅអូរកន្សែង ពាក់ព័ន្ធនឹងក្រុម "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក"[906]។ អង្គជំនុំជម្រះយល់ឃើញថា "ក្រុមនេះរួមមានអ្នកបង្កគ្រោះថ្នាក់ដល់បដិវត្តន៍សង្គមនិយម អ្នករិះគន់ ឬអ្នកប្រឆាំងនឹងបក្ស [...] ព្រមទាំងជនជាតិវៀតណាម [...] (រួមទាំងអតីតទាហានធីវគី សមាជិកហ្វ៊ូលរ៉ូ និងជនជាតិចាវ៉ាយមកពីវៀតណាម)"[907]។

៥១២. ក៏ប៉ុន្តែ នេះគ្រាន់ជាការអានដីកាដំណោះស្រាយដោយមិនត្រឹមត្រូវប៉ុណ្ណោះ។ បើទោះបីជាអង្គហេតុមួយចំនួនទាក់ទងនឹងអ្នកទាំងនេះ ត្រូវបានពណ៌នានៅក្នុងកថាខណ្ឌ ៥៨៩ ដល់ កថាខណ្ឌ ៦២៣ នៃដីកាដំណោះស្រាយក៏ដោយ ក៏អង្គហេតុទាំងអស់នេះពុំត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់ជាប្រភេទបទល្មើសនោះដែរ។ អង្គហេតុពាក់ព័ន្ធនឹងក្រុមចំនួនបីប៉ុណ្ណោះ ត្រូវបានកំណត់បទចោទថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមាន អតីតទាហាន និង អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស[908]។ វាច្បាស់ណាស់ថា ក្រុមដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះ គឺពុំស្ថិតនៅក្នុងចំណោមក្រុមទាំងបីដែលត្រូវបានកំណត់បទចោទប្រកាន់ ក្នុងដីកាដំណោះស្រាយនោះទេ។ ម្យ៉ាងវិញទៀត ភាពខុសគ្នាក្នុងបញ្ជីដែលគ្មានក្បាលគ្មានកន្ទុយនេះ ដែលរៀបរាប់ពីក្រុម "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" បង្កើតឡើងដោយអង្គជំនុំជម្រះ គឺមិនស្របគ្នាអ្វីសោះទៅនឹងការកំណត់យ៉ាងតឹងរ៉ឹងនូវអ្វីដែលត្រូវហៅថាជាក្រុមមួយដែលមានការកំណត់ច្បាស់លាស់ ដើម្បីអាចបង្ហាញឱ្យឃើញពីការធ្វើទុក្ខបុកម្នេញ[909]។

៥១៣. ដូច្នេះ អង្គហេតុទាំងឡាយដែលត្រូវបានពិនិត្យដោយអង្គជំនុំជម្រះ គឺពុំត្រូវបានសហចៅក្រមស៊ើបអង្កេតកំណត់ជាប្រភេទបទល្មើសនោះទេ។ ការអានដីកាដំណោះស្រាយដោយពុំត្រឹមត្រូវបែបនេះ បាននាំទៅដល់ការពង្រីកវិសាលភាពនៃបណ្តឹងជាក់ស្តែង[910]។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំ

---

[906] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨០-២៩៨២។

[907] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨២។

[908] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៧។

[909] សូមមើលខាងក្រោម កថាខណ្ឌ ៨៤៩-៨៥៣។

[910] សូមមើលខាងលើ កថាខណ្ឌ ៣៥៩-៤៦៤។

ជម្រះ ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅអូរកន្សែង ត្រូវតែដកចេញ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋមួយនេះ[911]។

## ផ្នែកទី ៧. ភ្នំក្រោល

៥១៤. **<u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ</u>**៖ នៅក្នុងសំអាងហេតុសាលក្រមរងការជំទាស់ អង្គជំនុំជម្រះបានរំឭកថា បើយោងតាមដីកាដំណោះស្រាយ អង្គជំនុំជម្រះត្រូវបានស្នើឱ្យវិនិច្ឆ័យលើអង្គហេតុដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[912]។ ស្របតាមន័យនេះ អង្គជំនុំជម្រះបានកំណត់ប្រភេទបទល្មើសចំពោះអង្គហេតុ ហើយបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មដែលបានលើកឡើងនេះ ត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងអង្គហេតុដែលបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល[913]។

៥១៥. មេធាវីការពារក្តីបានបង្ហាញឱ្យអង្គជំនុំជម្រះឃើញរួចមកហើយថា អង្គជំនុំជម្រះមិនត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុទាំងអស់នេះទេ ព្រោះថាដីកាដំណោះស្រាយមិនបានកំណត់អត្តសញ្ញាណជនជាប់ឃុំថាស្ថិតក្នុងក្រុមណាមួយដែលត្រូវបានកំណត់ច្បាស់លាស់[914]។ សូមរំឭកថា សេចក្តីសន្និដ្ឋាននៅត្រង់កថាខណ្ឌ ១៤១៦ នៃដីកាដំណោះស្រាយ លើកឡើងថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញនៅភ្នំក្រោល។ ត្រង់កថាខណ្ឌ ១៤១៧ នៃដីកាដំណោះស្រាយ ក្រុមចំនួនបី ដែលត្រូវបានកំណត់ច្បាស់លាស់ បានទទួលរងគ្រោះដោយការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ក្នុងនោះមានអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាដែលត្រឡប់មកពីបរទេស។ ការលើកឡើងតែ មួយគត់អំពីសមាសភាពរបស់

---

[911] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨០-២៩៨៣ និង ៤៣០៦។

[912] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០១៩, ៣០២៤។

[913] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៣៦-៣១៥១។

[914] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣៨៦-១៣៨៩។

អ្នកជាប់ឃុំនៅទីតាំងភ្នំក្រោល គឺនៅកថាខណ្ឌ ៦៣៤[915]។ ក៏ប៉ុន្តែ ការលើកឡើងតែមួយគត់នេះ ពុំបានកំណត់អត្តសញ្ញាណអ្នកជាប់ឃុំនៅទី តាំងភ្នំក្រោលថាស្ថិតក្នុងក្រុមណាមួយជាក់លាក់នោះឡើយ ដែលវានាំឱ្យការចោទ ប្រកាន់លើ ខៀវ សំផន ក្លាយជាគ្មានមូលដ្ឋាន។ អង្គជំនុំជម្រះបានបដិសេធចោល ទឡ្ហីករណ៍មួយនេះ ហើយយល់ថា ខ្លួនត្រូវបានស្នើឱ្យពិនិត្យអង្គហេតុទាំងនេះ តាម រយៈការអានដីកាដំណោះស្រាយដោយពុំត្រឹមត្រូវ[916]។ អង្គជំនុំជម្រះយល់ឃើញថា ក្រុមទាំងបីមិនត្រូវបានកំណត់ឱ្យបានពេញលេញនោះទេ ហើយថាវាអាចវិវត្តទៅតាម ពេលវេលា[917]។ នៅក្នុងសារណាបណ្ដឹងសាទុក្ខនេះ មេធាវីការពារក្ដីបានបង្ហាញឱ្យ ឃើញរួចមកហើយថា ការវិភាគលើដីកាដំណោះស្រាយបែបពន្លាតដូច្នេះ គឺជាកំហុស អង្គច្បាប់ដ៏ធ្ងន់ធ្ងរបំផុត[918]។

៥១៦. ការពុំបានកំណត់អត្តសញ្ញាណក្រុមឱ្យបានច្បាស់លាស់ គឺមិនអាចបញ្ជូន ខៀវ សំផន ទៅជំនុំជម្រះសម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញបានទេ។ ដោយហេតុថាការចោទ ប្រកាន់មួយនេះគ្មានមូលដ្ឋានគាំទ្រ អង្គជំនុំជម្រះមិនអាចគិតថា ខ្លួនត្រូវបានស្នើឱ្យ ពិនិត្យលើអង្គហេតុទាំងនេះបានទេ ហើយមិនអាចចាត់ទុកថា អង្គហេតុទាំងនេះត្រូវ បានបង្ហាញនៅភ្នំក្រោលនោះឡើយ។ ក្នុងស្ថានភាពនេះ ដោយបានប្រកាសថា ខៀវ សំផន ជាប់ពិរុទ្ធចំពោះអង្គហេតុទាំងនេះ អង្គជំនុំជម្រះក៏បានរំលោភផងដែរលើច្បាប់ នីតិវិធីរបស់ខ្លួន។ ដូច្នេះ សេចក្ដីសន្និដ្ឋានទាំងអស់នេះ ត្រូវទុកជាមោឃៈ[919]។

915 ដីកាដំណោះស្រាយ កថាខណ្ឌ ៦៣៤៖ "អតីតអ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោលដែលត្រូវបានស្ដាប់ចម្លើយ បាននិយាយថាពួកគេត្រូវបានចាប់ខ្លួន ដោយសារត្រូវបានគេសង្ស័យថាជាជនក្បត់បដិវត្តន៍ អាចជាការជាប់ពាក់ព័ន្ធជាមួយវៀតណាម ឬអាចត្រូវបានចោទថាជាខ្មែរយៈសេរីអា"។

916 សំអាងហេតុសាលក្រម កថាខណ្ឌ ១៧០, ៣១៣៧។

917 សំអាងហេតុសាលក្រម កថាខណ្ឌ ១៧០។

918 សូមមើលខាងលើ កថាខណ្ឌ ៣៥៩-៤៦៤។

919 សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៣៦-៣១៥១។

**ជំពូកទី ៣. កំហុស និងផលវិបាក ពាក់ព័ន្ធនឹងក្រុមជាក់លាក់**

**ផ្នែកទី ១. ជនជាតិចាម**

**១. គ្មានបណ្ដឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ នៅភូមិទ្រា**

៥១៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបកស្រាយដីកាបញ្ជូនរឿងទៅ ជំនុំជម្រះថាមាន បញ្ចូលអង្គហេតុនៃការធ្វើមនុស្សឃាត ដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ដែលបាន កើតឡើងនៅមន្ទីរសន្តិសុខភូមិទ្រា[920]។ អង្គជំនុំ ជម្រះគួរពិចារណាពីវិសាលភាពជាក់ស្ដែងនៃបណ្ដឹង និងគួរកត់សម្គាល់ថា ខ្លួនមិនអាចផ្ដន្ទាទោសហួសពីបណ្ដឹងឡើយ។ កថាខណ្ឌ ១៣៧៨ នៃដីកាដំណោះ ស្រាយ បានកំណត់អំពីវិសាលភាពនៃបណ្ដឹងមកកាន់អង្គជំនុំជម្រះ ចំពោះការប្រព្រឹត្តិអំពើមនុស្សឃាត "នៅក្នុងក្របខ័ណ្ឌនៃការធ្វើបាបជនជាតិចាម" នៅមន្ទីរសន្តិសុខក្រូចឆ្មារ និងនៅវត្តអូរត្រកួន។ វិសាល ភាពនៃ ការជំនុំជម្រះត្រូវបានកំហិតដោយសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែល សេចក្ដី សម្រេចនេះបានដកចេញយ៉ាងច្បាស់ក្រឡែតនូវមន្ទីរសន្តិសុខក្រូចឆ្មារ។ ដូច្នេះ អង្គជំនុំជម្រះមិនដែល ធ្លាប់ត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុដែលជាធាតុផ្សំនៃការធ្វើមនុស្សឃាត ក្នុងបទឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងភូមិទ្រានោះទេ។

៥១៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយទាញការសន្និដ្ឋានហួសពីវិសាលភាពអង្គហេតុ និង ភូមិសាស្ត្រនៃបណ្ដឹង។ សេចក្ដីសន្និដ្ឋានស្ដីពីការកាប់សម្លាប់នៅភូមិទ្រា ត្រូវទុកជាមោឃៈ។ ជាអាទិ៍ ការអះអាងដែលថា "ក្នុងឆ្នាំ១៩៧៨ ប្រជាជនចាមជាច្រើននាក់មកពីស្រុកក្រូចឆ្មារ ត្រូវ បានគេចាប់ បញ្ជូនខ្លួន ទៅកាន់មន្ទីរសន្តិសុខភូមិទ្រា។ [...] អ្នកដែលត្រូវបានគេចាត់ទុក ថាជាជនជាតិចាម ត្រូវ បានគេសម្លាប់ [...]"[921]។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាម រយៈការធ្វើមនុស្សឃាត មិនត្រូវបាន បង្ហាញនោះទេ ពាក់ព័ន្ធនឹងអង្គហេតុដែលបាន ប្រព្រឹត្តទៅនៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងឆ្នាំ១៩៧៨[922]។ ជាចុងក្រោយ សេចក្ដីសន្និដ្ឋាន បន្តបន្ទាប់ក្រោយៗមកទៀត ទាក់ទិននឹងការបញ្ចូលអង្គហេតុទាំងនេះ

[920] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣០៥។

[921] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦។

[922] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦-៣៣០៨។

ទៅក្នុងគោល នយោបាយ និងការសន្និដ្ឋានថាគោលនយោបាយនេះមានលក្ខណៈឧក្រិដ្ឋ ត្រូវតែចាត់ទុកជាមោឃៈ[923]។ ដូចគ្នាដែរសម្រាប់ការប្រកាសពិរុទ្ធភាព ខៀវ សំផន ចំពោះអង្គ ហេតុទាំងនេះ ដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈ ការធ្វើមនុស្សឃាត ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម[924]។

## ២. គ្មានបណ្តឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្រោមបទសហឧក្រិដ្ឋកម្មរួម

៥១៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនត្រូវបានស្នើសុំឱ្យ ពិនិត្យអង្គហេតុដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខ បុកម្នេញដោយមូលហេតុនយោបាយចំពោះជនជាតិចាម "ពាក់ព័ន្ធនឹងការអនុវត្តគោល នយោបាយនេះ តាមរយៈសហឧក្រិដ្ឋកម្មរួម"[925]។ យោងតាមខ្លឹមសារកថាខណ្ឌ ១៥២៥ នៃដីកាដំណោះស្រាយ ខៀវ សំផន មិនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពាក់ព័ន្ធនឹងជនជាតិចាម តាមរយៈទម្រង់នៃការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម នោះទេ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានលើបទឧក្រិដ្ឋដោយអង្គជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សំដៅ លើជនជាតិចាម ក្រោមទម្រង់នៃការទទួលខុសត្រូវមួយនេះ ត្រូវទុកជាមោឃៈ [926]។

## ផ្នែកទី ២. ជនជាតិវៀតណាម

[923] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩២-៣៩៩៨។

[924] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[925] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩១។

[926] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩៥, ៣៩៩៨, ៤៣០៦។

៥២០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ខ្លួនត្រូវបានស្នើសុំឱ្យ ពិនិត្យលើអង្គហេតុពាក់ព័ន្ធនឹងជនជាតិវៀតណាម នៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ[927]។ អង្គហេតុទាំងនេះ មិនត្រូវបានបង្ហាញនៅត្រង់កន្លែងណាមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឬក៏នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយឡើយ ហើយក៏មិនដែលត្រូវបានចាត់ទុកថាជាកម្មវត្ថុនៃការស៊ើបអង្កេត ក្នុងអំឡុងពេលស៊ើបសួរនោះដែរ[928]។ ទាំងអស់នេះជាមូលហេតុដែលគ្មានអង្គហេតុណាមួយពាក់ព័ន្ធនឹងវិធានការប្រឆាំងជនជាតិវៀតណាមក្នុងដែនសមុទ្រ ត្រូវបានកំណត់ជាប្រភេទបទល្មើសនៅក្នុងដីកាដំណោះស្រាយ។ សេចក្ដីសម្រេច ដែលតាមរយៈនោះ អង្គជំនុំជម្រះបានសន្និដ្ឋានអំពីការទទួលបណ្ដឹង ដោយយោងទៅលើឯកសារតែមួយគត់នៅក្នុងកំណត់សម្គាល់ចុងឯកសារនៃដីកាដំណោះស្រាយ[929] បានបង្កឱ្យមានយុត្តិនិសេធ[930]។ ទូរលេខរបស់កងពល ១៦៤ ត្រូវបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេត ក្នុង ចំណោមឯកសាររបស់កម្ពុជាប្រជាធិបតេយ្យជាច្រើនផ្សេងទៀត ដើម្បីបង្ហាញឱ្យឃើញពីចេតនាក្នុងការកម្ទេចក្រុមជនជាតិវៀតណាម[931]។

៥២១. ផ្អែកលើធាតុផ្សំតែមួយគត់នេះ អង្គជំនុំជម្រះមិនអាចពង្រីកវិសាលភាពនៃបណ្ដឹង ទៅដល់អង្គហេតុមួយចំនួនដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាមនៅលើផ្ទៃសមុទ្របានទេ។ អង្គជំនុំជម្រះធ្លាប់បានរំឭករួចមកហើយថា "[ដីកាដំណោះ ស្រាយដែលមានលក្ខណៈលម្អិតជាង ត្រូវមានការពិពណ៌នានូវអង្គហេតុដែលត្រូវបានចោទប្រកាន់] និងការកំណត់លក្ខណៈគតិយុត្តិរបស់វា"[932]។ អង្គជំនុំជម្រះបានប្រព្រឹត្ត កំហុសអង្គច្បាប់ ដោយពុំបានទាញផលវិបាកចេញពីការកត់សម្គាល់ទាំងអស់នេះរបស់ខ្លួន។ ព័ត៌មានទាំងឡាយទាក់ទងនឹងការចោទប្រកាន់លើជនជាប់ចោទ ត្រូវតែ មានលក្ខណៈលម្អិត ច្បាស់លាស់ និងពេញលេញ ដើម្បីអាចឱ្យគាត់មានលទ្ធភាពរៀបចំការការពារខ្លួន[933]។ ផ្អែកលើ

[927] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥៧។

[928] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦៩-៧០។ សូមមើលផងដែរ ខាងលើ កថាខណ្ឌ ៤៣៥-៤៣៨។

[929] ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៦ កំណត់សម្គាល់ចុងឯកសារ ៣៤៨៧។

[930] សេចក្ដីសម្រេច ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ E380/2 កថាខណ្ឌ ២១។

[931] ដីកាដំណោះស្រាយ កថាខណ្ឌ ៨១៦ កំណត់សម្គាល់ចុងឯកសារ ៣៤៨៧។

[932] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦។

[933] សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៨២-៨៥។

មូលដ្ឋាននៃភស្តុតាងដាច់តែឯងមួយនេះ និងមានបង្ហាញ តែនៅក្នុងកំណត់សម្គាល់ចុងឯកសារ អង្គជំនុំជម្រះបានរំលោភលើសិទ្ធិរបស់ ខៀវ សំផន ក្នុងការរៀបចំការការពារខ្លួនឱ្យបានសមស្រប។ ដូច្នេះ អង្គជំនុំជម្រះមិនគួរណាប្រកាសឱ្យ ខៀវ សំផន ជាប់ពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមរយៈការធ្វើមនុស្សឃាត បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការសម្លាប់រង្គាល និងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត សម្រាប់អង្គហេតុពាក់ព័ន្ធនឹងជន ជាតិវៀតណាមនៅសមុទ្រនោះទេ[934]។ ខៀវ សំផន ត្រូវតែទទួលបានការលើកលែងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះ។

## ផ្នែកទី ៣. អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៥២២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងកំហុសអង្គហេតុយ៉ាងច្បាស់ក្នុងការវិនិច្ឆ័យ ដោយបានកាត់សេចក្តីលើអង្គហេតុ ពាក់ព័ន្ធនឹងអត្ថិភាពនៃការចោទប្រកាន់ពីគោលនយោបាយស្តីពីវិធានការជាក់លាក់ប្រឆាំងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ[935]។ អង្គជំនុំជម្រះគួរណាពិចារណាពីវិសាលភាពជាក់ស្តែងនៃបណ្តឹង (១) និងគួរកត់សម្គាល់ថា ខ្លួនមិនអាចផ្តន្ទាទោសហួសពីបណ្តឹងបានឡើយ (២)។

## ១. ការរំលោភលើបណ្តឹងជាក់ស្តែងដោយអង្គជំនុំជម្រះ

៥២៣. យោងតាមដីកាដំណោះស្រាយ ខៀវ សំផន ត្រូវបានចោទប្រកាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទៅលើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីរ ស-២១ និងនៅក្រាំងតាចាន់។ ដីកាដំណោះស្រាយមិនបានបង្ហាញថា អតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ស្ថិតក្នុងចំណោមក្រុមជាក់លាក់នោះទេ (១.១)។ ការពង្រីកវិសាលភាពនៃបណ្តឹងជាក់ស្តែងដោយអង្គជំនុំជម្រះ ក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី គឺគ្មានសុពល

[934] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥៦-៣៤៦១, ៣៤៩០, ៣៤៩៣, ៣៤៩៩-៣៥០១, ៣៥១៤-៣៥១៩ និង ៤៣០៦។

[935] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧៤, ៣៥២០។

ភាព (១.២)។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសយ៉ាងច្បាស់នៅក្នុងការវិនិច្ឆ័យ ដោយបានធានាឱ្យមានការពង្រីកវិសាលភាពនៃការជំនុំជម្រះ (១.៣)។

## ១.១. គ្មានការបង្ហាញពីអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងចំណោមក្រុមជាក់លាក់ នៅក្នុងដីកាដំណោះស្រាយ

៥២៤. ពាក់ព័ន្ធនឹងទីតាំងនានាដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ សហចៅក្រមស៊ើបអង្កេតពុំធ្លាប់ដែលបានទទួលភារកិច្ចឱ្យស៊ើបអង្កេតលើគោលនយោបាយជាយថាហេតុណាមួយ ដែលគាំទ្រដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ។ ដូច្នេះ តាមលក្ខណៈឡូហ្សិក នៅក្នុងដីកាដំណោះស្រាយ អតីតទាហាន និងអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ពុំត្រូវបានកំណត់ថាជាក្រុមជាក់លាក់ ជាមួយនឹងពុទ្ធសាសនិក ជនជាតិចាម ជនជាតិវៀតណាម ក្នុងផ្នែក "ឃ. ការប្រព្រឹត្តិលើក្រុមមនុស្សជាក់លាក់នានា" ក្រោមចំណងជើង "៧. ការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" នៅក្នុងដីកាដំណោះស្រាយ នោះទេ[936]។

## ១.២. ការពង្រីកវិសាលភាពនៃបណ្តឹងជាក់ស្តែង នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី

៥២៥. យោងតាមសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាក្រុមមួយ ហើយគោលនយោបាយមួយស្តីពីវិធានការជាក់លាក់មួយចំនួនត្រូវបានអនុវត្តទៅលើពួកគេ ព្រោះថាទីតាំងឧក្រិដ្ឋកម្មនានាដែលត្រូវបានជ្រើសរើសយកនៅក្នុងសំណុំរឿង ០០២/០២ គឺបានបង្ហាញឱ្យឃើញពីគោលនយោបាយមួយនេះ។ បើយោងតាមអង្គជំនុំជម្រះ "ការចោទប្រកាន់ចំពោះអង្គហេតុដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ ពាក់ព័ន្ធនឹងគោលនយោបាយនៃការចាត់ទុកជាគោលដៅនូវអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ"[937]។ ដើម្បីគាំទ្រដល់ការអះអាងនេះ អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងកំណត់សម្គាល់ជើងទំព័រ៖

---

[936] ដីកាដំណោះស្រាយ មាតិកាសង្ខេប ទំព័រ ៥ និងកថាខណ្ឌ ៧៤០ ដល់ ៨៤០។

[937] សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ E301/9/1 កថាខណ្ឌ ៤៤។

"ដីកាដំណោះស្រាយបានចោទប្រកាន់ថា មានប្រព័ន្ធមួយដែលកំណត់គោលដៅទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ។ អង្គហេតុរងការចោទប្រកាន់ពាក់ព័ន្ធនឹងប្រព័ន្ធនេះ ត្រូវបានបញ្ចូលក្នុងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសហករណ៍នៅត្រាំកក់ (ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៩) ការដ្ឋានទំនប់១មករា (ដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៦) មន្ទីរសន្តិសុខ ស-២១ (ដីកាដំណោះស្រាយ កថាខណ្ឌ ៤៣២) មន្ទីរសន្តិសុខក្រាំងតាចាន់ (ដីកាដំណោះស្រាយ កថាខណ្ឌ ៤៩៨, ៥០០)"[938]។

៥២៦. ការវិភាគរបស់អង្គជំនុំជម្រះពិតជាមានកំហុសច្បាស់ខ្លាំងណាស់។ ក្នុងចំណោមកថាខណ្ឌទាំងឡាយដែលត្រូវបានបង្ហាញខាងលើ គ្មានត្រង់ណាមួយដែលបង្ហាញពី "ប្រព័ន្ធ" ប្រឆាំងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយដែលពាក្យ "ប្រព័ន្ធ" នេះមានន័យមិនច្បាស់លាស់ និងបង្កជាបញ្ហាថែមទៀត។ វាពិបាកនឹងនិយាយតាមបែបផ្សេងពីនេះខ្លាំងណាស់ ព្រោះថា ដូចដែលបានលើកឡើងនៅក្នុងជំពូកមុន គ្មានកថាខណ្ឌណាមួយដែលត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ជើងទំព័រដែលលើកមកពិភាក្សា បានបង្ហាញពីការប្រព្រឹត្តិជាក់លាក់លើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរឡើយ លែកលែងតែកថាខណ្ឌ ៤៩៨ ចេញ។ អង្គជំនុំជម្រះអានដីកាដំណោះស្រាយដោយពុំត្រឹមត្រូវ ក្នុងនោះ កថាខណ្ឌ ២០៦ ក្រោមចំណងជើងថា "វិធានការផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា" បានបញ្ជាក់ច្បាស់ថា៖

"សហចៅក្រមស៊ើបអង្កេតត្រូវបានប្ដឹងអំពីការប្រព្រឹត្តិនានាប្រឆាំងនឹងជនជាតិចាម នៅក្នុងភូមិភាគកណ្ដាល ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ប្រឆាំងនឹងជនជាតិវៀតណាមនៅក្នុងខេត្តស្វាយរៀង និងខេត្តព្រៃវែង (ភូមិភាគបូព៌ា) និងក្នុងអំឡុងពេលនៃការចូលលុកលុយនៅប្រទេសវៀតណាម ការប្រឆាំងចំពោះពុទ្ធសាសនិកនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ និងការប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ព្រឹត្តិការណ៍ចុងក្រោយនេះ បង្កើតបានជាឧទាហរណ៍មួយក្នុងចំណោម

---

[938] សេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E301/9/1** កំណត់សម្គាល់ជើងទំព័រលេខ ៩៥។

ឧទាហរណ៍យ៉ាងច្រើននៃអំពើប្រឆាំងទៅនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។

៥២៧. វាពុំមែនជាគោលនយោបាយសំដៅចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទូទាំងផ្ទៃប្រទេសនោះទេ តែវាជាអង្គហេតុពីរប្រភេទ ដោយមួយប្រភេទពាក់ព័ន្ធនឹងការជម្លៀសប្រជាជនទីក្រុងភ្នំពេញ ដែលសហចៅក្រមស៊ើបអង្កេតនិយាយថា ពួកខ្លួនត្រូវបានស្នើសុំឱ្យពិនិត្យក្រោមរូបភាពជាវិធានការជាក់លាក់ប្រឆាំងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ហើយមួយប្រភេទទៀតគឺពាក់ព័ន្ធនឹងព្រឹត្តិការណ៍ផ្សេងៗទៀតដែលសហចៅក្រមស៊ើបអង្កេតមិនត្រូវបានស្នើសុំឱ្យពិនិត្យ ក្រោមទិដ្ឋភាពដូចគ្នានេះ។ ដូច្នេះ អង្គជំនុំជម្រះគ្មានយុត្តាធិការវិនិច្ឆ័យលើការទទួលខុសត្រូវរបស់ ខៀវ សំផន ដោយយោងទៅគោលនយោបាយជាយថាហេតុណាមួយរបស់ ប.ក.ក សំដៅចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរបានទេ។ ហេតុដូច្នេះ ខៀវ សំផន ពុំចាំបាច់ឆ្លើយតបទៅនឹងការអនុវត្តគោលនយោបាយដែលអង្គជំនុំជម្រះបង្កើតឡើងតាមទំនើងចិត្តនៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួននោះទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងការប្រព្រឹត្តិលើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅគ្រប់ទីតាំងឧក្រិដ្ឋកម្មទាំងអស់។

### ១.៣. កំហុសជាក់ស្តែងក្នុងការវិនិច្ឆ័យលើវិសាលភាពនៃការជំនុំជម្រះ

៥២៨. នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ តបតាមការស្នើសុំរបស់មេធាវីការពារក្តី អង្គជំនុំជម្រះបានធ្វើយុត្តិកម្មលើជំហរមួយនេះ និងបានផ្តល់ជូនភាគីតាមរយៈអ៊ីមែល នូវសំអាងហេតុនៃសេចក្តីសម្រេចមួយដែលបានចេញក្នុងអំឡុងពេលសវនាការ ដោយបានសម្រេចថា សំណួរទាំងឡាយរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅទំនប់ត្រពាំងថ្ម (ជាទីតាំងដែលពួកគេពុំត្រូវបានលើកឡើងមកបង្ហាញនៅក្នុងដីកាដំណោះស្រាយ) គឺមានភាពពាក់ព័ន្ធ បើទោះណាជាមានការជំទាស់ពីមេធាវីការពារក្តីរបស់ នួន ជា។ ទោះបីជាគ្មានគោលនយោបាយអ្វីសោះប្រឆាំងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងដីកាដំណោះស្រាយ ទាក់ទងនឹងអង្គហេតុ ដែលជាកម្មវត្ថុនៃការពិនិត្យក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានធ្វើយុត្តិកម្មលើ

អនិយតភាពនៃជំហររបស់ខ្លួន៖ "អង្គជំនុំជម្រះយល់ឃើញថា សំណួររបស់សហព្រះរាជអាជ្ញា គឺមានភាពពាក់ព័ន្ធនឹងអត្ថិភាពនៃគោលនយោបាយដែលត្រូវបានចោទប្រកាន់ ធ្វើឡើងប្រឆាំងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បន្ថែមទៅលើការបោសសម្អាតផ្ទៃក្នុង (sic)"[939]។

៥២៩. ជំហរនេះត្រូវបានប្រកាន់យកដោយផ្ទុយគ្នាទាំងស្រុងជាមួយនឹងវិសាលភាពនៃបណ្តឹងជាក់ស្តែង និងបានបណ្តាលឱ្យខាតបង់ពេលវេលាយ៉ាងច្រើនសន្ធឹកសន្ធាប់ ព្រោះថា សាក្សីមួយចំនួនត្រូវបានស្តាប់ចម្លើយទាក់ទងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ សម្រាប់គ្រប់ទីតាំងឧក្រិដ្ឋកម្មទាំងអស់ក្នុងសំណុំរឿង ០០២/០២។ សហព្រះរាជអាជ្ញាថែមទាំងទទួលបានពេលវេលាបន្ថែមទៀតផង ដើម្បីធ្វើការបង្ហាញឯកសារមួយចំនួនទាក់ទងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក្នុងអំឡុងពេលសវនាការលើឯកសារគន្លឹះ ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើក្រុមជាក់លាក់នានា[940]។ សេចក្តីសម្រេចមួយនេះមានកំហុសយ៉ាងជាក់ស្តែង និងបានជះឥទ្ធិពលទៅលើវិធីសាស្ត្ររបស់អង្គជំនុំជម្រះក្នុងសំអាងហេតុសាលក្រម។

## ២. ការផ្តន្ទាទោសក្រោមបទសហឧក្រិដ្ឋកម្មរួមចំពោះឧក្រិដ្ឋកម្មនៅក្រៅបណ្តឹង

៥៣០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានពង្រីកយុត្តាធិការលើអង្គហេតុ ដើម្បីបញ្ចូលអត្ថិភាពគោលនៃគោលនយោបាយចាត់វិធានការជាក់លាក់មួយចំនួនប្រឆាំងនឹងអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[941]។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់ពាក់ព័ន្ធនឹងអត្ថិភាពនៃគោលនយោបាយជាក់លាក់ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានធ្វើឡើងដោយរំលោភលើបណ្តឹងមកកាន់អង្គជំនុំជម្រះ[942]។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងនោះ ត្រូវទុកជាមោឃៈ ព្រោះថាវាមិនអាចយកធ្វើជាមូលដ្ឋាននៃការទទួលខុសត្រូវរបស់ ខៀវ សំផន ចំពោះសហឧក្រិដ្ឋកម្ម

[939] សារអេឡិកត្រូនិក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E362** (កត់សម្គាល់នៅក្នុងអត្ថបទដើម)។

[940] ប្រតិចារឹក ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/391.1** ម៉ោងប្រហែល 09.17.42។

[941] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧៤, ៣៥២០, ៣៩៨៨, ៤០២៣-៤០២៤។

[942] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០២៦-៤០៤៩។

រួម[943]។ ការផ្តន្ទាទោស ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវទុកជាមោឃៈ។

## មាតិកាទី ៤. ការដកអង្គហេតុចេញ តាមរយៈការបំបែកកិច្ចដំណើរការនីតិវិធី

### ជំពូកទី ១. អង្គច្បាប់

៥៣១. វិធានផ្ទៃក្នុងមានចែងអំពីការបំបែកកិច្ចដំណើរការនីតិវិធី (វិធាន ៨៩ ស្ទួនពីរ) នៅក្នុងដំណាក់កាលជំនុំជម្រះ ហើយក៏មានចែងផងដែរអំពីការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ (វិធាន ៨៩ ស្ទួនបី)។

៥៣២. វិធាន ៨៩ ស្ទួនពីរ អនុញ្ញាតឱ្យអង្គជំនុំជម្រះបំបែកកិច្ចដំណើរការនីតិវិធី “ពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយ ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប។ ដូច្នេះ ការចោទប្រកាន់ត្រូវបានផ្តាច់ចេញពីគ្នា និងត្រូវជំនុំជម្រះដាច់ពីគ្នា។

៥៣៣. វិធាន ៨៩ *ស្ទួនបី* អនុញ្ញាតឱ្យអង្គជំនុំជម្រះ “អាចសម្រេចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដោយដកចេញនូវអង្គហេតុមួយចំនួនដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ” (វិធាន ៨៩ ស្ទួនបី-១)។ វាជាការបោះបង់ចោលជាស្ថាពរនូវរាល់ការចោទប្រកាន់ (វិធាន ៨៩ ស្ទួនបី-៣)៖

> “អង្គជំនុំជម្រះសាលាដំបូង ត្រូវបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានដកចេញ។ នៅពេលដែលសេចក្តីសម្រេចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះចូលជាស្ថាពរ

---

[943] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

អង្គហេតុដែលត្រូវបានដកចេញ នឹងមិនអាចត្រូវប្រើជាមូលដ្ឋានសម្រាប់ដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដដែលនោះបានឡើយ”[944]។

៥៣៤. ក្រុមអ្នកតាក់តែងវិធាននេះ បានដាក់បញ្ចូលទៅក្នុងការបោះបង់ចោលនូវការចោទប្រកាន់មួយនេះ នូវគោលការណ៍ *non bis in idem* ដែលចែងថា “គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសាជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ”[945]។

៥៣៥. អាស្រ័យហេតុនេះ តាមរយៈការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសម្រេចពិនិត្យអង្គហេតុដែលខ្លួនបានដកចេញ នៅពេលក្រោយ។ អង្គជំនុំជម្រះមិនពិនិត្យលើអង្គហេតុទាំងនោះជាបណ្តោះអាសន្ន។ តាមរយៈការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ អង្គជំនុំជម្រះសម្រេចលែងពិនិត្យអង្គហេតុដែលខ្លួនបានដកចេញ។ អង្គជំនុំជម្រះមិនពិនិត្យលើអង្គហេតុទាំងនោះជាស្ថាពរ។ ពេលដែលអង្គជំនុំជម្រះបានសម្រេចលើអង្គហេតុ ឬបានបោះបង់ចោលអង្គហេតុរួចហើយ ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវចូលជាស្ថាពររួចហើយនោះ អង្គហេតុទាំងអស់នោះលែងអាចយកមកប្រើធ្វើជាមូលដ្ឋាននៃការចោទប្រកាន់លើជនជាប់ចោទបានទៀតហើយ។

៥៣៦. ក្នុងករណីបច្ចុប្បន្ននេះ អង្គជំនុំជម្រះបានបំបែកកិច្ចដំណើរការនីតិវិធីចំនួនពីរលើក ហើយបានកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២។ អង្គជំនុំជម្រះបានកំណត់វិសាលភាព និងបានវិនិច្ឆ័យសំណុំរឿង ០០២/០១ ដែលមានសាលក្រមចូលជាស្ថាពររួចហើយ[946]។ អង្គជំនុំជម្រះបានកំណត់វិសាលភាព និងបានវិនិច្ឆ័យសំណុំរឿង ០០២/០២[947] ហើយជាចុងក្រោយ បានសម្រេចបោះបង់អង្គហេតុដែលត្រូវ

---

[944] យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម។ វិធាន ៨៩ *ស្ទួនបី* បញ្ជាក់បន្តថា៖ “ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានដកចេញ អាចត្រូវបានប្រើប្រាស់ក្នុងករណីដែលភស្តុតាងទាំងនោះពាក់ព័ន្ធនឹងអង្គហេតុដែលនៅសល់ផ្សេងទៀត”។

[945] មាត្រា ១៤-៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[946] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36**។

[947] សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E301/9/1**, ឧបសម្ព័ន្ធកំណត់អំពីវិសាលភាពសំណុំរឿង ០០២/០២ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E301/9/1.1**។

បានដកចេញពីសំណុំរឿង ០០២/០១ និង ០០២/០២[948]។ សេចក្ដីសម្រេចនេះពុំត្រូវបានរងបណ្ដឹងឧទ្ធរណ៍នោះទេ ហើយដូច្នេះ សេចក្ដីសម្រេចនេះត្រូវចូលជាធរមាន[949]។

៥៣៧. អនុលោមតាមច្បាប់ជាធរមាន ទោះជាតាមវិធីណាក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចសម្រេចក្នុងសំណុំរឿង ០០២/០២ លើអង្គហេតុដែលខ្លួនធ្លាប់បានកាត់សេចក្ដីរួចហើយក្នុងសំណុំរឿង ០០២/០១ និងលើអង្គហេតុដែលខ្លួនធ្លាប់បានដកចេញពីសំណុំរឿង ០០២/០២ រួចហើយនោះដែរ ហើយអង្គជំនុំជម្រះខ្លួនឯងក៏បានបោះបង់ចោលអង្គហេតុទាំងអស់នោះជាស្ថាពរថែមទៀត។ ទោះជាត្រូវស្ថិតក្នុងការកំណត់ប្រភេទបទល្មើសដូចគ្នា ឬផ្សេងគ្នា ឬក៏ជាមួយនឹងអង្គហេតុផ្សេងទៀតដែលមានលក្ខណៈស្ថិតក្នុងការកំណត់ប្រភេទបទល្មើសតែមួយ ក៏ការពិនិត្យលើអង្គហេតុទាំងនោះ គឺជាការរំលោភលើវិធានផ្ទៃក្នុង និងគោលការណ៍ *non bis in idem*។

### ជំពូកទី ២. កំហុស និងផលវិបាកពាក់ព័ន្ធនឹងក្រុមជាក់លាក់

### ផ្នែកទី ១. ជនជាតិចាម

### ១. គ្មានបណ្ដឹងពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត/ការជម្លៀសដោយបង្ខំ

៥៣៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយពុំបានកំណត់វិសាលភាពនៃបណ្ដឹងមកត្រឹមអង្គហេតុនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ តែនៅក្នុងក្របខ័ណ្ឌនៃអង្គហេតុដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា (១.១) ហើយអង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គច្បាប់ដែរ ដោយបានផ្ដន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុនៅក្រៅវិសាលភាពនៃបណ្ដឹង (១.២)។

---

[948] សេចក្ដីសម្រេចចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ E439/5។

[949] គ្មានភាគីណាមួយបានប្ដឹងសាទុក្ខ ស្របតាមវិធាន ១០៤-៤-ក ដែលចែងអំពីបណ្ដឹងសាទុក្ខភ្លាមៗចំពោះសេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីនោះទេ។

## ១.១. បណ្តឹងពីការជម្លៀសប្រជាជន ដំណាក់កាលទីពីរ តែនៅក្នុងក្របខ័ណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

៥៣៩. អង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវថា ឧបសម្ព័ន្ធនៃសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម បានកំណត់អំពីវិសាលភាពសំណុំរឿង ០០២/០២ មកត្រឹមអង្គហេតុដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ២២៦, ២៦៨ និង ២៨១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបំភ្លេចកថាខណ្ឌ ៤៣ នៃសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលបានកំណត់យ៉ាងច្បាស់ពីវិសាលភាពនៃការជំនុំជម្រះ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ សម្រាប់ជនជាតិចាម ក្រោមការកំណត់ប្រភេទបទល្មើសថាជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។ កថាខណ្ឌមួយនេះពិតជាសំខាន់សម្រាប់កំណត់វិសាលភាពនៃការជំនុំជម្រះ៖

> “ដោយឡែក អង្គជំនុំជម្រះកត់សម្គាល់ថា ការជម្លៀសជនជាតិភាគតិចចាម បង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់ស្តីពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា រួមទាំងជាមធ្យោបាយមួយនៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការជម្លៀសប្រជាជន (ដំណាក់កាលទីពីរ) និងការប្រព្រឹត្តិចំពោះក្រុមដែលក្លាយជាគោលដៅ។ អង្គជំនុំជម្រះបានដកអង្គហេតុនៃការចោទប្រកាន់ទាំងនេះចេញ ដោយផ្អែកលើគោលនយោបាយពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាម រួមទាំងអង្គហេតុស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ចេញពីវិសាលភាពនៃសំណុំរឿង ០០២/០១។ ទោះជាយ៉ាងនេះក្តី ការប្រព្រឹត្តិចំពោះជនជាតិចាម និងអង្គហេតុស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា រួមទាំងក្នុងដំណើរការជម្លៀសប្រជាជន (ដំណាក់កាលទីពីរ) ត្រូវបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២”[950]។

---

[950] សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E301/9/1** កថាខណ្ឌ ៤៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៥៤០. អនុលោមតាមសេចក្តីសម្រេចនេះ អង្គជំនុំជម្រះត្រូវបានស្នើឱ្យពិនិត្យលើអង្គហេតុនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ សម្រាប់តែឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទៅលើជនជាតិចាម អំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ ប៉ុណ្ណោះ។

## ១.២. ការផ្តន្ទាទោសចំពោះអង្គហេតុនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ នៅក្រៅវិសាលភាពនៃបណ្តឹង

៥៤១. ដោយរំលោភលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនត្រូវបានស្នើឱ្យពិនិត្យ និងមានយុត្តាធិការជំនុំជម្រះលើអង្គហេតុនៅក្រៅវិសាលភាព នៃ"ការរើសអើង" ដោយមូលហេតុនយោបាយ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ (១.២.១)[951] និងលើអង្គហេតុនៃការជម្លៀសដោយបង្ខំ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ (១.២.២)[952]។

### ១.២.១. ការផ្តន្ទាទោសចំពោះអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុនយោបាយ នៅក្រៅវិសាលភាពនៃបណ្តឹង

៥៤២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសថា ខ្លួនមានយុត្តាធិការជំនុំជម្រះលើអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ ខណៈដែលអង្គហេតុទាំងនោះ មិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០២ ដូចដែលបានកំណត់នៅក្នុងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ[953]។ ដូច្នេះ ពាក់ព័ន្ធនឹងអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ រាល់សេចក្តីសន្និដ្ឋានទាំងឡាយដែលត្រូវបានធ្វើដោយរំលោភទៅលើវិសាលភាពនៃបណ្តឹង ត្រូវទុកជាមោឃៈ។

---

[951] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣២០។

[952] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤។

[953] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣២០។

ក្នុងនោះមានជាអាទិ៍ សេចក្ដីសន្និដ្ឋានដែលសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនចាមដោយបង្ខំ ពីភូមិភាគបូព៌ា ទៅកាន់ភូមិភាគកណ្ដាល ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងខែតុលា ឆ្នាំ១៩៧៥[954]។ ហេតុដូចនេះ សេចក្ដីសន្និដ្ឋានបន្តបន្ទាប់ក្រោយៗមកទៀត ទាក់ទិននឹងការបញ្ចូលអង្គហេតុទាំងអស់នេះ ដែលត្រូវបានកំណត់ប្រភេទបទល្មើសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅក្នុងគោលនយោបាយ ហើយ និងការសន្និដ្ឋានថាគោលនយោបាយនេះមានលក្ខណៈឧក្រិដ្ឋ ត្រូវទុកជាមោឃៈដូចគ្នា[955]។ ដូចគ្នាដែរសម្រាប់ការប្រកាសពិរុទ្ធភាព ខៀវ សំផន ចំពោះអង្គហេតុទាំងនេះ ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម[956]។

### ១.២.២. ការផ្ដន្ទាទោសចំពោះអង្គហេតុនៃការជម្លៀសដោយបង្ខំ នៅក្រៅវិសាលភាពនៃបណ្ដឹង

៥៤៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានប្រកាសថា ខ្លួនមានយុត្តាធិការជំនុំជម្រះលើអង្គហេតុនៃការជម្លៀសដោយបង្ខំ នៅក្នុងអំឡុងពេលនៃការផ្លាជម្លៀសប្រជាជន ដំណាក់កាលទីពីរក្រោមការកំណត់ប្រភេទបទល្មើសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត សម្រាប់ការជម្លៀសដោយបង្ខំ ខណៈដែលអង្គហេតុទាំងនេះនៅក្រៅវិសាលភាពដែលត្រូវបានកំណត់ដោយសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ[957]។ រាល់សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងអង្គហេតុនៃការជម្លៀសដោយបង្ខំ ត្រូវបានធ្វើឡើងហួសពីសមត្ថកិច្ច ហេតុដូច្នេះត្រូវទុកជាមោឃៈ[958]។ ដូចគ្នាដែរ សម្រាប់សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលសម្រេចថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ ត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងប្រជាជនចាម អំឡុងពេលនៃ

---

[954] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២២-៣៣២៦ យោងទៅកថាខណ្ឌ ៣២៦១-៣២៦៨។

[955] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩៥-៣៩៩៦, ៣៩៩៨។

[956] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[957] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣៣៥។

[958] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣៦-៣៣៣៩។

ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ[959]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានបញ្ចូលអង្គហេតុទាំងនេះ ដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ ទៅក្នុងគោលនយោបាយមួយដែលអង្គជំនុំជម្រះកំណត់ថាមានលក្ខណៈ "ឧក្រិដ្ឋ"[960]។ សេចក្តីសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ ហើយដូចគ្នាដែរសម្រាប់ការប្រកាសពិរុទ្ធភាព ខៀវ សំផន ចំពោះអង្គហេតុទាំងនេះ ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម[961]។

## ២. គ្មានបណ្តឹងពីអង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងៗទៀត/ការជម្លៀសដោយបង្ខំ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ

៥៤៤. លើសពីនេះទៅទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ទ្វេដង ដោយបានវិនិច្ឆ័យលើអង្គហេតុដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសប្រជាជនចាមដោយបង្ខំ ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ[962]។ អង្គជំនុំជម្រះបានរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ (២.១) ព្រោះថា ខៀវ សំផន ធ្លាប់បានត្រូវកាត់សេចក្តី និងផ្តន្ទាទោសជាស្ថាពររួចមកហើយ ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសប្រជាជនចាមដោយបង្ខំ ក្នុងក្របខ័ណ្ឌនៃការជម្លៀសប្រជាជន ដំណាក់កាលទីពីរ (២.២)[963]។

### ២.១. គោលការណ៍អាជ្ញាអស់ជំនុំ

[959] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៤០។

[960] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩៧-៣៣៩៨។

[961] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[962] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤។

[963] សូមមើលខាងលើ កថាខណ្ឌ ៩២៦-៩៣១, សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ផ្នែកសម្រេចសេចក្តី។

៥៤៥. គោលការណ៍អាជ្ញាអស់ជំនុំ អាចត្រូវបានឱ្យនិយមន័យថាជា "បណ្តុំនៃអានុភាពទាំងឡាយដែលភ្ជាប់ទៅនឹងសេចក្តីសម្រេចតុលាការ ពោលគឺសច្ចភាពនីត្យានុកូល"[964]។ គុណភាពមួយនេះ ដែលត្រូវបានផ្តល់ដល់គ្រប់សេចក្តីសម្រេចតុលាការ ពាក់ព័ន្ធនឹងការតវ៉ាដែលត្រូវបានកាត់សេចក្តីរួចរាល់ហើយ គឺ "រារាំងមិនឱ្យយករឿងរ៉ាវតែមួយមកជំនុំជម្រះឡើងវិញ រវាងភាគីដដែលៗ ក្នុងរឿងក្តីមួយផ្សេងទៀតនោះទេ តែត្រូវបើកផ្លូវតវ៉ា"[965]។ មូលដ្ឋាននៃគោលការណ៍នេះ ដែលត្រូវបានសម្តែងតាមបុរាណភាសិតឡាតាំង *res judicata pro veritate habetur* ou *res judicata pro veritae accipitur* (ដែលមានន័យថា៖ "រឿងរ៉ាវដែលត្រូវបានជំនុំជម្រះរួចរាល់ហើយ ត្រូវចាត់ទុកជាសច្ចភាព"[966]) គឺមានគោលបំណងចម្បងដើម្បីការពារសេចក្តីសម្រេចតុលាការ និងសច្ចភាពគតិយុត្តិ[967]។ គោលការណ៍អាជ្ញាអស់ជំនុំ គឺជាការរារាំងមិនឱ្យមានការដេញដោលឡើងវិញលើអង្គហេតុដែលត្រូវបានជំនុំជម្រះចប់រួចរាល់ហើយ។ ក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍អាជ្ញាអស់ជំនុំ គឺជាផ្នែកមួយនៃវិធានច្បាប់ និងយុត្តិសាស្ត្រ[968]។ ឧទាហរណ៍ តុលាការពិសេសទាំងអស់យល់ឃើញថា គោលការណ៍មួយនេះ "នាំទៅដល់

---

[964] សៀវភៅ វាក្យស័ព្ទច្បាប់ និពន្ធដោយ G. CORNU ន័យទីប្រាំរបស់ពាក្យ Autorité [de la chose jugée] បោះពុម្ពឆ្នាំ២០០៣ គ្រឹះស្ថានបោះពុម្ពផ្សាយ PUF។

[965] សៀវភៅ វាក្យស័ព្ទច្បាប់ និពន្ធដោយ G. CORNU ន័យទីពីររបស់ពាក្យ Chose [autorité de la chose jugée] បោះពុម្ពឆ្នាំ២០០៣ គ្រឹះស្ថានបោះពុម្ពផ្សាយ PUF។

[966] សាលក្រម *Delalic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ២២៨ និងកំណត់សម្គាល់ជើងទំព័រលេខ២៦០។

[967] សូមមើល តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Brumărescu ទល់នឹង ប្រទេសរូម៉ានី* (សំណើលេខ ២៨៣៤២/៩៥) ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦១ "ធាតុមួយក្នុងចំណោមធាតុផ្សំជាសារវន្តនៃឧត្តមភាពច្បាប់ គឺគោលការណ៍សន្តិសុខនៃទំនាក់ទំនងគតិយុត្តិ ដែលគោលការណ៍នេះមិនចង់ឱ្យដំណោះស្រាយស្ថាពរដែលផ្តល់ដល់វិវាទមួយដោយតុលាការ ត្រូវបានយកមកចោទជាបញ្ហាឡើងវិញ"។

[968] ឧទាហរណ៍ សូមមើល សាលក្រម *Delalic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) កថាខណ្ឌ ២២៨, *រដ្ឋអាជ្ញា ទល់នឹង Simic និងអ្នកផ្សេងទៀត* សំណុំរឿង IT-95-9-PT សេចក្តីសម្រេចលើ ១) សំណើរបស់ Stevan Torodovic សុំឱ្យពិនិត្យឡើងវិញសេចក្តីសម្រេចចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩ ២) សំណើរបស់ CICR សុំឱ្យពិនិត្យឡើងវិញដីកាកំណត់កាលបរិច្ឆេទចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ និង ៣) ល័ក្ខខ័ណ្ឌក្នុងការចូលមើលភ័ស្តុតាង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០០ កថាខណ្ឌ ៩-១០, *រដ្ឋអាជ្ញា ទល់នឹង Bizimungu និងអ្នកផ្សេងទៀត* សំណុំរឿង ICTR-99-50-T, *Decision on Prosper Mugiraneza's Second Motion to Dismiss for Deprivation of his Right to Trial Without Undue Delay* ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ៦, *រដ្ឋអាជ្ញា ទល់នឹង Karemera និងអ្នកផ្សេងទៀត* សំណុំរឿង ICTR-98-44-T សេចក្តីសម្រេចលើសំណើរបស់ Joseph Nzirorera សុំឱ្យ

សំណួរចង់ដឹងថា តើបញ្ហានេះធ្លាប់ត្រូវបានដោះស្រាយចប់សព្វគ្រប់ហើយ ឬនៅ នៅពេលដែលបុគ្គលម្នាក់ដដែល ត្រូវជំនុំជម្រះជាលើកទីពីរ”[969]។

## ២.២. ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ

៥៤៦. នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានអះអាងបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទីពីរ សម្រាប់ “ប្រជាជនពី ៣០០.០០០ ទៅ ៤០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅ នៅចន្លោះពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៧ ពីភូមិភាគមួយទៅភូមិភាគមួយទៀត”[970]។ ពាក់ព័ន្ធនឹងលក្ខណៈរើសអើងនៃការជម្លៀសប្រជាជនដែលត្រូវបានចោទប្រកាន់នេះវិញ តុលាការកំពូលបានអះអាងថា “ពុំអាចនិយាយបានថា មានការបង្ហាញឱ្យឃើញថាការជម្លៀសប្រជាជនត្រូវបានធ្វើឡើងក្នុងលក្ខណៈរើសអើង ឬដោយចេតនារើសអើង” ហើយថា “ការជម្លៀសប្រជាជន ដំណាក់កាលទីពីរពុំមែនជាការរើសអើង ឬកើតចេញពីចេតនាធ្វើទុក្ខបុកម្នេញ” នោះទេ[971]។ ការជម្លៀសប្រជាជនចាមត្រូវបានធ្វើឡើងពីភូមិភាគបូព៌ាទៅកាន់ភូមិភាគកណ្ដាល ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងខែតុលា ឆ្នាំ១៩៧៥[972]។ ដូច្នេះ ក្រោមបទចោទប្រកាន់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការជម្លៀសដោយបង្ខំ អង្គហេតុទាំងនេះត្រូវបានសម្រេចនៅក្នុងសាលដីកាស្ថាពរ នៃសំណុំរឿង ០០២/០១ ចប់រួចរាល់ ហើយសាលដីកានេះជាអាជ្ញាអស់ជំនុំ ពាក់ព័ន្ធនឹងអង្គហេតុទាំងអស់នេះ។ អនុលោមតាម

---

ដកចេញនូវការចោទប្រកាន់ថាមានការត្រូវរ៉ូវជាមួយJuvenal Kajelijeli អនុលោមតាមគោលការណ៍អាជ្ញាអស់ជំនុំ (« *Collateral Estoppel* ») ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៤, *រដ្ឋអាជ្ញា ទល់នឹង* Karadzic សំណុំរឿង IT-95-5/18-T, *Decision on Accused's Motion to Strike Scheduled Shelling Incident on Grounds of Collateral Estoppel* ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ កថាខណ្ឌ ៥។

[969] សាលក្រម *Delalic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ២២៨។

[970] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៥៨។

[971] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧០៥-៧០៦។

[972] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣៦ កំណត់សម្គាល់ជើងទំព័រលេខ១១២៧៤ យោងទៅកថាខណ្ឌ ២៩៩៣។

គោលការណ៍គ្មានការកាត់ទោសពីរដងលើបទល្មើសដដែល អង្គជំនុំជម្រះគួរតែកត់សម្គាល់ថា ខៀវ សំផន ធ្លាប់ត្រូវបានប្រកាសថាជាប់ពិរុទ្ធ និងផ្តន្ទាទោសជាស្ថាពរ ដោយតុលាការកំពូលរួចមកហើយ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត សម្រាប់អង្គហេតុពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ដំណាក់កាលទីពីរ[973]។ សេចក្តីសន្និដ្ឋានលើបទឧក្រិដ្ឋពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ ត្រូវទុកជាមោឃៈ[974]។

## ផ្នែកទី ២. ជនជាតិវៀតណាម

៥៤៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ខ្លួនអាចពិនិត្យលើអង្គហេតុដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ពាក់ព័ន្ធនឹងជនរងគ្រោះវៀតណាម នៅត្រាំកក់[975]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានទទួលស្គាល់ថា ជនជាតិវៀតណាមត្រូវបានដកចេញពីក្នុងការពិនិត្យអង្គហេតុដែលជាធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ដោយសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ ដូច្នេះ វាមិនត្រឹមត្រូវសោះឡើយដែលអង្គជំនុំជម្រះយល់ឃើញថា ដោយសារតែខ្លួនត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុដែលជាធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ នៅតាមទីតាំងមួយចំនួន ទើបខ្លួនអាចពិនិត្យលើអង្គហេតុពាក់ព័ន្ធនឹងជនរងគ្រោះវៀតណាមនៅតាមទីតាំងទាំងនេះបាន "បើទោះជាជនរងគ្រោះផ្សេងទៀតទាំងនេះ មិនទាន់ត្រូវ

---

[973] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០៨៩-១០៩០ និងផ្នែកសម្រេចសេចក្តីជាភាសាបារាំង ទំព័រ ៦២៣។

[974] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣៣៥-៣៣៤០, ៣៩៩៧-៣៩៩៨, ៤៣០៦។

[975] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥២។

បានបញ្ជាក់ច្បាស់ដូចនោះក៏ដោយ"[976]។ សូមរំឭកថា អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុ តែមិនមែនលើការកំណត់បទចោទប្រកាន់ឡើយ[977]។

៥៤៨. ក៏ប៉ុន្តែ សម្រាប់សហករណ៍ត្រាំកក់[978] ដីកាដំណោះស្រាយបានផ្តាច់ចេញយ៉ាងច្បាស់នូវអង្គហេតុពាក់ព័ន្ធនឹង "ការប្រព្រឹត្តិលើក្រុមជាក់លាក់នានា" ពីអង្គហេតុផ្សេងៗទៀត[979]។ នៅក្នុងផ្នែកអង្គហេតុពាក់ព័ន្ធនឹង "ការប្រព្រឹត្តិលើក្រុមជាក់លាក់នានា" អង្គហេតុមួយចំនួន ដែលអាចជាធាតុផ្សំនៃការបាត់ខ្លួនជនជាតិវៀតណាម ត្រូវបានលើកមកបង្ហាញ[980]។ អង្គហេតុទាក់ទងនឹងសហករណ៍ត្រាំកក់ ពុំស្ថិតនៅក្នុងនោះទេ។ ដូច្នេះ វាច្បាស់ណាស់ថា អង្គហេតុដែលអាចជាធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំ ដែលស្ថិតនៅក្រៅផ្នែកទាំងអស់នៃដីកាដំណោះស្រាយ ទាក់ទងនឹង "ការប្រព្រឹត្តិលើក្រុមជាក់លាក់នានា" នឹងមិនពាក់ព័ន្ធជាមួយជនរងគ្រោះវៀតណាមនោះទេ។ ភ័ស្តុតាងដែលត្រូវបានយោងដើម្បីគាំទ្រអង្គហេតុទាំងនេះ អាចបញ្ជាក់លើចំណុចនេះបាន[981]។ម្យ៉ាងវិញទៀត ឧទាហរណ៍ដែលលើកឡើងពីកំណត់ហេតុស្តាប់ចម្លើយរបស់ រៀល សន គឺបង្ហាញឱ្យឃើញច្បាស់ពីការផ្តាច់ចេញនេះ នៅក្នុងដីកាដំណោះស្រាយ។ ក្នុងអំឡុងពេលស្តាប់ចម្លើយ ជាដំបូង គាត់និយាយពីអង្គហេតុនៃការបាត់ខ្លួនពេលយប់ ជាពិសេសការបាត់ខ្លួនពូរបស់គាត់[982]។ ចំណុចត្រង់នេះ ត្រូវបានយោងដើម្បីគាំទ្រអង្គហេតុនៃការ

---

[976] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៥២។

[977] វិធាន ៩៨-២ នៃវិធានផ្ទៃក្នុង "សាលក្រមត្រូវសម្រេចសេចក្តីត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"។

[978] ជាទីតាំងតែមួយគត់ដែលលោក ខៀវ សំផន ត្រូវបានផ្តន្ទាទោសសម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ដែលក្នុងនោះមានជនរងគ្រោះវៀតណាម។

[979] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៩/៣២១ (សម្រាប់អង្គហេតុទាក់ទងនឹង "ការប្រព្រឹត្តិលើក្រុមជាក់លាក់នានា") និងកថាខណ្ឌ ៣១០-៣១៨ (សម្រាប់អង្គហេតុផ្សេងៗទៀត)។

[980] ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០។

[981] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១១ និង ៣១៨។

[982] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/5511** (D232/48 នៅក្នុងដីកាដំណោះស្រាយ) ERN 00402499 ទំព័រ ៣។

បាត់ខ្លួននៅត្រាំកក់ នៅក្រៅផ្នែកទាក់ទងនឹង "ក្រុមជាក់លាក់នានា"[983]។ ចុះមកក្រោមបន្តិច នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែល រៀល សន បាននិយាយពីជនជាតិវៀតណាមដែលបាន "បាត់ខ្លួន"[984]។ ចំណែកឯចំណុចនេះវិញ ត្រូវបានយោងដើម្បីគាំទ្រអង្គហេតុនៃការបាត់ខ្លួន នៅក្នុងផ្នែកទាក់ទងនឹង "ការប្រព្រឹត្តិលើក្រុមជាក់លាក់នានា"[985]។

៥៤៩. អង្គហេតុនៃការបាត់ខ្លួនដោយបង្ខំនៅសហករណ៍ត្រាំកក់ គឺមិនពាក់ព័ន្ធនឹងជនរងគ្រោះវៀតណាមឡើយ ដែលករណីរបស់ពួកគេត្រូវបានលើកយកមកពិភាក្សាយ៉ាងច្បាស់នៅក្នុងផ្នែកជាក់លាក់នៃដីកាដំណោះស្រាយ ហើយដែលផ្នែកនោះត្រូវបានដកចេញពីវិសាលភាពសំណុំរឿង ០០២/០២ ក្នុងពេលបំបែកកិច្ចដំណើរការនីតិវិធី។ ដូច្នេះ អង្គជំនុំជម្រះបានរំលោភលើវិសាលភាពនៃបណ្តឹង ដោយយល់ឃើញថា ក្រោមការការពារពីអង្គហេតុផ្សេងៗទៀតដែលជាធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំនៅត្រាំកក់ ខ្លួនអាចពិនិត្យលើអង្គហេតុពាក់ព័ន្ធនឹងជនរងគ្រោះវៀតណាម។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានទាំងឡាយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ពាក់ព័ន្ធនឹងជនរងគ្រោះវៀតណាមនៅត្រាំកក់ ត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះ[986]។

## ភាគទី ៣. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម

## មាតិកាទី ១. ការមិនគោរពគោលការណ៍នីត្យានុកូលភាព

### ជំពូកទី ១. កំហុសពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព

៥៥០. អង្គជំនុំជម្រះយល់ឃើញថា ល័ក្ខខ័ណ្ឌតម្រូវនៃភាពអាចដឹងជាមុនបានថាជាបទល្មើស និងភាពអាចដឹងជាមុនបានថាមានច្បាប់ចែង ដែលចាំបាច់ដល់ការគោរពគោលការណ៍នីត្យានុកូលភាព ត្រូវបានបំពេញ

[983] ដីកាដំណោះស្រាយ កថាខណ្ឌ ៣១៨ កំណត់សម្គាល់ចុងឯកសារ ១៣១៤។

[984] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/5511** (D232/48 នៅក្នុងដីកាដំណោះស្រាយ) ERN 00402500 ទំព័រ ៤។

[985] ដីកាដំណោះស្រាយ កថាខណ្ឌ ៣២០ កំណត់សម្គាល់ចុងឯកសារ ១៣១៩។

[986] សំអាងហេតុសាលក្រម កថាខណ្ឌ ១២០១-១២០៤, ៣៩២៧ និង ៤៣០៦។

"ជាលក្ខណៈទូទៅ" ក្រោយពីអង្គជំនុំជម្រះបានធ្វើការ "វាយតម្លៃដោយសត្យានុម័តិ" លើកត្តាចំនួនបីរួចមក ក្នុងនោះមានអត្ថិភាពនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការចូលរួម តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលអង្គហេតុកើតឡើង ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងមុខងាររបស់ជនជាប់ចោទ ក្នុងនាមជាសមាជិកនៃស្ថាប័នដឹកនាំរបស់កម្ពុជា[987]។ អង្គជំនុំជម្រះបានប្រកាន់យកផងដែរនូវវិធីសាស្ត្រដែលតុលាការកំពូលបានអនុវត្តក្នុងសាលដីកាសំណុំរឿង ០០២/០១ និងបានបដិសេធចោល[988] ទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលបានបង្ហាញឱ្យឃើញថា វិធីសាស្ត្របែបនេះមិនត្រឹមត្រូវនោះទេ[989]។

៥៥១. តាមរយៈការធ្វើដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ធ្ងន់ធ្ងរ ដោយពុំបានអនុវត្តលក្ខណៈវិនិច្ឆ័យគតិយុត្តិត្រឹមត្រូវនៃគោលការណ៍នីត្យានុកូលភាព។ តាមរបៀបឱកាសនិយម អង្គជំនុំជម្រះបានបំបែរកម្មវត្ថុនៃគោលការណ៍មួយនេះ (ផ្នែកទី ១) ដែលត្រូវបានបកស្រាយទៅតាមការប្រព្រឹត្តិរបស់ជនជាប់ចោទ តែមិនមែនទៅតាមគុណភាពរបស់ច្បាប់ទេ (ផ្នែកទី ២) ហើយអង្គជំនុំជម្រះបានពិនិត្យលំៗលើល័ក្ខខ័ណ្ឌតម្រូវជាសារវន្តនៃភាពអាចដឹងជាមុនបានថាជាបទល្មើស និងភាពអាចដឹងជាមុនបានថាមានច្បាប់ចែង (ផ្នែកទី ៣)។

### ផ្នែកទី ១. ការបំបែរកម្មវត្ថុនៃគោលការណ៍អាជ្ញាអស់ជំនុំ តាមបែបឱកាសនិយម

៥៥២. អង្គជំនុំជម្រះយល់ឃើញថា "ពាក់ព័ន្ធនឹងការដឹងឮថាមានច្បាប់ចែង និងភាពអាចគ្រោងទុកមុនបាន អង្គជំនុំជម្រះត្រូវតែពិចារណាលើសពីនិយមន័យបច្ចេកទេសនៃបទល្មើសនេះ ដោយគោរពទៅតាមគោលបំណងនៃគោលការណ៍នីត្យានុកូលភាព"[990]។ ក៏ប៉ុន្តែ ការពិចារណាលើគោលបំណងនៃគោល

---

[987] សំអាងហេតុសាលក្រម កថាខណ្ឌ ២០-៣២, ៣០០, ៣២៥-៣២៦, ៦៥១, ៦៥៤, ៦៦១, ៦៧២-៦៧៣, ៦៨៨, ៧០០, ៧១២, ៧២៣, ៧៥៧, ៧៥៩, ៧៦១-៧៦៣, ៧៦៥-៧៦៧, ៧៧០-៧៧១, ៧៨០-៧៨១, ៧៨៤-៧៨៩, ៣៧០៣, ៣៧០៤, ៣៧០៧, ៣៧២១។

[988] សំអាងហេតុសាលក្រម កថាខណ្ឌ ២០-៣២។

[989] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០០-៣៨០។

[990] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥១ (និងកំណត់សម្គាល់ជើងទំព័រលេខ២០១៧-២០១៨ យោងទៅផ្នែកផ្សេងៗទៀតនៃសំអាងហេតុសាលក្រម និងសាលដីកាសំណុំរឿង ០០២/០១), កថាខណ្ឌ ៣០។ ជាបឋម អង្គជំនុំជម្រះបានផ្តោតសំខាន់លើការពិនិ

ការណ៍នីត្យានុកូលភាព ដើម្បីគេចមិនពិនិត្យលើភាពអាចដឹងជាមុនបានថាជាបទល្មើស និងភាពអាចដឹងជាមុនបានថាមានច្បាប់ចែង នៃនិយមន័យបច្ចេកទេសនៃបទល្មើស គឺមិនត្រឹមតែផ្ទុយទៅនឹងច្បាប់ជាធរមានប៉ុណ្ណោះទេ តែថែមទាំងផ្ទុយទៅនឹងកម្មវត្ថុផ្ទាល់របស់គោលការណ៍នេះទៀតផង។

៥៥៣. យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប គឺច្បាស់លាស់ខ្លាំងណាស់៖

> "សញ្ញាណរបស់ "ច្បាប់" តម្រូវឱ្យមានលក្ខខ័ណ្ឌគុណភាព ក្នុងនោះមានភាពអាចដឹងជាមុនបានថាជាបទល្មើស និងភាពអាចដឹងជាមុនបានថាមានច្បាប់ចែង ជាដើម។ លក្ខខ័ណ្ឌគុណភាពទាំងអស់នេះ ត្រូវតែបំពេញឱ្យបាន ទាំងចំពោះការកំណត់និយមន័យនៃបទល្មើសក្តី ទាំងចំពោះទោសទណ្ឌដែលកើតចេញពីបទល្មើសនេះក្តី។ ផ្តើមចេញពីពាក្យពេចន៍នានាក្នុងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយបើចាំបាច់ ដោយមានជំនួយក្នុងការបកស្រាយបទប្បញ្ញត្តិនោះដោយតុលាការ អ្នកទទួលខុសត្រូវមុខច្បាប់ត្រូវតែអាចដឹងបានថា តើអំពើសកម្ម និងអំពើអកម្មអ្វីខ្លះដែលនាំឱ្យខ្លួនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ហើយថាតើទោសមួយណានឹងត្រូវប្រកាសចំពោះអំពើសកម្មដែលបានប្រព្រឹត្ត និង/ឬអំពើអកម្ម។ លើសពីនេះទៀត ភាពអាចដឹងថាមានច្បាប់ចែងនៃច្បាប់ មិនជំទាស់ទៅនឹងការស្វែងរកការប្រឹក្សាយោបល់ច្បាស់លាស់របស់បុគ្គលពាក់ព័ន្ធ ដើម្បីអាចវាយតម្លៃនៅក្នុងកម្រិតសមរម្យមួយ នៅក្នុងកាលៈទេសៈនៃរឿងហេតុ អំពីផលវិបាកទាំងឡាយដែលអាចកើតចេញពីអំពើកំណត់មួយ"[991]។

ត្យភាពអាចដឹងឮបានថាជាបទល្មើស និងភាពអាចដឹងមុនបានថាមានច្បាប់ចែង មុននឹងពិនិត្យលើការកំណត់ការចោទប្រកាន់ ឬទម្រង់នៃការចូលរួម៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៦ និង ៧៥៧, ៧៥៩, ៧៦១-៧៦៣, ៧៦៥-៧៦៧, ៧៧០-៧៧១, ៧៧៤-៧៧៨, ៧៨០-៧៨១, កថាខណ្ឌ ៦៥៤ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៦៦១ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៦៧៣ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៦៨៨ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៧០០ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៧១២ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៧២៣ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៧៨៩ និងកថាខណ្ឌបន្តបន្ទាប់, កថាខណ្ឌ ៣៧០៤ និងកថាខណ្ឌបន្តបន្ទាប់។

[991] សាលដីកា *Kafkaris ទល់នឹង ប្រទេសស៊ីប* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ១៤០។

"បទល្មើសត្រូវតែកំណត់ឱ្យបានច្បាស់លាស់ដោយច្បាប់ ទាំងច្បាប់ជាតិ ទាំងច្បាប់អន្តរជាតិ។ ល័ក្ខខ័ណ្ឌនេះត្រូវបានបំពេញ នៅពេលបុគ្គលអាចដឹងតាមពាក្យពេចន៍នៃបទប្បញ្ញត្តិពាក់ព័ន្ធ ហើយបើចាំបាច់ត្រូវមានជំនួយពីការបកស្រាយរបស់តុលាការ និងប្រឹក្សាច្បាប់ច្បាស់លាស់ថា តើអំពើសកម្ម និងអំពើអកម្មណាដែលនឹងនាំឱ្យខ្លួនមានការទទួលខុសត្រូវព្រហ្មទណ្ឌ"[992]។

"យោងតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស នីតិព្រហ្មទណ្ឌត្រូវតែកំណត់ឱ្យបានច្បាស់លាស់នូវបទល្មើស និងទោសទាំងឡាយដែលមានចែងដោយច្បាប់ សំដៅធ្វើយ៉ាងណាឱ្យច្បាប់នេះអាចឱ្យគេអាចដឹងឮបាន និងអាចគ្រោងទុកមុនបាន នៅក្នុងអានុភាពនៃការអនុវត្តរបស់វា។ ផ្តើមចេញពីពាក្យពេចន៍នានាក្នុងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយបើចាំបាច់ ដោយមានជំនួយក្នុងការបកស្រាយបទប្បញ្ញត្តិនោះដោយតុលាការ អ្នកទទួលខុសត្រូវចំពោះមុខច្បាប់ត្រូវតែអាចដឹងបានថា តើអំពើសកម្ម និងអំពើអកម្មអ្វីខ្លះដែលនាំឱ្យខ្លួនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ"[993]។

៥៥៤. អនុលោមតាមគោលការណ៍នីត្យានុកូលភាព និងកម្មវត្ថុរបស់វា គឺនិយមន័យនៃបទឧក្រិដ្ឋ (និងទោស)[994] ឯណោះទេ ដែលត្រូវតែអាចឱ្យគេដឹងឮបាន និងអាចគ្រោងទុកមុនបាន។ ដូច្នេះ វាមិនមែនជារឿងដែលត្រូវព្យាយាមពិនិត្យមើលថា តើបទល្មើសត្រូវផ្តន្ទាទោសដោយច្បាប់ ឬទេ នៅសម័យកាលនៃអង្គហេតុរងការចោទប្រកាន់។ គេត្រូវពិនិត្យផងដែរអំពីលក្ខណៈប្រាកដប្រជានៃការផ្តន្ទាទោសចំពោះបទល្មើសនោះដោយច្បាប់ ដើម្បីធានាថា "សាមីជនអាចដឹង [នៅសម័យកាលនៃអង្គហេតុ] បានថា តើអំពើសកម្ម និងអំពើអកម្មអ្វីខ្លះ ដែលអាចបណ្តាលឱ្យគាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ និងអាច

---

[992] សាលដីកា *Vasiliauskas ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥៤។

[993] សាលដីកា *G.I.E.M. S.R.L. និងអ្នកផ្សេងទៀត ទល់នឹង ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ២៤២។

[994] សាលដីកា *Kafkaris ទល់នឹង ប្រទេសស៊ីប* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ១៤៣-១៤៨, ១៥០។ សូមមើលផងដែរ សាលដីកា *Maktouf និង Damjanović ទល់នឹង ប្រទេសបូស្នី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ ៦៥-៧៦។

ឱ្យគាត់កែតម្រូវការប្រព្រឹត្តិរបស់ខ្លួនទៅតាមភាពជាក់ស្តែង"[995]។ គោលការណ៍នីត្យានុកូលភាព គឺជាមធ្យោបាយធានាការអនុវត្តនូវសេរិច្ឆា ចៀសវាងអំណាចផ្ដាច់ការ និងធានាសមភាពចំពោះការផ្ដន្ទាទោស[996]។

៥៥៥. ដោយផ្អែកលើយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះបានអះអាងថា តាមច្បាប់ "មានធាតុផ្សំមួយមិនអាចខ្វះបាន គឺការបកស្រាយតាមផ្លូវតុលាការ។ គេត្រូវបកស្រាយចំណុចស្រពេចស្រពិល និងសម្របទៅតាមការប្រែប្រួលនៃស្ថានការណ៍"[997]។ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា ពុំមានការហាមឃាត់ចំពោះ "ការបកស្រាយជាបន្តបន្ទាប់លើវិធាននៃការទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈការបកស្រាយតាមផ្លូវតុលាការ ពីរឿងក្តីមួយទៅរឿងក្តីមួយទៀត ប្រសិនបើលទ្ធផលនៃការបកស្រាយស៊ីចង្វាក់គ្នាជាមួយនឹងខ្លឹមសារនៃបទល្មើស និងអាចប្រមើលឃើញជាមុនបានយ៉ាងសមស្រប"[998]។ ទោះយ៉ាងនេះក្តី គេក៏គេចមិនផុតពីកាតព្វកិច្ចក្នុងការពិនិត្យលើភាពអាចដឹងជាមុនបានថាជាបទល្មើស និងភាពអាចដឹងជាមុនបានថាមានច្បាប់ចែងអំពីការកំណត់បទល្មើស។ ផ្ទុយទៅវិញ គេត្រូវពិនិត្យមើលលើភាពអាចដឹងជាមុនបានថាជាបទល្មើស និងភាពអាចដឹងជាមុនបានថាមានច្បាប់ចែងអំពីការកំណត់បទល្មើស ដូចដែលត្រូវបានបកស្រាយ និងបំភ្លឺ។ យោងតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប "ក្នុងករណីជាក់ស្តែងនេះ គេត្រូវ "ស្វែងរកមើលថា ក្នុងរឿងក្តី តើអត្ថបទច្បាប់ ដែលត្រូវអានទន្ទឹមគ្នាជាមួយនឹងយុត្តិសាស្ត្របកស្រាយ បំពេញបានល័ក្ខខ័ណ្ឌនេះនៅសម័យកាលអង្គហេតុដែរឬ

[995] សាលដីកា Kononov *ទល់នឹង ប្រទេសឡេតូនី* ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ១៨៧ យោងនៅត្រង់កថាខណ្ឌ ២៨ នៃសំអាងហេតុសាលក្រម។

[996] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣០០-៣០២ និង ៣០៦-៣០៧ យោងជាអាទិ៍ទៅសាលដីកា Vasiliauskas *ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៥៣-១៥៤ និងទៅសាលដីកា Kokkinakis *ទល់នឹង ប្រទេសក្រិក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី២៥ ខែឧសភា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៥២។

[997] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨ ដែលទំនងជាផ្អែកដោយប្រយោលលើ សាលដីកា Vasiliauskas *ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៥៥។

[998] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩ យោងទៅ សាលដីកា Vasiliauskas *ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៥៥ និងយោងផងដែរទៅ សាលដីកា Kononov *ទល់នឹង ប្រទេសឡេតូនី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ១៨៥។

ទេ”[999]។ “យោងតាមបម្រាមមិនឱ្យអនុវត្តបែបពង្រីកនៃនីតិព្រហ្មទណ្ឌ ល័ក្ខខ័ណ្ឌតម្រូវនៃមាត្រា ៧ នឹងមិនអាចត្រូវចាត់ទុកថាបានគោរពចំពោះជនជាប់ចោទនោះទេ បើគ្មានការបកស្រាយកម្រិតអប្បបរមាពីយុត្តិសាស្ត្រដែលអាចឱ្យគេដឹងឮបាន និងអាចគ្រោងទុកបានដោយសមហេតុសមផលនោះ”[1000]។

៥៥៦. ជាឧទាហរណ៍ជាក់ស្តែង តុលាការសិទ្ធិមនុស្សអឺរ៉ុប បានពិន័យចំពោះការបកស្រាយដែលកើតចេញពីការប្រែក្រឡាស់យុត្តិសាស្ត្រដែលមិនអាចឱ្យគេគ្រោងទុកជាមុនបាន[1001] ការបកស្រាយបែបពង្រីក និងមិនអាចឱ្យគេគ្រោងទុកមុនបានចំពោះបទល្មើស ដែលវាធ្វើឱ្យខូចប្រយោជន៍ជនជាប់ចោទ និងដែលមានវិសមិតភាពជាមួយនឹងខ្លឹមសារផ្ទាល់នៃបទល្មើស[1002] ព្រមទាំងបានពិន័យផងដែរចំពោះការផ្តន្ទាទោសលើបទល្មើសដែលកើតចេញពីការវិវត្តផ្នែកយុត្តិសាស្ត្រដែលត្រូវបានពង្រឹង ក្រោយការប្រព្រឹត្តិអង្គហេតុរងការចោទប្រកាន់[1003] ឬការផ្តន្ទាទោសដោយអនុវត្តតាមបទប្បញ្ញត្តិមិនច្បាស់លាស់ ដែលនាំឱ្យមានការបកស្រាយផ្សេងៗគ្នា[1004]។ ទាក់ទងនឹងចំណុចនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានវិនិច្ឆ័យថា យុត្តិសាស្ត្រមួយដែលមានភាពមិនស៊ីចង្វាក់គ្នា គឺខ្វះភាពច្បាស់លាស់ចាំបាច់សម្រាប់បញ្ចៀសនូវរាល់ហានិភ័យនៃការអនុវត្តតាមទំនើងចិត្ត និងអាចអនុញ្ញាតឱ្យម្នាក់ៗអាចគ្រោងទុកជាមុនបាននូវផលវិបាកនៃអំពើរបស់ខ្លួន[1005]។

---

[999] សាលដីកា *Dragonotiu និង Militaru-Pidhorni ទល់នឹង ប្រទេសរូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ៣៦-៣៨។ សូមមើលផងដែរ៖ សាលដីកា *Contrada ទល់នឹង ប្រទេសអ៊ីតាលី (លេខ ៣)* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៥ កថាខណ្ឌ ៦៤។

[1000] សាលដីកា *Dragonotiu និង Militaru-Pidhorni ទល់នឹង ប្រទេសរូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣។

[1001] សាលដីកា *Dragonotiu និង Militaru-Pidhorni ទល់នឹង ប្រទេសរូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ៣៩-៤៨។

[1002] សាលដីកា *Navalnyye ទល់នឹង ប្រទេសរុស្ស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៦៨។

[1003] សាលដីកា *Contrada ទល់នឹង ប្រទេសអ៊ីតាលី (លេខ ៣)* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៥ កថាខណ្ឌ ៦៤-៧៦។

[1004] សាលដីកា *Žaja ទល់នឹង ប្រទេសក្រូអាស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ កថាខណ្ឌ ៩៩-១០៦។

[1005] សាលដីកា *Žaja ទល់នឹង ប្រទេសក្រូអាស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ កថាខណ្ឌ ១០៣។

៥៥៧. ហេតុដូច្នេះ ទាំងគោលបំណងនៃគោលការណ៍នីត្យានុកូលភាព ទាំងការបំភ្លឺជាលំដាប់ តាមរយៈការបកស្រាយរបស់តុលាការ គឺសុទ្ធតែមិនអនុញ្ញាតឱ្យអង្គជំនុំជម្រះមិនពិនិត្យលើភាពអាចដឹងជាមុនថាជាបទល្មើស និងភាពអាចដឹងជាមុនថាមានច្បាប់ចែង នៃនិយមន័យបច្ចេកទេសបទល្មើស នៅសម័យអង្គហេតុរងការចោទប្រកាន់បាននោះទេ។ ដូចគ្នាដែរសម្រាប់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។

## ផ្នែកទី ២. ការវិនិច្ឆ័យនៅតាមការប្រព្រឹត្តិរបស់ជនជាប់ចោទ

៥៥៨. អង្គជំនុំជម្រះបានយល់ស្របជាមួយនឹងការវិនិច្ឆ័យរបស់តុលាការកំពូល ដែលលើកឡើងថា "ពាក់ព័ន្ធនឹងភាពអាចព្យាករណ៍ទុកមុនបានថាជាបទល្មើស ជនជាប់ចោទ "ត្រូវតែអាចដឹងបានថា តើការប្រព្រឹត្តិរបស់គាត់មានលក្ខណៈឧក្រិដ្ឋ ក្នុងន័យដែលបានយល់ជាទូទៅដែរឬទេ ដោយមិនចាំបាច់សំអាងទៅលើបទប្បញ្ញត្តិណាមួយជាក់លាក់នោះ""[1006]។ អង្គជំនុំជម្រះ "យល់ស្របទៅនឹងការយល់ឃើញដែលថា កាលណាឧក្រិដ្ឋកម្មកាន់តែមានភាពធ្ងន់ធ្ងរ កាន់តែធ្វើឱ្យជនជាប់ចោទបានដឹងជាទូទៅថា អំពើបែបនោះអាចនឹងត្រូវផ្តន្ទាទោស"[1007]។ បន្ទាប់មក អង្គជំនុំជម្រះពិចារណាតែលើអត្ថិភាពនៃការចោទប្រកាន់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម" ដើម្បីសន្និដ្ឋានថា "ជាលក្ខណៈទូទៅ" ល័ក្ខខ័ណ្ឌតម្រូវនៃការអាចព្យាករណ៍ដឹងថាជាបទល្មើសត្រូវបានបំពេញ[1008]។

៥៥៩. ឯកសារយោងតែមួយគត់សម្រាប់គាំទ្រការវិនិច្ឆ័យរបស់តុលាការកំពូល គឺសេចក្តីសម្រេចមួយរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលអះអាងថា "ចំពោះភាពអាចយល់ដឹងជាមុនបាន ជនជាប់ចោទ "ត្រូវតែអាចយល់ដឹងថាអំពើដែលខ្លួនប្រព្រឹត្ត គឺជាបទល្មើស ក្នុងន័យដែលគេអាចយល់ដឹងជាទូទៅបាន ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះ

---

[1006] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០ យោងទៅ សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៦២។

[1007] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០។

[1008] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៦, ៦៥១, ៦៥៤, ៦៦១, ៦៧៣, ៦៨៨, ៧០០, ៧១២, ៧២៣, ៧៨៩។

ទេ"[1009]។ ទឡ្ហីករណ៍នេះពុំបានផ្អែកលើឯកសារយោងណាមួយសោះ ហើយផ្ទុយគ្នាទាំងស្រុងទៅនឹងយុត្តិសាស្ត្រអចិន្ត្រៃយ៍របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប[1010] ដែលលើកឡើងថា ការប្រព្រឹត្តិដែលលើកឡើងមកនេះ មានពណ៌នានៅក្នុង "ពាក្យពេចន៍នៃបទប្បញ្ញត្តិពាក់ព័ន្ធ" ហើយប្រាកដណាស់ថា វាពុំមែនជាការប្រព្រឹត្តិរបស់ជនជាប់ចោទនោះទេ។ ដូច្នេះ គឺគុណភាពរបស់ច្បាប់ទេដែលមានបញ្ហា ពុំមែនគុណភាពរបស់ជនជាប់ចោទនោះឡើយ។

៥៦០. បើទោះជាការអះអាងដោយគ្មានមូលដ្ឋាន នៅក្នុងសេចក្តីសម្រេចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ធ្លាប់ត្រូវបានយោងកាលពីមុនដោយអង្គបុរេជំនុំជម្រះក៏ដោយ[1011] ក៏អង្គជំនុំជម្រះមួយនេះបានពិនិត្យលើភាពអាចព្យាករណ៍បាននៃធាតុផ្សំរបស់សហឧក្រិដ្ឋកម្មរួម មុននឹងធ្វើការសន្និដ្ឋានថា ធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួម-ទម្រង់ ៣ ពុំអាចត្រូវបានជនជាប់ចោទដឹងមុនបានថាជាបទល្មើស នៅចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩ នោះទេ[1012]។ ទោះជាកាលពីពេលមុនតុលាការកំពូលបានយោងដូចគ្នា ទៅលើសេចក្តីសម្រេចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីមួយនេះ នៅក្នុងសាលដីកាក្នុងរឿងក្តី ឌុច[1013] ក៏ដោយ ក៏ទន្ទឹមគ្នានោះដែរ តុលាការកំពូលបានអះអាងថា៖

> "[...] មុខងារការពារនៃគោលការណ៍នីត្យានុកូលភាព ដូចបានគូសបញ្ជាក់ខាងលើ អង្គជំនុំជម្រះនៃ អ.វ.ត.ក ត្រូវមានកាតព្វកិច្ចក្នុងការសម្រេចថា <u>ការកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម</u> ឬទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ អាចយកមកអនុវត្តបាននៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ខ្លួន <u>ហើយជនជាប់ចោទត្រូវតែ</u>អាចយល់ដឹងជាមុនថាជា

[1009] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៦២ កំណត់សម្គាល់ជើងទំព័រលេខ១៩៨៣ យោងទៅ *រដ្ឋអាជ្ញា ទល់នឹង* Hažihasanović *និងអ្នកផ្សេងទៀត* សំណុំរឿង IT-01-47-AR72 សេចក្តីសម្រេចលើបណ្តឹងជំទាស់នឹងយុត្តាធិការ (*ការទទួលខុសត្រូវរបស់ថ្នាក់លើ*) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៣៤។

[1010] សូមមើលខាងលើ កថាខណ្ឌ ៥៥៣។

[1011] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ **D97/15/9** កថាខណ្ឌ ៤៥។

[1012] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ **D97/15/9** កថាខណ្ឌ ៨៧។

[1013] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៦។

បទល្មើស និងដឹងជាមុនថាមានច្បាប់ចែង។ បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ការពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន និងដោយមានសំអាងហេតុអំពីការកំណត់ទាំងនេះ មានសារៈសំខាន់ចាំបាច់ណាស់ក្នុងការធានាអំពីធម្មានុរូបរបស់ស្ថាប័ន និងសេចក្ដីសម្រេចរបស់ អ.វ.ត.ក"[1014]។

៥៦១. នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានបោះបង់ចោលទាំងស្រុងនូវការវិភាគមួយនេះ ដោយមិនដែលធ្លាប់យកមកធ្វើជាសំអាងម្ដងណាសោះ។ តុលាការកំពូលបានជ្រើសរើសយកការគាំទ្រដល់វិចារណកិច្ចដែលគ្មានមូលដ្ឋានរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ដើម្បីទាញចេញនូវផលវិបាកថា "អ្វីដែលតម្រូវនោះ គឺមិនមែនជាការពិចារណាអំពីពាក្យពេចន៍បច្ចេកទេសក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនោះឡើយ ប៉ុន្តែនៅត្រង់ថា តើជាទូទៅគេអាចយល់ដឹងជាមុនបានថាអំពើនោះតម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ឬយ៉ាងណា"[1015]។ វិចារណកិច្ចនេះមានកំហុសតាមផ្លូវច្បាប់ ហើយអង្គជំនុំជម្រះមិនអាចសំអាងដោយត្រឹមត្រូវលើវិចារណកិច្ចមួយនេះដើម្បីគេចវេសមិនពិនិត្យលើភាពអាចគ្រោងទុកមុនបាននៃនិយមន័យនៃបទល្មើសនោះដែរ។

៥៦២. ការកម្រិតត្រឹមអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងភាពអាចដឹងជាមុនបានអំពីចរិតដាក់ទោសទណ្ឌចំពោះការប្រព្រឹត្តិ គឺស្មើនឹងចាត់ទុកថា គេមិនចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ជាមុនពីធាតុផ្សំនៃបទល្មើស និងទោសឡើយ។

៥៦៣. វិចារណកិច្ចមួយនេះដែលផ្ទុយពីកម្មវត្ថុផ្ទាល់ និងគោលបំណងនៃគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស ត្រូវបានបដិសេធចោលយ៉ាងច្បាស់ដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត

---

[1014] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ នៅត្រង់កថាខណ្ឌ ៩០ តុលាការកំពូលបានប្រកាសដែរថា "គោលការណ៍នីត្យានុកូលភាពការពារបុគ្គលឱ្យរួចផុតពីការប្រើប្រាស់តាមទំនើងចិត្តនូវអំណាចនយោបាយ ឬអំណាចតុលាការ ដោយរារាំងអង្គការនីតិបញ្ញត្តិមិនឱ្យកំណត់គោលដៅលើបុគ្គលជាក់លាក់ណាមួយ ដោយមិនមានចែងក្នុងច្បាប់ជាមុន"។

[1015] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៦៥ យោងទៅកថាខណ្ឌ ៧៦២។

ប្រទេសយូហ្គោស្លាវី[1016]។ ប្រាកដណាស់ វិធារណកិច្ចនេះ ក៏មិនត្រូវបានយកមកអនុវត្តដោយតុលាការសិទ្ធិមនុស្សអឺរ៉ុបនោះដែរ សូម្បីតែពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតក៏ដោយ។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Vasiliauskas ទល់នឹង ប្រទេសលីទុយអានី* អ្នកស្នើសុំបានដឹងយ៉ាងច្បាស់ថា អំពើមនុស្សឃាតក្រោមបទប្រល័យពូជសាសន៍ ដែលគាត់ត្រូវបានផ្តន្ទាទោស គឺមានការដាក់ទោសទណ្ឌដោយច្បាប់ ហើយថា "អំពើរបស់គាត់មានលក្ខណៈឧក្រិដ្ឋ ក្នុងន័យដែលមនុស្សទូទៅអាចយល់ដឹងបាន ដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយនោះឡើយ"។ សភាជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអឺរ៉ុបបាន ១) ពិនិត្យលើលទ្ធភាពនៃការ ដឹងបានរបស់អ្នកស្នើសុំអំពីបទប្បញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងចំណុចនេះ នៅសម័យកាលនៃអង្គហេតុ[1017] និង ២) ពិនិត្យលើភាពដឹងបានថាមានច្បាប់ចែង ដោយវិភាគលើពាក្យពេចន៍បច្ចេកទេសនៃនិយមន័យរបស់ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ នៅសម័យអង្គហេតុ។ និយមន័យនោះ មិនសូវមានលក្ខណៈទូលាយដូចនិយមន័យដែលត្រូវបានអនុវត្តចំពោះអ្នកស្នើសុំនោះទេ[1018]។ តុលាការបានសន្និដ្ឋានថា ទោះជាច្បាប់ពាក់ព័ន្ធត្រូវបានដឹងឮដោយអ្នកស្នើសុំនៅសម័យនោះក៏ដោយ "ក៏ការផ្តន្ទាទោស [...] ចំពោះអំពើប្រល័យពូជសាសន៍ មិនត្រូវបានដឹងមុនថាមាន

---

1016 សាលក្រម *Vasiljević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១៩៨ ដែលនៅត្រង់នោះ ចៅក្រមបានរំឭកថា បទល្មើស "ត្រូវតែកំណត់ឱ្យបានច្បាស់គ្រប់គ្រាន់ ដើម្បីអាចឱ្យគេដឹងមុនបានថាមានច្បាប់ចែង" និងកំណត់សម្គាល់ជើងទំព័រលេខ៥៤១ ដែលនៅត្រង់នោះ ចៅក្រមបានបដិសេធចោលទឡ្ហីករណ៍របស់រដ្ឋអាជ្ញាដែលលើកឡើងថា គេត្រូវធ្វើការបែងចែកឱ្យដាច់ពីគ្នារវាងគោលការណ៍នីត្យានុកូលភាព (អត្ថិភាពនៃបទល្មើស) និងគោលការណ៍នៃលក្ខណៈជាក់លាក់ (និយមន័យនៃបទល្មើសដែលលើកឡើង ឬនិយមន័យនៃធាតុផ្សំរបស់វា)។ រដ្ឋអាជ្ញាលើកឡើងដូច្នេះថា៖ "វាច្បាស់ណាស់ថា គោលការណ៍នីត្យានុកូលភាពតម្រូវថា ឧក្រិដ្ឋកម្មត្រូវតែមានចែងក្នុងច្បាប់ នៅពេលវេលា និងទីកន្លែងដែលអំពើពាក់ព័ន្ធត្រូវបានប្រព្រឹត្ត។ ប៉ុន្តែ ទាំងអស់នេះមិនមែនមានន័យថា បទល្មើសត្រូវតែមានធាតុផ្សំរៀបរាប់ឱ្យបានលម្អិតជាមុននោះទេ" (*រដ្ឋអាជ្ញា ទល់នឹង Vasiljević* សំណុំរឿង IT-98-32-T សារណារបស់អយ្យការស្តីពីច្បាប់ អនុលោមតាម "អំពើហិង្សាលើជីវិត និងបុគ្គល" ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ៥)។

1017 សាលដីកា *Vasiliauskas ទល់នឹងប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៦៧-១៦៨។

1018 សាលដីកា *Vasiliauskas ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៦៩-១៨៥។

ច្បាប់ចែង នៅពេលមានការកាប់សម្លាប់បក្សពួកនោះដែរ”[1019]។ ដូច្នេះ តុលាការបានកត់សម្គាល់ថាមានការរំលោភលើគោលការណ៍នីត្យានុកូលភាព[1020]។ ហេតុដូច្នេះ បើទោះជាអំពើប្រល័យពូជសាសន៍ត្រូវបានចោទប្រកាន់ជាបទឧក្រិដ្ឋនៅសម័យកាលនោះ ហើយបើទោះបីជាច្បាប់ពាក់ព័ន្ធអាចត្រូវដឹងឮបានដោយអ្នកស្នើសុំក៏ដោយ ក៏គាត់ពុំអាចព្យាករណ៍ទុកជាមុនបានអំពីការអនុវត្តនិយមន័យទូលាយនៃអំពើប្រល័យពូជសាសន៍បានដែរ។ បើទោះជាគាត់អាចបានដឹងថាការប្រព្រឹត្តិរបស់ខ្លួន អាចនឹងត្រូវទទួលរងទោសក៏ដោយ ក៏គាត់បានក្លាយជាជនរងគ្រោះដោយការរំលោភលើគោលការណ៍នីត្យានុកូលភាពរួចបាត់ទៅហើយ។

៥៦៤. ដោយអនុវត្តតាមវិចារណកិច្ចរបស់តុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានយល់ស្របនឹងការបង្កើតអញ្ញត្រកម្មចំពោះគោលការណ៍នីត្យានុកូលភាព សម្រាប់ជនជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។ ក្នុងឋានៈជាធាតុផ្សំសំខាន់នៃឧត្តមភាពច្បាប់ គោលការណ៍នេះត្រូវតែទទួលបានការគោរពក្នុងគ្រប់កាលៈទេសៈទាំងអស់។ គោលការណ៍នេះជាផ្នែកមួយនៃការធានាទាំងឡាយដ៏តិចតួចបំផុត ដែលមិនអនុញ្ញាតឱ្យមានបដិប្បញ្ញត្តិណាមួយនោះឡើយ ទោះជាក្នុងពេលមានសង្គ្រាម ឬគ្រោះអាសន្នសាធារណៈពិសេសអ្វីផ្សេងក៏ដោយ[1021]។

៥៦៥. ដូច្នេះ វិធីសាស្ត្ររបស់អង្គជំនុំជម្រះមិនត្រឹមតែមានកំហុសអង្គច្បាប់ទេ តែថែមទាំងមិនអាចទទួលយកបានដោយថៅក្រមដែលត្រូវគោរពគុណតម្លៃនៃសង្គមប្រជាធិបតេយ្យ និងឧត្តមភាពនៃច្បាប់ទៀតផង។

---

[1019] សាលដីកា *Vasiliauskas ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៨៦។

[1020] សាលដីកា *Vasiliauskas ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៩១។

[1021] មាត្រា ៤-២ នៃកតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, សេចក្តីសង្កេតទូទៅ លេខ ២៩ ការប្រកាសអាសន្ន (មាត្រា ៤) គណៈកម្មាធិការសិទ្ធិមនុស្ស CCPR/C/21/Rev.1/Add.11 ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៧, *បញ្ហាជាក់លាក់នានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស៖ អាទិភាពថ្មីៗ ជាពិសេសភេរវកម្ម* គណៈកម្មាធិការសិទ្ធិមនុស្ស E/CN.4/Sub.2/2003/WP.1 ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ កថាខណ្ឌ ៦៣-៦៥, មាត្រា ១៥-២ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, សាលដីកា *Vasiliauskas ទល់នឹង ប្រទេសលីទុយអានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ១៥៣។

## ផ្នែកទី ៣. ការពិនិត្យចោលៗ មិនសមរម្យ លើល័ក្ខខ័ណ្ឌតម្រូវនៃគោលការណ៍

៥៦៦. អង្គជំនុំជម្រះចាត់ទុកការពិនិត្យលើល័ក្ខខ័ណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព សម្រាប់ជនជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត គ្រាន់តែជាទម្រង់ការមួយដែលត្រូវបំពេញ "ជាទូទៅ" ប៉ុណ្ណោះ។ ក៏ប៉ុន្តែការពិនិត្យនេះគួរត្រូវបានធ្វើសម្រាប់ជនជាប់ចោទម្នាក់ៗ ជាលក្ខណៈពិសេស និងស៊ីជម្រៅបំផុត។

៥៦៧. អង្គជំនុំជម្រះថែមទាំងមិនបានយកចិត្តទុកដាក់ពិនិត្យលើការអាចដឹងឮបាន និងការអាចព្យាករណ៍បាននៃធាតុផ្សំបរិបទនានា ដែលចាំបាច់ដល់ការកំណត់បទចោទពីអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការកំណត់បទចោទពីការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[1022] ថែមទៀតផង។ អង្គជំនុំជម្រះក៏មិនបានយកចិត្តទុកដាក់ពិនិត្យលើអ្វីដែលគេហៅថាជាគោលការណ៍ទូទៅ ពាក់ព័ន្ធនឹងអំពើអកម្មដែលអាចជាប់ទោស ដែលត្រូវអនុវត្តដូចគ្នាទៅលើគ្រប់ទម្រង់នៃការទទួលខុសត្រូវ[1023]។ ក៏ប៉ុន្តែ គោលការណ៍នីត្យានុកូលភាព គឺត្រូវអនុវត្តលើគ្រប់អ្វីៗទាំងអស់ដែលអាចនាំឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ[1024]។

៥៦៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះក៏មិនបានយកចិត្តទុកសោះតែម្តង លើការដែលថាប្រព័ន្ធច្បាប់កម្ពុជា គឺជាប្រព័ន្ធទ្វិកនិយមដែលពុំអនុញ្ញាតឱ្យមានការអនុវត្តដោយផ្ទាល់នូវបទដ្ឋានអន្តរជាតិ នៅក្នុងច្បាប់ជាតិនោះទេ[1025]។ ដោយសារតែគ្មានវិធានការច្បាប់ស្តីពីការដាក់បញ្ចូលច្បាប់អន្តរជាតិទៅក្នុងច្បាប់ជាតិ

---

[1022] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០០-៣១៦, ៣២៥-៣៥៥។

[1023] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧០៣។

[1024] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩០, សាលដីកា *Korbely ទល់នឹង ប្រទេសហុងគ្រី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ ៧៨, ៨១-៨៥, ៩៥។

[1025] ដូចគ្នានឹងច្បាប់បារាំង ដែលស្ថិតក្នុងប្រព័ន្ធច្បាប់ស៊ីវិល ហើយដែលប្រទេសកម្ពុជាយកលំនាំតាមដែរនោះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា ៣១ ចែងអំពីការអនុវត្តសិទ្ធិមនុស្ស ដូចដែលបានកំណត់នៅក្នុងសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ វាក្យខ័ណ្ឌចុងក្រោយ ("ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់") មាត្រា ៣៨ វាក្យខ័ណ្ឌទី ៣ ("ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើបានទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិ

[1026] ដូច្នេះ អ្វីដែលពលរដ្ឋកម្ពុជាអាចគិតទុកមុនបានដោយសមហេតុសមផល នៅទសវត្សរ៍ឆ្នាំ១៩៧០ នោះគឺការអនុវត្តនូវបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងគោលការណ៍នីត្យានុកូលភាពដែលមានចែងនៅក្នុងនោះ[1027]។ ក្រមនេះពុំមានចែងពីបទប្បញ្ញត្តិណាមួយទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ។ បទប្បញ្ញត្តិទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនោះ ត្រូវបានបញ្ចូលក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩[1028]។ ទោះជាអង្គជំនុំជម្រះទាំងអស់របស់ អ.វ.ត.ក

---

ច្បាប់") មាត្រា ៩០ ("រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ [...] រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ")។

[1026] សាលដីកា *Kononov ទល់នឹង ប្រទេសឡេតូនី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប សភាជាន់ខ្ពស់) ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ២០៨ (ពាក់ព័ន្ធនឹងសម័យកាលនៃការតាក់តែងច្បាប់ និងទំនៀមទម្លាប់សង្គ្រាម រហូតដល់មានគោលការណ៍ Nuremberg៖ "ទាំងច្បាប់អន្តរជាតិក្តី ទាំងច្បាប់ជាតិក្តី (ច្បាប់ជាតិនេះមានបញ្ចូលទាំងវិធានអន្តរជាតិដែលយកមកដាក់ក្នុងនោះផង) ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ និងការកំណត់អំពីការទទួលខុសត្រូវនៅក្នុងកម្រិតជាតិ។ ជាពិសេស នៅពេលដែលច្បាប់ជាតិពុំបានកំណត់ពីធាតុផ្សំនៃឧក្រិដ្ឋកម្មសង្គ្រាម តុលាការជាតិអាចយោងទៅលើច្បាប់អន្តរជាតិដើម្បីគាំទ្រការវិនិច្ឆ័យរបស់ខ្លួន ដោយពុំមានការរារាំងដល់ការអនុវត្តគោលការណ៍ គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) កថាខណ្ឌ ២១២ ("ជាចុងក្រោយ នៅពេលដែលច្បាប់អន្តរជាតិពុំមានកំណត់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់នូវទណ្ឌកម្មដែលភ្ជាប់ទៅនឹងអំពើឧក្រិដ្ឋកម្មសង្គ្រាមណាមួយនោះ តុលាការជាតិ ក្រោយពីបានវិនិច្ឆ័យថាជនជាប់ចោទមានពិរុទ្ធភាពរួចហើយ អាចកំណត់ទោស ដោយផ្អែកលើមូលដ្ឋាននៃនីតិព្រហ្មទណ្ឌជាតិ"), តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣ ព្រឹត្តិប័ត្រព្រហ្មទណ្ឌ ឆ្នាំ២០០៣ លេខ ១២២ (រឿងក្តី *Aussaresses*៖ "ទំនៀមទម្លាប់អន្តរជាតិមិនអាចបំពេញភាពខ្វះខាតនៃច្បាប់ចោទប្រកាន់បានទេ ក្រោមការកំណត់ប្រភេទបទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គហេតុដែលប្តឹងដោយដើមបណ្តឹងរដ្ឋប្បវេណី")។

[1027] ក្រមព្រហ្មទណ្ឌ និងច្បាប់អាជ្ញា ឆ្នាំ១៩៥៦ **001-91/6/1.1** មាត្រា ១ មាត្រា ២ និងមាត្រា ៦។ សូមមើលផងដែរ ការយោងទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមាននៅសម័យនោះ៖ មាត្រា ៤ វាក្យខ័ណ្ឌទី ១ ("ការចោទប្រកាន់ ការចាប់ខ្លួន ការឃុំខ្លួនបុគ្គលណាម្នាក់ អាចប្រព្រឹត្តទៅបានតែក្នុងករណីដែលបានកំណត់ដោយច្បាប់ និងស្របទៅតាមនីតិវិធីច្បាប់" ERN FR 00366791) មាត្រា ១៩ វាក្យខ័ណ្ឌទី ២ ("ការកាត់សេចក្តី ឬផ្តន្ទាទោសបុគ្គលណាម្នាក់ អាចធ្វើទៅបាន លុះត្រាតែបទល្មើសមានចែងដោយច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើ និងចូលជាធរមាននៅមុនពេលដែលបទល្មើសកើតឡើង" ERN FR 00366794)។ សូមមើលបន្ថែមទៀត ការយោងទៅមាត្រា ៤ នៃក្រមលេខ ៨៥៧-នស ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៥៤ ("តុលាការទាំងអស់នេះ (*តុលាការកម្ពុជា*) អនុវត្តក្រមផ្សេងៗដែលត្រូវតាក់តែងឡើងសម្រាប់ព្រះរាជាណាចក្រខ្មែរ ច្បាប់ និងវិធាននានាជាធរមាន ដែលត្រូវបានប្រកាស និងផ្សព្វផ្សាយស្របតាមច្បាប់" ERN FR 00366794)។

[1028] ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា ១៨៣ ដល់មាត្រា ១៩៨។ សូមមើលផងដែរ មាត្រា ៨ ដែលត្រូវបានយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ៩២ (កថាខណ្ឌ ២១) នៃសំអាងហេតុសាលក្រម៖ "បទប្បញ្ញត្តិនៃក្រមនេះពុំអាចនាំឱ្យឱ្យមានការបង្កើតនូវ

យល់ឃើញថាច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ២០០៤ ធ្វើឱ្យច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចអនុវត្តបាននៅ អ.វ.ត.ក ក៏ដោយចុះ[1029] ក៏ច្បាប់នេះពុំមានជាធរមាន ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះដែរ[1030]។

៥៦៩. លើសពីនេះទៀត ដូចដែលមេធាវីការពារក្តីបានលើកឡើងរួចមកហើយថា[1031] វាពិតជាលំបាកណាស់ក្នុងការកំណត់វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ("ការអនុវត្តដែលត្រូវបានទទួលយកថាដូចជាច្បាប់") ថាស្ថិតក្នុងសម័យកាលណាមួយនោះ ទោះជាសព្វថ្ងៃនេះក៏ដោយ ("បើទោះជាមានធនធានបច្ចេកវិទ្យា និងទូរគមនាគមន៍ ក៏ដោយក្តី")។ ការទទួលបានឯកសារទាក់ទងនឹងច្បាប់នេះ ដែលជាធម្មតាមិនមែនជាលាយលក្ខណ៍អក្សរ និងមានការវិវត្តរហូតនោះ ត្រូវតែធ្វើឱ្យប្រសើរជាងនេះ។ ចាប់ពីឆ្នាំ២០១២ មក បញ្ហានៃការកំណត់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានក្លាយជាកិច្ចការស្នូលរបស់គណៈកម្មាធិការច្បាប់អន្តរជាតិ ដែលនៅពេលបញ្ចប់កិច្ចការនេះ គឺត្រូវបង្កើតឱ្យចេញជាមគ្គុទេសក៍មួយដែលមានសេចក្តីអធិប្បាយ សម្រាប់ចៅក្រម អ្នកច្បាប់ អ្នកថ្នឹកការ ដែលពួកគេត្រូវសុំឱ្យជួយកំណត់អំពីអត្ថសញ្ញាណច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

៥៧០. ការកំណត់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិកាលពី៤០ឆ្នាំមុន គឺពិតជាមានហានិភ័យខ្លាំងបំផុត ដូចដែលសក្ខីកម្មបានបង្ហាញពីការដែលចៅក្រម អ.វ.ត.ក ធ្វើការកំណត់វិធានខុសៗគ្នា។ ឧទាហរណ៍ ចៅក្រមខ្លះបានកំណត់ពីភាពចាំបាច់នៃទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ សម្រាប់ការកំណត់បទ

---

ស្ថានភាពយុត្តិនិសេធចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរដែលកំណត់ដោយច្បាប់ដោយឡែក ទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សហចៅក្រមស៊ើបអង្កេតលើកឡើងថា ផ្នែកដែលត្រូវគូសបន្ទាត់ពីក្រោម គឺយោងទៅលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **D308/3** កថាខណ្ឌ ២០)។

[1029] សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៨, សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៦៣។

[1030] ដូចគ្នាដែរ បើទោះជាមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ ១៩៦៦ បានលើកឡើងពីច្បាប់ជាតិ "ឬ" ច្បាប់អន្តរជាតិក៏ដោយ ក៏កតិកាសញ្ញានេះពុំត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះដែរ (ទើបតែមកដល់ឆ្នាំ១៩៨០ ប៉ុណ្ណោះ)។

[1031] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៨១-៣៨៣ និងការយោងដែលលើកឡើង។

ចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយចំណែកចៅក្រមផ្សេងទៀត មិនធ្វើដូច្នេះទេ[1032]។ ចៅក្រមខ្លះបានកំណត់អត្ថិភាពនៃការរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដាច់ដោយឡែក[1033]។ ចៅក្រមខ្លះបានកំណត់ចេតនាប្រយោល សម្រាប់ការសម្លាប់រង្គាល ហើយចៅក្រមផ្សេងទៀត មិនធ្វើដូច្នេះទេ[1034]។

៥៧១. ការបកស្រាយខុសៗគ្នាអំពីច្បាប់មួយដ៏ប្រែប្រួល និងដែលពិបាកកំណត់ខ្លាំងដោយចៅក្រមវិជ្ជាជីវៈ បើទោះជាបីពួកគេមានធនធានគ្រប់បែបយ៉ាង នៅក្នុងទសវត្សរ៍ឆ្នាំ២០០០ គឺមិនអាចឱ្យគេគិតបានថាពលរដ្ឋកម្ពុជានៅទសវត្សរ៍ឆ្នាំ១៩៧០ អាចដឹងបានយ៉ាងច្បាស់លាស់គ្រប់គ្រាន់ "ក្នុងនោះ គិតទាំងជំនួយពីការបកស្រាយរបស់តុលាការ និងការប្រឹក្សាច្បាប់ច្បាស់លាស់ថា តើអំពើសកម្ម និងអំពើអកម្មណាដែលនឹងនាំឱ្យខ្លួនមានការទទួលខុសត្រូវព្រហ្មទណ្ឌ"[1035] អនុលោមតាមវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ហើយដូចគ្នានេះ ដោយផ្តើមចេញពីការគិតតាមបែបសន្មតសុទ្ធសាធថា គាត់អាចគ្រោងទុកមុនបានថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចយកមកអនុវត្តលើគាត់បាន)។

៥៧២. ដូច្នេះ តាមផ្លូវច្បាប់ វាមិនអាចទទួលយកបានទេ ដែលត្រូវកម្រិតជាស្វ័យប្រវត្តិត្រឹមអត្ថិភាពនៃការចោទប្រកាន់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដើម្បីវាយតម្លៃ "ជាលក្ខណៈទូទៅ" ថាលក្ខខណ្ឌនៃភាពអាចដឹងជាមុនបានថាមានច្បាប់ចែង នៃគោលការណ៍នីត្យានុកូលភាព

[1032] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/2/12**, **D427/4/14**, **D427/1/26** (បដិសេធចោលសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត) *ផ្ទុយពី* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ ឯកសារ **E95/8**។

[1033] សាលក្រម *ឌុច* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦៦ *ផ្ទុយពី* សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២០៧-២១៣, សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ **D427/2/12**, **D427/4/14**, **D427/1/26** (បដិសេធចោលសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត)។

[1034] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥២២ បដិសេធចោលសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។

[1035] សូមមើលខាងលើ កថាខណ្ឌ ៥៥៣ និង ៥៦៦។

ត្រូវបានបំពេញ ក្នុងករណីជាក់ស្តែងមួយនេះ[1036]។ វាមិនអាចទទួលយកបានផងដែរ ដែលត្រូវកម្រិតជាស្វ័យប្រវត្តិត្រឹមការកាន់កាប់ "តួនាទីបញ្ជា" ដើម្បីចាត់ទុកថា "ជាលក្ខណៈទូទៅ" ល័ក្ខខ័ណ្ឌនៃភាពអាចដឹងឮបានអំពីវិធានគតិយុត្តិនានា ត្រូវបានបំពេញ ក្នុងករណីជាក់ស្តែងនេះ[1037]។ ដូច្នេះ ពាក់ព័ន្ធនឹងចំណុចចុងក្រោយនេះ អង្គជំនុំជម្រះកាន់តែមិនបានធ្វើការពិនិត្យឱ្យបានស៊ីជម្រៅ និង "តាមបុគ្គលម្នាក់ៗ" ដូចដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានធ្វើ ទោះជាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិក្តី[1038]។ ជាពិសេស អង្គជំនុំជម្រះក៏មិនដែលខ្វាយខ្វល់ធ្វើការចង្អុលបង្ហាញ សូម្បីតែតាមលក្ខណៈទ្រឹស្តី ថាតើ ខៀវ សំផន ត្រូវធ្វើដូចម្តេចទើបអាចទទួលដឹងឮបានអំពីយុត្តិសាស្ត្រក្រោយសង្គ្រាម ដែលអង្គជំនុំជម្រះយកមកធ្វើជាសំអាង ក្នុងនោះរួមទាំងជាភាសាដែលគាត់អាចយល់បានថែមទៀតផង។

៥៧៣. សរុបសេចក្តីមក កំហុសអង្គច្បាប់របស់អង្គជំនុំជម្រះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតដល់សេចក្តីសម្រេចរបស់ខ្លួន។ ប្រសិនបើអង្គជំនុំជម្រះបានធ្វើការពិនិត្យដែលជាល័ក្ខខ័ណ្ឌ និងបានអនុវត្តលក្ខណៈវិនិច្ឆ័យគតិយុត្តិត្រឹមត្រូវនៃគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះនឹងមិនអាចសន្និដ្ឋានបានថាគោលការណ៍នេះត្រូវបានគោរពនោះទេ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលមិនត្រឹមត្រូវ[1039] ក៏ដូចជាការផ្តន្ទាទោស និងទោសដែលត្រូវបានប្រកាសដោយផ្អែកលើសេចក្តីសន្និដ្ឋានទាំងនោះ[1040] ត្រូវទុកជាមោឃៈ។

៥៧៤. ហេតុដូច្នេះ អង្គជំនុំជម្រះបានអនុវត្តច្បាប់ដែលគ្មានអត្ថិភាព នៅពេលដែលអង្គហេតុកើតឡើង[1041]។

[1036] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០, ៣០០, ៣២៦, ៦៥១, ៦៥៤, ៦៦១, ៦៧៣, ៦៨៨, ៧០០, ៧១២, ៧២៣, ៧៨៩, ៣៧០៤, ៣៧០៧។

[1037] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១, ៣០០, ៣២៦, ៦៥១, ៦៥៤, ៦៦១, ៦៧៣, ៦៨៨, ៧០០, ៧១២, ៧២៣, ៧៨៩, ៣៧០៤, ៣៧០៧។

[1038] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣១៦-៣១៨ និងការយោងដែលត្រូវបានរៀបរាប់។

[1039] សំអាងហេតុសាលក្រម កថាខណ្ឌ ២០-៣២, ៣០០, ៣២៦, ៦៥១, ៦៥៤, ៦៦១, ៦៧៣, ៦៨៨, ៧០០, ៧១២, ៧២៣, ៧៨៩, ៣៧០៣, ៣៧០៤, ៣៧០៧។

[1040] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៦-៤៣២៨, ៤៤០០-៤៤០២។

[1041] ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវ សូមមើលខាងក្រោម កថាខណ្ឌ ១៩៣៨-១៩៦៥ និង ២១២០-២១២៣។

## ជំពូកទី ២. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត

## ផ្នែកទី ១. អង្គច្បាប់៖ គ្មានការបញ្ចូលចេតនាប្រយោលនៅក្នុងធាតុផ្សំអត្តនោម័តិ

៥៧៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា និយមន័យនៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានរួមបញ្ចូលចេតនាប្រយោល នៅឆ្នាំ១៩៧៥[1042]។ ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះបានលើកឡើង គឺពុំមានមូលដ្ឋានគតិយុត្តិដែលមានសុពលភាពចំពោះការអះអាងមួយនេះនោះទេ (១)។ លើសពីនេះទៀត និយមន័យនៃចេតនាដែលជាល័ក្ខខ័ណ្ឌតម្រូវនេះ ពុំបំពេញបាននូវល័ក្ខខ័ណ្ឌតម្រូវនៃភាពអាចដឹងជាមុនបានថាជាបទល្មើស និងភាពអាចដឹងជាមុនបានថាមានច្បាប់ចែង ដែលចាំបាច់សម្រាប់ការគោរពឱ្យបាននូវគោលការណ៍នីត្យានុកូលភាពនោះទេ (២)។

### ១. គ្មានមូលដ្ឋានគតិយុត្តិដែលមានសុពលភាព

៥៧៦. ជាបឋម ការពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់ និងការពុំមានភាពច្បាស់លាស់នៃឯកសារយោងដែលបានលើកឡើង គឺបង្ហាញឱ្យឃើញពីកង្វះមូលដ្ឋានគតិយុត្តិដែលមានសុពលភាព (១.១)។ បន្ទាប់មកច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥ ពុំបានបញ្ចូលចេតនាប្រយោលទៅក្នុងនិយមន័យនៃធាតុផ្សំអត្តនោម័តិ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតនោះទេ (១.២)។ ម្យ៉ាងវិញទៀត ការសំអាងទៅលើគោលការណ៍ទូទៅនៃច្បាប់ថាជាប្រភពនៃច្បាប់នោះ គឺ គ្មានសុពលភាពសម្រាប់កំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មមួយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាលក្ខណៈទូលាយក្នុងបំណងបន្ទាបចេតនាដែលជាល័ក្ខខ័ណ្ឌតម្រូវនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ (១.៣)។ ជាចុងក្រោយ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះមិនបានរាយការណ៍អំពីភ័ស្តុតាងដែលបង្ហាញឱ្យឃើញអំពីអត្ថិភាពនៃគោលការណ៍ទូទៅនៃច្បាប់ដែលបន្ទាបធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត មកត្រឹមចេតនាប្រយោល នៅសម័យកាលអង្គហេតុនោះទេ (១.៤)។

---

1042 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥០។

## ១.១. ការយល់ច្រឡំ និងការច្របល់បញ្ចូលគ្នាពុំត្រឹមត្រូវ រវាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់

### ១.១.១. ការចោទប្រកាន់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកំណត់ដោយគោលការណ៍ទូទៅនៃច្បាប់

៥៧៧. អង្គជំនុំជម្រះបានរំឭកដោយត្រឹមត្រូវថា និយមន័យជាធរមានស្តីពីការធ្វើមនុស្សឃាត ត្រូវតែឆ្លុះបញ្ចាំងពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥[1043] ហើយបានអះអាងថា អង្គជំនុំជម្រះ និងតុលាការកំពូល "បានវាយតម្លៃទៅលើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥"[1044]។ ផ្ទុយពីការអះអាងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវាយតម្លៃថា "ការពិចារណាទៅលើគោលការណ៍ច្បាប់ទូទៅ អាចជាជំនួយដល់ការកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងករណីដែលឧក្រិដ្ឋកម្មនោះត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[1045]។ អង្គជំនុំជម្រះពុំបានយោងលើប្រភពណាមួយ ដើម្បីគាំទ្រជំហរដែលជាការលាយបញ្ចូលគ្នាមិនធ្លាប់មាន រវាងអត្ថិភាពនៃការចោទប្រកាន់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងខ្លឹមសាររបស់វា ដែលត្រូវបានកំណត់ដោយគោលការណ៍ទូទៅនៃច្បាប់។

### ១.១.២. ភាពចាំបាច់នៃការបែងចែកដាច់ពីគ្នារវាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់

៥៧៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយថ្លែងថា ខ្លួនជឿជាក់ថា "ការពិនិត្យពិច័យទៅលើយុត្តិសាស្ត្រជាតិ និងយុត្តិសាស្ត្រអន្តរជាតិ មុនឆ្នាំ១៩៧៥ និងច្បាប់ទាំងឡាយដែលចែងពីគោលការណ៍ទូទៅនៃច្បាប់ដែលថា នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តដោយចេតនា និងដោយស្ម័គ្រចិត្ត នូវអំពើទាំងឡាយណាដែលអាចនឹងបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្ស អំពើនោះគឺជាការធ្វើមនុស្សឃាត ឬជាឧក្រិដ្ឋកម្មដែលមានស្ថានទម្ងន់ស្រដៀងគ្នានៅក្នុងប្រព័ន្ធច្បាប់ជាតិនីមួយៗ"[1046]។ តាមរយៈការធ្វើ

[1043] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៤។

[1044] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៥។

[1045] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1046] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ដូច្នេះ អង្គជំនុំជម្រះបានយល់ច្រឡំដោយពុំត្រឹមត្រូវ រវាងប្រភពផ្សេងៗនៃច្បាប់ជាធរមាននៅក្នុងនីតិសាធារណៈអន្តរជាតិ។

៥៧៩. នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានបដិសេធចោលទឡ្ហីករណ៍ស្រដៀងគ្នារបស់អយ្យការ ដែលព្យាយាមបង្ហាញឱ្យឃើញពីអត្ថិភាពនៃវិធានមួយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលទទួលស្គាល់សហឧក្រិដ្ឋកម្មរួម-ទម្រង់៣ ដោយអយ្យការបានផ្អែកលើ "ការអនុវត្តជាទូទៅក្នុងផ្នែកព្រហ្មទណ្ឌ នៅក្នុងកម្រិតជាតិ"។ អយ្យការបានអះអាងថា ការអនុវត្តថ្នាក់ជាតិ "ពុំអាចធ្វើជាមូលដ្ឋានសម្រាប់បង្ហាញអំពីវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបាននោះទេ ដោយហេតុថាខ្វះសមាសភាពចៅក្រមអន្តរជាតិ"[1047]។ តុលាការកំពូលបានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការរក្សា "<u>ការបែងចែកដាច់ពីគ្នារវាងច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុក ព្រមទាំងរវាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគោលការណ៍ទូទៅនៃច្បាប់ក្នុងស្រុក</u>"[1048]។

៥៨០. នៅត្រង់នេះ ពាក់ព័ន្ធនឹងការធ្វើមនុស្សឃាតដោយចេតនាប្រយោល ការវិនិច្ឆ័យរបស់អង្គជំនុំជម្រះ គឺគ្មានសុពលភាព ព្រោះថាអង្គជំនុំជម្រះពុំបានបញ្ជាក់ប្រាប់ឱ្យបានច្បាស់ថា តើខ្លួនកំណត់និយមន័យនៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសំអាងទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ឬក៏ទៅលើគោលការណ៍ទូទៅនៃច្បាប់។ ផ្ទុយទៅវិញ សំអាងហេតុរបស់អង្គជំនុំជម្រះ បានស្តែងឱ្យឃើញថា អង្គជំនុំជម្រះមានការយល់ច្រឡំរវាងប្រភពពីរផ្សេងគ្នានៃនីតិសាធារណៈអន្តរជាតិ ដែលបាននាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសដែលត្រូវបានរិះគន់ដោយតុលាការកំពូល។

## ១.២. អវត្តមាននៃចេតនាប្រយោលនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឆ្នាំ១៩៧៥

[1047] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៥។

[1048] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៥៨១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា ចេតនាប្រយោលគឺជាផ្នែកមួយនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ដោយផ្អែកលើមូលដ្ឋានផ្ទុំគ្នានៃរឿងក្តី *គ្រូពេឡូ* ថាជា "ប្រភពយោងមួយក្នុងចំណោមប្រភពយោងផ្សេងៗទៀត" (១.២.១) និងដោយសារមាន "ការចង្អុលបង្ហាញ" នៅក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអចិន្ត្រៃយ៍នានា (១.២.២) និងការអនុវត្តផ្សេងៗនៅក្នុងច្បាប់ជាតិ "ដែលជួយបញ្ជាក់បន្ថែម" ដល់ការបកស្រាយបែបពង្រីកលើរឿងក្តី *គ្រូពេឡូ*ដោយតុលាការកំពូល (១.២.៣)។ មេធាវីការពារក្តីសូមអះអាងឡើងវិញអំពីជំហររបស់ខ្លួននៅក្នុងសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ និងក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ ដែលថា នៅសម័យអង្គហេតុ "ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនមានបទដ្ឋានណាមួយផ្សេងទៀតដែលមានលក្ខណៈបន្ទាប់បន្សំ ឬស្ថិតនៅក្រោមចេតនាសម្លាប់នោះឡើយ" (១.២.៤)[1049]។ ក្នុងករណីបន្ទាប់បន្សំ គោលការណ៍នៃការអនុវត្តបែបប្រតិសកម្មនៃនីតិព្រហ្មទណ្ឌ ដែលស្រាលជាងនេះ អាចនឹងបដិសេធចោលនូវបទដ្ឋានដែលខ្សោយជាងចេតនាផ្ទាល់ក្នុងការសម្លាប់ ដែលបានសម្រេចយកដោយអង្គជំនុំជម្រះ (១.២.៥)។

### ១.២.១. គ្មានចេតនាប្រយោលនៅក្នុងរឿងក្តី *គ្រូពេឡូ*

៥៨២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអះអាងដូចតុលាការកំពូលដែរថា រឿងក្តី *គ្រូពេឡូ* អាចចាត់ទុកបានថាជា "មូលដ្ឋានសំអាងមួយក្នុងចំណោមមូលដ្ឋានសំអាងផ្លូវច្បាប់ជាច្រើន ក្នុងការដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់ដោយចេតនា ទោះបីចារីបានប្រព្រឹត្តអំពើដោយចេតនាក្នុងកម្រិតទាបជាងចេតនាផ្ទាល់ក៏ដោយ"[1050]។

[1049] សារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៩, សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៩៥។

[1050] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៦។

៥៨៣. ជាបឋម តុលាការកំពូលបានបកស្រាយធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ក្នុង "លក្ខណៈទូលាយ"[1051] ដែលបង្កឱ្យមានបញ្ហា ព្រោះវាបានរំលោភលើគោលការណ៍នីត្យានុកូលភាព ដែលតម្រូវឱ្យមានការបកស្រាយតឹងរ៉ឹង និងផ្តល់ផលអនុគ្រោះដល់ជនជាប់ចោទ។

៥៨៤. បន្ទាប់មក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានទាញការសន្និដ្ឋានថា "ទោះបីជាសាលក្រមក្នុងរឿងក្តី *ក្រូពេឡ* មិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ពីល័ក្ខខ័ណ្ឌវិនិច្ឆ័យដែលប្រើសម្រាប់កំណត់ធាតុផ្សំអត្តនោម័តិ ដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់"[1052]។ ក៏ប៉ុន្តែ បើទោះជាមានការកត់សម្គាល់បែបនេះក៏ដោយចុះ ក៏អង្គជំនុំជម្រះមិនអាចផ្អែកលើយុត្តិសាស្ត្រតែមួយគត់នេះ ដែលពុំបានផ្តល់ឱ្យបានច្បាស់លាស់នូវនិយមន័យនៃធាតុផ្សំអត្តនោម័តិនៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ដើម្បីអាចអះអាងបានជាលក្ខណៈទូទៅថា "យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី ២" បានបញ្ចូលចេតនាប្រយោលទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនេះ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥។ ការអះអាងមួយនេះ ដែលគ្មានការវិភាគអ្វីសោះនោះ ត្រូវតែរងការពិន័យ។

៥៨៥. ជាចុងក្រោយ ការវិភាគអំពីអង្គហេតុនៃរឿងក្តី *ក្រូពេឡ* មិនគាំទ្រសេចក្តីសន្និដ្ឋានរបស់តុលាការកំពូលដែលអង្គជំនុំជម្រះបានយកតាម ដែលថា "ចេតនាបានរួមបញ្ចូលហានិភ័យនៃគ្រោះថ្នាក់ដល់អាយុជីវិតរបស់បុគ្គលទាំងឡាយដែលត្រូវបានគេយកមកពិសោធ ដោយដឹងថា ការធ្វើបែបនេះទំនងជានឹងនាំឱ្យមានការបាត់បង់ជីវិត"[1053]។ តុលាការកំពូល ក្នុងសាលដីកាសំណុំរឿង ០០២/០១ និងអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ បានជ្រើសរើសយកការបកស្រាយដែលមិនស៊ីចង្វាក់គ្នាអ្វីសោះទៅនឹងដំណើរការជំរំនៃរបបណាហ្ស៊ី។ ការវិភាគទៅលើអង្គហេតុអាចនាំទៅដល់ការបកស្រាយតែមួយគត់គឺ ៖ វាបានបង្ហាញឱ្យឃើញច្បាស់ឥតមន្ទិលថា ក្នុងចំណោមការផ្តន្ទាទោសទាំងឡាយដោយតុលាការយោធាអាមេរិក គឺគ្មានការផ្តន្ទាទោសណាមួយបានផ្អែកលើចេតនាប្រយោលនោះទេ។ បទពិសោធន៍

[1051] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៤១០។

[1052] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៦។

[1053] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ទាំងឡាយនៃការជ្រើសរើសឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ប្រឆាំងនឹងជនជាប់ចោទ គឺបទពិសោធន៍ទាំងប្រាំបីនេះ (ក) (ខ) (គ) (ឃ) (ង) (ច) (ឆ) និង (ជ)។ ជាក់ស្តែង ចេតនាផ្ទាល់ក្នុងការសម្លាប់ត្រូវបានបង្ហាញឱ្យឃើញតាមរយៈការធ្វើពិសោធន៍ទាំងអស់នៅក្នុងជំរំមរណៈ (Ravensbruck, Saschsenhausen, Natzweiler, Dachau និង Buchenwald)។ ជំរំប្រមូលផ្តុំរបស់របបណាហ្ស៊ីទាំងនេះ កំណត់ឱ្យជនជាប់ឃុំទាំងអស់ត្រូវតែស្លាប់ លើកលែងតែកាលៈទេសៈពិសេស។ លើសពីនេះទៀត ចេតនាផ្ទាល់ក្នុងការសម្លាប់ បានស្តែងឱ្យឃើញច្បាស់តាមរយៈវិធីសាស្ត្រហួសប្រមាណនានាក្នុងការធ្វើពិសោធន៍លើជនជាប់ឃុំ ឬអ្នកដែលគេយកមកទុកពិសោធន៍។ វាគ្មានអ្វីត្រូវសង្ស័យនោះទេ អំពីលទ្ធផលនៃការធ្វើពិសោធន៍មរណៈទាំងនេះ។ វាពុំមែនជាការ "ប្រថុយប្រថានជីវិតមនុស្សដែលគេទុកសម្រាប់ពិសោធ"នោះទេ ផ្ទុយទៅវិញ ចារីរំពឹងថាការធ្វើពិសោធន៍ទាំងអស់នេះនឹងនាំទៅដល់ការស្លាប់នៅទីបំផុត។

៥៨៦. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយោងទៅលើរឿងក្តី*គ្រូពេទ្យ* ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានដែលថា និយមន័យនៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺមានបញ្ចូលចេតនាទាបជាងចេតនាផ្ទាល់ក្នុងការសម្លាប់ នៅឆ្នាំ ១៩៧៥។

### ១.២.២. ការមិនអាចរកបាននូវ "ការចង្អុលបង្ហាញ" នៅក្នុងយុត្តិសាស្ត្រ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា មុនពេលអង្គហេតុកើតឡើង

៥៨៧. ដើម្បីរក្សានិយមន័យទូលាយនៃធាតុផ្សំអត្តនោម័តិ នៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយោងទៅលើយុត្តិសាស្ត្រមុនឆ្នាំ១៩៧៥ របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[1054]។ អង្គជំនុំជម្រះ

---

[1054] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៥, សូមមើលកំណត់សម្គាល់ជើងទំព័រលេខ១៩៩៣ យោងទៅ សាលដីកា *Kvočka* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ២៦១, សាលដីកា *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៣៩, សាល

បានអះអាងដោយពុំត្រឹមត្រូវថា យុត្តិសាស្ត្រសព្វថ្ងៃរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលទទួលស្គាល់ "នាពេលបច្ចុប្បន្ន" ថា ចេតនាប្រយោលអាចគ្រប់គ្រាន់ដើម្បីកំណត់ចេតនាសម្លាប់ ដោយ "ផ្តល់ការចង្អុលបង្ហាញប្រាកដមែន" អំពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥[1055]។ ក៏ប៉ុន្តែ យុត្តិសាស្ត្រនានារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលអង្គជំនុំជម្រះបានយោង បានអនុវត្តជាលើកដំបូងនូវបទដ្ឋានមួយទាបជាងចេតនាផ្ទាល់ក្នុងការសម្លាប់ សម្រាប់អង្គហេតុដែលកើតមុនអង្គហេតុរបស់ អ.វ.ត.ក។ លើសពីនេះទៀត យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ពុំដែលបានផ្អែកលើសេចក្តីសម្រេចអន្តរជាតិមុនៗ ដើម្បីបញ្ញត្តកម្រិតថ្មីនៃចេតនា សម្រាប់ឧក្រិដ្ឋកម្មមនុស្សឃាតនោះឡើយ។ ជាចុងក្រោយ អង្គជំនុំជម្រះបានកត់សម្គាល់ថា "ទាក់ទិននឹងការប្រើប្រាស់ពាក្យពេចន៍ជាក់លាក់នោះ យុត្តិសាស្ត្រនេះមិនស៊ីចង្វាក់គ្នាទាំងស្រុងនោះទេ" និងថា "សេចក្តីសម្រេចមួយចំនួនរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានលើកឡើងថា ការគិតទុកជាមុន គឺជាល័ក្ខខ័ណ្ឌតម្រូវនៃគោលបំណងធ្វើមនុស្សឃាត"[1056]។ ការកត់សម្គាល់នេះ គួរតែនាំឱ្យអង្គជំនុំជម្រះបដិសេធចោលនូវយុត្តិសាស្ត្រនេះ។ ម្យ៉ាងវិញទៀត នៅក្នុងរឿងក្តី ឌុច តុលាការកំពូលបានអះអាងដោយត្រឹមត្រូវថា "រឿងក្តីទាំងនេះមិនមានអានុភាពចងកាតព្វកិច្ច និងមិនមែនជាប្រភពច្បាប់នៃច្បាប់អន្តរជាតិសម្រាប់ អ.វ.ត.ក ទេ"[1057]។ ដូច្នេះ យុត្តិសាស្ត្រនេះមិនអាចយកមកប្រើបានជាដាច់ខាតដើម្បីផ្តល់ "ការចង្អុលបង្ហាញ" អំពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥។ យុត្តិសាស្ត្រនេះមិនមានភាពពាក់ព័ន្ធសោះឡើយដើម្បីគាំទ្រថា នៅឆ្នាំ១៩៧៥ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានរាប់បញ្ចូលចេតនាប្រយោលក្នុងអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត។

---

ដីកា *Dragomir Milošević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០៨។

[1055] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៥។ សូមមើលផងដែរ សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៤៖ "ផ្ទុយទៅនឹងការសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ប្រការនេះមិនបានរារាំងអង្គជំនុំជម្រះមិនឱ្យយោងទៅសេចក្តីសម្រេចក្រោយៗមកទៀតដែលស្រាយបំភ្លឺ ឬបកស្រាយច្បាប់នោះឡើយ" កំណត់សម្គាល់ជើងទំព័រលេខ១៩៩២ យោងទៅ ផ្នែកទី ២.២. គោលការណ៍នីត្យានុកូលភាព, ផ្នែកទី ៤.២.១.២. ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

[1056] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៥។

[1057] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៧។

### ១.២.៣. ការមិនអាចផ្អែកបានលើការអនុវត្តច្បាប់ជាតិ

៥៨៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយោងតាមសេចក្តីសន្និដ្ឋានរបស់តុលាការកំពូលដែលថា "ទម្លាប់អនុវត្តក្នុងស្រុក" ""បានបញ្ជាក់បន្ថែមទៀត" ទៅលើសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានរួមបញ្ចូលនូវសញ្ញាណនៃចេតនាប្រយោល"[1058]។

៥៨៩. វិចារណកិច្ចគតិយុត្តិរបស់តុលាការកំពូល ដែលត្រូវបានយោងដោយអង្គជំនុំជម្រះនេះ គឺមិនត្រឹមត្រូវទេ។ ទោះជាមានទម្លាប់អនុវត្តក្នុងស្រុកដែលទទួលយកចេតនាប្រយោល ដើម្បីកំណត់ការធ្វើមនុស្សឃាត នៅក្នុងច្បាប់ជាតិក៏ដោយ ក៏វាមិនអាច "ជួយបញ្ជាក់បន្ថែម" នូវសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវរបស់តុលាការកំពូលដែលថា រឿងក្តី *ត្រូពេឡូ* បានបញ្ជាក់ឱ្យឃើញច្បាស់ពីបទដ្ឋាននៃធាតុផ្សំអត្តនោម័តិទាបជាងចេតនាផ្ទាល់ក្នុងការសម្លាប់ ដើម្បីកំណត់អំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ បាននោះទេ។

៥៩០. វិធីតែមួយគត់ដើម្បីកំណត់លក្ខណៈនៃវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាមរយៈមធ្យោបាយច្បាប់ជាតិ គឺត្រូវបង្ហាញឱ្យឃើញតាមរយៈច្បាប់ជាតិ នូវអត្ថិភាពនៃ "ការអនុវត្តជាទូទៅដែលត្រូវបានទទួលយកថាដូចជាច្បាប់ (*opinio juris*)"[1059]។ ក៏ប៉ុន្តែ ទាំងអង្គជំនុំជម្រះ ទាំងតុលាការកំពូល នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះបានយកមកធ្វើជាមូលដ្ឋាន សុទ្ធតែពុំបានព្យាយាមបង្ហាញឱ្យឃើញអំពីធាតុផ្សំចាំបាច់នីមួយៗក្នុងចំណោមធាតុផ្សំទាំងពីរ ដើម្បីយកមកសំអាងតាមផ្លូវច្បាប់ថាមានវិធានទំនៀមទម្លាប់នៅឆ្នាំ១៩៧៥ ដែលចែងថា ធាតុផ្សំអត្តនោម័តិអាចមានកម្រិតទាបជាងចេតនាផ្ទាល់ក្នុងការសម្លាប់[1060]។

---

1058 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៧។

1059 របាយការណ៍របស់គណៈកម្មាការច្បាប់អន្តរជាតិ គម្រោងនៃសេចក្តីសន្និដ្ឋានស្តីពីការកំណត់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងមតិយោបល់ដែលពាក់ព័ន្ធ សេចក្តីសន្និដ្ឋាន ២ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ A/73/10 កថាខណ្ឌ ៥១, មាត្រា ៣៨-១ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។

1060 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៧-៦៥០។

៥៩១. បន្ថែមពីលើនេះទៀត នៅក្នុងសាលដីកា សំណុំរឿង ០០២/០១ តុលាការកំពូលបានផ្អែកលើការយោងមួយដែលមិនត្រឹមត្រូវនៅក្នុងច្បាប់ជាតិ ការយោងទៅលើច្បាប់ដែលកើតក្រោយអង្គហេតុ និងប្រភពសំអាងខ្លះៗដែលមាននៅមុនឆ្នាំ១៩៧៥ ដែលមិនអាចកំណត់បាននំពីវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥។ មេធាវីការពារក្ដីសូមយោងទៅទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន[1061]។

## ១.២.៤. សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥

៥៩២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសំអាងសេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលលើកឡើងថា ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត គឺមានបញ្ចូលនូវចេតនាប្រយោល ក្នុងឆ្នាំ១៩៧៥ ទៅក្នុងការបកស្រាយមួយចំនួន ដែល “ក្នុងនោះ” មានការបកស្រាយបែបពង្រីកលើរឿងក្ដី*គ្រូពេទ្យ* ដោយតុលាការកំពូល ដែលត្រូវបានសន្មតថា “ជួយបញ្ជាក់បន្ថែម” តាមរយៈការយោងទៅច្បាប់ជាតិខ្លះៗ នៅក្នុងឆ្នាំ១៩៧៥។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយយល់ឃើញថា យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនាពេលបច្ចុប្បន្ន បានផ្ដល់ “ការចង្អុលបង្ហាញ” មួយចំនួនពាក់ព័ន្ធនឹងស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិ នាឆ្នាំ១៩៧៥។

៥៩៣. លើសពីនេះទៀត ច្បាប់ទំនៀមទម្លាប់អន្តរជាតិសព្វថ្ងៃ ដូចដែលបានបញ្ញត្តនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម បានបញ្ជាក់អះអាងពីចក្ខុវិស័យរឹតត្បិតនៃចេតនាឧក្រិដ្ឋ។ មាត្រា ៣១-១ នៃលក្ខន្តិកៈទីក្រុងរ៉ូម បានបញ្ញត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពាក់ព័ន្ធនឹងចេតនានៃបទឧក្រិដ្ឋនានាដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការយ៉ាងច្បាស់លាស់ថា៖ “ជនម្នាក់ត្រូវទទួលខុសត្រូវ និងទទួលទណ្ឌកម្មព្រហ្មទណ្ឌ ចំពោះបទ

[1061] សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៤២១-៤២៩។

ល្មើសព្រហ្មទណ្ឌស្ថិតនៅក្នុងយុត្តាធិការតុលាការ តែក្នុងករណីដែលធាតុជាសំខាន់ៗត្រូវបានប្រព្រឹត្ត ដោយចេតនា និងដោយការដឹង"[1062]។

៥៩៤. ដូច្នេះ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ចេតនាផ្ទាល់គឺជាល័ក្ខខ័ណ្ឌតម្រូវច្បាស់ណាស់។ គេត្រូវបង្ហាញភ័ស្តុតាងថា "ជននោះបង្កឱ្យកើតផលវិបាកនោះ ឬជននោះមានសតិដឹងថា វានឹងកើតមាននៅក្នុងដំណើរប្រព្រឹត្តធម្មតានៃព្រឹត្តិការណ៍"[1063]។

៥៩៥. គ្មានប្រភពសំអាងណាមួយនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលផ្តល់សុពលភាពដល់ការអះអាងរបស់អង្គជំនុំជម្រះដែលថា ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត បានបញ្ចូលចេតនាប្រយោល នៅឆ្នាំ១៩៧៥ នោះទេ។ នេះមិនមែនចង់មានន័យថា ពុំមានវិធាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពាក់ព័ន្ធនឹងបញ្ហានៃការកំណត់អំពីធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតនោះទេ តែគ្រាន់តែចង់និយាយថា ការកំណត់នេះពុំបានរាប់បញ្ចូលចេតនាប្រយោល។ គោលការណ៍ទាំងឡាយសម្រាប់ការបកស្រាយក្នុងផ្នែកព្រហ្មទណ្ឌ ត្រូវនាំតុលាការកំពូលឱ្យបដិសេធចោលសេចក្តីសន្និដ្ឋានគតិយុត្តិមួយនេះ។

### ១.២.៥. ជាការបន្ទាប់បន្សំ ការអនុវត្តបែបប្រតិសកម្មនៃនីតិព្រហ្មទណ្ឌទន់ភ្លន់ជាង

៥៩៦. ជាការបន្ទាប់បន្សំ បើទោះជាស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥ អនុញ្ញាតឱ្យមានការចោទប្រកាន់ចំពោះចេតនាទាបជាងចេតនាផ្ទាល់ក្នុងការសម្លាប់ ពាក់ព័ន្ធនឹងការធ្វើមនុស្សឃាតក៏ដោយចុះ ក៏គេត្រូវដេកចេញនូវបទដ្ឋានធាតុផ្សំអត្តនោម័តិនេះ ស្របតាមគោលការណ៍នៃការអនុវត្តបែបប្រតិសកម្មនៃនីតិព្រហ្មទណ្ឌដែលទន់ភ្លន់ជាងគេបង្អស់។

---

[1062] សេចក្តីសម្រេចធ្វើឡើងអនុលោមតាមវាក្យខ័ណ្ឌ ក) និង ខ) នៃមាត្រា ៦១-៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម ពាក់ព័ន្ធនឹងការចោទប្រកាន់របស់រដ្ឋអាជ្ញា ប្រឆាំងនឹង Jean-Pierre Bemba Gombo (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ៣៦០៖ "ពាក់ព័ន្ធនឹងចេតនាដោយប្រយោល ដែលជាទម្រង់ទី៣ នៃចេតនា ការធ្វេសប្រហែស (recklessness) ឬរាល់ទម្រង់ផ្សេងទៀតនៃពិរុទ្ធភាពដែលទាបជាង អង្គជំនុំជម្រះយល់ស្របថា ទស្សនៈទានទាំងនេះមិនត្រូវបានបញ្ចូលក្នុងមាត្រា ៣០ នៃលក្ខន្តិកៈទេ"។

[1063] មាត្រា ៣០-២-ខ នៃលក្ខន្តិកៈទីក្រុងរ៉ូម។

៥៩៧. កិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ បានបង្ហាញឱ្យឃើញពីចេតនាអនុវត្តបែបប្រតិសកម្មនៃនីតិព្រហ្មទណ្ឌដែលទន់ភ្លន់ជាងនេះ ដោយបានបញ្ជាក់ពីភាពអាចអនុវត្តបាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលបានបញ្ញត្តនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម សម្រាប់ច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ មាត្រា ៩ បង្ហាញយ៉ាងច្បាស់ពីលក្ខន្តិកៈទីក្រុងរ៉ូម ថាដូចជាប្រភពសំអាងនៃច្បាប់៖

> "យុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមាន ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចដែលបានកំណត់ក្នុងអនុសញ្ញាឆ្នាំ១៩៤៨ស្តីពីការបង្ការ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ១៩៩៨ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ដូចបានកំណត់ក្នុងជំពូក ២ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១"[1064]។

៥៩៨. ជាក់ស្តែង ជាគោលការណ៍ នីតិព្រហ្មទណ្ឌមិនមានភាពប្រតិសកម្មឡើយ លើកលែងតែវាមានលក្ខណៈទន់ភ្លន់ជាង។ ដូច្នេះ ការបង្ហាញអំពីច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយនេះ ដូចដែលបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម អាចត្រូវបានបកស្រាយឱ្យស្របតែទៅនឹងគោលការណ៍គ្រឹះទាំងឡាយរបស់ច្បាប់ព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យមានការអនុវត្តច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានកំណត់ដោយលក្ខន្តិកៈទីក្រុងរ៉ូម កាលណាការកំណត់អំពីគោលការណ៍ទាំងអស់នោះ មានភាពទន់ភ្លន់ជាង។

៥៩៩. ចេតនាផ្ទាល់ក្នុងការសម្លាប់ ជាល័ក្ខខ័ណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត។ ហេតុដូច្នេះ បើទោះជាក្នុងករណីដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥ អាចនឹងរាប់បញ្ចូលចេតនាទាបជាងចេតនាផ្ទាល់ក្នុងការសម្លាប់ក៏ដោយ ក៏ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅ

---

[1064] មាត្រា ៩ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ឆ្នាំ១៩៧៥ គួរតែត្រូវបានដកចេញ ឱ្យបានជាប្រយោជន៍ដល់ការអនុវត្តនូវបទដ្ឋានសព្វថ្ងៃដែលតឹងរ៉ឹងជាង ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលបានបញ្ញត្តដោយលក្ខន្តិកៈទីក្រុងរ៉ូម។

៦០០. ច្បាប់ទំនៀមទម្លាប់អន្តរជាតិពុំអនុញ្ញាតឱ្យអង្គជំនុំជម្រះបន្ទាបធាតុផ្សំអត្តនោម័តិ នៃការធ្វើមនុស្សឃាតមកជាចេតនាប្រយោលឡើយ។ បម្រាមនេះក៏អនុវត្តដូចគ្នាដែរ ចំពោះគោលការណ៍ទូទៅនៃច្បាប់ ដែលពុំមែនជាប្រភពនៃច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ដើម្បីយកមកគាំទ្រការបកស្រាយផ្ទុយពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥។ ជាពិសេសនៅពេលដែលគោលការណ៍ទាំងនោះ ត្រូវបានលើកឡើងក្នុងករណីយ៉ាងច្បាស់លាស់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអនុញ្ញាតឱ្យឈានដល់ការធ្វើសេចក្តីសន្និដ្ឋានថា និយមន័យនៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅឆ្នាំ១៩៧៥ គឺមានរាប់បញ្ចូលចេតនាប្រយោល។

## ១.៣. ការយោងគ្មានសុពលភាពទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីបន្ទាបចេតនាដែលជាលក្ខខណ្ឌតម្រូវ

៦០១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រមូលផ្តុំ “គោលការណ៍ច្បាប់ទូទៅ [ដែល] អាចជាជំនួយដល់ការកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងករណីដែលឧក្រិដ្ឋកម្មនោះត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ”[1065] មុននឹងសន្និដ្ឋានថា “ប្រព័ន្ធច្បាប់ក្នុងស្រុកទាំងនេះ ភាគច្រើនទទួលស្គាល់ថា បទដ្ឋាននៃធាតុផ្សំអត្តនោម័តិ ក្នុងកម្រិតទាបជាងចេតនាផ្ទាល់ អាចយកមកអនុវត្តបាន ទាក់ទិនការធ្វើមនុស្សឃាតដោយចេតនាកម្រិតទាបបំផុត នោះគឺចេតនាប្រយោល”[1066]។ អង្គជំនុំជម្រះពុំបានបង្ហាញឱ្យឃើញថា គោលការណ៍ទូទៅនៃច្បាប់ គឺជាប្រភពចម្បងនៃច្បាប់ជាធរមាន នៅ អ.វ.ត.ក សម្រាប់កំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលមានអត្ថិភាពក្នុងឆ្នាំ១៩៧៥ (១.៣.១)។ ការពិតទៅ គោលការណ៍ទូទៅនៃច្បាប់គ្រាន់តែជាប្រភពសំអាងបន្ទាប់បន្សំ ដែលមិនអាចជំនួសវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដើម្បីកំណត់ធាតុផ្សំ ឧក្រិដ្ឋកម្ម

---

[1065] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៨។

[1066] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥០។

មួយបានទេ (១.៣.២)។ បន្ថែមពីលើនេះទៀត ការយោងលើគោលការណ៍ទូទៅនៃច្បាប់ ត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងបំផុតដោយគោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌ ក្នុងនោះ មានគោលការណ៍នីត្យានុកូលភាព និងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (១.៣.៣)។

**១.៣.១. គ្មានសំអាងហេតុពីការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ថាជាមូលដ្ឋាន សំអាងចម្បងសម្រាប់កំណត់ធាតុផ្សំឧក្រិដ្ឋកម្ម នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ**

***១.៣.១.១. យុត្តិសាស្ត្ររបស់ អ.វ.ត.ក មិនទទួលស្គាល់ការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់សម្រាប់កំណត់ធាតុផ្សំឧក្រិដ្ឋកម្ម***

***- យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ***

៦០២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានផ្អែកលើអង្គបុរេជំនុំជម្រះ ដើម្បីផ្តល់ទឡ្ហីករណ៍តាមផ្លូវច្បាប់ចំពោះការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ សម្រាប់កំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ក្នុងច្បាប់អន្តរជាតិ នាឆ្នាំ១៩៧៥។ យុត្តិសាស្ត្រតែមួយគត់របស់ អ.វ.ត.ក ដែលអង្គជំនុំជម្រះបានយោងនេះ ពុំអាចយកធ្វើជាមូលដ្ឋានដែលមានសុពលភាពចំពោះការអះអាងនេះបានទេ។ ជាបឋម ដោយពុំបានធ្វើការវិភាគណាមួយ អង្គបុរេជំនុំជម្រះបានត្រឹមតែប្រកាសថា គោលការណ៍ទូទៅនៃច្បាប់ ត្រូវបានពិចារណាដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី "ក្នុងការកំណត់មិនត្រឹមតែធាតុផ្សំនៃបទឧក្រិដ្ឋអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកំណត់វិសាលភាពទម្រង់នៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋអន្តរជាតិទៀតផង"[1067]។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់យ៉ាងច្បាស់ ដោយបានធ្វើមិនដឹងចំពោះផ្នែកសំខាន់ចំនួនពីរ ក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលផ្នែកទាំងនោះពុំគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះនោះទេ។ អង្គបុរេជំនុំជម្រះបានអះអាង ម្យ៉ាងថា "ឋានៈពិតប្រាកដនៃគោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌជាប្រភពជំនួយ ឬប្រភពសំខាន់នៃច្បាប់អន្តរជាតិ គឺមានលក្ខណៈ

[1067] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៨៤។

មិនច្បាស់"[1068]។ ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះបានសម្រេចដកចេញ ដោយចិត្តឯងនូវការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ សម្រាប់ការកំណត់ជាលក្ខណៈទូលាយនូវធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួម-ទម្រង់ ៣ ដើម្បីការពារគោលការណ៍នីត្យានុកូលភាព ព្រោះថាការបកស្រាយមួយនេះ មិនមានមូលដ្ឋានគាំទ្រណាមួយនោះទេ នៅក្នុងច្បាប់កម្ពុជា នៅសម័យកាលនៃអង្គហេតុ[1069]។ ការបំភ្លេចចោលដោយចេតនារបស់អង្គជំនុំជម្រះនូវផ្នែកសំខាន់នៃយុត្តិសាស្ត្រដែលត្រូវបានយោង ហើយដែលលើកឡើងផ្ទុយពីការអះអាងរបស់ខ្លួន បង្ហាញឱ្យឃើញថា អង្គជំនុំជម្រះបានដឹងយ៉ាងច្បាស់អំពីភាពមិនអាចអនុវត្តបានរបស់យុត្តិសាស្ត្រនោះ ក្នុងការកំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត។ នេះជាការឆ្លុះបញ្ចាំងដ៏ល្អបំផុតពីលក្ខណៈមិនត្រឹមត្រូវនៃវិចារណកិច្ចការរបស់អង្គជំនុំជម្រះ។ តុលាការបានប្រព្រឹត្តកំហុស ដោយបានយោងទៅលើយុត្តិសាស្ត្រដាច់តែឯង និងមិនអាចអនុវត្តបានថែមទៀត ដើម្បីធ្វើជាសំអាងលើការយោងរបស់ខ្លួនទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីកំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្ម ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

***- យុត្តិសាស្ត្ររបស់តុលាការកំពូល***

---

[1068] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ **D97/15/9** កថាខណ្ឌ ៨៤ យោងនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ២៣៨ ទៅលើសាលក្រម *Furundžija* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៧៧, កថាខណ្ឌ ៨៦ យោងនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ២៤៤ ទៅលើសាលក្រម *Furundžija* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៧៨, សេចក្តីសម្រេច *Milutinović* ស្តីពីការជំទាស់យុត្តាធិការ លើកឡើងដោយ Dragoljub Ojdanić (ការបង្កិតបង្កំដោយប្រយោល) (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦, យោបល់ផ្ទាល់ខ្លួនរបស់ចៅក្រម Bonomy កថាខណ្ឌ ២៧ កំណត់សម្គាល់ជើងទំព័រលេខ២៤៥, សាលដីកា *Erdemović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧, យោបល់ផ្ទាល់ខ្លួនលើកឡើងរួមគ្នារបស់លោកស្រីចៅក្រម McDonald និងលោកចៅក្រម Vohrah កថាខណ្ឌ ៥៧, យោបល់ផ្ទាល់ខ្លួន និងផ្ទុយរបស់ចៅក្រម Stephen កថាខណ្ឌ ២៥ កំណត់សម្គាល់ជើងទំព័រលេខ២៤៦, សាលក្រម *Furundžija* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៧៨ និងសាក្រម *Kunarac និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៤៣៩ កំណត់សម្គាល់ជើងទំព័រលេខ២៤៧, សាលដីកា *Blaškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៣៤-៤២។

[1069] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ **D97/15/9** កថាខណ្ឌ ៨៧។

៦០៣. សាលដីកាសំណុំរឿង ០០២/០១ ក៏មិនអនុញ្ញាតឱ្យផ្តល់មូលដ្ឋានគតិយុត្តិដល់ការយោងលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីកំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥ នោះដែរ។ តុលាការកំពូលបានបង្ហាញយ៉ាងច្បាស់នូវគោលការណ៍ទូទៅនៃច្បាប់របស់អារ្យប្រទេសនានា តែនៅក្នុងក្របខ័ណ្ឌនៃការវាយតម្លៃរបស់ខ្លួនលើសហឧក្រិដ្ឋកម្មរួម-ទម្រង់ ៣ ប៉ុណ្ណោះ។ តុលាការកំពូលបានអះអាងថាការអនុវត្តជាទូទៅនៅក្នុងវិស័យព្រហ្មទណ្ឌកម្រិតជាតិ៖

> "អាចប្រើតែដើម្បីកំណត់អត្តសញ្ញាណគោលការណ៍ទូទៅនៃច្បាប់ (ក្នុងស្រុក) ឬប្រើជាចំណុចយោងសម្រាប់បកស្រាយឧក្រិដ្ឋកម្មក្នុងច្បាប់អន្តរជាតិ រួមទាំងគោលការណ៍ និងសញ្ញាណពាក់ព័ន្ធប៉ុណ្ណោះ ដោយហេតុថា សញ្ញាណនៃនីតិព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើង ដោយផ្អែកលើគោលគំនិតនៅក្នុងនីតិព្រហ្មទណ្ឌក្នុងស្រុក"[1070]។

៦០៤. ដើម្បីផ្តល់មូលដ្ឋានដល់ការអះអាងមួយនេះ អង្គជំនុំជម្រះបានយោងតែទៅមាត្រាចំនួនពីរនៃលទ្ធិជាភាសាអាល្លឺម៉ង់។ ក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានយោងផងដែរទៅកថាខណ្ឌ ៣៨៧ និងកថាខណ្ឌបន្តបន្ទាប់ ដែលទំនងជាបានធ្វើការពិនិត្យ ដោយពុំមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ លើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅឆ្នាំ១៩៧៥។ តុលាការកំពូលពុំបានយោងលើវិធានច្បាប់ណាមួយ និងពុំបានផ្តល់ការវិនិច្ឆ័យណាមួយដែលជួយគាំទ្រផ្លូវច្បាប់ចំពោះជំហររបស់អង្គជំនុំជម្រះឡើយ។

### *១.៣.១.២. គ្មានយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលផ្តល់សុពលភាពដល់ការអនុវត្តគោលការណ៍ទូទៅនៃច្បាប់ ដើម្បីកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្ម*

---

[1070] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៥។

៦០៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយោងលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលពុំបានលើកឡើងអំពីសុពលភាពនៃការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មនោះទេ[1071]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានត្រឹមតែចង្អុលបង្ហាញអំពីមូលដ្ឋានសំអាងមួយចំនួន ដើម្បីកំណត់វិធីសាស្ត្រដែលត្រូវអនុវត្តក្នុងការកំណត់**អត្ថិភាព**នៃគោលការណ៍ទូទៅនៃច្បាប់ ដោយបានយោងទៅសេចក្តីសម្រេចមួយរបស់ អ.វ.ត.ក សាលក្រម *Furundžija* សាលក្រម *Kunarac* មតិផ្ទាល់ខ្លួនរបស់ចៅក្រម BONOMY នៅក្នុងសេចក្តីសម្រេច *Milutinović* មតិផ្ទាល់ខ្លួន និងរួមគ្នារបស់ចៅក្រម MCDONALD និងចៅក្រម VOHRAH និងមតិផ្ទាល់ខ្លួន និងមតិជំទាស់របស់ចៅក្រម STEPHEN ក្នុងសាលដីកា *Erdemović*។ ការវិភាគយុត្តិសាស្ត្រតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនេះ ដែលត្រូវបានយោងដោយអង្គបុរេជំនុំជម្រះ មិនអាចយកមកគាំទ្រការអះអាងថា គោលការណ៍ទូទៅនៃច្បាប់ជាមូលដ្ឋានសំអាងដែលមានសុពលភាពសម្រាប់កំណត់ធាតុផ្សំឧក្រិដ្ឋកម្ម ក្នុងច្បាប់អន្តរជាតិបានទេ[1072]។ ការ

---

[1071] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៨ កំណត់សម្គាល់ជើងទំព័រលេខ១៩៩៧-១៩៩៨។

[1072] សាលក្រម *Furundžija* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៧៧-១៧៨។ ផ្នែកនេះនៃសាលក្រម ដែលពាក់ព័ន្ធនឹងនិយមន័យនៃការរំលោភសេពសន្ថវៈ ពុំបានផ្តល់ការយោង និងការវិភាគច្បាស់លាស់ណាមួយទៅនឹងសុពលភាពផ្លូវច្បាប់ចំពោះការយោងទៅលើគោលកាណ៍ទូទៅនៃច្បាប់, សាលក្រម *Kunarac និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤៣៩។ សាលក្រម *Kunarac* យោងតាមយុត្តិសាស្ត្រដែលចែងតែអំពីច្បាប់ដែលមានស្រាប់ *Furundžija* ដោយពុំបានផ្តល់មូលដ្ឋានគតិយុត្តិបន្ថែម ពាក់ព័ន្ធនឹងសុពលភាពនៃការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់។ សេចក្តីសម្រេច *Milutinović* ស្តីពីការជំទាស់យុត្តាធិការ លើកឡើងដោយ Dragoljub Ojdanić (ការបង្កិតបង្ខំដោយប្រយោល) (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០០៦, យោបល់ផ្ទាល់ខ្លួនរបស់ចៅក្រម Bonomy កថាខណ្ឌ ២៧ ដែលយោងទៅ សាលដីកា *Blaškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី)។ យោបល់ផ្ទាល់ខ្លួននេះក៏នៅតែមិនបានផ្តល់ការបញ្ជាក់ណាមួយពាក់ព័ន្ធនឹងមូលដ្ឋានគតិយុត្តិនៃការអះអាងដែលថា គោលការណ៍ទូទៅនៃច្បាប់គឺជាប្រភពសំអាងសម្រាប់កំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬធាតុផ្សំអត្តនោម័តិនៃទម្រង់នៃការទទួលខុសត្រូវ។ ចៅក្រមរូបនេះបានបំភ្លឺបញ្ហាគន្លឹះនេះ ដើម្បីកំណត់អំពីច្បាប់សារធាតុជាធរមាន ដោយកម្រិតត្រឹមការលើកឡើងវិញនូវយុត្តិសាស្ត្រដែលលើកឡើងតែអំពីវិធានច្បាប់របស់ *Furundžija* និងសាលដីកា *Blaškic* ដែលតាមការបកស្រាយរបស់ចៅក្រមរូបនេះ យុត្តិសាស្ត្រនេះទំនងជានិយាយ “ដោយប្រយោលថា អង្គជំនុំជម្រះមួយអាចផ្អែកផងដែរលើគោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌ ដើម្បីកំណត់ពីវិសាលភាពនៃការអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវ”, សាលដីកា *Blaškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៣៤។ ចៅក្រមទាំងអស់យល់ឃើញថា “មានប្រយោជន៍ដែលត្រូវផ្អែកលើវិធីសាស្ត្រនានាដែលត្រូវបានប្រកាន់យកនៅក្នុងប្រព័ន្ធច្បាប់ជាតិ” ដោយពុំបាន

ពិនិត្យលើប្រភពសំអាងដែលយោងដោយអង្គជំនុំជម្រះ ដើម្បីគាំទ្រវិធីសាស្ត្ររបស់ខ្លួន សម្រាប់កំណត់អំពីគោលការណ៍ទូទៅនៃច្បាប់ ពុំបានផ្តល់ជាមូលដ្ឋានដែលមានសុពលភាពដល់ការអះអាងរបស់ខ្លួនថា "វាអាចមានប្រយោជន៍" ក្នុងការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីកំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

### *១.៣.១.៣. ភាពអាចអនុវត្តបានដោយមានល័ក្ខខ័ណ្ឌនៃមាត្រា ៣៨(១)(គ) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ សម្រាប់កំណត់ប្រភពសំអាងជាធរមាននៅ អ.វ.ត.ក*

៦០៦. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានអះអាងនៅក្នុងកំណត់សម្គាល់ជើងទំព័រថា "មាត្រា ៣៨(១)(គ) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ទទួលស្គាល់ "គោលការណ៍ច្បាប់ទូទៅដែលទទួលស្គាល់ដោយបណ្តារដ្ឋស៊ីវិល័យនានា" ថាជាប្រភពនៃច្បាប់អន្តរជាតិ"[1073]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ដោយបានអះអាងដោយប្រយោល តាមរយៈការយោងនេះថា "គោលការណ៍ច្បាប់ទូទៅដែលទទួលស្គាល់ដោយបណ្តារដ្ឋស៊ីវិល័យនានា" គឺជាប្រភពចម្បងឯករាជ្យមួយនៃច្បាប់ជាធរមាននៅ អ.វ.ត.ក ដោយស្មើគ្នាជាមួយនឹងច្បាប់អនុសញ្ញា និងទំនៀមទម្លាប់អន្តរជាតិ។

៦០៧. មាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ឆ្លុះបញ្ចាំងឱ្យឃើញពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពាក់ព័ន្ធនឹងប្រភពនៃច្បាប់ជាធរមាន នៅក្នុងច្បាប់អន្តរជាតិសាធារណៈបុរាណដែល

---

កំណត់ផ្លូវច្បាប់នូវរបៀបប្រព្រឹត្តទៅនៃវិធីសាស្ត្រទាំងអស់នោះ ដោយពុំបានបង្ហាញឱ្យបានច្បាស់ពីមូលដ្ឋាននៃសំអាងនៃគោលការណ៍ទូទៅនៃច្បាប់ ដែលត្រូវបានលើកឡើង, យោបល់ផ្ទាល់ខ្លួនលើកឡើងរួមគ្នារបស់លោកស្រីចៅក្រម McDonald និងលោកចៅក្រម Vohrah កថាខណ្ឌ ៥។ ចៅក្រមទាំងពីរយោងតែទៅលើរឿងក្តីនៃការផ្លាស់ប្តូរប្រជាជនក្រិក និងប្រជាជនទួរគី (តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍) និងរឿងក្តី *Assider ទល់នឹងអាជ្ញាធរជាន់ខ្ពស់* (CJCE) ដែលមានចែងអំពីលក្ខណៈវិនិច្ឆ័យរឹតត្បិតមួយចំនួនចំពោះការយោងទៅច្បាប់ជាតិ ដើម្បីកំណត់អំពីពាក្យពេចន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ, សាលដីកា *Erdemović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧, យោបល់ផ្ទាល់ខ្លួន និងផ្ទុយរបស់ចៅក្រម Stephen កថាខណ្ឌ ២៥។ យោបល់ផ្ទាល់ខ្លួន និងផ្ទុយនេះ លើកឡើងពីមាត្រា ៣៨-១-គ នៃលក្ខន្តិកៈទីក្រុងរ៉ូម ថាជាមូលដ្ឋាន ដោយពុំបានពន្យល់ពីមូលហេតុដែលមាត្រានេះអាចអនុវត្តបានចំពោះវិវាទនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។

[1073] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៨ កំណត់សម្គាល់ជើងទំព័រលេខ ១៩៩៧។

គ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ។ យោងតាមមាត្រានេះ ម្យ៉ាង មានប្រភពចម្បងនានាដែលមានបញ្ចូល "អនុសញ្ញាអន្តរជាតិនានា ដែលមានលក្ខណៈទូទៅ ឬលក្ខណៈពិសេស ស្តីពីវិធានមួយចំនួនដែលត្រូវបានទទួលស្គាល់យ៉ាងច្បាស់ដោយបណ្តារដ្ឋវិវាទ" "ទម្លាប់អន្តរជាតិថាដូចជាភ័ស្តុតាងនៃការអនុវត្តជាទូទៅដែលត្រូវបានទទួលយកថាដូចជាច្បាប់" និង "គោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយបណ្តាអារ្យប្រទេស" និងម្ខាងទៀត មានប្រភពបន្ទាប់បន្សំផ្សេងៗដែលមានផ្ទុក "សេចក្តីសម្រេចតុលាការ និងលទ្ធិរបស់អ្នកបោះពុម្ពផ្សាយឆ្នើមជាងគេមកពីបណ្តាប្រជាជាតិផ្សេងៗ"[1074]។

៦០៨. នៅក្នុងនីតិអន្តរជាតិសាធារណៈ ប្រភពចម្បងទាំងបី ត្រូវអនុវត្តដោយមានអានុភាពដូចគ្នា ដោយគ្មានឋានានុក្រមផ្លូវការរវាងប្រភពឯករាជ្យទាំងបីនៃច្បាប់ជាធរមាននេះទេ។ ការអនុញ្ញាតឱ្យយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយអារ្យប្រទេស ដែលមានបញ្ជាក់នៅមាត្រា ៣៨(១) មានមុខងារច្បាស់លាស់ណាស់នៅក្នុងអាណត្តិរបស់តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ និងតុលាការយុត្តិធម៌អន្តរជាតិ ក្នុងការបញ្ចៀសបាននូវស្ថានភាពមិនច្បាស់លាស់[1075]។ ស្ថានភាពមិនច្បាស់លាស់កើតឡើង នៅពេលតុលាការអន្តរជាតិត្រូវបដិសេធមិនសម្រេចសេចក្តី ដោយសារគ្មានវិធានពាក់ព័ន្ធជាធរមាន[1076]។

---

[1074] មាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។

[1075] Vladimir-Djuro Degan "ពាក់ព័ន្ធនឹងប្រភពនៃនីតិព្រហ្មទណ្ឌអន្តរជាតិ" *Chinese Journal of International Law* 4 លេខ ១ ឆ្នាំ២០០៥ ទំព័រ ៥១៖ "មានភាពខុសគ្នាសំខាន់មួយទៀតត្រង់ចំណុចនេះ។ នៅពេលដែលរដ្ឋពីរ ឬច្រើន ឯកភាពគ្នាលើយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬលើមជ្ឈត្តការអន្តរជាតិ រដ្ឋទាំងនោះរំពឹងថា ក្នុងដំណើរការនីតិវិធី ពួកគេនឹងទទួលបានសាលក្រមស្ថាពរក្នុងរឿងក្តីរបស់ខ្លួន។ ក្នុងន័យនេះ ដើម្បីចៀសវាងភាពមិនច្បាស់លាស់ ចៅក្រមត្រូវយោងទៅលើគ្រប់ប្រភពច្បាប់ទាំងអស់ដែលមានចែងនៅក្នុងមាត្រា ៣៨(១)។ ចៅក្រមត្រូវរកឱ្យឃើញនូវវិធានច្បាប់ដែលអាចអនុវត្តបានចំពោះគ្រប់ទំនាស់ទាំងអស់ដែលបណ្តារដ្ឋនានាអាចយោងទៅបាន"។

[1076] សូមមើល ពាក់ព័ន្ធនឹងមុខងារនៃគោលការណ៍ទូទៅនៃច្បាប់៖ Jean Combacau និង Serge Sur, *ច្បាប់អន្តរជាតិសាធារណៈ:* ឆ្នាំ ២០១០ (បោះពុម្ពលើកទី ៩) ទំព័រ ១០៨៖ "ច្រើនជាងសន្ធិសញ្ញា ឬទំនៀមទម្លាប់ គោលការណ៍ទូទៅនៃច្បាប់ គឺអាស្រ័យទៅតាមសកម្មភាពរបស់តុលាការ។ កម្មវត្ថុរបស់វាគឺត្រូវផ្តល់ដល់ចៅក្រមនូវមធ្យោបាយស្វែងរកដំណោះស្រាយផ្លូវច្បាប់ចំពោះគ្រប់វិវាទទាំងអស់ដែលបានដាក់ជូនខ្លួនពិនិត្យ ក្នុងករណីដែលច្បាប់ទំនៀមទម្លាប់ ឬច្បាប់អនុសញ្ញាពុំមានចែង"។

៦០៩. ដោយសារពុំមានមាត្រាកំណត់ឱ្យបានច្បាស់លាស់អំពីច្បាប់ជាធរមាននៅ អ.វ.ត.ក គេអាចលើកឡើងបានថា ប្រភពមូលដ្ឋានបុរាណនានានៃច្បាប់អន្តរជាតិ ត្រូវយកមកអនុវត្ត។ យ៉ាងណាមិញ លក្ខណៈពិសេសនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិជំទាស់ទៅនឹងការអនុវត្ត ដោយឥតពិចារណា និងស្វ័យប្រវត្តិ នូវមាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ចំពោះវិវាទពិសេសនៅ អ.វ.ត.ក[1077]។

៦១០. ដូច្នេះ ការបញ្ចៀសស្ថានភាពមិនច្បាស់លាស់ ដែលជាហេតុផលនៃការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ នៅក្នុងច្បាប់អន្តរជាតិបុរាណ មិនអាចអនុវត្តបានចំពោះវិវាទក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិបានទេ។ លក្ខណៈព្រហ្មទណ្ឌនៃច្បាប់នេះ កម្រិតភាពអាចអនុវត្តបាននៃមាត្រា ៣៨(១)(ក) ពាក់ព័ន្ធនឹងប្រភពច្បាប់នេះ។

៦១១. វាជាការសំខាន់ដែលត្រូវត្រឡប់មកពិនិត្យមើលបុព្វហេតុនៃគោលការណ៍ទូទៅ នៃនីតិព្រហ្មទណ្ឌ។ គោលការណ៍ទាំងនោះមានគោលបំណងតាំងខ្លួន ធានាទប់ទល់នឹងអំណាចផ្តាច់ការរបស់ចៅក្រម[1078]។ ការអនុវត្តគោលការណ៍ទាំងនេះ ក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាម ធ្វើឱ្យលេចចេញមុខងារមួយនេះ[1079] និងមិនគាំទ្រការយោងទៅប្រភពនេះ ដើម្បីកំណត់ច្បាប់សារធាតុទេ។

---

[1077] ពាក់ព័ន្ធនឹងប្រភេទនៃនីតិព្រហ្មទណ្ឌអន្តរជាតិ៖ Olivier de Frouville, *នីតិព្រហ្មទណ្ឌអន្តរជាតិ* ឆ្នាំ២០១២ (បោះពុម្ពលើកទី ១) ទំព័រ ៣៖ "នីតិព្រហ្មទណ្ឌអន្តរជាតិពាក់ព័ន្ធនឹងទិដ្ឋភាពព្រហ្មទណ្ឌនៃច្បាប់អន្តរជាតិសាធារណៈ។ គេអាចនិយាយតាមបែបម្យ៉ាងទៀតថា នីតិព្រហ្មទណ្ឌអន្តរជាតិ គឺអាស្រ័យលើច្បាប់អន្តរជាតិសាធារណៈ ជាមួយនឹងផលវិបាកសំខាន់នេះគឺថាមានអត្តសញ្ញាណនៃប្រភពផ្លូវការរវាងច្បាប់អន្តរជាតិសាធារណៈ និងនីតិព្រហ្មទណ្ឌអន្តរជាតិ។ [...] ប៉ុន្តែ បើនិយាយឱ្យជាក់ស្តែងទៅ នីតិព្រហ្មទណ្ឌអន្តរជាតិ ក៏ជាច្បាប់មួយដែលមានលក្ខណៈព្រហ្មទណ្ឌផងដែរ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1078] សូមមើល ឧទាហរណ៍៖ Vladimir-Djuro Degan "ពាក់ព័ន្ធនឹងប្រភពនៃនីតិព្រហ្មទណ្ឌអន្តរជាតិ" *Chinese Journal of International Law* 4 លេខ ១ ឆ្នាំ២០០៥ ទំព័រ ៥៤៖ "បើនិយាយពីប្រវត្តិវិញ គោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌ ត្រូវបានលេចឡើងជាលើកដំបូងនៅក្នុងច្បាប់ជាតិរបស់រដ្ឋមួយចំនួន ក្នុងតួនាទីធានាទប់ទល់នឹងអំណាចផ្តាច់ការរបស់ចៅក្រមដែលជាអង្គការរដ្ឋ។ ចាប់តាំងពីដំបូងមក គោលការណ៍នេះបានក្លាយជាផ្នែកមួយនៃសិទ្ធិមនុស្ស" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1079] សូមមើល ឧទាហរណ៍៖ *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ១២២, ១២៦, ១៥៥។ តុលាការយោធា Nuremberg បានទទួលស្គាល់គោលការណ៍គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង ថាពិតជាដូច្នេះមែន គោលការណ៍ដែលមិនតម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈ

៦១២. បន្ថែមពីនេះទៀត គោលការណ៍ទូទៅនៃច្បាប់ គ្រាន់តែជាប្រភពបន្ទាប់បន្សំ ដែលមិនអាចជំនួសវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ សម្រាប់កំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មបានឡើយ (១.៣.២) ហើយការអនុវត្តរបស់វា ត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងបំផុតដោយគោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌ ក្រោមគោលការណ៍នីត្យានុកូលភាព និងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (១.៣.៣)។

## ១.៣.២. ការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ដោយពុំបានគិតដល់ឋានានុក្រមនៃប្រភពច្បាប់

៦១៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអនុវត្តគោលការណ៍ទូទៅនៃច្បាប់ថាដូចជាប្រភពចម្បង និងឯករាជ្យ សម្រាប់កំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅឆ្នាំ១៩៧៥ ដែលផ្ទុយពីទម្លាប់អនុវត្តជាអន្តរជាតិ ដែលប្រឆាំងនឹងការធ្វើបែបនេះយ៉ាងតឹងរ៉ឹងបំផុត។ យុត្តិសាស្ត្ររបស់ អ.វ.ត.ក ពុំដែលបានដឹកនាំធ្វើការវិភាគណាមួយពាក់ព័ន្ធនឹងភាពស្របច្បាប់នៃការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់នោះទេ ហើយបានតែសំអាងទាំងស្រុងទៅលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីប៉ុណ្ណោះ[1080]។ អង្គជំនុំជម្រះបានផ្អែកលើយុត្តិសាស្ត្រមួយនេះ ដោយបានទៅឆ្ងាយរហូតមិនអើពើនឹងឋានានុក្រមដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសង្កត់ធ្ងន់ទៅវិញ។ យោងតាមយុត្តិសាស្ត្រដែលអង្គជំនុំជម្រះយកមកធ្វើជាសំអាង គោលការណ៍ទូទៅនៃច្បាប់មិនអាចអនុវត្តបានឡើយក្រោមវត្តមាននៃវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយជាងនេះទៅទៀត មិនអាចយកមកប្រើដើម្បីដកចេញនូវវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដើម្បីជំនួសដោយគោលការណ៍ទូទៅនៃច្បាប់បានទេ។

### *១.៣.២.១. យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី*

---

បុគ្គល បើចារីនៃអំពើដែលរងការចោទប្រកាន់ គ្មានសេរីភាពអត្តនោម័តិ គ្មានអំណាចសម្រេច ឬ "គោលការណ៍ស្តីពីពិរុទ្ធភាពជាលក្ខណៈបុគ្គល ដែលដកចេញនូវទណ្ឌកម្មរួមគ្នា"។

[1080] សូមមើលខាងលើ កថាខណ្ឌ ៦០២-៦០៥។

៦១៤. យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលធ្វើឡើងតាមចក្ខុវិស័យរបស់ចៅក្រម CASSESE បានស្នើឡើងនូវឋានានុក្រមមួយសម្រាប់ប្រភពនៃច្បាប់ជាធរមាន ដែលកំហិតយ៉ាងច្បាស់គោលការណ៍ទូទៅនៃច្បាប់មកត្រឹមតួនាទីមួយបន្ទាប់បន្សំ ហើយគោលការណ៍ទូទៅទាំងនោះអាចត្រូវលើកមកសំអាងតែនៅក្នុងដំណាក់កាលចុងក្រោយប៉ុណ្ណោះ[1081]។

៦១៥. ចរន្តនៃយុត្តិសាស្ត្រក្រោយពេលអង្គហេតុដែលបានវិនិច្ឆ័យ ត្រូវបានថែងដូច្នេះថា៖

> "នៅពេលដែលលក្ខន្តិកៈមិនអាចដោះស្រាយបញ្ហាជាក់លាក់មួយបាន និងពេលដែលរបាយការណ៍របស់អគ្គលេខាធិការមិនមានប្រយោជន៍ដល់ការបកស្រាយបញ្ហានោះ តុលាការអន្តរជាតិមានកាតព្វកិច្ចយោងទៅ ១) វិធាននានានៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ ២) គោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌអន្តរជាតិ ឬបើគ្មានទេ ៣) គោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌដែលដូចគ្នាទៅនឹងប្រព័ន្ធច្បាប់ធំៗដែលមាន ឬបើគ្មានទេ ៤) គោលការណ៍ទូទៅនៃច្បាប់ស្របតាមលក្ខខណ្ឌតម្រូវជាសារវ័ន្តនៃយុត្តិធម៌អន្តរជាតិ។ វាមានហេតុផលដែលត្រូវគិតថា អ្នកតាក់តែងលក្ខន្តិកៈមានចេតនាសំអាងចំណុចចុងក្រោយនេះទៅលើច្បាប់អន្តរជាតិ ហើយដែលជាលទ្ធផល គេគួរបំពេញនូវរាល់ភាពខ្វះចន្លោះជាយថាហេតុ ដោយត្រូវយោងទៅកម្រងនៃវិធានច្បាប់ទាំងនេះ"[1082]។

៦១៦. យុត្តិសាស្ត្រនេះបានបង្ហាញឱ្យឃើញច្បាស់ថា ចរន្តនេះមិនបានផ្តល់លទ្ធភាពដល់ចៅក្រមឱ្យសំអាងទៅលើគោលការណ៍ទូទៅនៃច្បាប់ តាមចិត្តចង់ក្រៅពីវិធានកម្រិតមួយចំនួន នោះទេ។ គឺទាល់តែក្នុងករណី

---

[1081] សៀវភៅនិពន្ធដោយ *Antonio Cassese និងអ្នកឯទៀត* នីតិព្រហ្មទណ្ឌអន្តរជាតិ៖ *ករណី និងសេចក្តីអធិប្បាយ* ឆ្នាំ២០១១ ទំព័រ ៣៤-៣៥។

[1082] សាលក្រម *Kupreškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៩១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ គួរកត់សម្គាល់ថា ប្រធានអង្គជំនុំជម្រះ គឺចៅក្រម CASSESE។

ដែលពុំមានវិធានច្បាស់លាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទើបគេអាចស្វែងរកការបំភ្លឺនៅក្នុងគោលការណ៍ទូទៅនៃច្បាប់[1083]។

៦១៧. យ៉ាងណាមិញ ក្នុងករណីជាក់ស្តែងនេះ គឺពិតជាមាននិយមន័យច្បាស់លាស់ និងត្រូវបានគេដឹង នៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥។ យោងតាមយុត្តិសាស្ត្រនេះ អង្គជំនុំជម្រះមិនអាចសំអាងទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីគាំទ្រថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត មានរាប់បញ្ចូលចេតនាប្រយោល ក្រោយពីបានអះអាងថាមានវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

### *១.៣.២.២. លក្ខន្តិកៈទីក្រុងរ៉ូម*

៦១៨. មាត្រា ២១(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ជាមាត្រាតែមួយគត់ដែលកំណត់អំពីប្រភពទាំងឡាយនៃច្បាប់ជាធរមាននៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ។ វិសាលភាពអនុវត្តរបស់វាកម្រិតត្រឹមទំនាស់ដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តែស្របគ្នាជាមួយការអនុវត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា ដោយបានបដិសេធចោលយ៉ាងច្បាស់នូវលក្ខណៈចម្បង និងឯករាជ្យរបស់គោលការណ៍

---

[1083] សាលក្រម *Furundžija* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌ ១៧៧-១៧៨។ គឺ "ទាល់តែពេលដែលវិធាននានានៃនីតិព្រហ្មទណ្ឌអន្តរជាតិ ពុំមានកំណត់អំពីសញ្ញាណមួយនៃនីតិព្រហ្មទណ្ឌ ទើបវាជាការត្រឹមត្រូវដែលត្រូវងាកទៅរកច្បាប់ក្នុងស្រុក" ហើយ "ជាមួយនឹងរាល់ការប្រុងប្រយ័ត្នដែលចាំបាច់" គេអាច "ស្វែងរកគោលការណ៍នីតិព្រហ្មទណ្ឌដែលដូចគ្នាទៅនឹងប្រព័ន្ធច្បាប់ធំៗ", សាលក្រម *Kunarac និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤៣៩។ "ការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ដែលដូចគ្នាទៅនឹងប្រព័ន្ធច្បាប់ធំៗរបស់ពិភពលោក នៅពេលដែលអវត្តមានវិធាននៃច្បាប់អន្តរជាតិអនុសញ្ញា ឬទំនៀមទម្លាប់ ពាក់ព័ន្ធនឹងបញ្ហាចោទ គឺអនុញ្ញាតឱ្យធ្វើការបកស្រាយវិធានអន្តរជាតិនានា ដើម្បីកំណត់បានអំពីកាលៈទេសៈដែលអំពើនៃការស៊កបញ្ចូលប្រដាប់ភេទ ដែលត្រូវបានកំណត់ខាងលើ បំពេញបានជាការរំលោភសេពសន្ថវៈ", សាលដីកា *Erdemović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧, យោបល់ផ្ទាល់ខ្លួនលើកឡើងរួមគ្នារបស់លោកស្រីចៅក្រម McDonald និងលោកចៅក្រម Vohrah កថាខណ្ឌ ៥។ ចៅក្រម MAC DONALD និងចៅក្រម VORAH បានអះអាងរួមគ្នាថា "ក្នុងករណីដែលប្រភពនៃច្បាប់អន្តរជាតិ មិនគ្រប់គ្រាន់ ឬពុំមានសោះតែម្តង គេអាចទទួលស្គាល់ច្បាប់ជាតិឱ្យជួយបកស្រាយពាក្យពេចន៍ និងទស្សនៈទាននានា ដែលត្រូវបានប្រើប្រាស់នៅក្នុងលក្ខន្តិកៈ និងវិធាន"។

ទូទៅនៃច្បាប់។ មាត្រានេះ ដែលមានចែងយ៉ាងច្បាស់ជាលើកដំបូងអំពីប្រភពនានាដែលអាចអនុវត្តបាននៅចំពោះមុខតុលាការអន្តរជាតិ និងឋានានុក្រមរបស់ប្រភពទាំងនោះ បានដកចេញនូវមាត្រា ៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ដោយបិទផ្លូវតវ៉ា ហើយនៅក្នុងក្របខ័ណ្ឌនេះ គោលការណ៍ទូទៅនៃច្បាប់គឺជាប្រភពបន្ថែម និងត្រូវបានកំណត់ល័ក្ខខ័ណ្ឌយ៉ាងតឹងរ៉ឹងបំផុត៖

"១. តុលាការត្រូវអនុវត្ត៖

ក) ទី ១ ច្បាប់លក្ខន្តិកៈនេះ ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ និងវិធាននីតិវិធី និងភ័ស្តុតាង។

ខ) ទី ២ តាមការសមស្រប សន្ធិសញ្ញា និងគោលការណ៍ និងវិធាននៃច្បាប់អន្តរជាតិជាធរមាន រួមបញ្ចូលទាំងគោលការណ៍នៃច្បាប់អន្តរជាតិស្តីពីជម្លោះប្រដាប់អាវុធ។

គ) <u>បើមិនដូច្នោះទេ គោលការណ៍ទូទៅនៃច្បាប់ ដែលតុលាការទាញចេញពីច្បាប់ជាតិតំណាងឱ្យប្រព័ន្ធច្បាប់ទាំងឡាយលើពិភពលោក រួមទាំង តាមការសមស្រប ច្បាប់ជាតិទាំងឡាយរបស់រដ្ឋដែលតាមធម្មតាមានយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌ ក្នុងករណីគោលការណ៍ទាំងនោះមិនមានវិសមិតភាពជាមួយលក្ខន្តិកៈនេះ ឬជាមួយច្បាប់អន្តរជាតិ ព្រមទាំងវិធាន និងបទដ្ឋានអន្តរជាតិដែលគេទទួលស្គាល់</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៦១៩. ក្នុងករណីជាក់ស្តែងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយោងទៅគោលការណ៍ទូទៅនៃច្បាប់ ដោយមិនបានធ្វើសេចក្តីសន្និដ្ឋានឱ្យឃើញថា ពិតជាគ្មានវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកំណត់អំពីធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាតពិតប្រាកដមែននោះទេ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសំអាងទៅលើគោលការណ៍ទូទៅនៃច្បាប់ ដោយពុំមានមូលដ្ឋានត្រឹមត្រូវ និងស្ថិតក្រៅក្របខ័ណ្ឌគតិយុត្តិ បើទោះជាការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ក្រោមវត្តមាននៃវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានហាមឃាត់ដាច់ខាតដោយការអនុវត្តជាអន្តរជាតិនាពេលក្រោយមកយ៉ាងណាក្តី តែវាត្រូវបានអនុគ្រោះទទួលយកច្រើន បើប្រៀបធៀបនឹងច្បាប់ជាធរមាននៅ អ.វ.ត.ក។

## ១.៣.៣. ការអនុវត្តដោយមិនគោរពគោលការណ៍នីត្យានុកូលភាព និងគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ

៦២០. បើទោះបីជានៅពេលដែលការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ត្រូវបានធ្វើយុត្តិកម្មត្រឹមត្រូវក៏ដោយ ក៏វាត្រូវបានកំហិត និងភ្ជាប់នូវល័ក្ខខ័ណ្ឌនៃការគោរពគោលការណ៍នីត្យានុកូលភាព និងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ កំហិតនេះរឹតតែត្រូវអនុវត្តខ្លាំងថែមទៀត ដើម្បីកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មក្នុងច្បាប់អន្តរជាតិ។

### *១.៣.៣.១. គោលការណ៍ទូទៅនៃច្បាប់ទុកដូចជាប្រភពបន្ទាប់បន្សំ និងគោលការណ៍នីត្យានុកូលភាព*

៦២១. អ.វ.ត.ក ពុំមានមាត្រាដែលរៀបរាប់អំពីប្រភពច្បាប់ជាធរមានទេ។ ផ្ទុយទៅវិញ យុត្តិសាស្ត្រមានភាពច្បាស់លាស់ណាស់ នៅត្រង់ចំណុចថា គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យនិយមន័យជាធរមាននៃការធ្វើមនុស្សឃាត ត្រូវតែឆ្លុះបញ្ចាំងអំពី**ស្ថានភាពច្បាប់ទំនៀមទម្លាប់អន្តរជាតិ** នាឆ្នាំ១៩៧៥[1084]។ លក្ខណៈធម្មជាតិជាក់ស្តែងទូទៅនៃគោលការណ៍**ទូទៅ**នៃច្បាប់ ដែលទទួលស្គាល់ដោយអារ្យប្រទេសជំទាស់នឹងការយោងទៅលើប្រភពទាំងនោះ ក្នុងក្របខ័ណ្ឌរបស់ អ.វ.ត.ក ដើម្បីកំណត់**ឱ្យបានច្បាស់**អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិ។

### *១.៣.៣.២. គោលការណ៍ទូទៅនៃច្បាប់ទុកដូចជាប្រភពបន្ទាប់បន្សំ និងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*

៦២២. អង្គជំនុំជម្រះបានរំឭកដោយត្រឹមត្រូវថា ខ្លួនត្រូវបានចងជាប់កាតព្វកិច្ចដោយគោលការណ៍នៃការបកស្រាយតឹងរ៉ឹងនៃនីតិព្រហ្មទណ្ឌ ហើយក្នុងករណីមានភាពមិនច្បាស់លាស់ និយមន័យត្រូវតែបកស្រាយឱ្យបានជាប្រយោជន៍ដល់ជនជាប់ចោទ[1085]។ គោលការណ៍គ្រឹះនីត្យានុកូលភាព តម្រូវឱ្យបកស្រាយ

---

[1084] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣៤។

[1085] សំអាងហេតុសាលក្រម កថាខណ្ឌ ២១។

ច្បាប់យ៉ាងតឹងរ៉ឹងបំផុត ហើយដូច្នេះ ហាមមិនឱ្យអង្គជំនុំជម្រះយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីពង្រីកនិយមន័យនៃឧក្រិដ្ឋកម្មក្នុងច្បាប់អន្តរជាតិ ប្រឆាំងនឹងសិទ្ធិជនជាប់ចោទបានទេ។ ដោយសន្និដ្ឋានផ្សេងពីនេះ អង្គជំនុំជម្រះបានរំលោភគោលការណ៍នីត្យានុកូលភាព និងបានប្រព្រឹត្តកំហុសអង្គច្បាប់យ៉ាងធ្ងន់ធ្ងរ។

## ១.៤. នត្ថិភាពនៃគោលការណ៍ទូទៅនៃច្បាប់ដែលបន្ទាបធាតុផ្សំអត្តនោម័តិមកត្រឹមចេតនាប្រយោល

៦២៣. ជាបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា "ការពិនិត្យពិច័យទៅលើយុត្តិសាស្ត្រជាតិ និងយុត្តិសាស្ត្រអន្តរជាតិ មុនឆ្នាំ១៩៧៥ និងច្បាប់ទាំងឡាយដែលចែងពីគោលការណ៍ទូទៅនៃច្បាប់ ដែលថា នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើដោយស្ម័គ្រចិត្ត និងដោយដឹងថាអំពើនោះទំនងជានឹងបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្ស អំពើនោះគឺជាការធ្វើមនុស្សឃាត ឬជាឧក្រិដ្ឋកម្មដែលមានស្ថានទម្ងន់ស្រដៀងគ្នានៅក្នុងប្រព័ន្ធច្បាប់ជាតិនីមួយៗ"[1086]។ អង្គជំនុំជម្រះមានកំហុស ដោយប្រកាន់យកនូវវិធីសាស្ត្រច្បោលៗ ផ្អែកលើច្បាប់ជាតិមួយសំណុំដែលមិនឯកភាពគ្នា (១.៤.១)។ អង្គជំនុំជម្រះបានដកចេញនូវច្បាប់ជាតិដែលផ្ទុយពីសេចក្តីសន្និដ្ឋានរបស់ខ្លួន (១.៤.២)។ នៅចុងបញ្ចប់ គោលការណ៍ទូទៅនៃច្បាប់ដែលកំណត់ដោយអង្គជំនុំជម្រះ មិនមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើជាសំអាងសម្រាប់ការចោទប្រកាន់ព្រហ្មទណ្ឌ និងបានបន្ទាបបែបពុំត្រឹមត្រូវនូវកម្រិតនៃចេតនា (១.៤.៣)។

### ១.៤.១. វិធីសាស្ត្រច្បោលៗ និងសំណាកគំរូមិនដូចគ្នា

៦២៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានធ្វើការវិភាគសើៗលើច្បាប់ប្រៀបធៀប ដោយបានចាត់ទុកសញ្ញាណសាំញ៉ាំពិសេសមួយចំនួននៃនីតិព្រហ្មទណ្ឌជាតិ នៅក្រោមបរិបទជាតិ ថាមាន

[1086] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

លក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសញ្ញាណនៃ "ចេតនាប្រយោល" ដែលអង្គជំនុំជម្រះបង្កើតឡើង[1087]។

៦២៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយកតាមការវិភាគរបស់តុលាការកំពូល នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ដែលលើកឡើងថា "ធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាតនៅក្នុងប្រព័ន្ធច្បាប់កុំមិនឡ រួមមាន ប្រទេសអង់គ្លេស ប្រទេសឥណ្ឌា និងប្រទេសអូស្ត្រាលី គឺមានភាពស៊ីចង្វាក់គ្នាជាមួយនឹងសញ្ញាណនៃចេតនាប្រយោល"[1088]។ ក៏ប៉ុន្តែ ក្នុងចំណោមប្រភពទាំងឡាយដែលត្រូវបានលើកមកសំអាង មានប្រភពមួយចំនួនតម្រូវឱ្យមានចេតនាបង្ករបួសរាងកាយ ឬហានិភ័យមួយដែលត្រូវកំណត់ថា "ស្ទើរតែកើតមានពិតប្រាកដ"។ ឧទាហរណ៍ មាត្រា ៣០០ នៃក្រមព្រហ្មទណ្ឌឥណ្ឌា ដែលត្រូវបានយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ បានបង្ហាញអំពីចេតនាដែលកំណត់អំពើមនុស្សឃាតថាជា "ចេតនាបង្កឱ្យមានរបួសរាងកាយ ដែលជាវីបានដឹងថាវាអាចនាំឱ្យជនរងគ្រោះស្លាប់"។ ក្នុងករណីនេះ ចេតនាតិចបំផុតដើម្បីអាចកំណត់បានជាការធ្វើមនុស្សឃាត គឺចេតនាបង្កឱ្យមានរបួសរាងកាយ ដែលអាចនាំទៅដល់សេចក្តីស្លាប់។

៦២៦. ឧទាហរណ៍ បើតាមអង្គជំនុំជម្រះយល់ឃើញថា "មាត្រា ១៨(ក) នៃច្បាប់ ឆ្នាំ១៩០០ ស្តីពីឧក្រិដ្ឋកម្ម (រដ្ឋ New South Wales) ផ្តន្ទាទោសអំពើដែលបានប្រព្រឹត្ត "ដោយមិនអើពើទៅលើអាយុជីវិតមនុស្ស ឬក្នុងចេតនាសម្លាប់ ឬប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរាងកាយរបស់អ្នកដទៃ"[1089]។ គួរកត់សម្គាល់ថា គេនៅឆ្ងាយពីភវនីយភាពសាមញ្ញនៅឡើយ។

៦២៧. ពាក់ព័ន្ធនឹងប្រទេសអង់គ្លេស អង្គជំនុំជម្រះបានយោងទៅរឿងក្តី *R ទល់នឹង Hyam* ពីឆ្នាំ១៩៧៤ "ដែលក្នុងនោះ ព្រឹទ្ធសភាអង់គ្លេសបានសម្រេចថា ទាក់ទិននឹងការធ្វើមនុស្សឃាត វាគ្រប់គ្រាន់ហើយបើត្រឹមតែបានគ្រោងទុកមុនថា លទ្ធផលខុសច្បាប់បានមកពីការសម្រេចបានសមិទ្ធផលដែលមានភវនីយភាព

[1087] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥០។

[1088] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៤៥។

[1089] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៤៥ កំណត់សម្គាល់ជើងទំព័រលេខ២០១០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

កម្រិតខ្ពស់”។ ក្នុងរឿងក្តីនេះ យោងតាមអង្គហេតុជាក់ស្តែង[1090] ព្រឹទ្ធសភាមិនបានឯកភាពគ្នានោះទេ ដែលនាំឱ្យមានមតិជំទាស់ចំនួនពីរ។ ក្នុងមតិជំទាស់មួយនោះ ចៅក្រមដ៏ចំណាន Diplock បានលើកឡើងពីបទដ្ឋានមួយដ៏តឹងរ៉ឹងបំផុត ដែលត្រូវបានអនុវត្តតាមដោយចៅក្រម Kilbrandon[1091]។ ដូច្នេះ នៅឆ្នាំ១៩៧៤ គឺពុំមានការឯកភាពគ្នាជាឯកច្ឆន្ទនោះទេ។

៦២៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់សំអាងហេតុ ដោយមិនបានផ្តល់វិធីសាស្ត្រដើម្បីគាំទ្រការវិភាគរបស់ខ្លួន។ យ៉ាងណាមិញ នីតិព្រហ្មទណ្ឌ គឺជាផ្នែកមួយនៃច្បាប់ប្រៀបធៀបដែលស្មុគស្មាញបំផុត[1092]។ ភាពស្មុគស្មាញនេះបាននាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសដោយបានចាត់ទុកដោយពុំត្រឹមត្រូវថា សញ្ញាណរឹតត្បិតបំផុតនៃចេតនាក្នុងច្បាប់ជាតិ មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងចេតនាប្រយោល។ ចេតនាប្រយោលនេះ ដែលត្រូវបានអង្គជំនុំជម្រះកំណត់និយមន័យថាជា “ករណីដែលបុគ្គលម្នាក់បានបង្ហាញឆន្ទៈក្នុងការប្រព្រឹត្តិ ដោយដឹងថាអំពើសកម្ម ឬអកម្មរបស់ខ្លួនទំនងជាបណ្តាលឱ្យជនរងគ្រោះម្នាក់ ឬច្រើននាក់ស្លាប់ និងយ៉ាងហោចណាស់បុគ្គលនោះទទួលយក ឬជ្រើសរើសយកលទ្ធភាពដែលអាចបណ្តាលឱ្យមានការបាត់បង់ជីវិត”[1093] គឺរឹតតែមិនអាចអនុវត្តបានថែមទៀត ព្រោះថាវាត្រូវបានបដិសេធចោលយ៉ាងច្បាស់ដោយច្បាប់កម្ពុជាកាលពីសម័យនោះ។

1090 នៅក្នុងរឿងក្តីនេះ (ដកស្រង់នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ២០១០ នៃកថាខណ្ឌ ៦៤៥ នៃសំអាងហេតុ) គឺនិយាយអំពីសកម្មភាពរបស់នារីម្នាក់ដែលបានដុតប្រអប់សំបុត្ររបស់គូប្រជែងខ្លួន មុននឹងចាកចេញ ដោយមិនបានប្រាប់អ្នកកាន់កាប់ផ្ទះឱ្យដឹង។ ចេតនារបស់ជនជាប់ចោទ គឺបន្លាចគូដណ្តឹងថ្មីរបស់អតីតសង្សារ ដើម្បីធ្វើឱ្យនាងប្តូរសង្កាត់។ នារីគូប្រជែងទាំងពីរនាក់បានស្លាប់ក្នុងភ្លើង។ ដូច្នេះ នេះជាហានិភ័យមួយដ៏ធំ។

1091 *R ទល់នឹង Hyam* [១៩៧៥] AC 55 ទំព័រ ៧២។

1092 ពាក់ព័ន្ធនឹងចំណុចនេះ សូមមើល Jean Pradel *នីតិព្រហ្មទណ្ឌប្រៀបធៀប* ឆ្នាំ២០១៦ ទំព័រ ១០២៖ “បញ្ហាចិត្តវិជ្ជា គឺតែងតែល្អិតល្អន់ជានិច្ច ហើយបញ្ហាចិត្តវិជ្ជាដែលមានក្នុងនីតិព្រហ្មទណ្ឌ គឺជាការបង្ហាញឱ្យឃើញពីចំណុចនេះស្រាប់។ អ្នកប្រព្រឹត្តអាចមានស្មារតីប្រែប្រួលខ្លាំង ហើយដើម្បីបកស្រាយពីកម្រិតផ្សេងៗគ្នានៃស្មារតីនេះ អ្នកឯកទេសផ្នែកនីតិព្រហ្មទណ្ឌបានប្រើប្រាស់ពាក្យពេចន៍ និងសំនួនវោហារផ្សេងៗ។ អ្វីដែលជាអកុសលនោះគឺថា ពាក្យតែមួយគឺមិនប្រាកដថាចង់និយាយអំពីការពិតដូចគ្នានោះទេ ហើយថាម្យ៉ាងវិញទៀតនោះ គឺពេលខ្លះ ទស្សនៈទានតែមួយដូចគ្នា តែត្រូវតាក់តែងដោយពាក្យខុសគ្នា”។

1093 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥០។

### ១.៤.២. ការដកចេញដោយពុំត្រឹមត្រូវនូវច្បាប់កម្ពុជាដែលតម្រូវឱ្យមានចេតនាផ្ទាល់ក្នុងការសម្លាប់

៦២៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថាមានគោលការណ៍ទូទៅនៃច្បាប់ ដែលផ្ទុយទៅនឹងច្បាប់ជាតិរបស់រដ្ឋដែលអង្គហេតុកើតឡើង ច្បាប់ជាតិរបស់ជនជាប់ចោទ និងរបស់ជនរងគ្រោះពាក់ព័ន្ធ[1094]។ អង្គជំនុំជម្រះបានជ្រើសរើសយកការអនុវត្តគោលការណ៍ទូទៅនៃច្បាប់ ខណៈដែលខ្លួនបានកត់សម្គាល់ថា "ករណីលើកលែងដ៏គួរឱ្យកត់សម្គាល់មួយចំពោះគោលការណ៍នេះ គឺច្បាប់ប្រទេសបារាំង និងច្បាប់ប្រទេសកម្ពុជា ដែលចូលជាធរមាននៅមុនឆ្នាំ១៩៧៥"[1095]។ ប្រាកដណាស់ វិចារណកិច្ចនេះ មិនត្រឹមត្រូវ និងមិនស្របតាមវិធាននានាដែលមានចែងនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ។ ឧទាហរណ៍ មាត្រា ២១-គ នៃលក្ខន្តិកៈទីក្រុងរ៉ូម តម្រូវឱ្យរាប់បញ្ចូល "ច្បាប់ជាតិទាំងឡាយរបស់រដ្ឋ ដែល អនុវត្តជាធម្មតាយុត្តាធិការលើបទល្មើសព្រហ្មទណ្ឌនោះ" ដើម្បីបកស្រាយគោលការណ៍ទូទៅនៃច្បាប់។ អង្គជំនុំជម្រះគួរតែទាញផលវិបាកចេញពីសេចក្តីកត់សម្គាល់របស់ខ្លួនពាក់ព័ន្ធនឹងច្បាប់កម្ពុជា ដែលផ្ទុយទៅនឹងគោលការណ៍ទូទៅនៃច្បាប់ដែលខ្លួនព្យាយាមបកស្រាយ។ ដោយពុំបានធ្វើដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់។

### ១.៤.៣. ការបន្ទាបមិនធ្លាប់មាននូវកម្រិតនៃចេតនា

៦៣០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានបន្ទាបកម្រិតនៃចេតនាឧក្រិដ្ឋ ដោយបំពានលើគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ ពុំធ្លាប់ដែលមានឡើយក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ដែលមានការសម្រេចយកនិយមន័យមួយដែលមានលក្ខណៈទូលាយនៃចេតនាដើម្បីកំណត់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត។ ទោះជាប្រៀបធៀបជាមួយយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយក្តី ក៏និយមន័យនៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ដែលកំណត់ដោយអង្គជំនុំជម្រះ គឺជាការបន្ទាបនូវកម្រិតនៃចេតនាឧក្រិដ្ឋដែលពុំធ្លាប់មាន។

---

[1094] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥០។

[1095] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៤៨។

៦៣១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រៀបធៀបដោយពុំត្រឹមត្រូវនូវចេតនា "ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរាងកាយរបស់ជនរងគ្រោះ ហើយដែលតាមរយៈការប៉ះពាល់នេះ គាត់គ្រាន់តែអាចគ្រោងទុកដោយសមហេតុសមផលថា វាអាចបង្កឱ្យមានការស្លាប់"[1096] ជាមួយនឹងចេតនាក្នុងការ "ប្រព្រឹត្តិអំពើដោយស្ម័គ្រចិត្ត និងដោយដឹងថាអំពើនោះ ទំនងជានឹងបណ្តាលឱ្យមានការបាត់បង់ជីវិតមនុស្ស" ក្រោមការកំណត់ថាជាចេតនាប្រយោល។ កម្រិតនៃចេតនាឧក្រិដ្ឋ កាន់តែទាបថែមទៀតនៅក្នុងនិយមន័យនៃចេតនាប្រយោលដែលជ្រើសយកដោយអង្គជំនុំជម្រះ ពីព្រោះថានិយមន័យរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ តម្រូវឱ្យមានលើសពីនេះចំពោះចេតនាផ្ទាល់ក្នុងការធ្វើឱ្យប៉ះពាល់ដល់បូរណភាពរាងកាយរបស់ជនរងគ្រោះ។ ដោយបានបំបាត់ល័ក្ខខ័ណ្ឌតម្រូវឱ្យអំពើទាំងឡាយត្រូវកំហិតមកត្រឹមការប្រព្រឹត្តិដោយចេតនា ដែលបង្កឱ្យមានការប៉ះពាល់ដល់បូរណភាពរាងកាយរបស់ជនរងគ្រោះ ដើម្បីពង្រីកទៅដល់អំពើគ្រប់ប្រភេទនោះ អង្គជំនុំជម្រះបានថែងអំពីនិយមន័យទូលាយមួយដែលស្ថិតនៅក្រៅក្របខ័ណ្ឌច្បាប់ទាំងស្រុង។ ផ្ទុយពីនិយមន័យសព្វថ្ងៃរបស់តុលាការព្រហ្មទណ្ឌ ដែលចាត់ទុកបទដ្ឋានជាធរមានសម្រាប់វាយតម្លៃលក្ខណៈគ្រោងទុកមុនបានថា "សមហេតុផល" អង្គជំនុំជម្រះពុំបានថែងអំពីលក្ខណៈវិនិច្ឆ័យគតិយុត្តិណាមួយ ក្នុងការវាយតម្លៃលក្ខណៈគ្រោងទុកមុនបាន (សត្យានុម័តិ និងអត្តនោម័តិ ឬទាំងពីរ) ឬកម្រិតនៃភវនីយភាពដែលជាល័ក្ខខ័ណ្ឌតម្រូវ សម្រាប់ដាក់ឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនោះទេ។

៦៣២. សរុបសេចក្តីមក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ដោយបន្ទាបកម្រិតនៃចេតនាឧក្រិដ្ឋដែលគ្មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាំងមុន និងក្រោយឆ្នាំ១៩៧៥។

---

[1096] សាលដីកា *Kvočka* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ២៦១, សាលដីកា *Dragomir Milošević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ១០៨, សាលក្រម Akayesu (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥៨៩, សាលក្រម *Blaškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ២១៧។

## ២. ភាពមិនអាចដឹងបាន និងភាពមិនអាចគ្រោងទុកមុនបាន នាឆ្នាំ១៩៧៥ នូវកម្រិតនៃចេតនាដែលបានកំណត់

៦៣៣. ដោយហេតុថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត គឺជាការសម្របសម្រួលគតិយុត្តិដែលមានលក្ខណៈស្មុគស្មាញពិសេស បន្ថែមពីលើភាពមិនត្រឹមត្រូវថែមទៀតនោះ នៅចុងបញ្ចប់ទៅ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា "វាមិនមានភាពស្រពេចស្រពិលទេដែលថា នៅឆ្នាំ១៩៧៥ គេអាចប្រមើលឃើញថាការសម្លាប់មនុស្សដោយចេតនាប្រយោល គឺជាបទឧក្រិដ្ឋ ហើយធ្វើឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល"[1097]។ ជាបឋម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានធ្វើការវិភាគទូទៅមួយតាមលក្ខណៈវិនិច្ឆ័យអរូបី បន្ទាប់មកទៀត អង្គជំនុំជំនុំជម្រះភ្លេចថា ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតតម្រូវឱ្យមានចេតនាផ្ទាល់ជាក់លាក់ក្នុងការសម្លាប់ នៅក្នុងច្បាប់កម្ពុជា និងជាចុងក្រោយ អង្គជំនុំជម្រះបានផ្អែកលើការបន្ថយជាលំដាប់នូវកម្រិតនៃចេតនាដោយពុំត្រឹមត្រូវ ដើម្បីធ្វើយុត្តិកម្មការដាក់បញ្ចូលចេតនាប្រយោលបែបប្រតិសកម្ម។

៦៣៤. ជាបឋម ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុង ការកំណត់និយមន័យឧក្រិដ្ឋកម្មមនុស្សឃាត ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នាឆ្នាំ១៩៧៥ និងក្នុងការកំណត់តួនាទីផ្សេងៗរបស់ម្ចាស់បណ្ដឹងសាទុក្ខ ដើម្បីសន្និដ្ឋានថា "ជាលក្ខណៈទូទៅ" គាត់អាចដឹងមុនបានថា ការប្រព្រឹត្តិស្របតាមនិយមន័យនៃការធ្វើមនុស្សឃាតនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចត្រូវផ្តន្ទាទោស ហើយគាត់អាចដឹងបានអំពីវិធាននានាដែលជាមូលដ្ឋាននៃការចោទប្រកាន់នេះ[1098]។

៦៣៥. បន្ទាប់មក អង្គជំនុំជម្រះពុំបានទាញផលវិបាកចេញពីការកត់សម្គាល់របស់ខ្លួនថា ការធ្វើមនុស្សឃាតក្នុងច្បាប់កម្ពុជា នៅឆ្នាំ១៩៧៥ តម្រូវឱ្យបង្ហាញភស្តុតាងអំពីមានចេតនាផ្ទាល់ជាក់លាក់ក្នុងការធ្វើឱ្យស្លាប់។ ដូច្នេះ អង្គជំនុំជម្រះបានរំលោភលើគោលការណ៍នីត្យានុកូលភាព។ អង្គជំនុំជម្រះគួរធ្វើដូចអង្គ

[1097] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥១។

[1098] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥១។ សូមមើលខាងលើ កថាខណ្ឌ ៥៦៦-៥៧៣។

បុរេជំនុំជម្រះដែរ ដោយត្រូវដកចេញនូវការយោងទៅលើគោលការណ៍ទូទៅនៃច្បាប់ ដើម្បីកំណត់អំពីធាតុផ្សំនៃបទល្មើស។ ក្នុងករណីណាក៏ដោយ ដោយសារថាការបកស្រាយអំពីអំពើមនុស្សឃាត ពីសំណាក់អង្គជំនុំជម្រះគ្មានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា និយមន័យនៃឧក្រិដ្ឋកម្មនេះអាចគ្រោងទុកមុនបាន និងអាចដឹងឮបានដោយម្ចាស់បណ្តឹងសាទុក្ខ[1099]។

៦៣៦. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា "ចេតនា (*dolus praeter intentionem*) ដែលកំណត់លក្ខណៈធាតុផ្សំអត្តនោម័តិនៃបទល្មើស តម្រូវឱ្យចេតនាមានកម្រិតទាបជាងចេតនាប្រយោល"[1100]។ វាពុំមែនជាការពិតទេដែលចេតនាប្រយោល ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះ មានកម្រិតខ្ពស់ជាងចេតនាដែលត្រូវបានបញ្ញត្តនៅក្នុងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦។ យោងតាមអង្គជំនុំជម្រះ មាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌនេះដែលចែងពីការចោទប្រកាន់មិនមែនពីបទមនុស្សឃាត តែចំពោះ "អំពើទាំងឡាយដែលសម្រេចបាន ឬបានធ្វើ ដោយស្ម័គ្រចិត្ត ក្នុងគោលបំណងធ្វើឧបឃាតដល់មនុស្ស តែគ្មានចេតនាធ្វើឱ្យគេស្លាប់" តម្រូវឱ្យមានចេតនាប្រព្រឹត្តអំពើឱ្យបានសម្រេច "ក្នុងគោលបំណងធ្វើឧបឃាតដល់មនុស្ស"។ វាចាំបាច់ដែលត្រូវបង្ហាញភ័ស្តុតាងអំពី កំហុសដោយចេតនា តែមិនមែនបង្ហាញត្រឹមតែក្នុងកំហុសក្នុងការប្រថុយប្រថាននោះទេ។ ចេតនានេះមិនទាបជាងចេតនាប្រយោល ដូចអង្គជំនុំជម្រះបានកំណត់នោះទេ។ វិចារណកិច្ចរបស់អង្គជំនុំជម្រះដែលខ្វះភាពហ្មត់ចត់ មានកំហុសជាថ្មីម្តងទៀត។

## ផ្នែកទី ២. កំហុស និងផលវិបាកតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗ

### ១. អំពីការដ្ឋានការងារត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង

៦៣៧. ការកំណត់ប្រភេទបទល្មើសឡើងវិញជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតចំពោះការស្លាប់មនុស្សបណ្តាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅ ត្រូវទុកជាមោឃៈ ព្រោះធាតុផ្សំ

[1099] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ **D97/15/9** កថាខណ្ឌ ៨៧។

[1100] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥១។

អត្តនោម័តិនៃការធ្វើមនុស្សឃាតពុំត្រូវបានបំពេញ ដោយសារគ្មានការបង្ហាញឱ្យឃើញថា ទាំងចារីផ្ទាល់ ទាំង ខៀវ សំផន មានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្សនៅត្រាំកក់[1101] ទំនប់ត្រពាំងថ្ម[1102] ទំនប់១មករា[1103] និងព្រលានយន្តហោះកំពង់ឆ្នាំង[1104]។ ដូច្នេះ អង្គជំនុំជម្រះពុំបានកំណត់ឱ្យបានត្រឹមត្រូវអំពីធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត។ សេចក្តីសន្និដ្ឋានទាំងអស់នេះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងនោះ នៅត្រាំកក់[1105] ទំនប់ត្រពាំងថ្ម[1106] ទំនប់១មករា[1107] និងព្រលានយន្តហោះកំពង់ឆ្នាំង[1108]។

## ២. នៅក្នុងមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល

៦៣៨. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមរូបភាពមនុស្សឃាត តាមរយៈការស្លាប់បណ្តាលមកពីការឃុំឃាំងនៅមន្ទីរ ស-២១ ពុំត្រូវបានបង្ហាញ ព្រោះថាធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ពុំត្រូវបានបំពេញ ដោយសារគ្មានការបង្ហាញឱ្យឃើញថា ទាំងចារីផ្ទាល់ ទាំង ខៀវ សំផន មានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្ស[1109]។ ដូច្នេះ អង្គជំនុំជម្រះពុំបានកំណត់ឱ្យបានត្រឹមត្រូវអំពីធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត។ សេចក្តីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ[1110]។

1101 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥។

1102 សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៧-១៣៨៩។

1103 សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧០-១៦៧៣។

1104 សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០១-១៨០៦។

1105 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

1106 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

1107 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

1108 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

1109 សំអាងហេតុសាលក្រម កថាខណ្ឌ ២៥៦៥។

1110 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

៦៣៩. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ពាក់ព័ន្ធនឹងការស្លាប់មនុស្សបណ្ដាលមកពីការប្រព្រឹត្តិនៅមន្ទីរក្រាំងតាចាន់ ពុំត្រូវបានបង្ហាញ ព្រោះថាធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ពុំត្រូវបានបំពេញ ដោយសារគ្មានការបង្ហាញថា ទាំងចារីផ្ទាល់ ទាំង ខៀវ សំផន មានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្ស[1111]។ ដូច្នេះ អង្គជំនុំជម្រះពុំបានកំណត់ឱ្យបានត្រឹមត្រូវអំពីធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត។ សេចក្ដីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ[1112]។

៦៤០. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ពាក់ព័ន្ធនឹងការស្លាប់របស់ឈ្មោះទូចបណ្ដាលមកពីល័ក្ខខ័ណ្ឌនៃការឃុំខ្លួននៅមន្ទីរសន្តិសុខភ្នំក្រោល ពុំត្រូវបានបង្ហាញ ព្រោះថាធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ពុំត្រូវបានបំពេញ ដោយសារពុំធ្លាប់មានការបង្ហាញឱ្យឃើញណាមួយថា ទាំងចារីផ្ទាល់ក្ដី ទាំង ខៀវ សំផន ក្ដី មានចេតនាផ្ទាល់ក្នុងការសម្លាប់មនុស្ស[1113]។ ដូច្នេះ អង្គជំនុំជម្រះពុំបានកំណត់ឱ្យបានត្រឹមត្រូវអំពីធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត។ សេចក្ដីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ[1114]។

## ជំពូកទី ៣. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ

៦៤១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ តាមរយៈការបកស្រាយពុំត្រឹមត្រូវលើធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ (ផ្នែកទី ១) ដែលនាំឱ្យអង្គជំនុំជម្រះធ្វើសេចក្ដីសន្និដ្ឋានពុំត្រឹមត្រូវ ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិក និងជនជាតិចាម (ផ្នែកទី ២)។

### ផ្នែកទី ១. អង្គច្បាប់

[1111] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨១៥, ២៨១៧។

[1112] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

[1113] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៦-៣១១៧។

[1114] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១១, ៤៣១៥-៤៣១៨, ៤៣២៨, ៤៣៦៣, ៤៣៦៦, ៤៣៨៣, ៤៤០០, ៤៤០២។

៦៤២. អង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញតម្រូវបង្ហាញភ័ស្តុតាងថា "ការប្រព្រឹត្តិអំពើដោយសកម្ម ឬដោយអកម្ម ដោយមានចេតនារើសអើង ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"[1115]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លេចនូវល័ក្ខខ័ណ្ឌថា ការដកហូតសិទ្ធ គឺមាន "គោលបំណង [...] ដកបុគ្គលទាំងនោះចេញពីក្នុងសង្គមដែលពួកគេរួមរស់ជាមួយពួកចារី ឬដកចេញពីភាពជាមនុស្សតែម្តង"[1116]។ អង្គជំនុំជម្រះបានយោងយ៉ាងច្បាស់ទៅលើសាលដីកាសំណុំរឿង ឌុច ដែលបានដកចេញនូវធាតុផ្សំមួយនេះនៃការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការវិភាគមិនត្រឹមត្រូវដែលមាននៅក្នុងកំណត់សម្គាល់ជើងទំព័រ (១)។ ផ្ទុយទៅវិញ ការពិនិត្យលើយុត្តិសាស្ត្រដំបូងគេ និងលើការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជាលើយុត្តិសាស្ត្រក្រោយសង្គ្រាម បានបង្ហាញឱ្យឃើញថា នៅឆ្នាំ១៩៧៥ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានតម្រូវឱ្យមានល័ក្ខខ័ណ្ឌមួយនេះ សម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ (២)។

## ១. ការវិភាគសើរៗពុំត្រឹមត្រូវលើសាលដីកាសំណុំរឿង ឌុច ដែលអង្គជំនុំជម្រះអនុវត្តតាម

៦៤៣. ដើម្បីកំណត់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះបានផ្អែកជាចម្បងលើយុត្តិសាស្ត្ររបស់តុលាការកំពូល នៅក្នុងសំណុំរឿង ឌុច ត្រង់កថាខណ្ឌ ២៣៦-២៤០[1117]។ តុលាការកំពូលបានបដិសេធចោលនៅក្នុងកំណត់សម្គាល់ជើងទំព័រ នូវចរន្តយុត្តិសាស្ត្រដែលតម្រូវថា ល័ក្ខខ័ណ្ឌចាំបាច់សម្រាប់កំណត់ប្រភេទបទល្មើសនៃការធ្វើទុក្ខបុកម្នេញ គឺត្រូវបង្ហាញឱ្យឃើញថា គោលបំណងគឺដើម្បីដកបុគ្គលទាំងឡាយដែលត្រូវបានកំណត់ជាគោលដៅនៃ "ការរើសអើង" ចេញពីក្នុងសង្គមជាក់ស្តែង[1118]។ ប៉ុន្តែ អង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវពីដំបូងថា អង្គជំនុំជម្រះសាលាដំបូងចំនួនពីររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង

---

[1115] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៣។

[1116] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៣។ សាលក្រម *Kupreškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦៣៤។

[1117] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៣ កំណត់សម្គាល់ជើងទំព័រលេខ២១៨៧ យោងទៅសាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៦-២៤០។

[1118] សាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨ កំណត់សម្គាល់ជើងទំព័រលេខ៥១៤។

អង្គជំនុំជម្រះសាលាដំបូងចំនួនមួយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា បានសម្រេចថា ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ តម្រូវថា ការដកហូតសិទ្ធិគឺក្នុង "គោលបំណង [...] ដកបុគ្គលទាំងនោះចេញពីក្នុងសង្គមដែលពួកគេរួមរស់ជាមួយពួកថារី ឬដកចេញពីភាពជាមនុស្សតែម្តង"[1119]។

៦៤៤. យ៉ាងណាមិញ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានដកយុត្តិសាស្ត្រនេះចេញ ក្រោមហេតុផលថា (១) អង្គជំនុំជម្រះផ្សេងៗទៀតនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌឧក្រិដ្ឋកម្មសម្រាប់ប្រទេសរ្វ៉ាន់ដា ពុំបានជ្រើសរើសយកលក្ខខណ្ឌនេះ ហើយ (២) ថាតុលាការក្រោយសង្គ្រាមលោកលើកទី ២ ពុំបានតម្រូវឱ្យមានលក្ខខណ្ឌមួយនេះ សម្រាប់ផ្តន្ទាទោសឧក្រិដ្ឋកម្មមួយនេះទេ[1120]។ ហេតុផលទាំងពីរដែលផ្តល់ឱ្យ និងដែលត្រូវយកតាមដោយអង្គជំនុំជម្រះ ដើម្បីបដិសេធចោលនូវគោលបំណងនៃការដកចេញ គឺគ្មានសុពលភាព។

## ២. លក្ខខណ្ឌតម្រូវឱ្យបង្ហាញថាមានគោលបំណងដកចេញដោយសារ "ការរើសអើង" ជាក់ស្តែង

### ២.១. លក្ខខណ្ឌមួយដែលមានការព្រមព្រៀងគ្នាពីដំបូង ត្រូវបំភ្លេចដោយអង្គជំនុំជម្រះ

៦៤៥. នៅក្នុងរឿងក្តី *Kupreškic* អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញយ៉ាងច្បាស់ថា៖

> "ការវិភាគលើឧទាហរណ៍នៃការធ្វើទុក្ខបុកម្នេញមួយចំនួនដែលមានបង្ហាញខាងលើ អាចឱ្យទាញបាននាមកត្តារួមមួយ៖ អំពើទាំងអស់នេះសំដៅបែងចែកបុគ្គលមួយចំនួនឱ្យខុសពីគេ និងព្យាបាទពួកគេ ដោយមូលហេតុរើសអើង <u>ដោយដកហូតពីពួកគេនូវការអនុវត្តសិទ្ធិនយោបាយ</u>

[1119] សាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨ កំណត់សម្គាល់ជើងទំព័រលេខ៥១៤ យោងទៅសាលក្រម *Kupreškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦៣៤, សាលក្រម *Kordic និង Cerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២១៤ និងសាលក្រម Ruggiu (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០០ កថាខណ្ឌ ២២។

[1120] សាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨ កំណត់សម្គាល់ជើងទំព័រលេខ៥១៤។

សង្គម ឬសេដ្ឋកិច្ច ដែលសមាជិកផ្សេងៗទៀតនៅក្នុងសង្គមទទួលបាន។ គេអាចចាត់ទុកបានថា គោលបំណងផ្ទាល់នៃការដកហូតសិទ្ធិនេះ គឺដើម្បីដកបុគ្គលទាំងអស់នោះចេញពីសង្គមដែលពួកគេរួមរស់ជាមួយចារី ឬក៏ដកចេញពីមនុស្សជាតិតែម្តង”[1121]។

៦៤៦. នៅក្នុងរឿងក្តី *Kordic និង Cerkez* អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ពីការព្រមព្រៀងគ្នារបស់ភាគីនានា ពាក់ព័ន្ធនឹងការកំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ៖

> “អយ្យការ និងមេធាវីការពារក្តី ព្រមព្រៀងគ្នាលើល័ក្ខខ័ណ្ឌនៃចេតនាដែលមានចែងនៅក្នុងសាលក្រម *Kupreškic* ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ៖ អំពើរបស់ជនជាប់ចោទត្រូវតែមានគោលដៅ “បែងចែកបុគ្គលមួយចំនួនឱ្យខុសពីគេ និងព្យាបាទពួកគេ ដោយមូលហេតុរើសអើង” ដើម្បី “ដកបុគ្គលទាំងអស់នោះចេញពីសង្គមដែលពួកគេរួមរស់ជាមួយពួកចារី ឬក៏ដកចេញពីមនុស្សជាតិតែម្តង”[1122]។

៦៤៧. នៅក្នុងរឿងក្តី *Kordic និង Cerkez* ដដែល អង្គជំនុំជម្រះសាលាដំបូងបានទទូចលើភាពចាំបាច់នៃការបកស្រាយយ៉ាងតឹងរ៉ឹងអំពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ ព្រោះថា “ការពង្រីកសញ្ញាណនៃធាតុផ្សំអត្តនោម័តិ គឺជាដំណើរការមួយងាយស្រួល តែគ្រោះថ្នាក់”[1123]។ ចៅក្រមទាំងអស់បានសន្និដ្ឋានដោយអះអាងថា “ដើម្បីបំពេញឱ្យបាននូវធាតុផ្សំអត្តនោម័តិតឹងរ៉ឹងបំផុតដែលជាល័ក្ខខ័ណ្ឌតម្រូវសម្រាប់បង្ហាញឱ្យឃើញឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ជនជាប់ចោទត្រូវតែទទួលយកគោលការណ៍ទាំងឡាយដែលបានកំណត់ដោយគោលនយោបាយរើសអើងកំពុងអនុវត្ត៖ “ដកបុគ្គលទាំងអស់នោះចេញពីសង្គមដែលពួកគេរួមរស់ជាមួយពួកចារី ឬក៏ដកចេញពីមនុស្ស

---

[1121] សាលក្រម *Kupreškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦៣៤។

[1122] សាលក្រម *Kordic និង Cerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២១៤។

[1123] សាលក្រម *Kordic និង Cerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២១៩។

ជាតិតែម្តង""[1124]។ ដូចគ្នានេះដែរ ក្នុងរឿងក្តី *Ruggiu* អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តលក្ខណៈវិនិច្ឆ័យគតិយុត្តិនេះ[1125]។

៦៤៨. ភស្តុតាងនៃលក្ខណៈ "ព្រមព្រៀងគ្នា" នៃចំណុចគតិយុត្តិមួយនេះ ដូចដែលបានកំណត់ដោយសាលក្រមក្នុងរឿងក្តី *Kordic និង Cerkez* គឺថាការផ្តល់សំអាងហេតុបែបនេះ ពុំបានរងបណ្តឹងឧទ្ធរណ៍ណាមួយដែលមានសុពលភាពនោះទេ។ ក្នុងរឿងក្តី *Kupreškic* គ្មានភាគីណាមួយបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងចំណុចនេះទេ។ នៅក្នុងរឿងក្តី *Kordic និង Cerkez* ក្នុងដំណាក់កាលសាលាដំបូង អយ្យការបានយកតាម និងយោងលើយុត្តិសាស្ត្រនេះ ដូចដែលមានចែងនៅក្នុងសាលក្រម *Kupreškic*[1126]។ ក៏ប៉ុន្តែអយ្យការបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងចំណុចនេះ។ ចំណុចនេះពុំបានជះឥទ្ធិពលលើសេចក្តីសម្រេចចុងក្រោយអំពីរបៀបមួយក្នុងចំណោមរបៀបទាំងឡាយដែលមានចែងនៅក្នុង មាត្រា ២៥-១ នោះទេ។

---

[1124] សាលក្រម *Kordic និង Cerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២២០។

[1125] សាលក្រម *Ruggiu* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០០ កថាខណ្ឌ ២២៖ "អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការពិនិត្យលើអំពើធ្វើទុក្ខបុកម្នេញដែលត្រូវបានទទួលស្គាល់ដោយជនជាប់ចោទ គឺអាចបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវធាតុផ្សំរួមមួយ។ អំពើទាំងនោះមានទម្រង់ជាការញុះញង់ផ្ទាល់ និងជាសាធារណៈ ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ការញុះញង់នេះត្រូវបានធ្វើឡើងតាមរយៈសម្ព័ន្ធផ្សាយតាមវិទ្យុ ក្នុងគោលបំណងបដិសេធចោល និងវាយប្រហារក្រុមជាតិពន្ធុទុតស៊ី និងជនជាតិប៊ែលហ្ស៊ិក ដោយមូលហេតុរើសអើង ដោយដកហូតពីពួកគេនូវសិទ្ធិជាមូលដ្ឋានសម្រាប់ការរស់រានមានជីវិត មានសេរីភាព និងដោយបដិសេធមិនផ្តល់ឱ្យពួកគេនូវឋានៈជាមនុស្ស ដែលត្រូវបានទទួលស្គាល់សម្រាប់ប្រជាជនផ្សេងទៀត។ ការបដិសេធនូវសិទ្ធិទាំងអស់នេះ អាចត្រូវបានចាត់ទុកថាមានគោលដៅចុងក្រោយ គឺថាបើពួកគេមិនស្លាប់ទេ យ៉ាងហោចណាស់ក៏ដាក់ពួកគេឱ្យដាច់ចេញពីសង្គមដែលពួកគេរស់នៅ ជាមួយនឹងពួកចារីដែលត្រូវបានចោទប្រកាន់ ឬក៏ដកពួកគេចេញពីមនុស្សជាតិតែម្តង" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1126] *Kordic និង Cerkez* សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់អយ្យការ កថាខណ្ឌ ២០០៖ "ធាតុផ្សំនៃស្ថានភាពផ្នត់គំនិតនេះអាចត្រូវបំពេញបាននៅពេលដែលអំពើរបស់ចារី "មានគោលដៅបែងចែកបុគ្គលមួយចំនួនឱ្យខុសពីគេ និងវាយប្រហារពួកគេ ដោយមូលហេតុរើសអើង" ដើម្បី "ដកបុគ្គលទាំងនោះចេញពីសង្គមដែលពួកគេរស់នៅជាមួយពួកចារី ឬក៏ដកចេញពីមនុស្សជាតិតែម្តង"" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ក្នុងកំណត់សម្គាល់ជើងទំព័រលេខអយ្យការយោងទៅលើកថាខណ្ឌ ៦៣៤ នៃសាលក្រម *Kupreškic*។

អយ្យការលើកឡើងថា វាជាបញ្ហាប្រយោជន៍ទូទៅសម្រាប់យុត្តិសាស្ត្រតុលាការ[1127]។ ក្នុងបរិបទនេះ អង្គជំនុំជម្រះតុលាការកំពូលមិនបានសម្រេចទេ តែបានត្រឹមតែអះអាងថា៖

> "ដោយស្របជាមួយនឹងយុត្តិសាស្ត្រតុលាការ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដើម្បីបង្ហាញឱ្យឃើញពីធាតុផ្សំអត្តនោម័តិនៃអំពើធ្វើទុក្ខបុកម្នេញ វាមិនចាំបាច់ត្រូវបង្ហាញភ័ស្តុតាងឱ្យឃើញពីអត្ថិភាពនៃចេតនារើសអើងជាក់លាក់ ដែលទំនងជាញ៉ាំងឱ្យមានផែនការ ឬគោលនយោបាយនៃការធ្វើទុក្ខបុកម្នេញ សំដៅដកមនុស្សមួយចំនួនចេញពីសង្គម ឬពីមនុស្សជាតិនោះទេ"[1128]។

៦៤៩. ក្នុងរឿងក្តី *Kordic និង Cerkez* អង្គជំនុំជម្រះតុលាការកំពូលបានយោងសាលដីកា *Blaškic* នៅក្នុងកំណត់សម្គាល់ជើងទំព័រ ធ្វើជាប្រភពគាំទ្រនៃការបោះបង់ចោលល័ក្ខខ័ណ្ឌតម្រូវឱ្យបង្ហាញភ័ស្តុតាងនៃចេតនាក្នុងការដកមនុស្សមួយចំនួនចេញពីក្នុងសង្គម សម្រាប់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ។ ក៏ប៉ុន្តែ ក្នុងសាលដីកា *Blaškic* ចៅក្រមទាំងអស់មិនបានផ្តល់សំអាងហេតុដល់សេចក្តីសន្និដ្ឋាននេះទេ ហើយក៏ពុំបានផ្អែកលើការយោងផ្លូវច្បាប់ ឬក៏លើការវិភាគណាមួយដើម្បីធ្វើយុត្តិកម្មចំពោះសេចក្តីសន្និដ្ឋានមួយនេះដែរ[1129]។ ផ្ទុយទៅវិញ សាលក្រម *Kupreškic* ដែលត្រូវបានយកតាមដោយសាលក្រម *Kordic និង Cerkez* បានផ្អែកលើយុត្តិសាស្ត្រក្រោយសង្គ្រាម។

---

[1127] *Kordic និង Cerkez* សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់អយ្យការ កថាខណ្ឌ ២.៥។

[1128] សាលដីកា *Kordic និង Cerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១១១ កំណត់សម្គាល់ជើងទំព័រលេខ១៣៤ យោងទៅ សាលដីកា *Blaškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៦៥។

[1129] សាលដីកា *Blaškic* ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៦៥៖ "ដោយស្របជាមួយនឹងយុត្តិសាស្ត្រតុលាការ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដើម្បីបង្ហាញឱ្យឃើញអំពីធាតុផ្សំអត្តនោម័តិនៃអំពើធ្វើទុក្ខបុកម្នេញ គឺវាមិនចាំបាច់បង្ហាញភ័ស្តុតាងឱ្យឃើញពីអត្ថិភាពនៃចេតនារើសអើងជាក់លាក់ដែលទំនងជាញ៉ាំងឱ្យមានផែនការ ឬគោលនយោបាយនៃការធ្វើទុក្ខបុកម្នេញ ដែលសំដៅដកមនុស្សមួយចំនួនចេញពីសង្គម ឬពីមនុស្សជាតិនោះទេ"

៦៥០. ផ្ទុយពីការបកស្រាយជ្រើសរើសដោយតុលាការកំពូល ក្នុងសាលដីកា ឌុច ហើយដែលត្រូវបានអនុវត្ត តាមដោយអង្គជំនុំជម្រះ អវត្តមាននៃការលើកឡើងឱ្យបានច្បាស់នូវល័ក្ខខ័ណ្ឌសំខាន់មួយនេះដោយអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូងផ្សេងៗទៀត នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា គឺរឹតតែជាភ័ស្តុតាងបង្ហាញឱ្យឃើញពីការបោះបង់ចោលនូវល័ក្ខខ័ណ្ឌនេះនៅឆ្នាំ១៩៩១ ពោលគឺក្រោយអង្គហេតុនៅឆ្នាំ១៩៧៥។

៦៥១. ពាក្យពេចន៍ជាក់លាក់អំពីចេតនាក្នុងការដកចេញនូវបុគ្គលដែលជាគោលដៅ ក្នុងនិយមន័យនៃធាតុផ្សំអត្តនោម័តិ ពុំត្រូវបានគេយកមកប្រើឡើងវិញឱ្យបានជាក់លាក់ បន្ទាប់ពីសាលដីកា *Blaškic* នោះទេ។ គ្មានសេចក្តីសម្រេចណាមួយក្នុងចំណោមសេចក្តីសម្រេចទាំងឡាយដែលបានធ្វើ ក្រោយពីមានសាលដីកា *Blaškic* បានផ្តល់ការបញ្ជាក់បន្ថែម ទាក់ទងនឹងមូលហេតុនៃការបោះបង់ចោលយ៉ាងច្បាស់នូវល័ក្ខខ័ណ្ឌនេះក្នុងសាលដីកា *Blaškic* ឡើយ[1130]។ លើសពីនេះទៀត ទាំងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ទាំងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា អង្គហេតុនៃការធ្វើទុក្ខបុកម្នេញ សុទ្ធតែត្រូវបានផ្តល់សំអាងហេតុថាជាការដកក្រុមដែលត្រូវបានធ្វើទុក្ខបុកម្នេញចេញពីសង្គម។ វាពុំមែនសោះឡើយថាជាចេតនាក្នុងការធ្វើសមានកម្ម ឬការប្រព្រឹត្តិដោយសមភាពនោះ។

៦៥២. ជាពិសេស អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបដិសេធចោលការព្រមព្រៀងដំបូង ដូចដែលបានបង្ហាញឱ្យឃើញតាមរយៈយុត្តិសាស្ត្របឋមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដែលតម្រូវឱ្យមានចេតនាក្នុងការដកបុគ្គលដែលត្រូវកំណត់ជាគោលដៅនៃការរើសអើងជាក់ស្តែង ចាត់ដូចជាតម្រុយ ថាយុត្តិសាស្ត្រនេះដែលផ្អែកលើយុត្តិសាស្ត្រក្រោយសង្គ្រាម គឺឆ្លុះបញ្ចាំងឱ្យឃើញពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាឆ្នាំ១៩៧៥។ ដូចគ្នាដែរចំពោះការអនុវត្តក្រោយមកទៀតរបស់

---

[1130] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៣ កំណត់សម្គាល់ជើងទំព័រលេខ២១៨៧ យោងទៅសាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៦-២៤០។ សូមមើល សាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៣៨ កំណត់សម្គាល់ជើងទំព័រលេខ៥១៤។

តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដែលធ្វើការផ្តន្ទាទោសតែចំពោះអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនៃចេតនាដកបុគ្គលទាំងអស់ ដែលត្រូវកំណត់ជាគោលដៅនៃការអនុវត្តវិធានការរើសអើង។

## ២.២. ការដកចេញ៖ ធាតុផ្សំសំខាន់នៃការធ្វើទុក្ខបុកម្នេញនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាម

៦៥៣. លក្ខខណ្ឌតម្រូវនៃចេតនាក្នុងការដកចេញពីសង្គមនូវបុគ្គលទាំងឡាយដែលត្រូវកំណត់គោលដៅ គឺបានបង្ហាញតាមរយៈសាលក្រមរបស់តុលាការយោធាអន្តរជាតិ Nuremberg និងសាលក្រម *Eichmann* របស់តុលាការក្រុងជេរូសាឡឹម ថាដូចជានាមកត្តារួម នៅពេលវាជាការធ្វើទុក្ខបុកម្នេញ។

៦៥៤. តុលាការយោធាអន្តរជាតិ Nuremberg បានលើកឡើងអំពីសំអាងហេតុដែលជាមូលដ្ឋាននៃការប្រកាសពិរុទ្ធភាពចំពោះ *Göring* ដែលសំអាងហេតុទាំងនោះផ្តោតសំខាន់លើចេតនាក្នុងការដកចេញនូវជនជាតិជ្វីប[1131]។ ដូចគ្នាដែរ ពាក់ព័ន្ធនឹងជនជាប់ចោទ *Von Ribbentrop*[1132]។ ពាក់ព័ន្ធនឹងជនជាប់

---

[1131] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ១៧៩-១៨០៖ "ក្រោយពីមានបាតុកម្មនាខែវិច្ឆិកា ឆ្នាំ១៩៣៨ មក Göring បានតម្រូវឱ្យជនជាតិជ្វីបបង់ប្រាក់ពិន័យមួយរយកោដិរិចស្មាក។ គាត់ធ្វើទុក្ខបុកម្នេញជនជាតិជ្វីបមិនត្រឹមតែនៅក្នុងប្រទេសអាល្លឺម៉ង់ទេ តែថែមទាំងនៅក្នុងទឹកដីដែលដណ្តើមបានទៀតផង។ សេចក្តីប្រកាសដែលគាត់បានធ្វើ ក៏ដូចជាសក្ខីរបស់គាត់នៅចំពោះមុខតុលាការ គឺបង្ហាញឱ្យឃើញថាគាត់ចាប់អារម្មណ៍ជាពិសេសចំពោះបញ្ហាថាតើត្រូវធ្វើដូចម្តេចដើម្បីកម្ចាត់ជនជាតិជ្វីបចេញពីជីវិតសេដ្ឋកិច្ចនៅអឺរ៉ុប និងដណ្តើមយកទ្រព្យសម្បត្តិរបស់ពួកគេ។ គាត់បានពង្រីកច្បាប់ប្រឆាំងជនជាតិជ្វីបរបស់អាណាចក្រអាល្លឺម៉ង់ទៅកាន់ប្រទេសដែលស្ថិតក្រោមការត្រួតត្រា ហើយបន្តិចម្តងៗ បានពង្រាយទាហានអាល្លឺម៉ង់ទៅដល់ទឹកដីទាំងនោះ។ ព្រឹត្តិបត្រច្បាប់អាល្លឺម៉ង់នៅទសវត្សរ៍ឆ្នាំ១៩៣៩ ១៩៤០ និង ១៩៤១ មាននូវក្រឹត្យច្បាប់ប្រឆាំងជនជាតិជ្វីបជាច្រើនដែលចុះហត្ថលេខាដោយ Göring។ ទោះបីថា Himmler ជាអ្នកទទួលបន្ទុកសម្លាប់ជនជាតិជ្វីបក៏ដោយ តែចំពោះ Göring វិញ បើទោះជាគាត់បានតវ៉ាក្នុងសវនាការក៏ដោយ ក៏គាត់ពុំបាននៅស្ងៀម ឬមិនមានសកម្មភាពអ្វីសោះនោះទេនៅក្នុងផ្នែកនេះ។ តាមរយៈក្រឹត្យចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៤១ គាត់បានបញ្ជាឱ្យ Himmler និង Heydrich ឈានទៅ "ដោះស្រាយឱ្យបានទាំងស្រុងលើបញ្ហាជនជាតិជ្វីបនៅក្នុងដែនឥទ្ធិពលអាល្លឺម៉ង់នៅអឺរ៉ុប" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1132] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ១៨៤៖ "នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៤៣ គាត់បានចូលរួមក្នុងកិច្ចពិភាក្សារវាង Hitler និង Horthy លើប្រធានបទស្តីពីការ

ចោទ Frank វិញ ចេតនាក្នុងការដកចេញស្តែងចេញឱ្យឃើញច្បាស់ផងដែរពីការវិភាគរបស់ចៅក្រម[1133]។ ពាក់ព័ន្ធនឹងការវាយតម្លៃលើការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ Frick ចៅក្រមទាំងអស់បានគូសបញ្ជាក់ថា "ជាអ្នកប្រឆាំងជនជាតិជ្វីបខ្លាំងក្លា Frick បានរៀបចំ ចុះហត្ថលេខា និងដាក់ឱ្យអនុវត្តនូវច្បាប់មួយចំនួនធំ សំដៅកម្ចាត់ជនជាតិជ្វីបចេញពីជីវភាពរស់នៅ និងពីសេដ្ឋកិច្ចអាល្លឺម៉ង់"[1134]។ ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ Streicher ចំពោះការធ្វើទុក្ខបុកម្នេញជនជាតិជ្វីបក៏សំអាងលើចេតនាក្នុងការដកចេញដូចគ្នាដែរ[1135]។ ការប្រកាសពិរុទ្ធភាពរបស់

និរទេសជនជាតិជ្វីបនៅប្រទេសហុងគ្រី ហើយបានប្រាប់រាជានុសិទ្ធិនៃប្រទេសនោះថា "ជនជាតិជ្វីបគួរត្រូវសម្លាប់ចោល ឬក៏អាចត្រូវដាក់នៅក្នុងជំរំប្រមូលផ្តុំ"" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1133] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ១៩៤៖ "ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីបបានចាប់ផ្តើមភ្លាមៗ។ ពីដើមមក ទឹកដីនេះមានប្រជាជនជ្វីប ចន្លោះពីពីរលានប្រាំសែន ទៅបីលានប្រាំសែននាក់។ ជនជាតិជ្វីបទាំងអស់ត្រូវបានបង្ខំឱ្យរស់នៅតាមសង្កាត់ជ្វីប ដាក់ឱ្យស្ថិតនៅក្រោមច្បាប់ពិសេស បង្អត់អាហារដែលចាំបាច់ដល់ការរស់រានមានជីវិតរបស់ពួកគេ ហើយជាចុងក្រោយ ត្រូវបានសម្លាប់ជាប្រព័ន្ធ និងសាហាវបំផុត។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤១ Frank បានប្រកាសប្រាប់សមាជិកគណៈរដ្ឋមន្ត្រីខ្លួនថា៖ "យើងត្រូវតែសម្លាប់ជនជាតិជ្វីប គ្រប់ទីកន្លែងដែលយើងជួបពួកគេ ហើយគ្រប់កន្លែង បើអាចធ្វើបាន ដើម្បីរក្សារចនាសម្ព័ន្ធ និងសិទិទ្ធពលរបស់អាណាចក្រអាល្លឺម៉ង់"។ ចាប់ពីថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៤៤ មក Frank បានវាយតម្លៃថាប្រជាជនជ្វីបនៅសល់តែមួយសែននាក់" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1134] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ១៩៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1135] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ១៩៨៖ "អត្ថបទកាសែត Der Stürmer ចំនួន ២៣ ដែលត្រូវបានសរសេរចន្លោះឆ្នាំ១៩៣៨ និងឆ្នាំ១៩៤១ និងដែលណែនាំឱ្យ "កម្ទេច" ជនជាតិជ្វីប ត្រូវបានដាក់ឱ្យពិភាក្សាដេញដោល សម្រាប់ជាឧទាហរណ៍មានលក្ខណៈសម្គាល់នៃការបង្រៀនរបស់គាត់។ វិចារណកថាមួយដែលចេញផ្សាយនៅខែកញ្ញា ឆ្នាំ១៩៣៨ ចាត់ទុកជនជាតិជ្វីបជា "មេរោគ" ជាមហន្តរាយ និងប្រកាសថាជនជាតិជ្វីបមិនមែនជាមនុស្ស និងចោទប្រកាន់ថាជា "បញ្ញើក្អែក" ជាសត្រូវ ជាសភាវៈចង្រៃ ទុច្ចរិតជន និងជាអ្នកចម្លងជំងឺដែលត្រូវតែកម្ទេចដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ"។ អត្ថបទដទៃទៀត ប្រកាសថា បញ្ហាជនជាតិជ្វីបអាចដោះស្រាយបានលុះត្រាតែ "សហគមន៍ជ្វីបទូទាំងពិភពលោក" ត្រូវបានកម្ទេចឱ្យក្លាយជាផេះ ហើយបានទាយទុកជាមុនថា ពីពេលនេះទៅប្រាំឆ្នាំខាងមុខ ផ្នូររបស់ជនជាតិជ្វីបនឹង "បញ្ជាក់ថា ប្រជាជនឧក្រិដ្ឋ និងឃាតករនេះ ប្រាកដជាទទួលជោគវាសនាដ៏សាកសមចំពោះខ្លួន"" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម), ទំព័រ ២០០ "ការដែល Striecher ជំរុញឱ្យប្រព្រឹត្តបទមនុស្សឃាត និងសម្លាប់ឱ្យផុតពូជនៅសម័យដែលនៅភាគខាងកើត ជនជាតិជ្វីបត្រូវបានសម្លាប់រង្គាលនៅក្នុងល័ក្ខខ័ណ្ឌគួរឱ្យរន្ធត់បំផុត សម្រេចបាននូវ "ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍" ដែលមានចែងក្នុងចំណោមឧក្រិដ្ឋកម្មសង្គ្រាម និងមានកំណត់ដោយលក្ខន្តិកៈ ហើយជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

Funk ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញជនជាតិជ្វីប ផ្អែកលើធាតុផ្សំមួយចំនួនដែលបង្ហាញឱ្យឃើញពីការដកចេញ[1136]។ ជនជាប់ចោទ Von Schirach ត្រូវបានទទួលស្គាល់ថាជាប់ពិរុទ្ធចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយតុលាការយោធាអន្តរជាតិ ដោយផ្អែកលើមូលដ្ឋានប្រហាក់ប្រហែលគ្នា[1137]។ ក្នុងចរន្តដដែលនេះដែរ តុលាការយោធាអន្តរជាតិបានជ្រើសយកការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរបស់ជនជាប់ចោទ Seyss-Inquart និងជនជាប់ចោទ Bormann ផ្អែកលើមូលដ្ឋាននៃការដកចេញ[1138]។ តុលាការក្រុងជេរូសាឡឹមបានបញ្ជាក់អះអាងអំពីការបកស្រាយនៃការធ្វើទុក្ខបុកម្នេញថាដូចជាការតម្រូវឱ្យមានគោលបំណងដកចេញ នៅក្នុងរឿងក្តី *Eichmann*[1139]។

---

[1136] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ២០១៖ "ក្នុងសក្ខីកម្មរបស់ខ្លួន Funk បានប្រកាសថាគាត់មានការធ្វើសចិត្តចំពោះភាពសាហាវឃោរឃៅកាលពីថ្ងៃទី១០ ខែវិច្ឆិកា។ តែគេបានដឹងថា នៅថ្ងៃទី១៥ ខែវិច្ឆិកា គាត់បានថ្លែងសុន្ទរកថាមួយ ដែលក្នុងនោះ គាត់បានពិពណ៌នាអំពីភាពឃោរឃៅនេះថាដូចជា "ការសម្តែងបែបហិង្សានូវការស្អប់ខ្ពើមរបស់ប្រជាជនអាល្លឺម៉ង់ ចំពោះការវាយប្រហារបែបឧក្រិដ្ឋដែលជនជាតិជ្វីបដឹកនាំធ្វើប្រឆាំងនឹងពួកគេ"។ នៅក្នុងសុន្ទរកថានោះ គាត់បានអះអាងដែរថា <u>ការដកជនជាតិជ្វីបទាំងអស់ចេញពីរាល់សកម្មភាពសេដ្ឋកិច្ចគួរកើតចេញដោយសមហេតុសមផលពីការដកពួកគេចេញពីជីវិតនយោបាយ</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1137] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ២១៥៖ "ដូច្នេះ ការនិរទេសជនជាតិជ្វីបបានចាប់ផ្តើម និងបន្តរហូតដល់សរទរដូវឆ្នាំ១៩៤២។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៤២ Von Schirach បានថ្លែងសុន្ទរកថាមួយ <u>ដោយក្នុងនោះគាត់ពន្យល់ថា គាត់បានបណ្តេញ "ជនជាតិជ្វីបនៅតាមសង្កាត់ជ្វីប ភាគខាងកើត រាប់សិនពាន់នាក់" សម្រាប់ "ជាការចូលរួមរបស់គាត់ចំពោះវិស័យវប្បកម្មអឺរ៉ុប"</u>" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1138] *ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ ភាគ ១ ទំព័រ ២២៥៖ "វិធានការមួយក្នុងចំណោមវិធានការទាំងឡាយរបស់ Seyss-Inquart ក្នុងឋានៈជាស្នងការរបស់ចក្រភពអាល្លឺម៉ង់សម្រាប់ប្រទេសហូឡង់ គឺការដាក់ចូលជាធរមាននូវច្បាប់សេដ្ឋកិច្ចពិសេសមួយចំនួនសម្រាប់ជនជាតិជ្វីប។ បន្ទាប់មកទៀត <u>មានក្រឹត្យច្បាប់មួយចំនួនតម្រូវឱ្យរាប់ចំនួនពួកជ្វីប បង្ខំពួកគេឱ្យរស់នៅតាមសង្កាត់ជ្វីប និងពាក់ផ្កាយដាវីដ</u>។ ជនជាតិជ្វីបត្រូវបានចាប់ខ្លួនផងដែរទៅតាមពេលវេលាទៀងទាត់ និងឃុំឃាំងនៅក្នុងជំរំប្រមូលផ្តុំ ហើយជាចុងក្រោយ ដោយមានសំណើរបស់ Heydrich ពួកគេត្រូវបាននិរទេសជាទ្រង់ទ្រាយធំ៖ <u>ក្នុងចំណោមប្រជាជនជ្វីបមួយសែនបួនម៉ឺននាក់ដែលរស់នៅប្រទេសហូឡង់ មានប្រមាណមួយសែនពីរម៉ឺននាក់ដែលត្រូវបានបញ្ជូនទៅជំរំប្រមូលផ្តុំ Auschwitz ដើម្បី "ដំណោះស្រាយចុងក្រោយ"។ Seyss-Inquart ទទួលស្គាល់ថាបានដឹងពីគោលដៅរបស់អ្នកទាំងនោះ</u> ប៉ុន្តែគាត់អះអាងថាបានឮពីអ្នកដែលធ្លាប់នៅ <u>Auschwitz</u> ថាជនជាតិជ្វីបទាំងនោះទទួលបានការប្រព្រឹត្តិល្អប្រសើរ ហើយថាគាត់ជឿជាក់ថាគេដាក់អ្នកទាំងនោះនៅទីនោះដើម្បីបញ្ជូនទៅប្រទេសមួយផ្សេងទៀត នៅក្រោយពេលចប់សង្គ្រាម។ យោងតាមភ័ស្តុតាង និងដោយសារតួនាទីផ្លូវការរបស់គាត់ គេមិនអាចជឿជាក់បានចំពោះការអះអាងមួយនេះ

៦៥៥. ដូច្នេះ ក្នុងករណីជាក់ស្តែងនេះ ដើម្បីកំណត់អំពីចរិតលក្ខណៈនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះត្រូវតែបង្ហាញឱ្យឃើញថា តើរាល់វិធានការទាំងឡាយដែលត្រូវកំណត់ថាជាការធ្វើទុក្ខបុកម្នេញ មានគោលបំណងដាក់ក្រុមឱ្យនៅដាច់ពីគេ ឬដកក្រុមចេញពីក្នុងសង្គម ស្ថិតនៅត្រង់ចំណុចណា។ ដោយពុំបានធ្វើដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ហើយនៅក្នុងការកំណត់

ទេ", ទំព័រ ២៣៤៖ "Bormann បានដើរតួនាទីយ៉ាងសកម្មនៅក្នុងការធ្វើទុក្ខបុកម្នេញជនជាតិជ្វីប ទាំងនៅក្នុងប្រទេសអាល្លឺម៉ង់ និងនៅតាមប្រទេសដែលស្ថិតក្រោមការត្រួតត្រា។ គាត់បានចូលរួមក្នុងកិច្ចពិភាក្សានានាដែលនាំទៅដល់ការបញ្ជូនជនជាតិជ្វីបប្រាំមួយម៉ឺននាក់ពីទីក្រុងវីយែន ទៅប្រទេសប៉ូឡូញ ដោយមានជំនួយពីកងការពារ (SS) និងប៉ូលីសសម្ងាត់រដ្ឋ។ គាត់បានចុះហត្ថលេខាលើក្រឹត្យចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៤១ ដែលពង្រីកការអនុវត្តច្បាប់ទាំងឡាយរបស់ Nuremberg ទៅកាន់ទឹកដីចំណុះនានានៅភាគខាងកើត។ ក្នុងបទបញ្ជាមួយចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៤២ គាត់បានប្រកាសថា ការកម្ទេចជនជាតិជ្វីបជាអចិន្ត្រៃយ៍ចេញពីទឹកដីរបស់អាណាចក្រអាល្លឺម៉ង់ (Plus Grande Allemagne) លែងអាចធ្វើបានតាមរយៈនិរប្រវេសន៍ទៀតហើយ តែគឺតាមរយៈការប្រើប្រាស់ "កម្លាំងគ្មានមេត្តា" នៅតាមជំរំពិសេសនានាភាគខាងលិចប៉ុណ្ណោះ"។ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៤៣ គាត់បានចុះហត្ថលេខាលើដីកាមួយដែលដកជនជាតិជ្វីបចេញពីការការពារដោយតុលាការធម្មតា ហើយបានដាក់ពួកគេឱ្យស្ថិតក្រោមយុត្តាធិការផ្តាច់មុខរបស់ប៉ូលីសសម្ងាត់រដ្ឋរបស់លោក Himmler" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1139] តុលាការក្រុងហ្សេរុយសាឡឹម រឿងក្តី Eichmann ៣៦ ILR ឆ្នាំ១៩៦៨ កថាខណ្ឌ ៥៦៖ "ជាមួយនឹងការឡើងកាន់អំណាចរបស់អ៊ីត្លែ ការធ្វើទុក្ខបុកម្នេញលើជនជាតិជ្វីបបានក្លាយជាគោលនយោបាយផ្លូវការមួយ និងមានទម្រង់ស្របតាមច្បាប់ស្ទើរតែទាំងស្រុងតាមរយៈច្បាប់ និងវិធាននានាដែលត្រូវបានផ្សព្វផ្សាយដោយរដ្ឋាភិបាលអាណាចក្រអាល្លឺម៉ង់ អនុលោមតាមអំណាចនីតិប្រតិបត្តិដែលសភាផ្តល់ឱ្យរដ្ឋាភិបាលនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៣៣ (វគ្គ ១៤ ភាគ ១ ទំព័រ ២១៥ [ដែលនៅត្រង់នោះ មានការចុះកាលបរិច្ឆេទខុស ថានៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៣៣]) និងតាមរយៈអំពើហិង្សាផ្ទាល់ទាំងឡាយដែលរៀបចំឡើងដោយរបបនេះ ដើម្បីប្រឆាំងនឹងបុគ្គល និងទ្រព្យសម្បត្តិរបស់ជនជាតិជ្វីប។ គោលដៅដំបូងនៃការធ្វើសកម្មភាពទាំងនេះ គឺដើម្បីដកហូតសិទ្ធិពីជនជាតិជ្វីប បន្ទាបបន្ថោកពួកគេ និងធ្វើឱ្យគេមានការភ័យខ្លាចក្នុងចិត្ត បំបែកពួកគេចេញពីប្រជាជនផ្សេងទៀត ដកពួកគេចេញពីជីវភាពសេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេស និងបិទប្រភពចំណូលរបស់ពួកគេ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម), កថាខណ្ឌ ២០១៖ "វាច្បាស់ណាស់ថាផ្នែកទាំងពីរនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវអនុវត្តចំពោះរាល់សកម្មភាពទាំងអស់របស់ជនជាប់ចោទប្រឆាំងនឹងជនជាតិជ្វីប នៅដំណាក់កាលចុងក្រោយ ចាប់ពីខែសីហា ឆ្នាំ១៩៤១ ហើយថានៅក្នុងដំណាក់កាលនោះ គាត់បានចូលរួមក្នុងគ្រប់អំពើអមនុស្សធម៌ទាំងអស់ដែលមានបង្ហាញនៅក្នុងមាត្រាច្បាប់ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យក្លាយទៅជាទាសករ ការបង្អត់អាហារ និងការនិរទេសប្រជាជនស៊ីវិល។ ការបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយ ឬផ្លូវចិត្ត លើប្រជាជនជ្វីប ក៏ជាអំពើអមនុស្សធម៌មួយដែរ ធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិល។ អំពើទាំងអស់នេះ ដែលប្រព្រឹត្តឡើងក្នុងគោលបំណងសម្លាប់រង្គាលប្រជាជនជ្វីប គឺជាក់ស្តែងទៅក៏ជាការធ្វើទុក្ខបុកម្នេញជនជាតិជ្វីប ដោយមូលហេតុជាតិសាសន៍ ពូជសាសន៍ សាសនា និងនយោបាយផងដែរ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ប្រភេទបទល្មើស អង្គជំនុំជម្រះបានអនុវត្តដោយពុំត្រឹមត្រូវនូវច្បាប់ជាធរមាននៅសម័យកាលនៃអង្គហេតុ ដូចដែលគេនឹងឃើញនៅផ្នែកខាងក្រោម[1140]។

**ផ្នែកទី ២. កំហុស និងផលវិបាកនៅតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗ**

**១. គ្មានចេតនារើសអើងចំពោះពុទ្ធសាសនិក និងព្រះសង្ឃ**

៦៥៦. អង្គជំនុំជម្រះមានកាតព្វកិច្ចបង្ហាញឱ្យឃើញថា តើវាល់វិធានការទាំងឡាយដែលត្រូវបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញ មានគោលបំណងដាក់ក្រុមឱ្យនៅដាច់ដោយឡែក ឬដកចេញពីក្នុងសង្គម ត្រូវបានធ្វើឡើងតាមរបៀបណា ហើយបានប្រព្រឹត្តកំហុស ដោយអះអាងថា ចេតនាមានលក្ខណៈរើសអើងដោយមិនអាស្រ័យទៅនឹងការចង់ដឹងថា តើគោលបំណងគឺឈានទៅសម្រេចឱ្យបានសមភាពដាច់ខាតមែន ឬទេ[1141]។ ដូច្នេះ ធាតុផ្សំអត្តនោម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពុំត្រូវបានបំពេញ ហើយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ[1142]។

**២. គ្មានចេតនារើសអើងចំពោះជនជាតិចាម**

៦៥៧. អង្គជំនុំជម្រះពុំបានកំណត់ថា តើវាល់វិធានការទាំងឡាយដែលត្រូវបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញមានគោលបំណងដាក់ក្រុមឱ្យនៅដាច់ដោយឡែក ឬដកចេញពីក្នុងសង្គម ត្រូវបានធ្វើឡើងតាមរបៀបណានោះទេ។ ដោយពុំបានបង្ហាញឱ្យឃើញដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់[1143]។ ដូច្នេះ ធាតុផ្សំអត្តនោម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាចំពោះជនជាតិចាម គឺពុំត្រូវបានបំពេញ ហើយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ[1144]។

---

[1140] សូមមើលខាងក្រោម កថាខណ្ឌ ៦៥៦-៦៥៧។

[1141] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៦។

[1142] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៦។

[1143] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៤-១៦៥៩, ១៦៩៥-១៦៩៧, ៣៣២០-៣៣២៦, ៣២៤៣, ៣៣២៩, ៣៣៣២។

[1144] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩០-៣៩៩៨, ៤៣០៦។

## ជំពូកទី ៤. កំហុសពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមអំពើអមនុស្សធម៌ផ្សេងៗទៀត

៦៥៨. យោងតាមខ្លឹមសារនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ខៀវ សំផន ត្រូវបានបញ្ជូនទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត។ នៅក្នុងការកំណត់អំពីនិយមន័យនៃឧក្រិដ្ឋកម្មនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ជាច្រើន[1145]។ អង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គច្បាប់នៅក្នុងការពិនិត្យលើគោលការណ៍នីត្យានុកូលភាព (ផ្នែកទី ១) និងដោយផ្តល់និយមន័យបែបបំប្រួញនៃលក្ខខ័ណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការ (ផ្នែកទី ២)។

### ផ្នែកទី ១. ការវាយតម្លៃពុំត្រឹមត្រូវលើនីត្យានុកូលភាពនៃឧក្រិដ្ឋកម្មដែលជាអំពើអមនុស្សធម៌ផ្សេងៗទៀត

៦៥៩. អង្គជំនុំជម្រះយល់ឃើញថា បន្ទាប់ពីបាន "ថ្លឹងថ្លែងទៅលើកត្តាទាំងនេះដោយសត្យានុម័តិរួចមក" អង្គជំនុំជម្រះសន្និដ្ឋានថា "ជនជាប់ចោទអាចប្រមើលឃើញ និងដឹងជាទូទៅថា អំពើអមនុស្សធម៌ផ្សេងៗទៀត អាចត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៥"[1146]។ ចៅក្រមពុំបានផ្តល់សំអាងហេតុណាមួយចំពោះការធ្វើសេចក្តីសន្និដ្ឋានជាទូទៅមួយនេះ ដែលត្រូវបានលើកឡើងដោយគ្មានកំណត់សម្គាល់ជើងទំព័រណាមួយជួយគាំទ្រនោះទេ។ អង្គជំនុំជម្រះបានត្រឹមតែនិយាយថា ខ្លួនបានពិចារណាលើ "ក្របខ័ណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា"[1147]។

៦៦០. មេធាវីការពារក្តីពុំជំទាស់នឹងអត្ថិភាពនៃឧក្រិដ្ឋកម្មដែលជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅសម័យកាលនៃអង្គហេតុនោះទេ។ ក៏ប៉ុន្តែ ការកត់សម្គាល់តែមួយគត់នេះគឺពិតជាមិនគ្រប់គ្រាន់ឡើយ ដើម្បីធ្វើឱ្យការចោទប្រកាន់អាចត្រូវដឹងជាមុនបានដោយជនជាប់ចោទ ថាជាអំពើល្មើស និងមានច្បាប់ចែង។

[1145] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២៤-៧២៧។

[1146] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1147] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២៣។

អំពើអមនុស្សធម៌ផ្សេងៗទៀតអាចមានលក្ខណៈជាការប្រព្រឹត្តិផ្សេងៗ។ វាជាប្រភេទបំពេញបន្ថែមមួយ ដែលតម្រូវឱ្យមានការពិនិត្យលើគោលការណ៍នីត្យានុកូលភាពឱ្យបានហ្មត់ចត់ជាងការពិនិត្យលើកឡើងដោយអង្គជំនុំជម្រះ។

៦៦១. មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រៀបរាប់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដាច់ដោយឡែកនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងបញ្ចប់ជាមួយនឹង "អំពើអមនុស្សធម៌ផ្សេងៗទៀត"។

៦៦២. អំពើអមនុស្សធម៌ផ្សេងៗទៀត ពុំមែនជាបទឧក្រិដ្ឋ ឬជាប្រភេទឧក្រិដ្ឋកម្មជាក់លាក់នោះទេ។ នៅក្នុងនិយមន័យនៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើអមនុស្សធម៌ផ្សេងៗទៀត មានគោលបំណងបង្កើតនូវការពង្រីកលើឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានរៀបរាប់យ៉ាងជាក់លាក់ ដែលត្រូវអនុវត្តដោយសទិសភាព តាមវិធាននៃការបកស្រាយលើប្រភេទដូចគ្នា។ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងតួនាទីជាប្រភេទបំពេញបន្ថែម ឬបើតាមសំនួនវោហាររបស់ Iris HAENEN ជាការ "ទទើសទទែង"[1148] ត្រូវបានដាក់បញ្ចូលក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដើម្បីរារាំងមិនឱ្យអំពើអមនុស្សធម៌មួយចំនួនទៀត ដែលមិនត្រូវបានរៀបរាប់ឱ្យបានច្បាស់លាស់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវដកចេញពីវិសាលភាពនៃនីតិព្រហ្មទណ្ឌអន្តរជាតិ។ ដូច្នេះ វាមានន័យថា អំពើសកម្ម ឬអំពើអកម្មដែលត្រូវផ្តន្ទាទោស មិនត្រូវធ្លាប់បានគ្របដណ្តប់ដោយខ្លឹមសារនៃបទឧក្រិដ្ឋណាមួយក្នុងចំណោមបទឧក្រិដ្ឋដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងច្បាប់ជាក់លាក់ណានោះទេ។ សេចក្តីសន្និដ្ឋាននេះត្រូវបានបញ្ជាក់អះអាងដោយយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា

---

[1148] អត្ថបទនិពន្ធដោយ Iris HAENEN *ការចាត់ថ្នាក់អំពើនានានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ* ព្រឹត្តិបត្រច្បាប់អាល្លឺម៉ង់ ឆ្នាំ២០១៣ ទំព័រ ៧៩០-៨២២ និង ការបង្ខំ និងការរៀបការ៖ *ការចោទប្រកាន់ចំពោះអំពើរៀបការដោយបង្ខំនៅក្នុងនីតិព្រហ្មទណ្ឌហូឡង់ អង់គ្លេស និងនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ* គ្រឹះស្ថានបោះពុម្ពផ្សាយ Intersentia ឆ្នាំ២០១៤។ ការបកប្រែសំនួនវោហារដោយមេធាវីការពារក្តី គឺយកតាមសំនួនវោហារ "*catch-all provision*" របស់អ្នកនិពន្ធ នៅក្នុងអត្ថបទដើមជាភាសាអង់គ្លេស។

ហើយកើតចេញផងដែរពីការបកស្រាយវេយ្យាករណ៍សមហេតុសមផល៖ ខនេះថែងអំពីអំពើអមនុស្សធម៌*ផ្សេងៗទៀត*[1149]។

៦៦៣. អំពើអមនុស្សធម៌ផ្សេងៗទៀត គឺទំនងជាផ្នែកនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបង្កើតឱ្យមានការលំបាកយ៉ាងខ្លាំង ជាមួយនឹងការគោរពគោលការណ៍នីត្យានុកូលភាព[1150]។ គោលការណ៍នីត្យានុកូលភាព (គ្មានបទល្មើស បើគ្មានច្បាប់ចែង) គឺជាគោលការណ៍គ្រឹះនៃការចោទប្រកាន់ព្រហ្មទណ្ឌអន្តរជាតិ ហើយដូច្នេះ ត្រូវអនុវត្តចំពោះគ្រប់តុលាការអន្តរជាតិទាំងអស់។ គេឃើញមានការលើកឡើងអំពីគោលការណ៍នេះនៅក្នុងខ្លឹមសារនៃមាត្រា ២-២ នៃលក្ខន្តិកៈទីក្រុងរ៉ូម[1151] និងនៅក្នុងមាត្រា ១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ គោលការណ៍នេះបង្កើតចេញជាអនុសាធ្យជាច្រើន ដែលក្នុងនោះមានគោលការណ៍នៃភាពអាចដឹងជាមុនបានថាមានច្បាប់ចែង ដែលតម្រូវឱ្យការប្រព្រឹត្តិបែបឧក្រិដ្ឋត្រូវមានភាពជាក់លាក់ និងច្បាស់លាស់។ និយមន័យបទឧក្រិដ្ឋមួយត្រូវតែមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីឱ្យចារីសក្តានុពលអាចដឹងបានថា តើអំពើសកម្ម ឬអំពើអកម្មដែលគេប្រព្រឹត្ត អាចត្រូវបានចោទប្រកាន់ព្រហ្មទណ្ឌដែរឬទេ។ យោងតាមគោលការណ៍នៃការមិនអនុវត្តបែបប្រតិសកម្ម គេមិនអាចចោទប្រកាន់ចំពោះអំពើសកម្មមួយ អំពើអកម្មណាមួយដែលត្រូវបានប្រព្រឹត្តនៅមុនការប្រកាសឱ្យប្រើច្បាប់សម្រាប់ដាក់ទោសចំពោះការប្រព្រឹត្តិប្រភេទនោះទេ វៀរលែងតែវិធានទាំង

---

[1149] អត្ថបទនិពន្ធដោយ Iris HAENEN *ការចាត់ថ្នាក់អំពើនានានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ* ព្រឹត្តិបត្រច្បាប់អាល្លឺម៉ង់ ឆ្នាំ២០១៣ ទំព័រ ៨១២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ការយោងដែលត្រូវបានរៀបរាប់ដើម្បីគាំទ្រការលើកឡើងនេះមាន៖ *"Jain កំណត់សម្គាល់ខាងលើ ១ ត្រង់ [កថាខណ្ឌ] ១០២៨ យោងទៅ សាលក្រម Kayishema កំណត់សម្គាល់ខាងលើ ៦៥ កថាខណ្ឌ ១៥០។ សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង* Mitar Vasiljević *(សាលក្រម) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សំណុំរឿង IT-98-32-T ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ២៣៤, រដ្ឋអាជ្ញា ទល់នឹង Dario Kordić & Mario Čerkez (សាលក្រម) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សំណុំរឿង IT-95-14/2-T ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៦៩*"។

[1150] សៀវភៅនិពន្ធដោយ Cherif BASSIOUNI *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រវត្តិ និងការវិវត្ត និងការអនុវត្តនាពេលបច្ចុប្បន្ន* Cambridge ឆ្នាំ២០១១ ទំព័រ ៤១១។

[1151] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២២-២៖ "និយមន័យនៃបទឧក្រិដ្ឋត្រូវតែបកស្រាយឱ្យបានតឹងរ៉ឹងបំផុត និងមិនអាចត្រូវបានពង្រីកដោយសទិសភាពបានទេ។ ក្នុងករណីមានភាពមិនច្បាស់លាស់ និយមន័យនេះត្រូវតែបកស្រាយឱ្យបានជាប្រយោជន៍ដល់ជនដែលជាកម្មវត្ថុនៃការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោស"។

នោះផ្តល់ភាពអនុគ្រោះដល់ជនជាប់ចោទ។ អនុសាធ្យនៃគោលការណ៍នេះ គឺការការពារសុចរិតភាពនៃសិទ្ធិរបស់ជនជាប់ចោទ។

៦៦៤. លោក CASSESSE អះអាងថា គោលការណ៍មិនប្រតិសកម្មនៃវិធានព្រហ្មទណ្ឌ បានចាក់ឫសយ៉ាងមាំចាប់ពីពេលនេះទៅ នៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ហើយថាតុលាការទាំងអស់គ្រាន់តែត្រូវអនុវត្តវិធាននីតិព្រហ្មទណ្ឌដែលមានអត្ថិភាពនៅពេលបទល្មើសរងការចោទប្រកាន់កើតឡើងប៉ុណ្ណោះ[1152]។ ក៏ប៉ុន្តែ តុលាការទាំងអស់បានគេចមិនអនុវត្តគោលការណ៍នេះឱ្យបានតឹងរ៉ឹង ហើយបានជ្រើសរើសវិធីសាស្ត្រទូលាយជាង ដែលក្នុងនោះការបកស្រាយ និងការបង្កើតរបស់តុលាការ ត្រូវបានអនុញ្ញាត តាមរយៈការសម្របសម្រួលគតិយុត្តិ។ ការពិនិត្យលើសេចក្តីសម្រេចថ្មីៗមួយចំនួនពាក់ព័ន្ធនឹងភាពមិនប្រតិសកម្មនៃច្បាប់ បានស្តែងឱ្យឃើញច្បាស់ថា តុលាការទាំងអស់បានព្យាយាមសម្រុះសម្រួលការដែលនីតិព្រហ្មទណ្ឌអន្តរជាតិ "ផ្សំឡើងភាគច្រើនពីវិធានទំនៀមទម្លាប់ដែលជារឿយៗត្រូវបានកំណត់អត្តសញ្ញាណ បំភ្លឺ ឬបញ្ជាក់ ឬដែលការកំណត់តាមផ្លូវគតិយុត្តិត្រូវបានធ្វើដោយតុលាការ"[1153] ជាមួយការបង្គាប់ថា ពិរុទ្ធភាពគឺមិនត្រូវដាក់ទៅលើបុគ្គលដែលមិនអាចដឹងបានដោយហេតុផលត្រឹមត្រូវថាតើអំពើនោះមានលក្ខណៈឧក្រិដ្ឋដែរឬទេ[1154]។ ប្រភេទបំពេញបន្ថែមនៃអំពើអមនុស្សធម៌ផ្សេងៗទៀតគឺស្ថិតក្នុងវិធីសាស្ត្រទូលាយនេះ និងឆន្ទៈក្នុងការសម្របសម្រួលនីតិព្រហ្មទណ្ឌអន្តរជាតិនេះ។ យ៉ាងណាមិញ យុត្តិសាស្ត្រអន្តរជាតិបានអភិវឌ្ឍនិយមន័យប្រយ័ត្នប្រយែងមួយនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ដល់គោលការណ៍មិនមែនជាបទល្មើស បើគ្មានច្បាប់ចែង។

៦៦៥. ដូច្នេះ វាពុំគ្រប់គ្រាន់ទេក្នុងការនិយាយថា ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត គឺអាចដឹងមុនបានថាមានចែងនៅក្នុងច្បាប់ ក្នុងសម័យកាលនៃអង្គហេតុ ខណៈដែលឧក្រិដ្ឋកម្មនេះមានលក្ខណៈជាការប្រព្រឹត្តិច្រើនបែបយ៉ាងនោះ។ ក្នុងឋានៈជាប្រភេទបំពេញបន្ថែម គួរតែត្រូវធ្វើការវិភាគមួយករណីម្តងៗចំពោះអង្គហេតុនីមួយៗដែលត្រូវបានចោទប្រកាន់ គឺមានន័យថាត្រូវកំណត់អត្តសញ្ញាណនៃការ

---

1152 សៀវភៅនិពន្ធដោយ Antonio CASSESSE *នីតិព្រហ្មទណ្ឌអន្តរជាតិ* ឆ្នាំ២០០៨ ទំព័រ ១១៣-១១៤។

1153 សៀវភៅនិពន្ធដោយ Antonio CASSESSE *នីតិព្រហ្មទណ្ឌអន្តរជាតិ* ឆ្នាំ២០០៨ ទំព័រ ១១៣-១១៤។

1154 អត្ថបទនិពន្ធដោយ Nicolas Azadi GOODFELLOW *ការចាត់ថ្នាក់ដោយពុំត្រឹមត្រូវចំពោះ "ការរៀបការដោយបង្ខំ" ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយតុលាការសៀរ៉ាឡេអូន* ទំព័រ ៨៤៣-៨៤៤។

ប្រព្រឹត្ត និងពិនិត្យមើលថាតើនៅសម័យកាលនៃអង្គហេតុ ការប្រព្រឹត្តិនោះអាចមានលក្ខណៈឧក្រិដ្ឋស្មើគ្នាទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដែរឬទេ។ ដោយពុំបានផ្តល់ការពិនិត្យហ្មត់ចត់លើនីត្យានុកូលភាពនៃបទល្មើសដែលចោទជាបញ្ហានេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលធ្វើឱ្យសេចក្តីសន្និដ្ឋានរបស់ខ្លួន គ្មានសុពលភាព។

## ផ្នែកទី ២. ការរំឭកបែបបំប្រួញនៃលក្ខខ័ណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការ

៦៦៦. អង្គជំនុំជម្រះបានរំឭកអំពីល័ក្ខខ័ណ្ឌអនីត្យានុកូលភាពផ្លូវការដែលលើកឡើងដោយតុលាការកំពូល នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ដែលល័ក្ខខ័ណ្ឌនេះជួយ“ដល់ការវាយតម្លៃទាំងទៅលើល័ក្ខខ័ណ្ឌនៃភាពអាចប្រមើលឃើញ និងថាតើការប្រព្រឹត្តនោះឈានដល់កម្រិតធ្ងន់ធ្ងរនៃបទល្មើសផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ឬយ៉ាងណា”[1155]។ យោងតាមខ្លឹមសារនៃសាលដីកាសំណុំរឿង ០០២/០១ ប្រសិនបើគ្មានភាពចាំបាច់ថា ការប្រព្រឹត្តិត្រូវតែមានចែងយ៉ាងច្បាស់ថាជាបទល្មើសនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិទេនោះ គេត្រូវកំណត់ឱ្យឃើញពីទំនាក់ទំនងពិតប្រាកដរបស់ច្បាប់ និងការហាមឃាត់ទាំងឡាយដែលមានចែងក្នុងលិខិតុបករណ៍នានា ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងមានជាធរមាននៅសម័យកាលអង្គហេតុ ដែលនាំទៅដល់ការចោទប្រកាន់ចំពោះអំពើអមនុស្សធម៌ផ្សេងៗទៀត[1156]។

៦៦៧. ដើម្បីកំណត់បានអំពីលក្ខណៈនៃការប្រព្រឹត្តិ ហើយប្រសិនបើវាមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងលក្ខណៈ និងភាពធ្ងន់ធ្ងរនៃអំពើផ្សេងៗទៀតដូចបានរៀបរាប់ យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិបានព្យាយាមកំណត់វិសាលភាពនៃការប្រព្រឹត្តិ រួចបន្ទាប់មក ធ្វើការប្រៀបធៀប ទៅនឹងវិធានអន្តរជាតិនានា ដើម្បីកំណត់មើលថា តើវាជាអំពើអមនុស្សធម៌ផ្សេងទៀតមែនដែរឬទេ។ តាមរយៈការវិនិច្ឆ័យស្វែងរកអនីត្យានុកូលភាពជាយថាហេតុនៃការប្រព្រឹត្តិដែលរងការចោទប្រកាន់នៅសម័យកាលនៃអង្គហេតុ តុលាការកំពូលបានឯកភាពជាមួយយុត្តិសាស្ត្រដែលលើកឡើងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។

---

1155 សំអាងហេតុសាលក្រម កថាខណ្ឌ ៧២៦។

1156 សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៤។

៦៦៨. ក្នុងសាលក្រម *Kupreškić* អង្គជំនុំជម្រះបានរំឮកថា សំនួនវោហារ "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺមានគោលបំណងដោយចេតនាក្នុងការបង្កើតនូវប្រភេទបំពេញបន្ថែម ដែលជាមូលហេតុដែលសមាសភាគទាំងឡាយរបស់វាមិនត្រូវបានរៀបរាប់ឱ្យអស់[1157]។ ប៉ុន្តែ ដើម្បីគោរពឱ្យបាននូវគោលការណ៍នីត្យានុកូលភាព និងអនុសាធ្យរបស់គោលការណ៍នេះ អង្គជំនុំជម្រះបានព្យាយាមរកដែនកំណត់ដែលច្បាស់លាស់ជាងនេះសម្រាប់ការបកស្រាយសំនួនវោហារអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងវិធានអន្តរជាតិនានា ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ ដូច្នេះ អង្គជំនុំជម្រះបានផ្អែកលើច្បាប់អន្តរជាតិមួយចំនួន ដើម្បីរកមើលសិទ្ធិមនុស្សជាមូលដ្ឋាន ដែលការរំលោភលើសិទ្ធិនេះអាចផ្សំបានជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ពេលរកឃើញហើយ សិទ្ធិជាមូលដ្ឋានទាំងនោះ "ត្រូវតែអនុវត្តជាលក្ខណៈប្រព័ន្ធ និងក្នុងទ្រង់ទ្រាយធំ។ គេអាចនិយាយម្យ៉ាងទៀតថា សិទ្ធិទាំងនោះត្រូវតែធ្ងន់ធ្ងរដូចគ្នាទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលមានចែងនៅក្នុងវាក្យខ័ណ្ឌផ្សេងៗទៀតនៃមាត្រា ៥"។ ជាចុងក្រោយ នៅក្នុងដំណាក់កាលចុងក្រោយនៃសេចក្ដីវិនិច្ឆ័យរបស់ខ្លួន អង្គជំនុំជម្រះយល់ឃើញថា នៅពេលរកឃើញដែនកំណត់គតិយុត្តិដែលអាចឱ្យកំណត់បានអំពីខ្លឹមសារនៃប្រភេទ "អំពើអមនុស្សធម៌" បានហើយ គេត្រូវយោងលើវិធានប្រហាក់ប្រហែលដើម្បីប្រៀបធៀប និងវាយតម្លៃភាពធ្ងន់ធ្ងរនៃអំពើហាមឃាត់[1158]។ ក្នុងរឿងក្ដី *Blagojevic* អង្គជំនុំជម្រះសាលាដំបូងបានរំឮកអំពីលក្ខណៈបំពេញបន្ថែមនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយបានបន្ថែមថា គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យអំពើដែលលើកឡើងត្រូវខុសពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀតដែលបានរៀបរាប់[1159]។ ផ្ទុយទៅវិញ ក្នុងរឿងក្ដី *Stakić* អង្គជំនុំជម្រះពុំបានឯកភាពតាមវិធីសាស្ត្រនេះទេ ដោយមូលហេតុថា៖

---

[1157] សាលក្រម *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ កថាខណ្ឌ ៥៦៣។

[1158] សាលក្រម *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៦៦។

[1159] សាលក្រម *Blagojevic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៦២៥។

"លិខិតុបករណ៍នានាដែលត្រូវបានលើកឡើងនៅក្នុងសាលក្រម *Kupreškić* បានផ្តល់ការកំណត់អំពីសិទ្ធិមនុស្សមួយចំនួនដែលខុសគ្នាបន្តិចបន្តួច។ ប៉ុន្តែ ទោះជាឋានៈនៃអត្ថបទទាំងអស់នោះ ធៀបទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិបែបណាក៏ដោយ ក៏សិទ្ធិទាំងឡាយដែលអត្ថបទទាំងនោះលើកឡើងមិនប្រាកដថាត្រូវបានទទួលស្គាល់ថាជាវិធាននៃនីតិព្រហ្មទណ្ឌអន្តរជាតិនោះដែរ។ អង្គជំនុំជម្រះសាលាដំបូងយោងទៅរបាយការណ៍របស់អគ្គលេខាធិការ ដែលលើកឡើងថា "ការអនុវត្តគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង តម្រូវឱ្យតុលាការអន្តរជាតិអនុវត្តវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមួយចំនួន ដែលជាផ្នែកមួយយ៉ាងច្បាស់នៃច្បាប់ទំនៀមទម្លាប់"។ អាស្រ័យដូចនេះ អង្គជំនុំជម្រះមានការរារែកក្នុងការប្រើប្រាស់ជាប្រព័ន្ធនូវច្បាប់ទាំងឡាយពាក់ព័ន្ធនឹងសិទ្ធិមនុស្សសម្រាប់ធ្វើជាមូលដ្ឋាននៃវិធាននីតិព្រហ្មទណ្ឌក្នុងលក្ខណៈដូចវិធានដែលមានចែងនៅក្នុងមាត្រា ៥(១) នៃលក្ខន្តិកៈ"[1160]។

៦៦៩. សាលដីកាសំណុំរឿង ០០២/០១ ហាក់ដូចជាបានធ្វើការសម្របសម្រួលរវាងសេចក្តីសម្រេចទាំងពីរដែលរៀបរាប់ខាងលើ។ ទោះជាសាលដីកានេះយល់ស្របនឹងវិធីសាស្ត្រដែលលើកឡើងក្នុងសាលក្រម *Kupreškić* ដោយបានលើកឡើងថា "អត្ថប្រយោជន៍នៃគោលគំនិតនេះ សម្រាប់កំណត់ល័ក្ខខ័ណ្ឌតម្រូវនៃភាពអាចដឹងជាមុនបាន" និងអាចឱ្យបញ្ចូល "គោលការណ៍តម្រូវនៃអនីត្យានុកូលភាពផ្លូវការជាអន្តរជាតិ" ក៏ដោយ ក៏សាលដីកាបានបញ្ជាក់ថាវាចាំបាច់ផងដែរដែលត្រូវទៅស្វែងរកមើលការហាមឃាត់នៅក្នុងលិខិតុបករណ៍ទាំងអស់នេះ ដែលនេះវាធ្វើឱ្យគេគិតថាសិទ្ធិមនុស្សតែឯកឯងមិនអាចផ្សំធ្វើជាមូលដ្ឋាននៃវិធាននីតិព្រហ្មទណ្ឌបានទេ[1161]។

៦៧០. សរុបសេចក្តីមក គោលការណ៍តម្រូវនៃអនីត្យានុកូលភាពផ្លូវការគឺអាចកំណត់បានតាមរយៈ "[ទំនាក់ទំនងជាវិជ្ជមាន] នៃសិទ្ធិ និងបម្រាម ដូចមានចែងក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស ដែលអនុវត្តបាននៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងបទចោទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត""[1162]។ សហចៅក្រម

---

[1160] សាលក្រម *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៧២១។

[1161] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៤។

[1162] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៤។

ស៊ើបអង្កេតបានយល់ស្របជាមួយនឹងការវិភាគនេះ ក្នុងអំឡុងពេលស៊ើបសួរសំណុំរឿង ០០៣ និង ០០៤[1163]។

៦៧១. តាមរយៈការកម្រិតតែលើការបង្ហាញអំពីការកំណត់អត្តសញ្ញាណសិទ្ធិជាមូលដ្ឋាននៅក្នុងលិខិតុបករណ៍នាសម័យនោះ អង្គជំនុំជម្រះបានបំប្រួញការវិភាគលើលក្ខខ័ណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការ និងជាក់ស្តែង ហើយអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់។ សរុបសេចក្តីមក រាល់សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងច្បាប់អនុវត្តបានចំពោះអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងសាលក្រមដែលរងការជំទាស់ត្រូវទុកជាមោឃៈ។

**មាតិកាទី ៣. កំហុសពាក់ព័ន្ធនឹងការប្រមូលធាតុផ្សំ**

**ជំពូកទី ១. សហករណ៍ និងការដ្ឋានការងារ**

**ផ្នែកទី ១. ត្រាំកក់**

**១. គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល**

៦៧២. ជាលក្ខណៈចម្បង អង្គជំនុំជម្រះមិនត្រូវបានស្នើសុំឱ្យពិនិត្យតាមផ្លូវច្បាប់លើការស្លាប់មនុស្សបណ្តាលមកពីលក្ខខ័ណ្ឌនៃការរស់នៅ ក្រៅឃុំទាំងប្រាំបី[1164] ការស្លាប់ក្រៅពីបណ្តាលមកពីការអត់អាហារ[1165] ការស្លាប់បណ្តាលមកពីការអត់អាហារ[1166] ការស្លាប់បណ្តាលមកពីបញ្ហាសុខភាព និងភាគច្រើនមកពី

---

[1163] ដីកាសម្រេចដែលមានការកោសលុបរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D301/5 កថាខណ្ឌ ៦៣៖ "ការវិភាគខាងលើបង្ហាញថា តុលាការអនុវត្តវិធីសាស្ត្របែបប្រយ័ត្នប្រយែងក្នុងការវាយតម្លៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដើម្បីធ្វើយ៉ាងណាធានាកុំឱ្យរំលោភបំពានគោលការណ៍នីត្យានុកូលភាព។ វិធីសាស្ត្រនេះតែងតែពាក់ព័ន្ធនឹងការយោងយុត្តិសាស្ត្រអន្តរជាតិ និងលិខិតុបករណ៍ច្បាប់ និងសិទ្ធិមនុស្សអន្តរជាតិ ដើម្បីកំណត់និយមន័យ ឬបញ្ជាក់ធាតុផ្សំនៃការប្រព្រឹត្តិ រួមមានធាតុផ្សំសត្យានុម័តិ និងដើម្បីកំណត់ថាតើការប្រព្រឹត្តិនោះមានលក្ខណៈដូចគ្នាទៅនឹងស្ថានភាព និងស្ថានទម្ងន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលោកផ្សេងៗទៀតដែរឬយ៉ាងណា"។

[1164] សូមមើលខាងលើ កថាខណ្ឌ ៣៦៧-៣៧១។

[1165] សូមមើលខាងលើ កថាខណ្ឌ ៣៧៨-៣៧៩។

[1166] សូមមើលខាងលើ កថាខណ្ឌ ៤៤៥-៤៤៧។

ល័ក្ខខ័ណ្ឌរស់នៅ[1167] ការស្លាប់បណ្តាលមកពីការអត់អាហារ ក្រៅឃុំសំរោង និងឃុំតាភេម[1168]។ លើសពីនេះទៅទៀត គេគួររំឭកថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ដោយចេតនាប្រយោល គឺពុំមានអត្ថិភាពទេនៅសម័យកាលនៃអង្គហេតុ ហើយថាអង្គជំនុំជម្រះបាន ប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យផ្ទុយពីនេះ[1169]។ ដូចដែលបានលើកឡើងខាងលើ ដោយពុំ មានភ័ស្តុតាងបង្ហាញអំពីឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល អង្គជំនុំជម្រះបានកំណត់បទចោទឡើងវិញ ដោយខុសច្បាប់ ឱ្យទៅជាបទនៃការធ្វើមនុស្សឃាតដោយចេតនាប្រយោល។ ដូច្នេះ អង្គជំនុំជម្រះបាន ប្រព្រឹត្តកំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្តីសម្រេចរបស់ខ្លួនគ្មានសុពលភាព[1170]។ ជាលក្ខណៈបន្ទាប់ បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ពាក់ព័ន្ធនឹងអំពើអកម្ម "ដែលនាំឱ្យមានពិរុទ្ធ" (១.១) ចេតនាប្រយោល (១.២) និងកំហុសអង្គហេតុបណ្តាលមកពីលក្ខណៈមិនសមហេតុសមផលនៃការកត់ សម្គាល់អង្គហេតុរបស់អង្គជំនុំជម្រះ ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិនៃ ការធ្វើមនុស្សឃាត ដោយចេតនាប្រយោល នៅត្រាំកក់ (១.៣)។

### ១.១. កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអំពើអកម្ម "នាំឱ្យមានពិរុទ្ធ"

៦៧៣. អង្គជំនុំជម្រះបានប្រកាសថា ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើ មនុស្សឃាតនៅសហករណ៍ត្រាំកក់ ត្រូវបានបំពេញ ម្យ៉ាងតាមរយៈ "ការបង្កើតល័ក្ខខ័ណ្ឌដែល បណ្តាលឱ្យមនុស្សស្លាប់" និងម្យ៉ាងទៀត តាមរយៈអំពើអកម្ម នោះគឺ "កង្វះវិធានការសមស្របដើម្បី កែប្រែ ឬកាត់បន្ថយល័ក្ខខ័ណ្ឌទាំងនោះ"[1171]។

៦៧៤. ម្យ៉ាង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនកំណត់តាមផ្លូវគតិយុត្តិនូវប្រភេទ និង វិសាលភាពនៃកាតព្វកិច្ចក្នុងការចាត់វិធានការដែលទម្លាក់ទៅលើចារីផ្ទាល់ ទាក់ទងនឹងការស្លាប់

---

1167 សូមមើលខាងលើ កថាខណ្ឌ ៤៦៥-៤៧០។

1168 សូមមើលខាងលើ កថាខណ្ឌ ៤៧១-៤៧៤។

1169 សូមមើលខាងលើ កថាខណ្ឌ ៥៧៥-៦៣៧។

1170 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៣៨-១១៥៥។ សូមមើលខាងលើ កថាខណ្ឌ ១៣៥-១៥៧។

1171 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤។

បណ្ដាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅកើតឡើងនៅសហការណ៍ត្រាំកក់[1172]។ នៅត្រង់កថាខណ្ឌ ៦២៧ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានរំឭកដោយត្រឹមត្រូវថា "បទឧក្រិដ្ឋមួយអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលនាំឱ្យមានពិរុទ្ធ ក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការ"។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ គឺអាចត្រូវធ្វើឡើងដោយហេតុផលអំពើអកម្ម តែក្នុងពេលដែលបុគ្គលនោះគេចមិនអនុវត្តអំពើមួយ បើទោះជាគាត់ត្រូវជាប់កាតព្វកិច្ចបំពេញក៏ដោយ[1173]។ "ការទទួលខុសត្រូវព្រហ្មទណ្ឌតម្រូវឱ្យមានជាទូទៅនូវអំពើដែលច្បាប់ហាមឃាត់[1174]" ហើយអំពើអកម្មមួយអាចនាំឱ្យមានពិរុទ្ធបាន លុះត្រាតែពាក់ព័ន្ធនឹងអំពើដែលត្រូវបានកំណត់ល័ក្ខខ័ណ្ឌ អនុលោមតាមវិធាននីតិព្រហ្មទណ្ឌប៉ុណ្ណោះ[1175]។ ក្នុងករណីជាក់ស្ដែងនេះ អង្គជំនុំជម្រះពុំបានបញ្ជាក់ថាតើកាតព្វកិច្ចក្នុងការចាត់វិធានការមួយណាត្រូវបានរំលោភ ហើយអនុលោមតាមវិធានអ្វីដែលអាជ្ញាធរស្រុកត្រាំកក់មានកាតព្វកិច្ចក្នុងការចាត់ "វិធានការសមស្របដើម្បីកែប្រែ ឬកាត់បន្ថយល័ក្ខខ័ណ្ឌទាំងនោះ" របស់ប្រជាជនស្រុកត្រាំកក់។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងលក្ខណៈនាំឱ្យមានពិរុទ្ធនៃអំពើអកម្ម ត្រូវបានធ្វើឡើងនៅក្រៅក្របខ័ណ្ឌច្បាប់ទាំងស្រុង និងដោយគ្មានការវិភាគគតិយុត្តិ និងអង្គហេតុឡើយ។ សេចក្ដីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ។

៦៧៥. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអនុវត្តលក្ខណៈវិនិច្ឆ័យពុំត្រឹមត្រូវក្នុងការវាយតម្លៃអំពីអំពើអកម្មនាំឱ្យមានពិរុទ្ធ ដែលកំណត់ធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាត។ អង្គជំនុំជម្រះបានត្រឹមប្រកាសដោយពុំមានការយោងណាមួយទៅលើភស្តុតាងច្បាស់លាស់ ឬការ

---

[1172] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤។

[1173] សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៨៨, សាលដីកា *Galić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៧៥, សាលដីកា *Blaškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៦៣ (ទាក់ទងនឹងការទទួលខុសត្រូវថ្នាក់លើ)។

[1174] សាលដីកា *Blaškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៦៣។

[1175] សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៨៨។

វិភាគគតិយុត្តិណាមួយលើភ័ស្តុតាង ថាអាជ្ញាធរស្រុកត្រាំកក់ជាប់ពិរុទ្ធចំពោះឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ដោយសារ "កង្វះវិធានការសមស្របដើម្បីកែប្រែ ឬកាត់បន្ថយល័ក្ខខ័ណ្ឌទាំងនោះ"[1176]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយពុំបានសំអាងហេតុចំពោះសេចក្ដីសន្និដ្ឋាននេះ។ កង្វះការវិភាគ និងការកំណត់និយមន័យគតិយុត្តិរបស់អង្គជំនុំជម្រះ ក្នុងការផ្ដន្ទាទោស បញ្ជាក់ឱ្យឃើញពីសេចក្ដីលម្អៀងរបស់អង្គជំនុំជម្រះ។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា ធាតុផ្សំសត្យានុម័តិត្រូវបានបំពេញ ពាក់ព័ន្ធនឹងអំពើអកម្មនាំឱ្យមានពិរុទ្ធ ត្រូវទុកជាមោឃៈ[1177]។

## ១.២. កំហុសអង្គច្បាប់ពាក់ព័ន្ធនឹង "ចេតនាប្រយោល"

៦៧៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានប្រកាសថាធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតត្រូវបានបំពេញ ក្រោមទម្រង់ជាចេតនាប្រយោល[1178]។ អង្គជំនុំជម្រះបានត្រឹមលើកឡើងនូវ**សម្មតិកម្ម**មួយពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត។ អង្គជំនុំជម្រះបានត្រឹមវាយតម្លៃថា អាជ្ញាធរស្រុកត្រាំកក់មានចេតនាដាក់ឱ្យអនុវត្តនូវល័ក្ខខ័ណ្ឌទាំងនេះ "ដោយដឹងថាល័ក្ខខ័ណ្ឌទាំងនេះអាចនឹងធ្វើឱ្យមានមនុស្សស្លាប់" ឬ "គាត់ទទួលយកលទ្ធភាពដែលអាចឱ្យស្លាប់មនុស្សនេះ"[1179]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនអាចសំអាងសេចក្ដីប្រកាសពិរុទ្ធភាពលើការរើសយក ក "ឬ" ខ នោះទេ តែត្រូវបង្ហាញឱ្យឃើញឱ្យហួសពីវិមតិសង្ស័យថា ធាតុផ្សំអត្តនោម័តិត្រូវបានបំពេញ។

៦៧៧. អង្គជំនុំជម្រះមិនបានបង្ហាញឱ្យឃើញថា អាជ្ញាធរស្រុកត្រាំកក់បានដឹងថាល័ក្ខខ័ណ្ឌដាក់ឱ្យអនុវត្ត អាចបណ្ដាលឱ្យមនុស្សស្លាប់ ហើយក៏មិនបានបង្ហាញថា អាជ្ញាធរបានទទួលយកលទ្ធភាពដែលល័ក្ខខ័ណ្ឌ

---

[1176] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1177] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៤-១១៤៥។

[1178] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៥។

[1179] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៥។

ទាំងនោះនាំទៅដល់ការស្លាប់នោះទេ[1180]។ ដូច្នេះ អង្គជំនុំជម្រះមិនបានកំណត់ឱ្យបានត្រឹមត្រូវនូវធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ដោយចេតនាប្រយោល។ សេចក្តីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

### ១.៣. លក្ខណៈមិនសមហេតុផលនៃការកត់សម្គាល់ឃើញអំពីអង្គហេតុ

### ១.៣.១. អវត្តមានភស្តុតាងក្នុងកម្រិតតម្រូវនៃការស្លាប់ដែលរងការចោទប្រកាន់

#### *១.៣.១.១. ពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ*

៦៧៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានវាយតម្លៃថា ភស្តុតាងទាំងឡាយបានបង្ហាញឱ្យឃើញអំពីរយៈកាលខ្វះអាហារធ្ងន់ធ្ងរ ដោយអង្គជំនុំជម្រះបានផ្អែកលើរបាយការណ៍មួយក្នុងចំណោមរបាយការណ៍ផ្សេងទៀតរបស់ភូមិភាគនិរតី ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៧[1181]។ ការយោងនេះមិនបានគាំទ្រសេចក្តីកត់សម្គាល់របស់អង្គជំនុំជម្រះដែលថា របាយការណ៍នេះបានជូនដំណឹងថាស្រុក និងឃុំមួយចំនួនជួបគ្រោះទុរ្ភិក្សនោះទេ[1182]។ ឃ្លាដែលពាក់ព័ន្ធតែមួយគត់នៅក្នុងរបាយការណ៍នេះ មិនស្ថិតនៅក្នុងទំព័រដែលចង្អុលប្រាប់ដោយអង្គជំនុំជម្រះទេ តែស្ថិតនៅទំព័របន្ទាប់ ហើយឃ្លានេះបានត្រឹមតែនិយាយបែបលក្ខណៈទូលាយថា នៅតំបន់តាកែវ "បញ្ហាជីវភាពប្រជាជនក៏អាចដោះស្រាយបានទោះបីឃុំខ្លះមានការខ្វះខាត ឬស្រុកខ្លះខ្វះខាតក៏ដោះស្រាយបានដែរ"[1183]។

៦៧៩. លើសពីនេះទៅទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានបញ្ជាក់ថា រៀល សន បានថ្លែងថា ចំនួនអ្នកស្លាប់បានកើនឡើងប្រហែលជានៅពេលជិតដាច់របបនេះ ដោយសារតែការខ្វះចំណី

---

[1180] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៥។

[1181] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២ កំណត់សម្គាល់ជើងទំព័រលេខ៣៨៨០, ៣៨៨១ យោងទៅ កថាខណ្ឌ ១០១៣ កំណត់សម្គាល់ជើងទំព័រលេខ៣២២៦៖ សេចក្តីរាយការណ៍របស់ភូមិភាគនិរតី ជូនអង្គការជាទីគោរពស្នេហា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ១៩៧៧ ឯកសារ **E3/853** ERN 00052827។

[1182] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៣ កំណត់សម្គាល់ជើងទំព័រលេខ៣២២៦៖ សេចក្តីរាយការណ៍របស់ភូមិភាគនិរតី ជូនអង្គការជាទីគោរពស្នេហា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារ **E3/853** ERN 00052827។

[1183] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៣។ សេចក្តីរាយការណ៍របស់ភូមិភាគនិរតី ជូនអង្គការជាទីគោរពស្នេហា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារ **E3/853** ERN 00052828 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

អាហារ[1184]។ ការយោងដែលបានលើកឡើង ពុំបង្ហាញពីកាស្លាប់ណាមួយនោះទេ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមានកំហុសផងដែរ ដោយបានបំភ្លៃសក្ខីកម្មរបស់ នាង អ៊ួច ដែលបាននិយាយថា ការខ្វះខាតអាហារមិនមែនបណ្ដាលមកពីការគ្រប់គ្រងមិនល្អនោះទេ ដែលនេះវាផ្ទុយពីផ្នែកនៃសក្ខីកម្មរបស់គាត់ដែលអង្គជំនុំជម្រះបានយោង[1185]។ ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្អែកលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាំង ស្រីមុំ ដើម្បីកត់សម្គាល់ថា មនុស្សមួយចំនួនស្លាប់ដោយសារហូបមិនគ្រប់គ្រាន់ ព្រោះថារបបអាហារប្រចាំថ្ងៃគឺមិនគ្រប់គ្រាន់[1186]។ ក៏ប៉ុន្តែនេះមិនមែនជាអ្វីដែលស្ដែងចេញតាមរយៈសក្ខីកម្មរបស់គាត់នោះទេ ព្រោះគាត់បាននិយាយពីភាពមិនទៀងទាត់នៃរបបអាហារ និងការលំបាកក្នុងការគ្រប់គ្រងរបបអាហារច្រើន[1187]។

៦៨០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា កម្មករមួយចំនួនបានស្លាប់ដោយសារការលំបាកក្នុងការទទួលបានអាហារ ដោយអង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ ឯក ហឿន[1188]។ សក្ខីកម្មនេះពុំបញ្ជាក់អះអាងថា អ្នកធ្វើការបានស្លាប់នៅតាមការដ្ឋានការងារនៅក្នុងស្រុកត្រាំកក់

[1184] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៣ កំណត់សម្គាល់ជើងទំព័រលេខ៣២២៧ យោងទៅ "ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ (រៀល សន) ឯកសារ **E1/278.1** ទំព័រ ២៩"។

[1185] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៤ កំណត់សម្គាល់ជើងទំព័រលេខ៣២២៨ "ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ (នាង អ៊ួច) ឯកសារ **E1/274.1** ទំព័រ ១០, ១៧-១៨ (ពិភាក្សាថា ការផ្ដល់ពីកន្លែងដែលបានភោគផលខ្ពស់ក៏នៅមិនទាន់គ្រប់គ្រាន់ដែរ", សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៦ កំណត់សម្គាល់ជើងទំព័រលេខ៣២៥៣ "ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ (នាង អ៊ួច) ឯកសារ **E1/274.1** ទំព័រ ៩"។

[1186] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៥ កំណត់សម្គាល់ជើងទំព័រលេខ ៣២៤៨ "ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារ **E1/254.1** ទំព័រ ១០-១១"។

[1187] ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ (ជាំង ស្រីមុំ) ឯកសារ **E1/254.1** ម៉ោង ០៩.៣៤.២២ "ចាស បានន័យថា អ្នកខ្លះស្លាប់ច្រើន -- ស្លាប់ដោយសារការហូបចុកច្រើនពេក អ្នកខ្លះ-- ដូចថាការហូបចុកច្រើនពេក បានន័យថាស្លាប់ហ្នឹង ពេលនោះអាហារប្រចាំថ្ងៃហ្នឹងវាមិនដែលគ្រប់គ្រាន់ ចាស អត់ដែលបានគ្រប់គ្រាន់ទេ។ ដល់តែពេលកម្ម -- មានកម្មវិធីថ្ងៃសាម -- ថ្ងៃ២០ ថ្ងៃ១០ ថ្ងៃ៣០ ហ្នឹង គេធ្វើកម្មវិធីម្ដងៗហ្នឹង ឱ្យហូបសេរី។ ដល់ពេលនោះវាអាហារប្រចាំថ្ងៃហ្នឹងវាមិនដែលបានហូបគ្រប់គ្រាន់ ដល់ទៅពេលហ្នឹងបានថ្ងៃ១០ហ្នឹង បានហូបគ្រប់គ្រាន់មួយពេលហ្នឹងទៅ ដូចថាវាការអត់ខ្លាំងពេកអីចឹងទៅ ដល់ពេលជួបប្រទះអាហារហ្នឹងចេះតែហូប។ ដល់តែហូបទៅវាដូចថាឆ្អាញ់ហួសហេតុពេក អ្នកខ្លះទៅស្ទះជាខ្យល់ ឬមួយបែកក្រពះស្លាប់នៅពេលហ្នឹងចាស នេះជាការពិតចាស" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1188] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥២ កំណត់សម្គាល់ជើងទំព័រលេខ៣៨៨៣ យោងទៅ កថាខណ្ឌ ១០២០។

ដោយសារខ្វះអាហារនោះទេ[1189]។ ការពិតទៅ ផ្នែកដែលលើកយកមកយោងនេះគឺមិនសូវច្បាស់លាស់ទេ ហើយទំនងជាបង្ហាញពីការស្លាប់ នៅការដ្ឋានខ្ទបត្របែក បណ្តាលមកពី "បញ្ហាឫសដូងបាត"[1190]។ នៅត្រង់កថាខណ្ឌ ១០២០ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានប្រើប្រាស់ដោយពុំត្រឹមត្រូវនូវកំណត់ហេតុស្តាប់ចម្លើយរបស់ សឹម ឈៀង ពាក់ព័ន្ធនឹងការស្លាប់មួយកើតឡើងនៅប៉ែនមាស និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលលើកឡើងពីការស្លាប់មនុស្ស នៅឃុំលាយបូរ និងឃុំតាភេម ដើម្បី "ផ្តល់ការបញ្ជាក់យ៉ាងសំខាន់ចំពោះភ័ស្តុតាងដែលបានបង្ហាញ [...] ថា មានការស្លាប់ជាច្រើន នៅក្នុងស្រុកត្រាំកក់"[1191]។ ភ័ស្តុតាងចុងក្រោយទាំងនេះមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ជាចុងក្រោយ នៅត្រង់កថាខណ្ឌ ១០៣៧ ការស្លាប់តែមួយគត់ដែលត្រូវបានបង្ហាញ កើតឡើងនៅឃុំលាយបូរ គឺការស្លាប់កូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន[1192]។

៦៨១. គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានបានថា ការស្លាប់គឺបណ្តាលមកពីរយៈពេលនៃការខ្វះអាហារ ដោយផ្អែកតែលើភ័ស្តុតាងដែលលើកឡើងនៅកថាខណ្ឌ ១០១១-១០១៦, ១០២០ និង ១០៣៧ ដែលមិនអាចបង្ហាញអង្គហេតុឱ្យឃើញហួសពីវិមតិសង្ស័យបាននោះទេ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

### *១.៣.១.២. អំពីការស្លាប់នៅមន្ទីរពេទ្យ ដោយសារកង្វះការថែទាំវេជ្ជសាស្ត្រ*

៦៨២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាតត្រូវបានបំពេញ ទាក់ទងនឹងការស្លាប់នៅមន្ទីរពេទ្យ ដោយសារកង្វះការថែទាំវេជ្ជសាស្ត្រ កង្វះ

---

[1189] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០ កំណត់សម្គាល់ជើងទំព័រលេខ៣២៨១។

[1190] ប្រតិចារឹក ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/298.1** ក្រោយម៉ោង ១៥.៥៥.៥០៖ "ប្រជាជនលើកដី អាខ្លះ ធ្លាក់ក្រសាល់ក្តិត បិទល៉ែងជិត នៅទល់ខោនៅហ្នឹងក៏អត់ គេអត់ថាអីដែរ។ ហើយអ្នកដែលធ្លាក់ក្រសាល់គូទហ្នឹង ក៏អត់ហ៊ានលាន់មាត់ទេ ធ្លាក់រហូតទាល់ស្លាប់។ រែកទៅវាធ្លាក់ក្រសាល់គូទ ហើយហូបអត់គ្រប់គ្រាន់ បបរាវៗ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1191] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០ កំណត់សម្គាល់ជើងទំព័រលេខ៣២៨២។

[1192] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៣៧ កំណត់សម្គាល់ជើងទំព័រលេខ៣៣៧០។ ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ក្រោយម៉ោង ១០.៥៥.២៦។

អាហារូបត្ថម្ភ និងការបាក់កម្លាំង[1193]។ ដើម្បីធ្វើការវិនិច្ឆ័យដូច្នេះបាន អង្គជំនុំជម្រះបានផ្អែកតែទៅលើសក្ខីកម្មរបស់ រៀល សន។ ក៏ប៉ុន្តែ រៀល សន មិនបានបញ្ជាក់ថាការស្លាប់គឺបណ្តាលមកពីកង្វះការថែទាំវេជ្ជសាស្ត្រនោះទេ[1194]។ គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់អាចនិយាយសរុបបែបនេះបាន ដោយពុំមានភស្តុតាងជាក់ស្តែង ដើម្បីឈានទៅធ្វើសេចក្តីសន្និដ្ឋានមួយនេះឡើយ។

## ១.៣.២. គ្មានភស្តុតាងបង្ហាញពីចេតនាប្រយោលចំពោះការស្លាប់បណ្តាលមកពីការអត់អាហារ និងល័ក្ខខ័ណ្ឌរស់នៅ

៦៨៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាតត្រូវបានបំពេញជាក់ស្តែង ក្រោមទម្រង់ជាចេតនាប្រយោល[1195]។ ប៉ុន្តែ អង្គជំនុំជម្រះបានសន្និដ្ឋានថា វាអាចដែរថាកត្តាមួយចំនួនដែលមិនចំណុះឱ្យឆន្ទៈរបស់អាជ្ញាធរ បានចូលរួមចំណែកមួយផ្នែកក្នុងបញ្ហាកង្វះចំណីអាហារ និង/ឬកង្វះធនធានវេជ្ជសាស្ត្រ[1196]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយពុំបានទាញផលវិបាកសមហេតុផលតែមួយគត់ពីសេចក្តីកត់សម្គាល់នេះ។

៦៨៤. ការវាយតម្លៃលើធាតុផ្សំអត្តនោម័តិ ជាការពិនិត្យបែបអត្តនោម័តិ ដោយត្រូវចាប់ផ្តើមពីទស្សនៈរបស់ចារីនៃបទល្មើស។ នៅទីនេះ គេមិនអាចកំណត់បាននូវទំនាក់ទំនងរវាងហេតុ និងផលទេ រវាងវិធានការដែលដាក់ឱ្យអនុវត្តដោយឆន្ទៈរបស់អាជ្ញាធរដើម្បីកសាងប្រទេសឡើងវិញ កត្តាដាច់ដោយឡែកផ្សេងៗដែលកើតឡើង - និងកត្តាដែលមានពីមុន - និងផលប៉ះពាល់របស់វាលើប្រជាជន។ ហេតុដូច្នេះ វាមានភាពមិនច្បាស់លាស់លើកត្តាទាំងឡាយដែលបណ្តាលឱ្យមានមហន្តរាយមនុស្សធម៌ ហើយការទទួលយកហានិភ័យអាស្រ័យលើការវាយតម្លៃខាងលើនេះ។ ចេតនាឧក្រិដ្ឋ ត្រូវវាយតម្លៃមុនការប្រព្រឹត្តិបទឧក្រិដ្ឋ មិនមែនក្រោយនោះទេ។

---

[1193] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤២ កំណត់សម្គាល់ជើងទំព័រលេខ៣៨៨៤ យោងទៅ កថាខណ្ឌ ១០៤៧។

[1194] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៤៧។

[1195] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៥។

[1196] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៥។

៦៨៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយពុំបានវាយតម្លៃភ័ស្តុតាងឱ្យបានច្បាស់លាស់ ទាក់ទងនឹងពេលវេលា។ អង្គជំនុំជម្រះយល់ឃើញថា គឺ "ការបន្តរក្សាល័ក្ខខ័ណ្ឌទាំងនេះក្នុងរយៈពេលយ៉ាងយូររួមទាំងរយៈពេលក្រោយឥទ្ធិពលទាំងនេះមានភាពច្បាស់លាស់" ដែលបង្ហាញឱ្យឃើញអំពីធាតុផ្សំអត្តនោម័តិ ក្នុងករណីជាក់ស្តែងនេះ[1197]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានបង្ហាញឱ្យឃើញពីការបំពេញបាននូវធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិ នៅពេលណាមួយទាក់ទងនឹងការស្លាប់បណ្តាលមកពីល័ក្ខខ័ណ្ឌរស់នៅក្នុងស្រុកត្រាំកក់។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចធ្វើសេចក្តីសន្និដ្ឋានបែបនេះបានទេ ដោយពុំមានភ័ស្តុតាងនោះ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការបំពេញបាននូវធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ត្រូវទុកជាមោឃៈ។

## ២. កំហុសដោយបានសន្និដ្ឋានថាមានការនិរទេសជនជាតិវៀតណាម

៦៨៦. ជាលក្ខណៈចម្បង សូមរំឭកថា អង្គជំនុំជម្រះទទួលបានបណ្តឹងខុសច្បាប់អំពី អង្គហេតុដែលជាធាតុផ្សំនៃការនិរទេស ដែលហាមឃាត់រាល់ការផ្តន្ទាទោសទាក់ទងនឹងអង្គហេតុនេះ[1198]។ យ៉ាងណាមិញ ក្រៅពីកំហុសអង្គច្បាប់នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការនិរទេសខ្លួន ត្រូវបានប្រព្រឹត្តឡើង "ចំពោះប្រជាជនវៀតណាមចំនួនយ៉ាងច្រើន ដែលត្រូវបណ្តេញចេញពីស្រុកត្រាំកក់ ហើយបញ្ជូនទៅប្រទេសវៀតណាម ដោយគ្មានការយល់ព្រមពីពួកគេនៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦"[1199]។ ដោយសារតែបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់បែបនេះ អង្គជំនុំជម្រះអាចយល់ឃើញថា ធាតុផ្សំពីរនៃឧក្រិដ្ឋកម្មត្រូវបានបំពេញ៖ ធាតុផ្សំសត្យានុម័តិដែលតម្រូវឲ្យមានការជម្លៀសប្រជាជនចេញពីព្រំដែនជាតិ (២.១) និងចេតនាជម្លៀសជនរងគ្រោះដោយបង្ខំ ឱ្យទៅនៅម្ខាងទៀតនៃព្រំដែនជាតិ (២.២)។

---

[1197] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៩៥។

[1198] សូមមើលខាងលើ កថាខណ្ឌ ៣៨០-៣៨៥។

[1199] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៩។

## ២.១. កំហុសដោយបានសន្និដ្ឋានថាជនរងគ្រោះពិតជាបានឆ្លងព្រំដែនប្រទេស

៦៨៧. ដើម្បីឱ្យឧក្រិដ្ឋកម្មនៃការនិរទេសអាចត្រូវបានបង្ហាញ ជនរងគ្រោះត្រូវតែបានផ្លាស់ទីទៅម្ខាងទៀតនៃព្រំដែនជាតិ[1200]។ អង្គជំនុំជម្រះយល់ឃើញថា ធាតុផ្សំនេះត្រូវបានបំពេញ ដោយបានថ្លែងថា ខ្លួនជឿជាក់ថា "ប្រជាជនវៀតណាមមួយចំនួនដែលត្រូវបានប្រមូលនៅស្រុកត្រាំកក់ បានឆ្លងព្រំដែនអន្តរជាតិ និងត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម"[1201]។

៦៨៨. ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើន ដើម្បីអាចទាញសេចក្តីសន្និដ្ឋានមួយនេះបាន។ អង្គជំនុំជម្រះមិនត្រឹមតែពុំបានផ្តល់សំអាងហេតុដល់សេចក្តីសម្រេចរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ប៉ុណ្ណោះទេ (២.១.១) តែការវិភាគលើភ័ស្តុតាងទាំងអស់ គឺពុំបានបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ពិតជាបានឆ្លងកាត់ព្រំដែនវៀតណាមប្រាកដមែននោះទេ (២.១.២)។ លើសពីនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសមួយចំនួន ដោយបានប្រើប្រាស់ភ័ស្តុតាងបានមកពីការធ្វើទារុណកម្ម (២.១.៣) និងដោយបានផ្អែកមួយផ្នែកធំលើភ័ស្តុតាងក្រៅវិសាលភាពនៃរឿងក្តី (២.១.៤)។

### ២.១.១. គ្មានសំអាងហេតុ

៦៨៩. ការវិនិច្ឆ័យរបស់អង្គជំនុំជម្រះនៅក្នុងការកំណត់ប្រភេទបទល្មើស គឺលំបាកក្នុងការតាមដាន[1202]។ ការភ្ជាប់គ្នានៃសេចក្តីសន្និដ្ឋានផ្ទុយគ្នា ធ្វើឱ្យមានការយល់ពុំច្បាស់លាស់លើមូលដ្ឋានទាំងឡាយដែលអង្គជំនុំជម្រះយកមកធ្វើជាសំអាង ដើម្បីបង្ហាញឱ្យឃើញពីធាតុផ្សំនៃឧក្រិដ្ឋកម្ម។ ភាពមិនច្បាស់លាស់នេះអាចត្រូវបានឃើញច្បាស់ណាស់ នៅពេលដែលត្រូវបង្ហាញឱ្យឃើញថាមានរឿងអ្វីកើតឡើងចំពោះជន

---

[1200] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៨១។

[1201] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

[1202] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៧-១១៥៩។

ជាតិវៀតណាមនៅស្រុកត្រាំកក់ និងនៅពេលចង់ដឹងថាតើពួកគេពិតជាបានឆ្លងព្រំដែនវៀតណាមពិតប្រាកដដែរឬទេ។

៦៩០. ជាបឋម អង្គជំនុំជម្រះបានវិនិច្ឆ័យថាមានការបង្ហាញឱ្យឃើញថា ជនជាតិវៀតណាម "បានបាត់ខ្លួននៅក្នុងស្រុកត្រាំកក់"។ អង្គជំនុំជម្រះបានសន្និដ្ឋានដែរថា មានការណែនាំឱ្យសម្លាប់ជនជាតិវៀតណាម "ក្នុងអំឡុងពេលដែលពួកគេត្រូវបានបង្ខំឱ្យចាកចេញពីស្រុក"។ អង្គជំនុំជម្រះបានបន្តថា ថ្នាក់ស្រុក "បានធ្វើការណែនាំឱ្យសម្លាប់ និងបោសសម្អាតប្រជាជនវៀតណាម" ហើយថា "ប្រជាជនវៀតណាមជាច្រើននាក់ត្រូវបានប្រមូលនៅក្នុងស្រុកត្រាំកក់ ពីចុងឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៦"[1203]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានពន្យល់ថា ភ័ស្តុតាងមិនអាចឱ្យធ្វើការសន្និដ្ឋានបានថាមានការសម្លាប់ជនជាតិវៀតណាមនោះទេ។ ទន្ទឹមគ្នានោះដែរ អង្គជំនុំជម្រះបានអះអាងថា៖

> "អង្គជំនុំជម្រះក៏មិនមានភ័ស្តុតាងដើម្បីឱ្យខ្លួនអាចដឹងឱ្យបានច្បាស់លាស់ ពីជោគវាសនារបស់ប្រជាជនវៀតណាមដែលត្រូវបានប្រមូលនៅក្នុងពេលនោះដែរ"[1204]។

៦៩១. អង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងដែលអាចឱ្យដឹងបានអំពីអ្វីដែលបានកើតឡើងចំពោះជនជាតិវៀតណាមដែលត្រូវបានប្រមូលនៅក្នុងស្រុកត្រាំកក់ គឺ "កង្វះភ័ស្តុតាង"[1205]។ ប៉ុន្តែ ដោយគ្មានការភ្ជាប់រឿង គ្មានការពន្យល់ អង្គជំនុំជម្រះបានសន្និដ្ឋានថា៖

> "[...] អង្គជំនុំជម្រះជឿជាក់ថា ការសន្និដ្ឋានប្រកបដោយហេតុផលតែមួយគត់ពីភ័ស្តុតាងជារួម គឺថា យ៉ាងហោចណាស់ ប្រជាជនវៀតណាមយ៉ាងច្រើន ត្រូវបានបង្ខំឱ្យទៅរស់នៅក្នុងប្រទេសវៀតណាមវិញ ដូចបានបញ្ជាក់តាមរយៈការវាយតម្លៃរបស់អង្គជំនុំជម្រះ ដោយផ្អែកលើទស្សនាវដ្ដីទង់បដិវត្ត ច្បាប់ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ និងទឡ្ហីករណ៍របស់អង្គជំនុំ

[1203] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៧។

[1204] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

[1205] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

ជម្រះទាក់ទងនឹងការដោះដូរដែលមាននៅពេលនោះ ដោយខ្មែរក្រោមបានទៅដល់ស្រុកត្រាំកក់ ជំនួសប្រជាជនវៀតណាមដែលបានចាកចេញពីស្រុកនេះ។ ចំណុចនេះធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ប្រជាជនវៀតណាមមួយចំនួនដែលត្រូវបានប្រមូលនៅស្រុកត្រាំកក់ បានឆ្លងព្រំដែនអន្តរជាតិ និងត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម"[1206]។

៦៩២. ការវិនិច្ឆ័យបែបនេះនាំឱ្យមានការអល់អែក។ ប្រសិនបើភ័ស្តុតាងមិនអាចឱ្យកំណត់បានថាមានរឿងអ្វីកើតឡើងចំពោះ "ជនជាតិវៀតណាមដែលត្រូវបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់លាស់" នៅក្នុងស្រុកត្រាំកក់ផង ចុះហេតុដូចម្តេចទើបអាចសន្និដ្ឋានបាន ដោយផ្អែកលើភ័ស្តុតាងដដែលៗទាំងនោះ ថាជនជាតិវៀតណាមមួយចំនួនធំត្រូវបានបណ្តេញចេញទៅប្រទេសវៀតណាម។ ទស្សនាវដ្តីទង់បដិវត្តចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ និងភ័ស្តុតាងទាក់ទងនឹងការដោះដូររវាងខ្មែរក្រោម និងជនជាតិវៀតណាម ត្រូវបានយោងយ៉ាងច្បាស់។ ក៏ប៉ុន្តែ បើតាមអង្គជំនុំជម្រះ ភ័ស្តុតាងទាំងនោះគឺបានត្រឹមតែ "បញ្ជាក់" "ទាញការសន្និដ្ឋាន" នោះប៉ុណ្ណោះ។ អង្គជំនុំជម្រះពុំបានបង្ហាញភ័ស្តុតាងដែលអាចឱ្យខ្លួន "ទាញការសន្និដ្ឋាន" នេះបាន។ ភាពមិនស៊ីចង្វាក់គ្នារបស់អង្គជំនុំជម្រះ បានឈានដល់ចំណុចកំពូលនៅចុងបញ្ចប់នៃការវិភាគរបស់ខ្លួនលើភ័ស្តុតាងទាំងអស់៖

> "អង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងខាងលើបញ្ជាក់ថា ជនជាតិវៀតណាមជាច្រើនត្រូវបានប្រមូលផ្តុំក្នុងស្រុកត្រាំកក់ ចាប់ពីចុងឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៦ ដោយពួកគេជាច្រើនត្រូវបានបញ្ជូនចេញ និង/ឬបាត់ខ្លួន[1207]"។

៦៩៣. សេចក្តីសន្និដ្ឋានដូចគ្នានេះ ត្រូវបានទាញចេញក្នុងពេលកំណត់ប្រភេទបទល្មើសសម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំនៅត្រាំកក់[1208]។ ការប្រើប្រាស់អាយតនិបាតពីរត្រួតគ្នា ដែលធ្វើឱ្យមានជម្រើសរវាងវាក្យសម្ព័ន្ធពីរ ឬត្រូវជ្រើសយកទាំងពីរ បង្ហាញឱ្យឃើញពីភាព

[1206] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

[1207] សំអាងហេតុសាលក្រម កថាខណ្ឌ ១១២៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1208] សំអាងហេតុសាលក្រម កថាខណ្ឌ ១២០១។

មិនប្រាកដប្រជារបស់អង្គជំនុំជម្រះ។ ភាពមិនច្បាស់លាស់នេះ ពុំមានតួនាទីអ្វីនៅក្នុងសេចក្ដីសន្និដ្ឋាន គតិយុត្តិមួយចំនួនដែលនាំទៅដល់ការប្រកាសអំពីពិរុទ្ធភាព ខៀវ សំផន នោះទេ។ តាមរយៈការធ្វើដូច្នេះ អង្គជំនុំជម្រះបានរំលោភលើគោលការណ៍ *in dubio pro reo* ដែលចែងថា វមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

៦៩៤. ដូច្នេះ អង្គជំនុំជម្រះគួរតែសន្និដ្ឋានថា ខ្លួនមិនអាចបង្ហាញឱ្យឃើញពីធាតុផ្សំនៃបទឧក្រិដ្ឋដែលថា ជនរងគ្រោះត្រូវបានផ្លាស់ទីឱ្យហួសព្រំដែនប្រទេសបានទេ។ ដោយពុំបានផ្ដល់សំអាងហេតុ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ គួរត្រូវបានដកចេញ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការនិរទេសជនជាតិវៀតណាម នៅត្រាំកក់។

## ២.១.២. សេចក្ដីសន្និដ្ឋានពុំត្រឹមត្រូវលើការបណ្ដេញជនជាតិវៀតណាមក្នុងចំនួនច្រើន

៦៩៥. ភស្តុតាងទាំងអស់ដែលត្រូវបានវិភាគដោយអង្គជំនុំជម្រះ គឺមិនបានបង្ហាញឱ្យឃើញនូវអ្វីដែលអង្គជំនុំជម្រះចង់បង្ហាញនោះទេ នោះគឺជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ត្រូវបានផ្លាស់ទីហួសពីព្រំដែនវៀតណាម។ សក្ខីកម្មនានាដែលបង្ហាញពីការប្រមូលជនជាតិវៀតណាមនៅស្រុកត្រាំកក់ មិនអាចឱ្យដឹងបានថាមានអ្វីកើតឡើងចំពោះអ្នកទាំងនោះឡើយ (២.១.២.១)។ ដោយហេតុថា ភស្តុតាងផ្សេងទៀតដែលត្រូវបានវិភាគ ពុំបានផ្ដល់ការបំភ្លឺបន្ថែមណាមួយទាក់ទងនឹងជោគវាសនារបស់អ្នកទាំងនោះ អង្គជំនុំជម្រះបានផ្អែកតែទៅលើភស្តុតាងទេសកាល ដើម្បីសន្និដ្ឋានលើជោគវាសនារបស់ជនជាតិវៀតណាមនៅត្រាំកក់ (២.១.២.២)។

### *២.១.២.១. ការមិនដឹងពីជោគវាសនារបស់ជនជាតិវៀតណាមដែលត្រូវបានប្រមូលនៅក្នុងស្រុកត្រាំកក់*

៦៩៦. ផ្ទុយពីការអះអាងរបស់អង្គជំនុំជម្រះ ដំណើរការមាតុភូមិនិវត្តន៍របស់ជនជាតិវៀតណាមដែលបង្ហាញដោយ ពេជ្រ ជឹម ពុំបានប្រព្រឹត្តទៅ នៅក្រោយខែមេសា ឆ្នាំ១៩៧៥[1209] តែនៅឆ្នាំ១៩៧២ ទៅវិញទេ។

[1209] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១០ កំណត់សម្គាល់ជើងទំព័រលេខ៣៧០៧។

នេះជាអ្វីដែលសាក្សីបានពន្យល់ នៅពេលមេធាវីការពារក្ដីសុំឱ្យគាត់បញ្ជាក់ថា តើដំណើរការមាតុភូមិនិវត្តន៍ដែលត្រូវបានលើកមកពិភាក្សាក្នុងអំឡុងពេលសួរដេញដោលដោយសហព្រះរាជអាជ្ញា បានកើតឡើងនៅឆ្នាំ១៩៧៥ មែនដែរឬទេ៖

> "សូមបញ្ជាក់ ខ្ញុំនិយាយវាព័ន្ធខ្លះដែរ។ ពេលសភាពគេដក វៀតណាមដកហ្នឹង ៧២ គឺមុនរំដោះ មិនមែនក្រោយ៧៥ទេ ដែលវៀតណាមដក យើងកាលនោះអង្គការឱ្យទាក់ទងឱ្យវៀតណាមដកចេញទៅវិញនោះ គឺក្នុង៧២ ឆ្នាំ៧២ មិនចាំខែទេ"[1210]។

៦៩៧. ប៉ុន្តែ ការបញ្ជាក់នេះស៊ីចង្វាក់គ្នាជាមួយចម្លើយពីមុនរបស់សាក្សី ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា។ ពេជ្រ ជឹម ពន្យល់ថា នាសម័យនោះ មានទាហានវៀតណាមនៅគ្រប់ទីកន្លែងក្នុងស្រុកត្រាំកក់ ហើយដោយមានការព្រមព្រៀងគ្នារវាងប្រទេសវៀតណាម និង ប.ក.ក ទាហានទាំងអស់នោះ ត្រូវបានបញ្ជូនទៅស្រុកកំណើតវិញ ក្នុងរយៈពេលពីរយប់[1211]។ អង្គជំនុំជម្រះខ្លួនឯងក៏បានកត់សម្គាល់ថា ការបញ្ជូនទាហានវៀតណាមត្រឡប់ទៅស្រុកកំណើតវិញ កើតមានឡើងនៅក្នុងរង្វង់ឆ្នាំ១៩៧២[1212]។ ដូច្នេះ ការពន្យល់របស់ ពេជ្រ ជឹម គឺអាចជឿជាក់បាន និងបានជួយបញ្ជាក់បន្ថែម។

៦៩៨. ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រើប្រាស់ដោយទុច្ចរិត និងបានបំភ្លៃសក្ខីកម្មរបស់សាក្សី ដើម្បីដាក់ដំណើរការមាតុភូមិនិវត្តន៍ឱ្យទៅនៅក្រោយខែមេសា ឆ្នាំ១៩៧៥។ អង្គជំនុំជម្រះវាយតម្លៃថា ដំណើរការមាតុភូមិនិវត្តន៍នេះ កើតឡើងក្រោយខែមេសា ឆ្នាំ១៩៧៥ ជាពិសេស ព្រោះថា យាយខុម និង ជន បានចូលរួមក្នុងដំណើរការនោះដែរ[1213]។ ក៏ប៉ុន្តែ ការយោងទាំងឡាយទៅលើសក្ខីកម្មរបស់ ពេជ្រ ជឹម ពុំបានគាំទ្រការអះអាងមួយនេះទេ។ ការពិតទៅ សាក្សីបានពន្យល់ថា ការងាររបស់ ខុម និង ជន គឺត្រូវរាប់ចំនួនអ្នកភៀសខ្លួន ឬអ្នកភៀសសឹកទាំងអស់ដែលមកដល់ក្នុងស្រុក[1214]។

---

[1210] ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/292.1** ប្រហែលម៉ោង ១៣.៥៧.១១។

[1211] ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចន្លោះម៉ោង ១០.៣០.៥៩ និង ១០.៥៧.១៦។

[1212] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨៣។

[1213] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១០។ សូមមើលផងដែរ កំណត់សម្គាល់ជើងទំព័រលេខ៣៧០៧។

[1214] ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចន្លោះម៉ោង ១០.៤២.១៥ និង ១០.៥៧.១៦។

៦៩៩. លើសពីនេះទៀត អង្គជំនុំជម្រះបានព្យាយាមប្រើប្រាស់វត្តមានរបស់យាយខុមនៅក្នុងស្រុក ដើម្បីធ្វើការសន្និដ្ឋានថា មាតុភូមិនិវត្តន៍ធ្វើឡើងក្រោយខែមេសា ឆ្នាំ១៩៧៥[1215]។ ផ្ទុយទៅវិញ គេមិនត្រូវភ្លេចទេថា ចាប់ពីឆ្នាំ១៩៧០ មក ស្រុកត្រាំកក់គឺជាតំបន់រំដោះ ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម[1216]។ យាយខុម មានវត្តមាននៅក្នុងស្រុករួចទៅហើយ និងកាន់តួនាទីជាលេខាស្រុក នៅមុនខែមេសា ឆ្នាំ១៩៧៥[1217]។ យោងតាមភ័ស្តុតាងទាំងនេះ ចៅក្រមប្រកបដោយវិចារណញ្ញាណ គួរសម្រេចថាសក្ខីកម្មទាំងឡាយរបស់ ពេជ្រ ជឹម ពាក់ព័ន្ធនឹងការបញ្ជូនជនជាតិវៀតណាមទៅស្រុកកំណើតវិញ នាឆ្នាំ១៩៧២ គឺមានភាពស៊ីចង្វាក់គ្នា។ ដូច្នេះ សេចក្តីសន្និដ្ឋានផ្ទុយរបស់អង្គជំនុំជម្រះ គួរត្រូវដកចេញ។

៧០០. សក្ខីកម្មរបស់ ឯក ហឿន មានភាពមិនច្បាស់លាស់។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានលើកឡើងថា ការស្តាប់ចម្លើយរបស់គាត់ មិនអាចឱ្យគេបែងចែកឱ្យដាច់ពីគ្នារវាងបទបញ្ជាឱ្យសម្លាប់ជនជាតិវៀតណាម និងបទបញ្ជាឱ្យផ្លាស់ទីអ្នកទាំងនោះបានទេ[1218]។ ជាការពិតណាស់ មានការលើកឡើងថា

---

[1215] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១០។

[1216] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/289.1** ម៉ោងប្រហែល ១៥.០៨.០១, ជាំង ស្រីមុំ៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ចន្លោះម៉ោង ០៩.២៥.៣៦ និង ០៩.២៩.៣៩, ពេជ្រ ជឹម៖ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ **E3/9587** ស/ឆ ៣, ៧។ ខឹម ហឿន៖ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E319/12.3.2** ស/ឆ ៧។

[1217] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/289.1** ម៉ោងប្រហែល ១៥.០៨.០១ (ពេជ្រ ជឹម ពន្យល់ថាគាត់ជាសមាជិកត្រៀមរបស់បក្ស នៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៧០ ហើយជាសមាជិកពេញសិទ្ធិនៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧១។ ពិធីបញ្ចូលក្នុងបក្សធ្វើឡើងនៅស្រុកត្រាំកក់ ដោយមានវត្តមានរបស់គារ និង ខុម ប្រធានបក្សស្រុក), ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចន្លោះម៉ោង ១៣.៤៩.១០ និង ១៣.៥៥.០៣, ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/292.1** ម៉ោងប្រហែល ០៩.១៦.២៤, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ **E3/4626** ERN 00373467 ("ក្រោយរំដោះឆ្នាំ១៩៧៥ ខុម នៅជាលេខាស្រុក ១០៥ រហូតដល់ដើមឆ្នាំ១៩៧៦") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម), ខឹម ហឿន៖ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E3/9480** ស/ឆ ២៨៤ ("ឈ្មោះ ខុម ធ្វើជាគណៈស្រុកយូរហើយ តាំងពីខ្ញុំនៅធ្វើការភូមិម្លេះ")។

[1218] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១១។

សាក្សីបានឃើញគេប្រមូលជនជាតិវៀតណាមទាំងឡាន១។ ប៉ុន្តែ គាត់បានឃើញអ្នកទាំងនោះចេញទៅតាមផ្លូវមួយ បញ្ច្រាសពីទិសដៅទៅព្រំដែន[1219]។

៧០១. សាន់ ឡូន បានផ្តល់សក្ខីកម្មថាបានចូលរួមដោយផ្ទាល់ក្នុងដំណើរការប្រមូលជនជាតិវៀតណាមដាក់ឡាន។ ប៉ុន្តែ អង្គជំនុំជម្រះបានបញ្ជាក់ថា គាត់ពុំបានដឹងពីអ្វីដែលកើតឡើងចំពោះអ្នកទាំងអស់ ដែលគាត់ប្រគល់ទៅឱ្យកងឈ្លបស្រុកនោះទេ ហើយគាត់បានបញ្ជាក់ថាលែងបានឃើញអ្នកទាំងនោះទៀត[1220]។ អង្គជំនុំជម្រះបានប្រើប្រាស់អត្ថបទដកស្រង់មួយចេញពីសៀវភៅកំណត់ត្រាក្រាំងតាចាន់ ដើម្បីព្យាយាមបញ្ជាក់ថាប្រតិបត្តិការប្រមូលជនជាតិវៀតណាមដែល សាន់ ឡូន លើកឡើង បានប្រព្រឹត្តទៅនៅដើមឆ្នាំ១៩៧៦។ ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះមិនគួរប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មមួយនេះទេ[1221]។ លើសពីនេះទៅទៀត អត្ថបទដកស្រង់ដែលត្រូវបានប្រើ ("កាលពីខែមករា ឆ្នាំ១៩៧៦ អង្គការបានសម្រេចបញ្ជូនខ្លួនពួកយួនទៅស្រុកវាវិញ")[1222] គឺពុំបានជួយគាំទ្រថា ជនជាតិវៀតណាមដែលបានបង្ហាញដោយ សាន់ ឡូន ពិតជាបានឆ្លងព្រំដែនវៀតណាមប្រាកដមែននោះទេ។ ព័ត៌មានទូទៅដូច្នេះ មិនអាចប្រើដើម្បីសន្និដ្ឋានពីជោគវាសនារបស់ជនជាតិវៀតណាម ដោយឡែក នៅត្រាំកក់បានទេ។

៧០២. សាក្សី ជាំង ស្រីមុំ បានបង្ហាញថាមានការប្រមូល "ជនជាតិវៀតណាមមួយចំនួន ឬមនុស្សដែលបានធ្វើពុតជាជនជាតិវៀតណាម" ក្នុងឃុំញ៉ែងញ៉ង នៅពេលដែលអង្គការស្រាវជ្រាវរកជនជាតិវៀតណាម ដើម្បីបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ[1223]។ ការប្រើប្រាស់អាយតនិបាត "ឬ" បង្ហាញឱ្យឃើញថាមិនមានភាពច្បាស់លាស់ណាមួយ ទាក់ទងនឹងការដឹងថា តើសាក្សីបាននិយាយពីជនជាតិវៀតណាម ឬពីអ្នកដែលធ្វើពុតជាជនជាតិវៀតណាម ដែលទាំងនេះវាបង្កើតឱ្យមានជាបញ្ហាដើម្បីបង្ហាញឱ្យឃើញថាមានបទឧក្រិដ្ឋចំពោះជនជាតិវៀតណាម។ លើសពីនេះទៀត តាមរយៈសក្ខីកម្មរបស់សាក្សី គឺពុំមាន

[1219] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១២។

[1220] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៤។

[1221] សូមមើល ខាងលើ កថាខណ្ឌ ២៨៩-២៩០។

[1222] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៥។

[1223] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ការបង្ហាញឱ្យឃើញថាពួកអ្នកដែលគាត់និយាយថាបានឡើងឡាន ពិតជាបានឆ្លងព្រំដែនប្រាកដមែននោះទេ។ អង្គជំនុំជម្រះបានបញ្ជាក់ថា យោងតាមសាក្សី អ្នកទាំងឡាយដែលត្រូវបានប្រមូល និងដឹកតាមឡាន គឺធ្វើដំណើរសំដៅតម្រង់ឆ្ពោះទៅភ្នំ មិនមែនទៅប្រទេសវៀតណាមទេ[1224]។

៧០៣. ជូ គីមឡុន បានឮសេចក្តីប្រកាសនៅក្នុងភូមិរបស់គាត់ ដើម្បីប្រមូលជនជាតិវៀតណាម និងបញ្ជូនពួកគេត្រឡប់ទៅស្រុកពួកគេវិញ។ សក្ខីកម្មនេះមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត ព្រោះថាវាផ្អែកលើការឮគេនិយាយ ដែលមិនស្គាល់ប្រភពច្បាស់លាស់[1225]។ អង្គជំនុំជម្រះបន្ថែមថា បើតាមសាក្សី មានជនជាតិវៀតណាមមួយគ្រួសារ និងប្រជាជនខ្មែរក្រោមម្នាក់ បាន "ធ្លាក់ចូលក្នុង "ល្បិចពិសពុល" នេះ"[1226]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះពុំបានពន្យល់ថា តើសក្ខីកម្មមួយមិនច្បាស់លាស់បែបនេះ អាចបង្ហាញជាភ័ស្តុតាងនៃការនិរទេសណាមួយបានដូចម្តេចទៅ។ ចំណែក រៀល សន វិញ គាត់បានលើកឡើងពីការបាត់ខ្លួនជនជាតិវៀតណាម ដោយពុំបានដឹងអ្វីឱ្យលើសពីនេះ[1227]។ ចំណែកឯ ផាន់ ឆេន អង្គជំនុំជម្រះទទួលស្គាល់ថា សក្ខីកម្មរបស់គាត់មិនអាចឱ្យកំណត់បានថា មានរឿងអ្វីកើតឡើងចំពោះជនជាតិវៀតណាម ទាំងទាហាន ឬជនស៊ីវិល បានទេ[1228]។

៧០៤. ការវិភាគនេះបង្ហាញឱ្យឃើញថា ភ័ស្តុតាងទាំងអស់ប្រើប្រាស់ដោយអង្គជំនុំជម្រះ មិនអាចឱ្យកំណត់បានថា ជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ពិតជាបានឆ្លងព្រំដែនវៀតណាមប្រាកដមែននោះទេ។ ភ័ស្តុតាងមួយចំនួន ថែមទាំងអាចឱ្យគេគិតបានផងដែរថា ជនជាតិវៀតណាមមួយចំនួនត្រូវបានបញ្ជូនទៅតាមទិសដៅបញ្ច្រាសពីផ្លូវទៅព្រំដែនទៀតផង។ គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់ អាចទាញសេចក្តីសន្និដ្ឋានចេញពីភ័ស្តុតាងទាំងអស់នេះថា ការនិរទេសជនជាតិវៀតណាមទៅប្រទេសវៀតណាម គឺជា "ការសន្និដ្ឋាន" សមហេតុផលតែមួយគត់ដែលអាចធ្វើបាននោះ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវតែបដិសេធចោល។

[1224] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៦។
[1225] សូមមើលខាងលើ កថាខណ្ឌ ៣១២-៣១៣។
[1226] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៦។
[1227] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៧។
[1228] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៧។

៧០៥. ប្រឈមនឹងកង្វះភ័ស្តុតាងផ្ទាល់នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើភ័ស្តុតាងទេសកាលមួយចំនួន ដូចជាទស្សនាវដ្ដីទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ និងភ័ស្តុតាងពាក់ព័ន្ធនឹងការដោះដូររវាងប្រជាជនវៀតណាម និងប្រជាជនខ្មែរក្រោម ដើម្បីសន្និដ្ឋានថា ជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ត្រូវបានផ្លាស់ទីឆ្លងព្រំដែនវៀតណាម។

### *២.១.២.២. ការសន្និដ្ឋានពង្រីក តាមរយៈភ័ស្តុតាងទេសកាល*

៧០៦. អង្គជំនុំជម្រះបានបំភ្លៃអត្ថន័យរបស់ទស្សនាវដ្ដីទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ ដោយបានសន្និដ្ឋានថា "ការបកស្រាយដ៏សមហេតុផលតែមួយនោះ គឺការលើកឡើងពី "ជនបរទេស" បានសំដៅទៅជនជាតិវៀតណាមដែលមានវត្តមាននាពេលកន្លងមកនៅក្នុងប្រទេសកម្ពុជា"[1229]។ ក៏ប៉ុន្តែ បើបានអានអត្ថបទទាំងស្រុងវិញ ទស្សនាវដ្ដីនេះពន្យល់ថា បញ្ហាគឺមានជាយូរមកហើយ "វណ្ណៈជិះជាន់" បានលក់ដីឱ្យបរទេស ហើយ "ចលនាខ្មែរក្រហម" បានតស៊ូដោយបានទទួលជ័យជម្នះលើ "ពួកចក្រពត្តិ"[1230]។ ផ្នែកបន្ទាប់មកទៀតបរិយាយថា ចលនាបានបណ្ដេញជនបរទេសរាប់សែននាក់ចេញពីប្រទេស[1231]។ ជាពិសេស មានការលើកឡើងថា បញ្ហាត្រូវបានដោះស្រាយជាពិសេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[1232] គឺមានន័យថាជាថ្ងៃដែលខ្មែរក្រហមចូលដល់ក្រុងភ្នំពេញ។ គេបានដឹងថា មុន

---

[1229] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៨ កំណត់សម្គាល់ជើងទំព័រលេខ៣៧៥០ យោងទៅ កថាខណ្ឌ ៣៤១៦ (មេធាវីការពារក្តីកត់សម្គាល់ថា ការយោងនេះមិនត្រឹមត្រូវទេ ព្រោះវាមិនមានការបង្ហាញណាមួយអំពីការបកស្រាយលើអត្ថបទដកស្រង់ចេញពីទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ ដែលលើកឡើងនោះទេ។ ផ្ទុយទៅវិញ ការបកស្រាយនេះ មាននៅក្នុងកថាខណ្ឌ ៣៣៨៧-៣៣៨៨។

[1230] ទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062749។

[1231] ទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062749 "[អានពុំបាន] ជាមួយចក្រពត្តិ ហើយដោយវិធីត្រឹមត្រូវ តាមគោលការណ៍បដិវត្តរបស់យើង។ គឺមហាចលនា មហាព្យុះសង្ឃរាប្រជាជាតិ និងមហាព្យុះសង្ឃរានៃបដិវត្តប្រជាធិបតេយ្យរបស់យើង បានបោសសម្អាតជនបរទេសទាំងនេះ រាប់សែននាក់ ឱ្យចេញផុតពីប្រទេសយើង ពីទឹកដីយើងទាំងអស់ជាស្ថាពរ"។

[1232] ទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062748 "ប៉ុន្តែ បដិវត្តរបស់យើង ហើយពិសេស ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ បានដោះស្រាយបញ្ហាយ៉ាងស្អាត ហើយដោះស្រាយទាំងមូល"។

ការមកដល់របស់ពួកខ្មែរក្រហម ជនជាតិបរទេសជាច្រើនបានរស់នៅក្នុងទីក្រុង ក្នុងចំណោមអ្នកទាំងនោះមាន ជនជាតិអាមេរិកាំង អឺរ៉ុប ជាដើម។ អ្នកដែលមិនទាន់បានភៀសខ្លួន ត្រូវបានប្រមូលផ្តុំនៅស្ថានទូតបារាំង ហើយត្រូវបណ្តេញចេញពីប្រទេស។ ដូច្នេះ ចៅក្រមមានវិចារណញ្ញាណគួរតែពិចារណាលើព្រឹត្តិការណ៍អង្គហេតុទាំងអស់នេះ ដើម្បីបកស្រាយទស្សនាវដ្តីទង់បដិវត្ត។

៧០៧. លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើមតិយោបល់របស់អ្នកជំនាញ Alexander HINTON ដើម្បីបកស្រាយទស្សនាវដ្តីទង់បដិវត្ត[1233]។ យោបល់របស់គាត់មិនអាចមានភាពពាក់ព័ន្ធបានទេ ព្រោះគាត់មាន "ជំនាញ" ខាង ស្រាវជ្រាវផ្នែកនរវិទ្យា និងជាតិពន្ធុសាស្ត្រឯណោះទេ។ ម្យ៉ាងវិញទៀត ការសិក្សារបស់គាត់ផ្តោតទៅលើ "បទពិសោធន៍រស់នៅជាក់ស្តែងរបស់ប្រជាជននៅក្នុងភូមិរបស់ពួកគេ" ក្នុងតំបន់ ៤១ តែមួយគត់[1234]។ ការបកស្រាយលើទស្សនាវដ្តីទង់បដិវត្ត មិនត្រឹមតែមិនស្ថិតក្នុងផ្នែកជំនាញរបស់គាត់ប៉ុណ្ណោះទេ តែលើសពីនេះទៀតនោះ ក្រសែភ្នែកផ្តោតលើអំពើប្រល័យពូជសាសន៍ ដែលគាត់យកមកពិភាក្សាលើភ័ស្តុតាងនានា បានធ្វើឱ្យប៉ះពាល់យ៉ាងច្បាស់ដល់លទ្ធភាពរបស់គាត់ក្នុងការវិភាគបែបសត្យានុម័តិ[1235]។ ជាងនេះទៅទៀត អង្គជំនុំជម្រះបានរំឭកថា ទស្សនាវដ្តីទង់បដិវត្ត គឺជាឯកសារឃោសនា ដែលមានភាពជឿទុកចិត្តបានតិចបំផុត[1236]។ អង្គជំនុំជម្រះពិចារណាដោយប្រយ័ត្នប្រយែងបំផុត នៅពេលទស្សនាវដ្តីទាំងនោះមានធាតុផ្សំដោះបន្ទុក ដោយពុំបានគិត ក្នុងករណីច្បាស់លាស់នេះ ដល់ការពន្លើសពាក្យពេចន៍ និងការបកស្រាយផ្សេងៗទៀតដែលអាចមាន។

៧០៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសផងដែរ ដោយបានសន្និដ្ឋានថា ការវិភាគលើទស្សនាវដ្តីទង់បដិវត្ត "ស៊ីចង្វាក់គ្នាជាមួយនឹងភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងទម្រង់ និងការបណ្តេញជនជាតិ

---

1233 សូមមើលខាងក្រោម កថាខណ្ឌ ១០៧០-១០៧៦, ១៨៩៥-១៨៩៧។

1234 ប្រតិចារឹក ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/403.1** ម៉ោង ០៩.២៤.០៩ ចន្លោះម៉ោង ១៥.១៦.១៨ និង ១៥.២០.៣០ និងមុនម៉ោង ១៥.៣២.២០។

1235 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ២២២៦-២២៣១។

1236 សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥។

វៀតណាមនៅទូទាំងប្រទេសពីកម្ពុជា ក្នុងឆ្នាំ១៩៧៥ និង ១៩៧៦ ផងដែរ"[1237]។ ការពិតទៅ ការយោងរបស់អង្គជំនុំជម្រះ គឺសំដៅទៅសេចក្តីសន្និដ្ឋានតែមួយគត់នៃការនិរទេស នៅក្នុងស្រុកព្រៃវែង។ ដូច្នេះ គេនៅឆ្ងាយពី "ទម្រង់ថ្នាក់ជាតិ"។ លើសពីនេះទៀត ដូចដែលនឹងឃើញនៅខាងក្រោម ភ័ស្តុតាងទាំងអស់មិនអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ជនជាតិវៀតណាមនៅព្រៃវែង ត្រូវបាននិរទេសទៅប្រទេសវៀតណាម នោះទេ[1238]។

៧០៩. ក្រៅពីកំហុសទាំងអស់នេះ សេចក្តីសន្និដ្ឋានមួយចំនួន ដែលមានលក្ខណៈទូទៅដូចគ្នា ក្នុងកម្រិត "ជាតិ" (ឬក៏នៅតែក្នុងខេត្តព្រៃវែងមួយគត់)[1239] គឺមិនគ្រប់គ្រាន់សម្រាប់បង្ហាញឱ្យឃើញពីអ្វីដែលកើតឡើងចំពោះអ្នកផ្សេងៗទៀត នៅកន្លែងផ្សេងបានទេ។ បើទោះជាត្រូវទទួលស្គាល់ថា ជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង ត្រូវបាននិរទេសក៏ដោយ ក៏វាពុំមែនជាភ័ស្តុតាងបង្ហាញថា ជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ត្រូវបាននិរទេសដូចគ្នាដែរនោះទេ។ ដោយពុំមានភ័ស្តុតាងគ្រប់គ្រាន់ អង្គជំនុំជម្រះមិនអាចប្រើប្រាស់ទស្សនាវដ្តីទង់បដិវត្ត ឆ្នាំ១៩៧៦ ធ្វើជាភ័ស្តុតាងបង្ហាញថា ជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ បានឆ្លងព្រំដែនវៀតណាមប្រាកដមែននោះទេ។ សេចក្តីសន្និដ្ឋានមិនសមហេតុនេះ ត្រូវតែដកចេញ។

៧១០. ការវិភាគលើភ័ស្តុតាងនៃការដោះដូរជនជាតិវៀតណាមជាមួយនឹងខ្មែរក្រោម គឺមិនត្រឹមតែស្ថិតនៅក្រៅវិសាលភាពនៃរឿងក្តីទេ[1240] តែក៏មិនអាចបង្ហាញឱ្យឃើញថា ជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ ពិតជាត្រូវបាននិរទេសទៅប្រទេសវៀតណាមនោះដែរ។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មខ្មែរក្រោមដែលមកពីប្រទេសវៀតណាម ហើយដែលត្រូវបានបញ្ជូនឱ្យទៅនៅក្នុងស្រុកត្រាំកក់។ ទោះជាអ្នកទាំងនោះបាននិយាយពីការវិលត្រឡប់របស់ខ្លួនមកកាន់ប្រទេសកម្ពុជា នៅក្នុងក្របខ័ណ្ឌនៃការដោះដូរយ៉ាងណា

---

[1237] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1238] សូមមើលខាងក្រោម កថាខណ្ឌ ៨៨២។

[1239] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៨ កំណត់សម្គាល់ជើងទំព័រលេខ៣៧៥១ យោងទៅ កថាខណ្ឌ ៣៤៣៣ (កថាខណ្ឌនេះរៀបរាប់តែពីករណីនិរទេសជនជាតិវៀតណាម នៅក្នុងខេត្តព្រៃវែង)។

[1240] សូមមើលខាងលើ កថាខណ្ឌ ១២០-១២៥។

ក្តី តែសម្រាប់អ្នកផ្សេងទៀត ព័ត៌មានដែលពួកគេបានផ្តល់ឱ្យ គឺផ្អែកលើអ្វីដែលគេនិយាយប្រាប់[1241]។ ភ័ស្តុតាងពុំបានបង្ហាញថា ជនជាតិវៀតណាមមកពីស្រុកត្រាំកក់ ពិតជាបានឆ្លងព្រំដែនវៀតណាម ប្រាកដមែននោះទេ។ រី ពៅ បានថ្លែងថាមិនបានឃើញជនជាតិវៀតណាមធ្វើដំណើរឆ្លងកាត់ នៅត្រង់ព្រំដែនវៀតណាម[1242]។ តាក សាន់ ក៏ពុំបានពិពណ៌នាអ្វីដែរត្រង់ចំណុចនេះ ក្នុងពេលគាត់ផ្តល់សក្ខីកម្ម[1243]។ បេង បឿន បាននិយាយអំពីជនជាតិវៀតណាមមួយគ្រួសារ ដែលបានចាកចេញពីស្រុកត្រាំកក់ តែគាត់មិនដឹងថាតើគ្រួសារនោះពិតជាត្រូវបានបញ្ជូនទៅប្រទេសវៀតណាមវិញ ឬអត់[1244]។ ថាន់ ធីម គ្រាន់តែបានឮគេនិយាយពីកម្មវិធីដោះដូរ តែគាត់ពុំបានឃើញទេ[1245]។

៧១១. អង្គជំនុំជម្រះបានវិភាគផងដែរលើបញ្ជី និងសេចក្តីរាយការណ៍មួយចំនួនស្តីពីខ្មែរក្រោមដែលមកដល់ស្រុកត្រាំកក់ នៅឆ្នាំ១៩៧៧[1246]។ ភ័ស្តុតាងជាឯកសារនេះ បានមកពីប័ណ្ណសារស្រុកត្រាំកក់ ដែលតម្លៃជាភ័ស្តុតាងរបស់វា ត្រូវបានជំទាស់[1247]។ ទោះយ៉ាងណាក៏ដោយ ភ័ស្តុតាងនេះអាចត្រឹមបង្ហាញឱ្យឃើញថាខ្មែរក្រោមបានមករស់នៅក្នុងស្រុកត្រាំកក់ប៉ុណ្ណោះ។ ដោយពុំមានភ័ស្តុតាងផ្ទាល់ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ គឺមិនសមហេតុសមផល ហើយដូច្នេះ ត្រូវតែដកចេញ។

---

[1241] រី ពៅ៖ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** មុនម៉ោង ០៩.២៥.00 ("បាទតាំងពីសម័យនោះ ពួកខ្មែរក្រហមហ្នឹង គេបានទំនាក់ទំនងបញ្ហា។ ធម្មតាមន្ត្រីរាជការ ខ្ញុំមិនដឹងតិចនិករបស់គេទេ ប៉ុន្តែក្រោយមកបានមន្ត្រីរបស់វៀតណាមហ្នឹងប្រាប់ថាបងប្អូនខ្មែរត្រូវវិលត្រឡប់ទៅភូមិកំណើតវិញ ដោយសារមានការដោះដូរ")។ បេង បឿន៖ ប្រតិចារឹក ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/287.1** ក្រោយម៉ោង ១៤.៤២.២៩ ("ខ្ញុំនៅចាំឆ្នាំមិនបានទេ។ គ្រាន់តែខ្ញុំនៅផ្ទះជិតនឹងវៀតណាមម្នាក់ទាំងប្តីទាំងប្រពន្ធហ្នឹងនៅជិតគ្នា។ ហើយក៏ពេលនោះ គេថាអង្គការនឹងបញ្ជូនបងប្អូនវៀតណាមទៅស្រុកវិញ មិនឮថា ផ្លាស់ប្តូរទេ"), ថាន់ ធីម៖ ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/289.1** ក្រោយម៉ោង ០៩.៣៩.២៥ ("បាទ ខ្ញុំធ្លាប់តែឮទេ អត់បានឃើញផ្ទាល់ទេបាទ អត់បានឃើញផ្ទាល់ទេ")។

[1242] រី ពៅ៖ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** មុនម៉ោង ០៩.៣១.៤២ ("បាទ ពេលនោះ ក្រោយការដោះដូរហើយ គ្រាន់តែឆ្លងព្រំដែនហើយ គេបិទច្រកចេញ គេអត់ឱ្យឆ្លងកាត់ទេ")។

[1243] ប្រតិចារឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1**។

[1244] ប្រតិចារឹក ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/287.1** ក្រោយម៉ោង ១៤.៤២.២៩។

[1245] ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/289.1** ក្រោយម៉ោង ០៩.៣៩.២៥។

[1246] សំអាងហេតុសាលក្រម កថាខណ្ឌ ១១២២-១១២៤។

[1247] សូមមើលខាងលើ កថាខណ្ឌ ៣២០-៣២៤។

## ២.១.៣. ការប្រើប្រាស់ភស្តុតាងបានមកពីទារុណកម្ម

៧១២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រើប្រាស់អត្ថបទដកស្រង់មួយចេញពីសៀវភៅកំណត់ត្រាក្រាំងតាចាន់ ដែលផ្ទុកព័ត៌មានមួយថា "កាលពីខែមករា ឆ្នាំ១៩៧៦ អង្គការបានសម្រេចបញ្ជូនជនជាតិយួនត្រឡប់ទៅស្រុកវិញ"[1248]។ ឯកសារនេះផ្ទុកទៅដោយសេចក្តីកត់ត្រានៃការសួរចម្លើយមួយចំនួនរបស់មន្ទីរសន្តិសុខក្រាំងតាចាន់ ដែលអង្គជំនុំជម្រះយល់ឃើញថា វាមានហានិភ័យពិតប្រាកដមួយដែលថាមានការប្រើទារុណកម្ម[1249]។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះយល់ឃើញថា បញ្ជី ឬសៀវភៅកត់ត្រាទាំងឡាយដែលបានមកពីតាមមន្ទីរសន្តិសុខនានា អាចអនុញ្ញាតឱ្យប្រើបាន "[ក្នុងល័ក្ខខ័ណ្ឌដែលឯកសារទាំងនោះ] មានផ្ទុកគំនិត និងមតិរបស់អ្នកធ្វើទារុណកម្ម"[1250]។

៧១៣. ទោះបីជាសេចក្តីសម្រេចនេះពុំត្រឹមត្រូវក៏ដោយ[1251] ក៏ការអានឯកសារនេះ មិនអាចឱ្យគេដឹងបានថាតើអត្ថបទដកស្រង់ដែលយកមកយោង ត្រូវគ្នានឹង "គំនិត" ឬ "មតិរបស់អ្នកធ្វើទារុណកម្ម" នៅក្រាំងតាចាន់ ឬមួយក៏ត្រូវគ្នាទៅនឹងព័ត៌មានដែលទាញចេញពីចម្លើយសារភាពរបស់អ្នកទោសដែរឬទេ។ ប៉ុន្តែ វាក្យស័ព្ទប្រើប្រាស់ជាទូទៅនៅក្នុងកំណត់ត្រាទាំងអស់នោះ[1252] បង្ហាញឱ្យឃើញថា ភាគច្រើនជា

---

[1248] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៥។

[1249] សេចក្តីសម្រេច ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៧៩។

[1250] សេចក្តីសម្រេច ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E350/8** កថាខណ្ឌ ៨៧។

[1251] សូមមើលខាងលើ កថាខណ្ឌ ២៥៨-២៩០។

[1252] សៀវភៅកំណត់ត្រាក្រាំងតាចាន់ គ្មានកាលបរិច្ឆេទ ឯកសារ **E3/5827** ERN 00270855 ("ចុចសួរទៅ វាឆ្លើយថា"), ERN 00270856 ("សារភាព") (ពីរដង), ERN 00270876 ("អាក្បត់នេះវាបានសារភាព អំពើក្បត់របស់វា មានដូចខាងក្រោមនេះ"), ERN 00270879 ("សារភាព ជាសកម្មភាពក្បត់មានគ្នាបីនាក់"), ERN 00270880 ("សារភាពថា"), ERN 00270883 ("ឥឡូវនេះយើងបានចាប់មកហើយ ហើយបានសួរចម្លើយវា"), ERN 00270887 ("អានេះវាសារភាពថា វាខ្ចិលធ្វើការងារណាស់"), ERN 00872829 ("បើតាមការសារភាពរបស់អ្នកបង្ហាញពីខាងលើ"), ERN 00270872 ("តាមការសួរបញ្ជាក់នូវចម្លើយអាសេង ពីបញ្ហាឈ្មោះឈៀង"), ERN 00270895 ("តាមការសាកសួរសាចុះសាឡើងរកខ្សែរយៈ តើដឹងពីណាទៅ"), ERN 00270896 ("សារភាព")។

ចម្លើយអ្នកទោស ដែលត្រូវបានប្រើប្រាស់ដើម្បីបង្ហាញការពិតនៃព័ត៌មានដែលត្រូវបានហាមឃាត់[1253]។ គួររំឭកថា នៅពេលសួរដេញដោល វង សារុន ចៅក្រម FENZ ធ្លាប់បានជំទាស់រួចមកហើយទៅនឹងការប្រើប្រាស់ឯកសារនេះ ដោយសារថាប្រហែលជាបានមកពីអំពើទារុណកម្ម[1254]។ សាក្សី វង សារុន ដែលមានចម្លើយរបស់ខ្លួននៅក្នុងឯកសារនោះ បានបញ្ជាក់ថាពិតជាដូច្នោះមែន[1255]។ ប្រធានអង្គជំនុំជម្រះខ្លួនឯង បានបង្គាប់ឱ្យសហព្រះរាជអាជ្ញាកុំចោទសំណួរទាក់ទងនឹងខ្លឹមសារនៃឯកសារនេះ[1256]។ ផ្ទុយនឹងជំហររបស់ខ្លួន អង្គជំនុំជម្រះបានប្រើប្រាស់ព័ត៌មានដែលមានលទ្ធភាពច្រើនថាបានមកពីការធ្វើទារុណកម្ម ដើម្បីធ្វើការបញ្ជាក់។ ឯកសារនេះត្រូវតែដកចេញជាដាច់ខាត។

## ២.១.៤. ការប្រើប្រាស់ភ័ស្តុតាងក្រៅវិសាលភាព

៧១៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានផ្អែកមួយផ្នែកធំលើភ័ស្តុតាងពាក់ព័ន្ធនឹងការដោះដូររវាងជនជាតិវៀតណាម និងប្រជាជនខ្មែរក្រោម នៅស្រុកត្រាំកក់[1257]។ ប្រសិនបើអង្គជំនុំជម្រះធ្លាប់បានរំឭកដោយត្រឹមត្រូវថា ខ្លួនមិនត្រូវបានស្នើឱ្យពិនិត្យលើអង្គហេតុដែលជាធាតុផ្សំនៃបទឧក្រិដ្ឋទាំងឡាយប្រឆាំងនឹងខ្មែរក្រោមផងនោះ[1258] ហេតុដូច្នេះ អង្គជំនុំជម្រះមិនគួរចាត់ទុកភ័ស្តុតាងនេះថាមានភាពពាក់ព័ន្ធសម្រាប់បទចោទប្រកាន់ផ្សេងៗទៀតនោះទេ ជាពិសេស សម្រាប់ឧក្រិដ្ឋកម្មនៃការនិរទេសជនជាតិវៀតណាម[1259]។ ដូចដែលបានឃើញពីខាងលើ ជំហរនេះពុំត្រឹមត្រូវទេ[1260]។ ដូច្នេះ រាល់ភ័ស្តុតាងទាំងអស់ទាក់ទងនឹងដំណើរមកដល់របស់ខ្មែរក្រោមនៅក្នុងស្រុកត្រាំកក់ គួរតែត្រូវ

---

[1253] សេចក្តីសម្រេច ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 កថាខណ្ឌ ៧៧។

[1254] ប្រតិចារឹក ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ E1/300.1 ម៉ោងប្រហែល ១១.២១.៥១។

[1255] ប្រតិចារឹក ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ E1/300.1 ក្រោយម៉ោង ១១.២៩.៣៥។

[1256] ប្រតិចារឹក ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ E1/300.1 ចន្លោះម៉ោង ១១.២១.៥១ និង ១១.២៩.៣៥ ("ការតាំងសំណួរចៀសវាងឱ្យសួរពាក់ព័ន្ធជាមួយនឹងសារធាតុ")។

[1257] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១៩-១១២៤ និង ១១៥៨។

[1258] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨៥។

[1259] សំអាងហេតុសាលក្រម កថាខណ្ឌ ៨១៦។

[1260] សូមមើលខាងលើ កថាខណ្ឌ ១២០-១២៥។

ដកចេញ។ ដោយសារវាមានសារៈសំខាន់ក្នុងការបង្ហាញឱ្យឃើញថា ជនជាតិវៀតណាមនៅស្រុកត្រាំកក់ ពិតជាបានឆ្លងព្រំដែនប្រាកដមែន កំហុសអង្គច្បាប់នេះធ្វើឱ្យសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះគ្មានសុពលភាព ដែលត្រូវតែកែតម្រូវ។

## ២.២. កំហុសពាក់ព័ន្ធនឹងចេតនាជម្លៀសជនរងគ្រោះដោយបង្ខំ ឱ្យទៅម្ខាងទៀតនៃព្រំដែនជាតិ

៧១៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានថា “មានការបញ្ជាក់ពីចេតនាខ្លាំងក្នុងការបញ្ជូនប្រជាជនទាំងនោះឱ្យហួសព្រំដែនកម្ពុជា”[1261]។ ក្នុងការកំណត់ប្រភេទបទល្មើស អង្គជំនុំជម្រះបានសន្និដ្ឋានថា៖

> “យ៉ាងហោចណាស់ ប្រជាជនវៀតណាមយ៉ាងច្រើន ត្រូវបានបង្ខំឱ្យទៅរស់នៅក្នុងប្រទេសវៀតណាមវិញ ដូចបានបញ្ជាក់តាមរយៈការវាយតម្លៃរបស់អង្គជំនុំជម្រះ ដោយផ្អែកលើទស្សនាវដ្ដីទង់បដិវត្ត ច្បាប់ចេញផ្សាយនៅខែមេសា ឆ្នាំ១៩៧៦ និងទឡ្ហីករណ៍អង្គជំនុំជម្រះទាក់ទងនឹងការដោះដូរដែលមាននៅពេលនោះ ដោយខ្មែរក្រោមបានទៅដល់ស្រុកត្រាំកក់ ជំនួសប្រជាជនវៀតណាមដែលបានចាកចេញពីស្រុកនេះ។ ចំណុចនេះធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ប្រជាជនវៀតណាមមួយចំនួនដែលត្រូវបានប្រមូលនៅស្រុកត្រាំកក់ បានឆ្លងព្រំដែនអន្តរជាតិ និងត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម ហើយថាមានការបញ្ជាក់ពីចេតនាខ្លាំងក្នុងការបញ្ជូនប្រជាជនទាំងនោះឱ្យហួសព្រំដែនកម្ពុជា”[1262]។

៧១៦. អង្គជំនុំជម្រះបានផ្អែកលើភ័ស្តុតាងដែលដើម្បីបង្ហាញឱ្យឃើញពីធាតុផ្សំសត្យានុម័តិដែលថា មនុស្សទាំងអស់ត្រូវតែបញ្ជូនចេញឱ្យហួសព្រំដែនប្រទេសមួយ។ ក៏ប៉ុន្តែ ដូចអ្វីដែលទើបតែត្រូវបានលើកឡើង សេចក្ដីសន្និដ្ឋាននេះ គ្មានសំអាងហេតុ និងមិនអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យបានទេ[1263]។ លើសពី

---

[1261] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

[1262] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

[1263] សូមមើលខាងលើ កថាខណ្ឌ ៦៨៧-៦៨៨។

នេះទៀត អង្គជំនុំជម្រះមិនបានពន្យល់ថា តើភ័ស្តុតាងណាខ្លះដែលអាចឱ្យខ្លួនសន្និដ្ឋានថាមានចេតនាបែបនេះ។

៧១៧. ផ្ទុយទៅវិញ អង្គជំនុំជម្រះ "យល់ឃើញថា ថ្នាក់ស្រុកបានធ្វើការណែនាំឱ្យសម្លាប់ និងបោសសម្អាតប្រជាជនវៀតណាម ក្នុងអំឡុងពេលដែលពួកគេត្រូវបានបង្ខំឱ្យចាកចេញពីស្រុក"[1264] ហើយថា "ភ័ស្តុតាងបង្ហាញពីការណែនាំយ៉ាងច្បាស់លាស់ឱ្យសម្លាប់ប្រជាជនវៀតណាម ពីថ្នាក់ស្រុក"[1265]។ ការកត់សម្គាល់ទាំងអស់នេះបង្ហាញឱ្យឃើញចេតនាសម្លាប់ ជាជាងចេតនាជម្លៀស។ ប្រឈមនឹងភាពផ្ទុយគ្នានេះ និងដោយសារគ្មានសំអាងហេតុ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងធាតុផ្សំអត្តនោម័តិគួរត្រូវដកចេញ។

៧១៨. **សេចក្តីសន្និដ្ឋាន** - កំហុសអង្គហេតុ និងអង្គច្បាប់ដែលទើបត្រូវបានអធិប្បាយ មានទម្ងន់ធ្ងន់ណាស់នៅក្នុងការផ្តន្ទាទោស ខៀវ សំផន ដោយសារថាវាបានរារាំងនូវការបំពេញបាននូវធាតុផ្សំពីរនៃបទឧក្រិដ្ឋនៃការនិរទេស។ កំហុសទាំងនេះបានបង្កឱ្យមានយុត្តិនិសេធយ៉ាងច្បាស់។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវតែដកចេញ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការនិរទេសជនជាតិវៀតណាម នៅក្នុងស្រុកត្រាំកក់[1266]។

## ៣. គ្មានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ

## ៣.១. គ្មានការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៧១៩. សូមរំឭកថា ជាលក្ខណៈចម្បង អង្គជំនុំជម្រះមិនទទួលបានបណ្តឹងជាក់ស្តែងអំពីអង្គហេតុដែលត្រូវបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះអតីតទាហាន និងអតីតអ្នករដ្ឋ

[1264] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៧។

[1265] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

[1266] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១០-១១២៥, ១១៥៧-១១៥៩, ៤០០៤, ៤២៣៧, ៤២៧១, ៤២៩២, ៤៣០៦។

ការនៃរបបសាធារណរដ្ឋខ្មែរ នៅក្រៅឃុំទាំងប្រាំបី[1267] អង្គហេតុនៃការតាមដាន និងការបាត់ខ្លួនអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[1268] និងលើអង្គហេតុក្រៅពីការកម្រិត "សិទ្ធិនយោបាយ" មួយចំនួននោះទេ[1269]។

៧២០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានកំណត់ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងដោយបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មនេះត្រូវបានបង្ហាញ[1270]។ អង្គជំនុំជម្រះបានសំអាងសេចក្ដីសន្និដ្ឋានរបស់ខ្លួនដោយពុំត្រឹមត្រូវ លើការដែលថា ចាប់ពីខែមេសា និងខែឧសភា ឆ្នាំ១៩៧៧ អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានក្លាយជាគោលដៅនៃការចាប់ខ្លួន និងការសម្លាប់។ ភស្តុតាងដាក់បន្ទុកទាំងឡាយដែលត្រូវបានអធិប្បាយនៅកថាខណ្ឌ ១០៦២, ១០៦៣, ១០៨១, ១០៨៣ និង ២៨១៣ នៃសំអាងហេតុសាលក្រម មានតម្លៃភស្តុតាងតិចតួចបំផុត ដែលគ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់ អាចទាញសេចក្ដីសន្និដ្ឋានបែបនេះបានឡើយ[1271]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយពុំបានកត់សម្គាល់អំពីអវត្តមាននៃភស្តុតាងដែលមានតម្លៃគ្រប់គ្រាន់ ពាក់ព័ន្ធនឹងបទបញ្ជាក្នុងការស្រាវជ្រាវរកចាប់ខ្លួនអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ (៣.១.១) និងប្រតិបត្តិការសម្លាប់រងការចោទប្រកាន់ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ នៅត្រាំកក់ (៣.១.២)។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើការយោងពុំត្រឹមត្រូវទៅផ្នែកពាក់ព័ន្ធនឹងក្រាំងតាចាន់ (៣.១.៣)។

### ៣.១.១. គ្មានភស្តុតាងអំពីបទបញ្ជាឱ្យស្រាវជ្រាវរកចាប់ខ្លួនអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

[1267] សូមមើលខាងលើ កថាខណ្ឌ ៣៦៧-៣៦៩, ៣៧២-៣៧៣។

[1268] សូមមើលខាងលើ កថាខណ្ឌ ៤៥១-៤៥៧។

[1269] សូមមើលខាងលើ កថាខណ្ឌ ៤៧៥-៤៨១។

[1270] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៨។

[1271] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៥ កំណត់សម្គាល់ជើងទំព័រលេខ៣៩៩៤ យោងទៅកថាខណ្ឌ ១០៦២, ១០៦៣, ១០៨០, ១០៨១ និងផ្នែក ១២.៣៖ មន្ទីរសន្តិសុខក្រាំងតាចាន់ កថាខណ្ឌ ២៨១៣។

៧២១. នៅត្រង់កថាខណ្ឌ ១០៦២ នៃសំអាងហេតុសាលក្រម ចៅក្រមបានប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ពាក់ព័ន្ធនឹងវគ្គរៀនសូត្រនយោបាយខ្លីមួយ ដែលគាត់បានចូលរួមក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលនៅពេលនោះ មេបញ្ជាការវរសេនាតូចរបស់គាត់ បានប្រកាសថា អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នឹងមិនត្រូវលើកលែងឱ្យទេ[1272]។ ជាបឋម ភ័ស្តុតាងនេះស្ថិតនៅក្រៅវិសាលភាពនៃរឿងក្តី ព្រោះថា វគ្គរៀនសូត្រនេះបានប្រព្រឹត្តធ្វើនៅក្នុងស្រុកកោះអណ្តែត ដែលមិនទាក់ទងអ្វីសោះជាមួយស្រុកត្រាំកក់[1273]។ បន្ទាប់មក ចម្លើយនេះគ្មានតម្លៃជាភ័ស្តុតាងសោះឡើយ មិនមែនត្រឹមតែដោយសារកាលបរិច្ឆេទនៃវគ្គរៀនសូត្រនយោបាយនេះមិនត្រូវបានគេស្គាល់នោះទេ[1274] តែ សេង សឿន ក៏បានបញ្ជាក់ថែមទៀតដែរថា គាត់ពុំបានដឹងថាបាវ ធ្វើដោយចិត្តឯង ឬក៏គាត់ទទួលបានការណែនាំឱ្យធ្វើ[1275]។

៧២២. សក្ខីកម្មទីពីរសម្រាប់គាំទ្រសេចក្តីសន្និដ្ឋាននេះ គឺសក្ខីកម្មរបស់ រៀល សន។ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់គាត់អាចឱ្យគេសន្និដ្ឋានបានថា មេឃុំ និងមេភូមិផ្សេងៗបានទទួលបញ្ជាឱ្យស្រាវជ្រាវរកអតីតទាហាន ចាប់ពីថ្នាក់ព្រីន្ទបាលទោឡើង ឬអតីតនគរបាល ចាប់ពីនាយរងទី១ ឡើងទៅ ហើយត្រូវ "បោសសម្អាត" ពួកគេ ក្នុងកិច្ចប្រជុំមួយនៅឆ្នាំ១៩៧៦ ឬក្រោយមកទៀត[1276]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមានកំហុស ដោយមិនបានទាញផលវិបាកចេញពីភាពផ្ទុយគ្នារបស់សាក្សី ពាក់ព័ន្ធនឹងកាលបរិច្ឆេទនៃការប្រជុំរងការចោទប្រកាន់ ដែលអង្គជំនុំជម្រះក៏បានធ្វើការកត់សម្គាល់លើភាពផ្ទុយគ្នានេះ

[1272] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៦២ កំណត់សម្គាល់ជើងទំព័រលេខ៣៥១៣។

[1273] ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោងប្រហែល ១០.៥០.៥៥ និង ១០.៥៩.១៥។

[1274] កាលបរិច្ឆេទគឺពិតជាសំខាន់ ព្រោះគេគួររំឭកថា នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានវិនិច្ឆ័យថា "ភ័ស្តុតាងនៃការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅចន្លោះពីចុងខែមេសា ដល់ខែឧសភា ឆ្នាំ១៩៧៥ មានមូលដ្ឋានខ្សោយ លើកលែងតែពាក់ព័ន្ធទៅនឹងការសម្លាប់នៅក្នុងខេត្តបាត់ដំបង ទួលពោធិ៍ជ្រៃ និងសៀមរាប ព្រមទាំងការសម្លាប់មួយចំនួនទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ"។ សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩០៤។

[1275] ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោងប្រហែល ១០.៥៤.១២។

[1276] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៦២ កំណត់សម្គាល់ជើងទំព័រលេខ៣៥១៧៖ "ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ (រៀល សន) ឯកសារ **E1/279.1** ទំព័រ ៥២-៥៤ ទំព័រ ៥៥-៥៧ ទំព័រ ៦៧"។

ដែរ[1277]។ ដោយពុំមានកាលបរិច្ឆេទច្បាស់លាស់ ប្រឈមនឹងការមិនអាចមានកាលប្រវត្តិមួយ និងការចងចាំស៊ីចង្វាក់គ្នាពីការប្រជុំនេះ សក្ខីកម្មរបស់ រៀល សន គឺគ្មានតម្លៃជាភ័ស្តុតាង[1278]។ ដោយធ្វើការអានបែបជ្រើសរើសលើសក្ខីកម្មរបស់គាត់ ដើម្បីអាចទាញការសន្និដ្ឋានថា សាក្សីមានការចងចាំ "ច្បាស់លាស់" ដោយសារថានាសម័យនោះគាត់ជាតំណាងមន្ទីរពេទ្យស្រុក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ តាមរយៈការរំលោភលើគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[1279]។

៧២៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយបានអះអាងថា សក្ខីកម្មរបស់ រៀល សន "ស៊ីចង្វាក់គ្នា" នឹងខ្លឹមសារនៃទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយខែកញ្ញា-តុលា ឆ្នាំ១៩៧៦ ដែលបានលើកឡើងអំពី "ជម្លោះស្លាប់រស់"[1280]។ អង្គជំនុំជម្រះពុំបានផ្តល់ការវិភាគណាមួយ និងពុំបានពន្យល់ន័យនៃសំនួនវោហារ "ជម្លោះស្លាប់រស់" ដែលឃ្លាតចេញពីបរិបទរបស់វាថែមទៀត។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងទាំងអស់នេះថា ជំហរមិនព្យាបាទចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានប្រែប្រួលចាប់ពីឆ្នាំ១៩៧៦[1281]។ ដូច្នេះ សេចក្តីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ។

## ៣.១.២. គ្មានភ័ស្តុតាងអំពីប្រតិបត្តិការសម្លាប់ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ នៅស្រុកត្រាំកក់

[1277] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៦២៖ "ពេលខ្លះភ័ស្តុតាងរបស់ រៀល សន បានផ្តល់ពេលវេលាជាក់លាក់នៃកិច្ចប្រជុំនេះ។ នៅពេលមួយ គាត់ហាក់ដូចជាប៉ាន់ប្រមាណថា កិច្ចប្រជុំនេះបានកើតឡើងនៅមុនពេលនេះ ដោយសារតែគាត់លើកឡើងពីអ្នកដែលត្រូវបានគេជម្លៀសជាច្រើននាក់មកពីទីក្រុងភ្នំពេញ និងខេត្តតាកែវ នៅពេលនោះ។ នៅពេលផ្សេងទៀត គាត់បានលើកឡើងថា កិច្ចប្រជុំអាចធ្វើឡើងមុនពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ក្រោយមក គាត់បានកែប្រែអ្វីដែលគាត់បានលើកឡើង ដោយផ្អែកលើមូលដ្ឋានថា គាត់បានចូលរួមជាតំណាងមន្ទីរពេទ្យស្រុក"។

[1278] ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ (រៀល សន) ឯកសារ **E1/279.1** ម៉ោង ១៥.០៣.១១ និង ១៥.២១.២៦។

[1279] លើសពីនេះ ការយោងទាំងឡាយដែលត្រូវបានចង្អុលបង្ហាញនៅទំព័រ ៦៧ គឺពុំត្រឹមត្រូវទេ ដោយក្នុងទំព័រនេះនៃប្រតិចារឹក មិនមាននិយាយពីការបោសសម្អាតទេ។ សំអាងហេតុសាលក្រម កថាខណ្ឌ ១០៦២ កំណត់សម្គាល់ជើងទំព័រលេខ៣៥១៧៖ "ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ (រៀល សន) ឯកសារ **E1/279.1** ទំព័រ ៥២-៥៤ ទំព័រ ៥៥-៥៧ ទំព័រ ៦៧"។

[1280] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៦២ កំណត់សម្គាល់ជើងទំព័រលេខ៣៥២២។

[1281] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៦៣។

៧២៤. នៅត្រង់កថាខណ្ឌ ១០៦៣ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានផ្អែកដោយពុំត្រឹមត្រូវលើសក្ខីកម្មក្រៅវិសាលភាពរបស់ ឃឹម ហឿន និងលើរបាយការណ៍ចំនួនពីរ ដែលក្នុងនោះ មួយនៅក្រៅវិសាលភាពភូមិសាស្ត្រ[1282] ហើយដែលរបាយការណ៍ទាំងពីរបង្ហាញពីការបោសសម្អាត ដើម្បីសន្និដ្ឋានថាមានការប្រឹងប្រែងរួមគ្នាក្នុងការប្រមូលអ្នកដែលត្រូវសង្ស័យថាជាអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ចាប់ពីខែមេសា ឆ្នាំ១៩៧៧។ វាជាការសន្និដ្ឋានមួយ និងជាការនិយាយជាលក្ខណៈទូទៅជ្រុលហួសហេតុ តាមរយៈរបាយការណ៍មួយ ដែលបង្ហាញតែពីការកំណត់អត្តសញ្ញាណអតីតទាហានប្រាំមួយនាក់ ដែលពាក់ស័ក្តិ ១ និង ស័ក្តិ ២។

៧២៥. នៅត្រង់កថាខណ្ឌ ១០៨០ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានផ្អែកលើភស្តុតាងជាឯកសារដែលមានតម្លៃតិចតួចបំផុត ដើម្បីអះអាងថា អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ងាយនឹងត្រូវគេចាប់ខ្លួនបំផុត ដោយការគិត ការនិយាយស្តី ឬការប្រព្រឹត្តិដែលគេចាត់ទុកថាប្រឆាំងនឹងបដិវត្តន៍ ហើយថាមានប្រតិបត្តិការសម្លាប់ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដែលក្នុងអំឡុងពេលនោះ អតីតទាហានសាធារណរដ្ឋខ្មែរ "ជាច្រើន" រួមនឹងក្រុមគ្រួសារពួកគេ ត្រូវបានសម្លាប់នៅស្រុកត្រាំកក់។ សេចក្តីរាយការណ៍ទាំងប្រាំដែលអង្គជំនុំជម្រះបានយោង គឺមានតែសេចក្តីរាយការណ៍ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ របស់ឃុំពពេល មួយប៉ុណ្ណោះ ដែលលើកឡើងពីការកម្ទេច និងការស្លាប់របស់អតីតទាហានសាធារណរដ្ឋខ្មែរ[1283]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានទាញសេចក្តីសន្និដ្ឋានទូទៅ ទាក់ទងនឹងអត្ថិភាពនៃប្រតិបត្តិការសម្លាប់ដែលកំពុងប្រព្រឹត្តទៅក្នុងស្រុកត្រាំកក់ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ទៅលើអតីតទាហានសាធារណរដ្ឋខ្មែរ និងគ្រួសាររបស់ពួកគេ ដោយផ្អែកលើមូលដ្ឋាននៃឃ្លាតែមួយថា "គ្រួសារទាហានដែលត្រូវអង្គការកម្ទេច និងស្លាប់បាត់ ១០៦ គ្រួសារ មានចំនួន ៣៩៣ នាក់" ដែលមាននៅក្នុងសេចក្តីរាយការណ៍មួយចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧

---

[1282] សូមមើលខាងលើ កថាខណ្ឌ ៣៦៧-៣៦៩, ៣៧២-៣៧៣។

[1283] "គ្រួសារទាហានដែលត្រូវអង្គការកម្ទេច និងស្លាប់បាត់ ១០៦ គ្រួសារ មានចំនួន ៣៩៣ នាក់" បណ្ណសារស្រុកត្រាំកក់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2048** ERN 00079090។

របស់ឃុំពពេល[1284]។ ជាចុងក្រោយ នៅត្រង់កថាខណ្ឌ ១០១៨ នៃសំអាងហេតុសាលក្រម ភ័ស្តុតាងជាឯកសារដែលលើកយកមក និយាយពីប្រជាជនថ្មី តែមិនិយាយពីអតីតទាហានសាធារណរដ្ឋខ្មែរទេ។ ដូច្នេះ ភ័ស្តុតាងនេះមិនអាចប្រើសម្រាប់គាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះបានឡើយ។

### ៣.១.៣. ការយោងពុំត្រឹមត្រូវទៅផ្នែកពាក់ព័ន្ធនឹងក្រាំងតាចាន់

៧២៦. កថាខណ្ឌ ២៨១៣ ដែលត្រូវបានចង្អុលបង្ហាញនៅក្នុងកំណត់សម្គាល់ជើងទំព័រ នៃកថាខណ្ឌ ១១៧៥ នៃសំអាងហេតុសាលក្រម សម្រាប់គាំទ្រដល់ការអះអាងថា ចាប់ពីខែមេសា និងខែឧសភា ឆ្នាំ១៩៧៧ អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានចាត់ទុកជាគោលដៅនៃការចាប់ខ្លួន និងសម្លាប់ ដោយផ្អែកលើភ័ស្តុតាងដាក់បន្ទុក គឺយោងទៅការកំណត់ប្រភេទបទល្មើសសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅក្រាំងតាចាន់[1285]។ ក្នុងកថាខណ្ឌនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានកំណត់ជាគោលដៅ ដោយសារបុណ្យស័ក្តិរបស់ពួកគេ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដោយបានចង្អុលបង្ហាញកថាខណ្ឌ ២៦៤៣ នៃសំអាងហេតុសាលក្រម ក្នុងកំណត់សម្គាល់ជើងទំព័រ។ ក៏ប៉ុន្តែ កថាខណ្ឌនេះលើកឡើងតែពីបណ្តឹង មកកាន់អង្គជំនុំជម្រះប៉ុណ្ណោះ។ ដូច្នេះ អង្គជំនុំជម្រះមានកំហុសនៅក្នុងការប្រើប្រាស់ភ័ស្តុតាងសម្រាប់សន្និដ្ឋានថាមានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះលើចំណុចនេះ ត្រូវទុកជាមោឃៈ។

## ៣.២. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជនថ្មី

[1284] បណ្ណសារស្រុកត្រាំកក់ ចុះថ្ងៃទី១១ ខែមេសា ឯកសារ **E3/4629** ERN 00143476, បណ្ណសារស្រុកត្រាំកក់ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2050** ERN 00079111, បណ្ណសារស្រុកត្រាំកក់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2048** ERN 00079087-00079088។

[1285] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៥ កំណត់សម្គាល់ជើងទំព័រលេខ៣៩៩៤។

៧២៧. ជាលក្ខណៈចម្បង គួររំឭកថា អង្គជំនុំជម្រះមិនទទួលបានបណ្ដឹងជាក់ស្ដែងពីអង្គហេតុដែលជាធាតុផ្សំនៃ "ការប្រព្រឹត្តិរើសអើង" ចំពោះប្រជាជនថ្មី នៅត្រាំកក់ទេ[1286]។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានមិនសមហេតុសមផលថា មានការរើសអើងជាក់ស្ដែងចំពោះប្រជាជនថ្មីនៅត្រាំកក់ ដោយពុំមានភ័ស្ដុតាងបញ្ជាក់[1287]។ ការរើសអើងជាក់ស្ដែងចំពោះប្រជាជនថ្មីនៅត្រាំកក់ ពុំមានភ័ស្ដុតាងបញ្ជាក់ក្នុងកម្រិតតម្រូវនោះទេ ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីរបបអាហារខុសៗគ្នា (៣.២.១) លក្ខខ័ណ្ឌការងារអាក្រក់ជាង (៣.២.២) ជាពិសេស នៅតាមកងចល័តយុវជន (៣.២.៣) ការប្រព្រឹត្តិ "ហួសហេតុ" (៣.២.៤) និងការតាមដាន និងការចាប់ខ្លួន (៣.២.៥)។

### ៣.២.១. គ្មានភ័ស្ដុតាងពីការទទួលបានរបបអាហារផ្សេងដោយប្រជាជនថ្មី នៅត្រាំកក់

៧២៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាប្រជាជនថ្មីទទួលបានអាហារតិចជាងអ្នកផ្សេងទៀត[1288]។ នៅត្រង់កថាខណ្ឌ ១០១៦ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានយោងទៅលើភ័ស្ដុតាងដាក់បន្ទុកមួយចំនួនដែលអះអាងថា ប្រជាជនថ្មីទទួលបានអាហារតិច (ពេជ្រ ជឹម, កែវ ច័ន្ទតារា, តាក សាន់) និងសក្ខីកម្មដោះបន្ទុកមួយចំនួនដែលនិយាយថាពុំមានការបែងចែកខុសគ្នាទេ (ពេជ្រ ជឹម, នាង អ៊ួច, ជាំង ស្រីមុំ)។

៧២៩. ភ័ស្ដុតាងដាក់បន្ទុក មានតម្លៃជាភ័ស្ដុតាងតិចតួចបំផុត ឬក៏ទោះជាយ៉ាងណាក៏ដោយ ក៏មិនអាចឱ្យគេដឹងបានថា តើអ្នកណាជាអ្នកឱ្យធ្វើដូច្នេះ។ ពេជ្រ ជឹម បានអះអាងជាច្រើនលើកច្រើនសាថា "បញ្ហារបបហ្នឹង គឺកំណត់រៀបរយដូចៗគ្នា"[1289]។ ប៉ុន្ដែ គាត់បានអះអាងដែរថា ជាក់ស្ដែង គាត់បាន "មើលទៅ មានលាក់ហូប ឧបមា សហករណ៍ៗគេ ហូបពីរនាក់ទៅ ហើយប្រជាជនរំដោះថ្មីបីនាក់ទៅ"[1290]។ ផ្ទុយទៅវិញ គាត់ពុំបានបញ្ជាក់ពីទីកន្លែង ពេលវេលា ចំនួន និងអ្វីដែលសំខាន់បំផុតនោះគឺនរណាជាអ្នក

---

[1286] សូមមើលខាងលើ កថាខណ្ឌ ៣៦៧-៣៦៩, ៣៧៤-៣៧៧, ៤៤៨-៤៥០, ៤៧៥-៤៨១។

[1287] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៦-១១៧៩។

[1288] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ៤០០៣ យោងទៅកថាខណ្ឌ ១០១៦។

[1289] ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ E1/291.1 ម៉ោងប្រហែល ១៤.០១.០៤។

[1290] ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ E1/291.1 ម៉ោងប្រហែល ១៤.០១.០៤។

ធ្វើការបែងចែកនេះ។ ជាពិសេស ការដែលគាត់បានចង្អុលបង្ហាញថា ទង្វើនេះត្រូវបានធ្វើ "ដោយស្ងាត់ៗ" គឺចង់បង្ហាញឱ្យឃើញថា វាពុំមែនជាការប្រព្រឹត្តិត្រឹមត្រូវ ឬជាវិធានផ្លូវការនោះទេ។ ដូច្នេះ អង្គជំនុំជម្រះពុំគួរទាញសេចក្ដីសន្និដ្ឋានទូ ទៅលើការដែលប្រជាជនថ្មីទទួលបានអាហារតិចជាងអ្នកផ្សេងទៀត ដោយផ្អែកលើមូលដ្ឋានភ័ស្តុតាងមួយនេះឡើយ។ ម្យ៉ាងវិញទៀត ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ មានភាពមិនច្បាស់លាស់ ហើយដោយសារតែហេតុនេះ គឺគាត់ខ្វះភាពជឿជាក់បាន។ គាត់ពុំបានពន្យល់ថា តើគាត់ធ្វើដូចម្ដេចទើបអាចសន្និដ្ឋានបានថា ប្រជាជនថ្មីទទួលបានអាហារតិចជាងប្រជាជនមូលដ្ឋាន[1291]។

៧៣០. អង្គជំនុំជម្រះខ្វះអនាគតិ ដោយមិនយកចិត្តទុកដាក់លើភ័ស្តុតាងដោះបន្ទុក។ អង្គជំនុំជម្រះបានត្រឹមតែបង្ហាញ តែពុំបានពិចារណាសក្ខីកម្មដោះបន្ទុករបស់ ពេជ្រ ជឹម, នាង អ៊ូច និង ជាំង ស្រីមុំ[1292]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានបំភ្លេចចោលភ័ស្តុតាងដោះបន្ទុកមួយចំនួន ដោយគ្មានមូលហេតុ។ ឧទាហរណ៍ អង្គជំនុំជម្រះពុំបានបង្ហាញសក្ខីកម្មរបស់ សៅ ហ៊ាន ដែលអង្គជំនុំជម្រះបានយកមកធ្វើជាសំអាងបែបចោះៗបំផុត ដើម្បីបង្ហាញឱ្យឃើញពីល័ក្ខខ័ណ្ឌការងារផ្សេងគ្នាសម្រាប់ប្រជាជនថ្មី។ សៅ ហ៊ាន បានឆ្លើយទៅនឹងសំណួរថា "តើលោកអាចជម្រាបបានទេ ថាតើប្រជាជនពេញសិទ្ធិហ្នឹងគេទទួលអាហារបានរបៀបណាដែរ? ប៉ុនណាដែរបើប្រៀបធៀបទៅនឹងប្រភេទក្រុមផ្សេង?" "ការហូបអាហារសហករណ៍តែមួយ អ្នកពេញសិទ្ធិ ក៏ដូចអ្នកមិនពេញសិទ្ធិដែរ"[1293]។

៧៣១. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រើប្រាស់កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ រៀល សន ដើម្បី "បញ្ជាក់" លើភ័ស្តុតាងទន់ខ្សោយបំផុតដែលជួយគាំទ្រសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំ

---

[1291] ប្រតិចារឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ម៉ោងប្រហែល ១៤.១៤.០៤៖ "គេច្រើនលើយើងបន្តិចបន្តួចហ្នឹង ហើយគ្រាន់តែហូបបបរ ហូបអីហ្នឹងទៅ ជួនកាលហូបមិនឆ្អែតអីចឹងទៅ ក៏ខ្ញុំទឹកភ្នែកអីចឹងទៅ ដើរចេញទៅ ហូបហើយ ប៉ុន្តែមិនឱ្យគេឃើញ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1292] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៦។

[1293] ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/264.1** ម៉ោងប្រហែល ១៥.៥៩.០២។ សូមមើល សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៨ កំណត់សម្គាល់ជើងទំព័រលេខ៣២៦២។

ជម្រះថា មានការទទួលបានអាហារខុសគ្នា[1294]។ បើតាមអង្គជំនុំជម្រះ រៀល សន បាននិយាយថា ប្រជាជនថ្មីស្លាប់ដោយខ្វះអាហារូបត្ថម្ភ ខណៈដែលប្រជាជនមូលដ្ឋាន កម្រនឹងស្លាប់ដោយសារការហូបមិនគ្រប់គ្រាន់ណាស់[1295]។ ជាបឋម គេគួររំឭកអំពីតម្លៃជាភស្តុតាងតិចតួចនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះថា សាក្សីពុំត្រូវបានសួរដេញដោលពាក់ព័ន្ធនឹងប្រធានបទនេះ ក្នុងអំឡុងពេលសវនាការនោះទេ។ ម្យ៉ាងវិញទៀត ការអានកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អាចឱ្យគេដឹងបានថា វាបានពន្យល់ពីភាពខុសគ្នារវាងប្រជាជនថ្មី និងប្រជាជនចាស់ មិនមែនតាមរយៈភាពខុសគ្នានៃរបបអាហារទេ តែគឺតាមរយៈការដែលប្រជាជនមូលដ្ឋាន "គេអ្នកមូលដ្ឋានគេដឹង" និង "គេដឹងកន្លុកកន្លែងរកស៊ីបាន រកស៊ីក្រៅបាន"[1296]។ អង្គជំនុំជម្រះមិនអាចសំអាងសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថាប្រជាជនថ្មីទទួលរងទុក្ខខ្លាំង និងស្លាប់ដោយសារខ្វះអាហារូបត្ថម្ភ ចំណែកឯប្រជាជនមូលដ្ឋានមិនសូវប្រឈមនឹងការខ្វះអាហារូបត្ថម្ភ លើមូលដ្ឋាននៃបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាតែមួយបានទេ[1297]។ ម្យ៉ាង សាក្សីទំនងជាទាញសេចក្តីសន្និដ្ឋានទូទៅដោយផ្អែកលើបទពិសោធន៍ប្រពន្ធរបស់គាត់ ហើយម្យ៉ាងទៀត សាក្សីពុំត្រូវបានសួរដេញដោលលើផ្នែកនេះក្នុងចម្លើយរបស់គាត់ដែលត្រូវបានធ្វើនៅក្រៅក្របខ័ណ្ឌតុលាការ ដែលមិនអាចប្រើដើម្បីបង្ហាញឱ្យឃើញអង្គហេតុសំខាន់មួយបានទេ[1298]។

## ៣.២.២ .គ្មានភស្តុតាងបង្ហាញពីល័ក្ខខ័ណ្ឌការងារមិនសូវល្អសម្រាប់ប្រជាជនថ្មី

[1294] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៦ កំណត់សម្គាល់ជើងទំព័រលេខ៣២៥៩៖ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ រៀល សន ឯកសារ **E3/5859** ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ទំព័រ ៣៦១-៣៦២ ERN 00418844-00418845។

[1295] បទសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ រៀល សន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ឯកសារ **E3/5859** ERN 00418844។

[1296] បទសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ រៀល សន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ឯកសារ **E3/5859** ERN 00418844។ "សៈ ចុះពួកមូលដ្ឋានអត់សូវខ្វះទេ?"។ សាក្សីឆ្លើយសំណួរនេះ ដោយសម្តែងការយល់ឃើញផ្ទាល់ខ្លួនបែបពុំច្បាស់លាស់៖ "គេអត់សូវខ្វះទេ គេអ្នកមូលដ្ឋានគេដឹង គេដឹងកន្លុកកន្លែងរស៊ីបាន រកស៊ីក្រៅបាន ដូចថា យាយខ្ញុំអញ្ចើងគាត់ដឹងអ្នកណានៅគ្រប់គ្រងក្នុងភូមិនេះ គាត់មកឃុបឃិតបានដូងអីហូប នាយអាយ"

[1297] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ៤០០៥ យោងទៅ កថាខណ្ឌ ១០១៦។

[1298] សូមមើលខាងលើ កថាខណ្ឌ ៣០៦-៣១១។

៧៣២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា មានការបង្ហាញឱ្យឃើញថាប្រជាជនថ្មីមានល័ក្ខខ័ណ្ឌការងារអាក្រក់ជាង ដោយយោងទៅកថាខណ្ឌ ១០១៧ ដល់ ១០២០ នៃផ្នែកសំអាងហេតុសាលក្រម[1299]។ នៅកថាខណ្ឌ ១០១៧ ក្នុងឃ្លាផ្តើមសេចក្តី អង្គជំនុំជម្រះបានសន្និដ្ឋានដោយត្រឹមត្រូវថា ក្នុងចំណោមកត្តាទាំងឡាយដែលកំណត់អំពីល័ក្ខខ័ណ្ឌការងារនៅត្រាំកក់ មានទីកន្លែង ភារកិច្ចដែលត្រូវបំពេញ ពេលវេលាប្រចាំឆ្នាំ ស្ថានភាពដី អាកប្បកិរិយារបស់អ្នកគ្រប់គ្រង និងប្រភេទប្រជាជនពាក់ព័ន្ធ។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានដោយពុំសមហេតុសមផលក្នុងឃ្លាបន្ទាប់ថា "ល័ក្ខខ័ណ្ឌបានផ្លាស់ប្តូរ អាស្រ័យទៅលើប្រភេទប្រជាជន"[1300]។ អង្គជំនុំជម្រះបានបំភ្លៃភ័ស្តុតាង និងមិនបានផ្តល់យុត្តិកម្មណាមួយសម្រាប់គាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ប្រភេទប្រជាជនគឺជាកត្តាកំណត់។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុផងដែរ ដោយពុំបានចង្អុលបង្ហាញ ថាតើល័ក្ខខ័ណ្ឌអាក្រក់ជាងសម្រាប់ប្រជាជនថ្មីបែបដូចម្តេចទៅ។ កថាខណ្ឌ ១០១៧ នៃសំអាងហេតុសាលក្រម ពុំមានកំណត់សម្គាល់ជើងទំព័រនោះទេ។ សក្ខីកម្មនានាដែលមានបង្ហាញនៅត្រង់កថាខណ្ឌ ១០១៨-១០១៩ អាចត្រូវបានប្រើធ្វើជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានលើអង្គហេតុនេះ តែអង្គជំនុំជម្រះបានត្រឹមតែរៀបរាប់ពីសក្ខីកម្ម ដោយពុំបានផ្តល់សំអាងហេតុថាតើភ័ស្តុតាងទាំងនោះបង្ហាញពីល័ក្ខខ័ណ្ឌការងារខុសគ្នាសម្រាប់ប្រជាជនថ្មីបែបដូចម្តេចទៅ។

៧៣៣. អង្គជំនុំជម្រះបានប្រើប្រាស់ដោយពុំត្រឹមត្រូវនូវសក្ខីកម្មរបស់ សៅ ប៉ាន ដែលបើទោះជាគាត់អះអាងថា "ប្រសើរជាងគេគឺក្រុមពេញសិទ្ធិ"[1301] ក៏ដោយ ក៏គាត់ពុំអាចបញ្ជាក់បានថាតើការប្រព្រឹត្តិនោះវាប្រសើរជាងបែបដូចម្តេចទៅ គឺគាត់បានត្រឹមតែនិយាយថា "ក្នុងការងារធ្វើ អ្នកពេញសិទ្ធិច្រើនតែធ្វើមេពួក មេក្រុមអី ធ្វើការស្មើៗគ្នាដូចគ្នា។ ចំពោះអ្នកប្រធានក៏ធ្វើដូចគ្នា មានអ្នកពេញសិទ្ធិគ្រប់គ្រងតាមពួក"[1302]។ ម្យ៉ាងវិញទៀត ជាការពិតណាស់ថា ប៊ុន សារឿន, តាក សាន់ និង អៀម យេន បានពិពណ៌នាអំពីល័ក្ខខ័ណ្ឌលំបាក ប៉ុន្តែសក្ខីកម្មរបស់ពួកគាត់មិនអនុញ្ញាតឱ្យអង្គជំនុំជម្រះបង្ហាញឱ្យឃើញពីការប្រព្រឹត្តិខុសគ្នាបាននោះទេ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមានកាតព្វកិច្ចបង្ហាញឱ្យឃើញនូវអសមភាព

---

[1299] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ៤០០៦ យោងទៅ កថាខណ្ឌ ១០១៧ ដល់ ១០២០។

[1300] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៧។

[1301] ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/264.1** ក្រោយម៉ោង ១៥.៥៥.៣១។

[1302] ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/264.1** ក្រោយម៉ោង ១៥.៥៩.០២។

ក្នុងការប្រព្រឹត្តិ។ កថាខណ្ឌ ១០១៩ នៃសំអាងហេតុសាលក្រម បង្ហាញថាសក្ខីកម្មដាក់បន្ទុកនានាដែលរៀបរាប់ពីម៉ោងធ្វើការ មិនអាចឱ្យគេបង្ហាញឱ្យឃើញពីការប្រព្រឹត្តិខុសគ្នានោះទេ។ ផ្ទុយទៅវិញ មាស សុខា ដែលត្រូវបានយោងដោយអង្គជំនុំជម្រះ ដោយភ្លេចបញ្ជាក់ថាគាត់ជាប្រជាជនមូលដ្ឋាន បានពិពណ៌នាអំពីល័ក្ខខ័ណ្ឌប្រហាក់ប្រហែលគ្នាសម្រាប់អ្នកធ្វើការទាំងអស់[1303]។

## ៣.២.៣. ស្ថានភាពមិនខុសគ្នានៅតាមកងចល័តយុវជន

៧៣៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាល័ក្ខខ័ណ្ឌការងារដាក់ឱ្យអនុវត្តនៅតាមកងចល័តយុវជន "មានស្ថានភាពលំបាកយ៉ាងខ្លាំង" ហើយបន្ទាប់មកធ្វើឱ្យគេគិត ដោយពុំនិយាយឱ្យបានច្បាស់ថា ល័ក្ខខ័ណ្ឌទាំងនោះពិបាកខ្លាំងជាងសម្រាប់ប្រជាជនថ្មី[1304]។ ជាការពិតណាស់ថា ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានរៀបរាប់អំពីល័ក្ខខ័ណ្ឌការងារលំបាក ប៉ុន្តែ ក្នុងសក្ខីកម្មរបស់គាត់ គ្មានអ្វីអាចឱ្យគេអះអាងបានថា ល័ក្ខខ័ណ្ឌការងារទាំងនោះលំបាកខ្លាំងជាងសម្រាប់ប្រជាជនថ្មីនោះទេ[1305]។ ដូចគ្នាដែរសម្រាប់ ឯក ហឿន ដែលបានបញ្ជាក់ថា អ្នកធ្វើការ (ដោយពុំបានបញ្ជាក់ "ប្រភេទ") ធ្លាក់ខ្លួនឈឺ មានការលំបាកក្នុងការទទួលបានអាហារ ស្តាប់នៅតាមការដ្ឋានការងារនៅត្រាំកក់[1306]។ ស្របជាមួយនោះដែរ សក្ខីកម្មរបស់ នុត នូវ ដែលថាប្រជាជនថ្មីធ្លាក់ខ្លួនឈឺញឹកញាប់ជាងប្រជាជនមូលដ្ឋាន ព្រោះពួកគាត់មិនទម្លាប់ធ្វើការងារនៅតាមស្រែ គឺមិនអាចគាំទ្រថាល័ក្ខខ័ណ្ឌការងារដែលដាក់ឱ្យអនុវត្តគឺខុសគ្នាទៅតាមប្រភេទមនុស្សនោះទេ[1307]។ គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់ អាចទាញសេចក្តីសន្និដ្ឋាន និងនិយាយសរុបជាទូទៅជ្រុលហួសហេតុ តាមរយៈភ័ស្តុតាងដែលមានតម្លៃជាភ័ស្តុតាងតិចតួចបំផុតបែបនេះបាននោះទេ។

## ៣.២.៤. គ្មានភ័ស្តុតាងសត្យានុម័តិអំពីការធ្វើបាប "ខ្លាំង" លើប្រជាជនថ្មី

---

[1303] សំអាងហេតុសាលក្រម កថាខណ្ឌ ១០១៩ កំណត់សម្គាល់ជើងទំព័រលេខ៣២៧៣។

[1304] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០។

[1305] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០ កំណត់សម្គាល់ជើងទំព័រលេខ៣២៧៧, ៣២៧៨។

[1306] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០ កំណត់សម្គាល់ជើងទំព័រលេខ៣២៨១។

[1307] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២០ កំណត់សម្គាល់ជើងទំព័រលេខ៣២៧៩។

៧៣៥. អង្គជំនុំជ្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយយល់ឃើញថា ភស្តុតាងដែលរៀបរាប់ពីរបៀបដែលប្រជាជនថ្មីបានទទួលរង "ការធ្វើបាបយ៉ាងខ្លាំង និងត្រូវបានចាត់ទុកថាជា "ទាសករគ្មានតម្លៃ" ដោយមានកម្មាភិបាលដែលគេជ្រើសរើសជាពិសេសចេញពីប្រជាជនមូលដ្ឋាន ជេរប្រមាថ ឬវាយដំពួកគេរួមទាំងកូនចៅរបស់ប្រជាជនថ្មីផង"[1308]។ ភស្តុតាងសម្រាប់គាំទ្រសេចក្តីសន្និដ្ឋាននេះ គឺមាននៅក្នុងកថាខណ្ឌ ១០២៣ នៃសំអាងហេតុសាលក្រម[1309] ដែលនៅត្រង់នោះ អង្គជំនុំជម្រះបានសន្និដ្ឋានថាមានលទ្ធភាពនៃការដកហូតអាហារ ដោយពុំមានការបែងចែក ក្នុងករណីមាន "ការប្រព្រឹត្តិល្មើស ឬការមិនសម្រេចតាមផែនការ"[1310]។ ដូច្នេះ ក្នុងកថាខណ្ឌនេះ ពុំមានបង្ហាញពីការប្រព្រឹត្តិបែបរើសអើងនោះទេ។

៧៣៦. ពាក់ព័ន្ធនឹងភស្តុតាងបង្ហាញនៅក្នុងកថាខណ្ឌ ១០២៣ មានតែ រី ពៅ និង អ៊ុម វណ្ណៈ ប៉ុណ្ណោះ ដែលបានលើកឡើងពីការប្រព្រឹត្ត "ដាក់លាក់" ចំពោះប្រជាជនថ្មី។ ប៉ុន្តែ អង្គជំនុំជម្រះបានត្រឹមយកសក្ខីកម្មរបស់ រី ពៅ មកទាំងដុល ដោយគ្មានធ្វើការវិភាគណាមួយទាក់ទងនឹងភាពជឿជាក់បាននៃសម្តីរបស់គាត់ទេ។ អង្គជំនុំជម្រះគ្រាន់តែបាននិយាយថា សាក្សីបានផ្តល់សក្ខីកម្មថា "ប្រជាជន ១៧ មេសា ដែលត្រូវទទួលរងការធ្វើបាបយ៉ាងខ្លាំង ហើយត្រូវគេចាត់ទុកដូចជា"កញ្ជះដាច់ថ្លៃ" ហើយប្រជាជនមូលដ្ឋានអាចជេរ ឬវាយប្រជាជន ១៧ មេសា បាន" ដោយគ្មានការវិភាគអ្វីសោះ[1311]។ ក្នុងសវនាការ រី ពៅ បាននិយាយថា៖

> "បាទ កាលពីសម័យនោះ គេបែងចែកជាបីប្រភេទអ៊ីចឹង។ អ៊ីចឹងចំណែកពួកខ្ញុំដប់ -- មកពីយួន និងបងប្អូនចេញពីភ្នំពេញទៅ ប្រជាពលរដ្ឋ ប្រជាជន១៧មេសាហ្នឹង គេចាត់ទុកដូចជាខ្ញុំកញ្ជះដាច់ថ្លៃរបស់គេអ៊ីចឹង។ ជាឧបករណ៍មួយសម្រាប់គេរ៉ៃគេតប់។ អ៊ីចឹងការហូប ការដេក

[1308] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧។

[1309] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ៤០០៧ យោងទៅកថាខណ្ឌ ១០២៣។

[1310] សំអាងហេតុសាលក្រម កថាខណ្ឌ ១០២៣, សម្រាប់ ប៊ុន សារឿន សូមមើល កំណត់សម្គាល់ជើងទំព័រលេខ៣២៨៩ និងសម្រាប់ អ៊ុម វណ្ណៈ សូមមើល កំណត់សម្គាល់ជើងទំព័រលេខ៣២៩០។

[1311] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ៤០០៧ យោងទៅ កថាខណ្ឌ ១០២៣។

ដើរ ឈរ អង្គុយ គឺក្រឹត្យវិន័យគេតឹងតែងណាស់។ អត់មានយើងដើររហេតរហូតបាន ឬមួយហូប បើសិនណាយើងចាប់ត្រីបាន ត្រូវយកទៅដាក់ក្នុងសហករណ៍។ បើយើងលួចលាក់ អាហ្នឹងគេចាប់ជាកម្លាំង មួយកងហាររបស់គេអ៊ីចឹង គេឱ្យរកត្រីយើងតែបុគ្គលម្នាក់ឯងហូបឱ្យអស់។ អាហ្នឹងកន្លែងខ្ញុំនៅគឺអ៊ីចឹងតែម្តង។ សកម្មភាពរបស់វាធ្វើទារុណកម្មមកលើយើងខ្លាំងណាស់"[1312]។

៧៣៧. សក្ខីកម្មស្តីពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ មិនអាចឱ្យគេសន្និដ្ឋានថាមានការប្រព្រឹត្តិជាទូទៅចំពោះប្រជាជនថ្មីទាំងអស់គ្នានោះទេ។ លើសពីនេះទៀត ដោយគេពុំដឹងថាតើគាត់រៀបរាប់អំពីឥរិយាបទរបស់អ្នកទទួលខុសត្រូវ ឬអាជ្ញាធរ ឬសមាជិកធម្មតាក្នុងកងរបស់គាត់យ៉ាងណានោះ សក្ខីកម្មរបស់គាត់ គឺហាក់ដូចជាការពិពណ៌នាអំពីការប្រព្រឹត្តិខុសរបស់ប្រជាជនមូលដ្ឋានមួយចំនួន ដែលផ្ទុយពីអនុសាសន៍របស់ ប.ក.ក[1313]។ រី ពៅ បានបង្ហាញពីអារម្មណ៍របស់គាត់ថា ប្រជាជនថ្មីត្រូវបានគេចាត់ទុកដូចជា "កញ្ចះដាច់ថ្លៃ" ដោយបានលើកឡើងនូវជ្រុងចំនួនបីនៃការប្រព្រឹត្តិបែបរើសអើងនេះ។ ជាបឋមតាមរយៈការជេរប្រមាថរបស់ប្រជាជនមូលដ្ឋាន ដែលអាចឈានដល់ការវាយតប់ថែមទៀត។ ប៉ុន្តែគាត់ពុំបានផ្តល់ឧទាហរណ៍ជាក់ស្តែងណាមួយចំពោះការនិយាយជាទូទៅ មិនបានពិស្តារនេះទេ។ បន្ទាប់មក រី ពៅ បាននិយាយថា ប្រជាជនថ្មីមិនអាចដើរហើរបានទេ។ ត្រង់ចំណុចនេះដូចគ្នាដែរ គ្មានឧទាហរណ៍ច្បាស់លាស់ ហើយជាពិសេស គ្មានការបញ្ជាក់ថាវាតើវាខុសពីស្ថានភាពរបស់ប្រជាជនមូលដ្ឋានដូចម្តេច។ ជាចុងក្រោយ គាត់លើកឧទាហរណ៍ពី "យើង" ដែលចាប់ត្រីបាន ដោយគ្មានការអនុញ្ញាត និងពីទណ្ឌកម្មដែលកើតមកពីអំពើនេះ ដោយគេពុំអាចកំណត់បានថាតើគាត់លើកឡើងពីឧប្បត្តិហេតុណាមួយដាច់តែឯង ឬមួយយ៉ាងណា និងថាតើឧប្បត្តិហេតុប្រភេទនេះពាក់ព័ន្ធតែប្រជាជនថ្មីទេ ឬយ៉ាងណា។

---

[1312] ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ម៉ោងប្រហែល ០៩.៤៤.២៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1313] សូមមើលខាងក្រោម កថាខណ្ឌ ១៤៩០-១៥១៧។

៧៣៨. អង្គជំនុំជម្រះមានកំហុស ដោយបានសន្និដ្ឋានថាប្រជាជនថ្មីបានទទួលរង "ការធ្វើបាបយ៉ាងខ្លាំង" នៅត្រាំកក់ ដោយផ្អែកលើមូលដ្ឋាននៃសក្ខីកម្មមួយមិនច្បាស់លាស់ និងមានលក្ខណៈលម្អិតតិចតួចទាក់ទងនឹងភស្តុតាងដែលលើកឡើង។

## ៣.២.៥. ការតាមដាន និងការចាប់ខ្លួន

៧៣៩. សេចក្តីសន្និដ្ឋានចុងក្រោយលើអង្គហេតុ សម្រាប់គាំទ្រថាមានការប្រព្រឹត្តិបែបរើសអើងលើប្រជាជនថ្មី គឺសេចក្តីសន្និដ្ឋានដែលថា ប្រជាជនថ្មី តែក៏មានអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងអ្នកផ្សេងៗទៀតដែលត្រូវចាត់ទុកថាជាការគំរាមកំហែងចំពោះ ប.ក.ក ដែរ "[គឺអាចត្រូវ] ចាប់ខ្លួន ពីបទមានគំនិត ពាក្យសម្តី ឬការប្រព្រឹត្តិ"[1314]។ កថាខណ្ឌ ១០៥៥ នៃសំអាងហេតុសាលក្រមដែលត្រូវបានយោង ពាក់ព័ន្ធនឹងភស្តុតាងបង្ហាញពីការតាមដានប្រជាជនដោយកងឈ្លប។ ប៉ុន្តែ វាមិនមែនជាការប្រព្រឹត្តិបែបរើសអើងនោះទេ។ ដូចគ្នានេះដែរ ភស្តុតាងលើកយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៣៤៧១ មិនអាចឱ្យចៅក្រមមានវិចារណញ្ញាណសន្និដ្ឋានបានថាមានការប្រព្រឹត្តិជាក់លាក់បានទេ។ ឃឹម បឿន បាននិយាយថា មនុស្សគ្រប់គ្នាត្រូវបានគេតាមដាន[1315]។

៧៤០. សក្ខីកម្មតែឯងរបស់ ថាន់ ធីម និង ប៊ុន សារឿន ទាក់ទងនឹងការតាមដានពួកគាត់ មិនអាចបង្ហាញឱ្យឃើញអំពីលក្ខណៈរើសអើងបានទេ។ ពួកគាត់លើកឡើងពីបទពិសោធន៍ផ្ទាល់ខ្លួន តែមិនអាចផ្តល់ការចង្អុលបង្ហាញទាក់ទងនឹងមូលហេតុ និងវិសាលភាពនៃការតាមដានរបស់ពួកគាត់បាន[1316]។ សក្ខីកម្មរបស់ វង់ សារុន ដែលរាយការណ៍ពីសម្តីរបស់ប្រពន្ធមេភូមិចានទាប គឺជាការឮតពីគេ និងមានតម្លៃជា

---

[1314] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៧៧ កំណត់សម្គាល់ជើងទំព័រលេខ៤០១០ យោងទៅ កថាខណ្ឌ ១០៥៥ និង ១០៨០។

[1315] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៥៥៖ "ភស្តុតាងរបស់ ឃឹម បឿន គឺថា ទាំងប្រជាជនចាស់ និងប្រជាជនថ្មី ត្រូវបានគេតាមដាន", កំណត់សម្គាល់ជើងទំព័រលេខ៣៤៧៤ "ប្រតិចារឹក ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ (ឃឹម បឿន) ឯកសារ **E1/296.1** ទំព័រ ៦៨-៦៩"។

[1316] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៥៥ កំណត់សម្គាល់ជើងទំព័រលេខ៣៤៧៣ "ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ (ថាន់ ធីម) ឯកសារ **E1/289.1** ទំព័រ ២១-២៤" និងកំណត់សម្គាល់ជើងទំព័រលេខ៣៤៧៧ "ប្រតិចារឹក ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ (ប៊ុន សារឿន) ឯកសារ **E1/288.1** ទំព័រ ៣១"។

ភ័ស្តុតាងតិចតួច។ អង្គជំនុំជម្រះពុំបានផ្តល់ការវិភាគណាមួយទាក់ទងនឹងភាពត្រឹមត្រូវនៃសម្តីដែលត្រូវបានរាយការណ៍នោះទេ ហើយលក្ខណៈជឿជាក់បានរបស់ពួកគាត់ គឺមិនអាចពឹងផ្អែកជាចម្បងលើសម្តីទាំងនេះបានទេ[1317]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះបានធ្វើការវាយតម្លៃមិនត្រឹមត្រូវលើភ័ស្តុតាងដោយពុំបានធ្វើការវិភាគណាមួយលើភាពជឿជាក់បានរបស់ ជាំង ស្រីមុំ នោះទេ។ អង្គជំនុំជម្រះបានត្រឹមលើកឡើងវិញនូវចម្លើយរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការដែលថា ឈ្លបបានតាមដានប្រជាជនថ្មី។ ប៉ុន្តែ ក្នុងសវនាការ ជាំង ស្រីមុំ គ្រាន់តែនិយាយថា អ្នកនៅតាមកងត្រូវគេសួរនាំក្នុងពេលសម្រាក ទាក់ទងនឹងប្រវត្តិរបស់ពួកគេ។ សក្ខីកម្មរបស់គាត់ មិនអាចឱ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានទាក់ទងនឹងវិសាលភាពនៃការតាមដាន និងលក្ខណៈរើសអើងបានទេ។ ភ័ស្តុតាងជាឯកសារដែលនិយាយថា មនុស្សតាមដានគ្នាទៅវិញទៅមក ពុំបានផ្តល់ធាតុផ្សំបន្ថែមដល់ប្រធានបទមួយនេះទេ[1318]។

៧៤១. ភ័ស្តុតាងទាំងឡាយដែលលើកឡើងដោយអង្គជំនុំជម្រះដើម្បីគាំទ្រកថាខណ្ឌ ១០៨០ នៃសំអាងហេតុសាលក្រម ក៏មិនអាចឱ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានបានដែរថា ប្រជាជនថ្មីអាចត្រូវចាប់ខ្លួននោះទេ។ ទាក់ទងនឹងប្រជាជនថ្មី អង្គជំនុំជម្រះបានបង្ហាញសេចក្តីរាយការណ៍ចំនួនពីរ ក្នុងនោះមានសេចក្តីរាយការណ៍ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៧៧ របស់ឃុំពពេល និងកំណត់ត្រាមួយចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៧ របស់ឃុំតាភេម[1319]។ សេចក្តីរាយការណ៍ទីមួយ គឺជាការស្នើសុំយោបល់ ទាក់ទងនឹងប្តីប្រពន្ធមួយគូ ដែលបានលួចរត់មួយលើក ហើយជាប្រជាជនថ្មី[1320]។ កំណត់ត្រាចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៧ សង្ខេបមកត្រឹមមួយឃ្លាថា "ស្នើតាមដានពិនិត្យសិន ប្រជាជនថ្មី ឬចាស់ សកម្មភាពយ៉ាងម៉េច

[1317] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៥៥ កំណត់សម្គាល់ជើងទំព័រលេខ៣៤៧៦ "ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ (វង សារុន) ឯកសារ **E1/300.1** ទំព័រ ៤៤-៤៥"។

[1318] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៥៥ កំណត់សម្គាល់ជើងទំព័រលេខ៣៤៨០ និង ៣៤៨១។

[1319] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៨០ កំណត់សម្គាល់ជើងទំព័រលេខ៣៥៨៩ និង ៣៥៩១។

[1320] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៨០ កំណត់សម្គាល់ជើងទំព័រលេខ៣៥៨៩, បណ្ណសារស្រុកត្រាំកក់ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2048** ERN 00079087-00079088។

ខ្លះទៀត ទៅមុខទៀតយ៉ាងម៉េច? ព្រោះវាយការណ៍មិនសូវច្បាស់"[1321]។ ដូច្នេះ ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះបាននិយាយ ការស្ថិតក្នុងប្រភេទជាប្រជាជនថ្មី ឬចាស់ គឺជាធាតុផ្សំដែលត្រូវសួរនាំក្នុងចំណោមធាតុផ្សំផ្សេងទៀត។

៧៤២. គ្មានចៅក្រមមានវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានថា មានការរើសអើងជាក់ស្តែងចំពោះប្រជាជនថ្មី ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងនេះបានទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះថា ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះប្រជាជនថ្មីនៅត្រាំកក់ ត្រូវបានបំពេញ ត្រូវទុកជាមោឃៈ។

## ៤. អវត្តមាននៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

៧៤៣. ជាលក្ខណៈចម្បង សូមរំឭកថា អង្គជំនុំជម្រះពុំត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុកើតឡើងប្រឆាំងនឹងពុទ្ធសាសនិក និងព្រះសង្ឃ នៅត្រាំកក់ទេ[1322]។ ដូចដែលបាននិយាយពីខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់បទចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ចំពោះពុទ្ធសាសនិក និងព្រះសង្ឃ ដោយពុំមានចេតនាដកពុទ្ធសាសនិកចេញពីមនុស្សជាតិ និងសង្គម[1323]។ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានថា ធាតុផ្សំនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនានៅត្រាំកក់ ត្រូវបានបំពេញ ព្រោះថាការប្រព្រឹត្តិដោយស្មើភាព គឺមិនអាចផ្សំបានជាការប្រព្រឹត្តិបែបរើសអើងបានឡើយ (៤.១) និងពីព្រោះគ្មានភស្តុតាងណាមួយទាក់ទងនឹងផលប៉ះពាល់ផ្លូវកាយ ឬផ្លូវចិត្តនៃព្រឹត្តិការណ៍ទាំងអស់នោះ មកលើពុទ្ធសាសនិក នោះដែរ (៤.២)។

---

[1321] សំអាងហេតុសាលក្រម កថាខណ្ឌ ១០៨០ កំណត់សម្គាល់ជើងទំព័រលេខ៣៥៩១, បណ្ណសារស្រុកត្រាំកក់ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/4107** ERN 00271016។

[1322] សូមមើលខាងលើ កថាខណ្ឌ ៤២៦-៤៣៤។

[1323] សូមមើលខាងលើ កថាខណ្ឌ ៦៤១-៦៥៦។

## ៤.១. ការប្រព្រឹត្តិស្មើភាព មិនផ្សំបានជាការប្រព្រឹត្តិបែបរើសអើង

### ៤.១.១. គ្មានការរើសអើងជាក់ស្តែងចំពោះព្រះសង្ឃ

៧៤៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយអះអាងថា "ការបង្ខំព្រះសង្ឃឱ្យបោះបង់ជំនឿរបស់ពួកគាត់ គឺជាការរើសអើងប្រឆាំងនឹងព្រះសង្ឃ" ព្រោះវាមាន "ផលប៉ះពាល់ខុសៗគ្នា ដែលផ្អែកដោយចៀសមិនផុតលើសារតារខុសៗគ្នារបស់ប្រជាជន"[1324]។ អង្គជំនុំជម្រះបានចាត់ទុកសញ្ញាណរើសអើងដោយប្រយោលជាក់ស្តែង ថាជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ និងដោយបានបកស្រាយបែបលក្ខណៈទូលាយនូវធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្ម ក្រៅក្របខ័ណ្ឌច្បាប់ទាំងស្រុង។ ប៉ុន្តែ នៅឆ្នាំ១៩៧៥ ដូចដែលនឹងបានឃើញនៅផ្នែកខាងក្រោម ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពុំបានរាប់បញ្ចូលការរើសអើងដោយប្រយោលទេ[1325]។ ហេតុដូច្នេះ ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពុំត្រូវបានបំពេញ ដោយពុំមានភ័ស្តុតាងបង្ហាញពីការរើសអើងដោយផ្ទាល់។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

### ៤.១.២. គ្មានការរើសអើងជាក់ស្តែង និងចេតនារើសអើងចំពោះពុទ្ធសាសនិក

៧៤៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអះអាងថា "ធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ត្រូវបានបង្ហាញទាក់ទងនឹងការបំផ្លិចបំផ្លាញនិមិត្តរូបតំណាងព្រះពុទ្ធសាសនា ការបាត់ខ្លួនអតីតព្រះសង្ឃ ការរឹបយកកន្លែងគោរពបូជា និងការហាមប្រាមលើការប្រតិបត្តិ ឬជំនឿសាសនា" ហើយនេះដោយមិនគិតថា តើគោលបំណងគឺដើម្បីឈានទៅសម្រេចឱ្យបានសមភាពដាច់ខាតមែនឬទេ[1326]។ ប៉ុន្តែ វិសាលភាពមិនរើសអើងនៃការហាមប្រាមមិនឱ្យមានសាសនាជាទូទៅ ដែលអនុវត្តចំពោះមនុស្សគ្រប់គ្នា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺផ្ទុយគ្នាទាំងស្រុងទៅនឹងសេចក្តីសន្និដ្ឋាន

[1324] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៥។

[1325] សូមមើលខាងក្រោម កថាខណ្ឌ ៩៥៤-៩៥៦។

[1326] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៦។

នេះ ដែលកំណត់អំពីការរើសអើងជាក់ស្ដែង។ តាមច្បាប់ ការរើសអើងតម្រូវឱ្យមានភាពខុសគ្នាក្នុងការប្រព្រឹត្ត។ ដូច្នេះ សេចក្ដីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ។

## ៤.២. គ្មានភ័ស្តុតាងអំពីផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តរបស់ពុទ្ធសាសនិក

៧៤៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានអះអាងថា “ផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្ត នៃព្រឹត្តិការណ៍ទាំងនេះ បានរំលោភលើសិទ្ធិជាមូលដ្ឋាន ក្នុងកម្រិតនៃភាពធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងបទល្មើសផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”[1327]។ អង្គជំនុំជម្រះបានផ្អែកលើសេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា ការលុបបំបាត់ការប្រតិបត្តិសាសនា ការលុបបំបាត់និមិត្តរូបនិយមសាសនា ការពុំមានលទ្ធភាពប្រគេចចង្ហាន់ គឺបានដកហូតពីប្រជាជននូវ “មូលដ្ឋានចិត្តសាស្ត្រ”[1328]។ សេចក្ដីសន្និដ្ឋានលើអង្គហេតុនេះ ផ្អែកលើសក្ខីកម្មអត្តនោម័តិ និងផ្ទាល់ខ្លួនតែមួយគត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន សារឿន ដែលនិយាយថា “គាត់យល់ថាគ្មានអ្វីជាទីពឹង” បើគ្មានវត្ត[1329]។ ភ័ស្តុតាងទីពីរដែលលើកឡើងដើម្បីវាយតម្លៃពីផលវិបាកនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា គឺជាការដែល “ជាទូទៅពិធីរៀបអាពាហ៍ពិពាហ៍មិនត្រូវបានធ្វើឡើងតាមប្រពៃណីខ្មែរឡើយ”[1330]។

៧៤៧. សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ផ្អែកលើភ័ស្តុតាងទាំងនេះ គឺជាការនិយាយសរុបទូទៅជ្រុលហួសហេតុ និងជាការសន្និដ្ឋានដែលគ្មានចៅក្រមមានវិចារណញ្ញាណណា អាចសន្និដ្ឋានបានបែបនេះនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ចំពោះពុទ្ធសាសនិកត្រូវបានបំពេញនោះទេ។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះនេះ ត្រូវទុកជាមោឃៈ។

---

[1327] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៦។

[1328] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៦ កំណត់សម្គាល់ជើងទំព័រលេខ៤០៣៩ យោងទៅ កថាខណ្ឌ ១១០៧។

[1329] សំអាងហេតុសាលក្រម កថាខណ្ឌ ១១០៧ កំណត់សម្គាល់ជើងទំព័រលេខ៣៦៩៩៖ “ប្រតិចារឹក ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ (ប៊ុន សារឿន) ឯកសារ **E1/288.1** ទំព័រ ២៦”។

[1330] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៦ កំណត់សម្គាល់ជើងទំព័រលេខ៤០៤០ យោងទៅ កថាខណ្ឌ ៣៦៣៨។

## ៥. កំហុសដោយបានសន្និដ្ឋានថាមានការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ចំពោះជនជាតិវៀតណាម

៧៤៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយល់ឃើញថាខ្លួនត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ពាក់ព័ន្ធនឹងការបញ្ជូនជនជាតិវៀតណាម នៅក្នុងស្រុកត្រាំកក់[1331]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីធាតុផ្សំសត្យានុម័តិ (៥.១) និងធាតុផ្សំអត្តនោម័តិ (៥.២) នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍។

### ៥.១. កំហុសដោយបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីធាតុផ្សំសត្យានុម័តិ

៧៤៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ ត្រូវបានបង្ហាញនៅក្នុងស្រុកត្រាំកក់ ដោយសារសកម្មភាពនៃការនិរទេសនៅក្នុងឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៦[1332]។ យោងតាមអង្គជំនុំជម្រះ អំពើទាំងនោះ គឺជាការរើសអើងជាក់ស្តែង និងជាការរំលោភលើ "សេរីភាព និងសិទ្ធិជាមូលដ្ឋាន" របស់អ្នកទាំងនោះ[1333]។

៧៥០. ក៏ប៉ុន្តែ មេធាវីការពារក្តីបានបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការនិរទេស ទាក់ទងនឹងជនជាតិវៀតណាមក្នុងស្រុកត្រាំកក់ ត្រូវបានបង្ហាញ[1334]។ អង្គជំនុំជម្រះគ្មានភ័ស្តុតាងដែលអាចឱ្យខ្លួននិយាយបានថា ជនជាតិវៀតណាមដែលត្រូវបានប្រមូលនៅក្នុងស្រុកត្រាំកក់ គឺត្រូវបានបណ្តេញចេញផុតពីព្រំដែនវៀតណាមនោះទេ។ ដូច្នេះ ដោយគ្មានភ័ស្តុតាងបង្ហាញពីការនិរទេស អង្គជំនុំជម្រះពុំមាន

---

[1331] សូមមើលខាងលើ កថាខណ្ឌ ៣៨០-៣៨៥, ៤១៦-៤១៧។

[1332] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៩០។

[1333] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៩-១១៩០។

[1334] សូមមើលខាងលើ កថាខណ្ឌ ៦៨៦-៧១៨។

គ្មានភ័ស្តុតាងធ្វើជាសំអាងថាមានការរើសអើងជាក់ស្តែង ដែលប្រមាថដល់សិទ្ធិជាមូលដ្ឋាន ទទួលស្គាល់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់អនុសញ្ញា បាននោះទេ[1335]។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះគួរត្រូវដកចេញ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ នៅក្នុងស្រុកត្រាំកក់[1336]។

## ៥.២. កំហុសដោយបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីធាតុផ្សំអត្តនោម័តិ

៧៥១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយយល់ឃើញថាធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ នៅក្នុងស្រុកត្រាំកក់ ត្រូវបានបង្ហាញ[1337]។ ដើម្បីអាចធ្វើសេចក្តីសន្និដ្ឋាននេះបាន អង្គជំនុំជម្រះផ្អែកលើធាតុផ្សំបី៖ "ការផ្តល់សេចក្តីណែនាំ និងបញ្ជាក់ពាក់ព័ន្ធនឹងការដឹកជញ្ជូនវៀតណាម របាយការណ៍សម័យកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងឯកសារបោះពុម្ពផ្សាយនាសម័យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងទស្សនាវដ្តីទង់បដិវត្ត ដែលកំណត់គោលដៅលើជនជាតិវៀតណាម"[1338]។ អង្គជំនុំជម្រះពុំបានធ្វើការយោងណាមួយដែលអាចឱ្យគេកំណត់បានអំពីភ័ស្តុតាងគាំទ្រធាតុផ្សំទាំងនេះ ហើយមេធាវីការពារក្តីបានត្រឹមតែព្យាយាមទាយមើលថាតើភ័ស្តុតាងមួយណាដែលត្រូវប្រើធ្វើជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋាននេះ។

៧៥២. ការវិភាគរបស់អង្គជំនុំជម្រះបានបង្ហាញឱ្យឃើញថាមាន "ការណែនាំឱ្យសម្លាប់ និងបោសសម្អាតប្រជាជនវៀតណាម ក្នុងអំឡុងពេលដែលពួកគេត្រូវបានបង្ខំឱ្យចាកចេញពីស្រុក"[1339]។ បើយោងតាមអង្គជំនុំជម្រះដដែល "ភ័ស្តុតាងបង្ហាញពីការណែនាំយ៉ាងច្បាស់លាស់ឱ្យសម្លាប់ប្រជាជនវៀតណាម ពី

---

[1335] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៣។

[1336] សំអាងហេតុសាលក្រម កថាខណ្ឌ ១១១០-១១២៥, ១១៨៩-១១៩២, ៤០០៥, ៤២៩២ និង ៤៣០៦។

[1337] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៩១។

[1338] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៩១។

[1339] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៧។

ថ្នាក់ស្រុក"[1340]។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងនេះ ពុំបានគាំទ្រដល់ការណែនាំទាក់ទងនឹងការដឹកជញ្ជូនប្រជាជនវៀតណាមទេ។

៧៥៣. ពាក់ព័ន្ធនឹងសេចក្តីរាយការណ៍នានាវិញ អង្គជំនុំជម្រះបង្ហាញតែសេចក្តីរាយការណ៍ចំនួនមួយគត់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ នៅក្នុងឃុំពពេល ដែលថាគ្រួសារខ្មែរក្រោមមួយចំនួន ត្រូវបានដោះដូរជាមួយប្រជាជនវៀតណាម។ ក៏ប៉ុន្តែ សេចក្តីរាយការណ៍នេះមិនត្រឹមតែពុំបានផ្តល់ព័ត៌មានណាមួយទាក់ទងនឹងចំនួន និងប្រភពរបស់ជនជាតិវៀតណាមដែលត្រូវបានដោះដូរទេ តែសេចក្តីរាយការណ៍នេះថែមទាំងមិនអាចបង្ហាញឱ្យឃើញពីចេតនារើសអើងចំពោះជនជាតិវៀតណាម នៅក្នុងស្រុកត្រាំកក់ទៀតផង[1341]។

៧៥៤. ជាចុងក្រោយ អង្គជំនុំជម្រះបានយោងទៅទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦ ដែលប្រកាសថា ជនបរទេសរាប់ពាន់នាក់ ត្រូវបានបណ្តេញចេញពីប្រទេស។ ក៏ប៉ុន្តែ ការស្មានរបស់អង្គជំនុំជម្រះដែលថា ទស្សនាវដ្តីទង់បដិវត្តនេះសំដៅលើជនជាតិវៀតណាមដែលត្រូវបណ្តេញចេញ មិនអាចបង្ហាញឱ្យឃើញពីចេតនារើសអើងចំពោះជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ពាក់ព័ន្ធនឹងអង្គហេតុនៃការនិរទេសក្នុងឆ្នាំ១៩៧៥ និង ១៩៧៦ បានទេ[1342]។

៧៥៥. ដូច្នេះ អង្គជំនុំជម្រះគ្មានភ័ស្តុតាងណាមួយដែលអាចឱ្យសន្និដ្ឋានបានថា មានចេតនាណាមួយក្នុងការកំណត់គោលដៅចំពោះជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ដោយសាររឿងពូជសាសន៍ ពាក់ព័ន្ធនឹងអង្គហេតុនៃការនិរទេសក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ បាននោះទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងធាតុផ្សំអត្តនោម័តិ ត្រូវតែដកចេញ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ នៅស្រុកត្រាំកក់[1343]។

1340 សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៨។

1341 បណ្ណសារស្រុកត្រាំកក់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/2048** ERN 00079090។

1342 សូមមើលខាងលើ កថាខណ្ឌ ៧០៦-៧០៨។

1343 សំអាងហេតុសាលក្រម កថាខណ្ឌ ១១១០-១១២៥, ១១៨៩-១១៩២, ៤០០៥, ៤២៩២ និង ៤៣០៦។

## ៦. កំហុសដោយបានសន្និដ្ឋានថាមានការបាត់ខ្លួនដោយបង្ខំចំពោះជនជាតិវៀតណាម

៧៥៦. ក្រៅពីការប្រព្រឹត្តិខុសដោយយល់ឃើញថា អង្គហេតុនៃការបាត់ខ្លួនដោយបង្ខំនៅត្រាំកក់ អាចសំដៅចំពោះជនជាតិវៀតណាម[1344] អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយបានសន្និដ្ឋានថា "ប្រជាជនវៀតណាមត្រូវបានប្រមូលនៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ដោយបន្ទាប់ពីនោះ ពួកគេត្រូវបាននិរទេស និង/ឬបាត់ខ្លួនពីស្រុកត្រាំកក់"[1345]។ ដើម្បីលើកឡើងវិញនូវទឡ្ហីករណ៍ទាក់ទងនឹងការនិរទេស[1346] ការប្រើប្រាស់អាយតនិបាតពីរត្រួតគ្នា "និង/ឬ" បង្ហាញឱ្យឃើញថា អង្គជំនុំជម្រះពុំមានលទ្ធភាពសន្និដ្ឋានថាមានការបាត់ខ្លួនដោយបង្ខំ ជាជាងការនិរទេស ឱ្យហួសពីវិមតិសង្ស័យ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះថែមទាំងពុំបានព្យាយាមបង្ហាញឱ្យឃើញពីការបំពេញបាននូវធាតុផ្សំនៃឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ទាក់ទងនឹងជនជាតិវៀតណាមទៀតផង[1347]។ ប្រឈមនឹងភាពមិនច្បាស់លាស់នេះ អង្គជំនុំជម្រះមិនអាចសន្មតដូចដែលខ្លួនធ្លាប់បានធ្វើ ថាឧក្រិដ្ឋកម្មនេះត្រូវបានបង្ហាញ ដោយមិនរំលោភលើគោលការណ៍សច្ចធារណ៍និរទោសបាននោះទេ[1348]។ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ចែងថារាល់ភាពមិនច្បាស់លាស់ត្រូវតែដោះស្រាយឱ្យបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ អង្គជំនុំជម្រះមិនគួរសន្និដ្ឋានថាមានការបាត់ខ្លួនជនជាតិវៀតណាមដោយបង្ខំ នៅក្នុងស្រុកត្រាំកក់ និងមិនគួរផ្តន្ទាទោស ខៀវ សំផន សម្រាប់ការបាត់ខ្លួនទាំងនេះនោះទេ[1349]។

---

[1344] សូមមើលខាងលើ កថាខណ្ឌ ៥៤៧-៥៤៩។

[1345] សំអាងហេតុសាលក្រម កថាខណ្ឌ ១២១០។

[1346] សូមមើលខាងលើ កថាខណ្ឌ ៦៩២-៦៩៣។

[1347] សំអាងហេតុសាលក្រម កថាខណ្ឌ ១២០១-១២០៤ (ការវិនិច្ឆ័យរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការបំពេញបាននូវធាតុផ្សំនៃឧក្រិដ្ឋកម្ម យោងតែទៅលើកថាខណ្ឌ ១០៧១ ដែលបង្ហាញពីអង្គហេតុនៃការបាត់ខ្លួននៅក្នុងស្រុកត្រាំកក់ ដែលមិនពាក់ព័ន្ធនឹងជនជាតិវៀតណាម)។

[1348] សូមមើលខាងលើ កថាខណ្ឌ ២៣៧។

[1349] សំអាងហេតុសាលក្រម កថាខណ្ឌ ១២០១, ៣៩២៧, ៣៩២៨, ៤២៨២ និង ៤៣០៦។

## ៧. កំហុសដោយបានសន្និដ្ឋានថាមានការបាត់ខ្លួនខ្មែរក្រោមដោយបង្ខំ

៧៥៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានថាមានការបាត់ខ្លួនខ្មែរក្រោម ក្នុងឋានៈជាក្រុម[1350] ខណៈដែលយោងតាមសេចក្ដីសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះមិនត្រូវបានស្នើសុំដោយត្រឹមត្រូវឱ្យពិនិត្យលើអង្គហេតុពាក់ព័ន្ធនឹងខ្មែរក្រោមនោះទេ[1351]។ ដោយសារតែអង្គហេតុទាំងនេះមិនស្ថិតនៅក្នុងវិសាលភាពនៃរឿងក្ដី ដូច្នេះ វារឹតតែមិនអាច "មានភាពពាក់ព័ន្ធជាមួយនឹងបទចោទប្រកាន់ផ្សេងៗទៀត" ថែមទៀត[1352]។ ដូច្នេះ គឺដោយពុំត្រឹមត្រូវ និងខុសច្បាប់ទាំងស្រុងតែម្ដង ដែលអង្គជំនុំជម្រះបានប្រើប្រាស់ភ័ស្ដុតាងក្រៅវិសាលភាពទាំងនេះ សម្រាប់គាំទ្រធាតុផ្សំនៃឧក្រិដ្ឋកម្ម ក្នុងនោះមាន អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ជាដើម។ ដូច្នេះ អង្គជំនុំជម្រះមិនគួរសន្និដ្ឋានថាមានការបាត់ខ្លួនខ្មែរក្រោមដោយបង្ខំ នៅក្នុងស្រុកត្រាំកក់ និងមិនគួរផ្ដន្ទាទោស ខៀវ សំផន សម្រាប់ការបាត់ខ្លួនទាំងនេះទេ។ ដូច្នេះ សេចក្ដីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ[1353]។

## ផ្នែកទី ២. ទំនប់ត្រពាំងថ្ម

## ១. គ្មានអំពើមនុស្សឃាតដោយចេតនាប្រយោល

៧៥៨. អនុលោមតាមដីកាដំណោះស្រាយ អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យជាបឋមលើអង្គហេតុនៃការសម្លាប់រង្គាល។ ដូច្នេះ ខៀវ សំផន ត្រូវឆ្លើយតបចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាម រយៈការសម្លាប់រង្គាល ដោយសារតែការស្លាប់បណ្ដាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅ នៅទីតាំងទំនប់ត្រពាំងថ្ម[1354]។ ក៏ប៉ុន្តែ ដោយពុំមានភ័ស្ដុតាងបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល អង្គជំនុំជម្រះបានកំណត់បទចោទប្រកាន់ឡើងវិញដោយខុសច្បាប់ ទៅជាការធ្វើមនុស្សឃាតដោយចេតនាប្រយោល

---

1350 សំអាងហេតុសាលក្រម កថាខណ្ឌ ១២០១។

1351 សំអាងហេតុសាលក្រម កថាខណ្ឌ ៨១៦។

1352 សូមមើលខាងលើ កថាខណ្ឌ ៦៨៧-៦៨៨។

1353 សំអាងហេតុសាលក្រម កថាខណ្ឌ ១២០១, ៣៩២៧, ៣៩២៨, ៤២៨២ និង ៤៣០៦។

1354 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨១, ១៣៨៧, សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៣។

ដែលនាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គច្បាស់ និងដែលធ្វើឱ្យសេចក្តីសម្រេចរបស់ខ្លួនគ្មានសុពលភាព[1355]។

៧៥៩. បន្ទាប់មក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងការកំណត់ប្រភេទបទល្មើសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត។ ម្យ៉ាង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនបានកំណត់តាមផ្លូវគតិយុត្តិនូវប្រភេទ និងវិសាលភាពនៃកាតព្វកិច្ចក្នុងការចាត់វិធានការដែលទម្លាក់ទៅលើចារីផ្ទាល់ ទាក់ទងនឹងការស្លាប់បណ្តាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅ នៅទីតាំងទំនប់ត្រពាំងថ្ម។ ដើម្បីកំណត់ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត អង្គជំនុំជម្រះយល់ឃើញថា "អំពើសកម្ម ឬអកម្មកើតឡើងតាមរយៈការដាក់ល័ក្ខខ័ណ្ឌលើអ្នកធ្វើការដូចបានរៀបរាប់ខាងលើ ដែលបង្កឱ្យពួកគេស្លាប់។ ករណីនេះរួមទាំងគ្មានឆន្ទៈក្នុងការកែប្រែម៉ោងធ្វើការ និងល័ក្ខខ័ណ្ឌការងារ ឬល័ក្ខខ័ណ្ឌនៃការរស់នៅទៅតាមតម្រូវការរបស់អ្នកធ្វើការ ព្រមទាំងឆន្ទៈក្នុងការមិនផ្តល់តំហែទាំសុខភាពជាមូលដ្ឋានសមស្របផងដែរ"[1356]។ ដូច្នេះ អង្គជំនុំជម្រះពុំបានបញ្ជាក់ថា កាតព្វកិច្ចក្នុងការចាត់វិធានការមួយណាដែលត្រូវបានរំលោភ និងអនុលោមតាមវិធានណាខ្លះ ដែលអាជ្ញាធរទទួលបន្ទុកទីតាំងទំនប់ត្រពាំងថ្ម មានកាតព្វកិច្ចចាត់វិធានការ ដើម្បីធានាល័ក្ខខ័ណ្ឌនៃការរស់នៅ "ទៅតាម" និង "សមស្រប" តាមតម្រូវការរបស់កម្មករ។ ផ្ទុយទៅវិញ នៅត្រង់កថាខណ្ឌ ៦២៧ នៃសំអាងហេតុសាលក្រមរងការជំទាស់ អង្គជំនុំជម្រះបានរំឭកដោយត្រឹមត្រូវថា "អំពើអកម្មនឹងមានពិរុទ្ធភាព តែក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការប៉ុណ្ណោះ"។ ដូច្នេះ ដោយនិយាយផ្ទុយទៅនឹងអ្វីដែលមាននៅក្នុងសំអាងហេតុរបស់ខ្លួន និងដោយពុំបានកំណត់ឱ្យបានត្រឹមត្រូវអំពីកាតព្វកិច្ចក្នុងការចាត់វិធានការរបស់អាជ្ញាធរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដែលធ្វើឱ្យសេចក្តីសន្និដ្ឋាននេះគ្មានសុពលភាព[1357]។

៧៦០. ម្យ៉ាងទៀត ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិ អង្គជំនុំជម្រះបានកំណត់ចេតនាប្រយោលដូចខាងក្រោម៖

---

[1355] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៣-១៣៩០។ សូមមើលខាងលើ កថាខណ្ឌ ១៣៥-១៥៧។

[1356] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៨។

[1357] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៨។

"ការបន្តឱ្យមានល័ក្ខខ័ណ្ឌទាំងនេះក្នុងរយៈពេលយូរ រួមទាំងក្រោយពីអាជ្ញាធរនៅការដ្ឋានការងារដឹងច្បាស់អំពីផលប៉ះពាល់លើពួកគេក៏ដោយនោះ បង្ហាញថាអាជ្ញាធរនៅការដ្ឋានការងារ ស្ម័គ្រចិត្តដាក់ល័ក្ខខ័ណ្ឌបែបនេះ ដោយដឹងថាវានឹងបណ្តាលឱ្យជនរងគ្រោះស្លាប់ ឬព្រមទទួលយកលទ្ធភាពនៃផលវិបាកដែលអាចបណ្តាលឱ្យមានការស្លាប់បែបនេះ។ ចំណុចនេះបំពេញធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ក្នុងទម្រង់ជាចេតនាប្រយោល"[1358]។

៧៦១. ដូចដែលបានចង្អុលបង្ហាញខាងលើ នៅក្នុងសារណានេះ ការអនុវត្តនូវចេតនាប្រយោលនៅសម័យកាលអង្គហេតុនេះ គឺបង្កើតឱ្យមានកំហុសអង្គច្បាប់[1359]។ នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត អាចត្រូវកំណត់បានតែជាមួយនឹងចេតនាផ្ទាល់ក្នុងការសម្លាប់មួយប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមានកំហុសផងដែរក្នុងការវាយតម្លៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត។ ការវាយតម្លៃលើធាតុផ្សំអត្តនោម័តិ គឺជាការពិនិត្យបែបអត្តនោម័តិ ដូច្នេះ គេត្រូវផ្តើមចេញពីទស្សនៈរបស់ចារីនៃបទល្មើស។ ក៏ប៉ុន្តែ នៅទីនេះ ទំនាក់ទំនងរវាងហេតុ និងផល រវាងវិធានការដែលដាក់ឱ្យអនុវត្តដោយឆន្ទៈរបស់អាជ្ញាធរដើម្បីកសាងប្រទេសឡើងវិញ កត្តាដាច់ដោយឡែកផ្សេងៗដែលកើតឡើង - ដោយពុំគិតពីកត្តាដែលមានពីមុន - និងផលប៉ះពាល់លើប្រជាជន មិនអាចកំណត់បានទេ។ ហេតុដូច្នេះ វាមានភាពមិនច្បាស់លាស់លើកត្តាទាំងឡាយដែលបណ្តាលឱ្យមានមហន្តរាយមនុស្សធម៌ ហើយការទទួលយកហានិភ័យ គឺអាស្រ័យលើការវាយតម្លៃខាងលើនេះ។ ចេតនាឧក្រិដ្ឋ ត្រូវវាយតម្លៃមុនការប្រព្រឹត្តិបទឧក្រិដ្ឋ មិនមែនក្រោយនោះទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយពុំបានវាយតម្លៃភ័ស្តុតាងឱ្យបានច្បាស់លាស់ ទាក់ទងនឹងពេលវេលា។ ក៏ប៉ុន្តែ អង្គជំនុំជម្រះយល់ឃើញថា គឺ "ការបន្តឱ្យមានល័ក្ខខ័ណ្ឌទាំងនេះក្នុងរយៈពេលយូរ" ដែលជាធាតុផ្សំអត្តនោម័តិ។ ដូច្នេះ អង្គជំនុំជម្រះមានកាតព្វកិច្ចធ្វើការលម្អិតឱ្យបានច្បាស់លាស់នូវបទដ្ឋានពេលវេលានេះ តាមរយៈភ័ស្តុតាង

[1358] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៩។

[1359] សូមមើលខាងលើ កថាខណ្ឌ ៥៧៥-៦៣៧។

ដែលខ្លួនមាន។ ក្នុងស្ថានភាពនេះ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះ ទាក់ទងនឹងធាតុផ្សំ អត្តនោម័តិ ត្រូវទុកជាមោឃៈ[1360]។

៧៦២. សរុបសេចក្តីមក អង្គជំនុំជម្រះគួរតែសន្និដ្ឋានឱ្យបានសមហេតុសមផលថា ឧក្រិដ្ឋកម្មដែលលើកឡើង ពុំត្រូវបានបង្ហាញទេ ហើយគួរតែឱ្យ ខៀវ សំផន រួចផុតពីអង្គហេតុដែលរងការចោទប្រកាន់នេះ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់ត្រូវទុកជាមោឃៈដោយតុលាការកំពូល[1361]។

## ២. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៧៦៣. អង្គជំនុំជម្រះយល់ឃើញថា ខ្លួនត្រូវបានស្នើឱ្យពិនិត្យលើឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ នៅទីតាំងទំនប់ត្រពាំងថ្ម ពាក់ព័ន្ធនឹង "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក" ដែលពួកគេ "ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជន ផ្សេងទៀត"[1362]។ ដូចបានឃើញពីខាងលើ នៅក្នុងផ្នែកទាក់ទងនឹងបណ្តឹង អង្គជំនុំជម្រះត្រូវបានស្នើ ឱ្យកាត់សេចក្តីតែលើអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះប្រជាជនថ្មី ប៉ុណ្ណោះ[1363]។ បើយោងតាមអង្គជំនុំជម្រះ គឺមានការបង្ហាញឱ្យឃើញថា ប្រជាជនថ្មីត្រូវបានគេធ្វើ បាប និងដាក់ឱ្យស្ថិតក្នុងស្ថានភាពលំបាកជាងប្រជាជនផ្សេងទៀត៖

> "ប្រជាជនថ្មីត្រូវគេផាត់ចេញពីតំណែងជាមេដឹកនាំ ដោយប្រគល់ទៅឱ្យប្រជាជនចាស់ ដែល មានភារកិច្ចតាមដានប្រជាជនថ្មីនៅក្នុងអង្គភាពខ្លួន"[1364]។

---

[1360] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៩។

[1361] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៣-១៣៩០។

[1362] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤០៥, ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៨។

[1363] សូមមើលខាងលើ កថាខណ្ឌ ៤៨២-៤៨៣។

[1364] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤០៩។

៧៦៤. នេះជាសេចក្តីសន្និដ្ឋានតែមួយគត់របស់អង្គជំនុំជម្រះ ដើម្បីកំណត់អំពីការរើសអើងចំពោះប្រជាជនថ្មី។ ក្នុងនោះ អង្គជំនុំជម្រះបានយោងទៅលើកថាខណ្ឌ ១៣៤៥ នៃសំអាងហេតុសាលក្រមរងការជំទាស់ ដែលកថាខណ្ឌនេះលើកឡើងពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត។ ជាក់ស្តែង ក្នុងពេលផ្តល់សក្ខីកម្ម សម ស័ក្ត បានថ្លែងថា៖

> "ជំនាន់នោះ ប្រហាក់ប្រហែលគ្នា ព្រោះសុទ្ធតែពួកចេញពីទីក្រុងដូចគ្នា ធ្វើកងចល័តសុទ្ធតែ ១៧មេសាដូចគ្នា។ មានដែរ មានមូលដ្ឋានគេមានដែរ មិនអត់ទេមាន តែមូលដ្ឋានហ្នឹងគេយកតែថ្នាក់ គេហៅថាមើលយើង មើលការខុសត្រូវយើង ខុសត្រូវអីគេមើលលើយើង និយាយខុសនិយាយត្រូវអីគេមើលលើយើង ប៉ុណ្ណឹង"[1365]។

៧៦៥. ម្យ៉ាង អង្គជំនុំជម្រះផ្អែកតែលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីធ្វើជាសំអាងសម្រាប់ការប្រកាសអំពីពិរុទ្ធភាពនេះ ដែលវាពិតជាមិនគ្រប់គ្រាន់នោះទេ។ វាមិនសមហេតុសមផលទេ ដែលទាញសេចក្តីសន្និដ្ឋានទូទៅលើទីតាំងទំនប់ត្រពាំងថ្មទាំងមូល ដោយផ្អែកលើមូលដ្ឋានសក្ខីកម្មតែមួយ។ ម្យ៉ាងទៀត ទោះបីជា សម ស័ក្ត បានបង្ហាញពីតួនាទីផ្សេងគ្នារវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីក៏ដោយ ក៏គាត់បាននិយាយដែរថា គាត់មានអារម្មណ៍ "ប្រហាក់ប្រហែលគ្នា [...] កងចល័ត [...] ដូចគ្នា" ដែលជាការពិត ភាគច្រើនជាប្រជាជនថ្មី តែមិនមែនទាំងអស់នោះទេ។ ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានអំពីពិរុទ្ធភាពនេះ អង្គជំនុំជម្រះបានបំភ្លៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀត ដើម្បីកំណត់លក្ខណៈឧក្រិដ្ឋកម្មនេះ អង្គជំនុំជម្រះយល់ឃើញថា៖

> "អំពើដែលប្រព្រឹត្តលើក្រុមអ្នកធ្វើការទាំងនោះ បានរំលោភបំពានសិទ្ធិជាមូលដ្ឋានរបស់ពួកគេពាក់ព័ន្ធនឹងការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន សេរីភាព និងសន្តិសុខ និងការរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត ឬខុសច្បាប់ ដូចមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[1366]។

---

[1365] <u>សម ស័ក្ត</u>៖ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ម៉ោងប្រហែល ១០.០៨.៤៧។

[1366] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤១១។

៧៦៦. ប្រសិនបើគេលើកឡើងវិញអំពីសក្ខីកម្មរបស់ សម ស័ក្ត ដែលអង្គជំនុំជម្រះយកមកធ្វើជាសំអាង គឺវាបង្ហាញថាប្រជាជនចាស់លួចស្តាប់ និងតាមដានប្រជាជនថ្មី។ ការប្រព្រឹត្តិដែលត្រូវបានពណ៌នានេះ ពោលគឺការដែលមានកម្មករជាប្រជាជនចាស់តាមដាន ពុំទាន់ដល់កម្រិតនៃភាពធ្ងន់ធ្ងរតម្រូវសម្រាប់កំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទេ[1367]។

៧៦៧. សរុបសេចក្តីទៅ ភ័ស្តុតាងទាក់ទងនឹងការប្រព្រឹត្តិចំពោះប្រជាជនថ្មី មិនអាចឱ្យគេកត់សម្គាល់បានថាមានការរំលោភណាមួយលើសិទ្ធិជាមូលដ្ឋាននោះទេ ហើយក៏មិនអាចឱ្យនិយាយបានថា អំពើទាំងនោះបានឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរដែលជាល័ក្ខខ័ណ្ឌតម្រូវនោះដែរ។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញបានទេ។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងឡាយត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់[1368]។

### ផ្នែកទី ៣. ទំនប់១មករា

### ១. គ្មានអំពើមនុស្សឃាត ដោយចេតនាប្រយោល

៧៦៨. សូមរំឭកថា ជាលក្ខណៈចម្បង អង្គជំនុំជម្រះមិនត្រូវបានស្នើសុំឱ្យកាត់សេចក្តីលើការសម្លាប់មនុស្សនៅវត្តបារាយណ៍ជាន់ដែក[1369] ការស្លាប់បណ្តាលមកពីគ្រោះថ្នាក់[1370] និងការស្លាប់កើតឡើងក្រៅទំនប់ ១មករា នោះទេ[1371]។ គួររំឭកដែរថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយចេតនាប្រយោល ពុំមានអត្ថិភាពទេ នៅសម័យកាលនៃអង្គហេតុ ហើយថាអង្គជំនុំជម្រះបាន

---

[1367] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤១២។

[1368] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤០៧-១៤១៣។

[1369] សូមមើលខាងលើ កថាខណ្ឌ ៣៨៨-៣៩០។

[1370] សូមមើលខាងលើ កថាខណ្ឌ ៣៩១-៣៩២, ៤៨៧-៤៨៩។

[1371] សូមមើលខាងលើ កថាខណ្ឌ ៤៨៤-៤៨៦។

ប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានយល់ឃើញផ្ទុយពីនេះ[1372]។ ជាចុងក្រោយ ដូចដែលបាននិយាយពីខាងលើ ដោយពុំមានភ័ស្តុតាងបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល អង្គជំនុំជម្រះបានកំណត់បទចោទប្រកាន់ឡើងវិញដោយខុសច្បាប់ ទៅជាការធ្វើមនុស្សឃាតដោយចេតនាប្រយោលដែលធ្វើឱ្យអង្គជំនុំជម្រះមានកំហុសអង្គច្បាប់ នាំឱ្យសេចក្តីសម្រេចគ្មានសុពលភាព[1373]។ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ធាតុផ្សំសត្យានុម័តិនៃអំពើអកម្ម "នាំឱ្យមានពិរុទ្ធ" (១.១) និងកំហុសអង្គហេតុ ដោយបានផ្អែកលើសេចក្តីកត់សម្គាល់មិនសមហេតុផលមួយចំនួន ដើម្បីបង្ហាញឱ្យឃើញពីធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាតដោយចេតនាប្រយោល (១.២)។

## ១.១. កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអំពើអកម្ម "នាំឱ្យមានពិរុទ្ធ"

៧៦៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនបានកំណត់អំពីកាតព្វកិច្ចក្នុងការចាត់វិធានការដែលជាមូលដ្ឋាននៃលក្ខណៈមានពិរុទ្ធភាពនៃអំពើអកម្ម និងលក្ខណៈវិនិច្ឆ័យ ក៏ដូចជាការវិនិច្ឆ័យដែលនាំទៅដល់ការធ្វើសេចក្តីសន្និដ្ឋានថា វិធានការដាក់ចេញ គឺពុំសមស្រប។

៧៧០. ជាបឋម អង្គជំនុំជម្រះបានប្រកាសថា ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅទំនប់១មករា ត្រូវបានបំពេញ ម្យ៉ាងតាមរយៈ "ការដាក់ឱ្យអ្នកធ្វើការទទួលរងនូវល័ក្ខខ័ណ្ឌដែលបណ្តាលឱ្យពួកគេស្លាប់" និងម្យ៉ាងទៀត តាមរយៈអំពើអកម្ម "ដោយសារការមិនមានវិធានការសមស្របដើម្បីផ្លាស់ប្តូរ ឬលុបបំបាត់ល័ក្ខខ័ណ្ឌបែបនេះ"[1374]។ អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ ដោយមិនបានកំណត់តាមផ្លូវគតិយុត្តិនូវប្រភេទ និងវិសាលភាពនៃកាតព្វកិច្ចក្នុងការចាត់វិធានការ ដែលទម្លាក់ទៅលើចារីផ្ទាល់ ពាក់ព័ន្ធនឹងការស្លាប់អ្នកធ្វើការពី ៦ ទៅ ១០ នាក់ នៅទំនប់១មករា ការស្លាប់បណ្តាលមកពីការបាក់ដី និងការស្លាប់របស់ "អ្នកធ្វើការជាច្រើន" នាក់

---

[1372] សូមមើលខាងលើ កថាខណ្ឌ ៥៧៥-៦៣៧។

[1373] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៣៨-១១៥៥។ សូមមើលខាងលើ កថាខណ្ឌ ១៣៥-១៥៧។

[1374] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧២។

បណ្តាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅកើតឡើងនៅទំនប់១មករា[1375]។ នៅកថាខណ្ឌ ៦២៧ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានរំឭកដោយត្រឹមត្រូវថា "អំពើអកម្មនឹងមានពិរុទ្ធភាព តែក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការប៉ុណ្ណោះ"។ ក៏ប៉ុន្តែ អង្គជំនុំជម្រះពុំបានចង្អុលបង្ហាញថាតើកាតព្វកិច្ចក្នុងការចាត់វិធានការមួយណាដែលត្រូវបានរំលោភ ហើយអនុលោមតាមវិធានអ្វីដែលអាជ្ញាធរនៅទំនប់១មករា មានកាតព្វកិច្ចចាត់ "វិធានការសមស្របដើម្បីផ្លាស់ប្តូរ ឬលុបបំបាត់ល័ក្ខខ័ណ្ឌបែបនេះ"។ សេចក្តីសន្និដ្ឋានទាក់ទងនឹងលក្ខណៈជាប់ពិរុទ្ធនៃអំពើអកម្មនេះ គឺធ្វើឡើងក្រៅក្របខ័ណ្ឌច្បាប់ និងដោយពុំមានការវិភាគអង្គច្បាប់ និងអង្គហេតុ ហើយត្រូវទុកជាមោឃៈ។

៧៧១. លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអនុវត្តលក្ខណៈវិនិច្ឆ័យពុំត្រឹមត្រូវសម្រាប់វាយតម្លៃអំពើអកម្មនាំឱ្យមានពិរុទ្ធ ដែលកំណត់ធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាត។ អង្គជំនុំជម្រះពុំបានកំណត់តាមផ្លូវច្បាប់ ថាតើវិធានការនានាដែលដាក់ចេញដោយចារីផ្ទាល់ មិនសមស្របដូចម្តេចទៅ ហើយតើលក្ខណៈវិនិច្ឆ័យគតិយុត្តិមួយណាដែលត្រូវអនុវត្ត ដើម្បីកំណត់អំពីលក្ខណៈសមស្របនៃវិធានការទាំងនេះ[1376]។ ការពុំបានផ្តល់សំអាងហេតុលើចំណុចនេះដោយអង្គជំនុំជម្រះ គឺបានន័យថាអង្គជំនុំជម្រះពុំបានធ្វើការវិភាគ និងកំណត់តាមផ្លូវគតិយុត្តិ។ អង្គជំនុំជម្រះបង្ហាញឱ្យឃើញផងដែរពីភាពលម្អៀងរបស់ខ្លួន។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា ធាតុផ្សំសត្យានុម័តិត្រូវបានបំពេញ ពាក់ព័ន្ធនឹងអំពើអកម្មនាំឱ្យមានពិរុទ្ធ ត្រូវទុកជាមោឃៈ[1377]។

## ១.២. ភាពមិនសមហេតុផលនៃការកត់សម្គាល់ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃអំពើមនុស្សឃាត ដោយចេតនាប្រយោល

៧៧២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាត ដោយចេតនាប្រយោល ត្រូវបានបំពេញនៅទំនប់១មករា[1378]។ គ្មានករណីណាមួយក្នុងចំណោម

[1375] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧០, ១៦៧២។

[1376] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧២។

[1377] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧២-១៦៧៣។

[1378] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧០, ១៦៧២-១៦៧៣។

ករណីទាំងឡាយដែលលើកឡើងយកមកជាសំអាងនៃសេចក្តីសន្និដ្ឋាននេះ ត្រូវបានបង្ហាញឱ្យឃើញស្របទៅតាមលក្ខខ័ណ្ឌតម្រូវនៃកម្រិតនៃភស្តុតាងនោះទេ ទាំងចំពោះការស្លាប់របស់អ្នកធ្វើការពី ៦ ទៅ ១០ នាក់ ដែលរងការចោទប្រកាន់ នៅទំនប់១មករា (១.២.១) ការស្លាប់បណ្តាលមកពីគ្រោះថ្នាក់ (១.២.២) ឬទាំងការសន្និដ្ឋានថាមានការស្លាប់ក្នុងចំនួនច្រើនក្តី (១.២.៣)។

### ១.២.១. គ្មានភស្តុតាងក្នុងកម្រិតតម្រូវ អំពីការស្លាប់អ្នកធ្វើការពី ៦ ទៅ ១០ នាក់

៧៧៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា អ្នកធ្វើការពី ៦ ទៅ ១០ នាក់ បានស្លាប់នៅទំនប់១មករា ដោយសារការបង្កើតឱ្យមានលក្ខខ័ណ្ឌការងារ លក្ខខ័ណ្ឌនៃការរស់នៅ និងដោយពុំមានថ្នាំមានប្រសិទ្ធភាព ដោយផ្អែកលើភស្តុតាងរៀបរាប់នៅកថាខណ្ឌ ១៦២៩[1379]។ កថាខណ្ឌ ១៦២៩ នៃសំអាងហេតុសាលក្រម លើកឡើងថាមានមនុស្សតិចតួចទេដែលបានស្លាប់ដោយសារជំងឺ ឬរបួស នៅទំនប់១មករា តែអ្នកជំងឺត្រូវបានបញ្ជូនទៅភូមិរបស់ពួកគេវិញ ឬទៅតាមរោងព្យាបាល ហើយដែលពួកគេបានស្លាប់នៅទីនោះ[1380]។ គ្មានភស្តុតាងណាមួយបង្ហាញឱ្យឃើញក្នុងកម្រិតភស្តុតាងតម្រូវ ថាការស្លាប់បានកើតឡើងនៅទំនប់១មករា នោះទេ។ ភស្តុតាងនានាដែលមានរៀបរាប់នៅក្នុងកំណត់សម្គាល់ជើងទំព័រ បានត្រឹមចង្អុលបង្ហាញថា អ្នកជំងឺត្រូវបានជម្លៀសចេញពីការដ្ឋានទៅនៅតាមភូមិរបស់ពួកគេ ឬនៅមន្ទីរពេទ្យស្រុក[1381]។

៧៧៤. ពាក់ព័ន្ធនឹងការស្លាប់នៅទំនប់១មករា សក្ខីកម្មរបស់ មាស ឡៃហួរ មានតម្លៃភស្តុតាងតិចតួចបំផុត។ វាជាការឮគេនិយាយ ហើយសម្តីដែលត្រូវរាយការណ៍ មានភាពមិនច្បាស់លាស់[1382]។ កំណត់ហេតុស្លាប់ចម្លើយរបស់ កង អ៊ិត ក៏មិនបានបង្ហាញពីការស្លាប់ដែលកើតឡើងនៅទំនប់១មករា ដែរ។ គាត់

---

[1379] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៣០ កំណត់សម្គាល់ជើងទំព័រលេខ៥៦៧២ យោងទៅ កថាខណ្ឌ ១៦២៩។

[1380] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦២៩ កំណត់សម្គាល់ជើងទំព័រលេខ៥៥៤៣។

[1381] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦២៩ កំណត់សម្គាល់ជើងទំព័រលេខ៥៥៤៣។

[1382] មាស ឡៃហួរ៖ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/305.1** ចន្លោះម៉ោង ១៣.៤៦.៤៦ និង ១៣.៤៩.៣១ "ចាស ដឹងពីយើងធ្វើការទាំងអស់គ្នាហ្នឹង ប្រធានកងគេថា អ្នកនេះស្លាប់ ដោយសាររាកអី អ៊ីចឹងទៅណា ព្យាបាលវាអត់ទាន់អ៊ីចឹងទៅដឹងអ៊ីចឹង។ ខ្ញុំមិនស្គាល់ពេទ្យឯណា ខ្ញុំអត់ដឹងដែរ តែឮតែប្រធានកងគេថាអ៊ីចឹង ក៏ថាតាមគេទៅ។ យើងព្យាបាលវាអត់ទាន់"។

គ្រាន់តែបានលើកឡើងពីអ្នកជំងឺ និងការបញ្ជូនពួកគេទៅមន្ទីរពេទ្យ ដោយគាត់ពុំបានឃើញពីការស្លាប់នោះទេ[1383]។ ចំណែកឯសក្ខីកម្មរបស់ អ៊ុន រ៉ន វិញ ត្រូវបានបំភ្លៃដោយអង្គជំនុំជម្រះ។ អ៊ុន រ៉ន គ្រាន់តែបាននិយាយថា អ្នកជំងឺពីរនាក់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យស្រុក។ គាត់ពុំបាននិយាយអ្វីពីការស្លាប់របស់អ្នកទាំងពីរនោះទេ៖

> "ចាស មានឈឺខ្លាំង ដល់ពេលឈឺខ្លាំង គេបញ្ជូនទៅពេទ្យ។ បើតាមខ្ញុំមើលអ្នកឈឺខ្លាំងហ្នឹងឯងអត់មានឈឺអីទេ គឺរាកអាចម៍។ ដល់ពេលរាកអាចម៍ទៅគ្នានៅហ្នឹងរោង រាកមែន អានោះមិនមែនរាកពុតទេ រាកមែន។ រាកទៅគេថាយកទៅពេទ្យស្រុក បញ្ជូនទៅស្រុក បញ្ជូនៗទៅអត់ឃើញមានមកវិញទេ មិនដឹងជា ជា ឬមិនជាម៉េចយ៉ាងណាខ្ញុំអត់ដឹង ប៉ុនដឹងតែបាត់ខ្លួនអត់ឃើញមកវិញ។ ពីរនាក់ដែលខ្ញុំឃើញ។ បញ្ជូនទៅទាំងពីរនាក់ហ្នឹងឯង បាត់ទាំងពីរនាក់ហ្នឹងឯង មិនដឹងជាជា ឬមិនជាមិនដឹង"[1384]។

៧៧៥. ពេលសួរថាតើគាត់បានឮគេនិយាយពីករណីផ្សេងទៀតប្រហាក់ប្រហែលគ្នាដែរឬទេ គាត់ឆ្លើយថាអត់ទេ[1385]។ អង្គជំនុំជម្រះពុំបានបញ្ជាក់ពីអ្វីដែលអនុញ្ញាតឱ្យខ្លួនទាញសេចក្តីសន្និដ្ឋានចេញពីសក្ខីកម្មនេះបានថា មានការបង្ហាញឱ្យឃើញថា អ្នកជំងឺស្លាប់នៅទំនប់១មករា នោះទេ។ ស្របជាមួយគ្នានេះដែរ សក្ខីកម្មរបស់ សៀង សុវិដា ដែលមានអាយុ ១១ ឆ្នាំ នៅឆ្នាំ១៩៧៥ និយាយតែពីការដែលអ្នកជំងឺបាន

---

[1383] កង អ៊ុត កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ **E3/7775** ERN 00229056 ("មានអ្នកឈឺច្រើនព្រោះដោយសារធ្វើការយ៉ាប់យ៉ឺនពេក និងហួសកម្លាំង។ ប្រភេទជំងឺទាំងនោះមានដូចជា គ្រុនក្តៅ ចុកពោះ។ នៅទីនោះ មិនមានមន្ទីរពេទ្យទេ តែមានគ្រូពេទ្យដើរមើល និងមានថ្នាំពេទ្យ (ថ្នាំអាចម៍ទន្សាយ)។ ក្នុងករណីបើមានអ្នកណាឈឺធ្ងន់ធ្ងរ គេបញ្ជូនទៅមន្ទីរពេទ្យដែលនៅឆ្ងាយពីការដ្ឋាន គេមិនទុកឱ្យស្លាប់ទីនោះទេ")។

[1384] ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ចន្លោះម៉ោង ០៩.៣០.០០ និង ០៩.៣៣.១៧។

[1385] ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ចន្លោះម៉ោង ០៩.៣៣.១៧ និង ០៩.៣៦.៤៣៖ ("ស៖ [...] អ៊ីចឹងក្រៅពីករណីដែលអ្នកស្រីឃើញជាក់ស្តែងហ្នឹងភ្នែកអ៊ីចឹង តើអ្នកស្រីមានដឹង ឬក៏មានឮថាមានករណីបែបៗហ្នឹង ប្រហែលជាប៉ុន្មានករណីទៀតនៅក្នុងក្រុម កងដែលអ្នកស្រីធ្វើការនោះដែរឬទេ? ឆ៖ ចាស ឃើញតែពីរនាក់ហ្នឹងឯង បាត់យកទៅពេទ្យស្រុក ក៏បាត់ឈឹងទៅមិនដឹងទៅសម្រាកស្រុកឯណា អីឯណី ខ្ញុំអត់ដឹង")។

ត្រឡប់ទៅភូមិរបស់ពួកគេវិញ[1386]។ សក្ខីកម្មរបស់ អ៊ុំ ជី ដែលមិនច្បាស់លាស់ គឺមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ គាត់បាននិយាយនៅក្នុងសវនាការថា "សម័យហ្នឹង បើអ្នកណាឈឺធ្ងន់ គឺបញ្ជូនទៅមន្ទីរពេទ្យស្រុករបស់សម័យហ្នឹង។ ហើយអ្នកខ្លះក៏អាចជាមកវិញទៅ អ្នកខ្លះក៏ស្លាប់នៅនឹងកន្លែងពេទ្យហ្នឹងទៅ"[1387]។ អង្គជំនុំជម្រះពុំបានបញ្ជាក់ថាតើ អ៊ុំ ជី បានដឹងដោយរបៀបណាថាមនុស្សមួយចំនួនស្លាប់នៅមន្ទីរពេទ្យ។ ដូច្នេះ អង្គជំនុំជម្រះបានផ្អែកទាំងងងឹតងងល់លើសក្ខីកម្មមួយនេះ ដោយគ្មានធ្វើការវិភាគអ្វីសោះ។

៧៧៦. កំណត់ហេតុស្តាប់ចម្លើយរបស់ អៀង ឆាំ គ្មានតម្លៃជាភ័ស្តុតាងអ្វីសោះ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានផ្អែកលើចម្លើយទូទៅ មិនច្បាស់លាស់មួយរបស់សាក្សីរូបនេះ ទៅនឹងសំណួរនាំមុខ[1388]។ សាក្សីពុំបានបញ្ជាក់ពី ទីកន្លែង" ដែលគាត់បានឃើញអ្នកជំងឺដែលលើកឡើង ចំនួនមនុស្ស" ឬជាងនេះទៅទៀតនោះ គឺប្រភពព័ត៌មានរបស់គាត់ ទាក់ទងនឹងការបណ្តុះបណ្តាលអ្នកព្យាបាល។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានត្រឹមតែលើកឡើងពីភ័ស្តុតាងដែលចាត់ទុកថាជាភ័ស្តុតាងដាក់បន្ទុក ដោយពុំបានធ្វើការវិភាគចាំបាច់លើភ័ស្តុតាងទាំងអស់នោះ នៅក្នុងការពិនិត្យលើភ័ស្តុតាងសមហេតុសមផលនោះទេ។

៧៧៧. ស៊ូ សឿន ដែលពុំបានលើកឡើងពីការស្លាប់ណាមួយក្នុងពេលគាត់ផ្តល់សក្ខីកម្មនោះ ក៏ពុំបានគាំទ្រការអះអាងរបស់អង្គជំនុំជម្រះដែលថា "អ្នកមានជំងឺនៅទំនប់១មករា ត្រូវគេបញ្ជូនទៅតាមសហករណ៍

---

[1386] ប្រតិចារឹក ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ចន្លោះម៉ោង ១៣.៥៦.១១ និង ១៣.៥៨.២៩៖ "ភាគច្រើនៗតែដឹកជាមួយអ្នកដឹកស្បៀង ហ្នឹងតាមខ្ញុំយល់។ បើថារឿងផ្សេងដូចខ្ញុំអត់សូវដឹងដែរកន្លែងហ្នឹង ប៉ុន្តែបើមានមក ដូចនៅការដ្ឋានផ្សេង កាលខ្ញុំនៅផ្សេងពីការដ្ឋានហ្នឹង មានឈឺដឹកតាមអ្នកសេដ្ឋកិច្ចអ៊ីចឹងមក"។

[1387] ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/326.1** ចន្លោះម៉ោង ១៣.៣៣.១៨ និង ១៣.៣៥.១៩។

[1388] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/5513** ERN 00402449៖ "ឆ៖ តើលោកមានបានឃើញអ្នកជំងឺស្លាប់ ដោយសារការព្យាបាលពីគ្រូពេទ្យក្មេងៗទាំងនោះដែរឬទេ? ឆ៖ តាមការជួបប្រទះរបស់ខ្ញុំ ខ្ញុំឃើញនៅកន្លែងខ្លះមានគ្នាច្រើនធ្វើការងារខ្វះអនាម័យ ហូបមិនគ្រប់គ្រាន់ ថ្នាំពេទ្យគ្មានគុណភាព គ្រូពេទ្យគ្មានចំណេះដឹង ដែលជាមូលហេតុធ្វើឱ្យអ្នកជំងឺស្លាប់"។

របស់ខ្លួនវិញ ក្រោយពេលយកទៅព្យាបាលនៅមន្ទីរពេទ្យកំពង់ចាមរួច" នោះទេ[1389]។ ការពិនិត្យដោយយកចិត្តទុកដាក់លើសក្ខីកម្មរបស់គាត់ ចោទឡើងជាបញ្ហាមួយចំនួនទាក់ទងនឹងភាពជឿជាក់បានរបស់គាត់ និងជាពិសេសនោះ ទាក់ទងនឹងភាពជឿទុកចិត្តបាននៃការចងចាំរបស់គាត់។ ពេលត្រូវចោទសួរថាតើគាត់ដឹងថាដែលមានអ្នកជំងឺត្រឡប់ទៅភូមិវិញ ឬត្រូវបញ្ជូនទៅមន្ទីរពេទ្យដែរឬទេ គាត់បានឆ្លើយដំបូងថា៖ "ចាស ត្រង់ហ្នឹង ខ្ញុំក្តាប់អត់បានទេ ព្រោះតាមបើស្រុកខ្ញុំ ខ្ញុំក្តាប់បាន តែអ្នកឈឺគេបញ្ជូនទៅមន្ទីរពេទ្យ។ ឯកន្លែង ក្នុងកន្លែងធ្វើការនៅទំនប់១មករា ហ្នឹងខ្ញុំក្តាប់អត់បានទេ"[1390]។ បន្ទាប់មក គាត់បន្ថែមថា "ចាស ខ្ញុំចាំថាកម្លាំងដែលឈឺនៅទំនប់១មករា គេបញ្ជូនមកមន្ទីរពេទ្យ ដល់ជាហើយមកសហករណ៍វិញ។ ខ្ញុំក្តាប់បានប៉ុណ្ណឹង"[1391]។ នៅចុងបញ្ចប់ គាត់បាននិយាយដោយបញ្ជាក់ថា៖ "ចាស មានអ៊ីចឹងមែន ប៉ុន្តែអ្នកឈឺធ្ងន់គេយកពីទំនប់១មករាមក យកទៅដាក់មន្ទីរពេទ្យកំពង់ចាម។ ដល់ពេលជា ត្រឡប់មកធ្វើការនៅសហករណ៍វិញ។ អាហ្នឹងតាមខ្ញុំចាំអ៊ីចឹង"[1392]។ ការប្រែប្រួលនៃការចងចាំរបស់គាត់ គួរតែនាំឱ្យអង្គជំនុំជម្រះមានការប្រយ័ត្នប្រយែងបំផុតក្នុងការប្រើប្រាស់សក្ខីកម្មរបស់គាត់។

៧៧៨. ទោះយ៉ាងណាក៏ដោយ យោងតាមភស្តុតាងទាំងអស់ទាក់ទងនឹងទំនប់១មករា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុយ៉ាងច្បាស់ ដោយបានសន្និដ្ឋានថា "អ្នកជំងឺដែលមានជំងឺធ្ងន់ធ្ងរត្រូវបានបញ្ជូនត្រឡប់ទៅភូមិរបស់ពួកគេវិញ ហើយក្រោយមកបានស្លាប់ ដោយសារតែមិនអាចព្យាបាលបាន"[1393]។ គ្មានភស្តុតាងណាមួយអាចគាំទ្រសេចក្តីសន្និដ្ឋាននេះឱ្យហួសពីវិមតិសង្ស័យបានទេ។ ដូច្នេះ សេចក្តីសន្និដ្ឋាន

---

[1389] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦២៩ កំណត់សម្គាល់ជើងទំព័រលេខ៥៥៤៣ "ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ (ស៊្វ សឿន) ឯកសារ E1/310.1 ទំព័រ ៥១-៥២, ៥៦-៥៧ (អ្នកមានជំងឺនៅទំនប់១មករា ត្រូវគេបញ្ជូនទៅតាមសហករណ៍របស់ខ្លួនវិញក្រោយពេលយកទៅព្យាបាលនៅមន្ទីរពេទ្យកំពង់ចាមរួច)"។

[1390] ស៊្វ សឿន៖ ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ E1/310.1 ម៉ោងប្រហែល ១៤.៤០.០១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1391] ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ E1/310.1 ម៉ោងប្រហែល ១៤.៤០.០១។

[1392] ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ E1/310.1 ម៉ោងប្រហែល ១៤.៤២.០០។

[1393] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦២៩ កំណត់សម្គាល់ជើងទំព័រលេខ៥៥៤៣។

របស់អង្គជំនុំជម្រះដែលថា "យ៉ាងហោចណាស់" អ្នកធ្វើការពី ៦ ទៅ ១០ នាក់ បានស្លាប់ នៅទំនប់១ មករា មិនអាចធ្វើជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាតបានទេ[1394]។

**១.២.២. គ្មានភស្តុតាង ក្នុងកម្រិតតម្រូវ អំពីការស្លាប់បណ្តាលមកពីគ្រោះថ្នាក់**

៧៧៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា មានការបង្ហាញឱ្យឃើញថា គ្រោះថ្នាក់ជាច្រើនបានបណ្តាលឱ្យមានការស្លាប់ ជាពិសេសដោយសារការបាក់ច្រាំងដី កប់អ្នកធ្វើការ[1395]។ អង្គជំនុំជម្រះបានរៀបរាប់ក្នុងកំណត់សម្គាល់ជើងទំព័រ នូវសក្ខីកម្មពីររបស់សាក្សីដែលបានឃើញការបាក់ដីដោយផ្ទាល់ភ្នែក ក្នុងនោះមាន មាស ឡៃហួរ និង នួន ណារុំ។

៧៨០. សក្ខីកម្មរបស់ មាស ឡៃហួរ មិនអាចបង្ហាញឱ្យឃើញថា អ្នកធ្វើការជាច្រើននាក់បានស្លាប់បណ្តាលមកពីការបាក់ដីសង្កត់ ដែលគាត់បានឃើញទេ[1396]។ អង្គជំនុំជម្រះមានកំហុស ដោយបានបង្ហាញសក្ខីកម្មរបស់គាត់ថាដូចជាច្បាស់លាស់ ខណៈដែលវាគ្រាន់តែជាការស្មានច្បាស់ក្រឡែត។ មាស ឡៃហួរ បាននិយាយថា៖ "ជួបដែរ ជួនកាលយើងរែកដីទៅ ជ្រៅទៅ ពេលយើងទៅជ្រកអីមួយភ្លែតក្រោមហ្នឹងទៅ <u>រលំដីមកលើសង្កត់ងាប់</u>"[1397]។ ម្យ៉ាងវិញទៀត គាត់បានលើកឡើងជាលក្ខណៈទូទៅអំពីឧប្បត្តិហេតុផ្សេងៗទៀត ដែលគាត់ពុំបានបញ្ជាក់ថាគាត់បានឃើញផ្ទាល់ភ្នែកនោះទេ។ ដូច្នេះ គេមិនអាចដឹងបានថាវាជាការឮគេនិយាយតគ្នា ឬក៏ជាសេចក្តីសន្និដ្ឋានរបស់ខ្លួនគាត់ផ្ទាល់៖ "ចាស អ្នកខ្លះដីសង្កត់ចំ

---

1394 សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧០ កំណត់សម្គាល់ជើងទំព័រលេខ៥៦៧២ យោងទៅ កថាខណ្ឌ ១៦២៩, ១៦៧២-១៦៧៣។

1395 សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧០ កំណត់សម្គាល់ជើងទំព័រលេខ៥៦៧២ យោងទៅ កថាខណ្ឌ ១៥៣៥។

1396 សំអាងហេតុសាលក្រម កថាខណ្ឌ ១៥៣៥ កំណត់សម្គាល់ជើងទំព័រលេខ៥២៣៦៖ "ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ (មាស ឡៃហួរ) ឯកសារ **E1/304.1** ទំព័រ ៤៦។ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ (មាស ឡៃហួរ) ឯកសារ **E1/305.1** ទំព័រ ១២-១៣, ២២ (នៅពេលគាត់ជាកម្មករនៅកងចល័ត គាត់បានឃើញការបាក់ដីសង្កត់មនុស្សដែលធ្វើការនៅក្នុងតំបន់ក្នុងឃុំមួយទៀត ដែលកំពុងជីកដី ហើយដីបាក់បានសម្លាប់ពួកគេមុនពេលកាយយកពួកគេចេញ")"។

1397 ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/304.1** ចន្លោះម៉ោង ១៣.៤០.២៣ និង ១៣.៤២.១៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ទៅ ដុំថ្មមកពីលើទៅក៏ងាប់ទៅ អ្នកខ្លះក៏គ្រាន់តែរបួសបាក់ដៃបាក់ជើងអីចឹងណា។ អ្នកខ្លះក៏រស់ អ្នកខ្លះក៏ងាប់ទៅ។ អ្នកដែលសង្កត់ដីខ្លាំងទៅងាប់។ ទម្រាំតែកាយចេញ ដាច់ដង្ហើមងាប់ហើយ"[1398]។

៧៨១. ចំណែកឯ នួន សារុំ វិញ បានផ្តល់ព័ត៌មានមួយចំនួនដែលមិនអាចឱ្យសន្និដ្ឋានបានថាមានការស្លាប់ដោយសារការរលំដីសង្កត់នោះទេ។គាត់បានបញ្ជាក់ថា "នៅពេលយើងកំពុងធ្វើការរយៈពេលប្រាំមួយប្រាំពីរខែហ្នឹង មិនមាន [អ្នកស្លាប់] ទេ"[1399]។ ដូច្នេះ បើទោះជាគាត់និយាយថាបានឃើញការបាក់រលំដីក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានចេញពីសក្ខីកម្មរបស់គាត់បានថា មានការស្លាប់ណាមួយកើតឡើងពីឧប្បត្តិហេតុនេះដែរ[1400]។ ជាចុងក្រោយ សក្ខីកម្មរបស់ ហ៊ុន សិត្ថានី, អ៊ុន រ៉ន និង អ៊ិត សេង គឺគ្រាន់តែជាការឮគេនិយាយតគ្នា និងមិនអាចប្រើធ្វើជាភ័ស្តុតាងបញ្ជាក់ពាក់ព័ន្ធនឹងការស្លាប់មនុស្សបណ្តាលមកពីការបាក់ដីសង្កត់បានទេ បើយោងតាមភាពទន់ខ្សោយរបស់សាក្សីផ្ទាល់ភ្នែកសន្មតទាំងអស់នេះនោះ[1401]។

## ១.២.៣. ការសន្និដ្ឋានមិនសមហេតុផលពីការស្លាប់មនុស្សក្នុងចំនួនច្រើន ដើម្បីបំពេញកង្វះភ័ស្តុតាង

[1398] ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/305.1** ចន្លោះម៉ោង ០៩.៤២.៥១ និង ០៩.៤៤.៥៥។

[1399] ប្រតិចារឹក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** ចន្លោះម៉ោង ១០.៤៨.៥៥ និង ១០.៥១.៥៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1400] ប្រតិចារឹក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** ចន្លោះម៉ោង ១១.១៥.៤៧ និង ១១.១៩.០៧៖ ("ចាស មានឃើញដែរ។ ឃើញអ្នកកាប់ ពួកយុវជនហ្នឹងកាប់ដីៗ ដោយសារការលុងដីវាជ្រៅ បាក់សង្កត់")។

[1401] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ៥២៣៦៖ "ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ (ហ៊ុន សិត្ថានី) ឯកសារ E1/305.1 ទំព័រ ៧០-៧១ (ដែលលើកឡើងថា គាត់កើតរើមនៅថ្ងៃបាក់ដី ប៉ុន្តែគេបានប្រាប់គាត់ថា មានគេស្លាប់ដោយសារហេតុការណ៍នេះ), ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ (អ៊ុន រ៉ន) ឯកសារ E1/307.1 ទំព័រ ១១, ៦១-៦២ (ដែលពិពណ៌នាថា គាត់ក៏បានឮអំពីការបាក់ដីសង្កត់កម្មករបីនាក់ ហើយបានសម្លាប់កម្មករម្នាក់នៅហ្នឹងកន្លែង។ ប៉ុន្តែ គាត់ពុំបានឃើញហេតុការណ៍នេះទេ ដោយសារគាត់នៅឆ្ងាយពីកន្លែងធ្វើការ ពោលគឺគាត់នៅកន្លែងស្នាក់នៅ)។ ប្រតិចារឹក ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ (អ៊ិត សេង) ឯកសារ E1/309.1 ទំព័រ ៣៩-៤០ (ដែលលើកឡើងថា គាត់បានឮថា មានហេតុការណ៍មនុស្សស្លាប់ដោយសារការបាក់ដីបណ្តាលមកពីជីកដីជ្រៅពេក)" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៧៨២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានថាការសន្និដ្ឋានសមហេតុផលតែមួយគត់ដែលអាចធ្វើបានអំពីវត្តមានរបស់កម្មករ ២០០០០ នាក់ នៅទីតាំងការងារដែលពុំមានល័ក្ខខ័ណ្ឌអនាម័យ ចំណីអាហារ និងវេជ្ជសាស្ត្រសមស្រប នោះគឺអ្នកធ្វើការក្នុងចំនួនច្រើនបានស្លាប់ដោយសារតែល័ក្ខខ័ណ្ឌទាំងនេះ[1402]។ អង្គជំនុំជម្រះពុំបានចង្អុលបង្ហាញការយោងទៅលើភ័ស្តុតាងណាមួយ ឬទៅលើកថាខណ្ឌផ្សេងទៀតនៃសំអាងហេតុសាលក្រម នៅក្នុងសេចក្ដីសន្និដ្ឋាននេះទេ។ ពាក់ព័ន្ធនឹងការនិយាយសរុបជាទូទៅ វាពុំមែនជាសេចក្ដីសន្និដ្ឋានសមហេតុសមផលទេ ទាក់ទងនឹងចំនួនកម្មករ ឬល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌនៃការរស់នៅ នៅទីតាំងធ្វើការនេះ។ អង្គជំនុំជម្រះបានទាញសេចក្ដីសន្និដ្ឋានដែលផ្ដល់ផលប្រយោជន៍តិចតួចបំផុតដល់ជនជាប់ចោទ ដោយពុំបានផ្ដល់សំអាងហេតុឱ្យបានត្រឹមត្រូវ។ សេចក្ដីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

## ១.៣. គ្មានភ័ស្តុតាងអំពីចេតនាប្រយោល ចំពោះការស្លាប់បណ្ដាលមកពីការអត់អាហារ និងល័ក្ខខ័ណ្ឌរស់នៅ

៧៨៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាធាតុផ្សំអត្តនោម័តិនៃការការធ្វើមនុស្សឃាត ត្រូវបានបំពេញជាក់ស្ដែង ក្រោមទម្រង់ជាចេតនាប្រយោល[1403]។ ជាបឋម អង្គជំនុំជម្រះបានសន្និដ្ឋានថា ចារីនៃឧក្រិដ្ឋកម្ម នៅកម្រិតការដ្ឋាន និងមជ្ឈិមបក្ស "<u>បានដឹង</u>ថា មិនមានអាហារ និងឱសថគ្រប់គ្រាន់ទេ នៅការដ្ឋានការងារទំនប់១មករា ប៉ុន្តែ ទោះជាយ៉ាងណាក្ដីនៅតែ<u>បន្ត</u>ជំរុញអ្នកធ្វើការនៅទំនប់ឱ្យបញ្ចប់ការងារ[1404]"។

៧៨៤. អង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងទាំងឡាយដែលត្រូវបានរៀបរាប់នៅត្រង់កថាខណ្ឌ ១៦៣៩ និង ១៦៤០ បង្ហាញឱ្យឃើញពីការដឹងរបស់ចារីនៃឧក្រិដ្ឋកម្ម។ ក៏ប៉ុន្តែ ភ័ស្តុតាងដែលមាននៅក្នុងកថាខណ្ឌយោងទាំងពីរនេះ សង្ខេបមកត្រឹមអត្ថបទមួយដកស្រង់ចេញពីទស្សនាវដ្ដីទង់បដិវត្ត ចេញផ្សាយខែ

---

[1402] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧០។

[1403] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧១-១៦៧៣។

[1404] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

តុលា-វិច្ឆិកា ឆ្នាំ១៩៧៧ ទាក់ទងនឹងស្ថានការណ៍ទូទៅរបស់កម្ពុជា[1405]។ ពាក់ព័ន្ធនឹងឆន្ទៈរបស់អាជ្ញាធរក្នុងការជំរុញកម្មករឱ្យបញ្ចប់ការងារ ទោះជាមានការកត់សម្គាល់ឃើញថាមានគ្រោះទុរ្ភិក្ស អង្គជំនុំជម្រះបានយោងទៅលើភ័ស្តុតាងមួយដែលមានតម្លៃទាបបំផុត នោះគឺអត្ថបទដកស្រង់ចេញពីសេវាកម្មផ្សព្វផ្សាយព័ត៌មានបរទេស ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៧៧ ដែលគេមិនដឹងថាបានរាយការណ៍ពីសម្តីអ្នកណាផងនោះទេ។ ដូច្នេះ អត្ថបទនេះមិនអាចគាំទ្រការលើកឡើងរបស់អង្គជំនុំជម្រះដែលថា ក្រោយពីបានដឹងអំពីបញ្ហាទាំងនេះនៅខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧ រួចហើយ ចារីបានបន្តជំរុញកម្មករឱ្យបញ្ចប់ការងារនៅក្នុងខែឧសភា ឆ្នាំ១៩៧៧ បាននោះទេ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុតាមរយៈសេចក្តីសន្និដ្ឋានមិនសមហេតុសមផលរបស់ខ្លួន។

៧៨៥. បន្ទាប់មក ដើម្បីវាយតម្លៃធាតុផ្សំអត្តនោម័តិ គេត្រូវធ្វើការពិនិត្យបែបអត្តនោម័តិ និងតាមរយៈទស្សនៈរបស់ចារីនៃបទល្មើស។ ការទទួលយកហានិភ័យថាអាចនឹងមានការស្លាប់ដោយចារី អាស្រ័យទៅនឹងការវាយតម្លៃខាងលើនេះ។ ចេតនាឧក្រិដ្ឋ គឺត្រូវវាយតម្លៃមុនការប្រព្រឹត្តិឧក្រិដ្ឋកម្ម មិនមែនក្រោយនោះទេ។ ក្នុងស្ថានភាពនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយពុំបានវាយតម្លៃភ័ស្តុតាងឱ្យបានច្បាស់លាស់ ទាក់ទងនឹងពេលវេលា។ អង្គជំនុំជម្រះបានសំអាងធាតុផ្សំអត្តនោម័តិលើការបានដឹងអំពីគ្រោះទុរ្ភិក្ស និងការរក្សាផែនការផលិតកម្មដោយចារី ទោះជាក្រោយខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧ក្តី[1406]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយពុំបានវាយតម្លៃភ័ស្តុតាងឱ្យបានច្បាស់លាស់ទាក់ទងនឹងកាលបរិច្ឆេទនៃការស្លាប់ដែលរងការចោទប្រកាន់។

៧៨៦. អង្គជំនុំជម្រះមិនបានកំណត់អំពីការបំពេញបាននូវធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិ នៅពេលណាមួយ ទាក់ទងនឹងការស្លាប់បណ្តាលមកពីល័ក្ខខ័ណ្ឌនៃការរស់នៅ និងល័ក្ខខ័ណ្ឌការងារ នៅទំនប់១មករា។ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចធ្វើសេចក្តីសន្និដ្ឋានមួយនេះបានដូចអង្គជំនុំជម្រះទេ

---

[1405] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៣៩ កំណត់សម្គាល់ជើងទំព័រលេខ៥៥៧២៖ "នៅកន្លែងខ្លះ បញ្ហាបាយទឹកមិនទាន់សម្រេចបានទៅតាមរបបកំណត់នៅឡើយទេ។ ក្នុងការត្រួតពិនិត្យចំណុចនេះ វាអាចនឹងបន្តធ្លាក់ចុះតទៅទៀត។ [...] កន្លែងណាដែលខ្វះបាយទឹក ត្រូវតែមានដំណោះស្រាយ។ ដោះស្រាយដោយជួយផ្តល់ស្បៀង គឺជារឿងមួយ។ ប៉ុន្តែ ចាំបាច់ត្រូវដោះស្រាយកម្មាភិបាលដែលទទួលខុសត្រូវ"។

[1406] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៧១-១៦៧២។

ដោយគ្មានភស្តុតាងនោះ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការបំពេញបាននូវធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ត្រូវទុកជាមោឃៈ។

## ២. គ្មានការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ

## ២.១. ការប្រព្រឹត្តិលើប្រជាជនថ្មី

៧៨៧. ដូចដែលបាននិយាយពីខាងលើ អង្គជំនុំជម្រះមិនត្រូវបានស្នើសុំឱ្យវិនិច្ឆ័យសេចក្តីលើអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុនយោបាយ ចំពោះប្រជាជនថ្មីនៅទំនប់១មករា នោះទេ[1407]។ ជាលក្ខណៈបន្ទាប់បន្សំ ការពិនិត្យមិនលម្អៀងលើភស្តុតាងដាក់បន្ទុកដែលត្រូវបានជ្រើសរើសយក គឺបង្ហាញឱ្យឃើញថា សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់នោះ គឺថា ពុំមានការរើសអើងចំពោះប្រជាជនថ្មីទេ (២.១.១) ហើយការប្រព្រឹត្តិដែលរងការចោទប្រកាន់ ដូចដែលបានជ្រើសដោយអង្គជំនុំជម្រះ គឺមិនបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានទេ។

### ២.១.១. គ្មានការរើសអើងជាក់ស្តែងចំពោះប្រជាជនថ្មី

៧៨៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាខ្លួនបានលើកឡើងនូវ "លក្ខណៈមួយចំនួន ដែលប្រជាជនថ្មីត្រូវបានគេរើសអើង បើប្រៀបធៀបជាមួយនឹងប្រជាជនមូលដ្ឋាន" នៅកថាខណ្ឌ ១៦៤១-១៦៥៣[1408]។

#### *២.១.១.១. ការដកចេញនូវភស្តុតាងក្រៅវិសាលភាពនៃការជំនុំជម្រះ*

៧៨៩. ជាបឋម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានជ្រើសរើសភស្តុតាងក្រៅវិសាលភាពនៃការជំនុំជម្រះ ដើម្បី "បង្ហាញឱ្យឃើញថា" ប្រជាជនថ្មីបានទទួលរងការប្រព្រឹត្តិបែបរើសអើង ដោយ

---

[1407] សូមមើលខាងលើ កថាខណ្ឌ ៣៩៣-៣៩៤។

[1408] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៨។

អង្គជំនុំជម្រះបានស្នើឡើងនូវការវាយតម្លៃ "ក្នុងបរិបទទូលាយ" ដែលមានបញ្ចូលភ័ស្តុតាងទាក់ទងនឹងរបៀបនៃការប្រព្រឹត្តិលើប្រជាជនថ្មី ក្នុងសហគមន៍ដើមរបស់ពួកគេ និងក្នុងបរិបទនយោបាយទូទៅរបស់ ប.ក.ក[1409]។ អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ ដោយបានប្រកាសថាខ្លួនអាចផ្អែកលើភ័ស្តុតាងក្រៅវិសាលភាពទាំងនេះបាន ដើម្បីបំភ្លឺអំពីបរិបទ បង្ហាញឱ្យឃើញពីធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មតាមរយៈការទាញសេចក្តីសន្និដ្ឋាន និង "បង្ហាញពីលំនាំនៃការប្រព្រឹត្តិដោយចេតនា"[1410]។ ដូច្នេះ ភ័ស្តុតាងដែលបង្ហាញ នៅកថាខណ្ឌ ១៦៤២-១៦៤៨ នៃសំអាងហេតុសាលក្រម គឺមិនអាចប្រើប្រាស់បានសម្រាប់ធ្វើសេចក្តីសន្និដ្ឋានពីបទឧក្រិដ្ឋបានទេ។

### *២.១.១.២. ភ័ស្តុតាងបង្ហាញអំពីការប្រព្រឹត្តិដោយសមភាព*

៧៩០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាខ្លួនបានលើកឡើងនូវ "លក្ខណៈមួយចំនួន ដែលប្រជាជនថ្មីត្រូវបានគេរើសអើង បើប្រៀបធៀបជាមួយនឹងប្រជាជនមូលដ្ឋាន" នៅកថាខណ្ឌ ១៦៤១-១៦៥៣[1411]។ ភ័ស្តុតាងរៀបរាប់នៅកថាខណ្ឌ ១៦៥០ ដល់ ១៦៥៣ នៃសំអាងហេតុសាលក្រម គឺមិនគាំទ្រថាមានទម្រង់នៃ "ការរើសអើង" បានទេ។ ផ្ទុយទៅវិញ ចៅក្រមមានវិចារណញ្ញាណគួរតែសន្និដ្ឋានថាមានការប្រព្រឹត្តិដោយស្មើភាពជាមួយប្រជាជនផ្សេងៗទៀត។

- <u>**ការប្រព្រឹត្តិដោយសមភាព**</u>

៧៩១. អង្គជំនុំជម្រះបានទទួលស្គាល់ជាច្រើនលើកថា ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន គឺត្រូវបានដាក់ឱ្យស្ថិតក្នុងល័ក្ខខ័ណ្ឌលំបាកដូចគ្នា[1412]។ សក្ខីកម្មរបស់ គង់ អ៊ុត, មាស ឡៃហួរ, អ៊ុំ ជី, ឱ ហួ, ស៊ូ សឿន

---

[1409] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៤១។ សូមមើលខាងលើ កថាខណ្ឌ ១២០-១២៥។

[1410] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៤១ យោងទៅ ផ្នែក ២.៥.៦។

[1411] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៨។

[1412] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥០៖ "ក្នុងស្ថានភាពមួយចំនួន ទាំងប្រជាជនថ្មី ទាំងប្រជាជនចាស់ បានទទួលការលំបាកដូចគ្នា។ [...]", កថាខណ្ឌ ១៦៥៣ "ស្ថានភាពនៅការដ្ឋានការងារទំនប់១មករា មានសភាពយ៉ាប់យ៉ឺនសម្រាប់ប្រជាជនថ្មី និងប្រជា

និង សួន កានិល (សំណុំរឿង ០០២/០១) គឺលើកឡើងយ៉ាងច្បាស់ពីបញ្ហានេះ[1413]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមិនបានទាញផលវិបាកចេញពីភស្តុតាងដោះបន្ទុកទាំងនេះ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយបានដកចេញបែបជ្រើសរើសនូវសក្ខីកម្មដោះបន្ទុករបស់ អ៊ុំ ជី និង ឱ ហ្វ ដោយមូលហេតុតែមួយគត់គឺថា អ្នកទាំងពីរជាអ្នកគ្រប់គ្រង ហើយពួកគាត់មានហេតុផលនឹងរកវិធីបន្ថយឱ្យបានជាអប្បរមានូវពិរុទ្ធភាពរបស់ពួកគាត់ ទាក់ទងនឹងការធ្វើបាបកម្មករ ឬការរើសអើងលើក្រុមជាក់លាក់[1414]។ អង្គជំនុំជម្រះបានប្រើប្រាស់ទឡ្ហីករណ៍នេះជាច្រើនលើកច្រើនសា ខណៈដែលខ្លួនមានកាតព្វកិច្ចធ្វើការវិភាគលើសក្ខីកម្មទាំងអស់នេះ ដោយត្រូវប្រៀបធៀបជាមួយនឹងភស្តុតាងផ្សេងទៀត។ ក៏ប៉ុន្តែ ក្នុងករណីជាក់ស្តែងនេះ ដូចដែលគេទើបបានឃើញសក្ខីកម្មរបស់ពួកគាត់ គឺស៊ីចង្វាក់គ្នាជាមួយនឹងសាក្សីផ្សេងៗទៀត។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានលាក់បាំងទិដ្ឋភាពមួយនេះ ដែលមិនស៊ីចង្វាក់គ្នានឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។

- **<u>ការយល់ច្រឡំរវាងការរើសអើងជាក់ស្តែង ជាមួយនឹងបំណងប្រាថ្នាចង់បានសមភាពដាច់ខាត</u>**

៧៩២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុនៅក្នុងការរាប់ “ករណីរើសអើង” លើប្រជាជនថ្មី[1415] ដោយបានលើកឡើងពី “លក្ខណៈមួយចំនួន ដែលប្រជាជនថ្មីត្រូវបានគេរើសអើង បើប្រៀបធៀបជាមួយនឹងប្រជាជនមូលដ្ឋាន”[1416]។ ភស្តុតាងទាំងឡាយដែលអង្គជំនុំជម្រះបានរៀបរាប់សម្រាប់គាំទ្រសេចក្តី

---

ជនមូលដ្ឋាន”, កថាខណ្ឌ ១៦៨៨ “ទោះបីជាលក្ខខ័ណ្ឌមានភាពលំបាកចំពោះអ្នកធ្វើការភាគច្រើន នៅការដ្ឋានការងារទំនប់១មករាក្តី”។

[1413] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥០-១៦៥១, កំណត់សម្គាល់ជើងទំព័រលេខ៥៦១០, ៥៦១១, ៥៦១៣ និង ៥៦១៤៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/322.1** ទំព័រ ១៧, ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/304.1** ទំព័រ ៦៥, ប្រតិចារឹក ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/155.1** ទំព័រ ២៣, ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/301.1** ចន្លោះម៉ោង ០៩.៣៣.០៣ និង ០៩.៤៩.៤៤។

[1414] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥១។

[1415] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២។

[1416] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៨។

សន្និដ្ឋានទាំងនេះរបស់ខ្លួន ទាក់ទងនឹងការប្រព្រឹត្តិលើប្រជាជនថ្មី មិនអាចឱ្យចៅក្រមមានវិចារណញ្ញាណគាំទ្របានថាមានការរើសអើងនោះឡើយ។

៧៩៣. ***ការចោទប្រកាន់អំពីភស្តុតាងជាក់ស្តែង***។ អង្គជំនុំជម្រះយល់ឃើញថា ការរើសអើងជាក់ស្តែងអាចត្រូវបង្ហាញតាមរយៈភស្តុតាងដែលគេអាចកំណត់ថាមានភាពសត្យានុម័តិ៖ នួន ណារុំ បាននិយាយថា ប្រជាជនថ្មីត្រូវផាត់ចេញពីការទទួលបានតួនាទីដែលមានការទទួលខុសត្រូវ[1417]។ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី និយាយថា ប្រជាជនថ្មីមិនអាចស្នើសុំទៅធ្វើការនៅកន្លែងណាមួយជាក់លាក់បានទេ[1418]។ អ៊ុត សេង និយាយថា ប្រជាជនថ្មីគ្មានសិទ្ធិទទួលបានសម្លៀកបំពាក់ និងស្បែកជើងថ្មីទេ[1419]។ បើតាម ហ៊ុន សិត្ថានី ប្រជាជនថ្មីមិនអាចផ្តល់ហេតុផលនៅពេលពួកគេប្រព្រឹត្តកំហុសតូចតាចបានទេ ហើយត្រូវទទួលយកការទិតៀន[1420] ហើយប្រជាជនមូលដ្ឋាន "មាន<u>សិទ្ធិច្រើនជាងប្រជាជនថ្មី</u>" ព្រោះប្រជាជនថ្មីពុំត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងពិធីសម្ពោធ[1421]។

៧៩៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបាននិយាយថា ឱ ហូ បានផ្តល់សក្ខីកម្មថា "ប្រជាជនថ្មីត្រូវបានគេស្តីបន្ទោសនៅពេលប្រព្រឹត្តកំហុសតូចតាច និងប្រសិនបើពួកគេប្រព្រឹត្តកំហុសធ្ងន់ធ្ងរ

---

[1417] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ៥៦១៧៖ "ប្រតិចារឹក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ (នួន ណារុំ) ឯកសារ **E1/339.1** ទំព័រ ២១"។

[1418] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ៥៦១៨៖ "ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ (ហ៊ុន សិត្ថានី) ឯកសារ **E1/305.1** ទំព័រ ៧១"។

[1419] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ៥៦២០៖ "ប្រតិចារឹក ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ (អ៊ុត សេង) ឯកសារ **E1/309.1** ទំព័រ ១៩, ៣១។ <u>ប្រជាជនចាស់មួយចំនួនក៏ជួបប្រទះការខ្វះខាតសម្លៀកបំពាក់ដែរ</u>។ *សូមមើលខាងលើ* កថាខណ្ឌ ១៦០០" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1420] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ៥៦២២៖ "ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ (ហ៊ុន សិត្ថានី) ឯកសារ **E1/306.1** ទំព័រ ៨" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1421] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ ៥៦២៤ និង ៥៦២៥៖ "ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ (ហ៊ុន សិត្ថានី) ឯកសារ **E1/306.1** ទំព័រ ៤៩-៥០, ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ (ហ៊ុន សិត្ថានី) ឯកសារ E1/305.1 ទំព័រ ៧០" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

មេឃុំមិនអាចធានាសុវត្ថិភាពរបស់ពួកគេបានទេ"[1422]។ ការពិតទៅ ឱ ហូ បាននិយាយខុសពីនេះ ដោយគាត់បញ្ជាក់ថា៖ "នែ៎ ប្រជាជនចាស់ និងប្រជាជនថ្មីហ្នឹង កាលណាវាមានកំហុសទៅ អប់រំដូចតែគ្នា ស្តីបន្ទោសដូចតែគ្នា"[1423]។ ពាក់ព័ន្ធនឹងកំហុសធ្ងន់ធ្ងរវិញ គាត់បន្តថា៖ "ប្រជាជន១៧មេសា តែកាលណាប្រព្រឹត្តខុសហើយ ខុសតិចតួច មេភូមិដាស់តឿនជេរស្តីទៅ តែបើខុសខ្លាំង មេភូមិជេរស្តីមិនកើតទេទាន។ មិនអាចនឹងធានាបាន ព្រោះកំហុសដែលធ្វើទៅវាខុសធ្ងន់ទៅនោះ ក៏ប៉ុន្តែនៅក្នុងភូមិរបស់ខ្ញុំនេះ វាគ្មានប្រភេទបែបហ្នឹងទេ"[1424]។ ដោយសារតែ ឱ ហូ និយាយថាគាត់មិនដែលជួបប្រទះស្ថានភាពបែបនេះនៅក្នុងឃុំរបស់គាត់ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានដោយផ្អែកលើការឮគេនិយាយតគ្នាមិនច្បាស់លាស់បានទេ។

៧៩៥. ភស្តុតាងទាំងអស់នេះមានតម្លៃជាភស្តុតាងតិចតួចពេក ដើម្បីបង្ហាញឱ្យឃើញក្នុងកម្រិតភស្តុតាងតម្រូវថា ប្រជាជនថ្មីងាយនឹងត្រូវគេស្តីបន្ទោសចំពោះការប្រព្រឹត្តិល្មើស ឬកំហុស ជាលក្ខណៈទូទៅ[1425]។ ភស្តុតាងទាំងនេះមិនអាចធ្វើជាមូលដ្ឋានថាមាន "ការរើសអើងជាក់ស្តែង" ដែលជាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយបានទេ។

៧៩៦. ***ការយល់ឃើញបែបអត្តនោម័តិមិនច្បាស់លាស់ថាមានការប្រព្រឹត្តិមិនស្មើភាពគ្នា***។ ឧទាហរណ៍ផ្សេងៗទៀតលើកឡើងដោយអង្គជំនុំជម្រះ គឺមានលក្ខណៈអត្តនោម័តិ។ អ៊ុត សេង បាននិយាយថា ប្រជាជនថ្មីត្រូវបានចាត់ទុកដូចជាខ្មាំង ហើយដូច្នេះ ពួកគេមានការភ័យខ្លាចក្នុងការមានទំនាក់ទំនងមិត្តភាពជាមួយប្រជាជនមូលដ្ឋាន[1426]។ ហ៊ុន សិត្ថានី និយាយថា ប្រជាជនថ្មីបានធ្លាក់ចុះខ្សោយកម្លាំង

---

[1422] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២។

[1423] ប្រតិចារឹក ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/301.1** ម៉ោងប្រហែល ០៩.៤២.២៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1424] ប្រតិចារឹក ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/301.1** ម៉ោងប្រហែល ០៩.៤៥.១២។

[1425] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៨-១៦៨៩។

[1426] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ៥៦១៨៖ "ប្រតិចារឹកថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ (អ៊ុត សេង) ឯកសារ **E1/309.1** ទំព័រ ៣១"។

ដោយសារតែល័ក្ខខ័ណ្ឌនៃការរស់នៅដែលគេបង្កើតឡើងសម្រាប់អ្នកទាំងនោះ[1427]។ អ៊ុន រ៉ន បានកត់សម្គាល់ថា គាត់មិនអាចសម្រាកញឹកញាប់ដូចប្រជាជនមូលដ្ឋានបានទេ[1428]។ ភ័ស្តុតាងទាំងអស់នេះដែលអង្គជំនុំជម្រះបានសំអាងលើ គឺមានតម្លៃជាភ័ស្តុតាងតិចតួច។ ជាក់ស្តែង ប្រជាជនថ្មីពុំបានផ្តល់កាលៈទេសៈច្បាស់លាស់នៃការចោទប្រកាន់របស់ពួកគាត់ថាមានការប្រព្រឹត្តិមិនស្មើភាពគ្នានោះទេ។ វាគ្រាន់តែជាចម្លើយ ដែលមិនបានចង្អុលបង្ហាញពីភ័ស្តុតាងជាក់ស្តែងនៃការប្រព្រឹត្តិមិនសូវប្រសើរដូចទៅនឹងការប្រព្រឹត្តិចំពោះប្រជាជនមូលដ្ឋានតែប៉ុណ្ណោះ។ ចៅក្រមមានវិចារណញ្ញាណគួរសន្និដ្ឋានថា ភ័ស្តុតាងទាំងអស់នេះមិនអាចគាំទ្រថាមាន “ការរើសអើងជាក់ស្តែង” បានទេ។ នៅកថាខណ្ឌ ១៦៥៣ នៃសំអាងហេតុសាលក្រម ដោយពុំមានភ័ស្តុតាងជាក់ស្តែង និងស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះ អង្គជំនុំជម្រះបានសន្និដ្ឋានដោយពុំត្រឹមត្រូវថា ប្រជាជនថ្មីជាទូទៅភ័យខ្លាចត្រូវចាប់ខ្លួន ឬបញ្ជូនទៅលត់ដំដោយសារកងឈ្លប និងដោយសារថា អ្នកធ្វើការនៅទំនប់១មករា បានបាត់ខ្លួន។

## ២.១.២. ការចោទប្រកាន់ចំពោះការប្រព្រឹត្តិលើប្រជាជនថ្មី

៧៩៧. ជាបឋម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអះអាងអំពីអត្ថិភាពនៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការប្រព្រឹត្តិស្មើភាពគ្នា ដោយពុំបានផ្តល់ប្រភពច្បាប់សម្រាប់គាំទ្រការលើកឡើងនេះ[1429]។ បន្ទាប់មក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានថាការប្រព្រឹត្តិដូចដែលបានស្តែងចេញ តាមរយៈការពិពណ៌នា នៅក្នុងកថាខណ្ឌ ១៦៥៣ នៃសំអាងហេតុសាលក្រម គឺបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ប្រជាជនថ្មី ក្នុងការទទួលបានការប្រព្រឹត្តិស្មើភាពគ្នា[1430]។ ក៏ប៉ុន្តែ ពុំមានសិទ្ធិជាមូលដ្ឋានក្នុងការចូលរួមបោះឆ្នោតតាមសន្ទូត ឬចូលរួមពិធីផ្លូវការ

---

[1427] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ៥៦២៦៖ “ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ (ហ៊ុន សិត្ថានី) ឯកសារ **E1/306.1** ទំព័រ ៥៣”។

[1428] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥២ កំណត់សម្គាល់ជើងទំព័រលេខ៥៦២៧៖ “ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ (អ៊ុន រ៉ន) ឯកសារ **E1/307.1** ទំព័រ ១៤-១៥ (បន្ថែមថា ខុសពីប្រជាជនមូលដ្ឋាន ដោយសារប្រជាជនថ្មីខ្លាចស្លាប់ ពួកគេមិនអាចសួរអ្នកធ្វើការជាមួយគ្នាពីប្រវត្តិពួកគេទេ”។

[1429] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៩ កំណត់សម្គាល់ជើងទំព័រលេខ៥៧៤១ យោងទៅ កថាខណ្ឌ ១៦៥៣។

[1430] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៩ កំណត់សម្គាល់ជើងទំព័រលេខ៥៧៤១ យោងទៅ កថាខណ្ឌ ១៦៥៣។

នានានោះទេ ហើយក៏គ្មានសិទ្ធិដាច់ខាតដែលមិន "ងាយ" នឹងត្រូវគេស្តីបន្ទោស និងមិនខ្លាចត្រូវចាប់ខ្លួន ឬលត់ដំ (ភ័ស្តុតាងក្រៅវិសាលភាព) នោះដែរ[1431]។ ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស អង្គច្បាប់ ដោយមិនបានកំណត់អំពីកម្រិតនៃភាពធ្ងន់ធ្ងរចាំបាច់ ដើម្បីឱ្យការរើសអើងជាក់ស្តែងមួយ ដែលរំលោភលើសិទ្ធិជាមូលដ្ឋាន អាចត្រូវកំណត់បានថាជាការធ្វើទុក្ខបុកម្នេញ។ កំហុសនីមួយៗដាច់ពីគ្នា ក្នុងចំណោមកំហុសទាំងអស់នេះ ធ្វើឱ្យអស់សុពលភាពចំពោះសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដែលថា ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញចំពោះប្រជាជនថ្មី ត្រូវបានបំពេញ។

## ២.២. ការប្រព្រឹត្តិចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៧៩៨. ជាលក្ខណៈចម្បង ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះមិនត្រូវបានស្នើសុំដោយត្រឹមត្រូវឱ្យពិនិត្យលើ អង្គហេតុនៃ "ការរើសអើង" លើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទេ[1432]។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានកំណត់ធាតុផ្សំ សត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការ នៃរបបសាធារណរដ្ឋខ្មែរ និងដោយបានសន្និដ្ឋានថាឧក្រិដ្ឋកម្មនេះត្រូវបានបង្ហាញ[1433]។ គ្មានករណីណា មួយក្នុងចំណោមករណីទាំងឡាយដែលលើកយកមកជាសំអាងសម្រាប់សេចក្តីសន្និដ្ឋាននេះ ត្រូវបាន បង្ហាញឱ្យឃើញ ស្របតាមកម្រិតនៃភ័ស្តុតាងតម្រូវទេ ទាំងសម្រាប់ការអនុវត្តការកំណត់អត្តសញ្ញាណ អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលត្រូវចាប់ខ្លួននៅទំនប់១មករា (២.២.១) ការចាប់ខ្លួន និងការបាត់ខ្លួនឪពុករបស់ ហ៊ុន សិត្ថានី (២.២.២) ឬទាំងការចាប់ខ្លួន និងការបាត់ខ្លួនក្រុម អតីតទាហានក្តី (២.២.៣)។

### ២.២.១. គ្មានភ័ស្តុតាងក្នុងកម្រិតតម្រូវ អំពីប្រតិបត្តិការកំណត់អត្តសញ្ញាណអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

1431 សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៨៩។

1432 សូមមើលខាងលើ កថាខណ្ឌ ៤៩០-៤៩២។

1433 សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩០-១៦៩២។

៧៩៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសំអាងសេចក្តីសន្និដ្ឋានទូទៅរបស់ខ្លួនដែលថា អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវចាត់ទុកជាខ្មាំង ត្រូវបានចាប់ខ្លួន និងបាត់ខ្លួន លើការយល់ឃើញជាទូទៅលើគោលនយោបាយខ្មាំង[1434]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្អែកលើសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា មានគោលនយោបាយធ្វើបញ្ជីនៅថ្នាក់ស្រុក និងតំបន់ ដើម្បីកំណត់អត្តសញ្ញាណទាហានស័ក្តិខ្ពស់ៗ ដើម្បីចាប់ខ្លួន ចាដូចជា "អង្គហេតុ" មួយ ដែលគាំទ្រថាមានការរើសអើងជាក់ស្តែងចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅទំនប់១មករា ប្រាកដមែន[1435]។ វិធីសាស្ត្ររបស់អង្គជំនុំជម្រះ គឺពិតជាពុំត្រឹមត្រូវទេ។ អង្គជំនុំជម្រះបានផ្អែកលើអត្ថិភាពបែបសន្មតថាមានគោលនយោបាយមួយ - ជាមួយនឹងភ័ស្តុតាងក្រៅវិសាលភាព - ដើម្បីបំពេញធាតុផ្សំឧក្រិដ្ឋកម្មមួយដែលខ្លួនគ្មានលទ្ធភាពបង្ហាញឱ្យឃើញ ដោយផ្អែកតែទៅលើភ័ស្តុតាងនានានៅតាមទីតាំងដែលត្រូវបានស្នើសុំឱ្យអង្គជំនុំជម្រះពិនិត្យ។

### ២.២.២. គ្មានភ័ស្តុតាងក្នុងកម្រិតតម្រូវ អំពីការចាប់ខ្លួន/ការបាត់ខ្លួនឪពុករបស់ ហ៊ុន សិត្ថានី

៨០០. សក្ខីកម្មរបស់ ហ៊ុន សិត្ថានី ដែលត្រូវបានយោងជាភ័ស្តុតាងតែមួយគត់ដែលបង្ហាញពីការចាប់ខ្លួនឪពុករបស់គាត់ ដោយមូលហេតុនយោបាយ គឺជាការឮតៗគ្នា។ ក្នុងអំឡុងពេលសវនាការ គាត់បាននិយាយដូច្នេះថា៖

> "ប្អូនខ្ញុំឃើញនឹងភ្នែក ប្រាប់ថា ហៅយកទៅជួយលីឈើ ទៅជួយសែងឈើគេ យោធាមកហៅ។ ប្អូនខ្ញុំឃើញ ប្អូនខ្ញុំដឹង ខ្ញុំជិកនៅប្លង់ជាប់ហ្នឹង តែខ្ញុំថ្ងៃនោះ ខ្ញុំមករដូវហ្នឹង ល្ងាចខ្ញុំ

---

[1434] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៦០ កំណត់សម្គាល់ជើងទំព័រលេខ៥៦៤៦ យោងទៅ កថាខណ្ឌ ៣៨៤០ និង ៣៨៤៧។

[1435] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩០ កំណត់សម្គាល់ជើងទំព័រលេខ៥៧៤៣ យោងទៅ កថាខណ្ឌ ១៦៦០, ១៦៦២-១៦៦៣។

សម្រាក គឺយប់ហ្នឹងឯង ប្រហែលជាម៉ោងប្រាំពីរយប់ហ្នឹង។ រួចទាល់តែភ្លឺឡើង បានប្អូនខ្ញុំមកប្រាប់ថា "បងគេហៅប៉ាទៅបាត់ហើយ មួយយប់ហើយ អត់ឃើញប៉ាយើងមកវិញទេ""[1436]។

៨០១. ដោយផ្អែកលើរឿងរ៉ាវតែមួយគត់ដែលបង្ហាញពីសម្ដីនិយាយតពីបងប្អូនរបស់ ហ៊ុន សិត្ថានី ទាក់ទងនឹងការចាប់ខ្លួនបុគ្គលម្នាក់ដែលជាគ្រូបង្រៀននៅសម័យ លន់ នល់ អង្គជំនុំជម្រះបានសន្និដ្ឋានថាមានការអនុវត្ត "គោលនយោបាយ" មិនពិតមួយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ដែលធ្វើការនៅទំនប់១មករា។ វាគឺជាសេចក្ដីសន្និដ្ឋានមិនសមហេតុសមផល ហើយត្រូវទុកជាមោឃៈ។

## ២.២.៣. គ្មានភស្តុតាងក្នុងកម្រិតតម្រូវ អំពីការចាប់ខ្លួន/ការបាត់ខ្លួនក្រុមអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

៨០២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្អែកលើសក្ខីកម្មរបស់ អ៊ុត សេង ដើម្បីអះអាងថា ក្រុមអ្នកធ្វើការដែលមានសមាសភាពអតីតទាហាន លន់ នល់ ត្រូវបានចាប់ និងបាត់ខ្លួន[1437]។ បើទោះជាសាក្សីនិយាយថាបានឃើញផ្ទាល់ភ្នែកពីការមកហៅកម្មករពីរទៅបីនាក់ នៅពេលយប់ នៅការដ្ឋានការងារក៏ដោយ [1438] ក៏ផ្ទុយមកវិញ គាត់បានបញ្ជាក់យ៉ាងច្បាស់ថា គាត់មិនដឹងថានរណានាំអ្នកទាំងអស់នោះទៅទេ[1439]។ ម្យ៉ាងវិញទៀត សម្ដីរបស់ អ៊ុត សេង គឺជាការលាយបញ្ចូលគ្នារវាងការឮតពីគេ និងការស្មានទាក់ទងនឹងការពាក់ព័ន្ធបែបសន្មតរបស់កម្មករទាំងអស់នេះជាមួយនឹងរបប លន់ នល់។ គាត់គ្រាន់តែនិយាយថា៖ "តាមខ្ញុំចាំ គឺជួបកាលនោះ កងរបស់ខ្ញុំកាប់ជិតកងរបស់ប្រជាជន គឺ

[1436] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៦២ កំណត់សម្គាល់ជើងទំព័រលេខ៥៦៥៥ ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ E1/306.1 ចន្លោះម៉ោង ០៩.៥០.១២ និង ០៩.៥២.៤២។

[1437] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩០ កំណត់សម្គាល់ជើងទំព័រលេខ៥៧៤៤ យោងទៅ កថាខណ្ឌ ១៦៦២-១៦៦៣។

[1438] ប្រតិចារឹក ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ E1/309.1 ម៉ោងប្រហែល ០៩.២៤.០៥។

[1439] ប្រតិចារឹក ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ E1/309.1 ម៉ោងប្រហែល ០៩.២៤.០៥ "យើងមិនអាចថាអ្នកនោះជាឈ្លបឬក៏ជាអីទេ ព្រោះជាសម្លៀកបំពាក់ខ្មៅៗដូចគ្នា", ម៉ោងប្រហែល ០៩.២៦.១៤ "គ្មានកងទ័ពប្រដាប់ដោយកាំភ្លើង ឬ -- គឺខ្លួនទទេ។ ហើយយើងមិនអាចមើលថា អ្នកណាជាអ្នកជាឈ្លប ឬក៏ជាស្អីនោះ យើងមិនអាចដឹងទេ"។

ថាប្រជាជនភូមិថ្មី ដែលមាន -- ប្រជាជនភូមិថ្មី និយាយរួម ពួក១៧មេសាមួយក្រុមហ្នឹង គឺជាមានអ្នកជាប់និន្នាការជាទាហាន ជាស្ទើរៗច្រើន ក្នុងដែលជាប់និន្នាការ"។ ប៉ុន្តែ គាត់មិនអាចបញ្ជាក់បានពីប្រភពនៃការអះអាងរបស់ខ្លួន ទាក់ទងនឹងការជាប់ពាក់ព័ន្ធដែលរងការចោទប្រកាន់នេះ[1440]។ ទាក់ទងនឹងការសម្លាប់អ្នកទាំងនោះវិញ ជាថ្មីម្តងទៀត វាគ្រាន់តែជាការឮគេនិយាយតគ្នាប៉ុណ្ណោះ។ អ៊ុត សេង ពុំដឹងថាមានអ្វីកើតឡើងចំពោះកម្មករទាំងនោះឱ្យប្រាកដទេ។ គាត់បាននិយាយដូច្នេះថា៖ "យើងចាប់អារម្មណ៍ថាប្រាកដជាមានបញ្ហា។ គ្រាន់ថាយកទៅសម្លាប់ត្រង់ណានោះ យើងមិនដឹងទេ។ គ្រាន់តែដឹងថាចេញទៅ គឺមានបញ្ហាប៉ុណ្ណឹង"[1441]។ គាត់បានអះអាងដែរថា នៅពេលស្អែកឡើង គាត់បានឮប្រធានវរៈយុវជននិយាយលេងសើចជាមួយសមាជិកម្នាក់របស់ "ឈ្លប" យុវជនថា៖

> "វាជាចៃដន្យ ប្រធានវរយុវជន។ ក្នុងនោះវាមានឈ្លបសម្រាប់វរៈ សុទ្ធតែអ្នកវៃប្រហារហ្នឹង។ អ៊ីចឹងវានិយាយលេងគ្នាទេ តែយើងដើរកាត់ទៅឮ ក៏ថា "គេចូលអណ្តូងហើយ អាប៉ុន្មាននាក់យប់មិញ""[1442]។

៨០៣. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានដោយផ្អែកតែលើអង្គហេតុចំនួនពីរបង្ហាញដោយ ហ៊ុន សិត្ថានី និង អ៊ុត សេង ថាមានការរើសអើងជាក់ស្តែងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ដោយពុំដឹងថាតើអ្នកទាំងអស់នោះពិតជាត្រូវបានសម្លាប់ពិតមែនឬអត់ តើនរណាជាអ្នកបញ្ជាឱ្យចាប់ខ្លួនពួកគេ ហើយក្រោមហេតុផលអ្វីនោះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថាប.ក.ក បានបញ្ជាឱ្យធ្វើការរើសអើងចំពោះប្រជាជនថ្មីបានទេ។ អង្គជំនុំជម្រះក៏មិនអាចសន្និដ្ឋានបានថា មានចេតនាជាក់លាក់របស់ចារីក្នុងការដាក់អ្នកទាំងនោះឱ្យស្ថិតក្រោមការប្រព្រឹត្តិបែបនេះនោះដែរ[1443]។ សេចក្តីសន្និដ្ឋានមិនសមហេតុសមផលនេះ ត្រូវទុកជាមោឃៈ។

---

[1440] ប្រតិចារឹក ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/309.1** ម៉ោងប្រហែល ០៩.២១.២៧។

[1441] ប្រតិចារឹក ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/309.1** ម៉ោងប្រហែល ០៩.២១.២៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1442] ប្រតិចារឹក ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/309.1** ចន្លោះម៉ោង ០៩.២១.២៧ និង ០៩.២៤.០៥។

[1443] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩០។

## ៣. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

## ៣.១. គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាម

៨០៤. ដូចដែលបាននិយាយពីខាងលើ អង្គជំនុំជម្រះមិនត្រូវបានស្នើឱ្យវិនិច្ឆ័យលើអង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុសាសនា ចំពោះជនជាតិចាម នៅទំនប់១មករា ទេ[1444]។ លើសពីនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាចំពោះជនជាតិចាម ដោយពុំមានចេតនាដកជនជាតិចាមចេញពីក្នុងសង្គម[1445]។ ក្រោយពីបានពិចារណាលើបញ្ហាបឋមនានារួចមក (៣.១.១) ការពិនិត្យលើសេចក្តីសន្និដ្ឋានអង្គហេតុរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការប្រព្រឹត្តិលើជនជាតិចាម នៅទំនប់១មករា បង្ហាញឱ្យឃើញពីលក្ខណៈមិនសមហេតុសមផល និងមិនសមស្របនៃសេចក្តីសន្និដ្ឋានទាំងនោះ សម្រាប់ធ្វើជាសំអាងថាមានការរើសអើងជាក់ស្តែង ដែលជាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ (៣.១.២)។

### ៣.១.១. បញ្ហាបឋម

៨០៥. អង្គជំនុំជម្រះពុំបានផ្តល់ការយោងណាមួយដែលមានសុពលភាពសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានថា ជនជាតិចាមត្រូវបានដាក់ឱ្យស្ថិតក្រោមវិធានការរើសអើង នៅទំនប់១មករានោះទេ ហើយអង្គជំនុំជម្រះបានផ្អែកលើភស្តុតាងក្រៅវិសាលភាពមួយចំនួន។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា មានការបង្ហាញឱ្យឃើញថា ជនជាតិចាមធ្វើការនៅទំនប់១មករា បានក្លាយជាកម្មវត្ថុនៃវិធានការរើសអើង (ការបង្ខំឱ្យហូបសាច់ជ្រូក និងហាមឃាត់មិនឱ្យប្រតិបត្តិសាសនា និងនិយាយភាសារបស់ពួកគាត់) ដោយផ្អែកលើកថាខណ្ឌ ១៦៥៨ នៃសំអាងហេតុសាលក្រម។ ក៏ប៉ុន្តែ នៅក្នុងកថាខណ្ឌ គឺលើកឡើងពីសក្ខីកម្មរបស់ គង់ អ៊ុត ទាក់ទងនឹងការបាត់ខ្លួនមនុស្ស[1446]។

---

[1444] សូមមើលខាងលើ កថាខណ្ឌ ៣៩៥។

[1445] សូមមើលខាងលើ កថាខណ្ឌ ៦៤២-៦៥៥, ៦៥៧។

[1446] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩៥ កំណត់សម្គាល់ជើងទំព័រលេខ៥៧៥៣ យោងទៅ កថាខណ្ឌ ១៦៥៨។

៨០៦. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យលើអង្គហេតុកើតឡើងនៅទំនប់១មករា តាមរយៈអង្គហេតុកើតឡើងនៅតាមកន្លែងផ្សេងៗក្នុងភូមិភាគកណ្តាល និងនៅកន្លែងផ្សេងៗទៀតនៃប្រទេសកម្ពុជា និងក្នុងបរិបទនៃវិធានការប្រឆាំងនឹងក្រុមនេះ នៅតាមភូមិនានាក្នុងតំបន់ ៤១, ៤២ និង ៤៣[1447]។ ភស្តុតាងទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ និងមិនអាចប្រើដើម្បីបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មនៅតាមទីកន្លែងដែលជាកម្មវត្ថុនៃបណ្តឹងនោះទេ។

## ៣.១.២. គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាមនៅទំនប់១មករា

៨០៧. ក្រោយពីបានពិនិត្យយ៉ាងយកចិត្តទុកដាក់លើភស្តុតាងទាក់ទងនឹងការប្រព្រឹត្តិចំពោះជនជាតិចាម នៅទំនប់១មករា ត្រង់កថាខណ្ឌ ១៦៥៦-១៦៥៨ នៃផ្នែកសំអាងហេតុសាលក្រមរួចមក មានការបង្ហាញថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានយល់ថាមានការបង្ហាញឱ្យឃើញថា ជនជាតិចាមបានរងគ្រោះពីការរើសអើង ព្រោះថាពួកគាត់ត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក (៣.១.២.១) និងត្រូវបានហាមឃាត់មិនឱ្យគោរពបូជាសាសនា (៣.១.២.២) និងនិយាយភាសាកំណើតរបស់ពួកគាត់ (៣.១.២.៣)[1448]។

### *៣.១.២.១. ការចោទប្រកាន់ពីការបង្ខំជនជាតិចាមឱ្យហូបសាច់ជ្រូក*

៨០៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ជនជាតិចាមបានរងគ្រោះដោយសារការរើសអើងនៅទំនប់១មករា ព្រោះថា "ចាមត្រូវបានគេបង្ខំឱ្យហូបសាច់ជ្រូក នៅពេលដែលមានរបបអាហារសាច់ជ្រូក (ទោះបីជាមិនមានញឹកញាប់ក៏ដោយ) ឬក៏គ្មានហូបតែម្តង"[1449]។ ការពិតទៅ សាក្សី "ជាច្រើនរូប" ដែលអង្គជំនុំជម្រះបានយោងទៅរក គឺមានចំនួនតែបីនាក់ប៉ុណ្ណោះ ក្នុងនោះមាន អ៊ុំ ជី, សៀង សុវិដា និង មាស ឡៃហួរ។ ជាបឋម វាទំនងជាសំខាន់ដែលត្រូវដាក់សក្ខីកម្មរបស់ អ៊ុំ ជី

---

[1447] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៤-១៦៥៥ យោងទៅ ផ្នែក ១៣.២.៦។

[1448] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៩។

[1449] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៦ កំណត់សម្គាល់ជើងទំព័រលេខ៥៦៣៧, ៥៦៣៨។

នៅក្នុងបរិបទរបស់វាឡើងវិញ នោះគឺបរិបទខ្វះចំណីអាហារ។ ពាក់ព័ន្ធនឹងអាហារដែលមាន អ៊ុំ ជី បាននិយាយថា៖

> “ចំណែកអាហារវិញ ពេលព្រឹកគេឱ្យស៊ីបាយ ពេលល្ងាចស៊ីបបរ ប៉ុន្តែនិយាយពីសម្ល ការហូប ចុកវាមិនគ្រប់គ្រាន់ទេ ពីព្រោះមានត្រកួនស្ងោរ និងជាមួយត្រីកញ្ចុះប្រឡាក់ឱ្យតូចៗហ្នឹង។ ជួនកាលយូរគេឱ្យសាច់ជ្រូកម្តងអីអ៊ីចឹងទៅ”[1450]។

៨០៩. ដូច្នេះ វត្តមានសាច់នៅតុអាហារ គឺជាអ្វីដែលពិសេស និងវិជ្ជមានសម្រាប់ការផ្តល់សារធាតុចិញ្ចឹមដល់កម្មករ។ អង្គជំនុំជម្រះបានកត់សម្គាល់ដោយត្រឹមត្រូវថា បើយោងតាមភស្តុតាង ការឱ្យហូបសាច់ជ្រូក គឺមិនញឹកញាប់ទេ[1451]។ ម្យ៉ាងវិញទៀត គឺវាមិនមែនជាការ “បង្ខំ” ជនជាតិចាមឱ្យហូបសាច់ជ្រូកនោះទេ។ វាច្បាស់ណាស់ថា ប្រសិនបើពួកគាត់មិនចង់ហូប គាត់អាចមិនហូបបាន។ អ៊ុំ ជី បាននិយាយថា៖

> “ចាមសម័យហ្នឹង បើអ្នកណាគេកាន់បានគេអត់ហូបទេ សុខចិត្តៗហូបអំបិល។ បើអ្នកខ្លះគ្នាហៅរ ចេះតែហុតៗទឹកទៅ ប៉ុណ្ណឹងគ្រាន់”[1452]។

៨១០. ដូច្នេះ ភស្តុតាងពុំបានបង្ហាញថា មានការប្រព្រឹត្តិខុសគ្នាចំពោះជនជាតិចាមទេ។ ផ្ទុយទៅវិញ ពួកគេទទួលបានការប្រព្រឹត្តិដូចប្រជាជនទូទៅដែរ។ កំណត់ហេតុស្តាប់ចម្លើយដែលយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៥៦៣៤ ដើម្បីគាំទ្រដល់ការអះអាងអំពីការប្រព្រឹត្តិបែបរើសអើងចំពោះជនជាតិចាម គឺច្បាស់លាស់ខ្លាំងណាស់៖ “ចំណែកការហូបចុកវិញ គឺដូចខ្មែរយើងដែរ”[1453]។ ដូច្នេះ អាជ្ញាធរនៅ

---

[1450] ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ E1/326.1 ចន្លោះម៉ោង ១៣.២៧.៤៨ និង ១៣.៣០.៤៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1451] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៦ កំណត់សម្គាល់ជើងទំព័រលេខ៥៦៣៧។

[1452] ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ E1/326.1 ចន្លោះម៉ោង ១៣.៣០.៤៨ និង ១៣.៣៣.១៨។

[1453] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៦ កំណត់សម្គាល់ជើងទំព័រលេខ៥៦៣៤៖ “កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួប ណុន E3/9349 ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ទំព័រ ៦ ERN 00239924 (“សួរ៖ តើលោកដឹងពីការសម្លាប់ជនជាតិចាមដែរឬទេ? ឆ្លើយ៖ ចំពោះជនជាតិចាមនៅក្នុងក្រុមរបស់ខ្ញុំ មិនមានការចាប់យកទៅសម្លាប់ទេ។ ប៉ុន្តែ នៅពេលអ្នកទាំងនោះចេញពីកន្លែងខ្ញុំ ខ្ញុំមិន

ទំនប់១មករា បានប្រព្រឹត្តលើជនជាតិចាមដូចមនុស្សទូទៅដែរ។ អាជ្ញាធរមិនបានចាត់វិធានការវិជ្ជមាន ដើម្បីផ្តល់ជម្រើសជាសាច់ផ្សេងចំពោះជនជាតិចាមនៅទំនប់១មករា នោះទេ។ នេះមិនមែនជាភ័ស្តុតាង ដែលអាចឱ្យសន្និដ្ឋានបានថាមានការរើសអើងបានឡើយ។

### *៣.១.២.២. បម្រាមមិនឱ្យគោរពបូជាសាសនា*

៨១១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ជនជាតិចាមបានរងគ្រោះដោយសារ ការរើសអើងនៅទំនប់១មករា ព្រោះថាពួកគេមិនអាចប្រតិបត្តិសាសនារបស់ខ្លួនបាន[1454]។ ភ័ស្តុតាង មានភាពច្បាស់លាស់ណាស់។ ការប្រតិបត្តិសាសនាមិនត្រូវបានអនុញ្ញាតទាំងសម្រាប់ប្រជាជនខ្មែរ និង សម្រាប់ប្រជាជនចាម[1455]។ សក្ខីកម្មជាលាយលក្ខណ៍អក្សរជាច្រើន បានបញ្ជាក់អំពីចំណុចនេះ ផងដែរ[1456]។ ដូច្នេះ ដោយសារពុំមានការប្រព្រឹត្តិខុសគ្នា សេចក្តីសន្និដ្ឋានតែមួយគត់គឺថា ពុំមានការ រើសអើងជាក់ស្តែងទេ ទោះជាផលវិបាកនៃវិធានការមិនរើសអើងបែបណាក៏ដោយ។

### *៣.១.២.៣. បម្រាមមិនឱ្យនិយាយភាសាកំណើតរបស់ពួកគាត់*

៨១២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ជនជាតិចាមមិនត្រូវបានអនុញ្ញាតឱ្យ និយាយភាសារបស់ពួកគាត់ នៅទំនប់១មករា ដោយផ្អែកលើសក្ខីកម្មចំនួនពីររបស់ ឱ ហូ និង មាស

---

ដឹងទេ។ គេមិនឱ្យនិយាយភាសាចាមទេ។ ចំណែកការហូបចុកវិញ គឺដូចខ្មែរយើងដែរ។ ក្នុងករណីដែលមានសម្លសាច់ជ្រូក បើមិន ហូប គឺគ្មានអ្វីហូបទេ។ ចំពោះការគោរពប្រពៃណី គឺគេហាមឃាត់ ជាពិសេសស្ត្រី គេមិនឱ្យយកក្រមាគ្របក្បាលទេ")"។

[1454] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៦, ១៦៥៩, ១៦៩៥។

[1455] ប្រតិចារឹក ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E1/353.1** ទំព័រ ៣១ មុនម៉ោង ១០.៥៥.៤៧, ប្រតិចារឹក ថ្ងៃទី០៦ ខែតុលា ឆ្នាំ ២០១៥ ឯកសារ **E1/354.1** មុនម៉ោង ១១.០២.២៥, កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ **E3/375** ERN 00348800។

[1456] ឧទាហរណ៍ សូមមើល៖ កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាត់ អ៊ីសា ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៨ ឯកសារ **E3/5207** ERN 00221864 ("ពួកគេចង់បំបាត់សាសនាទាំងអស់ រួមទាំងសាសនាអ៊ីស្លាម និងព្រះពុទ្ធសាសនា")។ កំណត់ហេតុនៃការស្តាប់ចម្លើយ ជិ លី ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ **E3/5290** ERN 00330736, 00330738។

ឡៃហួរ[1457]។ ក៏ប៉ុន្តែ ឱ ហ៊ូ មិនធ្លាប់បានបង្ហាញពីការហាមឃាត់ណាមួយចំពោះជនជាតិចាមមិនឱ្យនិយាយភាសារបស់ពួកគាត់ទេ។ ដូច្នេះ នៅសល់តែសក្ខីកម្មតែឯងរបស់ មាស ឡៃហួរ ប៉ុណ្ណោះ។

## ៣.២. ការប្រព្រឹត្តិស្មើភាពគ្នា មិនមែនជាធាតុផ្សំនៃការប្រព្រឹត្តិរើសអើង

៨១៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ការប្រព្រឹត្តិស្មើភាពគ្នា ថាជាការរើសអើង "ដោយប្រយោល" និងដោយបានប្រកាសថាជាការរើសអើងមួយដែរ ចំពោះអំពើអកម្មដែលអាជ្ញាធរនៅទំនប់១មករា មិនបានចាត់វិធានការវិជ្ជមានដើម្បីផ្តល់ជម្រើសជាសាច់ផ្សេងដល់ជនជាតិចាមនៅទំនប់១មករា។ ដោយធ្វើដូច្នេះ អង្គជំនុំជម្រះបានចាត់ទុកសញ្ញាណនៃការរើសអើងដោយប្រយោលជាក់ស្តែង ថាជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ និងបានបកស្រាយធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្ម ជាលក្ខណៈទូលាយ ក្រៅក្របខ័ណ្ឌច្បាប់ទាំងស្រុង។ ក៏ប៉ុន្តែនៅឆ្នាំ១៩៧៥ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ពុំបានរាប់បញ្ចូលការរើសអើងដោយប្រយោលទៅក្នុងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញទេ។ ដូច្នេះ ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពុំត្រូវបានបំពេញ ដោយសារពុំមានភស្តុតាងនៃការរើសអើងដោយផ្ទាល់។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការបំពេញបាននូវធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញត្រូវទុកជាមោឃៈ[1458]។

## ផ្នែកទី ៤. ព្រលានយន្តហោះកំពង់ឆ្នាំង

៨១៤. យោងតាមខ្លឹមសារនៃដីកាដំណោះស្រាយ ខៀវ សំផន ត្រូវឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ដោយសារមានកម្មករជាច្រើននាក់បានស្លាប់ បណ្តាលមកពីល័ក្ខខ័ណ្ឌដែលបានបង្កើតឡើងនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ជាពិសេស ការបង្អត់អាហារ ល័ក្ខខ័ណ្ឌនៃការស្នាក់នៅមិនល្អ ការ

---

[1457] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៥៦ កំណត់សម្គាល់ជើងទំព័រលេខ៥៦៣៦៖ "ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ (ឱ ហ៊ូ) ឯកសារ **E1/301.1** ទំព័រ ១៦, ៧១។ ប្រតិចារឹក ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ (មាស ឡៃហួរ) ឯកសារ **E1/304.1** ទំព័រ ៨៥"។

[1458] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩៥-១៦៩៧។

ថៃទាំវេជ្ជសាស្ត្រ និងវិធានការអនាម័យមិនគ្រប់គ្រាន់ ក៏ដូចជាការបាក់កម្លាំងបណ្តាលមកពីការតម្រូវឱ្យធ្វើការងារលំបាក និងគ្រោះថ្នាក់[1459]។ ក៏ប៉ុន្តែ ដោយពុំមានភស្តុតាងដើម្បីបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល អង្គជំនុំជម្រះបានកំណត់បទចោទប្រកាន់ឡើងវិញដោយខុសច្បាប់ ឱ្យទៅជាការធ្វើមនុស្សឃាតដោយចេតនាដោយប្រយោល ដែលនាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គច្បាប់ និងដែលធ្វើឱ្យសេចក្តីសម្រេចរបស់ខ្លួនគ្មានសុពលភាព[1460]។

៨១៥. ដើម្បីកំណត់លក្ខណៈធាតុផ្សំសត្យានុម័តិនៃការសម្លាប់រង្គាល អង្គជំនុំជម្រះកត់សម្គាល់ថា៖ "លក្ខខណ្ឌផ្សេងៗត្រូវបានកំណត់ឡើងដែលនាំឱ្យមនុស្សជាច្រើននាក់ស្លាប់ រួមទាំងការដាក់ប្រជាជនឱ្យស្ថិតក្នុងល័ក្ខខ័ណ្ឌការងារដែលគ្មានសុវត្ថិភាព និងការបង្ខំពួកគេឱ្យធ្វើការរយៈពេលយូរ ដោយគ្មានម្ហូបអាហារគ្រប់គ្រាន់"[1461]។

៨១៦. អង្គជំនុំជម្រះថ្លែងថាខ្លួនជឿជាក់ថា អ្នកស្លាប់ទាំងអស់នេះគឺជាលទ្ធផលនៃ "ប្រតិបត្តិការតែមួយក្នុងការធ្វើឱ្យមនុស្សស្លាប់ ហើយជារួម អង្គជំនុំជម្រះយល់ឃើញថា ធាតុផ្សំនៃការសម្លាប់រង្គាលត្រូវបានបង្ហាញនៅក្នុងកាលៈទេសៈទាំងនោះ"[1462]។

៨១៧. យោងតាមខ្លឹមសារនៃសេចក្តីសន្និដ្ឋាននេះ អង្គជំនុំជម្រះបានធ្វើការយោងទៅលើកថាខណ្ឌ ១៧៥៥ និង ១៧៥៨ នៃសំអាងហេតុសាលក្រមដែលរងការជំទាស់។ កថាខណ្ឌ ១៧៥៥ បង្ហាញពីសក្ខីកម្មរបស់ កែវ គីន, នួន ត្រិច និង ហ៊ឹម ហាន ដែលអ្នកទាំងបីបាននិយាយថាបានឃើញកម្មករស្លាប់ និងរបួសក្រោយពីមានការបំផ្ទុះថ្ម។

៨១៨. បន្ទាប់មក អង្គជំនុំជម្រះបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញថា "មនុស្សជាច្រើននាក់បានស្លាប់ដោយសារតែការបំផ្ទុះ និងការប្រុងប្រយ័ត្នលើបញ្ហាសុវត្ថិភាពមិនគ្រប់គ្រាន់ ដូចជាការមិនមាន

[1459] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦៩៥-១៦៩៦, ដីកាដំណោះស្រាយ កថាខណ្ឌ ៣៩១-៣៩២, ១៣៨៧។

[1460] សំអាងហេតុសាលក្រម កថាខណ្ឌ ១៣៨៣-១៣៩០។ សូមមើលខាងលើ កថាខណ្ឌ ១៣៥-១៥៧។

[1461] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០០។

[1462] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០០។

ឧបករណ៍ការពារជាដើម"[1463]។ ក៏ប៉ុន្តែ បញ្ហានៃការស្លាប់ដែលជាប់ទាក់ទងនឹងគ្រោះថ្នាក់ការងារ បើទោះជាត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ៣៩២ ក៏ដោយ ក៏វាត្រូវបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ដោយរំលោភបំពានលើវិសាលភាពនៃបណ្ដឹងដែរ។ យោងតាមខ្លឹមសារនៃកថាខណ្ឌ ៩៧ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា មានការលើកឡើងពីការស្លាប់ពីរប្រភេទ៖ ការស្លាប់ទាក់ទងនឹងកង្វះអាហារ និងការស្លាប់ទាក់ទងនឹងការសម្លាប់ដែលមិនត្រូវបានកំណត់ប្រភេទបទល្មើសថាជាការសម្លាប់រង្គាល ដោយសហចៅក្រមស៊ើបអង្កេតនោះទេ។ ដូច្នេះ វាមិនដែលធ្លាប់មានការលើកឡើងពីការស្លាប់បណ្ដាលមកពីគ្រោះថ្នាក់ នៅការដ្ឋាននោះទេ។ ហេតុដូច្នេះ ជាចម្បង ខៀវ សំផន ពុំចាំបាច់ឆ្លើយតបនឹងអង្គហេតុដែលកើតចេញពីការរំលោភនីតិវិធីនេះឡើយ។

៨១៩. បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រើប្រាស់សេចក្ដីសន្និដ្ឋានទាក់ទងនឹងគ្រោះថ្នាក់ការងារទាំងអស់នេះ ដើម្បីសម្រេចថា ភ័ស្តុតាងបានបង្ហាញ "ពីការមិនអើពើរបស់ចារីអំពីជោគវាសនារបស់អ្នកធ្វើការទាំងនោះ ឬការមិនគិតអំពីលទ្ធភាពដែលនាំឱ្យពួកគេស្លាប់"[1464]។

៨២០. ពាក់ព័ន្ធនឹងកង្វះអាហារ ចៅក្រមបានសន្និដ្ឋានថា "ម្ហូបអាហារត្រូវបានផ្ដល់ដល់អ្នកធ្វើការទាំងនោះ បើទោះជាមិនគ្រប់គ្រាន់ ធៀបទៅនឹងប្រភេទ និងផែនការការងារដែលពួកគេត្រូវបានបង្ខំឱ្យធ្វើក៏ដោយ"[1465]។

៨២១. តាមរយៈភ័ស្តុតាងទាំងអស់នេះ អង្គជំនុំជម្រះបានកំណត់បទចោទប្រកាន់ឡើងវិញដោយខុសច្បាប់ ហើយនិយាយថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ត្រូវបានបង្ហាញ[1466]។ ពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះយល់ឃើញថា "អំពើសកម្ម ឬអកម្មដែលពាក់ព័ន្ធ ត្រូវបានរៀបចំឡើងតាមរយៈការដាក់លក្ខខ័ណ្ឌលើអ្នកធ្វើការដែលបានបណ្ដាលឱ្យពួកគេ

---

[1463] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧៩៥។

[1464] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០១។

[1465] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០២។

[1466] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០៤។

ស្លាប់ និងដោយសារពុំមាន**វិធានការសមស្រប**សម្រាប់ផ្លាស់ប្តូរ ឬជួយបន្ធូរបន្ថយល័ក្ខខ័ណ្ឌបែបនេះ”[1467]។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះមានកំហុស និងបាននិយាយផ្ទុយខ្លួនឯងនៅក្នុងសំអាងហេតុរបស់ខ្លួន ដោយពុំបានកំណត់អំពីកាតព្វកិច្ចផ្លូវច្បាប់ក្នុងការចាត់វិធានការរបស់អាជ្ញាធរទទួលបន្ទុកការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[1468]។

៨២២. បន្ទាប់មក អង្គជំនុំជម្រះបានធ្វើការកំណត់ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ដោយបានប្រើប្រាស់ចេតនាប្រយោល។ ដូចដែលបានចង្អុលបង្ហាញពីខាងលើ[1469] ដោយយល់ឃើញថា ការធ្វើមនុស្សឃាត ដោយចេតនាប្រយោល មាននៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់។ នៅសម័យកាលអង្គហេតុ ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ត្រូវបានកំណត់លក្ខណៈតែតាមរយៈចេតនាក្នុងការសម្លាប់មួយគត់។ លើសពីនេះទៀត អង្គជំនុំជម្រះមានកំហុសផងដែរ ក្នុងការវាយតម្លៃធាតុផ្សំអត្តនោម័តិ ដោយយល់ឃើញថា៖

> “ការរក្សាល័ក្ខខ័ណ្ឌទាំងនេះរយៈពេលយូរ រួមទាំងក្រោយពេលផលប៉ះពាល់ជាអវិជ្ជមានទៅលើអ្នកធ្វើការទាំងនោះបានលេចឡើងច្បាស់លាស់ បង្ហាញថាកម្មាភិបាលគ្រប់គ្រងការដ្ឋានការងារមានឆន្ទៈដាក់ល័ក្ខខ័ណ្ឌបែបនេះ ដោយដឹងថាល័ក្ខខ័ណ្ឌទាំងនេះនឹងនាំឱ្យជនរងគ្រោះស្លាប់ ឬដឹងពីលទ្ធភាពនៃផលវិបាកនៃល័ក្ខខ័ណ្ឌនេះ អាចបណ្តាលឱ្យមនុស្សស្លាប់។ ចំណុចនេះបានបំពេញធាតុផ្សំអត្តនោម័តិនៃអំពើ មនុស្សឃាត ក្នុងទម្រង់ជាចេតនាប្រយោល”[1470]។

៨២៣. អង្គជំនុំជម្រះត្រូវផ្តើមចេញពីទស្សនៈរបស់ចារីនៃបទល្មើស។ ទំនាក់ទំនងហេតុ និងផល គឺមិនអាចកំណត់បានរវាងវិធានការដាក់ចេញដោយឆន្ទៈរបស់អាជ្ញាធរក្នុងការកសាងប្រទេសឡើងវិញ និងកត្តា

[1467] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០៤។

[1468] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០៤។ សូមមើលផងដែរ សំអាងហេតុសាលក្រម កថាខណ្ឌ ៦២៧ និងខាងលើ កថាខណ្ឌ ៦៧៩។

[1469] សូមមើលខាងលើ កថាខណ្ឌ ៥៧៥-៦៣៧។

[1470] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០៥។

មិនចំណុះទាំងឡាយដែលបានកើតឡើង។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយមិនបានវាយតម្លៃភ័ស្តុតាងឱ្យបានច្បាស់លាស់ ទាក់ទងនឹងពេលវេលា។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រើប្រាស់ការគិតគូរលើពេលវេលា ដើម្បីកំណត់ធាតុផ្សំអត្តនោម័តិ ដោយនិយាយពី "ការរក្សាល័ក្ខខ័ណ្ឌទាំងនេះរយៈពេលយូរ" ដែលបានបង្ហាញឱ្យឃើញពីចេតនារបស់ចារី។ ដូច្នេះ សេចក្តីសន្និដ្ឋានមិនត្រឹមត្រូវទាំងអស់នេះ ទាក់ទងនឹងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ត្រូវទុកជាមោឃៈ[1471]។

៨២៤. ហេតុដូច្នេះ រាល់សេចក្តីសន្និដ្ឋានទាំងឡាយទាក់ទងនឹងការសម្លាប់រង្គាល និងការកំណត់បទចោទប្រកាន់ឡើងវិញឱ្យទៅជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ត្រូវទុកជាមោឃៈដូចគ្នា ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់[1472]។

**ជំពូកទី ២. មន្ទីរសន្តិសុខ**

**ផ្នែកទី ១. មន្ទីរ ស-២១**

**១. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ**

**១.១. កំហុសពាក់ព័ន្ធនឹងក្រុម "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមសន្មត" ដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់**

៨២៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថា ខ្លួនអាចកំណត់បានគ្រប់គ្រាន់ ប្រភេទ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត"[1473]។ អង្គជំនុំជម្រះសន្និដ្ឋានថា ក្រុមនេះមាន "អ្នកបន្ទុះបង្អាប់បដិវត្តន៍សង្គមនិយម និងអ្នករិះគន់ ឬប្រឆាំងនឹងបក្ស"។ អង្គជំនុំជម្រះបានចង្អុលបង្ហាញជាអាទិ៍ថា "ប្រភេទជាក់លាក់នៃខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត [...] មិនទាន់អស់នោះទេ" ហើយវា "បន្តរីករាលដាលថែមទៀតពីពេលមួយទៅពេលមួយ"[1474]។ ក៏ប៉ុន្តែ ការកត់សម្គាល់នេះ គឺពិតជាផ្ទុយគ្នាទាំងស្រុង

[1471] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០៥។

[1472] សំអាងហេតុសាលក្រម កថាខណ្ឌ ១៨០០-១៨០៦។

[1473] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០០។

[1474] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០០។

ទៅនឹងការកំណត់យ៉ាងតឹងរ៉ឹង នូវអ្វីដែលត្រូវបានហៅថាជាក្រុមមានលក្ខណៈគ្រប់គ្រាន់អាចកំណត់បាន[1475]។ ប្រសិនបើប្រភេទមានចំនួនច្រើន ហើយវាប្រែប្រួលទៅតាមពេលវេលា[1476] អង្គជំនុំជម្រះគួរតែកត់សម្គាល់ថា ក្រុម "ខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មត" គឺមិនមានលក្ខណៈគ្រប់គ្រាន់អាចកំណត់បានទេ។ ឈ្មោះរបស់ក្រុមនេះផ្ទាល់ គួរតែបានផ្តល់តម្រុយឱ្យអង្គជំនុំជម្រះយកទៅពិចារណា។ ម្យ៉ាងវិញទៀត គឺជាមួយនឹងឈ្មោះមានលក្ខណៈមិនច្បាស់លាស់ និងទូលាយ ដែលអង្គជំនុំជម្រះអាចយល់ឃើញថា បុគ្គលទាំងអស់ដែលត្រូវឃុំខ្លួននៅមន្ទីរ ស-២១ គឺបានរងគ្រោះដោយការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដោយពុំបានពិចារណាពីភាពសម្បូរបែបនៃអ្នកជាប់ឃុំ[1477]។ ដូចដែលអង្គជំនុំជម្រះបានយោងទៅរកយ៉ាងច្បាស់[1478] គេនឹងឃើញដូចគ្នានៅត្រង់ផ្នែកអូរកន្សែងថា ក្រុមនេះក៏មិនមានលក្ខណៈគ្រប់គ្រាន់អាចឱ្យកំណត់អត្តសញ្ញាណបានដែរ[1479]។

## ១.២. កំហុសពាក់ព័ន្ធនឹងការរើសអើងជាក់ស្តែង

៨២៦. អង្គជំនុំជម្រះមានកំហុស ដោយយល់ឃើញថា អំពើទាំងឡាយធ្វើឡើងប្រឆាំងនឹងខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត បានធ្វើឱ្យមានការរើសអើងជាក់ស្តែង។ អង្គជំនុំជម្រះបានសន្និដ្ឋានថា មនុស្ស "ត្រូវបានចាប់ខ្លួនក្នុងទ្រង់ទ្រាយធំ [...] ជាពិសេស ក្នុងពេលបោសសម្អាត និងក្នុងពេលមានជម្លោះជាមួយវៀតណាមឡើងកម្តៅខ្លាំង"[1480]។ ក៏ប៉ុន្តែ លក្ខណៈទ្រង់ទ្រាយធំនេះបង្ហាញឱ្យឃើញជាពិសេសថា ជនរងគ្រោះត្រូវបានជ្រើសរើស "ដោយងងឹតងងុល" ដែលបើតាមតុលាការកំពូល គឺវាមិនអាចបង្ហាញឱ្យឃើញពីលក្ខណៈវិនិច្ឆ័យនៃការរើសអើងជាក់ស្តែងបានទេ[1481]។ ហេតុដូច្នេះហើយបានជានៅ

---

[1475] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៤។

[1476] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៣៩ ដែលនៅត្រង់នោះ អង្គជំនុំជម្រះអះអាងថា "ប.ក.ក បានកំណត់ប្រភេទខ្មាំងសាជាថ្មីម្តងហើយម្តងទៀត"។

[1477] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០០-២៦០៤។

[1478] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០០ កំណត់សម្គាល់ជើងទំព័រលេខ៨៧៩០។

[1479] សូមមើលខាងក្រោម កថាខណ្ឌ ៨៤៩-៨៥៣។

[1480] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០១។

[1481] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៧៧។

ក្នុងរឿង្តី ឌុច តុលាការកំពូលបានទាត់ចោលសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖

"ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាតដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយទេ។ សកម្មភាពបែបនេះ មិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែបង្កើតឱ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ។ [...] ដោយសារតែគ្មានលក្ខណៈវិនិច្ឆ័យជាទូទៅណាមួយ សម្រាប់កំណត់គោលដៅជនរងគ្រោះទាំងនោះ ដូច្នេះអំពើឃោរឃៅនានាដែលបានប្រព្រឹត្តទៅលើជនរងគ្រោះ មិនមែនជាការរើសអើងជាក់ស្តែង ហើយក៏មិនមែនកើតចេញពីចេតនារើសអើង និងធ្វើទុក្ខបុកម្នេញផងដែរ។ ពាក់ព័ន្ធនឹងអំពើនានាដែលបានប្រព្រឹត្តទៅលើបុគ្គលទាំងនេះ តុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយបានកំណត់អំពើទាំងនេះថាជាអំពើធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ"[1482]។

៨២៧. ទោះជាសំណុំរឿងពីរផ្សេងគ្នាក៏ដោយ ក៏ភ័ស្តុតាងបង្ហាញនៅមន្ទីរ ស-២១ មិនប្រាកដជាជួយផ្តល់ធាតុផ្សំថ្មីៗ ដែលអាចឱ្យធ្វើសេចក្តីសន្និដ្ឋានមួយដែលខុសពីសេចក្តីសន្និដ្ឋានរបស់តុលាការកំពូលនោះទេ។ ហេតុដូច្នេះ ជាថ្មីទៀត សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ[1483]។

## ២. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

---

[1482] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៨៣។

[1483] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

៨២៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ត្រូវបានបង្ហាញ ទាក់ទងនឹងអ្នកទោសជនជាតិវៀតណាមនៅមន្ទីរ ស-២១[1484]។ ជាពិសេស អង្គជំនុំជម្រះមានកំហុសដោយយល់ឃើញថា "ជនជាតិវៀតណាម [...] ត្រូវបានកំណត់ជាគោលដៅ ដោយផ្អែកលើមូលដ្ឋានដែលថា ពួកគេត្រូវបាន ប.ក.ក ចាត់ទុកថាជាពូជសាសន៍ខុសពីប្រជាជនកម្ពុជា"[1485]។

## ២.១. គ្មានការពិចារណាអំពីបញ្ហាពូជសាសន៍នៅមន្ទីរ ស-២១

៨២៩. ភ័ស្តុតាងនានាដែលយោងដោយអង្គជំនុំជម្រះ ពុំបានគាំទ្រសេចក្តីកត់សម្គាល់បែបនេះទេ។ សៀវភៅកំណត់ត្រារបស់មន្ទីរ ស-២១ - ដែលការប្រើប្រាស់នៅទទួលរងការរិះគន់ - គឺបង្ហាញពីការមិនទុកចិត្តចំពោះជនជាតិវៀតណាម និងការគំរាមកំហែងរបស់ពួកគេលើបូរណភាពទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ។ កំណត់ត្រាទាំងអស់នោះ ចុះកាលបរិច្ឆេទឆ្នាំ១៩៧៨ ក្រោយពីមានការឈ្លានពានទឹកដីក្នុងទ្រង់ទ្រាយធំពីសំណាក់ប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧។ ក្នុងបរិបទនេះ ចៅក្រមមានវិចារណញ្ញាណគួរសន្និដ្ឋានថា ប្រទេសវៀតណាមត្រូវបានចាត់ទុកជាសត្រូវខាងយោធា និងនយោបាយ ដែលបានវាយប្រហារអធិបតេយ្យភាពទឹកដីរបស់កម្ពុជាធិបតេយ្យ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងពូជសាសន៍ ត្រូវបានកាត់ផ្តាច់ចេញពីអង្គហេតុ។

៨៣០. លើសពីនេះទៀត អង្គជំនុំជម្រះបានផ្អែកមួយផ្នែកធំលើសេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការកំណត់អត្តសញ្ញាណជនជាតិវៀតណាម និងជាតិពន្ធុវៀតណាមជាប់ខ្សែស្រឡាយខាងម្តាយ[1486]។ ក៏ប៉ុន្តែសេចក្តីសន្និដ្ឋានទាំងនេះ បើទោះជាត្រូវបានតវ៉ាក៏ដោយ[1487] ក៏វាពាក់ព័ន្ធតែជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា និងមិនមែនជនជាតិវៀតណាមជាប់ឃុំនៅមន្ទីរ ស-២១ ដែលជាអនិកជនវៀត

---

[1484] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០៧-២៦១០។

[1485] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០៧។

[1486] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០៨ កំណត់សម្គាល់ជើងទំព័រលេខ៨៨១០ យោងទៅ ការកំណត់អត្តសញ្ញាណជនជាតិវៀតណាម និងជាតិពន្ធុវៀតណាមជាប់សែខាងម្តាយ សំដៅជនជាតិវៀតណាមដែលរស់នៅប្រទេសកម្ពុជា។

[1487] សូមមើលខាងក្រោម កថាខណ្ឌ ១០៤៣-១០៤៨, ១០៩៦។

ណាមនោះទេ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាតិវៀតណាមជាប់ឃុំនៅមន្ទីរ ស-២១ "ត្រូវបានចាប់មកពីកន្លែងផ្សេងៗជិតព្រំដែនវៀតណាម និងក្នុងដែនទឹកនៃប្រទេសកម្ពុជា"[1488]។ ដូច្នេះ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានធ្វើការច្រឡំបញ្ចូលគ្នារវាងក្រុមផ្សេងៗ ដែលទង្វើនេះត្រូវទទួលពិន័យ។

៨៣១. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានកត់សម្គាល់ថាអ្នកទោសជនជាតិវៀតណាមត្រូវ "គេសន្មតថាជាខ្មាំងនយោបាយ"។ អង្គជំនុំជម្រះបានបន្តថា "ជនជាតិវៀតណាមដែលត្រូវបានឃុំឃាំង សួរចម្លើយ និងជាចុងក្រោយ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ត្រូវគេចាត់ទុកថាជាគិញ ឬជាទាហានវៀតណាមដែលជាខ្មាំងរបស់ ប.ក.ក និងបដិវត្តន៍"[1489]។ នេះជាអ្វីដែល ឌុច បានពន្យល់យ៉ាងច្បាស់។ បើតាម ឌុច ជនជាតិវៀតណាមត្រូវបានសួរចម្លើយ ដើម្បីទាញយកចម្លើយសារភាព ហើយចម្លើយមួយចំនួនត្រូវបានផ្សាយតាមវិទ្យុ។ គោលបំណង គឺដើម្បីបង្ហាញឱ្យឃើញថា ប្រទេសវៀតណាមមានគោលដៅឈ្លានពានប្រទេសកម្ពុជា និងបង្កើតសហព័ន្ធឥណ្ឌូចិន[1490]។ បើទោះបី ប.ក.ក កំណត់ថាអ្នកជាប់ឃុំវៀតណាមជាគិញ ឬទាហានវៀតណាមក៏ដោយ ក៏នោះមកពីដោយសារពួកអ្នកទាំងនោះត្រូវបានចាត់ទុកថាដូច្នេះមែន។ ក្នុងពេលកំពុងតែមានជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម វាច្បាស់ណាស់ថាពូជសាសន៍មិនមែនជាមូលហេតុនៃការចាប់ខ្លួនពួកគេទេ ប៉ុន្តែគឺដោយសារការពាក់ព័ន្ធរបស់ពួកគេជាមួយប្រទេសសត្រូវទៅវិញទេ ពោលគឺប្រទេសវៀតណាម ដែលប.ក.កយល់ថាមានមហិច្ឆតា

---

[1488] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០៧។

[1489] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦៩៨។

[1490] ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/436.1** ទំព័រ ៥៨ ចន្លោះម៉ោង ១៥.០១.០៤ និង ១៥.០៣.៣៣ "ពេលហ្នឹងហើយដែលមានបញ្ហាពីលើ។ ដោយឡែកទាហានយួន អត់សួរយកស៊ីច្រើនទេ សួរដើម្បីឱ្យទទួលស្គាល់ថា វាហ្នឹងមកឈ្លានពានទឹកដី ខ្មែរ យកប្រទេសកម្ពុជាដាក់ជាសហព័ន្ធឥណ្ឌូចិន ហើយឱ្យនិយាយឱ្យស្រួលទៅ ថតសំឡេង ផ្សាយតាមវិទ្យុ។ មួយអាទិត្យឱ្យបានពីរខ្សែអាត់។ មួយខ្សែអាត់ ប្រមាណ៥*មីនុត*អីប៉ុណ្ណេះ", ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/439.1** ទំព័រ ១១-១២ ចន្លោះម៉ោង ០៩.៤៥.៣៨ និង ០៩.៤៨.៣៣ "សួរទាហានយួន សួរចម្លើយពីរឿងផ្សេងៗ អត់ប្រយោជន៍ បានការអី។ ដូច្នេះ សំណួរដែលមានប្រយោជន៍ គឺសួរតែមេអ្នែង បក្សអ្នែងមានបញ្ហាឱ្យមកឈ្លានពានដីខ្មែរហ្នឹង បំណងស្អី? សួរតែប៉ុននុង ដើម្បីផ្សាយចិញ្ច្រាំរឿងនេះឱ្យសកលលោកជ្រាប។ ដូច្នេះ ទិសដៅដែលសួរមានតែមួយទេ អត់មានថាសួរពីរឿងយួនឈ្លានពានហ្នឹង អត់ប្រយោជន៍ទេ។ សួររឿងផ្សេងទៀត គឺអត់ប្រយោជន៍។ ដូច្នេះ សួរចិញ្ច្រាំតែរឿងយួនឈ្លានពាន ហើយផ្សាយវិទ្យុ។ នេះ ខ្ញុំឯកភាពជាមួយនឹងការណែនាំរបស់បក្សខ្ញុំ កាលនោះ", ប្រតិចារឹក សំណុំរឿង ០០១ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ **E3/525** ERN 00339792-93។

វាតទីនិយម។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថាជនជាតិវៀតណាមជាប់ឃុំនៅមន្ទីរ ស-២១ គឺត្រូវបានកំណត់ជាគោលដៅ ដោយមូលហេតុពូជសាសន៍របស់ពួកគេ គឺមិនសមហេតុផល និងត្រូវទុកជាមោឃៈ។

## ២.២. គ្មានការឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តី

៨៣២. អង្គជំនុំជម្រះមិនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលលើកឡើងថា ជនជាតិវៀតណាមមិនត្រូវបានកំណត់ជាគោលដៅ ដោយសារតែពូជសាសន៍របស់ពួកគេទេ ហើយក្នុងចំណោមកត្តាផ្សេងៗទៀត ពួកគេមិនបានទទួលរងការប្រព្រឹត្តិខុសគ្នាពីអ្នកជាប់ឃុំផ្សេងទៀតនោះទេ[1491]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានលើកឡើងវិញនូវអ្វីដែលខ្លួនហៅថាសេចក្តីណែនាំរបស់ ប៉ុល ពត ឱ្យបញ្ឈប់ការសួរចម្លើយជនជាតិខ្មែរ និងផ្តោតតែទៅលើជនបរទេស[1492]។ ក៏ប៉ុន្តែ ដូចដែលធ្លាប់បានលើកឡើងដោយមេធាវីការពារក្តី ឌុច បានពន្យល់ថាគម្រោងនេះមិនទទួលបានជោគជ័យទេ[1493]។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីសូមបញ្ជាក់ឡើងវិញអំពីជំហររបស់ខ្លួនក្នុងការលើកឡើងថា គ្មានការបង្ហាញឱ្យឃើញពីការប្រព្រឹត្តិខុសគ្នារវាងអ្នកជាប់ឃុំជនជាតិវៀតណាម និងអ្នកផ្សេងទៀតនោះទេ[1494]។ មានការពន្យល់ក្នុងអំឡុងពេលសវនាការថា អ្នកទោសជនជាតិបរទេស ក្នុងនោះមានទាំងជនជាតិអឺរ៉ុប និងអ្នកនេសាទថៃ ត្រូវបានកត់ត្រាថាជា "គិញ"[1495]។ ម្យ៉ាងវិញទៀត ឌុច បាននិយាយក្នុងសវនាការថា៖ "ភារកិច្ចរបស់ ស-២១ អ៊ីចឹង។ ប្រតិចារកម្ម ប្រឆាំងនឹងចារកម្ម។ ដូច្នេះ យួនក៏ដោយ បារាំងក៏ដោយ

[1491] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០៦។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១២០២-១២១១ និង ១២១៤-១២១៩។

[1492] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០៨ កំណត់សម្គាល់ជើងទំព័រលេខ៨៨១១ យោងទៅ កថាខណ្ឌ ២៤៦៩។

[1493] ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/437.1** ទំព័រ ៣១-៣៤ ចន្លោះម៉ោង ១១.០៨.៣៤ និង ១១.២១.៥៧។

[1494] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១២០៥។

[1495] ឡាច មាន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ឯកសារ **E1/421.1** ទំព័រ ៧៧-៧៨ ចន្លោះម៉ោង ១៥.៥៤.៥៤ និង ១៥.៥៦.៥២។ ឌុច៖ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/439.1** ទំព័រ ២០-២១ ចន្លោះម៉ោង ១០.៣៨.៣១ និង ១០.៤០.០០។

អាមេរិកក៏ដោយ”[1496]។ ដូច្នេះ ជនជាតិវៀតណាមត្រូវបានចាត់ទុកថាជាអ្នកប្រឆាំងនឹងបដិវត្តន៍ ដូចគ្នាជាមួយនឹងភ្នាក់ងារសេអ៊ីអា និងភ្នាក់ងារកាហ្សេបេដែរ។

៨៣៣. យោងតាមភស្តុតាងទាំងអស់នេះ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋានថា ជនជាតិវៀតណាមត្រូវបានកំណត់ជាគោលដៅ ដោយសារតែពូជសាសន៍របស់ពួកគេនោះទេ។ នេះក៏ជាការវិនិច្ឆ័យដែលអង្គជំនុំជម្រះបានប្រកាន់យកនៅក្នុងរឿងក្តី ឌុច[1497]។ ឌុច ត្រូវបានផ្តន្ទាទោសដោយសាលាដំបូងចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ព្រោះអ្នកទោសនៅ ស-២១ ត្រូវបានកំណត់ជាគោលដៅប្រឆាំងនឹងរបប[1498]។ ក្នុងការវិភាគរបស់ខ្លួន អង្គជំនុំជម្រះបានក្តោបយកជនជាតិវៀតណាមទាំងអស់ ដោយបានសន្និដ្ឋានថា ពួកគេបានទទួលរងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ អង្គជំនុំជម្រះយល់ឃើញថា “គោលនយោបាយ ប.ក.ក ទាក់ទងនឹងជនជាតិវៀតណាម និងជនជាតិភាគតិច ឬក្រុមសាសនាផ្សេងៗទៀត ចាត់ទុកបុគ្គលទាំងនេះថាជា “គិញ” ដែលប្រឆាំងនឹងបក្ស”[1499]។ បើទោះបីជាសេចក្តីសន្និដ្ឋានទាំងនេះអាចរងការតវ៉ាបាន ទាក់ទងនឹងក្រុមភាគតិចសាសនា និងវប្បធម៌ក៏ដោយ ក៏វាត្រូវទៅតាមតថភាពជាក់ស្តែង ទាក់ទងនឹងជនជាតិវៀតណាម នៅ ស-២១។

៨៣៤. តុលាការកំពូលមិនជំទាស់នឹងអង្គជំនុំជម្រះត្រង់ចំណុចនេះទេ តែបានត្រឡប់មករកសេចក្តីសន្និដ្ឋានថាមានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងនឹងអ្នកជាប់ឃុំដែលចំនួនមិនត្រូវបានកំណត់ ហើយត្រូវបានចាត់ទុកជាគោលដៅដោយងងឹតងងុល[1500]។ តុលាការកំពូលយល់ឃើញថា៖

> “ខណៈពេលដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាតដោយមិនរើសមុខ ដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយទេ។ សកម្មភាពបែបនេះមិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែ

---

[1496] ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/441.1** ទំព័រ ៦៣ ម៉ោងប្រហែល ១៥.០៦.៣៦។

[1497] សាលក្រម *ឌុច* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៨៦-៣៨៧។

[1498] សាលក្រម *ឌុច* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៨១-៣៨៦។

[1499] សាលក្រម *ឌុច* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៨៦។

[1500] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៨៤។

បង្កើតឱ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ”[1501]។

៨៣៥. អង្គជំនុំជម្រះពុំបានពិចារណាលើការវិនិច្ឆ័យមួយនេះ ដោយពុំបានធ្វើយុត្តិកម្មថាហេតុអ្វីបានជានៅក្នុងរឿងក្តីនេះ ការបកស្រាយភ័ស្តុតាងមានភាពខុសគ្នា។ យោងតាមភ័ស្តុតាងទាក់ទងនឹងឋានៈ និងមូលហេតុនៃការចាប់ខ្លួនអ្នកជាប់ឃុំជនជាតិវៀតណាមនៅ ស-២១ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថាជនជាតិវៀតណាមត្រូវបានកំណត់ជាគោលដៅដោយសារពូជសាសន៍របស់ពួកគេ ត្រូវទុកជាមោឃៈ។ ដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ មិនត្រូវបានបង្ហាញឱ្យឃើញនោះទេ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ[1502]។

## ផ្នែកទី ២. ក្រាំងតាចាន់

៨៣៦. សូមរំឭកថា អង្គជំនុំជម្រះត្រូវបានស្នើសុំឱ្យពិនិត្យដោយមិនត្រឹមត្រូវលើអង្គហេតុនៃ “ការរើសអើង” លើប្រជាជនថ្មី អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង “ក្រុម” ខ្មាំងពិតប្រាកដ និងខ្មាំងតាមសន្មត នៅក្រាំងតាចាន់។ ដូច្នេះ សេចក្តីសន្និដ្ឋានពាក់ព័ន្ធនានាត្រូវទុកជាមោឃៈ[1503]។

៨៣៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា “អំពើជាក់លាក់នៃការបាត់ខ្លួនដោយបង្ខំ អាចត្រូវបានប្រព្រឹត្តលើសពីម្តងលើមនុស្សតែម្នាក់”[1504]។ អំពើជាក់លាក់នៃការបាត់ខ្លួនដោយបង្ខំគឺជាការប្រព្រឹត្តិបែបឧក្រិដ្ឋបន្តជាប់រហូត។ បុគ្គលតែម្នាក់បានបាត់ខ្លួនក្នុងរយៈពេលណាមួយ ដែលក្នុងអំឡុងពេលនោះ មានការបដិសេធផ្តល់ព័ត៌មានពីជោគវាសនារបស់អ្នកបាត់ខ្លួន។ ទោះបីថាការបាត់ខ្លួនដោយបង្ខំពុំមែនជាឧក្រិដ្ឋកម្មនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងសរទរដូវនាឆ្នាំ១៩៧៥ ក៏ដោយ

[1501] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៨៣។

[1502] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦១០ និង ៤៣០៦។

[1503] សូមមើលខាងលើ កថាខណ្ឌ ៤៩៥-៥១០។

[1504] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៥៤។

ក៏ការសង្កេតជាទូទៅរបស់ក្រុមការងារទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ឬមិនស្ម័គ្រចិត្ត ក្នុងឋានៈជាឧក្រិដ្ឋកម្មបន្ត គឺបានផ្តល់ការបំភ្លឺច្បាស់លាស់ណាស់ទាក់ទងនឹងប្រភេទនៃការប្រព្រឹត្តិនេះ។ អ្នកជំនាញបានធ្វើការសង្កេតដូច្នេះថា៖

> "ការបាត់ខ្លួនដោយបង្ខំគឺជាគំរូដើមផ្ទាល់នៃអំពើបន្តមិនដាច់។ **អំពើនេះ**ចាប់ផ្តើមនៅពេលចាប់ជំរិត និងបន្តរហូត ដរាបណា**ឧក្រិដ្ឋកម្ម**មិនទាន់បញ្ចប់ [...]"[1505]។
> "ឧក្រិដ្ឋកម្មនេះមិនអាចឱ្យមានការបំបែកចេញពីគ្នាបានទេ ហើយការផ្តន្ទាទោស ត្រូវតែគ្របដណ្តប់លើអំពើទាំងអស់ដែលនាំឱ្យមានការបាត់ខ្លួនដោយបង្ខំ"[1506]។

៨៣៨. ការចែកចេញជាវគ្គដោយអង្គជំនុំជម្រះ ដែលក្នុងនោះ អង្គជំនុំជម្រះបានជ្រើសរើសយកឧក្រិដ្ឋកម្មចំនួនពីរនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលមានទម្រង់ជាអង្គហេតុកំណត់ថាជាការបាត់ខ្លួនដោយបង្ខំនៅក្រាំងតាចាន់ សម្រាប់បុគ្គលដដែលៗ ដូចគ្នានឹងអង្គហេតុដែលត្រូវបានកំណត់រួចហើយថាជាការបាត់ខ្លួនដោយបង្ខំទាក់ទងនឹងសហករណ៍ត្រាំកក់ គឺគ្មានសុពលភាព។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថាគេគួរពិចារណាលើអង្គហេតុកើតឡើងនៅក្រាំងតាចាន់ ពីបទចោទប្រកាន់នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ជាលក្ខណៈដាច់តែឯងខណៈដែលមនុស្សទាំងអស់នេះមួយចំនួន បានបាត់ខ្លួននៅត្រាំកក់ ហើយអង្គជំនុំជម្រះធ្លាប់បានសម្រេចរួចមកហើយថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញសម្រាប់អង្គហេតុនៅត្រាំកក់[1507]។

---

[1505] របាយការណ៍ក្រុមការងារទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ឬមិនស្ម័គ្រចិត្ត A/HRC/16/48 ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ កថាខណ្ឌ ៣៩-១ (យើងខ្ញុំជាអ្នកសរសេរជាអក្សរដិត)។

[1506] របាយការណ៍ក្រុមការងារទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ឬមិនស្ម័គ្រចិត្ត A/HRC/16/48 ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ កថាខណ្ឌ ៣៩-៥។

[1507] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៥៣។

៨៣៩. តាមលក្ខណៈសមហេតុសមផល ការដកហូតសេរីភាពដែលបានចាប់ផ្តើមដោយការចាប់ខ្លួននៅក្នុងសហករណ៍ត្រាំកក់ បានបន្តធ្វើពេញមួយដំណាក់កាលនៃការឃុំខ្លួននៅក្រាំងតាចាន់[1508]។ បើទោះជាការប្រព្រឹត្តិមានការពាក់ព័ន្ធនឹងចារីច្រើនរូបក៏ដោយ ក៏អង្គជំនុំជម្រះមានកំហុសដោយបានជ្រើសរើសឧក្រិដ្ឋកម្មចំនួនពីរនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ដោយមួយនៅក្នុងសហករណ៍ត្រាំកក់ និងមួយទៀតនៅក្រាំងតាចាន់ ទាក់ទងនឹងការបាត់ខ្លួនបុគ្គលដដែលៗ[1509]។ សេចក្តីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ។

៨៤០. ហេតុដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ឃើញថា ធាតុផ្សំសត្យានុម័តិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ត្រូវបានបំពេញ[1510]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ក៏ដូចជាសេចក្តីសន្និដ្ឋាននានាដែលកើតចេញពីនោះ ទាក់ទងនឹងការទទួលខុសត្រូវរបស់ ខៀវ សំផន ត្រូវទុកជាមោឃៈ[1511]។

## ផ្នែកទី ៣. អូរកន្សែង

៨៤១. សូមរំឭកថា អង្គជំនុំជម្រះមិនត្រូវបានស្នើសុំឱ្យពិនិត្យដោយត្រឹមត្រូវលើអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយចំពោះ “ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត” ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ចំពោះជនជាតិវៀតណាម និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស នៅទីតាំងអូរកន្សែងនោះទេ ហើយដូច្នេះសេចក្តីសន្និដ្ឋានទាំងអស់នេះត្រូវទុកជាមោឃៈ[1512]។

---

[1508] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៥៥។

[1509] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៥៨។

[1510] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៥៨។

[1511] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៦-៣៩៨៧, ៤៣០៦។

[1512] សូមមើលខាងលើ កថាខណ្ឌ ៥១១-៥១៣, ៥១៦-៥១៩។

## ១. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលជនជាតិវៀតណាមប្រាំមួយនាក់

៨៤២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតលើជនជាតិវៀតណាមប្រាំមួយនាក់ ត្រូវបានបង្ហាញ[1513]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះផ្អែកតែទៅលើសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់ ឆោម សែ[1514]។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ គាត់បានបញ្ជាក់ថា៖

> "ប្រហែលជានៅមុនឆ្នាំ១៩៧៩បន្តិច មុនពេលវៀតណាមវាយចូលខ្លាំងនៅឆ្នាំ១៩៧៩ ឃើញមានចាប់អ្នកទោសជាជនជាតិវៀតណាម (ស៊ីវិល) មួយក្រុមមានគ្នាប្រាំមួយនាក់ ពីសមរភូមិអូរយ៉ាដាវ តាមព្រំដែន ដោយសារអ្នកនោះបានចូលឈ្លបយកការណ៍បើកផ្លូវនៅផ្លូវលេខ ១៩ ដែលវៀតណាមខាងជើង និងខាងត្បូងប៉ុនប៉ងវាយយកផ្លូវនេះ។ ក្រោយពីបានសួរចម្លើយចប់សព្វគ្រប់ហើយ ថ្នាក់លើសម្រេចឱ្យបញ្ចប់អ្នកទាំងនោះទៅ ដោយមានបញ្ជាពីមេកងពល៨០១ ជាអ្នកសម្រេចឱ្យបញ្ចប់ ឯមន្ទីរខ្ញុំមានសិទ្ធិត្រឹមតែសួរយកចម្លើយ និងរៀបចំឯកសារ និងរបាយការណ៍ទៅថ្នាក់លើដើម្បីសម្រេចប៉ុណ្ណោះ"[1515]។

៨៤៣. នៅពេលដំបូង អង្គជំនុំជម្រះបានឯកភាពថា ខ្លួនមិនអាចសំអាងការប្រកាសអំពីពិរុទ្ធភាពមួយតែទៅលើកំណត់ហេតុស្តាប់ចម្លើយមួយមុខបានទេ[1516]។ លើសពីនេះទៀត កំណត់ហេតុស្តាប់ចម្លើយនេះបានបង្ហាញថា ឆោម សែ មិនបានចូលរួមក្នុងការសម្លាប់ទាំងនេះទេ ហើយទំនងជាគាត់មិនបានឃើញការសម្លាប់នោះផ្ទាល់ភ្នែកទៀតផង។ គាត់ពុំបានផ្តល់ការពន្យល់ណាមួយ ទាក់ទងនឹងកាលៈទេសៈនៃការសម្លាប់ជនជាតិវៀតណាមទាំងនោះទេ។ ដោយសារភាពទន់ខ្សោយនៃតម្លៃជាភ័ស្តុតាង និងការខ្វះភាព

---

[1513] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៥៩។

[1514] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩២៦ យោងទៅ កំណត់ហេតុនៃការស្តាប់ចម្លើយ ឆោម សែ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/405** ERN 00401303។

[1515] កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/405** ERN 00401303។

[1516] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៩។

ច្បាស់លាស់ ចម្លើយជាលាយលក្ខណ៍អក្សរនេះមិនអាចប្រើដើម្បីសន្និដ្ឋានថាមានការធ្វើមនុស្សឃាត ចំពោះជនជាតិវៀតណាមទាំងប្រាំមួយនាក់នេះបានទេ។

៨៤៤. ផ្ទុយទៅវិញ អង្គជំនុំជម្រះយល់ឃើញថាចម្លើយនេះត្រូវបានបញ្ជាក់អះអាងថាត្រឹមត្រូវ ក្នុងពេលសាក្សីផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១។ ក៏ប៉ុន្តែ ក្នុងសវនាការ ឆោម សែ បានបង្ហាញពីការសម្លាប់ក្រុមមនុស្សប្រាំមួយនាក់ ដោយគ្មានការបញ្ជាក់បន្ថែមលើសពីនេះ៖ "ដោយឡែកតែរឿងពួកក្រុម៦នាក់ អាហ្នឹងបានបទបញ្ជាទៅគឺឱ្យសម្លាប់ដែរ ស៊ូ សារឿន ដែរ"[1517]។

៨៤៥. អង្គជំនុំជម្រះយល់ថាខ្លួនអាចផ្អែកលើសក្ខីកម្មនេះបាន ដោយហេតុថាអង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគីចោទសំណួរដែលមានប្រយោជន៍ សម្រាប់វិសាលភាពនៃសំណុំរឿង ០០២/០២[1518]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះគ្រាន់តែបានអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាចោទសំណួរទាំងនេះ ក្រោមលេសថាវាពាក់ព័ន្ធនឹង "រចនាសម្ព័ន្ធយោធា" ឬ "ប្រព័ន្ធទំនាក់ទំនង"[1519]។ វាច្បាស់ណាស់ថា ភាគីមិនបានបង្អែបង្អង់ឡើយក្នុងការចោទសំណួរសុំការបញ្ជាក់មួយចំនួនទាក់ទងនឹងអង្គហេតុ ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។ ការសម្លាប់នៅអូរកន្សែង គឺច្បាស់ណាស់មិនស្ថិតនៅក្នុងវិសាលភាពនេះឡើយ។

៨៤៦. ដូច្នេះ ដោយសារតែពុំត្រូវបានសួរដេញដោលតទល់ប្រកបដោយសារៈប្រយោជន៍លើចំណុចជាក់លាក់មួយនេះ សក្ខីកម្មរបស់ ឆោម សែ ទាក់ទងនឹងការសម្លាប់នៅអូរកន្សែង គឺពុំមានតម្លៃជាភ័ស្តុតាងអ្វីច្រើនជាងសក្ខីកម្មជាលាយលក្ខណ៍អក្សរទេ ដូចគ្នាទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ដែរ។ ពុំមានសំណួរសុំការបញ្ជាក់ណាមួយត្រូវបានចោទសួរ ដែលអាចឱ្យគេកំណត់បានថាក្រុមទាំងប្រាំមួយនាក់ដែលគាត់បង្ហាញនេះជានរណា។ តម្លៃជាភ័ស្តុតាងមានកម្រិតនៃចម្លើយនេះ បូកផ្សំទៅនឹងការខ្វះភាពច្បាស់លាស់ទាក់ទងនឹងការសម្លាប់ទាំងនេះ គួរតែរារាំងមិនឱ្យសន្និដ្ឋានថាមានការធ្វើមនុស្សឃាតជនជាតិវៀតណាមប្រាំមួយនាក់ ដោយផ្អែកលើមូលដ្ឋានតែមួយគត់នេះបានទេ។

---

[1517] ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/159.1** មុនម៉ោង ១៥.៥៥.៥៨, ប្រតិចារឹក ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/177.1** ម៉ោងប្រហែល ១០.០០.១១។

[1518] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៦០។

[1519] ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/159.1** ម៉ោង ១៥.២១.៤៣។

៨៤៧. ដូច្នេះ សេចក្តីសន្និដ្ឋានអំពីការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាមប្រាំមួយនាក់ គួរត្រូវដកចេញ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងនេះ[1520]។

## ២. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៨៤៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថាក្រុម "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" គឺមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាន (២.១) ហើយថាការប្រព្រឹត្តិចំពោះក្រុមនេះបង្កើតបានជាការរើសអើងជាក់ស្តែង (២.២)។

### ២.១. កំហុសពាក់ព័ន្ធនឹងក្រុម "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" ដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់

៨៤៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថាប្រភេទ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" គឺមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាន[1521]។ អង្គជំនុំជម្រះបានវិនិច្ឆ័យថា ប.ក.កចាត់ទុក "ខ្មាំងប្រឆាំងបដិវត្តន៍ [...] អ្នកបង្កគ្រោះថ្នាក់ និងជនក្បត់បដិវត្តន៍ ពួកសក្តិភូមិ និងអ្នកចូលរួមនៅក្នុងការអនុវត្តបែបសក្តិភូមិ ជនជាតិវៀតណាម គិញបរទេស និងអ្នកឃុបឃិត" ថាស្ថិតក្នុងប្រភេទនេះ[1522]។ ក៏ប៉ុន្តែ ភាពខុសគ្នានៃបញ្ជីនេះ គឺមិនត្រូវគ្នាទៅនឹងការកំណត់យ៉ាងតឹងរ៉ឹងនូវអ្វីដែលគេហៅថាជាក្រុមដែលមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាននោះទេ[1523]។

---

[1520] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៥៩, ២៩៦៧, ២៩៦៨ និង ៤៣០៦។

[1521] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៣។

[1522] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៣។

[1523] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៤។

៨៥០. អង្គជំនុំជម្រះបានគាំទ្រថា "ប.ក.ក បានកំណត់ប្រភេទខ្មាំងសាជាថ្មីម្តងហើយម្តងទៀត"[1524]។ អង្គជំនុំជម្រះបានកំណត់ខ្មាំងជាច្រើនប្រភេទ ក្នុងនោះមានខ្មាំងខាងក្នុង គឺស្ថិតក្នុង "ជួរបក្ស ឬកងទ័ព ឬជាប្រជាជនស៊ីវិល" និងខ្មាំងខាងក្រៅដែល "មកពីក្រៅអង្គការ ឬមកពីក្រៅប្រទេស"[1525]។ អង្គជំនុំជម្រះទទួលស្គាល់ថា "ដែនកំណត់នៃប្រភេទខ្មាំងទាំងពីរនៅតែមានភាពស្រពេចស្រពិល"[1526]។

៨៥១. អង្គជំនុំជម្រះយល់ឃើញថា បុគ្គលដែលត្រូវចាត់ទុកថាបានផ្តល់ការគាំទ្រដល់សន្ធិសម្ព័ន្ធ សេរីនិយម មូលធននិយម ឬបុគ្គលដែលការប្រព្រឹត្តិត្រូវបានចាត់ទុកថាជាការប្រឆាំងបដិវត្តន៍ គឺស្ថិតក្នុងប្រភេទ "ខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មត" នេះ ដូចគ្នា[1527]។ បន្ទាប់មក អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណប្រភេទខ្មាំងជាក់លាក់ ក្នុងនោះមានអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ [1528] ប្រជាជនថ្មី[1529] អ្នកត្រឡប់មកពីបរទេស[1530] ព្រះសង្ឃ[1531] ភ្នាក់ងារសេអ៊ីអា កាហ្សេបេ និង "យួន"[1532]។

៨៥២. ដូច្នេះ វាច្បាស់ណាស់ថាប្រភេទ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" នេះ គឺពាក់ព័ន្ធនឹងប្រភេទរាយរងជាច្រើនដែលប្រមូលផ្តុំមនុស្សផ្សេងៗគ្នា និងត្រូវបានចាត់ទុកខុសៗពីគ្នាដោយប.ក.ក។ ដូច្នេះ អង្គជំនុំជម្រះគួរអនុវត្តតាមជំហររបស់តុលាការកំពូលដែលថា៖

---

[1524] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៣៩។

[1525] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤២។

[1526] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៤។

[1527] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៥-៣៨៤៦។

[1528] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៧។

[1529] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៨។

[1530] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៩។

[1531] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥០។

[1532] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥១-៣៨៥៣។

"ខណៈពេលដែលបដិវត្តន៍កំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាតដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយទេ។ សកម្មភាពបែបនេះ មិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែបង្កើតឱ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ"[1533]។

៨៥៣. ដោយហេតុតែពុំអាចកំណត់និយមន័យក្រុមដែលមានលក្ខណៈគ្រប់គ្រាន់អាចកំណត់អត្តសញ្ញាណបាន អង្គជំនុំជម្រះមិនអាចចាត់ទុកថាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញនៅអូរកន្សែងបានទេ។ សេចក្តីសន្និដ្ឋាននេះត្រូវដកចេញ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ។

## ២.២. កំហុសពាក់ព័ន្ធនឹងការរើសអើងជាក់ស្តែង

៨៥៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថា ជនជាតិចារ៉ាយ ១០០ នាក់, ផន ចុល, មឿង ចាន់ឌី និងអ្នកជាប់ឃុំដែលជាកងទ័ព ត្រូវបាន "ធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងអ្នកផ្សេងទៀត" ដោយសារពួកគេត្រូវបានចាត់ទុកថាជាខ្មាំង[1534]។ ប៉ុន្តែ អង្គជំនុំជម្រះបានពន្យល់ថា "របបឃុំឃាំងប្រែប្រួលទៅតាមអ្នកប្រព្រឹត្តកំហុសធ្ងន់ និងអ្នកប្រព្រឹត្តកំហុសស្រាល និងជាស្ត្រី និងកុមារ"[1535]។ អ្នកប្រព្រឹត្តកំហុសធ្ងន់ត្រូវឃុំខ្លួននៅកន្លែងមួយដែលពួកគេត្រូវចង និងមិនអាចចេញទៅខាងក្រៅបាន។ អ្នកជាប់ឃុំដែលបានប្រព្រឹត្តបទល្មើសស្រាល ពុំត្រូវដាក់ច្រវាក់ទេ និងអាចដើរចុះឡើងដោយសេរីនៅពេលថ្ងៃ[1536]។ ចំណែកឯស្ត្រី និងកុមារវិញ អង្គជំនុំជម្រះបានទទួលស្គាល់ថា "ត្រូវបាន

---

[1533] សាលដីកា *ឌុច* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ២៨៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1534] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៦-២៩៩០។

[1535] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩០៩។

[1536] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩១០។

គេអនុគ្រោះច្រើនជាង"[1537] ហើយអង្គជំនុំជម្រះខ្លួនឯងបានកត់សម្គាល់ថា ភាពខុសគ្នាក្នុងការប្រព្រឹត្តិគឺផ្អែកទៅលើប្រភេទនៃកំហុស ជាជាងហេតុផលនយោបាយ។

៨៥៥. លើសពីនេះទៀត ពាក់ព័ន្ធនឹងជនជាតិថារ៉ាយ អង្គជំនុំជម្រះបានយល់ឃើញថា "លក្ខណៈណែនណាន់តាន់តាប់ [នៃកន្លែងឃុំខ្លួន]" អាចឱ្យគេសន្និដ្ឋានបានថា ជនជាតិថារ៉ាយ "ត្រូវបានគេបន្តសន្មតថាជាខ្មាំងនៅក្នុងអំឡុងពេលឃុំខ្លួន"[1538]។ ភ័ស្តុតាងទាំងនេះមិនបង្ហាញឱ្យឃើញថាពួកគេត្រូវបានដាក់ឱ្យស្ថិតក្នុងរបបខុសគ្នា បើធៀបជាមួយនឹងអ្នកជាប់ឃុំផ្សេងៗទៀតនៅអូរកន្សែងនោះទេ។ លក្ខណៈណែនណាន់តាន់តាប់ គឺអាចបកស្រាយបានតាមការដែលអគារនានានៅអូរកន្សែង មិនសមស្របសម្រាប់ទទួលអ្នកទោសក្នុងចំនួនច្រើនបែបនេះក្នុងពេលតែមួយ[1539]។ ភ័ស្តុតាងពុំបានបង្ហាញថាជនជាតិថារ៉ាយបានទទួលរងការប្រព្រឹត្តិជាពិសេសនោះទេ[1540]។ គឺពុំមែនមានតែពួកគេទេដែលជាអ្នកទោសត្រូវគេសម្លាប់[1541]។ ដូច្នេះ អង្គជំនុំជម្រះមិនបានបង្ហាញឱ្យឃើញថាពួកគេបានទទួលរងការប្រព្រឹត្តិពិបាកជាងអ្នកផ្សេងទៀតបែបណានោះទេ។

៨៥៦. ដូចគ្នាដែរ ពាក់ព័ន្ធនឹងករណីរបស់ ផន ថុល។ អង្គជំនុំជម្រះយល់ឃើញថា ផន ថុល ត្រូវបានអប់រំ និងរងគ្រោះដោយការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស[1542]។ ក៏ប៉ុន្តែ បើយោងតាមអង្គជំនុំជម្រះ ការអប់រំគឺពាក់ព័ន្ធនឹងអ្នកទោសទាំងអស់ដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តកំហុសមិនសូវធ្ងន់ធ្ងរ និងត្រូវបានអនុវត្តនៅតាមមន្ទីរសន្តិសុខ ការដ្ឋានការងារ និងនៅទូទាំងប្រទេស[1543]។ ទោះបីជាសាក្សីបាន

[1537] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩១០។

[1538] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៦។

[1539] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៤៣។

[1540] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៣៥-២៩៥៨។

[1541] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៣៣-២៩៣៤។

[1542] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៧។

[1543] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧២ "ប.ក.ក បានរក្សាគោលនយោបាយអប់រំខ្មាំងដែលមានទោសកំហុស ឬស្ថានភាពមិនធ្ងន់ធ្ងរ អនុលោមតាមក្របខ័ណ្ឌបដិវត្តន៍។ គោលនយោបាយនេះ ត្រូវបានអនុវត្តដោយផ្ទាល់នៅតាមមន្ទីរសន្តិសុខ (និងការដ្ឋានការងារ) នៅទូទាំងប្រទេស និងតម្រូវឱ្យកសាងសមាសភាពមិនល្អ តាមរយៈការបំពាក់បំប៉ននយោបាយ ការទិតៀន និងស្វ័យទិតៀន និងការចាត់តាំងឱ្យធ្វើការងារ ដើម្បីរំសាយនិន្នាការប្រឆាំងបដិវត្តន៍។ គោលនយោបាយនេះ ត្រូវបានអនុវត្តដោយលេខាភូមិភាគ

ពន្យល់ថាបានរស់នៅក្នុងភាពភ័យខ្លាចត្រូវគេសម្លាប់ក៏ដោយ[1544] ក៏ភ័ស្តុតាងបានបង្ហាញថា គាត់ទទួលបានការប្រព្រឹត្តិមានភាពអនុគ្រោះជាងអ្នកផ្សេងទៀត។ ខ្លួនគាត់ផ្ទាល់បាននិយាយថាបានឃើញអ្នកទោសផ្សេងៗទៀតត្រូវបានគេវាយ និងឆក់ខ្សែភ្លើង ក្នុងពេលសួរចម្លើយ[1545]។ លើសពីនេះទៀត សាក្សីមិនមែនជាមនុស្សតែម្នាក់គត់មកពីចម្ការកៅស៊ូដែលត្រូវចាប់ខ្លួននោះទេ[1546]។ យោងតាមភ័ស្តុតាងទាំងអស់នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះថា "ផន ថុល ត្រូវបាន [...] ដាក់ឱ្យរស់នៅក្នុងល័ក្ខខ័ណ្ឌពិបាកខ្លាំងជាងអ្នកផ្សេងទៀត" គឺមិនត្រឹមត្រូវទេ[1547]។

៨៥៧. អង្គជំនុំជម្រះក៏មិនបានពន្យល់ថាតើ មឿង ចាន់ឌី "ត្រូវបាន [...] ដាក់ឱ្យរស់នៅក្នុងល័ក្ខខ័ណ្ឌពិបាកខ្លាំងជាងអ្នកផ្សេងទៀត" បែបណាទៅ[1548]។ ដូចគ្នានឹង ផន ថុល ដែរ គាត់ត្រូវបានចាប់ខ្លួនជាមួយនឹងកម្មករចម្ការកៅស៊ូផ្សេងទៀត និងបានទទួលរងការប្រព្រឹត្តិដូចគ្នានឹងអ្នកផ្សេងទៀត[1549]។ មេធាវីការពារក្តីពុំនិយាយឡើងវិញពីការរងទុក្ខវេទនា និងការភ័យខ្លាចរបស់ ផន ថុល និង មឿង ចាន់ឌី ក្នុងពេលគាត់ទាំងពីរជាប់ឃុំឃាំងនោះទេ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ការប្រព្រឹត្តិលើពួកគាត់ គឺពុំបានបង្ហាញឱ្យឃើញពីការរើសអើងជាក់ស្តែង ដោយហេតុផលនយោបាយទេ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថាពួកគាត់បានទទួលរងគ្រោះដោយការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ត្រូវដកចេញ។

៨៥៨. ជាចុងក្រោយ អង្គជំនុំជម្រះក៏មិនបានពន្យល់ថាតើអ្នកទោសជាទាហានដែលត្រូវចាប់ខ្លួននៅអូរកន្សែងបានទទួលរងការប្រព្រឹត្តិលំបាកជាងអ្នកជាប់ឃុំផ្សេងទៀតបែបណាទេ។ ជនជាប់ឃុំជាជនស៊ីវិល ត្រូវ

---

លេខាតំបន់ លេខាស្រុក លេខានៅថ្នាក់មូលដ្ឋាន កម្មាភិបាល ប.ក.ក និងកងទ័ពបដិវត្តន៍កម្ពុជា ក្នុងខ្សែចង្វាក់រដ្ឋបាលទាំងមូលរបស់បក្ស"។

[1544] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩២២។

[1545] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩០២។

[1546] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៨៧ និង ២៨៩៥។

[1547] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៧។

[1548] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៨។

[1549] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៩៥។

បានចាប់ឃុំខ្លួន និងដាក់ឱ្យស្ថិតក្នុងល័ក្ខខ័ណ្ឌនៃការរស់នៅលំបាកដូចគ្នា នៅអូរកន្សែង[1550]។ ភ័ស្តុតាងទាំងអស់នេះ មិនបានគាំទ្រថាពួកគេបានរងគ្រោះដោយការរើសអើសជាក់ស្តែង ដោយមូលហេតុនយោបាយទេ។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ មិនអាចត្រូវបានបង្ហាញបានទេ។ ដូច្នេះ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះ[1551]។

## ៣. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

៨៥៩. គួររំឭកថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងការចាប់ខ្លួន និងការធ្វើមនុស្សឃាតលើក្រុមជនជាតិវៀតណាមប្រាំមួយនាក់ គឺផ្អែកតែទៅលើកំណត់ហេតុស្តាប់ចម្លើយមិនច្បាស់លាស់របស់ ឆោម សែ មួយគត់[1552]។ ដោយហេតុតែពុំមានភ័ស្តុតាងផ្ទាល់ និងច្បាស់លាស់ អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានបែបនេះបានទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះក៏មិនអាចសំអាងតែលើភ័ស្តុតាងទាំងនេះ ដើម្បីសន្និដ្ឋានថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ ត្រូវបានប្រព្រឹត្តឡើង ពាក់ព័ន្ធនឹងជនជាតិវៀតណាមទាំងប្រាំមួយនាក់នេះបានទេ។ ដូច្នេះ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋមួយនេះ[1553]។

៨៦០. លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថាជនជាតិវៀតណាមទាំងនេះត្រូវបានធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍[1554]។ អង្គជំនុំជម្រះបានពិចារណាលើ "ភ័ស្តុតាងអំពីការចាប់ខ្លួន និងការសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ចំពោះ "គិញ" ជាជនជាតិវៀតណាម និងទាហានដែលត្រូវបានយល់ឃើញថាជាពួកធីវគី នៅចុងឆ្នាំ១៩៧៨"[1555]។ ដូច្នេះ ការចាប់ខ្លួនជនជាតិ

---

[1550] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩០៩-២៩២៥។

[1551] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[1552] សូមមើលខាងលើ កថាខណ្ឌ ៨៤២-៨៤៧។

[1553] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៩ និង ៤៣០៦។

[1554] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៦។

[1555] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៦។

វៀតណាម ត្រូវតែផ្អែកលើហេតុផលដូចគ្នានឹងចារ៉ាយដែរ ដែលបើតាមអង្គជំនុំជម្រះ គឺចារ៉ាយត្រូវបានចាប់ខ្លួនដោយមូលហេតុនយោបាយ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះពុំបានពន្យល់ថាហេតុអ្វីបរិបទប្រហាក់ប្រហែលគ្នានៃជម្លោះប្រដាប់អាវុធរវាងម្ខាងទាហានរបបធីវគី មុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[1556] និងម្ខាងទៀត ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម[1557] ត្រូវបានយល់ឃើញផ្សេងគ្នា។ គ្មានអ្វីអាចពន្យល់បានពីការបែងចែកភាពខុសគ្នានេះបានទេ ព្រោះថាអង្គជំនុំជម្រះបានបញ្ចូលផងដែរនូវក្រុម"ជនជាតិវៀតណាមទាំងនេះ" ទៅក្នុងប្រភេទមិនច្បាស់លាស់នៃ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" ដែលត្រូវបានកំណត់គោលដៅដោយហេតុផលនយោបាយ[1558]។

៨៦១. បើទោះជាកំណត់ហេតុស្តាប់ចម្លើយរបស់ ឆោម សែ មានតម្លៃជាភ័ស្តុតាងតិចតួចប៉ុនណាក៏ដោយ ក៏វាជាភ័ស្តុតាងតែមួយគត់ដែលបង្ហាញពីការចាប់ខ្លួនវៀតណាមទាំងប្រាំមួយនាក់នេះ។ ក៏ប៉ុន្តែ ខ្លឹមសារផ្ទាល់របស់កំណត់ហេតុនេះ ពុំបានគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រនោះទេ។ សាក្សីបានរៀបរាប់ថាវៀតណាមទាំងប្រាំមួយនាក់នេះ ត្រូវបានចាប់ខ្លួន "ប្រហែលជានៅមុនឆ្នាំ១៩៧៩ បន្តិច [...] ពីសមរភូមិអូរយ៉ាដាវ តាមព្រំដែន"[1559]។ ដូច្នេះ គ្មានអ្វីអាចឱ្យគេសន្និដ្ឋានបានថាពួកអ្នកទាំងនោះត្រូវបានចាប់ខ្លួនដោយមូលហេតុពូជសាសន៍បានទេ។ ផ្ទុយទៅវិញ ការចាប់ខ្លួននេះទំនងជាផលវិបាកនៃការដែលពួកគេស្ថិតនៅសមរភូមិ ក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម។ ហេតុដូច្នេះ ទោះជាមានជនជាតិវៀតណាមមួយចំនួនត្រូវបានចាប់ខ្លួននៅអូរកន្សែងក៏ដោយ ក៏គេមិនអាចសន្និដ្ឋានថាមូលហេតុនៃការចាប់ខ្លួន គឺជាប់ពាក់ព័ន្ធនឹងពូជសាសន៍របស់ពួកគេបានទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវដកចេញ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ពាក់ព័ន្ធនឹងជនជាតិវៀតណាមទាំងប្រាំមួយនាក់នៅអូរកន្សែង[1560]។

---

[1556] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៤៩-២៩៥០។

[1557] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៦។

[1558] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៨៣។

[1559] កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/405** ERN 00401303។

[1560] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៩ និង ៤៣០៦។

## ផ្នែកទី ៤. មន្ទីរសន្តិសុខភ្នំក្រោល

៨៦២. សូមរំឭកថា អង្គជំនុំជម្រះមិនត្រូវបានស្នើសុំដោយត្រឹមត្រូវឱ្យពិនិត្យលើអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយចំពោះ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" ការធ្វើឱ្យក្លាយជាទាសករ នៅទីតាំង ក-១៧ និងមន្ទីរសន្តិសុខភ្នំក្រោល ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែលមានទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស ពាក់ព័ន្ធនឹងអង្គហេតុនៃការធ្វើទារុណកម្មនៅទីតាំងមន្ទីរសន្តិសុខភ្នំក្រោល ក៏ដូចជាអង្គហេតុនានាទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំនៅ ក-១១ និងនៅមន្ទីរសន្តិសុខភ្នំក្រោល[1561]។

### ១. ការធ្វើមនុស្សឃាត

### ១.១. កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាលើ ហ៊ើស

៨៦៣. អង្គជំនុំជម្រះយល់ឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ត្រូវបានបង្ហាញនៅភ្នំក្រោល ពាក់ព័ន្ធនឹងការស្លាប់អ្នកទោសម្នាក់ឈ្មោះ ហ៊ើស[1562]។ អង្គជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋាន ដោយផ្អែកលើសំអាងហេតុដូចខាងក្រោម៖

> "អង្គជំនុំជម្រះជឿជាក់ថា អ៊ួង ដុស និង សុខ អ៊ែល បានឃើញការវាយធ្វើបាប និងការសម្លាប់ឈ្មោះ ហ៊ើស ដែលជាអ្នកជាប់ឃុំជាមួយពួកគាត់ ដោយអ្នកយាមគុកភ្នំក្រោល។ ដោយពិចារណាទៅលើភាពកាចសាហាវនៃការវាយប្រហារមុនពេលជនរងគ្រោះស្លាប់ ដែលជាការវាយដំលើរាងកាយដោយដំបងឈើរហូតដល់សន្លប់ ព្រមទាំងការបង្កព្យសនកម្មលើរាងកាយយ៉ាងព្រៃផ្សៃ ដោយការចាក់ជនរងគ្រោះនឹងកាំបិតចំពុះទុងនោះ អង្គជំនុំជម្រះយល់

[1561] សូមមើលខាងលើ កថាខណ្ឌ ៣៩៧-៤០៣, ៥១៤-៥១៦។

[1562] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៥។

ឃើញថា អ្នកយាមគុកមានចេតនាសម្លាប់ ហើយស។ អង្គជំនុំជម្រះជឿជាក់ថាទាំងធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ត្រូវបានបំពេញ"[1563]។

៨៦៤. សូមរំឭកថា អង្គជំនុំជម្រះបានសម្រេចថាធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាត គឺជាអំពើសកម្ម ឬអំពើអកម្មទាំងឡាយណាដែលអាចចោទប្រកាន់ចំពោះជនជាប់ចោទ ឬចំពោះមនុស្សម្នាក់ ឬច្រើននាក់ដែលជនជាប់ចោទត្រូវឆ្លើយតបតាមផ្លូវព្រហ្មទណ្ឌ ហើយដែលផលវិបាកនៃអំពើនោះ គឺបានបង្កឱ្យជនរងគ្រោះស្លាប់[1564]។ ដើម្បីសន្និដ្ឋានបានអំពីការកំណត់បាននៃឧក្រិដ្ឋកម្មនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងការវាយតម្លៃលើភ័ស្តុតាង (១.១.១) និងបានរំលោភលើគោលការណ៍គ្រឹះនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ (១.១.២)។

### ១.១.១. កំហុសក្នុងការប្រើប្រាស់តែភ័ស្តុតាងជាក់ស្តែងទន់ខ្សោយ

៨៦៥. ដើម្បីកំណត់ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅមន្ទីរសន្តិសុខភ្នំក្រោល អង្គជំនុំជម្រះបានផ្អែកលើកំណត់ហេតុស្តាប់ចម្លើយទាំងពីររបស់ អ៊ួង ដុស និង សុខ អ៊ែល (ស្លាប់) ដែលត្រូវបានធ្វើព្រមគ្នានៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ក្នុងភូមិរង្សី ដូចគ្នា ក្នុងខេត្តមណ្ឌលគិរី។ ក្រោយពីបានផ្តល់សក្ខីកម្មនេះនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតរួចមក បុរសទាំងពីរនាក់នេះបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1565]។ ជាបឋម អង្គជំនុំជម្រះមានកំហុសដោយយល់ឃើញថាឧក្រិដ្ឋកម្មត្រូវបានបង្ហាញ ដោយផ្អែកលើមូលដ្ឋានរឿងរ៉ាវមួយចំនួន ដែលមេធាវីការពារក្តីមិនមានលទ្ធភាពសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ក្នុងចំណោមពួកគាត់ទាំងពីរ។ ទាំង អ៊ួង ដុស និង សុខ អ៊ែល សុទ្ធតែពុំបានផ្តល់សក្ខីកម្មក្នុងសវនាការ។

---

[1563] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៥។

[1564] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២៧, សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៤១២។

[1565] អ៊ួង ដុស ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E3/6260**, សុខ អ៊ែល ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E3/6314**។

៨៦៦. ដោយហេតុថាភាពជឿជាក់បាននៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនាក់នេះ មិនអាចត្រូវបានពិសោធមើលនៅក្នុងសវនាការ បន្ទាប់មក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយពុំបានលើកឡើងពីកាលៈទេសៈដែលចម្លើយរបស់ដើមបណ្តឹងទាំងពីរនេះ បានផ្តល់នូវរឿងរ៉ាវប្រហាក់ប្រហែលគ្នា។ បើមើលតាមភាពដូចគ្នានៃកាលបរិច្ឆេទ និងទីកន្លែងធ្វើកំណត់ហេតុស្តាប់ចម្លើយពីរដំបូង ដោយសហចៅក្រមស៊ើបអង្កេត វាមានតម្រុយសត្យានុម័តិបង្ហាញពីលទ្ធភាពនៃការសមគំនិតគ្នារវាងរឿងរ៉ាវនានា យ៉ាងហោចណាស់ក៏ជាការ "ចម្លងគ្នា"។ អ្នកទាំងពីរនាក់នេះត្រូវបានស្តាប់ចម្លើយជាលើកដំបូងដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងភូមិរង្សី នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨។ យោងតាមអ្នកស៊ើបអង្កេត សុខ អ៊ែល ត្រូវបានស្តាប់ចម្លើយនៅម៉ោង ១០ និង ១០ នាទី ហើយ អ៊ួង ដុស នៅម៉ោង ១០ និង ១៥ នាទី[1566]។ ភ័ស្តុតាងសត្យានុម័តិទាំងនេះ ធ្វើឱ្យគេគិតបានថា ពួកគាត់បានផ្តល់សក្ខីកម្មនៅជិតគ្នា ដែលអាចឱ្យគេតវ៉ាបានលើ *"ភាពស៊ីចង្វាក់គ្នា"* យ៉ាងច្បាស់ក្រឡែតនៅក្នុងការរៀបរាប់របស់ពួកគាត់។ ប៉ុន្តែ គេគួររំឭកថា ក្នុងអំឡុងពេលសវនាការសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបាននិយាយជាច្រើនលើកច្រើនសាថា "ក្នុងករណីពុំមានឱកាសដើម្បីពិនិត្យទៅលើប្រភពនៃភ័ស្តុតាង ឬបុគ្គលដែលជាម្ចាស់ភ័ស្តុតាងទាំងនោះ ទម្ងន់នៃភ័ស្តុតាងបែបនេះត្រូវមានតិចតួច"[1567]។ ដោយពុំបានអនុវត្តវិធានសំខាន់មួយនេះនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ អង្គជំនុំជម្រះបានរងការរិះគន់ពីសំណាក់តុលាការកំពូល ទាក់ទងនឹង៖

> "កំណត់ហេតុស្តាប់ចម្លើយប្រមូលបានក្នុងពេលស៊ើបសួរ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះ។ ភ័ស្តុតាងនេះមានតម្លៃទាប ដែលជាការពិត អង្គជំនុំជម្រះសាលាដំបូងបានត្រឹមតែទទួលស្គាល់ជាទូទៅ ប៉ុន្តែពុំអាចយកប្រើប្រាស់ជាក់ស្តែងបានឡើយ។ ទាក់ទងទៅនឹងភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះសាលាដំបូងពិតជាពុំបានពន្យល់ពីមូលហេតុដែលខ្លួនពិចារណាឃើញថា បើទោះបីជាមានតម្លៃជាភ័ស្តុតាងកម្រិតទាបក៏ដោយ ក៏

---

[1566] អ៊ួង ដុស កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ឯកសារ **E3/7703**, សុខ អ៊ែល កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ឯកសារ **E3/7702**។

[1567] សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៣៤ និងកំណត់សម្គាល់ជើងទំព័រលេខ៩៤, សេចក្តីសម្រេច ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E96/7** កថាខណ្ឌ ២១-២២, ២៤-២៥, ២៧, ២៩, ៣៤, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ឯកសារ **E299** កថាខណ្ឌ ១៩។

ខ្លួននៅតែផ្តល់ការយល់ឃើញដោយផ្អែកលើមូលដ្ឋាននេះហួសពីវិមតិសង្ស័យ ទាក់ទងទៅនឹងហេតុការណ៍មួយៗនៃការសម្លាប់"[1568]។

### ១.១.២. ការរំលោភលើគោលការណ៍ចំពោះមុខ និងគោលការណ៍សមភាពនៃគូភាគី

៨៦៧. ដោយបានសម្រេចថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ត្រូវបានបង្ហាញនៅភ្នំក្រោល ដោយផ្អែកតែទៅលើចម្លើយពីររបស់ដើមបណ្តឹងរដ្ឋប្បវេណី - ដែលប្រមូលក្នុងពេលតែមួយ - ដោយពុំមានលទ្ធភាពក្នុងការតទល់គ្នាជាមួយជនជាប់ចោទ[1569] - អង្គជំនុំជម្រះបានរំលោភលើគោលការណ៍ច្បាប់ភស្តុតាងដែលខ្លួនឯងបានរំឮក[1570]។ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលយល់ឃើញដែរថា៖

> "យោងតាមយុត្តិសាស្ត្រដែលគួរឱ្យជឿជាក់បានរបស់តុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ការដាក់ពិរុទ្ធភាពពុំអាចផ្អែកតែមួយមុខ ឬដោយពុំបានពិចារណាវែងឆ្ងាយទៅលើភស្តុតាងរបស់សាក្សីណាម្នាក់ដែល ភាគីការពារក្តីពុំមានឱកាសសួរដេញដោលឡើយ លើកលែងតែជនជាប់ចោទត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការជំទាស់ភស្តុតាងប្រឆាំងនឹងខ្លួន"[1571]។

៨៦៨. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចជាច្រើនដងរួចមកហើយថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ មិនត្រូវបានទទួលស្គាល់នោះទេ ប្រសិនណាបើការផ្តន្ទាទោសលើជនជាប់ចោទ ផ្អែកលើសក្ខីកម្មមួយដែលជនជាប់ចោទគ្មានឱកាសអាចពិភាក្សាដេញដោលបានទាល់តែសោះ ហើយជនជាប់ចោទ

---

[1568] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៤៣០។

[1569] មរណៈភាពរបស់ សុខ អ៊ែល ពុំបានផ្តល់ភាពជឿជាក់ច្រើនជាងនេះដល់កំណត់ហេតុស្តាប់ចម្លើយរបស់គាត់ទេ។

[1570] អង្គជំនុំជម្រះខ្លួនឯងធ្លាប់រំឭកថា កំណត់ហេតុស្តាប់ចម្លើយមានតម្លៃជាភស្តុតាងតិចតួចបំផុត។ សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥។

[1571] សាលដីកាសំណុំរឿង ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ០០២/០១ កថាខណ្ឌ ២៩៦។

មិនត្រូវបានអនុញ្ញាតឱ្យធ្វើការតទល់ជាមួយសាក្សីដាក់បន្ទុកទេនោះ[1572]។ ដូច្នេះ គ្មានសេចក្ដីសម្រេចណាអាចផ្អែកលើភស្តុតាងដែលមិនត្រូវបានពិភាក្សាដេញដោលចំពោះមុខដោយភាគីបានទេ។ គោលការណ៍ចំពោះមុខ គឺជាអនុសាធ្យនៃសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដែលមិនអាចត្រូវយកមកចោទជាបញ្ហាបានឡើយ។ សភាព្រហ្មទណ្ឌ នៃសាលាវិនិច្ឆ័យបារាំង អនុវត្តការវិនិច្ឆ័យប្រហាក់ប្រហែលនេះដែរ[1573]។ អនុលោមតាមវាក្យខ័ណ្ឌទី ២ នៃមាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងចែងថា៖ "ចៅក្រមអាចសំអាងសេចក្ដីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលបានប្រគល់ជូនខ្លួននៅក្នុងអំឡុងពេលដេញដោល និងពិភាក្សាតទល់គ្នានៅចំពោះមុខខ្លួនប៉ុណ្ណោះ"។

៨៦៩. ដូច្នេះ អង្គជំនុំជម្រះមិនអាចសម្រេចថាឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតលើអ្នកទោសឈ្មោះ ហ៊ើស ត្រូវបានបង្ហាញនៅភ្នំក្រោល ដោយផ្អែកលើមូលដ្ឋាននៃកំណត់ហេតុស្ដាប់ចម្លើយទាំងពីរនេះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះមិនអាចស្ដាប់សក្ខីកម្មបាននៅក្នុងសវនាការ ហើយដែលមេធាវីការពារក្ដី ពុំមានឱកាសសួរដេញដោលពួកគាត់នោះទេ។ អង្គជំនុំជម្រះពុំបានបង្ហាញឱ្យឃើញអំពីភាពហ្មត់ចត់ចាំបាច់ក្នុងការផ្ដល់សេចក្ដីសំអាងហេតុលើការប្រកាសអំពីពិរុទ្ធភាព។ សេចក្ដីសន្និដ្ឋានទាំងឡាយរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការសម្លាប់ ហ៊ើស ត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់[1574]។

## ១.២. កំហុសដោយបានសន្និដ្ឋានថាមានការធ្វើមនុស្សឃាតដោយចេតនាប្រយោលលើ ទូច

៨៧០. អង្គជំនុំជម្រះយល់ឃើញថា ការធ្វើមនុស្សឃាតដោយចេតនាប្រយោលលើអ្នកទោសម្នាក់ឈ្មោះ ទូច គឺត្រូវបានបង្ហាញនៅភ្នំក្រោល ដោយផ្អែកលើមូលដ្ឋាននៃកំណត់ហេតុស្ដាប់ចម្លើយរបស់ សុខ អ៊ែល

[1572] សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥, សាលដីកា *Unterpertinger ទល់នឹងប្រទេសអូទ្រីស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៦ កថាខណ្ឌ ៣១, សាលដីកា *Saïdi ទល់នឹងប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣ កថាខណ្ឌ ៤៣-៤៤។

[1573] សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥។

[1574] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៥។

ជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាពហើយ[1575]។ អង្គជំនុំជម្រះមិនអាចសំអាងការប្រកាសពីពិរុទ្ធភាពតែទៅលើមូលដ្ឋាននៃភ័ស្តុតាងនេះបានទេ។ ដោយធ្វើដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ក្នុងការវាយតម្លៃលើភ័ស្តុតាង (១.២.១) ក៏ដូចជាទាក់ទងនឹងនីត្យានុកូលភាពនៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្ម (១.២.២)។

## ១.២.១. កំហុសដោយបានផ្អែកតែទៅលើកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គលស្លាប់ម្នាក់ ដើម្បីធ្វើជាមូលដ្ឋាននៃការប្រកាសពិរុទ្ធភាព

៨៧១. យោងតាមខ្លឹមសារនៃសាលក្រមដែលរងការជំទាស់ អង្គជំនុំជម្រះយល់ឃើញថាចម្លើយរបស់ សុខ អ៊ែល ទាក់ទងនឹងការស្លាប់អ្នកទោសម្នាក់ឈ្មោះ ទូច គឺអាចជឿជាក់បាន។ សុខ អ៊ែល បានឃើញ ទូច "ដេកស្លាប់ ផ្កាក់ក និងលៀនអណ្តាត"[1576]។ ក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួនអាចប្រើប្រាស់ចម្លើយរបស់អ្នកដែលស្លាប់ ដូចជាក្នុងករណីជាក់ស្តែងនេះ តែថានៅក្នុងស្ថានភាពដូច្នេះ "អង្គជំនុំជម្រះនឹងមិនសម្រេចសេចក្តីលើការដាក់ទោសណាមួយ ដោយផ្អែកតែលើចម្លើយបែបនេះទាំងស្រុងនោះទេ"[1577]។ តុលាការកំពូលបានយល់ស្របជាមួយនឹងវិធីសាស្ត្រមួយនេះ[1578]។ តុលាការកំពូលថែមទាំងបានកម្រិតការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយ ហើយត្រង់ចំណុចនេះ បានរំឭកពីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលលើកឡើងថា៖

> "ការដាក់ពិរុទ្ធភាពពុំអាចផ្អែកតែមួយមុខ ឬដោយពុំបានពិចារណាវែងឆ្ងាយទៅលើភ័ស្តុតាងរបស់សាក្សីណាម្នាក់ដែលភាគីការពារក្តីពុំមានឱកាសសួរដេញដោលឡើយ លើកលែងតែជនជាប់ចោទត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងការជំទាស់ភ័ស្តុតាងប្រឆាំងនឹងខ្លួន"[1579]។

---

[1575] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៦។

[1576] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៦។

[1577] សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៣១។

[1578] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៨៤-២៩៤។

[1579] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៩៦, សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥។

៨៧២. អង្គជំនុំជម្រះយល់ឃើញថា ខ្លួនអាចសំអាងលើកំណត់ហេតុស្តាប់ចម្លើយសាក្សីស្តាប់ម្នាក់ ក្នុងនោះរួមទាំងនៅពេលដែលកំណត់ហេតុនោះពាក់ព័ន្ធនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ។ ប៉ុន្តែ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនផ្តល់តម្លៃជាភ័ស្តុតាងតិចតួចបំផុតដល់កំណត់ហេតុទាំងនោះ និងបានសម្រេចថា "ការផ្តន្ទាទោសមិនអាចពឹងផ្អែកលើកំណត់ហេតុទាំងនោះទាំងស្រុង ឬជាសំខាន់នោះឡើយ"[1580]។ ដូច្នេះ ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយសាក្សីស្តាប់ម្នាក់ អាចត្រូវបានទទួលយក កំណត់ហេតុនោះគួរត្រូវបានសិក្សាដោយប្រយ័ត្នប្រយែងជាទីបំផុត ហើយអង្គជំនុំជម្រះមានកាតព្វកិច្ចផ្តល់សំអាងហេតុឱ្យបានហ្មត់ចត់បំផុត[1581]។ ក៏ប៉ុន្តែ ក្នុងករណីជាក់ស្តែងនេះ អង្គជំនុំជម្រះពុំបានផ្តល់ហេតុផលសមរម្យណាមួយនោះទេ ហើយបានត្រឹមប្រកាសថា សុខ អ៊ែល មានភាពជឿជាក់បាន ខណៈដែលចម្លើយរបស់គាត់កាលពីឆ្នាំ២០០៨ មិនត្រូវបានបញ្ជាក់បន្ថែមដោយភ័ស្តុតាងណាមួយផ្សេងទៀត ហើយវាមិនអាចឱ្យគេកំណត់អត្តសញ្ញាណអ្នកទោសដែលលើកឡើងនោះឱ្យបានប្រាកដនោះទេ។

៨៧៣. ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតលើអ្នកទោសឈ្មោះ ទូច ត្រូវបានបង្ហាញទេ[1582]។ សេចក្តីសន្និដ្ឋានមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

### ១.២.២. កំហុសក្នុងការអនុវត្តធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត

៨៧៤. ដើម្បីសម្រេចថាធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតលើអ្នកទោសឈ្មោះ ទូច ត្រូវបានបង្ហាញ អង្គជំនុំជម្រះបានលើកឡើងថា៖

> "ដីកាដំណោះស្រាយបានប្រមើលឃើញថា ការស្លាប់របស់អ្នកជាប់ឃុំដែលបណ្តាលមកពីល័ក្ខខ័ណ្ឌនៃការឃុំខ្លួន ស្ថិតនៅក្រោមការកំណត់ប្រភេទបទល្មើសជាការធ្វើមនុស្សឃាត អង្គ

---

[1580] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១-៧២។

[1581] សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥។

[1582] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៦។

ជំនុំជម្រះជឿជាក់ថា ការទុកអ្នកជាប់ឃុំស្ថិតនៅក្នុងលក្ខខណ្ឌនៃការឃុំខ្លួនដ៏លំបាកដោយចេតនា ឬការមិនបានកែប្រែនូវលក្ខខណ្ឌនៃការឃុំខ្លួន ឬអនាម័យ ដែលបណ្តាលឱ្យមានព្យសនកម្មកើតឡើងនោះ គឺជាការមិនយកចិត្តទុកដាក់ចំពោះជីវិតមនុស្ស ដោយបុគ្គលិករបស់មន្ទីរសន្តិសុខ ហេតុដូច្នេះ វាបានបំពេញនូវធាតុផ្សំ*ចេតនាដោយប្រយោល* (*dolus eventualis*)។ ហេតុនេះ ធាតុផ្សំអត្តនោម័តិនៃការធ្វើមនុស្សឃាត ត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងការស្លាប់បុគ្គលឈ្មោះ ទូច"[1583]។

៨៧៥. ដូចបានចង្អុលបង្ហាញពីខាងលើ នៅក្នុងសារណានេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ទាក់ទងនឹងនីត្យានុកូលភាពនៃការធ្វើមនុស្សឃាតដោយចេតនាដោយប្រយោល នៅសម័យកាលអង្គហេតុ[1584]។ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត អាចត្រូវបំពេញបានដោយផ្អែកតែទៅលើមូលដ្ឋាននៃចេតនាដោយផ្ទាល់ប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថាចេតនាប្រយោលត្រូវបានរកឃើញចំពោះការធ្វើមនុស្សឃាតលើឈ្មោះ ទូច។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងឡាយទាក់ទងនឹងការធ្វើមនុស្សឃាតនេះ ត្រូវទុកជាមោឃៈ។

## ១.៣. កំហុសទូទៅដោយមិនបានពិចារណាលើភស្តុតាងដោះបន្ទុក

៨៧៦. នៅក្នុងការវាយតម្លៃលើការធ្វើមនុស្សឃាតទាំងពីរនេះ អង្គជំនុំជម្រះហាក់ដូចជាបំភ្លេចចោលដោយចេតនានូវភស្តុតាងដោះបន្ទុក។ សក្ខីកម្មសាក្សីដែលត្រូវបានសួរដេញដោល ក្នុងអំឡុងពេលសវនាការមិនអាចឱ្យគេធ្វើសេចក្តីសន្និដ្ឋានបានឱ្យហួសពីវិមតិសង្ស័យថាមានការធ្វើមនុស្សឃាតនៅគុកភ្នំក្រោលបានទេ។ អង្គជំនុំជម្រះមិនបានពិចារណាលើភស្តុតាងដោះបន្ទុក។

---

[1583] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1584] សូមមើលខាងលើ កថាខណ្ឌ ៥៧៥-៦៣៦, ៦៣៨។

៨៧៧. ចាន់ តូច ដែលជាអ្នកជាប់ឃុំនៅភ្នំក្រោល បានបញ្ជាក់ថាតាមគាត់ដឹង អ្នកដែលជាប់ឃុំជាមួយគាត់ "អត់មានយកទៅសម្លាប់ទេ"[1585] ដោយបន្ទាប់មកទៀត គាត់បញ្ជាក់ថា នៅក្នុងចម្លើយមុនៗរបស់គាត់ ប្រាប់ទៅអ្នកស៊ើបអង្កេត គឺគាត់បានធ្វើ "សេចក្ដីសន្និដ្ឋានផ្ទាល់ខ្លួន"[1586]។

៨៧៨. ចាន់ តូច បានបញ្ជាក់ផងដែរថា គាត់ពុំបានដឹងរឿងទាក់ទងនឹងការសម្លាប់មនុស្សក្នុងពេលគាត់ជាប់ឃុំឃាំងទេ ដោយគាត់បានបន្ថែមថា គាត់ដឹងរឿងទាំងអស់នេះនៅពេល "ក្រោយៗមក"[1587] ទេ។ ទោះយ៉ាងណាក៏ដោយ គាត់មិនបានកំណត់ថាការសម្លាប់ដែលដឹងពីការនិយាយតៗគ្នានេះ បានកើតឡើងនៅក្នុងគុកភ្នំក្រោលឡើយ[1588]។ ដូចគ្នានេះដែរ ណោត សាវ៉ាត ដែលជាអតីតអ្នកជាប់ឃុំម្នាក់ដែរ និងដែលត្រូវបានសួរដេញដោលទាក់ទងនឹងប្រធានបទនេះ និងផ្ទៀងផ្ទាត់ជាមួយនឹងចម្លើយមុនៗរបស់គាត់ បានបញ្ជាក់ថាគាត់មិនបានឃើញដោយផ្ទាល់ភ្នែកពីការសម្លាប់ណាមួយនោះទេ គឺគាត់គ្រាន់តែរាយការណ៍ពីពាក្យឮគេនិយាយតគ្នាដែលបញ្ជាក់ត្រឹមថា "ដាក់នឹងឡានទៅ" តែគាត់មិន "ដឹងជាទៅសម្លាប់យ៉ាងម៉េច ភ្នែកវាអត់ឃើញ"[1589]។ ដូច្នេះ អង្គជំនុំជម្រះបានសម្រេចបំភ្លេចចោលភ័ស្ដុតាងទាំងអស់នេះ

---

[1585] ចាន់ តូច៖ ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/399.1** ទំព័រ ១៧ ក្រោយម៉ោង ០៩.៥៥.៥៥។

[1586] ចាន់ តូច៖ កំណត់ហេតុនៃការស្ដាប់ចម្លើយ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ ឯកសារ **E3/7694** ERN 00236706, ទាក់ទងនឹងកំណត់ហេតុស្ដាប់ចម្លើយ៖ ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/399.1** ទំព័រ ២៣ មុនម៉ោង ១០.១៣.៤៣ "[...] ប៉ុន្តែបាត់ ដឹងថាគេចាប់ទៅហើយ មានតែយកទៅវៃចោលតែប៉ុណ្ណឹង ខ្ញុំដឹងអ៊ីចឹង"។

[1587] ចាន់ តូច៖ ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/399.1** ទំព័រ ៣៥-៣៦ ចន្លោះម៉ោង ១១.០៧.២៥ និង ១១.០៩.៤៤។

[1588] ចាន់ តូច៖ ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/399.1** ទំព័រ ៣៥-៣៦ ចន្លោះម៉ោង ១១.០៧.២៥ និង ១១.០៩.៤៤។

[1589] ណោត សាវ៉ាត៖ ប្រតិចារឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/400.1** ទំព័រ ២៨-២៩ ចន្លោះម៉ោង ១១.១១.០២ និង ១១.១៧.០៦ "ស៖ តើលោកធ្លាប់ឮអ្វីមួយអំពីការសម្លាប់មនុស្សដែលត្រូវបានគេឃុំឃាំងនោះទេ? តើគេយកអ្នកទាំងនោះ យកទៅសម្លាប់នៅឯណាដែរ លោកដឹងទេ? ឆ៖ អត់ដឹងដែរ។ ប៉ុន្តែឃើញគេចេះតែដកចេញពីអាបន្ទប់ឃុំឃាំងនោះដាក់នឹងឡានទៅ មិនដឹងជាទៅសម្លាប់យ៉ាងម៉េច ភ្នែកវាអត់ឃើញ។ ស៖ ខ្ញុំសូមអានសម្រង់ខ្លីមួយចេញពីកិច្ចសម្ភាសន៍របស់លោក ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ **E3/7676** ខ្មែរ 00231531 អង់គ្លេស 00384152 បារាំង 00384258។ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ "មានការសម្លាប់ខ្លះ ប៉ុន្តែមិនសម្លាប់នៅក្នុងគុកទេ គេនាំទៅតាមផ្លូវទៅកាន់ខេត្តក្រចេះ"។ ហើយពីមុននេះ លោកក៏បាននិយាយថា លោកបានស្ដាប់ឮអ្នកដែលគេឃុំខ្លួននៅជាន់ខាងលើត្រូវបានគេដឹកទៅកាន់ទិសខាងលិច។ តើអ្នកណាដែលបានប្រាប់លោកថា អ្នក

ដែលដាក់ការសង្ស័យលើការជួបប្រទះហេតុការណ៍ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត នៅគុកភ្នំក្រោល ខណៈដែលភស្តុតាងទាំងអស់នោះបានមកពីសាក្សីដែលបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ និងមានតម្លៃខ្ពស់ជាងភស្តុតាងលើកឡើងនៅក្នុងសំអាងហេតុសាលក្រមរងការជំទាស់នេះថែមទៀត។ ម្យ៉ាងទៀត សក្ខីកម្មរបស់ពួកគាត់គួរនាំឱ្យអង្គជំនុំជម្រះធ្វើការថ្លឹងថ្លែងពីភាពខុសគ្នារវាងកំណត់ហេតុស្តាប់ចម្លើយដែលមើលទៅហាក់ដូចជាច្បាស់លាស់ តែបន្ទាប់មកបែរជាដឹងថាជាការឮតពីគេ ដែលធ្វើឱ្យគេនឹកឃើញពីការខ្វះភាពជឿទុកចិត្តបាន។

៨៧៩. **សរុបសេចក្តីទៅ** យោងតាមកង្វះភស្តុតាង អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យបានថា ការធ្វើមនុស្សឃាតទាំងពីរនេះ ត្រូវបានបង្ហាញនៅមន្ទីរសន្តិសុខភ្នំក្រោលបានទេ។ ដើម្បីទាញសេចក្តីសន្និដ្ឋានទាំងនេះបាន អង្គជំនុំជម្រះបានរំលោភលើច្បាប់ភស្តុតាង និងនិយាយផ្ទុយខ្លួនឯងនៅក្នុងសំអាងហេតុសាលក្រម។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់ទាក់ទងនឹងការធ្វើមនុស្សឃាតទាំងពីរនេះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់។

## ២. ការធ្វើឱ្យក្លាយជាទាសករ

### ២.១. បណ្តឹងខុសច្បាប់ពីអង្គហេតុនៃការចោទប្រកាន់

៨៨០. ដូចមេធាវីការពារក្តីបានពន្យល់ក្នុងផ្នែកនៃសារណានេះ ទាក់ទងនឹងបណ្តឹង សហចៅក្រមស៊ើបអង្កេតបានអនុវត្តហួសពីវិសាលភាពនៃបណ្តឹងដើមមកកាន់ខ្លួន ដោយបានធ្វើការសន្និដ្ឋានលើអង្គហេតុមួយចំនួនកើតឡើងនៅតាមទីតាំង ក-១៧ និងនៅគុកភ្នំក្រោល ដើម្បីសម្រេចថាឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ ត្រូវបានបង្ហាញ ខណៈដែលសហចៅក្រមស៊ើបអង្កេតត្រូវបានស្នើសុំឱ្យពិនិត្យតែលើអង្គហេតុកើតឡើងនៅ ក-១១ ប៉ុណ្ណោះ[1590]។ ដូច្នេះ អង្គជំនុំជម្រះអាចកាត់សេចក្តីលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើឱ្យទៅជាទាសករ បានតែនៅក្នុងវិសាលភាពនៃ ក-១១ ប៉ុណ្ណោះ។

---

ទោសដែលគេយកចេញទៅក្រៅហ្នឹង គឺត្រូវគេបញ្ជូនចេញទៅលិច គឺជាផ្លូវសំដៅទៅកាន់ខេត្តក្រចេះ អ្នកណាជាអ្នកប្រាប់លោក? ឆះទេ ការងារនេះ វាចេះតែឮទៅតាមពាក្យពេចន៍ដែលសាធារណៈ គេនិយាយ ប៉ុន្តែភ្នែកអត់ឃើញទេណា។ ឮគេនិយាយខ្សឹបៗគ្នាទៅ"។

[1590] សូមមើលខាងលើ កថាខណ្ឌ ៣៩៧-៣៩៨។

## ២.២. កង្វះភស្តុតាងសម្រាប់សន្និដ្ឋានថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម

៨៨១. ភស្តុតាងសម្រាប់បង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មនៅទីតាំង ក-១១ គឺមិនគ្រប់គ្រាន់ច្បាស់ណាស់។ ការយោងតែមួយគត់ទៅលើទីតាំង ក-១១ នៅក្នុងការកំណត់បទចោទប្រកាន់ គឺសក្ខីកម្មនៅក្នុងសវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណៃម និងកំណត់ហេតុស្តាប់ចម្លើយ អ៊ួម ម៉ុល។

៨៨២. ទីមួយពាក់ព័ន្ធនឹង កុល ណៃម ដើមបណ្តឹងរដ្ឋប្បវេណីបានមកផ្តល់សក្ខីកម្មនៅក្នុងវគ្គស្តីពីការរៀបការដោយបង្ខំ។ គាត់បានលើកឡើងពីមន្ទីរសន្តិសុខភ្នំក្រោល និងមន្ទីរ ក-១១ តែក្នុងអំឡុងពេលដែលគាត់ថ្លែងអំពីទុក្ខសោកវេទនារបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃគោលនយោបាយរៀបការដោយបង្ខំ គឺមានន័យថានៅក្រោយពីភាគីសួរសំណួរចប់[1591]។ ដូច្នេះ មេធាវីការពារក្តីពុំមានលទ្ធភាពសួរគាត់បាន ទាក់ទងនឹងប្រធានបទនេះ ដែលពុំមែនជាចំណុចស្នូលនៃសក្ខីកម្មរបស់គាត់។ ទីពីរ អង្គជំនុំជម្រះបានយោងទៅកំណត់ហេតុស្តាប់ចម្លើយមួយរបស់ អ៊ួម ម៉ុល[1592] ដែលជាសាក្សីបានស្លាប់បាត់ទៅហើយ ដែលមិនអាចចោទសួរបាន និងដែលធ្វើឱ្យភស្តុតាងមួយនេះមានតម្លៃតិចតួចបំផុត[1593]។

៨៨៣. ក្នុងករណីទាំងពីរនេះ លទ្ធភាពក្នុងការតទល់គ្នារបស់ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានកម្រិត ហើយការខ្វះភាពជឿទុកចិត្តបាននៃភស្តុតាងប្រមូលបាន គួរនាំអង្គជំនុំជម្រះឱ្យកត់សម្គាល់ថា ខ្លួនមិនអាចយល់ឃើញថាឧក្រិដ្ឋកម្មនេះត្រូវបានបង្ហាញ ដោយផ្អែកតែទៅលើភស្តុតាងទាំងនេះបានទេ។ អង្គជំនុំជម្រះគ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីសម្រេចថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើឱ្យទៅជាទាសករ ត្រូវបានបង្ហាញនៅ ក-១១ បានឡើយ។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើឱ្យទៅជាទាសករ ត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះអង្គហេតុទាំងនេះ។

---

[1591] កុល ណៃម៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោងប្រហែល ១៥.១៦.៣៨។

[1592] កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ួម ម៉ុល ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ឯកសារ **E3/7700**។

[1593] សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥។

### ៣. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

៨៨៤. អង្គជំនុំជម្រះយល់ឃើញថា ធាតុផ្សំសត្យានុម័តិនៃការរើសអើងជាក់ស្តែង ត្រូវបានកំណត់នៅពេលដែលបុគ្គលម្នាក់ត្រូវបានកំណត់ជាគោលដៅ ដោយមូលហេតុស្ថិតនៅក្នុងក្រុមមួយកំណត់ដោយថារីនៃឧក្រិដ្ឋកម្ម ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់មួយចំនួន (នយោបាយ ពូជសាសន៍ ឬសាសនា)[1594]។ ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មនេះតម្រូវឱ្យមានចេតនាជាក់លាក់ នោះគឺអនុវត្តការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[1595]។

៨៨៥. ដូចដែលបានពន្យល់នៅក្នុងផ្នែកទាក់ទងនឹងបណ្តឹង ដីកាដំណោះស្រាយពុំបានកំណត់អត្តសញ្ញាណ និងនិយមន័យនៃក្រុមដែលរងការធ្វើទុក្ខបុកម្នេញ ចំពោះអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខភ្នំក្រោលទេ[1596]។ អវត្តមាននិយមន័យនៃក្រុមដែលរងការធ្វើទុក្ខបុកម្នេញ គឺមានភាពពាក់ព័ន្ធផ្ទាល់ទៅលើការកំណត់បទចោទប្រកាន់ ព្រោះថាបើពុំមានក្រុមដែលត្រូវបានកំណត់និយមន័យ និងកំណត់អត្តសញ្ញាណទេ គេមិនអាចពន្យល់ពីលក្ខណៈវិនិច្ឆ័យដែលជាមូលដ្ឋាននៃការរើសអើងរងការចោទប្រកាន់បានទេ។ ដើម្បីការពារខ្លួន ដោយសារតែកង្វះការកំណត់អត្តសញ្ញាណបែបនេះ អង្គជំនុំជម្រះថ្លែងថាខ្លួន "ជឿជាក់ថាទាំងខ្មាំងនយោបាយពិតប្រាកដ ឬខ្មាំងតាមការសន្មត រួមមានក្រុមទាំងបីដែលបានបែងចែកជាក់លាក់នៅក្នុងដីកាដំណោះស្រាយ តែក៏មិនកម្រិតត្រឹមតែក្រុមទាំងបីនេះនោះដែរ"[1597]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា៖

> "ប.ក.ក បានកំណត់អត្តសញ្ញាណថាជាខ្មាំងចំពោះអ្នកដែលប្រឆាំងបដិវត្តន៍ អ្នកដែលរិះគន់ និងជនក្បត់បដិវត្តន៍ ភ្នាក់ងារបរទេស ដូចជាវៀតណាម ព្រមទាំងអ្នកចូលដៃជាមួយប្រភេទក្រុមមនុស្សខាងលើនេះផងដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា ក្រុមគោលដៅនៃ

---

[1594] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៤។

[1595] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៥។

[1596] សូមមើលខាងលើ កថាខណ្ឌ ៥១៤-៥១៦។

[1597] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៣៨។

"ខ្មាំងពិត ឬខ្មាំងតាមការសន្មតរបស់ប.ក.ក" ត្រូវបានញែកពីគ្នាគ្រប់គ្រាន់ ដើម្បីសម្រេចថាតើផលវិបាកដែលបានតម្រូវនោះ បានកើតឡើងដែរឬទេចំពោះក្រុមនោះ"[1598]។

៨៨៦. ក៏ប៉ុន្តែ ដូចដែលធ្លាប់បានរំឭកជាច្រើនលើកច្រើនសារួចមកហើយថា អង្គជំនុំជម្រះត្រូវបានស្នើឱ្យពិនិត្យលើការធ្វើទុក្ខបុកម្នេញតែទៅលើក្រុមបីប៉ុណ្ណោះ បើយោងតាមដីកាដំណោះស្រាយ ក្នុងនោះមាន អតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងប្រជាជនកម្ពុជាត្រឡប់មកពីបរទេស។ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មតរបស់ ប.ក.ក" ពុំស្ថិតក្នុងចំណោមក្រុមដែលរៀបរាប់នេះទេ ដែលធ្វើឱ្យគ្មានការចោទប្រកាន់ណាមួយអាចធ្វើទៅបាន។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសម្រេចថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយត្រូវបានបង្ហាញ ទាក់ទងនឹងអង្គហេតុប្រព្រឹត្តឡើងនៅភ្នំក្រោល[1599]។ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ។

## ៤. អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ

៨៨៧. យោងតាមខ្លឹមសារនៃសំអាងហេតុសាលក្រមរងការជំទាស់ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាអង្គហេតុកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញនៅតាមទីតាំងទាំងអស់នៅភ្នំក្រោល[1600]។ ក៏ប៉ុន្តែ ដូចដែលបានបញ្ជាក់ពីខាងលើ នៅក្នុងផ្នែកទាក់ទងនឹងបណ្ដឹង[1601] សហចៅក្រមស៊ើបអង្កេតត្រូវបានសហព្រះរាជអាជ្ញាស្នើសុំឱ្យពិនិត្យតែលើអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំនៅទីតាំងឈ្មោះ "ភ្នំក្រោល" នៅត្រង់កថាខណ្ឌ ៦៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលការពិតគឺ ក-១៧[1602]។ គ្មានអង្គហេតុនៃការបាត់ខ្លួនណាមួយផ្សេងទៀត ត្រូវបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

[1598] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៣៩។

[1599] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៥១។

[1600] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៦០-៣១៦៦។

[1601] សូមមើលខាងលើ កថាខណ្ឌ ៤០១-៤០៣។

[1602] សូមមើលខាងលើ កថាខណ្ឌ ១៣៥៣-១៣៦៤។

ទាក់ទងនឹង ក-១១ ឬភ្នំក្រោលទេ[1603]។ ដូច្នេះ ខៀវ សំផន ត្រូវឆ្លើយតបតែទៅនឹងអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំកើតឡើងនៅ ក-១៧ ប៉ុណ្ណោះ។

៨៨៨. ក៏ប៉ុន្តែ បុគ្គលទាំងពីររូបដែលត្រូវបានស្តាប់ចម្លើយទាក់ទងនឹងប្រធានបទនេះគឺ ចាន់ តូច និង អ្លួង ដុស ត្រូវបានជាប់ឃុំឃាំងតែនៅភ្នំក្រោល ពុំមែននៅ ក-១៧ ទេ[1604]។ ដូច្នេះ អង្គជំនុំជម្រះគ្មានភស្តុតាងណាមួយទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំនៅទីតាំង ក-១៧ ទេ។ លើសពីនេះ ភស្តុតាងទាំងឡាយដែលត្រូវបានបង្ហាញសម្រាប់ទីតាំងនានានៅ ក-១១ និងភ្នំក្រោល ផ្អែកតែទៅលើការឮគេនិយាយតគ្នា៖

> "នៅមន្ទីរសន្តិសុខនេះ អ្នកជាប់ឃុំបានជួបប្រទះនូវការបាត់ខ្លួនអ្នកជាប់ឃុំដែលជាប់ឃុំជាមួយគ្នា ដោយមិនមានការប្រាប់ពីមូលហេតុនៃការបាត់ខ្លួនរបស់ពួកគេទាំងនោះឡើយ ដែលធ្វើឱ្យអ្នកជាប់ឃុំជឿថា អ្នកបាត់ខ្លួនទាំងនោះត្រូវបានគេសម្លាប់។ ការរៀបរាប់មួយនៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញថាអ្នកជាប់ឃុំត្រូវបានគេប្រាប់ថា ពួកគេទាំងនោះត្រូវបញ្ជូនត្រឡប់ទៅភូមិកំណើតវិញ ប៉ុន្តែបន្ទាប់ពីពេលនោះមកមិនដែលបានឃើញពួកគេជារៀងរហូត។ សាក្សីផ្សេងទៀត បានឮព័ត៌មានផ្សេងៗគ្នា នៅពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ឬក្រោយពេលដួលរលំបានមួយរយៈខ្លីមក អ្នកជាប់ឃុំត្រូវបានគេដឹកទៅតាមផ្លូវទិសដៅទៅខេត្តក្រចេះ ដោយព័ត៌មានខ្លះបញ្ជាក់ច្បាស់ថា អ្នកជាប់ឃុំត្រូវបានគេយកទៅទីនោះដើម្បីសម្លាប់។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថា តាមពិតទៅ អ្នកជាប់ឃុំត្រូវបានគេដឹកទៅតាមផ្លូវទិសដៅទៅខេត្តក្រចេះ ក្រោយពីគេយកចេញពីមន្ទីរសន្តិសុខភ្នំក្រោល ដោយមិនមានការពន្យល់។ អង្គជំនុំជម្រះជឿជាក់ថា ការយកអ្នកជាប់ឃុំចេញ គឺជាការដកហូតសេរីភាព"[1605]។

[1603] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **D202** កថាខណ្ឌ ៨-១១។

[1604] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤០៧-១៤១០។

[1605] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៦១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

៨៨៩. បើទោះបីជាអង្គជំនុំជម្រះមិនបានកំណត់ដោយផ្ទាល់ក៏ដោយ ក៏អង្គជំនុំជម្រះខ្លួនឯងបានលើកឡើងថា ភ័ស្តុតាងដែលខ្លួនបានប្រើប្រាស់ គឺគ្មានអ្វីក្រៅតែពីការឮគេនិយាយតគ្នាទេ។ អង្គជំនុំជម្រះពុំបានបង្ហាញពីភ័ស្តុតាងផ្ទាល់ណាមួយទេ ហើយការផ្តន្ទាទោសផ្អែកតែលើការនិយាយសរុបជាទូទៅ។

៨៩០. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ សៅ សារុន អតីតលេខាតំបន់ ដើម្បីសម្រេចថា ការបាត់ខ្លួនទាំងឡាយដែលកើតឡើងនៅមន្ទីរសន្តិសុខ គឺជាលទ្ធផលនៃអំពើរបស់អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ ឬដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីប.ក.ក[1606]។ នៅត្រង់នេះជាថ្មីម្តងទៀត អង្គជំនុំជម្រះបានធ្វើការជ្រើសរើសផ្នែកដោយដុំៗ និងសម្រាប់តែដាក់បន្ទុកសុទ្ធសាធ ចេញពីសក្ខីកម្មនេះ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះវិនិច្ឆ័យគួរឱ្យឆ្ងល់ថា សៅ សារុន មិនអាចជឿជាក់បាន នៅពេលគាត់ផ្តល់ភ័ស្តុតាងដោះបន្ទុក និងមិនមែនជាភ័ស្តុតាងដាក់បន្ទុកសុទ្ធសាធ៖

> "ក្រោយពេលពិនិត្យមើលទៅលើនិន្នាការដែល សៅ សារុន ចង់កាត់បន្ថយតួនាទីរបស់គាត់នៅភ្នំក្រោល អង្គជំនុំជម្រះមិនផ្តល់ទម្ងន់ទៅលើការទម្លាក់អំពីការសួរចម្លើយទៅលើតែអ្នកកាន់តួនាទីនេះមុនគាត់ ឬការពិពណ៌នាអំពីតួនាទីរបស់គាត់នៅពេលនោះឡើយ"[1607]។

> "សៅ សារុន បានផ្តល់ភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងមន្ទីរ ក-១៧ ដែលមិនមានភាពស៊ីចង្វាក់ និងផ្ទុយទាំងស្រុងទៅនឹងការរៀបរាប់ផ្សេងៗទៀតរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ"[1608]។

> "អង្គជំនុំជម្រះយល់ថា ចំណុចដែលមិនស៊ីចង្វាក់គ្នានៅក្នុងសក្ខីកម្មរបស់ សៅ សារុន គឺដោយសារតែការដឹងអំពីកំហុស ចេតនាចង់កុហក់ និងការចង់កាត់បន្ថយការទទួលខុសត្រូវរបស់គាត់ និងបំណងក្នុងការចង់រុញចោលការទទួលខុសត្រូវជារួមលើល័ក្ខខ័ណ្ឌនៅមន្ទីរ ក-១៧ ទៅអ្នកផ្សេង។ ស្របជាមួយនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះនៅក្នុងការអនុវត្តលើភ័ស្តុ

---

[1606] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៦២។ សូមមើលផងដែរ ខាងក្រោម កថាខណ្ឌ ១៨៥៦-១៨៦១។

[1607] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០៨៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1608] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០៩១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

តាងដែលមិនស៊ីចង្វាក់គ្នារបស់សាក្សីនេះ ក្នុងករណីដែលអង្គជំនុំជម្រះមិនបានដោះស្រាយទៅលើទឡ្ហីករណ៍របស់គាត់នៅក្នុងចំណុចខាងក្រោម អង្គជំនុំជម្រះមិនផ្ដល់ទម្ងន់លើសក្ខីកម្មរបស់ សៅ សារុន ពាក់ព័ន្ធនឹងចំនួនអ្នកជាប់ឃុំ ឬល័ក្ខខ័ណ្ឌនៅមន្ទីរសន្តិសុខភ្នំក្រោលនោះឡើយ”[1609]។

៨៩១. ដូច្នេះ គឺជាមួយនឹងការវាយតម្លៃក្នុងទម្រង់ប្រែប្រួលមួយ ដែលអង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ សៅ សារុន។ ដោយអនុវត្តបទដ្ឋានពីរខុសគ្នានេះ អង្គជំនុំជម្រះបានរំលោភលើវិធានវាយតម្លៃភ័ស្តុតាង[1610]។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនត្រឹមតែមិនត្រូវបានសុំឱ្យពិនិត្យដោយត្រឹមត្រូវលើអង្គហេតុដែលខ្លួនបានសម្រេចនោះទេ តែម្យ៉ាងវិញទៀត បើយោងតាមកង្វះភ័ស្តុតាងយ៉ាងច្បាស់ អង្គជំនុំជម្រះក៏មិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យបានថា ឧក្រិដ្ឋកម្មរងការចោទប្រកាន់ត្រូវបានបង្ហាញនោះដែរ។ ដូច្នេះ តុលាការកំពូលត្រូវធ្វើមោឃភាពលើរាល់សេចក្ដីសន្និដ្ឋានទាំងអស់នេះ និងត្រូវសម្រេចឱ្យ ខៀវ សំផន រួចផុតពីការចោទប្រកាន់។

## ជំពូកទី ៣. ក្រុមជាក់លាក់នានា

### ផ្នែកទី ១. ជនជាតិចាម

៨៩២. ជាចម្បង ដូចដែលបានឃើញខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយបានវិនិច្ឆ័យលើអង្គហេតុដែលខ្លួនមិនត្រូវបានស្នើសុំឱ្យពិនិត្យដោយត្រឹមត្រូវ។ យុត្តាធិការលើរឿងក្ដីរបស់អង្គជំនុំជម្រះ មិនរាប់បញ្ចូលអង្គហេតុនៃ “ការរើសអើង” ដោយមូលហេតុសាសនា ចំពោះជនជាតិចាម កើតឡើងនៅទំនប់ ១មករា ទេ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យលើអង្គហេតុទាំងអស់នេះ[1611]។ អង្គជំនុំជម្រះក៏មិនធ្លាប់ត្រូវបានស្នើសុំឱ្យពិនិត្យលើអង្គហេតុដែលជាធាតុផ្សំនៃការធ្វើមនុស្សឃាត ក្នុងឋានៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងភូមិទ្រា ហើយដូច្នេះ អង្គជំនុំជម្រះមិន

---

[1609] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០៩២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1610] សូមមើលខាងលើ កថាខណ្ឌ ២៣៩។

[1611] សូមមើលខាងលើ កថាខណ្ឌ ៨០៥-៨១៣។

អាចសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត នៅមន្ទីរសន្តិសុខទ្រា នៅឆ្នាំ១៩៧៨ បានទេ[1612]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ផងដែរ ដោយបានប្រកាសថាខ្លួនមានយុត្តាធិការជំនុំជម្រះលើអង្គហេតុនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ ប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[1613]។ អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យលើអង្គហេតុនៃការជម្លៀសដោយបង្ខំ ប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទីពីរ ក្រោមការកំណត់បទចោទប្រកាន់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ ខណៈដែលអង្គជំនុំជម្រះគួរតែកត់សម្គាល់ថាអង្គហេតុទាំងនេះធ្លាប់ត្រូវបានវិនិច្ឆ័យចប់ជាស្ថាពររួចហើយ[1614]។ ម្យ៉ាងវិញទៀត សូមរំឭកថា អង្គជំនុំជម្រះមិនបានកំណត់ថាតើវិធានការទាំងឡាយដែលត្រូវកំណត់ថាជាការធ្វើទុក្ខបុកម្នេញ មានគោលបំណងដាក់ក្រុមឱ្យស្ថិតនៅដាច់ពីគេ ឬដកចេញពីសង្គម មានលក្ខណៈបែបយ៉ាងណានោះដែរ។ ដោយមិនបានធ្វើដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់[1615]។

៨៩៣. ជាបន្ទាប់បន្សំបំផុត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត (១) ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល (២) ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម (៣) ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (៤) និង ដោយមូលហេតុសាសនា (៥) និងឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ (៦)។

## ១. កង្វះភ័ស្តុតាងអំពីបទមនុស្សឃាតនៅភូមិទ្រា និងវត្តអូរត្រកួន

### ១.១. ភាពមិនច្បាស់លាស់ និងភាពជាទូទៅ ទាក់ទងនឹងការសម្លាប់នៅមន្ទីរសន្តិសុខភូមិទ្រា

[1612] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦-៣៣០៨។ សូមមើលខាងលើ កថាខណ្ឌ ៥១៧-៥១៩។

[1613] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣២០។ សូមមើលខាងលើ កថាខណ្ឌ ៥៣៨-៥៤៣។

[1614] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣៣៥។ សូមមើលខាងលើ កថាខណ្ឌ ៥៤៤-៥៤៦។

[1615] សូមមើលខាងលើ កថាខណ្ឌ ៦៤២-៦៥៥, ៦៥៧។។

៨៩៤. អង្គជំនុំជម្រះបានសន្និដ្ឋានដោយមិនត្រឹមត្រូវថា នៅឆ្នាំ១៩៧៨ ប្រជាជនចាមនៅស្រុកក្រូចឆ្មារជាច្រើននាក់ត្រូវបានចាប់ខ្លួន និងសម្លាប់នៅភូមិទ្រា ដោយសារពួកគេជាជនជាតិចាម ដោយផ្អែកលើមូលដ្ឋាននៃសក្ខីកម្មចំនួនបី[1616]។ វាជាសក្ខីកម្មរបស់ អ៊ីត សេន ទាក់ទងនឹងឧប្បត្តិហេតុមួយ និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ដែលមិនស៊ីចង្វាក់គ្នា ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះយល់ឃើញ និងដែលបានរាយការណ៍ពីឧប្បត្តិហេតុទីពីរ។

៨៩៥. ជាបឋម អ៊ីត សេន បានរត់ចេញពីផ្ទះដែលគេដាក់គាត់ និងបុរស ៤០ នាក់ផ្សេងទៀត។ ទាក់ទងនឹងការសម្លាប់ អង្គជំនុំជម្រះបានបំភ្លៃសក្ខីកម្មរបស់គាត់។ អង្គជំនុំជម្រះយល់ថា ក្នុងពេលគាត់លាក់ខ្លួនក្នុងគុម្ពោតព្រៃ គាត់បានឃើញជនជាតិចាមដែលត្រូវគេចងភ្នែក ត្រូវគេនាំទៅទន្លេ និងពន្លង់ក្នុងទឹក[1617]។ ផ្ទុយទៅវិញ អ៊ីត សេន បានអះអាងថាគាត់បានសង្កេតមើលឃុតឆាកនេះពីចម្ងាយ ពីផ្ទះដែលគាត់ត្រូវឃុំខ្លួន[1618]។ ចម្ងាយគឺសំខាន់ណាស់ ព្រោះអង្គជំនុំជម្រះបានសន្និដ្ឋានដោយមិនសមហេតុសមផលថា អ្នកទាំងអស់នោះជាចាម ខណៈដែលសាក្សីខ្លួនឯងបានបញ្ជាក់ថា គេមិនអាចកំណត់បានថានរណាជាចាមបានទេ ប្រសិនបើគេមិនស្លៀកសម្លៀកបំពាក់ប្រពៃណី និងមិនថ្វាយបង្គំនៅព្រះវិហារ[1619]។

៨៩៦. បន្ទាប់មក បើទោះជាត្រូវពិចារណាលើការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ក៏ដោយ ក៏សក្ខីកម្មរបស់គាត់បានត្រឹមបង្ហាញឱ្យឃើញថា ស្ត្រីនៅភូមិខ្សាច់ប្រឆេះកណ្តាល ប្រមាណ ១០ នាក់ត្រូវបានទាហាននាំយកទៅ ក្រោយពីនិយាយថាពួកគេជាចាម[1620]។ ពាក់ព័ន្ធនឹងការសម្លាប់ នៅទីបំផុតទៅគាត់ទទួលស្គាល់ថាបានកុហក់ អ៊ីសា ឧស្មាន ទាក់ទងនឹងអ្វីដែលគាត់និយាយថាបានឃើញ[1621]។

---

[1616] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦, កំណត់សម្គាល់ជើងទំព័រលេខ១១២២៣ យោងទៅ កថាខណ្ឌ ៣២៨១។

[1617] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៧៦។

[1618] ប្រតិចារឹក ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/342.1** ម៉ោងប្រហែល ១៥.២៤.០៥។

[1619] ប្រតិចារឹក ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/342.1** ម៉ោងប្រហែល ១១.២៧.៣៧ "ក្រៅពីសម្លៀកបំពាក់ហ្នឹង អ្នកគេស្គាល់គេសំឃុំាង។ គេដល់ពេលទៅគេសំយ៉ាំង ស្គាល់គេ ថាហ្នឹងអ៊ីស្លាម។ ដល់ថ្ងៃខែបួស គេបួស។ សំយ៉ាំង គេសំយ៉ាំង។ ស្គាល់កន្លែងនុំងហើយ។ បើសម្លៀកបំពាក់ដូចគ្នា ខ្លះមើលដូចគ្នា។ នេះអត់ស្គាល់ទេ អ៊ីស្លាម អត់អ៊ីស្លាមទេ"។

[1620] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៧៧-៣២៧៨។

[1621] កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ **E3/5193** ERN 00204445-00204446។

៨៩៧. បើទោះជាការរៀបរាប់របស់ ម៉ាត់ ស ស៊ីចង្វាក់គ្នានឹងរឿងរ៉ាវរបស់ នោ សាទះ ទាក់ទងនឹងការចាប់ឃុំខ្លួនពួកគាត់នៅក្នុងផ្ទះនៅភូមិទ្រាក៏ដោយ ក៏វាមានភាពខុសគ្នាយ៉ាងច្រើនទាក់ទងនឹងផ្នែកផ្សេងទៀតនៃអង្គហេតុ ជាពិសេសទាក់ទងនឹងចំនួនអ្នកជាប់ឃុំ[1622]។ ជាពិសេស ម៉ាត់ ស ជាមនុស្សតែម្នាក់គត់ដែលអះអាងថាបានឃើញតាមប្រហោងជញ្ជាំងផ្ទះនូវការសម្លាប់ស្ត្រីមួយចំនួនដែលបាននិយាយថា ខ្លួនមិនមែនជាខ្មែរ[1623]។ ក៏ប៉ុន្តែ ស្ថានភាពនៃការសង្កេតឃុតឆាកនេះរបស់គាត់ មិនអាចឱ្យគេវិនិច្ឆ័យថាសក្ខីកម្មរបស់គាត់អាចជឿទុកចិត្តបាននោះដែរ។ គាត់និយាយថាបានឃើញការម្លាប់មនុស្សពេលយប់តាមប្រហោង និងមានចម្ងាយប្រមាណជាងប្រាំបីម៉ែត្រពីផ្ទះ[1624]។ ម្យ៉ាងវិញទៀត សក្ខីកម្មរបស់គាត់ទាក់ទងនឹងការសម្លាប់ទាំងនេះ ក៏មិនស៊ីចង្វាក់គ្នា ព្រោះថា នោ សាទះ បានទទួលស្គាល់ថាមិនបានឃើញអ្វីនោះទេ។ ដូច្នេះ ជាចម្បង អង្គជំនុំជម្រះមិនអាចយល់ថា ធាតុផ្សំសត្យានុម័តិនៃការធ្វើមនុស្សឃាតត្រូវបានបំពេញនៅភូមិទ្រា ដោយផ្អែកតែទៅលើមូលដ្ឋានសក្ខីកម្មទាំងនេះបានទេ[1625]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

---

[1622] ម៉ាត់ ស៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/375.1** ក្រោយម៉ោង ១០.៣៥.៣៦ ("[...] គេឃុំឃាំងលើផ្ទះហ្នឹងជាង៣០ ហ្នឹងម្តង [...]") មុនម៉ោង ១១.៣២.៤៣ ("ស៖ [...] ក្នុងចំណោម ៣០ នាក់ ជាងហ្នឹង [...]") ក្រោយម៉ោង ១៤.១៤.៥៦ (ចំណែករឿងខ្ញុំ ខ្ញុំអត់ដឹងចម្លើយគាត់ផង។ រួចចម្លើយខ្ញុំ បើខ្ញុំឆ្លើយដូចមុនៗមកអ៊ីចឹង ដូចពីព្រឹកមិញមកអ៊ីចឹង។ បើចម្លើយ នោ សាទះ ហ្នឹងគាត់ឆ្លើយពាក្យហ្នឹង គឺខ្ញុំអត់បានដឹង"), <u>នោ សាទះ</u>៖ស្ត្រីជាប់ឃុំ ៣០០ នាក់ និង ស្ត្រី ៣០ នាក់ មិនត្រូវបាននាំទៅ ព្រោះពួកគេថាខ្លួនជាជនជាតិខ្មែរ។ ប្រតិចារឹក ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/350.1** ម៉ោងប្រហែល ១៤.១៧.១២ ("[...] គេតម្រង់ជួរមួយជួរៗទៅ។ ប្រហែលជា ៣០០, ៤០០ នាក់ ក្នុងមួយផ្ទះហ្នឹងនោះ") ម៉ោងប្រហែល ១៤.២១.២០ ("នៅសល់ប្រហែល ៣០ នាក់ [...]") ម៉ោងប្រហែល ១៥.២៣.០០ ("ឆ៖ ពួក គេហៅតែ គេឱ្យតែពួកខ្ញុំហូបមួយក្រុមពួកខ្ញុំហ្នឹង ៣០ នាក់ហ្នឹង")។

[1623] ប្រតិចារឹក ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/375.1** ម៉ោងប្រហែល ១៥.២២.៥៧ "ពេលខ្ញុំអង្គុយហ្នឹងឆ្ងាយដែរ ដល់ពេលគេយកមនុស្សចុះទៅសម្លាប់ចោលហ្នឹង ខ្ញុំក៏បានប្រលោះហ្នឹងគេចុះទៅអស់ហើយ គឺខ្ញុំចុះទៅម្តងពីរនាក់ៗហ្នឹង រាងស្រឡះ ខ្ញុំក៏ដើរទៅចំប្រលោះបង្អួចតែម្តងហ្នឹងគ្រូ។ ខ្ញុំចូលទៅកន្លែងនុំងផ្ទាល់តែម្តង អើតមើលតាមអាបង្អួចបែកគេហ្នឹង របេះទៅនឹង ខ្ញុំបានសម្លឹងមើលទៅ ឃើញច្បាស់តែម្តងហ្នឹង"។

[1624] ប្រតិចារឹក ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/375.1** ម៉ោងប្រហែល ១០.៥៤.៥៨, ១៥.៤៨.៣៣។

[1625] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦ កំណត់សម្គាល់ជើងទំព័រលេខ១១២២៣ យោងទៅ កថាខណ្ឌ ៣២៨១។

៨៩៨. ជាបន្ទាប់បន្សំ បើទោះបីសក្ខីកម្មរបស់ នោ សាទះ និង ម៉ាត់ ស អាចជឿជាក់បាន និងអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យពីការសម្លាប់ស្ត្រីចាមទាំង ១០ នាក់ ពីឃុំខ្សាច់ប្រឆេះកណ្តាលក៏ដោយ ក៏អង្គជំនុំជម្រះពុំបានផ្តល់សំអាងហេតុថា តើវាបង្ហាញឱ្យឃើញឱ្យហួសពីវិមតិសង្ស័យបានដោយរបៀបណា ដែលថា នៅឆ្នាំ១៩៧៨ "ប្រជាជនចាមជាច្រើននាក់មកពីស្រុកក្រូចឆ្មារ ត្រូវបានចាប់ខ្លួននាំយកទៅមន្ទីរសន្តិសុខភូមិទ្រា [...] ហើយអ្នកដែលត្រូវចាត់ទុកថាជាជនជាតិចាមត្រូវបានគេសម្លាប់ចោល"[1626]។ នៅត្រង់នេះ វាជាការនិយាយសរុបជាទូទៅមិនសមហេតុសមផល គ្មានភ័ស្តុតាង។ សេចក្តីសន្និដ្ឋាននេះត្រូវទុកជាមោឃៈដូចគ្នា[1627]។

## ១.២. កង្វះភ័ស្តុតាងចំពោះការចោទប្រកាន់ពីបទមនុស្សឃាត នៅវត្តអូរត្រកួន

៨៩៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា "មនុស្សជាច្រើននាក់ ដែលក្នុងចំណោមនោះ ភាគច្រើនជាប្រជាជនចាមមកពីស្រុកកងមាស តំបន់ ៤១ ត្រូវបានចាប់ខ្លួននាំយកទៅវត្តអូរត្រកួន នៅឆ្នាំ១៩៧៧ ដែលនៅទីនោះពួកគេត្រូវបានសម្លាប់"[1628]។ អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋានដោយមិនសមហេតុសមផលពីភ័ស្តុតាងដោយប្រយោលមួយដែលមានតម្លៃតិចតួច ថាប្រជាជនស៊ីវិលចាមមួយចំនួន ត្រូវបានសម្លាប់ជាក្រុមនៅក្នុងវត្តអូរត្រកួន[1629]។ ភ័ស្តុតាងទាំងឡាយដែលអង្គជំនុំជម្រះយកធ្វើជាមូលដ្ឋាននៃការសន្និដ្ឋានរបស់ខ្លួន គឺផ្អែកលើភ័ស្តុតាងដែលមានតម្លៃតិចតួច ពាក់ព័ន្ធនឹងការចាប់ខ្លួនជនជាតិចាម (១.២.១) និងវត្តមានរបស់ពួកគេ និងការសម្លាប់នៅវត្តអូរត្រកួន (១.២.២)។

### ១.២.១. កង្វះភ័ស្តុតាងអំពីការចាប់ខ្លួនជនជាតិចាមនៅតាមភូមិ

---

[1626] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨១, សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦ កំណត់សម្គាល់ជើងទំព័រលេខ ១១២២៣ យោងទៅ កថាខណ្ឌ ៣២៨១។

[1627] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦ កំណត់សម្គាល់ជើងទំព័រលេខ១១២២៣ យោងទៅ កថាខណ្ឌ ៣២៨១។

[1628] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦ កំណត់សម្គាល់ជើងទំព័រលេខ១១២២២ យោងទៅ កថាខណ្ឌ ៣៣០២។

[1629] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០២។

៩០០. វាគឺជាការខុសឆ្គងដែលអង្គជំនុំជម្រះយល់ថាមានភស្តុតាងគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថាមានការចាប់ខ្លួនជនជាតិចាមជាក្រុមៗ នៅតាមភូមិផ្សេងៗ ក្នុងស្រុកកងមាស ដើម្បីនាំយកទៅវត្តអូរត្រកួន[1630]។ អង្គជំនុំជម្រះគួរទាញផលវិបាកចេញពីការទទួលស្គាល់ថា ខ្លួនមានតែ "ភស្តុតាងដែលពួតៗគ្នា"[1631] ជាសំខាន់។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីផ្ទាល់តែបួនរូបប៉ុណ្ណោះ សម្រាប់អង្គហេតុប្រព្រឹត្តទៅនៅតាមភូមិនានា ក្នុងឃុំពាមជីកង (១.២.១.១) និងក្នុងភូមិអង្គរបាន ២ (១.២.១.២) ដែលមិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យបានថាមានការចាប់ខ្លួន ដោយមូលហេតុគ្រាន់តែជាចាមប៉ុណ្ណោះ។

### *១.២.១.១. ភូមិនានាក្នុងឃុំពាមជីកង នៅដើមឆ្នាំ១៩៧៧*

៩០១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកត់សម្គាល់ថា "នៅក្នុងឃុំពាមជីកង សមាជិកក្រុមកងឈ្លបដាវវែងបានចាប់ខ្លួនជនជាតិចាមរាប់រយនាក់ នៅដើមឆ្នាំ១៩៧៧"[1632]។ នៅក្នុងកំណត់សម្គាល់ជើងទំព័រ អង្គជំនុំជម្រះបានសំអាងលើសក្ខីកម្មចំនួនបី របស់សាក្សីពីររូប និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប និងកំណត់ហេតុស្តាប់ចម្លើយចំនួនបួន។ ភស្តុតាងទាំងអស់នេះ ដែលត្រូវបានវិភាគដាច់ដោយឡែកពីគ្នា និងព្រមជាមួយគ្នា មិនអាចឱ្យគេសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថាចាមរាប់រយនាក់ត្រូវបានចាប់ខ្លួននៅក្នុងឃុំពាមជីកងទេ[1633]។ កំណត់ហេតុស្តាប់ចម្លើយដែលយោងដោយអង្គជំនុំជម្រះមានតម្លៃតិចតួចបំផុត។ លើសពីនេះទៀត កំណត់ហេតុទាំងនោះមានភាពមិនច្បាស់លាស់៖ គេមិនអាចកំណត់បានថាតើវាជាសាក្សីផ្ទាល់ ឬជាការឮគេនិយាយតគ្នា ហើយជាទូទៅ ថាតើអ្វីខ្លះជាប្រភពនៃព័ត៌មានដែលគេយកមកនិយាយ។ ដោយសារថាអង្គជំនុំជម្រះមិនបានធ្វើការវិភាគណាមួយនោះដូច្នេះ អង្គជំនុំជម្រះមិនគួរប្រើប្រាស់កំណត់ហេតុទាំងនោះសម្រាប់ធ្វើសេចក្តីសន្និដ្ឋាននោះទេ។

---

[1630] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០២។

[1631] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០២។

[1632] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៩២។

[1633] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៩២ កំណត់សម្គាល់ជើងទំព័រលេខ១១១៦២។

៩០២. ពាក់ព័ន្ធនឹងសក្ខីកម្មក្នុងសវនាការ សេង ស្រ៊ុន ត្រូវបានស្តាប់ចម្លើយទាក់ទងនឹងការចោទប្រកាន់ពីការចាប់ខ្លួននៅតាមភូមិ ក្នុងឃុំពាមជីកង "នៅក្នុងឆ្នាំ១៩៧៧"[1634]។ ជាសមាជិកក្រុមឈ្លបដាវវែង សេង ស្រ៊ុន បានបង្ហាញពីការចាប់ខ្លួនចាមពី ២០០ ទៅ ៣០០ នាក់ នៅតាមភូមិ ដោយមិនមានការពន្យល់ថាតើគាត់បានតួលេខនេះដោយរបៀបណា[1635]។ គាត់ពុំបានបញ្ជាក់ថាតើគាត់ដឹងថាបុគ្គលទាំងនោះជាជនជាតិចាមដោយរបៀបណា។ គាត់ក៏ពុំបាននិយាយពីមូលហេតុនៃការចាប់ខ្លួនអ្នកទាំងនោះដែរ។

៩០៣. ឧប្បត្តិហេតុមួយទៀតត្រូវបានរៀបរាប់ដោយដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ដែលបាននិយាយថា គាត់ និងប្រពន្ធ បានរួចខ្លួន ខណៈពេលឈ្លបដាវវែងចាប់ផ្តើមប្រមូលជនជាតិចាមក្នុងភូមិសាច់ស្វ នាំយកទៅវត្តអូរត្រកួន[1636]។ នៅពេលគេចាប់ពួកគាត់ ពួកគាត់ត្រូវបានដោះលែងដោយ កាន ដែលជាចៅហ្វាយស្រុក ដោយហេតុជាអាទិ៍ថា ហ៊ីម ម៉ាន "គ្មានទាក់ទងពីណាទេ" ហើយថាគាត់ "អត់មានទៅណា"[1637]។ ដូច្នេះ សក្ខីកម្មរបស់គាត់បានបង្ហាញឱ្យឃើញថា នៅថ្នាក់ស្រុក មូលហេតុនៃការចាប់ខ្លួនគឺទាក់ទងនឹងការប្រព្រឹត្តិមិនល្អ ពុំមែនដោយសារហេតុផលជាជនជាតិចាមនោះទេ។ ម្យ៉ាងវិញទៀត ហ៊ីម ម៉ាន បានបញ្ជាក់អះអាងពីលក្ខណៈមិនរើសអើងនៃការចាប់ខ្លួន ដោយបាននិយាយថាជនជាតិចាម តែក៏មានជនជាតិខ្មែរដែរ ត្រូវបាននាំយកទៅសម្លាប់។ គាត់បាននិយាយដូច្នេះថា៖

[1634] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/346.1** ម៉ោងប្រហែល ១០.៤៧.២៤ ("[...] គឺនៅក្នុងឆ្នាំ១៩៧៧ ប៉ុន្តែនៅក្នុងខែណា ខ្ញុំមិនអាចកំណត់បានទេ") និង ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/346.1** ម៉ោងប្រហែល ១០.៥៧.៤៣ ("[...] ប៉ុន្តែថានៅក្នុងឃុំពាមជីកង ព្រឹត្តិការណ៍ដែលកើតឡើងគឺខ្ញុំដឹង គឺខ្ញុំជម្រាបតែនៅក្នុងឃុំពាមជីកង")។

[1635] ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/346.1** ចន្លោះម៉ោង ១០.៥៤.៥០ និង ១០.៥៧.៤៣ ("បាទ ហ្នឹងដូចខ្ញុំបានបញ្ជាក់ហើយថា ពីរបីរយនាក់ហ្នឹង អាហ្នឹងវានៅតាមភូមិ ក៏ប៉ុន្តែវាបូករួមនឹងបងប្អូនចាមដែលនៅចល័តទៀត វាអាចដល់ ៤០០ ឬ ៥០០ នាក់ ព្រោះអង្កាល់នុំង វាធម្មតា ឪពុកម្តាយ គឺរស់នៅដោយខ្លួនជាមួយនឹងក្មេងកុមារតូចៗ តែមនុស្សដែលពេញវ័យ គឺឈ្មមធ្វើការ គឺគេបានបញ្ជូនទៅការដ្ឋាន។ ដូច្នេះ ខ្ញុំនិយាយ ៤០០ ទៅ ៥០០ នេះ ខ្ញុំនិយាយពីប្រជាពលរដ្ឋចាមសរុបនៅក្នុងឃុំពាមជីកងហ្នឹង")។

[1636] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៩៣។

[1637] ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោងប្រហែល ១៤.០៤.៣៥ ("[...] កាន ហ្នឹងវាថាឱ្យទុកទៅម្នាក់នេះគ្មានទាក់ទងពីណាទេ វាៗដឹងថាខ្ញុំអត់មានទៅណា នៅក្នុងថ្នុកក្របីហ្នឹង ក្នុងបឹងហ្នឹង")។

"គេប្រមូលរបៀបហ្នឹងហើយ។ គេមិនចង់ឱ្យច្រឡំខ្មែរ បើសិនជាខ្មែរនៅក្នុងភូមិហ្នឹងដែរ ហ្នឹងវាកៀងចាមហ្នឹងវាច្រឡំខ្មែរ។ បាទ អ៊ីចឹងវាឱ្យខ្មែរទៅធ្វើការដើម្បីនៅតែចាម កុំឱ្យច្រឡំខ្មែរ និងចាមយកទៅសម្លាប់ជាមួយគ្នា។ រួចដល់ក្រោយមកទៀតហ្នឹង វាប្រមូលទាំងអស់អាដែងនៅពីក្រោយហ្នឹង ដែលថាឱ្យចេញផុតពីភូមិចាមឱ្យទៅនៅធ្វើការហ្នឹង ក្រោយមកអាហ្នឹងក៏ងាប់ដែរ ប្រមូលទៅទាំងអស់"[1638]។

៩០៤. ជាចុងក្រោយ សាក្សី សយ ខឿន សមាជិកក្រុមដាវវែង អស់រយៈពេលពីរខែនៅក្នុងឃុំពាមជីកង បាននិយាយថាគាត់បានចាប់ខ្លួនចាមនៅក្នុងភូមិសំបួរមាស "ក" របស់គាត់ នៅ "ចុង១៩៧៨"[1639]។ ដូច្នេះ បើតាមសាក្សីរូបនេះ ឧប្បត្តិហេតុនេះមិនមែនកើតឡើងនៅដើមឆ្នាំ១៩៧៧ទេ។ ពេលត្រូវចោទសួរដោយចៅក្រម FENZ និងក្រោយពីបានរារែកមួយសន្ទុះ[1640] គាត់ក៏ដាច់ចិត្តនិយាយថាគាត់បានចាប់មនុស្សពីរនាក់[1641]។

### ១.២.១.២. ការចាប់ខ្លួនទៅភូមិអង្គរបាន ២

[1638] ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោងប្រហែល ១១.២៥.១៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1639] ប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/374.1** ចន្លោះម៉ោង ១៥.២៦.៥៧ និង ១៥.៣០.៥១។

[1640] ប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/374.1** ចន្លោះម៉ោង ១៤.១៩.៤៦ និង ១៤.២២.៥៩៖ ("ខ្ញុំចង់សួរលោកបែបនេះថា តើប្រជាជននៅក្នុងភូមិរបស់លោកហ្នឹង តើលោកផ្ទាល់ចាប់ពួកអ្នកហ្នឹងប៉ុន្មាននាក់? ឆ៖ ភ្លេចអស់ហើយ។ ស៖ ជាថ្មីម្តងទៀត ខ្ញុំមិនរំពឹងឱ្យលោកប្រាប់ចំនួនពិតប្រាកដទេ ជាតួលេខច្បាស់នោះទេ ប៉ុន្តែ ដោយសារតែលោកធ្វើការតែពីរខែ នៅក្នុងក្រុមដាវវែង ហើយបានធ្វើការចាប់ខ្លួនហ្នឹងម្តងគត់ ហើយក៏អាចនឹងផ្តល់ការប៉ាន់ប្រមាណនូវចំនួនមនុស្សដែលលោកចាប់ខ្លួនដោយផ្ទាល់។ ឆ៖ ខ្ញុំភ្លេចអស់ហើយ អត់ចងចាំទេ")។

[1641] ប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/374.1** ចន្លោះម៉ោង ១៥.១០.00 និង ១៥.១៣.០២ ("ឆ៖ លោកបានឆ្លើយរួចមកហើយ ថាលោកមិនបានដឹងថាខ្លួនលោកផ្ទាល់នេះ បានចាប់ខ្លួនមនុស្សប៉ុន្មាននាក់ទេ។ ឥឡូវនេះ ខ្ញុំនិយាយពីក្រុមរបស់លោកដែលបានចុះទៅចាប់ខ្លួន និងប្រជាជនដែលត្រូវបានចាប់ខ្លួន។ ខ្ញុំព្យាយាមជាលើកចុងក្រោយ លោកសាក្សី។ ខ្ញុំឱ្យលេខនៃចំនួនបីទៅលោក គឺ ១០, ៥០, ឬ ១០០ នៃចំនួនប្រជាជនដែលបានចាប់។ នៅថ្ងៃនោះ តើលោកអាចប៉ាន់ប្រមាណចំនួនមនុស្សនេះ ដែលលោកនិងក្រុមរបស់លោកដែលបានចុះទៅចាប់ខ្លួនហ្នឹង ថាមានចំនួនប៉ុន្មាននាក់បានទេ ឬក៏លោកមិនអាច? ឆ៖ អត់ដឹងទេ ភ្លេចភ្លាំងអស់។ បានពីរនាក់ហ្នឹង។ ស៖ តើក្រុមរបស់លោកចាប់បានតែពីរនាក់ទេឬ? ឆ៖ ចាប់បានតែពីរនាក់")។

៩០៥. សេង គុយ បាននិយាយថាបានឃើញជនជាតិចាមនៅក្នុងភូមិរបស់គាត់ ត្រូវគេចាប់ខ្លួននៅឆ្នាំ១៩៧៧។ គាត់បានឮប្រធានសន្តិសុខឃុំស្តីបន្ទោសជនជាតិចាម តែសក្ខីកម្មរបស់គាត់មិនបានបំភ្លឺពីមូលហេតុនៃការចាប់ខ្លួនទេ[1642]។ ដូច្នេះ សក្ខីកម្មរបស់សាក្សីតែប៉ុន្មាននាក់នេះ ដែលបានឃើញការចាប់ខ្លួនដោយផ្ទាល់នៅក្នុងឆ្នាំ១៩៧៧ មិនអាចឱ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានបានថា ជនជាតិចាមត្រូវបានចាប់ខ្លួនដោយសារតែជាចាមនោះទេ។ អង្គជំនុំជម្រះបាននិយាយរួមជាទូទៅ ហើយដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជម្រះ ត្រូវទុកជាមោឃៈទាក់ទងនឹងចំណុចនេះ។

### ១.២.២. ភ័ស្តុតាងមិនគ្រប់គ្រាន់ទាក់ទងនឹងវត្តមានជនជាតិចាម និងការសម្លាប់ពួកគេនៅក្នុងវត្តអូរត្រកួន

៩០៦. អង្គជំនុំជម្រះក៏បានសន្និដ្ឋានដោយមិនត្រឹមត្រូវផងដែរថា មនុស្សជាច្រើននាក់ ដែលក្នុងនោះ **ភាគច្រើន** ជាជនជាតិចាមមកពីស្រុកកងមាស ត្រូវបានសម្លាប់នៅវត្តអូរត្រកួន នៅក្នុងឆ្នាំ១៩៧៧ ខណៈដែលភ័ស្តុតាងបង្ហាញថា ក៏មានដែរជនជាតិខ្មែរ ហើយការកំណត់អត្តសញ្ញាណជនជាតិចាម ទោះជាដោយសាក្សី មុយ វ៉ាន់នី ឬក៏ ស ឈាង ក្តី ក៏ពុំរឹងមាំដែរ[1643]។

៩០៧. ការអះអាងដែលថា "ការសម្លាប់នៅវត្តអូរត្រកួន ត្រូវបានបញ្ជាក់បន្ថែមដោយសមាជិកកងសន្តិសុខ" គឺពុំត្រឹមត្រូវទេ[1644]។ មានតែដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ម្នាក់គត់ដែលបាននិយាយថាបានស្តាប់ឮពីកន្លែងគាត់ពួននៅក្នុងគុម្ពោតព្រៃ ពីការសម្លាប់ជនជាតិចាម ដែលគាត់មិនដែលនិយាយថាវាស្ថិតនៅវត្តអូរត្រកួនទេ តែគឺនៅក្នុងភូមិសាច់សូផ្ទាល់តែម្តង[1645] និងជាងពីរខែ មុននឹងគាត់ជួបជាមួយ កាន និង

---

[1642] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៩៦។

[1643] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦។

[1644] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៩៧។

[1645] ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោងប្រហែល ១១.២៩.១៧ ("ខ្ញុំប្រាប់កន្លែងហ្នឹង ហើយដល់ពេលយប់ បាទខ្ញុំប្រាប់ទាល់តែយប់ យប់ទៅងងឹតមិនដឹងម៉ោងប៉ុន្មាន ប្រហែលជាម៉ោងប្រាំពីរអីហ្នឹង ងងឹត វាវៃពួកជនជាតិ ម៉េចក៏ខ្ញុំនៅនេះ ខ្ញុំដឹង វានៅក្បែរវណ្ណេប្រហែលជា ១០០ ម៉ែត្រហ្នឹងបាទ។ ម៉េចក៏ខ្ញុំដឹងបើនៅដល់ ១០០ម៉ែត្រ? បានជាដឹងឮសម្រែក [...]"), ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោងប្រហែល ១១.២៥.១៨ ("មានអី អាក្រៅភូមិសុទ្ធតែកាំភ្លើង បានក្រាបនៅគុម្ពោតព្រៃ។ ត្រឹមគុម្ពោតព្រៃហ្នឹងគុម្ពោតព្រៃហ្នឹង សំណាងល្អដែរ វាបានមើលខ្ញុំមិនឃើញបាទ មើលខ្ញុំមិនឃើញ [...]")។

ឈ្លបដាវវែង[1646]។ ដូច្នេះ សក្ខីកម្មរបស់កងកម្លាំងសន្តិសុខនៅវត្តអូរត្រកួន មិនអាចបញ្ជាក់បន្ថែមលើសក្ខីកម្មរបស់គាត់បានទេ ព្រោះសក្ខីកម្មទាំងនោះលើកឡើងពីអង្គហេតុផ្សេង។

៩០៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានអះអាងដោយពុំត្រឹមត្រូវថា "ភាគច្រើននៃអ្នកដែលត្រូវបាននាំទៅវត្តអូរត្រកួន គឺជាជនជាតិចាម" ស្របទៅតាមសក្ខីកម្មរបស់ មុយ វ៉ាន់នី ដែលផ្អែកតែទៅលើការឮតគ្នា[1647]។ ទោះយ៉ាងណាក៏ដោយ សាក្សីជាច្រើននាក់បាននិយាយថា ការចាប់ខ្លួនគឺពាក់ព័ន្ធមនុស្សគ្រប់គ្នា។ សំរិត មុនី បាននិយាយថាគាត់បានឃើញចាម និងខ្មែរត្រូវគេនាំយកពីសហករណ៍សំបួរមាស ទៅវត្តអូរត្រកួនដែលវាធ្វើឱ្យគេមានមន្ទិលលើចរិតជាក់លាក់នៃការចាប់ខ្លួន និងការសម្លាប់ដែលរងការចោទប្រកាន់។ គាត់បាននិយាយដូច្នេះថា៖ "[...] ក្រោយពីឆ្នាំ៧៧ មកដល់៧៩ បានបន្តរហូតសម្លាប់ហ្នឹង មិនមែនត្រឹមតែបងប្អូនអ៊ីស្លាមមួយទេអស់លោក និយាយពីប្រជាជនអ៊ីស្លាមចប់រួចស្រេចស្រួលបួល និយាយពីខ្មែរប៉ុនណាក៏មានដែរលោក"[1648]។

៩០៩. ពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយដែល "បញ្ជាក់បន្ថែម" ពីការកាប់សម្លាប់ជនជាតិចាមនៅវត្តអូរត្រកួន គេគួរកត់សម្គាល់ថា ដោយសារតែពុំមានការផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ និងលទ្ធភាពក្នុងការសួរដេញដោលសាក្សី ដូច្នេះតម្លៃជាភ័ស្តុតាងរបស់វាមានតិចតួចបំផុត។ ស ឈាង ដែលត្រូវ

---

ហ៊ឹម ម៉ាន មិនបាននិយាយពីឈ្លបដាវវែងទេ ព្រោះគាត់ពិពណ៌នាអំពីអ្នកវាយលុកដែលមានកាំភ្លើង៖ ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោងប្រហែល ១១.២៥.១៨ ("[...] មើលទៅឃើញខ្មៅសុទ្ធតែកាំភ្លើងអាកា បាទខ្មៅ។ ដល់ថាអ្នំ! មិនដឹងលោកណាទេ ខ្ញុំមិនដឹង [...]")។

[1646] គួររំឭកថា ហ៊ឹម ម៉ាន និយាយថាបានជួបកាន ក្រោយពីបាននៅ"ក្នុងទឹកប្រាំបីថ្ងៃ" និង "បីខែ ម្ភៃប្រាំបួនថ្ងៃ" "ក្នុងបឹង"៖ ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ចន្លោះម៉ោង ១៣.៤៥.៤៣ និង ១៣.៤៨.២៣, ម៉ោងប្រហែល ១៣.៤៨.២៣, ១៣.៥៥.១៤។

[1647] ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/373.1** ម៉ោងប្រហែល ១៣.៥៣.១៥ ("ស៖ ក្នុងចំណោមអ្នកដែលគេបញ្ជូនមកវត្តអូរត្រកួនហ្នឹង លោកដឹងយ៉ាងម៉េចបានថា មានជនជាតិចាមនោះ? ព្រោះអម្បាញ់មិញនេះ លោកថាលោកមានឃើញជនជាតិចាម ត្រូវបានគេនាំមកវត្ត។ អ៊ីចឹងលោក តើលោកឃើញផ្ទាល់ភ្នែក ឬក៏លោកបានដឹងរឿងនេះពីអ្នកផ្សេង ដែលអ្នកនោះគឺជាជនជាតិចាម? ឆ៖ <u>គេនិយាយ ឮគេនិយាយថា ដែលគេប្រមូល មានផែនការមួយប្រមូលចាមហ្នឹង។ ឮគេនិយាយអ៊ីចឹង ខ្ញុំមិនដឹងដែរ</u>") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1648] ប្រតិចារឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/347.1** ម៉ោងប្រហែល ១៦.០១.២៣។

បានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត មិនបានពន្យល់ថាហេតុដូចម្តេចបានជាគាត់ដឹងថា អ្នកទោសទាំង ២០ នាក់ ដែលគាត់និយាយថាបានឃើញ គឺជាជនជាតិចាម និងថាតើគាត់កំណត់ប្រភពដើមរបស់មនុស្សពី ៥០ ទៅ ១០០ នាក់ ដែលត្រូវគេនាំទៅឃុំខ្លួននៅមន្ទីរសន្តិសុខ ជារៀងរាល់ថ្ងៃ បានដោយរបៀបណា[1649]។ ដូចគ្នាដែរសម្រាប់កំណត់ហេតុស្តាប់ចម្លើយរបស់ ថុង គឹមឃុន ដែលនិយាយថាគាត់បានឃើញចាម ៥០០ នាក់ ត្រូវបានគេបណ្តើរពីកាណូតឆ្ពោះទៅកាន់វត្ត[1650]។

៩១០. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានដោយមិនសមហេតុសមផលថាមាន "ភ័ស្តុតាងផ្ទាល់" បង្ហាញពី "ប្រជាជនចាមត្រូវបានចាប់ចង និងឃុំឃាំងនៅវត្ត មុនពេលត្រូវបាននាំយកទៅជាក្រុម"[1651]។ ភ័ស្តុតាងទេសកាលទាំងនេះ មិនត្រូវបានបង្ហាញទេ និងមិនគ្រប់គ្រាន់សម្រាប់បង្ហាញឱ្យឃើញពីអត្ថិភាពនៃការសម្លាប់ជនជាតិចាម ឱ្យហួសពីវិមតិសង្ស័យបានទេ។ ដូច្នេះ ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតលើជនជាតិចាម មិនត្រូវបានបំពេញ ក្នុងកម្រិតភ័ស្តុតាងតម្រូវ ទាក់ទងនឹងជនរងគ្រោះនៅវត្តអូរត្រកួនទេ[1652]។

## ២. ការសម្លាប់រង្គាល

### ២.១. សេចក្តីសន្និដ្ឋានមិនសមហេតុផលអំពីតួលេខនៃការសម្លាប់ដែលបានបង្ហាញ

៩១១. ដោយរំឭកឡើងវិញអំពីសេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការធ្វើមនុស្សឃាត ពាក់ព័ន្ធនឹងការសម្លាប់នៅវត្តអូរត្រកួន និងនៅភូមិទ្រា[1653] អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបាននិយាយសរុបជាទូទៅ និងដោយបានស្មានលើចំនួនជនរងគ្រោះ[1654]។ ដូចដែលបានឃើញពីខាងលើ អង្គជំនុំជម្រះមិន

---

[1649] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០០។

[1650] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០០។

[1651] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០២។

[1652] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦។

[1653] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១១។

[1654] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១១។

បានបង្ហាញឱ្យឃើញក្នុងកម្រិតតម្រូវអំពីការចោទប្រកាន់ពីការសម្លាប់នៅទីកន្លែងទាំងពីរនេះទេ[1655]។ ដូច្នេះ សេចក្ដីសន្និដ្ឋានមិនច្បាស់លាស់នេះ ត្រូវទុកជាមោឃៈ។ ហេតុដូច្នេះ ធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល មិនត្រូវបានបំពេញទេ។

## ២.២. សេចក្ដីសន្និដ្ឋានមិនសមហេតុផលអំពីចេតនាសម្លាប់ជនជាតិចាមក្នុងទ្រង់ទ្រាយធំ

៩១២. អង្គជំនុំជម្រះបានសំអាងល័ក្ខខ័ណ្ឌតម្រូវនៃចេតនាសម្លាប់ជនជាតិចាម ជាទ្រង់ទ្រាយធំ ទាក់ទងនឹងការសម្លាប់ដែលរងការចោទប្រកាន់ លើជនជាតិចាមនៅវត្តអូរត្រកួន និងនៅភូមិទ្រា លើអត្ថិភាពនៃបទបញ្ជា និងការប្រជុំរបស់ ប.ក.ក សំដៅកំណត់អត្តសញ្ញាណ និងចាប់ខ្លួនខ្មាំង រួមទាំងជនជាតិចាមផងដែរ[1656]។ ជាអាទិ៍ អង្គជំនុំជម្រះបានយោងក្នុងកំណត់សម្គាល់ជើងទំព័រ ទៅលើកថាខណ្ឌ ៣២៧៥ និង ៣២៨១ ដើម្បីគាំទ្រថាមានបទបញ្ជាឱ្យធ្វើការបោសសម្អាតជនជាតិចាមទាំងអស់។ ប៉ុន្តែ ភ័ស្តុតាងដែលត្រូវបានបង្ហាញដើម្បីគាំទ្រសេចក្ដីសន្និដ្ឋាននៅក្នុងកថាខណ្ឌ ៣២៧៥ មិនអាចឱ្យសន្និដ្ឋានបានថា កែ ពក បានបញ្ជាបែបនេះនៅក្នុងពេលប្រជុំបានទេ (២.២.១)។ ចំណែកឯកថាខណ្ឌ ៣២៨១ វិញ គឺលើកឡើងពីការសម្លាប់ជនជាតិចាមដែលរងការចោទប្រកាន់ នៅភូមិទ្រា ដូចដែលបង្ហាញឱ្យឃើញតាមរយៈសក្ខីកម្មរបស់សាក្សីពីររូប និងដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប ដែលគេបានឃើញរួចមកហើយពីខាងលើថា សក្ខីកម្មទាំងអស់នេះមិនគ្រប់គ្រាន់សម្រាប់គាំទ្រសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះនោះទេ[1657]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមិនបានផ្ដល់សំអាងហេតុចំពោះសេចក្ដីសន្និដ្ឋាននេះនៅក្នុងការកំណត់បទចោទប្រកាន់ និងមិនបានផ្ដល់ការយោងត្រឹមត្រូវ ដើម្បីគាំទ្រថាមានបទបញ្ជា និងការប្រជុំរបស់ ប.ក.ក ទាក់ទងនឹងភូមិភាគកណ្ដាលទេ[1658]។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ក៏មិនសមហេតុសមផលដែរ បើយោងតាមភ័ស្តុតាង (២.២.២)។

---

[1655] សូមមើលខាងលើ កថាខណ្ឌ ៨៩៥-៩១០។

[1656] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១៣។

[1657] សូមមើលខាងលើ កថាខណ្ឌ ៨៩៥-៨៩៨។

[1658] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១៣។

### ២.២.១. គ្មានភ័ស្តុតាងអំពីបទបញ្ជារបស់ កែ ពក ឱ្យកម្ទេចជនជាតិចាម

៩១៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយយល់ឃើញថាមានការបង្ហាញឱ្យឃើញថា កិច្ចប្រជុំមួយរវាងមេដឹកនាំភូមិភាគបូព៌ា បានប្រព្រឹត្តទៅនៅកំពង់ថ្ម ដែលនៅពេលនោះ កែ ពក បានឱ្យ បាន សៀក កម្ទេចចាមឱ្យអស់[1659]។ ពុំមានភ័ស្តុតាងក្នុងម្រិតតម្រូវស្តីពីអត្ថិភាពនៃបទបញ្ជានេះទេ។ សេចក្តីសន្និដ្ឋាននេះ គឺជាការស្មានរបស់អង្គជំនុំជម្រះ ដែលផ្អែកលើការបំភ្លៃសក្ខីកម្មរបស់ វ៉ាន់ ម៉ាត់ ដែលគាត់បានលើកឡើងពីកិច្ចប្រជុំរបស់អ្នកទទួលខុសត្រូវភូមិភាគបូព៌ា ដែលការប្រជុំនោះដឹកនាំដោយ កែ ពក និងនិយាយពីការកម្ទេចខ្មាំង បន្ទាប់មក គឺការបោសសម្អាតជនជាតិចាមដែលត្រូវធ្វើក្នុងភូមិជំនីក[1660]។

៩១៤. ក៏ប៉ុន្តែ វ៉ាន់ ម៉ាត់ និយាយថាបានឮគេពិភាក្សាគ្នាពីគោលនយោបាយកម្ទេច "ឱ្យអស់នៅភូមិភាគបូព៌ាហ្នឹង កុំថាតែចាម ខ្មែរចល័តអីមក កម្ទេចអស់ ព្រោះខាងនោះ វាពួកក្បត់អង្គការ"[1661]។ម្យ៉ាងទៀត គាត់បានបញ្ជាក់អះអាងថា ពុំមានការលើកឡើងពីផែនការសំដៅជាពិសេសចំពោះជនជាតិចាមនោះទេ[1662]។ សក្ខីកម្មរបស់គាត់ស៊ីចង្វាក់គ្នាជាមួយនឹងសក្ខីកម្មរបស់ បាន សៀក ដែលភ័ស្តុតាងដោះបន្ទុករបស់គាត់ គឺមិនអាចត្រូវបដិសេធ ដោយហេតុផលថាគាត់ប៉ុនប៉ងបន្ថយតួនាទីរបស់ខ្លួននោះទេ ខណៈដែល វ៉ាន់ ម៉ាត់ និយាយដូចគ្នានឹងគាត់ដែរ[1663]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើភ័ស្តុតាងទាំងនេះដើម្បីសន្និដ្ឋានថាមានបញ្ជាពី កែ ពក សំដៅលើជនជាតិចាម។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

### ២.២.២. គ្មានភ័ស្តុតាងអំពីបទបញ្ជាពីថ្នាក់ភូមិភាគ នៅភូមិភាគកណ្តាល

---

[1659] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៧៥។

[1660] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៧៤។

[1661] ប្រតិចារឹក ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/398.1** ម៉ោងប្រហែល ១០.៤៤.៣៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1662] ប្រតិចារឹក ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/398.1** ម៉ោងប្រហែល ១៣.៤០.០៥។

[1663] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៧៣។

៩១៥. នៅក្នុងក្របខ័ណ្ឌនៃការកំណត់បទចោទប្រកាន់ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាមានបទបញ្ជាពីថ្នាក់លើឱ្យកំណត់គោលដៅលើជនជាតិចាមនៅក្នុងភូមិភាគកណ្តាល[1664]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានផ្តល់ការយោងណាមួយដែលមានសុពលភាពសម្រាប់គាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនឡើយ។

### *២.២.២.១. ភ័ស្តុតាងទាក់ទងនឹងស្រុកកំពង់សៀម*

៩១៦. អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ ប្រាក់ យុត លេខាស្រុកកំពង់សៀម ដែលបានបញ្ជាក់ថា ថ្នាក់លើបានបញ្ជាឱ្យបោសសម្អាតជនជាតិចាមនៅក្នុងតំបន់ ៤១[1665]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានពន្យល់ថាតើផ្នែកនេះនៃចម្លើយរបស់កម្មាភិបាលម្នាក់ ដែលអង្គជំនុំជម្រះយល់ថា មានបំណងចង់បន្ធូរបន្ថយការទទួលខុសត្រូវរបស់ខ្លួន អាចជឿជាក់បានដោយរបៀបណា[1666]។ ផ្ទុយទៅវិញ ភ័ស្តុតាងផ្សេងៗទៀតមិនអាចបញ្ជាក់បន្ថែមលើសក្ខីកម្មរបស់ ប្រាក់ យុត ត្រង់ចំណុចនេះបានទេ។

៩១៧. សេង ស្រ៊ុន និយាយថាបានចូលរួមក្នុងកិច្ចប្រជុំមួយនៅវត្តអូរត្រកួន ដែលកោះហៅដោយ អោ អាន។ ដូចដែលអង្គជំនុំជម្រះត្រូវបង្ខំចិត្តទទួលស្គាល់ សេង ស្រ៊ុន បាននិយាយថាជនជាតិចាមមិនត្រូវបានលើកមកពិភាក្សាក្នុងកិច្ចប្រជុំនេះទេ[1667]។ ក៏ប៉ុន្តែ ភ័ស្តុតាងដោះបន្ទុកមួយនេះត្រូវបានដកចេញដោយពុំត្រឹមត្រូវ ហើយគឺមានតែការសន្និដ្ឋានរបស់សាក្សីប៉ុណ្ណោះ ដែលថាជនជាតិចាមត្រូវបានចាត់ទុកជាខ្មាំងរបស់របប ប៉ុល ពត ដែលត្រូវបានជ្រើសរើសយកដោយអង្គជំនុំជម្រះ[1668]។ វិធីសាស្ត្រដូចគ្នាត្រូវបានប្រើប្រាស់សម្រាប់ យូ វ៉ាន់ ដែលត្រូវបានសន្និតថាជួយបញ្ជាក់បន្ថែមអំពីអត្ថិភាពនៃបទបញ្ជាដែលបានដាក់ចុះ។ យូ វ៉ាន់ បាននិយាយថាបានចូលរួមធ្វើបញ្ជី ដែលក្នុងនោះមានឈ្មោះ "ទាហាននៃរបបសីហនុ

---

[1664] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៧ កំណត់សម្គាល់ជើងទំព័រលេខ១១២២៤ យោងទៅ កថាខណ្ឌ ៣២៩០។

[1665] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៩០។

[1666] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៩១។

[1667] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៦ កំណត់សម្គាល់ជើងទំព័រលេខ១១១៣៦៖ "ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ (សេង ស្រ៊ុន) ឯកសារ E1/346.1 ទំព័រ ៧៨-៧៩"។

[1668] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៦។

ប្រជាជនចាម និងប្រជាជនវៀតណាម” ក្នុងស្រុកកំពង់សៀម[1669]។ វាមិនត្រឹមតែពុំមែនជាបញ្ជីដាក់លាក់សម្រាប់ប្រជាជនចាមទេ តែអង្គជំនុំជម្រះថែមទាំងពុំបានពន្យល់ ថាតើបញ្ជីនេះបង្ហាញអំពីអត្ថិភាពនៃការប្រជុំដែលនៅពេលនោះ ប្រាក់ យុត បានទទួលបញ្ជាឱ្យសម្លាប់ជនជាតិចាមបានដោយរបៀបណាទៅ។

៩១៨. លើសពីនេះទៀត អង្គជំនុំជម្រះបានកត់សម្គាល់ថា គេមិនអាចបង្ហាញបានថាតើការណែនាំរបស់ ប្រាក់ យុត ប្រាប់ទៅ យូ វ៉ាន់ ឱ្យធ្វើបញ្ជី កើតឡើងមុន ឬក្រោយការប្រជុំនៅព្រៃទទឹង[1670]។ ដូច យូ វ៉ាន់ បានបញ្ជាក់ ការណែនាំរបស់ អោ អាន កម្រិតត្រឹម “មនុស្សដែលជាប់ និងមានការទាក់ទងជាមួយជនជាតិទាំងនោះ” ដែលត្រូវតែ “បោសសម្អាត” ដែលជាពាក្យមួយគួរយល់ក្នុងន័យចង្អៀតនៃការធ្វើបញ្ជី[1671]។

## ២.២.២.២. ភស្តុតាងទាក់ទងនឹងស្រុកសន្ទុក

៩១៩. យាន លន់ ជាឈ្លបឃុំកំពង់ថ្ម ស្រុកសន្ទុក ដែលសក្ខីកម្មរបស់គាត់ត្រូវបានប្រើដោយអង្គជំនុំជម្រះ គឺពុំបានដឹងរឿងនេះទេ។ ការលើកឡើងរបស់គាត់ពី “បញ្ជាឱ្យចាប់នោះគឺពីថ្នាក់ៗតំបន់ ថ្នាក់ខេត្ត” គឺជាការឮតពីគេ និងជាការសន្និដ្ឋាន[1672]។ ខ្លួនគាត់ផ្ទាល់មិនបានចូលរួមក្នុងកិច្ចប្រជុំណាមួយទេ។ ដូច្នេះ អង្គជំនុំជម្រះមានកំហុស ដោយបានទាញសេចក្ដីសន្និដ្ឋានចេញពីសក្ខីកម្មរបស់គាត់។

## ២.២.២.៣. ភស្តុតាងទាក់ទងនឹងស្រុកកងមាស

៩២០. អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ សយ ឌឿន ជាឈ្លបដាវវែង នៅក្នុងឃុំពាមជីកង ដែលបាននិយាយថាបញ្ជាឱ្យចាប់ជនជាតិចាមគឺចេញមកពីភាព ជាប្រធានឃុំ ដែលគាត់អាចទទួលបញ្ជាបន្តពី

---

[1669] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៧។

[1670] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៨ កំណត់សម្គាល់ជើងទំព័រលេខ១១១៤៨។

[1671] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៨។

[1672] ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/317.1** ប្រហែលម៉ោង ១៤.០៩.០២៖ (“គាត់ប្រធានឃុំ ដល់ទៅរៀនមក គេយកមកអនុវត្តប្រាប់មកពីរៀន ពីខេត្តទៅ”)។

កាន[1673]។ ក៏ប៉ុន្តែ សយ ឌឿន ខ្លួនឯងបានបញ្ជាក់ថាគាត់មិនមានវត្តមាននៅក្នុងកិច្ចប្រជុំរវាង ភាព និង កាន ទេ ដោយគាត់បាននិយាយថា៖ “គាត់ប្រជុំគ្នា ខ្ញុំអត់ដឹងដែរ”[1674]។ ដូច្នេះ ចម្លើយរបស់គាត់ទាក់ទងនឹងប្រភពនៃបទបញ្ជាឱ្យចាប់ប្រជាជនចាម គឺជាការស្មាន។

៩២១. ម្យ៉ាងវិញទៀត សយ ឌឿន មានភាពមិនច្បាស់លាស់ខ្លាំងនៅក្នុងសម្ដីដែលគាត់បានឮ។ បើទោះបីជាគាត់បានអះអាងថាបានឮ ភាព និយាយពី “[ផែនការ] ថាមិនឱ្យទុក [ចាម] មួយទេ” ក៏ដោយ ក៏ពេលគេចោទសួរគាត់ទាក់ទងនឹងសម្ដីពិតប្រាកដដែល ភាព បាននិយាយពាក់ព័ន្ធនឹងផែនការនេះ គាត់បានត្រឹមឆ្លើយថា “ខ្ញុំភ្លេចអស់ហើយ”[1675]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចមានហេតុផលត្រឹមត្រូវសំអាងលើការឮគេនិយាយតគ្នាមិនច្បាស់លាស់នេះ ដើម្បីធ្វើការសន្និដ្ឋានទាក់ទងនឹងប្រភពនៃបទបញ្ជាថ្នាក់លើបានទេ។

៩២២. ដូចគ្នានេះដែរ ការដែល សយ ឌឿន បានឃើញនៅថ្នាក់ឃុំ នូវបញ្ជីឈ្មោះជនជាតិចាមដែលគាត់នឹងត្រូវទៅចាប់ខ្លួនជាមួយនឹងឈ្លបដាវវែង គឺគ្រាន់តែជាការបង្ហាញឱ្យឃើញអំពីអត្ថិភាពនៃការអនុវត្តការធ្វើបញ្ជីមុននឹងមានការចាប់ខ្លួន នៅពាមជីកង ប៉ុណ្ណោះ[1676]។ ផ្ទុយទៅវិញ សក្ខីកម្មរបស់គាត់ ពុំបានផ្ដល់ព័ត៌មានទាក់ទងនឹងមូលហេតុនៃការចាប់ខ្លួន ឬទាក់ទងនឹងអត្ថិភាពនៃបទបញ្ជារបស់ថ្នាក់នៅពីលើឃុំនោះទេ។

៩២៣. ជាចុងក្រោយ សាក្សី សំរិត មុយ បាននិយាយថាគាត់បានចូលរួមប្រជុំ នៅភូមិដំណាក់ស្វាយ ដែលដឹកនាំប្រជុំដោយ កាន ហើយពេលនោះ ប្រធានបទនៃសុន្ទរកថាគឺប្រាប់ប្រជាជនឲ្យគោរពអង្គការ[1677]។ គាត់ពុំបានរាយការណ៍ពីពាក្យពេចន៍ណាមួយទាក់ទងនឹងជនជាតិចាមទេ។ ដូច្នេះ ការប្រៀបធៀបរវាង

---

[1673] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៥។

[1674] ប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/374.1** ប្រហែលម៉ោង ១៤.៣៣.២៦។

[1675] ប្រតិចារឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/374.1** ចន្លោះម៉ោង ១៤.០៦.៣៥ និង ១៤.១០.១៥។

[1676] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៩។

[1677] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៨៦។

កិច្ចប្រជុំនេះជាមួយនឹងការចាប់ខ្លួនប្រជាជនចាម គឺជាការស្មានរបស់គាត់ប៉ុណ្ណោះ។ អង្គជំនុំជម្រះមានកំហុស ដោយបានផ្អែកលើការនិយាយសរុបជាទូទៅបែបនេះ។

៩២៤. ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងអត្ថិភាពនៃបទបញ្ជាឱ្យសម្លាប់ប្រជាជនចាមជាច្រើន គឺផ្អែកលើសក្ខីកម្មទន់ខ្សោយ និងមិនច្បាស់លាស់។ កង្វះភស្តុតាង ទាំងផ្ទាល់ និងមិនផ្ទាល់ មិនអាចឱ្យអង្គជំនុំជម្រះបង្ហាញឱ្យឃើញក្នុងកម្រិតតម្រូវអំពីអត្ថិភាពនៃចេតនាចាំបាច់ សម្រាប់កំណត់ជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការសម្លាប់រង្គាលបានទេ ហើយដូច្នេះ អង្គជំនុំជម្រះមិនអាចយល់ថាឧក្រិដ្ឋកម្មនេះត្រូវបានបង្ហាញ ពាក់ព័ន្ធនឹងការសម្លាប់នៅវត្តអូរត្រកួន និងនៅភូមិទ្រា បាននោះទេ។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ[1678]។

### ៣. ការធ្វើទារុណកម្ម

៩២៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយយល់ថាការវាយដំលើ អ៊ីត សេន និងបុរស១ជនជាតិចាមនៅមន្ទីរសន្តិសុខភូមិទ្រា នៅថ្ងៃចាប់ខ្លួន អ៊ីត សេន ក្នុងឆ្នាំ១៩៧៨ គឺធ្វើឡើងដើម្បីបង្ហាញឱ្យឃើញថាតើអ្នកជាប់ឃុំទាំងអស់ជាសមាជិកក្រុមចាមពិតមែន ឬយ៉ាងណា[1679]។ ជាបឋម អង្គជំនុំជម្រះផ្អែកតែទៅលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ីត សេន ដែលមិនមានការបញ្ជាក់បន្ថែម និងដែលមិនអាចឱ្យបង្ហាញឱ្យឃើញពីធាតុផ្សំសត្យានុម័តិនៃការធ្វើទារុណកម្ម ឱ្យហួសពីវិមតិសង្ស័យបានទេ[1680]។ លើសពីនេះទៀត សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះគឺផ្ទុយគ្នា ព្រោះថា អ៊ីត សេន បានបញ្ជាក់ថា ការវាយដំនេះគឺដើម្បីបង្ហាញឱ្យឃើញថាតើអ្នកជាប់ឃុំជាសមាជិកក្រុមចាមមែនដែរ ឬយ៉ាងណា ខណៈដែលអ្នកវាយដំបានដឹងរួចទៅហើយថាពួកគេជាសមាជិកក្រុមចាមពិតប្រាកដមែន[1681]

[1678] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១៣។

[1679] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១៨។

[1680] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១៧ កំណត់សម្គាល់ជើងទំព័រលេខ១១២៣៨ យោងទៅ កថាខណ្ឌ ៣២៧៦។

[1681] ប្រតិចារឹក ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/342.1** ចន្លោះម៉ោង ១៤.៣៧.១៥ និង ១៤.៣៩.២៨ ("វាដឹងថាចាមហើយ [...]")។

។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្អែកតែលើចម្លើយទាំងនេះដើម្បីយល់ថា ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មត្រូវបានបង្ហាញ[1682]។ សេចក្តីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ។

## ៤. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

### ៤.១. គ្មានការរើសអើងជាក់ស្តែងចំពោះជនជាតិចាម ក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទីពីរ

៩២៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសម្រេចថាការផ្លាស់ទីលំនៅប្រជាជនចាម នៅក្នុងក្របខ័ណ្ឌនៃការផ្លាស់ទីលំទ្រង់ទ្រាយធំនៃប្រជាជនពីភូមិភាគបូព៌ាទៅកាន់ភូមិភាគកណ្តាល អាចត្រូវកំណត់ថាជាការរើសអើង[1683]។ ប៉ុន្តែ អង្គជំនុំជម្រះបានកត់សម្គាល់ដោយត្រឹមត្រូវថា "ការបំបែកនេះគឺជាផ្នែកមួយនៃការផ្លាស់ទីលំនៅប្រជាជនក្នុងក្របខ័ណ្ឌទូលំទូលាយពីភូមិភាគបូព៌ាទៅកាន់ភូមិភាគកណ្តាល (ឧត្តរចាស់) ដែលមានបំណងបែងចែកប្រជាពលរដ្ឋនៅទូទាំងប្រទេសកម្ពុជា"[1684]។ អង្គជំនុំជម្រះបានរំឭកដោយត្រឹមត្រូវផងដែរពីសេចក្តីសន្និដ្ឋានរបស់តុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ ទាក់ទងនឹងការចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ សំដៅចំពោះប្រជាជនថ្មី[1685]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនបានអនុវត្តការពិសោធជ្រើសរើសដោយតុលាការកំពូល ដែលយោងតាមការពិសោធនោះ៖

> "ដើម្បីបង្ហាញអំពីការធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មីដូចមាននៅក្នុងសំណុំរឿងបច្ចុប្បន្ន <u>ចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ការផ្លាស់ទីលំនៅប្រជាជនបានធ្វើឱ្យប៉ះពាល់យ៉ាងហោចណាស់ ជា</u>

[1682] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣១៨-៣៣១៩។

[1683] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៦៨, ៣៣២២។

[1684] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៦៨។ សូមមើលផងដែរ កថាខណ្ឌ ៣៣២២។

[1685] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២១។

ចម្បង ឬតែប្រជាជនថ្មីប៉ុណ្ណោះ ដូច្នេះ គឺជាការរើសអើង ឬថា នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ប្រជាជនថ្មីបានទទួលរងការប្រព្រឹត្តិខុសប្លែកពីប្រជាជនចាស់"[1686]។

៩២៧. អនុវត្តតាមការពិសោធនេះ តុលាការកំពូលបានទាត់ចោលសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដោយវិនិច្ឆ័យថា "ដោយសារការផ្លាស់ទីលំនៅនេះបានប៉ះពាល់មិនត្រឹមតែប្រជាជនថ្មី ដូច្នេះពុំអាចនិយាយបានថា ជាការរើសអើងជាក់ស្ដែង ឬបង្ហាញពីចេតនារើសអើងឡើយ"[1687]។ ការអនុវត្តការពិសោធនេះចំពោះអង្គហេតុជាក់ស្ដែងឥឡូវនេះ គួរនាំឱ្យអង្គជំនុំជម្រះសន្និដ្ឋានថាការផ្លាស់ទីលំនៅប្រជាជនចាម ពុំមែនជាការរើសអើងទេ ព្រោះថាវាមិនកម្រិតត្រឹមតែជនជាតិចាមនោះទេ និងគួរនាំឱ្យសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថាមានការប្រព្រឹត្តិខុសគ្នាចំពោះជនជាតិចាម នៅក្នុងក្របខ័ណ្ឌនៃការផ្លាស់ទីលំនៅប្រជាជន ក្លាយជាមោឃៈ។ ដូច្នេះ អង្គជំនុំជម្រះមានកំហុស ដោយយល់ថាធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះជនជាតិចាម ត្រូវបានបំពេញ ហើយសេចក្ដីសន្និដ្ឋានទាំងឡាយរបស់អង្គជំនុំជម្រះ ក្នុងន័យនេះ ត្រូវទុកជាមោឃៈ[1688]។

## ៤.២. កំហុសពាក់ព័ន្ធនឹងគោលបំណងចម្បងនៃការជម្លៀសប្រជាជន

៩២៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានកំណត់ថាមានចេតនារើសអើងចំពោះជនជាតិចាមនៅភូមិភាគបូព៌ា ដោយសារតែការបះបោរ និងដោយបានសន្និដ្ឋានថា "ជនជាតិចាមត្រូវបានគេបំបែក គឺដើម្បីឱ្យសហគមន៍របស់ពួកគេបែកបាក់" ដែលធ្វើឱ្យគោលបំណងនេះធំជាងគោលបំណងផ្សេងទៀត[1689]។ នៅត្រង់កថាខណ្ឌ ៣២៦៨ អង្គជំនុំជម្រះសន្និដ្ឋានថា មានការបង្ហាញថាជនជាតិចាមត្រូវបានបំបែកនៅភូមិភាគកណ្ដាល "ដើម្បីបន្ថយភាពតានតឹង" ក្រោយពីមានការបះបោរនៅកោះផល

[1686] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧០១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1687] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧០២។

[1688] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៦៨, ៣៣២២។

[1689] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២២ កំណត់សម្គាល់ជើងទំព័រលេខ៣២៦៨, ៣៣២៣។

និងស្វាយឃ្លាំង[1690]។ ដើម្បីសន្និដ្ឋានដូចនេះបាន អង្គជំនុំជម្រះសំអាងតែទៅលើការបកស្រាយរបស់ខ្លួនលើឯកសារមួយគត់ដែលជាទូរលេខ ១៥ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥[1691]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះគួរពិចារណាលើកត្តាចំនួនបី ដែលនិយាយផ្ទុយពីសេចក្តីសន្និដ្ឋាននេះ។

៩២៩. ជាបឋម អង្គជំនុំជម្រះបានឯកភាពជាមួយមេធាវីការពារក្តីថា ការផ្លាស់ទីលំនៅប្រជាជនចាមចំនួន ៥០០០០ នាក់ គឺស្ថិតនៅក្នុងក្របខ័ណ្ឌនៃផែនការពង្រាយប្រជាជននៅទូទាំងប្រទេសកម្ពុជា[1692]។ ប៉ុន្តែ អង្គជំនុំជម្រះយល់ឃើញ "ដែរថា" មានការបំបែកជនជាតិចាមដើម្បីបន្ថយភាពតានតឹង[1693]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានពន្យល់ថាតើលក្ខណៈវិនិច្ឆ័យគតិយុត្តិ ឬការវិនិច្ឆ័យមួយណាដែលអាចនាំឱ្យអង្គជំនុំជម្រះយកការយល់ឃើញទីពីរនេះ មកដាក់ពីលើគោលបំណងមិនរើសអើងក្នុងការពង្រាយប្រជាជននោះទេ។ វាជាសេចក្តីសន្និដ្ឋានមិនសមហេតុសមផល។

៩៣០. បន្ទាប់មក អង្គជំនុំជម្រះមិនបានបង្ហាញពីការផ្លាស់ទីលំនៅប្រជាជនចាមដែលរស់នៅព្រំដែនវៀតណាម ដោយសារមូលហេតុជម្លោះប្រដាប់អាវុធ។ ក៏ប៉ុន្តែ វាគឺជាភ័ស្តុតាងជាសារវន្តដែលលេចចេញពីក្នុងចំណោមភ័ស្តុតាងនៅក្នុងសំណុំរឿង[1694]។ ជាចុងក្រោយ និងជាពិសេស វាជាការពុំត្រឹមត្រូវនោះទេ ដែលសន្និដ្ឋានថាមានឆន្ទៈក្នុងការដាក់ទណ្ឌកម្ម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនទាំងនេះ ខណៈដែលការជម្លៀសប្រជាជនត្រូវបានគ្រោង មុនពេលមានការបះបោរនៅកោះផល និងស្វាយឃ្លាំងទៅទៀត[1695]។

---

[1690] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៦២ កំណត់សម្គាល់ជើងទំព័រលេខ១១០១៥ និង ១១០១៦ យោងទៅ កថាខណ្ឌ ៣២១២។

[1691] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/154** ERN 00008494។

[1692] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២១២។

[1693] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២១២។

[1694] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/154** ERN 00008494៖ "យើងខ្ញុំដកតែតាមចំណុចសំខាន់នៅតាមដងទន្លេ និងព្រំដែន ឯខាងត្បូងឃុំ មិនដកទេ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1695] សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦១១-១៦១៣, កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃ២០-២៤ សីហា ១៩៧៥ ឯកសារ **E3/216**, ឯកសារ "ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ា

៩៣១. ដូច្នេះ អង្គជំនុំជម្រះមានកំហុស ដោយមិនបានយកចិត្តទុកដាក់លើកត្តាទាំងបីនេះ ដែលគួរត្រូវបានយកមកពិចារណាដោយចៅក្រមមានវិចារណញ្ញាណគ្រប់រូប។ គេត្រូវធ្វើសេចក្ដីសន្និដ្ឋានដូច្នេះថា ការផ្លាស់ទីលំនៅប្រជាជនមិនសំដៅជាក់លាក់តែលើជនជាតិចាម ក្នុងបំណងបំបែកពួកគេនោះទេ។ ហេតុដូច្នេះ ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ មិនត្រូវបានបំពេញ ហើយសេចក្ដីសន្និដ្ឋានមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ[1696]។

## ៤.៣. ការបង្ហាញដោយខុសច្បាប់ពីការចាប់ខ្លួនក្រៅវិសាលភាពនៃការជំនុំជម្រះ ដើម្បីប៉ុនប៉ងបង្ហាញឱ្យឃើញពីកម្រិតនៃភាពធ្ងន់ធ្ងរដែលជាល័ក្ខខ័ណ្ឌតម្រូវ

៩៣២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវាយតម្លៃពីភាពធ្ងន់ធ្ងរនៃអំពើ ដោយបានបញ្ចូល "ការចាប់ខ្លួន" មិនច្បាស់លាស់ មិនមានឯកសារយោងគាំទ្រ និងចម្លែក ទៅក្នុងការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះ[1697]។ ដូច្នេះ ការផ្លាស់ទីលំនៅប្រជាជនចាម កើតឡើងនៅក្នុងបរិបទទូលំទូលាយនៃការផ្លាស់ទីលំនៅប្រជាជន ដោយហេតុផលចម្បងគឺសេដ្ឋកិច្ច និងសន្តិសុខ គឺមិនអាចត្រូវកំណត់បទចោទប្រកាន់ថាជាការរើសអើងជាក់ស្ដែង ដែលជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញបានទេ។ ដូច្នេះ សេចក្ដីសន្និដ្ឋានដែលថាការផ្លាស់ទីលំនៅប្រជាជនចាម ពីភូមិភាគបូព៌ា ទៅកាន់ភូមិភាគកណ្ដាល គឺជាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវទុកជាមោឃៈ[1698]។

---

នយោបាយស្ដារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក" ខែកញ្ញា ឆ្នាំ១៩៧៥ ឯកសារ E3/781។ សូមមើលផងដែរ សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៣១។

[1696] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៦៨។

[1697] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៥។ សូមមើលផងដែរ កថាខណ្ឌ ៣៣២០។

[1698] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៦។

## ៥. គ្មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

៩៣៣. អង្គជំនុំជម្រះមានកំហុស ដោយបានកំណត់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ចំពោះជនជាតិចាម ដោយមិនមានភ័ស្តុតាងនៃការរើសអើងជាក់ស្តែង (៥.១)។ លើសពីនេះទៀត ការកំហិតទាំងនេះ គឺមិនត្រូវបានបង្កើតឡើងជាមួយនឹងចេតនាធ្វើការរើសអើងចំពោះជនជាតិចាម ដោយហេតុផលនៃការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេទេ (៥.២)។ បន្ទាប់មកទៀត ការរំលោភលើសិទ្ធជាមូលដ្ឋាននានាដែលចាំបាច់សម្រាប់កំណត់ការធ្វើទុក្ខបុកម្នេញ មិនត្រូវបានបំពេញទេ (៥.៣)។ ជាចុងក្រោយ កម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើដែលកំណត់ការរើសអើងជាក់ស្តែង គឺមិនឈានដល់ចំណុចតម្រូវនោះទេ ដើម្បីបង្ហាញពីធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញ (៥.៤)។

### ៥.១. គ្មានភ័ស្តុតាងអំពីការរើសអើងជាក់ស្តែងចំពោះជនជាតិចាម

#### ៥.១.១. ភ័ស្តុតាងអំពីការប្រព្រឹត្តិមិនខុសគ្នា ពាក់ព័ន្ធនឹងរបបអាហារ និងការកំហិតនានាចំពោះការប្រតិបត្តិសាសនា និងវប្បធម៌ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

៩៣៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមិនបានទាញផលវិបាកចេញពីការប្រព្រឹត្តិមិនខុសគ្នាលើប្រជាជនទាំងអស់ ពាក់ព័ន្ធនឹងរបបអាហារ និងការកំហិតទាំងឡាយចំពោះការប្រតិបត្តិសាសនា និងវប្បធម៌ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ[1699]។ សេចក្តីសន្និដ្ឋានគ្មានសុពលភាពទាំងឡាយរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការប្រព្រឹត្តិលើជនជាតិចាមនៅទំនប់១មករា មិនអាចប្រើធ្វើជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានផ្ទុយបានទេ (៥.១.១.១)។ គ្មានភ័ស្តុតាងបង្ហាញអំពីអត្ថិភាពនៃ "គោលនយោបាយ" ចាត់វិធានការជាក់លាក់ប្រឆាំងនឹងជនជាតិចាម ក្នុងឋានៈជាក្រុមជាតិពន្ធុដាច់ដោយឡែក (៥.១.១.២)។ ការកំហិតចំពោះការប្រតិបត្តិសាសនា និងវប្បធម៌ ត្រូវបានអនុវត្តចំពោះប្រជាជនទាំងអស់ រួមទាំងជនជាតិចាមផងដែរ ហើយដូច្នេះ ជាលទ្ធផល ការប្រព្រឹត្តិគឺស្មើភាពគ្នា (៥.១.១.៣)។

##### *៥.១.១.១. សេចក្តីសន្និដ្ឋានគ្មានសុពលភាពរបស់អង្គជំនុំជម្រះ អំពីការប្រព្រឹត្តិចំពោះជនជាតិចាមនៅទំនប់១មករា*

[1699] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨, ៣៣២៩។

៩៣៥. ដើម្បីសន្និដ្ឋានថាការប្រព្រឹត្តិចំពោះជនជាតិចាមគឺជាការរើសអើង អង្គជំនុំជម្រះបានរំឭកអំពីសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា ពួកគេត្រូវបង្ខំឱ្យហូបសាច់ជ្រូក ហាមឃាត់មិនឱ្យប្រតិបត្តិសាសនា និងនិយាយភាសាកំណើតរបស់ពួកគេ[1700]។ គេបានឃើញរួចមកហើយថា សេចក្តីសន្និដ្ឋានទាំងអស់នេះពុំត្រូវបានគាំទ្រដោយភស្តុតាងគ្រប់គ្រាន់នោះទេ ហើយដូច្នេះ វាគួរតែត្រូវទុកជាមោឃៈ[1701]។

### *៥.១.១.២. គ្មានភស្តុតាងអំពីអត្ថិភាពនៃ "គោលនយោបាយ" ចាត់វិធានការដាក់លាក់ប្រឆាំងនឹងប្រជាជនចាមក្នុងឋានៈជាក្រុមជាតិពន្ធុ និងសាសនាដាច់ដោយឡែក*

៩៣៦. ដើម្បីគាំទ្រថាការប្រព្រឹត្តិលើប្រជាជនចាមមានភាពរើសអើង អង្គជំនុំជម្រះយល់ថាមានការបង្ហាញឱ្យឃើញថា ប.ក.កបានដាក់ឱ្យអនុវត្តនូវ "គោលនយោបាយ" ចាត់វិធានការដាក់លាក់ប្រឆាំងនឹងប្រជាជនចាម ក្នុងឋានៈជាក្រុមជាតិពន្ធុ និងសាសនាដាច់ដោយឡែក[1702]។ កថាខណ្ឌ ៣២២៨ ដែលត្រូវបានយោងទៅរកនៅក្នុងកំណត់សម្គាល់ជើងទំព័រ និយាយថាប.ក.កមានគោលនយោបាយចំពោះជនជាតិចាម ហើយ "គោលនយោបាយនេះមានការវិវត្តទៅតាមពេលវេលា"៖

> "[១] នៅបណ្តាឆ្នាំដំបូងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងការប៉ុនប៉ងដំបូងៗរបស់ ប.ក.ក ក្នុងការបញ្ច្រាបពួកប្រជាជនចាម ពួកគេបានកំណត់គោលដៅលើជនជាតិចាម តាមរយៈការរឹតបន្តឹងលើការប្រតិបត្តិវប្បធម៌ និងសាសនារបស់ជនជាតិចាម។ [២] នៅពេលដែលជនជាតិចាមប្រឆាំងនឹងការបោះបង់អត្តសញ្ញាណជាតិពន្ធុ និងសាសនារបស់ពួកគេ "ការបះបោរ" ត្រូវបានបង្ក្រាបយ៉ាងព្រៃផ្សៃ ហើយមេដឹកនាំការបះបោរត្រូវបានគេសម្លាប់ ឯសហគមន៍ចាមត្រូវបានបំបែក។ [៣] បន្លាស់ប្តូរចុងក្រោយមួយបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ នៅពេលដែលមានការបញ្ជាឱ្យបោសសម្អាតជនជាតិចាមទាំងអស់"[1703]។

---

[1700] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨, កំណត់សម្គាល់ជើងទំព័រលេខ១១២៥៨ យោងទៅផ្នែក ១១.២.២២។

[1701] សូមមើលខាងលើ កថាខណ្ឌ ៨០៤-៨១៣។

[1702] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨, កំណត់សម្គាល់ជើងទំព័រលេខ១១២៥៩ យោងទៅ កថាខណ្ឌ ៣២២៨។

[1703] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២២៨។

៩៣៧. សេចក្តីសន្និដ្ឋានលើអង្គហេតុនេះគឺផ្ទុយគ្នា ព្រោះថាបើគេតាមដានមើលការវិនិច្ឆ័យរបស់អង្គជំនុំជម្រះ ដំណាក់កាលទីមួយនៃការបង្ក្រាបមានរយៈពេល "នៅបណ្តាឆ្នាំដំបូងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ" ពោលគឺច្រើនឆ្នាំចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[1704]។ បន្ទាប់មកមានដំណាក់កាលទីពីរ ក្រោយពីការបះបោរ ដែលចាប់ពីពេលនោះមក មេដឹកនាំត្រូវបានសម្លាប់ ហើយសហគមន៍ត្រូវបានបំបែក។ ក៏ប៉ុន្តែ ការបះបោរដែលលើកឡើងនៅក្នុងអំឡុងពេលនៃការពិភាក្សាដេញដោល គឺកើតឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ នៅកោះផល និងនៅក្នុងខែតុលា ឆ្នាំ១៩៧៥ នៅស្វាយឃ្លាំង ពោលគឺក្នុងរយៈពេលប៉ុន្មានខែដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចដែលមេធាវីការពារក្តីធ្លាប់បានធ្វើការកត់សម្គាល់រួចហើយ ការបង្ក្រាបដែលបានកើតឡើង គឺមិនមែនបណ្តាលមកពីសាសនារបស់ប្រជាជនចាមនោះទេ តែគឺមកពីមានការវាយប្រហារលើអ្នកទទួលខុសត្រូវមូលដ្ឋានម្នាក់[1705]។

៩៣៨. លើសពីនេះទៀត អង្គជំនុំជម្រះបានយោងតែទៅលើការដាក់ឱ្យអនុវត្តនូវគោលនយោបាយ[1706] ដែលទំនងជាដើម្បីសន្និដ្ឋានថាពិតជាមានគោលនយោបាយនេះមែន។ វាជាការវិនិច្ឆ័យចេញពីសម្មតិកម្មគ្មានសុពលភាព ដែលគ្មានសំអាងលើភ័ស្តុតាងជាក់ស្តែងណាមួយ ហើយទាំងអស់នេះ ក៏ដោយសារថាទាំងឯកសារជាលាយលក្ខណ៍អក្សរ ទាំងសុន្ទរកថារបស់ប.ក.ក គឺមិនធ្លាប់ដែលបានអំពាវនាវឱ្យមានវិធានការជាក់លាក់ណាមួយលើក្រុមជនជាតិចាមនោះទេ[1707]។

### *៥.១.១.៣. ការរឹតត្បិតចំពោះការប្រតិបត្តិសាសនា និងវប្បធម៌របស់ជនជាតិចាម ជាលទ្ធផលការប្រព្រឹត្តិស្មើភាពគ្នា*

---

[1704] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២២៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1705] សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦៣០-១៦៤២។

[1706] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២២៨, កំណត់សម្គាល់ជើងទំព័រលេខ១០៨៨៨ យោងទៅ កថាខណ្ឌ ៣២២៩-៣២៥០ (ត្រូវទៅនឹងផ្នែក ១៣.២.៦ "ការរឹតបន្តឹងលើការប្រតិបត្តិវប្បធម៌ និងសាសនារបស់ជនជាតិចាម"), កំណត់សម្គាល់ជើងទំព័រលេខ ១០៨៨៩ យោងទៅ កថាខណ្ឌ ៣២៥១-៣២៦៨ (ក្នុងនោះ កថាខណ្ឌ ៣២៦០-៣២៦៨ ដំណាក់កាលទីពីរនៃការផ្លាស់ទីលំនៅប្រជាជន), កំណត់សម្គាល់ជើងទំព័រលេខ១០៨៩០ យោងទៅផ្នែក ១៣.២.៩ ការសម្លាប់ និងឃុំខ្លួនជនជាតិចាម។

[1707] សូមមើលខាងក្រោម កថាខណ្ឌ ១៥៦១-១៥៧៤។

៩៣៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាការរឹតត្បិតបង្កើតឡើងចំពោះជនជាតិចាម ដែលបង្កើតបានជា "ការរើសអើងជាក់ស្តែង" គឺមានដូចតទៅ៖ "[១] ការហាមឃាត់ការអធិដ្ឋានជារៀងរាល់ថ្ងៃ [២] ការបង្ខំជនជាតិចាមឱ្យបរិភោគសាច់ជ្រូក [៣] និងការឱ្យស្លៀកពាក់សម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ [៤] ការបង្ខំឱ្យពួកគេនិយាយតែភាសាខ្មែរ [៥] ការដុតគម្ពីរសាសនា [៦] និងការរុះរើវិហារអ៊ីស្លាម ឬប្រើសម្រាប់គោលបំណងផ្សេងក្រៅពីការអធិដ្ឋាន [៧] អ្នកដែលប្រឆាំងនឹងត្រូវចាប់ខ្លួន និង/ឬយកទៅសម្លាប់"[1708]។ បើយោងតាមភ័ស្តុតាងនៅក្នុងសំណុំរឿង គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋានថាមានការប្រព្រឹត្តិបែបរើសអើង តាមរយៈភ័ស្តុតាងបង្ហាញពីការប្រព្រឹត្តិមិនខុសគ្នាលើជនជាតិចាមនៅក្នុងស្រុកក្រូចឆ្មារ នៅតាមកន្លែងផ្សេងៗក្នុងភូមិភាគកណ្តាល ក៏ដូចជាកន្លែងផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពេញមួយសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

- **<u>ការប្រព្រឹត្តិដូចគ្នាលើជនជាតិចាមនៅក្នុងស្រុកក្រូចឆ្មារ នៅតាមកន្លែងផ្សេងៗក្នុងភូមិភាគកណ្តាល និងនៅកន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ</u>**

៩៤០. **ស្រុកក្រូចឆ្មារ**។ អង្គជំនុំជម្រះបានសន្និដ្ឋានដោយមិនត្រឹមត្រូវថាមាន "វិធានការជាក់លាក់នានា" ដោយផ្អែកលើមូលដ្ឋាននៃការប្រជុំ "មានលក្ខណៈបើកចំហ" ដើម្បីធ្វើការ "ណែនាំហាមឃាត់សាសនា និងការប្រតិបត្តិសាសនា ដូចជាការទុកសក់វែង និងទទូរកន្សែងក៏បានធ្វើចំពោះទាំងជនជាតិខ្មែរ និងជនជាតិចាម"[1709]។ ដើម្បីធ្វើដូច្នេះបាន អង្គជំនុំជម្រះមានកំហុសដោយមិនបានយកចិត្តទុកដាក់ចង់ដឹងថាតើវិធានការទាំងអស់នេះអនុវត្តដូចគ្នាចំពោះមនុស្សគ្រប់រូប ឬយ៉ាងណា ដោយអង្គជំនុំជម្រះបានត្រឹមតែពិចារណាលើផលវិបាករបស់វិធានការទាំងនោះលើប្រជាជនចាម ដោយបានអះអាងថា "ជនជាតិចាមរងផលប៉ះពាល់ខ្លាំងជាពិសេស ដោយសារតែពួកគេត្រូវផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងការរស់នៅ និងការ

[1708] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨។

[1709] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៣២ កំណត់សម្គាល់ជើងទំព័រលេខ១០៨៩៩, ១០៩០១។

ប្រតិបត្តិសាសនារបស់ពួកគេ ដើម្បីគោរពទៅតាមការណែនាំនេះ"[1710]។ ផ្ទុយទៅវិញ បញ្ហានៃការរើសអើងគួរត្រូវគិតគូរដោយលក្ខណៈសត្យានុម័តិ ដោយត្រូវយកចិត្តទុកដាក់ស្វែងរកមើលថាតើមានភាពខុសគ្នាដែរ ឬអត់ ក្នុងការប្រព្រឹត្តិរវាងបុគ្គលផ្សេងៗគ្នាក្នុងចំណោមប្រជាជនទាំងអស់។ ក៏ប៉ុន្តែ សម្រាប់របបខ្មែរក្រហម ករណីមិនមែនដូច្នោះទេ។ ដូចគ្នាដែរ ទាក់ទងនឹងការតម្រូវឱ្យប្រជាជនទាំងអស់និយាយភាសាខ្មែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ទោះជាមានលក្ខណៈមិនរើសអើងយ៉ាងណាក្តី "ជាក់ស្តែង គឺការកំណត់គោលដៅទៅលើវប្បធម៌ចាម បើទោះបីជាអាច ឬមិនអាចបកស្រាយថា វាគ្រាន់តែជាការកំណត់ឱ្យប្រជាជនទាំងអស់គ្នាប្រើប្រាស់ភាសាខ្មែរក្តី"[1711]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានថាការរឹតត្បិតការប្រតិបត្តិសាសនា និងវប្បធម៌ចាមនៅក្នុងស្រុកក្រូចឆ្មារ ដែលត្រូវបានរៀបរាប់នៅកថាខណ្ឌ ៣២៣៨ គឺជាវិធានការជាក់លាក់ ខណៈដែលវិធានការទាំងនោះត្រូវអនុវត្តចំពោះមនុស្សគ្រប់គ្នា[1712]។ ក្នុងចំណោមអំពើទាំងឡាយដែលអង្គជំនុំជម្រះបានរៀបរាប់ អំពើដែលអាចកំណត់បានជាការរើសអើង គឺមានតែការបង្ខំឱ្យហូបសាច់ជ្រូក និងការចោទប្រកាន់ថាគម្ពីរគូរ៉ាអានត្រូវបានដុតបំផ្លាញ។ ក៏ប៉ុន្តែ សម្រាប់អំពើទាំងពីរប្រភេទនេះ ដូចបង្ហាញនៅផ្នែកខាងក្រោម ភ័ស្តុតាងមិនបានគាំទ្រសេចក្តីសន្និដ្ឋានដាក់បន្ទុករបស់អង្គជំនុំជម្រះនោះទេ[1713]។

៩៤១. **តាមកន្លែងផ្សេងៗក្នុងភូមិភាគកណ្តាល**។ ដូចគ្នាដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានកំណត់ថាការណែនាំដែលត្រូវអនុវត្តចំពោះមនុស្សគ្រប់គ្នាដោយមិនមានការបែងចែក គឺជា "វិធានការជាក់លាក់"[1714]។ ប៉ុន្តែ អង្គជំនុំជម្រះបានទទួលស្គាល់យ៉ាងច្បាស់ថា "ការហាមឃាត់លើសាសនាត្រូវបានអនុវត្តចំពោះក្រុមសាសនាដទៃទៀត ដូចជាពុទ្ធសាសនិកខ្មែរក៏ដោយ"[1715]។ អង្គជំនុំជម្រះគួរសន្និដ្ឋានថា ការហាមឃាត់គឺអនុវត្តចំពោះសាសនាទាំងអស់ដោយគ្មានការលើកលែង ហើយដូច្នេះ ការ

---

[1710] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៣២។

[1711] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៣៣។

[1712] សូមមើលខាងក្រោម កថាខណ្ឌ ៩៥៤-៩៥៦។

[1713] សូមមើលខាងក្រោម កថាខណ្ឌ ៩៤៤, ៩៤៨។

[1714] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៤២-៣៣២៨។

[1715] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៤២។

ប្រព្រឹត្តិចំពោះជនជាតិចាម គឺមិនមានអ្វីខុសគ្នាទេ។ គ្មានចៅក្រមមានវិចារណញ្ញាណណាសន្និដ្ឋានថាមានការរើសអើង ដោយផ្អែកលើមូលដ្ឋានថា "ប្រជាជនចាមត្រូវបានកំណត់គោលដៅជាពិសេសនៅក្នុងការអនុវត្តនេះ" នេះនោះទេ ហើយវាមានន័យថា អង្គជំនុំជម្រះបានគិតតែទៅលើផលវិបាកនៃវិធានការទាំងនេះ ដោយពុំបានពិចារណាពីចេតនារបស់អ្នកដែលដាក់ចេញនូវវិធានការទាំងនេះ[1716]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ការប្រព្រឹត្តិមិនខុសគ្នា ថាជាការរើសអើង ខណៈដែលចេតនានៃការប្រព្រឹត្តិខុសគ្នា គឺជាមូលដ្ឋាននៃការរើសអើង[1717]។ ម្យ៉ាងវិញទៀត គេបានឃើញពីខាងលើនូវកំហុសរបស់អង្គជំនុំជម្រះ ដើម្បីសន្និដ្ឋានថាមានការប្រព្រឹត្តិបែបរើសអើងលើជនជាតិចាមនៅទំនប់១មករា[1718]។ ក្នុងចំណោមអំពើទាំងឡាយរៀបរាប់ដោយអង្គជំនុំជម្រះ អំពើដែលអាចកំណត់បានថាជាការរើសអើង គឺមានតែការបង្ខំឱ្យបរិភោគសាច់ជ្រូក និងការចោទប្រកាន់ថាគម្ពីរគូរ៉ាអានត្រូវបានដុតបំផ្លាញប៉ុណ្ណោះ។ ក៏ប៉ុន្តែ សម្រាប់អំពើទាំងពីរប្រភេទនេះ ដូចដែលបង្ហាញនៅផ្នែកខាងក្រោម ភ័ស្តុតាងមិនបានគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ទាក់ទងនឹងភូមិភាគកណ្តាលនោះទេ[1719]។

៩៤២. **កន្លែងផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញថា ការរឹតត្បិតចំពោះជនជាតិចាម "នៅតាមទីកន្លែងផ្សេងៗដទៃទៀតជាច្រើននៅទូទាំងប្រទេសកម្ពុជា" គឺជាវិធានការជាក់លាក់បង្ហាញឱ្យឃើញពីការរើសអើងជាក់ស្តែង[1720]។ វិធានការជាក់លាក់ទាំងនោះ រួមមានការរឹតត្បិតការប្រតិបត្តិសាសនា និងវប្បធម៌ចាម "នៅកន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជា" ក្រោមទម្រង់ជាការហាមឃាត់ការថ្វាយបង្គំប្រចាំថ្ងៃ ការបង្ខំជនជាតិចាមឱ្យបរិភោគសាច់ជ្រូក និងស្លៀកពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ ការនិយាយភាសាខ្មែរ ការដុតគម្ពីរគូរ៉ាអាន និងការរុះរើព្រះវិហារ[1721]។ ក៏ប៉ុន្តែ ការរឹតត្បិតទាំងនេះ គឺអនុវត្តចំពោះប្រជាជនគ្រប់គ្នាដោយមិនមានការបែងចែក

---

[1716] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៤២។

[1717] សូមមើលខាងក្រោម កថាខណ្ឌ ៩៥៤-៩៥៦។

[1718] សូមមើលខាងលើ កថាខណ្ឌ ៨០៤-៨១៣។

[1719] សូមមើលខាងក្រោម កថាខណ្ឌ ៩៤៥, ៩៤៩។

[1720] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៥០, ៣៣២៨, ៣៣២៩។

[1721] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៥០។

ហើយដូច្នេះ វាមិនអាចកំណត់ថាជាការរើសអើងបានទេ ដោយមូលហេតុគ្រាន់តែវាមានផលវិបាកសំខាន់លើរបៀបរស់នៅរបស់ប្រជាជនចាមនោះ។ គឺមានតែការចោទប្រកាន់ពីការបង្ខំឱ្យហូបសាច់ជ្រូក និងការដុតបំផ្លាញគម្ពីរគូរ៉ានប៉ុណ្ណោះ ដែលអាចបង្កើតបានជាការប្រព្រឹត្តិបែបខុសគ្នា។

- **<u>ការចោទប្រកាន់ពីការប្រព្រឹត្តិមិនស្មើភាពគ្នាចំពោះជនជាតិចាម ដោយគ្មានភស្តុតាងគាំទ្រ</u>**

៩៤៣. ការពិនិត្យលើភស្តុតាងដែលអង្គជំនុំជម្រះយកមកធ្វើជាមូលដ្ឋាន បង្ហាញឱ្យឃើញថាគ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋានបានអំពីអត្ថិភាពនៃវិធានការតែពីរប្រភេទនេះបានទេ។

*គ្មានការបង្ខំឱ្យហូបសាច់ជ្រូក*

៩៤៤. **ស្រុកក្រូចឆ្មារ**។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាជនជាតិចាមត្រូវបានបង្ខំឱ្យហូបសាច់ជ្រូក[1722]។ តាមការពិតទៅ ចំណុចនេះមិនបានបង្ហាញតាមរយៈភស្តុតាងដែលមានក្នុងសំណុំរឿងទេ។ ផ្ទុយទៅវិញ ភស្តុតាងក្នុងសំណុំរឿងបានបង្ហាញថា ក្នុងរយៈពេលចែករបបអាហារ មានរបបអាហារតែមួយប៉ុណ្ណោះសម្រាប់មនុស្សគ្រប់គ្នា ព្រោះថាខ្មែរក្រហមមិនបានផ្តល់ជាប្រព័ន្ធនូវជម្រើសមុខម្ហូបសម្រាប់ប្រជាជនចាមនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន គ្រាន់តែបាននិយាយថា៖ "នៅក្នុងឆ្នាំ១៩៧៥ ហ្នឹងដដែល អ៊ីចឹងរបបនោះ មានការរឹតបន្តឹងពីបញ្ហាសាសនា បង្ខំឱ្យស៊ីសាច់ជ្រូក ហើយបិទមិនឱ្យសំយ៉ាំង"[1723]។ ក៏ប៉ុន្តែ គាត់មិនបានបញ្ជាក់ថាតើនៅក្នុងស្ថានភាពបែបណាដែលអាជ្ញាធរបានបង្ខំជនជាតិចាមឱ្យហូបសាច់ជ្រូក។ គេមិនបានដឹងថាតើជនជាតិចាមទទួលបានអាហារដូចគ្នានឹងអ្នកគ្រប់គ្នាដែរ ឬយ៉ាងណា តើពួកគេមានជម្រើសក្នុងការហូប ឬមិនហូបដែរឬទេ និងថាតើមានទណ្ឌកម្មដែរឬទេ បើមិនព្រមហូប។ លទ្ធភាពផ្សេងៗគ្នាទាំងនេះគឺពិតជាសំខាន់ណាស់ និងគួរត្រូវបានពិចារណាដោយអង្គជំនុំជម្រះ មុននឹងទាញសេចក្តីសន្និដ្ឋានណាមួយ ពីព្រោះថាបទពិសោធន៍គឺផ្សេងៗពីគ្នា។ សាក្សី វ៉ាន់ ម៉ាត់ បាននិយាយថា៖ "ជួនកាលគេហូបសាច់ជ្រូកទៅ យើងមានអំបិលមាន

[1722] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៣៨ កំណត់សម្គាល់ជើងទំព័រលេខ១០៩២៥ យោងទៅ កថាខណ្ឌ ៣២៣២-៣២៣៦។

[1723] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៣៥ កំណត់សម្គាល់ជើងទំព័រលេខ១០៩១២។

អី លួចហូបអំបិលអីទៅ មានស្អី តាមហ្នឹងទៅ។ គេហូបសាច់ជ្រូកហូបទៅ ប៉ុន្តែយើងគេឱ្យអាម៉េច យើងយកទៅទុកណាសិនទៅ។ យើងហូបអត់បាន ចេះតែហូបម៉េច"[1724]។ សក្ខីកម្មរបស់គាត់បង្ហាញឱ្យឃើញថា ជនជាតិចាមអាចបដិសេធមិនហូបសាច់ជ្រូកបាន ដោយសារតែពុំមានជម្រើសផ្សេងជំនួសឱ្យសាច់ជ្រូក។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានរៀបរាប់ពីបទពិសោធន៍ប្រហាក់ប្រហែលគ្នានេះដែរ[1725]។ ក្នុងល័ក្ខខ័ណ្ឌបែបនេះ គ្មានចៅក្រមមានវិចារណញ្ញាណណាសន្និដ្ឋានបានថា ខ្មែរក្រហមបានបង្ខំជនជាតិចាមឱ្យហូបសាច់ជ្រូកនោះទេ។ សក្ខីកម្មនានាបានបង្ហាញថា ក្នុងក្របខ័ណ្ឌនៃការហូបរួមនៅតាមសហករណ៍ មនុស្សគ្រប់គ្នាហូបដូចគ្នា ដោយគ្មានការបែងចែក ហើយពួកគេមិនត្រូវបានផ្តល់ជម្រើសអ្វីជំនួសឱ្យសាច់ជ្រូកទេ។ ភាពលាំនេះ គឺមានច្រើន។

៩៤៥. **នៅតាមកន្លែងផ្សេងៗក្នុងភូមិភាគកណ្តាល**។ ដូចគ្នានឹងស្រុកក្រូចឆ្មារដែរ ភស្តុតាងមិនបានបង្ហាញថា ជនជាតិចាមត្រូវបានបង្ខំឱ្យហូបសាច់ជ្រូកទេ តែមានរបបអាហារមួយសម្រាប់មនុស្សគ្រប់គ្នា ដោយមិនមានមុខម្ហូបពិសេសសម្រាប់ជនជាតិចាមនោះទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះផ្អែកតែទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន និងកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួនដែលមិនបានមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ។ ក៏ប៉ុន្តែ សក្ខីកម្មរបស់ ហ៊ីម ម៉ាន បង្ហាញថាគ្មានការតាមដាននោះទេ[1726]។ សក្ខីកម្មនានាដែលត្រូវបានរៀបរាប់នៅក្នុងកំណត់សម្គាល់ជើងទំព័រ ហើយដែលគេគួររំឭកពីតម្លៃជាភស្តុតាងតិចតួចនៃឯកសារទាំងនោះ គឺបញ្ជាក់ថាមានមុខម្ហូបទូទៅសម្រាប់សហករណ៍ទាំងមូល ដោយពុំមានសាច់អ្វីផ្សេងសម្រាប់ជនជាតិចាមទេ[1727]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ គួរត្រូវទុកជាមោឃៈ។

---

[1724] ប្រតិចារឹក ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/398.1** ម៉ោងប្រហែល ១១.២៦.៤៣។

[1725] ប្រតិចារឹក ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/393.1** ម៉ោងប្រហែល ០៩.២៨.១២។

[1726] ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោងប្រហែល ១១.០៧.២៥ ("រួចដល់ពេលទៅហូប [...] ក៏គ្មានឈ្លបគ្មានអីទៅមើលទេ")។

[1727] កំណត់ហេតុនៃការស្តាប់ចម្លើយ ជួប ណុន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ **E3/9349** ERN 00239924៖ ("ចំណែកឯការហូបចុកវិញ គឺដូចខ្មែរយើងដែរ។ ក្នុងករណីដែលមានសម្លសាច់ជ្រូក បើមិនហូប គឺគ្មានអ្វីហូបទេ"), កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម គីមសាន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ **E3/5528** ERN 00418592៖ ("គេឱ្យជនជាតិចាមទាំងនោះហូបសាច់ជ្រូក ដូចជាប្រជាជនខ្មែរដែរ")។

៩៤៦. **កន្លែងផ្សេងៗក្នុងប្រទេសកម្ពុជា ក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។** ជាថ្មីម្តងទៀត គេគួរបញ្ជាក់ពីលក្ខណៈនៃ "ការបង្ខំ" ឱ្យហូបសាច់ជ្រូកនេះ។ សក្ខីកម្មបានបង្ហាញថា ខ្មែរក្រហមបានផ្តល់អាហារដូចគ្នាចំពោះមនុស្សគ្រប់គ្នា។ វាគ្រាន់តែពុំមានអ្វីជំនួសសាច់ជ្រូក នៅពេលគេផ្តល់អាហារនោះ។ នេះមិនមែនជាវិធានការជាក់លាក់ទេ តែជាការប្រព្រឹត្តិមិនរើសអើងនៅក្នុងក្របខ័ណ្ឌនៃអាហារតែមួយសម្រាប់សហករណ៍ទាំងមូល។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បាននិយាយប្រាប់តុលាការថា ជនជាតិចាមត្រូវបង្ខំឱ្យហូបសាច់ជ្រូក ព្រោះថាពួកគេពុំទទួលបានអាហារផ្សេងនោះទេ[1728]។ គេគួររំឭកថា ប្រទេសទាំងមូលកំពុងប្រឈមនឹងកង្វះអាហារ។ ទោះបីជា ម៉ី ពៅ បានលើកឡើងពីការស្លាប់ឪពុករបស់គាត់ ដោយសារការអត់បាយ ដោយហេតុតែគាត់បានបន្តប្រកែកមិនព្រមហូបសាច់ជ្រូក[1729]ក៏ដោយ ក៏គាត់មិនបានបង្ហាញពីទណ្ឌកម្មណាមួយពីសំណាក់ពួកខ្មែរក្រហម ក្រោយពីមានការបដិសេធរបស់ឪពុកគាត់នោះទេ។ នៅក្នុងភូមិភាគនិរតី ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង បានពន្យល់ថាគេឱ្យគាត់ហូបសាច់ជ្រូកដាក់ក្នុងបបរ មានមនុស្សម្នាក់កាន់អាវុធឈរពីក្រោយ រង់ចាំមើលគាត់ហូបឱ្យអស់[1730]។ នេះគឺជាសក្ខីកម្មតែមួយគត់ដែលលើកឡើងយ៉ាងពិតប្រាកដពីការគំរាមកំហែងទាក់ទងនឹងប្រធានបទនេះ។ គឺដោយមានកំហុសឆ្គងដែលអង្គជំនុំជម្រះយល់ថាខ្លួនអាចសន្និដ្ឋានជាទូទៅថាជនជាតិចាមត្រូវបង្ខំឱ្យហូបសាច់ជ្រូក ក្រោមការគំរាមកំហែង[1731] ដោយផ្អែកតែទៅលើសក្ខីកម្មមួយនេះ ខណៈដែលបទពិសោធន៍គឺខុសៗគ្នានៅទូទាំងប្រទេស។ សម្រាប់ភូមិភាគពាយ័ព្យ ហួន ជឿម បានផ្តល់សក្ខីកម្មថា ចាមមួយចំនួនដែលបានបដិសេធបរិភោគសាច់ជ្រូក គឺត្រូវទទួលទណ្ឌកម្ម

---

[1728] ប្រតិចារឹក ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/393.1** ចន្លោះម៉ោង ០៩.២៨.១២ និង ០៩.៣២.២៦។

[1729] ប្រតិចារឹក ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/393.1** ម៉ោងប្រហែល ០៩.២៨.១២។

[1730] ប្រតិចារឹក ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ចន្លោះម៉ោង ១៥.៤៦.00 និង ១៥.៤៧.១១។

[1731] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៤២៖ ("ជនជាតិចាមត្រូវបានពួកខ្មែរក្រហមតាមដានយ៉ាងជាប់លាប់ ប្រសិនបើពួកគេបដិសេធមិនគោរពតាមការណែនាំដែលរឹតបន្តឹងលើការប្រតិបត្តិសាសនារបស់ពួកគេទេនោះ ឧទាហរណ៍ដូចថា បដិសេធក្នុងការហូបសាច់ជ្រូកនោះ ពួកគេនឹងត្រូវបានចាត់ទុកថាប្រឆាំងនឹងអង្គការ ហើយត្រូវទទួលរងទណ្ឌកម្ម"), កថាខណ្ឌ ៣២៤៥៖ ("បន្ទាប់ពី ប.ក.ក បានមកដល់ភូមិភាគកណ្តាល (ឧត្តរចាស់) ពួកគេបានកំហិតដោយបង្ខំចំពោះការរឹតបន្តឹងទៅលើការប្រតិបត្តិវប្បធម៌ និងសាសនារបស់ជនជាតិចាម នៅតាមទីកន្លែងផ្សេងៗ នៅក្នុងភូមិភាគ។ ការរឹតបន្តឹងទាំងអស់នេះ រួមមាន [...] ការបង្ខំជនជាតិចាមឱ្យហូបសាច់ជ្រូក"), កថាខណ្ឌ ៣៣២៨៖ ("ការហាមឃាត់នេះរួមមាន [...] ការបង្ខំជនជាតិចាមឱ្យបរិភោគសាច់ជ្រូក")។

តែគាត់មិនបានផ្តល់សេចក្តីលម្អិតណាមួយទាក់ទងនឹងប្រភេទនៃទណ្ឌកម្មនោះទេ ហើយផ្នែកនេះនៃសក្ខីកម្មរបស់គាត់ គឺជាការឮតពីគេ។ ផ្នែកដែលនៅសល់ក្នុងសក្ខីកម្មផ្ទាល់របស់គាត់ គឺជាភស្តុតាងដោះបន្ទុក៖

> “ឆ៖ ខ្ញុំដឹងតាមរយៈបងប្អូនខ្មែរអ៊ីស្លាមហ្នឹងដែលគាត់ធ្លាប់ទៅរស់នៅ រកត្រីរកនឹងទន្លេហ្នឹងជាមួយខ្ញុំ គាត់បានប្រាប់ខ្ញុំអ៊ីចឹង។ បានខ្ញុំថា មកនៅកន្លែងខ្ញុំអីមិនបាច់ភ័យទេ ទោះបីមិនហូបសាច់ជ្រូកក៏ហូបស្អីក៏បានដែរ តែសំខាន់មិនកុំឱ្យជំទាស់នឹងគេ ទំនាស់នឹងគេអ៊ីចេះចុះអត់បានទេ”[1732]។

៩៤៧. សក្ខីកម្មពីរផ្សេងទៀត គឺសក្ខីកម្មរបស់ ហ៊ុន ឈុនលី និង ប៉ែជុយ ជីបសែ ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១ បើទោះជាលើកបង្ហាញពីការដែលជនជាតិចាមត្រូវបង្ខំឱ្យហូបសាច់ជ្រូកក៏ដោយ ក៏មិនអាចឱ្យគេមានភស្តុតាងច្បាស់លាស់ទាក់ទងនឹងលក្ខខ័ណ្ឌនៃការបង្ខំនេះដែរ[1733]។ គ្មានព័ត៌មានណាមួយត្រូវបានផ្តល់ឱ្យ ទាក់ទងនឹងប្រភពនៃព័ត៌មានរបស់សាក្សីទាំងពីរនាក់នេះទេ។ គេក៏មិនដឹងពីអាជ្ញាធរដែលបានតាក់តែង និងថាតើបទបញ្ជានេះត្រូវបានអនុវត្តដោយរបៀបណានោះដែរ។ ជាចុងក្រោយ ការស្មានរបស់ អ៊ីសា ឧស្មាន ដែលភាពលម្អៀងរបស់គាត់ត្រូវចោទឡើង[1734] ទាក់ទងនឹងភស្តុតាងដោះបន្ទុក គឺមិនបានជួយបញ្ជាក់បន្ថែមសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះនោះទេ។ បើទោះជាគេត្រូវយល់ស្របជាមួយនឹងអ្នកជំនាញរូបនេះ ទាក់ទងនឹងការសន្មតរបស់គាត់ដែលថា “ចំពោះអ្នកដែលមិនហូបគឺអាចបណ្តាលមកពី [ប្រធានៗនៅ] មូលដ្ឋានបង្ហាញពីការអាណិតអាសូរ”[1735] ចំពោះពួកគេក៏ដោយក៏នេះវាបង្ហាញឱ្យឃើញថាប្រធានៗនៅមូលដ្ឋានគ្រប់គ្រងបញ្ហាទាំងនេះដោយឯករាជ្យ ហើយដូច្នេះ គឺគ្មានបទបញ្ជាពីថ្នាក់ដឹកនាំ ប.ក.ក នោះទេ។ ដូច្នេះ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋាន

---

[1732] ប្រតិចារឹក ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/485.1** ម៉ោងប្រហែល ១០.៥០.៥៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1733] ហ៊ុន ឈុនលី៖ ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/149.1** ចន្លោះម៉ោង ១៥.៤៤.៣៤ និង ១៥.៤៦.៣០។ សាក្សីគ្រាន់និយាយថា “គេបង្ខំចាមឱ្យស៊ីសាច់ជ្រូកទៀត” (នៅបាត់ដំបង), ប៉ែជុយ ជីបសែ៖ប្រតិចារឹក ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ឯកសារ **E1/144.1** ចន្លោះម៉ោង ០៩.២៥.៤៥ និង ០៩.២៨.០៥ (“[...] ហើយវាឱ្យចាមហ្នឹងគឺ តែវាកាប់ជ្រូក វាឱ្យហូបសាច់ជ្រូកដែរ។ ដូច្នេះហើយ ដើម្បីរស់ គ្នាក៏ធ្វើតាមតែវាឱ្យធ្វើអី គឺធ្វើនោះ”)។

[1734] សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៥៩៩-១៦០៥។

[1735] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៤៧។

ថាមានការបង្ហាញថា ប.ក.ក បាន "បង្ខំ" ជនជាតិចាមឱ្យហូបសាច់ជ្រូកនៅទូទាំងប្រទេសកម្ពុជា ក្រោមលក្ខណ្ឌនៃទណ្ឌកម្ម បាននោះទេ[1736]។

## *ការដុតបំផ្លាញគម្ពីគូរ៉អាន*

៩៤៨. **ស្រុកក្រូចឆ្មារ**។ គ្មានភស្តុតាងជឿជាក់បានណាមួយបង្ហាញថា គម្ពីរគូរ៉អានត្រូវបានដុតនៅក្នុងស្រុកក្រូចឆ្មារនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បាននិយាយជាន់កែងខ្លួនឯងលើចំណុចនេះ។ ជាដំបូង គាត់និយាយថាគម្ពីរគូរ៉អានត្រូវ "បានប្រមូល និងបំផ្លាញចោល"[1737] ហើយបន្ទាប់មកទៀត គាត់ថាគាត់មិនដឹង "យកទៅខាងណាខាងណីទេ"[1738]។ម្យ៉ាងវិញទៀត បើទោះជាសាក្សី វ៉ាន់ ម៉ាត់ បាននិយាយថាគម្ពីគូរ៉អានទាំងអស់ត្រូវដុតចោល ហើយគម្ពីរមួយចំនួនត្រូវបានប្រើជាក្រដាស "កិតអាចម៍" នៅក្នុងភូមិជំនីកក៏ដោយ[1739] ក៏គាត់ពុំបានផ្តល់ប្រភពនៃព័ត៌មានទូទៅមួយនេះទេ។ ដូច្នេះ សក្ខីកម្មរបស់គាត់មានតម្លៃជាភស្តុតាងតិចតួចបំផុត។ ត្រង់នេះជាថ្មីម្តងទៀត សេចក្តីលម្អិតគឺសំខាន់ណាស់ ព្រោះថាដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានអះអាងថា គម្ពីរគូរ៉អានត្រូវបានប្រមូលយកទៅទុកនៅតាមមន្ទីរនានា ឬនៅផ្ទះមេភូមិ[1740]។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនបាននិយាយពីការបំផ្លាញ

---

[1736] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៤៥។

[1737] ប្រតិចារឹក ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ (នោ សាទះ) ឯកសារ **E1/350.1** ចន្លោះម៉ោង ១៥.៣១.១៦ និង ១៥.៣៥.០០៖ ("វាធ្វើបាប វាចង់បំបាត់សាសនា អស់ហើយនោះ វាអត់ឱ្យយើងថ្វាយបង្គំនៅក្នុងព្រះវិហារទេ តាមផ្ទះក៏វាមិនឱ្យដែរ។ រៀនសូត្រចាម ក៏វាមិនឱ្យដែរ គម្ពីរគូរ៉អាន វាដុត ដូចថាវាប្រមូល វាមិនដឹងយកទៅខាងណាខាងណីទេ វាអត់ឱ្យយើងកាន់ទេ")។

[1738] ប្រតិចារឹក ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ (នោ សាទះ) ឯកសារ **E1/350.1** ម៉ោងប្រហែល ១៥.៣៥.០០៖ ("រង្វង់៧៥ ហ្នឹង ហើយ។ ចាប់ផ្តើមបាក់ចែកពីគ្នាចេញពីផ្ទះហ្នឹងទៅ គេប្រមូលហើយ អ្នកដូចគេថាបោសសម្អាតនៅភូមិហ្នឹងនោះ គេអត់ឱ្យមានទេ។ ដឹងគេដុត ដឹងគេយកទៅខាងណាទេ")។

[1739] ប្រតិចារឹក ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/398.1** មុនម៉ោង ០៩.៤៣.២៨។

[1740] ប្រតិចារឹក ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ (សុះ មីន) ឯកសារ **E1/343.1** ម៉ោងប្រហែល ១៦.០២.៥៥ ("ខ្ញុំសូមជម្រាបថា គម្ពីរគូរ៉អានដែលខ្ញុំរកឃើញ កន្លែងគេប្រមូលផ្តុំនៅផ្ទះប្រធានភូមិហ្នឹងតែម្តង"), ចន្លោះម៉ោង ១៥.៥៦.៤៥ និង ១៥.៥៩.៤៥ ("[...] ហើយគេប្រមូលយកគម្ពីរហ្នឹងទៅដាក់ម្តុំនៅកន្លែងមន្ទីរគេហ្នឹង គេមិនឱ្យប្រជាជនប្រើប្រាស់ទេ ហើយគម្ពីរគូរ៉អាននៅៗ គេប្រមូលយកទាំងអស់ សូម្បីតែគម្ពីរតូចតាចម៉េចក៏ដោយ គេប្រមូលយកអស់")។

ទេ[1741]។ ដូច្នេះ ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងទាំងអស់នេះ គ្មានចៅក្រមមានវិចារណញ្ញាណណា អាចសន្និដ្ឋានបានថាខ្មែរក្រហមបានដុតបំផ្លាញគម្ពីរគូរ៉អាន នៅក្នុងស្រុកក្រូចឆ្មារបានទេ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ[1742]។

៩៤៩. **នៅតាមទីកន្លែងផ្សេងៗក្នុងភូមិភាគកណ្តាល**។ ភស្តុតាងគាំទ្រសេចក្តីសន្និដ្ឋានដែលថា គម្ពីរគូរ៉អានត្រូវបានបំផ្លាញ គឺពុំមានតម្លៃនោះទេ។ សាក្សី សុះ កំរី បាននិយាយនៅចំពោះមុខតុលាការថា "សៀវភៅសាសនាអត់មានទេ ព្រោះយើងត្រូវបានជម្លៀសមួយចំនួនហ្នឹង គឺអ្វីដែលនេះហ្នឹងគឺត្រូវកម្ទេចចោល ត្រូវបំបាត់ចោល។ ហើយអ្នកដែលនៅសេសសល់ហ្នឹង ក៏មិនហ៊ានប្រើប្រាស់ដែរ អ៊ីចឹងនាំគ្នាដុតចោល ជួនកាលកប់ចោលអស់ទៅ"[1743]។ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន វិញ និយាយថា៖ "នៅឆ្នាំ១៩៧៥ ពេលគេជម្លៀសយើងចេញ គម្ពីរគូរ៉អានក៏ត្រូវគេប្រមូលដូចគ្នា។ ខ្ញុំមិនដឹងថាគេយកគម្ពីរទាំងនោះទៅទុកឯណាទេ"[1744]។ ដោយផ្អែកលើភស្តុតាងផ្ទុយគ្នាទាំងនេះ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋានបានថាអាជ្ញាធរខ្មែរក្រហម បានបំផ្លាញគម្ពីរគូរ៉អាននៅក្នុងភូមិភាគកណ្តាលបានឡើយ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

៩៥០. **កន្លែងផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ក្នុងពេលពេញមួយសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ**។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយផ្អែកតែទៅលើកិច្ចសម្ភាសន៍របស់ Nate THAYER មកពីក្រុមប្រឹក្សាស្រាវជ្រាវវិទ្យាសាស្ត្រសង្គម ដើម្បីសន្និដ្ឋានថា "នៅទូទាំងប្រទេស [...] គម្ពីរអាល់គូរ៉អានត្រូវបានរឹបអូស និងដុតបំផ្លាញចោល"[1745]។ កិច្ចសម្ភាសន៍ទាំងនោះត្រូវបានដឹកនាំធ្វើដោយ Nate THAYER និងក្រុមការងាររបស់គាត់ ជាមួយជនភៀសខ្លួន នៅប្រទេសថៃ ក្នុងទសវត្សរ៍

---

[1741] ប្រតិចារឹក ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ (សុះ មីន) ឯកសារ **E1/343.1** ចន្លោះម៉ោង ១៥.៥៦.៤៥ និង ១៥.៥៩.៤៥ ("[...] ហើយគេប្រមូលយកគម្ពីរហ្នឹងទៅដាក់ម្តុំនៅកន្លែងមន្ទីរគេហ្នឹង គេមិនឱ្យប្រជាជនប្រើប្រាស់ទេ ហើយគម្ពីរគូរ៉អាននៅៗ គេប្រមូលយកទាំងអស់ សូម្បីតែគម្ពីរតូចតាចម៉េចក៏ដោយ គេប្រមូលយកអស់")។

[1742] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៣៤, ៣២៣៨។

[1743] ប្រតិចារឹក ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ ឯកសារ **E1/415.1** ម៉ោងប្រហែល ១០.៤២.០៣។

[1744] ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/349.1** ម៉ោងប្រហែល 15.34.52។

[1745] សំអាងហេតុសាលក្រម កថាខណ្ឌ ៣២៤៩, ៣២៥០។

ឆ្នាំ១៩៨០។ វាជាកិច្ចសម្ភាសន៍ធ្វើឡើងក្រៅក្របខ័ណ្ឌតុលាការ ដែលមិនត្រូវបានពិភាក្សាដេញដោល និងត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃទម្រង់បែបបទមួយធ្វើរួចជាស្រេចជាភាសាអង់គ្លេស និងបំពេញដោយដៃ។ ម្យ៉ាងទៀត អង្គជំនុំជម្រះមានកំហុស ដោយមិនបានទាញផលវិបាកចេញពីការដែលគ្មានសាក្សីណាម្នាក់បានមកផ្តល់សក្ខីកម្មលើចំណុចនេះ។ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចធ្វើសេចក្តីសន្និដ្ឋានបែបនេះ ដោយផ្អែកលើភ័ស្តុតាងទាំងនេះបាននោះទេ។

៩៥១. ដូច្នេះ អង្គជំនុំជម្រះមានកំហុសអង្គហេតុ ដោយបានកំណត់ថាជា "វិធានការជាក់លាក់" ចំពោះវិធានរឹតត្បិតមួយចំនួនទាក់ទងនឹងការប្រតិបត្តិសាសនា ដែលត្រូវបានអនុវត្តដូចគ្នាចំពោះមនុស្សគ្រប់រូប។

## ៥.១.២. ការរឹតត្បិតសេរីភាពសាសនា

៩៥២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានដោយពុំមានការវិភាគណាមួយថា អង្គជំនុំជម្រះ "រកមិនឃើញថា ការហាមឃាត់បែបនេះ [ការប្រតិបត្តិសាសនា និងវប្បធម៌របស់ប្រជាជនចាម] ត្រូវបានអនុញ្ញាតនោះឡើយ"[1746]។ អង្គជំនុំជម្រះបានត្រឹមធ្វើការយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ ទៅលើផ្នែកទាក់ទងនឹងការធ្វើទុក្ខបុកម្នេញនៅក្នុងច្បាប់ជាធរមាន នៅត្រង់កថាខណ្ឌ ៧១៩ ដល់កថាខណ្ឌ ៧២១ ប៉ុណ្ណោះ។ គេអាចបានត្រឹមវាយតម្លៃថាអង្គជំនុំជម្រះប្រហែលជាចង់យោងជាពិសេសទៅសេចក្តីដកស្រង់ខាងក្រោម៖

> "អង្គជំនុំជម្រះយល់ស្របជាមួយមេធាវីការពារក្តី នួន ជា ដែលថាសេរីភាពសម្តែងពីការគោរពសាសនា ឬជំនឿរបស់ខ្លួន អាចត្រូវបានដាក់កំហិតមួយចំនួន។ ប៉ុន្តែ ការកំហិតទាំងនោះ ត្រូវតែកំណត់ដោយបញ្ញត្តិច្បាប់ និងមានសារៈសំខាន់ដល់ការការពារសន្តិសុខ

[1746] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨ កំណត់សម្គាល់ជើងទំព័រលេខ១១២៦៤។ ប្រតិចារឹក ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/343.1** ចន្លោះម៉ោង ១៤.១៧.២០ និង ១៤.២០.១៨។

សណ្តាប់ធ្នាប់សាធារណៈ សុខភាព សីលធម៌ ឬសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់បុគ្គលផ្សេងទៀត”[1747]។

“អង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃទៅលើការដាក់កំហិតណាមួយលើសេរីភាពសាសនា ឬសេរីភាពក្នុងការសម្តែងការគោរពសាសនា ផ្អែកលើអង្គហេតុ ក្នុងសំណុំរឿងនេះ ជាមួយនឹងការពិចារណាទៅលើបទប្បញ្ញត្តិទាំងនេះ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដើម្បីកំណត់ថាតើការដាក់កំហិតទាំងនេះត្រូវបានច្បាប់អនុញ្ញាត ឬជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពសាសនា ដែលត្រូវបានចាត់ទុកថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាដែរឬទេ”[1748]។

៩៥៣. ប៉ុន្តែ អង្គជំនុំជម្រះមានកំហុសអង្គច្បាប់ ដោយបានវាយតម្លៃធាតុផ្សំសត្យានុម័តិនៃ “ការរើសអើងជាក់ស្តែង” ដោយបានបញ្ចូលទៅក្នុងនោះនូវការវាយតម្លៃអំពីល័ក្ខខ័ណ្ឌតម្រូវថា អំពើទាំងនោះ “មិនទទួលស្គាល់ ឬប្រមាថសិទ្ធិជាមូលដ្ឋានទទួលស្គាល់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់អនុសញ្ញា” តាមរយៈឃ្លាប្រយោគមួយ និងដោយគ្មានការវិភាគតតិយុត្តិ[1749]។ អង្គជំនុំជម្រះខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់សំអាងហេតុ ដោយពុំបានពន្យល់ថាតើការរឹតត្បិតទាំងអស់នោះមិនត្រូវអនុញ្ញាតនៅក្នុងច្បាប់បែបដូចម្តេចទៅ។ អង្គជំនុំជម្រះក៏មានកំហុសអង្គច្បាប់ផងដែរ ដោយបានច្របល់បញ្ចូលគ្នារវាងសំណួរថាតើមានការប្រព្រឹត្តិខុសគ្នាចំពោះប្រជាជនចាមដែរ ឬអត់ ជាមួយនឹងសំណួរថាតើមានការរំលោភលើសិទ្ធិជាមូលដ្ឋានដែរ ឬអត់។ សំណួរទាំងពីរនេះគឺជាធាតុផ្សំខុសគ្នាពីការធ្វើទុក្ខបុកម្នេញ។ “សេចក្តីសន្និដ្ឋាន” របស់អង្គជំនុំជម្រះ រឹតតែពុំគប្បីថែមទៀត ព្រោះថាអង្គជំនុំ

[1747] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1748] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1749] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨។

ជម្រះមិនបានពិចារណាថាអំពើទាំងនេះធ្វើឱ្យប៉ះពាល់ដល់សេរីភាពសាសនា[1750]។ សេចក្តីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

## ៥.១.៣. ការចោទប្រកាន់ខុសច្បាប់ពីការរើសអើងដោយប្រយោល

៩៥៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ថាជាការរើសអើងជាក់ស្តែង ចំពោះការប្រព្រឹត្តិមិនខុសគ្នាដែលបានបង្កឱ្យមានផលវិបាកជាពិសេសលើប្រភេទបុគ្គលមួយក្រុម[1751]។ អង្គជំនុំជម្រះគាំទ្រថា វិធានការទាំងឡាយគឺមានភាពជាក់លាក់ ទោះបីជាមានលក្ខណៈមិនរើសអើងក៏ដោយ - ព្រោះវាត្រូវអនុវត្តរបៀបតែមួយចំពោះប្រជាជនគ្រប់គ្នា - ព្រោះថាវាបានបង្កឱ្យមានផលប៉ះពាល់ជាក់លាក់លើជនជាតិចាម។

៩៥៥. តាមការពិតទៅ អង្គជំនុំជម្រះបានប៉ុនប៉ងកំណត់ថាជាការរើសអើងដោយប្រយោល តែមិននិយាយឱ្យចំ។ ធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺ អង្គជំនុំជម្រះមិនបានពន្យល់ ថាតើការរើសអើងជាក់ស្តែង ក្នុងន័យទូលាយដែលមានរាប់បញ្ចូលការរើសអើងដោយប្រយោល ត្រូវបានដាក់បញ្ចូលក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ នៅឆ្នាំ១៩៧៥ ដោយរបៀបណា។ ការរើសអើងដោយប្រយោល មិនមែនជាសញ្ញាណនៃនីតិព្រហ្មទណ្ឌនោះទេ តែជាសញ្ញាណនៃសិទ្ធិមនុស្សដែលទើបតែមាននាពេលថ្មីៗនេះប៉ុណ្ណោះ។ នៅក្នុងគណៈកម្មាធិការសិទ្ធិមនុស្ស ទស្សនាទាននៃការរើសអើងដោយប្រយោល បានលេចឡើងនៅក្នុងឆ្នាំ១៩៩៥[1752]។ គឺទើបតែចាប់ពីចុងទសវត្សរ៍ឆ្នាំ

---

[1750] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣០៖ "អង្គជំនុំជម្រះយល់ឃើញថា អំពើដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមនេះ បានរំលោភបំពានលើសិទ្ធិ និងសេរីភាពជាមូលដ្ឋានជាច្រើន ទាក់ទងនឹងការផ្លាស់ទីលំនៅ សេចក្តីថ្លៃថ្នូរបុគ្គល សេរីភាព និងសន្តិសុខ សេរីភាពពីការចាប់ខ្លួនតាមទំនើងចិត្ត ឬដោយខុសច្បាប់ ការជំនុំជម្រះជាសាធារណៈ និងយុត្តិធម៌ និងសមភាពនៅចំពោះមុខច្បាប់"។

[1751] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨។

[1752] គណៈកម្មាធិការសិទ្ធិមនុស្ស *Simunek និងគូកន ទល់នឹង សាធារណរដ្ឋឆេក* សេចក្តីកត់សម្គាល់ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៥ សំណុំរឿងលេខ CCPR/C/54/D/516/1992 កថាខណ្ឌ ១១.៧៖ "ដោយមិនរងឥទ្ធិពលដោយហេតុផលនយោបាយ ច្បាប់មួយអាចល្មើសលើមាត្រា ២៦ ប្រសិនបើវាមានឥទ្ធិពលរើសអើង", *Althammer និងគូកន ទល់នឹង ប្រទេសអូទ្រីស* សេចក្តីកត់សម្គាល់ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៣ សំណុំរឿងលេខ 998/2001, CCPR/C/78/D/998/2001 កថាខណ្ឌ ១០.២៖ "គណៈកម្មាធិការសូមរំឭក

២០០០ ប៉ុណ្ណោះ ដែលវាត្រូវបានទទួលស្គាល់ក្នុងយុត្តិសាស្ត្ររបស់តុលាការសិទ្ធមនុស្សអឺរ៉ុប ទាក់ទងនឹងការរើសអើង។ ទស្សនាទាននេះត្រូវបានដាក់បញ្ចូលដោយសន្សឹមៗដោយតុលាការសិទ្ធិមនុស្សអឺរ៉ុបទៅក្នុងសាលដីកា *Hugh Jordan ទល់នឹង ប្រទេសអង់គ្លេស* ក្នុងឆ្នាំ២០០១[1753]។ ទើបតែមកដល់ឆ្នាំ២០០៧ ប៉ុណ្ណោះ ដែលវាត្រូវបានចែងដោយសាលដីការបស់អង្គជំនុំជម្រះជាន់ខ្ពស់ ក្នុងរឿងក្តី *D.H. និងអ្នកឯទៀត ទល់នឹងសាធារណរដ្ឋឆែក* ដែលលើកឡើងថា "ភាពខុសគ្នាក្នុងការប្រព្រឹត្តិក៏អាចជាផលប៉ះពាល់អសមាមាត្រនៃគោលនយោបាយ ឬវិធានការមួយ ដែលទោះបីជាត្រូវតាក់តែងឡើងដោយអព្យាក្រឹតក៏ដោយ ក៏វាមានឥទ្ធិពលរើសអើងលើក្រុម [...] ស្ថានភាពបែបនេះត្រូវបានវិភាគថាជា "ការរើសអើងដោយប្រយោល" ដែលមិនតម្រូវចាំបាច់ឱ្យមានចេតនារើសអើង"[1754]។

៩៥៦. ជាសារវន្ត សញ្ញាណនៃការរើសអើងដោយចេតនាប្រយោល ដែលមិនតម្រូវឱ្យមានចេតនារើសអើង គឺមិនត្រូវគ្នានឹងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដូចបានកំណត់និយមន័យនៅសម័យកាលនៃអង្គហេតុនោះទេ។ ដូច្នេះ "ការរើសអើងជាក់ស្តែង" ដែលជាធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញ នៅសម័យកាលអង្គហេតុ គឺពុំបានរាប់បញ្ចូលការរើសអើងជាក់

---

ថា ការរំលោភលើមាត្រា ២៦ អាចបណ្តាលមកផងដែរពីឥទ្ធិពលរើសអើងនៃវិធានមួយ ឬវិធានការមួយដែលមើលទៅហាក់ដូចជាអព្យាក្រឹត ឬគ្មានចេតនារើសអើងអ្វីសោះ។ (៧) យ៉ាងណាមិញ គេអាចនិយាយបានថាការរើសអើងដោយប្រយោលនេះ បានផ្អែកលើហេតុផលដែលមានចែងនៅក្នុងមាត្រា ២៦ នៃកតិកាសញ្ញា បានតែក្នុងករណីថាផលប៉ះពាល់នៃវិធានមួយ ឬសេចក្តីសម្រេចមួយធ្វើ ឱ្យប៉ះពាល់តែទៅលើ ឬជាលក្ខណៈអសមាមាត្រចំពោះមនុស្សជាក់លាក់មួយចំនួន ដោយមូលហេតុជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀត ដើមកំណើតជាតិសាសន៍ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀត។ លើសពីនេះទៀត វិធាន និងសេចក្តីសម្រេចដែលមានផលប៉ះពាល់នេះ គឺពុំមែនជាការរើសអើងនោះទេ ប្រសិនបើវាសំអាងលើមូលហេតុសត្យានុម័តិ និងសមហេតុសមផល"។

[1753] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Hugh Jordan ទល់នឹង ប្រទេសអង់គ្លេស* (សំណើលេខ 24746/94) ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ ១៥៤៖ "នៅពេលដែលគោលនយោបាយ ឬវិធានការមួយ មានផលប៉ះពាល់អសមាមាត្រទៅលើក្រុមមួយជាក់លាក់ គេមិនបដិសេធទេដែលថាវាអាចត្រូវចាត់ទុកថាជាការរើសអើង បើទោះជាគ្មានគោលបំណង ឬសំដៅដោយជាក់លាក់លើក្រុមនោះក៏ដោយ"។

[1754] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *D.H. និងអ្នកឯទៀត ទល់នឹងសាធារណរដ្ឋឆែក* (សំណើលេខ 57325/00) ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ១៨៤។

ស្តែងដោយប្រយោលនោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ធាតុផ្សំសត្យានុម័តិនៃការធ្វើទុក្ខបុកម្នេញ ត្រូវបានបំពេញបានទេ ក្នុងករណីជាក់ស្តែងនេះ។

## ៥.២. គ្មានចេតនារើសអើង ចំពោះការប្រតិបត្តិសាសនា/វប្បធម៌

៩៥៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថាការកំហិតដែលត្រូវបានបង្ហាញ គឺត្រូវបង្កើតឡើងក្នុងចេតនាធ្វើការរើសអើងចំពោះជនជាតិចាម ដោយមូលហេតុនៃការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ[1755]។ ក៏ប៉ុន្តែ ពុំមានភ័ស្តុតាងអំពីចេតនារើសអើងណាមួយ ដោយមូលហេតុសាសនានោះឡើយ (៥.២.១)។ បន្ទាប់មកទៀត អង្គជំនុំជម្រះមានកំហុស ដោយពុំបានពន្យល់ថាតើជនជាតិចាមអាចត្រូវបានធ្វើទុក្ខបុកម្នេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយមូលហេតុនយោបាយ និងសាសនា ក្នុងពេលតែមួយបានដូចម្តេចទៅ (៥.២.២)។

### ៥.២.១. គ្មានភ័ស្តុតាងអំពីចេតនារើសអើងដោយមូលហេតុសាសនា

៩៥៨. អង្គជំនុំជម្រះមិនអាចកំណត់ពីមូលហេតុនៃការរើសអើងចំពោះជនជាតិចាម ក្នុងឋានៈជាក្រុមសាសនា ដោយគ្រាន់តែប្រកាសថា វិធានការទាំងឡាយដែលរងការចោទប្រកាន់ ត្រូវបាន "ប្រព្រឹត្តដោយមានការពិចារណាយ៉ាងហ្មត់ចត់ និងដោយចេតនា ក្នុងគោលបំណងរើសអើងប្រឆាំងនឹងជនជាតិចាម <u>ដោយសារតែការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ</u>" បានទេ[1756]។ អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុតាមច្បាប់ចំពោះសេចក្តីសន្និដ្ឋានគតិយុត្តិមួយឡើយ។ អង្គជំនុំជម្រះមិនបានចង្អុលបង្ហាញការយោងណាមួយនៅក្នុងកំណត់សម្គាល់ជើងទំព័រ។ អង្គជំនុំជម្រះទំនងជាផ្អែកលើមូលដ្ឋានសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវរបស់ខ្លួនដែលថា មានវិធានការដែលបង្កផលប៉ះពាល់លើការប្រតិបត្តិសាសនា និងវប្បធម៌ ដើម្បីសន្និដ្ឋានថាមានចេតនារើសអើង។ ក៏ប៉ុន្តែ វាជាធាតុផ្សំពីរផ្សេងគ្នា ដែលចាំបាច់ត្រូវមានសំអាងហេតុសម្រាប់ធាតុផ្សំនីមួយៗ។ លើសពីនេះទៀត ដូចដែលបានបង្ហាញឱ្យឃើញពីខាងលើ

---

[1755] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៩។

[1756] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

អង្គជំនុំជម្រះប៉ុនប៉ងកំណត់ការរើសអើងជាក់ស្តែងដោយប្រយោល ដោយគ្មានចេតនារើសអើង[1757]។ ជាចុងក្រោយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុវប្បធម៌ ពុំមាននៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិទេ។ ដូច្នេះ គឺមានតែការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាប៉ុណ្ណោះ ដែលអាចផ្សំបានជាឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការ ហើយការធ្វើទុក្ខបុកម្នេញនេះ មិនត្រូវបានបង្ហាញឱ្យឃើញ ហួសពីវិមតិសង្ស័យនោះទេ។

## ៥.២.២. វិសមិតភាពនៃសេចក្តីសន្និដ្ឋានទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា

៩៥៩. នៅក្នុងផ្នែកនៃការកំណត់ប្រភេទបទល្មើស ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ អង្គជំនុំជម្រះបានសន្និដ្ឋានថាជនជាតិចាម ក្នុងឋានៈជាក្រុមនយោបាយ ត្រូវបានកំណត់ជាគោលដៅនៃការរើសអើង ដោយហេតុថាពួកគេត្រូវបានចាត់ទុកជាខ្មាំង ដោយសារការបះបោររបស់ពួកគេនៅក្នុងភូមិភាគបូព៌ា[1758]។ នៅក្នុងផ្នែកនៃការកំណត់បទចោទប្រកាន់ ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អង្គជំនុំជម្រះបានសន្និដ្ឋានដោយខ្លីថា ការរើសអើងដែលរងការចោទប្រកាន់ត្រូវបានបង្កើតឡើង "ដោយចេតនាក្នុងការរើសអើងប្រឆាំងនឹងជនជាតិចាម ដោយសារតែការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ"[1759]។ អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាខ្លួនធ្វើការផ្លាស់ប្តូរមូលហេតុនៃការធ្វើទុក្ខបុកម្នេញ ក្នុងការវិភាគរបស់ខ្លួនលើបទចោទប្រកាន់ពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។ បើតាមចៅក្រមដដែលៗ តើជនជាតិចាមមិនត្រូវបានកំណត់ជាគោលដៅ ដោយសារការបះបោររបស់ពួកគេនៅក្នុងភូមិភាគបូព៌ាទេឬ? ការមិនបានផ្តល់ការវិនិច្ឆ័យត្រង់ចំណុចនេះដោយអង្គជំនុំជម្រះ ធ្វើឱ្យសេចក្តីសន្និដ្ឋានទាំងឡាយរបស់ខ្លួនក្លាយជាមោឃៈ។

---

[1757] សូមមើលខាងលើ កថាខណ្ឌ ៩៥៤-៩៥៦។

[1758] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៣។

[1759] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៩។

## ៥.៣. ការរំលោភលើសិទ្ធិជាមូលដ្ឋាន

៩៦០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានធ្វើការកំណត់លើការរំលោភលើសិទ្ធិជាមូលដ្ឋានតាមរយៈអង្គហេតុខុសពីអង្គហេតុដែលកំណត់ពីការរើសអើងជាក់ស្តែង។ គ្មានការរឹតត្បិតណាមួយក្នុងចំណោមការរឹតត្បិតទាំងឡាយដែលត្រូវរៀបរាប់ និងដែលអង្គជំនុំជម្រះបានយោងដើម្បីកំណត់អំពីការរើសអើងជាក់ស្តែង បានរំលោភលើសិទ្ធិជាមូលដ្ឋានដែលមានក្នុងបញ្ជីទេ។ បើយោងតាមអង្គជំនុំជម្រះ "អំពើ" រើសអើង មានដូចតទៅ៖ "[១] ការហាមឃាត់ការអធិដ្ឋានជារៀងរាល់ថ្ងៃ [២] ការបង្ខំជនជាតិចាមឱ្យបរិភោគសាច់ជ្រូក [៣] និងការឱ្យស្លៀកពាក់សម្លៀកបំពាក់ និងកាត់សក់ដូចប្រជាជនខ្មែរ [៤] ការបង្ខំឱ្យពួកគេនិយាយតែភាសាខ្មែរ [៥] ការដុតគម្ពីរសាសនា [៦] និងការរុះរើវិហារអ៊ីស្លាម ឬប្រើសម្រាប់គោលបំណងផ្សេងក្រៅពីការអធិដ្ឋាន [៧] អ្នកដែលប្រឆាំងនឹងត្រូវចាប់ខ្លួន និង/ឬយកទៅសម្លាប់"[1760]។

៩៦១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអះអាងថា អំពើទាំងនេះ "បានរំលោភបំពានលើសិទ្ធិ និងសេរីភាពជាមូលដ្ឋានជាច្រើន ទាក់ទងនឹងការផ្លាស់ទីលំនៅ សេចក្តីថ្លៃថ្នូរបុគ្គល សេរីភាព និងសន្តិសុខ សេរីភាពពីការចាប់ខ្លួនតាមទំនើងចិត្ត ឬដោយខុសច្បាប់ ការជំនុំជម្រះជាសាធារណៈ និងយុត្តិធម៌ និងសមភាពនៅចំពោះមុខច្បាប់ ដូចមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[1761]។ នៅក្នុងកថាខណ្ឌនេះ គេគួរគួសបញ្ជាក់ថាអង្គជំនុំជម្រះមិនបានចាត់ទុកថាអំពើទាំងនេះធ្វើឱ្យប៉ះពាល់ដល់សេរីភាពសាសនានោះទេ។ ជាពិសេស អង្គជំនុំជម្រះមិនបានពន្យល់ថាតើការរឹតត្បិតទាំងឡាយចំពោះការប្រតិបត្តិសាសនា និងវប្បធម៌របស់ជនជាតិចាម ដែលត្រូវបានជ្រើសរើសសម្រាប់ធ្វើជាមូលដ្ឋាននៃការរើសអើងជាក់ស្តែង បានរំលោភលើសេរីភាព និងសិទ្ធិជាមូលដ្ឋានដែលមានរៀបរាប់នៅកថាខណ្ឌ ៣៣៣០ នៃសំអាងហេតុសាលក្រម ដោយរបៀបណា។

[1760] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣២៨។

[1761] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣០។

## ៥.៤. កម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើដែលកំណត់ការរើសអើងជាក់ស្តែង

៩៦២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានធ្វើការវាយតម្លៃពីកម្រិតនៃភាពធ្ងន់ធ្ងរនៃ "ការប្រព្រឹត្តិបែបរើសអើង" ដោយធ្វើមិនដឹងពីអង្គហេតុពិពណ៌នានៅក្នុងផ្នែកវិចារណកិច្ចរបស់ខ្លួនដែលកំណត់ពីការចោទប្រកាន់ចំពោះការប្រព្រឹត្តិបែបរើសអើង។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានកំណត់អំពីកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើរើសអើងដែលជាលក្ខខ័ណ្ឌតម្រូវ តាមរយៈ៖

> "អំពើដែលបានរកឃើញដោយឡែកថា បង្កើតបានជាបទល្មើសជាក់លាក់ផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (រួមមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្នុងអំឡុងពេលផ្លាស់ទីលំនៅដំណាក់កាលទី២ (រួមទាំង ការធ្វើទារុណកម្ម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការផ្លាស់ទីលំនៅដោយបង្ខំ) ព្រមទាំងអំពើដែលមិនចាំបាច់ថាបង្កើតបានជាបទល្មើសផងដែរ (ជាពិសេស ការចាប់ខ្លួន)"[1762]។

៩៦៣. ជាបឋម អំពើទាំងអស់ដែលត្រូវបានបង្ហាញនៅក្នុងដំណាក់កាលនេះនៃការវិនិច្ឆ័យ ពុំត្រូវបានកំណត់ថាជាការប្រព្រឹត្តិបែបរើសអើង នៅត្រង់កថាខណ្ឌ ៣៣២៨ នៃផ្នែកសំអាងហេតុសាលក្រមទេ។ អង្គជំនុំជម្រះមិនធ្លាប់ដែលបានចាត់ទុកឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ការធ្វើទារុណកម្ម ឬអំពើប្រល័យពូជសាសន៍ ថាជាធាតុផ្សំដែលជាមូលដ្ឋាននៃការប្រព្រឹត្តិបែបរើសអើង នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាដែលរងការចោទប្រកាន់។ អំពើទាំងអស់នេះមិនអាចត្រូវបានដាក់បញ្ចូលបែបនេះបានឡើយ ដើម្បីវាយតម្លៃពីកម្រិតនៃភាពធ្ងន់ធ្ងរចំពោះការប្រព្រឹត្តិបែបរើសអើងដែលជាលក្ខខ័ណ្ឌតម្រូវសម្រាប់កំណត់ថាជាការធ្វើទុក្ខបុកម្នេញ។ បន្ទាប់មក ដូចដែលបានបង្ហាញឱ្យឃើញពីខាងលើ ធាតុផ្សំនៃឧក្រិដ្ឋកម្មទាំងអស់នេះគឺពុំត្រូវបានបង្ហាញឱ្យឃើញហួសពីវិមតិ

---

[1762] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣១។

សង្ស័យ[1763] ហើយពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ ខៀវ សំផន ត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនេះ។ លើសពីនេះទៀត អង្គជំនុំជម្រះបានសង្កត់ធ្ងន់លើអំពើជាក់លាក់មួយចំនួនដែលត្រូវបានកម្រិតផ្នែកភូមិសាស្ត្រ ដើម្បីកំណត់បទចោទប្រកាន់ថាជាការធ្វើទុក្ខបុកម្នេញសំដៅចំពោះជនជាតិចាម នៅទូទាំងប្រទេស និងក្នុងរយៈកាលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ សេចក្តីបំប្រួញនេះ គឺចោទជាបញ្ហា នៅពេលដែលអង្គជំនុំជម្រះបានប្រើប្រាស់តែធាតុផ្សំអង្គហេតុនៅតាមទីកន្លែងផ្សេងៗ ដើម្បីសម្រេចថាមានគោលនយោបាយជាទូទៅមួយដែលសម្រេចដោយ ប.ក.ក ខណៈដែលគ្មានឯកសារណាមួយជួយគាំទ្រសេចក្តីសន្និដ្ឋានមួយនេះ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា “អំពើទាំងនេះ” បើទោះជាគេមិនអាចកំណត់អត្តសញ្ញាណបានថាមានអ្វីខ្លះក៏ដោយ បានឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរ តាមរយៈឥទ្ធិពលពូនផ្តុំរបស់វា ដើម្បីកំណត់បានថាជាការធ្វើទុក្ខបុកម្នេញ គឺត្រូវទុកជាមោឃៈ[1764]។

## ៦. ការរំលោភលើគោលការណ៍អាជ្ញារស់ជំនុំ

### ៦.១. ការរំឭកពីការគ្មានការចរិតរើសអើងនៃការជម្លៀសដោយបង្ខំ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ

៩៦៤. អង្គជំនុំជម្រះបានផ្តើមធ្វើការវិនិច្ឆ័យ ដោយបានរំឭកឡើងវិញអំពីការទទួលស្គាល់របស់ខ្លួនថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានបង្ហាញឱ្យឃើញចំពោះការផ្លាស់ទីលំនៅប្រជាជនចាមដោយបង្ខំ ពីភូមិភាគបូព៌ាទៅកាន់ភូមិភាគកណ្តាល នៅក្នុងខែកញ្ញា និងខែតុលា ឆ្នាំ១៩៧៥[1765]។ ដូចដែលបានឃើញពីខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានកំណត់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះជនជាតិចាម ខណៈដែលពុំមានភ័ស្តុតាងពីការរើសអើងជាក់ស្តែងចំពោះជនជាតិចាម ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ហើយដែលការបំបែកពួកគេគឺគ្មានគោលបំណងចម្បងធ្វើឱ្យ

---

[1763] សូមមើលខាងលើ កថាខណ្ឌ ៨៩៤-៩៦៥។

[1764] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣១។

[1765] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣៦ កំណត់សម្គាល់ជើងទំព័រលេខ១១២៧៤ យោងទៅ កថាខណ្ឌ ២៩៩៣។

សហគមន៍របស់ពួកគេខ្ចាត់ខ្ចាយនោះទេ[1766]។ ចាប់ពីពេលដែលអង្គជំនុំជម្រះបរាជ័យក្នុងការបង្ហាញឱ្យឃើញថា ការផ្លាស់ទីប្រជាជនចាមក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ គឺជាការរើសអើង អង្គជំនុំជម្រះគួរកត់សម្គាល់ថា ពួកគេត្រូវបានរាប់បញ្ចូលនៅក្នុងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែលធ្លាប់ត្រូវបានពិនិត្យរួចមកហើយដោយចៅក្រមដដែលៗនៅក្នុងសំណុំរឿង ០០២/០១។

## ៦.២. ការរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ

៩៦៥. អង្គជំនុំជម្រះបានសម្រេចសេចក្តីដោយរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ[1767]។ ខៀវ សំផន ធ្លាប់ត្រូវបានវិនិច្ឆ័យសេចក្តី និងផ្តន្ទាទោសជាស្ថាពរចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ នៅក្នុងក្របខ័ណ្ឌនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ[1768]។ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានបញ្ជាក់អះអាងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានបង្ហាញទាក់ទងនឹងអង្គហេតុនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ សម្រាប់ “៣០០.០០០ ទៅ ៤០០.០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅ នៅចន្លោះពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៧ ពីភូមិភាគមួយទៅភូមិភាគមួយទៀត”[1769]។ ពាក់ព័ន្ធនឹងលក្ខណៈរើសអើងដែលរងការចោទប្រកាន់នៃការជម្លៀសប្រជាជននេះ តុលាការកំពូលបានអះអាងថា “ពុំអាចនិយាយបានថា មានការបង្ហាញឱ្យឃើញថា ការផ្លាស់ទីលំនៅប្រជាជនត្រូវបានធ្វើឡើងក្នុងលក្ខណៈរើសអើង ឬដោយចេតនារើសអើង” ហើយ “ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ពុំមែនជាការរើសអើង ឬកើតចេញពីចេតនាធ្វើទុក្ខបុកម្នេញ” នោះទេ[1770]។ ការផ្លាស់ទីលំនៅប្រជាជនចាម ត្រូវបានធ្វើពីភូមិភាគបូព៌ា ឆ្ពោះទៅកាន់ភូមិភាគ

[1766] សូមមើលខាងលើ កថាខណ្ឌ ៩២៦-៩៣១។

[1767] សូមមើលខាងលើ កថាខណ្ឌ ៥៤៤-៥៤៦។

[1768] សូមមើលខាងលើ កថាខណ្ឌ ៥៤៦ និងសាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ផ្នែកសម្រេចសេច ក្តី។

[1769] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៦៥៨។

[1770] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧០៥-៧០៦។

កណ្តាល ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ និងក្នុងខែតុលា ឆ្នាំ១៩៧៥[1771]។ ដូច្នេះ អង្គហេតុទាំងនេះធ្លាប់ត្រូវបានជំនុំជម្រះជាស្ថាពររួចហើយ ហើយសាលដីកាសំណុំរឿង ០០២/០១ មានអានុភាពអាជ្ញាអស់ជំនុំ ទាក់ទងនឹងអង្គហេតុទាំងនេះ។

## ផ្នែកទី ២. ជនជាតិវៀតណាម

### ១. ការនិរទេស

៩៦៦. ជាចម្បង យើងត្រូវរំឭកថា អង្គជំនុំជម្រះបានទទួលបណ្តឹងមិនជាក់ស្តែងអំពី អង្គហេតុដែលជាធាតុផ្សំនៃការនិរទេស ដែលហាមឃាត់រាល់ការផ្តន្ទាទោស ទាក់ទងនឹងអង្គហេតុទាំងនេះ[1772]។ ប៉ុន្តែ ក្រៅពីកំហុសអង្គច្បាប់នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការនិរទេស ត្រូវបានប្រព្រឹត្ត ដោយហេតុថា "ចំនួនប្រជាជនវៀតណាមដ៏ច្រើនដែលត្រូវបានបណ្តេញចេញពីខេត្តព្រៃវែង នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦" បាននោះទេ[1773]។ ទោះបីជាអង្គជំនុំជម្រះមិនមានហេតុផលត្រឹមត្រូវក្នុងការនិយាយសរុបជាទូទៅយ៉ាងណាក៏ដោយ (១.១) ក៏បើយោងតាមភ័ស្តុតាង អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានដាច់ខាតថាមានការបណ្តេញជនជាតិវៀតណាម (១.២) ក្នុងបរិយាកាសបង្ខិតបង្ខំ (១.៣) ឬថាមានចេតនានិរទេសពួកគេនោះឡើយ (១.៤)។

### ១.១. ការសន្និដ្ឋានពង្រីកមិនសមហេតុផលរបស់អង្គជំនុំជម្រះ

៩៦៧. អង្គជំនុំជម្រះបានពិចារណា ករណីជាក់លាក់មួយចំនួននៃគ្រួសារមកពីភូមិចំនួនបីនៅក្នុងខេត្តព្រៃវែង ដែលត្រូវបានប្រមូល និងជម្លៀសតាមទូក[1774]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាខ្លួនសន្និដ្ឋានថា បើតាមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី "ជនជាតិវៀតណាមជាច្រើននាក់ត្រូវ

[1771] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៣៦ កំណត់សម្គាល់ជើងទំព័រលេខ១១២៧៤ យោងទៅ កថាខណ្ឌ ២៩៩៣។

[1772] សូមមើលខាងលើ កថាខណ្ឌ ៣៨០-៣៨៥។

[1773] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៧។

[1774] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៥។

ប្រមូល [នៅទូទាំងខេត្តព្រៃវែង] និងជម្លៀសចេញ"[1775]។ ដូចគ្នាដែរសម្រាប់សេចក្តីសន្និដ្ឋានដែលថាជនជាតិវៀតណាម "ដ៏ច្រើន" ត្រូវបានបណ្តេញចេញពីខេត្តព្រៃវែង[1776]។

៩៦៨. ដោយសារតែភស្តុតាងដែលត្រូវបានបង្ហាញសំដៅតែលើភូមិចំនួនបី សេចក្តីសន្និដ្ឋានទាំងឡាយរបស់អង្គជំនុំជម្រះ គឺជាការសន្និដ្ឋានពង្រីកមិនសមហេតុផលយ៉ាងច្បាស់។ សេចក្តីសន្និដ្ឋានទាំងនោះរឹតតែត្រូវបដិសេធចោលថែមទៀត ព្រោះថាភស្តុតាងមិនអាចបង្ហាញឱ្យឃើញពីករណីជាក់លាក់នៃការនិទេសគ្រួសារចេញពីភូមិទាំងបីនេះទេ។

## ១.២. អលទ្ធភាពក្នុងការបង្ហាញករណីប្រមូល និងបណ្តេញជនជាតិវៀតណាម

៩៦៩. សម្រាប់អង្គហេតុនៃការនិរទេសនៅក្នុងខេត្តព្រៃវែង អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មចំនួនពីរក្នុងពេលសវនាការ[1777] កំណត់ហេតុស្តាប់ចម្លើយពីរ[1778] និងឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយ[1779]។ ក៏ប៉ុន្តែ ដើម្បីអាចបង្ហាញឱ្យឃើញពីករណីនៃការនិរទេស អង្គជំនុំជម្រះមិនស្ទាក់ស្ទើរនឹងរំលោភលើគោលការណ៍វាយតម្លៃភស្តុតាងដែលខ្លួនឯងជាអ្នកថែងដោយផ្ទាល់នោះទេ។

### ១.២.១. ការបំភ្លៃសក្ខីកម្មរបស់ សៅ សាក់

៩៧០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើសក្ខីកម្មរបស់ សៅ សាក់ ដើម្បីសន្និដ្ឋានថាជនជាតិវៀតណាមនៅភូមិអន្លង់ទ្រា ត្រូវបានបណ្តេញចេញទៅប្រទេសវៀតណាម។ អង្គជំនុំជម្រះមិនបាន

[1775] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1776] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៧។

[1777] សៅ សាក់ បានមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ និងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥។ ដួង អឿន បានមកផ្តល់សក្ខីកម្មក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦។

[1778] កំណត់ហេតុនៃការស្តាប់ចម្លើយ ឯម ប៊ុននីម ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៩ ឯកសារ **E3/7760**, កំណត់ហេតុនៃការស្តាប់ចម្លើយ ប៊ុន រើន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ឯកសារ **E3/7811**។

[1779] ឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពៅ ហុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ **E3/7165a**។

ពិចារណាលើសក្ខីកម្មទាំងមូល ដែលនាំឱ្យមានការបំភ្លៃសក្ខីកម្មរបស់គាត់។ អង្គជំនុំជម្រះបានអះអាងថា សៅ សាក់ បានឃើញគេប្រមូលវៀតណាមនៅភូមិរបស់គាត់[1780]។ ក៏ប៉ុន្តែ នៅកន្លែងផ្សេងនៃសក្ខីកម្មរបស់គាត់ គាត់បានពន្យល់ថាមិនបានឃើញព្រឹត្តិការណ៍ទាំងនេះទេ ដោយគាត់បញ្ជាក់ថាវាកើតឡើងដោយគេមិនបានឃើញ ច្រើនតែពេលយប់[1781]។ យោងតាមភាពផ្ទុយគ្នាទាំងនេះ អង្គជំនុំជម្រះមិនបានពន្យល់ថាហេតុអ្វីបានជាជ្រើសរើសយករឿងរ៉ាវមួយជាជាងយករឿងរ៉ាវមួយទៀត។

៩៧១. អង្គជំនុំជម្រះបានអះអាងដែរថា សាក្សីបានឮគេនិយាយថាជនជាតិវៀតណាមដែលត្រូវប្រមូល ត្រូវបញ្ជូនទៅខាងក្រោម គឺមានន័យថាប្រទេសវៀតណាម[1782]។ ប៉ុន្តែ អង្គជំនុំជម្រះបានបំភ្លេចផ្នែកនៃសក្ខីកម្មរបស់ សៅ សាក់ ដែលបញ្ជាក់ថា តាមការពិតទៅ ជនជាតិវៀតណាមមិនត្រូវបានបញ្ជូនទៅប្រទេសវៀតណាមទេ។ សៅ សាក់ និយាយថា ដឹងថា អ្នកទាំងនោះត្រូវបានបញ្ជូនទៅសម្លាប់នៅកន្លែងមួយ តែក៏មិនបានបញ្ជាក់ថាទីណាដែរ[1783]។ ម្យ៉ាងវិញទៀត ចម្លើយផ្ទុយគ្នា និងមិនច្បាស់លាស់ទាំងអស់នេះ គឺផ្អែកលើការឮតពីគេ។ អង្គជំនុំជម្រះមិនអាចផ្អែកលើចម្លើយទាំងនេះបានទេ។

៩៧២. លើសពីនេះទៀត អង្គជំនុំជម្រះមិនបានយកចិត្តទុកដាក់ធ្វើការបញ្ជាក់ពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍ទាំងនេះទេ។ ព័ត៌មាននេះគឺពិតជាសំខាន់ ព្រោះថាបើតាមការបកស្រាយដែលអង្គជំនុំជម្រះបានធ្វើ ទាក់ទងនឹងវិសាលភាពនៃបណ្ដឹង អង្គហេតុនៃការនិរទេសគឺកម្រិតត្រឹមឆ្នាំ១៩៧៥ និង ១៩៧៦ ប៉ុណ្ណោះ។ ក្នុងពេលផ្ដល់សក្ខីកម្ម សៅ សាក់ បានបង្ហាញចំណុចដៅប្រវត្តិសាស្ត្រចំនួនពីរដែលមិនស្របគ្នា។ ជាដំបូងគាត់បាននិយាយថាវាកើតឡើង “នៅក្រោយព្រឹត្តិការណ៍ សោ ភឹម”[1784] ព្រោះថា “បើតាម [គាត់] គិតទៅ តាំងពីយើងចប់សង្គ្រាម លន់ នល់”[1785]។ ព្រឹត្តិការណ៍ទីមួយ កើតឡើងនៅឆ្នាំ១៩៧៨ ហើយទីពីរ

---

[1780] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣០។

[1781] ប្រតិចារឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/363.1** ក្រោយម៉ោង ០៩.៤៣.០៣។

[1782] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣០។

[1783] ប្រតិចារឹក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** ក្រោយម៉ោង ១៥.១៩.៣១។

[1784] ប្រតិចារឹក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** ក្រោយម៉ោង ១៥.២១.០៥។

[1785] ប្រតិចារឹក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** ក្រោយម៉ោង ១៥.២២.២៥។

ចាប់ផ្តើមពីឆ្នាំ១៩៧០។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសម្រេចថាព្រឹត្តិការណ៍ទាំងនេះ បានកើតឡើងនៅឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៦ បានទេ។

៩៧៣. យោងតាមភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះមិនអាចសំអាងលើសក្ខីកម្មរបស់ សៅ សាក់ ដើម្បីសន្និដ្ឋានថាជនជាតិវៀតណាមនៅភូមិអន្លង់ទ្រា នៅក្នុងខេត្តព្រៃវែង ត្រូវបាននិរទេសទៅកាន់ប្រទេសវៀតណាមបានឡើយ។

### ១.២.២. កំហុសក្នុងការសំអាងលើកំណត់ហេតុស្តាប់ចម្លើយ

៩៧៤. កំណត់ហេតុទាំងពីរដែលជ្រើសរើសដោយអង្គជំនុំជម្រះ ក៏មិនអាចឱ្យគេសន្និដ្ឋានបានថាជនជាតិវៀតណាមនៅភូមិអន្លង់ទ្រា ត្រូវបាននិរទេសទៅកាន់ប្រទេសវៀតណាមបាននោះដែរ[1786]។ ជាបឋម បុគ្គលទាំងនោះមិនអាចត្រូវបានសួរដេញដោលក្នុងពេលសវនាការដើម្បីទទួលបានការស្រាយបំភ្លឺ ទាក់ទងនឹងព័ត៌មានដែលត្រូវបានរាយកាណ៍នៅក្នុងចម្លើយរបស់ពួកគាត់។ ដូច្នេះ កំណត់ហេតុទាំងនោះមានតម្លៃជាភ័ស្តុតាងតិចតួច និងមិនអាចប្រើធ្វើជាមូលដ្ឋានតែឯងដើម្បីបង្ហាញពីធាតុផ្សំនៃបទឧក្រិដ្ឋ[1787]។

៩៧៥. សក្ខីកម្មរបស់ ឯម ប៊ុននីម បានបង្ហាញថា ដោយសារតែគាត់នៅតូចនៅឡើយពេលដែលអង្គហេតុកើតឡើង គាត់មិនដែលបានចូលរួមប្រជុំ និងមិនបានដឹងពីផែនការណាមួយក្នុងការបណ្តេញជនជាតិវៀតណាមនោះទេ។ គាត់មិនបានពន្យល់ថាតើគាត់បានដឹងដោយរបៀបណាថាអាជ្ញាធរស៊ីវិលបានអំពាវនាវឱ្យជនជាតិវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ និងថាតើក្នុងកាលៈទេសៈបែបណាដែលគាត់អាចបានឃើញទូកដឹកជនជាតិវៀតណាមធ្វើដំណើរសំដៅទៅអ្នកលឿង[1788]។ ចម្លើយរបស់ ប៊ុនរើន ក៏មិនច្បាស់លាស់ខ្លាំងណាស់ដែរ។ គាត់មិនបានបញ្ជាក់ថាមានអ្វីកើតឡើងចំពោះកូនជនជាតិវៀតណាមដែលអង្គជំនុំជម្រះបាននិយាយ និងថាតើក្មេងនោះពិតជាត្រូវបានហៅទៅមែនឬយ៉ាងណា។

---

[1786] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣០។

[1787] សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥។

[1788] កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៩ ឯកសារ **E3/7760** ERN 00296235។

ដូច្នេះ ព័ត៌មានដែលថាជនជាតិវៀតណាមត្រូវបានបញ្ជូនទៅប្រទេសវៀតណាម គឺផ្អែកលើការឮគេនិយាយតគ្នា[1789]។ បើមើលតាមកង្វះភាពច្បាស់លាស់ កង្វះភាពទុកចិត្តបាន និងតម្លៃជាភ័ស្តុតាងតិចតួចនៃកំណត់ហេតុស្តាប់ចម្លើយទាំងនេះ អង្គជំនុំជម្រះមិនគួរណាយកមកធ្វើជាសំអាងនោះទេ។

៩៧៦. ម្យ៉ាងវិញទៀត គ្មានភ័ស្តុតាងណាមួយបានជួយបញ្ជាក់បន្ថែមលើចម្លើយទាំងនេះទេ។ គេបានឃើញហើយថា សក្ខីកម្មរបស់ សៅ សាក់ ទាក់ទងនឹងជោគវាសនារបស់ជនជាតិវៀតណាម គឺមិនអាចទុកចិត្តបាន និងមិនអាចឱ្យគេកំណត់បានថាវាកើតឡើងនៅពេលណា[1790]។ លើសពីនេះ អង្គហេតុទាំងឡាយដែលលើកឡើងនៅក្នុងចម្លើយផ្សេងៗ គឺខុសៗពីគ្នា។ ដូច្នេះ អង្គហេតុទាំងនោះមិនអាចជួយបញ្ជាក់បន្ថែមឱ្យគ្នាទៅវិញទៅមកបានទេ[1791]។ ដូច្នេះ ដោយផ្អែកលើភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យបានថា ជនជាតិវៀតណាមត្រូវបានប្រមូលនៅក្នុងភូមិអន្លង់ទ្រា ហើយរឹតតែមិនអាចថាជនជាតិវៀតណាមពិតជាបានឆ្លងព្រំដែនវៀតណាមមែននោះដែរ។ ដោយសារថាធាតុផ្សំទាំងនេះមិនអាចត្រូវបានបង្ហាញ ដូច្នេះសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា ជនជាតិវៀតណាមនៅភូមិអន្លង់ទ្រាត្រូវបាននិរទេសទៅកាន់ប្រទេសវៀតណាម គឺត្រូវតែដកចេញ[1792]។

### ១.២.៣. កំហុសក្នុងការសំអាងលើសក្ខីកម្មរបស់ ដួង អឿន

៩៧៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ថាជនជាតិវៀតណាមនៅភូមិពោធិ៍ចិន្តាំ ត្រូវបាននិរទេសទៅប្រទេសវៀតណាម[1793]។ សេចក្តីសន្និដ្ឋាននេះផ្អែកតែទៅលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន[1794]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានលើកឡើងថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលថាជនជាតិវៀតណាមនៅក្នុងភូមិភាគរបស់គាត់ ដូចជា តាគី យាយម៉ាន់ និងកូនចៅរបស់គាត់

---

[1789] កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ឯកសារ **E3/7811** ERN 00271360-61។

[1790] សូមមើលខាងលើ កថាខណ្ឌ ៩៧០-៩៧៣។

[1791] សូមមើលខាងលើ កថាខណ្ឌ ២៤១-២៤២។

[1792] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣៦ និង ៣៥០៥។

[1793] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៥-៣៥០៧។

[1794] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣១។

ត្រូវត្រឡប់ទៅប្រទេសវៀតណាមវិញ គឺផ្អែកលើការឮតពីគេ[1795]។ អង្គជំនុំជម្រះបានទទួលស្គាល់ផង ដែរថា កាលៈទេសៈនៃការវិលត្រឡប់នេះ មិនត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់នោះទេ។ ដោយផ្អែក ទៅលើភស្តុតាងមានកម្រិត និងមិនស៊ីចង្វាក់គ្នាទាំងអស់នេះ អង្គជំនុំជម្រះមិនបានពន្យល់ថាតើខ្លួនអាច សន្និដ្ឋានបានដោយរបៀបណាថាជនជាតិវៀតណាមនៅពោធិ៍ចិន្តាំ ត្រូវបាននិរទេសទៅប្រទេសវៀត ណាម។ ដូច្នេះ ដោយសារពុំមានភស្តុតាងផ្ទាល់ និងច្បាស់លាស់ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវតែដកចេញ។

### ១.២.៤. កំហុសក្នុងការសំអាងលើឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៩៧៨. អង្គជំនុំជម្រះមានកំហុស ដោយបានសំអាងលើឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មួយ ដើម្បីសន្និដ្ឋានថាជនជាតិវៀតណាមនៅភូមិអង្គរយសត្រូវបានបណ្តេញចេញ។ ទោះបីជាអង្គជំនុំ ជម្រះយល់ឃើញថាភស្តុតាងមួយនេះមានតម្លៃជាភស្តុតាងតិចតួចក៏ដោយ ក៏អង្គជំនុំជម្រះបានប្រព្រឹត្ត កំហុស ដោយបានអះអាងថាខ្លួនប្រើប្រាស់ភស្តុតាងនេះសម្រាប់តែ “បញ្ជាក់អះអាងអំពីអត្ថិភាពនៃការ ផ្លាស់ទីជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង ក្នុងឆ្នាំ១៩៧៥” ខណៈដែលអង្គជំនុំជម្រះបានទៅហួស ឆ្ងាយពីនេះនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន[1796]។ នៅក្នុងពេលធ្វើការកំណត់ប្រភេទបទល្មើស អង្គជំនុំ ជម្រះយល់ឃើញថាមានការបង្ហាញថា “ករណីជាក់ស្តែងនីមួយៗនៃក្រុមគ្រួសារវៀតណាមដែលត្រូវ បានប្រមូល បញ្ជូនចេញ និងឃើញមានការចាកចេញតាមទូក ត្រូវបានបង្ហាញ [...] នៅភូមិអង្គរយស [...]”[1797]។ ដូច្នេះ អង្គជំនុំជម្រះពុំបានគោរពគោលការណ៍របស់ខ្លួន ទាក់ទងនឹងការវាយតម្លៃភស្តុតាង [1798]។ សេចក្តីសន្និដ្ឋាននេះដែលផ្អែកតែទៅលើឧបសម្ព័ន្ធនេះ ត្រូវតែដកចេញ។

---

[1795] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣១។

[1796] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣២។

[1797] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៥។

[1798] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៣។ សូមមើលខាងលើ កថាខណ្ឌ ៣១៤-៣១៦។

៩៧៩. អង្គជំនុំជម្រះក៏ពុំអាចប្រើប្រាស់ឧបសម្ព័ន្ធនេះដើម្បី "បញ្ជាក់អះអាងអំពីអត្ថិភាពនៃការផ្លាស់ទីជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង ក្នុងឆ្នាំ១៩៧៥" បាននោះដែរ[1799]។ ម្យ៉ាង ភស្តុតាងផ្សេងៗទៀតដែលត្រូវបានបង្ហាញ មិនបានជួយគាំទ្រសេចក្តីសន្និដ្ឋាននេះទេ។ ម្យ៉ាងទៀត និងជាពិសេសទៀតនោះ អង្គជំនុំជម្រះបានដកចេញសាជាថ្មីពីគោលការណ៍នៃការវាយតម្លៃភស្តុតាង ដោយយល់ថាអង្គហេតុខុសៗគ្នា អាចជួយបញ្ជាក់បន្ថែមឱ្យគ្នាទៅវិញទៅមក[1800]។ អង្គហេតុកើតឡើងនៅក្នុងភូមិអង្គរយស ទាក់ទងនឹងបុគ្គលជាក់លាក់មួយចំនួន គឺមិនអាចជួយបញ្ជាក់បន្ថែមលើអង្គហេតុទាក់ទងនឹងបុគ្គលផ្សេងៗទៀតនៅក្នុងភូមិផ្សេងៗទៀតបានឡើយ។ ជាចុងក្រោយ បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធនេះ ពោលគឺគ្រួសាររបស់ឈ្មោះ ហុង ត្រូវត្រឡប់បកក្រោយវិញ ដោយសារត្រូវគេចាត់ទុកថាជាជនជាតិខ្មែរ[1801]។ វាច្បាស់ណាស់ថា អង្គជំនុំជម្រះមិនអាចជ្រើសយកអង្គហេតុទាំងនេះដើម្បីសន្និដ្ឋានថាមានការបណ្តេញមនុស្សឆ្លងកាត់ព្រំដែនវៀតណាមបានទេ។

៩៨០. **សេចក្តីសន្និដ្ឋាន**។ បើពិនិត្យមើលជារួម ភស្តុតាងមិនអាចឱ្យគេសន្និដ្ឋានថា ករណីគ្រួសារជាក់លាក់ត្រូវបានប្រមូល និងជម្លៀសតាមទូកនៅក្នុងភូមិអន្លង់ទ្រា ភូមិពោធិ៍ចិន្តាំ និងភូមិអង្គរយសបាននោះទេ[1802]។ ភស្តុតាងនេះរឹតតែមិនអាចឱ្យគេសន្និដ្ឋានបានថា គ្រួសារទាំងនេះពិតជាត្រូវបានបណ្តេញចូលទៅក្នុងព្រំដែនវៀតណាមនោះដែរ។ ដូច្នេះ ដោយពុំមានធាតុផ្សំទាំងនេះនៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការនិរទេសជនជាតិវៀតណាមនៅខេត្តព្រៃវែងបានទេ។ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះ[1803]។

## ១.៣. កំហុសក្នុងការពិចារណាលើលក្ខណៈបង្ខំនៃការបណ្តេញចេញ

[1799] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣២។

[1800] សូមមើលខាងលើ កថាខណ្ឌ ២៤១-២៤២។

[1801] ឧបសម្ព័ន្ធនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពៅ ហុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ **E3/7165a** ERN 00502653។

[1802] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០៥។

[1803] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០២-៣៩០៧ និង ៤៣០៦។

៩៨១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសម្រេចថាមានការបង្ហាញថា "ការចាកចេញរបស់ប្រជាជនវៀតណាមពីខេត្តព្រៃវែង និងស្វាយរៀង នៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ត្រូវបានធ្វើឡើងដោយបង្ខំ"[1804]។

៩៨២. ពាក់ព័ន្ធនឹងខេត្តស្វាយរៀង អង្គជំនុំជម្រះយល់ឃើញថាខ្លួនមិនអាចបង្ហាញឱ្យឃើញអំពីករណីនៃការនិរទេសជនជាតិវៀតណាមឱ្យហួសពីវិមតិសង្ស័យបានឡើយ។ ក្នុងករណីណាក៏ដោយ ការធ្វើសេចក្តីសន្និដ្ឋានថា "ទំនងជាថា"[1805] គឺជាការរំលោភលើគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយមិនបានគោរពបទដ្ឋាននៃភស្តុតាងក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ។ ដូច្នេះ គេមិនអាចបង្ហាញឱ្យឃើញថាជនជាតិវៀតណាមត្រូវបានបង្ខំឱ្យចាកចេញពីខេត្តស្វាយរៀងនោះទេ។

៩៨៣. ពាក់ព័ន្ធនឹងខេត្តព្រៃវែង អង្គជំនុំជម្រះយល់ឃើញថា ជនជាតិវៀតណាមត្រូវបង្ខំឱ្យចាកចេញពីខេត្តនេះដោយសារបរិយាកាសបង្ខិតបង្ខំបង្កើតឡើងដោយ "គោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់គោលដៅជាសាធារណៈលើប្រជាជនវៀតណាម ការរៀបចំបញ្ជីឈ្មោះ និងការអនុវត្តគោលនយោបាយសែស្រឡាយខាងម្តាយ"[1806]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើនដែលមិនអាចឱ្យសន្និដ្ឋានថាមានគោលនយោបាយមួយនេះ និងគោលនយោបាយសែស្រឡាយខាងម្តាយ[1807]។

៩៨៤. លើសពីនេះទៀត ភស្តុតាងទាំងនេះមានវិសាលភាពជាទូទៅ។ វាមិនអាចឱ្យអង្គជំនុំជម្រះបង្ហាញពីអត្ថិភាពនៃបរិយាកាសគំរាមកំហែងនៅក្នុងខេត្តពាក់ព័ន្ធ ពោលគឺក្នុងខេត្តព្រៃវែង ហើយជាពិសេសទៅទៀតនោះ គឺមិនអាចបង្ហាញពីលក្ខណៈបង្ខំនៃការបណ្តេញចេញនៅកន្លែងនោះបានទេ។ វាជាធាតុផ្សំមួយសំខាន់នៃឧក្រិដ្ឋកម្មក្រោមរូបភាពនៃការនិរទេស[1808]។ ម្យ៉ាងទៀត ពុំមានភស្តុតាងបង្ហាញពីការរៀបចំធ្វើបញ្ជីជនជាតិវៀតណាមនៅខេត្តព្រៃវែងនោះទេ[1809]។ សៅ សាក់ បានបញ្ជាក់ថា បញ្ជីទាំង

---

[1804] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៣។

[1805] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣៩ និង ៣៥០៥។

[1806] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៣។

[1807] សូមមើលខាងក្រោម កថាខណ្ឌ ១០៤៣-១០៤៨, ១៥៥៥-១៥៥៩។

[1808] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៨២។

[1809] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤២០-៣៤២៣។

នោះពាក់ព័ន្ធជនជាតិខ្មែរក្នុងភូមិ ហើយគាត់មិនដឹងពីការធ្វើបញ្ជីសម្រាប់ជនជាតិវៀតណាមទេ[1810]។ ដោយសារពុំមានភ័ស្តុតាងទាក់ទងនឹងលក្ខណៈបង្ខំនៃការប្រមូលផ្តុំ និងការបណ្តេញជនជាតិវៀតណាម ចេញពីក្នុងខេត្តព្រៃវែង អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យអំពីធាតុផ្សំមួយក្នុង ចំណោមធាតុផ្សំទាំងឡាយនៃបទឧក្រិដ្ឋនៃការនិរទេសបានទេ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំ ជម្រះត្រូវទុកជាមោឃៈ[1811]។

## ១.៤. កំហុសក្នុងការមិនបានបង្ហាញពីចេតនានៃការនិរទេសជនជាតិវៀតណាមក្នុងខេត្តព្រៃវែង

៩៨៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា "ការផ្លាស់ទីលំនៅជនជាតិវៀតណាមឆ្លងកាត់ ព្រំដែនកម្ពុជាដូចបានគូសបញ្ជាក់ខាងលើ គឺដោយមានចេតនា"[1812]។ អង្គជំនុំជម្រះបានសំអាងលើ អត្ថិភាពនៃគោលនយោបាយបណ្តេញជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។ ក៏ប៉ុន្តែ អង្គ ជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើនដែលមិនអាចឱ្យមានការសន្និដ្ឋានបានថា មានគោលនយោបាយ មួយនេះ[1813]។ លើសពីនេះទៀត ដោយបានផ្អែកតែលើគោលនយោបាយជាទូទៅនេះ អង្គជំនុំជម្រះបាន ប្រព្រឹត្តកំហុស ដោយមិនបានបង្ហាញឱ្យឃើញពីចេតនាក្នុងការនិរទេសជនជាតិវៀតណាមចេញពីខេត្ត ព្រៃវែង។

៩៨៦. សូមរំឭកថា "ធាតុផ្សំអត្តនោម័តិនៃការនិរទេស តម្រូវឱ្យមានចេតនាក្នុងការផ្លាស់ទីលំនៅជនរងគ្រោះ ដោយបង្ខំឱ្យឆ្លងកាត់ព្រំដែនប្រទេសមួយ"[1814]។ ក្នុងករណីបច្ចុប្បន្ននេះ ជនរងគ្រោះដែលត្រូវពិចារណា គឺជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង។ ច្បាស់ជាងនេះទៅទៀតនោះ គឺអង្គជំនុំជម្រះបានពិចារណា តែលើភ័ស្តុតាងទាក់ទងនឹងជនជាតិវៀតណាមនៅក្នុងភូមិអន្លង់ទ្រា ភូមិពោធិ៍ចិន្តាំ និងភូមិអង្គរយស។ ដោយសារពុំបានបង្ហាញអំពីភ័ស្តុតាងនៃចេតនាក្នុងការនិរទេសជនជាតិវៀតណាម នៅក្នុងភូមិទាំងនេះ

---

[1810] ប្រតិចារឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/363.1** មុនម៉ោង ០៩.៤១.១២។

[1811] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៣។

[1812] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៧។

[1813] សូមមើលខាងក្រោម កថាខណ្ឌ ១៥៥១-១៥៥២។

[1814] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៨៦។

សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវដកចេញ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះ[1815]។

## ២. ការសម្លាប់ជនជាតិវៀតណាម

### ២.១. កំហុសក្នុងការសន្និដ្ឋានលើការសម្លាប់ជនជាតិវៀតណាមបួនគ្រួសារនៅខេត្តស្វាយរៀង

៩៨៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថាករណីជាក់លាក់នៃការធ្វើមនុស្សឃាត ត្រូវបានបង្ហាញនៅក្នុងខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៨ ដោយសារការធ្វើមនុស្សឃាតលើជនជាតិវៀតណាមបួនគ្រួសារ[1816]។ សេចក្តីសន្និដ្ឋាននេះផ្អែកតែទៅលើសក្ខីកម្មរបស់ ស៊ិន ផែម ដែលចម្លើយរបស់គាត់សំអាងទាំងស្រុងលើអ្វីដែលគេនិយាយប្រាប់គាត់ ឬការឮតៗពីគេ។ នៅពេលគាត់និយាយថាគ្រួសារវៀតណាមដែលរស់នៅក្បែរៗផ្ទះរបស់គាត់ ត្រូវបាននាំយកទៅ និងបាត់ខ្លួន គាត់បានបញ្ជាក់ជាច្រើនលើកច្រើនសាថាគាត់មិនបានឃើញព្រឹត្តិការណ៍ទាំងអស់នេះទេ[1817]។ ដូច្នេះ ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះបានអះអាង វាពុំមានអ្វីដែលត្រូវសង្ស័យទេ ទាក់ទងនឹងសំណួរថាតើ ស៊ិន ផែម បានឃើញហេតុការណ៍ទាំងអស់នេះដែរ ឬអត់[1818]។

៩៨៨. អ្នកដែលបានរាយការណ៍ពីហេតុការណ៍ដែលថាជនជាតិវៀតណាមទាំងនេះត្រូវបានសម្លាប់ ក៏មិនបានឃើញព្រឹត្តិការណ៍នេះដោយផ្ទាល់ដែរ[1819]។ លើសពីនេះទៀត ភាពមិនច្បាស់លាស់នៃសក្ខីកម្មរបស់

---

[1815] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០២-៣៥០៧ និង ៤៣០៦។

[1816] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥៥, ៣៤៩០, ៣៤៩១ និង ៣៤៩៧។

[1817] ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ E1/367.1 ក្រោយម៉ោង ១០.៤៤.៤៥ "ដែលអត់ពីប្ដីខ្ញុំទៅ មានគេមកកាន់កាប់ក្រោយ។ ហើយដល់អ៊ីចឹងគេប្រមែប្រមូលយកទៅអស់រលីង រលត់ហើយ។ តែខ្ញុំអត់ស្គាល់គេទេ មិនដឹងពីណានៅណាទេ។ ខ្ញុំមិនដែលឃើញមុខគេផង", ក្រោយម៉ោង ១៥.៤៣.៣៧ "ខ្ញុំបានតែគេប្រាប់ដែរហ្នឹង ខ្ញុំដែលដើរទៅណា ខ្ញុំនៅផ្ទះធ្វើការងារ ទៅធ្វើឯណោះ បាត់ៗទៅ ខ្ញុំមិនសូវដែលនៅផ្ទះផង", ក្រោយម៉ោង ១៥.៥៣.៥២ "យកទៅយប់មិញ គេថាអ៊ីចឹង", មុនម៉ោង ១៥.៥៦.០៧ "មិនបានឃើញទេ", ក្រោយម៉ោង ១៥.៥៩.៤០ "ខ្ញុំមិនបានឃើញ"។

[1818] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥៣ កំណត់សម្គាល់ជើងទំព័រលេខ១១៦៣៦។

[1819] ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ E1/367.1 ចន្លោះម៉ោង ១៥.៥៩.៤០ និង ១៦.០១.៣៤។

ស៊ិន ឆែម មិនអាចឱ្យគេកំណត់បានពីអត្តសញ្ញាណសាកសពដែលគាត់និយាយថាបានឃើញនោះទេ[1820]។ ម្យ៉ាងវិញទៀត សក្ខីកម្មរបស់គាត់បង្ហាញថាវាអាចជាអ្នក ១៧ មេសា[1821]។ ដោយសារតែព័ត៌មានមិនច្បាស់លាស់ដូច្នេះ សាកសពទាំងនោះអាចជាសាកសពជនជាតិខ្មែរ។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថាវាអាចជាជនជាតិវៀតណាម គឺពុំមែនជាសេចក្ដីសន្និដ្ឋានសមហេតុផលតែមួយគត់ដែលអាចធ្វើបាននោះទេ[1822]។ សេចក្ដីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ។

៩៨៩. ជាចុងក្រោយ កាលបរិច្ឆេទនៃព្រឹត្តិការណ៍ទាំងនេះ គឺមានភាពមិនច្បាស់លាស់។ សាក្សីបាននិយាយជាន់កែងខ្លួនឯង ដោយបានពន្យល់ថាការចាប់ខ្លួនបុគ្គលជនជាតិវៀតណាមទាំងនេះ បានកើតឡើងមុនការចាប់ខ្លួនប្ដីរបស់គាត់ នៅចុងឆ្នាំ១៩៧៧។ បន្ទាប់មក គាត់បានប្ដូរចម្លើយ ដោយបាននិយាយថាវាបានកើតឡើងក្រោយការចាប់ខ្លួនប្ដីរបស់គាត់[1823]។ យោងតាមកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់សាក្សី ព្រឹត្តិការណ៍នេះកើតឡើងដំណាលគ្នានឹងការជ្រើសរើសប្រជាជនកម្ពុជាដើម្បីជម្លៀសចេញ[1824]។ កាលបរិច្ឆេទនៃការជ្រើសរើសនេះ មិនត្រូវបានបញ្ជាក់ទេ ប៉ុន្តែការជម្លៀសពួកគេបានធ្វើឡើង ក្នុងរដូវដកស្ទូង ឆ្នាំ១៩៧៨[1825]។ ភាពផ្ទុយគ្នាទាំងនេះ ទាក់ទងនឹងកាលបរិច្ឆេទនៃការសន្មតថាមានការចាប់ខ្លួនជនជាតិ វៀតណាម រឹតតែធ្វើឱ្យសក្ខីកម្មរបស់ ស៊ិន ឆែម ទន់ខ្សោយថែមទៀត។

៩៩០. សរុបសេចក្ដីទៅ អង្គជំនុំជម្រះបានផ្អែកតែទៅលើសក្ខីកម្មរបស់ ស៊ិន ឆែម ដែលគាត់មិនដែលបានឃើញការចាប់ខ្លួន ឬការសម្លាប់ជនជាតិវៀតណាមណាមួយនោះទេ។ បុគ្គលដែលបានរាយការណ៍ព័ត៌មានទាំងនេះប្រាប់គាត់ មិនត្រូវបានកំណត់អត្តសញ្ញាណ ហើយក៏មិនដែលបានឃើញការសម្លាប់ជនជាតិវៀតណាមនោះដែរ។ សាកសពគឺអាចពាក់ព័ន្ធជនជាតិខ្មែរផង និងជនជាតិវៀតណាមផង។ ដូច្នេះ ផ្ទុយពីគោលការណ៍ដែលមានចែងសម្រាប់វាយតម្លៃលើភ័ស្តុតាង អង្គជំនុំជម្រះមិនបានពិចារណា

[1820] ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/367.1** ម៉ោងប្រហែល ១៥.១៥.៣០។

[1821] កំណត់ហេតុនៃការស្ដាប់ចម្លើយ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ **E3/7794** ERN 00249917។

[1822] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥។

[1823] ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/367.1** មុនម៉ោង ១០.៤៤.៤៥ និងក្រោយម៉ោង ១០.៤៤.៤៥។

[1824] កំណត់ហេតុនៃការស្ដាប់ចម្លើយ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E3/7794** ERN 00249918។

[1825] កំណត់ហេតុនៃការស្ដាប់ចម្លើយ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E3/7794** ERN 00249917។

លើការដែលថា "ប្រភពនៃពាក្យចចាមអារ៉ាមមិនត្រូវបានសួរដេញដោល"[1826]។ ដោយសារថាភ័ស្តុតាងមួយនេះមិនត្រូវបានបញ្ជាក់បន្ថែមដោយភ័ស្តុតាងណាមួយផ្សេងទៀត ដែលអាចជឿទុកចិត្តបាននោះ ដូច្នេះ ភ័ស្តុតាងនេះគឺមិនបំពេញបាននូវកម្រិតនៃការប្រុងប្រយ័ត្នដែលជាល័ក្ខខ័ណ្ឌតម្រូវនោះទេ[1827]។ ដោយផ្អែកតែលើភ័ស្តុតាងមួយនេះ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋានថាមានការសម្លាប់ ជនជាតិវៀតណាមបួនគ្រួសារនៅខេត្តស្វាយរៀងបានទេ។ ដូច្នេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះ[1828]។

៩៩១. វាជាការសំខាន់ដែលត្រូវគូសបញ្ជាក់ថា ពាក់ព័ន្ធនឹងអង្គហេតុផ្សេងៗទៀត ប្រឈមនឹងភ័ស្តុតាងប្រភេទតែមួយដែលបានមកពីការឮតពីគេ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានការសម្លាប់ជនជាតិវៀតណាមនៅស្រុកព្រៃនប់៖

> "ភ័ស្តុតាងចចាមអារ៉ាមដែលមិនមានការគាំទ្រដោយប្រភពនៃពាក្យចចាមអារ៉ាមនោះ នៅមិនអាចកំណត់អត្តសញ្ញាណបាន និងដោយថាកាលបរិច្ឆេទនៃការបាត់ខ្លួនសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្ប វេណីនៅតែមិនច្បាស់លាស់នោះ គឺមិនគ្រប់គ្រាន់ក្នុងការបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ការចោទប្រកាន់ពីការសម្លាប់ជនជាតិវៀតណាមពិតជាបានកើតឡើង"[1829]។

៩៩២. ដូច្នេះ បើតាមលក្ខណៈសមហេតុសមផល អង្គជំនុំជម្រះគួរតែធ្វើសេចក្តីសន្និដ្ឋានដូចគ្នាសម្រាប់ការសម្លាប់ជនជាតិវៀតណាមទាំងបួនគ្រួសារ ដែលសំអាងដូចគ្នាលើការឮតពីគេដែលមិនមានការបញ្ជាក់បន្ថែមពីប្រភពដែលមិនត្រូវបានកំណត់ និងពីកាលបរិច្ឆេទមិនច្បាស់លាស់។ បទដ្ឋានពីរនេះ នៅក្នុងវិធីសាស្ត្រភ័ស្តុតាង ត្រូវទទួលរងពិន័យ[1830]។

---

[1826] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣។

[1827] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣។ សូមមើលផងដែរ សាលដីកា *Muvunyi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា) ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ៦៨-៧០។

[1828] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥៥, ៣៤៩០, ៣៤៩១, ៣៤៩៧ និង ៤៣០៦។

[1829] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦២-៣៤៦៤។

[1830] សូមមើលខាងលើ កថាខណ្ឌ ២៣៤។

## ២.២. កំហុសក្នុងការសន្និដ្ឋានលើការសម្លាប់ជនជាតិវៀតណាមនៅតាមសមុទ្រ

៩៩៣. ជាចម្បូង យើងត្រូវរំឭកថា អង្គជំនុំជម្រះទទួលបានបណ្ដឹងមិនជាក់ស្ដែងអំពី អង្គហេតុដែលជាធាតុផ្សំនៃការធ្វើមនុស្សឃាតលើជនជាតិវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ[1831]។ ប៉ុន្តែ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានករណីជាក់លាក់នៃការសម្លាប់ជនជាតិវៀតណាម នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ក្រោយខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ និងនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ បាននោះទេ[1832]។

៩៩៤. មុននឹងអធិប្បាយអំពីកំហុសរបស់អង្គជំនុំជម្រះ គេគួរបញ្ជាក់ថាតើអ្វីខ្លះទៅជាករណីជាក់លាក់នៃការធ្វើមនុស្សឃាតដែលជ្រើសរើសដោយអង្គជំនុំជម្រះ នៅក្នុងការកំណត់ប្រភេទបទល្មើស។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "អ្នកនេសាទជនជាតិវៀតណាម និងជនភៀសខ្លួនវៀតណាមយ៉ាងច្រើន ត្រូវបានសម្លាប់ដោយចេតនា ដោយកងកម្លាំងប្រដាប់អាវុធរបស់ ប.ក.ក ជាពិសេសបន្ទាប់ពីខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ នៅកំពង់ផែអូរឈើទាល ដូចដែលបានបង្ហាញជាភ័ស្តុតាងដោយ ប៉ាក់ សុខ និងដូចបានរាយការណ៍ដោយកងពល ១៦៤ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨"[1833]។

៩៩៥. ការវិភាគលើអង្គហេតុបង្ហាញថា ក្រោយខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ នៅកំពង់ផែអូរឈើទាល អង្គជំនុំជម្រះបានលើកឡើងពីការសម្លាប់ទារកម្នាក់ដែលត្រូវបោះចូលក្នុងទឹក[1834]។ ចំណែកឯនៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៧៨ វាជាករណីសម្លាប់ជនជាតិវៀតណាមនៅក្នុងកាណូតដែលលិច នេះវាម្យ៉ាង ហើយម្យ៉ាងទៀត គឺករណីជនជាតិវៀតណាមពីរនាក់ដែលធ្លាក់ទៅក្នុងទឹក[1835]។ ការវិភាគនេះហាក់ដូចជាបានបញ្ជាក់អះអាងដោយការវាយតម្លៃរបស់អង្គជំនុំជម្រះអំពីចំនួនមនុស្សស្លាប់ នៅក្នុងពេលកំណត់

---

[1831] សូមមើលខាងលើ កថាខណ្ឌ ៥២០-៥២១។

[1832] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩០, ៣៤៩៣ និង ៣៤៩៧។

[1833] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៣។

[1834] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥៩ និង ៣៤៦១។

[1835] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦០ និង ៣៤៦១។

បទចោទប្រកាន់ពីការសម្លាប់រង្គាល។ បើយោងតាមអង្គជំនុំជម្រះ វាមានហេតុផលសមរម្យដែលវាយតម្លៃថាមានមនុស្សស្លាប់ចំនួនប្រាំបីនាក់ នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ[1836]។ នៅពេលភ័ស្តុតាងមិនបានបង្ហាញឱ្យឃើញច្បាស់ អង្គជំនុំជម្រះបានជ្រើសយកចំនួនអ្នកស្លាប់ជាមធ្យមពីរនាក់យ៉ាងតិចក្នុងមួយគ្រួសារ និងយ៉ាងហោចណាស់ប្រាំនាក់ក្នុងមួយទូក។ បើទោះជាវិធីសាស្ត្រប្រថុយប្រថានមួយនេះ អាចឱ្យគេតវ៉ាបានក៏ដោយ[1837] ក៏វាអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីអនុវត្តតាមការវិនិច្ឆ័យរបស់អង្គជំនុំជម្រះ។ ដូច្នេះ យោងតាមការប៉ាន់ប្រមាណរបស់អង្គជំនុំជម្រះ ច្បាស់ណាស់ថាអង្គជំនុំជម្រះបានសន្និដ្ឋានថាមានការសម្លាប់ទារកម្នាក់ មនុស្សពីរនាក់ដែលធ្លាក់ក្នុងទឹក និងមនុស្សប្រាំនាក់ដែលលិចក្នុងទឹកជាមួយកាណូត។

៩៩៦. ប៉ុន្តែ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាម នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ បាននោះទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយបានសំអាងតែទៅលើច្បាប់ចម្លងនៃឯកសារមួយដែលមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត (២.២.១) ដោយបានសន្និដ្ឋានថាមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការសម្លាប់ជនមិនមែនស៊ីវិល (២.២.២) និងដោយបានយល់ថា បុគ្គលទាំងពីរនាក់ដែលធ្លាក់ក្នុងទឹកគឺត្រូវបានសម្លាប់ដោយចេតនា (២.២.៣)។

### ២.២.១. កំហុសក្នុងការសំអាងលើច្បាប់ចម្លងនៃឯកសារមួយកាលពីសម័យខ្មែរក្រហមដែលមានតម្លៃជាភ័ស្តុតាងតិចតួច

៩៩៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកតែទៅលើរបាយការណ៍មួយរបស់កងពល ១៦៤ ដើម្បីសន្និដ្ឋានថាមានការសម្លាប់ជនជាតិវៀតណាមនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨។ គេគួររំឭកថាវាពុំមែនជាឯកសារច្បាប់ដើមទេ តែជាច្បាប់ចម្លងដែលគេពុំដឹងថាត្រូវបានមកដូចម្តេច[1838]។ ដូច្នេះ ឯកសារ

---

[1836] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៩ កំណត់សម្គាល់ជើងទំព័រលេខ១១៧៨៧។

[1837] សូមមើលខាងក្រោម កថាខណ្ឌ ១០២៦-១០២៧។

[1838] សូមមើលខាងលើ កថាខណ្ឌ ៣២០-៣២៣។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៥១៨-៥១៩។

នេះមានតម្លៃជាភ័ស្តុតាងតិចតួច មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានថាមានការសម្លាប់ជនជាតិវៀតណាម ដោយសំអាងតែលើមូលដ្ឋានមួយនេះបានទេ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

៩៩៨. លើសពីនេះ ព្រឹត្តិការណ៍ពិពណ៌នានៅក្នុងឯកសារនេះ គឺខ្វះភាពច្បាស់លាស់។ ពុំមានការនិយាយអ្វីទាក់ទងនឹងជោគវាសនារបស់ជនជាតិវៀតណាមដែលនៅក្នុងកាណូតលិចនោះទេ។ ផ្ទុយទៅវិញរបាយការណ៍បានបង្ហាញពីវត្តមានកាណូតវៀតណាមជាច្រើនគ្រឿង[1839]។ ដូច្នេះ វាអាចថាអ្នកដែលនៅលើកាណូតលិច ត្រូវបានស្រង់ដោយកាណូតវៀតណាមផ្សេងៗទៀត។ ដោយសារខ្វះភាពច្បាស់លាស់ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថាជនជាតិវៀតណាមទាំងនេះបានស្លាប់ គឺពុំមែនជាសេចក្តីសន្និដ្ឋានសមហេតុសមផលតែមួយគត់ដែលអាចមាននោះទេ។ សេចក្តីសន្និដ្ឋាននេះ ត្រូវតែដកចេញ។

៩៩៩. ដោយសន្និដ្ឋានថាមានការសម្លាប់ជនជាតិវៀតណាម ដោយសំអាងតែលើភ័ស្តុតាងមួយនេះ អង្គជំនុំជម្រះបានអនុវត្តបទដ្ឋានពីរនៅក្នុងការវាយតម្លៃលើភ័ស្តុតាង។ ម្យ៉ាងទៀត អង្គជំនុំជម្រះយល់ថាខ្លួនមិនអាចសន្និដ្ឋានថាមានការសម្លាប់ "ជនជាតិវៀតណាម ១00 នាក់" ដោយសំអាងលើទូរលេខរបស់ភូមិភាគបស្ចិម ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ បានទេ ព្រោះថាទូរលេខនេះ "គឺមិនគ្រប់គ្រាន់ដើម្បីបង្ហាញភ័ស្តុតាងតាមបទដ្ឋានដែលបានតម្រូវអំពីហេតុការណ៍សម្លាប់ជាក់លាក់មួយ ឬច្រើនឱ្យហួសពីវិមតិសង្ស័យឡើយ"។ "ទូរលេខនេះមិនបានផ្តល់នូវព័ត៌មានលម្អិតណាមួយអំពីកាលៈទេសៈជាក់លាក់នៃការសម្លាប់ [...] មានភាពមិនច្បាស់លាស់អំពីប្រភពពាក់ព័ន្ធទៅនឹងចំនួនមនុស្សស្លាប់ដូចបានរាយការណ៍នោះដែរ [...] ក៏មិនមានការគាំទ្រដោយភ័ស្តុតាងដទៃទៀតឡើយ"[1840]។

[1839] របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/997** ERN 00020982 "យើងបាញ់កាណូតអាយួន" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1840] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៧១។

១០០០. ដូចបានលើកឡើង ទូរលេខចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ក៏ខ្វះភាពច្បាស់លាស់ដូចគ្នា ទាក់ទងនឹងកាលៈទេសៈពិតប្រាកដនៃការសម្លាប់ដែលសន្មត និងទាក់ទងនឹងការចង់ដឹងជាពិសេសថាតើអ្នកទាំងអស់នោះពិតជាស្លាប់មែន ឬយ៉ាងណា។ ឯកសារនេះមិនត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងណាមួយផ្សេងទៀតនោះទេ។ ដូច្នេះ អង្គជំនុំជម្រះគួរអនុវត្តបទដ្ឋានដូចគ្នានៅក្នុងការវាយតម្លៃលើភស្តុតាង និងគួរដកភស្តុតាងនេះចេញ។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាមនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ ត្រូវទុកជាមោឃៈ។

## ២.២.២. កំហុសក្នុងការសន្និដ្ឋានអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតជនមិនមែនស៊ីវិល

១០០១. ហេតុការណ៍ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ ដែលបានលើកឡើងនៅក្នុងទូរលេខរបស់កងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ បានកើតឡើងចំពេលជម្លោះប្រដាប់អាវុធជាមួយវៀតណាមឡើងកម្ដៅខ្លាំង។ យោងតាមឯកសារនេះ កងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យបានបាញ់ពន្លិចទូកវៀតណាមមួយគ្រឿង។ ពុំមានការបញ្ជាក់ថាតើវៀតណាមទាំងនេះជាប្រជាជនស៊ីវិល ឬជាទាហាននោះទេ។ ប៉ុន្តែ សាក្សីជាកងទ័ពជើងទឹកនាសម័យនោះ ដែលបានមកផ្ដល់សក្ខីកម្មអំពីអង្គហេតុទាំងនេះ បានពន្យល់ថា កងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យបានបាញ់ទៅលើទូកវៀតណាម ដើម្បីតបតនឹងការវាយប្រហារ ឬក្នុងករណីទូកដែលចូលក្នុងដែនទឹកកម្ពុជាប្រដាប់ដោយអាវុធតែប៉ុណ្ណោះ[1841]។ ដូច្នេះ ជាការសមហេតុផលដែលសន្និដ្ឋានថា ប្រជាជនវៀតណាមដែលមានវត្តមាននៅលើទូកនោះ អាចជាទាហាន ឬក៏ជាអ្នកនេសាទប្រដាប់ដោយអាវុធដែលចូលរួមក្នុងអរិភាព។ អាស្រ័យហេតុនេះ ច្បាស់ណាស់ថា ការវាយប្រហារ ឬការតបតនេះ មានការពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងជម្លោះប្រដាប់អាវុធជាមួយវៀតណាម និងមិនមែនជាការវាយប្រហារទូទៅជាលក្ខណៈប្រព័ន្ធទៅលើប្រជាជនស៊ីវិលនោះទេ[1842]។ ដូច្នេះ អង្គ

---

[1841] ម៉ាក ឈឿន៖ ប្រតិ **E1/512.1** 09.22.23, 09.24.31, 09.32.05 10.45.46 **E1/386.1** 14.08.12។

[1842] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១០។ សូមមើលផងដែរ សាលដីកា *Kunarac និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ៩១។

ជំនុំជម្រះមិនអាចកំណត់ប្រភេទបទល្មើសទាំងអស់នេះ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានឡើយ។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ[1843]។

## ២.២.៣. កំហុសពាក់ព័ន្ធនឹងការសម្លាប់អ្នកទោសាទ និងជនភៀសខ្លួនវៀតណាម

១០០២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយពិចារណាថា ការធ្វើមនុស្សឃាតជនជាតិវៀតណាមពីរនាក់ដែលបានធ្លាក់ពីលើកាណូត គឺជាចេតនា[1844]។ ជាក់ស្តែង ព័ត៌មានតិចតួចដែលមាននៅក្នុងឯកសារ ឱ្យយើងដឹងថា ប្រជាជនវៀតណាម ៧៦ នាក់ដែលបានចាប់ខ្លួន ត្រូវបាននាំយកទៅដីគោក។ ផ្ទុយទៅវិញ ក្នុងអំឡុងពេលចាប់ខ្លួន មនុស្សពីរនាក់បានធ្លាក់ចូលក្នុងទឹក ដោយសារតែកាណូតតូចឃ្លោង[1845]។ ដូច្នេះ តាមរយៈអង្គហេតុទាំងនេះ គេមិនអាចទាញការសន្និដ្ឋានថា ការដែលមនុស្សទាំងនេះធ្លាក់ចូលក្នុងទឹក គឺជាចេតនាបានទេ។ ផ្ទុយទៅវិញ មាស មុត ដែលជាអ្នកធ្វើរបាយការណ៍ បានបញ្ជាក់ថា៖ "រកពុំឃើញ"[1846]។ ផ្អែកលើធាតុផ្សំទាំងនេះ ពុំមានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចសន្និដ្ឋានអំពីចេតនាសម្លាប់បុគ្គលទាំងពីរនាក់នេះបានទេ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការធ្វើមនុស្សឃាតមនុស្សទាំងពីរនាក់នេះ ត្រូវតែបដិសេធចោល។

## ២.៣. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅក្នុងភូមិភាគបស្ចិម

១០០៣. ជាសំខាន់ សូមរំឭកថា អង្គជំនុំជម្រះទទួលបានបណ្តឹងខុសច្បាប់អំពី អង្គហេតុដែលជាធាតុផ្សំនៃការធ្វើមនុស្សឃាតលើប្រជាជនវៀតណាម ក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[1847]។ ប៉ុន្តែ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយផ្អែកតែទៅលើសក្ខីកម្មរបស់ ប្រាក់ ខឿន ដើម្បីសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើម្តាយក្មេក ប្រពន្ធ កូនប្រុសរបស់គាត់ និងសមាជិកនៃគ្រួសារចំនួន

---

[1843] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦១, ៣៤៩៣។

[1844] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៣។

[1845] របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ **E3/997** ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ERN 00020982។

[1846] របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ឯកសារ **E3/997** ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ERN 00020982។

[1847] សូមមើលខាងលើ កថាខណ្ឌ ៤៣៥-៤៣៨។

៦ ផ្សេងទៀត[1848]។ ជាក់ស្តែង ប្រាក់ ខឿន បានពន្យល់យ៉ាងច្បាស់ថាមិនបានឃើញការសម្លាប់ទាំងនេះទេ[1849]។

១០០៤.ម្យ៉ាងវិញទៀត អង្គជំនុំជម្រះខកខានមិនបានបង្ហាញថា ហ៊ឹម ដែលបានមកប្រាប់គាត់ថា គ្រួសាររបស់គាត់ត្រូវគេសម្លាប់នោះ ក៏មិនបានឃើញការសម្លាប់នេះដែរ[1850]។ ដូច្នេះ អង្គជំនុំជម្រះមិនបានចាប់អារម្មណ៍លើការដែល ហ៊ឹម ដែលជាប្រភពដើមនៃពាក្យចចាមអារ៉ាមនោះ មិនត្រូវបានសួរដេញដោលនោះទេ[1851]។ ពុំមានភ័ស្តុតាងអាចជឿជាក់ និងទុកចិត្តបានផ្សេងទៀតដែលគាំទ្រដល់សក្ខីកម្មរបស់ ប្រាក់ ខឿន ទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនបានបំពេញការងារដោយមានការប្រុងប្រយ័ត្នតាមការតម្រូវនោះឡើយ[1852]។ ផ្អែកលើភ័ស្តុតាងតែមួយនេះ ពុំមានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចធ្វើការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅក្នុងភូមិភាគបស្ចិមទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

១០០៥. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយសន្និដ្ឋានថា "កូនៗ [...] របស់ ប្រាក់ ខឿន [...] ត្រូវបានសម្លាប់ដោយចេតនាគិតទុកជាមុននៅលើកោះតាម៉ូវ នៅក្នុងឆ្នាំ១៩៧៧"[1853]។ តាមពិត អង្គជំនុំជម្រះគ្រាន់តែបានបញ្ជាក់ថា កូនប្រុសពៅរបស់ ប្រាក់ ខឿន ត្រូវគេនាំទៅកោះតាម៉ូវប៉ុណ្ណោះ[1854]។ កូនស្រីរបស់គាត់បីនាក់ទៀតស្លាប់ "នៅក្នុងសហករណ៍ និងកងចល័ត"[1855] ដែលជាព័ត៌មានចចាមអារ៉ាមពុំស្គាល់ពីប្រភព[1856]។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបានបង្ហាញពីកាលៈទេសៈនៃការស្លាប់របស់

---

[1848] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៧១. ៣៤៩០, ៣៤៩៤ និង ៣៤៩៧។

[1849] ប្រតិចារឹក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** មុនម៉ោង 11.29.57 ប្រហែលម៉ោង 13.37.04 មុនម៉ោង 13.41.33។

[1850] ប្រតិចារឹក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** ចន្លោះពីម៉ោង 13.42.33 ដល់ម៉ោង 13.51.53។

[1851] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣។

[1852] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣។ សូមមើលផងដែរ សាលដីកា *Muvunyi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ៦៨-៧០។

[1853] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1854] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦៧។

[1855] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦៧។

[1856] ប្រតិចារឹក ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/361.1** ម៉ោង 15.30.48។

កូនស្រីទាំងបីនាក់របស់គាត់ទេ[1857]។ ផ្អែកតាមធាតុផ្សំទាំងនេះ ពុំមានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចធ្វើការសន្និដ្ឋានថា ពួកគេត្រូវបានសម្លាប់នៅលើកោះតាម៉ូវបានទេ។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

## ២.៤. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅវត្តខ្សាច់

១០០៦. ជាសំខាន់ សូមរំឮកថា អង្គជំនុំជម្រះទទួលបានបណ្តឹងមិនត្រឹមត្រូវអំពីអង្គហេតុដែលជាធាតុផ្សំនៃការធ្វើមនុស្សឃាតលើប្រជាជនវៀតណាមនៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[1858]។ ប៉ុន្តែជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើ យាយហាយ និងតាឃុត (២.៤.១) និងការធ្វើមនុស្សឃាតសមាជិកគ្រួសាររបស់ ជុំ (២.៤.២)។ អង្គជំនុំជម្រះក៏បានសន្និដ្ឋានខុសផងដែរថា ប្រជាជនវៀតណាមទាំងអស់នៅក្នុង និងនៅជុំវិញភូមិយាង ត្រូវបានសម្លាប់នៅវត្តខ្សាច់ (២.៤.៣) និងថា ការសម្លាប់ត្រូវបានប្រព្រឹត្តតាមបញ្ជារបស់ថ្នាក់លើ (២.៤.៤)។

### ២.៤.១. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើយាយហាយ និងតាឃុត

១០០៧. អង្គជំនុំជម្រះមិនគួរសន្និដ្ឋានអំពីការសម្លាប់យាយហាយ និងតាឃុត ឡើយ។ ជាក់ស្តែង ស៊ាន ស៊ីង ឆ្លើយថាមិនបានដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេទេ។ គាត់ប្រហែលជាបានឮគេនិយាយថា ពួកគេត្រូវបានសម្លាប់មួយថ្ងៃមុនថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[1859]។ ព័ត៌មាននេះផ្អែកលើពាក្យចចាមអារ៉ាមដែលពុំស្គាល់ប្រភព។ មានភាពផ្ទុយគ្នាជាច្រើននៅក្នុងសក្ខីកម្មរបស់ អ៊ុំ ស៊ន់ ដែលនាំឱ្យធ្វើការសន្និដ្ឋានថា គាត់មិនបានឃើញការសម្លាប់ចាន់ថា និងជីដូនជីតារបស់ចាន់ថាទេ[1860]។ សាក្សីបានបញ្ជាក់ថាមិនអាចកំណត់អត្តសញ្ញាណមនុស្សដែលត្រូវគេសម្លាប់នៅវត្តខ្សាច់ និងមិនបានដឹងរឿងពាក់ព័ន្ធនឹងការ

---

[1857] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦៧។

[1858] សូមមើលខាងលើ កថាខណ្ឌ ៤៣៥-៤៣៨។

[1859] ប្រតិចារឹក ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E1/358.1** ក្រោយម៉ោង 13.36.16។

[1860] ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/366.1** ចន្លោះពីម៉ោង 09.27.21 ដល់ម៉ោង 09.37.51។

សម្លាប់ជីដូនជីតារបស់ចាន់ថានាពេលក្រោយនោះទេ[1861]។ អ៊ី វុន បានពន្យល់ថា គាត់បានដឹងតាមរយៈប្រជាជនភូមិចកថា យាយហាយ និងតាឃុត ត្រូវគេសម្លាប់នៅអណ្ដូងទួន នៅពេលរថយន្តវៀតណាមចូលមកដល់នៅឆ្នាំ១៩៧៩[1862]។ សាក្សីបានបញ្ជាក់ថា តាឃុត ទំនងជាត្រូវគេសម្លាប់ក្រោយពេលកងទ័ពវៀតណាមមកដល់[1863]។

១០០៨. ផ្អែកលើភ័ស្តុតាងទាំងនេះ ពុំមាននរណាម្នាក់បានឃើញហេតុការណ៍ដែលកើតឡើងចំពោះជីដូនជីតារបស់ចាន់ថាទេ។ ហេតុការណ៍ទាំងនេះក៏អាចកើតឡើងក្រោយពេលវៀតណាមចូលមកដល់ដែរ ហើយដូច្នេះ គឺស្ថិតនៅក្រៅវិសាលភាពពេលវេលានៃរឿងក្ដី។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនគួរសន្និដ្ឋានអំពីការធ្វើមនុស្សឃាតមនុស្សទាំងពីរនាក់នេះទេ។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

### ២.៤.២. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតសមាជិកគ្រួសាររបស់ ជុំ

១០០៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានថា សមាជិកគ្រួសារជាជនជាតិវៀតណាមរបស់ ជុំ ត្រូវបានសម្លាប់[1864]។ អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ អ៊ី វុន និង អ៊ុំ ស៊ន់ និងលើកំណត់ហេតុស្ដាប់ចម្លើយ ឡូញ ឃុន។ អ៊ុំ ស៊ន់ បានឆ្លើយថា ពួកគេប្រហែលជាត្រូវបានសម្លាប់នៅ "វគ្គទី១" ដោយមិនបានពន្យល់ថាវគ្គនេះសំដៅទៅលើអ្វីនោះទេ។ ទោះជាយ៉ាងនេះក្ដី គាត់បានបញ្ជាក់ថា "អត់បានដឹងទេ"[1865]។ អ៊ី វុន បានពន្យល់ថា គាត់មិនបានឃើញគេប្រមូលផ្ដុំគ្រួសាររបស់ ជុំ នៅវត្តទេ។ គាត់មិនបានបញ្ជាក់ថាតើគាត់បានដឹងដោយរបៀបណាទេថា គ្រួសាររបស់ ជុំ ត្រូវគេសម្លាប់នៅវត្ត ដោយហេតុថា គាត់មិនបានឃើញការសម្លាប់នេះ[1866]។ ជាចុងក្រោយ កំណត់ហេតុស្ដាប់ចម្លើយ ឡូញ ឃុន

[1861] ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/366.1** ចន្លោះពីម៉ោង 10.39.35 ដល់ម៉ោង 10.51.48។ គួរលើកឡើងថា ត្រង់កន្លែងនេះ អង្គជំនុំជម្រះបានបង្ហាញពីភាពលម្អៀង ដោយមិនអើពើចំពោះសំណួររបស់ក្រុមមេធាវីការពារក្ដី។

[1862] ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/368.1** ម៉ោង 11.06.52។

[1863] ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/368.1** ម៉ោង 10.02.55។

[1864] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧៩។

[1865] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/365.1** ក្រោយម៉ោង 13.56.33។

[1866] ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/368.1** មុនម៉ោង 10.12.09 ចន្លោះពីម៉ោង 10.46.44 ដល់ម៉ោង 10.52.56។

មានតម្លៃជាភស្តុតាងតិចតួច ដោយហេតុថាវាជាចម្លើយជាលាយលក្ខណ៍អក្សរ។ លើសពីនេះទៀត នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ មានការបញ្ជាក់ថា គាត់ក៏មិនបានឃើញការសម្លាប់នេះដែរ។ ការសន្និដ្ឋានរបស់គាត់ថា ជុំ និងគ្រួសាររបស់គាត់ត្រូវគេសម្លាប់នៅខ្សាច់ គ្រាន់តែជាការស្មានប៉ុណ្ណោះ[1867]។ ដោយគ្មានភស្តុតាងផ្ទាល់អំពីការសម្លាប់ទាំងនេះ អង្គជំនុំជម្រះពុំបានបំពេញការងារដោយមានការប្រុងប្រយ័ត្នតាមការតម្រូវនោះទេ។ អង្គជំនុំជម្រះមិនគួរសន្និដ្ឋានអំពីការសម្លាប់បុគ្គលទាំងនេះឡើយ។

១០១០. ជាចុងបញ្ចប់ អ៊ី វុន បានបញ្ជាក់ផងដែរថា ម្តាយរបស់ ជុំ ជាជនជាតិវៀតណាម រីឯឪពុករបស់ ជុំ ជាជនជាតិចិន[1868]។ គាត់បានបញ្ជាក់ថា ជុំ មានដើមកំណើតចិន និយាយតែ "ចិន"[1869]។ ដូច្នេះ គ្រួសាររបស់គាត់អាចត្រូវបានគេចាត់ទុកថាជាគោលដៅ សម្រាប់ហេតុផលផ្សេងក្រៅពីដើមកំណើតរបស់ពួកគាត់ជាជនជាតិវៀតណាម។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានលើការធ្វើមនុស្សឃាតទាំងនេះ ត្រូវទុកជាមោឃៈ។

## ២.៤.៣. កំហុសក្នុងការសន្និដ្ឋានអំពីការសម្លាប់ជនជាតិវៀតណាមនៅវត្តខ្សាច់

១០១១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយសន្និដ្ឋានថា "ជនជាតិវៀតណាមទាំងអស់ដែលរស់នៅក្នុង និងនៅជុំវិញភូមិយាង ស្រុកជីក្រែង (តំបន់ ១០៦) ខេត្តសៀមរាប ត្រូវបាននាំយកទៅ និងសម្លាប់ក្នុងទ្រង់ទ្រាយធំនៅវត្តខ្សាច់"[1870]។ អង្គជំនុំជម្រះផ្អែកលើសក្ខីកម្មរបស់ ស៊ាន ស៊ុង និង អ៊ី វុន។ ប៉ុន្តែព័ត៌មានរបស់ ស៊ាន ស៊ុង ដែលថា មនុស្សដែលគេបានប្រមូលផ្តុំ ប្រហែលជាមកពីភូមិជាច្រើនក្នុងស្រុកជីក្រែង ផ្អែកលើពាក្យចចាមអារ៉ាម[1871]។ ចំណែក អ៊ី វុន វិញ មិនត្រូវបានចោទសួរសំណួរថាតើ

---

[1867] កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ **E3/7686** ERN 00221620។

[1868] ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/368.1** មុនម៉ោង 09.42.57។

[1869] ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/368.1** ក្រោយម៉ោង 09.42.57។

[1870] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨២។

[1871] ប្រតិចារឹក ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E1/358.1** ចន្លោះពីម៉ោង 09.22.09 ដល់ម៉ោង 09.29.01 និងមុនម៉ោង 14.40.36។

គាត់បានដឹងដោយរបៀបណាថា មនុស្សមួយចំនួនមកពីអូរក្រោម[1872]។ ម្យ៉ាងវិញទៀត គាត់បានឆ្លើយថាមិនបានឃើញមនុស្សទាំងនោះត្រូវគេនាំទៅវត្តទេ[1873]។ លើសពីនេះទៀត ទោះបីជាសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងការសម្លាប់យាយហាយ និងតាយុត មិនត្រឹមត្រូវក៏ដោយ ក៏អង្គជំនុំជម្រះបានសន្និដ្ឋានថា ពួកគេត្រូវបានសម្លាប់ "នាពេលក្រោយមក" និងមិនមែននៅវត្តខ្សាច់នោះទេ[1874]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចផ្អែកការសន្និដ្ឋានទាំងពីរនេះបានទេ។

១០១២. ផ្អែកលើភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ប្រជាជនវៀតណាមទាំងអស់នៅក្នុង និងនៅជុំវិញភូមិយាង ត្រូវបានសម្លាប់នៅវត្តខ្សាច់ បានទេ។ ដូច្នេះ ការសន្និដ្ឋានពង្រីកមិនសមហេតុផលរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

### ២.៤.៤. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតនៅវត្តខ្សាច់តាមបញ្ជារបស់ថ្នាក់លើ

១០១៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានថា ការធ្វើមនុស្សឃាតនៅវត្តខ្សាច់ត្រូវបានប្រព្រឹត្តតាម "បញ្ជារបស់ថ្នាក់លើ"[1875]។ អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានបែបនេះ ដោយផ្អែកលើសក្ខីកម្មរបស់ ស៊ាន ស៊ុង និង អ៊ី វុន។ ទោះបីជាអង្គជំនុំជម្រះយល់ស្រប់ថា ព័ត៌មានទាំងនេះជាពាក្យចចាមអារ៉ាមក៏ដោយ ក៏អង្គជំនុំជម្រះបានពិចារណាថា ខ្លួនអាចផ្អែកលើព័ត៌មានទាំងនេះបាន ដោយសារតែភាពអាចជឿជាក់ និងភាពអាចជឿទុកចិត្តបាននៃសក្ខីកម្មរបស់ ស៊ាន ស៊ុង[1876]។ ប៉ុន្តែ អង្គជំនុំជម្រះបានពន្យល់យ៉ាងច្បាស់ថា បញ្ហានៃភ័ស្តុតាងជាពាក្យចចាមអារ៉ាម ស្ថិតនៅលើការដែលថា បុគ្គលដែលជាប្រភពដើមនៃពាក្យចចាមអារ៉ាម មិនអាចត្រូវបានសួរដេញដោល។ ដោយសារមូលហេតុនេះហើយទើបព័ត៌មានប្រភេទនេះត្រូវយកមកសិក្សា ដោយមានការប្រុងប្រយ័ត្នបំផុត[1877]។ តាមអង្គច្បាប់ មេភូមិ

---

[1872] ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/368.1** ម៉ោង 10.12.09។

[1873] ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/368.1** មុនម៉ោង 10.12.09។

[1874] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៧៩។

[1875] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨០, ៣៤៨២ និង ៣៤៩៥។.

[1876] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨០។

[1877] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៣។

ដែលជាប្រភពដើមនៃពាក្យចចាមអារ៉ាម មិនត្រូវបានសួរចម្លើយនោះទេ។ ដូច្នេះ ពុំមានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ ធ្វើការសន្និដ្ឋានដោយផ្អែកលើមូលដ្ឋាននេះ ថា ការសម្លាប់នៅវត្តខ្សាច់ត្រូវបានប្រព្រឹត្តតាមបញ្ជារបស់ថ្នាក់លើបានឡើយ។ ហេតុនេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ[1878]។

## ២.៥. កំហុសក្នុងការសន្និដ្ឋានអំពីការធ្វើមនុស្សឃាតលើជនជាតិវៀតណាមនៅក្នុងតំបន់ ៥០៥ (ក្រចេះ)

១០១៤. ជាលក្ខណៈចម្បង យើងសូមរំឭកថា អង្គជំនុំជម្រះទទួលបានបណ្ដឹងពុំត្រឹមត្រូវអំពីអង្គហេតុដែលជាធាតុផ្សំនៃការធ្វើមនុស្សឃាតលើប្រជាជនវៀតណាម នៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[1879]។ ប៉ុន្តែ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយផ្អែកលើការរៀបរាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ ដែលបានមកផ្ដល់សក្ខីកម្មអំពីការឈឺចាប់របស់គាត់ ដើម្បីសន្និដ្ឋានអំពីការធ្វើមនុស្សឃាតនៅក្នុងតំបន់ ៥០៥[1880]។ ជាក់ស្ដែង ការរៀបរាប់នេះមានតម្លៃជាភ័ស្តុតាងទាប ដោយហេតុថា ដើមបណ្ដឹងរដ្ឋប្បវេណីជាភាគីមួយនៃរឿងក្ដីដែលមកផ្ដល់សក្ខីកម្មអំពីការឈឺចាប់របស់គាត់។ ដូច្នេះ គាត់មានភាពលម្អៀង ហើយដោយគ្មានភ័ស្តុតាងសត្យានុម័តិផ្សេងទៀត អង្គជំនុំជម្រះមិនអាចផ្អែកតែទៅលើសក្ខីកម្មរបស់គាត់ ដើម្បីសន្និដ្ឋានអំពីការធ្វើមនុស្សឃាតបានឡើយ។ តម្លៃជាភ័ស្តុតាងនៃការរៀបរាប់របស់គាត់មានកម្រិតទាប ពីព្រោះដើមបណ្ដឹងរដ្ឋប្បវេណីមិនបានឃើញការសម្លាប់ដោយផ្ទាល់ភ្នែកទេ[1881]។ ដូច្នេះ អង្គហេតុដែលគាត់បានរៀបរាប់ ជាព័ត៌មានចចាមអារ៉ាម។ ផ្អែកលើតម្លៃជាភ័ស្តុតាងតិចតួចនៃភ័ស្តុតាងតែមួយនេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងការធ្វើមនុស្សឃាតលើជនជាតិវៀតណាម នៅតំបន់ ៥០៥ ត្រូវទុកជាមោឃៈ[1882]។

---

[1878] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨០, ៣៩៨២ និង ៣៩៩៥។

[1879] សូមមើលខាងលើ កថាខណ្ឌ ៩៣៥-៩៣៨។

[1880] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៣-៣៩៨៥, ៣៩៨៨ និង ៣៩៩៦។

[1881] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៣។

[1882] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៣-៣៩៨៥, ៣៩៨៨ និង ៣៩៩៦។

១០១៥. លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអំពីចំនួននៃការធ្វើមនុស្សឃាត ដែលដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់។ អង្គជំនុំជម្រះបានកំណត់យកការធ្វើមនុស្សឃាតលើសមាជិក ១៣ នាក់នៃគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំង ប្តីប្រពន្ធ និងកូនរបស់ខ្មែរនៅក្រចេះបី ឬបួននាក់ផ្សេងទៀត[1883]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានលើកឡើងថាអ្នកណាខ្លះជាសមាជិកទាំង ១៣ នាក់នៃគ្រួសាររបស់ អ៊ុច ស៊ុនឡាយ លើកលែងតែប្រពន្ធ កូនបីនាក់ ឪពុកម្តាយក្មេក និងប្អូនថ្លៃស្រីរបស់គាត់[1884]។ ដូច្នេះ ពុំមានការបញ្ជាក់ថាអ្នកណាជាសមាជិក ៦ នាក់ទៀត និងពីកាលៈទេសៈ និងមូលហេតុនៃការស្លាប់របស់ពួកគេទេ។ ដោយពុំមានការពន្យល់ និងគ្មានសំអាងហេតុ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយសន្និដ្ឋានអំពីការធ្វើមនុស្សឃាតទាំងនេះ។

១០១៦. សេចក្តីសន្និដ្ឋាននេះមានកំហុស ដោយសារតែអង្គជំនុំជម្រះមិនបានបង្ហាញឱ្យឃើញពីកាលៈទេសៈនៃការស្លាប់របស់ឪពុកម្តាយក្មេក និងប្អូនថ្លៃស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ជាក់ស្តែង សេចក្តីសន្និដ្ឋាននេះរៀបរាប់ពីកាលៈទេសៈដែលត្រូវបានចោទប្រកាន់នៃការសម្លាប់ប្រពន្ធ និងកូនទាំងបីរបស់គាត់ ប៉ុន្តែមិនបានលើកឡើងពីកាលៈទេសៈនៃការសម្លាប់ឪពុកម្តាយក្មេក និងប្អូនថ្លៃស្រីរបស់គាត់ ដែលទំនងជាកើតឡើងនៅក្នុងពេល "ដាច់ដោយឡែកពីគ្នា" យោងតាមអង្គជំនុំជម្រះ[1885]។ ដោយពុំមានការពន្យល់ពាក់ព័ន្ធនឹងកាលៈទេសៈនៃការស្លាប់របស់មនុស្សទាំងនេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវត្រូវទុកជាមោឃៈ។ បន្ថែមលើកំហុសនេះ ក៏មានភាពផ្ទុយគ្នាក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះផងដែរ។ ជាក់ស្តែង ក្នុងកថាខណ្ឌមួយចំនួនខាងក្រោម អង្គជំនុំជម្រះបានសន្និដ្ឋានថា ភ័ស្តុតាងមិនអាចឱ្យអង្គជំនុំជម្រះបង្ហាញឱ្យឃើញពីការធ្វើមនុស្សឃាតលើម្តាយក្មេករបស់ដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ[1886]។

---

[1883] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨៨។

[1884] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨៣ និង ៣៤៨៤។

[1885] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨៣ "នៅខែកញ្ញា ឆ្នាំ១៩៧៨ សាច់ញាតិរបស់គាត់ចំនួន ១៣ នាក់ រួមទាំងកូនៗចំនួន ៣ នាក់របស់គាត់ ប្រពន្ធរបស់គាត់ជាកូនកាត់ជនជាតិវៀតណាម និងឪពុកម្តាយប្រពន្ធរបស់គាត់ ព្រមទាំងប្អូនស្រីរបស់ប្រពន្ធគាត់ ត្រូវបានសម្លាប់នៅក្នុងពេលដាច់ដោយឡែកពីគ្នា"។

[1886] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨៦។

១០១៧. ដោយសារមានកំហុសច្រើនពេក សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងការធ្វើមនុស្សឃាតលើជនជាតិវៀតណាម ១៩ នាក់ នៅក្នុងតំបន់ ៥០៥ ត្រូវទុកជាមោឃៈ[1887]។

## ៣. ការសម្លាប់រង្គាលជនជាតិវៀតណាម

១០១៨. ជាលក្ខណៈចម្បង យើងសូមរំឭកថា អង្គជំនុំជម្រះទទួលបានបណ្តឹងពុំត្រឹមត្រូវអំពីអង្គហេតុដែលជាធាតុផ្សំនៃការសម្លាប់រង្គាលលើប្រជាជនវៀតណាមនៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[1888]។ ប៉ុន្តែជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការសម្លាប់រង្គាល ពាក់ព័ន្ធនឹងការធ្វើមនុស្សឃាតប្រជាជនវៀតណាមនៅស្វាយរៀង កំពង់ឆ្នាំង វត្តខ្សាច់ ក្រចេះ និងនៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យបានទេ[1889]។ ជាក់ស្តែង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ក្នុងការវិនិច្ឆ័យលើការធ្វើមនុស្សឃាតទៅលើប្រជាជនវៀតណាមដែលត្រូវបានបង្ហាញ[1890]។

### ៣.១. ការសន្និដ្ឋានរួមខុសនៅលើហេតុការណ៍ផ្សេងៗគ្នា

១០១៩. ទីមួយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថា ការធ្វើមនុស្សឃាតប្រជាជនវៀតណាមនៅស្វាយរៀង កំពង់ឆ្នាំង វត្តខ្សាច់ ក្រចេះ និងនៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ បណ្តាលឱ្យមានមនុស្សជាច្រើននាក់ស្លាប់[1891]។ ជាក់ស្តែង ដោយបន្ថែមករណីជាក់លាក់នៃការធ្វើមនុស្សឃាតដែលត្រូវបានបង្ហាញ នៅក្នុងភូមិភាគចំនួន ៥ ផ្សេងៗគ្នា អង្គជំនុំជម្រះបានប៉ាន់ស្មាន ថាមានចំនួនប្រមាណជាង ៦០ នាក់។

---

[1887] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨៨, ៣៤៩៦ និង ៣៤៩៧។ នៅកំណត់សម្គាល់ជើងទំព័រលេខ១១៧៨៧ អង្គជំនុំជម្រះបានប៉ាន់ស្មានថាមានអ្នកស្លាប់ចំនួន ១៩ នាក់នៅក្នុងខេត្តក្រចេះ។

[1888] សូមមើលខាងលើ កថាខណ្ឌ ៤៣៥-៤៣៨។

[1889] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០១។

[1890] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-១០១៧។

[1891] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៩ និង ៣៥០០។

១០២០. ទោះបីពុំមានការតម្រូវអំពីការកម្រិតអប្បបរមានៃចំនួនអ្នកស្លាប់ ដើម្បីកំណត់ប្រភេទបទល្មើសនៃការធ្វើមនុស្សឃាតជាការសម្លាប់រង្គាលក៏ដោយ ក៏ត្រូវបង្ហាញថាមានមនុស្សជាច្រើននាក់បានស្លាប់ និងមានចេតនាប្រព្រឹត្តមនុស្សឃាតក្នុងទ្រង់ទ្រាយធំ ដើម្បីបង្ហាញថាមានឧក្រិដ្ឋកម្មសម្លាប់រង្គាល[1892]។ ករណីនៃការធ្វើមនុស្សឃាតដាច់តែឯងដែលទំនងជាអាចត្រូវបានបង្ហាញនោះ មិនបំពេញតាមការតម្រូវអំពីកម្រិតនៃភាពធ្ងន់ធ្ងរទេ។

១០២១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយវិនិច្ឆ័យថាមានភ័ស្តុតាងបង្ហាញថាមានអ្នកស្លាប់ជាង ៦០ នាក់ ដោយពិចារណាទៅលើហេតុការណ៍ទាំងអស់ដែលពុំមានទំនាក់ទំនងគ្នា ដែលនេះមិនអាចឱ្យសន្និដ្ឋានអំពីការតម្រូវអំពីកម្រិតនៃភាពធ្ងន់ធ្ងរបានទេ។ ប្រសិនបើពិនិត្យមើលម្តងមួយៗ ហេតុការណ៍ទាំងនេះមិនអាចឱ្យពិចារណាថាមានភ័ស្តុតាងបង្ហាញថាមានមនុស្សស្លាប់ជាង ១៩ នាក់បានទេ[1893]។

១០២២. ដើម្បីបញ្ជាក់ពីការប្រមូលហេតុការណ៍ផ្សេងៗគ្នា អង្គជំនុំជម្រះបានពិចារណាថា ការសម្លាប់នៅស្វាយរៀង កំពង់ឆ្នាំង វត្តខ្សាច់ ក្រចេះ និងនៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ "សុទ្ធតែជាផ្នែកនៃប្រតិបត្តិការនៃការធ្វើមនុស្សឃាតដូចគ្នា"[1894]។ អង្គជំនុំជម្រះបានវិនិច្ឆ័យជាអាទិ៍ថា "ភ័ស្តុតាងទូទៅ" អាចឱ្យបង្ហាញថា ប.ក.ក បានកំណត់គោលដៅលើប្រជាជនវៀតណាម និងបានអំពាវនាវឱ្យសម្លាប់ពួកគេ។ យោងតាមអង្គជំនុំជម្រះ ប្រជាជនវៀតណាមត្រូវបានកំណត់គោលដៅថាជាសមាជិកនៃក្រុមរួមមួយ មិនមែនជាលក្ខណៈបុគ្គលទេ[1895]។ ការអះអាងបែបនេះ ដែលមិនត្រឹមត្រូវដូចដែលយើង

---

[1892] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥៥។

[1893] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ១៧៧៨៩៖ អង្គជំនុំជម្រះបានប៉ាន់ស្មានថាមានមនុស្ស ១៩ នាក់ត្រូវគេសម្លាប់នៅក្រចេះ។

[1894] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០០។

[1895] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០០។

ឃើញនៅខាងក្រោម[1896] មានលក្ខណៈទូទៅពេកដើម្បីបង្ហាញថា ករណីជាក់លាក់នៃការធ្វើមនុស្សឃាតប្រជាជនវៀតណាមដែលបានលើកឡើង បានកើតឡើងក្នុងអំឡុងពេលនៃ "ប្រតិបត្តិការនៃការធ្វើមនុស្សឃាតដូចគ្នា"។

១០២៣. ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះបានប្រមូលហេតុការណ៍បញ្ចូលគ្នា ដោយព្យាយាមរកកន្លែងស្រដៀងគ្នា[1897]។ ប៉ុន្តែ ហេតុការណ៍ទាំងនេះជាហេតុការណ៍ដែលបានកើតឡើងនៅក្នុងទីកន្លែងផ្សេងៗគ្នា នៅកាលបរិច្ឆេទខុសៗគ្នា នៅក្នុងកាលៈទេសៈផ្សេងៗគ្នា នៅក្នុងរយៈពេលដ៏វែង។ ជាក់ស្តែង ហេតុការណ៍ទាំងនេះកើតឡើងនៅក្នុងភូមិភាគចំនួន ៥ ផ្សេងៗគ្នានៅក្នុងប្រទេស នៅកាលបរិច្ឆេទមិនច្បាស់លាស់ និងខុសៗគ្នា។ ដូច្នេះ ដោយសារជាការធ្វើមនុស្សឃាតនៅក្នុងដែនទឹក អង្គជំនុំជម្រះបានកំណត់ថាហេតុការណ៍បានកើតឡើងនៅខែមេសា ឬឧសភា ឆ្នាំ១៩៧៧ និងនៅខែមីនា ឆ្នាំ១៩៧៨[1898]។ ហេតុការណ៍នៅកំពង់ឆ្នាំងត្រូវបានកំណត់ថាបានកើតឡើងនៅចុងឆ្នាំ១៩៧៧[1899] ហេតុការណ៍នៅស្វាយរៀង នៅឆ្នាំ១៩៧៨[1900] ហេតុការណ៍នៅក្រចេះ នៅខែកញ្ញា ឆ្នាំ១៩៧៨[1901] និងហេតុការណ៍នៅវត្តខ្សាច់បានកើតឡើងក្នុងទ្រង់ទ្រាយធំនៅចុងឆ្នាំ១៩៧៨[1902]។ ដូច្នេះ កាលបរិច្ឆេទទាំងនេះមានរយៈពេលជាងមួយឆ្នាំកន្លះ។

១០២៤. ក្រៅពីកាលបរិច្ឆេទដែលឃ្លាតឆ្ងាយពីគ្នា អង្គជំនុំជម្រះមិនបានបញ្ជាក់ហេតុផលថាតើហេតុការណ៍ដែលបានកើតឡើងនៅខែមេសា ឬឧសភា ឆ្នាំ១៩៧៧ នៅក្នុងកងទ័ពជើងទឹក ស្ថិតនៅក្នុង "ប្រតិបត្តិការដូចគ្នា" នឹងការធ្វើមនុស្សឃាតនៅវត្តខ្សាច់ នៅក្នុងភូមិភាគឧត្តរថ្មី នៅចុងឆ្នាំ១៩៧៨ ត្រង់កន្លែង

---

[1896] ផ្ទុយពីការអះអាងរបស់អង្គជំនុំជម្រះ ភ័ស្តុតាង និងជាពិសេស ឯកសារផ្លូវការរបស់ ប.ក.ក និងសុន្ទរកថា មិនដែលកំណត់គោលដៅលើជនស៊ីវិលវៀតណាមឡើយ។ សូមមើលខាងក្រោម កថាខណ្ឌ ១៤៨០-១៤៨៨, ១៥៥១-១៥៦០។

[1897] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០០។

[1898] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៣។

[1899] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦៦។

[1900] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩០។

[1901] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៦។

[1902] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៥។

ណានោះទេ។ អង្គជំនុំជម្រះក៏មិនបានបញ្ជាក់ហេតុផលថាតើការធ្វើមនុស្សឃាតនៅកំពង់ចាមនៅចុងឆ្នាំ១៩៧៧ នៅក្នុងកាលៈទេសៈមិនស្គាល់ ស្ថិតនៅក្នុង "ប្រតិបត្តិការដូចគ្នា" នឹងការធ្វើការមនុស្សឃាតនៅក្រចេះ នៅខែកញ្ញា ឆ្នាំ១៩៧៨ ត្រង់កន្លែងណាដែរ។

១០២៥. ប៉ុន្តែ អង្គជំនុំជម្រះផ្ទាល់បានរំឭកថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការសម្លាប់រង្គាល ត្រូវបានបង្ហាញ "វាមិនគ្រប់គ្រាន់ទេ ក្នុងការពិចារណាជារួមនូវព្រឹត្តិការណ៍ផ្សេងគ្នាដែលបានប្រព្រឹត្តនៅទីតាំងផ្សេងគ្នា កាលៈទេសៈខុសគ្នា ប្រព្រឹត្តដោយចារីខុសគ្នា នៅក្នុងរយៈពេលដ៏វែង"[1903]។ នេះជាកំហុសដែលអង្គជំនុំជម្រះបានប្រព្រឹត្តយ៉ាងពិតប្រាកដ។ ដំណើរការនេះត្រូវតែទទួលយក ហើយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

## ៣.២. ការសន្និដ្ឋានពង្រីកអំពីចំនួនជនរងគ្រោះ

១០២៦. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយធ្វើការប៉ាន់ស្មានចំនួននៃការធ្វើមនុស្សឃាតប្រជាជនវៀតណាមជាង ៦០ នាក់[1904]។ ដើម្បីបានតួលេខនេះ អង្គជំនុំជម្រះបានពិចារណាថា មានភាពសមហេតុផលដែលប៉ាន់ស្មានថាមានអ្នកស្លាប់ជាមធ្យម ២ នាក់ក្នុងមួយគ្រួសារ និង ៥ នាក់ក្នុងមួយទូក។ ការប៉ាន់ស្មានតាមឆន្ទានុសិទ្ធិនេះមិនផ្អែកលើភ័ស្តុតាង ឬមូលដ្ឋានសត្យានុម័តិណាមួយឡើយ។ ជាក់ស្តែង អង្គជំនុំជម្រះបានសម្រេចទទួលយកការប៉ាន់ស្មាននេះ ខណៈដែលខ្លួនបានកត់សម្គាល់ថា "ភ័ស្តុតាងមិនច្បាស់លាស់"[1905]។

១០២៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយធ្វើការប៉ាន់ស្មានមិនច្បាស់លាស់ទាំងនេះដែលមិនអាចបំពេញបន្ថែមលើការពុំមានភ័ស្តុតាង និងទិន្នន័យប្រជាសាស្ត្រនៃប្រជាជនវៀតណាមរស់នៅប្រទេសកម្ពុជា

---

[1903] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥៦។

[1904] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៩ កំណត់សម្គាល់ជើងទំព័រលេខ ១១៧៨៧។

[1905] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៩ កំណត់សម្គាល់ជើងទំព័រលេខ ១១៧៨៧។

នៅសម័យកើតហេតុ។ ដូច្នេះ ការប៉ាន់ស្មានរបស់អង្គជំនុំជម្រះថាមានប្រជាជនវៀតណាមសរុបជាង ៦០ នាក់ត្រូវបានសម្លាប់ ពុំផ្អែកលើមូលដ្ឋានអ្វីឡើយ និងត្រូវតែបដិសេធចោល។

## ៤. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

១០២៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ត្រូវបានបង្ហាញ ទាក់ទងនឹងប្រជាជនវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង"[1906]។ ជាក់ស្ដែង ដោយប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ អង្គជំនុំជម្រះអាចពិចារណាឃើញថា ប្រជាជនវៀតណាមដែលខ្លួនបានកំណត់ ជាក្រុមពូជសាសន៍មួយដែលអាចសម្គាល់បានយ៉ាងគ្រប់គ្រាន់ (៤.១) ពួកគេរងការធ្វើទុក្ខបុកម្នេញ ដោយអំពើនៃការនិរទេស ការចាប់ខ្លួន និងការធ្វើមនុស្សឃាត (៤.២) និងអំពើទាំងនេះជាការរើសអើងពិតប្រាកដ (៤.៣)។ ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថា ប្រជាជនវៀតណាមត្រូវបានកំណត់គោលដៅដោយចេតនា នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង (៤.៣)។

### ៤.១. កំហុសអំពីប្រជាជនវៀតណាមក្នុងឋានៈជាក្រុមពូជសាសន៍មួយដែលអាចកំណត់អត្តសញ្ញាណបានគ្រប់គ្រាន់

១០២៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថា "ប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា" អាចត្រូវបានសម្គាល់យ៉ាងគ្រប់គ្រាន់ថាជាក្រុមពូជសាសន៍មួយ[1907]។ ដើម្បីធ្វើដូច្នេះ អង្គជំនុំជម្រះបានផ្អែកលើការរៀបរាប់របស់ខ្លួនទាក់ទងនឹងភ្នាក់ងារ សេអ៊ីអា កាហ្សេបេ និងយួន[1908]។ ប៉ុន្តែក្រុមទាំងនេះមិនសំដៅដល់ប្រជាជនវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាទេ។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបានកំណត់ឱ្យបានច្បាស់លាស់ថាតើបុគ្គលណាខ្លះដែល ប.ក.ក ហៅថាជាភ្នាក់ងារយួន។

---

[1906] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៣។

[1907] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១១។

[1908] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១១ កំណត់សម្គាល់ជើងទំព័រលេខ ១១៨១៥។

យោងតាមការសន្និដ្ឋានផ្ទាល់របស់អង្គជំនុំជម្រះ អ្នកដែលសង្ស័យថាជាជនក្បត់ស្ទើរតែទាំងអស់ អាចត្រូវបានចាត់ទុកថាភ្នាក់ងារយួន។ ហេតុដូច្នេះ អង្គជំនុំជម្រះបានពន្យល់ថា ចាន់ ចក្រី ត្រូវបានចោទថាជាភ្នាក់ងារយួន[1909] មានន័យថា ប្រជាជនកម្ពុជាខ្លះក៏ស្ថិតនៅក្នុងក្រុមនេះដែរ។

១០៣០. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះពិចារណាថា គោលនយោបាយ "១ ទល់នឹង ៣០" ដែលមាននៅក្នុងសុន្ទរកថារបស់ ប៉ុល ពត សំដៅដល់ទាំងយុទ្ធជន និងប្រជាជនស៊ីវិលវៀតណាម។ ដោយធ្វើរបៀបនេះ អង្គជំនុំជម្រះបានបំភ្លៃសុន្ទរកថានេះយ៉ាងច្បាស់[1910]។ ដូចបានលើកឡើងខាងក្រោម[1911] អង្គជំនុំជម្រះបានបង្ហាញពីការលម្អៀងរបស់ខ្លួន ដោយមិនចាប់អារម្មណ៍លើសក្ខីកម្មដែលបានផ្តល់ក្នុងកាលៈទេសៈត្រឹមត្រូវ និងមានភាពស៊ីចង្វាក់នឹងសក្ខីកម្មរបស់អតីតទាហានដែលបានពន្យល់ថា សុន្ទរកថានេះសំដៅលើកទឹកចិត្តកងកម្លាំងប្រដាប់អាវុធរបស់កម្ពុជាប្រជាធិបតេយ្យដែលមានចំនួនតិច។ ទោះជាយ៉ាងនេះក្តី គ្មានអ្វីដែលអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា សុន្ទរកថានេះកំណត់គោលដៅជនជាតិវៀតណាមដែលរស់នៅព្រៃវែង និងស្វាយរៀងបានឡើយ។

១០៣១. កំហុសរបស់អង្គជំនុំជម្រះ គឺមកពីអង្គជំនុំជម្រះបានធ្វើជាខ្សែសង្វាក់ជាហូរហែ ក្នុងសំអាងហេតុរបស់ខ្លួន ឱ្យច្របូកច្របល់ រវាងភ្នាក់ងារយួន ទាហានវៀតណាម ប្រជាជនស៊ីវិលវៀតណាមនៅវៀតណាម និងប្រជាជនស៊ីវិលវៀតណាមនៅកម្ពុជា។ ដោយហៅមនុស្សទាំងអស់នេះដោយប្រើពាក្យទូទៅថា "ជនជាតិវៀតណាម" អង្គជំនុំជម្រះមិនបានកំណត់ថាតើជាជនជាតិវៀតណាមនៅកម្ពុជាដែលត្រូវបានកំណត់គោលដៅជាក់លាក់នៅក្នុងសុន្ទរកថា ឬឯកសារផ្សេងទៀតរបស់ ប.ក.ក ទេ។

១០៣២. ការខកខានរបស់អង្គជំនុំជម្រះ ក្នុងការកំណត់និយមន័យច្បាស់លាស់នៃក្រុមប្រជាជនវៀតណាម ដែលយោងតាមផ្នែកនានានៃសំអាងហេតុសាលក្រម អាចរាប់បញ្ចូលក្រុមមនុស្សផ្សេងៗ រួមទាំងប្រជាជន

---

[1909] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥១។

[1910] សូមមើលខាងក្រោម កថាខណ្ឌ ១៥៥១-១៥៦០។

[1911] សូមមើលខាងក្រោម កថាខណ្ឌ ១៥៥១-១៥៦០។

កម្ពុជាផងដែរ រារាំងមិនឱ្យពិចារណាថា ក្រុមត្រូវបានសម្គាល់យ៉ាងគ្រប់គ្រាន់ ទៅតាមនិយមន័យច្បាប់ដែលអាចឱ្យកំណត់ប្រភេទបទល្មើសជាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ[1912]។

## ៤.២. កំហុសក្នុងការពិចារណាពីការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាម ដោយការនិរទេស ការចាប់ខ្លួន និងមនុស្សឃាត

១០៣៣. យោងតាមសំអាងហេតុសាលក្រម ប្រជាជនវៀតណាមនៅព្រៃវែង និងស្វាយរៀង ត្រូវបានធ្វើទុក្ខបុកម្នេញ ដោយការនិរទេសខ្លួនពីខេត្តព្រៃវែងទៅប្រទេសវៀតណាម នៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ ការចាប់ខ្លួននៅក្នុងខេត្តទាំងពីរនៅចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ និងការកាប់សម្លាប់នៅខេត្តស្វាយរៀងក្នុងឆ្នាំ១៩៧៨[1913]។ ដូចបានបង្ហាញនៅខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានអំពីឧក្រិដ្ឋកម្មនៃការនិរទេស នៅក្នុងខេត្តព្រៃវែង។ តាមពិត ភ័ស្តុតាងនៅក្នុងសំណុំរឿង មិនអាចបង្ហាញពីការនិរទេសប្រជាជនវៀតណាមឱ្យហួសពីវិមតិសង្ស័យបានទេ[1914]។ ដូចគ្នាដែរចំពោះការសន្និដ្ឋានទាក់ទងនឹងការធ្វើមនុស្សឃាតដែលត្រូវបានបង្ហាញថាមាននៅស្វាយរៀង ក្នុងឆ្នាំ១៩៧៨[1915]។

១០៣៤. ពាក់ព័ន្ធនឹងការចាប់ខ្លួនប្រជាជនវៀតណាមពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ អង្គជំនុំជម្រះបានយោងទៅកថាខណ្ឌ ៣៤៥១ នៃសំអាងហេតុសាលក្រម[1916]។ កថាខណ្ឌនេះពាក់ព័ន្ធនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការវិភាគរបស់ខ្លួនលើអង្គហេតុដែលបានកើតឡើងនៅក្នុងខេត្តព្រៃវែង។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការរៀបរាប់របស់ ឡាច គ្រី, ថង ប៉ាល់ និង ដួង អឿន មានភាពមិនច្បាស់លាស់ទាក់ទងនឹងកាលបរិច្ឆេទ[1917]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចបង្ហាញថា ការចាប់ខ្លួន និងការបាត់ខ្លួនមនុស្សទាំងនេះ បានកើតឡើងចាប់ពីខែមេសា ឆ្នាំ១៩៧៧ ទៅបានទេ។ ដូច្នេះ នៅចំពោះមុខវិមតិសង្ស័យនេះ អង្គ

[1912] សំអាងហេតុសាលក្រម កថាខណ្ឌ ៧១៤។

[1913] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១២។

[1914] សូមមើលខាងលើ កថាខណ្ឌ ៩៦៦-៩៨៦។

[1915] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-៩៩២។

[1916] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១០ កំណត់សម្គាល់ជើងទំព័រលេខ ១១៨១៣។

[1917] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥០ និង ៣៤៥១។

ជំនុំជម្រះក៏មិនគួរសម្រេចយកការចាប់ខ្លួន និងការបាត់ខ្លួនទាំងនេះថាជាការធ្វើទុក្ខបុកម្នេញនៅចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ដែរ។

១០៣៥. ពាក់ព័ន្ធនឹងការចាប់គ្រួសារវៀតណាមនៅស្វាយរៀង ដែលអង្គជំនុំជម្រះបានសម្រេចយកថាជាការធ្វើទុក្ខបុកម្នេញផងដែរនោះ ពុំមានការយោងទៅសំអាងហេតុរបស់អង្គជំនុំជម្រះ ដែលអាចឱ្យកំណត់ការចាប់ខ្លួនថាជាការធ្វើទុក្ខបុកម្នេញទេ។ ប៉ុន្តែ យោងតាមការវិភាគអង្គហេតុ អង្គជំនុំជម្រះបានសន្និដ្ឋានអំពីការធ្វើអត្តឃាតរបស់ឪពុក សៀង ចាន់ថី និងពីការធ្វើមនុស្សឃាតគ្រួសារវៀតណាមចំនួន ៤ ដែលត្រូវបានជំទាស់[1918]។ អង្គជំនុំជម្រះពុំបានធ្វើការសន្និដ្ឋានអំពីការចាប់ខ្លួនផ្សេងទៀតឡើយ។

១០៣៦. អាស្រ័យហេតុនេះ ការនិរទេសនៅព្រៃវែង ការធ្វើមនុស្សឃាតនៅស្វាយរៀង និងការចាប់ខ្លួននៅក្នុងខេត្តទាំងពីរ មិនត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសន្និដ្ឋានថា ប្រជាជនវៀតណាមនៅព្រៃវែង និងស្វាយរៀង ត្រូវបានធ្វើទុក្ខបុកម្នេញ ដោយអំពើទាំងនេះ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវតែបដិសេធចោល។

## ៤.៣. កំហុសក្នុងការពិចារណាថាអំពើដែលបានរៀបរាប់ ជាការរើសអើងជាក់ស្តែង

១០៣៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយពិចារណាថា អំពើដែលបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនវៀតណាម ជាការរើសអើងជាក់ស្តែង[1919]។ តាមពិត មិនមែនដោយសារតែអំពើសំដៅដល់ប្រជាជនវៀតណាម ទើបអំពើទាំងនេះជាការរើសអើងជាក់ស្តែងនោះទេ គឺត្រូវបង្ហាញផងដែរថា ពួកគេត្រូវបានកំណត់គោលដៅដោយសារតែពូជសាសន៍របស់ពួកគេ។ បង្ហាញថាពួកគេស្ថិតនៅក្នុងក្រុមណាមួយដែលមិនត្រូវបានធ្វើទាល់តែសោះ មិនគ្រប់គ្រាន់ក្នុងការពិចារណាថា អំពើដែលបានប្រព្រឹត្តប្រឆាំងនឹងពួកគេ ជាការរើសអើងជាក់ស្តែង។ អង្គជំនុំជម្រះមិនបានបញ្ជាក់ថាតើហេតុអ្វីមនុស្សទាំងនេះត្រូវបានកំណត់គោលដៅ និងត្រង់កន្លែងណាទេ។ ប៉ុន្តែ អង្គជំនុំជម្រះបានសន្និដ្ឋានថា នៅសម័យកម្ពុជាប្រជា

---

[1918] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-៩៩២។

[1919] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១១។

ធិបតេយ្យ មូលហេតុនៃការចាប់ខ្លួនមានច្រើន។ ម្យ៉ាងទៀត សាក្សីខ្លះបានពន្យល់ថា សមាជិកគ្រួសាររបស់ពួកគេ ទោះបីជាមានដើមកំណើតជាជនជាតិវៀតណាមក្តីអាចត្រូវបានកំណត់គោលដៅ ដោយសារហេតុផលផ្សេង ទៅតាមសកម្មភាពរបស់ពួកគេកន្លងមក។

១០៣៨. ឧទាហរណ៍ ដួង អឿន បានបញ្ជាក់ថា ប្តីរបស់គាត់ជាអតីតទាហានវៀតណាម ដែលប្រកបអាជីវកម្ម និងជួញដូរ ដែលតម្រូវឱ្យគាត់ត្រូវធ្វើដំណើរទៅប្រទេសវៀតណាម[1920]។ ដោយសារតែកំពុងមានជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម ប្តីរបស់គាត់អាចត្រូវគេចាប់ខ្លួន ដោយសារតែការរកស៊ីរបស់គាត់។ ក្នុងន័យដូចគ្នានេះ សៀង ចាន់ធី បានរៀបរាប់ថា បងប្អូនរបស់គាត់ជាប់ពាក់ព័ន្ធជាមួយរបបចាស់[1921]។

---

[1920] ប្រតិចារឹក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/381.1** ចន្លោះពីម៉ោង 13.37.35 ដល់ម៉ោង 13.41.58 មុនម៉ោង 13.46.49 "ស. ដូច្នេះ ជាការពិត គឺថាគាត់ធ្លាប់ធ្វើជាកងទ័ពវៀតណាម។ ត្រឹមត្រូវដែរទេ? ឆ. ចាស ត្រឹមត្រូវ" និងប្រហែលម៉ោង 13.46.49។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០ ឯកសារ **E3/7562** ERN 00034082-00034085 (លោកស្រី ដួង អឿន បញ្ជាក់ថា គាត់គ្មានរបរច្បាស់លាស់ទេ។ គាត់លក់តែអាភៀនទេ។ ជារបរលួចលាក់ តែប៉ានបើកចំហ ជាប់គុក)។ សូមមើលផងដែរ៖ ឡាច គ្រី៖ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០០ **E3/7559** ERN 00034271-00034272, 00034276-00034277 (ជុយ មកប្រទេសកម្ពុជានៅឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហាររបស់ លន់ នល់។ គាត់រកស៊ី ដោយធ្វើដំណើរទៅមក វៀតណាម-កម្ពុជា។ កម្រិតជីវភាពរបស់គាត់មិនអាក្រក់ប៉ុន្មានទេនៅសម័យនោះ)។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅ សំ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០០ ឯកសារ **D230/1.1.49b** ERN 00451710-00451711 (ជុយ ជាទាហាន មុនមករស់នៅក្នុងភូមិ នៅឆ្នាំ១៩៧១ ក្រោយមក គាត់រកស៊ីលក់ដូរអីវ៉ាន់គ្រប់មុខ)។ ឯកសារនេះពុំមានលេខ E3 ប៉ុន្តែ ឯកសារនេះត្រូវបានបង្ហាញនៅក្នុងសវនាការ ក្នុងពេលដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ចូលមកបង្ហាញខ្លួន៖ ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/380.1** ទំព័រ ៥៦-៦១ ចន្លោះពីម៉ោង 14.42.15 ដល់ម៉ោង 15.01.04។

[1921] ប្រតិចារឹក ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧២ មុនម៉ោង 15.39.54 "បងប្រុសខ្ញុំពីរនាក់ទៀត ជម្លៀសពីភ្នំពេញទៅ។ គាត់ជាទាហាន និងជាប៉ូលីស"។ ប្រតិចារឹក ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/394.1** ទំព័រ ៦ ម៉ោង 09.21.14 "បងចាន់ថន បងទី១ គាត់ជាប៉ូលីស ប៉ូលីសលន់នល់ គាត់ពាក់ស័ក្តិ១ដែរ" ទំព័រ ១៤ មុនម៉ោង 09.50.32 "គេស្រង់ស្ថិតិ គេសួរទេ យើងប្រាប់គេថា គាត់ធ្លាប់ធ្វើទាហាន ធ្វើប៉ូលីសអីចឹងទៅ"។

១០៣៩. ដោយផ្អែកលើធាតុផ្សំទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពន្យល់ថា តើប្រជាជនវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ដោយរបៀបណាទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវតែបដិសេធចោល។

## ៤.៤. កំហុសក្នុងការសន្និដ្ឋានពីការកំណត់គោលដៅដោយចេតនាលើប្រជាជនវៀតណាម នៅខេត្តព្រៃវែង និងស្វាយរៀង

### ៤.៤.១. កំហុសក្នុងការពិចារណាពីការកំណត់អត្តសញ្ញាណជនជាតិវៀតណាម តាមរយៈបញ្ជីឈ្មោះ

១០៤០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបង្ហាញថា "ចាប់ពីខែមេសា ឆ្នាំ១៧៥ ប្រជាជនវៀតណាមត្រូវបានកំណត់អត្តសញ្ញាណដោយ ប.ក.ក តាមរយៈការបង្កើតបញ្ជីឈ្មោះ"[1922]។ អង្គជំនុំជម្រះបានយោងទៅការវិភាគរបស់ខ្លួនលើភស្តុតាងអំពីអត្ថិភាពនៃគោលនយោបាយ ចំពោះប្រជាជនវៀតណាមជាពិសេស ទាក់ទងនឹងការកំណត់អត្តសញ្ញាណរបស់ពួកគេ[1923]។ ការសន្និដ្ឋានទូទៅថា ប្រជាជនវៀតណាមត្រូវបានកំណត់អត្តសញ្ញាណតាមរយៈបញ្ជី មិនត្រឹមត្រូវនោះទេ[1924]។ ទោះជាយ៉ាងនេះក្តី ការសន្និដ្ឋាននេះមិនអនុវត្តចំពោះខេត្តព្រៃវែង និងស្វាយរៀងឡើយ។

១០៤១. តាមពិត ក្នុងន័យនេះ គ្មានភស្តុតាងណាសំដៅជាក់លាក់ដល់ទីតាំងទាំងពីរនេះទេ។ ធាតុផ្សំភស្តុតាងតែមួយគត់ដែលត្រូវបានដកស្រង់ពាក់ព័ន្ធនឹងខេត្តទាំងពីរនេះ គឺសក្ខីកម្មរបស់របស់ សៀង ចាន់ធី និង សៅ សាក់[1925]។ ក្នុងសក្ខីកម្មរបស់ពួកគេ ពុំមានអ្វីដែលគាំទ្រដល់ការសន្និដ្ឋានថា បញ្ជីឈ្មោះប្រជាជនវៀតណាមត្រូវបានរៀបចំឡើងនោះទេ។ សៅ សាក់ បានបញ្ជាក់ថា៖ "ដឹងគេធ្វើស្ថិតិខ្មែរ ប៉ុន្តែត្រង់ថាវៀតណាមហ្នឹង មិនបានដឹងទេ"[1926]។ ដូច្នេះ ជាការប្រព្រឹត្តិកំហុសដែលអង្គជំនុំជម្រះប្រើប្រាស់សក្ខីកម្មនេះដើម្បីអះអាងថា ថ្នាក់លើដឹងថាតើគ្រួសារណាខ្លះមានដើមកំណើតវៀតណាម។

---

[1922] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១០ និង ៣៥១៣។

[1923] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១០ កំណត់សម្គាល់ជើងទំព័រលេខ១១ ៨១១ ដែលយោងទៅកថាខណ្ឌ ៣៤២៣។

[1924] សូមមើលខាងក្រោម កថាខណ្ឌ ១៥៥១-១៥៦០។

[1925] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤២០ កំណត់សម្គាល់ជើងទំព័រលេខ១១៥៣១។

[1926] ប្រតិចារឹក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/363.1** មុនម៉ោង 09.41.12។

១០៤២. ការបង្កើតបញ្ជីឈ្មោះនៅកន្លែងផ្សេងទៀតក្នុងប្រទេស មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានទេថា ជាករណីនៅព្រៃវែង និងស្វាយរៀង ដោយគ្មានភ័ស្តុតាងបញ្ជាក់។ ប៉ុន្តែ គ្មានសក្ខីកម្មណាមួយដែលបានស្តាប់នៅសវនាការ ទាក់ទងនឹងខេត្តទាំងនេះ បញ្ជាក់ពីការបង្កើតបញ្ជីឈ្មោះប្រជាជនវៀតណាមនោះទេ។ ដូច្នេះ អង្គជំនុំជម្រះបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវភ័ស្តុតាងក្រៅខេត្តព្រៃវែង និងស្វាយរៀង ដើម្បីសន្និដ្ឋានថា ប្រជាជនវៀតណាមនៅទីតាំងទាំងពីរនេះ ត្រូវបានកំណត់គោលដៅដោយចេតនាដោយមូលហេតុពូជសាសន៍របស់ពួកគេ។

### ៤.៤.២. កំហុសក្នុងការសន្និដ្ឋានអំពីជាតិពន្ធុខ្មែរស្រឡាយខាងម្តាយ

១០៤៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយវិនិច្ឆ័យថាមានភ័ស្តុតាងបង្ហាញថា “គ្រួសារចម្រុះត្រូវបានកំណត់គោលដៅដោយផ្អែកលើមូលដ្ឋានជាតិពន្ធុខ្មែរស្រឡាយខាងម្តាយ”[1927]។ ដូចបានបង្ហាញនៅខាងក្រោម ការសន្និដ្ឋាននេះមិនត្រឹមត្រូវ។ ជាក់ស្តែង ភ័ស្តុតាងដែលអង្គជំនុំជម្រះទទួលយក គ្រាន់តែជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់មនុស្សមួយចំនួនដែលមកផ្តល់សក្ខីកម្មប៉ុណ្ណោះ។ ជាពិសេស ពុំមានសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានកោះហៅឱ្យចូលមកបង្ហាញខ្លួនណាម្នាក់ បញ្ជាក់ថាព័ត៌មានរបស់ពួកគេទទួលបានពីថ្នាក់លើនោះទេ។

១០៤៤. ដួង អឿន ក៏បានបញ្ជាក់ថា គាត់មិនបានដឹងថាព័ត៌មានទាំងនេះមកពីណាដែរ[1928]។ សក្ខីកម្មរបស់ ស៊ិន ឆែម ផ្អែកលើពាក្យចចាមអារ៉ាម[1929]។ អ៊ុច ស៊ុនឡាយ មិនមែនមកពីខេត្តព្រៃវែង និងស្វាយរៀងទេ។ម្យ៉ាងវិញទៀត សក្ខីកម្មរបស់គាត់មិនគាំទ្រដល់ជាតិពន្ធុខ្មែរស្រឡាយខាងម្តាយទេ ពីព្រោះគាត់បាន

[1927] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១០ និង ៣៥១៣។

[1928] ប្រតិចារិក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/381.1** ម៉ោង 14.13.59 “ខ្ញុំដឹងថាអ៊ីចឹងមែន ប៉ុនត្រង់អាម៉េចៗទៀត ខ្ញុំអត់ដឹងទេ។ បើដឹងថាគេយកកូនគាត់ទៅអស់រលីងហើយ គ្មាននៅសល់មួយទេ។ ខ្ញុំដឹងតែប៉ុណ្ណឹង។ ត្រង់ម៉េចៗទៀត ខ្ញុំអត់ដឹងទេ។ ខ្ញុំអត់ចាំផង”។

[1929] ប្រតិចារិក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/367.1** ម៉ោង 10.49.40។ គាត់លើកឡើងពីសម្តីរបស់បុរសម្នាក់ដែលធ្វើការជាមួយប្តីរបស់គាត់។

និយាយតែពីករណីកូនមានម្តាយជាជនជាតិវៀតណាម មិនមែនកូនមានឪពុកជាជនជាតិវៀតណាម។ មិនអាចកំណត់បានទេពីប្រភពនៃពាក្យចចាមអារ៉ាមដែលថា “ជីកស្មៅ ត្រូវជីកទាំងឫស”[1930]។ ឡាច គ្រី បានពន្យល់ថា “ខ្ញុំបាទ តាមខ្ញុំសង្កេតមើល មិនមែនៗកម្មាភិបាលនិយាយទេ គឺថាខ្ញុំបាទប្រជាជនក៏ដូចរូបខ្ញុំបាទដែរ អាចដឹង”[1931]។ ប្រាក់ ឌឿន មិនមែនមកពីខេត្តព្រៃវែង និងស្វាយរៀង ហើយការលើកឡើងរបស់គាត់ចេញពីការសង្កេតផ្ទាល់ខ្លួនរបស់គាត់[1932]។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ូ វ៉ាន ទោះបីជាតម្លៃជាភ័ស្តុតាងមានតិចតួចក៏ដោយ[1933] មិនគាំទ្រដល់ជាតិពន្ធុខ្មែរស្រឡាយខាងម្តាយទេ[1934]។

១០៤៥. អង្គជំនុំជម្រះក៏ផ្អែកលើបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ចាន់ គា ផងដែរ[1935]។ ប៉ុន្តែ បទសម្ភាសន៍ជាលាយលក្ខណ៍អក្សរនេះលើកឡើងផ្ទុយពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីជាតិពន្ធុខ្មែរស្រឡាយខាងម្តាយ។ ជាក់ស្តែង ចាន់ គា បានពន្យល់ថា នៅក្នុងករណីគ្រួសារចម្រុះមួយដែលមានឪពុកជាជនជាតិវៀតណាម ហើយម្តាយជាខ្មែរ កូនៗត្រូវបាននាំទៅជាមួយឪពុកជាជនជាតិវៀតណាម[1936]។ អង្គជំនុំជម្រះក៏បានបំភ្លៃសក្ខីកម្មរបស់ ហេង ឡៃហេង ដោយពិចារណាថា ការលើកឡើងរបស់គាត់គាំទ្រដល់គោលនយោបាយនៃខ្មែរស្រឡាយខាងម្តាយ[1937]។ អង្គជំនុំជម្រះបានបង្រួញដោយចេតនានូវចម្លើយមួយផ្នែករបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានអះអាងថា ក្នុងករណីម្តាយជាវៀត

[1930] ប្រតិចារឹក ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/395.1** ក្រោយម៉ោង 09.14.46។

[1931] ប្រតិចារឹក ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/379.1** ម៉ោង 14.31.13។

[1932] ប្រតិចារឹក ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/361.1** ប្រហែលម៉ោង 14.41.21។

[1933] សូមមើលខាងលើ កថាខណ្ឌ ៣០៦-៣១១។

[1934] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ូ វ៉ាន់ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥ ឯកសារ **E3/7498** ERN 00089576 (ប៉ូ វ៉ាន់ ពន្យល់ថា កូនរបស់ស្ត្រីវៀតណាមពីរនាក់ក៏ត្រូវបាននាំយកទៅដែរ។ គាត់មិនបានបញ្ជាក់ពីករណីកូនមានឪពុកជាជនជាតិវៀតណាម ដែលផ្ទុយទៅវិញ រួចខ្លួន នោះទេ)។

[1935] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤២៤ កំណត់សម្គាល់ជើងទំព័រលេខ១១៥៤៧។

[1936] បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ចាន់ គា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ឯកសារ **E3/7525** ERN 00089627-00089628។

[1937] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤២៤ កំណត់សម្គាល់ជើងទំព័រលេខ១១៥៤៧។

ណាម ហើយឪពុកជាខ្មែរ កូនខ្លះអាចនៅរស់។ ដើមបណ្តឹងរដ្ឋប្បវេណីនេះក៏បានអះអាងផងដែរថា "មួយចំនួនខ្លះកាត់ដូចគ្នា តែគេនៅរស់"[1938]។

១០៤៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយពិចារណាថា ករណីលើកឡើងដោយមេធាវីការពារក្តី ដែលផ្ទុយពីគោលនយោបាយកំណត់គោលដៅចំពោះខ្សែខាងម្តាយ ជាករណីដាច់ដោយឡែក[1939]។ ផ្ទុយទៅវិញ ដូចបានបង្ហាញខាងលើរួចហើយ ភ័ស្តុតាងដែលគាំទ្រដល់ខ្សែស្រឡាយខាងម្តាយ មិនសូវមានច្រើនទេ ហើយផ្អែកតែទៅលើការសន្និដ្ឋានផ្ទាល់ខ្លួនប៉ុណ្ណោះ។ ករណីខ្លះផ្ទុយនឹងទ្រឹស្តីដែលអង្គជំនុំជម្រះបានទទួលយក ហើយដូច្នេះ វាបំពេញបន្ថែមទៅលើករណីដែលមេធាវីការពារក្តីបានលើកឡើង ហើយដែលករណីទាំងនេះមិនមែនជាករណីដាច់ដោយឡែកនោះទេ[1940]។

១០៤៧. ជាចុងក្រោយ គប្បីត្រូវលើកឡើងជាពិសេសថា ពុំមានឯកសារផ្លូវការរបស់ ប.ក.ក ឬសុន្ទរកថាណាមួយ ដែលលើកឡើងពីទ្រឹស្តីនេះទេ។ អង្គជំនុំជម្រះបានបញ្ជាក់តែពីឯកសារមួយប៉ុណ្ណោះ ដែលលើកឡើងអំពីការតាមដានគ្រួសារចម្រុះមួយចំនួន[1941]។ ឯកសារនេះមិនបានបង្ហាញពីការចាត់វិធានការណាមួយចំពោះគ្រួសារទាំងនេះទេ។ ទោះជាយ៉ាងនេះក្តី ឯកសារនេះមិនគាំទ្រដល់ទ្រឹស្តីជាតិពន្ធុខ្សែស្រឡាយខាងម្តាយ ដូចដែលអង្គជំនុំជម្រះបានទទួលយកទេ។

១០៤៨. អាស្រ័យហេតុនេះ ច្បាស់ណាស់ថា អង្គជំនុំជម្រះពុំមានធាតុផ្សំនៃភ័ស្តុតាងគ្រប់គ្រាន់ដើម្បីសន្និដ្ឋានអំពីជាតិពិន្ទុខ្សែស្រឡាយខាងម្តាយទេ។ ដូច្នេះ អង្គជំនុំជម្រះបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវភ័ស្តុតាងនេះ ដើម្បីកំណត់ធាតុផ្សំអត្តនោម័តិនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍ទៅលើប្រជាជនវៀតណាមនៅព្រៃវែង និងស្វាយរៀង។

---

[1938] ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** មុនម៉ោង 14.33.00។

[1939] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤២៧។

[1940] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ១៩៩២-២០០០។

[1941] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤២៦។

### ៤.៤.៣. កំហុសក្នុងការពិចារណាពីការកំណត់គោលដៅប្រជាជនវៀតណាមនៅកម្ពុជា នៅក្នុងសេចក្តីប្រកាសរបស់ ប.ក.ក និងសុន្ទរកថា

១០៤៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយទទួលយក "ឯកសារសេសសល់ពីរបបនោះនៅក្នុងទស្សនាវដ្តីទង់បដិវត្ត និងសុន្ទរកថារបស់ឥស្សរជនជាថ្នាក់ដឹកនាំរបស់ ប.ក.ក ដែលកំណត់គោលដៅទៅលើជនជាតិវៀតណាម" ដើម្បីបង្ហាញធាតុផ្សំអត្តនោម័តិ[1942]។ អង្គជំនុំជម្រះមិនបានយោងទៅប្រភពជាក់លាក់ណាមួយ ដើម្បីធ្វើការសន្និដ្ឋានអំពីអង្គហេតុ។ ដូច្នេះ មេធាវីការពារក្តីមិនអាចដឹងថាអង្គជំនុំជម្រះផ្អែកលើភ័ស្តុតាងមួយណាទេ ដើម្បីសន្និដ្ឋានថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ កំណត់គោលដៅទៅលើប្រជាជនវៀតណាមដែលរស់នៅព្រៃវែង និងស្វាយរៀង។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយោងជាទូទៅទៅឯកសារ និងសុន្ទរកថារបស់ ប.ក.ក ដោយមិនបានបង្ហាញថាតើឯកសារ និងសុន្ទរកថាទាំងនោះកំណត់គោលដៅទៅលើប្រជាជនវៀតណាមនៅព្រៃវែង និងស្វាយរៀងត្រង់កន្លែងណាឡើយ។ ដោយគ្មានការបញ្ជាក់ហេតុផល សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវតែបដិសេធចោល។

១០៥០. ម្យ៉ាងវិញទៀត ផ្ទុយពីការអះអាងរបស់ខ្លួន អង្គជំនុំជម្រះមិនបានពិចារណាទៅលើជម្លោះប្រដាប់អាវុធដែលកើតមានជាមួយប្រទេសវៀតណាម ដើម្បីបកស្រាយសេចក្តីប្រកាសជាផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យចំពោះប្រទេសវៀតណាមទេ[1943]។ ដូចដែលបានបង្ហាញនៅខាងក្រោម ការសន្មតថា ប្រជាជនវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានកំណត់គោលដៅ ជាការបកស្រាយខុស និងត្រូវកែតម្រូវដោយតុលាការកំពូល[1944]។

## ៥. អំពើប្រល័យពូជសាសន៍

[1942] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៣។

[1943] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤១៦។

[1944] សូមមើលខាងក្រោម កថាខណ្ឌ ១០៥៩-១០៩៧។

១០៥១. ជាលក្ខណៈចម្បង យើងសូមរំឭកថា អង្គជំនុំជម្រះទទួលបានបណ្តឹងពុំត្រឹមត្រូវអំពីអង្គហេតុដែលជាធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ ដោយការធ្វើមនុស្សឃាតសមាជិកក្រុមប្រជាជនវៀតណាម នៅខាងក្រៅខេត្តព្រៃវែង និងស្វាយរៀង[1945]។ ប៉ុន្តែ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយយល់ឃើញខុសថា ធាតុផ្សំសត្យានុម័តិ (៥.១) និងអត្តនោម័តិ (៥.២) នៃអំពើប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាត ត្រូវបានបង្ហាញ នៅក្រៅខេត្តទាំងពីរ។

## ៥.១. កំហុសអំពីធាតុផ្សំសត្យានុម័តិ

### ៥.១.១. កំហុសអំពីការធ្វើមនុស្សឃាតប្រជាជនវៀតណាម

១០៥២. ដូចបានបង្ហាញខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានថា ប្រជាជនវៀតណាម ៦ នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខអូរកន្សែង ដោយផ្អែកតែទៅលើចម្លើយជាលាយលក្ខណ៍អក្សររបស់ នោម សែ[1946]។ ពាក់ព័ន្ធនឹង ស-២១ អង្គជំនុំជម្រះក៏បានសន្និដ្ឋានខុសផងដែរថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលប្រជាជនវៀតណាម ត្រូវបានបង្ហាញ[1947]។ ជាក់ស្តែង ពេលយោងទៅការកំណត់ប្រភេទបទល្មើសនៃការធ្វើមនុស្សឃាតនៅ ស-២១ អង្គជំនុំជម្រះមិនបានបញ្ជាក់ពីការធ្វើមនុស្សឃាតប្រជាជនវៀតណាមទេ[1948]។ អង្គជំនុំជម្រះហាក់ដូចជាមានការភាន់ច្រឡំជាមួយការធ្វើមនុស្សឃាតដោយចេតនាថាជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលប្រជាជនវៀតណាមជាជនរងគ្រោះ យោងតាមសំអាងហេតុសាលក្រម[1949]។ ដូចបានបង្ហាញខាងក្រោម ប្រជាជនវៀតណាមទាំងនេះមិនស្ថិតនៅក្នុងក្រុមជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានការពារនោះទេ[1950]។

---

1945 សូមមើលខាងលើ កថាខណ្ឌ ៤៣៥-៤៣៨។

1946 សូមមើលខាងលើ កថាខណ្ឌ ៨៤២-៨៤៧។

1947 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៥។

1948 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៥ កំណត់សម្គាល់ជើងទំព័រលេខ១១៨២៤ ដែលយោងទៅកថាខណ្ឌ ២៥៦០-២៥៧១ នៃសំអាងហេតុសាលក្រមដែលទាក់ទងនឹងការកំណត់ប្រភេទបទល្មើសនៃការធ្វើមនុស្សឃាតនៅ ស-២១។

1949 សំអាងហេតុសាលក្រម កថាខណ្ឌ ២៦២០-២៦២២។

1950 សូមមើលខាងក្រោម កថាខណ្ឌ ១០៥៦។

១០៥៣. ជាចុងក្រោយ ដូចដែលបានបង្ហាញនៅខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានអំពីការធ្វើមនុស្សឃាតប្រជាជនវៀតណាម នៅស្វាយរៀង ក្រចេះ និងកំពង់ឆ្នាំង[1951]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានអំពីការធ្វើមនុស្សឃាតប្រជាជនវៀតណាមនៅសមុទ្រ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ និងការធ្វើមនុស្សឃាតជីដូនជីតារបស់ ចាន់ថា និងគ្រួសាររបស់ ជុំ នៅវត្តខ្សាច់[1952]។

១០៥៤. ដោយមិនបានបង្ហាញឱ្យឃើញពីការធ្វើមនុស្សឃាតឱ្យហួសពីវិមតិសង្ស័យ អង្គជំនុំជម្រះមិនអាចប្រើប្រាស់ព័ត៌មានទាំងនេះដើម្បីសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត[1953] ដែល ខៀវ សំផន ត្រូវបានចោទប្រកាន់ ត្រូវបានបង្ហាញប្រឆាំងនឹងជនជាតិភាគតិចវៀតណាម[1954]។

### ៥.១.២. កំហុសក្នុងការពិចារណាពីការសម្លាប់ប្រជាជនវៀតណាមប្រាំមួយនាក់នៅអូរកន្សែង ក្នុងឋានៈជាក្រុមស្ថិតក្រោមការការពារ

១០៥៥. ដោយទទួលស្គាល់ថា ការធ្វើមនុស្សឃាតប្រជាជនវៀតណាម ៦ នាក់ នៅមន្ទីរសន្តិសុខអូរកន្សែង ត្រូវបានបង្ហាញ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយពិចារណាថា ប្រជាជនវៀតណាមទាំងនេះត្រូវបានសម្លាប់ ដោយសារតែពួកគេស្ថិតនៅក្នុងក្រុមដែលត្រូវបានការពារ[1955]។ ជាក់ស្តែង អង្គជំនុំជម្រះបានអះអាងថា ប្រជាជនវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ជាក្រុមជាតិពន្ធុសញ្ជាតិ និងពូជសាសន៍មួយដាច់ដោយឡែក និងជាក្រុមដែលត្រូវបានការពារ[1956]។ ប្រជាជនវៀតណាមទាំង ៦ នាក់ ដែលត្រូវបានចាប់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខអូរកន្សែង រស់នៅប្រទេសវៀតណាម មិនមែននៅ

---

[1951] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-៩៩២, ១០០៣-១០០៥, ១០១៤-១០១៧។

[1952] សូមមើលខាងលើ កថាខណ្ឌ ៩៩៣-១០០២, ១០០៦-១០១៣។

[1953] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៩៦។

[1954] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៤-៣៥១៨។

[1955] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៥-៣៥១៦។

[1956] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៤ កំណត់សម្គាល់ជើងទំព័រលេខ១១៨២២ ដែលយោងទៅកថាខណ្ឌ ៣៤១៩ ដែលថា ប្រជាជនវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា ជាក្រុមជាតិពន្ធុ សញ្ជាតិ និងពូជសាសន៍ដោយឡែក។

ប្រទេសកម្ពុជាទេ។ តាមចម្លើយរបស់ ឆោម សែ ពួកគេត្រូវបានចាប់ខ្លួនមុនឆ្នាំ១៩៧៩ តាមបណ្ដោយព្រំប្រទល់ ដែលពួកគេទើបតែឆ្លងផុត ដើម្បីមកស៊ើបការណ៍នៅប្រទេសកម្ពុជា[1957]។ ដូច្នេះ អង្គជំនុំជម្រះមិនគួរចាត់ទុកប្រជាជនវៀតណាមទាំងនេះថា ស្ថិតនៅក្នុងក្រុមប្រជាជនវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាឡើយ។ អង្គជំនុំជម្រះមិនអាចទទួលយកការធ្វើមនុស្សឃាតទាំងនេះនៅក្នុងការកំណត់បទល្មើសនៃអំពើប្រល័យពូជសាសន៍ឡើយ។

### ៥.១.៣. កំហុសក្នុងការចាត់ទុកប្រជាជនវៀតណាមដែលត្រូវបានសម្លាប់នៅមន្ទីរ ស-២១ ក្នុងឋានៈជាក្រុមស្ថិតក្រោមការការពារ

១០៥៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយពិចារណាថា ប្រជាជនវៀតណាមដែលត្រូវបានសម្លាប់នៅមន្ទីរ ស-២១ ស្ថិតនៅក្នុងក្រុមប្រជាជនវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានការពារ[1958]។ ជាក់ស្ដែង អង្គជំនុំជម្រះបានរំឮកថា ការចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធនឹងកម្លាំងប្រដាប់អាវុធ និងពលរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម[1959]។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានពិចារណាថា ប្រជាជនវៀតណាមជាប់ឃុំនៅមន្ទីរ ស-២១ មានទាហានវៀតណាម និងពលរដ្ឋវៀតណាមដែលភាគច្រើនត្រូវបានចាប់ខ្លួននៅជិតព្រំប្រទល់ ឬនៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ[1960]។ អង្គជំនុំជម្រះមិនគួរចាត់ទុកពួកគេថាស្ថិតនៅក្នុងក្រុមប្រជាជនវៀតណាមរស់នៅប្រទេសកម្ពុជាដែលត្រូវបានការពារនោះទេ។ មនុស្សទាំងនេះមិនអាចចាត់ទុកថាជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ទេ។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះក្នុងន័យនេះត្រូវតែបដិសេធចោល។

---

[1957] កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/405** ERN 00401303 "ប្រហែលជានៅមុនឆ្នាំ១៩៧៩ បន្តិច មុនពេលវៀតណាមវាយចូលខ្លាំងនៅឆ្នាំ១៩៧៩ ឃើញមានចាប់អ្នកទោសជាជនជាតិវៀតណាម (ស៊ីវិល) មួយក្រុមមានគ្នា៦នាក់ ពីសមរភូមិអូរយ៉ាដាវតាមព្រំដែន ដោយសារអ្នកនោះបានចូលឈ្លបយកការណ៍បើផ្លូវនៅផ្លូវលេខ១៩ ដែលវៀតណាមខាងជើង និងខាងត្បូងប៉ុនប៉ងវាយយកផ្លូវនេះ"។

[1958] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៤-៣៥១៦។

[1959] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០១២។ សូមមើលផងដែរ ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៨១។

[1960] សំអាងហេតុសាលក្រម កថាខណ្ឌ ២៤៦០-២៤៨៤ និង ២៦២២។

## ៥.១.៤. កំហុសក្នុងការចាត់ទុកប្រជាជនវៀតណាមនៅសមុទ្រក្នុងឋានៈជាក្រុមស្ថិតក្រោមការការពារ

១០៥៧. ដោយទទួលស្គាល់ថា ការធ្វើមនុស្សឃាតប្រជាជនវៀតណាមនៅសមុទ្រត្រូវបានប្រព្រឹត្ត នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយពិចារណាថា ពួកគេស្ថិតនៅក្នុងក្រុមជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានការពារ[1961]។ ដូចបានបង្ហាញខាងលើ ពុំមានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានថា វៀតណាមដែលត្រូវបានកំណត់គោលដៅ ក្នុងរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ជាជនស៊ីវិលបានទេ[1962]។ ទោះជាកុមារដែលត្រូវគេសម្លាប់នៅកំពង់ផែអូរឈើទាល ក្រោយខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ ឬទោះជាជនជាតិវៀតណាមដែលត្រូវគេសម្លាប់នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ ក៏ដោយ ក៏ពួកគេគឺជាពលរដ្ឋវៀតណាម ហើយទោះក្នុងករណីណាក៏ដោយ គឺមិនមែនជាជនជាតិវៀតណាមរស់នៅកម្ពុជាទេ[1963]។ ដោយសារមិនស្ថិតក្នុងក្រុមដែលត្រូវការពារ អង្គជំនុំជម្រះមិនអាចកំណត់ថាការធ្វើមនុស្សឃាតលើពួកគេជាអំពើប្រល័យពូជសាសន៍បានទេ។ ដូច្នេះ សេចក្តីសន្និដ្ឋាននេះត្រូវតែបដិសេធចោល។

## ៥.២. កំហុសអំពីធាតុផ្សំអត្តនោម័តិ

១០៥៨. អង្គជំនុំជម្រះបានសន្និដ្ឋានខុសពីអត្ថិភាពនៃធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ដើម្បីឱ្យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានបង្ហាញ ត្រូវបង្ហាញឱ្យឃើញពីចេតនាជាក់លាក់ក្នុងការកម្ទេចទាំងស្រុង ឬមួយផ្នែកនូវក្រុមដែលត្រូវបានការពារ[1964]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានកំណត់ថាតើមានចេតនាបំផ្លិចបំផ្លាញក្រុម “ទាំងស្រុង ឬមួយផ្នែក” (៥.២.១) និងដោយសន្និដ្ឋានថា មានចេតនាបំផ្លិចបំផ្លាញក្រុមដែលត្រូវការពារ (៥.២.២)។

---

[1961] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៤-៣៥១៦។

[1962] សូមមើលខាងលើ កថាខណ្ឌ ១០០១។

[1963] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥៩-៣៤៦១។

[1964] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៩៧។

### ៥.២.១. កំហុសក្នុងការមិនបានកំណត់អត្ថិភាពនៃចេតនាកម្ទេចក្រុម “មួយផ្នែក ឬទាំងស្រុង”

១០៥៩. ក្នុងពេលកំណត់ប្រភេទបទល្មើសនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អង្គជំនុំជម្រះបានសន្និដ្ឋានថា “សកម្មភាពរបស់ចារីផ្ទាល់ នៅក្នុងករណីនៃការសម្លាប់ខាងលើនេះ បង្ហាញពីចេតនាជាក់លាក់ក្នុងការកម្ទេចក្រុមជនជាតិវៀតណាមយ៉ាងជាក់ច្បាស់”[1965]។ ប៉ុន្តែ អង្គជំនុំជម្រះមិនធ្លាប់បានកំណត់ទេថា តើចេតនានេះសំដៅកម្ទេចក្រុមមួយផ្នែក ឬទាំងមូល ហើយក្នុងករណីកម្ទេចក្រុមមួយផ្នែក តើផ្នែកសំខាន់នៃក្រុមនោះត្រូវបានកំណត់មុខសញ្ញាដែរឬទេ។ ផ្ទុយទៅវិញ នេះគឺជាធាតុផ្សំដ៏សំខាន់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះបានរំឭកថា៖

> “ក្នុងករណីដែលការផ្ដន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ផ្អែកលើចេតនាក្នុងការកម្ទេចមួយផ្នែកនៃក្រុមដែលត្រូវទទួលបានការការពារ ផ្នែកដែលត្រូវបានកម្ទេចនោះត្រូវតែជាផ្នែកសំខាន់មួយរបស់ក្រុមដែលត្រូវទទួលបានការការពារ ហើយផ្នែកដែលត្រូវបានកំណត់គោលដៅនោះត្រូវមានសារៈសំខាន់គ្រប់គ្រាន់ ដែលអាចមានឥទ្ធិពលទៅលើក្រុមនោះទាំងមូល”[1966]។

១០៦០. អង្គជំនុំជម្រះក៏បានដកស្រង់ផងដែរនូវសាលដីកា *Krstić* ដែលផ្ដល់នូវសេចក្ដីបញ្ជាក់លើផ្នែកនេះនៃនិយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍៖

> “អនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ មានគោលបំណងទប់ស្កាត់ការកម្ទេចក្រុមមនុស្សទាំងមូលដោយចេតនា ហើយផ្នែកដែលត្រូវបានកំណត់គោលដៅនោះ ត្រូវមានសារៈសំខាន់គ្រប់គ្រាន់ ដែលអាចមានឥទ្ធិពលទៅលើក្រុមនោះទាំងមូល។ ថ្វីត្បិតតែអង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនទាន់បានពិចារណាលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងពីររបស់តុលាការនេះបានពិនិត្យរួចមកហើយ។ ក្នុងរឿងក្ដី *Jelisić* ជារឿងក្ដីដំបូងដែលបញ្ហានេះបានចោទឡើង អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា “មានការទទួលយកយ៉ាងទូលំទូលាយថា ចេតនា

---

[1965] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៨។

[1966] សំអាងហេតុសាលក្រម កថាខណ្ឌ ៨០២។

កម្មេចត្រូវតម្រង់ទៅរកផ្នែកសំខាន់នៃក្រុម យោងតាមគោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដែលនិយាយអំពីឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ"។ អង្គជំនុំជម្រះសាលាដំបូងដែលទទួលរឿងក្តី *Sikirica* បានឈានដល់ការធ្វើសេចក្តីសន្និដ្ឋាននេះ៖ "ផ្នែកនេះនៃនិយមន័យទាមទារឱ្យបង្ហាញអំពីមធ្យោបាយនៃភ័ស្តុតាងដែលបញ្ជាក់អំពីចេតនាកម្មេចចំនួនសំខាន់ ធៀបនឹងមនុស្សសរុបនៃក្រុម"។ ដូចអង្គជំនុំជម្រះសាលាដំបូងទាំងនេះបានបញ្ជាក់ ល័ក្ខខ័ណ្ឌតម្រូវនេះឆ្លុះបញ្ចាំងអំពីលក្ខណៈធំធេងនៃអំពើប្រល័យពូជសាសន៍ និងការសម្តែងការព្រួយបារម្ភនៅក្នុងអនុសញ្ញា ចំពោះផលប៉ះពាល់នៃការកម្មេចផ្នែកនោះទៅលើការរស់រានមានជីវិតរបស់ក្រុមទាំងមូល"[1967]។

១០៦១. ដើម្បីសម្រេចថាតើផ្នែកសំខាន់នៃក្រុមត្រូវបានកំណត់គោលដៅដែរឬទេ សាលដីកាដដែលនោះបញ្ជាក់ថា សារៈសំខាន់ខាងតួលេខ គឺជាកត្តាទីមួយដែលត្រូវយកមកពិចារណា៖

"កត្តាមួយចំនួនអាចត្រូវយកមកពិចារណា ដើម្បីកំណត់ថាតើផ្នែកដែលត្រូវបានកំណត់គោលដៅមានសារៈសំខាន់គ្រប់គ្រាន់ដែរឬទេ ដើម្បីឱ្យល័ក្ខខ័ណ្ឌនេះត្រូវបានបំពេញ។ ប្រសិនបើត្រូវគិតដំបូងគេដល់សារៈសំខាន់ខាងតួលេខនៃក្រុមដែលត្រូវបានកំណត់គោលដៅ គេមិនអាចឈប់ត្រឹមនេះបានទេ។ ចំនួនមនុស្សដែលត្រូវបានកំណត់គោលដៅ ត្រូវតែគិតគូរជាដាច់ខាតធៀបនឹងទំហំក្រុមទាំងមូល។ វាអាចមានប្រយោជន៍ ក្នុងការគិតដល់សារៈសំខាន់ខាងតួលេខនៃចំណែកក្រុមដែលត្រូវបានកំណត់គោលដៅ និងតួនាទីនៅក្នុងក្រុមទាំងមូល"[1968]។

១០៦២. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ដោយបានបំភ្លេចចោលផ្នែកដ៏សំខាន់នៃនិយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ឧក្រិដ្ឋកម្មនេះមានលក្ខណៈពិសេស ដោយសារចេតនាជាក់លាក់ និងលក្ខណៈ

---

[1967] សាលដីកា *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ៨ (អក្សរទ្រេត ក្នុងច្បាប់ដើម យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[1968] សាលដីកា *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ១២។

ធំធេងរបស់វា[1969]។ ប៉ុន្តែ ភស្តុតាង ដែលអង្គជំនុំជម្រះបានទទួលយក មិនបញ្ជាក់ថាផ្នែកសំខាន់នៃក្រុមត្រូវបានកំណត់គោលដៅទេ។ យើងបានឃើញថា សេចក្តីសន្និដ្ឋានអំពីការធ្វើមនុស្សឃាតភាគច្រើនទៅលើជនជាតិវៀតណាម ត្រូវបដិសេធចោល[1970]។ ដូច្នេះ ច្បាស់ណាស់ថា ការធ្វើមនុស្សឃាតដាច់ដោយឡែក ដែលអង្គជំនុំជម្រះអាចបង្ហាញឱ្យឃើញ មិនអាចយកមកប្រើដើម្បីអះអាងថាផ្នែកសំខាន់នៃក្រុមត្រូវបានកំណត់គោលដៅនោះទេ។ នេះជាការបំភ្លៃលើលក្ខណៈធំធេងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

១០៦៣. ទោះបីជាការធ្វើមនុស្សឃាតទាំងនេះទំនងជាត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យក៏ដោយ ក៏អង្គជំនុំជម្រះបានសន្និដ្ឋានថា មានការធ្វើមនុស្សឃាតជនជាតិវៀតណាម ៨ នាក់ នៅខេត្តស្វាយរៀង ១៤ នាក់ នៅខេត្តកំពង់ឆ្នាំង ១៩ នាក់ នៅខេត្តក្រចេះ និង ១០ នាក់ នៅវត្តខ្សាច់។ ប្រជាជនវៀតណាមដែលត្រូវបានសម្លាប់ នៅអូរកន្សែង មន្ទីរ ស-២១ និងក្នុងដែនទឹកកម្ពុជា មិនស្ថិតក្នុងក្រុមជនជាតិវៀតណាមដែលត្រូវទទួលបានការការពារទេ[1971]។ តួលេខនេះមិនអាចឱ្យអះអាងថា ផ្នែកសំខាន់នៃក្រុមជនជាតិវៀតណាមត្រូវបានកំណត់គោលដៅឡើយ។ បន្ថែមពីលើនេះ គេមិនអាចប្រៀបធៀបតួលេខទាំងនេះជាមួយប្រជាជនវៀតណាមសរុបដែលរស់នៅកម្ពុជា ក្នុងពេលធ្វើមនុស្សឃាតទាំងនេះបានទេ។

១០៦៤. ច្បាស់ណាស់ថាបើគ្មានទិន្នន័យប្រជាសាស្ត្រ[1972] គេមិនអាចធ្វើស្ថិតិអំពីចំនួនជនជាតិវៀតណាមរស់នៅកម្ពុជាបានទេ និងរឹតតែមិនអាចបង្ហាញចំនួនមនុស្សស្លាប់ ធៀបនឹងចំនួនសរុបនៃក្រុមបានទៅទៀត។ ដូច្នេះ អង្គជំនុំជម្រះបានពិចារណាដោយមិនត្រឹមត្រូវថា ខ្លួនមិនត្រូវការទិន្នន័យប្រជាសាស្ត្រទាំងនេះដើម្បីបង្ហាញអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ អង្គជំនុំជម្រះមិនមានលទ្ធភាពបង្ហាញថា តើផ្នែកសំខាន់នៃក្រុមត្រូវបានកំណត់គោលដៅដែរឬទេ។ ប៉ុន្តែ បើគ្មានព័ត៌មានដ៏សំខាន់នេះ អង្គជំនុំជម្រះមិន

---

[1969] សាលដីកា *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ១០ ដកស្រង់ Raphaël Lemkin៖ "អនុសញ្ញាអនុវត្តតែចំពោះឧក្រិដ្ឋកម្មដែលលក្ខណៈទ្រង់ទ្រាយធំប៉ុណ្ណោះ"។

[1970] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-១០១៧, ១០៥២-១០៥៤។

[1971] សូមមើលខាងលើ កថាខណ្ឌ ១០៥២, ៨២៨-៨៣៥។

[1972] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៩៧។ សូមមើលផងដែរ សេចក្តីសម្រេចចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E444/1** កថាខណ្ឌ ២២។ សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ១៩២១-១៩២៤។

អាចបង្ហាញអំពីចេតនាកម្ទេចក្រុមមួយផ្នែក ឬទាំងមូល និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានទេ។ ដោយហេតុថាអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមមិនអាចត្រូវបានបង្ហាញ អង្គជំនុំជម្រះមិនអាចផ្តន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋនេះបានទេ។

### ៥.១.២. កំហុសក្នុងការសន្និដ្ឋានអំពីចេតនាកម្ទេចក្រុមជនជាតិវៀតណាម

១០៦៥. អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីអត្ថិភាពនៃចេតនាជាក់លាក់ ក្នុងការកម្ទេចក្រុមជនជាតិវៀតណាមបានទេ។ ដើម្បីព្យាយាមបង្ហាញពីចេតនានេះ អង្គជំនុំជម្រះបានផ្អែកជាសំខាន់ ឬតែ[1973] លើអត្ថិភាពនៃគោលនយោបាយរបស់ ប.ក.ក សំដៅបណ្តេញជនជាតិវៀតណាមចេញពីកម្ពុជា រួចកម្ទេចចោល[1974]។ ជាក់ស្តែង ក្នុងការកំណត់ប្រភេទបទល្មើសដ៏ខ្លី អង្គជំនុំជម្រះបានសន្និដ្ឋានអំពីអត្ថិភាពគោលនយោបាយនេះ ដោយផ្អែកលើសុន្ទរកថា "១ ទល់នឹង ៣០" របស់ ប៉ុល ពត សុន្ទរកថារបស់ ខៀវ សំផន សេចក្តីថ្លែងការណ៍របស់ នួន ជា និងការវិភាគវគ្គរៀនសូត្រនយោបាយមួយចំនួនរបស់ជនជាប់ចោទ។

១០៦៦. ប៉ុន្តែ សេចក្តីសន្និដ្ឋាននេះត្រូវបានធ្វើឡើង ដោយមានកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើន[1975]។ ដោយសារបទចោទប្រល័យពូជសាសន៍ប្រឆាំង ខៀវ សំផន សំដៅលើជនជាតិវៀតណាមរស់នៅកម្ពុជា អង្គជំនុំជម្រះត្រូវបង្ហាញថា ចេតនាកម្ទេចផ្តោតលើក្រុមនេះ។ ដូច្នេះ អង្គជំនុំជម្រះចាំបាច់ត្រូវតែបែងចែកក្រុមនេះឱ្យដាច់ពីជនជាតិវៀតណាមផ្សេងទៀត។ ចំណុចនេះមានភាពចាំបាច់ណាស់ ពីព្រោះជម្លោះប្រដាប់អាវុធកំពុងកើតឡើងរវាងប្រទេសទាំងពីរ។ អង្គជំនុំជម្រះបានចៀសវាងធ្វើការបែងចែកដ៏សំខាន់នេះ។

---

[1973] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៧-៣៥១៨ ប្រសិនបើបញ្ចូលការបង្កើតបញ្ជីឈ្មោះ និងជាតិពន្ធុខ្សែស្រឡាយខាងម្តាយធាតុផ្សំទាំងនេះដែលត្រូវបានវិភាគនៅក្នុងគោលនយោបាយ នៅកថាខណ្ឌ ៣៣៨២ ដល់ ៣៤២៨។

[1974] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៧ និង ៣៥១៨ ដែលយោងជាលក្ខណៈប្រព័ន្ធទៅផ្នែកស្តីពីអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅជាក់លាក់ប្រឆាំងនឹងប្រជាជនវៀតណាម។

[1975] សូមមើលខាងក្រោម កថាខណ្ឌ ១៥៥១-១៥៦០។

១០៦៧. ជាក់ស្តែង អង្គជំនុំជម្រះបានច្របល់បញ្ចូលគ្នាជាប្រព័ន្ធនូវក្រុមវៀតណាមផ្សេងៗគ្នា៖ ប្រទេសវៀតណាម តំណាងនយោបាយវៀតណាម កងទ័ពវៀតណាម ជនស៊ីវិលវៀតណាម អ្នកដែលគេចាត់ទុកជា "ភ្នាក់ងារវៀតណាម" និងជនជាតិវៀតណាមរស់នៅកម្ពុជា មុន និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ជារឿយៗ អង្គជំនុំជម្រះមិនបានព្យាយាមពន្យល់ថា តើវៀតណាមណាខ្លះដែលត្រូវបានកំណត់គោលដៅច្បាស់លាស់ក្នុងឯកសារ ឬសេចក្តីថ្លែងការណ៍ផ្សេងទៀតរបស់សមាជិក ប.ក.ក ដែលអង្គជំនុំជម្រះបានវិភាគ។ ពេលអង្គជំនុំជម្រះបានបញ្ជាក់យ៉ាងកម្រ អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនទេថា គឺជនជាតិវៀតណាមរស់នៅកម្ពុជាដែលត្រូវបានកំណត់គោលដៅ។

### *៥.១.២.១. ការបំភ្លៃភ័ស្តុតាងអំពីទំនាក់ទំនងការទូតជាមួយវៀតណាម*

• **<u>កំហុសពាក់ព័ន្ធនឹងផលវិបាកនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៧៣</u>**

១០៦៨. ជាដំបូង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានរកឃើញថា តាំងពីការបែកបាក់ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ក្រោយការចុះហត្ថលេខាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៧៣ ប.ក.ក យល់ឃើញថា ជនជាតិវៀតណាមរស់នៅកម្ពុជាគួរទទួលបានចំណាប់អារម្មណ៍ដោយឡែក[1976]។ ប៉ុន្តែ ភ័ស្តុតាងដែលបានដកស្រង់មិនគាំទ្រដល់ទឡ្ហីករណ៍នេះទេ។

១០៦៩. ជាក់ស្តែង អង្គជំនុំជម្រះបានផ្អែកលើសេចក្តីថ្លែងការណ៍របស់ នួន ជា នៅចំពោះមុខអង្គជំនុំជម្រះដែលពន្យល់អំពីផលវិបាកនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។ ប៉ុន្តែ គាត់មិនបានបញ្ជាក់ ឬនិយាយសំដៅដល់ជនជាតិវៀតណាមរស់នៅកម្ពុជាទាល់តែសោះ[1977]។ អង្គជំនុំជម្រះក៏បានប្រើកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន គ្មានចុះកាលបរិច្ឆេទ ដែលលើកឡើងអំពីការមិនសប្បាយចិត្តរបស់វៀតណាម ពេល ប៉ុល ពត ប្រកែកមិនព្រមគោរពកិច្ចព្រមព្រៀង ដើម្បីបង្ហាញឯករាជ្យភាពពីពួកគេ[1978]។

---

[1976] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨២។

[1977] ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ ឯកសារ **E1/22.1** ចន្លោះពីម៉ោង 09.55.05 ដល់ម៉ោង 10.07.26។

[1978] កំណត់ហេតុសួរចម្លើយ ខៀវ សំផន ពុំមានកាលបរិច្ឆេទ ឯកសារ **E3/4038** ERN 00786549-00786550។

ប៉ុន្តែ ច្បាស់ណាស់ថា ករណីនេះពាក់ព័ន្ធនឹងកិច្ចការការទូតរវាងតំណាងរដ្ឋទាំងពីរ គឺមិនពាក់ព័ន្ធនឹងជនជាតិវៀតណាម ឬគោលនយោបាយណាមួយចំពោះជនជាតិវៀតណាមទេ។ ជាចុងក្រោយ ការយោងដល់សៀវភៅរបស់ Elisabeth BECKER ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានដដែលនេះ ក៏មិននិយាយសំដៅដល់ជនជាតិវៀតណាមរស់នៅកម្ពុជា នោះដែរ[1979]។ ដូច្នេះ ច្បាស់ណាស់ថា អង្គជំនុំជម្រះបានបំភ្លៃភ័ស្តុតាង ដែលមិនអាចឱ្យសន្និដ្ឋានថា ជនជាតិវៀតណាមរស់នៅកម្ពុជាត្រូវបានកំណត់គោលដៅដើម្បីបំផ្លិចបំផ្លាញនោះឡើយ។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

• <u>**កំហុសពាក់ព័ន្ធនឹងទស្សនាវដ្តី "ទង់បដិវត្ត" ចេញផ្សាយខែមេសា ឆ្នាំ១៩៧៦**</u>

១០៧០. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានធ្វើសេចក្តីអត្ថាធិប្បាយយ៉ាងវែងអន្លាយ ដើម្បីពន្យល់ថា មានភាពតានតឹងរវាងប្រទេសទាំងពីរ តាំងពីទសវត្សរ៍ឆ្នាំ១៩៧០ និងជំនួបរវាងមេដឹកនាំនៃប្រទេសទាំងពីរ នៅឆ្នាំ១៩៧៥[1980]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានបំភ្លៃខ្លឹមសារនៃទស្សនាវដ្តី "ទង់បដិវត្ត" ចេញផ្សាយខែមេសាឆ្នាំ១៩៧៦ ដោយបានសន្និដ្ឋានថា វាឆ្លុះបញ្ចាំងអំពីវិសមានចិត្តរបស់ ប.ក.ក ចំពោះជនបរទេស[1981]។ ជាក់ស្តែង អង្គជំនុំជម្រះបានកាត់ចោលអត្ថបទមួយផ្នែក ដើម្បីបង្វិតការអះអាងថា ជនបរទេសខ្លះត្រូវបានចោទថាលួចទ្រព្យសម្បត្តិរបស់ប្រជាជន និងធ្វើឱ្យអស់ទឹកដីក្នុងពេលកន្លងមក ទៅជិតការអះអាងមួយទៀតថា "ជនបរទេសទាំងនេះរាប់សែននាក់" ត្រូវបានបណ្តេញចេញ។ បើអានដូច្នេះ អត្ថបទនេះធ្វើឱ្យយើងគិតថា ជនបរទេសដែលត្រូវបានបណ្តេញចេញ សំដៅដល់ជនជាតិវៀតណាម[1982]។

---

[1979] សៀវភៅនិពន្ធដោយ E. Becker "នៅពេលដែលសង្គ្រាមរលត់ទៅ" ឯកសារ **E3/20** ERN FR 00638413-16 និង 00638599-600។

[1980] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨២-៣៣៨៦។ ភ័ស្តុតាងនេះមិនគាំទ្រដល់គោលនយោបាយបំផ្លាញជនជាតិភាគតិចវៀតណាម ដូច្នេះ ភ័ស្តុតាងមិនត្រូវលើកយកមកជជែកដោលនៅទីនេះឡើយ។

[1981] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨៧។

[1982] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨៧-៣៣៨៨។

១០៧១. ប៉ុន្តែ បើអានទាំងស្រុង អត្ថបទពន្យល់ថា បញ្ហានេះជាបញ្ហាចាស់ "វណ្ណៈជិះជាន់" បានលក់ដីឱ្យជនបរទេស ហើយចលនាខ្មែរក្រហមបានតស៊ូប្រឆាំងនឹង "ពួកចក្រពត្តិ" ដោយជោគជ័យ[1983]។ ឃ្លាបន្តមកទៀតពន្យល់ថា ចលនាបានបណ្តេញជនបរទេសរាប់សែននាក់ឱ្យចេញផុតពីទឹកដី[1984]។ ជាអាទិ៍ អត្ថបទនេះបានសរសេរថា បញ្ហាត្រូវបានដោះស្រាយ ជាពិសេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[1985] ពោលគឺ ថ្ងៃខ្មែរក្រហមចូលដល់រដ្ឋធានី។ យើងដឹងថា នៅភ្នំពេញ មុនពេលខ្មែរក្រហមចូលមកដល់ ជនបរទេសជាច្រើននាក់បានរស់នៅក្នុងរដ្ឋធានី មានទាំងអឺរ៉ុប អាមេរិក។ល។ អ្នកមិនទាន់រត់គេចត្រូវគេប្រមូលផ្តុំនៅស្ថានទូតបារាំង រួចបណ្តេញចេញពីប្រទេស។ ដូច្នេះ ចៅក្រមប្រកបដោយវិចារណញ្ញាណគួរណាតែគិតដល់ហេតុការណ៍ជាក់ស្តែងទាំងនេះ ដើម្បីបកស្រាយទស្សនាវដ្តីលេខនេះ។

១០៧២. អង្គជំនុំជម្រះមិនអាចប្រើប្រាស់ទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" "ទង់បដិវត្ត" និងឯកសារផ្សេងទៀត ចុះកាលបរិច្ឆេទឆ្នាំ១៩៧៨ និងឆ្នាំ១៩៧៩ ដើម្បីបកស្រាយទស្សនាវដ្តី "ទង់បដិវត្ត" ចេញផ្សាយខែមេសា ឆ្នាំ១៩៧៥ បានទេ[1986]។ បរិបទនៅចន្លោះកាលបរិច្ឆេទទាំងនេះពិតជាមានការវិវត្ត ហើយមានតែការវិភាគទាំងស្រុងលើអត្ថបទទស្សនាវដ្តី ឆ្នាំ១៩៧៦ ប៉ុណ្ណោះ ទើបអាចឱ្យមានការវិភាគជាសត្យានុម័តិ។ មិនមែនមានតែជនជាតិវៀតណាមទេ ជាជនបរទេសដែលមានវត្តមាននៅលើទឹកដីកម្ពុជា នៅខែមេសា ឆ្នាំ១៩៧៥។ ដូច្នេះ ការបកស្រាយលម្អៀងរបស់អង្គជំនុំជម្រះមិនសមហេតុផល និងមែនមែនជាការបកស្រាយតែមួយគត់ដែលអាចមានទេ។ អាស្រ័យហេតុនេះ ការបកស្រាយនេះត្រូវតែបដិសេធចោល[1987]។

---

[1983] ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062749។

[1984] ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062749 "ដោយទៅជាមួយចក្រពត្តិ ហើយដោយវិធីត្រឹមត្រូវ តាមគោលការណ៍បដិវត្តរបស់យើង។ គឺមហាចលនា មហាព្យុះសង្ឃរាប្រជាជាតិ និងមហាព្យុះសង្ឃរានៃបដិវត្តប្រជាធិបតេយ្យរបស់យើង បានបោសសម្អាតជនបរទេសទាំងនេះរាប់សែននាក់ ឱ្យចេញផុតពីប្រទេសយើង ពីទឹកដីយើងទាំងអស់ជាស្ថាពរ"។

[1985] ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062749 "ប៉ុន្តែ បដិវត្តន៍របស់យើង ហើយពិសេស ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ បានដោះស្រាយបញ្ហាយ៉ាងស្អាត ហើយដោះស្រាយទាំងមូល"។

[1986] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨៨។

[1987] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨៨។

• **កំហុសក្នុងការសន្និដ្ឋានថាសេចក្តីថ្លែងការណ៍ជារបស់មេដឹកនាំ**

១០៧៣. អង្គជំនុំជម្រះបានអះអាងថា ចាប់ពីខែឧសភា ឆ្នាំ១៩៧៦ "ប.ក.ក បន្តកំណត់អត្តសញ្ញាណជនជាតិវៀតណាមថាជាខ្មាំង"[1988]។ ការវិភាគលើប្រភពគាំទ្រដល់ទឡ្ហីករណ៍នេះបង្ហាញថា គឺវៀតណាមជាប្រទេស ដែលត្រូវគេកំណត់គោលដៅ ក៏ដូចជាទាហានវៀតណាម ឬសមាជិកកម្ពុជា ប្រជាធិបតេយ្យ ដែលត្រូវគេចោទថាជា "ភ្នាក់ងារ" វៀតណាម ដូចជា ចាន់ ចក្រី ជាដើម[1989]។ ការអះអាងរបស់អង្គជំនុំជម្រះថា សុន សេន បានចង្អុលបង្ហាញថា "សមាសភាពដ៏គ្រោះថ្នាក់ដែលតម្រូវឱ្យមានការសម្រិតសម្រាំង និងការប្រុងប្រយ័ត្ន ជាពិសេស ចំពោះអ្នកដែលជាសមាជិកគ្រួសារដែលត្រូវបានបោសសម្អាត គឺជារឿងចាំបាច់" មិនសំដៅដល់ជនជាតិវៀតណាមទេ[1990]។

១០៧៤. កំហុសដដែលត្រូវបានប្រព្រឹត្ត ជាមួយនឹងកិច្ចប្រជុំរៀនសូត្រ ដែលក្នុងពេលនោះ ប៉ុល ពត, នួន ជា និង ខៀវ សំផន បានចាត់ទុកវៀតណាម និង "ភ្នាក់ងារ" វៀតណាម ជាខ្មាំង[1991]។ ក្រៅពីការរិះគន់អំពីវគ្គរៀនសូត្រទាំងនេះ បរិបទមិនអាចឱ្យសន្និដ្ឋានថា មានការនិយាយសំដៅដល់ជនជាតិវៀតណាមរស់នៅកម្ពុជាឡើយ ប៉ុន្តែ ផ្ទុយទៅវិញ គឺសំដៅដល់រដ្ឋវៀតណាម និងតំណាងរដ្ឋ។ ជាក់ស្តែង ពេល នួន ជា និយាយអំពីខ្មាំងឃ្លួន ដែលមានមហិច្ឆតាបញ្ចូលកម្ពុជាប្រជាធិបតេយ្យទៅក្នុងសហព័ន្ធឥណ្ឌូចិន ច្បាស់ណាស់ថា គាត់សំដៅដល់ប្រវត្តិជាមួយបក្សកុម្មុយនីស្តវៀតណាម គឺមិនសំដៅដល់ជនជាតិវៀតណាម

---

[1988] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨៩។

[1989] សំអាងហេតុសាលក្រម កថាខណ្ឌ ២២៧១, ៣៧៧៥, ៣៧៩៣-៣៧៩៤ និង ៣៧៩៧។ សូមមើលផងដែរ E. Becker៖ ប្រតិចារឹក ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/261.1** ទំព័រ ៣៩។

[1990] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨៩ យោងទៅកថាខណ្ឌ ៣៧៩៧ ដែលយោងទៅកំណត់ហេតុនៃប្រជុំលេខា និងភ័ស្តុភារកងពល និងវរៈសេនាធំឯករាជ្យ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦ ឯកសារ **E3/804** ERN 00008480-00008481។

[1991] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩០។

រស់នៅកម្ពុជាទេ[1992]។ ពាក្យ "ភ្នាក់ងារ" វៀតណាម សំដៅដោយផ្ទាល់ដល់ខ្មែរជាសមាជិកកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវគេចោទថាចូលដៃជើងជាមួយវៀតណាម[1993]។

១០៧៥. លើសពីនេះទៀត អង្គជំនុំជម្រះមិនគួរណាទទួលយកសម្ដីរបស់ ឯក ហេន ដែលបានកំណត់ថា ខៀវ សំផន ជាអ្នកនិយាយ ក្នុងពេលប្រជុំនៅបុរីកីឡា[1994]។ ភាពមិនស៊ីចង្វាក់គ្នាច្រើន ក្នុងពេលផ្ដល់សក្ខីកម្ម និងនៅក្នុងចម្លើយផ្សេងៗរបស់គាត់ បង្ហាញឱ្យឃើញកង្វះភាពអាចជឿជាក់បាន និងភាពអាចជឿទុកចិត្តបាននៃចម្លើយរបស់គាត់[1995]។ អង្គជំនុំជម្រះគួរណាតែច្រានចោលចម្លើយរបស់គាត់ ដោយសារតែវាមានតម្លៃជាភស្តុតាងតិចតួច។ ទោះជាយ៉ាងណាក៏ដោយ សម្ដី ដែលគាត់បានចោទថាម្ចាស់បណ្ដឹងសាទុក្ខជាអ្នកនិយាយ មិនអាចឱ្យកំណត់បានទេថាតើចង់មានន័យថាម៉េច នៅពេលនិយាយថា "នៅកម្ពុជា គ្មានយួនទេ"។ អាចមានការបកស្រាយផ្សេងគ្នា។ នេះអាចមានន័យថា ចាប់ពីខែមេសា ឆ្នាំ ១៩៧៥ ជនជាតិវៀតណាម ទាំងទាហាន និងស៊ីវិល ដែលមានវត្តមាននៅកម្ពុជា ត្រូវបញ្ជូនត្រឡប់ទៅវៀតណាមវិញ។ ជាពិសេស នេះគឺជាសារបង្ហាញអំពីសាមគ្គីភាពរវាងអ្នកធ្វើការ"[1996]។ សម្ដីទាំងនេះ

---

[1992] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ១១៤៣៦ យោងទៅប្រតិចារឹករបស់ អ៊ូ ដាវ ដែលរៀបរាប់ពីសម្ដីរបស់ នួន ជា នៅក្នុងពេលប្រជុំមួយ នៅឆ្នាំ១៩៧៦។

[1993] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៤ "ពាក់ព័ន្ធនឹងគោលការណ៍ណែនាំរបស់គណៈកម្មាធិការមជ្ឈិម ចុះខែមិថុនាឆ្នាំ ១៩៧៨ ទោះបីជាបុគ្គលដែលបានឈប់ធ្វើ "សកម្មភាពក្បត់" ជាធម្មតាត្រូវទទួលរងការអប់រំឡើងវិញក្រោមគោនយោបាយនេះក៏ដោយ អង្គជំនុំជម្រះរកឃើញថា ទោះបីជាវាអាចអនុវត្តលើលើបុគ្គលដែល "ធ្វើជាភ្នាក់ងារយួន" ក៏ដោយ ក៏វាមិនបង្ហាញច្បាស់ថាតើប្រភេទនេះសំដៅក្រៅពីប្រជាជនខ្មែរដែលបានឃុបឃិតជាមួយវៀតណាម ដោយរួមបញ្ចូលទាំងប្រជាជនដែលជាជនជាតិភាគតិចវៀតណាមខ្លួនឯងផងដែរឬយ៉ាណា" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ ទង់បដិវត្ត ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ឯកសារ **E3/727** ERN 00064566 ដែលកំណត់យ៉ាងជាក់លាក់ថា ចក្រី, ឈូក, ធុច, ឌឿន, សោ ភឹម, ស៊ី, កែវ មាស និង ជ័យ ជាភ្នាក់ងារសេអ៊ីអា និងភ្នាក់ងារវៀតណាម។

[1994] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩០។

[1995] សំណើរបស់ ខៀវ សំផន ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ **F51** កថាខណ្ឌ ២០-២៩។

[1996] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ម៉ោង 11.22.28 "គាត់នាយតែរឿងការងារ ឱ្យប្រឹងតស៊ូសាមគ្គីស្រឡាញ់គ្នា ចេះរាប់អានគ្នា ជួយគ្នាណ៎ា។ គាត់មានយោបល់គឺល្អៗដែរចាស។ មិនមាននាំឱ្យយើងអីមានទំនាស់ទាស់ទែងគ្នាអី គាត់ឱ្យចេះសាមគ្គីគ្នាអ៊ីចឹងក្នុងក្រុម ក្នុងកអ៊ីចឹងឱ្យជួយគ្នា ពលកម្មដើម្បីស្តារសេដ្ឋកិច្ចប្រទេសជាតិ--រួចពីសង្គ្រាមនុះណ៎ា"។

ទោះពិត ឬមិនពិតក្តី មិនអាចគាំទ្រដល់អត្ថិភាពនៃគោលនយោបាយកម្ទេចជនជាតិវៀតណាមរស់នៅកម្ពុជាឡើយ។

១០៧៦. ករណីដូចគ្នាអាចត្រូវបានលើកឡើង ពាក់ព័ន្ធនឹងកំណត់ត្រាសរសេរដៃ ដែលត្រូវបានកំណត់ថាជារបស់ អៀង សារី ដែលនិយាយអំពីខ្មាំងជាទូទៅ[1997]។ បើនិយាយពីឆ្នាំ១៩៧៦ ឃ្លា "បដិវត្តន៍បានគាស់រំលើងឫសគល់" មិនអាចសំដៅដល់ជនជាតិវៀតណាមរស់នៅកម្ពុជាទេ[1998]។ អង្គជំនុំជម្រះខ្លួនឯងផ្ទាល់បានបញ្ជាក់ថា ទស្សនាវដ្តី "ទង់បដិវត្ត" ចេញផ្សាយខែមេសា ឆ្នាំ១៩៧៧ បានសំដៅដល់ "ភ្នាក់ងារ" វៀតណាម ដែលយើងបាននិយាយរួចមកហើយ គឺជាសមាជិកកម្ពុជាប្រជាធិបតេយ្យ[1999]។

១០៧៧. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានទទួលស្គាល់ថា សម្តីរបស់ ខៀវ សំផន ដែលបាននិយាយដល់វៀតណាមថាជា "ខ្មាំងស្ងួពូជ" បានកើតឡើង ក្នុងពេលជម្លោះប្រដាប់អាវុធឡើងកម្តៅខ្លាំង និងសំដៅដល់វៀតណាមក្នុងឋានៈជាប្រទេស[2000]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមិនបានពន្យល់ថាតើខ្លួនចង់បង្ហាញអំពីអ្វី តាមរយៈទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយខែសីហា ឆ្នាំ១៩៧៧ និងសក្ខីកម្មរបស់ មាស វឿន[2001]។ ទោះជាយ៉ាងណាក៏ដោយ មាស វឿន បានពន្យល់ថា សារក្នុងទស្សនាវដ្តីលេខនេះ មានគោលដៅអប់រំឱ្យយល់ជ្រួតជ្រាបឧបាយកលបោកបញ្ឆោតរបស់យួន និងវែកមុខខ្មាំងបង្កប់។ អង្គជំនុំជម្រះមិនធ្លាប់បង្ហាញទាល់តែសោះថា "ខ្មាំងបង្កប់" សំដៅដល់ជនជាតិវៀតណាមរស់នៅកម្ពុជា។ ផ្ទុយទៅវិញ ភស្តុតាងបង្ហាញថា ខ្មាំងបង្កប់សំដៅដល់សមាជិកកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវគេសង្ស័យថាចូលដៃជើងជាមួយវៀតណាម[2002]។

---

[1997] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩១។ សូមមើលផងដែរ ការរិះគន់កំណត់ត្រាខាងក្រោម កថាខណ្ឌ ១៤៥៨, ១៤៦៤។

[1998] សៀវភៅកំណត់ហេតុរបស់ អៀង សារី ចុះខែមករា ឆ្នាំ១៩៩៧ ឯកសារ **E3/925** ERN 00003823-00003824។

[1999] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩២។

[2000] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩២-៣៣៩៣។

[2001] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩៥។

[2002] ទង់បដិវត្ត ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ឯកសារ **E3/727** ERN 00064566។

១០៧៨. អង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវថា ជម្លោះប្រដាប់អាវុធបានឡើងកម្តៅខ្លាំងនៅឆ្នាំ១៩៧៧[2003]។ ជាក់ស្តែង លើកលែងតែមានការនិយាយច្បាស់ពីជនជាតិវៀតណាមរស់នៅកម្ពុជា វោហារសាស្ត្រប្រឆាំងវៀតណាមរបស់ ប.ក.ក គួរណាតែត្រូវបានបកស្រាយយ៉ាងសមហេតុផល ផ្តែកទៅលើជម្លោះដែលក្នុងនោះ វៀតណាមគឺជាប្រទេសខ្មាំងជាសត្រូវនុម័តិ។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើនដង ក្នុងការយល់ឃើញថា វោហារសាស្ត្រនេះសំដៅដល់ជនស៊ីវិលវៀតណាមផងដែរ។

- **<u>គ្មានការពិចារណាពីជម្លោះប្រដាប់អាវុធជាមួយវៀតណាម</u>**

***ឯកសារ FBIS និង SWB***

១០៧៩. នេះគឺករណីនៃការវិភាគលើឯកសារពីររបស់ FBIS ដែលអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ និងថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨[2004] ដែលមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត[2005]។ ឯកសារទីមួយ គឺជាសេចក្តីរាយការណ៍ដែលត្រូវបានសរសេរនៅក្នុងអត្ថបទសារព័ត៌មានបារាំង *L'Humanité Rouge* ដែលគេមិនស្គាល់អ្នកនិពន្ធ[2006]។ អ្នកនិពន្ធឯកសារទីពីរក៏មិនត្រូវបានស្គាល់ដែរ។ សម្តីទាំងនេះមិនត្រឹមតែមិនអាចកំណត់ថាជារបស់ ប.ក.ក ប៉ុណ្ណោះទេ ថែមទាំងត្រូវបាននិយាយ ភ្លាមៗក្រោយពីការឈ្លានពានទ្រង់ទ្រាយធំមកលើកម្ពុជាពីសំណាក់វៀតណាម[2007]។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះថា ជនស៊ីវិលវៀតណាមត្រូវបានកំណត់គោលដៅ មិនអាចយល់បានទេ ក្នុងបរិបទនេះ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមិនបានពន្យល់ថា តើអង្គជំនុំជម្រះបានឈានដល់ការធ្វើសេចក្តីសន្និដ្ឋានបែបនេះបានដោយរបៀបណា ឬតើអង្គជំនុំជម្រះបានប្រដូចជនស៊ីវិលវៀតណាមទៅនឹងជនជាតិវៀតណាមរស់នៅកម្ពុជាដែរឬទេ។ ដូច្នេះ សេចក្តីសន្និដ្ឋាននេះត្រូវតែបដិសេធ។

***សុន្ទរកថា ខៀវ សំផន នៅខែមេសា ឆ្នាំ១៩៧៨***

---

[2003] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩០។

[2004] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩៨។

[2005] សូមមើលខាងលើ កថាខណ្ឌ ៣២០-៣២៣. សូមមើលផងដែរ ខាងក្រោម កថាខណ្ឌ ១៨៩៨-១៩០៣។

[2006] កម្រងសារព័ត៌មាន FBIS ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ ឯកសារ **E3/292** ERN EN 00169281។

[2007] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៩។

១០៨០. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនបានពិចារណាថា ក្នុងសុន្ទរកថាពីរ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ និងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ខៀវ សំផន បានកំណត់គោលដៅលើ "ប្រជាជនវៀតណាមទាំងអស់ ដោយមិនរើសមុខ"[2008]។ ប៉ុន្តែ ថ្វីត្បិតតែអង្គជំនុំជម្រះបានផ្អែកលើឯកសារពីរដាច់ដោយឡែកពីគ្នា គឺមួយជាសំណុំឯកសាររបស់ SWB និងមួយទៀតជាកម្រងឯកសារផ្សព្វផ្សាយដោយគណៈកម្មាធិការអាណិកជនស្នេហាជាតិ នៃកម្ពុជាប្រជាធិបតេយ្យ ប្រចាំនៅប្រទេសបារាំង[2009] តាមពិត នេះគឺជាសុន្ទរកថាតែមួយប៉ុណ្ណោះ។ ជាក់ស្តែង ឯកសារនេះគឺជាប្រតិចារឹកសុន្ទរកថារបស់ ខៀវ សំផន ថ្លែងថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ក្នុងមិទ្ទីញ នៅទីក្រុងភ្នំពេញ ដើម្បីអបអរសាទរខួបលើកទី ៣ នៃជ័យជម្នះ ១៧ មេសា។ ប៉ុន្តែ ច្បាស់ណាស់ថា ប្រតិចារឹកទាំងពីរនេះមិនដូចគ្នាទាំងស្រុងទេ។ តាមពិត វាមិនមែនជារឿងភ្ញាក់ផ្អើលទេ ដោយសារតែកង្វះភាពអាចជឿទុកចិត្តបាននៃឯកសារបរទេសប្រភេទនេះ ដែលប្រតិចារឹកត្រូវបានបកប្រែដោយផ្នែក[2010]។ ដូច្នេះ ច្បាស់ក្រឡែតណាស់ថា ឯកសារទាំងនេះមិនអាចមានតម្លៃជាភស្តុតាងទេ។ អាស្រ័យហេតុនេះ ឯកសារទាំងនេះត្រូវបដិសេធចោល។

១០៨១. ទោះជាយ៉ាងនេះក្តី គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានបានថា នៅក្នុងសុន្ទរកថានេះ ខៀវ សំផន សំដៅដល់ "ប្រជាជនវៀតណាមទាំងអស់ ដោយមិនរើសមុខ" នោះឡើយ។ ជាការពិត កម្ពុជាប្រជាធិបតេយ្យទើបតែទទួលរងនូវការឈ្លានពានដោយអាវុធពីសំណាក់វៀតណាម។ វាជារឿងសមហេតុផលដែល ខៀវ សំផន ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ បានថ្លែងសុន្ទរកថាអំពាវនាវឱ្យសម្លាប់ខ្មាំងវៀតណាម ដែលគ្មាននរណាក្រៅពីកងទ័ពបដិបក្ខនៃរដ្ឋវៀតណាម។ គ្មានតម្រុយណាមួយនៅក្នុងសុន្ទរកថានេះអាចឱ្យសន្និដ្ឋានបានថា ខៀវ សំផន អាចកំណត់មុខសញ្ញាលើជន

---

2008 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩៩ និង ៣៤០០។

2009 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩៩ យោងទៅកម្រងសារព័ត៌មាន FBIS ដែលធ្វើប្រតិចារឹកសុន្ទរកថាមួយដែលបានថ្លែងនៅក្នុងជំនួបនៅភ្នំពេញ ដើម្បីអបអរសាទរខួបថ្ងៃទី១៧ ខែមេសា ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/562** និងកថាខណ្ឌ ៣៤០០ ដែលយោងទៅកម្រងឯកសារ ដែលត្រូវបានផ្សព្វផ្សាយដោយគណៈកម្មាធិការអ្នកស្នេហាជាតិនៃកម្ពុជាប្រជាធិបតេយ្យ នៅប្រទេសបារាំង ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/169**។

2010 សូមមើលខាងក្រោម កថាខណ្ឌ ១៩៩៨-១៩០៣។

ស៊ីវិលវៀតណាម ឬជនជាតិវៀតណាមរស់នៅកម្ពុជា ឡើយ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវបដិសេធចោល។

១០៨២. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានផ្អែកលើសៀវភៅរបស់ សម្តេច សីហនុ ដើម្បីបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយរបស់ ប.ក.ក ចំពោះវៀតណាម[2011]។ ទោះបីជាអង្គជំនុំជម្រះបានកត់សម្គាល់អំពីតម្លៃជាភ័ស្តុតាងតិចតួចដែលត្រូវផ្តល់ឱ្យឯកសារនេះក៏ដោយ ក៏អង្គជំនុំជម្រះនៅតែប្រើប្រាស់ឯកសារនេះដដែល។ ទោះជាយ៉ាងនេះក្តី ក្នុងបរិបទជម្លោះប្រដាប់អាវុធជាមួយវៀតណាម វាជារឿងសមហេតុផលក្នុងការសន្និដ្ឋានថា សម្តីវាយប្រហារលើវៀតណាមស្ថិតក្នុងការឃោសនានៃសង្គ្រាម ដើម្បីឱ្យប្រជាជនកម្ពុជារួបរួមគ្នាជុំវិញបក្ស ប្រឆាំងនឹងប្រទេសវៀតណាមឈ្លានពាន។

### *សុន្ទរកថា ប៉ុល ពត ស្តីពី "១ ទល់នឹង ៣០"*

១០៨៣. ក្នុងន័យដដែលនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយល់ឃើញថា សុន្ទរកថា "១ ទល់នឹង ៣០" របស់ ប៉ុល ពត សំដៅលើ "ប្រជាជនវៀតណាមទាំងអស់"[2012]។ នៅពេលទាញសេចក្តីសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះបានបំភ្លៃ និងផ្តាច់ចេញពីបរិបទទាំងស្រុងនូវខ្លឹមសារសុន្ទរកថានេះ ដែលថ្លែងភ្លាមៗ ក្រោយការឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជា។ អង្គជំនុំជម្រះភាន់ច្រឡំ ដោយបានយល់ឃើញថា ដោយសារ ប៉ុល ពត បានធ្វើការប្រៀបធៀបរវាងចំនួនប្រជាជនសរុបរបស់វៀតណាម និងចំនួនប្រជាជនសរុបរបស់កម្ពុជា វិធានការ ដែលគាត់បានប្រកាសក្នុងសុន្ទរកថា ក៏សំដៅលើជនស៊ីវិលផងដែរ[2013]។ ការបកស្រាយនេះមិនសមហេតុផលទេ។

១០៨៤. ច្បាស់ណាស់ថា ប៉ុល ពត បានធ្វើការប្រៀបធៀបកម្លាំង រវាងប្រទេសទាំងពីរ ដោយពន្យល់ថា កម្លាំងកម្ពុជាតិចជាងខ្លាំង ធៀបនឹងកម្លាំងវៀតណាម និងត្រូវបង្កើនការខិតខំប្រឹងប្រែង ដើម្បីវាយឈ្នះ

---

[2011] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០១។

[2012] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០២។

[2013] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០២។

ខ្មាំង[2014]។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបដិសេធចម្លើយក្នុងសវនាការរបស់អតីតយោធានៅសម័យនោះ ដែលពន្យល់ថា សុន្ទរកថា និងពាក្យស្លោក "១ ទល់នឹង ៣០" សំដៅលើកទឹកចិត្តកងទ័ពកម្ពុជាប្រជាធិបតេយ្យ ប្រឈមមុខនឹងខ្មាំងដែលមានចំនួនច្រើនលើសលុប[2015]។ នៅពេលសួរអំពីការនិយាយសំដៅក្នុងសុន្ទរកថាដល់ប្រជាជនវៀតណាម ៦០ លាននាក់ និងប្រជាជនកម្ពុជា ២ លាននាក់ ព្រុំ សារ៉ាត់ បានពន្យល់ថា៖

> "តាមពិត មិនមែនកងទ័ពវៀតណាមមានដល់ ៦០ លាន ហើយកងទ័ពខ្មែរ កម្ពុជាប្រជាធិបតេយ្យ មាន ២ លានទេពេលនោះ។ ប៉ុន្តែគ្រាន់តែជាអ្វីដែលកម្មាភិបាល យុទ្ធជនចេះ គេហៅថាយល់ពីវិធី និងរៀបចំមាត៌ាសកម្មភាពក្នុងការប្រយុទ្ធ ដំណើរការដណ្តើមយកជ័យជម្នះ"[2016]។

១០៨៥. សូមរំឭកថា ដើម្បីកំណត់អត្ថន័យនៃសេចក្តីថ្លែងការណ៍ជាសាធារណៈ ទាល់តែបុគ្គលពាក់ព័ន្ធជាអ្នកបកស្រាយទើបអាចយកជាការបាន[2017]។ ប៉ុន្តែ អង្គជំនុំជម្រះមិនត្រឹមតែមិនគិតដល់ភ័ស្តុតាងនេះប៉ុណ្ណោះទេ ថែមទាំងមិនបានផ្តល់ភ័ស្តុតាងស្របនឹងការសន្និដ្ឋានរបស់ខ្លួនទៀតផង។ ទោះជាយ៉ាងណាតុលាការ កំពូលបានបដិសេធការបកស្រាយរបស់អង្គជំនុំជម្រះទៅលើសុន្ទរកថាលោក ខៀវ សំផន អំពីការវាយយកឧត្តុង្គ[2018]។ ក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ តុលាការកំពូលបានស្តីបន្ទោសអង្គជំនុំជម្រះថា មិនបានពន្យល់ថា ហេតុអ្វីបានជាការប្រើប្រាស់ពាក្យ "ខ្មាំង" មិនសំដៅតែទៅលើមុខសញ្ញា

---

[2014] ទង់បដិវត្ត "អន្តរាគមន៍របស់សមមិត្តលេខា ប.ក.ក ក្នុងឱកាសនៃការប្រារព្ធខួបលើកទី ៣ នៃមហាជ័យជម្នះ ១៧ មេសា (...)" ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/4604** ERN FR 00520342។

[2015] <u>ព្រុំ សារ៉ាត់</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/382.1** ទំព័រ ៥០-៥១ ចន្លោះពីម៉ោង 15.36.43 ដល់ម៉ោង 15.42.37 "ការពិត នេះជាការប្រៀបធៀបកម្លាំងយោធា ១ ទល់ ៣០។ ដូច្នេះ ក្នុងឯកសារនេះ គឺបញ្ជាក់ច្បាស់ [...]។ ជាឯកសារដែលគាត់បានលើក ដោយឱ្យកងទ័ពទាំងអស់ចេះពិចារណាក្នុងយុទ្ធវិធីប្រយុទ្ធវាយកម្ទេចសត្រូវ"។ <u>ជួន ធី</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ទំព័រ ៧១ ប្រហែលម៉ោង 15.16.31 ទំព័រ ៧៣ ប្រហែលម៉ោង 15.23.06។

[2016] ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/382.1** ម៉ោង 15.36.43។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ៧៣៤-៧៤០ និង ២២៤៥។

[2017] សំអាងហេតុរបស់ចៅក្រម Geoffrey Henderson រឿងក្តី *Gbagbo* (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៩ កថាខណ្ឌ ២៨១ និង ២៨៣។

[2018] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៨៣។

យោធា[2019]។ អង្គជំនុំជម្រះបានសម្រេចដាកចេញពីសេចក្ដីណែនាំរបស់តុលាការកំពូល។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។ ទោះជាយ៉ាងនេះក្ដី សុន្ទរកថានេះ ដែលត្រូវបានវិភាគជាសត្យានុម័តិ ជាអាទិ៍ ដោយមានការសំដៅដល់បច្ចេកទេសទ័ពឈ្លប[2020] មិនអាចគាំទ្រដល់អត្ថិភាពនៃគោលនយោបាយបំផ្លិចបំផ្លាញក្រុមជនជាតិវៀតណាមរស់នៅកម្ពុជាបានឡើយ[2021]។

### *ទស្សនាវដ្ដី "ទង់បដិវត្ត" ចេញផ្សាយខែឧសភា-ខែមិថុនា និងខែកក្កដា ឆ្នាំ១៩៧៨*

១០៨៦. ទស្សនាវដ្ដី "ទង់បដិវត្ត" ចេញផ្សាយខែឧសភា-ខែមិថុនា និងខែកក្កដា ឆ្នាំ១៩៧៨ ស្ថិតក្នុងបរិបទដូចគ្នានេះដែរ[2022]។ ខ្មាំងវៀតណាម "ពិសពុលស្រួចស្រាវជាងគេ" សំដៅយ៉ាងច្បាស់ដល់ប្រទេសវៀតណាម "ឈ្លានពាន វាតទី លេបទឹកដី" និង "ភ្នាក់ងារ" ដែលមុននេះត្រូវបានកំណត់ថាជាអតីតសមាជិកកម្ពុជាប្រជាធិបតេយ្យ ដូចជា ចាន់ ចក្រី, សោ ភឹម, ឌឿន ឬ ជ័យ ជាដើម[2023]។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានថា សម្ដីទាំងនេះអាចសំដៅលើជនជាតិវៀតណាមរស់នៅកម្ពុជាឡើយ។

១០៨៧. ខ្លឹមសារនៃសៀវភៅកំណត់ត្រារបស់ ម៉ម ណៃ ដែលនិយាយអំពីគោលការណ៍ "១ ទល់នឹង ៣០" គ្មានអ្វីថ្មីនោះទេ[2024]។ យើងបានពន្យល់រួចមកហើយថា គោលការណ៍នេះបម្រើឱ្យការឃោសនា និងលើកទឹកចិត្តកងទ័ព ទល់នឹងពួកឈ្លានពានវៀតណាមដ៏ខ្លាំងក្លា[2025]។ អង្គជំនុំជម្រះមិនគួរណាប្រើប្រាស់

---

[2019] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៩៣០។

[2020] ទង់បដិវត្ត "បទឧទ្ទេសនាមរបស់សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជា ក្នុងឱកាសអបអរសាទរខួបលើកទី ៣ នៃមហាជ័យជម្នះ ១៧ មេសា (...)" ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/4604** ERN 00064716-00064717។

[2021] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៧។

[2022] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៣។

[2023] ទង់បដិវត្ត ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ឯកសារ **E3/727** ERN 00064566។

[2024] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៥។

[2025] សូមមើលខាងលើ កថាខណ្ឌ ១០៣០, ១០៦៥, ១០៨៣-១០៨៥។

កំណត់ត្រាផ្សេងទៀតរបស់អ្នកសួរចម្លើយនៅមន្ទីរ ស-២១ នោះឡើយ[2026]។ ជាក់ស្តែង អ្នកសរសេរមិនត្រូវបានកំណត់អត្តសញ្ញាណ ធ្វើឱ្យឯកសារទាំងនេះមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ទោះជាយ៉ាងណាក៏ដោយ កំណត់ត្រាទាំងនេះនិយាយសំដៅដល់ "ភ្នាក់ងារ" យួន ដែលជាសមាជិកកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវគេចោទថាចូលដៃជើងជាមួយវៀតណាម។ ក្រៅពីនេះ កំណត់ត្រាទាំងនេះចុះកាលបរិច្ឆេទឆ្នាំ១៩៧៨ ក្រោយពីការឈ្លានពានរបស់យោធាវៀតណាម។ គ្មានតម្រុយណាមួយនៅក្នុងឯកសារទាំងនេះ អាចឱ្យកំណត់អត្តសញ្ញាណជនជាតិវៀតណាមរស់នៅកម្ពុជាបានឡើយ។

១០៨៨. ទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" "ទង់បដិវត្ត" និងសំណុំឯកសារ FBIS ឆ្នាំ១៩៧៨ បានលើកឡើងភាសាដដែលជាប្រព័ន្ធ៖ ត្រូវការពារខ្លួនប្រឆាំងយួន និងរក្សា "ពូជសាសន៍កម្ពុជា"[2027]។ ក្នុងបរិបទនៃជម្លោះប្រដាប់អាវុធដដែល ក្រោយពីការឈ្លានពានពីរដងពីសំណាក់វៀតណាម រាល់ចៅក្រមប្រកបដោយវិចារណញ្ញាណសុទ្ធតែសន្និដ្ឋានថា នេះជាសុន្ទរកថាឃោសនាសម្រាប់លើកទឹកចិត្តកងទ័ព និងជំរុញប្រជាជនកម្ពុជាឱ្យរួមកម្លាំងគ្នា ទប់ទល់នឹងការវាយប្រហារពីខាងក្រៅ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានចៀសវាងមិនផ្តល់ការបកស្រាយទៅលើអត្ថបទទាំងនេះ។ ប៉ុន្តែ ជាថ្មីម្តងទៀត ច្បាស់ណាស់ថា គ្មានតម្រុយណាមួយអាចឱ្យអះអាងបានថា ពាក្យសម្តីទាំងនេះសំដៅដល់ជនជាតិវៀតណាមរស់នៅកម្ពុជានោះឡើយ។ ប្រការនេះក៏អនុវត្តផងដែរចំពោះសុន្ទរកថារបស់ ប៉ុល ពត, ខៀវ សំផន និង នួន ជា ដែលអង្គជំនុំជម្រះបានដកស្រង់ និងប្រើវោហារសាស្ត្រដដែល[2028]។

១០៨៩. ភ័ស្តុតាងអំពីភាសានៃឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ ដែលអង្គជំនុំជម្រះបានដកស្រង់ ពាក់ព័ន្ធនឹងវៀតណាម និង "ភ្នាក់ងារ" វៀតណាម មានទំនាក់ទំនងនឹងការឡើងកម្តៅនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម[2029]។ ឯកសារទាំងនេះគឺជាការឃោសនា ក្នុងសម័យសង្គ្រាម សំដៅដល់ខ្មាំងវៀតណាម និង "ភ្នាក់ងារ" វៀតណាម។ ឯកសារទាំងនេះមិនសំដៅជាក់លាក់

---

[2026] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៥។

[2027] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៦។

[2028] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៦ កំណត់សម្គាល់ជើងទំព័រលេខ១១៤៨៤ និង ១១៤៨៥។

[2029] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៧។

ដល់ជនជាតិវៀតណាមរស់នៅកម្ពុជាទេ។ ខ្លាំងខាងក្នុងសំដៅដល់សមាជិកកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវគេចោទថាចូលដៃជើងជាមួយវៀតណាម។

## *ទូរលេខ និងភ័ស្តុតាងក្រៅវិសាលភាព*

១០៩០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាទូរលេខនៅសម័យនោះបានលើកឡើងអំពីការសម្លាប់ជនស៊ីវិលវៀតណាម[2030]។ ទូរលេខទាំងនេះលាតត្រដាងអំពីការប៉ះទង្គិចគ្នាជាមួយវៀតណាមនៅតាមព្រំដែន។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានគិតដល់បរិបទនៃជម្លោះប្រដាប់អាវុធនេះទេ ដែលស្តែងឡើងជាសំខាន់ តាមរយៈការលុកលុយចូលព្រំដែនគ្នាទៅវិញទៅមកដោយក្រុមតូចៗដែលធ្វើសកម្មភាពជា "ទ័ពឈ្លប"។ អាចនិយាយបានម្យ៉ាងទៀតថា អង្គជំនុំជម្រះបានគិតគូរតាមរបៀបជ្រើសរើស... និងដាក់បន្ទុក។ ជាក់ស្តែង ក្នុងសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានប្រើប្រាស់ទូរលេខដដែលនេះ ដើម្បីបង្ហាញពីការប្រឈមមុខដាក់គ្នា នៅតាមព្រំដែន[2031]។ ប៉ុន្តែ ពេលបង្ហាញអំពីគោលនយោបាយតាមការសន្មត ការនិយាយសំដៅដល់ការវាយប្រហារគ្នា ការប៉ះទង្គិចគ្នា និងការរឹបអូសអាវុធ ត្រូវបានលាក់បាំង។ ទូរលេខទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា វៀតណាមដែលត្រូវបានចាប់ខ្លួន និងសម្លាប់ គឺជាមុខសញ្ញាយោធា មិនមែនជាជនស៊ីវិលទេ[2032]។ មេធាវីការពារក្តីធ្លាប់បានពញ្ញាក់

---

[2030] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០៨។

[2031] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៤ កំណត់សម្គាល់ជើងទំព័រលេខ៧៩៦ ដែលដកស្រង់ប្រយោគដូចគ្នានៃទូរលេខ **E3/1061**។ សូមមើលផងដែរ កថាខណ្ឌ ២៨៨ កំណត់សម្គាល់ជើងទំព័រលេខ៧៦០។ នៅកថាខណ្ឌ ២៩១ និងកំណត់សម្គាល់ជើងទំព័រលេខ ៧៧៥, ៧៧៦ និង ៧៧៩ អង្គជំនុំជម្រះដកស្រង់ប្រយោគដូចគ្នានៃទូរលេខ **E3/928**, **E3/1012** និង **E3/1062**។

[2032] សូមមើលឧទាហរណ៍ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៦ ឯកសារ **E3/1079** ERN 00052340-00052341។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ពុំមានចុះកាលបរិច្ឆេទ ឯកសារ **E3/1132** ERN 00160076 "យើងចាប់បាន [...] យួនម្នាក់ [...] វាវាយយុទ្ធជនយើងស្លាប់ នៅឃុំនេះដែរ។ តាមផ្លូវលេខ ១៣ ពួកយួនចូលឡានមក តែឃើញកាប់ឈើស្រះផ្លូវ វាក៏ត្រឡប់ទៅវិញ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ពុំមានចុះកាលបរិច្ឆេទ ឯកសារ **E3/1061** ERN 00231377-00231378។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ ឯកសារ **E3/181** ERN 00296226 "ខាងត្បូងផ្លូវលេខ ១ មុំមេសថ្ងក ខ្មាំងមានជីកលេនដ្ឋានទល់មុខយើង។ ពីមុនគ្មានទេ វានៅឆ្ងាយ។ ខាងផ្សារដើមអំពិល និងកុងអាង យប់មិញ មានឡានបើកចេញ ចូលច្រើនរហូតទល់ភ្លឺ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/1012** ERN 00020974 "នៅថ្ងៃទី១៩-៣ នៅមុំខាងជើងផ្លូវលេខ ១៩ និងខាងត្បូងផ្លូវលេខ ១៩ មានការ

អារម្មណ៍អង្គជំនុំជម្រះកុំឱ្យធ្វើខុសតាមសហព្រះរាជអាជ្ញា ដោយកាត់ និងបំភ្លៃទូរលេខទាំងនេះ[2033]។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ធ្វើការសន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងទាំងនេះ ថាជនស៊ីវិលត្រូវបានសម្លាប់ឡើយ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវទូរលេខទាំងនេះ ដែលនិយាយអំពីការវាយប្រហារនៅលើទឹកដីវៀតណាម ខណៈដែលអង្គហេតុទាំងនេះត្រូវបានដកចេញពីវិសាលភាពនៃការជំនុំជម្រះក្តី ក្នុងពេលបំបែកកិច្ចដំណើរការនីតិវិធី[2034]។ កំហុសអង្គច្បាប់នេះត្រូវបដិសេធចោល។ ទោះជាយ៉ាងនេះក្តី គ្មានអ្វីត្រូវសង្ស័យទេ ទូរលេខទាំងនេះមិនសំដៅលើជនជាតិវៀតណាមរស់នៅកម្ពុជាឡើយ។

១០៩១. អង្គជំនុំជម្រះបានយល់ឃើញថា ទូរលេខចំនួនបី ស័ក្តិសមនឹងទទួលបានការចាប់អារម្មណ៍ខ្ពស់ ដោយមិនពន្យល់ពីមូលហេតុ[2035]។ ទូរលេខរបស់ មាស មុត បានចុះកាលបរិច្ឆេទ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៧៧ គឺនៅថ្ងៃតែមួយនៃការចេញសេចក្តីថ្លែងការណ៍ផ្លូវការស្តីពីការផ្តាច់ទំនាក់ទំនងការទូតជាមួយវៀតណាម ដោយសារតែការឈ្លានពានទ្រង់ទ្រាយធំលើកដំបូង[2036]។ ទូរលេខនេះគ្រាន់តែបង្ហាញអំពីការគាំទ្ររបស់កងពល ១៦៤ ចំពោះ ប.ក.ក ប៉ុណ្ណោះ។

---

ប្រយុទ្ធគ្នា ពួកខ្មាំងយួនងាប់ ២៤ ក្បាល យើងយកបានអាវុធមួយចំនួន និងការពារទឹកដីបាន" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/928** ERN 00017026 "សរុបយួន ដែលចាប់បាន និងបាញ់ងាប់ ចាប់ពីថ្ងៃ ២៧-៣-៧៨ មកដល់ថ្ងៃទី៣០-៣-៧៨ មានចំនួន ១២០ ក្បាល ទូក ១០ សេស ដល់ ៣៧ សេស ចំនួន ៥ គ្រឿង អាវុធមួយចំនួន ក្នុងនោះ អឹម៧៩ ១ ដើម និងសម្ភារៈផ្សេងៗមួយចំនួន" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/1062** ERN 00052864 "ថ្ងៃ៦ ថ្ងៃ៧ ថ្ងៃ៨-៤ នេះ យើងកម្ទេចខ្មាំងបានជាង ១០០ ក្បាល យកអាវុធគ្រប់ធុនជិត ១០០ ដើម" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2033] ប្រតិចារឹក ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/392.1** ម៉ោង 10.39.27។

[2034] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/992** ERN 00001071 "ថ្ងៃ ២៧-២-៧៨ អង្គភាពយើងខ្ញុំបានសហការជាមួយកងតំបន់ បានលើកផែនការវ៉ៃទីតាំងរបស់ខ្មាំងយួនមួយកន្លែង នៅលើថ្នល់ជាតិលេខ ១៣ ចម្ងាយពីដីយើងចំនួន ១ គ.ម មួយថ្ងៃ មួយយប់ យើងម្ចាស់ការបានលើទីតាំង និងកម្ទេចខ្មាំងបានទាំងស្រុង។ សរុបលទ្ធផល យើងកម្ទេចខ្មាំងយួនបាន ៩៨ ក្បាលងាប់នៅកន្លែង"។

[2035] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៨។

[2036] ការប្រកាសរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ឯកសារ **E3/1265** ERN 00277200-00277201។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ៨១០។

១០៩២. ទូរលេខរបស់ រស់ ញឹម គឺជាឯកសារមួយ ដែលនិយាយជាក់លាក់សំដៅដល់គ្រួសារកូនកាត់ខ្មែរ-វៀតណាម[2037]។ លេខាភូមិភាគពាយ័ព្យបានស្នើសុំការណែនាំពីអង្គការ អំពីវិធីដោះស្រាយជាមួយគ្រួសារទាំងនេះ ដែលទំនងជាមានការភ័យខ្លាច។ អង្គជំនុំជម្រះមិនបានបញ្ជាក់ថា តើអង្គជំនុំជម្រះបានទាញការសន្និដ្ឋានយ៉ាងដូចម្ដេចចេញពីឯកសារនេះ។ រស់ ញឹម បានចង្អុលបង្ហាញថា ពួកនេះពុំទាន់មានសកម្មភាពប្រឆាំងទេ ប៉ុន្តែបើមាន គាត់នឹងចាត់ការ[2038]។ ថ្វីត្បិតតែយើងអាចសន្និដ្ឋានថា នៅខែឧសភា ឆ្នាំ១៩៧៨ ក្នុងពេលជម្លោះប្រដាប់អាវុធកំពុងឡើងកម្ដៅពេញបន្ទុក គ្រួសារទាំងនេះត្រូវបានតាមដានក៏ដោយ ក៏ឯកសារនេះបង្ហាញថា នៅពេលនោះ មិនមានចំណាត់ការអ្វីប្រឆាំងនឹងគ្រួសារទាំងនោះទេ។ ដូច្នេះ ឯកសារនេះជំទាស់នឹងការអះអាងរបស់អង្គជំនុំជម្រះថា មានគោលនយោបាយកម្ទេចក្រុមជនជាតិវៀតណាម តាំងពីខែមេសា ឆ្នាំ១៩៧៧។ ជាក់ស្ដែង ការបញ្ជាក់ថា ចំណាត់ការប្រឆាំងនឹងអ្នកទាំងនេះនឹងធ្វើឡើង តែក្នុងករណីមាន “សកម្មភាពប្រឆាំង” បង្ហាញថា សញ្ជាតិ ជាតិពន្ធុ ពូជសាសន៍ មិនមែនជាមូលហេតុនៃការតាមដាននេះទេ។

១០៩៣. ចំពោះទូរលេខរបស់ភូមិភាគបស្ចិម ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ ផ្នែកទីមួយសំដៅដល់អ្នកធ្វើសកម្មភាព “ខែទំនាស់” “វាយប្រហារ” “ប្រឆាំង” គឺអ្នក ១៧ មេសា អ្នករដ្ឋការចាស់ អាណិកជនចិន និងយួន[2039]។ ចំពោះការសំដៅដល់យួនដែលត្រូវបានកម្ទេច គ្មានតម្រុយណាមួយអាចឱ្យកំណត់ថាពួកគេមកពីណានោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ពួកគេជាជនជាតិវៀតណាមរស់នៅកម្ពុជាទេ។

***សេចក្ដីថ្លែងការណ៍ ថ្ងៃទី០២ ខែមករា ឆ្នាំ១៩៧៩***

---

[2037] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៩។

[2038] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ ឯកសារ **E3/863** ERN 00076287 “តែសកម្មភាពប្រឆាំងទេ នោះពុំទាន់មានទេ បើអ្នកណាមានសកម្មភាពឱ្យសម្រេចចោល”។

[2039] ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ ឯកសារ **E3/1094** ERN 00143603។

១០៩៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយល់ឃើញថា សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ១៩៧៩ ប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម សំដៅដល់ប្រជាជនវៀតណាមទាំងអស់ "ដោយមិនរើសមុខ"[2040]។ វាគួរឱ្យចម្លែកក្នុងការសន្និដ្ឋានថា ដោយហេតុថាសេចក្តីថ្លែងការណ៍អះអាងថា ប្រជាជនកម្ពុជាទាំងមូលប្រឆាំងនឹងខ្មាំងសត្រូវជនវៀតណាម មានន័យថា វៀតណាមទាំងអស់ត្រូវបានកំណត់គោលដៅ។ ប៉ុន្តែ មេធាវីការពារក្តីបានជម្រាបអង្គជំនុំជម្រះ អំពីការបកស្រាយខុសនេះរបស់សហព្រះរាជអាជ្ញារួចមកហើយ[2041]។ ជាក់ស្តែង សេចក្តីថ្លែងការណ៍នេះត្រូវបានធ្វើឡើង ខណៈពេលដែលកងទ័ពវៀតណាមកំពុងឈ្លានពានចូលកម្ពុជា។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចទាញសេចក្តីសន្និដ្ឋានក្រៅពីថា នេះជាសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលមួយ ដែលថ្កោលទោសការលុកលុយចូលប្រទេសខ្លួន ពីសំណាក់វៀតណាម និងកម្លាំងយោធា។

### *សក្ខីកម្មរបស់ ហេង ឡៃហ៊ាង និងការមិនអើពើនឹងភ័ស្តុតាងដោះបន្ទុក*

១០៩៥. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ជាមនុស្សតែម្នាក់គត់ដែលបាននិយាយថា មានគោលនយោបាយកម្ទេចជនជាតិវៀតណាមរស់នៅកម្ពុជា[2042]។ ប៉ុន្តែ ចម្លើយនេះមានតម្លៃជាភ័ស្តុតាងតិចតួច ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីនេះបានបាត់បង់សមាជិកគ្រួសារ។ ដូច្នេះ គាត់ខ្វះភាពសត្យានុម័តិ។ ក្រៅពីនេះទៀត អង្គជំនុំជម្រះខ្លួនឯងផ្ទាល់បានទទួលស្គាល់ថា បុគ្គលនេះមិនបានឃើញការសម្លាប់ណាមួយដោយផ្ទាល់នោះទេ[2043]។ ម្យ៉ាងវិញទៀត គាត់បានអះអាងថា គ្មានវៀតណាមនៅក្នុងឃុំរបស់គាត់ទេ ហើយគាត់

---

[2040] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤១២។

[2041] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២២៥១។

[2042] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤១៤ និង ៣៤១៥។

[2043] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៨៧។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** ក្រោយម៉ោង 14.41.42។

មិនដឹងថាមានរឿងកើតឡើងពិតប្រាកដលើជនជាតិវៀតណាមទេ[2044]។ គាត់បានឮគោលនយោបាយចំពោះជនជាតិវៀតណាមតែម្តងគត់ នៅដើមរបបនោះ ហើយព័ត៌មាននេះគឺជាពាក្យចចាមអារ៉ាម[2045]។ គាត់បានពន្យល់ថា គាត់បានឈប់ពីតួនាទីជាអ្នកចលនាអប់រំប្រជាជននៅក្នុងគណៈឃុំ នៅដើមឆ្នាំ ១៩៧៧។ ចាប់ពីពេលនោះមក គាត់ក្លាយជា "សមាជិករបស់ភូមិឃុំធម្មតា"[2046]។ ជាចុងក្រោយ អង្គជំនុំជម្រះខកខានមិនបានរំឭកថា ពេលបញ្ជាក់លើខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណីនេះឆ្លើយថា "ការធ្វើបដិវត្ត ឱ្យតែមានអ្នកប្រឆាំង គេមិនថាជនជាតិ ឬក៏ជនជាតិវៀតណាម ឬក៏ជនជាតិសាសន៍អីក៏ដោយ"[2047]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះបានបំភ្លេចចោលសក្ខីកម្មរបស់អតីតយោធាកម្ពុជាប្រជាធិបតេយ្យម្នាក់ ដែលបានអះអាងថា មិនមានគោលនយោបាយសម្លាប់ជនស៊ីវិលវៀតណាម និងសមាសភាពផ្សេងទៀតដែលគេយល់ថាប្រឆាំងទេ[2048]។

### *កំហុសពាក់ព័ន្ធនឹងការបង្កើតបញ្ជីឈ្មោះ និងការជាប់ខ្សែស្រឡាយខាងម្តាយ*

១០៩៦. ការបង្កើតបញ្ជីឈ្មោះ គឺជាភស្តុតាងចុងក្រោយដែលអង្គជំនុំជម្រះបានលើកឡើង ដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងជនស៊ីវិលវៀតណាម[2049]។ ប៉ុន្តែ ភស្តុតាងនេះក៏មិនអាចឱ្យបង្ហាញអំពីចេតនាបែបនេះបានឡើយ។ ជាក់ស្តែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនតែជនជាតិវៀតណាមទេដែលត្រូវបានធ្វើជំរឿន គឺប្រជាជនគ្រប់រូប ទាំងប្រជាជនថ្មី សមាជិករបបចាស់ និងខ្មែរ

---

[2044] ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** ក្រោយម៉ោង 14.34.35 "តែតំបន់ដែលនាងខ្ញុំនៅ មូលដ្ឋានដែលនៅគឺគ្មានសញ្ជាតិយួនទេ" ក្រោយម៉ោង 14.37.33 ក្រោយម៉ោង 14.41.42។

[2045] ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** ម៉ោង 14.40.16 "តាមស្តាប់មើល" "តាមដែលព័ត៌មានដែលជាសាច់ញាតិរបស់ខ្ញុំផ្ទាល់ហ្នឹង" មុនម៉ោង 15.59.23។

[2046] ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** មុនម៉ោង 15.14.46។

[2047] ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** មុនម៉ោង 16.11.57។

[2048] <u>មាស រឿន</u>៖ ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/387.1** ម៉ោង 09.13.46 "មិនទាន់មានឯកសារ ឬក៏មិនទាន់មានអីណែនាំដល់ថា នៅក្នុងខាងក្នុងទេ។ ដូច្នេះ កម្មេចយួនខាងក្រៅដែលវាឈ្លានពានជាសំខាន់។ នេះដែលតាមទិសដៅខ្ញុំក្តាប់បានយើង និងការណែនាំប៉ុណ្ណឹង"។

[2049] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៨។

ជាទូទៅ[2050]។ នេះបណ្តាលមកពីភាពចាំបាច់ក្នុងការត្រៀមរបបអាហារ និងស្បៀង តាមសហករណ៍។ ជាចុងក្រោយ យើងបានឃើញខាងលើថា ការជាប់ខ្សែស្រឡាយខាងម្តាយមិនត្រូវបានពិនិត្យផ្ទៀងផ្ទាត់នោះទេ[2051]។

១០៩៧. **សេចក្តីសន្និដ្ឋាន៖** តាមរយៈការពិនិត្យឯកសារទាំងអស់ ដែលអង្គជំនុំជម្រះយកមកបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងវៀតណាម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ឯកសារទាំងនេះសំដៅជនជាតិវៀតណាមរស់នៅកម្ពុជា។ អង្គជំនុំជម្រះបានអះអាងថាបានពិចារណាលើបរិបទនៃជម្លោះប្រដាប់អាវុធ ប៉ុន្តែ លើកលែងតែមួយ ឬពីរករណីប៉ុណ្ណោះ[2052] សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះបង្ហាញថា អង្គជំនុំជម្រះមិនបានធ្វើបែបនេះទេ។ អង្គជំនុំជម្រះក៏បានបំភ្លេចចោលទាំងស្រុងនូវការឃោសនាជាប្រចាំក្នុងឯកសារទាំងនេះ ដែលមានគោលដៅធ្វើឱ្យប្រជាជនកម្ពុជារួមកម្លាំងគ្នាប្រឆាំងនឹងខ្មាំងវៀតណាម ក្នុងពេលមានជម្លោះប្រដាប់អាវុធ។ បទចោទប្រល័យពូជសាសន៍ត្រូវបានធ្វើឡើងប្រឆាំងនឹងក្រុមជនជាតិវៀតណាមរស់នៅកម្ពុជា ដែលត្រូវទទួលបានការការពារ។ អង្គជំនុំជម្រះបានសន្និដ្ឋានថា មានការធ្វើមនុស្សឃាតលើជនជាតិវៀតណាម នៅខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជា នៅខេត្តកំពង់ឆ្នាំង នៅវត្តខ្សាច់ និងនៅខេត្តក្រចេះ។ ប៉ុន្តែ គ្មានឯកសារណាមួយ ដែលអង្គជំនុំជម្រះដកស្រង់ បានលើកឡើងអំពីហេតុការណ៍ទាំងនេះទាល់តែសោះ។ អង្គជំនុំជម្រះមិនបានបង្ហាញឱ្យឃើញចេតនាកម្ទេចជនជាតិវៀតណាមទាំងនេះ ដែលជាជនរងគ្រោះនៃការធ្វើមនុស្សឃាតឡើយ។ អង្គជំនុំជម្រះក៏មិនបានបង្ហាញអត្ថិភាពនៃគោលនយោបាយកម្ទេចជនជាតិវៀតណាម ចាប់ពីខែមេសា ឆ្នាំ១៩៧៧ នោះដែរ។ ដូច្នេះ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់សន្និដ្ឋានថា ធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានបំពេញ តាមរយៈគោលនយោបាយជាតិនោះឡើយ។ អាស្រ័យហេតុនេះ ខៀវ សំផន ត្រូវលើកលែងឱ្យរួចផុតពីបទឧក្រិដ្ឋនេះ។

---

[2050] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** ប្រហែលម៉ោង 09.38.42 ដែលត្រង់កន្លែងនេះ គាត់បានបញ្ជាក់ថា គាត់បានដឹងពីបញ្ជីឈ្មោះប្រជាជនខ្មែរ ប៉ុន្តែ មិនមែនដើម្បីធ្វើជំរឿនប្រជាជនវៀតណាមទេ។

[2051] សូមមើលខាងលើ កថាខណ្ឌ ១០៩២-១០៩៨។

[2052] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤១១ និង ៣៤១៣។

## ជំពូកទី ៤. ការរៀបអាពាហ៍ពិពាហ៍ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍

### ផ្នែកទី ១. ការរៀបអាពាហ៍ពិពាហ៍

### ១. កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

១០៩៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ក្នុងការបកស្រាយទៅលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ (១.១) និងមិនបានធ្វើតំណភ្ជាប់រវាងសិទ្ធិ និងបម្រាម ដូចមានចែងក្នុងលិខិតុបករណ៍អន្តរជាតិ នៅសម័យអង្គហេតុ (១.២)។ កំហុសទាំងនេះបណ្តាលឱ្យមានការរំលោភគោលការណ៍នីត្យានុកូលភាព និងផលវិបាករបស់វា (១.៣)។

### ១.១. ការវិភាគខុសលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពផ្លូវការ

១០៩៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិភាគខុសទៅលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពផ្លូវការ ផ្ទុយនឹងគោលការណ៍នីត្យានុកូលភាព។ ច្បាប់ជាធរមាននៅសម័យនោះមិនអាចឱ្យកាត់សេចក្តីអង្គហេតុដែលបានចោទប្រកាន់ចំពោះ ខៀវ សំផន បានទេ។ អង្គជំនុំជម្រះបានបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលព្យាយាមបង្ហាញអំពីបរាជ័យនៃការអនុវត្តល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការចំពោះអង្គហេតុនៃរឿងក្តី ដោយហេតុថា៖

> "បទល្មើសនៃអំពើអមនុស្សធម៌ផ្សេងទៀត មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធ ហើយនិយមន័យនៃបទល្មើសនេះមិនត្រូវបានកម្រិតត្រឹមតែបញ្ជីនៃប្រភេទជាក់លាក់នៃការប្រព្រឹត្តិនោះទេ។ មិនមានល័ក្ខខ័ណ្ឌតម្រូវថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានទទួលស្គាល់ថាជាប្រភេទជាក់លាក់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬជាប្រភេទជាក់លាក់នៃការប្រព្រឹត្តិជាមូលដ្ឋាន ដែលស្ថិតនៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀតត្រឹមឆ្នាំ១៩៧៥ នោះទេ"[2053]។

---

[2053] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៤១។

១១០០. ដោយកម្រិតវិចារណកិច្ចត្រឹមតែចំណុចទាំងនេះ ដើម្បីធានាឱ្យមានការគោរពគោលការណ៍នីត្យានុកូលភាព និងដោយផ្តល់និយមន័យខុសទៅធាតុផ្សំដែលរកបានដោយតុលាការកំពូល ក្នុងសាលដីកាសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់។ អង្គជំនុំជម្រះបានកម្រិតវិចារណកិច្ចរបស់ខ្លួនត្រឹមការដែលថា មិនមានលក្ខខណ្ឌតម្រូវឱ្យការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានទទួលស្គាល់ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅសម័យអង្គហេតុ ឬជាប្រភេទជាក់លាក់នៃការប្រព្រឹត្តិដែលស្ថិតនៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀត ត្រឹមកាលបរិច្ឆេទនោះទេ[2054]។ ការរកឃើញទាំងនេះមិនគ្រប់គ្រាន់ទេ។ អង្គជំនុំជម្រះមានកាតព្វកិច្ចអនុវត្តលក្ខខណ្ឌអនីត្យានុកូលភាពជាផ្លូវការ ដូចបានរៀបរាប់ក្នុងយុត្តិសាស្ត្ររបស់តុលាការកំពូល[2055] ដើម្បីធានាឱ្យបាននូវការគោរពគោលការណ៍នីត្យានុកូលភាព និងដើម្បីឱ្យអំពើនោះអាចត្រូវបានយល់ដឹង និងប្រមើលមើលបានដោយជនជាប់ចោទ។

១១០១. ចំពោះតំណភ្ជាប់រវាងសិទ្ធិជាមូលដ្ឋាន និងបម្រាម ដូចមានចែងក្នុងលិខិតុបករណ៍អន្តរជាតិនៅសម័យអង្គហេតុ ចៅក្រមបកស្រាយយុត្តិសាស្ត្ររបស់តុលាការកំពូលដូចតទៅ៖ "ការវាយតម្លៃថា តើការប្រព្រឹត្តិនោះរំលោភបំពានទៅលើសិទ្ធិជាសារវ័ន្តរបស់មនុស្សជាតិ ដូចបានបញ្ជាក់នៅក្នុងលិខិតុបករណ៍ច្បាប់អន្តរជាតិនោះ ឬយ៉ាងណា គឺជាវិធីមួយនៃការបង្ហាញលក្ខខណ្ឌតម្រូវនៃអនីត្យានុកូលភាពផ្លូវការជាអន្តរជាតិ"[2056]។

១១០២. ការបកស្រាយរបស់អង្គជំនុំជម្រះមិនត្រឹមត្រូវទេ និងបង្កើតបានជាកំហុសអង្គហេតុ។ ជាក់ស្តែង ចៅក្រមដកស្រង់វិចារណកិច្ចរបស់តុលាការកំពូលតែមួយផ្នែក ធ្វើឱ្យយល់ថា លក្ខខណ្ឌអនីត្យានុកូលភាពជាផ្លូវការគ្រាន់តែជាការកំណត់សិទ្ធិជាមូលដ្ឋានដែលត្រូវបានរំលោភបំពាន ដូចបានធានានៅក្នុងលិខិតុបករណ៍អន្តរជាតិ នៅសម័យអង្គហេតុ។ តក្កវិជ្ជានេះ គឺខុស និងគ្រោះថ្នាក់។ ដើម្បីជាការចងចាំ

---

[2054] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៤១។

[2055] សូមមើលខាងលើ កថាខណ្ឌ ៦៥៨-៦៦៥។

[2056] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២៦។

វិចារណកិច្ចក្នុងសាលដីកាសំណុំរឿង ០០២/០១ បង្ហាញយ៉ាងច្បាស់ថា សិទ្ធិមនុស្សតែមួយមុខមិនអាចបង្កើតបានជាគ្រឹះនៃបទដ្ឋាននៃនីតិព្រហ្មទណ្ឌបានទេ[2057]។

១១០៣. ជំហានបន្ថែមនេះ ដែលត្រូវបានអង្គជំនុំជម្រះលាក់បាំងទាំងស្រុង ត្រូវចាត់ទុកជាឆន្ទៈក្នុងការធានាឱ្យបានជាដាច់ខាតនូវគោលការណ៍នីត្យានុកូលភាព និងផលវិបាករបស់វា[2058]។ វាជាការគួរឱ្យភ្ញាក់ផ្អើលណាស់ក្នុងការមើលឃើញថា នៅក្នុងសំអាងហេតុសាលក្រម ពិតតែមានការលើកឡើងអំពីល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការតែពាក់កណ្ដាល ដោយយោងទៅលើសិទ្ធិជាមូលដ្ឋាន ក៏ដោយ ក៏អង្គជំនុំជម្រះមិនអនុវត្តទាំងស្រុងនូវល័ក្ខខ័ណ្ឌកាត់ក្បាលកាត់កន្ទុយនេះទេ នៅក្នុងផ្នែកស្ដីពីការកំណត់ប្រភេទបទល្មើសជាអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2059] ឬនៅក្នុងការកំណត់អំពីច្បាប់ជាធរមាន[2060]។ អង្គជំនុំជម្រះមិនបានធ្វើការស្រាវជ្រាវស៊ីជម្រៅទៅលើសិទ្ធិជាមូលដ្ឋាន នៅក្នុងលិខិតុបករណ៍អនុវត្តជាធរមាននៅសម័យអង្គហេតុទេ។ មានតែសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្សប៉ុណ្ណោះ ដែលត្រូវបានដកស្រង់យ៉ាងខ្លី នៅក្នុងផ្នែកស្ដីពីច្បាប់ជាធរមាន ហើយយោងតាមសេចក្ដីប្រកាសនោះ អង្គជំនុំជម្រះបានយល់ឃើញថា៖

> "សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ដោយសេរី គឺជាសិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដែលបានចែងថា អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបាន លុះត្រាណាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្ដីប្រពន្ធ"[2061]។

---

[2057] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៤។

[2058] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៤។

[2059] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨០-៣៦៩៤។

[2060] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៤០-៧៤៩។

[2061] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៤៣។

១១០៤. គោលការណ៍នីត្យានុកូលភាពទាមទារឱ្យមានការវិភាគហ្មត់ចត់ ហើយការលើកឡើងយ៉ាងខ្លីនូវបទប្បញ្ញត្តិតែមួយ មិនអាចគ្រប់គ្រាន់ឱ្យធានាបាននូវការគោរពគោលការណ៍នីត្យានុកូលភាពទេ[2062]។ បើគ្មានសំអាងហេតុដ៏សំខាន់នេះ ដើម្បីសន្និដ្ឋានអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ អង្គជំនុំជម្រះបានរំលោភលើគោលការណ៍នីត្យានុកូលភាព។

១១០៥. នៅក្នុងផ្នែកស្តីពីច្បាប់ជាធរមាន សំអាងហេតុសាលក្រមបានធ្វើបញ្ជីយុត្តិសាស្ត្ររបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ខណៈដែលរឿងក្តីទាំងនេះមិនស្ថិតក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទេ[2063]។ ប៉ុន្តែ នេះគឺជាភាពខុសគ្នាដ៏សំខាន់។ ជាក់ស្តែង ថ្វីត្បិតតែសាលដីកា *« AFRC »* ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ បានទទួលស្គាល់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាអំពើអមនុស្សធម៌ផ្សេងទៀត ក៏ដោយ ក៏វាអនុវត្តចំពោះអង្គហេតុដែលបានកើតឡើងក្រោយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦[2064]។ ម្យ៉ាងវិញទៀត បរិបទនៃ *Bush Wives* មិនអាចប្រៀបធៀបជាសត្យានុម័តិ ក្នុងកម្រិតនៃភាពធ្ងន់ធ្ងរ ជាមួយអង្គហេតុនៃរឿងក្តីយើងបានទេ។ *Bush Wives* គឺជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងទាសភាពផ្លូវភេទ នៃការរំលោភសេពសន្ថវៈដែលប្រព្រឹត្តដោយពួកជីវពល។ ស្ត្រីទាំងនេះត្រូវបានចាប់ជំរិតយកទៅក្នុងព្រៃ ដើម្បីរៀបការជាមួយជីវពលឧទ្ទាមផ្សេងទៀត និងត្រូវគេបង្ខំឱ្យធ្វើកិច្ចការផ្ទះ។ ស្ត្រីទាំងនោះ ដែលស្លុយកេរ្តិ៍ឈ្មោះក្នុងក្រសែភ្នែកនៃសង្គមសៀរ៉ាឡេអូន បានបន្តទទួលរងនូវការដៀលត្មះ ក្រោយជម្លោះ[2065]។

១១០៦. ដូច្នេះ យើងមិនយល់ទេ ហេតុអ្វីបានជាអង្គជំនុំជម្រះនិយាយអំពីយុត្តិសាស្ត្ររបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ដែលមិនស្ថិតក្រោមយុត្តាធិការពេលវេលារបស់ខ្លួន និងខណៈដែលអង្គជំនុំជម្រះមិនទាំងខ្វល់នឹងស្វះស្វែងរកច្បាប់ជាធរមាន នៅសម័យកម្ពុជាប្រជាធិបតេយ្យផង។ ម្យ៉ាង

---

[2062] សូមមើល ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវបានកោសលុប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **D301/5** កថាខណ្ឌ ៥២-៦៣។

[2063] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៤៤-៧៤៧។

[2064] សាលដីកា *AFRC* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨។

[2065] អត្ថបទរបស់ Neha JAIN ការរៀបការដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ - បញ្ហានៃការកំណត់និយមន័យ និងការចោទប្រកាន់ JICJ ឆ្នាំ២០០៨ ទំព័រ ១០១៥-១០១៦, ១០២៥-១០២៦។

វិញទៀត លក្ខន្តិកៈរបស់តុលាការអន្តរជាតិនានាមិនចែងអំពីបទប្បញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ខណៈដែលលក្ខន្តិកៈទីក្រុងរ៉ូមបាននិយាយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថ្មីៗ ដូចជាទេសភាពផ្លូវភេទ អំពើពេស្យាចារដោយបង្ខំ ឬការមានគភ៌ដោយបង្ខំ មិនមានការចែងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ដូចគ្នាដែរ លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ឆ្នាំ១៩៩៣) ឬតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ឆ្នាំ២០១០) មិនមានចែងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ខណៈដែលករណីទាំងនេះត្រូវបានលើកឡើង ជាអាទិ៍ នៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ការមិនចែងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងលក្ខន្តិកៈទាំងនេះ ធ្វើឱ្យគេជឿថាការផ្តន្ទាទោសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានបង្ហាញគ្រប់គ្រាន់ ដើម្បីបញ្ចូលអំពើនេះទៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[2066]។

១១០៧. ដោយបានប្រព្រឹត្តកំហុសឆ្គង ក្នុងការអះអាងថា អំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់ នៅសម័យអង្គហេតុ[2067] ទុកដូចជាគ្រប់គ្រាន់ និងដោយមិនបានធ្វើការវិភាគទៅលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងបង្កព្យសនកម្មដោយផ្ទាល់ដល់ ខៀវ សំផន។ ដើម្បីបង្ហាញថាការដាក់បញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាបទឧក្រិដ្ឋ អាចយល់ដឹង និងប្រមើលមើលបានដោយជនជាប់ចោទ អង្គជំនុំជម្រះគួរណាតែធ្វើតំណភ្ជាប់រវាងសិទ្ធិ និងបម្រាម ដូចមានចែងក្នុងអត្ថបទច្បាប់ជាធរមាន នៅសម័យអង្គហេតុ។

## ១.២. គ្មានតំណភ្ជាប់រវាងសិទ្ធិ និងបម្រាម នៅសម័យនោះ

[2066] អត្ថបទរបស់ Neha JAIN ការរៀបការដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ - បញ្ហានៃការកំណត់និយមន័យ និងការចោទប្រកាន់ JICJ ឆ្នាំ២០០៨ ទំព័រ ១០២៦។

[2067] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៤។

១១០៨. លិខិតុបករណ៍អន្តរជាតិជាច្រើន នៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ បានធានាឱ្យមានសិទ្ធិគោរពជីវិតឯកជន និងជីវិតគ្រួសារ៖ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨[2068] តុលាការសិទ្ធិមនុស្សអឺរ៉ុប ឆ្នាំ១៩៥០[2069] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦[2070] (កម្ពុជាទើបតែចូលជាសមាជិក នៅឆ្នាំ១៩៩២) អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៦៩[2071]។ មានតែសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សមួយគត់ ដែលនិយាយច្បាស់ដល់ការរៀបអាពាហ៍ពិពាហ៍ ដោយចែងថា "អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបាន លុះត្រាណាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធ"[2072]។

១១០៩. ការគ្មានចែងអំពីការរៀបអាពាហ៍ពិពាហ៍ នៅក្នុងលិខិតុបករណ៍អន្តរជាតិ នៅសម័យនោះ អាចយល់បាន ដោយគិតដល់ការវិវត្តនៃទំនៀមទម្លាប់នេះ ក្នុងនាមជាឧបករណ៍កំណត់រចនាសម្ព័ន្ធសង្គម។ អស់រយៈពេលជាយូរ ប្រព័ន្ធគតិយុត្តិជាច្រើនឆ្លុះបញ្ចាំងទស្សនៈជាប្រពៃណីនៃទំនៀមទម្លាប់រៀបអាពាហ៍ពិពាហ៍ ដែលត្រូវបានចាត់ទុកជាការបំពេញកិច្ចរបស់ក្រុម ឬពួកណាមួយ។ ការរៀបអាពាហ៍ពិពាហ៍ក្នុងនាមជាកិច្ចព្រមព្រៀងសង្គម គឺជាជម្រើសគ្រួសាររួមគ្នា ដែលធ្វើឡើង ដោយមានទស្សនៈផ្សេងៗគ្នា ទៅតាមសង្គមនីមួយៗ (កម្រិតអប់រំ សង្គម ឬសាសនា) តែមិនមែនជាជម្រើសបុគ្គល ដូចសព្វថ្ងៃ

---

[2068] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ មាត្រា ១៦-២៖ "អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធ"។

[2069] អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស ឆ្នាំ១៩៥០ មាត្រា ៨ ទាក់ទងនឹងសិទ្ធិទទួលបានគោរពជីវិតឯកជន និងគ្រួសារ៖ "ជនគ្រប់រូបមានសិទ្ធិទទួលបានការគោរពជីវិតឯកជន និងគ្រួសារ លំនៅដ្ឋាន និងសំបុត្រឆ្លើយឆ្លើយរបស់ខ្លួន"។

[2070] កតិកាសញ្ញាតអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ ឆ្នាំ១៩៦៦ មាត្រា ១៧៖"គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ។ ២. ជនគ្រប់រូបមានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ"។

[2071] អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៦៩ មាត្រា ១១៖ "គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ"។

[2072] សូមមើលខាងក្រោមអំពីបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងការព្រមព្រៀងរបស់ស្វាមីភរិយា កថាខណ្ឌ ១២៦០-១២៧០។

នេះទេ។ ការវិវត្តនៃសិទ្ធិមនុស្សអាចធ្វើឱ្យទស្សនាទាននេះវិវត្តផងដែរ ហើយទស្សនៈថ្មីៗចំពោះគ្រួសារបានលេចឡើង។ ចាប់ពីពេលនោះមក ទស្សនៈចំពោះការរៀបអាពាហ៍ពិពាហ៍ក្នុងឋានៈជារឿងរបស់បុគ្គល គឺមិនមែនជារឿងរបស់ក្រុមទៀតទេ។ គំនិតនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងនាមជាការបញ្ជាក់អំពីឯកត្តជនភាព គឺជាគំនិតដែលទើបតែកើតមានឡើងទេនៅក្នុងសង្គមជាច្រើន។ ប្រការនេះឆ្លុះបញ្ចាំងតាមរយៈការកែប្រែច្បាប់ថ្មីៗ នៅតាមរដ្ឋមួយចំនួន រួមទាំង នៅកម្ពុជាផងដែរ[2073]។

១១១០. សហចៅក្រមស៊ើបអង្កេតបានប្រកាន់យកមតិយោបល់ស្រដៀងគ្នានេះ យោងតាមសេចក្តីសម្រេចបដិសេធបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃការមានគភ៌ និងបង្កកំណើតដោយបង្ខំ។ ក្រោយពីការវិភាគម៉ត់ចត់ទៅលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា យោងតាមភាពមិនគ្រប់គ្រាន់នៃលិខិតុបករណ៍នៅសម័យនោះ ឧក្រិដ្ឋកម្មទាំងពីរនេះមិនអាចត្រូវបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតបានឡើយ[2074]។ ក្នុងន័យនេះ សហចៅក្រមស៊ើបអង្កេតបានព្យាយាមពន្យល់អំពីអវត្តមាននៃច្បាប់។

> "ការទទួលស្គាល់ដែលមានលក្ខណៈសន្សឹមៗ និងយឺត នៃការមានផ្ទៃពោះដោយបង្ខំថាជាបទឧក្រិដ្ឋក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិបែបនេះ បង្ហាញឱ្យឃើញភាពខ្វែងគំនិតគ្នា រវាងអ្នកប្រកាន់ទ្រឹស្តីសមូហភាពនិយម និងទំនៀមទម្លាប់ច្បាប់ដែលប្រកាន់បុគ្គលនិយម ដែលក្នុងនោះ ទម្លាប់ខុសប្លែកគ្នាបង្កើតបានជាទស្សនៈខ្វែងគ្នាស្តីពីជម្រើសក្នុងការបន្តពូជ ទំនាក់ទំនងផ្លូវភេទ ការរំលូតកូន និងការពង្រីកវិសាលភាពនៃសិទ្ធិស្ត្រី"[2075]។

១១១១. ដូច្នេះ ច្បាស់ក្រឡែតណាស់ថា អនុសញ្ញាអន្តរជាតិតែមួយគត់មិនគ្រប់គ្រាន់ឱ្យសន្និដ្ឋានអំពីអត្ថិភាពនៃអនីត្យានុកូលភាពជាផ្លូវការបានឡើយ។ លិខិតុបករណ៍អន្តរជាតិស្តីពីច្បាប់សង្គ្រាមមិនមានចែងអំពីការ

---

[2073] សូមមើលខាងក្រោម កថាខណ្ឌ ១១៣៣-១១៣៦។

[2074] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវបានកោសលុប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **D301/5**។

[2075] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវបានកោសលុប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **D301/5**, កថាខណ្ឌ ៧៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

រៀបអាពាហ៍ពិពាហ៍ទេ។ យើងមិនឃើញមានបទប្បញ្ញត្តិណាមួយ នៅក្នុងក្រម Lieber ឆ្នាំ១៨៦៣[2076] អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៨៩៩ និងឆ្នាំ១៩០៧[2077] លក្ខន្តិកៈទីក្រុង Nuremberg និងលក្ខន្តិកៈទីក្រុងតូក្យូ[2078] អនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែម[2079] ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យសម្ព័ន្ធមិត្ត[2080] និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់អាស៊ីចុងបូព៌ា[2081] នោះឡើយ។

១១១២. ក្នុងសាលដីកា ឌុច តុលាការកំពូលបានរំឭកថា អង្គជំនុំជម្រះអាចផ្អែកលើច្បាប់ក្នុងស្រុកជាធរមាននៅសម័យអង្គហេតុ ដើម្បីបង្ហាញថា តើជនជាប់ចោទអាចដឹងយ៉ាងសមហេតុផលថា អង្គហេតុដែលបានចោទប្រកាន់ត្រូវបានហាមឃាត់ និងផ្តន្ទាទោសដែរ ឬទេ[2082]។

១១១៣. ចំពោះច្បាប់ក្នុងស្រុកនៅសម័យនោះ គ្មានបទប្បញ្ញត្តិណាមួយក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ចែងអំពីការផ្តន្ទាទោសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ និងបទប្បញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ អាចឱ្យដឹងអំពីការយល់ឃើញទៅលើទំនៀមទម្លាប់នេះ

---

[2076] ក្រម Lieber, *Instructions for the Government of Armies of the United States in the Field* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៨៦៣។

[2077] អនុសញ្ញាទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមនៅលើផែនដី និងឧបសម្ព័ន្ធ៖ វិធានផ្នែកក្នុងទាក់ទងនឹងច្បាប់ និងទំនៀមទម្លាប់ស្តីពីសង្គ្រាមនៅលើផែនដី ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩០៧។

[2078] លក្ខន្តិកៈតុលាការយោធាអន្តរជាតិ ភ្ជាប់ជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងស្តីពីការចោទប្រកាន់ និងការផ្តន្ទាទោសឧក្រិដ្ឋជនសង្គ្រាមធំៗនៃមហាអំណាចអឺរ៉ុប Axe ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥។

[2079] អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវជោគវាសនារបស់អ្នករងរបួស និងអ្នកជំងឺនៅក្នុងកងកម្លាំងប្រដាប់អាវុធនៅជនបទ ជោគវាសនារបស់អ្នករងរបួស អ្នកជំងឺ និងលិចនាវានៃកងកម្លាំងប្រដាប់អាវុធនៅសមុទ្រ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩, កម្រងសន្ធិសញ្ញាអង្គការសហប្រជាជាតិ ភាគ ៧៥ ទំព័រ ៨៥, អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងនឹងការប្រព្រឹត្តិចំពោះអ្នកទោសសង្គ្រាម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩, កម្រងសន្ធិសញ្ញាអង្គការសហប្រជាជាតិ ភាគ ៧៥ ទំព័រ ១៣៥, ពិធីសារបន្ថែមនៃអនុញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការការពារប្រជាជនស៊ីវិលក្នុងពេលសង្គ្រាម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធអន្តរជាតិ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧។

[2080] ច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យសម្ព័ន្ធ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៤៥។

[2081] តុលាការយោធាអន្តរជាតិសម្រាប់តំបន់ចុងបូព៌ា ការប្រកាសពិសេសរបស់មេបញ្ជាការជាន់ខ្ពស់នៃកងកម្លាំងសម្ព័ន្ធនៅចុងបូព៌ានៅតូក្យូ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ (វិសោធនកម្មនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៤៦)។

[2082] សាលដីកា ឌុច ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៩៦។

នៅមុន និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ អាចយកមកអនុវត្តបាន នៅមុន និងក្រោយអង្គហេតុ រហូតដល់ឆ្នាំ២០០៧[2083]។ ដូច្នេះ ក្រមនេះអាចឱ្យយល់បានអំពីស្ថានភាពច្បាប់នៅកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ មាត្រា ១២៥ នៃក្រមនេះ ចែងថា៖ "អនីតិជនអាចនឹងរៀបអាពាហ៍ពិពាហ៍បាន លុះត្រាណាតែឪពុកម្តាយអនុញ្ញាតយល់ព្រមផង"។ មាត្រា ១៣៣ ចែងថា៖ "ប្រុស និងស្រី ជានីតិជន ហើយចង់រៀបអាពាហ៍ពិពាហ៍នឹងគ្នានោះ ក៏ត្រូវឱ្យបាន**អនុញ្ញាតពីបុព្វញាតិទាំងឡាយនោះ ដូចអនីតិជនដែរ**"។ គ្មានបទប្បញ្ញត្តិណាមួយចែងអំពីការយល់ព្រមពីប្តីប្រពន្ធទេ[2084]។

១១១៤. ដូច្នេះ ច្បាស់ណាស់ថា បទប្បញ្ញត្តិបង្ហាញឱ្យឃើញថា មានតែការយល់ព្រមពីឪពុកម្តាយប៉ុណ្ណោះទើបមានសារៈសំខាន់ ហើយអវត្តមាននៃការយល់ព្រមពីប្តីប្រពន្ធ មុនរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការអនុវត្តស្របច្បាប់ចំពោះការរៀបអាពាហ៍ពិពាហ៍។ ការកំណត់អំពីអវត្តមាននៃការយល់ព្រមពីប្តីប្រពន្ធនេះបញ្ជាក់ផងដែរអំពីអវត្តមាននៃអនីត្យានុកូលភាពជាតិ។

## ១.៣. ភាពមិនអាចផ្តន្ទាទោស ខៀវ សំផន បាន

១១១៥. ដូចបានរៀបរាប់រួចមកហើយ ប្រភេទបន្ថែមនៃអំពើអមនុស្សធម៌ផ្សេងទៀតចូលរួមក្នុងឆន្ទៈកសាងនីតិព្រហ្មទណ្ឌអន្តរជាតិ[2085]។ ការកសាងនេះត្រូវធ្វើឡើង ដោយគោរពគោលការណ៍ "គ្មានបទល្មើស បើគ្មានច្បាប់ចែង" និងផលវិបាករបស់វា[2086]។ ការវិភាគលក្ខខណ្ឌអនីត្យានុកូលភាពអាចឱ្យបំពេញលក្ខខណ្ឌតម្រូវនេះ។ ចំពោះសហចៅក្រមស៊ើបអង្កេត ការយោងទៅលើប្រភពបែបនេះ តាមរយៈការវិភាគលក្ខខណ្ឌនេះ "ក៏ជួយបំពេញគោលបំណងនៃការកំណត់ថា តើជនជាប់ចោទអាចប្រមើលមើល

[2083] អំពីការរក្សាទុកក្រមរដ្ឋប្បវេណីពីឆ្នាំ១៩២០ ដល់ឆ្នាំ២០០៧៖ ព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ មាត្រា ៨២៖ "ការចាត់ចែងអំពីក្រមរដ្ឋប្បវេណីចាស់៖ ក្រមរដ្ឋប្បវេណីចាស់ដែលបានអនុញ្ញាតប្រកាសឱ្យប្រើដោយព្រះមហាក្សត្រនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២៩ និងដែលត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់រហូតដល់មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មិនមានអានុភាពឡើយ"។

[2084] ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) (ភ្ជាប់ជាឧបសម្ព័ន្ធ)។

[2085] សូមមើលខាងលើ កថាខណ្ឌ ៦៥៨-៦៦៥។

[2086] សូមមើលខាងលើ កថាខណ្ឌ ៦៥៨-៦៦៥។

ដឹង និងអាចដឹងថាមានច្បាប់ចែងអំពីការស៊ើបអង្កេត និងការចោទប្រកាន់ចំពោះការប្រព្រឹត្តិបែបនោះ”[2087]។ ដូច្នេះ ការវិភាគដែលស្នើឡើងអាចឱ្យ “គាំទ្រដល់ការសន្និដ្ឋានដែលថា ត្រូវតែមានបទដ្ឋានដែលទទួលស្គាល់ជាទំនៀមទម្លាប់មួយ ដែលភ្ជាប់ទៅនឹងសិទ្ធិសមស្របរបស់មនុស្សជាតិ ដែលភាពអមនុស្សធម៌នៃអំពើនោះនឹងត្រូវវិនិច្ឆ័យ”[2088]។

១១១៦. សរុបសេចក្តីមក ច្បាស់ណាស់ថា មុនរបបកម្ពុជាប្រជាធិបតេយ្យ លិខិតុបករណ៍អន្តរជាតិមិនមានចែងអំពីនិយមន័យច្បាស់លាស់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬបទដ្ឋានគំរូនៃការការពារសំដៅបង្ការអំពើប្រភេទនេះនោះឡើយ ហើយអវត្តមាននៃការយល់ព្រមពីប្តីប្រពន្ធក្នុងការរៀបពាហ៍ពិពាហ៍នៅកម្ពុជា មានភាពស្របច្បាប់ នៅសម័យអង្គហេតុ។ តាមពិត អង្គជំនុំជម្រះបានរំលោភលើគោលការណ៍ភាពអាចយល់ដឹង និងប្រមើលមើលបានរបស់ ខៀវ សំផន[2089]។ ចំពោះភាពមិនគ្រប់គ្រាន់ជាក់ស្តែងនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានប្រព្រឹត្តឡើងនៅទូទាំងប្រទេស”[2090] បានទេ។ ក្នុងករណីលើកលែងដែលអង្គជំនុំជម្រះចង់កំណត់អង្គហេតុដែលបានចោទប្រកាន់ជាប្រតិសកម្ម ការពិនិត្យធាតុផ្សំមិនអាចឱ្យបង្ហាញអំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ចំពោះ ខៀវ សំផន បានឡើយ។

## ២. កំហុសក្នុងការពិនិត្យលើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

[2087] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវបានកោសលុប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **D301/5** កថាខណ្ឌ ៦៣។

[2088] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលត្រូវបានកោសលុប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **D301/5** កថាខណ្ឌ ៦៤ យោងទៅអត្ថបទរបស់ Tehri JYRKKIÖ អំពើអមនុស្សធម៌ផ្សេងៗទៀត ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ Helsinki Law Review ឆ្នាំ២០១១ ទំព័រ ២០៤ (កំណត់សម្គាល់ជើងទំព័រលេខ១០៧)។

[2089] សំអាងហេតុសាលក្រម ៣៦៨៦-៣៦៩៤។

[2090] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៤។

១១១៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ពាក់ព័ន្ធនឹងការពិនិត្យលើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត។ អង្គជំនុំជម្រះបានផ្តល់ការបកស្រាយខុសលើការពិនិត្យល័ក្ខខ័ណ្ឌតម្រូវនៃលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សធម៌ផ្សេងទៀតដូចបានរៀបរាប់ (២.១) ការឈឺចាប់ដែលបានទទួលរង (២.២) និងចេតនា (២.៣)។

## ២.១. កំហុសក្នុងការពិនិត្យលក្ខណៈវិនិច្ឆ័យនៃប្រភេទ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សធម៌ផ្សេងទៀតដូចបានរៀបរាប់

១១១៨. ការវាយតម្លៃលើលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សធម៌ផ្សេងទៀត អាចឱ្យកំណត់ធាតុផ្សំសត្យានុម័តិនៃអំពើអមនុស្សធម៌ផ្សេងទៀត។ ថ្វីត្បិតតែអង្គជំនុំជម្រះបានទទួលស្គាល់ថា ល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការជួយដល់ការពិនិត្យធាតុផ្សំនេះក៏ដោយ ក៏ការវិភាគមានចន្លោះប្រហោងរបស់អង្គជំនុំជម្រះបាននាំឱ្យប្រព្រឹត្តកំហុសជាច្រើន ខណៈដែលការរៀបពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ នៅមុនពេលកើតហេតុ (២.១.១) ឬក្រោយពេលកើតហេតុ (២.១.២) ឬនៅសម័យអង្គហេតុ (២.១.៣)។ អង្គជំនុំជម្រះបានព្យាយាមប៉ះប៉ូវកំហុសទាំងនេះ ដោយធ្វើការបែងចែកសិប្បនិម្មិត រវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

### ២.១.១. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសទេ នៅមុនពេលកើតហេតុ

នៅមុនពេលកើតហេតុ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ទាំងនៅក្នុងច្បាប់ជាតិ (២.១.១.១) និងក្នុងលិខិតុបករណ៍អន្តរជាតិ (២.១.១.២)។

#### *២.១.១.១. គ្មានការហាមឃាត់ នៅក្នុងច្បាប់ជាតិ*

១១១៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការវិភាគច្បាប់ មុនរបបកម្ពុជាប្រជាធិបតេយ្យ។ ជាដំបូង អង្គជំនុំជម្រះបានយល់ឃើញថា៖ "ការរៀបការតាមការផ្សំផ្គុំនៅក្នុងវប្បធម៌កម្ពុជា នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ផ្អែកលើជំនឿទុកចិត្តគ្នាទៅវិញទៅមករវាងឪពុកម្ដាយ និងកូន (...)"[2091]។

១១២០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានទទួលយកថា នីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ស្ថិតនៅត្រង់ "ជំនឿទុកចិត្តគ្នាទៅវិញទៅមករវាងឪពុកម្ដាយ និងកូន"។ អង្គជំនុំជម្រះមិនបានផ្ដល់ការកំណត់ប្រភេទបទល្មើសដល់ការរៀបរាប់តាមបែបសង្គម-នរសាស្ត្រនេះទេ។ គំនិតនេះត្រូវបានដកស្រង់ចេញសក្ខីកម្មរបស់ Kasumi NAKAGAWA[2092]។ អ្នកជំនាញបានធ្វើការសិក្សាអំពីការរៀបអាពាហ៍ពិពាហ៍ នៅកម្ពុជា។ ការសិក្សាទាំងនេះត្រូវបានធ្វើឡើងតាមបែបសង្គមសាស្ត្រ។ ពេលអ្នកជំនាញផ្ដល់សក្ខីកម្មនៅក្នុងសវនាការ ដោយបានផ្ដល់ព័ត៌មានជូនអង្គជំនុំជម្រះ ដូចជា សញ្ញាណនៃ "ជំនឿទុកចិត្តគ្នាទៅវិញទៅមក" ចៅក្រមជាអ្នកកំណត់ប្រភេទនៃព័ត៌មាននេះតាមផ្លូវច្បាប់ តាមពេលក្រោយ។ អង្គជំនុំជម្រះមានកាតព្វកិច្ចផ្ដល់សំអាងហេតុ ដែលត្រូវឈានទៅដល់ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ។ ប៉ុន្តែ មិនអីចឹងទេ អង្គជំនុំជម្រះបែរជាបណ្ដែតបណ្ដោយខ្លួនតាមការវិនិច្ឆ័យតាមចិត្តឯង ដោយព្យាយាមផ្ដល់ធម្មានុរូបដល់អវត្តមាននៃការយល់ព្រមពីប្ដីប្រពន្ធ មុនរបបកម្ពុជាប្រជាធិបតេយ្យ។ វិចារណកិច្ចបែបនេះមិនមាននៅក្នុងសាលក្រមព្រហ្មទណ្ឌឡើយ។

១១២១. ដោយសារតែការរៀបអាពាហ៍ពិពាហ៍គឺជាកិច្ចសន្យារដ្ឋប្បវេណី ដែលសព្វថ្ងៃ ត្រូវបានទទួលស្គាល់ថាជាជំនួបនៃឆន្ទៈ គេត្រូវចោទសួរអំពីបញ្ហាច្បាប់ដូចតទៅ៖ តើការយល់ព្រមពីប្ដីប្រពន្ធមានភាពចាំបាច់ដើម្បីផ្ដល់សុពលភាពដល់ការរៀបអាពាហ៍ពិពាហ៍ដែរឬទេ មុនរបបកម្ពុជាប្រជាធិបតេយ្យ? ចម្លើយ គឺមិនចាំបាច់ទេ[2093]។ តាមផ្លូវច្បាប់ ការយល់ព្រមចាំបាច់ដល់ការផ្ដល់សុពលភាពដល់កិច្ចសន្យាអាពាហ៍ពិពាហ៍ គឺការយល់ព្រមពីឪពុកម្ដាយ។

---

2091 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

2092 Kasumi NAKAGAWA៖ ឯកសារ **E1/473.1** ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ៩-១០ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ១២៣០២ នៃសំអាងហេតុសាលក្រម។

2093 សូមមើលខាងលើ កថាខណ្ឌ ១១១៣-១១៤, ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០ (ឧបសម្ព័ន្ធ)។

១១២២. ដូច្នេះ ដោយក្លែងបន្លំកុំឱ្យគេមើលឃើញអវត្តមាននៃការយល់ព្រមពីប្ដីប្រពន្ធ តាមរយៈគំនិតអរូបីនៃ "ជំនឿទុកចិត្តគ្នាទៅវិញទៅមក" អង្គជំនុំជម្រះមិនបានទាញសេចក្តីសន្និដ្ឋានគតិយុត្តិណាមួយទេ។ តាមផ្លូវច្បាប់ "ជំនឿទុកចិត្តគ្នា" នេះ មានន័យបង្កប់ថា គ្មានការព្រមព្រៀង ហើយដូច្នេះ មានន័យបង្កប់ថា មាន**<u>ការបង្ខិតបង្ខំ</u>**។ វាក្យស័ព្ទច្បាប់របស់ Gérard CORNU បានផ្ដល់និយមន័យជាច្រើនដល់ពាក្យ បង្ខិតបង្ខំ៖ "១. ត្រូវតែ (យោងតាមច្បាប់) ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ - ប្រើប្រាស់ក្នុងន័យនេះ មុនការអនុវត្តជាក់ស្ដែងនូវការបង្ខិតបង្ខំ" "អំណាចនៃការបង្ខិតបង្ខំស្ថិតនៅលើអាជ្ញាធររដ្ឋ (<u>ដែលចូលក្នុងនិយមន័យនៃវិធានច្បាប់</u>) និងអ្នកដែលត្រូវបានទទួលស្គាល់ថាមានសិទ្ធិ ដើម្បីធ្វើឱ្យគេគោរពសិទ្ធិនេះ"[2094]។

១១២៣. ដូច្នេះ ការបង្ខិតបង្ខំអាចស្របច្បាប់ ពីព្រោះបង្កើតឡើងដោយច្បាប់ និងចេញមកពីរដ្ឋ។ នេះគឺជាករណីតាមអំណាចនៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ តាមរយៈការប្រគល់ការយល់ព្រមក្នុងការផ្ដល់សុពលភាពលើការរៀបអាពាហ៍ពិពាហ៍ ទៅឱ្យឪពុកម្ដាយ មិនឱ្យទៅប្ដីប្រពន្ធ មានការបង្ខិតបង្ខំទ្វេដង។ មួយតាមផ្លូវច្បាប់ និងមួយទៀតតាមផ្លូវសីលធម៌។ ជាក់ស្ដែង ក្នុងក្របខ័ណ្ឌនៃសង្គមកម្ពុជានៅសម័យនោះ គឺសង្គមសមូហភាពជុំវិញគ្រួសារ វាហាក់ដូចលំបាកក្នុងការជឿថា ប្ដីប្រពន្ធអាចមានសេរីភាពក្នុងការប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍ដែលបានស្នើឡើង។ ការនិយាយតែម្តងគត់ដល់ការបង្ខិតបង្ខិត គឺ៖ "ជាទូទៅ ការរៀបការតាមការផ្សំផ្គុំមិនមានសមាសធាតុនៃការបង្ខំឡើយ"[2095]។ គ្មានកំណត់សម្គាល់ជើងទំព័រណាមួយគាំទ្រដល់ការអះអាងនេះ ដែលអាចឱ្យអង្គជំនុំជម្រះច្រានចោលសញ្ញាណនៃការបង្ខិតបង្ខំ ក្នុងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ ដូច្នេះ តាមរយៈការប្រើប្រាស់ពាក្យ "ជាទូទៅ" អង្គជំនុំជម្រះបានបង្កើតការសន្និដ្ឋានដ៏សំខាន់មួយ អំពីការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ និងភាពទូទៅដោយគ្មានមូលដ្ឋាន។ តាំងពីដើមដំបូងនៃការវិភាគ

[2094] និយមន័យវាក្យស័ព្ទច្បាប់ Gérard CORNU, PUF ឆ្នាំ២០០៣ ទំព័រ ២២២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរនិយមន័យផ្សេងទៀត៖ "៣. ជនរងគ្រោះនៃការប្រើកម្លាំង ឬហិង្សា", "៤. (ព្រហ្មទណ្ឌ) សម្ពាធខាងក្រៅដែលបញ្ជាក់ហេតុផលអ្នកដែលធ្វើសកម្មភាពក្រោមឥទ្ធិពលនៃកម្លាំង (ហិង្សាមនុស្ស ប្រធានស័ក្តិ) ដោយមិនអាចទប់ទល់បាន" ទំព័រ ២២២-២២៣, វចនានុក្រម Black's Law៖ ការកំហិត ការបង្ខំ ការបង្ខំដោយកម្លាំង ឬអាវុធ។

[2095] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៩។

នេះ អង្គជំនុំជម្រះមានកាតព្វកិច្ចកំណត់និយមន័យនៃការបង្ខិតបង្ខំតាមផ្លូវច្បាប់ ដើម្បីឱ្យយល់បរិបទនៃបទល្មើសដែលបានចោទប្រកាន់[2096]។ អង្គជំនុំជម្រះបានផ្តល់យុត្តិកម្មដល់អវត្តមាននៃសេចក្តីសន្និដ្ឋាននេះដូចតទៅ៖

"ចុងក្រោយ សម្ពាធសង្គមមានឥទ្ធិពលកម្រិតណា និងញឹកញាប់ប៉ុណ្ណា នៅក្នុងការរៀបការបែបប្រពៃណី ទៅលើលទ្ធភាពក្នុងការយល់ព្រមដោយសេរីនោះ គឺមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះឡើយ"[2097]។

១១២៤. ក្នុងការនិយាយថាបរិបទនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ពោលគឺតាមការផ្សំផ្គុំ គឺមិនពាក់ព័ន្ធនឹងអង្គហេតុដែលបានចោទប្រកាន់ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់។ កំហុសនេះកើតចេញពីគោលជំហរអត្តនោម័តិរបស់អង្គជំនុំជម្រះ ដែលនាំឱ្យធ្វើវិចារណកិច្ចដោយលម្អៀង។ ជាដំបូង អង្គជំនុំជម្រះមិនព្រមកំណត់ប្រភេទបទល្មើសនៃការបង្ខិតបង្ខំ ក្នុងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ដោយលាក់ខ្លួននៅពីក្រោយភាពសាមញ្ញដោយគ្មានមូលដ្ឋាន។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានច្រានចោលបរិបទទាំងស្រុង ដែលអាចឱ្យយល់អំពីលក្ខណៈពិសេសខាងវប្បធម៌នៃបទល្មើសដែលបានចោទប្រកាន់។

១១២៥. ដូច្នេះ វិចារណកិច្ចនេះមានលក្ខណៈផ្ទុយនឹងខ្លួនឯងទាំងស្រុង៖ អង្គជំនុំជម្រះបាននិយាយយ៉ាងវែងអំពីជំនឿទុកចិត្តគ្នាទៅវិញទៅមករវាងឪពុកម្តាយ និងកូន និងការប្រព្រឹត្តិទៅនៃពិធីតាមប្រពៃណី។ ដូច្នេះតាមពិត អង្គជំនុំជម្រះចាប់អារម្មណ៍លើបរិបទមួយផ្នែក។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានសម្រេចបដិសេធតាមទំនើងចិត្តនូវបរិបទមួយផ្នែកទៀត នៅពេលផ្នែកនេះពាក់ព័ន្ធនឹងលទ្ធភាពរបស់ប្តីប្រពន្ធ

[2096] ឧទាហរណ៍នៃនិយមន័យនៃការបង្ខិតបង្ខំក្នុងយុត្តិសាស្ត្រ៖ សាលក្រម *RUF* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ១៤៧១ សាលក្រម *AFRC* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ ៦៩៤ សាលដីកា *Kunarac និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ ១២៩ វចនានុក្រម Black's Law៖ ការកំហិត ការបង្ខំ ការបង្ខំដោយកម្លាំង ឬអាវុធ។

[2097] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៨។

ក្នុងការយល់ព្រមរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែ នេះគឺជាធាតុផ្សំដ៏សំខាន់សម្រាប់ការពិភាក្សាអំពីការកំណត់ប្រភេទបទល្មើស។ ដូច្នេះ អង្គជំនុំជម្រះបានបដិសេធធាតុផ្សំភ័ស្តុតាងដោះបន្ទុកជនជាប់ចោទ។

១១២៦. ការអះអាងមិនត្រឹមត្រូវនេះ ក៏ផ្ទុយផងដែរនឹងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ពាក់ព័ន្ធនឹងកម្រិតនៃភាពធ្ងន់ធ្ងរក្នុងការកំណត់អំពើអមនុស្សធម៌ផ្សេងទៀត ហើយដើម្បីវាយតម្លៃភាពធ្ងន់ធ្ងរនៃអំពើមួយ គេត្រូវពិចារណាលើបរិបទនៃការប្រព្រឹត្តអំពើនោះ[2098]។ ដូច្នេះ អង្គជំនុំជម្រះត្រូវពិចារណាលើបរិបទច្បាប់ និងវប្បធម៌ទាំងស្រុង នៃការរៀបអាពាហ៍ពិពាហ៍ មុនរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារតែលក្ខណៈពិសេសខាងវប្បធម៌ បទល្មើសនៃរឿងក្តីចោទឡើងនូវការលំបាកជាច្រើន ទាំងនៅក្រៅតុលាការផងដែរ។ អត្ថបទជាច្រើននៃលទ្ធិ ក៏ដូចជារឿងក្តីមុនៗ បានចោទឡើងនូវភាពស្មុគស្មាញ និងការលំបាកនៃការកំណត់សញ្ញាណថ្មីនេះ។ ដូច្នេះ បរិបទពីមុន បើពិនិត្យមើលទាំងមូល មានប្រយោជន៍ និងចាំបាច់ ដើម្បីឱ្យយល់ពីអង្គហេតុដែលបានចោទប្រកាន់។

១១២៧. ជាថ្មីម្តងទៀត វិចារណកិច្ចនេះអាចពន្យល់បានតែតាមរយៈឆន្ទៈពង្វាងបញ្ហាផ្លូវច្បាប់ ដែលទំនងជាអាចឱ្យបដិសេធការចោទប្រកាន់នេះ។ ក្នុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អ្នកជំនាញ Kasumi NAKAGAWA បានផ្តល់សេចក្តីចង្អុលបង្ហាញអំពីបរិបទសង្គម មុនរបបកម្ពុជាប្រជាធិបតេយ្យ៖

> "យោងតាមការសម្ភាសន៍របស់ខ្ញុំជាមួយមនុស្សជាច្រើននោះ ខ្ញុំបានសួរមនុស្សទាំងនោះនៅពេលដែលពួកគាត់នៅជាកុមារ មុនពេលរបបខ្មែរក្រហម ហើយខ្ញុំសួរថាតើជីវភាពគ្រួសារពួក

---

[2098] សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧៣៥, សាលក្រម *Krnojelac* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ១៣១, សាលក្រម *Simić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣, សាលក្រម *Vasiljević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២, សាលក្រម *Galić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ១៥៣, ២៣៥, សាលក្រម *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ១០១៣, សាលក្រម *Martić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ ៨៤។

គាត់យ៉ាងម៉េចដែរ ហើយជាពិសេសនោះ ខ្ញុំសួរថាតើឪពុកម្តាយរបស់ពួកគាត់វាយដំពួកគាត់ទេ តើគ្រូវាយដំដែរឬទេនៅសាលា? ពួកគាត់ឆ្លើយថា ឪពុក ឬម្តាយគាត់បានវ៉ៃគាត់ នៅពេលគាត់ធ្វើឱ្យបាត់គោ ក្របី ឪពុកខ្ញុំវាយខ្ញុំនៅពេលខ្ញុំមកផ្ទះយឺតពេល ហើយនៅសាលារៀនក្តី នៅពេលដែលសិស្សធ្វើខុស គ្រូវបានវាយដំផងដែរ។ អ៊ីចឹង គឺថា ការវាយដំរបស់ឪពុកម្តាយរបស់គ្រូនោះ គឺថាមិនមែនជាទម្រង់នៃទារុណកម្មធ្វើឱ្យឈឺចាប់ទេ គឺជាផ្នែកនៃឱវាទសម្រាប់កូនប្រុសកូនស្រី ឬក៏កូនសិស្ស ដើម្បីឱ្យពួកគេមានអនាគតល្អ មានការអប់រំល្អ គឺការវាយបែបនោះ គឺជាការស្រឡាញ់ទេ ជាការប្រដៅទេ”[2099]។

១១២៨. ភាពហិង្សាមានភាពគ្របដណ្តប់លើសលុប មុនរបបកម្ពុជាប្រជាធិបតេយ្យ។ គេអាចកំណត់ការបង្ខិតបង្ខំថាជាអំពើហិង្សា ឬសម្ពាធលើបុគ្គលម្នាក់ ដើម្បីតម្រូវឱ្យបុគ្គលនោះធ្វើអ្វីមួយ ឬរារាំងមិនឱ្យបុគ្គលនោះធ្វើអ្វីមួយតាមចិត្តចង់។ ការបង្ខិតបង្ខំអាចធ្វើឡើងលើផ្លូវកាយ ឬផ្លូវចិត្ត។ មុនរបបកម្ពុជាប្រជាធិបតេយ្យ សម្ពាធសង្គម ដែលសម្គាល់ដោយហិង្សាផ្លូវកាយ ឬផ្លូវចិត្ត អាចឱ្យដាក់ការបង្ខិតបង្ខំលើប្តីប្រពន្ធ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍។ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ការចាត់ចែងលើការរៀបអាពាហ៍ពិពាហ៍ត្រូវបានគ្រប់គ្រងដោយក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលមិនតម្រូវឱ្យមានការយល់ព្រមពីប្តីប្រពន្ធទេ។ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តម្រូវឱ្យមានការយល់ព្រមតែពីឪពុកម្តាយប៉ុណ្ណោះ ដែលជាអ្នកជ្រើសរើសគូស្រករឱ្យកូនរបស់ខ្លួន[2100]។

១១២៩. អ្នកជំនាញ Kasumi NAKAGAWA បានផ្តល់សេចក្តីបញ្ជាក់អំពីតួនាទីលើសលុបរបស់ឪពុកម្តាយមុនរបបកម្ពុជាប្រជាធិបតេយ្យ៖

“តាមប្រពៃណី សង្គមកម្ពុជាត្រូវបានរៀបចំដោយឪពុកម្តាយ ដើម្បីរៀបការកូន ឬក៏មានការយល់ព្រមពីឪពុកម្តាយដើម្បីឱ្យរៀបការកូនបាន ចំពោះការធ្វើសេចក្តីសម្រេចរបស់នារីវិញ

[2099] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ទំព័រ ៩ ម៉ោង 09.33.14 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2100] សូមមើលខាងលើ អវត្តមានតំណភ្ជាប់រវាងសិទ្ធិ និងបម្រាមដែលមានចែងនៅក្នុងអត្ថបទច្បាប់ដែលអនុវត្តនៅសម័យកើតហេតុ កថាខណ្ឌ ១១០៨-១១១៤។

កូនស្រីវិញ គឺមិនមានការសម្រេចទេ ពីព្រោះថាឪពុកម្ដាយខាងកូនស្រីជាអ្នកណែនាំកូនស្រីឱ្យរៀបការ ហើយកូនស្រីរង់ចាំឱ្យឪពុកម្ដាយធ្វើសេចក្ដីសម្រេចជំនួសនាង។ (...) តាមប្រពៃណីក្នុងវប្បធម៌កម្ពុជា ក៏ដូចជាវប្បធម៌របស់ជាតិមួយចំនួនដែរ គឺថាកូនប្រុសកូនស្រីមិនយល់ដឹងដូចមនុស្សដែលមានអំណាចទាំងស្រុងទេ។ [កូន] គេចាត់ទុកថាជាទ្រព្យសម្បត្តិ តែជាទ្រព្យសម្បត្តិរបស់ឪពុកម្ដាយ។ ដូច្នេះ ឪពុកម្ដាយគិតថា ពួកគេត្រូវតែធ្វើសេចក្ដីសម្រេចលើកូនៗរបស់ខ្លួនទាក់ទងទៅនឹងការអប់រំ ហើយនិងសិទ្ធិទៅលើការរៀបការកូនចៅនោះផងដែរ”[2101]។

១១៣០. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើន ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋានអំពីការរៀបអាពាហ៍ពិពាហ៍ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ជាអាទិ៍ ដោយមិនបានផ្ដល់សំអាងហេតុ មិនកំណត់ប្រភេទបទល្មើសនៃអង្គហេតុ និងច្រានចោលភស្តុតាងដោះបន្ទុក ខៀវ សំផន ក្នុងលក្ខណៈលម្អៀង។

### *២.១.១.២. គ្មានកិច្ចការពារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងលិខិតុបករណ៍អន្តរជាតិ*

១១៣១. នៅមុនពេលកើតហេតុ មិនមានការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ច្បាប់សង្គ្រាមមិនចែងអំពីការចោទប្រកាន់ ឬអំពើប្រហាក់ប្រហែលនេះទេ។ ដូចគ្នាផងដែរ ដូចបានលើកឡើងរួចមកហើយ អនុសញ្ញាអន្តរជាតិមិនទាន់លើកតម្កើងការរៀបអាពាហ៍ពិពាហ៍ និងការយល់ព្រមដោយសេរីពីប្ដីប្រពន្ធ ជាសិទ្ធិជាមូលដ្ឋានទេ[2102]។

## ២.១.២. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងឋានៈជាបទល្មើស នៅតែមិនមានភាពច្បាស់លាស់ ក្រោយពេលកើតហេតុ

---

[2101] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** ទំព័រ ២៨ ចន្លោះពីម៉ោង 10.41.20 ដល់ម៉ោង 10.43.20 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2102] សូមមើលខាងលើ ការវិភាគខុសលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ កថាខណ្ឌ ១០៩៩-១១០៧។

១១៣២. វិចារណកិច្ចទន់ខ្សោយរបស់អង្គជំនុំជម្រះត្រូវបានពន្យល់ តាមរយៈការដែលថាសូម្បីតែសព្វថ្ងៃនេះ ការផ្តន្ទាទោសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតែមានភាពស្មុគស្មាញ។ នៅកម្រិតកម្ពុជា និងអាស៊ាន ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសព្រហ្មទណ្ឌជាក់ស្តែងទេ (២.១.២.១) នៅកម្រិតអន្តរជាតិ នៅក្នុងច្បាប់ជាតិ ក៏ដូចគ្នាផងដែរ (២.១.២.២)។

### *២.១.២.១. ការផ្តន្ទាទោសលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតែមិនមានភាពច្បាស់លាស់ នៅកម្រិតកម្ពុជា និងតំបន់*

១១៣៣. នៅកម្រិតអាស៊ាន ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតែជាទម្លាប់ខាងវប្បធម៌ នៅប្រទេសជាច្រើន។ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩ អាស៊ានបានរៀបចំសន្និសីទមួយអំពាវនាវឱ្យបញ្ឈប់ការរៀបការកូនមុនអាយុកំណត់ ឬដោយបង្ខំ[2103]។ នៅកម្ពុជា ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ/ដោយបង្ខំនៅតែអនុវត្តនៅឡើយ ជាពិសេស នៅតាមជនបទ។ បើតាមអង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស) ក្នុងរបាយការណ៍ឆ្នាំ២០០៧៖

> "អាពាហ៍ពិពាហ៍នៅកម្ពុជា គឺជាអាពាហ៍ពិពាហ៍មួយដែលហ៊ុំព័ទ្ធដោយបញ្ហាសង្គម និងវប្បធម៌ ជាច្រើនជាន់ ហើយកើតមានពាសពេញនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ។ ស្ត្រីកម្ពុជាច្រើននាក់តែងចាត់ទុកខ្លួនថាជាមនុស្សទន់ខ្សោយជាងប្តីរបស់ខ្លួន ហើយកត្តានេះបានបង្កើតឱ្យមានបញ្ហាជាច្រើនដល់ស្ត្រី ជាពិសេស ស្ត្រីដែលរងការរំលោភបំពាន ឬស្ត្រីដែលចង់លះលែងប្តី។ តាមប្រពៃណី ស្ត្រីជាច្រើននៅកម្ពុជាត្រូវបានជំរុញឱ្យរៀបអាពាហ៍ពិពាហ៍តាំងពីវ័យក្មេង ឬជួនកាល មានការគាបសង្កត់ពីសំណាក់ក្រុមគ្រួសារឱ្យរៀបអាពាហ៍ពិពាហ៍។ ការទុកដាក់ឱ្យមានប្តីដោយឪពុកម្តាយជាធម្មតា ឪពុកម្តាយ ឬសមាជិកគ្រួសារណាម្នាក់ជាអ្នករៀបចំទុកដាក់កូនចៅ បញ្ហានេះនៅតែកើតមានដដែលៗ ជាពិសេស នៅតាមតំបន់ជនបទ នៅពេលដែល

---

[2103] អត្ថបទសារព័ត៌មាននៅលើវែបសាយរបស់អាស៊ាន "អាស៊ានអំពាវនាវឱ្យបញ្ឈប់ការរៀបការកុមារវ័យក្មេង និងដោយបង្ខំ សន្និសីទថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ដោយសហការជាដៃគូជាមួយ UNICEF និង UNFPA។ អាចរកបាននៅអាសយដ្ឋានខាងក្រោម៖ https://asean.org/asean-calls-ending-child-early-forced-marriage/។

ស្វាមី-ភរិយារៀបការរួចហើយ ជារឿយៗ តែងតែមានការគាបសង្កត់យ៉ាងខ្លាំងទៅលើគូស្វាមី-ភរិយាទាំងពីរកុំឱ្យលះលែងគ្នា”[2104]។

១១៣៤. ដូចគ្នាផងដែរ របាយការណ៍ក្រសួង ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ប្រកាសអាសន្នអំពីស្ថានភាពនេះ៖

“អាពាហ៍ពិពាហ៍ដោយបង្ខំនៅតែកើតមាន ហើយនៅពេលដែលបានរៀបការជាប្តីប្រពន្ធ មានការដាក់សម្ពាធយ៉ាងខ្លាំងលើពួកគេឱ្យរក្សាឱ្យបាននូវចំណងអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក៏ដោយ ក៏អាកប្បកិរិយាចំពោះអាពាហ៍ពិពាហ៍មានការផ្លាស់ប្តូរ ហើយភាគរយនៃស្ត្រីដែលគ្រួសាររបស់ខ្លួនបានរៀបចំអាពាហ៍ពិពាហ៍ មានការធ្លាក់ចុះ ពី ៥១% ក្នុងឆ្នាំ២០០០ ទៅ ៣៥% ក្នុងឆ្នាំ២០០៥។ ទម្លាប់នៃការរៀបអាពាហ៍ពិពាហ៍វ័យក្មេងនៅតែកើតមាន ហើយឪពុកម្តាយមួយចំនួនបានដាក់សម្ពាធលើកូនស្រីឱ្យរៀបការជាមួយបុរសដែលគាត់បានជ្រើសរើស តាំងពីនាងនៅក្មេង”[2105]។

១១៣៥. ក្រមព្រហ្មទណ្ឌកម្ពុជាមិនបានដាក់បញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាបទល្មើសទេ។ ការសិក្សាថ្មីៗនេះអំពីអាស៊ាន និងកម្ពុជា អាចឱ្យត្រឡប់មកនិយាយម្តងទៀតអំពីការបែងចែករវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងដោយបង្ខំ។ នៅក្នុងការសិក្សា ឬរបាយការណ៍ទាំងនេះ ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំមិនស្របច្បាប់ទេ ដូចអង្គជំនុំជម្រះបានព្យាយាមពន្យល់ នៅក្នុងសំអាងហេតុសាលក្រម។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ពីព្រោះសញ្ញាណទាំងនេះសំដៅដល់ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដែលគ្រួសាររើសគូស្រករដោយគ្មានការយល់ព្រមពីសាមីខ្លួន។ អ្នកជំនាញ Kasumi NAKAGAWA ក៏បានលើកឡើងផងដែរ អំពីការបង្ខិតបង្ខំ ក្នុងការរៀបអាពាហ៍ពិពាហ៍សម័យបច្ចុប្បន្ន នៅកម្ពុជា ដោយធ្វើការបែងចែក រវាងការរៀបអាពាហ៍ពិពាហ៍នៅទីក្រុង និងការរៀបអាពាហ៍ពិពាហ៍នៅទីជនបទ៖

---

[2104] របាយការណ៍របស់អង្គការលីកាដូ “ហិង្សាលើស្ត្រី៖ តើច្បាប់កម្ពុជារើសអើងនឹងស្ត្រីយ៉ាងដូចម្តេច?” ឆ្នាំ២០០៧ ទំព័រ ១៣-១៤។

[2105] របាយការណ៍រាជរដ្ឋាភិបាល ក្រសួងកិច្ចការនារីនៃប្រទេសកម្ពុជា សង្ខេបគោលនយោបាយទី ២ *Gender relations and attitudes Cambodia Gender assessment* ឆ្នាំ២០១៤ អាចរកមើលបាននៅលើអាសយដ្ឋានខាងក្រោម៖ https://www.kh.undp.org/content/dam/cambodia/docs/DemoGov/NearyRattanak4/Neary%20Rattanak%204%20-%20PB%20Gender%20Relations%20and%20Attitudes%20Eng.pdf។

"អ្នកក្រុង គឺថាពាក់កណ្តាល យ៉ាងហោចណាស់ ក៏គេជំទាស់តវ៉ាជាមួយឪពុកម្តាយរបស់គេដែរ ពាក់ព័ន្ធទៅនឹងការរៀបការនេះ។ សិស្សរបស់ខ្ញុំ គឺថានៅតែត្រូវបានឪពុកម្តាយបង្ខំឱ្យរៀបការ ដែលគាត់មិនចង់។ ប៉ុន្តែ នៅជនបទវិញ ខ្ញុំថា ៩០ ភាគរយ ហើយនៃស្ត្រីក្មេងៗ គឺថានៅតែរង់ចាំការផ្គូផ្គងគូស្រករពីឪពុកម្តាយរបស់គេ ឬក៏ថាមិនហ៊ានបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួនតវ៉ាទៅជាមួយឪពុកម្តាយ ឬក៏មិនហ៊ានប្រាប់ទៅឪពុកម្តាយ ថាខ្លួនហ្នឹងមានសង្សារអីនោះទេ"[2106]។

១១៣៦. ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងតាមការផ្សំផ្គុំ មិនអាចត្រូវបានប្រើប្រាស់ ដើម្បីរៀបរាប់អំពីស្ថានភាពតែមួយនោះឡើយ។ ការហៅអាពាហ៍ពិពាហ៍ "តាមការផ្សំផ្គុំ" បានវិវត្តទៅជាអាពាហ៍ពិពាហ៍ "ដោយបង្ខំ" តាមរយៈការវិវត្តនៃសិទ្ធិជាមូលដ្ឋាន។ ការយល់ព្រមទៅវិញទៅមករវាងប្តីប្រពន្ធ គឺជាសញ្ញាណថ្មីលេចឡើង ក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា តាមរយៈរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣[2107] និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩[2108]។ ចាប់តាំងពីពេលចេញច្បាប់នេះមក ការយល់ព្រមទៅវិញទៅមករវាងប្តីប្រពន្ធបានក្លាយជាល័ក្ខខ័ណ្ឌចាំបាច់ ដើម្បីឱ្យការរៀបអាពាហ៍ពិពាហ៍មានសុពលភាព។ ជារួម ពីឆ្នាំ១៩២០ ដល់ឆ្នាំ១៩៨៩ ការយល់ព្រមពីប្តីប្រពន្ធមិនមែនជាល័ក្ខខ័ណ្ឌ ដើម្បីឱ្យការរៀបអាពាហ៍ពិពាហ៍មានសុពលភាពទេ ពីព្រោះឪពុកម្តាយជាអ្នកយល់ព្រមជំនួសកូន។

### *២.១.២.២. ការផ្តន្ទាទោសលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតែមានភាពមិនច្បាស់លាស់ នៅកម្រិតអន្តរជាតិ និងក្នុងច្បាប់ជាតិ*

---

[2106] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ទំព័រ ៤៣ ក្រោយម៉ោង 13.36.17។

[2107] រដ្ឋធម្មនុញ្ញកម្ពុជា ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា ៤៥(៣)៖ "អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ"។

[2108] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។ អាចរកមើលបាននៅលើគេហទំព័រ៖ https://www.refworld.org/docid/3ae6b55c0.html។

១១៣៧. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការផ្តន្ទាទោសថ្មីដកស្រង់ចេញពីច្បាប់រដ្ឋប្បវេណី ដែលមិនមានអត្ថិភាពទេ នៅពេលកើតអង្គហេតុដែលបានចោទប្រកាន់[2109]។ ការពិនិត្យមួយត្រួសលើក្រមព្រហ្មទណ្ឌអាចឱ្យយល់អំពីភាពទាន់សម័យនៃបទល្មើសនេះ និងជាការបន្ថែម ក្រោយការកែប្រែច្បាប់ថ្មីៗនេះ៖ អាល្លឺម៉ង់ នៅឆ្នាំ២០០៥[2110] ន័រវេស នៅឆ្នាំ២០០៧[2111] ប៊ែលហ្ស៊ិក នៅឆ្នាំ២០០៥ និងនៅឆ្នាំ២០១៣[2112] បេណាំង នៅឆ្នាំ២០១២[2113] ស្វ៊ីស នៅឆ្នាំ២០១២[2114]។ បារាំងបានដាក់បញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាបទល្មើស តាមរយៈច្បាប់ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ ប៉ុន្តែ តែក្នុងករណីបុគ្គលម្នាក់ត្រូវគេបង្ខំឱ្យរៀបការ នៅបរទេសប៉ុណ្ណោះ[2115]។

១១៣៨. រដ្ឋភាគច្រើនសុខចិត្តជ្រើសយកផ្លូវរដ្ឋប្បវេណី ដើម្បីដោះស្រាយរឿងអាពាហ៍ពិពាហ៍ដោយបង្ខំ។ ថ្វីត្បិតតែការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានចែងជាបទល្មើសព្រហ្មទណ្ឌ តាមបណ្តារដ្ឋនានាក៏ដោយ ក៏ច្បាប់ក្នុងស្រុកភាគច្រើនបានកំណត់ថា អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ ដរាបណាមិនមានការការយល់ព្រមដោយសេរីពីប្តីប្រពន្ធ។

---

[2109] សូមមើលខាងលើ កថាខណ្ឌ ១០៩៨-១១១៦។

[2110] ក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ច្បាប់ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៥ ផ្នែក ២៤០(៤) (ប្រភព៖ Sahra MEKBOUL ការរៀបការដោយបង្ខំ៖ ការឆ្លើយតបនៃច្បាប់ និងបញ្ហាប្រឈមគតិយុត្តិ មជ្ឈមណ្ឌលព័ត៌មាន និងសិក្សាលើទេសន្តរប្រវេសន៍អន្តរជាតិ ២០០៨/៥ លេខ ១១៩)។

[2111] ក្រមព្រហ្មទណ្ឌន័រវេស ច្បាប់ឆ្នាំ២០០៧ មាត្រា ២២២(២) (ប្រភព៖ Sahra MEKBOUL ការរៀបការដោយបង្ខំ៖ ការឆ្លើយតបនៃច្បាប់ និងបញ្ហាប្រឈមគតិយុត្តិ មណ្ឌលព័ត៌មាន និងសិក្សាលើទេសន្តរប្រវេសន៍អន្តរជាតិ ២០០៨/៥ លេខ ១១៩)។

[2112] ក្រមព្រហ្មទណ្ឌប៊ែលហ្ស៊ិក ច្បាប់ទី ១ ឆ្នាំ២០០៥ ក្រោយមក ច្បាប់ទី ២ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៣ មាត្រា ៣៩១ ស្ទួនប្រាំ (ប្រភព៖ Sahra MEKBOUL ការរៀបការដោយបង្ខំ៖ ការឆ្លើយតបនៃច្បាប់ និងបញ្ហាប្រឈមគតិយុត្តិ មជ្ឈមណ្ឌលព័ត៌មាន និងសិក្សាលើទេសន្តរប្រវេសន៍អន្តរជាតិ ២០០៨/៥ លេខ ១១៩)។

[2113] ក្រមព្រហ្មទណ្ឌបេណាំង ច្បាប់ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ (ប្រភព៖ Sahra MEKBOUL ការរៀបការដោយបង្ខំ៖ ការឆ្លើយតបនៃច្បាប់ និងបញ្ហាប្រឈមគតិយុត្តិ មជ្ឈមណ្ឌលព័ត៌មាន និងសិក្សាលើទេសន្តរប្រវេសន៍អន្តរជាតិ ២០០៨/៥ លេខ ១១៩)។

[2114] ក្រមព្រហ្មទណ្ឌស្វ៊ីស ច្បាប់ឆ្នាំ២០១២ មាត្រា ២១២ (អត្ថបទរបស់ Géraldine BROWN, Thierry DELESSERT និង Marta ROCA I ESCODA ពីករណីកិច្ចគ្រួសារទៅហិង្សាក្នុងគ្រួសារ។ ការសិក្សាលើវឌ្ឍនភាពនៃនីតិព្រហ្មទណ្ឌស្វ៊ីស extenso Droit et société ២០១៧/៣ លេខ ៩៧)។

[2115] ក្រមព្រហ្មទណ្ឌបារាំង ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ មាត្រា ២២២(១៤)(៤) (អាចរកមើលបាននៅលើវែបសាយ légifrance)។

១១៣៩. នៅកម្រិតអឺរ៉ុប មិនមានឯកសណ្ឋានកម្មទេ។ បញ្ហានេះវិវត្តទៅមុខយឺតៗ។ នៅឆ្នាំ២០០២ គណៈកម្មាធិការរដ្ឋមន្ត្រីនៃរដ្ឋសមាជិកក្រុមប្រឹក្សាអឺរ៉ុបបានអនុម័តអនុសាសន៍មួយស្តីពីការការពារស្ត្រីប្រឆាំងនឹងអំពើហិង្សា ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងចំណោមអំពើហិង្សា និងបានជំរុញរដ្ឋសមាជិកឱ្យចាត់វិធានការចាំបាច់ ដើម្បីហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ ដោយគ្មានការយល់ព្រមពីប្តីប្រពន្ធ[2116]។ នៅឆ្នាំ២០១៨ ក្រុមប្រឹក្សាអឺរ៉ុប និងសភាអឺរ៉ុបបានចាប់ផ្តើមពិភាក្សាអំពីលទ្ធភាពធ្វើឯកសណ្ឋានកម្មនៃការផ្តន្ទាទោស នៅទូទាំងរដ្ឋសមាជិក។ នៅក្នុងរបាយការណ៍ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ សភាអឺរ៉ុប *"យល់ឃើញថាចាំបាច់ឱ្យរដ្ឋសមាជិកបង្កើនកិច្ចខិតខំប្រឹងប្រែងបង្ការ និងទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបញ្ឈប់ហិង្សា និងការរំលោភសិទ្ធិ"*។ ក្នុងន័យនេះ សភាអឺរ៉ុបបានស្នើឱ្យរដ្ឋសមាជិក *"ដាក់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌនូវអំពើបង្ខំមនុស្សពេញវ័យ ឬកុមារឱ្យរៀបអាពាហ៍ពិពាហ៍"*[2117]។ ឆន្ទៈនេះគាំទ្រដល់ការបង្កើតអនុសញ្ញាក្រុមប្រឹក្សាអឺរ៉ុបស្តីពីការបង្ការ និងទប់ស្កាត់អំពើហិង្សាលើស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ ហៅថាអនុសញ្ញាទីក្រុងអ៊ីស្តង់ប៊ុល ដែលហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅមាត្រា ៣៧[2118]។ ភាពជោគជ័យនៃអនុសញ្ញានេះនៅមានកម្រិតនៅឡើយ ពីព្រោះមកទល់នឹងសព្វថ្ងៃនេះ ថ្វីត្បិតតែអនុសញ្ញានេះចូលជាធរមាន ក្នុងរដ្ឋ ៣៤ ក៏ដោយ ក៏រដ្ឋ ៦ មិនទាន់បានចុះហត្ថលេខា ឬឱ្យសច្ចាប័ន ហើយរដ្ឋ ១១ ទៀតបានចុះហត្ថលេខា ប៉ុន្តែ មិនបានឱ្យសច្ចាប័ន។

---

[2116] អនុសាសន៍របស់សហភាពអឺរ៉ុបអំពីការការពារស្ត្រីប្រឆាំងនឹងហិង្សា (Rec(2002)5) ឆ្នាំ២០០២។ អាចរកមើលបាននៅលើអាសយដ្ឋាន៖ https://www.coe.int/fr/web/genderequality/recommendation-rec-2002-5-and-other-tools-of-the-council-of-europe-concerning-violence-against-women។

[2117] របាយការណ៍របស់សភាក្រុមប្រឹក្សាអឺរ៉ុប ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅអឺរ៉ុប-របាយការណ៍គណៈកម្មការស្តីពីសមភាព និងការមិនរើសអើង ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ទំព័រ ៣។ អាចរកមើលបាននៅលើអាសយដ្ឋានខាងក្រោម៖ http://website-pace.net/documents/19879/4648056/20180605-ForcedMarriage-FR.pdf/3d81607a-2880-47c6-974e-4b062a2a2844។

[2118] អនុសញ្ញានៃក្រុមប្រឹក្សាអឺរ៉ុបស្តីពីការបង្ការ និងការតស៊ូប្រឆាំងនឹងហិង្សាលើស្ត្រី និងហិង្សាក្នុងគ្រួសារ ក្រុមប្រឹក្សាអឺរ៉ុប ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤។ មានការផ្តល់សច្ចាប័នចំនួន ១០ នៅថ្ងៃចូលជាធរមាន។

### ២.១.២.៣. ការផ្តន្ទាទោសលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតែមានភាពមិនច្បាស់លាស់ ដោយសារបញ្ហាវប្បធម៌

១១៤០. ការលំបាកក្នុងការផ្តន្ទាទោសការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនមានតែនៅ អ.វ.ត.ក ទេ។ វាចោទឡើងនូវបញ្ហាគតិយុត្តិស្មុគស្មាញជាច្រើន ចំពោះរដ្ឋជាច្រើនដែលចង់ដាក់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌ កាលពីពេលថ្មីៗនេះ។ មានការបែកចេញពីគ្នា រវាងការអនុវត្តខាងវប្បធម៌បុរាណ និងការវិវត្តនៃសិទ្ធិមនុស្ស ជាមួយនឹងការកើនឡើងនៃអនុសញ្ញាអន្តរជាតិជាក់លាក់។ អាស្រ័យហេតុនេះ ចំពោះអ្នកនិពន្ធខ្លះ មានបញ្ហាប្រទាំងប្រទើសគ្នា រវាងសាកលនិយម និងសាបេក្ខនិយម ដែលមានភាពស្របច្បាប់នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ការចោទប្រកាន់ជាបទល្មើសត្រូវវាយតម្លៃដោយប្រយ័ត្នប្រយែងខ្ពស់ ដោយសារតែវាប៉ះពាល់ផ្ទាល់ដល់វប្បធម៌ខ្មែរ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ថ្វីត្បិតតែនៅក្នុងផ្នែកស្តីពីការវាយតម្លៃចុងក្រោយលើភស្តុតាង អង្គជំនុំជម្រះបានប្រកាសថា ក្នុងការវាយតម្លៃលើភាពអាចជឿជាក់បានរបស់សាក្សី អង្គជំនុំជម្រះបានសំអាងលើការណែនាំពីចៅក្រមខ្មែរ "ដើម្បីចៀសវាងភាពលម្អៀងកើតចេញពីបរិបទវប្បធម៌"[2119] ប៉ុន្តែ អង្គជំនុំជម្រះបានកំណត់ប្រភេទបទល្មើសនៃអង្គហេតុ ជាមួយនឹងចក្ខុវិស័យសហសម័យ។

១១៤១. ជាក់ស្តែង ថ្វីត្បិតតែមានតែសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សដែលចែងរួចទៅហើយអំពីការយល់ព្រមដោយសេរីពីប្តីប្រពន្ធ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក៏ដោយ ក៏ក្រមរដ្ឋប្បវេណីកម្ពុជា ធ្វើនីត្យានុកូលកម្មអវត្តមាននៃការយល់ព្រម ដោយគិតតែពីការយល់ព្រមពីឪពុកម្តាយ។ វាជាការសំខាន់ក្នុងការយល់ថា ថ្វីត្បិតតែសព្វថ្ងៃនេះ និងក្នុងពេលពិនិត្យភស្តុតាងលើសំណុំរឿង ០០២/០២ គំនិតនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពោលគឺការរៀបអាពាហ៍ពិពាហ៍ ដោយគ្មានការយល់ព្រមពីសាមីខ្លួនម្ខាង ឬទាំងសងខាង ហាក់ដូចជាត្រូវបានរដ្ឋជាច្រើនផ្តន្ទាទោសជាឯកច្ឆន្ទក៏ដោយ ក៏នៅពេលកើតអង្គហេតុដែលបានចោទប្រកាន់ មិនមានករណីបែបនេះឡើយ។

---

[2119] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២។ សូមមើលខាងលើ កថាខណ្ឌ ២៥៤-២៥៦។

១១៤២. ក្នុងអត្ថបទស្តីពីបញ្ហាប្រឈមផ្លូវច្បាប់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អ្នកនិពន្ធបានចោទសួរអំពី "បញ្ហាស្មុគស្មាញនៃអន្តរវប្បធម៌ទល់នឹងសិទ្ធិមនុស្ស និងបញ្ហាប្រឈមដោយប្រយោល"[2120]។ ដោយចោទសួរអំពីការប្រឈមគ្នានៃប្រព័ន្ធគតិយុត្តិផ្សេងៗ ជុំវិញសញ្ញាណនេះ អ្នកនិពន្ធបានយល់ឃើញថា៖

> "នៅចន្លោះទស្សនៈអឺរ៉ុប និងទស្សនៈបរទេសអំពីច្បាប់ មានលំហសង្គម និងគតិយុត្តិដែលបើកចំហទៅរកទស្សនៈ ដែលសាកលនិយម និងពហុនិយម ដូចជាសញ្ញាណស្មុគស្មាញ ដើម្បីគ្រោងទុកអំពីទំនាក់ទំនងមនុស្ស និងការបកប្រែច្បាប់ មានភាពផ្ទុយគ្នាក្នុងទំនាក់ទំនងស្មើភាព និងបំពេញបន្ថែមគ្នា (...)។ ដូចគ្នាផងដែរ ភាពផ្ទុយគ្នារវាងសាកលនិយម និងដោយឡែកនិយម អាចឱ្យមើលឃើញឥទ្ធិពលប្រយោលនៃឧត្តមានុភាពនៃសាកលនិយមនៃសិទ្ធិមនុស្ស ក្នុងឡូស៊ិកនៃការចម្លងគំរូគតិយុត្តិរបស់ប្រទេសអភិវឌ្ឍ ទៅប្រទេសកំពុងអភិវឌ្ឍ ដែលផ្តល់តួនាទីតិចតួចដល់ការបង្ហាញអំពីលក្ខណៈពិសេសនៃប្រទេសកំពុងអភិវឌ្ឍ"[2121]។

១១៤៣. ការត្រិះរិះពិចារណានេះពាក់ព័ន្ធនឹងរឿងក្តីយើង និងនាំឱ្យយើងចោទសំណួរដូចតទៅ៖ តើក្នុងតុលាការដែលត្រូវបានបង្កើតឡើង តាំងពីចប់របបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន អាចត្រូវបានចោទប្រកាន់ចំពោះអង្គហេតុទាំងនេះដែរឬទេ? ការកំណត់និយមន័យនៃសញ្ញាណនេះនាំឱ្យមានការពិភាក្សាផ្សេងៗ ក្នុងដំណើរការនរវិទ្យាគតិយុត្តិ ដែលអង្គជំនុំជម្រះបានព្យាយាមសម្រាយឱ្យងាយយល់។

១១៤៤. ក្នុងពេលផ្តល់សក្ខីកម្ម អ្នកជំនាញ Peg LEVINE បានពន្យល់ថា ហេតុអ្វីបានជាពាក្យ "បង្ខំ" មិនត្រូវបានប្រើប្រាស់នៅក្នុងសំណាកនៃការសិក្សារបស់គាត់[2122]។ ក្នុងពេលពិពណ៌នានោះ គាត់បានពន្យល់ថា

---

[2120] Sahra MEKBOUL ការរៀបការដោយបង្ខំ៖ ការឆ្លើយតបនៃច្បាប់ និងបញ្ហាប្រឈមគតិយុត្តិ មជ្ឈមណ្ឌលព័ត៌មាន និងសិក្សាលើទេសន្តរប្រវេសន៍អន្តរជាតិ ២០០៨/៥ លេខ ១១៩ ទំព័រ ៨៣។

[2121] Sahra MEKBOUL ការរៀបការដោយបង្ខំ៖ ការឆ្លើយតបនៃច្បាប់ និងបញ្ហាប្រឈមគតិយុត្តិ មជ្ឈមណ្ឌលព័ត៌មាន និងសិក្សាលើទេសន្តរប្រវេសន៍អន្តរជាតិ ២០០៨/៥ លេខ ១១៩ ទំព័រ ៩៧-៩៨។

[2122] Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/481.1** ទំព័រ ៣ ម៉ោង 09.09.02៖ "ប៉ាន់របស់ខ្ញុំ ដែលខ្ញុំបានយកទៅប្រើប្រាស់ក្នុងការសួរហ្នឹងគឺពាក្យថា "បង្ខិតបង្ខំ" នេះ ខ្ញុំមិនដែលបានទៅប្រើទេ"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ពាក្យ "បង្ខំ" បានលេចឡើងជាមួយនឹងការចោទប្រកាន់នៅ អ.វ.ត.ក ដែលបង្កើតជាអារម្មណ៍ "អៀនខ្មាស" ចំពោះអ្នកដែលគេសួរដេញដោលៈ

> "សូមលើកតាមរបៀបផ្សេង គឺមានន័យថា ក្រោយពេលពាក្យថា "ដោយបង្ខិតបង្ខំ" ហ្នឹងក្លាយទៅជាកម្មវត្ថុដែលមានសុពលភាពនៅ អ.វ.ត.ក ដែលប្រជាជនមានអារម្មណ៍យល់ឃើញថា ពួកគាត់ហ្នឹង គឺថាមានការខ្មាសអៀនណាស់ ក្នុងការប្រាប់ទៅដល់កូនចៅរបស់គាត់ ចំពោះការរៀបការបង្ខិតបង្ខំនេះ។ នេះគឺជាចម្លើយទីមួយ ទៅនឹងសំណួររបស់លោកស្រី។ ហើយទីពីរ ពួកគាត់មិនបានបកស្រាយផ្ទុយពីនេះអំពីការរៀបការរបស់គាត់នោះ ថាវាស្របច្បាប់ ឬយ៉ាងណានោះ។ ក៏ប៉ុន្តែ ថាតើពួកគាត់នេះព្រួយបារម្ភថាតើពួកគាត់អាចនឹងប្រាប់ទៅដល់សាធារណជន ឬក៏ថាប្រាប់ទៅដល់ប្រព័ន្ធផ្សព្វផ្សាយដោយរបៀបណាអំពីការរៀបការរបស់ពួកគាត់នោះ"[2123]។

១១៤៥. សេចក្តីសន្និដ្ឋានទាំងនេះបង្ហាញអំពីការបែកចេញពីគ្នា រវាងតថភាពវប្បធម៌ និងការកសាងគតិយុត្តិ ក៏ដូចជាភាពស្មុគស្មាញនៃការរំពៃមើលរបស់តុលាការលើអង្គហេតុ ដែលមិនពាក់ព័ន្ធតែនឹងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ ពាក់ព័ន្ធនឹងកម្ពុជា និងវប្បធម៌កម្ពុជា នៅគ្រប់សម័យកាល។

## ២.១.៣. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសព្រហ្មទណ្ឌ នៅសម័យអង្គហេតុ

១១៤៦. អង្គជំនុំជម្រះបានរំឭកអំពីមតិរបស់តុលាការកំពូលដែលថា ការវិភាគលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពអន្តរជាតិជាផ្លូវការ អាចឱ្យផ្ទៀងផ្ទាត់ថាតើអំពើប្រព្រឹត្តឈានដល់កម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដែរឬទេ[2124]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានធ្វើការវិភាគនេះទេ ទើបធ្វើឱ្យអង្គជំនុំ

---

[2123] Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/481.1** ទំព័រ ៣-៤ ចន្លោះពីម៉ោង 09.09.02 ដល់ម៉ោង 09.11.44។

[2124] សំអាងហេតុសាលក្រម កថាខណ្ឌ ៧២៦។

ជម្រះមិនបានប្រើប្រាស់ការវិភាគនេះ ដើម្បីវាយតម្លៃលើល័ក្ខខ័ណ្ឌតម្រូវនៃលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត[2125]។

១១៤៧. លក្ខណៈឧក្រិដ្ឋពិតជាជួយដល់ការវាយតម្លៃលក្ខណៈ និងភាពធ្ងន់ធ្ងរនៃអំពើដែលបានប្រព្រឹត្ត។ ក៏ប៉ុន្តែការវិភាគលើល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការបានបង្ហាញឱ្យឃើញថា លិខិតុបករណ៍អន្តរជាតិមិនមានចែងអំពីការការពារ ឬហាមឃាត់គ្រប់គ្រាន់ ដើម្បីបង្ហាញអំពីនីត្យានុកូលភាពនៃឧក្រិដ្ឋកម្ម នៅសម័យអង្គហេតុ នោះឡើយ។ អវត្តមាននៃការដាក់បញ្ចូលជាបទល្មើសព្រហ្មទណ្ឌ ក្នុងលំដាប់អន្តរជាតិ អាចឱ្យគិតដោយសមហេតុផលថា នៅសម័យនោះ អង្គហេតុដែលបានចោទប្រកាន់មិនត្រូវបានចាត់ទុកថាមានលក្ខណៈប្រហាក់ប្រហែល និងកម្រិតធ្ងន់ធ្ងរស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ។ លើសពីនេះទៀត នីត្យានុកូលកម្មអវត្តមាននៃការយល់ព្រមពីប្តីប្រពន្ធក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ អាចឱ្យរំលេចឃើញតម្រាយនៃការត្រិះរិះពិចារណាជាសត្យានុម័តិ ក្នុងសំណួរស្មុគស្មាញ ដែលអង្គជំនុំជម្រះបានព្យាយាមសម្រាយឱ្យងាយយល់ តាមរយៈការបង្ហាញអំពីការបែងចែកល្អអាក្រក់ រវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងដោយបង្ខំ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំហាក់ដូចជាការបន្តនិរន្តរភាពនៃទម្លាប់ខាងវប្បធម៌ ដែលមានស្រាប់ពីមុនមក រួចធ្វើឱ្យក្លាយជាទំនៀមទម្លាប់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គេមិនអាចនិយាយបានថាជាការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យទៅជាទាសករ ការនិរទេស។ល។

១១៤៨. អង្គជំនុំជម្រះក៏មិនយល់ឃើញថាមានប្រយោជន៍ ក្នុងការអនុវត្តវិធាននៃភាពស្រដៀងគ្នា ក្នុងការវាយតម្លៃធាតុផ្សំសត្យានុម័តិ នោះដែរ។ ក្នុងការកំណត់បទឧក្រិដ្ឋជាអំពើអមនុស្សធម៌ផ្សេងទៀត វិធាននៃភាពស្រដៀងគ្នាគួរណាតែអាចបម្រើដល់ការកំណត់ថា តើអំពើសកម្ម ឬអកម្ម ដែលចោទប្រកាន់ មានកម្រិតធ្ងន់ធ្ងរដូចអំពើដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានរៀបរាប់ក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរឬទេ។ ដើម្បីកំណត់ប្រភេទនៃអំពើណាខ្លះអាចមានលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហាក់គ្នា ពោលគឺស្រដៀងគ្នា អង្គជំនុំជម្រះគួរណាតែធ្វើការស្រាវជ្រាវលើយុត្តិសាស្រ្ត និងវាយតម្លៃប្រភេទនៃអំពើសកម្ម ឬអកម្ម ដែលត្រូវបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេង

---

[2125] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩២។

ទៀត[2126]។ ពេលមិនយកលក្ខណៈវិនិច្ឆ័យសត្យានុម័តិទាំងនេះមកអះអាងថា មានធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ រហូតដល់ថ្នាក់មិនអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យថា មានធាតុផ្សំសត្យានុម័តិនៃបទល្មើស។

១១៤៩. សិទ្ធិ និងបម្រាម ដូចមានចែងនៅក្នុងលិខិតុបករណ៍អន្តរជាតិ នៅសម័យអង្គហេតុ មិនគ្រប់គ្រាន់ឱ្យសន្និដ្ឋានថា បទល្មើសមានភាពស្របតាមគោលការណ៍នីត្យានុកូលភាព ហើយអាចប្រមើលមើលបាន និងយល់ដឹងបានដោយជនជាប់ចោទ។ ក្នុងករណីលើកលែងដែលបទល្មើសត្រូវបានអនុវត្តលើជនជាប់ចោទដោយប្រតិសកម្ម បរាជ័យនៃការអនុវត្តល័ក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ ភ្ជាប់នឹងលក្ខណៈពិសេសខាងវប្បធម៌នៃបទល្មើស និងការពិភាក្សារហូតមកទល់សព្វថ្ងៃនេះ ធ្វើឱ្យមិនអាចអះអាងឱ្យហួសពីវិមតិសង្ស័យថា ធាតុផ្សំសត្យានុម័តិត្រូវបានបំពេញ ពោលគឺភាពចាំបាច់ឱ្យអង្គហេតុមានកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងអំពើផ្សេងទៀត ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះស្តីពីអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវទុកជាមោឃៈ[2127]។

**២.១.៤. សេចក្តីសន្និដ្ឋានខុសរបស់អង្គជំនុំជម្រះ តាមរយៈការបែងចែកសិប្បនិម្មិត រវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ**

១១៥០. ដើម្បីដោះស្រាយអវត្តមាននៃការបង្ហាញគតិយុត្តិអំពីនីត្យានុកូលភាពនៃបទល្មើស អង្គជំនុំជម្រះបានព្យាយាមផ្អែកវិចារណកិច្ចរបស់ខ្លួនលើការបែងចែកសិប្បនិម្មិត រវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងដោយបង្ខំ៖

---

[2126] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨១-៥៨៥។ ការអនុវត្តវិធានស្តីពីចរិតលក្ខណៈប្រហាក់ប្រហែលគ្នា *(esjudem generis)* ដោយតុលាការកំពូល។

[2127] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨០-៣៦៩៤។

"ភ័ស្តុតាងពិពណ៌នានៅក្នុងផ្នែកនេះ រំលេចយ៉ាងច្បាស់ពីការអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានភាពខុសគ្នាយ៉ាងខ្លាំងពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ដោយគ្រួសាររបស់អនាគតប្តីប្រពន្ធមិនបានចូលរួមទាល់តែសោះនៅក្នុងការជជែកពិភាក្សា សហគមន៍មិនបានចូលរួម មិនមានទំនៀមទម្លាប់ប្រពៃណីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ហើយបុគ្គលម្នាក់ៗយល់ព្រមរៀបការ ដោយសារតែភ័យខ្លាចបក្សដាក់ទណ្ឌកម្ម"[2128]។

១១៥១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានអំពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចៅក្រមបានប្រព្រឹត្តកំហុស ក្នុងការសន្និដ្ឋានក្តោបរួមលើការអនុវត្តនៃការរៀបអាពាហ៍ពិពាហ៍ ខណៈដែលភ័ស្តុតាងបង្ហាញយ៉ាងច្បាស់ថា មិនមានការកំណត់អំពីការអនុវត្តដូចៗគ្នា នៅទូទាំងកម្ពុជាប្រជាធិបតេយ្យទេ[2129]។ ផ្ទុយទៅវិញ ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យរំលេចឱ្យឃើញបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ផ្អែកលើការព្រមព្រៀង និងការគោរពស្ត្រីភេទកាន់តែខ្លាំងឡើង (ការលុបចោលនូវពហុពន្ធភាព ការដំឡើងអាយុអប្បបរមាសម្រាប់រៀបអាពាហ៍ពិពាហ៍...)[2130]។ អង្គជំនុំជម្រះបានច្រានចោលបរិបទនៃការបង្ខិតបង្ខំ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ រួចគូសបញ្ជាក់អំពីការ "ភ័យខ្លាចបក្សដាក់ទណ្ឌកម្ម" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីកំណត់ថាមានការបង្ខិតបង្ខំ។ ការវាយតម្លៃបែបនេះបង្ហាញឱ្យឃើញថា ការបង្ខិតបង្ខំមានពីរប្រភេទ។ ការបង្ខិតបង្ខំមួយមានភាពស្របច្បាប់ ពីព្រោះត្រូវបានធ្វើឡើងដោយឪពុកម្តាយ និងការបង្ខិតបង្ខំមួយទៀតត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ ពីព្រោះត្រូវបានធ្វើជាឱ្យក្លាយជាទំនៀមទម្លាប់ នៅថ្នាក់រដ្ឋ។ ការវាយតម្លៃភ័ស្តុតាងមានការប្រែប្រួល ទៅតាមការចង់បានរបស់អង្គជំនុំជម្រះ ដែលបង្កឱ្យមានព្យសនកម្មជាក់ស្តែងដល់ ខៀវ សំផន។

[2128] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2129] សូមមើលខាងក្រោម កថាខណ្ឌ ១១៨៩-១២៨០។

[2130] សូមមើលខាងក្រោម កថាខណ្ឌ ១១៨៩-១២៨០។

១១៥២. ការបែងចែក រវាងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ និងដោយបង្ខំ មានលក្ខណៈសិប្បនិម្មិតខ្លាំង រហូតដល់ថ្នាក់អង្គជំនុំជម្រះខ្លួនឯងច្រឡំសញ្ញាណទាំងពីរនេះ។ ជាក់ស្តែង អង្គជំនុំជម្រះបានបន្ត ដោយអះអាងថា៖

"អង្គជំនុំជម្រះយល់ឃើញថា <u>អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យបាន**រៀបចំ**ការរៀបអាពាហ៍ពិពាហ៍</u> នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល នៅតាមទីតាំងភូមិសាស្ត្រផ្សេងៗគ្នាជាច្រើននៅទូទៅប្រទេសកម្ពុជា"[2131]។

១១៥៣. ការបែងចែក ដែលអង្គជំនុំជម្រះបានបង្ហាញ មិនបានការអ្វីទេ រហូតធ្វើឱ្យអង្គជំនុំជម្រះវង្វេងវង្វាន់នៅក្នុងភាសារបស់ខ្លួនផ្ទាល់[2132]។ ចំពោះការវាយតម្លៃលើសុពលភាពនៃការរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានក្តោបរួមទៀត ដែលមិនមាននៅក្នុងផ្នែកស្តីពីការកំណត់ប្រភេទបទល្មើសនៃអង្គហេតុទេ៖

"ការយល់ព្រមនៅមុនពិធី ឬនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នោះ <u>នៅក្នុងករណីភាគច្រើន</u> គឺមិនអាចចាត់ទុកថាជាការយល់ព្រមពិតប្រាកដឡើយ"[2133]។

១១៥៤. សេចក្តីសន្និដ្ឋានបែបនេះ ដែលបង្កផលវិបាកផ្ទាល់ដល់ការកំណត់ចរិតលក្ខណៈនៃបទឧក្រិដ្ឋ និងការទទួលខុសត្រូវរបស់ ខៀវ សំផន ត្រូវទុកជាមោឃៈ ពីព្រោះវាផ្អែកលើទឡ្ហីករណ៍ និងការវាយតម្លៃមិនត្រឹមត្រូវទៅលើភស្តុតាង[2134]។ បន្ទាប់មកទៀត ការពិពណ៌នាខុសនូវបរិបទនៃការរៀបអាពាហ៍ពិពាហ៍

[2131] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2132] ការភាន់ច្រឡំនេះមិនមែនកើតចេញពីកំហុសនៃការបកប្រែនៅក្នុងសំអាងហេតុសាលក្រមជាភាសាបារាំងទេ ពីព្រោះដោយពិនិត្យមើលភាសាអង់គ្លេស គេសង្កេតឃើញថា ពាក្យតែមួយត្រូវបានប្រើប្រាស់៖ « *The Chamber has found that DK authorities <u>arranged</u> marriages throughout the DK period and in numerous geographical locations throughout the territory of Cambodia* » (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2133] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2134] សូមមើលខាងក្រោមអំពីបញ្ហានៃការព្រមព្រៀង កថាខណ្ឌ ១២៦០-១២៧០។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ធ្វើឱ្យអង្គជំនុំជម្រះសន្និដ្ឋានថាមានធាតុផ្សំសត្យានុម័តិនៃបទក្រិដ្ឋ[2135]។ សេចក្តីសន្និដ្ឋាននេះត្រូវបានទាញចេញពីការបែងចែកនេះ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានផ្អែកវិចារណកិច្ចរបស់ខ្លួនលើការយល់ឃើញខុស និងជាអត្តនោម័តិទៅលើអង្គហេតុ ដោយមិនអនុវត្តល័ក្ខខ័ណ្ឌតម្រូវជាសត្យានុម័តិ ដើម្បីវាយតម្លៃអំពីលក្ខណៈ និងកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងដោយមិនបានផ្តល់សំអាងហេតុតាមផ្លូវច្បាប់។ បើអង្គជំនុំជម្រះកំណត់តាមផ្លូវច្បាប់នូវបរិបទនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ស្របតាមប្រពៃណី និងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងអនុវត្តវិធាននៃភាពស្រដៀងគ្នា អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យបានសមហេតុផលហេតុថា មានធាតុផ្សំសត្យានុម័តិឡើយ។

១១៥៥. ការដាក់បញ្ចូលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាបទល្មើសព្រហ្មទណ្ឌ ក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត មានភាពស្មុគស្មាញ និងចោទជាបញ្ហាច្រើនអនេក។ អ្នកនិពន្ធជាច្រើនខ្វែងគំនិតគ្នាលើបញ្ហានេះ។ ការខ្វែងគំនិតគ្នាខាងលទ្ធិនេះអាចឱ្យបង្ហាញឱ្យឃើញវិមតិសង្ស័យជុំវិញការកំណត់ប្រភេទបទល្មើសនេះ[2136]។ ប៉ុន្តែ ម្យ៉ាង វិមតិសង្ស័យមិនអាចកើតមានទេ ក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ដែល "ផលវិបាកជារួមត្រូវប៉ះទង្គិចដល់មនុស្សជាតិ ក្នុងកម្រិតដែលអាចត្រូវបានកំណត់ថាអមនុស្សធម៌"[2137]។ ម្យ៉ាងទៀត វិមតិសង្ស័យ ប្រសិនបើមាន ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ការបែងចែកសិប្បនិម្មិតនេះលេចត្រដែតឡើង ក្នុងរបៀបដែលអង្គជំនុំជម្រះបង្ហាញអំពីការឈឺចាប់ដែលបានទទួលរង។

---

2135 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩២។

2136 សូមមើលជាអាទិ៍៖ អត្ថបទរបស់ Valerie OOSTERVELD, *Forced Marriage and the Special Court for Sierra Leone: Legal Advances and Conceptual difficulties*, International Humanitarian Legal Studies ឆ្នាំ២០១១ ទំព័រ ១៤៧, អត្ថបទរបស់ Nicolas Azadi GOODFELLOW, *The Miscategorization of 'Forced Marriage' as a Crime against humanity by the Special Court for Sierra Leone* ទំព័រ ៨៦៦, អត្ថបទរបស់ Iris HAENEN, *Classifying acts as crimes against humanity in the Rome Statute of the International criminal court,* German Law Journal ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ ទំព័រ ៧៩៦-៨២២ និងសៀវភៅនិពន្ធដោយ Iris HAENEN*, Force & Marriage: The criminalisation of forced marriage in Dutch, English and international criminal law*, Intersentia ឆ្នាំ២០១៤។

2137 សាលក្រម *Kupreškic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦២២។

## ២.២. កំហុសក្នុងការពិនិត្យលើការឈឺចាប់ដែលទទួលរង ក្នុងការរៀបអាពាហ៍ពិពាហ៍

១១៥៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការសន្និដ្ឋានថា មានធាតុផ្សំនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយយល់ឃើញថា អង្គហេតុដែលបានចោទប្រកាន់ ឈានដល់កម្រិតធ្ងន់ធ្ងរដូចគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដូចបានរៀបរាប់[2138]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះកើតចេញពីការវាយតម្លៃខុស និងលម្អៀងលើសក្ខីកម្មអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយបានលាក់បាំង ជាអាទិ៍ ភស្តុតាងសំខាន់ៗអំពីការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី (២.២.១) និងកំណត់យកជាករណីទូទៅនូវករណីដាច់ដោយឡែកមិនតំណាងឱ្យភស្តុតាងទាំងមូល (២.២.២)។

### ២.២.១. ការវិភាគមិនត្រឹមត្រូវលើភស្តុតាង និងការពិចារណាខុសលើការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី

១១៥៧. ដើម្បីប៉ុនប៉ងចៀសវាងទាញផលវិបាកចេញពីការយល់ព្រមពីឪពុកម្តាយ ក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី[2139] អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុជាច្រើន ក្នុងគោលបំណងសន្និដ្ឋានថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការអនុវត្តជាទូទៅ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាមានវិធានចែងជាផ្លូវការក៏ដោយ។ ជាក់ស្តែង បើតាមអង្គជំនុំជម្រះ "ទោះបីជាការយល់ព្រមរបស់បុគ្គល គឺជាផ្នែកមួយនៃគោលការណ៍អាពាហ៍ពិពាហ៍របស់បក្សក៏ដោយ ក៏ក្នុងការអនុវត្ត ការព្រមព្រៀងរបស់ភាគីទាំងពីរមានសារៈសំខាន់តិចជាងការគោរពរបស់អនាគតគូស្រករ ចំពោះសេចក្តីណែនាំរបស់អង្គការដែរ ពីព្រោះជាគោលការណ៍ ការគោរពនេះត្រូវបានចាត់ទុកជាការបង្ហាញថា គេគិតដល់ផលប្រយោជន៍រួមរបស់ជាតិ វណ្ណៈកម្មករ កសិករ ប្រជាជន និងបដិវត្តន៍ ដែលនៅពីលើផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍គ្រួសារ"[2140]។

---

[2138] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩១-៣៦៩២។

[2139] សូមមើលខាងលើ កថាខណ្ឌ ១១១៩-១១៣០។

[2140] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤៨ កំណត់សម្គាល់ជើងទំព័រលេខ១១៩២៧។

១១៥៨. ដោយបន្តក្នុងការវិភាគខុសនេះទៀត អង្គជំនុំជម្រះបានសន្និដ្ឋានថា "ទាំងបុរស និងនារីត្រូវបានគេបង្ខំឱ្យរៀបការ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅទូទាំងប្រទេស"[2141] ដោយផ្អែកលើការវាយតម្លៃលម្អៀងទៅលើភស្តុតាង សំដៅគាំទ្រដល់ទស្សនៈរបស់ខ្លួនថា អ្នកណាក៏គ្មានជម្រើសអ្វីផ្សេងក្រៅពីគោរព និងស្តាប់តាមបញ្ជារបស់អង្គការជាដាច់ខាត លើគ្រប់វិស័យ[2142]។

### *២.២.១.១. ការមិនព្រមពិចារណាលើសម្ពាធសង្គម ក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ*

១១៥៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លៃទឡ្ហីករណ៍របស់មេធាវីការពារក្តីក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដែលបង្ហាញអំពីភាពស្រដៀងគ្នានៃដំណើរការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលតម្រូវឱ្យមានការយល់ព្រមពីអាជ្ញាធរ និងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដែលតម្រូវឱ្យមានការយល់ព្រមជាចាំបាច់ពីឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកមើលការខុសត្រូវ។ ក្នុងករណីទាំងពីរនេះ គោលបំណងនៅតែផ្តល់ឱ្យគូស្រករនូវក្របខ័ណ្ឌផ្លូវការ និងទទួលយកដោយសង្គម ដើម្បីកសាងគ្រួសារ[2143]។ ដូចយើងនឹងឃើញខាងក្រោម សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការអនុវត្តបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ មានកំហុសធ្ងន់ ប៉ុន្តែ មុននឹងចូលទៅដល់ការរិះគន់នេះ[2144] គួរកត់សម្គាល់ថា អង្គជំនុំជម្រះបានច្រានចោលដោយមិនត្រឹមត្រូវនូវទឡ្ហីករណ៍របស់មេធាវីការពារក្តីអំពីសារៈសំខាន់នៃសម្ពាធសង្គម ក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ[2145]។ បើតាមអង្គជំនុំជម្រះ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមានភាពខុសគ្នាពីការរៀប

---

2141 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០ កំណត់សម្គាល់ជើងទំព័រលេខ១២៣០៨។

2142 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៩-៣៦៩០។

2143 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៤២៥ ("មានការជំនួសសិទ្ធិអំណាចឪពុកម្តាយដោយអាជ្ញាធរមូលដ្ឋាន ក្នុងគោលដៅអនុញ្ញាតឱ្យប្រជាជនអាចរៀបការ និងកសាងគ្រួសារ") និង កថាខណ្ឌ ២៣៧៤ ("ទោះបីជាមានការផ្ទេរពីអ្នកមានអំណាចមេបាមួយ (ឪពុកម្តាយ) ទៅកាន់អ្នកមានអំណាចមេបាមួយទៀត (អាជ្ញាធរមូលដ្ឋាន ឬអង្គការ) ក៏ដោយ ក៏ដំណើរការមានភាពស្រដៀងគ្នាខ្លាំងនឹងការផ្សំផ្គុំតាមប្រពៃណី")។

2144 សូមមើលខាងក្រោម កថាខណ្ឌ ១១៩១-១២៤២។

2145 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៨, ៣៦៩៧។

អាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមិនមាន ការបង្ខិតបង្ខំទេ ដោយសារតែមាន "ជំនឿទុកចិត្តគ្នាទៅវិញទៅមក" រវាងកូន និងឪពុកម្តាយ[2146]។ សេចក្តីសន្និដ្ឋាននេះមិនត្រឹមតែខុសខាងអង្គច្បាប់ ដូចបានឃើញពីខាងលើទេ[2147] ថែមទាំងផ្ទុយនឹងភ័ស្តុតាងទៀតផង។

១១៦០. ជាក់ស្តែង សាក្សីជាច្រើនបានពន្យល់ថា សម្ពាធពីសង្គម និងពីឪពុកម្តាយ មិនអាចឱ្យជំទាស់នឹងការទុកដាក់ពីឪពុកម្តាយ ក្នុងការរៀបអាពាហ៍ពិពាហ៍បានទេ[2148]។ ចំណុចនេះក៏ត្រូវបានបញ្ជាក់ដោយអ្នកជំនាញ Kasumi NAKAGAWA នៅពេលគាត់បង្ហាញអំពីបែបបទនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី[2149]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្តល់ការយល់ឃើញល្អឥតខ្ចោះទៅលើការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបង្កើតការបែងចែកសិប្បនិម្មិត ជាមួយនឹងការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2150]។ ការយល់ឃើញនេះមានភាពខុសឆ្គង

---

[2146] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៨។

[2147] សូមមើលខាងលើ កថាខណ្ឌ ១១១៩-១១៣០។

[2148] អ៊ុំ យឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ប្រហែលម៉ោង 10.34.26។ អ៊ុំ សុផានី៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ប្រហែលម៉ោង 09.59.08។ មាស ឡៃហួរ៖ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/305.1** ចន្លោះពីម៉ោង 15.16.12 ដល់ម៉ោង 15.23.42។ កង អ៊ុត៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/322.1** ប្រហែលម៉ោង 10.55.19។

[2149] Kasumi NAKGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** ប្រហែលម៉ោង 10.49.23 ប្រហែម៉ោង 10.42.34, vers 10.41.20 ប្រហែលម៉ោង 10.51.40។ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ប្រហែលម៉ោង 09.53.17 ប្រហែលម៉ោង 09.28.14 ប្រហែលម៉ោង 10.50.05។

[2150] សំអាងហេតុសាលក្រម ១៤.៣.៨.២. បរិយាកាសបង្ខិតបង្ខំ កថាខណ្ឌ ៣៦៧០, ៣៦៧៤, ៣៦៧៦, ៣៦៩០។ សូមមើលផងដែរ កថាខណ្ឌ ៣៦៥៤ ដែលក្នុងកថាខណ្ឌនេះ អង្គជំនុំជម្រះផ្អែកលើយោបល់របស់ Kasumi NAKAGAWA។ អង្គជំនុំជម្រះយល់ឃើញថា បុគ្គលមិនបានយល់ព្រមរៀបការដោយឆន្ទៈផ្ទាល់របស់ពួកគេឡើយ ហើយជាលទ្ធផល ការរួមភេទនៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍នេះ ក៏មិនមែនជាឆន្ទៈរបស់ពួកគេដែរ។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីដែលតម្រូវឱ្យមានតែការយល់ព្រមពីឪពុកម្តាយ និងការរៀបអាពាហ៍ពិពាហ៍ដោយការរៀបចំមិនគិតគូរពីយោបល់របស់អ្នករៀបការ ដូច្នេះ អង្គជំនុំជម្រះគួរតែធ្វើការសន្និដ្ឋានដូចគ្នាចំពោះការរៀបការតាមប្រពៃណី ឬផ្សេងទៀត ដែលមិនមែនកើតចេញពីការព្រមព្រៀងរបស់អនាគតប្តីប្រពន្ធ។

ពីព្រោះជម្រើសចាប់បង្ខំពីឪពុកម្តាយនៅតែជាបញ្ហានៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន[2151]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រកែកដោយគ្មានមូលដ្ឋានច្បាប់ មិនព្រមពិចារណាថា ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ តាមអំណាច និងតាមការជ្រើសរើសពីឪពុកម្តាយ ដែលប្រពៃណីមិនអាចឱ្យជំទាស់តវ៉ាបាន មិនខុសពីអ្វីដែលអង្គជំនុំជម្រះបានរៀបរាប់ថាជាបរិបទនៃការបង្ខិតបង្ខំ ឬភ័យខ្លាចជាទូទៅ នោះឡើយ។ ប៉ុន្តែ ការផ្ទេរពីអំណាចឪពុកម្តាយទៅអំណាចរបស់អ្នកគ្រប់គ្រងនៅតាមមូលដ្ឋាន មានសារៈសំខាន់ មិនត្រឹមតែដើម្បីឱ្យយល់ថា តើ កម្មាភិបាល ប.ក.ក ចាត់ចែង ក្នុងបរិបទវប្បធម៌បែបណា ប៉ុណ្ណោះទេ ថែមទាំងដើម្បីគិតគូរដល់ផលប៉ះពាល់ទៅលើប្តីប្រពន្ធទៀតផង។ ដូច្នេះ អង្គជំនុំជម្រះបានធ្វើឱ្យការវិភាគរបស់ខ្លួនមានកំហុសឆ្គង ដែលធ្វើមោឃភាពដល់សេចក្តីសម្រេចរបស់ខ្លួន[2152]។

១១៦១. តាមរយៈកំហុសនេះ អង្គជំនុំជម្រះក៏ខកខានមិនបានបំពេញកាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុដល់សេចក្តីសម្រេចរបស់ខ្លួន។ ម្យ៉ាង អង្គជំនុំជម្រះមិនបានគិតដល់ការវិវត្តទៅមុខនៃការទទួលបានការយល់ព្រមពីអនាគតប្តីប្រពន្ធ បន្ថែមលើការយល់ព្រមពីសមូហភាព[2153]។ ដូចយើងនឹងឃើញខាងក្រោម ការអនុវត្តបទបញ្ជាអនុវត្តមិនបានល្អមិនប៉ះពាល់ដល់ឆន្ទៈនយោបាយរបស់ ប.ក.ក ក្នុងការបង្កើតវិធានថ្មីនេះ ធៀបនឹងប្រពៃណី នោះឡើយ។ ម្យ៉ាងទៀត យោងតាមបរិបទវប្បធម៌ អង្គជំនុំជម្រះមិនបានកំណត់ថា ហេតុអ្វីបានជាការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ដែលប្រជាជននៅកម្ពុជាបានអនុវត្តតាមប្រពៃណី តាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ អាចត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ដែលមានកម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មផ្សេងទៀត។

---

[2151] សម្រាប់ជាឧទាហរណ៍ សូមមើល អត្ថបទសារព័ត៌មានចំណងជើងថា "អាពាហ៍ពិពាហ៍ដោយការរៀបចំរងការស្តីបន្ទោសថាធ្វើឱ្យគ្រួសារបរាជ័យ" MARCHER A. ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ឯកសារ **E3/7288** នៅក្នុងអត្ថបទនេះ អ្នកនិពន្ធលើកឡើងពីបញ្ហាសង្គមដែលកើតចេញពីការបែកបាក់គ្រួសារ បន្ទាប់ពីរៀបការដោយមិនបានព្រមព្រៀង។ សូមមើលផងដែររឿងប្រលោមលោកខ្មែរ ដូចជា ទុំទាវ និងផ្កាស្រពោន ដែលត្រូវបានបញ្ចូលក្នុងការសិក្សាអក្សរសិល្ប៍ ដើម្បីរិះគន់ ឬទាក់ទាញចំណាប់អារម្មណ៍របស់ឪពុកម្តាយក្នុងការសម្រេចចិត្តអំពីការរៀបការរបស់កូនពួកគេ។

[2152] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៩។

[2153] សូមមើលខាងក្រោម កថាខណ្ឌ ១១៩១-១២៤២។

១១៦២. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានលង់ខ្លួនចូលទៅក្នុងវិចារណកិច្ចផ្ទុយគ្នា។ ជាក់ស្តែង ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីការឈឺចាប់ ដែលជនរងគ្រោះបានទទួលរង ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះបានយោងទៅកថាខណ្ឌ ៣៦៨៩ ដែលអង្គជំនុំជម្រះសន្និដ្ឋានថា "គោលនយោបាយរបស់ ប.ក.ក យល់ថាអង្គការអាចជំនួសឪពុកម្តាយ ឬក៏សំខាន់ជាងឪពុកម្តាយទៅទៀត"[2154]។ ប៉ុន្តែ អង្គជំនុំជម្រះមិនត្រឹមតែបំភ្លៃទម្រង់ការណ៍របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការផ្ទេរអំណាចឪពុកម្តាយជូនអង្គការប៉ុណ្ណោះទេ[2155] ថែមទាំងមិនបោះបង់ចោលឡូស៊ិករបស់ខ្លួនទៀតផង៖ ពិតមែនតែអង្គការពិតជាដើរតួជំនួសឪពុកម្តាយក្នុងការយល់ព្រមក៏ដោយ ក៏អង្គជំនុំជម្រះគួរណាតែយល់ឃើញថា ការយល់ព្រមពីអនាគតប្តីប្រពន្ធមិនចាំបាច់ទេ ទាំងមុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវីការពារក្តីត្រូវទៅពិនិត្យនៅកន្លែងផ្សេងក្នុងសំអាងហេតុសាលក្រម ដើម្បីព្យាយាមស្វែងយល់អំពីវិចារណកិច្ចរបស់អង្គជំនុំជម្រះលើការឈឺចាប់ បណ្តាលមកពីការរៀបចំពាហ៍ពិពាហ៍តាមលក្ខណៈផ្សេង នៅមុន និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងការឈឺចាប់ដែលបានលើកឡើង បណ្តាលមកពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍។

### *២.២.១.២. ការឈឺចាប់បណ្តាលមកពីទម្រង់នៃការរៀបអាពាហ៍ពិពាហ៍*

១១៦៣. អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្ម និងកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដើម្បីសន្និដ្ឋានអំពីការឈឺចាប់បណ្តាលមកពីអវត្តមានពិធីសាសនា និងអវត្តមានឪពុកម្តាយ ក្នុងពិធីរៀបអាពាហ៍ពិពាហ៍[2156]។ ប៉ុន្តែ ការវិភាគសមហេតុផលទៅលើសក្ខីកម្មទាំងនេះមិនអាចឱ្យសន្និដ្ឋានអំពីភាពធ្ងន់ធ្ងរជាទូទៅនៃការឈឺចាប់ ក្នុងកម្រិតដូចគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតដែលបានរៀបរាប់ឡើយ។

---

[2154] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ១២៣១៥ (នៃកថាខណ្ឌ ៣៦៩២) ដែលយោងទៅកថាខណ្ឌ ៣៦៨៩។

[2155] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៧-៣៦៨៨. សូមមើលខាងក្រោម កថាខណ្ឌ ១២៥២។

[2156] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨១។ សូមមើលផងដែរ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៣៣៧-២៣៣៨។

១១៦៤. ជាក់ស្តែង នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ដែលបានលើកឡើងអំពីករណី "៦០ គូ" ដែលត្រូវបានរៀបការ ក្នុងពិធីតែមួយជាមួយគាត់ ហើយពួកគេយំ ពីព្រោះមិនបាន "សុំម៉ែឪ"[2157]។ ក្រៅពីបញ្ហានៃភាពអាចជឿជាក់បានដែលចោទឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះ[2158] ប្រតិកម្មទាំងនេះ នៅថ្ងៃរៀបការតែមួយ មិនអាចឱ្យសន្និដ្ឋានថា "បណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើផ្លូវចិត្តដែលមានផលប៉ះពាល់រយៈពេលយូរទៅលើជនរងគ្រោះ"[2159] នោះឡើយ។ ភស្តុតាងសេសសល់ក៏មិនអាចឱ្យសន្និដ្ឋានក្នុងន័យនេះ ដោយសារអង្គជំនុំជម្រះមិនបានវាយតម្លៃឱ្យបានត្រឹមត្រូវលើភាពធ្ងន់ធ្ងរនៃការឈឺចាប់ បណ្តាលមកពីអវត្តមានឪពុកម្តាយ។ ឧទាហរណ៍ ក្នុងករណីរបស់ យី ឡៃស្រូវ គាត់បានឆ្លើយថាគាត់ "តូចចិត្ត" ដោយាសារឪពុកម្តាយមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងពិធីរៀបការរបស់គាត់[2160]។ ប៉ុន្តែ ការតូចចិត្តរបស់គាត់មិនអាចចាត់ទុកថាជាការឈឺចាប់ធ្ងន់ធ្ងរកម្រិតខ្ពស់បានទេ[2161]។ ការសង្កេតដូចគ្នាអនុវត្តចំពោះសក្ខីកម្មរបស់ ឃិន វ៉ាត ផងដែរ[2162]។ អង្គជំនុំជម្រះក៏បានបំភ្លៃខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយ ដែលមិនអាចឱ្យសន្និដ្ឋានអំពីការឈឺចាប់ធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងការឈឺចាប់ដែលបង្កឡើងដោយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត[2163]។

---

[2157] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨០ កំណត់សម្គាល់ជើងទំព័រលេខ១២២៨១ និង កថាខណ្ឌ ៣៦៨១ កំណត់សម្គាល់ជើងទំព័រលេខ១២២៨៤ (អវត្តមានឪពុកម្តាយ)។

[2158] សូមមើលខាងក្រោម កថាខណ្ឌ ១១៧៣, ១២៦២-១២៦៣។

[2159] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩២។

[2160] យី ឡៃស្រូវ៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/334.1** ម៉ោង 14.15.37។

[2161] យី ឡៃស្រូវ៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/334.1** ចន្លោះពីម៉ោង 14.06.08 ដល់ម៉ោង 14.25.58។ សូមមើលផងដែរ សំណៅជាភាសាខ្មែរ (ដើម) ទាក់ទងនឹងអារម្មណ៍របស់គាត់ពេលគ្មានវត្តមានឪពុកម្តាយរបស់គាត់នៅពេលរៀបការ ទំព័រ ៥០។

[2162] ឃិត វ៉ាត៖ ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/325.1** ម៉ោង 15.32.29។ សូមមើល សំណៅជាភាសាខ្មែរ ទំព័រ ៦៨ បន្ទាត់ ១២។ គាត់មិនបានលើកឡើងពីអវត្តមានរបស់ឪពុកម្តាយគាត់នៅពេលរៀបការ ដែលបង្កឱ្យមានការឈឺចាប់ខ្លាំង។ គាត់ក៏បានថ្លែងដែរថា ការរៀបការដែលដំបូងគាត់មិនប្រាថ្នាចង់បាននោះ មិនរារាំងគាត់មិនឱ្យមានមនោសញ្ចេតនាជាមួយប្តីគាត់ ដូចអ្វីដែលកើតឡើងនៅក្នុងការរៀបការតាមប្រពៃណី នោះទេ។

[2163] ទោះបីដើមបណ្តឹងរដ្ឋប្បវេណី វ៉ា លឹមហ៊ន់ និង មាស សាវ៉ាន បានលើកឡើងពីការឈឺចាប់ដែលបង្កឡើងដោយសារតែគ្មានការចូលរួម និងអវត្តមានរបស់ឪពុកម្តាយ និងគ្រួសាររបស់ពួកគាត់នៅក្នុងពិធីរៀបការក្តី ប៉ុន្តែពួកគាត់មិនបានលើកឡើងពីការឈឺចាប់ស្រ

១១៦៥. បញ្ហារយៈពេលនៃការឈឺចាប់បណ្ដាលមកពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ខុសពីប្រពៃណី ត្រូវបានបញ្ចៀសផងដែរ។ ជាក់ស្ដែង ពិតមែនតែ ព្រាប សុខឿន បាននិយាយអំពីការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត ប៉ុន្តែ គាត់បានពន្យល់ថាគូផ្សេងទៀតដែលរៀបការក្នុងពេលតែមួយជាមួយគាត់ មិនដូចគាត់ទេ[2164]។ អង្គជំនុំជម្រះចៀសវាងលើកឡើងនូវសក្ខីកម្មផ្នែកនេះ ដែលបង្ហាញអំពីការយល់ឃើញស្រប គ្នារបស់គូស្រករ រវាងអំណាចអង្គការ និងអំណាចឪពុកម្ដាយ តាមប្រពៃណី ជាមួយនឹងសញ្ញាណនៃ ការគោរពតាមការជ្រើសរើសដើម្បីប្រយោជន៍របស់ពួកគេ។ ប្រការនេះបង្ហាញថា ការយល់ឃើញ និង អារម្មណ៍របស់គូស្រករទាំងនោះ មិនស៊ីគ្នានឹងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះទេ។

### ***២.២.១.៣. ការឈឺចាប់ដែលវិភាគ នៅក្នុងផ្នែក ១៤.៣.១២.១ និងផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ***

---

ដៀងគ្នានឹងការឈឺចាប់បណ្ដាលមកពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានរៀបរាប់នោះទេ។ កំណត់ហេតុស្ដាប់ចម្លើយដើមប ណ្ដឹងរដ្ឋប្បវេណី វ៉ា លីមហ៊ន់ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ **E3/9756** ស./ឆ. ៤៥, ៤៨, ៥០ (គាត់ស្រឡាញ់ប្ដីគាត់ និង មិនដែលគិតចង់ចាកចេញពីគាត់ទេ ពីព្រោះគាត់សុភាព។ បន្ទាប់ពីរស់នៅជាមួយគ្នា ពួកគាត់ចាប់ផ្ដើមអាណិតគ្នាទៅវិញទៅមក)។ កំណត់ហេតុស្ដាប់ចម្លើយរដ្ឋប្បវេណី មាស សាវ៉ាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9736** ស./ឆ.១១០, ១១២, ១១៤, ១១៧ ("ស.៖ តើការដែលធ្លាប់រៀបការក្នុងសម័យខ្មែរក្រហមមានការប៉ះពាល់អ្វីខ្លះទេដល់ការរៀបការរបស់លោកស្រី? ឆ.១១០៖ អត់មានបញ្ហាអ្វីទេ។ ស.៖ តើកាលដែលគេបង្ខំឱ្យរួមដំណេក កាលពីគ្រាដំបូងៗ ប៉ះពាល់ដល់ភាពស្និទ្ធស្នាលដល់ការរួមរស់ជាមួយប្ដី ក្រោយលោកស្រីដែរឬទេ? ឆ.១១២៖ ខ្ញុំមិនមានបញ្ហាអ្វីទេ")។ គាត់បានទាមទារឱ្យមានសំណងចំពោះការឈឺចាប់របស់គាត់ដោយសារ តែការសម្លាប់ប្ដីគាត់ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ ឯកសារ **E3/6190** ERN 00521240។ នេះមានន័យថា គាត់ចាត់ទុកថា នេះជាជនដែលបង្កការឈឺចាប់ដល់គាត់។

[2163] <u>ព្រាប សុឃឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 09.35.00 "នៅក្នុងទុំងការហើយទៅ មាន អ្នកត្រូវគ្នាហ្នឹងភាគច្រើន។ ចាស គេយល់ថា គេបានទទួលការទុកដាក់គ្រួសារពីអង្គការ គេគោរពអង្គការវិន័យ គេត្រូវរ៉ូវគ្នាច្រើន។ គេរស់នៅនឹងគ្នា ជុំគ្នាសុខដុមរនាទៅចាស")។

[2164] <u>ព្រាប សុឃឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 09.35.00 "នៅក្នុងទុំងការហើយទៅ មាន អ្នកត្រូវគ្នាហ្នឹងភាគច្រើន។ ចាស គេយល់ថា គេបានទទួលការទុកដាក់គ្រួសារពីអង្គការ គេគោរពអង្គការវិន័យ គេត្រូវរ៉ូវគ្នាច្រើន។ គេរស់នៅនឹងគ្នា ជុំគ្នាសុខដុមរនាទៅចាស")។

១១៦៦. ថ្វីត្បិតតែយើងមិនជំទាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលការឈឺចាប់ពីស្ថានភាពរបស់ពួកគេក៏ដោយ ក៏យើងត្រូវវិភាគការឈឺចាប់ទាំងនេះ ដោយផ្អែកលើបរិបទនៅសម័យនោះ និងច្បាប់ជាធរមានស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត។ ការមិនគិតដល់ភាពចម្រុះគ្នានៃបទពិសោធន៍ និងអារម្មណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញអំពីកំហុសរបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃភ័ស្តុតាង។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានអនុវត្តឱ្យបានត្រឹមត្រូវនូវវិធីសាស្ត្រដែលបានប្រកាស ពាក់ព័ន្ធនឹងការវាយតម្លៃលើសក្ខីកម្មទាំងនេះ[2165]។ ជាក់ស្តែង អង្គជំនុំជម្រះបានផ្អែកជាសំខាន់លើរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវបានជ្រើសរើសជាពិសេស អាស្រ័យលើបទពិសោធន៍ឈឺចាប់ខ្លាំងរបស់ពួកគេ ដោយមិនតំណាងឱ្យបទពិសោធន៍ភាគច្រើនរបស់អ្នកដែលបានរៀបការ ក្នុងរបបនោះ[2166]។ ដូច្នេះ តាមរយៈការបដិសេធមិនព្រមពិនិត្យជារួម និងមិនលម្អៀង ទៅលើភ័ស្តុតាង និងតាមរយៈការមិនអើពើនឹងភាពផ្ទុយគ្នាដ៏សំខាន់នៃសក្ខីកម្មមួយចំនួន អង្គជំនុំជម្រះបានប្រើប្រាស់ករណីជាក់លាក់បំផុត ដើម្បីវាយតម្លៃជាទូទៅលើកម្រិតនៃការឈឺចាប់របស់អ្នកដែលបានរៀបការ ក្នុងរបបនោះ។

• **<u>គ្មានការពិចារណាលើការនិទានផ្ទុយគ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី</u>**

១១៦៧. ជាបឋម ការពិពណ៌នាអំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ ក្នុងរបបនោះ មិនអាចឱ្យសន្និដ្ឋានថាការរៀបអាពាហ៍ពិពាហ៍របស់ពួកគេ និងការរួមដំណេក បានបង្កការឈឺចាប់ធ្ងន់ធ្ងរក្នុងកម្រិតដូចគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត នោះឡើយ។ ជាក់ស្តែង ប្រសិនបើយើងពិនិត្យមើលសេចក្តីថ្លែងចុងក្រោយរបស់ពួកគេ ដើម្បីបង្ហាញការឈឺចាប់ និងព្យសនកម្ម មិនមែនការរៀបអាពាហ៍ពិពាហ៍

---

[2165] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥២៨ តបទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២៣-២៣២៨ ពាក់ព័ន្ធលក្ខណៈពិសេសនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[2166] មេធាវីការពារក្តីយោងទៅទឡ្ហីករណ៍របស់ខ្លួនពាក់ព័ន្ធនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៤១។

ក្នុងរបបនេះទេ ជាមូលហេតុចម្បងនៃការឈឺចាប់របស់ពួកគេ[2167]។ ជាក់ស្តែងពិតមែនតែ កុល ណែម បានលើកឡើងអំពីការឈឺចាប់ ដោយសារមិនបានរៀបការជាមួយគូដណ្តឹងរបស់ខ្លួន ប៉ុន្តែ សេចក្តីថ្លែងចុងក្រោយរបស់គាត់បានផ្តោតលើការឈឺចាប់ ដោយសារមិនអាចមានកូនជាមួយប្រពន្ធគាត់ នៅក្នុងរបបនោះ[2168]។ ដូចគ្នាផងដែរ ការឈឺចាប់ ដែល ង៉ែត ចាត បានលើកឡើង មានទំនាក់ទំនងនឹងការកាន់ទុក្ខចំពោះមរណភាពប្តីទីមួយ ហើយគាត់បានពន្យល់ថាគាត់បានរៀបការម្តងទៀត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាមការណែនាំពីមិត្តភក្តិ[2169]។ មានតែ សយ ណារឿន ម្នាក់គត់ ដែលបានសួរសំណួរទៅជនជាប់ចោទ អំពីការមិនខ្វល់នឹងមនោសញ្ចេតនារបស់សាមីខ្លួន ក្នុងការរៀបអាពាហ៍ពិពាហ៍[2170]។

១១៦៨. បញ្ហានៃភាពជាតំណាងនៃរឿងរ៉ាវទាំងនោះ ដែលជាស្នូលនៃការរិះគន់លើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះស្តីពីគោលនយោបាយរបស់ ប.ក.ក នឹងត្រូវពិនិត្យមើលខាងក្រោម[2171]។ ប៉ុន្តែ យើងត្រូវលើកឡើងជាមុនអំពីកំហុសជាច្រើន ដែលធ្វើឱ្យប៉ះពាល់ដល់ការពិនិត្យរឿងរ៉ាវអំពីបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានមកផ្តល់សក្ខីកម្ម ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍។ ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកោះហៅជាពិសេសឱ្យមកផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ រួមមាន ណុប ធីម, ប៉ែន សុចាន់, កុល ណែម, ព្រាប សុខឿន, ង៉ែត ចាត, សយ ណារឿន, ជា ឌៀប, ស៊ូ សុធារី និង អ៊ុំ យឿន។ អង្គជំនុំជម្រះក៏បានផ្អែកលើកំណត់ហេតុស្តាប់

---

[2167] សយ ណារឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ប្រហែលម៉ោង 11.35.15។ ង៉ែត ចាត៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** មុនម៉ោង 09.21.15។ កុល ណែម៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ប្រហែលម៉ោង 15.41.52។

[2168] កុល ណែម៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ប្រហែលម៉ោង 14.35.00 ("ខ្ញុំឈឺចាប់ដែរ។ ក៏ប៉ុន្តែបានខ្ញុំមកប្តឹងជាមួយលោកដូចថាមេធាវីឱ្យជួយ តើគិតយ៉ាងម៉េចធ្វើបាបខ្ញុំ? ធ្វើបានប្រពន្ធខ្ញុំឱ្យខ្ញុំទាល់តែអត់មានកូនមានចៅ ហើយមិនមែនត្រឹមប្រពន្ធខ្ញុំទេ កូនគេខ្លះៗទៀត") មុនម៉ោង 14.27.45 ("ប្រពន្ធហ្នឹងអត់ៗលែងទេ ខ្ញុំអត់លែងដែរនៅតែយក")។

[2169] ង៉ែត ចាត៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ប្រហែលម៉ោង 09.53.34។

[2170] សយ ណារឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ប្រហែលម៉ោង 11.35.58។ ក្នុងពេលចូលបង្ហាញខ្លួន គាត់បានគាត់បង្ហាញពីការឈឺចាប់របស់គាត់បណ្តាលមកពីការបាត់បង់ព្រហ្មចារី ក្នុងនាមជានារីខ្មែរម្នាក់ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** មុនម៉ោង 10.48.25។

[2171] សូមមើលខាងក្រោម កថាខណ្ឌ ១១៨៩-១២៨០។

ចម្លើយ ជាំង ស្រីមុំ, អែម អឿន និង ប៉ូ ឌីណា ព្រមទាំងបីទៀតមកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ គឺ សុំ ប៉េត, ខែត សុខន និងសាក្សី សួន យឹម[2172]។

១១៦៩. អង្គជំនុំជម្រះបានពិនិត្យជាប្រព័ន្ធលើភ័ស្តុតាងដាក់បន្ទុកទាំងនេះ ហើយបានទាញសេចក្តីសន្និដ្ឋានអំពីការវាយតម្លៃលើកម្រិតឈឺចាប់ ដោយមិនបានលើកឡើងនូវភាពខុសគ្នា ឬផ្ទុយគ្នា។ ជាក់ស្តែង ទោះបីជា ណុប ង៉ិម បាននិយាយអំពីការប្រកែកពីដំបូងមិនព្រមរៀបការជាមួយបុរសដែលគាត់មិនធ្លាប់ឃើញពីមុនក៏ដោយ ក៏គាត់បានបញ្ជាក់ថា "បានគ្រួសារ ខ្ញុំចេះស្រឡាញ់គ្នារហូត"[2173]។ អង្គជំនុំជម្រះក៏បានបំភ្លេចចោលនូវភ័ស្តុតាងដោះបន្ទុកផ្សេងទៀត ក្នុងសក្ខីកម្មរបស់គាត់ ជាអាទិ៍ មូលហេតុដែលគាត់មានចេតនាមិននិយាយអំពីការអល់អែកពីដំបូង ចំពោះការរៀបអាពាហ៍ពិពាហ៍ និងការវិវត្តជាវិជ្ជមាននៃទំនាក់ទំនងជាមួយប្តីគាត់ ហើយចម្លើយស៊ីចង្វាក់គ្នាមានក្នុងសំណុំរឿងផងដែរ[2174]។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានបំភ្លេចចោលសក្ខីកម្មមួយផ្នែករបស់ អ៊ុំ យឿន[2175] ដោយមិនលើកឡើងថាក្រោយពីរបបនោះដួលរលំ គាត់បានរៀបការជាថ្មីម្តងទៀត ជាមួយប្តីដែលគាត់បានរៀបការ ក្នុងរបប

---

[2172] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៧៩។

[2173] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៧៩ កំណត់សម្គាល់ជើងទំព័រលេខ១២២៧៤។ <u>ណុប ង៉ិម</u>៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** មុនម៉ោង 10.43.35។

[2174] <u>ណុប ង៉ិម</u>៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 15.50.17។ គាត់បាននិយាយថាគាត់មិនបានបង្ហាញពីការមិនសប្បាយចិត្តនឹងការរៀបការនេះទេ ពីព្រោះគាត់ចាត់ទុកខ្លួនឯងថា "ចាស់" ដើម្បីយល់ព្រមការរៀបការ និងព្រមព្រៀងជាមួយប្តីឬបស់គាត់ដើម្បីមើលថែគ្នាទៅវិញទៅមក។ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 11.12.25 ប្រហែលម៉ោង 14.20.13។ ពួកគាត់យល់ព្រមរស់នៅជាមួយគ្នា និងមានកូនជាមួយគ្នា។ ចំណែកប្តីរបស់គាត់ឈ្មោះ ព្រាប កប វិញ (គាត់រស់នៅជាមួយរហូតដល់សព្វថ្ងៃនេះ) មិនបាននិយាយពីការឈឺចាប់ពិសេស ដោយបញ្ជាក់ថាគាត់គោរពតាមបញ្ជាឱ្យរៀបការ។ ប៉ុន្តែ គាត់បានបញ្ជាក់ថា គ្មាននរណាម្នាក់បង្ខំគាត់អំពីរឿងផ្សំដំណេកក្នុងជីវិតគ្រួសាររបស់គាត់ទេ, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ស./ឆ.៧៥-៧៧។

[2175] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៧៩ កំណត់សម្គាល់ជើងទំព័រលេខ១២២៧៨។ <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** ប្រហែលម៉ោង 09.31.18។ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីពិតជាបានថ្លែងពីការឈឺចាប់ដែលត្រូវរៀបការផ្ទុយពីឆន្ទៈរបស់គាត់ក៏ដោយ តែគាត់មិនបាននិយាយពីការឈឺចាប់ដែលកើតចេញពីការរៀបការនៅក្នុងសេចក្តីថ្លែងរបស់គាត់ នៅចុងបញ្ចប់នៃការចូលមកបង្ហាញខ្លួននោះទេ។

កម្ពុជាប្រជាធិបតេយ្យ[2176]។ម្យ៉ាងវិញទៀត ទោះបីជា ង៉ែត ចាត និង ជា ឌៀប បានអះអាងយ៉ាងច្បាស់ថា ពួកគាត់បានឈឺចាប់ដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏នេះមិនមែនជាការឈឺចាប់ធ្ងន់ធ្ងរបំផុតដែរ[2177]។ ភស្តុតាងទាំងនេះមិនអាចឱ្យសន្និដ្ឋានអំពីការឈឺចាប់ក្នុងកម្រិតធ្ងន់ធ្ងរ តាមល័ក្ខខ័ណ្ឌតម្រូវ ដើម្បីកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ឡើយ។

១១៧០. **<u>ការយកស្ថានភាពដាច់ដោយឡែករបស់ ស៊្វ សុធារី មកធ្វើជាករណីទូទៅ៖</u>** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានប្រើប្រាស់រឿងរ៉ាវរបស់គាត់ ដើម្បីគាំទ្រដល់ការសន្និដ្ឋានជាទូទៅរបស់ខ្លួនអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទៅលើគូស្រករ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ត្រង់នេះទៀត នេះមិនមែនជាការបដិសេធការឈឺចាប់ផ្ទាល់ខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ប៉ុន្តែ ដោយលើកឡើងថា គាត់ឈឺចាប់បំផុតពីការរំលោភបំពានផ្លូវភេទ ដោយសារតែជាភេទទីបី អង្គជំនុំជម្រះគួរណាតែធ្វើវិចារណកិច្ចឱ្យចប់ចុងចប់ដើម[2178]។ ភេទទីបី នៅកម្ពុជា (ដែល

---

[2176] អ៊ុំ <u>យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** ប្រហែលម៉ោង 09.31.18។

[2177] <u>ង៉ែត ចាត</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** មុនម៉ោង 09.21.15 បន្ទាប់ពីមេធាវីរបស់គាត់អញ្ជើញឱ្យឡើងនិយាយពីការឈឺចាប់ដែលគាត់បានទទួលរងពីការរៀបការនៅក្នុងរបបខ្មែរក្រហម គាត់បែរជានិយាយភ្ជាប់នឹងការស្លាប់របស់ប្ដីរបស់គាត់ទៅវិញ៖ "ឆ. ខ្ញុំឈឺចាប់ខ្លាំង យ៉ក៏ ខ្ញុំនិយាយប្រាប់កូនខ្ញុំថា កូនអើយ ខ្ញុំម៉ែវេទនាណាស់ កុំតែបានកូនឯងទៅនឹងសាលារៀនយូរហ្នឹង កុំអីហ្នឹងម៉ែស្លាប់បាត់ហើយ កូនអើយ ដែលចេះតែឈឺចាប់ក្នុងខ្លួលខ្ញាញ់ ក្នុងខ្លួនញ៉័រ ជួនការទៅ <u>រាល់ៗថ្ងៃហ្នឹង មានរោគបេះដូង ឱ្យតែនឹកឃើញកន្លែងគេទាញដៃយកកូនខ្ញុំទៅ ប្ដីខ្ញុំទៅហ្នឹង ជួនកាលទៅ ចង់គាំងបេះដូងក៏មាន ព្រោះអីរាល់ថ្ងៃនេះខ្សោយបេះដូងតែម្ដង។ ដេកទៅញ៉័រ ហើយឈឺចង្អុះ</u>") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោមផ្នែកសំខាន់ ប៉ុន្តែអង្គជំនុំជម្រះមិនបានទទួលយក)។ សំខាន់ជាងនេះទៀត ង៉ែត ចាត បានរៀបរាប់រឿងនេះម្ដងហើយម្ដងទៀត នៅក្នុងសេចក្ដីថ្លែងព្យសនកម្ម នៅចុងបញ្ចប់នៃការចូលបង្ហាញខ្លួនរបស់គាត់ ប៉ុន្តែ មិនបាននិយាយពីការរៀបការរបស់គាត់នៅក្នុងរបបខ្មែរក្រហមនោះទេ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ម៉ោង 10.06.49។ <u>ជា ឌៀប</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ក្រោយម៉ោង 14.21.29 ("ខ្ញុំមិនដែលភ្លេចទេការស្លាប់របស់ឪពុកម្ដាយ បងប្អូនប្រុសស្រី សមាជិកគ្រួសាររបស់ខ្ញុំ... និងឪពុកម្ដាយខ្ញុំ")។

[2178] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៧៩ កំណត់សម្គាល់ជើងទំព័រលេខ១២២៧៧។ <u>ស៊្វ សុធារី</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** មុនម៉ោង 14.29.57 ម៉ោង 14.38.33 មុនម៉ោង 14.59.34។ ប្រតិចារឹក ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/463.1** មុនម៉ោង 14.03.43។ ជាការសំខាន់ត្រូវកត់សម្គាល់ផងដែរថា ការស្រឡាញ់ភេទដូចគ្នាមិនត្រូវបានទទួលស្គាល់នៅក្នុងវប្បធម៌ខ្មែរ មុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។

ហ៊ានប្រកាសប្រាប់គេឯង) គឺជាករណីលើកលែង នៅទសវត្សរ៍ឆ្នាំ១៩៧០។ ការមិនទទួលយក និង ឥរិយាបថមិនល្អចំពោះភេទទីបី មានទំនាក់ទំនងនឹងបរិបទវប្បធម៌ខ្មែរ។ ដូច្នេះ ការឈឺចាប់បណ្តាលមកពីស្ថានភាពដោយឡែករបស់ ស៊្វ សុធារី មិនអាចឱ្យអង្គជំនុំជម្រះយកមកទាញសេចក្តីសន្និដ្ឋានជារួមលើគូស្រករទាំងអស់ដែលបានរៀបការ នៅក្នុងរបបនោះបានទេ។

១១៧១. <u>ការពិនិត្យមិនគ្រប់ជ្រុងជ្រោយ និងដោយលម្អៀង ទៅលើកំណត់ហេតុស្តាប់ចម្លើយ</u>៖ ក្រៅពីតម្លៃជាភស្តុតាងតិចតួចនៃកំណត់ហេតុស្តាប់ចម្លើយរបស់ សួន យីម និង សុំ ប៉េត ដែលភាគីមិនអាចសួរដេញដោលបាន អង្គជំនុំជម្រះក៏បានពិនិត្យដោយលម្អៀងផងដែរ ដោយបំភ្លេចចោលនូវការវិវត្តនៃស្ថានភាពផ្លូវចិត្តរបស់ពួកគាត់។ ជាក់ស្តែង ដូច ណុប ធីម ដែរ អង្គជំនុំជម្រះបានបំភ្លេចចោលព័ត៌មានជាច្រើននៅក្នុងកំណត់ហេតុរបស់គាត់ ដែលលើកឡើងអំពីការវិវត្តនៃការឈឺចាប់ ទៅតាមពេលវេលា[2179]។ ភាពខុសគ្នា និងភាពចម្រុះគ្នានៃបទពិសោធន៍ ក្នុងកំណត់ហេតុ គឺជាភស្តុតាងជាច្រើន ដែលគួរណាតែ

---

[2179] <u>កំណត់ហេតុស្តាប់ចម្លើយ សួន យីម</u> ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E3/9829 ស./ឆ.២៩-៣០ ដែលត្រង់នេះ ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថាពុំមានបញ្ហាផ្លូវកាយ ឬផ្លូវចិត្តក្រោយរួមដំណេកទេ, ស./ឆ.៣៨ ("ស. តើប្រជាជននៅក្នុងប្រទេសកម្ពុជាមានការយល់ឃើញ ចំពោះអ្នកស្រីខុសប្លែកពីអ្នកដទៃដែរឬទេ ដោយសារតែអ្នកស្រីបានរៀបការនៅក្នុងរបបខ្មែរក្រហម? តើការរៀបការនោះ គឺជារឿងរ៉ាវដែលអ្នកស្រីអាចនិយាយជាសាធារណៈបានដែរឬទេ? ឆ.៣៨៖ ខ្ញុំមិនមានអារម្មណ៍ខ្មាស់អៀនទេ ដោយសារខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឱ្យរៀបការ"), ស./ឆ.៤០ ("ខ្ញុំមានអារម្មណ៍ខឹងសម្បារ ពិបាកចិត្ត។ <u>ប្រហែលជា ៤ ទៅ ៥ ឆ្នាំក្រោយមក ខ្ញុំមានអារម្មណ៍ខឹងសម្បារម្តងម្កាល។ ក្រោយពេលពួកវៀតណាមចូលមក យើងផ្តោតទៅលើការរកស៊ី ហើយការឈ្លោះគ្នាបានធ្លាក់ចុះ។ អារម្មណ៍បែបនោះបានបាត់បង់ហើយនៅពេលឥឡូវនេះដោយសារខ្ញុំមានវ័យចាស់"</u> (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោមផ្នែកដែលមិនបានលើកឡើងនៅក្នុងសំអាងហេតុសាលក្រម)។ ចម្លើយរបស់ សុំ ប៉ែត ក៏ត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ដោយផ្នែកផងដែរ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ពីរបៀបដែលប្តីប្រពន្ធគាត់ចេះរួមរស់នៅជាមួយគ្នានៅក្នុងជីវិតគ្រួសារ៖ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុំ ប៉ែត ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ E3/9824 ស./ឆ.៣១ ("សម្រាប់រូបខ្ញុំផ្ទាល់ មានអារម្មណ៍លំបាក ដោយសារយើងមិនស្គាល់ចិត្តគ្នា។ ចំពោះប្រពន្ធរបស់ខ្ញុំក៏មានអារម្មណ៍ភ័យខ្លាច <u>តែព្យាយាមសម្របសម្រួលខ្លួនតាមកាលៈទេសៈ</u>") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោមផ្នែកដែលមិនបានលើកឡើង)។ ធាតុផ្សំដោះបន្ទុកផ្សេងទៀត៖ ស./ឆ.៤៣ (ក្រោយការរៀបការ គាត់ និងប្រពន្ធគាត់បានសម្រេចចិត្តរស់នៅផ្ទះរបស់គាត់)។ ក្នុងន័យដូចគ្នានេះ កំណត់ហេតុស្តាប់ចម្លើយ ខែត សុខន ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ E3/9830 ស./ឆ.៨៦, ទោះបីជាគាត់បានលើកឡើងពីការឈឺចាប់ដោយសារតែរៀបការដែលខ្លួនមិនប្រាថ្នាក៏ដោយ ក៏គាត់បានសម្រេចចិត្តបន្តរស់នៅជាមួយប្តីគាត់។

នាំឱ្យអង្គជំនុំជម្រះយល់ឃើញថា ការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ មិនឈានដល់កម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតទេ[2180]។

- **ភាពផ្ទុយគ្នា និងភាពមិនស៊ីចង្វាក់គ្នានៃរឿងរ៉ាវមួយចំនួន ដែលត្រូវបានលាក់បាំង**

១១៧២. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយខកខានមិនបានលើកឡើងអំពីភាពផ្ទុយគ្នាច្បាស់ក្រឡែត ដែលគួរណាតែនាំឱ្យអង្គជំនុំជម្រះកត់សម្គាល់ឃើញកង្វះភាពអាចជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន។ កង្វះការបែងចែកសខ្មៅរបស់អង្គជំនុំជម្រះ ចំពោះចម្លើយតាមបែបស្រមើស្រមៃរបស់ អែម អឿន បង្ហាញឱ្យឃើញច្បាស់អំពីការលម្អៀងក្នុងការពិនិត្យភ័ស្តុតាង សំដៅរកតែដាក់បន្ទុក។ ទោះបីជាគាត់ចាត់ទុកខ្លួនជាជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏ អែម អឿន បានអះអាងថាគាត់បានជ្រើសរើសថ្ងៃរៀបការដោយខ្លួនឯង ដោយបានបញ្ជាក់ថា គាត់អាចប្រកែកបាន[2181]។ ចៅក្រមប្រកបដោយវិចារណញ្ញាណគ្រប់រូបគួរណាតែកត់សម្គាល់ថា សក្ខីកម្មនេះមិនអាចឱ្យសន្និដ្ឋានអំពីអត្ថិភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានទេ ពីព្រោះរឿងរ៉ាវរបស់ អែម អឿន ពោរពេញដោយភាពមិនស៊ីចង្វាក់គ្នា[2182]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបាន

[2180] កំណត់ហេតុស្តាប់ចម្លើយ ខែត សុខន ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ **E3/9830** ស./ធ.៨១-៨២ ប្តីគាត់បានសុំគាត់រួមដំណេកជាមួយ ប៉ុន្តែមិនបានបង្ខំគាត់ពីរបីយប់ក្រោយពេលរៀបការទេ។

[2181] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ក្រោយម៉ោង 16.03.12 ("ខ្ញុំយល់បានច្បាស់ថាកំណត់យកថា ថ្ងៃ១៧ មេសា ... នៅពេលនោះអ្នកដែលមានកម្មវិធីគាំទ្រ ស្រឡាញ់រាប់អានខ្ញុំជាបង ជាប្អូនខ្ញុំនោះ អ្នកមុខអ្នកការក្នុងតំបន់ទាំងអស់ទៅធ្វើពិធីការខ្ញុំ។ ដោយអ្នកទាំងអស់នុ៎ងហាក់ដូចជាយល់គំនិតមួយថាបើសិនមិនអប់ -- បើមិនយកគំនិតហ្នឹងទៅការវាទេ ប្រហែលអាហ្នឹងវាមានទឹកចិត្តផ្សេង ព្រោះអស់លោកដឹង។ ដឹងថា ខ្ញុំនឹងមិនចូលចិត្តស្តាប់អ្នកណាទាំងអស់"។ គួរកត់សម្គាល់ថា អែម អឿន បានចូលមកបង្ហាញខ្លួននៅក្នុងសំណុំរឿង ០០២/០១ ដែលនៅពេលនោះ គាត់មិនត្រូវបានសួរសំណួរអំពីការរៀបការទេ មានតែចម្លើយដែលគាត់ឆ្លើយចេញមកដោយឯកឯងពាក់ព័ន្ធនឹងប្រធានបទនេះប៉ុណ្ណោះ ដែលមាននៅក្នុងសំណុំរឿង។

[2182] ក្នុងចំណោមចម្លើយផ្ទុយផ្សេងទៀតរបស់ អែម អឿន នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់គាត់ គាត់បាននិយាយថានៅបន្តរស់នៅជាប្តីប្រពន្ធជាមួយប្រពន្ធរបស់គាត់ដែលគាត់រៀបការជាមួយនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែ គាត់ហាក់ដូចជាបានលែងលះនៅឆ្នាំ២០០២ រួចរៀបការសាជាថ្មី យោងតាមចម្លើយរបស់គាត់នៅក្នុងសវនាការ៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** ចន្លោះពីម៉ោង 14.47.41 ដល់ម៉ោង 14.58.00។ ចម្លើយតបរបស់ ខៀវ សំផន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ **F50/1** កថាខណ្ឌ ៥៦-៥៩។

យកចិត្តទុកដាក់លើសក្ខីកម្មរបស់គាត់ដែលមានតម្លៃជាភស្តុតាងតិចតួចបំផុត និងមិនគួរណាយកសក្ខីកម្មរបស់គាត់មកប្រើប្រាស់ឡើយ។

១១៧៣. **<u>ករណីរៀបអាពាហ៍ពិពាហ៍ជាថ្មី៖</u>** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានធ្វើការបូកសរុបរួមលើការឈឺចាប់របស់ស្ត្រីមេម៉ាយដែលត្រូវគេបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាថ្មី ដោយគ្មានភស្តុតាងគ្រប់គ្រាន់៖ សក្ខីកម្មរបស់ ង៉ែត ចាត និង មុំ វុន និងកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា ដែលជាសាក្សី ក្នុងសំណុំរឿង ០០២/០១[2183]។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចដកស្រង់សក្ខីកម្មរបស់ មុំ វុន ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនបើទោះជាមានភាពផ្ទុយគ្នាក៏ដោយ នោះឡើយ[2184]។ ជាជាងច្រានចោលសក្ខីកម្មរបស់គាត់តែម្តងដោយសារតែខ្វះភាពគួរឱ្យជឿជាក់បាន អង្គជំនុំជម្រះបែរជាសន្និដ្ឋាននៅកថាខណ្ឌ ៣៦៤៩ នៃសំអាងហេតុសាលក្រម ថា ហេតុការណ៍ពាក់ព័ន្ធនឹងប្តីទីមួយរបស់គាត់ត្រូវបានចាត់ទុកថាមាន "ភាពមិនស៊ីចង្វាក់គ្នាតិចតួច"។ ប៉ុន្តែ សេចក្តីសន្និដ្ឋាននេះមិនត្រឹមត្រូវទេ ពីព្រោះអង្គជំនុំជម្រះបានផ្អែកលើអត្ថិភាព និងមរណភាពនៃប្តីទីមួយរបស់គាត់ ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីការឈឺចាប់របស់ មុំ វុន ដោយសារការបង្ខំឱ្យរៀបការជាថ្មី ក្រោយពីបាត់បង់ប្តីទីមួយ។ ក្នុងគ្រប់ករណីទាំងអស់ ភាពផ្ទុយគ្នា និង

---

[2183] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ១២២៧៩ (នៃកថាខណ្ឌ ៣៦៨០)។

[2184] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨០ កំណត់សម្គាល់ជើងទំព័រលេខ១២២៨១។ សក្ខីកម្មរបស់ មុំ វុន មានភាពច្របូកច្របល់ និងផ្ទុយគ្នាទាក់ទងនឹងធាតុផ្សំសំខាន់ៗ ដើម្បីបញ្ជាក់ពីភាពអាចជឿទុកបាននៃសក្ខីកម្មនេះទេ ជាពិសេស ធាតុផ្សំដែលបានផ្តល់ទៅលើអត្តសញ្ញាណ និងជោគវាសនារបស់ប្តីដំបូងរបស់គាត់។ សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣៩៨។ ប្តីនេះត្រូវបានពណ៌នាជាបន្តបន្ទាប់ថាជាអតីតទាហានលន់នល់ អ្នកឡើងត្នោត ឬជាគ្រូបង្រៀន។ ដូចគ្នាដែរ មុំ វុន បានផ្តល់ព័ត៌មានជាច្រើនទាក់ទងនឹងកាលៈទេសៈនៃការលែងលះរបស់ពួកគាត់៖ មានម្តង គឺលែងលះគ្នាមុនឆ្នាំ១៩៧២ មានម្តងទៀត គឺបែកគ្នានៅឆ្នាំ១៩៧៥ ហើយព័ត៌មានទីបី ពួកគាត់រស់នៅជាមួយនៅឡើយទេនៅឆ្នាំ១៩៧៧។ ប្រឈមនឹងចម្លើយផ្ទុយគ្នាទាំងនេះដែលមានអត្ថន័យនៅសវនាការ គាត់មិនបានផ្តល់ការពន្យល់ស៊ីចង្វាក់គញនាជាមួយនឹងព័ត៌មានទាំងនេះទេ៖ មុំ វុន៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/475.1** ចន្លោះពីម៉ោង 15.51.06 ដល់ម៉ោង 15.58.48 (មានម្តង គាត់ទម្លាក់កំហុសលើប្តីគាត់ មានម្តងទៀត គាត់មិនអាចឆ្លើយ) បញ្ជាបកប្រែជាភាសាបារាំង សូមមើលប្រតិចារឹកជាភាសាខ្មែរ ទំព័រ ៨២ បន្ទាត់ ១០-១៤ ពាក់ព័ន្ធនឹងចម្លើយផ្ទុយគ្នាទៅលើមុខងាររបស់ប្តីទីមួយរបស់គាត់។ ប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/477.1** ចន្លោះពីម៉ោង 09.21.47 ដល់ម៉ោង 09.23.42 ("ដល់ពាក្យវាផ្ទុយអ៊ីចឹង ខ្ញុំអត់ដឹងឆ្លើយថាម៉េចទេ ព្រោះខ្ញុំចូលមកធ្វើការ ៧៧ គេជម្លៀសគាត់ចេញ ហៅទៅរៀនហ្នឹង ៧៥")។

តវិយាបថរបស់ មុំ វុន ក្នុងសវនាការ គួរណាតែនាំឱ្យចៅក្រមប្រកបដោយវិចារណញ្ញាណច្រានចោលសក្ខីកម្មរបស់គាត់។ ដើម្បីសន្និដ្ឋានអំពីការឈឺចាប់បណ្តាលមកពីការបង្ខំឱ្យរៀបការជាថ្មី អង្គជំនុំជម្រះបានប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយ ប៉ូ ឌីណា ខណៈដែលគាត់បានពន្យល់ថា ការរៀបការលើកទីពីរមិនបានកើតឡើងតាមការគ្រោងទុកទេ ពីព្រោះគាត់បានប្រកែក ទោះបីជាគាត់ត្រូវគេដាក់ទណ្ឌកម្មក៏ដោយ។ លើសពីនេះទៀត គាត់មិនបានចាត់ទុកការប៉ុនប៉ងរៀបការជាមូលហេតុនៃការឈឺចាប់នៅក្នុងរបបនោះទេ គឺការបាត់បង់គ្រួសារឯណោះទេដែលធ្វើឱ្យគាត់ឈឺចាប់[2185]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកសេចក្តីសន្និដ្ឋានរបស់ខ្លួនលើចម្លើយរបស់គាត់។

១១៧៤. **<u>ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំចិត្ត</u>៖** អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទៅលើអ្នកធ្លាប់មានគូដណ្តឹងពីមុន តាមរយៈការវាយតម្លៃខុសទៅលើភ័ស្តុតាង[2186]។ ជាក់ស្តែង ទោះបីជា យស ផល បានឆ្លើយថាគាត់មានអារម្មណ៍សោកស្តាយ ដោយសារមិនអាចរៀបការជាមួយគូដណ្តឹងបាន ក៏ដោយ ក៏នៅទីបំផុត គាត់បានកសាងមនោសញ្ចេតនាជាមួយប្រពន្ធដែលបានរៀបការក្នុងរបបនោះ ហើយគាត់មានកូនទៀតផង[2187]។ ត្រង់នេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានគិតគូរដល់សក្ខីកម្មរបស់គាត់ទាំងមូល និងការវិវត្តនៃស្ថានភាពផ្លូវចិត្ត ក្រោយពីរៀបការ។ អង្គជំនុំជម្រះបានអនុវត្តដំណើរការខុសឆ្គងដដែល ក្នុងការប្រើប្រាស់សក្ខីកម្មរបស់ កុល ណែម[2188]។

---

[2185] ប៉ូ ឌីណា៖ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/199.1** ប្រហែលម៉ោង 15.40.50។

[2186] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ១២២៨២ (នៃកថាខណ្ឌ ៣៦៨០)។ <u>យស ផល</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 10.52.32។

[2187] <u>យស ផល</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 10.39.30 ម៉ោង 10.59.05 មុនម៉ោង 11.05.25។ នៅក្នុងករណីពិសេសរបស់គាត់ គឺទំនាក់ទំនងរបស់គ្រួសារគូដណ្តឹងគាត់ជាមួយបណ្តាញជនក្បត់ដែលជាឧបសគ្គដល់ការរៀបការ។ ម្យ៉ាងទៀត គាត់បានពន្យល់ថា ជាទូទៅ ការរៀបការរវាងបុគ្គលដែលមានមនោសញ្ចេតនាជាមួយគ្នាទៅវិញទៅមកត្រូវបានអនុញ្ញាតលុះត្រាតែពួកគេមានប្រវត្តិរូបល្អ។ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** មុនម៉ោង 09.52.19, 10.00.47។

[2188] <u>កុល ណែម</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦, **E1/488.1** ម៉ោង 14.27.45 ក្រោយម៉ោង 14.35.00។ ទោះបី កុល ណែម បានលើកឡើងថា គាត់សោកស្តាយដែលមិនបានអាចរៀបការជាមួយគូដណ្តឹងរបស់គាត់ អ្វីដែលគាត់បានបង្ហាញនៅក្នុងសវនា

១១៧៥. **<u>សេចក្តីសន្និដ្ឋានទូទៅមិនតំណាងឱ្យភាពផ្សេងគ្នានៃរឿងរ៉ាវ៖</u>** ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានជាទូទៅអំពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ ដោយមិនបានលើកឡើងអំពីភាពខុសគ្នានៃរឿងរ៉ាវ និងអារម្មណ៍[2189]។ ដើម្បីសន្និដ្ឋានអំពីឥទ្ធិពលយូរអង្វែង និងការប៉ះទង្គិចបណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ទាំងនេះ អង្គជំនុំជម្រះបានផ្អែកដោយផ្តាច់មុខលើរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍[2190] ដែលយើងទើបនឹងឃើញការពិតផ្សេងគ្នាក្រៅពីភាពផ្ទុយគ្នា។ ដូចមេធាវីការពារក្តីបានតតាំងក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[2191] ការឈឺចាប់បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ឬដោយបង្ខំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានភាពប្រែប្រួល និងអាស្រ័យលើកាលៈទេសៈជាក់ស្តែងរបស់បុគ្គល។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះមានកំហុសអង្គហេតុ មិនត្រឹមតែតាមរយៈវិធីសាស្ត្រលម្អៀងទៅលើភ័ស្តុតាងប៉ុណ្ណោះទេ ថែមទាំងតាមរយៈការលាក់បាំងបញ្ហានៃភាពជាតំណាងនៃបទពិសោធន៍ទៀតផង។ ដោយធ្វើការជ្រើសរើសភ័ស្តុតាងដោយលម្អៀង ដើម្បីបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីការឈឺចាប់ដែលបានទទួលរង អង្គជំនុំជម្រះមិនបានផ្តល់មូលដ្ឋានត្រឹមត្រូវដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនទេ។ ជាក់ស្តែង ការប្រៀបធៀបជាមួយភ័ស្តុតាងទាំងមូលមិនអាចឱ្យសន្និដ្ឋានថាមានកម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះឡើយ។

## ២.២.២. ការប្រៀបធៀបជាមួយភ័ស្តុតាងទាំងមូល និងភាពជាតំណាង

១១៧៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយមិនបានគោរពតាមគោលការណ៍តម្រូវឱ្យពិនិត្យសក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើភ័ស្តុតាងទាំងមូលក្នុងសំណុំរឿង។ អង្គជំនុំជម្រះត្រូវគិត

---

ការថាជាការឈឺចាប់របស់គាត់នោះ គឺការដែលគាត់ពុំអាចមានកូនជាមួយប្រពន្ធដែលគាត់រៀបការនៅក្នុងរបបខ្មែរក្រហម និងរស់នៅជាមួយរហូតមកដល់សព្វថ្ងៃនេះ។

[2189] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨២ "បទពិសោធន៍ទាំងអស់នេះមានផលប៉ះពាល់រយៈពេលវែងទៅលើជនរងគ្រោះ ហើយពួកគាត់ជាច្រើននៅតែមានការភ័យខ្លាចដោយហេតុការណ៍ទាំងនោះរហូតមកដល់បច្ចុប្បន្ន"។

[2190] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨២ កំណត់សម្គាល់ជើងទំព័រលេខ១២២៨៧។

[2191] សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៣៨០។

ដល់ភាពផ្ទុយគ្នា និងសេចក្តីសន្និដ្ឋានសមហេតុផលផ្សេងទៀត មុននឹងទាញសេចក្តីសន្និដ្ឋានមិនអំណោយផលដល់ម្ចាស់បណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងដំណើរការរបស់ខ្លួនដោយមិនបានធ្វើការប្រៀបធៀបជាមួយភស្តុតាងទាំងមូល មុននឹងធ្វើសេចក្តីសន្និដ្ឋានជារួម។ ជំហានជាមុននេះមានសារៈសំខាន់ជាមូលដ្ឋាន ដើម្បីវិភាគលើតម្លៃជាភស្តុតាង និងភាពជាតំណាងនៃសក្ខីកម្មដែលទទួលបាន ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ដែលមាននិន្នាការ (២.២.២.១) មិនស្របគ្នានឹងនិន្នាការនៃវគ្គផ្សេងទៀតក្រៅពីវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០២ (២.២.២.២) ឬកំណត់ហេតុស្តាប់ចម្លើយ (២.២.២.៣)[2192]។

### *២.២.២.១. សក្ខីកម្មក្នុងក្របខ័ណ្ឌនៃវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍*

១១៧៧. ចំពោះវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ជាសរុប អង្គជំនុំជម្រះបានស្តាប់ចម្លើយអ្នកជំនាញ ២ នាក់ សាក្សី ២ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៩ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ៣ អំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម[2193]។ ប៉ុន្តែ ដូចបានឃើញពីខាងលើ សក្ខីកម្មភាគច្រើនលើសលុបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះត្រូវបានអង្គជំនុំជម្រះយកមកប្រើប្រាស់ ដើម្បីវាយតម្លៃលើកម្រិតធ្ងន់ធ្ងរនៃការឈឺចាប់តំណាងឱ្យទូទាំងប្រទេស។ លើសពីនេះទៀត អង្គជំនុំជម្រះបានធ្វើការជ្រើសរើសសក្ខីកម្មទាំងនេះយកតែផ្នែកដាក់បន្ទុកប៉ុណ្ណោះ។

១១៧៨. **ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ស្តីពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម**[2194]៖ ដូចបានរៀបរាប់ពីខាងលើ មិនមែនការឈឺចាប់បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ទេ ដែលត្រូវបានលើកឡើង ក្នុងពេលថ្លែងអំពីព្យសនកម្ម នៅចុងបញ្ចប់នៃការផ្តល់សក្ខីកម្ម[2195]។ ភស្តុតាងដ៏សំខាន់នេះគួរណាតែត្រូវបានអង្គជំនុំ

---

[2192] សូមមើល ឧបសម្ព័ន្ធ ខ១ ដល់ ខ៩។

[2193] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២២ កំណត់សម្គាល់ជើងទំព័រលេខ ២៣៥៤។

[2194] ង៉ែត ចាត, សយ ណាវឿន និង កុល ណែម (បុរស)។

[2195] ង៉ែត ចាត៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ប្រហែលម៉ោង 09.21.15។ សយ ណាវឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ប្រហែលម៉ោង 11.35.15 (គាត់បែរជាសួរសំណួរទៅជនជាប់ចោទអំពីការ

ជម្រះយកមកពិចារណា ប៉ុន្តែ អង្គជំនុំជម្រះមិនបានធ្វើបែបនេះទេ។ **<u>សាក្សី ២ នាក់</u>**[2196]**៖** ផាន់ ហ៊ីម បានឆ្លើយថា គាត់បានរៀបការខុសពីចិត្ត តាមការស្នើពីប្តីគាត់។ ប៉ុន្តែ គាត់បានផ្តល់សក្ខីកម្មអំពីការវិវត្តនៃមនោសញ្ចេតនារបស់ពួកគេ ទៅតាមពេលវេលា មុននឹងរួមដំណេក និងបន្តរួមរស់ជាមួយគ្នាទៀត ក្រោយពីរបបនោះ[2197]។ ណុប ងឹម បានជួបប្រទះបទពិសោធន៍ប្រហាក់ប្រហែលនេះ[2198]។ គ្មានសក្ខីកម្មណាមួយអាចឱ្យគាំទ្រដល់ការសន្និដ្ឋានអំពីភាពធ្ងន់ធ្ងរនៃការឈឺចាប់ដែលបានទទួលរង ក្នុងកម្រិតដូចគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតឡើយ។ **<u>ដើមបណ្តឹងរដ្ឋប្បវេណី ៩ នាក់ ដែលបានផ្តល់សក្ខីកម្មអំពីអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍</u>**[2199]**៖** សក្ខីកម្ម ៧ ក្នុងចំណោម ៩ ត្រូវបានអង្គជំនុំជម្រះយកមកប្រើប្រាស់ ដើម្បីវាយតម្លៃលើការឈឺចាប់បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍។ មេធាវីការពារក្តីសូមយោងទៅទឡ្ហីករណ៍ដែលបានរៀបរាប់ខាងលើ[2200]។ ចំពោះពីរនាក់ទៀត គឺ សេង សឿន និង ហេង ឡៃហ៊ាង អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីការឈឺចាប់ ដោយសារតែការរៀបអាពាហ៍ពិពាហ៍របស់គាត់ ទៅតាមពេលវេលាបានឡើយ[2201]។ ដូច្នេះ ក្នុងវគ្គស្តីពីការរៀបអាពាហ៍

រៀបការដោយបង្ខំ សេចក្តីស្រឡាញ់មិនអាចចាប់បង្ខំបានទេ)។ <u>កុល ណែម</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ប្រហែលម៉ោង 15.41.54។

[2196] ផាន់ ហ៊ីម និង ណុប ងឹម។

[2197] <u>ផាន់ ហ៊ីម</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ប្រហែលម៉ោង 15.41.03។

[2198] សូមមើលខាងលើ កថាខណ្ឌ ១១៦៦-១១៧៥។ <u>ណុប ងឹម</u>៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** មុនម៉ោង 10.43.40។

[2199] អ៊ុំ យឿន, ជា ឌៀប, ព្រាប សុឃឿន, មុំ វុន, ហេង ឡៃហ៊ាង, ប៉ែន សុចាន់, សេង សឿន (បុរស) និង យស ផល (បុរស) និង ស៊ូ សុធារី (ស្ត្រីប្តូរភេទ)។

[2200] សូមមើលខាងលើ កថាខណ្ឌ ១១៦៦-១១៧៥។

[2201] ថ្វីត្បិតតែ សេង សឿន បានឆ្លើយថាបានរៀបការជាមួយប្អូនស្រីជីដូនមួយរបស់ថ្នាក់លើគាត់ តាមការទទូចរបស់ថ្នាក់លើគាត់ ប៉ុន្តែ គាត់មិនបានលើកឡើងទាល់តែសោះពីការឈឺចាប់នៅក្នុងការរៀបការរបស់គាត់ នៅចុងបញ្ចប់នៃការចូលមកបង្ហាញខ្លួន និងក៏មិនបានលើកឡើងពីអង្គហេតុដែរ។ <u>សេង សឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** ម៉ោង 10.07.35។ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 11.37.55។ ទោះបីជាគាត់បានលើកឡើងពីការឈឺចាប់ដោយសារតែការរៀបការរបស់គាត់ក៏ដោយ ក៏ ហេង ឡៃហ៊ាង មិនបាននិយាយជាពិសេសពីការឈឺចាប់របស់គាត់ដែលបណ្តាលមកពីការចាប់ខ្លួនប្តីគាត់ដែលត្រូវគេចោទថាក្បត់ និងការងារក្រោយពេលសម្រាលកូនរួចទេ។ <u>ហេង ឡៃហ៊ាង</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** ក្រោយម៉ោង 09.47.33 ម៉ោង 14.01.14 (ជូនដំណឹង និងអញ្ជើញឪពុកម្តាយឱ្យចូលរួមពិធីរៀបការ) ប្រហែលម៉ោង 09.54.47 ក្រោយម៉ោង 10.00.14 ម៉ោង 11.22.52 (គ្មានការឃ្លាំមើលនៅយប់ផ្សំដំណេក ហើយទាល់ក្រោយ

ពិពាហ៍តែឯង សូម្បីតែជាមួយការជ្រើសរើសសាក្សីដោយអង្គជំនុំជម្រះ ការប្រៀបធៀបរឿងរ៉ាវផ្សេងៗ មិនអាចឱ្យសន្និដ្ឋានអំពីការឈឺចាប់បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបនោះ ដែលមានផលប៉ះពាល់យូរអង្វែង ក្នុងកម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានឡើយ។ វាជារឿងខុសឆ្គងដែលអង្គជំនុំជម្រះបានសន្និដ្ឋានផ្សេងពីនេះ ពីព្រោះសក្ខីកម្មនៅសេសសល់មិនត្រូវតាមន័យនេះទេ។

### *២.២.២.២. សក្ខីកម្មដែលទទួលបាន ក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០២ ក្រៅពីវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍*

១១៧៩. ការពិនិត្យភ័ស្តុតាង ក្នុងសំណុំរឿង ក្រៅពីវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ បង្ហាញអំពីភាពខុសគ្នាខ្លាំងរវាងរឿងរ៉ាវរបស់ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ វាមានប្រយោជន៍ក្នុងការមើលឃើញការធ្វេសប្រហែសរបស់អង្គជំនុំជម្រះ តាមវគ្គនីមួយៗ រួចយើងធ្វើសំយោគ។

១១៨០. **<u>វគ្គសហករណ៍ត្រាំកក់</u>៖** ក្នុងចំណោមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ១៤ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែសាក្សី ជាំង ស្រីមុំ ម្នាក់គត់ ដែលបានឆ្លើយថា គាត់បានរៀបការមិនសមតាមបំណង។ ទោះបីជាគាត់បានលើកឡើងអំពីការកើតទុក្ខពីដំបូងបណ្តាលមកពីការរៀបការដោយបង្ខំចិត្តក៏ដោយ ក៏គាត់បានឆ្លើយថាគាត់យល់ឃើញថាជាការរៀបការមានសុភមង្គល ពីព្រោះគូគាត់បានបណ្តុះមនោសញ្ចេតនាបន្តិចម្តងៗចំពោះគ្នាទៅវិញទៅមក និងបានកសាងគ្រួសាររហូតដល់មកសព្វថ្ងៃ។ ម្យ៉ាងវិញទៀត គាត់បានលើកឡើងអំពីការវិវត្តនៃមនោសញ្ចេតនារបស់ប្តីគាត់[2202]។ ដូច្នេះ សក្ខីកម្មនេះមិនអាចឱ្យកំណត់កម្រិតធ្ងន់ធ្ងរនៃការឈឺចាប់ ដើម្បី

---

មកទើបពួកគាត់ផ្សំដំណេក "នៅសម័យហ្នឹង" ពួកគាត់មិនស្រឡាញ់គ្នាទេ។ គាត់បានលើកឡើងពីការស្លាប់របស់ប្តីគាត់នៅសម័យខ្មែរក្រហមនៅក្នុងសេចក្តីថ្លែងការឈឺចាប់ នៅចុងបញ្ចប់នៃការបង្ហាញខ្លួនរបស់គាត់ ឯកសារ **E1/476.1** ក្រោយម៉ោង 16.11.57 ("ចំពោះរូបនាងខ្ញុំវិញ នាងខ្ញុំបានទទួលរងទុក្ខវេទនាឥតស្រាកស្រាន្ត បន្ទាប់ពីប្តីរបស់នាងខ្ញុំ ដែលអង្គការផ្គូផ្គងឱ្យនោះត្រូវបានចាប់ខ្លួនយកទៅបាត់។ នាងខ្ញុំត្រូវបានជាប់ចោទជាសាច់ញាតិរបស់ជនក្បត់។ នាងខ្ញុំត្រូវបានគេដកហូតសិទ្ធប្រជាជនធម្មតាន") និងម៉ោង 16.16.22។

[2202] <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 10.45.59 ("ចេះតែបន់ស្រន់ អ៊ីចឹងថាបើពិតជាគូព្រេងរបស់ខ្ញុំឱ្យចិត្តខ្ញុំចេះតែមានការទោរទន់អ៊ីចឹង ហ្នឹងខ្ញុំនិយាយចិត្តខ្ញុំជាការពិតតែម្តង។ ខ្ញុំថ្ងៃណាក៏ខ្ញុំបន់ស្រន់ព្រះដែរ បើថា

ចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានឡើយ។

១១៨១. **វត្តុទំនប់១មករា៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១០ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង ម្នាក់គត់ ដែលបានឆ្លើយថា គាត់បានរៀបការមិនសមតាមបំណង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2203] ។ ប៉ុន្តែ គាត់មិនបាននិយាយអំពីការឈឺចាប់បណ្ដាលមកពីការរៀបអាពាហ៍ពិពាហ៍របស់គាត់ទេ ទាំងក្នុងពេលរៀបរាប់អង្គហេតុ និងក្នុងពេលថ្លែងទុក្ខសោក នៅចុងសវនាការ[2204]។

១១៨២. **វត្តុទំនប់ត្រពាំងថ្ម៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ៩ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ត្រីម្នាក់បានឆ្លើយថា គាត់បានរៀបការមិនសមតាមបំណង និងបុរសម្នាក់បាននិយាយអំពីការរៀបការរបស់គាត់ តាមការផ្សំផ្គុំពីអង្គការ ជាមួយនារី

---

ពិតមែនជាបុរសហ្នឹងជាគូព្រេងរបស់ខ្ញុំ សូមឱ្យចិត្តខ្ញុំទោរទន់មានចិត្តអាណិចគេ។ ពេលនោះ ហាក់បីដូចជាគូព្រេងរបស់ខ្ញុំរហូតមកដល់សព្វថ្ងៃនេះ ចិត្តខ្ញុំដូចថា វាចេះតែដាក់ចិត្តម្ដងបន្តិចៗ មានការស្រឡាញ់ប្ដីចាស") មុនម៉ោង 10.50.52។ ប្រតិចារឹក ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/255.1** មុនម៉ោង 09.29.47 ("ស. ដូចលោកស្រីបានឆ្លើយពីមុនមកហើយ ក្រោយ៧៩ លោកស្រីនៅតែរួមរស់ជាមួយគ្នាដដែល ហើយមានកូនមានចៅ។ [...] លោកស្រីអាចពន្យល់ជូនអង្គជំនុំជម្រះថា លោកស្រីគឺមិនបានជ្រើសរើសយកប្ដីលោកស្រីនោះធ្វើជាគូស្រករទេ តែខាងប្ដីលោកស្រីទេដែលបង្ខំឱ្យលោកស្រីវិញ។ តើអ៊ីចឹងដែរឬអត់? ឆ. ចាស ខ្ញុំសូមបញ្ជាក់ថា ចំពោះរូបខ្ញុំ ចំពោះប្ដីរបស់ខ្ញុំក៏អត់មានបង្ខំដែរ ប៉ុន្តែ គឺសម្រេចចិត្តដាក់ខ្លួន ដាក់ចិត្ត បើកាលនោះគឺអង្គការគឺសម្រេចតែរៀបចំទៅលើអ្នកណាមួយហើយ គឺយើងអត់មានប្រឆាំងជាមួយបក្សបានទេ [...] តែយើងដាក់ចិត្តថារួមជាមួយគ្នុងគ្រួសរមែនពិត ប៉ុន្តែចិត្តវាមានអត់ទាន់ចិត្តស៊ីចង្វាក់គ្នា ចំពោះប្ដីរបស់ខ្ញុំក៏អ៊ីចឹង ចំពោះខ្ញុំក៏អ៊ីចឹងដែរ")។ បន្ទាប់មក សាក្សីបានពន្យល់ពីការវិវត្តនៃមនោសញ្ចេតនារបស់ប្ដីគាត់៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ម៉ោង 10.48.26៖ "ចំពោះខ្ញុំ ចេះតែយល់ឃើញថា គាត់មិនស្រឡាញ់ខ្ញុំ [...]។ ប៉ុន្តែ តាមការពិត ខ្ញុំមើលតែខាងក្រៅទេ តែចិត្តគេៗអត់អីទេ ពិតមែនគេថាគេនារីផ្សេងគេមិនត្រូវជាគូព្រេងរបស់គេ គេចាត់ទុកថាខ្ញុំហ្នឹងជាគូព្រេង ម្ល៉ោះហើយពេលហ្នឹងគេដាក់ចិត្តហើយ")។

[2203] ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១០ នាក់ មាន ៣ នាក់ឆ្លើយថាបានរៀបការដោយពុំមានការបង្ខិតបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[2204] ចៅ ឡាង៖ ប្រតិចារឹក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** មុនម៉ោង 14.40.35 ក្រោយម៉ោង 15.32.56 (ទោះបីគាត់និយាយថាបានលែងលះគ្នានៅឆ្នាំ១៩៨៨-១៩៨៩ ក្ដី ប៉ុន្តែ គាត់បានបញ្ជាក់ថា នេះមិនពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងរបស់ពួកគាត់ទេ៖ "នាងខ្ញុំលែងលះគ្នានេះ ដោយសារតែការរៀបការដោយបង្ខំសម័យខ្មែរក្រហម គឺឪពុកម្ដាយខាងប្ដីខ្ញុំហ្នឹង គាត់មិនពេញចិត្ត")។

ម្នាក់ដែលគាត់មិនធ្លាប់ស្គាល់ពីមុនមក[2205]។ យី ឡៃស្រូវ បាននិយាយអំពីការឈឺចាប់បណ្ដាលមកពីអវត្តមាននៃការចូលរួមពីឪពុកម្ដាយ ក្នុងពិធីរៀបការរបស់គាត់ និងការលែងលះប្ដីដែលគាត់មិនស្រឡាញ់ ក្រោយរបបនោះ[2206]។ បទពិសោធន៍ដ៏ក្រៀមក្រំរបស់គាត់មិនអាចឱ្យចៅក្រមប្រកបដោយវិចារណញ្ញាណសន្និដ្ឋានអំពីការឈឺចាប់កម្រិតធ្ងន់ធ្ងរចាំបាច់ ដើម្បីកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត បានឡើយ។ ចំណែកឯ មាន លឿយ ចម្លើយរបស់គាត់ផ្ទុយពីសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។ ជាក់ស្ដែង ចំពោះការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំស្របតាមប្រពៃណី គាត់បានយល់ឃើញថា៖ "ទោះបីមិនដែលស្គាល់គ្នា មិនដែលបាននិយាយគ្នាយ៉ាងម៉េច អង្គការគេរៀបការឱ្យហើយ គឺថាត្រូវតែមានចិត្តផ្ចួចផ្ដើម និងស្រឡាញ់រាប់អាន"[2207]។ នៅចុងសវនាការ គាត់បានលើកឡើងអំពីការឈឺចាប់ធ្ងន់ធ្ងរបណ្ដាលមកពីមរណភាពរបស់ប្រពន្ធគាត់ដែលបានរៀបការ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានបង្ហាញអំពីមនោសញ្ចេតនាចំពោះប្រពន្ធគាត់[2208] ធ្វើឱ្យយើងយល់ឃើញផ្សេងអំពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអង្គជំនុំជម្រះមិនបានយកមកពិចារណា។

១១៨៣. **__វត្ថុផ្សេងទៀតនៃសំណុំរឿង ០០២/០២៖__** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ២១ នាក់ ដែលឆ្លើយថា ពួកគេបានរៀបការ ក្នុងរបបនោះ បុរស ២ នាក់ និងស្ត្រី ២ នាក់ បានអះអាងថាបានរៀបការមិនសមតាមបំណង ហើយស្ត្រីម្នាក់បានឆ្លើយថា គាត់បានរៀបការតាមការផ្សំផ្គុំពីអង្គការ[2209]។ មាន

---

[2205] __យី ឡៃស្រូវ__៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/334.**1 ប្រហែលម៉ោង 14.03.44។ __មាន លឿយ__៖ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ចន្លោះពីម៉ោង 14.10.00 ដល់ម៉ោង 14.17.45។

[2206] __យី ឡៃស្រូវ__៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/334.1** ប្រហែលម៉ោង 14.15.37 ប្រហែលម៉ោង 14.23.21។

[2207] __មាន លឿយ__៖ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** មុនម៉ោង 14.22.39 ចន្លោះពីម៉ោង 14.10.00 ដល់ម៉ោង 14.17.45 ក្រោយម៉ោង 14.17.45 ("ចំពោះខ្ញុំ ដោយសារតែខ្ញុំបានសិក្សាខាងគុណធម៌ច្រើន [...] ចាប់ដៃគ្នាហើយគឺត្រូវតែស្រឡាញ់")។

[2208] __មាន លឿយ__៖ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ប្រហែលម៉ោង 14.26.41 ម៉ោង 14.55.04 "ចំពោះខ្ញុំ មិនដែលមានអារម្មណ៍សប្បាយចិត្តទេ មានតែអារម្មណ៍សោកសង្រេង ព្រោះការស្លាយអាល័យ ដែលប្រពន្ធដែលធ្លាប់បានរស់នៅជុំគ្នា ទោះបីតិចក្ដី ច្រើនក្ដីក៏ជាប្ដីប្រពន្ធដែរ"។

[2209] ម៉ី សារឿន, ជាល ជឿន, ឃិន វ៉ាត និង ជុំ សាមឿន (រៀបការដោយបង្ខំ) និង ធុច ស៊ីថន (រៀបការដោយការរៀបចំដោយអង្គការ)។

តែសក្ខីកម្មរបស់ ឃិន វ៉ាត មួយគត់ ដែលត្រូវបានអង្គជំនុំជម្រះទទួលយក ក្នុងសំអាងហេតុរបស់ខ្លួន។ ប៉ុន្តែ ដូចបានឃើញពីខាងលើ សក្ខីកម្មរបស់គាត់មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថាមានការឈឺចាប់កម្រិតធ្ងន់ធ្ងរហួសប្រមាណបានឡើយ[2210]។ ចំពោះអ្នកផ្សេងទៀត គ្មានអ្នកណាម្នាក់បានបង្ហាញពីការឈឺចាប់បណ្តាលមកពីការរៀបការ ដែលអាចឱ្យសន្និដ្ឋានថាមានកម្រិតធ្ងន់ធ្ងរ តាមល័ក្ខខ័ណ្ឌតម្រូវបានឡើយ[2211]។

## ២.២.២.៣. ចម្លើយជាលាយលក្ខណ៍អក្សរ

១១៨៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានទាញផលវិបាកចេញពីការប្រៀបធៀបចម្លើយជាលាយលក្ខណ៍អក្សរទាំងអស់របស់សាក្សី ដែលបានឆ្លើយថាបានរៀបការមិនសមតាមបំណង។ ត្រង់នេះទៀត ភាពមិនគ្រប់គ្រាន់នៃភ័ស្តុតាងអំពីភាពធ្ងន់ធ្ងរនៃការឈឺចាប់ ជាផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចឱ្យកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត បានឡើយ។

---

[2210] សូមមើលខាងលើ កថាខណ្ឌ ១១៥៧-១១៧៥។

[2211] ជាល ជឿន៖ ប្រតិចារឹក ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/484.1** ចាប់ពីម៉ោង 10.01.59។ គាត់មិនបានលើកឡើងពីការឈឺចាប់ទេ។ ម៉ី សារឿន៖ ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/459.1** ក្រោយម៉ោង 14.20.44។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ក៏មិនបាននិយាយពីការឈឺចាប់បណ្តាលពីការរៀបការរបស់គាត់ នៅក្នុងសេចក្តីថ្លែង នៅចុងបញ្ចប់នៃការចូលមកបង្ហាញខ្លួនរបស់គាត់ដែរ។ ជុំ សាមឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/321.1** ម៉ោង 14.27.54។ រៀបការចុងឆ្នាំ១៩៧៨ និងបែកពីប្តីរបស់គាត់ ៣ ថ្ងៃក្រោយពេលរៀបការដោយមិនដែលឃើញប្តីម្តងទៀតទេ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏មិនបានលើកឡើងពីការឈឺចាប់ដោយសារការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ។ ជាចុងក្រោយ ទោះបីជាបានបញ្ជាក់ថាបានចាប់អារម្មណ៍លើបុរសម្នាក់ផ្សេងទៀត មុនពេលរៀបការដោយការរៀបចំក៏ដោយ ក៏ ធុច ស៊ីថន មិនបានបង្ហាញពីការឈឺចាប់ពិសេសទេ។ ប៉ុន្តែ គាត់បានពន្យល់ថាបានជ្រើសរើសរៀបការជាមួយបញ្ញវន្តជាជាងកសិករ៖ ធុច ស៊ីថន៖ ប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/500.1** ក្រោយម៉ោង 14.59.00 ("ខ្ញុំត្រូវបង្ខំចិត្តការជាមួយប្តីរបស់ខ្ញុំ ព្រោះខ្ញុំគិតម្តងទៀតដែរថា បើសិនជាខ្ញុំមិនការជាមួយទេ គេឱ្យខ្ញុំការជាមួយកម្មករកសិករ") ប្រហែលម៉ោង 14.53.54 ("បញ្ហាបារម្ភដែលខ្ញុំបារម្ភបំផុត គឺខ្ញុំខ្លាចគាត់មានប្រពន្ធមុន មានស្រីបារាំងមុន ឬយ៉ាងម៉េច។ ហើយខ្ញុំៗ បញ្ហាហ្នឹងខ្ញុំមានការស្ទាក់ស្ទើរ")។

១១៨៥. **ប្រតិចារឹកសំណុំរឿង ០០២/០១៖** ក្នុងចំណោមអ្នកដែលបានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែដើមបណ្តឹងរដ្ឋប្បវេណី ២ នាក់គត់ បានឆ្លើយថា ពួកគាត់បានរៀបការមិនសមតាមបំណង គឺ អែម អឿន និង យស ផល។ សក្ខីកម្មរបស់អ្នកទាំងពីរត្រូវបានទទួលយក ក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។ ប៉ុន្តែ គ្មានអ្នកណាម្នាក់បាននិយាយអំពីការឈឺចាប់បណ្តាលមកពីការរៀបការនោះទេ ក្នុងពេលថ្លែងទុក្ខសោក នៅចុងសវនាការ[2212]។ ទោះជាយ៉ាងណាក៏ដោយ រឿងរ៉ាវរបស់ពួកគាត់មិនអាចចាត់ទុកថាមានកម្រិតធ្ងន់ធ្ងរចាំបាច់ដល់ការកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត នោះឡើយ។

១១៨៦. **កំណត់ហេតុគាំទ្រដល់ដីកាដំណោះស្រាយ៖** ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយ ១១៦ បុគ្គល ២១ នាក់ បានឆ្លើយថា ពួកគេបានរៀបការដោយបង្ខំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្នុងនោះ ៥ នាក់ បានមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ (យី ឡៃស្រូវ, ជាំង ស្រីមុំ, ស៊ូ សុធាវី, ហេង ឡៃប៉ាង និង យស ផល)។ ក្នុងចំណោមកំណត់ហេតុ ១៦ ទៀត បុគ្គល ៤ នាក់ បានលើកឡើងអំពីសម្ពាធ និង/ឬការគំរាមកំហែងឱ្យរៀបការ ប៉ុន្តែ គ្មានអ្នកណាម្នាក់បាននិយាយអំពីការឈឺចាប់ធ្ងន់ធ្ងរបណ្តាលមកពីការរៀបការរបស់ពួកគេរៀងៗខ្លួនទេ[2213]។ ផ្ទុយទៅវិញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន មិនត្រឹមតែបានលើកឡើងអំពីការរីកលូតលាស់នៃមនោសញ្ចេតនា ក្នុងជីវិតជាគូស្រករបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងបានបញ្ជាក់អំពីការទទួលបានជីវិតល្អប្រសើរក្រោយការរៀប

---

[2212] សូមមើលខាងលើ កថាខណ្ឌ ១១៧៤, ១៣២៩។

[2213] កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ទេស ឌីង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5560** ERN 00375558-00375559 (ពេលរៀបការ បុរសៗមិនយំទេ ប៉ុន្តែ នារីៗវិញ យំយ៉ាងខ្លាំងក្នុងចិត្តរបស់ពួកគេ)។ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ម៉ៅ គ្រឿន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5561** ERN 00375550-00375551 ការដាក់ទោសចំពោះការបដិសេធរៀបការ។ កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ សន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ **E3/953** ERN 00274345 (ការដាក់ទោសចំពោះការបដិសេធ ប៉ុន្តែរំពឹងពីរបបអនុគ្រោះក្រោយរៀបការរួច)។ កំណត់ហេតុស្តាប់ចម្លើយ ឌុក ស្នួរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/408** ស./ឆ.៩០-៩២ ("តើអ្នករៀបការសប្បាយចិត្តនឹងការរៀបការដូចនោះដែរឬទេ? ឆ.៩០៖ យើងមានអារម្មណ៍ធម្មតា ប៉ុន្តែ យើងមិនហ៊ានបដិសេធទេ ពីព្រោះអំណាចស្ថិតនៅលើដៃរបស់អង្គការ។ ស.៖ តើមានមនុស្សបដិសេធមិនរៀបការដែរឬទេ? ឆ.៩១៖ គ្មានអ្នកណាម្នាក់បដិសេធទេ យើងត្រូវគោរពវិន័យអង្គការ។ ស.៖ តើអ្នកដែលរៀបការថ្មីៗនេះ ត្រូវបានគេបង្ខំឱ្យរួមភេទជាមួយគ្នាដែរឬទេ? ឆ.៩២៖ អ្នកខ្លះ អាចរស់នៅជាមួយគ្នា ឯអ្នកខ្លះទៀតមិនអាចរស់នៅជាមួយគ្នា ក៏បែកគ្នាទៅ")។

ការទៀតផង[2214]។ ទិដ្ឋភាពនេះត្រូវបានអង្គជំនុំជម្រះបំភ្លេចចោល ដែលបង្ហាញអំពីការពិនិត្យភ័ស្តុតាងដោយលម្អៀង។

១១៨៧. **កំណត់ហេតុមកពីសំណុំរឿង ០០៣-០០៤៖** ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៨៦ ដែលបានដាក់បញ្ចូលក្នុងសំណុំរឿង តាមសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បុគ្គល ៣០ នាក់ បានឆ្លើយថាពួកគេបានរៀបការខុសពីចិត្ត។ កំណត់ហេតុ ៥ ដែលបានពិនិត្យពីខាងលើរួចហើយ ត្រូវបានអង្គជំនុំជម្រះទទួលយក ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនពីផលប៉ះពាល់នៃការរៀបពាហ៍ពិពាហ៍[2215]។ ក្នុងចំណោមកំណត់ហេតុនៅសេសសល់ អ្នកខ្លះមិនបាននិយាយអំពីការឈឺចាប់បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ទាល់តែសោះ។ អ្នកខ្លះទៀតបានឆ្លើយថា ពួកគេបានបណ្តុះមនោសញ្ចេតនាចំពោះគ្នាក្រោយការរៀបអាពាហ៍ពិពាហ៍ និងរួមរស់ជាប្តីប្រពន្ធជាធម្មតា។ អ្នកខ្លះទៀតបានលើកឡើងជាពិសេសអំពីការឈឺចាប់បណ្តាលមកពីមរណភាពនៃប្តី/ប្រពន្ធ ដែលបានរៀបការក្នុងរបបនោះ ឬបានបញ្ជាក់ថា បទពិសោធន៍មិនល្អបានរលត់រលាយអស់ ទៅតាមពេលវេលា[2216]។

---

[2214] កំណត់ហេតុស្តាប់ចម្លើយ ខៀវ ហន ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5559** ERN 00375526 (ពួកគាត់រស់នៅជាមួយគ្នាដូចបងប្រុស ប្អូនស្រី នៅក្នុងរបបខ្មែរក្រហម និងរៀបការជាមួយគ្នាជាថ្មីក្រោយរបបដួលរលំ ទៅតាមសំណើរបស់ម្តាយក្មេកគាត់)។ កំណត់ហេតុស្តាប់ចម្លើយ តាន់ វ៉ាដ៏នី ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ **E3/102** ERN 00350664 (ក្រោយពេលរៀបការជាមួយបញ្ញវន្តម្នាក់ដូចគាត់ដែរ ប្តីប្រពន្ធបានទៅជួបជុំឪពុករបស់ប្តីគាត់នៅក្រសួងការបរទេស)។ កំណត់ហេតុស្តាប់ចម្លើយ ជា ធី ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ **E3/5184** ERN 00197874 (គាត់ និងប្រពន្ធគាត់បានមករស់នៅក្នុងភូមិកំណើតរបស់ប្រពន្ធគាត់ ក្រោយរបបដួលរលំ)។ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហង់ អ៊ិន ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5558** ERN 00375518 ("ខ្ញុំមានឆន្ទៈមានកូនដទៃទៀតជាមួយគាត់ ពីព្រោះនៅពេលនោះ ខ្ញុំចាប់ផ្តើមចូលចិត្តប្តីរបស់ខ្ញុំ" ។ ពួកគាត់លែងលះគ្នាក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ពីព្រោះប្តីគាត់បោកប្រាស់គាត់ និងមានប្រពន្ធពីរបីនាក់ទៀត)។

[2215] ករណី សួន យឹម, ខែត សុខន, ស៊ុំ ប៉ែត, មាស សារ៉ន, វ៉ា លឹមហ៊ុន។ សូមមើលខាងលើ កថាខណ្ឌ ១១៥៧-១១៧៥។

[2216] សូមមើលឧទាហរណ៍៖ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9662** ស./ឆ.៥៥-៥៩ (ពួកគាត់ស្រឡាញ់គ្នាក្រោយរៀបការរួច) ស./ឆ.៨៦ (ពួកគាត់មានអារម្មណ៍ដូចជាប្តីប្រពន្ធផ្សេងទៀតដែរ)។ គាត់មិនបានលើកឡើងពីការរៀបការរបស់គាត់នៅក្នុងផ្នែក "ព្យសនកម្ម" នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ឯកសារ **E3/4963**។ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ **E3/9826** ស./ឆ.១៦៨ ("ពីមុនខ្ញុំធ្លាប់មានអារម្មណ៍អន់ចិត្ត មិនបានរៀការដូចនៅក្នុងសម័យនេះ រៀបការដោយ

១១៨៨. **សេចក្តីសន្និដ្ឋានអំពីកំហុស យោងតាមភ័ស្តុតាងទាំងមូល៖** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិនិត្យភ័ស្តុតាងទាំងមូល ក្នុងសំណុំរឿង មុននឹងសន្និដ្ឋានអំពីកម្រិតធ្ងន់ធ្ងរនៃការឈឺចាប់ ឬដោយមិនអើពើនឹងភ័ស្តុតាងផ្ទុយនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួន។ ជាក់ស្តែង ការវិភាគដោយយកចិត្តទុកដាក់លើភ័ស្តុតាងទាំងមូលផ្ទុះបញ្ចាំងឱ្យឃើញច្បាស់ថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ក្នុងការសន្និដ្ឋានអំពីភាពជាតំណាងនៃរឿងរ៉ាវ ដែលត្រូវបានជ្រើសរើសយកមកបង្ហាញអំពីការឈឺចាប់របស់ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចទាញការសន្និដ្ឋានផ្ទុយនឹងភ័ស្តុតាងភាគច្រើន ដែលបង្ហាញអំពីភាពខុសគ្នាខ្លាំង រវាងភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជ្រើសរើសលើប្រធានបទនេះ និងសាក្សីផ្សេងទៀត។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីការឈឺចាប់កម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានឡើយ។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ[2217]។

## ២.៣. កំហុសពាក់ព័ន្ធនឹងបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងការអនុវត្តបទបញ្ជា

១១៨៩. អង្គជំនុំជម្រះមិនបានបង្ហាញធាតុផ្សំសត្យានុម័តិ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នោះឡើយ[2218]។ ដូច្នេះឈរតែលើមូលដ្ឋាននេះ តុលាការកំពូលនឹងច្រានចោលការផ្តន្ទាទោស។ ក្នុងករណីលើកលែងដែលតុលាការកំពូលយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀតមានធាតុផ្សំគ្រប់គ្រាន់ តុលាការកំពូលត្រូវកត់សម្គាល់ថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ក្នុងការសន្និដ្ឋានអំពីចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។ ជាក់ស្តែង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ពាក់ព័ន្ធនឹងខ្លឹមសារនៃបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ (២.៣.១) និង

---

គ្មានអាចារ្យ គ្មានញាតិមិត្តចូលរួម រៀបការពេលនោះគ្រាន់តែចាប់ដៃហើយក៏ចប់។ ប៉ុន្តែ ដោយសារពេលវេលាកន្លងយូរទៅៗ អារម្មណ៍ទាំងអស់នោះក៏រំសាយបន្តិចម្តងៗទៅ”)។

[2217] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩១-៣៦៩២។

[2218] សូមមើលខាងលើ កថាខណ្ឌ ៦៥៨-៦៦៥។

ការអនុវត្តបទបញ្ជា (២.៣.២) ដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែល ខៀវ សំផន បានចូលរួម ដែលបង្ហាញអំពីចេតនាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម (២.៣.៣)។

១១៩០. *[កថាខណ្ឌជាន់គ្នា ដែលត្រូវលុបចោល ក្រោយពីកែតម្រូវ ប៉ុន្តែ រក្សាទុកដដែល ដើម្បីកុំឱ្យខុសលេខរៀង]*[2219]។

## ២.៣.១. កំហុសពាក់ព័ន្ធនឹងខ្លឹមសារបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

១១៩១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងខ្លឹមសារបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីសម្រេចកិច្ចការនេះ អង្គជំនុំជម្រះបានជ្រើសយកការបំភ្លេចចោលនូវគោលការណ៍ស្តីពីការព្រមព្រៀង ដែលអង្គភាពផ្លូវការរបស់ ប.ក.ក បានកំណត់យ៉ាងច្បាស់ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ (២.៣.១.១) និងបានទាញសេចក្តីសន្និដ្ឋានមិនសមទំនងអំពីវត្ថុបំណងនៃបទបញ្ជាជាផ្លូវការ (២.៣.១.២) ដោយបំភ្លៃ និងបំប្លែងភស្តុតាងដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

### *២.៣.១.១. កំហុសពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌទាំងពីរនៃការរៀបអាពាហ៍ពិពាហ៍ ដែល ប.ក.ក បានកំណត់*

១១៩២. អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនបានលើកឡើង គឺជាលទ្ធផលនៃសេចក្តីណែនាំពីថ្នាក់កំពូលរបស់ ប.ក.ក។ អង្គជំនុំជម្រះបានបដិសេធឯកសារផ្លូវការរបស់ ប.ក.ក ស្តីពីល័ក្ខខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ និងសក្ខីកម្មទាំងអស់របស់អតីតកម្មាភិបាលនៃរបបនោះ ដែលនិយាយផ្ទុយពីការរកឃើញរបស់អង្គជំនុំជម្រះ។ ជាក់ស្តែង ដើម្បីសន្និដ្ឋានថាមានគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះបានប្រកាន់យកវិចារណកិច្ចខុសឆ្គង៖ អត្ថិភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាភស្តុតាងបង្ហាញថា មានគោលនយោបាយស្តីពីការការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ បន្ទាប់មកទៀត

---

[2219] *[កំណត់សម្គាល់ជើងទំព័រជាន់គ្នា ដែលត្រូវលុបចោល ក្រោយពីកែតម្រូវ ប៉ុន្តែ រក្សាលេខទុកដដែល ដើម្បីកុំឱ្យខុសលេខរៀង]*។

ការវិភាគរបស់អង្គជំនុំជម្រះបានព្យាយាមគាំទ្រដល់សម្មតិកម្មពីដើមទីនេះ ដោយជ្រើសរើសសក្ខីកម្ម ព្រមទាំងបំភ្លៃឯកសារ និងសុន្ទរកថាផ្លូវការ ជាជាងការពិនិត្យភស្តុតាងដោយមិនលម្អៀង។

• **<u>ការវិភាគខុសលើឯកសារផ្លូវការ</u>**

១១៩៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ក្នុងការបកស្រាយលើបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ក្នុងការវិភាគមិនគ្រប់ជ្រុងជ្រោយ និងដោយលម្អៀង ទៅលើភស្តុតាង អង្គជំនុំជម្រះបានច្រានចោលសញ្ញាណដ៏សំខាន់នៃការយល់ព្រមរៀបអាពាហ៍ពិពាហ៍ នៅក្នុងគោលការណ៍របស់ខ្មែរក្រហម។ ប៉ុន្តែ អង្គជំនុំជម្រះបានដកស្រង់ចេញពីទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" ចេញផ្សាយខែវិច្ឆិកា ឆ្នាំ១៩៧៨ សម្រាប់យុវជន និងយុវនារីបដិវត្តន៍ នូវល័ក្ខខ័ណ្ឌពីរដែលត្រូវបានកំណត់សម្រាប់ការរៀបអាពាហ៍ពិពាហ៍៖ "ទីមួយ សាមីខ្លួនទាំងសងខាងយល់ព្រម។ ទីពីរ សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ [...]"[2220]។ ដើម្បីគេចវេះពីការផ្តល់តម្លៃជាភស្តុតាងដល់ឯកសារដ៏ជាក់ច្បាស់មួយនេះ អង្គជំនុំជម្រះបានពន្យល់ហេតុផលដោយមិនត្រឹមត្រូវថា វិធានទាំងនេះត្រូវបានចេញយឺតពេលទៅហើយ[2221]។ ផ្ទុយទៅវិញ ភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា គោលការណ៍ស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍មានតាំងពីមុនឆ្នាំ១៩៧៨ មកម្ល៉េះ។ ជាក់ស្តែង គោលការណ៍នេះមាននៅក្នុងសីលធម៌ ១២ ប្រការរបស់ ប.ក.ក ជាគោលការណ៍មូលដ្ឋានរបស់បក្ស ដែលត្រូវបានបំពាក់បំប៉នដល់យុទ្ធជន និងកម្មាភិបាលបដិវត្តន៍ តាំងពីឆ្នាំ១៩៦៨។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានលាក់បាំងសក្ខីកម្មរបស់សាក្សីជាច្រើន ដែលមិនត្រឹមតែបានលើកឡើងអំពីអត្ថិភាពសីលធម៌ ១២ ប្រការ ប៉ុណ្ណោះទេ ថែមទាំងបានគូសបញ្ជាក់ជាពិសេសអំពីសារៈសំខាន់នៃសីលធម៌ទាំងនេះចំពោះបក្សទៀតផង[2222]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរណាស់ ពីព្រោះសាក្សីបានបញ្ជាក់

---

[2220] យុវជន និងយុវនារីបដិវត្ត ខែតុលា ឆ្នាំ១៩៧៨ ឯកសារ **E3/765** ទំព័រ ៣៧-៣៨ ERN 00376494-00376495។

[2221] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤២។

[2222] សីលធម៌ទាំងនេះជា "ក្រិត្យវិន័យរបស់បក្សដែលជនបដិវត្តគ្រប់រូបត្រូវតែគោរព អនុវត្តតាមតាមគ្រប់ ខ ដោយជ្រួតជ្រាប និងភ្ជាក់រឭក" យុវជន និងយុវនារីបដិវត្ត ខែតុលា ឆ្នាំ១៩៧៨ **E3/765** ទំព័រ ២៤ ERN 00376487។ សាក្សីជាច្រើនបានបញ្ជាក់ពីសីលធម៌ទាំងនេះ ព្រមទាំងសារសំខាន់នៃសីលធម៌ទាំងនេះនៅក្នុងសវនាការ៖ <u>សាឡុត បាន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/66.1** ប្រហែលម៉ោង 09.57.51 មុនម៉ោង 10.23.01 ក្រោយម៉ោង 15.04.19 មុនម៉ោង 15.38.59 ("ស.៖ តើកិច្ចប្រជុំទាំង

ក្នុងសវនាការថា លក្ខខណ្ឌស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍ពីសាមីខ្លួន កើតមានតាំងកាលបរិច្ឆេទនេះមកម្ល៉េះ[2223]។ ពេលបំភ្លេចចោលភស្តុតាងសំខាន់ទាំងនេះ ដោយសារតែវាមិនស្របនឹងការគំនិតរបស់ខ្លួន អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយស្តែងឱ្យឃើញភាពលម្អៀង។

- **ចម្លើយស៊ីចង្វាក់គ្នារបស់កម្មាភិបាល ដែលត្រូវបានបដិសេធចោលយ៉ាងអយុត្តិធម៌**

១១៩៤. កំហុសចេតនារបស់អង្គជំនុំជម្រះស្តែងឡើងយ៉ាងច្បាស់ក្រឡែត ពីព្រោះអង្គជំនុំជម្រះបានបដិសេធចោលជាប្រព័ន្ធនូវសក្ខីកម្មរបស់អតីតកម្មាភិបាល ដែលបានបញ្ជាក់អះអាងអំពីភាពចាំបាច់នៃការយល់ព្រមពីសាមីខ្លួន ដោយហេតុថាអតីតកម្មាភិបាលទាំងនោះ "មានទំនោរចង់បន្ថយការទទួលខុសត្រូវ

---

អស់នេះ គេអាច-- នៅក្នុងកិច្ចប្រជុំទាំងអស់ហ្នឹង គេអាចរិះគន់អ្នកផ្សេងដែលយោងទៅតាមសីលធម៌ទាំង ១២ ប្រការ ដែលលោកបាននិយាយ ហើយតើគេត្រូវបង្ហាញអំពីចំណុចខ្សោយ ឬក៏កំហុសដែលគេបានប្រព្រឹត្តដែរឬទេនៅក្នុងកិច្ចប្រជុំបែបហ្នឹង? ឆ.៖ បាទ គេបង្ហាញ បើអ្នកឯងចូលទៅខាងប្រេត ឬក៏ចូលទៅខាងបិសាច នោះអ្នកនឹងកែទៅ។ បើអ្នកមិនកែទេ អ្នកអន្តរាយខ្លួនឯង ហើយក៏អន្តរាយដល់ប្រទេសជាតិដែរ")។ ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/67.1** ម៉ោង 15.24.33។ យុន គីម៖ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/89.1** ម៉ោង 09.34.01 ("ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងបញ្ហាសីលធម៌ គឺបានអប់រំណែនាំជាបន្តបន្ទាប់ដែរ។ បាទ ពីព្រោះបញ្ហាសីលធម៌នេះ ជាបញ្ហាមួយដែលអាចប៉ះពាល់ដល់គោលនយោបាយរបស់បក្សហ្នឹង។ អ៊ីចឹង គឺជាវិធានមួយតឹងរ៉ឹង។ បាទ អ្នកដែលមានសីលធម៌ហ្នឹង គឺជាកំហុសដ៏ធ្ងន់ធ្ងរ។ ដូច្នេះហើយបានជាទាំងអស់គ្នា ទាំងគេហ្នឹង ទាំងប្រជាពលរដ្ឋហ្នឹងប្រយ័ត្នប្រយែងទាំងអស់គ្នា ពិសេសក្នុងចំណោមយុវវ័យ។ បាទ ពីព្រោះយើងផ្តល់សិទ្ធិឱ្យដែរ មិនមែនថាមិនផ្តល់សិទ្ធិទេ។ បើសិនណាចង់បានប្តីប្រពន្ធ គឺឱ្យរាយការណ៍ មកតាមគណៈរបស់គេ។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/51.1** ចន្លោះពីម៉ោង 11.08.37 ដល់ម៉ោង 11.12.01 ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/436.1** ក្រោយម៉ោង 09.29.44 ប្រហែលម៉ោង 09.36.38។ គឹម វុន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ក្រោយម៉ោង 10.11.19។ នី កន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/76.1** ក្រោយម៉ោង 15.33.26។

[2223] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចាប់ពីម៉ោង 13.47.10 ("គឺចាប់ពីឆ្នាំ ៧០ ឬ ៧១ តម្រូវឱ្យអនាគតប្តីប្រពន្ធព្រមព្រៀងគ្នាទើបអាចរៀបការបាន")។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/51.1** ចាប់ពីម៉ោង 11.08.23។ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/436.1** ក្រោយម៉ោង 09.29.44 និងក្រោយម៉ោង 09.45.08 (គាត់បានរំឮកពីសីលធម៌ទាំង១២ ប្រការ ដែលមានតាំងពីឆ្នាំ១៩៦៨ និងដំណើរការរបស់គាត់ក្នុងការស្នើសុំរៀបការជាមួយប្រពន្ធរបស់គាត់នៅឆ្នាំ១៩៧៤)។

ផ្ទាល់ខ្លួនពួកគេតែប៉ុណ្ណោះ”[2224]។ ប៉ុន្តែ ពួកគេមកពីតំបន់ផ្សេងៗគ្នា និងមានមុខងារខុសៗគ្នាខាងស៊ីវិល និងយោធា។ ពួកគេភាគច្រើនមិនត្រឹមតែគ្មានតួនាទីពាក់ព័ន្ធនឹងការចាត់ចែងលើការរៀបអាពាហ៍ពិពាហ៍ក្នុងក្របខ័ណ្ឌនៃមុខងាររបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងបានទទួលការធានាមិនចោទប្រកាន់ពីសហព្រះរាជអាជ្ញាថែមទៀតផង ហេតុនេះ ពួកគេគ្មានហេតុផលអ្វីត្រូវកុហកនោះទេ[2225]។ ម្យ៉ាងទៀត ទាំងភ័ស្តុតាង និងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា គ្មានអ្នកណាម្នាក់ ក្នុងចំណោមពួកគេ មានតួនាទីជាអ្នកទទួលខុសត្រូវក្នុងការរៀបចំពិពាហ៍ពិពាហ៍ដោយបង្ខំទេ។ លើសពីនេះទៀត កម្មាភិបាលទាំងនេះជាអ្នកស័ក្តិសមបំផុតក្នុងការដឹងអំពីបទបញ្ជា ឬសេចក្តីណែនាំពីថ្នាក់ដឹកនាំ ប.ក.ក ដែលត្រូវដាក់ឱ្យអនុវត្តនៅតាមមូលដ្ឋាន។ ដូច្នេះ ការអះអាងដោយគ្មានមូលដ្ឋានថា ពួកគេមានទំនោរចង់បន្ថយការទទួលខុសត្រូវផ្ទាល់ខ្លួន ខណៈដែលសក្ខីកម្មរបស់ពួកគេមានភាពស៊ីចង្វាក់គ្នានឹងឯកសារផ្លូវការរបស់ ប.ក.ក និងចម្លើយរបស់សាក្សីមិនមែនជាកម្មាភិបាលផ្សេងទៀត[2226] គឺជាការសន្និដ្ឋានមិនសមហេតុផល។

១១៩៥. ម្យ៉ាងវិញទៀត ដូចបានរំឭកពីខាងលើ សាក្សី ដែលបានលើកឡើងអំពីសីលធម៌ ១២ ប្រការ ក្នុងនោះមានប្រការស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍ មិនមែនជាកម្មាភិបាលនោះទេ។ ត្រង់នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសស្តែងចេញពីការប្រើឆន្ទានុសិទ្ធិ ដោយបានបដិសេធសំណើរបស់មេធាវី

---

[2224] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦២៣ ដែលយោងទៅ កថាខណ្ឌ ៣៦១៧ (ឯក ហឿន, ប៉ាន ឈួង, ឌិ ហួ, សៅ សារុន, រៀល សន, មាស វឿន, ទេព ប៉ូច, យូ វ៉ាន់) កថាខណ្ឌ ៣៦៧៥, ៣៦១៣។

[2225] សូមមើលឧទាហរណ៍ លិខិតធានាអំពីការមិនចោទប្រកាន់ អ៊ុល ហឿន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E202/146.1** មានតែជាភាសាខ្មែរ, លិខិតធានាអំពីការមិនចោទប្រកាន់សាក្សី ឌិ ហួ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E202/167.1**, លិខិតធានាអំពីការមិនចោទប្រកាន់សាក្សី សៅ សារុន ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E202/256.1**, លិខិតធានាអំពីការមិនចោទប្រកាន់សាក្សី រៀល សន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E202/145.1**, លិខិតធានាអំពីការមិនចោទប្រកាន់សាក្សី មាស វឿន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E202/17/2**, លិខិតធានាអំពីការមិនចោទប្រកាន់សាក្សី ទេព ប៉ូច ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E202/273.1**, លិខិតធានាអំពីការមិនចោទប្រកាន់សាក្សី យូ វ៉ាន់ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E202/235.1**។ អ្នកដែលឆ្លើយថាបានមិនរៀបចំអាពាហ៍ពិពាហ៍៖ ឯក ហឿន៖ ប្រតិចារឹក ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/299.1** ប្រហែលម៉ោង 15.15.09, រៀល សន៖ ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/279.1** ក្រោយម៉ោង 11.07.40។

[2226] សូមមើលខាងលើ កថាខណ្ឌ ១១៥៧-១១៨៨។

ការពារក្ដីសុំកោះហៅសាក្សី François PONCHAUD ឱ្យមកផ្ដល់សក្ខីកម្មម្ដងទៀត[2227]។ ជាក់ស្ដែង សាក្សីរូបនេះ ដែលមានវត្តមាននៅកម្ពុជា មុនឆ្នាំ១៩៧៥ បានលើកឡើងអំពីសីលធម៌ ១២ ប្រការ នៅក្នុងសៀវភៅរបស់គាត់[2228]។ ដោយសារតែការបំបែកកិច្ចដំណើរការនីតិវិធី គាត់មិនអាចត្រូវបានសួរដេញដោលអំពីបទបញ្ញាស្ដីពីការរៀបអាពាហ៍ពិពាហ៍នោះទេ។ ការបដិសេធពីសំណាក់អង្គជំនុំជម្រះមិនព្រមស្ដាប់ការបំភ្លឺពីសាក្សីអព្យាក្រឹតអំពីបញ្ហានេះបានបង្កព្យសនកម្មដល់ម្ចាស់បណ្ដឹងសាទុក្ខ ដោយមិនអាចប្រែកែកបាន។ ផ្ទុយមកវិញ អង្គជំនុំជម្រះបានសម្រេចទទួលយកចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានជ្រើសរើសជាពិសេស ឱ្យមកនិយាយអំពី កាលៈទេសៈឈឺចាប់នៃការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន ដើម្បីសន្និដ្ឋានថាមានគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស[2229]។ ក្រៅពីវិមតិសង្ស័យជាបទដ្ឋាននៃការវាយតម្លៃលើភ័ស្ដុតាង ដែលរំលោភលើភាពយុត្តិធម៌នៃការជំនុំជម្រះក្ដី ដំណើរការរបស់អង្គជំនុំជម្រះក្នុងការសន្និដ្ឋានជាទូទៅរបស់ខ្លួនចោទជាបញ្ហាដ៏សំខាន់យ៉ាងពិតប្រាកដ។

***<u>ការវិភាគមិនគ្រប់ជ្រុងជ្រោយ និងលម្អៀងទៅលើសក្ខីកម្ម</u>***

១១៩៦. ភ័ស្ដុតាង ដែលបានបង្ហាញក្នុងសវនាការស្ដីពីការរៀបអាពាហ៍ពិពាហ៍ មានច្រើនសណ្ឋាន។ វគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍បានផ្ដោតជាសំខាន់លើបទពិសោធន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលតាំងខ្លួនជាជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ប៉ុន្តែ ដើម្បីទទួលបានចក្ខុវិស័យជារួមនៅថ្នាក់ជាតិ

---

[2227] សេចក្ដីសម្រេច ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E408/6/2** ជាអាទិ៍ នៅកថាខណ្ឌ ៦ អង្គជំនុំជម្រះមានកំហុសក្នុងការពិចារណាថា សក្ខីកម្មរបស់គាត់ "គឺជាផ្នែកនៃភ័ស្ដុតាងដែលមាននៅក្នុងសំណុំរឿង ០០២/០២" និងប្រធានបទទាក់ទងនឹងសហករណ៍ ការដ្ឋានការងារ និងការរៀបការដោយបង្ខំ។ សូមមើលខាងលើ កថាខណ្ឌ ១៦៧ និងជើង ១៩១។

[2228] សូមមើលជាអាទិ៍ ឯកសារយោងក្នុងសៀវភៅរបស់គាត់៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/294.1** ចន្លោះពីម៉ោង 13.35.03 ដល់ម៉ោង 13.38.21។ នៅក្នុងសំណើចូលមមកបង្ហាញខ្លួនរបស់យើងសម្រាប់សំណុំរឿង ០០២/០២ ដើម្បីនិយាយពីបរិបទប្រវត្តិសាស្ត្រ ជម្លោះប្រដាប់អាវុធ សហករណ៍ និងការដ្ឋានការងារ និងការកំណត់គោលដៅចំពោះក្រុមជាក់លាក់មួយចំនួន សំណើរបស់ ខៀវ សំផន (ឧបសម្ព័ន្ធ) ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E305/5.2** ERN 00986397។

[2229] សូមមើលផងដែរ សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២៣-២៣២៨, ២៤៥០-២៤៥១។

អង្គជំនុំជម្រះមិនអាចទាញសេចក្ដីសន្និដ្ឋានទូទៅលើអត្ថិភាពនៃករណីដោយឡែកបានទេ។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានអើពើនឹងភស្តុតាងផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួន។ ការមិនពិចារណាលើបញ្ហានៃភាពជាតំណាងនៃសក្ខីកម្មទាំងនេះនៅថ្នាក់ជាតិដែលមេធាវីការពារក្ដីបានលើកឡើង[2230] កើតចេញពីដំណើរការខុសឆ្គង។ កំហុសទាំងនេះមាននៅក្នុងការពិនិត្យភស្តុតាង ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ និងក្នុងវគ្គផ្សេងទៀត ក៏ដូចជាក្នុងចម្លើយជាលាយលក្ខណ៍អក្សរ។ កំហុស ចំពោះភស្តុតាងប្រភេទនីមួយៗ នឹងត្រូវពិនិត្យមួយម្ដងៗ ព្រមទាំងផលវិបាកខាងស្ថិតិដែលកើតចេញពីសេចក្ដីសន្និដ្ឋានខុសរបស់អង្គជំនុំជម្រះ។

- **<u>វគ្គស្តីការរៀបអាពាហ៍ពិពាហ៍</u>**

១១៩៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានទាញផលវិបាកចេញពីសក្ខីកម្មរបស់សាក្សី ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍[2231]។ ជាក់ស្ដែង សាក្សីជាច្រើនបានបញ្ជាក់អះអាងអំពីល័ក្ខខ័ណ្ឌស្ដីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍នៃបទបញ្ជាផ្លូវការរបស់ ប.ក.ក។ ក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនអង្គជំនុំជម្រះបានច្រានចោលដោយមិនត្រឹមត្រូវ ជាអាទិ៍ នូវសារៈសំខាន់នៃសក្ខីកម្ម ដែលទោះបីជាបានលើកឡើងអំពីបទពិសោធន៍មួយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ សម្រាប់ករណីរបស់ខ្លួនផ្ទាល់ក៏ដោយក៏បាននិយាយពីបទពិសោធន៍ផ្សេងទៀតនៃការរៀបអាពាហ៍ពិពាហ៍ផងដែរ។ គឺករណីរបស់ ណុប ធីម និង សេង សឿន ជាអតីតកម្មាភិបាលថ្នាក់ខ្ពស់[2232]។ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនផ្សេង

---

[2230] សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៤១-២៤៤៤។

[2231] សរុប សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១៤ នាក់ បូកអ្នកជំនាញ ២ នាក់។ កំហុសដែលបានប្រព្រឹត្តិក្នុងការពិនិត្យសក្ខីកម្មរបស់អ្នកជំនាញ នឹងត្រូវពិនិត្យនៅខាងក្រោម។ សូមមើលយោបល់របស់អ្នកជំនាញខាងក្រោម កថាខណ្ឌ ១២០៩-១២១០។

[2232] <u>ណុប ធីម</u>៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** មុនម៉ោង 11.20.45 ម៉ោង 13.39.01 (ការរៀបការដោយបង្ខំសម្រាប់សមាជិកកង និងអ្នកស្រឡាញ់គ្នា)។ <u>សេង សឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** មុនម៉ោង 15.26.31 (រៀបការជាមួយប្អូនស្រីជីដូនមួយរបស់ថ្នាក់លើគាត់)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** ក្រោយម៉ោង 09.59.48 និង ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** មុនម៉ោង 11.21.32 (លទ្ធភាពបដិសេធការរៀបការដោយការរៀបចំ សម្រាប់ការរៀបការនៅស្ពាន)។

ទៀត ជាកម្មាភិបាលថ្នាក់ទាប ឬជាប្រជាជនសាមញ្ញ ក៏បានអះអាងផងដែរថា បទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍មិនតាមបំណងរបស់ពួកគេ មិនដូចអ្នកផ្សេងទេ[2233]។

១១៩៨. ដូច្នេះ ចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកោះហៅជាពិសេសឱ្យមកនិយាយអំពីបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួន ៧ នាក់ ស្មើនឹង ៥០% បានលើកឡើងដោយចិត្តឯងថា ពួកគេបានដឹងអំពីការអនុវត្តផ្សេងទៀត ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2234]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានចៀសវាងទាញផលវិបាកពីសក្ខីកម្មទាំងនេះ ដែលបង្ហាញអំពីអវត្តមាននៃគោលនយោបាយឯកសណ្ឋាន។ ដូចយើងនឹងឃើញខាងក្រោម អង្គជំនុំជម្រះបានបន្តធ្វើខុសទៀត ដោយបានបដិសេធមតិយោបល់របស់អ្នកជំនាញដែលមានការកត់សម្គាល់ដូចគ្នានេះដែរ[2235]។

## *<u>វត្ថុផ្សេងទៀតក្រៅពីការរៀបអាពាហ៍ពិពាហ៍ ក្នុងសំណុំរឿង ០០២/០២</u>*

១១៩៩. ដំណើរការរបស់អង្គជំនុំជម្រះស្តែងឱ្យឃើញកំហុសឆ្គង ពីព្រោះអង្គជំនុំជម្រះមិនបានពិចារណាលើភ័ស្តុតាង ក្នុងវត្ថុផ្សេងទៀត ដែលមិនអាចឱ្យសន្និដ្ឋានថាមានគោលនយោបាយឯកសណ្ឋានស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

---

[2233] ហេង ឡៃហ៊ាង៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** មុនម៉ោង 13.46.50 មុនម៉ោង 13.48.54 (គាត់អាចបដិសេធនឹងសំណើរៀបការមុនៗជាច្រើន និងបានបដិសេធមិនរៀបការជាមួយបុរសផ្សេងៗគ្នាដោយគ្មានផលវិបាកអ្វីសោះ) ក្រោយម៉ោង 13.39.13 (ត្រូវមានការយល់ព្រមរបស់ប្តីប្រពន្ធ មុននឹងរៀបការពួកគេ "ដល់ពេលផ្តួងហើយ សួរសាមីខ្លួនទាំងពីរទៅ គេយល់ព្រម យល់ស្របទៅ")។ យស ផល៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 10.39.30 ប្រហែលម៉ោង 11.09.24។ ផាន់ ហ៊ឹម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ចាប់ពីម៉ោង 14.22.10 (រៀបការដោយបង្ខំសម្រាប់គាត់ ប៉ុន្តែតាមសំណើរបស់ប្តីគាត់។ អត់មានការបង្ខំសម្រាប់អ្នកផ្សេងទៀតនៅក្នុងក្រុមរបស់គាត់ទេ)។ អ៊ំ យឿន៖ ប្រតិចារឹក ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ម៉ោង 10.38.13។ ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ក្រោយម៉ោង 15.10.03។

[2234] សូមមើល ឧបសម្ព័ន្ធ ខ១ និង ខ៥។

[2235] សូមមើលយោបល់របស់អ្នកជំនាញខាងក្រោម កថាខណ្ឌ ១២០៩-១២១០។

១២០០. **<u>វគ្គសហករណ៍ត្រាំកក់</u>៖** ក្នុងវគ្គនេះ បុគ្គល ១៤ នាក់ បានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបានបដិសេធជាប្រព័ន្ធនូវសក្ខីកម្មរបស់កម្មាភិបាល ដែលបញ្ជាក់អំពីភាពចាំបាច់នៃការយល់ព្រមពីប្តីប្រពន្ធ។ មានតែសក្ខីកម្មរបស់ ពេជ្រ ជឹម មួយគត់ ដែលទទួលបានការចាប់អារម្មណ៍ពីអង្គជំនុំជម្រះ ពីព្រោះ "គាត់បានបញ្ជាក់ថា ច្បាស់ណាស់ថា អ្នកដែលស្ទាក់ស្ទើរក្នុងការឆ្លើយតបនៅក្នុងពិធីអាពាហ៍ពិពាហ៍ មិនយល់ព្រមទៅនឹងការរៀបការនោះទេ"[2236]។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសទីមួយ ដោយបានលាក់បាំងផ្នែកផ្សេងទៀតនៃសក្ខីកម្មរបស់សាក្សីនេះ ដែលគួរណាតែនាំឱ្យអង្គជំនុំជម្រះវិនិច្ឆ័យផ្សេងពីនេះ។ ជាក់ស្តែង ពេជ្រ ជឹម បាននិយាយសង្កត់ធ្ងន់ជាច្រើនដងលើគោលការណ៍ស្តីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍ ដោយបានរៀបរាប់លម្អិតច្បាស់លាស់ ដែលអង្គជំនុំជម្រះគួរណាតែយកមកពិចារណា[2237]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានលើកឡើងអំពីសារៈសំខាន់នៃសេចក្តីពន្យល់របស់សាក្សីនេះ អំពីចម្ងាយឆ្ងាយនៃមន្ទីរខ្លះ ដែលចូលរួមចំណែកដល់ការអនុវត្តមិនបានត្រឹមត្រូវនូវវិធានរបស់ ប.ក.ក ក្នុងការអនុវត្តជាក់ស្តែង[2238]។

១២០១. ដូចគ្នាផងដែរ អង្គជំនុំជម្រះបានបំភ្លេចចោលទាំងស្រុង នៅក្នុងសំអាងហេតុរបស់ខ្លួន នូវសក្ខីកម្មរបស់កម្មាភិបាល ៤ រូបផ្សេងទៀត គឺ ខឹម បឿន, នាង អ៊ួច, ភ្នៅ យ៉ាវ និង ផាន់ ឆេន ដែលបាននិយាយផង

---

[2236] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦១៧, ៣៦២៣។ សាក្សីដែលត្រូវបានបដិសេធ៖ រៀល សន, ឱ ហួ, មាស រឿន, ទេព ប៉ូច និង យូ វ៉ាន់។

[2237] ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ម៉ោង 13.57.08 ("[...] ប៉ុនសួរម៉ែឪគេផង បងប្អូនគេផង ហើយសំខាន់សាមីខ្លួន គេ<u>ព្រម</u>មិនព្រម") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** ប្រហែលម៉ោង 09.16.08 និង 09.18.38។ ម្យ៉ាងវិញទៀត គាត់បានបញ្ជាក់៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ ២០១៥ ឯកសារ **E1/290.1** ម៉ោង 13.47.10 "តែរៀបការមិនឱ្យរៀបហ្នឹង គេឱ្យសុំ<u>ច្បាប់</u>គេ។ ប្រុសហ្នឹងសុំច្បាប់ហើយ សួរស្រី ដឹងឮទាំងអស់គ្នា <u>យល់ព្រម</u>បានឱ្យការ។ ហើយបើការអត់ច្បាប់មិនកើត។ ត្រូវតែមានដឹងឮ សួរបងប្អូន ឬម៉ែឪ យល់ព្រមផង ឬអ្នកអាណាព្យាបាលជាមេនៅហ្នឹង គឺគោលការណ៍អ៊ីចឹង") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/491.1** មុនម៉ោង 09.09.07។

[2238] <u>ពេជ្រ ជឹម</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** ក្រោយម៉ោង 09.08.11, 09.18.38 (ករណីមន្ទីរឆ្ងាយនៅក្នុងព្រៃ)។

ដែរអំពីវិធាននៃការយល់ព្រមជាមុនចំពោះការរៀបអាពាហ៍ពិពាហ៍[2239]។ សក្ខីកម្មទាំងនេះមិនអាចឱ្យសន្និដ្ឋានថា មេដឹកនាំ ប.ក.ក មានឆន្ទៈមិនខ្វល់ពីការយល់ព្រមពីសាមីខ្លួនចំពោះការរៀបអាពាហ៍ពិពាហ៍ នោះឡើយ។ ទឡ្ហីករណ៍របស់អង្គជំនុំជម្រះដែលថា សក្ខីកម្មទាំងនេះមិនអាចជឿជាក់បាន ពីព្រោះចេញមកពីអតីតកម្មាភិបាល គឺមិនត្រឹមត្រូវទេ ពីព្រោះសក្ខីកម្មរបស់សាក្សីជាសាមញ្ញជនអំពីសហករណ៍ត្រាំកក់ បានបញ្ជាក់អះអាងអត្ថិភាពនៃវិធាននៃការយល់ព្រមនេះ[2240]។ សៅ ហ៊ាន និង រី

---

[2239] នាង អ៊ូច ហៅ តាសាន ដែលត្រូវបានអះអាងថាជាប្រធានស្រុកត្រាំកក់ចុងក្រោយគេ មិនចងចាំថាមានគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ទេ ប៉ុន្តែ គាត់បានលើកឡើងពីដំណើរការពិគ្រោះយោបល់ប្រជាជន មុនរៀបចំអាពាហ៍ពិពាហ៍ឱ្យពួកគេ។ <u>នាង អ៊ូច</u>៖ ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥, **E1/274.1** ម៉ោង 10.53.33។ ប្រតិចារឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/275.1** ម៉ោង 11.26.40 ប្រហែលម៉ោង 09.23.56។ គាត់បានបញ្ជាក់ថា ឈ្មោះរបស់ពួកគេមានឆ្លុតកណ្តាល ពេលពួកគេមិនយល់ព្រម។ គាត់បានបញ្ជាក់ជាពិសេសពីអត្ថិភាពនៃការអនុវត្តផ្សេងៗគ្នានៅថ្នាក់ក្រោម៖ ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/274.1** ម៉ោង 10.51.30។ ប្រតិចារឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/275.1** ក្រោយម៉ោង 11.28.54។ ខឹម ហឿន បញ្ជាក់អះអាងសក្ខីកម្មរបស់គាត់។ ជាអតីតប្រធានឃុំជាងទង គាត់បានឆ្លើយថា មនុស្សម្នាក់ដែលគេជ្រើសឱ្យរៀបការ អាចជំទាស់បាន៖ <u>ខឹម ហឿន</u>៖ ប្រតិចារឹក ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/296.1** ម៉ោង 09.54.47។ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/297.1** មុនម៉ោង 10.04.05។ ម្យ៉ាងវិញទៀត គាត់បានបញ្ជាក់អះអាងពីអត្ថិភាពនៃគោលការណ៍ពីរ ទាក់ទងនឹងការព្រមព្រៀងដែលកើតចេញពីសីលធម៌បដិវត្ត ដែលតាមរយៈនោះ មិនត្រូវប្រកាន់អាកប្បកិរិយាមិនសមរម្យជាមួយស្ត្រីឡើយ។ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/297.1** ម៉ោង 13.45.44, 13.51.04។

[2240] ភ្លៅ យ៉ារ ដែលឆ្លើយថាពុំមានតួនាទីអ្វីសោះនៅក្នុងការរៀបចំអាពាហ៍ពិពាហ៍ បានបញ្ជាក់អះអាងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ដែលនៅក្នុងនោះ គាត់បានបញ្ជាក់ថា ការរៀបការត្រូវបានរៀបចំឡើងតាមសំណើរបស់បុគ្គល និង/ឬជាការរៀបចំតែអាចប្រកែកបាន ដោយពុំមានបញ្ហា។ <u>ភ្លៅ យ៉ារ</u>៖ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/264.1** ម៉ោង 10.47.38។ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/264.1** ប្រហែលម៉ោង 10.47.38 (បញ្ជាអះអាងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់)។ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី 12.11.2009, **E3/5515**, Q/R 32។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/264.1** មុនម៉ោង 10.55.54, 10.58.53។ អង្គជំនុំជម្រះក៏ត្រូវបង្ខំចិត្តទទួលស្គាល់ផងដែរថា ទោះបីជាបានលើកឡើងពីករណីរៀបការដោយបង្ខំក៏ដោយ ក៏ ឯម ភឿន អតីតព្រះសង្ឃ អាចបដិសេធសំណើសុំរៀបការ ដោយគ្មានផលវិបាក៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦២៥។ <u>ឯម ភឿន</u>៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/263.1** ប្រហែលម៉ោង 13.41.15។ ជាំង ស្រីមុំ សាក្សីផ្សេងទៀតអំពីសហករណ៍ត្រាំកក់ បញ្ជាក់ថាបានរៀបការទាំងខ្លួនមិនពេញចិត្ត នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែ បញ្ជាក់ថាមិនត្រូវបានគេបង្ខំទេ ហើយគាត់បាននិយាយបន្ថែមថា សំណួរទាក់ទងនឹងការព្រមព្រៀងគ្នាត្រូវបានចោទសួរទៅអនាគតប្តីប្រពន្ធនៅក្នុងពិធីរៀបការ។ <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ម៉ោង 09.53.04 ("រៀបការជាមួយនារី ដោយស្ម័គ្រចិត្តដោយខ្លួនឯង ឬមួយមានអ្នកណាបង្ខំចិត្តឬទេ? ប្តីខ្ញុំក៏ឆ្លើយថា "ខ្ញុំរៀបការដោយស្ម័គ្រចិត្ត អត់មានអ្នកណាបង្ខំចិត្តឡើយ"។ ក្រោយមកប្រធានកងក៏មកសួរខ្ញុំម្តង ដល់សួរខ្ញុំហើយ ខ្ញុំក៏ឆ្លើយថា "ខ្ញុំរៀបការដោយ

ពៅ បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ដោយមិនបញ្ជាក់ថា ពួកគេត្រូវបានបង្ខំនោះទេ ចំណែកឯ ជូ គីមឡន បានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចំពោះប្រជាជនថ្មី ប៉ុន្តែ បានបញ្ជាក់ថា គាត់បានសន្និដ្ឋានបែបនេះ ពីព្រោះប្ដីប្រពន្ធថ្មោងថ្មីបានប្រាប់ថាមិនចុះសម្រុងគ្នានៅពេលយប់[2241]។ **ស្ថិតិ**៖ ដូច្នេះ ក្នុងចំណោមសក្ខីកម្មទាំងអស់ដែលទទួលបានក្នុងវគ្គនេះ ដើមបណ្ដឹងរដ្ឋប្បវេណីតែម្នាក់គត់បានលើកឡើងអំពីអត្ថិភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ម្នាក់និយាយអំពីភាពខុសគ្នានៃបទពិសោធន៍ដោយបង្ខំ ឬមិនបង្ខំ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ៣ នាក់ និយាយអំពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ៧ នាក់ លើកឡើងអំពីភាពចាំបាច់នៃការយល់ព្រមជាមុនចំពោះការរៀបអាពាហ៍ពិពាហ៍ ម្នាក់មិនបញ្ជាក់អំពីប្រភេទនៃការរៀបអាពាហ៍ពិពាហ៍ និងម្នាក់លើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ក្រៅវិសាលភាពពេលវេលានៃសំណុំរឿង[2242]។ សមាមាត្រនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទាបយ៉ាងខ្លាំង ធៀបនឹងសមាមាត្រនៃវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍[2243]។

---

ស្ម័គ្រចិត្តដោយខ្លួនឯង គ្មាអ្នកណាបង្ខំចិត្តខ្ញុំ"") ប្រហែលម៉ោង 10.01.31 (ការជំទាស់របស់មេធាវីការពារក្តីដែលប្រធានអង្គជំនុំជម្រះបានទទួលយក ដែលថា ជាំង ស្រីមុំ មិនត្រូវបានបង្ខំឱ្យរៀបការទេ)។ សូមមើលផងដែរ សៅ ហ៊ាន៖ ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/265.1** ប្រហែលម៉ោង 10.10.08 (នៅក្នុងពិធីរៀបការ "គេគ្រាន់តែឱ្យឆ្លើយថាប្ដេជ្ញាយកអ្នកនេះ អ្នកនោះអស់មួយជីវិត")។ កំណត់ហេតុស្ដាប់ចម្លើយ ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9826** ស./ធ. ១៤៣ ("នៅក្នុងពិធីចាប់ដៃនេះ គណៈសហករណ៍បានសួរខាងប្រុសថា "ស្រឡាញ់ខាងស្រីពិតប្រាកដដែរឬទេ?" ខាងប្រុសឆ្លើយថា "ស្រឡាញ់ពិតប្រាកដ"។ បន្ទាប់មក គេសួរខ្ញុំវិញម្ដ"។ អ៊ុំ សុផានី រៀបការជាមួយគូដណ្ដឹងរបស់គាត់។ អ៊ុំ សុផានី៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/251.1** មុនម៉ោង 15.52.35។ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ម៉ោង 09.57.13 ("ខ្ញុំនិយាយថាសប្បាយរីករាយ ប៉ុន្តែសប្បាយរីករាយនឹងបានប្ដីដែលខ្ញុំពេញចិត្ត")។

[2241] សៅ ហ៊ាន៖ ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/265.1** ប្រហែលម៉ោង 10.10.08។ រី ពៅ៖ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ក្រោយម៉ោង 10.14.25។ ជូ គីមឡន៖ ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ក្រោយម៉ោង après 10.03.57 មុនម៉ោង avant 10.08.55។

[2242] រៀបការដោយការរៀបចំ ៣ នាក់ (ជាំង ស្រីមុំ, រី ពៅ និង ឯក ហេន) ដោយបង្ខំ ម្នាក់ (ជូ គីមឡន សម្រាប់ប្រជាជនថ្មី) ដោយគ្មានការបង្ខំ ៧ នាក់ (ភ្លៅ យ៉ាវ, ផាន់ ឆេន, នាង អ៊ូច, រៀល សន, ពេជ្រ ជីម, ខឹម ហឿន និង អ៊ុំ សុផានី) ម្នាក់ជួបប្រទះបទពិសោធន៍ផ្សេងៗគ្នា ទាំងដោយបង្ខំ និងមិនបង្ខំ (ឯម អឿង) ម្នាក់ ក្រៅវិសាលភាពពេលវេលា (វង់ សារុន) និង ម្នាក់ មិនបានបញ្ជាក់ (មិនបានបញ្ជាក់ថាដោយបង្ខំ ឬមិនបង្ខំ) (សៅ ហាន)។ ជាការសំខាន់ត្រូវកត់សម្គាល់ថា ពុំមានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះបញ្ជាក់ថាបានរៀបការដោយបង្ខំនៅក្នុងរបបខ្មែរក្រហម។

[2243] សូមមើឧបសម្ព័ន្ធ ៩១ និង ៩៦។

១២០២. **<u>វគ្គទំនប់១មករា</u>៖** បុគ្គល ១០ នាក់ បានផ្ដល់សក្ខីកម្ម ក្នុងវគ្គនេះ អំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបនោះ។ ក្នុងចំណោមនោះ កម្មាភិបាលខ្លះ រួមទាំង ឱ ហូ ដែលត្រូវបានអង្គជំនុំជម្រះបដិសេធ បានលើកឡើងអំពីលក្ខណៈវិនិច្ឆ័យនៃការយល់ព្រមរៀបអាពាហ៍ពិពាហ៍ ឯកម្មាភិបាលខ្លះទៀតមិនបាននិយាយទេ[2244]។ មានតែ ចៅ ឡាង ម្នាក់គត់ បានឆ្លើយថា គាត់បានរៀបការដោយបង្ខំ[2245] ចំណែកឯ សៀង សុវិដា បាននិយាយអំពីករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់បងស្រីគាត់ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិចារណាលើភាពវ័យក្មេងរបស់គាត់ ដើម្បីវាយតម្លៃអំពីភាពដឹងខុសត្រូវរបស់គាត់[2246]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនអើពើនឹងសក្ខីកម្មផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួន[2247]។ **<u>ស្ថិតិ</u>៖** ក្នុងវគ្គនេះ គួរកត់សម្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណី ២ នាក់ បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ស្មើនឹង ២០% ទល់នឹង ៣ នាក់ ដែលបាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ស្មើនឹង ៣០% ២ នាក់ បាននិយាយអំពីភាពខុសគ្នានៃបទពិសោធន៍ ស្មើនឹង ២០% ៣ នាក់ មិនបានបញ្ជាក់ប្រភេទនៃការរៀបអាពាហ៍ពិពាហ៍ ត្រូវជា ៣០%។

---

[2244] កម្មាភិបាលដែលបានលើកឡើងថាចាំបាច់ត្រូវមានការព្រមព្រៀងជាមុន៖ <u>ស៊ូ សឿន</u>៖ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/310.1** ម៉ោង 15.13.37 (“ខាងប្រធាន ខាងសង្កាត់ក៏គេសួរទៅសាមីខ្លួនខាងស្រី សាមីខ្លួនខាងប្រុស បើថាយល់ព្រមហើយ ក៏គេរៀបចំធ្វើពិធី”)។ <u>អ៊ុំ ជី</u>៖ ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/326.1** ម៉ោង 15.50.30។ កម្មាភិបាលដែលមិនបានលើកឡើងពីការព្រមព្រៀង និងការបង្ខំបង្ខំ៖ <u>ពេជ្រ សុខា</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/302.1**, ប្រតិចារឹក ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/303.1ន**, <u>យ៉ាន ឡុន</u>៖ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/317.1**។ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/318.1**។

[2245] <u>ចៅ ឡាង</u>៖ ប្រតិចារឹក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** មុនម៉ោង 14.40.35 (មានតែ ១ គូនៅក្នុងពិធីរៀបការ)។

[2246] <u>សៀង សុវិដា</u>៖ ប្រតិចារឹក ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** មុនម៉ោង 09.24.23 (គាត់មានអាយុ ១១ ឆ្នាំ ពេលបងស្រីគាត់រៀបការ) ម៉ោង 09.19.46 (បងស្រីរបស់គាត់មានអាយុ ១៥ ឬ ១៦ ឆ្នាំនៅពេលនោះ) ម៉ោង 11.11.43 (“ខ្ញុំបង្ខំគាត់ថាបងៗឯងការទៅ បាននៅភូមិ នៅជាអ្នកវ័យកណ្ដាលជាមួយម្ដាយឪពុកអីចឹងទៅណា”។ បងខ្ញុំថា អត់ទេ អត់ការ ប្រកែករហូតហើយទៅគេចាប់ការ គាត់ក៏ការទៅ”)។ អាយុរបស់បងស្រីខ្ញុំមិនសមស្របតាមបទបញ្ញារបស់កម្ពុជាប្រជាធិបតេយ្យ។

[2247] មាស ឡៃហួរ និង កង អ៊ុត បានផ្ដល់សក្ខីកម្មពីការរៀបការរបស់ពួកគេដែលឪពុកម្ដាយជាអ្នករៀបចំ៖ <u>មាស ឡៃហួរ</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/305.1** ម៉ោង 09.28.41 ម៉ោង 09.31.25 (“គេនាំខ្ញុំទៅយកណោះ ទៅយកណោះ គេផ្ដុំឱ្យខ្ញុំ ប៉ុន្តែខ្ញុំអត់យក។ ខ្ញុំថា ខ្ញុំសុកចិត្តនៅក្រមុំអីចឹងចុះ ខ្ញុំអត់យកទេប្ដី។ រួចទៅ អង្គការគេរៀបឱ្យទៅ”)។ <u>កង អ៊ុត</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/322.1** ម៉ោង 13.54.17 ក្រោយម៉ោង 13.29.26។

ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមិនបានទាញផលវិបាកពីរឿងរ៉ាវផ្សេងគ្នាទាំងនេះ[2248]។

១២០៣. **វគ្គទំនប់ត្រពាំងថ្ម៖** បុគ្គល ៩ នាក់ បានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ក្នុងរបបនោះ រួមទាំង ប៉ាន ឈួង ដែលសក្ខីកម្មរបស់គាត់ត្រូវបានអង្គជំនុំជម្រះបដិសេធយ៉ាងអយុត្តិធម៌។ អតីតកម្មាភិបាល ៤ នាក់ និងសាក្សីម្នាក់ជាសាមញ្ញជន បានបញ្ជាក់អំពីភាពចាំបាច់នៃការយល់ព្រមរៀបអាពាហ៍ពិពាហ៍[2249]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមិនបានទាញផលវិបាកពីភាពខុសគ្នានៃសាក្សីទាំងនេះដែលធ្វើការនៅអង្គភាពផ្សេងគ្នា។ ឧទាហរណ៍ យី ឡែស្រូវ បានឆ្លើយថា គាត់បានរៀបការមិនសមតាមបំណង ក្នុងរបបនោះ[2250]។ **ស្ថិតិ៖** ក្នុងចំណោមសក្ខីកម្មទាំងអស់ក្នុងវគ្គនេះ[2251] អង្គ

---

[2248] សូមមើលឧបសម្ព័ន្ធ ខ១ និង ខ៦។

[2249] កាន ថុល អនុកងរយ នៅស្រុកភ្នំស្រុក បានលើកឡើងពីការរៀបការដោយព្រមព្រៀង និងបញ្ជាក់ថាមិនបានឮគេនិយាយពីការរៀបការដោយបង្ខំទេ, <u>កាន ថុល</u>៖ ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/327.1** ចន្លោះពីម៉ោង 15.33.06 ដល់ម៉ោង 15.38.17។ ឈុំ សេង មេកងអនុសេនាធំនៅទំនប់ត្រពាំងថ្ម បានឆ្លើយថា ការរៀបការអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមពីខាងនារី៖ <u>ជុំ សេង</u>៖ ប្រតិចារឹក ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/332.1**, ម៉ោង 11.22.35។ <u>តក់ ប៊ុយ</u>៖ មេកងអនុសេនាតូចមានសមាជិក ៣០ នាក់ បានបញ្ជាក់ថា៖ "បាទគឺគេជ្រើសរើសខ្លួនឯង ហើយស្រឡាញ់នារីណា [...] គឺគេរកថ្ងៃរៀបអាពាហ៍ពិពាហ៍ឱ្យ")៖ <u>តក់ ប៊ុយ</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/333.1** ម៉ោង 14.03.52។ ឈុយ ហ៊ុយ បានបញ្ជាក់ថា៖ "ខ្ញុំបាទក៏បានដឹងថា ក្នុងសង្គមនោះ រៀបការហើយ ទាល់តែស្នើដល់មេប្រធាន១នារី មេប្រធានយុវជនស្នើដល់ទៅប្រធាននារី។ តើនារីទាំងពីរនោះយល់ស្រប មិនស្របក៏ស្រេចលើ នៅលើប្រធានកង"៖ <u>ឈុយ ហ៊ុយ</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/335.1** ចាប់ពីម៉ោង 11.08.55 ម៉ោង 11.29.29។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនបានលើកឡើងអំពីសក្ខីកម្មរបស់ ម៉ម សឿន ជាប្រជាជនធម្មតាដែលបានបញ្ជាក់អះអាងពីការវិវត្តពីការព្រមព្រៀងតាមប្រពៃណីរបស់ឪពុកម្តាយទៅជាការព្រមព្រៀងរបស់បុគ្គលនៅសម័យកម្ពុជាប្រជាធិបតេយ្យ ទោះបីជា ម៉ម សឿន បានលើកឡើងពីអត្ថិភាពនៃឯកសិទ្ធិរបស់បុរស ដោយមិនបានលើកឡើងពីការរៀបការដោយបង្ខំក៏ដោយ។ "គ្រាន់តែថា ខ្ញុំបានជម្រាបហើយថាអារឿងការរៀបការភាគីទាំងពីរ គេស្នេហ៍គ្នា ក៏ប៉ុន្តែខ្លះ ដូចខ្ញុំបានជម្រាបហើយថា ដូចក្នុងរៀបការខ្លះ យុវជនស្រឡាញ់នារី នារីមិនស្រឡាញ់យុវជន"៖ <u>ម៉ម សឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/325.1** មុនម៉ោង 10.12.56។

[2250] <u>យី ឡែស្រូវ</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/334.1** មុនម៉ោង 14.03.44។

[2251] ក្នុងចំណោមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង ៩ នាក់ ម្នាក់ផ្តល់សក្ខីកម្មអំពីការរៀបការដោយបង្ខំ (យី ឡែស្រូវ) ៥ នាក់ អំពីរៀបការដោយគ្មានការបង្ខំ (កាន ថុល, ឈុំ សេង, តក់ ប៊ុយ, ឈុយ ហ៊ុយ និង ប៉ាន់ ឈួង) ២ នាក់ អំពីការរៀបការដោយការ

ជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានទាញផលវិបាកពីភាពខុសគ្នានៃបទពិសោធន៍។ ជាក់ស្តែង សាក្សីតែម្នាក់គត់បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ស្មើនឹង ១១% ទល់នឹង ៥ នាក់ ស្មើនឹង ៥៦% ដែលបាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ២ នាក់ បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ស្មើនឹង ២២% និងម្នាក់ ស្មើនឹង ១១% បានផ្តល់សក្ខីកម្មអំពីភាពខុសគ្នានៅក្នុងកាលៈទេសៈនៃការរៀបអាពាហ៍ពិពាហ៍[2252]។

១២០៤. **<u>កន្លែងផ្សេងទៀតនៅទូទាំងប្រទេស</u>៖** ក្នុងចំណោមបុគ្គលទាំងអស់ ដែលបានស្តាប់ចម្លើយ ក្រៅពីវគ្គដូចបានលើកឡើងខាងលើ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ៤៧ នាក់ បាននិយាយអំពីបញ្ហារៀបអាពាហ៍ពិពាហ៍[2253]។ ៧ នាក់ បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ស្មើនឹង ១៥% ទល់នឹង ១៧ នាក់ ដែលបាននិយាយពីការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ស្មើនឹង ៣៦% ៦ នាក់ បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ស្មើនឹង ១៣% ៨ នាក់ បាននិយាយអំពីភាពខុសគ្នានៃបទពិសោធន៍ ដោយពួកគេមិនត្រូវបានបង្ខំឱ្យរៀបការ ក្នុងរបបនោះ ស្មើនឹង ១៧% ៧ នាក់ មិនបានបញ្ជាក់ប្រភេទនៃការរៀបអាពាហ៍ពិពាហ៍ ស្មើនឹង ១៥% និង ២ នាក់ បានលើកឡើងពីការរៀបអាពាហ៍ពិពាហ៍ ក្រៅវិសាលភាពពេលវេលានៃសំណុំរឿង ស្មើនឹង ៤%[2254]។ គួរកត់សម្គាល់ថា ក្នុងចំណោមបុគ្គលទាំង ៤៧ នាក់ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ២១ នាក់ បានរៀបការ ក្នុងរបបនោះ។ ក្នុងចំណោមបុគ្គលទាំង ២១ នាក់នេះ ៤ នាក់ បានឆ្លើយថា ពួកគេបានរៀបការដោយបង្ខំ ក្នុងរបបនោះ។ ត្រង់នេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានធ្វើការវិភាគមិនគ្រប់ជ្រុងជ្រោយ និងដោយលម្អៀង ទៅលើភ័ស្តុតាង និងមិនបានទាញផលវិបាកពីភាពខុសគ្នានៃរឿងរ៉ាវទាំងនោះ។

---

រៀបចំ (សែន សុផុន និង មាន លឿយ) និងម្នាក់ លើកឡើងថាបានជួបប្រទះបទពិសោធន៍ផ្សេងៗគ្នា ក្នុងនោះ មានការរៀបការដោយបង្ខំសម្រាប់អ្នកខ្លះ និងដោយគ្មានការបង្ខំសម្រាប់អ្នកខ្លះទៀត (ម៉ម សឿន)។

[2252] សូមមើលឧបសម្ព័ន្ធ ខ១ និង ខ៦។

[2253] សូមមើលឧបសម្ព័ន្ធ ខ១ និង ខ៦។

[2254] សូមមើលឧបសម្ព័ន្ធ ខ១ និង ខ៦។

១២០៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ជាអាទិ៍ ដោយបានបដិសេធសក្ខីកម្មរបស់ យូ វ៉ាន់ ដូច កម្មាភិបាលផ្សេងទៀតដែរ។ អតីតកម្មាភិបាលភូមិភាគនិរតី ដែលត្រូវបានចាត់បញ្ជូនទៅឃុំរអាង ស្រុកកំពង់សៀម បាននិយាយលម្អិតច្បាស់លាស់អំពីការរៀបចំអាពាហ៍ពិពាហ៍៖ "គឺបុរស និងនារី វានៅកងចល័ត ប៉ុន្តែ វាត្រូវតម្រូវគ្នាទៅ វាស្នើដល់ប្រធានភូមិ ប្រធានភូមិក៏ប្រាប់ដល់ប្រធានឃុំ ប្រធានឃុំក៏ប្រាប់ដល់មេស្រុក ក៏នាំគ្នាកោះហៅយករៀបការនៅមន្ទីរស្រុកទៅ"[2255]។ ការទទួលបានការព្រមព្រៀងជាចាំបាច់ត្រូវបានបញ្ជាក់ដោយថ្នាក់លើរបស់គាត់ឈ្មោះ ប្រាក់ យុត ជាលេខាស្រុកកំពង់សៀម ដែលបាននិយាយច្បាស់ជាងលើចំណុចនេះថាគាត់បានអានឯកសារ ប.ក.ក[2256]៖ "កាលណាគេអត់ស្រឡាញ់គ្នា យើងទៅបង្ខំដំចិត្ត ហ្នឹងវាខុសដែរ។ ខ្ញុំមើលក្នុងឯកសារខ្លះដែរ ខ្ញុំមិនចេះតែធ្វើទេ"[2257]។ សូមរំឭកថា សាក្សីទាំងពីរនេះមកផ្ដល់សក្ខីកម្មជាចម្បងអំពីជនជាតិចាម និងគ្មានហេតុផលអ្វីត្រូវនិយាយការពារខ្លួនពីរឿងរៀបអាពាហ៍ពិពាហ៍ទេ។

១២០៦. ម្យ៉ាងវិញទៀត ទោះជាផ្ដល់ ឬមិនផ្ដល់ទំនុកចិត្តលើសក្ខីកម្មរបស់ពួកគាត់អំពីឥរិយាបថផ្ទាល់ខ្លួន ក៏ដោយ ក៏អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានយល់ឃើញថា ចម្លើយរបស់ពួកគាត់មិនត្រឹមតែស៊ីចង្វាក់គ្នានឹងចម្លើយរបស់កម្មាភិបាលមកពីទីតាំងផ្សេងៗឆ្ងាយពីគ្នាប៉ុណ្ណោះទេ ថែមទាំងស៊ីចង្វាក់គ្នានឹងវិធានដូចមានចែងក្នុងសីលធម៌ ១២ ប្រការរបស់ ប.ក.ក ទៀតផង[2258]។ កំហុសរបស់អង្គជំនុំជម្រះមានសភាពធ្ងន់ធ្ងរណាស់ ពីព្រោះចម្លើយទាំងនេះក៏ស៊ីចង្វាក់គ្នាផងដែរនឹងចម្លើយរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន នៅក្នុងសវនាការ[2259]។

---

[2255] យូ វ៉ាន់៖ ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/376.1** (អសាធារណៈ) ម៉ោង 14.33.33។ ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/377.1** (អសាធារណៈ) ប្រហែលម៉ោង 11.32.17។

[2256] នៅក្នុងផ្នែក "បទបញ្ញត្តិស្ដីពីការរៀបអាពាហ៍ពិពាហ៍" អង្គជំនុំជម្រះយល់ឃើញថា គាត់មានបំណងបន្ធូរបន្ថយទំនួលខុសត្រូវរបស់គាត់ក្នុងឋានៈជាលេខាស្រុក នៅពេលដែលជាការដោះបន្ទុក (សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧៩ និង ៣៦០៩) ប៉ុន្តែអាចជឿជាក់បាននៅក្នុងករណីផ្ទុយ (សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦០៥)។

[2257] ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1** (អសាធារណៈ) ប្រហែលម៉ោង 11.24.31 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2258] សូមមើលខាងលើ កថាខណ្ឌ ១១៩២-១១៩៥។

[2259] សូមមើលខាងលើ កថាខណ្ឌ ១២០០-១២០២។ យស ផល៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 10.39.30 ប្រហែលម៉ោង 11.09.24 ("អាហ្នឹងគឺថាគូរបស់គេ ប្រវត្តិរូបរបស់គេ ដូចថា ថ្មីអ៊ីចឹងអត់មានអង្គការកម្មេច ខាង

១២០៧. លើសពីនេះទៀត ក្រៅពី សៅ សារុន សាក្សីពីរនាក់ផ្សេងទៀត គឺ ឌុច និង ជួន ធី បានឆ្លើយថា ពួកគេបានឮសេចក្ដីណែនាំពី ប៉ុល ពត ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ដែលបញ្ជាក់អំពីគោលការណ៍ស្ដីពីការយល់ព្រមរៀបអាពាហ៍ពិពាហ៍[2260]។ ម៉ឹង វេត បានលើកឡើងអំពីបទពិសោធន៍នៃការអនុវត្តការរៀបអាពាហ៍ពិពាហ៍ ប្រហាក់ប្រហែលនឹងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំស្របតាមប្រពៃណី៖ "អាហ្នឹងមិនមែនការបង្ខិតបង្ខំទេ ប៉ុន្តែមិនប៊ានតវ៉ា"[2261]។ នៅពេលរៀបរាប់អំពីនីតិវិធីនៃការស្នើសុំពីសំណាក់កម្មាភិបាលជាន់ខ្ពស់ គាត់បានបញ្ជាក់ថា សេចក្ដីណែនាំត្រូវបានផ្សព្វផ្សាយបន្តដោយផ្ទាល់មាត់ ក្នុងកិច្ចប្រជុំ ពាក់ព័ន្ធនឹងការជ្រើសរើសគូស្រករ[2262]។ ម្យ៉ាងវិញទៀត សូម្បីតែសាក្សី ដែលបាន

---

ប្រុសហ្នឹងក៏ខាងកម្មេច ខាងស្រីក៏អត់មានកម្មេច ហើយជាគូដណ្ដឹងគេ។ អាហ្នឹងគេល្អរបស់គេ គេបានទៅ")។ កំណត់ហេតុស្ដាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ធ.៨២ ("ដោយសារមានអ្នកខ្លះព្រមរៀបការតាមការចាត់តាំង ឯអ្នកខ្លះទៀតដែលបានយល់អំពីផែនការនេះ ឬមានមិត្តភក្តិនិយាយប្រាប់ពីគោលការណ៍បក្ស គេក៏បានប្រកែកមិនព្រមរៀបការ")។ ត្រូវគួសបញ្ជាក់ត្រង់នេះថា រស់ ស៊ុយ បានបញ្ជាក់ថា ច្បាប់របស់ ប.ក.ក ជាហេតុផលដើម្បីប្រឆាំងនឹងការបដិសេធមិនរៀបការ។

[2260] ជួន ធី៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/183.1** ចន្លោះពីម៉ោង 09.57.15 ដល់ម៉ោង 10.03.25 ម៉ោង 15.06.08។ ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ប្រហែលម៉ោង 09.06.12 ចាប់ពីម៉ោង 09.11.40 ចាប់ពីម៉ោង 09.33.27 (ការប្រជុំឆ្នាំ១៩៧៨ "ប៉ុល ពត និយាយថាសម្រេចលើសាមីខ្លួន គេជាអ្នកសម្រេច។ បើគេយល់ព្រម រៀបចំឱ្យគេទៅ កុំបង្ខំគេ")។ កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ធ.៣៣, ៣៤, ១០៤-១០៩, ១១៨, ១២៣, ១២៤, ១៣០-១៣៣ ដែលត្រូវបានទទួលយកធ្វើជាភស្តុតាងតាមសេចក្ដីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ **F51/3**។ ឌុច៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/436.1** មុនម៉ោង 09.49.22។ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/443.1** ចន្លោះពីម៉ោង 15.42.11 ដល់ម៉ោង 15.45.04 ម៉ោង 15.46.44 (ប្រជុំក្រោយរបបកម្ពុជាប្រជាធិបតេយ្យជាមួយ ប៉ុល ពត ហើយគាត់មិនដែលឃើញឯកសាររបស់បក្សដែលលើកឡើងពីគោលនយោបាយបង្ខំប្រជាជនឱ្យរៀបការ)។

[2261] ម៉ឹង វេត៖ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E1/449.1** ក្រោយម៉ោង 09.50.47 ម៉ោង 10.15.59។

[2262] ម៉ឹង វេត៖ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E1/449.1** មុនម៉ោង 10.02.35 មុនម៉ោង 10.05.54 មុនម៉ោង 10.15.59 មុនម៉ោង 10.18.24។ បញ្ហានៃការជ្រើសគូស្រករតាមប្រវត្តិរូប នឹងត្រូវសិក្សាពិនិត្យនៅខាងក្រោម។

អះអាងថាមិនដឹងខ្លឹមសារជាក់លាក់នៃបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក៏បាននិយាយអំពីសញ្ញាណនៃការព្រមព្រៀងដែរ[2263]។

១២០៨. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសារមិនបានទាញចេញពីភាពខុសគ្នានៃបទពិសោធន៍ អាស្រ័យតាមទីកន្លែង និងបុគ្គល នូវសេចក្តីសន្និដ្ឋានសមហេតុផលថា វិធានស្តីពីការព្រមព្រៀងច្បាស់លាស់ ដែល ប.ក.ក បានកំណត់ ត្រូវបានអនុវត្តជាក់ស្តែងមិនបានត្រឹមត្រូវ។ ម្យ៉ាងទៀត ការពិនិត្យជាទូទៅលើសក្ខីកម្មទាំងអស់ ក្នុងសំណុំរឿង ០០២/០២ ក្រៅពីវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ បញ្ជាក់អំពីភាពខុសគ្នានៃបទពិសោធន៍។

១២០៩. **<u>មតិយោបល់របស់អ្នកជំនាញ</u>៖** ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានបំភ្លៃសក្ខីកម្មរបស់ Kasumi NAKAGAWA និងមិនបានទាញសេចក្តីសន្និដ្ឋានត្រឹមត្រូវ[2264]។ ជាក់ស្តែង អ្នកជំនាញបានឆ្លើយថា៖ "ខ្ញុំ<u>មិនអាចរកឃើញ</u>ភ័ស្តុតាងណាមួយ ដែលថាមាន<u>គោលនយោបាយថ្នាក់កណ្តាល</u> គោលនយោបាយថ្នាក់ជាតិ ដាក់ចេញទៅថាបង្ខំឱ្យប្រជាជនរៀបការនោះទេ" បើទោះជាគាត់បានទទួលស្គាល់ថា ល័ក្ខខ័ណ្ឌទាំងពីរនៃសីលធម៌ប្រការទី ៦ របស់ ប.ក.ក មិនត្រូវបានអនុវត្តចំពោះគ្រប់ការរៀបអាពាហ៍ពិពាហ៍ទាំងអស់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះ

---

[2263] <u>សម្រាប់កម្មាភិបាល</u>៖ ផាន់ ឆែន, សុះ រំលី, ព្រំ សារុន, ផាន វ៉ាន, ធុច ស៊ីថន, ប៊ិត បឿន, សេង លីថេង។ <u>សម្រាប់ទាហាន</u>៖ ជិន គីមចុង, ស៊ុន វុត, ជិន សារឿន, ហ្វូន ជឿន និង ម៉ាក ឈឿន។ <u>សម្រាប់ប្រជាជនធម្មតា</u>៖ អ៊ឹត សេន, សុះ ពន់យ៉ាមីន, សែន ស្រ៊ុន, ហ៊ឹម ម៉ាន, ម៉ាត់ ស, ប្រាក់ ឌឿន, ថង ផល, អ៊ុន ឃឿង, សៀង ចាន់ធី, ខួយ មួយ, យន់ បិន។ ស្ថិតិ៖ សាក្សីដែលបានលើកឡើងពីការរៀបការដោយបង្ខំ៖ ១១ នាក់, សាក្សីដែលបានលើកឡើងពីការរៀបការដោយការព្រមព្រៀង៖ ៣២ នាក់, សាក្សីដែលបានលើកឡើងពីការរៀបការដោយការរៀបចំ៖ ១១ នាក់, សាក្សីដែលបានបញ្ជាក់ថាបានជួបប្រទះនូវបទពិសោធន៍ផ្សេងៗគ្នា៖ ១២ នាក់, សាក្សីដែលមិនបានបញ្ជាក់ពីប្រភេទនៃការរៀបការ៖ ១១ នាក់, សាក្សីក្រៅវិសាលភាពពេលវេលា៖ ៣ នាក់។ សូមមើល ឧបសម្ព័ន្ធ ខ៦។

[2264] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៣៣ កំណត់សម្គាល់ជើងទំព័រលេខ១១៨៨២ "លោកស្រីបានសន្និដ្ឋានថា គាត់ពុំមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការលើកឡើងអំពីថាតើមានគោលនយោបាយពីថ្នាក់លើបំផុតឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែរ ឬយ៉ាងណានោះទេ <u>ពីព្រោះ</u>ចំណុចនេះមិនមែនជា<u>ផ្នែកមួយនៃ</u>ការសិក្សារបស់គាត់ឡើយ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) ខណៈដែលលោកស្រីបានទទួលស្គាល់ ក្នុងកថាខណ្ឌដដែល និងកថាខណ្ឌបន្ទាប់ ៣៥៣៤ ថា គោលបំណងចម្បងនៃការស្រាវជ្រាវរបស់លោកស្រីគឺប្រមូលរឿងរ៉ាវរបស់ជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ នៅក្នុងរបបខ្មែរក្រហម ហើយយោបល់របស់លោកស្រីជាទូទៅគឺ "មានហេតុផលត្រឹមត្រូវ និងមានភាពស្របគ្នា"។

ឡើយ[2265]។ ថ្វីត្បិតតែអង្គជំនុំជម្រះបានអនុវត្តដំណើរការយ៉ាងត្រឹមត្រូវ តាមការប្រកាស នៅកថាខណ្ឌ ៣៥៣៤ នៃសំអាងហេតុសាលក្រម គឺ "វាយតម្លៃលើការសន្និដ្ឋាននៃការស្រាវជ្រាវរបស់គាត់ ដោយពិចារណាពីបរិបទនៃភស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះ" ក៏ដោយ ក៏អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ថា ការវិភាគភស្តុតាងបានបញ្ជាក់អះអាងអំពីការសន្និដ្ឋានរបស់អ្នកជំនាញ[2266]។ អង្គជំនុំជម្រះបានច្រានចោលដោយមិនត្រឹមត្រូវនូវសក្ខីកម្មរបស់ Peg LEVINE ដែលបានធ្វើការសន្និដ្ឋានស្រដៀងគ្នា៖ "លោកស្រីបានស្នើឱ្យខ្ញុំឆ្លើយថា ចាស ឬក៏មិនមែនទេ ថាតើការរៀបការដោយបង្ខំ ឬក៏អត់? [...] មិនមែននោះទេ"[2267]។

១២១០. សរុបសេចក្តីមក តាមរយៈការវិភាគមិនគ្រប់ជ្រុងជ្រោយ និងដោយលម្អៀងទៅលើភស្តុតាង និងផ្ទុយជាមួយភស្តុតាងស៊ីចង្វាក់គ្នា អង្គជំនុំជម្រះបានសន្និដ្ឋានថា ការយល់ព្រមពីប្តីប្រពន្ធចំពោះការរៀបអាពាហ៍ពិពាហ៍ មិនមែនជាគោលការណ៍ច្បាស់លាស់របស់ ប.ក.ក ទេ។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានទាញសេចក្តីសន្និដ្ឋានសមហេតុផលថា ការកើតឡើងនូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការអនុវត្តមិនត្រឹមត្រូវនូវបទបញ្ជាស្តីពីការរៀបពាហ៍ពិពាហ៍ពីសំណាក់កម្មាភិបាលមួយចំនួន។ កំហុសទាំងនេះ ដែលបានចូលរួមចំណែកក្នុងការកំណត់ចរិតលក្ខណៈខុសនៃគោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ បានបណ្តាលឱ្យមានយុត្តិនិសេធ។ ដូច្នេះ កំហុសទាំងនេះត្រូវទុកជាមោឃៈ។

### ២.៣.១.២. កំហុសពាក់ព័ន្ធនឹងគោលបំណងរបស់ ប.ក.ក

១២១១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីគោលបំណងតាមការសន្មតរបស់ ប.ក.ក តាមរយៈបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ដើម្បីឈានដល់

[2265] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ក្រោយម៉ោង 14.03.44 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** ម៉ោង 15.06.07 មុនម៉ោង 15.22.16 (ខ្ញុំមិនមានភស្តុតាងបញ្ជាក់ឱ្យច្បាស់ថា ឱ្យមានការគោលនយោបាយបង្ខំឱ្យរៀបការនោះទេ"។

[2266] សូមមើលខាងលើ ១១៩២-១២១០.

[2267] Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/481.1** ប្រហែលម៉ោង 10.46.41។

ការសន្និដ្ឋាននេះ ជាបឋម អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុស ដោយបានលាក់បាំងអវត្តមាននៃការយល់ព្រមពីសាមីខ្លួន ក្នុងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ដើម្បីសន្និដ្ឋានថាមានភាពខុសគ្នាជាមួយនឹងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកថាជាការបង្ខំ[2268]។ ដើម្បីព្យាយាមបញ្ចៀសឧបសគ្គរាំងស្ទះដល់វិចារណកិច្ចរបស់ខ្លួន ដោយវិធានស្តីពីការព្រមព្រៀងរបស់បក្ស ជាដំបូង អង្គជំនុំជម្រះបានវិភាគដោយលម្អៀងទៅលើឯកសារផ្លូវការរបស់ ប.ក.ក ដើម្បីអះអាងថាបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍មិនត្រូវបានអនុវត្តទេ ដោយសារតែការគោរពតាមវិន័យអង្គការ (២.៣.១.២.១)។ បន្ទាប់មកទៀត តាមរយៈការវាយតម្លៃខុស និងការបំភ្លៃភ័ស្តុតាង អង្គជំនុំជម្រះបានសន្និដ្ឋានថា គោលបំណងរបស់ ប.ក.ក គឺត្រួតពិនិត្យការរួមភេទ ដើម្បីបង្កើនចំនួនប្រជាជននៅក្នុងប្រទេស (២.៣.១.២.២)។

*២.៣.១.២.១. ការវិភាគលម្អៀងលើឯកសារ និងសុន្ទរកថាផ្លូវការ ស្តីពីជម្រើសរបស់ប្តី/ប្រពន្ធ*

១២១២. **ឯកសារ "<u>ហេតុទស្សនៈបដិវត្តន៍ និងមិនបដិវត្តន៍ ចំពោះបញ្ហានៃការកសាងគ្រួសារ</u>"៖** ដើម្បីព្យាយាមផ្តល់ការគាំទ្រដល់ទ្រឹស្តីរបស់ខ្លួនអំពីអវត្តមាននៃការយល់ព្រមរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថាជាគោលនយោបាយរបស់ ប.ក.ក អង្គជំនុំជម្រះបានធ្វើតាមវិធីអនុមាន និងសន្និដ្ឋានដោយពង្រីក ដោយបានប្រើប្រាស់អត្ថបទមនោគមន៍វិជ្ជារបស់បក្ស។ ជារឿយៗ អត្ថបទវែងៗ និងស្រពេចស្រពិល នៅក្នុងទស្សនាវដ្តីបដិវត្ត អាចពិបាកយល់ ដោយសារវាក្យស័ព្ទបំពាក់បំប៉នមនោគមន៍វិជ្ជា។ ប៉ុន្តែ មានឃ្លាប្រយោគច្បាស់លាស់ ដែលមិនទាមទារឱ្យមានការបកស្រាយ ដូចជា ការព្រមព្រៀងជាចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍ ក្នុងចំណោមសីលធម៌ ១២ ប្រការ ដែលអង្គជំនុំជម្រះបានច្រានចោលយ៉ាងអយុត្តិធម៌[2269]។ ក្នុងទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" ចេញផ្សាយឆ្នាំ ១៩៧៥ "បោះពុម្ពឡើងវិញអនុលោម" តាមទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" ចេញផ្សាយខែកុម្ភៈ ឆ្នាំ១៩៧៤ ស្តីពី "ការកសាងគ្រួសារ" ចំពោះយុវជន និងយុវនារីបដិវត្តន៍[2270]។ អង្គជំនុំជម្រះបាន

---

[2268] សូមមើលខាងលើ កថាខណ្ឌ ១១១៩-១១៣០ : ១១៥៧-១១៦២។

[2269] សូមមើលខាងលើ កថាខណ្ឌ ១១៩៣។

[2270] យុវជន និងយុវនារីបដិវត្ត ខែមិថុនា ឆ្នាំ១៩៧៥ ឯកសារ **E3/775** ទំព័រ ១-៦ ERN 00407097-00407100។

ធ្វើការបកស្រាយខុសយ៉ាងធ្ងន់ធ្ងរ ដែលគ្មានអ្វីក្រៅពីទុកជាមោឃៈ[2271]។ បើតាមអង្គជំនុំជម្រះ ឯកសារនេះបង្ហាញថា "បុគ្គលនីមួយៗត្រូវគោរពតាមការវាយតម្លៃ និងការសម្រេចរបស់អង្គការ ព្រោះមានតែអង្គការទេទើបពិនិត្យបានម៉ត់ចត់ និងគ្រប់ជ្រុងជ្រោយ" រួមទាំងពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍[2272]។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស តាមរយៈសេចក្តីសន្និដ្ឋានជារួម ក្រៅបរិបទ។ ម្យ៉ាង អង្គជំនុំជម្រះខកខានមិនបានពិចារណាលើសង្គ្រាមស៊ីវិលដែលឆាបឆេះពាសពេញប្រទេស នៅពេលសរសេរឯកសារនេះ (ឆ្នាំ១៩៧៤)។ ផ្ទុយទៅវិញ នេះជាកត្តាសំខាន់ ដែលឱ្យគេនឹកដល់ទង្វើរបស់យុទ្ធជនបានប្រព្រឹត្តលើស្ត្រី។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានបំភ្លេចចោលទាំងស្រុងនូវទស្សនៈថ្មីនៃទំនាក់ទំនងបុរស-ស្ត្រី ដែលបង្កើតឡើងដោយមនោគមន៍វិជ្ជាបដិវត្តន៍ ធៀបនឹងប្រពៃណី ដែលបង្ហាញនៅក្នុងឯកសារនេះ។ ក្នុងបរិបទដោយឡែកនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានលើកឡើងអំពីឆន្ទៈផ្តល់ជូនស្ត្រីនូវតួនាទីផ្សេងពីប្រពៃណី គឺតាមរយៈការរៀបអាពាហ៍ពិពាហ៍តែមួយគត់[2273]។

១២១៣. លើសពីនេះ អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ឃើញថា ជនគោលដៅនៃឯកសារបោះពុម្ពផ្សាយនេះ គឺកម្មាភិបាល និងយោធាបដិវត្តន៍វ័យក្មេង ដែលបានចូលរួមក្នុងចលនាតស៊ូ ដែលត្រូវទន់ភ្លន់ចំពោះឧត្តមគតិបដិវត្តន៍[2274] រួមទាំងក្នុងការ "ជ្រើសរើសគូស្រករ"[2275]។ ប៉ុន្តែគ្មានតម្រុយណាមួយ ក្នុងឯកសារនេះ អាចឱ្យសន្និដ្ឋានអំពីគោលនយោបាយ ឬចេតនារបស់ ប.ក.ក ក្នុងការជំរុញ និងបង្ខំប្រជាជនឱ្យរៀបការខុសពីឆន្ទៈខ្លួនឡើយ។ ផ្ទុយទៅវិញ ឯកសារនេះបានណែនាំឱ្យពិចារណាឱ្យបានល្អក្នុងការ

---

[2271] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤០-៣៥៤៣។

[2272] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤០-៣៥៤១, ៣៥៤៣-៣៥៤៤, ៣៦១៨។

[2273] គួរកត់សម្គាល់ថា ទស្សនៈជាប្រពៃណីអំពីស្ត្រីមានរំលេចនៅក្នុងកំណាព្យប្រពៃណីមួយៈ ច្បាប់ស្រីរបស់ ម៉ឺន មៃ ពុំមានកាលបរិច្ឆេទ ឯកសារ **E3/10659** ERN 01324417-01324425។ ទស្សនៈជាប្រពៃណីអំពីស្ត្រីនេះកំពុងតែជជែកគ្នានៅឡើយទេនាពេលបច្ចុប្បន្ននេះ។ សូមមើល គ្មានទេកន្លែងសម្រាប់ "ច្បាប់ស្រី" នៅក្នុងសាលារៀនក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ (ឌីខេមបូឌាដេលី) ឯកសារ **E3/10660** ERN 01328190-01328193។ នៅក្នុងអត្ថបទសារព័ត៌មានចុះផ្សាយឆ្នាំ២០១៥ គេលើកឡើងថា វិធានច្បាប់ស្រីត្រូវបានលុបចោលពីកម្មវិធីសិក្សា ទៅតាមសំណើរបស់ក្រសួងកិច្ចការនារី។

[2274] យុវជន និងយុវនារីបដិវត្ត ខែមិថុនា ឆ្នាំ១៩៧៥ ឯកសារ **E3/775** ទំព័រ ១-៦ ERN 00407097-00407100។

[2275] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤៣ រំឭកពីគោលការណ៍ណែនាំការជ្រើសរើសគូស្រករ។

ជ្រើសរើសគូស្រករ ក្នុងក្របខ័ណ្ឌនៃការប្ដេជ្ញាចិត្តបដិវត្តន៍[2276]។ នេះគឺជាការរំពឹកទាក់ទិននឹងសីលធម៌ ១២ ប្រការ ដូចអតីតកម្មាភិបាលបានបញ្ជាក់ និងពន្យល់ ក្នុងសវនាការ[2277]។ ម្យ៉ាងវិញទៀត ខ្លឹមសារទស្សនាវដ្ដី "យុវជន និងយុវនារីបដិវត្ត" ខាងលើ ស៊ីចង្វាក់គ្នានឹងចម្លើយរបស់ ពេជ្រ ជឹម ដែលត្រូវបានអង្គជំនុំជម្រះច្រានចោលយ៉ាងអយុត្តិធម៌។ ជាក់ស្ដែង ពេជ្រ ជឹម បានរំឭកអំពីប្រវត្តិនៃការរៀបអាពាហ៍ពិពាហ៍ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ដោយមានការយល់ព្រមពីអនាគតប្ដីប្រពន្ធ ឪពុកម្ដាយ ឬអាណាព្យាបាល និងអាជ្ញាធរមូលដ្ឋាន[2278]។ ដូច្នេះ អង្គជំនុំជម្រះមិនត្រឹមតែបានប្រព្រឹត្តកំហុស

---

[2276] យុវជន និងយុវនារីបដិវត្ត ខែមិថុនា ឆ្នាំ១៩៧៥ ឯកសារ **E3/775** ទំព័រ ១៦-២០ ERN 00407105-00407107 "ចំពោះបញ្ហាកសាងគ្រួសារនេះ បក្សមិនដែលហាមឃាត់ទេ តែយុវជន-យុវនារីបដិវត្តយើងត្រូវមានលោកទស្សនៈបដិវត្តឱ្យច្បាស់លាស់ ចំពោះបញ្ហានេះ។ ហើយសំខាន់បំផុត យុវជន-យុវនារីបដិវត្តយើងត្រូវក្ដាប់ឱ្យជាប់នូវភារកិច្ចបដិវត្តដ៏ធ្ងន់ធ្ងររបស់យើង។ [...] ដូច្នេះ យុវជន-យុវនារីបដិវត្តយើងត្រូវកម្ចាត់ចោលចេញឱ្យអស់ និងឱ្យជ្រះស្រឡះនូវទស្សនៈ គោលជំនហរខុសឆ្គងទាំងអម្បាលមាណ និងលោកទស្សនមិនបដិវត្តទាំងអស់ចំពោះការបញ្ហាកសាងគ្រួសារនេះ ដូចជាសេរីខាងសីលធម៌ គក់ក្រហល់អន្ទះអន្ទែង ឬរវើរវាយចង់កសាងគ្រួសារពីក្មេងពេក ឬសេរីមិនគោរពអង្គការវិន័យ មិនគោរពមតិសមូហភាពក្នុងការកសាងគ្រួសារជាដើម។ យើងត្រូវយល់ថា បញ្ហាគ្រួសារ យើងចង់កសាងពេលណាក៏បានដែរ។ តែវ័យយុវភាព យើងមានតែម្ដងគត់ក្នុងមួយជីវិតរបស់យើង។ តែយើងបណ្ដែតបណ្ដោយឱ្យវាកន្លងផុតទៅ ដោយឥតប្រយោជន៍ហើយ វាគ្មានពេលណានឹងវិលត្រឡប់មកវិញបានទេ ហើយយើងមុខជានឹងស្ដាយក្រោយមិនខានឡើយ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2277] ក្នុងចំណោមពួកគេ ឌុច ក៏បានអះអាងថា៖ "ក្នុងបញ្ហាជ្រើសរើសគូស្រករ គេមិនហាមដាច់ខាត [..] ការជ្រើសរើសគូស្រករប្ដីប្រពន្ធត្រូវគិត"។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/51.1** ក្រោយម៉ោង 11.08.23។ គាត់ក៏បានបញ្ជាក់ថាបានផ្ដួចផ្ដើមដោយខ្លួនឯង អនុលោមតាមនីតិវិធីដែលមានស្រាប់ដើម្បីស្នើសុំរៀបការជាមួយប្រពន្ធគាត់។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/51.1** ក្រោយម៉ោង 10.15.00។ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/436.1** ក្រោយម៉ោង 09.45.08។ សូមមើលផងដែរ ជួន ធី៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/183.1** ចាប់ពីម៉ោង 09.57.15។

[2278] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចាប់ពីម៉ោង 13.47.10 "គឺ៧០ មកគេរៀបចំអ៊ីចឹង គឺរបបតែមួយហ្នឹង។ ដល់៧១ ក៏វារបប រៀបចំក៏ទៅសុំ ហើយយល់ព្រម មេកង មេក្រុម គេយល់ព្រម គេដឹងឮ រៀបរយឱ្យអ៊ីចឹងទេ។ ហើយដល់វាច្រើនពេកទៅ រៀបណាឈ្នះ។ [...] អ៊ីចឹងបានបែកពាក្យថា ជាគូៗ ច្រើនគូហ្នឹង។ រៀបមួយៗអង្គាល់ហើយ។ ហើយការតឹងនេះ មិនចង់ឱ្យរៀប គឺចង់ឱ្យបង្កើតទ័ពច្រើន រឺឆាប់ឈ្នះ កុំសង្គ្រាមហ្នឹងវាយូរពេក។ កុំអាល់ឱ្យមានប្ដីប្រពន្ធនៅក្មេងៗទេ ចាំចាស់បន្តិច។ ជានយោបាយនាំអ៊ីចឹង។ អ្នកខ្លះមិនបាននាំឱ្យគេជ្រះស្រឡះអ៊ីចឹង ចេះតែនិយាយកាត់ទៅ វាកើតមានទំនាស់ ប៉ុន្តែ អ្នកណាដែលជ្រុលស្រឡាញ់គ្នាទៅហើយ ស្រឡាញ់ខ្លាំងទៅហើយ ទុកក៏មិនបានត្រូវតែរៀបឱ្យ។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ ឱ ហួ៖ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/301.1** ម៉ោង 13.54.20 (ពេលសង្គ្រាមមិនទាន់ចប់ អង្គការមិនអនុញ្ញាតឱ្យរៀបការទេ ពីព្រោះអង្គការត្រូវការយុទ្ធជន យុទ្ធនារីដើម្បីធ្វើសង្គ្រាម)។ Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី

ពាក់ព័ន្ធនឹងខ្លឹមសារទស្សនាវដ្ដី "យុវជន និងយុវនារីបដិវត្ត" ប៉ុណ្ណោះទេ ថែមទាំងបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវសេចក្ដីណែនាំចំពោះយោធាវ័យក្មេងនៃ ប.ក.ក ទៀតផង ដើម្បីទាញសេចក្ដីសន្និដ្ឋានខុសជារួមចំពោះប្រជាជនទាំងអស់។

១២១៤. **ឯកសារផ្សេងទៀតពីសម័យនោះ៖** អង្គជំនុំជម្រះក៏បានយោងខុសលើទស្សនាវដ្ដី "យុវជន និងយុវនារីបដិវត្ត" និង "ទង់បដិវត្ត" ផ្សេងទៀត ក៏ដូចជាសុន្ទរកថារបស់ ខៀវ សំផន ខែមេសា ឆ្នាំ១៩៧៨ ដើម្បីសន្និដ្ឋានថា ការសម្រេចពីអង្គការមានតម្លៃជាងការជ្រើសរើសជាឯកត្តជន ឬមនោសញ្ចេតនាផ្ទាល់ខ្លួន ហើយបើមិនគោរព ត្រូវទទួលទណ្ឌកម្ម រួមទាំងបញ្ហារៀបអាពាហ៍ពិពាហ៍ផងដែរ[2279]។ ប៉ុន្តែ គ្មានទស្សនាវដ្ដីបដិវត្តណាមួយ ដែលដកស្រង់ បានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ឬការកសាងគ្រួសារទេ។ ការអានឯកសារបោះពុម្ពផ្សាយទាំងនេះដោយមិនលម្អៀង គួរណាតែនាំឱ្យអង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះអំពាវនាវឱ្យយុវជន-យុវនារីប្រុងប្រយ័ត្ន ទាំងខាងស្មារតី និងសកម្មភាព ដើម្បីកសាងប្រទេស ស្របតាមមនោគមន៍វិជ្ជាបក្ស។ សេចក្ដីអំពាវនាវឱ្យគោរពតាមមនោគមន៍វិជ្ជាកុម្មុយនីស្ដ និងឧត្តមគតិស្នេហាជាតិ មិនអាចឱ្យចៅក្រមប្រកបដោយវិចារណញ្ញាណសន្និដ្ឋានថា ប.ក.ក មានឆន្ទៈបង្ខំប្រជាជនឱ្យរៀបអាពាហ៍ពិពាហ៍ឡើយ។

១២១៥. ដូចគ្នាផងដែរ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុស ដោយបានបំភ្លៃ និងបំប្លែងសុន្ទរកថា ខៀវ សំផន នៅខែមេសា ឆ្នាំ១៩៧៨[2280]។ ដោយមិនខ្វល់ថា សុន្ទរកថានេះត្រូវបានថ្លែងឡើង ក្នុងពេលសង្គ្រាមក្ដៅគគុកជាមួយវៀតណាម អង្គជំនុំជម្រះបានបំភ្លេចចោលទាំងស្រុងនូវខ្លឹមសារទាញចំណាប់អារម្មណ៍ប្រជាជនទៅលើជោគវាសនាប្រទេស ដោយអំពាវនាវឱ្យប្រុងប្រយ័ត្ន ចំពោះមុខសភាពការណ៍វឹកវរ។ ដោយផ្អែកលើសុន្ទរកថាដដែលនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថាអង្គការចង់ដើរតួជំនួសឪពុកម្ដាយ ឬ

១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** មុនម៉ោង 13.36.51 (រំឭកពីការកំហិតក្នុងការរៀបចំអាពាហ៍ពិពាហ៍សម្រាប់មនុស្សមួយចំនួននៅក្នុងប្រទេសមុនរយៈពេលច្បាស់លាស់មួយ)។

[2279] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤៤-៣៥៤៨ (កំណត់សម្គាល់ជើងទំព័រលេខ១១៩២៣-១១៩២៩) អង្គជំនុំជម្រះផ្អែកលើទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត ទង់បដិវត្ត លក្ខន្តិកៈនៃ ប.ក.ក និងសុន្ទរកថារបស់ ខៀវ សំផន។

[2280] ការប្រជុំគ្នានៅភ្នំពេញដើម្បីរំឭកខួបថ្ងៃទី១៧ មេសា (សំណុំឯកសារ SWB/FE/5791/B) ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/562** ERN 00249990។

អង្គការស្ថិតនៅពីលើឪពុកម្តាយ លើគ្រប់វិស័យ រួមទាំងការរៀបអាពាហ៍ពិពាហ៍ផងដែរ[2281]។ ការអានលម្អៀង និងមិនសមទំនង បានធ្វើឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា សុន្ទរកថានេះនិយាយអំពីការរៀបអាពាហ៍ពិពាហ៍[2282]។ ជាចុងក្រោយ អង្គជំនុំជម្រះខកខានមិនបានបំពេញកាតព្វកិច្ចផ្តល់សំអាងហេតុ ដោយមិនបានពន្យល់ថា ហេតុអ្វីបានជាមនោគមន៍វិជ្ជាកុម្មុយនីស្តដែលតម្កល់ផលប្រយោជន៍សមូហភាពពីលើផលប្រយោជន៍ផ្ទាល់ខ្លួន និងគ្រួសារ នាំឱ្យ ប.ក.ក បង្ខំប្រជាជនឱ្យរៀបការនៅទូទាំងប្រទេសទៅវិញ។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់របស់ជំនុំជម្រះត្រូវទុកជាមោឃៈ។

*២.៣.១.២.២. ការបំភ្លៃភស្តុតាងស្តីពីគោលបំណងផ្សេងទៀតដែលបានចោទប្រកាន់*

១២១៦. នៅក្នុងខ្សែគំនិតខុសឆ្គងដដែល អង្គជំនុំជម្រះបានសន្និដ្ឋានថា ប.ក.ក មានគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ផ្ទុយពីល័ក្ខខ័ណ្ឌផ្លូវការ ក្នុងគោលដៅគ្រប់គ្រងលើទំនាក់ទំនងផ្លូវភេទ ដើម្បីបង្កើនចំនួនប្រជាជន ក្នុងក្របខ័ណ្ឌអភិវឌ្ឍប្រទេស និងការពារជាតិប្រឆាំងនឹងវៀណាម[2283]។

១២១៧. **គោលបំណងគ្រប់គ្រងលើទំនាក់ទំនង៖** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានលាក់បាំងថា "គោលនយោបាយស្តីពីបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍របស់ ប.ក.ក" មានគោលដៅគ្រប់គ្រងលើទំនាក់ទំនងមនោសញ្ចេតនា និងទំនាក់ទំនងផ្លូវភេទ រវាងបុរស និងស្ត្រី ទាំងមុន និងក្រោយការរៀប

---

[2281] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៣៩, ៣៥៤៨ កំណត់សម្គាល់ជើងទំព័រលេខ១១៩២៧។ សូមមើលផងដែរ កថាខណ្ឌ ៣៦៧៨-៣៦៨៩, ៣៦៩១ ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ។

[2282] ដូចយោងលើ ERN 00249990 (ឧទាហរណ៍ "(១០) លើកកម្ពស់ថែរក្សាព្រលឹងជាតិ និងស្មារតីបដិវត្តឱ្យពុះកញ្ជ្រោលខ្លាំងជានិច្ច ដើម្បីត្រៀមលក្ខណៈមុនរួចជាស្រេចក្នុងការទប់ទល់ជាមួយនឹងឧបាយកលពិសពុលរបស់ខ្មាំង, (១១) មិនគិត ឬប្រព្រឹត្តអ្វីដែលបណ្តាលឱ្យខូចដល់ប្រយោជន៍ជាតិ ប្រជាជន បិដវត្ត និងបក្ស (១២) <u>ដាក់ប្រយោជន៍គ្រួសារ និងផ្ទាល់ខ្លួនទាំងស្រុងជាប្រយោជន៍រួមរបស់ជាតិ វណ្ណៈប្រជាជន និងបដិវត្ត</u> (១៣) ធានាទំនាក់ទំនងស្អិតរមួតជានិច្ចរវាងសមរភូមិក្រោយ និងសមរភូមិមុខ (១៤) រាល់គំនិតផ្តួចផ្តើម និងសកម្មភាពសមរភូមិក្រោយ ត្រូវជាការគាំទ្រស្វាហាប់ និងផ្គាត្រចង់ដល់សមរភូមិមុខ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោមផ្នែកដែលអង្គជំនុំជម្រះបានទទួលយកដោយផ្នែក)។

[2283] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤៩-៣៥៦៣។

អាពាហ៍ពិពាហ៍ ដោយមិនយល់ឃើញថា នេះគឺជាបទបញ្ហាស្ដីពីការរៀបអាពាហ៍ពិពាហ៍ តាមទស្សនៈប្រពៃណី ដែលហាមឃាត់ការរួមភេទក្រៅអាពាហ៍ពិពាហ៍[2284]។

១២១៨. ***ការគ្រប់គ្រង មុនការរៀបអាពាហ៍ពិពាហ៍៖*** អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានថា ចំពោះ ប.ក.ក ទំនាក់ទំនងរវាងបុរស និងស្ត្រី ក្រៅអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកថា "អាចបង្កគ្រោះថ្នាក់ដល់បដិវត្តន៍"[2285]។ ដើម្បីសម្រេចកិច្ចការនេះ អង្គជំនុំជម្រះបានយោងលើទស្សនាវដ្ដី "យុវជន និងយុវនារីបដិវត្ត" ចេញផ្សាយខែតុលា ឆ្នាំ១៩៧៨ និងសក្ខីកម្មមួយចំនួនទៀត ក្នុងសំណុំរឿង ០០២/០២ និងសំណុំរឿង ០០២/០១[2286]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានលាក់បាំងការចាក់ឫសក្នុងវប្បធម៌ខ្មែរនូវគោលការណ៍សីលធម៌របស់ ប.ក.ក។ ការកាត់បន្ថយគោលការណ៍សីលធម៌របស់បក្ស មកនៅត្រឹម "ការការពារបដិវត្តន៍" គឺជាការបដិសេធភ័ស្តុតាងដែលទទួលបានក្នុងពេលជំនុំជម្រះក្តី ស្តីពីគោលការណ៍សីលធម៌ និងទំនាក់ទំនងរវាងបុរស និងស្ត្រី ក្នុងវប្បធម៌ និងប្រពៃណីខ្មែរនៅមុន និងក្រោយរបបនោះ[2287]។ ឧទាហរណ៍ ច្បាប់ស្រីចែងថា៖ "ថាលេងដូចក្មេងញ៉េះញ៉ោះ ឃើញប្រុសកម្លោះ សសៀរចូលជិត។ សើចព្រៀងបញ្ឆៀងមិនគិត ប្រុសព្រើលបានចិត្ត វាហ៊ានដោយសារ។ ហៅស្រីអប្រីយ៍ឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន។ សើរើពុំធ្វើនឹងនួន ស្រដីមិនមួន មិនមានអៀនអន់។ ឃើញគេបៀបែរគយគន់ សើចស្នូរចំអន់ ចំអកឱ្យប្រុស"[2288]។ ដូច្នេះ ទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ រវាងបុរស និងស្ត្រី លែងត្រូវបានលើកទឹកចិត្តក្នុងប្រពៃណី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះត្រូវបានបញ្ជាក់អះអាងយ៉ាងខ្លាំងដោយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន[2289]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងវិចារណកិច្ចរបស់ខ្លួន ដោយមិនបានគិតដល់ការ

---

[2284] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៥៩-៣៥៦៣, ៣៦៦២-៣៦៦៥, ៣៦៦៩។

[2285] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៩-៣៦៦០។

[2286] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៦០-៣៦៦៣។

[2287] យុវជន និងយុវនារីបដិវត្ត ខែតុលា ឆ្នាំ១៩៧៨ **E3/765** ទំព័រ ៣៧ ERN 00376494 ("វានាំឱ្យប៉ះពាល់កិត្តិយសយើង ឥទ្ធិពលយើងខ្ញុំជាជនបដិវត្ត នាំឱ្យប៉ះពាល់ដល់ប្រពៃណីស្អាតស្អំ ថ្លៃថ្នូររបស់ប្រជាជនយើង។ ដូច្នេះ ប៉ះពាល់ដល់ប្រជាជនយើង")។

[2288] ច្បាប់ស្រីដោយ ម៉ឺន មៃ ពុំមានចុះកាលបរិច្ឆេទ ERN 013244317-18 (អត់មានការបកប្រែជាភាសាបារាំងនៅក្នុងសំណុំរឿង)។

[2289] ជួន ធី បានឆ្លើយថា៖ ("នៅក្នុងពេលនោះ គឺអត់មានគេហាមឃាត់ទេ ប៉ុន្តែគ្រាន់តែថាក្នុងសង្គមនោះគឺថា មនុស្សត្រូវមានខ្មែរត្រូវរស់នៅមានប្រពៃណី គឺការរៀបចំកុំឱ្យមានទុំមុនស្រគាលទេ។ ដូច្នេះ កន្លែងគេត្រូវស្មើ ឬក៏ការពេញចិត្តរបស់ខ្លួនក៏ស្មើ"។ ជួន ធី៖ ប្រតិ

បន្តនិរន្តរភាពនៃទិដ្ឋភាពនេះនៃមនោគមន៍វិជ្ជាបដិវត្តន៍ ជាមួយនឹងវប្បធម៌ខ្មែរនៅមុនរបបនោះ និងមិនបានទាញផលវិបាកនៃសេចក្តីសន្និដ្ឋានរបស់ខ្លួន[2290]។

១២១៩. ***<u>ព័ត៌មានរាយការណ៍ជូន "មជ្ឈិមបក្ស"</u>៖*** នៅកថាខណ្ឌ ៣៥៦២ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានសន្និដ្ឋានថា ការខុសសីលធម៌ និងវិធានការលើការខុសសីលធម៌ ត្រូវបានរាយការណ៍ជូន "មជ្ឈិមបក្ស"។ ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះបានផ្អែកលើរបាយការណ៍ពីររបស់

---

ចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/183.1** ចាប់ពីម៉ោង 09.59.09។ សូមមើលផងដែរ <u>យុន គីម</u>៖ ប្រតិចារឹក ថ្ងៃទី ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/89.1** ម៉ោង 09.34.01 (មេឃុំនៅតំបន់ក្រចេះ ទាក់ទងសីលធម៌ យុវជនមានសិទ្ធិរៀបការ ប៉ុន្តែពួកគេត្រូវរាយការណ៍ទៅថ្នាក់លើផ្ទាល់របស់ពួកគេ)។ ដោយលើកឡើងពីការរៀបការចាប់ពីឆ្នាំ១៩៧០-១៩៧១ ពេជ្រ ជឹម បានបញ្ជាក់ថា៖ "យុវជន និងនារីភេទក៏មានវ័យចាស់ជរាហើយ [...] តាមប្រពៃណីអត់ឱ្យយកគ្នា អត់ការ -- អត់ខុសប្រពៃណី ត្រង់ន័យថាបានគោរព។ ឱ្យជូនតាម៉ែឪ បងប្អូន <u>មហាជន</u>ជុំវិញដឹង ទុកជា<u>ពេញច្បាប់</u> ហើយសន្មតអ៊ីចឹង")។ <u>ពេជ្រ ជឹម</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** ម៉ោង 09.11.12។ សូមមើលផងដែរ <u>ខឹម បឿន</u>៖ ប្រតិចារឹក ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/296.1** ប្រហែលម៉ោង 15.22.34 ទំព័រ ៦៧ បន្ទាត់ ១៨-១៩។ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/297.1** ប្រហែលម៉ោង 14.39.13 គាត់យោងទៅកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E3/9487** ស./ឆ. ១៥៣-១៥៥។ <u>ជាំ ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/255.1** មុនម៉ោង 09.29.47 ("យើងដាក់ចិត្តថារួមជាមួយក្នុងគ្រួសារមែនពិត")។ សូមមើលផងដែរ <u>Peg LEVINE</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/482.1** ម៉ោង 09.56.29 ("ដោយសារតែយើងនិយាយអំពីរបបបរិសុទ្ធមួយដែលមានធម្មានុរូប ហើយបន្ទាប់មកគឺត្រូវបានគេទទួលស្គាល់នៅក្នុងសហគ្មន៍ថាជាអ្នកដែលរៀបអាពាហ៍ពិពាហ៍រួចហើយ។ នេះគឺជារឿងដែលសំខាន់ ហើយបន្ទាប់មកគឺដំណើរជីវិតរបស់ពួកគេទៅមុខដើម្បីបង្កើតកូនចៅ") ក្រោយម៉ោង 10.58.20 ("នៅពេលដែលខ្ញុំពិនិត្យមើលក្រមសីលធម៌ស្ត្រី គឺថាចំណុចទាំងអស់នោះ ដើរស្របតាមគោលការណ៍បដិវត្តន៍មួយចំនួន ជាពិសេសគឺការហាមឃាត់មិនឱ្យមានអំពើផិតក្បត់។ អ្វីដែលខ្ញុំអាចនិយាយនៅពេលនេះ គឺជាអ្វីដែល ប៉ុល ពត បាននិយាយអំពីបញ្ហានេះ ដែលវាស្របគ្នាទៅនឹងគោលនយោបាយសំខាន់ៗ ដើម្បីឱ្យប្រជាជនមានទំនាក់ទំនងគ្នាបានល្អជាចម្បងសិន មុននឹងចូលទៅដល់ការរួមដំណេករវាងភាគីទាំងពីរនេះ")។ សក្ខីកម្មទាំងនេះលើកឡើងពីបទពិសោធន៍របស់ស្ត្រីដែលបានមកផ្តល់សក្ខីកម្មនៅសវនាការ៖ <u>ជុំ សាមឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/321.1** ចន្លោះពីម៉ោង 14.29.44 ដល់ម៉ោង 14.32.44 ("ស្រីយើងមិនមែនការភ្លាម រឹបភ្លាមទេ")។ <u>ព្រាប សុឃឿន</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** មុនម៉ោង 14.35.00 ("ខ្ញុំមិនអាចបុរសណាប៉ះខ្លួនខ្ញុំបានទេ ព្រោះខ្ញុំតាំងចិត្តតាមឪពុកខ្ញុំគាត់បានអប់រំថា យើងខ្លួនជាស្រី មិនត្រូវការឱ្យប្រុសប៉ះដៃប៉ះជើងទេ")។ កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9826** ស./ឆ. ១៦៩-១៧១។

[2290] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦៣ ជាអាទិ៍ កំណត់សម្គាល់ជើងទំព័រលេខ១១៩៥៦ ដែលបង្ហាញពីការគោរពវិន័យចំពោះស្ត្រី និងសារសំខាន់នៃការរៀបការ ហើយបើមិនអ៊ីចឹងទេ បុរស និងស្ត្រីដែលស្រឡាញ់ ត្រូវបានចាត់ទុកថាប្រព្រឹត្តខុសសីលធម៌។

មន្ទីរ ៤០១ ផ្ញើជូនអង្គការ និងទូរលេខរបស់ សារុន ផ្ញើជូន “បង”។ ប៉ុន្តែ ការបកស្រាយឯកសារទាំងពីរនេះ គឺខុសស្រឡះ[2291]។ ម្យ៉ាង អង្គជំនុំជម្រះបានសន្និដ្ឋានថា “មជ្ឈិមបក្ស” បានដឹង ខណៈដែលរបាយការណ៍ទាំងនោះប្រើពាក្យអង្គការ ដោយគ្មានភស្តុតាងអំពីអ្នកទទួលពិតប្រាកដ។ ដូចយើងនឹងឃើញខាងក្រោម អង្គជំនុំជម្រះប្រើពាក្យ “មជ្ឈិមបក្ស” នេះ ជាប្រចាំ ដើម្បីភ្ជាប់ទំនាក់ទំនងសិប្បនិម្មិតរវាង ខៀវ សំផន និងអង្គហេតុ សូម្បីតែនៅពេលឈ្មោះគាត់មិនត្រូវបានលើកឡើងក៏ដោយ[2292]។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយករបាយការណ៍ដាច់ដោយឡែកទាំងនេះមកធ្វើជាករណីទូទៅ ខណៈដែលរបាយការណ៍ទាំងនេះផ្តោតលើហេតុការណ៍ផ្សេង ដែលទាក់ទិនជាសំខាន់នឹងសភាពការណ៍សន្តិសុខ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម[2293]។

១២២០. ***<u>ការគ្រប់គ្រង ក្រោយការរៀបអាពាហ៍ពិពាហ៍</u>៖*** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ប្តីប្រពន្ធមិនអាចលែងលះគ្នាបានទេ ក្នុងរបបនោះ ហើយជាទូទៅ ទំនាក់ទំនងរវាងគូស្រករត្រូវបានគ្រប់គ្រងដោយ ប.ក.ក[2294]។ ត្រង់នេះទៀត អង្គជំនុំជម្រះមិនបានគិតដល់បរិបទវប្បធម៌របស់កម្ពុជា ដោយបានធ្វើការវិភាគមិនគ្រប់ជ្រុងជ្រោយ និងលម្អៀងទៅលើសក្ខីកម្ម[2295]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លេចចោលនូវខ្លឹមសារនៃសម្តីរបស់ ប៉ុល ពត ដែលបញ្ជាក់អះអាងដោយ សៅ សារុន និង ជួន ជឺ អំពីការហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានផ្តោតលើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងអំពីការដាក់ទណ្ឌកម្មលើគូស្រករ

---

[2291] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦២ កំណត់សម្គាល់ជើងទំព័រលេខ១១៩៥៥ ដែលអង្គជំនុំជម្រះបានយោងទៅរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ ឯកសារ **E3/1092**, របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ ឯកសារ **E3/1094**, ទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/156**។

[2292] សូមមើលខាងក្រោម “មជ្ឈិមបក្ស” កថាខណ្ឌ ១៦១៨-១៦៣២។

[2293] គួរលើកឡើងថា ក្នុងរបាយការណ៍ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ ទោះបីជាមានការរាយការណ៍ថា ក្នុងតំបន់ ៣២ ការរៀបការត្រូវបានរៀបចំឡើង ៤២ គូ ក៏ដោយ ក៏ពុំមានកាបញ្ជាក់អ្វីសោះទាក់ទងនឹងប្រភេទនៃការរៀបការទាំងនេះ របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ ឯកសារ **E3/1094** ERN 00143617។

[2294] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៦៩។

[2295] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៦៦-៣៦៦៨។

ដែលមិនចុះសម្រុងគ្នា ដោយមិនផ្តល់ឧទាហរណ៍លម្អិតជាក់លាក់[2296]។ អង្គជំនុំជម្រះបានប្រព្រឹត្ត កំហុសអង្គហេតុ ដោយបានលាក់បាំងថាការលែងលះជារឿងមិនសមរម្យ ក្នុងវប្បធម៌ខ្មែរ តាំងពីមុន របបកម្ពុជាប្រជាធិបតេយ្យ[2297]។ ចំពោះការគ្រប់គ្រងការរួមដំណេក យើងនឹងពិនិត្យខាងក្រោម[2298]។

១២២១. <u>**គោលដៅបង្កើនចំនួនប្រជាជន៖**</u> អង្គជំនុំជម្រះបានជឿជាក់ថា គោលដៅនៃបទបញ្ញាស្តីពីការរៀប អាពាហ៍ពិពាហ៍ គឺដើម្បីជួយសម្រួលដល់កំណើនប្រជាជន។ ជាក់ស្តែង ទាំងបុរស និងស្ត្រីគ្មានជម្រើស អ្វីក្រៅរៀបអាពាហ៍ពិពាហ៍ និងរួមដំណេក ដើម្បីបង្កើតកូន[2299]។ ដើម្បីគាំទ្រដល់ការសន្និដ្ឋាននេះ អង្គ

---

[2296] <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** មុនម៉ោង 14.10.00 ប្រហែលម៉ោង 14.12.22។ <u>ជួន ធី</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/183.1** ចន្លោះពីម៉ោង 09.57.15 ដល់ម៉ោង 10.03.25។ ប្រតិចារឹក ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/**490.1 ចាប់ពីម៉ោង 09.13.46។ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯក សារ **E319/71.2.4** ស./ធ.១៨-៣៣។ <u>មាស រឿន</u>៖ ប្រតិចារឹក ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/131.1** ក្រោយម៉ោង 13.46.36។ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៦៨ កំណត់សម្គាល់ជើងទំព័រលេខ១២២៣៨-១២២៤៤ ដែលបានប្រើសក្ខីកម្ម របស់ ស៊ូ សុធារី, ឃិន វ៉ាត, យី ឡៃសួរ, ភ្លៅ យ៉ារ, ជា ឌៀប, យស ផល និង មាស ឡៃហួរ។ អង្គជំនុំជម្រះមិនបានទាញសេចក្តី សន្និដ្ឋានជាពិសេសអំពីកង្វះភាពអាចជឿងទុកបាននៃសក្ខីកម្មរបស់ យស ផល ដែលបាននិយាយថាមិនបានលែងលះទេ ពីព្រោះគាត់ មិន “ហ៊ាន” និង “ខ្លាច”៖ <u>យស ផល</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/464.1** ក្រោយម៉ោង 10.51.08។ ប៉ុន្តែ គាត់នៅតែជាប្តីរបស់ប្រពន្ធគាត់ ក្រោយចប់របប។

[2297] <u>Kasumi NAKAGAWA</u>៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** មុនម៉ោង 11.13.54 (“គូស្រករដែលរៀប ការហើយអាចនឹងលែងលះគ្នាបាន ប៉ុន្តែជាករណីកម្រ ពីព្រោះនៅពេលនោះ ពីព្រោះគឺថាសម័យនោះ គេត្រូវរក្សាគោលការណ៍ប្តីមួយ ប្រពន្ធមួយ។ អ៊ីចឹង គឺថាចំពោះបុរសក្នុងករណីខ្លះគេអាចមានប្រពន្ធច្រើន។ មិនមានហេតុផលដែលបុរសចង់លែងប្រពន្ធទេ គាត់ងាច រក្សាទុកប្រពន្ធច្រើនបាន។ ប៉ុន្តែ ចំពោះស្ត្រីវិញ គឺមានការខ្មាសអៀនបើសិនជាមានការលែងលះ។ អ៊ីចេងគឺថា ភាគីទាំងសងខាងហ្នឹង កម្រមានហេតុផលលែងលះណាស់”)។ ផ្ទុយនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះ NAKAGAWA បានរំឭកពីករណីលែងលះមួយក្នុង របបខ្មែរក្រហម ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ប្រហែលម៉ោង 15.55.00។ <u>សយ ណារឿន</u>៖ ប្រតិ ចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ក្រោយម៉ោង 11.14.34 (មូលហេតុដែលមិនលែងលះក្រោយរបបខ្មែរ ក្រហម៖ “ខ្លួនខ្ញុំជាស្ត្រីខ្មែរ ខ្ញុំមិនចង់ឱ្យកូនមានឪមួយ ឪពីរ ប្តីមួយ ប្តីពីរទេ”)។ កំណត់ហេតុស្តាប់ចម្លើយ ខែត សុខន ចុះថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០១៣ ឯកសារ **E3/9830** ស./ធ.៨៦-៨៨ (គាត់មិនចង់ចាកចេញពីប្តីគាត់ក្រោយការរៀបការ ពីព្រោះគាត់មិនចង់មានប្តី ច្រើន)។

[2298] សូមមើលខាងក្រោម កថាខណ្ឌ ១៣៩១-១៣៩៨.

[2299] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០៩០, ៣៥៥៨, ៣៦៩០-៣៦៩១, ៣៦៩៦-៣៦៩៨ ការកំណត់ប្រភេទបទល្មើសនៃអង្គហេតុ។

ជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយបានអះអាងផ្ទុយនឹងសេចក្តីសន្និដ្ឋានផ្សេងទៀតអំពីបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងក្នុងការវាយតម្លៃភ័ស្តុតាង។

១២២២. ***ភាពផ្ទុយគ្នារបស់អង្គជំនុំជម្រះ៖*** នៅកថាខណ្ឌ ៣៦៦៥ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានសន្និដ្ឋានថា ទោះបីជាក្រោយការរៀបការហើយក្តី "ទំនាក់ទំនងប្តីប្រពន្ធនៅតែត្រូវបានគ្រប់គ្រងជាទូទៅដោយ ប.ក.ក"។ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋាននេះ អង្គជំនុំជម្រះបានពន្យល់ថា ក្រោយពីរៀបការហើយ ប្តីប្រពន្ធត្រូវបានបំបែកឱ្យទៅធ្វើការ តាមកន្លែងរៀង១ខ្លួន។ របបនៃការសួរសុខទុក្ខគ្នាត្រូវបានកំណត់ ហើយបើគ្មានការកំណត់ទេ ត្រូវសុំការអនុញ្ញាតទៅជួបជុំគ្នា[2300]។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំ បានបញ្ជាក់អះអាងអំពីរបបនៃការសួរសុខទុក្ខនេះ ដោយប្តីប្រពន្ធត្រូវធ្វើការនៅកន្លែងផ្សេងគ្នា[2301]។ ប៉ុន្តែ គួរកត់សម្គាល់ថា វិធានការបំបែកនេះមិនជួយសម្រួលដល់ឱកាសមានគភ៌ឡើយ។ ការកត់សម្គាល់ដំបូងនេះមិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋាន ដូចខ្លួនបានធ្វើ ថា គោលដៅរបស់ ប.ក.ក គឺការបង្កើតកូនជូនអង្គការ នោះឡើយ។ ដូចយើងនឹងឃើញខាងក្រោម អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា មានវិធានការជាក់លាក់ ដើម្បីលើកទឹកចិត្តឱ្យបង្កកំណើត នោះឡើយ[2302]។

១២២៣. ***កំហុសក្នុងការវាយតម្លៃភ័ស្តុតាង៖*** ដើម្បីសន្និដ្ឋានអំពីគោលដៅបង្កើនប្រជាជន តាមរយៈការរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះបានធ្វើការពិនិត្យខុស និងលម្អៀងដាក់បន្ទុកទៅលើសុន្ទរកថារបស់ដឹកនាំជាន់ខ្ពស់ ប.ក.ក សុន្ទរកថាពីររបស់ ខៀវ សំផន នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ សេចក្តីដកស្រង់មួយចេញពីសៀវភៅរបស់ ខៀវ សំផន សក្ខីកម្ម ៣ របស់អតីតកម្មាភិបាល និងសក្ខីកម្ម ៧ របស់ដើមប

[2300] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៦២-៣៦៦៤។

[2301] <u>ឃិន វ៉ាត</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/325.1** ក្រោយម៉ោង 15.02.42 ម៉ោង 15.27.51 (មួយសប្តាហ៍ក្រោយរៀបការ គាត់ត្រូវឃ្លាតឆ្ងាយពីប្តីគាត់ដើម្បីធ្វើការ)។ <u>ជុំ សាមឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/321.1** មុនម៉ោង 14.27.54 (ពួកគាត់បែកគ្នាបីថ្ងៃក្រោយពេលរៀបការ)។ កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9662** (ពួកគាត់ស្រឡាញ់គ្នាក្រោយរៀបការរួច ហើយប្តីរបស់គាត់បានកុហកមេដើម្បីអាចត្រឡប់មកជួបប្រពន្ធនៅផ្ទះ)។

[2302] សូមមើលខាងក្រោម កថាខណ្ឌ ១២២៨-១២៣០។

ណ្តឹងរដ្ឋប្បវេណី ដែលបានមកបង្ហាញខ្លួន ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍[2303]។ បញ្ជីភ័ស្តុតាងដែលបានប្រើប្រាស់មានគោលដៅបង្កើតសំអាងហេតុបំភាន់ភ្នែក ដែលត្រូវបរាជ័យ នៅចំពោះមុខការពិនិត្យឡើងវិញ ដោយសារតែការបំភ្លៃខ្លាំងពេករបស់អង្គជំនុំជម្រះ ដែលនឹងត្រូវបដិសេធចោល។

១២២៤. ***ការបំភ្លៃ និងបំប្លែងឯកសាររបស់ ប.ក.ក និងសុន្ទរកថាស្តីពីវិធានការបង្កើនចំនួនប្រជាជន៖*** យើងមិនជំទាស់ទេថា ឯកសារផ្លូវការ ដែលអង្គជំនុំជម្រះបានបង្ហាញ ពិតជាបានលើកឡើងអំពីគោលដៅរបស់ ប.ក.ក ក្នុងការបង្កើនប្រជាជនកម្ពុជាប្រជាធិបតេយ្យ[2304]។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយបានបំភ្លេចចោលតែម្តងនូវសេចក្តីបញ្ជាក់របស់ឯកសារទាំងនេះអំពីវិធានការ ដើម្បីសម្រេចគោលដៅនេះ ដែលមិនជាប់ទាក់ទងទាល់តែសោះនឹងការអនុវត្តគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ប.ក.ក ចង់សម្រេចគោលដៅនេះ តាមរយៈការកែលម្អជីវភាព និងសុខភាពប្រជាជន[2305]។ នេះគឺជាបញ្ហាទាក់ទិននឹងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស ដែលត្រូវបានមេដឹកនាំ ប.ក.ក លើកឡើងជាច្រើនលើកច្រើនសា ទាំងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ[2306]។ ម្យ៉ាងវិញទៀត

---

[2303] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤៩-៣៥៥៧។

[2304] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៥០-៣៥៥៥។

[2305] សូមមើលឧទាហរណ៍ ទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ ឯកសារ **E3/25** ទំព័រ ៩៧ ERN 00063054 ("ដើម្បីឱ្យប្រជាជនកើនបានឆាប់ ទាល់តែជីវភាពឡើង សុខភាពបានល្អ")។

[2306] ទង់បដិវត្ត ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/748** ទំព័រ ១៧ ERN 00063246 ("កសាងប្រទេសឱ្យបានឆាប់រហ័ស ដើម្បីកសាងជីវភាពប្រជាជនយើងឱ្យបានគ្រប់គ្រាន់ធូរធាឆាប់រហ័សតាមរបប [...] សំណូមពរមួយទៀត គឺដើម្បីប្រជាជនយើងមានចំនួនកើនឆាប់រហ័ស") ទំព័រ ៣៨ ERN 00063259 ("២. ការដោះស្រាយជីវភាពប្រជាជនពាក់ព័ន្ធដល់មាគ៌ាគ្រប់ផ្នែករបស់បក្ស")។ សុន្ទរកថារបស់ប្រធានគណៈប្រធានរដ្ឋ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧៦ ឯកសារ **E3/549** ERN 00065899។ សុន្ទរកថារបស់ អៀង សារី នៅអង្គការសហប្រជាជាតិ ថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ ឯកសារ **E3/1586**, កថាខណ្ឌ ៥៦-៦០ និង ៦៣ ERN 00291028 ("៦៣. យើងត្រូវដើរលើផ្លូវដ៏វែងឆ្ងាយ ដើម្បីសម្រេចបានបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនយើង។ យើងត្រូវបង្កើនការខិតខំប្រឹងប្រែងឱ្យបានទ្វេរដង។ យើងកំពុងខិតខំប្រឹងប្រែងឱ្យបានកាន់តែខ្លាំងតាមតែអាចធ្វើបាន ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀតនូវស្ថានភាពរស់នៅរបស់ប្រជាជនយើង ដើម្បីឱ្យយើងមានកម្លាំងគ្រប់គ្រាន់ និងសុខភាពល្អ និងការស្នេហាជាតិយ៉ាងក្លៀវក្លា និងដើម្បីឱ្យប្រជាជនទាំងអស់មានការរីកចម្រើនឥតឈប់ឈរ និងបន្តការការពារជាតិ និងកសាងប្រទេសកម្ពុជាឱ្យបានសម្បូររុងរឿងយ៉ាងឆាប់រហ័ស")។ ទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៧ ឯកសារ **E3/11** ទំព័រ ៨៦-៨៩ ERN 00063164-00063165 ទំព័រ ១២៣-១២៤ ERN 00063183-00063184 ("យើងត្រូវតែខិតខំយកចិត្តទុកដាក់លើកស្ទួយជីវភាពប្រជាជន និងសុខភាពប្រជាជនយើង ឱ្យបានឆាប់រហ័សបំផុត ព្រោះយើងត្រូវការឱ្យមានប្រជាជនកម្ពុជាពី ១៥ លានទៅ ២០ លាននាក់ក្នុងកំឡុងជាង ១០ ឆ្នាំខាងមុខនេះ [...] យើងខំ

ឯកសារផ្សេងទៀតបញ្ជាក់អះអាងអំពីសេចក្តីតម្រង់ទិសនេះរបស់ ប.ក.ក និងការទិតៀនកម្មាភិបាលដែលធ្វេសប្រហែសនឹងតួនាទីរបស់ខ្លួនក្នុងការដឹកនាំ និងបម្រើប្រជាជន[2307]។ អង្គជំនុំជម្រះបានបំភ្លេចចោលឯកសារទាំងនេះ ដូចសក្ខីកម្មរបស់សាក្សីក្នុងន័យនេះដែរ[2308]។ ការវិភាគមិនលម្អៀងលើឯកសារ

---

ពុះពារថែបំប៉នលើកស្ទួយជីវភាពប្រជាជនគ្រប់ផ្នែកឱ្យបានឆាប់រហ័សថែមទៀត ដើម្បីប្រជាជនមួយរូបៗមានកម្លាំងពលំមាំមួន សុខភាពល្អរឹងប៉ឹង ស្មារតីស្នេហាជាតិមោះមុត ហើយប្រជាជនកម្ពុជាជារួមបានកើនឡើងជាលំដាប់យ៉ាងឆាប់រហ័ស")។ អង្គជំនុំជម្រះនៅតែប្រព្រឹត្តកំហុស ដោយបានលាក់បាំង និងបំភ្លៃខ្លឹមសារនៃឯកសារនានាសម័យកម្ពុជាប្រជាធិបតេយ្យទាំងនេះពាក់ព័ន្ធនឹងវិធានការដើម្បីបង្កើនចំនួនប្រជាជន ដោយហេតុថាមេធាវីការពារក្តីបានរំឭកពីប្រការនេះរួចហើយ។ សវនាការលើឯកសារគន្លឹះ៖ ប្រតិចារឹក ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/471.1** ចន្លោះពីម៉ោង 09.17.45 ដល់ម៉ោង 10.05.00។

[2307] ទង់បដិវត្ត ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/748** ទំព័រ ៣៨ ERN 00063259 ("ប៉ុន្តែ ឥឡូវនេះ ក្នុងឋានៈបក្សគ្រប់គ្រងទូទាំងប្រទេសទាំងមូល កម្មាភិបាលបក្ខជនទាំងអស់ត្រូវទទួលខុសត្រូវចំពោះជីវភាពប្រជាជន យើងមិនអាចនៅស្ងៀម ព្រងើយកន្តើយធ្វើវាហីបានទេ")។ យុវជន និងយុវនារីបដិវត្ត ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/732** ទំព័រ ២៥-២៩ ERN 00064296 -00064298 ("ប៉ុន្តែ ជាការគួរឱ្យស្តាយ និងគួរឱ្យឈឺចាប់បំផុត គឺនៅពេលដែលយើងរំដោះទីក្រុងភ្នំពេញ និងទូទាំងប្រទេសហើយ នៅពេលដែលបក្សក្តាប់រដ្ឋអំណាចទូទាំងប្រទេសហើយ កម្មាភិបាល និងយុទ្ធជន-យុទ្ធនារីបដិវត្តយើងខ្លះបែរទៅជាភ្លេចអស់នូវគុណូបការៈរបស់ប្រជាជន-មហាជន [...] នៅកន្លែងខ្លះទៀត មិត្តយើងមិនត្រឹមតែមិនគិតគូរដោះស្រាយជីវភាពប្រជាជនប៉ុណ្ណោះទេ [...] មិត្តយើងមិនសូវយកចិត្តទុកដាក់ក្នុងការដឹកជញ្ជូន ថែទាំទុកដាក់របស់របរដ៏មានតម្លៃទាំងនេះ ដែលប្រជាជនយើងត្រូវការចាំបាច់បំផុត [...] ការខុសឆ្គងទាំងនេះ ទោះចេតនាក្តី ឬអចេតនាក្តី សុទ្ធតែប៉ះពាល់ដល់ជីវភាពប្រជាជន ប៉ះពាល់ដល់មនោសញ្ចេតនាប្រជាជនខ្លាំងណាស់ ដូច្នេះ ក៏ប៉ះពាល់ដល់ចលនាបដិវត្ត និងឥទ្ធិពលបដិវត្តទាំងមូលផងដែរ។ បើយុវជន-យុវនារីបដិវត្តយើងមិនចាប់អារម្មណ៍កែប្រែ ឬដាច់ខាតកម្ចាត់នូវការខុសឆ្គង ដូចពោលខាងលើនេះទេ នោះចលនាបដិវត្តយើងពិតជាពុំមានកម្លាំងខ្លាំងក្លាឡើយ។ យើងពិតជាពុំអាចចលនាគៀងគរប្រជាជន-មហាជនបានច្រើនកុះករ ដើម្បីវាយសម្រុកស្តារសេដ្ឋកិច្ច ការពារប្រទេស កសាងប្រទេស") ទំព័រ ១៧ ERN 00064290 ("បើយើងមានមាគ៌ាមហាជនត្រឹមត្រូវ យើងមិនបង្ខិតបង្ខំប្រជាជន-មហាជនឱ្យលើកភ្លឺថ្មី ជីកប្រឡាយថ្មី តាមផែនការបស់បក្សដែលដាក់ចុះ ដោយប្រើអាជ្ញាសម្តុគគំរាមកំហែងថា បើអ្នកណាមិនធ្វើតាមបដិវត្ត អ្នកនោះជាជនក្បត់")។ ទង់បដិវត្ត ខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ ឯកសារ **E3/166** ទំព័រ ៣១-៣២ERN 00063205-00063206 ("ដូច្នេះ យើងមានលទ្ធភាពច្រើនណាស់ ក្នុងការអនុវត្តមាគ៌ាមហាជន គិតគូរជួយដោះស្រាយជូនប្រជាជន-មហាជនឱ្យបានចម្រើនធូរធាឡើងជាលំដាប់។ តែផ្ទុយទៅវិញ ហើយដែលជាការគួរឱ្យស្តាប់ និងគួរឱ្យឈឺចាប់បំផុត បក្ខជន និងកម្មាភិបាលបដិវត្តយើងខ្ញុំជាច្រើន បែរទៅជាវរល់ភ្លើតភ្លើនតែនឹងជ័យជម្នះ ភ្លេចគុណបំណាច់ដ៏សែនមហាធ្ងន់របស់ប្រជាជន-មហាជន")។ លក្ខន្តិកៈ ប.ក.ក. ឆ្នាំ១៩៧១ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៧២ ឯកសារ **E3/8380** ERN 00283541-00283542 (លក្ខណវិនិច្ឆ័យនៃថ្នាក់ដឹកនាំល្អម្នាក់សម្រាប់ការងារកសាងបក្ស)។ ង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ ឯកសារ **E3/25** ទំព័រ ទំព័រ ៩៧ ERN 00063054។

[2308] ឧទាហរណ៍ ពេលសួរអំពីគោលនយោបាយទូទៅរបស់ ប.ក.ក ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ជួន ធី បានឆ្លើយថា៖ ("ពេលហ្នឹងគឺខ្ញុំដែលឮ និយាយថាធ្វើម៉េចកសាងឱ្យប្រទេសយើងមានសេដ្ឋកិច្ចគ្រប់គ្រាន់ ឱ្យប្រជាជនយើងមានជីវភាពធូរធារ មានទឹកមានដី

ទាំងនេះមិនអាចឱ្យចៅក្រមប្រកបដោយវិចារណញ្ញាណសន្និដ្ឋាន ដូចអង្គជំនុំជម្រះ ថា ការបង្កើនចំនួនប្រជាជន បើតាម ប.ក.ក ត្រូវធ្វើឡើង តាមរយៈគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សេចក្តីសន្និដ្ឋានក្នុងន័យនេះត្រូវទុកជាមោឃៈ។

១២២៥. ***កំហុសក្នុងការវាយតម្លៃលើសក្ខីកម្មរបស់អតីតកម្មាភិបាល និងយោធា៖*** ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះបានប្រើសក្ខីកម្មរបស់ សៅ សារុន, មាស វឿន និង ជិន សារឿន ដោយបំភ្លៃខ្លឹមសារ និងបំភ្លេចចោលផ្នែកដោះបន្ទុកនៃសក្ខីកម្មទាំងនោះ។ ជាក់ស្តែង ទោះបីជាពួកគេបានលើកឡើងអំពីគោលបំណងបង្កើនចំនួនប្រជាជនក៏ដោយ ក៏គ្មានអ្នកណាម្នាក់បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬខុសពីចិត្ត ដើម្បីសម្រេចគោលដៅនេះឡើយ។ ផ្ទុយទៅវិញ ពួកគេបានបញ្ជាក់អំពីបុរេលក្ខខណ្ឌនៃការយល់ព្រមពីអនាគតប្តីប្រពន្ធ ជាផ្នែកដែលអង្គជំនុំជម្រះមានចេតនាបដិសេធចោល ក្នុងការពិនិត្យភ័ស្តុតាងដោយលម្អៀង[2309]។ ជាអាទិ៍ អង្គជំនុំជម្រះបានលាក់បាំងសេចក្តីពន្យល់របស់ សៅ សារុន ដែលមើលឃើញការបង្កើតកូន គឺជារឿងសមហេតុផលក្រោយពីការរៀបអាពាហ៍ពិពាហ៍ និងមិនទាក់ទងដោយផ្ទាល់នឹងគោលដៅទូទៅនៃការបង្កើនចំនួនប្រជាជនឡើយ[2310]។

---

មានបាយអីហូបចុកគ្រប់គ្រាន់ និយាយជីវភាពគ្រប់គ្រាន់")៖ ដួន ធី៖ ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ក្រោយម៉ោង 09.40.28។ សូមមើលផងដែរ ម៉ាក ឈឿន៖ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E1/511.1** ក្រោយម៉ោង 16.00.57 ("យើងអាចពង្រឹកកម្លាំងឱ្យបានច្រើន ដើម្បីការពារប្រទេស") ខណៈដែលគាត់អះអាងថាមិនដែលដឹងពីរឿងរៀបការដោយបង្ខំ)។

[2309] សៅ សារុន៖ ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** ម៉ោង 14.05.00 ("ឱ្យតែគេស្រឡាញ់ប្រុសស្រីគេស្រឡាញ់គ្នា" និងប្រហែលម៉ោង 14.18.16។ ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/85.1** ក្រោយម៉ោង 09.52.50 ("យើងអត់មានសិទ្ធិទៅបង្ខំគេទេ")។ មាស វឿន៖ ប្រតិចារឹក ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/131.1** ម៉ោង 13.46.36 "អង្កាល់នោះ ក្នុងភាគហ្នឹងបានប្រជុំឱ្យរៀបការ។ [...] គេឱ្យយទ្ធជនទៅមើលនារី គេស្រឡាញ់អ្នកណា គេប្រាប់ឱ្យគេប្រាប់ឈ្មោះដល់យើងមក យើងនឹងសួរបញ្ជាក់គេដែរ។ ដើម្បីថាគេស្រឡាញ់អ្នកនេះ ឬឈ្មោះនោះ ឈ្មោះនោះអី បើគេត្រូវ បានយើងរៀបឱ្យគេ។ បើគេមិនត្រូវទេ យើងអត់បាច់បង្ខំគេទេ អាហ្នឹងគឺថា -- ចំណែកខាងយោធាអ៊ីចឹង")។ ជិន សារឿន៖ ប្រតិចារឹក ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/454.1** ម៉ោង 14.10.01 ("មេបញ្ជាការខ្ញុំហ្នឹងគាត់សួរ [...] អត់មានការចាប់បង្ខំទេ")។

[2310] សៅ សារុន៖ ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** មុនម៉ោង 14.16.24 ("ស.៖ លោកសាក្សី តើលោកចាំបានដែរទេថាមានទទួលបាននូវការបញ្ជាពី ប៉ុល ពត ឬក៏ពីមេដឹកនាំណាមួយដើម្បីបង្កើនចំនួនប្រជាជន? ឆ.៖ ដូចថា អត់ឮទេបញ្ហានេះ មាតែបញ្ហារៀបការ អាហ្នឹងគឺមែន។ បញ្ហារៀបការមានប្តីប្រពន្ធគឺមែន អាហ្នឹងគឺឮច្បាស់។ ប៉ុន្តែ ការបង្កើន បើមានប្តីប្រពន្ធ

អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានយល់ឃើញថា រឿង "សមហេតុផល" និងតាមធម្មជាតិ ក្នុងការមានកូន ក្រោយការរៀបអាពាហ៍ពិពាហ៍ គឺជាគោលដៅពិសេសរបស់ ប.ក.ក ខណៈដែលវាជារឿងធម្មតារបស់សង្គមប្រពៃណីខ្មែរ ដូចសង្គមជាច្រើនផ្សេងទៀតដែរ។ សក្ខីកម្មជាច្រើនរួមទាំងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់ការវិភាគដូច សៅ សារុន ដែរ[2311]។

១២២៦. ម្យ៉ាងវិញទៀត ជួន ធី អតីតមេឃោធា នៅភូមិភាគបូព៌ា ដូច មាស វឿន ដែរ បានឆ្លើយថា គាត់បានឮ ប៉ុល ពត និយាយអំពីគោលនយោបាយបង្កើនចំនួនប្រជាជន ដោយជួយសម្រួលដល់ការរៀបអាពាហ៍ពិពាហ៍ ក្នុងកិច្ចប្រជុំមួយនៅខេត្តកំពង់ឆ្នាំង។ ប៉ុន្តែ ពេលសួរដេញដោលជាច្រើនដងលើបញ្ហានេះ ទាំងក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ជួន ធី នៅតែរក្សាចម្លើយដដែលថា មិនមាននិយាយអំពីការរៀបការដោយបង្ខំទេ៖ "ប៉ុល ពត និយាយថា សម្រេចលើសាមីខ្លួន គេជាអ្នកសម្រេច។

---

ហើយ បង្កើតហើយ អាហ្នឹងចំនួនប្រជាជនបាទ។ ស.៖ តើប្តីប្រពន្ធដែលត្រូវអង្គការរៀបការឱ្យហ្នឹង គឺត្រូវតែបង្កើតកូនចៅដែរឬទេ? ឆ.៖ ធម្មតា ប្រុសស្រីវាយកគ្នាហើយ ជួនការតែមួយឆ្នាំមានកូន ជួនកាលអ្នកខ្លះក៏ពីរឆ្នាំក៏មានកូនក៏មាន") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2311] ណុប ឌីម៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 11.12.25 ("ការហើយក៏ខ្ញុំអត់មានអីទេ ចេះតែទ្រាំយកគ្នាទៅធ្វើម៉េចទេអង្គការការឱ្យហើយ គេជំនាន់គេហៅអង្គការហើយចុះ។ អង្គការការឱ្យចេះតែទ្រាំយកទៅ បានគ្នាបានជាកូនបានជាចៅហើយ")។ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៩ ឯកសារ **E1/378.1** (អសាធារណៈ) មុនម៉ោង 13.41.13 ("បើកាលណាការហើយ បើយើងជិតទៅ វាត្រូវតែរួមដំណេក ឬក៏បើមិនរួមដំណេក ក៏យើងថា ការយ៉ាងម៉េច") ម៉ោង 13.47.27 ("ខ្ញុំអត់មានវិធានការអីដែលធ្វើឱ្យគូស្រករទាំងពីរនាក់នោះ បាត់បង់អីទេ មានតែការអប់រំក្នុងស្រុក ដើម្បីឱ្យគូស្រករទាំងពីរនោះចេះយល់ចិត្ត យល់គំនិតគ្នា ព្រោះយើងការរួចហើយ »)។ ប៊ិត ញឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ប្រហែលម៉ោង 11.23.42 (មិនចាំបាច់មានការណែនាំឱ្យរួមដំណេកទេ ព្រោះរៀបការរួចហើយ)។ នៅក្នុងវប្បធម៌ខ្មែរ ដែលការរៀបការត្រូវបានរៀបចំ គេមិនសួរចំៗទៅលើយប់ផ្សំដំណែករបស់គូស្វាមីភរិយាទេ ប៉ុន្តែគេសួរសំណួរទាក់ទងនឹងកូន និងលទ្ធភាពនៃការមានផ្ទៃពោះទៅវិញ។ Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** មុនម៉ោង 11.16.32។ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ក្រោយម៉ោង 11.05.23។ កំណត់ហេតុស្តាប់ចម្លើយរស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ឆ.៩៥ ("បើក្រោយរៀបការហើយ គឺគេសន្មតថាត្រូវតែមានកូនហើយ ប៉ុន្តែបើស្ត្រីនោះគ្មានកូន ក៏គ្មាននរណាចាប់បង្ខំដែរ")។ កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E3/10761** ស./ឆ.១៣៤ ("ជាធម្មតា ប្តីប្រពន្ធ ខ្ញុំមិនមានអារម្មណ៍ថាត្រូវបង្ខំរួមភេទជាមួយគ្នាទេ គឺយើងស្ម័គ្រចិត្ត")។ កំណត់ហេតុស្តាប់ចម្លើយ ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9826** ស./ឆ. ១៦៩-១៧១ ("ខ្ញុំគិតថា គង់តែប្តីប្រពន្ធនឹងគ្នា ខ្ញុំក៏សម្រេចចិត្តរួមដំណេកជាមួយគាត់តែម្តង")។

បើគេយល់ព្រម រៀបចំឱ្យគេទៅ កុំបង្ខំគេ"[2312]។ ផ្ទុយពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះ គាត់បានសន្និដ្ឋានថា៖ "គឺពេលនោះ គឺគេមានការរៀបចំឱ្យហើយ អត់មានគោលការណ៍អីទេ គឺការសម្រេចរៀបចំការនេះ ទៅលើការពេញចិត្តទាំងសងខាង"[2313]។ ដូច្នេះ អង្គជំនុំជម្រះបានស្តែងឱ្យឃើញភាពលម្អៀង តាមរយៈការទទួលយកសក្ខីកម្មរបស់សាក្សីតែមួយផ្នែក។

១២២៧. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្តល់ភាពអាចជឿជាក់បានខុសៗគ្នាដល់សក្ខីកម្មរបស់កម្មាភិបាល ប.ក.ក អំពីគោលនយោបាយ និងបទបញ្ជាចេញមកពីថ្នាក់ដឹកនាំ ប.ក.ក អាស្រ័យតាមការចង់បានរបស់អង្គជំនុំជម្រះ ដើម្បីគាំទ្រដល់ទស្សនៈរបស់ខ្លួន ដោយធ្វើការវិភាគលម្អៀងទៅលើភស្តុតាង។ បើប្រកាសថាសក្ខីកម្មទាំងនេះអាចជឿជាក់បាន ពាក់ព័ន្ធនឹងគោលដៅបង្កើនចំនួនប្រជាជនតាមរយៈការរៀបអាពាហ៍ពិពាហ៍ ក្នុងពេលជាមួយគ្នានោះ អង្គជំនុំជម្រះមិនអាចច្រានចោលការបញ្ជាក់អះអាងរបស់ពួកគេ អំពីល័ក្ខខ័ណ្ឌនៃការយល់ព្រមជាមុនពីសាមីខ្លួនចំពោះការរៀបអាពាហ៍ពិពាហ៍នោះឡើយ។ ចៅក្រមប្រកបដោយវិចារណញ្ញាណត្រូវសន្និដ្ឋានថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការរំលោភបំពានលើបទបញ្ជា និងគោលនយោបាយរបស់ ប.ក.ក។ សេចក្តីសន្និដ្ឋានផ្ទុយរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ។

១២២៨. ***កំហុសក្នុងការវាយតម្លៃលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖*** ដូចបានឃើញពីខាងលើ ភាពលម្អៀងរបស់អង្គជំនុំជម្រះ ស្ថិតនៅក្នុងការវាយតម្លៃលើសក្ខីកម្មទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី

---

[2312] ជួន ធី៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/183.1** ចាប់ពីម៉ោង 09.57.15។ ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ចាប់ពីម៉ោង 09.33.27។ កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ.៣៣, ៣៤, ១០៤-១០៩, ១១៨, ១២៣, ១២៤, ១៣០-១៣៣ ដែលត្រូវបានទទួលយកជាភស្តុតាងតាមសេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ **F51/3**។ សូមមើលផងដែរ កំណត់ហេតុស្តាប់ចម្លើយ របស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ឆ.៨២-៨៧ តាមការគិតរបស់គាត់ ការរៀបការត្រូវបានធ្វើឡើងដើម្បីបង្កើនចំនួនប្រជាជន ដោយបញ្ជាក់ថា៖ "អ្នកខ្លះទៀតដែលបានយល់អំពីផែនការនេះ ឬមានមិត្តភក្តិនិយាយប្រាប់ពីគោលការណ៍បក្ស គេក៏បានប្រកែកមិនព្រមរៀបការ")។

[2313] ជួន ធី៖ ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ប្រហែលម៉ោង 09.06.11 ម៉ោង 09.11.40 ("គឺនៅក្នុងអង្គភាពខ្ញុំ កន្លែងខ្ញុំរៀបចំទៅតាមការស្ម័គ្រចិត្ត ការពេញចិត្តទាំងសងខាង")។

ធៀបនឹងសំណុំរឿងទាំងមូល។ ជាក់ស្តែង អង្គជំនុំជម្រះខកខានមិនបានបំពេញភារកិច្ចរបស់ខ្លួន ក្នុងការប្រៀបធៀបភស្តុតាងទាំងមូលទាំងដាក់បន្ទុក និងដោះបន្ទុក មុននឹងទាញសេចក្តីសន្និដ្ឋាន។ ដូច្នេះ អង្គជំនុំជម្រះបានប្រើប្រាស់ជាចម្បងនូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីទាញសេចក្តីសន្និដ្ឋានជារួមលើគោលនយោបាយរបស់ ប.ក.ក។ អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់, ព្រាប សុខឿន, មុំ វុន, កុល ណែម, ង៉ែត ចាត, ស៊ូ សុធារី និង ជា ឌៀប[2314]។ ប៉ុន្តែ ដូចការវិភាគភស្តុតាងក្នុងផ្នែកមុនស្តីពីការព្រមព្រៀងដែរ បញ្ហានៃភាពជាតំណាងនៃសក្ខីកម្មរបស់ពួកគេ មានសារៈសំខាន់ណាស់។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ដែលជាភាគីនៃរឿងក្តី មានឱកាសផ្លាស់ប្តូរយោបល់គ្នាជាក្រុមអំពីបទពិសោធន៍របស់ខ្លួន បានមកបង្ហាញខ្លួន ជាពិសេស នៅក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ និងបានអះអាងដូចគ្នាហាក់ដូចជាចៃដន្យពេកថា ពួកគេបានទទួលការណែនាំឱ្យបង្កើតកូនជូនអង្គការ[2315]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានលើកឡើងអំពីភាពខុសគ្នានៃរឿងរ៉ាវ នៅពេលជាសាក្សីក្នុងវគ្គផ្សេងទៀត[2316]។

១២២៩. សំខាន់ជាងនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមានចេតនាបំភ្លេចចោលនូវភស្តុតាងដោះបន្ទុកនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ។ ជាក់ស្តែង ដោយបានយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះនិយាយអំពី "សេចក្តីណែនាំ" ពីអាជ្ញាធរ ដែលធ្វើជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ឱ្យបង្កើតកូន សុន្ទរកថាដដែលទាំងនេះបានស្នើឱ្យប្តីប្រពន្ធស្រឡាញ់គ្នា និងរួមរស់

[2314] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤៩-៣៥៥៧ និង ៣៦៣៥ (កំណត់សម្គាល់ជើងទំព័រលេខ១២១៥៦ និង ១២១៦០) ដែលអង្គជំនុំជម្រះផ្អែកលើសក្ខីកម្មរបស់ ស៊ូ សុធារី, ជា ឌៀប និង ប៉ែន សុចាន់។

[2315] ប៉ែន សុចាន់, ព្រាប សុឃឿន, សយ ណារឿយ, គុល ណែម, មុំ វុន, ង៉ែត ចាត, ស៊ូ សុធារី និង ជា ឌៀប ជាដើមបណ្តឹងរដ្ឋប្បវេណី ៨ នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីសរុប ៩ នាក់ ដែលបានចូលមកបង្ហាញខ្លួនសម្រាប់ផ្នែកស្តីពីការរៀបអាពាហ៍ពិពាហ៍។

[2316] ត្រង់នេះ មេធាវីការពារក្តីយោងទៅទឡ្ហីករណ៍ដែលមានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ ទាក់ទងនឹងភាពអាចជឿទុកបាននៃដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះទៅលើសុន្ទរកថាអំពី "ការបង្កើតកូនឱ្យអង្គការ"។ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២១-២៣២២, ២៤៥០-២៤៥១។

ជាមួយគ្នាដោយសុភមង្គលក្នុងជីវិតជាគូស្រករ ដែលត្រូវបានបញ្ជាក់អះអាងដោយសាក្សីជាច្រើន[2317]។ ក្នុងដំណើរការលម្អៀង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លេចចោលនូវភ័ស្តុតាងបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដើម្បីបង្កើតកូន មិនស៊ីគ្នានឹងខ្លឹមសារនៃសម្តីរបស់កម្មាភិបាលទាំងនោះទេ[2318]។ ម្យ៉ាងវិញទៀត គួរកត់សម្គាល់ថា ព្រាប សុខឿន មិនបានទទួលសេចក្តីណែនាំ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយរបស់ ប.ក.ក នោះទេ គឺផ្ទុយពីការសន្និដ្ឋានរបស់ ប.ក.ក[2319]។

---

[2317] ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ម៉ោង 15.32.08 "ថ្ងៃរៀបការហ្នឹង ខ្ញុំឮខាងមេបក្សគាត់បានលើកឡើងថា អង្គការយើងត្រូវការបង្កើនកម្លាំង។ អ៊ីចឹង អង្គការយើងនឹងអនុញ្ញាតឱ្យគូស្រករដើម្បីបង្កើតកូនឱ្យបានពង្រីកកម្លាំអប្រជាពលរដ្ឋ។ អ៊ីចឹងត្រូវធ្វើម៉េច យើងត្រូវរៀបការ យើងត្រូវរួមរស់នៅជាមួយគ្នា ចេះស្រឡាញ់គ្នា កសាង និងបង្កើតកូនឱ្យបក្ស") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោមផ្នែកដែលអង្គជំនុំជម្រះប្រើប្រាស់)។ ស៊្វ សុធារី៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** ម៉ោង 15.05.01 ម៉ោង 15.17.12 ក្រោយម៉ោង 15.11.26។ ពិធីតម្រូវឱ្យគូស្រករឡើងប្តេជ្ញាថាស្រឡាញ់ជាប្តីប្រពន្ធ។ សូមមើលផងដែរ ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** មុនម៉ោង 14.02.33 ម៉ោង 15.32.00 ("រៀបការរួច ឱ្យចេះស្រឡាញ់គ្នា ហើយកសាងសុភមង្គលឱ្យបានល្អអ៊ីចឹងទៅ ហើយទៅកុំឱ្យដូចថាមានកូនមានចៅអ៊ីចឹងទៅ ជួយអង្គការអ៊ីចឹងឱ្យបានច្រើនអ៊ីចឹងទៅ")។ មុំ វុន៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/475.1** មុនម៉ោង 13.40.35 ("កម្មាភិបាលដែលគេរៀបការឱ្យទាំង ៦០ គូហ្នឹង គេមានភារកិច្ចគេឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្តីប្រពន្ធហើយនេះ ត្រូវចេះស្រឡាញ់គ្នា មើលថែរក្សាគ្នា ហើយខំបង្កបង្កើនផលឱ្យបានច្រើន ដើម្បីយកសេដ្ឋកិច្ចនេះ ដើម្បីកម្ទេចខ្មាំងកុំឱ្យមានសល់")។ ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/482.1** ម៉ោង 14.02.07 (ការប្តេជ្ញារបស់អនាគតប្តីប្រពន្ធមើលថែគ្នាអស់មួយជីវិត)។ សយ ណារឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** មុនម៉ោង 10.51.06 ("ឱ្យស្រឡាញ់គ្នាចាប់ពីពេលនេះតទៅ បង្កបង្កើនផលឱ្យបានច្រើនពីមួយហិកតាប៉ុន្មានតោនទៅប៉ុន្មានតោនតាមកំណត់របស់អង្គការ ឱ្យបង្កបង្កើតជាមនុស្សឱ្យបានច្រើន")។

[2318] ព្រាប សុឃឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** មុនម៉ោង 09.37.05 ("នៅក្នុងទុំងការហើយទៅមានអ្នកត្រូវគ្នាហ្នឹងភាគច្រើន។ ចាស គេយល់ថា គេបានទទួលការទុកដាក់គ្រួសារពីអង្គការ គេគោរពអង្គការវិន័យ គេត្រូវរ៉ូវគ្នាច្រើន។ គេរស់នៅនឹងគ្នា ជុំគ្នាសុខដុមរនាទៅចាស" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ពេជ្រ ជីម៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** ប្រហែលម៉ោង 09.30.35 ("ទស្សនៈមហាជនថា "បានអង្គការការឱ្យគ្រាន់បើហើយ រុងរឿងហើយ"")។ ណុប ធីម៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 15.50.17។ សូមមើលផងដែរ កំណត់សម្គាល់ជើងទំព័រលេខ១២២២៦ (នៃកថាខណ្ឌ ៣៦៥៧) ដែលអង្គជំនុំជម្រះបានដកស្រង់សក្ខីកម្មរបស់ ណុប ធីម ដែលក្នុងនោះ គាត់បានលើកឡើងសម្តីរបស់តាទិត្យទូន្មានគូស្រករឱ្យរសនៅជាមួយគ្នាមានសុភមង្គល។

[2319] ដូចយោងខាងលើ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ម៉ោង 16.00.10 ("ខ្ញុំមិនអាចដឹងបាន [...] ខ្ញុំអត់ដឹងគោលការណ៍របស់បក្សគេយ៉ាងណាផង")។

១២៣០. ក្រៅពីការប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងលក្ខណៈមិនគ្រប់ជ្រុងជ្រោយ និងដើម្បីតែដាក់បន្ទុក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានធ្វើការវិភាគជារួមលើភស្តុតាង។ ប៉ុន្តែដូចភស្តុតាងអំពីការព្រមព្រៀងដែរ ការវិភាគសក្ខីកម្មទាំងអស់មិនអាចឱ្យបញ្ជាក់បានទេថា សុន្ទរកថាអំពីភាពចាំបាច់ក្នុងការបង្កើតកូន ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ មានលក្ខណៈទូទៅ។ ភាពខុសគ្នា រវាងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មផ្សេងទៀត នៅក្នុងសំណុំរឿង ០០២/០២ ជាតឹកតាងបង្ហាញអំពីការខុសឆ្គងនៃដំណើរការរបស់អង្គជំនុំជម្រះ ដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន[2320]។ ដូចគ្នាផងដែរ សាក្សី ដែលបានស្តាប់ចម្លើយ ក្នុងសំណុំរឿង ០០២/០១[2321] និងកំណត់ហេតុស្តាប់ចម្លើយ ដូចបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ[2322] ផ្តល់នូវការយល់ឃើញជាទូទៅខុសគ្នាលើ

---

[2320] សូមមើលឧបសម្ព័ន្ធ ខ១, ខ៥ និង ខ៦។ ផ្នែកស្តីពីអាពាហ៍ពិពាហ៍៖ មានការលើកឡើងពីការបង្កើតកូន ៨ នាក់ ស្មើនឹង ៥៧%, គ្មានការលើកឡើង ៦ នាក់ស្មើនឹង ៤៨%។ ប្រតិចារឹកក្នុងសំណុំរឿង ០០២/០២៖ មានការលើកឡើងពីការបង្កើតកូន ៤ នាក់ ស្មើនឹង ៥%, គ្មានការលើកឡើង ៧៦ នាក់ ស្មើនឹង ៩៥% (សូមបញ្ជាក់ថា ពុំមានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំង ៤ នាក់នេះ ដូចជា មាស វឿន, សៅ សារុន, ជួន ធី និង ម៉ាក ឈឿន ដែលបានលើកឡើងពីគោលបំណងនៃការបង្កើនចំនួនប្រជាជន បានផ្តល់សក្ខីកម្មពីការរៀបការដោយបង្ខំ ប៉ុន្តែ ពីការរៀបការដោយព្រមព្រៀងគ្នា)។

[2321] ជួន ធី បាននិយាយពីគោលបំណងនៃការបង្កើនចំនួនប្រជាជន ដែល ប៉ុល ពត បានលើកឡើង ប៉ុន្តែគាត់បានបញ្ជាក់ថា មិនមែនជាការរៀបការដោយបង្ខំទេ, ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/183.1** ចាប់ពីម៉ោង 09.57.15។ ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ចាប់ពីម៉ោង 09.33.27។ ចំណែកឯ សៅ សារុន វិញ ទោះបីជាគាត់បាននិយាយពីរឿងបង្កើតកូនក្រោយពេលរៀបការក៏ដោយ ប៉ុន្តែ គាត់លើកឡើងថា វាជាធម្មជាតិក្រោយពេលរៀបការ និងជាពិសេស ដោយពុំមានការបង្ខំប្រជាជនឱ្យរៀបការ, ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** មុនម៉ោង 14.10.00។ ជាការសំខាន់ត្រូវកត់សម្គាល់ថា ពុំមានសាក្សីណាម្នាក់ក្នុងចំណោមពួកគេទាំងនេះបានផ្តល់សក្ខីកម្មអំពីការណែនាំឱ្យបង្កើតកូននៅក្នុងពិធីរៀបការ។ ស្ថិតិប្រតិចារឹកសំណុំរឿង ០០២/០១៖ មានការលើកឡើងពីការបង្កើតកូន ១ នាក់ស្មើនឹង ៦% គ្មានការលើកឡើង ១៥ នាក់ស្មើនឹង ៩៤% ។ សូមមើល ឧបសម្ព័ន្ធ ខ២ និង ខ៧។

[2322] សាក្សីតែម្នាក់គត់បានលើកឡើងពីគោលបំណងនៃការបង្កើតកូនតាមរយៈការរៀបការ គឺ ស្វាយ បូរ៉ាមី, កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ **E3/5306** ERN 00347073-00347074 (នៅឆ្នាំ១៩៧៦ អង្គការត្រូវការមនុស្ស។ ដូច្នេះ ក្មេងៗត្រូវរៀបការ) ខណៈដែលសាក្សីពីរនាក់ទៀតបានផ្តល់សក្ខីកម្មផ្សេង កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ឯកសារ **E3/9355** ERN 00373394-00373395 (នៅឆ្នាំ១៩៧៥ ប្រជាជនអាយុរាងច្រើន ត្រូវរៀបការទាំងអស់) និងកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ **E3/9350** ERN 00239952 (ក្រោយពេលរៀបការ គេមិនហាមឃាត់យើងបង្កើតកូនទេ)។

រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់សក្ខីកម្មក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍[2323]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចផ្អែកលើសក្ខីកម្មទាំងនេះដើម្បីសន្និដ្ឋានថា គោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដើម្បីបង្កើនចំនួនប្រជាជនត្រូវបានអនុវត្តនៅទូទាំងប្រទេស នោះឡើយ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ។

១២៣១. ជាចុងក្រោយ ចំពោះកំណត់ហេតុទាំងអស់ដែលបានដាក់បញ្ចូលក្នុងសំណុំរឿង ០០៣-០០៤ តាមសំណើរបស់សហព្រះរាជអាជ្ញា ទោះបីជាសាក្សីខ្លះបានលើកឡើងអំពីសម្តីរបស់អាជ្ញាធរដែលបានរៀបចំអាពាហ៍ពិពាហ៍ ក្នុងគោលបំណងបង្កើនចំនួនប្រជាជនក៏ដោយ ក៏សាក្សីខ្លះទៀតជាច្រើនមិនធ្លាប់ឮអំពីការព្រួយបារម្ភ ឬសេចក្តីណែនាំបែបនេះឡើយ[2324]។ គួរកត់សម្គាល់ថា សូម្បីតែការដាក់បញ្ចូលកំណត់ហេតុជាច្រើន ដើម្បីគាំទ្រដល់ទស្សនៈរបស់សហព្រះរាជអាជ្ញាឱ្យបានរឹងមាំ ដែលអង្គជំនុំជម្រះចម្លងតាម មិនត្រូវគ្នានឹងសមាមាត្រនៃសក្ខីកម្មក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍នោះឡើយ[2325]។

១២៣២. យោងតាមភ័ស្តុតាងទាំងមូល ចៅក្រមប្រកបដោយវិចារណញ្ញាណមិនគួរណាសន្និដ្ឋានថា ភ័ស្តុតាងបង្ហាញ ប.ក.ក បានតាក់តែងគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីបង្កើនចំនួនប្រជា

---

[2323] សូមមើលឧបសម្ព័ន្ធ ខ២ និង ខ៨។ ស្ថិតិនៃចម្លើយដែលមាននៅក្នុងដីកាដំណោះស្រាយ៖ មានការលើកឡើងពីការបង្កើតកូន ១ នាក់ ស្មើនឹងប្រហែល ១%, គ្មានការលើកឡើង ១១៥ នាក់ ស្មើនឹង ៩៩%។

[2324] កំណត់ហេតុស្តាប់ចម្លើយ នៅ ចាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9562**, ស./ឆ.១៨៩ ("ស.៖ ក្រោយការរៀបការដោយបង្ខំ តើគេមានតម្រូវឱ្យមានកូនដែរឬទេ? ឆ.១៨៩៖ ទេ មិនមានដូច្នោះទេ។ គេគ្រាន់តែរៀបការដើម្បីឱ្យមានគូស្រករ ដើម្បីបម្រើអង្គការឱ្យបានប្រសើរឡើង" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ **E3/9662** ស./ឆ.៧៧ ("អង្គការមិនបានផ្តោតអារម្មណ៍ទៅលើក្មេងៗទេ គេឱ្យយើងមានកូនចៅទៅតាមធម្មជាតិ")។ កំណត់ហេតុស្តាប់ចម្លើយ ខៀន ចឹម ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E3/9828** ស./ឆ.៦ ("គេមិនបានប្រាប់ឱ្យយើងមានកូនទេ ហើយក៏មិនបានប្រកាសក្នុងពិធីរៀបការឱ្យយើងត្រូវមានកូន")។ កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ **E3/10768** ស./ឆ.២៤០ (ពុំមានគោលនយោបាយ "មាន" កូនទេ)។ កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម ឈាន ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E3/9765** ស./ឆ.៩៩-១០២។

[2325] សូមមើលឧបសម្ព័ន្ធ ខ២ និង ខ៩។ ស្ថិតិចម្លើយក្នុងសំណុំរឿង ០០៣/០០៤៖ មានការលើកឡើងពីការបង្កើតកូន៖ ៤ នាក់ស្មើនឹង ៥%, គ្មានការលើកឡើង៖ ៨២ នាក់ស្មើនឹង ៩៥%។

ជន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលមិនស៊ីចង្វាក់គ្នានឹងវិធានការដាក់លាក់ សំដៅជួយសម្រួលដល់ការមានគភ៌ ឬការបង្កកំណើត[2326]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះខកខានមិនបានលើកឡើងថា ដើម បណ្តឹងរដ្ឋប្បវេណីទាំងអស់ ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ បានបញ្ជាក់យ៉ាងច្បាស់អំពីកង្វះការថែទាំ និងថ្នាំពេទ្យ ទាក់ទិននឹងការបង្កកំណើតកូន ក្នុងក្របខ័ណ្ឌនៃការឈឺចាប់ដែលបានទទួលរង[2327]។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងនេះនឹងត្រូវទុកជាមោឃៈ។

១២៣៣. <u>**ការផ្តល់ភាពអាចជឿជាក់បានដោយមិនត្រឹមត្រូវដល់សក្ខីកម្មខុសប្លែកគេរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប**</u>៖ ភាពលម្អៀងរបស់អង្គជំនុំជម្រះស្តែងឱ្យឃើញយ៉ាងច្បាស់ក្រឡែត ក្នុងរបៀបនៃការវាយតម្លៃ និងប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ដែលត្រូវបានវិនិច្ឆ័យថា "អាចជឿជាក់បាន និងមានភាពស្របគ្នា"[2328]។ តាមពិត អង្គជំនុំជម្រះបានព្រងើយកន្តើយនឹងវិធានទាំងអស់ស្តីពីការវាយតម្លៃភ័ស្តុតាង ពីព្រោះ ជា ឡៀប ជាមនុស្សតែម្នាក់គត់ ដែលឆ្លើយដាក់ម្ចាស់បណ្តឹងសាទុក្ខដោយផ្ទាល់ ចំពោះអង្គហេតុពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍[2329]។ ជាក់ស្តែង អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់គាត់ ដើម្បីភ្ជាប់ទំនងទំនង រវាងគោលបំណងរបស់ ប.ក.ក ក្នុងការបង្កើនចំនួនប្រជាជន សំដៅបង្កើនចំនួនកងទ័ព ដើម្បីធ្វើសង្គ្រាមជាមួយវៀតណាម និងការចូលរួមផ្ទាល់ខ្លួនរបស់

---

[2326] <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** ប្រហែលម៉ោង 09.21.47 ប្រហែលម៉ោង 09.59.13 ។ <u>មុំ វុន</u>៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/475.1** មុនម៉ោង 15.12.23។ <u>ព្រាប សុឃឿន</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ម៉ោង 15.20.22។

[2327] <u>កុល ណែម</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ក្រោយម៉ោង 14.35.00 (សេចក្តីថ្លែងទុក្ខសោករបស់គាត់នៅចុងបញ្ចប់នៃការចូលបង្ហាញខ្លួន ពាក់ព័ន្ធនឹងការដែលគាត់មិនអាចមានកូន ដែលនេះក៏កើតឡើងចំពោះប្តីប្រពន្ធផ្សេងទៀតដែរ) ។ <u>សយ ណារឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** ម៉ោង 10.55.14 សេចក្តីថ្លែងទុក្ខសោករបស់គាត់នៅចុងបញ្ចប់នៃការចូលបង្ហាញខ្លួន គឺការបាត់បង់កូន ដោយសារតែគ្មានថ្នាំ និងការព្យាបាល។ <u>ង៉ែត ចាត</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ប្រហែលម៉ោង 09.28.52។

[2328] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦៩។

[2329] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៥៧ កំណត់សម្គាល់ជើងទំព័រលេខ១១៤៩៣ ដែលអង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ ជា ឡៀប ដើម្បីសន្និដ្ឋានថា ខៀវ សំផន ប្រហែលជាបានផ្តល់ការណែនាំអំពីការរៀបការ ដើម្បីបង្កើតកូន និងបង្កើនកងកម្លាំងការពារទឹកដី ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1**។

ខៀវ សំផន[2330]។ ប៉ុន្តែ ល័ក្ខខ័ណ្ឌ និងកាលៈទេសៈនៃសក្ខីកម្មរបស់ ជា ឌៀប គួរណាតែនាំឱ្យចៅក្រមប្រកបដោយវិចារណញ្ញាណបដិសេធចោល។

១២៣៤. ***ការនឹកឃើញយឺតពេលចំកាលៈទេសៈ៖*** ម្យ៉ាង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានគិតដល់លក្ខណៈយឺតពេលនៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ។ ជាក់ស្តែង ជា ឌៀប បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ និងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣ ដោយមិនបញ្ចេញឈ្មោះ ខៀវ សំផន ទាល់តែសោះ ខណៈដែលគាត់ទទួលបានដំណឹងអំពីការចោទប្រកាន់ប្រឆាំងនឹងរូបគាត់[2331]។ ទាល់តែនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ទើបគាត់បាននិយាយជាលើកទីមួយអំពីឈ្មោះម្ចាស់បណ្តឹងសាទុក្ខ ត្រូវនឹងជាងមួយខែ មុនពេលចាប់ផ្តើមការជំនុំជម្រះក្តីសំណុំរឿង ០០២ និងខណៈដែលគាត់ទទួលបានជំនួយពីមេធាវីអស់រយៈពេលជាងបួនឆ្នាំមកហើយ[2332]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានត្រឹមតែបញ្ជាក់ថា មេធាវីការពារក្តីមានឱកាសសួរដេញដោលលើប្រធានបទនេះ ដោយមិនកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចពន្យល់អំពីការប្រែក្រឡាស់នេះបានឡើយ[2333]។ ប៉ុន្តែ កាលៈទេសៈនៃសក្ខីកម្មដាក់បន្ទុកខុសប្លែកគេរបស់ ជា ឌៀប អំពីវគ្គរៀនសូត្រដែលគាត់សន្មតថា ខៀវ សំផន ជាអ្នកឧទ្ទេសនាម នៅវត្តឧណ្ណាលោម ហើយគាត់ជាសិក្ខាកាម គួរណាតែនាំឱ្យអង្គជំនុំជម្រះបដិសេធចោល ដោយសារតែគ្មានការ

---

[2330] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦៩, ៤២៤៧។

[2331] ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/5010**។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E3/5010b**។

[2332] មួយខែមុនសវនាការបឋមក្នុងសំណុំរឿង ០០២/០២ សវនាការបឋម៖ ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E1/240.1**។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E3/5010**។ ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E3/5010a** ERN 01003331-01003332 ដែលគាត់បានលើកលើងពី ខៀវ សំផន ជាលើកដំបូង។

[2333] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦៩។ គាត់ក៏មិនអាចពន្យល់ពីការផ្លាស់ប្តូរនេះបានទេ, ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ប្រហែលម៉ោង 11.20.50 និង 11.28.20។

បញ្ជាក់អះអាងច្បាស់លាស់លើចំណុចនេះ។ ទោះជាយ៉ាងនេះក្តី វគ្គរៀនសូត្រនេះមិនមានការបញ្ជាក់អះអាងពីកម្មាភិបាលណាម្នាក់មកពីក្រសួងពាណិជ្ជកម្មឡើយ[2334]។

១២៣៥. នៅពេលយល់ឃើញថា សក្ខីកម្មរបស់ ជា ឌៀប មានភាពអាចជឿជាក់បាន អង្គជំនុំជម្រះបានរំលោភលើកាតព្វកិច្ចរបស់ខ្លួន ក្នុងការវាយតម្លៃលើសក្ខីកម្មដោយប្រយ័ត្នប្រយែង ដោយផ្អែកលើភ័ស្តុតាងទាំងមូលក្នុងសំណុំរឿង។ ជាពិសេស អង្គជំនុំជម្រះបានអនុវត្តស្តង់ដារពីរមិនអាចទទួលយកបាន ក្នុងការវាយតម្លៃភ័ស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក។ ដូចបានឃើញខាងលើ អង្គជំនុំជម្រះបានបដិសេធជាប្រព័ន្ធនូវសក្ខីកម្មដោះបន្ទុករបស់អតីតកម្មាភិបាល ដែលបានផ្តល់ចម្លើយស៊ីចង្វាក់គ្នា ដោយលើកហេតុផលថាពួកគេមានទំនោរចង់បន្ថយការទទួលខុសត្រូវក្នុងការរៀបអាពាហ៍ពិពាហ៍[2335]។ ដោយមិនបានអនុវត្តភាពម៉ឺងម៉ាត់ដូចគ្នានេះចំពោះ ជា ឌៀប អង្គជំនុំជម្រះបានបំភ្លេចចោលបំណងប្រាថ្នារបស់គាត់ចង់ឱ្យផ្តន្ទាទោស ខៀវ សំផន ក្នុងឋានៈគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការជំនុំជម្រះក្តីដែលមិនតម្រូវឱ្យគាត់ធ្វើសម្បថ។ ការដែល ជា ឌៀប ស្រាប់តែ "នឹកឃើញ" សុន្ទរកថា ខៀវ សំផន និងសេចក្តីថ្លែងការណ៍របស់គាត់ ចំពេលល្អ ដើម្បីបំពេញចន្លោះប្រហោងនៃភ័ស្តុតាងអំពីការចូលរួមផ្ទាល់របស់ម្ចាស់បណ្តឹងសាទុក្ខ គឺជាហេតុផលនាំឱ្យបដិសេធសក្ខីកម្មរបស់គាត់[2336]។ ម្យ៉ាងទៀត ការពិនិត្យលើសក្ខីកម្មរបស់គាត់បង្ហាញឱ្យឃើញភាពផ្ទុយគ្នាខាងក្នុង និងខាងក្រៅ ដែលជាហេតុផលមិនគួរណាឱ្យអង្គជំនុំជម្រះប្រើប្រាស់។

---

[2334] ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** មុនម៉ោង 09.07.25 ("ចូលរួមក្នុងវគ្គឧណ្ណាលោមហ្នឹង មានយុទ្ធជននារីខាងពាណិជ្ជកម្មទាំងអស់ ក្នុងទីក្រុងភ្នំពេញអ៊ីចឹង ប៉ុន្តែមិនមែនយកទាំងអស់ទេ ក្នុងមួយកងៗ យកពីរបីនាក់ បួនប្រាំនាក់អីទេ ទៅមកចូលប្រជុំនៅវត្តឧណ្ណាលោមហ្នឹង")។ ការរៀបរាប់នេះមិនត្រូវបានបញ្ជាក់ដោយកម្មាភិបាលពាណិជ្ជកម្មផ្សេងទៀតទេ៖ ផាន់ ហ៊ឹម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.07.14 ("រឿងអស់ទាំងនេះ ខ្ញុំអត់ដែលដឹងផង")។ ប៊ិត ហឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ក្រោយម៉ោង 13.41.42 (គាត់បញ្ជាក់ថាបានចូលរួមវគ្គរៀនសូត្រ ២ លើក នៅបុរីកីឡាជាមួយ ប៉ុល ពត, ខៀវ សំផន និងអ្នកផ្សេងទៀត និងការប្រជុំ ៤ លើកក្នុងក្របខ័ណ្ឌពាណិជ្ជកម្មជាមួយ ខៀវ សំផន និងអ្នកផ្សេងទៀត ប៉ុន្តែពុំមានការបញ្ជាក់អ្វីលើវគ្គរៀនសូត្រណាមួយនៅវត្តឧណ្ណាលោមឡើយ)។ កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ឆ.២៦-៤០។

[2335] សូមមើលខាងលើ កថាខណ្ឌ ១១៩៣-១១៩៥។

[2336] សូមមើល សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៤៨០ អំពីការវាយតម្លៃភាពអាចជឿជាក់ និងភាពអាចទុកបាននៃសក្ខីកម្មរបស់សាក្សី សំ សិទ្ធី។

១២៣៦. ***ភាពផ្ទុយគ្នាខាងក្នុង និងខាងក្រៅ៖*** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានទាញផលវិបាកពីចម្លើយស្រពេចស្រពិល ដែលមេធាវីការពារក្តីទទួលបាន ពាក់ព័ន្ធនឹងការកំណត់ដោយ ជា ឡៀប ថា ខៀវ សំផន ជាអ្នកឧទ្ទេសនាម នៅក្នុងវគ្គរៀនសូត្រនេះ[2337]។ យោងលើការផុតកាលកំណត់ ពេលវេលានៃការនឹកឃើញ និងការពន្យល់ផ្ទុយគ្នា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទទួលយកការកំណត់អត្តសញ្ញាណម្ចាស់បណ្តឹងសាទុក្ខដោយដើមបណ្តឹងរដ្ឋប្បវេណី។

១២៣៧. ***ភាពផ្ទុយគ្នាជាមួយភ័ស្តុតាងផ្សេងទៀត៖*** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើសក្ខីកម្មខុសប្លែកគេនេះ ដើម្បីបង្ហាញ នៅកថាខណ្ឌ ៤២៤៧ នៃសំអាងហេតុសាលក្រម ថា ខៀវ សំផន បានឧទ្ទេសនាម ក្នុងវគ្គរៀនសូត្រមួយ ហើយក្នុងពេលនោះ គាត់បាននិយាយអំពីការរៀបអាពាហ៍ពិពាហ៍។ សក្ខីកម្មរបស់ ជា ឡៀប មិនត្រឹមតែមិនស្របគ្នានឹងភ័ស្តុតាងផ្សេងទៀតនោះទេ ថែមទាំងមានភាពមិនស៊ីចង្វាក់គ្នានឹងភ័ស្តុតាងសេសសល់ផ្សេងទៀត ដែលត្រូវបានអង្គជំនុំជម្រះបំភ្លេចចោលសូន្យឈឹងតែម្តង។ ជាក់ស្តែង ជា ឡៀប បាននិយាយថាបានជួប ខៀវ សំផន ពីរដង ម្តង នៅវត្តឧណ្ណាលោម និងម្តងទៀត នៅបុរីកីឡា ឬនៅស្តាតអូឡាំពិច នៅថ្ងៃកាត់ទោស ហ៊ូ នឹម និង ហ៊ូ យន់ នៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦[2338]។ ចំពោះការជួបលើកទីពីរនេះ អង្គជំនុំជម្រះគួរណាតែសង្កេតឃើញអំពីភាពមិនសមទំនងនៃរឿងរ៉ាវរបស់គាត់។ ជាក់ស្តែង ភ័ស្តុតាងបង្ហាញថា ហ៊ូ យន់ បានបាត់ខ្លួន តាំងពីថ្ងៃទី១៧

---

[2337] ការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តីទាំងពីរប្រព្រឹត្តនៅថ្ងៃទីពីរនៃការចូលមកបង្ហាញខ្លួនរបស់គាត់ និងនៅក្នុងសវនការរយៈពេលកន្លះថ្ងៃ ដែលមិនមានអ្វីគួរឱ្យពិសេសទេ ផ្ទុយនឹងអ្វីដែលអង្គជំនុំជម្រះចង់ឱ្យដឹងនៅក្នុងសំអាងហេតុរបស់ខ្លួននោះ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ចន្លោះពីម៉ោង 09.17.58 ដល់ម៉ោង 11.48.57។ ជាក់ស្តែង ក្នុងចម្លើយលើកដំបូងរបស់គាត់ គាត់បាននិយាយថា "ខ្ញុំមិនដែល<u>ជួប</u>គាត់ទេ ប៉ុន្តែ ខ្ញុំទៅហ្នឹង ខ្ញុំក៏ស្គាល់ គ្រាន់តែថាខ្ញុំឃើញគាត់ ខ្ញុំស្គាល់គាត់តែម្តង។ រួចទោះគេអ្នកផ្សេងទៀត ក៏គេប្រាប់ខ្ញុំដែរថា ហ្នឹងលោក ខៀវ សំផន ហើយ។ គេប្រាប់ខ្ញុំអ៊ីចឹង រួចខ្ញុំក៏ស្គាល់ដែរ ប៉ុន្តែខ្ញុំមិនដែលបានជួបកន្លែងណាផង" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ប៉ុន្តែ បន្តិចក្រោយមក គាត់និយាយផ្ទុយថា៖ "ខ្ញុំយល់ដែរ ខ្ញុំនឹកឃើញថា ខ្ញុំក៏រាងធ្លាប់<u>ប្រហែល</u> ប៉ុន្តែមិនដឹងប្រហែលកន្លែងណា ខ្ញុំមិនហ៊ានថា ព្រោះខ្ញុំមិនប្រាកដ។ ដល់ខ្ញុំប្រហែលទៅ ដល់ខ្ញុំមកឃើញពិតប្រាកដ គឺខ្ញុំដឹងថា មុខតែអ៊ំ ខៀវ សំផន ហើយ។ រួចដល់គេ<u>ប្រកាស</u>មក ក៏អ៊ីចឹងមែន។ គេប្រកាស ក៏គេប្រកាសថា អ៊ំ ខៀវ សំផន ហ្នឹងដែរ"។ ម្យ៉ាងវិញទៀត ដោយបញ្ជាក់ជាលើកដំបូងថាមិនស្គាល់មុខតំណែងរបស់ ខៀវ សំផន គាត់បានបន្ថែមថា៖ "គាត់ប្រកាសថា លោកអ៊ំ ខៀវ សំផន ជា<u>ទីប្រឹក្សា</u>")។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2338] <u>ជា ឡៀប</u>៖: ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ចន្លោះពីម៉ោង 09.07.25 ដល់ម៉ោង 09.16.03។

ខែមេសា ឆ្នាំ១៩៧៥ ហើយ ហ៊ូ នឹម ត្រូវបានចាប់ខ្លួន នៅដើមឆ្នាំ១៩៧៧[2339]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានទាញផលវិបាកពីការភាន់ច្រឡំច្បាស់ក្រឡែតរបស់ ជា ឌៀប លើអត្តសញ្ញាណមេដឹកនាំ និងកាលបរិច្ឆេទនៃហេតុការណ៍ ដែលគាត់អះអាងថាបានចូលរួម។ សក្ខីកម្មរបស់គាត់មិនអាចជឿជាក់បានទេ។

១២៣៨. ***ភាពផ្ទុយគ្នាអំពីអាយុរៀបអាពាហ៍ពិពាហ៍៖*** ជា ឌៀប បានអះអាងផងដែរថា៖ "[ខៀវ សំផន] បាននិយាយថា [...] តាមមុខក្រសួងទាំងអស់ឱ្យរៀបចំឱ្យមានគ្រួសារ។ គាត់ថាអ៊ីចឹង កុំទុកឱ្យនៅច្រើនពេក" ជាពិសេស អ្នក "ដែលមានអាយុពី ១៩ ឆ្នាំ ឡើងទៅ"[2340]។ ប៉ុន្តែ ការចោទប្រកាន់នេះផ្ទុយពីស្មារតី និងសេចក្តីណែនាំ ក្នុងឯកសារបោះពុម្ពផ្សាយផ្លូវការរបស់ ប.ក.ក ចុះកាលបរិច្ឆេទក្នុងពេលតែមួយ ដែលជំរុញឱ្យយុវជនកុំឆាប់រៀបការពេក ដោយមានការបញ្ជាក់អះអាងពីសាក្សីជាច្រើន[2341]។

---

[2339] ហ៊ូ នឹម៖ គួរកត់សម្គាល់ថា ដើម្បីផ្តល់ភាពអាចជឿជាក់បានដល់សក្ខីកម្មរបស់ ជា ឌៀប ទាំងមិនត្រឹមត្រូវ អង្គជំនុំជម្រះបានបំភ្លៃសក្ខីកម្មរបស់គាត់ ដើម្បីឱ្យមានភាពស៊ីចង្វាក់ជាមួយការចាប់ខ្លួន ហ៊ូ នឹម ដែលបញ្ជាក់ពីការពាក់ព័ន្ធរបស់ ខៀវ សំផន។ នៅត្រង់កថាខណ្ឌ ៤២២៧ នៃសំអាងហេតុសាលក្រម "បន្ទាប់ពីការចាប់ខ្លួន ហ៊ូ នឹម នៅខែមេសា ឆ្នាំ១៩៧៧ ខៀវ សំផន បានអំពាវនាវជាសាធារណៈឱ្យសួរចម្លើយនីរសាររបស់គាត់។ [...] អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីការចាប់ខ្លួន និងការស្លាប់របស់ ហ៊ូ នឹម នៅពេលនោះ" ដោយផ្អែកតែទៅលើការរៀបរាប់ដាច់ដោយឡែករបស់ ជា ឌៀប ប៉ុណ្ណោះ ខណៈដែល ជា ឌៀប បានលើកឡើងតែពីការប្រជុំជាមួយ ខៀវ សំផន ទាក់ទងនឹង ហ៊ូ នឹម នៅឆ្នាំ១៩៧៥, ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 15.02.15។ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ក្រោយម៉ោង 09.03.20 (ពេលចៅក្រម Lavergne ស្នើសុំការបញ្ជាក់អំពីកាលបរិច្ឆេទ គាត់បានឆ្លើយថា "ដឹងតែឆ្នាំ... ហើយខ្ញុំតាមខ្ញុំដែលចាំចងចាំបាន ប្រហែលជាចុង៧៥ ដើម៧៦ ពីរដងហ្នឹង")។ ដើម្បីធ្វើដូច្នេះ អង្គជំនុំជម្រះមិនអើពើនឹងការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តីទៅលើដើមបណ្តឹងរដ្ឋប្បវេណីអំពីភាពមិនស៊ីចង្វាក់គ្នាទាក់ទងនឹងកាលបរិច្ឆេទចាប់ខ្លួន ហ៊ូ នឹម, ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ចាប់ពីម៉ោង 11.43.29។ ហ៊ូ យន់៖ Philip SHORT៖ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** មុនម៉ោង 11.20.36។

[2340] ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ចន្លោះពីម៉ោង 13.47.02 ដល់ម៉ោង 13.51.50។

[2341] សូមមើលខាងលើ កថាខណ្ឌ ១២១២-១២១៣ (ការសន្និដ្ឋានមិនត្រឹមត្រូវអំពីការជ្រើសរើសគូស្រករ យុវជន និងយុវនារីបដិវត្តឆ្នាំ១៩៧៥)។ សូមមើលផងដែរ ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចាប់ពីម៉ោង 13.47.10 ("កុំអាល់ឱ្យមានប្តីប្រពន្ធនៅក្មេងៗទេ ចាំចាស់បន្តិច")។ ខឹម បឿន៖ ប្រតិចារឹក ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/296.1** ម៉ោង 09.54.47 (រៀបចំការរៀបការសម្រាប់អ្នកស្រឡាញ់គ្នា ឬអ្នកដែលមានអាយុច្រើន)។ សុន វុត៖ ប្រតិចារឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/411.1** ម៉ោង 14.41.30 ("កាលសម័យនោះគឺចាប់ផ្តើមពី៣០ឡើងបាទ នារីក៏ដូចគ្នាយ៉ាងអត់ណាស់ក៏ ២៨")។

១២៣៩. ***ភាពផ្ទុយគ្នាជាមួយសាក្សីមកពីក្រសួងពាណិជ្ជកម្ម៖*** ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានប្រៀបធៀបសក្ខីកម្មរបស់ ជា ឡៀប ជាមួយភ័ស្តុតាងផ្សេងទៀត។ ជាក់ស្តែង គាត់ជាមនុស្សតែម្នាក់គត់ ក្នុងចំណោមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ជាបុគ្គលិកនៅក្រសួងពាណិជ្ជកម្ម និងក្រសួងផ្សេងទៀតនៅទីក្រុងភ្នំពេញ ដែលបានចូលរួមវគ្គរៀនសូត្រ ដែលត្រូវបានសន្មតថា ខៀវ សំផន ជាអ្នកឧទ្ទេសនាម និងនិយាយអំពីគោលដៅបង្កើនចំនួនប្រជាជន តាមមធ្យោបាយរៀបការយុវជន-យុវនារី។ គាត់ក៏ជាមនុស្សតែម្នាក់គត់ ដែលបានអះអាងថា គាត់បានឮគេនិយាយអំពីបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ "នៅគ្រប់កិច្ចប្រជុំ" ដែលគាត់បានចូលរួម[2342]។ សក្ខីកម្មរបស់ ជា ឡៀប មានភាពខុសប្លែកគេ និងមិនស៊ីចង្វាក់ យោងតាមសក្ខីកម្មទាំងអស់អំពីការអនុវត្ត នៅក្រសួងជុំវិញទីក្រុងភ្នំពេញ[2343]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានទាញផលវិបាកពីភាពផ្ទុយគ្នាទាំងនេះ។ ការវិភាគមិនលម្អៀងទៅលើភ័ស្តុតាងគួរណាតែនាំឱ្យអង្គជំនុំជម្រះកត់សម្គាល់ថា ការងាក

[2342] ផាន់ ហ៊ីម ដែលធ្វើការនៅក្រសួងពាណិជ្ជកម្មដូចគ្នា មិនដែលឮការបញ្ជាបែបនេះទេ នៅក្នុងរបបខ្មែរក្រហម ហើយផ្ទុយទៅវិញ បានផ្តល់សក្ខីកម្មអំពីការរៀបការតាមការព្រមព្រៀង៖ <u>ផាន់ ហ៊ីម</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.03.22។ នៅក្នុងន័យដូចគ្នានេះ ប៊ិត ហឿន ជាកម្មាភិបាលម្នាក់ទៀតនៅក្រសួងពាណិជ្ជកម្ម បានផ្តល់សក្ខីកម្មដែលផ្ទុយនឹងការអះអាងរបស់ ជា ឡៀប៖ <u>ប៊ិត ហឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** មុនម៉ោង 11.29.45 (គាត់មិនដឹងពីការរៀបការដោយការរៀបចំ ទៅតាមឆន្ទៈរបស់អង្គការនៅក្នុងក្រសួងរបស់គាត់ ដោយគ្មានសំណើជាមុនរបស់បុគ្គល មិនទាន់មកដល់នៅក្នុងក្រសួងគាត់) ប្រហែលម៉ោង 11.23.41 (គាត់មិនបានទទួលការណែនាំឱ្យរួមដំណេក ពីព្រោះរៀបការរួចហើយ) ម៉ោង 11.18.21 (អាចបដិសេធមិនរៀបការ ប្រសិនបើគាត់មិនស្រឡាញ់ប្តីគាត់។ គាត់ និងនារីភាគច្រើនស្រឡាញ់ប្តីដែលគេស្នើឱ្យរៀបការជាមួយ)។

[2343] <u>ធុច ស៊ីផុន</u>៖ ប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/500.1** ក្រោយម៉ោង 14.51.08 (ក្រសួងសង្គមកិច្ច - "ស.៖ អ៊ីចឹងគេមិនដែលប្រាប់លោកស្រីថា អង្គការមានគោលបំណងបង្កើនចំនួនប្រជាជនឱ្យបានច្រើនក្នុងរយៈពេលឆាប់រហ័សទេឬ? ឆ.៖ ណុង! អត់មានដែលឮ ពេលហ្នឹងអត់មាននិយាយទេ ខ្ញុំអត់ដែលឮ")។ <u>សេង លីថេង</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/503.1** ម៉ោង 11.25.18 (រៀបការជាមួយស្ត្រីម្នាក់មកពីក្រសួងសង្គមកិច្ច "តើពេលនោះ គេមានណែនាំអំពីការដែលថា គូស្វាមីភរិយាហ្នឹង ត្រូវរស់នៅជាមួយគ្នា ហើយខំបង្កើតកូនដើម្បីបម្រើបដិវត្តន៍ដែរទេ? ឆ.៖ គេអត់មានណែនាំអ៊ីចឹងផង")។ <u>ឌុច</u>៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/436.1** មុនម៉ោង 09.49.22 មុនម៉ោង 09.52.11 (រៀបការដើម្បីចៀសវាងកំហុសសីលធម៌)។ សាក្សីផ្សេងទៀត ដូចជា ញ៉ែម អេន, ហ៊ីម ហ៊ុយ (ថ្នាក់ក្រោមរបស់ ឌុច នៅ ស-២១) និង ផាន់ វ៉ាន (អ្នកបើកបរនៅក្រសួងសង្គមកិច្ច) មិនដែលលើកឡើងពីគោលបំណងបង្កើនចំនួនប្រជាជនតាមរយៈការរៀបការទេ។

ចេញពីបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍បានកើតឡើងជាសំខាន់ នៅតំបន់ឆ្ងាយពីទីក្រុងភ្នំពេញ[2344]។

១២៤០. ***ភាពមិនស៊ីចង្វាក់គ្នានៃសក្ខីកម្មរបស់ រស់ ស៊ុយ៖*** ដើម្បីព្យាយាមបង្ហាញអំពីភាពស៊ីចង្វាក់គ្នាជាមួយ ជា ឌៀប អង្គជំនុំជម្រះបានផ្អែកលើកំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ជាកម្មាភិបាលក្រសួងពាណិជ្ជកម្ម ដែលបានលើកឡើងអំពីចំនួនអប្បបរមានៃការរៀបអាពាហ៍ពិពាហ៍[2345]។ ម្យ៉ាង ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះលើចម្លើយរបស់ ជា ឌៀប[2346] រស់ ស៊ុយ មិនបាននិយាយអំពីគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ផ្ទុយទៅវិញ គាត់បានគូសបញ្ជាក់អំពីគោលការណ៍ព្រមព្រៀងពីសាមីខ្លួន ដោយមានសិទ្ធិប្រកែក ឬយល់ព្រមចំពោះការស្នើរៀបការ[2347]។ ម្យ៉ាងទៀត កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដែលមេធាវីការពារក្តីមិនអាច សួរដេញដោលលើបញ្ហាជាក់លាក់នៃការរៀបអាពាហ៍ពិពាហ៍ មិនអាចយកមកប្រើប្រាស់ ដើម្បីបង្ហាញថា សេចក្តីណែនាំទាំងនេះត្រូវបាន "អនុវត្តជាក់ស្តែង" នៅក្រសួងពាណិជ្ជកម្ម បានទេ[2348]។ ក្រៅពីតម្លៃជាភស្តុតាងតិចតួច ចម្លើយរបស់ រស់ ស៊ុយ អំពីអត្ថិភាពនៃចំនួនអប្បបរមានេះ មិនស៊ីចង្វាក់គ្នានឹងភស្តុតាងក្នុងសំណុំរឿងឡើយ។ ថ្វីត្បិតតែគាត់បានបញ្ជាក់ថា ព័ត៌មាននេះចេញពី "ប្រធានក្រសួង" ឃ្លាំងរដ្ឋ ឈ្មោះ រឿង ក៏ដោយ ក៏គាត់បានទទួលស្គាល់ផងដែរថា៖ "ខ្ញុំអត់ដឹងថាបញ្ហានោះមកពីណានោះទេ"[2349]។ ជាពិសេស អង្គជំនុំជម្រះមិនបានធ្វើការវិភាគដោយមិនលម្អៀងឱ្យបានត្រឹមត្រូវទៅលើភស្តុតាង ដោយមិនបាន

---

[2344] សូមមើលខាងក្រោម កថាខណ្ឌ ១២៧១-១២៧២។

[2345] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧០ កំណត់សម្គាល់ជើងទំព័រលេខ១១៩៨០។

[2346] <u>ជា ឌៀប</u>៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** មុនម៉ោង 13.50.10 (ការលើកឡើងរបស់ ខៀវ សំផន) "គាត់មិនបាននិយាយថា <u>ស្រឡាញ់គ្នាស្រឡាញ់អីទេ</u> គាត់គ្រាន់តែប្រាប់ថាឱ្យរៀបចំគ្រួសារទៅ តាំងពីអាយុ ១៩ ឡើងទៅយុវជនអាយុ ២៥ <u>អីទុកធ្វើអីទៀត</u>" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) មុនម៉ោង 15.06.03 ("ខ្ញុំស្តាប់មិនច្រឡំទេ គឺគាត់និយាយអ៊ីចឹងមែន។ "ពី១៩ ដល់ ២៥, ៣០, ៣៥ អីរៀបអស់ទៅ ទុកតែក្មេងៗបានហើយ" គាត់ប្រាប់អ៊ីចឹងមែន")។

[2347] កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ឆ.៧៥ ("អាយុរៀបការគឺចាប់ពី ២០ ឆ្នាំឡើងទៅ") ៨២, ៨៣ (ស្ត្រីមានសិទ្ធិបដិសេធ ឬយល់ព្រមការរៀបការដែលបានស្នើឡើង)។

[2348] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៧ កំណត់សម្គាល់ជើងទំព័រលេខ១៣៨៦១។

[2349] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧០ កំណត់សម្គាល់ជើងទំព័រលេខ១១៩៨០។ កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ឆ.៨៤-៨៥, ៩០-៩១។

លើកឡើងអំពីដែនកំណត់របស់សាក្សីដែលមិនបានមកបង្ហាញខ្លួន និងបានទទួលស្គាល់ថា គាត់បាន សន្និដ្ឋាន "តាមការពិចារណា និងចក្ខុវិស័យផ្ទាល់របស់គាត់" ថា គោលដៅនៃការរៀបអាពាហ៍ពិពាហ៍ គឺដើម្បីបង្កើនចំនួនប្រជាជន និងលើកទឹកចិត្តបុគ្គលិកឃ្លាំងរដ្ឋឱ្យខំធ្វើការ[2350]។ ដំណើរការរបស់អង្គ ជំនុំជម្រះមានកំហុសឆ្គង ពីព្រោះអង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មជាលាយលក្ខណ៍អក្សរនេះតាម បែបជ្រើសរើស ដោយមិនបានបង្ហាញថា រស់ ស៊ុយ បាននិយាយអំពី "សិទ្ធិក្នុងការឆ្លើយថាព្រម ឬមិន ព្រម" ចំពោះការស្នើរៀបការ ស្របតាមគោលការណ៍របស់ ប.ក.ក[2351]។

១២៤១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ផងដែរ ដោយមិនបានលើកឡើងអំពី ភ័ស្តុតាងដែលជំទាស់នឹងអត្ថិភាពនៃការកំណត់ចំនួន។ ផាន់ ហ៊ីម ជាបុគ្គលិកក្រសួងពាណិជ្ជកម្ម មិន ដឹងអំពីអត្ថិភាពនៃការកំណត់ចំនួនរៀបអាពាហ៍ពិពាហ៍នោះទេ[2352]។ ផ្ទុយទៅវិញ គាត់បានអះអាងថា (ជាចម្លើយដែលអង្គជំនុំជម្រះបានបំភ្លេចចោលទាំងស្រុង) ការរៀបអាពាហ៍ពិពាហ៍នៅក្រសួងគាត់ត្រូវ បានធ្វើឡើង ដោយមានការយល់ព្រមពីសាមីខ្លួន និងតាមការស្នើពីបុរសៗ[2353]។ ជាចុងក្រោយ ក្នុង ដំណើរការលម្អៀង និងដាក់បន្ទុក អង្គជំនុំជម្រះខកខានមិនបានលើកឡើងថា ទាំង ផាន់ ហ៊ីម និង រស់

---

[2350] កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ធ.៨៥។ សូមមើលផងដែរ ផាន់ ហ៊ីម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.41.03 (ពុំមានការពិភាក្សា ឬវគ្គរៀនសូត្រអំពីស្ត្រី រៀបការរួចទេ តែពុំមានកូនក្រោយរៀបការរួច)។

[2351] កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ធ.៨២, ៩៣ ("ដោយសារមាន អ្នកខ្លះព្រមរៀបការតាមការចាត់តាំង ឯអ្នកខ្លះទៀតដែលបានយល់អំពីផែនការនេះ ឬមានមិត្តភក្តិនិយាយប្រាប់ពីគោលការណ៍បក្ស គេក៏បានប្រកែកមិនព្រមរៀបការ")។

[2352] ផាន់ ហ៊ីម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.03.22។

[2353] ទោះបីជាគាត់អះអាងថា ការរៀបការរបស់គាត់គឺធ្វើឡើងទាំងគាត់មិនពេញចិត្ត (និងបានទទួលស្គាល់ថាគាត់អាចបដិសេធ សំណើរៀបការមុនៗបាន) ប៉ុន្តែ ការរៀបការនេះត្រូវបានធ្វើឡើងតាមសំណើរបស់ប្តីគាត់ ហើយដែលនេះមិនមែនជាករណីនៃស្ត្រី ២០ នាក់ផ្សេងទៀតក្នុងពេលដំណាលគ្នានឹងគាត់នោះទេ។ ផាន់ ហ៊ីម៖ ប្រតិចារឹក ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/468.1** ម៉ោង 09.42.27 ("ពួកគេបានប្រាប់ទៅប្រធានកង គេព្រមព្រៀងយក បានជាអង្គការរៀបឱ្យគ្នា២០គូហ្នឹង") ចាប់ពីម៉ោង 09.24.36 (រំឭក ពីការជួបជាមួយប្តីរបស់គាត់ដែលគេរៀបចំឡើងមុនពេលប្តីស្នើរៀបការ)។ កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ចុះថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស./ធ.៧៥ (ការជួបមុខគ្នាត្រូវបានរៀបចំឡើងនៅក្នុងក្របខ័ណ្ឌការងារ ហើយប្រសិនបើបុរស ម្នាក់ស្រឡាញ់នារីម្នាក់ បុរសត្រូវសួរទៅនារីនោះថាតើនាងយល់ព្រមរៀបការ ឬក៏អត់) ស./ធ.៩៣។

ស៊ុយ មិនបាននិយាយអំពីការណែនាំជាប្រព័ន្ធឱ្យបង្កើតកូន ក្នុងគ្រប់កិច្ចប្រជុំនៃអង្គភាពរបស់ពួកគាត់ នៅក្រសួង ដូច ជា ខៀប បានអះអាង នោះទេ[2354]។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លេចចោលទាំងស្រុងនូវភស្តុតាងផ្ទុយនឹងសក្ខីកម្មរបស់ ជា ខៀប[2355]។

១២៤២. **សេចក្តីសន្និដ្ឋាន៖** គួរកត់សម្គាល់ថា វិធីសាស្រ្តទូទៅរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងភស្តុតាង ដើម្បីសន្និដ្ឋានថាមានគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងគោលដៅបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើង ដោយរំលោភលើគោលការណ៍ជាសារវ័ន្តនៃការពិនិត្យដោយមិនលម្អៀង។ ទឡ្ហីករណ៍បំភ្លៃ និងបំប្លែងនៃការបង្កើនចំនួនប្រជាជន កើតចេញពីដំណើរការនេះ ដែលរារាំងអង្គជំនុំជម្រះមិនឱ្យធ្វើការសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថាវិធានស្តីពីការព្រមព្រៀង ដែលជាគោលការណ៍របស់ ប.ក.ក ត្រូវបានអនុវត្តមិនត្រឹមត្រូវ។ អាស្រ័យហេតុនេះ ដំណើរការខុសឆ្គងនេះកំណត់ផងដែរ នូវចរិតលក្ខណៈនៃវិធីសាស្រ្តបង្ហាញភស្តុតាងអំពីការអនុវត្តបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។

### ២.៣.២. កំហុសពាក់ព័ន្ធនឹងការអនុវត្តបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍

១២៤៣. អង្គជំនុំជម្រះបានសន្និដ្ឋានថា អាជ្ញាធរបានរៀបចំអាពាហ៍ពិពាហ៍ ក្នុងពេញមួយរបបនោះ នៅគ្រប់ទីកន្លែងទូទាំងប្រទេស ដោយប្រាសចាកពីប្រពៃណី និងក្នុងបរិបទបង្ខិតបង្ខំលើអនាគតប្តីប្រពន្ធ។ ទាំង

---

[2354] ជា ខៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 15.06.03 (គោលបំណងចម្បងនៃការរៀបការគឺការបង្កើតកូន ដែលកម្មាភិបាលបានលើកឡើងម្តងហើយម្តងទៀតនៅក្នុងគ្រប់ប្រជុំទាំងអស់)។

[2355] ឧទាហរណ៍ ណុប ង៉ីម និង សេង សឿន រៀបការនៅក្នុងរបបខ្មែរក្រហម និងស្តាប់ចម្លើយ ក្នុងវគ្គស្តីពីការរៀបការដូច ជា ខៀប មិនបានលើកឡើងពីការណែនាំផ្លូវការឱ្យបង្កើតកូននោះឡើយ។ ណុប ង៉ីម ឆ្លើយថាមិនដែលឮពីការណែនាំទាំងនេះរបស់តាម៉ុក ឬអ្វីផ្សេងឡើយ ដោយគ្រាន់តែលើកឡើងពីការនិយាយលេងសើចទាក់ទងនឹងប្រធានបទនេះ ចំណែកឯ សេង សឿន វិញ គ្រាន់តែឆ្លើយថា បានឮតាម៉ុក បញ្ជាឱ្យថ្នាក់ក្រោមគិតគូរៀបចំការរៀបការសម្រាប់អ្នកដែលមានអាយុច្រើន។ ណុប ង៉ីម៖ ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ប្រហែលម៉ោង 11.14.36។ សេង សឿន៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** មុនម៉ោង 09.59.48។

បុរស ទាំងស្ត្រីគ្មានជម្រើសអ្វីក្រៅពីគោរពតាមបញ្ជាអង្គការឱ្យរៀបការ និងបង្កើតកូននោះឡើយ[2356]។ ផ្ទុយទៅវិញ ការវាយតម្លៃលើភ័ស្តុតាង ដើម្បីទាញការសន្និដ្ឋានអំពីចេតនារបស់ ប.ក.ក ក្នុងការអនុវត្តបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺមានកំហុសទាំងស្រុង ទាំងទៅលើការត្រួតពិនិត្យតាមសន្ទួតទាំងការផ្សព្វផ្សាយបទបញ្ជា (២.៣.២.១) រួមទាំងល័ក្ខខ័ណ្ឌក្រៅបទបញ្ជា (២.៣.២.២)។

### *២.៣.២.១. កំហុសពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការផ្សព្វផ្សាយបទបញ្ជា*

១២៤៤. បើតាមអង្គជំនុំជម្រះ ភ័ស្តុតាងបង្ហាញថា សេចក្តីណែនាំឱ្យថ្នាក់ក្រោមរៀបចំអាពាហ៍ពិពាហ៍ចេញមកពីថ្នាក់លើ ហើយថ្នាក់ក្រោមផ្ញើរបាយការណ៍អំពីការរៀបអាពាហ៍ពិពាហ៍ទាំងនេះត្រឡប់ទៅថ្នាក់លើវិញ[2357]។ ប៉ុន្តែ ដើម្បីសន្និដ្ឋានអំពីការរៀបចំ សំដៅគាំទ្រដល់ទស្សនៈរបស់ខ្លួនអំពីគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលតាក់តែងឡើងនៅថ្នាក់កំពូល ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយធ្វើការពិនិត្យភ័ស្តុតាងដោយលម្អៀង និងមិនពេញលេញ។

- **<u>កំហុសពាក់ព័ន្ធនឹងការផ្សព្វផ្សាយបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍</u>**

១២៤៥. **<u>វិធីសាស្ត្រជ្រើសរើសយកតែភ័ស្តុតាងដាក់បន្ទុក</u>៖** អង្គជំនុំជម្រះបានសន្និដ្ឋានថា ថ្នាក់ក្រោមរៀបចំអាពាហ៍ពិពាហ៍ ក្រោយពីទទួលបានសេចក្តីណែនាំពីថ្នាក់លើ ដែលបានផ្សព្វផ្សាយនៅតាមភូមិភាគ តំបន់ ស្រុក ឃុំ និងភូមិ ក្នុងពេលប្រជុំ និងវគ្គរៀនសូត្រ[2358]។ ការសន្និដ្ឋានដំបូងនេះសំដៅឈានទៅដល់ការសន្និដ្ឋានជារួមថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាគោលនយោបាយដែលមានការរៀបចំរបស់ ប.ក.ក[2359]។ ប៉ុន្តែ នេះមិនមែនជាសេចក្តីសន្និដ្ឋានសមហេតុផលនោះទេ។ ជាក់ស្តែង សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងអំពីសេចក្តីណែនាំមកពីអាជ្ញាធរថ្នាក់លើឱ្យ

---

[2356] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០-៣៦៩១។

[2357] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៣, ៣៦៨៩-៣៦៩១។

[2358] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦៤-៣៥៦៦។

[2359] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០-៣៦៩៣។

រៀបចំអាពាហ៍ពិពាហ៍ ដែលត្រូវបានជ្រើសយកមកគាំទ្រដល់សេចក្តីសន្និដ្ឋាននេះ គឺជាសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដដែល ដែលបានបញ្ជាក់អះអាងអំពីគោលការណ៍របស់ ប.ក.ក តម្រូវឱ្យមានការយល់ព្រមរៀបអាពាហ៍ពិពាហ៍[2360]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមានចេតនាបំភ្លេចចោលសក្ខីកម្មរបស់ពួកគេ ត្រង់ផ្នែកដែលបញ្ជាក់អះអាងអំពីបទបញ្ជាផ្ទុយពីសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

១២៤៦. ជាក់ស្តែង អង្គជំនុំជម្រះបានទទួលស្គាល់ថា សៅ សារុន បានចូលរួមប្រជុំមួយ ដែលក្នុងពេលនោះ ប៉ុល ពត បានលើកឡើងអំពីបញ្ហារៀបអាពាហ៍ពិពាហ៍ ប៉ុន្តែ អង្គជំនុំជម្រះបានចៀសវាងប្រើសក្ខីកម្មរបស់គាត់ ត្រង់កន្លែងដែលគាត់បានរំឭកអំពីគោលការណ៍ព្រមព្រៀងគ្នា និងលទ្ធភាពរបស់ឪពុកម្តាយក្នុងការចូលរួមក្នុងការរៀបអាពាហ៍ពិពាហ៍របស់កូន[2361]។ នៅក្នុងដំណើរការលម្អៀងទាំងស្រុង អង្គជំនុំជម្រះបានទទួលយកសក្ខីកម្មរបស់ ពេជ្រ ជឹម និង ខឹម បឿន មកពីស្រុកត្រាំកក់ តែត្រង់ផ្នែកដែលពួកគាត់បានអះអាងថា បានទទួលសេចក្តីណែនាំអំពីការរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានពិចារណាទាល់តែសោះទៅលើសក្ខីកម្មរបស់ពួកគាត់ ដែលបង្ហាញអំពីការតម្រូវជាចាំបាច់ឱ្យមានការយល់ព្រមពីអនាគតគូស្រករ ឬដែលពន្យល់ថា សេចក្តីលម្អិតនៃការរៀបចំអាស្រ័យទៅលើអាជ្ញាធរមូលដ្ឋានទទួលបន្ទុក[2362]។ ក្នុងន័យដដែលនេះ អង្គជំនុំជម្រះបានប្រើប្រាស់តាមរបៀបជ្រើសរើសនូវ

---

[2360] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦៥-៣៦៦៧។

[2361] <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** មុនម៉ោង 14.09.57 ("ប៉ុល ពត គាត់បញ្ជាក់ឧទ្ទេសនាមអីចឹង សំខាន់គឺខាងតំបន់ទៀត បានណែនាំជាគូក៏បាន ច្រើនគូក៏បាន ឱ្យតែគេឯកភាព ដូចខ្ញុំនិយាយប្រាប់ជម្រាបខាងលើ។ គេឯកភាពហើយ ពុកម៉ែគេដែលនៅជិតយើង ទាក់ទងឱ្យគេចូលរួមក្នុងការ កម្មវិធីអាពាហ៍ពិពាហ៍" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2362] <u>ពេជ្រ ជឹម</u>៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ម៉ោង 13.57.06 ("ពីលើគ្រាន់តែយល់ព្រមឱ្យធ្វើ ធ្វើយ៉ាងម៉េចក៏ធ្វើទៅ ជាក្រុមក៏បាន ជារាយក៏បាន ស្រេចយើងពិគ្រោះទៅ។ ឃុំ និងស្រុកពិគ្រោះទៅ ធ្វើដំណាលគ្នាទៅ ធ្វើទៅ ប៉ុនសួរម៉ែឪគេផង បងប្អូនគេផង ហើយសំខាន់សាម៉ីខ្លួន គេព្រមមិនព្រម")។ <u>ខឹម បឿន</u>៖ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/297.1** ម៉ោង 15.07.06 (គាត់បានអះអាងបញ្ជាក់លើការផ្តល់សក្ខីកម្មរបស់ ពេជ្រ ជឹម ដែលថាគឺថ្នាក់ក្រោមជាអ្នករៀបចំអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន ឬរួមគ្នា)។ ប្រតិចារឹក ឯកសារ **E1/296.1** ម៉ោង 09.55.37 និង ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/297.1** មុនម៉ោង 10.03.00, ម៉ោង 13.47.58 (អាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីបុគ្គល និងការដែលគេអាចបដិសេធការស្នើសុំរៀបការ)។ សូមមើលផងដែរ <u>នាង អ៊ួច</u> ដែលអះអាងបញ្ជាក់លើអង្គហេតុនេះ៖ ប្រតិចារឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/275**.1 ម៉ោង 11.25.17 (គាត់បានអះអាងបញ្ជាក់លើសម្តីរបស់ ខឹម បឿន ដែលថាការរៀបអាពាហ៍ពិពាហ៍មានភាពខុសគ្នាពីឃុំ

សក្ខីកម្មរបស់ មាស វឿន (យោធាភូមិភាគបស្ចិម) ស៊ូ សឿន (ភូមិភាគកណ្តាល) សេង សឿន (ភូមិភាគនិរតី) និង ហេង ឡៃប៉ាង (តំបន់ស្វយ័តក្រចេះ) ដែលសុទ្ធតែបានលើកឡើងអំពីតម្រូវការជាចាំបាច់ឱ្យសាមីខ្លួនយល់ព្រមជាមុន ចំពោះការរៀបអាពាហ៍ពិពាហ៍[2363]។ ដោយធ្វើការវិភាគមិនពេញលេញ និងលម្អៀងបែបនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់។ ការបកស្រាយបែបឱកាសនិយមទៅលើភស្តុតាងនឹងត្រូវទទួលរងទណ្ឌកម្ម ហើយសេចក្តីសន្និដ្ឋានដែលកើតចេញពីការបកស្រាយបែបឱកាសនិយមនេះ នឹងត្រូវទុកជាមោឃៈ។

១២៤៧. **<u>កំហុសពាក់ព័ន្ធនឹងការបកស្រាយរបាយការណ៍</u>៖** អង្គជំនុំជម្រះបានសន្និដ្ឋានថា ភស្តុតាងបានបង្ហាញថា ព័ត៌មានពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ត្រូវបានបញ្ជូនទៅអាជ្ញាធរថ្នាក់លើ តាមរយៈរបាយការណ៍។ ម្យ៉ាង ដូចបានបញ្ជាក់ខាងលើ របាយការណ៍តែពីរគត់ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ មិនអាចឱ្យទាញសេចក្តីសន្និដ្ឋានជារួមអំពីការអនុវត្តនៅទូទាំងប្រទេសបានទេ[2364]។ ម្យ៉ាងទៀត និងជាពិសេស អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុចំពោះការសន្និដ្ឋានរបស់ខ្លួនទេ ដោយគ្រាន់តែយល់ឃើញថា ពាក្យ "អង្គការ" នៅក្នុងរបាយការណ៍ទាំងនេះ គ្រប់គ្រាន់ឱ្យបង្ហាញថា "មជ្ឈិមបក្ស" នៅថ្នាក់កំពូល មិនត្រឹមតែទទួលបានព័ត៌មានអំពីការរៀបចំអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ថែមទាំងដឹងអំពីល័ក្ខខ័ណ្ឌជាក់លាក់នៃការរៀបចំនោះទៀតផង[2365]។ ផ្ទុយទៅវិញ ក្រៅពីមិនអាចទាញការសន្និដ្ឋានចេញពីរបាយការណ៍ពីរនេះនូវភស្តុតាងអំពីការរៀបចំជាទូទៅ នៅទូទាំងប្រទេស ឯកសារទាំងនេះ

មួយទៅឃុំមួយ) ម៉ោង 11.27.16 (គាត់មិនចាំទេថាបានឮសេចក្តីណែនាំទូទៅពីថ្នាក់លើ ដែលត្រូវជូនដំណឹងទៅថ្នាក់ក្រោមក្នុងការបង្ខំប្តីប្រពន្ធ ឱ្យរៀបការ)។

[2363] <u>មាស វឿន</u>៖ ប្រតិចារឹក ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/131.1** ម៉ោង 13.46.54។ <u>សេង សឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** ក្រោយម៉ោង 10.01.07, ម៉ោង 10.06.08។ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** មុនម៉ោង 11.21.29។ <u>ហេង ឡៃប៉ាង</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/4761** ម៉ោង 13.40.14។ <u>ស៊ូ សឿន</u>៖ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/310.1** ក្រោយម៉ោង 15.12.35 ("ក្នុងពេលនោះ មានរៀបចំអាពាហ៍ពិពាហ៍មាន។ ខាងប្រធាន ខាងសង្កាត់ ក៏គេសួរទៅសាមីខ្លួនខាងស្រី សាមីខ្លួនខាងប្រុស បើថាយល់ព្រមហើយ ក៏គេរៀបចំធ្វើពិធី") និងម៉ោង 15.25.52 ("ការរៀបចំសម្រេចត្រូវធ្វើពិធីគឺត្រូវធ្វើតាមសង្កាត់ សង្កាត់នីមួយៗគេអាចធ្វើបានម្ចាស់ការ")។

[2364] សូមមើលខាងលើ *ព័ត៌មានដែលផ្ញើជូនទៅ "មជ្ឈិមបក្ស"* កថាខណ្ឌ ១២១៩។

[2365] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៣, ៣៥៦៨ កំណត់សម្គាល់ជើងទំព័រលេខ ១១៩៧៥ និង ១១៩៧៦។

បង្ហាញត្រឹមតែចំនួនគូស្រករដែលបានរៀបការប៉ុណ្ណោះ[2366]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចយល់ឃើញថា ឯកសារទាំងនេះផ្តល់ភ័ស្តុតាងអំពីការណែនាំឱ្យរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការឯកភាពពីមេដឹកនាំ ប.ក.ក ឱ្យរៀបចំអាពាហ៍ពិពាហ៍ក្នុងល័ក្ខខ័ណ្ឌបែបនេះឡើយ។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានខុសរបស់អង្គជំនុំជម្រះ នឹងត្រូវទុកជាមោឃៈ។

### *២.៣.២.២. កំហុសពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌក្រៅបទបញ្ញា*

១២៤៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការសន្និដ្ឋានពីល័ក្ខខ័ណ្ឌផ្គូផ្គងគូស្រករដោយអាជ្ញាធរមូលដ្ឋាន និងការរៀបចំអាពាហ៍ពិពាហ៍។ ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាពិសេស ដោយសន្និដ្ឋានថា ការប្រើប្រាស់ការគំរាមកំហែង ដើម្បីបង្ខំមនុស្សឱ្យរៀបការ គឺជាការណែនាំពីថ្នាក់ដឹកនាំនយោបាយរបស់ ប.ក.ក[2367]។

- **<u>អាជ្ញាធរទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន</u>**

១២៤៩. អង្គជំនុំជម្រះបានសន្និដ្ឋានថា ភ័ស្តុតាងបានបង្ហាញថា ការរៀបការ តាមការស្នើពីសាមីខ្លួន ឬតាមការផ្សំផ្គុំពីអាជ្ញាធរ តម្រូវជាចាំបាច់ឱ្យមានការឯកភាពពីថ្នាក់លើ[2368]។ ការសង្កេតឃើញនេះ ស្របតាមល័ក្ខខ័ណ្ឌទីពីរនៃបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ដែលទាមទារឱ្យមានការយល់ព្រមពីសមូហភាព ដើម្បីឱ្យការរៀបការមានភាពស្របច្បាប់ មិនមែនជាភ័ស្តុតាងបង្ហាញអំពីឆន្ទៈរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ នេះជាការអនុវត្តជាទូទៅនៅក្នុងប្រទេសភាគច្រើន ចំពោះអាពាហ៍ពិពាហ៍តាមអាណាចក្រ និងសាសនចក្រ។ សាក្សីជាច្រើនបានបញ្ជាក់អះអាងអំពីភាពចាំបាច់នៃទម្រង់ការនេះ ដែលស្របនឹងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ[2369]។ ប៉ុន្តែអង្គជំនុំជម្រះបានប្រព្រឹត្តកំហុស

---

[2366] ជាពិសេស សូមមើលរបាយការណ៍នៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨ ឯកសារ **E3/1094** ERN 00143616។

[2367] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៣ ការគំណត់បទចោទលើអង្គហេតុ។

[2368] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦០២។

[2369] សូមមើលខាងក្រោម កថាខណ្ឌ ១២៥៧។

ដោយបានសន្និដ្ឋាន តាមរយៈការវិភាគលម្អៀងទៅលើភ័ស្តុតាងថា អាជ្ញាធរថ្នាក់លើ (អង្គជំនុំជម្រះចៀសវាងបញ្ជាក់អត្តសញ្ញាណច្បាស់លាស់) បានចេញសេចក្តីណែនាំឱ្យផ្សំផ្គុំគូស្រករ ដោយមាន ឬគ្មានការយល់ព្រមពីសាមីខ្លួន[2370]។

១២៥០. ដូចបានបង្ហាញខាងលើ អាជ្ញាធរទទួលបន្ទុករៀបចំអាពាហ៍ពិពាហ៍ត្រូវប្រាកដថា សាមីខ្លួនយល់ព្រម[2371]។ អង្គជំនុំជម្រះបានប្រើប្រាស់ករណីដាច់ដោយឡែកមួយដែលដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន បានលើកឡើង ដើម្បីច្រានចោលការពិតនៃគោលការណ៍នេះ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់ថា ក្នុងពិធីរៀបការ អនាគតស្វាមី-ភរិយាបានដឹងថាខ្លួនអាច "ក្រោកចេញ" បាន "បើមិនពេញចិត្ត"[2372]។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការបកស្រាយសក្ខីកម្មរបស់ ណុប ធីម។ ជាក់ស្តែង ថ្វីត្បិតតែគាត់បានឆ្លើយថា គាត់ត្រូវគេបង្ខំជាមួយស្ត្រីផ្សេងទៀតឱ្យរៀបការជាមួយជនពិការក៏ដោយ ក៏អង្គជំនុំជម្រះគួរណាតែចង្អុលបង្ហាញថា ស្ត្រីទាំងនោះមិនបានប្រកែកទេ[2373]។ ជាពិសេស អង្គជំនុំជម្រះបានបំភ្លេចចោលនូវធាតុផ្សំដ៏សំខាន់មួយនៃសក្ខីកម្មដែលមិនគាំទ្រដល់ការអះអាងអំពីការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស។ យ៉ាងណាមិញ ណុប ធីម បានបញ្ជាក់ថា ការអនុវត្តចំពោះករណីផ្ទាល់ខ្លួនរបស់គាត់ក្នុងឋានៈជាកម្មាភិបាលក្រោមបង្គាប់ តាម៉ុក

---

2370 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៩៨។ ពីព្រោះថា ទោះបីជាការយល់ព្រមរបស់អ្នកទាំងនោះមិនត្រូវបានលើកយកមកនិយាយនៅ ក្នុងផ្នែកនេះនៃសំអាងហេតុសាលក្រម *១៤.៣.៥.១ អាពាហ៍ពិពាហ៍ដែលអាជ្ញាធរបានស្នើឡើង* ប៉ុន្តែ មានការបកស្រាយបង្ហាញនៅក្នុងសំអាងហេតុសាលក្រមដដែលនេះ ឧទាហរណ៍ក្នុងផ្នែក *១៤.៣.៦* ដើម្បីធ្វើសេចក្តីសន្និដ្ឋាននៅក្នុងកថាខណ្ឌ ៣៦៩៣។ មេធាវីការពារក្តីបានយោងទៅទឡ្ហីករណ៍ខាងក្រោម នៅក្នុងកថាខណ្ឌ ១២៥៣។

2371 សូមមើលខាងលើ កថាខណ្ឌ ១១៨៩-១២៤២។

2372 សេង សឿន៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** ម៉ោង 10.01.07, ម៉ោង 10.06.08។ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ ឯកសារ **E1/466.1** មុនម៉ោង 11.21.29។

2373 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៩៧។ ណុប ធីម៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** បន្ទាប់ពីម៉ោង 11.02.33។

មិនដូចគ្នានឹងអ្នកសហករណ៍ទេ[2374]។ អង្គជំនុំជម្រះគួរណាតែពិចារណាដល់ភាពចម្រុះគ្នានៃបទពិសោធន៍។

• **ពិធីរៀបការ និងបុរេលក្ខខណ្ឌ**

១២៥១. អង្គជំនុំជម្រះបានសន្និដ្ឋានថា គោលនយោបាយ ប.ក.ក ស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅទូទាំងប្រទេស តម្រូវឱ្យផាត់ឪពុកម្ដាយចេញពីការរៀបការរបស់កូន និងតម្រូវឱ្យរៀបចំពិធីរួមគ្នាជាច្រើនគូ[2375]។ ត្រង់ចំណុចនេះទៀត សេចក្ដីសន្និដ្ឋាននេះផ្អែកលើការវិភាគលម្អៀង និងមិនគ្រប់ជ្រុងជ្រោយទៅលើភ័ស្ដុតាង ដោយច្រានចោលភ័ស្ដុតាងណាដែលផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួន ដោយគ្មានផ្ដល់សំអាងហេតុ។

១២៥២. **ការផាត់ឪពុកម្ដាយចេញពីដំណើរការនៃការរៀបអាពាហ៍ពិពាហ៍៖** អង្គជំនុំជម្រះបានសន្និដ្ឋានថា ក្នុងករណីភាគច្រើន អាជ្ញាធរ ប.ក.ក បានផាត់ឪពុកម្ដាយចេញពីដំណើរការនៃការរៀបអាពាហ៍ពិពាហ៍ក្នុងឆន្ទៈដើរតួជំនួសឪពុកម្ដាយ[2376]។ ការវិភាគនេះមានកំហុសធ្ងន់ ពីព្រោះ តាមពិត បទបញ្ញាស្ដីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានឱ្យតម្លៃលើការព្រមព្រៀងគ្នារវាងអនាគតប្ដីប្រពន្ធ ធំជាងការយល់ព្រមពីឪពុកម្ដាយ ដែលខុសពីប្រពៃណីខ្មែរពីមុន និងធំជាងការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន។ សូមរំឭកថា ខ្លឹមសារនៃឯកសាររបស់ ប.ក.ក ចំពោះយុវជនបក្ស (ដោយមិនបំភ្លៃអត្ថន័យដូចអង្គជំនុំជម្រះបានធ្វើ) បានជំរុញឱ្យធ្វើការជ្រើសរើសក្នុងឧត្ដមគតិបដិវត្តន៍ និងកសាង

[2374] ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 15.49.56 (គាត់មិនជំទាស់នឹងការរៀបការ ពីព្រោះគាត់គិតថា ខ្លួនគាត់ចាស់ហើយ) មុនម៉ោង 11.02.33 (ឡេងមិនមាត់ទេ ចេះតែការៗទៅ) មុនម៉ោង 11.18.46 និងនៅម៉ោង 13.39.16 (វាស្រឡាញ់គ្នា ទើបយើងការឱ្យ)។

[2375] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០-៣៦៩១។

[2376] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩១, ៣៦៩៣។

ប្រទេស[2377]។ ជាក់ស្តែង ថ្វីត្បិតតែពាក្យ "កូនអង្គការ" ត្រូវបានប្រើប្រាស់នៅក្នុងឯកសារនយោបាយក៏ដោយ ក៏លក្ខណៈវិនិច្ឆ័យនៃការព្រមព្រៀងគ្នារវាងអនាគតប្តីប្រពន្ធមានតម្លៃលើសគេ។

១២៥៣. ថ្វីត្បិតតែ យស ផល បានលើកឡើងថា អាជ្ញាធរមូលដ្ឋានមិនអនុញ្ញាតឱ្យគាត់រៀបការជាមួយគូដណ្តឹង ដោយហេតុថាសមាជិកគ្រួសារម្នាក់របស់សាមីខាងស្រីត្រូវបានអង្គការកម្ទេច ប៉ុន្តែ គាត់បានទទួលស្គាល់ថា ស្ថានភាពនេះមិនកើតឡើងចំពោះគូស្រករភាគច្រើនទេ[2378]។ ជាំង ស្រីមុំ ដែលបាននិយាយពាក្យ "កូនអង្គការ" បានគូសបញ្ជាក់ថា អាជ្ញាធរពិតជាបានពិនិត្យផ្ទៀងផ្ទាត់ការព្រមព្រៀងនៅក្នុងពិធីរៀបការមែន[2379]។ ដូចបានបញ្ជាក់ខាងលើ ការពិនិត្យផ្ទៀងផ្ទាត់នេះស៊ីចង្វាក់គ្នានឹងសក្ខីកម្មជាច្រើនទៀតនៅក្នុងសវនាការ[2380]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានលើកឡើងអំពីការជំនួសអំណាចឪពុកម្តាយ ដោយអំណាចរបស់អ្នកគ្រប់គ្រងនៅតាមមូលដ្ឋាន ដោយមិនបានរកឃើញថា អ្វីដែលថ្មីមិនដែលមានពីមុនមក គឺការយល់ព្រមពីសាមីខ្លួន។

១២៥៤. ***សក្ខីកម្មផ្ទុយ៖*** ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានទាញការសន្និដ្ឋានពីភ័ស្តុតាងក្នុងសំណុំរឿងដោយខុសឆ្គងថា ការយល់ព្រមពីសាមីខ្លួន និងអាជ្ញាធរ នាំឱ្យផាត់ឪពុកម្តាយចេញពីដំណើរការនៃការរៀបការ។ ត្រង់ចំណុចនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានបដិសេធចោលជាប្រព័ន្ធនូវសក្ខីកម្មរបស់អតីតកម្មាភិបាល ដែលផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួន។ អង្គជំនុំជម្រះថែមទាំងបានប្រើប្រាស់ទឡ្ហីករណ៍អំពីឆន្ទៈ "បន្ថយការទទួលខុសត្រូវផ្ទាល់ខ្លួន" ហើយផ្ទុយទៅវិញ អង្គ

---

[2377] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៣៩ កំណត់សម្គាល់ជើងទំព័រលេខ ១១៩១១ និងកថាខណ្ឌ ៣៦១០ កំណត់សម្គាល់ជើងទំព័រលេខ ១២០៥២។

[2378] <u>យស ផល</u>៖ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 10.39.47 ម៉ោង 11.10.50 ("អាហ្នឹងគឺជាគូរបស់គេ ប្រវត្តិរូបរបស់គេ ដូចថាថ្មីអញ្ចឹងអត់មានអង្គការកម្ទេច ខាងប្រុសហ្នឹងក៏អត់កម្ទេច ខាងស្រីក៏អត់មានកម្ទេច ហើយជាគូដណ្តឹងគេ។ អាហ្នឹងគេល្អរបស់គេ គេបានទៅ")។

[2379] <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 09.54.32 ("រៀបការជាមួយនារីដោយស្ម័គ្រចិត្តដោយខ្លួនឯង ឬមួយមានអ្នកណាបង្ខំចិត្តឬទេ? ប្តីខ្ញុំក៏ឆ្លើយថា "ខ្ញុំរៀបការដោយស្ម័គ្រចិត្តអត់មានអ្នកណាបង្ខំចិត្តឡើយ")។ ម្តាយគាត់ និងជីដូនគាត់មានវត្តមាននៅក្នុងពេលគាត់រៀបការ ទោះបីជាគាត់មិនបានទទួលដំណឹងជាមុនក្តី ឯកសារ **E1/254.1** ម៉ោង 10.09.49 ក្រោយម៉ោង 15.29.39។

[2380] សូមមើលខាងលើ កថាខណ្ឌ ១១៩៤-១១៩៥។

ជំនុំជម្រះមិនរួញរាក្នុងការប្រើប្រាស់ផ្នែកផ្សេងទៀតនៃសក្ខីកម្មរបស់ពួកគេ នៅពេលស្របនឹងទស្សនៈរបស់ខ្លួន[2381]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយច្រានចោលសក្ខីកម្មទាំងនេះ ពីព្រោះវាចេញមកពីកម្មាភិបាល ខណៈដែលសក្ខីកម្មទាំងនេះស៊ីចង្វាក់គ្នានឹងចម្លើយរបស់សាក្សីជាច្រើន។ ជាក់ស្តែង ខុសពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះ ការចូលរួមរបស់ឪពុកម្តាយមិនត្រូវបានបម្រុងទុកសម្រាប់តែបុគ្គលមានសិទ្ធិពិសេសនោះទេ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន រួមទាំងអ្នកដែលជាប្រជាជនសាមញ្ញ បានបញ្ជាក់អះអាងអំពីការចូលរួម ឬយ៉ាងហោចណាស់ វត្តមានរបស់ឪពុកម្តាយក្នុងពិធីរៀបការរបស់ពួកគេ[2382]។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះថា ក្នុងករណីភាគច្រើន ឪពុកម្តាយមិនមានវត្តមានក្នុងពិធីរៀបការ គឺភាន់ច្រឡំ និងត្រូវទុកជាមោឃៈ។

---

[2381] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦១២-៣៦១៣, ៣៦៣៩-៣៦៤០។ ឧទាហរណ៍ អង្គជំនុំជម្រះបានជ្រើសការប្រើប្រាស់ការផ្តល់សក្ខីកម្មរបស់ សៅ សារុន ដែលបានឮ ប៉ុល ពត និយាយអំពីការរៀបអាពាហ៍ពិពាហ៍ នៅក្នុងអង្គប្រជុំមួយ នៅទីក្រុងភ្នំពេញ។ ការផ្តល់សក្ខីកម្មរបស់គាត់ត្រូវបានស្រង់សម្តីយ៉ាងតិច៩ដង នៅក្នុងសំអាងហេតុសាលក្រម ស្តីពីការរៀបអាពាហ៍ពិពាហ៍៖ សម្រង់សម្តីនោះត្រូវបានវាយតម្លៃថាគួរឱ្យជឿជាក់ ៧ដង ដើម្បីអះអាងបញ្ជាក់លើបែបបទរៀបអាពាហ៍ពិពាហ៍ ឬប្រភពនៃសេចក្តីណែនាំ តែត្រូវបដិសេធ ២ ដង ពេលដែលគាត់អះអាងអំពីគោលការណ៍នៃការព្រមព្រៀងរៀបការ និងការដែលឪពុកម្តាយអាចចូលរួមក្នុងពិធីរៀបការ។ ប៉ុន្តែ សេចក្តីអះអាងរបស់ សៅ សារុន ត្រូវបានអះអាងបញ្ជាក់បន្ថែមដោយកម្មាភិបាលផ្សេងទៀត ដូចជា ពេជ្រ ជឹម ឬ ខឹម បឿន ដែលបានរំឭកផងដែរពីការដែលឪពុកម្តាយអាចចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់កូនៗ។ សូមមើល សំអាងហេតុនៃសាលក្រម កថាខណ្ឌ ៣៥៥៦, ៣៥៦៥-៣៥៦៧, ៣៥៩២, ៣៦១៧, ៣៦២៣, ៣៦៣២-៣៦៣៣។ <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** មុនម៉ោង 14.09.57។ <u>ពេជ្រ ជឹម</u>៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចាប់ពីម៉ោង 13.47.11 ម៉ោង 13.57.06 ម៉ោង 09.24.36 (គេអាចទៅសួរសុខទុក្ខ និងជម្រាបសួរក្រុមគ្រួសារ និងឪពុកម្តាយ ប្រសិនបើពួកគេនៅជិតៗកន្លែងរៀបការ)។ សូមមើលផងដែរសក្ខីកម្មរបស់ <u>ខឹម បឿន</u>៖ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/297.1** ម៉ោង 15.07.06។

[2382] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦១៦, ៣៦៤០។ <u>ប្រជាជនសាមញ្ញ</u>៖ <u>អ៊ុំ សុផានី</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/251.1** ម៉ោង 15.50.47។ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** មុនម៉ោង 09.57.16។ <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ម៉ោង 10.09.49។ <u>មាស ឡៃហួរ</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/305.1** ម៉ោង 09.28.47។ <u>កង អ៊ុត</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/322.1** ក្រោយម៉ោង 10.55.41 មុនម៉ោង 11.00.32។ <u>សេង ស្រ៊ុន</u>៖ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/346.1** ម៉ោង 11.51.47។ <u>ម៉ាត់ ស</u>៖ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/375.1** ម៉ោង 14.38.50 ម៉ោង 15.49.35។ <u>ថេង ផល</u>៖ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/371.1** ម៉ោង 14.06.23។ <u>ហ៊ឹម ម៉ាន</u>៖ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E1/350.1 ក្រោយម៉ោង 09.43.03 (បានរៀបការជាមួយនឹងគូដណ្តឹងគាត់ដោយមានឪពុកម្តាយចូលរួម)។ <u>មុី សាវឿន</u>៖ ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/459.1**

១២៥៥. ***គោលបំណងនៃការរៀបការច្រើនគូ៖*** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ការអនុវត្តជាទូទៅនៅទូទាំងប្រទេស ក្នុងការរៀបការច្រើនគូក្នុងពេលតែមួយជាមួយគ្នា មានគោលដៅ "ពន្លឿនការរៀបអាពាហ៍ពិពាហ៍ដែលមានមនុស្សច្រើននាក់ក្នុងទ្រង់ទ្រាយធំ"[2383]។ ដើម្បីសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះបានប្រើប្រាស់ ជាអាទិ៍ សក្ខីកម្មរបស់ ឯក ហឿន និង ស៊្វ សុធារី ដែលបានលើកឡើងអំពីពិធីរៀបការរួម នៅការដ្ឋាន ដែលមាន ៤០០ និង ១១៧ គូ។ ដូចមេធាវីការពារក្ដីបានលើកឡើងក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នេះគឺជាករណីជ្រុលហួសហេតុ ហើយអង្គជំនុំជម្រះមិនគួរណាយកសក្ខីកម្មទាំងនេះមកធ្វើជាករណីទូទៅទេ[2384]។ អង្គជំនុំជម្រះក៏មិនបានអើពើនឹងសេចក្ដីពន្យល់ដោះបន្ទុករបស់សាក្សីផ្សេងទៀត ដែលបានលើកឡើងពីហេតុផលនៃការរៀបចំអាពាហ៍ពិពាហ៍ច្រើនគូ។ ដូច្នេះ ក្នុងដំណើរការលម្អៀងរបស់ខ្លួន អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ ពេជ្រ ជឹម តែនៅពេលគាត់លើកឡើងអំពីការបង្កើនចំនួនការរៀបការ ដោយដកចោលការពន្យល់ ក្នុងចម្លើយដដែលនោះ អំពីហេតុផលនៃការបង្កើននោះ៖ "ដល់ ៧១ ក៏របបរៀបចំ [...]។ ហើយដល់វាច្រើនពេកទៅ [...]។ រៀបមួយៗអង្គាល់ហើយ"[2385]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះមិនអើពើនឹងសក្ខីកម្មរបស់ សៅ សារុន ដែលពន្យល់ថា ថ្វីត្បិតតែ ប៉ុល ពត លើកឡើងអំពីលទ្ធភាពរៀបការម្ដងច្រើនគូក៏ដោយ ក៏កម្មាភិបាលមូលដ្ឋាន (អ្នកខ្លះបានបញ្ជាក់អះអាងនៅក្នុងសវនាការ) មានសេរីភាពក្នុងការចាត់ចែងពិធី ទៅតាមស្ថានភាពជាក់ស្ដែង[2386]។ ដូច្នេះ យោងតាមភស្តុតាងក្នុងសំណុំរឿង វាជា

---

ឯកសារ ចន្លោះម៉ោង 15.47.50 និងម៉ោង 15.50.01។ <u>សៀង ចាន់ធី</u>៖ ប្រតិចារឹក ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/394.1** ក្រោយម៉ោង 09.54.20 ម៉ោង10.50.08។ <u>អតីតកម្មាភិបាល</u>៖ <u>ប៉ាន ឈួង</u>៖ ប្រតិចារឹក ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/360.1** ក្រោយម៉ោង 11.11.05។ <u>ឌិ ហួ</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/301.1** ក្រោយម៉ោង 14.41.19។ <u>ហេង ឡៃប៉ាង</u>៖ ប្រតិចារឹក ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/4761** មុនម៉ោង 09.48.04 ក្រោយម៉ោង 13.40.14 ម៉ោង14.01.24 (ឪពុកម្ដាយទទួលបានដំណឹង និងត្រូវបានអញ្ជើញឱ្យចូលរួមពិធីរៀបអាពាហ៍ពិពាហ៍)។

[2383] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩១ (ការកំណត់បទចោទលើអង្គហេតុ) ៣៦៣១-៣៦៣២។

[2384] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៣២។ សូមមើលផងដែរសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ២៤៥០។

[2385] <u>ពេជ្រ ជឹម</u>៖ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ចាប់ពីម៉ោង 13.47.11។

[2386] <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** មុនម៉ោង 14.09.57។ <u>ខឹម ហឿន</u>៖ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/296.1** មុនម៉ោង 09.54.14 ("ខ្ញុំនិយាយបានត្រឹមក្នុងក្របខណ្ឌដែលខ្ញុំរស់នៅ មួយគូក៏បាន ច្រើនគូ

រឿងមិនសមហេតុផលក្នុងការសន្និដ្ឋាន ដូចអង្គជំនុំជម្រះបានធ្វើ ថាការរៀបការច្រើនគូមានលក្ខណៈជាប្រព័ន្ធ។

១២៥៦. ***<u>ការប្ដេជ្ញា និងការណែនាំក្នុងពិធីរៀបការ៖</u>*** នៅកថាខណ្ឌ ៣៥៤៨ នៃសំអាងហេតុសាលក្រមរងបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការប្ដេជ្ញារបស់អនាគតគូស្រករផ្ទុះបញ្ចាំងអំពីការគោរពដាច់ខាតតាមសេចក្ដីណែនាំរបស់អង្គការ ដែលស្ថិតនៅពីលើផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍គ្រួសារ[2387]។ ប៉ុន្តែ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណាម្នាក់អាចធ្វើការសន្និដ្ឋានជាមួយនឹងការពិនិត្យភ័ស្តុតាងដោយលម្អៀងបែបនេះឡើយ។ ជាដំបូង អង្គជំនុំជម្រះបានបង្ហាញចក្ខុវិស័យត្រួសៗនៃមនោគមន៍វិជ្ជាកុម្មុយនីស្ត និងឆន្ទៈគិតគូរដល់ប្រយោជន៍រួម ក្នុងការប្ដេជ្ញាចិត្តខាងនយោបាយ និងផ្ទាល់ខ្លួន។ ដូចនៅប្រទេសខ្លះដែលគោរពចំពោះទង់ ឬបាវចនាជាតិ ប.ក.ក ប្រយុទ្ធដើម្បីឧត្តមគតិស្នេហាជាតិ ដែលពុះកញ្ជ្រោលឡើងដោយសារសង្គ្រាមស៊ីវិលទើបតែកន្លងផុតថ្មីៗ និងជ័យជម្នះលើរបបចាស់ដ៏ស្អុយអសោច។ ការប្រកាន់ជំហរបដិវត្តន៍លើការបង្កើតសង្គមថ្មី និងការអំពាវនាវឱ្យគោរពតាមទស្សនៈនៃគូស្រករថ្មីនេះ អាចមានផលប៉ះពាល់លើសុន្ទរកថារបស់កម្មាភិបាលមូលដ្ឋានមួយចំនួន ក្នុងពិធីរៀបការ។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសារមិនបានទាញផលវិបាកចេញពីការសង្កេតឃើញការអនុវត្តផ្សេងៗគ្នា នៅក្នុងពិធីរៀបការ។ ជាក់ស្ដែង ភ័ស្តុតាងបង្ហាញថា ការប្ដេជ្ញារបស់អនាគតស្វាមី-ភរិយាដែលនិយាយដល់អង្គការក្នុងពិធីរៀបការ ពុំមានលក្ខណៈជាប្រព័ន្ធ ហើយជួនកាល គ្មានការប្ដេជ្ញាទេ[2388]។

ក៏បាន។ តែខ្ញុំមិនដែលបានរៀបការច្រើនទេ បានយ៉ាងច្រើនបី បួនគូប៉ុណ្ណោះ")។ <u>ជួន ធី</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ក្រោយម៉ោង 09.43.20 (គេអាចរៀបអាពាហ៍ពិពាហ៍តែមួយគូ) ម៉ោង09.20.33 (ការរៀបការច្រើនគូត្រូវបានធ្វើឡើងដើម្បីចំណេញពេលវេលា)។ <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ម៉ោង 15.30.36 (ប្រជាជនធម្មតានៅត្រាំកក់ រៀបការតែមួយគូៗប៉ុណ្ណោះ នៅឆ្នាំ១៩៧៧)។

[2387] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១១៩២៨ (នៃកថាខណ្ឌ ៣៥៤៨) ដែលយោងទៅកថាខណ្ឌ ៣៦៣៣-៣៦៣៤។

[2388] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៣៣-៣៦៣៤។

១២៥៧. ឧទាហរណ៍ដូចជា នៅកថាខណ្ឌ ៣៦៣៥ អង្គជំនុំជម្រះបានលើកឡើងថា អាជ្ញាធរជាអធិបតីក្នុងពិធីរៀបការបានផ្ដល់ការណែនាំផ្សេងៗដល់គូស្រករ ដូចជាត្រូវស្រឡាញ់គ្នា រួមរស់ជាមួយគ្នា គោរពវិន័យ និងជួនកាល បង្កើតកូនជូនអង្គការ[2389]។ ភាពចម្រុះគ្នានៃសុន្ទរកថា និងការមិនមានឯកសណ្ឋានភាពនៃពិធីរៀបការ គួរណាតែនាំឱ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានថា ពុំមានសេចក្ដីណែនាំជាក់លាក់មកពីថ្នាក់ដឹកនាំ ប.ក.ក អំពីរបៀបរៀបចំអាពាហ៍ពិពាហ៍ទេ។ អង្គជំនុំជម្រះគួរណាតែសន្និដ្ឋានដោយផ្អែកលើភស្តុតាងក្នុងសំណុំរឿងថា ការរៀបចំពិធីដោយអាជ្ញាធរអាចធ្វើឱ្យការរួមរស់ជាមួយគ្នាក្លាយជាផ្លូវការ ឬស្របច្បាប់[2390] ផ្ដល់ការដឹងឮជាផ្លូវការចំពោះការកសាងជីវិតគូស្រករ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដែលរបបនោះទទួលស្គាល់។ ការទទួលបានការព្រមព្រៀង គឺជាទិដ្ឋភាពសំខាន់មួយនៃការផ្ដល់សុពលភាពដល់ការរៀបអាពាហ៍ពិពាហ៍[2391]។

១២៥៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញសេចក្ដីសន្និដ្ឋានជារួមអំពីបទពិសោធន៍ដោយឡែករបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានផ្ដល់សក្ខីកម្មក្នុងវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ ដោយមិនបាន

---

[2389] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៣៥។

[2390] ព្រំ សារុន៖ ប្រតិចារឹក ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/364.1** ម៉ោង 15.11.51។ ឱ ហួ៖ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/301.1** ក្រោយម៉ោង 14.39.15។ ទេព ប៉ូច៖ ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/461.1** ម៉ោង 15.07.48។ ថៅ ឡាង៖ ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** ម៉ោង 15.13.25។ ឃិន វ៉ាត៖ ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/325.1** ម៉ោង 15.40.44។ មុី សាវឿន៖ ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/459.1** ក្រោយម៉ោង 14.08.35។ ជាំង ស្រីមុំ៖ ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/255.1** មុនម៉ោង 09.29.19។

[2391] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/290.1** ម៉ោង 13.57.06។ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** ម៉ោង 09.16.46 ម៉ោង 09.18.41 ម៉ោង 09.22.43។ ជាំង ស្រីមុំ៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 09.54.32 និងមុនម៉ោង 09.56.12។ សៅ ប៊ាន៖ ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/265.1** ម៉ោង 10.10.09 (នៅក្នុងពិធីរៀបការ "គេគ្រាន់តែឱ្យឆ្លើយថាប្ដេជ្ញាយកអ្នកនេះ អ្នកនោះអស់មួយជីវិត ... ខាងប្រុសគេនិយាយថាយកនាងឯងអស់មួយជីវិត។ ខាងនារីគេថាយកបុរសហ្នឹងអស់មួយជីវិត")។ ប៉ាន ឈួង៖ ប្រតិចារឹក ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/360.1** មុនម៉ោង 11.11.05។ ម៉ាត់ ស៖ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ **E1/375.1** មុនម៉ោង 15.52.52 ("គេហៅថាចាប់ដីគ្នានឹងការតែម្ដង [...] គេរៀបចំតាមហ្នឹងតែម្ដង")។ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9826** ស/ឆ ១៤៣។

ប្រៀបធៀបនឹងភ័ស្តុតាងទាំងមូល[2392]។ អង្គជំនុំជម្រះគួរណាតែយល់ឃើញថា ការស្នើឱ្យប្តីប្រពន្ធឡើងប្តេជ្ញា គឺជាការសន្យាជាទម្លាប់ រវាងមនុស្សពីរនាក់ ថានឹងស្រឡាញ់គ្នា និងរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ[2393]។ អន្តរាគមន៍របស់អាជ្ញាធរក្នុងពិធីរៀបការ និងការប្តេជ្ញារបស់អនាគតប្តីប្រពន្ធ នៅចំពោះមុខអាជ្ញាធរ មិនអាចចាត់ទុកជាចេតនារបស់ ប.ក.ក ក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រង់ចំណុចនេះ មានកំហុសឆ្គង និងត្រូវទុកជាមោឃៈ។

• **<u>ការប្រើការគំរាមកំហែង និងបរិបទបង្ខិតបង្ខំនៅក្នុងប្រទេស</u>**

១២៥៩. កំហុសរបស់អង្គជំនុំជម្រះមិនកម្រិតត្រឹមការបំភ្លៃភ័ស្តុតាងអំពីគោលការណ៍ព្រមព្រៀង ឬការប្រព្រឹត្តទៅនៃពិធីរៀបការនោះទេ។ បើតាមអង្គជំនុំជម្រះ អាជ្ញាធរបានប្រើប្រាស់ការគំរាមកំហែង ដើម្បីបង្ខំឱ្យរៀបការ ដោយផ្ទាល់ ក្នុងក្របខ័ណ្ឌនៃការគោរពអង្គការវិន័យ ឬដោយប្រយោល ក្នុងបរិបទនៃការភ័យខ្លាចជាទូទៅ នៅទូទាំងប្រទេស។ នេះជាទឡ្ហីករណ៍ដ៏សំខាន់របស់អង្គជំនុំជម្រះ ដើម្បីធ្វើការសន្និដ្ឋានអំពីអប្រសិទ្ធភាពនៃគោលការណ៍ព្រមព្រៀងរបស់ ប.ក.ក ដែលខ្លួនមិនអាចជំទាស់អត្ថិភាពបាន។ ជាក់ស្តែង អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានថា ប្រជាជនគ្មានជម្រើសអ្វីផ្សេងក្រៅពីរៀបការ ហើយបើទោះជាយល់ព្រមក៏ដោយ ក៏មិនមែនជាការយល់ព្រមពិតប្រាកដឡើយ[2394]។ សេចក្តីសន្និដ្ឋានខុសទាំងនេះ បានមកពីការវិភាគលម្អៀងទៅលើភ័ស្តុតាង។

១២៦០. **<u>គ្មានការព្រមព្រៀងពិតប្រាកដ</u>៖** បើតាមអង្គជំនុំជម្រះ ផ្ទុយពីអត្ថបទផ្លូវការ និងសក្ខីកម្មរបស់អតីតកម្មាភិបាល ប.ក.ក ការព្រមព្រៀងរៀបការពីសំណាក់អនាគតប្តីប្រពន្ធ មិនមែនជាការពិតទេ ដោយហេតុថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានអះអាងថា ពួកគេគ្មានសិទ្ធិប្រកែកទេ ពីព្រោះពួកគេគិតថាត្រូវគោរពតាមបញ្ជាអង្គការ[2395]។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "ភ័ស្តុតាងច្រើនលើស

---

[2392] សូមមើលខាងលើ កថាខណ្ឌ ១១៩៩-១២១០។

[2393] សូមមើលខាងលើ កថាខណ្ឌ ១២២៥។

[2394] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦២៥, ៣៦៩០-៣៦៩១ (ការកំណត់បទចោទលើអង្គហេតុ)។

[2395] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦១៩។

លុបបង្ហាញថា ពួកគេមិនអាចបដិសេធការរៀបការ ដោយមិនទទួលរងបញ្ហានោះឡើយ”[2396]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស តាមរយៈការវាយតម្លៃមិនត្រឹមត្រូវ និងប្រើប្រាស់ភ័ស្តុតាងតាមបែបជ្រើសរើស។

១២៦១. ជាដំបូង អង្គជំនុំជម្រះបានផ្អែកជាចម្បងលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ក្នុងសវនាការវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីទាញសេចក្តីសន្និដ្ឋានជារួម។ ហេតុនេះ អង្គជំនុំជម្រះបានបដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តី លើបញ្ហាសំខាន់នៃភាពជាតំណាងនៃរឿងរ៉ាវទាំងនេះ នៅថ្នាក់ជាតិ[2397]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយខកខានមិនបានយកសក្ខីកម្មទាំងនេះមកប្រៀបធៀបជាមួយភ័ស្តុតាងទាំងមូល។ ផ្ទុយទៅវិញភ័ស្តុតាងក្នុងសំណុំរឿងទាំងមូល មិនអាចឱ្យសន្និដ្ឋានក្នុងន័យនេះបានទេ ដូចយើងនឹងឃើញខាងក្រោម។

១២៦២. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានបំភ្លៃភ័ស្តុតាង ដើម្បីសន្និដ្ឋានថា ការរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងដោយបង្ខំ ឬពួកគេបានយល់ព្រម ដោយសារខ្លាចការសងសឹក សូម្បីតែនៅពេលសាមីខ្លួននិយាយផ្ទុយពីនេះក៏ដោយ[2398]។ អង្គជំនុំជម្រះបានឈានដល់កម្រិតកំពូលនៃ

---

[2396] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២១០៦, ១២១០៨ ដោយព្រមទទួលយកករណីលើកលែង ឯម គឿង និង សុន វុត កំណត់សម្គាល់ជើងទំព័រលេខ ១២១០៦-១២១០៧។

[2397] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២១-២៣២៨, ២៤៤០-២៤៤៤, ២៤៥០-២៤៥១។

[2398] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦១៩-៣៦២០។ ឧទាហរណ៍ អង្គជំនុំជម្រះបានសម្រេចយកការរៀបការរបស់ សេង ស្រ៊ុន ថាជាការរៀបការដោយបង្ខំ ចំណែកឯសាក្សីនេះបានអះអាងថាការរៀបអាហ៍ពិពាហ៍របស់គាត់ត្រូវបានរៀបចំដោយគ្រួសារប្តីប្រពន្ធទាំងសងខាង៖ សេង ស្រ៊ុន៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/346.1** ម៉ោង 11.51.47។ ក្នុងន័យដូចគ្នានេះដែរ អ៊ិន យឿង ដែលត្រូវបានមេធាវីការពារក្តីបានចោទសួរ បានអះអាងថា បើតាមចម្លើយជាលាយលក្សណ៍អក្សររបស់គាត់ គាត់បានព្រមព្រៀងរៀបការដោយស្ម័គ្រចិត្ត ដូចគូស្រករយុវជនដទៃទៀតដែរ៖ អ៊ិន យឿង៖ ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/387.1** ម៉ោង 14.18.10 ចាប់ពីម៉ោង 15.39.49។ អង្គជំនុំជម្រះធ្វើមិនដឹងមិនឮចំពោះផ្នែកនៃការចោទសួរនេះ។ អង្គជំនុំជម្រះក៏ បានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា សៀង ចាន់ធី ត្រូវបានបង្ខំឱ្យរៀបការនៅក្នុងរបបនោះ ខណៈដែលខ្លួនមិនបានរំឭកពីការរៀបការរបស់ប្អូនស្រីគាត់ឡើយ៖ សៀង ចាន់ធី៖ ប្រតិចារឹក ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/394.1** មុនម៉ោង

ដំណើរការរបស់ខ្លួនដែលពោរពេញទៅដោយភាពខុសឆ្គង និងលម្អៀង ដោយសន្និដ្ឋានថា ការរំលោភក្រៅក្របខ័ណ្ឌអាពាហ៍ពិពាហ៍ដែលចោទប្រកាន់ដោយដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន គឺជាទណ្ឌកម្មដោយសារតែគាត់មិនព្រមរៀបការ[2399]។ ការប្រើប្រាស់ការរំលោភតែមួយករណី ដែលប្រព្រឹត្តដោយកម្មាភិបាលមូលដ្ឋាន មកធ្វើជាធាតុផ្សំសត្យានុម័តិនៃឥរិយាបថចេតនារបស់ ប.ក.ក ដើម្បីកំណត់ជាឧក្រិដ្ឋកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការសន្និដ្ឋានដ៏អាម៉ាស់បំផុត។ ម្យ៉ាង មានការទទួលស្គាល់នៅក្នុងកិច្ចពិភាក្សាដេញដោល តាំងពីពេលស៊ើបអង្កេតថា ការរំលោភសេពសន្ថវៈ គឺជាទង្វើដែលត្រូវបានខ្មែរក្រហមផ្ដន្ទាទោស និងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ[2400]។ ម្យ៉ាងទៀត ចំណុចនេះត្រូវបានអង្គជំនុំជម្រះបញ្ជាក់អះអាងដោយខ្លួនឯងផ្ទាល់ ក្នុងសេចក្ដីសម្រេចមួយ ក្នុងពេលជំនុំជម្រះក្ដី[2401]។ ប៉ុន្តែ អង្គជំនុំជម្រះមិនរួញរាក្នុងការប្រើប្រាស់អំពើរំលោភនេះ ដើម្បីបង្ហាញអំពីការបង្ខិតបង្ខំ ដែលផ្ទុះបញ្ចាំងអំពីគោលនយោបាយ ប.ក.ក ស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទោះបីជាករណីនេះជាការផ្ទុះបញ្ចាំងដ៏ល្អបំផុតថា កម្មាភិបាលមូលដ្ឋានមិនគោរពតាមការណែនាំរបស់ ប.ក.ក នៅថ្នាក់កំពូលក៏ដោយ។ ជាជាងការទាញផលវិបាកសមហេតុផល គឺថាមានការប្រាសចាកពីគោលនយោបាយនៅតាមមូលដ្ឋាន អង្គជំនុំជម្រះបែរជាប្រើប្រាស់អង្គហេតុទាំងនេះ ដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទៅវិញ។

១២៦៣. ម្យ៉ាងវិញទៀត ការប្រើប្រាស់ភ័ស្តុតាងក្រៅវិសាលភាព ជាការផ្ទុះបញ្ចាំងអំពីភាពលម្អៀងរបស់អង្គជំនុំជម្រះ គឺថា អង្គជំនុំជម្រះមានចេតនាធ្វើមិនដឹងមិនឮចំពោះការផ្ដល់តម្រុយរបស់សហព្រះរាជអាជ្ញាដល់ដើម បណ្ដឹងរដ្ឋប្បវេណី ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងដោយខ្លួនឯងផ្ទាល់ថា គាត់មិន

09.54.20 មុនម៉ោង 10.48.48 និងម៉ោង 10.50.08 (“រឿងហ្នឹងខ្ញុំមិនសូវច្បាស់ដែរ ព្រោះខ្ញុំនៅតូចដែរ ឮតែជាថាស្នើអង្គការៗ [...] ឮប៉ាខ្ញុំម៉ែខ្ញុំ ឮម្ដាយខ្ញុំថា “គេស្នើបងឯងការ”។ មកសួរម្ដាយខ្ញុំដែរមើលទៅ”)។

[2399] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦២១ (កំណត់សម្គាល់ជើងទំព័រលេខ ១២០៩៤), ៣៦៥៨, ៣៦៩០។

[2400] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៦-១៤២៩ ជាពិសេសកថាខណ្ឌ ១៤២៩ “គោលនយោបាយជាផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ គឺបង្ការបទឧក្រិដ្ឋនេះ និងដាក់ទណ្ឌកម្ម ដល់ចារី”។

[2401] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ **E306** កថាខណ្ឌ ៣។ សូមមើលផងដែរ សារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង០០២/០២ កថាខណ្ឌ ១៧១, ១៩៨-២០០។ សំអាងហេតុសាលក្រម កថាខណ្ឌ ១៨៦-១៨៨។

បានស្តាប់ពួកករណីផ្សេងទៀតស្រដៀងនឹងករណីរបស់គាត់ទេ[2402]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះគួរណាតែយល់ឃើញថា តាមរយៈសក្ខីកម្មនេះ មុំ វុន ត្រូវគេគំរាមសម្លាប់ បើសិនជាគាត់រាយការណ៍អំពីការរំលោភនេះ ដែលបញ្ជាក់ច្បាស់ថានេះគឺជាអំពើដែលរបបនោះហាមឃាត់។ ដូច Kasumi NAKAGAWA បានរំឭក "ការរំលោភសេពសន្ថវៈបែបហ្នឹងគឺជាការរំលោភអំណាច" ពីសំណាក់អាជ្ញាធរដែលត្រូវទទួលទណ្ឌកម្ម[2403]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសទាំងស្រុងខាងអង្គហេតុ និងអង្គច្បាប់ ដោយបានយកបទពិសោធន៍របស់ មុំ វុន មកផ្ទុះបញ្ចាំងអំពីគោលនយោបាយរបស់ ប.ក.ក។ ការប្រើប្រាស់ភ័ស្តុតាងតាមបែបអគតិ បង្ហាញអំពីដំណើរការលម្អៀងរបស់អង្គជំនុំជម្រះក្នុងការវិភាគភ័ស្តុតាងទាំងមូល។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះលើចំណុចនេះ នឹងត្រូវទុកជាមោឃៈ។

១២៦៤. ***<u>កំហុសពាក់ព័ន្ធនឹងករណីជនទទួលបានការអនុគ្រោះច្រើនជាងគេ៖</u>*** ដោយសារតែអង្គជំនុំជម្រះមិនអាចធ្វើមិនដឹងមិនឮទាំងស្រុងចំពោះសក្ខីកម្មរបស់សាក្សី ដែលបានអះអាងថាពួកគេមានសេរីភាពក្នុងការជ្រើសរើសគូស្រករ អង្គជំនុំជម្រះបានសន្និដ្ឋានថា យុទ្ធជនពិការ និងកម្មាភិបាលមួយចំនួន មានសិទ្ធិ

---

[2402] <u>មុំ វុន</u>៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/475.1** ម៉ោង 15.01.27 ម៉ោង 15.16.13 ("ស. [សហព្រះរាជអាជ្ញា] លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី អម្បាញ់មិញ លោកស្រីបាននិយាយថា មុនពេលដែលគេបង្ខំ រៀបការហ្នឹង លោកស្រីបានជំទាស់ម្តងហើយ បន្ទាប់មក មនុស្សប្រាំនាក់មករំលោភលោកស្រីនៅពេលយប់។ [...] អ៊ីចឹងលោកស្រីបានបញ្ជាក់ថា ដោយសារលោកស្រីជំ<u>ទាស់</u>មិនព្រមរៀបការហ្នឹងហើយ បានគេរំលោភលោកស្រី។ អ៊ីចឹង ខ្ញុំសួរលោកស្រីថា ហេតុអ្វី លោកស្រីមានមូលដ្ឋានអ្វីដែលអាចឱ្យលោកស្រីសន្និដ្ឋានថាដោយសារលោកស្រីជំទាស់មិនព្រមរៀបការហ្នឹងហើយ បានគេមករំលោភលោកស្រីហ្នឹង?" "ស. [សហព្រះរាជអាជ្ញា] ឥឡូវខ្ញុំនិយាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកស្រីវិញម្តង លោកស្រីបាននិយាយថាគេរំលោភលោកស្រី<u>ដោយសារ</u>លោកស្រីបាន<u>ជំទាស់</u>មិនព្រមរៀបការ ហើយក្រោយមកគេរំលោភហើយបានគេបង្ខំឱ្យរៀបការទៅ។ ខ្ញុំសួរលោកស្រីថា តើមានស្ត្រី ឬក៏នារីផ្សេងទៀតហ្នឹងត្រូវបានគេរំលោភដែរឬទេ មុននឹងពេលរៀបការហ្នឹង? ឆ. មុននឹងពេលនេះ ដែលគេរំលោភ គឺខ្ញុំដឹង<u>តែខ្លួនខ្ញុំទេ</u> <u>អ្នក</u>ផ្សេងទៀតគឺខ្ញុំអត់ដឹង" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2403] <u>Kasumi NAKAGAWA</u>៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 14.15.32 (តើវាអាចទេថាការរំលោភស្ត្រីពីរនាក់ដែលលោកស្រីនិយាយថា បានបដិសេធមិនព្រមរៀបការហ្នឹង គឺជាការប្រព្រឹត្តរបស់ថ្នាក់ក្រោម ដោយរំលោភទៅលើគោលនយោបាយផ្លូវការ និងសីលធម៌ប្រការ១ ដែលយើងបានពិភាក្សាពាក់ព័ន្ធនឹងបញ្ហារំលោភនេះមែនទេ? ឆ. ចាស គឺពិតណាស់។ ការរំលោភសេពសន្ថវៈបែបហ្នឹងគឺជាការរំលោភអំណាច")។ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦២ (កំណត់សម្គាល់ជើងទំព័រលេខ ១១៩៥៥)។

ពិសេសអាចស្នើសុំរៀបការ ឬត្រូវគេសួរយោបល់មុននឹងរៀបការ។ ករណីនេះមិនបានរារាំងមិនឱ្យអង្គជំនុំជម្រះសន្និដ្ឋានផ្ទុយទៅវិញថា នេះមិនមែនជាការព្រមព្រៀងពិតប្រាកដទេ[2404]។

១២៦៥. ***យុទ្ធជនពិការ៖*** អង្គជំនុំជម្រះបានសន្និដ្ឋានថា គោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលគាំទ្រដោយថ្នាក់ដឹកនាំកំពូល ប.ក.ក ចែងថា ក្នុងក្របខ័ណ្ឌអនុវត្តគោលនយោបាយ យុទ្ធជន ដែលគេចាត់ទុកជាវីរជនសង្គ្រាម ត្រូវរៀបការជាមួយនារីក្មេងៗ ដែលជ្រើសរើសពីក្នុងចំណោមប្រជាជនមូលដ្ឋាន[2405]។ ដើម្បីផ្សារភ្ជាប់ជាមួយ "ថ្នាក់ដឹកនាំកំពូល" អង្គជំនុំជម្រះបានផ្អែកលើសុន្ទរកថាមួយរបស់ ខៀវ សំផន ដោយមិនបញ្ជាក់ច្បាស់ថាតើជាសុន្ទរកថាមួយណាឲ្យប្រាកដ និងទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" ជាច្រើនលេខ ដែលត្រូវបានចាត់ទុកថា "ស៊ីចង្វាក់គ្នា" ជាមួយសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងអំពីករណីយកិច្ចបម្រើជាតិ និងការគោរពអង្គការវិន័យដោយឥតល័ក្ខខ័ណ្ឌ[2406]។ ក៏ប៉ុន្តែ ដូចបានរៀបរាប់លម្អិតខាងលើ អង្គជំនុំជម្រះខកខានមិនបានបំពេញកាតព្វកិច្ច ក្នុងការផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួន ដោយគ្រាន់តែយកករណីទូទៅមកសន្និដ្ឋានថាគ្មានការព្រមព្រៀង ដោយផ្អែកលើមូលដ្ឋាននេះ[2407]។

---

[2404] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០ (កំណត់សម្គាល់ជើងទំព័រលេខ១២៣០៦) ៣៦២៣ និង *ផ្នែក ១៤.៣.៤.៤ បុគ្គលដែលទទួលបានការគិតគូរជាងគេ*។

[2405] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៩០។

[2406] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៩០។ ប្រភពនៃអង្គជំនុំជម្រះ គឺសក្ខីកម្មរបស់ សេង សឿន, ណុប ធីម, ជា ឌៀប, ព្រាប សុខឿន និង ស៊ូ សុធារី។

[2407] ឧទាហរណ៍ សូមមើល៖ ឌុចដែលបានរំឭកពីល័ក្ខខ័ណ្ឌនេះ ប៉ុន្តែមិនដែលបានទទួលស្គាល់ការរៀបអាពាហ៍ពិពាហ៍របស់គាត់ជាការរៀបការដោយបង្ខំទេ <u>ឌុច</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/51.1** ក្រោយម៉ោង 10.15.52 ក្រោយម៉ោង 11.08.32។ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/436.1** ក្រោយម៉ោង 09.45.10។ សេង ស្រ៊ុន បានរៀបការជាមួយគូដណ្តឹងគាត់រួចទៅហើយ ប៉ុន្តែដោយសារការគោរពកិច្ចសន្យានោះ គាត់មិនត្រូវបានអនុញ្ញាតឱ្យរៀបការនៅពេលណាក៏បាននោះឡើយ។ <u>សេង ស្រ៊ុន</u>៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/346.1** ម៉ោង 11.51.47។ សូមមើលផងដែរ <u>Kasumi NAKAGAWA</u>៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** មុនម៉ោង 13.36.24 (រំឭកដល់ល័ក្ខខ័ណ្ឌហាមឃាត់មិនឱ្យរៀបការ នៅកន្លែងខ្លះនៅក្នុងប្រទេស ដូចជានៅកំពង់ចាម គឺតំបន់តែមួយដែល សេង ស្រ៊ុន ធ្លាប់រស់នៅ)។

១២៦៦. អង្គជំនុំជម្រះបានយកសៀវភៅរបស់ សម្តេច សីហនុ មកធ្វើជាធាតុផ្សំនៃភាពស៊ីចង្វាក់គ្នា។ នៅក្នុងសៀវភៅនេះ សម្តេច សីហនុ មានបន្ទូលថា ខៀវ សំផន បាននិយាយអំពីនារីក្មេងៗដែលគេនាំយកមករៀបការជាមួយយោធិនពិការ ក្នុងស្មារតីស្នេហាជាតិ ដោយ "បានយល់ព្រម" ថែទាំវីរជនដែលបានធ្វើពលីកម្មដើម្បីសង្គ្រោះជាតិ[2408]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានអើពើនឹងតម្លៃជាភ័ស្តុតាងតិចតួចនៃរឿងរ៉ាវនេះដែលនិយាយពីអំពើ និងការប្រព្រឹត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខ និងត្រូវបានរៀបចំឡើងក្រៅក្របខ័ណ្ឌតុលាការ។ លើសពីនេះទៀត យោងតាមសេចក្តីថ្លែងការណ៍ពីមុនៗដែលមានលក្ខណៈខុសគ្នា និងប្រែប្រួលមិនឈប់ឈររបស់ សម្តេច សីហនុ អង្គជំនុំជម្រះគួរណាតែវាយតម្លៃភ័ស្តុតាងនេះ ដោយប្រយ័ត្នប្រយែងបំផុត[2409]។ ម្យ៉ាងវិញទៀត និងជាពិសេស អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការប្រើប្រាស់សក្ខីកម្មតាមបែបជ្រើសរើស និងលម្អៀង ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន។ ជាអាទិ៍ អង្គជំនុំជម្រះបានច្រានចោលភ័ស្តុតាងផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួន ដោយគ្មានសំអាងហេតុ។ ជាក់ស្តែង អង្គជំនុំជម្រះមិនបានលើកឡើងអំពីសក្ខីកម្មរបស់ ស៊ូ សុធារី ដែលបានឆ្លើយថា ការរៀបការជាមួយជនពិការមិនមែនជាការរៀបការដោយបង្ខំទេ ឬសក្ខីកម្មរបស់ សេង សឿន ដែលបានដឹងតាមពាក្យចចាមអារ៉ាមអំពីការផ្សំផ្គុំជនពិការ ដោយសារតែពួកគេមានវ័យ "ចាស់" ឬជាចុងក្រោយ សក្ខីកម្មរបស់ ណុប ធីម ដែលត្រូវគេរៀបការជាមួយ ព្រាប កប អតីតទាហានពិការ និងមិនបានប្រកែកទេ ពីព្រោះគាត់យល់ថា "ចាស់ៗ" ហើយ[2410]។

---

[2408] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៨៦។

[2409] នៅក្នុងសម្រង់សម្តីផ្ទាល់របស់ខ្លួន អង្គជំនុំជម្រះបានកត់សម្គាល់នូវបន្ទូលបំផ្លើសរបស់ សម្តេច សីហនុ ជាពិសេសនៅក្នុងការប្រើប្រាស់សំណួនសេចក្តី "រៀបដោយបង្ខំ" ដោយមិនបានចោទសួរខ្លួនឯងថាមានប្រភពចេញមកពីណា។ លើសពីនោះ អង្គជំនុំជម្រះបានកត់សម្គាល់ថា សម្តេច សីហនុ តែងតែមានទម្លាប់អះអាងហើយប្រែក្រឡាស់វិញ ទៅតាមកាលៈទេសៈ។ សេចក្តីសន្និដ្ឋានបញ្ចប់៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E1/234.1** ឯកសារ ចន្លោះម៉ោង 10.58.52 និងម៉ោង 11.01.47 ("យើងឯកភាពគ្នាលើគ្រប់ចំណុចទាំងអស់ ទាំងផ្ទៃក្នុង ទាំងផ្នែកខាងក្រៅ [...] ជាមួយលោក ខៀវ សំផន យើងមើលសហករណ៍ [...] ប៉ុន្តែយើងមើលទៅមិនមានការភ័យខ្លាច"។)។

[2410] <u>ស៊ូ សុធារី</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ម៉ោង 15.47.39។ <u>ណុប ធីម</u>៖ ប្រតិចារឹក ថ្ងៃទី05 ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 15.49.56។

១២៦៧. ប្រសិនបើអង្គជំនុំជម្រះបានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវ លើសក្ខីកម្មទាំងមូលរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះគួរណាតែមើលឃើញថា មានសាក្សី ៤ នាក់ផ្សេងទៀតដែលនិយាយអំពីការរៀបអាពាហ៍ពិពាហ៍ជាមួយយោធិនពិការ[2411]។ ក្នុងចំណោមសាក្សីទាំង ៤ នាក់នេះ សែម អំ បានអះអាងថា គាត់បានឮទាហានម្នាក់ត្រូវគេបង្ខំឱ្យរៀបការ ប៉ុន្តែ ក្រោយមក គាត់បានសង្កេតឃើញថា ប្តីប្រពន្ធថ្មោងថ្មីគូនេះ "អត់មានជំទាស់គ្នា ឈ្លោះគ្នាអីទេ គាត់ស្រឡាញ់គ្នា"[2412]។ ម៉ក់ ឈឿន ជាយោធិនពិការ បានឆ្លើយថា គាត់បានរៀបការជាមួយនារីម្នាក់ដែលគាត់ស្គាល់យូរណាស់មកហើយតាមការព្រមព្រៀងគ្នា[2413]។ ម្យ៉ាងវិញទៀត គាត់បានបញ្ជាក់ថា គាត់មិនបានដឹងពីការរៀបការដោយបង្ខំទេ[2414]។ ចម្លើយទាំងនេះត្រូវគេបំភ្លេចសូន្យឈឹង។ បើពិនិត្យលើភ័ស្តុតាងទាំងមូល អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានគោលនយោបាយរបស់ ប.ក.ក បង្ខំឱ្យស្ត្រីរៀបការជាមួយយោធិនពិការទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយផ្អែកតែលើរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ និងមិនអើពើនឹងភ័ស្តុតាងសេសសល់ផ្សេងទៀត។ សេចក្តីសន្និដ្ឋានទាំងនេះ គ្មានអ្វីក្រៅពីទុកជាមោឃៈនោះឡើយ។

១២៦៨. ***កម្មាភិបាលបុរស៖*** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសន្និដ្ឋានថាទោះបីជាកម្មាភិបាលបុរសខ្លះត្រូវបានអនុញ្ញាតឱ្យជ្រើសរើសគូស្រករក៏ដោយ ក៏នារីត្រូវគេបង្ខំឱ្យរៀបការ ដោយគ្មានសួរនាំ ដោយ

---

[2411] គឺមាន ម៉ាក ឈឿន, សែម អំ, ឱ ហូ និង ជួន ធី នៅក្នុងនោះមានកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលត្រូវបានទទួលយកជាភ័ស្តុតាង សេចក្តី សម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ ឯកសារ **F51/3** នៅទីនេះ ជួន ធី ពន្យល់ពីការរៀបអាពាហ៍ពិពាហ៍ជនពិការ ថាស្ត្រីដែលមិនយល់ព្រមអាចបដិសេធបាន ដោយគ្មានផលវិបាកអ្វីឡើយ កំណត់ហេតុស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស/ធ ១៩១-១៩៨។

[2412] <u>សែម អំ</u>៖ ប្រតិចារឹក ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/478.1** ក្រោយម៉ោង 10.05.48។

[2413] <u>ម៉ាក ឈឿន</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E1/511.1** ម៉ោង 15.54.56 មុនម៉ោង 15.56.45 ("ពេលនោះមិនមានថាស្រឡាញ់អី ទាក់ទងគ្នាអីជានេះទេ ប៉ុន្តែ សួរជាយោបល់ សួរជាអីទៅ ក៏គេឯកភាពទៅ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង អុល ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ **E3/5833** ERN 00408325 (ដូចអង្គជំនុំជម្រះបានលើកឡើងដូច្នោះដែរ គាត់ទទួលបន្ទុកបញ្ជូននារីៗទៅរៀបការជាមួយនឹងយោធា ទោះបីជាគាត់បានបានដឹងច្បាស់ថានារីទាំងនោះស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្តក្តី តែអ្វីដែលច្បាស់នោះគឺថាមិនមាននារីណាបដិសេធឡើយ)។

[2414] <u>ម៉ាក ឈឿន</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E1/511.1** ម៉ោង 11.17.13។

អនុវត្តតាមគោលនយោបាយរបស់ ប.ក.ក[2415]។ អង្គជំនុំជម្រះបានផ្អែកលើការបំភ្លេសក្ដីកម្មរបស់ ប្រាក់ យុត និង ជាម គិន ដើម្បីសន្និដ្ឋានថាគ្មានការយល់ព្រម ឬមានការបង្ខិតបង្ខំជាប្រព័ន្ធឱ្យស្ត្រីរៀបការ[2416]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានលាក់បាំងភ័ស្តុតាងមួយផ្នែកដែលផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួន[2417]។ ដូច្នេះ ចម្លើយទាំងនេះមិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា មានតែកម្មាភិបាលបុរសប៉ុណ្ណោះ

---

[2415] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៩១។

[2416] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៩១ កំណត់សម្គាល់ជើងទំព័រលេខ១២០២៣ ដែលនៅទីនេះអង្គជំនុំជម្រះបានស្រង់សម្ដីតាមចម្លើយរបស់ ប្រាក់ យុត និង ជាម គិន។ កំហុសទីមួយរបស់អង្គជំនុំជម្រះ គឺបានប្រើប្រាស់ភ័ស្តុតាងក្រៅវិសាលភាព ពីព្រោះថាពិធីរៀបការ ប្រាក់ យុត បានប្រព្រឹត្តទៅ នៅឆ្នាំ១៩៧៤ គឺថាស្ថិតនៅក្រៅវិសាលភាពពេលវេលានៃការជំនុំជម្រះ។ បន្ទាប់មក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាថ្មីទៀត ដោយធ្វើមិនដឹងមិនឮសម្ដីរបស់សាក្សីដែលថា គាត់បានបញ្ជាក់ថាបានស្ម័គ្រចិត្តរៀបការ ពីព្រោះគាត់ស្រឡាញ់ប្ដីគាត់ ហើយគាត់បានបន្ថែមថាប្រសិនបើគាត់មិនយល់ព្រម គាត់ប្រាកដជាបដិសេធការរៀបការនោះ៖ <u>ប្រាក់ យុត</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1** មុនម៉ោង 11.12.11 ("ត្រូវតែខ្ញុំសម្រេចចិត្ត ព្រោះខ្លួនខ្ញុំជាស្រី ជៀសយកប្ដីមិនរួច [...] មិនមែនថាគាត់បង្ខំទេទាល់ខ្ញុំស្រឡាញ់ដែរបានយកគ្នាកើត។ អ៊ីចឹងខ្ញុំយកតាមគាត់បណ្ដោយទៅ បើអត់ស្រលាញ់ក៏ខ្ញុំអត់យកដែរ ខ្ញុំប្រកែកហួសបាត់ហើយ តែខ្ញុំស្រឡាញ់គាត់ដែរ។ អ៊ីចឹងគាត់ថា "បើស្រឡាញ់ ខ្ញុំគិតឱ្យ"") ម៉ោង 11.19.18។ ចម្លើយជាលាយលក្សណ៍របស់ ជាម គិន មិនអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះធ្វើសេចក្ដីសន្និដ្ឋានថាជាការរៀបការដោយបង្ខំ នៅក្នុងករណីរបស់គាត់នោះទេ។ ពីព្រោះថា ទោះបីជាមានសំណួរជាក់លាក់ ឬនាំមុខពីសំណាក់អ្នកស៊ើបអង្កេតផងនោះ គាត់គ្រាន់តែឆ្លើយថា៖ "គឺអង្គការជាអ្នករៀបការឱ្យពួកយើង"៖ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជាម គិន ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ ឯកសារ **E3/9524** ស/ឆ ១៣។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយទាញសេចក្ដីសន្និដ្ឋានចេញពីឃ្លាដ៏សាមញ្ញនេះ ថាសេចក្ដីសម្រេចក្នុងការរៀបការត្រូវបានបង្ខំប្រឆាំងនឹងបំណងរបស់គាត់។

[2417] ដូច្នេះ ប្រសិនបើ ប៊ិត ហឿន ដែលបានរៀបការតាមសំណើប្ដីរបស់គាត់ បានពន្យល់ថាគាត់អាចបដិសេធការស្នើរៀបការនោះបាន បានបញ្ជាក់ថាមានមនោសញ្ចេតនាចំពោះប្ដីគាត់ ដូច្នេះគាត់បានយល់ព្រមដោយស្ម័គ្រចិត្ត ដូចស្ត្រីដទៃទៀតនៅក្នុងកងចល័តរបស់គាត់ចំពោះប្ដីពួកគេ៖ <u>ប៊ិត ហឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ម៉ោង 11.19.12 មុនម៉ោង 11.28.21។ ផាន់ ហ៊ីម ដែលធ្វើការនៅក្រសួងពាណិជ្ជកម្ម ដូច ប៊ិត ហឿន ដែរនោះ បានអះអាងថាបានរៀបការទាំងបង្ខំ តែតាមការស្នើរៀបការរបស់ប្ដីគាត់ ខណៈដែលគាត់បានបដិសេធសំណើពីមុនៗតាំងពីឆ្នាំ១៩៧៥៖ <u>ផាន់ ហ៊ីម</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** មុនម៉ោង 10.46.58 និងម៉ោង 15.46.31 និងម៉ោង 14.28.26។ ប៉ុន្តែ គាត់បានបន្ថែមថាករណីគាត់ខុសពីស្ត្រី ២០ នាក់ទៀត ដែលបានរៀបការដោយការស្ម័គ្រចិត្ត៖ <u>ផាន់ ហ៊ីម</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.46.31។ ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/468.1** ម៉ោង 09.42.21។ សក្ខីកម្មទាំងនេះស្របគ្នាទៅនឹងចម្លើយជាលាយលក្សណ៍អក្សររបស់ រស់ ស៊ុយ ដែលបង្ហាញគោលការណ៍ដែលថា ទាំងបុរស ទាំងស្ត្រីអាចជ្រើសរើសប្ដីប្រពន្ធរបស់ខ្លួន។ ប៉ុន្តែគាត់បានពន្យល់ថាភាពរម្យទម និងភាពអៀនប្រៀនរបស់ស្ត្រីដែលមិនមានទម្លាប់រំឭកពីមនោសញ្ចេតនាចំពោះមនុស្សប្រុសដែលរាំងស្ទះដល់ការអនុវត្តពេញលេញនូវសមភាពរវាងបុរស និងស្ត្រី។ គាត់បានបញ្ជាក់ថា បន្ទាប់មក គេក៏បង្កើតជាឱកាសដើម្បីឱ្យបុរស និង

មានសិទ្ធិរៀបការ តាមការជ្រើសរើសរបស់ខ្លួន។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានទាំងនេះនឹងត្រូវទុកជាមោឃៈ។

១២៦៩. ***ការប្រកែកដោយគ្មានគ្រោះថ្នាក់ដល់ខ្លួនត្រូវបានបង្ហាញថាជាករណីលើកលែង៖*** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ករណីប្រកែកដោយគ្មានគ្រោះថ្នាក់ដល់ខ្លួន គឺជាការលើកលែងដោយបានប្រើប្រាស់សក្ខីកម្មរបស់ ឯម ភឿង និង សុន វុត[2418]។ បើតាមអង្គជំនុំជម្រះ បទពិសោធន៍របស់ពួកគេ អាចពន្យល់បានតាមរយៈកាលៈទេសៈពិសេស។ ដូច្នេះ អង្គជំនុំជម្រះបានបំភ្លៃសក្ខីកម្មរបស់ពួកគេ និងបានច្រានចោលភ័ស្តុតាងដោះបន្ទុក ដែលមិនអាចឱ្យសន្និដ្ឋានបែបនេះបានឡើយ។ តាមពិត ឯម ភឿង បានផ្តល់សក្ខីកម្មថា មិត្តភក្តិរបស់គាត់ ជាអតីតព្រះសង្ឃដូចគាត់ដែរ ត្រូវគេបង្ខំឱ្យរៀបការ ពីព្រោះ "ចាញ់បោកគេ"[2419] ដែលបង្ហាញថាអាជ្ញាធរគ្រប់គ្រងមិនបានអនុវត្តតាមវិធាន។ ការអានដោយមិនលម្អៀងនូវសក្ខីកម្មរបស់ សុន វុត ដែលបានបញ្ជាក់ថា គាត់បាន "តវ៉ា" ចំពោះការស្នើរៀបការ ព្រោះតែគាត់វាងនៅក្មេង ក៏មិនគ្រប់គ្រាន់ឱ្យសន្និដ្ឋានថា ការប្រកែករបស់គាត់ស្ថិតក្នុងកាលៈទេសៈពិសេសនោះដែរ។ សាក្សីនេះមិនអាចនិយាយអំពីអ្វីដែលអ្នកផ្សេងបានធ្វើ ឬតើពួកគេបាន "តវ៉ា" ឬអត់[2420]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញការសន្និដ្ឋានតាមផ្លូវកាត់។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ថា សាក្សី ដែលបានអះអាងថាត្រូវគោរពតាមការណែនាំរបស់អាជ្ញាធរ ដោយគិតថាគ្មានជម្រើសផ្សេង បានប្រកែកមិនព្រមរៀបការជាច្រើនដងជាមួយ

---

ស្ត្រីបានជួបគ្នា៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី រស់ ស៊ុយ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៥ E3/10620 ស/ឆ ៧៥។ ទាំងនេះត្រូវគ្នានឹងវប្បធម៌ខ្មែរដែលមានការរិតត្បិតដល់ការប្រព្រឹត្តរបស់ស្ត្រី។ សូមមើលផងដែរ កំណត់ហេតុស្តាប់ចម្លើយសាក្សី កែវ ធារី ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E3/9662 ស/ឆ ៨០-៨២ (ប្រសិនបើបុរសម្នាក់ចង់រៀបការនឹងស្ត្រី ម្នាក់ គាត់អាចស្នើសុំរៀបការ ហើយ "បើស្ត្រីណាធ្វើអ៊ីចឹង គេថាស្ត្រីនោះចង់បានប្តី")។

[2418] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦២៥។

[2419] ឯម ភឿង៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/263.1 ក្រោយម៉ោង 13.43.08។

[2420] សុន វុត៖ ប្រតិចារឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ E1/411.1 ម៉ោង 14.40.20 "(ខ្ញុំក៏ត្រូវឈ្មោះរៀបការដែរ។ ប៉ុន្តែខ្ញុំចេះតវ៉ានៅអង្គការបាន ផុតពីនោះគេអត់តវ៉ាបាន ខ្ញុំតវ៉ាបាន បានគេថាអង្គការទៅចុះ! [...] ខ្ញុំនៅវាងក្មេងផង ដូចថាគេរៀបឱ្យរបបកាលនោះ សម័យគេហៅថាមានរបប គឺគេត្រូវរៀប ដល់គេរៀបអាយុចាប់ពី៣០ណោះ មិនមែនរៀបតែអាយុ២៥, ២៦ បានទេ។ កាលសម័យនោះ គឺចាប់ពី៣០ឡើងបាទ នារីក៏ដូចគ្នា យ៉ាងអន់ក៏ ២៨ ទៅ ២៩ បានអាចយកគ្រួសារបាន"។ យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

មនុស្សផ្សេងៗគ្នា ដោយគ្មានគ្រោះថ្នាក់ដល់ខ្លួន[2421]។ ការប្រកែកច្រើនដង និងកាលៈទេសៈដែលបាន លើកឡើងនៅក្នុងរឿងរ៉ាវផ្សេងៗគ្នា អាចឱ្យសន្និដ្ឋានថាមានសម្ពាធសង្គមកើតចេញពីទស្សនៈ អវិជ្ជមាននៃការនៅលីវយូរក្នុងសង្គមខ្មែរ ជាជាងថាមានគោលនយោបាយស្តីពីការរៀបអាពាហ៍ ពិពាហ៍ដោយបង្ខំ។

១២៧០. ជាចុងក្រោយ ការរៀបការ ដោយគ្មានការព្រមព្រៀងពិតប្រាកដពីសាមីខ្លួនទាំងសងខាង តាមការស្នើពី ភាគីតែម្ខាង ឬតាមការផ្សំផ្គុំពីប្រធានរបស់ពួកគេ គួរណាតែនាំឱ្យអង្គជំនុំជម្រះយល់ឃើញថា នេះជា ការរំលោភលើបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ត្រង់ចំណុចនេះទៀត បញ្ហាភាពជាតំណាងនៃ រឿងរ៉ាវដែលបានទទួលយក និងភ័ស្តុតាងដោះបន្ទុកដែលត្រូវបានបំភ្លេចចោល ចោទជាបញ្ហាពិតប្រាកដ ក្នុងការវិភាគរបស់អង្គជំនុំជម្រះទៅលើភ័ស្តុតាង។ ការជំទាស់តវ៉ានឹងអត្ថិភាពនៃវិធាន ពីព្រោះវាត្រូវ បានរំលោភបំពាន មិនមែនជាសេចក្តីសន្និដ្ឋានសមហេតុផលទេ។

- **<u>ការលាក់បាំងនូវការអនុវត្តប្រាសចាសពីបទបញ្ញា</u>**

១២៧១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានបំភ្លេចចោលឯកសារនយោបាយរបស់ ប.ក.ក ដែលដាស់តឿនដល់កម្មាភិបាលអំពីភាពចាំបាច់ក្នុងការគិតគូរដល់សេចក្តីត្រូវការរបស់ប្រជាជន ក្រោម

---

[2421] ហេង ឡៃហ៊ាង៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/4761** មុនម៉ោង 13.46.12 មុនម៉ោង 13.47.34 (អាច បដិសេធការស្នើរៀបការមុនៗដោយគ្មានបញ្ហា) ម៉ោង 13.40.14 (នៅមូលដ្ឋាន មានភាពខុសគ្នា គេសួរយោបល់ប្រជាជនជាមុន)។ ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ក្រោយម៉ោង 13.51.02 (អាចបដិសេធការស្នើរៀបការ មុនៗ) ម៉ោង 15.25.53 (ថ្នាក់លើមិនបានគំរាមដល់ការស្នើរៀបការចុងក្រោយ)។ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** មុនម៉ោង 09.44.10 និងមុនម៉ោង 09.47.55។ ផាន់ ហ៊ីម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 14.28.26 ("តាំងពី៧៥ រហូត ខ្ញុំប្រកែកគាត់រហូត ទាល់តែដល់៧៨ហ្នឹង គឺប្រកែកគេលែងបាន។ ខ្ញុំចង់តែនៅម្នាក់ឯង ខ្ជិលចង់ យកគ្រួសារ ខ្ញុំចេះតែប្រកែករហូតទៅ។ ទៅដល់ថ្ងៃហ្នុង គឺខ្ញុំប្រកែកទៅ គេសង្កត់ជាប់")។ ធុច ស៊ីថន៖ ប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/500.1** បន្ទាប់ពីម៉ោង 14.59.13 (គាត់សម្រេចចៀសមិនរៀបការជាមួយនឹងអ្នកមិនចេះអក្សរ "ខ្ញុំអត់មាន សិទ្ធិជ្រើសរើសមនុស្សល្អ មនុស្សដែលខ្ញុំស្រឡាញ់។ ខ្ញុំសុខចិត្តការជាមួយគាត់ចុះ ព្រោះគាត់ជាអ្នកបញ្ញាជន")។

ការគ្រប់គ្រងរបស់ខ្លួន ដើម្បីគោរពតាមមាគ៌ាកសាងបក្ស[2422]។ ក៏ប៉ុន្តែ ការទិតៀនចំពោះកម្មាភិបាលដែលមិនបានគោរពតាមការណែនាំទាំងនេះបង្ហាញថា ផ្ទុយពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះ មាគ៌ារបស់ ប.ក.ក មិនត្រូវបានអនុវត្តឱ្យបានត្រឹមត្រូវទេ។

១២៧២. បញ្ហាអនុវត្តបទបញ្ជាត្រូវបានអតីតកម្មាភិបាលខ្មែរក្រហមបញ្ជាក់យ៉ាងច្បាស់។ ជាក់ស្តែង ពេជ្រ ជឹម បានទទួលស្គាល់ថា "អ្នកខ្លះមិនបាននាំឱ្យគេជ្រះស្រឡះអ៊ីចឹង ចេះតែនិយាយកាត់ៗទៅ វាកើតមានទំនាស់"[2423]។ ម៉ឹង វេត បានរំលេចឱ្យឃើញបញ្ហាសំខាន់មួយរបស់របបនោះ៖ "បុគ្គលអង្គភាពមួយៗ ដូចថាវាទៅជាផ្សេងៗគ្នា ចង់និយាយប្រជុំទៅ [...] ចេញទៅវិញខុសគ្នាទាំងអស់"[2424]។ នេះជាចំណុចមួយ ដែលមេធាវីការពារក្តីតែងតែលើកឡើងមិនឈប់ឈរ ក្នុងពេលជំនុំជម្រះក្តី ដូចបានបង្ហាញនៅក្នុងសវនាការសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១[2425]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានដោះស្រាយចំណុចដ៏សំខាន់នេះ ពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងផ្សេងគ្នាៗនូវគោលនយោបាយ។ និយាយឱ្យចំតែម្តង គឺករណីនៃបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះបានទាញហេតុផលខុស ដោយមិនបានប្រៀបធៀបរឿងរ៉ាវនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាមួយនឹងភស្តុតាងទាំងមូល មុននឹងទាញសេចក្តីសន្និដ្ឋានជារួមលើគោលនយោបាយរដ្ឋ។

- <u>ស្ថិតិនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងសំណុំរឿងទាំងមូល</u>

---

[2422] ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/732** ERN 00064290-00064295។ លក្ខន្តិកៈ ប.ក.ក នៅឆ្នាំ១៩៧១ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៧២ ឯកសារ **E3/8380** ERN 00283541-42 (លក្ខណៈវិនិច្ឆ័យនៃអ្នកដឹកនាំល្អ សម្រាប់ការកសាងការងារបក្សដឹកនាំ)។

[2423] <u>ពេជ្រ ជឹម</u>៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ **E1/290.1** ចាប់ពីម៉ោង 13.47.11. សូមមើលផងដែរ <u>ឱ ហួ</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ **E1/301.1** ម៉ោង 13.56.03 (នៅពេលសង្គ្រាមមិនទាន់ចប់ អង្គការមិនអនុញ្ញាតឱ្យរៀបការឡើយ ពីព្រោះអង្គការត្រូវការបុរស និងស្ត្រីដើម្បីប្រយុទ្ធ)។ <u>Kasumi NAKAGAWA</u>៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** មុនម៉ោង 13.36.24 (រំឭកពីការដល់ការហាមឃាត់ការរៀបចំអាពាហ៍ពិពាហ៍ចំពោះអ្នកណាម្នាក់ រហូតដល់ពេលណាមួយជាក់លាក់)។

[2424] <u>ម៉ឹង វេត</u>៖ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E1/449.1** ម៉ោង 11.05.20 មុនម៉ោង 11.02.05។

[2425] សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E1/234.1** ម៉ោង 14.00.20។

១២៧៣. ក្រៅពីកំហុសដូចបានរៀបរាប់លម្អិតខាងលើ ក្នុងការពិនិត្យភ័ស្តុតាងដែលអង្គជំនុំជម្រះបានផ្អែកជាមូលដ្ឋាន វិធីសាស្ត្រទូទៅនៃភ័ស្តុតាងកើតចេញពីដំណើរការខុសឆ្គងដែលធ្វើឱ្យប៉ះពាល់ដល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ។ ជាការពិត គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយផ្អែកជាសំខាន់លើរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានជ្រើសរើសជាពិសេស ឱ្យរៀបរាប់អំពីបទពិសោធន៍ភ័យរន្ធត់ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍របស់ពួកគេឡើយ។ វិធីសាស្ត្រមិនលម្អៀងគួរណាតែនាំឱ្យអង្គជំនុំជម្រះពិនិត្យភ័ស្តុតាងទាំងមូល ពីព្រោះចំនួននៃការរៀបចំពាហ៍ពិពាហ៍ដោយបង្ខំ មិនគ្រប់គ្រាន់ឱ្យបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយរបស់ ប.ក.ក ក្នុងន័យនេះទេ។ វិធីសាស្ត្រស្ថិតិគួរតែយកមកអនុវត្ត។

១២៧៤. **<u>វគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍</u>៖** គួរកត់សម្គាល់ថា បុគ្គលទាំងអស់ដែលត្រូវបានកោះហៅឱ្យមកផ្ដល់សក្ខីកម្ម នៅវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ បានលើកឡើងអំពីបទពិសោធន៍ផ្ទាល់ខ្លួននៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១៤ នាក់ ទាំងអស់គ្នាបានឆ្លើយថាពួកគាត់បានរៀបការទាំងទើសទាល់ និង/ឬដោយបង្ខំ នៅក្នុងរបបនោះ ថ្វីត្បិតតែ ៧ នាក់ ក្នុងចំណោមនោះ បានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀងគ្នា របស់គូផ្សេងទៀតក៏ដោយ។ ដូច្នេះ នៅក្នុងវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១00% បានរៀបការដោយបង្ខំ ហើយ ៥0% បានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀងរបស់គូផ្សេងទៀត[2426]។

១២៧៥. **<u>សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ក្រៅពីវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍</u>៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ៨0 នាក់ ដែលបានផ្ដល់សក្ខីកម្ម ក្រៅពីវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ ៣១ នាក់ បានឆ្លើយថាពួកគេបានរៀបការ ក្នុងរបបនោះ។ ក្នុងចំណោមបុគ្គលទាំង ៣១ នាក់នេះ មានតែ ៦ នាក់ប៉ុណ្ណោះ ដែលបានឆ្លើយថាត្រូវគេបង្ខំឱ្យរៀបការ។ ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ១៩%

[2426] សូមមើលឧបសម្ព័ន្ធ ខ៣ និង ខ៥។

ទល់នឹង ការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ៥៥% ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ១៣% និងការរៀបអាពាហ៍ពិពាហ៍ដោយគ្មានបញ្ជាក់ប្រភេទ ១៣%[2427]។ ជាក់ស្តែង ក្នុងចំណោមសាក្សីដែលត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មលើប្រធានបទផ្សេងៗ យើងមានការយល់ឃើញអំពីការអនុវត្តបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ ខុសពីវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍។

១២៧៦. **<u>សក្ខីកម្មសរុប ក្នុងសំណុំរឿង ០០២/០២</u>៖** ប្រសិនបើយើងធ្វើការគណនាឡើងវិញ ដោយគិតចំនួនសាក្សីទាំងអស់ ដែលបានមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ ទាំងមូល រួមទាំងសាក្សីក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ច្បាស់ណាស់យើងនឹងទទួលបានតួលេខផ្សេង។ ក្នុងចំណោមសាក្សីទាំងអស់ដែលបានមកផ្តល់សក្ខីកម្ម ក្នុងសំណុំរឿង ០០២/០២ សាក្សី ៩៤ នាក់ បានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2428]។ ក្នុងចំណោមសាក្សីទាំង ៩៤ នាក់នេះ ៤៥ នាក់ បានរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្មើនឹង ៤៨% នៃសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងពីការរៀបអាពាហ៍ពិពាហ៍។ ក្នុងចំណោមបុគ្គលទាំង ៤៥ នាក់ ដែលបានរៀបអាពាហ៍ពិពាហ៍ ក្នុងរបបនោះ ២០ នាក់ បានអះអាងថាបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ក្នុងនោះ ១៤ នាក់ ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍)។ ក្នុងចំណោមបុគ្គលទាំង ២០ នាក់ ដែលបាននិយាយអំពីបទពិសោធន៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួន ៧ នាក់ បានទទួលស្គាល់ថាបានឃើញការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ឬដឹងថាអ្នកផ្សេងអាចប្រកែកបាន[2429]។ ដូច្នេះ តួលេខទាំងនេះបង្ហាញថា មិនមានការអនុវត្តដូចគ្នានូវបទបញ្ជា

---

[2427] ក្នុងចំណោមអ្នកខ្លះដែលបានបញ្ជាក់ថាបានរៀបការដោយស្ម័គ្រចិត្ត ឬដោយគ្មានបញ្ជាក់ពីប្រភេទនៃអាពាហ៍ពិពាហ៍ ក៏បានរំឭកផងដែរពីបទពិសោធន៍ផ្សេងៗសម្រាប់មនុស្សផ្សេងទៀត។ សូមមើលឧបសម្ព័ន្ធ ខ៣ និង ខ៦។

[2428] សូមមើលឧបសម្ព័ន្ធ ខ៣, ខ៥ និង ខ៦។

[2429] ករណីសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងផ្នែកទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដែលបានរំឭកអំពីការរៀបការដោយការយល់ព្រមគ្នាទៅវិញទៅមក៖ <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ម៉ោង 10.38.51។ <u>យស ផល</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 09.59.50 ម៉ោង 10.39.47 ម៉ោង 11.10.50។ <u>សេង សឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** ក្រោយម៉ោង 10.01.07 ក្រោយម៉ោង 15.01.17។ <u>ជា ឌៀប</u>៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ក្រោយម៉ោង 15.10.29។ <u>ផាន់ ហ៊ីម</u>៖ ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E1/468.1 ចាប់ពីម៉ោង 09.41.06។ <u>ណុប ងីម</u>៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** មុន

ស្តីពីការរៀបអាពាហ៍ពិពាហ៍ទេ។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានគោលនយោបាយទូទៅស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបង្កើតឡើង និងគាំទ្រដោយថ្នាក់ដឹកនាំ ប.ក.ក នោះឡើយ។

១២៧៧. ***ចម្លើយជាលាយលក្ខណ៍អក្សរ៖*** ចម្លើយជាលាយលក្ខណ៍អក្សរមានតម្លៃជាភ័ស្តុតាងតិចតួច ដោយសារតែភាគីគ្មានលទ្ធភាពសួរដេញដោលសាក្សី។ ប៉ុន្តែ ប្រសិនបើអង្គជំនុំជម្រះយកចម្លើយជាលាយលក្ខណ៍អក្សរមកធ្វើជាធាតុផ្សំនៃភាពស៊ីចង្វាក់គ្នា អង្គជំនុំជម្រះគួរណាតែពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ។ ឯកសារប្រភេទនីមួយៗនឹងត្រូវពិនិត្យ គឺប្រតិចារឹកសំណុំរឿង ០០២/០១ ដែលមានតម្លៃជាកំណត់ហេតុក្នុងសំណុំរឿង ០០២/០២ កំណត់ហេតុគាំទ្រដល់ដីកាដំណោះស្រាយ និងកំណត់ហេតុមកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលត្រូវបានសហព្រះរាជអាជ្ញាស្នើសុំដាក់បញ្ចូលជាភ័ស្តុតាង។ ***ប្រតិចារឹកសំណុំរឿង ០០២/០១៖*** ក្នុងចំណោមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ១៦ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងសំណុំរឿង ០០២/០១, ៧ នាក់ បានរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមបុគ្គលទាំង ៧ នាក់នេះ ២ នាក់គត់ បានឆ្លើយថាបានរៀបការដោយបង្ខំ។ ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ២៩% ទល់នឹងការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ៧១%[2430]។ ***កំណត់ហេតុគាំទ្រដល់ដីកាដំណោះស្រាយ៖*** ក្នុងចំណោមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ១១៥ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ៥៦ នាក់ បានរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមបុគ្គលទាំង ៥៦ នាក់នេះ ២០ នាក់ បានឆ្លើយថាបានរៀបការដោយបង្ខំ។ ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ៣៤% ទល់នឹងការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ២៩% ស្មើនឹង ១៦ នាក់ ការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ៣០% ស្មើនឹង ១៧ នាក់ ការរៀបអាពាហ៍ពិពាហ៍ដោយគ្មានបញ្ជាក់ប្រភេទ ៥% ស្មើនឹង ៣ នាក់ និងការរៀបអាពាហ៍ពិពាហ៍ក្រៅយុត្តាធិការពេលវេលា ២% ស្មើនឹងម្នាក់[2431]។ ***កំណត់ហេតុមកពីសំណុំរឿង ០០៣-០០៤៖*** ក្នុងចំណោមសាក្សីទាំង ៨៦ នាក់ ដែលបានលើកឡើងអំពីបញ្ហារៀបអាពាហ៍

---

ម៉ោង 11.18.46 ម៉ោង 13.39.16។ ហេង ឡៃហ៊ាង៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** ម៉ោង 13.40.14 ក្រោយម៉ោង 13.42.04។

[2430] សូមមើលឧបសម្ព័ន្ធ ខ៣ និង ខ៧។

[2431] ឧបសម្ព័ន្ធ ខ៣ និង ខ៨។ ក្នុងចំណោមអ្នកខ្លះដែលបានបញ្ជាក់ថាបានរៀបការដោយស្ម័គ្រចិត្ត ឬដោយគ្មានបញ្ជាក់ពីប្រភេទនៃអាពាហ៍ពិពាហ៍ ក៏បានរំឭកផងដែរពីបទពិសោធន៍ផ្សេងៗសម្រាប់មនុស្សផ្សេងទៀត។

ពិពាហ៍ ៤៥ នាក់ បានរៀបអាពាហ៍ពិពាហ៍ក្នុងរបបនោះ និង ២៩ នាក់ ឆ្លើយថាបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ស្មើនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ៦៥% ទល់នឹងការរៀបអាពាហ៍ពិពាហ៍តាមការព្រមព្រៀង ៣៣% និងការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ២%[2432]។ ភាពខុសគ្នានៃភាគរយជាមួយចម្លើយប្រភេទផ្សេងទៀតមានភាពគួរឱ្យចាប់អារម្មណ៍។ ត្រង់ចំណុចនេះទៀត បញ្ហានៃការជ្រើសរើសលម្អៀងនៃកំណត់ហេតុទាំងនេះ គឺជាប៉ារ៉ាម៉ែត្រដែលគួរណាត្រូវយកមកពិចារណា។ ជាការពិត គួររំឭកថា កំណត់ហេតុទាំងនេះត្រូវបានដាក់បញ្ចូលជាភ័ស្តុតាង តាមសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីគាំទ្រដល់ការយល់ឃើញថាមានគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ម្យ៉ាងវិញទៀត សំណួរនាំមុខរបស់អ្នកស៊ើបអង្កេត និងអលទ្ធភាពក្នុងការសួរដេញដោលសាក្សីអាចឱ្យផ្តល់តម្លៃជាភ័ស្តុតាងតិចតួចបំផុតដល់កំណត់ហេតុទាំងនេះ[2433]។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមិនអាចផ្អែកលើរឿងរ៉ាវដែលត្រូវបានជ្រើសរើសជាពិសេស សម្រាប់គាំទ្រដល់ការយល់ឃើញរបស់សហព្រះរាជអាជ្ញា រួចទាញសេចក្តីសន្និដ្ឋានជារួមអំពីគោលនយោបាយរបស់ ប.ក.ក ដោយមិនបានប្រៀបធៀបជាមួយភ័ស្តុតាងទាំងមូល នោះឡើយ។

---

2432 ឧបសម្ព័ន្ធ ខ៣ និង ខ៩។ ក្នុងចំណោមអ្នកខ្លះដែលបានបញ្ជាក់ថាបានរៀបការដោយស្ម័គ្រចិត្ត ឬដោយគ្មានបញ្ជាក់ពីប្រភេទនៃអាពាហ៍ពិពាហ៍ ក៏បានរំឭកផងដែរពីបទពិសោធន៍ផ្សេងៗសម្រាប់មនុស្សផ្សេងទៀត។

2433 ជាឧទាហរណ៍ សូមមើល៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី ឈួម សារឿន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៤ ឯកសារ **E3/9578** ស/ផ ២៦ (“តើលោកដឹងអ្វីខ្លះអំពីការរៀបការដោយបង្ខំនៅក្នុងតំបន់របស់លោករស់នៅ?”)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហង់ ហោន ឯកសារ **E3/9518** ស/ផ ៤។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហោម ទន់ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ឯកសារ **E3/9486** ស/ផ ៨៩-៩១។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ហេង មី ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E3/9800** ស/ផ ១៨៥-១៨៦ (“អ្នកខ្លះគេបង្ខំឱ្យរៀបការ តើលោកដឹងទេថាហេតុអ្វីបានជាត្រូវគេបង្ខំឱ្យរៀបការ?”)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ខឹម ស៊ន ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ **E3/9747** ស/ផ ៩៦។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត យី ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ **E3/9832** ស/ផ ២៨២-២៨៥ (សំណួរនាំមុខរបស់អ្នកស៊ើបអង្កេតដែលលើកឡើងតែពីអាពាហ៍ពិពាហ៍ដោយបង្ខំ)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ឹម ពុំ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ **E3/9510** ស/ផ ១៧, ២២-២៣, ៥៦-៦០។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ែន ថុល ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E3/9775** ស/ផ ២៣។ កំណត់ហេតុស្តាប់ចម្លើយសាក្សី សេក សម្អាត ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E3/10783** ស/ផ ៨១,៨៤។ កំណត់ហេតុស្តាប់ចម្លើយសាក្សី សោម វណ្ណា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ **E3/9825** ស/ផ ៨១-៨២, ៩១-៩២។

១២៧៨. ការប្រៀបធៀបស្ថិតិទាំងមូល និងភាគរយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលសាក្សី ព្រមទាំងដើមបណ្ដឹងរដ្ឋប្បវេណី បានលើកឡើង ទោះជាបានផ្ដល់សក្ខីកម្មក្នុងវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ ឬលើអង្គហេតុផ្សេងទៀត មានភាពខុសគ្នាយ៉ាងខ្លាំង[2434]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងវិធីសាស្ត្របង្ហាញភស្តុតាង ដែលធ្វើឱ្យសេចក្ដីសន្និដ្ឋានរបស់ខ្លួនមានភាពខុសឆ្គង។ អង្គជំនុំជម្រះមិនអាចផ្អែកតែទៅលើសក្ខីកម្ម ក្នុងវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ ដើម្បីសន្និដ្ឋានថាមានគោលនយោបាយទូទៅនៅទូទាំងប្រទេស បានទេ ខណៈដែលសាក្សីជាច្រើនបានពន្យល់អំពីខ្លឹមសារពិតប្រាកដនៃបទបញ្ជារបស់ ប.ក.ក។ តាមរយៈដំណើរការបែបជ្រើសរើស និងលម្អៀង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ការអនុវត្តប្រាសចាកពីបទបញ្ជា គឺជាគោលនយោបាយដែលកម្ពុជាប្រជាធិបតេយ្យចង់បាន។ នេះគឺជាមូលហេតុនៃការបំភ្លៃ និងលាក់បាំងភស្តុតាងផ្ទុយ។

- **<u>អ្នកជំនាញ</u>**

១២៧៩. ភាពលម្អៀងរបស់អង្គជំនុំជម្រះរឹតតែស្ដែងឱ្យឃើញច្បាស់ក្រឡែត នៅក្នុងសំអាងហេតុ ដែលបដិសេធសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញពីររូប។ អ្នកជំនាញ Peg LEVINE ដែលបានពន្យល់អំពីរបៀបអនុវត្តវិធីសាស្ត្រគ្មានបុរេវិនិច្ឆ័យ និងការស្មានទុកជាមុន អំពីប្រភេទនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងដំណើរការជាលក្ខណៈវិធីសាស្ត្រ បានបញ្ជាក់ច្បាស់នៅក្នុងសវនាការថា៖ "បើយើងមើលពីទំនោរ ឬក៏អំពីការសន្និដ្ឋានអំពីការបង្ខំនៅក្នុងរបប ឬក៏នៅក្នុងពេលវេលាកម្ពុជាប្រជាធិបតេយ្យ គឺថា ខ្ញុំឆ្លើយថាមិនមានទេ"[2435]។ ដោយអនុវត្តវិធីសាស្ត្រផ្សេង ពីព្រោះការស្រាវជ្រាវរបស់គាត់ផ្ដោតលើអំពើហិង្សាផ្លូវភេទ Kasumi NAKAGAWA បានធ្វើការសន្និដ្ឋានស្រដៀងគ្នា ដោយបញ្ជាក់ថា គាត់ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា មានគោលនយោបាយនៅថ្នាក់លើ ឱ្យរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ទោះបីជាមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងខេត្តភាគច្រើនក៏ដោយ[2436]។ អ្នកជំនាញទាំង

---

[2434] ឧបសម្ព័ន្ធ ខ៣ និង ខ៥ ដល់ខ៩។

[2435] <u>Peg LEVINE</u>៖ ប្រតិចារឹក ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/481.1** ម៉ោង 10.43.26។

[2436] <u>Kasumi NAKAGAWA</u>៖ ប្រតិចារឹក ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/472.1** មុនម៉ោង 13.56.29 (ការស្រាវជ្រាវរបស់គាត់មិនបានគិតដល់ឯកសារនយោបាយ ឬឯកសារដទៃទៀតដែលមាន) ក្រោយម៉ោង 15.05.21។ អង្គជំនុំជម្រះបានទទួលស្គាល់ថា

នេះ ដែលបានធ្វើការសិក្សាតាមលក្ខណៈវិទ្យាសាស្ត្រ បានអនុវត្តវិធីសាស្ត្រសត្យានុម័តិ ដែលអង្គជំនុំជម្រះខកខានមិនបានអនុវត្ត ខណៈដែលបើយោងតាមតួនាទីរបស់ខ្លួនជាថៅក្រម អង្គជំនុំជម្រះគួរណាតែមានភាពម៉ឺងម៉ាត់ជាងនេះ។

១២៨០. ការប្រៀបធៀបភ័ស្តុតាងទាំងអស់ ក្នុងសំណុំរឿងទាំងមូល មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ករណីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលខ្លួនយល់ថាកើតឡើងមែន ស្ថិតក្រោមគោលនយោបាយចេតនារបស់មេដឹកនាំ ប.ក.ក នោះឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានអនុវត្តវិធីសាស្ត្រលម្អៀង និងជ្រើសយកតែភ័ស្តុតាងដាក់បន្ទុក ដើម្បីទាញសេចក្តីសន្និដ្ឋាន ដែលនឹងត្រូវទុកជាមោឃៈទាំងស្រុង រួមទាំងការផ្តន្ទាពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍[2437]។

## ផ្នែកទី ២. ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

### ១. កំហុសពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃការរំលោភសេពសន្ថវៈដែលប្រព្រឹត្ត ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

### ១.១. គ្មានការវិភាគទៅលើលក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ

១២៨១. អង្គជំនុំជម្រះមិនបានអនុវត្តលក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការនោះទេ។ ដើម្បីកំណត់អង្គហេតុនៃរឿងក្តីថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត អង្គជំនុំជម្រះបានយកនិយមន័យនៃការរំលោភសេពសន្ថវៈ ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦ ដើម្បីកំណត់ចរិតលក្ខណៈនៃឧក្រិដ្ឋកម្ម[2438]។ ដូចបានបញ្ជាក់ពីខាងលើ យោងតាមសាលដីកា សំណុំ

---

NAKAGAWA បានធ្វើតាមវិធីសាស្ត្រម៉ឺងម៉ាត់នៅក្នុងការស្រាវជ្រាវរបស់គាត់ និងមានចំណេះដឹងឯកទេសនៅក្នុងពេលលោកស្រីផ្តល់សក្ខីកម្ម សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៣៣។

[2437] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០-៣៦៩១, ៣៦៩៣, ៤២៩៣-៤២៩៤, ៤៣០៧, ៤៣៧០, ៤៤០០, ៤៤០២។

[2438] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៣១។ សាលក្រម ឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦២។

រឿង ០០២/០១ ថ្វីត្បិតតែពុំមានលក្ខខ័ណ្ឌតម្រូវថា អំពើប្រព្រឹត្តជាក់លាក់ត្រូវតែជាបទល្មើស តាមនីតិព្រហ្មទណ្ឌអន្តរជាតិ គេត្រូវកំណត់ទំនាក់ទំនងពិតប្រាកដរវាងសិទ្ធិ និងបម្រាម ដូចមានចែងនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សជាធរមាន ក្នុងអំឡុងពេលពាក់ព័ន្ធនឹងបទចោទនៃអំពើអមនុស្សធម៌ផ្សេងទៀត[2439]។ ដោយលើកឡើងអំពីនិយមន័យនៃការរំលោភសេពសន្ថវៈ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ អង្គជំនុំជម្រះយល់ថា ខ្លួនមិនចាំបាច់ធ្វើការវិភាគលើលក្ខខ័ណ្ឌនេះទេ[2440]។

១២៨២. ប៉ុន្តែ ខៀវ សំផន មិនត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈនោះទេ គឺពីបទអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរំលោភសេពសន្ថវៈ **<u>ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ</u>**។ បរិបទនេះត្រូវបានអង្គជំនុំជម្រះលាក់បាំងទាំងស្រុង ក្នុងការវិភាគរបស់ខ្លួន ហើយគ្មានការស្រាវជ្រាវស៊ីជម្រៅណាមួយត្រូវបានធ្វើឡើងឡើយ។ ផ្ទុយទៅវិញ បរិបទនេះត្រូវតែយកមកពិចារណា ក្នុងការកំណត់បទឧក្រិដ្ឋ ពីព្រោះវាមានផលប៉ះពាល់ផ្ទាល់ទៅលើធាតុផ្សំ។ ជាថ្មីម្តងទៀត ការកំណត់ចរិតលក្ខណៈអំពើអមនុស្សធម៌ផ្សេងទៀត ទាមទារឱ្យមានការវិភាគតាមផ្លូវច្បាប់ម៉ឺងម៉ាត់ ហើយចាំបាច់ត្រូវស្រាវជ្រាវលើសិទ្ធិ និងបម្រាម ដែលមានចែងក្នុងលិខិតុបករណ៍អន្តរជាតិនៅសម័យនោះ។ ការវិភាគដោយប្រយ័ត្នប្រយែងនេះមានគោលដៅមិនធ្វើឱ្យប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាព[2441]។ គួរឱ្យភ្ញាក់ផ្អើលណាស់ដែលយើងមើលឃើញថា ទាំងចំពោះអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទាំងចំពោះអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះមិនបានធ្វើការវិភាគបែបនេះទាល់តែសោះ ខណៈដែលខ្លួនបានធ្វើ នៅក្នុងក្របខ័ណ្ឌនៃសាលក្រមសំណុំរឿង ០០២/០១។

១២៨៣. ជាក់ស្តែង ដើម្បីកំណត់ធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំ អង្គជំនុំជម្រះបានផ្អែកលើនិយមន័យឥរិយាបថ ដែលបានដកស្រង់ចេញពីរឿងក្តីកាត់ទោសថៅក្រម នៅទីក្រុង Nuremberg លក្ខន្តិកៈទីក្រុងរ៉ូម និង

[2439] សាលដីកា សំណុំរឿង០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៨៤។ សូមមើលខាងលើ កថាខណ្ឌ ៦៦៦-៦៧១។

[2440] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៣១។ យោងទៅកំណត់សម្គាល់ជើងទំព័រលេខ២២៣៦៖ សាលក្រម ឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦២។

[2441] សូមមើលខាងលើ កថាខណ្ឌ ៦៥៩-៦៦៥។

សេចក្តីសម្រេចនានារបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[2442]។ ដូច្នេះ មេធាវីការពារក្តីមិនអាចហាមឃាត់ខ្លួនឯងមិនឱ្យគិតថា អង្គជំនុំជម្រះខកខានមិនបានធ្វើការវិភាគលើលក្ខខណ្ឌនេះ ក៏ព្រោះតែអង្គជំនុំជម្រះដឹងថា ខ្លួននឹងជួបប្រទះការលំបាក និងមិនអាចផ្តល់យុត្តិកម្មដល់គោលការណ៍នីត្យាកូលភាពបាន។ សរុបសេចក្តីមក ដោយមិនបានធ្វើការវិភាគលើលក្ខខណ្ឌនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយរំលោភលើគោលការណ៍នីត្យានុកូលភាព។

## ១.២. គ្មានការចែងអំពីការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ក្នុងលិខិតុបករណ៍អន្តរជាតិនៅសម័យនោះ

១២៨៤. ការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ពោលគឺ រវាងប្តីប្រពន្ធ មិនមែនជាបទល្មើសទេ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦[2443] ហើយក្រមនេះនៅជាធរមានជាផ្លូវការ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[2444]។ គ្មានបទប្បញ្ញត្តិណាមួយចែងអំពីការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ឬក្នុងចំណងអាពាហ៍ពិពាហ៍នោះទេ ក្នុងលិខិតុបករណ៍អន្តរជាតិនៃច្បាប់សង្គ្រាម។ ថ្វីត្បិតតែក្រម Lieber អនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែម អាចចែងអំពីការរំលោភសេពសន្ថវៈ និងការការពារស្ត្រី ក្នុងក្របខ័ណ្ឌជាក់លាក់នៃជម្លោះប្រដាប់អាវុធ ក៏ដោយ ក៏ពុំមានការចែងអំពីការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធនោះឡើយ។ ពុំមានការចែងក្នុងលក្ខន្តិកៈរបស់តុលាការពិសេស ឬតុលាការអន្តរជាតិនោះទេ។ ការរំលោភសេពសន្ថវៈ ដែលបានប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងទៀតដាច់ដោយឡែកនោះទេ ហើយក៏មិនធ្លាប់ត្រូវបានផ្តន្ទាទោស តាមនីតិព្រហ្មទណ្ឌអន្តរជាតិ ពីមុនមកនោះដែរ។ អង្គជំនុំជម្រះច្របល់បញ្ចូលគ្នានូវបទល្មើសពីរដាច់ដោយឡែកពីគ្នា ដែលទាមទារឱ្យមានវិចារណកិច្ចដាច់ដោយឡែកពីគ្នា៖ ការរំលោភសេពសន្ថវៈ និងការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនាំទៅដល់បរិបទដោយឡែក គឺ

---

[2442] សាលក្រម សំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៥៥៨។

[2443] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។

[2444] សាលក្រម ឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៩។

បរិបទនៃសមគ្គសង្វាស។ ក៏ប៉ុន្តែ បរិបទនេះត្រូវបានអង្គជំនុំជម្រះច្រានចោលទាំងស្រុង ហើយអង្គជំនុំជម្រះមានចេតនាបំភ្លេចចោលនូវបរិបទមួយផ្នែក រហូតធ្វើឱ្យមានការកំណត់និយមន័យបទឧក្រិដ្ឋខុស និងអនុវត្តខុស។

១២៨៥. ទោះជាយ៉ាងណាក្តី ការមិនវិភាគលើលក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ និងតំណភ្ជាប់រវាងសិទ្ធិ និងបម្រាម នៅក្នុងលិខិតុបករណ៍នៅសម័យនោះ គឺជាកំហុសអង្គច្បាប់។ ក្នុងលក្ខខ័ណ្ឌបែបនេះ អង្គជំនុំជម្រះមិនអាចនិយាយថា ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ពិតជាកើតឡើងមែន ហើយជាពិសេសទៅទៀត អង្គជំនុំជម្រះមិនអាចផ្តន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុទាំងនេះទេ។

## ១.៣. ភាពមិនអាចផ្តន្ទាទោស ខៀវ សំផន

១២៨៦. ដូចមេធាវីការពារក្តីបានរៀបរាប់រួចមកហើយ ប្រភេទបន្ថែមនៃអំពើអមនុស្សធម៌ផ្សេងទៀតកើតចេញពីឆន្ទៈកសាងនីតិព្រហ្មទណ្ឌអន្តរជាតិ ហើយការកសាងនេះត្រូវធ្វើឡើង ដោយគោរពតាមគោលការណ៍ "គ្មានបទល្មើស បើគ្មានច្បាប់ចែង"[2445]។ នៅពេលត្រូវវាយតម្លៃប្រភេទបន្ថែម អង្គជំនុំជម្រះត្រូវធ្វើការពិនិត្យតាមផ្លូវច្បាប់ឱ្យបានហ្មត់ចត់ ដែលទាមទារជាចាំបាច់ឱ្យមានការវិភាគលើលក្ខខ័ណ្ឌអនីត្យានុកូលភាពជាផ្លូវការ និងតំណភ្ជាប់រវាងសិទ្ធិ និងបម្រាម ក្នុងលិខិតុបករណ៍អន្តរជាតិ នៅពេលកើតហេតុ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសលើនិយមន័យបទឧក្រិដ្ឋ និងនីត្យានុកូលភាពនៃបទឧក្រិដ្ឋ នៅសម័យអង្គហេតុ។

១២៨៧. ចំពោះអវត្តមានបទដ្ឋាន ក្នុងលិខិតុបករណ៍អន្តរជាតិ ឬក្នុងច្បាប់អន្តរជាតិ ច្បាស់ណាស់ថា ចៅក្រមមិនអាចសន្និដ្ឋានថា ឧក្រិដ្ឋកម្មដែលចោទប្រកាន់បានកើតឡើងនោះឡើយ។ ពេលផ្តន្ទាទោស ខៀវ សំផន ពីអង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះបានរំលោភលើគោលការណ៍ស្តីពីភាពអាចយល់ដឹងបាន ឬភាពអាចប្រមើលមើលបាន។

---

[2445] សូមមើលខាងលើ កថាខណ្ឌ ៦៥៩-៦៧១។

## ២. កំហុសពាក់ព័ន្ធនឹងការពិនិត្យធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

### ២.១. កំហុសពាក់ព័ន្ធនឹងការពិនិត្យលើល័ក្ខខ័ណ្ឌតម្រូវនៃលក្ខណៈ និងភាពធ្ងន់ធ្ងរប្រហាក់ប្រហែល

#### ២.១.១. ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ទាំងនៅមុន និងក្រោយពេលកើតហេតុ

១២៨៨. ការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមានអត្ថិភាពទេ នៅពេលកើតហេតុ[2446]។ ការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏ពុំមានអត្ថិភាពដែរ នៅមុនកើតហេតុ និងពុំមានចែងជាក់លាក់ទេ នៅក្នុងច្បាប់កម្ពុជា រហូតមកទល់នឹងសព្វថ្ងៃនេះ។ ការគ្មានចែងជាបទល្មើស នៅថ្នាក់ជាតិ និងអន្តរជាតិ អាចឱ្យសន្និដ្ឋានបានថា អំពើអមនុស្សធម៌ផ្សេងទៀត មិនត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក និងមិនត្រូវបានផ្តន្ទាទោសពីមុនមក ក៏ព្រោះតែអំពើអមនុស្សធម៌ផ្សេងទៀតមិនត្រូវបានចាត់ទុកថាមានលក្ខណៈ និងកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត។

១២៨៩. នៅពេលបដិសេធមិនព្រមអនុវត្តល័ក្ខខ័ណ្ឌអនីត្យានុកូលភាព ដើម្បីផ្តន្ទាទោស ខៀវ សំផន អង្គជំនុំជម្រះមិនអាចកំណត់ឥរិយាបថនោះ និងថាតើវាមានលក្ខណៈ និងភាពធ្ងន់ធ្ងរស្រដៀងនឹងអំពើអមនុស្សធម៌ផ្សេងទៀតដែរឬទេ ដោយធ្វើការប្រៀបធៀបនឹងបទដ្ឋានអន្តរជាតិ។

១២៩០. អង្គជំនុំជម្រះក៏មិនយល់ឃើញថា មានប្រយោជន៍ ក្នុងការអនុវត្តវិធាននៃភាពស្រដៀងគ្នា ក្នុងការវាយតម្លៃធាតុផ្សំសត្យានុម័តិ។ ក្នុងការកំណត់បទឧក្រិដ្ឋជាអំពើអមនុស្សធម៌ផ្សេងទៀត វិធាននៃភាពស្រដៀងគ្នាគួរណាតែអាចបម្រើដល់ការកំណត់ថា តើអំពើសកម្ម ឬអកម្ម ដែលចោទប្រកាន់ មានកម្រិតធ្ងន់ធ្ងរដូចអំពើដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានរៀបរាប់ក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរឬទេ។ ដើម្បីកំណត់ប្រភេទនៃអំពើណាខ្លះអាចមានលក្ខណៈ និងភាពធ្ងន់

[2446] សូមមើលខាងលើ កថាខណ្ឌ ៦៥៩-៦៦៥។

ធូរប្រហាក់ប្រហែលគ្នា ពោលគឺស្រដៀងគ្នា អង្គជំនុំជម្រះគួរណាតែធ្វើការស្រាវជ្រាវលើយុត្តិសាស្ត្រ និងវាយតម្លៃប្រភេទនៃអំពើសកម្ម ឬអកម្ម ដែលត្រូវបានកំណត់ជាអំពើអមនុស្សធម៌ផ្សេងទៀត[2447]។ ពេលមិនយកលក្ខណៈវិនិច្ឆ័យសត្យានុម័តិទាំងនេះមកអះអាងថា មានធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្ម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ រហូតដល់ថ្នាក់មិនអាចបង្ហាញឱ្យឃើញពីវិមតិសង្ស័យថា ឥរិយាបថដែលចោទប្រកាន់មានលក្ខណៈ និងភាពធ្ងន់ធ្ងរស្រដៀងគ្នា[2448]។

### ២.១.២. កំហុសពាក់ព័ន្ធនឹងនិយមន័យនៃការរំលោភសេពសន្ថវៈដែលប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

១២៩១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ពាក់ព័ន្ធនឹងនិយមន័យដែលអាចអនុវត្តបានចំពោះអង្គហេតុដែលចោទប្រកាន់ ដោយដកស្រង់យកវិចារណកិច្ច ពីក្នុងរឿងក្តី ឌុច និងនិយមន័យនៃការរំលោភសេពសន្ថវៈ ដូចបានកំណត់នៅឆ្នាំ១៩៧៥៖

> "ការបញ្ចូលអង្គជាត ទោះបីជាមិនបានស៊ីជម្រៅក៏ដោយ ទៅក្នុង (ក) រន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗដែលប្រើប្រាស់ដោយចារី ឬ (ខ) ការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារី នៅពេលដែលការបញ្ចូលអង្គជាតនោះកើតឡើង ដោយគ្មានការយល់ព្រមពីជនរងគ្រោះ"[2449]។

១២៩២. ផ្ទុយទៅវិញ និយមន័យនេះពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ គឺមិនមែនការរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍នោះទេ ទោះជាដោយបង្ខំ ឬតាមការព្រមព្រៀងក៏ដោយ។ អាពាហ៍ពិពាហ៍ធ្វើឱ្យសមគ្គសង្វាសរវាងប្តីប្រពន្ធចាប់បដិសន្ធិឡើង និងមានឥទ្ធិពលផ្ទាល់ទៅលើការ

---

[2447] សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៩១-៥៩៥។ ការអនុវត្តគោលការណ៍នៃភាពស្រដៀងគ្នាដោយតុលាការកំពូល។

[2448] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៧-៣៦៩៨។

[2449] សំអាងហេតុសាលក្រម កថាខណ្ឌ ៧៣១ យោងទៅសាលក្រម ឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៣៦២ ក្នុងកំណត់សម្គាល់ជើងទំព័រលេខ២២៣៦។

វាយតម្លៃអំពីការព្រមព្រៀង។ ដូច្នេះ ធាតុផ្សំនេះផ្លាស់ប្តូរនិយមន័យដែលអង្គជំនុំជម្រះបានលើកឡើង និងច្បាប់ជាធរមាន នៅពេលកើតហេតុ។ តាមពិត អង្គជំនុំជម្រះបានផ្តល់និយមន័យខុសទៅលើឧក្រិដ្ឋកម្មដែលចោទប្រកាន់[2450]។ អង្គជំនុំជម្រះក៏មិនបានកំណត់និយមន័យឱ្យបានត្រឹមត្រូវនូវ "ការរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"។ អង្គជំនុំជម្រះបានត្រឹមតែផ្តល់និយមន័យនៃការរំលោភសេពសន្ថវៈ ដោយកាត់ផ្តាច់បទល្មើសចេញពីផ្នែកមួយនៃធាតុផ្សំ និង បរិបទរបស់វា។

១២៩៣. ការរំលោភសេពសន្ថវៈដែលប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ពោលគឺក្នុងបរិបទនៃសមគ្គសង្វាស គឺជាបទល្មើសឯករាជ្យ នៅក្នុងប្រទេសជាច្រើន។ ដូច្នេះ បទល្មើសឯករាជ្យខុសពីបទល្មើសនៃការរំលោភសេពសន្ថវៈ "តាមបែបបុរាណ"។ ការទទួលស្គាល់នេះទើបតែកើតឡើងថ្មីៗកន្លងទៅនេះ ពីព្រោះប្រពៃណីគតិយុត្តិទាំងអស់បានបដិសេធមិនព្រមចាត់ទុកការរំលោភសេពសន្ថវៈ ជាបទល្មើសក្នុងបរិបទបែបនេះ ដោយហេតុថា ធ្លាប់មាន (ឬនៅតែមាន អាស្រ័យតាមរដ្ឋ) សច្ចធារណ៍នៃការព្រមព្រៀងរវាងប្តីប្រពន្ធ។ តាមរបៀបដូចគ្នាដែលការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការចោទប្រកាន់ស្មុគស្មាញ ប្រទាញប្រទង់គ្នារវាងច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌ ការរំលោភសេពសន្ថវៈដែលប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ យកលំនាំតាមច្បាប់ទាំងពីរនេះ។ រដ្ឋជាច្រើនចាត់ទុកថាមានសច្ចធារណ៍ដាច់ខាតនៃការព្រមព្រៀងរវាងប្តីប្រពន្ធ។

### *២.១.២.១. ច្បាប់កម្ពុជា*

១២៩៤. នៅកម្ពុជា ថ្វីត្បិតតែមាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ចោទប្រកាន់បទរំលោភសេពសន្ថវៈក៏ដោយ ក៏ពុំមានការចែងអំពីការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធឡើយ ពោលគឺ ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍[2451]។ ក្រមនេះចែងអំពីបទល្មើសនៃការរំលោភសេពសន្ថវៈ ក្នុងខ្លឹមសារដូចខាងក្រោម៖

---

[2450] សូមមើលខាងលើ ផ្នែកទី១ អាពាហ៍ពិពាហ៍ កថាខណ្ឌ ១០៩៨-១២៨០ ជាពិសេស កថាខណ្ឌ ១០៩៨-១១១៦។

[2451] ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ មាត្រា ៤៤៣។

"ជនណាបញ្ចូល ឬប៉ងនឹងបញ្ចូល ទាំងបង្ខំ ឬទាំងគំរាម នូវអង្គជាតរបស់ខ្លួន ទៅក្នុងអង្គជាតនៃស្ត្រី ដែលប្រកែកមិនព្រមស្ម័គ្រផង ជននោះត្រូវទុកជាមានពិរុទ្ធ ក្នុងបទកំហែងរួមវេណីដល់ទីជម្រៅ"[2452]។

១២៩៥. អវត្តមាននៃការចោទប្រកាន់នេះមានប្រភពដើមនៅក្នុងច្បាប់រដ្ឋប្បវេណី ដែលចែងថា ក្នុងចំណងអាពាហ៍ពិពាហ៍ មាន "ករណីយកិច្ចរួមសង្វាស" ដែលកើតចេញពីសច្ចធារណ៍នៃការព្រមព្រៀងរវាងប្ដីប្រពន្ធ ក្នុងការរួមដំណេក។ ក្រោមអំណាចនៃក្រមនេះ ការរត់ចោលលំនៅសង្វាសដោយប្រពន្ធ គឺជាបទមជ្ឈិមដែលត្រូវផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ[2453]។

១២៩៦. នៅកម្ពុជា និងនៅរដ្ឋជាច្រើន សច្ចធារណ៍ដាច់ខាតនេះធ្វើឱ្យប្ដីប្រពន្ធរួចផុតពីទោសព្រហ្មទណ្ឌ ក្នុងករណីរំលោភសេពសន្ថវៈដែលប្រព្រឹត្តក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍។ សច្ចធារណ៍នេះទើបតែត្រូវបានជំទាស់តវ៉ាថ្មីៗកន្លងទៅនេះ។ ច្បាប់ ឆ្នាំ២០០៥ ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ បានដាក់បញ្ចូលការចោទប្រកាន់ពីបទរំលោភបំពានផ្លូវភេទ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍[2454]។ មាត្រា ៧ នៃច្បាប់នេះចែងថា៖ "អំពើល្មើសពានខាងផ្លូវភេទរួមមាន៖ - ការប្រើហិង្សាសេពសន្ថវៈ - ការបៀតបៀនកេរ្តិ៍ខ្មាស - ការធ្វើអាស្រូវភាស"[2455]។

១២៩៧. យើងកត់សម្គាល់ឃើញថា ថ្វីត្បិតតែច្បាប់នេះចោទប្រកាន់បទល្មើសពានខាងផ្លូវភេទ ដែលប្រព្រឹត្តក្នុងក្របខ័ណ្ឌប្ដីប្រពន្ធ ក៏ដោយ ក៏ពុំមានការចែងច្បាស់លាស់អំពីការរំលោភសេពសន្ថវៈទេ គឺមានតែ "ការប្រើហិង្សាសេពសន្ថវៈ"។ ពាក្យនេះមានន័យទូលំទូលាយណាស់ និងពិបាកកំណត់។ ដូច្នេះ យើងមិនអាចនិយាយបានថា ការរំលោភសេពសន្ថវៈរវាងប្ដីប្រពន្ធ គឺក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ មាន

---

2452 ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ មាត្រា ៤៤៣។

2453 ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ មាត្រា ៤៥២។

2454 ព្រះរាជក្រម ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។ អាចរកបាននៅអាសយដ្ឋានដូចតទៅ៖ https://www.wcwonline.org/pdf/lawcompilation/Cambodia_dv_victims2005.pdf

2455 ព្រះរាជក្រម ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ មាត្រា ៧។

ថែង និងប្រើប្រាស់ក្នុងច្បាប់កម្ពុជានោះទេ។ ដោយសារតែចន្លោះប្រហោងនេះ ការរំលោភសេពសន្ថវៈរវាងប្ដីប្រពន្ធ កម្រនឹងត្រូវបានតុលាការកម្ពុជាកាត់ទោសណាស់[2456]។ ដូច្នេះ នៅមុនឆ្នាំ២០០៩ ពុំមានការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈរវាងប្ដីប្រពន្ធទេ ពោលគឺ ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍។ ប្ដី ឬប្រពន្ធមិនអាចត្រូវបានចោទប្រកាន់ តាមរយៈការកំណត់ថាជាការរំលោភសេពសន្ថវៈ តាមបែបបុរាណឡើយ។ ដូចគ្នានេះដែរ អង្គជំនុំជម្រះមិនអាចផ្ដន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុទាំងនេះបានទេ។

### ២.១.២.២. ច្បាប់អន្តរជាតិ

១២៩៨. ឯកសារគតិយុត្តិ ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ បានចំណាយពេលយ៉ាងច្រើនក្នុងការកសាង និងនៅតែមិនពេញលេញ ឬគ្មានតែម្ដង ក្នុងរដ្ឋជាច្រើន។ ឧទាហរណ៍ នៅបារាំង ការទទួលស្គាល់ការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍បានជួបប្រទះការលំបាកសព្វបែបយ៉ាង។ ការលំបាកមួយបណ្ដាល ជាអាទិ៍ មកពីអត្ថិភាពនៃសច្ចធារណ៍នៃការព្រមព្រៀងចំពោះទំនាក់ទំនងផ្លូវភេទរវាងប្ដីប្រពន្ធ ស្របតាមករណីយកិច្ចរួមរស់ និងរួមសង្វាស ដែលកើតចេញពីកិច្ចសន្យាអាពាហ៍ពិពាហ៍[2457]។ ដូច្នេះ លទ្ធិ និងយុត្តិសាស្ត្រ បានជំទាស់ជាឯកច្ឆន្ទនឹងការចោទប្រកាន់ពីបទនេះ៖

---

[2456] របាយការណ៍របស់អង្គការ លីកាដូ "ហិង្សាលើស្ត្រី៖ តើច្បាប់កម្ពុជារើសអើងនឹងស្ត្រីយ៉ាងដូចម្ដេច?" ឆ្នាំ២០០៧ ទំព័រ ១៣-១៤ (https://www.licadho-cambodia.org/reports/files/112CAMBOWViolenceWomen_Report2007_ENG.pdf)។ អត្ថបទរបស់លោកស្រី Dorine VAN DER KEUR, *Legal and Gender Issues of Marriage and Divorce in Cambodia, 2.5 Domestic Violence and Marital Rape*។ អាចរកបាននៅអាសយដ្ឋាន៖ http://cambodialpj.org/article/legal-and-gender-issues-of-marriage-and-divorce-in-cambodia/

[2457] អត្ថបទរបស់លោកស្រី Audrey DARSONVILLE *ឃ្លាំងផ្ទុកឯកសារក្រមព្រហ្មទណ្ឌ និង ក្រមនីតិព្រហ្មទណ្ឌ Dallo ការ រំលោភសេពសន្ថវៈ កថាខណ្ឌ ៣នងទៅនឹងពេលមុនទំាការមានទំនាក់ទ-៣ , និង គុណវិបត្តិនៃការព្រមព្រៀង* ឆ្នាំ២០១១ (ធ្វើបច្ចុប្បន្នភាព៖ ខែវិច្ឆិកា ឆ្នាំ២០១៨)។

*"អំពើហិង្សា ដែលប្តីបានប្រព្រឹត្តទៅលើប្រពន្ធមានខាន់ស្លា ក្នុងចំណងអាពាហ៍ពិពាហ៍ស្រប ច្បាប់ មិនអាចបង្កើតជាបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈបានឡើយ"*[2458]។

១២៩៩. ខណៈដែលក្រមព្រហ្មទណ្ឌមិនមានចែង តុលាការកំពូលបារាំងបានទទួលស្គាល់ការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ជាលើកដំបូង នៅក្នុងសាលដីកា ឆ្នាំ១៩៩០[2459]។ តុលាការកំពូលបានទទួលស្គាល់ប៉ុន្មានឆ្នាំមុន ប៉ុន្តែ ក្នុងល័ក្ខខ័ណ្ឌថា ប្តីប្រពន្ធបានផ្តើមនីតិវិធីលែងលះជាមុន[2460]។ ការទទួលស្គាល់តាមផ្លូវច្បាប់នូវការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ទើបតែកើតឡើង ក្រោយការកែប្រែច្បាប់ នៅឆ្នាំ២០០៦[2461]។ ច្បាប់នេះមិនបានស្នើឡើងនូវបទល្មើសឯករាជ្យទេ ប៉ុន្តែអនុញ្ញាតឱ្យពង្រីកដែនអនុវត្តន៍នៃស្ថានទម្ងន់ទោសចំពោះប្តីប្រពន្ធ សហព័ទ្ធ អនីតិសង្វាសនី ឬដៃគូរួមរស់។ ដូចគ្នាផងដែរ នៅអាល្លឺម៉ង់ការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធមិនមែនជាបទល្មើសឯករាជ្យទេ ប៉ុន្តែ ជាស្ថានទម្ងន់ទោស[2462]។ នៅស្វ៊ីស ការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធត្រូវបានដាក់បញ្ចូលជាបទល្មើសដោយច្បាប់ ឆ្នាំ១៩៩២ ហើយផ្ទុយពីបទល្មើសផ្សេងទៀត ការចោទប្រកាន់ដំណើរការតែប្រសិនបើជនរងគ្រោះដាក់ពាក្យបណ្តឹងប៉ុណ្ណោះ[2463]។ ក្រោយកំណែទម្រង់ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៩៩ តុលាការអេស្ប៉ាញទទួលស្គាល់ថា

---

[2458] អត្ថបទ/សម្រង់អត្ថបទ របស់លោក GARÇON *ក្រមព្រហ្មទណ្ឌជាមួយកំណត់ចំណាំ បោះពុម្ពលើកទី២ ដោយ ROUSSELET, PATIN* និង *ANCEL* Sirey ឆ្នាំ១៩៥២-១៩៥៩ លេខ២៣។

[2459] តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩០ លេខ ៩០-៨៣៧៨០។

[2460] តុលាការកំពូលបារាំង រឿងក្តីព្រហ្មទណ្ឌ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៨៤ លេខ ៨៤-៩១២៨៨។

[2461] ច្បាប់ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៦ មាត្រា ១១ ដែលបានបញ្ចូលវាក្យខណ្ឌ ២ នៃមាត្រា ២២២-២២ នៃក្រមព្រហ្មទណ្ឌបារាំង៖ *"ការរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទផ្សេងទៀតត្រូវបានរាប់បញ្ចូល នៅពេលដែលពួកគេបានបង្ខំឱ្យជនរងគ្រោះ ក្នុងកាលៈទេសៈដែលមានចែងនៅក្នុងផ្នែកនេះ ទោះបីជាប្រភេទនៃទំនាក់ទំនងរវាងអ្នកប្រព្រឹត្ត និងជនរងគ្រោះនោះយ៉ាងដូចម្តេចក៏ដោយ ទោះបីជាពួកគេរួមរស់ជាមួយគ្នាដោយចំណងអាពាហ៍ពិពាហ៍ក្តី។ ក្នុងករណីនេះ ការសន្មតថាព្រមព្រៀងគ្នានៃសហព័ទ្ធចំពោះការរួមសង្វាសរាប់ជាបានការ រហូតដល់ពេលមានភ័ស្តុតាងបញ្ជាក់ផ្ទុយពីនោះ"*។

[2462] របាយការណ៍នៃការសិក្សារបស់ព្រឹទ្ធសភាបារាំង *ការតស៊ូប្រឆាំងអំពើហិង្សាក្នុងគ្រួសារ* ខែមីនា ឆ្នាំ២០០០។ អាចពិគ្រោះបាននៅក្នុងគេហទំព័រ៖ https://www.senat.fr/lc/lc86/lc86_mono.html.

[2463] អត្ថបទរបស់លោកស្រី Geraldine BROWN លោក Thierry DELESSERT និងលោកស្រី Marta ROCA I ESCODA *ពីករណីយកិច្ចអាពាហ៍ពិពាហ៍ឆ្ពោះទៅការរំលោភសេពសន្ថវៈសហព័ទ្ធ។ ការសិក្សាអំពីការវិវត្តនៃក្រមព្រហ្មទណ្ឌស្វ៊ីស* កម្រងស្នាដៃLextenso Droit et société ឆ្នាំ២០១៧/ខែមីនា លេខ៩៧ ទំព័រ ៥៩៥ ដល់ ៦១៤។

អត្ថិភាពនៃសមគ្គសង្វាសលែងរារាំងដល់ការកំណត់ជាការរំលោភសេពសន្ថវៈទៀតហើយ[2464]។ "ការរួចទោសសង្វាស" នេះ កើតមានក្នុងប្រទេសខ្លះ ដែលមានប្រពៃណីគតិយុត្តិ common law។ នៅចក្រភពអង់គ្លេស ការរួចទោសមានប្រភពដើមពីវ៉ូម៉ាំងនេះបានកើតឡើងតាំងពីយូរលង់ណាស់មកហើយ ដោយសារតែមានសច្ចធារណ៍នៃការព្រមព្រៀងគ្នារវាងប្តីប្រពន្ធ។ នៅឆ្នាំ១៩៩០ គណៈកម្មការកំណែទម្រង់ច្បាប់អង់គ្លេសបានតាក់តែងរបាយការណ៍មួយស្តីពី "ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍" និងបានស្នើឡើងជាលើកដំបូងនូវការលុបចោលការរួចទោសសង្វាសនេះ[2465]។ ដោយគ្មានកំណែទម្រង់ច្បាប់ ការផ្តន្ទាទោសលើកដំបូងពីបទរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ត្រូវបានសភាជាន់ខ្ពស់អង់គ្លេស ប្រកាសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១[2466]។ យោងតាមរឿងក្តីនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបក៏បានផ្តល់សុពលភាពជាលើកដំបូង ដល់សញ្ញាណនៃការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ[2467]។ ចក្រភពអង់គ្លេសបានបន្ថែមការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ជាស្ថានទម្ងន់ទោស ដោយមិនចែងជាបទល្មើសឯករាជ្យទេ តាមរយៈច្បាប់ ឆ្នាំ២០០៣។ រដ្ឋ ដូចជា បាបាដូស និងបេលីស ទទួលស្គាល់ការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ តែប្រសិនបើប្តី ឬប្រពន្ធបានដាក់ពាក្យសុំលែងលះ ដើម្បីផ្តាច់សមគ្គសង្វាសប៉ុណ្ណោះ[2468]។ ក្រៅពីនេះទៀត រដ្ឋជាច្រើនមិនបានធ្វើច្បាប់លើបញ្ហា

---

[2464] អត្ថបទរបស់លោកស្រី Geraldine BROWN លោក Thierry DELESSERT និងលោកស្រី Marta ROCA I ESCODA *ពីករណីយកិច្ចអាពាហ៍ពិពាហ៍ឆ្ពោះទៅការរំលោភសេពសន្ថវៈសហព័ទ្ធ។ ការសិក្សាអំពីការវិវត្តនៃក្រមព្រហ្មទណ្ឌស្វ៊ីស* កម្រងស្នាដៃ Lextenso Droit et société ឆ្នាំ២០១៧/ខែមីនា លេខ៩៧ ទំព័រ ដល់ ៦១៥។

[2465] អត្ថបទរបស់លោកស្រី Renée KOERING-JOULIN *ការរំលោភសេពសន្ថវៈរវាងសហព័ទ្ធ និង អភ័យឯកសិទ្ធិក្នុងសហព័ទ្ធនៅក្នុងច្បាប់ Common Law*, RSC ឆ្នាំ១៩៩៦ ទំព័រ៤៧៣។

[2466] អត្ថបទរបស់លោកស្រី Renée KOERING-JOULIN *ការរំលោភសេពសន្ថវៈរវាងសហព័ទ្ធ និង អភ័យឯកសិទ្ធិក្នុងសហព័ទ្ធនៅក្នុងច្បាប់ Common Law*, RSC ឆ្នាំ១៩៩៦ ទំព័រ៤៧៣។

[2467] សាលដីកា *CR* និង *SW ប្រឆាំងនឹងប្រទេសចក្រភពអង់គ្លេស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប) ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

[2468] កំណត់សម្គាល់នៃធនាគារពិភពលោក *ស្ត្រីនៃសហគ្រាស និង ច្បាប់* ធនាគារពិភពលោក ទំព័រ ៥។ អាចរកបាននៅក្នុងគេហទំព័រដូចតទៅ៖ http://pubdocs.worldbank.org/en/379891519938659824/Topic-Note-Protecting-Women-from-Violence-FR.pdf

នេះទេ ហើយនៅតែប្រើប្រាស់ទស្សនាទាននៃការរួចទោសសង្វាស រហូតដល់ថ្នាក់ការរំលោភសេពសន្ថវៈរវាងប្ដីប្រពន្ធមិនត្រូវបានចោទប្រកាន់ទេ[2469]។

១៣០០. សរុបសេចក្ដីមក នៅពេលអនុវត្តនិយមន័យ "បុរាណ" នៃការរំលោភសេពសន្ថវៈ ទៅលើអង្គហេតុដែលចោទប្រកាន់ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់។ ដោយហេតុថាបទចោទគឺជាបទរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះគួរណាតែធ្វើការពិនិត្យតាមផ្លូវច្បាប់ ក្រោមការកំណត់ថាជាការរំលោភសេពសន្ថវៈរវាងប្ដីប្រពន្ធ និងសន្និដ្ឋានថាបទល្មើសនេះពុំមានអត្ថិភាពទេ នៅសម័យអង្គហេតុ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះពុំមានលទ្ធភាពផ្ដន្ទាទោស ខៀវ សំផន ចំពោះអង្គហេតុទាំងនេះទេ។

## ២.២. កំហុសពាក់ព័ន្ធនឹងការពិនិត្យលើការទទួលខុសត្រូវលើការឈឺចាប់ ក្នុងបរិបទនៃទំនាក់ទំនងផ្លូវភេទ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

១៣០១. ជាសំខាន់ សូមរំឭកថា មានការជំទាស់តវ៉ាថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពុំមានអត្ថិភាពទេ នៅសម័យអង្គហេតុ និងពុំមានធាតុផ្សំគ្រប់គ្រាន់ទេ[2470]។ ជាបន្ទាប់បន្សំ យោងតាមការរៀបរាប់លម្អិតខាងលើអំពីច្បាប់ជាធរមាន និងនត្ថិភាពនៃការរំលោភសេពសន្ថវៈរវាងប្ដីប្រពន្ធ នៅសម័យអង្គហេតុ អង្គជំនុំជម្រះមិនអាចផ្ដន្ទាទោសម្ចាស់បណ្ដឹងសាទុក្ខ តាមគោលការណ៍នីត្យានុកូលភាពបានទេ[2471]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើន ដោយបានធ្វើការសន្និដ្ឋានជារួមថា ការរួមភេទក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានកម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

[2469] កំណត់សម្គាល់នៃធនាគារពិភពលោក *ស្ត្រីនៃសហគ្រាស និងច្បាប់* ធនាគារពិភពលោក ទំព័រ ៥។ អាចពិគ្រោះបាននៅក្នុងគេហទំព័រដូចតទៅ៖ http://pubdocs.worldbank.org/en/379891519938659824/Topic-Note-Protecting-Women-from-Violence-FR.pdf ឧទាហរណ៍ប្រទេស៖ ឥណ្ឌា ប្រ៊ុយណេដារូសាឡាម មីយ៉ាន់ម៉ា បង់ក្លាដេស ស្រីលង្កា អេត្យូពី កេនយ៉ា ស៊ូដង់ខាងត្បូង តង់ហ្សានី។

[2470] សូមមើលខាងលើ ផ្នែកទី១. អាពាហ៍ពិពាហ៍ កថាខណ្ឌ ១០៩៨-១២៨០។

[2471] សូមមើលខាងលើ/ខាងក្រោម កថាខណ្ឌ ១២៨៨-១៣៩៨។

តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត[2472]។ ជាបន្ទាប់បន្សំថែមទៀត អង្គជំនុំជម្រះពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថា មានធាតុផ្សំសត្យានុម័តិនៃការរំលោភសេពសន្ថវៈ នោះទេ និងដើម្បីសន្និដ្ឋានពីការកំណត់ចរិតលក្ខណៈឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃវប្បធម៌ខ្មែរ (២.២.១) ប៉ុន្តែ ភស្តុតាងទាំងមូលដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ មិនអាចឱ្យទាញសេចក្តីសន្និដ្ឋានបែបនេះបានទេ (២.២.២)។

## ២.២.១. កំហុសពាក់ព័ន្ធនឹងកម្រិតធ្ងន់ធ្ងរនៃការឈឺចាប់ និងការមិនពិចារណាដល់វប្បធម៌ខ្មែរ

១៣០២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយបានសន្និដ្ឋានថា មានធាតុផ្សំសត្យានុម័តិនៃអំពើរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តរបស់ស្ត្រីដែលទទួលរងការរំលោភសេពសន្ថវៈ កើតចេញពីកាតព្វកិច្ចរួមភេទក្រោយការរៀបអាពាហ៍ពិពាហ៍[2473]។

### *២.២.១.១. កំហុសពាក់ព័ន្ធនឹងអត្ថិភាពនៃករណីរំលោភសេពសន្ថវៈ*

១៣០៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ពិតជាមានការរំលោភសេពសន្ថវៈ នៅត្រាំកក់។ ជាក់ស្តែង បើតាមអង្គជំនុំជម្រះ "យ៉ាងហោចណាស់ ក៏មានការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានកើតឡើងម្តងដែរ នៅក្នុងសហករណ៍ត្រាំកក់"។ សម្តីនេះជាការបោកបញ្ឆោត ពីព្រោះវារំលេចឱ្យឃើញថា មានភស្តុតាងលើករណីផ្សេងទៀតនៃការរំលោភសេពសន្ថវៈ នៅត្រាំកក់ ដែលតាមពិត ពុំមាននោះទេ។ តាមពិត មានករណីតែមួយគត់ដែលត្រូវបានរកឃើញ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋាននេះ៖ ការរំលោភសេពសន្ថវៈទៅលើ ជាំង

---

[2472] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៨។ គួររំឭកថា បើតាមសំអាងហេតុសាលក្រម មានតែស្ត្រីទេដែលអាចជាជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈក្នុងសហព័ទ្ធ តែចំពោះបុរសមិមែនជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈ ហើយក៏មិនមែនជាជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទដែរ (សូមមើលសំអាងហេតុសាលក្រម កថាខណ្ឌ ៣៧០១)។

[2473] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៨។

ស្រីមុំ[2474]។ នេះជាករណីតែមួយគត់ ដែលអង្គជំនុំជម្រះយល់ឃើញថាមាន "ការរំលោភសេពសន្ថវៈ"។ ប៉ុន្តែ សូម្បីតែចំពោះអង្គហេតុទាំងនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម ដែលចោទប្រកាន់បានឡើយ។

## *គ្មានធាតុផ្សំសត្យានុម័តិ និងកម្រិតធ្ងន់ធ្ងរមិនគ្រប់គ្រាន់*

១៣០៤. តាមពិត ជាំង ស្រីមុំ មិនបានលើកឡើងអំពីការទទួលរងការឈឺចាប់ ក្នុងសក្ខីកម្មរបស់គាត់ទេ។ មានតែវិធីសាស្ត្រលម្អៀងរបស់អង្គជំនុំជម្រះប៉ុណ្ណោះដែលអាចឱ្យសន្និដ្ឋានបែបនេះ ដោយមិនអើពើនឹងភ័ស្តុតាងផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួន។ ផ្ទុយទៅវិញ ក្នុងសក្ខីកម្មរបស់គាត់ ជាំង ស្រីមុំ បានបញ្ជាក់ថាគាត់នៅតែរួមរស់ជាមួយប្តីដែលជាអ្នករំលោភគាត់ និងកូនៗ។ ម្យ៉ាងវិញទៀត ទោះបីជាគាត់បានឆ្លើយថាគាត់មិនចង់រៀបការក៏ដោយ ក៏ ជាំង ស្រីមុំ បានអះអាងយ៉ាងច្បាស់ថា ប្តីគាត់មិនបង្ខំឱ្យរួមភេទទេ។ គាត់បាននិយាយថា៖ "ចាស ការរួមដំណេក <u>គាត់អត់មានបង្ខំយើងទេ</u> ប៉ុន្តែ គាត់គ្រាន់តែនិយាយពាក្យសម្តីណែនាំយើងពីតួនាទីប្តីប្រពន្ធ ចាស។ យើងចៀសមិនផុតពីប្តីប្រពន្ធ។ គាត់គ្រាន់តែណែនាំប៉ុណ្ណឹងទេថាអនាគតទៅ យើងចៀសមិនផុតពីប្តីប្រពន្ធ។ អ៊ីចឹង <u>គាត់គ្រាន់តែណែនាំ ឬមួយពាក្យលួងលោមយើងតែប៉ុណ្ណឹងទេ បើគាត់បង្ខំចិត្តយើង ឬមួយគាត់បំពានលើយើង គាត់អត់ទេ</u>"[2475]។

១៣០៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនលើកឡើងថា ទាំងចំពោះ ជាំង ស្រីមុំ និងប្តីគាត់ ការក្លាយជាប្តីប្រពន្ធជាផ្លូវការធ្វើឱ្យការរួមភេទគឺជារឿងធម្មតា និងស្របច្បាប់។ លើសពីនេះទៅទៀត អង្គជំនុំជម្រះក៏ខកខានមិនបានបំពេញកាតព្វកិច្ចពិនិត្យលើភ័ស្តុតាងដោះបន្ទុក និងដាក់បន្ទុក ដោយមិនពិចារណាលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អំពីការរីកលូតលាស់នៃមនោសញ្ចេតនាជាប្តីប្រពន្ធនាពេលក្រោយមក[2476]។ ជាពិសេស យោងតាមចម្លើយរបស់គាត់ អង្គជំនុំជម្រះមិនអាចផ្អែកដោយ

---

[2474] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៧៤ កំណត់សម្គាល់ជើងទំព័រលេខ ១២២៦០ ដោយមិនបានធ្វើការសង្កេតជាក់ស្តែង។

[2475] <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ម៉ោង 15.43.48 (យើងគូសបន្ទាត់ពីក្រោម)។

[2476] <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 10.45.45 ("វាចេះតែដាក់ចិត្តម្តងបន្តិចៗមានការស្រឡាញ់ប្តីចាស") ម៉ោង 10.46.18 ("ប្តីក៏បានលួងលោម ថាយើងជៀសមិនផុតពីប្តីប្រពន្ធ មិនបាច់មានការលាក់លៀមអីទេ។ អ៊ីចឹង ខ្ញុំចេះតែស្តាប់គេផង")។

សមហេតុផលលើសក្ដីកម្មរបស់ ជាំង ស្រីមុំ ដើម្បីយល់ឃើញថាមានការរំលោភសេពសន្ថវៈ និងសន្និដ្ឋានថាមានការឈឺចាប់កម្រិតធ្ងន់ធ្ងរ ដែលអាចឱ្យកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀតនៃការរំលោភសេពសន្ថវៈបានទេ។

### *២.២.១.២. ករណីលើកឡើង ក្នុងផ្នែក ១៤.៣.៨.៣ ការរួមដំណេកដោយបង្ខំរវាងប្ដីប្រពន្ធ*

១៣០៦. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានជារួមថា បើការយល់ព្រមរៀបអាពាហ៍ពិពាហ៍មិន "ពិតប្រាកដ" ការរួមដំណេកក៏ត្រូវបានធ្វើឡើងដោយបង្ខំដែរ។ អង្គជំនុំជម្រះបានផ្អែកសេចក្ដីសន្និដ្ឋានរបស់ខ្លួនលើការចាំបាច់តម្រូវឱ្យប្ដីប្រពន្ធថ្មោងថ្មីរួមដំណេក ការតាមដានដើម្បីឱ្យប្រាកដថាពួកគេបានរួមដំណេក និងការបង្ខំឱ្យរួមដំណេក ក្នុងករណីរឹងទទឹង[2477]។ ដើម្បីឈានដល់ការសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះបានប្រើប្រាស់សក្ដីកម្មរបស់ ព្រាប សុខឿន, អ៊ុំ យឿន, មុំ វុន, ប៉ែន សុចាន់, ស៊ូ សុធាវី, ណុប ង៉ឹម និង ជា ឌៀប[2478]។

១៣០៧. ដូចយើងនឹងឃើញខាងក្រោម សក្ដីកម្មរបស់ ព្រាប ខឿន មិនអាចឱ្យឈានដល់ការសន្និដ្ឋានបែបនេះទេ[2479]។ ថ្វីត្បិតតែ អ៊ុំ យឿន បានឆ្លើយថាគាត់ត្រូវគេធ្វើឱ្យខ្លាញ់ក្នុងចិត្ត និងខឹងសម្បារនៅពេលគេបង្ខំឱ្យរៀបការ ប៉ុន្តែ គាត់បានបញ្ជាក់ថា ក្នុងពេលរួមរស់ជាមួយគ្នា ប្ដីគាត់បានធ្វើឱ្យគាត់សោយទុក្ខ។ ដើម្បីវាយតម្លៃការឈឺចាប់របស់គាត់ អង្គជំនុំជម្រះមិនបានយកចិត្តទុកដាក់ដល់ការនិយាយបន្ថែមថា ពួកគាត់បានជួបជុំគ្នាវិញ ក្រោយពីបែកគ្នាអស់បីឆ្នាំ ក្រោយរបបនោះដួលរលំ និងបាន "ស្រឡាញ់គ្នាតាមធម្មតា"[2480]។ ជាពិសេស អ៊ុំ យឿន មិនបាននិយាយពីការឈឺចាប់បណ្ដាលមកពីការរួមភេទជាមួយប្ដីទេ ក្នុងពេលថ្លែងអំពីព្យសនកម្ម នៅចុងសវនាការ។

---

[2477] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៩, ៣៦៦១។

[2478] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៨-៣៦៦១។

[2479] សូមមើលខាងក្រោម ករណីលើកឡើងនៅក្នុងផ្នែក *១៤.៣.១២.២ ផលប៉ះពាល់នៃការរួមដំណេកដោយបង្ខំទៅលើជនរងគ្រោះ* កថាខណ្ឌ ១៣១៣-១៣២៣។

[2480] <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ម៉ោង 13.35.12 និងបន្ទាប់ពីម៉ោង 13.40.43 ("បីឆ្នាំកន្លងមកហ្នឹង រាក់ទាក់រាប់អានធម្មតា [...] ស្រឡាញ់គ្នាតាមធម្មតាទេ")។

១៣០៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានទាញសេចក្តីសន្និដ្ឋានជារួមចេញពីរឿងរ៉ាវរបស់ មុំ វុន និង ប៉ែន សុចាន់។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនេះបានរួមភេទដោយបង្ខំជាមួយប្តី ក្រោមក្រសែភ្នែករបស់ឈ្លប។ កាលៈទេសៈពិសេសនៃបទពិសោធន៍ទាំងនេះ ដែលផ្ទុយទាំងស្រុងនឹងគោលការណ៍សីលធម៌របស់ ប.ក.ក គួរណាតែនាំឱ្យអង្គជំនុំជម្រះមានការប្រយ័ត្នប្រយែងជាងមុន។

១៣០៩. បញ្ហាភាពអាចជឿជាក់បានរបស់ មុំ វុន ត្រូវបានវែកញែកខាងលើរួចមកហើយ[2481]។ ចម្លើយរបស់ ប៉ែន សុចាន់ ចោទជាបញ្ហាផ្សេងទៀត។ ជាក់ស្តែង គាត់បានអះអាងថា គាត់បានរៀបការ នៅអាយុ ១៥ ឆ្នាំ និងត្រូវបានប្តីចាប់រំលោភ តាមបញ្ជារបស់ឈ្លប ដែលជាល័ក្ខខ័ណ្ឌពីរផ្ទុយនឹងបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍[2482]។ បន្ថែមលើការផ្សព្វផ្សាយរឿងរ៉ាវរបស់ ប៉ែន សុចាន់ តាមប្រព័ន្ធព័ត៌មាន ពីព្រោះវាខុសពីធម្មតា ដោយសារតែអាយុរបស់គាត់[2483] អង្គជំនុំជម្រះគួរណាតែពិចារណាយ៉ាងតាមភ័ស្តុតាងនៅសេសសល់ថា នេះគឺជាករណីខុសប្លែកពីគេ ដែលមិនអាចចាត់ទុកជាឧទាហរណ៍តំណាងឱ្យការឈឺចាប់បណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយទូទៅរបស់ ប.ក.ក បានឡើយ។

---

[2481] សូមមើលខាងលើ កថាខណ្ឌ ១១៧៣។

[2482] ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/482.1** ម៉ោង 13.44.12។ ប្រតិចារឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/483.1** ម៉ោង 09.06.20។

[2483] សាលដីកា ០០២/០១ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៤៨០ ការវាយតម្លៃលើភាពអាចជឿទុកចិត្ត និងភាពអាចជឿជាក់បានរបស់ សំ សិទ្ធី។ ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/483.1** ក្រោយម៉ោង 09.26.37 (សមិទ្ធិករភាពយន្តចាប់អារម្មណ៍នឹងរូបលោក ពីព្រោះគាត់នៅក្មេង កាលពីពេលរៀបការក្រោមរបបកម្ពុជាប្រជាធិបតេយ្យ "ស. ការ ពិភាក្សានាពេលក្រោយៗមកទៀត គេក៏និយាយថា គេចាប់អារម្មណ៍ជាមួយនឹងខ្សែរឿង ជាមួយនឹងរឿងរបស់លោកស្រី ដោយសារលោកស្រីនៅក្មេង អ៊ីចឹងមែនទេ? ឆ. ចាស អ៊ីចឹងមែន។ ស. តើគេមានប្រាប់ទេ ហេតុអ្វីបានជាអាយុក្មេងរបស់លោកស្រីហ្នឹងគឺជាចំណុចសំខាន់សម្រាប់ការថតភាពយន្តនោះទេ? ឆ. ចាស សំខាន់ណាស់ ព្រោះយើងនៅក្មេង មិនទាន់ពេញវ័យ គេថាបានកើតសាលាក្តីខ្មែរក្រហម យើងត្រូវតែដាក់ពាក្យបណ្តឹង ត្រូវតែថត និយាយឱ្យបងប្អូន និងក្មេងសាក្រោយបានដឹង កាលពី ជំនាន់ផ្តាច់ការនោះថា។ ខ្ញុំចង់និយាយដោយខ្លួនឯងថា") ក្រោយម៉ោង 11.47.35 គាត់លែងជានារីវ័យក្មេងក្នុងចំណោមស្ត្រីដែលរៀបការនោះទៀតហើយ។

១៣១០. អង្គជំនុំជម្រះក៏បានពឹងផ្អែកមិនត្រឹមត្រូវលើករណីខុសពីធម្មតារបស់ ស៊ូ សុធារី ដើម្បីយល់ឃើញថា ប្រពន្ធគាត់ជាជនរងគ្រោះនៃការបង្ខំឱ្យរួមភេទពីសំណាក់គាត់[2484]។ សេចក្តីសន្និដ្ឋាននេះគួរឱ្យភ្ញាក់ផ្អើលណាស់ ពីព្រោះ ដូចមេធាវីការពារក្តីបានលើកឡើងរួចមកហើយ ស៊ូ សុធារី បានមកផ្តល់សក្ខីកម្មក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលក្ខណៈពិសេសជាភេទទីបី និងមិនបាននិយាយដល់អារម្មណ៍ និងមនោសញ្ចេតនារបស់ប្រពន្ធគាត់ទាល់តែសោះ[2485]។ ដូច្នេះ អង្គជំនុំជម្រះមានភស្តុតាងតិចតួចបំផុត ដើម្បីសន្និដ្ឋានអំពីផលប៉ះពាល់នៃអំពើទាំងនោះទៅលើប្រពន្ធរបស់ ស៊ូ សុធារី និងកំណត់អំពីកម្រិតនៃភាពធ្ងន់ធ្ងរ។

១៣១១. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានពិចារណាលើចម្លើយផ្ទាល់របស់ ណុប ងឹម ដែលបានពន្យល់ថា៖ “គឺចំពោះខ្លួនខ្ញុំ អត់មានបង្ខំ ខាងនោះក៏មិនបង្ខំដែរ សំខាន់គឺចិត្ត។ ដូចខ្ញុំថា ថាគោរពវិន័យចាត់តាំង។ [...] អត់មានអ្នកណាបង្ខំណាអត់ទេ”[2486]។ ទោះបីជាអង្គជំនុំជម្រះធ្វើវិចារណកិច្ចគតិយុត្តិយ៉ាងណាក៏ដោយ ទៅលើលក្ខណៈបង្ខំជាស្វ័យប្រវត្តិនៃការរួមភេទ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬតាមការផ្សំផ្គុំ អង្គជំនុំជម្រះមិនអាចធ្វើមិនដឹងមិនឮចំពោះសម្តីរបស់សាមីខ្លួនពីអារម្មណ៍របស់ពួកគេបានឡើយ។ ផ្ទុយទៅវិញ ក្នុងករណីរបស់ ណុប ងឹម គាត់មិនយល់ឃើញថាត្រូវគេរំលោភទេ និងមិនបាននិយាយអំពីការឈឺចាប់នោះទេ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចប្រើប្រាស់សក្ខីកម្មរបស់គាត់ ដើម្បីសន្និដ្ឋានថាមានការឈឺចាប់កម្រិតធ្ងន់ធ្ងរ ដែលអាចឱ្យកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀតនៃការរំលោភសេពសន្ថវៈ បានទេ។

---

[2484] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៧, ៣៦៥៩។

[2485] ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ **F50/1** កថាខណ្ឌ ៤៦។ <u>ស៊ូ សុធារី</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/463.1** ម៉ោង 14.03.51។ សូមមើលខាងលើផងដែរ កថាខណ្ឌ ១១៧០។

[2486] <u>ណុប ងឹម</u>៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 14.19.56 និងម៉ោង 11.12.40 នៅទីនេះគាត់បញ្ជាក់ថា (“ចង់សួរថាអ៊ីចេះ ការហើយក៏ខ្ញុំអត់មានអីទេ ចេះតែទ្រាំយកគ្នាទៅ ធ្វើម៉េចទេអង្គការការឱ្យហើយ [...] អង្គការការឱ្យចេះតែទ្រាំយកទៅ បានគ្នាបានជាកូន បានជាចៅហើយ”)។

១៣១២. ដូចគ្នាផងដែរ ពិតមែនតែ ជា ខៀប បានឆ្លើយថា ការរួមដំណេក គឺជាជម្រើសរបស់ប្តីគាត់ ពេលពួកគាត់ជួបគ្នាជាលើកទីពីរ ក្រោយពីរៀបការរួច ប៉ុន្តែ គាត់មិនបាននិយាយពីការឈឺចាប់បណ្តាលមកពីការរួមភេទនេះទេ[2487]។ លើសពីនេះទៀត គាត់បានបញ្ជាក់ថា ដោយសារតែពួកគាត់មានអារម្មណ៍ថាត្រូវពួកឈ្លបតាមដាន ពួកគាត់មិនបានរួមភេទទេ នៅយប់ផ្សំដំណេក[2488]។ តាមរយៈការវាយតម្លៃលម្អៀងទៅលើភ័ស្តុតាង អង្គជំនុំជម្រះបានយល់ឃើញថារឿងរ៉ាវទាំងនេះរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចឱ្យសន្និដ្ឋានថា មានការឈឺចាប់បណ្តាលមកពីការរួមភេទដោយបង្ខំ ដែលឈានដល់កម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត។

### *២.២.១.៣. ករណីលើកឡើង ក្នុងផ្នែក ១៤.៣.១២.២ ផលប៉ះពាល់នៃការរួមដំណេកដោយបង្ខំទៅលើជនរងគ្រោះ*

១៣១៣. អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋានអំពីផលប៉ះពាល់នៃការរួមភេទដោយបង្ខំ ដោយផ្អែកទៅលើរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុខឿន និង សយ ណារឿន ព្រមទាំងអ្នកជំនាញ Kasumi NAKAGAWA ពាក់ព័ន្ធ ជាអាទិ៍ ការបាត់បង់ព្រហ្មចារី ចំពោះជនរងគ្រោះជាច្រើន និង រឹតតែធ្ងន់ធ្ងរថែមទៀត ក្នុងករណីខ្លះ ដោយសារតែការមានគភ៌មិនតាមបំណង[2489]។ ដើម្បីទាញ សេចក្តីសន្និដ្ឋានមិនអំណោយផលដល់ម្ចាស់បណ្តឹងសាទុក្ខ អង្គជំនុំជម្រះធ្វើមិនដឹងមិនឮជាប្រព័ន្ធ ចំពោះភ័ស្តុតាងដោះបន្ទុក និងភ័ស្តុតាងដែលបង្កមន្ទិលសង្ស័យដល់ភាពអាចជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

១៣១៤. <u>**សក្ខីកម្មផ្ទុយគ្នារបស់ ព្រាប សុខឿន**</u>៖ ជាក់ស្តែង អង្គជំនុំជម្រះមិនបានពិចារណាលើការពន្យល់បត់បែនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុខឿន ជាពិសេស នៅពេលឆ្លើយតបទៅនឹងការសួរដេញដោលរបស់មេធាវីការពារក្តី។ ឧទាហរណ៍ គាត់ទម្រាំដាក់ចិត្តឆ្លើយថា គាត់ត្រូវបានប្តីចាប់រំលោភ ប៉ុន្តែ បានអះអាងថាត្រូវគេជំរុញឱ្យនិយាយអំពីការរំលោភនេះឱ្យអស់ន័យសេចក្តី ដោយហេតុថាបើមិនអ៊ីចឹងទេ

---

2487 <u>ជា ខៀប</u>៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 14.07.26 និងមុនម៉ោង 15.34.22។ ប្រតិចារឹកថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ក្រោយម៉ោង 13.33.13។

2488 <u>ជា ខៀប</u>៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 14.05.55។

2489 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៣-៣៦៨៥។

“មិនមានភ័ស្តុតាងជាក់លាក់ទេ”[2490]។ អង្គជំនុំជម្រះមិនទាំងចាប់អារម្មណ៍លើផលប្រយោជន៍ដែលដើមបណ្តឹងរដ្ឋប្បវេណីនេះអាចមាន ក្នុងការកុហក ឬបំផ្លើសអង្គហេតុ ដើម្បីឱ្យម្ចាស់បណ្តឹងសាទុក្ខត្រូវបានផ្តន្ទាទោស។ ទោះជាយ៉ាងណា គាត់ជាភាគីនៃកិច្ចដំណើរការនីតិវិធី។ លើសពីនេះទៀត ចម្លើយដំបូងរបស់គាត់ ដើម្បីពន្យល់អំពីការផ្លាស់ប្តូររឿងរ៉ាវយឺតពេល គឺថា “ដល់ពេលក្រោយទៅ ដឹងដល់ឪខ្ញុំអឺចឹងទៅ គាត់អប់រំណែនាំអឺចឹងទៅ ហ្នឹងក៏ចប់ត្រឹមហ្នឹងទៅចាស។ ដល់ក្រោយទៀត ខ្ញុំបាននិយាយអ៊ីចឹងដែរ ចាស ក៏ខ្ញុំមិនបានបញ្ជាក់ថា គាត់ចាប់បង្ខំអីទេ”[2491]។ បន្ទាប់មកទៀត គាត់បានផ្តល់ចម្លើយថ្មីទៀត ដោយនិយាយថា គាត់ “នៅអៀនខ្មាស”។ អង្គជំនុំជម្រះគួរណាតែទាញផលវិបាកពីភ័ស្តុតាងទាំងនេះ ក្នុងការវាយតម្លៃទៅលើភាពអាចជឿទុកចិត្តបាននៃចម្លើយយឺតពេលរបស់គាត់។ ចំពោះការខកខានមិនបានធ្វើបែបនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលត្រូវទុកជាមោឃៈ។

១៣១៥. លើសពីនេះទៀត អង្គជំនុំជម្រះបានធ្វើមិនដឹងមិនឮជាប្រព័ន្ធចំពោះធាតុផ្សំផ្សេងទៀតនៃរឿងរ៉ាវរបស់គាត់ ដែលបង្កមន្ទិលសង្ស័យដល់ភាពធ្ងន់ធ្ងរនៃការឈឺចាប់ដែលគាត់បានទទួលរង ដោយសារតែការរំលោភសេពសន្ថវៈ។ យ៉ាងណាមិញ គាត់បានឆ្លើយថា គាត់បានសម្រេចចិត្តរស់នៅជាមួយប្តីគាត់ក្រោយពីពិភាក្សាគ្នារួច ហើយមនោសញ្ចេតនាបានកើតឡើងរវាងពួកគេ មុននឹងគាត់ស្លាប់ទៅ[2492]។ ផ្ទុយទៅវិញ នេះជាតម្រុយបង្ហាញថា ការរួមភេទត្រូវបានចាត់ទុកជាកាតព្វកិច្ចកើតចេញពីចំណង

---

[2490] ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 11.31.01។ នៅកថាខណ្ឌ ៣៦៤៩ អង្គជំនុំជម្រះបានបន្ទោសដល់មេធាវីការពារក្តីថាបានបម្លែងចម្លើយនេះដើម្បីសន្និដ្ឋានថាសក្ខីកម្មរបស់គាត់គួរឱ្យទុកចិត្តបាន និងគួរឱ្យជឿជាក់បាន។

[2491] ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 11.28.32 និងម៉ោង 11.31.01។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** មុនម៉ោង 15.18.40 (ឪពុកគាត់បានជួយរកប្តីគាត់បន្ទាប់ពីបានបាត់ខ្លួន និងជួយថែទាំគាត់ បន្ទាប់ពីគាត់បានបង្កើតកូនរួច)។

[2492] ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ម៉ោង 14.40.27 (“ដឹងគេរំលោភ ខ្លួនបានហ្នឹងទៅក៏ខ្ញុំមកនៅសហជីពវិញ”) ម៉ោង 15.14.49។ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** មុនម៉ោង 13.53.46 (“ខ្ញុំបាននិយាយហេតុផលពីការរស់នៅអីជាមួយគ្នាអ៊ីចឹងទៅ គាត់បាននិយាយប្រាប់ខ្ញុំថា យើងបានរស់នៅបានដល់លង់ខ្លួនខូចព្រហ្មចារីហើយ គាត់អង្វរចិត្តខ្ញុំថាឱ្យខ្ញុំហ្នឹងរស់នៅជាមួយគាត់ជាប្តីជាប្រពន្ធទៅ ដើម្បីឱ្យជីវិតយើងរស់នៅតទៅទៀត។ គាត់អត់មានអ្នកណាមកទេ គឺពិចារណាតែពីរនាក់ប្តីប្រពន្ធ”)។

អាពាហ៍ពិពាហ៍ ជាករណីយកិច្ចរួមសង្វាស ស្របតាមទស្សនៈប្រពៃណីនៃចំណងអាពាហ៍ពិពាហ៍។ ករណីនេះក៏ពន្យល់ផងដែរថា ហេតុអ្វីបានជាក្នុងការថ្លែងអំពីទុក្ខសោក គាត់បានលើកឡើងអំពីអវត្តមានរបស់ប្ដីគាត់ ក្នុងពេលគាត់មានគភ៌[2493]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានយកចិត្តទុកដាក់ដល់ភស្តុតាងទាំងនេះទេ។

### ២.២.១.៤. គ្មានការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ ក្នុងវប្បធម៌ខ្មែរនៅសម័យនោះ

១៣១៦. អង្គជំនុំជម្រះបានបំភ្លេចចោលទាំងស្រុងនូវបរិបទវប្បធម៌ និងបរិបទច្បាប់ ដែលមេធាវីការពារក្ដីបានលើកឡើង ហើយក្នុងនោះ ពុំមានទស្សនាទាននៃការរំលោភសេពសន្ថវៈទេ រហូតមកទល់នឹងពេលថ្មីៗនេះ[2494]។ ប៉ុន្តែ វាមានផលប៉ះពាល់ជាក់ស្ដែងទៅលើការយល់ឃើញអំពីការរួមភេទរវាងប្តីប្រពន្ធ មុន ក្នុង និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដូចអ្នកជំនាញ Kasumi NAKAGAWA បានរំឭក៖ "ស្ថានភាពមុនឆ្នាំ១៩៧៥ ហ្នឹង គឺខុសគ្នាឆ្ងាយណាស់ពីបច្ចុប្បន្ននេះ"[2495] [...] "យោងតាមការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាទៅលើស្ត្រីនៅក្នុងប្រទេសកម្ពុជា ឬក៏ក្នុងបណ្តាប្រទេសដទៃទៀតក្តី គឺមានការរាយការណ៍មកថា ការការរំលោភសេពសន្ថវៈនៅក្នុងចំណងអាពាហ៍ពិពាហ៍ ពិតជាកើតមាន ហើយចំណុចនេះអាចពិតមែន ដោយមិនគិតពីពេលវេលាណាក្តី មានគ្រប់ពេលទាំងអស់"[2496] [...] "សូម្បីតែឥឡូវនេះ នីតិព្រហ្មទណ្ឌកម្ពុជាមិនបានចែងឱ្យបានច្បាស់ថា ការរំលោភនៅក្នុងចំណងអាពាហ៍ពិពាហ៍ គឺជាបទល្មើសនោះទេ"[2497]។

---

[2493] ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ក្រោយម៉ោង 14.03.34 "បង្ខំខ្ញុំឱ្យរួមរក្សទាំងការឈឺចាប់ ទាំងខ្ញុំមិនចង់ [...]។ ឱ្យខ្ញុំចុកចាប់ក្នុងផ្លូវចិត្តផង ក្នុងរាងកាយផង។ ហើយមិនប៉ុណ្ណោះទៀតសោត ពេលខ្ញុំមានផ្ទៃពោះ គាត់មិនបានទុកឱ្យប្តីខ្ញុំនៅគ្រប់គ្រងខ្ញុំ នៅមើលថែទាំខ្ញុំ ឬរកអ្វីចំណីអាហារអីផ្គត់ផ្គង់ពេលខ្ញុំមានផ្ទៃពោះ ឬឆ្លងទន្លេទេ។ គឺគាត់យកប្តីខ្ញុំទៅសម្លាប់ចោល"។

[2494] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣៥០-២៣៥៥។

[2495] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 10.48.48។

[2496] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** មុនម៉ោង 11.08.27។

[2497] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 15.21.33. សូមមើលផងដែរ ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ក្រោយម៉ោង 15.32.44។

១៣១៧. ដូច Kasumi NAKAGAWA បានលើកឡើងរួចមកហើយ ចំពោះខ្មែរ បញ្ហាផ្លូវភេទជារឿងដែលហាមឃាត់មិនឱ្យនិយាយ សូម្បីតែរវាងម្ដាយ និងកូនស្រី[2498]។ មនោសញ្ចេតនាស្នេហាមិនត្រូវគេចាត់ទុកជាបុរេលក្ខខ័ណ្ឌឡើយ ក្នុងអាពាហ៍ពិពាហ៍តាមបែបប្រពៃណី ហើយក្នុងក្របខ័ណ្ឌនៃចំណងអាពាហ៍ពិពាហ៍ ស្ត្រីត្រូវបំពេញករណីយកិច្ចរបស់ខ្លួន៖

> "មុនសម័យកម្ពុជាប្រជាធិបតេយ្យ ស្ត្រីត្រូវបានរឹតត្បិត គឺមិនឱ្យគិត ឬមិនត្រូវគិតអំពីគំនិតស្នេហា ឬអ្វី មុនរៀបការនោះទេ។ គេគ្មានគំនិតយោបល់អ្វីទេ ទាក់ទងនឹងរឿងស្នេហា។ ស្ត្រីត្រូវតែបង្ហាញសម្ដែងពីមនោសញ្ចេតនារបស់ខ្លួនទៅប្ដី ទៅបុរស"[2499]។
> [...] "ពាក្យថា ស្រឡាញ់ ឬស្នេហា នេះ គឺពិបាកក្នុងការនិយាយ ឬក៏កំណត់អត្តសញ្ញាណណាស់ តាមប្រពៃណី ឬក៏ទំនៀមទម្លាប់ខ្មែរនោះ។ ស្ត្រីគឺត្រូវយល់តាមការសន្មតថា ខ្លួនមានប្ដី ខ្លួនត្រូវគោរពប្ដី ហើយគាត់ត្រូវតែស្រឡាញ់ប្ដី ប៉ុន្តែពាក្យថាស្នេហានេះក៏វាមានលក្ខណៈស្មុគស្មាញ"[2500]។

១៣១៨. ការគោរពប្រណិប័តន៍ប្ដីក្នុងក្របខ័ណ្ឌនៃចំណងអាពាហ៍ពិពាហ៍ រួមទាំងផ្លូវភេទ ត្រូវបានអនុវត្តនៅក្នុងជីវិតគូស្រករ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្រី ដែលបទប្បញ្ញត្តិខ្លះទើបតែត្រូវបានលុបចោលថ្មីៗនេះ៖

> "[...] នៅក្នុងឆ្នាំ២០០៦ ឬ ២០០៧។ គណៈកម្មាធិការស៊ីដវ (CEDAW) របស់អង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងការរើសអើងប្រឆាំងស្ត្រី បានផ្ដល់អនុសាសន៍ទៅដល់រដ្ឋាភិបាលកម្ពុ

[2498] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** ម៉ោង 11.14.27 មុនម៉ោង 11.24.18(ស្ដីអំពីការមិនមានការអប់រំណាផ្នែកផ្លូវភេទរវាងស្ត្រី), ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 11.14.27 (ប្ដីប្រពន្ធជាច្រើនគូដែលរៀបចំដោយឪពុកម្ដាយបានជួបមុខគ្នាលើកទី១នៅថ្ងៃរៀបអាពាហ៍ពិពាហ៍តែម្ដង ហើយគេប្រើពេលច្រើនខែមុននឹងរួមដំណេក)។

[2499] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ក្រោយម៉ោង 15.41.57។

[2500] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 10.39.56 និង មុនម៉ោង 10.44.57
។

ជាថា ឱ្យឈប់បង្រៀនច្បាប់ស្រី និងឈប់សរសេរនៅក្នុងសៀវភៅកម្មវិធីសិក្សាទៀតទៅ ព្រោះវាជានិមិត្តរូបនៃការគាបសង្កត់ស្ត្រីនៅប្រទេសកម្ពុជា។ ដូច្នេះ ក្នុងការឆ្លើយតបទៅនឹងអនុសាសន៍ពីគណៈកម្មាធិការស៊ីដវ គឺរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងអប់រំក៏បានលុបចោលទៅ។ ដូច្នេះ ជាផ្លូវការ ច្បាប់ស្រីនេះលែងបង្រៀននៅក្នុងកម្មវិធីរដ្ឋតទៅទៀតហើយ។ ទោះជាយ៉ាងណាក៏ដោយ ទស្សនៈនៃច្បាប់ស្រី ដែលយល់ថាជាការដកហូតនូវសេរីភាពរបស់ស្ត្រី នៅតែមានដដែល”[2501]។

១៣១៩. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិចារណាលើបរិបទវប្បធម៌ និងទស្សនាទានជាប្រពៃណីនៃជីវិតជាគូស្រករ ដែលរួមបញ្ចូលទាំងការរួមដំណេក។ ដោយហេតុថាព្រហ្មចារីមានសារៈសំខាន់ណាស់ចំពោះស្ត្រី វិធានការគ្រប់គ្រងលើទំនាក់ទំនងរវាងបុរស និងស្ត្រី តាមរយៈការរៀបអាពាហ៍ពិពាហ៍ គឺជារឿងចាំបាច់។ បើតាមអ្នកជំនាញ Peg LEVINE ព្រហ្មចារីមិនមែនត្រូវបានគិតគូរតែតាមបែបវេជ្ជសាស្ត្រនោះទេ ស្ត្រីខ្មែរភាគច្រើនចៀសវាងការប្រាស្រ័យទាក់ទងជាមួយបុរសដោយខ្លាចគេមើលមកមិនល្អ និងខ្លាចមានឈ្មោះជានារីមិនល្អដែលជួបគ្នាជាមួយបុរស[2502]។ ផ្ទុយមកវិញ នៅក្នុងជីវិតគូស្រករដែលបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ ការរួមភេទគឺជាសិទ្ធិចំពោះបុរស និងជាករណីយកិច្ចចំពោះស្ត្រី។

១៣២០. អាស្រ័យហេតុនេះ អង្គជំនុំជម្រះគួរណាតែវាយតម្លៃលើភាពធ្ងន់ធ្ងរនៃការឈឺចាប់របស់ស្ត្រី ដែលកើតចេញការរួមភេទជាមួយប្ដីក្នុងបរិបទវប្បធម៌ខ្មែរ នៅពេលកើតហេតុ ដែលក្នុងនោះ ស្ត្រីពុំមានសេរីភាពច្រើនក្នុងការទាក់ទងជាមួយបុរសទេ ហើយត្រូវគោរពប្រណិប័តន៍ប្ដីក្នុងការរស់នៅប្រចាំថ្ងៃ និងការរួមភេទ។ ដោយលាក់បាំងទិដ្ឋភាពនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងខកខានមិនបានពន្យល់អំពីការលាតត្រដាងយឺតពេលរបស់ ព្រាប សុខឿន ដែលទើបតែគិតឃើញទស្សនៈនៃការរំលោភសេពសន្ថវៈ និងការឈឺចាប់ ក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្ដី។

---

[2501] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 13.32.15។

[2502] Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.1** ម៉ោង 15.40.10។

១៣២១. ម្យ៉ាងវិញទៀត ជាទូទៅ អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ឃើញថា របៀបនៃការរៀបរាប់អំពីការរួមភេទលើកដំបូងរបស់ស្ត្រីជាមួយបុរសដែលខ្លួនមិនស្គាល់ ឬស្គាល់មិនសូវច្បាស់ មិនខុសគ្នាអាស្រ័យថាការរួមភេទនោះបានកើតឡើង ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំពីឪពុកម្តាយ ឬពីអាជ្ញាធរមូលដ្ឋាន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ អវត្តមានការអប់រំផ្លូវភេទ និងទម្ងន់សង្គម ធ្វើឱ្យបុរសមិនចាំបាច់ធានាឱ្យមានការយល់ព្រម ឬការត្រៀមខ្លួនពីស្ត្រីចំពោះការរួមភេទឡើយ។ ថ្វីត្បិតតែស្ថានភាពនេះមានលក្ខណៈគួរឱ្យសោកស្តាយ និងអយុត្តិធម៌ចំពោះស្ត្រីក៏ដោយ ក៏វាជាតថភាពសង្គមនៅកម្ពុជា ដែលអង្គជំនុំជម្រះគួរណាតែយកមកពិចារណា ក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ពីព្រោះតថភាពនេះត្រូវបានបញ្ជាក់ច្បាស់ក្នុងសវនាការ តាមរយៈរឿងរ៉ាវរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[2503]។

---

[2503] ជាំង ស្រីមុំ៖ ប្រតិចារឹក ទី២៩ ខែមករា ឆ្នាំ២០១៥ E1/254.1 ម៉ោង 10.46.18 ម៉ោង 15.43.48 (“គាត់អត់មានបង្ខំយើងទេ ប៉ុន្តែគាត់គ្រាន់តែនិយាយជាពាក្យសម្តីណែនាំយើងពីតួនាទីប្តីប្រពន្ធ។ យើងជាមិនផុតពីប្តីប្រពន្ធ គ្រាន់តែគាត់ណែនាំប៉ុណ្ណឹងទេ ថាអនាគតទៅ យើងចៀសមិនផុតពីប្តីប្រពន្ធ អ៊ីចឹងគាត់គ្រាន់តែណែនាំរឿងមួយភាគលួងលោមយើងតែប៉ុណ្ណឹងទេ”)។ ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា https://www.cignahealthbenefits.com/en/login-mobile ឆ្នាំ២០១៦ ឯកសារ E1/487.1 ក្រោយម៉ោង 14.38.09។ ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ E1/483.1 ម៉ោង 09.57.02។ ណុប ង៉ឹម៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E1/469.1 មុនម៉ោង 10.43.40 (“ទ្រាំបាន បានគ្រួសារខ្ញុំចេះស្រឡាញ់គ្នារហូត”) ម៉ោង 11.12.40 និងម៉ោង 14.19.56។ ប៊ិត ហឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ E1/502.1 ម៉ោង 11.23.28 (“ក្រោយពីរៀបការទៅ អាហ្នឹងគេទៅតាមគូៗរបស់ផងគេទៅ។ គេមិនចាំបាច់មានការណែនាំ គេដឹងតែមួយគូៗគ្នាគេ”)។ សយ ណារឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ E1/489.1 ម៉ោង 10.48.15 និងម៉ោង 11.10.23 ម៉ោង 10.51.58 គាត់ត្រូវស្តាប់តាមប្តីរបស់គាត់ តាមចិត្តរបស់គាត់ និងសុខចិត្តរស់នៅជាប្តីប្រពន្ធ។ ជុំ សាមឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ E1/321.1 ចន្លោះម៉ោង 14.31.44 និងម៉ោង 14.33.31 គាត់បានលើកឡើងពីការខ្វះបទពិសោធន៍ នៅពេលយប់ផ្សំដំណេក និងអំពីប្តីគាត់ដែលយល់ព្រមរង់ចាំមុននឹងផ្សំដំណេក។ សូមមើលផងដែរ កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E3/9662 ស/ឆ ៤៦-៤៩៖ និយមន័យនៃការរួមបវេណី នៃការរួមភេទ ប៉ុន្តែគាត់អៀនខ្មាស់និយាយមិនចេញ ដោយសារវប្បធម៌ខ្មែរ។ ស/ឆ ៥០, ៦៦-៦៧៖ ការខ្វះបទពិសោធន៍ នៅពេលយប់ផ្សំដំណេក៖ ការមិនធ្លាប់រួមភេទមុនពេលរៀបការ និងការខ្វះចំណេះដឹងផ្លូវភេទ។ ស/ឆ ៤២-៤៣៖ គាត់មិនហ៊ាននៅតែពីរនាក់តទល់ជាមួយប្តីគាត់ទេ ខ្លាចគាត់ចាប់រំលោភ រហូតដល់ពេលម្តាយគាត់និយាយប្រាប់។ ស/ឆ ៧៤-៧៥៖ខ្មាស់គេមិនហ៊ាននិយាយពីរឿងមិនបានផ្សំដំណេក។ ស/ឆ ៥៥-៥៩៖ ស្រឡាញ់ប្តី បន្ទាប់ពីបានរួមភេទជាមួយប្តី។

១៣២២. ប៉ុន្តែ ក្នុងដំណើរការបែបជ្រើសរើស និងលម្អៀង អង្គជំនុំជម្រះបែរជាសន្និដ្ឋានថា មានឆន្ទៈនយោបាយពី ប.ក.ក ក្នុងការជំរុញឱ្យរួមភេទដោយបង្ខំ ក្រោយការរៀបអាពាហ៍ពិពាហ៍ និងបានធ្វើការវិភាគភ័ស្តុតាងខុសទាំងស្រុង។ ក្នុងការវិភាគលើកម្រិតឈឺចាប់ អង្គជំនុំជម្រះគួរណាតែរកឃើញថា ការឈឺចាប់ចំពោះការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី មិនខុសគ្នាទេ បើផ្អែកលើរបៀបនៃការយល់ឃើញអំពីការរួមភេទ ក្នុងក្របខ័ណ្ឌនៃចំណងអាពាហ៍ពិពាហ៍។ លើសពីនេះទៀត ដូចបានឃើញខាងលើ អំពីបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍តាមការចង់បានរបស់ ប.ក.ក អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ពាក់ព័ន្ធនឹងការព្យាយាមរបស់បក្សក្នុងការដាក់បញ្ចូលទំនើបភាព ទៅក្នុងទំនាក់ទំនងរវាងបុរស និងស្ត្រី[2504]។

១៣២៣. កំហុសរបស់អង្គជំនុំជម្រះមានទំហំធំធេងណាស់ ដោយហេតុថាអង្គជំនុំជម្រះមិនបានប្រៀបធៀបរឿងរ៉ាវដែលបានជ្រើសរើស ជាមួយនឹងភ័ស្តុតាងទាំងមូល ដើម្បីឱ្យដឹងអំពីភាពជាតំណាងនៃការឈឺចាប់ ដូចបានកំណត់និយមន័យ និងអត្ថសញ្ញាណ។

## ២.២.២. កំហុសពាក់ព័ន្ធនឹងការវិភាគភ័ស្តុតាងទាំងមូល និងភាពជាតំណាង

១៣២៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការវិភាគតាមបែបជ្រើសរើស និងលម្អៀង ដោយមិនខ្វល់ពីភ័ស្តុតាងទាំងមូល ដែលបានដាក់នៅចំពោះមុខខ្លួន ដើម្បីសន្និដ្ឋានថា ការរួមភេទដែលស្ត្រីបានទទួលរង ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បង្កឱ្យមានការឈឺចាប់កម្រិតធ្ងន់ធ្ងរ ដែលអាចឱ្យកំណត់បានថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត។ ប៉ុន្តែ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ មិនឈរលើការពិនិត្យអាព្យាក្រឹតលើភ័ស្តុតាងទាំងមូលឡើយ។

### *២.២.២.១. សក្ខីកម្មនៅវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍*

[2504] សូមមើលខាងលើ កថាខណ្ឌ ១១៥១។

១៣២៥. ដូចបានឃើញពីខាងលើ នៅវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មអ្នកជំនាញ ២ នាក់ សាក្សី ២ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៩ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ៣ នាក់ អំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម[2505]។

១៣២៦. **<u>ដើមបណ្តឹងរដ្ឋប្បវេណី ៣ នាក់ អំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម៖</u>** ង៉ែត ចាត, សយ ណារឿន និង កុល ណែម (ប្រុស)។ ដូចបានលើកឡើងពីខាងលើ ទាំង ង៉ែត ចាត ទាំង សយ ណារឿន មិនបានលើកឡើងអំពីការឈឺចាប់បណ្តាលមកពីការរួមភេទ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ទេ ក្នុងពេលថ្លែងទុក្ខសោក នៅចុងសវនាការ[2506]។ ង៉ែត ចាត មិនបាននិយាយអំពីការឈឺចាប់នេះទាល់តែសោះ សូម្បីតែក្នុងពេលផ្តល់សក្ខីកម្មអំពីអង្គហេតុ[2507] ចំណែកឯ សយ ណារឿន គាត់បានលើកឡើងអំពីការឈឺចាប់បណ្តាលមកពីការបាត់បង់ព្រហ្មចារី ដែលសំខាន់ចំពោះស្ត្រីខ្មែរ[2508]។ ជាចុងក្រោយ កុល ណែម ក្នុងនាមជាបុរស មិនមែនជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈ នៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ម្យ៉ាងវិញទៀត កុល ណែម មិនបាននិយាយអំពីផលប៉ះពាល់នៃការរួមភេទលើប្រពន្ធគាត់នោះទេ ហើយគាត់បានឆ្លើយថា ការឈឺចាប់ ដែលគាត់បានទទួលរងជាមួយប្រពន្ធគាត់ គឺបណ្តាលមកពីការគ្មានកូន[2509]។ លើសពីនេះទៅទៀត គាត់បានបញ្ជាក់ថា ប្រពន្ធគាត់បានដឹងមុនអំពីការរៀបអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ហើយវាបានក្លាយជាប្រធានបទនៃការបង្អាប់គ្នារវាងស្រីៗនៅក្នុងក្រុម[2510]។ ដូច្នេះ សក្ខីកម្មរបស់គាត់មិនអាចឱ្យសន្និដ្ឋានថា ប្រពន្ធគាត់មានការឈឺចាប់ធ្ងន់ធ្ងរបណ្តាលមកពីការរៀបអាពាហ៍ពិពាហ៍ទេ។

---

[2505] សូមមើលខាងក្រោម កថាខណ្ឌ ១១៧៥-១១៨៧។ សូមមើលឧបសម្ព័ន្ធ ខ៥។

[2506] សូមមើលខាងលើ កថាខណ្ឌ ១១៥៦-១១៥៨។

[2507] គាត់បានរំឭកពីការលបស្តាប់របស់ពួកឈ្លប។ <u>ង៉ែត ចាត</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 16.05.27 ("អត់ហ៊ាននិយាយជាមួយគ្នា មានឈ្លបតូចៗ គេលបចាំស្តាប់")។ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ E1/489.1 មុនម៉ោង 09.09.43 "ខ្លាចគេញ ខ្លាចគេស្តាប់ដឹង")។

[2508] <u>សយ ណារឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** មុនម៉ោង 10.48.15 និង à 10.55.19។

[2509] <u>កុល ណែម</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ក្រោយម៉ោង 14.35.14 ("ធ្វើបាបប្រពន្ធខ្ញុំឱ្យខ្ញុំទាល់តែអត់មានកូន មានចៅ ហើយមិនមែនត្រឹមប្រពន្ធខ្ញុំទេ កូនគេខ្លះទៀត [...] អ្នកការជាមួយខ្ញុំហ្នឹង [...] កូនមកត្រូវរលូតៗ")។

[2510] <u>កុល ណែម</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 15.11.00។

១៣២៧. **សាក្សី ២ នាក់** គឺ ផាន់ ហ៊ីម និង ណុប ងឹម៖ ដោយសារតែសាក្សីទាំងពីរមិនត្រូវបានចាត់ទុកថាបានទទួលរងការរំលោភសេពសន្ថវៈ អង្គជំនុំជម្រះមិនអាចយកសក្ខីកម្មរបស់ពួកគាត់ ដូចបានធ្វើ មកគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួនអំពីភាពធ្ងន់ធ្ងរនៃការឈឺចាប់ ចំពោះឧក្រិដ្ឋកម្មនេះឡើយ[2511]។ ជាក់ស្តែង ផាន់ ហ៊ីម មិនត្រឹមតែមិនបាននិយាយអំពីការឈឺចាប់បណ្តាលមកពីការរួមភេទជាមួយប្តីគាត់ប៉ុណ្ណោះទេ ផ្ទុយទៅវិញ គាត់ថែមទាំងបានផ្តល់សក្ខីកម្មអំពីការវិវត្តនៃមនោសញ្ចេតនារបស់ពួកគាត់ ទៅតាមពេលវេលា មុននឹងរួមភេទទៀតផង[2512]។ ចំណែកឯ ណុប ងឹម មេធាវីការពារក្តីសូមយោងទៅទឡ្ហីករណ៍ដែលបានរៀបរាប់ខាងលើ នៅត្រង់កន្លែងដែលគាត់បានបញ្ជាក់យ៉ាងជាក់លាក់ថា គាត់មិនត្រូវគេបង្ខំឱ្យរួមភេទជាមួយប្តីគាត់ទេ[2513]។

១៣២៨. **ដើមបណ្តឹងរដ្ឋប្បវេណី ៩ នាក់ អំពីអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍** ក្នុងនោះ មានស្ត្រី ៦ នាក់ បុរស ២ នាក់ និងភេទទីបីម្នាក់[2514]។ អង្គជំនុំជម្រះបានទទួលយកតែសក្ខីកម្មរបស់ ព្រាប សុខឿន ម្នាក់គត់ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន។ ដូចបានរៀបរាប់ពីខាងលើ រឿងរ៉ាវរបស់គាត់មិនអាចឱ្យសន្និដ្ឋានថា គាត់បានទទួលរងការឈឺចាប់ ក្នុងកម្រិតប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀតឡើយ[2515]។ ដូច ជា ឌៀប ដែរ ទោះបីជាបានបញ្ជាក់ថាគាត់រៀបការខុសពីចិត្តក៏ដោយ ក៏ហេង ឡៃហ៊ាង មិនបាននិយាយអំពីផលប៉ះពាល់ជាក់លាក់បណ្តាលមកពីការរួមភេទ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ឡើយ[2516]។

---

[2511] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៩, ៣៦៦១ *ផ្នែក ១៤.៣.៨.៣ ការរួមដំណេកដោយបង្ខំរវាងប្តីប្រពន្ធ។*

[2512] ផាន់ ងឹម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.41.31។

[2513] ណុប ងឹម៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 14.19.56 និងម៉ោង 11.12.40។

[2514] អ៊ុំ យឿន, ជា ឌៀប, ព្រាប សុខឿន, មុំ វុន, ហេង ឡៃហ៊ាង, ប៉ែន សុចាន់, ស៊ូ សុធាវី (ស្ត្រីភេទទីបី), សេង ស្រ៊ុន (បុរស) និង យស ផល (បុរស)។

[2515] សូមមើលខាងលើ ករណីលើកឡើងនៅក្នុងផ្នែក *១៤.៣.៨.២ ផលប៉ះពាល់នៃការរួមដំណេកដោយបង្ខំទៅលើជនរងគ្រោះ* កថាខណ្ឌ ១៣១៣-១៣២៣។

[2516] ហេង ឡៃហ៊ាង៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/4761** ម៉ោង 16.12.09។ គាត់ចាំថាមិនមានការតាមដានទេ ហើយមិនបានផ្សំដំណេកនៅយប់ថ្ងៃរៀបការទេ ប៉ុន្តែច្រើនខែក្រោយមក ពីព្រោះថា “កាលពីពេលនោះ មិនទាន់ស្រឡាញ់គ្នាទេ”។ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/4761** ម៉ោង 09.54.02 ក្រោយម៉ោង 10.01.15 ម៉ោង 11.23.06។

១៣២៩. គ្មានចំណុចណាមួយ នៅក្នុងរឿងរ៉ាវរបស់បុរសទាំងនេះ អាចឱ្យចង្អុលបង្ហាញអំពីផលប៉ះពាល់ជាយថាហេតុលើស្ត្រីដែលពួកគាត់បានរៀបការជាមួយឡើយ។ យស ផល មិនបាននិយាយអំពីការឈឺចាប់របស់ប្រពន្ធដែលគាត់បានរៀបការជាមួយ នៅក្នុងរបបនោះឡើយ។ គាត់បានឆ្លើយថា គាត់មិនបានប៉ះពាល់ប្រពន្ធគាត់ទេ ក្រោយពេលរៀបការរួច គឺពួកគាត់បានចំណាយពេលវេលារៀនស្គាល់ចិត្តគ្នា និងឱ្យតម្លៃគ្នាទៅវិញទៅមកសិន មុននឹងរួមរស់ជាប្ដីប្រពន្ធ និងមានកូន[2517]។ ចំពោះ សេង សឿន គាត់មិនបានរៀបរាប់អំពីការរួមភេទទេ ទាំងក្នុងពេលផ្ដល់សក្ខីកម្មអំពីអង្គហេតុ ទាំងក្នុងពេលថ្លែងទុក្ខសោក នៅចុងសវនាការ[2518]។

១៣៣០. សរុបសេចក្ដីមក សូម្បីតែភ័ស្ដុតាង ដែលបានដាក់ជាពិសេស នៅវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ ក៏មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា ការឈឺចាប់ដែលស្ត្រីបានទទួលរងបណ្ដាលមកពីការរួមភេទដោយបង្ខំ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ មានកម្រិតធ្ងន់ធ្ងរស្មើនឹងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត បានដែរ។ អង្គជំនុំជម្រះក៏មិនអាចផ្អែកលើភ័ស្ដុតាងខាងលើ ដើម្បីសន្និដ្ឋានថាមានគោលនយោបាយជាតិរបស់ ប.ក.ក ស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានដែរ[2519]។

### *២.២.២.២. សក្ខីកម្ម ក្នុងសំណុំរឿង ០០២/០២ ក្រៅវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍*

១៣៣១. **វគ្គសហករណ៍ត្រាំកក់៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១៤ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែសាក្សី ជាំង ស្រីមុំ ម្នាក់គត់ ដែលបានឆ្លើយថា គាត់បានរៀបការ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចបានបង្ហាញពីខាងលើ ទោះបីជាគាត់មានអារម្មណ៍ថាត្រូវគេបង្ខំឱ្យរួមភេទជាមួយប្ដីគាត់នៅរាត្រីផ្សំដំណេកក៏ដោយ ក៏គាត់បានបញ្ជាក់

---

[2517] យស ផល៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 10.03.14 ម៉ោង 10.44.39 ម៉ោង 10.53.07 ។

[2518] សេង សឿន៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/465.1** ម៉ោង 10.07.42។

[2519] សូមមើលខាងក្រោម កថាខណ្ឌ ១២៤៣-១២៨០។

ជាច្រើនដងថា ប្ដីគាត់មិនបានបង្ខំគាត់ទេ ហើយពួកគាត់រួមរស់ជាមួយគ្នារហូតដល់សព្វថ្ងៃ[2520]។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានភាពឈឺចាប់ធ្ងន់ធ្ងរខ្លាំងបានទេ ចំពោះករណីរបស់គាត់។

១៣៣២. **វគ្គទំនប់១មករា៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១០ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង ម្នាក់គត់ដែលបានឆ្លើយថា គាត់បានរៀបការដោយបង្ខំ[2521]។ ប៉ុន្តែ គាត់មិនបានលើកឡើងអំពីការទទួលរងសម្ពាធ ឬការឈឺចាប់ណាមួយបណ្ដាលមកពីការរួមភេទជាមួយប្ដីគាត់ឡើយ ហើយគាត់បានបញ្ជាក់ថា ការលែងលះគ្នា នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនមកពីមូលហេតុនៃមនោសញ្ចេតនារបស់ពួកគាត់ទេ[2522]។

១៣៣៣. **វគ្គទំនប់ត្រពាំងថ្ម៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ៩ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ត្រីម្នាក់បានឆ្លើយថា គាត់បានរៀបការខុសពីចិត្ត ហើយបុរសម្នាក់បានរៀបការតាមការផ្សំផ្គុំ[2523]។ យី ឡៃស្រូវ មិនបាននិយាយអំពីការឈឺចាប់បណ្ដាលមកពីការរួមភេទជាមួយប្ដីគាត់ទេ ប៉ុន្តែ ប្ដីគាត់ជាអ្នកចាប់ផ្ដើមមុន នៅពេលជួបគ្នាលើកទីពីរ ដោយមិនបានរៀបរាប់លម្អិត[2524]។ ចំពោះ មាន លឿយ គាត់បានឆ្លើយថា ការរួមភេទគឺជាព្រមព្រៀងគ្នារវាងគូ

[2520] សូមមើលខាងលើ កថាខណ្ឌ ១១៨០, ១៣០៤-១៣០៥។

[2521] ក្នុងចំណោមសាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០ នាក់ ៣ នាក់ បានអះអាងថាមិនត្រូវបានគេបង្ខំឱ្យរៀបការទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[2522] ចៅ ឡាង៖ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** មុនម៉ោង 14.40.37 ក្រោយម៉ោង 15.32.23 បានលែងលះនៅឆ្នាំ ១៩៨៨-១៩៨៩ ("នាងខ្ញុំលែងលះគ្នានេះដោយសារតែការរៀបការដោយបង្ខំសម័យខ្មែរក្រហម គឺឪពុកម្ដាយខាងប្ដីខ្ញុំហ្នឹងគាត់មិនពេញចិត្ត")។

[2523] យី ឡៃស្រូវ៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/334.1** ម៉ោង 14.03.06។ មាន លឿយ៖ ប្រតិចារឹក ថ្ងៃទី ២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ចន្លោះម៉ោង 14.10.07 និងម៉ោង 14.15.38។

[2524] យី ឡៃស្រូវ៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/334.1** ម៉ោង 14.20.23។

គាត់[2525] និងបានបង្ហាញអំពីអារម្មណ៍ជិតដាមនឹងប្រពន្ធគាត់ដែលបានរៀបការក្នុងរបបនោះ ដោយបញ្ជាក់ថា មរណភាពរបស់ប្រពន្ធគាត់ គឺជាមូលហេតុនៃការឈឺចាប់[2526]។

១៣៣៤. **វត្ថុផ្សេងទៀតក្នុងក្របខ័ណ្ឌសំណុំរឿង ០០២/០២៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ២១ នាក់ ដែលបានរៀបអាពាហ៍ពិពាហ៍ក្នុងរបបនោះ មានស្ត្រី ៦ នាក់ ក្នុងចំណោមនោះ ស្ត្រីម្នាក់បានឆ្លើយថាបានរៀបការតាមការផ្សំផ្គុំពីអង្គការ ពីរនាក់ត្រូវគេបង្ខំឱ្យរៀបការ និងបីនាក់ទៀតបានរៀបការតាមការព្រមព្រៀង[2527]។ ប៉ុន្តែ គ្មានស្ត្រីណាម្នាក់បានលើកឡើងអំពីការឈឺចាប់បណ្ដាល មកពីការរួមភេទជាមួយប្ដីទេ។ ធុច ស៊ីថន មិនបានលើកឡើងអំពីការឈឺចាប់ទេ ហើយនៅពេលសួរថា តើគាត់បានទទួលការណែនាំអ្វីទេ គាត់បានឆ្លើយថា អត់ទេ ដោយបញ្ជាក់ថា នេះគឺជា "បញ្ហា - បារាំងហៅថា ឡាម៉ូរ៉ាល់លីតេ"[2528]។ ឃិន វ៉ាត បានឆ្លើយថាគាត់បានរួមដំណេក ក្រោយពី "អាណិត" ប្ដី[2529]។ ជុំ សាមឿន ដែលបានលើកឡើងអំពីការភ័យខ្លាចក្នុងនាមជានារីខ្មែរគ្មានបទពិសោធន៍ នៅយប់ផ្សំដំណេក បានអះអាងថា ប្ដីគាត់បានយល់ព្រមរង់ចាំសិន ហើយគាត់បានបញ្ជាក់ថា ក្រោយពីរៀបការបាន ៣ ថ្ងៃ ពួកគាត់ក៏បែកគ្នារហូត ហេតុនេះ ពួកគាត់មិនបានរួមដំណេកជាមួយគ្នាទេ[2530]។ លើសពីនេះទៅទៀត សូម្បីតែស្ត្រីដែលបានឆ្លើយថាត្រូវគេបង្ខំឱ្យរៀបការ ក៏មិនបានលើកឡើងអំពីផលប៉ះពាល់បណ្ដាលមក

---

[2525] <u>មាន លឿយ</u>៖ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ **E1/340.1** មុនម៉ោង 14.20.31 ចន្លោះម៉ោង 14.10.07 និងម៉ោង 14.15.38 ម៉ោង 14.17.56 ("ដោយសារតែខ្ញុំបានសិក្សាខាងគុណធម៌ច្រើន អ៊ីចឹងទោះបីល្អអាក្រក់យ៉ាងម៉េច ចាប់ដៃគ្នាហើយ គឺត្រូវតែស្រឡាញ់")។

[2526] <u>មាន លឿយ</u>៖ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ **E1/340.1** ម៉ោង 14.27.34 ម៉ោង 14.54.38។

[2527] ម៉ាត់ ស (យល់ព្រម), អ៊ុន យឿង (យល់ព្រម), ប៊ិត ហឿន (យល់ព្រម), ឃិន វ៉ាត (បង្ខំ), ជុំ សាមឿន (បង្ខំ) និង ធុច ស៊ីថន (រៀបដោយអង្គការ)។

[2528] <u>ធុច ស៊ីថន</u>៖ ប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/500.1** ក្រោយម៉ោង 15.03.46។

[2529] <u>ឃិន វ៉ាត</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/325.1** មុនម៉ោង 15.40.44 មុនម៉ោង 15.32.40 អារម្មណ៍របស់គាត់ក្រោយពីបានផ្សំដំណេក៖ "ការហើយបានប្រាំពីរថ្ងៃ គេឱ្យខ្ញុំត្រឡប់មកវិញ មិនអាចមិនមកបានទេ ព្រោះអីការចាត់តាំងរបស់គេ។ ម្ល៉ោះហើយ ខ្ញុំត្រូវបែកបាក់ប្ដីប្រពន្ធខ្ញុំដែលរៀបការថ្មីហ្នឹង ខ្ញុំត្រឡប់មកពោធិ៍ចិនតុងវិញ។ មិនអាចថាមិនមកបានទេ ព្រោះគេចាត់តាំងហើយ")។

[2530] <u>ជុំ សាមឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/321.1** ម៉ោង 14.27.20 ចន្លោះម៉ោង 14.31.44 និងម៉ោង 14.33.31។

ពីការរួមភេទឡើយ[2531]។ ចំពោះសក្ខីកម្មរបស់បុរសក្នុងវគ្គទាំងនេះវិញ ២ នាក់គត់ ក្នុងចំណោម ១៥ នាក់ បានឆ្លើយថា ពួកគាត់បានរៀបការខុសពីចិត្ត គឺ ជាល ជឿន និង ម៉ី សាវឿន។ ប៉ុន្តែ ក្នុងចំណោមអ្នកទាំងពីរ គ្មានអ្នកណាម្នាក់បានលើកឡើងអំពីផលប៉ះពាល់បណ្ដាលមកពីការរួមភេទជាមួយប្រពន្ធឡើយ។ ជាល ជឿន មិនបាននិយាយអ្វីសោះអំពីការរួមភេទ។ ម៉ី សាវឿន បានរង់ចាំរហូតដល់មានមនោសញ្ចេតនាចំពោះប្រពន្ធគាត់សិនទើបរួមភេទជាមួយគ្នា[2532]។ ដូច្នេះ គ្មានតម្រុយណាមួយអាចឱ្យសន្និដ្ឋានថា ប្រពន្ធរបស់ពួកគាត់មានការឈឺចាប់ធ្ងន់ធ្ងរកម្រិតខ្ពស់នោះទេ។

### *២.២.២.៣. ចម្លើយជាលាយលក្ខណ៍អក្សរ*

១៣៣៥. **ប្រតិចារឹកសំណុំរឿង ០០២/០១៖** ក្នុងចំណោមអ្នកបានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានស្ត្រីណាម្នាក់បានឆ្លើយថាបានរៀបការខុសពីចិត្តនោះទេ[2533]។ និយាយឱ្យចំតែម្តង នឹម សែម និង ស សៀក ដែលបានរៀបការនៅក្នុងរបបនោះ មិនបានលើកឡើងអំពីការឈឺចាប់ បណ្ដាលមកពីការរួមភេទទេ[2534]។ ចំពោះបុរស ដូចបានឃើញពីខាងលើ ចម្លើយរបស់ អែម អឿន និង យស ផល មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថាស្ត្រីមានការឈឺចាប់ បណ្ដាលមកពីការរួមភេទបានឡើយ[2535]។

១៣៣៦. **កំណត់ហេតុគាំទ្រដល់ដីកាដំណោះស្រាយ៖** ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយ ១១៦ បុគ្គល ២១ នាក់ បានឆ្លើយថាពួកគេបានរៀបការខុសពីចិត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្នុងនោះ ៥ នាក់ បានមកផ្ដល់សក្ខីកម្ម ក្នុងសំណុំរឿង ០០២/០២។ ចំពោះកំណត់ហេតុ ១៦ ទៀត គ្មានអ្នកណាម្នាក់បាន

---

[2531] ទោះបីជា អ៊ិន យឿង បានអះអាងថាត្រូវផ្សំដំណេក បើពុំនោះទេគេនឹងចាប់គាត់ទៅការិយាល័យឃុំក៏ដោយ តែគាត់មិនបានរំឭកដល់ការឈឺចាប់នៅក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងផ្លូវភេទរបស់គាត់ជាមួយប្តីគាត់ឡើយ។ ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/387.1** ក្រោយម៉ោង 15.39.49 ម៉ោង 14.18.10។

[2532] <u>ម៉ី សាវឿន</u>៖ ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/459.1** ក្រោយម៉ោង 14.10.57 និងក្រោយម៉ោង 14.20.24។

[2533] ស្ត្រីពីររូប ស សៀក និង នឹម សែម បានអះអាងថាបានរៀបការក្នុងរបបនេះ ប៉ុន្តែដោយការស្ម័គ្រចិត្ត។

[2534] ស សៀក៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/110.1**។ ប្រតិចារឹក ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/111.1។ នឹម សែម៖ ប្រតិចារឹក ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E1/126.1**។

[2535] សូមមើលខាងលើ កថាខណ្ឌ ១១៧៧-១១៧៨។

ឆ្លើយថាបានទទួលការឈឺចាប់បណ្តាលមកពីការរួមភេទ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ទេ។ ផ្ទុយទៅវិញ ចម្លើយខ្លះខុសពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវបានបំភ្លេចចោលដោយចេតនា[2536]។

១៣៣៧. **កំណត់ហេតុមកពីសំណុំរឿង ០០៣-០០៤៖** ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៨៥ មកពីសំណុំរឿង ០០៣-០០៤ បុគ្គល ៣០ នាក់ បានឆ្លើយថា ពួកគេបានរៀបការខុសពីចិត្ត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងនោះ មានស្ត្រី ១៧ នាក់ និងបុរស ១៣ នាក់។ ក្នុងចំណោមស្ត្រីទាំង ១៧ នាក់ ១០ នាក់ បាននិយាយអំពីផលប៉ះពាល់នៃការរួមភេទ[2537] ២ នាក់ បានអះអាងថាមិនបានរួមភេទ ក្រោយការរៀបអាពាហ៍ពិពាហ៍ភ្លាមៗ ដោយមិនបញ្ជាក់អំពីផលប៉ះពាល់ជាក់លាក់[2538] ម្នាក់បានឆ្លើយថាមិនបានរួមភេទទាល់តែសោះ[2539]។ ជាចុងក្រោយ ៤ នាក់ផ្សេងទៀត

---

[2536] កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ហាន ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5559** ERN 00375526 (ពួកគេរស់នៅជាមួយគ្នាដូចបងប្រុស ប្អូនស្រី ហើយបានរៀបការជាមួយគ្នាជាថ្មីក្រោយការដួលរលំនៃរបបនោះ ដោយម្តាយក្មេកបានស្នើសុំរៀបការ)។ អ្នកផ្សេងទៀតនិយាយពីការផ្សំដំណេក ប៉ុន្តែមិនមានឧប្បត្តិហេតុអ្វីចំពោះការរួមភេទនោះឡើយ៖ <u>ស្ត្រីៗ</u>៖ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ហង់ អ៊ិន ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5558** ERN 00375518 (ខ្ញុំមិន ហ៊ានរើបម្រះទេ ប្តីរបស់ខ្ញុំមិនមានភាពហិង្សាទេពីព្រោះខ្ញុំបានប្រគល់រាងកាយឱ្យគាត់ដោយសារខ្ញុំគ្មានជម្រើស" បន្ទាប់ពីនោះ គាត់ក៏ស្រឡាញ់ប្តីគាត់ និងចង់បង្កើតផ្សេងទៀតកូនជាមួយគ្នា)។ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ម៉ៅ គ្រឿន (ប្រពន្ធរបស់ ទេស ឌីង) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5561** ERN 00375552 ("ខ្ញុំមិនដែលមានផ្ទៃពោះក្នុងរបបខ្មែរក្រហម ពីព្រោះយើងមិនមានពេលនៅជាមួយគ្នា ហើយប្តីខ្ញុំនឹងខ្ញុំត្រូវបានបំបែកចេញពីគ្នា")។ <u>បុរសៗ</u>៖ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ទេស ឌីង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/5560** ERN 00375559 ("ប្រពន្ធរបស់ខ្ញុំ និងខ្ញុំបានពិភាក្សាគ្នាអំពីអ្វីដែលត្រូវធ្វើ ហើយបានធ្វើការសម្រេចចិត្តថាត្រូវទទួលយករឿងនេះ ដើម្បីរក្សាជីវិតរបស់យើងឱ្យបានគង់វង្ស")។ កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សារុធ (ភេទប្រុស) ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ **E3/5177** ERN 00196806 (ក្រោយការរួច គេឱ្យនៅជាមួយគ្នាបាន ៣ថ្ងៃ រួចបែកទៅធ្វើការរៀងៗខ្លួន)។ កំណត់ហេតុស្តាប់ចម្លើយ ឌុក ស្លូរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/408** ស/ឆ ៩៤ (ពួកគេមិនបានធ្វើដូច្នោះទេ [ត្រួតពិនិត្យមើលថាតើបានរួមភេទជាមួយគ្នាឬអត់])។

[2537] ជាម ញ៉ា, ម៉ក់ ម៉េត, ហ៊ុល ពៅ, ពៅ ស៊ីនួន, ពៅ សារ៉ុម, ថង ធឿយ, ទុំ ង៉ា, អ៊ុក ហ៊ីម និង មុំ ស្រឿង។

[2538] កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខែត សុខន ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ **E3/9830** ស/ឆ ៨១-៨២ (ប្តីគាត់សុំគាត់រួមភេទ ប៉ុន្តែមិនបានបង្ខំគាត់ចំនួនពីរបីយប់បន្ទាប់ពីរៀបការរួច)។ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខឿន ចឹម ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E3/9828** ស/ឆ ១១ (គាត់មិនបានរួមភេទជាមួយប្តីគាត់ នៅយប់ផ្សំដំណេកឡើយ ប៉ុន្តែក៏យល់ព្រមវិញប្អូនប្រាំយប់ក្រោយពីនោះ)។

បានឆ្លើយថា ពួកគាត់បានកសាងមនោសញ្ចេតនាចំពោះប្តី និងមិនបានទទួលរងបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត បណ្តាលមកពីការរួមភេទទេ[2540]។ ចម្លើយទាំងនេះផ្ទុយនឹងការសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះ នៅកថាខណ្ឌ ៣៦៥៩ និងកថាខណ្ឌ ៣៦៦១ នៃសំអាងហេតុសាលក្រម ដែលថាការរៀបអាពាហ៍ពិពាហ៍ដោយគ្មានការព្រមព្រៀង នាំឱ្យការរួមភេទរបស់ស្ត្រីជាមួយប្តីត្រូវធ្វើឡើងដោយបង្ខំ និងបង្កើតបានជាការរំលោភសេពសន្ថវៈ។

១៣៣៨. ដូចយើងទើបនឹងលើកឡើង ការពិនិត្យដោយយកចិត្តទុកដាក់ទៅលើសក្ខីកម្មដែលរៀបរាប់លម្អិតអំពីបទពិសោធន៍ និងអារម្មណ៍របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗ ធៀបនឹងភ័ស្តុតាងទាំងមូល មិនមានភាពស៊ីចង្វាក់គ្នាជាមួយការសន្និដ្ឋានរបស់អង្គជំនុំជម្រះទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានធ្វើវិចារណកិច្ចផ្លូវកាត់ និងយកករណីដោយឡែកដែលបានជ្រើស

---

[2539] កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចិច សុផា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ឯកសារ **E3/9831** ស/ឆ ១២០-១២១ គាត់មិនបានផ្សំដំណេក និង បានរស់នៅជាមួយប្តីគាត់ចំនួន២៩ថ្ងៃ មុនពេលប្តីគាត់ត្រូវគេសម្លាប់។

[2540] កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9662** ស/ឆ ៤០-៤៣, ៤៦-៤៩, ៥៥, ៥៩, ៨០ អ្នកទាំងពីរស្រឡាញ់គ្នាទៅវិញទៅមក បន្ទាប់ពីបានរួមភេទ និងបន្ទាប់ពីបានរស់នៅជាមួយគ្នាច្រើនឆ្នាំ ពួកគេមានមនោសញ្ចេតនាដូចប្តីប្រពន្ធដទៃទៀតដែលរៀបការដោយស្ម័គ្រចិត្តដែរ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ស្រី សឿម ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9826** ស/ឆ ១៦៩-១៧១ ("ប្តីរបស់ខ្ញុំមានអារម្មណ៍ចង់រួមភេទជាមួយនឹងខ្ញុំពីរបីដងមកហើយ ប៉ុន្តែខ្ញុំមិនព្រម<u>ខ្ញុំបានគិតចុះគិតឡើងថា បើជាប្តីប្រពន្ធជាមួយគ្នាហើយ ខ្ញុំក៏សំរេចចិត្តបណ្តោយខ្លួនឱ្យគាត់តែម្តងទៅ</u>។ ស. នៅពេលនោះ តើលោកស្រីមានអារម្មណ៍ថាគេគំរាមកំហែង ឬបង្ខំដែរឬទេ? តើប្តីរបស់លោកស្រីបានធ្វើអ្វីខ្លះនៅពេលដំបូង? ឆ.១៧០ ខ្ញុំមិនមានអារម្មណ៍ភ័យខ្លាចអ្វីនោះទេ ព្រោះពួកខ្ញុំរស់នៅជាមួយគ្នាយូរដែរហើយ")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី សួណន យឹម ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ **E3/9829** ស/ឆ ២៩-៣០ ("ស. តើអ្នកស្រីមានបញ្ហាផ្លូវកាយ ឬផ្លូវចិត្តដែលបណ្តាលមកពីការរួមភេទជាមួយនឹងប្តីរបស់អ្នកស្រី ដោយសារការភ័យខ្លាចដែរឬទេ? ឆ. ខ្ញុំមិនមានបញ្ហាអីទេ។ ស. តើអ្នកស្រីមានស្គាល់គូស្រករណាផ្សេងទៀត ដែលមានបញ្ហាផ្លូវកាយ ឬផ្លូវចិត្តដែលបណ្តាលមកពីការរួមភេទជាមួយនឹងអ្នកដែលខ្លួនមិនស្រលាញ់ដែរឬទេ? ឆ. ទេ")។ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី វ៉ា លឹមហ៊ន់ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ **E3/9756** ស/ឆ ៤៥, ៤៨, ៥០ (គាត់ស្រឡាញ់ប្តី និង មិនដែលគិតថាចង់ចាកចេញពីគាត់ទេ ពីព្រោះគាត់ស្លូត។ បន្ទាប់ពីរស់នៅជាមួយគ្នាមួយរយៈ ពួកគេក៏អាណិតគ្នាទៅវិញទៅមក)។ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9736** ស/ឆ ១១២ ("ស. តើការដែលគេបង្ខំឱ្យរួមភេទកាលពីគ្រាដំបូងៗ ប៉ះពាល់ដល់ភាពស្និទ្ធស្នាលដល់ការរួមរស់ជាមួយប្តីក្រោយលោកស្រីដែរឬទេ? ឆ.១១២. ខ្ញុំមិនមានបញ្ហាអ្វីទេ")។

រើសមកធ្វើជាករណីទូទៅ ខណៈដែលករណីទាំងនេះមិនតំណាងឱ្យបទពិសោធន៍របស់បុគ្គលភាគច្រើន ដែលបានរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។

១៣៣៩. សរុបសេចក្តីមក អង្គជំនុំជម្រះបានបង្ហាញឱ្យឃើញភាពលម្អៀង នាំឱ្យធ្វើសេចក្តីសន្និដ្ឋានរួមខុសលើការឈឺចាប់បណ្តាលមកពីការរួមភេទ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដំណើរការលម្អៀង និងជ្រើសរើស ក្នុងការវាយតម្លៃភ័ស្តុតាង បានរារាំងមិនឱ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានត្រឹមត្រូវទៅលើភ័ស្តុតាងដែលបានពិនិត្យ ពោលគឺ ធាតុផ្សំសត្យានុម័តិដែលអាចឱ្យសន្និដ្ឋានថាមានការរំលោភសេពសន្ថវៈ និងធាតុផ្សំដែលអាចឱ្យសន្និដ្ឋានថាមានការឈឺចាប់ មិនអាចឈានដល់កម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត។ ដូច្នេះ ការសន្និដ្ឋានខុសរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ[2541]។

១៣៤០. យើងនឹងឃើញថា គឺដំណើការលម្អៀង និងជ្រើសយកតែភ័ស្តុតាងដាក់បន្ទុកនេះហើយ ដែលនាំឱ្យអង្គជំនុំជម្រះបំភ្លៃ និងបំប្លែងភ័ស្តុតាង ដើម្បីធ្វើការសន្និដ្ឋានខុសអំពីការសន្មតថាមានគោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ប្រការនេះក៏ធ្វើមោឃភាពដល់សេចក្តីសន្និដ្ឋានអំពីចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ។

## ២.៣. កំហុសពាក់ព័ន្ធនឹងការតាមដានការរួមដំណេក

១៣៤១. ក្នុងដំណើរការបែបជ្រើសរើស និងអគតិ អង្គជំនុំជម្រះក៏បានសន្និដ្ឋានផងដែរថា ប្តីប្រពន្ធថ្មោងថ្មីត្រូវគេបង្ខំឱ្យរួមភេទ ដើម្បី "បង្កើត" កូន ក្នុងគោលដៅបង្កើនចំនួនប្រជាជន[2542]។ មេធាវីការពារក្តីសូមយោងទៅការរៀបរាប់លម្អិតខាងលើ អំពីនត្ថិភាពបទឧក្រិដ្ឋនៃការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធ នៅ

[2541] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨០-៣៦៩៤, ៤៣០៣-៤៣០៦, ៤៣៦១-៤៣៧៦, ៤៤០០, ៤៤០២។

[2542] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០-៣៧០០។

ពេលកើតហេតុ[2543]។ ដូច្នេះ មេធាវីការពារក្តីសូមរំឮកជាសំខាន់ថា អង្គជំនុំជម្រះមិនអាចផ្តន្ទាទោស ខៀវ សំផន ពីបទឧក្រិដ្ឋ ដែលគ្មានអត្ថិភាព នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានឡើយ។ ជាបន្ទាប់បន្សំ អង្គជំនុំជម្រះមិនអាចធ្វើការផ្តន្ទាទោសពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរំលោភសេពសន្ថវៈ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយផ្អែកលើភ័ស្តុតាងនៅក្នុងសំណុំរឿង បានឡើយ។ ជាក់ស្តែង ភ័ស្តុតាងទាំងនេះមិនអាចឱ្យបង្ហាញថា ការរំលោភសេពសន្ថវៈ ដែលអង្គជំនុំជម្រះយល់ឃើញថាពិតជាកើតមានមែនកើតចេញពីគោលនយោបាយដាច់ខាតរបស់ ប.ក.ក ដែលបានតាក់តែងឡើងនៅថ្នាក់កំពូល។ យោងតាមវិធីសាស្ត្រខុសទៅលើភ័ស្តុតាង អង្គជំនុំជម្រះបានសន្និដ្ឋានថា ការរួមដំណេកត្រូវធ្វើឡើងដោយបង្ខំតាមរយៈការចាត់វិធានការផ្សេងៗ (២.៣.១) ដែលនាំឱ្យមានការការរំលោភសេពសន្ថវៈទៅលើមនុស្សយ៉ាងហោចណាស់ម្នាក់ (២.៣.២)។

## ២.៣.១. វិធានការសំដៅធានាឱ្យមានការរួមដំណេក

១៣៤២. វិធានការជាច្រើនត្រូវបានអាជ្ញាធរបង្កើតឡើង ដើម្បីបង្ខំប្តីប្រពន្ធឱ្យរួមដំណេក ជាពិសេស ការតាមដាន (២.៣.១.១) ក្នុងបរិបទបង្ខិតបង្ខំ (២.៣.១.២)។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដើម្បីឈានដល់ការសន្និដ្ឋានទាំងនេះ។

### *២.៣.១.១. ការតាមដានការរួមដំណេក*

១៣៤៣. អង្គជំនុំជម្រះបាន "ជឿជាក់" ថា បន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍ "ជាទូទៅ" ប្តីប្រពន្ធត្រូវគេតាមដានដើម្បីឱ្យប្រាកដថា ពួកគេបានរួមដំណេក[2544]។ ប៉ុន្តែ ដើម្បីឈានដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះបានធ្វើការវិភាគខុសទៅលើភ័ស្តុតាង។ ការពិនិត្យមើលជារួមទៅលើសក្ខីកម្ម មិនអាចឱ្យអង្គជំនុំជម្រះទាញការសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យបែបនេះបានឡើយ។

---

[2543] សូមមើលខាងលើ កថាខណ្ឌ ១២៨១-១២៨៧។

[2544] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៤, ៣៦៥៩។

• <u>ការវិភាគភ័ស្តុតាងតាមបែបជ្រើសរើស និងលម្អៀង</u>

១៣៤៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកជាសំខាន់ទៀតលើបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកោះហៅជាពិសេសឱ្យមកផ្តល់សក្ខីកម្ម ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ដោយគ្មានការស្វែងរកភាពជាតំណាងនៃរឿងរ៉ាវរបស់ពួកគាត់ ធៀបនឹងភ័ស្តុតាងទាំងមូលនោះឡើយ[2545]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញសេចក្តីសន្និដ្ឋានជារួមលើគោលនយោបាយរបស់ ប.ក.ក ដោយច្រានចោលភ័ស្តុតាងបង្ហាញថា ការអនុវត្តរបស់កម្មាភិបាលមូលដ្ឋានខ្លះផ្ទុយពីសេចក្តីណែនាំជាទូទៅនៃបទបញ្ជាផ្លូវការស្តីពីការរៀបអាពាហ៍ពិពាហ៍។

១៣៤៥. **រឿងរ៉ាវមិនស៊ីចង្វាក់គ្នាលើការតាមដាន៖** ជាដំបូង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានប្រើប្រាស់សក្ខីកម្មដែលលើកអំពីការតាមដានជាទូទៅ នៅតាមសហករណ៍ និងការដ្ឋាន ដើម្បីសន្និដ្ឋានថាមានការតាមដានជាក់លាក់ទៅលើប្តីប្រពន្ធថ្មោងថ្មី។ ពិតមែនតែដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន, ព្រាប សុខឿន និង ជុំ សាមឿន បាននិយាយអំពីការឃ្លាំមើល ក្នុងបរិវេណកន្លែងដែលពួកគេស្នាក់នៅពេលយប់ជាមួយប្តីរៀងៗខ្លួន ប៉ុន្តែ យើងមិនអាចសន្និដ្ឋានថា ការឃ្លាំមើលទាំងនេះមានគោលដៅតាមដានរាត្រីផ្សំដំណេកឡើយ[2546]។ ការពន្យល់របស់ មាស ឡៃហួរ ថា ការតាមដានមានគោលដៅចង់ដឹងថាតើប្តីប្រពន្ធបានធ្វើពិធីសាសនាដែរឬទេ[2547] ក៏មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា

---

[2545] សំអាងហេតុសាលក្រម *ផ្នែក ១៤.៣.៨.១ ការតាមដាន*។

[2546] <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** មុនម៉ោង 09.19.35 (ដល់ពេលយប់ឡើង គេឱ្យអ្នកការពារហ្នឹង [...] មកមើល) មុនម៉ោង 11.27.03 ("មិនមែនទៅយកការងារអីហ្នឹងឱ្យសំខាន់ដែរ ប៉ុន្តែគ្រាន់តែឃើញវាមកនៅក្បែរក្រោមផ្ទះហ្នឹង មិនឆ្ងាយពីគ្នាប៉ុន្មានទេ") ម៉ោង 11.31.41 (មួយខែក្រោយមកទើបគាត់យល់ព្រមរួមដំណេកជាមួយប្តីគាត់)។ <u>ព្រាប សុខឿន</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ម៉ោង 14.31.27។ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ E1/488.1 ម៉ោង 09.23.08 ("កាលសម័យនោះ យើងអត់បាននិយាយច្រើនទេ ព្រោះមានគេតាមដាន")។ <u>ជុំ សាមឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/321.1** មុនម៉ោង 14.27.20 ("ដល់ពេលនោះ ក៏មាន មិនដឹងជាឈ្លបគេ ឬអ្វី ឮសូរជើងគេដើរនៅខាងក្រៅហ្នឹង") ម៉ោង 14.31.44 ("ខ្ញុំអត់ដឹងមានអ្វីកើតឡើងទេ")។

[2547] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២១៧៥ (នៃកថាខណ្ឌ ៣៦៤១)។

មានការតាមដានការរួមភេទរវាងប្តីប្រពន្ធថ្មោងថ្មីនោះឡើយ[2548]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានទាញសេចក្តីសន្និដ្ឋានជារួមអំពីវត្តមានឈ្លបជាប្រព័ន្ធក្នុងគោលដៅនេះ ខណៈដែលរឿងរ៉ាវ ដែលអង្គជំនុំជម្រះបានផ្អែកលើ មានភាពផ្ទុយគ្នាទៅវិញ។ ជាក់ស្តែង ថ្វីត្បិតតែអ្នកខ្លះនិយាយអំពីការតាមដានជាប្រព័ន្ធក៏ដោយ ក៏អ្នកខ្លះទៀតបានបញ្ជាក់ថាមានការតាមដាន ក្នុងករណីប្តីប្រពន្ធមិនចុះសម្រុងនឹងគ្នា ឬជាការតាមដានទូទៅ។ នេះគឺករណីរបស់ ហេង ឡៃហ៊ាង និង ជាំង ស្រីមុំ ហើយ ជាំង ស្រីមុំ បានបញ្ជាក់ថា គាត់មិនដឹងអំពីគោលបំណងនៃវត្តមានរបស់ឈ្លបទេ[2549]។

១៣៤៦. ម្យ៉ាងវិញទៀត ឥទ្ធិពលនៃការតាមដានប្តីប្រពន្ធថ្មោងថ្មីក៏មានភាពខុសគ្នា ទៅតាមករណីដែរ។ អ្នកខ្លះបានបញ្ជាក់ថាត្រូវគេបង្ខំឱ្យរួមភេទ[2550] ឯអ្នកខ្លះទៀតបានអះអាងថា វត្តមានរបស់ឈ្លបធ្វើឱ្យពួកគាត់នាំគ្នាសម្ងំស្ងៀម[2551]។ ប៉ុន្តែ ក្រៅពីបទពិសោធន៍ខុសៗគ្នាទាំងនេះ កំហុសជាសារវ័ន្តរបស់អង្គជំនុំជម្រះ គឺមិនបានសន្និដ្ឋានថា ឥរិយាបថរបស់ឈ្លបជាការបំពាន គឺមិនមែនជាផ្លែផ្កានៃគោលនយោបាយដែលសម្រេចនៅថ្នាក់កំពូលទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានទាញផលវិបាកចេញពីព័ត៌មានពាក់ព័ន្ធនឹងឈ្លបដែលធ្វើការតាមដាន។ ជាក់ស្តែង ដើមបណ្តឹងរដ្ឋ

[2548] <u>មាស ឡៃហួរ</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/305.1** ម៉ោង 09.47.16។

[2549] <u>ហេង ឡៃហ៊ាង</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** មុនម៉ោង 09.54.02 (<u>"ចំពោះអ្នកដែលត្រូវគ្នាអ៊ីចឹងទៅ គេមិនមានការតាមដានទេ</u>។ ចំពោះអ្នកដែលមិនពេញចិត្តនឹងគ្នា មិនចុះសម្រុងគ្នា គឺគេតាមដាន ស៊ើបអង្កេត")។ <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 10.47.53។ ជាំង ស្រីមុំ បានបញ្ជាក់ថាមិនច្បាស់ថាបានដឹងថាគេមកតាមដានចង់ដឹងថាប្តីប្រពន្ធត្រូវរ៉ូវគ្នា ឬដើម្បីដឹងថាពួកគេមាននិយាយអាក្រក់ពីអង្គការឬយ៉ាងណានោះទេ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 15.46.57។

[2550] <u>កុល ណែម</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ក្រោយម៉ោង 15.08.22។ <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ E1/254.1 ម៉ោង 10.41.56។

[2551] <u>ង៉ែត ចាត</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** មុនម៉ោង 09.09.43 (វត្តមានពួកគេនាំឱ្យប្តីប្រពន្ធនៅស្ងៀម មិនចេញស្តី "អត់ហ៊ាននិយាយអី គិតអីទេ ខ្លាចគេ ព្រោះអីឃើញឈ្លបដើរតាមផ្លូវកៀនកៀនជញ្ជាំងផ្ទះ")។ <u>ថៅ ឡាង</u>៖ ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** មុនម៉ោង 14.40.37 ឈ្លបម្នាក់តាមដានគាត់ ("គ្រាន់តែគេងស្ងៀមទាំងអស់គ្នាតែម្តង មិនហ៊ានកម្រើកខ្លួន")។

ប្បវេណីជាច្រើននាក់បានរៀបរាប់ថា ឈ្លបទាំងនេះសុទ្ធតែក្មេងៗ។ នេះជាចម្លើយរបស់ ស៊ូ សុធារី, ង៉ែត ចាត, ប៉ែន សុចាន់ និង មុំ វុន ហើយអ្នកខ្លះដឹងអំពីឥរិយាបថបំពានរបស់ឈ្លបទាំងនេះ[2552]។

១៣៤៧. អង្គជំនុំជម្រះបានទទួលយកសក្ខីកម្មមិនច្បាស់លាស់របស់ ជា ឌៀប។ ជាក់ស្តែង គាត់មិនបានឃើញអ្នកណាម្នាក់សោះ គាត់បានត្រឹមតែឮសម្រិបជើង[2553] ដែលគាត់គិតថាជាពួកអង្គរក្សប្រធានមុខព្រួញដែលគាត់ធ្វើការ ដោយគ្មានអ្វីមកសំអាង[2554]។ ក្រៅពីលក្ខណៈមិនច្បាស់លាស់នៃសក្ខីកម្មរបស់គាត់ ដែលមិនអាចឱ្យដឹងថាតើពិតជាមានការតាមដានមែន ឬក៏អត់ និងដោយអ្នកណា គាត់ជាមនុស្សតែម្នាក់គត់ដែលបានលើកឡើងអំពីការតាមដានបែបនេះ ក្នុងក្រសួងរបស់គាត់។ ជាក់ស្តែង គ្មានសាក្សីណាផ្សេងទៀតមកពីក្រសួងពាណិជ្ជកម្ម បានរៀបរាប់អំពីហេតុការណ៍ស្រដៀងគ្នានេះទេ[2555]។ អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋានជារួមចេញពីសក្ខីកម្មបែបនេះទេ និងយ៉ាងហោចណាស់គួរណាតែកត់សម្គាល់ថា រឿងរ៉ាវរបស់គាត់ខុសប្លែកពីគេ។

---

[2552] ដូច្នេះ ប៉ែនសុចាន់ បានបញ្ជាក់ថាឈ្លបត្រូវបានគេចាត់ឱ្យមកពេលយប់ "គេចល័តយប់ឡើង គេចល័តតាមដាន។ គឺជាល្បែងលេងសើចរបស់ពួកគេ"៖ ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/482.1** ក្រោយម៉ោង 14.40.47។ មុំ វុន បាននិយាយថាបានរួមភេទជាមួយនឹងប្តីគាត់ តាមបញ្ជារបស់ឈ្លបក្មេងៗ អាយុ ១៦-១៧ ឆ្នាំ ដែលប្រហែលជាទទួលបញ្ជាពីប្រធានកងឈ្មោះ ស៊ា ដែលគាត់រៀបរាប់ថាជាមនុស្សសំខាន់ និងប្រព្រឹត្តអំពើទាំងបំពាន៖ មុំ វុន៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/475.1** ក្រោយម៉ោង 13.43.34 (យុវជនឈ្លបអាយុ ១៦-១៧ឆ្នាំ) ម៉ោង 14.39.02 (ការបញ្ជានោះបានមកពីរ៉ុម និង ស៊ា) មុនម៉ោង 11.27.24 (រំឭកពីការប្រើអំណាចរបស់ប្រធានកងឈ្មោះ ស៊ា)។ ង៉ែត ចាត និង ស៊ូ សុធារី បនាផ្តល់សក្ខីកម្មក្នុងន័យដូចគ្នានេះដែរ៖ ង៉ែត ចាត៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 16.05.27។ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/489.1** មុនម៉ោង 09.09.43 (គាត់ភ័យខ្លាចឈ្លបលបស្តាប់ និងខ្លាចគេស្តាប់ដឹង ហើយប្តីគាត់ និងរូបគាត់មិនហ៊ាននិយាយទេ)។ ស៊ូ សុធារី៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ **E1/462.1** ក្រោយម៉ោង 14.39.15។

[2553] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២១៧៦ (នៃកថាខណ្ឌ ៣៦៤១)។

[2554] ជា ឌៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** មុនម៉ោង 14.05.55។ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** មុនម៉ោង 10.09.38។

[2555] ប៊ិត ហឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ម៉ោង 11.23.28។ ផាន ហ៊ឹម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.08.51 ("ខ្ញុំអត់ដែលឮផង")។ កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E3/10620** ស/ឆ ៩៥។

១៣៤៨. អង្គជំនុំជម្រះក៏បានបំភ្លៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន ដោយទទួលយកថា គាត់បាននិយាយអំពីការតាមដានការរួមដំណេករបស់ប្តីប្រពន្ធថ្មោងថ្មី ខណៈដែលគាត់គ្រាន់តែបញ្ជាក់ថា វាជាការស្តាប់ការ "និយាយគ្នា"[2556]។ អង្គជំនុំជម្រះក៏មិនអាចយករឿងរ៉ាវរបស់ ណុប ធីម មកសន្និដ្ឋានថា មានការតាមដានការរួមដំណេក តាមបញ្ជារបស់អាជ្ញាធរ នោះដែរ។ ជាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់ខ្លាចគេតាមដាន គាត់មិនបានឃើញអ្នកណាម្នាក់ទេ ហើយគាត់បានទទួលស្គាល់ថា គាត់មិនធ្លាប់ឮលេខាស្រុកចេញបញ្ជាឱ្យឈ្លបទៅតាមដានប្តីប្រពន្ធថ្មោងថ្មីទេ[2557]។ ម្យ៉ាងវិញទៀត គួរកត់សម្គាល់ថា ប្តីគាត់ ឈ្មោះ ព្រាប កប ក៏មិនបានលើកឡើងអំពីការតាមដានការរួមដំណេកដែរ និងបានឆ្លើយថាគាត់មិនបានទទួលការណែនាំឱ្យធ្វើអ្វីចំពោះគូស្រករ ក្រោយការរៀបអាពាហ៍ពិពាហ៍ទេ[2558]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិចារណាលើចម្លើយទាំងនេះ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ នឹងត្រូវទុកជាមោឃៈ។

១៣៤៩. **<u>របាយការណ៍ស្តីពីការតាមដាន</u>៖** អង្គជំនុំជម្រះបានផ្អែកទៅលើសក្ខីកម្មរបស់ រី ពៅ, ជាំង ស្រីមុំ, សុន វុត, ហេង ឡៃហ៊ាង និងកំណត់ហេតុស្តាប់ចម្លើយសាក្សី កុល សែត ដើម្បីសន្និដ្ឋានថា ឈ្លបរាយការណ៍ពីការតាមដានទៅ "ថ្នាក់លើ"[2559]។

១៣៥០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយល់ឃើញថាអាចជឿជាក់បានចំពោះសក្ខីកម្មរបស់ រី ពៅ ដែលបានអះអាងថាគេបានស្នើឱ្យកងរបស់គាត់តាមដានសកម្មភាពរបស់ប្តីប្រពន្ធថ្មោងថ្មីមកពីកងផ្សេងៗ ដោយរាយការណ៍ទៅប្រធានរៀង១ខ្លួន[2560]។ ការធ្វើដំណើរទៅច្រើនកន្លែង តាមការតម្រូវពីភារកិច្ចនេះ គួរណាតែនាំឱ្យអង្គជំនុំជម្រះពិចារណាលើរឿងរ៉ាវរបស់គាត់ ដោយប្រយ័ត្នប្រយែងបំផុត។ ទោះជាយ៉ាងណាក៏ដោយ សូម្បីតែចាត់ទុកថាសក្ខីកម្មរបស់គាត់អាចជឿជាក់បានក៏ដោយ ក៏អង្គជំនុំ

---

[2556] <u>ជូ គឹមឡុន</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** មុនម៉ោង 14.37.03។ គួរកត់សម្គាល់ថាក៏មានបញ្ហាបកប្រែជាភាសាបារាំងដែរ។

[2557] <u>ណុប ធីម</u>៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ក្រោយម៉ោង 14.18.13។

[2558] កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រាប កប ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ **E3/9818** ស/ឆ ៥៣។

[2559] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២១៨៣-១២១៨៥ (នៃកថាខណ្ឌ ៣៦៤៣)។

[2560] <u>រី ពៅ</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ **E1/262.1** មុនម៉ោង 13.54.11 (ប្រធានកងរបស់គាត់)។

ជម្រះគួរណាតែយល់ឃើញថា គាត់និយាយតែពីរបាយការណ៍ផ្ញើជូនមេកង គឺ "អាជ្ញាធរ" ថ្នាក់លើផ្ទាល់។ គ្មានភ័ស្តុតាងណាមួយអាចឱ្យសន្និដ្ឋានថា មេៗនៅថ្នាក់លើបានដឹងពីការអនុវត្តនេះឡើយ ហើយថ្នាក់ដឹកនាំ ប.ក.ក រឹតតែមិនដឹងទៅទៀត[2561]។

១៣៥១. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លៃងសក្ខីកម្មរបស់ ហេង ឡៃហ៊ាង។ ជាក់ស្តែង គាត់មិនបាននិយាយថា "អ្នកទទួលខុសត្រូវជាន់ខ្ពស់" ទទួលបានព័ត៌មានដែលប្រមូលបានពេលតាមដាន នោះឡើយ។ គាត់គ្រាន់តែនិយាយសំដៅដល់ "អ្នកគ្រប់គ្រង" កង ដោយបញ្ជាក់ថាអ្នកគ្រប់គ្រងជាអ្នកកោះហៅប្តីប្រពន្ធមកអប់រំ ឬព្រមាន[2562]។ ការពិនិត្យភ័ស្តុតាងដោយមិនលម្អៀង គួរណាតែនាំឱ្យអង្គជំនុំជម្រះពិចារណាទៅលើសក្ខីកម្មរបស់កម្មាភិបាលដែលស័ក្តិសម ដើម្បីឱ្យដឹងថាតើមានការចេញសេចក្តីណែនាំដែរឬទេ និងដោយអ្នកណា។ អង្គជំនុំជម្រះមិនបានធ្វើអ៊ីចឹងទេ ខណៈដែលភ័ស្តុតាងក្នុងសំណុំរឿងអាចឱ្យសន្និដ្ឋានថា គ្មានការណែនាំពីថ្នាក់លើឱ្យធ្វើការតាមដានបែបនេះទេ[2563]។

១៣៥២. **<u>តួនាទីរបស់ឈ្លបក្នុងឃុំ៖</u>** ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានអើពើនឹងភ័ស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង។ ជាក់ស្តែង សក្ខីកម្មរបស់ នាង អ៊ួច ជាលេខាស្រុកត្រាំកក់ចុងក្រោយបង្អស់ ត្រូវបានបំភ្លេចចោល។ ផ្ទុយទៅវិញ គាត់បានអះអាងថា គាត់មិនបានដឹងអំពីការតាមដានប្តីប្រពន្ធថ្មោងថ្មី ពីសំណាក់ឈ្លបទេ[2564]។ ម្យ៉ាងវិញទៀត គាត់បានពន្យល់ថា នេះមិនមែនជាតួនាទី

---

[2561] <u>រី ពៅ</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** មុនម៉ោង 13.54.11 (ប្រធានកងរបស់គាត់)។ <u>សុន វុត</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/412.1** ក្រោយម៉ោង 09.11.48 (អ្នកទទួលបន្ទុកតាមដានគឺជាមនុស្សជំនិតបំផុតរបស់មេបញ្ជាការ)។

[2562] <u>ហេង ឡៃហ៊ាង</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/476.1** មុនម៉ោង 13.54.51 ("អ្នក នៅ ក្នុង ក្រុម របស់ខ្លួន ហ្នឹង គឺគេឱ្យ ស៊ើបយ៉ាងនេះ យ៉ាងនោះអីចឹង ទៅឱ្យប្រាប់គេអ៊ីចឹងទៅណា។ មានហេតុផលរបៀបម៉េចៗ ប្រតិកម្មម៉េចកើតឡើងអីចឹង"។) និង ម៉ោង 13.55.19។

[2563] <u>ជួន ធី</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/490.1** ចាប់ពីម៉ោង 09.14.29។ <u>ពេជ្រ ជីម</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** មុនម៉ោង 09.27.04។ សូមមើលផងដែរ <u>ភ្លៅ យ៉ារ</u> ដែលបានអះអាងថាបានឮនិយាយ និងថាគឺប្រធានកងដែលជាអ្នកបញ្ជូនឈ្លបឱ្យទៅលបស្តាប់ពេលយប់ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/264.1** ក្រោយម៉ោង 10.55.29។ <u>ខឹម ហឿន</u>៖ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/296.1** ម៉ោង 16.07.05។

[2564] <u>នាង អ៊ួច</u>៖ ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/274.1** ចន្លោះម៉ោង 10.41.40 និងម៉ោង 10.49.11។

របស់ពួកគេទេ៖ "ឈ្លបឃុំគ្មានភារកិច្ចតាមដានប្ដីប្រពន្ធទើបរៀបការទេ គឺការពារសន្តិសុខនៅតាមឃុំ និងក្នុងស្រុកទាំងមូល ការពារសន្តិសុខ និងសុវត្ថិភាពនៅតាមឃុំ និងតាមស្រុក។ មានប៉ុណ្ណឹង"។ សក្ខីកម្មរបស់គាត់ស៊ីចង្វាក់គ្នានឹង យាន លន់ ជាឈ្លបនៅភូមិភាគកណ្ដាល៖ "ឈ្លបចុះធ្វើការជាមួយប្រជាជនហ្នឹងឯង [...]។ ប៉ុន្តែ គ្រាន់តែទៅពិនិត្យដូចជា មើលការខុសត្រូវចំពោះប្រជាពលរដ្ឋនៅហ្នឹងភូមិៗ ហ្នឹងអី ក្រែងលោវាឈ្លោះប្រកែកគ្នា"[2565]។

• **<u>ការតាមដាន ដោយរំលោភលើគោលការណ៍របស់ ប.ក.ក</u>**

១៣៥៣. អង្គជំនុំជម្រះក៏បានធ្វើការវិភាគខុសលើសក្ខីកម្មជាច្រើន ដោយបានច្រានចោល ឬបំភ្លៃព័ត៌មានមិនស្របនឹងការសន្និដ្ឋានរបស់ខ្លួន។ ជាអាទិ៍ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទទួលតាមតាមបែបជ្រើសរើសនូវសក្ខីកម្មរបស់ ឌុច អំពីកម្មាភិបាលឈ្មោះ ប៉ាង ដែលបានស្នើឱ្យអ្នកនៅក្រោមបង្គាប់ទៅតាមដានប្ដីប្រពន្ធថ្មោងថ្មី[2566]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះ ដែលបានប្រើប្រាស់ចម្លើយរបស់ ឌុច យ៉ាងទូលំទូលាយ ក្នុងសំអាងហេតុសាលក្រម បែរជាមិនបានគិតគូរដល់ ឌុច ទៅវិញ ក្នុងពេលពិចារណាពាក់ព័ន្ធនឹងគោលជំហររបស់ ប.ក.ក ចំពោះឥរិយាបថបែបនេះ៖

"តាមខ្ញុំដឹង មិនមានវិធានការជាក់លាក់ ដើម្បីតាមដាននោះទេ ប៉ុន្តែ មានកម្មាភិបាល<u>ខូចមួយចំនួន</u>បានបញ្ជាឱ្យគេទៅតាមដានមើលថា តើប្ដីប្រពន្ធមានបានរួមដំណេកជាមួយគ្នាដែរឬទេ។ ចំណុចនេះ គឺ<u>មិនទាក់ទង</u>នឹងបញ្ហានៃការ<u>រៀបការ</u>ដោយបង្ខំនោះទេ។ [...] គាត់ត្រូវគេដាក់ទណ្ឌកម្មដោយសារបានធ្វើ

---

[2565] <u>យាន លន់</u>៖ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/317.1** ម៉ោង 14.32.22។ សូមមើលផងដែរ <u>ស៊ូ សុធារី</u>៖ ប្រតិចារឹក ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/463.1** ចន្លោះម៉ោង 11.02.26 និងម៉ោង 11.06.26 ("គេតាមដានរឿងហ្នឹងហើយ") ម៉ោង 13.35.43 ("ការមកឈ្លបក្រោមផ្ទះខ្ញុំស្ដាប់រឿងរ៉ាវទាំងនេះគឺមានមេកងគេចាត់តាំងហើយ បានមានមនុស្សមកស៊ើបការណ៍)។

[2566] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤១ កំណត់សម្គាល់ជើងទំព័រលេខ ១២១៧៧។

បែបនេះ។ ជាដំបូង គាត់ត្រូវសុំទោសប្តីប្រពន្ធនោះ បន្ទាប់មក ដោយសារមានចំណុចផ្សេងទៀតដែលត្រូវស្តីបន្ទោសគាត់ គាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅ ស-២១ និងសម្លាប់ចោល"[2567]។

១៣៥៤. តាមរយៈចម្លើយនេះ ច្បាស់ណាស់ថា កម្មាភិបាលកម្រិតត្រឹម ឌុច ដឹងថា ការតាមដានភាពឯកជនរបស់ប្តីប្រពន្ធ គឺផ្ទុយនឹងមាគ៌ានយោបាយរបស់ ប.ក.ក និងត្រូវទទួលរងទណ្ឌកម្ម។ សាក្សីជាច្រើននាក់ផ្សេងទៀតបានបញ្ជាក់ថា ការតាមដានប្រភេទនេះប៉ះពាល់ដល់សីលធម៌ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យ៉ាងណាមិញ ធុច ស៊ីថន ដែលបានរៀបការក្នុងរបបនោះ បានពន្យល់ថា បញ្ហារួមដំណេកមិនត្រូវគេនិយាយទេ ពីព្រោះនេះជាបញ្ហា "សីលធម៌"[2568]។ យាន លន់ ក៏បានប្រកែកដាច់អហង្ការផងដែរថា គ្មានការណែនាំឱ្យតាមដានទេ ហើយគាត់បានបញ្ជាក់ថា វាជារឿងគួរឱ្យអាម៉ាស់ តាមវប្បធម៌និងប្រពៃណី[2569]។ អង្គជំនុំជម្រះគួរណាតែពិចារណាលើភ័ស្តុតាងជាសារវ័ន្តទាំងនេះ ដែលផ្ទុយនឹងការយល់ឃើញថា មានការរួមដំណេកដោយបង្ខំ តាមការចង់បានពីថ្នាក់កំពូលរបស់បក្ស។

១៣៥៥. ភ័ស្តុតាងមិនគ្រប់គ្រាន់ឱ្យអង្គជំនុំជម្រះសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ការតាមដាន គឺជាវិធានការរបស់ ប.ក.ក ដើម្បីឃ្លាំមើលថា តើប្តីប្រពន្ធថ្មោងថ្មីបានរួមភេទ ដើម្បីបង្កើតកូនជូនអង្គការដែរឬទេ។ លើសពីនេះទៀត រឿងរ៉ាវដែលទទួលយក ដែលបានលើកឡើងអំពីការតាមដានបែបនេះនៅមូលដ្ឋានមិនអាចយកមកធ្វើជាករណីទូទៅថាជាគោលនយោបាយថ្នាក់ជាតិបានទេ។

- **<u>ស្ថិតិនៃការតាមដាន ក្នុងសំណុំរឿងទាំងមូល</u>**

១៣៥៦. ដូចប្រធានបទផ្សេងទៀតដែរ បញ្ហាភាពជាតំណាងនៃរឿងរ៉ាវដែលបានលើកឡើងអំពីការតាមដានការរួមដំណេក មានសារៈសំខាន់ណាស់។ បញ្ហានេះនឹងត្រូវពិនិត្យទៅតាមប្រភេទភ័ស្តុតាង។

---

[2567] <u>ឌុច</u>៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ **E3/5789** ERN 00410174 (យើងគូសបន្ទាត់ពីក្រោម)។

[2568] <u>ធុច ស៊ីថន</u>៖ ប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/500.1** ក្រោយម៉ោង 15.03.46។

[2569] <u>យាន លន់</u>៖ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/317.1** ម៉ោង 14.43.21។

១៣៥៧. **សក្ខីកម្មទទួលបានក្នុងវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១៤ នាក់ ដែលបានមកផ្ដល់សក្ខីកម្មក្នុងវគ្គនេះ ១១ នាក់ បានឆ្លើយថា ពួកគេត្រូវបានតាមដាន ក្រោយពីរៀបការរួច។ ៧ នាក់ ក្នុងចំណោមនោះ បានបញ្ជាក់យ៉ាងជាក់លាក់ថា នេះជាការតាមដានការរួមដំណេក។ ៣ នាក់ បានអះអាង ពួកគេត្រូវបានតាមដាន ក្នុងក្របខ័ណ្ឌនៃការឃ្លាំមើលប្រជាជនជាទូទៅ និងម្នាក់បានលើកឡើងពីការតាមដានប្ដីប្រពន្ធ តែក្នុងករណីមិនចុះសម្រុងគ្នាប៉ុណ្ណោះ[2570]។ ជាចុងក្រោយ ២ នាក់ បានឆ្លើយថាពួកគេមិនត្រូវបានតាមដានទេ ចំណែកឯម្នាក់ទៀតមិនបានលើកឡើងអំពីបញ្ហានេះទាល់តែសោះ។ ជាថ្មីម្ដងទៀត យើងសង្កេតឃើញថា បុគ្គលភាគច្រើនក្នុងវគ្គនេះបាននិយាយថាត្រូវគេតាមដាន។ ដូច្នេះ ក្នុងវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍ បុគ្គល ដែលអះអាងថាត្រូវគេតាមដាន មានភាគរយខ្ពស់៖ ៧៩% ត្រូវគេតាមដាន (១១ នាក់) ១៤% មិនត្រូវគេតាមដាន (២ នាក់) និង ៧% មិនបាននិយាយអំពីបញ្ហានេះ (ម្នាក់)[2571]។

១៣៥៨. **សក្ខីកម្មទទួលបានក្នុងសំណុំរឿង ០០២/០២ ក្រៅវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍៖** ការពិនិត្យលើសក្ខីកម្មផ្សេងទៀត នៅក្នុងសំណុំរឿង ០០២/០២ ផ្ដល់នូវចក្ខុវិស័យមួយផ្សេងទៀតរួចទៅហើយ។ ជាក់ស្ដែង ក្នុងចំណោមមនុស្ស ៨០ នាក់ ដែលត្រូវបានសួរដេញដោលអំពីការរៀបអាពាហ៍ពិពាហ៍ ១៣ នាក់ ស្មើនឹង ១៦% បាននិយាយថាត្រូវគេតាមដាន ១០ នាក់ ស្មើនឹង ១២% មិនត្រូវគេតាមដាន ៥៤ នាក់ ស្មើនឹង ៦៨% មិនបានផ្ដល់ព័ត៌មានពីបញ្ហានេះ និង ៣ នាក់ ស្មើនឹង ៤% បានផ្ដល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ ក្រៅយុត្តាធិការពេលវេលានៃការជំនុំជម្រះក្ដី ដោយមិនបានរែកញែកលើប្រធានបទនេះ[2572]។

១៣៥៩. **ចម្លើយជាលាយលក្ខណ៍អក្សរ៖ សំណុំរឿង ០០២/០១ (១)៖** ក្នុងចំណោមសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ១៦ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ មានតែដើមបណ្ដឹងរដ្ឋប្បវេណី

[2570] សូមមើលឧបសម្ព័ន្ធ ខ៤ និង ខ៥។

[2571] សូមមើលឧបសម្ព័ន្ធ ខ៤ និង ខ៥។

[2572] សូមមើលឧបសម្ព័ន្ធ ខ៤ និង ខ៦។

អែម អឿន ម្នាក់គត់ ដែលបាននិយាយអំពីការតាមដានការរួមភេទ ក្រោយពីគាត់រៀបការរួច[2573]។ ដូច្នេះ ភាគរយអ្នកត្រូវគេតាមដានមានដូចតទៅ៖ ម្នាក់ ស្មើនឹង ៦% ត្រូវគេតាមដាន ទល់នឹង ១៤ នាក់ ស្មើនឹង ៨៨% មិនត្រូវគេតាមដាន និងម្នាក់ ស្មើនឹង ៦% នៅក្រោយយុត្តាធិការពេលវេលា ដែលមិនបាន និយាយអំពីប្រធានបទនេះ[2574]។ **<u>កំណត់ហេតុគាំទ្រដល់ដីកាដំណោះស្រាយ (២)</u>៖** ក្នុងចំណោមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ១១៥ នាក់ ដែលបានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានតែ ៩ នាក់ប៉ុណ្ណោះ បានឆ្លើយថាត្រូវគេតាមដាន នៅយប់ផ្សំដំណេក ស្មើនឹង ៨% ទល់នឹង ៥ នាក់ មិនត្រូវគេតាមដាន ស្មើនឹង ៤% ១០០ នាក់ មិនបាននិយាយអំពីប្រធានបទនេះ ស្មើនឹង ៨៧% និងម្នាក់ ស្មើនឹង ១% បានលើកឡើងអំពីការរៀបអាពាហ៍ពិពាហ៍ ក្រោយយុត្តាធិការពេលវេលានៃការជំនុំជម្រះក្តី[2575]។ **<u>កំណត់ហេតុមកពីសំណុំរឿង ០០៣-០០៤ (៣)</u>៖** ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៨៦ ដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ២៧ នាក់ ស្មើនឹង ៣២% បាននិយាយថាត្រូវគេតាមដាន ៧ នាក់ ស្មើនឹង ៨% មិនត្រូវគេតាមដាន ៥០ នាក់ ស្មើនឹង ៥៨% មិនបានផ្តល់ព័ត៌មានពីបញ្ហានេះ និង ២ នាក់ ស្មើនឹង ២% បានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍ ក្រោយយុត្តាធិការពេលវេលានៃការជំនុំជម្រះក្តី[2576]។

---

[2573] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ម៉ោង 16.01.07។ យស ផល បាននិយាយអំពីរឿងនោះ តែនៅពេលមកផ្តល់សក្ខីកម្ម ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងសំណុំរឿង ០០២/០២ និងមិនបាននិយាយ ក្នុងសំណុំរឿង ០០២/០១ ទេ៖ ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/197.1**។

[2574] សូមមើលឧបសម្ព័ន្ធ ខ៤ និង ខ៧។

[2575] សូមមើលឧបសម្ព័ន្ធ ខ៤ និង ខ៨។

[2576] លើសពីនោះ សាក្សីពីររូបបានផ្តល់សក្ខីកម្មអំពីអាពាហ៍ពិពាហ៍ផ្ទាល់របស់ពួកគេ ដែលស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ គឺថាព្រឹត្តិការណ៍ដែលកើតឡើងនៅឆ្នាំ១៩៧៤ មិនអនុញ្ញាតឱ្យអង្គជំនុំជម្រះសន្និដ្ឋានលើការផ្សំដំណេក ឬការតាមដានឡើយ៖ <u>ប្រាក់ យុត</u>៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ **E3/9499** ស/ឆ ៩៦-៩៧៖ "ឆ.៩៦ ទេ <u>អង្គការមិនបានបង្ខំ ឬដាក់សម្ពាធឱ្យយើងផ្សំដំណេក</u>ជាមួយគ្នាភ្លាមៗនោះទេ។ ក្រោយមកយើងបានបែកគ្នាទៅធ្វើការរៀងខ្លួន")។ កំណត់ហេតុស្តាប់ចម្លើយសាក្សី រៀល នាង ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ **E3/9652** ស/ឆ ២៨ (គាត់មិនដឹងថាគេតាមដានគាត់ឬអត់ទេ)។ សូមមើលឧបសម្ព័ន្ធ ខ៤ និង ខ៩។

១៣៦០. ការវិភាគភ័ស្តុតាងជាទូទៅបង្ហាញថា រឿងរ៉ាវអំពីការតាមដានការរួមដំណេកមិនមែនជាការអនុវត្តជារួមនោះទេ។ ការផ្តោតរឿងរ៉ាវទាំងនេះលើវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺជាលទ្ធផលនៃការជ្រើសរើសរបស់អង្គជំនុំជម្រះ ប៉ុន្តែមិនអាចឱ្យសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថាមានការតាមដានជាទូទៅលើប្តីប្រពន្ធថ្មោងថ្មី នៅទូទាំងប្រទេស និងមានការជំរុញពី ប.ក.ក បានឡើយ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះក្នុងន័យនេះ នឹងត្រូវទុកជាមោឃៈ។

### *២.៣.១.២. បរិបទបង្ខិតបង្ខំ និងការរួមភេទដោយបង្ខំ*

១៣៦១. អង្គជំនុំជម្រះបានធ្វើការបូកសរុបជារួមខុស ដោយគ្មានការគាំទ្រពីភ័ស្តុតាងក្នុងសំណុំរឿង ដោយបានសន្និដ្ឋានថា ប្តីប្រពន្ធមានអារម្មណ៍ថាត្រូវគេបង្ខំឱ្យរួមភេទជាមួយគ្នា ហើយត្រូវគេអប់រំ គំរាមសម្លាប់ ឬដាក់ទណ្ឌកម្ម ប្រសិនបើមិនព្រមរួមភេទ[2577]។

### *ការចាត់វិធានការក្រោយពេលរៀបអាពាហ៍ពិពាហ៍*

១៣៦២. ដើម្បីសន្និដ្ឋានថាមានការរំលោភសេពសន្ថវៈ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះបានពិចារណាជារួមថា ការចាត់វិធានការលើប្តីប្រពន្ធថ្មោងថ្មី ជាធាតុផ្សំដាក់បន្ទុក។ ដូចបានរំឭកពីខាងលើ តាមច្បាប់ជាធរមាន នៅពេលកើតហេតុ ការរំលោភសេពសន្ថវៈរវាងប្តីប្រពន្ធពុំមានអត្ថិភាពទេ ហើយការរួមភេទរវាងប្តីប្រពន្ធ គឺជារឿងឡូស៊ិក ក្រោយពីរៀបអាពាហ៍ពិពាហ៍។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាការរៀបចំទីលំនៅឱ្យប្តីប្រពន្ធទើបរៀបការ និងការអនុញ្ញាតឱ្យពួកគេឈប់សម្រាក គឺជាចេតនារបស់កម្មាភិបាលក្នុងការបង្ខំឱ្យពួកគេរួមភេទ។ ប៉ុន្តែ ដូច Peg LEVINE បានលើកឡើង កាតព្វកិច្ចរួមសង្វាសរវាងប្តីប្រពន្ធមាននៅក្នុងគ្រប់វប្បធម៌ ហើយនេះគឺជាខ្លឹមសារនៃការរៀបអាពាហ៍ពិពាហ៍[2578]។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជា

---

[2577] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩៦។

[2578] Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/480.1** ម៉ោង 15.50.16 (“ខ្ញុំមិនចង់មានភាពស្មុគស្មាញបន្ថែមទៀតទេពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅក្នុងសម័យខ្មែរក្រហមនោះ បើយើងនិយាយអំពីនៅលោកខាងលិច គេនិយាយអំពីយប់ គេហៅថារាត្រីទឹកឃ្មុំនោះ”)។

ច្រើន បានបញ្ជាក់អះអាងទស្សនៈនេះ៖ ក្រោយពីរៀបការជាផ្លូវការរួចមក ការរួមសង្វាស និងទំនាក់ទំនងស្និទ្ធស្នាលរវាងប្តីប្រពន្ធ គឺជារឿងឡូស៊ិក[2579]។

១៣៦៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយខកខានមិនបានពិចារណាលើបរិបទប្រពៃណីខ្មែរ ដែល ប្រជាជនប្រកាន់ខ្ជាប់នៅឡើយ នៅសម័យនោះ។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីត្រូវបានរៀបចំឡើងពីឪពុកម្តាយ ដើម្បីឱ្យកូនៗអាចកសាងគ្រួសារ ហើយទំនាក់ទំនងរវាងបុរស និងស្ត្រីត្រូវស្រុះស្រួលគ្នាក្នុងបរិបទនេះ។ តាមប្រពៃណី គេនិយាយដល់ការរួមសង្វាស និង/ឬការរួមភេទរវាងប្តីប្រពន្ធថ្មោងថ្មីដោយប្រយោល ក្នុងពិធីរៀបការ។ សញ្ញាណនៃការកសាងគ្រួសារ និងបង្កើតកូន គឺជាភ័ស្តុតាងមិនអាចប្រកែកបាន ដូចអ្នកជំនាញទាំងពីរបានលើកឡើង ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍[2580]។

---

[2579] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ **E1/291.1** ម៉ោង 09.24.36។ ប៊ិត បឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ម៉ោង 11.23.28។ ប៊ិត បឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ម៉ោង 11.23.28 "ក្រោយពីរៀបការទៅ អាហ្នឹងគេទៅតាមគូផងគេទៅ។ គេមិនបាច់មានការណែនាំ គេដឹងតែមួយគូៗគ្នាគេ"។)។ ណុប ងឹម៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 11.12.40 ("ចង់សួរថាអ៊ីចេះ ការហើយក៏ខ្ញុំអត់មានអីទេ ចេះ តែទ្រាំយកគ្នាទៅ ធ្វើម៉េចទេអង្គការការឱ្យហើយ [...] អង្គការការឱ្យចេះតែទ្រាំយកទៅ បានគ្នាបានជាកូន បានជាចៅហើយ")។ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1** មុនម៉ោង 13.42.27 ("បើកាលណាការហើយ បើយើងគិតទៅ វាត្រូវតែរួមដំណេក [...] បើមិនរួមដំណេក ក៏យើងថាការយ៉ាងម៉េច ?")។ ជាំង ស្រីមុំ៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ **E1/254.1** មុនម៉ោង 10.45.45។ ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 09.29.19 "ខ្ញុំ ជៀសមិនផុតពីប្តីប្រពន្ធ អីចឹងខ្ញុំត្រូវដាក់ចិត្តនៅពេលហ្នឹង"។ កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9662** ស/ឆ ៤០, ៤៣។

[2580] Kasumi NAKAGAWA៖ ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/472.**1 ម៉ោង 11.14.27 (ស្ត្រីមួយចំនួន គេណែនាំថាឱ្យ "ធ្វើតាមប្តីរបស់ខ្លួន នៅយប់រៀបការនោះ។ [...] ចំពោះក្រុមគ្រួសារមុនរបបខ្មែរក្រហមក្តី ហើយ ក្រោយរបបខ្មែរក្រហមក៏ដោយ គឺថារឿងទូទៅដែលគេសួរនោះ គេគ្រាន់តែសួរថា៖ តើអ្នកឯងមានកូនប៉ុន្មានហើយ? មានកូនឬនៅ? ដូច្នេះ វាជាការគួរសមជាង គឺថាគេសួរពាក្យថាតើមានកូនហើយឬនៅ? ឬថាតើចង់បានកូនហើយឬនៅ? ហ្នឹងហើយ គឺថាគេតែងប្រើសំណួរបែបនេះវិញទេទាក់ទងនឹងការបន្តពូជនោះ")។ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** មុនម៉ោង 11.06.23 សំណួរដែលសួរចង់ដឹងថាចំពោះការរួមដំណេកពេលយប់ដល់ប្តីប្រពន្ធច្រើនតែសម្គាល់លើការមានផ្ទៃពោះ។ សូមមើលផងដែរ Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/480.1** មុនម៉ោង 15.53.22 ("គូស្រករភាគច្រើនបាននិយាយថា វាដូចការរំពឹងទុក "ខ្ញុំរៀបការជាមួយអ្នកណាម្នាក់នេះ ហើយរំពឹងថានឹងមានកូនចៅសម្រាប់ក្រុមគ្រួសាររបស់ខ្លួន" ក៏ប៉ុន្តែវាមិនមែនមានការសន្និដ្ឋានណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់ថាស្ត្រីអាចនឹងត្រូវតែមានផ្ទៃពោះក្រោយការរៀបការរយៈពេលមួយឆ្នាំក្រោយមកនោះទេ")។

*<u>ការប្រើការគំរាមកំហែងពីអាជ្ញាធរ/ការរំលោភសេពសន្ថវៈក្រៅវិវាហភាព</u>*

១៣៦៤. អង្គជំនុំជម្រះបានបំភ្លៃ និងបំប្លែងភស្តុតាង ដោយបានបកស្រាយដាក់បន្ទុកមិនសមហេតុផល ដើម្បីសន្និដ្ឋានថា មានការគំរាមកំហែង និង/ឬសេចក្ដីណែនាំឱ្យប្ដីប្រពន្ធបង្ខំចិត្តរួមភេទជាមួយគ្នា[2581]។

១៣៦៥. **<u>សក្ខីកម្មទទួលបានក្រៅវគ្គស្ដីពីការរៀបអាពាហ៍ពិពាហ៍</u>៖** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការបកស្រាយដាក់បន្ទុកទៅលើសក្ខីកម្មរបស់ ប្រាក់ យុត ដែលបានឆ្លើយក្នុងសវនាការថា៖ "បន្ទាប់ពីរៀបការហើយ បើយើងគិតទៅ វាត្រូវតែរួមដំណេក បើមិនរួមដំណេក យើងថារៀបការយ៉ាងម៉េច។ បន្ទាប់មកប្រសិនបើមិនបានរួមដំណេក តើគោលបំណងនៃការរៀបការធ្វើអ្វីទៅ"។ ចម្លើយរបស់គាត់មិនអាចត្រូវបានបកស្រាយដោយសមហេតុផលថា ជាការបញ្ជាក់អំពីការគំរាមកំហែងចំពោះប្ដីប្រពន្ធនោះឡើយ។ គាត់គ្រាន់តែនិយាយតាមរបៀបអ្នកស្រុកស្រែថា ការរួមដំណេកគឺជារឿងដែលត្រូវធ្វើ ក្រោយការរៀបការ[2582]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានលាក់បាំងផ្នែកដ៏សំខាន់នៃការពន្យល់របស់គាត់៖

> "ចំពោះគូស្រករមិនរួមដំណេក ខ្ញុំអត់មាន<u>វិធានការ</u>អីដែលធ្វើឱ្យគូស្រករទាំងពីរនាក់នោះបាត់បង់អីទេ មានតែការអប់រំនៅក្នុងស្រុក ដើម្បីឱ្យគូស្រករទាំងពីរនោះចេះ<u>យល់ចិត្តយល់គំនិតគ្នា</u> ព្រោះយើង<u>ការរួចហើយ</u> តែថាឱ្យយកគូស្រករទាំងពីរនាក់នេះ ខ្ញុំជាចៅហ្វាយស្រុកដែលគាត់មិនបានរួមដំណេក ហើយយកគាត់ទៅ<u>ធ្វើបាប</u> <u>ធ្វើទោស</u> គឺអត់មាន"[2583]។

១៣៦៦. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនបានពិចារណាលើការយល់ឃើញផ្ទាល់អំពីការរៀបអាពាហ៍ពិពាហ៍របស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី។ ជាក់ស្ដែង ពិតមែនតែ ជាំង ស្រីមុំ បាន

---

[2581] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៥-៣៦៤៦។

[2582] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៥ កំណត់សម្គាល់ជើងទំព័រលេខ ១២១៨០។ <u>ប្រាក់ យុត</u>៖ ឯកសារ **E1/378.1** មុនម៉ោង 13.42.27។

[2583] <u>ប្រាក់ យុត</u>៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1** ម៉ោង 13.47.37 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

អះអាងថាគាត់ខ្លាចស្លាប់ និងគ្មានជម្រើសអ្វីផ្សេងក្រៅពីរួមដំណេក ប៉ុន្តែ គាត់ក៏បានបញ្ជាក់ថា ការភ័យខ្លាចរបស់គាត់បណ្តាលមកពីការស្លាប់របស់ឪពុកគាត់ ហើយទោះជាយ៉ាងណា គាត់ និងប្តីគាត់បានរៀបការ "ជាផ្លូវការ"[2584]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានផ្អែកលើសក្ខីកម្មរបស់ ម៉ម សឿន។ ទោះបីជាគាត់បានឆ្លើយថា អ្នកប្រកែកមិនព្រមរួមដំណេកអាចយកជីវិតទៅប្រថុយនឹងគ្រោះថ្នាក់ក៏ដោយ ក៏អង្គជំនុំជម្រះគួរណាតែយល់ឃើញថា សាក្សីនេះមិនអាចដឹងលម្អិតអំពីការតាមដាន ក្រោយការរៀបអាពាហ៍ពិពាហ៍ទេ ដោយសារតែគាត់ខ្លួនឯងផ្ទាល់មិនបានរៀបការទេនៅសម័យនោះ[2585]។

១៣៦៧. **<u>ការប្រើប្រាស់ដោយអង្គជំនុំជម្រះនូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍</u>៖** អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ក្នុងការវាយតម្លៃទៅលើសក្ខីកម្មរបស់ សយ ណារឿន, អ៊ុំ យឿន, ជា ឌៀប, កុល ណែម និង ប៉ែន សុចាន់។

១៣៦៨. ឧទាហរណ៍ អង្គជំនុំជម្រះមិនបានទាញផលវិបាកចេញពីសក្ខីកម្មរបស់ ប៉ែន សុចាន់។ ការរំលោភសេពសន្ថវៈដោយហិង្សាខ្លាំងពីសំណាក់ប្តីគាត់ តាមការស្នើពីឈ្លប ធ្វើឱ្យករណីរបស់គាត់ខុសប្លែកពីគេ ដោយវាកើតចេញពីស្នាដៃរបស់ឈ្លបក្មេងៗ[2586]។ បើតាម ប៉ែន សុចាន់ ឈ្លបមានទស្សនៈយល់ឃើញអំពីការរៀបការ យ៉ាងចាស់គំរឹលបំផុត៖ "បានចាប់ដៃគ្នាហើយ គឺប្តីប្រពន្ធហើយ ត្រូវតែចាប់រំលោភឱ្យបាន"។ នៅថ្ងៃបន្ទាប់ គាត់បានបញ្ជាក់ថា "រៀបចាប់ដៃហើយ គឺប្តីប្រពន្ធហើយ ធ្វើអីក៏ធ្វើទៅ"[2587]។

---

[2584] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២១៨៧ និង ១២១៨៦ (នៃកថាខណ្ឌ ៣៦៤៥, ៣៦៤៦)។ <u>ជាំង ស្រីម៉ុ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** មុនម៉ោង 10.45.45។ ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/255.1** មុនម៉ោង 09.29.19។ ដូចគ្នានេះដែរ ចំពោះ <u>អ៊ុន យឿង</u> អង្គជំនុំជម្រះបានធ្វើមិនដឹងមិនឮពីការដែលថាការរៀបការរបស់គាត់ធ្វើឡើងតាមឆន្ទៈរបស់គាត់ និង ប្តីគាត់ ហើយក៏ដូចជាករណីមនុស្សផ្សេងទៀតដែលមានលើកឡើងនៅក្នុងការផ្តល់សក្ខីកម្មរបស់គាត់ ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/387.1** ម៉ោង 14.18.10 ចាប់ពីម៉ោង 15.39.49។

[2585] <u>ម៉ម សឿម</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** ម៉ោង 15.56.26។

[2586] <u>ប៉ែន សុចាន់</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/482.1** ម៉ោង 14.35.37 ម៉ោង 14.40.47។

[2587] <u>ប៉ែន សុចាន់</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/482.1** មុនម៉ោង 15.44.46។ ប្រតិចារឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/483.1** ម៉ោង 09.57.02។

ដូច្នេះ ចៅក្រមប្រកបដោយវិចារណញ្ញាណគួរណាតែយល់ឃើញថា ឈ្លបហិង្សាបានផ្អែកលើទស្សនៈថា ប្ដីមានសិទ្ធិអំណាចគ្រប់បែបយ៉ាងក្នុងការរួមសង្វាសជាមួយប្រពន្ធ។ វាជារឿងមិនសមហេតុផលទេក្នុងការសន្និដ្ឋានថា ករណីហួសហេតុនេះស្ថិតក្នុងគោលនយោបាយរបស់ ប.ក.ក។

១៣៦៩. ដូចគ្នាផងដែរ អង្គជំនុំជម្រះបានផ្អែកលើករណីរំលោភសេពសន្ថវៈក្រៅវិសាលភាព លើ អ៊ុំ យឿន ពីសំណាក់មេរបស់ប្ដីគាត់ ដែលគាត់ចាត់ទុកជាមនុស្សសាហាវឃោរឃៅ។ ការរំលោភសេពសន្ថវៈ នេះគឺជាការដាក់ទណ្ឌកម្មចំពោះការមិនព្រមរួមភេទ[2588]។ ដូចបានឃើញពីខាងលើ[2589] ការរំលោភសេពសន្ថវៈ គឺជាការអនុវត្ត ដែល ប.ក.ក បានផ្ដន្ទាទោស។ ការរំលោភសេពសន្ថវៈជាទង្វើផ្ទុយនឹងការហាមឃាត់ទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ ផ្ទុយនឹងសីលធម៌នៃមនោគមន៍វិជ្ជាបដិវត្តន៍ និងទស្សនៈថ្មីអំពីស្ត្រី។ ដូច្នេះ បទពិសោធន៍របស់ អ៊ុំ យឿន មិនអាចជាតំណាងឱ្យគោលនយោបាយរបស់ ប.ក.ក បានទេ។

១៣៧០. Kasumi NAKAGAWA បានលើកឡើងអំពីការបំពានអំណាចពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលគាត់បានវិភាគថាជាបរាជ័យរបស់អាជ្ញាធរថ្នាក់លើ ក្នុងការដាក់ឱ្យអនុវត្ត "គោលនយោបាយដើម្បីការពារស្ត្រី"[2590]។ អង្គជំនុំជម្រះគួរណាតែយល់ឃើញថា ឥរិយាបថប្រភេទនេះគឺជាការប្រាសចាកយ៉ាងច្បាស់ក្រឡែតពីគោលនយោបាយរបស់ ប.ក.ក។ ក្នុងដំណើរការលម្អៀង និងខុសឆ្គង សំដៅផ្ដន្ទាទោសម្ចាស់បណ្ដឹងសាទុក្ខឱ្យខាងតែបាន អង្គជំនុំជម្រះបែរជាប្រើប្រាស់ការរំលោភសេពសន្ថវៈ ដែល

---

[2588] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៨។ <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ម៉ោង 13.54.30។

[2589] សូមមើលខាងលើ កថាខណ្ឌ ១១៧៣។

[2590] <u>Kasumi NAKAGAWA</u>៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 14.15.32 ("ការរំលោភសេពសន្ថវៈបែបហ្នឹង គឺជាការរំលោភអំណាច") ម៉ោង 14.13.24 ("មាននយោបាយតឹងតែងប្រឆាំងនឹងការរំលោភនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែអ្នកដែលប្រព្រឹត្តហ្នឹងមិនត្រូវបានដាក់ទណ្ឌកម្មទេ ពីព្រោះថាថ្នាក់លើមិនដឹងថាមានការប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះទេ មែនទេ? ឆ. ត្រឹមត្រូវហើយពិតជាមានគោលនយោបាយតឹងរ៉ឹងមែន ហើយអ្នកណាក៏ដឹងពីគោលនយោបាយនេះដែរ។ ខ្ញុំដឹងថាថ្នាក់លើមិនបានអនុវត្តគោលនយោបាយហ្នឹងទេ គឺគោលនយោបាយគេមានដើម្បីការពារស្ត្រី ក៏ប៉ុន្តែគេប្រើគោលនយោបាយនេះដើម្បីវាយប្រហារទៅលើស្ត្រីទៅវិញ")។ សូមមើលផងដែរសំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦២។

ខ្លួនដឹងថាក្រៅវិសាលភាព ក្រោមហេតុផលបោកបញ្ឆោត "ស្វែងយល់អំពីបរិបទទូទៅ" នៃការរៀបអាពាហ៍ពិពាហ៍។ តាមពិត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានយកការរំលោភសេពសន្ថវៈមកសន្និដ្ឋានថា បទឧក្រិដ្ឋរំលោភសេពសន្ថវៈមានធាតុផ្សំគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីការគំរាមកំហែងពីអាជ្ញាធរ (អំពើចេតនា) ឱ្យប្ដីប្រពន្ធរួមភេទដោយបង្ខំ[2591]។ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ នឹងត្រូវទុកជាមោឃៈ។

១៣៧១. **<u>ការមិនប្រើប្រាស់ដោយអង្គជំនុំជម្រះនូវសក្ខីកម្ម ក្នុងសំណុំរឿង ០០២/០២៖</u>** ដូចបានឃើញពីខាងលើ សាក្សីជាច្រើនបានអះអាងថា ករណីយកិច្ចរួមសង្វាស និងរួមភេទ ក្រោយពីរៀបអាពាហ៍ពិពាហ៍ (ដោយគ្មានការបង្ខិតបង្ខំ) គឺជាភ័ស្តុតាងមិនអាចប្រកែកបាន តាមលក្ខណៈប្រពៃណី[2592]។

១៣៧២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានលើកឡើងថា សូម្បីតែដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានឆ្លើយថាបានរៀបការមិនសមបំណង (ណុប ង៉ឹម, ផាន់ ហ៊ុម និង សេង សឿន) ក៏មិនបាននិយាយពីការរួមដំណេក ក្រោមការបង្ខិតបង្ខំដែរ[2593]។ ទោះបីជា ព្រាប សុខឿន បានផ្ដល់សក្ខីកម្មថាប្ដីគាត់បានរំលោភគាត់ក៏ដោយ ក៏គាត់គិតថាជាអំពើស្មគ្រចិត្តពីប្ដីគាត់។ ជាការពិត គាត់មិនបាននិយាយអំពី

---

[2591] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥២ និង ៣៥៣៥។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយធ្វើសេចក្ដីសន្និដ្ឋានថា ការរំលោភសេពសន្ថវៈក្រៅវិសាលភាពនៃការជំនុំជម្រះនេះ ពីដំបូងឡើយមានប្រភពមកពីការយល់ស្របនៃដើមបណ្ដឹងរដ្ឋប្បវេណីដែលព្រមព្រៀងទទួលយកទំនាក់ទមនងជាមួយនឹងប្ដីគាត់ ខណៈដែលគាត់បានបញ្ជាក់ថាមិនមានការណែនាំបែបនោះឡើយ៖ <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ម៉ោង 09.10.28 ប៉ុន្តែគឺថា ដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងបានបញ្ជាក់ថាទំនាក់ទំនងនោះត្រូវបានធ្វើឡើង "មួយ ឬពីរខែក្រោយមក" ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/462.1** ម៉ោង 13.31.20។

[2592] សូមមើលខាងលើ កថាខណ្ឌ ១៣៦២។

[2593] <u>ផាន ហ៊ុម</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.41.31 (បន្ទាប់ពីបានដឹងឮ និងពិភាក្សាគ្នា គាត់ចាប់ផ្ដើមមានចិត្តអាណិតប្ដីគាត់ ហើយក៏ចាប់ផ្ដើមរស់នៅជាប្ដីប្រពន្ធ)។ <u>ណុប ង៉ឹម</u>៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 14.19.56 និងម៉ោង 11.12.40។

ការគំរាមកំហែង ឬសេចក្តីណែនាំឱ្យធ្វើបែបនេះពីបុគ្គលខាងក្រៅណាម្នាក់ឡើយ[2594]។ អង្គជំនុំជម្រះក៏បានធ្វើមិនដឹងមិនឮផងដែរចំពោះសក្ខីកម្មជាច្រើនរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនិយាយផ្ទុយពីការសន្និដ្ឋានរបស់ខ្លួន។ ឧទាហរណ៍ ទោះបីជា ប្រាក់ ឌឿន បាននិយាយអំពីការតាមដានពីល្ពបក៏ដោយ ក៏គាត់បានបញ្ជាក់ថា ប្តីប្រពន្ធថ្មោងថ្មីមិនត្រូវគេដាក់ទណ្ឌកម្មទេ ហើយអង្គការណែនាំឱ្យរួមភេទ និងរស់នៅជាមួយគ្នា[2595]។ អង្គជំនុំជម្រះបានចៀសវាងក្នុងការលើកឡើងថា ដួច ជាំង ស្រីមុំ, ណុប ង៉ឹម និង ផាន់ ហ៊ីម ដែរ ស្រី សឿម បានពន្យល់ថា គាត់បានយល់ព្រមរួមភេទជាមួយប្តីគាត់ ពីព្រោះពួកគាត់ជាប្តីប្រពន្ធនឹងគ្នាហើយ។ ជាក់ស្តែង គាត់បានបន្ថែមថា គាត់មិនមាន "អារម្មណ៍ភ័យខ្លាច" ទេ ពីព្រោះពួកគាត់រស់នៅជាមួយគ្នាយូរដែរហើយ[2596]។

១៣៧៣. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុ ដោយសារមិនអើពើនឹងការសន្និដ្ឋានរបស់អ្នកជំនាញ Peg LEVINE ដែលបានអះអាងថា ក្នុងការអនុវត្តវិធីសាស្ត្រមិនជ្រើសរើស និងមិនលម្អៀង យើងឈានដល់ការធ្វើសេចក្តីសន្និដ្ឋានផ្សេងពីអង្គជំនុំជម្រះ[2597]។

## *ការលោក់បាំងការមិនរួមភេទ ដើម្បីបញ្ចៀសផលវិបាកធ្ងន់ធ្ងរ*

១៣៧៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា គេត្រូវលាក់បាំងការមិនរួមភេទ ដើម្បីបញ្ចៀសផលវិបាកធ្ងន់ធ្ងរ។ អង្គជំនុំជម្រះមិនត្រឹមតែផ្អែកតែលើសក្ខីកម្មពីររបស់ដើម

---

[2594] ព្រាប សុខឿន៖ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ម៉ោង 14.38.09។ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** មុនម៉ោង 11.23.27 ក្រោយម៉ោង 13.51.22 (គ្មានអ្នកណាបញ្ជាគាត់ឱ្យរួមដំណេកជាមួយប្តីគាត់ឡើយ ប៉ុន្តែប្តីគាត់បានរំលោភគាត់ ហើយបន្ទាប់មក បានលួងលោមគាត់ថាបានគ្នាជាប្តីប្រពន្ធទៅហើយ)។

[2595] ប្រាក់ ឌឿន៖ ប្រតិចារឹក ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/361.1** ក្រោយម៉ោង 15.58.14។

[2596] កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ចុះថ្ងៃទី១០៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E3/9826** ស/ធ 169-171។

[2597] Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/480.1** មុនម៉ោង 15.51.24 ("ប៉ុន្តែនៅក្នុងការសម្ភាសន៍របស់ខ្ញុំនេះ អត់មាននរណាប្រាប់ខ្ញុំថា ស្អែកឡើងមានអ្នកណាសួរពួកគាត់ថា ម៉េចទៅអ្នកឯងហ្នឹងបានដេកជាមួយគ្នា រួមដំណេកជាមួយគ្នាឬទេ។ នៅក្នុងប៉ាន់គំរូរបស់ខ្ញុំ មិនមានអ្នកណាម្នាក់ត្រូវបានគំរាមកំហែងថា បើអ្នកឯងមិនធ្វើតាមសំណើគេហ្នឹងទេ គឺថាអ្នកឯងត្រូវសម្លាប់ចោលនោះ គឺថាអត់មានអ្នកណាប្រាប់ខ្ញុំថាដូច្នេះទេ")។

បណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន និង យស ផល ប៉ុណ្ណោះទេ ថែមទាំងបានធ្វើការសន្និដ្ឋានសរុប ដោយមិនគិតពីបរិបទខ្មែរ[2598]។ ជុំ សាមឿន ចង់លាក់បាំងរឿងដែលគាត់មិនព្រមរួមដំណេក ក្រោយការរៀបអាពាហ៍ពិពាហ៍ ខណៈដែលគាត់មិនដឹងអំពីផលវិបាក[2599]។ យស ផល បានឆ្លើយថាគាត់ធ្វើពុតជាស្រឡាញ់ប្រពន្ធ ក្នុងរបបនោះ ប៉ុន្តែ គាត់បន្តរស់នៅជាមួយប្រពន្ធ ដោយសារតែសម្ពាធគ្រួសារ[2600]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានលើកឡើងថា ក្នុងវប្បធម៌ខ្មែរ ស្នេហារ៉ូម៉ង់ទិកមិនមែនជារឿងសំខាន់បំផុតទេ ពីព្រោះមានកត្តាកំណត់ផ្សេងទៀតចំពោះជីវិតជាប្ដីប្រពន្ធ។ នេះជាការពន្យល់របស់អ្នកជំនាញ Kasumi NAKAGAWA[2601]។

## *នីតិវិធីតាមដានប្ដីប្រពន្ធដែលមិនរួមដំណេក*

១៣៧៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា "ជាទូទៅ" នីតិវិធីតាមដានត្រូវបានរៀបចំឡើង ដោយអាជ្ញាធរបានកោះហៅប្ដីប្រពន្ធដែលមិនរួមដំណេកមកនិយាយដាច់ដោយឡែកពីគ្នា ឬរួមគ្នា[2602]។ ដើម្បីទាញសេចក្ដីសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ យូ វ៉ាន់, ប្រាក់ យុត និង សុន វុត។ ប៉ុន្តែ ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ថា ក្នុងចំណោមសាក្សីទាំងនេះ គ្មានអ្នកណាម្នាក់បានលើកឡើងអំពីអត្ថិភាពនៃការចាត់វិធានការលើប្ដីប្រពន្ធថ្មោងថ្មី ដែលមិន

---

[2598] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៧។

[2599] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៧ កំណត់សម្គាល់ជើងទំព័រលេខ ១២២០០។

[2600] <u>យស ផល</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/464.1** ម៉ោង 10.53.07 (សម្ពាធពីគ្រួសារសុំឱ្យរស់នៅជាមួយគ្នាក្រោយរបបខ្មែរក្រហម) ម៉ោង 11.05.33 (សម្ពាធពីរបបខ្មែរក្រហម)។ សូមមើលផងដែរ <u>អ៊ុំ យឿន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** ក្រោយម៉ោង 09.31.31 ("ចាស់ទុំ ម៉ែក្មេក បង្កើត ម៉ែក្មេក ម៉ែខ្លួនឯងហ្នឹង ហើយចាស់ៗទុំ បងប្អូនចេះតែថាបើបានជាកូន បានជាចៅហើយ ជុំគ្នាវិញទៅ។ ដល់ជុំគ្នាបានតែ៣ឆ្នាំ ក៏គាត់ស្លាប់ទៅ")។

[2601] <u>Kasumi NAKAGAWA</u>៖ ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/473.1** ម៉ោង 10.39.56 ក្រោយម៉ោង 15.41.57 ។

[2602] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៦។

បានរួមដំណេកនោះទេ[2603]។ សក្ខីកម្មជាច្រើនដែលទទួលបានក្នុងសវនាការបានបញ្ជាក់អះអាងដូចគ្នា[2604]។

១៣៧៦. លើសពីនេះទៀត ដូចបានឃើញពីខាងលើ ថ្វីត្បិតតែកម្មាភិបាលខ្លះបាននិយាយអំពីការតាមដានប្តីប្រពន្ធដែលមិនចុះសម្រុងនឹងគ្នាពីសំណាក់ប្រធានផ្ទាល់របស់ពួកគេក៏ដោយ ក៏ពួកគេបានអះអាងថាប្រធានទាំងនេះមានតួនាទីជាអ្នកផ្តល់ឱវាទដល់ប្តីប្រពន្ធថ្មោងថ្មី ដោយយោងទៅលើអាយុ និងឋានៈរបស់ពួកគាត់។ ពួកគាត់មានតួនាទីធ្វើយ៉ាងណាឱ្យប្តីប្រពន្ធដែលបានផ្សំផ្គុំចុះសម្រុងនឹងគ្នា[2605]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិចារណាលើសក្ខីកម្មរបស់សាក្សីទាំងនេះ ដែលបាននិយាយពីការទូន្មានពីការប្តេជ្ញាចិត្ត ជាជាងការដាក់ទណ្ឌកម្ម[2606]។ ប្រការនេះស៊ីចង្វាក់គ្នានឹងសម្តី និងការណែនាំរបស់កម្មាភិបាលខ្លះ ក្នុងពិធីរៀបអាពាហ៍ពិពាហ៍។

---

2603 ស៊ុន វុត៖ ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/412.1** ក្រោយម៉ោង 09.14.02 មុនម៉ោង 09.39.56 (គាត់បានឱ្យឧទាហរណ៍ប្តីប្រពន្ធមួយគូដែលបែកគ្នា ដោយសារតែពួកគាត់មិនចុះសម្រុងគ្នា តែក៏មិនមានការធ្វើអាក្រក់ដាក់គ្នាដែរ)។ យូ វ៉ាន់៖ ប្រតិចារឹក ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/3761** មុនម៉ោង 15.40.24។ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1** មុនម៉ោង 13.42.27 ម៉ោង 13.47.37។

2604 ឧទាហរណ៍ សូមមើល ប្រាក់ ខឿន ៖ ប្រតិចារឹក ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៥ **E1/361.1** ក្រោយម៉ោង 15.58.14 (ប្តីប្រពន្ធថ្មីថ្មោងទាំងនោះមិនត្រូវបានអង្គការដាក់ទណ្ឌកម្មឡើយ អង្គការឱ្យពួកគាត់ផ្សំដំណេក និងរស់នៅជាមួយគ្នា)។ សាក្សីត្រាំកក់៖ ខឹម ហឿន៖ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ **E1/296.1** ម៉ោង 09.59.35។ ភ្នៅ យ៉ាវ៖ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ **E1/264.1** ក្រោយម៉ោង 14.12.43 (ប្តីប្រពន្ធថ្មីថ្មោងត្រូវបានណែនាំផ្សំដំណេក ប៉ុន្តែមិនត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងដោយសារតែមិនចុះសម្រុងគ្នាឡើយ)។ នាង អ៊ួច៖ ប្រតិចារឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/275.1** មុនម៉ោង 11.35.01 (បានលើកពីករណីប្តីប្រពន្ធមិនចុះសម្រុងគ្នា ហើយបើតាមសម្តីគាត់ វិធានការគ្រាន់តែប្រធានកងណែនាំពួកគេឱ្យទៅរស់នៅជួបជុំគ្នាវិញ)។

2605 សូមមើលខាងលើ *"សេចក្តីរាយការណ៍ពីការតាមដាន"* កថាខណ្ឌ ១៣៤៩-១៣៥១។ ហេង ឡៃប៉ាង៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/4761** ក្រោយម៉ោង 13.55.19។ ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/291.1** មុនម៉ោង 09.27.04។

2606 ហេង ឡៃប៉ាង៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/4761** ក្រោយម៉ោង 13.55.19។ ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ **E1/291.1** មុនម៉ោង 09.27.04។

១៣៧៧. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ប.ក.ក បានចាត់វិធានការបង្ខំប្តីប្រពន្ធថ្មោងថ្មីឱ្យរួមភេទ នោះឡើយ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវបដិសេធចោល។

## ២.៣.២. កំហុសក្នុងការសន្និដ្ឋានអំពីករណីរំលោភសេពសន្ថវៈដែលបង្ហាញក្នុងសំណុំរឿង

១៣៧៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ ដែលខ្លួនយល់ឃើញថាពិតជាកើតឡើងមែន ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍[2607]។ សំអាងហេតុរបស់អង្គជំនុំជម្រះមិនត្រឹមតែស្រពេចស្រពិលលើករណីរំលោភសេពសន្ថវៈប៉ុណ្ណោះទេ (២.៣.២.១) ការវាយតម្លៃលើភស្តុតាងទាំងមូលថែមទាំងមិនអាចឱ្យសន្និដ្ឋានថា ប.ក.ក មានចេតនាប្រកាន់យកឥរិយាបថដែលចោទប្រកាន់ (២.៣.២.២) ទៀតផង។ ដូច្នេះ កំហុសត្រួតគ្នាទាំងនេះបានបណ្តាលឱ្យអង្គជំនុំជម្រះធ្វើសេចក្តីសន្និដ្ឋានខុសទាំងស្រុង (២.៣.២.៣)។

### *២.៣.២.១. កំហុសពាក់ព័ន្ធនឹងករណី "រំលោភសេពសន្ថវៈ" និងភាពជាតំណាង*

១៣៧៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសារគ្មានភាពច្បាស់លាស់អំពីករណីរំលោភសេពសន្ថវៈ ដែលខ្លួនយល់ឃើញថាពិតជាកើតឡើងមែន ក្នុងសំអាងហេតុសាលក្រម។ ដូច្នេះ មេធាវីការពារក្តីត្រូវទៅស្វែងរកក្នុងផ្នែកការរកឃើញផ្នែកអង្គហេតុ ពាក់ព័ន្ធនឹងបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍។ ដូច្នេះ ការពិនិត្យនឹងផ្តោតលើករណីដែលចាត់ទុកថាពិតជាកើតឡើងមែន និងករណីផ្សេងទៀតដែលលើកឡើង ក្នុងផ្នែក *"១៤.៣.៨.៣ ការរួមដំណេកដោយបង្ខំរវាងប្តីប្រពន្ធ"*។

- <u>**ករណីរំលោភសេពសន្ថវៈនៅសហករណ៍ត្រាំកក់**</u>

---

[2607] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០-៣៦៩៨។

១៣៨០. អង្គជំនុំជម្រះបានសន្និដ្ឋានថា ភស្តុតាង ដែលបានដាក់នៅចំពោះមុខខ្លួន បង្ហាញថា "យ៉ាងហោចណាស់ក៏មានការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងម្តងដែរ នៅក្នុងសហករណ៍ត្រាំកក់"[2608]។ មានតែម្តងនេះគត់ដែលអង្គជំនុំជម្រះបានសន្និដ្ឋានថា "ការរំលោភសេពសន្ថវៈ" ពិតជាបានកើតឡើងមែន។ ផ្ទុយទៅវិញ តាមរយៈការពិចារណាជារួម និងបោកបញ្ឆោត អង្គជំនុំជម្រះធ្វើឱ្យគេជឿថា ការរំលោភសេពសន្ថវៈមានច្រើនករណី។ តាមពិត អង្គជំនុំជម្រះអាចរកឃើញការរំលោភសេពសន្ថវៈតែម្តងគត់ ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន គឺករណីរបស់ ជាំង ស្រីមុំ[2609]។ ដូចបានឃើញពីខាងលើ ជាំង ស្រីមុំ ជាមនុស្សតែម្នាក់គត់ ក្នុងវគ្គសហករណ៍ត្រាំកក់ ដែលបានឆ្លើយថាបានរៀបការខុសពីចិត្ត។ ប៉ុន្តែ សក្ខីកម្មរបស់គាត់មិនអាចឱ្យសន្និដ្ឋានថា ការរំលោភសេពសន្ថវៈលើគាត់ពិតជាកើតឡើងទេ។ ជាក់ស្តែង ទោះបីជាមានការតាមដានពីឈ្លបក៏ដោយ ក៏ ជាំង ស្រីមុំ បានពន្យល់ថា៖ "ចំពោះប្តីរបស់ខ្ញុំ ក៏អត់មានបង្ខំដែរ ប៉ុន្តែ គឺសម្រេចចិត្តដាក់ខ្លួន ដាក់ចិត្ត។ [...] ទោះបីតែយើងមិនពេញចិត្តយ៉ាងណាក៏ដោយ ក៏យើងត្រូវតែសម្រេចចិត្តសម្រួមចិត្ត [...] ការស្រឡាញ់គ្នា មិនស្រឡាញ់គ្នា ក៏ត្រូវតែស្រឡាញ់ដែរពេលហ្នឹង"[2610]។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាជាការរំលោភសេពសន្ថវៈចំពោះករណីរបស់គាត់ទេ ពីព្រោះគាត់បានបញ្ជាក់ថា ក្រោយមក គាត់មិនត្រូវគេបង្ខំឱ្យរៀបការទេ ហើយគាត់រស់នៅយ៉ាងសុខដុមរមនា ជាមួយប្តីគាត់ដែលបានរៀបការនៅសម័យនោះ និងកូនៗ[2611]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លៃខ្លឹមសារនៃសក្ខីកម្មរបស់គាត់ ហើយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ នឹងត្រូវទុកជាមោឃៈ។

- **<u>ករណីផ្សេងទៀតដែលលើកឡើង ក្នុងផ្នែក *"១៤.៣.៨.៣ ការរួមដំណេកដោយបង្ខំរវាងប្តីប្រពន្ធ"*</u>**

---

[2608] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៧៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2609] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២២៦០ (នៃកថាខណ្ឌ ៣៦៧៤) ដែលយោងទៅកថាខណ្ឌ ៣៦៧៣ កំណត់សម្គាល់ជើងទំព័រលេខ ១២២៥៦។

[2610] <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ **E1/254.1** ម៉ោង 10.49.52. ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/255.1** មុនម៉ោង 09.29.19។

[2611] <u>ជាំង ស្រីមុំ</u>៖ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/254.1** ម៉ោង 10.49.52។ ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/255.1** មុនម៉ោង 09.29.19។

សូមមើលខាងលើ កថាខណ្ឌ ១១៧៩-១១៨៨ សូមមើល ជាំង ស្រីមុំ។

១៣៨១. ក្នុងផ្នែកនេះនៃសំអាងហេតុសាលក្រម ភ័ស្តុតាងជាច្រើនត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ដើម្បីសន្និដ្ឋានថាមានការរួមភេទដោយបង្ខំ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះ "ជឿជាក់" ថា ស្ត្រី ដែលបានលើកឡើងក្នុងផ្នែកនេះ គឺ អ៊ុំ យឿន, មុំ វុន, ព្រាប សុខឿន, ប៉ែន សុចាន់, ស៊្វ សុធារី, ជា ឌៀប និង ណុប ង៉ឹម លើកលែងតែ ផាន់ ហ៊ីម មួយចេញ ត្រូវគេបង្ខំឱ្យរួមភេទ។ បើតាមអង្គជំនុំជម្រះ គេគ្រាន់តែបង្ហាញថាគ្មានការរួមដំណេកពីដំបូងទី ដើម្បីសន្និដ្ឋានថាមានការរួមភេទដោយបង្ខំ[2612]។ ប៉ុន្តែ ភ័ស្តុតាងមិនអាចឱ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានបែបនេះឱ្យហួសពីវិមតិសង្ស័យបានទេ។ អង្គជំនុំជម្រះមិនត្រឹមតែបានប្រព្រឹត្តកំហុសក្នុងការវាយតម្លៃលើភាពអាចជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗ ដែលមេធាវីការពារក្តីបានរិះគន់ប៉ុណ្ណោះទេ ថែមទាំងបានប្រព្រឹត្តកំហុស ក្នុងវិធីសាស្ត្រអនុវត្តទៅលើភ័ស្តុតាងសេសសល់ផ្សេងទៀតដែលបានប្រើប្រាស់ទៀតផង។

១៣៨២. <u>**ដើមបណ្តឹងរដ្ឋប្បវេណីដែលបានមកផ្តល់សក្ខីកម្ម ក្នុងវគ្គស្តីពីការរៀបអាពាហ៍ពិពាហ៍ ដែលបានលើកឡើងអំពីការរំលោភសេពសន្ថវៈ៖**</u> បញ្ហានៃភាពអាចជឿជាក់បាន និងភាពជាតំណាង ដែលចោទឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ គឺ អ៊ុំ យឿន, មុំ វុន និង ព្រាប សុខឿន ត្រូវបានមេធាវីការពារក្តីលើកឡើងតាំងពីដើមទី ក្នុងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២។ បញ្ហាទាំងនេះត្រូវបានអង្គជំនុំជម្រះច្រានចោលយ៉ាងអយុត្តិធម៌ ដោយគ្មានសំអាងហេតុ[2613]។ ប៉ុន្តែ អង្គជំនុំជម្រះខកខានមិនបានផ្តល់សំអាងហេតុថា ហេតុអ្វីបានជារឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះមានភាពជាតំណាងឱ្យគោលនយោបាយរបស់ ប.ក.ក ខណៈដែលការប្រៀបធៀបជាមួយភ័ស្តុតាងផ្សេងទៀតបង្ហាញថា បទពិសោធន៍របស់ពួកគេ គឺជាករណីជ្រុលហួសហេតុ[2614]។ ការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីដោយសហព្រះរាជអាជ្ញា និង/ឬមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអង្គជំនុំជម្រះផ្តល់សុពលភាពដោយមិនត្រឹមត្រូវ ធ្វើឱ្យអង្គជំនុំជម្រះខកខានមិនបានបំពេញករណីយកិច្ចអនាគតិ។

---

2612 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៨-៣៦៦១។

2613 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៨-៣៦៤៩។

2614 សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ២៣២៧។

១៣៨៣. **ស្តង់ដារពីរនៃការពិនិត្យភ័ស្តុតាង៖** មេធាវីការពារក្តីសូមរំឭកថា ចៅក្រមប្រកបដោយវិចារណញ្ញាណ មានកាតព្វកិច្ចគោរពតាមគោលការណ៍ជាមូលដ្ឋាននៃសមធម៌ និងយុត្តិធម៌ ដែលតម្រូវមិនឱ្យអនុវត្ត បទដ្ឋានផ្សេងគ្នា សម្រាប់វាយតម្លៃលើសក្ខីកម្មដាក់បន្ទុក ឬដោះបន្ទុក។ អង្គជំនុំជម្រះបានធ្វើផ្ទុយពីនេះ ពីព្រោះអង្គជំនុំជម្រះបានបដិសេធជាប្រព័ន្ធសក្ខីកម្មរបស់កម្មាភិបាល លើកលែងតែ ក្នុងករណីពួកគេ រៀបរាប់អំពីភ័ស្តុតាង ដែលអង្គជំនុំជម្រះយល់ឃើញថាដាក់បន្ទុក។ ទឡ្ហីករណ៍ ដែលបានប្រើប្រាស់ ដើម្បីច្រានចោលសក្ខីកម្មទាំងនេះ ពាក់ព័ន្ធនឹងទំនោរចង់បន្ថយការទទួលខុសត្រូវផ្ទាល់ខ្លួន ក្នុងការរៀប អាពាហ៍ពិពាហ៍ ត្រូវបរាជ័យ នៅចំពោះមុខភ័ស្តុតាងជាច្រើននៅក្នុងសំណុំរឿងដែលមានភាពស៊ីចង្វាក់ គ្នាទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានយល់ឃើញថាអាចជឿជាក់បានជាប្រព័ន្ធ ចំពោះសក្ខីកម្មទាំង អស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនបានធ្វើការប្រៀបធៀបពិតប្រាកដជាមួយភ័ស្តុតាងផ្សេង ទៀត និងមិនបានលើកឡើងអំពីបំណងប្រាថ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ដែលចង់ ឱ្យផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខ។ ភាពមិនស៊ីចង្វាក់គ្នានៃសក្ខីកម្មរបស់ពួកគាត់ មិនត្រូវបានលើក ឡើងទាល់តែសោះ និងដូចគ្នាផងដែរចំពោះលក្ខណៈខុសប្លែកពីគេ ឬមិនស្របគ្នានៃអង្គហេតុដែលពួក គាត់បានរៀបរាប់។

១៣៨៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានអះអាងថា មេធាវីការពារក្តីមានឱកាសសួរដេញដោល ដោយមិនបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះទទួលបានជំនួយពីមេធាវី មានលទ្ធភាពចូលមើល សំណុំរឿង និងត្រូវបានមេធាវីប្រាប់ឱ្យត្រៀមខ្លួនជាមុន មុននឹងចូលមកបង្ហាញខ្លួន។ មេធាវីការពារក្តី ទាំងពីរក្រុម បើទោះជាការពារជនជាប់ចោទពីររូបផ្សេងគ្នាក៏ដោយ ក៏ត្រូវបែងចែកពេលវេលាគ្នាដើម្បី សួរដេញដោល ដោយមិនគិតពីការរំខានផ្សេងៗពីសំណាក់ភាគីនានា ឬចៅក្រម[2615]។

១៣៨៥. ដំណើរការរបស់អង្គជំនុំជម្រះមិនស្របនឹងគោលការណ៍ ដែលខ្លួនបានប្រកាសប្រកាន់យក ក្នុងការវាយ តម្លៃលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅកថាខណ្ឌ ៣៥២៨ នៃសំអាងហេតុសាលក្រម។

[2615] ជាឧទាហរណ៍ សូមមើល ប៉ែន សុចាន់៖ ប្រតិចារឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/483.1** ឯកសារ ចន្លោះម៉ោង 09.15.16 និងម៉ោង 11.56.52 (ការសាកសួរសម្រាប់មេធាវីការពារក្តីទាំងពីរក្រុម)។

ជាក់ស្តែង អង្គជំនុំជម្រះត្រូវពិនិត្យតាមករណីនីមួយៗដោយប្រយ័ត្នប្រយែង ផ្ទៀងផ្ទាត់ភាពមិនស៊ីចង្វាក់គ្នាលើអង្គហេតុសំខាន់ៗ ការជះឥទ្ធិពលលើចម្លើយរបស់សាមីខ្លួនតាមរយៈចេតនាលាក់បំពួនជាយថាហេតុ អត្ថិភាពនៃភ័ស្តុតាងស៊ីចង្វាក់គ្នានឹងខ្លឹមសារនៃសក្ខីកម្ម និងកាលៈទេសៈពាក់ព័ន្ធទាំងអស់នៃរឿងក្តី។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានធ្វើបែបនេះទេ។

១៣៨៦. វាមិនមែនជារឿងឥតប្រយោជន៍ទេក្នុងការលើកឡើងថា អង្គជំនុំជម្រះមានទំនោរធ្វើមិនដឹងមិនឮចំពោះការភ្លេច ឬការកែតម្រូវយឺតពេលនៅនាទីចុងក្រោយ ចំពោះសក្ខីកម្មរបស់ពួកគេលើចំណុចសំខាន់ៗ ដូចជា ការរំលោភសេពសន្ថវៈ ឬការស្លាប់សាច់ញាតិ[2616]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសារមិនអើពើនឹងភាពរាក់កំភែលនៃការពន្យល់របស់ អ៊ុំ យឿន ដែលបានឆ្លើយថា គាត់ "ភ្លេច" លើកឡើងអំពីការរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តដោយមេរបស់ប្តីគាត់ ដើម្បីអះអាង ក្នុងពេលតែមួយ នៅថ្ងៃចូលមកបង្ហាញខ្លួនថា នេះជាហេតុការណ៍មិនអាចបំភ្លេចបាន ក្នុងមួយជីវិតស្ត្រី[2617]។ ក្រៅពីសក្ខីកម្មយឺតពេលអំពីការរំលោភសេពសន្ថវៈ រឿងរ៉ាវរបស់គាត់មានភាពច្របូកច្របល់ ជាពិសេស ពាក់ព័ន្ធនឹងពេលវេលានៃការរួមភេទលើកដំបូងជាមួយប្តីគាត់។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានយល់ឃើញថា នេះជាភាពមិនស៊ីចង្វាក់គ្នាតិចតួច មិនធ្វើឱ្យប៉ះពាល់ដល់ភាពអាចជឿជាក់បានជារួមរបស់គាត់ទេ[2618]។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះថា កាលៈទេសៈ និងសេចក្តីលម្អិតនៃការរំលោភសេពសន្ថវៈ ដែលជាមូលដ្ឋាននៃការផ្តន្ទាទោស មានសារៈសំខាន់តិចតួច គឺជាការបង្ហាញឱ្យ

---

[2616] អ៊ុំ យឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** ម៉ោង 13.56.43។ មុំ វុន៖ ប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/477.1** មុនម៉ោង 09.41.44 ("ខ្ញុំភ្លេច ចាំអត់បាន") មុនម៉ោង 09.44.00 ("ប្តី និងកូនដែលស្លាប់នៅពេលក្រោយ គឺខ្ញុំអត់បានសរសេរទេ ព្រោះខ្ញុំភ្លេច")។

[2617] ទោះបីជាមានការអន្តរាគមន៍ពីមេធាវីជាតិក្តី ជាការច្បាស់ណាស់ដែលថា នៅក្នុងអត្ថបទជាភាសាខ្មែរនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ឯកសារ **E3/6011** ERN 00496720 ("ឈ្មោះថាន់ដែលជាប្រធានយោធា។ ពេលនោះ ឈ្មោះថាន់នេះក៏បានហៅខ្ញុំទៅណែនាំ និងបានធ្វើការគំរាមខ្ញុំ។ ដោយសារមានការគំរាម និងខ្លាចគេយកទៅសម្លាប់ ព្រោះគេបាននិយាយថាខ្ញុំមានជាប់ទាក់ទងជាមួយនឹងខ្សែក្បត់។ ដូចនេះខ្ញុំក៏យល់ព្រមតាមការបង្ខំរបស់ប្តីខ្ញុំ និងអ្នកដទៃ" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ អ៊ុំ យឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/462.1** ម៉ោង 13.56.43 បញ្ជាបកប្រែជាភាសាបារាំង ដូច្នេះ សូមមើលអត្ថបទដើមជាភាសាខ្មែរ ទំព័រ៥៣ បន្ទាត់៨-១០។

[2618] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៤៩។

ឃើញយ៉ាងច្បាស់ក្រឡែតនូវភាពលម្អៀងរបស់អង្គជំនុំជម្រះក្នុងការពិនិត្យភ័ស្តុតាង។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ។

១៣៨៧. ក្នុងវិធីសាស្ត្រលម្អៀងដដែល អង្គជំនុំជម្រះបានបន្ទោសមេធាវីការពារក្តីថាបានបំភ្លៃភ័ស្តុតាង និងបានចាត់ទុកថាគ្មានមូលដ្ឋាន ចំពោះទឡ្ហីករណ៍ដែលរិះគន់ដល់ភាពអាចជឿជាក់បាន និងភាពអាច ទុកចិត្តបាននៃសក្ខីកម្មរបស់ ព្រាប សុខឿន[2619]។ ប៉ុន្តែ មេធាវីការពារក្តីគ្រាន់តែបានគូសបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជំរុញឱ្យនិយាយឱ្យអស់អំពីការរំលោភសេពសន្ថវៈ ដែលបានលើកឡើងយឺតពេលនេះ៖ "គាត់បានលើកឡើងថា អ៊ំឯងនិយាយទៅ ខ្មាសអីទៀត ការដែលរំលោភហ្នឹងអ្វីខ្លះ អ៊ំឯងនិយាយឱ្យអស់មក។ គាត់និយាយថា កាលណាខ្មាស យើងមិនមានភ័ស្តុតាងជាក់លាក់ទេ អ៊ីចឹងនិយាយឱ្យច្បាស់លាស់ ដល់ទៅក៏ខ្ញុំនិយាយតាមដំណើរដើមទងពីដើមរហូតដល់ចប់ជម្រាបប្រាប់គាត់ទៅ ចាស"[2620]។ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសារបានបំភ្លៃ និងបំប្លែងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ក្នុងការសន្និដ្ឋានរបស់ខ្លួនអំពីការចាត់វិធានការលើ ព្រាប សុខឿន ដើម្បីឱ្យគាត់រួមភេទជាមួយប្តីគាត់[2621]។ ជាក់ស្តែង គាត់មិនបាននិយាយថាគាត់ត្រូវបាន "កម្មាភិបាលចាស់ទុំគំរាមកំហែង" ទេ។ គាត់គ្រាន់តែបានលើកឡើងអំពីការពិភាក្សាគ្នាជាមួយប្តីប្រពន្ធចំណាស់មួយគូ ដោយបញ្ជាក់ថាគាត់បានប្រាប់យាយនោះកុំឱ្យទៅចោលគាត់ និងឱ្យនៅ "និយាយលេង" ជាមួយគាត់ ពីព្រោះគាត់មិនហ៊ានដេកម្នាក់ឯង[2622]។ លើសពីនេះទៀត អង្គជំនុំជម្រះបានបំភ្លេចចោលការទទួលស្គាល់របស់គាត់ជាច្រើនដងថា គាត់មិនបានដឹងអំពីសេចក្តីណែនាំឱ្យប្តីគាត់រួមភេទទេ ហើយគាត់បានបន្ថែមថា ប្តីគាត់ធ្វើដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ហើយគាត់មិនបាន

[2619] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៩។

[2620] ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ម៉ោង 11.31.01។

[2621] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៣។

[2622] ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ក្រោយម៉ោង 14.35.38។

ទទួលបញ្ហាឱ្យរួមភេទជាមួយប្ដីគាត់ទេ[2623]។ គូផ្សេងទៀតជាច្រើន ដែលត្រូវគេបង្ខំឱ្យរៀបការ ចុះសម្រុងនឹងគ្នា និងបានរួមរស់ជាមួយគ្នា ក្រោយពីរៀបការរួច[2624]។

១៣៨៨. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនខ្វល់នឹងភាពផ្ទុយគ្នាជាច្រើននៃសក្ខីកម្មរបស់ មុំ វុន ដែលត្រូវបានចាត់ទុកថាមានភាពមិនស៊ីចង្វាក់គ្នាតិចតួច។ ប៉ុន្តែ ទោះបីជាផ្ដល់ការជឿជាក់លើរឿងរ៉ាវរបស់គាត់ក៏ដោយ ក៏លក្ខណៈដោយឡែកនៃបទពិសោធន៍របស់សាក្សីរូបនេះមិនអាចឱ្យអង្គជំនុំជម្រះទាញសេចក្ដីសន្និដ្ឋានជារួមអំពីគោលនយោបាយរបស់ ប.ក.ក បានឡើយ។ ជាក់ស្ដែង អំពើរបស់កម្មាភិបាល ដែលគាត់និយាយថាគាត់ជាជនរងគ្រោះ គឺជាការរំលោភទៅលើវិធានសីលធម៌របស់ ប.ក.ក និងគួរណាតែនាំឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា មានការរំលោភបំពានពីសំណាក់កម្មាភិបាលមូលដ្ឋាន[2625]។ ដូចបានឃើញពីខាងលើ ច្បាស់ណាស់ថា នេះគឺជាការរំលោភអំណាចពីសំណាក់កម្មាភិបាល ដែលធ្វើឱ្យគោលនយោបាយរបស់ ប.ក.ក ស្ដីពីការការពារស្ត្រី ទទួលបរាជ័យ[2626]។

១៣៨៩. ទោះជាយ៉ាងណាក៏ដោយ ក្រៅពីភាពផ្ទុយគ្នា និងភស្តុតាងថ្មីយឺតពេល អង្គជំនុំជម្រះមិនអាចផ្អែកលើរឿងរ៉ាវទាំងនេះ ដែលត្រូវបានជ្រើសរើសដោយសារតែលក្ខណៈដោយឡែក ដើម្បីទាញសេចក្ដីសន្និដ្ឋានជារួម បានឡើយ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ការរំលោភសេពសន្ថវៈ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេស គឺជាចេតនារបស់ ប.ក.ក និងសមាជិកថ្នាក់កំពូល បានឡើយ។

### ២.៣.២.២. ភស្តុតាងផ្សេងទៀតដែលអង្គជំនុំជម្រះយកមកប្រើ

---

2623 ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/487.1** ម៉ោង 15.30.51។ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** ក្រោយម៉ោង 09.14.50 មុនម៉ោង 11.23.27 ក្រោយម៉ោង 13.51.22។

2624 ព្រាប សុខឿន៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/488.1** មុនម៉ោង 09.37.04។

2625 មុំ វុន៖ ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/475.1** មុនម៉ោង 11.23.13។ ពីព្រោះថា គាត់មិនត្រឹមតែត្រូវបានបង្ខំឱ្យរួមដំណេកជាមួយកងឈ្លបអាយុ ១៦-១៧ឆ្នាំ ប៉ុណ្ណោះទេ ប៉ុន្តែមុនពិធីរៀបការនោះ គាត់ក៏ត្រូវបានបុរសប្រាំនាក់ចាប់រំលោភដោយគំរាមសម្លាប់ប្រសិនបើគាត់និយាយប្រាប់គេអំពីរឿងរំលោភនោះ។

2626 សូមមើលខាងលើ កថាខណ្ឌ ១២៦២-១២៦៣។

១៣៩០. **ភស្តុតាងផ្សេងទៀត៖** ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះមិនបានពិចារណាលើការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាននូវរឿងរ៉ាវរបស់ ប៉ែន សុចាន់ ដែលមានលក្ខណៈដាច់ដោយឡែកពីគេ និងជ្រុលហួសហេតុ ហើយគួរណាតែនាំឱ្យអង្គជំនុំជម្រះមានការប្រយ័ត្នប្រយែងជាងមុន ក្នុងការពិនិត្យលើភាពអាចជឿជាក់បានរបស់គាត់[2627]។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ទទួលយក និងជាពិសេស ប្រើប្រាស់ភស្តុតាងបែបនេះ ដើម្បីទាញសេចក្តីសន្និដ្ឋានជារួមអំពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះឡើយ។ ដូចគ្នាដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានយករឿងរ៉ាវខុសប្លែកពីគេរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី មកធ្វើជាមូលដ្ឋាននៃការសន្និដ្ឋានរបស់ខ្លួនអំពីការរួមភេទដោយបង្ខំ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[2628]។ ជាក់ស្តែង គាត់បានអះអាងដោយខ្លួនឯងផ្ទាល់ថា ភាពជាភេទទីបីរបស់គាត់បានរួមចំណែកធ្វើឱ្យការរំលោភបំពានពីសំណាក់កម្មាភិបាលមូលដ្ឋាន កាន់តែមានសភាពខ្លាំងក្លាឡើង។ ម្យ៉ាងវិញទៀត ចម្លើយរបស់គាត់អំពីកាលៈទេសៈពិសេសនៃការរួមភេទជាមួយប្រពន្ធគាត់ ដោយមានការជួយពីមេភូមិជិតស្និទ្ធនឹងគាត់ គឺមានលក្ខណៈខុសពីធម្មតា[2629]។ រឿងរ៉ាវរបស់គាត់មិនអាចចាត់ទុកថាមានភាពជាតំណាងនៅថ្នាក់ជាតិបានទេ។

១៣៩១. ចំណែកឯ ជា ខៀប វិញ គ្រាន់តែតាមរយៈការមិនព្រមរៀបការ អង្គជំនុំជម្រះបានជឿជាក់រួចហើយថាការរួមភេទមានលក្ខណៈបង្ខំ[2630]។ ប៉ុន្តែ ការវាយតម្លៃនេះមិនត្រឹមត្រូវទេ បើយោងតាមចម្លើយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបញ្ជាក់ថា ការរួមភេទបានកើតឡើង តាម "ជម្រើស" ពីប្តីគាត់ពេលជួបគ្នាជាលើកទីពីរ ដោយគ្មានលើកឡើងអំពីបរិបទភ័យខ្លាច ឬតាមដានទេ[2631]។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីលក្ខណៈបង្ខំនៃការរួមភេទជាមួយប្តីគាត់បានទេ បើយោងតាមចម្លើយរបស់គាត់។

---

2627 សូមមើលខាងលើ កថាខណ្ឌ ១៣០៩។

2628 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៧ កំណត់សម្គាល់ជើងទំព័រលេខ ១២២២៥។

2629 ស៊ូ សុធាវី៖ ឯកសារ **E1/462.1** ម៉ោង 15.26.40 មុនម៉ោង 14.35.29។

2630 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៩, ៣៦៦១, ៣៦៥៥ (កំណត់សម្គាល់ជើងទំព័រលេខ ១២២២០)។

2631 ជា ខៀប៖ ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 14.07.26។ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 10.06.20។ ម្យ៉ាងវិញទៀត ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់អំពីរឿងយប់ទី១ដែលមិនមានរឿង

១៣៩២. យោងតាមពាក្យពេចន៍របស់អង្គជំនុំជម្រះ ដែលថាស្ត្រីទាំងអស់ដែលបានលើកឡើងនៅក្នុងផ្នែកនេះ សុទ្ធតែត្រូវគេបង្ខំឱ្យរួមភេទ មេធាវីការពារក្តីទាញការសន្និដ្ឋានថាអង្គជំនុំជម្រះក៏គិតបញ្ចូលទាំង ណុប ងឹម ផងដែរ[2632]។ ក៏ប៉ុន្តែ ផ្ទុយពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះ និងដូចបានឃើញពីខាងលើ ណុប ងឹម ពិតជាបានឆ្លើយថា ការរួមភេទបានកើតឡើងតាមការព្រមព្រៀងគ្នា៖ "ចំពោះខ្លួនខ្ញុំ អត់មានបង្ខំ ខាងនោះក៏មិនបង្ខំដែរ"[2633]។

១៣៩៣. **ភាពជំនាញដែលបានផ្តល់ជូនក្នុងវត្ថុស្តីពីការរៀបអាពាហ៍ពិពាហ៍៖** អង្គជំនុំជម្រះបានប្រើប្រាស់ភាពជំនាញរបស់ Kasumi NAKAGAWA ដែលបានសន្និដ្ឋានថា ដរាបណាការរៀបអាពាហ៍ពិពាហ៍មិនមានការព្រមព្រៀងគ្នារវាងសាមីខ្លួន ការរួមភេទក៏មិនធ្វើឡើងដោយការព្រមព្រៀងគ្នាដែរ[2634]។ បើទទួលយកសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ពីព្រោះអង្គជំនុំជម្រះបានបំភ្លេចចោលភាពចាំបាច់ក្នុងការកំណត់ប្រភេទបទល្មើស ស្របតាមច្បាប់ជាធរមាន នៅពេលកើតហេតុ។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានរំឭក នៅកថាខណ្ឌ ៣៥៣៣ នៃសំអាងហេតុសាលក្រម ថា អ្នកជំនាញរូបនេះបានបញ្ជាក់ថា គម្រោងស្រាវជ្រាវពីរដំបូងរបស់គាត់មានភាព "លម្អៀង" ពីព្រោះគម្រោងទាំងនេះត្រូវបានរៀបចំឡើង ដើម្បីចងក្រងរឿងរ៉ាវរបស់បុរស និងស្ត្រីដែលជួបប្រទះអំពើហិង្សាផ្លូវភេទ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ជាចុងក្រោយ និងជាពិសេស ដូចបានឃើញពី

---

អ្វីកើតឡើងនោះ៖ "អត់មានបានរួមដំណេកជាមួយប្តីរបស់ខ្ញុំទេ [...] ខ្លួនខ្ញុំផ្ទាល់ ណាខ្លាចប្តី មួយទៀតខ្លាចឈ្លប ម្ល៉ោះហើយសុខចិត្តនាំគ្នាសម្ងំ អត់ហ៊ានមាត់ ហ៊ានកអីទាំងអស់" ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/466.1** ម៉ោង 14.05.55។

[2632] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៩, ៣៦៦១, ៣៦៥៧ (កំណត់សម្គាល់ជើងទំព័រលេខ ១២២២៦)។

[2633] ណុប ងឹម៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 14.19.56។ ដូចអង្គជំនុំជម្រះបានទទួលស្គាល់រួចមកហើយ ការណែនាំពីថ្នាក់លើគឺថា ប្តីប្រពន្ធថ្មីត្រូវ "រស់នៅជាមួយគ្នាដោយរីករាយ" សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៧ កំណត់សម្គាល់ជើងទំព័រលេខ ១២២២៦។

[2634] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥៤។

ខាងលើ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន ដែលពីដំបូងបានរៀបការខុសពីចិត្ត បានបញ្ជាក់ថា ក្រោយមក ពួកគេមិនត្រូវបានបង្ខិតបង្ខំឱ្យរួមភេទទេ[2635]។

១៣៩៤. យោងតាមភស្តុតាងទាំងនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ស្ត្រីទាំងអស់ត្រូវគេបង្ខំឱ្យរួមភេទជាមួយប្ដី ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ឡើយ[2636]។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ។

## *២.៣.២.៣. កំហុសតមកទៀតពាក់ព័ន្ធនឹងអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋ*

១៣៩៥. កំហុសត្រួតគ្នារបស់អង្គជំនុំជម្រះ ក្នុងការវិភាគភស្តុតាងអំពីការរៀបអាពាហ៍ពិពាហ៍ បានធ្វើឱ្យសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះខុសទាំងស្រុង។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានបានឡើយអំពីភាពអាចជឿទុកចិត្តបាន ឬភាពជាតំណាងនៃរឿងរ៉ាវដែលអង្គជំនុំជម្រះបានទទួលយក។ ការកើតឡើងនូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនគ្រប់គ្រាន់ឱ្យបង្ហាញថា ប.ក.ក មានគោលនយោបាយរៀបការប្រជាជនដោយបង្ខំ និងតម្រូវឱ្យប្ដីប្រពន្ធរួមភេទ ដើម្បីបង្កើតកូន សំដៅបង្កើនចំនួនប្រជាជន ក្នុងគោលដៅមិនទំនង និងមិនសមហេតុផល ដើម្បីបង្កើនចំនួនទាហានទប់ទល់នឹងវៀតណាម។

---

[2635] ជាឧទាហរណ៍៖ ប៊ិត ហឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ម៉ោង 11.23.28 ("ក្រោយពីរៀបការទៅ អាហ្នឹងគេទៅតាមគូៗរបស់ផងគេទៅ។ គេមិនចាំបាច់មានការណែនាំ គេដឹងតែមួយគូៗគ្នាគេ")។ ផាន ហ៊ឹម៖ ប្រតិចារឹក ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ **E1/467.1** ម៉ោង 15.41.31 (បន្ទាប់ពីបានដឹងឮ និង ពិភាក្សា គាត់ក៏ចាប់ផ្ដើមមានចិត្តអាណិតគាត់ ហើយពួកគេក៏ចាប់ផ្ដើមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ)។ ណុប ធីម៖ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/469.1** ម៉ោង 14.19.56 និងម៉ោង 11.12.40។ មាន លឿយ៖ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** មុនម៉ោង 14.20.31 (គាត់ និង ប្រពន្ធគាត់ស្ម័គ្រចិត្តផ្សំដំណេក)។ យី ឡៃស្រួ៖ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ **E1/334.1** ម៉ោង 14.20.23 (គាត់បានរួមដំណេកលើកទីមួយជាមួយប្ដីគាត់ ដោយសារប្ដីគាត់សុំគាត់ នៅពេលជួបមុខគ្នាលើកទីពីរ ដោយមិនបញ្ជាក់ថាគាត់ធ្វើដោយបង្ខំចិត្តឡើយ)។ សូមមើលផងដែរ Peg LEVINE៖ ប្រតិចារឹក ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/480.1** មុនម៉ោង 15.51.24 (មិនមានអ្នកណាម្នាក់ក្នុងសំណាកគំរូរបស់គាត់ត្រូវបានគេគំរាមសម្លាប់ឡើយ ប្រសិនបើគេមិនព្រមផ្សំដំណេក)។

[2636] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៩០-៣៦៩៨។

១៣៨៦. ការពិនិត្យមិនលម្អៀង និងជារួមលើភ័ស្តុតាងទាំងមូល ក៏មិនអាចឱ្យសន្និដ្ឋានថាមានសេចក្តីណែនាំពីថ្នាក់ដឹកនាំ ប.ក.ក ឱ្យតាមដានប្តីប្រពន្ធ ដើម្បីបង្ខំឱ្យរួមភេទ នោះដែរ។ ជាចុងក្រោយ និងជាពិសេសការវិភាគជាសត្យានុម័តិទៅលើភ័ស្តុតាងទាំងមូលមិនអាចឱ្យសន្និដ្ឋានថា មានទង្វើចេតនាក្នុងការបង្ខំប្រជាជនឱ្យរៀបការ ដើម្បីឱ្យរួមភេទ សំដៅបង្កើតកូនជូនអង្គការ នោះឡើយ។

១៣៨៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ក្នុងការវាយតម្លៃភ័ស្តុតាងគាំទ្រដល់ការសន្និដ្ឋានមិនសមហេតុផលរបស់ខ្លួន។ អង្គជំនុំជម្រះបានបដិសេធចោលដោយមិនត្រឹមត្រូវនូវឯកសារផ្លូវការរបស់ ប.ក.ក ពាក់ព័ន្ធនឹងគោលការណ៍នៃការព្រមព្រៀងក្នុងការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះបានបដិសេធចោលដោយលម្អៀង និងតាមទំនើងចិត្ត នូវរាល់សក្ខីកម្មរបស់អតីតកម្មាភិបាល ដែលបញ្ជាក់អះអាងអំពីគោលការណ៍នេះ និងមិនអើពើនឹងសក្ខីកម្មរបស់សាក្សី ដែលមានបទពិសោធន៍មិនស្របនឹងការសន្និដ្ឋានរបស់ខ្លួន។ អង្គជំនុំជម្រះក៏បានអនុវត្តវិធីសាស្ត្រខុសលើភ័ស្តុតាង ដោយសារមិនបានប្រៀបធៀបជាមួយភ័ស្តុតាងទាំងមូល ដែលមានសារៈសំខាន់ ពេលធ្វើការវិភាគលើគោលនយោបាយជាតិ។

១៣៨៨. ជាចុងក្រោយ អង្គជំនុំជម្រះបានធ្វើការបំភ្លៃភ័ស្តុតាងដោះបន្ទុកជាប្រព័ន្ធ ដែលរារាំងមិនឱ្យអង្គជំនុំជម្រះធ្វើការសន្និដ្ឋានសមហេតុផលត្រឹមត្រូវតែមួយគត់ គឺបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចែងអំពីការព្រមព្រៀងគ្នារវាងអនាគតប្តីប្រពន្ធ។ ការរៀបចំអាពាហ៍ពិពាហ៍នៅតាមមូលដ្ឋាន ដោយរំលោភលើវិធាននេះ គឺផ្ទុយនឹងគោលនយោបាយរបស់ ប.ក.ក។ ដូច្នេះសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត នឹងត្រូវអង្គជំនុំជម្រះតុលាការកំពូលទុកជាមោឃៈ[2637]។

## ភាគទី ៤. កំហុសពាក់ព័ន្ធនឹងគោលបំណងរួម

### មាតិកាទី ១. កំហុសពាក់ព័ន្ធនឹងផែនការបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក

[2637] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨៦-៣៦៩៤, ៤៣០៣-៤៣០៦, ៤៣៦១-៤៣៧៦, ៤៤០០, ៤៤០២។

១៣៩៩. ទសវត្សរ៍ឆ្នាំ១៩៧០ សម្គាល់ដោយសង្គ្រាមត្រជាក់ ជាពេលដែលប្រទេសនានាធ្វើចម្បាំងមនោគមន៍វិជ្ជាយ៉ាងក្ដៅគគុក រវាងប្លុកអាមេរិក និងប្លុកសូវៀត។ បរិបទភូមិសាស្ត្រនយោបាយត្រូវបានវិភាគអាស្រ័យទៅលើទំនោរងាកទៅរកប្លុកណាមួយ។ នៅអាស៊ី និងអាហ្វ្រិក នៅតាមរដ្ឋទើបទទួលបានឯករាជ្យថ្មីៗ និងយកចិត្តទុកដាក់ចង់បើកទំព័រប្រវត្តិសាស្ត្រថ្មី ពួកគេត្រូវការកសាងទំនាក់ទំនងថ្មី ជាមួយប្រទេសមិនចូលបក្សសម្ព័ន្ធ។ ក្នុងប្រទេសទាំងនេះ សង្គមនិយមជាចលនាគំនិតក៏ខ្លាំងក្លា ដែលជាគ្រឹះនៃការតស៊ូដើម្បីឯករាជ្យ ដូចនៅកម្ពុជាដែរ។ ការខូចខាតបង្កឡើងដោយការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក មកលើកម្ពុជា ក្នុងសង្គ្រាមជាមួយវៀតណាម និងការគាំទ្ររបស់អាមេរិកលើរបប លន់ នល់ បាននាំឱ្យមានការបដិសេធដាច់អហង្ការពីរបបខ្មែរក្រហមថ្មីនូវការជ្រៀតជ្រែកពីបរទេស។ ឆន្ទៈកសាងប្រព័ន្ធថ្មីក្នុងបដិវត្តន៍សង្គមនិយមត្រូវទទួលរងឥទ្ធិពលពីបរិបទពិសេសនេះ ដែលអង្គជំនុំជម្រះខកខានមិនបានយកមកពិចារណា។

១៤០០. តាំងពីដំណាក់កាលនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា ផែនការរបស់មេដឹកនាំ ប.ក.ក "ពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ"[2638]។ ក្នុងខ្សែគំនិតដូចនឹងសេចក្ដីសន្និដ្ឋានក្នុងសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះបានអះអាងថា ផែនការនេះ "មិនមានភាពគ្រប់គ្រាន់ ឬមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ"[2639] អង្គជំនុំជម្រះក៏បានសន្និដ្ឋានថា "គោលបំណងរួមនេះមិនមែនជាការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ តាមគោលបំណងបឋមរបស់វា ដូច្នេះ វាមិនអាចក្លាយទៅជាការប្រព្រឹត្តិឧក្រិដ្ឋកម្មទេ អនុលោមតាមច្បាប់ជាធរមាន"[2640]។ ប៉ុន្តែ តាមរយៈកំហុសអង្គច្បាប់នៅក្នុងវិធីសាស្ត្រពាក់ព័ន្ធនឹងភ័ស្តុតាងក្នុងសំណុំរឿង (ជំពូកទី ១) និងកំហុសអង្គហេតុ ក្នុងការបកស្រាយគោលបំណងរួម (ជំពូកទី ២) អង្គជំនុំជម្រះបានសន្និដ្ឋានថា ការអនុវត្តផែនការនយោបាយរបស់ ប.ក.ក ពឹងផ្អែកលើគោលនយោបាយឧក្រិដ្ឋ។

---

[2638] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤។

[2639] សាលក្រម ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧៧៨។

[2640] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៣។

## ជំពូកទី ១. កំហុសអង្គច្បាប់

១៤០១. អង្គជំនុំជម្រះអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ នៅក្នុងវិធីសាស្ត្រពិនិត្យលើគោលបំណងរួមរបស់ ប.ក.ក។ ជាបឋម ទោះបីជា នៅកថាខណ្ឌ ៣៧២៨ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានរំឭកអំពីវិសាលភាពនៃបណ្ដឹង ស្របតាមដីកាដំណោះស្រាយ និងដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនផ្ទាល់ក៏ដោយ[2641] ក៏តាមពិត អង្គជំនុំជម្រះបានទាញសេចក្ដីសន្និដ្ឋាន ដោយរំលោភលើវិសាលភាពនៃបណ្ដឹង ដូច្នេះសេចក្ដីសន្និដ្ឋានទាំងនេះត្រូវតែបដិសេធចោល។ កំហុសទាំងនេះ ដែលត្រូវបានរៀបរាប់ក្នុងផ្នែកបណ្ដឹង ពិតជាមានផលប៉ះពាល់លើរបៀបកំណត់អំពីគោលបំណងរួមដោយអង្គជំនុំជម្រះ[2642]។ ខណៈដែលអង្គជំនុំជម្រះបានកត់សម្គាល់ថា ខ្លួនត្រូវពិនិត្យតែលើការអនុវត្តការជម្លៀសប្រជាជន ដោយកម្រិតត្រឹម "ការអនុវត្តនូវការប្រព្រឹត្តិលើជនជាតិចាម ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនចេញពីភូមិភាគកណ្ដាល (ឧត្តរចាស់) ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ (ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២)"[2643] អង្គជំនុំជម្រះបែរជាចេញហួសពីដែនកំណត់នេះ និងបានវិនិច្ឆ័យជាថ្មីម្ដងទៀតលើអង្គហេតុ ដែល ខៀវ សំផន ត្រូវបានផ្ដន្ទាទោសរួចហើយ ក្នុងសំណុំរឿង ០០២/០១[2644]។ គួរឱ្យសោកស្ដាយណាស់ អង្គជំនុំជម្រះបានចេញហួសពីដែនកំណត់នេះទៀត ក្នុងពេលពិនិត្យលើ "ការកំណត់ក្រុមគោលដៅជាក់លាក់រួមមានជនជាតិចាម និងវៀតណាម"[2645]។

១៤០២. ម្យ៉ាងទៀត ក្រៅពីវិសាលភាពភូមិសាស្ត្រ និងពេលវេលា អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុស ដោយបានប្រើប្រាស់អង្គហេតុក្រៅយុត្តាធិការ ដើម្បីសម្រេចថាមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនក្នុងសំណុំរឿង ០០២/០២។ នេះគឺជាករណីរំលោភសេពសន្ថវៈ ក្រៅក្របខ័ណ្ឌអាពាហ៍ពិពាហ៍ ដែលត្រូវបានប្រើប្រាស់ដើម្បីសន្និដ្ឋានអំពីបរិបទបង្ខិតបង្ខំ ដោយផ្ទុយនឹងដីកាដំណោះស្រាយ និងសេចក្ដីសម្រេចផ្ទាល់របស់អង្គជំនុំ

[2641] ឧបសម្ព័ន្ធនៃសេចក្ដីសម្រេច E301/9/1 ស្ដីពីការបំបែកដំណើរការនីតិវិធីថ្មីនៃសំណុំរឿង ០០២ កថាខណ្ឌ ២-១) និង ៣-១)។

[2642] សូមមើលខាងលើ កថាខណ្ឌ ៣៨០-៥៤៩។

[2643] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧២៨។

[2644] សូមមើលខាងលើ កថាខណ្ឌ ៥៤៤-៥៤៦។

[2645] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧២៨។ សូមមើលខាងលើ កថាខណ្ឌ ៤៣៥-៤៣៨, ៥១៧-៥២១, ៥៣៨-៥៤៩។

ជម្រះលើបញ្ហារំលោភសេពសន្ថវៈ[2646]។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានលើកឡើងថា ការពិនិត្យលើការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន ត្រូវកម្រិតត្រឹមសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[2647] ប៉ុន្តែ អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្មហួសពីការចោទប្រកាន់ នៅតាមការដ្ឋានទាំងនេះ[2648]។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងមូលនៅក្រៅវិសាលភាពនៃបណ្តឹង នឹងត្រូវបដិសេធចោល[2649]។

១៤០៣. ដូចបានរម្លឹកពីខាងលើ ការគោរពតាមបណ្តឹងពីសំណាក់តុលាការ គឺជាធាតុផ្សំសំខាន់បំផុតនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[2650]។ ការរំលោភបំពានរបស់អង្គជំនុំជម្រះជាកំហុសអង្គច្បាប់ ដែលបង្កព្យសនកម្មលើម្ចាស់បណ្តឹងសាទុក្ខ ដោយមិនអាចប្រកែកបាន។ ជាក់ស្តែង គាត់ពុំមានលទ្ធភាពការពារខ្លួនឱ្យមានប្រសិទ្ធភាព ហើយនៅទីបំផុត គាត់ត្រូវគេផ្តន្ទាទោស ដោយផ្អែកលើអង្គហេតុដែលគាត់គ្មានការចាំបាច់ត្រូវទទួលខុសត្រូវ។

១៤០៤. ដើម្បីឈានដល់ការសន្និដ្ឋានអំពីគោលបំណងរួម អង្គជំនុំជម្រះបានបង្ហាញអំពីវិធីសាស្ត្ររបស់ខ្លួន៖ ពិនិត្យទៅលើ "អត្ថិភាពនៃគោលបំណងរួម ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ មុននឹងពិនិត្យទៅលើគោលនយោបាយ ដែលត្រូវបានអនុវត្ត ស្របតាមគោលបំណងនេះ" និងពិចារណាថា "តើឧក្រិដ្ឋកម្មដែលត្រូវបានបង្ហាញនៅតាមទីតាំងឧក្រិដ្ឋកម្ម បានកើតឡើងដោយសារតែគោលនយោបាយដែលពាក់ព័ន្ធ ហើយត្រូវបានប្រព្រឹត្តឡើងដើម្បីសម្រេច ឬអនុវត្តគោលបំណងរួមនេះដែរឬទេ"[2651]។

---

2646 សូមមើលខាងលើ កថាខណ្ឌ ១២៦២-១២៦៣។

2647 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧២៨។

2648 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧២៨។

2649 សូមមើលខាងលើ កថាខណ្ឌ ៤៦៩-៤៧០, ៤៧៤, ៤៨០-៤៨១, ៤៨៣, ៤៨៦, ៤៨៩, ៤៩២-៤៩៤, ៤៩៩, ៥០៤, ៥១០, ៥១៣, ៥១៦។

2650 សូមមើលខាងលើ កថាខណ្ឌ ៣៥១-៣៦៦, ៤៤០-៤៤៤, ៤៥៩-៤៦៤។

2651 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣២។

១៤០៥. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះក៏ត្រូវសន្មតថាធ្វើការប្រៀបធៀបទឡ្ហីករណ៍របស់ភាគីអំពីផែនការនយោបាយរបស់ ប.ក.ក។ ដូច្នេះ អង្គជំនុំជម្រះត្រូវពិនិត្យដោយមិនលម្អៀងទៅលើភ័ស្តុតាង ដែលភាគីបានលើកឡើង ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និងពេលជំនុំជម្រះក្តី ជាអាទិ៍ តាមរយៈការសួរដេញដោល និងសវនាការលើឯកសារគន្លឹះ។ ផ្ទុយទៅវិញ សំអាងហេតុសាលក្រមបង្ហាញថា អង្គជំនុំជម្រះខកខានមិនបានបំពេញកាតព្វកិច្ចពិនិត្យជាសត្យានុម័តិ និងដោយមិនលម្អៀងទៅលើអង្គហេតុ និងឯកសាររបស់ ប.ក.ក។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីផែនការបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក មិនត្រូវគ្នានឹងលទ្ធផលនៃការពិនិត្យភ័ស្តុតាងដោយមិនលម្អៀង។ យើងនឹងឃើញខាងក្រោមនេះថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដដែល នៅពេលធ្វើការវិភាគលើគោលនយោបាយ[2652]។

១៤០៦. កំហុសអង្គច្បាប់ពាក់ព័ន្ធនឹងអង្គហេតុជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ បានប៉ះពាល់ដល់ការពិនិត្យលើគោលបំណងរួម និងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការអនុវត្តគោលបំណងរួមនេះ។ ជាក់ស្តែង វាមិនមែនជារឿងឥតប្រយោជន៍ទេ ក្នុងការកត់សម្គាល់ថា មុននឹងសម្រេចលើបញ្ហាថាតើគោលបំណងរួមនាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដែរឬទេ អង្គជំនុំជម្រះបានសន្និដ្ឋានថា "គោលបំណងរួមនេះមិនមែនជាការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ តាមគោលបំណងបឋមរបស់វា [...] ការអនុវត្តដោយជោគជ័យនូវគោលបំណងរួម និងការផ្លាស់ប្តូរប្រទេសឱ្យទៅជាសង្គមបដិវត្តន៍សុទ្ធសាធមួយ គឺពឹងផ្អែកលើការអនុវត្តគោលនយោបាយដែលមានលក្ខណៈគ្រោះថ្នាក់ និងការលុបបំបាត់រាល់សមាសភាពប្រឆាំងបដិវត្តន៍ទាំងអស់ ដែលត្រូវបានមើលឃើញថាជាឧបសគ្គរាំងបក្ស ឬវឌ្ឍនភាពនៃបដិវត្តន៍សង្គមនិយម"[2653]។ ប្រការនេះបង្ហាញថា អង្គជំនុំជម្រះមិនបានពិនិត្យភ័ស្តុតាងអំពីគោលនយោបាយរបស់ ប.ក.ក ដោយអព្យាក្រឹតនោះទេ គឺផ្អែកលើភ័ស្តុតាងដែលគេប្តឹងមកខ្លួន។ ក្នុងការវិភាគរបស់អង្គជំនុំជម្រះ ការលាក់បាំងឧក្រិដ្ឋកម្ម គឺជាភ័ស្តុតាងនៃអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋ ពោលគឺមានន័យថា វិភាគភ័ស្តុតាងដោយស្វែងរកការបញ្ជាក់អះអាងទៅលើសម្មតិកម្មពីដើមទី។ ការពិនិត្យបន្តមកទៀតទៅលើគោលនយោបាយ ដើម្បីឱ្យដឹងថា តើវានាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដែរឬទេ មិនចាំបាច់ធ្វើក៏បានដែរ។

---

2652 សូមមើលខាងក្រោម កថាខណ្ឌ ១៤៣៨-១៤៤៧។

2653 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៣។

១៤០៧. ច្បាស់ណាស់ថា កំហុសអង្គច្បាប់ទាំងនេះ ពាក់ព័ន្ធនឹងការរំលោភបំពានលើវិសាលភាពនៃបណ្តឹង និង វិធីសាស្ត្រមិនត្រឹមត្រូវលើភ័ស្តុតាង មានផលប៉ះពាល់លើរបៀបនៃការកំណត់គោលបំណងរួមដោយ អង្គជំនុំជម្រះ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ[2654]។

## ជំពូកទី ២. កំហុសអង្គហេតុ

១៤០៨. ដំណើរការខុសឆ្គងរបស់អង្គជំនុំជម្រះ គឺជាផលនៃការបំផ្លើសមួយ។ ជាក់ស្តែង អង្គជំនុំជម្រះបានចាក់ គ្រឹះគោលនយោបាយឧក្រិដ្ឋ តាមរយៈការបង្ហាញដោយបំភ្លៃនូវទំនាក់ទំនងនយោបាយជាមួយវៀតណាម (ផ្នែកទី ១) និងខ្លឹមសារនៃផែនការបដិវត្តន៍សង្គមនិយមរបស់ ប.ក.ក (ផ្នែកទី ២)។ បន្ទាប់មកទៀត ដោយឈរលើមូលដ្ឋានមិនត្រឹមត្រូវទាំងពីរនេះ អង្គជំនុំជម្រះបានស្ថាបនាទស្សនៈរបស់ខ្លួនអំពីគោល បំណងរួម ដែលនាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

### ផ្នែកទី ១. ទំនាក់ទំនងនយោបាយជាមួយវៀតណាម នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

១៤០៩. អង្គជំនុំជម្រះបានប្រើប្រាស់ការវិភាគលើទំនាក់ទំនងនយោបាយជាមួយវៀតណាម នៅមុនខែមេសា ឆ្នាំ ១៩៧៥ ដើម្បីបង្កើតមូលដ្ឋាននៃគោលនយោបាយរបស់ ប.ក.ក ចំពោះវៀតណាម[2655]។ ថ្វីត្បិតតែការ វិភាគរបស់អង្គជំនុំជម្រះអាចឱ្យស្វែងយល់អំពីចំណុចប៉ះទង្គិច រវាងចលនាបដិវត្តន៍ពីរ និងមូលហេតុ នៃការឡើងកម្តៅដែលនាំឱ្យកើតជម្លោះប្រដាប់អាវុធ ក៏ដោយ ក៏អង្គជំនុំជម្រះមិនបានបង្ហាញថា ហេតុ អ្វីបានជាប្រការនេះបង្កឱ្យមានគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាម។

[2654] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៣-៣៧៤៣។

[2655] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨២-៣៣៨៥។

១៩១០. អង្គជំនុំជម្រះបានលើកឡើងពី "កំហឹងយូរអង្វែងរវាងជនជាតិខ្មែរ និងជនជាតិវៀតណាម" ដោយយោងលើការដកស្រង់មួយចេញពីសៀវភៅខ្មៅ[2656]។ ប៉ុន្តែ សម្រង់នេះគ្រាន់តែលាតត្រដាងអំពីហេតុការណ៍ប្រវត្តិសាស្ត្រ ដែលកើតឡើងនៅសតវត្សរ៍ទី ២ នៅពេលវៀតណាមយកទឹកដីចម្ប៉ា។ ហេតុការណ៍ទាំងនេះត្រូវគេយកមកឃោសនា ខណៈដែលនៅមុននេះបន្តិច គឺនៅខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមបានលើកទ័ពចូលមកឈ្លានពានកម្ពុជា។ ដូច្នេះ អង្គជំនុំជម្រះគួរណាតែធ្វើការបែងចែកឱ្យដាច់ រវាងការឃោសនា នៅក្នុងពេលកើតជម្លោះប្រដាប់អាវុធ និងគោលនយោបាយចំពោះជនស៊ីវិលវៀតណាមរស់នៅលើទឹកដីកម្ពុជា។

១៩១១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថា "មេដឹកនាំ ប.ក.ក កំណត់ថា វៀតណាម គឺជាសត្រូវស្រួចស្រាវយូរអង្វែងរបស់កម្ពុជា តាំងពីដើមខែកញ្ញា ឆ្នាំ១៩៧១ ក្នុងសមាជ ប.ក.ក លើកទី៣"[2657]។ ដើម្បីគាំទ្រដល់ការរកឃើញនេះ អង្គជំនុំជម្រះបានដកស្រង់សៀវភៅរបស់ ខៀវ សំផន និង Stephen MORRIS[2658]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានពន្យល់ថាហេតុអ្វីបានជាខ្លួនកំណត់យកពាក្យ "សត្រូវស្រួចស្រាវ" ដែលប្រើប្រាស់តែក្នុងសៀវភៅរបស់ Stephen MORRIS ដែលផ្អែកលើសៀវភៅរបស់ Stephen HEDER[2659]។ ផ្ទុយទៅវិញ លោក ខៀវ សំផន ដែលមានវត្តមាននៅក្នុងសមាជនោះដែរ បានផ្តល់គោលជំហរផ្សេងពី ប.ក.ក នៅសម័យនោះ៖

> "មហាសន្និបាតឆ្នាំ១៩៧១ (ខ្ញុំបានចូលរួម) បានកំណត់ថា វៀតណាមជាមិត្តមានទំនាស់។ ការកំណត់នេះគឺជាការកំណត់មាគ៌ានយោបាយមួយច្បាស់ចំពោះវៀតណាម។ បានន័យថាគេមិនមែនជាយុទ្ធមិត្តទេ តែក៏មិនមែនជាខ្មាំងដែរ។ ត្រូវអនុវត្តគោលការណ៍សាមគ្គីតស៊ូ តស៊ូសាមគ្គី។

---

[2656] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨២។

[2657] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨២។

[2658] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨២ ដែលយោងទៅកថាខណ្ឌ ២២៦ កំណត់សម្គាល់ជើងទំព័រលេខ ៥៣១។

[2659] សៀវភៅរបស់លោក Stephen MORRIS *Why Vietnam Invaded Cambodia* ឯកសារ **E3/7338** ERN EN 01001723។ លេខយោង ៣១ យោងទៅសៀវភៅរបស់លោក Stephen HEDER *កម្ពុជា៖ ពី ប៉ុល ពត ទៅ ប៉ែន សុវណ្ណ* ទំព័រ ១៩។

បើវៀតណាមនៅជាមិត្តហើយ អ្នកផ្សេងទៀតដែលដើរតាម ឬគាំទ្រវៀតណាម ក៏នៅតែជាមិត្ត”[2660]។

១៩១២. ដូច្នេះ ការប្រើប្រាស់ពាក្យ “សត្រូវស្រួចស្រាវ” ដោយ Stephen MORRIS មិនត្រឹមត្រូវទេ។ អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះយកតាមសំណេររបស់អ្នកនិពន្ធនេះជាជាង ខៀវ សំផន លើកលែងតែដោយសារអង្គជំនុំជម្រះចូលចិត្តពាក្យសត្រូវជាង សម្រាប់ទ្រឹស្តីរបស់ខ្លួន។ ក្រៅពីនេះទៀត ការរកឃើញនេះផ្ទុយនឹងសេចក្តីសន្និដ្ឋានមួយទៀតរបស់អង្គជំនុំជម្រះថា “ដំបូងឡើយ ខ្មែរក្រហមផ្តោតការចាប់អារម្មណ៍លើអ្នកជាប់ពាក់ព័ន្ធនឹងរបប លន់ នល់ និងខ្មាំងទូទៅដែលប្រឆាំងនឹងបដិវត្តន៍បែបម៉ាក្សលេនីន រួមមាន ពួកសក្តិភូមិ នាយទុន ចក្រពត្តិ និងពួកសេរីនិយម”[2661]។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានបន្ថែមថា៖ “ជាដំបូង ប្រទេសថៃ គឺជាខ្មាំងសំខាន់មួយ ប៉ុន្តែ ការផ្តោតការចាប់អារម្មណ៍បានចាប់ផ្តើមវិវត្តងាកទៅប្រទេសវៀតណាមវិញ នៅដើមឆ្នាំ១៩៧៦ រហូតដល់ពាក់កណ្តាលឆ្នាំនោះ”។ អាស្រ័យហេតុនេះ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានថា នៅឆ្នាំ១៩៧១ វៀតណាមជា “សត្រូវស្រួចស្រាវ” របស់ ប.ក.ក ទេ។

១៩១៣. ដូច្នេះ អង្គជំនុំជម្រះមិនគួរណាផ្អែកលើ “កំហឹងយូរអង្វែង” នេះ ដើម្បីពន្យល់អំពី “ការកំណត់អត្តសញ្ញាណដោយ ប.ក.ក ចំពោះជនជាតិវៀតណាមដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាថា ជាក្រុមមនុស្សដែលគួរទទួលបានចំណាប់អារម្មណ៍ដោយឡែក”[2662]។ ជាក់ស្តែង អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររវាងកម្ពុជា និងវៀតណាម មានទំនាក់ទំនងនឹងជនជាតិវៀតណាមដែលរស់នៅកម្ពុជា។ យើងបានឃើញពីខាងលើរួចមកហើយថា ឯកសារយោងជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការកំណត់មុខសញ្ញាលើជនជាតិវៀតណាម មិនបាននិយាយ

---

[2660] សៀវភៅរបស់លោក ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ **E3/16** ERN 00380487។

[2661] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤០។

[2662] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨២។

ដល់ក្រុមនេះទាល់តែសោះ[2663] គឺសំដៅដោយផ្ទាល់ដល់ប្រទេសវៀតណាម ដែលមានភាពសមហេតុផលជាង ជាមួយនឹងឯកសារយោងប្រវត្តិសាស្ត្រខាងលើ។

១៩១៤. ខុសពីការអះអាងរបស់អង្គជំនុំជម្រះ មហិច្ឆតារបស់វៀតណាមក្នុងការ "បង្កើតសហព័ន្ធឥណ្ឌូចិន" មិនមែនស្ថិតនៅតែក្នុងគំនិតរបស់មេដឹកនាំ ប.ក.ក នោះទេ។ Stephen MORRIS បានលើកឡើងនៅក្នុងសវនាការអំពីគំរូនៃសហព័ន្ធសូវៀត ដែលវៀតណាមចិញ្ចឹមចិត្តចង់បាន៖ "ប្រវត្តិសាស្ត្ររបស់វៀតណាម គឺជាប្រវត្តិសាស្ត្រយូរអង្វែងភ្ជាប់ទៅខាងត្បូង ចេញពីអ្វីដែលពេលនេះយើងហៅថាវៀតណាមខាងជើង ដើម្បីកាន់កាប់ដែនដីដែលក្រុមជាតិពន្ធុផ្សេងកាន់កាប់ រួមទាំង ពួកចាម ហើយនិងកម្ពុជា"[2664]។ David CHANDLER ក៏បានពន្យល់ផងដែរថា ពួកវៀតណាមមានទម្លាប់រំលោភដែនដីរបស់កម្ពុជារាល់តែដង ហើយព្រឹត្តិការណ៍ពីមុនមករបស់ឡាវ ដែល "ពួកវៀតណាមបានត្រួតត្រាបដិវត្តន៍ [...] និងបានដណ្តើមយកដោយកម្លាំងនូវដែនដីភាគច្រើនរបស់ឡាវ" ស្ថិតក្នុងការចងចាំរបស់មនុស្សគ្រប់គ្នា[2665]។ ពិតមែនតែយើងអាចនិយាយបានថា ភាពតានតឹង និងការមិនស្រុះស្រួលគ្នាដ៏សំខាន់ទាំងនេះ បានកើតឡើង រវាងចលនាបដិវត្តន៍ពីរ នៅមុនខែមេសា ឆ្នាំ១៩៧៥ ក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចសន្និដ្ឋានដោយគ្មានកំហុសថា វៀតណាមជា "សត្រូវស្រួចស្រាវ" យូរអង្វែងរបស់ ប.ក.ក ដើម្បីយកមកធ្វើជា

---

[2663] សូមមើលខាងលើ កថាខណ្ឌ ១០២៩-១០៣២, ១០៥៩-១០៦៧, ១០៩៧។

[2664] ប្រតិចារឹក ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/485.1** ម៉ោង 15.12.36៖ "ប្រវត្តិសាស្ត្ររបស់វៀតណាមគឺជាប្រវត្តិសាស្ត្រយូរអង្វែងមួយភ្ជាប់ទៅខាងត្បូង ចេញពីអ្វីដែលពេលនេះយើងហៅថាវៀតណាមខាងជើងដើម្បីកាន់កាប់ដែនដីដែលក្រុមជាតិពន្ធុផ្សេងកាន់កាប់ រួមទាំងពួកចាមហើយនឹងកម្ពុជា។ ផ្នែកធំមួយនៃអ្វីដែលជារបស់វៀតណាមខាងត្បូងនៅពេលនេះ ធ្លាប់ជាដែនដីរបស់កម្ពុជា ហើយបារាំងបានជួយកាត់ផ្តាច់ជាផ្លូវការពីកម្ពុជា បញ្ចូលទៅខាងត្បូងនៃប្រទេសវៀតណាម គឺនៅក្នុងសម័យអាណានិគមនិយមបារាំងនោះឯង ហើយខ្ញុំក៏គិតផងដែរថា ទស្សនទានទាំងមូលរបស់សហព័ន្ធឥណ្ឌូចិននោះ គឺដើម្បី ផ្តួចផ្តើមគំនិតនៅក្នុងកុម្មុយនីស្តអន្តរជាតិ នៅក្នុងឆ្នាំ ១៩៣០ គឺជាមហិច្ឆតាដឹកនាំ ហើយជាកត្តាជំរុញនៅក្នុងអាកប្បកិរិយារបស់កុម្មុយនីស្តវៀតណាមចំពោះកម្ពុជាក្នុងប៉ុន្មានទសវត្សរ៍ក្រោយមក។ ខ្ញុំគិតថាគំនិតនៃឥណ្ឌូចិនកាលនោះគឺយកគំរូពីសហភាពសូវៀត អ៊ីចឹងគឺថា មានអង្គភាពនយោបាយជនជាតិភាគតិចដែលបានផ្តល់ឱ្យនូវភាពជាអ្នកដឹកនាំទៅឱ្យក្រុមជនជាតិភាគតិចផ្សេងទៀត ដែលជាសហព័ន្ធ។ ដូច្នេះ ដូចក្នុងករណីរបស់សហភាពសូវៀត ក្រុមជនជាតិភាគតិចរុស្ស៊ីបានគ្រប់គ្រងលើប្រជាជនផ្សេងទៀតដែលមិនមែនជាជនជាតិរុស្ស៊ី នៅក្នុងសហភាពសូវៀត។ អ៊ីចឹងហើយគឺគេអាចមើលឥណ្ឌូចិនថាវៀតណាមជាប្រទេសដែលដឹកនាំក្នុងលក្ខណៈជា អ្នកដឹកនាំលើឡាវ និងកម្ពុជា។ គេមានឥទ្ធិពលច្រើនជាងប្រជាជនឡាវ និងកម្ពុជានៅក្នុងសហព័ន្ធឥណ្ឌូចិននោះ"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2665] សៀវភៅរបស់លោក David CHANDLER *ប៉ុលពត បងធំទី១* ឆ្នាំ១៩៩២ ឯកសារ **E3/17** ទំព័រ ១៨៣ ERN 01150861។

មូលដ្ឋានបង្ហាញអំពីគោលនយោបាយចំពោះជនជាតិវៀតណាម ដោយមិនរើសមុខ[2666]។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះក្នុងន័យនេះ នឹងត្រូវទុកជាមោឃៈ។

## ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងខ្លឹមសារនៃ "បដិវត្តន៍សង្គមនិយម"

១៤១៥. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានចាត់ទុកឆន្ទៈចង់បានឯករាជ្យរបស់ ប.ក.ក ជាធាតុផ្សំដាក់បន្ទុក ដោយមិនគិតពីបរិបទ ដែលខ្មែរក្រហមទើបតែចូលកាន់អំណាច (១)។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានសង្កត់ធ្ងន់លើសញ្ញាណ "មហាលោតផ្លោះ មហាអស្ចារ្យ" ដោយមិនពន្យល់ថាហេតុអ្វីបានជា ប.ក.ក ចាំបាច់ត្រូវការស្តារសេដ្ឋកិច្ចជាតិជាបន្ទាន់ (២)។

### ១. ឆន្ទៈចង់បានឯករាជ្យ ដែលស្តែងឡើងតាមរយៈបរិបទឆ្នាំ១៩៧៥

១៤១៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងវិធីសាស្ត្រពាក់ព័ន្ធនឹងការចង់បានឯករាជ្យរបស់ខ្មែរក្រហម។ ដោយដកស្រង់សុន្ទរកថារបស់ ខៀវ សំផន ដែលសង្កត់ធ្ងន់លើឯករាជ្យ ម្ចាស់ការ និងខ្លួនទីពឹងខ្លួន អង្គជំនុំជម្រះបានសន្និដ្ឋានថា ការលើកកម្ពស់មាគ៌ានេះ "ទីបំផុត ត្រូវបានអនុវត្តនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ"[2667]។ ថ្វីត្បិតតែមិនអាចប្រកែកបានថា ឯករាជ្យ គឺជាស្នូលសម្រាប់ ប.ក.ក ក៏ដោយ ក៏អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនគិតពីបរិបទឆ្នាំ១៩៧៥។ ជាក់ស្តែង អង្គជំនុំជម្រះបានកំណត់ថាប្រតិកម្មរបស់ ប.ក.ក ចំពោះជម្លោះជាមួយវៀតណាម គឺជាការខ្លាចស្រមោលខ្លួនឯងរបស់បក្ស ដោយមិនបានផ្សារភ្ជាប់ជាមួយឆន្ទៈចង់បានឯករាជ្យពីប្រទេសជិតខាង ដែលជម្លោះព្រំដែនបានស្តែងឡើងតាមរយៈការត្រួតត្រានយោបាយជាច្រើនឆ្នាំមកហើយ[2668]។

---

[2666] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤១៧។

[2667] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៤។

[2668] សូមមើលសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៦៧៤-៦៩១។

១៤១៧. ដោយមិនគិតពីបរិបទ អង្គជំនុំជម្រះបានស្តែងឱ្យឃើញភាពលម្អៀង ចំពោះការចាត់ទុកឆន្ទៈរបស់ ប.ក.ក ក្នុងការគេចខ្លួនចេញពីអាណាព្យាបាលរបស់បក្សកុម្មុយនីស្តវៀតណាម ថាជា "យុទ្ធនាការបំភាន់ភ្នែក" និងជា "គោលនយោបាយសេរីនិយម" ដោយរំឭកពីដើមកំណើតបក្សកម្ពុជា[2669]។ ពាក្យធ្ងន់ៗដែលបានប្រើប្រាស់ ក្នុងការរំឭកអំពីប្រវត្តិសាវតារនេះ បង្កប់នូវភាពលម្អៀងក្នុងការពិនិត្យភស្តុតាងទាំងអស់។ ក្នុងឆន្ទៈទាញ ខៀវ សំផន ឱ្យចូលពាក់ព័ន្ធនៅគ្រប់កម្រិត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញសេចក្តីសន្និដ្ឋានអំពីខ្លឹមសារតាមសន្មតនៃសមាជជាតិ ខណៈដែលអង្គជំនុំជម្រះបានរកឃើញថាមិនមានភាពច្បាស់លាស់ថាតើសមាជនេះពិតជាបានប្រារព្ធឡើងដែរឬទេ[2670]។ ទោះជាយ៉ាងនេះក្តី ឯកសារ ដែលអង្គជំនុំជម្រះយកមកធ្វើជាមូលដ្ឋាន ដើម្បីបង្ហាញអំពីខ្លឹមសារនៃគោលនយោបាយ គឺកិច្ចសម្ភាសន៍របស់អ្នកសារព័ត៌មានយូហ្គោស្លាវី ជាមួយ ប៉ុល ពត ដែលក្នុងនោះ គាត់មិនបាននិយាយដល់ ខៀវ សំផន ទាល់តែសោះ[2671]។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះថា ខៀវ សំផន ធ្វើជាអធិបតីក្នុងសមាជទាំងនេះ ត្រូវទុកជាមោឃៈ។

១៤១៨. អង្គជំនុំជម្រះមិនចាំបាច់និយាយដល់សមាជមិនច្បាស់លាស់ ដើម្បីសន្និដ្ឋានថា ប.ក.ក មានឆន្ទៈ ចង់បានឯករាជ្យជាតិឡើយ។ នៅក្នុងទស្សនាវដ្តី "ទង់បដិវត្ត" ឆ្នាំ១៩៧៦ គោលការណ៍ឯករាជ្យ រួមទាំងខាងសេដ្ឋកិច្ច ត្រូវបានបង្ហាញយ៉ាងច្បាស់[2672]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានស្វែងរកក្នុងឯកសារផ្លូវការរបស់ ប.ក.ក នូវមូលហេតុនាំឱ្យមានការប៉ុនប៉ងកសាងសេដ្ឋកិច្ចខ្លួនទីពឹងខ្លួន។ ថ្វីត្បិតតែអង្គជំនុំជម្រះបានរំឭកនៅកថាខណ្ឌ ៣៧៦៦ នៃសំអាងហេតុសាលក្រម អំពីមូលហេតុនៃការជម្លៀសប្រជាជនចេញពីក្រុងក៏ដោយ ក៏អង្គជំនុំជម្រះខកខានមិនបានបង្ហាញថា កសិកម្ម គឺជាធនធានតែមួយគត់របស់ប្រទេស ដែលអាចផ្តល់ទុនសម្រាប់ការកសាងប្រទេស តាមរយៈការដោះដូរពាណិជ្ជ

---

[2669] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤១។

[2670] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៥។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៥១៧, ១៦៩០។

[2671] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៤ កំណត់សម្គាល់ជើងទំព័រលេខ ៣៧៣៥។

[2672] ទស្សនាវដ្តីទង់បដិវត្ត លេខ៧ ចុះខែកក្កដា ឆ្នាំ១៩៧៦ ឯកសារ **E3/4** ERN 00062943៖ "មាគ៌ារបស់បក្សយើងក្នុងការកសាងសេដ្ឋកិច្ច ហិរញ្ញវត្ថុ គឺខ្លួនឧបត្ថម្ភខ្លួន។ ដូច្នេះសេដ្ឋកិច្ចរបស់បក្សយើង គឺចេញមកពីផលិតកម្មជាក់ស្តែង គឺចេញមកពីកសិកម្មជាមូលដ្ឋាន។ ដូច្នេះយើងខំធ្វើការតទៅទៀត ដើម្បីធ្វើជាទុន ជាទុនសម្រាប់ស្បៀង ជាទុនសម្រាប់ការពារប្រទេស ជាទុនសម្រាប់កសាងប្រទេសឱ្យបានឆាប់រហ័ស"។

កម្មជាមួយសម្ព័ន្ធមិត្តរបស់កម្ពុជាប្រជាធិបតេយ្យ។ ជាក់ស្តែង ការដោះដូរពាណិជ្ជកម្មដោយឯករាជ្យ ទាមទារឱ្យចរចាជាមួយសម្ព័ន្ធមិត្តនយោបាយ ឬជាមួយប្លុកមិនចូលបក្សសម្ព័ន្ធ ដូចជា ចិន កូរ៉េខាងជើង និងយូហ្គោស្លាវី ជាដើម។ អង្គជំនុំជម្រះខកខានមិនបានលើកឡើងអំពីសារៈសំខាន់នៃការដោះដូរពាណិជ្ជកម្មជាមួយប្រទេសទាំងនេះ និងជំនួយជាឱសថ ស្បៀងអាហារ ដែលទទួលបាន ដូចបានបញ្ជាក់ក្នុងកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍[2673]។

១៤១៩. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ក្នុងការសន្និដ្ឋានសរុបលើសញ្ញាណខ្លាំងក្នុងវគ្គរៀនសូត្រ ដោយមិនពិនិត្យមើលបរិបទនៃសង្គ្រាមត្រជាក់។ ប៉ុន្តែ ពាក្យ "សង្គ្រាមត្រជាក់" នេះផ្ទាល់ ធ្វើឱ្យនឹកឃើញដល់សង្គ្រាមមនោគមន៍វិជ្ជាដែលបោកបក់ខ្លាំងនៅសម័យនោះ។ មាន "មិត្ត" នយោបាយ និង "ខ្មាំងមនោគមន៍វិជ្ជា"។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ពាក់ព័ន្ធនឹងការសន្និដ្ឋានរបស់ខ្លួនអំពីវគ្គរៀនសូត្រ ដោយមិនគិតពីបរិបទ ដើម្បីដាក់ចម្បាំងមនោគមន៍វិជ្ជា និងនយោបាយ ឱ្យនៅផ្ទឹមគ្នានឹងចម្បាំងយោធា[2674]។

## ២. "មហាលោតផ្លោះ មហាអស្ចារ្យ" និងភាពធ្ងន់ធ្ងរនៃសភាពការណ៍ជាតិក្រោយជម្លោះ

១៤២០. ឯករាជ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យតម្រូវផងដែរ ឱ្យប្រទេសជាតិមានលទ្ធភាពផ្គត់ផ្គង់ជីវភាពប្រជាជន ក្រោយពីសម័យកាលនៃសង្គ្រាម និងការទម្លាក់គ្រាប់បែក ដែលក្នុងពេលនោះ ដំណាំត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីអស់។ របប លន់ នល់ រស់រានមានជីវិត អាស្រ័យនឹងជំនួយយោធារបស់អាមេរិក ក្នុងក្របខ័ណ្ឌនៃសម្ព័ន្ធភាពនយោបាយ និងយោធា។ ដោយសារការឡើងកាន់អំណាចរបស់ខ្មែរក្រហម គឺជាទីបញ្ចប់នៃជំនួយអាមេរិក រដ្ឋាភិបាលត្រូវស្វែងរកមធ្យោបាយថ្មីដើម្បីរស់។ ក្នុងក្របខ័ណ្ឌនេះ ពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យ" បានលេចត្រដែតឡើង។

---

[2673] ជាឧទាហរណ៍សូមមើល កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ឯកសារ **E3/230** ERN 00000711។ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ ឯកសារ **E3/238** ERN 00072458។

[2674] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៦។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៤៤៨-១៤៥២។

១៤២១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាថ្មីម្តងទៀត ពាក់ព័ន្ធនឹងឆន្ទៈទាញ ខៀវ សំផន ឱ្យចូលពាក់ព័ន្ធ[2675] ដោយចោទគ្មានមូលដ្ឋានថា គាត់ជាអ្នកថ្លែងសុន្ទរកថានៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦ ស្តីពីសម័យប្រជុំលើកទី ១ របស់សភាតំណាងប្រជាជនកម្ពុជា[2676]។ ប៉ុន្តែ សុន្ទរកថាបើកសម័យប្រជុំនេះមិនមែន ខៀវ សំផន ជាអ្នកថ្លែងទេ គឺ "ប្រធានគណៈអធិបតី" នៃសភាតំណាងប្រជាជនកម្ពុជា ដូចមេធាវីការពារក្តីធ្លាប់បានកត់សម្គាល់រួចមកហើយ[2677]។ ម្ចាស់បណ្តឹងសាទុក្ខមិនធ្លាប់កាន់តំណែងនេះទាល់តែសោះ។ ម្យ៉ាងវិញទៀត ឈ្មោះរបស់ ខៀវ សំផន លេចឡើងតែម្តងគត់ក្នុងឯកសារនេះ គឺនៅកន្លែងដែលលើកឡើងអំពីការជ្រើសតាំងគាត់ជាប្រធានគណៈប្រធានរដ្ឋ[2678]។ ឯកសារផ្សេងទៀតបញ្ជាក់ថា ខៀវ សំផន និង "ប្រធានគណៈអធិបតី" ជាមនុស្សពីរនាក់ផ្សេងគ្នា។ ខៀវ សំផន មិនត្រូវបានដកស្រង់ថាជាប្រធានគណៈអធិបតីទេ ក្នុងសេចក្តីប្រកាសព័ត៌មានដែលចេញនៅពេលចប់សម័យប្រជុំសភា[2679]។ ជាពិសេស ឯកសារមួយ ដែលអង្គជំនុំជម្រះយកមកប្រើក្នុងសំណុំរឿង ០០២/០១[2680] បង្ហាញអំពីសុន្ទរកថាមួយរបស់ម្ចាស់បណ្តឹងសាទុក្ខ នៅចំពោះមុខសភាតំណាងប្រជាជនកម្ពុជា ដែលក្នុងនោះគាត់ចាប់ផ្តើមសុន្ទរកថា ដោយសម្តែងនូវក្តីគោរពដល់ "សមមិត្តប្រធានជាទីស្រឡាញ់ដ៏ឧត្តុង្គឧត្តម សមមិត្តតំណាងកងទ័ពបដិវត្តន៍កម្ពុជាជាទីស្រឡាញ់"[2681]។ ក្នុងការសន្និដ្ឋានថា ខៀវ សំផន បានថ្លែង

---

[2675] យើងឃើញមាននិន្នាការនេះរបស់អង្គជំនុំជម្រះដែលចង់ពង្រីកមុខងាររបស់លោក ខៀវ សំផន ទៅតាមកាលបរិច្ឆេទដែលអង្គជំនុំជម្រះកំណត់សម្រាប់មហាសន្និបាតលើកទី៤នៃ ប.ក.ក នៅខែមករា ឆ្នាំ១៩៧៦ នៅកថាខណ្ឌ ៣៧៣៨ នៃសំអាងហេតុសាលក្រម។ សូមមើលខាងក្រោម កថាខណ្ឌ ១៧២៣-១៧២៨។

[2676] សំអាងហេតុសាលក្រម កថាខណ្ឌ៣៧៣៩។

[2677] ឯកសារស្តីពីមហាសន្និបាតលើកទី១ នីតិកាលទី១នៃសភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/165** ERN 00053610-15។ ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ **E1/169.1** ពីម៉ោង 10.17.32 ដល់ម៉ោង 11.32.20។

[2678] ឯកសារស្តីពីមហាសន្និបាតលើកទី១ នីតិកាលទី១នៃសភាតំណាងប្រជាជនកម្ពុជា ចុះថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ២០០៤ ឯកសារ **E3/165** ERN 00053634។

[2679] សេចក្តីថ្លែងការណ៍សារព័ត៌មាននៃសម័យប្រជុំពេញអង្គនីតិកាលទី១នៃសភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E2/262**។ សេចក្តីថ្លែងការណ៍សារព័ត៌មាននៃសម័យប្រជុំពេញអង្គដែលបានផ្សព្វផ្សាយនៅក្នុងមហាសន្និបាតនេះ ក៏មិនមានឈ្មោះលោក ខៀវ សំផន ជា "ប្រធានប្រតិភូ" ដែរ។

[2680] សាលក្រម ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ២៣៣ កំណត់សម្គាល់ជើងទំព័រលេខ ៧២៦។

[2681] "សេចក្តីរាយការណ៍របស់លោក ខៀវ សំផន" ឯកសារ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេស (FBIS) ខែឧសភាឆ្នាំ១៩៧៦ ឯកសារ **E3/273** ERN 00725795 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

សុន្ទរកថា ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសមិនអាចយល់បាន ដោយហេតុថា មេធាវីការពារក្តីបានលើកឡើងអំពីការភាន់ច្រឡំនេះ ដោយសារបញ្ហាបកប្រែ នៅក្នុងសវនាការស្តីពីឯកសារ រួចមកហើយ[2682]។ ជាពិសេស អង្គជំនុំជម្រះមិនគួរណានៅតែមានះធ្វើការសន្និដ្ឋានបែបនេះទៀត ខណៈដែលអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធកំហុសនេះរួចហើយក្នុងសំណុំរឿង ០០២/០១[2683]។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដែលចោទជាបញ្ហាកង្វះអនាគតិចំពោះ ខៀវ សំផន នឹងត្រូវទុកជាមោឃៈ ជាថ្មីម្តងទៀត។

១៤២២. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយខកខានមិនបានកត់សម្គាល់ថាពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យ" គឺជាសម្តីឆន្ទនិយម ដើម្បីព្យាយាមលើកទឹកចិត្តប្រជាជន ក្នុងសភាពការណ៍រីកររនៅក្នុងប្រទេស[2684]។ នៅចំពោះមុខភាពក្រីក្រនៅតាមជនបទ ដែលកាន់តែមានសភាពធ្ងន់ធ្ងរឡើងដោយសារសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ ទំនើបកម្មវិស័យកសិកម្មអន់ថយត្រូវបានមើលឃើញថាជាអាទិភាពបន្ទាន់ដាច់ខាត ក្នុងសម័យកាលរីតត្បិតជាពិសេស។ នៅក្នុងសេដ្ឋកិច្ចកម្ពុជាគ្រងរខ្យល់ក្រោយសង្គ្រាម ជម្រើសមានកម្រិតបំផុត។

១៤២៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានលើកឡើង ក្នុងឯកសារ ប.ក.ក និងកំណត់ហេតុស្តាប់ចម្លើយសាក្សី អំពីគម្រោងធ្វើការជាមួយគ្រប់សមាសភាពសង្គម ដើម្បីទប់ទល់នឹងសភាពការណ៍រីកររដែលកើតមានតាំងពីមុនពេលខ្មែរក្រហមចូលកាន់អំណាចម្ល៉េះ។ ជាក់ស្តែង ថ្វីត្បិតតែអង្គជំនុំជម្រះបាន

[2682] ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ **E1/169.1** ម៉ោង [10.22.43] នៅទីនេះ មេធាវីការពារក្តីបានលើកឡើងពីបញ្ហានៃការបកប្រែ និង បានផ្តល់ឯកសារយោងជាភាសាខ្មែរដែលញែកដាច់ពីគ្នារវាងប្រធានប្រតិភូនៃសភាតំណាងប្រជាជនកម្ពុជា និងប្រធានគណៈប្រធានរដ្ឋ។ សូមមើលផងដែរអត្ថបទដើមជាភាសាខ្មែរនៃឯកសារ E3/165 ERN 00053610។

[2683] សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០២៣៖ "ផ្ទុយទៅវិញ ទាក់ទងទៅនឹងសុន្ទរកថាបើកសម័យប្រជុំនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦ ជាការត្រឹមត្រូវដែលខៀវ សំផន បានអះអាងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្មតថា ជាសុន្ទរកថារបស់គាត់។ [...] ពុំមានការបញ្ជាក់នៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំនេះថា ខៀវ សំផន បានបំពេញតួនាទីជា"ប្រធានគណៈអធិបតី" និងថ្លែងសុន្ទរកថាបើកសម័យប្រជុំនោះឡើយ"។

[2684] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៩។

ដកស្រង់កំណាត់ហេតុ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[2685] ក៏ដោយ ក៏អង្គជំនុំជម្រះបានបំភ្លេចចោលប្រយោគ ដែលបង្ហាញអំពីភាពចាំបាច់ ក្នុងការ "ចេះសាមគ្គី" ឬ "ពង្រឹង-ពង្រីកសាមគ្គីភាព រវាងកម្មករ និងកសិករ"[2686]។

១៤២៤. ប៉ុន្តែ ក្នុងគ្រាអាសន្នខ្វះខាតសព្វបែបយ៉ាងនេះ សញ្ញាណនៃទ្រព្យសម្បត្តិរួម និងការបង្កបង្កើនផលជាសមូហភាព ក្នុងក្របខ័ណ្ឌនៃមនោគមន៍វិជ្ជាកុម្មុយនីស្ត សំដៅដល់ការប្រឹងប្រែងរួមគ្នាពីគ្រប់សមាសភាពសង្គម ដើម្បីធ្វើឱ្យប្រទេសជាតិរស់រានមានជីវិត[2687]។ នេះមិនមែនជាការធ្វើការ ដើម្បីផលប្រយោជន៍របស់មនុស្សមួយក្តាប់តូចនោះទេ គឺកសាងប្រទេស ដោយផ្អែកលើសង្គមថ្មី ដែលមនុស្សគ្រប់គ្នាអាចទទួលបានផលពីការងាររួម។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានលាក់បាំងទិដ្ឋភាពទាំងនេះ ហើយសុខចិត្តទាញសេចក្តីសន្និដ្ឋានដាក់បន្ទុក ចេញពីសក្ខីកម្មចម្រូងចម្រាស និងសួរជឿទុកចិត្តបានរបស់សាក្សី ដូចជា អែម អឿន និង ឯក ហេន ជាដើម[2688]។

១៤២៥. ការកសាងប្រទេសក៏ពឹងផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ក្នុងគំនិតធ្វើទំនើបកម្មប្រទេស ជាអាទិ៍ ដោយសហប្រតិបត្តិការបច្ចេកទេសជាមួយចិន ដែលខ្មែរក្រហមចម្លងពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យ" មកប្រើ[2689]។ សូមបញ្ជាក់នៅដំណាក់កាលនេះថា យើងមិនមានបំណងប្រាថ្នាលើកសរសើរ

---

[2685] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៩ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៦៨។

[2686] សេចក្តីសម្រេចរបស់គណៈមជ្ឈិមស្តីពីបញ្ហាមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/12** ERN 00003136។

[2687] បទសម្ភាស៍ ប៉ុល ពត ដោយអ្នកកាសែតយូហ្គោស្លាវី ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/5713** ERN 00775901-02, ERN 00775905-06។ សុន្ទរកថារបស់លោក ខៀវ សំផន ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/201** ERN 00292804-05។ សូមមើលផងដែរ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/380.1** (អសាធារណៈ) ទំព័រ ៦៨-៧០ ក្រោយម៉ោង 13.55.40។ យូ វ៉ាន់៖ ប្រតិចារឹក ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/377.1** (អសាធារណៈ) ទំព័រ ៥០-៥១ ម៉ោង 11.14.03 ទំព័រ ៦១-៦២ ម៉ោង 13.37.47។

[2688] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៩ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៧៣។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៧៥៥- ១៧៥៩។

[2689] ឧទាហរណ៍ សូមមើលប្រធានបទទាក់ទងនឹងគម្រោងសាងសង់រោងចក្រនៅក្នុងព្រៃ ឬក្នុងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងក្រោមការទទួលខុសត្រូវរបស់ សុន សេន៖ មហាសន្និបាតលើកទី១ នីតិកាលទី១នៃសភាតំណាងប្រជាជនកម្ពុជា កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ ឯកសារ **E3/222** ERN 00000770។ សង្ខេបសេចក្តីសម្រេចគណៈ

ហួសមេឃ ចំពោះគោលនយោបាយរបស់ ប.ក.ក នោះទេ គឺគ្រាន់តែលើកឡើងថាហេតុអ្វីបានជាគម្រោងនយោបាយរបស់បក្សត្រូវគ្នានឹងមនោគមន៍វិជ្ជាសង្គមនិយម ដែលតម្កល់សមូហភាពនៅពីលើឯកត្តជនភាព និងហេតុអ្វីបានជាគម្រោងនយោបាយទាំងនេះមិនមានលក្ខណៈឧក្រិដ្ឋ។

១៤២៦. ការចូលរួមរបស់ ខៀវ សំផន ក្នុងគម្រោងនយោបាយមួយ ដែលផ្តោតអាទិភាពលើវិស័យ "កសិកម្ម សេដ្ឋកិច្ច និងការពារជាតិ" មិនអាចឱ្យសន្និដ្ឋានថា គាត់មានចេតនាឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះទេ គឺគ្រាន់តែគាត់មានជំនឿលើគម្រោងនយោបាយមួយ ដូចគ្នានឹងគម្រោងនយោបាយរបស់ប្រទេសជាច្រើន នៅសម័យនោះ[2690]។ ជាក់ស្តែង អង្គជំនុំជម្រះបានកត់សម្គាល់ថា "គោលបំណងរួម ក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅប្រទេសកម្ពុជា តាមរយៈមហាអស្ចារ្យ មហាលោតផ្លោះ ដែលត្រូវបានបង្កើតឡើង ដើម្បីកសាង ការពារប្រទេស ឱ្យរួចផុតពីសត្រូវ និងផ្លាស់ប្តូរប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែររួបរួមគ្នាមួយ ដែលមានតែវណ្ណៈកម្មករ-កសិករ [...] មិនមែនជាការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ តាមគោលបំណងបឋមរបស់វា"[2691]។ ប៉ុន្តែ ភាពស្ទើរតែដូចគ្នានៃពាក្យ "គោលបំណងបឋម" បានផ្តល់មូលដ្ឋានដល់ការបកស្រាយលម្អៀងនាពេលខាងមុខ អំពីគោលនយោបាយរបស់ ប.ក.ក។

១៤២៧. លើសពីនេះទៀត ដោយបង្ហាញគម្រោងថាជាឆន្ទៈក្នុងការបង្កើត "សង្គមបដិវត្តន៍ស្អាតស្អំ"[2692] អង្គជំនុំជម្រះបានដាក់បញ្ចូលបាតុភាពដំបូងនៃចក្ខុវិស័យពូជសាសន៍និយម ដែល ប.ក.ក មិនធ្លាប់មានទាល់តែសោះ។ សញ្ញាណតែមួយគត់នៃពាក្យ "ស្អាតស្អំ" ដែលអង្គជំនុំជម្រះបានលើកឡើងក្នុងគោលនយោបាយ គឺជាសញ្ញាណផ្ទុយពីអ្វីដែលត្រូវបានមើលឃើញថាជាអំពើពុករលួយក្នុងរបបចាស់។ ដូច

អចិន្ត្រៃយ៍ ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/235** ERN 00019144។ កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ឯកសារ **E3/229** ERN 00000713។

[2690] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤២។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានស្រង់សម្តីយកមកធ្វើជាភ័ស្តុតាងនូវការចូលរួមរបស់លោក ខៀវ សំផន នៅក្នុងនយោបាយនៃការអន្តរាគមន៍ជាច្រើនលើកចំពោះមុខប្រទេសមិនចូលបក្សសម្ព័ន្ធ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៨៩។

[2691] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៣។

[2692] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

យើងនឹងឃើញ ពេលពិនិត្យលើគោលនយោបាយទាំងប្រាំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុធ្ងន់ធ្ងរ ក្នុងការបកស្រាយសុន្ទរកថា និងឯកសាររបស់ ប.ក.ក ដើម្បីសន្និដ្ឋានថា របបនោះមានរចនាសម្ព័ន្ធរើសអើងពូជសាសន៍។ ជាក់ស្តែង តាមរយៈការវាយតម្លៃជាអត្តនោម័តិ និងបំភ្លៃទៅលើភស្តុតាង អង្គជំនុំជម្រះបានសន្និដ្ឋានថា ការអនុវត្តគោលនយោបាយរបស់ ប.ក.ក តម្រូវជាចាំបាច់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ប៉ុន្តែ ការសន្និដ្ឋានសមហេតុផលមួយទៀត គឺថាគម្រោងបានងាកចេញពីគន្លង ដោយសារការអនុវត្តខុសទិសដៅនូវគោលនយោបាយ ដែលយល់មិនច្បាស់នៅតាមមូលដ្ឋាន និងផ្សព្វផ្សាយមិនបានត្រឹមត្រូវ ផ្ទុយពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះ[2693]។

## ផ្នែកទី ៣. ការផ្សព្វផ្សាយផែនការនយោបាយនៃ "បដិវត្តន៍សង្គមនិយម"

### ១. កំហុសពាក់ព័ន្ធនឹងមធ្យោបាយផ្សព្វផ្សាយគោលនយោបាយ

១៤២៨. អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋានអំពីគោលនយោបាយរបស់ ប.ក.ក ដោយផ្អែកលើទូរលេខ លិខិតឆ្លើយឆ្លង ឯកសារផ្លូវការ អត្ថបទ និងសុន្ទរកថាចុះផ្សាយក្នុងទស្សនាវដ្តីបដិវត្ត ប្រតិចារឹកនៃរបាយការណ៍ FBIS និងសេចក្តីសង្ខេបនៃ SWB របស់ ប៊ីប៊ីស៊ី ដែលភាគច្រើនត្រូវបានប្រមូលចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ទោះបីជាមានការប្រយ័ត្នប្រយែងខ្លះក្នុងការបង្ហាញភស្តុតាងក៏ដោយ[2694] ក៏អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្តល់តម្លៃជាភស្តុតាងដ៏សំខាន់ដល់ឯកសារទាំងអស់នោះ ដើម្បីទាញសេចក្តីសន្និដ្ឋាន (១.១) ប៉ុន្តែ ដោយធ្វើការវិភាគខ្លឹមសារ ក្នុងល័ក្ខខ័ណ្ឌប្រែប្រួលតាមការចង់បានរបស់អង្គជំនុំជម្រះ (១.២)។

### ១.១. កំហុសពាក់ព័ន្ធនឹងតម្លៃជាភស្តុតាងនៃឯកសារដែលបានប្រើប្រាស់

១៤២៩. កំហុសពីដើមទីរបស់អង្គជំនុំជម្រះ គឺបដិសេធមិនឱ្យមេធាវីការពារក្តីចូលមើលឯកសារច្បាប់ដើមទាំងអស់ដែលបានដាក់បញ្ចូលក្នុងសំណុំរឿង និងជាពិសេស មិនឱ្យមានលទ្ធភាពទទួលបានរាល់ព័ត៌មាន

[2693] សូមមើលខាងក្រោម កថាខណ្ឌ ១៤៣៤-១៤៣៧។

[2694] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦៩-៤៧២។

ទាំងអស់ពាក់ព័ន្ធនឹងការរក្សាទុក និងខ្សែចង្វាក់នៃការថែរក្សា-ទុកដាក់ឯកសារ[2695]។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានរក្សាគោលជំហររបស់ខ្លួនអំពី "សច្ចធារណ៍នៃភាពអាចជឿទុកចិត្តបាន" ចំពោះឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជូនត្រឹមតែជាសំណៅចម្លង[2696]។ ដើម្បីផ្តល់យុត្តិកម្មដល់សច្ចធារណ៍នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើចម្លើយរបស់សាក្សី ឆាំង យុ ជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា។ សាក្សីនេះមិនត្រឹមតែបានផ្តល់សក្ខីកម្មអំពីវិធីសាស្ត្រមិនសូវមានលក្ខណៈវិទ្យាសាស្ត្រ ដែលបានប្រើប្រាស់សម្រាប់បញ្ជាក់យថាភាពនៃឯកសារប៉ុណ្ណោះទេ[2697] ថែមទាំងបានបដិសេធមិនព្រមប្រាប់ទីតាំងទុកឯកសារដើម ដោយមានការឯកភាពពីអង្គជំនុំជម្រះទៀតផង[2698]។ ក្នុងបរិបទនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានផ្តល់តម្លៃជាភ័ស្តុតាងដ៏សំខាន់ដល់ឯកសារដែលប្រមូលចងក្រងដោយអង្គការក្រៅក្របខ័ណ្ឌតុលាការ ក្នុងល័ក្ខខ័ណ្ឌមិនច្បាស់លាស់ ដែលសូម្បីតែអង្គជំនុំជម្រះខ្លួនឯងផ្ទាល់ក៏មិនដឹងផង។ នៅចំពោះមុខភាពចំណាស់នៃអង្គហេតុ និងស្ថានភាពវឹកវរ នៅកម្ពុជា ក្រោយឆ្នាំ១៩៧៩ អង្គជំនុំជម្រះគួរណាតែអនុវត្តបទដ្ឋានភ័ស្តុតាងក្នុងកម្រិតខ្ពស់បំផុត ជាពិសេស ពេលគេដឹងអំពីទម្ងន់ដែលអង្គជំនុំជម្រះបានផ្តល់ទៅលើសំណៅចម្លងទាំងនោះ ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីគោលនយោបាយ ប.ក.ក។

១៤៣០. ចំពោះករណីជាក់លាក់នៃទូរលេខ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងគោលនយោបាយ ប.ក.ក និងខ្លឹមសារនៃទូរលេខ។ ជាក់ស្តែង ជារឿយៗ អង្គជំនុំជម្រះច្រើនតែភ្ជាប់ទូរលេខឆ្លើយឆ្លងគ្នានៅថ្នាក់មូលដ្ឋាន ទៅនឹងភ័ស្តុតាងអំពីគោលនយោបាយនៅថ្នាក់ជាតិ ទោះបីជាពុំមានភ័ស្តុ

---

[2695] ឧទាហរណ៍ សូមមើលសំណុំរឿង ០០២/០១៖ សេចក្តីសម្រេច ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ឯកសារ **E185**។

[2696] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៥៥ ស្តីពីទូរលេខ។ សូមរំឭកផងដែរ ចំពោះមុខតុលាការអន្តរជាតិ អ.វ.ត.ក នេះថា ស្ទើរតែពុំមានឯកសារដើមសោះនៅក្នុងផ្នែកទាក់ទងនឹងវត្ថុតាង។ សូមមើលអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E297** ក្នុងសំណុំរឿង ០០២/០១ (គឺទស្សនាវដ្តី *យុវជន និងយុវនារីបដិវត្ត* មួយលេខ និង ទស្សនាវដ្តី *ទង់បដិវត្ត* មួយលេខ ផ្តល់ដោយលោក Stephen HEDER)។

[2697] <u>ឆាំង យុ</u>៖ ប្រតិចារឹក ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **E1/37.1** ទំព័រ ៥២-៥៣។ ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **E1/38.1** ទំព័រ ១០-១២។

[2698] <u>ឆាំង យុ</u>៖ ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **E1/38.1** ម៉ោង 09.28.13។ សូមមើលខាងលើ កថាខណ្ឌ ៣២៦-៣២៨។

តាងថា ព័ត៌មានត្រូវបានបញ្ជូនទៅភ្នំពេញក៏ដោយ[2699]។ ជាពិសេស អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស អង្គហេតុ និងអង្គច្បាប់ ដោយបានប្រើប្រាស់ឯកសារទាំងនេះ ក្នុងន័យត្រឹមតែទាញសេចក្ដីសន្និដ្ឋាន អវិជ្ជមានលើគោលនយោបាយ ប.ក.ក។

## ១.២. ភាពលម្អៀងក្នុងតម្លៃប្រែប្រួលដែលបានផ្ដល់ទៅលើភ័ស្តុតាង

១៤៣១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាក់លាក់ ពាក់ព័ន្ធនឹងវិធីសាស្ត្រលម្អៀងលើខ្លឹមសារនៃឯកសារ និងទស្សនាវដ្ដីរបស់ ប.ក.ក។ ការប្រើប្រាស់ទស្សនាវដ្ដី "យុវជន និងយុវនារីបដិវត្ត" និង "ទង់បដិវត្ត" តាមបែបជ្រើសរើស ចោទជាបញ្ហាក្នុងការវិភាគទៅលើភ័ស្តុតាងដើម្បីតែដាក់បន្ទុក។ ជាក់ស្ដែង អង្គជំនុំជម្រះយល់ឃើញថាទស្សនាវដ្ដីទាំងនេះមានតម្លៃជាភ័ស្តុតាងធំធេងណាស់ ដើម្បីផ្ដល់ការបកស្រាយអវិជ្ជមានលើគោលនយោបាយ។ ចំពោះសុន្ទរកថាពាក់ព័ន្ធនឹងជនជាតិវៀតណាម អង្គជំនុំជម្រះបានសន្និដ្ឋានពង្រីកលើអ្វីដែលមិនបាននិយាយជាសត្យានុម័តិ[2700]។ ផ្ទុយទៅវិញ ដើម្បីពិនិត្យពាក្យពេចន៍ច្បាស់លាស់ពាក់ព័ន្ធនឹងបទបញ្ជាស្ដីពីការរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះបែរជាយល់ឃើញថា អត្ថបទទាំងនេះគ្រាន់តែជាការឃោសនា[2701]។ ការវិភាគលម្អៀង និងមិនគ្រប់ជ្រុងជ្រោយទៅលើភ័ស្តុតាងមានលក្ខណៈជាប្រព័ន្ធ។

១៤៣២. ជាអាទិ៍ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការប្រើប្រាស់ដោយជ្រើសរើសនូវកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ចុះខែមីនា ឆ្នាំ១៩៧៦ ដើម្បីបង្ហាញអំពីលក្ខណៈឃោសនានិយមនៃព័ត៌មានផ្សាយតាមវិទ្យុរបស់របបខ្មែរក្រហម[2702]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានបំភ្លេចចោលយ៉ាងអយុត្តិធម៌នូវផ្នែកមួយនៃកំណត់ហេតុដែលបង្ហាញថា កម្ពុជាប្រជាធិបតេយ្យចង់ឱ្យប្រជាជនយល់ជ្រួតជ្រាបអំពី

---

[2699] សូមមើលខាងលើ កថាខណ្ឌ ១០៩០-១០៩១ កថាខណ្ឌ ១៤៣០ និងខាងក្រោម កថាខណ្ឌ ១៥៤២, ១៦១៤, ១៦២៤-១៦២៦, ១៦២៩, ១៦៣៤, ១៦៣៩, ១៦៤៦, ១៦៤៩, ១៧១១។

[2700] ឧទាហរណ៍ សូមមើលខាងលើ កថាខណ្ឌ ១០៨៣-១០៨៥, ១៤៦៩-១៤៧១។ សូមមើលផងដែរសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៣៤-៧៤០។

[2701] សូមមើលខាងលើ កថាខណ្ឌ ១១៩៣។

[2702] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦៦។

រដ្ឋធម្មនុញ្ញរបស់ខ្លួន[2703]។ សម្រង់នេះគួរឱ្យចាប់អារម្មណ៍ណាស់ ពីព្រោះថាថ្វីត្បិតតែការឃោសនាត្រូវបានលើកឡើងក៏ដោយ ក៏កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពាក់ព័ន្ធតែសមាជិក ប.ក.ក ហើយកំណត់ហេតុមិនត្រូវបានផ្សព្វផ្សាយទៅខាងក្រៅឡើយ។ ដូច្នេះ ខ្លឹមសារកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ មិនអាចយកមកវិភាគថាជាយុទ្ធនាការផ្សព្វផ្សាយឡើយ។ កំណត់ហេតុនេះបង្ហាញថាមានឆន្ទៈផ្សព្វផ្សាយរដ្ឋធម្មនុញ្ញឱ្យប្រជាជនយល់ និងអនុវត្ត និងផ្តល់រូបភាពខុសពីអ្វីដែលគេហៅថាជាផែនការនយោបាយរបស់ ប.ក.ក។ អង្គជំនុំជម្រះគួរណាតែទាញផលវិបាក ជាជាងច្រានចោលទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលបដិសេធអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅលើជនជាតិចាម ដោយមូលហេតុពូជសាសន៍ ឬសាសនា ទល់នឹងឧត្តមគតិដែលបង្ហាញដោយរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដើម្បីភាព "សុខដុមរមនា" ក្នុង "មហាសាមគ្គីជាតិទាំងមូល" សំដៅកសាងប្រទេស[2704]។

១៤៣៣. កំណត់ហេតុកិច្ចប្រជុំ ឯកសារ FBIS ឯកសារ SWB និងទូរលេខផ្សេងទៀត គួរណាតែត្រូវបានវិភាគទាំងដោះបន្ទុក និងដាក់បន្ទុក ប៉ុន្តែ ឧទាហរណ៍នេះ ក្នុងចំណោមឧទាហរណ៍ផ្សេងទៀតជាច្រើនបង្ហាញថា អង្គជំនុំជម្រះមិនបានធ្វើបែបនេះទេ។ អង្គជំនុំជម្រះបានរំលោភលើគោលការណ៍ច្បាប់ដែលតម្រូវឱ្យធ្វើការវិភាគភ័ស្តុតាងដោយមិនលម្អៀង ធ្វើឱ្យអង្គជំនុំជម្រះមានការយល់ឃើញបំភ្លៃ និងមិនពេញលេញទៅលើគោលនយោបាយរបស់ ប.ក.ក។ យើងនឹងឃើញថា មានផលប៉ះពាល់ខ្លាំង ក្នុងការពិនិត្យគោលនយោបាយទាំងប្រាំដែលបានចោទប្រកាន់ បណ្តាលឱ្យមានព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ ដោយមិនអាចប្រកែកបាន។

---

[2703] កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ពាក់ព័ន្ធនឹងការងារឃោសនា ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/231** ERN 00017125-26៖ ("សំណួមពរ៖ ឱ្យផ្ទៃក្នុងយើង ប្រជាជនយើង កងទ័ពយើងក្តាប់រដ្ឋធម្មនុញ្ញបាន។ <u>ប្រជាជនយើងទាំងមូលត្រូវយល់អំពីរដ្ឋធម្មនុញ្ញរបស់ខ្លួន មិនមែនតែត្រឹមតំណាងទេដែលត្រូវយល់ដឹង</u>។ <u>ប្រជាជនត្រូវជ្រួតជ្រាបដើម្បីតាមដានតម្រែតម្រង់ការអនុវត្តឱ្យសមស្របតាមគោលបំណងខ្លួន និងផលប្រយោជន៍របស់ជាតិ</u>។ យើងធ្វើដូច្នោះ យើងចំណេញបានច្រើន៖ ទី១ ចំណេញដល់កម្មវិធីវិទ្យុ, ទី២ <u>ឆ្លៀតឱកាសអប់រំនយោបាយ</u>, ទី៣ យើងធ្វើនេះខុសគេទាំងអស់ នៅក្នុងសាកលលោក សូម្បីតែចិន និងវៀតណាម ក៏អត់ផ្សាយពីរដ្ឋធម្មនុញ្ញដែរ។ [...] យើងមិនអួតពីខ្លួនយើង ដើម្បីកុំឱ្យប៉ះពាល់។ <u>តែដាក់ស្តែងរដ្ឋធម្មនុញ្ញយើង ចេញមកពីការតស៊ូ។ ឈរលើរដ្ឋធម្មនុញ្ញនេះ យើងវាយសម្រាប់កសាងប្រទេស។ រដ្ឋធម្មនុញ្ញយើងខ្ញុំជានិមិត្តរូប ជាជ័យជម្នះនៃការតស៊ូរបស់យើង ជាគ្រឹះ មត៌កទុកឱ្យកូនចៅទៅអនាគត</u>"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2704] រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ឯកសារ **E3/259** ERN S00089844។ សូមមើល ផងដែរ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ១៨៤៥។

## ២. កំហុសពាក់ព័ន្ធនឹងវិសាលភាពនៃការផ្សព្វផ្សាយ

១៤៣៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានអំពីការផ្សព្វផ្សាយគោលនយោបាយតាមវិទ្យុ និងទស្សនាវដ្តីរបស់ ប.ក.ក។ ជាក់ស្តែង អង្គជំនុំជម្រះមិនបានទាញផលវិបាកចេញពីសេចក្តីសន្និដ្ឋានផ្ទាល់របស់ខ្លួនអំពីលទ្ធភាពតិចតួចរបស់ប្រជាជនក្នុងការស្តាប់វិទ្យុ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះឡើយ[2705]។ ដោយសារគ្មានវិទ្យុផ្ទាល់ខ្លួន ត្រឹមតែវត្តមានធុងបាស់នៅតាម "ការដ្ឋាន" មិនអាចឱ្យសន្និដ្ឋានថាមានការផ្សព្វផ្សាយគោលនយោបាយយ៉ាងទូលំទូលាយបានឡើយ[2706]។ ដូច្នេះ "ការចាក់ផ្សាយខ្សែអាត់សំឡេងសារភាពរបស់ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួន នៅក្នុងប្រទេសកម្ពុជា" មិនអាចយកមកបង្ហាញថាជាការផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅដល់ប្រជាជនទាំងអស់បានទេ[2707]។

១៤៣៥. ដូចគ្នាផងដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ពាក់ព័ន្ធនឹងភាពឡូស៊ិកនៃការបកស្រាយ និងវិភាគទស្សនាវដ្តីបដិវត្ត។ ក្រៅពីការវិភាគដាក់បន្ទុកជានិច្ចលើខ្លឹមសារ អង្គជំនុំជម្រះមិនបានពិចារណាដល់សក្ខីកម្មពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមទស្សនាវដ្តី "យុវជន និងយុវនារីបដិវត្ត" និង "ទង់បដិវត្ត" នោះឡើយ។ ជាក់ស្តែង ថ្វីត្បិតតែអង្គជំនុំជម្រះបានទទួលយកថា សាក្សី គីម វុន "ដែលធ្លាប់ធ្វើការនៅក្រសួងឃោសនាការ និងព័ត៌មាន ពុំអាចធ្វើការប៉ាន់ប្រមាណឱ្យបានច្បាស់អំពីចំនួនទស្សនាវដ្តីដែលត្រូវបានបោះពុម្ពផ្សាយបានទេ"[2708] ក៏ដោយ ក៏អង្គជំនុំជម្រះបានសន្និដ្ឋានថា មានការចែកចាយដល់ "កម្មាភិបាលនៅថ្នាក់ភូមិភាគ តំបន់ ស្រុក និងឃុំផងដែរ"[2709]។

---

[2705] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦៨។

[2706] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦៦។ ម្យ៉ាងទៀត សាក្សី ស សៀក ដែលធ្វើការផ្នែកវិទ្យុបានបញ្ជាក់ថា "ការចាក់ផ្សាយទាំងនេះ មិនមែនធ្វើឡើងជារៀងរាល់ថ្ងៃនោះទេ" កំណត់សម្គាល់ជើងទំព័រលេខ១៤៧២។

[2707] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦៦។

[2708] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៧៤។

[2709] សំអាងហេតុសាលក្រម កថាខណ្ឌ៤៧៥។

១៤៣៦. អង្គជំនុំជម្រះបានលាក់បាំងទាំងស្រុងនូវទិដ្ឋភាពសំខាន់មួយ ដែលចេញមកពីសាក្សីជាអ្នកគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ដែលបានមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ គឺថា មនុស្សតិចតួចណាស់មានលទ្ធភាពបានអាន និងយល់ខ្លឹមសារទស្សនាវដ្តីទាំងនោះ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មអំពីភាពខុសគ្នាទៅតាមស្រុក និងបញ្ហាអនក្ខរភាពតាមទីជនបទ រួមទាំងកម្មាភិបាលខ្មែរក្រហម ដូចជា ប្រាក់ យុត ជាដើម[2710]។ អង្គជំនុំជម្រះគួរណាតែបង្ហាញអំពីការលំបាកក្នុងការប្រាស្រ័យទាក់ទងគ្នា ដែលបានលើកឡើងក្នុងកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៅឆ្នាំ១៩៧៦[2711]។ ចំណុចនេះគួរណាតែរារាំងមិនឱ្យអង្គជំនុំជម្រះសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ទស្សនាវដ្តីអាចឱ្យជះឥទ្ធិពល និងបំពាក់បំប៉នមនោគមន៍វិជ្ជាដល់ប្រជាជន និងកម្មាភិបាល ក្នុងទ្រង់ទ្រាយធំ។

១៤៣៧. នេះជាចំណុចជាមូលដ្ឋាននៃការស្វែងយល់អំពីភាពបញ្ច្រាសគ្នា រវាងសេចក្តីណែនាំចុះផ្សាយនៅក្នុងទស្សនាវដ្តីអំពីការប្រព្រឹត្តិលើប្រជាជនតាមសហករណ៍ ឬអំពីបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងការពិតនៅនឹងកន្លែង។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនអើពើនឹងទឡ្ហីករណ៍នេះ ក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីផែនការនយោបាយរបស់ ប.ក.ក។ ផ្ទុយទៅវិញ នេះគឺជាចំណុចដែលត្រូវបានមេធាវីការពារក្តីលើកឡើងជាច្រើនលើកច្រើនសា និងត្រូវបង្ហាញម្តងទៀតនៅខាងក្រោម[2712]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនបានវែកញែកលើភ័ស្តុតាងអំពីគោលបំណងរួមរបស់ ប.ក.ក ក្នុងលក្ខណៈមិនលម្អៀងនោះទេ ហើយវាធ្វើឱ្យប៉ះពាល់ដល់សេចក្តីសន្និដ្ឋានតមកទៀតអំពីគោលនយោបាយទាំងប្រាំដែលបានចោទប្រកាន់។

[2710] François PONCHAUD៖ ប្រតិចារឹក ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/178.1** ម៉ោង [16.08.58] ប្រតិចារឹក ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ឯកសារ E1/180.1 ម៉ោង [11.00.46]។ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ ឯកសារ **E1/34.1** ម៉ោង [11.16.02]៖ "ខ្ញុំសមាជិកបក្សកម្ពុជា សម័យនោះ ខ្ញុំអត់បានទទួលដែរអត់សូវ ព្រោះខ្ញុំអត់សូវចេះអក្សរ ហើយអ៊ីចឹងអត់សូវបានមកយកទុកមើលអីទេ។ អ៊ីចឹងទៅ ឯកសារទាំងឡាយ ខ្ញុំមិនសូវបានយកទុកដាក់ដែរ"។

[2711] កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** ទំព័រ ៥ ERN 00017123។

[2712] សូមមើលខាងក្រោម កថាខណ្ឌ ១៤៩០-១៥០២។

**មាតិកាទី ២. កំហុសពាក់ព័ន្ធនឹងគោលនយោបាយទាំងប្រាំនៃគោលបំណងរួម និងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយទាំងនោះ**

**សេចក្តីផ្តើម. ដំណើរការខុសឆ្គងនៃការពិនិត្យលើគោលនយោបាយ**

១៤៣៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថាការអនុវត្តផែនការនយោបាយរបស់ ប.ក.ក បានធ្វើឡើង តាមរយៈគោលនយោបាយប្រាំ ដែលតម្រូវឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម។ ដើម្បីឈានដល់ការសន្និដ្ឋានបែបនេះ យើងនឹងមើលឃើញថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើន បណ្តាលមកពីវិធីសាស្ត្រដែលបានប្រកាន់យកដើម្បីធ្វើការសន្និដ្ឋាន នៅកថាខណ្ឌ ៣៨៦៤ និងកថាខណ្ឌ ៣៨៦៥ នៃសំអាងហេតុសាលក្រម។

១៤៣៩. ផ្តើមចេញពីដីកាដំណោះស្រាយដែលបញ្ជាក់ថា មេដឹកនាំ ប.ក.ក មានគោលបំណងរួមសម្រេចឱ្យបានបដិវត្តន៍សង្គមឆាប់រហ័សនៅកម្ពុជា “តាមរយៈគ្រប់មធ្យោបាយចាំបាច់” ក្នុងនោះមាន “គោលនយោបាយ” ចំនួនប្រាំផងដែរ អង្គជំនុំជម្រះបានប្រកាសថា ដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋាន អង្គជំនុំជម្រះនឹងពិនិត្យមើលថា “តើគោលនយោបាយទាំងនេះមានអត្ថិភាព ឬទេ តើគោលនយោបាយទាំងនេះរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដែរឬទេ ហើយថាតើវាជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងគោលបំណងរួមដែរឬទេ ដែលជាហេតុធ្វើឱ្យគោលបំណងរួមនេះមានលក្ខណៈឧក្រិដ្ឋ”[2713]។

១៤៤០. ដើម្បីផ្ទៀងផ្ទាត់អត្ថិភាពនៃគោលនយោបាយទាំងនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពិនិត្យមើលជាបឋមលើ “សេចក្តីថ្លែងការណ៍នានារបស់ ប.ក.ក និងឯកសារនាសម័យនោះ” ដែល “មានតម្លៃជាភ័ស្តុតាង”[2714]។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស តាំងពីកម្រិតដំបូងនេះ ដោយបានប្រើប្រាស់ឯកសារដែលមានតម្លៃជាភ័ស្តុតាងតិចតួច ឬដោយបានបំភ្លៃខ្លឹមសារនៃឯកសារ។

[2713] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៤។

[2714] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៥។

១៤៤១. ឧទាហរណ៍ដែលចោទជាបញ្ហាបំផុតនៃការបំភ្លៃនេះ គឺថា សុន្ទរកថារបស់មេដឹកនាំ ប.ក.ក ត្រូវបានកាត់ផ្តាច់ជាប្រព័ន្ធចេញពីបរិបទ និងបកស្រាយដាក់បន្ទុក តាមការចង់បានរបស់អង្គជំនុំជម្រះ ដើម្បីសន្និដ្ឋានថា គោលនយោបាយរបស់ ប.ក.ក មានលក្ខណៈឧក្រិដ្ឋ[2715]។

១៤៤២. ក្រៅពីការពិនិត្យលើសេចក្តីថ្លែងការណ៍ និងឯកសាររបស់ ប.ក.ក អង្គជំនុំជម្រះក៏បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពិនិត្យមើលលើ "ទម្រង់ស៊ីចង្វាក់គ្នានៃការប្រព្រឹត្តិនៅតាមទីតាំងឧក្រិដ្ឋកម្មដែលបញ្ជាក់ពីអត្ថិភាពនៃគោលនយោបាយដែលមជ្ឈិមបក្សបានបង្កើតឡើង"[2716]។ ប៉ុន្តែ នៅត្រង់នេះទៀត ការពិនិត្យមើលលើ "ទម្រង់ស៊ីចង្វាក់គ្នា" បាននាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ជាអាទិ៍ តាមរយៈការប្រើប្រាស់ភ័ស្តុតាងក្រៅវិសាលភាព។ ជាក់ស្តែង អង្គជំនុំជម្រះបានផ្អែកសេចក្តីសន្និដ្ឋានជាច្រើនរបស់ខ្លួនលើភ័ស្តុតាងក្រៅវិសាលភាពពេលវេលា និងភូមិសាស្ត្រនៃបណ្តឹង ដើម្បីបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយមួយ ឬលើកឡើងអំពីលក្ខណៈនៃគោលនយោបាយនោះដែលកើតមានតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ។ នេះគឺជាករណីជាក់លាក់ពាក់ព័ន្ធនឹងគោលនយោបាយកំណត់គោលដៅលើក្រុមជាក់លាក់[2717]។ ជាចុងក្រោយ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា អង្គជំនុំជម្រះ "នឹងធ្វើការវាយតម្លៃទៅលើថា តើឧក្រិដ្ឋកម្មដែលត្រូវបានបង្ហាញនៅតាមទីតាំងឧក្រិដ្ឋកម្មនៅក្នុងផ្នែកខាងលើនៃសាលក្រមនេះ ត្រូវបានប្រព្រឹត្តឡើង ដើម្បីសម្រេចគោលនយោបាយដែលត្រូវបានចោទប្រកាន់ដែរឬទេ ហើយថាតើឧក្រិដ្ឋកម្មទាំងនោះមាននៅក្នុងគោលបំណងរួមដែរ ឬយ៉ាងណា"[2718]។

១៤៤៣. ដូចជំហានផ្សេងទៀតនៃដំណើរការរបស់ខ្លួនដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការវិភាគរបស់ខ្លួន ជាបឋម ពីព្រោះអង្គជំនុំជម្រះបានប្រើប្រាស់សេចក្តីសន្និដ្ឋានខុសអំពីទីតាំងឧក្រិដ្ឋកម្ម និងបន្ទាប់មកទៀត ពីព្រោះអង្គជំនុំជម្រះបានធ្វើការបង្ហាញដោយបញ្ច្រាសន័យ។ ជាក់ស្តែង ផ្ទុយពីវិធីសាស្ត្រដែលបានប្រកាស អង្គជំនុំជម្រះមិនបានស្រាវជ្រាវរកសេចក្តីពន្យល់ផ្សេងទៀត

---

2715 សូមមើលខាងលើ កថាខណ្ឌ ១០៨០-១០៨៥។

2716 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៥។

2717 សូមមើលខាងលើ កថាខណ្ឌ ៤៦៩-៤៧០, ៤៧៤, ៤៨០-៤៨១, ៤៨៣, ៤៨៦, ៤៨៩, ៤៩២-៤៩៤, ៤៩៩, ៥០៤, ៥១០, ៥១៣, ៥១៦។

2718 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៥។

ចំពោះអង្គហេតុដែលបានចោទប្រកាន់ ក្រៅតែពីអត្ថិភាពនៃគោលនយោបាយ។ ដូចយើងនឹងឃើញខាងមុខ អំពីការរិះគន់លើការពិនិត្យរបស់អង្គជំនុំជម្រះទៅលើគោលនយោបាយនីមួយៗ ការបង្ហាញរបស់អង្គជំនុំជម្រះស្ថិតនៅក្នុងការសន្និដ្ឋានថា មានគោលនយោបាយ ពីព្រោះមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ វិចារណកិច្ចលម្អៀងនេះ នឹងត្រូវពិនិត្យនៅផ្នែកជាបន្តបន្ទាប់ខាងមុខ។

១៤៤៤. ការកើតឡើងនូវឧក្រិដ្ឋកម្មទាំងនេះ មិនមែនជាភស្តុតាងបង្ហាញពីគោលនយោបាយឧក្រិដ្ឋនោះទេ។ អត្ថិភាពនៃគោលនយោបាយទាំងប្រាំ ដែលអង្គជំនុំជម្រះបានសន្និដ្ឋានថាមាន តាមរយៈការពិនិត្យលើភស្តុតាងដោយលម្អៀង មិនមែនជាសេចក្តីសន្និដ្ឋានសមហេតុផលត្រឹមត្រូវ ក្រោយការបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ នោះទេ។

១៤៤៥. ដំណើរការជាអត្តនោម័តិរបស់អង្គជំនុំជម្រះ បានធ្វើឱ្យប្រឡូកប្រឡាក់ដល់ការពិនិត្យភស្តុតាងទាំងមូលលើគោលនយោបាយនីមួយៗ។ ជាក់ស្តែង អង្គជំនុំជម្រះបានកែប្រែខ្លឹមសារគោលនយោបាយ ដូចបានកំណត់ក្នុងដីកាដំណោះស្រាយ និងក្នុងសំណុំរឿង ០០២/០១ ឱ្យស៊ីគ្នាជាមួយនឹងការបំផ្លើស និងបំភ្លៃរបស់ខ្លួនអំពីគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក។ ពាក្យ "បំផ្លើស និងបំភ្លៃ" ត្រូវបានប្រើប្រាស់ដោយចេតនានៅទីនេះ ពីព្រោះដើម្បីផ្តល់លក្ខណៈឧក្រិដ្ឋដល់គោលនយោបាយផ្សេងៗទាំងនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសតាំងពីដើមទី ដោយបានផ្អែកលើសញ្ញាណ "ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត" ដើម្បីធ្វើសេចក្តីអត្ថាធិប្បាយមិនតិចជាង ៦៧ ទំព័រ[2719]។ ក្រោមលេសបង្ហាញអំពីកាលប្បវត្តិនៃការយល់ឃើញអំពី "ខ្មាំងរបស់ ប.ក.ក" អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រើសញ្ញាណរញ៉េរញ៉ៃ ដើម្បីបង្ហាញជាបន្ទាប់មកទៀតថាទិដ្ឋភាពនីមួយៗនៃគោលនយោបាយ ប.ក.ក គឺជាទម្រង់មួយផ្សេងនៃការវាយប្រហារខ្មាំង។ ភស្តុតាងទាំងអស់ត្រូវបានបកស្រាយ យោងតាមកំហុសពីដំបូងទីនេះ។

១៤៤៦. តាមរយៈការច្របល់បញ្ចូលគ្នាដោយចេតនា រវាងខ្មាំងយោធា និងខ្មាំងជាគូបដិបក្ខនយោបាយ អង្គជំនុំជម្រះបានលាក់បាំងបរិបទនៃជម្លោះប្រដាប់អាវុធ និងពាក្យពេចន៍ម៉ាក្សនិយមនៅសម័យនោះ។ ឈរ

[2719] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៤-៣៨៦៣ ទំព័រ ២២៥៩ ដល់ ២៣១៩។

លើមូលដ្ឋានខុសនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសនៃការវាយតម្លៃលើភ័ស្តុតាងបង្ហាញអំពីគោលនយោបាយដែលបានចោទប្រកាន់ ដោយបានបដិសេធចោលសក្ខីកម្មដែលមិនស្របនឹងការចង់បានរបស់ខ្លួន និងអនុវត្តវិធីសាស្ត្រជារួមតាមបែបជ្រើសរើសនៃសម្មតិកម្មពីដើមទី៖ អ្វីដែលមិនអាចឱ្យសន្និដ្ឋានថាមានគោលនយោបាយឧក្រិដ្ឋត្រូវតែច្រានចោល។

១៤៤៧. ដូច្នេះ កំហុសរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងអត្ថិភាពនៃគោលនយោបាយទាំងប្រាំ នឹងត្រូវពិនិត្យក្រោយពីបង្ហាញអំពីការវាយតម្លៃលម្អៀង និងសំដៅរកតែដាក់បន្ទុក ទៅលើភ័ស្តុតាង ដែលយកមកប្រើសម្រាប់គាំទ្រដល់ការបង្ហាញតាមបែបបំភ្លៃអំពីមូលដ្ឋាននយោបាយរបស់ ប.ក.ក ដោយមើលតែពីជ្រុងនៃសញ្ញាណខ្មាំង (ជំពូកទី ១)។ បន្ទាប់មកទៀត យើងនឹងពិនិត្យលើកំហុសពាក់ព័ន្ធនឹងគោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន និងបង្កើតសហករណ៍ ដែលអង្គជំនុំជម្រះបានក្តោបរួមក្រោមពាក្យ "ក្តាប់" និង "ដណ្តើមប្រជាជន"[2720] (ជំពូកទី ២) គោលនយោបាយស្តីពីមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (ជំពូកទី ៣) និងគោលនយោបាយកំណត់គោលដៅលើក្រុមជាក់លាក់ និងក្នុងក្របខ័ណ្ឌនៃបទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ លើកលែងតែអ្វីដែលបានដោះស្រាយរួចមកហើយនៅក្នុងផ្នែកស្តីពីឧក្រិដ្ឋកម្ម (ជំពូកទី ៤ និងជំពូកទី ៥)។

## ជំពូកទី ១. កំហុសពាក់ព័ន្ធនឹងការយល់ឃើញអំពីខ្មាំងរបស់ ប.ក.ក

១៤៤៨. ផ្នែកស្តីពីគោលនយោបាយទាំងប្រាំ នៃសំអាងហេតុសាលក្រម ចាប់ផ្តើម តាមរយៈការបង្ហាញអំពីអ្វីដែលជាមូលដ្ឋាននៃវិចារណកិច្ចរបស់អង្គជំនុំជម្រះ លើការយល់ឃើញអំពីគោលនយោបាយ ប.ក.ក[2721]។ ក្រោមលេសផ្តល់ "ទិដ្ឋភាពទូទៅនៃកាលប្បវត្តិក្នុងការកំណត់អត្តសញ្ញាណខ្មាំងរបស់ ប.ក.ក" អង្គជំនុំជម្រះបានកំណត់សម្មតិកម្មពីដើមទីខុស ដែលថាផែនការនយោបាយរបស់ ប.ក.ក វិលជុំវិញសញ្ញាណ

---

[2720] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦.៦.១។

[2721] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦.៣។ ខ្មាំងពិតប្រាកដ និង ខ្មាំងតាមការសន្មត។

នេះជាសំខាន់។ ដើម្បីសម្រេចកិច្ចការនេះ អង្គជំនុំជម្រះបានដាក់ផ្ទឹមគ្នានូវភ័ស្តុតាងដែលមិនជាប់ពាក់ព័ន្ធនឹងគ្នា[2722]។

១៤៤៩. អង្គជំនុំជម្រះបានប្រកាសថាខ្លួននឹងបង្ហាញថា "នៅពេញអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ពាក្យថាខ្មាំងត្រូវបានខ្មែរក្រហមពិភាក្សាយ៉ាងលម្អិត និងជាបន្ទាប់ នៅក្នុងអំឡុងកិច្ចប្រជុំ នៅគ្រប់កម្រិត ដូចជានៅក្នុងទូរលេខ វគ្គរៀនសូត្រ សុន្ទរកថា ឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក និងឯកសារផ្សេងទៀតដែលសេសសល់ពីសម័យកាលនោះ មានដូចជា សៀវភៅកំណត់ហេតុ និងសេចក្តីណែនាំអំពីគោលនយោបាយ ជាដើម"[2723]។

១៤៥០. ដូច្នេះ អង្គជំនុំជម្រះបានកសាងការយល់ឃើញរបស់ខ្លួនអំពីខ្មាំងរបស់ ប.ក.ក នៅក្នុងប្រភេទគោលនយោបាយ "រញ៉េរញ៉ៃ" ដោយមិនគិតពីតម្លៃជាភ័ស្តុតាងនៃឯកសារ ដែលអង្គជំនុំជម្រះបានផ្អែកលើ។ ទោះបីជាបានប្រកាសផ្ទុយពីនេះក៏ដោយ[2724] ក៏អង្គជំនុំជម្រះមិនគិតដល់បរិបទជម្លោះប្រដាប់អាវុធទេ មិនថាសង្គ្រាមជាមួយរបប លន់ នល់ នៅមុនខែមេសា ឆ្នាំ១៩៧៥ ឬជម្លោះប្រដាប់អាវុធជាមួយវៀតណាម (ផ្នែកទី ១)។ វិធីសាស្ត្រទាក់ទិននឹងភ័ស្តុតាងនេះ បាននាំឱ្យអង្គជំនុំជម្រះច្រឡំសង្គ្រាមយោធាជាមួយសង្គ្រាមមនោគមន៍វិជ្ជា ដោយមិនគិតពីកំហុសពាក់ព័ន្ធនឹងបរិបទសង្គម និងវប្បធម៌ខ្មែរ (ផ្នែកទី ២)។ ការច្រឡំនេះបានបង្កើតជាមូលដ្ឋានដល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីលក្ខណៈឧក្រិដ្ឋនៃការអនុវត្តផែនការនយោបាយរបស់ ប.ក.ក។ ជាក់ស្តែង គោលនយោបាយទាំងប្រាំដែលបានពិនិត្យ ចំណុះឱ្យការយល់ឃើញជារួមអំពីខ្មាំងរបស់ ប.ក.ក។

**ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងនិដ្ឋភាពទូទៅនៃការបញ្ញត្តិនៃសញ្ញាណខ្មាំង**

[2722] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៤-៣៧៥០។

[2723] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៤។

[2724] សំអាងហេតុសាលក្រម កថាខណ្ឌ៣៩៣៦។

១៤៥១. អង្គជំនុំជម្រះមិនបានពិចារណាគ្រប់គ្រាន់លើភាពខុសគ្នានៃប្រភពដែលបានប្រើប្រាស់ ដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។ ក្នុងការពិនិត្យឯកសារនៅសម័យនោះ អង្គជំនុំជម្រះបានប្រើប្រាស់ឯកសារ ដែលខ្លួនបានកំណត់ថាជា "ឯកសារផ្ទៃក្នុងពីសម័យនោះ"[2725]។ ប៉ុន្តែ ឯកសារជាច្រើនដែលអង្គជំនុំជម្រះយកមកប្រើ ដើម្បីទាញសេចក្តីសន្និដ្ឋានពីគោលនយោបាយ ប.ក.ក មានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ឧទាហរណ៍ អង្គជំនុំជម្រះបានផ្តល់តម្លៃដល់សៀវភៅកំណត់ហេតុរបស់ជនដែលមិនអាចស្គាល់មុខបាន ដែល "បង្ហាញអំពីការវិភាគវណ្ណៈផ្សេងៗរបស់ ប.ក.ក ក្នុងសង្គមកម្ពុជា"[2726] និងកំណត់ហេតុនៃកិច្ចប្រជុំយោធា[2727]។ ក្រៅពីបញ្ហានៃភាពអាចជឿទុកចិត្តបានលើឯកសារទាំងនេះ អង្គជំនុំជម្រះបានច្របល់បញ្ចូលគ្នា រវាងពាក្យ "ខ្មាំង" ដែលបានប្រើប្រាស់ក្នុងបរិបទយោធា និងក្នុងបរិបទមនោគមន៍វិជ្ជា។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានព្យាយាមបង្ហាញការវិវត្តខាងកាលប្បវត្តិនៃនិយមន័យនៃពាក្យខ្មាំង ខណៈដែលតាមការពិត អង្គជំនុំជម្រះត្រូវវិភាគ អាស្រ័យតាមបរិបទនៃ

ឯកសារ មិនមែនអាស្រ័យតែលើសម័យកាលទេ។

១៤៥២. វិធីសាស្ត្រខុសនេះបានផ្តល់ការយល់ឃើញខុសផងដែរអំពីគោលនយោបាយ ដែលបានរៀបរាប់។ កំហុសរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ស្ថិតនៅក្នុងការវិភាគភ័ស្តុតាង នៅមុនឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៥ (១) ឬពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ (២) ដែលអង្គជំនុំជម្រះបានបង្ហាញសញ្ញាណខ្មាំង ដោយកាត់ផ្តាច់ចេញពីបរិបទនៃឯកសារដែលបានប្រើប្រាស់។

### ១. កំហុសពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ នៅមុនឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៥

១៤៥៣. អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋានចេញពីសៀវភៅកំណត់ហេតុមួយ គ្មានចុះកាលបរិច្ឆេទ គ្មានឈ្មោះអ្នកសរសេរ ដែលត្រូវបានចងក្រងក្នុងបរិបទមិនស្គាល់ ដោយគ្មានព័ត៌មានអំពីខ្សែចង្វាក់នៃការ

---

[2725] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៥។

[2726] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៥០។

[2727] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៥០ កំណត់សម្គាល់ជើងទំព័រលេខ ១២៥១៦។

កាន់កាប់ឯកសារនេះ ឬគ្មានការបញ្ជាក់យថាភាព[2728]។ ខ្លឹមសារនៃឯកសារនេះពុំមានអ្វីជាផ្លូវការនោះទេ និងមិនអាចទទួលយកបានឡើយ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញសេចក្ដីពិចារណាជាទូទៅលើគោលនយោបាយ ប.ក.ក ចេញពីសៀវភៅកំណត់ហេតុនេះ។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានប្រើប្រាស់សេចក្ដីព្រាងលក្ខន្តិកៈ ប.ក.ក គ្មានចុះកាលបរិច្ឆេទ គ្មានឈ្មោះអ្នកតាក់តែង គ្មានភ័ស្តុតាងនៃការអនុម័តពីស្ថាប័នណាមួយរបស់បក្ស[2729]។ គ្មានសេចក្ដីសន្និដ្ឋានណាមួយគួរត្រូវបានទាញចេញពីឯកសារនេះឡើយ។

១៤៥៤. អង្គជំនុំជម្រះបានប្រើប្រាស់ឯកសារជាច្រើន ដែលលើកឡើងពីគោលជំហររបស់កងទ័ពបដិវត្តន៍កម្ពុជាចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ជាអាទិ៍ អង្គជំនុំជម្រះបានលើកឡើងអំពីបញ្ជាឱ្យកម្ទេចរបស់ "សមមិត្ត ពីន" ចុះខែមិថុនា ឆ្នាំ១៩៧៥ នៅភូមិភាគពិសេស ដោយមិនបង្ហាញអំពីកាលៈទេសៈនៃការចេញសេចក្ដីសម្រេចនេះ (សូមបញ្ជាក់ថាគាត់ជាហត្ថលេខីតែម្នាក់គត់នៃឯកសារនេះ ហើយគ្មានអ្នកណាម្នាក់ត្រូវបានចម្លងជូនឡើយ)[2730]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុដោយបានប្រើប្រាស់ឯកសារផ្ទៃក្នុងរបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលបានចេញសេចក្ដីសម្រេចនៅនឹងកន្លែង ក្រោយពេលទើបនឹងចេញពីជម្លោះរ៉ាំរ៉ៃ ដើម្បីទាញសេចក្ដីសន្និដ្ឋានជារួមលើគោលនយោបាយ ប.ក.ក ខណៈដែលអង្គជំនុំជម្រះធ្លាប់បានលើកឡើងថា មានកម្លាំងបះបោរសេសសល់មួយក្ដាប់តូចនៅភូមិភាគពាយ័ព្យ ជាដើម[2731]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយមិនបានលើកឡើងអំពីភាពខុសគ្នា នៅឆ្នាំ១៩៧៥ នៅក្នុងទស្សនាវដ្ដី "ទង់បដិវត្ត" រវាងខ្មាំងមនោគមន៍វិជ្ជា និងខ្មាំងយោធា ដែលប្រយុទ្ធនៅលើសមរភូមិខណៈដែលសាក្សី ដូចជា ភី ភួន ជាដើម បានពន្យល់នៅក្នុងសវនាការថា មានការបែងចែកនៅក្នុងបក្ស[2732]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិន

---

[2728] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៥០ កំណត់សម្គាល់ជើងទំព័រលេខ ១២៥០៨ និងកថាខណ្ឌ ៣៧៥១ នៅទីនេះ អង្គជំនុំជម្រះគ្រាន់តែបញ្ជាក់ថាទំនងជាសរសេរដោយ "ឡុង យ៉ា" ដោយគ្មានអ្វីច្បាស់លាស់ឡើយ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2729] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៩ កំណត់សម្គាល់ជើងទំព័រលេខ ១២៥០៨។

[2730] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៥២ កំណត់សម្គាល់ជើងទំព័រលេខ ១២៥១៧។

[2731] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៥៤។

[2732] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៦ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៩៥។ សូមមើល <u>រ៉ចាម តុន ហៅ ភី ភួន</u>៖ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/97.1** ក្រោយម៉ោង 09.24.17 ("ឆ. ក្នុងសង្គ្រាមគឺថា [...] គ្រប់ភូមិភាគ គ្រប់តំបន់

បានធ្វើការបែងចែករវាង "សញ្ញាណ" ខ្មាំងទាំងពីរនេះ ដែលមិនមានកម្រិតដូចគ្នាឡើយ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមានកាតព្វកិច្ចត្រូវទទួលស្គាល់ថា មានគោលជំហរផ្សេងគ្នា ចំពោះប្រជាជនថ្មី និងព្រះសង្ឃ ដែលអង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានទេថា ពួកគេត្រូវបានចាត់ទុកជាខ្មាំង[2733]។

១៤៥៥. ជាចុងក្រោយ គួរកត់សម្គាល់ថា អង្គជំនុំជម្រះបានផ្តល់ការបកស្រាយផ្សេងពីរដ្ឋធម្មនុញ្ញ ទៅតាមតម្រូវការ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន។ ជាក់ស្តែង អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋាន នៅកថាខណ្ឌ ៣៧៦៣ ថា រដ្ឋធម្មនុញ្ញ "រួមមានបទប្បញ្ញត្តិទូទៅ" ដែលចែងអំពីទោសកម្រិតខ្ពស់បំផុត ចំពោះសកម្មភាពប្រឆាំង ហើយបន្ទាប់មក អង្គជំនុំជម្រះបានប្រើបទប្បញ្ញត្តិនេះដើម្បីអះអាងថា បទប្បញ្ញត្តិនេះជាមូលដ្ឋាននៃការសម្លាប់។ ផ្ទុយទៅវិញ ពេលត្រូវលើកឡើងអំពីបទប្បញ្ញត្តិស្តីពីសេរីភាពសាសនា ដោយមានការរឹតត្បិតខ្លះ ឬបញ្ជាក់អំពី "មហាសាមគ្គីជាតិ"[2734] អង្គជំនុំជម្រះបានយល់ឃើញថារដ្ឋធម្មនុញ្ញគ្មានតម្លៃទាល់តែសោះ។ ការវាយតម្លៃដាក់បន្ទុកតែមួយមុខត្រូវតែបដិសេធចោល។

១៤៥៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានបង្ហាញថា ពាក្យ "មេក្បត់ លន់ នល់" មានប្រភពចេញមកពី ប.ក.ក ខណៈដែលតាមពិត ពាក្យនេះចេញមកពីរណសិរ្សរួបរួមជាតិកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេច សីហនុ ក្រោយពីរដ្ឋប្រហារទម្លាក់ព្រះអង្គ។ ក្នុងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥ ព្រះអង្គបានមានបន្ទូលអំពីបញ្ជី "ជនក្បត់" វែងជាងបញ្ជីរបស់ខ្មែរក្រហមទៅទៀត[2735]។ ការចាត់ទុករបប លន់ នល់ ដែលជាសម្ព័ន្ធមិត្តរបស់អាមេរិក ជារបបនាយទុន ដោយ ប.ក

---

គ្រប់ស្រុក គឺដូចខ្ញុំថាហ្នឹង គឺថាបើក្នុងសមរភូមិ គឺត្រូវវៃគ្នាហ្នឹងហើយ ក្នុងសមរភូមិ។ បើក្រៅពីសមរភូមិហ្នឹងគឺថា បើថាអ្នកដែលប្រឆាំងបដិវត្តន៍ហ្នឹង គឺថាក្នុងរយៈហ្នឹង ខ្ញុំក៏មិនឃើញ មិនឃើញជាក់ស្តែងអីទេ ប៉ុន្តែនិយាយថា អ្នកដែលប្រឆាំងបដិវត្តន៍ មិនដឹងជាមានវិធានការយ៉ាងម៉េច ខ្ញុំក៏អត់ដឹងដែរ។ ប៉ុន្តែឃើញ ដែលឃើញនៅ បើក្នុងសមរភូមិ ឃើញតែមានតែរឿងវៃគ្នាហ្នឹងហើយ មួយឈ្នះដែរ វៃគ្នាមួយឈ្នះដៃ សមរភូមិមួយៗ")។

[2733] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៥៧។

[2734] រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ឯកសារ **E3/259** ERN 00089844។ សូមមើលខាង លើ កថាខណ្ឌ ១៤៣២។

[2735] ព័ត៌មានពីកម្ពុជា ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ឯកសារ **E3/1287** ERN 00351593-94។ *"សីហនុ ប្រកាសថា "ជនមហាក្បត់" ២១នាក់ទៀតត្រូវយកមកកាត់ទោស"* ឯកសារ **E3/120** ទំព័រ ១០០ ERN 01580057។

.ក មិនអាចលាក់បាំងការពិតថា "អំពើក្បត់" ចេញមកពីរដ្ឋប្រហារប្រឆាំងនឹងសម្តេច សីហនុ បានទេ[2736]។ម្យ៉ាងវិញទៀត ការតស៊ូប្រឆាំងនឹងខ្មាំង តាមរយៈសហករណ៍ ក្នុង "ឯកសារមួយ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ [ដែល] បានចេញផ្សាយអំពីខួបឆ្នាំទីបីនៃការចាត់តាំងសហករណ៍កសិករ" សំដៅដោយផ្ទាល់ដល់វិធីដែលខ្មែរក្រហមសម្រេចបាននូវការផ្គត់ផ្គង់ស្បៀងដល់កងទ័ព ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០។ ដូច្នេះ បរិបទនេះមានសារៈសំខាន់ដែលត្រូវបង្ហាញ និងពុំមានទំនាក់ទំនងអ្វីជាមួយនឹងការវិវត្តនៃសញ្ញាណខ្មាំង នៅឆ្នាំ១៩៧៦ នោះទេ[2737]។

## ២. កំហុសពាក់ព័ន្ធនឹងរយៈពេល ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨

១៤៥៧. ដំណើរការខុសឆ្គងរបស់អង្គជំនុំជម្រះកាន់តែលេចឡើងច្បាស់ក្រឡែតថែមទៀត ក្នុងវិធីដែលអង្គជំនុំជម្រះបានបំភ្លៃទាំងស្រុងនូវអត្ថន័យនៃឯកសារដែលបានពិនិត្យ សម្រាប់រយៈពេល ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨។ ជាអាទិ៍ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការពិចារណាលើតម្លៃជាភស្តុតាងនៃឯកសារ ឬដោយមិនបានពិនិត្យឯកសារទាំងនោះឱ្យបានត្រឹមត្រូវ ក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធ។

## ២.១. សម្រាប់ឆ្នាំ១៩៧៦

១៤៥៨. អង្គជំនុំជម្រះបានប្រើ "សេចក្តីសង្ខេបអំពីវគ្គរៀនសូត្រ" ក្នុងសៀវភៅរបស់ Ben KIERNAN[2738]។ ប៉ុន្តែ សាស្ត្រាចារ្យសាកលវិទ្យាល័យរូបនេះ មិនព្រមមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ ទោះបីជាមានការប៉ុនប៉ងជាច្រើនដងក៏ដោយ[2739]។ ដោយហេតុថា ភាគីមិនអាចសួរសំណួរទៅគាត់អំពីប្រភពដើម ឬប្រភេទជាក់លាក់នៃសេចក្តីសង្ខេបនេះ និងជាទូទៅ អំពីការងារស្រាវជ្រាវរបស់គាត់ អង្គជំនុំជម្រះបានប្រើប្រាស់ឯកសារនេះដោយមិនត្រឹមត្រូវ ដើម្បីទាញសេចក្តីសន្និដ្ឋាន។ ការរិះគន់ស្រដៀងគ្នានេះក៏អនុវត្តផងដែរ ចំពោះការប្រើប្រាស់ពីសំណាក់អង្គជំនុំជម្រះនូវសៀវភៅកំណត់ហេតុ

---

[2736] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៥៥។

[2737] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៧៦។

[2738] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៩១ កំណត់សម្គាល់ជើងទំព័រលេខ ១២៦៤២។

[2739] សូមមើលអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E166/1/4។

ដែលអង្គជំនុំជម្រះបានកំណត់ថាជារបស់ អៀង សារី ប៉ុន្តែ គ្មានហត្ថលេខា ឬចុះកាលបរិច្ឆេទ និងគ្មានការបញ្ជាក់យថាភាពពីម្ចាស់សៀវភៅនេះ[2740]។ ត្រង់នេះទៀត នេះគឺជាឯកសារ ដែលទំនងជាទទួលបាន ក្នុងល័ក្ខខ័ណ្ឌមិនច្បាស់លាស់ "នៅក្នុងផ្ទះមួយដែលជាផ្ទះរបស់ អៀង សារី" រួចប្រហែលជាប្រគល់ជូន Ben KIERNAN នៅឆ្នាំ១៩៨៦ ក្នុងកាលៈទេសៈមិនច្បាស់លាស់ ដោយសារតែគាត់មិនបានចូលខ្លួនមកផ្តល់សក្ខីកម្ម[2741]។

១៤៥៩. ពិតមែនតែអង្គជំនុំជម្រះបានដកស្រង់ពីក្នុងលក្ខន្តិកៈ ប.ក.ក នូវវិធាន សំដៅតស៊ូប្រឆាំងនឹង "បក្សពួកនិយម"[2742] ក៏ដោយ ក៏អង្គជំនុំជម្រះមិនបានទាញផលវិបាកតាមក្រោយ ដោយកត់សម្គាល់ថា គោលការណ៍ទាំងនេះផ្ទុយពីការអនុវត្តខុសគន្លង ដែលបានសង្កេតឃើញមាន នៅតាមសហករណ៍ នោះឡើយ[2743]។ ជាពិសេស អង្គជំនុំជម្រះពិតជាបានមើលឃើញថា មានការណែនាំឱ្យ "គ្រប់អង្គការបក្ស និងបក្ខជនគ្រប់រូប ត្រូវល្អស្អាតបរិសុទ្ធខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ជានិច្ច"[2744]។ "ភាពបរិសុទ្ធ" ដែលគេសំដៅដល់នេះ ជាប់ពាក់ព័ន្ធនឹងគុណសម្បត្តិដែលកម្មាភិបាលត្រូវមាន គឺគ្មានទំនាក់ទំនងអ្វីជាមួយពូជសាសន៍នោះទេ ហើយមិនអាចប្រើជាបង្អែក ដើម្បីសន្និដ្ឋានថា វាបង្កើតជាមូលដ្ឋាននៃការប្រកាន់ពូជសាសន៍ ឬការរើសអើងចំពោះជនជាតិចាម និងជនជាតិវៀតណាម នោះឡើយ។ នេះគឺជាភ័ស្តុតាងដែលអង្គជំនុំជម្រះមិនបានយកមកពិចារណា នាពេលក្រោយមកទៀត។

១៤៦០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមិនបានពិចារណាសក្ខីកម្មរបស់ ឌុច ជាអ្នកគ្រប់គ្រងមន្ទីរ ស-២១ ទៅតាមបរិបទជាក់ស្តែង[2745]។ ក្រោមការទទួលខុសត្រូវរបស់យោធាផ្ទាល់ ឌុច ទទួល

[2740] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៦ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៩៥ កថាខណ្ឌ ៣៧៧៨។

[2741] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2742] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៦៥។

[2743] សូមមើលខាងលើ កថាខណ្ឌ ១៤៩០-១៥១០។

[2744] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៦៥ ដែលដកស្រង់ពីលក្ខន្តិកៈនៃ ប.ក.ក គ្មានកាលបរិច្ឆេទ ឯកសារ **E3/130** ERN 00442253 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2745] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៦៧។

ស្គាល់ថា សកម្មភាពនៃមន្ទីររបស់គាត់ធ្វើឡើងជាសម្ងាត់[2746]។ អង្គជំនុំជម្រះគួរណាតែគិត ដល់ភ័ស្តុតាងនេះ ដើម្បីសន្និដ្ឋានអំពីលក្ខណៈពិសេសនៃវគ្គរៀនសូត្រដែលរៀបចំឡើងនៅទីនោះ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ជាអាទិ៍ ដោយមិនបានថ្លឹងថ្លែងអំពីស្វ័យភាពដ៏ធំធេងខាងការសម្រេចចិត្តរបស់ សុន សេន ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍ និងជាពិសេស សិទ្ធិអំណាចពិសេសរបស់គាត់ជានាយសេនាធិការ[2747]។ សេចក្តីសម្រេចរបស់ សុន សេន ក្នុងក្របខ័ណ្ឌយោធា និងការងារស៊ើបការណ៍នៅសម័យនោះ គឺជារឿងផ្សេង[2748]។ ដូចគ្នាផងដែរ ពាក្យពេចន៍ប្រើប្រាស់ នៅមន្ទីរ ស-២១ ដូចជាពាក្យ “កម្ទេច” ជាដើម មានលក្ខណៈពិសេសសម្រាប់តែនៅមន្ទីរសន្តិសុខនេះ ដែលស្តែងឱ្យឃើញថាការពន្យល់របស់ ឌុច ដែលអង្គជំនុំជម្រះចម្លងយកទាំងដុលតែម្តង មានន័យផ្សេង[2749] នៅក្រោមន្ទីរ ស-២១។

១៤៦១. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមិនអើពើដោយខុសឆ្គងនឹងការពន្យល់របស់ ពេជ្រ ជឹម ដែលអង្គជំនុំជម្រះបានរំឭកក្នុងប្រធានបទនេះ ថា ពាក្យ “កម្ទេច” មានន័យថា លុបបំបាត់ចេញពីមនុស្សនូវ “អារម្មណ៍វណ្ណៈ ការគាបសង្កត់ និងកេងប្រវ័ញ្ចមនុស្សដទៃ ពោលគឺ បំបាត់ផ្នែកគំនិត”[2750]។ ដូច្នេះ ពាក្យនេះអាចមានន័យផ្សេងគ្នា អាស្រ័យទៅតាមបរិបទ។

១៤៦២. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនគួរណាទាញសេចក្តីសន្និដ្ឋានជារួមចេញពីសេចក្តីសម្រេចដែលមានលក្ខណៈដោយឡែកសម្រាប់វិស័យយោធានោះឡើយ។ ប្រការនេះមានសារៈសំខាន់ ដោយសារ អង្គជំនុំ

---

[2746] សូមមើលខាងក្រោម កថាខណ្ឌ ១៩០៥។

[2747] កំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារ **E3/182** ERN 00019108។ ស.ម ខៀវ [សុន សេន]៖ ទទួលសេនាធិការ និងសន្តិសុខ (ស្តីពីការចាត់តាំងគណៈសេនាធិការ) ERN 00019120។

[2748] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៦៨។

[2749] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥៨។

[2750] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥៨។ សូមមើលផងដែរ កថាខណ្ឌ ៣៨០១ កំណត់សម្គាល់ជើងទំព័រលេខ ១២៦៩០។ វាជាការគួរឱ្យចាប់អារម្មណ៍ក្នុងការលើកឡើងថាក្នុងជើងទំព័រនេះ អង្គជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានតាមរយៈការអះអាងមិនសមស្របរបស់ ពេជ្រ ជឹម ចំពោះកាលបរិច្ឆេទ ខណៈដែលអង្គជំនុំជម្រះមិនបានគិតដល់ភាពមិនស៊ីចង្វាក់គ្នាខ្លាំងជាងនោះទៅទៀត នៃសាក្សី ឯក ហេន និង អែម អឿន ស្តីពីវគ្គរៀនសូត្រដែលអ្នកទាំងពីរអះអាងថាបានចូលរួមរៀនសូត្រ។ សូមមើលខាងក្រោម កថាខណ្ឌ ១៧៥៤-១៧៥៩។

ជម្រះបាន "ជឿជាក់" ថា "ខៀវ សំផន មិនមានសិទ្ធិអំណាចប្រតិបត្តិផ្នែកកងទ័ពទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[2751]។

## ២.២. សម្រាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨

### ២.២.១. ការប្រើប្រាស់ភស្តុតាងដែលមានតម្លៃជាភស្តុតាងតិចតួច

១៤៦៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ពាក់ព័ន្ធនឹងការយកកំណត់ហេតុរបស់លោក GOSCHA មកបង្ហាញអំពីខ្លឹមសារនៃសម្តីរបស់ ប៉ុល ពត ក្នុងឱកាសសន្និសីទ នៅទីក្រុងប៉េកាំង នៅខែកញ្ញា ឆ្នាំ១៩៧៧[2752]។ ការរឹតត្បិតខ្លះលើការប្រើប្រាស់ ដែលកម្រិតត្រឹម "ខ្លឹមសារទូទៅ" មិនបានផ្តល់ភាពអាចជឿទុកចិត្តបានខ្លាំងជាងមុនទៅលើឯកសារនេះទេ ពាក់ព័ន្ធនឹង "ព័ត៌មានដែលបានមកពីកំណត់ហេតុ ដែលសាស្ត្រាចារ្យ [...] បានថតចម្លងសំណៅបកប្រែជាភាសាវៀតណាម [ដែល] ត្រូវបានរកឃើញនៅក្នុងបណ្ណាល័យកងទ័ពប្រជាជន នៅទីក្រុងហាណូយ"[2753]។ ការប្រើប្រាស់កំណត់ត្រារបស់លោក GOSCHA ពាក់ព័ន្ធនឹងកងពល និងកងវរសេនាធំ ទាមទារឱ្យមានមតិយោបល់ដូចគ្នា[2754]។ ដោយសារគ្មានព័ត៌មានអំពីអ្នកសរសេរកំណត់ហេតុ លក្ខខ័ណ្ឌនៃការកត់កំណត់ហេតុជាភាសាវៀតណាម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើខ្លឹមសារនៃកំណត់ត្រាទាំងនេះ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងឯកសារនេះត្រូវច្រានចោល។

១៤៦៤. អង្គជំនុំជម្រះក៏បានទាញការសន្និដ្ឋានចេញពី "សៀវភៅកំណត់ត្រារួមរបស់មន្ទីរសន្តិសុខ ស-២១" ដោយមិនស្គាល់ឈ្មោះអ្នកកត់ត្រា និងបរិបទ[2755]។ គ្មានព័ត៌មានអំពីខ្សែចង្វាក់នៃការទទួលបានឯកសារនេះ និងគ្មានការបញ្ជាក់យថាភាព។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញចេញពីកំណត់ត្រានេះនូវសេចក្តីពិចារណាជារួមលើគោលនយោបាយរបស់ ប.ក.ក។ អង្គជំនុំជម្រះបានប្រើ

---

[2751] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៥។

[2752] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨១៤។

[2753] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨១៤ កំណត់សម្គាល់ជើងទំព័រលេខ ១២៧៤៧-១២៧៤៩។

[2754] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨០៥។

[2755] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨២២។

ប្រាស់ជាថ្មីម្តងទៀតនូវសៀវភៅកំណត់ហេតុរបស់ អៀង សារី ដោយគ្មានបញ្ជាក់យថាភាព[2756]។ ការរិះគន់ដដែលខាងលើអនុវត្តចំពោះការប្រើប្រាស់នេះ[2757]។ ទោះជាយ៉ាងនេះក្តី កំណត់ហេតុទាំងនេះផ្ទុះបញ្ចាំងអំពីមនោគមន៍វិជ្ជា ដែលកើតមានក្នុងសម័យសង្គ្រាមត្រជាក់។

## ២.២.២. ការលាក់បាំងជម្លោះប្រដាប់អាវុធ ក្នុងសុន្ទរកថា និងសេចក្តីថ្លែងការណ៍ផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ

១៤៦៥. ការបង្ហាញពីសំណាក់អង្គជំនុំជម្រះនូវសុន្ទរកថា និងឯកសារផ្លូវការពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ផ្ទុះបញ្ចាំងអំពីរបៀបនៃការលាក់បាំងជម្លោះប្រដាប់អាវុធ ទោះបីជាមានការរំឭកនៅក្នុងទិដ្ឋភាពទូទៅនៃអង្គហេតុក៏ដោយ[2758]។ ជាក់ស្តែង នេះមិនមែនជាការរំឭកអំពីជម្លោះព្រំដែននោះទេ[2759] ហើយក៏មិនមែនជាការលើកឡើងអំពីជម្លោះប្រដាប់អាវុធនោះដែរ គឺជាការពិនិត្យមើលទៅលើផលប៉ះពាល់លើប្រតិកម្មជាផ្លូវការផ្សេងៗ នៅក្នុងប្រទេស។ មេធាវីការពារក្តីបានព្យាយាមបង្ហាញក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលនូវកាលប្បវត្តិនៃការប្រឈមមុខដោយអាវុធ ដោយគូសបញ្ជាក់ពីការឡើងកម្តៅនៃជម្លោះ នៅឆ្នាំ១៩៧៧-១៩៧៨ ដែលប្រកាសអំពីបរាជ័យរបស់កម្ពុជាប្រជាធិបតេយ្យ នៅខែមករា ឆ្នាំ១៩៧៩[2760]។ ដូច្នេះ ភស្តុតាងផ្សេងៗមិនអាចត្រូវបានបង្ហាញ និងវិភាគ ដោយមិនពិនិត្យមើលការប្រព្រឹត្តិទៅនៃហេតុការណ៍ទាំងនោះឡើយ។

### *២.២.២.១. សុន្ទរកថា និងឯកសារឆ្នាំ១៩៧៧*

---

[2756] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨០៣។

[2757] សូមមើលខាងលើ កថាខណ្ឌ ១៤៦៤។

[2758] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨១-២៩៣។

[2759] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៧៥។

[2760] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៨០១-៨១១ សម្រាប់ឆ្នាំ១៩៧៧-ឆ្នាំ១៩៧៨ និង កថាខណ្ឌ ៨១២-៨៣២ ចំពោះបរាជ័យដែលបានប្រកាសនៅឆ្នាំ១៩៧៩។

១៤៦៦. ***កំណត់ហេតុកិច្ចប្រជុំយោធា៖*** អង្គជំនុំជម្រះបានចំណាយពេលយ៉ាងយូរលើកំណត់ហេតុកិច្ចប្រជុំយោធា ដែលបង្ហាញអំពីតំណែងរបស់ សុន សេន[2761]។ ដូចបានបញ្ជាក់ពីខាងលើ តួនាទី និងតំណែងពិសេសរបស់ សុន សេន អាចឱ្យទាញសេចក្ដីសន្និដ្ឋានតែទៅលើការគ្រប់គ្រងរបស់គាត់លើវិស័យយោធា និងស៊ើបការណ៍ប៉ុណ្ណោះ[2762]។

១៤៦៧. ***ការរំឭកខួបជ័យជម្នះ ១៧ មេសា៖*** អង្គជំនុំជម្រះគួរណាតែគិតពីការឡើងកម្ដៅនៃជម្លោះប្រដាប់អាវុធ ដើម្បីពិនិត្យមើលបរិបទនៃសុន្ទរកថាអបអរសាទរជ័យជម្នះ និងលើកទឹកចិត្តកងទ័ព ក្នុងជម្លោះជាមួយវៀតណាមដែលកំពុងកើតឡើង[2763]។

១៤៦៨. ***សេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ស្ដីពីការផ្ដាច់ចំណងការទូតជាមួយវៀតណាម៖*** អង្គជំនុំជម្រះបានអះអាងដោយឥតអឹមអៀនថា សេចក្ដីថ្លែងការណ៍ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៧ របស់ ខៀវ សំផន ត្រូវបានថ្លែងក្នុងពេល "ជម្លោះ [...] បានឈានដល់កម្រិតខ្ពស់ថ្មីមួយ" ដោយ មិនបញ្ជាក់ឱ្យបានច្បាស់ថាតើហេតុការណ៍ណាខ្លះបានចូលរួមចំណែកធ្វើឱ្យវៀតណាមត្រូវបាន ចាត់ទុកជាខ្មាំង "ឈ្លានពាន វាតទីនិយម"[2764]។ ទោះជាយ៉ាងណា យើងចាំបាច់ត្រូវរំឭកបរិបទនៃហេតុការណ៍នៅចុងឆ្នាំ១៩៧៧[2765]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានចង្អុលបង្ហាញថា កម្រិតកំពូលនៃជម្លោះនេះបណ្ដាលម

[2761] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨០៤-៣៨០៥, ៣៧៨៩-៣៧៩០, ៣៧៩៧, ៣៧៩៩។

[2762] សូមមើលខាងលើ កថាខណ្ឌ ១៤៦០។

[2763] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨០៦-៣៨០៧។

[2764] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨១៦។

[2765] សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៨០៩-៨១០៖ "៨០៩. នៅពេលសួរដេញដោលសាក្សី ឡុង សាត លោកប្រធាន និល ណុន បានពិនិត្យមើលទូរលេខជាច្រើនរបស់ភ្នួង ដែលរាយការណ៍អំពីការចូលលុកលុយរបស់វៀតណាម ក្នុងទឹកដីកម្ពុជា និងការវាយប្រហាររោងចក្រ និងចំការកៅស៊ូ ដែលគាត់ជាអ្នកគ្រប់គ្រង។ ការវាយប្រហារពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែធ្នូ បណ្ដាលឱ្យទាហានដកថយ និងបង្ខំឱ្យប្រជាជន និងកម្មករនរត់គេច។ ការវាយប្រហារនេះជាការឱ្យដំណឹងមុនអំពីការចូលមករបស់កងទ័ពវៀតណាមដ៏ច្រើនសន្ធឹកសន្ធាប់ នៅចុងខែធ្នូ ឆ្នាំ១៩៧៧។ ៨១០. ដូច្នេះ ក្រោយពីការចរចាមិនវិវត្តទៅមុខ និងការប៉ះទង្គិចគ្នា ឡើងកម្ដៅខ្លាំង សារទូរលេខចុងក្រោយទាំងនេះបញ្ជាក់អំពីការបញ្ចប់ការតស៊ូរបស់កងទ័ព បូព៌ា និងការចូលមករបស់កងទ័ព វៀតណាមក្នុងទឹកដីកម្ពុជាមួយភាគធំ។ នៅក្នុងបរិបទនេះ កម្ពុជាប្រជាធិបតេយ្យបានផ្ដាច់ទំនាក់ទំនងការទូតជាចំហ និងប្រកាសជាផ្លូវការនូវជម្លោះដែលបង្កឡើងដោយវៀតណាម ដូចអ្នកជំនាញ SHORT បានពន្យល់នៅក្នុងសៀវភៅរបស់គាត់"។

កពីការចូលលុកលុយពីសំណាក់កងទ័ពវៀតណាម ក្នុងទឹកដីកម្ពុជា។ ឯកសារមួយចេញមកពីកងទ័ពកម្ពុជាប្រជាធិបតេយ្យ ត្រូវបានសរសេរយ៉ាងប្រចុចប្រញ៉ុច ដើម្បីលើកឡើងអំពីការវាយប្រហារ និងឧប្បត្តិហេតុផ្សេងៗ ដែលកើតឡើងនៅតាមព្រំដែនជាមួយកងកម្លាំងវៀតណាម[2766]។ វិធីសាស្រ្តខុសឆ្គងនេះបានចូលរួមចំណែកធ្វើឱ្យអង្គជំនុំជម្រះចាត់ទុកសម្ដីវាយប្រហារលើវៀតណាម ក្នុងឋានៈជារដ្ឋ ថាជាសម្ដីវាយប្រហារលើជនជាតិវៀតណាម និយាយជារួម និងអ្នករស់នៅកម្ពុជា និយាយដោយឡែកទៅវិញ។ ដូចយើងបានឃើញពីខាងលើ ការបង្ហាញនេះមិនស៊ីគ្នានឹងភ័ស្តុតាងនោះទេ[2767]។

### ២.២.២.២. សុន្ទរកថា និងឯកសារឆ្នាំ១៩៧៨

១៤៦៩. ដូចចំពោះសេចក្ដីថ្លែងការណ៍ ខែធ្នូ ឆ្នាំ១៩៧៧ ដែរ យើងមិនយល់ទេថា ហេតុអ្វីបានជានៅក្នុងការបង្ហាញអំពីសុន្ទរកថារបស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ នៅដើមឆ្នាំ១៩៧៨ អង្គជំនុំជម្រះមិនបានរំឭកពីការចូលលុកលុយរបស់វៀតណាមលើទឹកដីកម្ពុជា និងផលប៉ះពាល់ ក្រោយពីការឡើងកម្ដៅនៃជម្លោះអស់រយៈពេលជាច្រើនខែ។ យើងមិនអាចយល់ខ្លឹមសារនៃសុន្ទរកថា និងឯកសារផ្លូវការផ្សេងៗរបស់កម្ពុជាប្រជាធិបតេយ្យ ដែលអង្គជំនុំជម្រះបានដកស្រង់ ដោយមិនបានបង្ហាញអំពីការចូលលុកលុយរបស់វៀតណាមលើទឹកដីកម្ពុជាទេ[2768]។ ការប្រកាន់គោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ នៅលើឆាកជាតិ និងអន្តរជាតិ អាចយល់បាន លុះត្រាតែបង្ហាញទំហំនៃជម្លោះប្រដាប់អាវុធ ក្នុងឆ្នាំ១៩៧៨នេះ។

១៤៧០. នៅពេលលើកឡើងអំពីសុន្ទរកថារបស់ ប៉ុល ពត ថ្លែងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨[2769] និងនៅខែមេសា ឆ្នាំ១៩៧៨[2770] សុន្ទរកថារបស់ ខៀវ សំផន ថ្លែងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨[2771] និងសេច

---

[2766] កងទ័ពបដិវត្តបានអនុម័តតាមសេចក្ដីសម្រេចស្ដីពីជម្លោះជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៨ ឯកសារ **E3/1285** ERN 00244271។

[2767] សូមមើលខាងលើ កថាខណ្ឌ ១០៦៥-១០៩៧។

[2768] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨១៧-៣៨២៩។

[2769] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨១៨ កំណត់សម្គាល់ជើងទំព័រលេខ ១២៧៦០។

[2770] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨២៤។

ក្តីថ្លែងការណ៍ផ្លូវការនៅសម័យនោះ អង្គជំនុំជម្រះមិនអាចមិនយកចិត្តទុកដាក់ដល់អ្វីដែលពន្យល់អំពីស ម្តីប្រឆាំងនឹងវៀតណាម និងកងទ័ពវៀតណាមបានទេ។ បើធ្វើបែបនេះ អង្គជំនុំជម្រះបានប្រព្រឹត្ត កំហុសអង្គហេតុ និងអង្គច្បាប់។

១៤៧១. ភាពលម្អៀងក្នុងការវិភាគរបស់អង្គជំនុំជម្រះ លើសុន្ទរកថាដ៏ល្បីល្បាញ "១ ទល់នឹង ៣០" របស់ ប៉ុល ពត ក្នុងបរិបទនេះ ពិតជាគួរឱ្យភ្ញាក់ផ្អើល។ ច្បាស់ណាស់ថា នេះគឺជាសុន្ទរកថា សំដៅលើកទឹកចិត្ត កងទ័ពកម្ពុជាប្រជាធិបតេយ្យ ក្នុងការប្រយុទ្ធនាពេលខាងមុខប្រឆាំងនឹងវៀតណាម ក្រោយពីកងទ័ព សត្រូវបានចូលជ្រៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ[2772]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបាន បដិសេធទឡ្ហីករណ៍នេះរបស់មេធាវីការពារក្តី ដែលមានការគាំទ្រពីសក្ខីកម្មលម្អិត និងស៊ីចង្វាក់គ្នា របស់សាក្សីជាយោធា ដែលបានរត់ខ្ចាត់ខ្ចាយនៅលើសមរភូមិ[2773]។

១៤៧២. ដូចបានឃើញពីខាងលើ ការលាក់បាំងបរិបទរបស់សុន្ទរកថាផ្សេងៗ នៅសម័យកាលដ៏សំខាន់នៃ ជម្លោះប្រដាប់អាវុធ ធ្វើឱ្យមោឃៈដល់សេចក្តីសន្និដ្ឋាន សំដៅស្វែងរកភស្តុតាងអំពីការញុះញង់ឱ្យស្អប់ ពូជសាសន៍ និងប្រព្រឹត្តអំពើប្រល័យពូជសាសន៍[2774]។

**ផ្នែកទី ២. កំហុសតមកទៀតក្នុងការវិភាគអង្គហេតុ**

**១. ការបំភ្លៃឧស្សាហ៍ៈម៉ាក្សនិយមអំពីវណ្ណៈ**

**១.១. សារៈសំខាន់នៃមនោគមន៍វិជ្ជាម៉ាក្សនិយម ក្នុងភាសារបស់ ប.ក.ក**

---

[2771] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨២៣។

[2772] ទស្សនាវដ្តីទង់បដិវត្ត "បទឧទ្ទេសនាមរបស់សមមិត្តលេខាបក្សកុម្មុយនីស្តកម្ពុជាក្នុងឱកាសអបអរសាទរខួបទី៣នៃមហាជ័យ ជម្នះ ១៧មេសា និងកំណើតកម្ពុជាប្រជាធិបតេយ្យដ៏មហាអស្ចារ្យ និងរុងរឿង" ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/4604** ERN 00064707។

[2773] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៣៤-៧៥១។

[2774] សូមមើលខាងលើ កថាខណ្ឌ ១០៦៥-១០៩៧។

១៤៧៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិនិត្យឯកសារវិភាគទាំងអស់ទៅតាមពាក្យពេចន៍ម៉ាក្សនិយមនៅសម័យនោះ។ ពាក្យ "តស៊ូវណ្ណៈ" ឬ "កំហឹងវណ្ណៈ"[2775] ជាពាក្យប្រើប្រាស់ធម្មតា ប៉ុន្តែ ពាក់ព័ន្ធនឹងការប្រឈមមុខដាក់គ្នាខាងមនោគមន៍វិជ្ជាជាមួយខ្មាំងនយោបាយ។ ក្នុងបរិបទសង្គ្រាមត្រជាក់ និងក្នុងពេលទើបងើបចេញពីសង្គ្រាម ដែលគូបដិបក្ខមានការគាំទ្រពីអាមេរិក ការមិនទុកចិត្តលើប្រទេសនេះ និងសម្ព័ន្ធមិត្ត ស្តែងឱ្យឃើញយ៉ាងច្បាស់។ ក្នុងន័យនេះ គេត្រូវយល់អំពីសុន្ទរកថាកំណត់ហេតុកិច្ចប្រជុំ និងឯកសារតម្រង់ទិស ដែលអង្គជំនុំជម្រះបានដកស្រង់[2776]។ ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះបានចង្អុលបង្ហាញ ពាក្យខ្មាំងមិនមែន "ប្រើប្រាស់សំដៅលើខ្មាំងខាងក្រៅទូទៅ" នោះទេ គឺសម្រាប់ហៅអ្នកដែលគេចាត់ទុកថានៅខាងគូបដិបក្ខមនោគមន៍វិជ្ជា[2777]។ ទំនាក់ទំនងជាមួយប្រទេសតតិយលោកត្រូវបានធ្វើឡើង ដោយផ្អែកលើមូលដ្ឋានមនោគមន៍វិជ្ជា[2778]។

១៤៧៤. ភាសាម៉ាក្សនិយមដែលត្រូវបាន ប.ក.ក ប្រើប្រាស់យ៉ាងជាក់លាក់ មានភាពស្មុគស្មាញ ដោយសារតែខ្មែរក្រហមបានសម្របទៅនឹងតថភាពសង្គម និងវប្បធម៌ ដូចជា ការប្រើពាក្យ "ប្រជាជនថ្មី" ជាដើម។ សុន្ទរកថារបស់ ខៀវ សំផន ថ្លែងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៦ ស្ថិតក្នុងពាក្យពេចន៍ម៉ាក្សនិយមនេះ។ ជាក់ស្តែង ការនិយាយសំដៅដល់ "បនក្បត់ លន់ នល់" ថាជា "បរិវារចក្រពត្តិអាមេរិក" គឺជាភាសារបស់ជនកុម្មុយនីស្តនៅសម័យនោះ ជាពិសេស នៅថ្ងៃខួបជ័យជម្នះ ខែមេសា ឆ្នាំ១៩៧៥[2779]។ ថ្វីត្បិតតែអង្គជំនុំជម្រះបានបង្ហាញពីទិដ្ឋភាពឃោសនានៃឯកសារទំនាក់ទំនងមួយចំនួនក៏ដោយ[2780] ក៏អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិចារណាក្នុងសំអាងហេតុសាលក្រម នូវអ្វីដែលមិន

---

[2775] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៦២, ៣៧៦៦, ៣៨៥៦។

[2776] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៦៤ (ដែលរំឭកថាជម្លោះព្រំដែនជំរុញឱ្យមានការមិនទុកចិត្តពីសំណាក់ប្រទេសថៃ) កថាខណ្ឌ ៣៧៥២, កថាខណ្ឌ ៣៧៦៩-៣៧៧១, ៣៣៧៤, ៣៨០២, ៣៨០៦, ៣៨០៨, ៣៨១០-៣៨១៣។

[2777] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៦៨។

[2778] ទស្សនាវដ្តីទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-មករា ឆ្នាំ១៩៧៧ ឯកសារ **E3/25** ERN 00063038-39៖ "ត្រូវមានមិត្ត ជួយឧបត្ថម្ភក្នុងសាកលលោក ជាមិត្តឧបត្ថម្ភខាងស្មារតី ខាងនយោបាយ ខាងទូត កុំឱ្យខ្មាំងវាឯកោយើងបាន។ គេឧបត្ថម្ភយ៉ាងម៉េច គឺគេឧបត្ថម្ភគាំទ្រការតស៊ូរបស់យើង ហើយបើមានខ្មាំងមកឈ្លានពានអី គេឧបត្ថម្ភយើង គេថ្កោលទោសខ្មាំង"។

[2779] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៧៣។

[2780] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

ស្របនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួន។ កំហុសនេះជាក់ស្តែងណាស់ ជាពិសេស ពាក់ព័ន្ធនឹងសហករណ៍ ឬការរៀបអាពាហ៍ពិពាហ៍។

១៤៧៥. ប៉ុន្តែ ច្បាស់ណាស់ថា សុន្ទរកថាបង្ហាញអំពីការខិតខំប្រឹងប្រែងក្នុងស្មារតីស្នេហាជាតិ ឬរំឭកជ័យជម្នះយោធា អត្ថបទជូនចំពោះកម្មាភិបាល ប.ក.ក ឬការផ្សាយទៅអន្តរជាតិ ទាមទារឱ្យមានការវិភាគផ្សេងពីនេះ។

## ១.២. ភាពខុសគ្នារវាងការតស៊ូមនោគមន៍វិជ្ជា និងការតស៊ូពិតប្រាកដ

១៤៧៦. ផ្ទុយពីការអះអាងរបស់អង្គជំនុំជម្រះ ថ្វីត្បិតតែមានការវាយប្រហារប្រឆាំងនឹងគំនិតចក្រពត្តិ នាយទុន និងសក្តិភូមិក៏ដោយ ក៏គ្មានឯកសារណាមួយអាចឱ្យសន្និដ្ឋានថា ប.ក.ក ប្រឆាំងនឹងបុគ្គលទាំងឡាយណាដែលត្រូវបានចាត់ទុកថា "បានអនុវត្ត ឬបានគាំទ្រដល់សន្ធិសម្ព័ន្ធ ឬសេរីនិយម"[2781] នោះឡើយ។ ដូចគ្នាផងដែរ សញ្ញាណនៃវណ្ណៈសង្គម និងទ្រឹស្តីនៃការតស៊ូវណ្ណៈ ក្នុងមនោគមន៍វិជ្ជាម៉ាក្សនិយមរបស់ ប.ក.ក មិនអាចត្រូវបានវិភាគថាជាការតស៊ូតាមន័យត្រង់ប្រឆាំងនឹងក្រុម ដែលអង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណ ក្នុងបញ្ជីមួយលើសពីក្រុមដែលមានក្នុងដីកាដំណោះស្រាយ ទៅទៀត ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[2782]។

១៤៧៧. ជាក់ស្តែង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្តល់ប្រភេទ ដែលខ្លួនបានកំណត់ តាមរយៈការបូកសរុបរួម និងការបកស្រាយដាក់បន្ទុកទៅលើភ័ស្តុតាង គឺអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[2783] ប្រជាជនថ្មី[2784] "អ្នកត្រឡប់មកពីបរទេស"[2785] ព្រះសង្ឃ[2786] "ភ្នាក់ងារសេអ៊ីអា

[2781] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៥។

[2782] ដីកាដំណោះស្រាយ កថាខណ្ឌ ៥០០។

[2783] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៧។

[2784] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៨។

[2785] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៤៩។

[2786] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥០។

កាហ្សេបេ និងឃួន"[2787]។ ប៉ុន្តែ អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គឺជាខ្មាំងតែក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធជាមួយ លន់ នល់ ប៉ុណ្ណោះ។ ម្យ៉ាងទៀត ប្រជាជនថ្មី និងព្រះសង្ឃ មិនធ្លាប់ត្រូវបានចាត់ទុកជាខ្មាំងទាល់តែសោះ។

១៤៧៨. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការវិភាគរបស់ខ្លួន ដោយបានច្របល់បញ្ចូលគ្នានូវឯកសារបង្ហាញអំពីជម្លោះមនោគមន៍វិជ្ជា ជាមួយនឹងឯកសារផ្សេងទៀត ដែលនិយាយសំដៅយ៉ាងច្បាស់ដល់ជម្លោះប្រដាប់អាវុធ។ ប្រការនេះធ្វើឱ្យមានកំហុសឆ្គងដល់ការបង្ហាញអំពីសញ្ញាណខ្មាំង និងបង្កឱ្យមានការភាន់ច្រឡំ រវាងខ្មាំងនយោបាយ និងខ្មាំងយោធា[2788]។ កំហុសរបស់អង្គជំនុំជម្រះស្តែងឱ្យឃើញ តាមរយៈតម្រូវការក្នុងការកំណត់ក្រុមគោលដៅ ដោយរំលោភលើវិសាលភាពនៃបណ្តឹងនៅក្នុងដីកាដំណោះស្រាយ ដើម្បីប៉ុនប៉ងបង្កើតមូលដ្ឋានច្បាប់ សំដៅបង្ហាញអំពីឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា និងពូជសាសន៍ ក៏ដូចជាអំពើប្រល័យពូជសាសន៍[2789]។ ប៉ុន្តែ យើងបានឃើញពីខាងលើថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវបរាជ័យ នៅចំពោះមុខការពិនិត្យឡើងវិញ[2790]។ នេះគឺជាការលើកឡើងអំពី "វិធីសាស្ត្រ" ដើម្បីដាក់ផ្ទឹមគ្នានូវការពិតដែលខុសគ្នាស្រឡះ និងការប្រមូលផ្តុំសេចក្តីពិចារណាខាងមនោគមន៍វិជ្ជា ដូចជា ទស្សនះគ្រួសារដែលផ្ទុយនឹងទស្សនះប្រពៃណី ក្រោមជ្រុងនៃការតស៊ូប្រឆាំងនឹងខ្មាំង[2791]។

១៤៧៩. របៀបដែលអង្គជំនុំជម្រះបោះមូលដ្ឋាន ដើម្បីបង្កការភាន់ច្រឡំរវាងជនស៊ីវិលវៀតណាម និងខ្មាំងយោធា ស្តែងឱ្យឃើញច្បាស់អំពីវិធីបោកបញ្ឆោត។

---

[2787] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥១។

[2788] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៣៩-៣៨៤៦។

[2789] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥១។

[2790] សូមមើលខាងលើ កថាខណ្ឌ ៦៥៦-៦៥៧, ៧១៩-៧៥៧, ៧៨៧-៨១៣, ៨២៥-៨៣៥, ៨៤៨-៨៦១, ៨៨៤-៨៨៦, ៩២៦-៩៦៣, ១០២៨-១០៩៧។

[2791] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥៦-៣៨៦៣។

## ២. ការគាំទ្រច្រឡំរវាងខ្មាំងនយោបាយ និងខ្មាំងយោធា

## ២.១. កំហុសពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យ "យួន"

១៤៨០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា នៅពេលកើតហេតុ ពាក្យ "យួន" ត្រូវបាន "ប្រើប្រាស់ក្រោមទម្រង់ជាការប្រមាថមើលងាយ ក្នុងគោលបំណងវាយប្រហារខាងវោហារសាស្ត្រ ហើយបានប្រើប្រាស់សំដៅលើទាំងខាងយុទ្ធជន និងប្រជាជនស៊ីវិល"[2792]។ ការសង្កេតឃើញនេះផ្ទុះបញ្ច្រាំងនូវជំហររបស់អង្គជំនុំជម្រះ នៅពេលអះអាងថាខ្លួនត្រូវពិចារណា "រាល់ចេតនាអសុរោះដែលពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យយួន ឬខ្មាំង ដោយផ្អែកតាមករណីនីមួយៗ និងដោយពិចារណាទៅលើភ័ស្តុតាងទាំងមូល និងកាលៈទេសៈនៃការប្រើប្រាស់ពាក្យនេះ"[2793]។ តាមពិត អង្គជំនុំជម្រះមិនបានធ្វើការវិភាគ ដោយផ្អែកតាមករណីនីមួយៗទេ។

១៤៨១. ប៉ុន្តែ ការវិភាគនេះមានសារៈសំខាន់ណាស់ ពីព្រោះការប្រើប្រាស់ពាក្យ "យួន" មិនមានន័យដូចគ្នាទេ អាស្រ័យតាមការប្រើដោយយោធា ជនស៊ីវិលខ្មែរ ប្តីប្រពន្ធ ឬសមាជិកគ្រួសារវៀតណាម មេដឹកនាំ ប.ក.ក និងជាពិសេស អាស្រ័យតាមបរិបទ[2794]។ អង្គជំនុំជម្រះបានទទួលស្គាល់ថា ពាក្យនេះអាចសំដៅលើទាំងយុទ្ធជន និងប្រជាជនស៊ីវិល[2795]។

---

[2792] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥៣។

[2793] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៧៧, ៣៣៨១។

[2794] ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/112.1** ម៉ោង 09.36.41៖ ("ពាក្យយួនមិនមែនជាពាក្យដាច់សាច់ទេ ជាពាក្យប្រពៃណីរបស់ខ្មែរទេ។ មកសម័យនេះគឺគេរើសអើង ថាបើនិយាយយួនដាច់សាច់ ត្រូវនិយាយថាវៀតណាម។ ចុះខ្មែរយើងដែលហៅថាខ្មែរហ្នឹងវាមិនមានន័យទេ? អ៊ីចឹង ខ្ញុំថាពាក្យទាំងអស់នេះ ពាក្យថា "សៀម, យួន, ខ្មែរ, លាវ" ជាពាក្យបុរាណ ពាក្យសាមញ្ញធម្មតា យើងតែងតែនិយាយ។ អ៊ីចឹង ខ្ញុំសុំទោសតុលាការ ថាបើខ្ញុំច្រឡំពាក្យថាយួនអី កុំប្រកាន់។ [...] មិនមែនជាពាក្យដាច់សាច់ទេ។ អ៊ីចឹង ខ្ញុំសុំទោសកន្លែងហ្នឹង ក្រែងនិយាយទៅ មិនបានប្រើពាក្យសាធារណរដ្ឋសង្គមនិយមវៀតណាមអី សូមកុំប្រកាន់ ព្រោះដូនកាលយើងនិយាយថាខ្មែរអ៊ីចឹង។ និយាយខ្មែរវាមានន័យថាពេញហើយ បើនិយាយកម្ពុជាវាទូលំទូលាយអ៊ីចឹង")។

[2795] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៧៩។

១៤៨២. ប៉ុន្តែ ទោះបីជាពាក្យ "យួន" អាចត្រូវបានប្រើប្រាស់សំដៅទាំងប្រជាជន និងប្រទេសវៀតណាមក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចយល់ឃើញថា ក្នុងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក ពាក្យនេះសំដៅដល់ជនស៊ីវិលវៀតណាម បានឡើយ[2796]។ យើងបានឃើញពីខាងលើថា ក្នុងសុន្ទរកថា "១ ទល់នឹង ៣០" ប៉ុល ពត និយាយសំដៅយ៉ាងច្បាស់ដល់ប្រទេសវៀតណាម និងកងទ័ព[2797]។ អង្គជំនុំជម្រះមិនគួរណាផ្អែកលើការចាត់ទុកប្រទេសវៀតណាមជា "សត្រូវស្លូពូជរបស់ប្រជាជនកម្ពុជា និងបក្ស" ដើម្បីសន្និដ្ឋានថាពាក្យ "យួន" ត្រូវបានប្រើប្រាស់ក្នុងន័យប្រមាថមើលងាយលើជនស៊ីវិលវៀតណាម[2798] នោះឡើយ។ ក្នុងបរិបទនេះ ពាក្យវៀតណាម ឬ "យួន" សំដៅដល់ប្រទេសជិតខាង គឺមិនមែនជនស៊ីវិលឡើយ។ លើសពីនេះទៅទៀត អង្គជំនុំជម្រះគួរណាតែយល់ឃើញថា ប្រទេសវៀតណាមត្រូវបានចាត់ទុកជា "សត្រូវស្លូពូជ" តាំងពីមុនពេល ប.ក.ក ឡើងកាន់អំណាចមកម្ល៉េះ។ ជាក់ស្តែង សាក្សីបានពន្យល់ថា វៀតណាមត្រូវបានហៅបែបនេះ ច្រើនជំនាន់មកហើយ[2799]។ ដូចគ្នាផងដែរ ចំពោះការចាត់ទុកវៀតណាម "ជាសត្រូវគ្រោះថ្នាក់បំផុត"[2800]។ អង្គជំនុំជម្រះបានផ្អែក ជាអាទិ៍ លើសៀវភៅខ្មៅបោះពុម្ពផ្សាយនៅខែកញ្ញា ឆ្នាំ១៩៧៨ គឺក្រោយការឈ្លានពានរបស់យោធាវៀតណាមលើទឹកដីកម្ពុជា។ ក្នុងន័យនេះ វាជារឿងសមហេតុផលថា វៀតណាមត្រូវបានចាត់ទុកជាសត្រូវគ្រោះថ្នាក់បំផុត។ ប៉ុន្តែ អង្គជំនុំជម្រះមិនអាចប្រើប្រាស់ករណីនេះ ដើម្បីសន្និដ្ឋានថា ឯកសារឃោសនានេះសំដៅដល់ជនស៊ីវិលវៀតណាមនោះឡើយ។

១៤៨៣. អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុដល់សេចក្តីសម្រេចរបស់ខ្លួនឡើយ ពាក់ព័ន្ធនឹងទឡ្ហីករណ៍ដែលមេធាវីការពារក្តីបានលើកឡើង និងមានការគាំទ្រពីសក្ខីកម្មក្នុងសវនាការ[2801]។ ជាក់ស្តែង ចំពោះអ្នក

---

[2796] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៧៩ និង ៣៨៥៣។

[2797] សូមមើលខាងលើ កថាខណ្ឌ ១០៨៣-១០៨៥ កថាខណ្ឌ ១៤៦៩-១៤៧១។ សូមមើលផងដែរសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៣៤-៧៤០។

[2798] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨១។

[2799] ឧទាហរណ៍ សូមមើល៖ <u>មាស រឿន</u>៖ ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E1/387.1** ម៉ោង 10.07.07។ <u>ព្រុំ សារ៉ាត</u>៖ ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/383.1** មុនម៉ោង 09.30.57។

[2800] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨១។

[2801] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ២២១៨-២២២៥។

និយាយភាសាខ្មែរ សញ្ញាណរើងអើងពូជសាសន៍ផ្សារភ្ជាប់នឹងពាក្យ "យួន" មិនត្រូវគ្នានឹងការប្រើប្រាស់ផ្សេងៗ តាមកាលវេលា នៅកម្ពុជា ឡើយ។

១៤៨៤. អង្គជំនុំជម្រះមិនបានពន្យល់ឱ្យបានជាក់លាក់ថា ហេតុអ្វីបានជាអតីតប្តីប្រពន្ធ ឬសមាជិកគ្រួសារវៀតណាម បានប្រើពាក្យប្រមាថមើលងាយ ឬវាយប្រហារ ដើម្បីហៅសមាជិកគ្រួសាររបស់ខ្លួន។ ជាក់ស្តែង សូមរំឭកថា សាក្សី សៅ សាក់ មានម្តាយវៀតណាម នៅព្រៃវែង បានប្រើពាក្យ "យួន" ជាច្រើនដង ពេលនិយាយពីគ្រួសារដែលគេបញ្ជូនទៅវៀតណាមវិញ និងអ្នកភូមិផ្សេងទៀត[2802]។ ដួង អឿន មានប្តីវៀតណាម ក៏បានប្រើពាក្យ "យួន" ដើម្បីនិយាយពីវៀតណាមជាទូទៅ[2803]។

១៤៨៥. ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា ការប្រើប្រាស់ពាក្យ "យួន" ក្នុងសុន្ទរកថារបស់តំណាងកម្ពុជាប្រជាធិបតេយ្យ ស្មើនឹងការអំពាវនាវឱ្យប្រព្រឹត្តអំពើហិង្សារួចទៅហើយ។ តាមពិត សេចក្តីសន្និដ្ឋានសមហេតុផលត្រឹមត្រូវ គឺថា តំណាងទាំងនោះបានប្រើប្រាស់ពាក្យដែលខ្មែរតាមជនបទប្រើជាប្រចាំថ្ងៃ។ បរិបទនៃជម្លោះប្រដាប់អាវុធ គឺជាធាតុផ្សំតែមួយគត់ដែលពន្យល់អំពី "ភាពអសុរោះ" នៃសម្តីថ្កោលទោស ចំពោះអ្វីដែលកម្ពុជាប្រជាធិបតេយ្យចាត់ទុកជាការវាយប្រហារលើអធិបតេយ្យភាពរបស់ខ្លួន។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះលើចំណុចនេះ នឹងត្រូវទុកជាមោឃៈ។

### ២.២. កំហុសបណ្តាលមកពីការលាក់បាំងជម្លោះប្រដាប់អាវុធ

១៤៨៦. ដោយមិនបានកំណត់ឱ្យបានច្បាស់នូវអ្វីដែលលាក់បំពួនពីក្រោយពាក្យ វៀតណាម ឬ "ភ្នាក់ងារ" វៀតណាម អង្គជំនុំជម្រះមានចេតនារក្សាទុកការភាន់ច្រឡំចំពោះអ្នកដែល ប.ក.ក បានកំណត់មុខសញ្ញាតាមរយៈវោហារសាស្ត្រ។ ជាអាទិ៍ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយសារមិនបានព្យាយាមចង់

---

[2802] សៅ សាក់៖ ប្រតិចារឹក ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** ទំព័រ ១០៣-១០៤ មុនម៉ោង 15.20.15 ("[...] គេដេញៗទៅហើយនៅតែគ្រួសារដែលឪពុកម្តាយខ្មែរ ឪពុកម្តាយយួនអីជាប់បន្តិចបន្តួចហ្នឹង" ទំព័រ ៧២)។ ប្រតិចារឹក ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/362.1** ទំព័រ ១២៣ បន្ទាប់ពីម៉ោង 15.55.46 ("[...] គាត់កូនកាត់យួន-ចិន" ទំព័រ ៨៦) ប្រតិចារឹក ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/363.1** ទំព័រ ១៣ ម៉ោង 09.35.07 (ទំព័រ ៩) ទំព័រ ១៥ ម៉ោង 09.37.24 (ទំព័រ ១០)។

[2803] ដួង អឿន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/381.1** ទំព័រ ៤៣ ម៉ោង 11.04.34 (ទំព័រ ៣០)។

ដឹងអំពីអ្វីដែលលាក់បាំងពិតប្រាកដពីក្រោយពាក្យ "ភ្នាក់ងារ" វៀតណាម[2804]។ ដូច្នេះ ការឃ្លាតចាកពីន័យដើមអាចទៅរួច រវាងពាក្យ "ភ្នាក់ងារ" វៀតណាម និង "វៀតណាម"។

១៤៨៧. ចំណុចនេះស្តែងឱ្យឃើញច្បាស់ នៅកថាខណ្ឌ ៣៨៥៣ នៃសំអាងហេតុសាលក្រម។ ខណៈដែលធ្វើការវិភាគលើប្រភេទនៃ "ភ្នាក់ងារសេអ៊ីអា កាហ្សេបេ និងយួន (វៀតណាម)" អង្គជំនុំជម្រះបានយល់ឃើញបន្ទាប់មកទៀតថា "ភ្នាក់ងារវៀតណាម ឬយួន ត្រូវបានពិភាក្សាកាន់តែច្រើនឡើងៗ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"។ ដូច្នេះ យើងងាកចេញពី "ភ្នាក់ងារ" វៀតណាម ទៅ "វៀតណាម"។ អង្គជំនុំជម្រះបានយោងជាក់លាក់ទៅរកការបោសសម្អាតអតីតកម្មាភិបាល ឬសមាជិក ប.ក.ក[2805] ឬ "វៀតណាមវាតទី លេបទឹកដី"[2806]។ ថ្វីត្បិតតែច្បាស់ណាស់ថា ប្រភេទនេះមិនសំដៅដល់ "ភ្នាក់ងារស៊ើបការណ៍តាមន័យត្រង់"[2807] ក៏ដោយ ក៏តាមរយៈពាក្យ "ភ្នាក់ងារ" ប.ក.ក ហាក់ដូចជាចង់សំដៅដល់អ្នកដែលគេចោទថាបានចូលដៃជើងជាមួយវៀតណាម ជាពិសេស សមាជិក ប.ក.ក។ ផ្ទុយទៅវិញ គ្មានអ្វីអាចឱ្យសន្និដ្ឋានបានថា វៀតណាមត្រូវបានកំណត់គោលដៅ ដោយមិនរើសមុខ ឡើយ។ ដោយគ្មានផ្តល់សំអាងហេតុ ការពន្លាតប្រភេទ "ភ្នាក់ងារ" វៀតណាម ទៅដល់ជនជាតិវៀតណាម ជារឿងមិនសមហេតុផល។ ភាពមិនច្បាស់លាស់ខាងអត្ថន័យនេះត្រូវតែច្រានចោល ពីព្រោះវាត្រូវបានប្រើប្រាស់ ដើម្បីសន្និដ្ឋានអំពីអត្ថិភាពគោលនយោបាយឧក្រិដ្ឋចំពោះវៀតណាមទូទៅ ក្នុងគោលដៅបង្កើតជាមូលដ្ឋាននៃចេតនាប្រល័យពូជសាសន៍[2808]។

១៤៨៨. **សេចក្តីសន្និដ្ឋាន៖** កំហុសទាំងអស់របស់អង្គជំនុំជម្រះធ្វើឱ្យមោឃៈដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីការយល់ឃើញអំពីខ្មាំងដោយ ប.ក.ក។ សេចក្តីសន្និដ្ឋានខុសទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីកំណត់ខ្លឹម

---

[2804] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥១-៣៨៥៥។

[2805] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥៣ កំណត់សម្គាល់ជើងទំព័រលេខ ១២៨៧១ ដែលយោងទៅកថាខណ្ឌ ៣៧៩៣ ដែលនិយាយអំពីការចាប់ ចាន់ ចក្រី, ឈូក, យ៉ា និង កែវ មាស។ កថាខណ្ឌ ៣៨១១ និយាយពីការបោសសម្អាតនៅក្នុងក្រសួងការបរទេស នៅកថាខណ្ឌ ៣៨២០, ៣៨២៨ និង ៣៨២៩។

[2806] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥៣ កំណត់សម្គាល់ជើងទំព័រលេខ ១២៨៧១ ដែលយោងទៅ កថាខណ្ឌ ៣៨១៩។

[2807] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៥៤។

[2808] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤១៧ និង ៣៥១៧-៣៥១៨។

សារនៃគោលនយោបាយដែលបានចោទប្រកាន់ ក្រោមជ្រុងនៃការតស៊ូប្រឆាំងនឹងខ្មាំង។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានទាញការសន្និដ្ឋានចេញពីការចូលរួមរបស់ ខៀវ សំផន ក្នុងផែនការនយោបាយរបស់ ប.ក.ក ថាគាត់បានឯកភាពលើការយល់ឃើញខុសអំពីការតស៊ូប្រឆាំងនឹងខ្មាំង ដើម្បីទាញចេញនូវចេតនារបស់គាត់ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងក្របខ័ណ្ឌនៃសហឧក្រិដ្ឋកម្មរួម។ វិចារណកិច្ចខុសនេះធ្វើឱ្យមោឃៈដល់សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយដែលមានលក្ខណៈឧក្រិដ្ឋ[2809]។ ឈរលើសម្មតិកម្មខុសនេះ អង្គជំនុំជម្រះបានសន្និដ្ឋានអំពីអត្ថិភាព និងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយទាំងប្រាំ ដែលនឹងត្រូវពិនិត្យនៅពេលនេះ។

## ជំពូកទី ២. "គោលនយោបាយ" ជម្លៀសប្រជាជន សហករណ៍ និងការដ្ឋាន

### ផ្នែកទី ១. អត្ថិភាពនៃគោលនយោបាយជម្លៀសប្រជាជន

១៤៨៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយអនុវត្តហួសពីបណ្តឹងមកកាន់ខ្លួន ដោយបានធ្វើការអះអាងលើមូលហេតុនៃការជម្លៀសប្រជាជន និងអត្ថិភាពនៃវិធីប្រតិបត្តិស៊ីចង្វាក់គ្នានៃការជម្លៀសប្រជាជន ក្រោយពីទីក្រុងភ្នំពេញបានដួលរលំ។ ជាដំបូង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានធ្វើសេចក្តីអត្ថាធិប្បាយក្រៅយុត្តាធិការលើរឿងក្តី និងពេលវេលា ពាក់ព័ន្ធនឹងមូលហេតុនៃការជម្លៀសប្រជាជន ដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃផែនការ "ក្តាប់" និង "ដណ្តើមប្រជាជន"[2810]។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានធ្វើអត្ថាធិប្បាយអំពីវិធីប្រតិបត្តិស៊ីចង្វាក់គ្នានៃការជម្លៀសប្រជាជន ក្រោយពីទីក្រុងភ្នំពេញបានដួលរលំ[2811]។ ប៉ុន្តែ ការជម្លៀសប្រជាជនមិនស្ថិតនៅក្រោមវិសាលភាពនៃសំណុំរឿង ០០២/០២ នោះទេ។ អង្គជំនុំជម្រះបានរំលោភលើវិសាលភាពនៃបណ្តឹង។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ មិនអាចបង្កើតជាមូលដ្ឋានបង្ហាញអំពីលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋាន បានទេ[2812]។

---

[2809] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៩-៤២៩៩, ៤៣០៦-៤៣០៧, ៤៣១៦-៤៣១៨, ៤៣២៦-៤៣២៨។

[2810] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៧៧-៣៨៨៣។

[2811] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៣។

[2812] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៦, ៣៩១៨-៣៩២៩។

## ផ្នែកទី ២. គោលដៅរបស់សហករណ៍

១៤៩០. ការបង្កើត និងប្រតិបត្តិការសហករណ៍ គឺជាទិដ្ឋភាពតែមួយគត់នៃគោលនយោបាយរបស់ ប.ក.ក ដែល ខៀវ សំផន មិនបានជំទាស់ទេថា វាត្រូវបានដាក់បញ្ចូលក្នុងគោលបំណងរួម ទុកដូចជារបៀបដំណើរការសេដ្ឋកិច្ចរបស់សង្គមជនបទដូចជាកម្ពុជា នៅពេលកើតហេតុ។

១៤៩១. ជាបឋម អង្គជំនុំជម្រះបានយល់ឃើញថា "ជាការសមហេតុសមផល ក្នុងការពិចារណារួមគ្នាទៅលើការជម្លៀសប្រជាជន ការបង្កើតសហករណ៍ និងការដ្ឋានការងារ ដោយសារតែគោលនយោបាយទាំងនេះមានគោលដៅ និងមនោគមន៍វិជ្ជាជាន់គ្នា"[2813]។ អង្គជំនុំជម្រះបានបញ្ជាក់ថា យោងតាមការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះនឹងកម្រិតត្រឹមការពិនិត្យលើការអនុវត្តគោលនយោបាយជម្លៀសប្រជាជន "ត្រង់ចំណុចដែលពាក់ព័ន្ធនឹងជនជាតិចាមប៉ុណ្ណោះ"[2814]។ តាមរយៈការពិចារណាផ្តួបគ្នានេះ អង្គជំនុំជម្រះបានបង្កើតគោលនយោបាយថ្មី ហៅថា "ក្តាប់" និង "ដណ្តើមប្រជាជន" ដែលមិនមាននៅក្នុងដីកាដំណោះស្រាយ ឬសំណុំរឿង ០០២/០១[2815]។ ការបង្កើតថ្មីនេះ គឺជាការបង្ហាញបំភ្លៃដោយចេតនាអំពីគោលដៅរបស់សហករណ៍ ដើម្បីសន្និដ្ឋានអំពីលក្ខណៈឧក្រិដ្ឋ។

១៤៩២. ម្យ៉ាងវិញទៀត ដំណើរការនេះផ្ទុយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះថា "នេះបង្ហាញឱ្យឃើញថាជនជាតិចាមត្រូវគេបំបែក ដើម្បីឱ្យសហគមន៍របស់ពួកគេបែកបាក់ ពុំមែនគ្រាន់តែជាការចែកចាយកម្លាំងពលកម្មនោះឡើយ"[2816] ដោយបដិសេធចោលទឡ្ហីករណ៍របស់មេធាវីការពារក្តី[2817]។ ជាក់ស្តែងប្រសិនបើអង្គជំនុំជម្រះបានសន្និដ្ឋានថា ការជម្លៀសជនជាតិចាមត្រូវបានសម្រេច ក្នុងក្របខ័ណ្ឌនៃការកំណត់គោលដៅជាក់លាក់ អង្គជំនុំជម្រះពុំមានមូលហេតុអ្វីត្រូវពិនិត្យមើលគោលនយោបាយទាំងពីរនេះរួមគ្នាទេ។

---

[2813] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៧។

[2814] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៧។

[2815] សំអាងហេតុសាលក្រម កថាខណ្ឌ ១៦.៤.១។

[2816] សំអាងហេតុសាលក្រម កថាខណ្ឌ៣២៦៨។

[2817] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ១៦១១-១៦១៦។

១៤៩៣. តាមពិត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ពីព្រោះដូចគ្នានឹងការរកឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលថា ពុំមានការរើសអើងលើប្រជាជនថ្មីទេ ក្នុងការជម្លៀសប្រជាជនដំណាក់កាលទី ២[2818] ពុំមានការរើងអើសលើជនជាតិចាមឡើយ ក្នុងការជម្លៀសប្រជាជនមួយភាគធំដើម្បីបែងចែកប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យទៅតាមសហករណ៍ផ្សេងៗ ដោយសារហេតុផលសេដ្ឋកិច្ច។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ជាពិសេស អំពីគោលនយោបាយរបស់ ប.ក.ក (១) និងតួនាទីរបស់ ខៀវ សំផន (២) ពាក់ព័ន្ធនឹងសហករណ៍។

## ១. សេចក្តីសន្និដ្ឋានខុសអំពីគោលនយោបាយរបស់ ប.ក.ក

១៤៩៤. អង្គជំនុំជម្រះបានកំណត់ការពិភាក្សាអំពី "ផែនការវាយសម្រុកចុងក្រោយ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងទៀត [...] នៅក្នុងខែមិថុនា ឆ្នាំ១៩៧៤" និង "ផែនការរំដោះ និងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ [...] នៅដើមខែមេសា ឆ្នាំ១៩៧៥"។ នៅពេលវែកញែកអំពីតួនាទីរបស់ ខៀវ សំផន យើងនឹងឃើញកំហុសរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំ នៅខែមេសា ឆ្នាំ១៩៧៥ នៅមន្ទីរ ប-៥[2819]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានយល់ឃើញថា កាលបរិច្ឆេទនេះ គឺជាការចាប់ផ្តើមបង្កើតសហករណ៍ តាមរយៈការកំណត់ចរិតលក្ខណៈ

[2818] សាលដីកា ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧០២៖ "ទាក់ទងទៅនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំសមហេតុផលថា "ប្រជាជនភាគច្រើនលើសលុប" ដែលត្រូវបានផ្លាស់ទីលំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ គឺជា "ប្រជាជនថ្មី" ដោយសារភ័ស្តុតាងតិចតួចគាំទ្រការសន្និដ្ឋាននេះ។ តាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងភ័ស្តុតាងដែលបានយកមកសំអាងនោះឃើញថា ការផ្លាស់ទីលំនៅប្រជាជនដោយសារមូលហេតុសេដ្ឋកិច្ច និងចេញពីព្រំដែនវៀតណាម ពាក់ព័ន្ធទាំងប្រជាជនចាស់ ទាំងថ្មី ដែលជាការពិតមួយត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់របស់ខ្លួន។ ដោយសារការផ្លាស់ទីលំនៅនេះបានប៉ះពាល់មិនត្រឹមតែប្រជាជន*ថ្មី* ដូច្នេះពុំអាចនិយាយបានថា ជាការរើសអើងជាក់ស្តែង ឬបង្ហាញពីចេតនារើសអើងឡើយ"។ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2819] សូមមើលខាងក្រោម កថាខណ្ឌ ១៦៧៦-១៦៨០។

ខុសអំពីសេចក្ដីតម្រង់ទិសនយោបាយរបស់ ប.ក.ក និងការមិនអើពើនឹងភស្តុតាងទាំងអស់ដែលបង្ហាញថា មានការព្រួយបារម្ភជាប្រចាំចំពោះប្រជាជន។

## ១.១. សេចក្ដីតម្រង់ទិសនយោបាយដែលត្រូវបានកំណត់ចរិតលក្ខណៈខុស

១៤៩៥. ការបង្ហាញឯកសារផ្លូវការរបស់ ប.ក.ក ស្ដីពីសហករណ៍ ក្នុងសំអាងហេតុសាលក្រម ត្រូវបានធ្វើឡើងជាប្រព័ន្ធ ក្រោមជ្រុង "ខ្លាំង" និងគោលនយោបាយរើសរើងលើប្រជាជនថ្មី។ ប៉ុន្តែ ខ្លឹមសារ ដែលអង្គជំនុំជម្រះបានដកស្រង់ អាចឱ្យទាញសេចក្ដីសន្និដ្ឋានផ្សេង ដោយមិនគិតពីឯកសារដែលអង្គជំនុំជម្រះធ្វើមិនដឹងមិនឮតែម្ដង។

១៤៩៦. ជាក់ស្ដែង អង្គជំនុំជម្រះមិនបានពិចារណាលើមូលហេតុ ដូចបានបង្ហាញក្នុងទស្សនាវដ្ដីបដិវត្ត។ ខណៈដែលទស្សនាវដ្ដី "យុវជន និងយុវនារីបដិវត្ត" ចេញផ្សាយខែតុលា ឆ្នាំ១៩៧៥ បានរៀបរាប់អំពីស្ថានភាពមហន្តរាយក្នុងប្រទេស នៅខែមេសា ឆ្នាំ១៩៧៥ អង្គជំនុំជម្រះបានលើកឡើងតែផ្នែកដែលនិយាយថា "ប្រជាជនកម្ពុជា ៩៩,៩% ត្រូវទៅរស់នៅឯជនបទ" ផ្ទុយទៅវិញ ព័ត៌មានជាមូលដ្ឋាន គឺការសង្កេតឃើញពី "ការខ្វះសព្វគ្រប់ [...] ទីជម្រក ផ្ទះសម្បែង ខ្វះស្បៀងអាហារ ខ្វះមធ្យោបាយ និងឧបករណ៍ផលិតកម្មផ្សេងៗ"[2820]។ ការដកស្រង់ដាច់ក្បាលដាច់កន្ទុយនេះគឺជាតឹកតាងបង្ហាញអំពីភាពលម្អៀងរបស់អង្គជំនុំជម្រះ ពីព្រោះទស្សនាវដ្ដីនេះបន្តទៀត ដោយគូសបញ្ជាក់អំពីសភាពការណ៍ពិសេសដែលទាមទារឱ្យគ្រប់គ្នាខិតខំស្ដារប្រទេស មួយរយៈសិន[2821]។ ដូច្នេះ អង្គជំនុំជម្រះមានចេតនាបំភ្លេចចោលប្រយោគនេះ។

១៤៩៧. អង្គជំនុំជម្រះក៏បានបង្កការភាន់ច្រឡំផងដែរ ដោយមិនគិតដល់ភាពខុសគ្នានៃការប្រើប្រាស់ពាក្យ "ខ្លាំង" ក្នុងឯកសាររបស់ ប.ក.ក អាស្រ័យទៅតាមការលើកឡើងអំពីសហករណ៍ នៅមុនខែមេសា ឆ្នាំ១៩៧៥

[2820] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៥ កំណត់សម្គាល់ជើងទំព័រលេខ ១២៩៧។

[2821] ទស្សនាវដ្ដី យុវជន និងយុវនារីបដិវត្ត ខែតុលា ឆ្នាំ១៩៧៥ ឯកសារ **E3/729** ERN 00063400-01៖ "គឺសហករណ៍ផលិតកម្មពាសពេញជនបទកម្ពុជាយើងនេះហើយដែលជាអ្នករ៉ាប់រងដោះស្រាយការលំបាកស្មុគស្មាញ និងការខ្វះខាតសព្វគ្រប់ជាបណ្ដោះអាសន្ននេះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ឬក្រោយខែមេសា ឆ្នាំ១៩៧៥[2822]។ ទស្សនាវដ្ដី "ទង់បដិវត្ត" ចេញផ្សាយឆ្នាំ១៩៧៦-១៩៧៧ ដែលអង្គជំនុំជម្រះបានដកស្រង់នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ១២៩៣៣ និយាយអំពីរយៈកាលពីឆ្នាំ ១៩៧០ ដល់ឆ្នាំ១៩៧៥។ ពាក្យ "ដណ្ដើមប្រជាជន" ត្រូវបានប្រើប្រាស់ ដើម្បីពន្យល់អំពីយុទ្ធសាស្ត្រយោធា ក្នុងពេលសង្គ្រាមប្រឆាំងនឹង លន់ នល់ ប្រឈមមុខនឹងកងទ័ពដែលត្រូវធ្វើឱ្យទន់ខ្សោយខាងយោធា[2823]។ ទស្សនាវដ្ដីលេខដដែលនេះក៏និយាយផងដែរអំពីតួនាទីរបស់សហករណ៍ ក្នុងការផ្គត់ផ្គង់ស្បៀងដល់សមរភូមិមុខ នៅសម័យនោះ។

១៤៩៨. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ពាក់ព័ន្ធនឹងការប្រើភ័ស្តុតាង។ ជាក់ស្ដែង អង្គជំនុំជម្រះបានប្រើប្រាស់សៀវភៅរបស់ Ben KIERNAN ដែលគ្មានតម្លៃជាភ័ស្តុតាង ពីព្រោះសាស្ត្រាចារ្យរូបនេះមិនព្រមមកផ្តល់សក្ខីកម្ម និងមិនអាចត្រូវបានសួរ ដេញដោលអំពីប្រភពរបស់គាត់[2824]។ អង្គជំនុំជម្រះក៏បានផ្អែកជាសំខាន់លើកំណត់ហេតុស្តាប់ចម្លើយដែលមានតម្លៃជាភ័ស្តុតាងតិចតួច ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីការផ្លាស់ទីលំនៅប្រជាជនក្រៅពីការផ្លាស់ទីលំនៅជនជាតិចាម[2825]។ ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញការសន្និដ្ឋានអំពីសហករណ៍ទាំងមូល ក្រៅពីសហករណ៍ត្រាំកក់ និងការដ្ឋានក្រៅវិសាលភាព[2826]។

១៤៩៩. ម្យ៉ាងវិញទៀត ដោយលើកឡើងខុសអំពីនិក្ខេបបទរបស់ ខៀវ សំផន ដើម្បីបង្ហាញអំពីការបង្ខិតបង្ខំនៅតាមសហករណ៍[2827] អង្គជំនុំជម្រះមិនយកចិត្តទុកដាក់លើគោលបំណងរបស់ ប.ក.ក តាមរយៈការ

---

[2822] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៧៧-៣៨៧៨។

[2823] ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ ឯកសារ **E3/25** ERN 00063040៖ "បើខ្មាំងគ្មានប្រជាជន វាគ្មានកម្លាំងយោធា គ្មានកម្លាំងសេដ្ឋកិច្ច"។

[2824] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៩៨ កំណត់សម្គាល់ជើងទំព័រលេខ ១២៩៩៥។ ចំពោះ Ben KIERNAN សូមមើលខាងលើផងដែរ កថាខណ្ឌ ១៤៥៨។

[2825] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៥។

[2826] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៧។

[2827] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៤។ ត្រង់ចំណុចនេះ សូមមើលខាងក្រោម កថាខណ្ឌ ១៦៥៣។

បង្កើតសហករណ៍។ ដូច្នេះ អង្គជំនុំជម្រះបានធ្វើការវិភាគដាក់បន្ទុកតែមួយមុខគត់ ខណៈដែលភស្តុតាងជាច្រើនបង្ហាញអំពីឆន្ទៈគិតគូរដល់ប្រជាជន។

១៥០០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានយល់ឃើញថា ការបែងចែករវាងប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន មានន័យថា ប្រជាជនថ្មីទទួលបានការយកចិត្តទុកដាក់តិចជាងប្រជាជនមូលដ្ឋាន។ ពិតមែនតែឆន្ទៈលុបបំបាត់វណ្ណៈសង្គមចាស់មិនអាចប្រកែកបាន នៅក្នុងឯកសារតម្រង់ទិសទី ៦ របស់ ប.ក.ក ក៏ដោយ[2828] ក៏មុនការដកស្រង់របស់អង្គជំនុំជម្រះ ឯកសារនេះបញ្ជាក់ថា "កសិករថ្មីមានអ្នករដ្ឋការ អនុធន ឈ្មួញ នាយទុនជាតិ-កុំប្រាដ័រ អភិជនចាស់។ [...] ទៅមុខទៀតយើងខំពង្រឹងសម្ព័ន្ធភាពកម្មករ-កសិករ ទាំងចាស់ ទាំងថ្មី"[2829]។

១៥០១. ដើម្បីសន្និដ្ឋានពីការបង្កើន "យុទ្ធនាការកាន់តែខ្លាំងឡើងក្នុងការក្តាប់ប្រជាជននៅតាមសហករណ៍" អង្គជំនុំជម្រះបានប្រើប្រាស់តាមបែបជ្រើសរើសតែខ្លឹមសារទស្សនាវដ្តី "ទង់បដិវត្ត" ដែលខ្លួនបានដកស្រង់[2830]។ អង្គជំនុំជម្រះបានប្រឹងប្រែងរំលេចឱ្យឃើញ "ភាពចាំបាច់ក្នុងការជំរុញផលិតផលកសិកម្ម និងបង្កើនការបង្កផលស្រូវឱ្យបានលឿន" ដើម្បី "ដោះស្រាយបញ្ហាកង្វះខាតទាំងអស់ក្នុងប្រទេស"[2831] និង "ការបំពេញគោលដៅសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងដែលបាន និងកំពុងធ្វើ"[2832] ដោយមិនបានប្រៀបធៀបជាមួយសេចក្តីណែនាំដល់អ្នកគ្រប់គ្រងសហករណ៍។

១៥០២. ថ្វីត្បិតតែមេធាវីការពារក្តីទទួលស្គាល់ថា ភាសា ក្នុងទស្សនាវដ្តី "ទង់បដិវត្ត" ទាំងនេះ ជួនកាល អាចមានភាពស្រពេចស្រពិល ក៏ដោយ ក៏មានប្រយោគច្បាស់លាស់ ដែលអង្គជំនុំជម្រះគួរណាតែដកស្រង់

---

[2828] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៩៥។

[2829] ឯកសារលេខ ៦៖ អំពីការម្ចាស់ការ និងការអនុវត្តមាគ៌ានយោបាយ និងការប្រមូលកម្លាំងរណសិរ្សជាតិ និងប្រជាធិបតេយ្យរបស់បក្ស ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ឯកសារ **E3/99** ERN 00072401 និង 00072403។

[2830] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩៨។

[2831] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៩-៣៨៩១។

[2832] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៩៣។

ក្នុងក្របខ័ណ្ឌនៃការវិភាគលើភ័ស្តុតាងដោយមិនលម្អៀង[2833]។ សេចក្តីណែនាំមិនត្រូវបានអនុវត្តជារឿងមួយ ប៉ុន្តែ ការលាក់បាំងការចេញសេចក្តីណែនាំទាំងនេះ គឺជាកំហុស ដែលធ្វើមោឃភាពដល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីគោលនយោបាយរបស់ ប.ក.ក។

## ១.២. សេចក្តីណែនាំស្តីពីសហករណ៍ ដែលត្រូវបានលាក់បាំង

១៥០៣. ប្រការទី ១ នៃសីលធម៌ ១២ ប្រការ របស់ ប.ក.ក គឺថា "ត្រូវស្រឡាញ់ គោរព និងបម្រើប្រជាជន កម្មករ កសិករ"[2834]។ ដូច្នេះ មានការប្រគល់ការទទួលខុសត្រូវដល់ប្រធានសហករណ៍ឱ្យគោរព "គោលការណ៍របស់បក្ស គឺដោះស្រាយជីវភាព" ប្រជាជន[2835]។ ដូច្នេះ សហករណ៍ត្រូវបានបង្កើតឡើង ជាអាទិភាព សម្រាប់ជាវិធីកែលម្អមធ្យោបាយផលិតកម្ម ដើម្បីរក "ត្រី សាច់ បន្លែបន្តុកបានច្រើន" និងជាទូទៅ ដើម្បីលើកកម្ពស់ជីវភាព[2836]។ ការលើកកម្ពស់ជីវភាពប្រចាំថ្ងៃត្រូវបានចាត់ទុកជា

---

[2833] ជាឧទាហរណ៍ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៩៨ កំណត់សម្គាល់ជើងទំព័រលេខ ១២៩៩៥។ ទស្សនាវដ្តីទង់បដិវត្ត ខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ ឯកសារ **E3/166** ERN 00063214-15៖ ("ដោយបច្ចុប្បន្ននេះ យើងក៏ពុំសូវសម្បូរថ្នាំពេទ្យសម័យប៉ុន្មានដែរ ក្នុងឋានៈជាដឹកនាំកម្មាភិបាលយើងត្រូវគិតគូរធ្វើថ្នាំបុរាណឱ្យបានច្រើន និងគ្រប់មុខ សម្រាប់ព្យាបាល និងថែរក្សាសុខភាពប្រជាជនយើង")។

[2834] François PONCHAUD *កម្ពុជាឆ្នាំសូន្យ* ឆ្នាំ២០០៥ (បោះពុម្ពលើកទី៣) ឯកសារ **E243.1** ទំព័រ ១៣១-១៣២ ERN 00862432-34។

[2835] កំណត់ហេតុអំពីទស្សនកិច្ចគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ ឯកសារ **E3/216** ERN 00008490។ កាតព្វកិច្ចនេះឃើញមាននៅក្នុងទស្សនាវដ្តីបដិវត្តៈ ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/750** ERN 00063604-05 ("ដូច្នេះ ជីវភាពរបស់ប្រជាជនយើងសព្វថ្ងៃ មានការខ្វះខាតសម្បើមណាស់ ខ្វះខាតទាំងកាស៊ីចុក ខ្វះខាតទាំងការស្លៀកពាក់ ខ្វះខាតទាំងមធ្យោបាយ និងឧបករណ៍បង្កបង្កើនផល ខ្វះខាតទាំងសម្ភារៈប្រើប្រាស់ផ្សេងៗ និងថ្នាំសង្កូវទៀតផង [...] យុវជន យុវនារីបដិវត្តយើង ត្រូវឃើញហើយយល់នូវការពិតជាក់ស្តែងនេះឱ្យច្បាស់លាស់។ ឃើញថាជីវភាពរបស់ប្រជាជនយើងបច្ចុប្បន្ន នៅលំបាកលំបិន ខ្វះខាតសព្វគ្រប់។ យើងឃើញដូច្នេះ មិនមែនដើម្បីមួម៉ៅទុទិដ្ឋិនិយម ឬបន្ទោសទម្លាក់កំហុសទៅលើអ្នកនេះ អ្នកនោះ ឬអង្គការនេះ ឬអង្គការនោះឡើយ។ យុវជនយុវនារីបដិវត្ត យើង ត្រូវឃើញការពិតជាក់ស្តែងនេះ ហើយឈឺចាប់ ក្នុងឋានៈជាអ្នកបម្រើប្រជាជន និងជាសាច់ឈាមរបស់ប្រជាជន ដើម្បីយើងមានវិធានការជាក់ស្តែង ហើយចុះប្រឡូកផ្ទាល់ ជួយដោះស្រាយជីវភាពប្រជាជនយើង ឱ្យអស់លទ្ធភាព" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2836] ទស្សនាវដ្តីទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ ឯកសារ **E3/5** ERN 00063350។

កាតព្វកិច្ចបដិវត្តន៍[2837]។ ប.ក.ក ចាត់ទុកកាតព្វកិច្ចបដិវត្តន៍ជាផ្នែកមួយនៃការការពារជាតិ ជាអាទិ៍ ពីព្រោះគោលបំណង គឺផ្សារភ្ជាប់ប្រជាជនទៅនឹងបដិវត្តន៍ និងការខំប្រឹងប្រែងរបស់ជាតិ ក្នុងគ្រាអាសន្ននេះ[2838]។

១៥០៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានពិនិត្យមើលភ័ស្តុតាងអំពីសេចក្ដីណែនាំរបស់ ប.ក.ក តែក្នុងគោលដៅដាក់បន្ទុក។ ជាក់ស្ដែង អង្គជំនុំជម្រះបានយល់ឃើញថា ថ្នាក់ដឹកនាំបក្សមិនខ្វល់ពីល័ក្ខខ័ណ្ឌរស់នៅលំបាកវេទនាដែលគេរាយការណ៍ជូនទេ[2839] ប៉ុន្តែ ពេលមានការចាត់វិធានការជាក់ស្ដែង ដូចជា ពេលម៉ោងធ្វើការ ជាដើម អង្គជំនុំជម្រះបានសន្និដ្ឋានថា [ថ្នាក់ដឹកនាំបក្សបានដឹងថា] អ្នកធ្វើការត្រូវបានបង្ខំឱ្យធ្វើការ ដោយមិនគោរពតាមពេលវេលាកំណត់ ហើយគ្មានពេលសម្រាក”[2840]។

១៥០៥. ប៉ុន្តែ ទស្សនាវដ្ដី “ទង់បដិវត្ត” បានរៀបរាប់លម្អិតពីការចាត់វិធានការជាក់ស្ដែង ចំពោះប្រជាជន ក្នុងគោលដៅស្វែងរកដំណោះស្រាយ ដើម្បីជម្នះការលំបាកខាងការដាំដុះ ចិញ្ចឹមសត្វ មធ្យោបាយស្លៀកពាក់ និងទីលំនៅ[2841]។ ថ្វីត្បិតតែការចែករបបអាហារមានភាពចាំបាច់ដោយសារតែភាពខ្វះខាតក៏

[2837] ទស្សនាវដ្ដីទង់បដិវត្ត ខែតុលា-ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/748** ERN 00063258៖ “ត្រូវឃើញភារកិច្ចដោះស្រាយជីវភាពប្រជាជនជាភារកិច្ចមូលដ្ឋានយូរអង្វែងរហូតទៅ”។

[2838] ទស្សនាវដ្ដីទង់បដិវត្ត ខែតុលា-ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/748** ERN 00063260-61។ ទស្សនាវដ្ដីទង់បដិវត្ត ខែវិច្ឆិកា ឆ្នាំ១៩៧៦ ឯកសារ **E3/139** ERN 00064965-66 (“ហេតុអីបានជាបក្សកំណត់១៣ថាំង។ មកពីមានន័យសេដ្ឋកិច្ច និងនយោបាយ។ សំណូមពរគឺឱ្យប្រជាជនហូបគ្រប់គ្រាន់។ សម័យមុនរាប់សតវត្សមកហើយ ប្រជាជនពលករមិនដែលបានហូបឆ្អែតទេ។ ក្នុងសង្គ្រាមប្រជាជនត្រូវទ្រាំទ្រនូវការលំបាកវេទនាច្រើន ខ្វះមុខ ខ្វះក្រោយ។ ក្រោយរំដោះហើយឆ្នាំ១៩៧៥-១៩៧៦ ក្នុងរយៈពេល១ឆ្នាំកន្លះប្រជាជនក៏នៅតែខ្វះខាតទៀត។ ដូច្នេះហើយបានជាយើងខិតខំបង្កបង្កើនផលស្រូវឆ្នាំ១៩៧៦ នេះគឺដើម្បីផ្គត់ផ្គង់ប្រជាជនឱ្យបានគ្រប់គ្រាន់។ បើប្រជាជនបានហូបគ្រប់គ្រាន់ហើយ ប្រជាជនកក់ក្ដៅ ហើយជំរុញចលនាបដិវត្ត សង្គមនិយម និងកសាងសង្គមនិយមអោយកាន់តែលោតផ្លោះ”)។

[2839] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០០។

[2840] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១០-៣៩១១។

[2841] ទស្សនាវដ្ដីទង់បដិវត្ត ខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ ឯកសារ **E3/166** ERN 00063214-15។

ដោយ ក៏សេចក្តីណែនាំតម្រូវឱ្យធ្វើគ្រប់បែបយ៉ាង ដើម្បីកែលម្អស្ថានការណ៍[2842]។ ដូច្នេះ ការប្រើប្រាស់ប្រជាជនជាកម្លាំងធ្វើការ មិនមែនជាឆន្ទៈដាក់ឱ្យទៅជាទាសករទេ គឺជាជំហានធ្វើឱ្យប្រទេសរស់រានមានជីវិត ក្នុងគ្រាអាសន្ននេះ។ អាស្រ័យហេតុនេះ សូម្បីតែទាហានក៏ត្រូវបានចាត់ឱ្យធ្វើស្រែចម្ការ និងធ្វើសំណង់ដែរ[2843]។

## ១.៣. កំហុសពាក់ព័ន្ធនឹងការនាំចេញអង្ករ

[2842] ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/750** ERN 00063609៖ ("២. ចំពោះយុវជនយុវនារីបដិវត្តដែលនៅធ្វើការតាមមូលដ្ឋានឃុំភូមិ និងសហករណ៍នានា ត្រូវចុះប្រឡូកធ្វើពលកម្មជាមួយសមាជិកសហករណ៍ ហើយមានជីវភាពរស់នៅ ស៊ីចុកជាមួយប្រជាជន ក្នុងសហករណ៍តែម្តង មិនបាច់មានមន្ទីរ មានរបបដោយឡែកពីប្រជាជនឡើយ"។ ERN 000632611៖ ("ដូច្នេះ យុវជនយុវនារីបដិវត្តយើង ត្រូវទុកភារកិច្ចដោះស្រាយជីវភាពជូនប្រជាជនជាភារកិច្ចប្រចាំថ្ងៃរបស់ខ្លួន ហើយផ្សារភ្ជាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនទៅនឹងជីវភាពប្រជាជនជានិច្ច ក្នុងគ្រាស្រួល ក៏ដូចជាក្នុងគ្រាលំបាក" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ទស្សនាវដ្តីទង់បដិវត្ត ខែកក្កដា ឆ្នាំ១៩៧៦ ឯកសារ **E3/738** ERN 00062915-16៖ (ការសម្រេចភារកិច្ចបីគោនមួយហិចតា កែលម្អជីវភាពប្រជាជន៖ ១. តំរង់រកដីដែលល្អ ដែលខ្លាញ់, ២. បញ្ហាទឹក, ៣. អំពីការបង្កបង្កើនផលស្រូវ២ដងក្នុង១ឆ្នាំ៖ ដើម្បីជំរុញការកសាងសង្គមនិយមរបស់យើងឱ្យបានឆាប់រហ័សជាអតិបរមា ក៏ដូចជាដើម្បីការពារប្រទេស និងលើកកម្ពស់ជីវភាពប្រជាជនយើងបានល្អប្រពៃណីឆាប់រហ័ស, ៤. អំពីដំណាំផ្សេងៗ៖ ដើម្បីដោះស្រាយជីវភាពប្រជាជនចំពោះមុខផង និងយូរអង្វែងតទៅទៀតផង ហើយជាពិសេសយកចិត្តទុកដាក់លើដំណាំដែលអាចឱ្យផលនាំចេញទៅលក់ក្រៅប្រទេស, ៥. អំពីកម្លាំងពលកម្ម និងឧបករណ៍ផលិតកម្មកសិកម្ម៖ ដូច្នេះយកចិត្តទុកដាក់អំពីសុខភាព និងជីវភាពប្រជាជនឱ្យជិតដល់ និងចុះជានិច្ច" (យើងគូសបន្ទាត់ពីក្រោម))។ សូមមើលផងដែរ ទស្សនាវដ្តីទង់បដិវត្ត ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/166** ERN 00063206 និង 00063230-31 (ស្តីពីការទិតៀនចំពោះកម្មាភិបាលមូលដ្ឋានដែលមិនបានយកចិត្តទុកដាក់ដល់ប្រជាជន)។ ទស្សនាវដ្តីទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារ E3/215 ERN 00064618 (ស្តីពីភាពចាំបាច់ក្នុងការកែលម្អល័ក្ខខ័ណ្ឌជីវភាព និងគិតគូរដល់សុខភាពប្រជាជន)។ ទស្សនាវដ្តីទង់បដិវត្ត ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/745** ERN 00064452-53 (អំពីការចាត់វិធានការចំពោះបញ្ហាខ្វះខាតអាហារ) ទស្សនាវដ្តីទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៦ ឯកសារ **E3/762** ERN 00063298-99 (សារៈសំខាន់នៃការកសាងប្រទេស៖ "ត្រូវដោះស្រាយជីវភាពប្រជាជនយើងឱ្យឆាប់រហ័ស")។

[2843] ទស្សនាវដ្តីទង់បដិវត្ត ខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ ឯកសារ **E3/166** ERN 00063215។ គួរកត់សម្គាល់ថាកងទ័ពត្រូវមានកង្វល់ដូចគ្នា៖ កំណត់ហេតុអង្គប្រជុំកងទ័ព ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦ ឯកសារ **E3/804** ERN 00382609។ សូមមើលផងដែរ របាយការណ៍របស់ញឹម ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ ឯកសារ **E3/950** ERN 00021044។ របាយការណ៍របស់ញឹម ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៨ ឯកសារ **E3/863** ERN 00076286។

១៥០៦. អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា ការនាំចេញអង្ករ និងទិន្នផលស្រូវ "បីតោន ក្នុងមួយហិចតា" ត្រូវបានកំណត់ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយដែលមិនខ្វល់ពីប្រជាជន និងដោយសារតែភាពខ្វះខាតនៅតាមសហករណ៍[2844]។ អង្គជំនុំជម្រះបានធ្វើមិនដឹងមិនឮចំពោះភ័ស្តុតាងបង្ហាញអំពីគោលបំណងនៃការនាំចេញកសិផល ដែលជាមធ្យោបាយតែមួយគត់ក្នុងការទប់ទល់នឹងអវត្តមានឧស្សាហកម្ម និងរូបិយប័ណ្ណ និងដើម្បីទិញផលិតផលចាំបាច់សម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាជន ដូចជាឱសថជាដើម[2845]។ ក្នុងន័យនេះ ការដោះដូរពាណិជ្ជកម្មជាមួយប្រទេសសម្ព័ន្ធមិត្ត គឺជារឿងសំខាន់ ដើម្បីចែកចាយទំនិញទៅតាមភូមិភាគ[2846]។

១៥០៧. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមានចេតនាបំភ្លេចចោលឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញថាអង្ករសម្រាប់នាំចេញ គឺបានមកពីការបង្កបង្កើនផលលើសសេចក្តីត្រូវការ[2847]។ ឯកសារទាំងនេះមានភាពស៊ីចង្វាក់គ្នានឹងសក្ខីកម្មអំពីរបាយការណ៍ក្លែងក្លាយធ្វើពីមូលដ្ឋាន ជូនមេដឹកនាំ ប.ក.ក

---

[2844] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០១-៣៩០៨។

[2845] កំណត់ហេតុអំពីទស្សនកិច្ចគណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ ឯកសារ **E3/216** ERN 00008491។ កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ស្តីពី "គម្រោងផែនការបួនឆ្នាំកសាងសង្គមនិយមគ្រប់ផ្នែករបស់បក្ស ឆ្នាំ១៩៧៧-ឆ្នាំ១៩៨០" ថ្ងៃទ២១ ខែកក្កដា-ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ ឯកសារ **E3/213** ERN 00075827-28។ អត្ថបទក្រោមចំណងជើងថា "កម្ពុជាឆ្នាំរំដោះ" ដោយលោក François PONCHAUD ខែមករា ឆ្នាំ១៩៧៦ ឯកសារ **E3/4589** ERN 00323722។ អំពីថ្នាំសង្កូវ៖ បទសម្ភាស៍ជាមួយ ខូ វណ្ណី ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៥ ឯកសារ **E3/5659** ERN 00602360-61។ កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ **E3/35** ERN 00340564។

[2846] ទស្សនាវដ្តីទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៦ ឯកសារ **E3/762** ERN 00063301៖ ("វត្ថុធាតុដើម យើងនៅខ្វះខាតខ្លះ ត្រូវទិញពីក្រៅ")។ ទស្សនាវដ្តីទង់បដិវត្ត ខែមីនា ឆ្នាំ១៩៧៨ ឯកសារ **E3/745** ERN 00064452-53 (ការនាំចេញបន្ទាប់ពីបានទូទាត់នូវស្បៀងដើម្បីអាចនាំចូលវត្ថុធាតុដើមផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្ម និងជីវភាពប្រជាជន)។ សូមមើលឧទាហរណ៍ស្តីពីការផ្លាស់ប្តូរទំនិញ នៅខាងក្រោម កថាខណ្ឌ ១៧៧៨។

[2847] ទស្សនាវដ្តីទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062765។ ទស្សនាវដ្តីទង់បដិវត្ត ខែតុលា-ខែវិច្ឆិកា ឆ្នាំ១៩៧៧ ឯកសារ **E3/737** ERN 00064820។ កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** ERN 00017121 ("ស្នើសុំចំនួនស្រូវពិតប្រាកដ ខាងលើដឹងចំនួនដើម្បីងាយចាត់ចែង។ ម្យ៉ាងសម្រាប់ដោះស្រាយ ជីវភាពប្រជាជន តែម្យ៉ាងទៀតក៏គិតគូរលក់ដូរដែរ។ (...) ឯ ១០៣ ពីមុនអង្គការសម្រេចយក ១០០០ តោន ឥឡូវយកតែ ៥០០ តោនទេ។ ចំនួននេះក៏ទុកនៅកន្លែងនោះសិនចុះដើម្បីបម្រុងក្រែងខ្វះខាត")។

ស្តីពីអតិរេក និងការលាក់បាំងបញ្ហាខ្វះខាត នៅតាមសហករណ៍ ដែលធ្វើឱ្យមេដឹកនាំ មិនអាចដឹងឮពិតប្រាកដអំពីស្ថានភាពនៅតាមមូលដ្ឋាន[2848]។

១៥០៨. អាស្រ័យហេតុនេះ តាមរយៈការអានគ្រប់ជ្រុងជ្រោយលើកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ក្នុងការសន្និដ្ឋានថា "ការវាយ

---

[2848] ញឹប ហល់៖ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ **E1/336.1** មុនម៉ោង 10.51.13។ ម៉ម សឿន ហៅ ហេង សាមុត៖ ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ **E1/324.1** ក្រោយម៉ោង 15.37.03។ ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ **E1/325.1** ក្រោយម៉ោង 10.42.27។ នង សុផង់ ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/123.1** ម៉ោង 09.47.57៖ ("ខ្ញុំឃើញសារខ្លះកន្លែងខ្លះ គេរាយការណ៍ថា មកមួយហិកតាបីបួនតោន ប្រាំតោន រហូតមានកន្លែងខ្លះ មានដល់មួយហិកតាដប់តោនឯណោះ។ ចុះបើបានផលច្រើនម្ល៉េះៗ ចុះហេតុអ្វីបានជាប្រជាជនយើងនៅហូបបបរអ៊ីចឹង។ អានេះ ជាចំណោទឱ្យខ្ញុំនៅក្នុងសម័យនោះ។ ខ្ញុំគិតខ្លួនឯងទេ។ ហើយដល់ខ្ញុំឃើញសំណួររបស់អស់លោកអ៊ីចឹងទៅ ខ្ញុំជាការវិភាគឱ្យខ្ញុំថា ប្រហែលជាមានមនុស្សខ្លះហ្នឹង ចង់បានមុខ ចង់បានមាត់ បានជារាយការណ៍ក្នុងសារទូរលេខហ្នឹង វាបានសម្បូរសប្បាយ ការរីកចម្រើន តែផ្ទុយទៅវិញ មានរីកចម្រើនឯណា គឺថាសូម្បីតែការស្លៀកពាក់ ការហូបចុកមិនគ្រប់គ្រាន់ផង"។) និងនៅម៉ោង 09.49.59 គាត់បន្ថែមថា៖ ("ហើយខ្ញុំឃើញសារទូរលេខខ្លះ ដែលខ្ញុំបកហ្នឹង គឺជូនកាលអង្គការបញ្ជូនសម្ភារៈទៅជាអង្ករ ជាក្រណាត់អីច្រើនណាស់។ លោក ខៀវ សំផន ហ្នឹងចាត់ទៅក្នុង១ខែៗមិនដឹងប៉ុន្មានដងទេ។ តែប្រជាជន ទាំងអស់នោះ មិនបានទទួលការស្លៀកពាក់ដោយសមរម្យ ហើយឧបមា ដូចបញ្ជូនម៉ាស៊ីនដេរហ្នឹងទៅ វាយកគ្រល់ហ្នឹងចោលអស់រលីង ដូច្នេះដេរវាមិនកើត អាហ្នឹង។ នេះជា ទាំងអស់នោះជាអ្វីដែលជាបញ្ជាំង ឱ្យឃើញនូវជីវភាពប្រជាជនផង នូវបញ្ជាំងឱ្យឃើញនូវអាកប្បកិរិយារបស់អស់លោកនៅតាមមូលដ្ឋានហ្នឹងផង")។ សូមមើលផងដែរ បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជាថៃ ដោយ Masato MATSUSHITA និង Stephen HEDER ខែកុម្ភៈ-មីនា ឆ្នាំ១៩៨០ ឯកសារ **E3/1714** ERN 00324687 ("យើងយល់ឃើញថាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើននោះ គឺក្នុងសហករណ៍នីមួយៗ ត្រូវបានគេសន្មតថាជាសង្គមតូចមួយដែលពឹងអាស្រ័យលើខ្លួនឯង ហើយថាគ្រប់សហករណ៍ទាំងអស់ត្រូវផ្តល់ស្ថិតិអំពីការបង្កបង្កើនផលស្រូវ ចំនួនប្រជាជន និងតម្រូវការរបស់ប្រជាជនជូនទៅថ្នាក់លើ។ ចំនួនស្រូវដែលត្រូវបញ្ជូនទៅរដ្ឋ គឺជាការទទួលខុសត្រូវតែមួយគត់របស់ប្រធានសហករណ៍នីមួយៗ ប៉ុន្តែប្រធានសហករណ៍ជាច្រើនបានបំប៉ោងតួលេខផលិតផល ដើម្បីធ្វើឱ្យបក្សមើលទៅ ពួកគេថាជាមនុស្សល្អ ហើយពួកគេបានបញ្ជូនស្រូវទៅឱ្យរដ្ឋយ៉ាងច្រើន រហូតដល់ធ្វើឱ្យប្រជាជនខ្វះខាតអង្ករបរិភោគ")។ អត្ថបទដកស្រង់ពីសៀវភៅរបស់ R. A. BURGLER, *The eyes of the pineapple (ភ្នែកម្នាស់)* ឆ្នាំ១៩៩០ ឯកសារ **E3/7260** ERN FR 01238473។ សូមមើលផងដែរ សេចក្តីអះអាងរបស់សម្តេច សីហនុ នៅក្នុងបទសម្ភាសន៍ដែលបានផ្សព្វផ្សាយនៅក្នុងពេលពិភាក្សាដេញដោលបញ្ចប់នៅក្នុងសំណុំរឿង ០០២/០១៖ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E1/234.1** ទំព័រ ៤៨-៥១ ចន្លោះម៉ោង 11.00.32 និងម៉ោង 11.06.27។ គាត់បានផ្តល់សក្ខីកម្មថានៅពេលទស្សនកិច្ចជាផ្លូវការ (ភាគច្រើនសុទ្ធតែមាន លោក ខៀវ សំផន អមដំណើរ) អ្នកដែលគាត់ឃើញ "មើលទៅដូចថា មិនមានការភ័យខ្លាច អត់មានការហូបចុកខ្វះ មិនគ្រប់គ្រាន់អីទេ គឺមើលទៅដូចជាសុខភាពល្អ" ។

ការណ៍ [...] ទៅមន្ទីរ ៨៧០” និងអត្ថិភាពនៃទូរលេខ មានន័យថា មេដឹកនាំ ប.ក.ក ដឹងពីអ្វីដែលបានកើតឡើងនៅតាមសហករណ៍[2849]។ ករណីនេះមិនមែនអ៊ីចឹងទេ ហើយរឿងនិទានអំពីការគ្រប់គ្រងពី “មជ្ឈិមបក្ស” ទៅលើរាល់អ្វីៗដែលបានកើតឡើងនៅក្នុងប្រទេស មិនត្រូវគ្នានឹងភាពវឹកវរ និងភាពរញ៉េរញ៉ៃ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះឡើយ។

១៥០៩. ដូច្នេះ សេចក្តីសន្និដ្ឋានសមហេតុផលមួយទៀត គឺថា គណៈអចិន្ត្រៃយ៍ និង ប.ក.ក មិនដឹង និងក្តាប់មិនបាននូវអ្វីដែលបានកើតឡើងនៅក្នុងប្រទេសនោះឡើយ។ ការបញ្ជូន មាស វឿន នៅឆ្នាំ១៩៧៨ ទៅខេត្តព្រះវិហារ គឺជាឧទាហរណ៍ល្អឥតខ្ចោះបង្ហាញអំពីអវត្តមានការគ្រប់គ្រងពិតប្រាកដរបស់ទីក្រុងភ្នំពេញទៅលើផ្នែកផ្សេងទៀតនៃប្រទេស[2850]។ សក្ខីកម្មរបស់គាត់ត្រូវបានប្រើប្រាស់ខុស ដើម្បីបង្ហាញអំពីការដឹងរបស់ ខៀវ សំផន អំពីល័ក្ខខ័ណ្ឌពិតប្រាកដ នៅតាមសហករណ៍ ឬដើម្បីលើកឡើងអំពីការបោសសម្អាត[2851]។

១៥១០. កំហុសត្រួតគ្នារបស់អង្គជំនុំជម្រះ នៅក្នុងការវិភាគភ័ស្តុតាង បានបង្កព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ។ តាមរយៈសេចក្តីលម្អៀង អង្គជំនុំជម្រះបានធ្វើឱ្យសេចក្តីសន្និដ្ឋានទាំងអស់របស់ខ្លួនអំពីគោលនយោបាយបង្កើតសហករណ៍ និងការដ្ឋាន ក្លាយជាមោឃៈ។

## ២. កំហុសអំពីតួនាទីរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងសហករណ៍

### ២.១. កំហុសពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន

---

[2849] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៩៩។

[2850] <u>មាស វឿន</u>៖ ប្រតិចារិក ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/130.1** ចន្លោះម៉ោង [14.02.20 និងម៉ោង [14.08.42]។ មាស វឿន ត្រូវបានបញ្ជូនទៅតំបន់ព្រះវិហារ នៅចុងឆ្នាំ១៩៧៨ បន្ទាប់ពីមានសកម្មភាពបំពានលើប្រជាជនរបស់ កង ចាប ប្រធានភូមិភាគឧត្តរ។ នៅក្នុងពេលសម្ភាសន៍ជាមួយ ប៉ុល ពត នោះ កង ចាប បានស្នើសុំអង្កេតលើរឿងរ៉ាវដែលបានកើតឡើង ដែលនាំឱ្យគេមើលឃើញថាមិនមានការក្តាប់ស្ថានភាពបានល្អទេ។

[2851] សូមមើលខាងក្រោម កថាខណ្ឌ ១៨៣៤-១៨៣៥។

១៥១១. ក្នុងសេចក្តីសន្និដ្ឋានអំពីសហករណ៍ អង្គជំនុំជម្រះមានចេតនាលម្អសំអាងហេតុសាលក្រមទៅដោយការយោងទៅរកសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ។ ប៉ុន្តែសេចក្តីថ្លែងការណ៍ទាំងនេះភាគច្រើនធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[2852]។

១៥១២. ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានអំពីគោលនយោបាយរបស់ ប.ក.ក នៅមុនឆ្នាំ១៩៧៥ ពាក់ព័ន្ធនឹងការក្តាប់ប្រជាជន អង្គជំនុំជម្រះបានធ្វើការដកស្រង់មួយពីសៀវភៅរបស់ម្ចាស់បណ្តឹងសាទុក្ខ[2853] ដោយចៀសវាងលើកឡើងនៅក្នុងសៀវភៅនោះថា គាត់បានបញ្ជាក់ជាច្រើនដងថា គាត់បានធ្វើការស្រាវជ្រាវ ដើម្បីស្វែងយល់រឿងរ៉ាវដែលគាត់មិនបានដឹង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2854]។ ការកត់សម្គាល់ដូចគ្នានេះមានសុពលភាព សម្រាប់ការពិចារណារបស់គាត់លើការជម្លៀស ក្នុងសៀវភៅមួយទៀត ចុះកាលបរិច្ឆេទឆ្នាំ២០០៤[2855]។ ដូចគ្នាផងដែរ ក្នុងការប្រើប្រាស់កិច្ចសម្ភាសន៍ក្រោយអង្គហេតុ ប៉ុន្តែមិនមានចុះកាលបរិច្ឆេទ ពាក់ព័ន្ធនឹងលក្ខណៈបង្ខិតបង្ខំនៃសហករណ៍[2856] អង្គជំនុំជម្រះមានចេតនាមិនបង្ហាញថា ខៀវ សំផន បានបញ្ជាក់ថាគាត់បានធ្វើការត្រិះរិះពិចារណា ក្រោយរបបនោះ[2857]។

១៥១៣. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយទទួលយកសុន្ទរកថា ខៀវ សំផន ក្នុងឱកាសរំឭកខួប ១៧ មេសា ដែលក្នុងនោះ គាត់ "បានកោតសរសើរដល់ជ័យជម្នះនៃការបង្កបង្កើនផលកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងវិស័យសង្គម" ព្រមទាំងគោលដៅបង្កបង្កើនផលស្រូវបន្ថែម ទុកដូចជាគ្រប់

---

[2852] សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៨២៩-១៨៤០។

[2853] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៧៧ កំណត់សម្គាល់ជើងទំព័រលេខ ១២៩៣៥។

[2854] លោក ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ E3/3855 ទំព័រ ២០៧ ERN 00380441៖ "ចំពោះបញ្ហានេះ ខ្ញុំអាចឆ្លើយបានតែខ្លះៗនៅឡើយទេ។ ប៉ុន្តែខ្ញុំយល់ថា ការរកឃើញរបស់ខ្ញុំ ពិតមែនតែមិនទាន់ពេញលេញ អាចមានប្រយោជន៍ដែរ ក្នុងន័យថា វាអាចជាតម្រុយដើម្បីបើកឱ្យមានការស្រាវជ្រាវបានវែងឆ្ងាយថែមទៀត ដោយឈរលើការដែលអ្នកស្រាវជ្រាវពីមុនមក បានរកឃើញច្រើនណាស់មកហើយ តែចាំបាច់ត្រូវស្រាវជ្រាវឱ្យបានសត្យានុម័តិ កុំឱ្យទោរទន់តាមការលម្អៀង ឬតាមការស្អប់ ឬការខឹងសម្បារ"។

[2855] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៧៩ កំណត់សម្គាល់ជើងទំព័រលេខ ១២៩៣៩ ដែលស្រង់សម្តីពីក្នុងស្នាដៃ លោក ខៀវ សំផន *ប្រវត្តិសាស្ត្រ កម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឆ្នាំ២០០៤ ឯកសារ E3/18។

[2856] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៤-៣៨៨៥ កំណត់សម្គាល់ជើងទំព័រលេខ ១២៩៦២។

[2857] ចំពោះបទសម្ភាសន៍នេះ សូមមើលខាងក្រោម កថាខណ្ឌ ១៨១៧-១៨២៨។

គ្រាន់ឱ្យកំណត់ចរិតលក្ខណៈនៃឆន្ទៈប្រព្រឹត្តឧក្រិដ្ឋកម្ម នៅតាមសហករណ៍[2858]។ អង្គជំនុំជម្រះមិនបានពិចារណាសុន្ទរកថានេះ ក្នុងបរិបទនៃការប្រារព្ធខួបបដិវត្តន៍របស់ប្រមុខរដ្ឋមានតែឈ្មោះ។ គោលជំហរម៉ាក្សនិយមក្នុងការ "ចាត់ទុកផលប្រយោជន៍បុគ្គលសំខាន់តិចជាងផលប្រយោជន៍សមូហភាពរបស់ជាតិ វណ្ណៈ ប្រជាជន និងបដិវត្តន៍" មិនអាចឱ្យសន្និដ្ឋានថា គោលនយោបាយមានលក្ខណៈឧក្រិដ្ឋបានឡើយ[2859]។ លើសពីនេះទៀត អង្គជំនុំជម្រះខកខានមិនបានរំឭកថា ការលើកសរសើរពីភាពជឿនលឿនរបស់ប្រទេសកើតឡើង តែប៉ុន្មានសប្តាហ៍ក្រោយពេលចាប់ផ្តើមសង្គ្រាមជាចំហជាមួយវៀតណាម[2860]។

## ២.២. កំហុសពាក់ព័ន្ធនឹងការចូលរួមចំណែករបស់ ខៀវ សំផន

១៥១៤. ក្រៅពីការប្រើប្រាស់មិនសមរម្យនូវសេចក្តីថ្លែងការណ៍ក្រោយអង្គហេតុ និងប្រាសចាកពីបរិបទ ដើម្បីសន្និដ្ឋានថាម្ចាស់បណ្តឹងសាទុក្ខបានដឹងអំពីឧក្រិដ្ឋកម្ម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន ស្ថិតក្នុងចំណោមមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ខណៈដែលតួនាទីរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ គ្រាន់តែជាពិធីការប៉ុណ្ណោះ[2861]។ យើងនឹងឃើញនៅខាងក្រោមថាមុខងារផ្សេងទៀតរបស់គាត់គឺស្ថិតក្នុងវិស័យមានកម្រិត។ វត្តមានគាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍មិនបានផ្តល់ឋានៈឱ្យគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍ទេ[2862]។

១៥១៥. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមិនខ្លាចនឹងទាយស្មានអំពីអ្វីដែលម្ចាស់បណ្តឹងសាទុក្ខបានដឹង តាមរយៈកិច្ចប្រជុំមួយ ដែលគាត់គ្មានវត្តមាន៖

> "ទោះបីជាមិនមានភស្តុតាងគ្រប់គ្រាន់សម្រាប់បង្ហាញឱ្យស្របទៅនឹងបទដ្ឋានចាំបាច់ថា នួន ជា ឬ ខៀវ សំផន បានចូលរួមក្នុងដំណើរទស្សនកិច្ច នៅខែសីហា ឆ្នាំ១៩៧៥ ទៅកាន់ភូមិភាគ

[2858] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០៩។

[2859] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០៩។

[2860] សូមមើលខាងលើ កថាខណ្ឌ ១៤៦៥-១៤៧២។

[2861] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៤។

[2862] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៤, ៣៨៩១។

ពាយ័ព្យ ក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ដោយសារមុខតំណែងជាន់ខ្ពស់របស់ពួកគាត់ក្នុងបក្ស ពួកគាត់បានដឹងអំពីរបាយការណ៍ ហើយបានចូលរួមក្នុងការបង្កើតផែនការ និងគោលនយោបាយ ដែលឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នោះ”[2863]។

១៥១៦. គ្មានភ័ស្តុតាងណាមួយអាចឱ្យអង្គជំនុំជម្រះឈានដល់ការសន្និដ្ឋានបែបនេះឡើយ ដែលនឹងត្រូវទុកជាមោឃៈ។ ដំណើរការខុសឆ្គងនេះក៏ដូចគ្នាផងដែរ ចំពោះឯកសារ ឆ្នាំ១៩៧៥[2864]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ក្នុងការអះអាងថា ខៀវ សំផន បានដឹងអំពីល័ក្ខខ័ណ្ឌរស់នៅតាមមូលដ្ឋានដោយសារតែ “របាយការណ៍ផ្ញើជូនថ្នាក់លើ”[2865]។ ក្រៅពីកំហុសពាក់ព័ន្ធនឹងវិធីទំនាក់ទំនង និងចំណុចលើបញ្ហាស្មោះត្រង់នៃរបាយការណ៍បែបនេះ[2866] អង្គជំនុំជម្រះគួរណាតែបង្ហាញថា ការដឹងពីល័ក្ខខ័ណ្ឌលំបាកវេទនារបស់ប្រទេស និងប្រជាជន គឺជាការសង្កេតឃើញមុនការបង្កើតសហករណ៍ ក្នុងគោលដៅស្វែងរកដំណោះស្រាយ។ វិធីបង្ហាញការជឿជាក់ ដោយមិនផ្អែកលើភ័ស្តុតាងរឹងមាំ បានតម្រង់ទិសសេចក្តីសន្និដ្ឋានជាច្រើនពាក់ព័ន្ធនឹងការដឹងរបស់ ខៀវ សំផន ពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[2867]។ ការស្មាន ការសន្មត និងការជឿជាក់ ឈរលើការការបូកសរុបរួម មិនត្រូវគ្នានឹងវិចារណកិច្ចរបស់តុលាការអនាគតិនោះទេ និងមិនអាចឱ្យធ្វើការផ្តន្ទាទោសបាននោះឡើយ។

១៥១៧. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានកំណត់មិនត្រឹមត្រូវថា ខៀវ សំផន ជាប្រធានសមាជជាតិ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ ដើម្បីសន្និដ្ឋានថាគាត់បានចូលរួមចំណែកក្នុងគោលនយោបាយស្តីពីសហករណ៍ ដែលមានលក្ខណៈឧក្រិដ្ឋ។ អង្គជំនុំជម្រះភាន់ច្រឡំអត្តសញ្ញាណប្រធាន

---

[2863] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2864] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៩១។ អង្គជំនុំជម្រះបានសន្និដ្ឋានថា “ទោះបីជាឯកសារគោលនយោបាយខែកញ្ញាឆ្នាំ ១៩៧៥ មិនបានបញ្ជាក់ឈ្មោះអ្នកដែលបានរៀបរៀងឯកសារនេះ ឬអ្នកដែលទទួលខុសត្រូវចំពោះផែនការ និងគោលនយោបាយដែលបានកំណត់នេះក៏ដោយ ក៏ឯកសារនេះបានបង្ហាញច្បាស់ថាគោលបំណងសំខាន់គឺការពិនិត្យមើលការអនុវត្តមាគ៌ាបក្សក្នុងការកសាងប្រទេសក្រោយពេលរំដោះ” (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2865] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៣។

[2866] សូមមើលខាងលើ កថាខណ្ឌ ១៥០៦-១៥០៨ និងខាងក្រោម កថាខណ្ឌ ១៦២៥-១៦២៦។

[2867] សូមមើលខាងក្រោម កថាខណ្ឌ ១៨០៨-១៩៣៧។

អង្គប្រជុំ ប៉ុន្តែគ្មានតម្រុយណាមួយក្នុងខ្លឹមសារសមាជ និងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ អាចឱ្យសន្និដ្ឋានអំពីការតាក់តែងគោលនយោបាយឧក្រិដ្ឋបានឡើយ[2868]។ ដូចគ្នាផងដែរ ឈរលើសក្ខីកម្មច្របូកច្របល់ ផ្ទុយគ្នា និងមិនអាចជឿជាក់បាន អង្គជំនុំជម្រះបានសន្និដ្ឋានថា ខៀវ សំផន បានចូលរួមចំណែកផ្សព្វផ្សាយសុន្ទរកថាប្រឆាំងខ្មាំង ក្នុងវគ្គរៀនសូត្រ[2869]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនបានបង្ហាញថា ហេតុអ្វីបានជាផែនការសេដ្ឋកិច្ចរបស់ ប.ក.ក ក្នុងការប្រតិបត្តិការសហករណ៍ មិនអាចកាត់ផ្តាច់ចេញពីគោលនយោបាយនេះ។

## ៣. កំហុសពាក់ព័ន្ធនឹងលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយ

១៥១៨. ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងអំពីអង្គហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើប្រជាជនថ្មី ក្រៅពីឃុំទាំងប្រាំបីនៅស្រុកត្រាំកក់[2870] អង្គហេតុនៃ "ការប្រព្រឹត្តិរើសអើង" ទៅលើប្រជាជនថ្មីនៅត្រាំកក់[2871] អង្គហេតុតាមដាន និងធ្វើឱ្យបាត់ខ្លួនចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅត្រាំកក់[2872] អង្គហេតុប្រឆាំងនឹងពុទ្ធសាសនិកនៅត្រាំកក់[2873] អង្គហេតុនៃការសម្លាប់នៅវត្តបារាយណ៍ជាន់ដែក[2874] អង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុនយោបាយទៅលើប្រជាជនថ្មីនៅទំនប់១មករា[2875] អង្គហេតុនៃ "ការរើសអើង" លើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទំនប់១មករា[2876] អង្គហេតុនៃ "ការរើសអើង" ដោយមូលហេតុសាសនានៅទំនប់១មករា[2877] អង្គហេតុនៃការធ្វើឱ្យបាត់ខ្លួននៅទំនប់១មករា[2878] អង្គ

---

[2868] សូមមើលខាងលើ កថាខណ្ឌ ១៩១៧ និងខាងក្រោម កថាខណ្ឌ ១៦៩៩-១៦៩០។

[2869] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៦។ អំពីវគ្គរៀនសូត្រ សូមមើលខាងក្រោម កថាខណ្ឌ ១៧៥៤-១៧៦២។

[2870] សូមមើលខាងលើ កថាខណ្ឌ ៣៦៧-៣៦៩, ៣៧៤-៣៧៧។

[2871] សូមមើលខាងលើ កថាខណ្ឌ ៤៤៨-៤៥០។

[2872] សូមមើលខាងលើ កថាខណ្ឌ ៤៥១-៤៥៧។

[2873] សូមមើលខាងលើ កថាខណ្ឌ ៤២៦-៤៣៤។

[2874] សូមមើលខាងលើ កថាខណ្ឌ ៣៨៨-៣៩០។

[2875] សូមមើលខាងលើ កថាខណ្ឌ ៣៩៣-៣៩៤។

[2876] សូមមើលខាងលើ កថាខណ្ឌ ៤៩០-៤៩២។

[2877] សូមមើលខាងលើ កថាខណ្ឌ ៣៩៥។

ហេតុនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅការដ្ឋានទំនប់ត្រពាំងថ្ម និងអង្គហេតុនៃការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[2879] នោះឡើយ។

១៥១៩. ដើម្បីជាការចងចាំ ក្នុងផ្នែកនៃសារណានេះ ពាក់ព័ន្ធនឹងការបំពេញធាតុផ្សំ មេធាវីការពារក្តីបានជំទាស់នឹងឧក្រិដ្ឋកម្មមួយចំនួន ដែលបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋាន។ អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ថា ធាតុផ្សំនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយនៅត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងដោយមូលហេតុសាសនា មិនមានគ្រប់គ្រាន់ទេ នៅត្រាំកក់ និងទំនប់១មករា[2880]។ ជាចុងក្រោយ ចំពោះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ មេធាវីការពារក្តីបានបង្ហាញថា មិនបានកើតឡើងទេ នៅត្រាំកក់[2881]។

១៥២០. ដូចចំពោះគោលនយោបាយទាំងអស់ដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយល់ឃើញថា អត្ថិភាពនៃឧក្រិដ្ឋកម្មនៅកម្រិតសហករណ៍ គឺជាភ័ស្តុតាងបង្ហាញថា មានគោលនយោបាយឧក្រិដ្ឋ។ ផែនការបង្កើត និងប្រតិបត្តិការសហករណ៍ ថ្វីត្បិតតែមានទំនាក់ទំនងនឹងគោលបំណងរួម មិនបណ្តាលឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មទេ។ ការចូលរួមក្នុងគោលបំណងរួម ដើម្បីបង្កើតគោលនយោបាយ ដោយផ្អែកលើគោលការណ៍សង្គមនិយម និងកម្មសិទ្ធិសមូហភាព មិនមានលក្ខណៈឧក្រិដ្ឋទេ។ គោលដៅខ្លួនទីពឹងខ្លួនខាងស្បៀងអាហារ តាមបែបសមូហភាពនិយម ក៏មិនមែនជាគោលដៅឧក្រិដ្ឋដែរ។

១៥២១. គោលនយោបាយនេះមិននាំឱ្យមានអំពើមនុស្សឃាត ការដាក់ឱ្យទៅជាទាសករ ការបាត់ខ្លួនដោយបង្ខំ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ឬនយោបាយ ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស ដូចការសន្និដ្ឋានខុសរបស់អង្គជំនុំជម្រះ នោះឡើយ[2882]។ ដូច្នេះ អង្គជំនុំជម្រះបានបដិសេធដោយមិន

---

[2878] សូមមើលខាងលើ កថាខណ្ឌ ៣៨៦។

[2879] សូមមើលខាងលើ កថាខណ្ឌ ៣៨៦-៣៨៧, ៤៨២-៤៨៣, ៤៩៣-៤៩៥។

[2880] សូមមើលខាងលើ កថាខណ្ឌ ៧១៩-៧៤៧, ៧៦៣-៧៦៧, ៧៨៧-៨១៣។ សូមមើលខាងលើផងដែរ ៦៤២-៦៥៧។

[2881] សូមមើលខាងលើ កថាខណ្ឌ ៧៤៨-៧៥៥។

[2882] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៩-៣៩២០, ៣៩២២-៣៩២៣, ៣៩២៧-៣៩២៩។

ត្រឹមត្រូវ នូវទឡ្ហីករណ៍របស់មេធាវីការពារក្តី[2883]។ កំហុសត្រួតគ្នារបស់អង្គជំនុំជម្រះក្នុងការពិនិត្យភ័ស្តុតាងធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចរបស់ខ្លួន។ ឥរិយាបថមិនល្អរបស់អ្នកគ្រប់គ្រងសហករណ៍អាចឱ្យយល់អំពីការប្រព្រឹត្តខុសទិសដៅ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានពិចារណាលើភ័ស្តុតាង ដែលបង្ហាញថា ការធ្វើបាបប្រជាជនមិនត្រូវបានដាក់បញ្ចូលក្នុងគោលបំណងរួមនោះទេ ហើយផ្ទុយមកវិញ គឺមានគោលដៅកែលម្អជីវភាពប្រជាជន ដើម្បីធានាឱ្យមានការចូលរួមក្នុងផែនការបដិវត្តន៍។

១៥២២. ការបរាជ័យរបស់គោលនយោបាយ តាមរយៈការខ្វះខាតមធ្យោបាយ អសមត្ថភាពកម្រិតខ្ពស់ ការគ្រប់គ្រងមិនល្អ និងការងាកទៅរកភាពផ្តាច់ការរបស់កម្មាភិបាល និងអ្នកគ្រប់គ្រងសហករណ៍ និងការដ្ឋាន មិនធ្វើឱ្យគោលបំណងរួមមានលក្ខណៈឧក្រិដ្ឋទេ។ ភ័ស្តុតាងពាក់ព័ន្ធនឹងគោលការណ៍ និងមូលហេតុនាំឱ្យបង្កើតសហករណ៍ មិនអាចឱ្យឈានទៅដល់ការសន្និដ្ឋានបែបនេះ ដោយសមហេតុផលបានឡើយ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា គោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាន នាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងក្របខ័ណ្ឌនៃគោលបំណងរួម និងឧក្រិដ្ឋកម្មនៅតាមទីតាំងដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២[2884]។ ដូច្នេះ ខៀវ សំផន មិនមែនជាអ្នកទទួលខុសត្រូវទេ។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានទាំងអស់ក្នុងន័យនេះ នឹងត្រូវទុកជាមោឃៈ[2885]។

### ជំពូកទី ៣. "គោលនយោបាយ" មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស

### ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ

### ១. កំហុសពាក់ព័ន្ធនឹងដើមកំណើតនៃមន្ទីរសន្តិសុខ

### ១.១. ភាពហិង្សានៃចលនាបដិវត្តរបស់ ប.ក.ក

[2883] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២៩។

[2884] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៩-៣៩២០, ៣៩២២-៣៩២៣, ៣៩២៧-៣៩២៩។

[2885] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៥-៤២៧៨, ៤២៨០-៤២៨២, ៤២៩៩, ៤៣០៦, ៤៣១៣-៤៣១៥, ៤៣២៦-៤៣២៨។

១៥២៣. អង្គជំនុំជម្រះមានការភាន់ច្រឡំ ដោយផ្អែកលើឯកសារដ៏មិនគួរឱ្យជឿជាក់មួយរបស់ FBIS ដើម្បីអះអាងថា "នួន ជា បានទទួលស្គាល់ ក្រោយឆ្នាំ១៩៦០ ថា អង្គការ "បានសម្រេចប្រកាន់យកសកម្មភាពនយោបាយ និងហិង្សាប្រដាប់អាវុធ ក្នុងការប្រយុទ្ធប្រឆាំង និងយកជ័យជម្នះលើខ្មាំង" ដែលមានអាវុធ និងឧបករណ៍ផ្តាច់ការដើម្បីបង្ក្រាប និងកាប់សម្លាប់ប្រជាជន"[2886]។ ម្យ៉ាងវិញទៀត នួន ជា មិនបានបង្ហាញនៅក្នុងសវនាការអំពីគោលនយោបាយតស៊ូប្រដាប់អាវុធ ប៉ុន្តែ នួន ជា បានបង្ហាញពីឆន្ទៈក្នុងការរំដោះខ្លួនចេញពីការត្រួតត្រារបស់វៀតណាម[2887]។ អង្គជំនុំជម្រះក៏គួរពិចារណាផងដែរទៅលើការបង្ក្រាបដោយហិង្សាទៅលើការងើបបះបោររបស់កសិករនៅសំឡូត ដែលខ្មែរក្រហមគាំទ្រការប្រយុទ្ធដែលត្រូវបានលើកឡើងនៅក្នុងបរិបទប្រវត្តិសាស្ត្រ[2888]។ គឺដើម្បីឆ្លើយតបនឹងការដណ្តើមយកដីធ្លីទើបគ្រោងធ្វើការតស៊ូប្រដាប់អាវុធ[2889]។ ធាតុផ្សំនៃបរិបទទាំងនេះពន្យល់ពីការផ្លាស់ប្តូរយុទ្ធសាស្ត្រនៅឆ្នាំ១៩៦៦ និងការបើកការប្រយុទ្ធនៅឆ្នាំ១៩៦៧។ អាស្រ័យហេតុនេះ អាចមានការសន្និដ្ឋានសមហេតុផលមួយផ្សេងទៀតក្រៅពីធ្វើការសន្និដ្ឋានពីភាពហិង្សានៃចលនាបដិវត្ត។

---

[2886] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣៤។ ចំពោះបញ្ហាខ្វះការទុកចិត្តទៅលើឯកសារ FBIS សូមមើលខាងក្រោម កថាខណ្ឌ ១៨៩៨-១៨៩៩។

[2887] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣១២៤ ដែលយោងទៅកថាខណ្ឌ ៣៧៤១ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៨៥។ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣១២៤ ដែលយោងទៅកថាខណ្ឌ ២០៥ ដែលតាមពិតគឺជាកថាខណ្ឌ ២០៦ ទៅវិញទេ។ នួន ជា៖ ប្រតិចារឹក ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ឯកសារ **E1/16.1** ម៉ោង 09.31.23 "ឆ្នាំ១៩៦២ ហ្នឹង ជាមហាសន្និបាតបក្សលើកទី១ អំលើកទី២ បានសម្រេចតស៊ូរួមផ្សំនយោបាយ និងអាវុធ ដោយយកនយោបាយជាមូលដ្ឋាន មិនមែនយកអាវុធជាសំខាន់ទេ អាវុធនេះគ្មានអីទេ មានតែកាំបិត ពូថៅ ដំបង"។ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ឯកសារ **E1/25.1** ម៉ោង 11.09.53 "តាមខ្ញុំចាំ បក្សនៅតែតស៊ូនយោបាយជាមូលដ្ឋានដដែល ឯការតស៊ូដោយអាវុធជាការរួមផ្សំបន្ទាប់បន្សំគ្រាន់តែការពារខ្លួនទេ ការពារកម្មាភិបាលទេ ដូចខ្ញុំបានជម្រាបរួចមកហើយពីលើកមុននោះ។ ឯការតស៊ូនោះ នៅតែតស៊ូនយោបាយនៅឡើយទេ"។ ប្រតិចារឹក ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ **E1/14.1** ម៉ោង 14.13.16 "យើងត្រូវតស៊ូនយោបាយរួមផ្សំអាវុធដោយនៅតែយកនយោបាយជាមូលដ្ឋាន ហើយអាវុធសម្រាប់ការពារកម្លាំងតាមការចាំបាច់"។ អង្គជំនុំជម្រះអាចរាប់បញ្ចូលផងដែរ ទស្សនាវដ្តីទង់បដិវត្ត ខែមករា ឆ្នាំ១៩៧៧ ដែលបានដាក់កាលបរិច្ឆេទឆ្នាំ ១៩៦៦ ថាជាឆ្នាំនាំការបង្កើតគោលនយោបាយរៀបចំការតស៊ូដោយ

អាវុធ។ សូមមើលទស្សនាវដ្តីទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ ឯកសារ **E3/25** ERN 00063024។

[2888] សំអាងហេតុសាលក្រម កថាខណ្ឌ ២១២។

[2889] ទស្សនាវដ្តីទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ ឯកសារ **E3/25** ERN 00063026 "តាមចាំ គឺដើមឆ្នាំ៦៧។ ផ្ទុះអាវុធនេះ ដោយគ្មានសារាចរណែនាំពីមជ្ឈឹមបក្សទេ។ [...] កាលនោះផ្ទុះ នៅបាត់ដំបង នៅសំឡូត"។

១៥២៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយផ្អែកលើសក្ខីកម្មរបស់ ឌុច ដើម្បីបញ្ជាក់ថា នៅដើមឆ្នាំ១៩៦០ បក្សបាន "ប្តេជ្ញាបោសសម្អាតសមាសធាតុអាក្រក់ដែលមិនអាចកសាងបាន [...] រហូតមកដល់ពេលនោះ ខ្មាំងបីប្រភេទ ត្រូវបានកំណត់"[2890]។ ទោះយ៉ាងណា ឌុច បានអត្ថាធិប្បាយលើកំណត់ហេតុនៃកិច្ចប្រជុំឃោធាមួយ ដែលលើកឡើងពីខ្មាំងបីប្រភេទ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦[2891]។ យើងមិនដឹងថា តើអ្វីដែលនាំឱ្យ ឌុច អះអាងថា បក្សទំនងជាបានកំណត់ប្រភេទខ្មាំងទាំងបី នៅឆ្នាំ១៩៦០ នោះឡើយ។ យើងត្រូវដឹងថា ឌុច ទទួលបានចំណេះដឹងអំពីគោលនយោបាយរបស់ ប.ក.ក តាមរយៈការអានសំណុំឯកសាររបស់តុលាការ។ ដូច្នេះ វាជាឧទាហរណ៍មួយដ៏គួរឱ្យចាប់អារម្មណ៍ អំពីការរំលោភបំពានរបស់អង្គជំនុំជម្រះលើគោលការណ៍របស់ខ្លួន។ ផ្អែកលើគោលការណ៍នេះ អង្គជំនុំជម្រះត្រូវផ្អែកលើសក្ខីកម្មរបស់ ឌុច "តែក្នុងករណីដែលសក្ខីកម្មនេះពាក់ព័ន្ធនឹងអង្គហេតុដែល ឌុច បានដឹង នៅសម័យអង្គហេតុ តែប៉ុណ្ណោះ"[2892]។ វាច្បាស់ណាស់ថានៅឆ្នាំ១៩៦០ ឌុច មិនបានដឹងអំពីគោលនយោបាយដែលបក្សបានអនុម័តនោះ។ ដូច្នេះ សេចក្តីសន្និដ្ឋានលើអង្គហេតុនេះត្រូវតែបដិសេធចោល។

## ១.២. ការបង្កើតមន្ទីរសន្តិសុខ

១៥២៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយប្រើប្រាស់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅមុនខែមេសា ឆ្នាំ១៩៧៥ ដើម្បីបង្ហាញពីគោលនយោបាយប្រឆាំងខ្មាំង ក្នុងសម័យខ្មែរក្រហម[2893]។ ជាក់ស្តែង ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងនៅចំស្នូលបរិបទនៃជម្លោះប្រដាប់អាវុធជាមួយរបប លន់ នល់ និងខណៈពេលដែលវៀតណាមមានបំណងត្រួតត្រាបដិវត្តកម្ពុជា។ ធាតុផ្សំទាំងនេះមិនអាចប្រើជាមូលដ្ឋាន ដើម្បីបង្ហាញអំពីសេចក្តីប្រកាសគោលនយោបាយប្រឆាំងនឹងខ្មាំងបានឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស

[2890] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣៤។

[2891] ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/441.1** ចន្លោះម៉ោង13.46.02 និង 13.51.14។ កំណត់ហេតុនៃការប្រជុំលេខា, អនុលេខា និង វរៈសេនាធំ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ ឯកសារ **E3/13** ERN 00052414-15។ សូមមើលខាងលើផងដែរ កថាខណ្ឌ ១៤៦៣។

[2892] សំអាងហេតុសាលក្រម កថាខណ្ឌ ២០៨០។

[2893] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣៤-៣៩៤១។

ដោយសន្និដ្ឋានថា មានមន្ទីរសន្តិសុខយ៉ាងហោចណាស់ចំនួន ២០០[2894]។ តាមពិត អង្គជំនុំជម្រះមិនគួរផ្តល់សុពលភាពដល់ការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ ដោយសារវាបានផ្តល់ព័ត៌មានតិចតួច និងការអនុវត្តវិធីសាស្ត្រស្រាវជ្រាវ[2895]។ លោក Craig ETCHESON បម្រើការងារឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា និងបម្រើការងារឱ្យការិយាល័យសហព្រះរាជអាជ្ញា[2896]។ ដូច្នេះ វាច្បាស់ណាស់ថា គាត់បានគាំទ្រការស្រាវជ្រាវរបស់មជ្ឈមណ្ឌលនេះ ដែលបន្ទាប់មក ត្រូវបានប្រើយ៉ាងទូលំទូលាយ ដោយការិយាល័យសហព្រះរាជអាជ្ញា[2897]។ ដោយសារកង្វះភាពជឿជាក់លើលោក Henry LOCARD អង្គជំនុំជម្រះមិនបានយកចិត្តទុកដាក់ជាមុន ដោយផ្តែកតែមួយមុខលើការស្រាវជ្រាវរបស់មជ្ឈមណ្ឌល ដើម្បីសន្និដ្ឋានថា យ៉ាងហោចណាស់មានមន្ទីរសន្តិសុខចំនួន ២០០ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ សេចក្តីសន្និដ្ឋាននេះ ត្រូវតែបដិសេធ។

## ២. ការបំភ្លៃឯកសារ និងសុន្ទរកថាផ្លូវការ

### ២.១. អត្ថបទ និងសុន្ទរកថា

១៥២៦.ដើម្បីបង្ហាញពីអត្ថិភាព នៃពាក្យ “ខ្មាំង” ដែលគេប្រើជាទូទៅ និងដើម្បីទាញសេចក្តីសន្និដ្ឋានចេញពីពាក្យនេះ នូវគោលនយោបាយឧក្រិដ្ឋមួយ អង្គជំនុំជម្រះបានបំភ្លៃឯកសារផ្លូវការរបស់ ប.ក.ក និងសុន្ទរកថារបស់ថ្នាក់ដឹកនាំបក្ស។

#### ២.១.១. ការបំភ្លៃអត្ថបទ

##### *២.១.១.១. កំហុសក្នុងការវាយតម្លៃលើរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ*

---

[2894] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៤។

[2895] *Genocide Sites in Cambodia* ឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩ គ្មានកាលបរិច្ឆេទ ឯកសារ **E3/2366** ERN EN 00188710-11។

[2896] Craig ETCHESON ស្ថិតនៅក្នុងចំណោមស្ថាបនិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ ក្នុងឆ្នាំ១៩៩៤ ដែលលោកបានដឹកនាំមជ្ឈមណ្ឌលនេះរយៈពេល២ឆ្នាំ បន្ទាប់មកលោកបានធ្វើការជាអ្នកពិគ្រោះយោបល់ រយៈពេល ៣ ឆ្នាំ។ លោកបានធ្វើការសម្រាប់គម្រោង *Cambodian Genocide Program* ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ ក្រោយមកក៏ធ្វើការរយៈពេល៦ឆ្នាំសម្រាប់សហព្រះរាជអាជ្ញា នៅក្នុងតុលាការនេះ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១២។

[2897] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៤៩។

១៥២៧. អង្គជំនុំជម្រះបានយល់ឃើញថា "ក្របខ័ណ្ឌកំណត់បែបបទសម្រាប់ផ្តន្ទាទោសខ្លាំងឱ្យជាប់ឃុំឃាំង និង ជារឿយៗ ឱ្យបាត់បង់ជីវិត នៅមន្ទីរសន្តិសុខ មានមូលដ្ឋានច្បាប់នៅក្នុងរដ្ឋធម្មនុញ្ញ ហើយត្រូវបានដាក់ឱ្យអនុវត្ត តាមរយៈក្រឹត្យមួយរបស់បក្ស" [2898]។ ដើម្បីធ្វើដូចនេះ អង្គជំនុំជម្រះបានបំភ្លៃបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះបានយោងលើមាត្រា១០នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "អំពើទាំងឡាយណាដែលមានលក្ខណៈអរិភាព និងបំផ្លិចបំផ្លាញ ដែលបង្កគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរបំផុត" [2899]។

១៥២៨. ម្យ៉ាងវិញទៀត ការដាក់ទោសយ៉ាងធ្ងន់ធ្ងរចំពោះរាល់ការធ្វើឱ្យប៉ះពាល់ដល់ជាតិ មិនមែនជាការអនុវត្តផ្ទាល់នៅសម័យកម្ពុជាប្រជាធិបតេយ្យឡើយ ពោលគឺ គ្រប់រដ្ឋអធិបតេយ្យប្រកាន់យកបទប្បញ្ញត្តិស្រដៀងគ្នានេះ។ គេគ្រាន់តែយោងលើក្រមព្រហ្មទណ្ឌជាតិ សូម្បីតែក្រមព្រហ្មទណ្ឌសហសម័យ ដើម្បីវាយតម្លៃពីរឿងនេះ គឺគ្រប់គ្រាន់បាត់ទៅហើយ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានជ្រើសរើសអនុមានវិធី ដោយផ្សារភ្ជាប់គំនិតនៃការដាក់ទណ្ឌកម្មធ្ងន់ធ្ងរទៅនឹងមរណភាព។ បទប្បញ្ញត្តិខាងលើមិនសំដៅទាល់តែសោះទៅលើការប៉ះពាល់លើរូបរាងកាយ។

១៥២៩. ដោយសារការវាយតម្លៃមិនត្រឹមត្រូវលើភ័ស្តុតាង សេចក្តីសន្និដ្ឋាននេះ[2900] កាន់តែត្រូវចាត់ទុកជាមោឃៈថែមទៀត ខណៈដែលអង្គជំនុំជម្រះបានអនុវត្តស្តង់ដាពីរទាក់ទងនឹងរដ្ឋធម្មនុញ្ញ។ ជាក់ស្តែង អង្គជំនុំជម្រះបានវិនិច្ឆ័យថាសេចក្តីសន្និដ្ឋានអាចជឿទុកចិត្តបាន ដើម្បីទាញយកធាតុផ្សំដាក់បន្ទុក ដូចជានៅទីនេះ ដើម្បីសន្និដ្ឋានថា រដ្ឋធម្មនុញ្ញបង្កប់ជាស្រេចនូវគោលនយោបាយធ្វើបាបខ្លាំង ប៉ុន្តែ បានចាត់ទុកថាជារឿងមិនពិត នៅពេលដែលវាមានបង្កប់នូវធាតុផ្សំដោះបន្ទុក[2901]។

[2898] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៥។

[2899] រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ឯកសារ **E3/259** មាត្រា ១០។

[2900] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៥។

[2901] ឧទាហរណ៍ សូមមើល សេរីភាពសាសនា និង សញ្ញាណនៃ "មហាសាមគ្គីជាតិ"។ រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ឯកសារ **E3/259** ERN 00089844។

### *២.១.១.២. កំហុសក្នុងការវាយតម្លៃលើសេចក្តីសម្រេចរបស់គណៈកម្មការមជ្ឈិម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ និងលើអំណាចសម្រេចសម្លាប់មនុស្ស*

១៥៣០. អង្គជំនុំជម្រះបានបំភ្លៃសេចក្តីសម្រេចរបស់គណៈកម្មការមជ្ឈិម ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដើម្បីទាញការសន្និដ្ឋានពីអំណាចសម្រេចប្រហារជីវិត ក្នុងបរិបទនៃការបោសសម្អាត[2902]។ នៅក្នុងផ្នែកសំអាងហេតុទាំងមូល ឯកសារនេះត្រូវបានប្រើជាមូលដ្ឋាននៃគោលនយោបាយបោសសម្អាត និងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅក្នុងមន្ទីរសន្តិសុខ។ ការប្រើប្រាស់ឯកសារនេះ ដោយលម្អៀង និងជាលក្ខណៈប្រព័ន្ធ គឺជាការសារភាពមួយថា អង្គជំនុំជម្រះមិនមានធាតុផ្សំភ័ស្តុតាងគ្រប់គ្រាន់ឡើយ។ ក្នុងករណីណាក៏ដោយ មិនមានចំណងទាក់ទងណាមួយរវាង ខៀវ សំផន និងឯកសារនេះទេ[2903]។ សេចក្តីសន្និដ្ឋានផ្អែកលើឯកសារនេះ ត្រូវទុកជាមោឃៈ[2904]។

### *២.១.១.៣. ការបំភ្លៃសេចក្តីណែនាំរបស់គណៈកម្មការមជ្ឈិម ចេញផ្សាយនៅខែមិថុនា ឆ្នាំ១៩៧៨*

១៥៣១. នៅខែមិថុនា ឆ្នាំ១៩៧៨ ប.ក.ក បានចេញសេចក្តីណែនាំលើកលែងទោស "ខ្មាំង" ដែលបានធ្វើសកម្មភាពប្រឆាំងបដិវត្តមុនឆ្នាំ១៩៧៥[2905]។ ចំពោះឯកសារនេះ អង្គជំនុំជម្រះបានទទួលយកសក្ខីកម្មរបស់ ឌុច ក្នុងការឆ្លើយទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត ដែលក្នុងនោះ គាត់ពិពណ៌នាឯកសារនេះថាជា "កលល្បិច" ដើម្បីបន្ធូរអារម្មណ៍ប្រជាជន[2906]។ ការលើកឡើងនេះមិនផ្អែកលើអង្គហេតុសត្យានុម័តិណាមួយសោះ តែផ្អែកតែទៅលើការវាយតម្លៃអត្តនោម័តិរបស់ ឌុច ដែលបានសារភាពនៅក្នុងសវនាការថា គាត់មិនបានចូលរួមក្នុងការប្រជុំណាមួយរបស់ក្រុមគណៈកម្មការមជ្ឈិម

---

[2902] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៥-៣៩៥៦។

[2903] សូមមើលខាងក្រោម កថាខណ្ឌ ១៧១៨- ១៧២២។

[2904] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៥-៣៩៥៦។

[2905] សេចក្តីណែនាំរបស់គណៈមជ្ឈិម ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ឯកសារ **E3/764**។

[2906] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧១។ កំណត់ហេតុស្តាប់ចម្លើយឌុច ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ឯកសារ **E3/15**។

ឬគណៈកម្មការអចិន្ត្រៃយ៍ឡើយ[2907]។ ការលើកឡើងខាងលើ ក៏មិនត្រូវបានគាំទ្រដោយធាតុផ្សំណាមួយផ្សេងទៀតឡើយ ហើយ ឌុច មិនសំអាងលើអ្វីក្រៅពីមតិផ្ទាល់ខ្លួនរបស់គាត់ ខណៈដែលគាត់បានសារភាពថា គាត់គ្មានលទ្ធភាពមើលឃើញអ្វីនៅខាងក្រៅ ស-២១ ឡើយ[2908]។ ហេតុដូច្នេះ ឯកសារដែលបានរៀបរាប់ខាងលើ គួរតែត្រូវបានពិនិត្យដោយសត្យានុម័តិ ជាពិសេស ដោយផ្អែកលើស្ថានការណ៍ នាពាក់កណ្តាលឆ្នាំ១៩៧៨។ នៅពេលកម្តៅនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាមឡើងដល់កំពូល បំណងប្រាថ្នាចង់មានរណសិរ្សរួបរួមមួយ និងបន្ធូរបន្ថយជម្លោះផ្ទៃក្នុង គឺមានលក្ខណៈសមហេតុផល[2909]។ អង្គជំនុំជម្រះគួរតែពិចារណាលើធាតុផ្សំមួយនេះ។

### *២.១.២. ការបំភ្លៃសុន្ទរកថា និងធាតុផ្សំដែលមានតម្លៃជាភស្តុតាងទាប*

១៥៣២. ម្តងហើយម្តងទៀត អង្គជំនុំជម្រះបានបំភ្លៃសុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខ។ ដូច្នេះ អង្គជំនុំជម្រះបានបកស្រាយពីការប្រើពាក្យ "ខ្មាំង" របស់ ខៀវ សំផន ក្នុងន័យដាក់បន្ទុក ដោយយកវាចេញពីបរិបទដើម្បីធ្វើឱ្យការប្រើពាក្យនេះ មានចរិតឧក្រិដ្ឋ។ ទោះយ៉ាងណាក៏ដោយ ក្នុងបរិបទបដិវត្តន៍កុម្មុយនីស្ត ពាក្យខ្មាំងមានចរិតមនោគមវិជ្ជាច្រើនជាងចរិតផ្សេងទៀត។

#### *២.១.២.១. សុន្ទរកថា ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧*

---

[2907] ឌុច ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ចន្លោះម៉ោង09.04.35 និងម៉ោង 09.06.05៖ "ស. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកជាសមាជិកគណៈមជ្ឈិមដែរឬទេ? ឆ៖ ខ្ញុំអត់ទាន់បានចូលមជ្ឈិមនឹងគេនៅឡើយទេ។ ស. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដដែលហ្នឹង តើលោកធ្លាប់ត្រូវបានកោះហៅទៅប្រជុំនៅគណៈមជ្ឈិមដែរឬទេ? ឆ. អត់ទេ"។ (យើងគូសបន្ទាត់ពីក្រោម)។

[2908] ឌុច ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ម៉ោង 09.06.05។

[2909] សេចក្តីណែនាំរបស់គណៈមជ្ឈិម ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ឯកសារ **E3/764** "បក្សអំពាវនាវឱ្យអ្នកភាន់ច្រឡំទាំងអស់ឱ្យមកចូលរួមចិត្តរួមថ្លើមជាមួយប្រជាជាតិ និងប្រជាជនយើងវិញ ការពារប្រទេស កសាងប្រទេស និងលើកស្ទួយជីវភាពប្រជាជនឱយបានរីកចម្រើនឆាប់រហ័ស ហើយឈានទៅសម្បូរសប្បាយគ្រប់ផ្នែក" ERN 00079282។

១៥៣៣. អង្គជំនុំជម្រះបានបន្ថយក និងបកស្រាយខុស នូវសុន្ទរកថាដែលបានថ្លែងក្នុងឱកាសបុណ្យខួបលើកទីពីរនៃការរំដោះ ដែល ខៀវ សំផន បានថ្លែងថា៖ "យើងត្រូវតែបោសសម្អាតខ្លាំង ស្របតាមបន្ទាត់នៃគោលនយោបាយផ្ទៃក្នុង គោលនយោបាយការបរទេស និងគោលនយោបាយយោធា របស់អង្គការបដិវត្តយើង"[2910]។ ខ្លាំងដែលគាត់បានពិពណ៌នានៅក្នុងសុន្ទរកថានេះ គឺមានចរិតនយោបាយ។ វាជាការថ្លែងមួយ នៅក្នុងបរិបទ នៃការប្រារព្ធពិធីជ័យជំនះ ១៧ មេសា នៃបដិវត្តន៍កុម្មុយនីស្ត និងការកាត់ផ្តាច់ចេញពីរបបចាស់។ នៅក្នុងបរិបទនៃការប្រឈមមុខដាក់គ្នាផ្នែកមនោគមវិជ្ជា នៅក្នុងក្របខ័ណ្ឌនៃសុន្ទរកថាឃោសនាផ្តោតលើជ័យជំនះ ១៧ មេសា៖ សុន្ទរកថានេះបានអំពាវនាវឱ្យបន្តការតស៊ូវណ្ណៈ ដើម្បីទទួលបានជ័យជំនះនយោបាយ នៅក្នុងក្របខ័ណ្ឌនៃការប្រឈមមុខដាក់គ្នាស្រួចស្រាល់ខាងមនោគមន៍វិជ្ជា នាសម័យនោះ។ លើសពីនេះទៀត ការយោងទៅលើគោលនយោបាយការបរទេស សំដៅទៅលើបរិបទនៃសង្គ្រាមត្រជាក់។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបំភ្លៃសុន្ទរកថាក្នុងន័យដាក់បន្ទុក ដើម្បីធ្វើឱ្យវាមានចរិតឧក្រិដ្ឋ។

### *២.១.២.២. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន*

១៥៣៤. អង្គជំនុំជម្រះក៏បានប្រើប្រាស់ខុស នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ដែលបានលើកឡើងពីសុន្ទរកថាមួយ ដែលទំនងជាបានថ្លែងដោយ ខៀវ សំផន នៅឆ្នាំ១៩៧៧ នៅផ្សារច្បារអំពៅ។ ខៀវ សំផន ទំនងជាបានប្រើពាក្យសម្តីសាហាវៗ នៅចំពោះមុខប្រជាជនមួយក្រុមដែលជម្លៀសមកពីភូមិភាគបូព៌ា[2911]។ ម្យ៉ាង អង្គហេតុនៃជម្លៀសប្រជាជនដំណាក់កាលទី ៣ ទាំងនេះ ស្ថិតនៅក្រៅវិសាលភាព ដែលអង្គជំនុំជម្រះមិនគួរពិចារណា[2912] ហើយលើសពីនេះទៀត គេពិបាកនឹងជឿបានលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះណាស់ ចំពោះការចងចាំភ្លាមៗ និងយ៉ាងងាយស្រួលរបស់គាត់អំពី ខៀវ

---

[2910] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦០។ សុន្ទរកថារបស់លោក ខៀវ សំផន ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ ឯកសារ **E3/200**។

[2911] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦១។ ព្រាប ឈួន ប្រតិចារឹក ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/504.1** ម៉ោង 15.30.25។

[2912] សេចក្តីជំទាស់របស់លោកស្រីមេធាវី GUISSÉ នៅពេលផ្តល់សក្ខីកម្មរបស់ ព្រាប ឈួន ប្រតិចារឹក ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/504.1** ម៉ោង 15.42.44 និងម៉ោង 15.45.58។

សំផន បន្ទាប់ពីការជំនុំជម្រះក្តី ០០២/០១ ទោះបីជាគាត់បានធ្វើអន្តរាគមន៍ក្នុងការជំនុំជម្រះក្តីលើកដំបូងក៏ដោយ។ សេចក្តីប្រកាសរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ មិនមានបញ្ជាក់ទាល់តែសោះអំពីការជួបតាមសន្មតជាមួយ ខៀវ សំផន ទេ[2913]។

១៥៣៥. ដោយសារសំណើសុំឱ្យកោះហៅ ព្រាប ឆុន ត្រូវបានធ្វើឡើងយ៉ាងយឺតយ៉ាវបំផុត[2914] នោះគេត្រូវមានការប្រុងប្រយ័ត្នបន្ថែមទៀត ក្នុងការពិនិត្យមើលសក្ខីកម្មរបស់គាត់ ជាពិសេស ដោយហេតុផលថាដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះគួរតែស្វែងរកធាតុផ្សំភ័ស្តុតាងដែលមិនមានក្នុងករណីនេះ មកបញ្ជាក់។ មិនមានភ័ស្តុតាងផ្សេងទៀតបញ្ជាក់អំពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយគ្មានសុទ្ធរកថាណាមួយដែលថ្លែងដោយ ខៀវ សំផន នៅក្នុងសំណុំរឿង បង្ហាញពីពាក្យពេជន៍ស្រដៀងគ្នានោះដែរ។ យោងតាមដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់បណ្តឹងសាទុក្ខទំនងជាបានគំរាមសម្លាប់ជនក្បត់នឹងកម្ពុជាប្រជាធិបតេយ្យ។ ក៏ប៉ុន្តែ គ្មានអ្វីអាចយកមកបញ្ជាក់ពីសុន្ទរកថាបែបនេះ នៅទីកន្លែង និងកាលបរិច្ឆេទទាំងនេះទេ។ អង្គជំនុំជម្រះមានកំហុសក្នុងការទាញសេចក្តីសន្និដ្ឋានដាក់បន្ទុក ដោយផ្អែកលើសក្ខីកម្មដែលមានតម្លៃជាភ័ស្តុតាងទាប។ សេចក្តីសន្និដ្ឋានទាំងនោះ ត្រូវទុកជាមោឃៈ[2915]។

### ២.១.២.៣. សក្ខីកម្មរបស់ ខៀវ សំផន ស្តីពីទិតៀន និងស្វ័យទិតៀន

១៥៣៦. អង្គជំនុំជម្រះផ្អែកលើសក្ខីកម្មរបស់ ខៀវ សំផន ក្នុងអំឡុងពេលសវនាការលើសំណុំរឿង ០០២/០១ ស្តីពីការអនុវត្តគោលការណ៍ទិតៀន និងស្វ័យទិតៀន ដើម្បីសន្និដ្ឋានថា គោលការណ៍នេះមានគោល

---

[2913] ព្រាប ឈួនៈ ប្រតិចារឹក ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E1/505.1** ចន្លោះម៉ោង09.17.44 និង 09.34.35។ ដើមបណ្តឹងបានអះអាងថាមិនបានរំឭកដល់ការជួបជាមួយនឹងលោក ខៀវ សំផន ទេនៅក្នុងចម្លើយរបស់លោក។

[2914] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបន្ថែមទៀត ស្តីអំពីតួនាទីរបស់ជនជាប់ចោទ និងសុំឱ្យទទួលយកចម្លើយពាក់ព័ន្ធ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E436/1**។ សូមមើលផងដែរ ការជំទាស់របស់មេធាវីការពារក្តីទៅនឹងការស្នើសុំយឺតយ៉ាវ ប្រតិចារឹក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E1/471.1** ម៉ោង 10.52.58។

[2915] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦១។

បំណងបណ្តុះ "កំហឹងវណ្ណៈ"[2916]។ បន្ទាប់មក អង្គជំនុំជម្រះបានប្រើប្រាស់សញ្ញាណទាំងនេះ ដើម្បីសន្និដ្ឋានថា ការអនុវត្តគោលការណ៍ស្វ័យទិតៀន បង្កឱ្យមានចេតនារើសអើងចំពោះប្រជាជនថ្មី ដែលចេតនានេះអាចបង្ហាញពីចេតនាឧក្រិដ្ឋ។ នេះគឺជាការចង្អុលចំៗចំពោះការបំភ្លៃ និងការបំផ្លើសពាក្យសម្តីរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ក្នុងការឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ម្ចាស់បណ្តឹងបានពន្យល់ពីគោលបំណងនៃវគ្គសិក្សាស្វ័យទិតៀន នៅក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម៖

> "ការធ្វើស្វ័យទិតៀនត្រូវអនុលោមតាមគោលការណ៍នៃការតស៊ូវណ្ណៈ និងជាពិសេស សម្រាប់សមាជិកបក្ស។ [...] មិនដូចថ្នាក់ដឹកនាំដទៃទៀតដែលជាបញ្ញាជន ឬតិចជាងបន្តិច ហើយឆ្លងកាត់វគ្គទិតៀន និងស្វ័យទិតៀន ហើយពួកគេអាចលុតដំខ្លួនឯង និងអាចកម្ចាត់ទស្សនៈមូលធននិយម និងផ្តោតការខិតខំប្រឹងប្រែងរបស់ពួកគេទៅលើ ដើម្បីរួមរស់ទាំងស្រុងនៅក្នុងចលនាតស៊ូជាមួយនឹងការខិតខំទាំងអស់ដែលពួកគេបានធ្វើ។ ប៉ុន្តែ ខ្ញុំមិនអាចធ្វើវាបានជោគជ័យទេ។ សូមជម្រាបលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី! នេះគឺជាអ្វីដែលខ្ញុំចង់ប្រាប់លោកស្រី"[2917]។

១៥៣៧. ម្យ៉ាង គោលការណ៍ស្វ័យទិតៀនមិនមែនត្រូវបានអនុវត្តតែក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ តែនៅក្នុងគណបក្សម៉ាក្សនិយម និងបដិវត្ត នាសម័យនោះផងដែរ។ ម្យ៉ាងវិញទៀត យោងតាមការបញ្ជាក់ពី ខៀវ សំផន ការអនុវត្តនេះ គឺដើម្បីឱ្យ សមាជិករបស់ ប.ក.ក ជាពិសេស អាចផ្តោតការយកចិត្តទុកដាក់លើគោលដៅបដិវត្ត។ តាមរយៈការបញ្ជាក់ថា "មិនអាចធ្វើវាបានដោយជោគជ័យទេ" ខៀវ សំផន មិនត្រឹមតែបានបង្ហាញថា គោលការណ៍នេះក៏អនុវត្តចំពោះគាត់ផងដែរ ប៉ុន្តែវាគឺជាកិច្ចខិតខំប្រឹងប្រែងដែលត្រូវធ្វើ នៅក្នុងក្របខ័ណ្ឌនៃជម្រើសនយោបាយ។

១៥៣៨. បុគ្គលគ្រប់រូប រួមទាំងម្ចាស់បណ្តឹងសាទុក្ខ មានសិទ្ធិស្វ័យសម្រេចពីគំនិតរបស់ខ្លួន ដរាបណាគំនិតនេះមិនមានលក្ខណៈឧក្រិដ្ឋ។ ក្នុងករណីនេះ ស្វ័យទិតៀន ដែលជាឧបករណ៍នៃការតស៊ូវណ្ណៈ មិនគាំទ្រ

[2916] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៧។ ("នៅក្នុងសវនាការ ខៀវ សំផន បានទទួលស្គាល់ថារបបកសាងរបស់បក្សតាមរយៈការប្រជុំទិតៀន និងស្វ័យទិតៀន គឺជាមូលដ្ឋានគ្រឹះខាងសតិអារម្មណ៍សម្រាប់ការតស៊ូវណ្ណៈ")។

[2917] លោក ខៀវ សំផន ប្រតិចារឹក ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/103.1** ចន្លោះម៉ោង10.09.21 និងម៉ោង 10.14.14។

គោលនយោបាយឧក្រិដ្ឋណាមួយទេ តែវាត្រូវបានគេមើលឃើញថាជាឧបករណ៍សម្រាប់បណ្តុះមនសិការនយោបាយ។ ដូច្នេះ អង្គជំនុំជម្រះបានបំភ្លៃសុន្ទរកថារបស់ម្ចាស់បណ្តឹង និងបានបំផ្លើសដើម្បីកំណត់ការអនុវត្តគោលនយោបាយឧក្រិដ្ឋចំពោះប្រជាជនថ្មី ដោយយកសុន្ទរកថានោះចេញពីបរិបទទាំងស្រុង។

១៥៣៩. ការប្រើពាក្យ "ខ្មាំង" គឺជាវោហារសាស្ត្រនយោបាយ។ ខៀវ សំផន មិនមែនជាមនុស្សតែម្នាក់គត់ដែលប្រើពាក្យនេះនៅក្នុងបរិបទមនោគមន៍វិជ្ជានោះទេ។ អ្នកនិពន្ធជាច្រើនបានសរសេរលើបញ្ហានេះ ហើយបានពន្យល់ថា ហេតុដូចម្តេចបានជាសញ្ញាណនៃពាក្យ "ខ្មាំង" ឬ "សត្រូវផ្ទៃក្នុង" ប្រសូត្រចេញពីសំណង់នយោបាយ និងប្រវត្តិសាស្ត្រ៖

> "សំណង់នៃពាក្យខ្មាំងផ្ទៃក្នុងនេះ ប្រសូត្រចេញមកពីល្បែងដណ្តើមទីតាំង សហប្រតិបត្តិការ និងការដកខ្លួន ក៏ដូចជាជម្លោះផលប្រយោជន៍នៅក្នុងសមរភូមិមួយ ក្នុងពេលវេលាមួយ។ ការបង្រួបបង្រួមនៃរបបសូវៀតក្នុងទសវត្សឆ្នាំ១៩២០ សង្គ្រាមត្រជាក់ សង្គ្រាមអាណានិគម ការបញ្ចប់នៃការពុះពិភពលោកជាពីរដោយភាពមិនប្រាកដប្រជា និងភាពស្រពិចស្រពិល សាកលភាវូបនីយកម្ម។ល។ ហាក់ដូចជាគំរូប្រវត្តិសាស្ត្រនៃភាពតានតឹងសង្គម។ ពួកគេម្នាក់ៗបកស្រាយរចនាសម្ព័ន្ធនៃល្បែងនយោបាយជាក់លាក់ និងបង្ហាញពីដំណើរការការិយាធិបតេយ្យពិសេស ដែលក្នុងនោះក៏មានផ្នែកមួយនិយាយពី "ខ្មាំងផ្ទៃក្នុង" ដែរ[2918]។

១៥៤០. វោហាសាស្ត្ររបស់សត្រូវ គឺជាផ្នែកមួយនៃការយកគំរូតាមគោលនយោបាយក្នុងបរិបទនៃការប្រឈមមុខរវាងប្រព័ន្ធកុម្មុយនីស្ត និងមូលធននិយម។ ស្ទ័យទិតៀន ដែលបានអនុវត្តនៅក្នុងរបបកុម្មុយនីស្ត គឺជាផ្នែកមួយនៃវិធីសាស្ត្រដូចគ្នា។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនអើពើនឹងវោហារសាស្ត្រនយោបាយនៃសុន្ទរកថារបស់ ខៀវ សំផន ស្តីពីការតស៊ូវណ្ណៈ ដើម្បីផ្តល់ឱ្យសុន្ទរកថាទាំងនោះនូវអត្ថ

---

[2918] អត្ថបទសរសេរដោយ Ayse CEYHAN និង Gabriel PÉRIÈS *ខ្មាំងផ្ទៃក្នុង៖ការកសាងសុន្ទរកថា និងនយោបាយ* វប្បធម៌ និងជម្លោះ រដូវស្លឹកឈើជ្រុះ ឆ្នាំ២០០១ ទំព័រ ៣។

ន័យអវិជ្ជមានទាក់ទងនឹងគោលនយោបាយខក្រិដ្ឋ[2919]។ អង្គជំនុំជម្រះបានបំភ្លៃពាក្យសម្តីរបស់គាត់ទាំងស្រុង។ ការសន្និដ្ឋានទាំងនេះ ត្រូវតែធ្វើមោឃភាព[2920]។

## ២.២. ការដឹងឮពីការកម្ទេចខ្មាំង

### ២.២.១. ទស្សនាវដ្តីបដិវត្តន៍

១៥៤១. ដើម្បីសន្និដ្ឋានថា "ការកម្ទេចខ្មាំង គឺជាព្រឹត្តិការណ៍ដែលគេស្គាល់ជាទូទៅ នៅក្នុងជួរបក្ស" អង្គជំនុំជម្រះបានប្រើប្រាស់ទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជនយុវនារីបដិវត្តជាច្រើន[2921]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនអាចផ្អែកលើការបកស្រាយរបស់ខ្លួន ដោយឈរលើមូលដ្ឋាននៃឯកសារទាំងនោះទេ។ ដោយបានទទួលស្គាល់ខ្លួនឯងថា "សេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងសម្រាប់គោលបំណងឃោសនាអាចគួរឱ្យទុកចិត្តបានតិចតួច"[2922] អង្គជំនុំជម្រះគួរតែបានពិចារណាថា ទស្សនាវដ្តីទាំងនោះ បានផ្អែកលើវោហារសាស្ត្រជាក់លាក់មួយ។ ផ្នែកមួយស្តីពីភ័ស្តុតាងនៃសារណានេះ បានបញ្ជាក់ខាងលើរួចមកហើយថា ការឃោសនាអាចឱ្យពួកគេបញ្ចុះបញ្ចូលប្រជាជន ប្រមូលផ្តុំប្រជាជនក្នុងបរិបទសង្គម/នយោបាយជាក់លាក់ ដែលជារឿយៗ ប្រាសចាសពីតថភាពដោយចេតនា ដោយបំផ្លើសតថភាព[2923] ដើម្បីបំផុសភាពរំជួលចិត្តខាងនយោបាយ និងការចូលរួមក្នុងជីវភាពនយោបាយ។ ក្នុងករណីនេះ ទស្សនាវដ្តីទង់បដិវត្ត និងយុវជន និងយុវនារីបដិវត្ត ត្រូវបានប្រើសម្រាប់ប្រមូលផ្តុំប្រជាជនជុំវិញស្មារតីនៃការតស៊ូវណ្ណៈ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយដាក់ទន្ទឹមគ្នានូវអត្ថបទស្តីពីការតស៊ូមនោគមន៍វិជ្ជា និងអត្ថបទស្តីពីការតស៊ូប្រដាប់អាវុធ (ឧទាហរណ៍ ការនិយាយយោងលើសង្គ្រាមប្រឆាំងនឹងរបប លន់ នល់)។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយការបកប្រែត្រ

[2919] សូមមើលផងដែរសំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧០។

[2920] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៥, ៣៩៥៦, ៣៩៦០-៣៩៦៣, ៣៩៦៧-៣៩៧១។

[2921] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៨-៣៩៥៩។

[2922] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៥។ សូមមើលផងដែរ កថាខណ្ឌ ៤៧២, ៤៧៩។

[2923] សូមមើលខាងលើ កថាខណ្ឌ ២៩១-២៩២។

ង់ៗនូវអត្ថបទដកស្រង់ ដើម្បីសន្និដ្ឋានថា ទស្សនាវដ្ដីទាំងនេះជំរុញការម្ទេចខ្មាំង តាមរយៈមន្ទីរសន្តិសុខ ហើយអង្គហេតុនៃការកម្ទេចខ្មាំង ត្រូវបានគេដឹងជាទូទៅនៅក្នុងប្រទេស និងក្នុងជួរបក្ស[2924]។

### ២.២.២. ទូរលេខ និងរបាយការណ៍

១៥៤២. បន្ទាប់មក អង្គជំនុំជម្រះបានរទូរលេខនៃរបាយការណ៍ ដែលបញ្ជូនពីលេខាធិការភូមិភាគទៅអង្គការ ដើម្បីថ្លែង "ជឿជាក់ថា ទូរលេខទាំងនេះបង្ហាញថា គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ បានគ្រប់គ្រងការអនុវត្តគោលនយោបាយរបស់បក្ស ស្របតាមតួនាទីដែលបានប្រគល់ជូនពួកគេ"[2925]។ ពិតមែនតែទូរលេខអាចលើកឡើងពី "ខ្មាំង" តែវាបានធ្វើឡើងជាលក្ខណៈសម្ងាត់ទាំងស្រុង ពីព្រោះគេមិនដឹងថាអ្នកនិពន្ធចង់និយាយសំដៅលើ "នរណា" លើ "អ្វី" ឡើយ។ លើសពីនេះទៀត អង្គជំនុំជម្រះបានលុបចោលទាំងស្រុង នូវបរិបទនៃជម្លោះប្រដាប់អាវុធ ហើយមិនបានធ្វើការផ្ទៀងផ្ទាត់ ឬប្រៀបធៀបទាល់តែសោះ ចំពោះព័ត៌មានដែលបានបញ្ជូនក្នុងទូរលេខទាំងនេះ ពាក់ព័ន្ធនឹងដំណើរវិវត្តនៃជម្លោះប្រដាប់អាវុធនៅក្នុងប្រទេស។ ក្រៅពីនេះ អង្គជំនុំជម្រះមិនបានផ្ដល់សំអាងហេតុគាំទ្រសេចក្ដីសន្និដ្ឋានរបស់ខ្លួន និងមិនបានពន្យល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះជឿជាក់ថា ទូរលេខទាំងនេះ បង្ហាញពីការអនុវត្តគោលនយោបាយរបស់បក្ស។ ដោយហេតុផលទាំងអស់នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវតែចាត់ទុកជាមោឃៈ[2926]។

### ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងគោលនយោបាយ

១៥៤៣. ដូចបានឃើញខាងលើរួចមកហើយ យុត្តាធិការលើរឿងក្ដីរបស់អង្គជំនុំជម្រះ មិនបានគ្របដណ្ដប់លើការស្លាប់ដោយសារល័ក្ខខ័ណ្ឌនៃការឃុំឃាំង អង្គហេតុនៃការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខទោសពីសំណាក់អ្នកយាម និងអ្នកសួរចម្លើយ និងល័ក្ខខ័ណ្ឌនៃការបាត់ខ្លួននៅក្រាំងមន្ទីរក្រាំង

---

[2924] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៥៨-៣៩៥៩។

[2925] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៤។

[2926] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៤។

តាចាន់ឡើយ[2927]។ លើសពីនេះទៀត អង្គជំនុំជម្រះទទួលបានបណ្តឹងដោយមិនស្របច្បាប់អំពីអង្គហេតុ "ការរើសអើង" ប្រឆាំងនឹងប្រជាជនថ្មី អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង "ក្រុម" ខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត នៅមន្ទីរក្រាំងតាចាន់[2928]។

១៥៤៤. ដូចបានឃើញខាងលើរួចមកហើយថា អង្គជំនុំជម្រះបានទៅហួសដែនបណ្តឹងសុំឱ្យពិនិត្យ ដោយពិនិត្យ និងទទួលយកតាមផ្លូវច្បាប់ អង្គហេតុពាក់ព័ន្ធនឹង "សត្រូវពិតប្រាកដ ឬសត្រូវតាមការសន្មត" នៅមន្ទីរអូរកន្សែង[2929]។ ដូច្នេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងក្រុមនេះ ត្រូវតែច្រានចោល[2930]។ អង្គជំនុំជម្រះក៏បានទៅហួសដែនបណ្តឹងសុំឱ្យពិនិត្យផងដែរ ដោយសន្និដ្ឋានថា មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ទៅលើជនជាតិវៀតណាម នៅអូរកន្សែង[2931]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានពិចារណាលើបណ្តឹងអំពីអង្គហេតុទាក់ទងនឹងកង្វះការត្រួតពិនិត្យខាងវេជ្ជសាស្ត្រ និងការធ្វើទុក្ខទោសពីសំណាក់ឆ្មាំ និងអ្នកសួរចម្លើយ[2932]។ សេចក្តីសន្និដ្ឋានស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ និងក្រោមរូបភាពអំពើអមនុស្សធម៌ផ្សេងទៀត នៅក្នុងទម្រង់នៃការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សទាក់ទងនឹងអង្គហេតុទាំងនេះ ត្រូវតែច្រានចោល[2933]។

១៥៤៥. នៅទីបញ្ចប់ អង្គជំនុំជម្រះបានអនុវត្តហួសបណ្តឹង ដោយទទួលយកអង្គហេតុនៃការធ្វើឱ្យទៅជាទាសករ នៅទីតាំង ក-១៧ និងមន្ទីរសន្តិសុខភ្នំក្រោល ដោយទទួលយកអង្គហេតុនៃការធ្វើទារុណកម្ម ក្រោមទម្រង់នៃអំពើអមនុស្សធម៌ផ្សេងទៀត ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងដោយ

---

[2927] សូមមើលខាងលើ កថាខណ្ឌ ៤០៤-៤១៥។

[2928] សូមមើលខាងលើ កថាខណ្ឌ ៤៩៥-៥១០។

[2929] សូមមើលខាងលើ កថាខណ្ឌ ៥១១-៥១៣។

[2930] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៣។

[2931] សូមមើលខាងលើ កថាខណ្ឌ ៤១៦-៤១៧។

[2932] សូមមើលខាងលើ កថាខណ្ឌ ៤១៨-៤១៩។

[2933] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៩៤-២៩៩៩ និង ៣០០៤, ៣០០៦, ៣០០៨-៣០១០។

ទទួលយកអង្គហេតុនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់នៃការបាត់ខ្លួនដោយបង្ខំនៅ ក-១១ និងនៅភ្នំក្រោល[2934]។ ជាលក្ខណៈសមហេតុផល សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវតែបដិសេធចោល។

១៥៤៦. ដូចបានឃើញខាងលើរួចមកហើយ កំហុសរបស់អង្គជំនុំជម្រះ មិនអាចនាំឱ្យសន្និដ្ឋានពីអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ នៅ ស-២១ ឡើយ[2935]។ ហើយវាក៏មិនអាចឱ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានពីអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (អំពើអមនុស្សធម៌ផ្សេងទៀត) ក្រោមរូបភាពនៃការបាត់ខ្លួនដោយបង្ខំនៅក្រាំងតាចាន់ ចំពោះមនុស្សដែលបានបាត់ខ្លួននៅសហករណ៍ត្រាំកក់[2936]។ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពឃាតកម្ម និងការសម្លាប់រង្គាលលើជនជាតិវៀតណាម មិនអាចត្រូវបានរកឃើញនៅអូរកន្សែងឡើយ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងជាតិសាសន៍ ក៏មិនត្រូវបានរកឃើញដែរ[2937]។ ជាចុងក្រោយ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំពើឃាតកម្ម ពាក់ព័ន្ធនឹងឈ្មោះ ហ៊ើស ការធ្វើឱ្យទៅជាទាសករ នៅ ក-១១ ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត ក្នុងទម្រង់នៃការបាត់ខ្លួនដោយបង្ខំនៅភ្នំក្រោល ក៏ត្រូវតែចាត់ទុកជាមោឃៈដែរ[2938]។

១៥៤៧. អង្គជំនុំជម្រះបានប្រកាសថា ខៀវ សំផន ទទួលខុសត្រូវ និងមានទោសពីបទប្រព្រឹត្តឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល។ អង្គជំនុំជម្រះបានផ្តល់យុត្តិកម្មដល់ការផ្តន្ទាទោសនេះ ដោយឈរលើមូលដ្ឋាននៃអត្ថិភាព នៃ"គោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ការដាក់ឱ្យនៅដាច់តែឯង អ្នកដែលត្រូវបានចាត់ទុកថាជាសត្រូវដ៏គ្រោះថ្នាក់

[2934] សូមមើលខាងលើ កថាខណ្ឌ ៣៩៧-៤០៣។

[2935] សូមមើលខាងលើ កថាខណ្ឌ ៨២៨-៨៣៥។

[2936] សូមមើលខាងលើ កថាខណ្ឌ ៨៣៦-៨៤០។

[2937] សូមមើលខាងលើ កថាខណ្ឌ ៨៤១-៨៦១។

[2938] សូមមើលខាងលើ កថាខណ្ឌ ៨៦២-៨៦៩, ៨៨០-៨៩១។

បំផុត"[2939]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយកំណត់អត្ថិភាពនៃឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខថាជាគោលនយោបាយមួយ ខណៈដែលឧក្រិដ្ឋកម្មទាំងនេះ គ្រាន់តែជាការបង្ហាញពីការដើរខុសគន្លងនៃដំណើរការសន្តិសុខនៃរបបនេះ[2940] ហើយមិនមែនជាផ្នែកផ្ទាល់មួយនៃផែនការនយោបាយកសាងបដិវត្តន៍សង្គមនិយម ដែល ខៀវ សំផន បានចូលរួមនោះឡើយ។

១៥៤៨. ភាពចាំបាច់នៃអត្ថិភាពនៃគោលនយោបាយទូទៅប្រឆាំងនឹងខ្មាំង ដូចដែលអង្គជំនុំជម្រះបានកំណត់ (ក្រោមរូបភាពជាច្រើន និងដោយប្រែប្រួល) នាំឱ្យផ្សារភ្ជាប់ តាមបែបសិប្បនិម្មិត នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងមន្ទីរសន្តិសុខ ទៅនឹងម្ចាស់បណ្តឹងសាទុក្ខ ខណៈដែលភស្តុតាងជាច្រើនបង្ហាញថា មន្ទីរសន្តិសុខស្ថិតនៅក្រោមបញ្ជាការយោធា ដែលជាវិស័យមួយមិនស្ថិតនៅក្រោមដែនអំណាចរបស់គាត់ទាល់តែសោះ[2941]។ ដូច្នេះ អង្គជំនុំជម្រះបានច្រានចោលដោយមិនត្រឹមត្រូវ នូវទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលអង្គជំនុំជម្រះបានរំឭកដោយផ្នែកខ្លះប៉ុណ្ណោះ[2942]។

១៥៤៩. នៅក្នុងសំអាងហេតុទូទៅរបស់ខ្លួន អង្គជំនុំជម្រះបានសន្និដ្ឋានថា មានការអនុវត្តគោលនយោបាយដោយបណ្តាញរដ្ឋបាលរបស់បក្សទាំងមូល[2943] ដោយផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើសារផ្សេងៗដែលបានផ្ញើទៅ មន្ទីរ ៨៧០ ឬទៅអង្គការ ដើម្បីបញ្ចូល ខៀវ សំផន ទៅក្នុងនោះ[2944]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយដាក់សញ្ញាណស្វ័យទិតៀន នៅក្នុងកម្រិតដូចគ្នានឹងការប្តេជ្ញាចិត្តបដិវត្ត និងការកសាងខ្លួនឡើងវិញ ក្នុងន័យដាក់ទណ្ឌកម្មក្នុងករណីមានកំហុស[2945]។ អង្គជំនុំជម្រះ

[2939] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៥។

[2940] សូមមើលសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៦៩-១៤៧៩។

[2941] សូមមើលសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៨០-១៤៨៤។

[2942] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣២។

[2943] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៥។

[2944] សូមមើលខាងក្រោម កថាខណ្ឌ ១៦១៦-១៦៣៩។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយមិនបានទាញផលវិបាកពីការដែលមន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ស្រុក។ សូមមើលសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ១៤៨៥-១៤៨៦។

[2945] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៨, ៣៩៧២។

ក៏បានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយរាប់បញ្ចូលទៅក្នុងគោលនយោបាយ នូវអង្គហេតុ និងឧក្រិដ្ឋកម្ម ដែលមិនត្រូវបានស្នើសុំឱ្យអង្គជំនុំជម្រះពិនិត្យដោយស្របច្បាប់ និង/ឬដែលមិនបានរកឃើញឱ្យលើសពីវិមតិសង្ស័យ[2946]។

១៥៥០. លើសពីនេះទៅទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនទាញយកផលវិបាកនៃប្រតិបត្តិការសម្ងាត់ និងបិទបាំងនៃមន្ទីរសន្តិសុខជាទូទៅ និងដោយឡែក មន្ទីរ ស-២១ និងដោយសន្និដ្ឋានថា គោលនយោបាយឧក្រិដ្ឋនៃគម្រោងរួម ត្រូវបានអនុវត្តនៅទីនោះ[2947]។ ក៏ប៉ុន្តែ ដូចយើងនឹងឃើញនៅខាងក្រោម[2948] ធាតុផ្សំនៃភ័ស្តុតាងនៅក្នុងសំណុំឯកសារស្តីពីមន្ទីរសន្តិសុខ និងការគ្មានភ័ស្តុតាងបង្ហាញអំពីការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទីនោះ មិនអាចឱ្យគេសន្និដ្ឋានថា គម្រោងរួមបណ្តាលឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះឡើយ។ សេចក្តីសន្និដ្ឋានទាំងអស់ក្នុងន័យនេះ និងការផ្តន្ទាទោសដោយហេតុផលនេះ ត្រូវទុកជាមោឃៈ[2949]។

## ជំពូកទី ៤. "គោលនយោបាយ" ចំពោះក្រុមពិសេស

### ផ្នែកទី ១. គោលនយោបាយចំពោះជនជាតិវៀតណាម

១៥៥១. ដូចយើងបានឃើញខាងលើរួចមកហើយថា អង្គជំនុំជម្រះបានទៅហួសដែនបណ្តឹងមកកាន់ខ្លួន ដោយពិនិត្យ និងទទួលយកតាមផ្លូវច្បាប់នូវអង្គហេតុនៃការនិរទេសជនជាតិវៀតណាម[2950]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពនិរទេសខ្លួនជនជាតិវៀតណាម នៅ

---

[2946] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧៤-៣៩៧៦។ សូមមើលខាងលើ (បណ្តឹង)៖ កថាខណ្ឌ ៣៩៧-៤០៣ កថាខណ្ឌ ៥១៤-៥១៦ (ភ្នំក្រោល) កថាខណ្ឌ ៤០៤-៤១៥ (ក្រាំងតាចាន់) កថាខណ្ឌ ៤១៦-៤១៩, ៥១១-៥១៣ (អូរកន្សែង) កថាខណ្ឌ ៤៩៥-៥០១០ (ក្រាំងតាចាន់) កថាខណ្ឌ ៤២០-៤២៥ (ការបោសសម្អាត) (ធាតុផ្សំ)៖ កថាខណ្ឌ ៨២៥-៨៣៥ (មន្ទីរស-២១) កថាខណ្ឌ ៨៣៦-៨៤០ (ក្រាំងតាចាន់) កថាខណ្ឌ ៨៤១-៨៦១ (អូរកន្សែង) កថាខណ្ឌ ៨៦២-៨៩១ (ភ្នំក្រោល)។

[2947] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៨៧។

[2948] សូមមើលខាងក្រោម កថាខណ្ឌ ១៨៤៩-១៨៧៨។

[2949] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧៨-៣៩៨១, ៣៩៨៣, ៣៩៨៥-៣៩៨៧។

[2950] សូមមើលខាងលើ កថាខណ្ឌ ៣៨០-៣៨៥។

ត្រាំកក់ និងនៅព្រៃវែង ត្រូវតែបដិសេធចោល[2951] រួមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ ចំពោះការបញ្ជូនខ្លួនជនជាតិវៀតណាមចេញពីស្រុកត្រាំកក់[2952]។ អង្គជំនុំជម្រះក៏បានទៅហួសដែនបណ្តឹងផងដែរ ដោយពិនិត្យអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំរបស់ជនជាតិវៀតណាមនៅត្រាំកក់[2953]។ ដូច្នេះ សេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្មនេះ ត្រូវតែបដិសេធចោល[2954]។ នៅចុងបញ្ចប់ អង្គជំនុំជម្រះបានទៅហួសដែនបណ្តឹងទៀត ដោយវិភាគ និងទទួលយកដោយស្របច្បាប់ អង្គហេតុពាក់ព័ន្ធនឹងជនជាតិវៀតណាមនៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[2955]។ ដូច្នេះ សេចក្តីសន្និដ្ឋានស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពឃាតកម្ម ការសម្លាប់រង្គាល និងប្រល័យពូជសាសន៍ នៅក្រៅខេត្តទាំងពីរនេះ ត្រូវទុកជាមោឃៈ[2956]។

១៥៥២. បន្ថែមលើកំហុសពាក់ព័ន្ធនឹងវិសាលភាពនៃបណ្តឹង យើងបានឃើញពីខាងលើមកហើយថា កំហុសរបស់អង្គជំនុំជម្រះមិនអាចនាំទៅដល់ការសន្និដ្ឋានពីអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពនៃការនិរទេសជនជាតិវៀតណាមនៅត្រាំកក់ និងព្រៃវែង[2957] ឬពីអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពនៃការបាត់ខ្លួនជនជាត់វៀតណាមដោយបង្ខំនៅត្រាំកក់នោះដែរ[2958]។ ហើយអង្គជំនុំជម្រះក៏មិនអាចឈានទៅសន្និដ្ឋានបាន ពីអត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពឃាតកម្ម និងសម្លាប់រង្គាលលើជនជាតិវៀតណាម នៅស្វាយរៀង នៅក្នុងដែនទឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ ១៩៧៨ ក្នុងខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ និងនៅវត្តខ្សាច់ ទាក់ទងនឹងជីដូនជីតារបស់ ចន្ថា និងក្រុមគ្រួសាររបស់ ជុំ[2959]។ អង្គជំនុំជម្រះក៏មិនអាចសន្និដ្ឋានបានថា មានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

[2951] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៩ និង ៣៥០៧។

[2952] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៨៩-១១៩២។

[2953] សូមមើលខាងលើ កថាខណ្ឌ ៥៤៧-៥៤៩។

[2954] សំអាងហេតុសាលក្រម កថាខណ្ឌ ១២០១។

[2955] សូមមើលខាងលើ កថាខណ្ឌ ៥២០-៥២១, ៤៣៥-៤៣៨, ៣៨០-៣៨៥។

[2956] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៣-៣៥០១ និង ៣៥១៩។

[2957] សូមមើលខាងលើ កថាខណ្ឌ ៩៦៦-៩៨៦, ១០២៨, ១០៣៣-១០៣៦។

[2958] សូមមើលខាងលើ កថាខណ្ឌ ៧៥៦។

[2959] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-១០១៧។

ជាតិ ក្រោមរូបភាពធ្វើទុក្ខម្នេញ ដោយមូលហេតុជាតិសាសន៍វៀតណាម នៅត្រាំកក់ ព្រៃវែង និង ស្វាយរៀង[2960] ឬមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាមនោះ ឡើយ[2961]។

១៥៥៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសន្និដ្ឋានថាមានគោលនយោបាយចាត់វិធានការប្រឆាំងនឹងជនជាតិវៀតណាម[2962]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសក្នុងការពិចារណាថា ការកសាងបដិវត្តសង្គមនិយមនៅកម្ពុជា បណ្តាលឱ្យមានការវាយប្រហារទៅលើជនជាតិវៀតណាម។ ក្រៅពីការអះអាងទូទៅរបស់ខ្លួន ដែលថា ប.ក.ក កំពុងតស៊ូប្រឆាំងនឹងខ្មាំង អង្គជំនុំជម្រះមិនបានពន្យល់ថា តើការប្រព្រឹត្តិលើជនជាតិវៀតណាមនេះ បានបម្រើឱ្យការអនុវត្តគម្រោងនយោបាយរួម នៅត្រង់ចំណុចណា នោះទេ។

១៥៥៤. ជាសម្ព័ន្ធមិត្តក្នុងអំឡុងពេលសង្គ្រាមប្រឆាំងនឹងអាមេរិក ប្រទេសវៀតណាម និងប្រទេសកម្ពុជា មានប្រវត្តិសាស្ត្រមួយពោរពេញដោយភាពតានតឹងនៃជម្លោះព្រំដែន និងការតស៊ូដើម្បីឥទ្ធិពលនៅកម្រិតនៃគណបក្សកុម្មុយនីស្តទាំងពីរ។ សម័យកាលរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានសម្គាល់ដោយជម្លោះប្រដាប់អាវុធជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលកាន់តែពង្រឹងខ្លួនកាន់តែខ្លាំងឡើង ពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីដល់កម្រិតកំពូល រហូតដល់កងទ័ពវៀតណាមវាយចូលដល់ភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩។ ទាំងនេះគឺជាហេតុផលតែមួយគត់នៃសកម្មភាព និងការថ្លែងសុន្ទរកថារបស់ ប.ក.ក ពាក់ព័ន្ធនឹងវៀតណាមក្នុងអំឡុងពេលនោះ ហើយគឺក្នុងក្របខ័ណ្ឌនេះតែមួយគត់ ដែលជនជាតិវៀតណាមត្រូវបានគេចាត់ទុកថាជាសត្រូវ[2963]។ ចៅក្រមមិនលម្អៀង និងសមហេតុផល គួរតែធ្វើសេចក្តីសន្និដ្ឋានក្នុងន័យនេះ។

---

[2960] សូមមើលខាងលើ កថាខណ្ឌ ៧៤៨-៧៥៥, ៨៥៩-៨៦១, ៨២៨-៨៣៥, ១០២៨-១០៥០។

[2961] សូមមើលខាងលើ កថាខណ្ឌ ១០៥១-១០៩៧។

[2962] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០០០-៤០១៥។

[2963] សូមមើលខាងលើ កថាខណ្ឌ ១៤៤៨-១៤៨៨។

១៥៥៥. ទោះយ៉ាងណា សម្រាប់អង្គជំនុំជម្រះ ការសន្និដ្ឋានពីអត្ថិភាពនៃគោលនយោបាយមួយ គឺចាំបាច់ពីព្រោះវាជាមធ្យោបាយតែមួយគត់សម្រាប់បង្ហាញពីចេតនានៃការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ គឺនៅក្នុងល័ក្ខខ័ណ្ឌទាំងនេះហើយ ដែលអង្គជំនុំជម្រះអាចសន្និដ្ឋានលើប្រធានបទនៃការធ្វើទុក្ខបុកម្នេញ៖

> "ទាក់ទងនឹងធាតុផ្សំអត្តនោម័តិ អង្គជំនុំជម្រះបានកត់សម្គាល់ថាការកំណត់គោលដៅជាប្រព័ន្ធលើបុគ្គលជនជាតិវៀតណាម ដោយសារតែការសន្មតពីជាតិសាសន៍របស់ពួកគេ ដូចដែលបានបង្ហាញដោយភ័ស្តុតាងតាមរយៈ ការរៀបចំបញ្ជីឈ្មោះ គោលនយោបាយខ្សែស្រឡាយខាងម្តាយដែលត្រូវបានអនុវត្តចំពោះគ្រួសារចម្រុះ និងការបោះពុម្ពផ្សាយឯកសារសេសល់ពីរបបនោះ នៅក្នុងទស្សនាវដ្តីទង់បដិវត្ត និងសុន្ទរកថារបស់ឥស្សរជនជាថ្នាក់ដឹកនាំរបស់ ប.ក.ក ដែលកំណត់គោលដៅទៅលើជនជាតិវៀតណាម។ ដោយផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះជឿជាក់ថា ជនជាតិវៀតណាមត្រូវបានកំណត់គោលដៅដោយចេតនានៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ដោយផ្អែកលើការសន្មតពីជាតិសាសន៍របស់ពួកគេ និងយល់ឃើញថា ចេតនាជាក់លាក់ក្នុងការរើសអើងលើពូជសាសន៍ត្រូវបាបនបង្ហាញ។ ហេតុដូច្នេះ អង្គជំនុំជម្រះជឿជាក់ថាធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ត្រូវបានបំពេញ"[2964]។

១៥៥៦. សំអាងហេតុមានលក្ខណៈស្ទើរតែដូចគ្នា ទៅនឹងធាតុផ្សំអត្តនោម័តិនៃបទប្រល័យពូជសាសន៍ដែរ៖

> "ចំពោះធាតុផ្សំអត្តនោម័តិវិញ អង្គជំនុំជម្រះបានរកឃើញថា ប.ក.ក បានកំណត់គោលដៅជាពិសេសលើប្រជាជនវៀតណាមជាក្រុម រួមទាំងជនស៊ីវិលផង នៅទូទាំងសម័យកម្ពុជាប្រជាធិបតេយ្យ។ ជាពិសេស អង្គជំនុំជម្រះអង្គជំនុំជម្រះបានរកឃើញថា "គោលនយោបាយ ១ ទល់នឹង ៣០" របស់ ប៉ុល ពត បានកំណត់គោលដៅយ៉ាងជាក់លាក់លើកងកម្លាំងប្រដាប់អាវុធវៀតណាម ក៏ដូចជាជនស៊ីវិលវៀតណាមផងដែរ។ ជនជាប់ចោទត្រូវបានរកឃើញថា

[2964] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៣។

បានធ្វើបទឧទ្ទេសនាម ឬចូលរួមវគ្គបណ្ដុះបណ្ដាលនយោបាយ ដែលនៅទីនោះជនជាតិវៀតណាម ឬ "ភ្នាក់ងារ" វៀតណាម ត្រូវកំណត់ថាជាខ្មាំង។ ខៀវ សំផន បាននិយាយសំដៅម្ដងហើយម្ដងទៀត និងជាសាធារណៈលើប្រទេសវៀតណាមដោយពាក្យអុជអាល ហើយ នួន ជា បានលើកឡើងជាសាធារណៈថា ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជាបាន "កម្ទេចកលល្បិច" សហព័ន្ធសហព័ន្ធឥណ្ឌូចិនរបស់វៀតណាមដែលមានគោលបំណងលេបត្របាក់ទឹកដី កម្ពុជា និងគោលបំណងកម្ទេចចោលឱ្យអស់នូវពូជសាសន៍អម្បូរកម្ពុជា។ អង្គជំនុំជម្រះជឿជាក់ទៀតថា ជនជាតិវៀតណាមត្រូវបានកំណត់អត្តសញ្ញាណដោយ ប.ក.ក តាមរយៈការបង្កើតបញ្ជីឈ្មោះ និងថា គ្រួសារចម្រុះត្រូវបានកំណត់គោលដៅដោយផ្អែកលើជាតិពន្ធុខ្សែស្រឡាយខាងម្ដាយ"[2965]។

១៥៥៧. ដូច្នេះ អង្គជំនុំជម្រះផ្អែកលើសុន្ទរកថាឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ របស់ ប.ក.ក ដោយបំភ្លៃសុន្ទរកថានោះ ដើម្បីបង្ហាញពីការញុះញង់ឱ្យមានការស្អប់ខ្ពើមជាតិសាសន៍ ដែលមិនមែនជាការសន្និដ្ឋានសមហេតុផលមួយ បើគេធ្វើការវិភាគដោយសត្យានុម័តអំពីពាក្យសម្ដី ឬទស្សនាវដ្ដីរបស់បក្ស។ ដូចយើងបានឃើញខាងលើហើយ វាច្បាស់ណាស់ថាមេដឹកនាំទាំងអស់ដែលបានថ្លែងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ តែងតែថ្លែងសំដៅទៅប្រទេសវៀតណាម ដែលជាសត្រូវរបស់រដ្ឋ និងទៅកងទ័ពវៀតណាម[2966]។

១៥៥៨. នេះជាករណីជាក់ស្ដែង ចំពោះសុន្ទរកថានានារបស់ ខៀវ សំផន ដែលអាចត្រូវបានគេបកស្រាយថាគ្រាន់តែជាការលើកទឹកចិត្តសម្រាប់កិច្ចខិតខំប្រឹងប្រែងរបស់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ដើម្បីការពារដែនដីជាតិប្រឆាំងនឹងសត្រូវយោធា ក្នុងសង្គ្រាមមួយ ដែល ប.ក.ក ទើបបានប្រកាសជាចំហចាប់តាំងពីខែធ្នូ ឆ្នាំ១៩៧៧ មកប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ ជម្លោះប្រដាប់អាវុធនេះ គឺជាចំណុចស្នូលនៃរាល់ក្ដីកង្វល់ ដែលមានតាំងមុនកាលបរិច្ឆេទនោះទៅទៀត ហើយអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយលាក់បាំងទិដ្ឋភាពនេះ ដើម្បីផ្ដល់យុត្តិកម្មដល់ការផ្ដន្ទាទោស។ ដោយដាក់ជនស៊ីវិលវៀតណាម

[2965] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥១៧។

[2966] សូមមើលខាងលើ កថាខណ្ឌ ១០៥៨-១០៩៧។

និងប្រទេសវៀតណាមក្នុងឋានៈជារដ្ឋ និងកងទ័ពរបស់វៀតណាមនៅក្នុងកម្រិតដូចគ្នា អង្គជំនុំជម្រះមិនត្រឹមតែបំភ្លៃភស្តុតាងប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញភាពអគតិទៀតផង។

១៥៥៩. អង្គជំនុំជម្រះបានថ្លែងដោយជឿជាក់ផងដែរថា ជនស៊ីវិលវៀតណាមត្រូវបានចាត់ទុកជាគោលដៅទាំងនៅខេត្តព្រៃវែង ទាំងនៅខេត្តស្វាយរៀង ហើយនេះគឺជាផ្នែកសំខាន់មួយនៃគោលនយោបាយនេះប្រឆាំងនឹងជនជាតិវៀតណាម។ ទោះយ៉ាងណាក្តី វាត្រូវបានគេមើលឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថាមានអំពើឃាតកម្មនៅក្នុងខេត្តទាំងនេះ[2967] និងថាទ្រឹស្តីអំពីខ្សែស្រឡាយខាងម្តាយដែលទំនងជាបានបញ្ជាក់ដោយគោលនយោបាយបំផ្លិចបំផ្លាញរបស់ ប.ក.ក មិនបានឈរលើការពិនិត្យលើអង្គហេតុឡើយ[2968] ហើយថា ប្រជាជនទាំងមូលមានជាប់ពាក់ព័ន្ធនឹងការធ្វើជំរឿន ជាពិសេសដំណើរការរបស់សហករណ៍ដែលទាមទារការគណនារបបអាហាររបស់ប្រជាជនម្នាក់ៗ[2969]។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបានផ្សារភ្ជាប់សុន្ទរកថា ទស្សនាវដ្តីទង់បដិវត្ត/ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត និង ចារិនៃឧក្រិដ្ឋកម្ម ទៅនឹងទីកន្លែងទាំងនេះ ដែលមិនដាក់គោលដៅលើជនជាតិវៀតណាមរស់នៅក្នុងប្រទេសកម្ពុជាឡើយ។

១៥៦០. ហេតុដូច្នេះ អង្គជំនុំជម្រះមិនបានរកឃើញអត្ថិភាពនៃគោលនយោបាយទូទៅមួយដែលចាត់វិធានការអរិភាពប្រឆាំងនឹងជនជាតិវៀតណាមសុទ្ធ ឬគោលនយោបាយកម្ទេចជនជាតិវៀតណាម ដោយផ្នែក ឬទាំងស្រុង ក្នុងឋានៈជាក្រុមពូជសាសន៍ នោះទេ[2970]។ ដោយសារកំហុសអង្គហេតុ និងអង្គច្បាប់ដែលបានពិនិត្យខាងលើ អង្គជំនុំជម្រះបានបរាជ័យក្នុងការបង្ហាញពីឧក្រិដ្ឋកម្មទាំងអស់ ដែលខ្លួនបានចាត់ទុកថាជាផ្នែកមួយនៃគោលនយោបាយនេះ[2971]។ ក្នុងលក្ខខ័ណ្ឌទាំងនេះ រាល់ការសន្និដ្ឋានរបស់អង្គជំនុំ

---

[2967] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-១០១៧។

[2968] សូមមើលខាងលើ កថាខណ្ឌ ១០៤៣-១០៤៨។

[2969] សូមមើលខាងលើ កថាខណ្ឌ ១០៩៦។

[2970] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០០០, ៤០០៣-៤០០៤។

[2971] សូមមើលខាងលើ កថាខណ្ឌ ៩៦៦-១០៩៧។

ជម្រុះលើអត្ថិភាពនៃគោលនយោបាយនេះ និងលើការដែលថា គោលនយោបាយនេះទំនងជាបានបម្រើគម្រោងរួម ត្រូវទុកជាមោឃៈ[2972] រួមទាំងការផ្ដន្ទាទោស ខៀវ សំផន ផងដែរ[2973]។

## ផ្នែកទី ២. គោលនយោបាយចំពោះជនជាតិចាម

១៥៦១. គួររំឭកថា ខៀវ សំផន ទទួលបានការលើកលែងការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ពាក់ព័ន្ធនឹងការកាប់សម្លាប់ជនជាតិចាម[2974]។ ការរិះគន់លើគោលនយោបាយ (រងការចោទប្រកាន់) ចំពោះក្រុមនេះ នឹងត្រូវរឹតត្បិត ក្នុងការកាត់ទោសគាត់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ក្រោមរូបភាពមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារហេតុផលនយោបាយ និងសាសនា និងក្រោមរូបភាពអំពើអមនុស្សធម៌ផ្សេងទៀត ចំពោះអង្គហេតុដែលត្រូវបាត់ចាត់ទុកថាជាការជម្លៀសជនជាតិចាមដោយបង្ខំ។

១៥៦២. ដូចដែលបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយវិនិច្ឆ័យអង្គហេតុដែលមិនបានប្ដឹងមកខ្លួនដោយស្របច្បាប់។ ជាក់ស្ដែង យុត្តាធិការលើរឿងក្ដីរបស់អង្គជំនុំជម្រះ មិនគ្របដណ្ដប់លើអង្គហេតុ នៃ"ការរើសអើង" ដោយហេតុផលសាសនាប្រឆាំងនឹងជនជាតិចាមដែលបានកើតឡើងនៅទំនប់១មករា។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវិនិច្ឆ័យអង្គហេតុទាំងនេះ[2975]។ អង្គជំនុំជម្រះក៏មិនដែលបានទទួលបណ្ដឹងអំពីអង្គហេតុដែលជាធាតុផ្សំនៃឃាតកម្ម ក្នុងទម្រង់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅភូមិទ្រាឡើយ ហើយដោយមូលហេតុនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា មានធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពឃាតកម្ម នៅមន្ទីរសន្តិសុខភូមិទ្រា ក្នុងឆ្នាំ១៩៧៨ នោះដែរ[2976]។ សេចក្ដីសន្និដ្ឋានទាំងអស់ ក្នុងន័យនេះ ត្រូវទុកជាមោឃៈ។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានប្រកាសខ្លួនថាមានយុត្តាធិការក្នុងការវិនិច្ឆ័យលើអង្គ

[2972] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០០០-៤០១២។

[2973] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩១-៤២៩៥។

[2974] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៨។

[2975] សូមមើលខាងលើ កថាខណ្ឌ ៣៩៥។

[2976] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣០៦-៣៣០៨។ សូមមើលខាងលើ កថាខណ្ឌ ៥១៧-៥១៨។

ហេតុនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលបានប្រព្រឹត្តទៅក្នុងអំឡុងពេលប្រជាជនដំណាក់កាលទី ២[2977]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយវិនិច្ឆ័យអង្គហេតុនៃការជម្លៀសដោយបង្ខំ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលជម្លៀសប្រជាជនដំណាក់កាលទី ២ ក្រោមបទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើអមនុស្សធម៌ផ្សេងទៀត ពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ ខណៈដែលអង្គជំនុំជម្រះគួរតែបានកត់សម្គាល់ថា អង្គហេតុទាំងនេះត្រូវបានជំនុំជម្រះស្ពាលរួចហើយ[2978]។ រាល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ ក្នុងន័យនេះ ត្រូវតែចាត់ទុកជាមោឃៈ។

១៥៦៣. បន្ថែមលើបញ្ហាវិសាលភាពនៃបណ្តឹង ដូចបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ធ្វើឱ្យសេចក្តីសន្និដ្ឋានរបស់ខ្លួនអស់សុពលភាព ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ក៏ដូចជាឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការជម្លៀសដោយបង្ខំ។ អង្គហេតុដែលមិនបានអះអាងឱ្យហួសពីវិមតិសង្ស័យ មិនអាចដាក់បញ្ចូលទៅក្នុង "គោលនយោបាយ" ដែលអង្គជំនុំជម្រះចាត់ទុកថាមានលក្ខណៈឧក្រិដ្ឋនោះឡើយ។ រាល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ នៅក្នុងន័យនេះ ត្រូវទុកជាមោឃៈ។ ដូចបានឃើញខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថាបានរកឃើញធាតុផ្សំសត្យានុម័តិនៃបទឧក្រិដ្ឋកម្មតាមរយៈអំពើឃាតកម្ម ស្របតាមកម្រិតតម្រូវនៃភ័ស្តុតាង ចំពោះជនរងគ្រោះនៅវត្តអូរត្រកួន និងជនជាតិចាមមួយចំនួនធំនៅស្រុកក្រូចឆ្មារ ក្នុងឆ្នាំ១៩៧៧[2979]។ ធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិ នៃឧក្រិដ្ឋកម្ម តាមរយៈការសម្លាប់រង្គាល ពាក់ព័ន្ធនឹងការកាប់សម្លាប់នៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧ និងនៅភូមិទ្រា ក្នុងឆ្នាំ១៩៧៨ ក៏មិនអាចបង្ហាញឱ្យឃើញថាមានមូលដ្ឋាននោះដែរ។ រាល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ ក្នុងន័យនេះ ត្រូវតែចាត់ទុកជាមោឃៈ។

---

[2977] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣២០។ សូមមើលខាងលើ កថាខណ្ឌ ៥៣៨-៥៤២។

[2978] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១៨៤, ៣៣៣៥។ សូមមើលខាងលើ កថាខណ្ឌ ៥៣៨-៥៤២, ៥៤៤-៥៤៦។

[2979] សូមមើលខាងលើ កថាខណ្ឌ ៨៩៤-៩២៤។

១៥៦៤. ដូចដែលបានឃើញខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយពិចារណាថា បានរកឃើញធាតុផ្សំសត្យានុម័តិនៃឧក្រិដ្ឋកម្មតាមរយៈការធ្វើទារុណកម្ម ចំពោះការវាយដំលើ អ៊ិត សែន និងបុរស១ជនជាតិចាម នៅមន្ទីរសន្តិសុខភូមិទ្រា នៅថ្ងៃចាប់ខ្លួន អ៊ិត សែន ក្នុងឆ្នាំ១៩៧៨[2980]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងន័យដដែល ដោយពិចារណាថាមានធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្ម តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើជនជាតិចាម ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនទ្រង់ទ្រាយធំ ពីភូមិភាគបូព៌ាទៅភូមិភាគកណ្តាល[2981]។ រាល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ នៅក្នុងន័យនេះ ត្រូវតែចាត់ទុកជាមោឃៈ។ ដូចដែលបានឃើញខាងលើ ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសន្និដ្ឋានថាមានធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិ នៃបទឧក្រិដ្ឋតាមរយៈការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនាលើជនជាតិចាម ស្របតាមកម្រិតតម្រូវនៃភ័ស្តុតាង នៅទំនប់១មករា ស្រុកក្រូចឆ្មារ ភូមិភាគកណ្តាល និងនៅកន្លែងផ្សេងៗនៃប្រទេសកម្ពុជា[2982]។ រាល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ នៅក្នុងន័យនេះ ត្រូវទុកជាមោឃៈ។ នៅចុងបញ្ចប់ ដូចដែលបានឃើញខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា បានរកឃើញការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមរូបភាពអំពើអមនុស្សធម៌ផ្សេងទៀត ចំពោះអង្គហេតុនៃការជម្លៀសដោយបង្ខំ ក្នុងអំឡុងពេលជម្លៀសប្រជាជនដំណាក់កាលទី ២[2983]។ សេចក្តីសន្និដ្ឋានទាំងនេះ ត្រូវទុកជាមោឃៈ។

១៥៦៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា មានអត្ថិភាពនៃ "គោលនយោបាយរបស់ ប.ក.ក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលកំណត់គោលដៅលើជនជាតិចាម ដោយសារតែអត្តសញ្ញាណរបស់ក្រុមពួកគេ"[2984]។ បើតាមអង្គជំនុំជម្រះ វិធានការទាំងនេះគឺជា "ផ្នែកមួយនៃគោលនយោបាយជាមូលដ្ឋានរបស់បក្សក្នុងការបង្កើតសង្គមខ្មែរមួយដែលមិនមានសាសនា និង

[2980] សូមមើលខាងលើ កថាខណ្ឌ ៩២៥។

[2981] សូមមើលខាងលើ កថាខណ្ឌ ៩២៦-៩៣៦។

[2982] សូមមើលខាងលើ កថាខណ្ឌ ៨០៤-៨១៣, ៩៣៣-៩៦៣។ សូមមើលផងដែរ កថាខណ្ឌ ៦៤២-៦៥៥, ៦៥៧។

[2983] សូមមើលខាងលើ កថាខណ្ឌ ៩៦៤-៩៦៥។

[2984] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩០។

រួបរួមគ្នា”[2985]។ ប៉ុន្តែ គោលបំណងតាមសន្មតនេះរបស់អង្គជំនុំជម្រះ កើតចេញពីការបកស្រាយខុសលើទៅភ័ស្តុតាង។ គ្មានឯកសារផ្លូវការណាមួយរបស់ ប.ក.ក អាចឱ្យបង្ហាញអំពីគោលនយោបាយប្រឆាំងនឹងជនជាតិចាម (១) ដែលត្រូវបានបញ្ជាក់អះអាងដោយសាក្សីជាច្រើន (២) និងពន្យល់ថាហេតុអ្វីបានជាភ័ស្តុតាងមិនបញ្ជាក់អំពីការកំណត់គោលដៅលើជនជាតិចាម (៣)។

## ១. គ្មានឯកសារផ្លូវការស្តីពីគោលនយោបាយជាតិប្រឆាំងនឹងជនជាតិចាម

១៥៦៦. ក្រៅពីសង្គមគ្មានសាសនា ផែនការនយោបាយរបស់ខ្មែរក្រហម ក្រោយពេលឡើងកាន់អំណាច គឺប្រែក្លាយទៅជាសង្គមមិនជឿព្រះ ដែលសាសនាត្រូវទុកមួយឡែក ធៀបនឹងគោលបំណងបដិវត្តន៍នៃការកសាងប្រទេស[2986]។ ខុសពីការអះអាងរបស់អង្គជំនុំជម្រះ អត្តសញ្ញាណជាក់លាក់របស់ជនជាតិចាមក្នុងឋានៈជាសមាជិកក្រុម មិនចោទជាបញ្ហាដល់ ប.ក.ក ទេ ហើយផ្ទុយទៅវិញ ប.ក.ក ចាត់ទុកជនជាតិចាមជាប្រជាជនកម្ពុជា ដែលត្រូវបានស្ញើចសរសើរអំពីការចូលរួមក្នុងបដិវត្តន៍ នៅក្នុងបទយកការណ៍មួយ ចុះខែតុលា ឆ្នាំ១៩៧៥[2987]។ នៅក្នុងឯកសារនោះ គេហៅថា “បងប្អូនខ្មែរឥស្លាម” ដែលមិនបង្ហាញអំពីការប្រឆាំងនឹងជនជាតិចាមទេ។

១៥៦៧. នេះគឺជាភ័ស្តុតាងដ៏សំខាន់ ដែលពន្យល់ផងដែរថា ហេតុអ្វីបានជាអង្គជំនុំជម្រះមិនអាចរកបាននូវឯកសារនយោបាយរបស់បក្សដែលចាត់ទុកជនជាតិចាមជាខ្មាំង។ ជាក់ស្តែង ក្នុងទស្សនាវដ្តី “ទង់បដិវត្ត” ឆ្នាំ១៩៧៦ គេនិយាយសំដៅដល់ប្រជាជាតិនៃកម្ពុជាប្រជាធិបតេយ្យ “ដែលមានទាំងជនជាតិខ្មែរ ទាំង

---

[2985] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩០។

[2986] ឧទាហរណ៍ សូមមើលឯកសារ “អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស” ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ឯកសារ **E3/99** ERN 00072400៖ “ពីមុនយើងប្រមូលកម្លាំងប្រជាជាតិប្រជាធិបតេយ្យដើម្បីវាយខ្មាំងរំដោះប្រទេស។ ឥឡូវយើងប្រមូលដើម្បីការពារប្រទេសឱ្យណែន និងកសាងប្រទេសឱ្យខ្លាំងក្លា” (យើងគូសបន្ទាត់ពីក្រោម)។

[2987] *Moslem guaranteed full Democratic liberties* ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៥ (FBIS) ឯកសារ **E3/272** ERN EN 00167520 *(« After liberation, [Cambodian Moslem] quickly achieved political awakening. Correctly educates and guided by the revolutionary organization, they have formes a new revolutionary concept regarding problems of production and the nation. Closely united with teh Cambodian brothers, they have organized themselves into solidarity groups for production […]. »).*

ជនជាតិផ្សេងៗ ដែលមាននៅតាមមូលដ្ឋាននានា"[2988]។ នៅឆ្នាំ១៩៧៧ ឯកសារបោះពុម្ពផ្សាយមួយរបស់កម្ពុជាប្រជាធិបតេយ្យ បាននិយាយអំពីប្រជាជន ដែលរួមមានជនជាតិខ្មែរ និង "ជនជាតិភាគតិចមួយចំនួនទៀត ដែលកំពុងរស់នៅជាមួយគ្នា ក្នុងមហាគ្រួសារ មានការសាមគ្គីគ្នាយ៉ាងជិតស្និទ្ធ ក្នុងបុព្វហេតុការពារ និងកសាងប្រទេស"[2989]។ ដូចគ្នាផងដែរ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈជានិមិត្តរូប បានលើកឡើងអំពីភាព "សុខដុមរមនា" និង "មហាសាមគ្គីជាតិទាំងមូល" ដើម្បីកសាងប្រទេស[2990]។ ត្រង់នេះទៀត គ្មានការចាត់ទុកជនជាតិចាមជាខ្មាំងទេ។

១៥៦៨. ទោះបីជាយើងគិតថាឯកសារទាំងនេះសុទ្ធតែជាការឃោសនាក៏ដោយ ក៏គួរកត់សម្គាល់ថា សារមានភាពវិជ្ជមាន និងអំពាវនាវឱ្យរួបរួមជាតិ។ ប៉ុន្តែ នៅពេលចង់បរិហារគូបដិបក្ខ ឬខ្មាំងនយោបាយ ដែលត្រូវបានចាត់ទុកជាពួកចក្រពត្តិ នាយទុន ឬប្រតិកិរិយា ប.ក.ក ធ្វើការបរិហារ។ មិនមានករណីបែបនេះចំពោះជនជាតិចាមឡើយ។

១៥៦៩. ជំនួសឱ្យការទាញសេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ យោងតាមភ័ស្តុតាងឯកសារ គឺថាមិនមានគោលនយោបាយកំណត់គោលដៅលើជនជាតិចាម អង្គជំនុំជម្រះបែរជាប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយផ្តើមចេញពីការកើតឡើងនូវឧក្រិដ្ឋកម្ម ដើម្បីប៉ុនប៉ងផ្តល់យុត្តិកម្មដល់ទ្រឹស្តីរបស់ខ្លួនដោយបំភ្លៃភ័ស្តុតាង[2991]។ ភាពស្មុគស្មាញនៃការប៉ុនប៉ងផ្តល់យុត្តិកម្មដល់អត្ថិភាពនៃគោលនយោបាយនេះ បង្ហាញឱ្យឃើញច្បាស់អំពីការស្ថាបនាដ៏ឆ្ពាតវៃជាចាំបាច់ ដើម្បីឈានដល់សេចក្តីសន្និដ្ឋាននេះ ដែលគួរណាតែបញ្ជាក់ដោយអង្គហេតុ ប្រសិនបើមានអត្ថិភាពមែន។

---

[2988] ទស្សនាវដ្តី ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៦ ឯកសារ **E3/759** ERN 00062749។

[2989] កម្ពុជាប្រជាធិបតេយ្យឈានទៅមុខ ខែសីហា ឆ្នាំ១៩៧៧ ឯកសារ **E3/1388** ERN S00679919 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[2990] រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ឯកសារ **E3/259** ERN FR S 00012651។

[2991] ជាពិសេស សូមមើលការបំប្លែងសម្តីរបស់លោក ខៀវ សំផន ដែលមិនពាក់ព័ន្ធនឹងជនជាតិចាមទាល់តែសោះ សំអាងហេតុនៃសាលក្រម កថាខណ្ឌ ៣២០៧, ៣២១១, ៣២១៦។

១៥៧០. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបាន "ជឿជាក់ថា ការប្រព្រឹត្តិទៅលើជនជាតិចាម បង្ហាញអំពីគោលដៅរបស់ ប.ក.ក ក្នុងការបង្កើតសង្គមមួយដែលមិនមានសាសនារួបរួមគ្នាដោយមិនមានការបែងចែកវណ្ណៈ ហើយដើម្បីសម្រេចបានបែបនេះ បក្សមានចេតនាក្នុងការលុបបំបាត់វណ្ណៈ និងវប្បធម៌ ជាតិ និងសាសនាដែលខុសគ្នាទាំងអស់ចេញ"[2992]។ ក្រៅពីនេះទៀត អង្គជំនុំជម្រះបានយល់ឃើញថា "គោលដៅនេះត្រូវបានអនុវត្តឡើង តាមរយៈគោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យនៅដោយឡែក និងកម្ទេចខ្លាំង"[2993]។

១៥៧១. ដើម្បីឈានដល់ការធ្វើសេចក្ដីសន្និដ្ឋាននេះ អង្គជំនុំជម្រះបានប្រមូលផ្ដុំការតស៊ូវណ្ណៈ ផែនការលុបបំបាត់សាសនា ការតស៊ូប្រឆាំងនឹងសាសនា និងការតស៊ូប្រឆាំងនឹងខ្មាំង។ ដំណើរការនេះផ្ទុយគ្នាស្រឡះនឹងការប៉ុនប៉ងបង្ហាញអំពីការប្រព្រឹត្តិជាក់លាក់ ដោយសារតែភាពជាសមាជិកក្រុមជនជាតិចាម។ ដំណើរការនេះមិនត្រឹមតែខុសឆ្គង ដោយសារតែគ្មានភស្តុតាងបង្ហាញអំពីគោលនយោបាយប្រឆាំងនឹងជនជាតិចាម ដែលត្រូវបាន ប.ក.ក កំណត់នៅថ្នាក់ជាតិប៉ុណ្ណោះទេ ថែមទាំងផ្ទុយនឹងការពិតនៃអង្គហេតុទៀតផង។

## ២. គ្មានគោលនយោបាយជាតិ ដែលបញ្ជាក់ដោយសាក្សី

### ២.១. កម្មាភិបាលជាន់ខ្ពស់

១៥៧២. អង្គជំនុំជម្រះបានលាក់បាំងដោយមិនត្រឹមត្រូវនូវសក្ខីកម្មរបស់សាក្សីជាច្រើន ដែលរាំងស្ទះដល់ទ្រឹស្ដីរបស់ខ្លួនអំពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងជនជាតិចាម។ ផ្ទុយទៅវិញ ឌុច ដែលអង្គជំនុំជម្រះបានយល់ឃើញថាអាចជឿជាក់បាន ជាច្រើនដង ទោះបីជាគាត់ចូលចិត្តស្មានក៏ដោយ បានឆ្លើយនៅក្នុងសវនាការថា ទាំង សុន សេន ទាំង នួន ជា "មិនដែលណែនាំអំពីបញ្ហាជនជាតិចាមទេ អត់សោះ"[2994]។ ម្យ៉ាងទៀត គាត់មិន "ដែលបានកត់សម្គាល់ពីការចាប់ខ្លួនជនជាតិចាមណាម្នាក់ទេ"

---

[2992] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩៣។

[2993] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩៣។

[2994] ឌុច៖ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/438.1** ទំព័រ ៣១ ម៉ោង 10.35.01 និងអំពីការសន្និដ្ឋានពេលក្រោយព្រឹត្តិការណ៍របស់ឌុច ទំព័រ ៣៣ ម៉ោង 10.39.11។

ហើយជាពិសេស គាត់បានអះអាងថា "គ្មានគោលនយោបាយសម្លាប់ជនជាតិចាម" នោះទេ ដោយគាត់បានឆ្លើយថា "ឯកសារបក្សអត់មានទេ ខ្ញុំអត់ទាន់ឃើញទេអង្គាល់ណោះ"[2995]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានធ្វេសប្រហែសនឹងទិដ្ឋភាពនេះនៃសក្ខីកម្មរបស់ប្រធាន ស-២១ ជាមន្ទីរសន្តិសុខធំជាងគេនៅក្នុងប្រទេស ដែលមានបុគ្គលិកជាជនជាតិចាមផងដែរ[2996]។ ក្នុងកម្រិតខ្ពស់ អង្គជំនុំជម្រះគួរណាតែយកចិត្តទុកដាក់លើចម្លើយរបស់ ម៉ាត់ លី ជាជនជាតិចាមស្ថិតនឹងមេដឹកនាំជាន់ខ្ពស់ ប.ក.ក ដែលបានបដិសេធគំនិតនៃគោលនយោបាយជាក់លាក់ប្រឆាំងនឹងជនជាតិចាម[2997]។ ជាក់ស្តែង គាត់បានឆ្លើយថា ប៉ុល ពត "មិនស្អប់" ចាមទេ ហើយមូលហេតុនៃការចាប់ខ្លួន រួមទាំងគ្រួសារគាត់ គឺដោយសារគេចោទថាជាខ្មែរសេរីអា កាហ្សេបេ ឬដៃជើងយួន[2998]។ ម្យ៉ាងវិញទៀត គាត់បានលើកឡើងអំពីការបង្ក្រាបខ្មែរ "ឱ្យអស់"[2999]។

## ២.២. អ្នកជំនាញ

១៥៧៣. អង្គជំនុំជម្រះមិនអើពើនឹងចម្លើយស៊ីចង្វាក់គ្នារបស់អ្នកជំនាញ ឬសាក្សីជាច្រើន ដែលដឹងច្បាស់ នោះទេ។ ម្យ៉ាងវិញទៀត សូមរំឭកថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបដិសេធមិនព្រមកោះហៅ Stephen HEDER និង François PONCHAUD ឱ្យមកផ្តល់សក្ខីកម្មម្តងទៀត តាមការស្នើសុំ

---

[2995] ឧទ្ធ៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/443.1** ទំព័រ ១១៧-១១៨ ក្រោយម៉ោង 15.36.37 ទំព័រ ១២២ ម៉ោង 15.46.40។

[2996] ឧទ្ធ៖ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ទំព័រ ៥៥ ម៉ោង 11.26.57។ ដូចបានបញ្ជាក់ថា ស៊ឹម មែល សមាជិកចាមនៅមន្ទីរ ស-២១ ត្រូវបានដាក់ទណ្ឌកម្មដោយសារបានប្រព្រឹត្តកំហុសជាច្រើន ដោយមិនគិតពីសញ្ជាតិចាមរបស់គាត់ទេ។

[2997] សៀវភៅរបស់លោក Ben KIERNAN *អំពើប្រល័យពូជសាសន៍នៅកម្ពុជា ឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩៖ ពូជសាសន៍ មនោគមន៍វិជ្ជា និងអំណាច* ឆ្នាំ១៩៩៦ ឯកសារ **E3/1593** ទំព័រ ៣២៣ ERN FR 00639036។ លោក ម៉ាត់ លី នៅក្នុងគណៈកម្មាធិការនៃ ប.ក.ក នៅត្បូងឃ្មុំ។ បទសម្ភាស៍ជាមួយលោក ម៉ាត់ លី ដោយលោក Stephen HEDER មិនមានកាលបរិច្ឆេទ ឯកសារ **E3/390** ERN FR 00479808-09 និង 19។

[2998] ចម្លើយរបស់លោក ម៉ាត់ លី ផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០០ ឯកសារ **E3/7821** ERN FR 00611786។

[2999] ចម្លើយរបស់លោក ម៉ាត់ លី ផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០០ ឯកសារ **E3/7821** ERN FR 00611786។

របស់មេធាវីការពារក្តី[3000]។ ទោះជាយ៉ាងនេះក្តី នៅក្នុងសំណុំរឿង ០០២/០១ អ្នកជំនាញ និងសាក្សីទាំងនេះបាននិយាយដូចៗគ្នាថា មិនមានគោលនយោបាយជាក់លាក់ប្រឆាំងនឹងជនជាតិចាមទេ។ ថ្វីត្បិតតែ Philip SHORT បាននិយាយអំពី "ការបង្ក្រាប [ដ៏សាហាវឃោរឃៅលើការបះបោរ]" នៅឆ្នាំ ១៩៧៥ ប៉ុន្តែ គាត់បានយល់ឃើញថា "មិនមានការប៉ុនប៉ងដើម្បីលុបបំបាត់ក្រុមជាតិពន្ធុណាមួយទេ" ពាក់ព័ន្ធនឹងជនជាតិចាម[3001]។ François PONCHAUD ដែលធ្លាប់រស់នៅរាប់ទសវត្សរ៍ នៅក្នុងសង្គមកម្ពុជា បានបញ្ជាក់ក្នុងន័យដូចគ្នានេះ ដោយបានលើកឡើងអំពីការកើនឡើងនូវភាពតានតឹង នៅឆ្នាំ ១៩៧៨ "ព្រោះមានរឿងសង្គ្រាមនឹងវៀតណាម"[3002]។ ម្យ៉ាងវិញទៀត Stephen HEDER បានឆ្លើយនៅក្នុងសវនាការថា គោលនយោបាយដំបូងដែលត្រូវបានចាត់ទុកថាប្រឆាំងនឹងជនជាតិចាម "ត្រូវបានអនុវត្តដោយកម្មាភិបាលដែលជាជនជាតិចាមផ្ទាល់តែម្តង"[3003]។ សូម្បីតែ Henri LOCARD ដែលមានភាពអគតិលើ ខៀវ សំផន និងស្អប់មេធាវីការពារក្តី ក៏បានទទួលស្គាល់នៅក្នុងសវនាការថា ក្នុងការងារប្រមូលចងក្រងពាក្យស្លោករបស់កម្ពុជាប្រជាធិបតេយ្យ គាត់មិនឃើញមាន "ពាក្យស្លោកណាប្រឆាំងជនជាតិចាមនោះទេ" ហើយគាត់បានបន្ថែមទៀតថា "មិនមែនដោយសាររបបនោះស្អប់ពួកគាត់ជាជនជាតិភាគតិចនោះទេ"[3004]។

១៥៧៤. ដូច្នេះ ដូចបានវែកញែកយ៉ាងទូលំទូលាយខាងលើ បញ្ហាមិនមែនគោលនយោបាយកំណត់គោលដៅជាក់លាក់នោះឡើយ គឺការអនុវត្តវិធានការស្មើភាពចំពោះប្រជាជនទាំងអស់[3005]។ ភាពចម្រុះគ្នានៃសក្ខីកម្មរបស់អតីតកម្មាភិបាល និងអ្នកគ្រប់គ្រងនៅតាមមូលដ្ឋាន ដែលត្រូវបានបញ្ជាក់អះអាងពីអ្នកជំនាញបង្ហាញឱ្យឃើញថា មិនមានគោលនយោបាយចេញមកពី ប.ក.ក នោះទេ គឺមានការគ្រប់គ្រងនៅតាម

---

[3000] សូមមើលខាងលើ កថាខណ្ឌ ១៦៥- ១៧៣។

[3001] Philip SHORT៖ ប្រតិចារឹក ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/192.1** ទំព័រ 19 ម៉ោង 09.40.54។

[3002] François PONCHAUD៖ ប្រតិចារឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/179.1** ម៉ោង 13.44.15។ ប្រតិចារឹក ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/180.1** ម៉ោង 10.23.30។

[3003] Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/223.1** ម៉ោង 15.15.25។

[3004] Henri LOCARD៖ ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E1/450.1** ក្រោយម៉ោង 15.22.40។ ប្រតិចារឹក ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E1/453.1** ក្រោយម៉ោង 09.34.01។

[3005] សូមមើលខាងលើ កថាខណ្ឌ ៩៣៩-៩៦១។

មូលដ្ឋានលើប្រជាជនខ្មែរ ឬចាម[3006]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានចេញពីភ័ស្តុតាងទាំងនេះថា មានការអនុវត្តដូចៗគ្នា ឬមានសេចក្តីណែនាំមកពីមេដឹកនាំ ប.ក.ក ឱ្យកំណត់គោលដៅជាក់លាក់លើជនជាតិចាមនោះឡើយ ហើយនេះគឺជាការពន្យល់ថា ការពិនិត្យអង្គហេតុដោយមិនលម្អៀង និងជាសត្យានុម័តិ មិនអាចឱ្យសន្និដ្ឋានអំពីការកំណត់គោលដៅលើជនជាតិចាមឡើយ។

## ៣. ការកំណត់គោលដៅលើជនជាតិចាម ដោយគ្មានភ័ស្តុតាងបង្ហាញ

១៥៧៥. ដូចបានឃើញពីខាងលើ ក្រៅពីកំហុសអង្គច្បាប់ពាក់ព័ន្ធនឹងវិសាលភាពនៃបណ្តឹង និងគោលការណ៍នីត្យានុកូលភាព[3007] អង្គជំនុំជម្រះមិនបានបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ជនជាតិចាមត្រូវបានកំណត់គោលដៅ ក្នុងក្របខ័ណ្ឌនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬសាសនា នោះឡើយ[3008]។ ពួកគេបានធ្វើការ ក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងប្រជាជនផ្សេងទៀតដែរ នៅតាមសហករណ៍ និងការដ្ឋាន ពួកគេត្រូវបានជម្លៀស ក្នុងពេលជាមួយគ្នានឹងប្រជាជនផ្សេងទៀតដែរ ហើយពួកគេបានទទួលរងនូវការប្រព្រឹត្តិដូចគ្នានឹងប្រជាជនផ្សេងទៀតដែរ ពាក់ព័ន្ធនឹងការចាប់ខ្លួន។ ជោគវាសនារបស់ពួកគេមិនខុសពីខ្មែរមិនកាន់សាសនាឥស្លាមនោះឡើយ។ ម្យ៉ាងវិញទៀត សាក្សីជាច្រើនបានសង្កត់ធ្ងន់លើការរៀបរាប់អំពីការប្រព្រឹត្តិស្មើភាពគ្នា ដែលផ្ទុយនឹងការសន្និដ្ឋានអំពីអត្ថិភាពនៃការរើសអើង ឬចេតនារើសអើងលើជនជាតិចាម[3009]។

---

[3006] គួរកត់សម្គាល់ថាភាពខុសគ្នានេះត្រូវបានលើកឡើងតាមហេតុការណ៍ ដោយចៅក្រមស៊ើបសួរ ទោះបីជាចៅក្រមមិនបានទាញចេញជាសេចក្តីសន្និដ្ឋានសមហេតុសមផលយ៉ាងណាក្តី។ ពីព្រោះថា នៅកថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយ ចៅក្រមបង្ខំចិត្តលើកឡើងថា "ចាមក្នុងស្រុកត្រាំកក់ ត្រូវបានប្រព្រឹត្តដូចគ្នានឹងអ្នកផ្សេងទៀតដែរ"។ ដូចគ្នានេះដែរ នៅកថាខណ្ឌ ៥០០ ចៅក្រមបានកត់សម្គាល់ទាក់ទងនឹងមន្ទីរសន្តិសុខ ក្រាំងតាចាន់ ថា៖ "ប៉ុន្តែ ប្រជាជនកណ្តាលក៏មានប្រជាជនមូលដ្ឋាន អតីតទាហាន លន់ នល់ កម្មាភិបាលនៃ ប.ក.ក ចិន វៀតណាម និងចាមផងដែរ។ ទាក់ទងនឹងចាម សាក្សីដែលរស់នៅក្នុងស្រុកត្រាំកក់ និយាយថា ចាមត្រូវបានគេប្រព្រឹត្តដូចគ្នានឹងអ្នកដទៃដែរ"។ យើងក៏បានរកឃើញសេចក្តីទាំងនោះ នៅក្នុងសក្ខីកម្មនៅសវនាការផងដែរ ស្តីពីមន្ទីរសន្តិសុខត្រាំកក់។

[3007] សូមមើលខាងលើ ផ្នែកទី ២ និងទី ៣។

[3008] សូមមើលខាងលើ កថាខណ្ឌ ៩៣៩-៩៦១។

[3009] សូមមើលខាងលើ កថាខណ្ឌ ៩២៦-៩៣២។

១៥៧៦. ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត/ការជម្លៀសដោយបង្ខំ សូមរំឭកថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានរំលោភលើវិសាលភាពនៃបណ្ដឹង[3010]។ ចាប់ពីពេលដែលអង្គជំនុំជម្រះខកខានមិនបានបង្ហាញថា ការផ្លាស់ទីលំនៅជនជាតិចាម នៅដំណាក់កាលទីពីរ មានលក្ខណៈរើសអើង អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ថា ជនជាតិចាមត្រូវបានរាប់បញ្ចូលក្នុងការផ្លាស់ទីលំនៅដំណាក់កាលទីពីរ ដែលត្រូវបានចោទប្រកាន់ក្រុមដដែលពិនិត្យរួចមកហើយ ក្នុងសំណុំរឿង ០០២/០១។ ក៏ប៉ុន្តែ ខៀវ សំផន ត្រូវបានជំនុំជម្រះ និងផ្ដន្ទាទោសជាស្ថាពររួចមកហើយ ពីបទឧក្រិដ្ឋទាំងនេះ[3011]។ ដូច្នេះ អង្គជំនុំជម្រះបានសម្រេច ដោយរំលោភលើគោលការណ៍អាជ្ញាអស់ជំនុំ និងមិនអាចយកអង្គហេតុទាំងនេះមកបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយបានឡើយ។

១៥៧៧. ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសអំពីអត្ថិភាពនៃគោលនយោបាយ ដែលនាំឱ្យចាត់វិធានការប្រឆាំងនឹងជនជាតិចាម ជាអាទិ៍ នាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀត/ការជម្លៀសដោយបង្ខំ សម្រាប់ជាមធ្យោបាយដើម្បីសម្រេចគោលបំណងរួម ដែលធ្វើឱ្យគោលនយោបាយមានលក្ខណៈឧក្រិដ្ឋ[3012]។ ច្បាស់ណាស់ថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសទាំងនេះ ពីព្រោះអង្គជំនុំជម្រះត្រូវការអត្ថិភាពនៃគោលនយោបាយ ដើម្បីសន្និដ្ឋានអំពីចេតនារបស់ ខៀវ សំផន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងនេះអំពីពិរុទ្ធភាពរបស់ ខៀវ សំផន នឹងត្រូវទុកជាមោឃៈ[3013]។

## ផ្នែកទី ៣. គោលនយោបាយប្រឆាំងនឹងអតីតទាហាន និងអ្នករាជការនៃរបបសាធារណរដ្ឋខ្មែរ

3010 សូមមើលខាងលើ កថាខណ្ឌ ៥៣៨-៥៤៦។

3011 សូមមើលខាងលើ កថាខណ្ឌ ៩២៦-៩៣២,៩៦៤-៩៦៥។

3012 សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩២-៣៩៩៨។

3013 សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩, ៤៣២៦-៤៣២៧។

១៥៧៨. ដូចបានឃើញពីខាងលើ វិសាលភាពនៃយុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះមិនគ្របដណ្តប់លើអង្គហេតុនៃ "ការរើសអើង" ទៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅសហករណ៍ត្រាំកក់ទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា មានឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ លើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅសហករណ៍ត្រាំកក់នោះឡើយ[3014]។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានទទួលបណ្តឹងមិនស្របច្បាប់អំពីអង្គហេតុនៃ "ការរើសអើង" ទៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅការដ្ឋានទំនប់១មករា ហើយអង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា មានឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញបានឡើយ[3015]។ ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះបានទទួលបណ្តឹងមិនស្របច្បាប់អំពីអង្គហេតុនៃ "ការរើសអើង" ទៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅក្រាំងតាចាន់ និងមិនអាចសន្និដ្ឋានថា មានឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញបានឡើយ[3016]។ អង្គហេតុទាំងនេះមិនអាចរាប់បញ្ចូលទៅក្នុងភ័ស្តុតាងអំពីគោលនយោបាយ "ឧក្រិដ្ឋ" ប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នោះឡើយ។ លើសពីនេះទៀត ដូចបានឃើញពីខាងលើផងដែរ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងអំពីគោលនយោបាយប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នោះឡើយ[3017]។

១៥៧៩. ដូចបានឃើញពីខាងលើ ការពិនិត្យភ័ស្តុតាងមិនអាចឱ្យសន្និដ្ឋានថា មានឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ លើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅសហករណ៍ត្រាំកក់ នោះឡើយ។ ដូច្នេះ សេចក្តីសន្និដ្ឋានដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយ "ឧក្រិដ្ឋ" ត្រូវទុកជាមោឃៈ[3018]។ ដូចបានឃើញពីខាងលើ មិនមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ លើអតីតទាហាន និងអ្នករដ្ឋការ

---

[3014] សូមមើលខាងលើ កថាខណ្ឌ ៣៧២-៣៧៣, ៤៥១-៤៥៧។

[3015] . សូមមើលខាងលើ កថាខណ្ឌ ៤៩០-៤៩២។

[3016] សូមមើលខាងលើ កថាខណ្ឌ ៥០០-៥០៤។

[3017] សូមមើលខាងលើ កថាខណ្ឌ ៥២២-៥៣០។

[3018] សូមមើលខាងលើ កថាខណ្ឌ ៧១៩-៧២៦។

នៃរបបសាធារណរដ្ឋខ្មែរ នៅការដ្ឋានទំនប់១មករា នោះឡើយ។ សេចក្តីសន្និដ្ឋានដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយ "ឧក្រិដ្ឋ" ត្រូវទុកជាមោឃៈ[3019]។

១៥៨០. ដូចបានឃើញពីខាងលើ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងអំពីគោលនយោបាយជាក់លាក់ប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅទូទាំងប្រទេសនោះឡើយ។ ជាក់ស្តែង គោលនយោបាយជាក់លាក់តែមួយគត់ប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយ គឺគោលនយោបាយប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ "ក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ"[3020]។

១៥៨១. អង្គជំនុំជម្រះមានទឡ្ហីករណ៍តិចតួចបំផុត ដើម្បីគាំទ្រដល់អត្ថិភាពនៃការប្រព្រឹត្តិជាក់លាក់លើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ ជាអាទិ៍ អង្គជំនុំជម្រះបានផ្អែកលើសេចក្តីថ្លែងការណ៍ ដែលត្រូវបានសន្មតថាជារបស់ ខៀវ សំផន ដែលត្រូវបានចេញ ភ្លាមៗក្រោយពីទទួលបានជ័យជម្នះលើកងទ័ព លន់ នល់ ក្នុងបរិបទនៃការបញ្ចប់ជម្លោះប្រដាប់អាវុធ ដោយប្រើភាសាឃោសនាស្របជាមួយនឹងជ័យជម្នះរបស់កងទ័ពប្រជាជនរំដោះជាតិកម្ពុជា។ ដូច្នេះ អង្គជំនុំជម្រះបានធ្វើការពិនិត្យភស្តុតាងតាមបែបជ្រើសរើស ដោយបានដកស្រង់ចេញពីសារជ័យជម្នះនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ តែឃ្លា "ពួកខ្មាំងបានដាច់ខ្យល់ស្លាប់ទាំងក្តីឈឺចាប់បំផុត"[3021]។ ប៉ុន្តែ សុន្ទរកថានេះ គឺជាការកោតសរសើរដល់កងទ័ពជ័យជម្នះ ហើយខ្មាំងដែលគាត់និយាយនោះ គឺជា "ពួកចក្រពត្តិអាមេរិក" និងបរិវារជាថ្នាក់ដឹកនាំនៃ "របបពុករលួយបំផុត" គឺមិនសំដៅដល់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងមូលនោះទេ[3022]។

---

[3019] សូមមើលខាងលើ កថាខណ្ឌ ៧៩៨-៨០៣។

[3020] សូមមើលខាងលើ កថាខណ្ឌ ៥២២-៥៣០។ ដីកាដំណោះស្រាយ កថាខណ្ឌ ២០៦។

[3021] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៣៧។

[3022] សារជ័យជម្នះរបស់លោក ខៀវ សំផន ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ឯកសារ **E3/118** ERN 00846160 ("ក្រោយពីការវាយប្រយុទ្ធដ៏ស្វិតស្វាញ និងអង់អាចក្លាហានបំផុត ក្រោយពីអត់ធន់នឹងទុក្ខវេទនា និងការលំបាកគ្រប់បែបយ៉ាង ជាមួយនឹងវីរភាពដ៏អស្ចារ្យ និងក្រោយពីអត់ធន់នឹងពលីកម្មដ៏អស្ចារ្យ អស់រយៈពេលប្រាំឆ្នាំ និងមួយខែមក កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាដ៏ក្លាហានបំផុតរបស់យើង និងប្រជាជនអស្ចារ្យរបស់យើងបានកម្ទេចទាំងស្រុងនូវសង្គ្រាមឈ្លានពានដ៏ព្រៃផ្សៃបំផុតរបស់ពួក

១៥៨២. អង្គជំនុំជម្រះមិនខ្លាចនឹងប្រើប្រាស់ហេតុការណ៍នៅទួលពោធិ៍ជ្រៃ នៅភូមិភាគពាយ័ព្យ[3023] ដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយបែបនេះ ខណៈដែល ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលលើកលែងឱ្យរួចផុតពីការចោទប្រកាន់ពីអង្គហេតុទាំងនេះ ដោយបានសន្និដ្ឋានជាអាទិ៍ថា "ការទទួលខុសត្រូវនេះពុំស្ថិតក្រោមសញ្ញាណនៃសហឧក្រិដ្ឋកម្មរួមនោះទេ ពីព្រោះអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅ (ដែលជាគោលបំណងឧក្រិដ្ឋរួម) ពុំត្រូវបានបង្ហាញដោយសមហេតុផលឡើយ"[3024]។

១៥៨៣. ហេតុផលតែមួយគត់ ដែលនាំអង្គជំនុំជម្រះសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយផ្អែកលើទស្សនៈច្របូកច្របល់អំពីខ្មាំង គឺថា វាមានភាពចាំបាច់ ដើម្បីឱ្យមានធាតុផ្សំអត្តនោម័តិនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ទោះជាយ៉ាងណាក៏ដោយ ការពិនិត្យធាតុផ្សំអង្គហេតុដោយសត្យានុម័តិ និងមិនលម្អៀង មិនអាចឱ្យសន្និដ្ឋានអំពីការប្រព្រឹត្តិជាក់លាក់លើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅសហករណ៍ត្រាំកក់ នៅការដ្ឋានទំនប់១មករា ដែលអ្នកធ្វើការរស់នៅក្នុងល័ក្ខខ័ណ្ឌដូចៗគ្នា នៅមន្ទីរសន្តិសុខ ស-២១ ឬនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលអ្នកទោសទទួលរងនូវជោគវាសនាដូចៗគ្នា។ ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា មានឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅតាមទីតាំងទាំងនេះ ហើយឧក្រិដ្ឋកម្មនេះស្ថិតក្នុងគោលបំណងរួម[3025]។

---

ចក្រពត្តិអាមេរិក និងបានកម្ទេចទាំងស្រុងនូវរបបហ្វាស៊ីស ក្បត់ និង ពួកពុករលួយបំផុតរបស់ពួកអាក្បត់ លន់ នល់, សិរីមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង សូស្តែន ហ្វែណង់ដេស" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3023] សំអាងហេតុសាលក្រម កថាខណ្ឌ កថាខណ្ឌ ៤០៣៦។

[3024] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១១០០។ សូមមើលផងដែរ កថាខណ្ឌ ៨៥៩ ដែលតុលាការកំពូលបានលើកឡើងថាធាតុផ្សំភ័ស្តុតាងប្រឆាំងទៅនឹង "ទស្សនៈដែលថាមានគោលនយោបាយទូទៅ ចាប់ពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៥"។

[3025] សំអាងហេតុសាលក្រម កថាខណ្ឌ កថាខណ្ឌ ៤០៥៩-៤០៦១។

១៥៨៤. ការប្រើប្រាស់ធាតុផ្សំក្រៅវិសាលភាពនៃបណ្តឹង ដើម្បីប៉ះប៉ូវកង្វះភ័ស្តុតាងពីទីតាំងជាកម្មវត្ថុនៃបណ្តឹង គឺជាកំហុសដែលត្រូវបដិសេធចោល។ ដូច្នេះ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះដែលត្រូវបានធ្វើឡើង ដោយរំលោភលើវិសាលភាពនៃបណ្តឹង ដើម្បីប៉ុនប៉ងបង្ហាញអំពីគោលនយោបាយឧក្រិដ្ឋកម្ម នឹងត្រូវទុកជាមោឃៈ[3026]។ សេចក្តីសន្និដ្ឋានជាទូទៅថា គោលនយោបាយឧក្រិដ្ឋមានអត្ថិភាព និងស្ថិតក្នុងគោលបំណងរួម ក៏នឹងត្រូវទុកជាមោឃៈផងដែរ[3027]។

១៥៨៥. ប្រសិនបើអង្គជំនុំជម្រះបានប្រកាសឱ្យ ខៀវ សំផន ជាប់ពិរុទ្ធពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅតាមទីតាំងនានានៃសំណុំរឿង ០០២/០២ ដោយផ្អែកតែលើគោលនយោបាយនេះ អង្គជំនុំជម្រះតុលាការកំពូលក៏ត្រូវធ្វើមោឃភាពសេចក្តីសម្រេចលើការផ្តន្ទាទោសផងដែរ[3028]។

### ផ្នែកទី ៤. គោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិក

១៥៨៦. ដូចបានឃើញពីខាងលើ យុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះមិនគ្របដណ្តប់លើអង្គហេតុនៃ "ការរើសអើង" លើពុទ្ធសាសនិក និងព្រះសង្ឃ នៅសហករណ៍ត្រាំកក់ទេ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយយល់ថាខ្លួនបានទទួលបណ្តឹងអំពីអង្គហេតុទាំងនេះ និងបានជំនុំជម្រះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា លើពុទ្ធសាសនិក និងព្រះសង្ឃ នៅសហករណ៍ត្រាំកក់។ ហេតុនេះ សេចក្តីសន្និដ្ឋាន ដែលរាប់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងគោលនយោបាយ "ឧក្រិដ្ឋ" ត្រូវទុកជាមោឃៈ[3029]។

---

[3026] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០២៦-៤០៣៣, ៤០៣៥, ៤០៣៨, ៤០៤២-៤០៤៧, ៤០៥១, ៤០៥៣។

[3027] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦០-៤០៦១។

[3028] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៩។

[3029] សូមមើលខាងលើ កថាខណ្ឌ ៤២៦-៤៣៤។

១៥៨៧. ដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា លើពុទ្ធសាសនិក និងព្រះសង្ឃ នៅសហករណ៍ត្រាំកក់ ដោយគ្មានចេតនាបណ្តេញព្រះសង្ឃចេញពីសង្គម[3030]។

១៥៨៨. ដូចបានឃើញពីខាងលើផងដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយល់ឃើញហួសពីវិមតិសង្ស័យថា មានឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា លើពុទ្ធសាសនិក និងព្រះសង្ឃ នៅសហករណ៍ត្រាំកក់[3031]។

១៥៨៩. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងពុទ្ធសាសនិក ត្រូវបានធ្វើឡើង ដោយរំលោភលើវិសាលភាពនៃបណ្តឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងអង្គជំនុំជម្រះ។ ដូច្នេះ ខៀវ សំផន មិនចាំបាច់ត្រូវទទួលខុសត្រូវនោះទេ ហើយសេចក្តីសន្និដ្ឋានទាំងនេះត្រូវទុកជាមោឃៈ ជាលក្ខណៈចម្បង។ ជាលក្ខណៈបន្ទាប់បន្សំ អង្គជំនុំជម្រះតុលាការកំពូលគ្មានអ្វីក្រៅពីកត់សម្គាល់ថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋប្រឆាំងនឹងពុទ្ធសាសនិក ដោយផ្អែកលើធាតុផ្សំអង្គហេតុក្នុងសំណុំរឿង។ គ្មានភ័ស្តុតាងបង្ហាញឱ្យហួសពីវិមតិសង្ស័យអំពីការរើសអើងលើព្រះសង្ឃ ឬការប្រព្រឹត្តិឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា នៅសហករណ៍ត្រាំកក់ ឬនៅកន្លែងផ្សេងទៀតឡើយ[3032]។

១៥៩០. ជាក់ស្តែង របបកម្ពុជាប្រជាធិបតេយ្យបដិវត្តន៍ ផ្តល់អាទិភាពដល់ការកសាងប្រទេស ដែលទាមទារឱ្យមានការចូលរួមពីប្រជាជនទាំងអស់។ ការប្រតិបត្តិសាសនាត្រូវបានរឹតត្បិតជារួម ដោយគ្មានការចាត់វិធានការជាក់លាក់ណាមួយឡើយ ហើយបុគ្គលគ្រប់រូបទទួលបានការប្រព្រឹត្តិដូចៗគ្នា ដោយគ្មានការរើសអើង។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអនុវត្តសញ្ញាណនៃការរើសអើងដោយប្រយោល ដែលគ្មានអត្ថិភាពនៅពេលកើតហេតុ[3033]។

---

[3030] សូមមើលខាងលើ កថាខណ្ឌ ៦៤១-៦៥៦។

[3031] សូមមើលខាងលើ កថាខណ្ឌ ៧៤៣-៧៤៧។

[3032] សូមមើលខាងលើ កថាខណ្ឌ ៧៤៣-៧៤៧។

[3033] សូមមើលខាងលើ កថាខណ្ឌ ៩៥៤-៩៥៦។

១៥៩១. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញនូវការប្រព្រឹត្តិជាក់លាក់លើព្រះសង្ឃនៅសហករណ៍ត្រាំកក់ ឬនៅកន្លែងផ្សេងទៀតឡើយ[3034]។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋសំដៅចាត់វិធានការប្រឆាំងនឹងពុទ្ធសាសនិក ឬសន្និដ្ឋានថាគោលនយោបាយឧក្រិដ្ឋនេះស្ថិតក្នុងគោលបំណងរួមឡើយ។ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះក្នុងន័យនេះ រួមទាំងការផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខ ត្រូវទុកជាមោឃៈ [3035]។

## ជំពូកទី ៥. ការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍

១៥៩២. ដូចបានឃើញខាងលើ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានឡើយអំពីអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋសំដៅរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ និងប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ក្នុងក្របខ័ណ្ឌនេះ[3036]។

## ជំពូកទី ៦. កំហុសពាក់ព័ន្ធនឹងគោលបំណងរួមដែលបានចោទប្រកាន់

១៥៩៣. ការពិនិត្យស៊ីជម្រៅលើគោលនយោបាយនីមួយៗដែលអង្គជំនុំជម្រះបានចោទប្រកាន់ និងអង្គហេតុគាំទ្រដល់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ បង្ហាញឱ្យឃើញកំហុសត្រួតគ្នារបស់អង្គជំនុំជម្រះ ក្នុងការផ្សារភ្ជាប់នឹងគោលបំណងរួម។ ដូចបានបង្ហាញនៅដើមភាគទី ៥ នៃសារណានេះ សម្មតិកម្មពីដើមទីរបស់អង្គជំនុំជម្រះអំពីការកំណត់ផែនការនយោបាយរបស់ ប.ក.ក តែតាមរយៈជ្រុងនៃ "ការតស៊ូប្រឆាំងនឹងខ្មាំង" មិនត្រឹមត្រូវទេ។ ប៉ុន្តែ ផ្តើមចេញពីសម្មតិកម្មខុសនេះ ដូចសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើពីមុនដែរ អង្គជំនុំជម្រះស្ថាបនាបានជាគោលនយោបាយផ្សេងៗ។ ប្រការនេះបង្កឱ្យមានភាពលម្អៀងដល់របៀបពិនិត្យភ័ស្តុតាង និងប៉ះពាល់ដល់វិចារណកិច្ចរបស់អង្គជំនុំជម្រះ។

---

[3034] សូមមើលខាងលើ កថាខណ្ឌ ៧៤៣-៧៤៧។

[3035] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០១៧-៤០២២, ៤២៩៧-៤២៩៨។

[3036] សូមមើលខាងលើ កថាខណ្ឌ ១២៤៣-១២៨០ (កំហុសលើបទប្បញ្ញត្តិ) កថាខណ្ឌ ១៣៤១-១៣៩៨ (ការរំលោភសេពសន្ថវៈ)។

## ផ្នែកទី ១. គោលបំណងរួមខុសពីគោលនយោបាយ "ឧក្រិដ្ឋ"

១៥៩៤. ការប្រែប្រួលជាច្រើននៃគោលបំណងរួម ដែលអង្គជំនុំជម្រះបានកំណត់ បង្ហាញឱ្យឃើញអំពីភាពលម្អៀងរបស់អង្គជំនុំជម្រះ ដើម្បីអាចដាក់បញ្ចូលនូវគោលនយោបាយឧក្រិដ្ឋទៅក្នុងគោលបំណងរួមនោះ។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានកំណត់គោលបំណងរួមនេះ យោងតាមរយៈកាលប្រវត្តិសាស្ត្រដែល ប.ក.ក បានឆ្លងកាត់ និងដោយបានសន្និដ្ឋានថា ការប្រាសចាកក្នុងការអនុវត្តគោលបំណងរួមនេះ គឺជាមូលដ្ឋាន[3037]។ គោលបំណងរួមតែមួយគត់ដែលមានអត្ថិភាព គឺការកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជា ក្នុងក្របខ័ណ្ឌនៃសង្គមមួយផ្តោតលើការគ្រប់គ្រងប្រព័ន្ធកសិកម្មទំនើបជាសមូហភាព។ គោលបំណងនេះមិនមានលក្ខណៈឧក្រិដ្ឋទេ ហើយអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងការកំណត់គោលដៅ និងខ្លឹមសារ និងដោយបានសន្និដ្ឋានថា ការអនុវត្តគោលបំណងនេះនាំឱ្យមានគោលនយោបាយឧក្រិដ្ឋ[3038]។

១៥៩៥. គោលដៅនៃការបង្កើត និងប្រតិបត្តិការសហករណ៍ គឺជាជម្រើសសេដ្ឋកិច្ចសមូហនិយម ស្របតាមបាតគ្រឹះម៉ាក្សនិយមរបស់ ប.ក.ក។ ការបង្កើតសហករណ៍ដំបូងៗ ដើម្បីផ្គត់ផ្គង់ស្បៀងដល់សមរភូមិមុខ ក្នុងសម័យសង្គ្រាមប្រឆាំងនឹងរបប លន់ នល់ មិនបានផ្លាស់ប្តូរប្រព័ន្ធចាត់តាំងនេះឱ្យទៅជាប្រព័ន្ធ "តស៊ូប្រឆាំងនឹងខ្មាំង" ទេ[3039]។ ដូចគ្នាផងដែរ ការមិនគោរពតាមសេចក្តីណែនាំរបស់ ប.ក.ក ពីសំណាក់អ្នកគ្រប់គ្រងនៅតាមមូលដ្ឋាន និងបរាជ័យរបស់សហករណ៍ក្នុងការសម្រេចគោលដៅកែលម្អស្ថានភាពរបស់ប្រជាជន មិនមែនជាការបង្ហាញអំពី "គោលនយោបាយ" ចេតនាក្នុងការដាក់ឱ្យទៅជាទាសករ និងធ្វើបាបនោះទេ ប៉ុន្តែ នេះគឺជាបរាជ័យនៃផែនការសេដ្ឋកិច្ចផ្តោតលើកសិកម្មទ្រង់ទ្រាយធំក្នុងស្ថានភាពវិបត្តិ[3040]។

---

[3037] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៨-៤០៧៤។

[3038] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៨-៤០៧៤

[3039] សូមមើលខាងលើ កថាខណ្ឌ ១៤៩០-១៥១០។

[3040] សូមមើលខាងលើ កថាខណ្ឌ ១៥០៣-១៥០៤។

១៥៩៦. សុន្ទរកថាថ្លែងក្នុងពេលមានជម្លោះប្រដាប់អាវុធ មិនមែនជាការបង្ហាញអំពី "គោលនយោបាយ" នោះទេ គឺជាការប្រកាន់គោលជំហររបស់កម្ពុជាប្រជាធិបតេយ្យ ចំពោះការឈ្លានពានយោធា ក្នុងបរិបទដែលខាងកម្ពុជាមានកម្លាំងទ័ពចាញ់ប្រៀបគេ[3041]។ ដូចគ្នាផងដែរ ការវាយប្រហារលើរដ្ឋវៀតណាម ជាខ្មាំងយោធា មិនមានទំនាក់ទំនងអ្វីជាមួយនឹងគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាមរស់នៅកម្ពុជាទេ[3042]។

១៥៩៧. ការទុកសាសនាទាំងអស់នៅមួយឡែក និងការរឹតត្បិតការប្រតិបត្តិសាសនា មិនមែនជាវិធានការដាក់លាក់ប្រឆាំងនឹងក្រុមខ្លះទេ ពីព្រោះវាពាក់ព័ន្ធនឹងប្រជាជនទាំងអស់ ដោយមិនរើសមុខ[3043]។ម្យ៉ាងវិញទៀត ជនជាតិចាម ពុទ្ធសាសនិក អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងប្រជាជនថ្មី បានរស់នៅក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងប្រជាជនផ្សេងទៀតដែរ នៅតាមសហករណ៍ និងការដ្ឋាន[3044]។

១៥៩៨. ដំណើរការមន្ទីរសន្តិសុខ ក្រោមការត្រួតពិនិត្យពីកងទ័ព ក្នុងលក្ខណៈសម្ងាត់បំផុត[3045] បាននាំឱ្យមានការអនុវត្តផ្សេងគ្នាខាងសន្តិសុខ ដែលមិនស្ថិតក្នុងគោលបំណងរួមសំដៅកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជា។ ដូច្នេះ ក្នុងលក្ខណៈខុសឆ្គង អង្គជំនុំជម្រះបានកំណត់ការអនុវត្តផ្សេងគ្នានេះថាជា "គោលនយោបាយកម្ទេចខ្មាំង" ដែលកើតមានតាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ ជាអាទិ៍ ដោយបានបំភ្លៃសុន្ទរកថាមនោគមន៍វិជ្ជានៃការតស៊ូវណ្ណៈ[3046]។

១៥៩៩. អង្គជំនុំជម្រះមិនពិនិត្យអង្គហេតុជារួម និងជាសត្យានុម័តិ តែបែរជាយកចិត្តទុកដាក់ តែនៅពេលអង្គហេតុទាំងនេះគាំទ្រដល់ទស្សនៈរបស់ខ្លួនអំពីគោលនយោបាយឧក្រិដ្ឋប៉ុណ្ណោះ ដោយបានលាក់បាំងភ័ស្តុ

[3041] សូមមើលខាងលើ កថាខណ្ឌ ១០៧៣-១០៨៥។

[3042] សូមមើលខាងលើ កថាខណ្ឌ ១០៥៨-១០៩៧, ១៥៥១-១៥៦០។

[3043] សូមមើលខាងលើ កថាខណ្ឌ ៧៤៣-៧៤៧, ៩៣៤-៩៦៣។

[3044] សូមមើលខាងលើ កថាខណ្ឌ ៧១៩-៧៤៧, ៧៦៣-៧៦៧, ៧៨៧-៨១៣។

[3045] សូមមើលខាងក្រោម កថាខណ្ឌ ១៩០៥។

[3046] សូមមើលខាងលើ កថាខណ្ឌ ១៤៧៣-១៤៧៩។

តាងដោះបន្ទុកទាំងស្រុង[3047]។ ដំណើរការដាក់បន្ទុកជាប្រចាំនេះនាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គច្បាប់ ដោយរំលោភលើគោលការណ៍នីត្យានុកូលភាព ដើម្បីទទួលយកឧក្រិដ្ឋកម្ម ដែលមិនមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅសម័យកើតហេតុ និងប្រព្រឹត្តកំហុសអង្គហេតុ ក្នុងការបកស្រាយភស្តុតាង[3048]។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺជាគំរូបង្ហាញច្បាស់អំពីកំហុសអង្គហេតុ និងអង្គច្បាប់នៃសំអាងហេតុសាលក្រម[3049]។

១៦០០. មូលហេតុសំខាន់ដែលនាំឲ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុស គឺមកពីអង្គជំនុំជម្រះបានយល់ឃើញថា បើមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម គឺមានគោលនយោបាយឧក្រិដ្ឋ។ ប៉ុន្តែ ឧក្រិដ្ឋកម្មមិនមែនជាគោលនយោបាយទេ។ នេះគឺជាវិចារណកិច្ចកើតចេញពីតក្កសាស្ត្រ ដែលត្រូវបានរិះគន់ក្នុងរបៀបដែលអង្គជំនុំជម្រះអនុវត្តច្បាប់នៃសហឧក្រិដ្ឋកម្មរួម[3050]។ ដោយសារគ្មានទំនាក់ទំនងរវាង ខៀវ សំផន និងឧក្រិដ្ឋកម្ម អង្គជំនុំជម្រះបានសម្រេចបង្កើតគោលនយោបាយឧក្រិដ្ឋ ដើម្បីផ្តន្ទាទោសគាត់។ ប៉ុន្តែ តាមរបៀបដូចគ្នាដែលឧក្រិដ្ឋកម្មមិនមែនជាគោលនយោបាយ ការចូលរួមក្នុងគោលបំណងរួមគ្មានលក្ខណៈឧក្រិដ្ឋ មិនមែនជាចេតនាឧក្រិដ្ឋទេ។

## ផ្នែកទី ២. ការចូលរួមខុសពីចេតនាឧក្រិដ្ឋ

១៦០១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា គោលបំណងរួមក្លាយជាមានលក្ខណៈឧក្រិដ្ឋ តាមរយៈគោលនយោបាយ ដែលមានភាពចាំបាច់ដល់ការអនុវត្តគោលបំណងរួម[3051]។ ការពិនិត្យដោយលម្អៀងទៅលើការទំនាក់ទំនង និងបណ្តាញរដ្ឋបាលរបស់ ប.ក.ក មានគោលដៅទាញ ខៀវ សំផន ឱ្យចូលពាក់ព័ន្ធ "ដោយប្រយោល" ដោយសារតែគ្មានភស្តុតាងបង្ហាញអំពី

3047 សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៨-៤០៧៤

3048 សូមមើលខាងលើ កថាខណ្ឌ ៦៤២-៦៥៧។

3049 សូមមើលខាងលើ កថាខណ្ឌ ១១៨៩-១២៨០។

3050 សូមមើលខាងក្រោម កថាខណ្ឌ ១៩៩៩-២០០០។

3051 សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៨។

ការចូលរួមចំណែករបស់គាត់ ក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម[3052] ដូចគ្នានឹងអត្តសញ្ញាណសមាជិកនៃគោលបំណងរួម ដែលត្រូវនឹងកម្មាភិបាលទាំងអស់នៃកម្ពុជាប្រជាធិបតេយ្យ នៅតាមអង្គភាពនានារបស់ ប.ក.ក និងអ្នកគ្រប់គ្រងភូមិភាគ និងស្រុក[3053]។

១៦០២. ការឯកភាពធម្មតារបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះគោលបំណងរួម ដើម្បីធ្វើបដិវត្តន៍សង្គមនិយម នៅកម្ពុជាប្រជាធិបតេយ្យ មិនមានន័យស្មើនឹងការឯកភាពចំពោះផែនការឧក្រិដ្ឋនោះទេ។ ការរកឃើញរបស់អង្គជំនុំជម្រះថា "ខៀវ សំផន បានផ្សព្វផ្សាយគោលបំណងរួម ហើយជំរុញដល់មហាជនឱ្យអនុវត្តគោលបំណងរួមនេះ តាមរយៈគោលនយោបាយនានា" មិនគ្រប់គ្រាន់ឱ្យសន្និដ្ឋានអំពីការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមនោះឡើយ[3054]។ អង្គជំនុំជម្រះត្រូវបង្ហាញឱ្យឃើញការឯកភាព និងការចូលរួមចំណែករបស់គាត់ក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម ដើម្បីរកឱ្យឃើញចេតនាឧក្រិដ្ឋកម្មរបស់គាត់។

១៦០៣. ប៉ុន្តែ យើងនឹងឃើញខាងក្រោមថា ភ័ស្តុតាងដែលលើកមកយកបង្ហាញ ដើម្បីសន្និដ្ឋានអំពីការដឹង និងការចូលរួមចំណែករបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងឧក្រិដ្ឋកម្ម ជាអាទិ៍ វិសាលភាពនៃតួនាទីរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[3055] មានកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើនក្នុងការប៉ុនប៉ងពង្រីកការទទួលខុសត្រូវ ក្នុងក្របខ័ណ្ឌសហឧក្រិដ្ឋកម្មរួម ចំពោះគោលបំណងរួមដែលត្រូវបានកំណត់មិនត្រឹមត្រូវ[3056]។ ទោះជាយ៉ាងណា ការពិនិត្យភ័ស្តុតាងដោយមិនលម្អៀងពីសំណាក់អង្គជំនុំជម្រះ និងការអនុវត្តច្បាប់ខុស ធ្វើឱ្យប៉ះពាល់ដល់សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះអំពីគោលបំណងរួម ដែលនឹងត្រូវទុកជាមោឃៈ[3057]។

---

[3052] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៩-៤០៧៣។ សូមមើលខាងលើ កថាខណ្ឌ ១៦៤៤-១៦៤៩។

[3053] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៧០។

[3054] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៧០។

[3055] សូមមើលខាងក្រោម កថាខណ្ឌ ១៦៥២-១៨០៣។

[3056] សូមមើលខាងក្រោម កថាខណ្ឌ ១៨០៤-១៩៣៤, ២០០១-២០៣០។

[3057] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៨-៤០៧៤

**ភាគទី ៥. កំហុសពាក់ព័ន្ធនឹងការទទួលខុសត្រូវ**

**មាតិកាទី ១. ការរំលោភលើគោលការណ៍នៃការទទួលខុសត្រូវជាឯកត្តជន**

**ជំពូកទី ១. គ្មានទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងទីតាំងឧក្រិដ្ឋកម្ម**

១៦០៤. ទិដ្ឋភាពមួយដ៏គួរឱ្យភ្ញាក់ផ្អើលបំផុតនៃសំអាងហេតុសាលក្រម គឺអង្គជំនុំជម្រះស្មានថាខ្លួនមិនចាំបាច់បង្ហាញឱ្យឃើញនូវទំនាក់ទំនងរវាង ខៀវ សំផន និងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០២/០២ ក៏ដូចជាឧក្រិដ្ឋកម្មនោះទេ។ អង្គជំនុំជម្រះបានផ្តោតវិចារណកិច្ចរបស់ខ្លួនលើអត្ថិភាពនៃគោលនយោបាយឧក្រិដ្ឋក្នុងគោលដៅ "ផ្តល់លក្ខណៈឧក្រិដ្ឋ" ដល់គោលបំណងរួម ដើម្បីឈានទៅដល់ការផ្តន្ទាទោស តាមរយៈសហឧក្រិដ្ឋកម្មរួម។ ប៉ុន្តែ ដូចបានឃើញពីខាងលើ ច្បាប់នៃសហឧក្រិដ្ឋកម្មរួមទាមទារឱ្យបង្ហាញឱ្យឃើញការចូលរួមរបស់ ខៀវ សំផន ក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម និងក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយដែលបានចោទប្រកាន់ បើយោងតាមវិចារណកិច្ចរបស់អង្គជំនុំជម្រះ។ មុននឹងគិតដល់កំហុសណាខ្លះដែលបានប្រព្រឹត្ត ក្នុងការពិនិត្យមើលការទទួលខុសត្រូវរបស់ ខៀវ សំផន យើងចាំបាច់ត្រូវលើកឡើងអំពីរបៀបដែលអង្គជំនុំជម្រះប៉ុនប៉ងដោយឥតប្រយោជន៍ក្នុងការផ្សារភ្ជាប់ ខៀវ សំផន ទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់។

**ផ្នែកទី ១. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅសហករណ៍ត្រាំកក់**

១៦០៥. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ អង្គជំនុំជម្រះបានលើកឡើងជាទូទៅអំពី ខៀវ សំផន ដូចជា ចំណាប់អារម្មណ៍របស់គាត់នៅឆ្នាំ១៩៦៩ ពេលគាត់ចូលព្រៃម៉ាគី[3058] សុន្ទរកថាស្តីពីគោលនយោបាយទូទៅនៅឆ្នាំ១៩៧៦[3059] ការវិភាគពីសហករណ៍ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[3060] ការបកស្រាយរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យអំពីសាសនា ក្រោយសម័យកើតហេតុ[3061] និងសេចក្តី

---

[3058] សំអាងហេតុសាលក្រម កថាខណ្ឌ ៩០៤។

[3059] សំអាងហេតុសាលក្រម កថាខណ្ឌ ៩៧០។

[3060] សំអាងហេតុសាលក្រម កថាខណ្ឌ១០២១-១០២២។

[3061] សំអាងហេតុសាលក្រម កថាខណ្ឌ១០៩០។

ថ្លែងការណ៍អំពីសារៈសំខាន់តិចតួចរបស់ព្រះសង្ឃ ដែលយើងមិនឃើញមានឯកសារយោង[3062]។ ក្រៅពីការកត់សម្គាល់ឥតប្រយោជន៍អំពីលទ្ធភាពនៃទស្សនកិច្ច ដែលអង្គជំនុំជម្រះមិនអាចបង្ហាញភ័ស្តុតាងបាន[3063] គួរបញ្ជាក់ថា គ្មានតម្រុយណាមួយក្នុងការពិនិត្យទៅលើអង្គហេតុអំពីសហករណ៍ត្រាំកក់ អាចឱ្យសន្និដ្ឋានអំពីទំនាក់ទំនងផ្ទាល់រវាង ខៀវ សំផន និងទីតាំងឧក្រិដ្ឋកម្ម ក៏ដូចជាឧក្រិដ្ឋកម្មនោះឡើយ។

## ផ្នែកទី ២. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅទំនប់ត្រពាំងថ្ម

១៦០៦. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្ម អង្គជំនុំជម្រះបានលើកឡើងជាទូទៅអំពី ខៀវ សំផន ដូចជា សុន្ទរកថាដដែលស្តីពីគោលនយោបាយទូទៅនៅឆ្នាំ១៩៧៧ ដែលគាត់បានថ្លែងលើកសរសើរអំពី "កម្លាំងមនុស្ស" និងសមិទ្ធផលរបស់កម្ពុជាប្រជាធិបតេយ្យជាទូទៅ ក្នុងន័យឃោសនាក្នុងបរិបទនៃការរំឭកខួប នៅថ្ងៃទី១៥ ខែមេសា[3064]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានដកស្រង់ចម្លើយនៅក្នុងសវនាការ ដែល ខៀវ សំផន បាននិយាយអំពីទស្សនកិច្ចនៅទំនប់ត្រពាំងថ្ម ដោយបានពន្យល់ថា គាត់មិនបានដឹងថាទំនប់នេះ "បានមកដោយការបង់ថ្លៃវាខ្ពស់យ៉ាងនេះទេ"[3065]។ យើងនឹងឃើញខាងក្រោមអំពីរបៀបរៀបចំទស្សនកិច្ចផ្លូវការដោយអ្នកគ្រប់គ្រងការដ្ឋាន ធ្វើយ៉ាងណាកុំឱ្យឃើញពីការលំបាករបស់អ្នកធ្វើការ[3066]។ ទោះជាយ៉ាងណា គ្មានភ័ស្តុតាងណាមួយអាចឱ្យបង្ហាញអំពីវត្តមានរបស់គាត់ ក្នុងពេលប្រព្រឹត្តឧក្រិដ្ឋកម្ម នៅទំនប់ត្រពាំងថ្មនោះទេ ហើយអង្គជំនុំជម្រះមិនអាចភ្ជាប់ទំនាក់ទំនងរវាង ខៀវ សំផន និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទំនប់ត្រពាំងថ្មនោះឡើយ។

---

[3062] សំអាងហេតុសាលក្រម កថាខណ្ឌ១១៨៥ កំណត់សម្គាល់ជើងទំព័រលេខ ៤០៣៧ ដែលនៅទីនេះ មិនមានលើកឡើងពីលោក ខៀវ សំផន។

[3063] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៣៧៖ "នៅក្នុងការវិភាគចុងក្រោយ បើទោះបីអាចថា នួន ជា និង ខៀវ សំផន បានទៅធ្វើទស្សនកិច្ចនៅស្រុកត្រាំកក់ ក្នុងអំឡុងពេលពាក់ព័ន្ធនេះ ហើយបើទោះបីជាអង្គជំនុំជម្រះបានផ្តល់សំអាងហេតុខាងលើថា នួន ជា បានទៅសួរសុខទុក្ខ តាម៉ុក នៅជិតទីរួមខេត្តតាកែវនោះ ក៏ភ័ស្តុតាងនេះមិនបង្ហាញពីកាលៈទេសៈនៃដំណើរទស្សនកិច្ចជាក់លាក់ណាមួយរបស់ថ្នាក់ដឹកនាំទាំងនេះ ទៅកាន់ស្រុកត្រាំកក់ ដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់ឡើយ"។

[3064] សំអាងហេតុសាលក្រម កថាខណ្ឌ ១២២១ កំណត់សម្គាល់ជើងទំព័រលេខ ៤១៦៣, ១២២៤, ៤១៧០, ១២៩៦, ៤៤៣៣, ១៣១៦, ៤៥០៤។

[3065] សំអាងហេតុសាលក្រម កថាខណ្ឌ ១២៥៤។

[3066] សូមមើលខាងក្រោម កថាខណ្ឌ ១៨៤៣-១៨៤៤, ២១៣០។

១៦០៧. ប៉ុន្តែ សូម្បីតែក្រោយពីរកឃើញថា ខៀវ សំផន កំពុងធ្វើដំណើរទៅចិន វៀតណាម និងកូរ៉េខាងជើង នៅចុងខែសីហា ឆ្នាំ១៩៧៥ ខណៈដែលគណៈអចិន្ត្រៃយ៍ចុះទៅទស្សនកិច្ច នៅភូមិភាគពាយ័ព្យក៏ដោយ ក៏អង្គជំនុំជម្រះបានសន្និដ្ឋានដោយមិនសមទំនងថា អង្គជំនុំជម្រះ "ជឿជាក់ថា ដោយសារតែតួនាទីខ្ពស់នៅក្នុងបក្ស [គាត់] បានទទួលនូវរបាយការណ៍ និងបានចូលរួមនៅក្នុងការអភិវឌ្ឍផែនការ និងគោលនយោបាយដែលបានឆ្លុះបញ្ចាំងនៅក្នុងនោះ"[3067]។ ទោះជាយ៉ាងនេះក្តី សេចក្តីសន្និដ្ឋានមិនសមហេតុផល និងលម្អៀងនេះ មិនបានបង្ហាញឱ្យឃើញទំនាក់ទំនងរវាង ខៀវ សំផន និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទំនប់ត្រពាំងថ្ម នោះឡើយ។

## ផ្នែកទី ៣. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅទំនប់១មករា

១៦០៨. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងទំនប់១មករា អង្គជំនុំជម្រះបានលើកឡើងជាទូទៅអំពី ខៀវ សំផន ដូចជា ការវិភាគក្រោយអង្គហេតុទៅលើការសាងសង់ទំនប់[3068] និងសុន្ទរកថាក្នុងឱកាសរំឭកខួបជ័យជម្នះ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧[3069]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានបង្ខំចិត្តសន្និដ្ឋានថា "ល័ក្ខខ័ណ្ឌតម្រូវមិនត្រូវបានបំពេញឡើយ ចំពោះភ័ស្តុតាងដែលថា ខៀវ សំផន បានចុះទៅពិនិត្យមើលការដ្ឋានការងារទំនប់១មករា ដែរនោះ"[3070]។ ត្រង់នេះទៀត គ្មានភ័ស្តុតាងណាមួយអាចឱ្យភ្ជាប់ទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងការដ្ឋានទំនប់១មករា ក៏ដូចជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីនោះឡើយ។

## ផ្នែកទី ៤. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅព្រលានយន្តហោះកំពង់ឆ្នាំង

[3067] សំអាងហេតុសាលក្រម កថាខណ្ឌ ១២៥៦ សេចក្តីសន្និដ្ឋានមាននៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៤២៨៩។

[3068] សំអាងហេតុសាលក្រម កថាខណ្ឌ ១៥០៨ កំណត់សម្គាល់ជើងទំព័រលេខ ៥១៤៥។

[3069] សំអាងហេតុសាលក្រម កថាខណ្ឌ ១៥១៧ កំណត់សម្គាល់ជើងទំព័រលេខ ៥១៨១-៥១៨២។ កថាខណ្ឌ ១៥២៧ កំណត់សម្គាល់ជើងទំព័រលេខ ៥២០៧។

[3070] សំអាងហេតុសាលក្រម កថាខណ្ឌ ១៤៩០។

១៦០៩. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងព្រលានយន្តហោះកំពង់ឆ្នាំង អង្គជំនុំជម្រះបានលើកឡើងជាទូទៅអំពី ខៀវ សំផន ដូចជា វត្តមានរបស់គាត់ក្នុងកិច្ចប្រជុំចំនួនបីរបស់គណៈអចិន្ត្រៃយ៍ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ នៅពេលគម្រោងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានលើកយកមកពិភាក្សា[3071]។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានកត់សម្គាល់ថា "ទស្សនកិច្ចរបស់ ខៀវ សំផន ទៅការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំងនេះ មិនត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ"[3072]។ ត្រង់នេះទៀត គ្មានភស្តុតាងណាមួយអាចឱ្យភ្ជាប់ទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ក៏ដូចជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីនោះឡើយ។

## ផ្នែកទី ៥. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខ ស-២១

១៦១០. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ អង្គជំនុំជម្រះបានលើកឡើងជាទូទៅអំពី ខៀវ សំផន ដូចជា សុន្ទរកថា ឆ្នាំ១៩៧៨ ថ្លែង ដើម្បីរំឭកខួបជ័យជម្នះ ១៧ មេសា[3073] ទំនាក់ទំនងរវាងសុន្ទរកថា ប៉ុល ពត និង "សេចក្តីថ្លែងការណ៍របស់បងគណៈប្រធានរដ្ឋ" ដែលបានលើកឡើងតែក្នុងសៀវភៅកំណត់ត្រា ស-២១ ដោយមិនបង្ហាញថាជាម្ចាស់បណ្តឹងសាទុក្ខ[3074] សំបុត្រផ្ញើជូនគាត់ដោយ ហួត សម្បត្តិ ពី ស-២១ ដោយមិនអាចសន្និដ្ឋានថាគាត់បានទទួលសំបុត្រនេះដែរឬទេ[3075] និងចម្លើយរបស់គាត់អំពីមន្ទីរ ៨៧០ ដោយគ្មានទំនាក់ទំនងជាមួយ ស-២១[3076]។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានដកស្រង់ចម្លើយផ្សេងៗរបស់ ឌុច ដែលលើកឡើងអំពីការជជែកគ្នាជាមួយ នួន ជា ពាក់ព័ន្ធនឹងការឆ្លើយដាក់ ខៀវ សំផន នៅក្នុងចម្លើយសារភាពមួយចំនួន ដោយមិនបានជូនដំណឹងដល់ម្ចាស់

---

[3071] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧២៣ កំណត់សម្គាល់ជើងទំព័រលេខ ៥៨៣៤-៥៨៣៥ កថាខណ្ឌ ១៧២៤ កំណត់សម្គាល់ជើងទំព័រលេខ ៥៨៣៨ កថាខណ្ឌ ១៧២៧ កំណត់សម្គាល់ជើងទំព័រលេខ ៥៨៥៤។

[3072] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧៩២។

[3073] សំអាងហេតុសាលក្រម កថាខណ្ឌ ២១៧៣ កំណត់សម្គាល់ជើងទំព័រលេខ ៧៣០១។

[3074] សំអាងហេតុសាលក្រម កថាខណ្ឌ ២១៧៣ កំណត់សម្គាល់ជើងទំព័រលេខ ៧២៩៨ កថាខណ្ឌ ២៥៥៧។

[3075] សំអាងហេតុសាលក្រម កថាខណ្ឌ ២១៧៩។

[3076] សំអាងហេតុសាលក្រម កថាខណ្ឌ ២១៨៩ កំណត់សម្គាល់ជើងទំព័រលេខ ៧៣៤៩។

បណ្តឹងសាទុក្ខ[3077]។ អង្គជំនុំជម្រះបានលើកឡើងអំពីសក្ខីកម្មរបស់សាក្សី ម៉ម ណៃ ដែលនិយាយផ្ទុយពី ឌុច ដែលថា ស-២១ ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គណៈមជ្ឈិម[3078]។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ប៉ង់ មិនធ្លាប់នាំសារពី ខៀវ សំផន ទៅឱ្យ ឌុច ទេ[3079]។ ជាចុងក្រោយ អង្គជំនុំជម្រះបានយោងលើចម្លើយរបស់ម្ចាស់បណ្តឹងសាទុក្ខនៅក្រោយរបបនោះ ដែលគាត់បានធ្វើការវិភាគលើការបោសសម្អាត ហើយយើងនឹងឃើញថា ចម្លើយទាំងនេះមិនបង្ហាញអំពីការដឹងរបស់គាត់ នៅសម័យកើតហេតុនោះទេ[3080]។

១៦១១. អង្គជំនុំជម្រះក៏បានពិនិត្យមើលករណីរបស់កម្មាភិបាលជាច្រើនរបស់ ប.ក.ក ដែលត្រូវបានបោសសម្អាត ដោយមិនបង្ហាញទំនាក់ទំនងរវាងវត្តមានរបស់ពួកគេ នៅមន្ទីរ ស-២១ និង ខៀវ សំផន[3081] ឧទាហរណ៍ កង ចាប ដែលអង្គជំនុំជម្រះបានបញ្ជាក់ថា គាត់ជាអ្នកចាប់ខ្លួនសាច់ញាតិរបស់ម្ចាស់បណ្តឹងសាទុក្ខ[3082]។ អង្គជំនុំជម្រះក៏បានលើកឡើងអំពីជំនួបជាមួយ ឌុច នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មុនវៀតណាមវាយចូលបន្តិច ចំណែកឯប្រធាន ស-២១ បានឆ្លើយផ្ទុយពីនេះ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គ្មានអ្វីអាចឱ្យភ្ជាប់ទំនាក់ទំនងរវាង ខៀវ សំផន និង ស-២១ នៅសម័យកើតហេតុបានទេ[3083]។ ក្រៅពីភ័ស្តុតាងទេសកាល ជាមួយនឹងវិចារណកិច្ចអំពីការបោសសម្អាត អង្គជំនុំជម្រះមិនអាចបង្ហាញទំនាក់ទំនងរវាង ខៀវ សំផន និង ស-២១ ឬវត្តមានរបស់គាត់នៅ ស-២១ ឬការដឹងអំពី ស-២១ ឡើយ។

---

[3077] សំអាងហេតុសាលក្រម កថាខណ្ឌ ២២២៧ កំណត់សម្គាល់ជើងទំព័រលេខ ៧៤៩១ កថាខណ្ឌ ២២២៨ កំណត់សម្គាល់ជើងទំព័រលេខ ៧៤៩៤។

[3078] សំអាងហេតុសាលក្រម កថាខណ្ឌ ២១៨៣ កំណត់សម្គាល់ជើងទំព័រលេខ ៧៣២៧។

[3079] សំអាងហេតុសាលក្រម កថាខណ្ឌ ២២១៣ កំណត់សម្គាល់ជើងទំព័រលេខ ៧៤៣០។

[3080] សំអាងហេតុសាលក្រម កថាខណ្ឌ ២២៧០ កំណត់សម្គាល់ជើងទំព័រលេខ ៧៦៥៦ កថាខណ្ឌ ២៣១៣ កំណត់សម្គាល់ជើងទំព័រលេខ ៧៨១៦។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៨៥៨-១៨៦១។

[3081] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣០០, កថាខណ្ឌ ២៣១៣, កំណត់សម្គាល់ជើងទំព័រលេខ៧៨១៣ និង ៧៨១៦ កថាខណ្ឌ ២៣១៨ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៨៥១-១៨៥៣, ១៨៦២-១៨៧៣។

[3082] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣២០។

[3083] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣៧៣ កថាខណ្ឌ ២៥៥៧-២៥៥៨។

## ផ្នែកទី ៦. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខក្រាំងតាចាន់

១៦១២. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ អង្គជំនុំជម្រះបានលើកឡើងអំពី ខៀវ សំផន ក្នុងក្របខ័ណ្ឌនៃរបាយការណ៍មួយដែលបញ្ជាក់ថា មនុស្សម្នាក់បាននិយាយអំពីឈ្មោះគាត់ នៅឃុំត្រពាំងធំខាងត្បូង[3084]។ គ្មានអ្វីផ្សេងទៀតអាចត្រូវបានលើកឡើង ដើម្បីបង្ហាញទំនាក់ទំនងរវាង ម្ចាស់បណ្តឹងសាទុក្ខ និងក្រាំងតាចាន់ ក៏ដូចជាឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្តនៅទីនោះឡើយ។

## ផ្នែកទី ៧. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខអូរកន្សែង

១៦១៣. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះបានលើកឡើងអំពី ខៀវ សំផន តែម្តងគត់ ក្នុង "មហាសន្និបាត [...] ដែលបានរៀបចំឡើងនៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ នៅស្តាតអូឡាំពិក ក្នុងក្រុងភ្នំពេញ" ក្នុងឱកាសបង្កើតកងពល ៨០១[3085]។ គ្មានអ្វីផ្សេងទៀតអាចត្រូវបានលើកឡើង ដើម្បីបង្ហាញទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងអូរកន្សែង ក៏ដូចជាឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្តនៅទីនោះឡើយ។

## ផ្នែកទី ៨. គ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម នៅមន្ទីរសន្តិសុខភ្នំក្រោល

១៦១៤. ក្នុងសំអាងហេតុសាលក្រម ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល អង្គជំនុំជម្រះបានលើកឡើងអំពី ខៀវ សំផន តែម្តងគត់ ដោយបង្ហាញអំពីឈ្មោះដែលគេប្រើប្រាស់ជាទូទៅ នៅក្នុងលេខកូដទូរលេខរបស់អង្គភាពទំនាក់ទំនង ក-១៧[3086]។ ប៉ុន្តែ គ្មានទូរលេខណាមួយដែល ខៀវ សំផន បានទទួល ជាប់ទាក់ទងនឹងភ្នំក្រោលឡើយ[3087]។ ម្យ៉ាងវិញទៀត សៅ សារុន បានអះអាងថា គាត់បាននិយាយជាមួយ ខៀវ សំ

[3084] សំអាងហេតុសាលក្រម កថាខណ្ឌ ២៧២៣ កថាខណ្ឌ ២៨០៥។

[3085] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៦៣។

[3086] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨៦៣។

[3087] សូមមើលខាងក្រោម កថាខណ្ឌ ១៦២៤-១៦២៥។ សូមមើលផងដែរ កថាខណ្ឌ ១៨៥៦។

ផន តែម្តងគត់ ក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់គាត់ ពាក់ព័ន្ធនឹង "បញ្ហាសេដ្ឋកិច្ច"[3088]។ គ្មានអ្វីផ្សេងទៀតអាចត្រូវបានលើកឡើង ដើម្បីបង្ហាញទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខ និងភ្នំក្រោល ក៏ដូចជាឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្តនៅទីនោះឡើយ។

១៦១៥. **សេចក្តីសន្និដ្ឋានជារួម៖** គួរកត់សម្គាល់ថា អង្គជំនុំជម្រះមានការលំបាកក្នុងការរកឱ្យឃើញចំណងពាក់ព័ន្ធរវាង ខៀវ សំផន និងទីតាំងឧក្រិដ្ឋកម្ម ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២។ នេះពន្យល់ថាមធ្យោបាយតែមួយគត់ក្នុងការព្យាយាមទាញឱ្យគាត់ទទួលខុសត្រូវ គឺឆ្លងកាត់តាមទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ដើម្បីប៉ុនប៉ងបង្ហាញទំនាក់ទំនងដោយប្រយោល តាមរយៈការស្ថាបនាគោលនយោបាយឧក្រិដ្ឋ។ តម្រូវការនេះស្តែងឱ្យឃើញកាន់តែច្បាស់ ក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តិលើក្រុមជាក់លាក់ វៀតណាម ចាម ក៏ដូចជាអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលសញ្ញាណនៃគោលនយោបាយមានសារៈសំខាន់ ដើម្បីប៉ុនប៉ងភ្ជាប់ ខៀវ សំផន ទៅនឹងឧក្រិដ្ឋកម្ម តាមរយៈសុន្ទរកថា និងសកម្មភាពរបស់គាត់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែ ប្រការនេះមិនអាចច្រានចោលភាពចាំបាច់ក្នុងការបង្ហាញការចូលរួមចំណែកជាធម្មតា ក្នុងគោលបំណងរួមគ្មានលក្ខណៈឧក្រិដ្ឋ និងការចូលរួមចំណែកក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយដែលអង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណ។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដែលមិនអាចឱ្យសន្និដ្ឋានអំពីការចូលរួមចំណែករបស់ ខៀវ សំផន ក្នុងឧក្រិដ្ឋកម្ម។

## ជំពូកទី ២. មធ្យោបាយសិប្បនិម្មិត ដើម្បីប៉ះប៉ូវការគ្មានទំនាក់ទំនង និងសមូហភាពូបនីយកម្មនៃការទទួលខុសត្រូវ

១៦១៦. ដើម្បីប៉ះប៉ូវការគ្មានទំនាក់ទំនងរវាង ខៀវ សំផន និងឧក្រិដ្ឋកម្ម អង្គជំនុំជម្រះបានប្រើប្រាស់មធ្យោបាយសិប្បនិម្មិត ដើម្បីដាក់បញ្ចូលការទទួលខុសត្រូវរបស់គាត់ ទៅក្នុងការទទួលខុសត្រូវរួម តាមរយៈការប្រើពាក្យក្តោបរួម (ផ្នែកទី ១) តាមរយៈការសន្មតលើមធ្យោបាយទំនាក់ទំនង និងសារដែលគាត់បានទទួល (ផ្នែកទី ២) ដោយលាក់បាំងគោលការណ៍រក្សាការសម្ងាត់ (ផ្នែកទី៣)។

[3088] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០៤១។

## ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យក្ដោបរួម

១៦១៧. ក្នុងសមូហភាវូបនីយកម្មការទទួលខុសត្រូវ ផ្ទុយនឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរកការទទួលខុសត្រូវជាឯកត្តជនរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងសំអាងហេតុសាលក្រមទាំងមូល អង្គជំនុំជម្រះបានប្រើពាក្យក្ដោបរួម ដែលមិនសំដៅដល់អង្គភាពណាមួយឱ្យប្រាកដរបស់ ប.ក.ក។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការទាញសេចក្ដីសន្និដ្ឋានអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ដោយបានប្រើពាក្យ "មជ្ឈិមបក្ស" (១) "អង្គការ" (២) និង "៨៧០" (៣) ដោយមិនបានកំណត់អត្តសញ្ញាណសមាជិកច្បាស់លាស់នៃសហឧក្រិដ្ឋកម្មរួម ដែលអង្គជំនុំជម្រះបានសំដៅដល់។

### ១. "មជ្ឈិមបក្ស"

១៦១៨. អង្គជំនុំជម្រះបានយល់ឃើញថា ពាក្យ "មជ្ឈិមបក្ស" សំដៅជារួមដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក នៅទីក្រុងភ្នំពេញ ពោលគឺ គណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម គណៈយោធា មន្ទីរ ៨៧០ មន្ទីររដ្ឋបាល (ស-៧១) ព្រមទាំងមន្ទីរ និងអង្គភាពក្រោមឱវាទ[3089]។ នៅក្នុងការពិនិត្យសំអាងហេតុសាលក្រម ជាអាទិ៍ក្នុងផ្នែកទី *១៦. គោលបំណងរួម* និងផ្នែកទី *១៨. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន* ពាក្យក្ដោបរួមនេះត្រូវបានប្រើដោយមិនត្រឹមត្រូវ ដើម្បីផ្សារភ្ជាប់ ខៀវ សំផន ទៅនឹងសេចក្ដីសម្រេចទាំងអស់របស់អង្គភាពកម្ពុជាប្រជាធិបតេយ្យ ដែលគាត់មិនមែនជាសមាជិក[3090]។

#### ១.១. "មជ្ឈិមបក្ស" មិនត្រូវបានកំណត់ក្រៅបរិបទ

---

[3089] សំអាងហេតុសាលក្រម កថាខណ្ឌ ផ្នែក *៥.១.៤ មជ្ឈិមបក្ស*។

[3090] ជាឧទាហរណ៍ សូមមើលសំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៧ (កំណត់សម្គាល់ជើងទំព័រលេខ ១១០៦), ៣៨៤ (កំណត់សម្គាល់ជើងទំព័រលេខ ១១៤២), ៣៨៧៩ (កំណត់សម្គាល់ជើងទំព័រលេខ ១២៩៣៩), ៣៩១១ (កំណត់សម្គាល់ជើងទំព័រលេខ ១៣០៤៧), ៣៩៦២-៣៩៦៣, និង ៤០៦៥ (កំណត់សម្គាល់ជើងទំព័រលេខ ១៣៤៣៥)។

១៦១៩. អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុស៊ីចង្វាក់គ្នា ពេលហៅគណៈអចិន្ត្រៃយ៍ និងអង្គភាពចំណុះ ស-៧១ ថាជា "មជ្ឈិមបក្ស" ខណៈដែលអ្នកជំនាញ និងសាក្សីជាអតីតកម្មាភិបាល ប.ក.ក មិនអាចផ្តល់និយមន័យឱ្យបានច្បាស់លាស់បានឡើយ[3091]។ បើតាម Stephen HEDER ពាក្យ "ស្រពេចស្រពិលនេះ" សំដៅដល់កម្រិតនៃរចនាសម្ព័ន្ធ ឬឋានានុក្រមបក្ស ដែលអាចមានអង្គភាពច្រើន ឬតែមួយ ទៅតាមបរិបទ[3092]។

១៦២០. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រើប្រាស់ពាក្យនេះដោយចិត្តឯង ដោយមិនផ្អែកលើភ័ស្តុតាង ដើម្បីអាចឱ្យកំណត់ថា តើ "មជ្ឈិម" សំដៅដល់អ្វី និងជាអ្នកណា ពេលអង្គជំនុំជម្រះប្រើពាក្យនេះ។ ដោយសារតែគ្មានភាពច្បាស់លាស់នៃពាក្យនេះ អង្គជំនុំជម្រះមិនអាចប្រើពាក្យនេះ ដោយរួមបញ្ចូលទាំងមន្ទីរ និងថ្នាក់ផ្សេងៗ ទៅតាមការចង់សន្និដ្ឋានរបស់ខ្លួនបានទេ[3093]។ ដោយមិនកំណត់ឱ្យបានច្បាស់ថាតើសញ្ញាណនេះមានន័យយ៉ាងដូចម្តេចទៅតាមករណី អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានប្រើសញ្ញាណទូទៅនេះ ដើម្បីទាញសេចក្តីសន្និដ្ឋានដែលពោរពេញទៅដោយកំហុស អំពីការទទួលខុសត្រូវរបស់ ខៀវ សំផន[3094]។

## **១.២. កំហុសពាក់ព័ន្ធនឹងការទំនាក់ទំនង (ផ្នែកទី ៦ នៃសំអាងហេតុសាលក្រម)**

### **១.២.១. ផ្នែកទី ៦.២ ប្រព័ន្ធនៃទំនាក់ទំនងការងារ**

---

[3091] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦០-៣៦១ សូមមើល កំណត់សម្គាល់ជើងទំព័រលេខ ១០២៦-១០២៧។

[3092] Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/222.1** មុនម៉ោង 09.37.55។

[3093] ជាឧទាហរណ៍៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦១ អង្គជំនុំជម្រះអង្គជំនុំជម្រះបានចាត់ទុកថា "មជ្ឈិមបក្ស" នេះ រួមបញ្ចូលទាំងការិយាល័យនៅជុំវិញមន្ទីរ ស-៧១ ក្នុងនោះមាន ការិយាល័យក-១២។ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៨កំណត់សម្គាល់ជើងទំព័រ ១០៦៤ អង្គជំនុំជម្រះកត់សម្គាល់ថា ក-១២ ជាកន្លែងចតរថយន្ត និងអ្នកបើកបរជូន"មជ្ឈិមបក្ស"។ សំអាងហេតុនៃសាលក្រម កថាខណ្ឌ ៣៧៧ កំណត់សម្គាល់ជើងទំព័រលេខ ១១០៦ និងកថាខណ្ឌ ៣៨៤ កំណត់សម្គាល់ជើងទំព័រលេខ ១១៤២ អង្គជំនុំជម្រះកត់សម្គាល់ថា "មជ្ឈិមបក្ស" ប្រហែលជាបានទទួលខុសត្រូវដោយផ្ទាល់លើផ្នែកស្វយ័ត ហើយច្រាស់មកវិញ ជាអ្នកទទួលរបាយការណ៍ពីផ្នែកនោះ។ សំអាងហេតុនៃសាលក្រម កថាខណ្ឌ ៤២៤ កំណត់សម្គាល់ជើងទំព័រលេខ ១២៨០ អង្គជំនុំជម្រះបានសន្និដ្ឋានថា កងទ័ពប្រជាជនរំដោះជាតិកម្ពុជាស្ថិតនៅក្រោមការត្រួតត្រាដោយផ្ទាល់ពីភូមិភាគ គឺមិនមែនពី "មជ្ឈិមបក្ស"នោះទេ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

[3094] ជាឧទាហរណ៍ សូមមើល សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨, ៤៣១៤, ៤៣១៧, ៤៣២២។

១៦២១. ការប្រើពាក្យ "មជ្ឈិមបក្ស" បណ្ដាលឲ្យកើតចេញកំហុសជាច្រើនរបស់អង្គជំនុំជម្រះ នៅក្នុងសំអាងហេតុសាលក្រម។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋាននៅកថាខណ្ឌ ៩៨៣ ថា "ទំនាក់ទំនងខ្សែទទឹងនៅក្រៅគណៈកម្មាធិការមជ្ឈិម គឺមានតិចតួចបំផុត"។ សេចក្ដីសន្និដ្ឋាននេះមិនអាចឱ្យដឹងថា តើអង្គជំនុំជម្រះសំដៅដល់អង្គភាព ឬមន្ទីរណាឱ្យប្រាកដ ពីព្រោះសាក្សីដែលអង្គជំនុំជម្រះបានផ្អែកលើ បានឆ្លើយថា ពួកគេមិនដឹងថាតើពាក្យនេះសំដៅដល់អ្វីទេ ហើយអាចបានត្រឹមតែទាញសម្មតិកម្ម ឬមិននិយាយតែម្ដង[3095]។

---

[3095] សូមមើលសំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៥២៤ (នៃកថាខណ្ឌ ៩៨៣)។ នី កន៖ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/78.1** ម៉ោង 09.39.31 (គាត់មិនបានបញ្ជាក់ថា "មជ្ឈិមបក្ស" ទេ តែគ្រាន់តែថា "ទំនាក់ទំនងត្រូវបានធ្វើឡើងតាមរយៈរចនាសម្ព័ន្ធឋានានុក្រម")។ Craig ETCHESON ប្រតិចារឹកនៃសំណុំរឿង ០០១ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ ឯកសារ **E3/55** ERN 00330504 (ទោះបីជាគាត់លើកឡើងពី "មជ្ឈិមបក្ស" ក៏គាត់បានបញ្ជាក់ថា "មជ្ឈិមបក្សគឺជាស្ថាប័នតែមួយគត់ ដែលបានយល់ដឹងពីស្ថានភាពទាំងអស់ដែលកើតឡើងនៅក្នុងប្រទេស")។ សួន កានិល៖ ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/154.1** មុនម៉ោង 14.37.36 ("ស. ពាក់ព័ន្ធទៅនឹងសារទូរលេខផ្ញើពីមជ្ឈិមមកដល់ភូមិភាគរបស់លោក។ តើមន្ទីរ ឬក៏អង្គភាព នៅមជ្ឈិមនោះដែលកាន់កាប់បញ្ហាសារទូរលេខនោះមានឈ្មោះអ្វីដែរ? ឆ. អ្នកដែលកាន់កាប់នៅមជ្ឈិមហ្នឹងគឺខ្ញុំៗអត់ដឹងទេ បញ្ហាហ្នឹង អត់ ព្រោះរបបហ្នឹងគេៗអត់ គេមិនបញ្ចេញឈ្មោះតែម្ដងខ្ញុំនិយាយឱ្យចំ។ គឺការងារខ្ញុំៗដឹង ការងារគេៗដឹង")។ ផាន វ៉ាន់៖ ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/153.1** មុនម៉ោង 09.10.24 ("[ឆ្លងកាត់] តាមរយៈ "៨៧០")។ សូមមើលផងដែរ កំណត់សម្គាល់ជើងទំព័រលេខ ១៥២៥ (នៃកថាខណ្ឌដូចគ្នា ៩៨៣)។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** ម៉ោង 09.53.41 ("ស. តើគណៈកម្មាធិការភូមិភាគត្រូវរាយការណ៍ ទៅកម្រិតណាមួយទៀតដែរឬទេ ចំពោះស្ថានការណ៍ទូទៅនោះ? ឆ. នៅខាងលើផ្ទាល់របស់ភូមិភាគនីមួយៗ គឺអចិន្ត្រៃយ៍មជ្ឈិម និយាយឱ្យចំគឺ លេខា និងអនុលេខាមជ្ឈិម")។ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/380.1** ម៉ោង 09.21.16 (ថ្នាក់លើរបស់គាត់កម្រិតតែត្រឹមថ្នាក់តំបន់ប៉ុណ្ណោះ)។ ស៊ូ សឿន៖ ប្រតិចារឹក ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ **E1/310.1** ម៉ោង 15.25.52 (គាត់មិនបានលើកឡើងពី"មជ្ឈិមបក្ស"ទេ តែតែគ្រាន់តែថា "ទំនាក់ទំនងត្រូវបានធ្វើឡើងតាមរយៈរចនាសម្ព័ន្ធឋានានុក្រម")។ សួន កានិល៖ ប្រតិចារឹក ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/154.1** មុនម៉ោង 14.37.36។ នង សុផង់ អ្នកទទួលខុសត្រូវកងទូរលេខសម្រាប់ ប៉ុល ពត នៅភ្នំពេញ ទោះបីជាគាត់រំឮកដល់ពាក្យ "មជ្ឈិម" ក្ដី តែគាត់ទទួលស្គាល់ថាមិនដឹងមជ្ឈិមនោះជាអ្វីទេ ប្រតិចារឹក ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E1/121.1** ក្រោយម៉ោង 09.42.13។ ប្រតិចារឹក ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E1/122.1** ម៉ោង 11.35.41 ("ដូច្នេះចំពោះខ្លួនខ្ញុំ គឺខ្ញុំវាច្របូកច្របល់ហើយដល់អ៊ីចឹង មិនដឹងអ្នកណាជាគណៈអចិន្ត្រៃយ៍ អ្នកណាជាស្អីៗ។ ប៉ុន្តែតាមខ្ញុំយល់ដោយខ្លួនឯងទេ ឯន័យអនុវត្តរបស់ពួកខ្ញុំហ្នឹង គឺថាអត់ខ្វល់ពីរឿងគណៈ៨៧០មក ៨៧០ អង្គការ៨៧០ អីទេ ឱ្យតែឃើញសារគឺៗសំដៅទៅចូល ក-១ ទាំងអស់តែម្ដង")។ យុន គីម៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/88.1** ម៉ោង 10.18.59 (គាត់គ្រាន់តែលើកឡើងថា "មជ្ឈិម" នៅភ្នំពេញប៉ុណ្ណោះ)។

១៦២២. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានសន្និដ្ឋាននៅកថាខណ្ឌ ៩៨៤ អំពីការទំនាក់ទំនងក្នុង "មជ្ឈិមបក្ស" ថា "កំណត់ហេតុប្រជុំដែលនៅមានរហូតដល់ពេលនេះ បង្ហាញថាគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ បានប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាគ្នាអំពីគោលនយោបាយរបស់ ប.ក.ក"[3096]។ ប៉ុន្តែ កំណត់ហេតុប្រជុំ ដែលអង្គជំនុំជម្រះបានប្រើប្រាស់ មានតែនៅចន្លោះពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ខែមិថុនា ឆ្នាំ១៩៧៦ ហើយអង្គជំនុំជម្រះមិនគួរណាផ្អែកលើឯកសារអាចជំទាស់តវ៉ាបានរបស់សាស្ត្រាចារ្យ GOSCHA ដែលយើងបានឃើញពីខាងលើអំពីកង្វះភាពអាចជឿទុកចិត្តបាន[3097]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចទាញសេចក្ដីសន្និដ្ឋានអំពីភាពទៀងទាត់នៃការផ្លាស់ប្ដូរយោបល់បែបនេះ ក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ ម្យ៉ាងវិញទៀត ការវាយតម្លៃដោយមិនលម្អៀងទៅលើកំណត់ហេតុទាំងនេះគួរណាតែនាំឱ្យអង្គជំនុំជម្រះកត់សម្គាល់ថា សេចក្ដីសម្រេចតែងតែត្រូវបានធ្វើឡើងដោយ "អង្គការ" ឬ "សមមិត្តលេខា" ឬគណៈអចិន្ត្រៃយ៍ ហើយច្បាស់ណាស់ គឺមិនមែនគណៈមជ្ឈិមទេ[3098]។

១៦២៣. ក្នុងដំណើរការរញ៉េរញ៉ៃ និងច្របូកច្របល់ដដែល អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ក្នុងការទាញសេចក្ដីសន្និដ្ឋានដាក់បន្ទុក ដោយបានលើកឡើងថា មេដឹកនាំជាន់ខ្ពស់ ប.ក.ក ជួបទល់មុខគ្នា ឬជួបជុំគ្នា នៅមន្ទីរ ក-១ និង ក-៣។ ជាក់ស្ដែង គ្មានសាក្សីណាម្នាក់អាចឆ្លើយដោយមិនស្មានទេថា ការរស់នៅកៀកគ្នានាំឱ្យមានការចូលរួមពីមេដឹកនាំជាន់ខ្ពស់ទាំងអស់ក្នុងកិច្ចប្រជុំរួម[3099]។

---

[3096] សំអាងហេតុសាលក្រម កថាខណ្ឌ ៩៨៤ កំណត់សម្គាល់ជើងទំព័រលេខ ១៥២៦ (ដែលយោងទៅកថាខណ្ឌ ៣៥៧)។

[3097] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧ កំណត់សម្គាល់ជើងទំព័រលេខ ១០១១។ សូមមើលខាងលើ កថាខណ្ឌ ២១៨-២២៥។

[3098] សំអាងហេតុសាលក្រម កថាខណ្ឌ ៩៨៤ កំណត់សម្គាល់ជើងទំព័រលេខ ១៥២៦។ ឧទាហរណ៍ កំណត់ហេតុអង្គប្រជុំស្ដីពីការបូកសរុបសង្គមកិច្ច សុខាភិបាល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ឯកសារ **E3/226** ERN 00017152-53។ កំណត់ហេតុអង្គប្រជុំការងារភូមិ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** ERN 00017119។ សូមមើលផងដែរ កំណត់ហេតុអង្គប្រជុំ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/237** ERN 00072476 (មានបញ្ហាបកប្រែជាភាសាបារាំងទាក់ទងនឹងគណៈអចិន្ត្រៃយ៍ សូមមើលអត្ថបទជាភាសាខ្មែរ ERN 00072476)។ កំណត់ហេតុនេះបានបញ្ជាក់ច្បាស់ថា គឺអង្គការជាអ្នកនិយាយ ហើយ [គណៈកម្មាធិការ]អចិន្ត្រៃយ៍ ជាអ្នកសម្រេចបង្កើតគណៈកម្មាធការបក្សដឹកនាំក្នុងក្រសួងឧស្សាហកម្ម។

[3099] សំអាងហេតុសាលក្រម កថាខណ្ឌ ៩៨៤ កំណត់សម្គាល់ជើងទំព័រលេខ ១៥២៧ ដែលយោងផងដែរទៅកថាខណ្ឌ ៥៨៩។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** ម៉ោង 13.39.28 គាត់មិនស្គាល់ការិយាល័យ "មជ្ឈិម"ទេ ពីព្រោះជាទី

១៦២៤. ដូចគ្នាផងដែរ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទាញសេចក្តីសន្និដ្ឋានជាទូទៅអំពីលិខិតទាក់ទងគ្នា ដែលត្រូវបានផ្ញើជូន "មជ្ឈិមបក្ស" ពាក់ព័ន្ធនឹងការបញ្ជូនបញ្ជា សំណើ និងព័ត៌មាន តាមទូរស័ព្ទ និងការបញ្ជូនទូរលេខពីថ្នាក់ក្រោម[3100]។ ដោយប្រើពាក្យក្តោបរួម អង្គជំនុំជម្រះបានលាក់បាំងទាំងស្រុងនូវសក្ខីកម្មរបស់ អឿន តាន ប្រធានកងការពាររបស់ ប៉ុល ពត និង នង សុផង់ អ្នកគ្រប់គ្រងទូរលេខ ដែលអាចឱ្យដក ខៀវ សំផន ចេញពី "មជ្ឈិមបក្ស" ដែលជាស្ថាប័នធ្វើសេចក្តីសម្រេចនេះ[3101]។

### ១.២.២. ផ្នែកទី ៦.២.២ ទំនាក់ទំនងរវាងមជ្ឈិមបក្ស និងភូមិភាគ ឬតំបន់ស្វយ័ត

១៦២៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានរកឃើញថា ភូមិភាគ និងតំបន់ស្វយ័តបានរាយការណ៍ផ្ទាល់ជូន "មជ្ឈិមបក្ស" ខណៈដែលភស្តុតាងអាចឱ្យកំណត់អត្តសញ្ញាណអ្នកទទួលច្បាស់លាស់ ដែល

---

កន្លែងសម្ងាត់ សូមមើលអត្ថបទជាភាសាខ្មែរ ទំព័រ ៤៩ បន្ទាត់ ៥-៦។ អឿន តាន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/86.1** មុនម៉ោង 09.46.20 (គាត់បានឃើញថ្នាក់ដឹកនាំប្រជុំ តែមិនដឹងពីខ្លឹមសារនៃការប្រជុំនោះទេ ព្រោះគាត់នៅចម្ងាយពីនោះ២០ម៉ែត្រ)។ ស រី៖ ប្រតិចារឹក ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/156.1** ម៉ោង 11.40.05 (គាត់មិនធ្លាប់បានចូលរួមប្រជុំទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) និង ម៉ោង 09.58.56 (គាត់យាមនៅជាន់ទី២ និងដើរល្បាតពេលយប់)។ សាឡុត បាន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/66.1** ម៉ោង 14.09.35 (គាត់មិនធ្លាប់បានចូលរួមប្រជុំគណៈមជ្ឈិមទេ តែធ្លាប់ឃើញ ខៀវ សំផន ប្រជុំជាមួយ នួន ជា និងប៉ុល ពត នៅ ក-១ នៅពេលគាត់ទៅជួបប្រជុំគាត់ដែលធ្វើការនៅរោងបាយនៃការិយាល័យនេះ)។

[3100] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៨៥, ៤៨៦។

[3101] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៨៥ កំណត់សម្គាល់ជើងទំព័រលេខ ១៥២៩-១៥៣០ និង កថាខណ្ឌ ៤៨៦ កំណត់សម្គាល់ជើងទំព័រលេខ ១៥៣១-១៥៣៣។ ជាពិសេស សូមមើល អឿន តាន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/86.1** ចន្លោះម៉ោង13.41.50 និង 13.53.13។ សូមមើលផងដែរ ស រី ថ្នាក់ក្រោមរបស់ អឿន តាន នៅក១ បានពន្យល់ថា អឿន តាន ទទួលបញ្ជាពី ប៉ុល ពត និងនួន ជា ប្រតិចារឹក ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/156.1** ម៉ោង 11.35.52. នង សុផង់៖ ប្រតិចារឹក ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E1/120.1** ម៉ោង 13.58.00។ ទោះបីជាគាត់មានទំនាក់ទំនងជាមួយ លោក ខៀវ សំផន ក្នុងការផ្ញើទំនិញទៅមូលដ្ឋានយ៉ាងណាក្តី នង សុផង់ បានអះអាងថាមិនធ្លាប់បានទទួលការណែនាំពីថ្នាក់លើឱ្យបញ្ជូនទូរលេខទទួលពីមូលដ្ឋាន ដែលមានចម្លងជូនទៅ លោក ខៀវ សំផន ឡើយ។

មិនរួមបញ្ចូលម្ចាស់បណ្តឹងសាទុក្ខទេ[3102]។ ជាក់ស្តែង សាក្សីដ៏សំខាន់បំផុត គឺ ផាន វ៉ាន និង សៅ សារុន មកពីតំបន់ស្វយ័តមណ្ឌលគិរី ព្រមទាំង នង សុផង់ ជាអ្នកគ្រប់គ្រងទូរលេខ បានបែងចែកច្បាស់រវាងលិខិតផ្ញើជូន ប៉ុល ពត[3103] និងលិខិតផ្ញើជូន និងចេញពី ខៀវ សំផន ហើយលិខិតរបស់គាត់គ្មានអ្វីសម្ងាត់នោះទេ គឺពាក់ព័ន្ធនឹងការចែកចាយផលិតផល[3104]។

១៦២៦. ម្យ៉ាងវិញទៀត ភស្តុតាងក្នុងសំណុំរឿងក៏អាចឱ្យសន្និដ្ឋានថា អំណាចសម្រេចស្ថិតលើ ប៉ុល ពត និង នួន ជា ដោយសារតែពួកគាត់មានតំណែងនៅក្នុងគណៈអចិន្ត្រៃយ៍[3105]។ ដូច្នេះ អង្គជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានខុស ជាមួយនឹងពាក្យ "មជ្ឈិមបក្ស" ខណៈដែលអង្គជំនុំជម្រះអាចកំណត់បានថាអ្នកណាជាអ្នកទទួលសារប្រភេទណា និងអាចដក ខៀវ សំផន ចេញពីទូរលេខដែលមិនជាប់ទាក់ទងនឹងមុខងាររបស់គាត់។

## ១.៣. កំហុសពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាន នៅក្នុងផ្នែកទី *១៦. គោលបំណងរួម*

---

[3102] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៨៧ កំណត់សម្គាល់ជើងទំព័រលេខ ១៥៣៤។

[3103] ~~សៅ សារុន~~៖ ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/83.1** ក្រោយម៉ោង 09.59.22 នៅទីនេះ សហព្រះរាជអាជ្ញាបានបង្ហាញដល់គាត់នូវទូរលេខកម្ពុជាប្រជាធិបតេយ្យ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ឯកសារ **E3/383** ចុះថ្ងៃទី០១ ខែមករា ឆ្នាំ ១៩៧៨ ចំពោះគាត់ ៨៧០ គឺ ប៉ុល ពត (មានបញ្ហាបកប្រែ សូមមើលជាភាសាខ្មែរ ទំព័រ ១៩ បន្ទាត់ ៦) មុនម៉ោង 10.22.44 (គឺ ប៉ុល ពត ដែលឆ្លើយឆ្លងតាមទូរលេខ)។ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/84.1** ក្រោយម៉ោង 09.23.42។ ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/85.1** ក្រោយម៉ោង 15.40.08។

[3104] ផាន វ៉ាន កូនប្រុសរបស់ ឡាំង អតីតប្រធានតំបន់មណ្ឌលគិរី មុន សៅ សារុន បានអះអាងថា ទូរលេខដែលបានបញ្ជូនទៅមិត្តហែម ពាក់ព័ន្ធនឹងបញ្ហាផ្សេងខុសពីសន្តិសុខ គឺទាក់ទងនឹងសម្ភារៈដែលត្រូវចែកចាយទៅតាមតំបន់ និងមានទម្រង់មិនសម្ងាត់៖ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/151.1** ម៉ោង 15.19.48 មានបញ្ហាបកប្រែ សូមមើលជាភាសាខ្មែរ ទំព័រ ៧៦ បន្ទាត់ ៥-៧ ម៉ោង 15.50.25 "[ខៀវ សំផន] មិនមានពាក់ព័ន្ធនឹងសន្តិសុខទេ។ ខ្ញុំមិនដែលឃើញឈ្មោះគាត់ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខទេ"។ នង សុផង់៖ ប្រតិចារឹក ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E1/120.1** ម៉ោង 13.50.43 ម៉ោង 13.53.08 ម៉ោង 13.56.04 នង សុផង់ អ្នកទទួលខុសត្រូវខាងទំនាក់ទំនងបានអះអាងថាបានបញ្ជូនទូរលេខទៅ "មជ្ឈិម" ដែលខុសគ្នាពីទូរលេខផ្ញើទៅលោក ខៀវ សំផន ដែលមានលក្ខណៈ "លាត" ពាក់ព័ន្ធនឹងការចែកចាយសម្ភារៈទៅកាន់ភូមិភាគ និងសម្រាប់បុណ្យជាតិ។

[3105] សេចក្តីព្រាងលក្ខន្តិកៈ ប.ក.ក ឯកសារគ្មានចុះកាលបរិច្ឆេទ ឯកសារ **E3/8380** ទំព័រ ១៨ ERN 00283510។

១៦២៧. ពាក្យមិនច្បាស់លាស់ "មជ្ឈិមបក្ស" ត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ខុសយ៉ាងទូលំទូលាយ នៅក្នុងការរកឃើញរបស់ខ្លួន ខណៈដែលភស្តុតាងមិនបានសំដៅដល់ពាក្យនេះទេ។ ឧទាហរណ៍ អង្គជំនុំជម្រះបានសន្និដ្ឋានថា ខៀវ សំផន បានទទួលស្គាល់ក្នុងសៀវភៅរបស់គាត់ថា ការជម្លៀសដោយបង្ខំស្ថិតក្នុងក្របខ័ណ្ឌនៃកម្មវិធីនយោបាយរបស់ "មជ្ឈិមបក្ស" ខណៈដែលក្នុងសៀវភៅនោះ គាត់និយាយតែពី ប៉ុល ពត និងមេដឹកនាំ ប.ក.ក ដោយបានបញ្ជាក់ថា គាត់ស្ថិតនៅក្រៅស្នូលដឹកនាំខ្មែរក្រហម គឺគណៈអចិន្ត្រៃយ៍[3106]។

១៦២៨. ដូចគ្នាផងដែរ អង្គជំនុំជម្រះបានយល់ឃើញថា "មជ្ឈិមបក្សបានចេញសេចក្តីណែនាំទាក់ទងនឹងម៉ោងធ្វើការ" នៅការដ្ឋានទំនប់១មករា[3107]។ ប៉ុន្តែ បើយើងពិនិត្យមើលសេចក្តីយោងនៃភស្តុតាងឯកសារដែលបានដកស្រង់ គឺសុន្ទរកថាមួយរបស់ ប៉ុល ពត នៅឆ្នាំ១៩៧៨ សៀវភៅរបស់ ខៀវ សំផន នៅក្រោយរបបនោះ ទស្សនាវដ្តី "ទង់បដិវត្ត" មួយច្បាប់ របាយការណ៍មួយរបស់ FBIS និងឯកសារពីរទៀតរបស់ ប.ក.ក គ្មានឯកសារណាមួយនិយាយសំដៅដល់ "មជ្ឈិមបក្ស" ឡើយ ដោយឯកសារនីមួយៗលើកឡើងអំពីអង្គភាពនានាដែលត្រូវបានកំណត់អត្តសញ្ញាណ[3108]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយទាញសេចក្តីសន្និដ្ឋានដោយចេតនាពីការបង្កើតអង្គភាពរួមមួយដែលតាមពិតគ្មានអត្ថិភាព[3109]។

---

[3106] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៧៩ កំណត់សម្គាល់ជើងទំព័រលេខ ១២៩៣៩។ សៀវភៅរបស់ លោក ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ខែឧសភា ឆ្នាំ២០០៧ ឯកសារ **E3/18** ទំព័រ ១២៧ ERN 00103873 ។

[3107] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១១ កំណត់សម្គាល់ជើងទំព័រលេខ ១៣០៤៧ ដែលយោងទៅកថាខណ្ឌ ១២៧៧ ដែលយោងទៅកថាខណ្ឌ ១៥០៩។

[3108] សំអាងហេតុសាលក្រម កថាខណ្ឌ ១៥០៩ សេចក្តីសន្និដ្ឋានផ្អែកលើកថាខណ្ឌ ១៥០៥-១៥០៨ កំណត់សម្គាល់ជើងទំព័រលេខ ៥១៣៧-៥១៤៥។ ឧទាហរណ៍ អង្គជំនុំជម្រះបានស្រង់សម្តីចេញពីសៀវភៅរបស់ លោក ខៀវ សំផន ខណៈដែលលោក ខៀវ សំផន គ្រាន់តែបានលើកឡើងពីបញ្ហាបច្ចេកទេសនៃអ្នកទទួលខុសត្រូវតាមមូលដ្ឋាន សៀវភៅរបស់ លោក ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ **E3/16** ទំព័រ ៩០-៩១ ERN 00380500-01។

[3109] ឧទាហរណ៍ផ្សេងទៀត សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៣។ អង្គជំនុំជម្រះបានសន្និដ្ឋានថា "សមាជិកនៅថ្នាក់ខ្ពស់បំផុតនៃ ប.ក.ក រួមទាំង ប៉ុល ពត, នួន ជា និង ខៀវ សំផន បានដឹងនាំពីល័ក្ខខ័ណ្ឌរស់នៅ នៅទីនោះផ្ទាល់"។ ក៏ប៉ុន្តែ មានធាតុផ្សំភស្តុតាងជាច្រើនអាចផ្តល់ជាសេចក្តីសន្និដ្ឋានបានស្តីពីការដែល "មជ្ឈិមបក្ស" មានបំណងរក្សាទុកកម្លាំងពលកម្មរបស់ប្រជាជនឱ្យមានសុខ

១៦២៩. អង្គជំនុំជម្រះក៏បានបំភ្លឺ និងបំប្លែងភស្តុតាងគាំទ្រដល់ការរកឃើញរបស់ខ្លួនថា ទូរលេខ និងរបាយការណ៍ ដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះ ត្រូវបានផ្ញើជូន "មជ្ឈិមបក្ស" ដែលបង្ហាញអំពីអត្ថិភាពនៃខ្សែចង្វាក់ទំនាក់ទំនង តាមរយៈការផ្ញើរបាយការណ៍ជាទៀងទាត់ និងជាប្រព័ន្ធ តាមឋានានុក្រមរវាងភូមិភាគ និងថ្នាក់ដឹកនាំ ប.ក.ក ខណៈដែលរបាយការណ៍ទាំងនេះត្រូវបានផ្ញើជូនអង្គការ ដែលមានន័យផ្សេង[3110]។

## ១.៤. កំហុសពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននៅក្នុងផ្នែកទី ១៨. ការទទួលខុសត្រូវព្រហ្មទណ្ឌ

១៦៣០. នៅក្នុងសេចក្តីសន្និដ្ឋានអំពីការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ យើងដឹងថា កំហុសរបស់អង្គជំនុំជម្រះ តាមរយៈការប្រើពាក្យទូលំទូលាយ និងមិនកំណត់នៃ "មជ្ឈិមបក្ស" មានគោលដៅធ្វើឱ្យអាចសន្និដ្ឋានអំពីការដឹងពីឧក្រិដ្ឋកម្ម ការចូលរួមចំណែក និងការទទួលខុសត្រូវរបស់ ខៀវ សំផន[3111]។ ប៉ុន្តែ ភាពមិនច្បាស់លាស់បាននាំឱ្យអង្គជំនុំជម្រះធ្វើសេចក្តីសន្និដ្ឋានផ្ទុយ។

---

ភាពល្អ ប៉ុន្តែ ប.ក.ក ឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងជំងឺដែលបានរាលដាល និងភាពអត់ឃ្លាន នោះគឺកំណត់ហេតុកិច្ចប្រជុំ ដែលនៅពេលនោះពាក្យអង្គការត្រូវបានប្រើប្រាស់។ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ ១៣០៥៨ (នៃកថាខណ្ឌ ៣៩១១) ដែលផ្អែកលើកំណត់ហេតុកិច្ចប្រជុំ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** និង ឯកសារ FBIS, *Radio Calls for Attention to Year's Last Crop* ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៧ (FBIS) ឯកសារ **E3/1339**។ អង្គជំនុំជម្រះបានប្រើប្រាស់រូបមន្តទូលំទូលាយ និងស្រពិចស្រពិលនេះ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនស្តីពីការរៀបអាពាហ៍ពិពាហ៍ និង ស្តីពីមន្ទីរសន្តិសុខ អូរកន្សែង ដោយមិនព្យាយាមបញ្ជាក់ថា តើបានយោងទៅអង្គភាពមួយណាជាក់លាក់នៃ ប.ក.ក ឡើយ៖ អំពីការជំនួសអំណាចឪពុកម្តាយ អនុលោមតាមសេចក្តីណែនាំរបស់ "មជ្ឈិមបក្ស" (កថាខណ្ឌ ៤០៦៥ កំណត់សម្គាល់ជើងទំព័រលេខ ១៣៤៣៥)។ អូរកន្សែង បញ្ជូនព័ត៌មានបន្តទៅកាន់ "មជ្ឈិមបក្ស" អំពីសកម្មភាពរបស់ខ្លួន រួមទាំងការសម្លាប់អ្នកទោសចារ៉ាយ ចំនួន ១០០ នាក់ (កថាខណ្ឌ ៤០៧០)។

[3110] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៩៩ (កំណត់សម្គាល់ជើងទំព័រលេខ ១២៩៩៩) និង ៣៩៦២-៣៩៦៣។

[3111] សំអាងហេតុសាលក្រម ការដឹងឮ កថាខណ្ឌ ៤២០៨ និង ៤២៣៦ ទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត កថាខណ្ឌ ៤៣១៤ និង ៤៣១៧ និងការទទួលខុសត្រូវរបស់ថ្នាក់លើ កថាខណ្ឌ ៤៣២២។ ទោះបីជាទម្រង់នៃការទទួលខុសត្រូវចុងក្រោយនេះមិនត្រូវបានរាប់បញ្ចូលក្តី ប៉ុន្តែ អង្គជំនុំជម្រះបានយល់ឃើញថា គោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំបានផ្តល់លទ្ធភាពដល់ ខៀវ សំផន ក្នុងការធ្វើអន្តរាគមន៍ ក្នុងកិច្ចប្រជុំ "មជ្ឈិមបក្ស" ជាពិសេស កិច្ចប្រជុំគណៈអចិន្ត្រៃយ៍។

១៦៣១. ជាក់ស្តែង ជាដំបូង អង្គជំនុំជម្រះបានសន្និដ្ឋានថា "ការនៅជាប់កៀកនឹងមជ្ឈិមបក្សបានជួយឱ្យ ខៀវ សំផន ដឹងជាបន្តបន្ទាប់អំពីការបង្កើតផែនការ ការអនុវត្តផែនការ និងភាវនីយភាពដែលថា ឧក្រិដ្ឋកម្ម នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ បានកើតឡើង" "ខៀវ សំផន [...] បានដឹងអំពីសេចក្តីថ្លែងការណ៍ជាសាធារណៈដែលធ្វើឡើងដោយសមាជិកមជ្ឈិមបក្ស" ហើយហេតុដូច្នេះ ខៀវ សំផន បានដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម និង "ដឹងអំពីភាវនីយភាពជាក់ស្តែងដែលថា ការអនុវត្តនូវគោលនយោបាយទាំងនេះនឹងនាំមកនូវការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[3112]។ ដូច្នេះ អង្គជំនុំជម្រះមិនបានរាប់បញ្ចូល ខៀវ សំផន ទៅក្នុង "មជ្ឈិមបក្ស" នេះទេ។ ប៉ុន្តែ អង្គជំនុំជម្រះបានសន្និដ្ឋានបន្តមកទៀតថា "ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់ដែលមានឋានៈពិសេសនៅក្នុងមជ្ឈិមបក្ស ខៀវ សំផន បានគាំទ្រគោលបំណងរួម [...]"[3113]។

១៦៣២. **សេចក្តីសន្និដ្ឋាន៖** ចៅក្រមប្រកបដោយវិចារណញ្ញាណគ្រប់រូប គួរណាតែព្យាយាមទាញសេចក្តីសន្និដ្ឋាន ដោយបែងចែកឱ្យដាច់រវាងអង្គភាពផ្សេងៗរបស់ ប.ក.ក អាស្រ័យតាមភ័ស្តុតាងដែលបានប្រើប្រាស់។ ភាពផ្ទុយគ្នាទាំងនេះ ក្នុងវិចារណកិច្ចរបស់អង្គជំនុំជម្រះ បង្ហាញអំពីភាពគ្មានវិធីសាស្ត្រ និងឆ្លុះបញ្ចាំងឱ្យឃើញកំហុសធ្ងន់ធ្ងររបស់អង្គជំនុំជម្រះក្នុងការប្រើពាក្យ "មជ្ឈិមបក្ស" ដែលធ្វើឱ្យសេចក្តីសន្និដ្ឋានទាំងអស់លើប្រធានបទនេះក្លាយជាមោឃៈ[3114]។

---

[3112] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ក្នុងន័យដូចគ្នានេះដែរ សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៤ ស្តីពីសហករណ៍ និងការដ្ឋានការងារ អង្គជំនុំជម្រះបានសន្និដ្ឋានថា៖ "ខៀវ សំផន បានលើកទឹកចិត្ត និងផ្តល់ការគាំទ្រផ្នែកសីលធម៌ ជាសាធារណៈ ដោយបើកចំហ និងយ៉ាងសកម្មដល់កម្មាភិបាល ប.ក.ក ក្នុងការអនុវត្តគោលនយោបាយរបស់ បក្សគ្រប់ពេលវេលាទាំងអស់"។ សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៧ អង្គជំនុំជម្រះបានសន្និដ្ឋានថា "តាមរយៈអំពើរបស់គាត់ ខៀវ សំផន បានផ្តល់ជំនួយជាក់ស្តែង និងការគាំទ្រផ្នែកសីលធម៌ដល់មជ្ឈិមបក្សក្នុងការបង្កើត និងអនុវត្តគោលនយោបាយនេះ។ អំពើទាំងនេះបានជះឥទ្ធិពលយ៉ាងច្រើនលើការប្រព្រឹត្តឧក្រិដ្ឋកម្មដោយកម្មាភិបាល ប.ក.ក ហើយ ខៀវ សំផន បានដឹងឮគ្រប់ពេលពីធាតុផ្សំសំខាន់ នៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយចារីផ្ទាល់។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន បានជួយ និងសម្របសម្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត (ដោយចេតនាប្រយោល) នៅមន្ទីរសន្តិសុខ និងក្នុងបរិបទនៃការបោសសម្អាតផ្ទៃក្នុង"។

[3113] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3114] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨, ៤២៣៦-៤៣២៨, ៤៣១៤, ៤៣១៧, ៤៣៨២-៤៣៨៣។

## ២. អង្គការ

១៦៣៣. ដូចពាក្យ "មជ្ឈិមបក្ស" ដែរ អង្គជំនុំជម្រះបានប្រើពាក្យ "អង្គការ" នៅក្នុងសំអាងហេតុសាលក្រមទាំងមូល ដើម្បីផ្សារភ្ជាប់ ខៀវ សំផន តាមបែបសិប្បនិម្មិត ទៅនឹងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០២/០២ ខណៈដែលអង្គជំនុំជម្រះបានដឹងច្បាស់អំពីភាពស្រពេចស្រពិលនៃសញ្ញាណនេះ ដែលត្រូវបកស្រាយអាស្រ័យតាមបរិបទ[3115]។

## ២.១. កំហុសពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននៅក្នុងផ្នែកទី ១៦. គោលបំណងរួម

១៦៣៤. អង្គជំនុំជម្រះបានសន្និដ្ឋាន នៅកថាខណ្ឌ ៣៩៦២ ថា "ទូរលេខផ្ញើទៅអង្គការ គឺជាភស្តុតាងច្បាស់លាស់ពីការចូលរួមផ្ទាល់របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងយុទ្ធនាការកំណត់អត្តសញ្ញាណ និងកម្ទេចខ្មាំងខ្សែខ្មាំង"[3116]។ ប៉ុន្តែ ចំពោះចំណុចផ្សេងទៀតនៃផ្នែកទី ១៦ យើងយល់តាមរយៈវិចារណកិច្ចថា អង្គជំនុំជម្រះបានកំណត់ថា ប៉ុល ពត គឺជាអង្គការ[3117]។ ទោះជាយ៉ាងណា ជួនកាល អង្គជំនុំជម្រះមានការភាន់ច្រឡំ នៅក្នុងការវិភាគភស្តុតាង ដោយបានប្រើពាក្យ "អង្គការ" ជារួម សម្រាប់របាយការណ៍ និងទូរលេខផ្ញើពីភូមិភាគនានា ខណៈដែលពាក្យនៅក្នុងឯកសារ គឺខុសៗគ្នា ដូចជាគណៈ ៨៧០ អង្គការ ៨៧០ ឬបង ប៉ុល[3118]។ ចំណុចនេះមិនបានរារាំងអង្គជំនុំជម្រះមិនឱ្យ "ជឿជាក់" ដោយមិនត្រឹមត្រូវថា ភស្តុតាងទាំងនេះ "បង្ហាញអំពីការតាមដានរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មា

---

[3115] សំអាងហេតុសាលក្រម *ផ្នែក ៥.១.៨ អង្គការ* កថាខណ្ឌ ៣៩២ កំណត់សម្គាល់ជើងទំព័រលេខ ៩៤៩ (នៅទីនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា អង្គការ ជាអង្គភាពអនាមិក និងត្រូវបានមើលឃើញថាមានអំណាចគ្រប់គ្រងសង្គមទាំងមូល) កថាខណ្ឌ ៣៨៨។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៦៤០-១៦៤៩។

[3116] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦២។

[3117] សំអាងហេតុសាលក្រម កថាខណ្ឌ ៣០១៣ កំណត់សម្គាល់ជើងទំព័រលេខ ១៣០៦៥ ដែលនៅទីនេះអង្គជំនុំជម្រះបានយោងទៅកំណត់ហេតុនៃគណៈអចិន្ត្រៃយ៍ ដែលនៅទីនោះសេចក្តីសម្រេចរបស់ ប៉ុល ពត គឺជាសេចក្តីសម្រេចរបស់អង្គការ។

[3118] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១២ កំណត់សម្គាល់ជើងទំព័រលេខ ១៣០៤៨ កថាខណ្ឌ ៣៩៦៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣១៨៩-១៣១៩៣។

ធិការអចិន្ត្រៃយ៍បក្ស លើការអនុវត្តគោលនយោបាយបក្ស ស្របតាមអាណត្តិរបស់ខ្លួន”[3119]។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចទាញសេចក្ដីសន្និដ្ឋានបែបនេះទេ ខណៈដែលភ័ស្តុតាងបង្ហាញថា អំណាចប្រមូលផ្ដុំលើ ប៉ុល ពត ដែលត្រូវគេហៅឈ្មោះនៅក្នុងឯកសារ[3120]។

១៦៣៥. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានទុកឱ្យមានភាពមិនច្បាស់លាស់លើពាក្យនេះ ផ្ទុយទៅវិញ អង្គជំនុំជម្រះគួរណាតែផ្ដល់សំអាងហេតុដល់សេចក្ដីសម្រេចរបស់ខ្លួន អាស្រ័យតាមបរិបទនៃភ័ស្តុតាង ហើយមិនត្រូវទាញសេចក្ដីសន្និដ្ឋានជាទូទៅលើពាក្យ “អង្គការ” នោះទេ ខណៈដែលពាក្យនេះអាចសំដៅដល់បក្ស ប៉ុល ពត តែម្នាក់ឯង ឬអាជ្ញាធរមូលដ្ឋានស៊ីវិល ឬយោធា ទៅតាមបរិបទ ដូចយើងនឹងឃើញខាងក្រោម។

## ២.២. កំហុសពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋាននៅក្នុងផ្នែកទី ១៨. ការទទួលខុសត្រូវព្រហ្មទណ្ឌ

១៦៣៦. ត្រង់នេះទៀត គួរកត់សម្គាល់ថា កំហុសរបស់អង្គជំនុំជម្រះមិនមែនធម្មតានោះទេ គឺចូលក្នុងន័យប្រើពាក្យ “អង្គការ” ដើម្បីជួយសម្រួលដល់ការភ្ជាប់ទំនាក់ទំនងជាមួយម្ចាស់បណ្ដឹងសាទុក្ខ[3121]។ ជាក់ស្ដែង អង្គជំនុំជម្រះបានលើកឡើងថា ខៀវ សំផន បានលើកទឹកចិត្តប្រជាជនឱ្យគាំទ្រដល់កម្មវិធីរបស់អង្គ

---

[3119] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣១៨៩-១៣១៩៤។

[3120] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១២ កំណត់សម្គាល់ជើងទំព័រលេខ ១៣០៤៨ កថាខណ្ឌ ៣៩៦៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣១៨៩-១៣១៩៣។ គួររំឮកថា សក្ខីកម្មរបស់ សៅ សារុន ប្រធានតំបន់ស្វយ័ត ១០៥ ដែលមានឈ្មោះនៅលើទូរលេខ បានពន្យល់ដល់អង្គជំនុំជម្រះថា ប៉ុល ពត ពិតជាអ្នកទទួលទូរលេខ ហើយ ប៉ុល ពត ជាអ្នកឆ្លើយទូរលេខ។ សៅ សារុន៖ ប្រតិចារឹក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/83.1** ក្រោយម៉ោង 09.59.22 នៅទីនេះ សហព្រះរាជអាជ្ញាបានបង្ហាញទូរលេខកម្ពុជាប្រជាធិបតេយ្យ ទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៨ ឯកសារ **E3/383** ដូច្នេះបើតាមយោបល់គាត់ ៨៧០ គឺជា ប៉ុល ពត (មានបញ្ហាបកប្រែ សូមមើលជាភាសាខ្មែរ ទំព័រ ១៩ បន្ទាត់ ៦) មុនម៉ោង 10.22.44 (គឺ ប៉ុល ពត តែម្ដងជាអ្នកឆ្លើយទូរលេខ)។ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/84.1** ក្រោយម៉ោង 09.23.42។ ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/85.1** ក្រោយម៉ោង 15.40.08 (ការិយាល័យ ៨៧០ ឬបង ម-៨៧០ គឺ ប៉ុល ពត)។

[3121] ជាពិសេស នៅក្នុងចំណុច *១៨.១.២. ការដឹងឮនៅខណៈពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម*, *១៨.២.១.១. ការគាំទ្រគោលបំណងរួម* (កថាខណ្ឌ ៤២៥៧), *១៨.២.១.២. ការលើកកម្ពស់គោលបំណងរួម* (កថាខណ្ឌ ៤២៦៣) និង *១៨.២.១.៣. ការលើកទឹកចិត្ត ការញុះញង់ និងការផ្ដល់នូវធម្មានុរូបលើការអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយ* (កថាខណ្ឌ ៤២៦៧, ៤២៦៨)។

ការដើម្បីកសាង និងការពារកម្ពុជាប្រជាធិបតេយ្យ និង/ឬលើកកម្ពស់ "ផែនការសេដ្ឋកិច្ចបួនឆ្នាំរបស់អង្គការ និងទ្រទ្រង់គ្រប់ស្ថានការណ៍តាមការកំណត់របស់បក្ស"[3122]។ ប៉ុន្តែ ការអានដោយមិនលម្អៀងនូវភស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋានទាំងនេះ អាចឱ្យកត់សម្គាល់ថា គេមិនប្រើពាក្យអង្គការនោះទេ គឺពាក្យប្រជាជន ឬបក្សឯណោះទេ[3123]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានបញ្ជាក់ថាតើឯកសារ ដែលខ្លួនយកមកសំអាង សំដៅដល់អ្នកណា ឬអង្គភាពណាឱ្យប្រាកដ[3124]។

## ៣. "៨៧០"

១៦៣៧. លេខកូដ ៨៧០ ដែលមានន័យផ្សេងៗគ្នា ទៅតាមបរិបទ ក៏ត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ ដើម្បីផ្សារភ្ជាប់ ខៀវ សំផន ទៅនឹងឧក្រិដ្ឋកម្ម ជាអាទិ៍ តាមរយៈការចូលរួមចំណែករបស់គាត់ ក្នុងឋានៈជាសមាជិកសហឧក្រិដ្ឋកម្មរួម[3125]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានបង្កឱ្យមានភាពច្របូកច្របល់គ្នារវាងលេខកូដ ៨៧០ ដែលប្រើប្រាស់ក្នុងន័យជាច្រើន និងមន្ទីរ ៨៧០ ដើម្បី

[3122] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៣៩១២ (នៃកថាខណ្ឌ ៤២៥៧) កំណត់សម្គាល់ជើងទំព័រលេខ ១៣៩២៥ (នៃកថាខណ្ឌ ៤២៦៧ គូសបន្ទាត់ពីក្រោម នៅក្នុងសំណៅដើម) ដែលយោងទៅកំណត់សម្គាល់ជើងទំព័រលេខ ១២៤៨៩ (នៃកថាខណ្ឌ ៣៧៤២) ដែលផ្អែកទៅលើចម្លើយជាច្រើនរបស់ លោក ខៀវ សំផន។

[3123] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤២ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៨៩។

[3124] សូមមើលផងដែរសំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៨ *(១៨.២.១.៣. ការលើកទឹកចិត្ត ការញុះញង់ និងការផ្តល់នូវចម្នាទូបលើការអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយ)* និង ៤៣០៤ (១៨.២.២. ចេតនា)។ សូមមើលផងដែរ កថាខណ្ឌ ៤២៤៨ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៦២ ដែលយោងទៅកថាខណ្ឌ ៣៥៦៩ និង ៣៦១១ (កំណត់សម្គាល់ជើងទំព័រលេខ ១២០៥៣) ដែលនៅទីនេះ អង្គជំនុំជម្រះបានប្រើប្រាស់ពាក្យពេចន៍ទាំងនេះដើម្បីធ្វើសេចក្តីសន្និដ្ឋានចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមរបស់ លោក ខៀវ សំផន ដែលបានអប់រំដល់កម្មាភិបាលពីភាពចាំបាច់ក្នុងការផ្តាច់ខ្លួនចេញពីឪពុកម្តាយដើម្បីបម្រើអង្គការ ដោយផ្អែកតែទៅលើសក្ខីកម្មរបស់ ជា ឌៀប ដែលមិនទាំងចេះពន្យល់អត្ថន័យនៃពាក្យ អង្គការនោះផង។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១២៣៣-១២៤២។

[3125] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៧១ (*១៦.៤.៥. សំអាងច្បាប់*)។ កថាខណ្ឌ ៤២២៥ (*១៨.១.២.២. មន្ទីរសន្តិសុខ ទីកន្លែងសម្លាប់មនុស្ស និងការបោះសម្អាតផ្ទៃក្នុង*)។ កថាខណ្ឌ ៤២៥៧ (*១៨.២.១.១. ការគាំទ្រគោលបំណងរួម*)។ កថាខណ្ឌ ៤២៧៦ (*១៨.២.១.៥. ការផ្តល់លទ្ធភាព និង ការគ្រប់គ្រងការអនុវត្តគោលបំណងរួម និងគោលនយោបាយនៃគោលបំណងរួមនេះ*)។

សន្និដ្ឋានអំពីការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ តាមរយៈការបំពេញមុខងាររបស់គាត់នៅមន្ទីរ ៨៧០[3126]។

១៦៣៨. ជាក់ស្តែង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានទាញការសន្និដ្ឋានថា ខៀវ សំផន មិនបានជំនួស ខឿន ទេ និងគ្មានតួនាទីដឹកនាំ នៅមន្ទីរ ៨៧០ នោះឡើយ ហើយអង្គជំនុំជម្រះមិនអាចកំណត់មុខងាររបស់គាត់ឱ្យបានច្បាស់ ជាមួយនឹងអង្គភាពនេះ[3127]។ ប៉ុន្តែ ដូចយើងនឹងឃើញខាងក្រោម មុខងាររបស់ ខៀវ សំផន ពាក់ព័ន្ធនឹងមន្ទីរនេះ កម្រិតត្រឹមការចែកចាយសម្ភារៈដល់ភូមិភាគនានា និងទិដ្ឋភាពខ្លះនៃពាណិជ្ជកម្ម ទៅតាមការសម្រេចពីគណៈអចិន្ត្រៃយ៍[3128]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានទាញសេចក្តីសន្និដ្ឋានអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន តាមរយៈការវិភាគរបាយការណ៍ និងទូរលេខ ពាក់ព័ន្ធនឹងមន្ទីរ ៨៧០ ខណៈដែលការអានឯកសារដោយមិនលម្អៀងគួរណាតែនាំឱ្យអង្គជំនុំជម្រះកត់សម្គាល់ថា ពាក្យជាច្រើនត្រូវបានប្រើប្រាស់ សម្រាប់អ្នកទទួល គឺ គណៈ ៨៧០ អង្គការ ៨៧០ មន្ទីរ ៨៧០ ឬជួនកាលបង[3129]។

---

[3126] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨៩។

[3127] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៥ (*៨.៣.៤.១. សមាជិកភាពមន្ទីរ ៨៧០*)។

[3128] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៩។ នង សុផង់៖ ប្រតិចារឹក ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E1/120.1** ម៉ោង 13.49.09 (គាត់បានអះអាងបន្ថែមពីចម្លើយរបស់គាត់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី ទាក់ទងនឹងទូរលេខពាក់ព័ន្ធនឹង លោក ខៀវ សំផន ទាក់ទងនឹងការចែកចាយអំបិល អង្ករ ក្រណាត់ សម្លៀកបំពាក់ ស្បែកជើង និងសម្ភារៈផ្សេងទៀតសម្រាប់អង្គភាពណាមួយ ដែលជាអ្នកចែកបន្តទៅប្រជាជន។ គាត់ទទួលខុសត្រូវលើសម្ភារៈ និងផលិតផលផ្សេងៗសម្រាប់ប្រជាជន។) ម៉ោង 14.01.02។ សាឡុត បាន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/68.1** ម៉ោង 11.11.46 ("មិនដឹងជាមានភារកិច្ចអីទេ ៨៧០ ក៏មិនដឹង តែក្នុង៨៧០ ហើយ គេហៅថា ៨៧០ទាំងអស់គ្នាហើយ ជាទូទៅជំនាន់នោះ។ មន្ទីរ៨៧០ អ្នកណាក្នុងមន្ទីរ៨៧០ ហ្នឹងគឺសុទ្ធតែ៨៧០ តែទាំងអស់ហ្នឹង")។ ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/69.1** ម៉ោង 09.26.46 ក្រោយម៉ោង 09.38.34 ("ឯបង ខៀវ សំផន លោកនៅតែក្នុងមន្ទីរទេ លោកអត់មានចេញទៅណាបានទេ")។ <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/83.1** ម៉ោង 11.56.02 (ពួកគាត់និយាយគ្នាតែមួយលើកនោះគត់ និង និយាយតែពីបញ្ហាសម្ភារៈដែលត្រូវផ្តល់ជូនប្រជាជន)។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៧៦៣-១៧៦៩។

[3129] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៧១ "កៃ ពក ទទួលខុសត្រូវលើការសាងសង់ទំនប់ ១មករា ហើយបានរាយការណ៍អំពីការសាងសង់នេះទៅមន្ទីរ៨៧០។ រស់ ញឹម ជាលេខាភូមិភាគពាយ័ព្យ បានចុះពិនិត្យទំនប់ត្រពាំងថ្ម ហើយបានផ្តល់របាយការណ៍

១៦៣៩. ដូច្នេះ អង្គជំនុំជម្រះមិនអាចមិនបញ្ជាក់ថា តើគេប្រើលេខកូដ ៨៧០ ក្នុងបរិបទណាខ្លះ មុននឹងទាញសេចក្ដីសន្និដ្ឋាន ខណៈដែលសាក្សីជាច្រើនបានពន្យល់ថាលេខកូដ ៨៧០ សំដៅដល់អង្គភាពផ្សេងៗ[3130] ដោយគេមានចេតនាទុកឱ្យមានភាពស្រពេចស្រពិល ក្នុងក្របខ័ណ្ឌនៃគោលការណ៍រក្សាការសម្ងាត់របស់ ប.ក.ក[3131]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយធ្វើមិនដឹងមិនឮចំពោះសក្ខីកម្មរបស់ នង សុផង់ ជាអ្នកគ្រប់គ្រងទូរលេខ។ ជាក់ស្ដែង គាត់បានឆ្លើយថា ខៀវ សំផន មិនមែននៅគណៈ ៨៧០ ទេ ហើយគាត់បានកំណត់ថាជាគណៈអចិន្ត្រៃយ៍ ដែលមានប្រព័ន្ធទំនាក់ទំនងខុសពី

---

លម្អិតអំពីស្ថានភាពរស់នៅ និងធ្វើការ នៅក្នុងភូមិភាគទៅមន្ទីរ៨៧០ និងគាត់គ្រប់គ្រងដោយផ្ទាល់ទៅលើគណៈកម្មាធិការតំបន់៥ ដែលទទួលខុសត្រូវលើការសាងសង់ទំនប់"។ ធាតុផ្សំភ័ស្តុតាងដទៃទៀតនៅក្នុងសំណុំរឿងនេះ អាចឱ្យគេយល់ឃើញផងដែរថា ទូរលេខមួយចំនួនត្រូវបានផ្ញើទៅ ប៉ុល ពត និង/ឬ នួន ជា សូមមើលជាពិសេស ទូរលេខរបស់ កែ ពក, ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/952** ERN 00000766។ ទូរលេខរបស់ សោ ភឹម, ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារ **E3/879** ERN 00001071។ គួរគត់សម្គាល់ថា ទោះបីជា សួន កានិល អ្នកបកប្រែទូរលេខនៃភូមិភាគកណ្ដាលបានកត់សម្គាល់ឃើញថា គណៈ ៨៧០ ឬ ម-៨៧០ ជាអង្គភាពមួយមែន តែគាត់ទទួលស្គាល់ថាមិនបានទាក់ទងមន្ទីរ ៨៧០ នោះទេ, សួន កានិល៖ ប្រតិចារឹក ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/155.1** ម៉ោង 11.29.38 ម៉ោង 11.40.46។

[3130] <u>Stephen HEDER</u>៖ ប្រតិចារឹក ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/225.1** ក្រោយម៉ោង 15.09.43 ម៉ោង 15.34.04។ ឧទាហរណ៍ សូមមើលកំណត់ហេតុកិច្ចប្រជុំនៃគណៈអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារ **E3/182** ERN 00019110 (ស.ម យ៉ែម៖ ការិយាល័យ ៨៧០) ERN FR 00292871 (នៅកថាខណ្ឌចុងក្រោយ ពាក់ព័ន្ធនឹងមុខងារនៃការិយាល័យនេះ កំណត់ហេតុនៃអង្គប្រជុំផ្សេងៗ និងបណ្ណសារ) សូមមើលអត្ថបទជាភាសាខ្មែរ ERN 00019111។ សូមមើលផងដែរ <u>អឿន តាន</u>៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/86.1** ចន្លោះម៉ោង13.41.50 និងម៉ោង 13.53.13 ប្រធានកងការពារ ប៉ុល ពត បានពន្យល់ថា ប៉ុល ពត ខ្លួនឯងជាអ្នករក្សាទុកឯកសារ សារ និងសំបុត្រនៅ ក-១។ <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/83.1** ក្រោយម៉ោង 09.59.22 អំពីទូរលេខកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៨ ឯកសារ **E3/383** បើតាមសម្ដីគាត់ ៨៧០ គឺជា ប៉ុល ពត (មានបញ្ហាបកប្រែ សូមមើលជាភាសាខ្មែរ ទំព័រ ១៩ បន្ទាត់ ៦) មុនម៉ោង 10.22.44 (គឺ ប៉ុល ពត តែម្ដងដែលជាអ្នកឆ្លើយឆ្លងទូរលេខ)។ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/84.1** ក្រោយម៉ោង 09.23.42។ ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/85.1** ក្រោយម៉ោង 15.40.08 (ការិយាល័យ ៨៧០ ឬបងម-៨៧០ គឺមានន័យថាជា ប៉ុល ពត)។

[3131] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦២។

ម្ចាស់បណ្ដឹងសាទុក្ខ[3132]។ ដោយមិនអើពើនឹងភ័ស្ដុតាងទាំងនេះ នៅក្នុងសេចក្ដីសន្និដ្ឋានអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ពាក់ព័ន្ធនឹង ៨៧០ អង្គជំនុំជម្រះបានធ្វើឱ្យសេចក្ដីសម្រេចរបស់ខ្លួនមានកំហុស។ អង្គជំនុំជម្រះមិនអាចប្រើប្រាស់មធ្យោបាយសិប្បនិម្មិតនេះ ដើម្បីសន្និដ្ឋានអំពីការគាំទ្រ និងការជួយរបស់គាត់ដល់ ប.ក.ក ឱ្យសម្រេចគោលដៅ និង "ជួយឱ្យរដ្ឋបាលរបបកម្ពុជាប្រជាធិបតេយ្យដំណើរការទៅដោយរលូន" ក្នុងទិសដៅបំផ្លាញប្រជាជនរបស់ខ្លួន នោះឡើយ[3133]។ សេចក្ដីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះ ក្នុងន័យនេះ ត្រូវទុកជាមោឃៈ។

## ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងមធ្យោបាយទំនាក់ទំនង

១៦៤០. ដើម្បីប៉ះប៉ូវភាពមិនគ្រប់គ្រាន់នៃភ័ស្ដុតាង ដែលអាចឱ្យភ្ជាប់ទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង ខៀវ សំផន អង្គជំនុំជម្រះបានសន្និដ្ឋានអំពីការចូលរួមរបស់ ខៀវ សំផន តាមរយៈការទទួលបានទស្សនាវដ្ដីបដិវត្ត (១) និងការដឹងអំពីរចនាសម្ព័ន្ធ និងទំនាក់ទំនងរបស់កងទ័ព (២)។

### ១. ទស្សនាវដ្ដី "ទង់បដិវត្ត" "យុវជន និងយុវនារីបដិវត្ត"

១៦៤១. អង្គជំនុំជម្រះបានសន្និដ្ឋានថា ទស្សនាវដ្ដី "ទង់បដិវត្ត" និង "យុវជន និងយុវនារីបដិវត្ត" គឺជាមធ្យោបាយផ្សព្វផ្សាយ និងលើកកម្ពស់គោលនយោបាយផ្សេងៗរបស់ ប.ក.ក ក្នុងក្របខ័ណ្ឌនៃគោល

---

[3132] នង សុផង់៖ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ **E3/64** ERN 00328033។គណៈអចិន្ត្រៃយ៍បញ្ជូនសារតាមរយៈនីរសា ប៉ុន និង ថេរ ដែលកាន់សារដោយផ្ទាល់ជូនទៅគណៈ៨៧០ ចំណែកឯ លោក ខៀវ សំផន បញ្ជូនសំបុត្រសរសេរដៃតាមរយៈនីរសា ក-១ ដែលផ្ញើបន្តទៅក-១ ឬចូនកាលទូរស័ព្ទ។

[3133] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧, ៤២៧៦។ កថាខណ្ឌ ៤២២៥ ("ដើម្បីឈានដល់ការយល់ឃើញបែបនេះ អង្គជំនុំជម្រះបានពិចារណាចំពោះវត្តមានរបស់ ខៀវ សំផន ដែលបានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត និងនួន ជា និងការពិតដែលថា គាត់នៅតែជាសមាជិកម្នាក់ក្នុងចំណោមសមាជិកមួយចំនួនតូចនៃមន្ទីរ ៨៧០ បន្ទាប់ពីខឿន បានបាត់ខ្លួនអស់រយៈពេលប្រហែលពីរឆ្នាំ មុនការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ)។

បំណងរួម សម្រាប់បក្ខជន[3134]។ ទស្សនាវដ្ដីទាំងនេះបម្រើឱ្យការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងអ្នកដែលបក្សចាត់ទុកជាខ្មាំង[3135]។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានអះអាងយ៉ាងដាច់ណាត់ថា តាមរយៈការទទួលបានទស្សនាវដ្ដីទាំងនេះ ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្ម ជាអាទិ៍ ជោគវាសនារបស់ខ្មាំង ហើយសេចក្ដីថ្លែងការណ៍របស់គាត់បានបន្ទរតាមអត្ថបទពាក់ព័ន្ធនឹងវៀតណាម[3136]។ ត្រង់ចំណុចចុងក្រោយនេះ សូមរំឭកថា បរិបទនៃសុន្ទរកថា ក្នុងពេលមានជម្លោះប្រដាប់អាវុធ ត្រូវបានអង្គជំនុំជម្រះលាក់បាំងទាំងស្រុង[3137]។

១៦៤២. ម្យ៉ាង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ពាក់ព័ន្ធនឹងតម្លៃជាភស្តុតាងនៃទស្សនាវដ្ដីទាំងនេះ ដែលយើងឃើញថា ក្នុងសំណុំរឿង មានឯកសារច្បាប់ដើមតែពីរប៉ុណ្ណោះ[3138] ហើយក្នុងករណីឯកសារទាំងនេះត្រូវបានដាក់បញ្ចូលជាភស្តុតាង សម្រាប់សំណុំរឿង ០០២ ទាំងមូល ការកត់សម្គាល់លើប្រធានបទនេះ ក្នុងសំណុំរឿង ០០២/០១ នៅដដែល[3139]។ ម្យ៉ាងទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស នៅក្នុងសេចក្ដីសន្និដ្ឋានអំពីការទទួលបានទស្សនាវដ្ដីនេះយ៉ាងពិតប្រាកដពីសំណាក់បក្ខជនទាំងអស់ និងជាពិសេស ថ្នាក់ឃុំ[3140]។ ជាក់ស្ដែង អតីតកម្មាភិបាលថ្នាក់ខ្ពស់បង្គួរជាច្រើននាក់ មកពីភូមិភាគនានា បាន

---

[3134] ឧទាហរណ៍ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៩ *(១៦.២.២. ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ខែមករា ឆ្នាំ១៩៧៩៖ បដិវត្តន៍សង្គមនិយម)* កថាខណ្ឌ ៣៧៤៧ *(១៦.៣.១. ទិដ្ឋភាពទូទៅនៃកាលប្បវត្តិក្នុងការកំណត់អត្តសញ្ញាណខ្មាំងរបស់ ប.ក.ក)* កថាខណ្ឌ ៣៧៥៨-៣៧៥៩, ៣៧៧៧, ៣៧៨០, ៣៧៨២។

[3135] សំអាងហេតុសាលក្រម *១៦. គោលបំណងរួម* ឧទាហរណ៍ កថាខណ្ឌ ៣៨៦៣ *(១៦.៣.២.៣. ការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងខ្មាំង)* កំណត់សម្គាល់ជើងទំព័រលេខ ១២៩០១-១២៩០៥ ដែលយោងទៅផ្នែកផ្សេងទៀត។ ចំពោះកំហុសរបស់អង្គជំនុំជម្រះស្ដីពីខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មត សូមមើលខាងលើផងដែរ កថាខណ្ឌ ១៤៥១-១៤៨៨។

[3136] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៦ *(១៨.១.២. ការដឹងឮនៅខណៈពេលដែលមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម - មន្ទីរសន្តិសុខ ទីកន្លែងសម្លាប់មនុស្ស និងការបោសសម្អាតផ្ទៃក្នុង)*, ៤២៥៣ *(១៨.១.៣. ការដឹងឮនៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម)*, ៤២៦៩ *(១៨.២.១.៣. ការលើកទឹកចិត្ត ការញុំញង់ ការផ្ដល់នូវធម្មានុរូបលើការអនុវត្តគោលបំណងរួមតាមរយៈគោលនយោបាយ)*។

[3137] សូមមើលខាងលើ កថាខណ្ឌ ១៤៨៦-១៤៨៨។

[3138] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៧៨។ សូមមើលខាងលើ កថាខណ្ឌ ៣២៣។

[3139] សារណាបណ្ដឹងសាទុក្ខ០០២/០១ កថាខណ្ឌ ២៨។ សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៥១៩។

[3140] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៧៧ កំណត់សម្គាល់ជើងទំព័រលេខ ១៥០០, ១៥០១។

ផ្តល់សក្ខីកម្មខុសពីនេះ ដោយបានបញ្ជាក់ថា ពួកគេមិនបានទទួល ឬដឹងអំពីទស្សនាវដ្តីទាំងនេះទេ[3141] ខណៈដែលអ្នកខ្លះទៀតមិនបានចាប់អារម្មណ៍លើខ្លឹមសារ ដែលមិនមែនគ្រប់គ្នាសុទ្ធតែយល់នោះទេ[3142]។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការទទួលបាន ទស្សនាវដ្តីទាំងនេះយ៉ាងទូលំទូលាយពីសំណាក់បក្ខជន មិនស៊ីគ្នានឹងភ័ស្តុតាងក្នុងសំណុំរឿងទេ។

១៦៤៣. អង្គជំនុំជម្រះក៏មិនអាចសន្និដ្ឋានដោយគ្មានភ័ស្តុតាងលម្អិតថា ខៀវ សំផន មានលទ្ធភាពទទួលបានទស្សនាវដ្តីទាំងនេះ "ដោយសារតួនាទីទទួលខុសត្រូវរបស់គាត់" ឬគាត់បានដឹងអត្ថបទជាក់លាក់ ដែលអង្គជំនុំជម្រះបានដកស្រង់ ដើម្បីសន្និដ្ឋានអំពីការដឹងអង្គហេតុ។ ជាក់ស្តែង សេចក្តីសន្និដ្ឋានថា ម្ចាស់

---

[3141] នៅត្រាំកក់ ប្រធានស្រុកបានទទួលពួកគេ តែមិនមែនប្រធានឃុំទេ៖ ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/291.1** ម៉ោង 15.49.47។ នាង អ៊ួច៖ ប្រតិចារឹក ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/273.1** ម៉ោង 13.53.21 ("បានឃើញនៅ ៗ សហករណ៍ៗនៅឃុំហ្នឹង គេចែកមកតាមសហករណ៍តាមឃុំ តែខ្ញុំមិនសូវជាចាប់អារម្មណ៍អានអីទេ"។) ម៉ោង 13.53.21 (មិនមានសៀវភៅនេះច្រើនទេ គេចែកនៅតាមឃុំ នៅក្នុងឃុំទេ មិនមែនដល់ដៃប្រជាជនទេ។ ចែកតាមឃុំ មួយឃុំមួយៗ អ៊ីចឹងទៅ។)។ នុត នូវ៖ ប្រតិចារឹក ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/276.1** ម៉ោង 14.15.04 (ប្រធានឃុំស្រែរនោង)។ ប្រតិចារឹក ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/277.1** ម៉ោង 15.44.38 (មិនបានទេ "ទស្សនាវដ្តីទង់បដិវត្ត" ជំនាន់នោះ គេអត់ដែលចែកទេ បើថ្នាក់លើៗប្រហែលជាមាន ប៉ុន្តែចំពោះខ្ញុំមិនដែលបានអានទេ)។ ខឹម ហឿន៖ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/297.1** ម៉ោង 14.36.39 (គាត់បានអះអាងលើចម្លើយមុនៗថាគាត់មិនបានដឹងថាមានទស្សនាវដ្តីបដិវត្តនេះទេ នៅពេលគាត់នៅឃុំ តែបានឃើញពេលគាត់ធ្វើការនៅស្រុក)។ រៀល សន៖ ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/278.1** ម៉ោង 14.14.52 (អនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់ បានបដិសេធថាមិនដែលបានឃើញទស្សនាវដ្តីទង់បដិវត្តទេ)។ ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/279.1** ម៉ោង 15.35.52។ នៅកន្លែងផ្សេងទៀតក្នុងប្រទេស ប៉ាន ឈួង៖ ប្រតិចារឹក ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ **E1/359.1** ម៉ោង 11.18.37 (ប្រធានត្រួតពិនិត្យកម្លាំងកងចល័ត នៅតំបន់៥ នៅក្រោម តាវ៉ាល់ បានអះអាងថាមិនធ្លាប់បានឃើញទស្សនាវដ្តីបែបនោះទេ)។ ម៉ឹង វេត៖ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ឯកសារ **E1/448.1** មុនម៉ោង 11.20.00។

[3142] ពេជ្រ ជឹម៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/291.1** ម៉ោង 15.49.47 ("រំឭកដល់គោលនយោបាយឱ្យកម្មាភិបាលមួយៗធ្វើឡើងវិញ។ ប៉ុន្តែកន្លងមក ដល់ខំសម្រុកពេកទៅ ភ្លេចមើលក្បួន។ [...] មិនត្រឹមមិនធ្វើ ទុកលើហ៊ឹងទេ ធ្វើឱ្យខុសទេ គ្រាន់ថាវារវល់ អត់បានតម្រង់")។ ប៉ាក សុខ៖ ប្រតិចារឹក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ **E1/369.1** ម៉ោង 14.32.34 ("ឮដែរ "ទស្សនាវដ្តីទង់បដិវត្ត" ប៉ុន្តែក៏មិនសូវចាប់អារម្មណ៍អីដែរ ទង់បដិវត្តកម្ពុជាប្រជាធិបតេយ្យ។ បានតែឮ ប៉ុន្តែគ្រាន់តែឮ ហើយក៏អត់បានវិភាគអីទេ"។)។ ជិន គឹមថុង៖ ប្រតិចារឹក ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ឯកសារ **E1/406.1** ម៉ោង 11.26.10 ("ឯកសារទង់បដិវត្ត ឯកសារយុវជន យុវនារី ពេលខ្លះក៏បានអាន ពេលខ្លះក៏មិនបានអាន។ អ៊ីចឹងខ្លឹមសារខ្ញុំមិនចាំបានទាំងអស់ទេ"។)។

បណ្តឹងសាទុក្ខដឹងអំពីការចាប់ខ្លួន ចាន់ ចក្រី, ឈូក និង កែវ មាស និងការអនុវត្តគោលនយោបាយនានារបស់ ប.ក.ក គ្រាន់តែជាការស្មានប៉ុណ្ណោះ[3143]។

## ២. រចនាសម្ព័ន្ធ និងការទំនាក់ទំនងរបស់កងទ័ព

១៦៤៤. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីរចនាសម្ព័ន្ធ និងការទំនាក់ទំនងរបស់កងទ័ព ដោយបានសម្រេចប្រើប្រាស់ពាក្យ "មជ្ឈិមបក្ស" សម្រាប់ហៅជារួមចំពោះថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក នៅទីក្រុងភ្នំពេញ រួមទាំងគណៈយោធាផងដែរ[3144]។ ការប្រើប្រាស់យ៉ាងទូលំទូលាយនេះ ក្នុងសំអាងហេតុសាលក្រមទាំងមូល[3145] បានបម្រើដល់ការទាញសេចក្តីសន្និដ្ឋានខុស ដោយមិនគិតដល់មុខងារជាក់លាក់នៃអង្គភាពនានារបស់ ប.ក.ក និងដោយបានបូកបញ្ចូលទាំងមុខងារដែលប្រគល់ជូនកងទ័ព ដើម្បីផ្សារភ្ជាប់ទៅ ខៀវ សំផន តាមបែបសិប្បនិម្មិត[3146]។

១៦៤៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានយល់ឃើញថា ពេលបង្កើតកងទ័ពបដិវត្តន៍កម្ពុជាថ្មី កងពលភូមិភាគមួយចំនួនត្រូវបានដាក់ឱ្យស្ថិតនៅក្រោម "ការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម" និងជាពិសេស ក្រោមបញ្ជារបស់សេនាធិការ[3147]។ ប៉ុន្តែ គ្មានភ័ស្តុតាងណាមួយអាចឱ្យឈានដល់ការសន្និដ្ឋានបែបនេះឡើយ។ ជាក់ស្តែង សាក្សី ដែលអង្គជំនុំជម្រះបានលើកឡើង គឺ គង់ គីម និង ឌុច មិនបាននិយាយពីគណៈមជ្ឈិមទាល់តែសោះ ប៉ុន្តែ បានអះអាងថា កងទ័ពមជ្ឈិមត្រូវរាយការណ៍

---

[3143] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៦ និង ៤២៥៣។ នៅក្នុងកថាខណ្ឌទី១ អង្គជំនុំជម្រះបានផ្អែកលើបទសម្ភាសន៍ជាមួយលោក ខៀវ សំផន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបរាប់ដាច់ៗពីគ្នា និងស្រពិចស្រពិលរបស់ អែម អឿន នៅក្នុងសំណុំរឿង ០០២/០១ អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/117.1** ចន្លោះម៉ោង09.46.41 និង 09.51.21។ ចម្លើយក្រោយរបបកម្ពុជាប្រជាធិបតេយ្យ "គ្មានកាលបរិច្ឆេទ" ជាមួយ លោក ខៀវ សំផន ទាំងអស់នោះមិនអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះសន្និដ្ឋានលើការដឹងឮរបស់គាត់នៅក្នុងរបបនោះទេ កំណត់សម្គាល់ជើងទំព័រលេខ ១៣៧៨៩-១៣៧៩០។

[3144] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៦១។ សូមមើលខាងលើ កថាខណ្ឌ ១៦១៨-១៦៣២។

[3145] ជាពិសេស នៅក្នុងផ្នែកទី៥ និងទី៦ ព្រមទាំងផ្នែកទី ១៦ គម្រោងរួម និងទី ១៨ ការទទួលខុសត្រូវ។

[3146] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤, ៤២៧, ៤៥០, ៤៥៥, ៥០៨-៥១១, ៣៩៦២-៣៩៦៣, ៤០៦៨-៤០៧៤, ៤២០៨, ៤៣១៧, ៤២៣៦។

[3147] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤ កំណត់សម្គាល់ជើងទំព័រលេខ ១២៨២។

ជូនសេនាធិការ ក្រោមបញ្ជារបស់ សុន សេន[3148]។ ឡុញ ដុស បានបញ្ជាក់អះអាងចំណុចនេះ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់។ ថ្វីត្បិតតែគាត់បានឆ្លើយថា សុន សេន ធ្វើការនៅ "កន្លែងមជ្ឈិម" ក-១ ជាមួយ ប៉ុល ពត និងអ្នកផ្សេងទៀតក៏ដោយ ក៏គាត់មិនធ្លាប់ទៅទីនោះ និងមិនដឹងថាគេសម្រេចយ៉ាងម៉េចទេ[3149]។ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រើប្រាស់ដោយមិនត្រឹមត្រូវនូវទស្សនាវដ្ដី "ទង់បដិវត្ត" ចេញផ្សាយខែសីហា ឆ្នាំ១៩៧៥ ដើម្បីបញ្ជាក់អះអាងទៅលើទស្សនៈអំពីកងទ័ពមជ្ឈិមក្រោមការគ្រប់គ្រងរបស់ "គណៈមជ្ឈិម" ពីព្រោះនៅក្នុងឯកសារដើមជាភាសាខ្មែរ គេប្រើពាក្យ "មជ្ឈិមបក្ស" គឺមិនមែន "គណៈមជ្ឈិម" ទេ[3150]។ ដូចគ្នាផងដែរ អង្គជំនុំជម្រះបានបំភ្លៃសក្ខីកម្មរបស់ Stephen HEDER និង ឌុច ដើម្បីសន្និដ្ឋានអំពី "ការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធា" លើកងទ័ពបដិវត្តន៍កម្ពុជា[3151]។ ជាក់ស្ដែង Stephen HEDER បាននិយាយថា កងទ័ពបដិវត្តន៍កម្ពុជាស្ថិតក្រោមឱវាទសេនាធិការ ក្រោមការគ្រប់គ្រងរបស់ សុន សេន និងបញ្ជាក់ថា កងទ័ពនេះចំណុះឱ្យ "ប៉ុល ពត" ចំណែកឯ ឌុច បាននិយាយអំពីអង្គភាពដឹកនាំផ្សេងៗរបស់បក្ស[3152]។

---

[3148] គង់ គីម៖ ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/138.1** ម៉ោង 15.36.09 ម៉ោង 15.49.36 គាត់បានរំឭកពីកងទ័ព ឬកម្លាំងមជ្ឈិម ដោយបញ្ជាក់ថាគឺស្ថិតនៅក្រោមឱវាទនៃសេនាធិការ និងមិនបាននិយាយពីគណៈមជ្ឈិមទេ។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** ចន្លោះម៉ោង10.21.41 និង 10.27.24 កងទ័ពស្ថិតនៅក្រោមការទទួលខុសត្រូវរបស់សេនាធិការ។ តាមសម្ដីឌុច កងទ័ពត្រូវបានត្រួតត្រាដោយលេខា អនុលេខាបក្ស ដោយគណៈអចិន្ត្រៃយ៍។

[3149] កំណត់ហេតុស្ដាប់ចម្លើយ ឡុញ ដុស ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/70** ស/ឆ ១៤, ១៦-១៩ ("ខ្ញុំគ្រាន់តែដឹងថាគាត់ចាកចេញពីសេនាធិការស្ទើររាល់ព្រឹក ថាទៅកន្លែងមជ្ឈិម។ គាត់ទៅកន្លែងក-១ តែខ្ញុំមិនដឹងថាគាត់ទៅជួបជាមួយអ្នកណាទេ។ ខ្ញុំមិនដឹងថាគាត់ធ្វើអ្វីទេនៅទីនោះ ហើយខ្ញុំមិនដែលទៅដល់ទីនោះទេ។ ខ្ញុំមិនស្គាល់ទីកន្លែងរបស់ក៏មួយទេ ខ្ញុំគ្រាន់តែដឹងថាគាត់ទៅទីនោះប៉ុណ្ណោះ)។

[3150] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២៨២ (នៃកថាខណ្ឌ៤២៤)។ ទស្សនាវដ្ដីទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ ឯកសារ **E3/5** ទំព័រ ២៤ ERN 00063324។ សូមមើលអត្ថបទជាភាសាខ្មែរ ទំព័រ ២៤ ERN 00063324។ ចំណែកឯអត្ថបទរបស់ T. Carney *Cambodia 1975-1978 : Rendez-vous With Death* ឯកសារ **E3/49** ទំព័រ ៩ ERN FR 00724069 លោកបានផ្អែកលើទស្សនាវដ្ដីទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ ហើយតាមឯកសារនេះ គាត់បានលើកឡើងថា "សេនាធិការនៃកងទ័ពបដិវត្តកម្ពុជា ៖ ប៉ុល ពត ប្រធាន សុន សេន ហៅខៀវ ប្រធានសេនាធិការ"។

[3151] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧។

[3152] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២៩៥ (នៃកថាខណ្ឌ ៤២៧)។ Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/222.1** ម៉ោង 14.08.22។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/53.1** ម៉ោង

ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះមានកំហុសឆ្គងដោយសារហេតុផលជាច្រើន និងត្រូវទុកជាមោឃៈ។

១៦៤៦. នៅកថាខណ្ឌ ៥០៨ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះក៏បានបំភ្លៃភ័ស្តុតាងដែលបានដកស្រង់ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនថា សារ និងរបាយការណ៍ជាលាយលក្ខណ៍អក្សរដែល សុន សេន បានទទួល ត្រូវបានបញ្ជូនបន្តទៅ "មេដឹកនាំ ប.ក.ក" ខណៈដែលភ័ស្តុតាងបង្ហាញយ៉ាងច្បាស់ថា ឯកសារទាំងនេះត្រូវបានបញ្ជូនបន្តទៅតែអង្គការ ដែលយើងបានឃើញថា ភាគច្រើន គឺជា ប៉ុល ពត នៅលើរបាយការណ៍ប្រភេទនេះ[3153]។ លើសពីនេះទៀត នៅកថាខណ្ឌ ៥០៩ អង្គជំនុំជម្រះបានប្រើប្រាស់របាយការណ៍ និងទូរលេខជាច្រើន ដោយមិនត្រឹមត្រូវ ដើម្បីសន្និដ្ឋានថា សារទាក់ទងគ្នារបស់កងពលខ្លះត្រូវបានផ្ញើជូនសេនាធិការ រួចត្រូវបាន សុន សេន បញ្ជូនបន្តទៅ "មជ្ឈិមបក្ស"[3154]។ ប៉ុន្តែភ័ស្តុតាងដែលបានប្រើប្រាស់មិនអាចឱ្យអង្គជំនុំជម្រះទាញការសន្និដ្ឋានបែបនេះបានទេ។ អង្គជំនុំជម្រះមិនអាចផ្អែកយ៉ាងមុតមាំលើកំណត់ហេតុស្តាប់ចម្លើយ ឡុញ ឌុស បានទេ ពីព្រោះក្រៅពីមិនបានមកបង្ហាញខ្លួន គាត់បានបញ្ជាក់ថា គាត់មិនធ្លាប់ទៅមន្ទីររបស់ សុន សេន និងមិនអាចដឹងថា តើ សុន សេន ចាត់ចែងយ៉ាងដូចម្តេចជាមួយរបាយការណ៍ទាំងនោះទេ[3155]។ លើសពីនេះទៀត ក្នុងផ្នែកផ្សេងទៀតនៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានប្រើប្រាស់របាយការណ៍ និងទូរលេខ ដែលបញ្ជាក់ថា អ្នកទទួលចំណារដែល សុន សេន ហៅ ខៀវ ចារលើរបាយការណ៍ផ្ញើពីកងពល គឺអង្គការ[3156]។

10.14.29។ លើសពីនោះ ប៉ុន្មានថ្ងៃក្រោយមក ឌុចបានពន្យល់ដល់អង្គជំនុំជម្រះថា កងទ័ពមជ្ឈិមស្ថិតនៅក្រោមការត្រួតត្រារបស់គណៈអចិន្ត្រៃយ៍ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/55.1 ចន្លោះម៉ោង 10.21.41 និងម៉ោង 10.27.24។

[3153] សំអាងហេតុសាលក្រម កថាខណ្ឌ ៥០៨។ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ ១៥៨៩ នៅទីនេះមានការលើកឡើងពីការរាយការណ៍របស់ មុត ស្តីពីកងទ័ពនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ឯកសារ **E3/1082** ERN 00143520។ ការរាយការណ៍របស់ សាន ពីកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/1199** ERN 00052312។

[3154] សំអាងហេតុសាលក្រម កថាខណ្ឌ ៥០៩ កំណត់សម្គាល់ជើងទំព័រលេខ ១៥៩០។ យោងដល់ចម្លើយរបស់ ឡុញ ឌុស និងផ្នែក *១២.៤.២.៤* និង *១២.៥* នៃសាលក្រម។ ម្យ៉ាងទៀត មានបញ្ហាមិនស៊ីចង្វាក់គ្នារវាងអត្ថបទជាភាសាផ្សេងៗនៃកថាខណ្ឌ ៥០៩។ ជាក់ស្តែង អត្ថបទជាភាសាខ្មែរនិយាយពីគណៈកម្មាធិការមជ្ឈិមបក្ស ចំណែកឯក្នុងសំណៅពីរភាសាទៀត គឺ "មជ្ឈិមបក្ស"។

[3155] កំណត់ហេតុស្តាប់ចម្លើយ ឡុញ ឌុស ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ **E3/70** ស/ឆ ១៦-១៩។

[3156] ឧទាហរណ៍ នៅក្នុងផ្នែក ១២.៤.២.៤៖ ការមើលខុសត្រូវលើកងពល ៨០១ ដោយនាយសេនាធិការនៃកងទ័ពបដិវត្តកម្ពុជា សំអាងហេតុនៃសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៩៨២៤-៩៨២៥ (នៃកថាខណ្ឌ ២៩៧៣) ចំណាររបស់ លោក ខៀវ សំផន

១៦៤៧. ជាចុងក្រោយ ក្នុងផ្នែក ១២.៥ ជាពិសេស នៅកថាខណ្ឌ ៣០៤៧ ស្តីពីកងពល ៩២០ អង្គជំនុំជម្រះបានសន្និដ្ឋានខុសទៀតថា "កងពល ៩២០ រាយការណ៍ផ្ទាល់ទៅមជ្ឈិមបក្ស ហើយទទួលការណែនាំពីនាយសេនាធិការ សុន សេន"។ ជាក់ស្តែង ពិតមែនតែ ឌុច និង សៅ សារុន ដែលត្រូវបានលើកយកមកសំអាង បាននិយាយថា "មជ្ឈិម" ទាក់ទងផ្ទាល់ជាមួយកងទ័ពមជ្ឈិមក្តី ក៏ ឌុច បានបញ្ជាក់ថា មជ្ឈិម គឺជា ប៉ុល ពត ដែលជាអ្នកគ្រប់គ្រងកងទ័ព និងទទួលសេចក្តីរាយការណ៍ពីសេនាធិការ[3157] ចំណែកឯ សៅ សារុន បានទទួលស្គាល់ថា គាត់មិនដឹងថាគណៈមជ្ឈិមមានសមាសភាពអ្នកណាខ្លះនោះទេ[3158]។ លើសពីនេះទៀត ឯកសារជាលាយលក្ខណ៍អក្សរផ្សេងទៀតបញ្ជាក់ថា កងពល ៩២០ ស្ថិតនៅក្រោមបញ្ជារបស់ ខៀវ (សុន សេន) ហើយគាត់បានបញ្ជូនរបាយការណ៍ និង/ឬទូរលេខ ទៅឱ្យអង្គការ និង/ឬបង ៨៧[3159]។

---

ទៅកាន់ "អង្គការ" មិនមែនទៅកាន់ "មជ្ឈិមបក្ស" ដូចការលើកឡើងរបស់អង្គជំនុំជម្រះនោះទេ។ សូមមើលផងដែរ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/1199**, ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ ឯកសារ **E3/1127**, ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៧ ឯកសារ **E3/1033**, ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ឯកសារ **E3/1082**។

[3157] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១០៣១៨ (នៃកថាខណ្ឌ ៣០៤៧)។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** ក្រោយម៉ោង 11.20.45។ គួរកត់សម្គាល់ថាមានបញ្ហានៃការបកប្រែជាភាសាបារាំង នៅក្នុងឯកសារយោងនេះ។ សាក្សីមិនបាននិយាយពីគណៈមជ្ឈិមទេ តែនិយាយថា "មជ្ឈិមបក្ស"។ សូមមើលជាភាសាខ្មែរ ទំព័រ ៣៦ បន្ទាត់ ៥-៦។

[3158] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១០៣១៨ (នៃកថាខណ្ឌ ៣០៤៧)។ សៅ សារុន៖ ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/83.1** មុនម៉ោង 10.04.01 ("ស. តើលោកនៅចាំទេ ថាតើអ្នកណាខ្លះស្ថិតនៅក្នុងគណៈមជ្ឈិមរបស់បក្សនៅឆ្នាំ១៩៧៨នោះ? ឆ. អាហ្នឹងការងារខាងលើ ខ្ញុំអត់យល់ទេ"។)។ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនាឆ្នាំ២០១២ ឯកសារ **E1/84.1** ក្រោយម៉ោង 09.23.42 ក្រោយម៉ោង 09.36.51 (ប៉ុល ពត ជាអ្នកណែនាំ និងប្រាប់ថាទៅទាក់ទងអ្នកណា) ចន្លោះម៉ោង 09.56.12 និង 10.06.48 (ទោះបីជាគាត់អះអាងថាបានឃើញសមាជិកគណៈមជ្ឈិមនៅក្នុងកិច្ចប្រជុំ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រួមទាំង លោក ខៀវ សំផន យ៉ាងណាក្តី តែសេចក្តីពន្យល់របស់គាត់មិនពាក់ព័ន្ធគ្នាឡើយ)។ សូមមើលជាភាសាខ្មែរដែលច្បាស់លាស់ជាងនៅទំព័រ ១៨-២០។

[3159] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១០៣១៨ (នៃកថាខណ្ឌ ៣០៤៧) ជាឧទាហរណ៍ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/1022** (ចម្លងជូនបង៨៧)។ ទូរលេខនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/1199** (ចំណារ៖ អង្គការ)។

១៦៤៨. ភ័ស្តុតាងស៊ីចង្វាក់គ្នាទាំងនេះអាចឱ្យសន្និដ្ឋានថា ក្នុងបរិបទនេះ អង្គការសំដៅដល់ ប៉ុល ពត។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមានចេតនាប្រើពាក្យ "មជ្ឈិមបក្ស" ជំនួសឱ្យអង្គការ និងលេខកូដផ្សេងទៀតដែល ប៉ុល ពត បានប្រើ[3160]។ ប៉ុន្តែ កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ បញ្ជាក់យ៉ាងច្បាស់៖ "ស.ម លេខា៖ ទទួលរួមយោធា និងសេដ្ឋកិច្ច"[3161] ជាមុខងាររយោធារបស់ ប៉ុល ពត ដែលត្រូវបានបញ្ជាក់ដោយសាក្សីជាច្រើន នៅក្នុងសវនាការ[3162]។ ទោះជាយ៉ាងនេះក្តី ក្នុងដំណើរការដាក់បន្ទុក អង្គជំនុំជម្រះនៅតែសន្និដ្ឋានខុសថា "ពេលខ្លះ កម្មាភិបាលយោធាក៏បានចូលរួមនៅក្នុងអង្គប្រជុំ ឬសន្និបាតធំៗនៅក្រុងភ្នំពេញផងដែរ ដោយអង្គប្រជុំ ឬសន្និបាតខ្លះ មានការចូលរួមពីសំណាក់មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក រួមទាំង នួន ជា និង ខៀវ សំផន ផងដែរ"[3163] ខណៈដែលភ័ស្តុតាងដែលបានប្រើប្រាស់មិនអាចឱ្យបង្ហាញអង្គហេតុនេះឱ្យហួសពីវិមតិសង្ស័យបានឡើយ[3164]។

---

[3160] សំអាងហេតុសាលក្រម ឧទាហរណ៍ កថាខណ្ឌ ៥០៨, ៥០៩, ២៨៧៥។

[3161] កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារ **E3/182** ERN FR 00292868 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3162] ឧទ្ទ.៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** ចន្លោះម៉ោង10.21.41 និង 10.27.24។ អ៊ឹង រ៉េន៖ ប្រតិចារឹក ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/158.1** ម៉ោង 15.49.17 (អនុប្រធានកងពល៨០១ "ខាងផ្នែកយោធាមាន សុន សេន។ សុន សេន ហ្នឹងហើយជាអ្នកគ្រប់គ្រងកងពលទាំងអស់។ ឯពីលើ សុន សេន ហ្នឹង ខ្ញុំថាគ្មាននរណាក្រៅពី ប៉ុល ពត ទេ ដែលគ្រប់គ្រង សុន សេន ហ្នឹងក្នុងរចនាសម្ព័ន្ធ តាមខ្ញុំមើលគឺអ៊ីចឹងឯង។)។ Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/222.1** ម៉ោង 14.08.22។ បទសម្ភាសន៍ជាមួយ អៀង សារី ដោយ Stephen HEDER ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ឯកសារ **E3/89** ERN 00062462 (កងទ័ពស្ថិតនៅក្រោមបញ្ជារបស់ ប៉ុល ពត និង សុន សេន)។

[3163] សំអាងហេតុសាលក្រម កថាខណ្ឌ ៥១០។

[3164] សំអាងហេតុសាលក្រម កថាខណ្ឌ ៥១០ កំណត់សម្គាល់ជើងទំព័រលេខ ១៥៩៦។ ការផ្តល់សក្ខីកម្មរបស់ ឆោម សេ និង ចម្លើយជាលាយលក្ខណ៍អក្សរដែលមិនអាចគួរឱ្យជឿជាក់បាន របស់ ប្រាក់ យឿន និង កុយ ម៉ុន ដែលរំឭកពីការប្រជុំផ្សេងៗ តែនៅក្នុងឆ្នាំ១៩៧៥ ដដែល គឺបន្ទាប់ពីថ្ងៃជ័យជម្នះ ដែលមិនអាចឱ្យគេភ្ជាប់ទំនាក់ទំនងទៅរវាង លោក ខៀវ សំផន និងកងទ័ពបានឡើយ ក្រៅតែពីមុខងារក្លែងក្លាយ នៅក្នុងសម័យកាលនៃរណសិរ្សរួមរួមជាតិកម្ពុជា។ ឆោម សេ៖ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/159.1** ក្រោយម៉ោង 14.04.06 (ការប្រជុំនៅខែកក្កដា ឆ្នាំ១៩៧៥ នៅកីឡដ្ឋានអូឡាំពិក ដើម្បីបង្កើតកងទ័ពមជ្ឈិម។ សូមមើលជាភាសាខ្មែរ ទំព័រ ៥៩-៦០ បន្ទាត់ ២៤-៤) មុនម៉ោង 14.11.49។ កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យឿន ថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨ ឯកសារ **E3/3471** ERN 00205019 (គាត់អះអាងថាបានចូលរួមមួយលើកក្នុងពិធីខួបកំណើតបក្ស បន្ទាប់ពីថ្ងៃរំដោះ ដែលនៅក្នុងពេលនោះគាត់បានជួប "នួន ជា និង លោក ខៀវ សំផន នៅលើវេទិកា" ហើយគឺ លោក ខៀវ សំផន ដែលជាអ្នកថ្លែងសុន្ទរ

១៦៥៩. **_ក្នុងផ្នែកទី ១៦. គោលបំណងរួម និងផ្នែកទី ១៨. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន៖_** ក្នុងផ្នែកទាំងនេះ យើងដឹងអំពីគោលបំណងនៃកំហុសរបស់អង្គជំនុំជម្រះ ដើម្បីដាក់បញ្ចូល ខៀវ សំផន ទៅក្នុងសេចក្ដីសម្រេចប្រភេទឃោធា[3165]។ អង្គជំនុំជម្រះបានយល់ឃើញថា សុន សេន "បានបញ្ជូនព័ត៌មានជាទៀងទាត់ជូន [មជ្ឈិមបក្ស]" ពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន រួមទាំងការសម្លាប់អ្នកទោសជនជាតិចាវ៉ាយជាង ១០០ នាក់ នៅមន្ទីរសន្តិសុខអូរកន្សែង[3166]។ ត្រង់ចំណុចនេះទៀត អង្គជំនុំជម្រះបានទុកឱ្យមានស្រពេចស្រពិលអំពីបុគ្គលជាក់លាក់ដែលទទួលបានព័ត៌មាននេះ។ ដោយសារភាពស្រពេចស្រពិលនេះ អង្គជំនុំជម្រះអាចសន្និដ្ឋានខុសថា ខៀវ សំផន បានគាំទ្រដល់គោលបំណងរួមតាមរយៈការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ និងកិច្ចប្រជុំនាពេលក្រោយមកទៀត ដែលក្នុងពេលនោះ សុន សេន បានរាយការណ៍អំពីការសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង[3167]។ ប៉ុន្តែ ដូចយើងនឹងឃើញខាងក្រោម ការពិភាក្សាអំពីព្រលានយន្តហោះកំពង់ឆ្នាំង នៅដំណាក់កាលគម្រោង មិនអាចឱ្យសន្និដ្ឋានអំពីការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខពីឧក្រិដ្ឋកម្មនៅព្រលានយន្តហោះកំពង់ឆ្នាំង និងការទទួលខុសត្រូវខាងឃោធារបស់គាត់នោះឡើយ សូម្បីតែតាមរយៈការផ្ទេរសិទ្ធិក៏ដោយ[3168]។ ដំណើរការខុសឆ្គងរបស់អង្គជំនុំជម្រះ តាមរយៈការប្រើពាក្យក្ដោបរួម ដើម្បីទុកឱ្យ

---

កថា)។ កំណត់ហេតុស្ដាប់ចម្លើយ កុយ ម៉ុន ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ឯកសារ **E3/369** ERN 00195436 (សន្និបាត នៅឆ្នាំ ១៩៧៥ នៅស្ដាតអូឡាំពិក "មានលោក ប៉ុល ពត ដឹកនាំប្រជុំ មានលោក អៀង សារី, ខៀវ សំផន, នួន ជា, សម្ដេច ប៉ែននុត ចូលរួមជាអធិបតី។ ខ្លឹមសារប្រជុំ គឺនិយាយអំពីការជ័យជម្នះថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ គឺបានដោយសារប្រជាជន និងកងទ័ព ហើយបានលើកផែនការកងទ័ពមជ្ឈិម និងភូមិភាគ ឱ្យបង្កបង្កើនផល និងធ្វើស្រែ។ ក្នុងសន្និបាតនោះ គេបានប្រកាសពីសមាសភាពអ្នកដឹកនាំថា ប៉ុល ពត ជាលេខាមជ្ឈិមបក្ស, នួន ជា ជាអនុលេខាមជ្ឈិមបក្ស ខៀវ សំផន ជាគណៈប្រធានរដ្ឋ អៀង សារី ទទួលការងារការបរទេស ឯ សម្ដេច ប៉ែន នុត ជាសម្ដេចចៅហ្វាវាំង"។ យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3165] សូមមើលខាងលើ កថាខណ្ឌ ១៦១៨-១៦៣២។

[3166] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៧០។ នៅក្នុងកថាខណ្ឌដដែលនេះ បន្ទាប់ពីឃ្លាខាងលើ គេលើកឡើងថា "នួន ជា និង ប៉ុល ពត បានចេញការណែនាំដោយផ្ទាល់ទៅលេខាតំបន់ ១០៥ ដែលត្រួតត្រាលើមន្ទីរសន្តិសុខភ្នំក្រោល ហើយ និងធានាថាការណែនាំពីថ្នាក់លើត្រូវបានអនុវត្តនៅទូទាំងតំបន់ស្វយ័ត"។

[3167] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៨។

[3168] សូមមើលខាងក្រោម កថាខណ្ឌ ១៧៤២, ១៨៤៦-១៨៤៨។

មានភាពស្រពេចស្រពិល នឹងត្រូវបដិសេធ ហើយសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ[3169]។

## ផ្នែកទី ៣. គោលការណ៍រក្សាការសម្ងាត់

១៦៥០. អង្គជំនុំជម្រះបានទទួលស្គាល់ថា "រចនាសម្ព័ន្ធប្រតិបត្តិការជាក់លាក់របស់ ប.ក.ក ត្រូវបានរក្សាជាការសម្ងាត់" ដោយបញ្ជាក់ថា ចាប់តាំងពី "ដំណាក់កាលដំបូងនៃការវិវត្តរបស់បក្ស" ការសម្ងាត់មាន "សារៈសំខាន់" សូម្បីតែនៅក្រោយពេលឡើងកាន់អំណាច ដើម្បី "ធ្វើកិច្ចការផ្ទៃក្នុងជាសម្ងាត់ និងលាក់កំបាំង"[3170]។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយចង់កម្រិតគោលការណ៍រក្សាការសម្ងាត់នេះត្រឹមកម្មាភិបាលថ្នាក់ទាប ដែលដឹងសើៗអំពីការរៀបចំអំណាចនៅក្នុងបក្ស[3171]។ ជាក់ស្ដែង ភ័ស្ដុតាងបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា គោលការណ៍រក្សាការសម្ងាត់អនុវត្តចំពោះបក្ខជនទាំងអស់ សូម្បីតែកម្មាភិបាលថ្នាក់កំពូល។ គោលការណ៍ ដែលកើតចេញពីសកម្មភាពជាសម្ងាត់តាំងពីយូរ បានជំរុញឱ្យម្នាក់ៗកម្រិតត្រឹមដែននៃមុខការរបស់ខ្លួន គិតតែពីការងារខ្លួន មិនជ្រៀតជ្រែកចូលការងារអ្នកដទៃ។ គោលការណ៍នេះត្រូវបានបញ្ជាក់អះអាងពីសាក្សីគ្រប់ជាន់ថ្នាក់ជាច្រើននាក់[3172]។ អង្គជំនុំជម្រះបាន

[3169] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦២-៣៩៦3, ៤០៦៨-៤០៧៤, ៤២០៨, ៤៣១៧, ៤២៣៦, ៤២៥៨។

[3170] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២, ៣៩៣៩។ សូមមើលផងដែរ កថាខណ្ឌ ៣៩៨ ទាក់ទងនឹងលក្ខណៈវិនិច្ឆ័យទាំង១០ សម្រាប់ការជ្រើសរើសថ្នាក់ដឹកនាំបក្សដែលមានចែងនៅក្នុងលក្ខន្តិកៈបក្សទាំងពីរ ជាពិសេសចំណុច (៦) ការប្រុងប្រយ័ត្នបដិវត្តន៍រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្តន៍របស់បក្ស។ ជាឧទាហរណ៍ សូមមើលកថាខណ្ឌ ៣៩២ និង ៣៦២ ទាក់ទងនឹងការិយាល័យ ៨៧០ ("ភាពមិនច្បាស់លាស់ទាក់ទងនឹងអត្ថន័យនៃលេខកូដ ៨៧០" ស៊ីចង្វាក់គ្នាជាមួយនឹងការព្យាយាមរក្សាការសម្ងាត់ជាទូទៅ របស់ ប.ក.ក")។

[3171] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២ កំណត់សម្គាល់ជើងទំព័រលេខ ៩៤៥។

[3172] ឧទាហរណ៍ សូមមើល កម្មាភិបាលថ្នាក់ខ្ពស់ និង ស្និទ្ធជាមួយ ប៉ុល ពត នៅមុន និងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ៖ ឌុច ប្រធានមន្ទីរស-២១ បានសារភាពថាមិនបានដឹងពីចំណុចលម្អិតនៃ មន្ទីរ ៨៧០ ឬចំណុចលម្អិតនៃមជ្ឈិម ហើយជាច្រើនលើកច្រើនសាគាត់បានលើកឡើងថា ម្នាក់ៗបំពេញតួនាទីរៀងៗខ្លួន <u>ឌុច៖</u> ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** ម៉ោង 10.03.58 ម៉ោង 13.35.18 រហូតដល់ម៉ោង 13.39.28 ម៉ោង 14.19.10។ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/56.1** មុនម៉ោង 10.19.00 (ស-២១ មិននៅក្រោមឱវាទក្រសួងណាមួយឡើយ តែស្ថិតនៅក្រោមការត្រួតត្រារបស់ សុន សេន, នួន ជា និង ប៉ង់ ដែលតំណាង ប៉ុល ពត)។ ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/57.1** មុនម៉ោង 09.58.19។ ប្រតិចារឹក ថ្ងៃទី៥

ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/60.1** ម៉ោង 14.04.29 (ការយល់ឃើញរបស់គាត់ចំពោះការរៀបចំរបបកម្ពុជាប្រជាធិបតេយ្យ បានកែលម្អ បន្ទាប់ពីបានពិនិត្យសំណុំរឿងស៊ើបអង្កេត)។ ប្រតិចារឹក ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/61.1** មុនម៉ោង 09.40.52 (គាត់មិនដែលទៅមន្ទីរ ៨៧០ ទេ) ម៉ោង 10.00.23 ("ការងារគេ គេដឹង ការងារយើង យើងដឹង។ ការងារ ស-២១ ខ្ញុំត្រូវតែដឹង។ ក្រៅពីការងារ ស-២១ ខ្ញុំគ្មានសិទ្ធិដឹងទេ")។ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ម៉ោង 09.27.36 (ការសម្ងាត់គឺដាច់ខាតតែម្តង)។ <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/83.1** មុនម៉ោង 10.04.01 ("ស. តើលោកនៅចាំទេថាតើអ្នកណាខ្លះស្ថិតនៅក្នុងគណៈមជ្ឈិមរបស់បក្សនៅឆ្នាំ១៩៧៨នោះ? ឆ. អាហ្នឹងការងារខាងលើ ខ្ញុំអត់យល់ទេ")។ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/84.1** មុនម៉ោង 11.40.59។ សាឡុត បាន អ្នកទទួលខុសត្រូវនៅក្រសួងការបរទេស បានលើកឡើងជាច្រើនដង អំពីគោលការណ៍រក្សាការសម្ងាត់ ដែលថាម្នាក់ៗដឹងតែកិច្ចការផ្ទាល់ខ្លួនមិនត្រូវដឹងពីកិច្ចការអ្នកដទៃ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/66.1** មុនម៉ោង 09.58.31 ក្រោយម៉ោង 14.10.50។ ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/67.1** មុនម៉ោង 09.05.00 ម៉ោង 09.42.46។ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/68.1** មុនម៉ោង 11.51.57 ("ការងារអ្នកណា អ្នកហ្នឹងដឹង ដឹងតែការងារឯងបានហើយ។ នេះជាទ្រឹស្តីដើម្បីការពារសន្តិសុខរួម") មុនម៉ោង 11.21.45។ ប្រតិចារឹក ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/70.1** ម៉ោង 09.14.06 ម៉ោង 14.01.18 ("ការងារលោកដែលលោកបានដឹង និងបានធ្វើ គឺត្រឹមតែថ្នាក់របស់លោកតែប៉ុណ្ណោះ [...] លោកអត់អាចធ្វើការ ងារណាដែលខ្ពស់ជាងឋានៈរបស់លោកទេ។ អ៊ីចឹង ឬមិនមែនទេ? ឆ. បាទ អ៊ីចឹងមែន។ ស. ចុះអ្នក ក្រសួងដទៃៗទៀត ស្ថាប័នដទៃៗទៀត ក្រៅពីកន្លែងលោក ការបរទេស ហ្នឹង គេមានឋានៈប្រហែលលោកដែរ គេអាចធ្វើលើសពីថ្នាក់របស់គេទេ ឬក៏ថាគឺត្រឹមតែថ្នាក់របស់គេហ្នឹងតែប៉ុណ្ណឹងទេ? ឆ. ខ្ញុំមិនដឹងទេ។ រឿងថ្នាក់គេដទៃទៀត គេឱ្យសិទ្ធិយ៉ាងម៉េច ខ្ញុំអត់ដឹងទេ។ ប៉ុន្តែការអប់រំពីពិសេសរបស់បង អៀង សារី គាត់អប់រំខ្ញុំតែត្រឹមកម្រិតខ្ញុំហ្នឹងថា "ឯងនៅក្របខ័ណ្ឌណា ធ្វើតាមតែក្របខ័ណ្ឌប៉ុណ្ណឹងទៅ កុំទៅគិតគេ"។ តែប៉ុណ្ណឹងបាទ"។)។ ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/71.1** ម៉ោង 09.45.57 ("ថាតើការសម្ងាត់ ការរក្សាការសម្ងាត់ ជាទ្រឹស្តី ដែលគេអប់រំនៅក្នុងក្របខ័ណ្ឌនៃការរៀនសូត្រដែរឬទេ? ឆ. ទ្រឹស្តីនេះអប់រំនៅក្នុងការរៀនសូត្រប្រចាំថ្ងៃតែម្តងបាទ"។) ម៉ោង 09.48.53។ អៀង ផាន់ មេបញ្ជាការកងវរសេនាធំនៃភូមិភាគនីរតី បានចូលរួមប្រយុទ្ធ នៅភូមិភាគបូព៌ា <u>អៀង ផាន់</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/193.1** ម៉ោង 10.19.48។ ប្រតិចារឹក ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/493.1** ចាប់ពីម៉ោង 09.46.49 ("ទាក់ទងនឹងឯកសារសម្ងាត់គឺថា ផ្នែកខាងខ្ញុំខាងក្រោម អត់បានទេ។ បើឯកសារណែនាំជារួម មានលក្ខណៈធំទូលាយ អាហ្នឹងខាងក្រោមទទួលបាន ប៉ុន្តែបើឯកសារដូចថា ត្រូវឃាត់ខ្លួនចាប់អ្នកនេះអ្នកនោះ គឺសម្រាប់ខាងខ្ញុំអី អត់ដឹងទេ។ ហើយសម្រាប់ថ្នាក់លើ គេចែកជូនហើយថ្នាក់លើ។ [...] ខ្ញុំបានបញ្ជាក់ខាងដើមហើយ ថានៅកម្ពុជាប្រជាធិបតេយ្យសម័យនោះគឺថា លាក់ការណ៍ដឹកនាំជាសំខាន់ ការងារខ្ញុំៗដឹង ការងារអ្នកនោះ មេគឺមេដឹងហើយ។ ដល់អ៊ីចឹងគេៗបែងចែកច្បាស់ណាស់ ការងារណាត្រូវឱ្យខាងក្រោមដឹង ការងារណាថ្នាក់លើដឹង គឺមានការបែងចែកច្បាស់លាស់ណាស់ មិនមែនចេះតែចម្លងជូនទូទៅ")។ ឈូក រីន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/182.1** ក្រោយម៉ោង 11.14.42 ("ខ្ញុំបានជម្រាបហើយ សម្ងាត់បំផុត។ [...] មេដឹកនាំហ្នឹង គឺអាថ៌កំបាំងបំផុត និងសម្ងាត់បំផុត"។)។ នង សុផង់៖ ប្រតិចារឹក ថ្ងៃទី៥ ខែ កញ្ញា ឆ្នាំ២០១២ ឯកសារ **E1/122.1** ម៉ោង 11.35.41 ("ដូច្នេះចំពោះខ្លួនខ្ញុំ គឺខ្ញុំវាច្របូកច្របល់ហើយដល់អ៊ីចឹង មិនដឹងអ្នកណាជាគណៈអចិន្ត្រៃយ៍ អ្នកណាជាស្អីៗ។ ប៉ុន្តែតាមខ្ញុំយល់ដោយខ្លួនឯងទេ ឯន័យអនុវត្តរបស់ពួកខ្ញុំហ្នឹង គឺថាអត់ខ្វល់ពីរឿងគណៈ៨៧០មក ៨៧០ អង្គការ៨៧០ អីទេ ឱ្យតែឃើញសារគឺៗសំដៅទៅ

យកគោលការណ៍នេះមកប្រើដាក់បន្ទុក ដើម្បីសន្និដ្ឋានថា ការប្រព្រឹត្តិលើខ្នាំងហ៊ុំព័ទ្ធទៅដោយការសម្ងាត់ខ្ពស់បំផុត[3173]។

១៦៥១. អង្គជំនុំជម្រះបានយល់ខុសថា គោលការណ៍រក្សាការសម្ងាត់មិនអនុវត្តចំពោះ ខៀវ សំផន នោះទេ ដោយសារតែវត្តមាន និងការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ "ទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត និង នួន ជា" តួនាទីរបស់គាត់នៅមន្ទីរ ៨៧០ រហូតដល់ចុងរបបនោះ ក្រោយពី ឌឿន បាត់ខ្លួន[3174]។ ប៉ុន្តែ សេចក្តីសន្និដ្ឋាននេះ គឺជាការស្មានសុទ្ធសាធ។ ជារួម ដោយសារតែគ្មានភ័ស្តុតាងអំពីការដឹងរបស់ ខៀវ សំផន អង្គជំនុំជម្រះបានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខ "មិនគួរមិនបានដឹង"។ នៅពេលសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានលាក់បាំង ជាអាទិ៍ សក្ខីកម្មជាច្រើនដែលបញ្ជាក់អំពីលទ្ធភាពតិចតួចរបស់ ខៀវ សំផន ក្នុងការទទួលបានព័ត៌មានសម្ងាត់បំផុត[3175]។ ចំពោះតួនាទីរបស់គាត់នៅមន្ទីរ ៨៧០ និងគណៈកម្មាធិការពាណិជ្ជកម្ម

ចូល ក-១ ទាំងអស់តែម្តង")។ សូមមើលជាភាសាខ្មែរ ទំព័រ ៣១ បន្ទាត់ ៥-១២។ ប្រតិចារឹក ថ្ងៃទី៦ ខែ៩ ឆ្នាំ២០១២ ឯកសារ **E1/123.1** ចាប់ពីម៉ោង 11.59.49 ("គោលការណ៍បីយ៉ាង គឺអ្វីដែលត្រូវនិយាយ អ្វីដែលមិនត្រូវនិយាយ គឺមិនត្រូវ និយាយ។ អ្វីដែលមិនត្រូវសួរ គឺមិនត្រូវសួរ។ ដូច្នេះគឺថា មិនដឹង មិនឮ មិនឃើញ និងមិននិយាយនូវអ្វីទាំងឡាយណាដែរជាការងារសម្ងាត់"។) ម៉ោង 13.42.28។ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ឯកសារ **E1/33.1** មុនម៉ោង 14.17.40។

[3173] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៣៨-៣៩៣៩, ៣៩៦៨, ៣៩៨៦។ ប៉ុន្តែ នៅកថាខណ្ឌ ៣៩៥៨ មានការលើកឡើងថា "ទោះបីជាមានគោលការណ៍រក្សាការសម្ងាត់របស់បក្សក៏ដោយក៏ការកំទេចខ្មាំងត្រូវបានទេការយ៉ាងច្រើនក្នុងចូលបក្ស"។

[3174] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៥។

[3175] ជាឧទាហរណ៍ អឿន តាន ដែលជាប្រធានយាមការពារនៅក-១ និងជាអ្នកទទួលខុសត្រូវចែកចាយទូរលេខ និងសំបុត្ររបស់ ប៉ុល ពត បានអះអាងថា មិនធ្លាប់ដែលបានបញ្ជូនទូរលេខ និងសំបុត្រ ទៅអ្នកណាំផ្សេងក្រៅពី នួន ជាឡើយ បន្ទាប់ពី ប៉ុល ពត បានអានរួចហើយ ដោយបញ្ជាក់ថា ប៉ុល ពត រក្សាទុកឯកសារនៅ ក-១។ អឿន តាន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/86.1** ចន្លោះម៉ោង 13.41.50 និង 13.53.13។ សូមមើលផងដែរ ស វិ អ្នកក្រោមបង្គាប់របស់ អឿន តាន នៅ ក-១ ដែលបានពន្យល់ថា អឿន តាន ទទួលបញ្ជាប៉ុល ពត និង នួន ជា ប្រតិចារឹក ថ្ងៃទី ខែ ឆ្នាំ ឯកសារ ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/156.1** ម៉ោង 11.35.52. សូមមើលផងដែរ នង សុផង់៖ ប្រតិចារឹក ថ្ងៃទី ខែ ឆ្នាំ ឯកសារ03.09 ឆ្នាំ២០១២ ឯកសារ **E1/120.1** ម៉ោង 13.50.43 ម៉ោង 13.53.08 ម៉ោង 13.56.04 ម៉ោង 13.58.00. សូមមើលខាងលើ កថាខណ្ឌ ១៦២១-១៦២៤។

យើងនឹងឃើញខាងក្រោមថា អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាគោលការណ៍រក្សាការសម្ងាត់មិនអនុវត្ត ចំពោះម្ចាស់បណ្តឹងសាទុក្ខបានឡើយ[3176]។ ដូច្នេះ សេចក្តីសន្និដ្ឋាននេះនឹងត្រូវទុកជាមោឃៈ។

## មាតិកាទី ២. កំហុសទូទៅពាក់ព័ន្ធនឹងតួនាទីរបស់ ខៀវ សំផន

## ជំពូកទី ១. កំហុសពាក់ព័ន្ធនឹងសម័យកាលមុនរបបកម្ពុជាប្រជាធិបតេយ្យ

## ផ្នែកទី ១. កុមារភាព យុវវ័យ និងអាជីព

១៦៥២. ដើម្បីគាំទ្រដល់សេចក្តសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីភរវនីយភាពនៃការប្រព្រឹត្តិបទឧក្រិដ្ឋ ហើយ គាត់បានផ្តល់ការគាំទ្រដល់គោលបំណងរួម នៅមុនអង្គហេតុ[3177] អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គ ហេតុ ដោយបានរៀបរាប់ឡើងវិញអំពីខ្សែជីវិតរបស់គាត់ ជាអាទិ៍ និក្ខេបបទបណ្ឌិត (១) ក៏ដូចជា សកម្មភាព និងការសេពគប់របស់គាត់ (២)។

### ១. កំហុសពាក់ព័ន្ធនឹងនិក្ខេបបទបណ្ឌិត

១៦៥៣. ក្រោយពីបានពិពណ៌នាខ្លឹមសារនៃនិក្ខេបបទរបស់ ខៀវ សំផន នៅឆ្នាំ១៩៥៩ ដែលបង្ហាញអំពីភាពខុស គ្នា រវាងគំនិតដែលមានក្នុងនិក្ខេបបទនោះ និងគោលនយោបាយនាពេលក្រោយរបស់ ប.ក.ក[3178] អង្គ ជំនុំជម្រះបានអះអាងថា ខៀវ សំផន បានសរសេរថា យើងត្រូវ "បង្ខំ" ប្រជាជនឱ្យបង្កបង្កើនផលជា សមូហភាព[3179] រួចបានសន្និដ្ឋានថា និក្ខេបបទរបស់ ខៀវ សំផន "បង្ហាញអំពីការជឿជាក់ជាវិជ្ជមាន របស់គាត់ចំពោះគោលនយោបាយរបស់ ប.ក.ក ស្តីពីសមូហភាវូបនីយកម្ម ដែលរួមមាន តាមរយៈការ ជំរុញដាក់ប្រជាជនឱ្យស្ថិតនៅក្រោមគំនិតផ្តួចផ្តើមនៃការបង្កបង្កើនផលជូនរដ្ឋ"[3180]។ ផ្ទុយទៅវិញ

[3176] សូមមើលខាងក្រោម កថាខណ្ឌ ១៧៦៣-១៧៦៩ និង ១៧៧០-១៧៩៨។

[3177] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៤, ៤២០៦, ៤២៥៧។

[3178] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៦៧-៥៦៨។

[3179] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨៤។

[3180] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៦។

និក្ខេបបទនេះមិនបាននិយាយអំពីការបង្ខំអ្នកណាម្នាក់ទេ[3181]។ អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋាន ចេញពីនិក្ខេបបទនេះថា ខៀវ សំផន ដឹងអំពីភវនីយភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ ហេតុដូច្នេះ សេចក្ដីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

## ២. កំហុសពាក់ព័ន្ធនឹងសកម្មភាព និងការសេពគប់

១៦៥៤. មុននឹងសន្និដ្ឋានថា ខៀវ សំផន បានផ្ដល់ការគាំទ្រដល់ ប.ក.ក និងគោលនយោបាយបក្ស តាំងពីមុន ពេលចូលក្នុងបក្សទៅទៀត[3182] អង្គជំនុំជម្រះបានជឿជាក់ថា គាត់មានទំនាក់ទំនងផ្ទាល់ជាមួយនិស្សិត

---

[3181] និក្ខេបបទរបស់ លោក ខៀវ សំផន ឯកសារ **E3/123** (ដែលឧទ្ទិសដល់សម្ដេចសីហនុ និងប្រទេសកម្ពុជា ERN 00767295)៖ "រដ្ឋាភិបាលត្រូវខិតខំធ្វើឱ្យកសិករមានទម្លាប់បន្តិចម្ដងបន្តិចម្ដងក្នុងការធ្វើកិច្ចសហប្រតិបត្តិការ។ ត្រូវបង្កើតក្រុមការងារសម្រាប់ជួយគ្នាទៅវិញទៅមកដែលនៅក្នុងនោះ ឧបករណ៍សម្រាប់ធ្វើការងារ ដីធ្លី និង ផលិតផល បានមកពីការងារស្ថិត នៅជាកម្មសិទ្ធិឯកជន ប៉ុន្តែត្រូវបានដាក់ឱ្យដំណើរការតាមរយៈវិធីសាស្ត្រធ្វើការងាររួម។ ការបង្កើតក្រុមការងារសម្រាប់ជួយគ្នាទៅវិញទៅមកនេះ ពិតជាមានលក្ខណៈសមស្របទៅនឹងគោលគំនិតនាពេលបច្ចុប្បន្នរបស់កសិករខ្មែរ (...)។ ជា បឋម ការជួយគ្នាទៅវិញទៅមកនេះ អាច ធ្វើឱ្យ បាន សម្រេច សម្រាប់ការងារ ដែលបានកំណត់ច្បាស់លាស់ មួយ ហើយ បន្ទាប់មក សម្រាប់ ការងារ ដែល ធ្វើ ឱ្យមានលក្ខណៈជាទូទៅ។ ការជួយគ្នាទៅវិញទៅមកនេះ អាចទៅជាមានលក្ខណៈអចិន្ត្រៃយ៍ និងបម្រើឱ្យការបង្កើតសហករណ៍ផលិតកម្ម នៅតាមភូមិឋាននានាដែលបទពិសោធន៍មានលក្ខណៈគួរឱ្យជឿជាក់ និងជាស្ថាពរ (...)។ ដូច្នេះ ផ្ទៃដីថ្មីៗនឹងអាចរកបាន ដោយមិនធ្វើឱ្យផ្លាស់ប្ដូរដល់បច្ចេកទេសបច្ចុប្បន្ន និង ដោយមិនស្រូបយកមូលធនច្រើនពេកដែលមិនអាចធ្វើការប្រើប្រាស់ដើម្បីអភិវឌ្ឍវិស័យឧស្សាហកម្ម។" (ទំព័រ ១៧៤-១៧៥ ERN 00767392)។ "សូមយល់សំណើខ្ញុំឱ្យច្បាស់។ យើងមិនមែនស្នើឱ្យបំបាត់វណ្ណៈដែលមានចំណូលលើសលុបនោះទេ។ (...) យើងយល់ឃើញថាគេអាច និងត្រូវតែទាញយកលទ្ធភាពចូលរួមវិភាគទានរបស់ក្រុមនេះ តាមរយៈការកែប្រែម្ចាស់អចលនទ្រព្យ ឈ្មួញកណ្ដាល ព្រឹទ្ធិករទាំងនេះ ឱ្យទៅជាវណ្ណៈសហគ្រិនមូលធនកសិកម្ម ឬឧស្សាហកម្ម។ ដូច្នេះត្រូវព្យាយាមបង្វែរពួកគេចេញពីសកម្មភាពអផលិតភាព ដឹកនាំពួកគេឱ្យចូលរួមក្នុងការផលិត។ (...) កាត់បន្ថយធនលាភដីធ្លី និងព្រឹត្តិកម្ម និងទស្សនវិស័យឧស្សាហបនីយកម្ម (...) អូសទាញម្ចាស់អចនទ្រព្យឱ្យ "រៀបចំ" កម្មសិទ្ធិរបស់ខ្លួនឡើងវិញ ដើម្បីផ្លាស់ប្ដូរវិធីអន់ថយនៃការទាញយកប្រយោជន៍ពីដីធ្លីជាដំណាក់ៗ ដោយវិធីទាញយកប្រយោជន៍មូលធននិយមដែលតម្រូវឱ្យមានការប្រើប្រាស់មូលធន និងបុគ្គលិកទទួលប្រាក់បៀវត្ស" (ទំព័រ ១១៣-១១៤ ERN 00767435-36)។ "ម្ចាស់កម្មសិទ្ធិដីយល់យ៉ាងច្បាស់ថា ម្យ៉ាង ពន្ធដីត្រូវបានកាត់បន្ថយ ហើយការចងការដោយយកការប្រាក់ខ្ពស់ហួសប្រមាណត្រូវបានហាមឃាត់ និងម្យ៉ាងទៀត ទស្សនវិស័យនៃការទទួលបានកម្រៃខ្ពស់ជាង ត្រូវបានផ្ដល់ឱ្យពួកគេតាមរយៈ ការអភិវឌ្ឍឧស្សាហកម្ម និងកសិកម្ម។ តាមរយៈការយល់ឃើញនេះ យើងអាចនាំពួកគេឱ្យប្រែក្លាយខ្លួនជាសហគ្រិនមូលធននិយមផ្នែកកសិកម្ម ឬក៏ផ្នែកឧស្សាហកម្ម។ គឺដោយហេតុដូច្នេះហើយដែលយើងអាចបង្កើតបាននូវប្រភពនៃស្ថានភាពថ្មីមួយ" (ទំព័រ ១៦៩ ERN 00767435)។

មកពីបរទេស ដែលនាពេលក្រោយមក បានកាន់កាប់មុខតំណែងសំខាន់ៗ នៅក្នុង ប.ក.ក[3183]។ អង្គជំនុំជម្រះបានរៀបរាប់ខុសអំពីសកម្មភាព និងការសេពគប់របស់គាត់ ទាំងនៅបារាំង សម្រាប់ការសិក្សារបស់គាត់ ទាំងពេលត្រឡប់មកកម្ពុជាវិញ។

១៦៥៥. ជាក់ស្តែង អង្គជំនុំជម្រះបានផ្សារភ្ជាប់ ខៀវ សំផន ទៅនឹងអនាគតមេដឹកនាំ ប.ក.ក និងជំនឿជាក់របស់ពួកគេ តាំងពីពេលចូលក្នុង "រង្វង់ម៉ាក្សនិយម" ក្រោយពេលទៅដល់ទីក្រុងប៉ារីសបានពីរបីខែ និងក្រោយពេលតែងតាំងនាពេលក្រោយជាប្រធានសហភាពនិស្សិតខ្មែរ[3184]។ ពិតមែនតែអង្គជំនុំជម្រះបានសំអាងលើចម្លើយរបស់គាត់ ប៉ុន្តែ អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះមិនពិចារណាដល់ចម្លើយទាំងមូលរបស់គាត់។ ជាក់ស្តែង ខៀវ សំផន ពិតជាបានរៀបរាប់អំពីការសេពគប់ និងកម្លាំងជំរុញចិត្តគាត់ នៅសម័យនោះ ដែលបង្ហាញអំពីការចូលប្រឡូកតិចតួចរបស់គាត់ក្នុងមជ្ឈដ្ឋានម៉ាក្សនិយម និងឯករាជ្យភាពរបស់គាត់ខាងនយោបាយ[3185]។

---

[3182] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧។

[3183] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧៣។

[3184] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៦៥-៥៦៦។

[3185] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៥៧៥៧ (នៃកថាខណ្ឌ ៥៦៥) នៅទីនេះអង្គជំនុំជម្រះផ្អែកជាពិសេសលើចម្លើយរបស់ លោក ខៀវ សំផន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារ **E1/21.1** ចន្លោះម៉ោង 14.20.36 និងម៉ោង 14.25.11 ("ឌិក សុគន្ធ បានមកនិយាយស្នើខ្ញុំឱ្យចូលរួមក្នុងរង្វង់ម៉ាក្សស៊ីស។ ខ្ញុំក៏បានឆ្លើយតបគាត់វិញថា ខ្ញុំចង់បាន<u>ឯករាជ្យ</u>ជាតិ តែខ្ញុំមិនយល់អ្វីពីកុម្មុយនីស្ត ពីម៉ាក្សស៊ីសអីទេ។ [...] ខ្ញុំក៏មិនចង់ឱ្យគាត់មើលមកខ្ញុំថា ជាមនុស្សកំសាកញី ខ្ញុំក៏យល់ព្រមទទួល។ ប៉ុន្តែ ខ្ញុំក៏បានឃើញបរិយាកាសនៅប៉ារីស មានលក្ខណៈនយោបាយខ្លាំង។ ដូច្នេះ <u>ខ្ញុំត្រូវការដកឃ្លាឆ្ងាយបន្តិច</u> ដើម្បីខ្ញុំមានពេលពិនិត្យ សង្កេត ហើយត្រិះរិះពិចារណា។ ខ្ញុំក៏សម្រេចទៅម៉ុងប៉ូលីយេ [...]។ ដល់បីឆ្នាំក្រោយមក ទើបខ្ញុំឡើងមកនៅប៉ារីស ដើម្បីរៀនចំនិក្ខេបទរបស់ខ្ញុំខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ពេលនោះ ខ្ញុំក៏ត្រូវតែចូលរួមប្រជុំជាទៀងទាត់នៅក្នុងរង្វង់ម៉ាក្សស៊ីស។ ប៉ុន្តែបរិបទប្រវត្តិសាស្ត្របាន<u>ប្រែប្រួល</u>ថ្មីស្រឡះហើយ កិច្ចព្រមព្រៀងហ្សឺណែវបានទទួលស្គាល់ឯករាជ្យកម្ពុជាហើយ។ ដូច្នេះមិនដូចជំនាន់ សាឡុត ស, យុន សឿន, វ័ត្ន សាមឿន អីទៀតទេ។ ពេលនោះ គេនាំគ្នាត្រៀមខ្លួនចូលរួមតស៊ូ ប្រឆាំង<u>អាណានិគមនិយម</u>បារាំង ពេលនោះ គឺគេ<u>សង្កត់លើស្មារតីស្នេហាជាតិ</u> ដែលត្រូវរួមចំណែក-- ពេលនេះពេលដែលខ្ញុំមកចូលរួមកាលដែលខ្ញុំមកប៉ារីសនេះ គឺគេសង្កត់លើ<u>ស្មារតីស្នេហាជាតិ</u>ដែលត្រូវរួមចំណែកពង្រឹងពង្រីក និង<u>ការពារឯករាជ្យជាតិ</u>។ [...] មុននឹងគាត់ចេញដំណើរត្រឡប់ទៅប្រទេសវិញ អៀង សារី ក៏បានប្រគល់ភារកិច្ចគ្រប់គ្រង រង្វង់មកឱ្យខ្ញុំ។ តាមមើលទៅគាត់<u>អស់ជម្រើស</u>ហើយ។ អ្នកដែលជឿជាក់ហើយសកម្មៗដូចជា ឌិក សុគន្ធ, សុន សេន ជាដើម បាន<u>ត្រឡប់ទៅប្រទេសវិញអស់ហើយ</u>"។ យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E1/234.1** ម៉ោង 15.18.25 ម៉ោង 15.32.24។ សៀវភៅរបស់លោក ខៀវ សំផន

១៦៥៦. ដោយហេតុថា គ្មានភស្តុតាងណាមួយបញ្ជាក់ថា ក្រោយពេលវិលត្រឡប់មកកម្ពុជាវិញ ខៀវ សំផន បានសេពគប់ជាមួយអនាគតមេដឹកនាំ ប.ក.ក ទាំងនេះ អង្គជំនុំជម្រះបានបិទស្លាក "កុម្មុយនីស្ត" ដោយមិនត្រឹមត្រូវ លើសារព័ត៌មានឯករាជ្យមួយដែលគាត់បានបង្កើតឡើងឈ្មោះ *L'Observateur*[3186]។ អង្គជំនុំជម្រះមិនត្រឹមតែបំភ្លៃសម្តីរបស់ ខៀវ សំផន ប៉ុណ្ណោះទេ ថែមទាំងបានប្រើប្រាស់សម្តីគ្មានការបញ្ជាក់អះអាងរបស់ អៀង ធីរិទ្ធ ដែលបានឆ្លើយថា អ្នកស្រីបានចូលរួមផ្តល់ហិរញ្ញប្បទានដល់សារព័ត៌មាន *L'Observateur* នៅក្នុងកិច្ចសម្ភាសន៍មួយក្រៅក្របខ័ណ្ឌតុលាការ[3187]។ អង្គជំនុំជម្រះហ៊ានដល់ថ្នាក់ប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរ ស-២១ ទៀតផង[3188]។ លើសពីនេះទៀត ការពិនិត្យភស្តុតាងគួរណាតែនាំឱ្យអង្គជំនុំជម្រះធ្វើសេចក្តីសន្និដ្ឋានអំណោយផលដល់ម្ចាស់បណ្តឹងសាទុក្ខ[3189]។

---

*ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឆ្នាំ២០០៤ ខែឧសភា ឆ្នាំ២០០៧ ឯកសារ **E3/18** ទំព័រ ៤៨ ERN 00103827 ("ខ្ញុំបានចុះឈ្មោះចូលបក្សកុម្មុយនីស្តបារាំងជាមួយគេទាំងឡាយ ពីព្រោះខ្ញុំជឿជាក់លើសាមគ្គីភាពជាបងប្អូន រវាងបងប្អូនគ្រប់ជនជាតិ")។

[3186] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៦៩។

[3187] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៧៧៣ (នៃកថាខណ្ឌ ៥៦៩)។

[3188] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៧៧៣ (នៃកថាខណ្ឌ ៥៦៩)។ សូមមើលខាងលើ កថាខណ្ឌ ២៥៨-២៩០។

[3189] លោក ខៀវ សំផន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារ **E1/21.1** ម៉ោង 14.37.32 ("មិត្តភក្តិខ្ញុំដែលខ្ញុំបានស្គាល់នៅស្រុកបារាំង ហើយដែលបានចូលមកក្នុងស្រុកមុនខ្ញុំ។ ដូចជា ហ៊ូ យន់, ហ៊ូ នឹម និងមិត្តភក្តិផ្សេងទៀត ដែលខ្ញុំស្គាល់តាមរយៈគាត់បានស្នើឱ្យខ្ញុំចេញកាសែតមួយ ដើម្បីជាសំឡេងរបស់បញ្ញាជន សាស្ត្រាចារ្យ អ្នករដ្ឋការ។ នេះហើយដែលបាននាំឱ្យខ្ញុំមានគំនិតចេញកាសែតឡូបសែរវ៉ាទ័រ ជាកាសែតចេញពីរដងក្នុងមួយអាទិត្យ ជាភាសាបារាំង គោលជំហររបស់កាសែតខ្ញុំ គឺគាំទ្រដាច់ខាតនយោបាយអព្យាក្រឹតរបស់សម្តេចនរោត្តម សីហនុ។ ប៉ុន្តែគួសបញ្ជាក់ ចំពោះអ្នកដឹកនាំខ្មែរនូវការចាំបាច់ឱ្យមានវិធានការកែទម្រង់ប្រជាធិបតេយ្យខ្លះ ក្នុងទិសដៅធ្វើឱ្យមានតុល្យភាពខ្លះក្នុងសង្គម។ កុំឱ្យមានការខុសគ្នាខ្លាំងពេករវាងអ្នកមាន និងអ្នកក្រ ហើយឱ្យស្រទាប់ក្រោមនៃសង្គមបានទទួលផលពីនយោបាយអព្យាក្រឹតផង ដើម្បីពង្រឹកមូលដ្ឋាននយោបាយនៃនយោបាយនេះ ទប់នឹងការប្រឆាំងរបស់ លន់ នល់ និងបក្សពួក។ គឺខ្ញុំសំដៅអ្នកដឹកនាំកម្ពុជា។ ដូច្នេះហើយបានជាខ្ញុំសរសេរជាភាសាបារាំង ពីព្រោះពេលនោះអ្នកដឹកនាំកម្ពុជាមិនសូវអានកាសែតខ្មែរទេ" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) ក្រោយម៉ោង 14.40.42 ("កាសែតខ្ញុំនេះច្បាស់ណាស់មិនមែនជាកាសែតកុម្មុយនីស្តទេ ហើយក៏មិនមែនឧបត្ថម្ភដោយពួកកុម្មុយនីស្ត [...] អ្នកដែលឧបត្ថម្ភដល់កាសែតខ្ញុំភាគច្រើន មិនមែនជាជនកុម្មុយនីស្តទេ ទោះបីមានអ្នកកុម្មុយនីស្តខ្លះក៏ដោយ តែភាគច្រើនគេជាតំណាងរាស្ត្រនៃសភាជាតិ ដូចជា ហ៊ូ យន់, ហ៊ូ នឹម, អ៊ុច វ៉ែន, សី ណែម ជា

១៦៥៧. បន្ថែមលើនេះទៀត ការឃ្លាំមើលយ៉ាងជិតដល់ និងការបៀតបៀនជាប្រចាំលើ ខៀវ សំផន ពីសំណាក់អាជ្ញាធរ[3190] គួរណាតែរារាំងអង្គជំនុំជម្រះមិនឱ្យសន្និដ្ឋានអំពីការនៅជាប់កៀកនឹងអនាគតមេដឹកនាំ ប.ក.ក នៅសម័យនោះ។ ទោះជាយ៉ាងណាក៏ដោយ ការដឹងរបស់បញ្ញវន្តដែលបានទៅសិក្សានៅប្រទេសបារាំង មិនអាចបង្ហាញថា ខៀវ សំផន គាំទ្រដល់ផែនការ និងសកម្មភាពរបស់ ប.ក.ក បានឡើយ។

១៦៥៨. ដូច្នេះ ផ្អែកលើភ័ស្តុតាង គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចយល់ឃើញថា ការដឹងផ្ទាល់ខ្លួនអាចឱ្យសន្និដ្ឋានអំពីការគាំទ្រដល់ផែនការឧក្រិដ្ឋរួមនោះឡើយ។ អង្គជំនុំជម្រះមិនអើពើនឹងភ័ស្តុតាងដោះបន្ទុកដែលបង្ហាញអំពីឆន្ទៈរបស់ ខៀវ សំផន តាំងពីរបប សីហនុ ក្នុងការបម្រើជាតិ និងធ្វើកំណែទម្រង់ជាបណ្តើរៗ ពីលើចុះក្រោម[3191] ក៏ដូចជាសុចរិតភាព ការគិតដល់កិត្តិយស និងភាពមិនពុករលួយរបស់គាត់[3192]។

ដើម"។ យើងគូសបន្ទាត់ពីក្រោម)។ ហ៊ុន ឈុនលី៖ ប្រតិចារឹក ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/150.1** មុនម៉ោង 15.58.25 ("កាសែតឡឺបសែវ៉ាទ័រនេះ គឺមិនឆ្វេងភ្លែក មិនគាំទ្រអយុត្តិធម៌សង្គម"។)។ Philip SHORT៖ ប្រតិចារឹក ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ក្រោយម៉ោង 11.34.16។

[3190] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៦៩។

[3191] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧០-៥៧១។ សារណាបណ្តឹងសាទុក្ខ០០២/០១ កថាខណ្ឌ ២៩៦។ លោក ខៀវ សំផន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារ **E1/21.1** ម៉ោង 15.25.54 ("ប៉ុន្តែខ្ញុំឆ្លៀតឱកាសនេះ ធ្វើការដើម្បីមានប្រយោជន៍ដល់លោកផង និងដល់ប្រទេសទាំងមូលផង។ ខ្ញុំមិនបានភ្លេចគម្រោងរបស់ខ្ញុំចង់កែទម្រង់សេដ្ឋកិច្ច ដើម្បីរៀបចំឱ្យមានគ្រឹះមួយជាបណ្តើរៗនៃសេដ្ឋកិច្ចមួយឯករាជ្យនោះទេ"។)។ Philip SHORT៖ ប្រតិចារឹក ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ម៉ោង 11.34.16។ សៀវភៅរបស់ Elizabeth BECKER "នៅពេលដែលសង្គ្រាមរលត់ទៅ" ឆ្នាំ១៩៨៦ ឯកសារ **E3/20** ទំព័រ ១០៥ ERN 00232128។

[3192] មេធាវីការពារក្តីបានលើកឡើងថាអង្គជំនុំជម្រះមិនបានធ្វើសេចក្តីសន្និដ្ឋាននៃសំណុំរឿង ០០២/០១ របស់ខ្លួន ចំពោះប្រធានបទនេះឡើងវិញទេ នៅក្នុងសំណុំរឿង ០០២/០២ ទោះបីជាមិនមានភ័ស្តុតាងផ្ទុយក៏ដោយ៖ សាលក្រម ០០២/០១ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៣៦០ និង ៩៨៨។ ជាឧទាហរណ៍ សូមមើលផងដែរ ឌុច៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** មុនម៉ោង 11.47.11 (គេចាត់ទុក លោក ខៀវ សំផន "សុទ្ធតែព្រះពុទ្ធ ជាមនុស្សដែលស្អាតស្អំបំផុត។ សីហនុ ខ្លួនឯងក៏ជឿទុកចិត្ត ខៀវ សំផន")។

១៦៥៩. អាស្រ័យហេតុនេះ កំហុសរបស់អង្គជំនុំជម្រះបណ្តាលឱ្យមានយុត្តិនិសេធ ហើយសេចក្តីសន្និដ្ឋានជាបន្តបន្ទាប់អំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ត្រូវទុកជាមោឃៈ។

**ផ្នែកទី ២. សមាជិក ប.ក.ក**

១៦៦០. ម្តង អង្គជំនុំជម្រះបានសន្និដ្ឋានថា ខៀវ សំផន បានដឹងថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្ត ក្រោយឆ្នាំ១៩៧៥ ដោយសារតែតាំងពីចូលក្នុងជួរ ប.ក.ក នៅឆ្នាំ១៩៦៩ គោលនយោបាយត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្តសាកល្បង ហើយបែបផែនប្រតិបត្តិការបានលេចចេញជារូបរាង ដែលគាត់ "អាចដឹង" ក្នុងឋានៈជា "សមាជិកសំខាន់មួយរូបនៅក្នុងជួរថ្នាក់ដឹកនាំនៃ ប.ក.ក"[3193]។ ម្តង អង្គជំនុំជម្រះបានសន្និដ្ឋានថា គាត់បានផ្តល់ការគាំទ្រដល់ ប.ក.ក និងគោលនយោបាយបក្ស "យ៉ាងហោចណាស់ [...] តាំងពីឆ្នាំ១៩៦៧"[3194]។ សេចក្តីសន្និដ្ឋានដែលមានភាពផ្ទុយគ្នាទាំងនេះ បានផ្អែកលើការបំភ្លៃភ័ស្តុតាង និងការស្មាន។

១៦៦១. អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទនៃការគាំទ្ររបស់ ខៀវ សំផន ដល់ ប.ក.ក និងគោលនយោបាយបក្ស ចាប់ពីឆ្នាំ១៩៦៧ យ៉ាងយូរបំផុត ពោលគឺ នៅពេលគាត់ចូលព្រៃម៉ាគី[3195] ត្រូវជាពីរឆ្នាំមុនពេលគាត់ចូល ប.ក.ក។ បើតាមអង្គជំនុំជម្រះ កាលបរិច្ឆេទជាក់លាក់នៃការចូលបក្សមិនសំខាន់ទេ ព្រោះ "ត្រឹមឆ្នាំ១៩៧០ ខៀវ សំផន មានទំនាក់ទំនងផ្ទាល់" ជាមួយនឹងអនាគតមេដឹកនាំ ប.ក.ក[3196]។ អង្គជំនុំជម្រះក៏បានអះអាងផងដែរថា នួន ជា ជាអ្នកនាំ ខៀវ សំផន ចូលព្រៃម៉ាគី[3197]។

---

[3193] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧។

[3194] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧។

[3195] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧ ដែលយោងទៅកថាខណ្ឌ ៥៧៣-៥៧៤។

[3196] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧៣។

[3197] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧២ ដែលយោង កថាខណ្ឌ ២១១។

១៦៦២. ជាដំបូង ការអានជាសត្យានុម័តិ និងដោយមិនលម្អៀងនូវប្រភពគាំទ្រដល់ទឡ្ហីករណ៍ចុងក្រោយនេះ បង្ហាញថា អង្គជំនុំជម្រះគ្មានមូលដ្ឋានទាល់តែសោះ[3198]។ បន្ទាប់មកទៀត យើងទើបតែឃើញថា "ការទាក់ទងផ្ទាល់" ពីមុន ជាមួយអតីតមេដឹកនាំ ប.ក.ក ក៏គ្មានមូលដ្ឋាន មិនគ្រប់គ្រាន់ផងដែរ ដើម្បីទាញសេចក្តីសន្និដ្ឋានដាក់បន្ទុក[3199]។ ជាចុងក្រោយ យើងមិនសូវយល់ថា តើការគ្រាន់តែរត់គេចខ្លួនពីការគំរាមសម្លាប់ និងធ្វើដំណើរពីភូមិមួយទៅភូមិមួយដើម្បីលាក់ខ្លួន នាំឱ្យមានការគាំទ្រដល់ ប.ក.ក និងគោលនយោបាយបក្ស បានតាមរបៀបណា។

១៦៦៣. ជាពិសេស កាលបរិច្ឆេទចូល ប.ក.ក របស់ ខៀវ សំផន នៅឆ្នាំ១៩៦៩ មានសារៈសំខាន់។ ភាពយឺតយ៉ាវ ធៀបនឹងការចូលបក្សរបស់អនាគតមេដឹកនាំ ប.ក.ក គឺ ២ ឆ្នាំ ក្រោយពេលគាត់ចូលព្រៃម៉ាគី បង្ហាញថា គាត់នៅដោយឡែកពី ប.ក.ក និងសកម្មភាពបក្ស។ អាស្រ័យហេតុនេះ និងដោយសារតែកង្វះអតីតភាពក្នុងបក្ស បក្សមិនអាចចាត់ទុកគាត់ជា "សមាជិកសំខាន់មួយរូបនៅក្នុងជួរថ្នាក់ដឹកនាំ" បានទេ ហើយគាត់ក៏មិនដឹងអំពីគោលនយោបាយដែលបានរៀបចំឡើងដែរ។ ភ័ស្តុតាងបញ្ជាក់ទៀតថា គាត់បានក្លាយជាសមាជិកត្រៀមគណៈមជ្ឈិម ២ ឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧១ និងជាសមាជិកពេញសិទ្ធិ ៥ ឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៦[3200]។

១៦៦៤. អាស្រ័យហេតុនេះ កំហុសរបស់អង្គជំនុំជម្រះបណ្តាលឱ្យមានយុត្តិនិសេធ ហើយសេចក្តីសន្និដ្ឋានជាបន្តបន្ទាប់អំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ត្រូវទុកជាមោឃៈ។

**ផ្នែកទី ៣. ពីឆ្នាំ១៩៧០ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥**

១៦៦៥. ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសអំពីតួនាទីរបស់ ខៀវ សំផន ពីឆ្នាំ១៩៧០ ដល់ខែមេសា ឆ្នាំ១៩៧៥ ដើម្បីសន្និដ្ឋានអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់[3201]។

[3198] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៤៨៦ (នៃកថាខណ្ឌ ២១១)។

[3199] សូមមើលខាងលើ កថាខណ្ឌ ១៦៥៤-១៦៥៩។

[3200] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧៤។

[3201] សំអាងហេតុសាលក្រម កថាខណ្ឌ ២១៩, ២២០, ២៣១-២៣២, ៥៧៥-៥៨១ និងជាពិសេស ៥៨២។

## ១. ការគាំទ្រដល់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

១៦៦៦. តាមរយៈការរំឭកថា "ខៀវ សំផន មិនបានបដិសេធការគាំទ្ររបស់គាត់ចំពោះរណសិរ្សរួបរួមជាតិកម្ពុជា ហើយក៏មិនបានព្យាយាមធ្វើការបញ្ជាក់អំពីតួនាទីរបស់គាត់ជាសាធារណៈដែរ"[3202] អង្គជំនុំជម្រះខកខានមិនបានពិចារណាលើកាលៈទេសៈនៃការគាំទ្ររបស់ខ្មែរក្រហម ក្រោមការផ្តួចផ្តើមពី ប៉ុល ពត ដល់រណសិរ្សរួបរួមជាតិកម្ពុជា ដែល សម្តេច សីហនុ បានបង្កើតឡើង ក្រោយពីរដ្ឋប្រហាររបស់ លន់ នល់ ប្រឆាំងនឹងព្រះអង្គ[3203]។ ម្យ៉ាងវិញទៀត ខៀវ សំផន បានពន្យល់ថា គាត់ឯកភាពថាគាត់ត្រូវគេណែនាំឱ្យស្គាល់ថាជា "មេដឹកនាំសំខាន់មួយរូប" របស់រណសិរ្សរួបរួមជាតិកម្ពុជា យោងតាមសភាពការណ៍ប្រទេសជាតិ[3204] ទោះបីជាមានការគំរាមពីមុនពីសំណាក់សម្តេច ធ្វើឱ្យគាត់រត់ចូលព្រៃម៉ាគីក៏ដោយ[3205]។ ដូច្នេះ អង្គជំនុំជម្រះបានវាយតម្លៃខុសលើបរិបទនយោបាយ នៅសម័យនោះ ដោយបានសន្និដ្ឋានថា ខៀវ សំផន មានតួនាទីក្នុងការ "ធានាចំពោះសាធារណជនអំពីផែនការរបស់ ប.ក.ក"[3206] ខណៈដែលឥស្សរជនលេចធ្លោបំផុតរបស់រណសិរ្សរួបរួមជាតិកម្ពុជា គឺ សម្តេច សីហនុ ឯណោះទេ។

---

[3202] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧៥។

[3203] សារគាំទ្រដែលផ្ញើទៅសម្តេចសីហនុ ចន្លោះពេលបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលចុះហត្ថលេខាដោយ ហ៊ូ យន់, ហ៊ូ នឹម និង លោក ខៀវ សំផន ដែលតាមពិត ផ្ញើដោយ ប៉ុល ពត សូមមើលការបោះពុម្ពផ្សាយរបស់ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ "សៀវភៅខ្មៅ" ខែកញ្ញា ឆ្នាំ១៩៧៨ ឯកសារ **E3/23** ទំព័រ ៣៦ និង ៤៥ ERN 00289678 និង ERN 00289675។ សៀវភៅរបស់លោក Philip SHORT *ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ **E3/9** ទំព័រ ២៥៨ ERN 00639713។ សៀវភៅរបស់ លោក ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ **E3/16** ទំព័រ ៤២ និង ៤៣ ERN 00643863-64។

[3204] សៀវភៅរបស់ លោក ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ខែឧសភា ឆ្នាំ២០០៧ ឯកសារ **E3/18** ទំព័រ ៥៦ ERN 00103831។ "ប៉ុន្តែដើម្បីខ្ញុំដើរតួនាទីជាស្ពានបានលុះត្រាតែឃើញខ្ញុំចេញមុខជាអ្នកដឹកនាំមួយសំខាន់នៃកម្លាំងតស៊ូនៅក្នុងប្រទេសតែម្តង។ ការពិតជាក់ស្តែង ខ្ញុំមិនមានតួនាទីជាអ្នកដឹកនាំអ្វីទាំងអស់ នេះហើយដែលធ្វើឱ្យខ្ញុំមានការទើសទាល់ខ្លាំងណាស់ តែសភាពការណ៍តម្រូវឱ្យខ្ញុំកាត់ខ្មាស់ កាត់អៀន សុខចិត្តធ្វើការ "លះបង់" ហើយបំពេញភារកិច្ច ដើម្បីរួមចំណែកក្នុងការតស៊ូសង្គ្រោះជាតិតាមសមត្ថភាព និងសភាពការណ៍ជាក់ស្តែងរបស់ខ្ញុំ"។

[3205] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧២។

[3206] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៨២។

ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានធ្វើការបង្ហាញមុខងាររបស់គាត់ខ្ពស់ហួសមេឃ[3207] ខណៈដែលមុខងារទាំងនេះគ្រាន់តែជានិមិត្តរូប និងកម្រិតត្រឹមការតំណាងការទូតនៃចលនានោះប៉ុណ្ណោះ[3208]។

## ២. ការឃោសនា សុន្ទរកថា និងសេចក្ដីអំពាវនាវឱ្យតស៊ូដោយហិង្សា

១៦៦៧. ដើម្បីឈានដល់ការសន្និដ្ឋានខុស អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសជាច្រើនផងដែរ ដោយបានសន្មតថា ខៀវ សំផន ជាអ្នកថ្លែងសុន្ទរកថា និង/ឬចេញសេចក្ដីប្រកាសព័ត៌មានផ្សេងៗរបស់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលបង្ហាញអំពីការគាំទ្ររបស់ដល់គោលបំណងរួម[3209]។ ប៉ុន្តែ អង្គជំនុំជម្រះមិនអាចផ្អែកលើសុន្ទរកថាថ្លែងក្នុងពេលសង្គ្រាម ដើម្បីសន្និដ្ឋានអំពីភាពហិង្សានៃចលនា និងភាពហិង្សារបស់ម្ចាស់បណ្ដឹងសាទុក្ខបានទេ។ អង្គជំនុំជម្រះមិនត្រឹមតែព្រងើយកន្តើយនឹងសក្ខីកម្មផ្ទុយជាច្រើនប៉ុណ្ណោះទេ[3210] ថែមទាំងបានលាក់បាំងភស្តុតាងបង្ហាញថា សម្ដេច សីហនុ ដើរតួ

---

[3207] សំអាងហេតុសាលក្រម កថាខណ្ឌ ២១៩, ២២០, ៥៧៦-៥៧៧។

[3208] ត្រង់ចំណុចនេះ សូមមើល ជួន ប្រសិទ្ធ កំណត់ហេតុស្ដាប់ចម្លើយសាក្សី ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ **E3/96** ERN 00342220 ("មុនឆ្នាំ១៩៧៥ គាត់គឺឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាមេបញ្ជាការយោធា តំណែងដែលមានតែឈ្មោះ ពីព្រោះថា ប៉ុល ពត ជាមេបញ្ជាការពិតប្រាកដ។ នៅពេលដដែលនោះ នៅពេលដែលគាត់ធ្វើដំណើរទៅកាន់បរទេស គឺ អៀង សារី ជាអ្នកមានអំណាច ចំណែកឯ ខៀវ សំផន គឺជាប្រធានគណៈប្រតិភូ")។ សំអាងហេតុសាលក្រម កថាខណ្ឌ ៥៨០ កំណត់សម្គាល់ជើងទំព័រលេខ ១៨១៥ (ការទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូ នៅខែធ្នូ ឆ្នាំ១៩៧៤) និង ១៨១៦ (ការតែងតាំង នៅខែមករា ឆ្នាំ១៩៧៥)។ សំអាងហេតុសាលក្រម កថាខណ្ឌ ៥៨០ កំណត់សម្គាល់ជើងទំព័រលេខ ១៨១៥ ដែលផ្អែកលើអត្ថបទ *ទស្សនកិច្ចនៃគណៈប្រតិភូរដ្ឋាភិបាលប្រជាជនបដិវត្តន៍នៃសាធារណរដ្ឋវៀតណាមខាងត្បូង ពីថ្ងៃទី២៥ ដល់ទី ២៩ ធ្នូ, ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៥* (FBIS) ឯកសារ **E3/30** ERN 00701456-57។ គួរកត់សម្គាល់ថានៅក្នុងអត្ថបទនេះ មានតែសមាជិករបស់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប៉ុណ្ណោះ ដែលឃើញមានឈ្មោះ ដូចជា ហ៊ូ នឹម, ហ៊ូ យន់ និងគាត ឈន់។

[3209] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣១-២៣២, ៥៧៨, ៥៨១, ៥៨២។

[3210] វ៉ាចាម គុន ហៅ ភី ភួនៈ ប្រតិចារឹក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/96.1** ចន្លោះម៉ោង 15.41.13 និងម៉ោង 15.46.03 (នៅចំណាំ លោក ខៀវ សំផន ដោយរំឭកពីសារៈសំខាន់ក្នុងការប្រមូលរាល់កម្លាំងពីគ្រប់ស្រទាប់សង្គម និងដោយនិយាយថាគាត់មិនដែលគិតដល់អំពើហិង្សាឡើយ តែគឺតដល់ការគោរពគោលការណ៍សីលធម៌)។ តឹម វុនៈ ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/112.1** ក្រោយម៉ោង 14.30.48 (ស្ដីពីពាក្យពេចន៍របស់រណសិរ្ស និង ការសុំឱ្យប្រុងប្រយ័ត្នមានភាពអត់ធ្មត់ និង ភាពអត់ធ្មត់ក្នុងសម័យសង្គ្រាម)។ ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/112.1** មុនម៉ោង 14.35.26 (សាក្សីត្រូវបានសាកសួរដើម្បីដឹងថាតើ លោក ខៀវ សំផន បានប្រើប្រាស់ពាក្យពេចន៍ដែលមានចរិតហិង្សាដែរឬទេ៖ "ពាក្យដែលលោក

នាទីយ៉ាងសំខាន់ ក្នុងការប្រាស្រ័យទាក់ទងរបស់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[3211] ទៀតផង។

១៦៦៨. ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា តួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ បានចូលរួមចំណែកដល់គោលបំណងរួម ហើយគោលបំណងនេះមានលក្ខណៈឧក្រិដ្ឋ ឬមានគោលនយោបាយឧក្រិដ្ឋ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ នឹងត្រូវទុកជាមោឃៈ[3212]។

## ផ្នែកទី ៤. ការចូលរួមក្នុងកិច្ចប្រជុំគណៈមជ្ឈិម នៅខែមិថុនា ឆ្នាំ១៩៧៤ និងខែមេសា ឆ្នាំ១៩៧៥

១៦៦៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ក្នុងសន្និដ្ឋានរបស់ខ្លួនអំពីការចូលរួម និងការគាំទ្ររបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំអំពីការវាយសម្រុកផ្តាច់ព្រ័ត្រ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[3213]។

---

ខៀវ សំផន ញុះញង់ ខ្ញុំដូចមិនដែលឮទេ។ បើអប់រំ ដំបូងគឺមានរៀនសីលធម៌១២ប្រការ”។)។ គួរកត់សម្គាល់ថា សាក្សីបានបញ្ជាក់ថា គាត់មិនគិតថាលោក ខៀវ សំផន សរសេរសុន្ទរកថាដោយខ្លួនឯងទេ កាលពីសម័យនោះ។

[3211] សួង ស៊ីគឿន៖ ប្រតិចារឹក ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/101.1** ម៉ោង 14.28.26 (ទាក់ទងនឹងទីភ្នាក់ងារសារព័ត៌មានកម្ពុជា៖ “ពេលនោះ<u>ព្រះអង្គជាប្រធាន</u> ហើយជាប្រធានអ្វីៗដែលចេញពីព្រះអង្គយើងផ្សាយទាំងអស់។ យើងមិនមានអំណាច ឬមានសិទ្ធិ ឬមានចេតនានឹងបំបិទ ឬទប់ស្កាត់អ្វីៗដែលចេញពីព្រះអង្គឡើយ។ ឃើញទេ គឺថាជានយោបាយ ហើយជាមនោសញ្ចេតនា ក៏យើងមិនមានបំណងទៅនឹងអ្វីដែលចេញពីប្រធានប្រមុខនៃការតស៊ូនៃចលនាតស៊ូរបស់យើង យើងផ្សាយទាំងអស់ ហើយក៏ជាកិត្តិយសរបស់យើងដែរបាទ”។)។ អុង ថុងហឿង៖ ប្រតិចារឹក ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/105.1** ម៉ោង 15.44.32 (ព្រឹត្តបត្ររណសិរ្សរួបរួមជាតិ៖ “និយាយឱ្យចំ <u>សម្តេចនរោត្តមសីហនុជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា</u> ហើយតាមធម្មតាគាត់មាន*ប៉ូលតាំង*របស់គាត់មួយ។ គាត់ចូលចិត្តមាន*ប៉ូលតាំង*របស់គាត់មួយ មានព្រឹត្តបត្ររបស់គាត់មួយ។ ហើយព្រឹត្តិបត្រមួយទៀតចេញមកពីការិយាល័យរណសិរ្សរួបរួមជាតិ ដែលចេញផ្សាយតាមវិទ្យុរណសិរ្សរួបរួមជាតិ”)។ គីម វុន៖ ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/112.1** ម៉ោង 13.56.18៖ “ខ្ញុំនឹកស្មានថាមិនមែន លោក ខៀវ សំផន គាត់សរសេរខ្លួនឯងទាំងអស់ទេ ព្រោះនៅក្នុងក្រុមមេដឹកនាំរណសិរ្សរួបរួមជាតិកម្ពុជា ទាល់តែមានការសម្រេចពីសម្តេចព្រះនរោត្តម សីហនុ ដែរ បានលោក ខៀវ សំផន អាចនឹងធ្វើបាន។ នេះតាមការសន្និដ្ឋានរបស់ខ្ញុំទេ [...] ប៉ុន្តែជាគោលការណ៍របស់រណសិរ្សរួបរួមជាតិកម្ពុជា ថ្នាក់ដឹកនាំត្រូវតែឆ្លងកាត់ការយល់ព្រមពីសម្តេចព្រះនរោត្តមសីហនុ” (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3212] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៨២, ៤២៥៧, ៤៣០៦, ៤៣៨៩។

[3213] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨០-៣៨៨២។

## ១. ការងាកត្រឡប់មករកកិច្ចប្រជុំ ខែមិថុនា ឆ្នាំ១៩៧៤

១៦៧០. អង្គជំនុំជម្រះបានងាកត្រឡប់មករកសេចក្ដីសន្និដ្ឋានរបស់ខ្លួន ក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំ ខែមិថុនា ឆ្នាំ១៩៧៤ ដែលអង្គជំនុំជម្រះកំណត់ថាជាពេលធ្វើសេចក្ដីសម្រេចលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[3214]។ ការងាកត្រឡប់មកវិញនេះបានធ្វើឡើង ក្រោយពីអង្គជំនុំជម្រះតុលាការកំពូលបានធ្វើមោឃភាពចំណុចនេះ ដែលបដិសេធការវាយតម្លៃលម្អៀងរបស់អង្គជំនុំជម្រះទៅលើភស្តុតាង[3215]។ ការងាកត្រឡប់របស់អង្គជំនុំជម្រះមករកសេចក្ដីសម្រេចរបស់ខ្លួនវិញ លើកិច្ចប្រជុំគណៈមជ្ឈិម ខែមិថុនា ឆ្នាំ១៩៧៤ នេះ ដោយផ្អែកលើភស្តុតាងដដែលៗ នៅក្នុងក្របខ័ណ្ឌសំណុំរឿង ០០២/០១ ផ្ទុះបញ្ជាំងឱ្យឃើញភាពលម្អៀងក្នុងសេចក្ដីសន្និដ្ឋានជាច្រើនរបស់អង្គជំនុំជម្រះ[3216]។

១៦៧១. ខណៈដែលអង្គជំនុំជម្រះបានទាយស្មានយ៉ាងវែងអន្លាយ នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ អំពីការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំនេះ[3217] ដោយបដិសេធយ៉ាងដាច់អហង្ការនូវសក្ខីកម្មរបស់ សូ សុជាតិ ដែលត្រូវបានចោទថានិយាយកុហក ដោយសារ "ទឹកចិត្តរបស់អ្នកស្រីក្នុងការជួយប្ដីរបស់គាត់"[3218] អង្គជំនុំជម្រះបានត្រឡប់មករកសេចក្ដីសន្និដ្ឋានរបស់ខ្លួនវិញទាំងស្រុង។

១៦៧២. ដូច្នេះ ក្នុងសំណុំរឿង ០០២/០២ ដោយសារតែមានបញ្ហាប្រយោលផ្សេង អង្គជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះលែង "ជឿជាក់" ថា ខៀវ សំផន មានវត្តមានក្នុងកិច្ចប្រជុំ នៅខែមិថុនា ឆ្នាំ១៩៧៤

---

[3214] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩២។

[3215] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០០៨-១០០៩។

[3216] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣០, ៥៨៣-៥៨៤, ៥៨៧-៥៨៨។

[3217] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៣៨។

[3218] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៣៩។ សូមមើលផងដែរសំអាងហេតុសាលក្រម កថាខណ្ឌ ៥៨៧ កំណត់សម្គាល់ជើងទំព័រលេខ ១៨៣៨។

ដោយបន្តប្រើប្រាស់ចម្លើយដដែលរបស់សាក្សីដ៏សំខាន់ឈ្មោះ រ៉ចាម គុន ប៉ុន្តែ លើកនេះ បានសន្និដ្ឋានថា សាក្សីនិយាយសំដៅដល់កិច្ចប្រជុំខែមេសា ឆ្នាំ១៩៧៥ ទៅវិញទេ[3219]។

១៦៧៣. ការប្រែក្រឡាស់នេះកាន់តែលេចធ្លោ និងបង្ហាញច្បាស់អំពីអំពើរបស់អង្គជំនុំជម្រះគិតតែពីខំរកភ័ស្តុតាងដាក់បន្ទុក ពីព្រោះនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានចាត់ទុកថា កាលបរិច្ឆេទនៃការពិភាក្សាអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ អាចត្រូវបានជ្រើសរើសជាពិសេសនៅខែមិថុនា ឆ្នាំ១៩៧៤ ដើម្បី "ឱ្យ ខៀវ សំផន [...] អាចចូលរួមបាន"[3220]។ ដោយបដិសេធចោលភាពផ្ទុយគ្នាជាច្រើនដែលមេធាវីការពារក្តីបានលើកឡើង ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ ភី ភួន អំពីកាលបរិច្ឆេទខែមិថុនា ឆ្នាំ១៩៧៤ នេះ អង្គជំនុំជម្រះបែរជាយល់ឃើញសក្ខីកម្មរបស់គាត់មានភាព "ច្បាស់" ខ្លាំង[3221]។

១៦៧៤. ប៉ុន្តែ ក្នុងកិច្ចសម្ភាសន៍ ដែលមេធាវីការពារក្តីបានស្នើសុំឱ្យទទួលយកជាភ័ស្តុតាងមិនបានសម្រេច រ៉ចាម គុន បានទទួលស្គាល់ថា គាត់មានការភាន់ច្រឡំ ក្រោយពីបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១[3222] ធ្វើឱ្យចោទជាបញ្ហាដល់ភាពអាចជឿជាក់បានរបស់គាត់។

១៦៧៥. ពិតមែនតែអង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មនេះមានភាព "ច្បាស់" ក៏ដោយ ក៏នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបែរជាធ្វើការសន្និដ្ឋានផ្សេងទៅវិញ ដោយបានកំណត់យកសេចក្តីសម្រេចស្តីពីការជម្លៀសប្រជាជន នៅខែមេសា ឆ្នាំ១៩៧៥ វិញម្តង។

---

[3219] សំអាងហេតុសាលក្រម កថាខណ្ឌ៥៨៨ និង ៥៨៦។

[3220] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៣៨៖ "អង្គជំនុំជម្រះយល់ឃើញថា កិច្ចប្រជុំក្នុងខែមិថុនាឆ្នាំ ១៩៧៤ មុខជាត្រូវបានរៀបចំឡើងដើម្បីឱ្យខៀវ សំផន និង អៀង សារី អាចចូលរួមបាន និងរាយការណ៍ជូនសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ពីកិច្ចប្រជុំផ្សេងៗជាមួយនឹងមេដឹកនាំជាន់ខ្ពស់ប្រទេសចិន វៀតណាម និងឡាវ"។

[3221] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៣៩។

[3222] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ឯកសារ **E220**។ សាក្សីម្នាក់រូបនៅតុលាការខ្មែរក្រហម បានលើកឡើងវិញពីអ្វីដែលគាត់បាននិយាយអំពីលោក ហោ ណាំហុង ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ (The Cambodia Daily) ឯកសារ **E220.1** ERN 00894319-20។

## ២. កិច្ចប្រជុំ ខែមេសា ឆ្នាំ១៩៧៥ នៅមន្ទីរ ប-៥

## ២.១. ភាពផ្ទុយគ្នា និងកង្វះភាពអាចជឿជាក់បានរបស់ ភី ភួន ដែលត្រូវបានធ្វើមិនដឹងមិនឮ

១៦៧៦. ជាក់ស្តែង សក្ខីកម្មរបស់ រ៉ាចាម គុន ហៅ ភី ភួន មានសារៈសំខាន់មិនអាចខ្វះបាន សម្រាប់ទាញ ខៀវ សំផន ឱ្យចូលរួមពាក់ព័ន្ធក្នុងផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជាផ្នែកមួយនៃគោលបំណងរួម[3223]។ ដូច្នេះ ភាពមិនស៊ីចង្វាក់គ្នារបស់ ភី ភួន ត្រូវបានព្រងើយកន្តើយជាថ្មីម្តងទៀត ខណៈដែលសក្ខីកម្មរបស់ សូ សុជាតិ ត្រូវបានពិនិត្យយ៉ាងល្អិតល្អន់[3224]។ ប៉ុន្តែយើងត្រូវងាកមកមើលសក្ខីកម្មរបស់ ភី ភួន វិញ ដើម្បីកត់សម្គាល់ថា ការពិពណ៌នារបស់គាត់អំពីកិច្ចប្រជុំពីរផ្សេងគ្នា មិនអាចឱ្យជំនួសគ្នាបានឡើយ[3225]។

១៦៧៧. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបំភ្លេចចោលយ៉ាងស្រួលនូវភស្តុតាងផ្ទុយពីសក្ខីកម្មរបស់ រ៉ាចាម គុន ហៅ ភី ភួន ហៅ ជាម។ នៅពេលសួរដេញដោលលើរយៈកាលមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មេរបស់ ភី ភួន ឈ្មោះ សាឡុត បាន ជាអង្គរក្ស ជាក្មួយ និងជាពេទ្យរបស់ ប៉ុល ពត បានពន្យល់ថា ភី ភួន មិនធ្វើការនៅមន្ទីរ ប-៥ ទេ៖ "ជាម ទៅម្តងម្កាលដែរ ធ្វើជានីរសារ រកត្រី រកសាច់ផ្តល់ជូនខ្មមនោះ"[3226]។ អង្គជំនុំជម្រះមិនបានយកចិត្តទុកដាក់ដល់សក្ខីកម្មរបស់ សាឡុត បាន ដែលបានបន្ថយតួនាទីសំខាន់របស់ រ៉ាចាម គុន ហៅ ភី ភួន នោះទេ។

[3223] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៨០ ("ផែនការវាយសម្រុកចុងក្រោយ និងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងទៀត ត្រូវបានយកមកពិភាក្សា នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក នៅក្នុងដើមខែមិថុនាឆ្នាំ១៩៧៤ ដែលមានការចូលរួមពី ប៉ុល ពត, នួន ជា, សោ ភឹម, កុយ ធួន, តាម៉ុក, វន វ៉េត, រស់ ញឹម និងសុន សេន"។)។

[3224] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៨៦ និង ៥៨៨។ សូមមើលផងដែរសាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១៣៩។

[3225] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល សំណុំរឿង ០០២/០១ កថាខណ្ឌ ២០-៣៣។

[3226] សាឡុត បាន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/68.1** ម៉ោង 11.29.12។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/69.1** ចាប់ពីម៉ោង 13.40.02 ជាម នៅខាងកើតទន្លេសាប ជាមួយនឹង ប៉ង់ "ខ្មមដែលខ្ញុំនិយាយថាខ្ញុំនៅហ្នុង នៅខាងលិចទន្លេសាប នៅក្រាំងបេង ក្រាំងដូង អីហ្នឹង។ ប៉ង់ មិនមាននៅទេ ប៉ង់ អត់មាននៅហ្នុងទេ មានតែខ្ញុំដែលជាអ្នកគ្រប់គ្រង បន្ទាប់ពី ប៉ុល ពត។ ដូច្នេះប៉ង់អត់មានចេញចូលអីពីខាងលិចទន្លេទៅខាងកើតទន្លេទេ ប៉ង់នៅតែប្រចាំនៅខាងកើតទន្លេតែរហូត"។

១៦៧៨. ចម្លើយរបស់ សាឡុត បាន មានភាពស៊ីចង្វាក់គ្នានឹង អឿន តាន ជាអង្គរក្សដ៏សំខាន់ម្នាក់ទៀតរបស់ ប៉ុល ពត។ អ្នកទាំងពីរបានរំឭកថា ស្របតាមគោលការណ៍រក្សាការសម្ងាត់ ដែលមានការបញ្ជាក់អះអាងពីអតីតកម្មាភិបាលជាច្រើន កងការពារត្រូវគេតម្រូវឱ្យឈរយាមឆ្ងាយពីកន្លែងប្រជុំ ធ្វើឱ្យពួកគេមិនអាចស្ដាប់ឮអ្វីទេ[3227]។ រឿងរ៉ាវរបស់ ភី ភួន គួរណាតែត្រូវយកមកប្រៀបធៀបនឹងភ័ស្តុតាងផ្សេងទៀត ហើយអង្គជំនុំជម្រះគួរណាតែសន្និដ្ឋានថា គាត់មិនអាចស្ដាប់ឮប្រធានបទនៃការពិភាក្សាក្នុងកិច្ចប្រជុំដ៏សំខាន់បែបនេះទេ។

## ២.២. សេចក្តីលម្អិតនៃភាពផ្ទុយគ្នាជាមួយភ័ស្តុតាងផ្សេងៗអំពីមន្ទីរ ប-៥

១៦៧៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ភ័ស្តុតាងបង្ហាញហួសពីវិមតិសង្ស័យថា រឿងរ៉ាវរបស់ រ៉ែចាម តុន មានភាព "ស៊ីចង្វាក់គ្នា" ជាមួយចម្លើយរបស់ នួន ជា, អៀង សារី និង ខៀវ សំផន។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមិនបានបញ្ជាក់ថា ហេតុអ្វីបានជាខ្លួនបដិសេធចោលភ័ស្តុតាងសំខាន់ផ្ទុយនឹងចម្លើយរបស់ រ៉ែចាម តុន ហៅ ភី ភួន នោះទេ។ តារាងប្រៀបធៀបខ្លឹមសារនៃសក្ខីកម្មផ្សេងៗជាប្រទីបបំភ្លឺអំពីភាពខុសគ្នាមិនអាចផ្សះផ្សាបាននៃសក្ខីកម្ម។

| ឈ្មោះ | ការពិពណ៌នាអំពីមន្ទីរ ប-៥ និងកិច្ចប្រជុំ |
|---|---|
| រ៉ែចាម តុន ហៅ ភី ភួន | - មន្ទីរ ប-៥ ស្ថិតនៅភូមិតាំងពោន[3228]។<br>- គាត់បានលើកឡើងអំពីកិច្ចប្រជុំធំមួយ ហើយក្នុងពេលនោះ ប៉ុល ពត, នួន ជា, ខៀវ សំផន, តាម៉ុក, សុន សេន, កុយ ធួន, វន វ៉េត, ចេង អន និង សោ ភឹម បានពិភាក្សា |

[3227] អឿន តាន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/86.1** មុនម៉ោង 11.33.02 ("ខ្ញុំអត់ដែលដឹងទេ ព្រោះផ្នែកការពារអ្នកដឹកនាំជាន់ខ្ពស់អ៊ីចឹង គេមិនដែលប្រាប់យើងទេ។ ការងារដឹកនាំគឺដឹកនាំ។ ការងារសំខាន់ខាងការពារ គឺដឹងថាការពារចម្ងាយតែ ២០ ម៉ែត្រទៅ ១០ ម៉ែត្រ ១៥ម៉ែត្រប៉ុណ្ណឹង។ គេមិនដែលប្រាប់យើងទេ"។)។

[3228] រ៉ែចាម តុន ហៅ ភី ភួន៖ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/97.1** ម៉ោង 09.53.39។

| ឈ្មោះ | ការពិពណ៌នាអំពីមន្ទីរ ប-៥ និងកិច្ចប្រជុំ |
|---|---|
| | អំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ រួច "អង្គប្រជុំទាំងមូលឯកភាពទះដៃ"[3229]។ |
| នួន ជា | - មានវត្តមានក្នុងកិច្ចប្រជុំស្តីពីការជម្លៀសប្រជាជន ដែលគាត់បានប្រកែកថាមិនមែននៅមន្ទីរ ប-៥ ទេ។<br>- ប៉ុល ពត បោះទីតាំងនៅមន្ទីរ ប-៥ ចាប់ពីដើមខែមេសា ឆ្នាំ១៩៧៥ ជាទីបញ្ជាការសម្រាប់រំដោះភ្នំពេញ។ មន្ទីរ ប-៥ ស្ថិតនៅក្រោមបង្គាប់ ប៉ុល ពត។<br>- គាត់បាននិយាយពី ប៉ុល ពត នៅមន្ទីរ ប-៥៖ "គ្មានពីណាទេ។ មានតែពួកដែលនៅភូមិភាគ គេមករាយការណ៍ជូនគាត់ ហើយមានអ្នកការពារប៉ុន្មាននាក់ទេ ព្រោះត្រូវនៅស្ងាត់ នេះខ្ញុំសូមជម្រាបលោកប្រធាន។ សង្គ្រាមឈ្លបណា ធ្លូន់មិនបានទេ មានចំនួនច្រើនមិនបានទេ ស្ងាត់ ចល័ត រហ័ស នេះបានធ្វើសង្គ្រាមឈ្លបបាន។ ផ្លាស់កន្លែងឱ្យញឹក បើមិនអ៊ីចឹងទេ ខ្មាំងវ៉ៃខ្ទេចខ្ទីអស់ហើយ។ ស៖ តើលោកធ្លាប់បានចូលរួមប្រជុំនៅមន្ទីរ ប-៥ដែរឬទេ? ឆ៖ ខ្ញុំដូចមិនដែលបានចូលប្រជុំនៅមន្ទីរ ប-៥ ទេ គ្រាន់តែពេលទៅជួប ប៉ុល ពត ម្តងម្កាល ឯទៅប្រជុំរួមអីហ្នឹងគេ មិនដែលទៅប្រជុំទេ"[3230]។ គួរកត់សម្គាល់ថា ក្នុងភាសាខ្មែរ នួន ជា បានប្រកែកថាមិនដែលបានចូលប្រជុំនៅមន្ទីរ ប-៥ ទេ[3231]។ |
| ខៀវ សំផន | - គាត់មិនបានចូលរួមក្នុងការងារនេះទេ ប៉ុន្តែ បានតាមដានហេតុការណ៍ ដែល ប៉ុល ពត សង្ខេបជូនគាត់ ម្តងម្កាល[3232]។ គាត់បានប្រកាសថា៖<br>"នៅចុងខែមីនា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានគេអញ្ជើញទៅទីបញ្ជាការរួម ប.ក.ក ដែលមានទីតាំងនៅភូមិដូង [...] ខាងលិចឧដុង្គបន្តិច ដើម្បីតាមដានការវាយសម្រុកជាចុងក្រោយ |

[3229] វ៉ាចាម គុន ហៅ ភី ភួន៖ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/97.1** ម៉ោង 09.42.32 និងម៉ោង 09.51.13។

[3230] នួន ជា៖ ប្រតិចារឹក ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ ឯកសារ **E1/35.1** មុនម៉ោង 10.21.31 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3231] ដូចខាងលើ ប្រតិចារឹកជាភាសាខ្មែរ ទំព័រ ១៩ បន្ទាត់ ៣-៤, ៦-៧។

[3232] លោក ខៀវ សំផន កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/27** ERN 00156614។ ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារ **E1/21.1** ក្រោយម៉ោង 16.01.33។

| ឈ្មោះ | ការពិពណ៌នាអំពីមន្ទីរ ប-៥ និងកិច្ចប្រជុំ |
| --- | --- |
| | ទៅលើរដ្ឋធានីភ្នំពេញ។ [...] រាល់ថ្ងៃខ្ញុំទៅស្ដាប់វិទ្យុទាក់ទងជាមួយកម្មាភិបាលយោធាមួយចំនួន ដើម្បីតាមដានសមរភូមិប្រយុទ្ធ”[3233]។ |
| អៀង សារី | - គាត់បានកំណត់យកការសម្រេច អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅចុងខែមីនា ឬដើមខែមេសា ខណៈដែលគាត់មិនបានឃើញទេ។<br>- ម្យ៉ាងវិញទៀត គាត់បានលើកឡើងអំពីជំនួបទល់មុខគ្នាជាមួយ ប៉ុល ពត នៅឆ្នាំ ១៩៧៤ ដើម្បីប៉ុនប៉ងពិភាក្សាអំពីប្រធានបទនេះ គាត់បាននិយាយថា៖<br>“ប៉ុល ពត ឆ្លើយនឹងខ្ញុំ គឺថាគេមានពិសោធន៍អស់ហើយ សមមិត្តសូមកុំគិតណឹង មិត្តគិតតែភារកិច្ចរបស់មិត្តនៅក្រៅទៅបានហើយ។ [...] ដូច្នេះ បញ្ហានៅភ្នំពេញ បញ្ហាហ្នឹងត្រូវតែជម្លៀសចេញពីភ្នំពេញដែរបានដោះស្រាយរួច។ ខ្ញុំបានទប់ទល់ហ្នឹងថាជម្លៀសទាំងអស់ ឬមួយយ៉ាងម៉េច? គាត់អាណឹងចាំជាក់ស្ដែង។ ឆ្លើយហ្នឹង គឺថា ចាំជាក់ស្ដែង ក៏ប៉ុន្តែ ពាក្យជម្លៀសមានប្រើពេល ៧៤ ហ្នឹង”[3234]។ |
| សាឡុត បាន | - គាត់នៅជាប្រចាំជាមួយ ប៉ុល ពត មុនរំដោះទីក្រុងភ្នំពេញ និងជា “អ្នកគ្រប់គ្រងបន្ទាប់ពី ប៉ុល ពត”។ នៅទីនោះ មានតែអ្នកដាំបាយម្នាក់ និងកងការពារពីរនាក់។នួន ជា មកជួប ប៉ុល ពត ម្ដងម្កាលប៉ុណ្ណោះ[3235]។<br>- ការជួបជុំគ្នា “បីបួនប្រាំនាក់” មិនមានទេ។ អាចមានការជួបជុំគ្នាម្នាក់ពីរនាក់ប៉ុណ្ណោះ”[3236]។ |

[3233] សៀវភៅរបស់ លោក ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ខែឧសភា ឆ្នាំ២០០៧ ឯកសារ **E3/18** ទំព័រ ៦៨ ERN 00103838 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3234] បទសម្ភាសន៍ អៀង សារី ដោយ Stephen HEDER ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ឯកសារ **E3/89** ERN 00062457។

[3235] សាឡុត បាន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/68.1** ម៉ោង 11.27.36។ ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/69.1** មុនម៉ោង 11.35.18 ក្រោយម៉ោង 13.41.45 (“បើប៉ង់មិននៅទេ ខ្ញុំទទួលពីប៉ុលពតផ្ទាល់”)។

[3236] សាឡុត បាន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/66.1** ម៉ោង 11.12.49 មុនម៉ោង 11.55.32 (យើងគូសបន្ទាត់ពីក្រោម) (“ស. តើអ្នកណាធ្វើការនៅក្នុងផ្ទះនុ៎ង? គឺថាផ្ទះដែលអាចផ្លាស់ប្ដូរ ប៉ុន្តែក្នុងតំបន់ដែលហ្នឹង តើមេដឹកនាំណាដែលធ្វើការនៅក្នុងផ្ទះនុ៎ង? ឆ. គឺប៉ុល ពត បាទ។ ស. តើមានមេដឹកនាំដែលមកពីតំបន់ ឬក៏ភូមិភាគផ្សេងទៀត មកជួបលោក ប៉ុល ពត

| ឈ្មោះ | ការពិពណ៌នាអំពីមន្ទីរ ប-៥ និងកិច្ចប្រជុំ |
| --- | --- |
| | - គាត់បានឃើញ ខៀវ សំផន ប៉ុន្តែ មិនមានជា "ការប្រជុំអីធំដុំទេ"[3237]។ |

១៦៨០. នៅពេលធ្វើការប្រៀបធៀបចម្លើយផ្សេងគ្នាទាំងនេះ យើងមើលមិនឃើញថា តើអង្គជំនុំជម្រះអាចសន្និដ្ឋានថាចម្លើយរបស់ នួន ជា, អៀង សារី និង ខៀវ សំផន ស៊ីចង្វាក់គ្នាជាមួយចម្លើយរបស់ ភី ភួន តាមរបៀបណានោះទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះមានកំហុសធ្ងន់ធ្ងរណាស់។

## ២.៣. ភស្តុតាងផ្សេងទៀតដែលមិនត្រូវបានយកចិត្តទុកដាក់

១៦៨១. លើសពីនេះទៀត អង្គជំនុំជម្រះគួរណាតែទាញផលវិបាកចេញពីការកត់សម្គាល់របស់ខ្លួនថា ខៀវ សំផន មិនជាប់ពាក់ព័ន្ធអ្វីនឹងកិច្ចការយោធាទេ។ អៀង សារី បានឆ្លើយថា ប៉ុល ពត ប្រាប់គាត់ឱ្យគិតតែភារកិច្ចរបស់ខ្លួន ហើយគាត់បានពន្យល់ថា ប៉ុល ពត ជាមួយ សុន សេន និង នួន ជា ព្រមទាំងមេភូមិភាគ ជាអ្នកគ្រប់គ្រងការជម្លៀស[3238]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនបានលើកឡើងថា ខៀវ សំផន ជាសមាជិកត្រៀមធម្មតានៃគណៈមជ្ឈិម មិនអាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចបានទេ[3239]។

១៦៨២. ទោះបីជា ប៉ុល ពត បោះទីតាំងនៅខាងលិចឧដុង្គ ដើម្បីសម្រួលដល់ការបញ្ជារំដោះទីក្រុងភ្នំពេញ ក៏ដោយ ក៏ក្នុងសំណុំរឿង ០០២/០១ ឬក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានផ្អែកមិនសមហេតុ

ដែរឬទេ? ឆ. តាមការគាត់អញ្ជើញ ម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ។ យូរៗម្តង ខ្ញុំឃើញម្តង យូរៗម្តង"។) ក្រោយម៉ោង 11.30.51 ("ចន្លោះ៧០ ដល់៧៥ ភាគច្រើនខ្ញុំនៅជាប់ [ប៉ុល ពត]"។)។

[3237] សាឡូត បាន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/68.1** ម៉ោង 11.25.22។

[3238] បទសម្ភាសន៍ អៀង សារី ដោយ Stephen HEDER ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ឯកសារ **E3/89** ERN FR 00332685។ សំអាងហេតុនៃសាលក្រម កថាខណ្ឌ ៣៨៨២ ("លេខាភូមិភាគបានស្នើ និងទទួលការណែនាំពីមេដឹកនាំចិនខ្ពស់ រួមទាំង ប៉ុល ពត, នួន ជា និង សុន សេន ដែលស្ថិតនៅមន្ទីរប-៥ នៅពេលនោះ"។)។ សាឡូត បាន៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ឯកសារ **E1/68.1** ក្រោយម៉ោង 11.25.22។

[3239] លក្ខន្តិកៈ ប.ក.ក នៅឆ្នាំ១៩៧៦ ឯកសារគ្មានកាលបរិច្ឆេទ ឯកសារ **E3/130** ទំព័រ ១៩ ERN 00442277។

ផលលើសក្ខីកម្មរបស់ វ៉ាចាម គុន តែមួយគត់ ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានចូលរួម និងអនុម័តផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥។ ជាក់ស្តែង ការរៀបចំកិច្ចប្រជុំនៅតាំងពោន នៅកាលបរិច្ឆេទនេះ ដូចសាក្សីបានរៀបរាប់ មិនត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យទេ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

## ជំពូកទី ២. កំហុសពាក់ព័ន្ធនឹងកន្លែងស្នាក់នៅ កន្លែងធ្វើការ និងការធ្វើដំណើរ

១៦៨៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយបានទាញសេចក្តីសន្និដ្ឋានខុសអំពីកន្លែងស្នាក់នៅ និងកន្លែងធ្វើការ ក៏ដូចជាការធ្វើដំណើររបស់ ខៀវ សំផន នៅក្នុងប្រទេស។ កំហុសទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីសន្និដ្ឋានអំពីការដឹងអំពីឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវរបស់គាត់[3240]។

### ផ្នែកទី ១. កំហុសពាក់ព័ន្ធនឹងការនៅកៀកនឹងមេដឹកនាំ ប.ក.ក

១៦៨៤. អង្គជំនុំជម្រះបានបរិយាយយ៉ាងវែងលើការទាក់ទងជិតស្និទ្ធរបស់ ខៀវ សំផន ជាមួយ ប៉ុល ពត, នួន ជា និងមេដឹកនាំផ្សេងទៀតនៃ ប.ក.ក ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែគាត់បានស្នាក់នៅ និងធ្វើការ នៅមន្ទីរ ក-១ ផង និង ក-៣ ផង[3241]។ ជាក់ស្តែង អង្គជំនុំជម្រះបានទាញការសន្និដ្ឋានពង្រីកអំពីការដឹងរបស់ម្ចាស់បណ្តឹងសាទុក្ខ ដោយសារតែការនៅកៀកនេះ និង "ជំនួបទល់មុខគ្នា" ជាយថាហេតុ[3242]។ ប៉ុន្តែដូចបានឃើញពីខាងលើ គោលការណ៍រក្សាការសម្ងាត់ មានសារៈសំខាន់ណាស់ ក្នុងដំណើរការរបស់ ប.ក.ក[3243]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះមិនបានទាញផលវិបាកថា ទោះបីជាទៅមន្ទីរ ក-១ ជាទៀងទាត់ក៏ដោយ ក៏ ខៀវ សំផន មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍

[3240] សំអាងហេតុសាលក្រម កថាខណ្ឌ៤២០៨, ៤២២៥ និង ៤៣១៤។

[3241] សំអាងហេតុសាលក្រម កថាខណ្ឌ៤៨៤, ៥៨១, ៥៨៣-៥៨៨។

[3242] សំអាងហេតុសាលក្រម កថាខណ្ឌ៤៨៤ កំណត់សម្គាល់ជើងទំព័រលេខ ១៥២៧។ ត្រង់ចំណុចនេះ វាជាការសំខាន់ គួរកត់សម្គាល់ថា មានតែ ផាន វ៉ាន់ ទេដែលបានលើកឡើងពីការសន្ទនាតែពីរនាក់តទល់ គឺនិយាយពីអៀង ធីរិទ្ធ និងនួន ជា ប្រតិចារឹក ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/152.1** ម៉ោង 10.07.28។

[3243] សូមមើលខាងលើ កថាខណ្ឌ ១៦៥០-១៦៥១។

ឡើយ។ អង្គជំនុំជម្រះគួរណាតែកត់សម្គាល់ឱ្យបានត្រឹមត្រូវថា ការនៅកៀកខាងផ្លូវកាយមិនមែនមានន័យថា ជាការនៅកៀកខាងអំណាច ឬខាងការទទួលខុសត្រូវនោះទេ។ ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា "ការនៅកៀក" នឹង "មជ្ឈិមបក្ស" ធ្វើឱ្យ ខៀវ សំផន ដឹងជាប្រចាំអំពីការបង្កើតផែនការ ការអនុវត្តផែនការ និងភវនីយភាពដែលថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត[3244]។

១៦៨៥. ម្យ៉ាងវិញទៀត ការពិនិត្យដោយមិនលម្អៀងទៅលើភ័ស្តុតាងបង្ហាញថា ក្រោយពីចាកចេញពីមន្ទីរ ក-១ ខៀវ សំផន បានទៅរស់នៅមន្ទីរ ក-៣ ខណៈដែល នួន ជា និង អៀង សារី មកម្តងម្កាល ចំណែកឯ ប៉ុល ពត ស្នាក់នៅជាប្រចាំនៅមន្ទីរ ក-១[3245]។ ជាក់ស្តែង សាក្សីជាច្រើនបានបញ្ជាក់អះអាងអំពីភាពខុសគ្នានៃកន្លែងស្នាក់នៅ និងជាពិសេស ភាពខុសគ្នានៃតួនាទីរបស់ ខៀវ សំផន ដែលផ្តោតលើការបែងចែកសម្ភារៈទៅតាមភូមិភាគ និងតំបន់[3246]។ សាក្សីទាំងនេះបានអះអាងថា ពួកគេមិនដឹងខ្លឹមសារនៃការពិភាក្សា រវាងអ្នកនៅមន្ទីរ ក-១ និងមន្ទីរ ក-៣ នោះទេ ដែលមិនអាចឱ្យបញ្ជាក់អះអាងលើទស្សនៈ

---

[3244] សំអាងហេតុសាលក្រម កថាខណ្ឌ៤២០៨ និង ៤២២៥។

[3245] សំអាងហេតុសាលក្រម កថាខណ្ឌ៤៨៤។ ត្រង់ចំណុចនេះ វាជាការសំខាន់ គួរកត់សម្គាល់ថា មានតែ ផាន វ៉ាន ទេដែលបានលើកឡើងពីការសន្ទនាតែពីរនាក់តទល់ គឺនិយាយពីអៀង ធីរិទ្ធ និងនួន ជា ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/152.1** ម៉ោង 10.07.28។ ដូច្នេះ វាមិនសមហេតុផលទេ ក្នុងការដាក់បញ្ចូលគ្នាសម្តីមនុស្សគ្រប់គ្នា ដើម្បីទាញជាសេចក្តីសន្និដ្ឋានចោទប្រកាន់លើ លោក ខៀវ សំផន។

[3246] អឿន តាន៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/86.1** ម៉ោង 11.13.46 (លោក ខៀវ សំផន និង នួន ជា រស់នៅ ក-៣ អៀង សារី នៅ ប-១)។ សូត្រ ទឿង៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ **E3/423** ស/ឆ ១៨៣ ("ពេលខ្លះ នួនជាស្នាក់នៅក-១ ហើយនៅពេលខ្លះ ស្នាក់នៅក-៣")។ ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/63.1** ម៉ោង 14.05.17។ ឡុង ឈឿង៖ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/208.1** ចន្លោះម៉ោង 09.47.01 និង 09.48.51។ បញ្ហានៃការបកប្រែ សូមមើលជាភាសាខ្មែរ ទំព័រ ១៣ បន្ទាត់ ១២។ (សាក្សីបានពន្យល់ថា ទោះបីជាគាត់បានឃើញអ្នកទាំងនោះនៅ ក-៣ យ៉ាងណាក្តី "តែពួកគេរស់នៅកន្លែងផ្សេងៗគ្នា" ហើយក៏មិនជួបគ្នារាល់ថ្ងៃនោះដែរ ព្រោះម្នាក់ៗមានការងាររៀងៗខ្លួន)។

ថា ខៀវ សំផន ដឹងគ្រប់យ៉ាងបានទេ[3247] ហើយទស្សនៈនេះក៏ត្រូវបានបដិសេធដោយភស្តុតាងពាក់ព័ន្ធនឹងមធ្យោបាយទាក់ទងផងដែរ[3248]។

## ផ្នែកទី ២. កំហុសពាក់ព័ន្ធនឹងការចុះទស្សនកិច្ចនៅតាមការដ្ឋាន

១៦៨៦. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយបានសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបាន "ធ្វើដំណើរទៅទីជនបទនៃប្រទេសកម្ពុជា ដើម្បីពិនិត្យមើលការដ្ឋាននានា ក្នុងអំឡុងរបបកម្ពុជា ប្រជាធិបតេយ្យ" ទុកដូចជាទម្លាប់ជារឿយៗ[3249]។ ប៉ុន្តែ អង្គជំនុំជម្រះបានយោងដល់ការអម "ព្រះរាជដំណើរ" សម្តេច សីហនុ ដោយ ខៀវ សំផន តែម្តងគត់ ជាពិសេស ទៅពិនិត្យមើលការដ្ឋានទំនប់ត្រពាំងថ្ម[3250]។ ផ្ទុយទៅវិញ របៀបរៀបចំដំណើរទស្សនកិច្ចទាំងនេះមិនអាចឱ្យសន្និដ្ឋានថា "ខៀវ សំផន បានសង្កេតមើលលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារយ៉ាងលំបាកវេទនាបំផុតរបស់កម្មករ-កសិករ ដូចជា រួមទាំងការការអត់ឃ្លាន ជំងឺ និងការស្លាប់"[3251]។

១៦៨៧.ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានបំភ្លេចចោលនូវព្រះរាជបន្ទូលរបស់ សម្តេច សីហនុ ក្នុងកិច្ចសម្ភាសន៍មួយ មិនយូរប៉ុន្មាន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ៖ "ជាមួយនឹង ខៀវ សំផន ខ្ញុំមើលស្រែ មើលសហករណ៍ មើលជំរំការងារ ពួកគាត់ធ្វើការ ហើយយើងមើលទៅដូចថា មិនមានការភ័យខ្លាច អត់មានការហូបចុកខ្វះ មិនគ្រប់គ្រាន់អីទេ គឺមើលទៅដូចជាសុខភាពល្អ"[3252]។ យើងអាចមិនផ្តល់ការជឿជាក់ដល់បទអន្តរាគមន៍តាមប្រព័ន្ធផ្សព្វផ្សាយបាន។ ប៉ុន្តែ សាក្សី ហេង សាមួត ជាអ្នកធ្វើការនៅទំនប់

---

[3247] សំអាងហេតុសាលក្រម កថាខណ្ឌ៥៨៩ កំណត់សម្គាល់ជើងទំព័រលេខ ៤៨៤៦។

[3248] ជាឧទាហរណ៍ សូមមើលសំអាងហេតុសាលក្រម កថាខណ្ឌ៣៩១២។ សូមមើលខាងលើ កថាខណ្ឌ ១៦២៤-១៦២៥, ១៦៥០-១៦៥១។

[3249] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩០ កំណត់សម្គាល់ជើងទំព័រលេខ១៨៤៩ ដល់កថាខណ្ឌ ៦០៦។

[3250] សំអាងហេតុសាលក្រម កថាខណ្ឌ៦០៦។

[3251] សំអាងហេតុសាលក្រម កថាខណ្ឌ៤៣១៤។

[3252] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល៖ ប្រតិចារិក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E1/234.1** ចន្លោះម៉ោង 10.58.52 និងម៉ោង 11.01.47។

ត្រពាំងថ្ម បានពន្យល់ថា ពេលទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ នៅការដ្ឋាន គេដាក់អ្នកល្អ អ្នកធាត់ៗឱ្យនៅឈរពីមុខ ហើយចម្លើយនេះត្រូវបានបញ្ជាក់អះអាងពីសាក្សីផ្សេងទៀត[3253]។

១៦៨៨. ជាចុងក្រោយ និងជាពិសេស អង្គជំនុំជម្រះគួរណាតែទាញផលវិបាកពីការកត់សម្គាល់ផ្ទាល់របស់ខ្លួន អំពីការមិនអាចសន្និដ្ឋានបានថា ខៀវ សំផន មានវត្តមាន នៅតាមការដ្ឋានជាច្រើន ដែលជាកម្មវត្ថុនៃ សំណុំរឿង ០០២/០២[3254]។ មុខងារមានកម្រិតរបស់គាត់បង្ហាញថា ការធ្វើដំណើរក្នុងប្រទេសក៏ត្រូវ បានកម្រិតផងដែរ។

១៦៨៩. សេចក្តីសន្និដ្ឋានខុសរបស់អង្គជំនុំជម្រះអំពី "ការនៅកៀក" នឹង "មេដឹកនាំ ប.ក.ក" និងការធ្វើដំណើរ ដ៏កម្ររបស់គាត់នៅក្នុងប្រទេស មិនអាចយកមកប្រើជាមូលដ្ឋាន ដើម្បីទម្លាក់ឱ្យគាត់ទទួលខុសត្រូវ ក្នុងក្របខ័ណ្ឌនៃសហឧក្រិដ្ឋកម្មរួម ឬការជួយជំរុញនោះឡើយ។ សេចក្តីសន្និដ្ឋានផ្ទុយពីនេះរបស់អង្គ ជំនុំជម្រះ នឹងត្រូវទុកជាមោឃៈ[3255]។

## ជំពូកទី ៣. កំហុសពាក់ព័ន្ធនឹងតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## ផ្នែកទី ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា

១៦៩០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា "ការភ្ជាប់ ខៀវ សំផន [ទៅនឹង សមាជជាតិពិសេស នៅខែមេសា និងខែធ្នូ ឆ្នាំ១៩៧៥ និងសមាជរបស់រណសិរ្សរួបរួមជាតិកម្ពុជា នៅ ខែកុម្ភៈ ឆ្នាំ១៩៧៥] ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាអ្នក តំណាងរណសិរ្សរួបរួមជាតិកម្ពុជា និងតួនាទីផ្សេងទៀតនេះ បានជួយប្រកបដោយប្រសិទ្ធភាពក្នុងការ

---

[3253] <u>ម៉ម សឿម ហៅ ហេង សាមុត</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** មុនម៉ោង 15.38.45។ សាក្សីផ្សេងទៀត៖ សូមមើលខាងក្រោម កថាខណ្ឌ ១៨៤៣។

[3254] សូមមើលខាងលើ កថាខណ្ឌ ១៦០៥-១៦០៩។

[3255] សំអាងហេតុសាលក្រម កថាខណ្ឌ៤៣០៦, ៤៣១៣-៤៣១៨។

ធ្វើឱ្យគោលនយោបាយរបស់ ប.ក.ក មានធម្មានុរូប នៅលើឆាកអន្តរជាតិ"[3256]។ ជាដំបូង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយកការចូលរួមរបស់ ខៀវ សំផន ក្នុងសមាជ មកប្រើជាភស្តុតាងដាក់បន្ទុក ខណៈដែលអង្គជំនុំជម្រះបានសន្និដ្ឋានថា "ពុំមានភាពច្បាស់លាស់ទេថា តើកិច្ចប្រជុំក្នុងខែមេសា និងខែធ្នូ ឆ្នាំ១៩៧៥ នោះពិតជាបានធ្វើឡើងមែន ឬមិនមែន"[3257]។ បើគ្មានភស្តុតាងបង្ហាញថា សមាជទាំងនោះពិតជាបានធ្វើឡើងមែន ឬមិនមែន អង្គជំនុំជម្រះមិនអាចសន្និដ្ឋានយ៉ាងឡូស៊ិកថា ម្ចាស់បណ្តឹងសាទុក្ខបានជួយធ្វើឱ្យ "គោលនយោបាយរបស់ ប.ក.ក មានធម្មានុរូប នៅលើឆាកអន្តរជាតិ"[3258] បានឡើយ។ ដោយសារហេតុផលដូចគ្នានេះ អង្គជំនុំជម្រះក៏មិនអាចសន្និដ្ឋានបានដែរថា ភស្តុតាងបង្ហាញថា សមាជមិនច្បាស់លាស់ទាំងនេះឆ្លុះបញ្ចាំងអំពីមាគ៌ានយោបាយរបស់ ប.ក.ក នៅសម័យនោះ[3259]។ បើគ្មានភាពច្បាស់លាស់ ការកត់សម្គាល់អំពីការមិនអាចសន្និដ្ឋានថាសមាជទាំងនេះត្រូវបានធ្វើឡើងមែន ឬមិនមែន គួរណាតែនាំឱ្យអង្គជំនុំជម្រះចៀសវាងការទាញសេចក្តីសន្និដ្ឋានណាមួយលើប្រធានបទនេះ។

១៦៩១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំ ឬសន្និបាតធំៗ ជាមួយកម្មាភិបាលយោធា នៅទីក្រុងភ្នំពេញ[3260]។ ប៉ុន្តែ ការពិនិត្យដោយមិនលម្អៀងទៅលើភស្តុតាងគាំទ្រដល់សេចក្តីសន្និដ្ឋាននេះ បង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខមានវត្តមានតែក្នុងមិទ្ទីងឆ្នាំ១៩៧៥ ម្តងគត់ ដោយសារតែគាត់មានមុខតំណែងឧបកិច្ចជាមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា[3261]។ ម្យ៉ាងវិញទៀត ការសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខបាន "ផ្សព្វផ្សាយជាសាធារណៈ បានបញ្ជាក់ និងគាំទ្រគោលបំណងរួម" ក្នុងក្របខ័ណ្ឌនេះ ក៏មានកំហុសឆ្គងផងដែរ យោងតាមបរិបទ

---

[3256] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៣។

[3257] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៣។

[3258] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៣។

[3259] សំអាងហេតុសាលក្រម កថាខណ្ឌ៣៧៣៥ និង កំណត់សម្គាល់ជើងទំព័រលេខ១៣៩០៨ (នៃកថាខណ្ឌ ៤២៦២)។

[3260] សំអាងហេតុសាលក្រម កថាខណ្ឌ ៥១០។

[3261] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៥៩៦ ដែលនៅទីនោះអង្គជំនុំជម្រះបានប្រើប្រាស់ការផ្តល់សក្ខីកម្មរបស់ ឆោម សែ និង ចម្លើយរបស់ ប្រាក់ យឿន និង កុយ ម៉ុន។ សូមមើលខាងក្រោម កថាខណ្ឌ ១៧២៤។

ប្រវត្តិសាស្ត្រ[3262]។ ជាក់ស្តែង ដូចបានឃើញ ក្នុងសំណុំរឿង ០០២/០១ រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានសមាសភាពផ្សេងៗ ក្រោមការដឹកនាំរបស់ សម្តេច សីហនុ[3263]។ ប្រសិនបើយើងដើរតាមឡូស៊ិករបស់អង្គជំនុំជម្រះ ការចូលរួមរបស់ សម្តេច សីហនុ ក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺស្មើនឹង សម្តេច សីហនុ គាំទ្រដល់មាគ៌ានយោបាយរបស់ ប.ក.ក ក្នុងពេលនោះ និងគាំទ្រដល់គោលបំណងរួម។ យើងឃើញច្បាស់អំពីដែនកំណត់នៃវិចារណកិច្ចនេះ។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចទាញសេចក្តីសន្និដ្ឋានបែបនេះឡើយ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការវាយតម្លៃលើភ័ស្តុតាង និងបរិបទនយោបាយ នៅសម័យនោះ។ សេចក្តីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះ ដែលផ្អែកលើវិចារណកិច្ចនេះ នឹងត្រូវទុកជាមោឃៈ[3264]។

## ផ្នែកទី ២. ប្រធានគណៈប្រធានរដ្ឋ

១៦៩២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុជាច្រើន ពាក់ព័ន្ធនឹងអង្គការចាត់តាំង (១) មុខងារ និងការទទួលខុសត្រូវ (២) និងសុន្ទរកថារបស់ ខៀវ សំផន (៣) ដើម្បីសន្និដ្ឋានអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ ដោយសារតែមុខតំណែងជាប្រធានគណៈប្រធានរដ្ឋ[3265]។

[3262] សំអាងហេតុសាលក្រម កថាខណ្ឌ *(១៨.២.១.២. ការលើកកម្ពស់គោលបំណងរួម)*។ សូមមើលផងដែរ កថាខណ្ឌ៣៧៣៥ ("លោក ខៀវ សំផន បានដឹកនាំសមាជជាតិ ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥") និង ៣៨៩៧ ("លោក ខៀវ សំផន នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ បានធ្វើជាអធិបតីក្នុងពិធីសមាជជាតិមួយ ដែលគាត់បានបង្ហាញរដ្ឋធម្មនុញ្ញថ្មី")។

[3263] សាលក្រម ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៩៨។ សូមមើលផងដែរ របាយការណ៍របស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ក្រោមចំណងជើងថា៖ "អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ" ឆ្នាំ១៩៧៣ ឯកសារ **E3/28** ទំព័រ ១០, ១៣ ERN FR 00068109-10, ទំព័រ ២៣-២៩ ERN FR 00068118។

[3264] សំអាងហេតុសាលក្រម កថាខណ្ឌ៥៥៩៣, ៣៧៣៥, ៣៨៩៧, ៤២៦២, ៤៣០៦-៤៣០៨។

[3265] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩០-៥៩៩ និង ៤២៤១-៤២៤៣, ៤២៥៣, ៤២៥៧, ៤២៦២-៤២៦៤, ៤២៦៥-៤២៧០, ៤២៧១, ៤២៧៣, ៤២៨១, ៤៣១៤, ៤៣៨៩។

## ១. កំហុសពាក់ព័ន្ធនឹងការចាត់តាំង

១៦៩៣. ដូចយើងនឹងបង្ហាញខាងក្រោម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានរកឃើញថា គណៈមជ្ឈិមជាអ្នកចាត់តាំង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ប៉ុន្មានថ្ងៃ មុនពេល សម្តេច សីហនុ លាលែងពីតំណែង ដោយផ្អែកលើឯកសារតែមួយគត់ ដែលមានចំណងជើងថា "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[3266]។ ប៉ុន្តែ អង្គជំនុំជម្រះបានទទួលស្គាល់ថា ក្រោយពីរដ្ឋាភិបាលថ្មីត្រូវបានបង្កើតឡើង "រដ្ឋមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកក្រសួង រាយការណ៍ និងទទួលការណែនាំពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃ ប.ក.ក"[3267]។ ការសន្និដ្ឋាននេះគាំទ្រដល់ទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា ការសម្រេចតែងតាំងចេញមកពីគណៈអចិន្ត្រៃយ៍។ កំហុសនេះបណ្តាលឱ្យមានយុត្តិនិសេធ និងត្រូវបដិសេធចោល។

## ២. កំហុសពាក់ព័ន្ធនឹងមុខងារ និងការទទួលខុសត្រូវ

១៦៩៤. ម្យ៉ាងវិញទៀត ទោះបីជាមានការទទួលស្គាល់ តាំងពីសំណុំរឿង ០០២/០១ ថា មុខតំណែងផ្លូវការរបស់ ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ គ្រាន់តែជា "តួនាទីដែលមានលក្ខណៈជានិមិត្តរូបភាគច្រើន"[3268] ក៏ដោយ ក៏អង្គជំនុំជម្រះនៅតែប្រើមុខតំណែងនេះមកដាក់បន្ទុកលើរូបគាត់។ អង្គជំនុំជម្រះធ្វើមិនដឹងមិនឮនឹងការមិនទុកចិត្តគាត់ពីសំណាក់ ប.ក.ក ដែលស្តែងឡើងតាមរយៈការមិនកាន់មុខតំណែងក្នុងគណៈប្រធានរដ្ឋតែម្នាក់ឯង គឺអមដោយកម្មាភិបាលសំខាន់ពីររូបទៀតដែលមានឋានៈខ្ពស់ជាងគាត់ ក្នុង ប.ក.ក (គឺ សោ ភឹម និង រស់ ញឹម ជាអនុប្រធានគណៈប្រធានរដ្ឋ) ខុសពីករណីរបស់

[3266] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៦, ៩១៤។ សូមមើលខាងក្រោម កថាខណ្ឌ ១៧១៧។ សូមមើលផងដែរ កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/197** ERN 00000747 (ប៉ុល ពត បានសម្រេច បន្ទាប់ពីសម្តេច សីហនុ សុំលាលែងពីតំណែង ជាមួយនឹងការព្រមព្រៀងរបស់គណៈអចិន្ត្រៃយ៍)។ Philip SHORT៖ ប្រតិចារឹក ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ម៉ោង 11.58.16 (កិច្ចប្រជុំគណៈមជ្ឈិមកម្រធ្វើឡើងណាស់ ហើយការប្រជុំមានបំណងគ្រាន់តែទទួលយកសេចក្តីសម្រេចដែលបានកំណត់ដោយគណៈអចិន្ត្រៃយ៍)។

[3267] សំអាងហេតុសាលក្រម កថាខណ្ឌ ៩១៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3268] សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៣៨១។ សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៩។

សម្តេច សីហនុ ជា "ប្រមុខរដ្ឋ"[3269]។ ការមិនទុកចិត្តនេះស្តែងចេញ តាមរយៈការទើបដំឡើងគាត់ជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម នៅឆ្នាំ១៩៧៦ គឺក្នុងឆ្នាំតែមួយដែលគាត់ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ខណៈដែលគាត់ជាសមាជិកត្រៀមតាំងពី ៥ ឆ្នាំមុន[3270]។

១៦៩៥. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានយល់ឃើញថា នៅក្នុងក្របខ័ណ្ឌនៃតួនាទីនេះ ការទទួលខុសត្រូវរបស់គាត់កម្រិតជាសំខាន់ត្រឹមភារកិច្ចការទូត និង "ការផ្សព្វផ្សាយទូទៅអំពីមាគ៌ា ប.ក.ក" ជាអាទិ៍ តាមរយៈសុន្ទរកថាថ្លែងក្នុងន័យនេះ[3271]។ ជាក់ស្តែង គាត់បានគាំទ្រដល់ ប.ក.ក និងគោលនយោបាយបក្ស[3272] ឯកភាព និងលើកកម្ពស់គោលបំណងរបស់បក្ស សំដៅកសាង និងការពារប្រទេស ខ្លួនទីពឹងខ្លួន មហាលោតផ្លោះ មហាអស្ចារ្យ[3273] ព្រមទាំងអំពាវនាវឱ្យមហាជនធ្វើការរួមគ្នានៅតាមវាលស្រែ និងរោងចក្រ ដើម្បីបង្កើនផលិតកម្ម និងការពារប្រទេស...[3274]។

១៦៩៦. ប៉ុន្តែ អង្គជំនុំជម្រះបានជ្រើសយកការអះអាងថា គាត់មានភារកិច្ចជួយ "ផ្សព្វផ្សាយទូទៅអំពីមាគ៌ា ប.ក.ក" ដោយមិនពន្យល់ថា តើអ្វីទៅជា "មាគ៌ា ប.ក.ក" ដែលមិនមានលក្ខណៈឧក្រិដ្ឋទេ បើតាមន័យទូទៅនៃពាក្យនេះ។ ដូចអង្គជំនុំជម្រះបានទទួលស្គាល់តាមក្រោយថាគោលនយោបាយមិនមានលក្ខណៈឧក្រិដ្ឋទេ ខុសពីការអនុវត្ត[3275]។

---

[3269] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៦ កំណត់សម្គាល់ជើងទំព័រលេខ១៨០៨។

[3270] លោកត្រូវបានតែងតាំងជាបេក្ខជនសមាជិក នៅឆ្នាំ១៩៧០ នៅក្នុងឆ្នាំតែមួយដែលលោកត្រូវបានតែងតាំង នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលសុទ្ធតែមិនមែនជារឿងចៃដន្យឡើយ។ ហើយបើទោះបីជាគាត់បានចូលព្រៃម៉ាគីនៅឆ្នាំ១៩៦៧ ក្តី តែលុះដល់២ឆ្នាំក្រោយមក ទើបលោកត្រូវបានតាម៉ុក ទទួលឱ្យចូលជាសមាជិកបក្ស។

[3271] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៩។

[3272] សំអាងហេតុសាលក្រម កថាខណ្ឌ៤២៥៧។

[3273] សំអាងហេតុសាលក្រម កថាខណ្ឌ៤២៦២។

[3274] សំអាងហេតុសាលក្រម កថាខណ្ឌ៤២៦៥។

[3275] សំអាងហេតុសាលក្រម កថាខណ្ឌ៣៧៤៣។

១៦៩៧. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានសន្និដ្ឋានថា តាមរយៈមុខងារជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បាន "ទទួល" លិខិតពីអង្គការលើកលែងទោសអន្តរជាតិ ខណៈដែលនៅក្នុងកថាខណ្ឌដដែលនោះ អង្គជំនុំជម្រះបានទទួលស្គាល់ថា តំណែងរបស់គាត់គ្រាន់តែជាតំណែងឧបកិច្ច[3276]។ ប៉ុន្តែ ពុំមានភស្តុតាងបង្ហាញថា គាត់បានទទួលលិខិតទាំងនេះទេ[3277]។

## ៣. កំហុសពាក់ព័ន្ធនឹងសុន្ទរកថា

១៦៩៨. ចំពោះសុន្ទរកថាផ្សេងៗ ដែលត្រូវបានសន្មតថា ខៀវ សំផន ជាអ្នកថ្លែង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយបានយកមកធ្វើជាភស្តុតាងគាំទ្រដល់ការបង្កើតរដ្ឋថ្មី និង/ឬឯកភាពលើគោលនយោបាយរបស់ ប.ក.ក និង/ឬថ្កោលទោសការឈ្លានពានពីសំណាក់វៀតណាម[3278]។

### ៣.១. សុន្ទរកថាដែលត្រូវបានសន្មតខុសថា ខៀវ សំផន ជាអ្នកថ្លែង

១៦៩៩. អង្គជំនុំជម្រះបានសន្មតថា ខៀវ សំផន ជាអ្នកថ្លែងសុន្ទរកថាថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៦ (សុន្ទរកថាទី ១ ក្រោយពីតែងតាំងជាប្រធានគណៈប្រធានរដ្ឋ) ដើម្បី "គាំទ្រការបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យថ្មី និងស្ថាប័ននានា"[3279]។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រើប្រាស់សុន្ទរកថាដដែលនេះម្តងទៀត ដើម្បីកត់សម្គាល់ថា "គោលបំណងនៃការសម្រេចបាននូវមហាលោតផ្លោះ មហាអស្ចារ្យ ត្រូវបានជំរុញជាថ្មីម្តងទៀតដោយ ខៀវ សំផន" ហើយគាត់បាន "អនុម័តអាទិភាពនៃការកសាង និងការពារប្រទេស ដោយឯករាជ្យ ខ្លួនទីពឹងខ្លួន ឱ្យបានឆាប់រហ័ស"[3280]។

---

[3276] សំអាងហេតុសាលក្រម កថាខណ្ឌ៤០៤៨។

[3277] សូមមើលខាងក្រោម កថាខណ្ឌ ១៧៩៩-១៨០៣។

[3278] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៨។

[3279] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៨ កំណត់សម្គាល់ជើងទំព័រលេខ ១៨៧៧, ៣៧៣៩។ ឯកសារទាក់ទងនឹងសម័យប្រជុំលើកទី១ នៃសភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/165**។

[3280] សំអាងហេតុសាលក្រម កថាខណ្ឌ៣៧៣៩។

១៧០០. ប៉ុន្តែ ការសន្មតនេះខុសទាំងស្រុង និងត្រូវបានទុកជាមោឃៈរួចមកហើយ នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១[3281]។ មិនមានការចង្អុលបង្ហាញថា ឈ្មោះ ខៀវ សំផន ឬ ប្រធានគណៈប្រធានរដ្ឋ ជាអ្នកថ្លែងសុន្ទរកថាទេ[3282]។ អាស្រ័យហេតុនេះ ការអះអាងពីអង្គជំនុំជម្រះថា ខៀវ សំផន បានថ្លែងសុន្ទរកថា និងគាំទ្រដល់ការបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យថ្មី និងស្ថាប័ននានា។ល។ ត្រូវទុកជាមោឃៈ។

១៧០១. ឧទាហរណ៍មួយទៀតនៃសម្តី ដែលត្រូវបានសន្មតថា ខៀវ សំផន ជាអ្នកនិយាយ ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ គឺនៅក្នុងឯកសារ ចុះខែកញ្ញា ឆ្នាំ១៩៧៦ ដែលអង្គជំនុំជម្រះយកមកប្រើ ដើម្បីទម្លាក់ការទទួលខុសត្រូវលើគាត់[3283]។ ប៉ុន្តែ អង្គជំនុំជម្រះមិនអាចផ្អែកលើឯកសារសង្ស័យមួយនេះ ដែលគ្មានការបញ្ជាក់បន្ថែម និងត្រូវបានសាក្សីម្នាក់ពន្យល់ថាជាកិច្ចសម្ភាសន៍ក្លែងក្លាយថែមទៀតផង[3284]។

## ៣.២. សុន្ទរកថាផ្សេងទៀត

១៧០២. ដើម្បីគាំទ្រដល់ការសន្និដ្ឋានអំពីសុន្ទរកថា ខៀវ សំផន ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ អង្គជំនុំជម្រះបានប្រើប្រាស់សុន្ទរកថាមួយ នៅខែមករា ឆ្នាំ១៩៧៦ ស្តីពីសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មី ខណៈដែល

---

[3281] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០២៣។

[3282] ឯកសារស្តីពីមហាសន្និបាតលើកទី១ នីតិកាលទី១នៃសភាតំណាងប្រជាជនកម្ពុជា ចុះថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/165**។ សេចក្តីថ្លែងការណ៍សារព័ត៌មាននៃសម័យប្រជុំពេញអង្គ នីតិកាលទី១នៃសភាតំណាងប្រជាជនកម្ពុជា ចុះថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/262**។ សូមមើលខាងលើផងដែរ កថាខណ្ឌ ១៩២១។

[3283] ជាឧទាហរណ៍ សូមមើល៖ សំអាងហេតុសាលក្រម កថាខណ្ឌ៤២៤១ និង កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៤៤ កថាខណ្ឌ៤២៥៣ និង កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៧៥ (ឯកសារ **E3/608**)។

[3284] ជាឧទាហរណ៍ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ១៣៨៤៤ (នៃកថាខណ្ឌ ៤២៤១) កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៧៥ (នៃកថាខណ្ឌ៤២៥៣)។ សវនាការស្តីពីឯកសារគន្លឹះ៖ ប្រតិចារឹក ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ **E1/518.1** ក្រោយម៉ោង 11.14.48 នៅក្នុងពេលនោះ មេធាវីការពារក្តីបានរំឭកថា លោក François PONCHAUD បានអះអាងក្នុងសវនាការនេះថា គឺជាបទសម្ភាសន៍ "បំភ្លៃ" ទេ។

គាត់នៅកាន់តំណែងជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា[3285]។ អង្គជំនុំជម្រះបានប្រើប្រាស់សុន្ទរកថាទាំងបី ដែលត្រូវបានផ្សព្វផ្សាយ ក្នុងឱកាសប្រារព្ធខួបជ័យជម្នះ ១៧ មេសា[3286] និងសុន្ទរកថាថ្លែង ក្រោយពីផ្ទុះសង្គ្រាមព្រំដែនជាមួយវៀតណាម ដែលកាន់តែមានសភាពខ្លាំងក្លាឡើង[3287] ក្នុងលក្ខណៈលម្អៀង និងមិនគ្រប់ជ្រុងជ្រោយ នៅក្នុងសេចក្តីសន្និដ្ឋានអំពីគោលបំណងរួម[3288]។ ផ្ទុយទៅវិញ សុន្ទរកថាទាំងនេះមិនអាចឱ្យសន្និដ្ឋានអំពីការឯកភាព ឬគាំទ្ររបស់ ខៀវ សំផន ដល់ទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម ឬអំពីការដឹងរបស់គាត់នូវឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ឡើយ[3289]។ ម្យ៉ាងវិញទៀត កំហុសរបស់អង្គជំនុំជម្រះអំពីសុន្ទរកថាទាំងនេះ ត្រូវបានអត្ថាធិប្បាយលម្អិតនៅក្នុងផ្នែកពាក់ព័ន្ធនៃសារណានេះ។

១៧០៣. សរុបសេចក្តីមក កំហុសអង្គហេតុរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ដោយសារតែមុខតំណែងជាប្រធានគណៈប្រធានរដ្ឋ និងការពិចារណាយកតំណែងឧបកិច្ចនេះមកធ្វើជាស្ថានទម្ងន់ទោស បណ្តាលឱ្យមានយុត្តិនិសេធ និងត្រូវទុកជាមោឃៈ។

## ផ្នែកទី ៣. "សមាជិក" គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍

១៧០៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានយល់ឃើញថា ខៀវ សំផន ស្ថិតនៅក្នុងចំណោមសមាជិក ប.ក.ក មួយក្រុមតូច "ដែលទទួលបានព័ត៌មានពេញលេញ" ដោយហេតុថាគាត់នៅក្នុង

---

[3285] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៨៧៨ នៃកថាខណ្ឌ៥៩៨ បទយកការណ៍នៃទីក្រុងភ្នំពេញ ស្តីពីសមាជជាតិលើកទី៣៖ របាយការណ៍របស់ លោក ខៀវ សំផន (FBIS) ចុះថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ឯកសារ **E3/273**។

[3286] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៨៧៦-១៨៨០ នៃកថាខណ្ឌ ៥៩៨។

[3287] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៨៨០ នៃកថាខណ្ឌ ៥៩៨។

[3288] ឧទាហរណ៍ សូមមើលសំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៣៤, ៣៧៧៣, ៣៨០៧, ៣៨២៣, ៣៨៥៧, ៣៩០៩, ៣៩១៦, ៣៩៦០, ៣៩៧០។

[3289] ជាឧទាហរណ៍ សារៈសំខាន់នៃការកែលម្អជីវភាពរស់នៅរបស់ប្រជាជន និង ការអនុវត្តដែលបញ្ជាក់ថាមិនមែនជាការងារដោយបង្ខំ និងការធ្វើទៅជារបបទាសភាពនោះទេ៖ "ការប្រារព្ធខួបជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ (FBIS) ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/275** ERN 00896397។ "សុន្ទរកថារបស់ខៀវសំផននៅកិច្ចប្រជុំគម្រប់ខួប" (SWB) ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/201** ERN 00292806-07។

គណៈមជ្ឈិម និងមាន "តួនាទីពិសេស" ក្នុងបក្ស ដោយសារតែ "វត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំមួយចំនួន" របស់គណៈអចិន្ត្រៃយ៍ ដែល "ពិភាក្សា និងសម្រេចលើបញ្ហាសំខាន់ៗ"[3290] ដើម្បីបង្ហាញបង្ហាញអំពីការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[3291]។

១៧០៥. ជាដំបូង ខៀវ សំផន ជាសមាជិកត្រៀម រួចជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិម ប៉ុន្តែ មិនធ្លាប់ជាសមាជិកគណៈអចិន្ត្រៃយ៍ទេ។ អង្គជំនុំជម្រះបានទទួលស្គាល់ថា "ទោះបីជាលក្ខន្តិកៈ ប.ក.ក ផ្តល់អំណាចប្រតិបត្តិការខ្ពស់បំផុតទៅឱ្យគណៈកម្មាធិការមជ្ឈិមក៏ដោយ ក៏ការត្រួតពិនិត្យពិតប្រាកដទៅលើ ប.ក.ក ត្រូវបានអនុវត្តដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណៈកម្មាធិការមជ្ឈិម"[3292]។ ផ្ទុយនឹងសេចក្តីសន្និដ្ឋាននេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដើម្បីផ្តន្ទាទោស ខៀវ សំផន ដោយសារតែសមាជិកភាពរបស់គាត់ក្នុងគណៈមជ្ឈិម (១) និងវត្តមានរបស់គាត់ក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈអចិន្ត្រៃយ៍ (២) ជាអាទិ៍ ដោយសារតែប្រជាធិបតេយ្យប្រមូលផ្តុំ (៣)។

## ១. សមាជិកភាពក្នុងគណៈមជ្ឈិម

១៧០៦. ដើម្បីប៉ុនប៉ងផ្សារភ្ជាប់ ខៀវ សំផន ទៅនឹងឧក្រិដ្ឋកម្ម អង្គជំនុំជម្រះបានពង្រីកសិទ្ធិអំណាចរបស់គណៈមជ្ឈិម (១.១) ដែលអង្គជំនុំជម្រះបានសន្មតថាជាអ្នកធ្វើសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ (១.២) បានកំណត់កាលបរិច្ឆេទចូលជាសមាជិកពេញសិទ្ធិរបស់គណៈមជ្ឈិម (១.៣) និងបានកំណត់ថាគាត់បានចូលរួមក្នុងមហាសន្និបាត ដោយគ្មានភស្តុតាង (១.៤)។

### ១.១. កំហុសពាក់ព័ន្ធនឹងវិសាលភាពនៃមុខងារ និងសិទ្ធិអំណាចរបស់គណៈមជ្ឈិម

[3290] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៤ និង ៦២៤។

[3291] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៦-៤២៣៨។

[3292] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧។ សូមមើលផងដែរ កថាខណ្ឌ ៣៤៦៖ "ដូចកត់សម្គាល់នៅក្នុងផ្នែកខាងក្រោម គណៈកម្មាធិការអចិន្ត្រៃយ៍គឺជាស្ថាប័នសម្រេចកំពូលរបស់ ប.ក.ក"។

១៧០៧. ជាបឋម ទន្ទឹមនឹងការលើកឡើងថា ថ្នាក់មួយទៀត ក្រៅពីសមាជិកគណៈមជ្ឈិម មិនមានចែងនៅក្នុងលក្ខន្តិកៈ ប.ក.ក ទេ អង្គជំនុំជម្រះបានផ្អែកលើ "សេចក្ដីបញ្ជាក់" របស់ ឌុច ដើម្បីសន្និដ្ឋានថា សមាជិកគណៈមជ្ឈិម "និងសមាជិកត្រៀម" មានប្រមាណពី ២០ ទៅ ៣០ នាក់[3293]។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបែបនេះ ដោយគ្មានការពន្យល់នោះទេ ជាពិសេស យោងតាមការមិនដឹងរបស់ ឌុច អំពីអង្គហេតុលើប្រធានបទនេះ ដោយហេតុថា ឌុច មិនធ្លាប់ជាសមាជិកគណៈមជ្ឈិម និងមិនធ្លាប់ចូលរួមប្រជុំគណៈមជ្ឈិម (ដូចគ្នាផងដែរ ចំពោះគណៈអចិន្ត្រៃយ៍)[3294]។

១៧០៨. បន្ទាប់មកទៀត អង្គជំនុំជម្រះបានផ្អែកតែលើកំណត់ហេតុសរសេរដៃនៃលក្ខន្តិកៈ ឆ្នាំ១៩៧១ ដោយមិនស្គាល់អ្នកសរសេរ ដើម្បីអះអាងថា គណៈមជ្ឈិមមានអំណាចតែងតាំង[3295] ខណៈដែលអង្គជំនុំជម្រះធ្លាប់បានអះអាងថា អង្គជំនុំជម្រះនឹងលើកយកខ្លឹមសារនៃកំណត់ហេតុនេះមកធ្វើជាសំអាង តែក្នុងករណីខ្លឹមសារទាំងនោះត្រូវបានគាំទ្រដោយភស្តុតាងផ្សេងទៀតប៉ុណ្ណោះ[3296]។

១៧០៩. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានផ្អែកលើលក្ខន្តិៈ ប.ក.ក ដើម្បីអះអាងថាគណៈមជ្ឈិមមានភារកិច្ចត្រួតពិនិត្យការអនុវត្តគោលនយោបាយបក្ស និងផ្អែកលើសៀវភៅរបស់ ខៀវ សំផន ដែលបាន "ទទួលស្គាល់" ថា គណៈមជ្ឈិម "បានចេញសេចក្ដីបង្គាប់នានា"[3297]។ អង្គជំនុំជម្រះបានជឿជាក់ថា ទូរលេខ

---

[3293] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦។

[3294] ជាឧទាហរណ៍ ឌុច៖ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ទំព័រ ៣-៤ ចន្លោះម៉ោង 09.03.13 និងម៉ោង 09.08.33។ ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/57.1** មុនម៉ោង 11.13.54 ("សម្រាប់រូបខ្ញុំ មិនដែលបានចូលទៅប្រជុំជាមួយនឹងអចិន្ត្រៃយ៍ ឬជាមួយមជ្ឈិមទេ")។ ប្រតិចារឹក ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/60.1** ចាប់ពីម៉ោង 13.34.55 (មានបញ្ហានៃការបកប្រែជាភាសាបារាំង សូមមើលជាភាសាខ្មែរ ទំព័រ ៥១ បន្ទាត់ ៨-៩៖ បក្ខជនធម្មតាមិនចូលរួមប្រជុំជាមួយគណៈមជ្ឈិមទេ ហើយកាន់តែមិនមានសិទ្ធិប្រើប្រាស់ឯកសារនៃកិច្ចប្រជុំគណៈកម្មាធិការ) ក្រោយម៉ោង 13.45.15 ("ការធ្វើការងាររបស់អចិន្ត្រៃយ៍មជ្ឈិម។ ឱ្យខ្ញុំដឹងច្បាស់គឺអត់ដឹងទេ ក៏ប៉ុន្តែជាគោលការណ៍គឺដឹង ព្រោះមេខ្ញុំប្រាប់")។ ប្រតិចារឹក ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/61.1** ក្រោយម៉ោង 09.40.52 ក្រោយម៉ោង 09.47.10។

[3295] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧។

[3296] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៤។

[3297] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៥ និង ៦០០។

ផ្ញើជាទៀងទាត់ពីលេខាភូមិភាគដែលរាយការណ៍អំពីសភាពការណ៍ បង្ហាញថាគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ តាមដានការអនុវត្តគោលនយោបាយបក្ស ស្របតាមអាណត្តិរបស់ខ្លួន[3298]។

១៧១០. អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះផ្អែកលើលក្ខន្តិកៈ ខណៈដែលអង្គជំនុំជម្រះបានលើកឡើងអំពីភាពខុសគ្នារវាងទ្រឹស្តីក្នុងលក្ខន្តិកៈ និងការអនុវត្តជាក់ស្តែង[3299]។ អង្គជំនុំជម្រះបានបំភ្លៃសំណេររបស់ ខៀវ សំផន និងមិនបានយកចិត្តទុកដាក់ដល់ចម្លើយរបស់គាត់ ចំពោះមុខចៅក្រមដែលត្រូវបានគាំទ្រដោយភ័ស្តុតាងផ្សេងទៀត ដែលថា គណៈមជ្ឈិម ក្រោមឱវាទគណៈអចិន្ត្រៃយ៍ មិនមានអំណាចពិតប្រាកដនោះទេ គឺគ្រាន់តែជាកន្លែងផ្សព្វផ្សាយសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ប៉ុណ្ណោះ[3300]។

១៧១១. ក្រៅពីនេះទៀត ការពិនិត្យជាសត្យានុម័តិលើទូរលេខទាំងនោះបង្ហាញថា ទូរលេខមិនត្រូវបានផ្ញើជូនគណៈមជ្ឈិមទេ គឺផ្ញើជូន "អង្គការ" ឬ "អង្គការ ៨៧០" ឬ "គណៈ ៨៧០" ដោយចម្លងជូនសមាជិកបួននាក់ដដែលៗនៃគណៈអចិន្ត្រៃយ៍[3301]។ ដូចគ្នាផងដែរ ឯកសារ ដែលអង្គជំនុំជម្រះបានផ្អែកលើ គឺជារបាយការណ៍ប្រចាំថ្ងៃផ្ញើជូនមន្ទីរ ៨៧០ ឬគណៈអចិន្ត្រៃយ៍[3302]។ លើសពីនេះទៀត សាក្សីបានអះអាងថា ទូរលេខត្រូវបានប្រគល់ជូនតែ ប៉ុល ពត និង នួន ជា ប៉ុណ្ណោះ[3303]។

---

[3298] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦៤។ សូមមើលផងដែរ កថាខណ្ឌ ៣៨៩៩។

[3299] ជាឧទាហរណ៍៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧។ ម្យ៉ាងវិញទៀត ថ្វីត្បិតតែនៅក្នុងនៅក្នុងលក្ខន្តិកៈ សភាត្រូវរួមប្រជុំរាល់៤ឆ្នាំម្តង តែនៅក្នុងការអនុវត្ត សភាបានធ្វើសមាជនៅឆ្នាំ ១៩៦០, ១៩៧១, ១៩៧៦ និង ឆ្នាំ១៩៧៨។

[3300] មេធាវីការពារក្តីយោងទៅការពង្រីកសេចក្តីនៅក្នុងសារណាបណ្តឹងសាទុក្ខ ០០២/០១ របស់យើង កថាខណ្ឌ ១២២-១២៣។

[3301] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៣១៨៩-១៣១៩៣ (នៃកថាខណ្ឌ ៣៩៦៤)។ សមាជិកគណៈអចិន្ត្រៃយ៍ដែលបានលើកឡើងនោះ គឺមាន ប៉ុល ពត, នួន ជា, អៀង សារី និងវន វ៉េត។ សូមមើលផងដែរ ទូរលេខ នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ១២៩៩៩ (នៃកថាខណ្ឌ ៣៨៩៩) ដែលផ្ញើទៅ "អង្គការ"។

[3302] ជាឧទាហរណ៍៖ សេចក្តីសម្រេច ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/12** ERN 00224363 (មន្ទីរ ៨៧០)។ កំណត់ហេតុប្រជុំ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** ERN FR 00323936 (គណៈអចិន្ត្រៃយ៍)។

[3303] សូមមើលខាងលើ កថាខណ្ឌ ១៦២៤-១៦២៥។

១៧១២. ជាក់ស្តែង ភស្តុតាងទាំងនេះបង្ហាញផ្ទុយទៅវិញថា គណៈមជ្ឈិមមិនមានតួនាទីតាមដានការអនុវត្ត គោលនយោបាយបក្សទេ ហើយតាមជាក់ស្តែង អំណាចរបស់គណៈមជ្ឈិម ដូចមានចែងជាទ្រឹស្តីក្នុងលក្ខន្តិកៈ ត្រូវបាន "ផ្ទេរ"[3304] ជូនគណៈអចិន្ត្រៃយ៍ (ជាពិសេស ប៉ុល ពត និង នួន ជា)។ ដូច្នេះ អង្គជំនុំជម្រះមិនអាចពង្រីកមុខងាររបស់គណៈមជ្ឈិម រួចសន្និដ្ឋានថា ខៀវ សំផន "ទទួលបានព័ត៌មានពេញលេញ" ឬបានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មទេ[3305]។

## ១.២. កំហុសពាក់ព័ន្ធនឹងការសន្មតសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថាជារបស់គណៈមជ្ឈិម

១៧១៣. ដោយសារ ខៀវ សំផន បានក្លាយជាសមាជិក (បម្រុង) របស់គណៈមជ្ឈិម នៅឆ្នាំ១៩៧១ អង្គជំនុំជម្រះបានសន្មតសេចក្តីសម្រេចសំខាន់ៗរបស់គណៈអចិន្ត្រៃយ៍ថាជារបស់គណៈមជ្ឈិម ក្នុងលក្ខណៈឆ្លៀតឱកាស និងដោយខុសឆ្គង។

១៧១៤. ទីមួយ បើតាមអង្គជំនុំជម្រះ គណៈមជ្ឈិមបានធ្វើសេចក្តីសម្រេចមួយ នៅខែឧសភា ឆ្នាំ១៩៧២ ដើម្បីបិទផ្សារ បញ្ឈប់ការប្រើប្រាស់រូបិយវត្ថុ និងរៀបចំសហករណ៍ នៅតាមតំបន់រំដោះ[3306]។ អង្គជំនុំជម្រះបានផ្អែកតែលើ Philip SHORT និង នួន ជា។ Philip SHORT បាននិយាយពីសេចក្តីសម្រេចរបស់គណៈមជ្ឈិម ឯ នួន ជា បានអះអាងថាជាសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍[3307]។ អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះទទួលយកចម្លើយរបស់អ្នកជំនាញ ជាជាងសក្ខីកម្មផ្ទាល់របស់ នួន ជា ជាសមាជិកគណៈអចិន្ត្រៃយ៍ (ខណៈដែលអង្គជំនុំជម្រះបានធ្វើបញ្ច្រាសទៅវិញ បើសិន

---

[3304] ពាក្យពេចន៍ ដែលអង្គជំនុំជម្រះបានប្រើប្រាស់ ក្នុងសាលក្រម ឧុច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៨៥។

[3305] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៤, ៦២៤, ៣៩១៣, ៤២៥៧, ៤២៥៩, ៤២៦០។

[3306] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣៩ និង ៣៨៧២។

[3307] សំអាងហេតុសាលក្រម កថាខណ្ឌ ២២៧ និងកំណត់សម្គាល់ជើងទំព័រលេខ ៥៣៨ (SHORT ដែលបញ្ជាក់ថាគឺជាគំនិតផ្តួចផ្តើមរបស់ ប៉ុល ពត)។ កថាខណ្ឌ ២៣៩ និងកំណត់សម្គាល់ជើងទំព័រលេខ ៥៧០ (នួន ជា)។

ជាត្រូវដាក់បន្ទុក)[3308]។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់ អាចទម្លាក់ការទទួលខុសត្រូវលើ ខៀវ សំផន ដោយផ្អែកលើមូលដ្ឋាននេះទេ[3309]។

១៧១៥. ទីពីរ ដើម្បីគាំទ្រដល់ការសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយរបស់ ប.ក.ក ប្រឆាំងនឹងខ្មាំង អង្គជំនុំជម្រះបានសន្មតថា នៅពាក់កណ្តាលឆ្នាំ១៩៧៤ គណៈមជ្ឈិមបានសម្រេចឈប់ទទួលបក្ខជនថ្មី ដើម្បីទប់ស្កាត់កុំឱ្យគិញបង្កប់ស៊ីរូងផ្ទៃក្នុងចូលក្នុងជួរបក្ស[3310]។ អង្គជំនុំជម្រះបានផ្អែកដោយមិនសមហេតុផលលើទស្សនាវដ្តី "ទង់បដិវត្ត" បីលេខ ដោយបំភ្លៃខ្លឹមសារ ពីព្រោះមិននិយាយអំពីគណៈមជ្ឈិមទេ គឺ "បក្ស"[3311]។

១៧១៦. ទីបី បើតាមអង្គជំនុំជម្រះ គណៈមជ្ឈិមទៀតជាអ្នកពិភាក្សាអំពីផែនការវាយសម្រុកផ្តាច់ព្រ័ត្រ និងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅខែមិថុនា ឆ្នាំ១៩៧៤[3312]។ អង្គជំនុំជម្រះក៏មិនបានពន្យល់ទៀតថា ហេតុអ្វីបានជាអង្គជំនុំជម្រះទទួលយកសក្ខីកម្មផ្ទាល់របស់ នួន ជា ដែលថា នេះគឺជា "ការប្រជុំគណៈអចិន្ត្រៃយ៍បក្សមិនពេញអង្គមួយ"[3313] ហើយបែរជាមិនទទួលយកទស្សនាវដ្តី "ទង់បដិវត្ត" ដែលលើកឡើងអំពីកិច្ចប្រជុំមួយរបស់គណៈមជ្ឈិមនៅកាលបរិច្ឆេទនេះ ក្នុងចំណោមភស្តុតាងទាំងអស់ដែលអង្គជំនុំជម្រះបានផ្អែកលើ[3314]។

---

[3308] ឧទាហរណ៍ សូមមើល៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧ ស្តីពីប្រជាធិបតេយ្យប្រមូលផ្តុំ។ គឺជាឧទាហរណ៍មួយដ៏ល្អឥតខ្ចោះនៃការអនុវត្តបានមួយចំណែក នៃស្តង់ដារពីរនៃអង្គជំនុំជម្រះ (សូមមើលខាងលើ កថាខណ្ឌ ២៣៤)។

[3309] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧ ដែលនៅទីនេះ អង្គជំនុំជម្រះបង្ហាញថា លោក ខៀវ សំផន "នៅក្នុងជួរនៃគណៈមជ្ឈិម" ដោយមិនបានបញ្ជាក់ច្បាស់ថា ទោះជាយ៉ាងណា លោកគ្រាន់តែជាសមាជិកត្រៀម គ្មានសិទ្ធិបោះឆ្នោតនៅពេលនោះឡើយ ហើយដោយមិនបានបង្ហាញពីធាតុផ្សំភស្តុតាងណាមួយដែលថាលោកមានវត្តមាន។

[3310] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០២ និង ៣៩៤០។

[3311] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២០៤ (នៃកថាខណ្ឌ ៤០២)។

[3312] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣០ និង ៣៨៨០។

[3313] <u>នួន ជា</u>៖ ប្រតិចារឹក ថ្ងៃទី២២ ខែវិច្ឆិកាឆ្នាំ២០១១ ឯកសារ **E1/14.1** ក្រោយម៉ោង 15.14.19។

[3314] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៥៤៧ (នៃកថាខណ្ឌ ២៣០)។

១៧១៧. ទីបួន អង្គជំនុំជម្រះបានយល់ឃើញថា គណៈមជ្ឈិមជាអ្នកចេញឯកសារមួយ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ក្រោមចំណងជើងថា "សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន" ពាក់ព័ន្ធជាអាទិ៍ ការតែងតាំងសមាជិករដ្ឋាភិបាល ការបង្កើតរបបរាយការណ៍ សិទ្ធិកម្ទេច ឬការកំណត់បុណ្យជាតិ[3315]។ ឯកសារនេះ (មិនមានបញ្ជាក់អ្នកចូលរួម) មិនត្រឹមតែមានភាពសង្ស័យប៉ុណ្ណោះទេ[3316] ថែមទាំងគ្មានសាក្សីណាម្នាក់ឆ្លើយថាធ្លាប់ឃើញ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៀតផង ហើយគ្មានភ័ស្តុតាងណាមួយបង្ហាញថាមានកិច្ចប្រជុំគណៈមជ្ឈិមនោះឡើយ។ ក្រៅពីនេះទៀត អ្នកជំនាញបានសន្មតថាជាសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ដូចអង្គជំនុំជម្រះបានលើកឡើងនៅក្នុងសំណុំរឿង ០០១[3317]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានពន្យល់ ក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ថាហេតុអ្វីបានជាអង្គជំនុំជម្រះមិនបានយកចិត្តទុកដាក់ដល់មតិរបស់អ្នកជំនាញទាំងនោះ លើចំណុចនេះជាពិសេស ទោះបីជាអង្គជំនុំជម្រះបានសន្និដ្ឋានដោយខ្លួនឯងថា គណៈអចិន្ត្រៃយ៍ជាអ្នកធ្វើសេចក្តីសម្រេចសំខាន់ៗក៏ដោយ[3318]។

១៧១៨. យោងតាមសេចក្តីសន្និដ្ឋាននេះ និងភ័ស្តុតាង អង្គជំនុំជម្រះគួរណាតែទទួលស្គាល់ថាសេចក្តីសម្រេចទាំងអស់ខាងលើត្រូវបានធ្វើឡើងដោយគណៈអចិន្ត្រៃយ៍។ លើសពីនេះទៅទៀត ទោះបីជានេះគឺជាសេចក្តីសម្រេចរបស់គណៈមជ្ឈិមក៏ដោយ ក៏មិនមានភ័ស្តុតាងបង្ហាញថា កិច្ចប្រជុំត្រូវបានរៀបចំឡើង ឬ ខៀវ សំផន មានវត្តមានឡើយ។ ម្យ៉ាងវិញទៀត ចំពោះសេចក្តីសម្រេច ចុះខែមិថុនា ឆ្នាំ១៩៧៤ អង្គជំនុំជម្រះបានត្រឡប់មករកសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងសំណុំរឿង ០០២/០១ ដែលថា ខៀវ សំ

---

[3315] សំអាងហេតុសាលក្រម ជាពិសេស កថាខណ្ឌ ៤១៤, ៤១៦, ៥៩៦, ៣៧៣៩, ៣៨៥៥-៣៨៥៦, ៣៨៩៩, ៣៩៥៥។ សូមមើលផងដែរ កថាខណ្ឌ ៤២៥៩-៤២៦០។

[3316] សូមមើលខាងលើ កថាខណ្ឌ ៣២៣។ សារណាបណ្តឹងសាទុក្ខ០០២/០១ កថាខណ្ឌ ៤៩៩។

[3317] Philip SHORT៖ ប្រតិចារឹក ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ម៉ោង 13.58.09។ សូមមើលផងដែរ ការផ្តល់សក្ខីកម្មរបស់ Craig ETCHESON នៅក្នុងសំណុំរឿង ០០១៖ សាលក្រម ឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ១០៣។

[3318] ជាឧទាហរណ៍៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦, ៣៥៧, ៦០៤, ៦២៤, ៤៣២២។

ផន បានចូលរួម[3319]។ ទោះបីជាកិច្ចប្រជុំរបស់គណៈមជ្ឈិមក៏ដោយ ក៏អង្គជំនុំជម្រះគួរណាតែទាញផលវិបាក និងទទួលស្គាល់ថា សមាជិកមិនប្រាកដថាបានចូលរួមប្រជុំទាំងអស់គ្នាទេ ដូចករណីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងមហាសន្និបាតដែរ[3320]។

១៧១៩. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋានពីការដឹង ចេតនា ឬការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម ចេញពីសេចក្តីសម្រេចទាំងនេះ និងសមាជិកភាពរបស់ ខៀវ សំផន ក្នុងគណៈមជ្ឈិម បានឡើយ[3321]។

## ១.៣. កំហុសពាក់ព័ន្ធនឹងកាលបរិច្ឆេទចូលជាសមាជិកពេញសិទ្ធិ

១៧២០. ដើម្បីទាញ ខៀវ សំផន ឱ្យចូលរួមពាក់ព័ន្ធ ជាអាទិ៍ នឹងសេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[3322] អង្គជំនុំជម្រះបានកំណត់ដោយមិនត្រឹមត្រូវយកខែមករា ឆ្នាំ១៩៧៦ ជាកាលបរិច្ឆេទចូលជាសមាជិកពេញសិទ្ធិរបស់គាត់ក្នុងគណៈមជ្ឈិម ក្នុងមហាសន្និបាតបក្សលើកទី ៤ ដែលត្រូវបានរៀបចំឡើងនៅកាលបរិច្ឆេទនោះ ហើយក្នុងពេលនោះ លក្ខន្តិកៈបក្សត្រូវបានអនុម័ត[3323]។

---

[3319] សូមមើលខាងលើ កថាខណ្ឌ ១៦៦៩-១៦៧៥។ ដោយសំអាងលើធាតុផ្សំភ័ស្តុតាងដូចគ្នានឹងសំណុំរឿង ០០២/០១ ម្តងនេះ អង្គជំនុំជម្រះ បានប្រកាសថា "មិនបានរកឃើញភ័ស្តុតាងណាមួយគួរឱ្យជឿជាក់បាន ដើម្បីកំណត់ថា លោក ខៀវ សំផន ឬ អៀង សារី បានចូលរួមក្នុងកិច្ចប្រជុំនេះឡើយ" (កំណត់សម្គាល់ជើងទំព័រលេខ ៥៤៨ នៃកថាខណ្ឌ ២៣០ នៃសំអាងហេតុសាលក្រម)។

[3320] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧ ដែលនៅទីនេះ អង្គជំនុំជម្រះបានធ្វើសេចក្តីសន្និដ្ឋានថា គណៈអចិន្ត្រៃយ៍ "អាចធ្វើឡើង (និងជាញឹកញាប់គឺដូច្នេះ) ដោយអវត្តមានសមាជិកមួយរូប ឬច្រើនរូបនៃគណៈកម្មាធិការនេះ"។ ចំពោះសមាជ សូមមើលខាងក្រោម កថាខណ្ឌ ១៧២៣-១៧២៨។

[3321] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧, ៤២០៨, ៤២៥៩, ៤២៦០, ៤៣១៣, ៤៣១៦។

[3322] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧, ៤២៥៩ និងជាពិសេសកថាខណ្ឌ ៤២៦០។

[3323] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣ និងកំណត់សម្គាល់ជើងទំព័រលេខ ៩៤៨, ៣៥៥, ៥៧៤, ៦០០, ៣៧៣៨។

១៧២១. ជាដំបូង ឯកសារដែលមានលក្ខន្តិកៈនេះមិនមានចុះកាលបរិច្ឆេទទេ[3324]។ បន្ទាប់មកទៀត ភ័ស្តុតាងភាគច្រើន សម្រាប់គាំទ្រដល់សេចក្តីសន្និដ្ឋានអំពីកាលបរិច្ឆេទនៃមហាសន្និបាត[3325] ឬកាលបរិច្ឆេទចូលជាសមាជិករបស់ ខៀវ សំផន[3326] មិនគាំទ្រដល់ការសន្និដ្ឋាននេះទេ។ ភ័ស្តុតាងផ្សេងទៀតដែលបានលើកឡើង គឺសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន និងសក្ខីកម្មរបស់ Stephen HEDER មិនគ្រប់គ្រាន់ទេ។ ជាក់ស្តែង ខៀវ សំផន តែងតែអះអាងថា គាត់បានចូលជាសមាជិកពេញសិទ្ធិ នៅឆ្នាំ១៩៧៦ ប៉ុន្តែដោយមិនបញ្ជាក់ខែ ឬនិយាយពីដើមឆ្នាំ១៩៧៦ ឬជារឿយៗ (កៀកនឹងការពិត) ខែមិថុនា ឆ្នាំ១៩៧៦[3327]។ ពេលសួរពីកាលបរិច្ឆេទអនុម័តលក្ខន្តិកៈ Stephen HEDER បានឆ្លើយថា គេប្រាប់គាត់នៅក្នុងកិច្ចសម្ភាសន៍នានាថា គឺខែមករា ឆ្នាំ១៩៧៦ និងបានបញ្ជាក់អំពីអត្ថិភាពជាសក្តានុពលនៃឯក

[3324] ម្យ៉ាងទៀត ដូចអង្គជំនុំជម្រះបានលើកឡើង ដោយយោងទៅឯកសារនោះដដែលៗជាច្រើនលើកច្រើនសាដូច្នោះដែរ ("លក្ខន្តិកៈ ប.ក.ក ឯកសារ **E3/130** ឯកសារគ្មានកាលបរិច្ឆេទ") លើកលែងតែ១ នៅត្រង់កំណត់សម្គាល់ជើងទំព័រលេខ ១២៤៦៦ នៃកថាខណ្ឌ ៣៧៣៨ ("លក្ខន្តិកៈ ប.ក.ក ឯកសារ **E3/130** [ឯកសារ E3/214] ខែមករា ឆ្នាំ១៩៧៦")។

[3325] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៩៤៨ (នៃកថាខណ្ឌ ៣៥៤)៖ ឌុច៖ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/52.1** ក្រោយម៉ោង 13.55.26 (ឌុចមិនបាននិយាយពីសមាជទេ ប៉ុន្តែបាននិយាយពីលក្ខន្តិកៈ និងបានបង្ហាញពីកាលបរិច្ឆេទ "ឆ្នាំ១៩៧៦"បន្ទាប់ពីបានផ្តល់កាលបរិច្ឆេទនោះ នៅក្នុងសំណួរដែលបានសួរទៅគាត់)។ កំណត់ហេតុនៃនសការវិភាគដែលសរសេរឡើងដោយ Craig ETCHESON ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ **E3/494** ទំព័រ ៣ ERN 00314780 (នៅជើងទំព័រនៃការវិភាគរបស់ខ្លួន ETCHESON បានយោងទៅឯកសារមួយ ដែលតាមពិតទៅ មិនទាំងនិយាយដល់សមាជលើកទី៤ ហើយក៏មិននិយាយដល់លក្ខន្តិកៈ ហើយក៏គ្មានកាលបរិច្ឆេទ ឆ្នាំ១៩៧៦ ដែរ។ សូមមើលឯកសារដែលបានដាក់បញ្ចូលក្នុងសំណុំឯកសារ ដែលមានលេខកូដ E3/196)។

[3326] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៩៩៨ (នៃកថាខណ្ឌ ៣៥៥) និងកំណត់សម្គាល់ជើងទំព័រលេខ ១៧៨៩ (កថាខណ្ឌ ៥៧៤)៖ សាឡុត បាន និង ឌុច ក៏បានបញ្ជាក់ត្រឹមតែ "ឆ្នាំ១៩៧៦"។ ដូចគ្នានេះដែរ នៅក្នុងបទសម្ភាសន៍ជាមួយ អៀង សារី ដោយ HEDER។

[3327] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៩៩៨ (នៃកថាខណ្ឌ ៣៥៥) និងកំណត់សម្គាល់ជើងទំព័រលេខ ១៧៨៩ (នៃកថាខណ្ឌ ៥៧៤) [ដែលនៅទីនេះដាក់តាមលំដាប់កាលវេលា]៖ លិខិតឆ្នាំ២០០១ ឯកសារ **E3/205** ERN 00623772 ("ពាក់កណ្តាលឆ្នាំ១៩៧៦")។ សៀវភៅ ឯកសារ **E3/18** ទំព័រ ១៥៦ ERN 00595512 ("ខែមិថុនា ឆ្នាំ១៩៧៦") - សូមមើលផងដែរ ទំព័រ ៧២ កំណត់សម្គាល់ជើងទំព័រលេខ ២ ERN 00595431 ("ខែមិថុនា ឆ្នាំ១៩៧៦")។ កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/27** ទំព័រ ៩ ERN 00156672 ("ឆ្នាំ១៩៧៦ »)។ ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/198.1** ម៉ោង 14.43.26 ("ចុងឆ្នាំ៧៥ ដើមឆ្នាំ៧៦")។

សារយោងមួយ ដែលគាត់មិនបានផ្តល់ជូន[3328]។ បន្ទាប់មកទៀត ថ្វីត្បិតតែគាត់បានភ្ជាប់ទំនាក់ទំនងរវាងមហាសន្និបាតលើកទី ៤ និងការចូលជាសមាជិកពេញសិទ្ធិរបស់ ខៀវ សំផន ក៏ដោយ[3329] ក៏ Stephen HEDER (ត្រូវបានអង្គជំនុំជម្រះបំភ្លេចចោល) បានឆ្លើយថា ខៀវ សំផន ត្រូវបានដំឡើងជាសមាជិកពេញសិទ្ធិ ក្នុងពេលតែមួយជាមួយគ្នានឹងការតែងតាំងគាត់ជាប្រធានគណៈប្រធានរដ្ឋ[3330]។ ប៉ុន្តែ បើតាមអង្គជំនុំជម្រះ ការតែងតាំងនេះត្រូវបាន "គណៈមជ្ឈិម" ធ្វើឡើងក្រៅផ្លូវការនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ និងជាផ្លូវការ នៅពាក់កណ្តាលខែមេសា[3331]។

១៧២២. យោងតាមភ័ស្តុតាងទាំងនេះ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានថា ខៀវ សំផន ក្លាយជាសមាជិកពេញសិទ្ធិ នៅខែមករា ឆ្នាំ១៩៧៦ ក្នុងមហាសន្និបាតលើកទី ៤ របស់ ប.ក.ក និងទាញគាត់ឱ្យជាប់ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ "គណៈមជ្ឈិម" ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នោះឡើយ។ វិមតិសង្ស័យគួរណាតែបានជាប្រយោជន៍ដល់គាត់ ពីព្រោះគ្មានភ័ស្តុតាងបង្ហាញថា គាត់មានវត្តមានក្នុងមហាសន្និបាតនេះទេ។

## ១.៤. កំហុសពាក់ព័ន្ធនឹងវត្តមានក្នុងមហាសន្និបាត

១៧២៣. ដើម្បីទម្លាក់ឱ្យ ខៀវ សំផន ទទួលខុសត្រូវ អង្គជំនុំជម្រះបានផ្អែកលើការចូលរួមរបស់គាត់ក្នុងមហាសន្និបាតរបស់ ប.ក.ក នៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨[3332] ដោយគ្មានភ័ស្តុតាងបង្ហាញអំពីវត្តមានរបស់គាត់។

---

[3328] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៩៩៨ (នៃកថាខណ្ឌ ៣៥៣)៖ Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/222.1** ម៉ោង 09.47.25។

[3329] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៩៩៨ (នៃកថាខណ្ឌ ៣៥៥) និងកំណត់សម្គាល់ជើងទំព័រលេខ ១៧៨៩ (នៃកថាខណ្ឌ ៥៧៤)៖ Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/223.1** មុនម៉ោង 11.09.40។

[3330] Philip SHORT៖ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ម៉ោង 13.44.33។

[3331] សំអាងហេតុសាលក្រម កថាខណ្ឌ៥៩៦។

[3332] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៩, ៤២៥៧, ៤២៥៩, ជាពិសេសកថាខណ្ឌ៤២៦០។

១៧២៤. នៅក្នុងសេចក្ដីសន្និដ្ឋានទាំងអស់អំពីមហាសន្និបាតលើកទី ៤ នៅឆ្នាំ១៩៧៦[3333] អង្គជំនុំជម្រះមិនបានលើកឡើងនូវភ័ស្ដុតាងអំពីការចូលរួមរបស់ ខៀវ សំផន ទាល់តែសោះ។ អង្គជំនុំជម្រះគ្រាន់តែអះអាងថា មនុស្សរាប់រយនាក់ រួមទាំងសមាជិកគណៈមជ្ឈិម បានចូលរួម[3334] ដោយផ្អែកលើសក្ខីកម្មរបស់ នោម សែ ដែលបាននិយាយអំពីមិទ្ទីងឃោធា នៅខែកញ្ញា ឆ្នាំ១៩៧៥ គឺមិនមែនមហាសន្និបាតទេ[3335]។

១៧២៥. ចំពោះមហាសន្និបាតលើកទី ៥ អង្គជំនុំជម្រះបានសន្និដ្ឋានថា មហាសន្និបាតបានប្រព្រឹត្តទៅ នៅថ្ងៃទី ០១ និងថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨[3336] ដោយផ្អែកលើភ័ស្ដុតាងដែលមិនបញ្ជាក់អំពីវត្តមានរបស់ ខៀវ សំផន ទាល់តែសោះ[3337]។ យោងតាមភ័ស្ដុតាងទាំងនេះ ការជួបជុំគ្នាដ៏ខ្លីខុសពីធម្មតានេះ មាន

---

[3333] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៣, ៣៤៥, ៥៧៤, ៣៧៣៨, ៣៧៦៥, ៤២៥៧, ៤២៥៩។ ធាតុផ្សំភ័ស្ដុតាង ស្ថិតនៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៩៥៨ (នៃកថាខណ្ឌ ៣៤៥) ដែលរៀបចំនៅក្នុងទីនេះ និងក្នុងកំណត់សម្គាល់ជើងទំព័រលេខ ៩៤៨ (នៃកថាខណ្ឌ ៣៤៣)៖ Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/222.1** ម៉ោង 09.47.25 (នៅទីនេះ គាត់បានបង្ហាញថាគេនិយាយប្រាប់គាត់នៅក្នុងបទសម្ភាសន៍ថាលក្ខន្តិកៈត្រូវបានអនុម័ត នៅខែមករា ឆ្នាំ១៩៧៦)។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/52.1** ក្រោយម៉ោង 13.55.26 (ឌុចមិនបាននិយាយពីសមាជទេ ប៉ុន្តែបាននិយាយពីលក្ខន្តិកៈ និងបានបង្ហាញពីកាលបរិច្ឆេទ "ឆ្នាំ១៩៧៦"បន្ទាប់ពីបានផ្ដល់កាលបរិច្ឆេទនោះ នៅក្នុងសំណួរដែលបានសួរទៅគាត់)។ កំណត់ហេតុវិភាគដោយ Craig ETCHESON ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ **E3/494** ទំព័រ ៣ ERN 00314780 (នៅជើងទំព័រនៃការវិភាគរបស់ខ្លួន ETCHESON បានយោងទៅឯកសារមួយ ដែលតាមពិតទៅ មិនទាំងនិយាយដល់សមាជលើកទី៤ ហើយក៏មិននិយាយដល់លក្ខន្តិកៈ ហើយក៏គ្មានកាលបរិច្ឆេទ ឆ្នាំ១៩៧៦ ដែរ។ សូមមើលឯកសារដែលបានដាក់បញ្ចូលក្នុងសំណុំរឿងដែលមានលេខកូដ **E3/196**)។

[3334] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥។

[3335] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៩៥៨ (នៃកថាខណ្ឌ ៣៤៥)៖ នោម សែ៖ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/159.1** ទំព័រ ៥៨ ម៉ោង 11.51.10 ទំព័រ ៧១-៧២, ម៉ោង 13.55.37។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/159.1** ចន្លោះម៉ោង 09.21.23 និងម៉ោង 09.23.05 (ការប្រជុំទាំងបីលើកដែលគាត់បានចូលរួមប្រព្រឹត្តទៅនៅស្ដាតអូឡាំពិក) មុនម៉ោង 09.28.07 (អង្គប្រជុំទាំងបី បានប្រព្រឹត្តទៅ នៅឆ្នាំ១៩៧៥ និង នៅឆ្នាំ១៩៧៥ តែប៉ុណ្ណោះ)។ សាក្សីម្នាក់ទៀតតែម្នាក់គត់ ដែលត្រូវបានបង្ហាញនៅកំណត់សម្គាល់ជើងទំព័រលេខ គឺ សៅ សារុន ដែលបាននិយាយការប្រជុំ នៅឆ្នាំ១៩៧៨ សូមមើលបន្ទាប់ពីនេះ។

[3336] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣២១ និង ៣៧៤២។

[3337] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ៧៨៧ (នៃកថាខណ្ឌ ២៣២១) និងកំណត់សម្គាល់ជើងទំព័រលេខ ១២៤៨៦ (នៃកថាខណ្ឌ ៣៧៤២)។

គោលដៅជ្រើសតាំងថ្នាក់ដឹកនាំថ្មី[3338]។ ដើម្បីអះអាងថា មនុស្សរាប់រយនាក់ រួមទាំងសមាជិកគណៈមជ្ឈិម បានចូលរួម[3339] អង្គជំនុំជម្រះបានផ្អែកលើចម្លើយរបស់ សៅ សារុន ដែលថា មិទ្ទីងដែលគាត់បានចូលរួមនៅឆ្នាំ១៩៧៨ ត្រូវបានធ្វើឡើងនៅខែកញ្ញា ក្នុងរយៈពេល ១០ ថ្ងៃ ហើយបញ្ហាដែលបានពិនិត្យមើលជាសំខាន់ គឺធ្វើយ៉ាងណាឱ្យប្រជាជនបានហូបចុកគ្រប់គ្រាន់ មានផ្ទះសម្បែងសមរម្យ ឬបើកផ្សារឡើងវិញ[3340]។ ថ្វីត្បិតតែ សៅ សារុន បានបញ្ជាក់អំពីវត្តមាន ខៀវ សំផន ក្នុងមិទ្ទីងនេះ ក៏ដោយ (តាមការស្នើសុំឱ្យបញ្ជាក់លើកំណត់ហេតុស្តាប់ចម្លើយរបស់គាត់)[3341] ក៏មិនមានភ័ស្តុតាងបញ្ជាក់ឱ្យហួសពីវិមតិសង្ស័យថា នេះជាមហាសន្និបាតបក្សលើកទី ៥ ដូចអង្គជំនុំជម្រះបានបង្ហាញឡើយ។

១៧២៦. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមិនអើពើនឹងចម្លើយរបស់ ខៀវ សំផន ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត អំពីចន្លោះពេលរវាងមហាសន្និបាតពីរ ថា មហាសន្និបាត ឆ្នាំ១៩៧៦ ជា "មហាសន្និបាតលើកទី ៣ និងជាលើកចុងក្រោយ" ក្រោយពីមហាសន្និបាត ឆ្នាំ១៩៦០ និងមហាសន្និបាត ឆ្នាំ១៩៧១[3342]។ គ្មានតម្រុយណាមួយចង្អុលបង្ហាញថា គាត់បានចូលរួមមហាសន្និបាត ឬគាត់បានដឹងអំពីមហាសន្និបាត ឆ្នាំ១៩៧៨ នោះឡើយ។

១៧២៧. ក្រៅពីនេះទៀត អង្គជំនុំជម្រះធ្វើមិនដឹងមិនឮនឹងលក្ខន្តិកៈ ដែលអង្គជំនុំជម្រះបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ ដែលចែងថា "ចំនួនតំណាងពេញសិទ្ធិ ដែលត្រូវបានអញ្ជើញចូលរួមក្នុងមហា

---

[3338] ឯកសារនៃសមាជលើកទី៥របស់បក្ស ថ្ងៃទី១-២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ឯកសារ **E3/816** (មិនមានដាក់ឈ្មោះអ្នកចូលរួម)។ សៀវភៅរបស់លោក SHORT ឯកសារ **E3/9** ERN 00639967។

[3339] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥ និងកំណត់សម្គាល់ជើងទំព័រលេខ ៩៥៨ ដែលយោងទៅប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/84.1** ទំព័រ ២១-២៦។ ធាតុផ្សំភ័ស្តុតាងត្រូវបានចុះនៅកំណត់សម្គាល់ជើងទំព័រលេខ ៩៥៧ នៃកថាខណ្ឌ ៣៤៥ ដដែល ដើម្បីគាំទ្រដល់ការលើកឡើងថាមានសមាជលើកទី៥ មានបញ្ចូលសក្ខីកម្មដែលរបស់ សៅ សារុន ទំព័រ ១៧។ គ្មានសក្ខីកម្មណាមួយដែលលើកឡើងពីវត្តមានរបស់ លោក ខៀវ សំផន ឡើយ។

[3340] សៅ សារុន៖ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/84.1** ទំព័រ ១៧-២៦។

[3341] សៅ សារុន៖ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនាឆ្នាំ២០១២ ឯកសារ **E1/84.1** ទំព័រ ២៦-២៧ ចន្លោះម៉ោង10.03.04 និង 10.04.52។

[3342] កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/27** ERN 00156672 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

សន្និបាតតំណាងទូទាំងប្រទេស ត្រូវគណៈកម្មាធិការមជ្ឈិមកំណត់"[3343]។ ដូច្នេះ លក្ខន្តិកៈមិនបានចែងថា សមាជិកទាំងអស់របស់គណៈមជ្ឈិមត្រូវចូលរួមក្នុងមហាសន្និបាតជាដាច់ខាតនោះទេ។

១៧២៨. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ខៀវ សំផន បានចូលរួមក្នុងមហាសន្និបាតលើកទី ៤ និងលើកទី ៥ របស់ ប.ក.ក និងទម្លាក់គាត់ឱ្យទទួលខុសត្រូវ ដោយផ្អែកលើមូលដ្ឋាននេះ បានឡើយ[3344]។

១៧២៩. <u>**សរុបសេចក្តីមក៖**</u> ទោះជាក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានចេញពីសមាជិកភាពសាមញ្ញរបស់ ខៀវ សំផន ក្នុងគណៈមជ្ឈិម ថា គាត់ស្ថិតក្នុងក្រុមសមាជិក ទទួលបានព័ត៌មានពេញលេញ និងបានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម[3345]។ កំហុសរបស់អង្គជំនុំជម្រះបណ្តាលឱ្យមានយុត្តិនិសេធ ហើយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

## ២. វត្តមានក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈអចិន្ត្រៃយ៍

១៧៣០. ដោយហេតុថា ខៀវ សំផន មិនធ្លាប់ជាសមាជិកគណៈអចិន្ត្រៃយ៍ ("គឺជាស្ថាប័នសម្រេចកំពូលរបស់ ប.ក.ក"[3346]) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះបានទាញការសន្និដ្ឋានអំពីការទទួលខុសត្រូវរបស់គាត់ ចេញពីវត្តមានរបស់គាត់ក្នុងកិច្ចប្រជុំមួយចំនួន។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ពាក់ព័ន្ធនឹងភស្តុតាងអំពីកិច្ចប្រជុំទាំងនេះ ក្នុងរបបនោះ (២.១) ការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំ (២.២) និង "តួនាទីពិសេស" របស់គាត់ (២.៣)។

---

[3343] លក្ខន្តិកៈ ប.ក.ក ឯកសារ **E3/130** មាត្រា ២២ ERN 00292932។ សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៥ ដែលនៅទីនេះ អង្គជំនុំជម្រះបានបង្ហាញថាមហាសន្និបាតក៏ត្រូវបានគេហៅថាសមាជបក្សដែរ។

[3344] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣២១, ៤២២៩, ៤២៥៧, ៤២៥៩, ៤២៦០។

[3345] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧៤, ៦០៤, ៦២៤, ៣៩១៣, ៣៩៦៤, ៤២០៧, ៤២០៨, ៤២២៩, ៤២៥៧, ៤២៥៩, ៤២៦០, ៤៣១៣, ៤៣១៦។

[3346] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៦។

## ២.១. កំហុសពាក់ព័ន្ធនឹងភស្តុតាងអំពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

១៧៣១. អង្គជំនុំជម្រះបានយល់ឃើញថា កំណត់ហេតុកិច្ចប្រជុំនៅសេសសល់រហូតមកដល់សព្វថ្ងៃបង្ហាញថា គណៈអចិន្ត្រៃយ៍បានធ្វើការប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាអំពីគោលនយោបាយរបស់ ប.ក.ក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[3347]។ អង្គជំនុំជម្រះបានផ្អែកលើឯកសារចំនួន ៣៨ ពាក់ព័ន្ធនឹងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ក្នុងនោះ ឯកសារ ២៦ ត្រូវបានទទួលយក នៅមុនការជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ហើយឯកសារផ្សេងទៀតត្រូវបានទទួលយក ក្នុងពេល និងក្រោយពេលបញ្ចប់ការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ (ឯកសារទាំងនេះត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅបង្ហាញភាពស៊ីចង្វាក់គ្នាប៉ុណ្ណោះ)[3348]។

១៧៣២. ម្ចាស់បណ្តឹងសាទុក្ខសូមយោងទៅទឡ្ហីករណ៍មុនៗរបស់ខ្លួនអំពីការទទួលយក និងតម្លៃជាភស្តុតាងតិចតួចបំផុត ឬសូន្យតែម្តង នៃឯកសារទាំងនេះ ហើយគ្មានឯកសារណាមួយត្រូវបានផ្តល់ជូនជាច្បាប់ដើម ព្រមទាំងគ្មានបុគ្គលណាម្នាក់ ដែលជាប្រភពផ្តល់ឯកសារទាំងនេះ បានចូលមកបង្ហាញខ្លួនឡើយ[3349]។

១៧៣៣. ប៉ុន្តែ ទោះជាឧបមាថាឯកសារទាំងនេះពិតជាបានថតចម្លងចេញពីច្បាប់ដើមក៏ដោយ ក៏ឯកសារទាំងនេះមិនអាចធ្វើជាមូលដ្ឋាន សម្រាប់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះបានឡើយ។ អ្វីដែលអាចទាញការសន្និដ្ឋានបាន គឺកិច្ចប្រជុំខ្លះត្រូវបានធ្វើឡើង នៅកាលបរិច្ឆេទមួយចំនួន និងនិយាយអំពីប្រធានបទមួយចំនួន ដោយជួនកាលមានបង្ហាញឈ្មោះអ្នកចូលរួម (ដោយមិនបញ្ជាក់រយៈពេលនៃវត្តមានរបស់ពួកគេក្នុងកិច្ចប្រជុំ)។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអ្វីហួសពីនេះ និងធ្វើការសន្និដ្ឋានពង្រីកបានឡើយ។

---

[3347] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៨៤ ដែលយោងទៅកថាខណ្ឌ ៣៥៧ ដែលយោងទៅកថាខណ្ឌ ៣៤៧។ សូមមើលផងដែរ កថាខណ្ឌ ៣៧៤០។

[3348] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៧-៣៥៤។

[3349] សូមមើលខាងលើ កថាខណ្ឌ ២១៧-២២៦ និង ៣២៦-៣២៨។

១៧៣៤. ក្នុងចំណោមឯកសារទាំងនេះ ឯកសារ ១៦ ប៉ុណ្ណោះ មានឈ្មោះ ខៀវ សំផន ក្នុងចំណោមអ្នកចូលរួមប្រជុំ (ដោយមិនបញ្ជាក់រយៈពេលនៃវត្តមានរបស់គាត់) នៅកាលបរិច្ឆេទ ចន្លោះពីថ្ងៃទី០៩ ខែតុលា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ដោយនិយាយអំពីប្រធានបទមួយចំនួន[3350]។

១៧៣៥. អង្គជំនុំជម្រះមិនអាចធ្វើអ្វីហួសពីនេះ និងសន្និដ្ឋានអំពីការទទួលខុសត្រូវរបស់គាត់ (រួមទាំងចំពោះហេតុការណ៍ដែលកើតឡើងតាមក្រោយ) តាមរយៈការទាញជាករណីទូទៅ ដោយគ្មានភស្តុតាងបញ្ជាក់អំពីការចូលរួមរបស់គាត់ក្នុង "កិច្ចប្រជុំជាច្រើន" របស់គណៈអចិន្ត្រៃយ៍ ឬ "ការចូលរួមជាទៀងទាត់" របស់គាត់ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលផ្តល់ "តួនាទីពិសេស" ដល់គាត់ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[3351]។

## ២.២. កំហុសពាក់ព័ន្ធនឹង "ការចូលរួម" របស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍

១៧៣៦. ខៀវ សំផន មិនធ្លាប់លាក់បាំងទេថា គាត់បានចូលរួមក្នុងកិច្ចប្រជុំ "បើកទូលាយ" ដល់អ្នកមិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ ដែលនិយាយអំពីបញ្ហាទូទៅ នោះឡើយ។ ប៉ុន្តែ គាត់តែងតែអះអាងថា គាត់ត្រូវគេអញ្ជើញឱ្យចូលរួមប្រជុំ ពាក់ព័ន្ធនឹងមុខងារមានកម្រិតបំផុតរបស់គាត់ ដែលភាគច្រើនជាមុខងារពិធីការ ហើយគាត់មិនធ្លាប់ចូលរួមពិភាក្សា ឬសម្រេចអ្វីឡើយ[3352]។ ដើម្បីបញ្ជាក់ផ្ទុយពីនេះ អង្គជំនុំជម្រះបានធ្វើការវិភាគខុស និងលម្អៀងទៅលើកំណត់ហេតុកិច្ចប្រជុំចំនួន ១៦ ដែលបង្ហាញអំពីវត្តមានរបស់ ខៀវ សំផន។

---

[3350] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១០១១ (នៃកថាខណ្ឌ ៣៥៧)។ ទំពីជាអង្គជំនុំជម្រះបង្ហាញច្បាស់ថា ឯកសារចំនួន១៦ ដែលបញ្ជាក់ថា លោក ខៀវ សំផន មានវត្តមាន តែបញ្ជីនោះមានកំហុស។ ក្នុងចំណោមឯកសារទាំង ២០ ដែលកត់ត្រានោះ គឺមានតែឯកសារតែ១៦ប៉ុណ្ណោះ គឺ៖ E3/197, E3/217, E3/218, E3/219, E3/220, E3/221, E3/222, E3/223, E3/224, E3/226, E3/227, E3/229, E3/230, E3/231, E3/232, E3/233។

[3351] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤០, ៤២២៥, ៤២៣០, ៤២៣៦, ៤២៣៩, ៤២៥៧, ៤២៥៨, ៤២៧៧, ៤៣១៦។

[3352] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០១។ សូមមើលផងដែរ កំណត់សម្គាល់ជើងទំព័រលេខ ១៨៩១ និង ១៨៩២ នៃកថាខណ្ឌ ៦០៣។

១៧៣៧. ដើម្បីអះអាងថា ខៀវ សំផន "បានចូលរួម [យ៉ាងសកម្ម] នៅក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈកម្មាធិការអចិន្ត្រៃយ៍" អង្គជំនុំជម្រះបានផ្អែកលើកំណត់ហេតុ ២ ដែលបញ្ជាក់ថា "គាត់បានរាយការណ៍ [...] យ៉ាងហោចណាស់ ពីរលើកដែរ"[3353]។ ប៉ុន្តែ ឯកសារទាំងពីរនេះបង្ហាញអំពីការចូលរួមតែពីរដងគត់៖ គាត់បានរាយការណ៍ជូនគណៈអចិន្ត្រៃយ៍ អំពីការបោះឆ្នោត និងការលាលែងពីតំណែងរបស់ សម្តេច សីហនុ[3354]។ ការគ្រាន់តែឡើងរាយការណ៍បង្ហាញអំពីការនៅក្រោមបង្គាប់ និងឋានានុក្រម[3355] គឺមិនមានន័យថាគាត់បានចូលរួមក្នុងការពិភាក្សា ឬសម្រេចឡើយ[3356]។ បន្ទាប់មកទៀត ប្រធានបទនៃការរាយការណ៍នេះគឺជាក់លាក់បំផុត និងគ្មានទំនាក់ទំនងជាមួយឧក្រិដ្ឋកម្ម ឬមានគោលបំណងឧក្រិដ្ឋឡើយ[3357]។

១៧៣៨. ការអានកំណត់ហេតុទាំង ១៦ នេះឱ្យបានត្រឹមត្រូវ ដែលមានបញ្ជាក់ឈ្មោះ ខៀវ សំផន បង្ហាញថាការចូលរួមរបស់គាត់ គឺអកម្មទាំងស្រុង ១៤ ដង ហើយ ២ ដង គឺគ្មានបានការ និងផ្តោតលើបញ្ហាទាក់ទិនមុខងាររបស់គាត់ ពាក់ព័ន្ធនឹងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងប្រជាជន។ ជាក់ស្តែង គ្មានឯកសារណាមួយលើកឡើងអំពីការថ្លែងការណ៍របស់ម្ចាស់បណ្តឹងសាទុក្ខ ឬការចូលរួមចំណែករបស់គាត់ ក្រៅពីការរាយការណ៍ពីរដងនេះឡើយ[3358]។

---

[3353] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០២។

[3354] កំណត់ហេតុអង្គប្រជុំ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232**។ កំណត់ហេតុអង្គប្រជុំ ថ្ងៃទី១១-១៣ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/197**។ ខ្លឹមសារដែលគេហៅថា របាយការណ៍នោះ មិនមានបញ្ជាក់ពីសំណើណាមួយឡើយ គ្រាន់តែជាការរាយការណ៍ពីព្រឹត្តិការណ៍ប៉ុណ្ណោះ។

[3355] SHORT៖ ប្រតិចារឹក ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ទំព័រ ៧១ បន្ទាត់១២ ដល់ទំព័រ ៧២ បន្ទាត់ ៣ ម៉ោង 13.39.09។

[3356] បន្តពីសេចក្តីរាយការណ៍ស្តីពីការបោះឆ្នោត "អង្គការ" បានផ្តល់ការណែនាំ (**E3/232** ទំព័រ ១-២ ERN 00323932-33)។ បន្ទាប់ពីរបាយការណ៍ស្តីពីការលាលែងពីតំណែងរបស់សម្តេចសីហនុ "អង្គការ" បានផ្តល់ការណែនាំ ហើយ *"ស.ម លេខា"* សម្រេចថាត្រូវចាត់វិធានការបែបណា (**E3/197** ទំព័រ ១-៣ ERN 00000744-46)។

[3357]ម្យ៉ាងទៀត គេកត់សម្គាល់ឃើញថា គឺនៅពេលក្រោយរបាយការណ៍នោះ ទើបលក្ខណៈមិនពិតនៃការបោះឆ្នោតបានលេចឡើង (E3/232)។

[3358] សូម្បីបញ្ហាទាក់ទងនឹងពាណិជ្ជកម្មក៏មិនមានផង។

១៧៣៩. ម្យ៉ាងវិញទៀត ដើម្បីប្រកាសថា ខៀវ សំផន "បានទទួលព័ត៌មានពេញលេញ នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ" ទោះបីជាគាត់បានបដិសេធថាគាត់មិនបានដឹងឧក្រិដ្ឋកម្មក៏ដោយ អង្គជំនុំជម្រះបានបង្កើតបញ្ជីទូទៅមួយនៃបញ្ហាដែលបាន "ពិភាក្សា"[3359]។ ប៉ុន្តែ គ្មានតម្រុយណាមួយ នៅក្នុងខ្លឹមសារនៃកំណត់ហេតុកិច្ចប្រជុំទាំងនេះ នៅចន្លោះខែតុលា ឆ្នាំ១៩៧៥ និងខែមិថុនា ឆ្នាំ១៩៧៦ អាចឱ្យសន្និដ្ឋានអំពីការដឹងឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលនោះ[3360] និងនាពេលក្រោយឡើយ។

១៧៤០. អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋានចេញពីវត្តមាន ខៀវ សំផន ក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈអចិន្ត្រៃយ៍ នូវការដឹង ចេតនា ឬការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ[3361]។

១៧៤១. ការសន្និដ្ឋានពង្រីក និងភាពលម្អៀងបង្ហាញឱ្យឃើញច្បាស់ តាមរយៈការទម្លាក់ការទទួលខុសត្រូវលើ ខៀវ សំផន ដោយផ្អែកលើកំណត់ហេតុកិច្ចប្រជុំចំនួន ៣ ដែលបានលើកឡើងអំពីព្រលានយន្តហោះកំពង់ឆ្នាំង នៅចំពោះមុខគាត់។ បើតាមអង្គជំនុំជម្រះ ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំគណៈ

---

[3359] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៣។

[3360] ជាឧទាហរណ៍ ក្នុង១៦លើកនោះ មានតែមួយលើកប៉ុណ្ណោះដែលបានលើកឡើង បើនិយាយពីបញ្ហា "ចាប់ចង" គឺនៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦។ កំណត់ហេតុនោះ រំឭកពីការចាប់ឈ្មោះ លឿន និងបក្ខពួក ដោយកងទ័ពតំបន់ ព្រមទាំងឈ្មោះ អ៊ុក មឿន ដែលមានគម្រោងគេចខ្លួនទៅវៀតណាម។ បន្ទាប់ពីរបាយការណ៍នោះមក អង្គការបានណែនាំឱ្យធ្វើការស៊ើបអង្កេត (កំណត់ហេតុថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** ERN 00323933-34)។ ព័ត៌មានទាំងនេះមិនគ្រប់គ្រាន់ទេដើម្បីធ្វើការសន្និដ្ឋានអំពីការដឹងឮ ការចាប់ចងមិនស្របច្បាប់ ឬការចាប់ចងទ្រង់ទ្រាយធំ។ ម្យ៉ាងទៀត នៅក្នុងកាលបរិច្ឆេទនេះ ការចាប់ចងធំៗមិនទាន់ចាប់ផ្ដើមនៅឡើយ។ ចំពោះបញ្ហាទាក់ទិនល័ក្ខខ័ណ្ឌរស់នៅ នៅតាមស្រុកស្រែចម្ការ (ជាពិសេស ជំងឺ មរណភាព និងការខ្វះស្បៀងអាហារ)" អង្គជំនុំជម្រះបានផ្អែកទៅលើកំណត់ហេតុពីរ ដែលនៅក្នុងនោះ គេអាចមើលឃើញថា គោលដៅរបស់អង្គការ គឺគ្រប់គ្រងល័ក្ខខ័ណ្ឌរស់នៅរបស់ប្រជាជន ដោយគិតគូរឱ្យអាជ្ញាធរមូលដ្ឋានផ្ដល់នូវតួលេខពិតប្រាកដលើការប្រមូលផល ដើម្បីដោះស្រាយបញ្ហាដែលបានរាយការណ៍ (កំណត់ហេតុចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** ERN 00323935) ឬក៏គោលបំណងរបស់ ប.ក.ក នៅក្នុងការផលិតថ្នាំពេទ្យ និង ការដឹកជញ្ជូនទៅកាន់សហករណ៍មូលដ្ឋាន ជាមួយនឹងផ្នែកពាណិជ្ជកម្ម ដើម្បីបម្រើប្រជាជន (កំណត់ហេតុចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ឯកសារ **E3/226** ERN 00296162)។

[3361] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៩០, ៣៨៩១, ៣៩១៣, ៤២០៨, ៤២២៤, ៤២២៥, ៤២២៨, ៤២៣០, ៤២៣៦, ៤២៣៩, ៤២៥៧, ៤២៥៨, ៤២៧៧, ៤២៨៤, ៤៣១៣, ៤៣១៦។

អចិន្ត្រៃយ៍ នៅខែតុលា ឆ្នាំ១៩៧៥ និង "កិច្ចប្រជុំក្រោយៗ" ហើយក្នុងពេលនោះ សុន សេន បានរាយការណ៍អំពីការសាងសង់ព្រលានយន្តហោះ[3362]។

១៧៤២. ជាដំបូង កំណត់ហេតុទីមួយ ចុះខែតុលា ឆ្នាំ១៩៧៥ (គណៈអចិន្ត្រៃយ៍គ្រោងសាងសង់) មិនមានបញ្ជាក់ឈ្មោះអ្នកចូលរួមទេ ហើយគ្មានតម្រុយណាមួយបង្ហាញថា ខៀវ សំផន មានវត្តមាននោះឡើយ[3363]។ បន្ទាប់មក កំណត់ហេតុទីពីរ ចុះខែមីនា ឆ្នាំ១៩៧៦ បង្ហាញថា គណៈអចិន្ត្រៃយ៍បន្តសិក្សាបញ្ហានេះតទៅទៀត[3364]។ កំណត់ហេតុទីបី ចុះខែឧសភា ឆ្នាំ១៩៧៦ ដែលអង្គជំនុំជម្រះបានសន្និដ្ឋានថា "យ៉ាងហោចណាស់មានកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដែល សុន សេន រាយការណ៍ [...] អំពីភាពរីកចម្រើននៃការសាងសង់ព្រលានយន្តហោះ" ជាកំណត់ហេតុតែមួយគត់ដែលត្រូវលើកឡើង។ កំណត់ហេតុនោះបញ្ជាក់ថា៖ "ត្រូវចាក់គ្រួសច្រើន" និងប្រក់ដំបូល "ធ្វើម៉េចកុំឱ្យក្តៅ"[3365]។ ជាចុងក្រោយ អង្គជំនុំជម្រះមិនបានលើកឡើងថា កំណត់ហេតុកិច្ចប្រជុំចុះខែមេសា ឆ្នាំ១៩៧៦ ដែលក្នុងពេលនោះ មានការសម្រេចលើការសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មិនមានបង្ហាញវត្តមានរបស់ ខៀវ សំផន ទេ[3366]។

១៧៤៣. គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណាម្នាក់អាចទម្លាក់ការទទួលខុសត្រូវលើ ខៀវ សំផន ចំពោះឧក្រិដ្ឋកម្ម ដោយផ្អែកលើភ័ស្តុតាងទាំងនេះទេ។

---

[3362] សំអាងហេតុសាលក្រម កថាខណ្ឌ៤២៥៨។ សូមមើលផងដែរ កថាខណ្ឌ ៤២៤, ១៧២៣ (កំណត់សម្គាល់ជើងទំព័រលេខ ៥៨៣៤-៥៨៣៦), ១៧២៧ (កំណត់សម្គាល់ជើងទំព័រលេខ ៥៨៥៤), ៤៣១៣។

[3363] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧២៣ និងកំណត់សម្គាល់ជើងទំព័រលេខ ៥៨៣៤ ដែលយោងទៅកំណត់ហេតុ ឯកសារ **E3/182**។ ម្យ៉ាងទៀត អង្គជំនុំជម្រះមិនបានធ្វើជាមុននូវបញ្ជីទៅលើកំណត់ហេតុទាំងនេះ ក្នុងចំណោមកំណត់ហេតុដែលបញ្ជាក់ថាមានវត្តមានរបស់ លោក ខៀវ សំផន ឡើយ (សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១០១១ នៃកថាខណ្ឌ ៣៥៧)។

[3364] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧២៣ និងកំណត់សម្គាល់ជើងទំព័រលេខ ៥៨៣៥ ដែលយោងទៅកំណត់ហេតុ ឯកសារ **E3/229**។

[3365] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧២៧ និងកំណត់សម្គាល់ជើងទំព័រលេខ ៥៨៥៤ ដែលយោងទៅកំណត់ហេតុ ឯកសារ **E3/222**។

[3366] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧២៣ និងកំណត់សម្គាល់ជើងទំព័រលេខ ៥៨៣៦ ដែលយោងទៅកំណត់ហេតុ ឯកសារ **E3/235**។

១៧៤៤. ដូចគ្នាផងដែរ អង្គជំនុំជម្រះមិនអាចធ្វើបែបនេះ ដោយផ្អែកលើចម្លើយលាយលក្ខណ៍អក្សរប្លែកខុសគេតែមួយគត់ ដែលថា គាត់បានចូលរួមក្នុងកិច្ចប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍ នៅខែកញ្ញា ឆ្នាំ១៩៧៥ ដើម្បីសន្និដ្ឋានអំពីការចូលរួមរបស់គាត់ជាទៀងទាត់ក្នុងកិច្ចប្រជុំ សំដៅពិភាក្សាអំពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងគោលបំណងរួម ជាអាទិ៍ វិស័យកសិកម្ម គ្រោះរាំងស្ងួត និងឧស្សាហកម្ម[3367]។ ដោយផ្អែកតែលើមូលដ្ឋាននេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា កិច្ចប្រជុំនេះបានកើតឡើងឡើយ។

## ២.៣. កំហុសពាក់ព័ន្ធនឹង "តួនាទីពិសេស" របស់ ខៀវ សំផន

១៧៤៥. បើតាមអង្គជំនុំជម្រះ ខៀវ សំផន មាន "តួនាទីពិសេសនៅក្នុងបក្ស ដោយសារតែវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួន ដែលពិភាក្សា និងសម្រេចលើបញ្ហាសំខាន់ៗ"[3368]។ អង្គជំនុំជម្រះមិនបានពន្យល់លម្អិតលើបញ្ហានេះឡើយ។

១៧៤៦. ខៀវ សំផន មិនមែនជាមនុស្សតែម្នាក់នៅក្នុងបក្ស ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំគណៈ អចិន្ត្រៃយ៍ "បើកទូលាយ" ដល់អ្នកមិនមែនជាសមាជិក នោះឡើយ។ ប៉ុន្តែ អង្គជំនុំជម្រះបានទទួលស្គាល់ថា ខុសពីអ្នកផ្សេង ខៀវ សំផន មិនមានទំនួលខុសត្រូវនៅភូមិភាគ ឬតំបន់ និងមិនមានអំណាចពិតប្រាកដក្នុងការដឹកនាំអង្គភាពជាក់លាក់ណាមួយឡើយ[3369]។ ខុសពីអ្នកផ្សេង គាត់ចូលបក្សយឺតជាងគេ ការ

[3367] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៨ និងកំណត់សម្គាល់ជើងទំព័រលេខ ១៣៨៩១ ដែលយោងទៅកថាខណ្ឌ ៣៨៩១ ដែលយោងទៅកំណត់សម្គាល់ជើងទំព័រលេខ ១២៩៧៧ បទសម្ភាសន៍ អៀង សារី ដោយ Stephen HEDER ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ឯកសារ E3/89។ ចំពោះតម្លៃនៃចម្លើយជាលាយលក្ខណ៍អក្សរ (ទាំងចម្លើយរបស់សាក្សីដែលបានទទួលមរណភាព) សូមមើលខាងលើ កថាខណ្ឌ ២៩៦-៣០២។

[3368] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០, ៦០៤, ៦២៤, ៤២២៤, ៤២៣០, ៤២៣៦, ៤២៧៧, ៤៣១៦។

[3369] ជាឧទាហរណ៍៖ សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣២០-៤៣២៥ (នៅក្នុងទីនេះ អង្គជំនុំជម្រះមិនបាន កំណត់យកការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយទទួលស្គាល់ថា លោក ខៀវ សំផន មិនបានធ្វើការត្រួតត្រាណាមួយពិតប្រាកដឡើយ ហើយជាពិសេសទទួលស្គាល់ពីតួនាទីរបស់លោក ក្នុងផ្នែកពាណិជ្ជកម្ម "ដែលកម្រិតតែត្រឹមមុខងាររដ្ឋបាល") កថាខណ្ឌ ៦១៦ (ដែលនៅទីនេះ អង្គជំនុំជម្រះអះអាងថាមិនអាចសន្និដ្ឋានថាលោកជាប្រធានមន្ទីរ៨៧០ សូម្បីជាកម្មាភិបាលដឹកនាំម្នាក់នៅក្នុងមន្ទីរ៨៧០)។ សូមមើលផងដែរ

តែងតាំងគាត់ឱ្យចូលកាន់តំណែងក្នុងរដ្ឋាភិបាលតាំងពីឆ្នាំ១៩៧០ “គឺមានតែឈ្មោះ” គ្មាន “សិទ្ធិអំណាច [...] ឬការទទួលខុសត្រូវ” នៅក្នុងជួរកងទ័ព មុខងារគាត់ “គឺជាភារកិច្ចការទូត”[3370]។ ខុសពីអ្នកផ្សេង ខៀវ សំផន ត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិគណៈមជ្ឈិម ដើម្បីតែកាន់មុខតំណែងជាប្រមុខរដ្ឋ ក្រោយការលាលែងរបស់ សម្ដេច សីហនុ[3371]។

១៧៤៧. ជាក់ស្ដែង ក្រៅពីកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលបង្ហាញអំពីវត្តមានម្ដងម្កាល និងអកម្មជានិច្ច លើកលែងតែការឡើងរាយការណ៍ពីរដងមិនបានការ ភ័ស្តុតាងទាំងអស់នៅក្នុងសំណុំរឿងអាចឱ្យសន្និដ្ឋានថា ខៀវ សំផន ពិតជាកាន់មុខតំណែងពិសេស គឺមុខតំណែងគ្មានឥទ្ធិពល ឬអំណាច ដែល ប.ក.ក យល់ថាមានប្រយោជន៍ក្នុងការផ្ដល់ជូនបញ្ញវន្តមួយរូបដែលមិនមែនជាសមាជិក “វង់ផ្ទៃក្នុង”[3372]។

១៧៤៨. **<u>សរុបសេចក្ដីមក</u>** ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋានថា ខៀវ សំផន កាន់តំណែងពិសេសក្នុងបក្ស តាមរយៈវត្តមានរបស់គាត់ ក្នុងកិច្ចប្រជុំមួយចំនួនរបស់គណៈអចិន្ត្រៃយ៍ រួចទម្លាក់ការទទួលខុសត្រូវលើគាត់ នោះឡើយ។

### ៣. ប្រជាធិបតេយ្យប្រមូលផ្ដុំ

១៧៤៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ តាមបែបបទប្រជាធិបតេយ្យប្រមូលផ្ដុំ ដែលផ្ដល់លទ្ធភាពឱ្យគាត់ធ្វើបទអន្តរាគមន៍[3373]។

---

សាលក្រមសំណុំរឿង០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១០០៥ និង ១០០៧ (ដែលនៅទីនេះ អង្គជំនុំជម្រះទទួលស្គាល់ថា លោក ខៀវ សំផន មិនមានអំណាចដាក់បញ្ជា ទោះបីតែឯង ឬរួមគ្នា ដោយសារតែមិនមានអំណាចគ្រប់គ្រាន់)។

[3370] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៧៦-៥៧៧, ៥៩៣-៥៩៥, ៥៩៧, ៥៩៩។

[3371] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៩៦។

[3372] សារណាបណ្ដឹងសាទុក្ខ០០២/០១ កថាខណ្ឌ ៥៤៧ និងឯកសារយោងដែលបានស្រង់សម្ដី។

[3373] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៩ និង ៤៣២២, ៣៩០-៣៩៧ និង ៣៩៩។

១៧៥០. ចំពោះគណៈមជ្ឈិម ភ័ស្តុតាងមិនអាចគាំទ្រដល់ការអះអាងបែបនេះទេ ពាក់ព័ន្ធនឹងកិច្ចប្រជុំដែលអង្គជំនុំជម្រះទំនងជាសំដៅដល់[3374]។ គ្មានភ័ស្តុតាងអំពីការរៀបចំកិច្ចប្រជុំ ឬគ្មានភ័ស្តុតាង ឬគ្មានភ័ស្តុតាងគ្រប់គ្រាន់អំពីវត្តមានរបស់ ខៀវ សំផន[3375]។ ពិសេសជាងនេះទៀត គ្មានភ័ស្តុតាងអំពីការធ្វើបទអន្តរាគមន៍ណាមួយពីសំណាក់គាត់ឡើយ។

១៧៥១. ចំពោះគណៈអចិន្ត្រៃយ៍ ជាអង្គការសម្រេចកំពូល អង្គជំនុំជម្រះមិនបានបញ្ជាក់ថាជាកិច្ចប្រជុំបែបណាទេ[3376]។ អង្គជំនុំជម្រះជឿជាក់ថា សេចក្តីសម្រេចគន្លឹះរបស់គណៈអចិន្ត្រៃយ៍ "មិនមែនត្រូវបានធ្វើឡើងដោយ ប៉ុល ពត តែម្នាក់ឯងនោះទេ ផ្ទុយទៅវិញ សេចក្តីសម្រេចទាំងនេះត្រូវបានធ្វើឡើងជាសមូហភាព ដែលមានន័យថា មានមតិយោបល់ និងមានការឯកភាពជាឯកច្ឆន្ទពីគណៈកម្មាធិការទាំងមូល"[3377]។ ប៉ុន្តែ ខៀវ សំផន មិនមែនជាសមាជិកគណៈអចិន្ត្រៃយ៍ទេ។ ក្រៅពីនេះទៀត គ្មានភ័ស្តុតាងបង្ហាញថា ខៀវ សំផន បានធ្វើបទអន្តរាគមន៍ផ្សេងក្រៅពីឡើងរាយការណ៍នោះឡើយ (២ ដងគត់)[3378]។

១៧៥២. លើសពីនេះទៀត សេចក្តីសន្និដ្ឋាននេះរបស់អង្គជំនុំជម្រះផ្ទុយនឹងការសន្និដ្ឋានថា ប៉ុល ពត និង នួន ជា "មានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយបំផុត" ឬជា "អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចុងក្រោយបំផុត"[3379]។ បន្ថែមលើនេះទៀត សេចក្តីសន្និដ្ឋាននេះផ្អែកលើចម្លើយរបស់ នួន ជា, អៀង សារី និង ខៀវ សំផន ដែលត្រូវបានជ្រើសរើសដោយយកចិត្តទុកដាក់ខ្លាំងជាង

---

[3374] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៩ ដែលនៅទីនេះហាក់ដូចជាលោកឡើងអំពីសមាជបក្ស និង សេចក្តីសម្រេច ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៧៦។

[3375] សូមមើលខាងលើ កថាខណ្ឌ ១៧១៧ និង ១៧២៣-១៧២៨។

[3376] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣២២។

[3377] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3378] សូមមើលខាងលើ កថាខណ្ឌ ១៧៣៧-១៧៣៨។

[3379] សំអាងហេតុសាលក្រម កថាខណ្ឌ៥៦១, ៤១២៧, ៤១៨៧, ៤១៩៦, ៤៣៧៧។

ចម្លើយរបស់អ្នកជំនាញដោះបន្ទុក[3380]។ ម្ចាស់បណ្តឹងសាទុក្ខសូមយោងទៅទឡ្ហីករណ៍ពី មុនៗរបស់ខ្លួន អំពីការជ្រើសសម្រាំង តម្លៃ និងការបំភ្លៃចម្លើយដែលត្រូវបានប្រើប្រាស់ ផ្ទុយនឹងភ័ស្តុតាងផ្សេងទៀត[3381]។ ម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែសូមបន្ថែមថា អង្គជំនុំជម្រះមិនបានពន្យល់ថា ហេតុអ្វីបានជាអង្គជំនុំជម្រះបានសម្រេចផ្អែកលើចម្លើយ ដែលត្រូវបានចម្លងឡើងវិញនៅក្នុងឯកសារមួយ គ្មានចុះកាលបរិច្ឆេទ គ្មានឈ្មោះអ្នកនិពន្ធ ជាជាងចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងបរិបទតុលាការ ដែលមានតម្លៃជាភ័ស្តុតាងសំខាន់ជាង[3382]។ ជាចុងក្រោយ ការអានកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដែលអង្គជំនុំជម្រះបានផ្អែកលើយ៉ាងខ្លាំង បង្ហាញថា លេខាតែឯង ឬលេខា និងអនុលេខា ជាអ្នកធ្វើសេចក្តីសម្រេច[3383]។

១៧៥៣. សរុបសេចក្តីមក អង្គជំនុំជម្រះមិនអាចផ្អែកលើបែបបទប្រជាធិបតេយ្យប្រមូលផ្តុំ ដើម្បីទម្លាក់ការទទួលខុសត្រូវលើ ខៀវ សំផន បានឡើយ ហើយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

---

[3380] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩២-៣៩៥ និង ៣៩៧។ គឺជាឧទាហរណ៍មួយដ៏ល្អឥតខ្ចោះនៃការអនុវត្តបានមួយចំណែកនៃស្តង់ដារពីរនៃអង្គជំនុំជម្រះ សូមមើលខាងលើ កថាខណ្ឌ ២៣៤។

[3381] សារណាបណ្តឹងសាទុក្ខ០០២/០១ កថាខណ្ឌ ១២៦-១៣៨។

[3382] កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/27** ERN 00156618-19 ("គណៈកម្មាធិការមជ្ឈិម មិនមានអំណាចពិតប្រាកដទេ ខុសពីគណៈកម្មាធិការអចិន្ត្រៃយ៍។ នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នេះ ផ្អែកលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ មនុស្សដែលសំខាន់ជាងគេ គឺលេខា និងអនុលេខា បានន័យថា ប៉ុល ពត និង នួន ជា។ [...] លេខា និងអនុលេខាអនុវត្តអំណាចរបស់ខ្លួនក្នុងចន្លោះពេលនៃមហាសន្និបាត បានន័យថាពួកគេជាអ្នកសម្រេចការងារទាំងអស់ ដោយមានការរឹតត្បិតតែមួយទេ គឺគោរពតាមស្មារតីនៃមហាសន្និបាត។ ដូច្នេះបានន័យថា ប៉ុល ពត មានអំណាចធំណាស់")។

[3383] ជាឧទាហរណ៍ កំណត់ហេតុនៃអង្គប្រជុំដែលសេចក្តីសម្រេចត្រូវបានចេញ ឬបានផ្តល់ការណែនាំ ដែលមានបញ្ជាក់វត្តមាននៃលេខា និងអនុលេខា ដែលសុទ្ធតែជាសមាជិកគណៈអចិន្ត្រៃយ៍៖ កំណត់ហេតុនៃអង្គប្រជុំការងារឃោសនាការ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ ឯកសារ **E3/225** ERN 00000837, 00000840-41។ កំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋាន ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/232** ERN 00017116, 00017118-19។ កំណត់ហេតុប្រជុំការងារសង្គមកិច្ចសុខាភិបាល ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ឯកសារ **E3/226** ERN 00017147, 00017153-59 (លេខាជាអ្នកសម្រេច)។

## ផ្នែកទី ៤. មុខងារបន្ទាប់បន្សំ

### ១. វគ្គរៀនសូត្រ

១៧៥៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ខៀវ សំផន "បានចូលរួម និងបង្រៀនវគ្គរៀនសូត្រនយោបាយ" ដែលមានសិក្ខាកាម "ចាប់ពីយុវជន រហូតដល់កម្មាភិបាល ប.ក.ក និងអ្នកត្រឡប់មកពីបរទេស ដែលមានចំនួនរាប់សិបនាក់ រហូតដល់រាប់ពាន់នាក់" ដោយពួកគេបានទទួលការបង្រៀនពីវិធី "កំណត់អត្តសញ្ញាខ្មាំង និងស្វែងរកជនក្បត់"[3384]។ នៅក្នុងផ្នែកនេះនៃសំអាងហេតុសាលក្រម ការវិភាគដោយលម្អៀងរបស់អង្គជំនុំជម្រះទៅលើភ័ស្តុតាង ស្តែងឱ្យឃើញយ៉ាងច្បាស់ក្រឡែត។ ជាក់ស្តែង សាក្សីដែលត្រូវបានលើកឡើង ដើម្បីឈានដល់ការសន្និដ្ឋាននេះ បានរៀបរាប់រឿងរ៉ាវផ្សេងៗ និងខុសៗគ្នា អំពីខ្លឹមសារនៃវគ្គរៀនសូត្រ និងសម្តីដែលត្រូវបានសន្មតថា ខៀវ សំផន ជាអ្នកនិយាយ។ ម្យ៉ាង អង្គជំនុំជម្រះបានរំលោភលើគោលការណ៍ពិនិត្យភ័ស្តុតាង ដោយធ្វើមិនដឹងមិនឮជាប្រព័ន្ធចំពោះភាពខុសគ្នាដ៏សំខាន់ជាច្រើនរបស់សាក្សី ដែលផ្តល់សក្ខីកម្មដាក់បន្ទុកអំពីសម្តីដែលត្រូវបានសន្មតថា ខៀវ សំផន គឺជាអ្នកនិយាយ។ (១.១) ម្យ៉ាងទៀត អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ក្នុងការវាយតម្លៃលើសក្ខីកម្មអំពីខ្លឹមសារនៃវគ្គរៀនសូត្រនយោបាយទាំងនេះ និងតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងក្របខ័ណ្ឌវគ្គរៀនសូត្រទាំងនេះ (១.២)។

#### ១.១. កំហុសពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់សាក្សីដាក់បន្ទុក

១៧៥៥. ក្នុងចំណោមសាក្សីដែលត្រូវបានអង្គជំនុំជម្រះលើកឡើង ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន មានតែ អែម អឿន និង ឯក ហេន ប៉ុណ្ណោះ ដែលបានសន្មតជាក់លាក់ថា ខៀវ សំផន ជាអ្នកនិយាយអំពី "ខ្មាំង"។ អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ពួកគេ ដើម្បីសន្និដ្ឋានអំពីការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងការផ្សព្វផ្សាយគោលនយោបាយស្តីពី "ខ្មាំង"។ ក៏ប៉ុន្តែ គ្មានសក្ខីកម្មណាមួយអាចឱ្យ

[3384] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៧។

សន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ម្ចាស់បណ្តឹងសាទុក្ខបានផ្សព្វផ្សាយគោលនយោបាយបែបនេះ ឬមានចេតនាផ្តល់ការគាំទ្រណាមួយដល់គោលនយោបាយនេះឡើយ។

១៧៥៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយយល់ឃើញថាអាចជឿជាក់បាន ចំពោះសម្តីរបស់សាក្សីដែលបានឆ្លើយថា ឮ ខៀវ សំផន អំពាវនាវឱ្យកំណត់អត្តសញ្ញាណ និងស្វែងរកខ្មាំង និងជនក្បត់។ សាក្សីទាំងនេះ គឺ ឯក ហេន (១.១.១) និង អែម អឿន (១.១.២)[3385]។ ប៉ុន្តែ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់យល់ឃើញថា ចម្លើយទាំងនេះអាចជឿជាក់/ទុកចិត្តបានគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីសម្តីពិតប្រាកដរបស់ ខៀវ សំផន នោះឡើយ។

## ១.១.១. ភាពផ្ទុយគ្នារបស់ អែម អឿន

១៧៥៧. អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ អែម អឿន ដើម្បីបង្ហាញថា ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងអំពី "ជនក្បត់បដិវត្តន៍" និង "ខ្មាំងបង្កប់"[3386]។ ដើមបណ្តឹងរដ្ឋប្បវេណីនេះមិនបានផ្តល់សក្ខីកម្មគួរឱ្យជឿជាក់បាន នៅចំពោះមុខតុលាការ។ ជាក់ស្តែង សក្ខីកម្មរបស់គាត់ពោរពេញដោយភាពផ្ទុយគ្នា និងភាពមិនសមទំនង ទាំងនៅក្នុងសវនាការ និងក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អែម អឿន បានឆ្លើយថាគាត់បាន "ចូលរួមវគ្គ" រៀនសូត្រ តែម្តងគត់ នៅបុរីកីឡា[3387]។ ការនឹកឃើញសម្តីគ្រប់ម៉ាត់នៃបទឧទ្ទេសនាមរបស់ ខៀវ សំផន ស្តីពីការជំរុញឱ្យតាមដាន "ខ្មាំង" គឺមិនអាចទៅរួចទេ ដោយហេតុថា អែម អឿន បានពន្យល់ថា អ្នកឧទ្ទេសនាមទាំងអស់បាននិយាយដដែលៗដូចៗគ្នា[3388]។

---

[3385] ស្តីពីបញ្ហាជាក់លាក់ពាក់ព័ន្ធនឹងសម្តីដែល លោក ខៀវ សំផន បាននិយាយ ស្តីពីការរៀបអាពាហ៍ពិពាហ៍ នៅក្នុងវគ្គរៀនសូត្រមួយនៅវត្តឧណ្ណាលោម ជំនុំជំរះក៏បានដកស្រង់សំដីរបស់ ជា ខៀប ដែរ។ សូមមើលខាងលើ កថាខណ្ឌ ១២៣៣-១២៣៧។

[3386] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ១៩០៤។ អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/115.1** ទំព័រ ២៤ ដល់ ៣៣, ៤៦ ដល់ ៤៨ ដូចដែលអង្គជំនុំជម្រះបានស្រង់សម្តី។

[3387] អែម អឿន ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/115.1** ក្រោយម៉ោង 10.11.49។

[3388] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ម៉ោង 15.51.52។

ខណៈដែលគាត់បានសម្រេចយកខែមិថុនា ឆ្នាំ១៩៧៥ ជាពេលដែលគាត់មកដល់ទីក្រុងភ្នំពេញ[3389] គាត់មិនអាចកំណត់ពេលវេលាត្រឹមត្រូវនៃវគ្គរៀនសូត្រនេះបានទេ។ ជាក់ស្តែង គាត់បានកំណត់កាលបរិច្ឆេទនៃវគ្គរៀនសូត្រនេះខុសគ្នា ក្នុងពេលផ្តល់សក្ខីកម្ម គឺពីដំបូង នៅឆ្នាំ១៩៧៧[3390] រួច នៅឆ្នាំ១៩៧៥[3391] បន្ទាប់មក នៅឆ្នាំ១៩៧៦[3392] ហើយជាចុងក្រោយ គាត់បាននិយាយថា វគ្គរៀនសូត្រនយោបាយត្រូវបានធ្វើឡើង "ប្រហែលជាពីរខែក្រោយពេលខ្ញុំចូលមករៀនពេទ្យ"[3393]។

១៧៥៨. ភាពមិនសមទំនងបានឈានដល់កម្រិតកំពូល ពេលគាត់អះអាងថាក្នុងវគ្គរៀនសូត្រនោះ ខៀវ សំផន គឺជាប្រធានគណៈប្រធានរដ្ឋ ជាមុខងារដែលគាត់បានឮចេញពីមាត់របស់ឪពុកគាត់ ដែលបាត់ខ្លួន នៅឆ្នាំ១៩៧៤[3394]។ ម្យ៉ាងវិញទៀត រឿងរ៉ាវផ្សេងៗគ្នាអំពីកាលៈទេសៈនៃការស្លាប់របស់ម្តាយគាត់ (ប្រែប្រួលទៅតាមអ្នកសួរសំណួរ នៅក្នុងសវនាការតែមួយ[3395]) និងចម្លើយគួរឱ្យភ្ញាក់ផ្អើលអំពីការរៀបការ

---

[3389] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** ម៉ោង 09.11.47 (មកដល់មន្ទីរពេទ្យសូវៀត នៅខែមិថុនា ៧៥)។

[3390] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** មុនម៉ោង 09.11.47៖ ("ខ្ញុំគិតថានៅចុងឆ្នាំ៧៧")។

[3391] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** ម៉ោង 09.15.11 ឆ្លើយទៅនឹងសំណួរដែលចង់សួរថា តើតាំងពីពេលណាមកដែលគាត់នៅភ្នំពេញ នៅពេលរៀនសូត្រ នៅបុរីកីឡា គាត់ឆ្លើយថា៖ ("មកដល់ពីរខែ បានខ្ញុំចូលសិក្សាវគ្គសិក្សានយោបាយ"។ សូមមើលផងដែរ ម៉ោង 09.16.20។

[3392] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** មុនម៉ោង 09.22.46 និង បន្ទាប់ម៉ោង 09.25.36។

[3393] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** ពីម៉ោង 09.22.46 ដល់ម៉ោង 09.28.59។

[3394] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** ម៉ោង 14.59.53។ <u>ស្តីពីការបាត់ខ្លួនរបស់ឪពុកគាត់</u>៖ ម៉ោង 15.24.58៖ ("បាត់ខ្លួននៅឆ្នាំ ៧៤")។ ម៉ោង 15.31.46៖ "ខ្ញុំទទួលស្គាល់ គឺ ១៩៧៤"។។ <u>ស្តីពីតួនាទីរបស់ លោក ខៀវ សំផន</u>) ម៉ោង 15.49.17៖ ("តួនាទីដែលខ្ញុំបានដឹង ព្រោះខ្ញុំបានដឹងទៅតាមដំណើរឪពុកខ្ញុំផង លោកខឹមគណៈតំបន់ផង និងលោក សោ ភឹម ផង គឺខ្ញុំស្គាល់នាទីថា លោក ខៀវ សំផន ធ្វើអ្វី លោក នួន ជា គាត់ធ្វើអ្វី")។ សូមរំឭកថា លោក ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ នៅខែមេសា ឆ្នាំ១៩៧៦៖ ឯកសារដែលនិយាយអំពីសមាជទី១ នីតិកាលទី១ នៃសភាតំណាងប្រជាជនកម្ពុជា ប្រព្រឹត្តទៅ ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/165** ERN 00301353។ អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/116.1 ម៉ោង 15.57.30៖ "គឺរឿងពិតជាខ្ញុំបាននិយាយ"។។

[3395] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/116.1** មុនម៉ោង 15.02.25 ("ម្តាយខ្ញុំស្លាប់ក្រោយពេលគាត់ឃើញគេហៅខ្ញុំទៅ")។ មុនម៉ោង 15.26.39 ("នៅពេលក្រោយឆ្នាំ ៧៤ ម្តាយខ្ញុំស្លាប់។ គាត់ស្លាប់នោះគឺនៅពេលដែលគាត់ឃើញគេយករូបខ្ញុំទៅ។ អ៊ីចឹងហើយបានខ្ញុំចាំជាប់ គឺចាំនៅពេលដែលម្តាយស្លាប់")។ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ឯកសារ

របស់គាត់ ធ្វើឱ្យប៉ះពាល់ភាពអាចជឿជាក់បានជាទូទៅនៃសក្ខីកម្មរបស់គាត់[3396]។ អង្គជំនុំជម្រះមិនអាចផ្អែកលើសក្ខីកម្មរបស់គាត់ ក្នុងក្របខ័ណ្ឌនៃការពិភាក្សាសម្រេច និងខកខានមិនបានបំពេញកាតព្វកិច្ចផ្តល់សំអាងហេតុ ដោយធ្វើមិនដឹងមិនឮទាំងស្រុងចំពោះភាពផ្ទុយគ្នារហូតនៅក្នុងសក្ខីកម្មរបស់គាត់ទាំងមូល ដែលត្រូវបានលើកឡើងក្នុងពេលសួរដេញដោលរបស់មេធាវីការពារក្តី។

## ១.១.២. ភាពច្របូកច្របល់របស់ ឯក ហេន

១៧៥៩. ចម្លើយរបស់ ឯក ហេន ក៏មានភាពច្របូកច្របល់ខ្លាំង មិនអាចឱ្យអង្គជំនុំជម្រះមកធ្វើជាមូលដ្ឋានបង្ហាញអំពីសម្តីរបស់ ខៀវ សំផន បានឡើយ។ ជាក់ស្តែង គាត់បានឆ្លើយក្នុងសវនាការថា គាត់បានចូលរួមប្រជុំ ពីរដង នៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨។ គាត់បានអះអាងថា កិច្ចប្រជុំលើកទីពីរនិយាយអំពីប្រធានបទខ្លាំង ប៉ុន្តែ គាត់មិនអាចប្រាប់បានថា តើ នួន ជា ឬ ខៀវ សំផន ជាវាគ្មិននោះទេ[3397]។ ចម្លើយផ្ទុយគ្នារបស់គាត់អំពីអត្តសញ្ញាណ និងខ្លឹមសារនៃសម្តីរបស់អ្នកឧទ្ទេសនាម ត្រូវបានធ្វើឱ្យកាន់តែអស់តម្លៃដោយចម្លើយថ្មី នៅក្នុងកំណត់ហេតុមកពីសំណុំរឿង ០០៣-០០៤ ដែលទើបត្រូវបាន

---

**E1/117.1** មុនម៉ោង 09.50.00 (“ពេលដែលខ្ញុំនឹកគ្រប់បញ្ហាម្តាយខ្ញុំស្លាប់ហេតុតែស្លាប់ [...] ដល់មើលចុះមើលឡើង អូ ម្តាយខ្ញុំស្លាប់នៅក្នុងពេលយន្តហោះទម្លាក់គ្រាប់បែក។ ហើយខ្ញុំពិចារណាមើលទៀតថា មុនពេលនឹងតើមានរឿងអីទៀត [...] មើលចុះមើលឡើង អូ មុនពេលទម្លាក់គ្រាប់បែកនេះ ឪពុកខ្ញុំត្រូវការចាប់”)។ ម៉ោង 09.51.21៖ (“យន្តហោះទម្លាក់ពីយប់ ព្រលឹមឡើងម្តាយស្លាប់ទៀត។ ទុក្ខវេទនាធ្ងន់ធ្ងរ”)។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ ឯកសារ **E3/1729** ERN 00786184 ឯកសារ អែម អឿន បានធ្វើការពណ៌នាមួយផ្សេងទៀត ដោយនិយាយថាម្តាយគាត់ត្រូវគេចាប់នៅវត្តព្រៃព្រះស្មោន និងត្រូវពួកប៉ុល ពត សម្លាប់៖ ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/117.1** ក្រោយម៉ោង 10.12.02។ ម៉ោង 10.14.24 (គាត់អះអាងបញ្ជាក់ថាម្តាយគាត់ស្លាប់ បន្ទាប់ពីយន្តហោះអាមេរិកទម្លាក់គ្រាប់បែក)។

[3396] អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/115.1** ក្រោយម៉ោង 16.03.21។ សូមមើលខាងលើផងដែរ កថាខណ្ឌ ១១៧២។

[3397] ឯក ហេន៖ ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ក្រោយម៉ោង 14.04.37 និងមុនម៉ោង 15.28.00។ ការភាន់ច្រឡំរបស់គាត់កាន់តែឃើញច្បាស់ទៀតនៅពេលដែលគាត់យោងទៅខ្សែអាត់ថតសម្លេងចំពោះអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបសួរ៖ ប្រតិចារឹក ឯកសារ **D94/8.1** ERN 00936440-41 ចាក់ផ្សាយនៅក្នុងសវនាការ ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ក្រោយម៉ោង 14.31.48។

ទទួលយកជាភ័ស្តុតាងកាលពីពេលថ្មីៗកន្លងទៅនេះ[3398]។ ឯក ហេន បានទទួលស្គាល់ថា គាត់ប្រហែលជា "ឆ្លើយខុសសំណួរ" ដោយសារតែគាត់មានការ "ភ្លេចភ្លាំង"[3399]។ ទោះជាយ៉ាងណាក៏ដោយ ប្រឈមនឹងភាពច្របូកច្របល់ និងភាពមិនច្បាស់លាស់ អង្គជំនុំជម្រះមិនគួរណាផ្អែកលើសក្ខីកម្មរបស់គាត់ សម្រាប់សេចក្តីសន្និដ្ឋានរបស់ខ្លួន នោះឡើយ។

## ១.២. កំហុសពាក់ព័ន្ធនឹងខ្លឹមសារនៃវគ្គរៀនសូត្រនយោបាយ

១៧៦០. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រើប្រាស់សម្តីដែលត្រូវបានសន្មតថា ខៀវ សំផន ជាអ្នកនិយាយ អំពីផែនការសេដ្ឋកិច្ចទូទៅរបស់ ប.ក.ក ដើម្បីបញ្ជាក់ពីការចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម។ ជាក់ស្តែង ក្រៅពីសាក្សីខាងលើដែលបានផ្តល់ចម្លើយប្រែប្រួល និងច្របូកច្របល់ប្រធានបទ ដែលត្រូវបានពិភាក្សានៅក្នុងវគ្គរៀនសូត្រ ដូចបានរៀបរាប់ដោយសាក្សីដែលបានលើកឡើងនៅក្នុងសំអាងហេតុសាលក្រម មិនអាចឱ្យអះអាងអំពីចេតនាឧក្រិដ្ឋរបស់ម្ចាស់បណ្តឹងសាទុក្ខឡើយ។ គ្មានតម្រុយណាមួយអាចឱ្យសន្និដ្ឋានថា គោលនយោបាយ ដែលត្រូវបានឧទ្ទេសនាម នៅក្នុងវគ្គរៀនសូត្រទាំងនេះ មានលក្ខណៈឧក្រិដ្ឋ ឬ ខៀវ សំផន មាន តួនាទីសំខាន់ឡើយ។ សាក្សី ដែលអង្គជំនុំជម្រះបានលើកឡើង ដូចជា ពាន ឃាន, ភី ភួន, អ៊ុង ចុងហឿង, ជា សាយ, Philip SHORT និង សៅ សារុន មិនបានឆ្លើយក្នុងន័យនេះទេ។

---

[3398] សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ **F51** កថាខណ្ឌ ១៦-៥៤។

[3399] ឯក ហេន៖ ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ E1/217.1 ម៉ោង 14.15.01។ គួរកត់សម្គាល់៖ ទោះបីជាគាត់នឹកឃើញស្រពិចស្រពិលក្តី តែគាត់បានបញ្ជាក់ថា ពាក្យសម្តីដែលគាត់បានឮ លោក ខៀវ សំផន និយាយ មិនមានអ្វីអវិជ្ជមានទេ។ ឯក ហេន៖ ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** មុនម៉ោង 11.23.39 ("គាត់និយាយតែរឿងការងារ ឱ្យប្រឹងតស៊ូ សាមគ្គីគ្នា ស្រឡាញ់គ្នា ចេះរាប់អានគ្នា ជួយគ្នាណា។ គាត់មានយោបល់គឺល្អដែរ")។

១៧៦១. សាក្សី ដែលបានលើកឡើងអំពីវត្តមានរបស់ ខៀវ សំផន ក្នុងមិទ្ទីង បានអះអាងថា គាត់មិនសូវនិយាយស្តីទេ ដោយសារតែ នួន ជា មានតួនាទីជាអ្នកបង្រៀន[3400]។ ជា សាយ បានបន្ថែមថា "ខៀវ សំផន មិនសូវបានបង្រៀនទេ"[3401]។ សាក្សីជាច្រើនផ្សេងទៀតបានលើកឡើងអំពីវត្តមានធម្មតារបស់ ខៀវ សំផន ក្នុងពេលបើកវគ្គរៀនសូត្រ ដូចជា សៅ សារុន ជាដើម ដែលបាននិយាយថា ប៉ុល ពត និង នួន ជា ជាអ្នកបង្រៀន ក្នុងវគ្គរៀនសូត្រ[3402] ប៉ុន្តែ ចម្លើយនេះមិនត្រូវបានយកចិត្តទុកដាក់ទេ។ ចម្លើយនេះមានភាពស៊ីចង្វាក់គ្នាជាមួយ រ៉ចាម គុន ហៅ ភី ភួន ជាសាក្សីដ៏សំខាន់របស់អង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០១៖ "ការដឹកនាំប្រជុំនៅនុ៎ង មានតែអ៊ំ ប៉ុល ពត ហើយអ៊ំ នួន ជា នេះ ជាអ្នកដឹកនាំប្រជុំកន្លែងហ្នឹង"[3403] ពិតមែនតែ អៀង សារី និង ខៀវ សំផន មានវត្តមានក៏ដោយ។ ម្យ៉ាងទៀត គាត់មិនចាំថា ឮគេនិយាយពាក្យ "កម្ទេច" ខ្លាំងទេ[3404]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានលាក់បាំងទាំងស្រុងនូវផ្នែកនេះនៃសក្ខីកម្មរបស់គាត់។

១៧៦២. ចំពោះខ្លឹមសារនៃវគ្គរៀនសូត្រទាំងនេះ ជា សាយ ក៏បានអះអាងផងដែរថា មិនមានការញុះញង់ឱ្យ "ធ្វើអំពើអាក្រក់" អ្វីទេ គឺលើកទឹកចិត្ត "ឱ្យខំការងារឱ្យរីកចម្រើនកសាងប្រទេស" ហើយគាត់បានបន្ថែមទៀតថា "គឺថាអប់រំឱ្យធ្វើល្អ ខ្ញុំមានអារម្មណ៍តាំងពីនុ៎ងមក" គឺ "ធ្វើអំពើល្អ មិនធ្វើអំពើអាក្រក់

---

[3400] ត្រូវគ្នាទៅនឹងតួនាទីក្នុងការអប់រំដែលគាត់តែងតែនិយាយថាធ្លាប់បានរ៉ាប់រង។ នួន ជា៖ ប្រតិចារឹក ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ **E1/14.1** ក្រោយម៉ោង 14.55.43។ ប្រតិចារឹក ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ឯកសារ **E1/23.1** ក្រោយម៉ោង 14.05.10។ សូមមើលផងដែរសំអាងហេតុសាលក្រម កថាខណ្ឌ៥៤១ កំណត់សម្គាល់ជើងទំព័រលេខ ១៦៨៨។

[3401] ជា សាយ៖ ប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ **E1/124.1** ក្រោយម៉ោង 13.59.04៖ ("ខៀវ សំផន មិនសូវបានបង្រៀនទេ ដូចលោក នួន ជា បានគាត់បង្រៀនច្រើន [...] ខ្ញុំចង់សំដៅថា ពេលដែលខ្ញុំធ្លាប់រៀនសាចុះសាឡើង ជួបគាត់តែម្តង ក្រៅពីនោះ គឺលោក នួន ជា ច្រើនបង្រៀន")។

[3402] <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/82.1** ម៉ោង 10.00.04 និងម៉ោង 11.03.32។ វាក៏ជាការមានប្រយោជន៍ដែរក្នុងការបង្ហាញសក្ខីកម្មរបស់ ស្នួង ស៊ីគឿន អតីតកម្មាភិបាលនៅក្រសួងការបរទេស ដែលបានរំឮកពីវគ្គរៀនសូត្រនៅបុរីកីឡាសម្រាប់កម្មាភិបាលបក្ស ដែលក្នុងពេលនោះបានឃើញ លោក ខៀវ សំផន ពីចម្ងាយ៖ ស្នួង ស៊ីគឿន ប្រតិចារឹក ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/102.1** មុនម៉ោង 14.18.22៖ "គឺមាន ប៉ុល ពត និង នួន ជា មានពីរនាក់ធ្វើបទឧទ្ទេសនាម ក្នុងវគ្គនៅក្នុងសាលាបក្សនេះ"។

[3403] រ៉ចាម គុន ហៅ ភី ភួន៖ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/97.1** មុនម៉ោង 14.31.06។

[3404] រ៉ចាម គុន ហៅ ភី ភួន៖ ប្រតិចារឹក ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/99.1** មុនម៉ោង 11.36.08។

ទៅលើអ្នកដទៃណា បាទ។ មានតែជួយអ្នកផងទាំងពួង"[3405]។ ចំណែកឯ ពាន ឃាន គាត់បានលើកឡើងអំពីសុន្ទរកថាបង្ហាញគោលនយោបាយកសាង "ប្រទេសធ្វើម៉េចឱ្យរីកចម្រើន"[3406]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនបានលើកឡើងថា មិនមានមូលដ្ឋានអាចឱ្យទាញបាននូវចេតនាឧក្រិដ្ឋរបស់ ខៀវ សំផន ចេញពីសម្ដីជាពាក្យចចាមអារ៉ាម ដូច អ៊ុង ផុងហឿង[3407] ឬ Philip SHORT បានលើកឡើង[3408]។ ដូច្នេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា ការចូលរួមរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងវគ្គរៀនសូត្រ អាចឱ្យសន្និដ្ឋានអំពីការចូលរួមចំណែកដ៏សំខាន់របស់គាត់ ក្នុងសហឧក្រិដ្ឋកម្មរួម។ ដូច្នេះ សេចក្ដីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះក្នុងន័យនេះ នឹងត្រូវទុកជាមោឃៈ[3409]។

## ២. សមាជិកមន្ទីរ ៨៧០

១៧៦៣. អង្គជំនុំជម្រះបានរកឃើញយ៉ាងត្រឹមត្រូវថា "ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់ ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងមន្ទីរ ៨៧០ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានទេថា គាត់បានបំពេញតួនាទីជាប្រធានមន្ទីរ ៨៧០ ឬគាត់ជាកម្មាភិបាលដឹកនាំ"[3410]។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានយល់ឃើញថា ខៀវ សំផន បានក្លាយជាសមាជិកមន្ទីរ ៨៧០ នៅខែតុលា ឆ្នាំ ១៩៧៥ (២.១) និងបានចាត់ទុក ខៀវ ជា "អ្នកគ្រប់គ្រងពីមុន" របស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងមន្ទីរនេះ ដែលជាការសន្និដ្ឋានពង្រីកលើតួនាទីរបស់ ខៀវ សំផន ផ្ទុយពីការសន្និដ្ឋានផ្ទាល់របស់ខ្លួន (២.២)។

---

[3405] ជា សាយ៖ ប្រតិចារឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E1/124.1 ក្រោយម៉ោង 10.26.22។

[3406] ពាន ឃាន៖ ប្រតិចារឹក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ ឯកសារ E1/73.1 ទំព័រ ២១-២៥ ដូចបានស្រង់សម្ដីដោយអង្គជំនុំជម្រះ។

[3407] អ៊ុង ផុងហឿង៖ ប្រតិចារឹក ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/107.1 ម៉ោង 13.59.56។ មិនមានសក្ខីកម្មដោយផ្ទាល់ស្ដីពីវគ្គរៀនសូត្រដែល លោក ខៀវ សំផន បានបង្រៀនដល់បញ្ញាជនឡើយ។ លោក អ៊ុង ផុងហឿង បានស្រង់សម្ដីដែលប្រពន្ធគាត់បានឮ នៅពេលគាត់មកដល់ប្រទេសកម្ពុជា នៅដើមឆ្នាំ ៧៦។ ប្រតិចារឹក ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/103.1 មុនម៉ោង 15.36.23 ("[លោក ខៀវ សំផន] គាត់បង្រៀនយើងថាមករកផ្លូវស្នេហាជាតិហ្នឹងត្រឹមត្រូវហើយ។ ត្រូវមានមោទនភាពជាតិ។ ហើយទីពីរ ប្រទេសកម្ពុជាកំពុងតែកសាង ឱ្យទុកចិត្តប្រជារាស្ត្រ ប្រជាជនកម្ពុជា ហើយឱ្យខំកសាងខ្លួន ផ្សេងទៀតខ្ញុំអត់ចាំទេ")។

[3408] Philip SHORT "ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ" ឯកសារ E3/9 ទំព័រ ៤០៧-៤១០ ERN FR 00639870-73។

[3409] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៥, ៦០៧, ៣៧៣៦, ៣៧៣៩ និង កថាខណ្ឌ ៤២៥៣, ៤២៦២, ៤២៦៤, ៤២៧២, ៤៣០៦។

[3410] សំអាងហេតុសាលក្រម កថាខណ្ឌ៦១៦។

## ២.១. កំហុសពាក់ព័ន្ធនឹងសមាជិកភាពនៃមន្ទីរ ៨៧០ នៅខែតុលា ឆ្នាំ១៩៧៥

១៧៦៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួន អំពីការសហការរបស់ម្ចាស់បណ្ដឹងសាទុក្ខ ជាមួយមន្ទីរ ៨៧០ ដោយខកខានមិនបានលើកឡើងថា ការសហការនេះគឺពាក់ព័ន្ធផ្ដាច់មុខតែបញ្ហាទាក់ទិននឹងពាណិជ្ជកម្មប៉ុណ្ណោះ។ ជាដំបូង អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា "សឿ វ៉ាស៊ី ហៅ ឌឿន [...] ត្រូវបានតែងតាំងជាប្រធានមន្ទីរ នៅខែតុលា ឆ្នាំ១៩៧៥ និង ខៀវ សំផន [...] ចូលរួមប្រហែលជានៅពេលជាមួយគ្នានោះដែរ"[3411]។ ដើម្បីឈានដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះបានផ្អែក ជាអាទិ៍ លើកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥[3412]។ ក៏ប៉ុន្តែឯកសារនេះមិនបានបញ្ជាក់ថា ម្ចាស់បណ្ដឹងសាទុក្ខជាសមាជិកមន្ទីរ ៨៧០ ទេ គឺចាត់តាំងគាត់ឱ្យ "ទទួលរណសិរ្ស និងរាជរដ្ឋាភិបាល ពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ"[3413]។ ដូច្នេះ ក្នុងកំណត់ហេតុនេះ គ្មានការភ្ជាប់ការចាត់តាំងគាត់ទៅនឹងមុខងារណាមួយនៅមន្ទីរ ៨៧០ ឡើយ គឺអ្នកផ្សេងទៀតត្រូវបានចាត់តាំង[3414]។

១៧៦៥. អង្គជំនុំជម្រះមិនអាចផ្អែកលើចម្លើយរបស់ម្ចាស់បណ្ដឹងសាទុក្ខ ដែលតែងតែភាន់ច្រឡំ ដោយបានលើកឡើងអំពីមុខងារទាំងអស់របស់គាត់ ក្នុងក្របខ័ណ្ឌនៃបញ្ជីតម្លៃ និងការទទួលខុសត្រូវរបស់គាត់ក្នុងការ

---

[3411] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៨។

[3412] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៨ កំណត់សម្គាល់ជើងទំព័រលេខ ១៩០៩។

[3413] កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារ **E3/182** ទំព័រ ១-២ ERN 00019108 ("ស.ម មិត្តហែម ទទួលរណសិរ្ស រាជរដ្ឋាភិបាល **ពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ**" យើងខ្ញុំជាអ្នកដាក់អក្សរដិត)។ អ្នកទទួលបន្ទុក "ពាណិជ្ជកម្មជាតិ និងអន្តរជាតិ" គឺ កុយ ធួន (ស.ម ធុច)។

[3414] កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារ **E3/182** ទំព័រ ២ ERN 00019109។ ឌឿន ត្រូវបានចាត់តាំងជា "ប្រធានមន្ទីរនយោបាយ ៨៧០" និង "ស.ម យ៉ែម" ត្រូវបានចាត់តាំងឱ្យនៅ ការិយាល័យ ៨៧០។

បែងចែកសម្ភារៈទៅតាមភូមិភាគ និងបញ្ជានាំចេញ[3415]។ ប៉ុន្តែ ឯកសារផ្លូវការរបស់ ប.ក.ក អាច បញ្ជាក់អំពីការចងចាំស្រពេចស្រពិលនេះ។

១៧៦៦. ជាក់ស្តែង ថ្វីត្បិតតែ ខៀវ សំផន បានលើកឡើងនូវកាលបរិច្ឆេទខែតុលា ឆ្នាំ១៩៧៥ សម្រាប់មុខងារទាំងអស់របស់គាត់ ក៏ដោយ ក៏កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឆ្នាំ១៩៧៦ អាចឱ្យកែតម្រូវការប៉ាន់ប្រមាណរបស់គាត់ ពីព្រោះគណៈកម្មាធិការពាណិជ្ជកម្មទើបតែត្រូវបានបង្កើតឡើង នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ "សម្រាប់ពិនិត្យរៀបចំទំនិញដែលត្រូវទិញ"[3416]។ ក្រោយមក ទាល់តែនៅថ្ងៃទី២១ ខែមេសា បន្ទាប់ពីមានការបញ្ជាក់ "អំពីបញ្ហាពាណិជ្ជកម្ម និងឧស្សាហកម្ម" និង "ចំពោះគណៈប្រតិភូពាណិជ្ជកម្មកូរ៉េ" ទើបម្ចាស់បណ្តឹងសាទុក្ខត្រូវបានចាត់តាំងឱ្យធ្វើការជាមួយ វ៉ាន់ (អៀង សារី) និង ទូច ពាក់ព័ន្ធនឹង "ជំនួយបច្ចេកទេស"[3417]។ ដូច្នេះ ការចាត់តាំងគាត់ទៅក្នុងវិស័យនេះ មានកម្រិតយ៉ាងខ្លាំង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋានចេញពីភស្តុតាងទាំងនេះថា ម្ចាស់បណ្តឹងសាទុក្ខក្លាយជាសមាជិកមន្ទីរ ៨៧០ នៅខែតុលា ឆ្នាំ១៩៧៥ បានឡើយ។ គ្មានកំណត់ហេតុណាមួយផ្សេងទៀតរបស់គណៈអចិន្ត្រៃយ៍ ក្នុងចំណោមកំណត់ហេតុដែលអង្គជំនុំជម្រះលើកយកមកគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន បង្ហាញថា មានតួនាទីជាក់លាក់ណាមួយត្រូវបានប្រគល់ជូន ខៀវ សំផន ពាក់ព័ន្ធនឹងមន្ទីរ ៨៧០ ឡើយ ក្រៅពីវិស័យទាំងនេះ ទោះជានៅមុន ឬក្រោយខែតុលា ឆ្នាំ១៩៧៥ ក៏ដោយ[3418]។

---

[3415] លោក ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឆ្នាំ២០០៤ ឯកសារ **E3/18** ទំព័រ 80 ERN 005954391909។

[3416] កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/234** ទំព័រ ១ ERN 00000749 ("បន្ទាប់ពីសេចក្តីរាយការណ៍ត្រួសៗ របស់ស.ម វ៉ាន់ និង ស.ម ធុច ស្តីពីការទាក់ទងជាមួយចិនរួចមក អចិន្ត្រៃយ៍បានសម្រេចដូចតទៅ៖ ១-បញ្ហាពាណិជ្ជកម្ម ក-ចាត់តាំងគណៈកម្មាធិការមួយដើម្បីពិនិត្យរៀបចំទំនិញដែលត្រូវទិញ")។ ផ្នែកបន្ថែមទៀតនៃកំណត់ហេតុបានលម្អិតភារកិច្ចនៃគណៈកម្មាធិការ នៅក្នុង "បញ្ជីទំនិញដែលគេជួយ និងបញ្ជីទំនិញដែលទិញគេ"។

[3417] សេចក្តីសង្ខេបសេចក្តីសម្រេច នៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី១៩, ២០, ២១ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/236** ទំព័រ ៤ ERN 0322971។

[3418] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៨ កំណត់សម្គាល់ជើងទំព័រលេខ ១៩០៩ ដែលយោងទៅកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ឯកសារ **E3/227, E3/231, E3/232, E3/233, E3/217, E3/197, E3/220** និងឯកសារ **E3/222**។

១៧៦៧. ផ្ទុយទៅវិញ កំណត់ហេតុគណៈអចិន្ត្រៃយ៍ដែលបូកសរុបកិច្ចប្រជុំមួយចំនួននៅខែមេសា ឆ្នាំ១៩៧៦ បានចង្អុលបង្ហាញថា គណៈកម្មាធិការមួយចំនួនត្រូវបានបង្កើតឡើង "នៅជុំវិញ ៨៧០"[3419] ក្នុងនោះ "ខាងមន្ទីរ ជាជំនួយបច្ចេកទេស មានសមមិត្ត វ៉ាន់ សមមិត្ត ហែម សមមិត្ត ទូច"[3420]។ ដូច្នេះ ទាល់តែនៅខែមេសា ឆ្នាំ១៩៧៦ ទើបឈ្មោះ ខៀវ សំផន ត្រូវបានបង្ហាញនៅ "ខាងមន្ទីរ" និងក្នុង តួនាទីកម្រិតត្រឹម "ជំនួយបច្ចេកទេស" ដែលត្រូវនឹងតួនាទីដែលគាត់តែងតែអះអាងថាជាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម។ ហេតុនេះ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា គាត់ជាសមាជិកមន្ទីរ ៨៧០ តាំងពីខែតុលា ឆ្នាំ១៩៧៥ ហើយអង្គជំនុំជម្រះមិនបានភ្ជាប់ទំនាក់ទំនងរវាងជំនួយបច្ចេកទេស និងដែនសកម្មភាពមានកម្រិតរបស់គាត់ជាមួយគណៈកម្មាធិការពាណិជ្ជកម្ម[3421]។ ប៉ុន្តែ នេះគឺជាសេចក្តីសន្និដ្ឋានសមហេតុផលដែលចាំបាច់ ហើយត្រូវនឹងការសង្កេតឃើញរបស់អង្គជំនុំជម្រះពីអវត្តមានភស្តុតាងអំពីឋានៈរបស់គាត់ជាកម្មាភិបាលដឹកនាំនៃមន្ទីរ ៨៧០។

## ២.២. កំហុសពាក់ព័ន្ធនឹងការកំណត់ថា ខឿន ជា "អ្នកកាន់តំណែងមុន" ខៀវ សំផន

១៧៦៨. អង្គជំនុំជម្រះបានយល់ឃើញយ៉ាងត្រឹមត្រូវថា "ការទទួលខុសត្រូវជាក់លាក់របស់ ខៀវ សំផន នៅក្នុងមន្ទីរ ៨៧០ [...] នៅតែមានភាពមិនច្បាស់លាស់" ធ្វើឱ្យអង្គជំនុំជម្រះពិចារណាយ៉ាងឡូស៊ិកថា ខ្លួនមិនអាចសន្និដ្ឋានថា គាត់ជាប្រធាន ឬកម្មាភិបាលដឹកនាំរបស់មន្ទីរនេះបានទេ[3422]។ ផ្ទុយទៅវិញក្នុងឃ្លាដដែលនេះ អង្គជំនុំជម្រះបានកំណត់ថា ខឿន ជា "អ្នកគ្រប់គ្រងពីមុន" របស់ ខៀវ សំផន។ ការអះអាងនេះមិនត្រឹមត្រូវទេ ពីព្រោះវាមានន័យថា ខៀវ សំផន ឡើងជំនួស ខឿន ជាសេចក្តីសន្និដ្ឋានដែលត្រូវបានអង្គជំនុំជម្រះបដិសេធចោលយ៉ាងត្រឹមត្រូវ។ កំហុសទាំងនេះមិនចម្លែកទេ ពីព្រោះវាគឺជា

---

[3419] សង្ខេបសេចក្តីសម្រេចនៃគណៈអចិន្ត្រៃយ៍ កិច្ចប្រជុំ ថ្ងៃទី១៩, ២០, ២១ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/236** ទំព័រ ១ ERN 00019142 ("អំពីការរៀបចំចាត់តាំងគណៈកម្មាធិការផ្សេងៗនៅជុំវិញ ៨៧០៖ គណៈកម្មាធិការពាណិជ្ជកម្ម៖ សមមិត្ត វិត, សមមិត្ត ញ៉ែម, សមមិត្ត ឈឿន" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3420] សង្ខេបសេចក្តីសម្រេចនៃគណៈអចិន្ត្រៃយ៍ កិច្ចប្រជុំ ថ្ងៃទី១៩, ២០, ២១ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/236** ទំព័រ ១ ERN 00322971 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3421] សូមមើលខាងក្រោម កថាខណ្ឌ ១៧៧០-១៧៩៨។

[3422] សំអាងហេតុសាលក្រម កថាខណ្ឌ៦១៦។

មូលដ្ឋាននៃការបូកសរុបរួមរបស់អង្គជំនុំជម្រះទៅលើព័ត៌មាន ដែល ខៀវ សំផន បានទទួល ដោយសារតែសមាជិកភាពរបស់គាត់នៅមន្ទីរ ៨៧០ ឬសកម្មភាពដែលគាត់បានធ្វើ ក្រោយពី ខឿន បាត់ខ្លួន។ ការកត់សម្គាល់ថា "ទូរលេខមួយចំនួន ដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ចុះកាលបរិច្ឆេទក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ [...] ផ្ញើទៅមន្ទីរ ៨៧០" មិនបាន ផ្តល់ភ័ស្តុតាងថា ខៀវ សំផន ជាអ្នកទទួលនោះឡើយ[3423]។ ម្យ៉ាងវិញទៀត គ្មានសារ ឬទូរលេខណាមួយ ដែលផ្ញើជូន ខៀវ សំផន ក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់គាត់ អាចឱ្យសន្និដ្ឋានថា គាត់បានផ្លាស់ប្តូរសកម្មភាព ក្រោយពី ខឿន ចាកចេញឡើយ[3424]។

១៧៦៩. ដោយសារតែ "មុខងារជាក់លាក់របស់ការិយាល័យ ៨៧០ [...] នៅតែមិនមានភាពច្បាស់លាស់ដដែល"[3425] អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបោះបង់ចោលការសង្កេតឃើញរបស់ខ្លួនអំពីអវត្តមាននៃភ័ស្តុតាង ដែលអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានអំពីមុខតំណែងជាកម្មាភិបាលរបស់ម្ចាស់បណ្តឹងសាទុក្ខ និងការជំនួសតំណែង ខឿន។ ដូច្នេះ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានទាញចេញពីការសន្និដ្ឋានពង្រីកទាំងនេះនូវសេចក្តីសន្និដ្ឋានដាក់បន្ទុកលើ ខៀវ សំផន ដែលបន្ទាប់មកទៀត ត្រូវបានប្រើប្រាស់ ដើម្បីសន្និដ្ឋានអំពីការចូលរួមចំណែកដ៏សំខាន់របស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។ ដូច្នេះ សេចក្តីសន្និដ្ឋានខុសទាំងនេះ នឹងត្រូវទុកជាមោឃៈ[3426]។

## ៣. ការត្រួតពិនិត្យលើគណៈកម្មាធិការពាណិជ្ជកម្ម

១៧៧០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានយល់ឃើញថា "ខៀវ សំផន បានអនុវត្តកិច្ចការត្រួតពិនិត្យដ៏សំខាន់ [...] អំពីបញ្ហាពាណិជ្ជកម្ម"[3427]។ ដើម្បីឈានដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះបានធ្វើការបកស្រាយខុសទៅលើភ័ស្តុតាង ដែលរៀបរាប់លម្អិតអំពីមុខងាររបស់គាត់ពាក់ព័ន្ធនឹង

---

[3423] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៥។

[3424] សូមមើលខាងលើ កថាខណ្ឌ ១៦២៤-១៦២៥។

[3425] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៦៥។

[3426] សំអាងហេតុសាលក្រម កថាខណ្ឌ ៦០៨, ៦១០, ៦១៦, ៤២២៥, ៤២៥៧, ៤២៧៦, ៤៣០៦, ៤៣០៧។

[3427] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២១។

ពាណិជ្ជកម្ម (៣.១) និងបានធ្វើការសន្និដ្ឋានពង្រីកលើតួនាទីពិតប្រាកដរបស់គាត់ ដោយផ្អែកលើរបាយការណ៍ផ្ញើជូនគាត់ (៣.២) ទស្សនកិច្ច និងវគ្គរៀនសូត្រ (៣.៣)។

## ៣.១. កំហុសពាក់ព័ន្ធនឹងមុខងារ និងវិសាលភាពនៃមុខងារ នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម

១៧៧១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានអំពី "ការត្រួតពិនិត្យលើកិច្ចការពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ" របស់ម្ចាស់បណ្ដឹងសាទុក្ខ ខណៈដែលអង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះមិនអាច "បង្ហាញឱ្យបានជាក់លាក់អំពីមុខតំណែងទាំងអស់ ដែល ខៀវ សំផន ត្រូវទទួលខុសត្រូវនោះទេ"[3428]។ សេចក្ដីសន្និដ្ឋានខុសនេះបណ្ដាលជាអាទិ៍មកពីការអានមិនគ្រប់ជ្រុងជ្រោយនូវឯកសារអំពីមុខងាររបស់ ខៀវ សំផន ពាក់ព័ន្ធនឹងពាណិជ្ជកម្ម។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ពាក់ព័ន្ធនឹងខ្លឹមសារនៃមុខងារទាំងនេះ (៣.១.១) ដោយបានធ្វើការសន្និដ្ឋានពង្រីកលើរបាយការណ៍ ចម្លងជូនគាត់ (៣.១.២) ព្រមទាំងទស្សនកិច្ច និងមុខងាររបស់គាត់ នៅឃ្លាំងរបស់គណៈកម្មាធិការពាណិជ្ជកម្ម (៣.១.៣)។

### ៣.១.១. កំហុសពាក់ព័ន្ធនឹងប្រភេទនៃមុខងារ

១៧៧២. ជាក់ស្ដែង ថ្វីត្បិតតែអង្គជំនុំជម្រះបានដកស្រង់កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ដែលបានចាត់តាំង ខៀវ សំផន ឱ្យទទួលខុសត្រូវផ្នែក "ពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ" ក៏ដោយ ក៏អង្គជំនុំជម្រះខកខានមិនបានលើកឡើងថា កំណត់ហេតុនោះបញ្ជាក់ថា "សមមិត្តធុច" ជាឈ្មោះហៅក្រៅរបស់ កុយ ធួន ជាអ្នកទទួលបន្ទុក "ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស"[3429]។ ដូច្នេះ ឯកសារនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា តាំងពីឆ្នាំ១៩៧៥ មក មុខងាររបស់ម្ចាស់បណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងពាណិជ្ជកម្មមានកម្រិតយ៉ាងខ្លាំង[3430]។ ដូចគ្នាផងដែរ ពិតមែនតែអង្គជំនុំ

---

[3428] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៩។

[3429] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៧ កំណត់សម្គាល់ជើងទំព័រលេខ ១៩៤៥។

[3430] ចំពោះកំណត់ហេតុកិច្ចប្រជុំគណៈចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ឯកសារ **E3/182** គួរបញ្ជាក់ថាការបកប្រែជាភាសាបារាំងបាត់អត្ថន័យដើមនៃអត្ថបទជាភាសាខ្មែរ សូមមើល ERN 00019108 ERN FR 00292868។ « Camarade Hem,

ជម្រះបានដកស្រង់កំណត់ហេតុកិច្ចប្រជុំ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ ដើម្បីលើកឡើងអំពីមុខងាររបស់ ខៀវ សំផន ពាក់ព័ន្ធនឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយចិន និងគណៈកម្មាធិការពិនិត្យ "បញ្ហាធនាគារ"[3431] ក៏ដោយ ក៏អង្គជំនុំជម្រះមិនបានលើកឡើងអំពីភស្តុតាងបង្ហាញអំពីដែនកំណត់នៃជំនួយបច្ចេកទេសនេះ (៣.១.១.១) និងអវត្តមានភស្តុតាងស្តីពីសេចក្តីណែនាំដែលគាត់បានចេញ (៣.១.១.២)។

## ៣.១.១.១. ការមិនអើពើនឹងវិជ្ជាភាពបច្ចេកទេសសុទ្ធសាធនៃមុខងាររបស់ ខៀវ សំផន

១៧៧៣. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការត្រួតពិនិត្យរបស់ ខៀវ សំផន លើគណៈកម្មាធិការពាណិជ្ជកម្ម មានភាពផ្ទុយគ្នានឹងឯកសារផ្លូវការនានារបស់កម្ពុជាប្រជាធិបតេយ្យ ដែលអង្គជំនុំជម្រះបានដកស្រង់។ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបែបនេះ ដោយអង្គជំនុំជម្រះខ្លួនឯងបានលើកឡើង ក្នុងកំណត់ហេតុកិច្ចប្រជុំទាំងពីរ ចុះខែមេសា ឆ្នាំ១៩៧៦ ថា វន វេត មិនត្រឹមតែទទួលបន្ទុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការតែងតាំងសមាជិកគណៈកម្មាធិការនេះទៀតផង គឺមាន រិត, ញ៉ែម និង ឈឿន[3432]។ លើសពីនេះទៀត កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦ បញ្ជាក់យ៉ាង

---

responsable du front et du gouvernement royal, du commerce pour ce qui est des listes et des prix » មានភាពខុសគ្នាបន្តិច តែជាចំណុចសំខាន់ ដែលគេអាចមើលឃើញជាភាសាអង់គ្លេស ERN 00183393 *« Responsible for the Front and the Royal Government, and Commerce for accounting and pricing »*។ ដូច្នេះ គឺពិតជាមានការកម្រិតវិសាលភាពនៃអន្តរាគមន៍របស់ម្ចាស់បណ្តឹងសាទុក្ខនៅក្នុងកំណត់ហេតុនេះ ដូចដែលលោក ខៀវ សំផន តែងតែនិយាយបញ្ជាក់៖ កំណត់ហេតុសួរចម្លើយថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/37** ERN 00156676, ERN 00156683។ សៀវភៅរបស់ លោក ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* ឆ្នាំ២០០៤ ឯកសារ **E3/18** ទំព័រ ៧៤-៧៥ ERN 00103845-46 ទំព័រ ១៨០ ERN 00103898។ "លិខិតចំហជូនជនរួមជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ នៅប៉ៃលិន" ឯកសារ **E3/205** ERN FR 00623773។

[3431] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៧ កំណត់សម្គាល់ជើងទំព័រលេខ ១៩៤៦។

[3432] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៧ កំណត់សម្គាល់ជើងទំព័រលេខ ១៩៤៨។ សង្ខេបសេចក្តីសម្រេចនៃគណៈអចិន្ត្រៃយ៍ កិច្ចប្រជុំ ថ្ងៃទី១៩, ២០, ២១ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/236** ទំព័រ ១-២ ERN 00019142-43។ សូមមើលផងដែរសេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ **E3/12** ERN 00000762-63 "រដ្ឋាភិបាលត្រូវជាអង្គការរបស់បក្សសុទ្ធសាធ [...] ត្រូវមានឥទ្ធិពលនៅក្នុងបក្ស នៅក្នុងប្រទេស នៅក្រៅប្រទេស ចំពោះប្រទេសជាមិត្តក្តី ចំពោះខ្មាំងក្តី [...] សមមិត្ត វន៖ ឧបនាយកទទួលខាងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ [...] ១. ការងាររដ្ឋាភិបាលត្រូវឧបនាយកទាំង៣ទទួល។ ដូច្នេះឧបនាយកទាំង៣ត្រូវខ្លាំង ខ្លាំងទាំងបុគ្គល ខ្លាំងទាំងម៉ាស៊ីនធ្វើការងារ"។

ច្បាស់ថា "អំពីបញ្ហាពាណិជ្ជកម្ម និងឧស្សាហកម្ម" និងចំពោះគណៈប្រតិភូពាណិជ្ជកម្មកូរ៉េ ខៀវ សំផន ហៅ ហែម ត្រូវបានចាត់តាំងឱ្យធ្វើការជាមួយ វ៉ាន់ និង ទូច ខាងមន្ទីរ ជា "ជំនួយបច្ចេកទេស"[3433] ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានទាញផលវិបាកពីសេចក្តីបញ្ជាក់អំពីតួនាទីបច្ចេកទេសរបស់ម្ចាស់បណ្តឹងសាទុក្ខ នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម។

១៧៧៤. អង្គជំនុំជម្រះមិនអាចសន្និដ្ឋានអំពីអំណាចសម្រេច ឬមុខតំណែងតាមឋានានុក្រមរបស់ ខៀវសំផន បានទេ ពីព្រោះ ឌឿន មិនមែន ខៀវ សំផន ទេ ត្រូវបានចាត់តាំងឱ្យបង្កើតក្រុមមួយ សម្រាប់ពាណិជ្ជកម្មក្រៅប្រទេស នៅខែឧសភា ឆ្នាំ១៩៧៦[3434]។ ដូច្នេះ អង្គជំនុំជម្រះបង្កឱ្យមានការភាន់ច្រឡំថា ម្ចាស់បណ្តឹងសាទុក្ខមានការទទួលខុសត្រូវកាន់តែច្រើន នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម ចាប់ពីខែតុលា ឆ្នាំ១៩៧៦ តទៅ ដោយហេតុថា "ខ្សែបណ្តាញរាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្មបានផ្លាស់ប្តូរពី ឌឿន ទៅ ខៀវ សំផន វិញ"[3435]។ ជាក់ស្តែង ការអះអាងនេះផ្ទុយនឹងភស្តុតាងជាក់ស្តែងបំផុតដែលអង្គជំនុំជម្រះបានលាក់បាំង។ របាយការណ៍ពាណិជ្ជកម្មមិនត្រឹមតែបានផ្ញើជូន ខៀវ សំផន ខណៈដែល ឌឿន នៅតែជាអ្នកទទួលខុសត្រូវខាងពាណិជ្ជកម្ម[3436] ប៉ុន្តែ គឺ ឌឿន ជាអ្នកថ្លែងសុន្ទរកថា ក្នុងឋានៈជាអ្នកទទួលខុសត្រូវ ក្នុង "ពិធីលៀងសាយភោជនជាកិត្តិយសដល់សមមិត្ត វន វ៉េត" ដែលគណៈ

---

[3433] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៧ កំណត់សម្គាល់ជើងទំព័រលេខ ១៩៤៨។ សង្ខេបសេចក្តីសម្រេច គណៈអចិន្ត្រៃយ៍ កិច្ចប្រជុំថ្ងៃទី១៩, ២០, ២១ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ **E3/236** ERN 00322971។

[3434] កំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ស្តីពីបញ្ហាពាណិជ្ជកម្ម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ឯកសារ **E3/220** ERN 00000827។ វាជាការសំខាន់ក្នុងការបញ្ជាក់ថាគឺ ឌឿន ដែលធ្វើរបាយការណ៍ទៅគណៈអចិន្ត្រៃយ៍។

[3435] សំអាងហេតុសាលក្រម កថាខណ្ឌ៦១៨។ សូមមើលផងដែរ កថាខណ្ឌ ៤២២៥ ដែលនៅទីនេះ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ដោយមិនសមហេតុផល អំពី "ការសន្មតរបស់ លោក ខៀវ សំផន ចំពោះតួនាទីនៃការមើលខុសត្រូវរបស់ឌឿន នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម នៅត្រឹមចុងខែតុលាឆ្នាំ ១៩៧៦"។

[3436] *លោក ខៀវ សំផន ទទួលស្វាគមន៍គណៈប្រតិភូពាណិជ្ជកម្មយូហ្គោស្លាវី* ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ ឆ្នាំ១៩៧៧ ឯកសារ **E3/1485** ERN 00714165៖ ("(...) មានវត្តមានក្នុងឱកាសកិច្ចពិភាក្សា ភាគីកម្ពុជា គឺមានសមមិត្ត វន វ៉េត ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច សមមិត្តជឿន ឌឿន ប្រធានគណៈកម្មាធិការពាណិជ្ជកម្ម សមមិត្ត ចេង អន ប្រធានគណៈកម្មាធិការឧស្សាហកម្ម និងកម្មាភិបាលមួយចំនួនមកពីក្រសួងការបរទេស" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ម្យ៉ាងវិញទៀត លោក ខៀវ សំផន ត្រូវបានស្រង់សម្តី ក្នុងនាមប្រធានគណៈប្រធានរដ្ឋដែលទទួលគណៈប្រតិភូអន្តរជាតិ ប៉ុន្តែលោកមិនមែនជាអ្នកដឹកនាំការពិភាក្សាឡើយ។

ប្រតិភូ
យូហ្គោស្លាវីបានរៀបចំឡើង នៅខែកុម្ភៈ ឆ្នាំ១៩៧៧[3437]។

១៧៧៥. អង្គជំនុំជម្រះក៏ខកខានមិនបានលើកឡើងថា នៅខែធ្នូ ឆ្នាំ១៩៧៨ អៀង សារី អមដោយ វិត បានដឹកនាំការចរចាជាមួយចិន[3438]។ ដូច្នេះ ខៀវ សំផន មិនមានតួនាទីជាអ្នកចរចាទេ ទោះបីជាមានការចម្លងជូន "របាយការណ៍នៃការពិភាក្សាជាមួយគណៈប្រតិភូពាណិជ្ជកម្មបរទេស និងទំនាក់ទំនងផ្សេងៗទៀតទាក់ទិនពាណិជ្ជកម្មអន្តរជាតិ" ក៏ដោយ។ សាក្សីជាច្រើនបានបញ្ជាក់អះអាងថា សេចក្តីសម្រេចបានធ្វើឡើងនៅកម្រិតគណៈអចិន្ត្រៃយ៍[3439]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយធ្វើមិនដឹងមិនឮនឹងភស្តុតាងផ្ទុយនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួន។

### ៣.១.១.២. គ្មានភស្តុតាងអំពីសេចក្តីណែនាំរបស់ ខៀវ សំផន

១៧៧៦. នៅក្នុងគំនរឯកសារ ដែលបានរៀបរាប់ ពីកថាខណ្ឌ ៦១៧ ដល់កថាខណ្ឌ ៦២១ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានដកស្រង់តែឯកសារចំនួន ៥ និងសក្ខីកម្មរបស់ សគីម ល្មុត ដែលត្រូវបានសន្មតថាមានភាពស៊ីចង្វាក់គ្នាជាមួយឯកសារទាំងនោះ ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនថា "គណៈកម្មាធិការពាណិជ្ជកម្ម ជាញឹកញាប់ បានស្នើសុំសេចក្តីណែនាំពី ខៀវ សំផន លើបញ្ហាពាណិជ្ជកម្ម"[3440]។

---

[3437] "លោក ខៀវ សំផន ទទួលស្វាគមន៍គណៈប្រតិភូពាណិជ្ជកម្មយូហ្គោស្លាវី" ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ ឆ្នាំ១៩៧៧ ឯកសារ **E3/1485** ERN 00714165, 00714167-68។

[3438] របាយការណ៍នៃការ ប្រជុំរវាង ស.ម អៀង សារី និង គណៈប្រតិភូពាណិជ្ជកម្មចិន ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ឯកសារ **E3/1639** ERN 00003539។ កំណត់ហេតុស្តីពីការចរចាររវាងគណៈប្រតិភូពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ និងគណៈប្រតិភូក្រសួងពាណិជ្ជកម្មក្រៅប្រទេសនៃសាធារណរដ្ឋប្រជាមានិតចិន ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨ ពេលរសៀល ឯកសារ **E3/829** ERN 00002712-13។

[3439] ស្នួង ស៊ីគឿន៖ ប្រតិចារឹក ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/104.1** ម៉ោង 11.29.41។ Philip SHORT *ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ* ឯកសារ **E3/9** ទំព័រ ៣៩៨ ERN FR 00639853។ ប្រតិចារឹក ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E3/189.1** ម៉ោង 13.42.31។

[3440] សំអាងហេតុសាលក្រម កថាខណ្ឌ៦១៩ កំណត់សម្គាល់ជើងទំព័រលេខ ១៩៥៥។

• **<u>កំហុសពាក់ព័ន្ធនឹងការបកស្រាយឯកសារចម្លងជូន ដើម្បីសុំមតិយោបល់</u>**

១៧៧៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ពីព្រោះឯកសារដែលដកស្រង់មិនបង្ហាញថា យោបល់ដែលបានស្នើសុំ ស្ថិតក្រោមអំណាចទូទៅរបស់ ខៀវ សំផន លើគណៈកម្មាធិការពាណិជ្ជកម្មនោះឡើយ គឺគ្រាន់តែជាប់ទាក់ទងផ្ទាល់នឹងបេសកកម្មបច្ចេកទេសដែលបានប្រគល់ជូនគាត់។

១៧៧៨. ជាក់ស្តែង កម្មវត្ថុនៃរបាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ជាប់ពាក់ព័ន្ធនឹងបែបបទអនុវត្តន៍នៃការដឹកជញ្ជូនទំនិញ នៅក្នុងក្របខ័ណ្ឌបណ្តូរពាណិជ្ជកម្មជាមួយយូហ្គោស្លាវី[3441]។ របាយការណ៍ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៧៧ និយាយអំពីបណ្តូរពាណិជ្ជកម្មជាមួយយូហ្គោស្លាវី និងការពិភាក្សា “នៅក្រសួងពាណិជ្ជកម្ម” ស្តីពីសម្ភារៈដែលត្រូវទិញ និងបរិមាណ[3442]។ របាយការណ៍ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨ ពាក់ព័ន្ធនឹងជំនួយចិន សម្រាប់ការជួសជុលម៉ាស៊ីន និងការចារចាអំពីល័ក្ខខ័ណ្ឌ និងបរិមាណកៅស៊ូដែលត្រូវទិញ[3443]។ របាយការណ៍នេះបង្ហាញថា វន វ៉េត បានបញ្ជាក់គោលជំហររួចមកហើយ “នៅពេលជប់លៀងលារបស់ក្រុមពាណិជ្ជកម្ម” និងបាន “យល់ស្របតាមការលើកឡើងរបស់មិត្តចិនហើយ”[3444]។ ឯកសារ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ គឺជាសារផ្ញើជូន សុខ ក្នុងក្របខ័ណ្ឌបណ្តូរពាណិជ្ជកម្មជាមួយចិន ពាក់ព័ន្ធនឹងការបញ្ជាទិញផលិតផល និងទំនិញផ្សេងៗ (ប្រេងម៉ាស៊ីន កៅស៊ូសម្រាប់ចាក់ថ្នល់ គ្រឿងបន្លាស់ឡាន។ល។)[3445]។ របាយការណ៍ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ១៩៧៨ ក៏ពិភាក្សាអំពីបណ្តូរពាណិជ្ជកម្មជាមួយចិនដែរ[3446] ចំណែកឯរបាយការណ៍

---

[3441] សេចក្តីរាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ឯកសារ **E3/1615** ERN 00067709។

[3442] សេចក្តីរាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៧ ឯកសារ **E3/3514** ERN 00002855-57។

[3443] សេចក្តីរាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨ ឯកសារ **E3/3455** ERN 00188514-16។

[3444] សេចក្តីរាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨ ឯកសារ **E3/3455** ERN 00188515។ របាយការណ៍បញ្ចប់ដោយរំឭកពីសេចក្តីសម្រេចដែលបានចេញរួច។

[3445] សេចក្តីរាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ ឯកសារ **E3/334** ERN 00069092-96។

[3446] សេចក្តីរាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/3461** ERN 00188537-38។ គឺនិយាយអំពីបញ្ហាស្រូវសាឡី និងប្រេងម៉ាហ្សូត។

ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ពាក់ព័ន្ធនឹងត្រាក់ទ័រយូហ្គោស្លាវី[3447]។ ប្រធានបទនៃឯកសារទាំងអស់នេះពាក់ព័ន្ធដោយផ្ទាល់នឹងសម្ភារៈដែលត្រូវបែងចែកឱ្យបានទាន់ពេលវេលាតាមភូមិភាគនានា។ ដូច្នេះ យោបល់ដែលស្នើសុំពី ខៀវ សំផន ជាប់ទាក់ទងនឹងភារកិច្ចរបស់គាត់លើវិស័យនេះ។ម្យ៉ាងវិញទៀត គួរកត់សម្គាល់ថា ក្នុងរបាយការណ៍ទាំងនេះ វ៉ាន់ រិត គឺជាអ្នកដឹកនាំការចរចា និងមានសេរីភាពក្នុងការបង្ហាញអំពីគោលជំហរផ្លូវការរបស់កម្ពុជាប្រជធិបតេយ្យ។

១៧៧៩. ដូច្នេះ ការស្នើសុំ "មតិ" ឬ "យោបល់" ពី ខៀវ សំផន (ជាពាក្យប្រើប្រាស់ក្នុងឯកសារនានា) គឺជាទម្រង់ផ្លូវការសុទ្ធសាធ។ ម្យ៉ាងវិញទៀត គ្មានឯកសារណាមួយបង្ហាញថា ខៀវ សំផន ចេញសេចក្តីណែនាំឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយល់ឃើញថា ការចម្លងរបាយការណ៍ជូនគាត់បញ្ជាក់អំពីអំណាចត្រួតពិនិត្យ។

១៧៨០. ការសន្និដ្ឋានសមហេតុផលមួយទៀត គឺថា ខៀវ សំផន ត្រូវបានចម្លងជូននូវរបាយការណ៍ទាំងនេះ ពីព្រោះគាត់ត្រូវផ្តល់ជំនួយបច្ចេកទេស ដោយសារតែបទពិសោធន៍របស់គាត់នៅក្រសួងពាណិជ្ជកម្ម កាលពីសម័យ សម្តេច សីហនុ[3448]។ ម្យ៉ាងវិញទៀត យើងនឹងឃើញខាងក្រោមថា[3449] ឯកសារទាំងអស់គ្រាន់តែបញ្ជាក់អះអាងអំពីមុខងារមានកម្រិតទាំងនេះ ដែលម្ចាស់បណ្តឹងសាទុក្ខមិនធ្លាប់បានជំទាស់ម្តងណាឡើយ។

• **<u>កំហុសពាក់ព័ន្ធនឹងសក្ខីកម្មរបស់ សគឹម លុត</u>**

---

[3447] សេចក្តីរាយការណ៍នៃគណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ឯកសារ **E3/1637** ERN 00278399-400 (របាយការណ៍មានចំណារ៖ "[ច្បាប់ចម្លង] ផ្ញើជូនបងហែមហើយ")។

[3448] David CHANDLER៖ ប្រតិចារឹក ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/92.1** ម៉ោង 14.10.06។

[3449] សូមមើលខាងក្រោម កថាខណ្ឌ ១៧៨៥-១៧៩០។

១៧៨១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានផ្អែកលើសក្ខីកម្មរបស់ សាគីម ល្មុត ដើម្បីសន្និដ្ឋានថា "គណៈកម្មាធិការពាណិជ្ជកម្ម ជាញឹកញាប់ បានស្នើសុំសេចក្ដីណែនាំពី ខៀវ សំផន លើបញ្ហាពាណិជ្ជកម្ម"[3450]។

១៧៨២. ***សេចក្ដីសន្និដ្ឋានខុស ផ្អែកលើការស្មានរបស់សាក្សី៖*** ម្យ៉ាង សាក្សីនេះត្រូវបានអង្គជំនុំជម្រះចាត់ទុកជាសាក្សីបញ្ជាក់អះអាងលើឯកសារ ដែលយើងទើបនឹងមើលឃើញថា មិនគាំទ្រដល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះនោះឡើយ។ ម្យ៉ាងទៀត សក្ខីកម្មរបស់ សគីម ល្មុត មិនអាចបង្ហាញអំពីអ្វីដែលអង្គជំនុំជម្រះបានអះអាងនោះទេ។ ថ្វីត្បិតតែគាត់ជាអ្នកបកប្រែ សម្រាប់គណៈកម្មាធិការពាណិជ្ជកម្ម ដូចមានបញ្ជាក់ ជាអាទិ៍ នៅក្នុងរបាយការណ៍ E3/1615 ក៏ដោយ ក៏ការនិយាយរបស់គាត់ពីរឿង ខៀវ សំផន មិនត្រូវគ្នានឹងហេតុការណ៍ ដែលគាត់បានជួបប្រទះដោយផ្ទាល់ឡើយ។ ជាក់ស្ដែង សាក្សីនេះបានឆ្លើយយ៉ាងច្បាស់នៅក្នុងសវនាការថា គាត់ស្មាន ពេលអត្ថាធិប្បាយលើឯកសារដែលគាត់មិនធ្លាប់ឃើញ នៅមុនពេលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបង្ហាញជូនគាត់[3451]។ គាត់ក៏បានទទួលស្គាល់តាមត្រង់ថា គាត់មិនធ្លាប់ធ្វើការជាមួយម្ចាស់ បណ្ដឹងសាទុក្ខទេ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់មិនដឹងថាគាត់មានមុខងារអ្វីឱ្យពិតប្រាកដនោះដែរ ពាក់ព័ន្ធនឹងពាណិជ្ជ

[3450] សំអាងហេតុសាលក្រម កថាខណ្ឌ៦១៩ កំណត់សម្គាល់ជើងទំព័រលេខ ១៩៥៤។

[3451] <u>សគីម ល្មុត</u>៖ ប្រតិចារឹក ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/81.1** ប្រហែលម៉ោង 10.16.35 ("ស៖ បាទ សូមអរគុណ។ អ៊ីចឹង ដូចគ្នានេះដែរ ខ្ញុំសូមបញ្ជាក់លោកសាជាថ្មីថា តាមអ្វីដែលលោកអះអាងអម្បាញ់មិញនេះ គឺលោកមិនបានដឹងជាអង្គហេតុច្បាស់លាស់ពីទំនាក់ទំនងការងាររបស់ឈ្មោះ ហែម នេះ ទៅលើស្ថាប័នខាងពាណិជ្ជកម្ម និងខាងសេដ្ឋកិច្ចនោះទេ មុនពេលដែលអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតបង្ហាញលោកនោះ។ តើអ៊ីចឹងត្រឹមត្រូវទេ? ឆ៖ បាទ ត្រឹមត្រូវហើយ បាទ។ បាទ អ៊ីចឹង ហើយបាទ ទាល់តែមានឯកសារហ្នឹងមកបង្ហាញខ្ញុំ បានហ៊ានសន្និដ្ឋានថាអ៊ីចឹង" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម), ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/80.1** ប្រហែលម៉ោង 09.35.09 ("បាទ នេះគឺខ្ញុំឃើញតែទំនាក់ទំនងហ្នឹង <u>ខ្ញុំយល់ស្របអ៊ីចឹង</u> ឃើញថាដោយសារឈរលើឯកសារទំនាក់ទំនងគ្នាទេ") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម), ប្រតិចារឹក ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/79.1** ប្រហែលម៉ោង 11.39.59 ("... ដែលខ្ញុំឃើញនៅលើចំណារឯកសារខ្លះ ដែលលោកស៊ើបអង្កេតយកទៅបង្ហាញខ្ញុំនោះ។ ប៉ុន្តែ <u>អាចសន្និដ្ឋានបានថា ខាងមន្ទីរពាណិជ្ជកម្មហ្នឹងធ្វើអ្វីៗ</u> គឺថា<u>ផ្ញើទៅ</u>ៗបងវន <u>បងហែម</u> អ៊ីចឹង" យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

កម្ម[3452]។ នេះគឺជាចំណុចមួយ ដែលអង្គជំនុំជម្រះគួរណាតែលើកឡើង៖ ការមិនដឹងរបស់ សគីម ល្មុត អំពីមុខងារពិតប្រាកដរបស់ ខៀវ សំផន មានលក្ខណៈផ្ទុយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះ អំពីសិទ្ធិអំណាចគួរឱ្យកត់សម្គាល់របស់គាត់ នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសយ៉ាងច្បាស់ក្រឡែត នៅក្នុងវិធីសាស្ត្របង្ហាញភស្តុតាង ដោយបានប្រើប្រាស់ការសន្និត និងការបកស្រាយរបស់ សគីម ល្មុត ដើម្បីសន្និដ្ឋានថា គាត់បាន "បញ្ជាក់ថា វ៉ាន់ រិត ពុំអាចធ្វើសេចក្ដីសម្រេចមួយចំនួន ហើយត្រូវគោរពតាម វន វេត និង ខៀវ សំផន"[3453]។ អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋានសមហេតុផលចេញពីសក្ខីកម្មនេះថា ម្ចាស់បណ្ដឹងសាទុក្ខមានអំណាចត្រួតពិនិត្យបានឡើយ។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

១៧៨៣. ***ការមិនយកចិត្តទុកដាក់លើភាពស្មើរតែគ្មានសកម្មភាពធនាគារ៖*** អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយមិនបានទាញផលវិបាកចេញពីអវត្តមានសកម្មភាពធនាគារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឱ្យគ្មានន័យខ្លឹមសារចំពោះមុខងារដែលត្រូវបានសន្និតថាជារបស់ ខៀវ សំផន។ ជាក់ស្ដែង ខណៈដែលអង្គជំនុំជម្រះបានយកការស្មានរបស់ សគីម ល្មុត មកធ្វើជាមូលដ្ឋាននៃការសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះធ្វើមិនដឹងមិនឮទាល់តែសោះនឹងផ្នែកដ៏សំខាន់មួយនៃសក្ខីកម្មរបស់គាត់ ដែលបង្ហាញអំពីដែនកំណត់ជាសត្យានុម័តិរបស់ ខៀវ សំផន នៅក្នុងសកម្មភាពរបស់ខ្លួន។ បន្ទាប់ពីត្រូវបានកោះហៅឱ្យមកទីក្រុងភ្នំពេញ ដើម្បីធ្វើការនៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា សគីម ល្មុត បានរៀបរាប់ថា ធនាគារនេះ គឺជា "ធនាគារមានតែឈ្មោះ"[3454] ដែល "ក្រៅពីទស្សនកិច្ចរបស់គណៈប្រតិភូបរទេស គឺគ្មានប្រតិបត្តិការអ្វីទាំងអស់" ដោយសារតែខ្វះមធ្យោបាយខាងរូបិយវត្ថុ និងសមត្ថ

---

[3452] <u>សគីម ល្មុត</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/79.1** ប្រហែលម៉ោង 15.28.44, ប្រតិចារឹក ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/81.1** ប្រហែលម៉ោង 10.31.52, ប្រតិចារឹក ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/79.1** ប្រហែលម៉ោង 11.24.35។

[3453] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៩ កំណត់សម្គាល់ជើងទំព័រលេខ ១៩៥៤, ១៩៦០។ សូមមើលផងដែរ ការអធិប្បាយរបស់មេធាវីការពារក្ដី អំពីការស្មានរបស់សាក្សី និងវិធីសាស្ត្រមិនត្រឹមត្រូវរបស់អ្នកស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ក្នុងការ សួរដេញដោលសាក្សីនេះ៖ សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ ២៤៥-២៤៩។

[3454] <u>សគីម ល្មុត</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/79.1** ប្រហែលម៉ោង 09.40.47។

ភាព[3455]។ សតិម ល្អុត ក៏បានចាត់ទុកជា "ធនាគារមានឈ្មោះតែថាធនាគារ" ដែលដំណើរការជាមួយនឹងសកម្មភាពតិចតួចបំផុត[3456]។ ក្រៅពីមិនធ្លាប់ជួបម្ចាស់បណ្តឹងសាទុក្ខ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន អង្គជំនុំជម្រះគួរណាតែយកចិត្តទុកដាក់លើការរៀបរាប់របស់គាត់អំពីសកម្មភាពមានកម្រិតនៃវិស័យធនាគារ និងគណៈកម្មាធិការពាណិជ្ជកម្ម។ ដូច្នេះ អង្គជំនុំជម្រះមិនអាចចាត់ទុកមុខងាររបស់ ខៀវ សំផន ជាមួយនឹង "ធនាគារមានតែឈ្មោះ" នេះ ជាសក្ខីភាពនៃអំណាចក៏សំខាន់លើបញ្ហាពាណិជ្ជកម្មទេ។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការវិភាគមិនគ្រប់ជ្រុងជ្រោយ និងលម្អៀង ទៅលើសក្ខីកម្មនេះ។

- **<u>កំហុសពាក់ព័ន្ធនឹងការខ្វះជំនួយបច្ចេកទេស</u>**

១៧៨៤. អង្គជំនុំជម្រះក៏មិនអាចផ្អែកលើតួនាទីរបស់ ខៀវ សំផន ក្នុងការ "សម្រួលដល់ការបែងចែកសម្ភារៈ និងផលិតផល ទៅតាមបណ្តាភូមិភាគ"[3457] ដើម្បីសន្និដ្ឋានអំពី "ការត្រួតពិនិត្យដ៏សំខាន់" លើគណៈកម្មាធិការពាណិជ្ជកម្ម[3458] បានឡើយ។ ជាក់ស្តែង សាក្សី ដែលបានលើកឡើងពីភារកិច្ចនេះរបស់ ខៀវ សំផន បានរៀបរាប់អំពីការងារបច្ចេកទេស និងរដ្ឋបាល ក្នុងការចាត់ចែងលើសំណើសុំទំនិញពីភូមិភាគ[3459]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយមិនបានពិចារណាលើភស្តុតាងដោះបន្ទុកនេះ។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនបានទាញផលវិបាកពីការគ្មានភស្តុតាងបញ្ជាក់អំពីសេចក្តីណែនាំណាមួយចេញពី ខៀវ សំផន ពាក់ព័ន្ធនឹងពាណិជ្ជកម្ម ក្រៅពីការបែងចែក

---

[3455] <u>សតិម ល្អុត</u>៖ ប្រតិចារឹក ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ ឯកសារ **E1/79.1** ប្រហែលម៉ោង 09.42.32។

[3456] <u>សតិម ល្អុត</u>៖ ប្រតិចារឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/80.1** ប្រហែលម៉ោង 14.01.13។

[3457] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៩។

[3458] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២១។

[3459] <u>ខៀវ នៅ</u>៖ ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/90.1** ប្រហែលម៉ោង 10.56.54 ប្រហែលម៉ោង 15.11.54។ សាក្សីក៏បានរៀបរាប់អំពីជំនួបពីរលើកជាមួយម្ចាស់បណ្តឹងសាទុក្ខ៖ ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/90.1** ប្រហែលម៉ោង 14.21.47 ប្រហែលម៉ោង 11.34.25 ប្រហែលម៉ោង 11.49.13 (ខៀវ សំផន "រីករាយ ព្រោះរបស់ហ្នឹងវានៅសល់សល់ទំនេរ។ អ៊ីចឹង យកទៅឱ្យប្រជាជនប្រើប្រាស់ចាត់ចែង"។ <u>គីម វុន</u>៖ ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/112.1** ប្រហែលម៉ោង 15.58.02។ <u>សៅ សារុន</u>៖ ប្រតិចារឹក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E1/83.1** ប្រហែលម៉ោង 11.56.02។ <u>ស្នួង ស៊ីគឿន</u>៖ ប្រតិចារឹក ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/107.1** ប្រហែលម៉ោង 15.37.13។

ផលិតផលទៅតាមភូមិភាគ។ តាមពិត សំអាងហេតុសាលក្រមបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា អង្គជំនុំជម្រះបានធ្វើការសន្និដ្ឋានពង្រីក ចេញពីឯកសារផ្ញើជូន ខៀវ សំផន។

### ៣.២. ការសន្និដ្ឋានពង្រីកចេញពីរបាយការណ៍ផ្ញើជូន ខៀវ សំផន

១៧៨៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានទាញសេចក្ដីសន្និដ្ឋានពង្រីកចេញពីឯកសារផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យដែលផ្ញើជូនផ្ទាល់ ឬចម្លងជូនម្ចាស់បណ្ដឹងសាទុក្ខ ថា គាត់ត្រួតពិនិត្យលើគណៈកម្មាធិការពាណិជ្ជកម្ម[3460]។ ការពិនិត្យដោយយកចិត្តទុកដាក់លើរបាយការណ៍ និងឯកសារទាំងនេះ អាចឱ្យបញ្ជាក់អះអាងផ្ទុយទៅវិញអំពីដែនអន្តរាគមន៍មានកម្រិតរបស់ ខៀវ សំផន ក្នុងក្របខ័ណ្ឌនៃជំនួយបច្ចេកទេស ដូចបានកំណត់ក្នុងកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ខាងលើ។ មានតែការអានឯកសារនេះដោយលម្អៀង និងមិនត្រឹមត្រូវប៉ុណ្ណោះ ទើបនាំឱ្យអង្គជំនុំជម្រះមើលឃើញការបង្ហាញអំពីអំណាចទូទៅក្នុងការត្រួតពិនិត្យលើគណៈកម្មាធិការពាណិជ្ជកម្ម។

១៧៨៦. វិចារណកិច្ចរបស់អង្គជំនុំជម្រះមិនត្រឹមត្រូវទេ ពីព្រោះខ្លឹមសាររបាយការណ៍ទាំងនេះ និងចំណារនៅក្នុងរបាយការណ៍ទាំងនេះ មិនសំដៅជាក់លាក់ដល់សេចក្ដីសម្រេចរបស់ ខៀវ សំផន ឡើយ គឺសំដៅដល់សេចក្ដីសម្រេចរបស់ វន វ៉េត[3461] ឬការរង់ចាំសេចក្ដីសម្រេចពីអង្គការ ជាទូទៅ[3462]។

---

[3460] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៨ កំណត់សម្គាល់ជើងទំព័រលេខ ១៩៤៩-១៩៥១ កថាខណ្ឌ ៦១៩ កំណត់សម្គាល់ជើងទំព័រលេខ ១៩៥៤-១៩៥៩ កថាខណ្ឌ ៦២០ កំណត់សម្គាល់ជើងទំព័រលេខ ១៩៦០-១៩៦៣។

[3461] ឧទាហរណ៍៖ សម្ភារៈដែលប្រទេសយូហ្គោស្លាវីស្នើលក់ ឯកសារ **E3/340** ERN 00712106៖ វ៉ាន់ រិទ្ធ បានចារថា៖ "បងហែម ណែនាំមកថា បងវន សម្រេចមិនយកទេ ឱ្យរកមធ្យោបាយឆ្លើយទៅក្រុមហ៊ុន រុដណាប់" ដូច្នេះ លោក ខៀវ សំផន មិនមែនជាអ្នកសម្រេចទេ គឺ វន វ៉េត។

[3462] ឧទាហរណ៍៖ ជូន បងហែម ជាទីគោរពស្នេហា៖ សេចក្ដីរាយការណ៍ស្ដីពីការជួបមិត្តកូរ៉េ នៅស្ថានទូត ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៧៦ ឯកសារ **E3/2041** ERN 00091073-00091074៖ សេចក្ដីរាយការណ៍ត្រូវបានចម្លងជូនលោក ខៀវ សំផន ប៉ុន្តែ បញ្ជាក់ថា៖ ("<u>មតិយើង</u>៖ ចាំអង្គការសម្រេច ទើបយើងជូនដំណឹងក្រោយ")។ ឯកសារផ្សេងទៀត ដែលផ្ញើ ឬចម្លងជូនលោក ខៀវ សំផន មានសេចក្ដីប្រហាក់ប្រហែលគ្នា៖ ជូនចំពោះ បងឌឿន ជាទីគោរព និងស្នេហា៖ សេចក្ដីរាយការណ៍អំពីបញ្ហាកូរ៉េ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ឯកសារ **E3/2038** ERN 00091065 ("ចាំស្នើមតិអង្គការសិន"), ជូនចំពោះ បងហែម ជាទី គោរពស្នេហា៖ សេចក្ដីរាយការណ៍ស្ដីពីមិត្តកូរ៉េស្នើជួប នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦ ឯកសារ **E3/2040** ERN 00003044 ("ចំពោះមតិដែលមិត្តកូរ៉េលើក

១៧៨៧. ដូចបានឃើញពីខាងលើ[3463] វាជារឿងឡូស៊ិកដែល ខៀវ សំផន ត្រូវបានចម្លងជូននូវឯកសារ "ស្ដីពីការប្រើប្រាស់ឥណទានរបស់ចិនពីសំណាក់កម្ពុជាប្រជាធិបតេយ្យ"[3464] ដោយសារតែឋានៈរបស់គាត់ជាសមាជិកគណៈកម្មាធិការ ដែលត្រូវបានបង្កើតឡើង "សម្រាប់ពិនិត្យរៀបចំទំនិញ" ដែលត្រូវទិញពីចិន[3465]។ នេះក៏ពន្យល់ផងដែរថា "សារផ្ញើទៅមករវាងក្រុមហ៊ុន FORTRA និង Ren Fung" ក៏ត្រូវបានផ្ញើជូនគាត់ផងដែ[3466]។ ប៉ុន្តែ លិខិតទាំងនេះទាក់ទិននឹងការផ្លាស់ប្ដូរយោបល់គ្នាក្នុងន័យបច្ចេកទេសខ្លាំង អំពីការលក់វត្ថុធាតុដើម និងគ្រឿងបន្លាស់ឧស្សាហកម្ម មិនមែនជាសក្ខីភាពនៃអំណាចត្រួតពិនិត្យរបស់ ខៀវ សំផន ទេ។

១៧៨៨. ទឡ្ហីករណ៍ថា "របាយការណ៍ពាក់ព័ន្ធនឹងវិស័យនេះត្រូវបានផ្ញើជូនជាសំខាន់ទៅ ខៀវ សំផន ហើយឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងផ្នែកសេដ្ឋកិច្ច គឺ វន វ៉េត ជាញឹកញាប់ ត្រូវបានចម្លងជូននៅក្នុងរបាយការណ៍ ក្នុងនាមជាអ្នកទទួលទីពីរ បន្ទាប់ពី ខៀវ សំផន" គឺជាការសន្និដ្ឋានពង្រីករបស់អង្គជំនុំជម្រះ។ ជាក់ស្ដែង គ្មានតម្រុយណាមួយអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា លេខរៀងនៃបញ្ជីឈ្មោះអ្នកដែលត្រូវចម្លងជូន មានន័យអ្វីឡើយ។ លើសពីនេះទៀត យើងបានឃើញថា វន វ៉េត គឺជាអ្នកដឹកនាំការចរចាដោយផ្ទាល់ជាមួយយូហ្គោស្លាវី ខុសពី ខៀវ សំផន ដែលគ្មានមធ្យោបាយណាផ្សេងទៀតក្នុងការដឹងខ្លឹមសារកិច្ចពិភាក្សា ក្រៅពីការចម្លងជូនឡើយ[3467]។ ករណីនេះបង្ហាញថា ទោះបីជាទទួលបានព័ត៌មានក៏ដោយ ក៏គាត់មិនស្ថិតក្នុងខ្សែចង្វាក់ធ្វើសេចក្ដីសម្រេចឡើយ។

ឡើងទាំងប៉ុន្មាននេះ យើងខ្ញុំនឹងយកទៅរាយការណ៍ជូនអង្គការ ដើម្បីស្នើមតិយោបល់"), ជូន បង ហែម ជាទីគោរពស្នេហា៖ សេចក្ដីរាយការណ៍ស្ដីពីការជួបមិត្តកូរ៉េ នៅស្ថានទូត ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ឯកសារ **E3/2041** ERN 00091074 ("តើយោបល់អង្គការយ៉ាងម៉េច សុំឱ្យអង្គការឆ្លើយឱ្យគេវិញផង")។

[3463] សូមមើលខាងលើ កថាខណ្ឌ ១៧៧៧-១៧៨០។

[3464] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៩ កំណត់សម្គាល់ជើងទំព័រលេខ ១៩៥៧។

[3465] កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ - ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ - បញ្ហាពាណិជ្ជកម្ម ឯកសារ **E3/220** ERN 00000827។

[3466] សំអាងហេតុសាលក្រម កថាខណ្ឌ ៦១៩។

[3467] សូមមើលខាងលើ កថាខណ្ឌ ១៧៧៣-១៧៧៥។

១៧៨៩. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានចង្អុលបង្ហាញថា ខៀវ សំផន នៅតែបន្តទទួលបានរបាយការណ៍ នៅចុងឆ្នាំ១៩៧៨ "បន្ទាប់ពី វន វ៉េត ត្រូវបានចាប់ខ្លួន" ធ្វើដូចជាការចាប់ខ្លួននេះជាប់ពាក់ព័ន្ធនឹងរបាយការណ៍។ តាមពិត ឯកសារ ដែលអង្គជំនុំជម្រះបានដកស្រង់ ពាក់ព័ន្ធនឹងរបាយការណ៍ពាណិជ្ជកម្មជាមួយចិន តាមរយៈក្រុមហ៊ុនមានមូលដ្ឋាននៅហុងកុង[3468] គឺស្ថិតនៅក្នុងប្រភេទឯកសារដែលបានផ្ញើពីមុន។ ដូច្នេះ ប្រភេទនៃការផ្ញើ ដើម្បីគ្រាន់តែជ្រាបជាព័ត៌មាន មិនបានផ្លាស់ប្តូរទេ។

១៧៩០. លើសពីនេះទៀត ក្នុងចំណោមឯកសារទាំងបី ដែលអង្គជំនុំជម្រះបានដកស្រង់ នៅចុងឆ្នាំ១៩៧៨ ឯកសារទីមួយពាក់ព័ន្ធនឹងវិធានការដឹកជញ្ជូនទំនិញមកពីចិន[3469] ឯកសារទីពីរ គឺជាកំណត់ហេតុនៃការចរចាជាមួយគណៈប្រតិភូចិន ផ្ញើជូនបងវ៉ាន់ (អៀង សារី)[3470] ផងដែរ ហើយឯកសារទីបីមានចំណារសរសេរដៃអានដាច់ខ្លះអត់ខ្លះ ឯអ្នកទទួលទីមួយមើលមិនច្បាស់[3471]។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានលើកឡើងថា ខៀវ សំផន មិនមែនទទួលរបាយការណ៍ទាំងនេះតែម្នាក់ឯងទេ និងមិនអាចទាញលក្ខណៈពិសេសចេញពីរយៈពេលនេះទេ ក្រោយការចាប់ខ្លួន វន វ៉េត។ ទោះជាយ៉ាងនេះក្តី អ្វីទាំងអស់ជាប់ពាក់ព័ន្ធនឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយចិន ដែល ខៀវ សំផន ត្រូវតាមដានសម្រាប់សម្ភារៈដែលត្រូវនាំចូល។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានយល់ឃើញថា អង្គជំនុំជម្រះអាចសន្និដ្ឋានចេញពីចំនួនរបាយការណ៍ចម្លងជូន ខៀវ សំផន ថា គាត់មានអំណាចសំខាន់ខណៈដែលរបាយការណ៍ទាំងនេះស្ថិតក្រោមមុខការមានកម្រិតរបស់គាត់ តាមការសម្រេចពីគណៈអចិន្ត្រៃយ៍។

---

[3468] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២០ កំណត់សម្គាល់ជើងទំព័រលេខ ១៩៦៣។

[3469] របាយការណ៍របស់គណៈកម្មាធិការពាណិជ្ជកម្ម ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ឯកសារ **E3/1636** ERN 00278330។

[3470] កំណត់ហេតុស្តីពីការចរចា ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៧៨ ឯកសារ **E3/829** ERN 00002713។

[3471] លិខិតរបស់ក្រុមហ៊ុន ហ្សិត្រា ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៧៨ ឯកសារ **E3/2520** ERN 00278371 (ចំណារ៖ "ផ្ញើទៅ [អានមិនដាច់] តាមរយៈ ក-១១")។

## ៣.៣. កំហុសពាក់ព័ន្ធនឹងការពិនិត្យ និងវគ្គរៀនសូត្រ

១៧៩១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានយល់ឃើញថា ការចុះពិនិត្យនៅតាមឃ្លាំងរដ្ឋ អម ដោយ វ៉ាន់ រិត គឺជាភ័ស្តុតាងបង្ហាញអំពីអំណាច "សំខាន់" របស់ ខៀវ សំផន នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម។ ការដកស្រង់តាមបែបជ្រើសរើសនូវចម្លើយរបស់សាក្សីមួយចំនួន មិនអាចឱ្យធ្វើការសន្និដ្ឋានបែបនេះទេ[3472]។

១៧៩២. ជាក់ស្តែង រស់ ស៊ុយ ជាអ្នកធ្វើការនៅឃ្លាំងរដ្ឋ បានបញ្ជាក់អះអាងអំពីការនាំចេញ ដោយដោះដូរជាមួយទំនិញផ្ញើទៅតាមមូលដ្ឋាន[3473]។ សក្ខីកម្មរបស់គាត់បញ្ជាក់ថា វាជារឿងឡូស៊ិកដែល ខៀវ សំផន ទទួលបានព័ត៌មានអំពីបណ្តូរពាណិជ្ជកម្ម។ ម្យ៉ាងវិញទៀត ថ្វីត្បិតតែគាត់បានលើកឡើងពីការចុះពិនិត្យដ៏កម្រររបស់ ខៀវ សំផន ក៏ដោយ ក៏គាត់មិនអាចរៀបរាប់ឱ្យបានច្បាស់អំពីតួនាទីរបស់ ខៀវ សំផន ឡើយ[3474]។ បើតាមសម្តី រស់ ស៊ុយ ឈ្មោះ រិត ជាអ្នកទទួលខុសត្រូវលើគណៈកម្មាធិការពាណិជ្ជកម្ម[3475]។ ស៊ឹម ហោ ដែលត្រូវបានអង្គជំនុំជម្រះដកស្រង់ផងដែរ បានធ្វើការនៅរោងចក្រមួយ។ ក្នុងឱកាសនោះ គាត់បានឃើញ រិត និង ខៀវ សំផន មកពិនិត្យផលិតផលសម្រាប់នាំចេញ[3476]។ ដោយសារតែគាត់ដឹងថា ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ គាត់ក៏សន្មតយកថា ខៀវ សំផន គឺជាថ្នាក់លើរបស់ រិត ដោយមិនដឹងព័ត៌មានលម្អិត[3477]។ ប៉ុន្តែ សក្ខីកម្មជាទូទៅរបស់គាត់មិនអាចឱ្យអង្គ

---

[3472] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២០ កំណត់សម្គាល់ជើងទំព័រលេខ ១៩៦៤។ គឺ រស់ ស៊ុយ, ស៊ឹម ហោ, យ៉ិន គុជ និង ប៊ិត ឿន ហៅ ប៊ិត ណា។

[3473] <u>រស់ ស៊ុយ</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/184.1** ប្រហែលម៉ោង 10.21.09 ប្រហែលម៉ោង 15.35.00 ប្រហែលម៉ោង 16.01.49។

[3474] <u>រស់ ស៊ុយ</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/184.1** ប្រហែលម៉ោង 10.35.47 ប្រហែលម៉ោង 13.53.20 ប្រហែលម៉ោង 14.30.36។ គួរកត់សម្គាល់ថា រស់ ស៊ុយ បាននឹកឃើញអំពីចរិតចេះដាក់ខ្លួនរបស់លោក ខៀវ សំផន។

[3475] <u>រស់ ស៊ុយ</u>៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/184.1** ប្រហែលម៉ោង 15.33.54។

[3476] <u>ស៊ឹម ហោ</u>៖ ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/206.1** ប្រហែលម៉ោង 14.34.58 ប្រហែលម៉ោង 15.34.27។

[3477] <u>ស៊ឹម ហោ</u>៖ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/207.2** ប្រហែលម៉ោង 13.57.40 ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/206.1** ប្រហែលម៉ោង 14.34.58។

ជំនុំជម្រះសន្និដ្ឋានអំពីការត្រួតពិនិត្យសំខាន់លើគណៈកម្មាធិការពាណិជ្ជកម្ម ដែលសាក្សីបានមើលឃើញតែក្នុងរោងចក្ររបស់គាត់នោះឡើយ។

១៧៩៣. អង្គជំនុំជម្រះក៏បានផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សី យ៉ិន គុជ ដើម្បីបង្ហាញអំពីការចុះពិនិត្យរបស់ ខៀវ សំផន។ ជាដំបូង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានប្រើប្រាស់កំណត់ហេតុមួយ ដើម្បីបង្ហាញពីអំពើ និងការប្រព្រឹត្តិរបស់ ខៀវ សំផន[3478]។ ឯកសារនេះគួរណាតែត្រូវបដិសេធចោល។ បន្ទាប់មកទៀត កំណត់ហេតុនេះមិនផ្តល់ការបំភ្លឺលើមុខងាររបស់ ខៀវ សំផន នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្មទេ។ ជាក់ស្តែង យ៉ិន គុជ បានអះអាងថា គាត់បានឃើញ នួន ជា និង ខៀវ សំផន ក្នុងពេលចុះពិនិត្យឃ្លាំង ដោយបញ្ជាក់ថា "វ៉ាន់ រិត ជាប្រធានធំ" នៅក្រសួងពាណិជ្ជកម្ម[3479]។

១៧៩៤. ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋាន ផ្អែកលើសក្ខីកម្មតែមួយគត់ ថា ខៀវ សំផន បាន "ប្រជុំជាមួយកម្មករ និងកម្មាភិបាលពាណិជ្ជកម្ម" ហើយក្នុងពេលនោះ គាត់បាន "ថ្កោលទោសពួកអ្នកដែលខ្ជិលធ្វើការថាជាខ្មាំងរបស់បក្ស"[3480]។ ប៊ិត ណា មិនត្រឹមតែជាមនុស្សម្នាក់គត់ដែលបានចូលរួមក្នុងកិច្ចប្រជុំជាច្រើន នៅចំពោះមុខ ខៀវ សំផន ប៉ុណ្ណោះទេ ព័ត៌មានដែលគ្មានឯកសារណាផ្សេងទៀតស្របជាមួយផងរបស់គាត់ថែមទាំងមិនអាចជឿទុកចិត្តបានទៀតផង ដោយសារតែការនឹកឃើញប្រហែលៗ និងច្របូកច្របល់ជារួមរបស់គាត់។ ជាក់ស្តែង នៅក្នុងសវនាការ គាត់បានបញ្ជាក់ថា គាត់មិនដឹងមុខងាររបស់ ខៀវ សំផន ទេ[3481] ហើយក៏មិនដឹងថាគណៈអចិន្ត្រៃយ៍ជាអ្វីដែរ[3482]។

---

[3478] សូមមើលខាងលើ កថាខណ្ឌ ២៩៦-៣០៥។

[3479] កំណត់ហេតុស្តាប់ចម្លើយសាក្សី យ៉ិន គុជ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ **E3/437** ERN 00373523។

[3480] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២០ កំណត់សម្គាល់ជើងទំព័រលេខ ១៩៦៥។

[3481] <u>ប៊ិត ហឿន</u> ហៅ <u>ប៊ិត ណា</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ប្រហែលម៉ោង 13.50.00 ("នៅសម័យហ្នឹង ខ្ញុំមិនដឹងដែរ។ តែគ្រាន់តែដឹងថា ខៀវ សំផន នៅក្រោមតា នួន ជា" និងក្រោយម៉ោង 14.23.31 គាត់បានសន្និដ្ឋានថា លោក ខៀវ សំផន បានចូលរួមប្រជុំខាងពាណិជ្ជកម្ម ៤ លើក "ក្នុងឋានៈជាអ្នកជួយឱ្យយោបល់"។

[3482] <u>ប៊ិត ហឿន</u> ហៅ <u>ប៊ិត ណា</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ប្រហែលម៉ោង 13.53.16។

១៧៩៥. ចំពោះការដឹងអំពីគណៈកម្មាធិការពាណិជ្ជកម្ម អង្គជំនុំជម្រះមិនបានបង្ហាញអំពីភាពផ្ទុយគ្នា ដែលមេធាវីការពារក្តីបានលើកឡើងទេ។ ជាក់ស្តែង ក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០០៤ ជាដំបូង គាត់បានឆ្លើយថា ប្រធានមន្ទីរពាណិជ្ជកម្ម គឺជាស្ត្រី[3483] បន្ទាប់មក គាត់បាននិយាយថា វ៉ាន់ រិត មិនមានអ្នកណាធំជាងគាត់ទេ នៅគណៈកម្មាធិការពាណិជ្ជកម្ម[3484]។ ម្យ៉ាងវិញទៀត នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅឆ្នាំ២០១៦ គាត់បានសន្មតថា វន វ៉េត និង សុន សេន គឺជាមនុស្សតែម្នាក់[3485] ហើយគាត់ក៏បានបញ្ជាក់អះអាងក្នុងសវនាការផងដែរ[3486]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានបង្ហាញថា ក្រៅពីមានភាពច្របូលច្របល់ហើយ "ការចងចាំ" របស់ ប៊ិត ណា មិនកើតឡើងដោយឯកឯងទេ។ ជាក់ស្តែង ក្រោយពីមានសំណួរនាំមុខពីបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងកិច្ចសម្ភាសន៍លើកទីពីរ គាត់បាននិយាយឈ្មោះ ខៀវ សំផន ជាលើកទីមួយ ក្នុងវគ្គរៀនសូត្រ នៅបុរីកីឡា[3487]។ ប៉ុន្តែ នៅពេលចង់ដឹងថា តើអ្នកណាជាអ្នកនិយាយអំពីបញ្ហាខ្លាំង អង្គជំនុំជម្រះបានចៀសវាងកត់សម្គាល់ថា ប៊ិត ណា បានឆ្លើយថា គឺ នួន ជា[3488]។

---

[3483] ប៊ិត ហឿន ហៅ ប៊ិត ណា៖ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ ឯកសារ **E3/5647** ERN 00054385។

[3484] ប៊ិត ហឿន ហៅ ប៊ិត ណា៖ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ ឯកសារ **E3/5647** ERN 00054381 ("ស៖ ចុះមីងអ្នកដែលនៅក្នុងក្រសួងពាណិជ្ជកម្មហ្នឹង អ្នកដែលធំជាង វណ្ណ រិទ្ធ ហ្នឹងពីណាគេទៅ? ឆ៖ មានតែតាហ្នឹង")។ សាក្សីបានបញ្ជាក់នៅក្នុងសវនាការថាគាត់បានឆ្លើយបែបនេះមែន៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ប្រហែលម៉ោង 14.10.52។

[3485] ប៊ិត ហឿន ហៅ ប៊ិត ណា៖ កំណត់ហេតុស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **E3/10721 ស/ឆ. ១៣១**៖ ("វន វ៉េត ក៏មិនដែលឃើញ ហើយ សុន សេន ក៏មិនធ្លាប់ឃើញ។ ឮតែគេថា សង្ស័យជាមនុស្សតែមួយក៏មិនដឹង")។

[3486] ប៊ិត ហឿន ហៅ ប៊ិត ណា៖ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/502.1** ប្រហែលម៉ោង 13.58.08។

[3487] ប៊ិត ហឿន ហៅ ប៊ិត ណា៖ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ ឯកសារ **E3/5647** ERN 00054387។ ជាដំបូង សុជា ជាអ្នកសម្ភាសន៍ លើកឈ្មោះ នួន ជា។ បន្ទាប់មក ខណៈដែលសាក្សីមិនបាននិយាយអ្វីក្នុងន័យនេះ អ្នកសម្ភាសន៍បន្ថែមទៅនឹងសំណួរបន្ទាប់៖ ("ចុះអាពេលទៅរៀនហ្នឹង នៅបក្សពេញសិទ្ធិអ្ហេះ? អាទៅរៀនជាមួយ នួន ជា ជាមួយ ខៀវ សំផន ហ្នឹង បក្សពេញសិទ្ធិ?")។ វិធីនេះនឹងត្រូវអនុវត្តដដែលៗ សម្រាប់សំណួរបន្តបន្ទាប់ទៀត។ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ ឯកសារ **E3/5647** ERN FR 00054388។ នៅ ក្នុងកិច្ចសម្ភាសន៍លើកទីមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់មិនបានលើកឈ្មោះ ខៀវ សំផន ទាល់តែសោះ ក្នុងវគ្គរៀនសូត្រទាំងនេះ។ សូមមើល កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០២ ឯកសារ **E3/5647** ERN 00054418 ([សំណួរ] សុជា៖

១៧៩៦. ម្យ៉ាងវិញទៀត និងជាពិសេស អង្គជំនុំជម្រះបានធ្វើការវិភាគមិនគ្រប់ជ្រុងជ្រោយ និងលម្អៀង ទៅលើសក្ខីកម្មរបស់គាត់ ដោយមិនបានបង្ហាញចំណុចសំខាន់មួយនៃចម្លើយរបស់គាត់ ដែលផ្លាស់ប្តូរទាំងស្រុងនូវខ្លឹមសារនៃការសន្និដ្ឋានរបស់អង្គជំនុំជម្រះថា ខៀវ សំផន បានថ្កោលទោស"ពួកអ្នកដែលខ្ជិលធ្វើការថាជាខ្មាំងរបស់បក្ស"។ ជាក់ស្តែង នៅក្នុងចម្លើយពីមុនរបស់គាត់ ដែលត្រូវបានរំឭកនៅក្នុងសវនាការ ការសួរឆ្លើយអំពីខ្មាំងមានដូចខាងក្រោម៖

> "ស៖ អ្នកណាដែលគេចាត់ទុកថា ជនប្រភេទណាខ្លះដែលគេចាត់ទុកជាខ្មាំងរបស់បដិវត្តន៍ហ្នឹង ដែលគេបានលើកឡើងនិយាយក្នុងអង្គប្រជុំរបស់ ដែលមាន ខៀវ សំផន នួន ជា បង្រៀនហ្នឹង? គាត់មានពន្យល់ថា សមាសភាពយ៉ាងម៉េចៗ ដែលជាខ្មាំងរបស់អង្គការ? ឆ៖ អូហ៍! ជួនកាល គេហៅថាខ្មាំងក្នុងខ្លួនយើងក្នុងអីហ្នឹង ខ្មាំងសតិអារម្មណ៍យើងដឹកនាំគេខ្ជិលច្រអូសអី"[3489]។

១៧៩៧. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីភាពជឿជាក់បានរបស់ ប៊ិត ណា ជាអាទិ៍ ដោយបានលាក់បាំងសក្ខីកម្មរបស់គាត់ ត្រង់ផ្នែកបានមកពីការសួរដេញដោលរបស់មេធាវីការពារក្តី។ អង្គជំនុំជម្រះខកខានមិនបានបំពេញកាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុ ដោយទទួលយកសក្ខីកម្មមិនអាចជឿទុកចិត្តបាននេះ ដែលអង្គជំនុំជម្រះបានប្រើប្រាស់តាមបែបជ្រើសរើស

---

ពេលដែលគាត់មកបង្រៀន គាត់មានឧទ្ទេសនាមខ្លួនគាត់ឱ្យយើងដឹងដែរឬអត់ទេ? គាត់មកដល់ គាត់ ប្រកាសថា គាត់ឈ្មោះនេះៗ ឬក៏យើងដឹងខ្លួនឯង? [ចម្លើយ] ណា៖ ដឹងខ្លួនឯងតាមគ្នាឯងដឹង"), ERN 00054422 ([សំណួរ] សុជា៖ កាលសម័យហ្នឹង មីងដែលបានឮស្គាល់ឈ្មោះមេដឹកនាំណាផ្សេងទៀត ក្រៅពីមីងនិយាយមិញទេ? [ចម្លើយ] ណា៖ អត់។ [សំណួរ] សុជា៖ មីងឮឈ្មោះពីណាខ្លះ កាលសម័យហ្នឹង? [ចម្លើយ] ណា៖ សម័យហ្នឹង ប៉ុល ពត នួន ជា សុន សេន។ [សំណួរ] សុជា៖ ប៉ុណ្ណឹងទេ? [ចម្លើយ] ណា៖ ចា៎" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3488] ប៊ិត ហឿន ហៅ ប៊ិត ណា៖ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ ឯកសារ **E3/5647** ERN 00054389 ("ស៖ អ្នណាគេអ្នកនិយាយ ខៀវ សំផន ឬ នួន ជា? ឆ៖ នួន ជា")។

[3489] ប៊ិត ហឿន ហៅ ប៊ិត ណា៖ កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៤ ឯកសារ **E3/5647** ERN 00054389 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ដើម្បីតែដាក់បន្ទុក។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះមិនអាចផ្អែកលើសក្ខីកម្មរបស់គាត់ ដើម្បីសន្និដ្ឋានអំពីតួនាទីរបស់ ខៀវ សំផន នៅក្នុងគណៈកម្មាធិការពាណិជ្ជកម្មបានឡើយ។

១៧៩៨. **សេចក្តីសន្និដ្ឋាន៖** សក្ខីកម្មទាំងនេះមិនអាចឱ្យសន្និដ្ឋានអំពីអំណាចដ៏សំខាន់របស់ ខៀវ សំផន ទៅលើគណៈកម្មាធិការពាណិជ្ជកម្មបានទេ។ គោលជំហររបស់អង្គជំនុំជម្រះមិនត្រឹមត្រូវទេ ដោយហេតុថា ដើម្បីបដិសេធការទទួលខុសត្រូវរបស់ថ្នាក់លើ អង្គជំនុំជម្រះបានទទួលស្គាល់ថា ចំពោះ “បញ្ហាពាក់ព័ន្ធនឹងពាណិជ្ជកម្ម [...] តួនាទីរបស់ ខៀវ សំផន ត្រូវបានកម្រិតត្រឹមមុខងាររដ្ឋបាលក្នុងតួនាទីនោះ”[3490]។ ការត្រួតគ្នានៃកំហុសអង្គហេតុផ្សេងៗទាំងនេះធ្វើឱ្យអង្គជំនុំជម្រះសន្និដ្ឋានអំពីអំណាចត្រួតពិនិត្យដ៏សំខាន់របស់ ខៀវ សំផន។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ នឹងត្រូវទុកជាមោឃៈ។

## ៤. អ្នកទទួលខុសត្រូវក្រសួងការបរទេស

១៧៩៩. ទោះបីជាអង្គជំនុំជម្រះបានអះអាងថា ខ្លួនមិនអាចសន្និដ្ឋានថា ខៀវ សំផន ទទួលខុសត្រូវលើក្រសួងការបរទេស ក្នុងពេល អៀង សារី អវត្តមាន ដោយយោងលើភស្តុតាង “មានភាពមិនច្បាស់លាស់” ទាក់ទងនឹងការចោទប្រកាន់នេះ ក៏ដោយ ក៏អង្គជំនុំជម្រះលើកឡើងអំពី “លទ្ធភាព” ដែលថា ខៀវ សំផន អាចជួយបណ្តោះអាសន្នបន្តិចបន្តួច និងម្តងម្កាល[3491]។

១៨០០. ប្រការនេះអាចឱ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានតាមក្រោយថា ខៀវ សំផន “មិនអាចព្រងើយកន្តើយ” នឹងលិខិត ដែលអង្គការលើកលែងទោសអន្តរជាតិបានផ្ញើជូនគាត់ ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ បានទេ “ដោយសារតែ [គាត់] ជាប់ទាក់ទងខ្លាំងជាមួយ អៀង សារី និងក្រសួងការបរទេស”[3492]។

---

[3490] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣២៣។

[3491] សំអាងហេតុសាលក្រម កថាខណ្ឌ ៦២៣។

[3492] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥០ និងកថាខណ្ឌ ៤២៥៣។ សូមមើលផងដែរ កថាខណ្ឌ ៤០៤៨។ ឋានៈជាប្រធានគណៈប្រធានរដ្ឋតែមួយមុខមិនមែនជាភស្តុតាងអំពីការទទួលបានលិខិតដែលគេផ្ញើជូនទេ។

១៨០១. ប៉ុន្តែ ការជាប់ទាក់ទងខ្លាំងជាមួយ អៀង សារី និងក្រសួងការបរទេស មិនមែនជាភ័ស្តុតាងបង្ហាញអំពីការទទួលនេះទេ គឺគ្រាន់តែជាការស្មាន ពីព្រោះអង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋានចេញពី "ការជាប់ទាក់ទងខ្លាំង" នូវការជួយបណ្តោះអាសន្នបន្តិចបន្តួច និងម្តងម្កាលរបស់លោក ខៀវ សំផន នៅក្រសួងការបរទេស ក្នុងពេល អៀង សារី អវត្តមាន ឡើយ។

១៨០២. លើសពីនេះទៀត វាជារឿងមិនសមហេតុផលក្នុងការសន្និដ្ឋានអំពី "លទ្ធភាព" នៃការជួយបណ្តោះអាសន្នបន្តិចបន្តួច និងម្តងម្កាល ដោយយោងលើភ័ស្តុតាង "មានភាពមិនច្បាស់លាស់" ទាក់ទងនឹងប្រធានបទនេះ[3493] គឺសក្ខីកម្មរបស់ ឡុង នរិន្ទ, សាឡុត បាន និង ស្វង ស៊ីគឿន នៅក្នុងសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្របានពិនិត្យដោយលម្អៀង និងមិនគ្រប់ជ្រុងជ្រោយ។ ជាក់ស្តែង ឡុង នរិន្ទ បានពន្យល់ថា ពេលមានភ្ញៀវ ក្នុងពេល អៀង សារី អវត្តមាន "វន វ៉េត ឬក៏ ខៀវ សំផន ដែលមកហ្នឹង អត់មានសម្រេចអីទេ" ហើយការ "ជំនួស" មានន័យថា ខៀវ សំផន និង វន វ៉េត មកទទួលភ្ញៀវនៅក្រសួង ក្នុងពេល អៀង សារី អវត្តមាន[3494]។ អង្គជំនុំជម្រះបានបំភ្លៃ និងបំប្លែងសក្ខីកម្មរបស់ សាឡុត បាន ជាបុគ្គលសំខាន់នៅក្រសួងការបរទេស ដែលថា វត្តមាន ខៀវ សំផន នៅក្រសួង កម្រិតត្រឹមជំនួបជាមួយផ្នែកបញ្ញាជន" (មិនមែនដើម្បី "ដឹកនាំការប្រជុំអំពីជនបរទេស" ដូចអង្គជំនុំជម្រះបានអះអាងទេ) ដោយគាត់មិនបាន "ប្រាស្រ័យទាក់ទង" ទេ[3495]។ បញ្ញាជន ស្វង ស៊ីគឿន បានបញ្ជាក់ថា កម្មវត្ថុនៃការជួបពីរដងជាមួយ ខៀវ សំផន គឺពាក់ព័ន្ធនឹងការសរសេរអត្ថបទមួយ ដើម្បីចុះផ្សាយ ប៉ុន្តែមិនបានសរសេរ ឬចុះផ្សាយអ្វីទេ[3496]។

១៨០៣. ដោយផ្អែកលើភ័ស្តុតាងទាំងនេះ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានអំពីលទ្ធភាពនៃការជួយបណ្តោះអាសន្ន ក្នុងក្របខ័ណ្ឌមុខងារបន្ទាប់បន្សំរបស់ ខៀវ សំផន ឬអំពីទំនាក់ទំនងជាមួយ អៀង សារី និងក្រសួងការបរទេស ហើយសន្និដ្ឋានអំពីការដឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

---

[3493] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៩៦៦-១៩៧១ នៃកថាខណ្ឌ ៦២២-៦២៣។

[3494] ឡុង នរិន្ទ៖ ប្រតិចារឹក ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **E1/19.1** ប្រហែលម៉ោង 14.25.55។

[3495] សាឡុត បាន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/66.1** ប្រហែលម៉ោង 14.19.54, ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ ឯកសារ **E1/68.1** ប្រហែលម៉ោង 11.13.48។

[3496] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៩៧០ នៃកថាខណ្ឌ ៦២៣ ដែលដកស្រង់ ស្វង ស៊ីគឿន។

ដូចបានរាយការណ៍ក្នុងលិខិតរបស់អង្គការលើកលែងទោសអន្តរជាតិ ដែលគាត់បានទទួល និង/ឬមិនអាចមិនដឹងបានទេ។ កំហុសរបស់អង្គជំនុំជម្រះបណ្តាលឱ្យមានយុត្តិនិសេធ ហើយសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ។

## មាតិកាទី ៣. កំហុសពាក់ព័ន្ធនឹងការដឹងរបស់ ខៀវ សំផន

## ជំពូកទី ១. ការប្រែប្រួលកម្រិតនៃការដឹង ទៅតាមពេលវេលា

១៨០៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអះអាងថា កម្រិតនៃការដឹងតាមការតម្រូវមានការប្រែប្រួល អាស្រ័យថាតើអំពើ ដែលចោទប្រកាន់លើជនជាប់ជាប់ កើតឡើង នៅមុន ក្នុងពេល ឬក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្ម[3497]។ ការអះអាងរបស់អង្គជំនុំជម្រះមានភាពមិនច្បាស់លាស់។ ការអះអាងនេះបង្កឱ្យមានភាពភ្ញាក់ផ្អើល ពីព្រោះវាត្រូវបានគាំទ្រដោយកំណត់សម្គាល់ជើងទំព័រមួយ ដែលគ្រាន់តែយោងដល់កថាខណ្ឌពាក់ព័ន្ធនឹងធាតុផ្សំចេតនាតាមការតម្រូវ អាស្រ័យតាមទម្រង់នៃការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម-ទម្រង់១៖ ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ។ យើងសំដៅដល់តែសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដែលបង្កព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ ពោលគឺ សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវ ដែលយកមកផ្តន្ទាទោសគាត់។

១៨០៥. ជាក់ស្តែង អង្គជំនុំជម្រះបានប្រកាសនៅកថាខណ្ឌ ៣៧១៥ ថា ធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋម្មរួម-ទម្រង់ទី ១ គឺចេតនាដោយចំពោះ។ អង្គជំនុំជម្រះមិនបានលើកឡើងអំពីធាតុផ្សំណាមួយពាក់ព័ន្ធនឹងកម្រិតនៃការដឹង ដែលនាំឱ្យមានការប្រែប្រួល ទៅតាមពេលវេលាកើតអំពើដែលបានចោទប្រកាន់។ ប៉ុន្តែ យើងនឹងមើលឃើញថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការអនុវត្តវិធានច្បាប់ នៅពេលកំណត់ធាតុផ្សំអត្តនោម័តិរបស់ ខៀវ សំផន ចំពោះសហឧក្រិដ្ឋកម្មរួម ដោយបានប្រើប្រាស់ធាតុផ្សំ

---

[3497] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣៧២៦ យោងដល់កថាខណ្ឌ ៣៧១៥, ៣៧១៧, ៣៧១៩, ៣៧២០, ៣៧២២ និង ៣៧២៥។

ក្រោយអង្គហេតុ ដែលមិនបង្ហាញអំពីការដឹង ឬចេតនារបស់គាត់ នៅពេលកើតហេតុ ដើម្បីសន្និដ្ឋាន អំពីការដឹង និងចេតនារបស់គាត់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3498]។

១៨០៦. នៅកថាខណ្ឌ ៣៧២២ អង្គជំនុំជម្រះបានយល់ឃើញថា ធាតុផ្សំអត្តនោម័តិតាមការតម្រូវ ដើម្បីបង្កើតបានជាការជួយជំរុញ គឺថា ជនជាប់ចោទដឹងថាបទឧក្រិដ្ឋនេះអាចនឹងត្រូវបានប្រព្រឹត្តឡើង ហើយអំពើរបស់ខ្លួនបានជួយសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋនោះដោយចារី។ គេក៏ត្រូវបង្ហាញផងដែរថា ជនជាប់ចោទដឹងអំពីធាតុផ្សំសំខាន់នៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយចារី។ យើងនឹងឃើញខាងក្រោមថា អង្គជំនុំជម្រះមិនបានបង្ហាញអំពីការដឹងនេះទេ ពាក់ព័ន្ធនឹងការធ្វើមនុស្សឃាតនៅត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល[3499]។

១៨០៧. ដូច្នេះ អង្គជំនុំជម្រះហាក់ដូចជាចង់និយាយថា កម្រិតនៃការដឹងតាមការតម្រូវមានការប្រែប្រួល ទៅតាមទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់។ ទោះក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានអះអាងថា កម្រិតតាមការតម្រូវមានភាពប្រែប្រួល ទៅតាមពេលវេលាកើតអំពើដែលបានចោទប្រកាន់ ធៀបនឹងពេលវេលាប្រព្រឹត្តឧក្រិដ្ឋកម្ម។

## ជំពូកទី ២. ការដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត

១៨០៨. ជាចម្បង មេធាវីការពារក្តីសូមលើកឡើងថា ការបង្ហាញរបស់អង្គជំនុំជម្រះអំពី "ការដឹងយ៉ាងច្បាស់អំពីភាវនីយភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[3500] មិនអាចយកមកធ្វើជាមូលដ្ឋាន ចំពោះចេតនារបស់ ខៀវ សំផន ក្នុងការជួយជំរុញឧក្រិដ្ឋកម្មនោះឡើយ[3501]។ ជាក់ស្តែង អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានកំណត់ធាតុផ្សំអត្តនោម័តិនៃការជួយជំរុញថាជា "ការដឹងថាបទឧក្រិដ្ឋអាចនឹងត្រូវ

[3498] សូមមើលខាងក្រោម កថាខណ្ឌ ២០៣១-២០៣៨។

[3499] សូមមើលខាងក្រោម កថាខណ្ឌ ២១៣៧-២១៤០។

[3500] សំអាងហេតុសាលក្រម ផ្នែក ១៨.១.១។

[3501] សូមមើល ជាអាទិ៍ សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៥ កំណត់សម្គាល់ជើងទំព័រលេខ ១៤០២៨ និងកថាខណ្ឌ ៤៣១៧ កំណត់សម្គាល់ជើងទំព័រលេខ ១៤០៣៣។

បានប្រព្រឹត្តឡើង"[3502]។ យើងនឹងឃើញនៅខាងក្រោមថា ចេតនាកម្រិតទាបនេះមិនមានអត្ថិភាពទេ នៅពេលកើតអង្គហេតុដែលបានចោទប្រកាន់ឡើយ[3503]។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ[3504]។

១៨០៩. ជាបន្ទាប់បន្សំ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុ ដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋាននេះ។ អង្គជំនុំជម្រះមិនគួរណាយកទស្សនៈរបស់សហព្រះរាជអាជ្ញាមកទាញការសន្និដ្ឋានថា ខៀវ សំផន "បង្ហាញអំពីការជឿជាក់ជាវិជ្ជមានរបស់គាត់ ចំពោះគោលនយោបាយរបស់ ប.ក.ក ស្តីពីសមូហភាវូបនីយកម្ម ដែលរួមមានតាមរយៈការជំរុញ ដាក់ប្រជាជនឱ្យស្ថិតនៅក្រោមគំនិតផ្តួចផ្តើមនៃការបង្កបង្កើនផលជូនរដ្ឋ"[3505]។ នេះគឺជាការបំភ្លៃការសិក្សាសេដ្ឋកិច្ច ដែល ខៀវ សំផន បានការពារ ដើម្បីធ្វើកំណែទម្រង់ពិភពកសិករ/កសិកម្មនៃប្រទេសរបស់គាត់ ដោយរួមបញ្ចូលប្រជាជនគ្រប់ស្រទាប់វណ្ណៈ[3506]។ ក្រៅពីនេះទៀត ផ្ទុយទៅវិញ នៅក្នុងនិក្ខេបបទរបស់គាត់ គាត់មិនដែលនិយាយអំពី "ការដាក់" ប្រជាជនទេ[3507]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុស ដោយបានយល់ឃើញថា ពីឆ្នាំ១៩៦៩ ដល់ខែមេសា ឆ្នាំ១៩៧៥ "ខៀវ សំផន ជាសមាជិកសំខាន់មួយរូបនៅក្នុងជួរថ្នាក់ដឹកនាំនៃ ប.ក.ក" បានដឹងអំពីគោលនយោបាយដែលបានរៀបចំឡើង និងដាក់ឱ្យអនុវត្តសាកល្បងនៅតាមតំបន់រំដោះ[3508]។ ក្នុង

[3502] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧២២។

[3503] សូមមើលខាងក្រោម កថាខណ្ឌ ២១៣៧-២១៤០។

[3504] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨។

[3505] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៦។

[3506] និក្ខេបបទរបស់លោក ខៀវ សំផន ខែឧសភា ឆ្នាំ១៩៥៩ ឯកសារ **E3/123** ERN 00767393៖ "យើងមិនមែនស្នើឱ្យបំបាត់វណ្ណៈដែលមានចំណូលលើសលុបនោះទេ" ERN 00767437៖ "ដូច្នេះ វាអាចមានប្រយោជន៍ក្នុងការផ្តល់ការពន្យល់បំភ្លឺចាំបាច់នានាដល់ម្ចាស់កម្មសិទ្ធិដី ដើម្បីជួយពួកគេឱ្យយល់ច្បាស់អំពីទស្សនៈវិស័យជាទូទៅដែលត្រូវបានផ្តល់ដល់ពួកគេ តាមរយៈកំណែទម្រង់"។

[3507] និក្ខេបបទរបស់លោក ខៀវ សំផន ខែឧសភា ឆ្នាំ១៩៥៩ ឯកសារ **E3/123** ERN 00767441 "រដ្ឋាភិបាលត្រូវខិតខំប្រមែប្រមូលប្រជាកសិករ សម្រាប់ការជួយគ្នាទៅវិញទៅមក [...] និងនៅទីបញ្ចប់ រដ្ឋាភិបាលត្រូវខិតខំធ្វើឱ្យកសិករមានទម្លាប់បន្តិចម្តងៗក្នុងការធ្វើកិច្ចសហប្រតិបត្តិការ។ ការបង្កើតក្រុមប្រវាស់ដៃ ដែលក្នុងនោះឧបករណ៍ធ្វើការ ដីធ្លី និងផលិតផលបានមកពីការងារ ស្ថិតនៅជាកម្មសិទ្ធិឯកជន ប៉ុន្តែ ត្រូវបានដាក់ឱ្យដំណើរការតាមវិធីសាស្ត្រធ្វើការងាររួម មានលក្ខណៈសមស្របទៅនឹងគោលគំនិតនាពេលបច្ចុប្បន្នរបស់កសិករខ្មែរ"។ សូមមើលខាងលើផងដែរ កថាខណ្ឌ ១៦៥២-១៦៥៩។

[3508] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧។

ពេលនោះ ខៀវ សំផន ទើបតែត្រូវគេបញ្ចូលទៅក្នុងជួរ ប.ក.ក។ គាត់មិនទទួលបានសេចក្ដីទុកចិត្តពីមេដឹកនាំទេ និងត្រូវគេទុកមួយឡែក[3509]។ ពេលក្លាយជាសមាជិកត្រៀមគណៈមជ្ឈិម នៅឆ្នាំ១៩៧១ គាត់គ្មានអំណាចអ្វីទាំងអស់[3510]។ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណាម្នាក់អាចសន្និដ្ឋានថា ពីឆ្នាំ១៩៦៩ ដល់ខែមេសា ឆ្នាំ១៩៧៥ គាត់ជា "សមាជិកសំខាន់មួយរូបនៅក្នុងជួរថ្នាក់ដឹកនាំនៃ ប.ក.ក" និងដឹងអំពីគោលនយោបាយដែលអនុវត្តនៅតាមតំបន់រំដោះ នោះឡើយ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានត្រឹមតែស្មានអំពីការដឹងអំពីការរៀបចំគោលនយោបាយ។ អង្គជំនុំជម្រះមិនបានបញ្ជាក់ទាល់តែសោះថាតើជា "គោលនយោបាយ" ឬ "វិធីប្រតិបត្តិការ" អ្វីខ្លះ ហើយហេតុអ្វីបានជាវាមានលក្ខណៈឧក្រិដ្ឋ[3511]។ ដំណើរការស្មាន និងមិនច្បាស់លាស់នេះ ត្រូវតែបដិសធចោល។

១៨១០. អង្គជំនុំជម្រះក៏មិនបានផ្ដល់សំអាងហេតុថា ហេតុអ្វីបានជាសេចក្ដីសម្រេច ឆ្នាំ១៩៧២ ស្ដីពីការ "បិទទីផ្សារ និងការចាត់តាំងសហករណ៍ ដោយប្រមូលធនធានមនុស្សនៅតាមសហគមន៍ដោយបង្ខំដើម្បីបង្កើនការបង្កបង្កើនផលកសិកម្ម" បង្ហាញថា ខៀវ សំផន បានដឹង "ច្បាស់អំពីភវនីយភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[3512]។ សេចក្ដីសម្រេចនេះមិនមានលក្ខណៈឧក្រិដ្ឋនោះទេ ហើយក៏មិនអាចឱ្យគ្រោងទុកជាមុនថា ឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្តនោះដែរ។ លើសពីនេះទៀត យើងបានបញ្ជាក់រួចមកហើយថា នៅឆ្នាំ១៩៧២ ក្នុងឋានៈជាសមាជិកត្រៀមនៃគណៈមជ្ឈិម ខៀវ សំផន មិនមានអំណាចអ្វីទាល់តែសោះ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចអះអាងថា ដោយសារតែគាត់មានអំណាចក្នុងជួរ ប.ក.ក នៅខែកញ្ញា ឆ្នាំ១៩៧៥ គាត់ "បានអំពាវនាវឱ្យកម្ចាត់ថ្នាក់ដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ និងរៀបចំផែនការរំដោះប្រទេសពីកងកម្លាំងនៃរបបនេះ តាមរយៈមធ្យោបាយហិង្សា"[3513]។ យើងសូមរំឭកអំពីជម្លោះប្រដាប់អាវុធ រវាង ប.ក.ក និងសាធារណរដ្ឋខ្មែរ ហើយលើកលែងតែមានភ័ស្តុតាងផ្ទុយមកបញ្ជាក់

---

[3509] សូមមើលខាងលើ កថាខណ្ឌ ១៦៦០-១៦៦៤។

[3510] សូមមើលខាងលើ កថាខណ្ឌ ១៦៦០-១៦៦៤។

[3511] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧៖ "គោលនយោបាយនានាត្រូវបានរៀបចំឡើង ដាក់ឱ្យសាកល្បង និងអនុវត្តនៅក្នុងតំបន់រំដោះ ហើយបែបផែនទាំងនេះបានលេចចេញជារូបរាង"។

[3512] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧។

[3513] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

សង្គ្រាម គឺជាការប្រើអំពើហិង្សាទៅវិញទៅមករវាងគូបដិបក្ខ។ ដូច្នេះ អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុថា ហេតុអ្វីបានជាមានភវនីយភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្រោយពេលរំដោះ។

១៨១១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយមិនបានបញ្ជាក់ថា តើ ខៀវ សំផន បានដឹងអង្គហេតុដូចបានរៀបរាប់ដែរឬទេ ដូចជាការសម្លាប់អ្នកប្រឆាំងនយោបាយ និងការបោសសម្អាតក្នុងជួរ ប.ក.ក តាំងពីឆ្នាំ១៩៧៣ ការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃ ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ គោលនយោបាយស្តីពីការកសាងគ្រួសារ នៅដើមឆ្នាំ១៩៧៤ និងការសម្លាប់អ្នកមានទំនាក់ទំនងជាមួយវៀតណាម[3514]។ ដោយគ្មានភ័ស្តុតាងអំពីការដឹងរបស់ ខៀវ សំផន អំពីហេតុការណ៍ទាំងនេះ អង្គជំនុំជម្រះមិនអាចទាញការស្មានចេញពីមុខតំណែងរបស់គាត់ នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និង ប.ក.ក និងការទាក់ទងជាមួយមេដឹកនាំ បានទេ[3515]។ ក្រៅពីនេះទៀត ដូចបានឃើញពីខាងលើ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីតួនាទីរបស់ ខៀវ សំផន នៅមុន និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនត្រឹមត្រូវទេ[3516]។ អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះអំពីការដឹងរបស់ ខៀវ សំផន អំពី"ភវនីយភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម" ត្រូវទុកជាមោឃៈ[3517]។

១៨១២. អង្គជំនុំជម្រះបាន "ជឿជាក់" ថា ខៀវ សំផន បាន "ដឹងជាបន្តបន្ទាប់អំពីការបង្កើតផែនការ ការអនុវត្តផែនការ និងភវនីយភាពដែលថាឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ បានកើតឡើង" ហើយគាត់ "បានដឹងអំពីគោលនយោបាយរបស់ ប.ក.ក" ទាំងមូល[3518]។ សេចក្តីសន្និដ្ឋានជារួមនេះក្តោបទាំងគោលនយោបាយឧក្រិដ្ឋស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅកថាខណ្ឌមុន អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា ប.ក.ក "ក៏បានដាក់ចេញនូវគោលនយោបាយរបស់ខ្លួនលើការកសាង

---

[3514] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧។

[3515] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨។

[3516] សូមមើលខាងលើ កថាខណ្ឌ ១៦៥២-១៨០៣។

[3517] សំអាងហេតុសាលក្រម ផ្នែក ១៨.១.១។

[3518] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨។

គ្រួសារ នៅដើមឆ្នាំ១៩៧៤ ហើយបានចាប់ផ្តើមរៀបចំអាពាហ៍ពិពាហ៍ជូនកម្មាភិបាល"[3519]។ អង្គជំនុំជម្រះបានក៏បានសន្និដ្ឋានខុសទៀតថា "គោលនយោបាយនៃការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងការកសាងគ្រួសារ មានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងគោលបំណងរួម"[3520] ហើយ "ការរៀបអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងដោយមានការបង្ខំ"[3521]។ ប៉ុន្តែ ដូចបានបង្ហាញពីខាងលើ តាមរយៈកំហុសអង្គហេតុ និងអង្គច្បាប់ធ្ងន់ធ្ងរ អង្គជំនុំជម្រះបានសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយបែបនេះ ដើម្បីបង្កើនចំនួនប្រជាជន[3522]។

១៨១៣. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រើប្រាស់ភ័ស្តុតាងក្រៅវិសាលភាពពេលវេលានៃការជំនុំជម្រះក្តី ដើម្បីប៉ុនប៉ងបង្ហាញអំពីវិធីប្រតិបត្តិការស៊ីចង្វាក់គ្នា ដែលខ្លួនមិនអាចធ្វើបាន ដោយសារតែពុំមានភ័ស្តុតាងស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅមុនឆ្នាំ១៩៧៥[3523]។ ដូច្នេះ ការសន្និដ្ឋានថា ខៀវ សំផន ដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត មិនផ្អែកលើភ័ស្តុតាងណាមួយឡើយ។ ផ្ទុយទៅវិញ យើងបានបង្ហាញពីខាងលើថា បទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍របស់ ប.ក.ក តាំងពីមុនរបបកម្ពុជាប្រជាធិបតេយ្យ

---

[3519] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) កំណត់សម្គាល់ជើងទំព័រលេខ ១៣៧៣៥ ដែលអង្គជំនុំជម្រះបានយោងទៅផ្នែក *៣.៥ ការរៀបអាពាហ៍ពិពាហ៍នៅកម្ពុជា មុនឆ្នាំ១៩៧៥* និងកថាខណ្ឌ ៣៥៤០។

[3520] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៤។

[3521] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៦។

[3522] សូមមើលខាងលើ ជាពិសេស កថាខណ្ឌ ១២១២-១២១៥ (ឯកសារ "លោកទស្សនៈបដិវត្តន៍ និងមិនបដិវត្តន៍ ទាក់ទងនឹងបញ្ហាកសាងគ្រួសារ")។

[3523] សូមមើលសក្ខីកម្មរបស់កម្មាភិបាលដែលបានរៀបការតាមការព្រមព្រៀងគ្នា៖ ប្រាក់ យុត៖ ប្រតិចារឹក ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ឯកសារ **E1/378.1** ប្រហែលម៉ោង 11.07.58 ប្រហែលម៉ោង 11.12.08 ប្រហែលម៉ោង 11.18.26 ការរៀបការរបស់គាត់ត្រូវបានអង្គជំនុំជម្រះយល់ជា "ការផ្សំផ្គុំ" ខណៈដែលសាក្សីបានសង្កត់ធ្ងន់លើការយល់ព្រមចំពោះការរៀបការ ដោយបញ្ជាក់ថា៖ "មិនមែនថាគាត់បង្ខំទេ ទាល់ខ្ញុំស្រឡាញ់ដែរ បានយកគ្នាកើត។ អ៊ីចឹង ខ្ញុំយកតាមគាត់បណ្តោយទៅ បើក្នុងហ្នឹងមានចិត្តស្រឡាញ់គាត់ដែរ ហើយក៏តាមគាត់បណ្តោយ បើអត់ស្រឡាញ់ ក៏ខ្ញុំអត់យកដែរ ខ្ញុំប្រកែកបាត់ហើយ តែខ្ញុំស្រឡាញ់គាត់ដែរ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម), សៅ ម៉ុង៖ ប្រតិចារឹក ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ **E1/491.1** មុនម៉ោង 09.34.44 ("ស៖ តើស្ត្រីដែលរៀបការជាមួយលោក នៅពេលនោះហ្នឹង ដែលជាប្រពន្ធលោកហ្នឹង តើលោកធ្លាប់ស្គាល់ពីមុនមកដែរឬទេ? ឆ៖ ស្គាល់ បានទំនាក់ទំនងគ្នា ស្រឡាញ់គ្នា។ ស៖ ដូច្នេះ អាពាហ៍ពិពាហ៍ហ្នឹង គឺទាំងលោកទាំងសងខាង លោក ហើយប្រពន្ធទាំងសងខាង គឺចង់ឱ្យរៀបការជាមួយនឹងគ្នា បានន័យថាអ៊ីចឹង ត្រឹមត្រូវដែរឬទេ? ឆ៖ ត្រឹមត្រូវ"), ស្វ សុជាតិ៖ ប្រតិចារឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/204.1** ចន្លោះម៉ោង 14.02.55 និងម៉ោង 14.13.07។

តម្រូវជាចាំបាច់ឱ្យមានការយល់ព្រមពីអនាគតប្ដីប្រពន្ធ ដោយអនុវត្តតាមសីលធម៌ ១២ ប្រការ[3524]។ ដូច្នេះ អង្គជំនុំជម្រះមិនបានបង្ហាញថា នៅមុនខែមេសា ឆ្នាំ១៩៧៥ ខៀវ សំផន បានដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត។

១៨១៤. អង្គជំនុំជម្រះក៏មិនអាចផ្អែកជាទូទៅលើមុខងារជានិមិត្តរូបរបស់ម្ចាស់បណ្ដឹងសាទុក្ខ ក្នុងសម័យរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដោយមិនបានផ្ដល់សំអាងហេតុថា ហេតុអ្វីបានជាមុខងារទាំងនេះអាចឱ្យគាត់ដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនាពេលខាងមុខ ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍[3525]។ លើសពីនេះទៀត សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះផ្ទុយនឹងការរកឃើញរបស់ខ្លួនផ្ទាល់ថា "រណសិរ្សរួបរួមជាតិកម្ពុជាបានផ្សព្វផ្សាយកម្មវិធីនយោបាយស្ដីពីភាពស្មើគ្នារវាងភេទទាំងពីរ ហើយព្យាយាមលុបបំបាត់ប្រពៃណីអន់ថយដែលរើសអើងទៅលើស្ត្រី" តាមរយៈ ជាអាទិ៍ ការលុបបំបាត់ពហុពន្ធភាព[3526]។ ជំហរនេះផ្ទុយនឹងគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបណ្ដាលឱ្យមានការរំលោភសេពសន្ថវៈរវាងប្ដីប្រពន្ធ[3527]។

១៨១៥. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានផ្អែកលើមុខងារ និងសកម្មភាពរបស់ម្ចាស់បណ្ដឹងសាទុក្ខ និងការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំមួយចំនួន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីសន្និដ្ឋានអំពីការដឹងអំពី "ភវនីយភាព" នៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ខណៈដែលគ្មានភ័ស្តុតាងណាមួយបង្ហាញអំពីសេចក្ដីសម្រេចរបស់ ប.ក.ក ពាក់ព័ន្ធនឹងការបង្កើតគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[3528]។ ភ័ស្តុតាងខ្វះភាពអាចជឿជាក់បាន ជាអាទិ៍ សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៅប មិនអាចឱ្យសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីការរៀបអាពាហ៍ពិពាហ៍

[3524] សូមមើលខាងលើ កថាខណ្ឌ ១៦៦៦។

[3525] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨។

[3526] សំអាងហេតុសាលក្រម កថាខណ្ឌ ២៧៣។

[3527] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៦។

[3528] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៨។

ដោយបង្ខំ ឬគោលនយោបាយក្នុងន័យនេះឡើយ[3529]។ សេចក្តីសន្និដ្ឋានផ្ទុយពីនេះរបស់អង្គជំនុំជម្រះនឹងត្រូវទុកជាមោឃៈ[3530]។

## ជំពូកទី ៣. ការដឹងអំពីឧក្រិដ្ឋកម្ម ក្នុងពេលប្រព្រឹត្ត

### ផ្នែកទី ១. សហករណ៍ និងការដ្ឋាន

#### ១. កំហុសរួមចំពោះការដ្ឋានទាំងអស់

១៨១៦. ដើម្បីសន្និដ្ឋានអំពីការដឹងរបស់ ខៀវ សំផន អង្គជំនុំជម្រះបានប្រើប្រាស់ចម្លើយមួយចំនួនរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលធ្វើឡើងក្រោយអង្គហេតុ ជាអាទិ៍ ក្នុងក្របខ័ណ្ឌកិច្ចសម្ភាសន៍[3531]។ ជាពិសេស អង្គជំនុំជម្រះបានប្រើប្រាស់ចម្លើយទាំងនេះ ដើម្បីកំណត់ថា ម្ចាស់បណ្តឹងសាទុក្ខ "បានដឹងពីល័ក្ខខ័ណ្ឌការងារដ៏អាក្រក់នៅតាមសហករណ៍ និងតាមការដ្ឋានការងារ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[3532]។ ប៉ុន្តែ អង្គជំនុំជម្រះបានប្រកាន់យកការសន្និដ្ឋានជារួមនេះ ដោយផ្អែកលើការបំភ្លៃដោយចេតនានូវកិច្ចសម្ភាសន៍ទាំងនេះ ដោយបានលាក់បាំង ជាអាទិ៍ ភ័ស្តុតាងដោះបន្ទុកដែលបង្ហាញថាចម្លើយរបស់ ខៀវ សំផន បានផ្អែកលើព័ត៌មានទទួលបានក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។

#### ១.១. ការបំភ្លៃចម្លើយរបស់ ខៀវ សំផន ក្នុងពេលសម្ភាសន៍

##### ១.១.១. កិច្ចសម្ភាសន៍របស់ ហេង រស្មី ជាមួយ ខៀវ សំផន

១៨១៧. ជាដំបូង អង្គជំនុំជម្រះបានកត់សម្គាល់ថា ខៀវ សំផន "បានបង្ហាញអំពីភាពចាំបាច់ក្នុងការខិតខំធ្វើការដោយមិនខ្វល់អំពីជំងឺ ដើម្បីទទួលបានទិន្នផលស្រូវបីដងច្រើនជាងប្រទេសចិន និងវៀតណាម"[3533]។

---

[3529] សូមមើលខាងលើ កថាខណ្ឌ ១២៤៩ ("កំហុសពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការផ្សព្វផ្សាយបទបញ្ជា")។

[3530] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២០៧-៤២០៨ កថាខណ្ឌ ៤៣២៦-៤៣២៧។

[3531] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤។

[3532] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៦។

[3533] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣៧៥៦៖ កិច្ចសម្ភាសន៍របស់ ហេង រស្មី ជាមួយ ខៀវ សំផន ឯកសារគ្មានចុះកាលបរិច្ឆេទ **E3/587** ERN 00424201-00424202។

អ្វីដែលអង្គជំនុំជម្រះមិនបានបញ្ជាក់ គឺថា មុននឹងនិយាយសម្តីបែបនេះ គាត់បានពន្យល់ទៅដៃគូសន្ទនាថា នៅពេលកើតហេតុ គាត់មិនបានដឹងអំពីល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌរស់នៅរបស់ប្រជាជន ឬការសម្លាប់នៅតាមការដ្ឋាននានាទេ៖

> "ខ្ញុំនៅតែផ្ទះ ខ្ញុំនៅតែមួយកន្លែងទេ មួយកន្លែងហ្នឹង ម៉ាកន្លែង គឺថា នៅកន្លែងទីស្នាក់ការបញ្ជាការរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យតែម្តង។ ចេញតែពេលណាដែលខ្ញុំត្រូវជូនព្រះកូណាដើរទេ [មានភារកិច្ច] បានដើរ។ អត់មានភារកិច្ច អត់ដើរ ហើយភារកិច្ចអ្នកណា អ្នកហ្នឹងដឹង អ្នកផ្សេងកុំចង់ដឹង កុំចង់ឮ។ ដូច្នេះ អាហ្នឹងខ្ញុំគោរពតាមហ្នឹង ខ្ញុំអត់ដឹង ប៉ុន្តែ ម៉េចបាន... អាហ្នឹងក៏ខ្ញុំគិត ក៏ខ្ញុំចេះតែដេញ ខ្ញុំបាននិយាយហើយថា ខ្ញុំចង់ គឺថាខំធ្វើអ៊ីចឹង វាត្រូវប៊ិនចេះតែជេរជេរជេរថា ខ្មែរក្រហមបង្អត់បាយ ខ្មែរក្រហមបង្អត់បាយ អាហ្នឹង... ដូចពិបាកដែរ អាហ្នឹង។ ដូច្នេះ យើងត្រូវស្រាវជ្រាវ ចុះដល់ស្រាវជ្រាវទៅយើងឃើញយ៉ាងម៉េច? ខ្ញុំគិតទេ"[3534]។

១៨១៨. ដូច្នេះ សម្តីរបស់ម្ចាស់បណ្តឹងសាទុក្ខ គឺគ្រាន់តែជាការស្មាន ដូចគាត់ធ្លាប់បានទទួលស្គាល់ដោយខ្លួនឯងផ្ទាល់។ ជាក់ស្តែង ប្រសិនបើអង្គជំនុំជម្រះយកការត្រិះរិះពិចារណានេះមកប្រឆាំងនឹងម្ចាស់បណ្តឹងសាទុក្ខ ដោយទម្លាក់លើគាត់នូវចេតនាផ្តល់ហេតុផលដាក់បន្ទុក អង្គជំនុំជម្រះខកខានដោយចេតនាមិនបានអះអាងថា ការត្រិះរិះពិចារណានេះមានភាពចាំបាច់ ពីព្រោះ ខៀវ សំផន មិនដឹងអំពីឧក្រិដ្ឋកម្មទេនៅពេលកើតហេតុ។

### ១.១.២. កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ (ឯកសារ E3/4050)

[3534] កិច្ចសម្ភាសន៍របស់ ហេង រស្មី ជាមួយ ខៀវ សំផន ឯកសារគ្មានចុះកាលបរិច្ឆេទ **E3/587** ERN 00424200-00424201 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៨១៩. អង្គជំនុំជម្រះបានប្រើប្រាស់ប្រតិចារឹកពីរនៃកិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដែលគ្មានព័ត៌មានអាចឱ្យផ្ទៀងផ្ទាត់យថាភាពបាន[3535]។ អង្គជំនុំជម្រះបានប្រើប្រាស់កិច្ចសម្ភាសន៍ទីមួយ (ឯកសារ E3/4050) ដើម្បីអះអាងថា "កិច្ចសម្ភាសន៍នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យបានបង្ហាញអំពីការដឹងឮរបស់គាត់ពីសម័យនោះថា [...] ធ្វើៗ ទាំងអ្នកឈឺ ធ្វើទាំងអ្នកជា ហើយគាត់បានបន្ថែមទៀតថា អ្នកឈឺល្មមៗក៏ធ្វើនឹងគេដែរ"[3536]។ តាមរយៈសម្រង់នេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីល័ក្ខខ័ណ្ឌរស់នៅ និងល័ក្ខខ័ណ្ឌការងារ នៅពេលកើតហេតុ។ ប៉ុន្តែ ខៀវ សំផន បានបង្ហាញជាថ្មីម្ដងទៀតអំពីការត្រិះរិះពិចារណារបស់គាត់ នៅ**ក្រោយ**អង្គហេតុ។ គ្មានតម្រុយណាមួយនៅក្នុងសម្រង់នេះបញ្ជាក់ថា គាត់និយាយអំពីការដឹងរបស់គាត់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះឡើយ។

១៨២០. ម្យ៉ាងវិញទៀត ភ័ស្តុតាងនេះចោទឡើងនូវបញ្ហាយថាភាពយ៉ាងធ្ងន់ធ្ងរ។ ឯកសារនេះមិនមានចុះកាលបរិច្ឆេទ ធ្វើឱ្យយើងមិនដឹងថា តើ ខៀវ សំផន បានផ្ដល់ព័ត៌មានទាំងនេះនៅពេលណា។ យើងដឹងថា កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងក្រោយអង្គហេតុ ប៉ុន្តែមិនដឹងអ្វីជាដុំកំភួនទៀតទេ។ ផ្ទុយទៅវិញ កាលបរិច្ឆេទ គឺជាធាតុដ៏សំខាន់ ពេលយើងដឹងថា ម្ចាស់បណ្ដឹងសាទុក្ខបានផ្ដល់ព័ត៌មានជាច្រើន ក្រោយអង្គហេតុ ជាអាទិ៍ ចាប់ពីពេលគាត់បានអានសៀវភៅរបស់ Philip SHORT ដែលអង្គជំនុំជម្រះខ្លួនឯងផ្ទាល់បានលើកឡើង នៅក្នុងផ្នែកផ្សេងទៀតនៃសំអាងហេតុសាលក្រម[3537]។ យើងក៏មិនស្គាល់អ្នកធ្វើប្រតិចារឹក ហើយសំណួរដែល ខៀវ សំផន ហាក់ដូចជាបានឆ្លើយ ក៏មិនត្រូវបានវាយបញ្ចូល។ ដូច្នេះនេះប្រហែលជាឯកសារកាត់ក្បាលកាត់កន្ទុយ។ ជាចុងក្រោយ នៅក្នុងកំណត់សម្គាល់ជើងទំព័រលេខ ១៣៧៥៧ ពាក់ព័ន្ធនឹងឯកសារនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះបាន "យល់ឃើញថា ខៀវ សំផន ពុំបានអះអាងឱ្យបានច្បាស់លាស់ចំពោះស្ថានភាពនានានៅអាងទំនប់ត្រពាំងថ្មនោះទេ ប៉ុន្តែគាត់បានបង្ហាញអំពីការដឹងដ៏ទូលំទូលាយរបស់គាត់ ចំពោះស្ថានភាពការងារនៅឯការដ្ឋានការងារជាច្រើន [ទៅវិញទេ]" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ តាមពិត អង្គជំនុំជម្រះបានស្មាន ពីព្រោះ

---

[3535] កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4050**, កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043**។

[3536] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤, កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4050**។

[3537] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៥។

តាមរយៈការអានឯកសារនេះ អង្គជំនុំជម្រះមិនអាចដឹងថា តើម្ចាស់បណ្ដឹងសាទុក្ខនិយាយសំដៅដល់អ្វីនោះទេ។ ហេតុនេះហើយបានជាអង្គជំនុំជម្រះប្រើពាក្យ "ទៅវិញទេ" ដែលគ្មានអ្វីក្រៅពីការសន្និដ្ឋានពង្រីករបស់អង្គជំនុំជម្រះ។ រឿងរ៉ាវនេះមានភាពមិនច្បាស់លាស់ មិនលម្អិត ហើយសំណួរមិនត្រូវបានវាយបញ្ចូល។ ដូច្នេះ យើងមិនអាចដឹងថាតើម្ចាស់បណ្ដឹងសាទុក្ខនិយាយសំដៅដល់អ្វីឱ្យប្រាកដនោះទេ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះមិនគួរណាផ្អែកលើឯកសារ E3/4050 នេះ ដែលមិនឆ្លើយតបនឹងបទដ្ឋានអប្បបរមានៃការវាយតម្លៃភ័ស្តុតាង ហើយថាភាពមានភាពគួរឱ្យសង្ស័យជាសត្យានុម័តិ។

## ១.១.៣. កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ (ឯកសារ E3/4043)

១៨២១. បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រើប្រាស់កិច្ចសម្ភាសន៍ទីពីរ (ឯកសារ E3/4043) ដើម្បីអះអាងថា ខៀវ សំផន "បានពិពណ៌នាអំពីស្ថានភាពដ៏អាក្រក់នៅការដ្ឋានការងារ និងការឈឺចាប់របស់អ្នកធ្វើការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[3538]។ ការពិនិត្យលើឯកសារនេះចោទឡើងនូវបញ្ហាយថាភាពដដែល ដូចកិច្ចសម្ភាសន៍មុនដែរ៖ គ្មានព័ត៌មានអំពីកាលបរិច្ឆេទ ម្ចាស់ឯកសារ ឬសំណួរ ដែលមិនត្រូវបានវាយបញ្ចូល។ ដូច្នេះ យើងមិនអាចដឹងថា តើ ខៀវ សំផន បានឆ្លើយនឹងសំណួរ ក្នុងបរិបទបែបណាទេ។

១៨២២. បើគ្មានធាតុផ្សំទាំងនេះ និងជាពិសេស បើគ្មានសំណួរដែលបានចោទសួរ យើងអាចត្រឹមតែអានកិច្ចសម្ភាសន៍ទាំងពីរដោយអត្តនោម័តិ ធ្វើឱ្យយើងមិនអាចទាញសេចក្ដីសន្និដ្ឋានជាសត្យានុម័តិ ដោយគោរពតាមបទដ្ឋានវាយតម្លៃភ័ស្តុតាងបានទេ។ ដោយមិនពិចារណាដល់កាលៈទេសៈពិសេសទាំងនេះ អង្គជំនុំជម្រះមានចេតនាបំភ្លៃសម្ដីរបស់ ខៀវ សំផន។ ជាក់ស្ដែង អង្គជំនុំជម្រះបានធ្វើប្រតិចារឹកឡើងវិញនូវឃ្លាដូចខាងក្រោម៖

[3538] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤។

"ប៉ុន្តែ រឿងអត់ថ្នាំសង្កូវ ខ្ញុំមានភារកិច្ចទិញថ្នាំសង្កូវពីខាងក្រៅ។ ទិញច្រើនណាស់ ហើយទិញនេះអត់មានថ្នាំអ្វីក្រៅពីថ្នាំរាកមួល អាថ្នាំគ្រុន គេហៅថា ថ្នាំជំងឺទូទៅរបស់ប្រជាជន។ មិនមែនថ្នាំអីប្រណីត ប៉េនីស៊ីលីនអី ថ្នាំឈឺសួត ឈឺអី អត់ទេ។ សម្រុកប្រមូលលុយដែលមានទាំងប៉ុន្មានហ្នឹង ទិញអាថ្នាំទូទៅហ្នឹងតែម្តង។ ខ្ញុំហើយ ខ្ញុំអ្នកអនុវត្តអារឿងហ្នឹង ខ្ញុំមិនមែនសម្រេចខ្លួនឯងទេ គណៈអចិន្ត្រៃយ៍ទេជាអ្នកសម្រេច។ *តែខ្ញុំជាអ្នកអនុវត្ត ខ្ញុំឃើញអាហ្នឹង។* ប៉ុន្តែ វាអត់គ្រប់ទេ ទិញយ៉ាងម៉េចក៏វាមិនគ្រប់។ [...] *បង្ខំឱ្យគ្នាធ្វើ អត់បាយ ដើរខ្លួនឯងមិនចង់រួចផងក៏ឱ្យទៅធ្វើទៀត។* [...] ស្លាប់នេះទៀត ភាគច្រើនដែលអត់ថ្នាំ ដែលអត់បាយ អត់ថ្នាំសង្កូវ មិនមែនដោយសារបង្អត់បាយ បង្អត់ថ្នាំសង្កូវទេ វាខ្វះ។ អានេះដែលខ្ញុំចង់និយាយឱ្យឃើញឱ្យច្បាស់"[3539] (អង្គជំនុំជម្រះជាអ្នកដាក់អក្សរឱ្យទ្រេត)។

១៨២៣. ការចម្លងសម្រង់នេះឡើងវិញបង្កការភាន់ច្រឡំ។ អង្គជំនុំជម្រះមានចេតនាកាត់ចោលភ័ស្តុតាងដោះបន្ទុក ដើម្បីបង្កើតបានជាសក្ខីកម្មមួយដាក់បន្ទុកទាំងស្រុងលើ ខៀវ សំផន ដោយមានចេតនាបំភ្លៃសម្តីរបស់គាត់។ ជាក់ស្តែង អង្គជំនុំជម្រះបានកាត់តសម្រង់នេះ ដោយយកឃ្លាមកពីសំណួរផ្សេងៗគ្នាមកដាក់បន្តគ្នា។ តាមពិត ពីមួយឃ្លាទៅមួយឃ្លា ម្ចាស់បណ្តឹងសាទុក្ខបានឆ្លើយទៅនឹងសំណួរផ្សេងគ្នា។ អង្គជំនុំជម្រះបានជ្រើសរើសយកតែភ័ស្តុតាងដាក់បន្ទុកមកបង្ហាញជារួម ដែលជាការបំភ្លៃភ័ស្តុតាង ហើយវិធីនេះត្រូវតែបដិសេធចោល។

១៨២៤. លើសពីនេះទៅទៀត សូមរំឭកថា សំណួរស្ទើរតែមិនត្រូវបានធ្វើប្រតិចារឹក ដោយសារឮមិនច្បាស់។ ចំណាត់ការដាក់បន្ទុកនេះមិនឆ្លុះបញ្ចាំងសម្តីរបស់ ខៀវ សំផន នោះទេ ដូចបង្ហាញក្នុងការប្រៀបធៀបជាមួយសម្រង់ដើម។

| **សម្រង់របស់អង្គជំនុំជម្រះ** | **សម្រង់ដើមនៃកិច្ចសម្ភាសន៍** |
| --- | --- |
| "ប៉ុន្តែ រឿងអត់ថ្នាំសង្កូវ ខ្ញុំមានភារកិច្ចទិញថ្នាំសង្កូវពីខាងក្រៅ។ ទិញច្រើនណាស់ ហើយទិញនេះអត់មាន | "ប៉ុន្តែ រឿងអត់ថ្នាំសង្កូវ ខ្ញុំមានភារកិច្ចទិញថ្នាំសង្កូវពីខាងក្រៅ។ ទិញច្រើនណាស់ ហើយទិញនេះអត់មាន |

[3539] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤ (អង្គជំនុំជម្រះជាអ្នកដាក់អក្សរទ្រេត)។

| | |
|---|---|
| ថ្នាំអ្វីក្រៅពីថ្នាំរាកមួល អាថ្នាំគ្រុន គេហៅថា ថ្នាំជំងឺទូទៅរបស់ប្រជាជន។ មិនមែនថ្នាំអីប្រណីត ប៉េនីស៊ីលីនអី ថ្នាំឈឺស្លូត ឈឺអី អត់ទេ។ សម្រុកប្រមូលលុយដែលមានទាំងប៉ុន្មានហ្នឹង ទិញអាថ្នាំទូទៅហ្នឹងតែម្តង។ ខ្ញុំហើយ ខ្ញុំអ្នកអនុវត្តអារឿងហ្នឹង ខ្ញុំមិនមែនសម្រេចខ្លួនឯងទេ គណៈអចិន្ត្រៃយ៍ទេជាអ្នកសម្រេច។ *តែខ្ញុំជាអ្នកអនុវត្ត ខ្ញុំឃើញអាហ្នឹង*។ ប៉ុន្តែវាអត់គ្រប់ទេ ទិញយ៉ាងម៉េចក៏វាមិនគ្រប់។ [...] *បង្ខំឱ្យគ្នាធ្វើ អត់បាយ ដើរខ្លួនឯងមិនចង់រួចផង ក៏ឱ្យទៅធ្វើទៀត*។ [...]”[3540]។ | ថ្នាំអ្វីក្រៅពីថ្នាំរាកមួល អាថ្នាំគ្រុន គេហៅថា ថ្នាំជំងឺទូទៅរបស់ប្រជាជន។ មិនមែនថ្នាំអីប្រណីត ប៉េនីស៊ីលីនអី ថ្នាំឈឺស្លូត ឈឺអី អត់ទេ។ សម្រុកប្រមូលលុយដែលមានទាំងប៉ុន្មានហ្នឹង ទិញអាថ្នាំទូទៅហ្នឹងតែម្តង។ ខ្ញុំហើយ ខ្ញុំអ្នកអនុវត្តអារឿងហ្នឹង ខ្ញុំមិនមែនសម្រេចខ្លួនឯងទេ គណៈអចិន្ត្រៃយ៍ទេជាអ្នកសម្រេច។ *តែខ្ញុំជាអ្នកអនុវត្ត ខ្ញុំឃើញអាហ្នឹង*។ ប៉ុន្តែវាអត់គ្រប់ទេ ទិញយ៉ាងម៉េចក៏វាមិនគ្រប់។ សភាពការណ៍ពេលនោះ យើងទើបតែចេញពីសង្គ្រាម អ៊ីចឹង វាធម្មតាទេ ការអត់ ការខ្វះ ហៅថាយើងត្រូវប្រយុទ្ធ ដោយខ្វះសព្វ ខ្វះគ្រប់មែនទែន! ចុះហេតុម៉េចបានជាបង្ខំម្ល៉េះ? បង្ខំឱ្យគ្នាធ្វើ អត់បាយ ដើរខ្លួនឯងមិនចង់រួចផង ក៏ឱ្យទៅធ្វើទៀត”[3541]។ |

១៨២៥. ក្នុងសម្រង់នេះ អង្គជំនុំជម្រះខកខានមិនបានដាក់បញ្ចូលផ្នែកដែលត្រូវបានមេធាវីការពារក្តីគូសបន្ទាត់ពីក្រោម។ ប៉ុន្តែ ផ្នែកនេះរំឭកអំពីបរិបទប្រវត្តិសាស្ត្រ គឺក្រោយសង្គ្រាម ដែលជាភ័ស្តុតាងដោះបន្ទុក ពីព្រោះមិនមែនជាឆន្ទៈរបស់កម្ពុជាប្រជាធិបតេយ្យ។ ពេលម្ចាស់បណ្តឹងសាទុក្ខបង្ហាញថា គាត់មានភារកិច្ចទិញថ្នាំសង្កូវ អង្គជំនុំជម្រះបានដាក់បញ្ចូលសម្តីរបស់គាត់ ដើម្បីធ្វើជាភ័ស្តុតាងដាក់បន្ទុក៖ “ខ្ញុំអ្នកអនុវត្តអារឿងហ្នឹង ខ្ញុំមិនមែនសម្រេចខ្លួនឯងទេ គណៈអចិន្ត្រៃយ៍ទេជាអ្នកសម្រេច។ តែខ្ញុំជាអ្នកអនុវត្ត ខ្ញុំឃើញអាហ្នឹង។ ប៉ុន្តែវាអត់គ្រប់ទេ ទិញយ៉ាងម៉េចក៏វាមិនគ្រប់”[3542]។ អង្គជំនុំជម្រះមានចេតនាលុបចោលឃ្លាបន្តមកទៀត។

[3540]កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959, សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤។

[3541]កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959។

[3542]កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959, (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៨២៦. ជាចុងក្រោយ ការសួររបស់ ខៀវ សំផន ថា "ចុះហេតុម៉េចបានជាបង្ខំម្ល៉េះ?" ហាក់ដូចជាបង្ហាញអំពីការស្វែងយល់ពីសំណាក់គាត់ទៅវិញទេ[3543]។ ប៉ុន្តែ ដើម្បីឱ្យមានភាពច្បាស់លាស់ គេត្រូវមានសំណួរ ប៉ុន្តែ មិនអ៊ីចឹងទេ។ ក្នុងភាពសង្ស័យ អង្គជំនុំជម្រះគួរណាតែសន្និដ្ឋានថា ជាថ្មីម្តងទៀត ម្ចាស់បណ្តឹងសាទុក្ខបង្ហាញអំពីការត្រិះរិះពិចារណាក្រោយអង្គហេតុ។

| **សម្រង់របស់អង្គជំនុំជម្រះ** | **សម្រង់ដើមនៃកិច្ចសម្ភាសន៍** |
|---|---|
| "ស្លាប់នេះទៀត ភាគច្រើនដែលអត់ថ្នាំ ដែលអត់បាយ អត់ថ្នាំសង្កូវ មិនមែនដោយសារបង្អត់បាយ បង្អត់ថ្នាំសង្កូវទេ វាខ្វះ"[3544]។ | "ចាត់ចែងការងារ រស់នៅរាល់ថ្ងៃ ប្រចាំថ្ងៃនេះ អត់ចេះ។ មិនមែនថាអត់ចេះ អ្នកខ្លះមិនទទួលខុសត្រូវ។ ហ្នឹងដែលនាំឱ្យមានការស្លាប់ ហើយស្លាប់នេះទៀត ភាគច្រើនដែលអត់ថ្នាំ ដែលអត់បាយ អត់ថ្នាំសង្កូវ មិនមែនដោយសារបង្អត់បាយ បង្អត់ថ្នាំសង្កូវទេ វាខ្វះ"[3545]។ |

១៨២៧. នៅក្នុងសម្រង់ទីពីរនេះ សំណួរទីមួយ (មិនត្រូវបានធ្វើប្រតិចារឹក) ត្រូវបានសួរ ហើយ ខៀវ សំផន បានឆ្លើយ ជាមួយនឹងពាក្យ "**<u>តាមខ្ញុំយល់</u>**" ដែលមានន័យថា នេះជាការយល់របស់គាត់ តាមរយៈការសិក្សាឯកសារ ក្រោយអង្គហេតុ ដូចគាត់បាននិយាយម្តងហើយម្តងទៀត ក្នុងកិច្ចពិភាក្សាដេញដោល[3546]។ ខណៈដែល ខៀវ សំផន ធ្វើការរិះគន់លើការគ្រប់គ្រងរបស់កម្មាភិបាលមួយចំនួន តាមការយល់របស់គាត់ក្រោយអង្គហេតុ អង្គជំនុំជម្រះបានកាត់សម្តីរបស់គាត់យកត្រឹមតែ៖ "ស្លាប់នេះទៀត ភាគច្រើនដែលអត់ថ្នាំ ដែលអត់បាយ អត់ថ្នាំសង្កូវ មិនមែនដោយសារបង្អត់បាយ បង្អត់ថ្នាំសង្កូវ

[3543]កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959។

[3544]កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959, សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៥។

[3545]កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959។

[3546]កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959, (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ទេ វាខ្វះ"[3547]។ ការបង្ហាញដោយដោយកាត់ក្បាលកាត់កន្ទុយនេះមិនឆ្លុះបញ្ចាំងការសង្ស័យ និងការឆ្លើយរបស់ម្ចាស់បណ្ដឹងសាទុក្ខ នៅក្នុងកិច្ចសម្ភាសន៍ក្រោយអង្គហេតុនេះទេ។

១៨២៨. ដូច្នេះ អង្គជំនុំជម្រះបានបំភ្លៃ និងបំប្លែងទាំងស្រុងនូវចម្លើយរបស់ម្ចាស់បណ្ដឹងសាទុក្ខ។ ការទាញសេចក្ដីសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះអំពីការដឹងរបស់ ខៀវ សំផន ផ្អែកតែលើការរំលោភបទដ្ឋាននៃភ័ស្ដុតាង[3548]។ យោងតាមបញ្ហាយថាភាព និងបញ្ហាបទដ្ឋាននៃភ័ស្ដុតាង ឯកសារ E3/4043 និង E3/4050 គួរណាតែត្រូវដកចេញពីកិច្ចពិភាក្សាដេញដោល[3549]។ ការប្រើប្រាស់ឯកសារទាំងនេះដើម្បីដាក់បន្ទុក ធ្វើមោឃភាពដល់សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។

## ១.២. កំហុសពាក់ព័ន្ធនឹងការដឹងអំពីលក្ខខ័ណ្ឌរស់នៅក្នុងខេត្តព្រះវិហារ

១៨២៩. អង្គជំនុំជម្រះបានអះអាងថា ខៀវ សំផន បានដឹង "អំពីល័ក្ខខ័ណ្ឌរស់នៅក្នុងសហករណ៍នៅខេត្តព្រះវិហារ" នៅពេលកើតហេតុ[3550]។

### ១.២.១. សហករណ៍ព្រះវិហារមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្ដី

១៨៣០. ជាបឋម សូមបញ្ជាក់ថា អង្គជំនុំជម្រះបានទទួលបណ្ដឹងតែអំពីសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ ហេតុដូច្នេះ សហករណ៍ព្រះវិហារមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្ដីទេ ហើយ ខៀវ សំផន មិនចាំបាច់ត្រូវឆ្លើយតបអ្វីនោះទេ។ អង្គជំនុំជម្រះមិនអាចយកភ័ស្ដុតាងក្រៅវិសាលភាពមកធ្វើជាមូលដ្ឋាននៃការ

[3547] កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043** ERN 00780959, សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤។

[3548] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៤-៤២១៨។

[3549] កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4050**, កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4043**។

[3550] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៦។

សន្និដ្ឋានអំពីអង្គហេតុដែលខ្លួនមិនបានទទួលបណ្តឹងនោះឡើយ។ នេះជាដំណើរការអនុមានដែលត្រូវបដិសេធចោល។ ជាបន្ទាប់បន្សំ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ក្នុងការវាយតម្លៃភ័ស្តុតាងដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន។

### ១.២.២. កំហុសពាក់ព័ន្ធនឹងវិធីសាស្ត្របង្ហាញភ័ស្តុតាង

១៨៣១. ជាក់ស្តែង ដើម្បីទាញសេចក្តីសន្និដ្ឋាននេះ អង្គជំនុំជម្រះបានយោងទៅរកកថាខណ្ឌ ៤២៣២ ដល់ កថាខណ្ឌ ៤២៣៤។ ជាដំបូង អង្គជំនុំជម្រះបានប្រើប្រាស់លិខិតចំហរបស់ម្ចាស់បណ្តឹងសាទុក្ខ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ មានចំណងជើងថា *"ស្វែងរកការពិត - សំបុត្រចំហជូនបងប្អូនរួមជាតិទាំងអស់"*[3551] ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ក្នុងពេលបោសសម្អាតផ្ទៃក្នុង ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[3552]។ អង្គជំនុំជម្រះក៏បានប្រើប្រាស់លិខិតនេះផងដែរ ដើម្បីអះអាងថា គាត់បានដឹងអំពីល័ក្ខខ័ណ្ឌរស់នៅ នៅតាមការដ្ឋាន និងសហករណ៍[3553]។ ប៉ុន្តែ អង្គជំនុំជម្រះបានបំភ្លៃសម្តីរបស់ ខៀវ សំផន ជាថ្មីម្តងទៀត។ ជាក់ស្តែង គាត់បានលើកឡើងអំពីការចាប់ខ្លួនសមាជិកគ្រួសាររបស់ប្រពន្ធគាត់ នៅខេត្តព្រះវិហារ។ ចៅក្រមបានបំភ្លៃបរិបទនៃអង្គហេតុ។ ខៀវ សំផន បានពន្យល់ ជាអាទិ៍ ថា គាត់បាន "ដឹងឮ" អំពីការចាប់ចងនេះ "ដោយចៃដន្យ"[3554]។ ម្យ៉ាងវិញទៀត ចម្លើយនេះស៊ីចង្វាក់គ្នានឹងភ័ស្តុតាងផ្សេងទៀតនៅក្នុងសំណុំរឿង ដែលបានបង្ហាញថា ខៀវ សំផន មិនទទួលបន្ទុកបញ្ហាសន្តិសុខទេ[3555]។

---

[3551]លិខិតរបស់លោក ខៀវ សំផន *ស្វែងរកការពិត - សំបុត្រចំហជូនបងប្អូនរួមជាតិទាំងអស់* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ឯកសារ **E3/205**។

[3552]សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៥។

[3553]សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៦។

[3554]លិខិតរបស់លោក ខៀវ សំផន *ស្វែងរកការពិត - សំបុត្រចំហជូនបងប្អូនរួមជាតិទាំងអស់* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ឯកសារ **E3/205** ERN 00002796។

[3555]សូមមើលខាងក្រោម កថាខណ្ឌ ១៨៤២-១៨៤៤។

១៨៣២. នៅក្នុងឯកសារដដែលនេះ និងក្នុងសម្រង់មួយដែលអង្គជំនុំជម្រះមិនបានដកស្រង់ គាត់បានពន្យល់ថា គាត់បានគិតថាការចាប់ចងនេះ គឺជាករណីដាច់ដោយឡែក៖

> "គឺប្រពន្ធខ្ញុំបាននិយាយប្រាប់ខ្ញុំទាំងទឹកភ្នែក អំពីបងប្អូនបង្កើត និងសាច់ញាតិរបស់គាត់ត្រូវគេចាប់ដាក់ខ្នោះដៃខ្នោះជើង អស់រយៈពេលជាង ១ ឆ្នាំ ដំបៅរលេះរលួយ ជាមួយប្រជាជនជាច្រើនទៀត។ ប៉ុន្តែ ដោយមានការដោះលែងជនរងគ្រោះ និងមានការចាប់ខ្លួនលេខាបក្សភូមិភាគនោះ ក៏នាំឱ្យខ្ញុំដឹងរឿងនេះជាអំពើឃោរឃៅផ្ទាល់របស់បុគ្គលតែប៉ុណ្ណោះ។ វិន័យហាមមិនឱ្យខ្ញុំដើរហើរ ដោយគ្មានការអនុញ្ញាត"[3556]។

១៨៣៣. ជាក់ស្តែង អង្គជំនុំជម្រះបានប្រើប្រាស់ឯកសារនេះ ដើម្បីទាញការសន្និដ្ឋានអំពីការដឹងជាទូទៅអំពីមន្ទីរសន្តិសុខ ការដ្ឋាន និងសហករណ៍ ខណៈដែលនៅក្នុងអត្ថបទដដែលនេះ ខៀវ សំផន បានពន្យល់ថា វាគឺជាករណីដោយឡែក បណ្តាលមកពីអំពើផ្ទាល់របស់លេខាបក្សភូមិភាគនោះ។

១៨៣៤. បន្ទាប់មកទៀត អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ មាស វឿន ដើម្បីព្យាយាមបញ្ជាក់អះអាងអំពីការដឹងរបស់ ខៀវ សំផន។ ពិតមែនតែ មាស វឿន ឆ្លើយថា ខៀវ សំផន បានសួរគាត់អំពីសភាពការណ៍នៅខេត្តព្រះវិហារ ហើយគាត់បានរាយការណ៍[3557] ប៉ុន្តែ គាត់បានអះអាងផងដែរថា គាត់មិនបានទទួលចម្លើយពី ខៀវ សំផន វិញទេ ធ្វើឱ្យមិនមានភស្តុតាងបង្ហាញថា ខៀវ សំផន បានដឹងទេ[3558]។ ម្យ៉ាងវិញទៀត គាត់ក៏បានបញ្ជាក់ផងដែរថា គាត់មិនជួប ខៀវ សំផន ទេ ហើយគាត់ទៅខេត្តព្រះវិហារដំបូង តាមបញ្ជារបស់ ប៉ុល ពត ដើម្បី "ទៅស៊ើបមើលតើគេចាប់ប្រជាជនមែន ឬអត់"[3559]។ សូមរំឭកថា ការចុះពិនិត្យរបស់ មាស វឿន ត្រូវនឹងពេលជម្លោះប្រដាប់អាវុធឡើងកម្តៅខ្លាំង។ បន្ទាប់

---

[3556] លិខិតរបស់លោក ខៀវ សំផន *ស្វែងរកការពិត - សំបុត្រចំហជូនបងប្អូនរួមជាតិទាំងអស់* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ឯកសារ **E3/205** ERN 00002796។

[3557] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៣, មាស វឿន៖ ប្រតិចារឹក ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/130.1** ចន្លោះម៉ោង 14.07.52 និងម៉ោង 14.12.58។

[3558] <u>មាស វឿន</u>៖ ប្រតិចារឹក ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/130.1** ប្រហែលម៉ោង 09.42.45។

[3559] <u>មាស វឿន</u>៖ ប្រតិចារឹក ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/130.1** ចន្លោះម៉ោង 14.04.13 និងម៉ោង 14.12.58។

មកទៀត គាត់បាននិយាយថា គាត់ទៅខេត្តនេះ និងបានសង្កេតឃើញ "ភាពហួសហេតុ" និងការចាប់ចងជាច្រើនដោយអ្នកគ្រប់គ្រងភូមិភាគ ហើយគាត់បានដោះលែងអ្នកជាប់ឃុំ[3560]។

១៨៣៥. សរុបសេចក្តីមក គ្មានចំណុចណាមួយក្នុងរឿងរ៉ាវរបស់ មាស វឿន ផ្ទុយនឹងចម្លើយរបស់ ខៀវ សំផន នោះទេ ហើយគ្មានតម្រុយណាមួយឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា ហេតុការណ៍នេះបញ្ជាក់អំពីការដឹងរបស់គាត់អំពីអង្គហេតុ នៅតាមសហករណ៍ទាំងអស់ ជាពិសេស សហករណ៍នៅត្រាំកក់ នោះឡើយ។ ផ្ទុយទៅវិញ ការតម្រូវឱ្យមានការស៊ើបអង្កេតពី មាស វឿន ដើម្បីទទួលបានព័ត៌មានលម្អិតអំពីសមាជិកគ្រួសាររបស់គាត់ គឺជាតឹកតាងបង្ហាញអំពីការមិនដឹងស្ថានភាពនៅនឹងកន្លែងទៅវិញទេ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានទាំងនេះពាក់ព័ន្ធតែនឹងខេត្តព្រះវិហារមួយគត់ គឺមិនពាក់ព័ន្ធនឹងទីតាំងផ្សេងទៀត ដូចបានរៀបរាប់ក្នុងដីកាដំណោះស្រាយឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រើប្រាស់ដោយខុសឆ្គងនូវទីតាំងក្រៅវិសាលភាពនេះ ដើម្បីសន្និដ្ឋានថា "ខៀវ សំផន បានដឹងអំពីល័ក្ខខ័ណ្ឌការងារដ៏អាក្រក់នៅតាមសហករណ៍ និងតាមការដ្ឋានការងារ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[3561]។ ការអះអាងនេះរបស់អង្គជំនុំជម្រះផ្អែកតែលើការស្មាន និងការបំភ្លៃភ័ស្តុតាង។ ដូច្នេះ សេចក្តីសន្និដ្ឋានអំពីសហករណ៍ព្រះវិហារ និងការប្រើប្រាស់សេចក្តីសន្និដ្ឋានទាំងនេះ នៅក្នុងសំអាងហេតុសាលក្រម ត្រូវទុកជាមោឃៈ[3562]។

## ១.៣. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការប្រព្រឹត្តិរើសអើងចំពោះប្រជាជនថ្មី

១៨៣៦. អង្គជំនុំជម្រះយល់ឃើញថា មានការបង្ហាញឱ្យឃើញថា "ខៀវ សំផន បានដឹងអំពីការរើសអើងទៅលើប្រជាជនថ្មីនៅតាមសហករណ៍ និងការដ្ឋានការងារ"[3563]។ ដើម្បីទាញសេចក្តីសន្និដ្ឋាននេះបាន អង្គ

---

[3560] មាស វឿន៖ ប្រតិចារឹក ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/130.1** ប្រហែលម៉ោង 14.27.54។

[3561] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦១៦។

[3562] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៦១៦។

[3563] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៧។

ជំនុំជម្រះផ្អែកតែទៅលើសៀវភៅរបស់ ខៀវ សំផន មានចំណងជើងថា "*ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ*"[3564] និងដោយបានបំភ្លៃសម្ដីរបស់គាត់។

១៨៣៧. សៀវភៅនេះមិនតំណាងឱ្យការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីអង្គហេតុនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ នៅក្នុងសៀវភៅនេះ ខៀវ សំផន បានផ្ដល់ការវិភាគបច្ចុប្បន្នរបស់គាត់លើអង្គហេតុក្នុងរបបកម្ពុជាធិបតេយ្យ ក្រោយពីបានអានស្នាដៃជាច្រើនរបស់អ្នកជំនាញ។ ម្យ៉ាងទៀត អង្គជំនុំជម្រះបាននិយាយជាន់កែងខ្លួនឯងនៅក្នុងសំអាងហេតុសាលក្រម ដោយបានទាញសេចក្ដីសន្និដ្ឋាននេះ ព្រោះថានៅក្នុងផ្នែកទាក់ទងនឹងការវាយតម្លៃលើភ័ស្ដុតាង អង្គជំនុំជម្រះបានប្រកាសពីការប្រើប្រាស់មួយផ្សេងទៀតលើសៀវភៅនេះ៖

> "អង្គជំនុំជម្រះយល់ឃើញថាសក្ខីកម្មរបស់ ខៀវ សំផន មានអត្ថប្រយោជន៍សម្រាប់ព្រឹត្តិការណ៍ដែលបានកើតឡើងនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ហើយអង្គជំនុំជម្រះបានពឹងផ្អែកទៅលើសក្ខីកម្មទាំងនេះ ដោយមានការប្រុងប្រយ័ត្ន និងពិនិត្យទៅលើភ័ស្ដុតាងគាំទ្រផ្សេងៗទៀតផងដែរ។ <u>ទោះជាយ៉ាងណា អង្គជំនុំជម្រះបានពឹងផ្អែកទៅលើឯកសារបោះពុម្ពផ្សាយរបស់គាត់ដែលមានចំណងជើងថា ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជាពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងកម្រិតកំណត់មួយប៉ុណ្ណោះ ដោយកត់សម្គាល់អំពីការយោងយ៉ាងច្រើននៅក្នុងឯកសារនេះ ទៅលើការងារស្រាវជ្រាវរបស់ Philip SHORT និងអ្នកនិពន្ធផ្សេងទៀ</u>ត។ អង្គជំនុំជម្រះបានយោងទៅលើឯកសារនេះ តែត្រង់ចំណុចដែលឯកសារនេះផ្ដល់ព័ត៌មានអំពីប្រវត្តិសាស្ត្រដែលមិនធ្លាប់ត្រូវបានទទួលស្គាល់ពីមុន និងជាព័ត៌មានប្រវត្តិសាស្ត្រពិសេសរបស់ជនជាប់ចោទ ឬជាព័ត៌មានដែលគាំទ្រដល់ព័ត៌មានដែលអាចជឿជាក់បានដទៃទៀត ដែលមាននៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ"[3565]។

[3564] សៀវភៅរបស់លោក ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ **E3/16**។

[3565] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៨៣៨. គេត្រូវកត់សម្គាល់ថា អង្គជំនុំជម្រះពុំបានអនុវត្តតាមវិធានដែលខ្លួនបានកំណត់ និងបានប្រើប្រាស់តែសៀវភៅរបស់ ខៀវ សំផន ដើម្បីសន្និដ្ឋានថាគាត់បានដឹងឮអំពីការប្រព្រឹត្តិរើសអើងចំពោះប្រជាជនថ្មីនៅសម័យអង្គហេតុ។ សេចក្តីសន្និដ្ឋាននេះ ដែលត្រូវបានធ្វើដោយរំលោភលើបទដ្ឋានវាយតម្លៃភ័ស្តុតាង ត្រូវទុកជាមោឃៈ។

## ១.៤. គ្មានភ័ស្តុតាងពីការដឹងឮអំពីឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋានការងារ នៅសម័យអង្គហេតុ

១៨៣៩. សេចក្តីសន្និដ្ឋានដែលថា ខៀវ សំផន បានដឹងពីល័ក្ខខ័ណ្ឌការងារលំបាកវេទនានៅតាមសហករណ៍ និងការដ្ឋានការងារ ក្នុងអំឡុងពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងដោយរំលោភលើវិធានគ្រប់គ្រងច្បាប់ភ័ស្តុតាង[3566]។ គ្មានភ័ស្តុតាងមានតម្លៃណាមួយ បានជួយបញ្ជាក់អះអាងការលើកឡើងនេះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមិនបានពិចារណាលើភ័ស្តុតាងដោះបន្ទុក។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ គឺបង្ហាញឱ្យឃើញជាពិសេសពីរបៀបដែលខ្លួនមិនបានបំពេញកាតព្វកិច្ចក្នុងការផ្តល់សំអាងហេតុដល់សេចក្តីសម្រេចរបស់ខ្លួន។ អង្គជំនុំជម្រះពុំបានយោងទៅទីតាំងណាមួយក្នុងចំណោមទីតាំងពាក់ព័ន្ធនានាក្នុងសំណុំរឿង ០០២/០២ ហើយបានសន្និដ្ឋានអំពីការដឹងឮ និងការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខ តែតាមរយៈពាក្យពេចន៍ទូទៅបំផុត។

១៨៤០. អង្គជំនុំជម្រះមិនដែលបានយកចិត្តទុកដាក់ផ្តល់សំអាងហេតុដល់សេចក្តីសន្និដ្ឋានរបស់ខ្លួន សម្រាប់មួយទីតាំងម្តងៗ ដូចអ្វីដែលគួរធ្វើ នោះឡើយ។ អវត្តមាននៃចំណងទាក់ទងរវាង ខៀវ សំផន និងទីតាំងនានាដែលជាកម្មវត្ថុនៃការចោទប្រកាន់ គឺបង្ហាញឱ្យឃើញអំពីវិធីសាស្ត្របែបអនុមានដែលប្រើប្រាស់ដោយអង្គជំនុំជម្រះ។ គ្មានភ័ស្តុតាងបង្ហាញឱ្យឃើញពីចំណងទាក់ទងរវាងម្ចាស់បណ្តឹងសាទុក្ខ ជាមួយនឹងទីតាំងឧក្រិដ្ឋកម្មនានាឡើយ ទាំងនៅក្នុងសេចក្តីសន្និដ្ឋាន អំពីការទទួលខុសត្រូវរបស់គាត់នៅក្នុងសំអាងហេតុសាលក្រម ទាំងនៅក្នុងសេចក្តីសន្និដ្ឋានអំពីការកំណត់ប្រភេទបទល្មើសសម្រាប់ឧក្រិដ្ឋកម្មនីមួយៗ។ គេរកមិនឃើញចំណងនេះនៅកន្លែងណាមួយឡើយ។ អវត្តមាននៃចំណងនេះគួរនាំអង្គជំនុំ

[3566] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៦។

ជម្រះឱ្យកត់សម្គាល់ថា ពុំមានភ័ស្តុតាងដែលអាចបង្ហាញឱ្យឃើញហួសពីវិមតិសង្ស័យបានថា នៅសម័យអង្គហេតុ ខៀវ សំផន បានដឹងឮអំពីឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តនៅតាមការដ្ឋានការងារ និងសហករណ៍ ដែលគាត់ត្រូវបានចោទប្រកាន់ នោះទេ។ សេចក្តីសន្និដ្ឋានទាំងអស់ដែលនិយាយផ្ទុយពីនេះ ត្រូវទុកជាមោឃៈ[3567]។

## ២. សហករណ៍ត្រាំកក់

១៨៤១. នៅសហករណ៍ត្រាំកក់ អង្គជំនុំជម្រះបានសន្និដ្ឋានថា មានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពូជសាសន៍ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ[3568]។ តាំងពីដើមរហូតដល់ចប់នៃសំអាងហេតុសាលក្រម ទាក់ទងនឹងការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខអំពីឧក្រិដ្ឋកម្មដែលកំពុងប្រព្រឹត្តធ្វើនៅតាមសហករណ៍ និងការដ្ឋានការងារ អង្គជំនុំជម្រះពុំបាននិយាយយោងទៅទីតាំងសហករណ៍ត្រាំកក់នោះទេ។ គេពុំបានរកឃើញភ័ស្តុតាងណាមួយពាក់ព័ន្ធនឹងទីតាំងនេះឡើយ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញពីចេតនាណាមួយក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មបានឡើយ[3569]។

## ៣. ទំនប់ត្រពាំងថ្ម

### ៣.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង

១៨៤២. អង្គជំនុំជម្រះបានភាន់ច្រឡំរវាងការដឹងឮអំពីអត្ថិភាពនៃទីតាំង និងការដឹងឮអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីតាំងនោះ។ អង្គជំនុំជម្រះបានផ្តល់ភ័ស្តុតាងបញ្ជាក់ថា ខៀវ សំផន បានដឹងអំពីអត្ថិភាពនៃ

---

[3567] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១០-៤២១៨។

[3568] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៤៥, ១១៥៥, ១១៥៩, ១១៧៩, ១១៨៧, ១១៩២, ១១៩៩, ១២០៤។

[3569] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៣-៤២៨៧។

ទីតាំងទំនប់ត្រពាំងថ្ម ដោយគ្មានអ្វីភ្ជាប់រូបគាត់ទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនោះឡើយ។ គ្មានអ្វីបង្ហាញឱ្យឃើញពីការដឹងណាមួយអំពីឧក្រិដ្ឋកម្មនៅសម័យកាលអង្គហេតុនោះទេ[3570]។ អង្គជំនុំជម្រះបានត្រឹមធ្វើសេចក្ដីសន្និដ្ឋានជាទូទៅមួយ ដើម្បីបង្ហាញឱ្យឃើញពីការដឹងឮរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទីតាំងទំនប់ត្រពាំងថ្ម ដោយ "អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងពេលអនុវត្តគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ"[3571]។ សេចក្ដីសន្និដ្ឋានមិនច្បាស់លាស់នេះបង្ហាញពីការវិនិច្ឆ័យបែបអនុមានដោយអង្គជំនុំជម្រះ ដោយសារតែពុំមានភ័ស្តុតាងទាក់ទងនឹងការដឹងរបស់ម្ចាស់បណ្ដឹងសាទុក្ខ អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីតាំងទំនប់ត្រពាំងថ្ម នៅសម័យកាលអង្គហេតុ។ សេចក្ដីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ ហើយការផ្ដន្ទាទោស ខៀវ សំផន ក្នុងន័យនេះ ត្រូវទុកជាមោឃៈដូចគ្នា[3572]។

## ៣.២. កំហុសរបស់អង្គជំនុំជម្រះក្នុងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន

១៨៤៣. ក្នុងពេលជំនុំជម្រះសំណុំរឿង ០០២/០១ ខៀវ សំផន បានប្រកាសថាបានទៅទស្សនកិច្ចនៅទីតាំងទំនប់ត្រពាំងថ្ម៖ "ខ្ញុំបានឃើញទំនប់ទាំងអស់នោះ ខ្ញុំរីករាយរំភើបចិត្តមែនទែនពេលនោះ។ ប៉ុន្តែដល់មកស្ដាប់សក្ខីកម្មបងប្អូនដែលបានមកចូលរួម ដែលបានមកធ្វើសក្ខីកម្មជាបន្តបន្ទាប់ ទើបខ្ញុំរន្ធត់ចិត្តខ្លាំងមែនទែន។ ខ្ញុំមិនបានដឹងថា ទំនប់នោះប្រឡាយនោះ វាបានមកដោយការបង់ថ្លៃវាខ្ពស់យ៉ាងនេះទេ"[3573]។ ក្រោយពីបានស្ដាប់ចម្លើយសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើននាក់ លើប្រធានបទនៃទស្សនកិច្ចផ្លូវការនៅកន្លែងនោះរួចមក ដោយក្នុងនោះមានទស្សនកិច្ចរបស់ ខៀវ សំផន ដែរ អង្គជំនុំជម្រះបានគូសបញ្ជាក់ថា៖ "រដ្ឋអំណាចមូលដ្ឋានបានប៉ុនប៉ងលាក់បាំងទិដ្ឋភាពមួយចំនួននៃស្ថានភាពពិតប្រាកដដែលអ្នកធ្វើការបានជួបប្រទះនៅនឹងកន្លែង ដូចដែលបានពន្យល់ដោយសាក្សីជាច្រើននាក់ដែលបានផ្ដល់

---

[3570] សូមមើលខាងក្រោម កថាខណ្ឌ ១៨៤៣-១៨៤៤។

[3571] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៨។

[3572] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១០-៤២១៨។

[3573] ខៀវ សំផន៖ ប្រតិចារឹក ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/198.1** ទំព័រ ១៧, សំអាងហេតុសាលក្រម កថាខណ្ឌ ១២៥៤។

សក្ខីកម្មថា មានតែអ្នកធ្វើការដែលមានសុខភាពល្អប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យឈរនៅជួរជិតនឹងភ្ញៀវ"[3574]។

១៨៤៤. អង្គជំនុំជម្រះពុំបានទាញផលវិបាកពីការទទួលស្គាល់ផ្ទាល់របស់ខ្លួន។ គេគួរសួរថាហេតុអ្វីបានជាអាជ្ញាធរមូលដ្ឋានលាក់បាំងស្ថានភាពអ្នកធ្វើការ ដោយបានសម្រេចបង្ហាញកន្លែងការងារមួយ ជាមួយនឹងកម្មករដែលមានសុខភាពល្អ។ សេចក្តីសន្និដ្ឋានសមហេតុសមផលដែលអង្គជំនុំជម្រះគួរធ្វើនោះគឺថា គេមានចេតនាលាក់បាំងព័ត៌មានមួយចំពោះអ្នកដទៃ គឺដើម្បីតែមិនចង់ឱ្យអ្នកនោះបានដឹងអំពីព័ត៌មាននោះតែប៉ុណ្ណោះ។ ដូច្នេះ ទោះបីជាគេលាក់បាំងចំពោះមេដឹកនាំដែលទៅបំពេញទស្សនកិច្ច និង ខៀវ សំផន នូវស្ថានភាពពិតប្រាកដរបស់អ្នកធ្វើការនៅទំនប់ត្រពាំងថ្មក៏ដោយ ក៏ដើម្បីតែមិនចង់ឱ្យពួកគាត់ដឹងអំពីការពិតនៃល័ក្ខខ័ណ្ឌរស់នៅ និងល័ក្ខខ័ណ្ឌការងារនៅការដ្ឋាន។ ហើយ គ្មានអ្វីនៅក្នុងសំណុំរឿងនិយាយផ្ទុយពីនេះទេ។ ប៉ុន្តែ អង្គជំនុំជម្រះបានធ្វើមិនដឹងមិនឮសោះតែម្តងពីទិដ្ឋភាពមួយនេះ និងដោយផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានផ្ទាល់របស់ខ្លួន អង្គជំនុំជម្រះបានសន្និដ្ឋានអំពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលរបស់ម្ចាស់បណ្តឹងសាទុក្ខ និងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្មនានានៅទីតាំងទំនប់ត្រពាំងថ្មដោយហេតុថា ខៀវ សំផន "បានបដិសេធថាគាត់មិនបានសង្កេតឃើញដោយផ្ទាល់នូវល័ក្ខខ័ណ្ឌនៅតាមទីតាំងទាំងនេះ ឬមិនបានដឹងឮជាក់ស្តែងអំពីល័ក្ខខ័ណ្ឌទាំងនេះ"[3575]។ ដោយធ្វើដូច្នេះ អង្គជំនុំជម្រះបាននិយាយផ្ទុយពីសំអាងហេតុរបស់ខ្លួននៅកថាខណ្ឌ ១២៦០ និងបានបំភ្លេចចោលដោយចេតនានូវភ័ស្តុតាងដោះបន្ទុកសម្រាប់ម្ចាស់បណ្តឹងសាទុក្ខ។ គ្មានភ័ស្តុតាងណាមួយដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង អាចឱ្យសន្និដ្ឋានបានថា ខៀវ សំផន បានដឹងឮអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីតាំងទំនប់ត្រពាំងថ្ម ក្នុងអំឡុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ នោះទេ។ សេចក្តីសន្និដ្ឋានដែលថា គាត់

---

[3574] សំអាងហេតុសាលក្រម កថាខណ្ឌ ១២៦០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ ៤៣០៣៖ "ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ (ញ៉ិប ហាល់) ឯកសារ E1/336.1 ទំព័រ ២២-២៣, ២៤ ប្រតិចារឹក ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ (ឈុំ សេង) ឯកសារ E1/332.1 ទំព័រ ២៨-២៩ (ផ្តល់សក្ខីកម្មថា ពេលសម្តេចទំនប់ តាវ៉ាល់ បញ្ជា "ឱ្យយកតែអ្នកធាត់ៗ" យកទៅឈរដើម្បីទទួលភ្ញៀវចិន)"។

[3575] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៣។

បានដឹងឮអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃគោលនយោបាយនៃការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ ដែលរួមបញ្ចូលទាំងទីតាំងទំនប់ត្រពាំងថ្ម ត្រូវទុកជាមោឃៈ[3576]។

## ៤. ទំនប់១មករា

១៨៤៥. នៅទំនប់១មករា អង្គជំនុំជម្រះបានសន្និដ្ឋានថា មានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា ពូជសាសន៍ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរជាមនុស្ស និងក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ[3577]។ តាំងពីដើមរហូតដល់ចប់នៃសំអាងហេតុសាលក្រមរងការជំទាស់ ទាក់ទងនឹងការដឹងឮរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅតាមសហករណ៍ និងការដ្ឋានការងារ អង្គជំនុំជម្រះពុំបាននិយាយយោងម្ដងសោះទៅទីតាំងទំនប់១មករា។ ពុំមានភ័ស្ដុតាងណាមួយត្រូវបានបង្ហាញទាក់ទងនឹងទីតាំងនេះទេ។ អង្គជំនុំជម្រះពុំបានបង្ហាញទាល់តែសោះអំពីការដឹងឮរបស់ ខៀវ សំផន អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទំនប់១មករា។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញពីចេតនាណាមួយក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មខាងលើបានទេ[3578]។

## ៥. ព្រលានយន្តហោះកំពង់ឆ្នាំង

១៨៤៦. អង្គជំនុំជម្រះថ្លែងថា "អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន បានដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងពេលអនុវត្តគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ"[3579]។ តាំងពីដើមរហូតដល់ចប់នៃសំអាងហេតុសាលក្រមរងការជំទាស់ ទាក់ទងនឹងការដឹងឮរបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅតាមសហករណ៍ និងការដ្ឋានការងារ អង្គជំនុំជម្រះពុំបាននិយាយយោងម្ដងសោះទៅទីតាំងព្រលានយន្តហោះកំពង់ឆ្នាំង។ ពុំមានភ័ស្ដុតាងណាមួយលើកឡើងពី

[3576] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៨។

[3577] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៦៦, ១៦៧៣, ១៦៨៤, ១៦៩២, ១៦៩៧, ១៧០៧, ១៧១២។

[3578] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៣-៤២៨៧។

[3579] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៨។

ទីតាំងនេះទេ។ ភាពស្ងាត់ស្ងៀមរបស់អង្គជំនុំជម្រះ គឺជាការទទួលស្គាល់ជាក់ស្តែងថា ខ្លួនមិនមានភស្តុតាងណាមួយដើម្បីសន្និដ្ឋានបានពីការដឹងឮរបស់ ខៀវ សំផន ទាក់ទងនឹងព្រលានយន្តហោះកំពង់ឆ្នាំងនោះទេ។

១៨៤៧. អង្គជំនុំជម្រះបានត្រឹមបង្ហាញឱ្យឃើញពីការដឹងឮនេះ តាមរយៈសេចក្តីសន្និដ្ឋានទូទៅមួយចំនួនដែលត្រូវបានប្រកាន់យក ជាមួយនឹងវិធីសាស្ត្របែបអនុមាន និងការអានដោយពុំត្រឹមត្រូវនូវភស្តុតាងក្រៅវិសាលភាព[3580]។ អង្គជំនុំជម្រះកាន់តែមិនអាចបង្ហាញឱ្យឃើញពីការដឹងឮអំពីលក្ខខ័ណ្ឌជាក់លាក់នានានៃដំណើរការរបស់ព្រលានយន្តហោះកំពង់ឆ្នាំង ដោយសារតែលក្ខណៈពិសេសនៃទីតាំងមួយនេះ។ ដូចដែលអង្គជំនុំជម្រះខ្លួនឯងបានធ្លាប់កត់សម្គាល់រួចហើយ ទីតាំងព្រលានយន្តហោះកំពង់ឆ្នាំង ដំបូងផុត គឺជាទីតាំងយោធា៖ "ព្រលានយន្តហោះយោធានោះ ត្រូវបានសាងសង់ដោយមានការសហការយ៉ាងជិតស្និទ្ធិជាមួយរដ្ឋាភិបាលចិន ដែលនេះជាផ្នែកសំខាន់មួយនៃយុទ្ធសាស្ត្ររបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ"[3581]។ ដោយសារតែហេតុនេះហើយបានជារចនាសម្ព័ន្ធឋានានុក្រមនៃព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវដឹកនាំដោយកម្មាភិបាលយោធានៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលអង្គជំនុំជម្រះបានគូសបញ្ជាក់ផងដែរថា៖ "កងពល ៥០២ នៃកងទ័ពអាកាសរបស់កងទ័ពបដិវត្តន៍កម្ពុជា មានភារកិច្ចការពារដែនអាកាសរបស់កម្ពុជា។ ក្រៅពីភារកិច្ចដទៃទៀត ដូចជាការយាមកាមព្រលានយន្តហោះពោធិ៍ចិនតុង កងពល ៥០២ បានដឹកនាំការសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំងនេះ"[3582]។

១៨៤៨. ដូច្នេះ វាបង្ហាញឱ្យឃើញថា ទីតាំងនេះត្រូវគ្រប់គ្រងដោយអង្គភាពយោធា ដែលមិនត្រូវអ្វីបន្តិចសោះទៅនឹងការទទួលខុសត្រូវរបស់ ខៀវ សំផន នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ មានការនិយាយជាច្រើនលើកច្រើនសា ក្នុងសំអាងហេតុសាលក្រមថាម្ចាស់បណ្តឹងសាទុក្ខគ្មានអំណាចទាក់ទងនឹងបញ្ហាយោធា និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនៅក្នុងរចនាសម្ព័ន្ធបញ្ជានោះទេ[3583]។ អង្គជំនុំជម្រះបានប្រើប្រាស់កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដែលមិនអាចបង្ហាញឱ្យឃើញពីការដឹងឮអំពី

---

[3580] សូមមើលខាងលើ "កំហុសរួមចំពោះទីតាំងទាំងអស់" កថាខណ្ឌ ១៨១៦-១៨៤០។

[3581] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧២៣។

[3582] សំអាងហេតុសាលក្រម កថាខណ្ឌ ១៧២៥។

[3583] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣២០-៤៣២៥។

ឧក្រិដ្ឋកម្មបាននោះទេ[3584]។ ហេតុដូច្នេះ ពុំមានចំណងទាក់ទងណាមួយរវាងទីតាំងព្រលានយន្តហោះកំពង់ឆ្នាំង ជាមួយនឹង ខៀវ សំផន នោះទេ។ គ្មានភស្តុតាងណាមួយ បានភ្ជាប់ម្ចាស់បណ្តឹងសាទុក្ខទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង ក្នុងអំឡុងពេលពេញមួយសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឱ្យគេមិនអាចសន្និដ្ឋានថាគាត់បានដឹងឮអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទីតាំងមួយនេះទេ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានទូទៅរបស់អង្គជំនុំជម្រះថា ខៀវ សំផន "បានដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលអនុវត្តគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ" ដែលមានព្រលានយន្តហោះកំពង់ឆ្នាំងនៅក្នុងនោះដែរ ត្រូវទុកជាមោឃៈ[3585]។

## ផ្នែកទី ២. មន្ទីរសន្តិសុខនានា

១៨៥៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយយល់ថា ខៀវ សំផន បានដឹងពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ក្នុងពេលបោសសម្អាតផ្ទៃក្នុង នៅក្នុងអំឡុងពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[3586]។ ជាបឋម គេគួរគូសបញ្ជាក់ថា ការបោសសម្អាតពុំមែនជាបទល្មើសដាក់លាក់ និងពុំមែនជា "ទីតាំងឧក្រិដ្ឋកម្ម" ទេ។ គឺឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ទៅវិញទេ ដែលអង្គជំនុំជម្រះមានភារកិច្ចកាត់សេចក្តី។ ប្រសិនបើឧក្រិដ្ឋកម្មមួយចំនួនត្រូវបានប្រព្រឹត្តដោយសារការបោសសម្អាតសម្រាប់មន្ទីរសន្តិសុខ នោះគឺវាពាក់ព័ន្ធតែមួយផ្នែកប៉ុណ្ណោះនៃឧក្រិដ្ឋកម្មដែលត្រូវបានរកឃើញនៅតាមមន្ទីរសន្តិសុខ។ ដូច្នេះ អង្គជំនុំជម្រះគួរណាបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន ថាឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខនីមួយៗ ក្នុងចំណោមមន្ទីរសន្តិសុខទាំងបួនដែលជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ តែវាជាអ្វីដែលអង្គជំនុំជម្រះពុំបានធ្វើ (១)។ម្យ៉ាងវិញទៀត សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការបោសសម្អាត ក៏ពុំត្រឹមត្រូវដូចគ្នា (២)។

---

[3584] សូមមើលខាងលើ កថាខណ្ឌ ១៧៤១-១៧៤២។

[3585] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២១៨។

[3586] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៥។

## ១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង

១៨៥០. ដោយបានសន្និដ្ឋានពីការដឹងឮរបស់ ខៀវ សំផន អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការបោសសម្អាតផ្ទៃក្នុង[3587] អង្គជំនុំជម្រះបានសម្រេចដោយពុំត្រឹមត្រូវ ដោយមិនបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន ពេលអង្គហេតុកើតឡើងនៅមន្ទីរ ស-២១ (១.១) ក្រាំងតាចាន់ (១.២) អូរកន្សែង (១.៣) និងភ្នំក្រោល (១.៤)។

## ១.១. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១

១៨៥១. នៅមន្ទីរ ស-២១ អង្គជំនុំជម្រះបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស[3588]។ អង្គជំនុំជម្រះបានសន្និដ្ឋានផងដែរថាមានការបង្ហាញឱ្យឃើញពីការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ដូចជាការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តិអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ឬធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បូរណភាពរាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក និងជនស៊ីវិល នូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងត្រឹមត្រូវ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[3589]។

---

[3587] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៥។

[3588] សំអាងហេតុសាលក្រម កថាខណ្ឌ ២៥៦០-២៦១៨។

[3589] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦១៩-២៦៣៣។ ការដឹងរបស់លោក ខៀវ សំផន អំពីអង្គហេតុ ដែលជាការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធនឹងឈ្លើយសឹក និងជនស៊ីវិលវៀតណាម ត្រូវបានជំទាស់តវ៉ាខាងក្រោម នៅកថាខណ្ឌ ១៨៨៨-១៨៨៩។

១៨៥២. អង្គជំនុំជម្រះមិនដែលធ្លាប់បានលើកបង្ហាញពីការដឹងឮរបស់ ខៀវ សំផន ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចបង្ហាញខាងលើ កំពុងត្រូវបានប្រព្រឹត្តនោះទេ។ ហេតុដូច្នេះ ទោះបីជាការដឹងឮអំពីឧក្រិដ្ឋកម្មពុំមែនជាធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមក៏ដោយ ក៏អង្គជំនុំជម្រះបានប្រើប្រាស់វាមួយផ្នែកធំដើម្បីសន្និដ្ឋានពីចេតនា។ ដូច្នេះ ពាក់ព័ន្ធនឹងមន្ទីរ ស-២១ ដោយគ្មានការដឹងឮរបស់ ខៀវ សំផន ថាឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្ត វាមានការលំបាកក្នុងការបង្ហាញឱ្យឃើញពីចេតនាដោយផ្ទាល់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ[3590]។

១៨៥៣. ផ្ទុយទៅវិញ ពាក់ព័ន្ធនឹងការជួយ និងការជំរុញ ការដឹងឮអំពីធាតុផ្សំចម្បងៗនៃឧក្រិដ្ឋកម្ម គឺជាធាតុផ្សំដែលត្រូវបង្ហាញឱ្យឃើញ[3591]។ នៅ ស-២១ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការធ្វើមនុស្សឃាតដោយចេតនាដោយប្រយោល ត្រូវបានប្រព្រឹត្ត ដោយសារតែលក្ខខ័ណ្ឌនៃការឃុំឃាំង ការបូមឈាម ការធ្វើពិសោធន៍វេជ្ជសាស្ត្រ[3592]។ ដោយសារគ្មានការដឹងឮអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅ ស-២១ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា "ខៀវ សំផន បានដឹងឮគ្រប់ពេលពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយចារីផ្ទាល់" ត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវរួចផុតពីការចោទប្រកាន់ថាបានជួយ និងជំរុញឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតដោយចេតនាដោយប្រយោលនៅមន្ទីរ ស-២១[3593]។

## ១.២. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខក្រាំងតាចាន់

១៨៥៤. នៅក្រាំងតាចាន់ អង្គជំនុំជម្រះបានសន្និដ្ឋានថា មានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់

[3590] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៣-៤២៨៧។

[3591] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១២។

[3592] សំអាងហេតុសាលក្រម កថាខណ្ឌ ២៥៦៤-២៥៦៥ និងកថាខណ្ឌ ២៥៦៧-២៥៦៨។

[3593] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៧-៤៣១៨។

ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស និងការបាត់ខ្លួនដោយបង្ខំ[3594]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនដែលធ្លាប់បានបង្ហាញថា ខៀវ សំផន បានដឹងឮ ពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះនៅក្រាំងតាចាន់នោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញពីចេតនាដោយផ្ទាល់ណាមួយ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបង្ហាញពីខាងលើបានឡើយ[3595]។

## ១.៣. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខអូរកន្សែង

១៨៥៥. នៅអូរកន្សែង អង្គជំនុំជម្រះបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស[3596]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនដែលធ្លាប់បានបង្ហាញថា ខៀវ សំផន បានដឹងពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះនៅអូរកន្សែងនោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញពីចេតនាដោយផ្ទាល់ណាមួយ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មខាងលើបានទេ[3597]។

## ១.៤. គ្មានការដឹងឮពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខភ្នំក្រោល

១៨៥៦. នៅភ្នំក្រោល អង្គជំនុំជម្រះបានសន្និដ្ឋានថាមានការបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ[3598]។

[3594] សំអាងហេតុសាលក្រម កថាខណ្ឌ ២៨១៧, ២៨២៧, ២៨៣២, ២៨៤៣, ២៨៤៧, ២៨៥១, ២៨៥៨។

[3595] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៣-៤២៨៧។

[3596] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៥៩-៣០១០។

[3597] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៣-៤២៨៧។

[3598] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៧, ៣១២៦, ៣១៣១, ៣១៥១, ៣១៥៩ និង ៣១៦៦។

ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនដែលធ្លាប់បានបង្ហាញថា ខៀវ សំផន បានដឹងពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ នៅភ្នំក្រោលនោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចបង្ហាញឱ្យឃើញពីចេតនាដោយផ្ទាល់ណាមួយ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មខាងលើបានទេ[3599]។

## ២. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងអំឡុងពេលនៃការបោសសម្អាត

១៨៥៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាច្រើន ដោយសន្និដ្ឋានថា ខៀវ សំផន បានដឹងឮថាឧក្រិដ្ឋកម្មមួយចំនួនត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលនៃការបោសសម្អាត ធ្វើឡើងក្នុងរយៈពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះមិនគួរណាសំអាងលើចម្លើយក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្ហាញឱ្យឃើញពីការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខ នៅពេលអង្គហេតុកើតឡើងនោះទេ (២.១)។ អង្គជំនុំជម្រះមានកំហុសផងដែរ ដោយយល់ថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួន និងការស្លាប់របស់កម្មាភិបាលជាន់ខ្ពស់ ម្យ៉ាង (២.២) និងម្យ៉ាងទៀត ពីការស្លាប់របស់កម្មាភិបាលថ្នាក់ក្រោម និងប្រជាជនស៊ីវិល (២.៣)។

## ២.១. កំហុសដោយបានសំអាងលើចម្លើយក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្ហាញឱ្យឃើញពីការដឹងឮ

១៨៥៨. ដើម្បីសន្និដ្ឋានបានថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួន និងការស្លាប់របស់អតីតកម្មាភិបាលជាន់ខ្ពស់មួយចំនួន "ក្នុងពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ"[3600] អង្គជំនុំជម្រះបានផ្អែកតែទៅលើកិច្ចសម្ភាសន៍ និងការបោះពុម្ពផ្សាយមួយចំនួនរបស់ ខៀវ សំផន ធ្វើឡើងក្រោយរបបនេះ។ វិធីសាស្ត្របែបនេះ គឺចោទជាបញ្ហា ដើម្បីបង្ហាញឱ្យឃើញពីការដឹងឮក្នុងអំឡុងពេលនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3601]។ អង្គជំនុំជម្រះយល់ឃើញជាអាទិ៍ថា ចម្លើយនានារបស់ ខៀវ សំផន ដែលពន្យល់ថាគាត់មិនបានដឹងថា

---

[3599] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៣-៤២៨៧។

[3600] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៤។

[3601] សំអាងហេតុសាលក្រម ផ្នែក ១៨.១.២។

មានការចាប់ខ្លួននៅក្នុងរបបនោះ គឺមិនអាចជឿជាក់បានទេ ដោយសារថាគាត់បានទទួលស្គាល់ថាបានឃើញការចាប់ខ្លួន[3602]។ ក៏ប៉ុន្តែ វាជាការបំភ្លៃសម្ដីរបស់ ខៀវ សំផន ដែលត្រូវបានយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ ព្រោះគាត់បាននិយាយថា៖

> "ខ្ញុំបានឃើញសមាជិកមួយចំនួនរបស់គណៈកម្មាធិការមជ្ឈិម បាត់ខ្លួនម្ដងមួយៗ។ ខ្ញុំមិនអាចផ្ដល់ជូនលោកចៅក្រមអំពីឈ្មោះពួកគេបានទេ ពីព្រោះខ្ញុំមិនជិតស្និទ្ធនឹងពួកគេនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនដឹងទាល់តែសោះអំពីទំហំនៃហេតុការណ៍នោះ"[3603]។

១៨៥៩. ដូច្នេះ ម្ចាស់បណ្ដឹងសាទុក្ខមិនធ្លាប់និយាយថាបានឃើញការចាប់ខ្លួននោះទេ។ វាមានភាពខុសគ្នាយ៉ាងច្បាស់រវាងការលែងបានឃើញបុគ្គលមួយចំនួន និងការបានឃើញការចាប់ខ្លួនពួកគេ ជាពិសេសក្នុងសម័យដែលគោលការណ៍រក្សាការសម្ងាត់ ស្ថិតជាចំណុចស្នូលនៃដំណើរការរបស់ប.ក.ក។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសំអាងលើចម្លើយរបស់គាត់ ដើម្បីសន្និដ្ឋានថាគាត់បានដឹងឮអំពីការចាប់ខ្លួន នៅពេលអង្គហេតុកើតឡើងបាននោះទេ។

១៨៦០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសផងដែរ ដោយបានប្រើប្រាស់កិច្ចសម្ភាសន៍មួយរបស់ ខៀវ សំផន ជាមួយ Stephen HEDER នៅឆ្នាំ១៩៨០ ដើម្បីបង្ហាញឱ្យឃើញពីការដឹងឮរបស់គាត់អំពីការចាប់ខ្លួន និងការស្លាប់អតីតកម្មាភិបាលជាន់ខ្ពស់ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[3604]។ កិច្ចសម្ភាសន៍នេះទទួលបានក្រៅក្របខ័ណ្ឌតុលាការ គឺមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ខ្លឹមសារនៃកិច្ចសម្ភាសន៍នេះបង្ហាញភាគច្រើនពីការវិភាគនយោបាយក្រោយរបបខ្មែរក្រហម លើបញ្ហាកម្មាភិបាលដែលត្រូវបានចោទថាក្បត់ ដែលខ្លឹមសារនេះមិនអាចឱ្យគេអះអាងបានថា ខៀវ សំផន បានដឹងអំពីការចាប់ខ្លួនពួកគេនៅសម័យនោះបានទេ។ អង្គជំនុំជម្រះបានអះអាងដោយពុំត្រឹមត្រូវផងដែរថា ខៀវ សំផន បានទទួលស្គាល់នៅក្នុងកិច្ចសម្ភាសន៍ដដែលនេះថា "គណៈកម្មាធិការមជ្ឈិមបក្ស "មិនដល់ពាក់កណ្ដាល" ត្រូវ

---

[3602] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២០។

[3603] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២០ កំណត់សម្គាល់ជើងទំព័រលេខ ១៣៧៦៩ យោងដល់កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/210** ERN 00156690 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3604] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២១។

បានកម្ចាត់ចោលនៅក្នុងការបោសសម្អាត រួមជាមួយនឹង “ជិតពាក់កណ្តាលក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍””[3605]។ ជាថ្មីម្តងទៀត វាជាការបំភ្លៃសម្តីរបស់ ខៀវ សំផន។ គាត់បានពន្យល់ថាតួលេខទាំងនេះ ត្រូវគ្នាទៅនឹង “ភ្នាក់ងារវៀតណាម” ដែលបង្កប់នៅក្នុងជួរគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍។ គាត់ពុំបាននិយាយថាតួលេខនេះ ត្រូវគ្នានឹងចំនួននៃការបោសសម្អាតនោះទេ។ លើសពីនេះទៀត កិច្ចសម្ភាសន៍នេះ គឺធ្វើឡើងក្រោយរបបខ្មែរក្រហម និងមិនអាចគាំទ្រថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ នៅពេលអង្គហេតុកើតឡើងបាននោះទេ។

១៨៦១. ជាលក្ខណៈទូទៅ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដោយបានផ្អែកលើការបោះពុម្ពផ្សាយ និងកិច្ចសម្ភាសន៍មួយចំនួនជាមួយ ខៀវ សំផន ដែលធ្វើឡើងក្រោយអង្គហេតុ និងពេលខ្លះ គ្មានកាលបរិច្ឆេទ ដើម្បីអះអាងថា គាត់បានដឹងឮអំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ នៅពេលអង្គហេតុកើតឡើង[3606]។ ខៀវ សំផន ពុំធ្លាប់ពន្យល់ថា គាត់បានដឹងឮអំពីការចាប់ខ្លួនទាំងនេះទេ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ក្នុងកិច្ចសម្ភាសន៍ទាំងអស់នេះដែលជាការវិភាគក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្ទុយទៅវិញ គាត់បានអះអាងថា គាត់ទើបបានដឹងអំពីការចាប់ខ្លួនទាំងនេះក្រោយឆ្នាំ១៩៧៩ មកហើយទេ[3607]។ ហេតុដូច្នេះ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋានបានថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួន និងការស្លាប់របស់កម្មាភិបាលជាន់ខ្ពស់ នៅពេលព្រឹត្តិការណ៍ទាំងនេះបានកើតឡើង។ អង្គជំនុំជម្រះគួរតែទាញផលវិបាកចេញពីការគ្មានភ័ស្តុតាងគាំទ្រលើការដឹងឮនាពេលបច្ចុប្បន្ននេះ អំពីអង្គហេតុ។ សេចក្តីសន្និដ្ឋានទាំងឡាយរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

## ២.២. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការបោសសម្អាតកម្មាភិបាលជាន់ខ្ពស់មួយចំនួននៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា

### ២.២.១. ភឿន

[3605] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២២។

[3606] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២១-៤២២៣។

[3607] កំណត់ហេតុសួរ ចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/210** ERN 00156690-00156691។

១៨៦២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន ដឹងថា ឌឿន ត្រូវបានបោសសម្អាត[3608]។ អង្គជំនុំជម្រះយល់ថា ការពន្យល់របស់ ខៀវ សំផន ដែលថាគាត់បានដឹងអំពីការចាប់ខ្លួនឌឿន ក្រោយពីរបបខ្មែរក្រហមដួលរលំ គឺមិនអាចជឿបានទេ ដោយអង្គជំនុំជម្រះបានផ្អែកតែទៅលើភ័ស្តុតាង កាលៈទេសៈមួយចំនួន។ ក៏ប៉ុន្តែ ដោយគ្មានភ័ស្តុតាងអំពីកិច្ចប្រជុំជាក់លាក់ ដែលនៅពេលនោះការចាប់ខ្លួនឌឿន ត្រូវបានលើកមកពិភាក្សា ដោយមានវត្តមានរបស់ ខៀវ សំផន អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានចេញពីវត្តមានរបស់គាត់ ក្នុងកិច្ចប្រជុំមួយចំនួនដែលគាត់មិនបានដឹងឮនោះបានទេ។ ពាក់ព័ន្ធនឹង "ទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយ ប៉ុល ពត និង នួន ជា" គឺត្រូវប្រើទឡ្ហីករណ៍ដដែលដូចគ្នា។ ម្យ៉ាងវិញទៀត សេចក្តីកត់សម្គាល់លើអង្គហេតុទាំងនេះ ត្រូវបានតវ៉ាពីខាងលើរួចមកហើយ[3609]។

១៨៦៣. ការកត់សម្គាល់ដែលថា ខៀវ សំផន "នៅតែជាសមាជិកម្នាក់ក្នុងចំណោមសមាជិកមួយចំនួនតូចនៃមន្ទីរ ៨៧០ បន្ទាប់ពី ឌឿន បានបាត់ខ្លួន" ក៏មិនអាចឱ្យគេបង្ហាញឱ្យឃើញថាគាត់បានដឹងពីការចាប់ខ្លួនឌឿន នោះដែរ។ គោលការណ៍រក្សាការសម្ងាត់ មានវត្តមាននៅគ្រប់ទីកន្លែងនៅក្នុងប.ក.ក។ ដោយគ្មានភ័ស្តុតាងផ្ទាល់ពីការដឹងឮអំពីការចាប់ខ្លួននេះ ការពន្យល់របស់ ខៀវ សំផន ដែលថាគាត់មិនបារម្ភចំពោះអវត្តមានរបស់ឌឿន ដោយសារតែឌឿនអវត្តមានញឹកញាប់ គឺជាការពន្យល់សមហេតុសមផលមួយផ្សេងទៀតដែលអាចមាន។ ដូចដែលបានឃើញរួចមកហើយ គ្មានអ្វីអាចឱ្យគេសន្និដ្ឋានបានថាគាត់ទទួលបន្ទុកតួនាទីត្រួតពិនិត្យនៅក្នុងគណៈកម្មាធិការពាណិជ្ជកម្ម នៅពេលមានការបោសសម្អាតករដ្ឋាភិបាលក្រសួង[3610]។ បើទោះជាមានករណីដូច្នេះមែនក៏ដោយ ក៏វានៅតែមិនបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន អំពីការចាប់ខ្លួនឌឿន ដោយសារពុំមានភ័ស្តុតាងច្បាស់លាស់លើចំណុចនេះ។ វិធីសាស្ត្រស្មានៗរបស់អង្គជំនុំជម្រះ គួរត្រូវទទួលរងពិន័យ ហើយសេចក្តីសន្និដ្ឋានទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីការចាប់ខ្លួនឌឿន ត្រូវទុកជាមោឃៈ។

---

[3608] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៥។

[3609] សូមមើលខាងលើ កថាខណ្ឌ ១៦៨៤-១៦៨៦។

[3610] សូមមើលខាងលើ កថាខណ្ឌ ១៧៧០-១៧៩៨។

### ២.២.២. ចាន់ ចក្រី, ឈូក, កុយ ធួន និង កែវ មាស

១៨៦៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីជោគវាសនារបស់ ចាន់ ចក្រី, ឈូក, កែវ មាស និង កុយ ធួន[3611]។ អង្គជំនុំជម្រះមិនគួរណាសំអាងលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន ដើម្បីអះអាងថា ក្នុងវគ្គអប់រំនយោបាយមួយនៅបុរីកីឡា ម្ចាស់បណ្ដឹងសាទុក្ខបានលើកឡើងវិញពីការចោទប្រកាន់របស់ នួន ជា ចំពោះ ចាន់ ចក្រី, កុយ ធួន និង កែវ មាស។ ភាពផ្ទុយគ្នារបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ក្នុងពេលផ្ដល់សក្ខីកម្ម គួរណានាំអង្គជំនុំជម្រះឱ្យកត់សម្គាល់ពីកង្វះនៃភាពជឿជាក់បានរបស់គាត់[3612]។ កិច្ចសម្ភាសន៍នានាផ្ដល់ដោយ ខៀវ សំផន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលមួយចំនួនគ្មានកាលបរិច្ឆេទ និងបង្ហាញក្រៅបរិបទ ក៏មានតម្លៃជាភ័ស្តុតាងតិចតួចបំផុតដូចគ្នា។ លើសពីនេះ និងជាពិសេសទៅទៀតនោះ វាជាការពន្យល់អំពីអ្វីដែលគាត់បានយល់ក្រោយពីរបបនេះដួលរលំ[3613]។ ដូច្នេះ កិច្ចសម្ភាសន៍ទាំងនេះក៏មិនអាចឱ្យគេសន្និដ្ឋានបានថា ខៀវ សំផន បានដឹងឮអំពីការបោសសម្អាតទាំងនេះ នៅពេលអង្គហេតុកើតឡើងបាននោះដែរ។

១៨៦៥. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រើប្រាស់ទស្សនាវដ្ដីទង់បដិវត្ត ដែលនៅក្នុងនោះ ចាន់ ចក្រី, ឈូក និង កែវ មាស ត្រូវបាន "ថ្កោលទោសជាចំហ" ដើម្បីសន្និដ្ឋានថាមានការដឹងឮរបស់ ខៀវ សំផន អំពីការចាប់ខ្លួនអ្នកទាំងនោះ ព្រោះថា ខៀវ សំផន "អាចពិនិត្យមើលបាន" នូវទស្សនាវដ្ដីទាំងនេះ[3614]។

---

[3611] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៦។

[3612] សូមមើលខាងលើ កថាខណ្ឌ ១៦៩០-១៨០៣, ជាអាទិ៍ ចម្លើយផ្ទុយគ្នារបស់ អែម អឿន កថាខណ្ឌ ១៧៥៧-១៧៥៨, សូមមើលផងដែរ សារណាបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៣២។

[3613] សូមមើល ឧទាហរណ៍ កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន ដោយមិនស្គាល់អ្នកសម្ភាសន៍ មិនដឹងកាលបរិច្ឆេទ ឯកសារ **E3/4024** "ប៉ុន្តែ ឥឡូវ មានការចាប់ចង ក៏អីចឹងដែរ លោក [ប៉ុល ពត] ប្រមូលដំណឹងច្រើនណាស់ លោកត្រូវការប្រមូលដំណឹងច្រើនណាស់។ លោក ប៉ុល ពត តាមតែខ្ញុំធ្លាប់ស្គាល់គាត់ លោកអនុវត្តគោលការណ៍ហ្នឹងចុះ ជាអ្នកដឹកនាំមួយដែលតាមដាន ហើយពិសេស ជាអ្នកដឹកនាំមួយដែលតាមដានកម្មាភិបាលស្អិតណាស់" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3614] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៦។

សេចក្តីសន្និដ្ឋានដាច់ខាតមួយនេះ គួរត្រូវដកចេញ[3615]។ ពុំមានការបង្ហាញឱ្យឃើញថា ខៀវ សំផន បានទទួល ឬបានអានទស្សនាវដ្តីទាំងនេះទេ។ ជាចុងក្រោយ អង្គជំនុំជម្រះបានផ្អែកលើសៀវភៅរបស់ ខៀវ សំផន ដែលបង្ហាញពីការឃុំឃាំង កុយ ធួន រយៈពេលប្រាំបួនខែ នៅពេលគណៈអចិន្ត្រៃយ៍បញ្ជូនគាត់ទៅមន្ទីរ ស-២១[3616]។ ក៏ប៉ុន្តែ ដូចដែលធ្លាប់បានគូសបញ្ជាក់ជាច្រើនលើកច្រើនសារួចមកហើយថា ម្ចាស់បណ្តឹងសាទុក្ខបានយោងទៅលើស្នាដៃរបស់អ្នកនិពន្ធជាច្រើនរូប ក្នុងនោះមាន Philip SHORT និង Ben KIERNAN ដើម្បីវិភាគលើអ្វីដែលកើតឡើងនៅក្នុងអំឡុងពេលនៃរបបនោះ[3617]។ អង្គជំនុំជម្រះបានបំភ្លេចចោលដោយចេតនានូវអង្គហេតុមួយនេះ ដើម្បីសន្និដ្ឋានថា សៀវភៅរបស់ ខៀវ សំផន អាចបង្ហាញឱ្យឃើញពីការដឹងឮនៅពេលអង្គហេតុកើតឡើង។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

### ២.២.៣. ហ៊ូ នឹម

១៨៦៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន "បានដឹងអំពីការចាប់ខ្លួន និងការស្លាប់របស់ ហ៊ូ នឹម នៅពេលនោះ"[3618]។ ប៉ុន្តែ អង្គជំនុំជម្រះបានទទួលស្គាល់ថា គ្មានហេតុផលណាមួយដែលត្រូវយល់ថាម្ចាស់បណ្តឹងសាទុក្ខពិតជាបានទទួលសំបុត្ររបស់ ហ៊ូ នឹម ដែលត្រូវឃុំខ្លួននៅមន្ទីរ ស-២១ នោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រើប្រាស់ចម្លើយរបស់ម្ចាស់បណ្តឹងសាទុក្ខក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ចុះកាលបរិច្ឆេទឆ្នាំ២០០៧ ប្រាប់ទៅសហចៅក្រមស៊ើបអង្កេត

---

[3615] សូមមើលខាងលើ កថាខណ្ឌ ១៦៤១-១៦៤៣។

[3616] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៦។

[3617] សៀវភៅរបស់លោក ខៀវ សំផន *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* ឯកសារ **E3/16** ERN 00380445 "ខ្ញុំលម្អៀងទៅយល់ស្របតាមអ្នកនិពន្ធ ហ្វីលិព ហ្សត ដែលគាត់សរសេរថា ប៉ុល ពត មិនមែនល្ងង់ខ្លៅរហូតដល់ជឿលើឯកសារដែលបានមកពីការធ្វើទារុណកម្មនោះទេ។ ប៉ុន្តែ លោក ហ្វីលិព ហ្សត ហាក់ដូចជានិយាយហួសបន្តិចហើយ ដែលគាត់ថា តួនាទីនៃ (គុក) ស-២១ និងសេចក្តីសារភាពដែលវាផ្តល់ឱ្យនោះ មិនមែនសម្រាប់ផ្តល់ព័ត៌មានទេ គឺ សម្រាប់តែផ្តល់ភ័ស្តុតាងនៃអំពើក្បត់ ដែលក្រុមដឹកនាំត្រូវការ ដើម្បីចាប់អ្នកដែលគេបានសម្រេចរួចទៅហើយថាត្រូវចាប់នោះ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3618] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៧។

ដែលនៅក្នុងចម្លើយទាំងនោះ ខៀវ សំផន ត្រូវបានសួរនាំ ក្រោយពីគាត់បានស្រាវជ្រាវឯកសារទាក់ទងនឹងអ្វីដែលគាត់មិនបានដឹងទាក់ទងនឹងសម័យកម្ពុជាប្រជាធិបតេយ្យ។ កំណត់ហេតុសួរចម្លើយមួយនេះមិនអាចបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន អំពីការចាប់ខ្លួន ហ៊ូ នឹម នៅពេលអង្គហេតុកើតឡើងនោះទេ។ ម្យ៉ាងទៀត នៅក្នុងចម្លើយនោះ ម្ចាស់បណ្ដឹងសាទុក្ខបានពន្យល់ថា គាត់មិនអាច "បង្ហាញការមិនយល់ស្រប [...] ជាសាធារណៈ" នោះទេ ហើយថា ប៉ុល ពត បានប្រាប់គាត់យ៉ាងច្បាស់ថា គាត់គ្រាន់តែជា "អ្នកបច្ចេកទេស" ប៉ុណ្ណោះ[3619]។ ជាចុងក្រោយ បើយោងតាមសក្ខីកម្មរបស់ ជា ឌៀប ខៀវ សំផន បាន "កោះហៅ" និរសាររបស់ ហ៊ូ នឹម ដើម្បី "សួរចម្លើយពួកគេ"។ ក៏ប៉ុន្តែ ក្រៅពីការរិះគន់ទាក់ទងនឹងកង្វះភាពជឿជាក់បានរបស់គាត់[3620] រឿងរ៉ាវរបស់ ជា ឌៀប គឺបង្ហាញពីវគ្គអប់រំនយោបាយជាមួយសន្និបាត ពុំមែនជាការសួរចម្លើយដឹកនាំដោយ ខៀវ សំផន ដូចដែលអង្គជំនុំជម្រះបានលើកឡើងនោះទេ ដោយបានបញ្ជាក់ថាគ្មានអ្វីត្រូវបាននិយាយទាក់ទងនឹងប្រធានបទទាំងឡាយដែលត្រូវបានលើកមកពិភាក្សានោះឡើយ។ យោងតាមភ័ស្តុតាងទាំងនេះ ចៅក្រមមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួន ហ៊ូ នឹម នៅពេលអង្គហេតុកើតឡើងបានទេ។

## ២.២.៤. ជូ ជេត ហៅ ស៊ី

១៨៦៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន បានដឹងឮអំពីការសម្លាប់ ជូ ជេត[3621]។ អង្គជំនុំជម្រះបានសំអាងជាថ្មីលើកិច្ចសម្ភាសន៍របស់ ខៀវ សំផន ជាមួយ Stephen HEDER ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ដែលនៅក្នុងនោះ មានការនិយាយថាគេត្រូវបែងចែកឱ្យដាច់ពីគ្នារវាងអ្វីដែលគាត់បានដឹងក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងអ្វីដែលគាត់បានដឹងពិតប្រាកដនៅក្នុងសម័យកាលអង្គហេតុ។ ម្យ៉ាងវិញទៀត សក្ខីកម្មទូទៅ មិនច្បាស់លាស់ និងគ្មានអ្វីគាំទ្ររបស់ Philip SHORT ដែលថា "ប៉ុល ពត បានចាត់តាំង ខៀវ សំផន ឱ្យទទួលភារកិច្ចស៊ើប

---

[3619] កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ **E3/37** ERN 00156677-00156678។

[3620] សូមមើលខាងលើ កថាខណ្ឌ ១២៣៣-១២៤២ ("ការផ្ដល់ភាពអាចជឿជាក់បានដោយមិនត្រឹមត្រូវដល់សក្ខីកម្មខុសប្លែកគេរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប")។

[3621] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៨។

អង្កេតលើបញ្ហាពិបាកៗ” ក៏មិនបានបង្ហាញឱ្យឃើញថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួន និងការសម្លាប់ ជូ ជេត នៅពេលអង្គហេតុកើតឡើងនោះដែរ។

១៨៦៨. ជាចុងក្រោយ គឺវាមិនសមហេតុសមផលទេសម្រាប់ចៅក្រមមានវិចារណញ្ញាណគ្រប់រូបដែលសំអាងតែលើភ័ស្តុតាងតាមរយៈការឮតពីគេ ដើម្បីសន្និដ្ឋានថា “ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចពិភាក្សារបស់គណៈកម្មាធិការអចិន្ត្រៃយ៍អំពីជោគវាសនារបស់ ជូ ជេត”[3622]។ ជាពិសេស ផ្នែកនេះនៃសក្ខីកម្មរបស់ ឌុច ដែលថាគាត់បានដឹងពី ប៉ង់ ថា ខៀវ សំផន ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការពិភាក្សាទាក់ទងនឹងជោគវាសនារបស់ ជូ ជេត គឺត្រូវតែដកចេញជាដាច់ខាត ព្រោះបានមកដោយការធ្វើទារុណកម្ម។ ទោះបីជា ឌុច បាននិយាយជាន់កែងខ្លួនឯងនៅក្នុងចម្លើយផ្សេងៗរបស់គាត់ក៏ដោយ ក៏កំណត់ហេតុមួយចំនួនក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយទាំងនេះ បានបង្ហាញថាគាត់បាននិយាយបែបនេះជាមួយប៉ង់ ក្រោយពីប៉ង់ ត្រូវបានសួរចម្លើយនៅ ស-២១[3623]។ ឌុច បានព្យាយាមតវ៉ាលើចម្លើយមុនៗរបស់គាត់ ដោយបានអះអាងថាកិច្ចសន្ទនារបស់គាត់ជាមួយប៉ង់ បានធ្វើ ឡើងមុនការសួរចម្លើយប៉ង់[3624] តែបើទោះជាយ៉ាងណាក៏ដោយ ក៏វាមិនបានបដិសេធពីការដែលថា វាបានកើតឡើងក្នុងពេលដែលប៉ង់ត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ នោះដែរ។ គ្មាននរណាម្នាក់អាចបដិសេធបានពីបរិយាកាសគំរាមកំហែងជាទូទៅនៃទីកន្លែង និងហានិភ័យដែលថាព័ត៌មានទាំងអស់នេះត្រូវទទួលបានដោយសារការធ្វើទារុណកម្ម ឬយ៉ាងហោចណាស់ ក៏ស្ថិតក្រោមការបង្ខិតបង្ខំដែរ។ ច្បាស់ណាស់ថា វាគួរតែរារាំងរាល់ចៅក្រមមានវិចារណញ្ញាណគ្រប់រូបមិនឱ្យចាត់ទុកចម្លើយទាំងនោះថាត្រឹមត្រូវ និងមិនឱ្យយកមកធ្វើជាសំអាង ដើម្បីធ្វើសេចក្តីសន្និដ្ឋានកំណត់បែបនេះបាននោះទេ ទាក់ទងនឹងការ

---

[3622] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៨ ដែលដកស្រង់សក្ខីកម្មរបស់ ឌុច។

[3623] កំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី០៤-០៥-០៦ ខែឧសភា ឆ្នាំ១៩៩៩ ឯកសារ **E3/347** ERN 00002496 “ដោយយោងតាមអ្វីដែលត្រូវបានឆ្លើយតបដោយយោងតាមអ្វីនិយាយដោយ ឈឹម សំអោក ហៅ ប៉ង់ ដែលបានប្រាប់ខ្ញុំពីរឿងនេះ បន្ទាប់ពីគាត់បានបំពេញនូវចម្លើយរបស់គាត់រួចរាល់ហើយនោះ ហើយខ្ញុំក៏បាននិយាយជជែកលេងក្រៅផ្លូវការ និងរំឭករឿងរ៉ាវជាមួយគាត់ប្រហែលជា ១០ ថ្ងៃបន្ទាប់។ ក្នុងករណីចាំបាច់មួយចំនួន ខៀវ សំផន ត្រូវបានហៅឱ្យទៅចូលរួមក្នុងអង្គប្រជុំអំពីការចាប់ខ្លួន”។

[3624] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/443.1** ចន្លោះម៉ោង 09.44.22 និងម៉ោង 10.07.50។

ទទួលខុសត្រូវរបស់ ខៀវ សំផន[3625]។ ដូច្នេះ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីជោគវាសនារបស់ ជូ ជេត និងការសម្លាប់គាត់ ត្រូវទុកជាមោឃៈ។

## ២.២.៥. វន វ៉េត និង សោ ភឹម

១៨៦៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន "បានដឹងអំពីស្ថានភាពរបស់ វន វ៉េត និងជោគវាសនារបស់ សោ ភឹម"[3626]។ អង្គជំនុំជម្រះបានផ្អែកជាចម្បងលើចម្លើយរបស់ ខៀវ សំផន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ សម្រាប់ករណី វន វ៉េត និងផ្អែកតែទៅលើចម្លើយដដែលនេះ សម្រាប់ករណី សោ ភឹម។ ដូចបានឃើញពីខាងលើ ចម្លើយទាំងនេះមិនអាចឱ្យអង្គជំនុំជម្រះបង្ហាញឱ្យឃើញពីការដឹងឮរបស់គាត់អំពីអង្គហេតុ នៅក្នុងអំឡុងពេលវាកំពុងកើតឡើងនោះទេ។

១៨៧០. សម្រាប់ វន វ៉េត អង្គជំនុំជម្រះយល់ថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួនរបស់គាត់ក្នុងអំឡុងពេលសន្និបាតបក្សលើកទី៥ នាចុងឆ្នាំ១៩៧៨ ដោយមានវត្តមានរបស់គាត់។ ប្រភពព័ត៌មានរបស់អង្គជំនុំជម្រះ មានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ គឺចម្លើយជាលាយលក្ខណ៍អក្សររបស់ កែ ពក ទទួលបានក្រៅក្របខ័ណ្ឌតុលាការ និងកំណត់ហេតុសួរចម្លើយ ឌុច ដែលផ្អែកលើសម្ដីរបស់ កែ ពក។ លើសពីនេះទៀត វាជាការបំភ្លៃភ័ស្តុតាង។ ប្រវត្តិរូបផ្ទាល់ខ្លួនរបស់ កែ ពក បង្ហាញយ៉ាងច្បាស់ថា ការចាប់ខ្លួនបានកើតឡើងក្រោយការបញ្ចប់មហាសន្និបាត៖

> "ពេលបើកមហាសន្និបាតលើកទី៥ នៅពេលសាលសភា ខែ... ៧៨ មុនយួនចូល ពេលកំពុងប្រជុំ ស្រាប់តែផ្អើលឈុល ពេលនោះ ចេង អន ថាមានកូនទូកមួយបណ្ដែត ដល់ទៅមើលឃើញតែនំកន្ទក់។ <u>មហាសន្និបាតក៏បិទ</u>។ បិទហើយ ប៉ុល ពត ប្រាប់ខ្ញុំកុំអាលទៅ ចាំមើលកុន

---

[3625] សូមបញ្ជាក់ថា ការជំទាស់របស់មេធាវីការពារក្ដីត្រូវបានបដិសេធចោលដោយអយុត្តិធម៌ ក្នុងពេលសហព្រះរាជអាជ្ញាសួរដេញដោលអំពីកាលៈទេសៈនៃ "ការនិយាយដដែកលេង"។

[3626] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២២៩។

សិន។ ខ្ញុំគិតថាយ៉ាងម៉េចអញ្ចេះ ហើយក៏ទៅដេកនៅកន្លែងមជ្ឈិម។ ស្រាប់តែម៉ោង១រសៀល គេចាប់តាកឺ+វន វេត។ រួចហើយ ប៉ុល ពត សួរថា មានឃើញកុនទេ។ ខ្ញុំស្មានតែកុនមែនទែន ការពិត គឺកុនចាប់តាកឺ+វន វេត នេះឯង"[3627]។

១៨៧១. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានអះអាងថា វន វេត ត្រូវបានចាប់ខ្លួន "ក្នុងអំឡុងពេល" សន្និបាតលើកទី ៥ ហើយអង្គជំនុំជម្រះមិនអាចចាត់ទុកកំណត់ហេតុសួរចម្លើយ ឌុច ថាជាភស្តុតាងបញ្ជាក់បន្ថែមបានទេ ព្រោះថាកំណត់ហេតុនេះផ្អែកលើប្រភពតែមួយដូចគ្នា៖ កែ ពក[3628]។ ចំណែកឯសៀវភៅរបស់ Philip SHORT ដែលត្រូវបានយោងផងដែរដោយអង្គជំនុំជម្រះ គឺវាគ្រាន់តែបង្ហាញថា វន វេត ត្រូវបញ្ជូនទៅស-២១ នៅថ្ងៃបន្ទាប់ពីសន្និបាត។ គ្មានភស្តុតាងណាមួយអាចឱ្យគេសន្និដ្ឋានបានអំពីវត្តមានរបស់ ខៀវ សំផន នៅក្នុងអំឡុង និងក្រោយសន្និបាតនេះ បើទោះជាគាត់បានចូលរួមសន្និបាតនេះក៏ដោយ[3629]។ ការបំភ្លៃភស្តុតាងនេះ គួរទទួលរងពិន័យ។ ដោយគ្មានភស្តុតាង សេចក្តីសន្និដ្ឋានដែលថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួន វន វេត នៅពេលអង្គហេតុកើតឡើង ត្រូវទុកជាមោឃៈ។

## ២.២.៦. រីង ឆែម ហៅ សុខ សាផុន ហៅ ភួង

១៨៧២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន "បានជួយសម្រួលយ៉ាងសកម្មដល់ការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់ ភួង"[3630]។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះបានបំភ្លៃខ្លឹមសារសៀវភៅរបស់ ខៀវ សំផន ដែលមិនបានបង្ហាញពីការជួយណាមួយដល់ការចាប់ខ្លួននេះទេ តែផ្ទុយទៅវិញ ខ្លឹមសារនេះបានបញ្ជាក់ថា ដោយយកចិត្តទុកដាក់អំពីផាសុកភាពរបស់ ភួង គាត់គ្មាននឹកសង្ស័យពីរឿងអ្វីផ្សេងទៀតទាល់តែសោះ ព្រោះថា "នេះជាទម្លាប់ហូរហែមកតែគ្រប់កម្មាភិបាល ភូមិភាគ ឬតំបន់ផ្សេងៗ ដែលមកធ្វើការជាមួយគណៈអចិន្ត្រៃយ៍អំពីកិច្ចការទាក់ទងពីភូមិភាគ និងតំបន់

[3627] ប្រវត្តិរបស់ កែ ពក ឯកសារគ្មានចុះកាលបរិច្ឆេទ **E3/2782** ERN 00095553 (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3628] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣២១ កំណត់សម្គាល់ជើងទំព័រលេខ ៧៨៤៧។

[3629] សូមមើលខាងលើ កថាខណ្ឌ ១៧០៤-១៧៥៣។

[3630] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣០។

របស់គេ”[3631]។ ចម្លើយយ៉ាងច្បាស់លាស់ទាំងនេះរបស់ ខៀវ សំផន ត្រូវបានបំភ្លៃដោយអង្គជំនុំជម្រះ។ ចម្លើយទាំងនេះបានបង្ហាញឱ្យឃើញថា ការចាប់ខ្លួនត្រូវបានធ្វើយ៉ាងសម្ងាត់បំផុតដោយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាអ្នកទទួលបន្ទុកអនុវត្ត។

១៨៧៣. ដោយពុំមានភ័ស្តុតាងមានតម្លៃណាផ្សេងទៀតដែលអាចបង្ហាញឱ្យឃើញថា ខៀវ សំផន បានដឹងឮអំពីការចាប់ខ្លួនរបស់ ភួង អង្គជំនុំជម្រះបានលើកឡើងវិញពីទឡ្ហីករណ៍ដដែលៗអំពី “ឋានៈពិសេសរបស់ ខៀវ សំផន នៅក្នុងបក្ស និងភាពស្និទ្ធស្នាលជាមួយ ប៉ុល ពត និង នួន ជា”។ ក៏ប៉ុន្តែ ការស្មានៗនេះ គឺមិនសមហេតុសមផលនោះទេ និងមិនអាចជាភ័ស្តុតាងតែមួយគត់ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះបានទេ។ ដោយគ្មានភ័ស្តុតាងផ្ទាល់អំពីការដឹងឮរបស់ ខៀវ សំផន អំពីការចាប់ខ្លួន ភួង នៅពេលអង្គហេតុកើតឡើង សេចក្តីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

## ២.៣. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការបោសសម្អាតថ្នាក់ក្រោម

១៨៧៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ខៀវ សំផន “បានដឹងអំពីការបោសសម្អាតទូទៅ និងការសម្លាប់ប្រជាជនទូទាំងប្រទេស”[3632]។ ជាបឋម វាជាការសន្និដ្ឋានពង្រីកមិនសមហេតុសមផល។ ភ័ស្តុតាងដែលត្រូវបានវិភាគ គឺកម្រិតត្រឹមព្រឹត្តិការណ៍មួយចំនួនដែលបានកើតឡើងនៅខេត្តព្រះវិហារ ហើយដែល ខៀវ សំផន បានដឹង[3633]។ ក៏ប៉ុន្តែ ខេត្តព្រះវិហារពុំស្ថិតក្នុងចំណោមទីតាំងឧក្រិដ្ឋកម្ម ឬមន្ទីរសន្តិសុខ នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង០០២/០២ នោះទេ។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបានពន្យល់ថា តើ ខៀវ សំផន អាចដឹងពីការចាប់ខ្លួន និងល័ក្ខខ័ណ្ឌនៃការឃុំខ្លួនប្រជាជននៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកលើមូលដ្ឋាននៃព្រឹត្តិការណ៍តែមួយបានដូចម្តេចទៅ[3634]។ ការសន្និដ្ឋានពង្រីកនេះ គឺពុំសមហេតុសមផល និងត្រូវទុកជាមោឃៈ។

---

[3631] សៀវភៅរបស់លោក ខៀវ សំផន *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហរជាបន្តបន្ទាប់របស់ខ្ញុំ* បោះពុម្ពផ្សាយខែឧសភា ឆ្នាំ ២០០៧ ឯកសារ **E3/18** ERN 00103886។

[3632] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣១។

[3633] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣២ និង ៤២៣៣។

[3634] សូមមើលខាងលើ កថាខណ្ឌ ១៨៣៩-១៨៣៥។

១៨៧៥. ភ័ស្តុតាងមួយផ្សេងទៀតដែលអង្គជំនុំជម្រះប្រើប្រាស់ដើម្បីគាំទ្រការអះអាងរបស់ខ្លួន គឺជាកិច្ចសម្ភាសន៍គ្មានកាលបរិច្ឆេទរបស់ ខៀវ សំផន ជាមួយអ្នកនិពន្ធម្នាក់មិនស្គាល់អត្តសញ្ញាណ នោះគឺឯកសារ **E3/4041** ដែលមានបញ្ហាខ្លាំងអំពីយថាភាព[3635]។ ក៏ប៉ុន្តែ កាលបរិច្ឆេទ គឺជាធាតុផ្សំមួយសំខាន់ នៅពេលគេដឹងអំពីព័ត៌មានយល់ច្រឡំច្រឡំដោយ ខៀវ សំផន ក្រោយរបបនោះ[3636]។ លើសពីនេះទៀត ឯកសារនេះកត់ត្រាតែចម្លើយរបស់ ខៀវ សំផន ដោយគេពុំបានដឹងពីសំណួរដែលបានចោទសួរ។ ម្យ៉ាងវិញទៀត ឃ្លាមួយចំនួនដែលយោងដោយអង្គជំនុំជម្រះ គឺដាក់ក្នុងសញ្ញាឃ្នាប ដែលទំនងជាមានន័យថាមិនមែនជាចម្លើយដើមរបស់ ខៀវ សំផន[3637]។ ប្រឈមនឹងបញ្ហាខ្លាំងនៃភាពជឿទុកចិត្តបាន និងយថាភាពទាំងអស់នេះ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសំអាងសេចក្តីសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន លើឯកសារមួយនេះបានទេ។ ឯកសារនេះត្រូវបដិសេធចោល ហើយសេចក្តីសន្និដ្ឋានត្រូវទុកជាមោឃៈ។

១៨៧៦. អង្គជំនុំជម្រះបានបំភ្លៃខ្លឹមសារលិខិតចំហមួយសរសេរដោយ ខៀវ សំផន នៅក្នុងឆ្នាំ២០០១។ អង្គជំនុំជម្រះបានយោងតែទៅលើផ្នែកមួយ ដែលក្នុងនោះ ខៀវ សំផន បានពន្យល់ថាបានឮ "ដោយចៃដន្យ" អំពីករណីចាប់ខ្លួនសមាជិកគ្រួសារប្រពន្ធរបស់គាត់[3638]។ ប៉ុន្តែ អង្គជំនុំជម្រះបានធ្វើមិនដឹងតែម្តងចំពោះការពន្យល់របស់គាត់ថា គាត់មិនបានដឹងពីការកាប់សម្លាប់ទាល់តែសោះ ហើយវិន័យបានហាមគាត់មិនឱ្យដើរហើរដោយគ្មានការអនុញ្ញាត។ ប៉ុន្តែ ម្ចាស់បណ្តឹងសាទុក្ខបានរំឭកផងដែរអំពីគោលការណ៍រក្សាការសម្ងាត់៖

---

[3635] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣១។

[3636] សំអាងហេតុសាលក្រម កថាខណ្ឌ ១៩៥។

[3637] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣១ ដែលដកស្រង់កិច្ចសម្ភាសន៍ជាមួយ ខៀវ សំផន គ្មានចុះកាលបរិច្ឆេទ ឯកសារ **E3/4041** ERN 00782573 "អានេះហើយដែលវាច្រើន។ នេះហើយដែលវានាំឱ្យច្រើន"។

[3638] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣២ ដែលដកស្រង់លិខិតរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០១ ឯកសារ **E3/205** ERN 00002796។

"ព្រមជាមួយនេះ លាក់ការសម្ងាត់ តឹងតែង "កិច្ចការអ្នកណា អ្នកនោះដឹង កិច្ចការគេ មិនដឹង មិនឮ មិនឃើញ" ហាមមិនឱ្យអ្នកណាប៉ាននិយាយពីរឿងអ្វីប្រាប់ខ្ញុំទាល់តែសោះ។ ទាំងអស់នេះហើយដែលបានរាំងខ្ញុំមិនឱ្យដឹងអ្វីៗទាំងអស់ដែលបានកើតឡើងនៅក្នុងប្រទេស។ ខ្ញុំដឹងតែអ្វីដែលអ្នកដឹកនាំ ប.ក.ក ប្រាប់ឱ្យខ្ញុំដឹងតែប៉ុណ្ណោះ។ លុះដល់ចលនាត្រូវរលំរលាយទៅហើយ ទើបបងប្អូនសាច់ញាតិអ្នករងគ្រោះ និងអ្នកដែលគេបានឃើញផ្ទាល់ ឬដឹងឮ រៀបរាប់ប្រាប់ខ្ញុំអំពីការកាប់សម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃ ស្ដាប់ទៅគួរឱ្យព្រឺក្បាល"[3639]។

១៨៧៧. ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចមានហេតុផលត្រឹមត្រូវ ដើម្បីទាញសេចក្ដីសន្និដ្ឋានចេញពីលិខិតចំហនេះថា ខៀវ សំផន បានដឹងអំពី "ការចាប់ខ្លួន និងការឃុំឃាំងជនស៊ីវិល ឬស្ថានភាពដែលប្រជាជនជួបប្រទះនៅទូទាំងប្រទេស" បាននោះទេ[3640]។

១៨៧៨. ទាក់ទងនឹងប្រធានបទដដែលនេះដែរ អង្គជំនុំជម្រះបានផ្អែកទៅលើសក្ខីកម្មរបស់ មាស រឿន ដែលថា ខៀវ សំផន បានផ្ញើទូរលេខមួយឱ្យគាត់ ដើម្បីសុំព័ត៌មានទាក់ទងនឹងជោគវាសនារបស់គ្រួសារប្រពន្ធរបស់គាត់[3641]។ មាស រឿន មិនត្រឹមតែនិយាយថាគាត់មិនអាចដឹងថាតើទូរលេខរបស់គាត់ផ្ញើត្រឡប់មកវិញ បានទៅដល់ ខៀវ សំផន ដែរ ឬយ៉ាងណាប៉ុណ្ណោះទេ[3642] តែលើសពីនេះទៀត ការដែល ខៀវ សំផន បានស្នើសុំព័ត៌មាន គឺវាបង្ហាញឱ្យឃើញថាគាត់ពុំមានព័ត៌មានទាំងនោះទៅវិញទេ។ ហេតុដូច្នេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា ខៀវ សំផន បានដឹងអំពីល័ក្ខខ័ណ្ឌនៃការរស់នៅ ការចាប់ខ្លួន និងការសម្លាប់មនុស្សក្រៅពីក្រុមគ្រួសារប្រពន្ធរបស់គាត់ ពុំមែនជាសេចក្ដីសន្និដ្ឋានតែមួយដែលអាច

[3639] លិខិតរបស់លោក ខៀវ សំផន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០១ ឯកសារ **E3/205** ERN 00002796។

[3640] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៤។

[3641] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៣។

[3642] ប្រតិចារឹក ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ឯកសារ **E1/132.1** ចន្លោះម៉ោង 14.18.50 និងម៉ោង 14.27.25 "ក្នុងពេលដែល មានផ្ញើសារតបទៅវិញនុ៎ង អត់ឮ។ អើយ ប្រាប់ថា អត់ឮគ្មានទេ ពីព្រោះថា វាឮមិនច្បាស់ ដឹងស្អីជាស្អី គាត់ប្រាប់ខ្ញុំអ៊ីចឹងមកក៏ សារហ្នឹងត្រូវស្អុបចូលហ្នឹងសិនទៅ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ "សរសេរប្រាប់គាត់មកវិញ រាយការណ៍ប្រាប់គាត់មកវិញអំពីក្រុមគ្រួសារគាត់ ម្ដាយរបស់គាត់ ប្អូនរបស់គាត់ និងសភាពប្រជាជន ការអត់ឃ្លានយ៉ាងម៉េច ខ្លះៗ។ ហើយខ្ញុំសរសេរសារហ្នឹងមកវិញ តែសារនោះដល់ ឬមិនដល់ អត់ឃើញគាត់ឆ្លើយតបមកវិញទេ។ ខ្ញុំបានបញ្ជាក់អ៊ីចឹងឯង បាទ។ ខ្ញុំចាំតែម្ដង ឱ្យរាយតែម្ដងប៉ុណ្ណឹង"។

មាននោះទេ ហើយវាជាការសន្និដ្ឋានពង្រីក។ ហេតុដូច្នេះ សេចក្ដីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ ហើយមិនអាចប្រើធ្វើជាមូលដ្ឋាននៃការសន្និដ្ឋានទូទៅទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលបោសសម្អាតផ្ទៃក្នុងបានទេ[3643]។

## ផ្នែកទី ៣. ក្រុមជាក់លាក់នានា

### ១. ជនជាតិចាម

១៨៧៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានកែខៃការគ្មានភ័ស្តុតាងដោយផ្ទាល់ ឬដោយប្រយោលដែលបញ្ជាក់ថា នៅពេលអង្គហេតុកើតឡើង ខៀវ សំផន បានដឹងពីការប្រព្រឹត្តិឧក្រិដ្ឋកម្មលើជនជាតិចាម ដែលត្រូវបានចោទប្រកាន់ចំពោះរូបគាត់ (១.១) តាមរយៈការសន្និដ្ឋានមិនត្រឹមត្រូវ (១.២)។

### ១.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង

១៨៨០. គ្មានភ័ស្តុតាងដោយផ្ទាល់ ឬដោយប្រយោលពាក់ព័ន្ធណាមួយ បញ្ជាក់ថា នៅពេលអង្គហេតុកើតឡើង ខៀវ សំផន បានដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មដូចខាងក្រោម ដែលរូបគាត់ត្រូវរងការចោទប្រកាន់នោះទេ៖ - ឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលដែលរងការចោទប្រកាន់ នៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧ និងនៅភូមិទ្រា ក្នុងឆ្នាំ១៩៧៨ - ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង ក្នុងឆ្នាំ១៩៧៨ និងតាមរយៈការធ្វើទារុណកម្ម នៅថ្ងៃចាប់ខ្លួន អ៊ីត សេន ក្នុងឆ្នាំ១៩៧៨ នៅភូមិទ្រា - ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ - ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និង - ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការផ្លាស់ទីលំនៅដោយបង្ខំ នៅចុងឆ្នាំ១៩៧៥។

---

[3643] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៤ និង ៤២៣៥។

## ១.២. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន

១៨៨១. សេចក្តីសន្និដ្ឋានពុំត្រឹមត្រូវរបស់អង្គជំនុំជម្រះដែលថា ខៀវ សំផន "បានដឹងអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មលើជនជាតិចាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ" ផ្អែកតែទៅលើការទាញសន្និដ្ឋានបណ្តាក់តគ្នា និងលើភ័ស្តុតាងទេសកាលដែលត្រូវបានសន្និដ្ឋាន និងដែលត្រូវប្រើធ្វើជាចំណុចចាប់ផ្តើមទៅសេចក្តីសន្និដ្ឋានមួយផ្សេងទៀត ហើយបន្តបែបនេះរហូត[3644]។ ក៏ប៉ុន្តែ ប្រសិនបើគេអាចបង្ហាញឱ្យឃើញពីការដឹង តាមរយៈភ័ស្តុតាងដោយប្រយោល សេចក្តីសន្និដ្ឋាននេះត្រូវតែជាសេចក្តីសន្និដ្ឋានសមហេតុសមផលតែមួយគត់។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានទាញសេចក្តីសន្និដ្ឋានទាក់ទងនឹងការដឹងជាលក្ខណៈទូទៅ មិនច្បាស់លាស់ និងជាសរុប ("ឧក្រិដ្ឋកម្មមួយចំនួន" "ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ") ដោយមិនបានបញ្ជាក់អំពីឧក្រិដ្ឋកម្មដែល ខៀវ សំផន បានដឹង ហើយជាពិសេសនោះ អំពីពេលវេលាដែលគាត់បានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ។ បន្ទាប់មក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ទាក់ទងនឹង ភ័ស្តុតាងនីមួយៗក្នុងចំណោមភ័ស្តុតាងទេសកាលទាំងឡាយដែលខ្លួនយកមកធ្វើជាសំអាង ដើម្បីទាញសេចក្តីសន្និដ្ឋានទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន ដោយពុំបានពន្យល់ថាហេតុអ្វីបានជាសេចក្តីសន្និដ្ឋាននោះ គឺជាសេចក្តីសន្និដ្ឋានសមហេតុសមផលតែមួយគត់។

១៨៨២. ជាបឋម អង្គជំនុំជម្រះមិនបានបង្ហាញឱ្យឃើញតាមលក្ខណៈសមហេតុសមផលថា ប.ក.កបានចាត់វិធានការយ៉ាងច្បាស់ប្រឆាំងនឹងជនជាតិចាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[3645]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយយល់ថាមានការបង្ហាញឱ្យឃើញថា ខៀវ សំផន "បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការថែរក្សា "ផ្តែផ្តាបដិវត្តន៍ និងជាតិសាសន៍កម្ពុជាឱ្យបានជារៀងរហូត""[3646] ដោយពុំបានចង្អុលបង្ហាញការយោងណាមួយសម្រាប់ការរៀបរាប់មួយនេះទេ។ ការពិតទៅ វាជាសេចក្តីដកស្រង់ចេញពីកំណត់ហេតុ FBIS E3/294 ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ

---

[3644] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៦។

[3645] សូមមើលខាងលើ កថាខណ្ឌ ៨៩២-៩៦៥ កថាខណ្ឌ ១៥៦១-១៥៨៥។

[3646] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៦។

១៩៧៨ ដែលសំណៅដើមជាភាសាខ្មែរ ពុំអាចរកបាន។ ដូច្នេះ អង្គជំនុំជម្រះមិនអាចប្រើប្រាស់ឯកសារនេះបានទេ បើមិនមានការបញ្ជាក់បន្ថែម[3647]។

១៨៨៣. បើទោះថាពាក្យសម្ដីទាំងអស់នេះត្រូវបាននិយាយដោយ ខៀវ សំផន ក្នុងខ្លឹមសារដូច្នេះពិតមែនក៏ដោយចុះ ក៏អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានអំពីការដឹងឮរបស់គាត់អំពីឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ដោយសារតែកាលបរិច្ឆេទនៃឧក្រិដ្ឋកម្មទាំងនោះ "គាប់ជួន" ជាមួយនឹងគោលនយោបាយកម្ទេចជនជាតិចាមដែលរងការចោទប្រកាន់ ចាប់ពីឆ្នាំ៧៧-៧៨ និងជាមួយនឹងគោលនយោបាយដូចគ្នាចំពោះជនជាតិវៀតណាម ក្នុងខែមេសា ឆ្នាំ១៩៧៧។ ការបកស្រាយដាក់បន្ទុកនេះ ពុំមែនជាសេចក្ដីសន្និដ្ឋានសមហេតុសមផលតែមួយគត់នោះទេ ខណៈដែលមានការវាយលុកលុយក្នុងជម្លោះប្រដាប់អាវុធជាមួយវៀតណាម។

១៨៨៤. អង្គជំនុំជម្រះមិនអាចផ្អែកលើការគាំទ្ររបស់ ខៀវ សំផន ចំពោះផែនការរួមមិនមែនឧក្រិដ្ឋ ដើម្បីសន្និដ្ឋានថាគាត់បានដឹងអំពីការអនុវត្តគោលនយោបាយ "ក្នុងការបន្សុទ្ធសង្គមខ្មែរតែមួយ ដែលមានតែកម្មករ-កសិករ" ដោយពុំបានពន្យល់ថា តើវាជាសេចក្ដីសន្និដ្ឋានសមហេតុសមផលតែមួយដែលអាចមាន បានដោយដូចម្ដេចទៅ[3648]។ សេចក្ដីសន្និដ្ឋានទាក់ទងនឹងឋានៈ "ពិសេស" ឬ "មេដឹកនាំជាន់ខ្ពស់" របស់ ខៀវ សំផន ពុំមែនជាការបង្ហាញឱ្យឃើញពីការដឹងឮអំពីឧក្រិដ្ឋកម្មជាក់លាក់នោះទេ។

១៨៨៥. អង្គជំនុំជម្រះគួរណាពន្យល់ថា តើខ្លួនផ្អែកលើធាតុផ្សំអង្គហេតុជាក់ស្ដែងអ្វីខ្លះ ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានដឹងថាផែនការរួម តម្រូវឱ្យមានបទឧក្រិដ្ឋប្រឆាំងនឹងជនជាតិចាម និងមានបំណងចង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងអស់នោះ[3649]។ អង្គជំនុំជម្រះមិនបានធ្វើដូច្នេះទេ ព្រោះថាបើយោងតាមភស្តុតាង អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ខៀវ សំផន មានចេតនាឧក្រិដ្ឋដែលជាល័ក្ខខ័ណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មនីមួយៗក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយដែលចោទប្រកាន់ចំពោះរូបគាត់នោះទេ។ សេចក្ដីសន្និដ្ឋាន

[3647] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

[3648] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

[3649] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

ទាំងឡាយផ្ទុយពីនេះ របស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ រួមទាំងការប្រកាសអំពីពិរុទ្ធភាពដោយអង្គជំនុំជម្រះ ត្រង់ចំណុចនេះផង[3650]។

## ២. ជនជាតិវៀតណាម

១៨៨៦. ជាលក្ខណៈចម្បង យើងសូមរំឭកថា អង្គជំនុំជម្រះទទួលបានបណ្តឹងពុំត្រឹមត្រូវអំពីអង្គហេតុដែលជាធាតុផ្សំនៃការនិរទេសជនជាតិវៀតណាមនៅត្រាំកក់ ខេត្តព្រៃវែង និងខេត្តស្វាយរៀង[3651] និងអង្គហេតុដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ចំពោះជនជាតិវៀតណាមនៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង[3652]។ ដូច្នេះ អង្គជំនុំជម្រះគួរតែពិនិត្យតែទៅលើភ័ស្តុតាងទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាមនៅក្នុងខេត្តពីរនេះ។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុដែលរារាំងខ្លួនមិនឱ្យបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការនិរទេសជនជាតិវៀតណាម ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[3653]។ កំហុសរបស់អង្គជំនុំជម្រះទាំងអស់នេះ ក៏មិនអាចឱ្យខ្លួនបង្ហាញឱ្យឃើញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការសម្លាប់ជនជាតិវៀតណាមនៅក្នុងខេត្តស្វាយរៀង កំពង់ឆ្នាំង ក្រចេះ នៅក្នុងដែនទឹកនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ និងនៅវត្តខ្សាច់ ទាក់ទងនឹងជីដូនជីតារបស់ចាន់ថា និងគ្រួសាររបស់ ជុំ បាននោះដែរ[3654]។ ហេតុដូច្នេះ បើតាមលក្ខណៈសមហេតុសមផល សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលថា "ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ" ត្រូវទុកជាមោឃៈ[3655]។

---

[3650] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[3651] សូមមើលខាងលើ កថាខណ្ឌ ៣៨០-៣៨៥។

[3652] សូមមើលខាងលើ កថាខណ្ឌ ៤៣៥-៤៣៨ កថាខណ្ឌ ៥២០-៥២១។

[3653] សូមមើលខាងលើ កថាខណ្ឌ ៦៨៦-៧១៨ កថាខណ្ឌ ៧៤៨-៧៥៥ កថាខណ្ឌ ៧៥៦ កថាខណ្ឌ ៩៦៦-១០៩៧។

[3654] សូមមើលខាងលើ កថាខណ្ឌ ៩៨៧-១០១៧។

[3655] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៩។

១៨៨៧. ប៉ុន្តែ ជាលក្ខណៈបន្ទាប់បន្សំ ដោយទទួលស្គាល់ថាឧក្រិដ្ឋកម្មពិតជាត្រូវបានប្រព្រឹត្តមែន ការគ្មានភស្តុតាងទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មលើជនជាតិវៀតណាម នៅពេលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត (២.១) មិនអនុញ្ញាតឱ្យសន្និដ្ឋានបែបនេះបានទេ (២.២)។

## ២.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង

១៨៨៨. កថាខណ្ឌ ៤២៣៧ និង ៤២៣៩ នៃសំអាងហេតុសាលក្រម ពុំដែលបង្ហាញពីការដឹងឮរបស់ ខៀវ សំផន អំពីអង្គហេតុខាងក្រោមនេះទេ៖

- ការនិរទេសជនជាតិវៀតណាមដែលត្រូវប្រមូលនៅក្នុងស្រុកត្រាំកក់ នាចុងឆ្នាំ១៩៧៥ ដើមឆ្នាំ ១៩៧៦ ជាពិសេសក្នុងអំឡុងរយៈពេលបួនថ្ងៃ ដើមឆ្នាំ១៩៧៦[3656]។
- ការនិរទេសជនជាតិវៀតណាមពីខេត្តព្រៃវែង ក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦[3657]។
- ការសម្លាប់ជនជាតិវៀតណាមបួនគ្រួសារនៅខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៨ អ្នកនេសាទ និងជនភៀសខ្លួនវៀតណាម នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ និងនៅកំពង់ផែអូរឈើទាល ក្រោយខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ បងប្អូនរបស់ ប្រាក់ ខឿន និងសមាជិកជនជាតិវៀតណាមប្រាំមួយគ្រួសារផ្សេងទៀត ក្នុងឆ្នាំ១៩៧៧ បងប្អូនរបស់ អ៊ុច ស៊ុនឡាយ និងសមាជិកខ្មែរបី ឬបួនគ្រួសារទៀត នៅក្នុងខេត្តក្រចេះ នៅខែកញ្ញា ឆ្នាំ១៩៧៨ ជនស៊ីវិលវៀតណាមនៅវត្តខ្សាច់ នៅចុងឆ្នាំ១៩៧៨[3658]។
- ការចាប់ខ្លួនជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង ចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩[3659]។
- ការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ជនជាតិវៀតណាមនៅ ស-២១[3660]។

[3656] សំអាងហេតុសាលក្រម កថាខណ្ឌ ១១៥៧ និង ៣៥០៩។

[3657] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៣-៣៥០៧។

[3658] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤៩៧ កថាខណ្ឌ ៣៤៩៩-៣៥០១ កថាខណ្ឌ ៣៥១០-៣៥១៣ និង កថាខណ្ឌ ៣៥១៥-៣៥១៩។

[3659] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥០៩-៣៥១៣។

[3660] សំអាងហេតុសាលក្រម កថាខណ្ឌ ២៦០៥-២៦១០ និង ៣៥០៩។

– ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាមនៅអូរកន្សែង[3661]។

១៨៨៩. ទោះជាអង្គជំនុំជម្រះបានសន្និដ្ឋានថា "ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិវៀតណាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[3662] ក៏ដោយ ក៏អង្គជំនុំជម្រះមិនដែលនិយាយថា តើគាត់បានដឹងអំពីឧក្រិដ្ឋកម្មអ្វីខ្លះ ហេតុអ្វី និងពេលណា ដែលគាត់បានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ នោះទេ។ លើសពីនេះទៀត កាលបរិច្ឆេទនៃឧក្រិដ្ឋកម្ម ច្រើនតែមិនច្បាស់លាស់ គឺមានតែឆ្នាំប៉ុណ្ណោះដែលបញ្ជាក់ច្បាស់លាស់។ ដូច្នេះ អង្គជំនុំជម្រះមិនដែលខ្វល់ខ្វាយចង់ដឹងថា តើ ខៀវ សំផន នៅកន្លែងណា ពេលឧក្រិដ្ឋកម្មកើតឡើង និងអ្វីដែលគាត់អាចបាននិយាយនៅមុន ក្នុងពេល ឬក្រោយព្រឹត្តការណ៍កើតឡើង ដែលទាំងអស់នេះអាចធ្វើយុត្តិកម្មថាគាត់បានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះបាន។ អង្គជំនុំជម្រះមិនគួរប្រើប្រាស់ភស្តុតាងដោយប្រយោល ដើម្បីធ្វើការសន្និដ្ឋានពីការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មដែលមិនត្រូវបានបញ្ជាក់ ប្រឆាំងនឹងជនជាតិវៀតណាម នោះទេ។

## ២.២. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន

១៨៩០. ជាបឋម អង្គជំនុំជម្រះមិនគួរយល់ថា ការរំឮកអំពីអត្ថិភាពនៃគោលនយោបាយប.ក.ក ក្នុងការចាត់វិធានការជាក់លាក់ប្រឆាំងនឹងជនជាតិវៀតណាម គឺអាចឱ្យសន្និដ្ឋានបានពីការដឹងឮរបស់ ខៀវ សំផន នោះទេ។ ក្រៅពីនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានបកស្រាយ និងដោយបានបំភ្លៃសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន ដើម្បីសន្និដ្ឋានថាមានការដឹងឮរបស់គាត់អំពីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាម (២.២.១)។ ជាចុងក្រោយ ភស្តុតាងទាំងឡាយដែលត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះ គឺមិនអាចឱ្យសន្និដ្ឋានបានថា ខៀវ សំផន បានដឹងអំពីឋានៈជនដែលត្រូវទទួលបានការការពារនៃអ្នកជាប់ឃុំជនជាតិវៀតណាម និងដឹងថាពួកគេបានទទួលរងការធ្វើបាបនោះទេ (២.២.២)។

[3661] សំអាងហេតុសាលក្រម កថាខណ្ឌ ២៩៥៩ កថាខណ្ឌ ២៩៩៤-២៩៩៩ និង ៣៥០៩។

[3662] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៩។

## ២.២.១. កំហុសដោយបានសំអាងលើគោលនយោបាយរបស់ ប.ក.ក ដើម្បីសន្និដ្ឋានពីការដឹងឮរបស់ ខៀវ សំផន

### *២.២.១.១. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីការនិរទេស*

១៨៩១. អង្គជំនុំជម្រះបានសន្និដ្ឋានដោយមិនត្រឹមត្រូវថា ខៀវ សំផន បានគាំទ្រការបញ្ជូនប្រជាជនវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ[3663]។ អង្គជំនុំជម្រះបានយោងទៅកថាខណ្ឌ ៤២៧១ ដែលទាក់ទងនឹងការបណ្តេញជនជាតិវៀតណាម បានយោងទៅកថាខណ្ឌ ៣៣៩០ ជាពិសេស ទៅកំណត់សម្គាល់ជើងទំព័រ ១១៤៣៧ និងទៅកថាខណ្ឌ ៣៤០០ នៃសំអាងហេតុសាលក្រម។ ក៏ប៉ុន្តែ នៅក្នុងកថាខណ្ឌ ៣៤០០ ផ្នែកនៃសុន្ទរកថាដែលយោងដោយអង្គជំនុំជម្រះ ពុំបានបង្ហាញទាល់តែសោះពីការបញ្ជូនជនជាតិវៀតណាមចេញពីប្រទេសកម្ពុជា៖

> "ប្រជាជនរបស់យើងបានធ្វើការដុសខាត់យ៉ាងខ្លាំង ក្នុងការតស៊ូប្រយុទ្ធដើម្បីការពារប្រទេសប្រឆាំងនឹងពួកចក្រពត្តិនិយម វាតទីនិយម និងពួកប្រតិកិរិយាមកពីគ្រប់ទិសទី ដើម្បីដឹកនាំបដិវត្តន៍សង្គមនិយម និងបង្កបង្កើនផល។ ជាពិសេស ការវាយប្រយុទ្ធប្រឆាំងនឹងយួនឈ្លានពាន វាតទីនិយម លេបទឹកដី បានលើកកម្ពស់ សម្បជញ្ញៈនយោបាយ និងស្នេហាជាតិរបស់ប្រជាជនយើង ហើយនិង*ដុតកំហឹងស្នេហាជាតិ* និងកំហឹងវណ្ណៈឱ្យឆេះសន្ធោសន្ធៅខ្លាំងឡើងៗ។ ហេតុដូច្នេះហើយ កម្លាំងនយោបាយ និងមនោគមន៍វិជ្ជារបស់ប្រជាជនយើងមានលក្ខណៈកាន់តែរឹងមាំខ្លាំងឡើងៗ [ក្នុងអត្ថបទដើម ពុំមានអក្សរទ្រេត]"[3664]។

១៨៩២. ហេតុដូច្នេះ ភ័ស្តុតាងមួយនេះមិនអាចគាំទ្រថាមានការដឹងឮរបស់ ខៀវ សំផន ពីការនិរទេសជនជាតិវៀតណាមនៅកម្ពុជាទៅកាន់ប្រទេសវៀតណាមនោះទេ។ ចំណែកឯនៅកថាខណ្ឌ ៣៣៩០ មានការបញ្ជាក់ថា៖ "សាក្សី ឯក ហេន ដែលជាអ្នកធ្វើការនៅក្នុងអង្គភាពរោងចក្រកាត់ដេរមួយស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ ៨៧០ បានផ្តល់សក្ខីកម្មថា គាត់ និងអ្នកចូលរួមផ្សេងទៀត ប្រហែលពី ៤០០ ទៅ

---

[3663] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៧ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨២៦។

[3664] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០០ យោងដល់សុន្ទរកថាលោក ខៀវ សំផន ថ្លែងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/169** ERN S 00704523-00704524។

៥០០ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលមួយដែលធ្វើឡើងដោយ ខៀវ សំផន ដែលពេលនោះ គាត់បានពន្យល់ថា "យើងត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន ខ្មែរ និងខ្មែរចេះស្រឡាញ់គ្នា""។ នៅក្នុងកំណត់សម្គាល់ជើងទំព័រ អង្គជំនុំជម្រះបញ្ជាក់ថា "ឯក ហែន បានផ្តល់សក្ខីកម្មថា មាន "តែខ្មែរ អត់មានយួនទេ" នៅក្នុងប្រទេសកម្ពុជានៅពេលនោះ។ អង្គជំនុំជម្រះក៏បានរំឭកផងដែរថា វគ្គអប់រំនេះត្រូវបានធ្វើឡើងបន្ទាប់ពី ប៉ង់ ត្រូវបានចោទប្រកាន់ (គាត់ត្រូវបានចាប់ខ្លួននៅក្នុង ឬប្រហែលខែមេសា ឆ្នាំ១៩៧៨)"[3665]។

១៨៩៣. ភាពផ្ទុយគ្នាជាច្រើន និងបញ្ហានៃការចងចាំរបស់សាក្សីនៅក្នុងពេលផ្តល់សក្ខីកម្ម គួរនាំឱ្យអង្គជំនុំជម្រះដកសក្ខីកម្មរបស់គាត់ចេញ[3666]។ សាក្សីបានច្រឡំជាច្រើនដងនូវវគ្គអប់រំមួយដែលឧទ្ទេសនាមដោយ ខៀវ សំផន និងវគ្គមួយទៀត ដោយ នួន ជា តាមកាលបរិច្ឆេទយូរណាស់ហើយ នៅឆ្នាំ១៩៧៦ និងពាក់កណ្តាលឆ្នាំ១៩៧៨ ហើយដែលប្រធានបទនៃវគ្គទាំងនោះ គឺខុសៗគ្នា។ អង្គជំនុំជម្រះបានអះអាងជាន់កែងខ្លួនឯង ដោយថ្លែងថាវគ្គនេះធ្វើឡើងក្រោយខែមេសា ឆ្នាំ១៩៧៨ និងដោយបានគាំទ្រថា សម្តីរបស់ ខៀវ សំផន បានបង្ហាញថាគាត់បានដឹងថា ការនិរទេសជនជាតិវៀតណាមទៅកាន់ប្រទេសវៀតណាម គឺកំពុងប្រព្រឹត្តធ្វើនៅចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦...។ ដូច្នេះ អង្គជំនុំជម្រះមិនគួរទាញសេចក្តីកត់សម្គាល់លើអង្គហេតុកំណត់ដាច់ខាតដូច្នេះ តាមរយៈសម្តីដែលត្រូវបានរាយការណ៍ដោយសាក្សីម្នាក់ដែលស្ទើរតែពុំអាចជឿទុកបាន ៤០ ឆ្នាំ ក្រោយអង្គហេតុកើតឡើងបាននោះទេ ហើយម្យ៉ាងទៀតជាសាក្សីដែលបានបង្ហាញឱ្យឃើញពីបញ្ហាចងចាំជាច្រើន[3667]។ ចម្លើយទាំងអស់របស់ ឯក ហែន គួរតែត្រូវដកចេញដោយសមហេតុសមផលបំផុត[3668]។ លើសពីនេះទៀត បើទោះបីជាការបកស្រាយជាច្រើនអាចត្រូវបានជ្រើសរើសយកក៏ដោយ ក៏អ្វីដែលសំខាន់ គឺការកំណត់ថាតើសម្តីសន្មតទាំងអស់នេះត្រូវបានយល់ដោយអង្គសន្និបាត ក្នុងអំឡុងវគ្គអប់រំនយោបាយនេះ ក្នុងន័យសេចក្តីដូចម្តេច។ ដើម្បីកំណត់អំពីអត្ថន័យដែលត្រូវផ្តល់ឱ្យសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ អ្វីដែលពាក់ព័ន្ធគឺរបៀបដែលអ្នកមានវត្តមាន បានបកស្រាយសម្តីរបស់វាគ្មិន នៅសម័យកាលអង្គហេតុ និងពុំមែនជាអ្វីដែល

[3665] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ១១៤៣៧។

[3666] សំណើ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ F51 កថាខណ្ឌ ២០-២៨។ សូមមើលខាងលើផងដែរ កថាខណ្ឌ ២១៤០។

[3667] សំណើ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ F51 កថាខណ្ឌ ២៣-២៤។

[3668] សំណើ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ F51 កថាខណ្ឌ ២០-២៨ + ឧបសម្ព័ន្ធ ឯកសារ F51.1.1។

បកស្រាយដោយចៅក្រម ៤០ ឆ្នាំ ក្រោយមកហើយនោះទេ[3669]។ ក៏ប៉ុន្តែ បើយោងតាម ឯក ហេន វាច្បាស់ណាស់ថាជាសារនិយាយទៅកាន់អ្នកធ្វើការឱ្យចេះសាមគ្គី និងរួបរួមគ្នា[3670]។ ចម្លើយរបស់គាត់មិនបង្ហាញឱ្យឃើញអ្វីទាក់ទងនឹងសម្ដីរបស់ ខៀវ សំផន ដែលអាចឱ្យគេយល់ថាជាការគាំទ្រដល់ការបញ្ជូនជនជាតិវៀតណាមទៅប្រទេសវៀតណាមវិញនោះទេ។ ដូច្នេះ ចៅក្រមមិនមានហេតុផលត្រឹមត្រូវដើម្បីអះអាងជាស្វ័យប្រវត្តិថា "ខៀវ សំផន បានធ្វើការគាំទ្រយ៉ាងចំហចំពោះការបញ្ជូនប្រជាជនវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ" បាននោះទេ។

១៨៩៤. ដើម្បីធ្វើការ "បញ្ជាក់បន្ថែម" អង្គជំនុំជម្រះបានផ្អែកផងដែរទៅលើប្រតិចារឹកកិច្ចសម្ភាសន៍របស់ នៅ សារឹម ជាមួយវិទ្យុសំឡេងសហរដ្ឋអាមេរិក[3671]។ ក៏ប៉ុន្តែ ចម្លើយជាលាយលក្ខណ៍អក្សរមួយនេះ ក្រៅក្របខ័ណ្ឌតុលាការ មានតម្លៃជាភ័ស្តុតាងតិចតួចបំផុត[3672]។ ទោះយ៉ាងណាក៏ដោយ ប្រតិចារឹកនេះ មិន

---

[3669] សំអាងហេតុរបស់ចៅក្រោម Geoffrey Henderson ក្នុងរឿងក្តី Gbagbo (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ២៧១ និង ២៩៣។

[3670] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ប្រហែលម៉ោង 11.22.28 "គាត់និយាយតែរឿងការងារ ឱ្យប្រឹងតស៊ូសាមគ្គី ស្រឡាញ់គ្នា ចេះរាប់អានគ្នា ជួយគ្នាណា។ គាត់មានយោបល់គឺល្អៗដែរ ចាស។ មិនមាននាំឱ្យយើងអី មានទំនាស់ទាស់ទែងគ្នាអី គាត់ឱ្យចេះសាមគ្គីគ្នា អ៊ីចឹង ក្នុងក្រុម ក្នុងកង អ៊ីចឹង ឱ្យជួយគ្នា ពលកម្មដើម្បីស្តារសេដ្ឋកិច្ចប្រទេសជាតិ។ យើងកំពុងតែរួចពីសង្គ្រាមនុះណា"។

[3671] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៧ កំណត់សម្គាល់ជើងទំព័រលេខយោងដល់កថាខណ្ឌ ៤២៧១ យោងដល់កថាខណ្ឌ ៣៣៩០ និងកំណត់សម្គាល់ជើងទំព័រលេខ១១៤៣៧ "ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ (ឯក ហេន) ឯកសារ **E1/217.1** ទំព័រ ៣៤, ៣៦ និង ៤០។ អង្គជំនុំជម្រះកត់សម្គាល់ថា ឯក ហេន បានផ្តល់សក្ខីកម្មថា មាន "តែខ្មែរ អត់មានយួនទេ" នៅក្នុងប្រទេសកម្ពុជានៅពេលនោះ។ អង្គជំនុំជម្រះក៏បានរំឭកឡើងវិញផងដែរថា វគ្គបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើង បន្ទាប់ពី ប៉ង់ ត្រូវបានចោទប្រកាន់ (គាត់ត្រូវបានចាប់ខ្លួននៅក្នុង ឬប្រហែលខែមេសា ឆ្នាំ១៩៧៨)។ សូមមើលផងដែរ ប្រតិចារឹកនៃបទសម្ភាសន៍របស់ នៅ សារឹម ដោយវិទ្យុសំឡេងសហរដ្ឋអាមេរិក ឯកសារ **E3/6934** ទំព័រ ១២, ១៩ និង ១៩៦ ERN 01326470, 01326477, 01326654 (នៅ សារឹម បានវិលត្រឡប់ពីប្រទេសបារាំងមកកាន់ប្រទេសកម្ពុជា នៅដើមឆ្នាំ១៩៧៦។ នៅពេលមកដល់ គាត់បានចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានខ្មែរ-សូវៀត ក្នុងទីក្រុងភ្នំពេញ រួមជាមួយនឹងអ្នកវិលត្រឡប់មកប្រទេសកម្ពុជាវិញផ្សេងៗទៀត។ ខៀវ សំផន បានមកបង្រៀនពួកគេ ហើយប្រាប់ពួកគេថា "ប្រជាជនទាំងឡាយរស់នៅក្នុងប្រទេសកម្ពុជា ត្រូវធ្វើស្រែ តែអ្នកដែលមិនចេះធ្វើស្រែ ជាពិសេស ជនជាតិវៀតណាម ត្រូវបញ្ជូនទៅវៀតណាមវិញ។ ហេតុដូច្នេះ ខ្មែរក្រហមបានរៀបចំគម្រោងការបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ")។

[3672] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៩។

អាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីភស្តុតាងអំពីអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទបាននោះទេ[3673]។ ម្យ៉ាងទៀត អង្គជំនុំជម្រះពុំបានពន្យល់ថា តើខ្លឹមសារនៃកិច្ចសម្ភាសន៍នេះមានសក្តានុពលអាចបញ្ជាក់បន្ថែមលើសក្ខីកម្មរបស់ ឯក ហេន បានដោយរបៀបណា ដោយហេតុថា វាបានលើកឡើងថា វគ្គអប់រំដែល ឯក ហេន បានចូលរួម គឺធ្វើឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៨[3674] និងវគ្គអប់រំដែល នៅ សារីម បានចូលរួម គឺនៅចុងឆ្នាំ១៩៧៦[3675]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានដោយផ្អែកលើមូលដ្ឋានភស្តុតាងទាំងនេះថា សម្តីរបស់ ខៀវ សំផន "ឆ្លុះបញ្ចាំងអំពីខ្លឹមសារសំខាន់ បែបបទ និងការអនុវត្តចុងក្រោយ នៃគោលបំណងរួមស្តីពីការនិរទេសប្រជាជនវៀតណាមទាំងអស់ឆ្លងកាត់ព្រំដែន នៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦" បាននោះទេ[3676]។ លើសពីនេះទៀត ការយល់ឃើញថាសម្តីរបស់ម្ចាស់បណ្តឹងសាទុក្ខ ឆ្លុះបញ្ចាំងពីផែនការរួមក្នុងការនិរទេសជនជាតិវៀតណាម មិនបានអនុញ្ញាតឱ្យអង្គជំនុំជម្រះបង្ហាញឱ្យឃើញពីការដឹងឮរបស់គាត់ថា ជនជាតិវៀតណាមនៅក្នុងស្រុកត្រាំកក់ ត្រូវបាននិរទេសនៅចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦ និងចេញពីខេត្តព្រៃវែងនៅឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ នោះទេ។ ដោយសារពុំមានភស្តុតាង អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា ខៀវ សំផន បានដឹងថាឧក្រិដ្ឋកម្មនៃការនិរទេស ត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បាននោះទេ។ សេចក្តីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ។

### *២.២.១.២. កំហុសពាក់ព័ន្ធនឹងសម្តីបែបសន្ធូតជំរុញឱ្យមានការស្អប់ខ្ពើម*

១៨៩៥. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយយល់ឃើញថា ខៀវ សំផន "បានជំរុញប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យឱ្យ "ស្អប់យួនកាន់តែខ្លាំងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ" ហើយបានលើកទឹកចិត្តឱ្យមានការប្រុងប្រយ័ត្ន និង "កំហឹង" ប្រឆាំងនឹងខ្មាំងវៀតណាម" និងដោយបានអះអាង

---

[3673] សំណើ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ **F51** កថាខណ្ឌ ៣០-៣៤ និងកថាខណ្ឌ ៤១-៤៤។ សូមមើលផងដែរ សំអាងហេតុសាលក្រម កថាខណ្ឌ ៧១-៧២។

[3674] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧២។

[3675] ប្រតិចារឹកនៃបទសម្ភាសន៍របស់ នៅ សារីម ដោយវិទ្យុសំឡេងសហរដ្ឋអាមេរិក ឯកសារ **E3/6934** ERN 01326470, 01326477, 01326654។

[3676] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៧។

ថា គាត់បានអំពាវនាវជាមួយមេដឹកនាំផ្សេងៗទៀតឱ្យបណ្តេញចេញ សម្លាប់ឱ្យផុតពូជ និងកម្ទេចជនជាតិវៀតណាម ហើយដើម្បី "ការពារពូជសាសន៍ខ្មែរ" ខៀវ សំផន បានអំពាវនាវឱ្យកម្ពុជាប្រជាធិបតេយ្យ "ស្អាតជាអចិន្ត្រៃយ៍" "អត់មាន" វៀតណាម"[3677]។ ជាបឋម ការអះអាងដែលលើកឡើងថា "ខៀវ សំផន បានអំពាវនាវឱ្យកម្ពុជាប្រជាធិបតេយ្យ "ស្អាតជាអចិន្ត្រៃយ៍" "អត់មាន" វៀតណាម" គឺមិនត្រឹមត្រូវនោះទេ។ ការរៀបរាប់នេះ គឺបានមកពីទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ ១៩៧៧ ដែលត្រូវបានយោងនៅក្នុងកថាខណ្ឌ ៣៤០៧ នៃសំអាងហេតុសាលក្រម[3678]។ ដូច្នេះ ពាក្យសម្តីទាំងនេះ គឺមិនត្រូវបាននិយាយដោយ ខៀវ សំផន ទេ។ សេចក្តីកត់សម្គាល់នេះ ត្រូវកែសម្រួល។

១៨៩៦. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា សម្តីរបស់ ខៀវ សំផន "ជារឿយៗធ្វើការជ្រើសរើសសំដៅរើសអើងប្រជាជនវៀតណាមជារួម"[3679]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះពុំបានភ្ជាប់ទំនាក់ទំនងណាមួយរវាងពាក្យសម្តីទាំងនេះ ជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាម នៅវត្តខ្សាច់ ឬនៅខេត្តក្រចេះ ជាដើម ហើយមិនអាចឱ្យកំណត់បានថាតើ ខៀវ សំផន ពិតជាបានដឹងអំពីឧក្រិដ្ឋកម្មទាំងអស់នោះដែរ ឬយ៉ាងណា។ ជាពិសេស គេគួររំឭកថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានច្របល់បញ្ចូលគ្នារវាងរដ្ឋវៀតណាមជាសត្រូវ ជាមួយនឹងប្រជាជនវៀតណាមដែលរស់ក្នុងប្រទេសកម្ពុជា[3680]។

១៨៩៧. មុននឹងយកចិត្តទុកដាក់ពិនិត្យមើលខ្លឹមសារនៃសម្តី និងបុគ្គលនានាដែលសម្តីទាំងនោះសំដៅទៅរក គេគួរពិនិត្យលើប្រភេទឯកសារដែលអង្គជំនុំជម្រះបានយកមកធ្វើជាមូលដ្ឋានដើម្បីចាត់ទុកថា ខៀវ សំផន ជាអ្នកនិយាយសម្តីទាំងអស់នោះ។ អង្គជំនុំជម្រះបានយោងជាពិសេសទៅលើកថាខណ្ឌ ៣៤០៦ និង ៣៤០៧ នៃសំអាងហេតុសាលក្រម និងជាលក្ខណៈទូទៅ ទៅលើកថាខណ្ឌ ៣៤១៦ ដែលស្របគ្នានឹងសេចក្តីសន្និដ្ឋានស្តីពីអត្ថិភាពនៃគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាម។

---

[3677] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨។

[3678] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៧ កំណត់សម្គាល់ជើងទំព័រលេខ ១១៥០៣ យោងដល់កំណត់សម្គាល់ជើងទំព័រលេខ ១១៤៩៨ ដកស្រង់ទស្សនាវដ្តី "ទង់បដិវត្ត" ចេញផ្សាយខែមេសា ឆ្នាំ១៩៧៧ ឯកសារ **E3/742** ERN 00062993។

[3679] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨។

[3680] សូមមើលខាងលើ កថាខណ្ឌ ១០៥៨-១០៩៧ កថាខណ្ឌ ១៥៥១-១៥៦០។

***<u>សុន្ទរកថាក្នុងឆ្នាំ១៩៧៨ និងឆ្នាំ១៩៧៩</u>***

១៨៩៨. នៅត្រង់កថាខណ្ឌ ៣៤០៦ អង្គជំនុំជម្រះបានយោងនៅក្នុងកំណត់សម្គាល់ជើងទំព័រ ១១៤៨៤ ទៅលើឯកសារចំនួនបួន ដែលផ្ទុកទៅដោយការកត់ត្រាឡើងវិញនូវសុន្ទរកថារបស់ ខៀវ សំផន ដោយរបាយការណ៍បរទេស[3681]។ អង្គជំនុំជម្រះមិនបានបញ្ជាក់ទេ តែគេឃើញច្បាស់ថា ឯកសារពីរក្នុងចំណោមឯកសារទាំងនោះ គឺកត់ត្រាឡើងវិញនូវសុន្ទរកថាដដែលតែមួយ ដែល ខៀវ សំផន បានថ្លែងនៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៧៨ ក្នុងឱកាសជួបជុំមហាជននៅភ្នំពេញ ដើម្បីប្រារព្ធខួបលើកទី៣ ថ្ងៃជ័យជម្នះ ១៧ មេសា។ ម្យ៉ាង វាជាសេចក្តីដកស្រង់នៃខ្សែអាត់សំឡេងនៃសុន្ទរកថារបស់ ខៀវ សំផន នៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៧៨ កត់ត្រាឡើងវិញនៅក្នុងកម្រងសារព័ត៌មាន SWB ឯកសារ **E3/562** និងម្យ៉ាងទៀត វាជាការកត់ត្រាឡើងវិញនូវសុន្ទរកថាដដែលតែមួយ នៅក្នុងកម្រងឯកសារផ្សព្វផ្សាយដោយគណៈកម្មាធិការអ្នកស្នេហាជាតិកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសបារាំង ឯកសារ **E3/169**។ ការអានឯកសារទាំងពីរនេះ បង្ហាញឱ្យឃើញពី កង្វះភាពជឿទុកចិត្តបាន ដែលត្រូវផ្តល់ទៅឱ្យការកត់ត្រាឡើងវិញទាំងនេះ ដែលបានមកពីកម្រងសារព័ត៌មានបរទេស ដូចជា SWB, FBIS ឬទស្សនាវដ្តីបារាំងនានា។ ខណៈដែលវាជាសុន្ទរកថាតែមួយដូចគ្នា ពាក្យពេចន៍ដែលត្រូវបានកត់ត្រាឡើងវិញ ក៏ដូចជាផ្នែកមួយចំនួននៃសុន្ទរកថា គឺមិនស៊ីគ្នាទាល់តែសោះ។ សូមលើកឧទាហរណ៍តែមួយមកបញ្ជាក់នោះ គឺថាក្នុងការកត់ត្រាឡើងវិញដោយកម្រងឯកសារផ្សព្វផ្សាយដោយគណៈកម្មាធិការអណិកជនស្នេហាជាតិកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសបារាំង គេរកមិនឃើញទាល់តែសោះនូវសម្តីដែលត្រូវ

[3681] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៦ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៨៤ ដកស្រង់ឯកសារដូចតទៅ៖ ឯកសារកម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា៖ “ជយោ! ខួបលើកទី ៣ នៃមហាជ័យជម្នះ ១៧ មេសា និងកំណើតកម្ពុជាប្រជាធិបតេយ្យ - សុន្ទរកថារបស់សមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ” ឯកសារ **E3/169** ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨, មិទ្ទីងនៅទីក្រុងភ្នំពេញដើម្បីប្រារព្ធខួបជ័យជម្នះ ១៧ មេសា៖ អត្ថបទដកស្រង់ចេញពីខ្សែអាត់សំឡេងនៃសុន្ទរកថារបស់ ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងមិទ្ទីង (កម្រងឯកសារ SWB/FE/5791/B) ឯកសារ **E3/562** ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨, សម្តេច សីហនុ ខៀវ សំផន ថ្លែងសុន្ទរកថា នៅក្នុងពិធីជប់លៀងបក្សកុម្មុយនីស្តកម្ពុជា (កម្រងឯកសារ FBIS) ឯកសារ **E3/294** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៨, កិច្ចប្រជុំកងទ័ពគាំទ្រសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលស្តីពីការឈ្លានពានរបស់កងទ័ពសង្គមនិយមវៀតណាម (កម្រងឯកសារ FBIS) ឯកសារ **E3/296** ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៩។

កត់ត្រាឡើងវិញនៅក្នុងកម្រងសារព័ត៌មាន SWB ដូចជា "កម្ទេចឱ្យអស់រាល់បណ្ដាភ្នាក់ងារពួកឈ្លានពាន ពួកវាតទីនិយមវៀតណាមសាហាវព្រៃផ្សៃ ដែលមាននៅក្នុងអង្គភាព ព្រមទាំងទឹកដីប្រទេសកម្ពុជាយើង"[3682]។ ពាក្យពេចន៍ទាំងអស់នេះ ត្រូវបានយោងដោយអង្គជំនុំជម្រះ ធ្វើដូចជា ខៀវ សំផន បាននិយាយពាក្យសម្ដីទាំងនេះពិតប្រាកដមែន[3683]។

១៨៩៩. ដូច្នេះ វាមិនសមហេតុសមផលទេដែលត្រូវសំអាងលើភ័ស្តុតាងនេះ។ កម្រងសារព័ត៌មាន FBIS និង SWB ក៏ដូចជាកម្រងឯកសារផ្សព្វផ្សាយដោយគណៈកម្មាធិការអ្នកស្នេហាជាតិកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសបារាំង គឺសុទ្ធតែជារបាយការណ៍បរទេសដែលបកប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេស ឬទៅជាភាសាបារាំង នូវសុន្ទរកថានានារបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ ម្យ៉ាងទៀត ជារឿយៗវាគ្រាន់តែជាការសរសេរឡើងវិញដោយផ្នែកៗ នូវសុន្ទរកថាដែលមិនអាចឱ្យគេទទួលបាននូវពាក្យពេចន៍ទាំងស្រុង ក្នុងបរិបទរបស់វានោះបានទេ[3684]។ ដូច្នេះ វាច្បាស់ណាស់ថា ឯកសារទាំងនេះ គឺអាចទទួលបានតម្លៃជាភ័ស្តុតាងតិចតួចតែប៉ុណ្ណោះ។ បើមើលតាមការបង្ហាញឱ្យឃើញពីភាពខុសគ្នាដែលលើកឡើងសម្រាប់ឯកសារពីរក្នុងចំណោមឯកសារទាំងនេះ ដែលកត់ត្រាឡើងវិញនូវសុន្ទរកថាតែមួយដូចគ្នា ឯកសារទាំងនោះក៏មិនអាចត្រូវប្រើប្រាស់ក្នុងគោលបំណងធ្វើការបញ្ជាក់បន្ថែមបានដែរ[3685]។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនគួរសំអាងលើឯកសារទាំងនេះដើម្បីបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន ថាឧក្រិដ្ឋកម្មលើជនជាតិវៀតណាមត្រូវបានប្រព្រឹត្តនោះទេ។ ដូច្នេះ សេចក្ដីកត់សម្គាល់របស់អង្គជំនុំជម្រះនៅក្នុងកថាខណ្ឌ ៣៤០៦ ដែលថា "ខៀវ សំផន បានបន្តសង្កត់ធ្ងន់ពីសារៈសំខាន់នៃការការពារ និងថែរក្សាជោគជ័យនៃបដិវត្តន៍ និង "ពូជសាសន៍កម្ពុជា" ពីវៀតណាម "វាតទីនិយម" និង "ទេសានុពន្ធន៍និយម"" ត្រូវទុកជាមោឃៈ ពីព្រោះវាមិនអាចបង្ហាញឱ្យហួសពីវិមតិសង្ស័យ។

---

[3682] អត្ថបទដកស្រង់ចេញពីខ្សែអាត់សំឡេងនៃសុន្ទរកថារបស់ ខៀវ សំផន (កម្រងឯកសារ SWB) ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/562** ERN 00249989-00249990។

[3683] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨ និង ៤២៩៣ យោងដល់កថាខណ្ឌ ៤២៣៨។

[3684] សូមមើល ឧទាហរណ៍ អត្ថបទដកស្រង់ចេញពីខ្សែអាត់សំឡេងនៃសុន្ទរកថារបស់ ខៀវ សំផន (កម្រងឯកសារ SWB) ចុះថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/562** ERN EN S00010558 "ដកស្រង់ចេញពីខ្សែអាត់សំឡេងនៃសុន្ទរកថារបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3685] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

១៩០០. ទោះយ៉ាងណាក៏ដោយ បើទោះជាខ្លឹមសារទូទៅនៃសុន្ទរកថា - ដោយសារពុំមានពាក្យពេចន៍ច្បាស់លាស់ - ត្រូវបានទទួលស្គាល់ក៏ដោយ ក៏គេគួររំឭកថា សុន្ទរកថាទាំងនេះត្រូវបានថ្លែងនៅចន្លោះខែមេសា ឆ្នាំ១៩៧៨ ដល់ខែមករា ឆ្នាំ១៩៧៩។ ដូច្នេះ វាបានកើតឡើងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ និងជាពិសេសទៀតនោះ គឺក្រោយការឈ្លានពានយោធាទ្រង់ទ្រាយធំចំនួនពីរលើករបស់វៀតណាម។ ពាក្យពេចន៍ទាំងឡាយដែលត្រូវបានយោងដោយអង្គជំនុំជម្រះ គឺផ្ទុះបញ្ជាំងយ៉ាងច្បាស់ថាជាសារឃោសនា[3686]។ ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន បាននិយាយទៅដល់ការការពារជាតិប្រឆាំងនឹងវៀតណាម ក្នុងនាមជាប្រទេសសត្រូវ។ គេមិនអាចចាត់ទុកបានជាដាច់ខាតថា ពាក្យពេចន៍ទាំងនេះសំដៅទៅលើប្រជាជនវៀតណាម លើកលែងតែចង់បំភ្លៃវា។ នេះជាអ្វីដែលអង្គជំនុំជម្រះបានធ្វើ ដោយបានដកចេញជាស្វ័យប្រវត្តិនូវសម្តីថា "ពូជសាសន៍ខ្មែរ" ខណៈដែលសុន្ទរកថាទាំងអស់នោះបើអានទាំងស្រុងវិញ គឺជាការអំពាវនាវឱ្យមានការសាមគ្គីភាពជាតិ និងការរួបរួមប្រជាជនកម្ពុជាប្រឈមមុខនឹងបរិបទដ៏លំបាក។ ម្យ៉ាងទៀត អង្គជំនុំជម្រះមិនបានពន្យល់ថា តើការចង់រក្សា "ពូជសាសន៍ខ្មែរ" អាចឱ្យគេសន្និដ្ឋានបានពីការដឹងឮរបស់ ខៀវ សំផន ថាឧក្រិដ្ឋកម្មលើជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាត្រូវបានប្រព្រឹត្តបានដោយរបៀបណា[3687]។ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចសន្និដ្ឋានបានថា ពាក្យសម្តីរបស់ ខៀវ សំផន សំដៅទៅលើជនជាតិវៀតណាម ព្រោះថាអង្គជំនុំជម្រះក៏បានយោងផងដែរទៅសម្តីវាយការណ៍ដោយ ឯក ហេន[3688] ដែលសម្តីទាំងនោះមិនអាចបង្ហាញឱ្យឃើញពីការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខថា ឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្តលើ ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជានោះទេ[3689]។

***<u>កំហុសពាក់ព័ន្ធនឹងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក</u>***

[3686] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

[3687] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨។

[3688] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០៦ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៨៤។

[3689] សូមមើលខាងលើ កថាខណ្ឌ ១៨៩១-១៨៩៤។ សូមមើលផងដែរ សំណើ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ **F51** កថាខណ្ឌ ២០-២៨។

១៩០១. អង្គជំនុំជម្រះបានយោងផងដែរទៅលើកថាខណ្ឌ ៣៩០៧ នៃសំអាងហេតុសាលក្រម ដើម្បីគាំទ្រថា មានការដឹងឮរបស់ ខៀវ សំផន[3690]។ ក៏ប៉ុន្តែ កថាខណ្ឌនេះនិយាយពី ឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក ចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ ជាពិសេស ទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដី យុវជន និង យុវនារីបដិវត្ត ដែលមិនត្រូវបានសរសេរ ដោយ ខៀវ សំផន និងមិនអាចប្រើធ្វើជាមូលដ្ឋានដើម្បី កំណត់លក្ខណៈអំពីសម្ដីរបស់ គាត់បានទេ។ ម្យ៉ាងទៀត គ្មានភស្តុតាងណាមួយអាចឱ្យគេនិយាយបាន ថា ខៀវ សំផន បានទទួលទស្សនាវដ្ដីទាំងនេះ ហើយជាពិសេសនោះ ថាគាត់បានអានទស្សនាវដ្ដីទាំង នោះគ្រប់ច្បាប់នោះដែរ[3691]។ ជាចុងក្រោយ អង្គជំនុំជម្រះបានបំភ្លៃអត្ថន័យនៃឯកសារ ទាំងនោះ ដោយ មិនបានពិចារណាឱ្យបានគ្រប់គ្រាន់អំពីផ្នែកឃោសនាដែលមាននៅ ក្នុងឯកសារបោះពុម្ពទាំងនេះ[3692]។ របៀបដែលអង្គជំនុំជម្រះបំបែកគុណនាមសម្រាប់ បន្ទុះបង្អាប់ឱ្យដាច់ចេញពីគ្នា មុននឹងយកមកផ្គុំឱ្យ ចេញជាដុំៗ គឺកើតចេញមកពីការ បំភ្លៃភស្តុតាង។ វាច្បាស់ណាស់ថា បើអាននៅក្នុងបរិបទរបស់វា ពាក្យពេចន៍ទាំងនេះគឺ សំដៅទៅលើខ្មាំងវៀតណាម ក្នុងឋានៈជារដ្ឋ ឬជាភ្នាក់ងាររបស់ជនជាតិវៀត ណាម ដូចដែលបានឃើញថាជាពួកកម្មាភិបាល ឬសមាជិកបក្សដែលត្រូវចោទថាមានទំនាក់ ទំនងជា មួយប្រទេសវៀតណាម[3693]។ វាមិនសមហេតុសមផលនោះទេដែលយល់ថា ពាក្យពេចន៍ទាំងនេះ សំដៅចំពោះជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា។

១៩០២. បន្ទាប់មក អង្គជំនុំជម្រះបានយោងទៅលើកថាខណ្ឌ ៣៩១៦ ដែលជាសេចក្ដីសន្និដ្ឋានអំពីអត្ថិភាពនៃ គោលនយោបាយចំពោះជនជាតិវៀតណាម។ ប៉ុន្តែ សេចក្ដីសន្និដ្ឋាននេះ ពុំត្រឹមត្រូវនោះទេ ពីព្រោះភស្តុ តាងមិនអាចបង្ហាញឱ្យឃើញពីគោលនយោបាយដឹកនាំធ្វើប្រឆាំងនឹងជនជាតិវៀតណាម នៅប្រទេស កម្ពុជាទេ[3694]។ ម្យ៉ាងទៀត សុន្ទរកថាទាំងឡាយរបស់ ខៀវ សំផន ដែលអង្គជំនុំជម្រះបានយោង ដើម្បី

[3690] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨២៩។

[3691] សូមមើលខាងលើ កថាខណ្ឌ ១៦១៦-១៦៨៩។

[3692] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

[3693] សូមមើលខាងលើ កថាខណ្ឌ ១០៥៨-១០៩៧ កថាខណ្ឌ ១៥៥១-១៥៦០។

[3694] សូមមើលខាងលើ កថាខណ្ឌ ១៥៥១-១៥៦០។

គាំទ្រថាមានគោលនយោបាយនេះ គឺបានមកជាប្រព័ន្ធពីកម្រងសារព័ត៌មាន SWB ឬ FBIS[3695]។ កង្វះភាពជឿទុកចិត្តបាននៃឯកសារទាំងនេះ គួរណានាំអង្គជំនុំជម្រះឱ្យដកវាចេញ ដូចគ្នានឹងសៀវភៅរបស់ សម្តេច នរោត្តម សីហនុ ដែរ[3696]។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចសំអាងលើសុន្ទរកថាដើមណាមួយរបស់ ខៀវ សំផន ដោយសារថាការកត់ត្រាឡើងវិញដែលត្រូវបានប្រើប្រាស់ គឺមិនអាចទុកចិត្តបាន។ ពាក់ព័ន្ធនឹងភ័ស្តុតាង ដែលអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានថាមានការដឹងឮរបស់ ខៀវ សំផន ថាឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា សេចក្តីសន្និដ្ឋានទាំងឡាយរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

១៩០៣. ក៏ប៉ុន្តែ ប្រសិនបើត្រូវសន្មតថា ខៀវ សំផន ពិតជាបាននិយាយសម្តីទាំងនេះមែនក៏ដោយ ក៏ខ្លឹមសារសម្តីទាំងនោះមិនអាចឱ្យសន្និដ្ឋានបានថាជនជាតិវៀតណាមត្រូវបានកំណត់ជាគោលដៅបានដែរ។ អង្គជំនុំជម្រះមិនធ្លាប់បានភ្ជាប់ទំនាក់ទំនងរវាងសុន្ទរកថាទាំងនេះ ជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាមនោះទេ។ ដូច្នេះ វាមិនសមហេតុសមផលទេដែលសន្និដ្ឋានថា ខៀវ សំផន បានដឹងពីការសម្លាប់ជនជាតិវៀតណាមនៅខេត្តស្វាយរៀង ឬនៅវត្តខ្សាច់ ជាដើមនោះ។ ហេតុដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងការដឹងបែបសន្មតរបស់ ខៀវ សំផន អំពីធាតុផ្សំជាទូទៅបែបនេះ ត្រូវទុកជាមោឃៈ[3697]។ គេនឹងឃើញនៅផ្នែកខាងក្រោមថា[3698] សេចក្តីសន្និដ្ឋាននេះគឺជាកត្តាកំណត់របស់អង្គជំនុំជម្រះ ដើម្បីសន្និដ្ឋានថាម្ចាស់បណ្តឹងសាទុក្ខមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិវៀតណាម។ ហេតុដូច្នេះ អង្គជំនុំជម្រះក៏មិនអាចសន្និដ្ឋានថា ខៀវ សំផន បានប្រព្រឹត្ត [ឧក្រិដ្ឋ

---

[3695] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩៣ ដកស្រង់ "សុន្ទរកថារបស់ ខៀវ សំផន ក្នុងមិទ្ទីងរំឭកខួប" (កម្រងឯកសារ SWB/FE/5490/C) ឯកសារ **E3/200** ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧, កថាខណ្ឌ ៣៣៩៩ ដកស្រង់មិទ្ទីងនៅទីក្រុងភ្នំពេញដើម្បីប្រារព្ធខួបជ័យជម្នះ ១៧ មេសា (កម្រងឯកសារ SWB/FE/5791/B) ឯកសារ **E3/562** ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨, កថាខណ្ឌ ៣៤០០ ដកស្រង់ឯកសារកម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា៖ "ជយោ! ខួបលើកទី ៣ នៃមហាជ័យជម្នះ ១៧ មេសា និងកំណើតកម្ពុជាប្រជាធិបតេយ្យ - សុន្ទរកថារបស់សមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ" ឯកសារ **E3/169** ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨។

[3696] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៤០១។

[3697] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៩។

[3698] សូមមើលខាងក្រោម កថាខណ្ឌ ២០៧៥-២០៩០។

កម្ម] ដោយសារតែគាត់បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងដោយសារការចូលរួមរបស់គាត់ទៅក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បាននោះទេ[3699]។

### *២.២.៣. កំហុសពាក់ព័ន្ធនឹងការដឹងឮរបស់ ខៀវ សំផន អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មលើជនជាតិវៀតណាមនៅ ស-២១*

១៩០៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយយល់ថា ខៀវ សំផន "បានដឹងអំពីឋានៈដែលត្រូវទទួលបានការពាររបស់ជនជាប់ឃុំជាជនជាតិវៀតណាមនៅមន្ទីរសន្តិសុខ ស-២១ ហើយបានដឹងអំពីការធ្វើបាបពួកគេ"[3700]។ បើតាមអង្គជំនុំជម្រះ ខៀវ សំផន បានដឹងអំពីឋានៈជាជនដែលត្រូវបានទទួលការការពាររបស់ជនជាតិវៀតណាមនៅ ស-២១ និងការធ្វើបាបលើពួកគេ ដោយសារគាត់មានឋានៈជាសមាជិកមន្ទីរ ៨៧០ និង "មុខតំណែងពិសេសនៅក្នុងជួរបក្ស"[3701]។ ការអះអាងនេះមិនត្រឹមតែពុំត្រឹមត្រូវប៉ុណ្ណោះទេ[3702] តែជាងនេះទៅទៀតនោះ វាថែមទាំងពុំមែនជាសេចក្តីសន្និដ្ឋានតែមួយគត់ដែលអាចមាននោះទេ។ អង្គជំនុំជម្រះធ្វើមិនដឹងពីគោលការណ៍រក្សាការសម្ងាត់ដែលត្រូវអនុវត្តចំពោះសមាជិកបក្សទាំងអស់[3703]។ អនុលោមតាមគោលការណ៍នេះ កម្មាភិបាលប.ក.ក ដែលក្នុងនោះមាន ខៀវ សំផន ដែរ ពុំបានដឹងអំពីសេចក្តីលម្អិតពាក់ព័ន្ធនឹងការចាត់តាំងក្នុងបក្សនោះទេ។ ម្យ៉ាងទៀតពួកគេមិនតម្រូវឱ្យដឹងពីកិច្ចការដែលមិនមែនជារបស់ខ្លួននោះទេ។

---

[3699] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[3700] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៩។ ការយោងទៅផ្នែក ៤.១ ហាក់ដូចជាមិនត្រឹមត្រូវ ហើយអង្គជំនុំជម្រះគួរណាតែយោងទៅផ្នែក ៤.៣.២.៤ "ការដឹងឮរបស់ជនជាប់ចោទ"។

[3701] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០។

[3702] សូមមើលខាងលើ កថាខណ្ឌ ១៧០៤-១៧៥៣។ សូមមើលផងដែរ កថាខណ្ឌ ៦០៣-៦០៤ នៃសំអាងហេតុសាលក្រម។

[3703] សូមមើលខាងលើ កថាខណ្ឌ ១៦៥០-១៦៥១។

១៩០៥. ស-២១ គឺជាមន្ទីរសន្តិសុខស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់សេនាធិការ[3704]។ ក៏ប៉ុន្តែ ខៀវ សំផន គ្មានការទទួលខុសត្រូវផ្នែកយោធានោះទេ[3705]។ម្យ៉ាងទៀត សាក្សីទាំងអស់ដែលធ្លាប់ធ្វើការនៅ ស-២១ បានពន្យល់ថា វាជាកន្លែងស្ថិតក្រោមការការពារសន្តិសុខខ្ពស់បំផុត។ របងពីរជាន់ គឺអាចឱ្យគេការពារបរិវេណនោះបាន[3706] ហើយមានច្រកចូលតែមួយប៉ុណ្ណោះ ដែលការពារដោយកងសន្តិសុខ ហើយគឺមានតែយានជំនិះរបស់ ស-២១ ប៉ុណ្ណោះ ដែលអនុញ្ញាតឱ្យចូលតាមច្រកនោះបាន[3707]។ ឌុច បានបញ្ជាក់ថា៖ "[...] ទាក់ទងពីក្រៅក៏មិនបានទាក់ទង អាអ្នកពីក្រៅទៅទាក់ទងក៏អត់។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង សន្តិសុខសុវត្ថិភាពរបស់ ស-២១ វាការពារដោយមធ្យោបាយបែបនេះ"។ សាក្សីមួយចំនួន ដែលជាអ្នកយាមនៅ ស-២១ បានបញ្ជាក់ផងដែរថា ពួកគេគ្មានសិទ្ធិទាក់ទងជាមួយអ្នកពីខាងក្រៅ។ ការរក្សាការសម្ងាត់ ក៏តឹងតែងផងដែរ ពាក់ព័ន្ធនឹងការសួរចម្លើយ[3708]។ ឯកសារទាំងឡាយធ្វើ

---

[3704] ឌុច៖ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/440.1** ទំព័រ ៣១ ប្រហែលម៉ោង 11.13.20, កិច្ចសម្ភាសន៍របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ជាមួយ ឌុច ចុះថ្ងៃទី ០៤-០៥ ខែឧសភា ឆ្នាំ១៩៩៩ ឯកសារ **E3/347** ERN EN 00025523។

[3705] សូមមើលខាងលើ កថាខណ្ឌ ១៦៤៤-១៦៤៩។

[3706] តយ តេង៖ ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ឯកសារ **E1/420.1** ទំព័រ ៦២ មុនម៉ោង 14.01.38, ឡាច មាន៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ឯកសារ **E1/422.1** ទំព័រ ៤៣-៤៤ ចន្លោះម៉ោង 13.48.18 និងម៉ោង 13.54.21, ប្រាក់ ខន៖ ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/425.1** ទំព័រ ២៤-២៥ ចន្លោះម៉ោង 10.38.07 និងម៉ោង 10.40.58, ហ៊ឹម ហ៊ុយ៖ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/428.1** ទំព័រ ៦៩-៧០ ចន្លោះម៉ោង 15.13.11 និងម៉ោង 15.20.08, សួស ធី៖ ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/430.1** ទំព័រ ២៦-២៧ ក្រោយម៉ោង 10.53.05, ឌុច៖ ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ទំព័រ ៤-៩ ចន្លោះម៉ោង 09.07.58 និងម៉ោង 09.25.32។

[3707] ប្រាក់ ខន៖ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ឯកសារ **E1/423.1** ទំព័រ ១១-១២ ចន្លោះម៉ោង 09.29.42 និងម៉ោង 09.36.03, ឌុច៖ ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ទំព័រ ៨ ប្រហែលម៉ោង 09.23.35, ហ៊ឹម ហ៊ុយ៖ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/428.1** ទំព័រ ១៨ ក្រោយម៉ោង 09.51.51 ទំព័រ ៧០-៧១ ចន្លោះម៉ោង 15.16.11 និងម៉ោង 15.22.58។

[3708] ឡាច មាន៖ ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ឯកសារ **E1/422.1** ទំព័រ ៤៥ ក្រោយម៉ោង 13.54.21, ប្រាក់ ខន៖ ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/425.1** ទំព័រ ២៧-២៨ ចន្លោះម៉ោង 10.46.33 និងម៉ោង 10.51.23, ហ៊ឹម ហ៊ុយ៖ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/428.1** ទំព័រ ៦២-៦៣ ចន្លោះម៉ោង 14.30.56 និងម៉ោង 14.33.18, ឌុច៖ ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ទំព័រ ៩ ក្រោយម៉ោង 09.25.32 ទំព័រ ៥១ ប្រហែលម៉ោង 14.19.29។

នៅ ស-២១ គឺចរាចរទៅតាមខ្សែបញ្ជាយ៉ាងតឹងរ៉ឹងបំផុត[3709]។ យោងតាមសន្និសុខជុំវិញ ស-២១ និង ការបញ្ជាផ្នែកយោធានៃមន្ទីរនេះ គ្មានចៅក្រមមានវិចារណញ្ញាណណាមួយអាចសន្និដ្ឋានបានថា ខៀវ សំផន ដឹងអំពីការធ្វើបាបលើអ្នកជាប់ឃុំជាជនជាតិវៀតណាមនៅ ស-២១ បាននោះទេ។

១៩០៦. អង្គជំនុំជម្រះក៏មិនអាចសំអាងលើជំនួបខ្លីរវាង ខៀវ សំផន និង ឌុច នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីយល់ថា គាត់បានដឹងអំពីការធ្វើបាបជនជាតិវៀតណាមនៅ ស-២១ បាននោះដែរ[3710]។ អង្គជំនុំជម្រះធ្លាប់បានគូសបញ្ជាក់ពីរឿងនេះរួចមកហើយ ឯ ឌុច បាននិយាយជាន់កែងខ្លួនឯងនៅក្នុងចម្លើយរបស់គាត់ ទាក់ទងនឹង ខៀវ សំផន[3711]។ នៅចំពោះមុខតុលាការយោធាកម្ពុជា នៅឆ្នាំ២០០២ ឌុច បានអះអាងថាគាត់មិនដែលបានជួប ខៀវ សំផន ទេ៖ "ចំណែក ខៀវ សំផន និង អៀង សារី វិញ រហូតមកដល់ថ្ងៃនេះ ពុំមានបានជួបមុខគ្នាម្ដងណាឡើយ"[3712]។ ផ្ទុយទៅវិញ នៅចម្លើយក្រោយៗមកទៀត គាត់បានបញ្ជាក់ថាបានជួប ខៀវ សំផន នៅពុទ្ធិកវិទ្យាល័យ ក្នុងអំឡុងកិច្ចប្រជុំមួយនាថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ភាពផ្ទុយគ្នាទាំងនេះ ចោទជាបញ្ហា ទាក់ទងនឹងភាពជឿជាក់បានរបស់ ឌុច ជាពិសេសក្រោយពីគាត់បានពន្យល់ក្នុងសវនាការថា គាត់នៅចងចាំបានល្អជាងនេះ នាពេលនោះ[3713]។ ការពន្យល់មិនច្បាស់លាស់ទាំងឡាយទាក់ទងនឹងខ្លឹមសារ "គួរឱ្យសង្ស័យ" នៃកំណត់ហេតុសួរចម្លើយរបស់គាត់នៅចំពោះមុខតុលាការយោធានៅក្នុងឆ្នាំ២០០២ ក៏ធ្វើឱ្យប៉ះពាល់ផងដែរដល់ភាពជឿជាក់បានរបស់សាក្សី[3714]។ ដូច្នេះ នៅក្នុងមន្ទិលបែបនេះ អង្គជំនុំជម្រះគួរណាដកចម្លើយរបស់គាត់ចេញ។

---

[3709] ហ៊ឹម ហ៊ុយ៖ ប្រតិចារឹក ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/428.1** ទំព័រ ៣៣ ចន្លោះម៉ោង 10.59.25 និងម៉ោង 11.01.09, ស្វួស ធី៖ ប្រតិចារឹក ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/430.1** ទំព័រ ៣០-៣១ ចន្លោះម៉ោង 11.09.10 និងម៉ោង 11.11.45 ទំព័រ ៣២ ក្រោយម៉ោង 11.14.09, ប្រតិចារឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/432.1** ទំព័រ ៧២-៧៣ ចន្លោះម៉ោង 15.40.25 និងម៉ោង 15.47.20, ឌុច៖ ប្រតិចារឹក ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/435.1** ទំព័រ ១២-១៣ ចន្លោះម៉ោង 09.41.06 និងម៉ោង 09.47.14, ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ទំព័រ ៣២ ចន្លោះម៉ោង 11.09.08។

[3710] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០។

[3711] សំអាងហេតុសាលក្រម កថាខណ្ឌ ២៥៥៧ កំណត់សម្គាល់ជើងទំព័រលេខ ៨៦៧៣។

[3712] កំណត់ហេតុសួរចម្លើយរបស់តុលាការយោធា ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០២ ឯកសារ **E3/530** ERN 00095691។

[3713] ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ចន្លោះម៉ោង 15.40.00 និងម៉ោង 15.53.10។

[3714] ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ **E1/442.1** ចន្លោះម៉ោង 15.40.00 និងម៉ោង 16.02.17។

១៩០៧. ទោះយ៉ាងណាក៏ដោយ បើទោះជាការប្រជុំនេះបានប្រព្រឹត្តទៅពិតមែនក៏ដោយចុះ ក៏វាមិនអាចបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន អំពីឋានៈជាជនទទួលបានការការពាររបស់ជនជាតិវៀតណាមជាប់ឃុំ និងការធ្វើបាបដែលពួកគេបានទទួលរងនោះដែរ។ បើយោងតាមចម្លើយថ្មីៗបំផុតរបស់ ឌុច ការប្រជុំបានធ្វើឡើងនៅក្រៅ ស-២១ គឺនៅពុទ្ធិកវិទ្យាល័យសុរាម្រិត។ បុគ្គលផ្សេងៗដែលនៅក្រៅ ស-២១ ក្នុងនោះមានប្រធានៗឃ្លាំងរដ្ឋ ក៏បានចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ[3715]។ ខៀវ សំផន បាននិយាយទៅកាន់មនុស្សប៉ុន្មាននាក់ដែលមានវត្តមាន និងមិនមែននិយាយដោយផ្ទាល់ទៅកាន់ ឌុច នោះទេ ដើម្បីពន្យល់ប្រាប់ពួកគេឱ្យបន្តធ្វើការងារ បើទោះជាវៀតណាមបានរុលចូលយ៉ាងណាក៏ដោយ។ ជំនួបរយៈពេលប៉ុន្មាននាទីនេះ[3716] គឺជាលើកទីមួយ និងជាពេលតែម្តងគត់ដែលសាក្សីបានជួប ខៀវ សំផន[3717]។ ឌុច ថែមទាំងបានបញ្ជាក់ពីការភ្ញាក់ផ្អើលរបស់គាត់ ដោយសារជាធម្មតា ពួកគាត់គ្មានសិទ្ធិជួបមុខគ្នាទេ៖

> "ខ្ញុំជួបគាត់តែមួយដងគត់។ ខ្ញុំមិនអស់ចិត្តនឹងការជួបជាមួយ ខៀវ សំផន ពិតមែន បានន័យថា ព្រោះខ្ញុំមិនមានសិទ្ធិទៅជួបគាត់ទេ ហើយគាត់ក៏មិនមានសិទ្ធិជួបខ្ញុំដែរ។ ហេតុអី ក៏គាត់មក។ ប៉ុន្តែ ខ្ញុំទទួលយកការណែនាំរបស់គាត់ទៅផ្សព្វផ្សាយបន្តនៅ ស-២១។ វាមិនមែនជាការជួបក្រៅផ្លូវការទេ"[3718]។

១៩០៨. ដូច្នេះ វាច្បាស់ណាស់ថា ខៀវ សំផន គ្មានទំនាក់ទំនងអ្វីឡើយជាមួយ ស-២១ ហើយគាត់ក៏មិនស្គាល់ ឌុច នៅសម័យកាលអង្គហេតុនោះដែរ។ គ្មានចៅក្រមមានវិចារណញ្ញាណណាមួយអាចទាញសេចក្តីសន្និដ្ឋានពីជំនួបនេះបានថា ម្ចាស់បណ្តឹងសាទុក្ខបានដឹងពី ស-២១ និងពីអ្វីដែលបានកើតឡើងនៅទីនោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចទាញសេចក្តីសន្និដ្ឋានចេញពីភស្តុតាងទាំងនេះថាមានការដឹងឮរបស់ ខៀវ សំផន អំពី ឋានៈជាជនទទួលបានការការពារនៃអ្នកជាប់ឃុំជនជាតិវៀតណាម និងការ

---

[3715] ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ **E1/437.1** ប្រហែលម៉ោង 09.34.11។

[3716] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ **E1/443.1** ប្រហែលម៉ោង 09.29.20។

[3717] ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ **E1/437.1** ប្រហែលម៉ោង 09.38.04។

[3718] កំណត់ហេតុស្តាប់ចម្លើយសាក្សី ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ឯកសារ **E3/452** ERN 00146551។

ធ្វើបាបលើពួកគេនោះបានទេ។ ជាចុងក្រោយ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសំអាងលើការផ្សព្វផ្សាយចម្លើយសារភាព រូបថត និងខ្សែភាពយន្តមួយស្តីពីឈ្លើយសឹកវៀតណាម ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីការធ្វើបាបលើពួកគេ[3719]។ ជាបឋម ពាក់ព័ន្ធនឹងខ្សែភាពយន្ត អង្គជំនុំជម្រះបានទទួលស្គាល់ថា វាត្រូវបានចាក់បញ្ចាំងឱ្យបុគ្គលិក ស-២១ មើល ក្នុងអំឡុងវគ្គរៀនសូត្រមួយ[3720]។ ដូច្នេះ គេមិនអាចយល់ថា ខៀវ សំផន បានដឹងនោះទេ។ ម្យ៉ាងទៀត ការផ្សព្វផ្សាយចម្លើយសារភាព និងរូបថតទាហានវៀតណាមដែលជាប់ឃុំនៅ ស-២១ មិនអាចឱ្យគេយល់ឃើញបានជាដាច់ខាតថា ខៀវ សំផន បានដឹងថាអ្នកទាំងនោះបានទទួលរងការធ្វើបាប។ ចម្លើយសារភាព និងរូបថតទាំងអស់នេះ មិនអាចឱ្យគេដឹងបានឡើយ ពីរបៀបនៃការប្រព្រឹត្តិទៅលើឈ្លើយសឹកទាំងអស់នោះនៅក្នុងមន្ទីរសន្តិសុខ។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវដកចេញ។

១៩០៩. សរុបសេចក្តីទៅ ចៅក្រមមិនមានភស្តុតាងដែលអាចបង្ហាញឱ្យឃើញអំពីការដឹងឮណាមួយរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅ ស-២១ នោះទេ។ ផ្ទុយទៅវិញ សន្តិសុខ និងការសម្ងាត់ដែលមានជុំវិញទីតាំងមួយនេះ បន្ថែមទៅលើការដែលវាស្ថិតក្រោមឋានានុក្រមយោធា គឺសុទ្ធតែជាធាតុផ្សំដែលគួរតែនាំអង្គជំនុំជម្រះឱ្យសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខមិនបានដឹងអំពីអ្វីដែលកើតឡើងនៅ ស-២១ នៅសម័យកាលអង្គហេតុទេ។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ[3721]។

## ៣. ពុទ្ធសាសនិក

១៩១០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានកែខៃកង្វះខាតភស្តុតាងដោយផ្ទាល់ ឬដោយប្រយោលដែលបញ្ជាក់ថា ខៀវ សំផន បានដឹងនៅពេលអង្គហេតុកើតឡើង នូវការប្រព្រឹត្តិឧក្រិដ្ឋកម្មលើពុទ្ធសាសនិក ដែលគាត់ទទួលរងការចោទប្រកាន់ (៣.១) តាមរយៈការសន្និដ្ឋានមិនត្រឹមត្រូវ (៣.២)។

---

[3719] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០។

[3720] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៨ និង ២៤៧៦។

[3721] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៩។

### ៣.១. គ្មានការដឹងឮនៅពេលអង្គហេតុកើតឡើង

១៩១១. គ្មានភស្តុតាងដោយផ្ទាល់ណាមួយបញ្ជាក់ថា ខៀវ សំផន បានដឹងឮអំពីការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា សម្រាប់អង្គហេតុពាក់ព័ន្ធនឹងព្រះសង្ឃ និងពុទ្ធសាសនិក នៅត្រាំកក់នោះទេ។

### ៣.២. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន

### ៣.២.១. សេចក្តីសន្និដ្ឋានទូទៅ មិនច្បាស់លាស់ និងមិនលម្អិត

១៩១២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានទាញសេចក្តីសន្និដ្ឋានទាក់ទងនឹងការដឹងឮ ជាលក្ខណៈទូទៅ មិនច្បាស់លាស់ និងជារួម ("ឧក្រិដ្ឋកម្មមួយចំនួន" "ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ") ដោយមិនបញ្ជាក់ឱ្យបានច្បាស់អំពីឧក្រិដ្ឋកម្មទាំងឡាយដែល ខៀវ សំផន បានដឹងឮ និងជាពិសេស ថាតើនៅពេលណាដែលគាត់បានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ[3722]។ ក្នុងករណីជាក់ស្តែងនេះ មានតែឧក្រិដ្ឋកម្មមួយប៉ុណ្ណោះដែលត្រូវចោទប្រកាន់។ ហេតុដូច្នេះ ខៀវ សំផន ពុំដឹងអ្វីសោះអំពី "ឧក្រិដ្ឋកម្ម" ដែលលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋាននេះ ហើយសេចក្តីសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

### ៣.២.២. គោលនយោបាយរបស់ ប.ក.ក មិនគ្រប់គ្រាន់បង្ហាញឱ្យឃើញពីការដឹងឮ

១៩១៣. អង្គជំនុំជម្រះមិនបានបង្ហាញឱ្យបានសមហេតុសមផលថា តើគោលនយោបាយដែលរងការចោទប្រកាន់របស់ប.ក.កដែលបង្ខំឱ្យព្រះសង្ឃលាចាកសិក្ខាបទ ជាភស្តុតាងបង្ហាញពីការដឹងឮរបស់ ខៀវ សំផន ថាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា នៅត្រាំកក់ កំពុងត្រូវបានប្រព្រឹត្តបានដោយរបៀបណា។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានទាញសេចក្តីសន្និដ្ឋានចេញពីអត្ថិភាពរងការចោទប្រកាន់នៃគោលនយោបាយដាក់ចេញមកពីនីតិបុគ្គល ថាមានការដឹងឮអំពី "ឧក្រិដ្ឋកម្ម" ជាក់លាក់ ដោយបុគ្គលម្នាក់។ អង្គជំនុំជម្រះមិនបានពន្យល់អំពីការវិនិច្ឆ័យរបស់ខ្លួន និង

---

[3722] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៣។

មិនបានពន្យល់ថាតើសេចក្តីសន្និដ្ឋាននេះ គឺជាសេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់បានដោយរបៀបណា។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

### ៣.២.៣. ការគាំទ្រជាសាធារណៈចំពោះព្រះពុទ្ធសាសនា ត្រូវបានបង្ហាញជាការដាក់បន្ទុក

១៩១៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសន្និដ្ឋានថាសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ ខៀវ សំផន គឺជា "ល្បិចដោះខ្លួន" និងជា "ការលាក់បាំងប្រក្រតីភាព" ដោយបានផ្អែកលើភស្តុតាងដូចតទៅនេះ៖ សេចក្តីប្រកាសរបស់រណសិរ្សរួបរួមជាតិកម្ពុជា នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៧៤ ដែលថាព្រះពុទ្ធសាសនា គឺជាសាសនា និងនៅតែជាសាសនារបស់រដ្ឋ[3723] សុន្ទរកថាទាំងអស់របស់ ខៀវ សំផន ដូចដែលត្រូវរាយការណ៍នៅក្នុងកម្រងសារព័ត៌មាន FBIS មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[3724] សុន្ទរកថារបស់ ខៀវ សំផន សម្តែងគារវកិច្ចចំពោះព្រះសង្ឃ ដូចដែលត្រូវរាយការណ៍នៅក្នុងកម្រងសារព័ត៌មាន FBIS ផ្សព្វផ្សាយនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥[3725] និងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥ ដែលត្រូវបានផ្សាយក្រោយសន្និបាតជាតិវិសាមញ្ញ ក្រោមអធិបតីភាពរបស់ ខៀវ សំផន ក្នុងឋានៈជា "ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ" ដែលក្នុងសេចក្តីថ្លែងការណ៍នោះ និយាយពីការចូលរួមរបស់ព្រះសង្ឃតំណាងឱ្យសហគមន៍សង្ឃ ដូចដែលត្រូវរាយការណ៍នៅក្នុងកម្រងសារព័ត៌មាន FBIS[3726]។

[3723] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤០ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៣៤ ដកស្រង់កថាខណ្ឌ ២៦៣ យោងដល់កំណត់សម្គាល់ជើងទំព័រលេខ ៦៥៩ "កម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា" ឯកសារ **E3/1391** ទំព័រ ១០ ERN S 00722343 ("ព្រះពុទ្ធសាសនានៅតែជាសាសនារបស់រដ្ឋ")។ សូមមើលផងដែរ អត្ថបទបោះពុម្ពផ្សាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា៖ "ដំណឹងពីកម្ពុជា (លេខ ៦៩៥)" ឯកសារ **E3/1254** ចុះថ្ងៃទី០៣-០៥ ខែមេសា ឆ្នាំ១៩៧៤ ERN FR S 00000083-S 00000084 ។

[3724] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤០ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៣៥។

[3725] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤០ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៣៦។

[3726] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤០ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៣៧ ដកស្រង់កថាខណ្ឌ ១០៨៦ យោងដល់កំណត់សម្គាល់ជើងទំព័រលេខ ៣៦២២៖ "សមាជពិសេស" សម្រេចរក្សាព្រះរាជតំណែង សម្តេច សីហនុ និង ប៉ែន នុត" (កម្រងឯកសារ FBIS) ឯកសារ **E3/118** ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥ ERN FR 00700264-00700265"។ គួរដកស្រង់ផងដែរនូវ

១៩១៥. ក្រៅតែពីបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានផ្អែកលើភស្តុតាងមួយចំនួនដែលមានតម្លៃតិចតួចបំផុតនោះ ពោលគឺឯកសារយកចេញពីកម្រងសារព័ត៌មាន FBIS ដែលពុំមានការបញ្ជាក់បន្ថែម[3727] អង្គជំនុំជម្រះថែមទាំងពុំបានពន្យល់ថា តើខ្លួនអាចទាញសេចក្តីសន្និដ្ឋានចេញពីឯកសារទាំងនេះបានដោយរបៀបណា ដើម្បីបង្ហាញពីការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មជាក់លាក់ដែលកើតឡើងនៅត្រាំកក់។

១៩១៦. អង្គជំនុំជម្រះបានសន្និដ្ឋានថាមានការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនានៅត្រាំកក់ ក្នុងនោះមានអង្គហេតុនៃការចាប់ខ្លួនព្រះសង្ឃ និងការផ្សឹកព្រះសង្ឃនៅត្រាំកក់ ដែលមិនទាក់ទងអ្វីសោះជាមួយនឹងសហករណ៍ត្រាំកក់។ សុន្ទរកថា និងឯកសារខុសៗគ្នាទាំងអស់នេះ មិនបង្ហាញទាល់តែសោះអំពីសហករណ៍ត្រាំកក់ និងថែមទាំងចុះកាលបរិច្ឆេទពីរបីថ្ងៃក្រោយពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម ឬមុននេះទៀតផង។ ឯកសារទាំងនេះមានកាលបរិច្ឆេទដែលស្ថិតនៅចន្លោះពីថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៧៤ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៥។ ម្យ៉ាងវិញទៀត ពុំមានទំនាក់ទំនងណាមួយត្រូវបានធ្វើឡើយ រវាងកាលបរិច្ឆេទទាំងនេះ ជាមួយនឹងឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់នៅត្រាំកក់។

១៩១៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្តើមចេញពីគោលការណ៍ថា ខៀវ សំផន បានដឹងថាព្រះសង្ឃត្រូវបានចាប់ខ្លួន និងផ្សឹក នៅត្រាំកក់[3728]។ ទោះបីជាមិនហ៊ានអះអាងដោយចំហ អង្គជំនុំជម្រះមិនបានទាញផលវិបាកចេញពីកង្វះភស្តុតាងគាំទ្រការចោទប្រកាន់នេះនោះទេ។ គ្មានចៅក្រមមានវិចារណញ្ញាណណាអាចធ្វើការស្មានបានយ៉ាងច្រើនដូច្នេះ ចេញពីវត្តមានសមាជិកសង្ឃនៅពេលទទួលសម្តេច នរោត្តម សីហនុ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥[3729] ឬពីការដែលម្ចាស់បណ្តឹងសាទុក្ខ "បានផ្អាក

---

កំណត់សម្គាល់ជើងទំព័រលេខ ៣៦២៣ ដែលនិយាយសំដៅដល់ សម្តេច សីហនុ៖ "សារលិខិតរបស់ សម្តេច សីហនុ សាទរសមាជពិសេស" (កម្រងឯកសារ FBIS) ឯកសារ **E3/1364** ចុះខែឧសភា ឆ្នាំ១៩៧៥ ERN 00700290។

[3727] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៧។

[3728] សំអាងហេតុសាលក្រម, កថាខណ្ឌ ៤២៤០-៤២៤១។

[3729] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤១។

ជាបណ្ដើរៗនូវការកោតសរសើរចំពោះព្រះសង្ឃ" ក្នុងសុន្ទរកថាមួយចំនួនដែលត្រូវរាយការណ៍ដោយកម្រងសារព័ត៌មាន FBIS បាននោះទេ[3730]។

១៩១៨. វិធីសាស្ត្របែបលម្អៀង និងមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះ គឺរឹតតែបង្ហាញឱ្យឃើញច្បាស់ថែមទៀត នៅពេលពិនិត្យលើការអះអាងរបស់អង្គជំនុំជម្រះដែលថា ម្ចាស់បណ្ដឹងសាទុក្ខបាននិយាយយ៉ាង "មុតមាំ" អំពីព្រះពុទ្ធសាសនា ដែលអង្គជំនុំជម្រះមានការលំបាកក្នុងការរៀបរាប់[3731]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះនៅតែមានះក្នុងការនិយាយសរុបជាទូទៅគ្មានមូលដ្ឋាន ដោយបានសន្និដ្ឋានថា ខៀវ សំផន "បានណែនាំយ៉ាងមុតមាំអំពីការរៀបចំអាពាហ៍ពិពាហ៍ ដោយគ្មានវត្តមានព្រះសង្ឃ និងតាមលក្ខណៈមួយដែលផ្ទុយពីប្រពៃណីទូទៅនៃពុទ្ធសាសនា"[3732]។ ការអះអាងនេះពុំបានផ្អែកទៅលើភ័ស្តុតាងណាមួយ សូម្បីតែទៅលើសក្ខីកម្ម - ដែលអាចរិះគន់បាន - របស់ ជា ឌៀប ជាដើមបណ្ដឹងរដ្ឋប្បវេណីតែម្នាក់គត់ដែលបានលើកឡើងអំពីម្ចាស់បណ្ដឹងសាទុក្ខ ភ្ជាប់ទៅនឹងការរៀបអាពាហ៍ពិពាហ៍[3733]។ ការអះអាងដែលថា "ការអនុវត្តបែបនេះនៅតែបន្តឥតឈប់ឈរនៅចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ក្រោមការឃ្លាំមើលរបស់ ខៀវ សំផន" គឺគ្មានមូលដ្ឋានគាំទ្រដូចគ្នា[3734]។ គេត្រូវកត់សម្គាល់ថា ការវិនិច្ឆ័យគតិយុត្តិ និងកាតព្វកិច្ចក្នុងការផ្ដល់សំអាងហេតុ បានរងផលប៉ះពាល់ដោយអានុភាពនៃវិធីសាស្ត្ររបស់អង្គជំនុំជម្រះ។

១៩១៩. ខៀវ សំផន បានប្រកាសថា គាត់មិនបានទទួលព័ត៌មានអំពីបញ្ហាពាក់ព័ន្ធនឹងការប្រតិបត្តិសាសនា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទេ[3735]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានបដិសេធចោលសេចក្ដីអះអាងនេះ ខណៈដែលខ្លួនគ្មានភ័ស្តុតាងផ្ទុយពីនេះ[3736]។ ទោះយ៉ាងណាក៏ដោយ

[3730] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤២។

[3731] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤២។

[3732] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤២។

[3733] សូមមើលខាងលើ កថាខណ្ឌ ១២៣៣-១២៤២។

[3734] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3735] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ **E1/528.1** ចន្លោះម៉ោង 10.48.33 និងម៉ោង 10.57.25។

[3736] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៣។

ការហាមឃាត់ការប្រតិបត្តិព្រះពុទ្ធសាសនាដោយបើកចំហ ក៏ដូចជាសាសនាទាំងអស់ ក្នុងអំឡុងរបប កម្ពុជាប្រជាធិបតេយ្យ មិនអាចប្រើដើម្បីបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្ម នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាដែលរងការចោទប្រកាន់ នៅត្រាំកក់បានទេ។ ការដឹងឮ បែបសន្មតរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ចំពោះព្រះ សង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកនៅត្រាំកក់ ដោយផ្អែកលើភស្តុតាងទាំងនេះ មិនប្រាកដថាជាសេចក្តី សន្និដ្ឋានសមហេតុសមផលតែមួយគត់នោះទេ តែគឺជាសេចក្តីសន្និដ្ឋានចោទប្រកាន់តែមួយគត់។ សេចក្តីសន្និដ្ឋាននេះ ត្រូវទុកជាមោឃៈ[3737]។

១៩២០. ពុំមានភស្តុតាងគាំទ្រការអះអាងទូទៅមួយនេះទេ។ នៅក្នុងកំណត់សម្គាល់ជើងទំព័រ អង្គជំនុំជម្រះបាន យោងទៅលើកថាខណ្ឌ ៣៥៧០ នៃសំអាងហេតុសាលក្រម ដែលក្នុងនោះ មានផ្នែកមួយដែលដក ស្រង់ចេញពីសុន្ទរកថាមួយរបស់ ខៀវ សំផន៖ “ប្តេជ្ញាក្រេបយកនូវគំរូវីរភាពដ៏ខ្ពង់ខ្ពស់ និងថ្លៃថ្នូរនៃ កងទ័ពបដិវត្តន៍យើងដោយ [...] តម្កល់ប្រយោជន៍ជាតិ វណ្ណៈ ប្រជាជន និងបដិវត្តន៍ ធំជាងប្រយោជន៍ ផ្ទាល់ខ្លួន និងផលប្រយោជន៍គ្រួសារ ហើយប្រមូលផ្តុំរាល់ការខិតខំប្រឹងប្រែងដើម្បីបំពេញកាតព្វកិច្ច ទាំងអស់ ដែលបក្សបានប្រគល់សេចក្តីទុកចិត្តជូនយើងគ្រប់គ្នា”[3738]។ គ្មានការបង្ហាញណាមួយអំពីព្រះ ពុទ្ធសាសនានៅក្នុងសុន្ទរកថានេះទេ។

## ៤. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

១៩២១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានកែខៃកង្វះភស្តុតាងដោយផ្ទាល់ ឬ ដោយប្រយោល ដែលបញ្ជាក់ថា ខៀវ សំផន បានដឹងនៅពេលអង្គហេតុកើតឡើង នូវការប្រព្រឹត្តិឧក្រិដ្ឋ កម្មចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ តាមរយៈការសន្និដ្ឋានពុំត្រឹមត្រូវ។ អង្គជំនុំជម្រះមិនបានសន្និដ្ឋានឱ្យឃើញច្បាស់ពីការដឹងឮរបស់គាត់នៅពេលអង្គហេតុកើតឡើង នូវការ

[3737] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៣ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៥០ យោងដល់កថាខណ្ឌ ៣៥៧០។

[3738] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៧០ កំណត់សម្គាល់ជើងទំព័រលេខ ១១៩៨១ “អត្ថបទសុន្ទរកថារបស់ ខៀវ សំផន នៅ ក្នុងមិទ្ទីងអបអរសាទរខួបលើកទីបីនៃជ័យជម្នះ ១៧ មេសា និងកំណើតកម្ពុជាប្រជាធិបតេយ្យ” ឯកសារ **E3/202** ពុំមានចុះកាល បរិច្ឆេទ ទំព័រ ៥ ERN 00287222។

ប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ទំនប់១មករា ស-២១ និងនៅក្រាំងតាចាន់ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតលើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ចន្លោះពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងចន្លោះពីខែតុលា ឆ្នាំ១៩៧៥ ដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ នៅ ស-២១ និងនៅក្រាំងតាចាន់[3739]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រើប្រាស់ ជាលក្ខណៈដែលគេមិនអាចយល់បាន នូវភ័ស្តុតាងមួយចំនួនមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើម្បីទាញសេចក្ដីសន្និដ្ឋានទាក់ទងនឹងការដឹងឮជាទូទៅអំពីឧក្រិដ្ឋកម្មនៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្ត។

### ៤.១. កំហុសពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីការដឹងឮរបស់ ខៀវ សំផន

### ៤.១.១. តួនាទី "គន្លឹះ" របស់ ខៀវ សំផន នៅក្នុងជ័យជម្នះរបស់ ប.ក.ក ១៧ មេសា ១៩៧៥

១៩២២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានជ្រើសរើសធ្វើជាភ័ស្តុតាងដាក់បន្ទុក នូវសេចក្ដីសន្និដ្ឋានគ្មានមូលដ្ឋានរបស់ខ្លួនថា ខៀវ សំផន បានដើរតួនាទីគន្លឹះនៅក្នុងការទទួលបានជ័យជម្នះរបស់ ប.ក.ក ១៧ មេសា ១៩៧៥ ខណៈដែលខ្លួនបានទទួលស្គាល់ថា ខៀវ សំផន គ្មានតួនាទីផ្នែកយោធាណាមួយនោះ[3740]។

### ៤.១.២. សុន្ទរកថារបស់ ខៀវ សំផន នៅចុងឆ្នាំ១៩៧២ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ និងនៅខែមករា ឆ្នាំ១៩៧៥

១៩២៣. នៅត្រង់កថាខណ្ឌ ៤២៤៤ នៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានបង្ហាញពីសុន្ទរកថាមួយរបស់ ខៀវ សំផន នៅឆ្នាំ១៩៧២ ប៉ុន្តែ ពុំមានការអំពាវនាវណាមួយរបស់គាត់ឱ្យកម្ចាត់អតីតទាហាន និងអតីតអ្នករដ្ឋការជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងអ្នកក្រោមបង្គាប់ពួកគេ "នៅចុងឆ្នាំ១៩៧២" នៅ

---

[3739] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៤-៤២៤៥ និងយោងទៅផ្នែក ១៨.២.២.៣.៤។

[3740] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៤។

ត្រង់កថាខណ្ឌ ៩០៣៧ ដែលអង្គជំនុំជម្រះបានយោងទៅរក នោះទេ[3741]។ ហើយក៏គ្មានការបង្ហាញផងដែរអំពីការវាយសម្រុកផ្តាច់ព្រ័តដែល ខៀវ សំផន បានប្រកាសនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ នៅកថាខណ្ឌ ២៣២ ដែលត្រូវបានយោងទៅរកផងដែរ[3742]។ អង្គជំនុំជម្រះភាន់ច្រឡំ ព្រោះថា គឺនៅកថាខណ្ឌ ២៣១ ទេ ដែលខ្លួនបានលើកបង្ហាញថា "នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ បន្ទាប់ពីការប្រកាសតាមវិទ្យុដោយ ខៀវ សំផន"[3743]។ ជាចុងក្រោយ អង្គជំនុំជម្រះបានបង្ហាញផងដែរអំពីសេចក្តីថ្លែងការណ៍មួយរបស់ ខៀវ សំផន ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ ទាក់ទងនឹងការសម្លាប់ជនក្បត់ទាំងប្រាំពីរនាក់នៃរបបសាធារណរដ្ឋខ្មែរ[3744]។

១៩២៤. ទោះយ៉ាងណាក៏ដោយ ក្រៅពីការដែលវាជាសុន្ទរកថាដែលត្រូវរាយការណ៍ដោយកម្រងសារព័ត៌មាន FBIS ដែលមានតម្លៃតិចតួចបំផុតនោះ អង្គជំនុំជម្រះមិនអាចប្រើប្រាស់សេចក្តីថ្លែងការណ៍ទាំងអស់នេះដែលបានកើតឡើងនៅក្នុងពេលកំពុងមានជម្លោះជាមួយទាហាននៃរបបសាធារណរដ្ឋខ្មែរ ដើម្បីទាញសេចក្តីសន្និដ្ឋានទាក់ទងនឹងរយៈពេលដែលជាកម្មវត្ថុនៃការជំនុំជម្រះបាននោះទេ។ បើទោះជាថាសុន្ទរកថាទាំងនេះ ពិតត្រឹមត្រូវមែនក៏ដោយចុះ ក៏វាមិនអាចធ្វើជាមូលដ្ឋាននៃការដឹងឮណាមួយរបស់ ខៀវ សំផន ទាក់ទងនឹងការប្រព្រឹត្តិក្រោយមកទៀតនូវឧក្រិដ្ឋកម្មចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ទំនប់១មករា ស-២១ និងនៅក្រាំងតាចាន់ បានដែរ។ ម្យ៉ាងវិញទៀត ដូចដែលគេបានឃើញខាងលើ អង្គហេតុទាំងអស់នេះធ្លាប់ត្រូវបានជំនុំជម្រះរួចមកហើយនៅក្នុងសំណុំរឿង ០០២/០១[3745]។

---

[3741] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៥៣។

[3742] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៥៤។

[3743] សំអាងហេតុសាលក្រម កថាខណ្ឌ ២៣១ កំណត់សម្គាល់ជើងទំព័រលេខ ៥៥៤ "ការជំរុញឱ្យប្រជាជនរួបរួមគ្នាធ្វើការវាយប្រហារក្នុងពេលចូលឆ្នាំថ្មី (កម្រងឯកសារ FBIS) ឯកសារ **E3/30** ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៤ ERN 00783125-00783131"។

[3744] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៤ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៥៥ យោងដល់កថាខណ្ឌ ២៣១។

[3745] សូមមើលខាងលើ កថាខណ្ឌ ១៥៨២, សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១១០០។ សូមមើលផងដែរ កថាខណ្ឌ ៩៦៨ ក្នុងនោះអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ភ័ស្តុតាងផ្ទុយនឹង "អត្ថិភាពនៃគោលនយោបាយទូទៅចាប់ពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧៥"។

### ៤.១.៣. ការធានាលើកលែងទោសពីសំណាក់ ខៀវ សំផន រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា

១៩២៥. ការធានាលើកលែងទោសពីសំណាក់ ខៀវ សំផន ចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅខែមីនា-មេសា ឆ្នាំ១៩៧៥ ក្នុងករណីពួកគេចុះចូលជាមួយរណសិរ្សរួបរួមជាតិកម្ពុជា គឺមិនបង្ហាញឱ្យឃើញជាដាច់ខាតពីការដឹងឮអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនាពេលក្រោយមកទៀតនោះទេ។ ប្រភពទាំងអស់ដែលបញ្ជាក់ក្នុងកំណត់សម្គាល់ជើងទំព័រនៃកថាខណ្ឌ ៩០២៨ គឺសុទ្ធរកថាដូចដែលត្រូវរាយការណ៍នៅក្នុងកម្រងសារព័ត៌មាន FBIS[3746]។

### ៤.១.៤. សេចក្តីថ្លែងការណ៍ទាក់ទងនឹងការកម្ទេចរបបចាស់

១៩២៦. ដូចគ្នាដែរចំពោះការចោទប្រកាន់ពីបទជំរុញឱ្យទម្លាក់របបផ្តាច់ការ លន់ នល់[3747]។ សារថ្លែងអំពីជ័យជម្នះរបស់ ខៀវ សំផន នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ដូចដែលត្រូវរាយការណ៍នៅក្នុងកម្រងឯកសារព័ត៌មាន FBIS គឺមិនបង្ហាញឱ្យឃើញជាដាច់ខាតពីការដឹងឮរបស់ ខៀវ សំផន អំពីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងក្រោយមកទៀត[3748]។ ការស្វាគមន៍ចំពោះការកម្ទេចរបបបរាជ័យមួយ ក្នុងករណីទទួលបានជ័យជម្នះផ្នែកយោធា ពុំមែនជាបទឧក្រិដ្ឋទេ។ វាក៏មិនអាចជាភ័ស្តុតាងនៃការដឹងឮអំពីឧក្រិដ្ឋកម្មក្រោយមកទៀតបាននោះដែរ។ គេត្រូវកត់សម្គាល់ថា អង្គជំនុំជម្រះគ្មានភ័ស្តុតាងណាមួយដែលអាចឱ្យសន្និដ្ឋានថាមានការដឹងឮបានទេ។

## ៤.២. ការដឹងឮអំពីឧក្រិដ្ឋកម្មជាក់លាក់

---

[3746] សំអាងហេតុសាលក្រម កថាខណ្ឌ ៩០២៨។

[3747] សំអាងហេតុសាលក្រម កថាខណ្ឌ ៩២៤៥ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៥៧ យោងដល់កថាខណ្ឌ ៩០២៧។

[3748] សំអាងហេតុសាលក្រម កថាខណ្ឌ ៩២៤៥ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៥៨ យោងដល់កថាខណ្ឌ ៩០៣៧។

១៩២៧. អង្គជំនុំជម្រះបានយោងទៅលើការវាយតម្លៃ "លម្អិត" របស់ខ្លួន អំពីចេតនាទាក់ទងនឹង "ទំហំនៃការដឹងឮរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាក់លាក់ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"[3749]។ ដូចដែលនឹងឃើញនៅផ្នែកខាងក្រោម គ្មានភ័ស្តុតាងណាមួយបញ្ជាក់ថា ខៀវ សំផន បានដឹងថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ត្រូវបានប្រព្រឹត្តចំពោះអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ទំនប់១មករា មន្ទីរ ស-២១ និងក្រាំងតាចាន់ នោះទេ ហើយក៏គ្មានភ័ស្តុតាងបញ្ជាក់ថាគាត់បានដឹងថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ត្រូវបានប្រព្រឹត្តលើអតីតទាហាន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ចន្លោះពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងចន្លោះពីខែតុលា ឆ្នាំ១៩៧៥ ដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ នៅ ស-២១ និងនៅក្រាំងតាចាន់ នោះដែរ[3750]។

## ផ្នែកទី ៤. កំហុសពាក់ព័ន្ធនឹងការដឹងឮអំពីឧក្រិដ្ឋកម្មនៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍

១៩២៨. មុនត្រូវបានស្នើសុំដោយត្រឹមត្រូវឱ្យពិនិត្យលើអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍ អង្គជំនុំជម្រះធ្លាប់បានសម្រេចនៅក្នុងសំណុំរឿង ០០២/០១ ថាមានគោលនយោបាយ "អាពាហ៍ពិពាហ៍ដោយមិនស្ម័គ្រចិត្ត"[3751]។ ការវិនិច្ឆ័យជាមុនរបស់អង្គជំនុំជម្រះចំពោះអង្គហេតុ អាចពន្យល់បានពីរបៀបដែលអង្គជំនុំ

---

[3749] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៦ យោងដល់ផ្នែក ១៨.២.២.៣.៤។

[3750] សូមមើលខាងក្រោម កថាខណ្ឌ ២០៩៩-២១១៣។

[3751] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៣០ ក្នុងនោះអង្គជំនុំជម្រះបានសន្និដ្ឋានថា "ភ័ស្តុតាងមួយចំនួនបានបង្ហាញយ៉ាងច្បាស់អំពីការរៀបអាពាហ៍ពិពាហ៍ដោយមិនស្ម័គ្រចិត្តនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា បញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ គឺជាគោលនយោបាយមួយរបស់ប.ក.ក" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ ភ័ស្តុតាងពាក់ព័ន្ធនឹងខ្លឹមសារ និងការអនុវត្តគោលនយោបាយស្តីពីបញ្ញត្តិទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ និងវិសាលភាពនៃការរៀបអាពាហ៍ពិពាហ៍នេះ គឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២"។ ឧទាហរណ៍ សូមមើល អែម អឿន៖ ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/113.1** ចន្លោះម៉ោង 16.05.25 និងម៉ោង 16.06.56 (អន្តរាគមន៍របស់លោកប្រធានទៅនឹងសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ "អង្គជំនុំជម្រះបានដកចេញ បានន័យថាមិនរាប់បញ្ចូលនូវការរៀបការដោយបង្ខំទេ [...]។ អ៊ីចឹង ការរៀបចំនូវសំណួរ សុំចៀសវាងនូវការតាំងសំណួរក្រៅអង្គហេតុ ដែលអង្គជំនុំជម្រះបានកំណត់សម្រាប់បំបែកមកធ្វើសវនាការនៅដំណាក់កាលដំបូង សំណុំរឿង ០០២/០១"), ជួន ធី៖ ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/183.1** មុនម៉ោង

ជម្រះបានប្រមាថចំពោះការអនុវត្តច្បាប់ដោយត្រឹមត្រូវ និងការពិនិត្យមិនលម្អៀង លើភ័ស្តុតាងដែលមិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានបានអំពីអត្ថិភាពនៃគោលនយោបាយរៀបការដោយបង្ខំ ណែនាំដោយ ប.ក.ក[3752]។

១៩២៩. អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប តែមួយ និងដែលធ្វើឡើងនៅក្នុងល័ក្ខខ័ណ្ឌដែលគួរតែនាំអង្គជំនុំជម្រះឱ្យដកសក្ខីកម្មមួយនេះចេញ។ ដូចដែលបានឃើញខាងលើរួចមកហើយ[3753] ហេតុផលតែមួយគត់ដែលអង្គជំនុំជម្រះវិនិច្ឆ័យថា រឿងរ៉ាវរបស់គាត់ "អាចជឿជាក់បាន និងមានភាពស្របគ្នា" ជាអាទិ៍ ពាក់ព័ន្ធនឹងកិច្ចប្រជុំនៅវត្តឧណ្ណាលោម ដែលត្រូវបានសន្មតថាដឹកនាំដោយ ខៀវ សំផន គឺមកពីវាជាភ័ស្តុតាងតែមួយគត់ដែលអាចឱ្យគេភ្ជាប់ទំនាក់ទំនងរវាងម្ចាស់បណ្តឹងសាទុក្ខជាមួយនឹងគោលនយោបាយនៃការរៀបចំអាពាហ៍ពិពាហ៍[3754]។

១៩៣០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសផងដែរ នៅក្នុងការបកស្រាយលើភ័ស្តុតាងទេសកាល ដើម្បីសន្និដ្ឋានថាមានការដឹងឮរបស់ ខៀវ សំផន ក្នុងនោះមានសម្តីរបស់គាត់អំពាវនាវឱ្យ "ផ្តាច់មនោសញ្ចេតនាផ្ទាល់ខ្លួនដើម្បីអង្គការ" និងដើម្បីបង្កើនចំនួនប្រជាជនឱ្យបានឆាប់រហ័ស[3755] ចម្លើយជាលាយលក្ខណ៍អក្សររបស់ រស់ ស៊ុយ និងសៀវភៅរបស់ សម្តេច នរោត្តម សីហនុ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[3756]។ ក៏ប៉ុន្តែ ដូចដែលបានឃើញពីខាងលើផងដែរថា ភ័ស្តុតាងទាំងអស់នេះមិនអាចឱ្យគេសន្និដ្ឋានបានថាមានការដឹងឮអំពីឧក្រិដ្ឋកម្មនានាដែលរងការចោទប្រកាន់ ក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍

---

10.03.25 (អន្តរាគមន៍របស់លោកប្រធាន៖ "នៅក្នុងសំណុំរឿង ០០២/០១ គឺមិនមានអង្គហេតុអំពីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ") ប្រហែលម៉ោង 14.32.12។

[3752] សូមមើលខាងលើ កថាខណ្ឌ ១១៩៨-១២៨០ កថាខណ្ឌ ១៣៤១-១៣៩៨។

[3753] សូមមើលខាងលើ កថាខណ្ឌ ១២៣៣-១២៤២។

[3754] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៥៦៩។ សូមមើលខាងលើ កថាខណ្ឌ ១២៣៣-១២៤២។

[3755] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤២-៤២៤៨។ សូមមើលផងដែរ កថាខណ្ឌ ៣៥៥៧, ៣៥៦៩-៣៥៧១, ៣៥៨១, ៣៥៩០, ៣៦១១, ៣៦៣៥។

[3756] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៤៧-៤២៤៨។

ពិពាហ៍បាននោះទេ[3757]។ មុខតំណែងរបស់គាត់ ដែលជាប់ទាក់ទងជាមួយពាណិជ្ជកម្ម និងសក្ដីកម្មនានាដែលទាក់ទងជាមួយនឹងមុខតំណែងទាំងនេះ មិនអាចបង្ហាញឱ្យឃើញថាគាត់ជាប្រភពនៃការរៀបចំការរៀបការដោយបង្ខំ នៅក្នុងក្រសួងនេះបានទេ ហើយក៏មិនអាចបង្ហាញឱ្យឃើញថាគាត់បានដឹងអំពីការរៀបការទាំងនោះបានដែរ[3758]។

១៩៣១. ជាចុងក្រោយ ការប្រើប្រាស់ពាក្យពេចន៍ទូទៅថា "មជ្ឈិមបក្ស"[3759] មិនអាចឱ្យគេបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាង ខៀវ សំផន ជាមួយនឹងគោលនយោបាយរៀបការដោយបង្ខំបាននោះទេ ព្រោះថារបាយការណ៍ទាំងពីរដែលបានធ្វើឡើង និងដែលបង្ហាញពីការរៀបការ គឺមិនអាចឱ្យគេសន្និដ្ឋានថាមានការដឹងឮអំពីឧក្រិដ្ឋកម្ម និងការដឹងឮអំពីខ្លឹមសារនៃឧក្រិដ្ឋកម្មទាំងនោះដោយ ខៀវ សំផន បាននោះទេ[3760]។ ដោយហេតុថាអង្គជំនុំជម្រះមិនបានបង្ហាញឱ្យឃើញពីការដឹងឮរបស់ ខៀវ សំផន អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅសម័យអង្គហេតុ ដូច្នេះ រាល់សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ នៅក្នុងន័យនេះត្រូវទុកជាមោឃៈ[3761]។

## ជំពូកទី ៤. ការដឹងពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម

១៩៣២. អង្គជំនុំជម្រះប្រព្រឹត្តកំហុសអង្គហេតុ ដោយពិចារណាថា ខៀវ សំផន មិនអាចមិនដឹងអំពីរបាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ និងគណៈកម្មការសិទ្ធិមនុស្សស្ដីពីការប្រហារជីវិត និង

[3757] សូមមើលខាងលើ កថាខណ្ឌ ១២២១-១២៣២។

[3758] សូមមើលខាងលើ កថាខណ្ឌ ១៦៥២-១៨០៣ ជាពិសេស កថាខណ្ឌ ១៧៧០-១៧៩៨។

[3759] សូមមើលខាងលើ កថាខណ្ឌ ១៦១៨-១៦៣២ ("មជ្ឈិមបក្ស") កថាខណ្ឌ ១៦៣៣-១៦៣៦ ("អង្គការ") កថាខណ្ឌ ១៦៥០-១៦៥១ ("គោលការណ៍រក្សាការសម្ងាត់")។

[3760] សូមមើលខាងលើ កថាខណ្ឌ ១២៩៩-១២៨០ ("កំហុសពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងការផ្សព្វផ្សាយបទបញ្ជា") កថាខណ្ឌ ១៦១៨-១៦៣២ ("មជ្ឈិមបក្ស")។

[3761] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៧-៤២៩៩ កថាខណ្ឌ ៤៣០៣-៤៣០៨ កថាខណ្ឌ ៤៣២៦-៤៣២៧។

ការធ្វើបាបប្រជាជនស៊ីវិលឡើយ[3762]។ ក៏ប៉ុន្តែ គ្មានអ្វីដែលអាចឱ្យសន្និដ្ឋានបានថា គាត់បានទទួលរបាយការណ៍ទាំងនេះនោះទេ[3763]។ "ទំនាក់ទំនងជិតស្និទ្ធ" របស់គាត់ជាមួយ អៀង សារី មិនមែនជាភ័ស្តុតាងនៃការដឹងនេះទេ ប៉ុន្តែគឺជាការស្មានសុទ្ធសាធរបស់អង្គជំនុំជម្រះ ដែលត្រូវតែបដិសេធចោល។ លើសពីនេះទៀត អង្គជំនុំជម្រះមិនអាចប្រើការសន្និដ្ឋានខុសរបស់ខ្លួនអំពីការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខដែលថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត"នៅក្នុងបរិបទនៃការបង្កើត និងការដាក់ឱ្យដំណើរការសហករណ៍ និងការដ្ឋានការងារ ក៏ដូចជានៅក្នុងបរិបទនៃការបោសសម្អាតផ្ទៃក្នុង"[3764]។

១៩៣៣. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានផ្អែកលើសេចក្តីថ្លែងការរបស់ ខៀវ សំផន ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីសន្និដ្ឋានថាលោកបានដឹងពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3765]។ ជាក់ស្តែង ពិតមែនតែគាត់បានទទួលស្គាល់នៅពេលក្រោយមកថា មានការកាប់សម្លាប់មនុស្សក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានធ្វើការបង្ហាញអំពីការដឹងឮរបស់គាត់ នៅក្រោយអង្គហេតុជាក់លាក់នៃឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០២ ឡើយ។ ការសន្និដ្ឋានស្មានទូទៅបែបនេះ មិនអាចនាំទៅដល់ការរកឃើញទំនួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទចំពោះបទឧក្រិដ្ឋជាក់លាក់ណាមួយឡើយ។ ដូច្នេះ សេចក្តីថ្លែងការទាំងនេះរបស់ ខៀវ សំផន មិនអាចគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះបានឡើយ។

១៩៣៤. ការរកឃើញរបស់អង្គជំនុំជម្រះទាក់ទងនឹងវគ្គសិក្សា និងការប្រមូលផ្តុំទ្រង់ទ្រាយធំ ដែលក្នុងឱកាសនោះ មានការលើកទឹកចិត្តឱ្យប្រកាន់អាកប្បកិរិយាឧក្រិដ្ឋប្រឆាំងនឹងជនជាតិវៀតណាម អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងអ្នករិះគន់បដិវត្តន៍ ដែលយើងនឹងជំទាស់នៅ

---

[3762] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥០។ ការរកឃើញនេះត្រូវបានលើកឡើងម្តងទៀតនៅកថាខណ្ឌ ៤២៥៣ យោងទៅកំណត់សម្គាល់ជើងទំព័រដែលលេខ ៤០៤៨។

[3763] សូមមើលខាងលើ កថាខណ្ឌ ១៦៩៧, ១៨០០។

[3764] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥១។ សូមមើលខាងលើ កថាខណ្ឌ ១៨១៦-១៨៤៨ កថាខណ្ឌ ១៨៤៩-១៨៧៨។

[3765] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥២។

ផ្នែកខាងក្រោម[3766]។ ចំពោះករណី ខៀវ សំផន មានលទ្ធភាពអានទស្សនាវដ្តីទង់បដិវត្ត និងយុវជន និងយុវនារីបដិវត្ត[3767] មេធាវីការពារក្តីបានគូសបញ្ជាក់រួចហើយថា ពុំមានភស្តុតាងណាមួយអាចឱ្យយើងសន្និដ្ឋានបានថាគាត់មានលទ្ធភាពទទួលបានទស្សនាវដ្តីទាំងនេះ និងជាពិសេសថាគាត់បានអានវាគ្រប់លេខនោះទេ[3768]។ មួយវិញទៀត អង្គជំនុំជម្រះក៏មិនបានពន្យល់ដែរថា តើការដែល ខៀវ សំផន បានដឹងឮអំពីសុន្ទរកថាថ្លែងដោយអ្នកទទួលខុសត្រូវជាន់ខ្ពស់ ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយ បង្ហាញពីការដឹងរបស់គាត់ពីការប្រព្រឹត្តិឧក្រិដ្ឋកម្មបានយ៉ាងដូចម្តេច[3769]។ អង្គជំនុំជម្រះមិនបានបញ្ជាក់ថាតើជាគោលគោលនយោបាយអ្វីនោះទេ ហើយកាន់តែមិនបញ្ជាក់ទៅទៀតថាតើគាត់បានដឹងឮអំពីឧក្រិដ្ឋកម្មណាខ្លះ តាមរយៈសុន្ទរកថាទាំងនេះ។ ការប៉ាន់ស្មានបែបនេះរបស់អង្គជំនុំជម្រះ ត្រូវទុកជាមោឃៈ។

១៩៣៥. ទីបំផុត អង្គជំនុំជម្រះផ្អែកលើបទសម្ភាសន៍មួយរបស់ ខៀវ សំផន នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ ដែលគាត់ទំនងជាបាននិយាយថា "ជនក្បត់ដែលនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ត្រូវបានសម្លាប់អស់ហើយ"[3770]។ បើទោះជាគេអាចគិតថា គាត់និយាយសំដៅទៅលើសមាជិកនៃអតីតរបបសាធារណរដ្ឋខ្មែរក៏ដោយ ក៏ វាមិនមានការបញ្ជាក់ណាមួយអាចឱ្យដឹងថា គាត់ចង់សំដៅទៅលើនរណាម្នាក់ នៅពេលណា ឬកន្លែងណា ដែលការសម្លាប់នោះបានកើតឡើងនោះដែរ។ ដូច្នេះ ក្រៅពីការចោទប្រកាន់ជាទូទៅអំពីការដឹងឮរបស់ ខៀវ សំផន ពីការកាប់សម្លាប់មនុស្សក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះមិនបានបង្ហាញឱ្យហួសពីវិមតិសង្ស័យថា គាត់បានដឹងថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនោះទេ[3771]។

---

[3766] សូមមើលខាងក្រោម កថាខណ្ឌ ២០០១-២០៣០។ សូមមើល ជាពិសេស ការរិះគន់ទៅលើកថាខណ្ឌ ៤២៧១-៤២៧៣ នៃសំអាងហេតុសាលក្រម។

[3767] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៣។

[3768] សូមមើលខាងលើ កថាខណ្ឌ ១៦៤១-១៦៤៣។

[3769] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៣។

[3770] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៣ កំណត់សម្គាល់ជើងទំព័រលេខ ១៣៨៧៥។

[3771] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៤។

១៩៣៦. ទាក់ទងទៅនឹងបទបញ្ញាស្តីពីការរៀបការ អង្គជំនុំជម្រះបានសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីឧក្រិដ្ឋកម្ម បន្ទាប់ពីឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តរួចហើយ[3772] ដោយយោងទៅកថាខណ្ឌ ៤២៧៣ ដែលជា ឌៀប បានលើកឡើងថា ខៀវ សំផន បាននិយាយពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងយោងទៅការសន្និដ្ឋានរបស់ខ្លួន ដែលថាគោលនយោបាយនេះ "ត្រូវបានដាក់ឱ្យអនុវត្តប្រាកដមែន" ជាពិសេសនៅក្នុងក្រសួងពាណិជ្ជកម្ម[3773]។ តាមពិត អង្គជំនុំជម្រះបានប្រើប្រាស់ ទឡ្ហីករណ៍ដូចគ្នានឹងការសន្និដ្ឋានរបស់ខ្លួនលើការដឹងឮក្នុងអំឡុងពេលអង្គហេតុ។ ដូច្នេះ អង្គជំនុំជម្រះទទួលរងការរិះគន់ដដែលចំពោះកំហុសទាំងនេះរបស់ខ្លួន ដោយមិនបានបង្ហាញពីការដឹងរបស់ ខៀវ សំផន ពីការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្នុងក្របខ័ណ្ឌនៃអាពាហ៍ពិពាហ៍ ទាំងក្នុងកំឡុងពេល និងក្រោយពេលប្រព្រឹត្ត[3774] ឬអំពីការចូលរួមចំណែករបស់គាត់ ក្នុងឧក្រិដ្ឋកម្មទាំងនេះដែរ[3775]។

១៩៣៧. ការមានលទ្ធភាពទទួលបានទស្សនាវដ្តីទង់បដិវត្ត មិនអាចឱ្យអង្គជំនុំជម្រះសន្និដ្ឋានថា ម្ចាស់បណ្តឹងសាទុក្ខដឹងឮអំពីឧក្រិដ្ឋកម្មជាក់លាក់នោះទេ បើយោងតាមបទបញ្ញាជាក់ស្តែងរបស់ ប.ក.ក ស្តីពីការព្រមព្រៀងរៀបការ នៅក្នុងទស្សនាវដ្តីទាំងនេះ។ មួយវិញទៀត សុន្ទរកថាស្តីពីការបង្កើនចំនួនប្រជាជនពាក់ព័ន្ធជាមួយ គោលបំណងនៃការកែលំអស្ថានភាពរស់នៅរបស់ប្រជាជន ដូចការលើកឡើង នៅក្នុងឯកសារផ្លូវការ និងគោលជំហរផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៀត គ្មានកំណត់ហេតុប្រជុំណាមួយអាចឱ្យសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការរំលោភសេពសន្ថវៈនៅក្នុងក្របខ័ណ្ឌនៃអាពាហ៍ពិពាហ៍ទាំងនេះឡើយ។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះមិនមានមូលដ្ឋានទេ និងត្រូវទុកជាមោឃៈ[3776]។

---

[3772] សំអាងហេតុសាលក្រម ផ្នែក *១៨.១.៣ ការដឹងឮនៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម*។

[3773] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៣។

[3774] សូមមើលខាងលើ កថាខណ្ឌ ១២៣៣-១២៤២។

[3775] សូមមើលខាងក្រោម កថាខណ្ឌ ២០២៥-២០២៨។

[3776] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៤ កថាខណ្ឌ ៤៣០៣-៤៣០៨ កថាខណ្ឌ ៤៣២៦-៤៣២៧។

## មាតិកាទី ៤. កំហុសពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម

## ជំពូកទី ១. សហឧក្រិដ្ឋកម្មរួមតាមផ្លូវច្បាប់

១៩៣៨. សហឧក្រិដ្ឋកម្មរួម-ទម្រង់ទី១ ជាទម្រង់ទំនួលខុសត្រូវដែលត្រូវបានកំណត់ជាលើក ដំបូងដោយសាលាក្តីចំពោះកិច្ច ដោយផ្អែកលើអត្ថបទ និងយុត្តិសាស្ត្រក្រោយសង្គ្រាម លោកលើកទី២[3777]។ ធាតុផ្សំនៃទម្រង់ទំនួលខុសត្រូវនេះ សង្កត់ធ្ងន់ជុំវិញគោលបំណង ឧក្រិដ្ឋរួម ដែលមានទិសដៅតែមួយគត់ដូចគ្នា (ផ្នែកទី ១) និងចេតនាផ្ទាល់ក្នុងការ ប្រព្រឹត្តិឧក្រិដ្ឋកម្ម (ផ្នែកទី ២)

### ផ្នែកទី ១. ចរិតឧក្រិដ្ឋនៃគោលបំណង ស្ថិតត្រង់ធាតុផ្សំសត្យានុម័តិ

១៩៣៩. អង្គជំនុំជម្រះបានវិព្ញកយ៉ាងត្រឹមត្រូវថា ធាតុផ្សំសត្យានុម័តិនៃសហឧក្រិដ្ឋកម្មរួម មានសមាសធាតុសត្យានុម័តិបី រួមមាន មនុស្សច្រើននាក់ គោលបំណងរួមដែលមានចរិតឧក្រិដ្ឋក្នុងការប្រព្រឹត្តិ ឬចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្ម និងការចូលរួមចំណែកយ៉ាងសំខាន់របស់ជនជាប់ចោទក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មរងការចោទប្រកាន់[3778]។ ចំណុចស្នូលនៃធាតុផ្សំសត្យានុម័តិ គឺចរិតឧក្រិដ្ឋនៃគោលបំណងរួម (១) ដែលត្រូវតែកំណត់ឱ្យបានជាក់លាក់តាមរយៈការចូលរួមចំណែកដ៏សំខាន់របស់ជនជាប់ចោទ ដែលជាមូលដ្ឋាននៃការសម្រេចលើពិរុទ្ធភាព (២)។

#### ១. គោលបំណងរួមមានចរិតឧក្រិដ្ឋ

១៩៤០. លក្ខណៈវិនិច្ឆ័យគតិយុត្តិដែលជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ត្រូវបានវិព្ញកយ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះ (១.១) ប៉ុន្តែ ការពិពណ៌នាអំពីអង្គច្បាប់ជាធរមានរបស់អង្គជំនុំជម្រះ ពុំបំភ្លឺឱ្យបានគ្រប់គ្រាន់ ឬត្រឹមត្រូវ លើចំណុចច្បាប់ជាក់លាក់ដែលជាបណ្តឹបញ្ហាវិវាទពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០២ (១.២)។

---

[3777] សូមមើលសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣២-៤៣៧។

[3778] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧០៨។

## ១.១. ការរំឭកពីអង្គច្បាប់បានយ៉ាងត្រឹមត្រូវ ប៉ុន្តែមិនពេញលេញ និងពិបាកយល់

១៩៤១. អង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវថា "គោលបំណងរួមតម្រូវឱ្យមាន គោលដៅចម្បង ឬគោលដៅមួយក្នុងចំណោមគោលដៅចម្បងនានា ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម (ពោលគឺ ការសម្រេចគោលបំណងនេះត្រូវតែ "ប្រព្រឹត្តបទឧក្រិដ្ឋមួយ") ឬមានគម្រោងប្រព្រឹត្តបទឧក្រិដ្ឋមួយ ឬច្រើន ជាមធ្យោបាយដើម្បីសម្រេចគោលដៅមួយ ទោះគោលដៅនោះមិនមានចរិតឧក្រិដ្ឋផ្ទាល់ក៏ដោយ (ពោលគឺវា "តម្រូវឱ្យមាន" ការប្រព្រឹត្តិឧក្រិដ្ឋកម្ម"[3779]។

១៩៤២. ការរំឭកអំពីច្បាប់នេះត្រឹមត្រូវហើយ ប៉ុន្តែខ្លីពេក វាមិនអាចឱ្យមានការកំណត់ក្របខ័ណ្ឌគតិយុត្តិដែលបំភ្លឺដល់បញ្ហាស្នូល និងជាក់លាក់នៃសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០២ បានឡើយ។ ជាក់ស្ដែង ការអនុវត្តទ្រឹស្ដីសហឧក្រិដ្ឋកម្មរួមនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០២ រួមបញ្ចូលគ្នានូវធាតុផ្សំស្មុគស្មាញចំនួនបី ដែលធ្វើឱ្យទម្រង់ទំនួលខុសត្រូវនេះប្រទាញប្រទង់គ្នាជាមួយនឹងគោលការណ៍ចម្បងនៃទំនួលខុសត្រូវបុគ្គល (១.១.១)។ យោងតាមដីកាដំណោះស្រាយ ខៀវ សំផន ត្រូវតែឆ្លើយតបទៅនឹងការចោទប្រកាន់ថាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមទ្រង់ទ្រាយធំមួយ (១.១.២) ដោយមានគោលបំណងមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់ (១.១.៣) ហើយដែលក្នុងនោះ ចារីសំខាន់ៗមិនចាំបាច់ទាល់តែជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនេះទេ (១.១.៤)។ គួរគប្បីរំឭកអំពីអង្គច្បាប់ដែលគ្របដណ្ដប់លើបញ្ហាទាំងនេះ។

### ១.១.១. គោលការណ៍គ្មានបទល្មើស គ្មានទោស

១៩៤៣. គោលការណ៍ជាមូលដ្ឋានស្ដីពីទំនួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសាលដីកាចំនួនពីរដែលជាគ្រឹះនៃនីតិព្រហ្មទណ្ឌអន្តរជាតិ។ ជាការពិត តុលាការយោធាអន្តរជាតិ Nuremberg បានសង្កត់ធ្ងន់លើសារៈសំខាន់របស់វាដូចតទៅនេះ៖

---

[3779] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧០៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

"គេនឹងកត់សម្គាល់ឃើញថា មាត្រា៩ប្រើពាក្យ "តុលាការនឹងអាចសម្រេច"។ ដូច្នេះតុលាការមានអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចថាអង្គការមួយជាអង្គការឧក្រិដ្ឋ។ អំណាចឆន្ទានុសិទ្ធិនេះគឺជាអំណាចតុលាការ។ អំណាចនេះមិនអនុញ្ញាតឱ្យចៅក្រមបំពេញកិច្ចតាមទំនើងចិត្តឡើយ។ អំណាចនេះ ត្រូវតែបានអនុវត្តស្របតាមគោលការណ៍ច្បាប់ជាធរមាន ដែលក្នុងនោះ មានគោលការណ៍សំខាន់បំផុតមួយ គឺ "ពិរុទ្ធភាពបុគ្គល ដែលដកចេញនូវការដាក់ទណ្ឌកម្មជាសមូហភាព[3780]។

១៩៤៤. ក្នុងន័យដូចគ្នានេះដែរ សាលដីកា *Tadić* បានសង្កត់ធ្ងន់លើ៖

"សម្មតិកម្ម [...] ថា នៅក្នុងច្បាប់អន្តរជាតិក៏ដូចជានៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ការទទួលខុសត្រូវព្រហ្មទណ្ឌផ្អែកលើគោលការណ៍ពិរុទ្ធភាពជាលក្ខណៈបុគ្គល៖ គ្មាននរណាម្នាក់អាចដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើ ឬប្រតិបត្តិការ ដែលគាត់មិនបានពាក់ព័ន្ធដោយផ្ទាល់ ឬមិនបានចូលរួមក្រោមរូបភាពណាមួយឡើយ ("គោលការណ៍គ្មានបទល្មើសគ្មានទោស")[3781]។

១៩៤៥. សហឧក្រិដ្ឋកម្មរួមជាទម្រង់ទំនួលខុសត្រូវដែលគាំទ្រដោយរដ្ឋអាជ្ញា ប៉ុន្តែវាមានគ្រោះថ្នាក់ ដោយសារវាអាចពង្រីកទំហំនៃការទទួលខុសត្រូវព្រហ្មទណ្ឌរហូតដល់ថ្នាក់ផ្ដាច់ចំណងពាក់ព័ន្ធជាមួយនឹងគោល

---

[3780] *ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ* ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៤៦ តុលាការយោធាអន្តរជាតិ វ៉ុល ១ ទំព័រ ២៥៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3781] សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៨៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ សាលក្រម *Kordic និង Cerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៣៦៤, សាលដីកា *Brima* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ៧២, សាលដីកា *Sesay* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ៣១២, សាលដីកា *Taylor* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ ៣៨៧។

ការណ៍ទំនួលខុសត្រូវបុគ្គល។ ហានិភ័យមានទំហំធំធេង កាលណាទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ត្រូវបាន អនុវត្តនៅក្នុងសេណារីយ៉ូអង្គហេតុដែលអំពើឧក្រិដ្ឋកម្មស្ថិតនៅសែនឆ្ងាយពីបុគ្គលដែលជាគោលដៅនៃ ការចាប់ឱ្យទទួលខុសត្រូវ។ ជាពិសេស គឺករណីក្នុងសំណុំរឿង ០០២ នេះតែម្តង។ ទ្រឹស្តីសហឧក្រិដ្ឋ កម្មរួម ដូចបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ ច្របាច់បូកបញ្ចូលគ្នានូវរាល់ធាតុផ្សំដែលអាចផ្តាច់ ចំណងពាក់ព័ន្ធរវាងអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម និងឧក្រិដ្ឋកម្ម។

### ១.១.២. ភាពច្បាស់លាស់ជាចាំបាច់ ចំពោះគោលបំណងរួមទ្រង់ទ្រាយធំ

១៩៤៦. បញ្ហានៃភាពអនុវត្តបាននៃទម្រង់ទំនួលខុសត្រូវនេះក្នុងករណីសហឧក្រិដ្ឋរួម "ទ្រង់ទ្រាយធំ" ត្រូវបាន លើកឡើងក្នុងរឿងក្តី *Brđanin* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ ចៅក្រមសាលាដំបូងបានសម្រេចឱ្យជនជាប់ចោទរួចផុតពីទោស និងបានពិចារណាជាអាទិ៍ថា៖

> "អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាមិនសមរម្យទេក្នុងការយកទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទមកចោទជាបញ្ហា ដោយឈរលើមូលដ្ឋាននៃការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមមួយបើគិតពីទំហំនៃការចោទប្រកាន់ក្នុងរឿងក្តីនេះ ដែលរដ្ឋអាជ្ញាព្យាយាមដាក់បញ្ចូលទៅក្នុងសហឧក្រិដ្ឋកម្មរួម នូវបុគ្គលម្នាក់ដែលបើតាមមុខតំណែងរបស់គាត់ គឺគាត់ស្ថិតនៅឃ្លាតឆ្ងាយពីការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់លើគាត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សហឧក្រិដ្ឋរួម អាចអនុវត្តក្នុងករណីនៃការបោសសម្អាតជនជាតិភាគតិច ដូចដែលត្រូវបានទទួលស្គាល់នៅក្នុងសាលដីកានៃរឿងក្តី *Tadić* ក៏មែនពិត ក៏ប៉ុន្តែ នៅពេលដែលសាលាឧទ្ធរណ៍កំណត់និយមន័យនៃសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះនេះដឹងយ៉ាងច្បាស់ថាបំណងឧក្រិដ្ឋរួមនេះ មានទំហំតូចជាងផែនការដែលរងការចោទប្រកាន់ក្នុងរឿងក្តីនេះ។ ការពិនិត្យលើរឿងក្តីដែលតុលាការបានវិនិច្ឆ័យ ដែលក្នុងនោះទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានអនុវត្ត បញ្ជាក់គាំទ្រដល់ទស្សនៈនេះ"[3782]។

[3782] សាលក្រម *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៣៥៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ កំណត់សម្គាល់ជើងទំព័រលេខ ៨៩០៖ "ក្នុងរឿងក្តីនៅចំពោះមុខ

១៩៤៧. ទោះបីជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានទទួលស្គាល់ថា វាអាចទៅរួចក្នុងការគិតពីទំនួលខុសត្រូវក្នុងរឿងក្តីដ៏ធំអស្ចារ្យបែបនេះក៏ដោយ ក៏ខ្លួនបានសង្កត់ធ្ងន់លើលក្ខខ័ណ្ឌតឹងរ៉ឹងនៃការអនុវត្តសហឧក្រិដ្ឋកម្មរួម[3783]ដែរ។ ជាពិសេស "ក្នុងរឿងក្តីបែបនេះ [ត្រូវតែ] កំណត់គោលបំណងឧក្រិដ្ឋរួម ឱ្យបានជាក់លាក់គ្រប់គ្រាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយវាត្រូវតែត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ"[3784]។

១៩៤៨. អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏បានរំឭកដែរថា "សហឧក្រិដ្ឋកម្មរួមមិនមែនជាទស្សនទានគ្មានដែនកំណត់ដែលអាចឱ្យសន្និដ្ឋានពីពិរុទ្ធភាពរបស់ជនជាប់ចោទ តាមវិធីភ្ជាប់ទំនាក់ទំនងនោះទេ"[3785]។ ទាក់ទងនឹងការកំណត់បទល្មើសនៃបំណងឧក្រិដ្ឋរួមនេះ ចាំបាច់ត្រូវ៖

> "កំណត់គោលដៅឧក្រិដ្ឋរួម ដោយបញ្ជាក់គោលបំណងឧក្រិដ្ឋដែលបានគិតទុកផង និងវិសាលភាពរបស់វាផង (ឧទាហរណ៍ តាមរយៈវិសាលភាពលំហ និងទេសកាល នៃសហឧក្រិដ្ឋកម្មរួម និងលក្ខណៈសម្គាល់ទូទៅនៃជនរងគ្រោះ) ត្រូវតែរកឱ្យឃើញថាអ្នកចូលរួមមិនត្រឹមតែមានគោលបំណងឧក្រិដ្ឋដូចគ្នាប៉ុណ្ណោះទេ គឺថែមទាំងប្រព្រឹត្តរួមគ្នា ក្នុងក្របខ័ណ្ឌនៃសហ

---

តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមត្រូវបានអនុវត្តចំពោះអំពើដែលមានវិសាភាពតូចជាង កម្រិតត្រឹមប្រតិបត្តិការយោធាជាក់លាក់ និងសមាជិកកងកម្លាំងប្រដាប់អាវុធ (សាលក្រម *Krstić* កថាខណ្ឌ ៦១០) ទីតាំងភូមិសាស្ត្រតឹតត្បិត (សាលក្រម *Simić* កថាខណ្ឌ ៩៨៤ និង ៩៨៥) និងជនប្រដាប់អាវុធមួយក្រុមតូច ដែលធ្វើសកម្មភាពព្រមគ្នាដើម្បីប្រព្រឹត្តបទឧក្រិដ្ឋមួយ (សាលដីកា *Tadić* ទំព័រ ២៣២ និងទំព័របន្តបន្ទាប់, សាលក្រម *Vasiljević* កថាខណ្ឌ ២០៨) ឬជំរំឃុំឃាំងតែមួយ ក្នុងករណីសហឧក្រិដ្ឋកម្មរួម ទម្រង់ទី២ (សាលក្រម *Krnojelac* កថាខណ្ឌ ៨៤)" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3783] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤២៩-៤៣០។

[3784] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤២៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3785] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤២៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ឧក្រិដ្ឋកម្មរួម និងរកឱ្យឃើញការចូលរួមចំណែករបស់ជនជាប់ចោទក្នុងការសម្រេចបាននូវគោលបំណងរួម"[3786]។

១៩៤៩. អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបញ្ចប់ដោយសង្កត់ធ្ងន់ទៅលើខ្លឹមសារឧក្រិដ្ឋនៃសហឧក្រិដ្ឋកម្មរួម៖

"ការអនុវត្តទំនួលខុសត្រូវរបស់គាត់ចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវមានភស្តុតាងគាំទ្រគ្រប់គ្រាន់ និងត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ ថា ជនជាប់ចោទមិនមែនបានត្រឹមតែសេពគប់ឧក្រិដ្ឋជនប៉ុណ្ណោះទេ គឺថែមទាំងមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ គាត់បានសហការជាមួយអ្នកដទៃទៀតដើម្បីសម្រេចគោលដៅនេះ ហើយបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងបទឧក្រិដ្ឋនេះ"[3787]។

### ១.១.៣. គោលបំណងមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តងទេ ប៉ុន្តែសម្រេចបានដោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម

១៩៥០. គេត្រូវកំណត់ចេតនាឧក្រិដ្ឋឱ្យបានហ្មត់ចត់ ក្នុងករណីគោលបំណងរួមមិនមានចរិតឧក្រិដ្ឋផ្ទាល់តែម្តង។ ជាគោលការណ៍ គោលបំណងឧក្រិដ្ឋរួមរួមត្រូវបានចាត់ទុកថាមានលក្ខណៈឧក្រិដ្ឋ ព្រោះថា **គោលដៅចម្បងមួយ ឬច្រើន គឺការប្រព្រឹត្តិឧក្រិដ្ឋកម្ម**។ ដូច្នេះ យោងតាមឧទាហរណ៍គំរូ នៅក្នុងសាលដីការឿងក្តី *Tadić* "ក្នុងករណីបង្កើតគម្រោងសម្លាប់មនុស្ស ក្នុងពេលសម្រេចគោលដៅរួមនេះ (ទោះបីសហចារីម្នាក់ៗមានតួនាទីខុសគ្នាក្នុងកិច្ចការនេះក៏ដោយ) សហចារីនៃគម្រោងសុទ្ធតែមានចេតនាសម្លាប់"[3788]។

---

[3786] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3787] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣១។

[3788] សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៩៥១ ចេតនាឧក្រិដ្ឋដែលជាស្នូលនៃទំនួលខុសត្រូវបុគ្គល ត្រូវតែមានលក្ខណៈច្បាស់លាស់ មិនច្រឡំបល់ និងផ្ទាល់។ ក្នុងករណីគោលបំណងមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តង ជានិច្ចកាល ទិដ្ឋភាពឧក្រិដ្ឋត្រូវតែជាស្នូលនៃគោលបំណងឧក្រិដ្ឋរួម។ ក្នុងសម្មតិកម្មនេះ គោលបំណងនេះអាចត្រូវបានកំណត់ថាមានចរិតឧក្រិដ្ឋ តែក្នុងករណីដែលការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬច្រើន គឺជាមធ្យោបាយដើម្បីសម្រេចគោលដៅដែលមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តង។ និយាយម្យ៉ាងទៀត ចំពោះសហឧក្រិដ្ឋកម្មរួម-ទម្រង់ ១ ការធ្វើតេស្តដើម្បីកំណត់ថាតើគោលបំណងរួមមានលក្ខណៈឧក្រិដ្ឋ ឬអត់ អាចបំព្រួញមកត្រឹមសមីការខាងក្រោម៖

- គោលបំណងរួម = ឧក្រិដ្ឋកម្ម (ឧទាហរណ៍ "សហឧក្រិដ្ឋកម្មរួមដើម្បីធ្វើមនុស្សឃាត")[3789] ឬ
- គោលបំណងរួម = ផែនការ X ដោយប្រព្រឹត្តបទឧក្រិដ្ឋ (ឧទាហរណ៍ "បង្កើតទឹកដីមួយសម្រាប់តែជនជាតស៊ែប៊ី ដោយបណ្តេញប្រជាជនក្រូអាត និងបរទេស នេះជាឧក្រិដ្ឋកម្មនៅក្នុងបទចោទទី ១០ និង ១១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[3790]។

## ១.១.៤. ចំណងពាក់ព័ន្ធជាមួយចារីបង្គោលដែលមិនចាំបាច់តែជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម

១៩៥២. អង្គជំនុំជម្រះបានអះអាងថា អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម អាចដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលចារីបង្គោល មិនមែនជាអ្នកចូលរួមក្នុងផែនការរួមនេះ[3791]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស

---

[3789] សាលក្រម *Popovic* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨០៥។

[3790] សាលក្រម *Martić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ ៤៤៥ តម្កល់នៅដំណាក់កាលបណ្តឹងសាទុក្ខ នៅក្នុងសាលដីកា *Martić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ១១២។ សូមមើលផងដែរ៖ សាលក្រម *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ១០៩៧, សាលក្រម *Prlić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ៤១, សាលដីកា *Brima* (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ៧៦ ៨១-៨២ ៨៤។

អង្គច្បាប់ ដោយបានកំណត់លក្ខណៈវិនិច្ឆ័យគតិយុត្តិជាធរមានដើម្បីវាយតម្លៃថា តើមានចំណងពាក់ព័ន្ធគ្រប់គ្រាន់រវាងជនដៃដល់ និងអ្នកចូលរួមណាម្នាក់នៅក្នុងគោលបំណងរួមដែរ ឬអត់។ វាមិនត្រឹមត្រូវទេក្នុងការកំណត់លក្ខណៈវិនិច្ឆ័យមួយដែលតម្រូវថា "អ្នកចូលរួមក្នុងគោលបំណងរួមនេះ [បាន] ប្រើចារីម្នាក់ក្នុងចំណោមចារីបង្គោល ក្នុងគោលបំណងចូលរួមចំណែកដល់ការសម្រេចគោលបំណងរួម"[3792]។

១៩៥៣. អង្គជំនុំជម្រះបានផ្អែកលើសាលដីការឿងក្តី *Brđanin និង Krajišnik* ដើម្បីគាំទ្រការអះអាងនេះ[3793]។ ក៏ប៉ុន្តែ សាលដីការឿងក្តី *Brđanin* ដែលត្រូវបានយកជាគំរូដោយសាលដីការឿងក្តី *Krajišnik* តម្រូវឱ្យអ្នកចូលរួមម្នាក់នៅក្នុងគោលបំណងរួម [បាន] ប្រើចារីសំខាន់ទាំងអស់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ("ចារីសំខាន់នៃឧក្រិដ្ឋកម្ម" ឬ "នៅពេលប្រើជនដៃដល់បង្គោល")[3794]។ ដូច្នេះ គេត្រូវបង្ហាញពីចំណងពាក់ព័ន្ធជាមួយចារីបង្គោលនីមួយៗ ប្រសិនបើឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដោយចារីបង្គោលច្រើននាក់។ លើសពីនេះទៀត ក្នុងករណីដែលអ្នកចូលរួមត្រូវចាប់ឱ្យទទួលខុសត្រូវចំពោះអំពើដែលបានប្រព្រឹត្តដោយបុគ្គលម្នាក់ទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការកំណត់និយមន័យគោលបំណងឧក្រិដ្ឋ ឱ្យបានហ្មត់ចត់៖

> "អង្គជំនុំជម្រះសាលាឧទ្ធរណ៍អះអាងថា ការប្រើទស្សនទាននៃសហឧក្រិដ្ឋកម្មរួមដើម្បីកំណត់ទំនួលខុសត្រូវបុគ្គលចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តផ្ទាល់ដោយអ្នកដទៃទៀត តម្រូវឱ្យមាន

[3791] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១១។

[3792] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3793] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១១ កំណត់សម្គាល់ជើងទំព័រលេខ ១២៣៦៩។

[3794] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០, សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ២២៥។

និយមន័យតឹងរ៉ឹងនៃគោលបំណងរួម។ គោលការណ៍នេះត្រូវអនុវត្ត ដោយមិនអាស្រ័យលើប្រភេទនៃសហឧក្រិដ្ឋកម្មរួមរងការចោទប្រកាន់ឡើយ”[3795]។

## ១.២. ការពង្រីកវិសាលភាពនៃគោលបំណងឧក្រិដ្ឋរួមទៅតាមពេលវេលា

១៩៥៤. អង្គជំនុំជម្រះបានរំឭកយ៉ាងត្រឹមត្រូវថា “ខ្លឹមសារនៃគម្រោង ផែនការ ឬគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមអាចប្រែប្រួល និងផ្លាស់ប្តូរតាមពេលវេលាដើម្បីបញ្ចូលឧក្រិដ្ឋកម្មបន្ថែម”[3796]។ ក៏ប៉ុន្តែគប្បីត្រូវរំឭកអំពីស្តង់ដារជាធរមានចំពោះភ័ស្តុតាងទេសកាល (១.២.១) និងតម្រូវការចាំបាច់នូវភាពច្បាស់លាស់អំពីកាលប្បវត្តិ (១.២.២)។

### ១.២.១. ភ័ស្តុតាងទេសកាល

១៩៥៥. អង្គជំនុំជម្រះបានរំឭកថា ការព្រមព្រៀងឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មថ្មី ដើម្បីសម្រេចគោលបំណងឧក្រិដ្ឋរួម អាចត្រូវបានទាញសន្និដ្ឋានចេញពីកត្តាទេសកាល ជាពិសេស ក្នុងស្ថានភាពដែលអ្នកចូលរួមត្រូវបាន “ជូនដំណឹងថាឧក្រិដ្ឋកម្មផ្សេងៗគ្នាត្រូវបានប្រព្រឹត្ត ដើម្បីសម្រេចគោលបំណងរួម ហើយពួកគេមិនចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការប្រព្រឹត្តិបទឧក្រិដ្ឋប្រភេទនោះ ហើយនៅបន្តអនុវត្តគោលបំណងរួម”[3797]។ អង្គជំនុំជម្រះពឹងផ្អែកលើសាលដីកា *Krajišnik* របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលជាយុត្តិសាស្ត្រផ្ទុវការ។ ចៅក្រមមិនបានផ្តល់ប្រភពច្បាប់ណាមួយ ដើម្បីគាំទ្រដល់ការអះអាងនេះទេ ដែលជាផ្នែកមួយនៃការវិភាគជាក់ស្តែង។ អាស្រ័យហេតុនេះ សូមរំឭកថា វាត្រូវតែជាការសន្និដ្ឋានសមហេតុផលតែមួយគត់។

---

[3795] សាលដីកា *Krnojelac* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ១១៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3796] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧០៩។

[3797] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧០៩ កំណត់សម្គាល់ជើងទំព័រលេខ ១២៣៦១ យោងដល់សាលក្រម *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ១០៩៨។

### ១.២.២. ការសន្និដ្ឋានលើអង្គហេតុជាក់លាក់ និងកាលប្បវត្តិចាំបាច់

១៩៥៦. ក្នុងរឿងក្តី *Krajišnik* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបដិសេធការប្រកាសពិរុទ្ធភាពរបស់ *Krajišnik* ចំពោះបទឧក្រិដ្ឋថ្មី ដោយចោទទោសអំពីអវត្តមានសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ជាពិសេស ទាក់ទងនឹងកាលប្បវត្តិនៃព្រឹត្តិការណ៍។ ដូច្នេះ សាលាឧទ្ធរណ៍បានបដិសេធការសន្និដ្ឋានព្រាវៗអំពីអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែល *"ចាំបាច់ត្រូវបង្ហាញឱ្យបានច្បាស់អំពីរបៀប និងពេលដែលវិសាលភាពនៃគោលបំណងរួមត្រូវបានពង្រីក"* និងត្រូវបង្ហាញថាតើ *"នៅចំណុចណានៃពេលវេលា សមាជិកជាថ្នាក់ដឹកនាំនៃសហឧក្រិដ្ឋកម្មរួម បានដឹងអំពីបទឧក្រិដ្ឋថ្មីផ្សេងៗ និងថាតើ "នៅពេលណា សមាជិកថ្នាក់មូលដ្ឋាននៃគោលបំណងរួម បានដឹងអំពីឧក្រិដ្ឋកម្មដែលបានរីករាលដាលនេះ"*[3798]។

## ២. ការចូលរួមចំណែកសំខាន់ចាំបាច់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់

១៩៥៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថាមានគោលការណ៍ទូទៅមួយដែលចែងថា ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អាចមានទម្រង់ជាអំពើអកម្មមានពិរុទ្ធ (២.១)។ លើសពីនេះទៀត នៅក្នុងក្របខ័ណ្ឌនៃគោលបំណងរួមដែលមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តង ការចូលរួមចំណែកក្នុងគោលបំណងរួម ត្រូវតែទាក់ទងទៅនឹងទំហំឧក្រិដ្ឋកម្ម (២.២)។

### ២.១. ការចូលរួមក្នុងគោលបំណងរួមតាមរយៈអំពើអកម្មមានពិរុទ្ធ គ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ

១៩៥៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនបានផ្តល់សំអាងហេតុគាំទ្រដល់ការអះអាងរបស់ខ្លួនអំពីអត្ថិភាពនៃគោលការណ៍ទូទៅមួយដែលត្រូវបានអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែល

---

[3798] សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ១៧១ ១៧៥-១៧៦ ២០៣។

ចែងថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយអាចបណ្ដាលមកពីអំពើអកម្មមានពិរុទ្ធ ចាប់ពីពេលណាកាតព្វកិច្ចផ្លូវច្បាប់តម្រូវឱ្យធ្វើសកម្មភាព ដោយអនុលោមជាពិសេសតាមទម្រង់ទំនួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម[3799]។ អង្គជំនុំជម្រះមិនបានផ្ដល់មូលដ្ឋានច្បាប់រឹងមាំសម្រាប់ការអះអាងលក្ខណៈទូទៅនេះទេ។ ម៉្យាង អង្គជំនុំជម្រះគ្រាន់តែយោងទៅសេចក្ដីសន្និដ្ឋានរបស់ខ្លួនក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ ហើយម៉្យាងទៀត គឺគ្រាន់តែយោងទៅកថាខណ្ឌដែលមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតនៅក្នុងសំអាងហេតុសាលក្រមក្នុងសំណុំរឿង ០០២/០២ (កថាខណ្ឌ ៦៩០ ស្ដីពីការឃុំឃាំង និង កថាខណ្ឌ ៧០១ ស្ដីពីទារុណកម្ម)។

១៩៥៩. ទាក់ទងទៅនឹងសំអាងហេតុសាលក្រមក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះមិនបានធ្វើការវាយតម្លៃផ្ទាល់ខ្លួនទេ គឺគ្រាន់តែបញ្ចូលកំណត់សម្គាល់ជើងទំព័រមួយដែលយោងទៅយុត្តិសាស្ត្រចំនួន ៣ របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងយោងទៅយុត្តិសាស្ត្រមួយទៀតរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា[3800]។ ក៏ប៉ុន្តែ សាលដីកាក្នុងរឿងក្ដី *Kvočka* របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មិនបានបង្កើត "គោលការណ៍ទូទៅ" ណាមួយទេ។ រីឯការសន្និដ្ឋាននៅក្នុងកថាខណ្ឌ ៦៦៣ នៃសាលដីកា *Blaškić* ដែលអង្គជំនុំជម្រះបានយោងធ្វើជាមូលដ្ឋាន បាន

---

[3799] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧០៣។

[3800] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កំណត់សម្គាល់ជើងទំព័រលេខ ២១៥៩៖ "សាលដីកា *Kvočka* របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី កថាខណ្ឌ ១៨៧ ៤២១ និង ៥៥៦។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានសម្រេចស្របគ្នាថា បទឧក្រិដ្ឋមួយអាចប្រព្រឹត្តឡើងដោយអំពើអកម្មដែលអាចនាំឱ្យមានពិរុទ្ធ ក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការ ហើយថា ជនជាប់ចោទអាចទទួលខុសត្រូវដោយផ្ទាល់ចំពោះការចូលរួមចំណែកចំពោះបទឧក្រិដ្ឋ តាមរយៈអំពើអកម្មនោះ ក្នុងស្ថានភាពដែលជនជាប់ចោទមានកាតព្វកិច្ចត្រូវចាត់វិធានការ (សូមមើល ឧទាហរណ៍ សាលដីកា *Blaškić* របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី កថាខណ្ឌ ៦៦៣, សាលដីកា *Galić* របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី កថាខណ្ឌ ១៦៨ និង ១៧៥, សាលដីកា *Ntagerura* របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា កថាខណ្ឌ ៣៣៤)"។

កំណត់ត្រឹមតែទ្រឹស្តីទំនួលខុសត្រូវក្នុងឋានៈជាមេ[3801]។ ទាក់ទងទៅនឹងសាលដីកាក្នុងរឿងក្តី *Galić* សេចក្តីយោងដែលបានបញ្ជាក់នៅក្នុង កថាខណ្ឌ ១៦៨ មានការភាន់ច្រឡំយ៉ាងជាក់ស្តែង ពីព្រោះកថាខណ្ឌនេះនិយាយអំពីបញ្ហាត្រួតទោស គឺមិនមែនទាក់ទងនឹងបញ្ហាអំពើអកម្មមានពិរុទ្ធនោះទេ។ ចំណែកឯកថាខណ្ឌ ១៧៥ គឺវាគ្រាន់តែសំដៅទៅលើសាលដីកា Ntagerura នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាដែលថែងថា ភាគីមិនបានជំទាស់នឹងលទ្ធភាពនៃការចាប់ជនជាប់ចោទឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើអកម្មនោះទេ[3802]។ លើសពីនេះទៅទៀត សាលដីកាក្នុងរឿងក្តី *Galić* លើកឡើងអំពីទំនួលខុសត្រូវក្នុងការបញ្ជា។ រឿងក្តី *Ntagerura* លើកឡើងអំពីបញ្ហានៃអំពើអកម្មមានពិរុទ្ធ ក្នុងឋានៈជាចារីបង្គោល តែមិនមែនក្នុងឋានៈជាសហឧក្រិដ្ឋកម្មរួមនោះទេ[3803]។

## ២.២. ការចូលរួមក្នុងគោលបំណងឧក្រិដ្ឋរួម

១៩៦០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវាយតម្លៃអំពីការចូលរួមចំណែករបស់អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម នៅក្នុងបរិបទនៃគោលបំណងរួមដែលមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តង ដោយសារការចូលរួមចំណែករបស់គាត់ក្នុងគោលបំណងរួម ក្នុងទិដ្ឋភាពមិនឧក្រិដ្ឋ[3804]។ អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមចាំបាច់ត្រូវតែបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលជាស្នូលនៃសហឧក្រិដ្ឋកម្មរួម[3805]។ កត្តានេះសមហេតុផល ពីព្រោះចាំបាច់ត្រូវតែបង្ហាញពីទំនាក់ទំនង

---

[3801] សាលដីកា *Blaškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៦៣។

[3802] សាលដីកា *Ntagerura* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ៣៣៤។

[3803] សាលក្រម *Ntagerura Ntagerura* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ៦៥៩។

[3804] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៥-៤២៥៦។

[3805] សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ៦៩៦ (“អ្វីដែលសំខាន់នៅក្នុងច្បាប់ គឺថា ជនជាប់ចោទបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងក្របខ័ណ្ឌនៃសហឧក្រិដ្ឋកម្មរួម”) (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) យោងដល់សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣០។

ហេតុ និងផល រវាងការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម និងការប្រព្រឹត្តិបទឧក្រិដ្ឋ។ យុត្តិសាស្ត្រក្រោយសង្គ្រាម នៅក្នុងរឿងក្តី *Ponzano* តម្រូវថា "ការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទក្នុងអំពើរងការចោទប្រកាន់ ត្រូវតែបង្ហាញពីទំនាក់ទំនងហេតុ និងផល"[3806]។

១៩៦១. ក្នុងការបង្ហាញអំពីច្បាប់ជាធរមាន ជាបឋម អង្គជំនុំជម្រះបានកត់សម្គាល់ថា "ការចូលរួមរបស់ជនជាប់ចោទ [...] អាចមានទម្រង់ជាការជួយជ្រោមជ្រែង ឬការរួមចំណែកក្នុងការសម្រេចគោលបំណងរួម"[3807]។ ដូច្នេះ អង្គជំនុំជម្រះមិនបានពិចារណាថាចាំបាច់ត្រូវមានការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មទេ ហើយថែមទាំងបានបន្ថែមទៀតថា "ការចូលរួមចំណែកនេះមិនចាំបាច់ជាល័ក្ខខ័ណ្ឌមិនអាចខ្វះបាន ដែលថាបើគ្មានការចូលរួមចំណែករបស់គាត់ទេ ឧក្រិដ្ឋកម្មមិនអាច ឬមិនត្រូវបានប្រព្រឹត្តនោះទេ"[3808]។ ទន្ទឹមនឹងនោះ អង្គជំនុំជម្រះបែរជារំឭកថា "ត្រូវតែមានទំនាក់ទំនងហេតុផល រវាងការចូលរួមចំណែកនេះ និងបទឧក្រិដ្ឋដែលបានប្រព្រឹត្ត"[3809]។

១៩៦២. នៅពេលអនុវត្តច្បាប់ទៅលើអង្គហេតុ អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ថា "ចាំបាច់ត្រូវកំណត់ថាតើជនជាប់ចោទបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ក្នុងក្របខ័ណ្ឌនៃគោលបំណងរួមដែរឬទេ" ទោះបីជាខ្លួនបានយល់ច្រឡំជាថ្មីម្តងទៀត ដោយបានលើកឡើងអំពី "<u>អំពើសកម្ម និងអកម្មរបស់ជនជាប់ចោទ</u>"[3810]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស នៅត្រង់ការអនុវត្តលក្ខណៈវិនិច្ឆ័យនេះតែម្តង ពីព្រោះនៅក្នុងការអនុវត្តជាក់ស្តែង ដោយមិនវាយតម្លៃលើការចូលរួមចំណែកដ៏

---

[3806] សូមមើល សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩០ ដកស្រង់ រឿងក្តី *Feurstein និងអ្នកឯទៀត* កិច្ចដំណើការនីតិវិធីជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាម នៅទីក្រុងហាំប៊ឺក ប្រទេសអាល្លឺម៉ង់ (ពីថ្ងៃទី០៤ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៤៨) សាលក្រមចេញ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៤៨ (ប្រតិចារឹកដើមត្រូវបានរក្សាទុកនៅការិយាល័យតម្កល់ឯកសារសាធារណៈ ស្រុក Kew ក្រុង Richmond, សំណៅចម្លងអាចរកបាននៅបណ្ណាល័យនៃតុលាការអន្តរជាតិ)។

[3807] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១០។

[3808] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១០។

[3809] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១០។

[3810] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

សំខាន់របស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ អង្គជំនុំជម្រះបែរជាបានត្រឹមតែសន្និដ្ឋានថា ជនជាប់ចោទបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងរួម[3811]។ យើងនឹងឃើញលម្អិតថាតើ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុគាំទ្រដល់ការចូលរួមចំណែករបស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋយ៉ាងដូចម្តេច តាមរយៈការចូលរួមរបស់គាត់ក្នុងទិដ្ឋភាពមិនឧក្រិដ្ឋនៃគោលបំណង[3812]។

## ផ្នែកទី ២. ធាតុផ្សំអត្តនោម័តិ៖ ចេតនាប្រព្រឹត្តបទឧក្រិដ្ឋរួម នៅចំស្នូលនៃគោលបំណងរួម

១៩៦៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានថែងថា ធាតុផ្សំអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួម អាចត្រូវបានកំណត់តែតាមរយៈចេតនាប៉ុណ្ណោះ គឺចេតនា**ចូលរួម**ក្នុងគោលបំណងរួម និងចេតនាប្រព្រឹត្តបទឧក្រិដ្ឋដែលចេញមកពីគោលបំណងនោះ[3813]។ តាមពិត ច្បាប់ចែងថាជនជាប់ចោទត្រូវតែមានចេតនាចូលរួមក្នុងការ**សម្រេចបាន**ទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួមផង និងចេតនាប្រព្រឹត្តបទឧក្រិដ្ឋផង[3814]។ ជាក់ស្តែង នៅក្នុងសហឧក្រិដ្ឋកម្មរួម-ទម្រង់ ១ គម្រោងគឺជាបទឧក្រិដ្ឋ។ អាស្រ័យហេតុនេះហើយបានជាមានការច្របាច់បញ្ចូលគ្នារវាងចេតនាចូលរួមក្នុងគោលបំណង និងចេតនាប្រព្រឹត្តបទឧក្រិដ្ឋ។

១៩៦៤. ដើម្បីត្រឡប់ទៅឧទាហរណ៍ដែលបានបង្ហាញនៅក្នុងរឿងក្តី *Tadić* "ក្នុងករណីបង្កើតគោលបំណងសម្លាប់មនុស្ស ក្នុងពេលសម្រេចគោលដៅរួមនេះ (ទោះបីសហចារីម្នាក់ៗមានតួនាទីខុសគ្នាក្នុងកិច្ចការ

[3811] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧-៤២៧៨។

[3812] សូមមើលខាងក្រោម កថាខណ្ឌ ២០០១-២០៣០។

[3813] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១២-៤២៧៩។

[3814] សាលដីកា *Stanišić et Župljanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ៣៧៥, សាលដីកា *Popović* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១៣៦៩, សាលដីកា *Munyakazi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦០, សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៣៦៥។

នេះក៏ដោយ) សហចារីទាំងអស់នៃគម្រោងសុទ្ធតែមានចេតនាសម្លាប់”[3815]។ សូម្បីតែក្នុងករណីសហឧក្រិដ្ឋកម្មរួម-ទម្រង់១ ដែលគោលបំណងមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តងក៏ដោយ ក៏ចេតនាចូលរួមក្នុងការសម្រេចគោលបំណងក្រោមទិដ្ឋភាពឧក្រិដ្ឋ ស្ថិតនៅចំណុចស្នូលនៃធាតុផ្សំអត្តនោម័តិដែរ។ លក្ខណៈវិនិច្ឆ័យសម្រាប់សហឧក្រិដ្ឋកម្មរួម-ទម្រង់ ១ មានលក្ខណៈច្បាស់ណាស់៖ “ធាតុផ្សំចាំបាច់គឺចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ណាមួយ (សហចារីទាំងអស់សុទ្ធតែមានចេតនានេះដូចគ្នា)”[3816]។

១៩៦៥. ក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានបដិសេធមូលដ្ឋានបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ដោយលើកហេតុផលថាវាមិនមែនជាកំហុសអង្គច្បាប់ទេ ពីព្រោះអង្គជំនុំជម្រះបានតម្រូវ “នៅក្នុងកថាខណ្ឌដដែលថា អ្នកចូលរួមក្នុងសហឧក្រិដ្ឋរួម ចាំបាច់ត្រូវតែមានចេតនាដូចគ្នានឹងចារីបង្គោលនៃឧក្រិដ្ឋកម្មរងការចោទប្រកាន់ ពោលគឺមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់មួយ”[3817]។ ទោះយ៉ាងនេះក្តី វាមិនធ្វើឱ្យផ្លាស់ប្តូរអ្វីទាល់តែសោះដល់ល័ក្ខខ័ណ្ឌតម្រូវស្តីពីចេតនាដែលអង្គជំនុំជម្រះបានផ្តល់និយមន័យខុស ក្នុងសំណុំរឿង ០០២/០១ និងក្នុងសំណុំរឿង ០០២/០២។ ព្យសនកម្មមានពិតជាក់ស្តែង ពីព្រោះការបង្កើតច្បាប់មិនត្រឹមត្រូវនេះ បណ្តាលឱ្យមានការបែងចែកឱ្យដាច់ពីគ្នារវាងគោលបំណង និងបទឧក្រិដ្ឋ។ ជាពិសេស ក្នុងក្នុងរឿងក្តីនេះ អង្គជំនុំជម្រះបានទាញការសន្និដ្ឋានថាមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ដោយគ្រាន់តែផ្អែកលើការចូលរួមក្នុងគម្រោងប៉ុណ្ណោះ។ ក៏ប៉ុន្តែ ក្នុងសហឧក្រិដ្ឋម្មរួមទម្រង់ទី១ គោលបំណងចាំបាច់ត្រូវតែជាឧក្រិដ្ឋកម្ម និង នៅក្នុងក្របខ័ណ្ឌនៃគោលបំណងមិនមែនលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តង ហើយ ការចូលរួមចំណែកត្រូវតែផ្តោតទៅលើទិដ្ឋភាពឧក្រិដ្ឋនៃគម្រោង។ ការបែងចែកធ្វើឡើងដោយអង្គជំនុំជម្រះដែលបណ្តាលឱ្យល័ក្ខខ័ណ្ឌតម្រូវនៃចេតនាឧក្រិដ្ឋរលាយសាបសូន្យ មិនត្រឹមត្រូវនោះទេ។

---

[3815] សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៩៦។

[3816] សាលដីកា *Tadić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២២៨។

[3817] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០៥៣។

## ជំពូកទី ២. ការប្រព្រឹត្តិកំហុសដើម្បីគេចចេញពីធាតុផ្សំសត្យានុម័តិ

## ផ្នែកទី ១. ការវិវត្តកាលប្បវត្តិនៃសហឧក្រិដ្ឋកម្មរួម និងការកំណត់និយមន័យនៃគោលបំណងរួម

១៩៦៦. ក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ តុលាការកំពូលបានគូសបញ្ជាក់យ៉ាងច្បាស់អំពីបញ្ហាសំខាន់ទាក់ទងនឹងការកំណត់ប្រភេទបទល្មើសនៃគោលបំណងរួម៖

> "គោលបំណងរួមគឺជាចំណុចស្នូលនៃទម្រង់ទំនួលខុសត្រូវ ពីព្រោះធាតុផ្សំនេះចងភ្ជាប់សមាជិកទាំងអស់ជាមួយសហឧក្រិដ្ឋកម្មរួម និងផ្តល់យុត្តិកម្មដល់ការចោទប្រកាន់សមាជិកនីមួយៗចំពោះអំពើរៀងៗខ្លួនរបស់ពួកគេ ដើម្បីឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ ទោះយ៉ាងនេះក្តី ដើម្បីផ្តល់យុត្តិកម្មដល់ការចោទប្រកាន់បែបនេះ វាមិនគ្រប់គ្រាន់ទេដោយគ្រាន់តែសមាជិកដែលព្រមព្រៀងធ្វើសកម្មភាពរួមគ្នា ស្ម័គ្រចិត្តចូលរួមក្នុងគោលបំណងរួមណាមួយនោះ។ ទន្ទឹមនឹងនេះ គោលបំណងនេះចាំបាច់ត្រូវមានលក្ខណៈឧក្រិដ្ឋទៀតផង"[3818]។

១៩៦៧. គួរកត់សម្គាល់ថាក្នុងសំណុំរឿង ០០២ សហឧក្រិដ្ឋកម្មរួម-ទម្រង់ទី ១ បានទទួលរងនូវការបង្ខូចទម្រង់យ៉ាងខ្លាំងបំផុតក្នុងដំណាក់កាលផ្សេងៗនៃនីតិវិធី។ ការបង្ខូចទម្រង់ទាំងនេះមានគោលបំណងបំពេញបង្គ្រប់លក្ខណៈមិនឧក្រិដ្ឋផ្ទាល់តែម្តងនៃគោលនយោបាយរបស់ ប.ក.ក។ ការបង្ខូចទម្រង់ទាំងនេះពាក់ព័ន្ធនឹងការបង្កើតលក្ខណៈវិនិច្ឆ័យគតិយុត្តិដែលអាចអនុវត្តបាន ដើម្បីកំណត់លក្ខណៈថាគោលបំណងរួមមានលក្ខណៈឧក្រិដ្ឋ (១)។ តាមរយៈនីតិវិធី គោលបំណងរួមនៅក្នុងហេតុការណ៍ វិវត្ត និងផ្លាស់ប្តូរផងដែរ ទៅតាមសញ្ញាណ "នយោបាយ"។ ទស្សនទាននេះមិនមានក្នុងច្បាប់ទេ ប៉ុន្តែត្រូវបានអនុម័តដោយចៅក្រម អ.វ.ត.ក ទាំងអស់ ដែលបានសម្រេចសេចក្តីលើសំណុំរឿង ០០២ ក្នុងគោលបំណងសម្រាលចេតនាឧក្រិដ្ឋចាំបាច់ដើម្បីកំណត់ថាគោលបំណងរួមមានលក្ខណៈឧក្រិដ្ឋ (២)។

[3818] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៨៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

## ១. ការប៉ុនប៉ងម្តងហើយម្តងទៀត ដើម្បីពង្រីកវិសាលភាពនៃគោលបំណងរួមក្នុងច្បាប់ ដើម្បីបញ្ចូលឧក្រិដ្ឋកម្មនៅក្រៅគោលបំណងនេះ

១៩៦៨. ច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួមត្រូវបានបង្ខូចទម្រង់ដោយចៅក្រមនៃសំណុំរឿង ០០២។ នីតិវិធីត្រូវបានកែប្រែជាច្រើនលើកច្រើនគ្រាពាក់ព័ន្ធនឹង លក្ខណៈវិនិច្ឆ័យដែលអាចអនុវត្តបាន សំដៅធ្វើយ៉ាងណាប្រែក្លាយគោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់ ឱ្យ ទៅជាមានចរិតឧក្រិដ្ឋតែម្តងនៅទីបញ្ចប់។ ការបង្កើតយុត្តិសាស្ត្រខុស និងគ្រោះថ្នាក់បែបនេះ ត្រូវបានធ្វើឡើង ដោយរំលោភលើគោលការណ៍គ្រឹះនៃច្បាប់។ សំខាន់ជាងនេះទៅទៀត វាឆ្លុះបញ្ចាំងពីភាពលម្អៀងរបស់ចៅក្រមក្នុងសំណុំរឿង ០០២ ដែលបានត្រៀមខ្លួនផ្លាស់ប្តូរវិធានស្តីពីទំនួលខុសត្រូវ ដោយជាន់ឈ្លីការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដើម្បីឈានដល់ការផ្តន្ទាទោស។ អាស្រ័យហេតុនេះហើយបានជា ពីដំបូង គេអះអាងថាផែនការនេះមានលក្ខណៈឧក្រិដ្ឋ ប្រសិនបើឧក្រិដ្ឋកម្មកើតឡើងចេញពីផែនការនេះ (១.១) ហើយបន្ទាប់មក ប្រសិនបើមានភវនីយភាពនៃការប្រព្រឹត្តិបទឧក្រិដ្ឋដែលចារីមិនចង់ប្រព្រឹត្ត ឬចាំបាច់ត្រូវប្រព្រឹត្ត (១.២)។

### ១.១. ទស្សនៈគាំទ្រច្រឡំក្នុងដីកាដំណោះស្រាយ និងក្នុងសាលក្រមសំណុំរឿង ០០២/០១÷ គោលបំណងមានលក្ខណៈឧក្រិដ្ឋ ប្រសិនបើឧក្រិដ្ឋកម្មកើតចេញពីគោលបំណងនេះ

១៩៦៩. ការនិយាយលម្អិតអំពីគោលបំណងរួមបែងចែកជាបីផ្នែកនៅក្នុងដីកាដំណោះស្រាយ។ ជាបឋម មានអនុផ្នែកមួយស្តីពី "ការកំណត់លក្ខណៈអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" នៅក្នុងផ្នែកទីមួយនៃដីកាដំណោះស្រាយ ក្រោមចំណងជើងថា "ការពិពណ៌នាអំពីអង្គហេតុ"[3819]។ បន្ទាប់មកទៀត ផ្នែកស្តីពីច្បាប់ជាធរមាន ព្យាយាមពិពណ៌នាសហឧក្រិដ្ឋកម្មរួម-ទម្រង់១ និងទី ២ ថាជាទម្រង់នៃការប្រព្រឹត្តិដែលអាចអនុវត្តបានចំពោះមុខ អ. វ. ត. ក[3820]។ ចុងបញ្ចប់ ផ្នែកកំណត់ប្រភេទបទល្មើសនៃអង្គហេតុ មានអនុផ្នែកមួយហៅថា "សហឧក្រិដ្ឋកម្មរួម"[3821]។ នៅក្នុងដីកាដំណោះស្រាយ ផ្នែកទាក់ទងនឹងច្បាប់ដែល

---

[3819] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-២២០។

[3820] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៨។

[3821] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២១-១៥៤២។

អាចអនុវត្តបានកំណត់យ៉ាងត្រឹមត្រូវនូវគោលបំណងឧក្រិដ្ឋរួមថាជាគោលបំណង "ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនៅក្រោមយុត្តាធិការរបស់ អ. វ. ត. ក ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋនោះ"[3822]។

១៩៧០. ក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយថា ដីកាដំណោះស្រាយបានកំណត់គោលបំណងរួមថាមានលក្ខណៈឧក្រិដ្ឋ ពីព្រោះថា ទោះបីជាវា "មិនមានលក្ខណៈឧក្រិដ្ឋផ្ទាល់តែម្តង ឬមិនមានលក្ខណៈឧក្រិដ្ឋទាំងស្រុង" ក្តី "ការដាក់ឱ្យអនុវត្តគោលនយោបាយទាំងនេះ (ការជម្លៀសប្រជាជន និងវិធានការប្រឆាំងនឹងក្រុមជាក់លាក់) បណ្តាលឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ"[3823]។ នៅក្នុងផ្នែកកំណត់ប្រភេទអង្គហេតុ អង្គជំនុំជម្រះបានកំណត់ថាគោលបំណងរួមមានលក្ខណៈឧក្រិដ្ឋ "ប្រសិនបើសហឧក្រិដ្ឋកម្មរួមនេះបណ្តាលឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ"[3824]។ ដូច្នេះ អង្គជំនុំជម្រះបានកំណត់ថាគោលបំណងនេះមានលក្ខណៈ "ឧក្រិដ្ឋ" ពីព្រោះ "គោលនយោបាយដែលបង្កើតឡើងដោយខ្មែរក្រហម បានផ្តល់ជាលទ្ធផល ឬបណ្តាលឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ជាមធ្យោបាយដើម្បីសម្រេចគោលដៅ"[3825]។

១៩៧១. មេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ចំពោះវិធីសាស្ត្រច្បាប់មិនត្រឹមត្រូវនេះ ដែលបានជួយឱ្យអង្គជំនុំជម្រះកំណត់លក្ខណៈឧក្រិដ្ឋនៃគោលបំណងរួម នៅក្រៅក្របខ័ណ្ឌគតិយុត្តិ ដើម្បីចាប់ ខៀវ សំផន ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០១[3826]។ សាលដីកាសំណុំរឿង ០០២/០១ បានបដិសេធការបកស្រាយនេះ ដោយបញ្ជាក់ពីចំណុចនេះថា "អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានចែងលក្ខណៈវិនិច្ឆ័យនេះ គឺនៅពេលដែលខ្លួននិយាយថាត្រូវតែបញ្ចូលឧក្រិដ្ឋកម្មទាំងឡាយណា ឱ្យតែឧក្រិដ្ឋកម្មនោះបណ្តាលមកពីការអនុវត្តគោលបំណងរួម"[3827]។

---

[3822] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២១។

[3823] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧៧៨។

[3824] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៨១៣។

[3825] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៨០៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ កថាខណ្ឌ ៨៣៥។

[3826] សារណាបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៤៣០-៥១៦ កថាខណ្ឌ ២៤៥៨-២៤៦៨។

[3827] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៤៩។

## ១.២. ឧសុរ្ទនៈតាន់ច្រឡំនៅក្នុងសាលដីកាសំណុំរឿង ០០២/០១÷ គោលបំណងមានលក្ខណៈឧក្រិដ្ឋ ប្រសិនបើមានភវនីយភាពនៃការប្រព្រឹត្តិបទឧក្រិដ្ឋដែលចារីមិនចង់ប្រព្រឹត្ត ឬមិនចាំបាច់ប្រព្រឹត្ត

១៩៧២. កាលនោះ ដល់វេនតុលាការកំពូលបានលង់ខ្លួនវិញម្តង ក្នុងប្រតិបត្តិការជួយសង្គ្រោះអង្គជំនុំជម្រះសាលាដំបូង។ ប្រតិបត្តិការនេះបាននាំទៅដល់ការបង្កើតច្បាប់មួយហួសសម័យ ដែលធ្វើឱ្យខូចខាតយ៉ាងខ្លាំងដល់ច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួម ទាក់ទងនឹងលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់លក្ខណៈឧក្រិដ្ឋនៃគោលបំណងរួម។ ជាក់ស្តែង តុលាការកំពូលបានដើរថយពីយុត្តិសាស្ត្រអចិន្ត្រៃយ៍នៃតុលាការចំពោះកិច្ច ដោយពង្រីកលក្ខណៈវិនិច្ឆ័យគតិយុត្តិជាធរមាន ដើម្បីកំណត់លក្ខណៈឧក្រិដ្ឋរបស់គោលបំណងរួមមួយ។ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ វាពិតណាស់ថា កថាខណ្ឌ ៨០៧ បានត្រឹមតែរំឭកពីច្បាប់ជាធរមាន ដែលមិនត្រូវបានជំទាស់ពីសំណាក់មេធាវីការពារក្តី ស្របតាម យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា។ ប៉ុន្តែ តាមរបៀបមួយផ្ទុយស្រឡះ និងមិនស៊ីគ្នាជាមួយច្បាប់ដែលខ្លួនទើបតែបានរំឭក តុលាការកំពូលបានថែងនៅក្នុងកថាខណ្ឌតែមួយ (កថាខណ្ឌ ៨០៨) នូវលក្ខណៈវិនិច្ឆ័យគតិយុត្តិថ្មីមួយ ដើម្បីកំណត់លក្ខណៈឧក្រិដ្ឋនៃគោលបំណងរួម នៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយគ្មានយុត្តិសាស្ត្រយោងណាមួយបញ្ជាក់គាំទ្រគោលជំហររបស់ខ្លួនឡើយ។

១៩៧៣. យោងទៅតាមតុលាការកំពូល គោលបំណងរួមមានលក្ខណៈឧក្រិដ្ឋផ្ទាល់ ល្អិកណាអ្នកចូលរួមបានបង្កើតកិច្ចព្រមព្រៀងមួយ ដើម្បីសម្រេចគោលបំណងរួមដែលមិនមានលក្ខណៈឧក្រិដ្ឋ ទោះជាគ្មានចេតនាឱ្យចង់ឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ហើយគ្មានការប្រព្រឹត្តិជាក់ស្តែងនូវបទឧក្រិដ្ឋដែលចារីមិនចង់ធ្វើក៏ដោយ ឱ្យតែអ្នកចូលរួមព្រមទទួលយកហានិភ័យមួយក្នុងការបន្តអនុវត្តគោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋនេះបណ្តាលឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[3828]។ នៅក្នុងសំណង់គតិយុត្តិមិនត្រឹមត្រូវនេះ លក្ខណៈឧក្រិដ្ឋនៃគោលបំណងរួម អាស្រ័យជាចម្បងលើឆន្ទៈឯកតោភាគីរបស់បុគ្គលដែល

[3828] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៨។

អាចមិនយល់អំពីគោលបំណងរួម ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដើម្បីសម្រេចគោលបំណងរួមមិនឧក្រិដ្ឋ។ តុលាការកំពូលថែមទាំងពន្យល់ទៀតថា៖

> "យើងអាចបកស្រាយថាការផ្ទេរសិទ្ធិអំណាចទៅចារីផ្ទាល់ កាលណាសមាជិកទាំងអស់ដែលយល់ព្រមលើគោលបំណងរួម មិនគ្រោងប្រព្រឹត្តដោយខ្លួនឯងនូវអំពើជាធាតុផ្សំសត្យានុម័តិនៃបទឧក្រិដ្ឋ តែប្រគល់កិច្ចការនេះដល់អ្នកដទៃអនុវត្ត ដោយទុកឱ្យចារីផ្ទាល់ ធ្វើការសម្រេចជាចុងក្រោយ ថាតើត្រូវ ឬមិនត្រូវប្រព្រឹត្តអំពើសត្យានុម័តិនៃឧក្រិដ្ឋកម្ម"[3829]។

១៩៧៤. ជាសំណាងល្អ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ មិនដើរតាមវិចារណកិច្ចនេះដែលផ្ទុយនឹងច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួម ហើយបានធ្វើតាមទឡ្ហីករណ៍របស់មេធាវីការពារក្តី[3830]។ ជាក់ស្តែង អង្គជំនុះជម្រះបានបកមកបង្កើតលក្ខណៈវិនិច្ឆ័យគតិយុត្តិត្រឹមត្រូវមួយ ដើម្បីកំណត់លក្ខណៈគោលបំណងឧក្រិដ្ឋរួម នៅក្នុងក្របខ័ណ្ឌនៃសហឧក្រិដ្ឋកម្មរួម។ ទោះយ៉ាងនេះក្តី អង្គជំនុំជម្រះបានចាប់យកការអនុវត្តមួយតាមផ្លូវច្បាប់ចំពោះអង្គហេតុ។ ការអនុវត្តនេះស្តែងឱ្យឃើញពីការបង្ខូចអង្គច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួម ដែលមិនអាចទទួលយកបាន។ ការបញ្ចូលទស្សទាន "គោលនយោបាយ" ដើម្បីកំណត់ថាគោលបំណងមានចរិតឧក្រិដ្ឋ គឺជាមូលដ្ឋានគ្រឹះនៃប្រតិបត្តិការសម្រាលចេតនាឧក្រិដ្ឋដែលលេចឡើងឥតឈប់ឈរ នៅក្នុងសំណុំរឿង ០០២។

## ២. ការវិវត្តជាប់ជានិច្ចនៃគោលបំណង "ឧក្រិដ្ឋ" ដោយមិនគោរពច្បាប់

១៩៧៥. នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានកំណត់យ៉ាងត្រឹមត្រូវអំពីលក្ខណៈវិនិច្ឆ័យគតិយុត្តិដែលអាចអនុវត្តបាន ដើម្បីកំណត់អំពីគោលបំណងឧក្រិដ្ឋរួម តាមវិធីមិនច្បាស់លាស់។ ម៉្យាងវិញទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការអនុវត្តច្បាប់ស្តីពីសហឧក្រិដ្ឋរួម ចំពោះអង្គហេតុនៃរឿងក្តីនេះ។ និយមន័យនៃគោលបំណងរួមបានវិវត្តបន្តិចម្តងៗទៅតាមកិច្ចដំណើរការនីតិវិធី។ ផែនការរួមត្រូវបានប៉ះ

[3829] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨០៩។

[3830] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧១៥។

ប៉ូវ និងពង្រីក នៅក្នុងសំអាងហេតុសាលក្រមសំណុំរឿង ០០២/០២ ដែលធ្វើឱ្យគោលបំណងរួម កាន់តែមានភាពស្រពេចស្រពិល (២.១)។ អង្គជំនុំជម្រះបានកែប្រែច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួម ដោយប្រើទស្សនាទាន "គោលនយោបាយ" ដែលនៅក្រៅច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួម។ សញ្ញាណ "គោលនយោបាយ" គឺជាចំណុចស្នូលនៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០២ ហើយការភ្ជាប់ឧក្រិដ្ឋកម្មទៅនឹងគោលនយោបាយ បន្ទាប់មក ទៅនឹងផែនការរួម ស្ថិតនៅចំកណ្តាលភាពស្រអាប់នៃសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០២ (២.២)។

## ២.១. គោលបំណងរួមទូលាយ និងប្រែប្រួលពេញមួយរយៈពេលនៃកិច្ចដំណើរការនីតិវិធី

១៩៧៦. នៅក្នុងដីកាដំណោះស្រាយ គោលបំណងដែលជាធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម គឺជា "គោលបំណងរួមដើម្បីសម្រេចបានបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅកម្ពុជា តាមគ្រប់មធ្យោបាយចាំបាច់ តាមជំហាន "មហាលោតផ្លោះ មហាអស្ចារ្យ" និង តាមរយៈការរពារបក្សប្រឆាំងនឹងខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ"[3831]។

១៩៧៧. ក្នុងសាលក្រមសំណុំរឿង ០០២/០១ គោលបំណងរួម គឺ៖

- "ដើម្បីរំដោះប្រទេសកម្ពុជា និងកសាងរបបសង្គមនិយម ជាបួនដំណាក់កាល"។
- "ដើម្បីសម្រេចបានបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅកម្ពុជា តាមគ្រប់មធ្យោបាយចាំបាច់ តាមជំហាន "មហាលោតផ្លោះ មហាអស្ចារ្យ" និងតាមរយៈការរពារបក្សប្រឆាំងនឹងខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ" ដូចការដកស្រង់ចេញពីដីកាដំណោះស្រាយ។
- "សម្រេចបានបដិវត្តន៍សង្គមនិយម ដែលមានគោលដៅជាអាទិភាពកសាង និងការពារប្រទេសយ៉ាងឆាប់រហ័ស"។
- "សម្រេចបានបដិវត្តន៍សង្គមនិយមនៅប្រទេសកម្ពុជា"[3832]។

---

[3831] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦, ១៥២៤។

[3832] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧២៤, ៧៧៧, ៨០៥។

១៩៧៨. នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ គោលបំណងរួមក្នុងរឿងក្ដីនេះ គឺ "សម្រេចបានបដិវត្តន៍សង្គមនិយម (ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង)"[3833]។

១៩៧៩. ក្នុងសំអាងហេតុសាលក្រមសំណុំរឿង ០០២/០២ ចៅក្រមបានកែប្រែខ្លឹមសារនៃគោលបំណងរួមនេះ ដោយកំណត់និយមន័យដូចតទៅ៖ "គោលបំណងរួមក្នុងការសម្រេចបានបដិវត្តន៍សង្គមនិយមនៅកម្ពុជាយ៉ាងឆាប់រហ័ស ស្របតាមជំហាន "មហាលោតផ្លោះ មហាអស្ចារ្យ" ដើម្បីកសាងនិងការពារប្រទេសពីសំណាក់ខ្មាំង និងប្រែក្លាយប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែរមួយគ្មានសាសនា និងស្មើភាពដែលមានតែវណ្ណៈកម្មករ-កសិករ"[3834]។ អង្គជំនុំជម្រះក៏បានពិចារណាផងដែរថា៖

> "ការសម្រេចបានជោគជ័យនៃគោលបំណងរួម ពោលគឺការប្រែក្លាយប្រទេសឱ្យក្លាយជាសង្គមបដិវត្តបរិសុទ្ធមួយ បានឆ្លងកាត់ការអនុវត្តគោលនយោបាយដែលនាំទៅរកវិនាសកម្ម និងការកម្ទេចរាល់សមាសភាពប្រឆាំងបដិវត្តន៍ទាំងអស់ ដែលត្រូវបានមើលឃើញថាជាការបង្កឧបសគ្គដល់បក្ស ឬវឌ្ឍនភាពនៃបដិវត្តន៍សង្គមនិយម។ នៅក្នុងផ្នែក ១៦.៣ អង្គជំនុំជម្រះបានពិនិត្យមើលប្រភេទខ្មាំងពិតប្រាកដ ឬខ្មាំងតាមការសន្មត ដែលការកម្ទេចជនទាំងនេះជាចំណុចស្នូលនៃគោលបំណងរួម"[3835]។

១៩៨០. ដូច្នេះ គោលបំណងរួមដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ មិនច្បាស់លាស់ទេ។ អំណើះតទៅ អង្គជំនុំជម្រះហាក់ដូចជាញែកគោលដៅ "កម្ទេចសមាសភាពប្រឆាំងបដិវត្តន៍"ឱ្យនៅតែឯង ដើម្បីដាក់វានៅចំស្នូលនៃគោលបំណងរួម។ អង្គជំនុំជម្រះក៏បានជ្រើសយកវិធីសាស្ត្រសម្រាប់ពិនិត្យគោលបំណងរួមដែលប្រែប្រួល។ ដូច្នេះ យោងទៅតាមបទឧក្រិដ្ឋ គោលបំណងរួមប្រែប្រួលរវាងគោលបំណង៖

---

[3833] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១៥-៨១៦។

[3834] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៦៩។

[3835] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៣។

- “ជំរុញដល់ការសម្រេចបានគោលបំណងរួម ក្នុងការកសាងបដិវត្តន៍សង្គមនិយមដោយជោគជ័យ យ៉ាងឆាប់រហ័ស តាមជំហាន “មហាលោតផ្លោះ មហាអស្ចារ្យ” ដើម្បីកសាង និងការពារប្រទេស ពីសំណាក់ខ្មាំង ប្រែក្លាយប្រជាជនទាំងស្រុងឱ្យទៅជាសង្គមស្មើភាពមួយ ដែលមានតែវណ្ណៈ កម្មករ-កសិករ[3836]”។
- “ជំរុញដល់ការសម្រេចបានគោលបំណងរួម ក្នុងការកសាងបដិវត្តន៍សង្គមនិយមដោយជោគជ័យ យ៉ាងឆាប់រហ័ស តាមជំហាន “មហាលោតផ្លោះមហាអស្ចារ្យ” ដើម្បីការពារប្រទេសពីសំណាក់ ខ្មាំង និងកែប្រែសង្គមទាំងស្រុង[3837]”។
- “ជំរុញដល់ការសម្រេចបានគោលបំណងរួម ក្នុងការកសាងបដិវត្តន៍សង្គមនិយមដោយជោគជ័យ យ៉ាងឆាប់រហ័ស តាមជំហាន “មហាលោតផ្លោះមហាអស្ចារ្យ” ដើម្បីការពារប្រទេសពីសំណាក់ ខ្មាំង និងប្រែក្លាយប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែរមួយដែលគ្មានសាសនា និងស្មើភាព ដែលមានតែវណ្ណៈកម្មករ-កសិករ”[3838]។
- “ជំរុញដល់ការសម្រេចបានគោលបំណងរួម ក្នុងការកសាងបដិវត្តន៍សង្គមនិយមដោយជោគជ័យ ឆាប់រហ័ស តាមជំហាន “មហាលោតផ្លោះ មហាអស្ចារ្យ” ដើម្បីការពារប្រទេសពីសំណាក់ខ្មាំង និងប្រែក្លាយប្រជាជនទាំងស្រុងទៅជាសង្គមខ្មែរស្មើភាពមួយ”[3839]។
- ជំរុញដល់ការសម្រេចបានគោលបំណងរួម ក្នុងការកសាងបដិវត្តន៍សង្គមនិយមដោយជោគជ័យ ឆាប់រហ័ស តាមជំហាន “មហាលោតផ្លោះ មហាអស្ចារ្យ” ដើម្បីការពារប្រទេសពីសំណាក់ខ្មាំង និងប្រែក្លាយប្រជាជនទាំងស្រុងឱ្យទៅជាសង្គមខ្មែរមួយគ្មានសាសនា និងស្មើភាព ដែលមានតែ វណ្ណៈកម្មករ-កសិករ”[3840]។
- ជំរុញដល់ការសម្រេចបានគោលបំណងរួម ក្នុងការកសាងបដិវត្តន៍សង្គមនិយមដោយជោគជ័យ យ៉ាងឆាប់រហ័ស តាមជំហាន “មហាលោតផ្លោះ មហាអស្ចារ្យ” ដើម្បីការពារប្រទេសពីសំណាក់

---

[3836] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩១៨, ៤០០៥, ៤០១១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3837] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៧៦, ៣៩៧៨, ៣៩៧៩, ៣៩៨១, ៣៩៨៣, ៣៩៨៥, ៣៩៨៦, ៤០៦៦។

[3838] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៩៣, ៣៩៩៤, ៣៩៩៥, ៣៩៩៦, ៣៩៩៧ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3839] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០០៣, ៤០០៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3840] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០២១ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ខ្មាំង និងប្រែក្លាយប្រជាជនទាំងស្រុងឱ្យទៅជាសង្គមខ្មែរមួយស្មើភាពដែលមានតែវណ្ណៈកម្មករ-កសិករ"[3841]។

## ២.២. គោលបំណងឧក្រិដ្ឋ តាមរយៈ "គោលនយោបាយ"

### ២.២.១. ការបង្ខូចច្បាប់ស្តីពីសហឧក្រិដ្ឋកម្មរួម តាមរយៈការបញ្ចូល "គោលនយោបាយ" ទៅក្នុងការកំណត់ប្រភេទបទល្មើសនៃគោលបំណងរួម

#### *២.២.១.១. ការបញ្ចូល "គោលនយោបាយ" ទៅក្នុងដីកាដំណោះស្រាយ*

១៩៨១. យោងតាមដីកាដំណោះស្រាយ ដើម្បីសម្រេចបានគោលបំណងរួម គោលនយោបាយចំនួន ៥ ត្រូវបានកំណត់ដោយថ្នាក់ដឹកនាំនៃ ប.ក.ក។ ចាប់តាំងពីផ្នែក "អង្គហេតុ" មូលដ្ឋានគ្រឹះនៃទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿង ០០២ ត្រូវបានកំណត់រួចជាស្រេចថា មានគោលបំណងរួមមួយ **និង**គោលនយោបាយចំនួនប្រាំ ដើម្បីសម្រេចបានគោលបំណងនេះ[3842]។ ដូច្នេះ ទស្សនទាននៃគោលនយោបាយលេចចេញជាលើកដំបូងនៅក្នុងដីកាដំណោះស្រាយ។ នៅក្នុងផ្នែក "ការកំណត់ប្រភេទបទល្មើសចំពោះអង្គហេតុ" ឧក្រិដ្ឋកម្មទាំងឡាយត្រូវបានផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយ ពីព្រោះយោងតាមសហចៅក្រមស៊ើបអង្កេត ការអនុវត្តគោលនយោបាយទាំងនេះជាការប្រព្រឹត្តិបទឧក្រិដ្ឋ ឬការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ[3843]។ ការថែងដូចនេះមិនមានភាពច្បាស់លាស់ និងមិនបំភ្លឺឱ្យឃើញសារជាតិនៃគោលនយោបាយទាំងនេះតាមផ្លូវច្បាប់ឡើយ។

១៩៨២. ជួនកាល ការអនុវត្តគោលនយោបាយទាំងនេះជាការប្រព្រឹត្តិបទឧក្រិដ្ឋ ដូច្នេះ នយោបាយត្រូវបំព្រួញមកត្រឹមបទឧក្រិដ្ឋ។ ឧទាហរណ៍ គោលនយោបាយមួយមានគោលដៅសម្លាប់។ ជួនកាលទៀត ការអនុវត្តគោលនយោបាយទាំងនេះជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ។ ក្នុងករណីនេះ គេដកខ្លួនចេញពីគោលបំណងរួម ដោយបញ្ចូលមួយជំហានបន្ថែមទៀតដើម្បីឈានដល់ឧក្រិដ្ឋកម្ម។ ការដកពិសោធន៍

---

[3841] សំអាងហេតុសាលក្រម កថាខណ្ឌ ៤០៥៣, ៤០៥៦, ៤០៦០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3842] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-១៥៧។

[3843] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២៤-១៥២៥។

ផ្លូវច្បាប់ (ជាការប្រព្រឹត្តិ ឬការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិ) មិនត្រូវចាប់ផ្តើមចេញពីគោលនយោបាយទេ តែត្រូវចេញពីគោលបំណងរួម។ ក៏ប៉ុន្តែ ដីកាដំណោះស្រាយមិនដែលនិយាយថាគោលនយោបាយគឺជាផ្នែកមួយនៃគោលបំណងរួមទេ។ ដូច្នេះ ចំណុចចាប់ផ្តើមនៃវិចារណកិច្ចតាមផ្លូវច្បាប់ មិនត្រឹមត្រូវទេ។ ឋានៈផ្លូវច្បាប់នៃគោលនយោបាយទាំងនេះចោទជាបញ្ហា។ ដីកាដំណោះស្រាយមិនមាននិយាយអ្វីទាំងអស់ទាក់ទងនឹងប្រធានបទនេះ និងមិនផ្តល់ចម្លើយណាមួយឡើយ។

### *២.២.១.២. គោលនយោបាយក្នុងសាលក្រមសំណុំរឿង ០០២/០១*

១៩៨៣. សាលក្រមសំណុំរឿង ០០២/០១ ផ្តល់នូវការបំភ្លឺខ្លះៗទៅលើទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០២ និងជាពិសេសលើតួនាទីចម្រូងចម្រាស់នៃគោលនយោបាយ នៅចំពោះមុខច្បាប់៖

> "គោលបំណងរួមនេះមិនចាំបាច់តែមានលក្ខណៈឧក្រិដ្ឋ ឬមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ។ ទោះយ៉ាងនេះក្តី គោលបំណងរួមនេះត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ថាវាត្រូវបានសម្រេចឡើង ដោយអនុវត្តគោលនយោបាយជម្លៀសប្រជាជន (ផ្នែកទី ១៤.២ ខាងក្រោម) ព្រមទាំងវិធានការប្រឆាំងនឹងក្រុមជាក់លាក់មួយចំនួន (ផ្នែកទី ១៤.៣ បន្ទាប់ពីនេះ) និងថាការអនុវត្តគោលនយោបាយទាំងនេះបណ្តាលឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ"[3844]។

១៩៨៤. សាលក្រមសំណុំរឿង ០០២/០១ បង្ហាញថា វិចារណកិច្ចតាមផ្លូវច្បាប់ត្រូវចាប់ផ្តើមចេញពីគោលនយោបាយ តែមិនមែនចេញពីគោលបំណងរួមទេ។ ទោះយ៉ាងនេះក្តី អង្គជំនុំជម្រះបានរំឭកដោយត្រឹមត្រូវអំពីធាតុផ្សំសត្យានុម័តិដែលជាល័ក្ខខ័ណ្ឌតម្រូវចាំបាច់នៃ "គោលបំណងរួមក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ឬជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ"[3845]។ តាមច្បាប់ គឺគោលបំណងរួមវិញទេដែលត្រូវតែជាការប្រព្រឹត្តិបទឧក្រិដ្ឋ ឬជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ។ ក៏ប៉ុន្តែ នៅក្នុងសាលក្រមនេះ អង្គ

---

[3844] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧៧៨។

[3845] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៦៩២។

ជំនុំជម្រះបែរជាចាប់ផ្ដើមចេញពីគោលនយោបាយទៅវិញ។ ដូច្នេះ អង្គជំនុំជម្រះបានធ្វើឱ្យខូចដល់លក្ខណៈវិនិច្ឆ័យគតិយុត្តិជាធរមាន តាមរយៈការបន្ថែមមួយជំហានទៀតដែលញែកគោលបំណងរួមឱ្យឃ្លាតចេញពីបទឧក្រិដ្ឋ។

១៩៨៥. គំនូសបំព្រួញខាងក្រោមបង្ហាញពីរបៀបដែលការបន្ថែមជំហានទីបីដែលមិនមានចែងក្នុងច្បាប់ អាចឱ្យកំណត់គោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋថាមានលក្ខណៈឧក្រិដ្ឋ។ គំនូសបំព្រួញទីមួយបង្ហាញពីវិចារណកិច្ចគតិយុត្តិត្រឹមត្រូវជាធរមាន ដែលនាំទៅដល់ការសន្និដ្ឋានថាគោលបំណងរួមនេះមិនមានលក្ខណៈឧក្រិដ្ឋនោះទេ។




១៩៨៦. គំនូសបំព្រួញខាងក្រោមនេះមានជំហានបន្ថែមមួយទៀតក្នុងវិចារណកិច្ច ដែលមិនមានចែងក្នុងច្បាប់ ហើយដែលអនុញ្ញាតឱ្យចៅក្រមកំណត់ថាគោលបំណងរួមមានលក្ខណៈឧក្រិដ្ឋ។ អង្គជំនុំជម្រះបានដើរតាមវិចារណកិច្ចមួយនេះ។




### *២.២.១.៣. គោលនយោបាយក្នុងសាលក្រមសំណុំរឿង ០០២/០១ និងការជំនុំជម្រះលើសំណុំរឿង ០០២/០២*

១៩៨៧. ក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានពន្យល់ថា "នៅក្នុងរឿងក្ដីនេះ គោលបំណងរួម (ដូចដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង) ក្នុងការសម្រេចបានបដិវត្តន៍សង្គមនិយម ត្រូវតែពិនិត្យមើលនៅក្នុងបរិបទនៃគោលនយោបាយរបស់ ប.ក.ក"[3846]។ តុលាការកំពូលបានបន្ថែមថា៖

> "ពិតមែនតែអង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ច្បាស់លាស់ថា គោលនយោបាយទាំងនេះ *ជាផ្នែក*ជាក់ស្ដែងមួយនៃគោលបំណងរួមនៅក្នុងនីតិព្រហ្មទណ្ឌ (ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាបង្ហាញភាពខុសគ្នារវាងគោលបំណងរួម (មិនមានលក្ខណៈឧក្រិដ្ឋ) និងគោលនយោបាយ) ក៏ប៉ុន្តែ បើយោងតាមអង្គជំនុំជម្រះសាលាដំបូង គោលនយោបាយដែលជាកម្មវត្ថុនៃការជំនុំជម្រះមានទំនាក់ទំនងផ្ទាល់នឹងការសម្រេចបានបដិវត្តន៍សង្គមនិយមនៅប្រទេសកម្ពុជា"[3847]។

[3846] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3847] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៩៨៨. អាស្រ័យហេតុនេះ តុលាការកំពូលក៏បានបង្កើតទស្សនទាននៃ "គោលនយោបាយដែលមានទំនាក់ទំនងផ្ទាល់" ទៅនឹងការសម្រេចបានគោលបំណងរួម។ ទស្សនទាននេះមិនត្រូវបានកំណត់និយមន័យទេ។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះមិនបានសម្រេចឱ្យច្បាស់ថាតើគោលនយោបាយទាំងនេះជាផ្នែកនៃគោលបំណងរួមដែរឬទេ។ ទោះយ៉ាងនេះក្តី គេអាចទាញការន្និដ្ឋានចេញពីវិចារណកិច្ចរបស់អង្គជំនុំជម្រះបានថា គោលបំណងរួម និងគោលនយោបាយ គឺជាទស្សនទានពីរខុសគ្នា ដែលមិនអាចច្រឡំគ្នាបានឡើយ ដោយហេតុថាគោលនយោបាយ គឺជាមធ្យោបាយនៃ "ការអនុវត្ត" គោលបំណងរួម។ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលបានបញ្ជាក់ច្បាស់ថា គោលនយោបាយ ត្រូវបានច្រឡំគ្នានឹងសញ្ញាណច្បាប់នៃពាក្យ "មធ្យោបាយ"៖

> "គឺនៅក្នុងបរិបទនេះហើយដែលត្រូវយល់អំពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា គោលបំណងរួមត្រូវតែសម្រេចឱ្យបាន "តាមគ្រប់មធ្យោបាយចាំបាច់" ហើយ ចំពោះរឿងក្តីនេះ "មធ្យោបាយ"ទាំងអស់នេះ គឺជាគោលនយោបាយជម្លៀសប្រជាជន និងវិធានការប្រឆាំងនឹងក្រុមជាក់លាក់។ ដូច្នេះ ទោះបីការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអាចខ្វះភាពជាក់លាក់ក៏ដោយ តែគេពុំអាចមានមន្ទិលទេថា កម្មវត្ថុស្នូលនៃសំណុំរឿង ០០២/០១ ស្ថិតត្រង់ទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយទាំងពីរនេះ គឺមិនមែនភាពចាំបាច់ក្នុងការសម្រេចបានបដិវត្តន៍សង្គមនិយម "តាមគ្រប់មធ្យោបាយចាំបាច់"នោះទេ។ ក្នុងន័យនេះ គោលបំណងរួមក្នុងការសម្រេចបានបដិវត្តន៍សង្គមនិយម តាមរយៈគោលនយោបាយទាំងនេះ ពិតជាមានលក្ខណៈឧក្រិដ្ឋ។ និយាយម្យ៉ាងទៀត ដោយហេតុថា គេត្រូវសម្រេចគោលបំណងរួម តាមរយៈការប្រព្រឹត្តិបទឧក្រិដ្ឋ ស្របតាមការគ្រោងទុកនៅក្នុងគោលនយោបាយទាំងនេះ គោលដៅសម្រេចបានបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅកម្ពុជា គឺប្រាកដជាមានលក្ខណៈឧក្រិដ្ឋ"[3848]។

១៩៨៩. ក្នុងសំណង់គតិយុត្តិដោយឯកឯងនេះ តុលាការកំពូលបានពិចារណាថា នយោបាយមានទិដ្ឋភាពឧក្រិដ្ឋ និងមិនឧក្រិដ្ឋ។ តុលាការកំពូលបានទាញយកចរិតឧក្រិដ្ឋនៃគោលបំណងរួម "ចេញពីទិដ្ឋភាពឧក្រិដ្ឋ នៃ

[3848] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១៦ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

គោលនយោបាយទាំងពីរ ដែលជាកម្មវត្ថុស្នូលនៃសំណុំរឿង ០០២/០១"[3849]។ យោងតាមវិចារណកិច្ច របស់តុលាការកំពូល ទីមួយ ចាំបាច់ត្រូវបង្ហាញពីអត្ថិភាពនៃគោលនយោបាយមួយ និងទីពីរ ត្រូវកំណត់បទឧក្រិដ្ឋដែល "ស្ថិតក្នុងក្របខ័ណ្ឌនៃគោលបំណងរួម ក្នុងន័យថាគោលនយោបាយ" "ជាការប្រព្រឹត្ត ឬជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ដោយអនុវត្តគោលការណ៍ដែលបានចែងខាងលើ"[3850]។

១៩៩០. តុលាការកំពូលបានគាំទ្រទ្រឹស្តីសហឧក្រិដ្ឋកម្មរួមដែលត្រូវបានបង្កើតឡើង នៅក្នុងដីកាដំណោះស្រាយ ហើយដែលបន្ទាប់មកត្រូវបានអង្គជំនុំជម្រះយកមកប្រើ ដោយបង្កើតឡើងនូវទស្សនទាន "គោលនយោបាយ ដែលមានទំនាក់ទំនងផ្ទាល់នឹងគោលបំណងរួម" ដើម្បីបញ្ចូលបទឧក្រិដ្ឋទៅក្នុងគោលបំណងរួម ដោយកែសម្រួលធាតុផ្សំនៃគោលបំណងរួម។ ការកែសម្រួលឱ្យស្របនឹងច្បាប់នេះ ត្រូវបានធ្វើឡើងនៅក្រៅក្របខ័ណ្ឌច្បាប់ទាំងស្រុង ហើយថែមទាំងបានកែប្រែក្របខ័ណ្ឌនៃការចោទប្រកាន់ទៀតផង។ ទ្រឹស្តីនេះមិនអាចយកមកអនុវត្ត ដោយមិនបំពានសមធម៌នៃការជំនុំជម្រះក្តីឡើយ។

១៩៩១. នៅក្នុងសំអាងហេតុសាលក្រមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួននឹងសម្រេច "លើសំណួរថាតើគោលបំណងរួមពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋដែរឬទេ ហើយជាផលវិបាក ប្រសិនបើគោលបំណងរួមត្រូវបានអនុវត្ត តាមរយៈគោលនយោបាយដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ (ផ្នែកទី ១៦.៤៖ ការអនុវត្តគោលបំណងរួម) គោលបំណងរួមមានលក្ខណៈឧក្រិដ្ឋ"[3851]។ ដូច្នេះ អង្គជំនុំជម្រះបានយកវិចារណកិច្ចផ្លូវច្បាប់មិនត្រឹមត្រូវរបស់តុលាការកំពូល ដើម្បីកំណត់ថាតើគោលបំណងរួមជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋដែរឬទេ៖

> "អង្គជំនុំជម្រះពិចារណាថា ក្នុងរឿងក្តីនេះ ពាក្យ "តាមគ្រប់មធ្យោបាយចាំបាច់" សំដៅទៅលើគោលនយោបាយក្នុងការសម្រេចបានបដិវត្តន៍សង្គមនិយមនៅកម្ពុជា។ អង្គជំនុំជម្រះនឹង

[3849] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១៦។

[3850] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៥៩។

[3851] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ពិនិត្យនៅផ្នែខាងក្រោមថា តើគោលនយោបាយទាំងនេះធ្លាប់មានអត្ថិភាព ឬទេ [១] ថាតើគោលនយោបាយទាំងនេះជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋដែរឬទេ [២] និងថាតើគោលនយោបាយទាំងនេះ មានទំនាក់ទំនងផ្ទាល់ទៅនឹងគោលបំណងរួមដែរឬទេ [៣] ដែលជាហេតុធ្វើឱ្យគេកំណត់ថាគោលបំណងនេះមានលក្ខណៈឧក្រិដ្ឋ”[3852]។

១៩៩២. ដូច្នេះ ប្រាកដណាស់ វិចារណកិច្ចត្រូវចាប់ផ្តើមចេញពីគោលនយោបាយ។ គោលបំណងរួមត្រូវបានផ្ទេរទៅកាន់តួនាទីបន្ទាប់បន្សំវិញ។ គេអាចធ្វើគំនូសបំព្រួញនៃពីការដកពិសោធន៍ថ្មីរបស់អង្គជំនុំជម្រះដូចនេះ៖




១៩៩៣. ទាំងនេះជាវិចារណកិច្ចបញ្ច្រាសពីវិចារណកិច្ច ដែលត្រូវផ្តល់ឧត្តមភាពដល់ការបង្ហាញធាតុផ្សំបទល្មើសនៃទម្រង់ទំនួលខុសត្រូវ ក្នុងបរិបទនៃការជំនុំជម្រះក្តីព្រហ្មទណ្ឌ។ វិចារណកិច្ចបែបនេះពុំមានមូលដ្ឋានច្បាប់ឡើយ និងជាប់ពាក់ព័ន្ធនឹងសច្ចធារណ៍នៃពិរុទ្ធភាព ដែលផ្ទុយនឹងវិធាននៃនីតិវិធីព្រហ្មទណ្ឌ។ លើសពីនេះទៅទៀត នៅក្នុងទស្សនៈនេះនៃគោលបំណងរួម ដែលត្រូវបានមើលឃើញតែតាមរយៈការអនុវត្តគោលនយោបាយមួយ ឬច្រើន អង្គជំនុំជម្រះបានបញ្ចូលដោយប្រយោលនូវសញ្ញាណនៃភវនីយភាពនៃការប្រព្រឹត្តិបទឧក្រិដ្ឋនៅក្រៅសហឧក្រិដ្ឋកម្ម-ទម្រង់ទី ១។ ជាក់ស្តែង ការអនុវត្តគោល

[3852] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៤។

នយោបាយអាស្រ័យលើអ្នកអនុវត្ត ទោះជាគោលដៅពីដំបូងនៃគោលបំណងរួមនេះយ៉ាងម៉េចក៏ដោយ។ លើសពីនេះទៀត អង្គជំនុំជម្រះបានរំកិលកម្រិតនៃការចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម ទៅដំណាក់កាលមួយដែលក៏មិនមាននៅក្នុងធាតុផ្សំបទល្មើសនៃសហឧក្រិដ្ឋកម្មរួម-ទម្រង់១ នោះដែរ។

### *២.២.២. គោលនយោបាយមិនច្បាស់លាស់ ពង្រីក និងមានចន្លោះប្រហោង*

១៩៩៤. ផ្នែក "កំណត់ប្រភេទអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម" នៅក្នុងដីកាដំណោះស្រាយ ចាប់ផ្តើមដោយពន្យល់អំពីគោលបំណងរួម តាមរយៈនិយមន័យពង្រីក ដែលបង្កឱ្យមានការភាន់ច្រឡំដូចតទៅនេះ៖ ការសម្រេចបានបដិវត្តន៍សង្គមនិយមនៅកម្ពុជាយ៉ាងរហ័ស តាមគ្រប់មធ្យោបាយ ចាំបាច់ តាមជំហាន "មហាលោតផ្លោះ មហាអស្ចារ្យ" **និង**តាមរយៈ ការការពារបក្សប្រឆាំងនឹងខ្មាំងផ្ទៃក្នុង និងខ្មាំងពីខាងក្រៅ[3853]។ បន្ថែមលើគោលបំណងរួម ដីកាដំណោះស្រាយអះអាងថា មានគោលនយោបាយចំនួនប្រាំដើម្បីសម្រេចបានគោលបំណងរួម៖

> "ដើម្បីសម្រេចបានគោលបំណងរួមនេះ មេដឹកនាំ ប.ក.ក បានកំណត់ និងអនុវត្តគោលនយោបាយចំនួនប្រាំ ដូចតទៅ៖
>
> ១) ជម្លៀសប្រជាជនជាច្រើនលើកច្រើនសាពីទីក្រុងទៅកាន់ទីជនបទ និងពីជនបទមួយទៅជនបទមួយផ្សេងទៀត។
>
> ២) បង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ។
>
> ៣) កសាងឡើងវិញ "សមាសភាពមិនល្អ" និងកម្ទេច "ខ្មាំង" នៅក្នុងជួរបក្ស និងក្រៅបក្ស។
>
> ៤) ចាត់វិធានការដោយឡែកប្រឆាំងនឹងក្រុមជាក់លាក់មួយចំនួន ជាពិសេសជនជាតិចាមវៀតណាម ពុទ្ធសាសនិក និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (មន្ត្រីរដ្ឋការ ទាហាន និងក្រុមគ្រួសាររបស់ពួកគេ)។
>
> ៥) ដាក់បទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍"[3854]។

---

[3853] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦។

[3854] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៧។

១៩៩៥. ជាបឋម ទំនាក់ទំនងរវាងគោលបំណងរួម និងគោលនយោបាយ មិនមានភាពច្បាស់លាស់។ គោលនយោបាយតស៊ូប្រឆាំងនឹងខ្មាំង ហាក់ដូចជាត្រូវបានលើកឱ្យខ្ពស់ស្មើកម្រិតនៃគោលបំណងរួម[3855]។ បន្ទាប់មក ជាលក្ខណៈបញ្ញត្តិ គោលនយោបាយមិនដែលត្រូវបានកំណត់ឱ្យបានច្បាស់លាស់ទេ។ ជាឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា គោលនយោបាយបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ "ក៏មានគោលបំណងផងដែរក្នុងការស្រាវជ្រាវរកខ្មាំង ការពារខ្លួនប្រឆាំងនឹងខ្មាំង អប់រំកែប្រែខ្មាំង និង "កម្ទេច"ខ្មាំង[3856]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតក៏បានបញ្ចូល**គោលដៅ** ទៅក្នុងគោលនយោបាយដែលមិនមែនជាគោលបំណងរួមផងដែរ។ ជាឧទាហរណ៍ សហចៅក្រមបានថ្លែងនៅក្នុងកថាខណ្ឌ២០៧ នៃដីកាដំណោះស្រាយថា៖ "គោលដៅ [មួយ] ក្នុងចំណោមគោលដៅឯទៀតនៃគោលនយោបាយនេះ [ចំពោះក្រុមជាក់លាក់] គឺការកសាងសង្គមមួយគ្មានសាសនា និងស្មើភាព គ្មានការបែងចែកវណ្ណៈ តាមរយៈការលុបបំបាត់រាល់ភាពខុសគ្នាខាងជាតិសាសន៍ សាសនា សង្គម និងវប្បធម៌"។ សហចៅក្រមក៏បានបញ្ចូលថែមទៀត ជាគោលដៅ នូវគោលនយោបាយមួយផ្សេងទៀត ទៅក្នុងគោលនយោបាយនេះ៖ "គោលដៅ [មួយទៀត] នៃគោលនយោបាយនេះ គឺកម្ចាត់ខ្មាំង និងកម្ទេចក្រុមមនុស្សមួយចំនួន ទាំងស្រុង ឬមួយផ្នែក"។ ការភាន់ច្រឡំរវាងគោលនយោបាយ គោលដៅ និងគោលបំណងរួម។

១៩៩៦. ក្នុងសាលក្រមសំណុំរឿង ០០២/០១ អង្គជំនុំជម្រះក៏បានលើកឡើងពី "គោលដៅនៃគោលបំណងរួម" បន្ថែមលើគោលនយោបាយ៖ "គោលបំណងរួមនេះគឺជាការការកសាងបដិវត្តសង្គមនិយមមួយ ដែលគោលដៅជាអាទិភាព គឺកសាង និងការពារប្រទេស យ៉ាងឆាប់រហ័ស"[3857]។

---

[3855] សូមមើលខាងលើ កថាខណ្ឌ ១៩៧៩-១៩៨០។

[3856] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦៩។

[3857] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ៧៧៧។

១៩៩៧. ក្នុងសាលដីកាសំណុំរឿង ០០២/០១ តុលាការកំពូលក៏បានចេញសេចក្តីសម្រេចលើគោលដៅនៃគោលបំណងរួមនេះ ក្នុងន័យដូចតទៅ៖ "ការធ្វើឱ្យក្លាយជាទាសករ គឺជាគោលដៅមួយក្នុងចំណោមគោលដៅសំខាន់ៗផ្សេងទៀតនៃរបប [ខ្មែរក្រហម]"[3858]។

១៩៩៨. ក្នុងសំអាងហេតុសាលក្រមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានតម្លើងកម្រិតគោលនយោបាយស្តីអំពីខ្មាំង មកដល់ចំណុចស្នូលនៃគោលបំណងរួម[3859]។ វាហាក់ដូចជាអង្គជំនុំជម្រះបានច្របូកច្របល់បញ្ចូលគ្នារវាង "ទស្សនទាន" នៃពាក្យគោលបំណងរួម នៃពាក្យគោលនយោបាយ និងនៃពាក្យគោលដៅ ដែលជាមូលហេតុធ្វើឱ្យគោលបំណងរួមកាន់តែស្រពេចស្រពិល។

### ២.២.៣. ការពិចារណាតាមលក្ខណៈវង្វង់ហេតុ-ផល តាមអនុមានវិធីពីរជំហាន

១៩៩៩. ទីបំផុត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រើប្រាស់អនុមានវិធីពីរជំហានហួសហេតុ៖ ដោយហេតុមានបទឧក្រិដ្ឋ គឺមានគោលនយោបាយ ដោយហេតុមានគោលនយោបាយ គឺមានបទឧក្រិដ្ឋ។




២០០០. ភាពច្របូកច្របល់ខ្លាំង និងការផ្លាស់ប្តូរឥតឈប់ឈរនៃគោលបំណងរួមបង្ហាញពីការលំបាកខ្លាំងក្នុងការផ្សារភ្ជាប់បទឧក្រិដ្ឋទៅ ខៀវ សំផន ដែលជាមូលហេតុនាំឱ្យមានកំហុសក្នុងការកំណត់ថាមានធាតុផ្សំសត្យានុម័តិ និងធាតុផ្សំអត្តនោម័តិ ដែលជាធាតុផ្សំចាំបាច់សម្រាប់ការទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម។

[3858] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨២៨។

[3859] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧៤៣។

## ផ្នែកទី ២. ការតវ៉ាច្រឡំលើការចូលរួមចំណែករបស់ ខៀវ សំផន

២០០១. ការរំឭកអំពីល័ក្ខខ័ណ្ឌដែលអាចធ្វើឱ្យជនជាប់ចោទទទួលខុសត្រូវ តាមរយៈសហឧក្រិដ្ឋកម្មរួមបង្ហាញយ៉ាងច្បាស់ពីកំហុសដែលបានប្រព្រឹត្តដោយអង្គជំនុំជម្រះ ដើម្បីចៀសវាងធាតុផ្សំសត្យានុម័តិនៅក្នុងការអនុវត្តទម្រង់នៃការទទួលខុសត្រូវចំពោះម្ចាស់បណ្តឹងសាទុក្ខ។ ជាការពិត អង្គជំនុំជម្រះជាអ្នកបង្ហាញអំពីធាតុផ្សំសត្យានុម័តិ ក្នុងករណីរបស់ ខៀវ សំផន ដោយកំណត់ដូចតទៅនេះ៖ ១/ គោលបំណងរួមមានលក្ខណៈឧក្រិដ្ឋ ដែលជាការប្រព្រឹត្តិបទឧក្រិដ្ឋ ឬជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ២/ មនុស្សច្រើននាក់ដែលជាមួយអ្នកទាំងនេះគោលបំណងរួមត្រូវបានអនុវត្ត ៣/ ការចូលរួមចំណែកដ៏សំខាន់របស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ក្នុងការពិនិត្យលើដំណាក់កាលទាំងបីនេះ។

២០០២. នៅក្នុងរយៈពេលនៃការផ្តល់សំអាងហេតុ វាហាក់ស្តែងឡើងឱ្យឃើញថាអង្គជំនុំជម្រះបានធ្វើការស៊ើកបញ្ចូលមួយដែលនាំឱ្យខ្លួនប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់។ ដោយបានបញ្ចូលមួយជំហានបន្ថែមតាមរយៈគោលនយោបាយ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថាការចូលជាសមាជិក និងការចូលរួមចំណែកក្នុងគោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋ "គឺគោលបំណងកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជា" "តាមគ្រប់មធ្យោបាយចាំបាច់"[3860] គឺជាល័ក្ខខ័ណ្ឌគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានចូលជាសមាជិក និងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងគោលនយោបាយឧក្រិដ្ឋដែលអង្គជំនុំជម្រះបានកំណត់។ ដូចដែលបានឃើញខាងលើ[3861] ការភាន់ច្រឡំរបស់អង្គជំនុំជម្រះលើតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខ បណ្តាលមកពីខ្លួនបំណងប្រាថ្នាផ្សារភ្ជាប់តួនាទីរបស់គាត់ទៅនឹងគោលនយោបាយឧក្រិដ្ឋទាំងនេះ ដោយលក្ខណៈសិប្បនិម្មិត។ ក្នុងការកំណត់ប្រភេទបទល្មើស ការពិចារណារកហេតុផលបែបនេះ បង្កឱ្យមានការលំបាកជាច្រើនដែលកើតចេញពីកំហុសដែលអង្គជំនុំជម្រះបានប្រព្រឹត្ត។

---

[3860] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៨៦៥។

[3861] សូមមើលខាងលើ កថាខណ្ឌ ១៦០៤-១៨០៣។

២០០៣. ជាបឋម អង្គជំនុំជម្រះមិនបានបង្ហាញឱ្យហួសពីវិមតិសង្ស័យអំពីអត្ថិភាពនៃគោលនយោបាយដែលខ្លួនបានកំណត់ថាមានលក្ខណៈឧក្រិដ្ឋ និងអំពីគោលបំណងឧក្រិដ្ឋដែលបានគ្រោងទុកនៃផែនការនយោបាយរបស់ ប.ក.ក ឡើយ[3862]។ អង្គជំនុំជម្រះបានខំព្យាយាមធ្វើការបង្ហាញខាងលើដោយបញ្ចូលទស្សនទាននៃពាក្យ "កម្ទេចខ្មាំង" ដែលមានទ្រង់ទ្រាយច្រើនសណ្ឋាន ហើយប្រែប្រួល។ ខ្លួនខំប្រឹងរហូតដល់ប្រព្រឹត្តកំហុសអង្គហេតុយ៉ាងគឃ្លើន ពិសេសតាមរយៈការមើលរំលងជម្លោះប្រដាប់អាវុធ[3863]។ បន្ទាប់មក អង្គជំនុំជម្រះមិនបានកំណត់ឱ្យច្បាស់ថាតើមានទំនាក់ទំនងយ៉ាងដូចម្តេច រវាងសមាជិកនៃគោលបំណងរួម និងចារីទាំងអស់។ ទីបញ្ចប់ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយច្របូកច្របល់រវាងការចូលរួមក្នុងគោលបំណងរួម និងការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម។

### *គោលបំណងរួមត្រូវបានកំណត់ដោយមិនត្រឹមត្រូវ ដោយសារផ្តើមចេញពីបទឧក្រិដ្ឋ*

២០០៤. ដូចដែលយើងទើបតែបានឃើញនៅពេលពិនិត្យមើលច្បាប់ ក្នុងករណីសំណុំរឿងមានទ្រង់ទ្រាយធំអង្គជំនុំជម្រះគួរណាកំណត់ "គោលបំណងឧក្រិដ្ឋរួមឱ្យច្បាស់លាស់គ្រប់គ្រាន់" និង បង្ហាញអំពីគោលបំណងនេះ "ឱ្យហួសពីវិមតិសង្ស័យ"[3864] ដើម្បីកំណត់ថាតើលោក ខៀវ សំផន បានចូលរួមចំណែកយ៉ាងដូចម្តេចខ្លះក្នុងគោលបំណងរួមនេះ។ ការប្រែប្រួលជាច្រើននៃគោលបំណងរួមនៅក្នុងផ្នែកសំអាងហេតុទាំងមូលនៃសាលក្រម បញ្ជាក់ពីការខកខានរបស់អង្គជំនុំជម្រះលើចំណុចនេះ[3865]។ វាក៏បង្ហាញផងដែរអំពីអលទ្ធភាពក្នុងការកំណត់ថាផែនការកសាងបដិវត្តន៍សង្គមនិយមជាផែនការឧក្រិដ្ឋចំតួ។

២០០៥. មូលហេតុដែលនាំឱ្យអង្គជំនុំជម្រះមិនអាចផ្តល់និយមន័យច្បាស់លាស់ និងជាក់លាក់នៃគោលបំណងរួម គឺមកពីវាមិនមែនជាផ្នែកមួយនៃអ្វីដែលគេហៅថាផែនការនយោបាយរបស់ ប.ក.ក សម្រាប់កំណត់និយមន័យដល់ផែនការនយោបាយនេះ ប៉ុន្តែ គឺមកពីវាជាផ្នែកមួយនៃកាលៈទេសៈនៃបទឧក្រិដ្ឋ

---

[3862] សូមមើលខាងលើ កថាខណ្ឌ ១៥៣៨-១៦០៣។

[3863] សូមមើលខាងលើ កថាខណ្ឌ ១៥៥១-១៥៨៨។

[3864] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤២៤។

[3865] សូមមើលខាងលើ កថាខណ្ឌ ១៩៧៦-២០០០។

នានាសម្រាប់ទាញការសន្និដ្ឋានថាមានគោលនយោបាយឧក្រិដ្ឋទាំង ៥។ ការពិចារណាបញ្ច្រាស់ទិស នេះ គឺជាមូលដ្ឋានភាន់ច្រឡំរបស់គោលនយោបាយទាំងនេះដែលត្រូវបានប្រឌិតឡើងទាំងស្រុង ក្នុងគោលបំណងផ្តន្ទាទោស។ ក្នុងករណីនេះ អង្គជំនុំជម្រះបានពិចារណាថាគឺគោលនយោបាយសម្រាប់ការអនុវត្តគោលបំណងរួមទេដែលមានលក្ខណៈឧក្រិដ្ឋ។ ដើម្បីអនុវត្តតាមតក្កវិជ្ជារបស់ខ្លួន អង្គជំនុំជម្រះត្រូវតែបង្ហាញថាតើ ខៀវ សំផន បានចូលរួមចំណែកក្នុងទិដ្ឋភាពឧក្រិដ្ឋយ៉ាងដូចម្តេច ហើយដែលតាមរយៈទិដ្ឋភាពទាំងនេះ បង្ហាញថាគាត់បានចូលរួមក្នុងឧក្រិដ្ឋកម្មដែលកើតចេញពីគោលនយោបាយទាំងនេះ បើតាមអង្គជំនុំជម្រះ។

២០០៦. ទោះយ៉ាងណា នៅពេលដែលខ្លួនមិនថែងអ្វីមួយខុស ដើម្បីសន្និដ្ឋានថាមានគោលនយោបាយទាំងនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថាមានទិដ្ឋភាពឧក្រិដ្ឋនៃផែនការនយោបាយរបស់ ប.ក.ក ដោយបំភ្លៃផែនការនោះ និងបំភ្លៃភ័ស្តុតាង[3866]។ ជាការពិត អង្គជំនុំជម្រះមិនមែនពិនិត្យមើលថាតើគោលបំណងរួមជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មយ៉ាងដូចម្តេចនោះទេ គឺខ្លួនមើលថាតើខ្លួនត្រូវកែច្នៃគោលនយោបាយយ៉ាងម៉េចដើម្បីអាចដាក់បញ្ចូលបទឧក្រិដ្ឋបាន។ គឺកំហុសពីដំបូងទីជាមូលដ្ឋាននេះហើយដែលធ្វើការពិចារណា និងការសន្និដ្ឋានរបស់អង្គជំនុំជម្រះលើអត្ថិភាពនៃគោលនយោបាយផ្សេងៗក្លាយជាមោឃៈ។

២០០៧. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនលើទំនាក់ទំនងដែលមានរវាងចារីផ្ទាល់ និងសមាជិកនៃសហឧក្រិដ្ឋកម្មរួម។ ដូចដែលយើងបានឃើញខាងលើ យោងតាមយុត្តិសាស្ត្រ អង្គជំនុំជម្រះត្រូវតែរកឱ្យឃើញថា អ្នកចូលរួមក្នុងគោលបំណងរួមបានប្រើចារីសំខាន់ៗទាំងអស់នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់។ ទោះយ៉ាងនេះក្តី ទាក់ទងនឹងឧក្រិដ្ឋកម្មនៅតាមសហករណ៍ ឧក្រិដ្ឋកម្មទាក់ទងនឹងជនជាតិចាម និងវៀតណាម ដែលបានកើតឡើងនៅលើទីតាំងភូមិសាស្ត្រផ្សេងៗគ្នា ដោយជនល្មើសសំខាន់ៗពុំត្រូវបានកំណត់អត្តសញ្ញាណ អង្គជំនុំជម្រះមិនបានបង្ហាញអំពីទំនាក់ទំនងទាំងនេះទេ។ ដោយធ្វើដូច្នេះ អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុគាំទ្រសេចក្តីសម្រេចរបស់ខ្លួន។ អាស្រ័យហេតុនេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះលើការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខតាមរយៈសហឧក្រិដ្ឋកម្មរួម ចំពោះឧក្រិដ្ឋកម្មទាំងនេះ មិនមានសុពលភាពនោះទេ។

---

[3866] សូមមើលខាងលើ កថាខណ្ឌ ១៩៣៨-១៦០៣។

## *ការចូលរួមរបស់ម្ចាស់បណ្តឹងសាទុក្ខក្នុងគោលបំណងរួមខុសគ្នាពីការចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម*

២០០៨. ដោយសម្រួលពាក្យពេចន៍ យើងគប្បីរំឭកអំពីសាលដីកាក្នុងរឿងក្តី *Brđanin* ថាអង្គជំនុំជម្រះមិនអាចត្រឹមតែសន្និដ្ឋានថាម្ចាស់បណ្តឹងសាទុក្ខបានសេពគប់ "ឧក្រិដ្ឋជន" ប៉ុណ្ណោះទេ គឺត្រូវរកឱ្យឃើញថាគាត់ "មានចេតនាប្រព្រឹត្តិបទឧក្រិដ្ឋ" និង "បានសហការជាមួយមនុស្សដទៃទៀតដើម្បីសំរេចគោលដៅនេះ ហើយលើសពីនេះទៀត ត្រូវរកឱ្យឃើញថាគាត់បាន "ចូលរួមចំណែកយ៉ាងសំខាន់ក្នុងបទឧក្រិដ្ឋ"[3867]។ ក៏ប៉ុន្តែ នៅក្នុងការសន្និដ្ឋានរបស់ខ្លួនស្តីពីតួនាទី និងការចូលរួមចំណែករងការចោទប្រកាន់ អង្គជំនុំជម្រះបានសន្និដ្ឋានជាមូលដ្ឋានថា ខៀវ សំផន បានចូលរួមចំណែកក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយ តាមរយៈការសេពគប់ញឹកញាប់ជាមួយសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍[3868] និងបានសន្និដ្ឋានថាគាត់មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ និងបានចូលរួមចំណែកក្នុងការព្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ តាមរយៈសុន្ទរកថាជាផ្លូវការដែលគាត់បានថ្លែង ក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬសេចក្តីថ្លែងការមួយចំនួនដែលគាត់បានធ្វើនាពេលហេតុការណ៍បានកន្លងផុតទៅយូរហើយ និងតាមរយៈមុខតំណែងរបស់គាត់ដែលគ្រាន់តែមានទំនាក់ទំនងជាមួយទិដ្ឋភាពមិនមានលក្ខណៈឧក្រិដ្ឋនៃគោលបំណងរួម[3869]។ ការពិចារណារកហេតុផលនេះរបស់អង្គជំនុំជម្រះ គឺជាប្រភពនៃកំហុសជាច្រើន នៅក្នុងការសន្និដ្ឋានរបស់ខ្លួនលើការចូលរួមចំណែករបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម។ ដោយមិនអាចកំណត់សកម្មភាពជាក់លាក់ណាមួយរបស់ខៀវ សំផន ដែលបញ្ជាក់ថាគាត់ចូលរួមចំណែកក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម អង្គជំនុំជម្រះបានប្រើល្បិចកែច្នៃធ្វើយ៉ាងណាដើម្បីដាក់បញ្ចូល ខៀវ សំផន ទៅក្នុងការទទួលខុសត្រូវរួម ដែលផ្ទុយពីភាពចាំបាច់តម្រូវកំណត់ទំនួលខុសត្រូវជាបុគ្គលរបស់គាត់។

---

[3867] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤៣១។ សូមមើលខាងលើ កថាខណ្ឌ ១៩៤៦-១៩៤៩ កថាខណ្ឌ ១៩៦០-១៩៦២។

[3868] សូមមើលខាងលើ កថាខណ្ឌ ១៧៣០-១៧៤៨។

[3869] សូមមើលខាងលើ កថាខណ្ឌ ១៦៥២-១៨០៣។

២០០៩. ក្រៅពីកំហុសជាទូទៅពាក់ព័ន្ធនឹងការចូលរួមចំណែករងការចោទប្រកាន់របស់ម្ចាស់បណ្តឹងសាទុក្ខ (១) អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសដោយបានពិចារណាថាការគាំទ្រ (២) និងការលើកស្ទួយគោលបំណងរួមរបស់គាត់ (៣) គឺគ្រប់គ្រាន់ដើម្បីបង្ហាញថាគាត់បានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម ក្នុងខណៈដែលតួនាទីជាទូទៅរបស់គាត់ ក្នុងជួរប.ក.ក និងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនបានអនុញ្ញាតឱ្យសន្និដ្ឋានបែបនេះបានទេ។ ដូចគ្នានេះដែរ ការជំរុញផែនការនយោបាយរបស់ ប.ក.ក មិនអនុញ្ញាតឱ្យសន្និដ្ឋានថាគាត់បានលើកស្ទួយទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម (៤) ឬថាគាត់មិនបានលើកទឹកចិត្ត ញុះញង់ ផ្តល់ភាពស្របច្បាប់ (៥) សម្របសម្រួល ហើយកាន់តែជាងនេះទៅទៀត គឺវាមិនអាចអនុញ្ញាតឱ្យសន្និដ្ឋានថាគាត់បានគ្រប់គ្រងលើទិដ្ឋភាពឧក្រិដ្ឋទាំងនេះឡើយ (៦)។

## ១. កំហុសទូទៅ

២០១០. ដូចដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់មួយ ដោយបានរំឭកឡើងវិញពីសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវរបស់ខ្លួនទាក់ទងនឹងគោលបំណងរួម ជាពិសេស ទាក់ទងនឹងលក្ខណៈឧក្រិដ្ឋនៃគោលបំណងនេះ និងការចូលរួមរបស់ ខៀវ សំផន[3870]។ លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបែរជាវាយតម្លៃ យ៉ាងដាច់ខាត ថា ខៀវ សំផន បានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្ម តាមរយៈគោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋចំពោះ ហើយមិនមែនតាមរយៈការប្រព្រឹត្តិបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់មកលើគាត់ ក្នុងក្របខ័ណ្ឌសហឧក្រិដ្ឋកម្មរួមឡើយ។

២០១១. ដូចដែលបានកត់សម្គាល់ខាងលើ នៅពេលធ្វើបទបង្ហាញអំពីច្បាប់ អង្គជំនុំជម្រះមិនបានកំណត់ឱ្យបានត្រឹមត្រូវអំពីធាតុផ្សំបទល្មើសចាំបាច់នៃការចូលរួមចំណែក សម្រាប់ប្រកាសអំពីទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល តាមរយៈសហឧក្រិដ្ឋកម្មរួមឡើយ[3871]។ នៅពេលអនុវត្តច្បាប់ចំពោះអង្គហេតុ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងត្រឹមត្រូវថា "ចាំបាច់ត្រូវកំណត់ថាតើជនជាប់ចោទបានចូលរួមចំណែក

[3870] សូមមើលខាងលើ កថាខណ្ឌ ១៣៩៩-១៦០៣។

[3871] សូមមើលខាងលើ កថាខណ្ឌ ១៩៥៧-១៩៦២។

យ៉ាងសំខាន់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលជាផ្នែកមួយនៃគោលបំណងរួមដែរឬទេ"[3872]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានបញ្ជាក់វិធីសាស្ត្ររបស់ខ្លួនដូចតទៅនេះ៖ "ឥឡូវនេះ អង្គជំនុំជម្រះនឹងពិនិត្យមើលថាតើលោក ខៀវ សំផន បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងគោលបំណងរួមដែរឬទេ"[3873]។ នៅក្នុងបរិបទនៃសហឧក្រិដ្ឋកម្មរួម ដែលមានគោលបំណងមិនឧក្រិដ្ឋចំនួន ការចូលរួមចំណែកមិនមែនត្រូវចូលក្នុងការអនុវត្តគោលបំណងរួមនោះទេ (មិនមានលក្ខណៈឧក្រិដ្ឋ) គឺត្រូវតែចូលទៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋទៅវិញទេ។ ដូចដែលយើងនឹងឃើញលម្អិតនៅផ្នែកខាងក្រោម អង្គជំនុំជម្រះបានត្រឹមតែសន្និដ្ឋានយ៉ាងសាមញ្ញថាជនជាប់ចោទបានចូលរួមចំណែកយ៉ាងសំខាន់ទៅក្នុងគោលបំណងរួមតែប៉ុណ្ណោះ[3874]។

## ២. ការគាំទ្រ

២០១២. អង្គជំនុំជម្រះបានយល់ច្រឡំដោយបានពិចារណាថា ខៀវ សំផន បានផ្តល់ការគាំទ្រដល់ ប.ក.ក និងដល់គោលនយោបាយរបស់បក្ស" ចាប់តាំងពីដើមឆ្នាំ ១៩៦៧ មកម្ល៉េះ[3875]។ ដូចដែលបានរៀបរាប់រួចមកហើយ គឺថានៅពេលនោះគាត់ទើបតែចូលព្រៃម៉ាគី។ ក្នុងឋានៈគាត់ជាបញ្ញាជន មេដឹកនាំមិនទុកចិត្តគាត់ទេ ហើយគាត់ត្រូវបានគេទុកឱ្យនៅឆ្ងាយពីគេ។ គាត់បានក្លាយជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមនៅក្នុងឆ្នាំ ១៩៧១ នេះហើយទេ ពោលគឺគាត់មិនមានអំណាចទាល់តែសោះ នៅក្នុងស្ថាប័ននេះ ហើយដែលស្ថាប័ននេះផ្ទាល់ក៏គ្មានអំណាចធ្វើការសម្រេចណាមួយដែរ[3876]។ អ្វីដែលសំខាន់ជាងនេះទៀតនោះ គឺថាអង្គជំនុំជម្រះមិនបានបញ្ជាក់ថាតើគោលនយោបាយណាខ្លះដែល ខៀវ សំផន ទំនងជាបានគាំទ្រ ចាប់តាំងពីឆ្នាំ ១៩៦៧ មក។

---

[3872] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៥។

[3873] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៦។

[3874] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧-៤២៥៨។ សូមមើលខាងក្រោម កថាខណ្ឌ ២០១២-២០៣០។

[3875] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧។

[3876] សូមមើលខាងលើ កថាខណ្ឌ ១៦៦០-១៦៦៤ កថាខណ្ឌ ១៧០៤-១៧៥៣។

២០១៣. អង្គជំនុំជម្រះក៏បានយល់ច្រឡំផងដែរ ដោយបានពិចារណាថា ទោះបីជា "គោលបំណងនៃការធ្វើបដិវត្តន៍សង្គមនិយមមិនមានលក្ខណៈឧក្រិដ្ឋចំតួក៏ដោយ [...] ក៏តាមរយៈការបន្តកាន់កាប់តំណែងនៅក្នុង ប.ក.ក និងក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យ ពេញមួយរយៈពេលដែលត្រូវបានចោទប្រកាន់ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ខៀវ សំផន បានគាំទ្រ ជំរុញលើកទឹកចិត្តដោយប្រយោល ផ្តល់ភាពស្របច្បាប់ តាមរយៈវត្តមានរបស់គាត់ ដូច្នេះ គឺគាត់បានសម្រួលដល់ការអនុវត្តគោលបំណងរួមដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ"[3877]។ ទោះបីយើងមិនអាចទប់ចិត្តខ្លួនឯងកុំឱ្យស្រង់យកសិល្បវិធីរបស់អង្គជំនុំជម្រះ ក្នុងការរៀបរាប់អំពីការគាំទ្រក្រោមទ្រង់ទ្រាយដ៏សប្លូរបែបរបស់ ខៀវ សំផន ដល់គោលបំណងរួមក៏ដោយ ក៏ដូចដែលយើងបានឃើញខាងលើ គឺថាការគាំទ្ររបស់គាត់មិនជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋឡើយ។ ការបង្ហាញអំពីការគាំទ្ររបស់ ខៀវ សំផន ចំពោះ "គោលដៅបដិវត្តន៍របស់បក្ស"[3878]ដែលមិនមានលក្ខណៈឧក្រិដ្ឋចំតួ មិនអាចអនុញ្ញាតឱ្យសន្និដ្ឋានថាគាត់បានគាំទ្រការអនុវត្តគោលបំណងរួមមួយដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ។ ការសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

២០១៤. អង្គជំនុំជម្រះក៏បានយល់ច្រឡំផងដែរ ដោយបានសន្និដ្ឋានថាម្ចាស់បណ្តឹងសាទុក្ខ "បានចូលរួមក្នុងការពិភាក្សាទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការបោសសម្អាតខ្មាំង ក្នុងនោះមាន ជូ ជេត ហៅ ស៊ី ជាលេខាភូមិភាគបស្ចិម"[3879]។ ដូចបានឃើញខាងលើ ការសន្និដ្ឋាននេះមិនត្រឹមត្រូវទេ[3880]។ អង្គជំនុំជម្រះក៏បានយល់ច្រឡំផងដែរ ដោយបានអះអាងថាវត្តមានរបស់ ខៀវ សំផន នៅពេលសមាជិកគណៈអចិន្ត្រៃយ៍បង្ហាញរបាយការណ៍ស្តីពីសហករណ៍ ការដ្ឋាន និងភូមិភាគដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ អាចអនុញ្ញាតឱ្យសន្និដ្ឋានបានថា ខៀវ សំផន បានគាំទ្រចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋ[3881]។ មានកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ នៅខែតុលា ឆ្នាំ ១៩៧៥ ដែលក្នុងឱកាសនេះ មានការសន្មតថា ខៀវ សំផន មានវត្តមាន ហើយមានការពិភាក្សាតែអំពីគម្រោងសាងសង់ព្រលានយន្តហោះ

[3877] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧។

[3878] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧។

[3879] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៨។

[3880] សូមមើលខាងលើ កថាខណ្ឌ ១៨០៧-១៨០៨។

[3881] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៨។ សូមមើលខាងលើ កថាខណ្ឌ ១៨១៦-១៨៤៨។

កំពង់ឆ្នាំងតែប៉ុណ្ណោះ[3882]។ ដូចគ្នាដែរ វត្តមានជាសទ្ធតរបស់គាត់នៅក្នុងកិច្ចប្រជុំនេះ ក៏មិនអាចអនុញ្ញាតឱ្យសន្និដ្ឋានថាគាត់បានគាំទ្រដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មបានឡើយ។ អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលថា "ក្នុងឋានៈគាត់ជាសមាជិកគណៈកម្មាធិការមជ្ឈិម ខៀវ សំផន បានចូលរួមក្នុងមហា សន្និបាតបក្សលើកទី ៣ ទី ៤ និងទី ៥ ដែលក្នុងឱកាសទាំងនេះ គោលនយោបាយដែលចេញពី គណៈកម្មាធិការអចិន្ត្រៃយ៍ទាក់ទងនឹងមាគ៌ានយោបាយទូទៅរបស់បក្ស ត្រូវបានអនុម័ត ដោយអនុលោមទៅតាមរបៀបរបបនៃគោលការណ៍លទ្ធិប្រជាធិបតេយ្យប្រមូលផ្តុំ"[3883]។ ជាការពិត ពុំមានការបញ្ជាក់អំពីអ្វីទាំងអស់ នៅក្នុងការសន្និដ្ឋាននេះ។ តើគោលនយោបាយអ្វីខ្លះទំនងជាត្រូវបានអនុម័ត ? ហើយយកទៅអនុវត្តយ៉ាងដូចម្តេច? តើគោលនយោបាយទូទៅរបស់បក្សជាអ្វី? ដោយមានលក្ខណៈទូទៅខ្លាំងពេក វាពិបាកនឹងយល់ពីអ្វីដែលអង្គជំនុំជម្រះកំពុងព្យាយាមបង្ហាញ ពោលគឺពិបាកនឹងយល់ថាតើការសន្និដ្ឋានរបស់អង្គជំនុំជម្រះផ្អែកលើអ្វី។ ទោះយ៉ាងណាក្តី ការសន្និដ្ឋានរបស់អង្គជំនុំជម្រះទាក់ទងនឹងមហាសន្និបាតបក្ស និងលទ្ធិប្រជាធិបតេយ្យប្រមូលផ្តុំ មិនត្រឹមត្រូវទេ[3884]។

២០១៥. អង្គជំនុំជម្រះបានសន្និដ្ឋានខុសម្តងទៀតថាការដែល ខៀវ សំផន បានយល់ព្រមតាមសេចក្តីណែនាំសំដៅជំរុញឱ្យស្រុកនានាផលិតស្រូវ ៣ តោនក្នុងមួយហិកតា ក៏ដូចជា "ការដែលគាត់បានការពារជាសាធារណៈនូវរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ" ឬក៏ការប្រែក្លាយប្រជាជនឱ្យទៅជា "សង្គមកម្មករ-កសិករ" សុទ្ធតែជាការគាំទ្ររបស់គាត់ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋ[3885]។ ជាការពិត គោលនយោបាយទាំងនេះមិនជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ[3886]។ ដូច្នេះ វាមិនអាចបង្ហាញថា ខៀវ សំផន គាំទ្រដល់ទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួមឡើយ។

---

[3882] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៨។ សូមមើលខាងលើ កថាខណ្ឌ ១៨៤៦-១៨៤៨។

[3883] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៩។

[3884] សូមមើលខាងលើ កថាខណ្ឌ ១៧៤៩-១៧៥៣ កថាខណ្ឌ ១៦៩០-១៨០៣។

[3885] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៩។

[3886] សូមមើលខាងលើ កថាខណ្ឌ ១៤៨៩-១៥២២។

២០១៦. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានផ្អែកលើសេចក្ដីសម្រេចចុះថ្ងៃទី ៣០ ខែមីនាឆ្នាំ ១៩៧៦[3887] ដើម្បីពិចារណាថា ក្នុងឋានៈជាសមាជិកគណៈកម្មាធិការមជ្ឈិម ខៀវ សំផន បានឯកភាពផ្ទេរអំណាចសម្រេចលើការប្រហារជីវិតទៅថ្នាក់ដឹកនាំផ្សេងៗក្នុងឋានានុក្រមនៃ ប.ក.ក[3888]។ ដូចគ្នានេះដែរ ដូចដែលបានបង្ហាញខាងលើ គម្រោងដែលថាមានការធ្វើបាបជនជាតិវៀតណាម ជាងជនជាតិខ្មែរនៅ ស-២១ ត្រូវបានបង្ហាញបញ្ជាក់ថាវាមិនមានអត្ថិភាពនោះទេ[3889]។ សំខាន់ជាងនេះទៀត គឺថា អង្គជំនុំជម្រះមិនបានបង្ហាញថា ខៀវ សំផន ដឹងអំពីគោលនយោបាយបែបនេះនោះទេ[3890] ក្នុងខណៈដែលគាត់មិនទាំងដឹងអំពីអត្ថិភាពនៃមន្ទីរ ស-២១ ក្នុងអំឡុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យផងនោះ[3891]។ នៅទីបញ្ចប់ ដូចដែលបានឃើញខាងលើផងដែរ ការសន្និដ្ឋានទាក់ទងនឹងវត្តមានរបស់ម្ចាស់បណ្ដឹងសាទុក្ខក្នុងអំឡុងពេលចាប់ខ្លួន វន វេត មិនត្រឹមត្រូវទេ[3892]។

២០១៧. ដោយយោងតាមធាតុផ្សំភ័ស្តុតាងទាំងអស់នេះ ក្រៅពីមុខតំណែងដែលកាន់កាប់ដោយ ខៀវ សំផន នៅក្នុង ប.ក.ក និងការគាំទ្ររបស់គាត់ចំពោះគោលនយោបាយកសិកម្ម និង "មាគ៌ានយោបាយទូទៅរបស់បក្សដែលមិនមានលក្ខណៈឧក្រិដ្ឋ" អង្គជំនុំជម្រះមិនមានធាតុផ្សំភ័ស្តុតាងណាមួយដែលអនុញ្ញាតឱ្យសន្និដ្ឋានថា ខៀវ សំផន បានចូលរួម និងគាំទ្រគោលបំណងរួមមួយដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ ហើយជាក់លាក់ជាងនេះទៀត គឺពុំមានភ័ស្តុតាងណាមួយដែលអនុញ្ញាតឱ្យសន្និដ្ឋានថាគាត់បានគាំទ្រទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយដែលអង្គជំនុំជម្រះបានកំណត់នោះទេ។ អាស្រ័យហេតុនេះ រាល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះក្នុងន័យនេះ ត្រូវទុកជាមោឃៈ[3893]។

---

[3887] សូមមើលខាងលើ កថាខណ្ឌ ១៧០៤-១៧៥៣។

[3888] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦០។

[3889] សូមមើលខាងលើ កថាខណ្ឌ ៨២៨-៨៣៥។

[3890] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦០។

[3891] សូមមើលខាងលើ កថាខណ្ឌ ១៨៥១-១៨៥៣។

[3892] សូមមើលខាងលើ កថាខណ្ឌ ១៨៦៩-១៨៧១។

[3893] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៥៧-៤៣០៨ និង ៤៣០៦។

## ៣. ការលើកកម្ពស់

២០១៨. យោងទៅតាមសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ ម្ចាស់បណ្តឹងសាទុក្ខបាន "ណែនាំឱ្យអនុវត្ត អះអាងគាំទ្រ និងការពារគោលបំណងរួមនេះ"[3894]។ ជាការគាំទ្រដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះបានយោងទៅលើ "កំណត់ហេតុប្រជុំ" ដែលក្នុងនោះ មានការបានលើកឡើងថាខៀវ សំផន ទំនងជាបានធ្វើជាគណៈធិបតីនៃសន្និបាតជាតិដែលបានប្រព្រឹត្តទៅក្រោយព្រឹត្តិការណ៍ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥[3895]។ ដូចដែលបានបញ្ជាក់ខាងលើ ការអះអាងនេះពឹងផ្អែកទៅលើ ការភាន់ច្រឡំអំពីអង្គហេតុ។ ដូច្នេះ ត្រូវតែចាត់ទុកវាជាមោឃៈ[3896]។

២០១៩. បន្ទាប់មក អង្គជំនុំជម្រះបានបញ្ជាក់ថា នៅខែឧសភា ឆ្នាំ ១៩៧៥ ម្ចាស់បណ្តឹងសាទុក្ខបានចូលរួមជាមួយសមាជិកដទៃទៀតនៃគណៈកម្មាធិការមជ្ឈិម និងមេដឹកនាំជាន់ខ្ពស់ ក្នុងកិច្ចប្រជុំរយៈពេល ១០ ថ្ងៃ នៅឯវត្តព្រះកែវមរកត ដែលបានកំណត់ "មូលដ្ឋានគ្រឹះនៃការកសាងបដិវត្តន៍សង្គមនិយមឱ្យបានឆាប់រហ័ស តាមរយៈការផ្លាស់ទីលំនៅប្រជាជន ការបង្កើតសហករណ៍ ការកសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងការចាប់ផ្តើមគម្រោងការពារជាតិ"[3897]។ មិនត្រឹមតែមានភស្តុតាងមិនគ្រប់គ្រាន់ដើម្បីធ្វើការសន្និដ្ឋានលើខ្លឹមសារ និងអ្នកចូលរួមជាក់លាក់ក្នុងកិច្ចប្រជុំនេះប៉ុណ្ណោះទេ គឺអង្គជំនុំជម្រះថែមទាំងមិនអាចសន្និដ្ឋានថា ផែនការកសាងបដិវត្តន៍សង្គមនិយមនេះមានលក្ខណៈឧក្រិដ្ឋបានឡើយ[3898]។

២០២០. លើសពីនេះទៀត អង្គជំនុំជម្រះបានយល់ឃើញថា "ក្នុងឋានៈជាប្រធានរដ្ឋថ្មី លោក ខៀវ សំផនបានឯកភាព និងជំរុញគោលដៅសំដៅកសាង និងការពារប្រទេស [...] តាមរយៈជំហាន "មហាលោតផ្លោះមហាអស្ចារ្យ""[3899]។ ជាការគាំទ្រដល់ការយល់ឃើញរបស់ខ្លួន អង្គជំនុំជម្រះបានផ្អែកលើផ្នែកទី

[3894] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦២។

[3895] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦២។

[3896] សូមមើលខាងលើ កថាខណ្ឌ ១៦៩០-១៦៩១។

[3897] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦២។

[3898] សូមមើលខាងលើ កថាខណ្ឌ ១៧៥៤-១៨០៣ កថាខណ្ឌ ១៤៩០-១៥២២។

[3899] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦២។

១៦ នៃសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ ដែលនិយាយអំពីគោលបំណងរួម ហើយដែលក្នុងផ្នែកនេះ កំហុសអង្គហេតុជាច្រើនត្រូវបានស្រង់បង្ហាញនៅផ្នែកខាងលើ[3900]។ នៅចុងបញ្ចប់ អង្គជំនុំជម្រះបានផ្អែកលើសុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខដែលខ្លួនបានបំភ្លៃខ្លឹមសារ[3901]។ អាស្រ័យហេតុនេះ ការសន្និដ្ឋានបំផ្លើសដែលថាអង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន "មិនត្រឹមតែចូលរួមក្នុងគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់ គាត់បានណែនាំឱ្យអនុវត្ត បញ្ជាក់គាំទ្រ និងការពារគោលបំណងរួមនេះ យ៉ាងសកម្ម ស្វាហាប់ និងជាសាធារណៈ ទាំងនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិទៀតផង" ផ្អែកទៅលើកំហុសអង្គហេតុជាច្រើនរហូតដល់ថ្នាក់ត្រូវតែចាត់ទុកការសន្និដ្ឋាននេះជាមោឃៈ[3902]។

## ៤. ការជំរុញ ការញុះញង់ ការផ្តល់ភាពស្របច្បាប់

២០២១. យោងទៅតាមសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ តាមរយៈតំណែងផ្សេងៗរបស់គាត់ លោក ខៀវ សំផន "បានប្រើប្រាស់មុខការរបស់គាត់ ដើម្បីគាំទ្រ ហើយតាមរយៈការគាំទ្រនេះ គឺគាត់បានផ្តល់ភាពស្របច្បាប់ដល់ការអនុវត្តគោលបំណងរួម ទាំងក្នុងប្រទេស ទាំងលើឆាកអន្តរជាតិ"[3903]។ គាត់ទំនងជាបានអំពាវនាវឱ្យប្រជាជនធ្វើការរួមគ្នា នៅតាមវាលស្រែ និងរោងចក្រ ដើម្បីការពារប្រទេស[3904]។ ដូចដែលបានបញ្ជាក់ខាងលើ ការអះអាងបែបនេះផ្អែកលើការយល់ច្រឡំអំពីគោលនយោបាយ និងការវាយតម្លៃមិនត្រឹមត្រូវលើភ័ស្តុតាង[3905]។ អង្គជំនុំជម្រះក៏បានប្រើប្រាស់សេចក្តីថ្លែងការមួយចំនួនធំរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលត្រូវបានធ្វើឡើងក្រោយការរលំទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលនៅក្នុងនោះគាត់បានពិពណ៌នាអំពីការងារដែលបានធ្វើដោយកម្មករនៅតាមការដ្ឋាន

[3900] សូមមើលខាងលើ កថាខណ្ឌ ១៤០៨-១៤៣៧។ សូមមើលខាងលើផងដែរ កថាខណ្ឌ ១៧៥៤-១៨០៣ និង កថាខណ្ឌ ១៤៩០-១៥២២។

[3901] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៣។ សូមមើលខាងលើ កថាខណ្ឌ ១៧៥៤-១៨០៣។

[3902] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៤។

[3903] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៥។

[3904] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៥។

[3905] សូមមើលខាងលើ កថាខណ្ឌ ១៣៩៩-១៦០៣។

និងសហករណ៍[3906]។ ការសន្និដ្ឋានទាំងនេះផ្អែកតែទៅលើការវាយតម្លៃផ្ទាល់ខ្លួន ដែល ខៀវ សំផន បាន ធ្វើ បន្ទាប់ពីហេតុការណ៍បានកើតឡើងផុតទៅហើយ។ ការវាយតម្លៃផ្ទាល់ខ្លួននេះមិនបញ្ជាក់អំពីការដឹង ឮណាមួយ នៅពេលដែលហេតុការណ៍កំពុងតែកើតឡើងឡើយ។ ដូច្នេះ អង្គហេតុទាំងនេះមិនពាក់ព័ន្ធ នឹងផ្នែកស្តីអំពីការកំណត់ប្រភេទទម្រង់ទំនួលខុសត្រូវ ក្នុងក្របខ័ណ្ឌសហឧក្រិដ្ឋកម្មរួមឡើយ។ នៅ ផ្នែកខាងលើ មេធាវីការពារក្តីបានធ្វើការបង្ហាញរួចហើយអំពីការវាយតម្លៃភ័ស្តុតាងមិនត្រឹមត្រូវ[3907]។ អង្គជំនុំជម្រះក៏បានផ្អែកលើសេចក្តីថ្លែងការរបស់ សម្តេច សីហនុ ក្នុងខណៈដែល ដូចបានបញ្ជាក់ខាង លើរួចហើយ សម្តេច សីហនុ បានមានបន្ទូលជាន់កែងខ្លួនឯងម្តងហើយម្តងទៀត ដល់ថ្នាក់គេមិនអាច ជឿជាក់លើពាក្យសម្តីរបស់ព្រះអង្គបាន ហើយមេធាវីការពារក្តីមិនដែលមានឱកាសសាកសួរព្រះអង្គ មុនពេលទ្រង់សោយព្រះទិវង្គតឡើយ។ នៅក្នុងល័ក្ខខ័ណ្ឌនេះ ការប្រើ "ភ័ស្តុតាង" នេះត្រូវតែច្រាន ចោល ពីព្រោះវារំលោភលើគោលការណ៍នៃស្តង់ដារភ័ស្តុតាង[3908]។

២០២២. អង្គជំនុំជម្រះបានផ្អែកលើសេចក្តីថ្លែងការជាសាធារណៈរបស់ ខៀវ សំផន ទាក់ទងនឹងសហករណ៍ និងការដ្ឋានសំខាន់ៗមួយចំនួន[3909]។ មេធាវីការពារក្តីបានបង្ហាញរួចហើយថាការវាយតម្លៃលើសេចក្តី ថ្លែងទាំងនេះរបស់អង្គជំនុំជម្រះ ផ្អែកលើការយល់ខុសលើភ័ស្តុតាង ដែលជាហេតុនាំឱ្យរាល់ការ សន្និដ្ឋាន ដែលផ្អែកលើមូលដ្ឋានទាំងនេះ ត្រូវតែត្រូវបានចាត់ទុកជាមោឃៈ[3910]។ យោងទៅតាមសំអាង ហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ ម្ចាស់បណ្តឹងសាទុក្ខក៏បានអំពាវនាវដល់ប្រជាជន "ឱ្យកាត់ផ្តាច់ អារម្មណ៍ផ្ទាល់ខ្លួនទាំងអស់ពីឪពុកម្តាយ ដើម្បីយកអង្គការជាឪពុកម្តាយជំនួស" និងបង្កើនចំនួនប្រជា ជនកម្ពុជាប្រជាធិបតេយ្យ[3911]។ មេធាវីការពារក្តី បានបង្ហាញម្តងហើយម្តងទៀតថាការសន្និដ្ឋានច្រំ

[3906] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៥។

[3907] សូមមើលខាងលើ កថាខណ្ឌ ១៤៨៩-១៥២២ កថាខណ្ឌ ១៨១៦-១៨៤០។

[3908] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៥។ សូមមើលខាងលើ កថាខណ្ឌ ២៩៣-៣០៥។

[3909] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៧។

[3910] សូមមើលខាងលើ កថាខណ្ឌ ១៤០៨-១៤១៤ កថាខណ្ឌ ១៤៨៩-១៥២២ កថាខណ្ឌ ១៤០៨-១៤៣៧។

[3911] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៨។

ដែល ក្នុងសំអាងហេតុសាលក្រមនេះ ផ្អែកលើការយល់ច្រឡំអំពីអង្គហេតុ និងការវាយតម្លៃភស្តុតាងមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះ[3912]។

២០២៣. ទាក់ទងនឹងពុទ្ធសាសនិក អង្គជំនុំជម្រះបានអះអាងថា ខៀវ សំផន "បានបោកបញ្ឆោតភ្នែកឱ្យសាធារណជនមើលទៅឃើញថាពុទ្ធសាសនាត្រូវបានរក្សាបដិបត្តិជាប្រក្រតី ក្នុងខណៈដែលខ្លួនជំរុញយ៉ាងខ្លាំងក្លាឱ្យរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈមិនត្រឹមត្រូវតាមប្រពៃណី"[3913]។ ជាបឋម គួរកត់សម្គាល់ថា ពាក្យ "បោកបញ្ឆោតភ្នែក" ដែលត្រូវបានជ្រើសរើស ដើម្បីកំណត់អត្តចរិតជាសន្មតរបស់ម្ចាស់បណ្ដឹងសាទុក្ខ។ ជម្រើសនេះធ្វើឱ្យយើងភ្ញាក់ផ្អើលនៅត្រង់ថាវាជាផ្អែកលើការយល់ឃើញផ្ទាល់ខ្លួន ដែលមិនមានភស្តុតាងណាមួយគាំទ្រទាល់តែសោះ។ ដូច្នេះ វាគឺជាការបកស្រាយ និងជាយោបល់ទូន្មានរបស់អង្គជំនុំជម្រះដែលមិនអាចមានតម្លៃជាការសន្និដ្ឋានអ្វីទាល់តែសោះ នៅក្នុងបរិបទនៃការជំនុំជម្រះក្តីព្រហ្មទណ្ឌ[3914]។ លើសពីនេះទៀត មិនមានភស្តុតាងណាមួយគាំទ្រដល់ការសន្និដ្ឋានបែបនេះឡើយ[3915]។ ការសន្និដ្ឋានថាម្ចាស់បណ្ដឹងសាទុក្ខបានបដិសេធជាសាធារណៈចំពោះបទឧក្រិដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យទៅលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវតែត្រូវបានចាត់ទុកជាមោឃៈ ដោយមូលហេតុដូចគ្នា[3916]។ នៅទីបំផុត អង្គជំនុំជម្រះបានផ្អែកលើសុន្ទរកថារបស់ ខៀវ សំផន ជាច្រើន ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានញុះញង់ឱ្យស្អប់ជនជាតិវៀតណាម[3917]។ មេធាវីការពារក្តីបានពិនិត្យភស្តុតាងទាំងអស់នេះឡើងវិញ ហើយបានបង្ហាញអំពីកំហុសរបស់អង្គជំនុំជម្រះ នៅក្នុងផ្នែកពាក់ព័ន្ធនៃសារណាបណ្ដឹងសាទុក្ខនេះ[3918]។

---

[3912] សូមមើលខាងលើ កថាខណ្ឌ ១០៩៨-១៣៩៨។

[3913] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៨។

[3914] នៅកន្លែងផ្សេងទៀតនៃសំអាងហេតុសាលក្រម អង្គជំនុំជម្រះបានលើកឡើងក្នុងន័យគួរឱ្យភ្ញាក់ផ្អើលផងដែរ ដើម្បីនិយាយអំពីម្ចាស់បណ្ដឹងសាទុក្ខ នៅក្នុងផ្នែកស្តីពីពុទ្ធសាសនិក សូមមើលកថាខណ្ឌ ៤២៤១ នៃសំអាងហេតុសាលក្រម៖ "ទោះជាយ៉ាងនេះក្ដី ខៀវ សំផន នៅតែបន្តគាំទ្រជាសាធារណៈដល់ការធ្វើឱ្យមានភាពប្រក្រតីដដែល"។

[3915] សូមមើលខាងលើ កថាខណ្ឌ ១៩១០-១៩២០ កថាខណ្ឌ ២០៩៤។

[3916] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦។ សូមមើលខាងលើ កថាខណ្ឌ ១៩២១-១៩២៧ កថាខណ្ឌ ២០៩៩-២១១៣។

[3917] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៦៩។

[3918] សូមមើលខាងលើ កថាខណ្ឌ ១០៥៨-១០៩៧ កថាខណ្ឌ ១៥៥១-១៥៦០ កថាខណ្ឌ ១៨៨៦-១៩០៩ កថាខណ្ឌ ២០៧៥-២០៩០។

២០២៤. អាស្រ័យហេតុនេះ ត្រូវតែធ្វើមោឃភាពលើការសន្និដ្ឋានដែលថាអង្គជំនុំជម្រះជឿជាក់ថាម្ចាស់បណ្តឹងសាទុក្ខ "មិនត្រឹមតែចូលរួមក្នុងគោលបំណងរួមប៉ុណ្ណោះទេ គឺថែមទាំងជំរុញ និងញុះញង់ឱ្យអនុវត្តគោលបំណងនេះ តាមរយៈគោលនយោបាយរបស់ ប.ក.ក និងតាមរយៈការប្រើប្រាស់មុខតំណែងរបស់គាត់ជាមេដឹកនាំជាន់ខ្ពស់ ដើម្បីផ្តល់ធម្មានុរូបដល់គោលបំណងរួមនេះ" ពីព្រោះការសន្និដ្ឋាននេះផ្អែកលើការវាយតម្លៃភ័ស្តុតាងមិនត្រឹមត្រូវ[3919]។

## ៥. ការណែនាំឯកការចោទប្រកាន់

២០២៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុជាច្រើន ដោយបានសន្និដ្ឋានថា "ខៀវ សំផនមិនត្រឹមតែចូលរួមក្នុងគោលបំណងរួមប៉ុណ្ណោះទេ គឺថែមទាំងបានផ្តល់ការណែនាំយ៉ាងសកម្មក្នុងបំណងអនុវត្តគោលបំណងរួមនេះ តាមរយៈគោលនយោបាយផ្សេងៗ"[3920]។ ជាការពិត អង្គជំនុំជម្រះបានភាន់ច្រឡំ ដោយបានដកស្រង់ខ្លឹមសារនៃបទសម្ភាសន៍ជាមួយ នៅ សារឹម ដើម្បីពិចារណាថា"ខៀវ សំផន បានសម្តែងការគាំទ្រចំពោះគោលនយោបាយ ប. ក.ក ទាក់ទងនឹងការនិរទេសជនជាតិវៀតណាម"[3921]។ យើងបានពន្យល់រួចហើយថាវាគឺជាចម្លើយជាលាយលក្ខណ៍អក្សរក្រៅក្របខ័ណ្ឌតុលាការ[3922]។ ដូច្នេះ វាមានតម្លៃជាភ័ស្តុតាងតិចតួចណាស់ ហើយក្នុងករណីណាក៏ដោយ ក៏វាមិនអាចប្រើដើម្បីរៀបរាប់ពីអំពើ

---

[3919] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧០។

[3920] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៤។

[3921] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧១ កំណត់សម្គាល់ជើងទំព័រលេខ ១១៩៣៥ យោងដល់កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧ ដែលដកស្រង់ ឯក ហេន ប៉ុន្តែ ជាពិសេស ខ្លឹមសារនៃបទសម្ភាសន៍ជាមួយ នៅ សារឹម ដោយវិទ្យុសំឡេងសហរដ្ឋអាមេរិក ៖ "ប្រតិចារឹកនៃបទសម្ភាសន៍របស់ នៅ សារឹម ដោយវិទ្យុសំឡេងសហរដ្ឋអាមេរិក ឯកសារ E3/6934 ទំព័រ ១២, ១៩ និង ១៩៦ ERN 01326470, 01326477, 01326654 (នៅ សារឹម បានវិលត្រឡប់ពីប្រទេសបារាំងមកកាន់ប្រទេសកម្ពុជា នៅដើមឆ្នាំ១៩៧៦។ នៅពេលមកដល់ គាត់បានចូលរួមវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានខ្មែរ-សូវៀត ក្នុងទីក្រុងភ្នំពេញ រួមជាមួយនឹងអ្នកវិលត្រឡប់មកប្រទេសកម្ពុជាវិញផ្សេងៗទៀត។ ខៀវ សំផន បានមកបង្រៀនពួកគេ ហើយប្រាប់ពួកគេថា "ប្រជាជនទាំងឡាយរស់នៅក្នុងប្រទេសកម្ពុជាត្រូវធ្វើស្រែ តែអ្នកដែលមិនចេះធ្វើស្រែ ជាពិសេស ជនជាតិវៀតណាម ត្រូវបញ្ជូនទៅវៀតណាមវិញ។ ហេតុដូច្នេះ ខ្មែរក្រហមបានរៀបចំគម្រោងការបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសវៀតណាមវិញ") (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3922] សូមមើលខាងលើ កថាខណ្ឌ ១៨៩៤។

និងការប្រព្រឹត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខបានឡើយ[3923]។ អង្គជំនុំជម្រះក៏បានភាន់ច្រឡំផងដែរ ដោយបានយោងទៅសុន្ទរកថាមួយរបស់ ខៀវ សំផន ដែលមាននៅក្នុងកម្រងឯកសារផ្សព្វផ្សាយដោយគណៈកម្មាធិការអណិកជនស្នេហាជាតិនៃកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសបារាំង[3924] ដែលភាពគួរឱ្យទុកចិត្តបាននៃឯកសារនេះរងការរិះគន់[3925]។ ទោះយ៉ាងណាក្តី សម្រង់ដែលដកស្រង់ដោយអង្គជំនុំជម្រះ មិនពាក់ព័ន្ធនឹងការនិរទេសជនជាតិវៀតណាម ឬគោលនយោបាយបំផ្លិចបំផ្លាញដទៃទៀតឡើយ។

២០២៦. ការកត់សម្គាល់លើអង្គហេតុមួយចំនួនទាក់ទងនឹងការនិយាយស្តីរបស់ ខៀវ សំផន លើជនជាតិវៀតណាម[3926] និងលើ ប៉ង់[3927] ផ្អែកលើសក្ខីកម្មរបស់ ឯក ហេន ដែលមេធាវីការពារក្តីបានគូសបញ្ជាក់រួចហើយថាអង្គជំនុំជម្រះមិនអាចផ្តល់ភាពជឿជាក់ដល់គាត់បានទេ ដោយមូលហេតុក្នុងសក្ខីកម្មរបស់គាត់មានភាពផ្ទុយគ្នាជាច្រើន[3928]។ លើសពីនេះទៀត អង្គជំនុំជម្រះមិនបានបញ្ជាក់ថាតើហេតុអ្វីបានជាការដែល ខៀវ សំផន ទំនងបានចូលរួម "សន្និបាត" នាខែឧសភា ឆ្នាំ ១៩៧៥ ដែលក្នុងឱកាសនោះមានការលើកឡើងអំពីស្វែងរកខ្មាំងនៃរបបចាស់ អាចអនុញ្ញាតឱ្យបង្ហាញថាខៀវ សំផន ទំនងជា "បានផ្តល់ការណែនាំយ៉ាងសកម្ម"[3929]។ រីឯការសន្និដ្ឋានលើអង្គហេតុដែលថានៅឆ្នាំ ១៩៧៧ ខៀវ សំផន បានប្រាប់ដល់ប្រជាជនថាគោលបំណងនៃបដិវត្តន៍ គឺដើម្បីលុបបំបាត់របប លន់ នល់ សក្តិភូមិ និងពួក

---

[3923] សំអាងហេតុសាលក្រម កថាខណ្ឌ ៦៩។

[3924] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧១ យោងដល់កថាខណ្ឌ ៣៤០០។

[3925] សូមមើលខាងលើ កថាខណ្ឌ ១០៨០-១០៨២ កថាខណ្ឌ ១៨៩៨-១៩០២។

[3926] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៣៨ យោងដល់កថាខណ្ឌ ៣៣៩០, កថាខណ្ឌ ៤២៧១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៣៩ យោងដល់កថាខណ្ឌ ៣៥១៧ យោងដល់កថាខណ្ឌ ៣៣៨៥ ៣៣៩០ ៣៣៩១ និង ៣៣៩៦។ ការដកស្រង់របស់អង្គជំនុំជម្រះ នៅកថាខណ្ឌ ៤២៧១ បានមកពីកថាខណ្ឌ ៣៣៩១ ដែលយោងដល់កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៦ ដែលដកស្រង់ភ័ស្តុតាងជាច្រើនអំពីបទឧទ្ទេសនាមរបស់មេដឹកនាំជាច្រើន។ ចំពោះបទឧទ្ទេសនាមរបស់លោក ខៀវ សំផន ប្រភពតែមួយគត់ គឺ ឯក ហេន។

[3927] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧២ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៦។

[3928] សូមមើលខាងលើ កថាខណ្ឌ ១០៧៥, ១៧៥៩, ១៨៩២-១៨៩៤។ សូមមើលផងដែរ សំណើរបស់លោក ខៀវ សំផន ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ **F51** កថាខណ្ឌ ២០-២៨។

[3929] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧២។

នាយទុន ការសន្និដ្ឋាននេះមិនមានប្រភពគាំទ្រឡើយ។ ជាការពិត ការយោងទៅកថាខណ្ឌ ៤២៧២ ក៏មិនអនុញ្ញាតឱ្យយើងដឹងថាតើការអះអាងនេះផ្អែកលើប្រភពណាមួយឡើយ[3930]។

២០២៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយផ្អែកជាប្រចាំទៅលើដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម អឿន ដើម្បីពិចារណាថា ខៀវ សំផន បានគាំទ្រគោលបំណងរួមនេះ[3931]។ កង្វះខាតនៃភាពគួរជឿទុកចិត្តបានរបស់សាក្សីរូបនេះ ដែលមេធាវីការពារក្តីបានបង្ហាញយ៉ាងក្បោះក្បាយ គួរតែល្មមអាចទប់ស្កាត់អង្គជំនុំជម្រះកុំឱ្យផ្អែកលើសក្ខីកម្មនេះ[3932]។ ដូចគ្នាដែរ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឈុន[3933] ដែលបានដកស្រង់ដោយអង្គជំនុំជម្រះ ដើម្បីអះអាងថា ខៀវ សំផន ទំនងជាបានធ្វើសេចក្តីអត្ថាធិប្បាយដូចតទៅនេះ៖ "ទុកមិនចំណេញ ដកចេញមិនខាត"[3934]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះបានដកស្រង់សម្តីរបស់ ប៊ិត ណា ដើម្បីពិចារណាថា ខៀវ សំផន បានណែនាំកម្មាភិបាលនៅក្រសួងពាណិជ្ជកម្មអំពីវិន័យសីលធម៌ ដោយថ្កោលទោស"អ្នកដែលខ្ជិលធ្វើការ "ថាជាខ្មាំងរបស់បក្ស[3935]។ ក៏ប៉ុន្តែ មេធាវីការពារក្តីបានលើកឡើងរួចហើយថា ការសន្និដ្ឋាននេះមិនត្រឹមត្រូវទេ ពីព្រោះពាក្យសម្តីរបស់គាត់ត្រូវបានបំភ្លៃ[3936]។

២០២៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើតែឯកសារ FBIS និង SWB ដើម្បីសន្និដ្ឋានថា ខៀវ សំផន បានគាំទ្រនៅចំពោះមុខកម្មាភិបាល "ដល់ភាពចាំបាច់ក្នុងការសម្រេចផែនការបង្កបង្កើន

---

[3930] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧២ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤១ យោងដល់កថាខណ្ឌ ៤២៧២។

[3931] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧២ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤២ យោងដល់កថាខណ្ឌ ៣៩៤២ និង ៣៩៤៣, កថាខណ្ឌ ៤២៧២ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៦ យោងដល់កថាខណ្ឌ ៤២២៦ កំណត់សម្គាល់ជើងទំព័រលេខ ១៣៧៨៨, កថាខណ្ឌ ៤២៧៣ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៨ យោងដល់កថាខណ្ឌ ៣៩៤២, កថាខណ្ឌ ៤២៧៣ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៩ យោងដល់កថាខណ្ឌ ៣៩៦៧ កំណត់សម្គាល់ជើងទំព័រលេខ ១៣២០៤។

[3932] សូមមើលខាងលើ កថាខណ្ឌ ១៧៥៧-១៧៥៨ កថាខណ្ឌ ១៨៦៥។

[3933] សូមមើលខាងលើ កថាខណ្ឌ ១៥៣៤-១៥៣៥។

[3934] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧២ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៣ យោងដល់កថាខណ្ឌ ៣៩៦១។

[3935] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧២ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៤ យោងដល់កថាខណ្ឌ ៦២០។

[3936] សូមមើលខាងលើ កថាខណ្ឌ ១៧៩៤-១៧៩៧។

ផល"[3937]។ ភាពជឿជាក់នៃឯកសារទាំងនេះត្រូវបានជំទាស់[3938]។ ដោយមូលហេតុនេះ អង្គជំនុំជម្រះមិនគួរណាផ្អែកលើឯកសារទាំងនេះទេ។ ជាចុងក្រោយ ទាក់ទងនឹងបញ្ហាអាពាហ៍ពិពាហ៍នៅឯក្រសួងពាណិជ្ជកម្ម[3939] អង្គជំនុំជម្រះមិនគួរណាផ្អែកលើដើមបណ្តឹងរដ្ឋប្បវេណី ជា ដៀប ដើម្បីពិចារណាថា លោក ខៀវ សំផន បានស្នើសុំទៅក្រសួងទាំងអស់ឱ្យរៀបចំអាពាហ៍ពិពាហ៍នោះទេ[3940]។ យោងតាមកំហុសអង្គហេតុយ៉ាងច្រើននេះ អង្គជំនុំជម្រះមិនអាចអះអាងថា ម្ចាស់បណ្តឹងសាទុក្ខ "បានផ្តល់ការណែនាំយ៉ាងសកម្មដើម្បីអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយផ្សេងៗ"[3941]។ អាស្រ័យហេតុនេះ ការសន្និដ្ឋាននេះត្រូវទុកជាមោឃៈ ហើយអង្គជំនុំជម្រះមិនអាចពិចារណាថា ខៀវ សំផន បានចូលរួមចំណែកក្នុងគោលបំណងរួម និងថាគាត់ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ ដោយមូលហេតុគាត់ចូលរួមនៅក្នុងសហឧក្រិដ្ឋរួមនោះទេ[3942]។

## ៦. ការសម្រួល និងការត្រួតពិនិត្យ

២០២៩. យោងតាមសំអាងហេតុសាលក្រមរងបណ្តឹងសាទុក្ខនេះ ក្នុងឋានៈជាសមាជិកមន្ទីរ ៨៧០ និងទទួលបន្ទុកត្រួតពិនិត្យលើក្រសួងពាណិជ្ជកម្ម និងជំនួញរបស់កម្ពុជាប្រជាធិបតេយ្យ ម្ចាស់បណ្តឹងទំនងជា "បានជួយដោយផ្ទាល់ឱ្យរដ្ឋបាលរបស់កម្ពុជាប្រជាធិបតេយ្យដំណើរការយ៉ាងរលូន ក្នុងទិសដៅបំផ្លាញប្រជាជនរបស់ខ្លួន"[3943]។ ការសន្និដ្ឋាននេះត្រូវបានធ្វើឡើង ដោយផ្អែកលើការបកស្រាយមិនត្រឹមត្រូវអំពីមុខតំណែងរបស់ ខៀវ សំផន ទាក់ទងនឹងមន្ទីរ ៨៧០ និងពាណិជ្ជកម្ម[3944]។ ការសន្និដ្ឋានអំពីឋានៈ

---

[3937] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៣ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៧ យោងដល់កថាខណ្ឌ ៣៩១៦ កំណត់សម្គាល់ជើងទំព័រលេខ ១៣០៦៧។

[3938] សូមមើលខាងលើ កថាខណ្ឌ ១៨៩៨-១៩០២។

[3939] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៣ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៥០ និង ១៣៩៥១។

[3940] សូមមើលខាងលើ កថាខណ្ឌ ១២៣៣-១២៤២, ១៨១៥, ១៩២៩, ១៩៣៦, ២០២៨, ២១១៧។

[3941] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៤។

[3942] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[3943] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៦។

[3944] សូមមើលខាងលើ កថាខណ្ឌ ១៧៦៣-១៧៩៨។

របស់គាត់ជា "អ្នកត្រួតពិនិត្យលើបញ្ហាពាណិជ្ជកម្ម" ដោយហេតុថារូបគាត់ "ផ្ទាល់" ទំនងជាអ្នកធ្វើយ៉ាងណាឱ្យប្រាកដថាភារកិច្ចរបស់ ឌឿន ត្រូវបានបំពេញ ជាការភាន់ច្រឡំ[3945]។ ដូចបានឃើញខាងលើ កំហុសជាច្រើនរបស់អង្គជំនុំជម្រះធ្វើឱ្យសេចក្តីសម្រេចរបស់ខ្លួនត្រូវទុកជាមោឃៈ[3946]។ លើសពីនេះ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានសន្និដ្ឋានថា "ក្នុងតួនាទីគាត់ជាអ្នកត្រួតពិនិត្យការនាំចេញ និងនាំចូលទំនិញមកកម្ពុជាប្រជាធិបតេយ្យ"[3947] ម្ចាស់បណ្តឹងសាទុក្ខ ទំនងជាបាន "យកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យសហករណ៍ផ្តល់ទិន្នផលសម្បូរភាព ដើម្បីនាំចេញ" តាមរយៈការរឹបអូសស្រូវជាអតិបរមា ទោះបីមានគ្រោះរាំងស្ងួត កង្វះស្បៀងអាហារ និងល័ក្ខខ័ណ្ឌការងារដ៏លំបាករបស់កម្មករ និងពលករតាមសហករណ៍។ ដូចដែលបានបញ្ជាក់ខាងលើ ការចោទប្រកាន់ទាំងនេះផ្អែកលើកំហុសអង្គហេតុជាច្រើន ដែលបានប្រព្រឹត្តដោយអង្គជំនុំជម្រះ ដែលត្រូវតែបដិសេធចោល និងមិនអាចគាំទ្រសេចក្តីសន្និដ្ឋានបែបនេះបានទេ[3948]។

២០៣០. លើសពីនេះទៀត យោងទៅតាមសំអាងហេតុសាលក្រម "មុខតំណែងពិសេស" នៅក្នុង ប.ក.ក និងវត្តមានរបស់គាត់ នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ បានធ្វើឱ្យគាត់ដឹងឮស៊ីជម្រៅអំពីសកម្មភាពរបស់បក្ស[3949]។ ខៀវ សំផន ទំនងជាបានចូលរួមនៅក្នុងកិច្ចប្រជុំមួយចំនួនស្តីពីសេចក្តីសម្រេចបោសសម្អាតដែលក្នុងនោះមានការបោសសម្អាត កង ចាប[3950]។ ដូចដែលបានបញ្ជាក់ខាងលើ ការសន្និដ្ឋាននេះផ្អែកលើកំហុសអង្គហេតុ និងការវាយតម្លៃភ័ស្តុតាង មិនត្រឹមត្រូវ[3951]។ យោងតាមអង្គជំនុំជម្រះ ម្ចាស់បណ្តឹងសាទុក្ខទំនងជាបាន "យល់ព្រមដោយតុណ្ហីភាព" ចំពោះការធ្វើបាបជនស៊ីវិល[3952]។ ជាបឋមគួរគប្បីគូសបញ្ជាក់ពីភាពខុសទំនងនៃពាក្យ "យល់ព្រមដោយតុណ្ហីភាព"។ ពាក្យនេះឆ្លុះបញ្ចាំងអំពី

---

[3945] សូមមើលខាងលើ កថាខណ្ឌ ១៧៦៨-១៧៦៩ កថាខណ្ឌ ១៧៧០-១៧៩៨។

[3946] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៦។ សូមមើលខាងលើ កថាខណ្ឌ ១៧៦៣-១៧៦៩។

[3947] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៦។

[3948] សូមមើលខាងលើ កថាខណ្ឌ ១៥០៦-១៥១០ កថាខណ្ឌ ១៤៩០-១៥២២ កថាខណ្ឌ ១៧៧០-១៧៩៨។

[3949] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៧។

[3950] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៧។

[3951] សូមមើលខាងលើ កថាខណ្ឌ ១៨៥១-១៨៥៣ កថាខណ្ឌ ១៨៥៧-១៨៧៨។

[3952] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៧។

កង្វះធាតុផ្សំភស្តុតាងដាក់បន្ទុកលើ ខៀវ សំផន។ គេមិនអាចបង្ហាញភស្តុតាងបញ្ជាក់អំពីការយល់ព្រមក្នុងចិត្ត ពោលគឺការសម្តែងការយល់ព្រមមួយដែលបញ្ជាក់អំពីចេតនា និងឆន្ទៈរបស់មនុស្សម្នាក់តាមរយៈការនៅស្ងៀមមិននិយាយស្តី។ ការសន្និដ្ឋាននេះផ្អែកលើការវាយតម្លៃភស្តុតាងមិនត្រឹមត្រូវ និងកំហុសអង្គហេតុ និងអង្គច្បាប់ដែលបានរៀបរាប់ខាងលើ[3953]។ នៅចុងបញ្ចប់ អង្គជំនុំជម្រះ បានកត់សម្គាល់ថា ម្ចាស់បណ្តឹងសាទុក្ខ "បានបិទបាំងព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅខាងក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយបានបដិសេធការប្រព្រឹត្តិបទឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំនេះ"[3954]។ ការសន្និដ្ឋាននេះក៏ផ្អែកលើកំហុសអង្គហេតុ និងអង្គច្បាប់ ទាក់ទងនឹងការដឹងឮជាសន្ទតអំពីឧក្រិដ្ឋកម្ម នៅពេលហេតុការណ៍កំពុងកើតឡើង[3955]។ អាស្រ័យហេតុនេះ ការសន្និដ្ឋានចុងក្រោយរបស់អង្គជំនុំជម្រះដែលថា ខៀវ សំផន មិនត្រឹមតែបានចូលរួមក្នុងគោលបំណងរួមប៉ុណ្ណោះទេ គឺថែមទាំងបានសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគោលបំណងរួមនេះ តាមរយៈគោលនយោបាយផ្សេងៗដែលត្រូវបានអនុម័ត" ផ្អែកលើកំហុសអង្គហេតុ និងអង្គច្បាប់ និងការវាយតម្លៃភស្តុតាងមិនត្រឹមត្រូវ ត្រូវទុកជាមោឃៈ[3956]។

## ជំពូក ៣. កំហុសលើធាតុផ្សំអវត្តនោម័តិ

## ផ្នែកទី ១. កំហុសទូទៅលើធាតុផ្សំនៃចេតនាប្រព្រឹត្តបទល្មើស

## ១. ការរំឭកអំពីកំហុសលើចេតនាចូលរួមក្នុងគោលបំណងឧក្រិដ្ឋរួម

២០៣១. អង្គជំនុំជម្រះបានសន្និដ្ឋានថា ចេតនារបស់ ខៀវ សំផន ក្នុងការចូលរួមក្នុងគោលបំណងរួមត្រូវបានបង្ហាញ តាមរយៈការដែលថាគាត់ "ជាសមាជិកម្នាក់នៃក្រុមមនុស្សដែលបានធ្វើសកម្មភាពរួមគ្នា ដើម្បីអនុវត្តគោលបំណងរួម" និង "លើសពីនេះទៀត [...] តាមរយៈការចូលរួមចំណែករបស់គាត់ ក្នុងបំណងធ្វើឱ្យគោលបំណងនេះជឿនលឿនទៅមុខ"[3957]។ ក្រៅពីបានប្រព្រឹត្តកំហុស ក្នុងការកំណត់

---

[3953] សូមមើលខាងលើ កថាខណ្ឌ ១៨៤៩-១៨៧៨។

[3954] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៧។

[3955] សូមមើលខាងលើ កថាខណ្ឌ ១៨០៤-១៩៣៧។

[3956] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៨។

[3957] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៧៩ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៦៥ យោងដល់ផ្នែក ១៦.៤.៥។

និយមន័យនៃគោលបំណងរួម គួរគប្បីរំឭកថា អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ជាពិសេស ដោយបានសន្និដ្ឋានថា គោលបំណងរួមនេះពាក់ព័ន្ធនឹងគោលនយោបាយឧក្រិដ្ឋ[3958]។

២០៣២. មួយវិញទៀត អង្គជំនុំជម្រះក៏បានយល់ច្រឡំដែរ ដោយបានពិចារណាថា សមាជិកភាព[3959] និងការចូលរួមចំណែក[3960] ក្នុងគោលបំណងរួមដែលមិនមានលក្ខណៈឧក្រិដ្ឋ អនុញ្ញាតឱ្យខ្លួនសន្និដ្ឋានថា គាត់បានចូលរួមចំណែកក្នុងគោលនយោបាយឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ក្នុងខណៈដែលខ្លួនត្រូវតែបង្ហាញអំពីចេតនាចូលរួមក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួម ហើយក្នុងករណីនេះ គឺចេតនាចូលរួមក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយរងការចោទប្រកាន់[3961]។

## ២. វិចារណកិច្ចមិនត្រឹមត្រូវក្នុងការទាញការសន្និដ្ឋានអំពីចេតនាឧក្រិដ្ឋ

២០៣៣. វិចារណកិច្ចរបស់អង្គជំនុំជម្រះមិនត្រឹមត្រូវទេ ពីព្រោះខ្លួនបានពិចារណាថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយចារីបង្គោល ដែលត្រូវបានបញ្ចូលបែបសិប្បនិម្មិតទៅក្នុងគោលបំណងរួមដែលមិនមានលក្ខណៈឧក្រិដ្ឋ គឺជាការគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះ។ (២.១) ដោយធ្វើដូចនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយមិនដែលដោះស្រាយបញ្ហាទាក់ទងនឹងចេតនាពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិចាំបាច់ជាក់លាក់ ចំពោះឧក្រិដ្ឋកម្មរងការចោទប្រកាន់នីមួយៗ (២.២)។

### ២.១. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម នៅក្នុងគោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋចំតួ

២០៣៤. គួរគប្បីរំឭកពីវិចារណកិច្ចមិនត្រឹមត្រូវរបស់អង្គជំនុំជម្រះក្នុ ងការកំណត់លក្ខណៈនៃគោលបំណងរួមដែលមានលក្ខណៈឧក្រិដ្ឋ នៅក្នុងសហឧក្រិដ្ឋកម្មរួម។ ជំហានដំបូងមានដូចតទៅ៖ - មានបទឧក្រិដ្ឋ

---

[3958] សូមមើលខាងលើ កថាខណ្ឌ ១៤៣៨-១៦០៣។

[3959] សូមមើលខាងលើ កថាខណ្ឌ ១៥៩៣-១៦០៣។

[3960] សូមមើលខាងលើ កថាខណ្ឌ ២០០១-២០៣០។

[3961] សូមមើលខាងលើ កថាខណ្ឌ ១៩៦៣-១៩៦៥។

**ហើយ**បទឧក្រិដ្ឋទាំងនេះបណ្តាលមកពីការអនុវត្ត "គោលនយោបាយ"[3962]។ បទឧក្រិដ្ឋទាំងនេះត្រូវបានបញ្ចូលបែបសិប្បនិម្មិត ទៅក្នុង "គោលនយោបាយ" ជាផ្នែកមួយនៃគោលបំណងរួម ពីព្រោះគោលនយោបាយនេះមានចំណងពាក់ព័ន្ធជាក់ស្តែងជាមួយគោលបំណងរួម ដែលមិនមានលក្ខណៈឧក្រិដ្ឋចំពោះ។

២០៣៥. ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយចាប់ផ្តើមរាល់ផ្នែកទាក់ទងនឹងចេតនារបស់ ខៀវ សំផន ដោយរំឭកជាបឋមថាខ្លួនបានពិចារណាថា "ឧក្រិដ្ឋកម្ម [X,Y, Z] ត្រូវបានបង្ហាញថាពិតជាបានកើតឡើងមែន ដោយជាប់ទាក់ទងនឹងការអនុវត្តគោលនយោបាយ [X]" និងពិចារណាថា "ឧក្រិដ្ឋកម្មទាំងនេះគឺជាផ្នែកមួយនៃគោលបំណងរួមស្របតាមគោលនយោបាយ [X] របស់ ប.ក.ក.[3963]។ វិចារណកិច្ចនេះមិនត្រឹមត្រូវទេ ហើយត្រូវទុកជាមោឃៈ។ ជាក់ស្តែង វិចារណកិច្ចនេះមិនអាចប្រើជាចំណុចចាប់ផ្តើមសម្រាប់ការផ្តល់សំអាងហេតុរបស់អង្គជំនុំជម្រះលើចេតនារបស់ ខៀវ សំផន ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ ដែលគួរតែត្រូវបានកំណត់ដោយអាកប្បកិរិយា ឬអំពើជាក់លាក់នៃម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងនេះ។

២០៣៦. ជំហានទីពីរនៃខ្សែគំនិតរបស់អង្គជំនុំជម្រះ គឺត្រូវសន្និដ្ឋានដោយគ្មានសំអាងហេតុថា ការអនុវត្ត "គោលនយោបាយនេះ" ជាការអះអាងថា ខៀវ សំផន មានចេតនាចង់ឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ។

២០៣៧. នៅចុងបញ្ចប់ ជាជំហានទីបី និងចុងក្រោយនៃខ្សែគំនិតរបស់ខ្លួន អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានយ៉ាងដាច់ខាត ថាការចូលរួមរបស់ ខៀវ សំផន នៅក្នុង "សហឧក្រិដ្ឋកម្មរួម" (គោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋ) គឺជាការគ្រប់គ្រាន់ដើម្បីបង្ហាញថា ដូចអ្នកចូលរួមដទៃទៀតនៅក្នុងសហឧក្រិដ្ឋកម្មរួមដែរ គាត់មានចេតនាប្រព្រឹត្តិបទឧក្រិដ្ឋ X, Y និង Z ខណៈដែលអង្គជំនុំជម្រះត្រូវតែបង្ហាញអំពីការចូលរួមរបស់គាត់ ក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលបំណងរួមនេះ។ ដោយខកខានមិន

---

[3962] យើងឃើញថា អង្គជំនុំជម្រះបានធ្វើវិចារណកិច្ចវិលចុះវិលឡើង ដែលធ្វើឱ្យឧក្រិដ្ឋកម្មកើតចេញពីគោលនយោបាយ និងគោលនយោបាយកើតចេញពីឧក្រិដ្ឋកម្ម។ សូមមើលខាងលើ កថាខណ្ឌ ១៩៨១-២០០០។

[3963] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨០, ៤២៨៣, ៤២៨៨, ៤២៩១, ៤២៩៦, ៤២៩៩, ៤៣០៣។

បានបង្ហាញអំពីការចូលរួមក្នុងទិដ្ឋភាពឧក្រិដ្ឋនេះ អង្គជំនុំជម្រះបានបង្កើត តាមរយៈការបន្ទាបកម្រិតចេតនាឧក្រិដ្ឋនេះ នូវការទទួលខុសត្រូវព្រហ្មទណ្ឌមួយចំពោះអំពើអ្នកដទៃ ដែលមិនស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ណាមួយឡើយ។

**២.២. លំនាំខ្ចៃការធ្ងន់ធ្ងរនៅជាចេតនាចាំបាច់ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ តែមិនមែនចំពោះ "ឧក្រិដ្ឋកម្ម" ជាទូទៅ**

២០៣៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានវាយតម្លៃជាប្រព័ន្ធអំពីចេតនារបស់ ខៀវ សំផន ដោយផ្អែកលើ "ឧក្រិដ្ឋកម្ម" ជាទូទៅ ដោយមិនបានវាយតម្លៃដាច់ដោយឡែកលើធាតុផ្សំចាំបាច់នៃចេតនាឧក្រិដ្ឋ ចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់នីមួយៗ ក្នុងខណៈដែលការកំណត់ប្រភេទបទល្មើសមិនអាចត្រូវបានធ្វើឡើង ដោយគ្មានការវាយតម្លៃនេះឡើយ។ នេះគឺជាកំហុសដែលបណ្តាលឱ្យការសន្និដ្ឋានទាំងអស់របស់អង្គជំនុំជម្រះក្លាយជាមោឃៈ។

**ផ្នែកទី ២. សហករណ៍ និងការដ្ឋាន**

២០៣៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ការធ្វើឱ្យក្លាយជាទាសករ អំពើអមនុស្សធម៌ដទៃទៀត ឬការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ការបាត់ខ្លួនដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងនៅព្រលានយន្តហោះកំពង់ឆ្នាំង[3964]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានវិនិច្ឆ័យថាឧក្រិដ្ឋកម្មទាំងនេះជាផ្នែកមួយនៃគោលបំណងរួម[3965]។ អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុស អង្គហេតុ និងអង្គច្បាប់ ដោយបានរៀបរាប់ធាតុផ្សំភ័ស្តុតាងដែលមិនអាចបង្ហាញពីចេតនាឧក្រិដ្ឋណាមួយ (១) និងដោយមិនបានផ្តល់សំអាងហេតុ ចំពោះការបង្ហាញពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ (២)។

[3964] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨២។

[3965] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨០។

## ១. គ្មានការបង្ហាញចេតនាឧក្រិដ្ឋ

២០៤០. អង្គជំនុំជម្រះបានរៀបរាប់ធាតុផ្សំភ័ស្តុតាងដែលមិនទាក់ទងនឹងចេតនាឧក្រិដ្ឋណាមួយ (១.១)។ អង្គជំនុំជម្រះបានផ្អែក ដោយមិនត្រឹមត្រូវ ទៅលើការដឹងឮជាសន្មតរបស់ ខៀវ សំផន អំពីល័ក្ខខ័ណ្ឌការងារ និងការរស់នៅ តាមការដ្ឋានទាំងនេះ (១.២) ដោយមិនទាញផលវិបាកពីអវត្តមានភ័ស្តុតាងនៃការជំរុញឱ្យប្រព្រឹត្តការរើសអើងលើប្រជាជនថ្មី (១.៣)។ លើសពីនេះទៀត អង្គជំនុំជម្រះ បានសន្និដ្ឋានពង្រីកស្មានៗថា ខៀវ សំផន មានចេតនាចង់ឱ្យដោះស្រាយជោគវាសនារបស់ខ្មាំងដោយសម្ងាត់ (១.៤)។

### ១.១. គ្មានទំនាក់ទំនងជាមួយចេតនាឧក្រិដ្ឋ

#### ១.១.១. គ្មានចេតនាឧក្រិដ្ឋក្នុងការគាំទ្រដល់គោលបំណងរួមដែលមិនមានលក្ខណៈឧក្រិដ្ឋ

២០៤១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ ដោយហេតុថា "គាត់នៅតែបន្តគាំទ្រគោលបំណងរួមដែល [មិនមានលក្ខណៈឧក្រិដ្ឋ] ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ចំពោះការបង្កើត និងប្រតិបត្តិការរបស់សហករណ៍ និងការដ្ឋាន"[3966]។ ក៏ប៉ុន្តែ ការបង្កើត និងដាក់ឱ្យដំណើរការសហករណ៍ និងការដ្ឋាន មិនមែនជាបទឧក្រិដ្ឋនោះទេ។ ការណ៍ដែល ខៀវ សំផន គាំទ្រសេដ្ឋកិច្ចប្រភេទនេះមិនអនុញ្ញាតឱ្យយើងសន្និដ្ឋានថា មានធាតុផ្សំចេតនាចាំបាច់គ្រប់គ្រាន់ ចំពោះបទឧក្រិដ្ឋដែលបានចោទប្រកាន់នីមួយៗនៅតាមសហករណ៍ និងការដ្ឋានបានឡើយ។ លើសពីនេះទៀត អង្គជំនុំជម្រះក៏មិនបានបង្ហាញអំពីការដឹងឮរបស់ម្ចាស់បណ្តឹងសាទុក្ខ អំពីបទឧក្រិដ្ឋដែលចារីបង្គោលបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋានទាំងនេះដែរ[3967]។ ដូច្នេះ ជាថ្មីម្តងទៀត វាជាការចូលរួមចំណែករបស់ ខៀវ សំផន ក្នុងគោល

---

[3966] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៦៨ យោងដល់កថាខណ្ឌ ៤២១០ (ការដឹងឮ - សហករណ៍ និងការដ្ឋាន)។

[3967] សូមមើលខាងលើ កថាខណ្ឌ ១៨១៦-១៨៤៨។

បំណងរួម (មិនមានលក្ខណៈឧក្រិដ្ឋ) ដែលការចូលរួមចំណែកនេះត្រូវបានចោទប្រកាន់ និងយកមកធ្វើជាមូលដ្ឋាន ដើម្បី "បង្ហាញពី" ចេតនាឧក្រិដ្ឋរបស់គាត់[3968]។

### ១.១.២. គ្មានចេតនាឧក្រិដ្ឋ ក្នុងបំណងប្រាថ្នាអភិវឌ្ឍសេដ្ឋកិច្ច

២០៤២. អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា ខៀវ សំផន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ តាមរយៈវត្តមានរបស់គាត់ "នៅក្នុងកិច្ចប្រជុំផ្សេងៗ ដែលក្នុងឱកាសនោះ មានការរៀបចំ និងពិភាក្សាផែនការដាំស្រូវឱ្យបានបីតោនក្នុងមួយហិកតា"[3969] និងតាមរយៈការណ៍ដែលថាគាត់ "បានណែនាំជាសាធារណៈឱ្យប្រកាន់យកមាគ៌ា "មហាអស្ចារ្យ មហាលោតផ្លោះ" "ដែលមិនធ្លាប់មានពីមុនមក" ក្នុងគោលបំណងកែប្រែកម្ពុជាប្រជាធិបតេយ្យឱ្យទៅជាការដ្ឋានកសាងដ៏ធំមួយ"[3970]។ ការកំណត់គោលដៅសេដ្ឋកិច្ច និងផែនការ[3971] កាន់តែមិនអាចអនុញ្ញាតឱ្យការធ្វើការផ្សារភ្ជាប់ទំនាក់ទំនងជាមួយបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹង ខៀវ សំផន ដោយហេតុថាការអភិវឌ្ឍកសិកម្មមានគោលបំណងយ៉ាងជាក់លាក់ ដើម្បីដោះស្រាយបញ្ហារបស់ប្រជាជនឱ្យបានឆាប់រហ័ស[3972]។

### ១.១.៣. គ្មានចេតនាឧក្រិដ្ឋ តាមរយៈការដឹងឮអំពីការផ្លាស់ប្តូរសង្គម

២០៤៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ ដោយហេតុថាគាត់ទំនងជាបានដឹងថាប្រជាជន "កំពុងទទួលរងការ

---

[3968] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៦៨ យោងដល់កថាខណ្ឌ ៤២១០ (ការដឹងឮ - សហករណ៍ និងការដ្ឋាន) យោងកំណត់សម្គាល់ជើងទំព័រលេខ ១៣៧៤០ ដល់ផ្នែក ១៨.២.១.២៖ ការលើកកម្ពស់គោលបំណងរួម

[3969] សំអាងហេតុសាលក្រម, កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៦៩ យោងដល់កថាខណ្ឌ ៤២៥៨។

[3970] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៧០ និង ១៣៩៧១ យោងដល់កថាខណ្ឌ ៤២៦២ កថាខណ្ឌ ៤២៦៥-៤២៦៦។

[3971] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៧២ យោងដល់កថាខណ្ឌ ៤២១៤ និង ៤២៦៧។

[3972] សូមមើលខាងលើ, កថាខណ្ឌ ១៤៩០-១៥១០។

ផ្លាស់ប្តូរ ដើម្បីបង្កើតសង្គមកម្មករ-កសិករ ដែលត្រូវបានបង្ខំឱ្យធ្វើការជាសមូហភាព"[3973]។ ការដឹងឮពីការផ្លាស់ប្តូរសង្គមទៅរកគំរូសេដ្ឋកិច្ចសង្គមនិយមសមូហភាព មិនអាចអនុញ្ញាតឱ្យសន្និដ្ឋានថាមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋបានឡើយ។

## ១.១.៤. គ្មានចេតនាឧក្រិដ្ឋ តាមរយៈការត្រួតពិនិត្យលើ "ការចែកចាយ" ស្រូវទៅបរទេស

២០៤៤. អង្គជំនុំជម្រះបានសន្និដ្ឋានខុសថា ខៀវ សំផន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ ដោយហេតុថាគាត់ទំនងជាបានត្រួតពិនិត្យលើការរឹបអូសយកស្រូវ និងការចែកចាយទៅបរទេស[3974]។ ជាដំបូង អង្គជំនុំជម្រះបានសង្ខេបមិនត្រឹមត្រូវលើតួនាទីរបស់ ខៀវ សំផន[3975] បន្ទាប់មក អង្គជំនុំជម្រះបានព្រងើយកន្តើយនឹងភស្តុតាងដោះបន្ទុកអំពីការលាក់បាំងការខ្វះខាតស្បៀងពីសំណាក់ប្រធានសហករណ៍ និងការដ្ឋាន[3976]។

## ១.២. ការមិនបានដឹងឮអំពីល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌរស់នៅដែលបានកំណត់

២០៤៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានអះអាងថា ខៀវ សំផន ដឹងថា "ស្ថានភាពការងារ និងជីវភាពរស់នៅដ៏យ៉ាប់យ៉ឺន" "ត្រូវបានកំណត់ដោយចេតនានៅតាមសហករណ៍ និងការដ្ឋាននៅទូទាំងប្រទេស"[3977]។ អង្គជំនុំជម្រះមិនត្រឹមតែមិនបានបង្ហាញអំពីការដឹងឮនេះប៉ុណ្ណោះ

---

[3973] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៧៣ យោងដល់កថាខណ្ឌ ៤២១០ ដែលយោងកំណត់សម្គាល់ជើងទំព័រលេខ ១៣៧៤០ ដល់ផ្នែក ១៨.២.១.២៖ ការលើកកម្ពស់គោលបំណងរួម។

[3974] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៧៦ យោងដល់កថាខណ្ឌ ៤២៧៥។ កថាខណ្ឌដែលចង្អុលបង្ហាញជាកំណត់សម្គាល់ជើងទំព័រអំពីការប្រព្រឹត្តិលើពុទ្ធសាសនិក គឺខុសយ៉ាងច្បាស់ក្រឡែត។ អង្គជំនុំជម្រះទំនងជាចង់ចង្អុលបង្ហាញកថាខណ្ឌ ៤២៧៦ ទៅវិញទេ។

[3975] សូមមើលខាងលើ កថាខណ្ឌ ១៦៥២-១៨០៣។

[3976] សូមមើលខាងលើ កថាខណ្ឌ ១៥០៦-១៥១០។

[3977] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៧៥ យោងដល់កថាខណ្ឌ ៤២១៥ (ការដឹងឮ - សហករណ៍ និងការដ្ឋាន) កថាខណ្ឌ ៤២៣១ (ការដឹងឮ - មន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការបោសសម្អាតផ្ទៃក្នុង) និងកថាខណ្ឌ ៤២៣៤ (ការដឹងឮ - មន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការបោសសម្អាតផ្ទៃក្នុង)។

ទេ គឺថែមទាំងមិនដឹងថាការដាក់វិធានការបែបនេះ ដើរផ្ទុយពីផែនការសហករណ៍ដែលត្រូវបានកំណត់ដោយ ប.ក.កថែមទៀតផង[3978]។

## ១.៣. គ្មានភ័ស្តុតាងពាក់ព័ន្ធនឹងការជំរុញឱ្យមានការប្រព្រឹត្តិការរើសអើងទៅលើប្រជាជនថ្មី

២០៤៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានអះអាងថា ខៀវ សំផន "បានជំរុញកម្មាភិបាលឱ្យដាក់ការងារឱ្យប្រជាជនថ្មីច្រើនជាង និងមិនអោយអាហារបរិភោគគ្រប់គ្រាន់ ដោយសារគាត់គាំទ្រដល់ការប្រព្រឹត្តិរើសអើងចំពោះសត្រូវវណ្ណៈដែលត្រូវបានសន្មតថាជាឧបសគ្គដល់ការរីកចម្រើនរបស់ ប.ក.ក[3979]"។ ក៏ប៉ុន្តែ ដូចដែលបានឃើញខាងលើ គាត់មិនបានដឹងអំពីការរើសអើងរវាងប្រជាជនចាស់ និងប្រជាជនថ្មីនោះទេ ហើយពាក្យសម្តីរបស់គាត់កាលពីឆ្នាំ២០០៤ ត្រូវបានបំភ្លៃ[3980]។

## ១.៤. គ្មានចេតនារួមតែមួយ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

២០៤៧. អង្គជំនុំជម្រះក៏គ្មានភ័ស្តុតាងដើម្បីសន្និដ្ឋានថា ខៀវ សំផន មានចេតនារើសអើងខ្លាំងរបស់បក្សដោយមូលហេតុនយោបាយ[3981] និងមានចេតនារួមដូចគ្នាជាមួយអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដទៃទៀតក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[3982]។

---

[3978] សូមមើលខាងលើ កថាខណ្ឌ ១៥០៣-១៥០៥។

[3979] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៧៧ យោងដល់កថាខណ្ឌ ៤២១៧ (ការដឹងឮ - សហករណ៍ និងការដ្ឋាន) និងកថាខណ្ឌ ៤២៧៣ (ការចូលរួមចំណែក - សេចក្តីណែនាំអំពីការអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយរបស់ខ្លួន)។

[3980] សូមមើលខាងលើ កថាខណ្ឌ ១៨៣៦-១៨៣៨។

[3981] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១។

[3982] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨២។

## ១.៥. គ្មានធាតុផ្សំភ័ស្តុតាងដែលបង្ហាញអំពីចេតនាចង់ឱ្យដោះស្រាយ "ជោគវាសនារបស់ខ្មាំងជាសម្ងាត់"

២០៤៨. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសអង្គហេតុផងដែរ ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាចង់ឱ្យដោះស្រាយជោគវាសនារបស់ខ្មាំងជាសំងាត់ ដោយយោងទៅកំណត់សម្គាល់ជើងទំព័រ គឺមិនមែនយោងទៅឯកសារជាក់លាក់ណាមួយដែលអាចឱ្យ ខៀវ សំផន យល់ដឹងច្បាស់អំពីអ្វីដែលគេចោទប្រកាន់មកលើគាត់ឡើយ ប៉ុន្តែយោងទៅជំពូកទាំងដុលៗតែម្តង[3983]។ ការគ្មានសំអាងហេតុលម្អិតអំពីទេសកាលនេះ បង្ហាញពីកង្វះភ័ស្តុតាងដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ។

## ២. គ្មានសំអាងហេតុអំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់

២០៤៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋាន ដោយផ្អែកលើមូលដ្ឋាននៃធាតុផ្សំភ័ស្តុតាងខាងលើថា "ខៀវ សំផន មានចេតនាចង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅតាមសហករណ៍ និងនៅតាមការដ្ឋាន"[3984]។ អង្គជំនុំជម្រះនៅតែបន្តប្រព្រឹត្តកំហុសទៀត ដោយបានសន្និដ្ឋានថា "ដោយហេតុថាគាត់ចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដូចគ្នានឹងអ្នកចូលរួមផ្សេងទៀតក្នុងផែនការនេះដែរ គឺ [គាត់] មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ការធ្វើឱ្យក្លាយជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើដែលចាត់ទុកថាជាការបាត់ខ្លួនដោយបង្ខំ" និង "មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ"[3985]។

២០៥០. តាមការពិត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ជាទូទៅ ដោយខកខានមិនបានវាយតម្លៃពីចេតនាជាក់លាក់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នីមួយៗ។ ទន្ទឹមនឹងនោះ

---

[3983] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨១ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៧៨ យោងដល់ផ្នែក ១៦.៤.២.១.២។

[3984] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[3985] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨២។

ប្រសិនបើខ្លួនបានពិនិត្យលើភស្តុតាងដោយមិនលម្អៀងវិញ ប្រហែលជាអង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនមិនអាចសន្និដ្ឋានថា ខៀវ សំផន មានចេតនាឧក្រិដ្ឋចំពោះបទឧក្រិដ្ឋនីមួយៗដែលត្រូវបានចោទប្រកាន់នោះទេ។

២០៥១. អង្គជំនុំជម្រះគួរណាទាញការសន្និដ្ឋានចេញពីអវត្តមាននៃភស្តុតាងផ្ទាល់ ឬប្រយោលទាក់ទងនឹងចេតនាសម្លាប់របស់ ខៀវ សំផន នៅទំនប់១មករា និងទំនប់ត្រពាំងថ្ម ក៏ដូចជាពីអវត្តមានភស្តុតាងទាក់ទងនឹងការកំហិតលើជនណាម្នាក់ "អំពីកម្មសិទ្ធសមរម្យដែលជននោះអាចមាន" នៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង។ អង្គជំនុំជម្រះក៏មិនមានភស្តុតាងអំពីចេតនារបស់គាត់ក្នុងការប្រព្រឹត្តិការរើសអើងចំពោះប្រជាជនថ្មី អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយមូលហេតុនយោបាយ" ក្នុងគោលបំណង "ដកបុគ្គលទាំងនេះចេញពីសង្គម" ហើយក៏មិនមានភស្តុតាងអំពីចេតនាបង្កឱ្យមានការឈឺចាប់ខ្លាំង ឬរបួសស្នាមផ្លូវចិត្ត ឬផ្លូវកាយធ្ងន់ធ្ងរដល់ជនរងគ្រោះ ឬធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរជាមនុស្សរបស់គាត់"។

២០៥២. ដូច្នេះ អង្គជំនុំជម្រះគួរណាកត់សម្គាល់ថា ខ្លួនមិនមានភស្តុតាងដើម្បីសន្និដ្ឋានថា ខៀវ សំផន មានចេតនាឧក្រិដ្ឋចំពោះបទឧក្រិដ្ឋនីមួយៗដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងគាត់នោះទេ៖ - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត នៅទំនប់១មករា និងទំនប់ត្រពាំងថ្ម - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការដាក់ឱ្យក្លាយជាទាសករនៅត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង - ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើប្រជាជនថ្មី អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង -ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស នៅត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង និងក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំនៅត្រាំកក់ ទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង។ ដោយមិនធ្វើដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់។ រាល់ការសន្និដ្ឋានរបស់អង្គជំនុំជម្រះដែលផ្ទុយពីការលើកឡើងរបស់មេធាវី

ការពារក្តី ត្រូវចាត់ទុកជាមោឃៈ រួមទាំងការប្រកាសពិរុទ្ធភាពចំពោះបទឧក្រិដ្ឋតាមរយៈសហឧក្រិដ្ឋកម្មរួមទាំងនេះ[3986]។

## ផ្នែកទី ៣. មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស និងការបោសសម្អាត

២០៥៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យក្លាយជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើដែលចាត់ទុកថាជាការបាត់ខ្លួនដោយបង្ខំ[3987]។ ដើម្បីឈានដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុជាច្រើន។ ជាការពិត ដូចដែលបានឃើញខាងលើ គឺវាមិនត្រឹមត្រូវទេក្នុងការអះអាងថា ខៀវ សំផន បានចូលរួមចំណែកក្នុងការបោសសម្អាតនៅទូទាំងប្រទេស[3988]។ កំហុសមួយផ្សេងទៀតពាក់ព័ន្ធនឹងការអះអាងថា គាត់បានដឹងអំពីការចាប់ខ្លួនមេដឹកនាំជាន់ខ្ពស់ នៃ ប.ក.ក[3989]។

២០៥៤. លើសពីនេះទៅទៀត ការពិចារណាថា ការបោសសម្អាតដែល "មានជាប់ចំពាក់ចំពិនទៅនឹងគោលនយោបាយបង្កើត និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស" មិនអាចឱ្យអោយអង្គជំនុំជម្រះរួចផុតពីកាតព្វកិច្ចក្នុងការបង្ហាញអំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋរបស់ ខៀវ សំផន ដែលចំពោះបទឧក្រិដ្ឋទាំងនេះ គាត់ត្រូវបានផ្តន្ទាទោសទាក់ទងនឹងមន្ទីរសន្តិសុខនីមួយៗ[3990]។ អង្គជំនុំជម្រះមិនដែលបានព្យាយាមបង្ហាញថា តើ ខៀវ សំផន បានដឹងដែរឬទេអំពីអត្ថិភាពនៃមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល។ ទាក់ទងនឹងមន្ទីរ ស-២១ ដូចដែលបានឃើញខាងលើ កិច្ចប្រជុំដែលត្រូវបានសន្មតថាប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលក្នុងអំឡុងពេលនោះ ឌុច ទំនងជាបាន

[3986] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[3987] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៧។

[3988] សូមមើលខាងលើ កថាខណ្ឌ ១៨៥៧-១៨៧៨។

[3989] សូមមើលខាងលើ កថាខណ្ឌ ១៨៦២-១៨៧៣។

[3990] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៤។

ឃើញលោក ខៀវ សំផន ជាលើកដំបូង មិនអាចអនុញ្ញាតឱ្យអះអាងថា ខៀវ សំផនបានដឹងឮអំពីអត្ថិភាពនៃមន្ទីរ ស-២១ នោះទេ[3991]។

២០៥៥. បើទោះជា ខៀវ សំផន ដឹងឮអំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ និងជាន់ទាបក៏ដោយចុះ ក៏ប្រការនេះមិនអាចឱ្យបញ្ជាក់បានថា គាត់មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ឬការធ្វើទារុណកម្ម នៅមន្ទីរ ស-២១ ជាដើម។ ការសន្និដ្ឋាននេះកាន់តែមិនសមហេតុផលទៅទៀត ដោយហេតុថាឧក្រិដ្ឋកម្មនៅក្នុងមន្ទីរសន្តិសុខទាំងនេះមិនមែន ត្រូវបានប្រព្រឹត្តចំពោះតែកម្មាភិបាលជាន់ខ្ពស់ប៉ុណ្ណោះទេ។ ចុះការដឹងឮរបស់ ខៀវ សំផន អំពីអត្ថិភាពនៃអ្នកទោសផ្សេងទៀតនៅតាមមន្ទីរសន្តិសុខទាំងនេះ? ការចាកចេញពីការដឹងឮអំពីការចាប់ខ្លួនមួយចំនួន ទៅកាន់ចេតនាប្រព្រឹត្តបទឧក្រិដ្ឋទាំងអស់ដែលត្រូវបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ ជាការសន្និដ្ឋានមិនសមហេតុផលដែលផ្អែកលើការស្មានព្រាវៗ។ ការសន្និដ្ឋាននេះត្រូវទុកជាមោឃៈ។

២០៥៦. ដូចគ្នាដែរចំពោះការអះអាងរបស់អង្គជំនុំជម្រះដែលថា៖

> "ខៀវ សំផន បានជំរុញឱ្យកម្មាភិបាលកំណត់អត្តសញ្ញាណខ្មាំងដែលរារាំងការងារបដិវត្តន៍របស់បក្ស បានញុះញង់ឱ្យពួកគេចងកំហឹង និងប្រុងប្រយ័ត្នចំពោះខ្មាំង ហើយគាត់បានព្រមានថា ជនក្បត់គឺត្រូវតែសម្លាប់ចោល"។

> "គាត់បានគាំទ្រគោលការណ៍រក្សាការសម្ងាត់ និងបានដឹងអំពីការចាប់ខ្លួនមនុស្សដែលរីករាលដាលនៅតាមមូលដ្ឋាន ដោយផ្អែកលើការជាប់ពាក់ព័ន្ធពិតប្រាកដ ឬជាសន្មតរបស់ពួកគេជាមួយខ្មាំង។ ខ្លួនគាត់ផ្ទាល់បានដឹងអំពីការឃុំខ្លួនតាមទំនើងចិត្ត និងល័ក្ខខ័ណ្ឌនៃការឃុំខ្លួន នៅព្រះវិហារ ហើយគាត់បានប្រើសិទ្ធិអំណាចរបស់គាត់ ដើម្បីឱ្យគេដោះលែងសមាជិកទាំងអស់នៃក្រុមគ្រួសារសាច់ថ្លៃរបស់គាត់"។

[3991] សូមមើលខាងលើ កថាខណ្ឌ ១៨៥១-១៨៥៣ កថាខណ្ឌ ១៨៥៧-១៨៧៨។

"២៥ឆ្នាំបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន នៅតែបន្តការពារ គោលបំណងនៃបដិវត្តន៍ ដោយចាត់ទុកថាវាត្រឹមត្រូវគ្រប់កាលៈទេសៈ គ្រប់ទីកន្លែង (វានៅតែ មានភាពចាំបាច់ និងមានភាពត្រឹមត្រូវតាមផ្លូវសីលធម៌) ជាជាងការការពារគោលការណ៍សិទ្ធិ មនុស្ស"[3992]។

២០៥៧. ការអះអាងទាំងនេះមិនបង្ហាញទាល់តែសោះអំពីចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងភ្នំក្រោល។ អង្គជំនុំជម្រះបានបំភ្លៃពាក្យសម្ដីរបស់ ខៀវ សំផន ដោយអះអាងថាគាត់ បានជំរុញឱ្យកម្មាភិបាលកំណត់អត្តសញ្ញាណខ្មាំង និងញុះញង់ឱ្យស្អប់ពួកគេ"[3993]។

២០៥៨. ទាក់ទងនឹងហេតុការណ៍នៅព្រះវិហារ វាមិនមែនជាអង្គហេតុក្នុងវិសាលភាពនៃការជំនុំជម្រះក្ដី ក្នុង សំណុំរឿង ០០២/០២ នោះទេ ហើយទោះក្នុងករណីណាក៏ដោយ ក៏វាមិនអាចឱ្យអះអាងថា ខៀវ សំ ផន បានដឹងឮអំពីការចាប់ខ្លួន និងល័ក្ខខ័ណ្ឌនៃការឃុំខ្លួនរបស់ប្រជាជនស៊ីវិលទាំងអស់បានឡើយ[3994]។ ចំពោះការបន្តការគាំទ្ររបស់គាត់ដល់គោលដៅបដិវត្តន៍ បន្ទាប់ពីហេតុការណ៍បានកន្លងផុតទៅ២៥ឆ្នាំ ហើយ អង្គជំនុំជម្រះបានយោងមិនត្រឹមត្រូវទៅសៀវភៅរបស់ ខៀវ សំផន ដែលជាមូលហេតុនាំឱ្យ មេធាវីការពារក្ដី មិនអាចផ្ទៀងផ្ទាត់ប្រភពរបស់វាបាន[3995]។ សំខាន់ជាងនេះទៀត ដោយផ្អែកលើ សៀវភៅមួយក្បាល ដែលផ្ដោតជាសំខាន់លើការវិភាគព្រឹត្តិការណ៍ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិប តេយ្យ តាមរយៈការបោះពុម្ពផ្សាយរបស់អ្នកស្រាវជ្រាវផ្សេងៗ អង្គជំនុំជម្រះមិនបានពន្យល់ថា តើអ្វី ជាភ័ស្តុតាងបញ្ជាក់អំពីចេតនារបស់ ខៀវ សំផន នៅសម័យអង្គហេតុ។

២០៥៩. លើសពីនេះទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានពិចារណាថា ពាក្យសម្ដីរបស់ ខៀវ សំ ផន មានភាពផ្ទុយគ្នា ទាក់ទងនឹងការដឹងឮអំពីការចាប់ខ្លួន[3996] ក្នុងខណៈដែលពាក្យសម្ដីទាំងនេះមាន

---

[3992] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៥។

[3993] សូមមើលខាងលើ កថាខណ្ឌ ២០២៥-២០២៨។

[3994] សូមមើលខាងលើ កថាខណ្ឌ ១៨៧៤-១៨៧៨។

[3995] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៥ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៩២។

[3996] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៦។

ភាពស៊ីចង្វាក់គ្នាឥតខ្ចោះ។ លោកបានអះអាងថា លោកមិនដែលដឹងអំពីការចាប់ខ្លួនណាមួយក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ លើកលែងតែដឹងដោយចៃដន្យតែម្តងគត់អំពីការចាប់ខ្លួនបងប្អូនខាងប្រពន្ធរបស់គាត់ នៅឯព្រះវិហារ។ ក្រៅពីនេះ អង្គជំនុំជម្រះបានប្រើប្រាស់សេចក្តីថ្លែងការណ៍ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាការវិភាគរបស់គាត់លើអ្វីដែលគាត់បានយល់បន្ទាប់ពីរបបនេះបានរលំទៅ។ អង្គជំនុំជម្រះមិនត្រឹមតែមិនអាចអះអាងថា សេចក្តីថ្លែងការណ៍ទាំងនេះមានភាពផ្ទុយគ្នាប៉ុណ្ណោះទេ គឺថែមទាំងមិនអាចអះអាងថា វាបញ្ជាក់អំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋនៅសម័យនោះទៀតផង។

២០៦០. នៅចុងបញ្ចប់ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយទាញការសន្និដ្ឋានពីការចូលរួមរបស់ ខៀវ សំផន ក្នុងគោលបំណងរួម និងក្នុងគោលនយោបាយពាក់ព័ន្ធនឹងខ្មាំង ថា គាត់មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម[3997]។ ការចូលរួមក្នុងគោលបំណងរួម និងចេតនា គឺជាធាតុផ្សំនៃបទល្មើសជាក់លាក់សម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈសហឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះមិនគួរណាទាញការសន្និដ្ឋានពីការចូលរួមក្នុងគោលបំណងរួម (ដែលមិនមានលក្ខណៈឧក្រិដ្ឋចំតួងផងនោះ) ថា ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម។

២០៦១. ជាការសន្និដ្ឋាន ការកំណត់ធាតុផ្សំនៃចេតនាប្រព្រឹត្តបទល្មើសរបស់អង្គជំនុំជម្រះ ចោទជាបញ្ហា និងមានកំហុសច្រើនយ៉ាង។ កំហុសទាំងនេះស្តែងចេញ តាមរយៈការគ្មានភស្តុតាងទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីអត្ថិភាពនៃមន្ទីរសន្តិសុខ និងបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅទីនោះ។ ដោយផ្អែកលើមូលហេតុនេះ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានបានថា ម្ចាស់បណ្តឹងសាទុក្ខមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឱ្យក្លាយជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តី

[3997] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៧។

ថ្លៃថ្នូររបស់មនុស្ស និងអំពើដែលចាត់ទុកថាជាការបាត់ខ្លួនដោយបង្ខំ[3998]។ ការសន្និដ្ឋាននេះត្រូវទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែបានរួចផុតពីទោស[3999]។

## ផ្នែកទី ៤. ក្រុមជាក់លាក់

### ១. ជនជាតិចាម

២០៦២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តបទល្មើសចាំបាច់ ទាក់ទងនឹងបទឧក្រិដ្ឋប្រឆាំងជនជាតិចាម[4000]។ (ការគ្មាន) សំអាងហេតុរបស់អង្គជំនុំជម្រះ ជាភោគសញ្ញានៃកង្វះភស្តុតាងផ្ទាល់ ឬប្រយោលនៃចេតនាឧក្រិដ្ឋរបស់ម្ចាស់បណ្តឹងសាទុក្ខ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងជនជាតិចាម។ សំអាងហេតុនេះមានតែមួយកថាខណ្ឌ ហើយមិនមានបញ្ជាក់តម្រុយកាលប្បវត្តិទាល់តែសោះ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានរៀបរាប់ធាតុផ្សំភស្តុតាងដែលមិនអាចអះអាងអំពីចេតនាឧក្រិដ្ឋណាមួយសោះ (១.១) និងដោយបានមិនផ្តល់សំអាងហេតុណាមួយ ដើម្បីបង្ហាញអំពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ (១.២)។

### ១.១. គ្មានចេតនាឧក្រិដ្ឋដែលត្រូវបានបង្ហាញ

#### ១.១.១. អត្ថិភាពនៃគោលនយោបាយមិនគ្រប់គ្រាន់ប្រឆាំងនឹងខ្មាំង ដើម្បីបង្ហាញពីចេតនា

២០៦៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាឧក្រិដ្ឋ ដោយគ្រាន់តែផ្អែកលើមូលដ្ឋាននៃការផ្សារភ្ជាប់ការប្រព្រឹត្តិលើជនជាតិចាមនៅវត្តអូរត្រកួន និងនៅមន្ទីរសន្តិសុខទ្រា ទៅនឹង "គោលនយោបាយ"ចំពោះ "ខ្មាំង"[4001]។

[3998] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៧។

[3999] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[4000] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

[4001] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

### ១.១.១.១. ចេតនាជាក់លាក់របស់ ខៀវ សំផន ចំពោះ "ខ្មាំង"

២០៦៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានរំឭកការសន្និដ្ឋានខុសរបស់ខ្លួនដែលថា ខៀវ សំផន មានចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិការរើសអើងចំពោះខ្មាំង[4002]។ អង្គជំនុំជម្រះគ្រាន់តែយោងទៅសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងកំណត់សម្គាល់ជើងទំព័រ ទាក់ទងនឹងមន្ទីរសន្តិសុខកន្លែងសម្លាប់មនុស្ស និងការបោសសម្អាតផ្ទៃក្នុង[4003]។ ជាបឋម អង្គជំនុំជម្រះគួរណាទាញផលវិបាកចេញពីអវត្តមាននៃការនិយាយអំពីជនជាតិចាម ដែលបង្ហាញពីការគ្មានចេតនាជាក់លាក់ណាមួយ ក្នុងការកំណត់ក្រុមជនជាតិចាមជាគោលដៅ។ បន្ទាប់មក ដូចដែលបានឃើញខាងលើ ភ័ស្តុតាងដែលត្រូវបានប្រើដោយអង្គជំនុំជម្រះ មិនអាចបញ្ជាក់ពីចេតនារើសអើងចំពោះ "ខ្មាំង" របស់ ខៀវ សំផន ទេ[4004]។

### ១.១.១.២. ការគាំទ្រចំពោះគោលនយោបាយប្រឆាំងខ្មាំង

២០៦៥. អង្គជំនុំជម្រះហាក់ដូចជាចង់និយាយថា ខៀវ សំផន បានផ្តល់ការគាំទ្រដល់គោលនយោបាយចំពោះខ្មាំង ជាពិសេស ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើមនុស្សឃាត និងការសម្លាប់រង្គាល[4005]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានផ្តល់ការចង្អុលបង្ហាញទាក់ទងនឹងទីតាំង ឬកាលបរិច្ឆេទ នៃការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះឡើយ។ បន្ទាប់មក ដូចដែលបានឃើញខាងលើ ភ័ស្តុតាងដែលអង្គជំនុំជម្រះបានយកមកធ្វើជាសំអាង មិនអាចឱ្យសន្និដ្ឋានបានពីការគាំទ្ររបស់គាត់ដល់ "គោលនយោបាយប្រឆាំងខ្មាំង" ជាពិសេស ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើមនុស្សឃាត និងការសម្លាប់រង្គាល[4006]។

---

[4002] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

[4003] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៩០ យោងដល់ផ្នែក ១៨.២.២.២។

[4004] សូមមើលខាងលើ កថាខណ្ឌ ២០៥៣-២០៦១។

[4005] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩ កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៩០ យោងដល់ផ្នែក ១៨.២.២.២។

[4006] សូមមើលខាងលើ កថាខណ្ឌ ២០១២-២០១៧។

### ១.១.២. "គោលនយោបាយរើសអើង" មិនគ្រប់គ្រាន់ដើម្បីបង្ហាញពីចេតនាឧក្រិដ្ឋ

២០៦៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានទាញការសន្និដ្ឋានមិនសមហេតុផល ថា ខៀវ សំផន មានចេតនាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មលើជនជាតិចាម[4007]។ ការប្រើប្រាស់ឈ្នាប់ផ្សារភ្ជាប់ឃ្លា "អាស្រ័យហេតុនេះ" បញ្ជាក់ពីការពិតដែលថា អង្គជំនុំជម្រះបានទាញការសន្និដ្ឋានពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋរបស់ ខៀវ សំផន ចេញពីអត្ថិភាពនៃគោលនយោបាយ**រើសអើងនានា** (ជាពហុវចនៈជាលើកដំបូង) ដែលមានគោលបំណង "បំបែកក្រុមពួកគេ" "រឹតត្បិតការបដិបត្តិសាសនា និងវប្បធម៌របស់ខ្លួន" និង "សម្លាប់សមាជិកក្រុមដែលមិនព្រមចុះចូល"[4008]។

### ១.១.៣. ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមមិនមានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីបង្ហាញពីចេតនាប្រព្រឹត្តបទឧក្រិដ្ឋ

២០៦៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ការចូលរួមរបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម បង្ហាញពីចេតនាដូចសមាជិកដទៃទៀតដែរ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ព្រមទាំងអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការជម្លៀសជនជាតិចាមដោយបង្ខំ[4009]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានទាំងពន្យល់ពីខ្សែគំនិតបញ្ជាក់ហេតុផលរបស់ខ្លួន ទាំងផ្តល់សំអាងហេតុណាមួយឡើយ។ ក្នុងករណីណាក៏ដោយ ក៏អង្គជំនុំជម្រះមិនបានបង្ហាញអំពីគោលនយោបាយជាក់លាក់ទាក់ទងនឹងជនជាតិចាមដែល ខៀវ សំផន បានចូលរួម។

---

[4007] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

[4008] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

[4009] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

### ១.១.៤. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី២

២០៦៨. ដូចដែលបានឃើញខាងលើ អង្គជំនុំជម្រះប្រើវិធីសាស្ត្រផ្សារភ្ជាប់ឧក្រិដ្ឋកម្មទៅនឹងនយោបាយ មុននឹងទាញការសន្និដ្ឋានចេញពីអត្ថិភាពនៃនយោបាយនេះ ថាមានចេតនាឧក្រិដ្ឋ។ វិធីសាស្ត្រនេះមិនត្រឹមត្រូវទេ។ លើសពីនេះទៀត ក្រៅពីមិនត្រឹមត្រូវ វិធីសាស្ត្រនេះមិនអាចទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះជនជាតិចាមបានឡើយ។ ការធ្វើទុក្ខបុកម្នេញរងការចោទប្រកាន់ដោយមូលហេតុនយោបាយប្រឆាំងជនជាតិចាម ត្រូវបានកំណត់ត្រឹមតែចំពោះអង្គហេតុនៃការផ្លាស់ទីលំនៅដោយបង្ខំដំណាក់កាលទី២ ដែលជាបទឧក្រិដ្ឋ ដែលមិនមានជាប់ទាក់ទងនឹងគោលនយោបាយប្រឆាំងខ្មាំង និងគោលនយោបាយរើសអើងដោយមូលហេតុសាសនា។ ប្រការនេះគួរតែអាចនាំអង្គជំនុំជម្រះឱ្យកត់សម្គាល់ថា អង្គហេតុនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ជាអាជ្ញាអស់ជំនុំ[4010]។

### ១.២. គ្មានសំអាងហេតុទាល់តែសោះ ទាក់ទងនឹងចេតនាប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់

២០៦៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានដោយផ្អែកលើព័ត៌មានរៀបរាប់ខាងលើថា ខៀវ សំផន "មានចេតនាជាក់លាក់រើសអើងខ្មាំង ដោយមូលហេតុពួកគេមានជាប់និន្នាការនយោបាយជាមួយខ្មាំង ដោយពិតប្រាកដ ឬដោយសន្មត និងដោយបានសន្និដ្ឋានថា ខៀវ សំផន បានគាំទ្រគោលនយោបាយ ដែលមានគោលបំណងកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យនៅឯកោ និងកម្ទេចខ្មាំង ជាពិសេស គឺថាគាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើមនុស្សឃាត និងការសម្លាប់រង្គាល"[4011]។

២០៧០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានបន្ថែមថា "ភ័ស្តុតាងបង្ហាញថា ដោយហេតុថាគាត់ចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ខៀវ សំផន ក៏ដូចជាអ្នកចូលរួមផ្សេងទៀតក្នុង

[4010] សូមមើលខាងលើ កថាខណ្ឌ ៩៦៤-៩៦៥។

[4011] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

ផែនការនេះ មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលនយោបាយ និងហេតុសាសនា និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអង្គហេតុដែលត្រូវបានកំណត់ថាជាការជម្លៀសជនជាតិចាមដោយបង្ខំ"[4012]។ តាមពិត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានធ្វើការសន្និដ្ឋានជាលក្ខណៈទូទៅបែបនេះ ដោយមិនវាយតម្លៃពីចេតនាជាក់លាក់ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នីមួយៗ។

២០៧១. ដូច្នេះ អង្គជំនុំជម្រះគួរតែទាញការសន្និដ្ឋានចេញពីអវត្តមាននៃភស្តុតាងផ្ទាល់ ឬប្រយោលទាក់ទងនឹងចេតនារបស់ ខៀវ សំផន ក្នុងការសម្លាប់ជនជាតិចាម នៅវត្តអូរត្រកួន នៅឆ្នាំ១៩៧៧ និងនៅក្នុងភូមិទ្រា ក្នុងឆ្នាំ១៩៧៨ និងសម្លាប់ជនជាតិចាមទ្រង់ទ្រាយធំ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់។

២០៧២. អង្គជំនុំជម្រះគួរណាទាញការសន្និដ្ឋានចេញពីអវត្តមាននៃភស្តុតាងផ្ទាល់ ឬប្រយោល ទាក់ទងនឹងចេតនារបស់ ខៀវ សំផន ក្នុងការដកហូតសេរីភាពតាមទំនើងចិត្តពីជនជាតិចាម នៅភូមិទ្រា ក្នុងឆ្នាំ១៩៧៨ ឬគាត់មានហេតុផលក្នុងការដឹងថា អំពើរបស់គាត់មានភវនីយភាពបណ្តាលឱ្យមានលទ្ធផលនេះ។ ពុំមានអំពើណាមួយរបស់ម្ចាស់បណ្តឹងសាទុក្ខ ត្រូវបានបង្ហាញទាក់ទងនឹងអង្គហេតុ និងទីតាំងទាំងនេះ និងចេតនាធ្វើទារុណកម្មនៅក្នុងភូមិទ្រា ក្នុងឆ្នាំ១៩៧៨ នៅថ្ងៃចាប់ខ្លួន អ៊ីត សេន នោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយជម្នះសន្និដ្ឋានអំពីចេតនារបស់ម្ចាស់បណ្តឹងសាទុក្ខ។

២០៧៣. អង្គជំនុំជម្រះមិនបានទាំងទាញការសន្និដ្ឋានចេញពីអវត្តមាននៃភស្តុតាងផ្ទាល់ ឬប្រយោលពាក់ព័ន្ធនឹងចេតនារបស់ ខៀវ សំផន ក្នុងការ "រើសអើងជនជាតិចាម ដោយមូលហេតុនយោបាយ" ក្នុងគោលបំណង "ដកពួកគេចេញពីសង្គម" ក្នុងអំឡុងពេលផ្លាស់ទីលំនៅដំណាក់កាលទី២ ទាំងទាញការសន្និដ្ឋានចេញពីអវត្តមានភស្តុតាងពាក់ព័ន្ធនឹងចេតនា "រើសអើងជនជាតិចាម ដោយមូលហេតុ

---

[4012] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

សាសនា” ដើម្បី “ដកបុគ្គលទាំងនេះចេញពីសង្គម” កំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ទាំងទាញការសន្និដ្ឋានចេញពីអវត្តមានភ័ស្តុតាងពាក់ព័ន្ធនឹងចេតនាបង្កការឈឺចាប់ខ្លាំង [ដល់ពួកគេ] ឬបង្ករបួសស្នាមផ្លូវចិត្ត និងផ្លូវកាយលើជនរងគ្រោះ ឬបង្កការប៉ះពាល់ធ្ងន់ធ្ងរដល់ភាពថ្លៃថ្នូររបស់មនុស្ស” នៅចុងឆ្នាំ១៩៧៥។ ដោយខកខានមិនបានធ្វើដូចនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់។

២០៧៤. ហេតុដូច្នេះ អង្គជំនុំជម្រះបានកំហុសអង្គហេតុ និងអង្គច្បាប់ដោយបានសន្និដ្ឋានថា ខៀវ សំផន មានចេតនាឧក្រិដ្ឋចំពោះ៖ - ឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត និងការសម្លាប់រង្គាលដែលត្រូវបានចោទប្រកាន់ នៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៧ និងនៅក្នុងភូមិទ្រា ក្នុងឆ្នាំ១៩៧៨ - បទឧក្រិដ្ឋនៃការដាក់ក្នុងមន្ទីរឃុំឃាំង នៅឆ្នាំ១៩៧៨ និងការធ្វើទារុណកម្ម នៅថ្ងៃចាប់ខ្លួន អ៊ីត សេន នៅឆ្នាំ១៩៧៨ នៅក្នុងភូមិទ្រា - ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយក្នុងកំឡុងពេលផ្លាស់ទីលំនៅដំណាក់កាលទី២ - បទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការផ្លាស់ទីលំនៅដោយបង្ខំនៅចុងឆ្នាំ១៩៧៥។ រាល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះពីអត្ថិភាពនៃចេតនា និងការផ្តន្ទាទោសគាត់ចំពោះបទឧក្រិដ្ឋទាំងនេះ ត្រូវទុកជាមោឃៈ[4013]។

## ២. ជនជាតិវៀតណាម

### ២.១. គ្មានចេតនានិរទេស

២០៧៥. អង្គជំនុំជម្រះបានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា “ខៀវ សំផន ក៏ដូចជាអ្នកចូលរួមផ្សេងទៀតក្នុងសហឧក្រិដ្ឋកម្មរួម មានចេតនានិរទេសប្រជាជនវៀតណាមទៅប្រទេសវៀតណាម” [4014]។ យោងទៅតាមអង្គជំនុំជម្រះ ចេតនានេះកើតចេញពីការអំពាវនាវដែលម្ចាស់បណ្តឹងសាទុក្ខបានធ្វើ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបញ្ជូនប្រជាជនវៀតណាមពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម”។ ជាការបង្ហាញ អង្គជំនុំជម្រះបានយោងទៅធាតុផ្សំភ័ស្តុតាងដូចគ្នានឹងភ័ស្តុតាងដើម្បី

---

[4013] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៨៩។

[4014] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩២។

បង្ហាញពីការដឹងឮរបស់ ខៀវ សំផន អំពីការដែលឧក្រិដ្ឋកម្មកំពុងតែត្រូវបានប្រព្រឹត្ត[4015]។ ទាក់ទងនឹងការនិរទេសជនជាតិវៀតណាមនេះ គឺមានយោងទៅចម្លើយរបស់ ឯក ហេន និង "ភាពស៊ីចង្វាក់" ជាមួយប្រតិចារឹកនៃបទសម្ភាសន៍ជាមួយ នៅ សារឹម ដោយវិទ្យុសំឡេងសហរដ្ឋអាមេរិក[4016]។ ទោះយ៉ាងនេះក្តី ដូចដែលបានបង្ហាញខាងលើ អង្គជំនុំជម្រះមិនអាចផ្អែកលើភ័ស្តុតាងទាំងនេះបានទេ ដោយសារតែកង្វះភាពគួរឱ្យទុកចិត្តបានរបស់ ឯក ហេន ម្យ៉ាង និងម្យ៉ាងទៀត តម្លៃជាភ័ស្តុតាងនៃប្រតិចារឹករបស់ នៅ សារឹម មានតិចតួចបំផុត[4017]។

២០៧៦. លើសពីនេះទៀត ធាតុផ្សំភ័ស្តុតាងទាំងនេះមិនអាចបង្ហាញអំពីការដឹងឮរបស់ ខៀវ សំផន ទាក់ទងនឹងការនិរទេសជនជាតិវៀតណាមពីត្រាំកក់ និងព្រៃវែង នៅចុងឆ្នាំ១៩៧៥ ដើមឆ្នាំ១៩៧៦ បានទេ។ អាស្រ័យហេតុនេះ ភ័ស្តុតាងទាំងនេះកាន់តែមិនអាចបង្ហាញទៅទៀតថា ខៀវ សំផន មានចេតនានិរទេសជនជាតិវៀតណាមពីកម្ពុជាទៅប្រទេសវៀតណាម។ ដោយគ្មានភ័ស្តុតាងផ្សេងទៀតទាក់ទងនឹងចេតនារបស់ ខៀវ សំផន ក្នុងការនិរទេសជនជាតិវៀតណាមពីត្រាំកក់ និងព្រៃវែងទៅកាន់ប្រទេសវៀតណាម អង្គជំនុំជម្រះមិនអាចចាប់ឱ្យគាត់ទទួលខុសត្រូវចំពោះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការនិរទេសជនជាតិវៀតណាមបានទេ។ ដូច្នេះគាត់ត្រូវតែរួចផុតពីទោស ចំពោះបទឧក្រិដ្ឋនេះ។

## ២.២. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើមនុស្សឃាត និងការសម្លាប់រង្គាល

២០៧៧. អង្គជំនុំជម្រះបានកំហុសអង្គហេតុ និងអង្គច្បាប់ដោយបានសន្និដ្ឋានថា ខៀវ សំផន "មានចេតនាផ្ទាល់ចង់សម្លាប់ប្រជាជនវៀតណាមនៅកម្ពុជាក្នុងទ្រង់ទ្រាយធំ ពីខែមេសា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"[4018]។ អង្គជំនុំជម្រះបានពិចារណាខុសថា "ពាក្យសម្តី និងអំពើរបស់ ខៀវ សំផន ក្នុងកំឡុង

---

[4015] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩២ "អង្គជំនុំជម្រះយោងទៅសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ស្តីពីជនជាតិវៀតណាម ក្នុងផ្នែក ១៨.១.២.៣.២ ខាងលើ"។

[4016] សូមមើលខាងលើ កថាខណ្ឌ ១៨៩០-១៩០៩។

[4017] សូមមើលខាងលើ កថាខណ្ឌ ១៨៩២-១៨៩៤។

[4018] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៣។

របបកម្ពុជាប្រជាធិបតេយ្យបង្ហាញថា គាត់មានចេតនាសម្លាប់ផ្ទាល់"។ ជាបឋម "ការមើលងាយ" មនុស្ស មិនមែនមានន័យថាមានចេតនាចង់សម្លាប់មនុស្សនោះទេ។ លើសពីនេះ គួររំឮកថាអង្គជំនុំជម្រះបានវិនិច្ឆ័យថាមានភស្តុតាងគ្រប់គ្រាន់ចំពោះការធ្វើឃាតជនជាតិវៀតណាម នៅខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ នៅវត្តខ្សាច់ ខេត្តកំពង់ឆ្នាំង និងខេត្តក្រចេះ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនដែលពន្យល់ថា តើពាក្យសម្តីរបស់ ខៀវ សំផន អនុញ្ញាតឱ្យបង្ហាញថាគាត់មានចេតនាសម្លាប់ជនជាតិវៀតណាម នៅទីកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើងដែរឬទេ។ ក្នុងករណីដែលគ្មានភស្តុតាងផ្ទាល់ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាម្នាក់អាចសន្និដ្ឋានបានថា ខៀវ សំផន មានចេតនាសម្លាប់ជនជាតិវៀតណាមមទាំងនេះបានទេ។

២០៧៨. ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួន អង្គជំនុំជម្រះបានយោងយ៉ាងសាមញ្ញទៅនឹងការដឹងឮរបស់ ខៀវ សំផន ពីការចេញបញ្ជាជាមួយមេដឹកនាំបក្សកុម្មុយនីស្តដទៃទៀតឱ្យគេ "សម្លាប់ជនជាតិវៀតណាមឱ្យអស់ [...] និងកម្ទេចឱ្យសាបសូន្យ"[4019]។ ប្រសិនបើគ្មានប្រភពផ្ទាល់ណាមួយត្រូវបានដកស្រង់នៅក្នុងកំណត់សម្គាល់ជើងទំព័រ គឺបានន័យថា តាមពិតទៅ សម្រង់ទាំងនេះបានមកពីឯកសារ SWB ដែលមានអត្ថបទដកស្រង់ចេញពីសុន្ទរកថាមួយដែលទំនងជាត្រូវបានថ្លែងដោយ ខៀវ ផន ក្នុងអំឡុងកិច្ចប្រជុំមហាជននៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨[4020]។ ក៏ប៉ុន្តែ "ការកត់ចម្លងឡើងវិញ" នូវសុន្ទរកថារបស់ ខៀវ សំផន មិនមានភាពគួរឱ្យ ទុកចិត្តបានគ្រប់គ្រាន់ ដើម្បីអះអាងថាគាត់ពិតជាបាននិយាយពាក្យពេចន៍ទាំងនេះនោះទេ[4021]។ មួយវិញទៀត ពាក្យពេចន៍ទាំងនេះក៏មិនត្រូវបានកត់បញ្ចូលទៅក្នុងកម្រងឯកសារ ដែលផ្សព្វផ្សាយដោយគណៈកម្មាធិការអាណិកជនស្នេហាជាតិនៃកម្ពុជា

---

[4019] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨។

[4020] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៣៩៩ យោងដល់មិទ្ទីងនៅទីក្រុងភ្នំពេញដើម្បីប្រារព្ធខួបថ្ងៃទី១៧ ខែមេសា (កម្រងឯកសារ SWB/FE/5791/B) ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ ឯកសារ **E3/562** ERN 00249989-00249990 "បណ្តេញចេញ និងកម្ទេចឱ្យអស់ពួកឈ្លានពាន ពួកវាតទីនិយមវៀតណាមសាហាវព្រៃផ្សៃ ឱ្យចេញផុតពីទឹកដីកម្ពុជា" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) "កម្ទេចឱ្យអស់រាល់បណ្តាញភ្នាក់ងារពួកឈ្លានពាន ពួកវាតទីនិយមវៀតណាមសាហាវព្រៃផ្សៃ ឱ្យចេញផុតពីទឹកដីកម្ពុជា" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) "កម្ទេចចោលខ្មាំងតាមគ្រប់រូបភាពទាំងអស់ ជាពិសេស ពួកឈ្លានពាន ពួកខ្មាំងវាតទីនិយមវៀតណាម"។

[4021] សូមមើលខាងលើ កថាខណ្ឌ ១៨៩៨-១៩០២។

ប្រជាធិបតេយ្យប្រចាំប្រទេសបារាំងដែលមានសុន្ទរកថាដដែលនេះដែរ[4022]។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានឱ្យហួសពីវិមតិសង្ស័យថា ខៀវ សំផន បានប្រើពាក្យពេចន៍ទាំងនេះឡើយ[4023]។

២០៧៩. លើសពីនេះទៀត វាច្បាស់ណាស់ថា អង្គជំនុំជម្រះបានបំភ្លៃពាក្យពេចន៍ដែលត្រូវបានកត់ចម្លង នៅក្នុងឯកសារ SWB នេះ។ ជាការពិត នៅក្នុងឯកសារនេះ មានសរសេរថាមនុស្សគោលដៅជា "ភ្នាក់ងាររបស់វៀតណាមឈ្លានពាន និងវាតទីនិយម" ឬក៏ "យួនខ្មាំងវាតទី និងលេបទឹកដី"[4024]។ ទោះយ៉ាងណាអង្គជំនុំជម្រះបានយល់ស្របថា "ភ្នាក់ងារវៀតណាម" សំដៅទៅលើជនជាតិខ្មែរដែលត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងជាមួយវៀតណាម។ ដូច្នេះ វាមិនសមហេតុផលទេ ក្នុងការសន្និដ្ឋានថាពាក្យពេចន៍ទាំងនេះត្រូវបានប្រើឡើងដើម្បី "ប្រឆាំងនឹងប្រជាជនវៀតណាមដែលមានដើមកំណើតជាវៀតណាមជាទូទៅ"[4025]។ អាស្រ័យហេតុនេះ ធាតុផ្សំភ័ស្តុតាងទាំងនេះមិនអាចធ្វើជាមូលដ្ឋានដើម្បីបង្ហាញអំពីចេតនារបស់ ខៀវ សំផន ក្នុងការសម្លាប់ជនជាតិវៀតណាមដែលមានដើមកំណើតជាវៀតណាមបានឡើយ។

---

[4022] កម្រងឯកសារផ្សព្វផ្សាយដោយគណៈកម្មាធិការអណិកជនស្នេហាជាតិកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសបារាំង៖ "ជយោ! ខួបលើកទី ៣ នៃមហាជ័យជម្នះ ១៧ មេសា និងកំណើតកម្ពុជាប្រជាធិបតេយ្យ - សុន្ទរកថារបស់សមមិត្ត ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ" ឯកសារ **E3/169** ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ ERN S 00704520។

[4023] មិទ្ទីងនៅទីក្រុងភ្នំពេញដើម្បីប្រារព្ធខួបជ័យជម្នះ ១៧ មេសា (កម្រងឯកសារ SWB/FE/5791/B) ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ **E3/562** ERN 00249989-00249990។

[4024] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៩០៤ "ពាក់ព័ន្ធនឹងគោលការណ៍ណែនាំរបស់គណៈកម្មាធិការមជ្ឈិម ចុះខែមិថុនា ឆ្នាំ១៩៧៨ ទោះបីជាបុគ្គលដែលបានឈប់ធ្វើសកម្មភាពក្បត់ ជាធម្មតាត្រូវទទួលរងការអប់រំឡើងវិញនៅក្រោមគោលនយោបាយនេះក៏ដោយ ក៏អង្គជំនុំជម្រះរកឃើញថា ទោះបីជាវាអាចអនុវត្តលើបុគ្គលដែលធ្វើជាភ្នាក់ងារយួនក៏ដោយ ក៏វាមិនបង្ហាញច្បាស់ថា តើប្រភេទនេះសំដៅក្រៅពីប្រជាជនខ្មែរដែលបានឃុបឃិតជាមួយវៀតណាម ដោយរួមបញ្ចូលទាំងប្រជាជនដែលជាជនជាតិភាគតិចវៀតណាមខ្លួនឯងផងដែរ ឬយ៉ាងណា" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។ សូមមើលផងដែរ ទស្សនាវដ្ដី "ទង់បដិវត្ត" ចេញផ្សាយខែឧសភា-ខែមិថុនា ឆ្នាំ១៩៧៨ ឯកសារ **E3/727** ERN 00064566 ដែលហៅ ចក្រី, ឈូក, ធុច, ឌឿន, សោ ភឹម, ស៊ី, កែវ មាស និងជ័យ ថាជាសេអ៊ីអា និងយួន។

[4025] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨។

២០៨០. ការអះអាងរបស់អង្គជំនុំជម្រះដែលថា ខៀវ សំផន បានជំរុញឱ្យកម្ពុជាប្រជាធិបតេយ្យ "បោសសម្អាតឱ្យស្អាតភ្លឹងតែម្តង" ដើម្បីរំដោះខ្លួនពីជនជាតិវៀតណាម"[4026] ក៏មិនត្រឹមត្រូវដែរ ហើយត្រូវតែបដិសេធចោល[4027]។ ក្នុងករណីដែលគ្មានភស្តុតាងបញ្ជាក់ថា ខៀវ សំផន មានចេតនាសម្លាប់ជនជាតិវៀតណាម នៅស្វាយរៀង ក្នុងដែនទឹកកម្ពុជា ក្នុងខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ និងនៅវត្តខ្សាច់ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា ខៀវ សំផន ត្រូវទទួលខុសត្រូវដោយមូលហេតុគាត់បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើមនុស្សឃាត និងការសម្លាប់រង្គាលលើជនជាតិវៀតណាម[4028]។

## ២.៣. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មធ្វើឱ្យបុកម្នេញដោយមូលហេតុពូជសាសន៍

២០៨១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន ក៏ដូចជាអ្នកចូលរួមដទៃទៀតក្នុងសហឧក្រិដ្ឋកម្មរួម មានចេតនាជាក់លាក់រើសអើងពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម។ ដើម្បីឈានដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះគ្រាន់តែបានអះអាងថា ខ្លួនជឿជាក់ថា "ចេតនាសម្លាប់ដែលមានក្នុងចិត្ត ខៀវ សំផន កើតចេញពីការដែលគាត់មានចេតនាជាក់លាក់រើសអើងជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍"[4029]។ ទោះយ៉ាងនេះក្តី អង្គជំនុំជម្រះគ្មានភស្តុតាងបង្ហាញថា ខៀវ សំផន មានចេតនាសម្លាប់ជនជាតិវៀតណាមដែលមានដើមកំណើតជាវៀតណាមនោះទេ[4030]។

២០៨២. លើសពីនេះទៅទៀត គ្មានប្រភពណាមួយគាំទ្រការសន្និដ្ឋានទាក់ទងនឹងចេតនាជាក់លាក់នោះឡើយ នៅអូរកន្សែង មន្ទីរ ស-២១ និងខេត្តស្វាយរៀង។ ដោយហេតុគ្មានភស្តុតាងបញ្ជាក់ពីចេតនាជាក់លាក់ទាក់ទងនឹងអំពើឃាតកម្មទាំងនេះ ខៀវ សំផន មិនអាចត្រូវបានចាប់ឱ្យទទួលខុសត្រូវបានទេ។

---

[4026] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៣៨។

[4027] សូមមើលខាងលើ កថាខណ្ឌ ១៨៩៥។

[4028] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៣។

[4029] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៣។

[4030] សូមមើលខាងលើ កថាខណ្ឌ ២០៧៧-២០៨០។

២០៨៣. សុន្ទរកថាដែល ខៀវ សំផន ប្រហែលជាបានថ្លែង ហើយដែលត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីបង្ហាញអំពីការដឹងឮរបស់គាត់អំពីឧក្រិដ្ឋកម្ម ផ្អែកលើការកត់ចម្លងសុន្ទរកថារបស់គាត់ដែលមាននៅក្នុងទស្សនាវដ្តីបរទេសមួយដែលមិនអាចជឿទុកចិត្តបាន[4031]។ លើសពីនេះអង្គជំនុំជម្រះបានបំភ្លៃសុន្ទរកថាទាំងនេះ នៅពេលនិយាយអំពីជនជាតិវៀតណាម ដោយពិចារណាថា ជនជាតិវៀតណាមដើមកំណើតវៀតណាម ត្រូវបានកំណត់ជាគោលដៅ។ ជាការពិត គឺមានការប្រើប្រាស់ជាប្រព័ន្ធនូវពាក្យ វៀតណាម វៀតណាមឈ្លានពាន និងលេបទឹកដី ឬភ្នាក់ងាររបស់វៀតណាមឈ្លានពាន ឬលេបទឹកដី។ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ គ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាមួយអាចសន្និដ្ឋានបានថា ខៀវ សំផន បានកំណត់ជនជាតិវៀតណាមដើមកំណើតវៀតណាមជាគោលដៅនោះទេ។

២០៨៤. លើសពីនេះទៀត បើទោះជា ខៀវ សំផន មានចេតនារើសអើងណាមួយក៏ដោយចុះ ក៏អង្គជំនុំជម្រះមិនដែលបានពន្យល់ថាតើការរើសអើងនេះផ្អែកលើការមូលហេតុពូជសាសន៍យ៉ាងដូចម្តេចឡើយ។ ដោយគ្មានភ័ស្តុតាងគាំទ្រចេតនាជាក់លាក់របស់ម្ចាស់បណ្តឹងសាទុក្ខ ក្នុងការសម្លាប់ជនជាតិវៀតណាមដោយមូលហេតុពូជសាសន៍ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ ត្រូវចាត់ទុកជាមោឃៈ ហើយ ខៀវ សំផន ត្រូវតែរួចផុតពីទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម[4032]។

២០៨៥. លើសពីនេះទៀត ពេលសន្និដ្ឋានថា ចេតនាសម្លាប់របស់ ខៀវ សំផន បានកើតចេញពីចេតនារើសអើងជាក់លាក់ដែលផ្អែកលើមូលដ្ឋានពូជសាសន៍ អង្គជំនុំជម្រះមិនបានបង្ហាញអំពីចេតនារើសអើងរបស់ ខៀវ សំផន លើពូជសាសន៍ ចំពោះការនិរទេស និងការចាប់ខ្លួនជនជាតិវៀតណាម។ ក៏ប៉ុន្តែ នៅត្រាំកក់ និងព្រៃវែង អង្គជំនុំជម្រះបានសន្និដ្ឋានថា ខៀវ សំផន បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ពីបទនិរទេសជនជាតិវៀតណាមតែប៉ុណ្ណោះ។ ដូច្នេះ អង្គជំនុំជម្រះមិនបានបង្ហាញចេតនា ខៀវ សំផន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំង

---

[4031] សូមមើលខាងលើ កថាខណ្ឌ ១៨៨៦-១៩០៩។

[4032] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

មនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ នៅត្រាំកក់ និងព្រៃវែង។ អាស្រ័យហេតុនេះ គាត់មិនអាចត្រូវបានចាប់ឱ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះនោះទេ[4033]។

## ២.៤. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយអំពើមនុស្សឃាត

២០៨៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន ក៏ដូចជាអ្នកចូលរួមក្នុងសហឧក្រិដ្ឋរួមដទៃទៀត មាន "ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ [...] ដោយសម្លាប់សមាជិកនៃក្រុមជាតិពន្ធុពូជសាសាន៍វៀតណាម"[4034]។ សម្រាប់អង្គជំនុំជម្រះ "ពាក្យសម្ដី និងអំពើរបស់របស់ ខៀវ សំផន ក្នុងកំឡុងរបបកម្ពុជាប្រជាធិបតេយ្យបង្ហាញថា គាត់មានចេតនាប្រល័យពូជសាសន៍តាមរយៈការបំផ្លាញជនជាតិវៀតណាមក្នុងឋានៈជាក្រុម"។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនដែលបញ្ជាក់ថាតើអំពើនោះជាអ្វីឡើយ។ លើសពីនេះទៀត មេធាវីការពារក្ដីបានរំឮកជាច្រើនដងហើយថា ប្រសិនបើ ខៀវ សំផន ពិតជាបាននិយាយពាក្យពេចន៍ ដែលត្រូវបានដកស្រង់សម្ដីដោយអង្គជំនុំជម្រះមែននោះ ក៏ពាក្យពេចន៍ទាំងនេះមិនសំដៅលើជនជាតិវៀតណាមដើមកំណើតវៀតណាម ដែលជាក្រុមជាតិសាសន៍តែមួយនោះដែរ។ ដូច្នេះ គាត់មិនអាចមានចេតនាបំផ្លាញក្រុមនេះទេ។

២០៨៧. អង្គជំនុំជម្រះ មិនបានរកឃើញភ័ស្តុតាងណាមួយដែលអាចឱ្យសន្និដ្ឋានថា ខៀវ សំផន មានចេតនាបំផ្លាញមួយផ្នែក ឬទាំងមូល នៃក្រុមជនជាតិវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជាពីខែមេសា ឆ្នាំ១៩៧៧ ដល់ចុងបញ្ចប់នៃរបបនេះឡើយ។ ធាតុផ្សំភ័ស្តុតាងនៃការបំផ្លាញ "ទាំងមូល ឬមួយផ្នែក" ក៏ត្រូវបានមើលរំលងទាំងស្រុងដោយអង្គជំនុំជម្រះដែរ។ ដោយហេតុពុំមានភ័ស្តុតាង អង្គជំនុំជម្រះមិនបានរកឃើញអ្វីប្រសើរជាងការយោងទៅសម្រង់នៃភាពយន្តឯកសារមួយដែល ខៀវ សំផន ត្រូវបានសាកសួរក្នុងឆ្នាំ២០០៧ គឺជាង២៥ឆ្នាំក្រោយអង្គហេតុ។ អង្គជំនុំជម្រះមិនទាំងបានចម្លងឡើងវិញឱ្យដូចបេះបិទនូវពាក្យពេចន៍របស់ ខៀវ សំផន ដែលខ្លួនយល់ឃើញថាវាបង្ហាញអំពីចេតនាបំផ្លាញក្រុមជនជាតិវៀតណាមដែលមានដើមកំណើតជាវៀតណាម ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៧។ អង្គជំនុំ

---

[4033] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

[4034] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៥។

ជម្រះបានដាក់ពាក្យពេចន៍ទាំងនេះក្នុងកំណត់សម្គាល់ត្រាជើងទំព័រៈ "កំហឹងស្អប់ខ្ពើមក្រុមជាតិពន្ធុវៀតណាម ដែល ខៀវ សំផន មានតាំងពីយូរយារមកហើយ ស្តែងចេញយ៉ាងច្បាស់ពីបទសម្ភាសន៍មួយនៅឆ្នាំ២០០៧ ដែលក្នុងអំឡុងបទសម្ភាសន៍នេះ គាត់បាននិយាយរិះគន់យ៉ាងខ្លាំងលើជនជាតិវៀតណាម ថាជាអ្នកឈ្លានពាន និងថា វៀតណាមជា "មន្ទីរ ស-២១" ដ៏មហិមា ដើម្បីលុបលាងកំហុស "កូនមន្ទីរ ស-២១ នៅប្រទេសកម្ពុជា"[4035] ដោយគ្រាន់តែធ្វើកាយវិការលើកដៃគ្រវាស។

២០៨៨. ក្រៅតែពីនិយាយឱ្យតែពិរោះ សំណួរសួរជាបឋមថាតើ "កំហឹង ខៀវ សំផន ចំពោះក្រុមជាតិពន្ធុនេះ" ក្នុងឆ្នាំ២០០៧ អនុញ្ញាតឱ្យកំណត់ថាមានចេតនាបំផ្លាញក្រុមនេះយ៉ាងដូចម្តេច តាមផ្លូវច្បាប់។ បន្ទាប់មក អង្គជំនុំជម្រះមិនបានពន្យល់ថាតើ "ការរិះគន់ខ្លាំងៗ" ចំពោះពួកឈ្លានពាន និងប្រទេសវៀតណាម អាចឱ្យអះអាងថា ខៀវ សំផន មានកំហឹងប្រឆាំងនឹងក្រុមជាតិសាសន៍វៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា កាលពីសម័យកម្ពុជាប្រជាធិបតេយ្យបានយ៉ាងដូចម្តេច។ ជាចុងក្រោយ ការសម្តែងមតិរបស់ ខៀវ សំផន ក្នុងឆ្នាំ២០០៧ ទាក់ទងទៅនឹងការរងទុក្ខវេទនារបស់ខ្មែរនៅកម្ពុជាក្រោមពីសំណាក់ប្រទេសវៀតណាម ពុំមានអ្វីពាក់ព័ន្ធនឹងឃាតកម្មដែលប្រហែលជាត្រូវបានប្រព្រឹត្តលើជនជាតិវៀតណាម រវាងខែមេសា ឆ្នាំ១៩៧៧ និងទីចុងបញ្ចប់នៃរបបនេះទេ។ ឯកសារដកស្រង់នេះមិនអាចបង្ហាញថា ខៀវ សំផន មានចេតនាបំផ្លាញក្រុមជាតិសាសន៍វៀតណាមនៅសម័យអង្គហេតុបាននោះទេ។ ដូច្នេះ ខៀវ សំផន ត្រូវតែរួចផុតពីទោស ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាម។

## ២.៥. គ្មានចេតនាប្រព្រឹត្តអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ

២០៨៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន និងអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមផ្សេងទៀត មានចេតនាប្រព្រឹត្តការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[4036]។ អង្គជំនុំជម្រះបានពិចារណាថា ខៀវ សំផន "ដឹងថាជនជាតិវៀតណាមដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិ

[4035] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៤ កំណត់សម្គាល់ជើងទំព័រលេខ ១៤០០២។

[4036] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៥។

សុខ ស-២១ ជាមនុស្សដែលត្រូវបានការពារដោយអនុសញ្ញានេះ”។ ក៏ប៉ុន្តែធាតុផ្សំភ័ស្តុតាងនេះមិនអនុញ្ញាតឱ្យអះអាងថា គាត់មានចេតនាប្រព្រឹត្តមនុស្សឃាត ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរដទៃទៀតលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹងបុគ្គលទាំងនេះឡើយ។

២០៩០. អត្ថិភាពនៃការគាំទ្រផែនការបដិវត្តន៍ទាក់ទងនឹងខ្មាំង មិនអាចធ្វើឱ្យអង្គជំនុំជម្រះរួចផុតពីកាតព្វកិច្ចក្នុងការបង្ហាញអំពីចេតនាផ្ទាល់ ក្នុងការប្រព្រឹត្តិការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹងអ្នកជាប់ឃុំជនជាតិវៀតណាម នៅ ស-២១ បានឡើយ។ អង្គជំនុំជម្រះក៏មិនអាចទាញការសន្និដ្ឋានពីការចូលរួមរបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម ថាគាត់មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋបានដែរ។ វាជារឿងពាក់ព័ន្ធនឹងធាតុផ្សំភ័ស្តុតាងដាច់ដោយឡែកនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ អង្គជំនុំជម្រះមិនបាននិយាយអ្វីទាំងអស់ដើម្បីបញ្ជាក់ថា ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មនៅ ស-២១ ប្រឆាំងនឹងជនជាតិវៀតណាម។ អាស្រ័យហេតុនេះ ដោយគ្មានចេតនា ខៀវ សំផន មិនអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះបានទេ ហើយការប្រកាសពិរុទ្ធភាពត្រូវទុកជាមោឃៈ[4037]។

## ៣. ពុទ្ធសាសនិក

២០៩១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានរៀបរាប់ធាតុផ្សំភ័ស្តុតាងដែលមិនអាចបង្ហាញពីចេតនាជាក់លាក់ ក្នុងការរើសអើងដោយមូលហេតុសាសនា ប្រឆាំងនឹងពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនា (៣.១) និងដោយមិនបានទាញការសន្និដ្ឋានសមហេតុផលតែមួយគត់ គឺអវត្តមាននៃចេតនាឧក្រិដ្ឋរបស់ ខៀវ សំផន (៣.២)។

### ៣.១. គ្មានចេតនាឧក្រិដ្ឋដែលត្រូវបានបង្ហាញ

---

[4037] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦។

២០៩២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា "អំពើរបស់ខៀវ សំផន បង្ហាញថាគាត់មានចេតនាជាក់លាក់ចង់រើសអើងពុទ្ធសាសនិក ដោយសារតែពួកគេជាសមាជិកនៃក្រុមសាសនានេះ"[4038]។

### ៣.១.១. ការគាំទ្រដាច់ខាតចំពោះ "គោលនយោបាយ ប.ក.ក" ដែលត្រូវបានចោទប្រកាន់

២០៩៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយមិនបានផ្តល់សំអាងហេតុគាំទ្រការអះអាងស្រពេចស្រពិល និងគ្មានបញ្ជាក់ទេសកាល អំពីការ "គាំទ្រពេញទំហឹងរបស់ [ខៀវ សំផន] ចំពោះគោលនយោបាយរបស់ ប.ក.ក"[4039] ដែលទោះជាក្នុងករណីណាក៏ដោយ ក៏មិនអនុញ្ញាតឱ្យសន្និដ្ឋានថា គាត់មានចេតនារើសអើងជាក់លាក់ប្រឆាំងនឹងពុទ្ធសាសនិក។

### ៣.១.២. ចន្លោះប្រហោងជាក់ស្តែងនៃនិក្ខេបបទគាំទ្រដល់ការលាក់កំបាំងភាពមិនប្រក្រតី

២០៩៤. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានអះអាងថា ខៀវ សំផន ពោរពេញដោយអសុទ្ធចិត្ត ពេលគាត់បានសាទរព្រះសង្ឃចំពោះការចូលរួមចំណែករបស់ព្រះអង្គក្នុងបដិវត្តន៍[4040]។ និក្ខេបបទស្តីពី "ការលាក់កំបាងភាពមិនប្រក្រតី" មិនត្រូវបានគាំទ្រដោយភស្តុតាងផ្ទាល់ ឬប្រយោលណាមួយ ដូចដែលបានបង្ហាញខាងលើ[4041]។

### ៣.១.៣. ចេតនាលុបបំបាត់ព្រះពុទ្ធសាសនានៅកម្ពុជា

២០៩៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយមិនបានបញ្ជាក់ថាតើ "ការគាំទ្រដាច់ខាតចំពោះគោលនយោបាយរបស់ ប.ក.ក" អាចជាមូលដ្ឋាននៃការសន្និដ្ឋានថា ខៀវ សំផន មាន

---

[4038] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៨។

[4039] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៨។

[4040] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៧។

[4041] សូមមើលខាងលើ កថាខណ្ឌ ១៩១៤-១៩២០។

ចេតនាជាក់លាក់ចង់លុបបំបាត់ព្រះពុទ្ធសាសនាយ៉ាងដូចម្ដេច[4042] ឬ "រើសអើងពុទ្ធសាសនិកដោយមូលហេតុសាសនា" ក្នុងគោលបំណង "ដកបុគ្គលទាំងនេះចេញពីសង្គម" យ៉ាងដូចម្ដេច។

## ៣.១.៤. ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញពីចេតនា

២០៩៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថាការចូលរួមរបស់ ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម បង្ហាញថា ខៀវ សំផន ក៏ដូចអ្នកចូលរួមក្នុងផែនការនេះផ្សេងទៀត មានចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា"[4043]។ អង្គជំនុំជម្រះមិនបានទាំងពន្យល់ពីហេតុផល ទាំងផ្ដល់សំអាងហេតុ។

## ៣.២. ការសន្និដ្ឋានសមហេតុផលមានតែមួយគត់ គឺគ្មានចេតនាឧក្រិដ្ឋ

២០៩៧. ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ល័ក្ខខ័ណ្ឌតម្រូវចាំបាច់សម្រាប់ចេតនាឧក្រិដ្ឋ គឺចេតនា "រើសអើងដោយមូលហេតុសាសនា" ប្រឆាំងនឹងពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនានៅត្រាំកក់ ក្នុងបំណង "ដកបុគ្គលទាំងនេះចេញពីសង្គម"។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានបង្ហាញតាមរយៈភ័ស្តុតាងអង្គហេតុណាមួយឱ្យឃើញថា ខៀវ សំផន មានចេតនារើសអើងពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនានៅត្រាំកក់ "ដោយមូលហេតុសាសនា" ដើម្បី "ដកបុគ្គលទាំងនេះចេញពីសង្គមឡើយ" នៅត្រាំកក់។

២០៩៨. អង្គជំនុំជម្រះគួរណាទាញការសន្និដ្ឋានពីអវត្តមាននៃភ័ស្តុតាងផ្ទាល់ ឬប្រយោលនៃចេតនារបស់ខៀវ សំផន ក្នុងការរើសអើងពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនា នៅត្រាំកក់។ ដូច្នេះ ការសន្និដ្ឋានសមហេតុផលតែមួយគត់ចំពោះចៅក្រមមិនលម្អៀង គឺថា ខៀវ សំផន មិនបំពេញល័ក្ខខ័ណ្ឌតម្រូវចាំបាច់នៃចេតនាឧក្រិដ្ឋពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុ

[4042] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៨។

[4043] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៨។

សាសនា លើពុទ្ធសាសនិក និងព្រះសង្ឃពុទ្ធសាសនានៅត្រាំកក់ក្នុងឆ្នាំ ១៩៧៥។ រាល់ការសន្និដ្ឋានផ្ទុយពីនេះត្រូវទុកជាមោឃៈ[4044]។

## ៤. អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

២០៩៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានរៀបរាប់ធាតុផ្សំភ័ស្តុតាង ដែលមិនអាចបង្ហាញអំពីចេតនាជាក់លាក់របស់ ខៀវ សំផន ក្នុងការរើសអើង ដោយមូលហេតុនយោបាយប្រឆាំងនឹងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (៤.១) ឬចេតនាធ្វើឃាតអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (៤.២)។

### ៤.១. គ្មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

២១០០. *[កថាខណ្ឌលុបចោល ក្រោយពីកែតម្រូវ ប៉ុន្តែ រក្សាលេខទុកដដែល ដើម្បីកុំឱ្យខុសលេខរៀង]*។

#### ៤.១.១. តួនាទីជួរមុខរបស់ ខៀវ សំផន ក្នុងជ័យជម្នះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

២១០១. ដូចដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុដោយបានពិចារណាថា ខៀវ សំផន បានដើរតួនាទីជួរមុខក្នុងការធានាជ័យជម្នះរបស់ ប.ក.ក នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[4045]។ ទោះបីយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះមិនអាចទាញការសន្និដ្ឋាន ចេញពីតួនាទីដែលរងការចោទប្រកាន់ និងដែលស្ថិតក្នុងក្របខ័ណ្ឌសង្គ្រាមស៊ីវិលនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថា ខៀវ សំផន មានចេតនារើសអើងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ នៅត្រាំកក់ ពីថ្ងៃទី

[4044] សំអាងហេតុសាលក្រម កថាខណ្ឌ ៤២៩៧-៤២៩៨។

[4045] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០០ កំណត់សម្គាល់ជើងទំព័រលេខ ១៤០១០ យោងដល់កថាខណ្ឌ ៤២៤៤-៤២៤៥ (ការដឹងឮ - អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)។

២០ ខែមេសា ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងនៅទំនប់១មករា មន្ទីរ ស-២១ និងក្រាំងតាចាន់ ពីដើមឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[4046]។

## ៤.១.២. ការអំពាវនាវឱ្យប្រហារជីវិតមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ

២១០២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានផ្អែកលើការអំពាវនាវរបស់ខៀវ សំផន ដែលត្រូវបានធ្វើឡើងមុនថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ ឱ្យប្រហារជីវិតមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ ដើម្បីបំពេញល័ក្ខខ័ណ្ឌតម្រូវចាំបាច់នៃចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ[4047]។ ការអំពាវនាវទាំងនេះមានដែនកំណត់ក្នុងរយៈពេលសង្គ្រាមស៊ីវិលមុនខែមេសា ឆ្នាំ១៩៧៥ និងមិនអាចត្រូវបានប្រើប្រាស់ ដោយសមហេតុផលដោយអង្គជំនុំជម្រះដើម្បីបង្ហាញពីចេតនារើសអើងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់នៅត្រាំកក់ពីថ្ងៃទី២០ ខែមេសា ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងនៅទំនប់១មករា មន្ទីរ ស-២១ និងក្រាំងតាចាន់ ពីដើមឆ្នាំ១៩៧៧ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ បានទេ។

២១០៣. អង្គជំនុំជម្រះកាន់តែមិនមានសិទ្ធិអំណាចធ្វើដូច្នេះថែមទៀត ពីព្រោះថាការសម្លាប់មេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរត្រូវបានជំនុំជម្រះរួចហើយ ក្នុងការជំនុំជម្រះសំណុំរឿង ០០២/០១ ដោយតុលាការកំពូល ដែលបានពិចារណាថា "ការប្រហារជីវិតមេដឹកនាំសំខាន់ៗនៃរបបសាធារណរដ្ឋខ្មែរ ជាផ្នែកមួយនៃគោលបំណងរួម ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីភ្នំពេញ" និងបានតម្កល់ការផ្ដន្ទាទោសខៀវ សំផន ចំពោះអង្គហេតុទាំងនេះ ក្នុងការសម្រេចសេចក្ដីលើបណ្ដឹងសារទុក្ខ[4048]។ អង្គជំនុំជម្រះ

---

[4046] សូមមើលខាងលើ កថាខណ្ឌ ១៤៥១-១៤៥៦។

[4047] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០០។

[4048] សាលដីកា សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៥៩ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម) ក្នុងនោះ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ភ័ស្តុតាងផ្ទុយនឹង "អត្ថិភាពនៃគោលនយោបាយទូទៅ ចាប់ពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧៥។ សូមមើលផងដែរ កថាខណ្ឌ ៤៦៦។

មិនអាចកាត់សេចក្តីលើអង្គហេតុទាំងនេះជាថ្មីម្តងទៀត ដោយពុំរំលោភបំពានលើគោលការណ៍អាជ្ញាអស់ជំនុំបានឡើយ[4049]។

## ៤.១.៣. គ្មានភ័ស្តុតាងបង្ហាញចេតនារើសអើងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

២១០៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានអះអាង គ្មានសំអាងហេតុ ឬឯកសារយោងណាមួយ ថា ខៀវ សំផន ជា "ស្មោះស្ម័គ្រឥតងាករេនឹងគោលនយោបាយរើសអើងរបស់បក្ស ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ"[4050]។

២១០៥. ការអះអាងរបស់អង្គជំនុំជម្រះដែលថា "ខៀវ សំផន ត្រូវបានរកឃើញថាដូចគ្នានឹងអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដទៃទៀតដែរ គាត់មានចេតនាជាក់លាក់រើសអើងចំពោះមេដឹកនាំទាំងអស់នៃអតីតរបបសាធារណរដ្ឋខ្មែរ ជាពិសេសដោយហេតុថាពួកគេត្រូវបានចាត់ទុកថាអាចមានសមត្ថភាពរៀបចំចលនាប្រឆាំងបដិវត្តន៍វិញ" មិនមែនជាការបង្ហាញហេតុផលទេ[4051]។ ជាការពិត សម្មតកម្មរបស់អង្គជំនុំជម្រះ ជាទស្សនៈបែបសន្មតមួយលើសមាសភាពនៃអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដែលមិនមានលើកភ័ស្តុតាងដើម្បីគាំទ្រការអះអាងរបស់ខ្លួនឡើយ។ អង្គជំនុំជម្រះផ្អែកលើមូលដ្ឋាននេះតែមួយគត់ដើម្បីសន្និដ្ឋានថា ខៀវ សំផន មានចេតនាជាក់លាក់រើសអើងចំពោះអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងអស់។ ការសន្និដ្ឋានមិនសមហេតុផល និងមិនមានសំអាងហេតុនេះ ត្រូវទុកជាមោឃៈ។

២១០៦. លើសពីនេះទៅទៀត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានសម្តែងនូវការជឿជាក់ដោយពុំមានអង្គហេតុជាក់ស្តែងជាមូលដ្ឋាន ថា "ដោយមានជំហរគាំទ្រដោយឥតងាករេចំពោះគោល

[4049] សូមមើលខាងលើ កថាខណ្ឌ ៥៤៥, ១៣៤។

[4050] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០០។

[4051] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០០។

ការណ៍បដិវត្តន៍ ខៀវ សំផន មានចេតនាជាក់លាក់ក្នុងការធ្វើឱ្យមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរទាំងអស់ទទួលរងការធ្វើបាប"[4052]។ ការអះអាងដាច់ខាតនេះក៏មិនមែនជាការសន្និដ្ឋានមានសំអាងហេតុដែរ។

### ៤.១.៤. ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមមិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញពីចេតនា

២១០៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយបានសន្និដ្ឋានថា "ដោយសារតែការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមនេះតែម្តង ខៀវ សំផន ក៏ដូចជាអ្នកចូលរួមផ្សេងទៀតដែរ មានចេតនាជាក់លាក់ប្រព្រឹត្តឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងអតីតមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ"[4053]។ គោលបំណងរួមមិនមានលក្ខណៈឧក្រិដ្ឋចំពោះ ដែល ខៀវ សំផន ចូលរួមនេះ មិនអាចក្លាយជាសហឧក្រិដ្ឋកម្មរួម មួយរំពេចយ៉ាងនេះទេ។ អង្គជំនុំជម្រះត្រូវតែបង្ហាញថាតើអ្វីជាការចូលរួមចំណែកដ៏សំខាន់របស់ ខៀវ សំផន ក្នុងទិដ្ឋភាពឧក្រិដ្ឋ ដែលបណ្តាលឱ្យមានឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ក្នុងរឿងក្តីនេះ សុន្ទរកថារបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលដកស្រង់សម្តីដោយអង្គជំនុំជម្រះ មិនគ្រប់គ្រាន់ដើម្បីបង្ហាញអំពីចេតនានេះទេ។

### ៤.២. គ្មានភស្តុតាងបង្ហាញពីចេតនាប្រព្រឹត្តបទល្មើសជាអំពើមនុស្សឃាត

២១០៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសក្នុងការវាយតម្លៃភស្តុតាងរបស់ខ្លួន ដើម្បីសន្និដ្ឋានថា ខៀវ សំផន មានចេតនាប្រព្រឹត្តអំពើមនុស្សឃាត លើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរពីថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងរវាងខែតុលា ឆ្នាំ១៩៧៥ និង ចុងបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ នៅមន្ទីរ ស-២១ និងក្រាំងតាចាន់[4054]។

[4052] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០០។

[4053] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០០។

[4054] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០១-៤៣០២។

២១០៩. តាមការពិត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានលើកឡើងអំពីការអំពាវនាវក្នុងឆ្នាំ១៩៧២ ដើម្បីជាភ័ស្តុតាងដាក់បន្ទុក ហើយដែលការអំពាវនាវនេះទំនងជាកំណត់មេដឹកនាំជាន់ខ្ពស់នៃរបប សាធារណរដ្ឋខ្មែរ និងអ្នកក្រោមបង្គាប់របស់ពួកគេជាគោលដៅ[4055]។ ក៏ប៉ុន្តែ ការអំពាវនាវទាំងនេះត្រូវ បានធ្វើឡើងនៅក្នុងបរិបទសង្គ្រាមនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ហើយវាកំណត់តែ "មេដឹកនាំ ជាន់ខ្ពស់" ប៉ុណ្ណោះជាគោលដៅ។ លើសពីនេះទៀត ដូចដែលបានឃើញខាងលើ អង្គហេតុទាំងនេះត្រូវ បានវិនិច្ឆ័យជាស្ថាពររួចហើយ[4056]។

២១១០ ដូចដែលបានឃើញខាងលើ តាមពិត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើសេចក្តីថ្លែង ការមួយដែល ខៀវ សំផន ទំនងជាបានធ្វើ ហើយដែលមានសម្រង់សម្តីដូចនេះ "វត្ថុបំណងនៃបដិវត្តន៍ គឺដើម្បីកម្ទេចរបបលន់ នល់" ព្រមទាំងពួកនាយទុន សក្តិភូមិ និងបញ្ញវន្តដែលមានមុខតំណែងខ្ពស់ក្នុង របបនេះ និងដើម្បីសម្លាប់ជនក្បត់បក្ស ឬបដិវត្តន៍"[4057]។ នៅក្នុងកំណត់សម្គាល់ជើងទំព័រ អង្គជំនុំ ជម្រះបានយោងទៅកថាខណ្ឌ ៤២៤៤ និង ៤២៧២ ដែលមិនមានផ្តល់ព័ត៌មានអំពីប្រភពនៃការ អះអាងនេះឡើយ[4058]។ តាមការពិត ប្រភពនៃ "ការអះអាងនេះ" គឺជាដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឈុន ដែលមិនអាចទុកចិត្តបាន ដូចដែលយើងបានឃើញខាង[4059]។

---

[4055] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០២។

[4056] សូមមើលខាងលើ កថាខណ្ឌ ២១០៣។

[4057] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០២ កំណត់សម្គាល់ជើងទំព័រលេខ ១៤០១៣ យោងដល់កថាខណ្ឌ ៤២៤៤ និង ៤២៧២។ សូមមើលខាងក្រោមផងដែរ កថាខណ្ឌ ១៤៥១-១៤៥៦។

[4058] កថាខណ្ឌ ៤២៤៤ ស្ថិតនៅក្នុងផ្នែក "ការដឹងឮ" ដែលហាក់ដូចជាយោងដល់សេចក្តីប្រកាសដែលត្រូវបានសន្មតថាជារបស់ លោក ខៀវ សំផន ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ នៃកម្រងឯកសារ FBIS ដែលមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត ដោយគ្មានការ បញ្ជាក់បន្ថែម។ អង្គជំនុំជម្រះក៏បានយោងទៅកថាខណ្ឌ ៤២៧២ នៃសំអាងហេតុសាលក្រម នៅក្នុងផ្នែក "ការចូលរួមចំណែក"។ សុន្ទរកថាដែលត្រូវបានចោទថាជារបស់លោក ខៀវ សំផន នេះ ទំនងជាថ្លែង នៅឆ្នាំ១៩៧៧។ ប៉ុន្តែ ការយោង គឺខុសយ៉ាងច្បាស់ ក្រឡែត ពីព្រោះយោងទៅកថាខណ្ឌ ៤២៧២។

[4059] សូមមើលសំអាងហេតុសាលក្រម កថាខណ្ឌ ៣៩៦១ កំណត់សម្គាល់ជើងទំព័រលេខ ១៣១៨៥ យោងដល់សក្ខីកម្មរបស់ ព្រាប ឆុន ដែលបានលើកឡើងអំពីសុន្ទរកថាដែលត្រូវបានសន្មតថាជារបស់លោក ខៀវ សំផន នៅឆ្នាំ១៩៧៧។ សូមមើលខាងលើ កថាខណ្ឌ ១៥៣៤-១៥៣៥។

២១១១. អង្គជំនុំជម្រះក៏បានប្រព្រឹត្តកំហុសផងដែរ ដោយបានបង្កើតទំនាក់ទំនងបែបច្នៃប្រឌិត រវាង "ការអំពាវនាវទាំងនេះ" និងហេតុការន៍ដែលបានកើតឡើងនៅ ស-២១ និងក្រាំងតាចាន់ ក្នុខណ:ដែលនៅក្នុងការសន្និដ្ឋានអំពីអង្គហេតុនៅតាមមន្ទីរសន្តិសុខទាំងនេះ គ្មានអ្វីអាចឱ្យបង្ហាញថាពិតជាមានទំនាក់ទំនងខាងលើទេ[4060]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានអះអាងថាខ្លួន "ជឿជាក់ថាអតីតមេដឹកនាំនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងទាហាន និងមន្ត្រីរដ្ឋការ) និងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានកំណត់ជាគោលដៅដោយគោលនយោបាយរបស់ ប.ក.ក ដែលមានគោលបំណងកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់ឱ្យនៅឯកោ និង "កម្ទេច" បុគ្គលដែលគេចាត់ទុកថាជាខ្មាំងដ៏គ្រោះថ្នាក់បំផុត និងដោយបានជឿជាក់ថា ដោយសារតែការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួមនេះតែម្តងទើប ខៀវ សំផន ក៏ដូចជាអ្នកចូលរួមផ្សេងទៀត មានចេតនាប្រព្រឹត្តឧក្រិដ្ឋប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត"[4061]។

២១១២. **<u>ការសន្និដ្ឋាន</u>** មិនមានភ័ស្តុតាងផ្ទាល់ ឬប្រយោលណាមួយបង្ហាញពីចេតនារបស់ ខៀវ សំផន ក្នុងការរើសអើងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅត្រាំកក់ ពីថ្ងៃទី២០ ខែមេសា ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងនៅទំនប់១មករា មន្ទីរ ស-២១ និងក្រាំងតាចាន់ រវាងដើមឆ្នាំ១៩៧៧ និងថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ "ដោយមូលហេតុនយោបាយ" ដើម្បី "ដកបុគ្គលទាំងនេះចេញពីសង្គម"។ ដូចគ្នានេះដែរ មិនមានភ័ស្តុតាងផ្ទាល់ ឬប្រយោលណាមួយបញ្ជាក់អំពីចេតនាសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ពីថ្ងៃទី២០ ខែមេសា ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងពីខែតុលា ឆ្នាំ១៩៧៥ ដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅមន្ទីរ ស-២១ និងក្រាំងតាចាន់ឡើយ។

២១១៣. អង្គជំនុំជម្រះគួរណាទាញការសន្និដ្ឋានចេញពីអវត្តមានភ័ស្តុតាងនេះ ជាជាងទាញការសន្និដ្ឋានព្រាវៗដោយផ្អែកលើភ័ស្តុតាងមិនគ្រប់គ្រាន់ ឬអង្គហេតុដែលត្រូវបានវិនិច្ឆ័យជាស្ថាពររួចហើយ។ មានការសន្និដ្ឋានសមហេតុផលតែមួយគត់ គឺថាខៀវ សំផន មិនមានចេតនាដែលជាធាតុផ្សំចាំបាច់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

---

[4060] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០២។

[4061] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០២។

និងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើមនុស្សឃាត។ រាល់សេចក្តីសន្និដ្ឋានផ្ទុយនេះរបស់អង្គជំនុំជម្រះត្រូវទុកជាមោឃៈ[4062]។

## ផ្នែកទី ៥. ការរៀបអាពាហ៍ពិពាហ៍

២១១៤. អង្គជំនុំជម្រះបានពិចារណាថា "ខៀវ សំផន ត្រូវបានរកឃើញថាបានធ្វើសកម្មភាពក្នុងបំណងឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក្នុងក្របខ័ណ្ឌនៃគោលនយោបាយជាតិរបស់ ប.ក.ក ស្តីពីបទបញ្ជាទាក់ទងនឹងអាពាហ៍ពិពាហ៍" ហើយថាគាត់ក៏ដូចជាអ្នកចូលរួមផ្សេងទៀត [ក្នុងសហឧក្រិដ្ឋកម្មរួម] មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀតក្រោមទម្រង់ជាអង្គហេតុដែលត្រូវបានកំណត់ថាជាការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[4063]។

២១១៥. អង្គជំនុំជម្រះបានយោងជាពិសេសទៅលើសេចក្តីសន្និដ្ឋានអង្គហេតុរបស់ខ្លួន លើបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍[4064]។ ដូចបានឃើញខាងលើ ក្រៅពីផ្អែកលើកំហុសអង្គច្បាប់[4065] ការសន្និដ្ឋានទាំងនេះបណ្តាលមកពីការវាយតម្លៃខុស និងលម្អៀងលើភ័ស្តុតាង។ ជាការពិត អង្គជំនុំជម្រះបានសន្និដ្ឋានច្រឡំថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃអាពាហ៍ពិពាហ៍ ភ័ស្តុតាងគ្រប់គ្រាន់។ ដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋាន ថា ខៀវ សំផន មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះបានទេ។ យោងតាមអង្គជំនុំជម្រះ ចេតនានេះត្រូវបានបង្ហាញថាពិតជាមាន តាមរយៈការចូលរួមរបស់គាត់ ក្នុងគោលនយោបាយរបស់ ប.ក.ក ក្នុងការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ ដើម្បីបង្កើនចំនួនប្រជាជន ដោយដាក់បទបញ្ជាស្តីពីអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែ ដូចដែលយើងបានឃើញខាងលើ ការយល់ច្រឡំពាក់ព័ន្ធ

---

[4062] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០២។

[4063] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៥។

[4064] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៣ និងកំណត់សម្គាល់ជើងទំព័រលេខ ១៤០១៥-១៤០១៦ កថាខណ្ឌ ៤៣០៣ និងកំណត់សម្គាល់ជើងទំព័រលេខ ១៤០១៧។

[4065] សូមមើលខាងលើ កថាខណ្ឌ ១០៩៨-១១១៦ កថាខណ្ឌ ១២៨១-១២៨៧។

នឹងខ្លឹមសារនៃបទបញ្ជានេះ ការអនុវត្តបទបញ្ជានេះ និងការត្រួតពិនិត្យលើការផ្សំដំណោករងការចោទប្រកាន់ មិនអនុញ្ញាតឱ្យសន្និដ្ឋានថាមានគោលនយោបាយបែបនេះនោះទេ[4066]។

២១១៦. ជាការពិត ដូចដែលយើងបានពន្យល់ខាងលើ អង្គជំនុំជម្រះបានសន្និដ្ឋានខុសថាអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាគោលនយោបាយជាតិរបស់ ប.ក.ក[4067]។ ប្រសិនបើបានពិនិត្យភ័ស្តុតាងដោយមិនលម្អៀងវិញ អង្គជំនុំជម្រះប្រហែលជាកត់សម្គាល់ថាបទបញ្ជាស្តីពីអាពាហ៍ពិពាហ៍ ដូចដែលណែនាំដោយ ប.ក.ក. តម្រូវឱ្យមានការយល់ព្រមពីសហព័ទ្ធ និងកត់សម្គាល់ថាយោងតាមគោលការណ៍សីលធម៌ស្តីពីទំនាក់ទំនងរវាងបុរស និងស្ត្រី ដែលជាលក្ខណៈពិសេសនៃចលនាខ្មែរក្រហម រាល់ការរំលោភបំពានផ្លូវភេទសុទ្ធតែផ្ទុយនឹងគោលនយោបាយរបស់ពួកគេ[4068]។

២១១៧. ទោះយ៉ាងណាក្តី ការចោទប្រកាន់ដែលថាម្ចាស់បណ្តឹងសាទុក្ខទំនងជាបាន "ណែនាំ" ដោយបើកចំហឱ្យបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ ឱ្យបានឆាប់រហ័ស ហើយទន្ទឹមនឹងនោះបានជំរុញប្រជាជនឱ្យផ្តាច់អារម្មណ៍ផ្ទាល់ខ្លួនពីឪពុកម្តាយ ដោយឱ្យអង្គការដើរតួជាឪពុកម្តាយជំនួស" ផ្អែកលើពាក្យសម្តី និងសុន្ទរកថាក្រៅបរិបទដែលមិនមានអ្វីពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ទាល់តែសោះ[4069]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះផ្អែកតែលើមូលដ្ឋាននៃសក្ខីកម្មឯកឯង និងយឺតពេលរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប តែប៉ុណ្ណោះ ដើម្បីពិចារណាថា ខៀវ សំផន "បានណែនាំដល់គ្រប់ក្រសួងទាំងអស់ឱ្យរៀបចំអាពាហ៍ពិពាហ៍"។ ក៏ប៉ុន្តែ កង្វះការគួរជឿជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ និងភាពផ្ទុយគ្នានៃសក្ខីកម្មរបស់គាត់ជាមួយនឹងភ័ស្តុតាងផ្សេងៗទៀតទាំងប៉ុន្មាន គួរតែអាចនាំឱ្យអង្គជំនុំជម្រះច្រានចោលសក្ខីកម្មនេះ។

---

[4066] សូមមើលខាងលើ កថាខណ្ឌ ១១១៧-១២៨០ កថាខណ្ឌ ១២៨៨-១៣៩៨។

[4067] សូមមើលខាងលើ កថាខណ្ឌ ១១៨៩-១២៨០ កថាខណ្ឌ ១៣៩១-១៣៩៨។

[4068] សូមមើលខាងលើ កថាខណ្ឌ ១១៩២-១១៩៥ កថាខណ្ឌ ១៣៩៥-១៣៩៨។

[4069] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៤, ៤២៤៨។ សូមមើលខាងលើ កថាខណ្ឌ ១២២១-១២៣២។

២១១៨. ហេតុដូចនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានពិចារណាថាបានរកឃើញថា តាមរយៈទង្វើរបស់គាត់ ខៀវ សំផន មានចេតនាចង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយដាក់បទបញ្ជាស្តីពីអាពាហ៍ពិពាហ៍ដែលមានលក្ខណៈឧក្រិដ្ឋ។ ការសន្និដ្ឋានទាំងនេះត្រូវតែទុកជាមោឃៈ[4070]។

## មាតិកាទី ៥. ការយល់ច្រឡំលើការជួយ និងការជំរុញ

២១១៩. ជាការកត់សម្គាល់ អង្គជំនុំជម្រះមិនបានទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់អំពីការស្លាប់ដោយចេតនាប្រយោល នៅត្រាំកក់[4071] ទំនប់១មករា[4072] និក្រាំងតាចាន់ឡើយ[4073]។ លើសពីនេះ គោលការណ៍នីត្យានុកូលភាពហាមឃាត់ការអនុវត្តស្តង់ដារនៃការបង្ហាញចេតនាឧក្រិដ្ឋដែលទាបជាងចេតនាសម្លាប់ដោយផ្ទាល់[4074]។ បន្ទាប់មក ការកែប្រភេទបទល្មើសមិនស្របច្បាប់ទេ នៅត្រាំកក់[4075] ទំនប់ត្រពាំងថ្ម[4076] ទំនប់១មករា[4077] និងក្រាំងតាចាន់[4078]។ មួយវិញទៀត ទោះយ៉ាងណាក្តី ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ឡើយ នៅត្រាំកក់[4079] ទំនប់ត្រពាំងថ្ម[4080] ទំនប់១មករា[4081] និងក្រាំងតាចាន់[4082]។ ទាក់ទងនឹងការទទួលខុសត្រូវរបស់ ខៀវ សំផន ចំពោះការជួយជ្រោមជ្រែង និងការជំរុញ អង្គជំនុំជម្រះបានប្រព្រឹត្ត

[4070] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៣-៤៣០៦។

[4071] សូមមើលខាងលើ កថាខណ្ឌ ៣៦៧-៣៧១ កថាខណ្ឌ ៣៧៨-៣៧៩ កថាខណ្ឌ ៤៤៥-៤៤៧ កថាខណ្ឌ ៤៦៥-៤៧៤។

[4072] សូមមើលខាងលើ កថាខណ្ឌ ៣៩១-៣៩២ កថាខណ្ឌ ៤៨៧-៤៨៩។

[4073] សូមមើលខាងលើ កថាខណ្ឌ ៤០៥-៤០៧។

[4074] សូមមើលខាងលើ កថាខណ្ឌ ៥៧៥-៦៤០។

[4075] សូមមើលខាងលើ កថាខណ្ឌ ១៣៥-១៥៧, ៦៧២។

[4076] សូមមើលខាងលើ កថាខណ្ឌ ៧៥៨។

[4077] សូមមើលខាងលើ កថាខណ្ឌ ៧៦៨។

[4078] សូមមើលខាងលើ កថាខណ្ឌ ៨១៦-៨២១។

[4079] សូមមើលខាងលើ កថាខណ្ឌ ៦៧២-៦៨៥។

[4080] សូមមើលខាងលើ កថាខណ្ឌ ៧៥៩-៧៦២។

[4081] សូមមើលខាងលើ កថាខណ្ឌ ៧៦៨-៧៨០។

[4082] សូមមើលខាងលើ កថាខណ្ឌ ៨២០-៨២៤។

កំហុសអង្គច្បាប់ (ជំពូកទី ១) និងអង្គហេតុ ក្នុងការវាយតម្លៃលើធាតុផ្សំសត្យានុម័តិ (ជំពូកទី ២) និងធាតុផ្សំអត្តនោម័តិ (ជំពូកទី ៣) ដែលសុទ្ធតែជាធាតុផ្សំចាំបាច់ ដើម្បីបង្កើតបានជាទម្រង់នៃទំនួលខុសត្រូវនេះ។

## ជំពូក ១. ការជួយជ្រោមជ្រែង និងការជំរុញ តាមផ្លូវច្បាប់

២១២០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ក្នុងការកំណត់និយមន័យនៃធាតុផ្សំអត្តនោម័តិចំពោះការជួយជ្រោមជ្រែង និងការជំរុញ ដោយបានសន្និដ្ឋានថា ដើម្បីរកឃើញពិរុទ្ធភាព ជនជាប់ចោទត្រូវតែដឹងថា "អំពើរបស់ខ្លួននឹងបណ្ដាលឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនេះ"[4083]។ ក៏ប៉ុន្តែ ចេតនាស្ដង់ដារទាបនេះមិនមានទេ នៅសម័យអង្គហេតុដែលត្រូវបានចោទប្រកាន់។

២១២១. អង្គជំនុំជម្រះបានផ្អែកលើប្រភពដូចគ្នានឹងសាលក្រមសំណុំរឿង ០០២/០១ គឺផ្អែកលើសាលដីកានៃរឿងក្ដី *Blaškić* របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងយុត្តិសាស្ត្ររបស់តុលាការទីក្រុង Nuremberg ក្នុងរឿងក្ដី *Einsatzgruppen*[4084]។ មេធាវីការពារក្ដីបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងនិយមន័យនេះ ដោយលើកហេតុផលថា យុត្តិសាស្ត្រ *Blaškić* កើតក្រោយអង្គហេតុដែលត្រូវបានចោទប្រកាន់ ហើយថាមិនមានសាលដីកាដទៃទៀត នៃសាលាឧទ្ធរណ៍នៃតុលាការចំពោះកិច្ចយកគំរូតាមយុត្តិសាស្ត្រនេះឡើយ។ តុលាការនេះបានអនុម័តិនិយមន័យដូចនេះវិញទេ៖ "ទាល់តែជនជាប់ចោទដឹងថា អំពើដែលគាត់បានធ្វើចូលរួមចំណែកក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់ដោយចារីបង្គោលនោះ"[4085]។ លើសពីនេះទៀត មេធាវីការពារក្ដីបានគូសបញ្ជាក់ថាលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិច្រានចោលចេតនាសម្រួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋបន្ថែមពីលើការដឹងឮ។

---

[4083] សំអាងហេតុសាលក្រម កថាខណ្ឌ ៣៧២២។

[4084] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១២៤១៧។

[4085] សារណាបណ្ដឹងសាទុក្ខលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៨។

២១២២. ទាក់ទងទៅនឹងរឿងក្តី *Einsatzgruppen* ការបកស្រាយរបស់អង្គជំនុំជម្រះមិនគាំទ្រដល់ធាតុផ្សំអត្តនោម័តិកម្រិតទាបទេ។ ជាក់ស្តែង តុលាការបានបញ្ជាក់ថា ជនជាប់ចោទទាំងអស់ ជាសមាជិកនៃ *Einsatzgruppen* ហើយបេសកកម្មដែលជនជាប់ចោទដឹងឮ គឺជាការអនុវត្តកម្មវិធីធ្វើឃាតទ្រង់ទ្រាយធំ[4086]។ មេធាវីការពារក្តីក៏បានកត់សម្គាល់ផងដែរថា ក្នុងរឿងក្តីស្តីពីការនិរទេសពីក្រុង Hechingen និងរឿងក្តី *Zyklon B.* ជនជាប់ចោទទាំងអស់ត្រូវបានផ្តន្ទាទោសពីបទសមគំនិត ពីព្រោះពួកគេដឹងថាខ្លួនបានចូលរួមចំណែកក្នុងបទឧក្រិដ្ឋជាក់លាក់មួយ[4087]។ ដោយពុំមានការឆ្លើយតបរបស់តុលាការកំពូលចំពោះបញ្ហានេះ នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ មេធាវីការពារក្តីសូមបញ្ជាក់ម្តងទៀតអំពីទឡ្ហីករណ៍សង្ខេប និងដែលមានរៀបរាប់លម្អិតនៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១[4088]។

២១២៣. កំហុសអង្គច្បាប់របស់អង្គជំនុំជម្រះ ធ្វើឱ្យការសន្និដ្ឋានទាំងអស់របស់ខ្លួនស្តីពីការទទួលខុសត្រូវរបស់ម្ចាស់បណ្តឹងសាទុក្ខចំពោះការជួយជ្រោមជ្រែង និងការជំរុញ អស់សុពលភាព[4089]។

### ជំពូកទី ២. កំហុសពាក់ព័ន្ធនឹងធាតុផ្សំអត្តនោសញ្ចេតនា/អត្តនោម័តិ

២១២៤. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថាមានធាតុផ្សំសត្យានុម័តិគ្រប់គ្រាន់ចំពោះទម្រង់នៃការទទួលខុសត្រូវពីបទបានជួយជ្រោមជ្រែង និងជំរុញ តាមរយៈអំពើមនុស្សឃាតដោយចេតនាប្រយោល ដែលត្រូវបានចោទប្រកាន់ ចំពោះអង្គហេតុនៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង (១) និងមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល (២)។

[4086] សារណាបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៩។

[4087] សារណាបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៩០។

[4088] សារណាបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៧-៩២។

[4089] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៨, ៤៣២៨។

## ១. គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតដោយចេតនាប្រយោល នៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង

២១២៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានចាត់ទុកថាការគាំទ្រផ្នែកសីលធម៌ និងការជំរុញដោយតុណ្ហីភាពដល់ស្ថាប័នដែលមានសិទ្ធិអំណាចចេញចសេចក្ដីសម្រេច (១.១) ការគាំទ្រផ្នែកសីលធម៌ និងការជំរុញយ៉ាងសកម្ម ដល់កម្មាភិបាលនៃ ប.ក.ក (១.២) ជាមូលដ្ឋានបញ្ជាក់ថាមានធាតុផ្សំសត្យានុម័តិគ្រប់គ្រាន់ ដើម្បីឱ្យ ខៀវ សំផន ទទួលខុសត្រូវ ចំពោះការជួយជ្រោមជ្រែង និងការជំរុញ។ អង្គជំនុំជម្រះធ្វើអ្វីៗទាំងអស់ដោយមិនបានផ្ដល់សំអាងហេតុគាំទ្រសេចក្ដីសន្និដ្ឋានដ៏សំខាន់របស់ខ្លួនទៅលើឥទ្ធិពលដ៏សំខាន់នៃជំនួយជាក់ស្ដែង និងការគាំទ្រផ្នែកសីលធម៌ ដែលត្រូវបានចោទប្រកាន់ ទៅលើការស្លាប់របស់កម្មករដែលធ្វើការនៅក្នុងសហករណ៍ (១.៣)។

## ១.១. ការគាំទ្រផ្នែកសីលធម៌ និងការលើកទឹកចិត្តដោយតុណ្ហីភាពដល់ស្ថាប័នមានសិទ្ធិអំណាចចេញសេចក្ដីសម្រេច

### ១.១.១. ភាពច្របូកច្របល់រវាង"គោលនយោបាយ" ឧក្រិដ្ឋកម្ម និងគោលបំណងឧក្រិដ្ឋរួម

២១២៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានចាត់ទុកថាជាធាតុផ្សំដាក់បន្ទុកនូវវត្តមាន និងការចូលរួមរបស់ ខៀវ សំផន ក្នុងកិច្ចប្រជុំផ្សេងៗរបស់មេដឹកនាំ ប.ក.ក ដែលក្នុងឱកាសនេះ ផែនការសេដ្ឋកិច្ច គម្រោងសាងសង់ប្រព័ន្ធស្រោចស្រព និង"ការអនុវត្តគោលនយោបាយរបស់ ប.ក.ក ត្រូវបានរៀបចំចេញជាផែនការ និងពិនិត្យ" ជាពិសេស "ការអនុវត្តគោលនយោបាយនានាទាក់ទងនឹងសហករណ៍ និងការដ្ឋាន"[4090]។ ជាបឋម អង្គជំនុំជម្រះមិនបានពន្យល់ថាតើហេតុអ្វីបានជាតែមួយរំពេចសោះ ខ្លួនបានលើកឡើងពីគោលនយោបាយជាពហុវចនៈទៅវិញ។ បន្ទាប់មក អង្គជំនុំជម្រះមិនបានពន្យល់អំពីទំនាក់ទំនងមិនចំហរចំៗ ដែលខ្លួនបានបង្កើតឡើង រវាងគោលនយោបាយ និងបទល្មើសមនុស្សឃាតដោយចេតនាប្រយោលដែលត្រូវបានចោទប្រកាន់ ចំពោះអង្គហេតុនៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង។

[4090] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

២១២៧. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានថា ខៀវ សំផន "បានគាំទ្រខាងផ្លូវសីលធម៌ និងលើកទឹកចិត្តជាតុណ្ហីភាព ដល់ស្ថាប័នដែលមានសិទ្ធិអំណាចចេញសេចក្តីសម្រេច ដែលស្ថាប័នទាំងនេះបានបន្តកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងគោលបំណងធ្វើផែនការ និងអនុវត្តគោលបំណងឧក្រិដ្ឋ"[4091] ដោយគ្មានពន្យល់ថាតើមានគោលបំណងឧក្រិដ្ឋណាខ្លះ។

### ១.១.២. ការលើកទឹកចិត្តដោយតុណ្ហីភាពតម្រូវឱ្យមានវត្តមានជាក់ស្តែងរបស់ជនជាប់ចោទនៅកន្លែងកើតហេតុ

២១២៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានចាត់ទុកថា "ការលើកទឹកចិត្តដោយតុណ្ហីភាព"ជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃការជួយជ្រោមជ្រែង និងលើកទឹកចិត្ត"[4092]។ ក៏ប៉ុន្តែ តាមច្បាប់ គេអាចចាត់ទុកថា "មានឯកភាពដោយតុណ្ហីភាព ឬការលើកទឹកចិត្ត"[4093] លុះត្រាតែ ជនជាប់ចោទមានវត្តមានដោយផ្ទាល់ នៅក្បែរ ឬនៅនឹងកន្លែងឧក្រិដ្ឋកម្ម ក្នុងកាលៈទេសៈជាក់លាក់ណាមួយ ក្នុងឋានៈជា "អ្នកមើលដោយនៅស្ងៀម"។ ដូច្នេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានថា ខៀវ សំផន បាន លើកទឹកចិត្តដោយតុណ្ហីភាព ក្នុងខណៈដែលខ្លួនមិនបានបង្ហាញថា ខៀវ សំផន មានវត្តមាននៅកន្លែងប្រព្រឹត្តបទល្មើសមនុស្សឃាត ដោយចេតនាប្រយោល នៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង នៅពេលដែលឧក្រិដ្ឋកម្មទាំងនេះកំពុងតែត្រូវបានប្រព្រឹត្ត។

## ១.២. ការគាំទ្រខាងសីលធម៌ អ្នកឆានាខាងសីលធម៌ និងការលើកទឹកចិត្តយ៉ាងសកម្មដល់កម្មាភិបាល ប.ក.ក

### ១.២.១. ការកោតសរសើរចំពោះការធ្វើការងាររហ័សរហួននៅក្នុង "សុន្ទរកថា ការថ្លែងការណ៍ ការណែនាំ និងសន្និសីទរបស់ ខៀវ សំផន"

[4091] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៣ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[4092] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៣។

[4093] សាលដីកា *Brđanin* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ២៧៧។

២១២៩. ដូចបានឃើញខាងលើ[4094] អង្គជំនុំជម្រះមិនបានផ្តល់សំអាងហេតុគាំទ្រការអះអាងរបស់ខ្លួនដែលថា ការសរសើររបស់ ខៀវ សំផន "លើកទឹកចិត្តដល់កម្មាភិបាលរក្សាល័ក្ខខ័ណ្ឌការងារដែលអនុញ្ញាតឱ្យពួកគេសម្រេចគោលដៅដែលបានកំណត់ដោយបក្ស ដោយមិនមានការព្រួយបារម្ភ ផលវិបាកសម្រាប់កម្មករ-កសិករថ្មី"[4095]។

## ១.២.២. ការចុះទស្សនកិច្ចរបស់ ខៀវ សំផន "នៅតាមសហករណ៍ និងការដ្ឋាន"

២១៣០. ដូចដែលបានឃើញខាងលើ[4096] អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានផ្អែកការចុះធ្វើទស្សនកិច្ចដែលត្រូវបានចោទប្រកាន់ "នៅតាមសហករណ៍ និងការដ្ឋាន" ដើម្បីសន្និដ្ឋានថា "វត្តមានរបស់ ខៀវ សំផន នៅតាមសហករណ៍ និងនៅតាមការដ្ឋាន ផ្តល់ភាពស្របច្បាប់ដល់ការអនុវត្តជាដាច់ខាតនូវគោលនយោបាយឧក្រិដ្ឋ"[4097]។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានប្រើប្រាស់ទស្សនទានមិនមែនច្បាប់នៃពាក្យ "នយោបាយ" ដែលខ្លួនបានកំណត់នៅក្នុងបរិបទនៃការជួយជ្រោមជ្រែង និងការលើកទឹកចិត្ត ថាមានលក្ខណៈ "ឧក្រិដ្ឋ" ដោយគ្មានផ្តល់សំអាងហេតុទាល់តែសោះ។ អង្គជំនុំជម្រះមិនបានបង្ហាញថាដំណើរទស្សនកិច្ចរបស់ម្ចាស់បណ្តឹងសាទុក្ខដែលត្រូវបានចោទប្រកាន់ បានចូលរួមចំណែកក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ។ ដូចខ្លួនធ្លាប់បានទទួលស្គាល់កន្លងមក គឺអង្គជំនុំជម្រះកាន់តែមិនអាចបង្ហាញអំពីការចូលរួមចំណែកនេះទៅទៀត ទាក់ទងនឹងការដ្ឋានត្រពាំងថ្ម ដោយហេតុថាពេលចុះទស្សនកិច្ច អ្នកទទួលខុសត្រូវសហករណ៍ និងការដ្ឋានទាំងអស់ ធ្វើយ៉ាងណាលាក់បាំងបញ្ហាឱ្យជិត[4098]។ មួយវិញទៀត រឿងនេះក៏ត្រូវបានបញ្ជាក់ដោយ សីហានុ ដែលបានអម

[4094] សូមមើលខាងលើ កថាខណ្ឌ ២០២១-២០២២។

[4095] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៤។ ពុំមានការយោងដល់កំណត់សម្គាល់ជើងទំព័រទេ។

[4096] សូមមើលខាងលើ កថាខណ្ឌ ១៨១៦-១៨៤៨។

[4097] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៤ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[4098] សូមមើលសំអាងហេតុសាលក្រម កថាខណ្ឌ ១២៦០។ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ ៤៣០៣៖ "ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ (ញិប ហល់) ឯកសារ **E1/336.1** ទំព័រ ២២-២៣, ២៤ ប្រតិចារឹក ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ (ឈុំ សេង)

ដំណើរលោក ខៀវ សំផន ក្នុងអំឡុងពេលធ្វើដំណើរដ៏កម្រទាំងនេះ ហើយបានផ្តល់សក្ខីកម្មនៅលើកញ្ចក់ទូរទស្សន៍បារាំងថាប្រជាជន "មិនវេទនាទេ មើលទៅ ពួកគេដូចជាមិនមានភ័យតក់ស្លុតអីទេ។ ពួកគេបានទទួលអាហារូបត្ថម្ភមិនខ្វះខាតទេ"[4099]។ HEDER ក៏បានសង្កត់ធ្ងន់លើការដែលថាមានការតំណាលរឿងជាច្រើនទាក់ទងនឹងការរៀបចំបិទបាំងការពិតឱ្យមើលទៅឃើញល្អ សម្រាប់តែឱកាសដែលអ្នកមកពីមជ្ឈិម ឬពីខាងលើ ចុះមកមូលដ្ឋាន"[4100]។

## ១.៣. គ្មានសំអាងហេតុពីផលប៉ះពាល់ខ្លាំងនៅលើការស្លាប់របស់កម្មករដែលធ្វើការនៅក្នុងសហករណ៍

២១៣១. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុ ដោយបានសន្និដ្ឋានដោយគ្មានសំអាងហេតុថា "ការលើកទឹកចិត្ត" និង "ការគាំទ្រខាងសីលធម៌" ដែលផ្តល់ដោយ ខៀវ សំផន "ជះឥទ្ធិពលយ៉ាងខ្លាំងដល់ការស្លាប់កម្មករដែលធ្វើការនៅក្នុងសហករណ៍ និងនៅការដ្ឋាន"[4101]។ មិនមានការបង្ហាញទំនាក់ទំនងហេតុផលណាមួយសោះ។ គ្មានប្រធានសហករណ៍ គ្មានប្រធានអង្គភាព ឬគ្មានអតីតកម្មាភិបាលណាម្នាក់ ដែលត្រូវបានសួរដេញដោលនៅក្នុងសវនាការ បានលើកឡើងពីការលើកទឹកចិត្តពីសំណាក់ ខៀវ សំផន ដែលត្រូវបានចោទប្រកាន់នេះទេ។ បើទោះជា ទំនាក់ទំនងទំនងជាត្រូវបានបង្ហាញក៏ដោយចុះ ក៏ប៉ុន្តែ អង្គជំនុំជម្រះគួរណាពន្យល់ថាតើផលប៉ះពាល់ខ្លាំងនោះស្ថិតនៅត្រង់ណា។ ក្នុងរឿងក្តីនេះ មិនមានសំអាងហេតុទាល់តែសោះលើចំណុចនេះ។

## ២. គ្មានធាតុផ្សំសត្យានុម័តិចំពោះអំពើមនុស្សឃាតនៅមន្ទីរ ស-២១ ត្រាំងតាចាន់ និងភ្នំក្រោល

ឯកសារ **E1/332.1** ទំព័រ ២៨-២៩ (ផ្តល់សក្ខីកម្មថា ពេលសម្ភោធទំនប់ តាវ៉ាល់ បញ្ជា "ឱ្យយកតែអ្នកធាត់ៗ" យកទៅឈរដើម្បីទទួលភ្ញៀវចិន)"។

[4099] ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣ ឯកសារ **E1/234.1** មុនម៉ោង 11.01.53, វីដេអូមានចំណងជើងថា "សម្តេច នរោត្តម សីហនុ លើកឡើងអំពីជីវិតរបស់ព្រះអង្គ ក្នុងរបបខ្មែរក្រហម" ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៧៩ ឯកសារ **E3/2897R**។

[4100] Stephen HEDER៖ ប្រតិចារឹក ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/225.1** ប្រហែលម៉ោង 14.14.48។

[4101] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៥។

២១៣២. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសម្រេចយកការជួយជ្រោមជ្រែង និងលើកទឹកចិត្តជំនួយជាក់ស្តែង (២.១) និងការគាំទ្រខាងសីលធម៌ (២.២) ដល់មជ្ឈិមបក្ស ជាមូលដ្ឋាននៃធាតុផ្សំសត្យានុម័តិនៃការទទួលខុសត្រូវរបស់ ខៀវ សំផន។ អង្គជំនុំជម្រះមិនបានពន្យល់ថាតើអំពើរងការចោទប្រកាន់ទាំងនេះ ជះឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តិអំពើមនុស្សឃាត នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល យ៉ាងដូចម្តេច? (២.៣)។

## ២.១. ជំនួយជាក់ស្តែងដល់មជ្ឈិមបក្ស

២១៣៣. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសម្រេចជាទូទៅថា ខៀវ សំផន បានផ្តល់ "ជំនួយជាក់ស្តែង [...] ដល់មជ្ឈិមបក្សក្នុងការបង្កើត និងអនុវត្តគោលនយោបាយនេះ"[4102]។ អង្គជំនុំជម្រះមិនបានចង្អុលបង្ហាញឯកសារយោងច្បាស់លាស់ជាក់លាក់ ហើយក៏មិនយោងទៅលើកថាខណ្ឌដទៃទៀតនៃសាលក្រមឡើយ។ ទោះយ៉ាងណាក្តី ជំនួយជាក់ស្តែងត្រូវតែចូលរួមចំណែកក្នុងការប្រព្រឹត្តិបទល្មើសមនុស្សឃាតដោយចេតនាប្រយោល មិនមែនចូលរួមចំណែកក្នុងការបង្កើត និងអនុវត្ត "គោលនយោបាយ" នោះទេ។

២១៣៤. អង្គជំនុំជម្រះបានអះអាងនៅក្នុងកថាខណ្ឌមុនថា ខៀវ សំផន បានចូលរួម និងផ្តល់ជាយោបល់ក្នុងកិច្ចប្រជុំរបស់ស្ថាប័នដែលមានសិទ្ធិអំណាចចេញសេចក្តីសម្រេច ដែលក្នុងអំឡុងពេលនោះ មានការពិភាក្សាអំពីជោគវាសនារបស់ខ្មាំង ហើយគាត់បានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ ប.ក.ក"[4103]។ នៅក្នុងកំណត់សម្គាល់ជើងទំព័រ អង្គជំនុំជម្រះគ្រាន់តែយោងទៅផ្នែក "ការដឹងឮ" របស់ ខៀវ សំផន។ ដូច្នេះ អង្គជំនុំជម្រះមិនបានពន្យល់ថាតើអ្វីខ្លះជាអំពើដែលគាត់បានប្រព្រឹត្ត ហើយដែលវាជាជំនួយដល់ការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះ។ វត្តមានរបស់ខៀវ សំផនក្នុងកិច្ចប្រជុំដែលរងការចោទប្រកាន់ ត្រឹមតែប៉ុណ្ណឹងមិនអាចគ្រប់គ្រាន់ទេ ក្នុងការបង្ហាញអំពីជំនួយជាក់ស្តែងដល់ការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់។

[4102] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៧។

[4103] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៦ កំណត់សម្គាល់ជើងទំព័រលេខ ១៤០៣០ យោងដល់កថាខណ្ឌ ៤២២១-៤២៣៤។

## ២.២. ការគាំទ្រខាងសីលធម៌ដល់មជ្ឈិមបក្ស

២១៣៥. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានផ្អែកលើការសន្និដ្ឋានរបស់ខ្លួនដែលថា ខៀវ សំផន ទំនងជាបាន "គាំទ្រខាងសីលធម៌ដល់មជ្ឈិមបក្ស ក្នុងការបង្កើត និងអនុវត្តគោលនយោបាយនេះ"[4104]។ មិនមានឯកសារយោង កំណត់សម្គាល់ជើងទំព័រ ឬការពន្យល់ណាមួយដើម្បីគាំទ្រដល់ការសន្និដ្ឋាននេះឡើយ។ គ្រាន់តែលើកឡើងអំពីវត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំ មិនអាចអនុញ្ញាតឱ្យសន្និដ្ឋានថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ តាមផ្លូវច្បាប់ ថាមានការគាំទ្រខាងផ្លូវសីលធម៌ ដែលជាមូលដ្ឋាននៃការទទួលខុសត្រូវ ចំពោះជំនួយ និងការលើកទឹកចិត្តឡើយ។ ជាថ្មីម្តងទៀត ការគាំទ្រខាងផ្លូវសីលធម៌ត្រូវតែចូលរួមចំណែកក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ គឺមិនមែនជាការគាំទ្រជាទូទៅ ដល់ "គោលនយោបាយ" នោះទេ។

## ២.៣. គ្មានសំអាងហេតុពីការជះឥទ្ធិពលខ្លាំងទៅលើការប្រព្រឹត្តិអំពើមនុស្សឃាតដោយចេតនាប្រយោល

២១៣៦. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានដោយគ្មានសំអាងហេតុថា "ជំនួយជាក់ស្តែង [...] ដល់មជ្ឈិមបក្ស" និង"ការគាំទ្រខាងផ្លូវសីលធម៌ដល់មជ្ឈិមបក្ស" ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការប្រព្រឹត្តិបទឧក្រិដ្ឋដោយកម្មាភិបាល ប.ក.ក"[4105]។ គ្មានទំនាក់ទំនងណាត្រូវបានបង្កើតឡើងរវាង ខៀវ សំផន និងកម្មាភិបាលនៃ ប.ក.ក ដែលជាអ្នកប្រព្រឹត្តអំពើមនុស្សឃាតដោយចេតនាប្រយោល នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល។ បើទោះជាអាចមានការបង្ហាញទំនាក់ទំនងណាមួយក៏ដោយចុះ ក៏អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសដែរ ដោយហេតុខកខានមិនបានបង្ហាញថាតើការជះឥទ្ធិពលនេះបានបំពេញតាមលក្ខខ័ណ្ឌតម្រូវចាំបាច់នៃបទល្មើសយ៉ាងដូចម្តេច ហើយដែលលក្ខខ័ណ្ឌនេះតម្រូវឱ្យមានការជះឥទ្ធិពលខ្លាំងទៅលើការប្រព្រឹត្តិបទឧក្រិដ្ឋនេះ។

---

[4104] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៧។

[4105] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៧។

## ជំពូកទី ៣. កំហុសពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តិ

## ១. គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាប្រយោល នៅត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង

២១៣៧. ធាតុផ្សំអត្តនោម័តិនៃទំនួលខុសត្រូវ ចំពោះការជួយជ្រោមជ្រែង និងការលើកទឹកចិត្តមិនបានបំពេញលក្ខខ័ណ្ឌតម្រូវចាំបាច់នោះទេ ពីព្រោះមិនមានភស្តុតាងខ្ពស់ស្មើនឹងលក្ខខ័ណ្ឌតម្រូវដែលបញ្ជាក់ថា ខៀវ សំផន អាចព្យាករណ៍បានថាកំហិតដែលបានដាក់ទៅលើសហករណ៍ និងការដ្ឋាន នឹងបណ្តាលឱ្យមានមនុស្សស្លាប់ ហើយអង្គជំនុំជម្រះក៏មិនបានផ្តល់សំអាងហេតុណាមួយដើម្បីគាំទ្រដល់ការសន្និដ្ឋានថា ខៀវ សំផន ដឹងឮគ្រប់ពេលវេលា អំពីធាតុផ្សំសំខាន់ៗនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តដោយចារីផ្ទាល់។

២១៣៨. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្អែកលើការសន្និដ្ឋាននានាក្នុងផ្នែក ១៨.១.១ នៃសំអាងហេតុសាលក្រម[4106]។ ដូចដែលបានឃើញខាងលើ គឺមិនមានភស្តុតាងណាមួយដើម្បីគាំទ្រដល់ការសន្និដ្ឋានថាលោក ខៀវ សំផន អាចព្យាករណ៍បានថាលក្ខខ័ណ្ឌដែលដាក់ទៅលើ សហករណ៍ និងការដ្ឋាន នឹងបណ្តាលឱ្យមានមនុស្សស្លាប់ឡើយ[4107]។

២១៣៩. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ ដោយបានសន្និដ្ឋានគ្មានសំអាងហេតុថា ខៀវ សំផន "បានដឹងគ្រប់ពេលវេលាអំពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយចារីផ្ទាល់"[4108]។ ផ្ទុយទៅវិញ មិនមានភស្តុតាងផ្ទាល់ ឬប្រយោល គាំទ្រការអះអាងនេះ ក្នុងកម្រិតនៃលក្ខខ័ណ្ឌតម្រូវចាំបាច់នោះទេ។

---

[4106] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៥ កំណត់សម្គាល់ជើងទំព័រលេខ ១៤០២៨ យោងដល់ផ្នែក ១៨.១.១។

[4107] សូមមើលខាងលើ កថាខណ្ឌ ១៨០៨-១៨១០។

[4108] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៥។

## ២. គ្មានធាតុផ្សំអត្តនោម័តិចំពោះអំពើមនុស្សឃាតដោយចេតនាប្រយោល នៅមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល

២១៩០. អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានផ្អែកលើការសន្និដ្ឋានខុសដែលថា ខៀវ សំផន បានដឹងថាបទល្មើសអំពើមនុស្សឃាតដោយចេតនាប្រយោលត្រូវបានប្រព្រឹត្ត នៅ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល។ ជាបឋម អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានរំឭកអំពីការសន្និដ្ឋានខុសរបស់ខ្លួនទាក់ទងនឹងការដឹងឮរបស់ ខៀវ សំផន អំពីការបោសសម្អាតផ្សេងៗ ហើយដែលការដឹងឮនេះរងការចោទប្រកាន់[4109]។ បន្ទាប់មក អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គហេតុ ដោយបានផ្អែកលើការសន្និដ្ឋាននានានៅក្នុងផ្នែក ១៨.១.១ នៃសំអាងហេតុរបស់សាលក្រម[4110]។ ដូចដែលបានឃើញខាងលើ មិនមានភស្តុតាងណាមួយដើម្បីគាំទ្រដល់ការសន្និដ្ឋានថាលោក ខៀវ សំផនអាចព្យាករណ៍បានថាការអនុវត្តទាក់ទងនឹងការប្រព្រឹត្តិចំពោះខ្មាំងនឹងបណ្តាលឱ្យមានមនុស្សស្លាប់ នៅតាមមន្ទីរសន្តិសុខនោះទេ[4111]។ ទីបំផុត អង្គជំនុំជម្រះបានប្រព្រឹត្តកំហុស ដោយបានសន្និដ្ឋានគ្មានសំអាងហេតុថា ខៀវ សំផន "ដឹងគ្រប់ពេលវេលាអំពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយចារីផ្ទាល់"[4112]។ ផ្ទុយទៅវិញ មិនមានភស្តុតាងផ្ទាល់ ឬប្រយោល គាំទ្រការអះអាងនេះ ក្នុងកម្រិតនៃល័ក្ខខ័ណ្ឌតម្រូវចាំបាច់នោះទេ។ ដូច្នេះ មិនមានទាំងធាតុផ្សំសត្យានុម័តិ ទាំងធាតុផ្សំអត្តនោម័តិនៃការជួយជ្រោមជ្រែង និងការលើកទឹកចិត្តឡើយទាក់ទងនឹងអង្គហេតុទាំងនេះ។ អង្គជំនុំជម្រះប្រព្រឹត្តកំហុស បើខ្លួនសន្និដ្ឋានខុសពីនេះ។ ដូច្នេះ ខៀវ សំផន ត្រូវតែត្រូវបានលើកលែងទោសពីបទមនុស្សឃាតដោយចេតនាប្រយោលដែលត្រូវបានចោទប្រកាន់ចំពោះអង្គហេតុនៅ ត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម និងព្រលានយន្តហោះកំពង់ឆ្នាំង និងមន្ទីរ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល[4113]។

[4109] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៦ កំណត់សម្គាល់ជើងទំព័រលេខ ១៤០២៩ យោងដល់ផ្នែក ១៨.១.២.២។ សូមមើលខាងលើផងដែរ កថាខណ្ឌ ១៨៥៧-១៨៧៨។

[4110] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៥ កំណត់សម្គាល់ជើងទំព័រលេខ ១៤០២៨ យោងដល់ផ្នែក ១៨.១.១។

[4111] សូមមើលខាងលើ កថាខណ្ឌ ១៨០៨-១៨១៥ ("ការដឹងថាឧក្រិដ្ឋកម្មនឹងត្រូវប្រព្រឹត្ត")។

[4112] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៧។

[4113] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣១៥, ៤៣១៨ និង ៤៣២៨។

## សេចក្តីសន្និដ្ឋានសរុប

២១៤១. ទំហំ និងចំនួនទំព័រនៃសំអាងហេតុសាលក្រមសំណុំរឿង ០០២/០២ មិនបានបញ្ជាក់ពីភាពរឹងមាំនៃសំអាងហេតុសាលក្រមដ៏វែងអន្លាយនេះទេ។ ពីទំព័រមួយទៅទំព័រមួយ មានកំហុសអង្គច្បាប់ និងអង្គហេតុរដែរដឹក ដែលធ្វើឱ្យការសន្និដ្ឋានទាំងអស់ក្លាយជាមោឃៈ។ បន្ថែមលើកំហុសដំបូងទាក់ទងនឹងការប្រកាសសាលក្រម អង្គជំនុំជម្រះពិតជាបានប្រព្រឹត្តកំហុសអង្គច្បាប់ជាច្រើន ទាក់ទងនឹងវិសាលភាពនៃបណ្តឹង គោលការណ៍នីត្យានុកូលភាព ការធានាឱ្យបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ កំហុសអង្គហេតុ និងអង្គច្បាប់ចំពោះធាតុផ្សំចាំបាច់ នៃបទឧក្រិដ្ឋ និងគោលនយោបាយដែលត្រូវបានចោទប្រកាន់។ វិធីសាស្ត្រលម្អៀងរបស់អង្គជំនុំជម្រះក្នុងការបកស្រាយច្បាប់ និងពិនិត្យភ័ស្តុតាង ការសន្និដ្ឋានទាំងអស់របស់ខ្លួនលើការទទួលខុសត្រូវ ក្លាយជាមោឃៈ។ ឧទាហរណ៍ដ៏ល្អឥតខ្ចោះដើម្បីឆ្លុះបញ្ចាំងពីវិធីសាស្ត្រខុសរបស់អង្គជំនុំជម្រះ ក្នុងផ្នែកសំអាងហេតុទាំងមូលតែម្តង គឺកំហុសអង្គច្បាប់ទាក់ទងនឹងការផ្តន្ទាទោសលោកខៀវ សំផន ចំពោះការសម្លាប់រង្គាល នៅភ្នំក្រោល ក្នុងខណៈដែលខ្លួនឯងផ្ទាល់បានពិចារណាថា "បទល្មើសនេះមិនត្រូវបានបង្ហាញថាពិតជាបានកើតឡើងទេ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខនេះ"[4114]។ ការសន្និដ្ឋាននេះរបស់អង្គជំនុំជម្រះគ្មានជម្រើសអ្វីក្រៅពីត្រូវបានចាត់ទុកជាមោឃៈដូចការសន្និដ្ឋានដទៃទៀតនោះទេ។

២១៤២. នៅចុងបញ្ចប់ អង្គជំនុំជម្រះបានយល់ច្រឡំជាទូទៅលើតួនាទីរបស់ម្ចាស់បណ្តឹងសាទុក្ខ និងការសន្និដ្ឋានដែលខ្លួនបានទាញ។ ជាការពិត អង្គជំនុំជម្រះមិនបានបង្ហាញពីការចូលរួមដ៏សំខាន់ ក្នុងសហឧក្រិដ្ឋកម្មរួមដែលមានគោលបំណងប្រព្រឹត្តឧកក្រិដ្ឋកម្ម ហើយក៏មិនបានបង្ហាញថាគាត់បានជួយ និងលើកទឹកចិត្តឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនោះដែរ[4115]។

---

[4114] សំអាងហេតុសាលក្រម កថាខណ្ឌ ៣១១៨ រួច ៤៣០៦ និង ៤៣៤១។ បន្ទាប់មកទៀត អង្គជំនុំជម្រះបានបូកបញ្ចូលដោយមិនត្រឹមត្រូវនូវសេចក្តីប្រកាសពិរុទ្ធភាពនេះជាមួយសេចក្តីប្រកាសពិរុទ្ធភាពផ្សេងទៀត នៅកថាខណ្ឌ ៤៣៣៧។

[4115] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣០៦-៤៣០៧, ៤៣១១, ៤៣១៣-៤៣១៨, ៤៣២៦-៤៣២៨។

២១៤៣. **អាស្រ័យហេតុនេះ** សូមតុលាការកំពូលមេត្តាអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ កែតម្រូវសំអាងហេតុសាក្រមទាំងស្រុង ហើយសម្រេចឱ្យ ខៀវ សំផន រួចផុតពីទោសតែម្តង ចំពោះអង្គហេតុដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២។

## ជាសំណើបន្ទាប់បន្សំបំផុត

២១៤៤. ក្នុងករណីអភូតហេតុអស្ចារ្យ បើអង្គជំនុំជម្រះតុលាការកំពូលតម្កល់ការផ្តន្ទាទោស ខៀវ សំផន ក្នុងបណ្តឹងសាទុក្ខនេះ ខ្លួនមិនអាចសម្រេចផ្តន្ទាទោសគាត់ឱ្យជាប់ពន្ធនាគារអស់មួយជីវិតបានទេ ហើយគួរតែអនុវត្តយ៉ាងម៉ត់ចត់បំផុតក្នុងការកំណត់បរិមាណទោស។

### ១. ការបង្ហាញអំពីភាពលម្អៀងទាក់ទងនឹងគោលដៅនៃការដាក់ទោស

២១៤៥. យោងតាមយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី "ក្នុងការកំណត់ទោស និងសម្រេចដាក់ទោសមួយដែលត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងមួយត្រូវតែពិចារណាលើតួនាទីនៃទោសនេះនៅថ្ងៃអនាគត"[4116]។ យុត្តិសាស្ត្រនេះនៅតែ "ជាធរមាន ហើយទទួលស្គាល់គោលបំណងសំខាន់ៗពីរនៃការផ្តន្ទាទោស គឺការដាក់ទោសស្មើនឹងកម្រិតបទល្មើសដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះតាមផ្លូវច្បាប់ និងការធ្វើឱ្យញញើត"[4117]។ មាន "គោលបំណងបន្ទាប់បន្សំពីរទៀត ដូចជាការផ្តន្ទាទោសជាសាធារណៈ ការពន្យល់ដល់ជនជាប់ចោទ ជនរងគ្រោះ សាធារណជនឱ្យយល់ថាច្បាប់ត្រូវបានអនុវត្ត ទីមួយ និង ទីពីរ គឺការកែប្រែឱ្យប្រសើរ"[4118]។ រីឯក្នុងរឿងក្តីយើងនេះ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់នូវអ្វីដែលខ្លួនចាត់ទុកថាជាកាតព្វកិច្ចចម្បងរបស់ខ្លួន គឺ "ដើម្បី

---

[4116] សាលក្រម *Prlić និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១២៧៤ (ភាគ ៤)។

[4117] សាលក្រម *Prlić និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១២៧៥ (ភាគ ៤)។

[4118] សាលក្រម *Prlić និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៣ កំណត់សម្គាល់ជើងទំព័រលេខ ២៣៧៥ (នៃកថាខណ្ឌ ១២៧៥ ភាគ ៤)។

បង្ហាញដល់ជនរងគ្រោះដែលនៅរស់រានមានជីវិត ដល់ក្រុមគ្រួសារពួកគេ ដល់សាក្សី និងសាធារណជនទូទៅ ថាការផ្តន្ទាទោសត្រូវបានធ្វើ អនុលោមតាមច្បាប់”[4119]។

២១៤៦. របៀបពិចារណានេះ ជារោគសញ្ញានៃភាពលម្អៀងរបស់អង្គជំនុំជម្រះដែលបានតាំងខ្លួនជាអ្នកជ្រោងទង់ដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនខ្វល់ពីការអនុវត្តនីតិព្រហ្មទណ្ឌឱ្យបានត្រឹមត្រូវ ដើម្បីជនជាប់ចោទដែលជាតួអង្គដ៏សំខាន់នៅក្នុងការជំនុំជម្រះ។ ដូច្នេះ គោលបំណងបន្ទាប់បន្សំនៃការទប់ស្កាត់ជាទូទៅ បែរក្លាយជាមូលដ្ឋានគ្រឹះនៃការពិចារណារបស់ខ្លួន ដោយមើលរំលងគោលការដ៏សំខាន់បំផុតនៃការដាក់ទោសស្មើនឹងកម្រិតបទល្មើសដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះ[4120]។។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានកត់សម្គាល់ “ខុសពីការសងសឹក [ការដាក់ទោសស្មើនឹងកម្រិតបទល្មើសដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះ] បង្កប់នូវគោលការណ៍មិនជ្រុលនិយមមួយ ពោលគឺតម្រូវឱ្យមានការអនុវត្តគោលការណ៍ស្តីពីការផ្តន្ទាទោសឱ្យត្រឹមត្រូវ និងសមរម្យ គឺមិនតម្រូវអ្វីលើសពីហ្នឹងទេ”។ (គូសបន្ទាត់ពីក្រោម ក្នុងឯកសារដើម)[4121]។

២១៤៧. នៅក្នុងរបាយការណ៍ឆ្នាំ១៩៨៧ គណៈកម្មការកាណាដាទទួលបន្ទុកការកំណត់ទោស ក៏បានសង្កត់ធ្ងន់ផងដែរថា យោងទៅតាមគោលការណ៍ដាក់ទោសធ្ងន់ធ្ងរ៖

---

[4119] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៤៨។

[4120] សាលក្រម *D. Nikolić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ១៣២, សាលដីកា *Kordić និង Čerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១០៧៤ យោងដល់សាលដីកា *Delalić និងបក្ខពួក* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៨០៦។

[4121] សាលដីកា *Kordić និង Čerkez* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១០៧៥ យោងដល់សាលដីកា R. c. M. (C.A), 1 SCR 500 របស់តុលាការកំពូលកាណាដា ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៦ កថាខណ្ឌ ៨០, សាលក្រម *D. Nikolić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ១៤០។

"រាល់សេចក្តីសម្រេចផ្តន្ទាទោសគំរូ (មានន័យថាការដាក់ទណ្ឌកម្មធ្ងន់ជាងកម្រិតបទល្មើសទៅលើជនល្មើស ដើម្បីធ្វើជាគំរូដល់សេចក្តីសម្រេចដទៃទៀត) មិនមានយុត្តិកម្មគាំទ្រទេ ពីព្រោះសេចក្តីសម្រេចទាំងនេះបង្កប់ន័យថាការធ្វើឱ្យជនល្មើសឈឺចាប់រងទុក្ខ អាចត្រូវបានប្រើជាមធ្យោបាយ ឬជាធនធាន ដើម្បីធ្វើឱ្យជនល្មើស សក្តានុពលក្រែងញញើត"[4122]។

២១៤៨. អង្គជំនុំជម្រះបានធ្លាក់ទៅក្នុងភាពជ្រុលនិយមនេះ ដោយបានផ្តន្ទាទោស ខៀវ សំផន លើសពីទំនួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់។ ក្នុងឋានៈខ្លួនជាអ្នកវាយតម្លៃកម្រិតទោស ដោយឯករាជ្យ អង្គជំនុំជម្រះបែរជាយកឆន្ទានុសិទ្ធិជាអំណាចសម្រេចតាមទំនើងចិត្ត ដែលបង្កព្យសនកម្មដល់ ខៀវ សំផន[4123]។ អាស្រ័យហេតុនេះ តុលាការកំពូលត្រូវតែសម្រាលទោសគាត់។

## ២. កំហុសលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត

## ២.១. កំហុសចេញពីការពិចារណាអំពីភស្តុតាងនៅក្រៅវិសាលភាព

២១៤៩. អង្គជំនុំជម្រះបានលើកឡើងពីកត្តា "ដែលខ្លួនចាត់ទុកថាមានភាពពាក់ព័ន្ធដើម្បីកំណត់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត" ដែលក្នុងចំណោមកត្តាទាំងនេះ មានការពិចារណាទាំងមូលអំពីផលប៉ះពាល់នៃអង្គហេតុពាក់ព័ន្ធទៅលើជនរងគ្រោះ[4124]។ ដោយមូលហេតុនេះ អង្គជំនុំជម្រះបានគិតពិចារណាអំពីការរំលោភសេពសន្ថវៈលើអ្នកទោសនៅក្នុងមន្ទីរសន្តិសុខ[4125]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេត បានសម្រេចយ៉ាងច្បាស់ថាមិនបញ្ជូនជនជាប់ចោទទៅជំនុំជម្រះពីបទរំលោភសេពសន្ថវៈ ដែលត្រូវបានប្រព្រឹត្តនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ ដោយមូលហេតុថា៖

---

[4122] របាយការណ៍របស់គណៈកម្មការកាណាដាស្តីពីការកំណត់ទោស *កែប្រែការផ្តន្ទាទោស៖ វិធីសាស្ត្រកាណាដា* ចុះខែកុម្ភៈ ឆ្នាំ ១៩៨៧ ទំព័រ ១៤៦, ១៤៧ ដែលត្រូវបានដកស្រង់នៅក្នុងសាលដីកា R. c. M. (C.A), 1 SCR 500 របស់តុលាការកំពូលកាណាដា ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៦ កថាខណ្ឌ ៧៨។

[4123] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៤៧ និងកថាខណ្ឌបន្តបន្ទាប់។

[4124] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៦១។

[4125] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៦៥។

"គោលនយោបាយផ្លូវការរបស់ ប.ក.ក ស្តីពីការរំលោភសេពសន្ថវៈ មានគោលបំណងទប់ស្កាត់បទឧក្រិដ្ឋ នេះ និងផ្តន្ទាទោសជនល្មើស។ ទោះបីជា ដោយជាក់ស្បាន់ គោលនយោបាយនេះមិនអាចឈានទៅទប់ស្កាត់ការរំលោភសេពសន្ថវៈក៏ដោយ ក៏គេមិនអាចចាត់ទុកថា ការរំលោភសេពសន្ថវៈជាបទឧក្រិដ្ឋមួយដែលបានប្រើប្រាស់ដោយមេដឹកនាំ ប.ក.ក ដើម្បីអនុវត្តគោលបំណងរួមបានដែរ"[4126]។

២១៥០. ដូច្នេះ ចំពោះអង្គហេតុនៃការរំលោភសេពសន្ថវៈទាំងនេះ ជនជាប់ចោទទាំងអស់សុទ្ធតែបានទទួលសេចក្តីសម្រេចលើកលែងការចោទប្រកាន់ ដែលបានក្លាយជាអាជ្ញាអស់ជំនុំរួចហើយ[4127]។ លើសពីនេះទៀត អង្គជំនុំជម្រះបានទទួលស្គាល់ម្តងហើយម្តងទៀតនៅក្នុងឆ្នាំ២០១៤ ឆ្នាំ២០១៥ ឆ្នាំ២០១៦ និងឆ្នាំ២០១៩ នៅក្នុងសំអាងហេតុសាលក្រម ថា ខ្លួនមិនបានទទួលបណ្តឹងជាក់ស្តែងពីអង្គហេតុទាំងនេះ នោះទេ[4128]។ លើសពីនេះទៀត អង្គជំនុំជម្រះបានរំឭកថា ដើម្បីកំណត់ទោសឱ្យបានសមស្របទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តត្រូវ "គិតគូរពីកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ ក៏ដូចជា អំពី [ទម្រង់] និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទក្នុងបទល្មើសនេះ"[4129]។ ទោះជាយ៉ាងនេះក្តី ដោយចាត់ទុកការរំលោភសេពសន្ថវៈនៅតាមមន្ទីរសន្តិសុខជាអង្គហេតុដែលត្រូវបានបង្ហាញ និងជាភ័ស្តុតាងបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដើម្បីកំណត់ទោស ខៀវ សំផន[4130] អង្គជំនុំជម្រះបានចាប់ តាមព្រឹត្តន័យ ឱ្យ ខៀវ សំផន ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលគាត់មិនដែលត្រូវបានចោទប្រកាន់។

---

4126 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៩។

4127 សារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ កថាខណ្ឌ ១៧៤-១៧៥។

4128 អនុស្សរណៈ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ៣, សេចក្តីសម្រេច ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ E348/4 កថាខណ្ឌ ១១, សេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ឯកសារ E306/7/3 កថាខណ្ឌ ១៧-១៩, សំអាងហេតុសាលក្រម កថាខណ្ឌ ១៨៧-១៨៨។

4129 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៤៩។

4130 សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៦១។

២១៥១. ទោះយ៉ាងណាក្តី ដូចអ្វីដែលធ្លាប់បានរំលឹក គឺថា "មានគោលការណ៍ទូទៅមួយដែលតម្រូវឱ្យចៅក្រមពិចារណាប្រឆាំងនឹងជនជាប់ចោទ ក្នុងគោលបំណងកំណត់ទោស តែចំពោះការចោទប្រកាន់ណាដែលត្រូវបានបង្ហាញហួសពីវិមតិសង្ស័យតែប៉ុណ្ណោះ"[4131]។ សំខាន់ជាងនេះទៀត ចៅក្រមអាចពិចារណាប្រឆាំងនឹងជនជាប់ចោទ តែចំពោះអ្វីដែលត្រូវបានចោទប្រកាន់លើគាត់ប៉ុណ្ណោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសមួយដែលធ្វើឱ្យសាលក្រមមិនមានសុពលភាព។ ដូច្នេះ ខៀវ សំផន ត្រូវតែទទួលបានការកាត់បន្ថយទោស។

## ២.២. កំហុសលើតួនាទីរបស់ ខៀវ សំផន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម

២១៥២. អង្គជំនុំជម្រះបានវាយតម្លៃភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដោយផ្អែកលើមូលដ្ឋាននៃការសន្និដ្ឋានខុសដែលថា "តួនាទីរបស់ ខៀវ សំផន នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម មានទំហំធំធេង និងមានឥទ្ធិពលខ្លាំងក្លា"[4132]។ អង្គជំនុំជម្រះបានផ្អែកលើធាតុផ្សំភ័ស្តុតាង ទាក់ទងនឹងខ្លឹមសារជាក់លាក់នៃការចូលរួមតាមសន្មតរបស់គាត់ ដោយមិនគិតពីទម្រង់ និងកម្រិតនៃការចូលរួមនេះ ដែលខុសពីអ្វីដែលខ្លួនបានរំឭក និងអ្វីដែលណែនាំឱ្យអនុវត្តដោយយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[4133]។ ជាការពិត តាមការអនុវត្តរបស់ចៅក្រមនៃតុលាការនេះ ជាទូទៅ ទម្រង់នៃការចូលរួមបន្ទាប់បន្សំ ឬដោយប្រយោលបណ្តាលឱ្យមានការដាក់ទណ្ឌកម្មមិនសូវធ្ងន់[4134]។

---

[4131] ឧទាហរណ៍៖ សាលក្រម *Muhimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ កថាខណ្ឌ ៥៩០។

[4132] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨៥។

[4133] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨៩, សាលដីកា *Aleksovski* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ១៨២ យោងដល់សាលក្រម *Kupreškić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៨៥២៖ "ដើម្បីកំណត់ភាពធ្ងន់ធ្ងរនេះ តុលាការត្រូវពិចារណាដល់កាលៈទេសៈពិសេសនៃរឿងក្តី ព្រមទាំងទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទក្នុងបទល្មើសនោះ" (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម), សាលក្រម *Ntaganda* ស្តីពីទោស (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ ១៦។

[4134] សាលដីកា *Gacumbitsi* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ២០១, សាលក្រម *Semanza* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៥៦២-៥៦៣, សាលក្រម *Ntagerura និងអ្នកឯទៀត* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤

២១៥៣. ឧទាហរណ៍ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ចៅក្រមបានដាក់ទោសខុសគ្នាលើជនជាប់ចោទទាំងពីរ ដោយហេតុតែការចូលរួមរបស់ពួកគេក្នុងឧក្រិដ្ឋកម្មមិនដូចគ្នា។ Gérard NTAKIRUTIMANA ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល២៥ឆ្នាំ ពីបទចូលរួមដោយផ្ទាល់ក្នុងការអនុវត្តអំពើប្រល័យពូជសាសន៍ ក្នុងខណៈដែល Elizaphan NTAKIRUTIMANA ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល១០ឆ្នាំ ពីបទជួយ និងលើកទឹកចិត្តអ្នកដទៃឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ពីព្រោះតុលាការបានពិចារណាអំពីវ័យចាស់ជរា និងចរិតល្អរបស់គាត់មុនពេលអង្គហេតុបានកើតឡើង[4135]។

២១៥៤. ក្នុងសាលក្រម *Mucić* ក្នុងឆ្នាំ១៩៩៨ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី៖ "បានគិតពីការដែលថាគ្មានសាក្សីណាម្នាក់បានចង្អុលបង្ហាញថា ជនជាប់ចោទបានចូលរួមយ៉ាងសកម្មក្នុងអំពើមនុស្សឃាត ឬការធ្វើទារុណកម្មណាមួយ ដែលជាការទទួលខុសត្រូវរបស់គាត់ក្នុងឋានៈជាមេ"[4136]។ យុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ក៏បានទទួលស្គាល់ផងដែរថា "ការចូលរួមដោយប្រយោលនៅក្នុងឧក្រិដ្ឋកម្ម អាចបង្កើតជាស្ថានសម្រាលទោស" ពីព្រោះវាមិនធ្ងន់ធ្ងរដល់ [...] ការប្រព្រឹត្តិបទឧក្រិដ្ឋក្នុងឋានៈជាចារីបង្គោល"[4137]។ លើសពីនេះទៀត នៅក្នុងសាលក្រម *Aleksovski* អង្គជំនុំជម្រះបានចង្អុលបង្ហាញថា

---

កថាខណ្ឌ ៨១៣, សាលក្រម *Muhimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥ កថាខណ្ឌ ៥៩៣, សាលក្រម *Kalimanzira* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ៧៤៤។

[4135] សាលក្រម *Ntakirutimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៨៩៤-៩១៦ (កថាខណ្ឌ ៨៩៧៖ "Élizaphan Ntakirutimana មិនមានតួនាទីសំខាន់ទេ ក្នុងពេលវាយប្រហារ។ គាត់មិនបានចូលរួមដោយផ្ទាល់ក្នុងការសម្លាប់រង្គាលនោះទេ ហើយអង្គជំនុំជម្រះមិនបានរកឃើញថា គាត់បានបាញ់ទៅលើជនភៀសខ្លួន ឬគាត់បានកាន់អាវុធនោះឡើយ")។

[4136] សាលក្រម *Mucić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ ១២៤៨ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[4137] សាលក្រម *Krstić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៧១៤។

ទោះបីជាគាត់មានឋានៈជាចារីផ្ទាល់ក៏ដោយ ក៏ជនជាប់ចោទបានចូលរួមក្នុងកម្រិតតិចតួច ក្នុងអំពើហិង្សាដែលត្រូវបានចោទប្រកាន់លើគាត់។ ហេតុដូចនេះ អង្គជំនុំជម្រះបានផ្តន្ទាទោសគាត់ឱ្យជាប់ពន្ធនាគារ ២ ឆ្នាំ ៦ ខែ[4138]។

២១៥៥. ក្នុងរឿងក្តីយើងនេះ អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ថា ខៀវ សំផន បាន "លើកទឹកចិត្ត និងគាំទ្រដល់ខ្មែរក្រហម" ហេតុនេះហើយបានជាគាត់ត្រូវបានផ្តន្ទាទោសពីបទបានជួយជ្រោមជ្រែង និងលើកទឹកចិត្ត[4139]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានគូសបញ្ជាក់អំពីលក្ខណៈប្រយោលនៃទម្រង់នៃការចូលរួមនេះទេ ហើយក៏មិនបានទាញការសន្និដ្ឋានចាំបាច់ពីលក្ខណៈនេះ ក្នុងការកំណត់បរិមាណទោសដែរ។ លើសពីនេះទៀត អង្គជំនុំជម្រះបានសន្និដ្ឋានថា ខៀវ សំផន "បានចូលរួមក្នុងគោលបំណងរួម" និង "បានអះអាង ការពារ និងអនុម័តមាគ៌ាបក្ស" ដោយមិនគិតពីកម្រិតនៃការចូលរួមចំណែករបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម[4140]។

២១៥៦. ទីបំផុត ការវិភាគពីប្រកាសទោសនៅក្រុង Nuremberg បង្ហាញថា ការដាក់ទោស ខៀវ សំផន ធ្ងន់ធ្ងរហួសពេក។ នៅចំពោះមុខតុលាការយោធាអន្តរជាតិ មានតែអ្នកដែលមានតួនាទី និងទំនួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះដែលត្រូវបានផ្តន្ទាទោសឱ្យជាប់ទោសជាអតិបរមា[4141]។ ករណីជនជាប់ចោទឈ្មោះ Funk ជាឧទាហរណ៍ដ៏ល្អ។ គាត់ត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គាត់បានពន្យល់ជាសាធារណៈអំពីការរើសអើងលើជនជាតិជ្វីប និងបានប្រាប់ថា គាត់ជាសមាជិកនៃអង្គភាពមួយដែលបញ្ជាឱ្យគេផ្តល់កម្លាំងពលកម្ម ដោយនិរទេសពួកកាន់សាសនាជ្វីវទៅធ្វើកាងារដោយបង្ខំ។ ក៏ប៉ុន្តែ គាត់មិនមានតួនាទីដែលមានឥទ្ធិពល ក្នុងកម្មវិធីផ្សេងៗដែលគាត់បានចូលរួមនោះទេ។ ទាំងនេះជាមូលហេតុដែលនាំឱ្យតុលាការយោធាដាក់ទោសគាត់ទាន់ពេលវេលា ស្របតាមទំហំនៃតួនាទីរបស់គាត់។ គួរជាគំរូ ទោះជាប្រឈមមុខនឹងឧក្រិដ្ឋកម្មដ៏

---

[4138] សាលក្រម *Aleksovski* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ កថាខណ្ឌ ២៣៦, ២៤៤។

[4139] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨២។

[4140] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨២, ៤៣៨៣។

[4141] ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមធំៗ តុលាការយោធាអន្តរជាតិទីក្រុង Nuremberg ឆ្នាំ១៩៤៧។

អាក្រក់បំផុតចំពោះមនុស្សជាតិក៏ដោយ ក៏ចៅក្រមនៅទីក្រុង Nuremberg មិនដែលងាកចេញពីកាតព្វកិច្ចក្នុងការដាក់ទោសឱ្យសមមាត្រនឹងការចូលរួមរបស់ជនជាប់ចោទក្នុងឧក្រិដ្ឋកម្មនោះឡើយ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវតែគោរពគោលការណ៍នេះដែរ។

២១៥៧. ដូច្នេះ អង្គជំនុំជម្រះបរាជ័យក្នុងវាយតម្លៃលើកត្តាពាក់ព័ន្ធទាំងអស់ ដើម្បីកំណត់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។ ទោសដែលដាក់លើ ខៀវ សំផន មិនសមាមាត្រនឹងការចូលរួមចំណែករបស់គាត់។ ដូច្នេះ ត្រូវតែសម្រាលទោសគាត់ឱ្យបានទាន់ពេលវេលា។

## ៣. កំហុសពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស

### ៣.១. កំហុសចំពោះការរំលោភបំពានមុខតំណែងមានអំណាច និងឥទ្ធិពល

២១៥៨. អង្គជំនុំជម្រះបានអះអាងថា ខៀវ សំផន បានរំលោភបំពានមុខតំណែងមានអំណាច និងឥទ្ធិពលរបស់ខ្លួន ដោយបានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងការអនុវត្តមុខងារផ្លូវការរបស់គាត់ ហើយបានដាក់ស្ថានទម្ងន់ទោសលើ ខៀវ សំផន ដោយផ្អែកលើមូលដ្ឋាននេះ[4142]។ ទោះយ៉ាងនេះក្តី អង្គជំនុំជម្រះបានគូសបញ្ជាក់ជាច្រើនដងអំពីអវត្តមាននៃអំណាចជាក់ស្តែងរបស់ ខៀវ សំផន។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា ខៀវ សំផន "មិនមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការចេញបញ្ជាដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះទេ"[4143] "គាត់មិនមានទំនួលខុសត្រូវ ឬអំណាចយោធាឡើយក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[4144] និងថែមទាំងបានបញ្ជាក់ថា គាត់មានតែតួនាទីជានិមិត្តរូបនៅក្នុងក្របខ័ណ្ឌនៃមុខតំណែងរបស់គាត់ជាប្រធាននៃគណៈប្រធានរដ្ឋតែប៉ុណ្ណោះ[4145]។

២១៥៩. គួរកត់សម្គាល់ថា ក្នុងសាលក្រម *Kayishema និង Ruzindana* អង្គជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា បានទទួលស្គាល់អវត្តមាននៃសិទ្ធិអំណាចរបស់ Obed RUZINDANA

---

[4142] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨៩។

[4143] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣២០។

[4144] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៩៣។

[4145] សំអាងហេតុសាលក្រម កថាខណ្ឌ ៥៩៦-៥៩៩។

ហើយបានផ្តល់ស្ថានសម្រាលទោសដល់គាត់[4146]។ ក្នុងរឿងក្តីយើងនេះ អង្គជំនុំជម្រះបានទាញសេចក្តីសន្និដ្ឋានផ្ទុយពីការសង្កេតរបស់ខ្លួនទាំងស្រុង ក្នុងខណៈដែលគ្មានចៅក្រមប្រកបដោយវិចារណញ្ញាណណាអាចកំណត់អំពីការរំលោភបំពានមុខតំណែងរបស់ ខៀវ សំផន ឡើយ។ ដូច្នេះ ទោស ខៀវ សំផន ត្រូវតែត្រូវបានសម្រាល។

២១៦០. ក្នុងករណីមានអភូតហេតុអស្ចារ្យ បើតុលាការកំពូលបែរជាតម្កល់របៀបពិចារណារបស់អង្គជំនុំជម្រះដើម្បីកំណត់ថាមានការរំលោភបំពានសិទ្ធិអំណាច តុលាការកំពូលមិនអាចចាត់ទុកវាជាស្ថានទម្ងន់ទោសបាននោះទេ។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះបានពិចារណារួចហើយនៅពេលវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម។ ជាការពិត អង្គជំនុំជម្រះបានពិចារណាថា ខៀវ សំផន "ដឹងអំពីបញ្ហាសំខាន់ៗ និងសេចក្តីសម្រេចគន្លឹះធំៗ" ដោយសារតែឋានៈគាត់ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងការចូលរួមរបស់គាត់ក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍[4147]។

២១៦១. អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា គាត់ "បានប្រើតំណែងមានឥទ្ធិពលរបស់គាត់ ដើម្បីគាំទ្រ ហើយតាមរយៈការគាំទ្រនេះ គឺគាត់បានផ្តល់ភាពស្របច្បាប់ដល់ការអនុវត្តគោលនយោបាយរបស់ ប.ក.ក"[4148]។ ដើម្បីជាការគាំទ្រដល់សំអាងហេតុនេះ អង្គជំនុំជម្រះបានយោងទៅផ្នែកទី ១៨ នៃសំអាងហេតុសាលក្រម ដែលពិពណ៌នាអំពីការចូលរួមចំណែករបស់គាត់ក្នុងឧក្រិដ្ឋកម្ម ក្នុងក្របខ័ណ្ឌនៃមុខតំណែងរបស់គាត់ជា "ឧបនាយករដ្ឋមន្ត្រី" "ប្រធានគណៈប្រធានរដ្ឋ" និង "បុគ្គលលេចមុខជាងគេនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ"។ ទោះយ៉ាងនេះក្តី ដូចដែលបានបញ្ជាក់ដោយចៅក្រមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងរឿងក្តី *Lubanga* "ធាតុផ្សំដែលត្រូវយក

---

[4146] សាលក្រម *Kayishema និង Ruzindana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ ទំព័រ ៥ នៃផ្នែកស្តីពីការផ្តន្ទាទោស កថាខណ្ឌចុងក្រោយ។

[4147] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨២។

[4148] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៨៣។

មកពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនេះ នឹងមិនត្រូវបានរាប់បញ្ចូលជាស្ថានទម្ងន់ទោសផង និងសម្រាលទោសផងឡើយ"[4149]។

២១៦២. ក្នុងន័យនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានរកឃើញកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកលើតួនាទីរបស់ជនជាប់ចោទពីរដងក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដើម្បីវាយតម្លៃភាពធ្ងន់ធ្ងរវាផង និងសម្រេចដាក់ស្ថានទម្ងន់ទោសផង។ ដូច្នេះ សាលាឧទ្ធរណ៍បានកែប្រែទោស[4150]។ ដោយសារហេតុផលទាំងនេះ ការរំលោភបំពានតួនាទី និងឥទ្ធិពល ដែលបង្ហាញដោយអង្គជំនុំជម្រះ មិនអាចត្រូវបានទទួលយកថាជាស្ថានទម្ងន់ទោសទេ។ ដូច្នេះ ទោសដែលដាក់លើ ខៀវ សំផន ត្រូវតែត្រូវបានសម្រាល។

## ៣.២. កំហុសចេញពីការគិតពីកម្រិតវប្បធម៌

២១៦៣. អង្គជំនុំជម្រះបានពិចារណាថា កម្រិតវប្បធម៌ដ៏ខ្ពង់ខ្ពស់របស់ ខៀវ សំផន និងការណ៍ដែលថា គាត់ "បានបញ្ចប់ឧត្តមសិក្សា ដោយជោគជ័យ" ជាស្ថានទម្ងន់ទោស[4151]។ ការជ្រើសរើសយកធាតុផ្សំនេះ មិនមានសំអាងហេតុ និងភាពពាក់ព័ន្ធ។ ជាក់ស្តែង នៅក្នុងរឿងក្តី *Stakić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានរកឃើញកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចាត់ទុកវិជ្ជាជីវៈរបស់ជនជាប់ចោទថាជាស្ថានទម្ងន់ទោស ដោយមិនបានផ្តល់សំអាងហេតុគាំទ្រសេចក្តីសម្រេចរបស់ខ្លួន៖

---

[4149] សាលក្រម *Lubanga* ស្តីពីទោស (តុលាការព្រហ្មទណ្ឌអន្តរជាតិ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៣៥ យោងដល់សាលដីកា *M. Nikolić* ស្តីពីទោស (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៥៨។

[4150] សាលដីកា *M. Nikolić* ស្តីពីទោស (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦១, ៦២។

[4151] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩០។

"អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិពេញលេញក្នុងការវាយតម្លៃលើស្ថានទម្ងន់ទោសក៏មែនពិត ប៉ុន្តែខ្លួនត្រូវតែផ្តល់សំអាងហេតុគួរឱ្យជឿជាក់បាន ដើម្បីគាំទ្រដល់ជម្រើសដែលខ្លួនបានធ្វើ។ ដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ពិចារណាថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសជាក់ស្តែង ដោយបានសម្រេច ដោយគ្មានអំណះអំណាងរឹងមាំដើម្បីគាំទ្រថា វិជ្ជាជីវៈរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍បង្កើតបានជាស្ថានទម្ងន់ទោស"[4152]។

២១៦៤. លើសពីនេះទៀត ក្នុងរឿងក្តី *Hadžihasanović និង Kubura* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានបញ្ជាក់ថា ការសម្រេចដាក់ស្ថានទម្ងន់ទោស ត្រូវធ្វើឡើងឱ្យស្របតាមទេសកាលនៃអង្គហេតុក្នុងរឿងក្តីនេះ[4153]។ យោងទៅតាមហេតុផលដដែលនេះ ក្នុងសាលដីការឿងក្តី *Simić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានទុកជាមោឃៈនូវវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកលើរឿងក្តី *Ntakirutimana* ដើម្បីរាប់បញ្ចូលវិជ្ជាជីវៈរបស់ជនជាប់ចោទជាស្ថានទម្ងន់ទោស។

២១៦៥. ដូច្នេះហើយទោះបីជា Blagoje SIMIĆ និង Gérard NTAKIRUTIMANA អនុវត្តវិជ្ជាជីវៈជាវេជ្ជបណ្ឌិតក៏ដោយ ក៏សាលាឧទ្ធរណ៍បានសង្កត់ធ្ងន់លើភាពមិនពាក់ព័ន្ធនៃការរាប់បញ្ចូលកត្តានេះជាស្ថានទម្ងន់ទោស បើយោងលើអង្គហេតុនៃរឿងក្តីនេះ[4154]។ បន្ថែមពីលើការដែល NTAKIRUTIMANA មិនបានគោរពតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន គាត់ត្រូវបានរកឃើញថាបានចូលរួមចំណែកក្នុង

---

[4152] សាលដីកា *Stakić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៤១៦។

[4153] សាលដីកា *Hadžihasanović និង Kubura* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ ៣២៨៖ "អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់សាជាថ្មីថា បញ្ហាចង់ដឹងថាកត្តាមួយចំនួនប៉ះពាល់ដល់អត្តចរិតរបស់ពិរុទ្ធជន បង្កើតបានជាស្ថានសម្រាល ឬស្ថានទម្ងន់ទោស អាស្រ័យមួយភាគធំលើកាលៈទេសៈពិសេសនៃរឿងក្តីនីមួយៗ" (ផ្នែកនេះមិនត្រូវបានបកប្រែជាភាសាបារាំងទេ)។

[4154] សាលដីកា *Simić និងគូកន* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ២៧២។

ការវាយប្រហារប្រដាប់អាវុធសំដៅទៅលើប្រជាជនស៊ីវិល នៅកន្លែងធ្វើការរបស់គាត់ទៀតផង[4155]។ គាត់ត្រូវបានចោទប្រកាន់ពីបទ "បានបោះបង់អ្នកជំងឺជាតិពន្ធុទុតស៊ីចោលទទេៗ"[4156] និងពីបទបាន បាញ់សម្លាប់គណនេយ្យករមន្ទីរពេទ្យនៅចំកណ្ដាលទីធ្លាអគារ។ ដូច្នេះ បរិបទមិនដូចគ្នាទាល់តែសោះ ជាមួយនឹងបរិបទដែល ខៀវ សំផន ត្រូវបានវិនិច្ឆ័យទោសឡើយ។

២១៦៦. ក្នុងរឿងក្ដីយើងនេះ ខ្សែគំនិតរបស់អង្គជំនុំជម្រះចាំងចិញ្ចែងចិញ្ចាច ដោយភាពខ្មៅស្រអាប់មើលមិនយល់។ ចៅក្រមបានភ្ជាប់ចំណងទាក់ទងតូចឆ្មារ រវាង "ឧត្ដមសិក្សា ទាំងផ្នែកច្បាប់ និងសេដ្ឋកិច្ច" របស់លោក ខៀវ សំន និងសមត្ថភាពរបស់គាត់ដែលត្រូវបានចោទប្រកាន់ថា "អាចវាយតម្លៃលើវិសាលភាព និងផលវិបាកនៃអំពើរបស់គាត់" ដោយមិនផ្ដល់សំអាងហេតុឱ្យបានលម្អិតជាងនេះទេ[4157]។ ធាតុផ្សំនេះមិនទាក់ទងទៅនឹងអង្គហេតុដែលគាត់ត្រូវបានចោទប្រកាន់និ ងអាចអនុវត្តចំពោះរាល់បុគ្គលដែលមានបញ្ញាស្មារតីធម្មតាដោយមិនគិតពីសាវតានៃការសិក្សារៀនសូត្ររបស់គាត់ឡើយ។ យុត្តិកម្មទូទៅ និងភាពមិនត្រឹមត្រូវនេះ មានកម្រិតទាបជាងបទដ្ឋាននៃការផ្ដល់សំអាងហេតុដែលអនុវត្តនៅក្នុងតុលាការអន្តរជាតិផ្សេងៗទៀត។

២១៦៧. អាស្រ័យហេតុនេះ កម្រិតវប្បធម៌របស់ ខៀវ សំផន មិនអាចបង្កើតបានជាស្ថានទម្ងន់ទោសនោះទេ។ ដូច្នេះ ការដាក់ទោសត្រូវតែពិនិត្យឡើងវិញ។

## ៤. កំហុសពាក់ព័ន្ធនឹងស្ថានសម្រាលទោស

### ៤.១. កំហុសពាក់ព័ន្ធនឹងការសហការរបស់ខៀវ សំផន ជាមួយ អ.វ.ត.ក

---

[4155] សាលក្រម *Ntakirutimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៧៩១។

[4156] សាលក្រម *Ntakirutimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៣៦៤, ៧៩១។

[4157] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩០។

២១៦៨. អង្គជំនុំជម្រះមិនបានផ្តល់ស្ថានសម្រាលទោសណាមួយឡើយ ចំពោះការសហការរបស់ ខៀវ សំផន ជាមួយ អ.វ.ត.ក ដោយមូលហេតុថា "ការសហការរបស់គាត់មានកម្រិតអប្បបរមាដូចដែលច្បាប់តម្រូវ"[4158]។ ការអះអាងនេះមិនពិត និងមិនឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងដែលគាត់បានធ្វើកន្លងមកទេ។ ដូច្នេះ គួរគប្បីបែងចែករវាងកាតព្វកិច្ចផ្លូវច្បាប់របស់ ខៀវ សំផន ក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីគាត់ និងរបៀបដែលគាត់បានអនុវត្តតាម។

២១៦៩. ដូច្នេះ គាត់បានបង្ហាញឆន្ទៈមោះមុត និងច្បាស់លាស់ ក្នុងការចូលរួមគ្រប់សវនាការ កាលណាគាត់មិនមានបញ្ហាសុខភាព។ គាត់ក៏បានបង្ហាញអាកប្បកិរិយាគំរូពេញមួយរយៈពេលឃុំឃាំង ទោះបីជាគាត់មានល័ក្ខខ័ណ្ឌឃុំឃាំងយ៉ាងណាក៏ដោយ។ លើសពីនេះទៀត ខៀវ សំផន បានចូលរួមយ៉ាងសកម្មក្នុងការការពារក្តីខ្លួន ទោះបីគាត់បាត់បង់ទំនុកចិត្តលើ អ.វ.ត.ក ក៏ដោយ។ ទង្វើនេះត្រូវតែទទួលបានការលើកទឹកចិត្ត។ ទោះជាត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតរួចហើយ នៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះលើសំណុំរឿង ០០២/០១ គាត់នៅតែបន្តសហការជាមួយអង្គជំនុំជម្រះ ដើម្បីចូលរួមចំណែកក្នុងការស្វែងរកការពិតជាជាងរាំងស្ទះការងារតុលាការ។ ក្នុងន័យនេះ លោក ខៀវ សំផន បានឆ្លើយសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងព្រំដែននៃការដឹងឮរបស់គាត់កាលពីសម័យអង្គហេតុ មិនត្រឹមតែនៅក្នុងសំណុំរឿង ០០២/០១[4159] ប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងឱកាសធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នៅក្នុងសំណុំរឿង ០០២/០២ ផងដែរ[4160]។

២១៧០. នៅចុងបញ្ចប់ អង្គជំនុំជម្រះបានកត់សម្គាល់ថា ខៀវ សំផន បាន "ទទួលស្គាល់ការរងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង [បាន] លំឱនកាយគោរពវិញ្ញាណក្ខ័ន្ធរបស់ជនរងគ្រោះដែលគ្មានទោសកំហុស

---

[4158] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩៧។

[4159] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៥៥។

[4160] ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ **E1/528.1** ប្រហែលម៉ោង 10.37.24 "ជាឱកាសដើម្បីខ្ញុំឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរឿងទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿងនេះ" ទំព័រ ២៣ ប្រហែលម៉ោង 10.37.24 ទំព័រ ២៤ ប្រហែលម៉ោង 10.48.33 ទំព័រ ២៥ មុនម៉ោង 10.57.25។

ទាំងអស់”[4161]។ ទោះយ៉ាងនេះក្តី ជាជាងការទទួលយកកត្តានេះជាស្ថានសម្រាលទោស អង្គជំនុំជម្រះបែរជានិយាយជាន់កែងខ្លួនឯងជាចំហ ដោយអះអាងថាគាត់មិនបានសម្តែងការអាណិតអាសូរចំពោះជនរងគ្រោះទៅវិញ[4162]។

២១៧១. ផ្អែកលើកត្តាទាំងនេះ ខៀវ សំផន មិនអាចសហការលើសពីនេះជាមួយ អ.វ.ត.ក ដោយមិនកាត់បន្ថយសិទ្ធិរបស់គាត់ក្នុងការការពារខ្លួនប្រកបដោយប្រសិទ្ធភាពឡើយ។ សំអាងហេតុរបស់អង្គជំនុំជម្រះបង្ហាញថា អង្គជំនុំជម្រះមិនបានត្រៀមខ្លួនទទួលយកការសម្រាលទោសដល់រូបគាត់ឡើយ លើកលែងតែគាត់និយាយដាក់បន្ទុកលើខ្លួនឯង ដោយមិនគោរពសិទ្ធិជាមូលដ្ឋានរបស់គាត់។ វិធារណកិច្ចនេះមិនត្រឹមត្រូវទេ។ ដូច្នេះ ត្រូវតែសម្រាលការដាក់ទោសគាត់ឱ្យសមមាត្រនឹងការសហការរបស់គាត់ជាមួយអង្គជំនុំជម្រះគ្រប់ជាន់ថ្នាក់ នៃ អ.វ.ត.ក។

## ៤.២. កំហុសដោយមិនគិតពីវ័យ និងស្ថានភាពសុខភាព

២១៧២. អង្គជំនុំជម្រះបានសម្រេចផ្តល់ស្ថានសម្រាលទោសតិចតួចបំផុតដល់វ័យចាស់ជរារបស់ ខៀវ សំផន ដោយមិនផ្តល់សំអាងហេតុទាល់តែសោះដើម្បីគាំទ្រការសម្រេចរបស់ខ្លួន[4163]។ ផ្ទុយទៅវិញ ខ្លួនបានផ្អែកលើវ័យចាស់ជរា និងស្ថានភាពសុខភាពថមថយរបស់ ខៀវ សំផន ដើម្បីផ្តល់ភាពស្របច្បាប់ដល់ការបំបែកកិច្ចដំណើរការនីតិវិធី[4164]។ ទឡ្ហីករណ៍ដែលបានលើកឡើងពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ កាន់តែអះអាងបញ្ជាក់ថែមទៀតក្នុងឆ្នាំ២០១៩ ដល់ការសម្រាលទោស។ លើសពីនេះទៅទៀត កត្តា

---

[4161] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៤៥ យោងដល់ប្រតិចារឹក ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ **E1/528.1** ប្រហែលម៉ោង 11.03.38។

[4162] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩៦។

[4163] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩៨។

[4164] សំអាងហេតុសាលក្រម កថាខណ្ឌ ៤ និង កំណត់សម្គាល់ជើងទំព័រលេខ ៨ (យោងដល់ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ **E124**), សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២៦ ខែមេសា ឆ្នា ២០១៣ ឯកសារ **E284** កថាខណ្ឌ ៣១ ៨៧, សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ **E301/9/1** កថាខណ្ឌ ២៧។

នេះត្រូវបានលើកកម្ពស់ទៅជាស្ថានសម្រាលទោសនៅក្នុងតុលាការអន្តរជាតិ ជាច្រើនលើកច្រើនសា ដោយសារតែវ័យក្មេង ឬដោយសារតែវ័យចំណាស់របស់ជនជាប់ចោទ[4165]។

២១៧៣. នៅក្នុងរឿងក្តី *Krajišnik* អង្គជំនុំជម្រះសាលាដំបូងបានធ្វើយុត្តិកម្មដល់ការពិចារណាលើវ័យចាស់ជរារបស់ជនជាប់ចោទ "ដោយយោងលើស្ថានភាពសុខភាពកាន់តែថមថយទៅតាមវ័យជរា ដោយមនុស្សកាន់តែចាស់ កាន់តែលំបាកអនុវត្តទោស"[4166]។ ហេតុនេះ តុលាការចំពោះកិច្ចបានគិតពីកត្តានេះសម្រាប់បុគ្គលដែលមានអាយុលើសពី ៦០ ឆ្នាំ[4167]។ ជាពិសេស ចៅក្រមបានគិតគូរពីវ័យចាស់ជរា និងស្ថានភាពសុខភាពផុយស្រួយរបស់ Élizaphan NTAKIRUTIMANA ដែលមានអាយុ ៧៨ ឆ្នាំ ហើយដែលបានចំណាយពេលជាងបួនឆ្នាំហើយ នៅក្នុងមន្ទីរឃុំឃាំង[4168]។ លើសពីនេះទៀត នៅក្នុងសាលដីការឿងក្តី *Đorđević* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់

---

[4165] សាលដីកា *Jelisić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ ១២៩-១៣០៖ សម្រាប់ជនជាប់ចោទ អាយុ ២៣ ឆ្នាំ, សាលក្រម *Blaskić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៧៧៨៖ សម្រាប់ជនជាប់ចោទ អាយុ ៣២ ឆ្នាំ, សាលក្រម *Erdemović* ស្តីពីការផ្តន្ទាទោស (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៨ កថាខណ្ឌ ១៦៖ សម្រាប់ជនជាប់ចោទ អាយុ ២៣ ឆ្នាំ។

[4166] សាលក្រម *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ១១៦២។

[4167] សាលក្រម *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ១១៦២, សាលដីកា *Đorđević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ៩៧៤ ៩៨០, សាលដីកា Arrêt *Krnojelac* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ២៥១, សាលក្រម *Simić* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ ១០៩៩។

[4168] សាលក្រម *Ntakirutimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៨៩៨ និង ៩០៦។

អតីតប្រទេសយូហ្គោស្លាវី ក៏បានគិតគូរពីអាយុរបស់ជនជាប់ចោទនៅពេលត្រូវបានដោះលែងពីការឃុំខ្លួន ដើម្បីវាយតម្លៃពីស្ថានភាពសុខភាពរបស់គាត់ឱ្យបានល្អបំផុត ក្នុងពេលអនុវត្តទោសទាំងមូល[4169]។

២១៧៤. ក្នុងរឿងក្តីនេះ ខៀវ សំផន មានអាយុ ៨៨ ឆ្នាំ ហើយបានចំណាយពេល ១២ ឆ្នាំ មកហើយ នៅក្នុងមន្ទីរឃុំឃាំង។ កត្តានេះមិនត្រូវបានយកមកពិចារណាទេ ក្នុងខណៈដែលគាត់មានវ័យចាស់ជាងជនជាប់ចោទដែលបានរៀបរាប់ខាងលើ នៅថ្ងៃផ្តន្ទាទោស និងថ្ងៃផុតទោសជាប់ពន្ធនាគាររបស់ពួកគេ។ ជាក់ស្តែង Krajišnik មានអាយុ ៦៨ ឆ្នាំ នៅពេលគាត់ត្រូវបានដោះលែងមុនកាលកំណត់[4170]។ រីឯ Đordević នឹងមានអាយុ ៧៦ ឆ្នាំ[4171]។ លើសពីនេះទៅទៀត និងដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបញ្ជាក់នៅក្នុងសាលដីកា Krajišnik "ការកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ២៧ ឆ្នាំ គឺជាការផ្តន្ទាទោសដ៏ធ្ងន់ធ្ងរ ជាពិសេស នៅពេលដែលយើងគិតពីវ័យចាស់ជរារបស់ Krajišnik"[4172]។ កាន់តែធ្ងន់ធ្ងរទៅទៀតនោះ សេចក្តីសន្និដ្ឋាននេះបង្ហាញពីលក្ខណៈមិនសមមាត្រនៃការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត ដែលបានប្រកាស និងផលប៉ះពាល់ដ៏សម្បើមនៃការផ្តន្ទាទោសនេះទៅលើ ខៀវ សំផន។ ផ្អែកលើហេតុផលទាំងអស់នេះ អង្គជំនុំជម្រះមិនអាចមិនគិតថាវ័យចាស់ជរារបស់គាត់ជាស្ថានសម្រាលទោសនោះទេ ហើយត្រូវតែប្រកាសទោស ក្នុងរយៈពេលកំណត់មួយ។

---

[4169] សាលដីកា *Đorđević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ កំណត់សម្គាល់ជើងទំព័រលេខ ២៨៦៨៖ "ប្រសិនបើអនុវត្តទោសទាំងអស់ និងក្រោយពីកាត់កងពេលវេលាដែលគាត់ជាប់ឃុំ គាត់នឹងមានអាយុ ៨៥ ឆ្នាំ នៅពេលដោះលែងឱ្យមានសេរីភាព"។

[4170] សាលក្រម *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌ ១១៨៣៖ ទោសរបស់គាត់ត្រូវបានបន្ថយមកត្រឹមជាប់ពន្ធនាគារ ២០ ឆ្នាំ នៅក្នុងនីតិវិធីបណ្តឹងសាទុក្ខ ហើយគាត់ត្រូវបានដោះលែងឱ្យមានសេរីភាពមុនកាលកំណត់ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣។

[4171] សាលដីកា *Đorđević* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ កំណត់សម្គាល់ជើងទំព័រលេខ ២៨៦៨ (នៃកថាខណ្ឌ ៩៧៤) និងកថាខណ្ឌ ៩៨០។ មេធាវីការពារក្តីសូមរំឮកថា Vlastimir ĐORĐEVIĆ មានអាយុ ៦៥ ឆ្នាំ នៅពេលគាត់ត្រូវបានផ្តន្ទាទោស ក្នុងនីតិវិធីបណ្តឹងសាទុក្ខ ឱ្យជាប់ពន្ធនាគារ ១៨ ឆ្នាំ នៅឆ្នាំ២០១៤។ ក្រោយពីកាត់កងរយៈពេលជាប់ឃុំ ៧ ឆ្នាំ គាត់នឹងមានអាយុ ៧៦ ឆ្នាំ នៅពេលដោះលែងឱ្យមានសេរីភាព។

[4172] សាលដីកា *Krajišnik* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ៧៨២។

២១៧៥. តាមរបៀបស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះបានពិចារណាថា វា "មិនត្រឹមត្រូវទេ" ក្នុងការគិតពីស្ថានភាពសុខភាពរបស់ ខៀវ សំផន។ ដើម្បីធ្វើដូចនេះ អង្គជំនុំជម្រះបានយោងទៅលើសេចក្ដីសម្រេចលើកាយនីតិសម្បទារបស់ ខៀវ សំផន ដែលត្រូវជំនុំជម្រះ[4173]។ អង្គជំនុំជម្រះបានផ្អែកតែលើឯកសារមួយនេះគត់ ដោយមិនបានពន្យល់ពីព័ត៌មានលម្អិតដែលនាំឱ្យខ្លួនសម្រេចយកជម្រើសនេះ។ លើសពីនេះទៀត គួរគប្បីគូសបញ្ជាក់ថា ការវាយតម្លៃនេះមិនមានគោលបំណងកំណត់ស្ថានភាពសុខភាពរបស់ ខៀវ សំផន ឱ្យបានពេញលេញនោះទេ ផ្ទុយទៅវិញ ដូចដែលចំណងជើងបញ្ជាក់ស្រាប់ វាគ្រាន់តែមានគោលបំណងកំណត់កាយនីតិសម្បទារបស់គាត់ក្នុងការចូលខ្លួនមកទទួលការជំនុំជម្រះតែប៉ុណ្ណោះ។

២១៧៦. ប្រាកដណាស់ "អ្នកជំនាញ" បានធ្វើការពិនិត្យរបស់ខ្លួន ស្របតាមលក្ខណៈវិនិច្ឆ័យនៅក្នុងសាលដីកា *Strugar* របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដូចតទៅ៖ "ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាប់ចោទ គឺជាការអនុវត្តសិទ្ធិរបស់ខ្លួន ស្របតាមក្របខ័ណ្ឌនៃការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ក្នុងការចូលរួមក្នុងការជំនុំជម្រះ ដោយអាចវាយតម្លៃបាន និងយល់បានពី "<u>គោលសំខាន់ៗ</u>" នៃកិច្ចដំណើរការនីតិវិធី"[4174]។ យោងតាមឃ្លាឃ្លោងដែលតាក់តែងឡើងដោយអង្គជំនុំជម្រះ វាជាការកំណត់ថាតើ ខៀវ សំផន មាន "សមត្ថភាពយល់ដឹងទូទៅក្នុងកម្រិតអប្បបរមា"ដែរឬទេ"[4175]។ ដូច្នេះ ការសន្និដ្ឋានដែលកើតចេញពីកត្តានេះ មិនមានភាពពាក់ព័ន្ធទាល់តែសោះនឹងសមត្ថភាពរបស់ ខៀវ សំផន ក្នុងការស៊ូទ្រាំនឹងការជាប់ពន្ធនាគាររយៈពេលយូរ។

២១៧៧. ទោះយ៉ាងណាក្ដី ដោយជ្រួតជ្រាបអំពីការចុះថមថយជាលំដាប់នៃស្ថានភាពសុខភាពរបស់គាត់ "អ្នកជំនាញ" របស់ អ.វ.ត.ក បានកត់សម្គាល់ថា "មុខងារចងចាំ និងបញ្ញាញាណរបស់ ខៀវ សំផន នឹងកាន់តែធ្លាក់ចុះបន្តិចម្ដងៗទៅតាមអាយុ" និងបានផ្ដល់អនុសាសន៍ "ឱ្យត្រួតពិនិត្យជាប្រចាំលើមុខងារ

---

[4173] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩៨ កំណត់សម្គាល់ជើងទំព័រលេខ ១៤១៨៩។

[4174] សេចក្ដីសម្រេច ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ **E460/5** កថាខណ្ឌ ៩ យោងដល់សាលដីកា *Strugar* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ៥៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[4175] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Pavle Strugar* សំណុំរឿងលេខ IT-01-42-A សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំបញ្ចប់កិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ៣៧។

បញ្ញាញាណរបស់គាត់” ព្រមទាំងឱ្យ “តាមដានសម្ពាធឈាម និងទម្ងន់របស់គាត់ ឱ្យបានដិតដល់”[4176]។ អង្គជំនុំជម្រះបានលាក់បាំងដោយចេតនានូវទិដ្ឋភាពវិវត្តដ៏សំខាន់នេះនៅក្នុងការកំណត់ទោស។ ជាលទ្ធផល អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសជាក់ស្តែង នៅក្នុងរបៀបវាយតម្លៃស្ថានភាពសុខភាពរបស់ ខៀវ សំផន ដែលត្រូវតែរាប់បញ្ចូលទៅក្នុងស្ថានសម្រាលទោស។ អាស្រ័យហេតុនេះ ទោសដែលប្រកាសត្រូវកាត់បន្ថយមកត្រឹមរយៈពេលកំណត់មួយ។

## ៤.៣. កំហុសស្តីពីសីលធម៌ល្អ

២១៧៨. អង្គជំនុំជម្រះបានបញ្ជាក់ថាមិនបាន “ស្តាប់សាក្សីអំពីបុគ្គលិកលក្ខណៈណាម្នាក់” ពាក់ព័ន្ធនឹង ខៀវ សំផន ឡើយ”[4177]។ ទោះបីជាអង្គជំនុំជម្រះបានសំដៅលើសាក្សីអំពីបុគ្គលិកលក្ខណៈ ដែលត្រូវបានស្តាប់ចម្លើយ នៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្តីសំណុំរឿង ០០២/០១ ក៏ដោយ ក៏ខ្លួនមិនបានព្យាយាមកំណត់ស្ថានសម្រាលដែលត្រូវផ្តល់ទៅដល់ចរិយាសម្បត្តិរបស់ ខៀវ សំផន ដោយមូលហេតុថាសាក្សីទាំងនេះ ត្រូវបានបដិសេធចោល នៅក្នុងការជំនុំជម្រះវគ្គ១[4178]។ ដូច្នេះ អង្គជំនុំជម្រះបានផ្តល់សុពលភាពដល់ការពិនិត្យពិចារណាខុសកន្លងមក ជាជាងបង្ខំចិត្តខ្លួនឯងឱ្យតឹងរ៉ឹង ដើម្បីវាយតម្លៃប្រកបដោយមនសិការខ្ពស់លើតម្លៃជាភ័ស្តុតាង ដែលត្រូវផ្តល់ទៅឱ្យសក្ខីកម្មទាំងនេះ[4179]។

[4176] សេចក្តីសម្រេច ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ **E460/5** កថាខណ្ឌ ៨។

[4177] សំអាងហេតុសាលក្រម កថាខណ្ឌ ៤៣៩៩។

[4178] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៤១៩០ (នៃកថាខណ្ឌ ៤៣៩៩)។

[4179] ស្វ សុជាតិ៖ ប្រតិចារឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/204.1**, ប្រតិចារឹក ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/206.1**។ ទន់ សឿន៖ ប្រតិចារឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E3/204.1** ទំព័រ ១១ ប្រហែលម៉ោង 09.42.26 ទំព័រ ១២ ប្រហែលម៉ោង 09.45.40 ទំព័រ ៣៤ ប្រហែលម៉ោង 11.21.21។ សុខ រឿ៖ ប្រតិចារឹក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E3/203.1** ប្រហែលម៉ោង 13.41.36។ Philippe JULLIAN-GAUFRES៖ ប្រតិចារឹក ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/194.1**។ ថៅ សុគន្ធ៖ ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/195.1** ទំព័រ ៥៣-៥៦ ប្រហែលម៉ោង 14.11.10 ទំព័រ ៥៩ ប្រហែលម៉ោង 14.28.22 ទំព័រ ៦៤-៦៥ ប្រហែលម៉ោង 14.46.22។

២១៧៩. ដោយមូលហេតុនេះ អង្គជំនុំជម្រះបានព្យាយាមពិចារណាអំពីចម្លើយសាក្សី ដែលត្រូវបានស្តាប់នៅក្នុងសំណុំរឿង ០០២/០១ កាលណាចម្លើយទាំងនេះមានធាតុផ្សំ ដែលអាចដាក់បន្ទុកលើ ខៀវ សំផន[4180]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនបានគិតថា វាមានប្រយោជន៍ក្នុងការពិនិត្យចម្លើយរបស់សាក្សីបន្ថែម ដែលបានមកផ្តល់សក្ខីកម្មលើអង្គហេតុដែលបានបញ្ជាក់ជាឯកច្ឆន្ទអំពីសីលធម៌ល្អរបស់គាត់[4181] ដោយផ្តល់សំអាងហេតុថា "ការបង្ហាញសមានចិត្តល្អរបស់គាត់ចំពោះអ្នកដទៃក្នុងឱកាសជាក់លាក់មួយចំនួន" មិនសំខាន់ទេ[4182]។

២១៨០. ក៏ប៉ុន្តែ គេមិនអាចកំណត់អំពីសីលធម៌ល្អរបស់ជនជាប់ចោទម្នាក់ តាមវិធីផ្សេងក្រៅពីសក្ខីកម្មជាបន្តបន្ទាប់អំពីអាកប្បកិរិយារបស់គាត់ ក្នុងពេលជាក់លាក់ណាផ្សេងៗក្នុងជីវិតរបស់គាត់។ លើសពីនេះទៀត ជំហរនេះ ជាការរំលោភបំពានយ៉ាងជាក់ស្តែងលើកាតព្វកិច្ចរបស់ចៅក្រមមានហេតុផល ក្នុង

[4180] សូមមើលខាងលើ កថាខណ្ឌ ១៦១-១៦៤។

[4181] ឡេង ឈឿង៖ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/208.1** ទំព័រ ៣៥-៣៦ ប្រហែលម៉ោង 11.37.49។ ស្នួង ស៊ីគឿន៖ ប្រតិចារឹក ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/107.1** ទំព័រ ៧៦-៧៧ ក្រោយម៉ោង 15.21.25។ គឹម វុន៖ ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/112.1**។ ស វិ៖ ប្រតិចារឹក ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ ឯកសារ **E1/157.1** ប្រហែលម៉ោង 09.29.36។ រស់ ស៊ុយ៖ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/184.1** ទំព័រ ៣៣ ប្រហែលម៉ោង 11.13.42 ទំព័រ ៣៤ ប្រហែលម៉ោង 11.17.49។ រ៉ោម គុន៖ ប្រតិចារឹក ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/100.1** ប្រហែលម៉ោង 15.38.27។ ឌុច៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1**។ François PONCHAUD៖ ប្រតិចារឹក ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/178.1**។ អ៊ុង ចុងហឿង៖ ប្រតិចារឹក ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ ឯកសារ **E1/103.1** ប្រហែលម៉ោង 13.53.28។ ហ៊ុន ឈុនលី៖ ប្រតិចារឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/150.1** ទំព័រ ៣ ប្រហែលម៉ោង 09.11.53 ទំព័រ ៧២-៧៣ ប្រហែលម៉ោង 15.27.05 ទំព័រ ៨១ ប្រហែលម៉ោង 15.58.15។ ឈូក រីន៖ ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/181.1** ទំព័រ ៣៥ ប្រហែលម៉ោង 11.38.33 ទំព័រ ៤៧ ប្រហែលម៉ោង 13.55.53, ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/182.1** ទំព័រ ៦៩ ប្រហែលម៉ោង 15.09.12 ទំព័រ ៧០ ប្រហែលម៉ោង 15.12.04។ ព្រុំ ស្ញូ៖ ប្រតិចារឹក ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/194.1** ប្រហែលម៉ោង 09.31.45។ នួន ហ៊ាន់៖ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/199.1** ទំព័រ ១៩ ប្រហែលម៉ោង 09.55.40 ទំព័រ ២៩ ប្រហែលម៉ោង 10.24.45។ Philip SHORT៖ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1**។ David CHANDLER៖ ប្រតិចារឹក ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/93.1**, ប្រតិចារឹក ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/95.1**។

[4182] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៩១៩០ (នៃកថាខណ្ឌ ៤៣៩៩) យោងដល់សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នា២០១៤ កថាខណ្ឌ ១១០៣។

ការពិចារណាអំពីធាតុផ្សំទាំងអស់នៃបុគ្គលិកលក្ខណៈ[4183]។ អង្គជំនុំជម្រះមិនដែលសង្ស័យលើភាពអាចទុកចិត្តរបស់សាក្សីទាំងនេះឡើយ។ ដូច្នេះ ពុំមានហេតុផលអ្វីដែលខ្លួនត្រូវនៅស្ងៀម និងមើលរំលងសក្ខីកម្មរបស់ពួកគាត់ ដែលសុទ្ធតែសរសើរ ខៀវ សំផន ក្នុងការកំណត់ទោសគាត់ឡើយ។

២១៨១. ពេញមួយជីវិតរបស់គាត់ ខៀវ សំផន បានបង្ហាញនូវចរិយាសម្បត្តិយ៉ាងពិតប្រាកដ។ អ្នកដែលធ្លាប់រាប់អានគាត់ស្ទើរតែទាំងអស់ បានចាត់ទុកគាត់ថាជា "មនុស្សស្អាតស្អំ" ដោយសារភាពស្មោះត្រង់ សុភាពរាបសា និងភាពក្លៀវក្លានៃការប្ដេជ្ញាចិត្តខ្ពស់របស់គាត់ចំពោះប្រជាជនកម្ពុជា[4184]។ គាត់មានបំណងមុតមាំក្នុងការធ្វើកំណែទម្រង់ប្រទេសរបស់គាត់ដោយសន្តិវិធី និងចាប់ផ្ដើមពីខាងលើ។ ដោយហេតុនេះហើយបានជាគាត់នៅតែមិនចេះពុករលួយ[4185] ហើយបន្តប្រឆាំងនឹងភាពអយុត្តិធម៌ដែលប្រជាជនរបស់គាត់បានទទួលរង[4186]។ រាល់សកម្មភាពរបស់គាត់សុទ្ធតែត្រូវបានជំរុញដោយគោលបំណង

---

[4183] សាលក្រម *Tadić* ស្ដីពីទោស (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី) ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦១។ ចំពោះឧទាហរណ៍នៃការពិចារណាដល់សីលធម៌ល្អ នៅមុនអង្គហេតុ សូមមើល សាលក្រម *Ntakirutimana* (តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ ៨៩៥ និង ៩០៦។

[4184] <u>សុខ រឿ</u>៖ ប្រតិចារឹក ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E3/203.1** ប្រហែលម៉ោង 13.41.36 ("គាត់មិនដែលមើលងាយកសិករទេ បាទ") ប្រហែលម៉ោង 13.42.51 ("គាត់អត់ដែលស្ដីពីរឿងការងារអីទេ។ ហើយគាត់មានតែណែនាំ [...]")។

[4185] <u>François PONCHAUD</u>៖ ប្រតិចារឹក ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/178.1** ទំព័រ ៩ ប្រហែលម៉ោង 09.37.57, ប្រតិចារឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/179.1** ប្រហែលម៉ោង 13.56.14។ <u>ឈូក រីន</u>៖ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/182.1** ប្រហែលម៉ោង 15.24.39។ <u>ហ៊ុន ឈុនលី</u>៖ ប្រតិចារឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/150.1** ទំព័រ ៧២ ប្រហែលម៉ោង 15.27.05 ទំព័រ ៨១-៨២ ប្រហែលម៉ោង 15.58.15។ <u>នូវ ហ៊ាន់</u>៖ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/199.1** ទំព័រ ១៩ ប្រហែលម៉ោង 09.57.47 ទំព័រ ២៩ ប្រហែលម៉ោង 10.24.45។ <u>ឌុច</u>៖ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ **E1/55.1** ទំព័រ ៤១ ប្រហែលម៉ោង 11.46.42។ <u>David CHANDLER</u>៖ ប្រតិចារឹក ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/93.1** ប្រហែលម៉ោង 14.42.53, ប្រតិចារឹក ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/95.1** ប្រហែលម៉ោង 14.19.18។ <u>Philip SHORT</u>៖ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ប្រហែលម៉ោង 11.34.18។

[4186] សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន លើសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ឯកសារ **E295/6/4** កថាខណ្ឌ ២១០ ("ពេលត្រឡប់មកដល់ប្រទេសកម្ពុជាវិញ លោក ខៀវ សំផន បានបង្កើតកាសែតឯករាជ្យមួយ។ តាមរយៈកាសែតនោះ លោកបានបរិហារអយុត្តិធម៌សង្គមនៃរបប សម្ដេច សីហនុ ប្រកបដោយភាពទន់ភ្លន់ និងដោយក្ដីក្លាហាន") យោងដល់ <u>François PONCHAUD</u>៖ ប្រតិចារឹក ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E1/178.1** ប្រហែលម៉ោង

ចង់ធ្វើយ៉ាងណាដើម្បី "កែលម្អជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា តាមរយៈបដិវត្តន៍សេដ្ឋកិច្ច" ហើយការកែលម្អនេះ គឺដើម្បីឱ្យ "ប្រទេសកម្ពុជាវិវត្តបន្តិចម្តងៗ ដោយមិនគំហ៊ុក"[4187]។

២១៨២. ដូច្នេះ ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះបានលើកឡើង នៅទីចុងបញ្ចប់នៃការជំនុំជម្រះសំណុំរឿង ០០២/០១ ធាតុផ្សំនៃបុគ្គលិកលក្ខណៈរបស់ ខៀវ សំផន ដែលត្រូវបានជម្រាបជូនតុលាការ បញ្ជាក់អំពីតម្លៃសីលធម៌របស់គាត់ គឺមិនមែនកំណត់មកត្រឹមតែទំនាក់ទំនងប្តីប្រពន្ធរបស់គាត់[4188] ឬ "មកត្រឹមឱកាសជាក់លាក់មួយចំនួន" ឡើយ[4189]។

២១៨៣. អង្គជំនុំជម្រះបានប្រព្រឹត្តជាក់ស្តែងក្នុងវាយតម្លៃ ដោយមិនបានផ្តល់ទម្ងន់បន្ថែមដល់ចម្លើយទាំងនេះ ដែលគួរគប្បីគួសបញ្ជាក់ថាវាបានមកពីសាក្សីផ្សេងៗអំពីអង្គហេតុ។ ដូច្នេះ ទោសលើ ខៀវ សំផន ត្រូវតែកាត់បន្ថយ ស្របតាមការពិចារណាទាំងនេះ។

---

09.37.57។ ហ៊ុន ឈុនលី៖ ប្រតិចារឹក ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/149.1** ប្រហែលម៉ោង 11.48.24, ប្រតិចារឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ឯកសារ **E1/150.1** ទំព័រ ៧៣ ប្រហែលម៉ោង 15.28.16 ទំព័រ ៨០ ប្រហែលម៉ោង 15.54.51 ទំព័រ ៨១ ប្រហែលម៉ោង 15.55.52។ នួរ ហ៊ាន់៖ ប្រតិចារឹក ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/199.1** ប្រហែលម៉ោង 10.23.45។ Philip SHORT៖ ប្រតិចារឹក ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/189.1** ទំព័រ ៣៧ ប្រហែលម៉ោង 11.26.40 ទំព័រ ៣៩ ប្រហែលម៉ោង 11.34.18។ David CHANDLER៖ ប្រតិចារឹក ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ឯកសារ **E1/93.1** ទំព័រ ៧៨-៧៩ ប្រហែលម៉ោង 14.41.23។ ចៅ សុគន្ធ៖ ប្រតិចារឹក ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/195.1** ប្រហែលម៉ោង 14.14.21។

[4187] Philippe JULLIAN-GAUFRES៖ ប្រតិចារឹក ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E1/194.1** ប្រហែលម៉ោង 14.23.56, សក្ខីកម្មរបស់ Philippe JULLIAN-GAUFRES គាំទ្រលោក ខៀវ សំផន ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០ ឯកសារ **E3/4077** ERN 00907759 ("បើតាមទស្សនះរបស់គាត់ ការកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចនេះត្រូវធ្វើឡើងបន្តិចម្តងៗ ពោលគឺ ពុំមែនធ្វើក្នុងជំហានមហាលោតផ្លោះ មហាអស្ចារ្យ តាមបែបប្រទេសចិន ដូចដែលមេដឹកនាំខ្មែរក្រហមបានអនុវត្ត នៅពេលដែលពួកគេឡើងកាន់អំណាចនោះទេ")។

[4188] សូ សុជាតិ៖ ប្រតិចារឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E1/204.1** ក្រោយម៉ោង 14.19.57 ("គឺថា គាត់ជាមនុស្ស អត់ធ្មត់ [...] ស្លូតបូត [...] ទោះបីលំបាកស្រួលយ៉ាងម៉េចក៏ដោយ មានតែគាត់ជួយ")។

[4189] សំអាងហេតុសាលក្រម កំណត់សម្គាល់ជើងទំព័រលេខ ១៩១៩០ (នៃកថាខណ្ឌ ៥៣៩៩) យោងដល់សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១១០៣។

២១៨៤. **ជាសេចក្តីសន្និដ្ឋាន** កំហុសទាំងអស់របស់អង្គជំនុំជម្រះធ្វើឱ្យសេចក្តីសម្រេចផ្តន្ទាទោសក្លាយជាមោឃៈ។

## អាស្រ័យហេតុនេះ

២១៨៥. មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

- ***ជាចម្បង កត់សម្គាល់***ពីមោឃភាពនៃសាលក្រមដែលបានប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ព្រមទាំងសំអាងហេតុដែលបានជូនដំណឹងដល់ភាគី នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ដោយរំលោភលើវិធានផ្ទៃក្នុង។
- ***ជាបន្ទាប់បន្សំ ធ្វើមោឃភាព***សាលក្រម និងសំអាងហេតុសាលក្រមនេះ ហើយ**ចេញ**សាលក្រមពីការគ្មានពិរុទ្ធភាពចំពោះបទចោទនីមួយៗ។
- ***ជាបន្ទាប់បន្សំបំផុត កែប្រែ***ការផ្តន្ទាទោស និង**ប្រកាស**ដាក់ទោសឲ្យជាប់ពន្ធនាគារ ក្នុងរយៈពេលកំណត់មួយ។

រក្សាសិទ្ធិគ្រប់បែបយ៉ាង

| | | |
|---|---|---|
| **មេធាវី គង់ សំអុន**<br><br>**មេធាវី Anta GUISSÉ** | ទីក្រុងភ្នំពេញ<br><br>ទីក្រុងភ្នំពេញ | |